សៀវភៅណែនាំការសិក្សា
ព្រះគម្ពីរមរមនសម្រាប់គ្រូបង្រៀន ថ្នាក់សិក្ខាសាលា

សៀវភៅណែនាំ
ការសិក្សាព្រះគម្ពីរមរមន
សម្រាប់គ្រូបង្រៀន
ថ្នាក់សិក្ខាសាលា

បោះពុម្ពដោយ
សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ
ទីក្រុងសលត៍ លេក រដ្ឋយូថាហ៍

សូមថ្លែងអំណរគុណចំពោះយោលប់ និងការកែលម្អ ។ សូមផ្ញើយោបល់ និង ការកែលម្អទាំងនោះ រួមទាំងកំហុសឆ្គងទាំងឡាយមកកាន់ ៖

Seminaries and Institutes of Religion Curriculum Services
50 E. North Temple St., Floor 8
Salt Lake City, Utah 84150-0008
USA
អ៊ីម៉ែល ៖ ces-manuals@ldschurch.org

សូមសរសេរឈ្មោះពេញ អាសយដ្ឋានរួដ និងស្តេករបស់អ្នក ។
សូមកុំភ្លេចសរសេរចំណងជើងសៀវភៅណែនាំការសិក្សា ។បន្ទាប់មក សូមផ្តល់មតិយោបល់របស់អ្នក ។

© **ឆ្នាំ ២០១២ ដោយ**Intellectual Reserve, Inc ។
រក្សាសិទ្ធិគ្រប់យ៉ាង
បោះពុម្ពនៅសហរដ្ឋអាមេរិក

អនុមតិជាភាសាអង់គ្លេស ៖ ១០/០៩
អនុមតិការបកប្រែ ៖ ១០/០៩
ការបកប្រែនៃ *Book of Mormon Seminary Teacher Manual*
Cambodian
09411 258

មាតិកា

សេចក្តីផ្តើមនៃ សៀវភៅណែនាំការសិក្សាព្រះគម្ពីរមរមនសម្រាប់គ្រួបង្រៀន

ថ្នាក់សិក្ខាសាលា vi
គោលបំណងរបស់យើង vi
ការរៀបចំមេរៀន vi
ការប្រើសៀវភៅណែនាំការសិក្សាសម្រាប់គ្រួបង្រៀនប្រចាំថ្ងៃ vii
កម្មវិធីសិក្សាថ្នាក់សិក្ខាសាលាប្រចាំថ្ងៃ (ម៉ោងចេញផ្សាយ និង ម៉ោងព្រឹកព្រលឹម) ix
ការប្រើមេរៀនសិក្សានៅផ្ទះ: x
កម្មវិធីថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ: xi
ធនធានដទៃទៀត xi

មេរៀនប្រចាំថ្ងៃ និង មេរៀនសិក្សានៅផ្ទះ:

មេរៀនទី ១ តួនាទីរបស់៨សិស្ស 1
មេរៀនទី ២ ការសិក្សាបទគម្ពីរ 4
មេរៀនទី ៣ ផែនការនៃសេចក្តីសង្គ្រោះ 7
មេរៀនទី ៤ ទំព័រចំណងជើង សេចក្តីផ្តើម និងទីបន្ទាល់នៃពូកសាក្សី 10
មេរៀនទី ៥ ៩សេចក្តីសង្ខេបនៃព្រះគម្ពីរមរមន 13
មេរៀនសិក្សានៅផ្ទះ: ការសិក្សាបទគម្ពីរ- សេចក្តីសង្ខេបនៃព្រះគម្ពីរមរមន (មេរៀនទី ១) 16

សេចក្តីផ្តើមអំពីគម្ពីរនីហ្វៃទីមួយ 18
មេរៀនទី ៦ នីហ្វៃទី ១ ១ 19
មេរៀនទី ៧ នីហ្វៃទី១ ២ 22
មេរៀនទី ៨ នីហ្វៃទី១ ៣–៤ 25
មេរៀនទី ៩ នីហ្វៃទី១ ៥ 28
មេរៀនទី ១០ នីហ្វៃទី១ ៦ និង ៩ 31
មេរៀនសិក្សានៅផ្ទះ: នីហ្វៃទី១ ១–៦; ៩ (មេរៀនទី ២) 34

មេរៀនទី ១១ នីហ្វៃទី១ ៧ 36
មេរៀនទី ១២ នីហ្វៃទី ១ ៨ 39
មេរៀនទី ១៣ នីហ្វៃទី១ ១០–១១ 42
មេរៀនទី ១៤ នីហ្វៃទី១ ១២ –១៣ 45
មេរៀនទី ១៥ នីហ្វៃទី១ ១៤ 48
មេរៀនសិក្សានៅផ្ទះ: នីហ្វៃទី ១ ៧–១៤ (មេរៀនទី ៣) 51

មេរៀនទី ១៦ នីហ្វៃទី១ ១៥ 53
មេរៀនទី ១៧ នីហ្វៃទី១ ១៦ 56
មេរៀនទី ១៨ នីហ្វៃទី១ ១៧ 59
មេរៀនទី ១៩ នីហ្វៃទី១ ១៨ 62
មេរៀនទី ២០ នីហ្វៃទី១ ១៩ 65
មេរៀនសិក្សានៅផ្ទះ: នីហ្វៃទី១ ១៥–១៩ (មេរៀនទី ៤) 68

មេរៀនទី ២១ នីហ្វៃទី១ ២០–២២ 70
សេចក្តីផ្តើមអំពីគម្ពីរនីហ្វៃទីពីរ 73
មេរៀនទី ២២ នីហ្វៃទី២ ១ 74
មេរៀនទី ២៣ នីហ្វៃទី២ ២ (ផ្នែកទី ១) 77
មេរៀនទី ២៤ នីហ្វៃទី២ ២ (ផ្នែកទី ២) 80
មេរៀនទី ២៥ នីហ្វៃទី២ ៣ 83
មេរៀនសិក្សានៅផ្ទះ: នីហ្វៃទី១ ២០–នីហ្វៃទី២ ៣ (មេរៀនទី ៥) 86

មេរៀនទី ២៦ នីហ្វៃទី២ ៤ 88
មេរៀនទី ២៧ នីហ្វៃទី២ ៥ 91
មេរៀនទី ២៨ នីហ្វៃទី២ ៦–៨ 94
មេរៀនទី ២៩ នីហ្វៃទី២ ៩:១–២៦ 97
មេរៀនទី ៣០ នីហ្វៃទី២ ៩:២៧–៥៤ និង នីហ្វៃទី២ ១០ 100
មេរៀនសិក្សានៅផ្ទះ: នីហ្វៃទី២ ៤–១០ (មេរៀនទី ៦) 103

មេរៀនទី ៣១ នីហ្វៃទី២ ១១ និង ១៦ 105
មេរៀនទី ៣២ នីហ្វៃទី២ ១២–១៥ 108
មេរៀនទី ៣៣ នីហ្វៃទី២ ១៧–២០ 111
មេរៀនទី ៣៤ នីហ្វៃទី២ ២១–២៤ 114
មេរៀនទី ៣៥ នីហ្វៃទី២ ២៥ 117
មេរៀនសិក្សានៅផ្ទះ: នីហ្វៃ៧៩ទី២ ១១–២៥ (មេរៀនទី ៧) 120

មេរៀនទី ៣៦ នីហ្វៃទី២ ២៦ 122
មេរៀនទី ៣៧ នីហ្វៃទី២ ២៧ 125
មេរៀនទី ៣៨ នីហ្វៃទី២ ២៨ 128
មេរៀនទី ៣៩ នីហ្វៃទី២ ២៩–៣០ 131
មេរៀនទី ៤០ នីហ្វៃទី២ ៣១ 134
មេរៀនសិក្សានៅផ្ទះ: នីហ្វៃទី២ ២៦–៣១ (មេរៀនទី ៨) 137

មេរៀនទី ៤១ នីហ្វៃទី២ ៣២ 139
មេរៀនទី ៤២ នីហ្វៃទី២ ៣៣ 142
សេចក្តីផ្តើមអំពីគម្ពីរយ៉ាកុប 145
មេរៀនទី ៤៣ យ៉ាកុប ១–២:១១ 146
មេរៀនទី ៤៤ យ៉ាកុប ២:១២–៣៥ 149
មេរៀនទី ៤៥ យ៉ាកុប ៣–៤ 152
មេរៀនសិក្សានៅផ្ទះ: នីហ្វៃទី២ ៣២–យ៉ាកុប ៤ (មេរៀនទី ៩) 155

មេរៀនទី ៤៦ យ៉ាកុប ៥:១–៥១ 157
មេរៀនទី ៤៧ យ៉ាកុប ៥:៥២–៧៧; យ៉ាកុប ៦ 160
មេរៀនទី ៤៨ យ៉ាកុប ៧ 163
សេចក្តីផ្តើមអំពីគម្ពីរអេណុស 166
មេរៀនទី ៤៩ អេណុស 167
សេចក្តីផ្តើមអំពីគម្ពីរយ៉ារ៉ុម 170
សេចក្តីផ្តើមអំពីគម្ពីរអោមណៃ 171
មេរៀនទី ៥០ យ៉ារ៉ុម និង អោមណៃ 172
មេរៀនសិក្សានៅផ្ទះ: យ៉ាកុប ៥–អោមណៃ (មេរៀនទី ១០) 175

សេចក្តីផ្តើមអំពីគម្ពីរពាក្យសម្តីនៃមរមន 177
សេចក្តីផ្តើមអំពីគម្ពីរម៉ូសាយ 178
មេរៀនទី ៥១ ពាក្យសម្តីនៃមរមន–ម៉ូសាយ ១ 179
មេរៀនទី ៥២ ម៉ូសាយ ២ 182
មេរៀនទី ៥៣ ម៉ូសាយ ៣ 185
មេរៀនទី ៥៤ ម៉ូសាយ ៤ 188
មេរៀនទី ៥៥ ម៉ូសាយ ៥–៦ 191
មេរៀនសិក្សានៅផ្ទះ: ពាក្យសម្តីនៃមរមន–ម៉ូសាយ ៦ (មេរៀនទី ១១) 194

មេរៀនទី ៥៦ ម៉ូសាយ ៧–៨ 196
មេរៀនទី ៥៧ ម៉ូសាយ ៩–១០ 199
មេរៀនទី ៥៨ ម៉ូសាយ ១១–១២:១៧ 202
មេរៀនទី ៥៩ ម៉ូសាយ ១២:១៨–១៤:១២ 205
មេរៀនទី ៦០ ម៉ូសាយ ១៥–១៧ 208
មេរៀនសិក្សានៅផ្ទះ: ម៉ូសាយ ៧–១៧ (មេរៀនទី ១២) 211

មេរៀនទី ៦១ ម៉ូសាយ ១៨ 213
មេរៀនទី ៦២ ម៉ូសាយ ១៩–២០ 216
មេរៀនទី ៦៣ ម៉ូសាយ ២១–២២ 219
មេរៀនទី ៦៤ ម៉ូសាយ ២៣–២៤ 222

មេរៀនទី ៦៥ ម៉ូសាយ ២៥ 225
មេរៀនសិក្សានៅផ្ទះ: ម៉ូសាយ ១៨–២៥ (មេរៀនទី ១៣) 228

មេរៀនទី ៦៦ ម៉ូសាយ ២៦ 230
មេរៀនទី ៦៧ ម៉ូសាយ ២៧ 233
មេរៀនទី ៦៨ ម៉ូសាយ ២៨–២៩ 236
សេចក្តីផ្តើមអំពីគម្ពីរអាលម៉ា 239
មេរៀនទី ៦៩ អាលម៉ា ១–២ 240
មេរៀនទី ៧០ អាលម៉ា ៣–៤ 243
មេរៀនសិក្សានៅផ្ទះ: ម៉ូសាយ ២៦–អាលម៉ា ៤ (មេរៀនទី ១៤) 246

មេរៀនទី ៧១ អាលម៉ា ៥:១–៣៦ 248
មេរៀនទី ៧២ អាលម៉ា ៥:៣៧–៦២ 251
មេរៀនទី ៧៣ អាលម៉ា ៦–៧ 254
មេរៀនទី ៧៤ អាលម៉ា ៨ 257
មេរៀនទី ៧៥ អាលម៉ា ៩–១០ 260
មេរៀនសិក្សានៅផ្ទះ: អាលម៉ា ៥–១០ (មេរៀនទី ១៥) 263

មេរៀនទី ៧៦ អាលម៉ា ១១ 265
មេរៀនទី ៧៧ អាលម៉ា ១២ 268
មេរៀនទី ៧៨ អាលម៉ា ១៣ 271
មេរៀនទី ៧៩ អាលម៉ា ១៤ 274
មេរៀនទី ៨០ អាលម៉ា ១៥–១៦ 277
មេរៀនសិក្សានៅផ្ទះ: អាលម៉ា ១១–១៦ (មេរៀនទី ១៦) 280

មេរៀនទី ៨១ អាលម៉ា ១៧ 282
មេរៀនទី ៨២ អាលម៉ា ១៨ 285
មេរៀនទី ៨៣ អាលម៉ា ១៩–២០ 288
មេរៀនទី ៨៤ អាលម៉ា ២១–២២ 291
មេរៀនទី ៨៥ អាលម៉ា ២៣–២៤ 294
មេរៀនសិក្សានៅផ្ទះ: អាលម៉ា ១៧–២៤ (មេរៀនទី ១៧) 297

មេរៀនទី ៨៦ អាលម៉ា ២៥–២៦ 299
មេរៀនទី ៨៧ អាលម៉ា ២៧–២៩ 302
មេរៀនទី ៨៨ អាលម៉ា ៣០ 305
មេរៀនទី ៨៩ អាលម៉ា ៣១ 308
មេរៀនទី ៩០ អាលម៉ា ៣២ 311
មេរៀនសិក្សានៅផ្ទះ: អាលម៉ា ២៥–៣២ (មេរៀនទី ១៨) 314

មេរៀនទី ៩១ អាលម៉ា ៣៣ 316
មេរៀនទី ៩២ អាលម៉ា ៣៤–៣៥ 319
មេរៀនទី ៩៣ អាលម៉ា ៣៦ 322
មេរៀនទី ៩៤ អាលម៉ា ៣៧ 325
មេរៀនទី ៩៥ អាលម៉ា ៣៨ 328
មេរៀនសិក្សានៅផ្ទះ: អាលម៉ា ៣៣–៣៨ (មេរៀនទី ១៩) 331

មេរៀនទី ៩៦ អាលម៉ា ៣៩ 333
មេរៀនទី ៩៧ អាលម៉ា ៤០ 336
មេរៀនទី ៩៨ អាលម៉ា ៤១ 339
មេរៀនទី ៩៩ អាលម៉ា ៤២ 342
មេរៀនទី ១០០ អាលម៉ា ៤៣–៤៤ 345
មេរៀនសិក្សានៅផ្ទះ: អាលម៉ា ៣៩–៤៤ (មេរៀនទី ២០) 348

មេរៀនទី ១០១ អាលម៉ា ៤៥–៤៨ 350
មេរៀនទី ១០២ អាលម៉ា ៤៩–៥១ 353
មេរៀនទី ១០៣ អាលម៉ា ៥២–៥៥ 356
មេរៀនទី ១០៤ អាលម៉ា ៥៦–៥៨ 359
មេរៀនទី ១០៥ អាលម៉ា ៥៩–៦៣ 362
មេរៀនសិក្សានៅផ្ទះ: អាលម៉ា ៤៥–៦៣ (មេរៀនទី ២១) 365

សេចក្តីផ្តើមអំពីគម្ពីរហេលេមិន 367
មេរៀនទី ១០៦ ហេលេមិន ១–២ 368
មេរៀនទី ១០៧ ហេលេមិន ៣–៤ 371
មេរៀនទី ១០៨ ហេលេមិន ៥ 374
មេរៀនទី ១០៩ ហេលេមិន ៦–៧ 377
មេរៀនទី ១១០ ហេលេមិន ៨–៩ 380
មេរៀនសិក្សានៅផ្ទះ: ហេលេមិន ១–៩ (មេរៀនទី ២២) 383

មេរៀនទី ១១១ ហេលេមិន ១០ 385
មេរៀនទី ១១២ ហេលេមិន ១១–១២ 388
មេរៀនទី ១១៣ ហេលេមិន ១៣ 391
មេរៀនទី ១១៤ ហេលេមិន ១៤ 394
មេរៀនទី ១១៥ ហេលេមិន ១៥–១៦ 397
មេរៀនសិក្សានៅផ្ទះ: ហេលេមិន ១០–១៦ (មេរៀនទី ២៣) 400

សេចក្តីផ្តើមនៃគម្ពីរនីហ្វៃទីបី ៖ គម្ពីរនីហ្វៃ 402
មេរៀនទី ១១៦ នីហ្វៃទី ៣ ១ 403
មេរៀនទី ១១៧ នីហ្វៃទី៣ ២–៥ 406
មេរៀនទី ១១៨ នីហ្វៃទី៣ ៦–៧ 409
មេរៀនទី ១១៩ នីហ្វៃទី៣ ៨–១០ 412
មេរៀនទី ១២០ នីហ្វៃទី៣ ១១:១–១៧ 415
មេរៀនសិក្សានៅផ្ទះ: នីហ្វៃទី៣ ១–១១:១៧ (មេរៀនទី ២៤) 418

មេរៀនទី ១២១ នីហ្វៃទី៣ ១១:១៨–៤១ 420
មេរៀនទី ១២២ នីហ្វៃទី៣ ១២ 423
មេរៀនទី ១២៣ នីហ្វៃទី៣ ១៣ 426
មេរៀនទី ១២៤ នីហ្វៃទី ៣ ១៤ 429
មេរៀនទី ១២៥ នីហ្វៃទី៣ ១៥–១៦ 432
មេរៀនសិក្សានៅផ្ទះ: នីហ្វៃទី៣ ១១:១៨–១៦:២០ (មេរៀនទី ២៥) 435

មេរៀនទី ១២៦ នីហ្វៃទី ៣ ១៧ 437
មេរៀនទី ១២៧ នីហ្វៃទី៣ ១៨ 440
មេរៀនទី ១២៨ នីហ្វៃទី៣ ១៩ 443
មេរៀនទី ១២៩ នីហ្វៃទី៣ ២០ 446
មេរៀនទី ១៣០ នីហ្វៃទី៣ ២១–២២ 449
មេរៀនសិក្សានៅផ្ទះ: នីហ្វៃទី៣ ១៧–២២ (មេរៀនទី ២៦) 452

មេរៀនទី ១៣១ នីហ្វៃទី ៣ ២៣ 454
មេរៀនទី ១៣២ នីហ្វៃទី៣ ២៤–២៦ 457
មេរៀនទី ១៣៣ នីហ្វៃទី៣ ២៧ 460
មេរៀនទី ១៣៤ នីហ្វៃទី៣ ២៨ 463
មេរៀនទី ១៣៥ នីហ្វៃទី៣ ២៩–៣០ 466
មេរៀនសិក្សានៅផ្ទះ: នីហ្វៃទី១ ២៣–៣០ (មេរៀនទី ២៧) 469

សេចក្តីផ្តើមអំពីគម្ពីរនីហ្វៃទីបួន ៖ គម្ពីរនីហ្វៃ 471
មេរៀនទី ១៣៦ នីហ្វៃទី ៤ 472
សេចក្តីផ្តើមអំពីគម្ពីរមរមន 475
មេរៀនទី ១៣៧ មរមន ១–២ 476
មេរៀនទី ១៣៨ មរមន ៣–៤ 479
មេរៀនទី ១៣៩ មរមន ៥–៦ 482
មេរៀនទី ១៤០ មរមន ៧–៨:១១ 485
មេរៀនសិក្សានៅផ្ទះ: នីហ្វៃទី ៤ ១–មរមន ៨:១១ (មេរៀនទី ២៨) 488

មេរៀនទី ១៤១ មរមន ៨:១២–៤១ 490
មេរៀនទី ១៤២ មរមន ៩ 493
សេចក្តីផ្តើមអំពីគម្ពីរអេធើរ 496
មេរៀនទី ១៤៣ អេធើរ ១ 497
មេរៀនទី ១៤៤ អេធើរ ២ 500
មេរៀនទី ១៤៥ អេធើរ ៣ 503

មេរៀនសិក្សានៅផ្ទះ៖ មរមន ៨:១២–អេធើរ ៣ (មេរៀនទី ២៩) 506

មេរៀនទី ១៤៦ អេធើរ ៤–៥ 508
មេរៀនទី ១៤៧ អេធើរ ៦ 511
មេរៀនទី ១៤៨ អេធើរ ៧–១១ 514
មេរៀនទី ១៤៩ អេធើរ ១២:១–២២ 517
មេរៀនទី ១៥០ អេធើរ ១២:២៣–៤១ 520
មេរៀនសិក្សានៅផ្ទះ៖ អេធើរ ៤–១២ (មេរៀនទី ៣០) 523

មេរៀនទី ១៥១ អេធើរ ១៣–១៥ 525
សេចក្តីផ្តើមអំពីគម្ពីរម៉ូរ៉ូណៃ 528
មេរៀនទី ១៥២ ម៉ូរ៉ូណៃ ១–៣ 529
មេរៀនទី ១៥៣ ម៉ូរ៉ូណៃ ៤–៥ 532
មេរៀនទី ១៥៤ ម៉ូរ៉ូណៃ ៦ 535
មេរៀនទី ១៥៥ ម៉ូរ៉ូណៃ ៧:១–១៩ 538
មេរៀនសិក្សានៅផ្ទះ៖ អេធើរ ១៣–ម៉ូរ៉ូណៃ ៧:១៩ (មេរៀនទី ៣១) 541

មេរៀនទី ១៥៦ ម៉ូរ៉ូណៃ ៧:២០–៤៨ 543
មេរៀនទី ១៥៧ ម៉ូរ៉ូណៃ ៨ 546
មេរៀនទី ១៥៨ ម៉ូរ៉ូណៃ ៩ 549
មេរៀនទី ១៥៩ ម៉ូរ៉ូណៃ ១០:១–៧, ២៧–២៩ 552
មេរៀនទី ១៦០ ម៉ូរ៉ូណៃ ១០:៨–២៦, ៣០–៣៤ 555
មេរៀនសិក្សានៅផ្ទះ៖ ម៉ូរ៉ូណៃ ៧:២០–១០:៣៤ (មេរៀនទី ៣២) 558

សេចក្តីបន្ថែម 560
តារាងការអានព្រះគម្ពីរ 560
ការណែនាំល្បឿនបង្រៀនសម្រាប់គ្រូបង្រៀនប្រចាំថ្ងៃ 561
យោបល់សម្រាប់ថ្ងៃដែលអាចផ្លាស់ប្តូរបាន 563
ការណែនាំល្បឿនបង្រៀនសម្រាប់គ្រូបង្រៀនមេរៀននៅផ្ទះ 564
សេចក្តីផ្តើមនៃចំណោះចំណាននខគម្ពីរ 565
សកម្មភាពចំណោះចំណាននខគម្ពីរ 566
វគ្គចំណោះចំណាននខគម្ពីរទាំង ១០០ 570
សេចក្តីផ្តើមនៃគោលលទ្ធិគ្រីស្ទ 571
គោលលទ្ធិគ្រីស្ទទាំងឡាយ 572
ផ្ទាំងចំណារ និងទំនាក់ទំនងរបស់វាទៅនឹងព្រះគម្ពីរមរមនដែលបានបោះពុម្ពរួច 577
ទិដ្ឋភាពទូទៅនៃការធ្វើដំណើរនៅក្នុងម៉ូសាយ ៧–២៤ 578
ទំព័រព្រះគម្ពីរមរមនដែលអាចមាន (ទំនាក់ទំនងដល់គ្នាទៅវិញទៅមក) 579

សេចក្តីផ្តើមនៃ *សៀវភៅណែនាំការសិក្សាព្រះគម្ពីរមរមនសម្រាប់គ្រូបង្រៀន ថ្នាក់សិក្ខាសាលា*

គោលបំណងរបស់យើង

គោលបំណងរបស់ថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថានសាសនា ៖

« គោលបំណងរបស់យើង គឺដើម្បីជួយយុវវ័យ និង មជ្ឈិមវ័យក្មេងឲ្យយល់ និងពឹងផ្អែកលើការបង្រៀន និងដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ឲ្យមានភាពសក្តិសមសម្រាប់ពរជ័យទាំងឡាយនៃព្រះវិហារបរិសុទ្ធ ហើយរៀបចំខ្លួនពួកគេ ក្រុមគ្រួសារពួកគេ និងអ្នកដទៃទៀត សម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ជាមួយនឹងព្រះវរបិតារបស់ពួកគេដែលគង់នៅឋានសួគ៌ » ។

ដើម្បីសម្រេចគោលបំណងរបស់យើង យើងបង្រៀនសិស្សអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អ ដូចដែលមាននៅក្នុងព្រះគម្ពីរ និងពាក្យសម្តីរបស់ព្យាការីទាំងឡាយ ។គោលលទ្ធិ និង គោលការណ៍ទាំងនេះ គឺត្រូវបានបង្រៀនតាមរបៀបមួយដែលដឹកនាំឲ្យមានការយល់ដឹង និងការស្តាប់ឡើង ។យើងជួយសិស្សទាំងឡាយឲ្យបំពេញតួនាទីរបស់ពួកគេនៅក្នុងដំណើរការនៃការរៀនសូត្រ និង រៀបចំពួកគេឲ្យបង្រៀនដំណឹងល្អដល់អ្នកដទៃទៀត ។

ដើម្បីជួយសម្រេចបានគោលបំណងទាំងនេះ អ្នកនិងសិស្សដែលអ្នកបង្រៀនត្រូវបានលើកទឹកចិត្តឲ្យសហការធ្វើតាមមូលដ្ឋានគ្រឹះនៃការបង្រៀន និងការរៀនដំណឹងល្អ នៅពេលអ្នកសិក្សាព្រះគម្ពីររួមគ្នាដូចខាងក្រោម ៖

- បង្រៀន និង រៀនសូត្រដោយព្រះវិញ្ញាណ ។
- បង្កើតបរិយាកាសរៀនសូត្រដែលពោរពេញដោយសេចក្តីស្រឡាញ់ ការគោរព និង មានគោលបំណង ។
- សិក្សាព្រះគម្ពីររាល់ថ្ងៃ និង អានមេរៀននៃវគ្គសិក្សា ។(តារាងសម្រាប់តាមដានការអានព្រះគម្ពីរ អាចរកឃើញនៅក្នុងសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។)
- យល់ពីបរិបទ និងមាតិកានៃព្រះគម្ពីរ និងពាក្យសម្តីរបស់ព្យាការីទាំងឡាយ ។
- ស្គាល់ យល់ ដឹងពីសេចក្តីពិត និងសារៈសំខាន់ ហើយអនុវត្តគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។
- ពន្យល់ ចែកចាយ និង ថ្លែងទីបន្ទាល់អំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។
- ចេះស្វាត់នូវវគ្គបទគម្ពីរសំខាន់ៗ និង គោលលទ្ធិគ្រឹះទាំងឡាយ ។

សៀវភៅណែនាំសម្រាប់គ្រូបង្រៀននេះ បានរៀបចំឡើងដើម្បីជួយដល់អ្នកឲ្យទទួលបានជោគជ័យក្នុងការសម្រេចនូវគោលបំណងទាំងនេះ ។

ការរៀបចំមេរៀន

ព្រះអម្ចាស់បានបញ្ជាដល់អស់អ្នកណាដែលបង្រៀនដំណឹងល្អរបស់ទ្រង់ឲ្យ « ត្រូវបង្រៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អរបស់យើង ដែលមាននៅក្នុងព្រះគម្ពីរបឺប និងព្រះគម្ពីរមរមន គឺជាភាពពោរពេញនៃដំណឹងល្អ » (គ. និង ស. ៤២:១២) ។ ទ្រង់បានណែនាំបន្ថែមទៀតថា សេចក្តីពិតទាំងនេះគួរត្រូវបានបង្រៀនដូចជា « ត្រូវបានដឹកនាំពីព្រះវិញ្ញាណ » ដែល « ត្រូវបានប្រទាន . . . ដោយពាក្យអធិស្ឋាននៃសេចក្តីជំនឿ » (គ. និង ស. ៤២:១៣–១៤) ។ នៅពេលអ្នករៀបចំមេរៀននីមួយៗ សូមស្វែងរកការដឹកនាំពីព្រះវិញ្ញាណប្រកបដោយការអធិស្ឋានដើម្បីជួយអ្នកឲ្យយល់ពីព្រះគម្ពីរ និងគោលលទ្ធិនានា និងគោលការណ៍ទាំងឡាយដែលមាន ។ ដូចគ្នាផងដែរ សូមធ្វើការតាមការបំផុសគំនិតពីព្រះវិញ្ញាណនៅពេលធ្វើគម្រោងជួយដល់សិស្សរបស់អ្នកឲ្យយល់ពីព្រះគម្ពីរ ត្រូវបានបង្រៀនដោយព្រះវិញ្ញាណបរិសុទ្ធ និងមានបំណងចង់អនុវត្តអ្វីដែលពួកគេបានរៀន ។

នៅក្នុងវគ្គសិក្សានេះ ព្រះគម្ពីរមរមនគឺជាអត្ថបទចម្បងសំខាន់របស់អ្នក នៅពេលអ្នករៀបចំបង្រៀន ។ សូមសិក្សាជំពូក ឬខគម្ពីរទាំងឡាយដែលអ្នកនឹងបង្រៀនប្រកបដោយការអធិស្ឋាន ។ សូមព្យាយាមយល់បរិបទ និងអត្ថបទនៃបណ្តុំបទគម្ពីរ រួមមានខ្សែរឿង ប្រជាជន ទីកន្លែង និងហេតុការណ៍ ។ នៅពេលអ្នកដឹងពីពីបរិបទ និងអត្ថបទនៃបណ្តុំបទគម្ពីរនីមួយៗហើយ សូមស្វែងរកគោលលទ្ធិ និងគោលការណ៍ដែលវាមាន ហើយសម្រេចថាតើសេចក្តីពិតមួយណាដែលសំខាន់បំផុតសម្រាប់សិស្សរបស់អ្នកដើម្បីយល់ និងអនុវត្តតាមវា ។ នៅពេលអ្នកបានកេរឃើញអ្វីដែលអ្នកត្រូវផ្តោតអារម្មណ៍លើហើយ អ្នកអាចសម្រេចថាតើវិធី របៀបដោះស្រាយ និងសកម្មភាពណាមួយដែលនឹងសមបំផុតដើម្បីជួយដល់សិស្សរបស់អ្នកក្នុងការរៀនសូត្រ និងអនុវត្តនូវសេចក្តីពិតដ៏ពិសិដ្ឋទាំងឡាយដែលមាននៅក្នុងព្រះគម្ពីរ ។

សៀវភៅណែនាំនេះត្រូវបានរចនាឡើងដើម្បីជួយដល់អ្នកនៅក្នុងដំណើរការនេះ ។ សូមរំឭកមេរៀនដោយប្រុងប្រយ័ត្ន ចំពោះអ្វីដែលទាក់ទងទៅនឹងបណ្តុំបទគម្ពីរដែលអ្នកនឹងបង្រៀន ។ អ្នកអាចជ្រើសរើសប្រើគំនិតដែលបានផ្តល់ឲ្យសម្រាប់បណ្តុំបទគម្ពីរទាំងអស់ ឬខ្លះៗ ឬអ្នកអាចបត់បែនគំនិតបង្រៀនទៅតាមតម្រូវការ និងកាលៈទេសៈនៃសិស្សដែលអ្នកបង្រៀន ។ នៅពេលអ្នកគិតពីរបៀបដើម្បីបត់បែនមេរៀននេះ សូមប្រាកដថានឹងធ្វើតាមការប្រឹក្សាពីអែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« តាមដែលខ្ញុំបានឮប្រធាន ផាកគី បានបង្រៀនជាញឹកញាប់ថា ជំបូង យើងត្រូវទទួលយកជាជំបូងសិន ហើយបន្ទាប់មកសម្របធ្វើតាម ។ ប្រសិនបើយើងគ្រោងមេរៀនដែលមាននៅក្នុងសៀវភៅដោយយកចិត្តទុកដាក់មុននឹងយើងបង្រៀននោះ យើងអាចធ្វើតាមព្រះវិញ្ញាណដើម្បីសម្របតាមវាបាន » (« A Panel Discussion with Elder Dallin H. Oaks » [ការចាក់ផ្សាយតាមផ្កាយរណបនៃថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាននៃសាសនា នៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១២], ៦, si.lds.org) ។

នៅពេលអ្នករៀបចំបង្រៀន សូមចងចាំពីសិស្សដែលត្រូវការជំនួយជាពិសេស ។ សូមសម្របសកម្មភាព និងការរំពឹងទុកនានាដើម្បីជួយដល់ពួកគេឲ្យទទួលបានជោគជ័យ ។ ទំនាក់ទំនងជាមួយនឹងឪពុកម្តាយ និងអ្នកដឹកនាំដែលនឹងជួយអ្នកឲ្យដឹងពីតម្រូវការរបស់សិស្ស ហើយជួយអ្នកឲ្យបានជោគជ័យក្នុងការផ្តល់នូវបទពិសោធន៍ដ៏មានន័យ និងជួយដល់ពួកគេ ។



សេចក្តីផ្តើមអំពីគម្ពីរ

នីហ្វៃទីមួយ

ហេតុអ្វីសិក្សាគម្ពីរនេះ ?

នៅពេលសិស្សសិក្សា នីហ្វៃទី ១ ពួកគេនឹងរកឃើញថា « សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់ទាំងឡាយនៃព្រះអម្ចាស់ មានមកលើជនទាំងអស់ណាដែលព្រះទ្រង់បានរើស ដោយសារសេចក្តីជំនឿរបស់ពួកគេ ដើម្បីធ្វើឲ្យគេខ្លាំងពូកែ » (នីហ្វៃទី ១ ១:២០) ។ ពួកគេក៏នឹងរៀនបានថា ព្រះមានព្រះទ័យចង់ប្រទានពរដល់កូនចៅរបស់ទ្រង់ ។ លីហៃ និង ប្រជាជនរបស់គាត់បានមានបទពិសោធន៍ពីសេចក្តីមេត្តាករុណា និង ពរជ័យពីព្រះ ដោយសារពួកគេធ្វើតាមព្រះបញ្ញត្តិរបស់ទ្រង់ ។ លីហៃ និង

តើគម្ពីរនេះត្រូវបានសរសេរទៅកាន់នរណា ហើយ ហេតុអ្វី ?

នីហ្វៃ មានគំនិតសរសេរសម្រាប់មនុស្សបីពួក ៖ កូនចៅរបស់ជីពុកគាត់ ពស្ត្រក្នុងសេចក្តីសញ្ញារបស់ព្រះអម្ចាស់នៅក្នុងសម័យចុងក្រោយ និង ប្រជាជនទាំងអស់ដែលនៅក្នុងពិភពលោកនេះ (សូមមើល នីហ្វៃទី ២ ៣៣:៣, ១៣) ។ គាត់បានសរសេរដើម្បីបញ្ចុះបញ្ចូលមនុស្សទាំងអស់ឲ្យមករកព្រះយេស៊ូវគ្រីស្ទ ហើយបានសង្គ្រោះ (សូមមើល នីហ្វៃទី១ ៦:៤) ។

- លីហៃ និង នីហ្វៃ ទទួលបានការនិមិត្តដែលរួមមានដើមឈើជីវិត ការប្រសូត ការបម្រើ និង ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ប្រវត្តិនៃជនជាតិសន្យា ការស្តារឡើងវិញនៃដំណឹងល្អ និង ឫទ្ធិអំណាចពួកសាវក និង សាសនាចក្រនៃកូនចៀមនៃព្រះ (សូមមើល នីហ្វៃទី ១ ៨; ១១–១៤) ។
- នីហ្វៃ បានឃើញពីរបៀបដើម្បីសង្គ្រោះពៅ ដែលនឹងនាំប្រជាជនរបស់គាត់ ទៅជនជាតិសន្យា (សូមមើល នីហ្វៃទី ១ ១៨:១) ។



មេរៀនទី ១៤៤

អេធើរ ២

សេចក្តីផ្តើម

ក្រោយពីការចាកចេញពីប៉មបាបិល លោកយ៉ារេឌ និងបងប្រុសរបស់លោក និងគ្រួសារ ព្រមទាំងមិត្តភក្តិរបស់លោក ត្រូវបានដឹកនាំដោយព្រះអម្ចាស់ឆ្ពោះកាន់ទីរហោស្ថាន ។ ព្រះអម្ចាស់បានបញ្ជាបងប្រុសរបស់យ៉ារេឲ្យសាងសង់ទូកចំនួនប្រាំបី ដើម្បីដាក់ប្រជាជនរបស់លោកឆ្លងកាត់សមុទ្រទៅកាន់ដែនដីសន្យា ។ នៅពេលបងប្រុសរបស់យ៉ារេ និង ប្រជាជនរបស់លោកបានគោរពតាមព្រះអម្ចាស់ដោយសេចក្តីជំនឿ នោះព្រះអម្ចាស់បានប្រទានការណែនាំ និងការដឹកនាំដែលចាំបាច់បំណាច់ដល់ពួកគេដើម្បីទទួលបានជោគជ័យ នៅក្នុងការធ្វើដំណើររបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

អេធើរ ២:១–១២

ប្រជាជនយ៉ារេឧបាប់ផ្តើមការធ្វើដំណើរបស់ពួកគេទៅកាន់ដែនដីសន្យា

ការបង្កើតចំណាប់អារម្មណ៍ និង ការផ្តោតការយកចិត្តទុកដាក់

សូមគ្រោងសកម្មភាពណាដែលនឹងបង្កើនចំណាប់អារម្មណ៍ និងជួយដល់អ្នករៀនទាំងឡាយឲ្យផ្តោតចំណាប់អារម្មណ៍របស់គេទៅលើព្រះគម្ពីរនៅក្នុងមេរៀននេះ ។ សកម្មភាពទាំងនេះនឹងមានប្រសិទ្ធភាពបំផុត នៅពេលវាខ្លី និងពេលវាដឹកនាំអ្នករៀនទាំងឡាយឲ្យផ្តោតទៅលើគោលការណ៍ដ៏សំខាន់នៃមេរៀននេះ ។

ដើម្បីជួយសិស្សឲ្យយល់ពីការដែលយើងទទួលបានពីព្រះ អាចរៀបចំយើងឲ្យទទួលបានការណែនាំ និងការដឹកនាំផ្សេងទៀតពីទ្រង់ សូមធ្វើ សកម្មភាពខាងក្រោម ៖

មុនពេលចាប់ផ្តើមថ្នាក់ សូមណែនាំអ៊ីមែលតំណាងឲ្យរបស់មានតម្លៃនៅក្នុងបន្ទប់ដែលអ្នករៀបចំ ។ សូមរៀបចំតម្រុយបី បួនដែលអាចដឹកនាំសិស្សឲ្យរកឃើញរបស់ដ៏មានតម្លៃនោះ ។ អ្នកនឹងត្រូវផ្តល់នូវតម្រុយទីមួយដល់សិស្ស ។ តម្រុយនោះនឹងនាំទៅរកតម្រុយមួយទៀត ដែលនឹងដឹកនាំទៅរកតម្រុយមួយថែមទៀត ហើយបន្តទៀតរហូតដល់សិស្សរកឃើញនូវរបស់មានតម្លៃនោះ ។ ក្រោយពីពួកគេបានរកឃើញរបស់នោះហើយ សូមសួរ ៖

- តើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកមិនបានយកចិត្តទុកដាក់នឹងតម្រុយទីមួយទេនោះ ? (ពួកគេនឹងមិនរកឃើញនូវតម្រុយទីពីរឡើយ ។)

សូមឲ្យសិស្សរំឭកពី អេធើរ ១:៤១–៤២ ដោយស្ងាត់ស្ងៀម ដោយរកមើលវគ្គនៃការណែនាំដំបូងរបស់ព្រះអម្ចាស់ក្នុងការដឹកនាំដល់ពួកសាសន៍យ៉ារេឧទៅកាន់ដែនដីសន្យា ។

ដើម្បីជួយសិស្សឲ្យឃើញពីចម្លើយរបស់ពួកសាសន៍យ៉ារេឧចំពោះការណែនាំទាំងនេះ សូមឲ្យសិស្សម្នាក់អាន អេធើរ ២:១–៣ ឮៗ ។

- តើពួកសាសន៍យ៉ារេឧបានឆ្លើយតបយ៉ាងណាចំពោះវគ្គនៃការណែនាំដំបូងរបស់ព្រះអម្ចាស់ ?

សូមឲ្យសិស្សម្នាក់អាន អេធើរ ២:៤–៦ ឮ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពរជ័យដែលពួកសាសន៍យ៉ារេឧបានទទួលក្រោយពីពួកគេបានធ្វើតាមវគ្គនៃការណែនាំដំបូង ។

- តើមានអ្វីកើតឡើង ក្រោយពីពួកសាសន៍យ៉ារេឧបានធ្វើតាមវគ្គនៃការណែនាំដំបូងរបស់ព្រះអម្ចាស់ ? (ព្រះអម្ចាស់បានប្រទានដល់ពួកគេនូវការណែនាំបន្ថែមទៀត តាមរយៈបងប្រុសរបស់យ៉ារេឧ ។)
- តើយើងអាចរៀនអ្វីខ្លះពីដំណើរឿងនេះអំពីរបៀបដើម្បីទទួលបានការដឹកនាំពីព្រះអម្ចាស់ ? (សិស្សអាចប្រើពាក្យខុសៗគ្នា ប៉ុន្តែចម្លើយរបស់ពួកគេគួរបង្ហាញពីគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងធ្វើសកម្មភាពដោយសេចក្តីជំនឿតាមការដឹកនាំដែលព្រះអម្ចាស់បានប្រទានដល់យើង នោះយើងអាចទទួលបាននូវការដឹកនាំបន្ថែមទៀតពីទ្រង់ ។** អ្នកអាចណែនាំ ពួកគេគូរសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីរបស់ពួកគេនៅក្បែរ អេធើរ ២:៦ ។)

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ និងអាចអនុវត្តគោលការណ៍នេះ សូមឲ្យពួកគេគិតអំពីអាយុណា ឬការបំផុសគំនិតណាមួយដែលពួកគេបានទទួលនៅពេលថ្មីៗនេះ៖ពីព្រះអម្ចាស់ ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់អានខ្លះនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ៉ាឆាត ជី សុត ដែលគ្រូម៉ូរនៃពួកសាវកដប់ពីរនាក់ អំពីរបៀបដែលយើងទទួលបានវិវរណៈជាញឹកញាប់ ៖



« វានឹងមកម្តងបន្តិចៗ ជាប់ណែក ជាកញ្ចប់ ដើម្បីឲ្យសមត្ថភាពរបស់អ្នកអាចរីកចម្រើនឡើង ។ នៅពេលបំណែកនីមួយៗបានធ្វើឡើងដោយសេចក្តីជំនឿ អ្នកនឹងត្រូវបានដឹកនាំទៅរកបំណែកផ្សេងទៀត រហូតដល់អ្នកទទួលបានចម្លើយទាំងមូល ។ ទម្រាំឲ្យអ្នករកឃើញនូវសេចក្តីជំនឿទៅលើសមត្ថភាពនៃព្រះអំពីការដែលយើងត្រូវការ ដើម្បីឆ្លើយតបការអធិស្ឋានរបស់យើង ។ ខណៈពេលដែលពេលខ្លះវាដឹងតែងតែខ្លាំង វាផ្តល់នូវពរជ័យយ៉ាងសំខាន់ក្នុងការរីកចម្រើនផ្ទាល់ខ្លួន » (« Using the Supernal Gift of Prayer » *Ensign* ឬ *លីអាហូណា*, ខែ ឧសភា ឆ្នាំ ២០០៧, ទំព័រ ៩) ។

សូមឲ្យសិស្សរង្គើយនឹងសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ ។ អ្នកអាចសរសេរសំណួរនេះនៅលើក្តារខៀន ឬអាចវាយតែ១ដើម្បីឲ្យសិស្សរកចម្លើយតែប៉ុណ្ណោះ ។

- តើនៅពេលណាដែលអ្នកបានធ្វើតាមការបំផុសគំនិតខាងវិញ្ញាណ ហើយបន្ទាប់មកបានទទួលនូវការដឹកនាំបន្ថែមទៀតពីព្រះនោះ ?

ការប្រើសៀវភៅណែនាំការសិក្សាសម្រាប់គ្រូបង្រៀនប្រចាំថ្ងៃ

សេចក្តីផ្តើមនៃគម្ពីរ

សេចក្តីផ្តើមនៃគម្ពីរនឹងផ្តល់នូវទិដ្ឋភាពទូទៅនៃគម្ពីរនីមួយៗនៅក្នុងព្រះគម្ពីរមរមន ។ នៅក្នុងចំណោមរឿងផ្សេងទៀត ពួកគេនឹងពន្យល់ពីអ្នកដែលសរសេរគម្ពីរនេះ វារៀបរាប់ពីគោលបំណងក្នុងការសរសេររបស់អ្នកសរសេរ ហើយវាផ្តល់នូវសេចក្តីសង្ខេបនៃអត្ថបទនៃគម្ពីរនីមួយៗ ។

សេចក្តីផ្តើមនៃបណ្តុំបទគម្ពីរ

សេចក្តីផ្តើមនៃបណ្តុំបទគម្ពីរផ្តល់នូវទិដ្ឋភាពទូទៅដ៏ខ្លីមួយនៃបរិបទ និងមាតិកានៃបណ្តុំបទគម្ពីរសម្រាប់មេរៀននីមួយៗ ។

ការផ្តុំខគម្ពីរ និងសេចក្តីសង្ខេបពីបរិបទ

បណ្តុំបទគម្ពីរ ជាញឹកញាប់ត្រូវបានចែកចេញជាផ្នែក ឬក្រុមតូចៗនៃខគម្ពីរ ដែលមានការផ្លាស់ប្តូរនៃប្រធានបទ ឬសកម្មភាព ។ សេចក្តីយោងនៃក្រុមខគម្ពីរនីមួយៗត្រូវបានបន្តដោយសេចក្តីសង្ខេបដ៏ខ្លីនៃហេតុការណ៍ ឬ ការបង្រៀននៅក្នុងក្រុមនៃខគម្ពីរនោះ ។

ជំនួយក្នុងការបង្រៀន

ជំនួយក្នុងការបង្រៀននឹងពន្យល់ពីគោលការណ៍ និងវិធីបង្រៀនជំណឹងល្អនានា ។ វាអាចជួយដល់អ្នកនៅក្នុងការខិតខំដើម្បីកែលម្អក្នុងនាមជាគ្រូបង្រៀនម្នាក់ ។

តួសេចក្តីនៃមេរៀន

តួសេចក្តីនៃមេរៀននេះ រួមមានការដឹកនាំសម្រាប់អ្នក នៅពេលអ្នកសិក្សា និងបង្រៀន ។ វាផ្តល់នូវគំនិតក្នុងការបង្រៀន រួមមានសំណួរ សកម្មភាព សម្តីដកស្រង់ ឌីយ៉ាក្រម និង តារាងនានា ។

គោលលទ្ធិ និង គោលការណ៍ទាំងឡាយ

នៅពេលគោលលទ្ធិ និងគោលការណ៍ទាំងឡាយលេចចេញមកពីការសិក្សានៃវគ្គព្រះគម្ពីរ វាបញ្ជាក់ជាអក្សរក្រាស់ខ្មៅដើម្បីជួយដល់អ្នកឲ្យរកឃើញ និងបញ្ជាក់ន័យដល់វានៅក្នុងការពិភាក្សារបស់អ្នកជាមួយនឹងសិស្ស ។

រូបភាព

រូបភាពនៃអ្នកដឹកនាំសាសនាចក្រ និងហេតុការណ៍នានាពីព្រះគម្ពីរ តំណាងឲ្យជំនួយដែលអ្នកអាចបង្ហាញឲ្យឃើញ ប្រសិនបើវាមាននៅពេលអ្នកបង្រៀន ។

ចំណេះចំណានខគម្ពីរ

វគ្គចំណេះចំណានខគម្ពីរទាំង ២៥ ដែលមាន នៅក្នុងព្រះគម្ពីរមរមនត្រូវបានគូសបញ្ជាក់ នៅក្នុងបរិបទនៃមេរៀនដែលវាលេចឡើង ។ មេរៀនទាំងនេះនីមួយៗក៏រួមមាននូវគំនិតក្នុង ការបង្រៀនសម្រាប់វគ្គនីមួយៗដែរ ។ ដើម្បីជួយអ្នកឲ្យមានភាពខ្ជាប់ខ្ជួននៅក្នុងការបង្រៀន ចំណេះចំណានខគម្ពីរ នោះមានសកម្មភាពក្នុងការរំឲ្យកចំណេះចំណានខគម្ពីរធ្វើឡើង នៅក្នុងសៀវភៅណែនាំនេះ ។ សម្រាប់គំនិតក្នុងការបង្រៀនចំណេះចំណានខគម្ពីរបន្ថែម សូមមើលក្នុងសេចក្តីបន្ថែមនៅចុងបញ្ចប់នៃ សៀវភៅណែនាំនេះ ។

ចន្លោះជួរឈរ

ចន្លោះជួរឈរអាចត្រូវបានប្រើសម្រាប់ ការរៀបចំមេរៀន រួមមានការសរសេរកត់ចំណាំ គោលការណ៍ បទពិសោធន៍ ឬគំនិតផ្សេងទៀត នៅពេលអ្នកទទួលបានការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

សម្ពីដកស្រង់ និងការពន្យល់បន្ថែមត្រូវបានផ្តល់នៅចុងបញ្ចប់នៃមេរៀនមួយចំនួន ដើម្បីផ្តល់ដល់អ្នកនូវការយល់ដឹងបន្ថែមនៃ គោលគំនិតជាក់លាក់នានា ឬវគ្គព្រះគម្ពីរ ។ សូមប្រើប្រាស់ព័ត៌មាននៅក្នុងផ្នែកនេះដើម្បីរៀបចំឆ្លើយនឹងសំណួរ ឬផ្តល់នូវការយល់ដឹងបន្ថែម នៅពេលអ្នកបង្រៀន ។

គំនិតបន្ថែមសម្រាប់ការបង្រៀន

គំនិតបន្ថែមសម្រាប់ការបង្រៀន មាននៅចុងបញ្ចប់នៃមេរៀនមួយចំនួន ។ វានឹងផ្តល់នូវយោបល់សម្រាប់ការបង្រៀនគោលលទ្ធិ និងគោលការណ៍ដែលមិនអាចរកឃើញ ឬបញ្ជាក់ន័យនៅក្នុងតួសេចក្តីនៃមេរៀននេះ ។ វាក៏ផ្តល់នូវយោបល់អំពីការប្រើប្រព័ន្ធផ្សព្វផ្សាយ ដូចជាការចាក់វីដេអូ ជាដើម ។



សូមចែកក្រដាសដល់សិស្ស ហើយប្រាប់ពួកគេថា ពួកគេនឹងសរសេរនូវការដាស់តឿនមួយដោយផ្អែកលើវគ្គចំណេះចំណានខគម្ពីរ ដែលពួកគេចូលចិត្តនៅក្នុងព្រះគម្ពីរមរមន ។ នៅក្បាលលើនៃក្រដាស សូមឲ្យសិស្សសរសេរថា ៖ « ខ្ញុំនឹងនិយាយរឿងខ្លះទៅកាន់ យុវវ័យនៅថ្ងៃចុងក្រោយ » ។ សូមឲ្យសិស្សម្នាក់ៗជ្រើសរើសវគ្គចំណេះចំណានខគម្ពីរដែលគេចូលចិត្ត ហើយបន្ទាប់មកសរសេរ ពាក្យដាស់តឿនមួយដល់យុវវ័យនៅថ្ងៃចុងក្រោយ ដោយផ្អែកលើសារលិខិតដែលពួកគេបានជ្រើសរើស ។ ការដាស់តឿនរបស់គេ អាចរួមមាន ការសង្ខេបនៃសេចក្តីពិតដ៏សំខាន់ដែលមាននៅក្នុងវគ្គចំណេះចំណានខគម្ពីរ ការពន្យល់មួយពីមូលហេតុដែលសេចក្តីពិត ទាំងនេះសំខាន់សម្រាប់យុវវ័យសព្វថ្ងៃនេះ និងការអញ្ជើញមួយដើម្បីធ្វើសកម្មភាពតាមសេចក្តីពិតទាំងនេះ ។ ការទូន្មាននេះអាចបញ្ចប់ ដោយការសន្យាមួយជូចជាអ្វីដែលមាននៅក្នុង មរមន ៧:៧ ឬ មរមន ៧:១០ ។ អ្នកអាចសុំឲ្យសិស្សពីរបីនាក់ចែកចាយការទូន្មាន ដែលគេសរសេរួចហើយដល់សិស្សក្នុងថ្នាក់ ។ អ្នកក៏អាចប្រមូលការទូន្មានទាំងនេះដើម្បីធ្វើជាតម្រុយសម្រាប់ចំណេះចំណានខគម្ពីរនា សកម្មភាពពេលក្រោយ ឬដើម្បីបង្ហាញដល់សិស្ស ។

កំណត់ចំណាំ ៖ អ្នកអាចប្រើសកម្មភាពនេះនៅពេលណាក៏បានអំឡុងពេលបង្រៀន ។ ឧទាហរណ៍ អ្នកអាចប្រើវានៅពេលបញ្ចប់ មេរៀននេះ ឬអ្នកអាចប្រើវាក្រោយពីការពិភាក្សា មរមន ៧ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

មរមន ៧ ។ការអង្វរចុងក្រោយរបស់លោកមរមន ឲ្យជឿលើព្រះគ្រីស្ទ ។

អែលឌើរ ដែហ្វ្រី អ៉រ ហុឡិន ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ពីការអង្វរ ចុងក្រោយរបស់លោកមរមន ឲ្យជឿលើព្រះគ្រីស្ទ ជាការអង្វរមួយដែលលោកបានសរសេរ ដល់ប្រជាជននៅក្នុងជំនាន់របស់យើង ក្រោយពីបានឃើញពីសេចក្តីបំផ្លិចបំផ្លាញនៃជាតិ សាសន៍បស់លោកទាំងមូល ។

« នៅក្នុងការស្លាប់តែឯង មរមនបានឆ្លងកាត់ពេលវេលា និងទីកន្លែងជាច្រើន ជាពិសេស ដល់ « សំណល់នៃវង្សអ៊ីស្រាអែល » ដែលនឹងអានបញ្ជីដ៏អស្ចារ្យរបស់លោកនាថ្ងៃណាមួយ ។ អ្នកទាំងឡាយណាដែលនៅក្នុងសម័យ និងកន្លែងផ្សេងត្រូវតែរៀនអ្វីដែលមានចំពោះមុខ លោកត្រូវបានបំផ្លិចចោល —ថាអ្នកទាំងអស់ត្រូវ « ជឿលើព្រះយេស៊ូវគ្រីស្ទ ថាទ្រង់គឺជា ព្រះពជប្រត្រានៃព្រះ » ថាបន្ទាប់ពីគេត្តាងទ្រង់នៅទីក្រុងយេរូសាឡិម « ដោយព្រះចេស្តា នៃព្រះវរបិតា . . . បានរស់ឡើងវិញជាថ្មី ដែលទ្រង់បានទទួលបានជ័យជំនះលើផ្នូរ ហើយ នៅក្នុងទ្រង់ផងដែរគឺជាខ្សែនៃសេចក្តីស្លាប់ដែលលេចឡើង ។

បន្ទាប់មក អស់អ្នកណាដែលត្រូវបានប្រោសលោះអាចនឹងរ៉ីកកាយ « នៅក្នុងស្ថានភាព មួយដ៏សប្បាយរ៉ីកកាយហើយគ្មានទីបំផុត » ដោយសារតែព្រះគ្រីស្ទ ។ [មរមន ៧:២, ៥–៧ ។] . . .

« ដើម្បី « ជឿលើព្រះគ្រីស្ទ » ជាពិសេសនៅពេលប្រទាំងនឹងលទ្ធផលដ៏សោកនាដកម្ម ប៉ុន្តែ ដែលអាចចៀសវាងបាននេះ គឺជាការអង្វរចុងក្រោយរបស់លោកមរមន និងជាសេចក្តីសង្ឃឹម តែមួយគត់របស់លោក ។ វាគឺជាគោលបំណងចុងក្រោយនៃគម្ពីរទាំងមូលដែលនឹងចេញមក ដល់ពិភពលោកនាថ្ងៃចុងក្រោយ ដោយមានឈ្មោះរបស់លោក » (*Christ and the New Covenant: The Messianic Message of the Book of Mormon* [ឆ្នាំ ១៩៩៧], ទំព័រ ៣២១–២២) ។

គំនិតបន្ថែមទាំងឡាយសម្រាប់ការបង្រៀន

មរមន ៧:៨–៩ ។ព្រះគម្ពីរបរិសុទ្ធ និង ព្រះគម្ពីរមរមន

សូមបង្ហាញព្រះគម្ពីរមរមនមួយក្បាល ដោយសរសេរថា « នេះ » ។ បន្ទាប់មក សូមបង្ហាញ ព្រះគម្ពីរបរិសុទ្ធមួយក្បាលដោយសរសេរថា « នោះ » ។ សូមឲ្យសិស្សអាន មរមន ៧:៨–៩ ដោយស្វាត់ៗដោយរកមើលអ្វីដែលលោកមរមនបានមានប្រសាសន៍អំពីទំនាក់ទំនងរវាង « នេះ » (ព្រះគម្ពីរមរមន) និង « នោះ » (ព្រះគម្ពីរបរិសុទ្ធ) ។

- តើការសិក្សាព្រះគម្ពីរមរមនបានពង្រឹងដល់ទីបន្ទាល់របស់អ្នកនៃសេចក្តីពិតនៅក្នុង ព្រះគម្ពីរបរិសុទ្ធដោយរបៀបណា ? តើការសិក្សាព្រះគម្ពីរបរិសុទ្ធបានពង្រឹងដល់ទីបន្ទាល់ របស់អ្នកនៃព្រះគម្ពីរមរមនដោយរបៀបណា ?

487

កម្មវិធីសិក្សាថ្នាក់សិក្ខាសាលាប្រចាំថ្ងៃ (ម៉ោងចេញផ្សាយ និងម៉ោងព្រឹកព្រលឹម)

សៀវភៅណែនាំនេះរួមមានមូលដ្ឋានគ្រឹះដូចខាងក្រោមសម្រាប់គ្រូបង្រៀនថ្នាក់សិក្ខាសាលាប្រចាំថ្ងៃ ៖ មេរៀនប្រចាំថ្ងៃសម្រាប់គ្រូបង្រៀនចំនួន ១៦០ មេរៀន ជំនួយដល់ការបង្រៀន និងធនធានក្នុងការបង្រៀនចំណេះចំណានខគម្ពីរ និងគោលលទ្ធិគ្រឹះទាំងឡាយ ។

មេរៀនប្រចាំថ្ងៃសម្រាប់គ្រូបង្រៀន

ទម្រង់នៃមេរៀន

មេរៀននីមួយៗនៅក្នុងក្នុងសៀវភៅណែនាំនេះ ផ្តោតលើបណ្តុំបទគម្ពីរជាជាងផ្តោតទៅលើគំនិត គោលលទ្ធិ ឬ គោលការណ៍ពិសេសណាមួយ ។ទម្រង់បែបនេះនឹងជួយដល់អ្នក និងសិស្សរបស់អ្នកឲ្យសិក្សាព្រះគម្ពីរតាមលំដាប់លំដោយ និងពិភាក្សាពីគោលលទ្ធិ និងគោលការណ៍ នៅពេលវាលេចឡើងនៅក្នុងបរិបទព្រះគម្ពីរ ។ នៅពេលសិស្សរៀនពីបរិបទដែលមានគោលលទ្ធិ ឬ គោលការណ៍មួយ នោះការយល់ដឹងពីសេចក្តីពិតនោះអាចត្រូវបានធ្វើឲ្យសឺជម្រៅបន្ថែមទៀត ។ លើសពីនេះសិស្សនឹងអាចឃើញ ហើយយល់កាន់តែច្បាស់ពីវិសាលភាពដ៏ពេញលេញនៃសារលិខិតដែលត្រូវបានបំផុសដោយអ្នកសរសេរព្រះគម្ពីរ ដែលមានបំណងដើម្បីផ្តល់ឲ្យ ។ ការបង្រៀនព្រះគម្ពីរតាមរបៀបនេះ ក៏នឹងជួយដល់សិស្សឲ្យរៀនពីរបៀបដើម្បីរក និងអនុវត្តសេចក្តីពិតដ៏អស់កល្បនៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនផងដែរ ។

នៅក្នុងមេរៀននីមួយៗ នឹងមិនមានផ្នែកនៃបណ្តុំបទគម្ពីរទាំងអស់ត្រូវបញ្ជាក់នោះទេ ។ ផ្នែកខ្លះមានការយកចិត្តទុកដាក់តិចជាង ដោយសារវាមិនសូវជាស្នូលនៃសារលិខិតទាំងអស់ពីអ្នកសរសេរដ៏បំផុសគិត ឬ ដោយសារវាអាចមិនសូវអនុវត្តចំពោះយុវវ័យ ។ អ្នកមានទំនួលខុសត្រូវក្នុងការសម្របសម្ពារមេរៀនទាំងនេះ ស្របតាមតម្រូវការ និងចំណាប់អារម្មណ៍របស់សិស្សដែលអ្នកបង្រៀន ។ អ្នកអាចសម្របគំនិតក្នុងមេរៀនដែលមាននៅក្នុងសៀវភៅណែនាំនេះ ដើម្បីធ្វើការសង្កត់ធ្ងន់ទៅលើគោលលទ្ធិ ឬគោលការណ៍ច្បាស់លាស់ណាមួយលើសពីអ្វីដែលបានផ្តល់ឲ្យនៅក្នុងជំនួយមេរៀននេះ ឬជ្រើសរើសគូសបញ្ជាក់បន្ថិចបន្ថូចលើវគ្គបណ្តុំបទគម្ពីរដែលត្រូវបានបង្កើតឡើងមានភាពសឺជម្រៅនៅក្នុងសៀវភៅនេះ ។ សូមស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធដើម្បីជួយដល់អ្នកឲ្យធ្វើការសម្របតាម នៅពេលអ្នករៀបចំបង្រៀន ។

គោលលទ្ធិ និង គោលការណ៍ទាំងឡាយ

នៅក្នុងតួសេចក្តីនៃមេរៀននីមួយៗ អ្នកនឹងឃើញថា គោលលទ្ធិ និងគោលការណ៍គន្លឹះមួយចំនួនត្រូវបានបញ្ជាក់ជាអក្សរក្រាស់ខ្មៅដិត ។ គោលលទ្ធិ និងគោលការណ៍ទាំងនេះត្រូវបានរកឃើញនៅក្នុងកម្មវិធីសិក្សាដោយសារ (១) វាផ្លុះបញ្ចាំងពីសារលិខិតដ៏សំខាន់នៃបណ្តុំបទគម្ពីរ (២) វាអាចអនុវត្តបានជាពិសេសចំពោះតម្រូវការ និងកាលៈទេសៈរបស់សិស្ស ឬ (៣) វាគឺជាគន្លឹះនៃសេចក្តីពិតដែលអាចជួយសិស្សឲ្យយល់សឺជម្រៅពីទំនាក់ទំនងរបស់គេជាមួយនឹងព្រះអម្ចាស់ ។ សូមប្រយត្ន័ថា ព្រះគម្ពីរមរមនបង្រៀនពីសេចក្តីពិតជាច្រើនលើសពីអ្វីដែលបានមាននៅក្នុងកម្មវិធីសិក្សានេះ ។ ប្រធាន ប៊ិយដ៍ យេ. ផាកកឺ បានបង្រៀនថា ព្រះគម្ពីរូមមាននូវ « ការបន្សំដ៏មិនចេះចប់នៃសេចក្តីពិតដែលនឹងសឺគ្នានឹងតម្រូវការរបស់បុគ្គលគ្រប់រូបនៅក្នុងគ្រប់ស្ថានភាព » (« The Great Plan of Happiness" [CES Symposium on the Doctrine and Covenants/Church History ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៣], ទំព័រ ២, si.lds.org) ។

នៅពេលអ្នកបង្រៀន សូមផ្តល់ដល់សិស្សនូវឱកាសជាបន្តបន្ទាប់ឲ្យរកមើលគោលលទ្ធិ និងគោលការណ៍នានានៅក្នុងព្រះគម្ពីរ ។ នៅពេលសិស្សបង្ហាញនូវសេចក្តីពិតដែលពួកគេរកឃើញ ជាញឹកញាប់ នោះពួកគេអាចប្រើពាក្យដែលខុសពីរបៀបដែលគោលលទ្ធិ ឬគោលការណ៍នានាបានចែងនៅក្នុងសៀវភៅណែនាំនេះ ។ ពួកគេក៏អាចរកឃើញនូវសេចក្តីពិតដែលមិនមាននៅក្នុងគម្រោងនៃមេរៀននេះដែរ ។ សូមប្រយត្ន័កុំនិយាយថា ចម្លើយរបស់សិស្សខុស ដោយសារតែពាក្យដែលពួកគេប្រើនោះខុសពីពាក្យដែលបានប្រើនៅក្នុងសៀវភៅណែនាំនេះ ឬដោយសារពួកគេរកឃើញសេចក្តីពិតមួយដែលមិនមាននៅក្នុងកម្មវិធីសិក្សានេះឡើយ ។ ទោះជាយ៉ាងណាក្តី ប្រសិនបើប្រយោគដែលសិស្សនិយាយខុសគោលលទ្ធិ នោះវាជាភារកិច្ចរបស់អ្នកដើម្បីជួយដល់សិស្សដោយកបទាបក្នុងការកែតម្រូវប្រយោគរបស់គេ ជាមួយបរិយាកាសនៃសេចក្តីស្រឡាញ់ និងទំនុកចិត្ត ។ ដោយការធ្វើដូច្នោះ អាចផ្តល់នូវបទពិសោធន៍រៀនសូត្រដ៏សំខាន់មួយដល់សិស្សនៅក្នុងថ្នាក់របស់អ្នក ។

ល្បឿន

សៀវភៅណែនាំនេះរួមមានមេរៀនប្រចាំថ្ងៃសម្រាប់ថ្នាក់សិក្ខាសាលាចំនួន ១៦០ មេរៀន ដែលអាចបណ្តាលឲ្យមានការអាក់ខានចំពោះកាលវិភាគសាលារៀន និងសហគមន៍ ហើយក៏មានពេលទំនេរខ្លះសម្រាប់រំឲ្យកបរិបទនៃព្រះគម្ពីរឡើងវិញ ឬសូត្រចំណេះចំណានខគម្ពីរ ។ អ្នកអាចសម្របសម្រួលមេរៀននេះ និងល្បឿននៃមេរៀនតាមពេលវេលាដែលអ្នកមានដើម្បីបង្រៀនវគ្គសិក្សានេះ ។ (សូមមើលសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះសម្រាប់ការណែនាំអំពីគំរូនៃល្បឿនបង្រៀន ។)

កិច្ចការជំនួសអវត្តមាន

សៀវភៅមគ្គុទេសន៍ការសិក្សានៃព្រះគម្ពីរមរមនសម្រាប់សិស្សថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ អាចត្រូវប្រើនៅក្នុងកម្មវិធីថ្នាក់សិក្ខាសាលាប្រចាំថ្ងៃ ជាធនធានមួយដើម្បីផ្តល់ដល់សិស្សនូវកិច្ចការជំនួសអវត្តមាន ។ មេរៀននៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សាសម្រាប់សិស្សសិក្សានៅផ្ទះ ស្របគ្នាទៅនឹងអ្វីដែលមាននៅក្នុងសៀវភៅសិក្សានេះ ។ សិស្សដែលមានអវត្តមានច្រើន អាចដាក់ឲ្យធ្វើការនេះពីសៀវភៅមគ្គុទេសន៍ការសិក្សាដែលស្របគ្នាទៅនឹងបរិបទដែលពួកគេបានខកខានមិនបានរៀននៅក្នុងថ្នាក់ ។ កិច្ចការនោះអាចបោះពុម្ពចេញពីគេហទំព័រ ស&វ ដូច្នេះអ្នកមិនចាំបាច់ចែកសៀវភៅទាំងមូលដល់សិស្សដែលត្រូវធ្វើកិច្ចការជំនួសអវត្តមាននោះទេ ។ ព័ត៌មានបន្ថែមទាក់ទងទៅនឹង *សៀវភៅមគ្គុទេសន៍ការសិក្សានៃព្រះគម្ពីរមរមនសម្រាប់សិស្សថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ* ត្រូវបានផ្តល់នៅក្នុងផ្នែកដែលមានចំណងជើងថា « កម្មវិធីថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ » ។

ជំនួយក្នុងការបង្រៀន

ជំនួយក្នុងការបង្រៀនមាននៅរឹមទំព័រនៃសៀវភៅណែនាំនេះ ។ ជំនួយក្នុងការបង្រៀនទាំងនេះជួយពន្យល់ និងបង្ហាញពីរបៀបដែលអ្នក និងសិស្សដែលអ្នកបង្រៀនអាចអនុវត្តគោលគ្រឹះនៃការបង្រៀន និងការរៀនសូត្រដំណឹងល្អនៅក្នុងការសិក្សារបស់អ្នកអំពីព្រះគម្ពីរមរមន ។ វាក៏ផ្តល់នូវយោបល់នានាអំពីរបៀបដើម្បីប្រើវិធីបង្រៀន ជំនាញ និងជំណោះស្រាយបង្រៀនផ្សេងៗដោយមានប្រសិទ្ធភាពផងដែរ ។ នៅពេលអ្នកយល់ពីគោលការណ៍ដែលមាននៅក្នុងជំនួយក្នុងការបង្រៀននេះ ហើយ សូមរកមើលរបៀបដើម្បីអនុវត្ត និងធ្វើវាជាប្រចាំនៅក្នុងការបង្រៀនរបស់អ្នក ។

ចំណេះចំណានខគម្ពីរ និងគោលលទ្ធិគ្រឹះ

ដើម្បីជួយសិស្សឲ្យទទួលយកបានសេចក្តីពិតដ៏អស់កល្បជានិច្ច និងដើម្បីបង្កើនទំនុកចិត្តរបស់គេក្នុងការរៀនសូត្រ និងការបង្រៀនពីព្រះគម្ពីរ ថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាននៃសាសនា (ស&វ) បានជ្រើសរើសវគ្គព្រះគម្ពីរមួយចំនួនសម្រាប់សិស្សរៀនឲ្យចងចាំអំឡុងពេលរៀននៅក្នុងវគ្គនេះ ។ បន្ថែមលើនេះ បញ្ជីនៃគោលលទ្ធិគ្រឹះក៏រួមបញ្ចូលដើម្បីបញ្ជាក់ពីគោលលទ្ធិគន្លឹះ ដែលសិស្សត្រូវយល់ ជឿ និងរស់នៅតាមពេញបួនឆ្នាំនៅក្នុងថ្នាក់សិក្ខាសាលានេះ និងសម្រាប់ពេញមួយជីវិតរបស់គេ ។ សៀវភៅណែនាំសម្រាប់វគ្គសិក្សានីមួយៗត្រូវបានរៀបចំដើម្បីបញ្ជាក់ពីគោលលទ្ធិគ្រឹះ នៅពេលវាបង្ហាញអំឡុងពេលការសិក្សាជាសើរីរបស់សិស្សក្នុងព្រះគម្ពីរនេះ ។ វគ្គចំណេះចំណានខគម្ពីរជាច្រើនត្រូវបានជ្រើសរើសដោយមានគោលលទ្ធិគ្រឹះនៅក្នុងគំនិត ដូច្នោះនៅពេលអ្នកបង្រៀនវគ្គចំណេះចំណានខគម្ពីរដល់សិស្ស អ្នកនឹងបង្រៀនគោលលទ្ធិគ្រឹះផងដែរ ។

នៅពេលបុគ្គលទាំងឡាយទទួលបានសេចក្តីពិតដ៏អស់កល្បជានិច្ចនៅក្នុងគំនិត និងដួងចិត្តរបស់គេហើយ នោះព្រះវិញ្ញាណបរិសុទ្ធនឹងនាំសេចក្តីពិតទាំងនេះឲ្យចងចាំ នៅពេលដែលចាំបាច់ និងផ្តល់ភាពក្លាហានដល់គេដើម្បីធ្វើសកម្មភាពក្នុងសេចក្តីជំនឿ (សូមមើល យ៉ូហាន ១៤:២៦) ។ប្រធានហាវីដ ជបុលយូ ហឹនធើរ បានបង្រៀន ៖

« ខ្ញុំសូមលើកទឹកចិត្តអ្នកយ៉ាងមឺងមាត់ ឲ្យប្រើបាស្រ់ព្រះគម្ពីរនៅក្នុងការបង្រៀនរបស់អ្នក ហើយធ្វើអ្វីគ្រប់យ៉ាងឲ្យអស់ពីលទ្ធភាពរបស់អ្នកដើម្បីជួយសិស្សទាំងឡាយឲ្យប្រើប្រាស់ព្រះគម្ពីរ និងចូលចិត្តប្រើប្រាស់ព្រះគម្ពីរ ។ ខ្ញុំចង់ឲ្យយុវវ៉ៃយវ៉ៃក្មេងរបស់យើងមានទំនុកចិត្តលើព្រះគម្ពីរ ។ . . .

« . . . យើងចង់ឲ្យសិស្សមានទំនុកចិត្តលើអានុភាព និងសេចក្តីពិតនៃព្រះគម្ពីរ មានទំនុកចិត្តដែលព្រះវរបិតាសួគ៌របស់គេកំពុងមានព្រះបន្ទូលពិតប្រាកដទៅកាន់ពួកគេតាមរយៈព្រះគម្ពីរ ហើយទំនុកចិត្តថាពួកគេអាចងាកទៅអានព្រះគម្ពីរ ហើយរកចម្លើយចំពោះបញ្ហាទាំងឡាយ និងការអធិស្ឋានរបស់គេ ។ . . .

« . . . យើងសង្ឃឹមថា គ្មានសិស្សណាម្នាក់របស់អ្នកនឹងចាកចេញពីថ្នាក់របស់អ្នកដោយការភ័យខ្លាច ឬ ខ្មាស់អៀន ឬ អាម៉ាស់មុខឡើយ ដោយថាពួកគេមិនអាចរកឃើញជំនួយដែលពួកគេត្រូវការ ដោយសារតែពួកគេមិនដឹងពីព្រះគម្ពីរគ្រប់គ្រាន់ល្មម ដើម្បីរកឃើញខគម្ពីរត្រឹមត្រូវនោះឡើយ » (« Eternal Investments » [សុន្ទរកថាថ្លែងទៅកាន់អ្នកអប់រំសាសនា CES នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨៩], ២, si.lds.org) ។

សូមមើលសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ សម្រាប់ព័ត៌មានបន្ថែមអំពីចំណេះចំណានខគម្ពីរ និងគោលលទ្ធិគ្រឹះនានា ។

ការប្រើមេរៀនសិក្សានៅផ្ទះ

សេចក្ដីសង្ខេបនៃមេរៀនរបស់សិស្ស

សេចក្ដីសង្ខេបនេះនឹងជួយអ្នកឲ្យស្គាល់បរិបទ និងគោលលទ្ធិ ហើយគោលការណ៍ទាំងឡាយ ដែលសិស្សបានសិក្សាក្នុងមួយសប្ដាហ៍នៅក្នុងសៀវភៅមគ្គុទេសក៍ការសិក្សារបស់សិស្ស ។

សេចក្ដីផ្ដើមនៃមេរៀន

សេចក្ដីផ្ដើមចំពោះមេរៀននេះ នឹងជួយអ្នកឲ្យស្គាល់ពីផ្នែកខ្លះៗនៃបណ្ដុំបទគម្ពីរមួយណា ដែលនឹងត្រូវប្រើសង្កត់បញ្ជាក់នៅក្នុងមេរៀននេះ ។

គួសេចក្ដីនៃមេរៀន

គួសេចក្ដីនៃមេរៀននេះ ផ្ដល់នូវការដឹកនាំសម្រាប់អ្នក នៅពេលអ្នកសិក្សា និងបង្រៀន ។ វាផ្ដល់នូវគំនិតក្នុងការបង្រៀន រួមមានសំណួរ សកម្មភាព សម្ដីដកស្រង់ ឌីយ៉ាក្រាម និងតារាងនានា ។

ការផ្ទុំខគម្ពីរ និងសេចក្ដីសង្ខេបពីបរិបទ

ខគម្ពីរត្រូវបានចាប់ជាក្រុម យោងតាមការផ្លាស់ប្ដូរនៅក្នុងបរិបទ ឬអត្ថបទដែលមានពេញមួយបណ្ដុំបទគម្ពីរ ។ សេចក្ដីយោងនៃក្រុមខគម្ពីរនីមួយៗត្រូវបានបន្តដោយសេចក្ដីសង្ខេបដ៏ខ្លីនៃព្រឹត្តការណ៍ ឬការបង្រៀននៅក្នុងក្រុមនៃខគម្ពីរនោះ ។

គោលលទ្ធិ និងគោលការណ៍ទាំងឡាយ

នៅពេលគោលលទ្ធិ និងគោលការណ៍ទាំងឡាយលេចចេញមកដោយឯកឯងពីការសិក្សានៃបទព្រះគម្ពីរ វាគូសបញ្ជាក់ជាអក្សរខ្មៅដិតដើម្បីជួយអ្នកឲ្យរកឃើញ និងបញ្ជាក់ន័យដល់វានៅក្នុងការពិភាក្សារបស់អ្នកជាមួយនឹងសិស្ស ។

សេចក្ដីផ្ដើមចំពោះមេរៀនបន្ទាប់

កថាខណ្ឌចុងក្រោយនៃមេរៀននីមួយៗនឹងផ្ដល់ជាគម្រុយមួយសម្រាប់មេរៀនបន្ទាប់ ។ សូមចែកចាយកថាខណ្ឌនេះជាមួយនឹងសិស្សរបស់អ្នក នៅពេលធ្វើសេចក្ដីសន្និដ្ឋានពីមេរៀននីមួយៗ ដើម្បីជួយពួកគេឲ្យរំពឹងមើលទៅការសិក្សាបទគម្ពីរនៅសប្ដាហ៍ក្រោយ ។



មេរៀនសិក្សានៅផ្ទះ

ពាក្យសម្ដីនៃមរមន –ម៉ូសាយ ៦ (មេរៀនទី ១១)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្ដីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្ដីសង្ខេបខាងក្រោមអំពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេសិក្សាពាក្យសម្ដីនៃមរមន ម៉ូសាយ ៦ (មេរៀនទី ១១) មិនមែនប្រើសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្ដោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ពាក្យសម្ដីនៃមរមន–ម៉ូសាយ ២)

សេចក្ដីផ្ដើម

មេរៀននេះនឹងជួយសិស្សឲ្យយល់ពីការបង្រៀនរបស់ស្ដេចបេនយ៉ាមីនទៅដល់បុត្រា និងប្រជាជនរបស់ទ្រង់បីឆ្នាំ មុនពេលទ្រង់សុគត ។ ស្ដេចបេនយ៉ាមីនបានបង្រៀនប្រជាជនរបស់ទ្រង់ ពីរបៀបដើម្បីទទួល និងរក្សាការផ្ដាច់បាបរបស់ពួកគេដោយការអនុវត្តសេចក្ដីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ។

យោបល់សម្រាប់ការបង្រៀន

ពាក្យសម្ដីនៃមរមន

នីហ្វៃ និង មរមនបង្ហាញពីទំនុកចិត្តរបស់ពួកគេទៅលើព្រះ

ម៉ូសាយ ២–៦

មេរៀនបន្ទាប់ (ម៉ូសាយ ៧–១៧)

កម្មវិធីថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ

កម្មវិធីថ្នាក់សិក្សានៅផ្ទះនឹងអនុញ្ញាតឲ្យសិស្សទទួលបានពិន្ទុនៅក្នុងថ្នាក់សិក្ខាសាលាដោយការបញ្ចប់មេរៀនផ្ទាល់ខ្លួននៅផ្ទះ ជាជាងការមកមេរៀននៅក្នុងថ្នាក់រាល់ថ្ងៃ ។ មេរៀនទាំងនេះមាននៅក្នុងសៀវភៅណែនាំមួយទៀតដែលហៅថា *សៀវភៅមគ្គុទេសន៍ការសិក្សានៃព្រះគម្ពីរមេរៀនសម្រាប់សិស្សថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ:* ។ មួយសប្តាហ៍ម្តង សិស្សនឹងជួបជាមួយនឹងគ្រូណែនាំថ្នាក់សិក្ខាសាលាដើម្បីប្រគល់កិច្ចការរបស់គេ និងចូលរួមនៅក្នុងថ្នាក់រៀន ។ សៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស និងមេរៀនក្នុងថ្នាក់ប្រចាំសប្តាហ៍ត្រូវបានពន្យល់បន្ថែមទៀតដូចខាងក្រោម ។

សៀវភៅមគ្គុទេសន៍ការសិក្សាសម្រាប់សិស្សសិក្សានៅផ្ទះ

សៀវភៅមគ្គុទេសន៍ការសិក្សានៃព្រះគម្ពីរមេរៀនសម្រាប់សិស្សថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះ: ត្រូវបានរៀបចំឡើងដើម្បីជួយសិស្សសិក្សានៅផ្ទះឲ្យទទួលបាននូវបទពិសោធន៍នៅក្នុងការសិក្សាព្រះគម្ពីរមេរៀនដែលស្រដៀងគ្នាទៅនឹងសិស្សថ្នាក់សិក្ខាសាលាដែលមករៀនប្រចាំថ្ងៃ ។ ហេតុដូច្នេះហើយ ល្បឿននៃសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស ក៏ដូចជាគោលលទ្ធិ និងគោលការណ៍ដែលវាគូសបញ្ជាក់លើនោះក៏លឿនប្រហែលគ្នាទៅនឹងអ្វីដែលនៅក្នុងសៀវភៅណែនាំនេះដែរ ។ សៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្សក៏រួមមាននូវការណែនាំអំពីចំណេះចំណានខគម្ពីរដែរ ។ វគ្គចំណេះចំណានខគម្ពីរត្រូវបានលើកឡើងនៅក្នុងបរិបទ នៅពេលវាលេចឡើងនៅក្នុងអត្ថបទព្រះគម្ពីរ ។ សកម្មភាពបន្ថែមត្រូវបានផ្តល់នៅចុងបញ្ចប់នៃមេរៀនដែលលើកឡើងពីវគ្គនោះ ។

រាល់សប្តាហ៍ សិស្សថ្នាក់សិក្ខាសាលាសិក្សានៅផ្ទះត្រូវបញ្ចប់មេរៀនបួនពីសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស ហើយចូលរួមនៅក្នុងថ្នាក់ប្រចាំសប្តាហ៍ដែលបង្រៀនដោយគ្រូថ្នាក់សិក្ខាសាលារបស់គេ ។ សិស្សបំពេញកិច្ចការមួយចំនួនពីសៀវភៅមគ្គុទេសន៍ការសិក្សានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់គេ ។ សិស្សគួរមានសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរពីរ ដើម្បីឲ្យពួកគេអាចទុកមួយជាមួយនឹងគ្រូបង្រៀន ហើយបន្តធ្វើការនៅក្នុងសៀវភៅមួយទៀត ។ នៅពេលសិស្សជួបនឹងគ្រូបង្រៀនរបស់គេរាល់សប្តាហ៍ សៀវភៅកំណត់ហេតុមួយត្រូវដាក់ឲ្យគ្រូបង្រៀននៅផ្ទះ ហើយមួយទៀតត្រូវឲ្យទៅសិស្សវិញ ដើម្បីប្រើសម្រាប់មេរៀននៅសប្តាហ៍ក្រោយទៀត ។ (ឧទាហរណ៍ ក្នុងមួយសប្តាហ៍ សិស្សបញ្ចប់កិច្ចការនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាទីមួយ ។ បន្ទាប់មក សិស្សយកសៀវភៅនេះទៅឲ្យគ្រូនៅក្នុងថ្នាក់ ។ នៅសប្តាហ៍ក្រោយ សិស្សបញ្ចប់កិច្ចការនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាទីពីរ ។ នៅពេលសិស្សឲ្យសៀវភៅកំណត់ហេតុការសិក្សាទីពីរទៅគ្រូ នោះគ្រូបង្រៀនត្រូវឲ្យសៀវភៅកំណត់ហេតុការសិក្សាទីមួយមកវិញ ។ ពេលនោះសិស្សនឹងប្រើសៀវភៅកំណត់ហេតុការសិក្សាទីមួយដើម្បីធ្វើកិច្ចការនៅសប្តាហ៍ក្រោយទៀត)។

សិស្សថ្នាក់សិក្ខាសាលាទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ហើយអានមេរៀននានា ប៉ុន្តែសិស្សសិក្សានៅផ្ទះគួរយល់ថា ពួកគេត្រូវបានរំពឹងឲ្យចំណាយពេលបន្ថែមពី ៣០ ទៅ ៤០ នាទីសម្រាប់មេរៀននីមួយនៅក្នុងមេរៀនទាំងបួនសម្រាប់ការសិក្សានៅផ្ទះនៅក្នុងដំណាក់នីមួយៗ និងចូលរួមនៅក្នុងថ្នាក់សិក្សានៅផ្ទះប្រចាំសប្តាហ៍ ។

មេរៀនសម្រាប់គ្រូបង្រៀនសិក្សានៅផ្ទះប្រចាំសប្តាហ៍

ដំណាក់នីមួយៗនៅក្នុង *សៀវភៅមគ្គុទេសន៍ការសិក្សានៃព្រះគម្ពីរមេរៀនសម្រាប់សិស្សថ្នាក់សិក្ខាសាលានៅផ្ទះ:* មាននូវមេរៀនជ្រាំនៅក្នុងសៀវភៅណែនាំសម្រាប់គ្រូបង្រៀនប្រចាំថ្ងៃ ។ នៅចុងបញ្ចប់នៃមេរៀននីមួយៗនៃមេរៀនទាំងជ្រាំនៅក្នុងសៀវភៅណែនាំនេះ អ្នកនឹងរកឃើញនូវមេរៀនសម្រាប់គ្រូបង្រៀននៅផ្ទះប្រចាំសប្តាហ៍ ។ មេរៀនសិក្សានៅផ្ទះនឹងជួយសិស្សឲ្យព្រឹក យល់កាន់តែស៊ីជម្រៅ ហើយអនុវត្តគោលលទ្ធិ និងគោលការណ៍នានាដែលពួកគេបានរៀន នៅពេលពួកគេបានបញ្ចប់មេរៀននៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្សក្នុងមួយសប្តាហ៍នេះ ។ មេរៀនទាំងនេះក៏មាននូវសេចក្តីពិតបន្ថែមលើសពីអ្វីដែលមាននៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្សទៅទៀត ។ (សម្រាប់ជំនួយនៅក្នុងការគ្រោងកាលវិភាគមេរៀនរបស់អ្នក សូមមើលការណែនាំល្បឿនសម្រាប់គ្រូបង្រៀនការសិក្សានៅផ្ទះនៅក្នុងសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ)។

ក្នុងនាមជាគ្រូបង្រៀនការសិក្សានៅផ្ទះ អ្នកគួរមានការយល់ដឹងទូទៅមួយអំពីអ្វីដែលសិស្សរបស់អ្នកកំពុងសិក្សានៅផ្ទះរាល់សប្តាហ៍ ដើម្បីឲ្យអ្នកអាចឆ្លើយទៅនឹងសំណួរ និងបង្កើតនូវការពិភាក្សាដ៏មានន័យនៅពេលអ្នកជួបនឹងពួកគេ ។ សូមឲ្យសិស្សយកព្រះគម្ពីរ សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ និងសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្សមកកាន់ថ្នាក់ប្រចាំសប្តាហ៍ ដើម្បីឲ្យពួកគេអាចបើកវានៅពេលរៀន ។ សូមសម្របមេរៀនតាមតម្រូវការរបស់សិស្សដែលអ្នកបង្រៀន និងស្របតាមការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ។ អ្នកក៏អាចបើកទៅមេរៀនប្រចាំថ្ងៃសម្រាប់គ្រូបង្រៀននៅក្នុងសៀវភៅណែនាំនេះ នៅពេលអ្នករៀបចំបង្រៀនបានដែរ ។ ការសិក្សាក្នុងជំនួយខាងការបង្រៀន និងវិធីបង្រៀនដែលប្រើនៅក្នុងមេរៀនប្រចាំថ្ងៃ អាចជួយពង្រឹងអ្នកក្នុងការបង្រៀនប្រចាំសប្តាហ៍របស់អ្នក ។ សូមត្រៀមបំពេញតម្រូវការជាពិសេសនានាដល់សិស្សដែលអ្នកបង្រៀន ។ ឧទាហរណ៍ ប្រសិនបើសិស្សម្នាក់ពិបាកសរសេរ សូមឲ្យគាត់ប្រើប្រដាប់ថតសំឡេង ឬហៅគំនិតរបស់គេដល់សមាជិកគ្រួសារ ឬមិត្តម្នាក់ដែលអាចសរសេរចម្លើយរបស់គេឲ្យបាន ។

នៅចុងបញ្ចប់នៃមេរៀនប្រចាំសប្តាហ៍នីមួយៗ សូមប្រមូលសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់សិស្ស និងលើកទឹកចិត្តពួកគេឲ្យបន្តសិក្សា ។ សូមចែកសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរដែលគេសម្រាប់កិច្ចការនៅសប្តាហ៍ក្រោយ ។ ដោយសារតែកម្រិតនៃពេលវេលា អ្នកមិនអាចបន្ថែមសេចក្តីបញ្ជាក់ដល់ចំណេះចំណានខគម្ពីរនៅក្នុងមេរៀនប្រចាំសប្តាហ៍របស់អ្នកបានឡើយ ។ នៅពេលអ្នកអានកិច្ចការនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់សិស្ស សូមឆ្លើយតបទៅនឹងកិច្ចការរបស់គេតាមពេលដោយការសរសេរកំណត់ចំណាំតូចមួយ ឬផ្តល់យោបល់នាពេលក្រោយនៅពេលអ្នកជួបពួកគេ ។ អ្នកក៏អាចរកវិធីផ្សេងទៀតដើម្បីបង្ហាញនូវការគាំទ្រ និងផ្តល់យោបល់កែតម្រូវដ៏មានប្រយោជន៍ ។ ការណ៍នេះនឹងជួយដល់សិស្សឲ្យដឹងថា អ្នកយកចិត្តទុកដាក់អំពីកិច្ចការរបស់គេ ហើយនឹងជួយជម្រុញដល់ពួកគេឲ្យខ្លាំងក្នុងកិច្ចការរបស់គេ ។

ធនធានដទៃទៀត

គ្រូបង្រៀនអាចមើលគេហទំព័ររបស់ថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា (si.lds.org) រកជំនួយនៅក្នុងការរៀបចំមេរៀន និងទទួលបានគំនិតបន្ថែមសម្រាប់ការបង្រៀនថែមទៀត ។ ធនធានខាងក្រោមនេះមាននៅក្នុងអិនធើណិតតាមរយៈអ្នកដឹកនាំរបស់អ្នក តាមរយៈមជ្ឈមណ្ឌលចែកចាយនៃសាសនាចក្រក្នុងស្រុក និងតាមរយៈហាងតាមអិនធើណិតនៃសាសនាចក្រ (store.lds.org) ៖

ធនធានឌី. ឌី. ឌី. សោតទស្សន៍នៃថ្នាក់សិក្ខាសាលា

សៀវភៅរូបភាពដំណឹងល្អ

កំណត់ហេតុការសិក្សាព្រះគម្ពីរ

វគ្គដាក់ចំណាំក្នុងសៀវភៅថ្នាក់សិក្ខាសាលា (ដែលរួមមាននូវកាលសម័យ និងបញ្ជីនៃសេចក្តីយោងចំណេះចំណានខគម្ពីរ និងពាក្យគន្លឹះទាំងឡាយ)

បណ្ណចំណេះចំណានខគម្ពីរ

ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងដំណឹងល្អ



ដើម្បីកម្លាំងនៃយុវជន

បណ្ណប្រកាសពេលវេលា

មេរៀនទី ១

តួនាទីរបស់សិស្ស

សេចក្តីផ្តើម

គោលបំណងនៃមេរៀននេះ គឺដើម្បីជួយដល់សិស្សទាំងអស់ឲ្យបំពេញតាមតួនាទីរបស់ពួកគេ នៅក្នុងការរៀនសូត្រពីដំណឹងល្អ ។ ពេលខ្លះ សិស្សគិតថា ទំនួលខុសត្រូវក្នុងការរៀនសូត្រ របស់ខ្លួន អាស្រ័យតែលើគ្រូបង្រៀនប៉ុណ្ណោះ ។ ប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធាន ទីមួយ បានមានប្រសាសន៍អំពីតម្រូវការទាំងសិស្ស និង គ្រូបង្រៀន ដើម្បីស្វែងរកការណែនាំ ពីព្រះវិញ្ញាណបរិសុទ្ធ ។

« បញ្ហា និងការល្បួងទាំងឡាយដែលសិស្សរបស់យើងបានជួបប្រទះ គ្រាន់តែក្នុងរយៈពេល ប្រាំឆ្នាំកន្លងទៅមានលក្ខណៈស្រាលជាងឆ្ងាយណាស់ បើប្រៀបធៀបទៅនឹងអ្វីដែលយើងមើល ឃើញនាពេលបច្ចុប្បន្ន ហើយវាមានលក្ខណៈកាន់តែពិបាកទៅនៅថ្ងៃអនាគត ។ ខ្ញុំមាន អារម្មណ៍ . . . ថា អ្វីដែលយើងបានធ្វើ និងកំពុងធ្វើ នឹងមិនគ្រប់គ្រាន់នោះទេ ។ យើងត្រូវការ ព្រះចេស្តាដ៏អស្ចារ្យជាងនេះ ដើម្បីទាញយកដំណឹងល្អមកចាក់ចូលនៅក្នុងដួងចិត្ត និង ជីវិតនៃ កូនសិស្សទាំងឡាយរបស់យើង ។ . . .

« អ្នកត្រូវតែមានព្រះវិញ្ញាណធ្វើជាដៃគូដ៏ខ្ជាប់ខ្ជួនរបស់អ្នក ដើម្បីបង្រៀនដោយព្រះចេស្តា ហើយសិស្សរបស់អ្នកនឹងមិនរស់រានខាងវិញ្ញាណបានទេ បើគ្មានព្រះវិញ្ញាណជាដៃគូរបស់ ពួកគេ » (« ព្រះវិញ្ញាណ ត្រូវតែជាដៃគូដ៏ខ្ជាប់ខ្ជួនរបស់យើង » [សុន្ទរកថាទៅកាន់អ្នកអប់រំ សាសនា ផ្នែក CES នៅថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០០៣] ទំព័រ ១ , si.lds.org) ។

នៅពេលដែលអ្នកបង្រៀនដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ហើយជួយសិស្សឲ្យរៀន ដោយព្រះចេស្តាដូចគ្នានោះ អ្នកអាចជួយពួកគេឲ្យក្លាយជាអ្នកផ្តាស់ប្រែចិត្តដ៏ពិត ចំពោះ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញនេះ ។ អ្នកអាចត្រូវការរំឭកគោលការណ៍ ដែលបានបង្រៀននៅក្នុងមេរៀននេះជាប្រចាំ ដើម្បីរំឭកសិស្សទាំងអស់ពីទំនួលខុសត្រូវនៅក្នុង ថ្នាក់របស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

ទំនួលខុសត្រូវផ្ទាល់ខ្លួនក្នុងការរៀនដោយការសិក្សា និង ដោយសេចក្តីជំនឿ

សូមអញ្ជើញសិស្សម្នាក់ឡើងមកខាងមុខថ្នាក់ ។ សូមពន្យល់ថា អ្នកចង់ជួយសិស្សនោះ ឲ្យរឹងមាំខាងវាងកាយខ្លាំងជាងមុន ។ បន្ទាប់ មក សូមហៅសិស្សទីពីរម្នាក់ទៀតមកខាងមុខ ហើយធ្វើអាវ៉ាំង់ប្រាំដង ។

ក្រោយពីសិស្សទីពីរបានធ្វើអាវ៉ាំង់រួចហើយ សូមសួរទៅសិស្សទីមួយថា ៖

- **តើការធ្វើអាវ៉ាំង់នោះ បានជួយឲ្យអ្នករឹងមាំជាងមុនដែរឬទេ ?**

សូមសួរទៅថ្នាក់ថា ៖

- **តើឧទាហរណ៍នៃការហាត់ប្រាណនេះ ទាក់ទងនឹងការទទួលខុសត្រូវរបស់អ្នកក្នុងការរៀនពីដំណឹងល្អយ៉ាងដូចម្តេច ? តើនរណា ទទួលខុសត្រូវចំពោះការរៀនពីដំណឹងល្អរបស់អ្នក ?**

សូមអញ្ជើញសិស្សម្នាក់ឲ្យអានពាក្យគោលលទ្ធិ និង សេចក្តីសញ្ញា ៨៨:១១៨ ឲ្យឮៗ ។

- **តើអ្នកគិតថា វាមានន័យដូចម្តេច ដើម្បី « ស្វែងរកការរៀនសូត្រ . . . គឺដោយសារការសិក្សា និង ដោយសារសេចក្តីជំនឿផង » ? (អ្នកអាចលើកឡើងថា*ការរៀនសូត្រដោយការការសិក្សា និងដោយសេចក្តីជំនឿ តម្រូវឲ្យមានការខិតខំរៀងៗខ្លួន* ។)**

អែលឌើរ ដេវីឌ អេ បែដណា នៃក្រុមនៃសាវកដប់ពីរនាក់ បាននិយាយអំពី អត្ថន័យនៃការរៀនដោយ សេចក្តីជំនឿ ។ សូមលើកទឹកចិត្តសិស្សឲ្យសរសេរសម្តីនេះទុកនៅកន្លែងណាមួយ (ប្រហែលនៅក្នុងកំណាត់ហេតុ សិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេររបស់ពួកគេ) ដូច្នេះ ពួកគេអាចមើលវាបានញឹកញាប់ អំឡុងពេលរៀនថ្នាក់ សិក្ខាសាលា ៖

« ការរៀនដោយសេចក្តីជំនឿ តម្រូវឲ្យមានការខំប្រឹងខាងវិញ្ញាណ សតិអារម្មណ៍ និងរាងកាយ ហើយមិនមែនគ្រាន់ តែជាការទទួលអំពើនោះទេ ។ . . . សិស្សម្នាក់ត្រូវតែអនុវត្តសេចក្តីជំនឿ និងប្រតិបត្តិដើម្បីទទួលបានចំណេះដឹង សម្រាប់ខ្លួនឯងផ្ទាល់ » (« ស្វែងរកការរៀនសូត្រដោយសេចក្តីជំនឿ » [ការថ្លែងទៅកាន់អ្នកអប់រំខាងសាសនា ផ្នែក CES ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០០៦] ទំព័រ ៣, si.lds.org) ។

ការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនប្រចាំថ្ងៃ

សូមពន្យល់ថា ការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនប្រចាំថ្ងៃ គឺជាផ្នែកមួយដ៏សំខាន់នៃការស្វែងរកការរៀនសូត្រដោយសារការសិក្សា និង ដោយសារសេចក្តីជំនឿ ។

សូមអញ្ជើញសិស្សឲ្យអាន ហេលេមិន ៣:២៩–៣០ ឲ្យឮៗ ។

- **តើអ្នកគិតថា វាមានភាពខុសគ្នាយ៉ាងណា រវាងការអានព្រះគម្ពីរមិនស្ទាប់ចប់ និង « ការកាន់តាមព្រះបន្ទូលនៃព្រះ » ?**
- **ដោយយោងតាម ខ ដែលយើងទើបតែបានអាន តើពរជ័យអ្វីខ្លះ ដែលបានមកពីការកាន់តាមព្រះបន្ទូលនៃព្រះ ?**
- **តើពរជ័យអ្វីផ្សេងទៀត ដែលមកតាមរយៈការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ?**
- **តើពេលណាដែលអ្នកទទួលបានពរជ័យនានា តាមរយៈការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនប្រចាំថ្ងៃ ?**

កំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់

កំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ អាចជាកំណត់ហេតុដែលចងភ្ជាប់ ជាសៀវភៅសរសេរមួយ ឬ សន្លឹកសៀវភៅដាក់ក្នុងសៀវភៅកង ។ នៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ សិស្សអាចធ្វើការកត់ចំណាំ និង សរសេរនូវការចាប់អារម្មណ៍ទាំងឡាយ អំឡុងពេលរៀន អំឡុងពេលសិក្សាផ្ទាល់ខ្លួន និង នៅក្នុងការប្រជុំសាសនាចក្រផ្សេងៗទៀត ។ នៅពេលពួកគេសរសេរ និង រៀបចំគំនិត ព្រមទាំងចំណាប់អារម្មណ៍របស់ខ្លួន នោះពួកគេនឹងត្រូវបានរៀបចំដើម្បីចូលរួមនៅក្នុងថ្នាក់ ពង្រីកការយល់ដឹងពីដំណឹងល្អ របស់ពួកគេ និង ទទួលបានវិវរណៈផ្ទាល់ខ្លួន ។

នៅពេលដែលសិស្សឆ្លើយសំណួរទាំងនេះ សូមប្រាកដថា ពួកគេយល់ថា **ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ជួយពង្រឹងទីបន្ទាល់របស់យើង អញ្ជើញព្រះវិញ្ញាណបរិសុទ្ធមកក្នុងជីវិតរបស់យើង និង ជួយយើងឲ្យរៀនដំណឹងល្អ ។**

សូមអញ្ជើញសិស្សឲ្យឆ្លើយនឹងសំណួរមួយក្នុងចំណោមសំណួរខាងក្រោម នៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ៖

- តើអ្នកអាចពង្រីកការសិក្សាព្រះគម្ពីរមរមនរបស់អ្នកឆ្នាំនេះបានដោយរបៀបណា ?
- តើការអានព្រះគម្ពីរមរមន បានជះឥទ្ធិពលដល់អារម្មណ៍របស់អ្នកអំពីព្រះយេស៊ូវគ្រីស្ទ តាមរបៀបណាខ្លះ ?

សូមអញ្ជើញសិស្សឲ្យដាក់គោលដៅមួយ ដើម្បីសិក្សាព្រះគម្ពីរមរមនប្រចាំថ្ងៃក្នុងឆ្នាំនេះ ។ សូមអញ្ជើញពួកគេឲ្យដាក់គោលដៅដើម្បីអានព្រះគម្ពីរមរមនឲ្យចប់ អំឡុងពេលសិក្ខាសាលាឆ្នាំនេះផងដែរ ។ អ្នកអាចផ្តល់ជាយោបល់ឲ្យពួកគេសរសេរទុកនូវគោលដៅទាំងនេះ នៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមរំឭកពួកគេថា គោលដៅទាំងនេះ អាចជួយពួកគេជាមួយនឹងតម្រូវការក្នុងកាតព្វកិច្ចចំពោះព្រះ និង ការអភិវឌ្ឍខ្លួន ។

ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ

អែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖ « ការអានព្រះគម្ពីរ ធ្វើឲ្យយើងចុះសម្រុងនឹងព្រះវិញ្ញាណនៃព្រះ ។ . . . ពីព្រោះយើងជឿថា ការអានព្រះគម្ពីរ អាចជួយយើងឲ្យទទួលបានវិវរណៈ យើងត្រូវបានលើកទឹកចិត្តឲ្យអានព្រះគម្ពីរម្តងហើយម្តងទៀត ។ តាមរបៀបនេះ យើងទទួលបានអ្វីដែលព្រះវរបិតាសួគ៌របស់យើងចង់ឲ្យយើងដឹង និងប្រតិបត្តិនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់យើងសព្វថ្ងៃ ។ នោះគឺជាហេតុផលមួយ ដែលពួកបរិសុទ្ធថ្ងៃចុងក្រោយជឿលើ *ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ* » (« ការអានព្រះគម្ពីរ និងវិវរណៈ » *Ensign* ខែ មករា ឆ្នាំ ១៩៩៥ ទំព័រ ៨) ។

ការរៀនសូត្រដោយព្រះវិញ្ញាណ

សូមចម្លងឌីយ៉ាក្រាមខាងក្រោមដាក់លើក្តារខៀន ។ សូមលុបពាក្យចេញពីឌីយ៉ាក្រាម ។ អ្នកនឹងសរសេរវា ពេលមេរៀនបោះជំហានទៅមុខ ។



សូមអញ្ជើញសិស្សម្នាក់ឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៥០:១៧–១៨ ឲ្យឮៗ ។

- យោងតាមខទាំងនេះ តើអ្វីខ្លះដែលព្រះអម្ចាស់ តម្រូវឲ្យគ្រូបង្រៀនដំណឹងល្អត្រូវមាន ? (ដើម្បីបង្រៀនសេចក្តីពិត ដោយព្រះចេស្តានៃព្រះវិញ្ញាណ) ។

សូមសរសេរ *ព្រះវិញ្ញាណបរិសុទ្ធ* និង *គ្រូបង្រៀន* នៅលើឌីយ៉ាក្រាម ដូចដែលបានបង្ហាញនៅខាងលើ ។ សូមចែកចាយគំនិតរបស់អ្នកអំពីការស្វែងរកការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលដែលអ្នកបង្រៀន ។ សូមជួយសិស្សឲ្យដឹងថា នៅក្នុងការរៀបចំ និងការបង្រៀនរបស់អ្នក អ្នកបានខិតខំដោយអស់ពីចិត្តដើម្បីត្រូវបានដឹកនាំដោយព្រះវិញ្ញាណ ។

សុំឲ្យសិស្សដាក់ប្រដាប់សៀតសៀវភៅចំណាំនៅត្រង់ គោលលទ្ធិ និង សេចក្តីសញ្ញា ៥០ (ដោយសារពួកគេនឹងត្រឡប់ទៅវគ្គនេះវិញនាពេលបន្តិចទៀត) ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី២ ៣៣:១ ឲ្យឮៗ ។

- តើព្រះវិញ្ញាណបរិសុទ្ធធ្វើអ្វីចំពោះអ្នករៀន នៅពេលដែលដំណឹងល្អត្រូវបានបង្រៀនទៅ ?

សូមពន្យល់ថា ដើម្បីរៀនដំណឹងល្អតាមរបៀបរបស់ព្រះអម្ចាស់ យើងត្រូវតែទទួលយកទំនួលខុសត្រូវដើម្បីរៀន ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។ សូមអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៥០:១៩–២១ ដោយស្ងាត់ៗ ។

- តើយើងគួរសរសេរអ្វី នៅជ្រុងក្រោមខាងស្តាំនៃត្រីកោណនេះ ? (សរសេរពាក្យ *សិស្ស ។*)
- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីទទួលបានសេចក្តីពិត ដោយព្រះវិញ្ញាណ ?

អ្នកអាចចង់បង្រៀនគោលការណ៍ខ្លះៗ អំពីការស្តាប់តិទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។ សូមជួយសិស្សឲ្យយល់ថា ជាធម្មតា ព្រះវិញ្ញាណទាក់ទងជាមួយនឹងយើងយ៉ាងស្ងៀមស្ងាត់ តាមរយៈអារម្មណ៍របស់យើង និង នៅក្នុងគំនិតរបស់យើង (សូមមើល នីហ្វៃទី១ ១៧:៤៥; គ. និង ស. ៨:២–៣) ។ ព្រះវិញ្ញាណបរិសុទ្ធ ក៏នាំអារម្មណ៍នៃសេចក្តីស្រឡាញ់ ភាពរីករាយ សេចក្តីសុខសាន្ត ភាពអត់ធ្មត់ ការបន្ទាបខ្លួន សុភាពរាបសា សេចក្តីជំនឿ និង សេចក្តីសង្ឃឹមមកដល់យើងដែរ (សូមមើល កាឡាទី ៥:២២–២៣; គ. និង ស. ១១:១២) ។

- តើអ្នកអាចធ្វើអ្វីបាននៅក្នុងថ្នាក់សិក្ខាសាលា ដើម្បីរៀបចំខ្លួនអ្នករៀនដោយព្រះវិញ្ញាណ ?

នៅផ្នែកនៃការពិភាក្សានេះ សូមជួយសិស្សឲ្យយល់ថា របៀបសំខាន់មួយដើម្បីរៀនដោយព្រះវិញ្ញាណ គឺត្រូវមានឆន្ទៈដើម្បីចែកចាយទីបន្ទាល់យើងជាមួយគ្នាទៅវិញទៅមក ។ សូមអានប្រសាសន៍ខាងក្រោមដោយ អែលឌើរ រីឆាដ ជី ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« នៅពេលសិស្សនិយាយពីសេចក្តីពិត | សេចក្តីពិតទាំងនេះ | ត្រូវបានបញ្ជាក់នៅក្នុងដួងចិត្តរបស់ពួកគេ ហើយពង្រឹងទីបន្ទាល់ផ្ទាល់ខ្លួនរបស់ពួកគេ » (« ដើម្បីយល់ និង រស់នៅតាមសេចក្តីពិត » | សុន្ទរកថាទៅកាន់អ្នកអប់រំខាងសាសនា ផ្នែក CES ថ្ងៃទី ៤ ខែ កុម្ភៈ ឆ្នាំ ២០០៥ | ទំព័រ ៣, si.lds.org) ។

សូមរំឭកសិស្សថា កម្មវិធីកាតព្វកិច្ចចំពោះព្រះ និង ការអភិវឌ្ឍខ្លួន រួមមានការស្នើសុំដើម្បីធ្វើការចែកចាយសេចក្តីពិតនៃដំណឹងល្អជាមួយនឹងអ្នកដទៃទៀត ។ សូមលើកទឹកចិត្តពួកគេ ឲ្យចែកចាយបទពិសោធន៍របស់ពួកគេនៅក្នុងថ្នាក់សិក្ខាសាលា នៅក្នុងក្រុម ឬ ការប្រជុំក្នុងថ្នាក់នានា និងនៅក្នុងការសន្ទនាជាមួយនឹងសមាជិកគ្រួសារ និង មិត្តភក្តិរបស់ពួកគេ ។ សូមបញ្ជាក់យ៉ាងហ្មត់ចត់ថា នៅពេលពួកគេខិតខំប្រឹងប្រែងដើម្បីពន្យល់ ចែកចាយ និងថ្លែងទីបន្ទាល់ពីសេចក្តីពិតនៃដំណឹងល្អ នោះព្រះនឹងបង្កើនសមត្ថភាពរបស់ពួកគេដើម្បីពិភាក្សាដំណឹងល្អជាមួយនឹងអ្នកដទៃទៀត ។

សូមត្រឡប់ទៅឌីយ៉ាក្រាមនៅលើក្តារខៀនម្តងទៀត ។ សុំឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្តីសញ្ញា ៥០:១៤, ២២ ឲ្យឮ ៗ ។

- តើខទាំងនេះ សង្ខេបពីតួនាទីនៃព្រះវិញ្ញាណបរិសុទ្ធ គ្រូបង្រៀន និង ការសិក្សាដំណឹងល្អរបស់សិស្ស ដោយរបៀបណា ? (អ្នកអាចពន្យល់ថា ព្រះវិញ្ញាណបរិសុទ្ធ ដែលត្រូវបានហៅថាជា ព្រះវិញ្ញាណ និង ព្រះដ៏ជាជំនួយផងដែរ នៅក្នុងវគ្គនេះ នឹងបង្រៀនពីសេចក្តីពិត ។ គ្រូបង្រៀន គឺត្រូវបង្រៀនដោយព្រះចេស្តានៃព្រះវិញ្ញាណ ហើយសិស្សត្រូវរៀនដោយព្រះចេស្តាដូចគ្នា ។)
- តើនឹងមានអ្វីកើតឡើង នៅពេលដែលសិស្សម្នាក់រៀន ដោយព្រះវិញ្ញាណ ហើយគ្រូបង្រៀនដោយព្រះវិញ្ញាណ ? (អ្នកអាចត្រូវការពន្យល់ថា *ស្អាងឡើង* មានន័យថា កសាងឡើង ពង្រឹង បំភ្លឺ ឬ ពង្រីក ។)

នៅក្នុងព្រះគម្ពីរមរមន អេណុស និង អាលម៉ា គឺជាគំរូនៃមនុស្សដែលបានរៀនដោយព្រះវិញ្ញាណ ។ សុំឲ្យសិស្សអាន អេណុស ១:៤–១០ និង អាលម៉ា ៥:៤៥–៤៧ ដោយស្ងាត់ៗ ។ (អ្នកអាចសរសេរ ខយោងទាំងនេះនៅលើក្តារខៀន) ។ បន្ទាប់មកសួរថា ៖

- តើអេណុស (ឬ អាលម៉ា) បានធ្វើអ្វីខ្លះដើម្បីរៀនដោយព្រះវិញ្ញាណ ?
- តើព្រះវិញ្ញាណបានធ្វើអ្វី សម្រាប់អេណុស (ឬ អាលម៉ា) ?

សូមអញ្ជើញសិស្សម្នាក់ ឲ្យអានប្រសាសន៍ខាងក្រោមដោយ អែលឌើរ បែដណា ៖

« យើងគួរតែចងចាំជានិច្ចថា ព្រះវិញ្ញាណបរិសុទ្ធ គឺជាគ្រូបង្រៀនដែល តាមរយៈការអញ្ជើញដោយត្រឹមត្រូវ អាចចូលមកក្នុងដួងចិត្តរបស់អ្នករៀនបាន » (« ស្វែងរកការរៀនសូត្រដោយសារសេចក្តីជំនឿ » ៨) ។

- តើអ្វីដែលយើងបានរៀនរួចហើយ ដែលពាក់ព័ន្ធចំពោះការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់អ្នក ក្នុងនាមជាសមាជិកម្នាក់នៅក្នុងថ្នាក់នេះ ដោយរបៀបណា ? (នៅពេលដែលសិស្សឆ្លើយសំណួរ សូមប្រាកដថា ពួកគេយល់ថា **នៅពេលដែលយើងបើកដួងចិត្តរបស់យើង ហើយស្វះដល់ព្រះដោយសេចក្តីជំនឿ នោះព្រះវិញ្ញាណបរិសុទ្ធនឹងជួយយើងឲ្យយល់ពីសេចក្តីពិតនៃដំណឹងល្អ ។**)

ដើម្បីជួយសិស្សពិចារណាពីរបៀប ដែលពួកគេអាចជួយគ្នាទៅវិញទៅមក ឲ្យរៀនដោយព្រះវិញ្ញាណ សូមសួរថា ៖

- តើសកម្មភាពណាខ្លះ ដែលយើងអាចធ្វើ ដើម្បីនឹងជួយអញ្ជើញព្រះវិញ្ញាណមកគង់នៅក្នុងថ្នាក់រៀនរបស់យើង ? (ចម្លើយអាចរួមមាន ការច្រៀងចម្រៀងបើក ការយកព្រះគម្ពីរមកថ្នាក់ ហើយប្រើព្រះគម្ពីរប្រចាំថ្ងៃ ការមានឆន្ទៈឆ្លើយសំណួរ និង ចែកចាយបទពិសោធន៍ ការអធិស្ឋានសម្រាប់គ្នាទៅវិញទៅមក និង ការសុំការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ) ។

ដើម្បីជួយសិស្សយល់ថា សកម្មភាពអវិជ្ជមានខ្លះ ក៏អាចមានឥទ្ធិពលលើថ្នាក់ទាំងមូលផងដែរ សូមសួរថា ៖

- តើឥរិយាបថ ឬ អាកប្បកិរិយាបែបណាខ្លះ ដែលរារាំងព្រះវិញ្ញាណមិនឲ្យមកគង់នៅក្នុងថ្នាក់សិក្ខាសាលា ?

សូមអញ្ជើញសិស្សឲ្យពិចារណា ពីតម្លៃនៃការមានព្រះវិញ្ញាណបរិសុទ្ធក្នុងនាមជាគ្រូបង្រៀនរបស់ពួកគេ ។

- តើមានពេលវេលាណាខ្លះដែលអ្នកមានបទពិសោធន៍ ថាព្រះវិញ្ញាណដើរតួនាទីរបស់ទ្រង់ជាគ្រូបង្រៀនមួយអង្គ ?

សូមបញ្ចប់ដោយការអញ្ជើញសិស្សឲ្យរៀនដោយសារការសិក្សា និង សេចក្តីជំនឿ នៅពេលពួកគេសិក្សាព្រះគម្ពីរមរមននៅក្នុងថ្នាក់សិក្ខាសាលាក្នុងឆ្នាំនេះ ។ អ្នកអាចធ្វើការតាមដានជាមួយនឹងសិស្ស ពេញមួយឆ្នាំ ដើម្បីលើកទឹកចិត្តពួកគេឲ្យបន្តនៅក្នុងកិច្ចការនេះ ។

វិចារណកថា និង ព័ត៌មានពីសាច់រឿង

នីហ្វៃទី ២ ៣៣:១ ។ សូមបើកដួងចិត្តរបស់យើងចំពោះព្រះវិញ្ញាណបរិសុទ្ធ

នៅផ្នែកមួយនៃការពិភាក្សារបស់អ្នកលើ នីហ្វៃទី ២ ៣៣:១ សូមគិតពីការអាននូវប្រសាសន៍ខាងក្រោមដោយ អែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« នីហ្វៃបង្រៀនយើង ‹ ត្បិតកាលណាមនុស្សមួយនិយាយ ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នឹងនាំ [សារលិខិត] ចូលទៅក្នុងចិត្តនៃកូនចៅមនុស្ស › (នីហ្វៃទី ២ ៣៣:១) ។ សូមចំណាំពីរបៀបដែលព្រះចេស្តានៃព្រះវិញ្ញាណ នាំសារលិខិតនេះ *ទៅ* ប៉ុន្តែមិនចាំបាច់*ទៅក្នុង*ដួងចិត្តនោះទេ ។ គ្រូបង្រៀនម្នាក់អាចពន្យល់ បង្ហាញ បញ្ចុះបញ្ចូល និង ថ្លែងទីបន្ទាល់ និង ធ្វើដូច្នោះដោយមានព្រះចេស្តានៃព្រះវិញ្ញាណដ៏អស្ចារ្យ និង ដោយមានប្រសិទ្ធភាព ។ ទីបំផុត ទោះយ៉ាងណាក្តី អត្ថន័យនៃសារលិខិតមួយ និង សាក្សីនៃព្រះវិញ្ញាណបរិសុទ្ធ បានទម្លុះចូលទៅក្នុងដួងចិត្ត បើសិនជាអ្នកទទួលអនុញ្ញាតឲ្យវាចូលទៅបាន ។ . . .

« អ្នករៀនម្នាក់ ដែលអនុវត្តសិទ្ធិជ្រើសរើសដោយសកម្មភាព ស្របតាមគោលការណ៍ត្រឹមត្រូវ គឺបើកដួងចិត្តរបស់ខ្លួនឲ្យព្រះវិញ្ញាណបរិសុទ្ធ ហើយអញ្ជើញការបង្រៀន ព្រះចេស្តានៃការថ្លែងទីបន្ទាល់ និង សាក្សីបញ្ជាក់របស់ទ្រង់ » (« ស្វែងរកការរៀនសូត្រដោយសេចក្តីជំនឿ » [ការថ្លែងទៅកាន់អ្នកអប់រំខាងសាសនា ផ្នែក CES ថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០០៦], ១, ៣, si.lds.org) ។

មេរៀនទី ២

ការសិក្សាព្រះគម្ពីរ

សេចក្តីផ្តើម

មេរៀននេះ នឹងជួយសិស្សឲ្យបើកការយល់ដឹងរបស់ពួកគេអំពីបំណងទាំងឡាយនៃព្រះគម្ពីរ ។ វាក៏នឹងជួយពួកគេឲ្យសិក្សាព្រះគម្ពីរតាមរបៀបដ៏មានន័យជាងមុនផងដែរ ។ វារួមមានសកម្មភាពនៃការរៀនអំពីការយល់ដឹងលើសាវតា និង សាច់រឿងនៃព្រះគម្ពីរ ការស្គាល់ និង ការយល់ពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយ និង ការអនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងនោះទៅក្នុងជីវិតរបស់យើង ។ នៅពេលសិស្សរីកចម្រើននូវសមត្ថភាពរបស់ពួកគេក្នុងការសិក្សាព្រះគម្ពីរ នោះសេចក្តីស្រឡាញ់ចំពោះព្រះគម្ពីរនឹងកើនឡើង រួមទាំងការយល់ដឹងអំពីដំណឹងល្អរបស់ពួកគេនឹងកើនឡើងដែរ ។ សូមគិតពីរបៀបដើម្បីរំឭកពីកិច្ចការសិក្សានៅក្នុងមេរៀននេះ ពេញមួយឆ្នាំ ។

យោបល់សម្រាប់ការបង្រៀន

តើយើងគួរតែចាប់យកការសិក្សាព្រះគម្ពីរនៅក្នុងថ្នាក់សិក្ខាសាលា ដោយរបៀបណា ?

ពីមុនថ្នាក់រៀនចាប់ផ្តើម សូមសរសេរប្រសាសន៍ដូចខាងក្រោមដោយប្រធាន ថូម៉ាស អេស ម៉នសុន នៅលើក្តារខៀន ។ (ប្រសាសន៍ខាងលើនេះ មាននៅទំព័រ ១០៧ នៃរបាយការណ៍សន្និសីទខែ តុលា ឆ្នាំ ១៩៧០) ។

« គោលដៅនៃការបង្រៀនដំណឹងល្អ . . . គឺមិនមែនដើម្បី ‹ ចាក់ដំណឹង › ទៅក្នុងគំនិតរបស់សមាជិកថ្នាក់រៀននោះទេ ។ . . . គោលបំណង គឺដើម្បីបំផុសបុគ្គលម្នាក់ៗ ឲ្យគិតអំពី មានអារម្មណ៍អំពី ហើយបន្ទាប់មកធ្វើអ្វីមួយអំពីការរស់នៅតាមគោលការណ៍នៃដំណឹងល្អ » (ប្រធាន ថូម៉ាស អេស ម៉នសុន) ។

សុំឲ្យសិស្សម្នាក់អានប្រសាសន៍នេះឲ្យឮៗ ។

- ផ្អែកលើប្រសាសន៍នេះ តើអ្វីគួរតែជាគោលដៅរបស់ខ្ញុំ ក្នុងនាមជាគ្រូបង្រៀនថ្នាក់សិក្ខាសាលារបស់អ្នក ? តើអ្វីគួរតែជាគោលដៅរបស់អ្នក ក្នុងនាមជាសិស្សថ្នាក់សិក្ខាសាលា ?

សូមប្រាប់សិស្សថា នៅក្នុងមេរៀននេះ ពួកគេនឹងស្វែងរកនូវរបៀបដើម្បី « គិតអំពី មានអារម្មណ៍អំពី ហើយបន្ទាប់មកបញ្ចេញសកម្មភាពអំពីការរស់នៅតាមគោលការណ៍ » ដែលបានបង្រៀននៅក្នុងព្រះគម្ពីរ ។

ការយល់ពីប្រវត្តិ និង សាច់រឿងនៃព្រះគម្ពីរ

សូមពន្យល់ថា រឿងមួយដែលសិស្សអាចធ្វើឲ្យរីកចម្រើនការសិក្សាព្រះគម្ពីររបស់ពួកគេ គឺត្រូវរៀនអំពី ប្រវត្តិ និង សាច់រឿងនៃដំណើររឿង និង វិវរណៈនៅក្នុងព្រះគម្ពីរ ។ ប្រវត្តិ និង សាច់រឿង ជាញឹកញាប់ត្រូវបានហៅថា បរិបទ ។

សូមអញ្ជើញសិស្សម្នាក់អានការប្រឹក្សាខាងក្រោមពីប្រធាន ថូម៉ាស អេស ម៉នសុន ៖

« សូមផ្តើមស្គាល់មេរៀនទាំងឡាយ ដែលព្រះគម្ពីរបង្រៀន ។ រៀនពីប្រវត្តិ និង សាច់រឿងនៃរឿងប្រៀបប្រដូចរបស់លោកចៅហ្វាយ និង ការដាស់តឿនរបស់ព្យាការីទាំងឡាយ ។ សិក្សាពីវា ហាក់ដូចជា វាកំពុងនិយាយទៅកាន់អ្នក ដោយសារវាគឺជាសេចក្តីពិត » (« ធ្វើជាខ្លួនអ្នកដ៏ល្អបំផុត » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៦៨) ។

សូមបង្ហាញថា ការយល់ពីប្រវត្តិ និង សាច់រឿងមួយ អាចជួយយើងឲ្យយល់ពីការបង្រៀនទាំងឡាយនៅក្នុងព្រះគម្ពីរ ។ វាផ្តល់ជាដំណឹងដែលបញ្ជាក់ និង នាំមកនូវជម្រៅនៃការយល់ដឹងពីដំណើររឿងយ៉ាងគ្រាលជ្រៅ ចំពោះគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៅក្នុងអត្ថបទព្រះគម្ពីរ ។

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖

តើនរណាជាអ្នកនិយាយនៅក្នុងខទាំងនេះ ?

តើគាត់កំពុងនិយាយទៅកាន់នរណា ?

តើមានអ្វីកើតឡើងនៅក្នុងដំណើររឿងនេះ ?

សូមពន្យល់ថា សំណួរទាំងនេះ អាចជួយយើងឲ្យយល់ពីបរិបទនៃការបង្រៀនមួយ ឬ ដំណើររឿងមួយនៅក្នុងព្រះគម្ពីរ ។

សុំឲ្យសិស្សចែកចាយពីអ្វីដែលពួកគេបានធ្វើ ដើម្បីទទួលបាននូវការយល់ដឹងល្អប្រសើរពីប្រវត្តិ និង សាច់រឿងនៃវគ្គទាំងឡាយក្នុងព្រះគម្ពីរ ។ អ្នកអាចចង់សរសេរគំនិតទាំងនេះខ្លះៗ នៅលើក្តារខៀន ។

សិស្សអាចលើកឡើងពីការអនុវត្តនានាដូចជា ការរកមើលន័យនៃពាក្យពិបាក ឬ ពាក្យមិនដែលឃើញ ការពិនិត្យមើលអត្ថបទជុំវិញនោះ ការអានសេចក្តីសង្ខេបនៃជំពូកនៅក្បាលជំពូក ឬ ការស្វែងរកលេខយោងសម្រាប់ការពន្យល់ និង ឯកសារយោងឆ្លងគ្នា ។ សូមប្រាកដថា បានលើកឡើងពីជំនាញទាំងនេះ ប្រសិនបើសិស្សមិនបានលើកឡើងទេ ។

ដើម្បីយករបៀបនៃការយល់ពីបរិបទនៃព្រះគម្ពីរមួយធ្វើជាគំរូ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ៣ ១៧:១–១០ ឲ្យឮៗ ។ សុំឲ្យថ្នាក់អានតាម រកមើលចម្លើយទៅនឹងសំណួរដែលអ្នកបានសរសេរនៅលើក្តារខៀន ។ អ្នកក៏អាចលើកទឹកចិត្តពួកគេឲ្យមើលនៅសេចក្តីសង្ខេបក្នុងក្បាលជំពូកបន្តិចៗផងដែរ ។

- តើនរណាដែលនិទានដំណើររឿងនេះ នៅក្នុង ខ ១, ៥–៦, និង ៩–១០ ? (មរមន) ។
- នៅក្នុងដំណើររឿងនេះ តើនរណាកំពុងតែនិយាយ ? តើនរណាកំពុងតែទទួលសារលិខិតនេះ ?
- តើមានរឿងអ្វីបានកើតឡើង ពីមុនព្រឹត្តិការណ៍នៅក្នុងដំណើររឿងនេះ ? (សូមមើលសេចក្តីសង្ខេបនៃជំពូកនៅ នីហ្វៃទី ៣ ៨–១៦ ។) តើចំណេះដឹងរបស់អ្នកពីប្រវត្តិនេះ មានឥទ្ធិពលយ៉ាងដូចម្តេចលើការយល់ដឹងរបស់អ្នកពីមូលហេតុដែលមនុស្សចង់បានព្រះអង្គសង្គ្រោះឲ្យគង់នៅយូរបន្តិចទៀតនោះ ? (សូមមើល នីហ្វៃទី៣ ១៧:៥–៦ ។) តើអព្ភូតហេតុអ្វីខ្លះដែលបានកើតឡើងក្រោយទ្រង់បានមានព្រះបន្ទូលថា ទ្រង់នឹងនៅ ? (សូមមើល នីហ្វៃទី៣ ១៧:៧–១០ ។)

ការស្គាល់ និង ការយល់ដឹងពីគោលលទ្ធិ ហើយនិងគោលការណ៍ទាំងឡាយ

សូមសង្កត់ធ្ងន់ថា នៅពេលសិស្សយល់ពីប្រវត្តិ និង សាច់រឿងនៃដំណើររឿងក្នុងព្រះគម្ពីរហើយ ពួកគេនឹងរៀបចំដើម្បីស្គាល់ និង យល់ពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយ ដែលមាននៅក្នុង ព្រះគម្ពីរបានប្រសើរជាង ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានការពិពណ៌នាពីគោលការណ៍នៃដំណឹងល្អដូចខាងក្រោម ដែលចែកចាយដោយ អែលឌើរ រីឆាដ ជី ស្កត នៃក្រុមនៃពួកសាវកដប់ពីរនាក់ថា ៖

« គោលការណ៍ទាំងអស់ បានប្រមូលផ្តុំសេចក្តីពិត ខ្ចប់ទុកសម្រាប់ការអនុវត្តន៍ចំពោះកាលៈទេសៈផ្សេងៗគ្នាដ៏ទូលំទូលាយមួយ » (« ការទទួលបានចំណេះដឹងខាងវិញ្ញាណ » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ទំព័រ ៨៦) ។

សូមពន្យល់ថា គោលលទ្ធិ និង គោលការណ៍ទាំងឡាយ គឺអស់កល្ប ជាសេចក្តីពិតដ៏ឥតប្រែប្រួលនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដែលផ្តល់នូវការដឹកនាំសម្រាប់ជីវិតរបស់យើង ។ វាគឺជាមេរៀន ដែលព្យាការីពីបុរាណ មានបំណងចង់ឲ្យយើងរៀនពីព្រឹត្តិការណ៍ រឿង និង ការបង្រៀននានា ដែលពួកគាត់បានសរសេរទុកនៅក្នុងព្រះគម្ពីរ ។ បង្ហាញថា អ្នកសរសេរខ្លះ នៅក្នុងព្រះគម្ពីរ បានប្រើឃ្លាដូចជា « ឡោះហើយ យើងអាចឃើញថា » (សូមមើល ហេលេមិន ៣:២៧–២៩) ឬ ពាក្យដូចជា *ហេតុដូច្នេះហើយ* (សូមមើល អាលម៉ា ៣២:១៦) ដើម្បីចង្អុលឲ្យចំៗ លើគោលលទ្ធិ និង គោលការណ៍ទាំងឡាយ ។ ទោះយ៉ាងណាក្តី គោលលទ្ធិ និង គោលការណ៍ទាំងឡាយជាច្រើន មិនត្រូវបាននិយាយដោយចំៗនោះទេ នៅក្នុងព្រះគម្ពីរនោះ ។ ផ្ទុយទៅវិញ សេចក្តីពិតទាំងនេះ ត្រូវបានបរិយាយ ហើយត្រូវបានបង្ហាញតាមរយៈជីវិតរបស់អ្នកទាំងនោះដែលនៅក្នុងព្រះគម្ពីរនេះ ។

ដើម្បីជួយសិស្សឲ្យរៀនស្គាល់គោលលទ្ធិ និង គោលការណ៍ទាំងឡាយ ដែលមិនបាននិយាយចេញដោយចំៗ សូមផ្តល់យោបល់ដល់ពួកគេថា នៅពេលពួកគេអាន ពួកគេគួរសួរខ្លួនឯងនូវសំណួរដូចខាងក្រោម ៖ តើអ្វីជាសារលិខិតនៅក្នុងរឿងនេះ ? តើអ្នកសរសេរមានបំណងឲ្យយើងរៀនអ្វីពីរឿងនេះ ? តើសេចក្តីពិតអ្វី ដែលត្រូវបានបង្រៀននៅក្នុងវគ្គនៃបទគម្ពីរនេះ ? អ្នកអាចកត់ត្រាចម្លើយទាំងនេះនៅលើក្តារខៀន ។

ដើម្បីជួយសិស្សអនុវត្តការស្គាល់នូវគោលលទ្ធិ និង គោលការណ៍ទាំងឡាយ សូមឲ្យពួកគេត្រឡប់ទៅ នីហ្វៃទី ៣ ១៧:១–១០ ។ សួរ ៖

- ឆ្លងតាមការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុង នីហ្វៃទី ៣ ១៧:២–៣ តើយើងអាចរៀនអ្វីពីការយល់ដឹងនូវព្រះបន្ទូលរបស់ទ្រង់ ?
- តើសេចក្តីពិតអ្វីដែលយើងអាចរៀនពីព្រះអង្គសង្គ្រោះ ពីក្នុង នីហ្វៃទី ៣ ១៧:៥–៧ ?
- ក្នុងការតបតនឹងសេចក្តីជំនឿដ៏អស្ចារ្យរបស់ប្រជាជន ព្រះអង្គសង្គ្រោះបានព្យាបាលពួកគេ ។ នៅក្នុង នីហ្វៃទី ៣ ១៧:៨–៩ តើគោលការណ៍ណាខ្លះដែលអ្នកឃើញអំពីការស្វែងរកពរជ័យពីព្រះអម្ចាស់ ? (គោលការណ៍មួយដែលសិស្សអាចរកឃើញ គឺថា ព្រះអម្ចាស់ ទ្រង់ឆ្លើយតបនូវបំណងប្រាថ្នាដ៏ស្មោះស្ម័គ្ររបស់យើងក្នុងការខិតខំទៅជិតទ្រង់) ។

ប្រសិនបើមានពេលឲ្យសិស្សអនុវត្តច្រើន ក្នុងការរកនូវគោលលទ្ធិ និង គោលការណ៍ទាំងឡាយ សូមអញ្ជើញពួកគេឲ្យរករឿងក្នុងព្រះគម្ពីរដែលពួកគេចូលចិត្ត ។ សុំឲ្យពួកគេរកគោលការណ៍ ដែលពួកគេបានរៀនពីរឿងទាំងនេះ ។ បន្ទាប់មកសូមអញ្ជើញពួកគេឲ្យចែកចាយរឿង និង គោលការណ៍ទាំងឡាយរបស់ពួកគេ ដែលពួកគេបានរៀនហើយ ។

ការអនុវត្តនូវគោលលទ្ធិ និង គោលការណ៍ទាំងឡាយ

ប្រធាន ប៊ិចដ៍ ឃេ ផាកកឺ នៃក្រុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា ៖

« គោលលទ្ធិពិត បើត្រូវបានយល់ច្បាស់ វានឹងកែប្រែឥរិយាបថ និង អាកប្បកិរិយា ។ ការសិក្សាពីគោលលទ្ធិនៃដំណឹងល្អ នឹងកែសម្រួលអាក្បកិរិយាបានលឿនជាងការសិក្សាពីអាក្បកិរិយា ដើម្បីអភិវឌ្ឍអាក្បកិរិយាទៅទៀត ។ . . . នោះគឺជាហេតុផលដែលយើងសង្កត់ធ្ងន់យ៉ាងធ្ងន់លើការសិក្សាពីគោលលទ្ធិនៃដំណឹងល្អ » (« ក្មេងតូចៗ » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ១៧) ។

សូមពន្យល់ថា នៅពេលដែលយើងយល់ពីគោលលទ្ធិ ឬ គោលការណ៍មួយ យើងដឹងច្រើនជាងអត្ថន័យនៃពាក្យជាច្រើន ។ យើងដឹងថាតើគោលលទ្ធិ ឬ គោលការណ៍ មានន័យយ៉ាងណានៅក្នុងជីវិតរបស់យើង ។ នៅពេលយើងស្គាល់គោលលទ្ធិ ឬ គោលការណ៍មួយ ហើយយល់ពីវា យើងអាចអនុវត្តវានៅក្នុងជីវិតរបស់យើង ។ សូមពន្យល់ថា ការអនុវត្តន៍អាចកើតឡើង នៅពេលយើងធ្វើអ្វីមួយពីគោលការណ៍ ដែលយើងបានរៀនហើយ ។ សិស្សដែលធ្វើតាមគោលការណ៍ ដែលពួកគេរៀនហើយ នឹងមានឱកាសដ៏កាន់តែអស្ចារ្យដើម្បីទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ដែលបញ្ជាក់ពីសេចក្តីពិតនៃគោលការណ៍ទាំងនោះ (សូមមើល នីហ្វៃទី ២ ៣២:៥; ម៉ូរ៉ូណៃ ១០:៥) ។ នេះគឺជាតម្លៃដ៏ពិត នៃចំណេះដឹងដែលទទួលបានពីការសិក្សាព្រះគម្ពីរ ។ សូមជួយសិស្សឲ្យមើលឃើញថា នៅពេលណាដែលពួកគេសិក្សាព្រះគម្ពីរ —មិនថាពួកគេនៅផ្ទះ នៅព្រះវិហារ នៅក្នុងថ្នាក់សិក្ខាសាលា ដោយធ្វើការជាមួយនឹងការកែសម្រួលថ្នាល់

ខ្លួន ឬ កាតព្វកិច្ចចំពោះព្រះ ឬ នៅក្នុងកន្លែងផ្សេងៗទៀតនោះទេ —គោលដៅសំខាន់មួយរបស់គេ គួរតែដើម្បីធ្វើឲ្យនៅក្នុងការខិតខំរបស់ពួកគេដើម្បីរស់នៅតាមដំណឹងល្អ ហើយខិតជិតទៅរកព្រះ ។

ដើម្បីជួយសិស្សឲ្យយល់ និង អនុវត្តន៍នូវគោលការណ៍ទាំងឡាយដែលពួកគេរកឃើញនៅក្នុងព្រះគម្ពីរ សូមលើកទឹកចិត្តពួកគេឲ្យអធិស្ឋានសុំជំនួយពីព្រះវិញ្ញាណបរិសុទ្ធ នៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។ សូមអញ្ជើញពួកគេឲ្យសួរសំណួរដូចខាងក្រោមជាដើម នៅពេលពួកគេសិក្សា ៖ តើព្រះអម្ចាស់ចង់ឲ្យខ្ញុំធ្វើអ្វីជាមួយនឹងចំណេះដឹងនេះ ? តើការណ៍នេះអាចធ្វើឲ្យមានភាពខុសគ្នាអ្វីខ្លះ នៅក្នុងជីវិតរបស់ខ្ញុំ ? តើខ្ញុំអាចចាប់ផ្តើម ឬ បញ្ឈប់ធ្វើអ្វីខ្លះឥឡូវ ដើម្បីឲ្យជីវិតរបស់ខ្ញុំបានប្រសើរជាងមុនបន្តិច ? តើជីវិតរបស់ខ្ញុំនឹងប្រសើរជាងមុនដោយរបៀបណា បើខ្ញុំធ្វើតាមរបៀបនេះ ? (អ្នកអាចសរសេរសំណួរទាំងនេះខ្លះ ឬ ទាំងអស់នៅលើក្តារខៀន ។ អ្នកក៏អាចផ្តល់យោបល់ឲ្យសិស្សសរសេរសំណួរទាំងនេះ ចូលក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ដើម្បីពួកគេអាចរកឃើញវាញឹកញាប់) ។

ដើម្បីបញ្ចប់ សូមបែងចែកសិស្សចេញជាគូៗ ។ សុំឲ្យពួកគេចែកចាយជាមួយនឹងគ្នាទៅវិញទៅមក នូវគោលការណ៍ដែលពួកគេបានរៀនរួច នៅថ្ងៃនេះពីក្នុង នីហ្វៃទី ៣ ១៧:១–១០ ។ លើកទឹកចិត្តពួកគេឲ្យនិយាយអំពីអ្វីដែលពួកគេបានធ្វើ ដើម្បីអភិវឌ្ឍការយល់ដឹងរបស់ពួកគេអំពីគោលការណ៍ទាំងនេះ និង ពីអ្វីដែលពួកគេនឹងធ្វើដើម្បីអនុវត្តអ្វីដែលពួកគេបានរៀន និង មានដឹង ។ សុំឲ្យពួកគេនិយាយពីរបៀបដែលការអនុវត្តន៍គោលការណ៍ទាំងនេះ អាចធ្វើឲ្យមានភាពខុសគ្នានៅក្នុងជីវិតរបស់ពួកគេ ។

គំនិតបន្ថែមក្នុងការបង្រៀន

ជំនាញ និង វិធីសាស្ត្រក្នុងការសិក្សាព្រះគម្ពីរ

ជំនាញខាងក្រោមនេះ នឹងជួយសិស្សទាំងឡាយនៅក្នុងការសិក្សាព្រះគម្ពីររបស់ពួកគេ ។ ជំនាញទាំងនេះ មានរួមទាំង ជាការរំឭកពេញមួយសៀវភៅសិក្សានេះ ។

និយមន័យពាក្យ ៖ ពាក្យខ្លះ ដែលព្យាការីបានប្រើ គឺមិនសូវស៊ាំនឹងយើងនោះទេ ។ វចនានុក្រមព្រះគម្ពីរបរិសុទ្ធ លេខយោងនៅក្នុងព្រះគម្ពីរ និង វចនានុក្រមធម្មតាៗ អាចជួយយើងឲ្យរៀនពីនិយមន័យនៃពាក្យផ្សេងៗ ហើយស្គាល់ពីពាក្យន័យដូចនឹងពាក្យទាំងនោះ ។ ឧទាហរណ៍ ៖ ពាក្យ *ព្រះមែស៊ី* នៅក្នុង នីហ្វៃទី ១ ១០:៤–១៧ ។

ការជំនួសឈ្មោះ ៖ ដើម្បីជួយខ្លួនអ្នក អនុវត្តនូវព្រះគម្ពីរនៅក្នុងជីវិតរបស់អ្នក សូមជំនួសឈ្មោះរបស់អ្នក ឲ្យឈ្មោះមួយ នៅក្នុងព្រះគម្ពីរ ។ ឧទាហរណ៍ ៖ នីហ្វៃទី ១ ១:១។

សេចក្តីយោងបទគម្ពីរ ៖ ភ្ជាប់វគ្គព្រះគម្ពីរនានាទៅគ្នាទៅវិញទៅមក ដើម្បីបញ្ជាក់ន័យ និង ដោះស្រាយចម្ងល់ ។ ឧទាហរណ៍ ៖ នៅរឹមទំព័រក្បែរ នីហ្វៃទី ៣ ១២:២៨ អ្នកអាចសរសេរកំណត់ចំណាំដើម្បីមើល គោលលទ្ធិ និង សេចក្តីសញ្ញា ៤២:២៣ ។

ហេតុ និង ផល ៖ សូមស្វែងរកនូវទំនាក់ទំនងឃ្លា ប្រសិនបើ-នោះ និង ដោយសារតែ-ហេតុដូច្នោះហើយ ។ ឧទាហរណ៍ ៖ នីហ្វៃទី ២ ១:៩ ។

ពាក្យគន្លឹះ ៖ ពាក្យ និង ឃ្លាទាំងឡាយ ដូចជាពាក្យ *មើលចុះ ហេតុដូច្នោះហើយ ដោយព្រោះ ទោះជាយ៉ាងណាក៏ដោយ* ឬ *ម្ល៉ោះហើយ* គឺជា ការអញ្ជើញដើម្បីបញ្ឈប់ និង ស្វែងរកសារលិខិតដ៏ជាក់លាក់នានា ។ ឧទាហរណ៍ ៖ ហេលេមិន ៦:៣៥–៣៦ ។

បញ្ជីព្រះគម្ពីរ ៖ ជាញឹកញាប់ ព្យាការី បានឲ្យបញ្ជីនៃការព្រមាន និង ឧបសគ្គនានា ។ នៅពេលអ្នករកឃើញបញ្ជី សូមគិតពីការដាក់លេខលើធាតុគន្លឹះនីមួយៗ ។ ឧទាហរណ៍ ៖ អាលម៉ា ២៦:២២ ។

សាច់រឿង ៖ នៅក្នុងដំណើររឿងក្នុងព្រះគម្ពីរ សូមកំណត់ថានរណាកំពុងតែនិយាយ គាត់កំពុងនិយាយទៅនរណា តើគាត់កំពុងនិយាយអំពីអ្វី ហើយតើពេលណា និង កន្លែងណាដែលព្រឹត្តិការណ៍នោះកំពុងតែកើតឡើង ។ ឧទាហរណ៍ ៖ សាច់រឿងនៃ អាលម៉ា ៣២:២១–៤៣ ត្រូវបានរកឃើញក្នុង អាលម៉ា ៣១:១, ៦–១១ និង ៣២:១–៦ ។

ភាពផ្ទុយគ្នា ៖ ការសរសេររបស់ព្យាការី ជារឿយៗបង្ហាញពីភាពផ្ទុយគ្នាក្នុង គំនិត ព្រឹត្តិការណ៍ និង ប្រជាជន ។ ភាពផ្ទុយគ្នាទាំងនេះ បញ្ជាក់យ៉ាងហ្មត់ចត់លើគោលការណ៍នានានៃដំណឹងល្អ ។ សូមស្វែងរកភាពផ្ទុយគ្នានៅក្នុងខ ក្នុងជំពូក មួយៗ និង ឆ្លងជំពូក និង សៀវភៅនានា ។ ឧទាហរណ៍ ៖ នីហ្វៃទី ២ ២:២៧; អាលម៉ា ៤៨:១–១៧ ។

ជំនួយចក្ខុ ៖ សូមស្វែងរកសេចក្តីលម្អិតដែលពិពណ៌នា ដែលអាចជួយអ្នកបង្កើតរូបភាព រូបារម្មណ៍ នៅពេលអ្នកអាន ។ ឧបមាថា អ្នកមានវត្តមាននៅក្នុងព្រឹត្តិការណ៍មួយចំនួន ។ ឧទាហរណ៍ ៖ អេណុស ១:១–៨ ។

និមិត្តរូប ៖ ពាក្យទាំងឡាយដូចជា *ដូចជា ដូច* ឬ *ប្រៀបដូចជា* ជួយយើងឲ្យស្គាល់នូវនិមិត្តសញ្ញា ។ សូមមើលហួសពីនិមិត្តសញ្ញា ដោយស្វែងរកធម្មជាតិរបស់វា ហើយគិតពីកេនតកណ្តរបស់វា ។ លេខយោង វចនានុក្រមព្រះគម្ពីរបរិសុទ្ធ និង ការណែនាំតាមប្រធានបទ អាចជួយការបកប្រែពីនិមិត្តសញ្ញាខ្លះៗ ។ ឧទាហរណ៍ ៖ ហេលេមិន ៨:១៤–១៥រួមមាន លេខយោងទៅខទាំងនោះ ។

ការពិចារណា ៖ ការពិចារណា រួមមាន ការគិត ការសញ្ជឹងគិតយ៉ាងម៉ឺងម៉ាត់ ការសួរសំណួរនានា និង ការវាយតម្លៃពីអ្វីដែលអ្នកដឹង និង អ្វីដែលអ្នកបានរៀន ។ ជាញឹកញាប់ ការពិចារណា ជួយយើងឲ្យយល់ពីអ្វីដែលយើងត្រូវធ្វើ ដើម្បីយកគោលការណ៍នានានៃដំណឹងល្អមកអនុវត្ត ។

មេរៀនទី ៣

ផែនការនៃសេចក្តីសង្គ្រោះ

សេចក្តីផ្តើម

ប្រធាន ប៊ិយង៍ យេ ផាកកឺ នៃក្លុ៉ម៉នៃពួកសាវកដប់ពីរនាក់ បានណែនាំគ្រូបង្រៀនថ្នាក់សិក្ខាសាលាទាំងឡាយ ឲ្យបង្ហាញពីសេចក្តីសង្ខេបនៃផែនការនៃសេចក្តីសង្គ្រោះ នៅដើមឆ្នាំនៃឆ្នាំសិក្សាថ្មី ៖

« សេចក្តីសង្ខេបនៃ ‹ ផែនការនៃសុភមង្គល › . . . បើត្រូវបានឲ្យនៅពេលចាប់ផ្តើមដំបូងបំផុត ហើយរំឭកឡើងវិញម្តងម្តាល វានឹងកាន់តែមានតម្លៃដ៏មហិមាចំពោះសិស្សរបស់អ្នក ។ . . .

« យុវវ័យធ្ងល់ថា ‹ ហេតុអ្វី ? › —ហេតុអ្វីបានជាយើងត្រូវបានបញ្ជា *ឲ្យធ្វើ* រឿងអ្វីមួយ ហើយហេតុអ្វីបានជាយើងត្រូវបញ្ជា *មិន* ឲ្យធ្វើរឿងផ្សេងៗទៀត ? ចំណេះដឹងពីផែនការនៃសុភមង្គល ទោះបីជានៅក្នុងទម្រង់បែបណាក្តី ក៏អាចផ្តល់ដល់គំនិតខ្ចីនូវ ‹ ហេតុអ្វី › ផងដែរ ។ . . .

« . . . ផ្តល់នូវអារម្មណ៍ជាមូលដ្ឋាន សម្រាប់ផែនការទាំងមូល ទោះបីគ្រាន់តែជាសេចក្តីលម្អិតពីរបីក៏ដោយ ។ . . . សូមឲ្យពួកគេដឹងថាផែនការនៃសុភមង្គលគឺជាអ្វី បន្ទាប់មកពួកគេនឹងមាននូវសំណួរ ‹ ហេតុអ្វី › ។' . . .

« . . . ប្រសិនបើអ្នកព្យាយាមផ្តល់ដល់ពួកគេនូវសំណួរ ‹ ហេតុអ្វី › សូមធ្វើតាមគំរូ [នេះ] ៖ ‹ ព្រះបានប្រទាននូវព្រះបញ្ញត្តិដល់ពួកគេ *ក្រោយពី*ប្រាប់ដល់ពួកគេនូវផែនការប្រោសលោះ ។› [អាលម៉ា ១២:៣២អក្សរទ្រេតបានបន្ថែម ។]" (" ផែនការដ៏អស្ចារ្យនៃសុភមង្គល " [ការប្រជុំពិភាក្សារបស់ CES ស្តីអំពីគោលលទ្ធិ និង សេចក្តីសញ្ញា/ប្រវត្តិសាសនាចក្រ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៣] ទំព័រ ២–៣, si.lds.org) ។

ដើម្បីឆ្លើយតបនឹងការប្រឹក្សារបស់ប្រធាន ផាកកឺ មេរៀននេះផ្តល់នូវសេចក្តីសង្ខេបពីផែនការសង្គ្រោះ ដូចដែលវាបានបង្រៀននៅក្នុងព្រះគម្ពីរ ។ មេរៀននេះ ផ្តោតទៅលើដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ដែលជា « ការពិតដ៏សំខាន់បំផុត គ្រឹះដ៏ចាំបាច់ និង គោលលទ្ធិដ៏សំខាន់នៃផែនការសង្គ្រោះដ៏អស្ចារ្យ និង ដ៏អស់កល្ប « (ដែហ្វ្រី អ័រ ហូឡិន « កិច្ចការផ្សព្វផ្សាយសាសនា និង ដង្វាយធួន » *Ensign* ខែ មីនា ឆ្នាំ ២០០១ ទំព័រ ៨) ។ នៅពេលសិស្សចាប់យល់ពីផែនការសង្គ្រោះ នោះសេចក្តីជំនឿរបស់ពួកគេលើព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ នឹងកើនឡើងផងដែរ ។ ពួកគេនឹងរីកចម្រើនឡើង នៅក្នុងការតាំងចិត្តដើម្បីធ្វើតាមព្រះបញ្ញត្តិទាំងឡាយ ទទួលបាននូវពិធីបរិសុទ្ធនៃការសង្គ្រោះ ហើយនៅស្មោះចំពោះសេចក្តីសញ្ញារបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

ផែនការសង្គ្រោះក្នុងព្រះគម្ពីរមរមន

សូមពន្យល់ថា នៅក្នុងពិភពវិញ្ញាណមុនជីវិតលើផែនដីនេះ យើងបានរៀនអំពីផែនការរបស់ព្រះវរបិតាសួគ៌របស់យើង សម្រាប់សេចក្តីសង្គ្រោះរបស់យើង (សូមមើល ម៉ូសេ ៤:១–២ ; អ័ប្រាហាំ ៣:២២–២៨) ។ តាមរយៈផែនការនេះ យើងអាចក្លាយដូចជាទ្រង់ហើយរស់នៅក្នុងវត្តមានរបស់ទ្រង់ជារៀងរហូត ។

នៅលើក្តារខៀន សូមសរសេរ *ផែនការសង្គ្រោះ រួមមាន* . . .

សុំឲ្យសិស្សបំពេញគំនិតនេះ នៅក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ឬ សៀវភៅសរសេរក្នុងថ្នាក់ ។

ក្រោយពីសិស្សបានសរសេរហើយ សូមចែកចាយនូវនិយមន័យនៃផែនការសង្គ្រោះដូចខាងក្រោម ។ អ្នកអាចសរសេរនៅលើក្តារខៀន ឬ លើក្រដាស មុនពេលថ្នាក់ចាប់ផ្តើម ។

ផែនការសង្គ្រោះ គឺជា « ភាពពេញលេញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដែលបានរៀបចំឡើង ដើម្បីនាំមកនូវអមតភាព និង ជីវិតដ៏អស់កល្បជានិច្ចដល់មនុស្ស ។ វារួមមាន ការបង្កើត ការធ្លាក់ និង ដង្វាយធួន រួមជាមួយនឹងព្រះបញ្ញត្តិដែលព្រះបានប្រទាន ពិធីបរិសុទ្ធ និង គោលលទ្ធិទាំងអស់ ។ ផែនការនេះ ធ្វើឲ្យវាអាចកើតមានចំពោះមនុស្សទាំងអស់ ដើម្បីត្រូវបានតម្កើងឡើង និងរស់នៅជាមួយព្រះជារៀងរហូត » (សេចក្តីណែនាំដល់បទគម្ពីរ « ផែនការប្រោសលោះ » scriptures.lds.org) ។

សុំឲ្យសិស្សលើកដៃឡើង ប្រសិនបើពាក្យដែលគេបានសរសេរ ត្រូវនឹងនិយមន័យនេះ តាមរបៀបណាក៏ដោយ ។ បន្ទាប់មកសូមសួរសំណួរដូចខាងក្រោមទៅសិស្សមួយចំនួនដែលបានលើកដៃឡើង ៖

- តើនិយមន័យរបស់អ្នក មានចំណុចរួមជាមួយនឹងនិយមន័យនេះយ៉ាងម៉េចខ្លះ ? ហេតុអ្វីបានជាអ្នករួមបញ្ចូលចំណុចនេះ នៅក្នុងនិយមន័យរបស់អ្នក ?

សូមចាត់ឲ្យសិស្សធ្វើការជាគូ ។ សុំឲ្យសិស្សម្នាក់ក្នុងមួយគូៗ អាន អាលម៉ា ២២:១២–១៤ ហើយសិស្សម្នាក់ទៀតអាន នីហ្វៃទី ២ ២:២៥–២៨ ។ (អ្នកអាចសរសេរឯកសារយោងទាំងនេះ លើក្តារខៀនបាន ។) សុំឲ្យសិស្សរកមើលផ្នែកនានានៃផែនការសង្គ្រោះ ដែលបានលើកឡើងនៅក្នុងវគ្គដែលពួកគេបានអាន ។ ក្រោយពីសិស្សបានអានរួចហើយ សុំឲ្យដៃគូនីមួយៗ ប្តូរវេនគ្នាចែកចាយនូវអ្វីដែលពួកគេបានរកឃើញ ។

សូមសរសេរព្រះគម្ពីរយោងខាងក្រោមនៅលើក្តារខៀន ៖ *នីហ្វៃទី ២ ៩:៦; នីហ្វៃទី ២ ១១:៥; អាលម៉ា ១២:២៥; អាលម៉ា ២៤:១៤; អាលម៉ា ៤២:៨; អាលម៉ា ៤២:១៥ ។*(អ្នកអាចសរសេរវា នៅលើក្តារខៀន មុនចាប់ផ្តើមថ្នាក់ ។)

សូមពន្យល់ថា នៅក្នុងព្រះគម្ពីរមរមន ព្យាការីបានប្រើចំណងជើងផ្សេងៗគ្នា ដើម្បីយោងទៅលើផែនការរបស់ព្រះវរបិតាសួគ៌ា ។ សូមអញ្ជើញសិស្សឲ្យបើកទៅ នីហ្វៃទី ២ ៩:៦ហើយ សុំឲ្យសិស្សម្នាក់អានខនោះ ឲ្យឮ ៗ ។

សេចក្តីសង្ខេប

នៅពេលដែលប្រធាន ផាកកឺ បានប្រឹក្សាដល់គ្រូបង្រៀនទាំងឡាយឲ្យចែកចាយមេរៀនមួយអំពីផែនការសង្គ្រោះ គាត់ក៏បានផ្តល់ដល់ពួកគេនូវកិច្ចការផ្ទាល់ខ្លួនមួយ « ដើម្បីរៀបចំរឿងសង្ខេបខ្លីមួយ ឬ សេចក្តីសង្ខេបនៃផែនការនៃសុភមង្គល » ជាផ្នែកនៃការសិក្សាព្រះគម្ពីររបស់ពួកគេ ។ គាត់បានប្រឹក្សាថា ៖ « រចនាវាឲ្យដូចជាគម្រោងមួយ ដែលសិស្សរបស់អ្នក អាចរៀបចំសេចក្តីពិតដែលអ្នកនឹងចែកចាយជាមួយពួកគេ » (« ផែនការដ៏អស្ចារ្យនៃសុភមង្គល » [ការប្រជុំពិភាក្សារបស់ CES ស្តីអំពីគោលលទ្ធិ និង សេចក្តីសញ្ញា/ប្រវត្តិសាសនាចក្រ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៣] ទំព័រ ២–៣, si.lds.org) ។ សូមប្រើការប្រឹក្សានេះ ជាមគ្គុទេសន៍មួយ នៅពេលអ្នករៀបចំមេរៀនបង្រៀន ។ អ្នកមិនគួរខំបង្រៀននូវរាល់សេចក្តីពិតនៃដំណឹងល្អនោះទេ ទោះបីជាសេចក្តីពិតទាំងអស់នោះ ត្រូវបានបញ្ចូលនៅក្នុងផែនការក៏ដោយ ។

- នៅក្នុងខនេះ តើឃ្លាណាដែលសំដៅលើផែនការរបស់ព្រះ ? (« ផែនការនៃការប្រោសប្រណីរបស់ព្រះបង្កបង្កើតដ៏ធំ ។ » សូមសរសេរខនេះ នៅលើក្តារខៀន ក្បែរនីហ្វៃទី ២ ៩:៦ ។)

សូមសិស្សឲ្យអានស្ងាត់ៗ នូវវគ្គព្រះគម្ពីរផ្សេងទៀត ដែលបានសរសេរនៅលើក្តារខៀន ដោយរកមើលឃ្លានានាដែលយោងទៅលើផែនការរបស់ព្រះវរបិតាសួគ៌ា ។ នៅពេលសិស្សរកឃើញនូវឃ្លាមួយ ដែលនិយាយអំពីផែនការរបស់ព្រះវរបិតាសួគ៌ សូមអញ្ជើញគាត់ឲ្យសរសេរវាលើក្តារខៀន ក្បែរនឹងសេចក្តីយោងបទគម្ពីរដែលគាត់បានរកឃើញ ។ បញ្ជីដែលបានបំពេញចប់នៅលើក្តារខៀន គួរតែមានទម្រង់បែបនេះ ៖

នីហ្វៃទី ២ ៩:៦— ផែនការនៃការប្រោសប្រណីរបស់ព្រះបង្កបង្កើតដ៏ធំ

នីហ្វៃទី ២ ១១:៥— ផែនការដ៏ធំ ហើយអស់កល្បជានិច្ចនៃការរំដោះពីសេចក្តីស្លាប់

អាលម៉ា ១២:២៥—ផែនការនៃសេចក្តីប្រោសលោះ

អាលម៉ា ២៤:១៤—ផែនការនៃសេចក្តីសង្គ្រោះ

អាលម៉ា ៤២:៨—ផែនការនៃសុភមង្គលដ៏មហិមា

អាលម៉ា ៤២:១៥—ផែនការនៃសេចក្តីមេត្តាករុណា

(ដើម្បីជួយសិស្សឲ្យកាន់តែមានអំណរគុណចំពោះការបង្រៀន ដែលមាននៅក្នុងព្រះគម្ពីរមរមន អ្នកអាចបង្ហាញថា ឃ្លាដូចជា « ផែនការសង្គ្រោះ » « ផែនការនៃសុភមង្គល » និង « ផែនការសេចក្តីប្រោសលោះ » ត្រូវបានលើកឡើងជាច្រើនដង នៅក្នុងព្រះគម្ពីរមរមន ប៉ុន្តែមិនមាននៅក្នុងព្រះគម្ពីរបរិសុទ្ធទេ) ។

- តើចំណងជើងទាំងនេះ បញ្ជាក់យ៉ាងហ្មត់ចត់អំពីផែនការរបស់ព្រះវរបិតាសួគ៌អ្វីខ្លះ ? (សូមប្រាកដថា សិស្សយល់ថា **ផែនការរបស់ព្រះវរបិតាសួគ៌គឺត្រូវបានរៀបចំឡើងដើម្បីនាំមកនូវសេចក្តីសង្គ្រោះ និង សុភមង្គលដ៏អស់កល្បជានិច្ច ដល់កូនចៅរបស់ទ្រង់ ។**)

សូមថ្លែងទីបន្ទាល់ថា យើងមិនអាចត្រឡប់ទៅកាន់ទីវត្តមានរបស់ព្រះ ហើយទទួលបាននូវសេចក្តីសង្គ្រោះដ៏អស់កល្បជានិច្ច ដោយគ្មានជំនួយដ៏ទេវភាពបានទេ ។ សូមអញ្ជើញសិស្សឲ្យអាន ម៉ូសាយ ៣:១៧ រៀងៗខ្លួន ដោយស្វែងរកនូវរូបភាពដ៏សំខាន់បំផុត នៅក្នុងផែនការសង្គ្រោះ ។ ក្រោយពីពួកគេបានរាយការណ៍អ្វីដែលពួកគេបានរកឃើញហើយ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ២:៨ ឲ្យឮៗ ។ សូមបញ្ជាក់យ៉ាងហ្មត់ចត់ថា **ព្រះយេស៊ូវគ្រីស្ទគឺជារូបភាពស្នូលនៅក្នុងផែនការសង្គ្រោះ ហើយដង្វាយធួនរបស់ទ្រង់ គឺជាអ្វីដែលធ្វើឲ្យផែនការនេះដំណើរការដល់កូនចៅរបស់ព្រះទាំងអស់ ។**សុំឲ្យសិស្សម្នាក់អានប្រសាសន៍ខាងក្រោម ថ្លែងដោយព្យាការី យ៉ូសែប ស៊្មីធ ៖

« គោលការណ៍ដ៏សំខាន់នៃសាសនារបស់យើង គឺជាទីបន្ទាល់ពីសាវក និង ព្យាការីទាំងឡាយដែលទាក់ទងនឹងព្រះយេស៊ូវគ្រីស្ទ ថាទ្រង់បានសុគត បានត្រូវគេបញ្ចុះ ហើយបានរស់ឡើងវិញម្តងទៀតនៅថ្ងៃទីបី ហើយបានយាងទៅស្ថានសួគ៌វិញ ហើយរឿងផ្សេងទៀតទាំងអស់ ដែលជាប់ពាក់ព័ន្ធដល់សាសនារបស់យើង គឺគ្រាន់តែជាសេចក្តីបន្ថែមលើវាប៉ុណ្ណោះ » (*ការបង្រៀនរបស់ប្រធាននៃសាសនាចក្រ ៖ យ៉ូសែប ស៊្មីធ* [២០០៧] ទំព័រ ៤៩) ។

អ្នកអាចពន្យល់ថា ពាក្យថា *សេចក្តីបន្ថែម* យោងទៅលើវត្ថុមួយ ឬ គំនិតមួយ ដែលទាក់ទងនឹងអ្វីមួយដែលមានសារៈសំខាន់ខ្លាំងជាង ដូចជាមែកមួយ ដែលជាផ្នែកមួយនៃដើមឈើមួយដើម ។ ដើមឈើមួយដើមអាចរស់បានដោយគ្មានមែកផង ប៉ុន្តែមែកមួយមិនអាចរស់ដោយឃ្លាតចេញពីឫស និងដើមរបស់ដើមឈើនោះឡើយ ។ ប្រធាន ប៊ិយដ៍ ឃេ ផាកគឺ នៃក្រុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា គោលលទ្ធិនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ គឺជា « ឫសដ៏សំខាន់នៃគោលលទ្ធិរបស់ពួកបរិសុទ្ធ ។ អ្នកអាចដឹងយ៉ាងច្រើនអំពីដំណាំឈូ ដូចដែលវាបំបែកពីមែកទីនោះ ប៉ុន្តែប្រសិនបើអ្នកគ្រាន់តែដឹងថាមែក និងផាងទាំងនោះ ដោយមិនបានជាប់នឹងឫសទេ នោះប្រសិនបើវាត្រូវបានកាត់ចេញពីសេចក្តីពិត វានឹងគ្មានជីវិត គ្មានសារធាតុ ហើយក៏គ្មានការប្រោសលោះលើពួកគេដែរ » (« អង្គបង្កបង្កើត » *Ensign* ខែ ឧសភា ឆ្នាំ ១៩៧៧ ទំព័រ ៥៦) ។

សូមពន្យល់ថា ផែនការរបស់ព្រះវរបិតាសួគ៌ ជារឿយៗត្រូវបានហៅថាជា ផែនការសង្គ្រោះ ដោយសារវាទាក់ទងនឹងការសង្គ្រោះយើង ។ ក្នុងនាមជាតួអង្គតែមួយគត់ដែល ធ្វើឲ្យសេចក្តីសង្គ្រោះរបស់យើងអាចកើតឡើងបាន តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ត្រូវបានហៅថា ព្រះអង្គសង្គ្រោះ ។

សូមសរសេរ *យើងត្រូវការបានសង្គ្រោះពី . . .* នៅលើក្តារខៀន ។

សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ៩:៦–១០ ឲ្យឮៗ ហើយបន្ទាប់មក សុំឲ្យសិស្សផ្សេងទៀតអាននីហ្វៃទី ៣ ៩:២១–២២ ឲ្យឮៗ ។ សូមអញ្ជើញសិស្សទាំងអស់ ឲ្យធ្វើតាមគ្នា ដោយស្វែងរកពីរបៀបដើម្បីបំពេញឃ្លានៅលើក្តារខៀន ។ អ្នកអាចស្នើពួកគេឲ្យគូសការរកឃើញនានារបស់ពួកគេ នៅក្នុងព្រះគម្ពីររបស់ពួកគេ ។

សុំឲ្យសិស្សចែកចាយនូវអ្វីដែលពួកគេបានរកឃើញ ហើយសរសេរចម្លើយរបស់គេ នៅលើក្តារខៀន ។ សូមប្រាកដថា ពួកគេយល់ថា តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ មនុស្សទាំងអស់ នឹងត្រូវបានសង្គ្រោះពីសេចក្តីស្លាប់ខាងសាច់ឈាម ។ សូមបញ្ជាក់ផងដែរថា តាមរយៈដង្វាយធួន យើងអាចបានសង្គ្រោះពីអំពើបាបរបស់យើង ដែលបើមិនដូច្នោះទេ យើងនឹងមិនគ្មានផ្លូវសម្រាប់ខ្លួនយើងអាចបានទៅរស់នៅក្នុងវត្តមានរបស់ព្រះឡើយ ។

សូមអានប្រសាសន៍ខាងក្រោមដែលដកស្រង់ចេញពីព្យាការី យ៉ាកុប ៖ « ឱ សេចក្តីល្អសប្បុរសនៃព្រះរបស់យើងធំណាស់ហ្ន៎ » (នីហ្វៃទី ២ ៩:១០) ។ « ឱសេចក្តីល្អសប្បុរសនៃព្រះរបស់យើងធំណាស់ហ្ន៎ ! » នីហ្វៃទី ២ ៩:១៣ ។

- តើប្រសាសន៍របស់យ៉ាកុប នៅក្នុង នីហ្វៃទី ២ ៩: ៦–១០ ជួយអ្នកឲ្យយល់ពីហេតុផល ដែលគាត់បាននិយាយនូវសម្តីសរសើរទាំងនេះ យ៉ាងដូចម្តេច ?
- យោងតាម នីហ្វៃទី ២ ៩:៧, ៩តើនឹងមានអ្វីកើតឡើង ប្រសិនបើគ្មានដង្វាយធួនទេនោះ ? (រូបកាយរបស់យើងនឹងស្លាប់ ហើយនឹងមិនអាចរស់ឡើងវិញម្តងទៀតនោះទេ ហើយវិញ្ញាណរបស់យើងនឹងស្ថិតនៅក្រោមពួកអារក្ស) ។

សូមមើលទៅប្រយោគចុងក្រោយ នៅក្នុងនិយមន័យនៃផែនការសង្គ្រោះ ដែលអ្នកបានចែកចាយពីលើកមុន នៅក្នុងមេរៀន ៖ « ផែនការនេះ ធ្វើឲ្យវាកើតមានចំពោះមនុស្សទាំងអស់ ដើម្បីបានតម្កើងឡើង និង រស់នៅជាមួយព្រះជារៀងរហូត » ។

- ហេតុអ្វីបានជាវាសំខាន់ដើម្បីយល់ថា ផែនការនេះ ធ្វើឲ្យភាពតម្កើងឡើងរបស់យើង*អាចកើតមានបាន* ប៉ុន្តែមិន*ជាក់ហាក់* ?(នៅពេលសិស្សឆ្លើយតបនឹងសំណួរនេះ សូមប្រាកដថា ពួកគេយល់ថា យើងមានសិទ្ធិជ្រើសរើស សមត្ថភាពដើម្បីរើសហើយធ្វើសម្រាប់ខ្លួនយើង ។ ភាពតម្កើងឡើងរបស់យើងពឹងផ្អែកលើផ្នែកលើរបៀបដែលយើងឆ្លើយតបនឹងពរជ័យ ដែលព្រះបានប្រទានដល់យើង) ។

សូមសរសេរនូវសេចក្តីយោងបទគម្ពីរដូចខាងក្រោម នៅលើក្តារខៀន ៖*នីហ្វៃទី ២ ២:២៥–២៨; នីហ្វៃទី ២ ៣១:១៧–២០; អាលម៉ា ៣៤:១៥–១៦* ។សុំឲ្យសិស្សសិក្សាពីវគ្គទាំងនេះដោយស្ងៀមស្ងាត់ និង សរសេរក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ នូវរឿងនានា ដែលព្រះគម្ពីរទាំងនេះបាននិយាយ ដែលយើងត្រូវធ្វើ ដើម្បីទទួលនូវអ្វីៗទាំងអស់ ដែលព្រះបានប្រទានដល់យើង តាមរយៈផែនការសង្គ្រោះរបស់ទ្រង់ ។

នៅពេលសិស្សមានពេលគ្រប់គ្រាន់ ដើម្បីបំពេញកិច្ចការនេះរួច សូមអញ្ជើញពួកគេឲ្យចែកចាយនូវចម្លើយរបស់ពួកគេជាមួយគ្នាទៅវិញទៅមក ។ នៅពេលពួកគេធ្វើដូច្នោះ សូមបង្ហាញនូវគំរូនៃការគោរពប្រតិបត្តិចំពោះ « ព្រះបញ្ញត្តិដែលព្រះបានប្រទាន ពិធីបរិសុទ្ធ និង គោលលទ្ធិ » ដែលបានលើកឡើងនៅក្នុងនិយមន័យ ដែលអ្នកបានចែកពេលមុន ។ (គំរូពីខទាំងនេះ រួមមានការអនុវត្តន៍សេចក្តីជំនឿលើការប្រែចិត្ត ការជ្រមុជទឹក និង ការទទួលព្រះវិញ្ញាណបរិសុទ្ធ) ។ ក្រោយពីការរាយការណ៍របស់សិស្ស សូមគិតពីការសួរនូវសំណួរខាងក្រោមនេះ ៖

- តើសកម្មភាពរបស់យើង មានឥទ្ធិពលលើសមត្ថភាពយើង ដើម្បីទទួលបាននូវពរជ័យទាំងឡាយនៃដង្វាយធួនយ៉ាងដូចម្តេច ? (នៅពេលសិស្សឆ្លើយ សូមរកឱកាសដើម្បីថ្លែងទីបន្ទាល់ថា **នៅពេលយើងជ្រើសរើស ដើម្បីរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយធ្វើតាមផែនការរបស់ព្រះ នោះយើងរៀបចំដើម្បីទទួលបាននូវជីវិតដ៏នៅអស់កល្បជានិច្ច តាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ**) ។
- តើការយល់ពីផែនការសង្គ្រោះ អាចជួយយើងឲ្យធ្វើតាមព្រះបញ្ញត្តិយ៉ាងដូចម្តេច ?

សុំឲ្យសិស្សអាន នីហ្វៃទី ២ ២:២៥ ឲ្យឮ ។

- តើតាមរបៀបណាខ្លះ ដែលផែនការសង្គ្រោះបាននាំមកនូវសេចក្តីអំណរដល់អ្នក ?

ដើម្បីបញ្ចប់មេរៀននេះ សូមពន្យល់ថា នៅពេលសិស្សសិក្សាព្រះគម្ពីរមុនមក ពួកគេនឹងរៀននូវគោលលទ្ធិជាច្រើនទៀតដែលទាក់ទងនឹងផែនការសង្គ្រោះ មេរៀននេះ បានបង្ហាញតែត្រឹមសេចក្តីសង្ខេបតែប៉ុណ្ណោះ ។ សូមលើកទឹកចិត្តសិស្ស នៅពេលពួកគេសិក្សាឲ្យរកមើលដោយយកចិត្តទុកដាក់នូវអ្វីៗទាំងអស់ ដែល ព្រះបានធ្វើសម្រាប់ពួកគេ ដែលជាផ្នែកនៃផែនការសង្គ្រោះរបស់ទ្រង់ និង ដើម្បីរកមើលដោយយកចិត្តទុកដាក់លើអ្វីៗទាំងអស់ ដែលពួកគេត្រូវធ្វើដើម្បីទទួលបាននូវពរជ័យដ៏ពេញលេញ ដែលព្រះបានគ្រោងសម្រាប់ពួកគេ ។ សូមថ្លែងទីបន្ទាល់របស់អ្នកពីសេចក្តីពិត ដែលបានពិភាក្សានៅក្នុងមេរៀននេះ ។

ទំព័រចំណងជើង សេចក្តីផ្តើម និង ទីបន្ទាល់នៃសាក្សី

សេចក្តីផ្តើម

នៅពេលអ្នកបង្រៀនព្រះគម្ពីរមរមន អ្នកនឹងជួយសិស្សឲ្យរកឃើញនូវការពិត ដែលនឹងនាំពួកគេខិតជិតទៅព្រះ ។ តាំងពីដើមគម្ពីរ វាច្បាស់ណាស់ថា អ្នកសរសេរនៃព្រះគម្ពីរមរមនមានបំណងឲ្យវា ថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។ ព្រះគម្ពីរ ក៏បានបញ្ជាក់ជាថ្មីពីសេចក្តីសញ្ញារបស់ព្រះជាមួយនឹងវង្សអ៊ីស្រាអែល ហើយបានបង្ហាញនូវតម្រូវការសម្រាប់កូនចៅរបស់ព្រះទាំងអស់គ្នាឲ្យធ្វើ និង រក្សាសេចក្តីសញ្ញាដ៏ពិសិដ្ឋ ។ នៅពេលសិស្សសិក្សាព្រះគម្ពីរមរមនដោយការអធិស្ឋាន ពួកគេនឹងទទួលបាននូវទីបន្ទាល់ដ៏អស្ចារ្យជាងនេះនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ និង នៃការស្តារឡើងវិញនៃសាសនាចក្ររបស់ទ្រង់នៅក្នុងថ្ងៃចុងក្រោយនេះ ។ ពួកគេក៏នឹងរៀនអនុវត្តសេចក្តីជំនឿដ៏កាន់តែអស្ចារ្យ ទៅលើព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធួនរបស់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

យោបល់សម្រាប់ការបង្រៀន មេរៀននេះប្រហែលជាតម្រូវពេលបង្រៀនយូរជាងម៉ោងបែងចែកសម្រាប់ថ្នាក់របស់អ្នក ។ សូមពិចារណាដោយការអធិស្ឋានថា តើផ្នែកណាមួយដែលថ្នាក់របស់អ្នកត្រូវការខ្លាំងបំផុត ។

ទំព័រចំណងជើង

សូមអញ្ជើញសិស្សឲ្យបើកទៅទំព័រចំណងជើងនៃព្រះគម្ពីរមរមន ។ ទំព័រនេះ ចាប់ផ្តើមជាមួយនឹងពាក្យ « ព្រះគម្ពីរមរមន ដំណើររឿងដែលបានសរសេរទុកដោយដៃរបស់ មរមន លើផ្ទាំងទាំងឡាយ ដែលបានដកស្រង់ចេញពីផ្ទាំងទាំងឡាយរបស់នីហ្វៃ » ។ ព្យាការីយ៉ូសែប ស៊្មីធ បានពន្យល់ពីភាពដើមនៃទំព័រចំណងជើងនេះ ៖

« ទំព័រចំណងជើងនៃព្រះគម្ពីរមរមន គឺជាការបកប្រែតាមន័យត្រង់ ដែលដកស្រង់ពីសន្លឹកចុងក្រោយគេបំផុត នៅខាងឆ្វេងនៃ . . . ផ្ទាំងចំណារមាស ដែលមាននូវកំណត់ត្រាដែលត្រូវបានបកប្រែ . . . និង . . . បាននិយាយថា ទោះដោយរបៀបណាៗក្តី ទំព័រចំណងជើងគឺមិនមែនជាការសរសេរតាមបែបសម័យទំនើបមួយណានោះទេ ហើយក៏មិនមែនជារបស់ខ្ញុំ ឬ របស់បុរសណាផ្សេងទៀតដែលបានរស់នៅ ឬ កំពុងរស់នៅក្នុងជំនាន់នេះទេ » (នៅក្នុងHistory of the Church, ១:៧១) ។

ការជំនួសឈ្មោះ

ការអញ្ជើញសិស្សឲ្យជំនួសឈ្មោះរបស់ពួកគេ ជួសឲ្យម្នាក់ដែលលេចឡើងនៅក្នុងខនៃព្រះគម្ពីរ ជួយធ្វើឲ្យការបង្រៀនព្រះគម្ពីរមានលក្ខណៈកាន់តែផ្ទាល់ខ្លួន ។ នៅពេលសិស្សអានឈ្មោះផ្ទាល់របស់គេ ជាផ្នែកមួយនៃព្រះគម្ពីរ ពួកគេអាចពិចារណាកាន់តែងាយស្រួល ពីរបៀបដែលគោលលទ្ធិ ឬ គោលការណ៍នៅក្នុងខនោះ អនុវត្តចំពោះខ្លួនគេ ។

សូមអញ្ជើញសិស្សអានទំព័រចំណងជើង នៃព្រះគម្ពីរមរមនដោយស្ងាត់ៗ ។ សុំឲ្យពួកគេរកមើលឃ្លាណាដែលនិយាយពីគោលបំណងនៃព្រះគម្ពីរមរមន ។ (អ្នកអាចឲ្យសិស្សនូវតម្រុយមួយថា គោលបំណងទាំងនេះ ត្រូវបានបង្ហាញថាជារឿងដែលព្រះគម្ពីរមរមននឹង « បង្ហាញដល់ » អស់អ្នកដែលអានវា) ។ សូមអញ្ជើញសិស្សមួយចំនួនឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ នៅពេលពួកគេបញ្ចប់ សុំឲ្យសិស្សអានកថាខណ្ឌទីពីរម្តងទៀតដោយខ្លួនឯង ដោយជំនួសឈ្មោះរបស់ពួកគេនៅក្នុងកន្លែងនៃ « សំណល់នៃវង្សអ៊ីស្រាអែល » ។

- **នៅពេលអ្នកអានព្រះគម្ពីរមរមន តើគោលបំណងណាមួយរបស់វាដែលបានបំពេញនៅក្នុងជីវិតរបស់អ្នក ? តើវាត្រូវបានបំពេញដោយរបៀបណា ?**
- **តើវាជួយអ្នកឲ្យដឹងដោយរបៀបណាថា អស់អ្នកដែលធ្វើសេចក្តីសញ្ញាជាមួយនឹងព្រះអម្ចាស់ នឹងមិនត្រូវ « កាត់ចេញជារៀងរហូត » នោះ ?**

សូមប្រាប់សិស្សថា វាអាចមានពេលខ្លះ ដែលពួកគេមានអារម្មណ៍ឯកោ ឬថាពួកគេត្រូវបាន « កាត់ចេញ » ។

- **ហេតុអ្វីបានជាវាសំខាន់ដើម្បីដឹងថា អំឡុងពេលពេលទាំងនេះ ថាអ្នកមិនត្រូវបាន « កាត់ចេញជារៀងរហូតនោះទេ » ?**
- **តើការសន្យានេះ គឺជាការបង្ហាញនៃសេចក្តីស្រឡាញ់របស់ព្រះចំពោះអ្នកដោយរបៀបណា ?**

ដើម្បីជួយសិស្សឲ្យមានអំណរគុណចំពោះគោលបំណងដ៏ចម្បងពីព្រះគម្ពីរមរមន សុំឲ្យសិស្សម្នាក់អានប្រសាសន៍ខាងក្រោមដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន ៖

« បេសកកម្មដ៏សំខាន់នៃព្រះគម្ពីរមរមន ដូចដែលបានកត់ត្រានៅលើទំព័រចំណងជើងគឺ « ដើម្បីជាការបរិវត្តន៍ដល់សាសន៍យូដា និង សាសន៍ដទៃថា ព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ ជាព្រះដ៏នៅអស់កល្បជានិច្ច ដែលបានសម្តែងរូបអង្គទ្រង់ដល់គ្រប់ទាំងសាសន៍ ។'

« អ្នកតាមស្វែងរកសេចក្តីពិតដ៏ស្មោះត្រង់ អាចទទួលបានទីបន្ទាល់ថា ព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ នៅពេលគាត់ពិចារណាដោយការអធិស្ឋាននូវពាក្យដ៏បំផុសគំនិតនៃព្រះគម្ពីរមរមន ។

« ជាងពាក់កណ្តាលនៃខគម្ពីរទាំងអស់ នៅក្នុងព្រះគម្ពីរមរមន និយាយអំពីព្រះអម្ចាស់របស់យើង ។ ទម្រង់ខ្លះនៃព្រះនាមរបស់ព្រះគ្រីស្ទត្រូវបានលើកឡើងយ៉ាងញឹកញាប់នៅក្នុងមួយខគម្ពីរ នៅក្នុងព្រះគម្ពីរមរមន ច្រើនជាងព្រះគម្ពីរសញ្ញាចាស់ ។

« ទ្រង់ត្រូវបានផ្តល់នាមឲ្យខុសៗគ្នាជាងមួយរយ នៅក្នុងព្រះគម្ពីរមរមន ។ នាមទាំងនោះ មានសារៈសំខាន់ជាពិសេសមួយ ក្នុងការពិពណ៌នាលក្ខណៈសម្បត្តិដ៏ទេវភាពរបស់ទ្រង់ » (« Come unto Christ » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៧ ទំព័រ ៨៣) ។

សូមចែកចាយទីបន្ទាល់របស់អ្នកថា ព្រះគម្ពីរមរមន គឺជាសាក្សីមួយថា ព្រះយេស៊ូវ គឺជាព្រះគ្រីស្ទ ។

បុព្វកថានៃព្រះគម្ពីរមរមន

សូមគូសរូបទ្វារកោងមួយលើក្តារខៀន (សូមមើលរូបភាពដែលភ្ជាប់មក) ឬ ធ្វើគំរូនៃទ្វារកោងមួយ ពីឈើ ឬ សម្ភារផ្សេងទៀត ។



សុំឲ្យសិស្សម្នាក់អានឮៗ នូវប្រសាសន៍ដោយ យ៉ូសែប ស៊្មីធ នៅក្នុងបព្វកថានៃព្រះគម្ពីរមរមន (សូមមើលកថាខណ្ឌប្រាំមួយ) ។ អ្នកគប្បីប្រាប់ សិស្សឲ្យគូសចំណាំប្រសាសន៍នៅក្នុងព្រះគម្ពីររបស់ពួកគេ ។

- តើអ្វីជាគោលបំណងនៃសិលាគន្លឹះ ?

សូមពន្យល់ថា សិលាគន្លឹះ គឺជាសិលាកណ្តាល នៅកំពូលនៃទ្វារកោង ។ នៅពេលទ្វារកោង ត្រូវបានសាងសង់ឡើង មានថ្មពីរសងខាងសង់ឡើងដើម្បីគាំទ្រវា ។ គម្លាតនៅកំពូលនៃទ្វារកោង គឺត្រូវបានវាស់យ៉ាងប្រុងប្រយ័ត្ន ហើយសិលាគន្លឹះត្រូវកាត់ឲ្យត្រូវវាយ៉ាងត្រឹមត្រូវ ។ នៅពេលសិលាគន្លឹះបានដាក់នៅកន្លែងដែលត្រឹមត្រូវ ទ្វារកោងអាចឈរដោយគ្មានជើងទ្រអ្វីទេ ។

- តើនឹងមានអ្វីកើតឡើងលើទ្វារកោង ប្រសិនបើសិលាគន្លឹះត្រូវបានគេដកចេញ ? (ប្រសិនបើអ្នកប្រើគំរូ សូមបង្ហាញដោយការដកចេញនូវសិលាគន្លឹះ) ។
- តើព្រះគម្ពីរមរមន ដើរតួដូចជាសិលាគន្លឹះទាក់ទងនឹងដំណឹងល្អដែលបានស្តារឡើងវិញ យ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់អានឮៗ នូវប្រសាសន៍ខាងក្រោមដោយ ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន ។ (អ្នកគប្បីរៀបចំប្រសាសន៍នេះ ជាក្រដាសចែកឲ្យសិស្សដើម្បីដាក់ចូលក្នុងព្រះគម្ពីររបស់ពួកគេ ។ ជាជម្រើសមួយទៀត អ្នកគប្បីអញ្ជើញសិស្សឲ្យសរសេរប្រសាសន៍របស់ប្រធាន ប៊ែនសឺន នៅក្នុងព្រះគម្ពីររបស់ពួកគេ នៅលើ ឬ ក្រោមនៃទំព័រទីមួយនៃបព្វកថា) ។

« មានរបៀបបីយ៉ាងដែលព្រះគម្ពីរមរមន គឺជាសិលាគន្លឹះនៃសាសនារបស់យើង ។ វាគឺជាសិលាគន្លឹះក្នុងភាពជាសាក្សីរបស់យើងអំពីព្រះគ្រីស្ទ ។ វាគឺជាសិលាគន្លឹះមូលដ្ឋាននៃគោលលទ្ធិរបស់យើង ។ វាគឺជាសិលាគន្លឹះនៃទីបន្ទាល់ » (« ព្រះគម្ពីរមរមន —សិលាគន្លឹះនៃសាសនារបស់យើង »*Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ៥) ។

ដើម្បីជួយសិស្សយល់ពីរបៀបដែលព្រះគម្ពីរមរមន គឺជាសិលាគន្លឹះនៃទីបន្ទាល់ សូមអញ្ជើញសិស្សម្នាក់អានប្រសាសន៍ខាងក្រោមដោយ ប្រធាន ប៊ែនសឺន ៖

« ព្រះគម្ពីរមរមនគឺជាសិលាគន្លឹះនៃទីបន្ទាល់ ។ ក៏ដូចជាទ្វារកោងចាក់ស្រុតដូច្នោះដែរ បើសិនជាសិលាគន្លឹះ ត្រូវបានដកចេញ ដូច្នេះការឈរឡើង ឬ ការធ្លាក់ចុះរបស់សាសនាចក្រ គឺវាអាស្រ័យលើភាពពិតពេញលេញនៃព្រះគម្ពីរមរមនយ៉ាងនោះដែរ ។ . . . ប្រសិនបើព្រះគម្ពីរមរមនពិត . . . នោះមនុស្សម្នាក់ត្រូវតែទទួលយកការអះអាងនៃការស្តារឡើងវិញ និង អ្វីៗទាំងអស់ដែលរួមដំណើរមកជាមួយវា » (« ព្រះគម្ពីរមរមន— សិលាគន្លឹះនៃសាសនារបស់យើង » ទំព័រ ៦) ។

- តើទីបន្ទាល់របស់អ្នកអំពីព្រះគម្ពីរមរមន បានមានឥទ្ធិពលលើទីបន្ទាល់របស់អ្នកអំពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អយ៉ាងដូចម្តេច ?
- តើព្រះគម្ពីរមរមន បាននាំអ្នកខិតជិតទៅព្រះដោយរបៀបណា ?

អ្នកគប្បីប្រាប់អំពីរបៀបដែលការសិក្សាព្រះគម្ពីរមរមនរបស់អ្នក បានពង្រឹងទីបន្ទាល់របស់អ្នក និង បាននាំអ្នកខិតជិតទៅរកព្រះ ។

សូមអញ្ជើញសិស្សឲ្យចូលរួមក្នុងការដើរតួសម្តែង ។ សុំឲ្យពួកគេគិតស្រមៃថា ពួកគេនឹងឲ្យព្រះគម្ពីរមរមនមួយក្បាលទៅនរណាម្នាក់ដែលមិនមែនជាសមាជិកនៃសាសនាចក្រនោះទេ ។ សូមជួយពួកគេរៀបចំដើរតួសម្តែង ដោយបែងចែកពួកគេជាពីរក្រុម ។ សុំឲ្យក្រុមទីមួយ អានកថាខណ្ឌទី ២ –៤ នៃបព្វកថានៃព្រះគម្ពីរមរមន ។ សុំឲ្យក្រុមទីពីរ អានកថាខណ្ឌ ៥–៨ ។ សូមឲ្យក្រុមទាំងពីរ រកមើលព័ត៌មាន ដែលពួកគេមានអារម្មណ៍ថាមានសារៈសំខាន់ ដើម្បីចែកចាយនៅពេលបង្រៀនអំពីព្រះគម្ពីរមរមន ។

ក្រោយពីឲ្យពេលសិស្សសិក្សា និង រៀបចំហើយ សូមអញ្ជើញសិស្សម្នាក់ឲ្យមកខាងមុខថ្នាក់ ដើរតួជាមនុស្សម្នាក់ដែលមិនមែនជាសមាជិកនៃសាសនាចក្រ ។ សុំឲ្យសិស្សម្នាក់ពីក្រុមមួយៗ នៃក្រុមទាំងពីរ មកខាងមុខថ្នាក់ផងដែរ ។ សូមពន្យល់ថា សិស្សទាំងពីរនាក់នេះនឹងធ្វើជាដៃគូអ្នកផ្សព្វផ្សាយសាសនា ។ ពួកគេនឹងប្រើសម្ភារដែលក្រុមរបស់ពួកគេបានរកឃើញ នៅក្នុងបព្វកថា ដើម្បីបង្រៀនសិស្សទីមួយអំពីព្រះគម្ពីរមរមន ។

នៅពេលសិស្សបញ្ចប់ការដើរតួសម្តែង អ្នកគប្បីសួរសិស្សទាំងអស់ ថាតើមានចំណុចបន្ថែមណាទៀតពីបុព្វកថា ដែលពួកគេអាចចែកចាយ បើពួកគេត្រូវបានជ្រើសរើសឲ្យបង្រៀន ។

អ្នកគប្បីបង្ហាញថា ព្រះគម្ពីរមរមន មិនមែនអះអាងថាផ្តល់ប្រវត្តិសាស្ត្រមួយរបស់មនុស្សទាំងអស់ដែលបានរស់នៅពីបុរាណ នៅក្នុងលោកខាងលិចនោះទេ ។ វាគឺជាកំណត់ត្រាតែលើកូនចៅរបស់លីហៃ (សាសន៍នីហ្វៃ និង សាសន៍លេមិន) និង ប្រជាជនសាសន៍

ការដើរតួសម្តែង

ការដើរតួសម្តែង ជួយសិស្សហ្វឹកហាត់ដោយការយកជំណោះស្រាយនៃដំណឹងល្អ ទៅអនុវត្តក្នុងស្ថានភាពនៃជីវិតពិត ។ ការដើរតួសម្តែង នឹងកាន់តែមានជោគជ័យ ប្រសិនបើអ្នកឲ្យព័ត៌មាន និង ពេលវេលាគ្រប់គ្រាន់ដល់អ្នកចូលរួម ដើម្បីរៀបចំ ។ នៅពេលសិស្សដើរតួសម្តែង ពួកគេនឹងប្រហែលជាធ្វើខុសខ្លះ ។ សូមប្រយ័ត្នប្រយែងចំពោះអារម្មណ៍ និង ឥរិយាបថរបស់ពួកគេ ហើយមិនត្រូវរិះគន់កំហុសទាំងនោះរបស់ពួកគេឡើយ ។ នៅចុងបញ្ចប់នៃការដើរតួសម្តែង គឺជាឱកាសដ៏ល្អ ដើម្បីសួរអ្នកមើល ថាតើមានគំនិតផ្សេងទៀតដែលពួកគេអាចលើកឡើង ប្រសិនបើពួកគេគឺជាអ្នកចូលរួមម្នាក់ដែរទេ ។

យ៉ាងឧប៉ុណ្ណោះ ។ ប្រហែលជាមានប្រជាជនផ្សេងទៀត ដែលបានរស់នៅលើទ្វីបនោះ ក្នុងលោកខាងលិចពីមុន អំឡុងពេល និង ក្រោយពេលព្រឹត្តិការណ៍ ដែលបានកត់ត្រានៅក្នុងព្រះគម្ពីរមរមន ។

សូមអញ្ជើញសិស្សអាន ម៉ូរ៉ូណៃ ១០:៣–៥ ដោយស្ងាត់ស្ងៀម ។

- ដោយយោងតាម ម៉ូរ៉ូណៃ តើយើងអាចដឹងថា ព្រះគម្ពីរមរមន ពិតដោយរបៀបណា ?

សូមអញ្ជើញសិស្សអានកថាខណ្ឌ ៨–៩ នៅក្នុងបព្ចកថានៃព្រះគម្ពីរមរមន ។ សុំឲ្យពួកគេរកមើលនូវសេចក្តីពិតបីបន្ថែម ដែលពួកគេនឹងទទួលបាននូវសាក្សីមួយ ប្រសិនបើពួកគេទទួលយកការតាំងចិត្តរបស់ម៉ូរ៉ូណៃ ។

សូមថ្លែងទីបន្ទាល់ទៅសិស្សថា **នៅពេលយើងអាន សូមពិចារណា និង អធិស្ឋានអំពីព្រះគម្ពីរមរមន នោះព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើជាសាក្សីថា វាជាការពិត ថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ថាយ៉ូសែប ស៊្មីធ គឺជាព្យាការីរបស់ព្រះម្ចាស់ និង ថាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជានគររបស់ព្រះនៅលើផែនដីនេះ ។**

ទីបន្ទាល់នៃពួកសាក្សីបីនាក់ និង ពួកសាក្សីប្រាំបីនាក់

សុំឲ្យសិស្សស្រមៃថា ពួកគេបានឃើញនរណាម្នាក់បានយករបស់ដ៏មានតម្លៃចេញពីផ្ទះរបស់អ្នកជិតខាងរបស់ខ្លួន ។

- នៅពេលដោះស្រាយបទល្មើសមួយ ហេតុអ្វីបានជាវាមានតម្លៃក្នុងការមានសាក្សីម្នាក់ ?
- ហេតុអ្វីបានជាវាមានសារៈសំខាន់ដើម្បីមានសាក្សីច្រើនជាងម្នាក់ ?

សុំឲ្យសិស្សអាន « ទីបន្ទាល់នៃពួកសាក្សីបីនាក់ » ដោយស្ងាត់ៗ ។ សូមអញ្ជើញពួកគេឲ្យរកមើលឃ្លា ដែលមានន័យពិសេសចំពោះពួកគេ ។ អ្នកគប្បីស្នើថា ពួកគេគួរតែគូសឃ្លាទាំងនេះទុក ។

- តើឃ្លាណាមួយ ដែលបានអ្នកគូស ? ហេតុអ្វីបានជាវាមានអត្ថន័យចំពោះអ្នក ? (អ្នកគប្បីបង្ហាញថា សំឡេងនៃព្រះ បានប្រកាសដល់ពួកសាក្សីបីនាក់ថា ថ្នាំងមាសត្រូវបានបកប្រែដោយអំណោយទាន និង ព្រះចេស្តានៃព្រះ) ។

សុំឲ្យសិស្សអាន « ទីបន្ទាល់នៃពួកសាក្សីប្រាំបីនាក់ » ឲ្យឮៗ ។ សូមអញ្ជើញសិស្សផ្សេងទៀតក្នុងថ្នាក់ឲ្យស្តាប់ ហើយរកមើលភាពខុសគ្នារវាងទីបន្ទាល់នៃពួកសាក្សីបីនាក់ និង ពួកសាក្សីប្រាំបីនាក់ ។

- តើភាពខុសគ្នាអ្វីខ្លះ ដែលអ្នកបានកត់សម្គាល់ឃើញ ?

សូមអញ្ជើញសិស្សឲ្យសរសេរទីបន្ទាល់របស់ខ្លួនគេផ្ទាល់ ឬ អារម្មណ៍អំពីព្រះគម្ពីរមរមន ។ ពួកគេគប្បីសរសេរវានៅក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ នៅលើក្រដាសទទេមួយនៅក្នុងព្រះគម្ពីររបស់ពួកគេ ។ សិស្សខ្លះ អាចមានអារម្មណ៍ថា ពួកគេមិនទាន់ដឹងថា ព្រះគម្ពីរមរមនគឺពិតនៅឡើយទេ ។ សូមលើកទឹកចិត្តពួកគេ ឲ្យស្វែងរកដើម្បីទទួលបាននូវទីបន្ទាល់មួយនៅក្នុងឆ្នាំនេះ ។

ជួយសិស្សឲ្យទទួលបាននូវទីបន្ទាល់

របៀបមួយដើម្បីជួយសិស្សទទួលបានទីបន្ទាល់ គឺត្រូវលើកទឹកចិត្តពួកគេឲ្យចែកចាយអារម្មណ៍របស់ពួកគេ អំពីជំណឹងល្អជាមួយនឹងអ្នកដទៃ រួមមានសមាជិកគ្រួសារ និង មិត្តភក្តិរបស់គេ ដែលនៅក្រៅថ្នាក់រៀន ។ ប្រធាន ប៊ិចម៍ ឃេ ផាកគី នៃក្រុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា ៖ « ឱ ! បើសិនជាខ្ញុំអាចបង្រៀនអ្នកនូវគោលការណ៍មួយនេះ ។ ទីបន្ទាល់មួយគឺត្រូវបាន *រកឃើញ* នៅក្នុង *ការថ្លែង* ពីវា ! . . .

« វាគឺជារបៀបមួយដើម្បីទទួលបាននូវសាក្សីមួយពីអ្វីដែលអ្នកបានអាន ឬ អ្វីដែលអ្នកផ្សេងបាននិយាយ ហើយនោះគឺជាការចាប់ផ្តើមដ៏ចាំបាច់មួយ ។ វាពិតជារបៀបមួយទៀតដែលព្រះវិញ្ញាណបញ្ជាក់ទៅអ្នក នៅក្នុងដើមទ្រូងរបស់អ្នកថា អ្វីដែល *អ្នក* បានថ្លែងទីបន្ទាល់នោះ គឺពិត » (« ទៀនៃព្រះអម្ចាស់ » *Ensign* ខែ មករា ឆ្នាំ ១៩៨៣ ទំព័រ ៥៤–៥៥) ។

សេចក្តីសង្ខេបនៃព្រះគម្ពីរមរមន

សេចក្តីផ្តើម

មេរៀននេះ ផ្តល់នូវសេចក្តីសង្ខេបពីព្រះគម្ពីរមរមន ។ សិស្សនឹងសិក្សាពីទីបន្ទាល់របស់យ៉ូសែប ស៊្មីធ ទាក់ទងនឹងការចេញមកនៃព្រះគម្ពីរមរមន ។ ពួកគេនឹងរៀនផងដែរ ពីរបៀបដែលព្រះគម្ពីរត្រូវបានចងក្រង និង សង្ខេបក្រោមការណែនាំពីស្ថានសួគ៌ ។ អ្នកសរសេរព្រះគម្ពីរមរមន បានឃើញជំនាន់ចុងក្រោយ ហើយពួកគេបានបញ្ចូលដំណើររឿង និង ការបង្រៀនដែលពួកគេដឹងថា គឺជាប្រយោជន៍ដ៏ធំបំផុតចំពោះយើង ។

យោបល់សម្រាប់ការបង្រៀន

ទីបន្ទាល់របស់ព្យាការី យ៉ូសែប ស៊្មីធ

មុនចាប់ផ្តើមថ្នាក់ សូមដាក់ព្រះគម្ពីរមរមននៅក្នុងប្រអប់មួយ ហើយខ្ចប់វាដូចជាអំណោយមួយ ។ សូមដាក់តាំងអំណោយនោះ លើតុមួយ នៅខាងមុខថ្នាក់ ហើយប្រាប់សិស្សថា វាជាអំណោយដ៏មានតម្លៃមួយ ។

- តើអ្វីខ្លះជាអំណោយដ៏មានតម្លៃបំផុត ដែលអ្នកបានទទួល ?
- តើអ្វីធ្វើឲ្យអំណោយមួយមានតម្លៃ ?
- តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលអ្នកឲ្យអំណោយមួយដែលអ្នកចាត់ទុកថា មានតម្លៃ ហើយអ្នកទទួលទទួលវាដោយមានសេចក្តីអំណរ ?

សូមអញ្ជើញសិស្សម្នាក់បើកអំណោយនោះ ហើយបង្ហាញសិស្សផ្សេងទៀត ឲ្យឃើញអ្វីដែលមាននៅខាងក្នុង ។

- តើនរណាបានឲ្យអំណោយនេះដល់យើង ?
- ហេតុអ្វីបានជាអ្នកមានអារម្មណ៍ថា អំណោយនេះមានតម្លៃ ?

សូមដាក់តាំងរូបភាព ម៉ូរ៉ូណៃ លេចមកឯ យ៉ូសែប ស៊្មីធ នៅក្នុងបន្ទប់របស់គាត់ (៦២៤៩២; *សៀវភៅរូបភាពដំណឹងល្អ* [ឆ្នាំ ២០០៩] ទំព័រ ៩១) ។

- តើព្រឹត្តិការណ៍អ្វី ដែលត្រូវបានបង្ហាញនៅក្នុងរូបភាពនេះ ?
- តើព្រឹត្តិការណ៍នេះ ជួយយ៉ាងដូចម្តេចចំពោះការស្តារឡើងវិញនៃដំណឹងល្អ ?

សូមពន្យល់ដល់សិស្សថា ពួកគេនឹងអាននូវពាក្យសម្តីរបស់ព្យាការី យ៉ូសែប ស៊្មីធ ថ្ងាល់ ឥឡូវនេះ អំពីការលេចចេញមកនៃព្រះគម្ពីរមរមន ។ សូមប្រាប់ពួកគេថា ទីបន្ទាល់របស់ព្យាការី យ៉ូសែប ស៊្មីធ ដែលសម្តែងឡើងនៅដើមដំបូងនៃព្រះគម្ពីរមរមន ត្រូវបានដកស្រង់ពីប្រវត្តិ —យ៉ូសែប ស៊្មីធ នៅក្នុងមុក្តាដ៏មានតម្លៃមហិមា ។ នៅពេលសិស្សបំពេញសកម្មភាពខាងក្រោម សូមឲ្យពួកគេអានពីមុក្តាដ៏មានតម្លៃមហិមា ។

សូមចាត់សិស្សឲ្យធ្វើការជាដៃគូ ។ សូមអញ្ជើញសិស្សម្នាក់ក្នុងដៃគូនីមួយៗ អាន យ៉ូសែប ស៊្មីធ —ប្រវត្តិ ១:៣០, ៣២–៣៥, ៤២ដោយស្ងាត់ស្ងៀម ។ សុំឲ្យសិស្សម្នាក់ទៀតនៅក្នុងដៃគូនីមួយៗអាន យ៉ូសែប ស៊្មីធ —ប្រវត្តិ១:៥១–៥៤, ៥៩–៦០ដោយស្ងាត់ស្ងៀម ។ សូមពន្យល់ថា នៅពេលពួកគេអានចប់ ដៃគូនីមួយៗ គួរតែបង្រៀនដៃគូមួយទៀត ពីអ្វីដែលពួកគេបានអាន ។

ក្រោយពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីអាន និង ពិភាក្សារួច សូមសួរ ៖

- តើអ្នកគិតថា វាអាចជួយ យ៉ូសែប ស៊្មីធ បានយ៉ាងដូចម្តេច ក្នុងការរង់ចាំរយៈពេលបួនឆ្នាំ មុនពេលគាត់អាចយកថ្មាំងមាសនោះមកផ្ទះជាមួយនឹងគាត់ ? (អំឡុងពេលនោះ យ៉ូសែប ត្រូវបានបង្រៀនដោយ ម៉ូរ៉ូណៃ ហើយគាត់បានធំលូតលាស់ឡើង ក្នុងរបៀបច្រើនយ៉ាង ។ (សូមមើល យ៉ូសែប ស៊្មីធ —ប្រវត្តិ ១:៥៤) ។
- នៅក្នុងដំណើររឿងរបស់ យ៉ូសែប ស៊្មីធ តើមានភស្តុតាងអ្វី ដែលអ្នកមើលឃើញថា **ព្រះអម្ចាស់បានរក្សាព្រះគម្ពីរមរមន ឲ្យចេញមកនៅក្នុងថ្ងៃចុងក្រោយ** ?
- នៅក្នុងដំណើររឿងរបស់ យ៉ូសែប ស៊្មីធ តើមានភស្តុតាងអ្វី ដែលអ្នកមើលឃើញថា **ព្រះគម្ពីរមរមនបានចេញមកដោយព្រះចេស្តានៃព្រះ** ?

ការពន្យល់សង្ខេបមួយអំពីព្រះគម្ពីរមរមន

ដើម្បីជួយសិស្សយល់ពីរបៀបដែលព្រះគម្ពីរមរមន ត្រូវបានចងក្រងឡើង សូមឲ្យពួកគេបើកទៅ « ការពន្យល់សង្ខេបមួយ អំពីព្រះគម្ពីរមរមន » នៅក្នុងទំព័របុព្វកថានៃព្រះគម្ពីរមរមន ។ សូមអញ្ជើញសិស្សបួននាក់ ប្តូរវេនគ្នាអានចំណុចនានា ១–៤ ឮៗ ។ នៅពេលពួកគេអាន សូមឲ្យសិស្សក្នុងថ្នាក់ផ្សេងទៀត ស្តាប់នូវរបៀបដែលថ្នាំងមាសទាំងនោះមួយៗ សំខាន់ចំពោះព្រះគម្ពីរមរមន ។ ឧបសម្ព័ន្ធលើសៀវភៅសិក្សានេះ រួមមានគំនូរដែលមានចំណងជើងថា « ថ្នាំងមាស និង ទំនាក់ទំនងរបស់ពួកគេទៅនឹងព្រះគម្ពីរមរមនដែលបាន

> ***ការផ្តល់នូវសេចក្តីសង្ខេប***
>
> ប្រធាន ប៊ិចម៍ ឃេ ផាកគី នៃក្រុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា ៖ « មានតម្លៃដ៏ធំ នៅក្នុងការបង្ហាញនូវ*សេចក្តីសង្ខេប* មួយ ប៉ុន្តែត្រូវជាសេចក្តីសង្ខេបដែលរៀបចំដ៏ប្រុងប្រយ័ត្នក្រៃលែង នៃការថ្លែងទាំងអស់នៅពេលចាប់ផ្តើមដំបូងបំផុត ។ . . . « . . . [សិស្ស] ចាំបានច្រើនជាងមុន នៅពេលពួកគេដឹងពីរបៀបដែលចំណែកទាំងអស់រួមចុលគ្នា ហើយពន្លឺនៃការរៀនសូត្របានភ្លឺកាន់តែខ្លាំងឡើង ។ ទម្រង់នៃការឃើញជាមុន គឺជាគម្រោងមួយ ហើយគឺកាន់តែមានតម្លៃជាងដែលសមនឹងពេលវេលា និង ការងារដែលដាក់ទុនជាមួយនឹងវា » (« The Great Plan of Happiness » [ការប្រជុំពិភាក្សារបស់ CES ស្តីអំពីគោលលទ្ធិ និង សេចក្តីសញ្ញា/ប្រវត្តិសាសនាចក្រ ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៣] ទំព័រ ២ si.lds.org) ។

បោះពុម្ពរួច » ។ គំនូរនេះ អាចជួយសិស្សឲ្យមើលឃើញពីឆ្នាំងមាស ដែលបានពិភាក្សានៅក្នុង « ការពន្យល់សង្ខេបមួយ អំពីព្រះគម្ពីរ មរមន » ។ (ប្រសិនបើអ្នកមានអារម្មណ៍ថា វានឹងជួយជាផ្នែកមួយនៃការពិភាក្សានេះ សូមបង្ហាញកថាខណ្ឌចុងក្រោយនៃការពន្យល់ សង្ខេបនេះ ដោយចាប់ផ្តើមដោយឃ្លា « អំពីការបោះពុម្ពផ្សាយនេះ » ។ សូមពន្យល់ថា ការបោះពុម្ពនីមួយៗនៃព្រះគម្ពីរមរមន បានរួម បញ្ចូលការកែប្រែបន្ថែមបន្ទូចបន្ទូចនៃការប្រកប និង កំហុសការវាយអក្សរ ។)

សូមបង្ហាញរូបភាព មរមនសង្ខេបឆ្នាំងមាស (៦២៥២០; *សៀវភៅរូបភាពដំណឹងល្អ* ទំព័រ ៧៣) ។ សូមពន្យល់ថា មនុស្សជាច្រើន បានរក្សាកំណត់ត្រានេះ ដែលនៅទីបញ្ចប់ ក្លាយទៅជាព្រះគម្ពីរមរមន ។ សូមសរសេរសេចក្តីយោងបទគម្ពីរខាងក្រោមលើក្តារខៀន ។ សុំឲ្យសិស្សសិក្សាវាដោយស្ងាត់ៗ ដោយរកមើលគោលការណ៍ខ្លះ ដែលជួយអ្នកសរសេរព្រះគម្ពីរមរមន សម្រេចនូវអ្វីដែលត្រូវបញ្ចូល ក្នុងកំណត់ត្រារបស់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យចែកចាយនូវអ្វីដែលពួកគេរកឃើញ ។ (អ្នកគប្បីសរសេរចម្លើយរបស់ពួកគេនៅលើ ក្តារខៀន) ។

នីហ្វៃទី១ ១:២០

នីហ្វៃទី១ ៦:៤–៦

នីហ្វៃទី២ ៤:១៥

នីហ្វៃទី២ ២៥:២៣, ២៦

នីហ្វៃទី២ ២៩:១១–១៣

ពាក្យសម្តីនៃមរមន ១:៤–៨

នីហ្វៃទី៣ ១៦:៤

ម៉ូរ៉ូណៃ ១:៤

- តើការយល់ពីគោលការណ៍ណែនាំទាំងនេះ គប្បីជួយអ្នក នៅពេលអ្នកសិក្សាពីព្រះគម្ពីរមរមនយ៉ាងដូចម្តេច ?

សូមចែកចាយទីបន្ទាល់របស់អ្នកថា អ្នកសរសេរព្រះគម្ពីរមរមន បានឃើញជំនាន់របស់យើង ហើយបានសរសេរអ្វីដែលនឹងជួយដល់ យើងខ្លាំងបំផុត ។សូមអញ្ជើញសិស្សម្នាក់អាន មរមន ៨:៣៥–៣៨ ឮៗ ។

- តើបញ្ហាអ្វី ដែលម៉ូរ៉ូណៃបានឃើញ ក្នុងចំណោមប្រជាជនក្នុងជំនាន់យើង ?
- ហេតុអ្វីបានជាវាសំខាន់ដើម្បីដឹងថា ម៉ូរ៉ូណៃ និង អ្នកសរសេរផ្សេងទៀតនៃព្រះគម្ពីរមរមន បានដឹងពីបញ្ហាដែលយើងនឹងជួបប្រទះ ?

សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន ដែលទាក់ទងនឹងរបៀបដើម្បីសិក្សា ព្រះគម្ពីរមរមន ៖

« បើសិនជាពួកលោកបានឃើញសម័យរបស់យើង និង បានជ្រើសរើសការណ៍ទាំងនោះដែលអាចមានតម្លៃអស្ចារ្យ បំផុតដល់យើង តើនោះមិនមែនជារបៀបដែលយើងគួរតែសិក្សាព្រះគម្ពីរមរមនដែរឬទេអី ? យើងគួរតែសួរខ្លួនឯង ជាញឹកញាប់ថា ‹ ហេតុអ្វីបានជាព្រះអម្ចាស់បំផុសគំនិតមរមន (ឬ ម៉ូរ៉ូណៃ ឬ អាលម៉ា) ឲ្យបញ្ចូលការណ៍នោះ នៅក្នុងបញ្ជីរបស់លោក ? តើមេរៀនអ្វីដែលខ្ញុំអាចរៀនពីរឿងនោះ ដើម្បីជួយខ្ញុំឲ្យរស់នៅក្នុងជំនាន់ និង សម័យកាលនេះ ? › » (« ព្រះគម្ពីរមរមន— សិលាគន្លឹះនៃសាសនារបស់យើង »*Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ៦) ។

សូមប្រាប់ដល់សិស្សថា ប្រជាជនដែលត្រូវបានកត់ត្រាដាក់ក្នុងព្រះគម្ពីរមរមន បានជួបប្រទះនូវបញ្ហាជាច្រើនដូចជាជំនាន់របស់យើង ដែរ ។ ទោះបីជាព្រះគម្ពីរមរមន គឺជាឯកសារពីបុរាណមួយក៏ដោយ ក៏គោលលទ្ធិ ប្រវត្តិសាស្ត្រ និង ដំណើររឿងរបស់គម្ពីរមានតម្លៃដ៏ មហិមានាពេលបច្ចុប្បន្ន ។

សុំឲ្យសិស្សម្នាក់អានឮៗ នូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយ ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន ។ (អ្នកគប្បីឲ្យសិស្សម្នាក់ៗ នូវ សេចក្តីថ្លែងការណ៍នេះមួយច្បាប់) ។ សុំឲ្យថ្នាក់ស្តាប់នូវពរជ័យទាំងឡាយដែលប្រធាន ប៊ែនសឺន បានសន្យាដល់អស់អ្នកដែល ចាប់ផ្តើមសិក្សា ព្រះគម្ពីរមរមនខ្លាំង ។

« វាមិនត្រឹមតែថា ព្រះគម្ពីរមរមន បង្រៀនយើងនូវការពិតប៉ុណ្ណោះទេ តែវាពិតបង្រៀនច្បាស់លាស់មែន ។ ព្រះគម្ពីរមរមនពុំមែនគ្រាន់ តែថ្លែងទីបន្ទាល់អំពីព្រះគ្រីស្ទប៉ុណ្ណោះនោះទេ ប៉ុន្តែវាពិតជាបានថ្លែងទីបន្ទាល់ពិតមែនផងដែរ ។ ប៉ុន្តែមានអ្វីៗច្រើនជាងនេះទៅទៀត ។ នៅក្នុងព្រះគម្ពីរមរមន មាននូវព្រះចេស្តាមួយដែលនឹងចូលទៅក្នុងជីវិតរបស់អ្នក នៅខណៈពេលដែលអ្នកចាប់ផ្តើមសិក្សាព្រះគម្ពីរនេះ ឲ្យបានហ្មត់ចត់ ។ អ្នកនឹងរកឃើញនូវព្រះចេស្តាដ៏កាន់តែធំមហិមា ដើម្បីទប់ទល់នឹងសេចក្តីល្បួង ។ អ្នកនឹងរកឃើញព្រះចេស្តាដើម្បី ជៀសវាងពីការចោកបញ្ឆោត ។ អ្នកនឹងរកឃើញព្រះចេស្តាដើម្បីឈរនៅលើផ្លូវត្រង់ និង ចង្អៀត ។ ព្រះគម្ពីរទាំងអស់ត្រូវបានហៅថាជា « ព្រះបន្ទូលទាំងឡាយនៃជីវិត » (សូមមើល គ. និង ស. ៨៤:៨៥) ហើយគ្មានព្រះគម្ពីរណាដែលពិតជាងនេះ ជាងព្រះគម្ពីរមរមន ឡើយ ។ នៅពេលអ្នកចាប់ផ្តើមស្រែកឃ្លាន និង ស្រេកតាមព្រះបន្ទូលទាំងនោះ អ្នកនឹងឃើញថា ជីវិតអ្នកនឹងបរិបូរណ៍ដ៏អស្ចារ្យជាង មុនឆ្ងាយណាស់ » (« ព្រះគម្ពីរមរមន— សិលាគន្លឹះនៃសាសនារបស់យើង » ទំព័រ ៧) ។

- តើអ្នកមានបទពិសោធន៍ទទួលបានពរជ័យពីការសិក្សាព្រះគម្ពីរមរមន ពេលណាដែរទេ ?

សូមចែកចាយទីបន្ទាល់របស់អ្នកថា ព្រះគម្ពីរមរមន បានផ្តល់ដល់យើងនូវព្រះចេស្តាដ៏កាន់តែធំមហិមា ដើម្បីទប់ទល់នឹងសេចក្តីល្បួង ដើម្បីជៀសវាងពីការចោកបញ្ឆោត ហើយនឹងដើម្បីឈរនៅលើផ្លូវត្រង់ និង ចង្អៀត ។សូមប្រាប់សិស្ស អំពីពេលមួយដែលអ្នកបាន ទទួលនូវពរជ័យទាំងនេះ ដែលជាលទ្ធផលនៃការសិក្សាព្រះគម្ពីរមរមន ។

មុននឹងថ្នាក់ចាប់ផ្តើម សូមសរសេរនូវបញ្ជីសំណួរ និង ព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖

តើមានព្រះទេ ? (សូមមើល អាលម៉ា ៣០:៣៧–៤៤) ។ តើខ្ញុំអាចស្គាល់ព្រះទេ ? (សូមមើល អាលម៉ា ២២:១៨) ។ តើព្រះ ខ្វល់ខ្វាយពីខ្ញុំឬទេ ? (សូមអាន នីហ្វៃទី៣ ១៣:២៦–៣២) ។

តើខ្ញុំអាចទប់ទល់នឹងសេចក្តីល្បួង និង អំពើបាបបានដោយរបៀបណា ? (សូមមើលហេលេមិន ៥:១២) ។

តើអ្វីគឺជាគោលបំណងនៃជីវិត ? (សូមមើល អាលម៉ា ៣៤:៣២–៣៤) ។

ពីមុនចាប់ផ្តើមថ្នាក់

បើសិនជាអាច សូមយកពេលរៀបចំថ្នាក់រៀន មុនចាប់ផ្តើមថ្នាក់ ។ សូមសរសេរសេចក្តីយោងបទគម្ពីរ សំណួរ និង សកម្មភាពផ្សេងទៀត នៅលើក្តារខៀន ពីមុនពេលចាប់ផ្តើមថ្នាក់ ។ វានឹងជួយអ្នក សន្សំពេលណែនាំដ៏មានតម្លៃ និង លុបបំបាត់ការរំខានដែលអាចផ្តាច់នូវការបង្រៀន និង ដំណើរការរៀនសូត្របាន ។

តើមានជីវិតក្រោយពីសេចក្តីស្លាប់ដែរឬទេ ? (សូមមើល អាលម៉ា ៤០:១១–១២, ២១–២៣) ។

តើខ្ញុំអាចរកឃើញសេចក្តីសុខសាន្ត និង សេចក្តីអំណរ ហើយរីករាយបានដោយរបៀបណា ? (សូមមើល ម៉ូសាយ ២:៤១; ៤:២–៣; អាលម៉ា ៤១:១០) ។

តើគ្រួសាររបស់ខ្ញុំអាចបានរីករាយ និង កាន់តែសាមគ្គីគ្នា ដោយរបៀបណា ? (សូមមើល ម៉ូសាយ ៤:១៤–១៥) ។

តើខ្ញុំអាចអភ័យទោសបាបត្រូវ និង ខុសបានដោយរបៀបណា ? (សូមមើល ម៉ូរ៉ូណៃ ៧:១៦–១៧) ។

ហេតុអ្វីបានជាព្រះអនុញ្ញាតឲ្យមានសេចក្តីអាក្រក់ និង ការរងទុក្ខកើតឡើង ? (សូមមើល នីហ្វៃទី២ ២:១–២, ១១–១៦, ២២–២៧; អាលម៉ា ១៤:៩–១១; ៦០:១៣) ។

សូមពន្យល់ថា បន្ថែមពីលើពរជ័យទាំងឡាយ ដែលបាននិយាយរួចមកហើយ ព្រះគម្ពីរមរមនរួមមានចម្លើយចំពោះសំណួរដ៏មានន័យបំផុតនៅក្នុងជីវិតរបស់យើង ។ សូមអញ្ជើញសិស្សឲ្យជ្រើសរើសសំណួរផ្ទាល់ខ្លួនមួយ ឬ ពីរ ហើយស្វែងរកវគ្គគម្ពីរអមមកជាមួយ ចំពោះចម្លើយទាំងនោះ ។ សូមឲ្យពេលពួកគេពីរបីនាទី ដើម្បីស្វែងរកចម្លើយ ។ អ្នកគប្បីដើរជុំវិញថ្នាក់រៀន ដោយជួយសិស្សតាមដែលគេត្រូវការ ។

- តើព្រះគម្ពីរមរមន ឆ្លើយតបចំពោះសំណួរទាំងអស់ដែលអ្នកបានជ្រើសរើសដោយរបៀបណា ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ិយដ៍ ឃេ ផាកគឺ នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ។ នៅពេលគាត់បានធ្វើសេចក្តីថ្លែងការណ៍នេះ គាត់កំពុងនិយាយទៅកាន់គ្រូបង្រៀនទាំងឡាយនៅថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថាន អំពីព្រះចេស្តានៃព្រះគម្ពីរ ក្នុងការឆ្លើយតបនូវរាល់សំណួរដ៏មានន័យបំផុតនៅក្នុងជីវិតរបស់យើង ។

« ប្រសិនបើសិស្សរបស់អ្នកយល់ស្គាល់នឹងវិវរណៈនានា នោះគ្មានសំណួរ —ផ្ទាល់ខ្លួន ឬ សង្គម ឬ នយោបាយ ឬ ការងារណា—ដែលត្រូវទៅដោយគ្មានចម្លើយនោះទេ ។ ត្រង់នេះ រួមមានភាពពេញលេញនៃដំណឹងល្អជារៀងរហូតតទៅ ។ ត្រង់នេះ យើងរកឃើញនូវគោលការណ៍នៃសេចក្តីពិត ដែលនឹងដោះស្រាយនូវរាល់ការភាន់ច្រឡំ និង រាល់ការខ្វល់ខ្វាយក្នុងចិត្ត ដែលនឹងជួបប្រទះក្នុងគ្រួសាររបស់មនុស្សជាតិ ឬ បុគ្គលណាក៏ដោយ » (« បង្រៀនព្រះគម្ពីរ » | សុន្ទរកថាថ្លែងទៅកាន់អ្នកអប់រំសាសនា CES នៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៧៧, ៣–៤, si.lds.org) ។

សូមចែកចាយពីរបៀបដែលព្រះគម្ពីរមរមន បានប្រទានពរដល់ជីវិតរបស់អ្នក ។ សូមរំឭកដល់សិស្សពីគោលដៅរបស់ពួកគេ ឲ្យអានព្រះគម្ពីរមរមនប្រចាំថ្ងៃ និង អានព្រះគម្ពីរមរមនទាំងមូលយ៉ាងហោចណាស់មួយឆ្នាំម្តង ។

វិចារណកថា និង ព័ត៌មានសាច់រឿង

ការពន្យល់សង្ខេបអំពីព្រះគម្ពីរមរមន « អំពីការបោះពុម្ពផ្សាយនេះ »

មានការសរសេរដោយដៃពីរនៃព្រះគម្ពីរមរមន ៖ ការសរសេរដោយដៃសំណៅដើម និង ការសរសេរដោយដៃរបស់អ្នកបោះពុម្ព ។ ចំណែកដ៏តូចមួយនៃការបោះពុម្ពសម្រាប់ការបោះពុម្ពឆ្នាំ ១៨៣០ នៃព្រះគម្ពីរមរមន ត្រូវផ្អែកលើការសរសេរដោយដៃសំណៅដើម ហើយអ្វីផ្សេងទាំងអស់ ត្រូវផ្អែកលើការសរសេរដោយដៃរបស់អ្នកបោះពុម្ព ដែលជាច្បាប់ចម្លងមួយនៃការសរសេរដោយដៃសំណៅដើម ។ នៅពេល យ៉ូសែប ស្ម៊ីធ បានរៀបចំការបោះពុម្ពព្រះគម្ពីរមរមននៅឆ្នាំ ១៨៤០ គាត់បានប្រើការសរសេរច្បាប់ដើមដោយដៃ ដើម្បីកែកំហុសអចេតនានានា និង ការលុបដែលបានកើតឡើងដោយអចេតនា នៅក្នុងការបោះពុម្ពឆ្នាំ ១៨៣០ ។ សម្រាប់ការបោះពុម្ពឆ្នាំ ១៩៨១ ដែលជាឯកសារសរសេរដោយដៃច្បាប់ដើម ត្រូវបានពិភាក្សាជាថ្មីម្តងទៀតដើម្បីរើឡើងវិញនូវពាក្យដើមនៅកន្លែងប្រហែល ២០ ។ ពាល់កំហុសនានានៅក្នុងព្រះគម្ពីរមរមន គឺជាកំហុសរបស់មនុស្ស ហើយការផ្លាស់ប្តូរនានា ដែលធ្វើឡើង គឺធ្វើឡើងដើម្បីស្តារឡើងវិញនូវព្រះគម្ពីរមរមន ឲ្យទៅនឹង និង គោលបំណងដើមរបស់វាវិញប៉ុណ្ណោះ ។ (សូមមើល *ដៃគូរយោងនៃព្រះគម្ពីរមរមន* ed. Dennis Largey [ឆ្នាំ ២០០៣] ទំព័រ ១២៤–២៥) ។

ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានសរសេរថា ៖

« វាចងភ្ជាប់ទៅជាការរៀបអក្សរបោះពុម្ពខុសខ្លះ នៅក្នុងការបោះពុម្ពលើកទីមួយ [នៃព្រះគម្ពីរមរមន] ហើយប្រហែលជាការលុបខ្លះនៃពាក្យមួយ ឬ ពីរ ។ អ្នកដែលបានបោះពុម្ពព្រះគម្ពីរក្រោមកាលៈទេសៈដ៏ប្រុងប្រយ័ត្ន និង ដែលអនុគ្រោះបំផុត បែរជាស្រងាកចិត្ត ដោយបានរកឃើញកំហុសនានា ខាងការរៀបអក្សរបោះពុម្ព និង បច្ចេកទេស ដែលខ្លះកើតឡើងក្រោយពេលមានកស្តុតាងនៃការពិនិត្យលើកចុងក្រោយ ។

« . . . ការត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់នៃបញ្ជីនៃការផ្លាស់ប្តូរ . . . បង្ហាញថា គ្មានការផ្លាស់ប្តូរមួយ ឬ ការបន្ថែមមួយដែលមិនស្ថិតនៅក្នុងភាពស្របគ្នានឹងអត្ថបទដើមនោះទេ ។ ការផ្លាស់ប្តូរនានា ត្រូវបានធ្វើឡើងលើវណ្ណយុត្តិ និង កំហុសតិចតួចពីរបីផ្សេងទៀត ដែលត្រូវការការកែតម្រូវ ប៉ុន្តែមិនដែលមានការផ្លាស់ប្តូរ ឬ ការបន្ថែមដែលផ្លាស់ប្តូរគំនិតដើមសូម្បីតែមួយ ។ នៅពេលវាលេចឡើងចំពោះយើង ការផ្លាស់ប្តូរ . . . គឺជាអ្វីដែលធ្វើឲ្យអត្ថបទច្បាស់ជាងមុន ហើយបង្ហាញថា វាត្រូវបានលុបចេញ ។ ខ្ញុំប្រាកដថា កំហុស ឬ ការលុបចេញនានានៅក្នុងការបោះពុម្ពលើកទីមួយនេះ គឺជាកំហុសដ៏ធំរបស់អ្នករៀបពុម្ព ឬ អ្នកបោះពុម្ព ។ *កំហុសទាំងនេះភាគច្រើន ដែលស្ថិតនៅក្នុងសំណៅលើកទីមួយ ត្រូវបានចាប់ដោយព្យាការី យ៉ូសែប ស្ម៊ីធ ខ្លួនគាត់ផ្ទាល់ ហើយគាត់បានកែតម្រូវ* » (*ចម្លើយចំពោះសំណួរពីដំណឹងល្អ* ចងក្រង ។ យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ជុំញ៉ូ រ៉ៃ ៥ ។ [ឆ្នាំ ១៩៥៧–៦៦], ២:១៩៩–២០០ អក្សរផ្តេកដើម) ។

មេរៀនសិក្សានៅផ្ទះ

ការសិក្សាបទគម្ពីរ –សេចក្តីសង្ខេបនៃព្រះគម្ពីរមរមន (ជំពូកទី ១)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀន សម្រាប់ការសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

ខាងក្រោមនេះ គឺជាសេចក្តីសង្ខេបមួយនៃព្រឹត្តិការណ៍ គោលលទ្ធិ និង គោលការណ៍នានាដែលសិស្សបានរៀន នៅពេលពួកគេបានបញ្ចប់មេរៀនសិស្សសម្រាប់សិក្សានៅផ្ទះ: បួន សម្រាប់ជំពូកទី ១ ។ ដោយដឹងពីអ្វីដែលសិស្សបានសិក្សា វានឹងជួយអ្នករៀបចំសម្រាប់ថ្នាក់របស់អ្នក ។ សេចក្តីសង្ខេបនេះ មិនមែនជាផ្នែកនៃមេរៀននោះទេ ហើយក៏មិនមែនមានន័យឲ្យត្រូវចែកចាយជាមួយនឹងសិស្សនោះដែរ ។ ដោយសារមេរៀនដែលអ្នកបង្រៀនសម្រាប់ជំពូកទី ១ ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍តែពីរបី នេះ: ពេលនោះអ្នកប្រហែលជាមានអារម្មណ៍រើបក្នុងការរំឭក ឬ ពិភាក្សាអ្វីផ្សេង ស្របតាមការបំផុសនៃព្រះវិញ្ញាណ និង សេចក្តីត្រូវការរបស់សិស្សអ្នក ។

ថ្ងៃទី ១ (ការសិក្សាព្រះគម្ពីរ)

សិស្សរៀនពីជំនាញ ដើម្បីជួយឲ្យពួកគេយល់ពីសាច់រឿង និង សាច់រឿងនៃព្រះគម្ពីរ ពីរបៀបដើម្បីសិក្សា និង ស្វែងរកនូវសេចក្តីពិតនៃដំណឹងល្អ និង ពីរបៀបដើម្បីអនុវត្តគោលលទ្ធិ និង គោលការណ៍នានានៃដំណឹងល្អនៅក្នុងជីវិតរបស់ពួកគេ ។

ថ្ងៃទី ១ (ផែនការសង្គ្រោះ)

មេរៀននេះ គឺជាសេចក្តីសង្ខេបខ្លីនៃផែនការសង្គ្រោះ ។ ព្រះគម្ពីរមរមន បង្រៀនថា ផែនការរបស់ព្រះវរបិតាសួគ៌ ត្រូវបានរៀបចំឡើងដើម្បីនាំកូនចៅរបស់ទ្រង់ទៅកាន់សេចក្តីសង្គ្រោះ និង សុភមង្គលដ៏នៅអស់កល្បជានិច្ច ។ ព្រះយេស៊ូវគ្រីស្ទ គឺជាតួអង្គសូលនៅក្នុងផែនការសង្គ្រោះនេះ ហើយដង្វាយធួនរបស់ទ្រង់ គឺជាអ្វីដែលធ្វើឲ្យផែនការនេះ ដំណើរការសម្រាប់កូនចៅរបស់ព្រះទាំងអស់ ។ នៅពេលយើងជ្រើសរើសដើរតាមផែនការរបស់ព្រះ យើងរៀបចំដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

ថ្ងៃទី ៣ (ទំព័រចំណងជើង បុព្វកថា និង ទីបន្ទាល់នៃពួកសាក្សី)

សម្ភារណែនាំដំបូងទៅកាន់ព្រះគម្ពីរមរមន ជួយបង្កើតគោលបំណងរបស់វា ហើយពន្យល់ពីភាពពិតពេញលេញ និង ភាពដ៏ទេវភាពនៃព្រះគម្ពីរ ។ ទំព័រចំណងជើងបង្រៀនថា ព្រះគម្ពីរមរមន គឺជាសាក្សីមួយថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។ នៅពេលយើងអាន សញ្ជឹងគិត និង អធិស្ឋានអំពីព្រះគម្ពីរមរមន ព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើជាសាក្សីថា វាគឺជាការពិត ថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ថាយ៉ូសែប ស្ម៊ីធ គឺជាព្យាការីមួយរបស់ព្រះ ហើយថាសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ គឺជានគររបស់ព្រះនៅលើផែនដី ។

ថ្ងៃទី ៤ (សេចក្តីសង្ខេបនៃព្រះគម្ពីរមរមន)

ទីបន្ទាល់របស់ព្យាការី យ៉ូសែប ស្ម៊ីធ បានជួយសិស្សពង្រឹងនូវទីបន្ទាល់របស់ពួកគេថា ព្រះគម្ពីរមរមន បានចេញមកដោយអំណោយទាន និង ព្រះចេស្តានៃព្រះ ។ ព្រះអម្ចាស់បានរក្សាទុកព្រះគម្ពីរមរមន ឲ្យចេញមកនៅក្នុងជំនាន់ចុងក្រោយនេះ ។ អ្នកសរសេរព្រះគម្ពីរមរមន បានឃើញជំនាន់របស់យើង ហើយបានសរសេរអ្វីដែលនឹងជួយដល់យើងខ្លាំងបំផុត ។ សូមលើកទឹកចិត្តសិស្សឲ្យគិតពីសំណួរ ដែលពួកគេមាន ហើយស្វែងរកចម្លើយនៅពេលពួកគេសិក្សាព្រះគម្ពីរមរមន ។

សេចក្តីផ្តើម

មេរៀនសម្រាប់សប្តាហ៍នេះ: បញ្ជាក់លើទំនួលខុសត្រូវរបស់សិស្សម្នាក់ៗ មានចំពោះការរៀនសូត្រដំណឹងល្អរបស់គេរៀងខ្លួន ។ វាក៏បញ្ជាក់លើតួនាទីចម្បងនៃព្រះគម្ពីរមរមន ក្នុងការជួយសិស្សកសាងនូវទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និង សាសនាចក្ររបស់ទ្រង់ដែរ ។ នៅពេលដែលអ្នកបង្រៀន សូមជួយសិស្សឲ្យយល់ពីសារៈសំខាន់នៃការសិក្សាដោយឧស្សាហ៍ព្យាយាមនូវព្រះគម្ពីរដ៏ពិសិដ្ឋនេះ និង ពរជ័យដែលនឹងបំពេញជីវិតរបស់ពួកគេ នៅពេលពួកគេធ្វើដូច្នោះ ។

យោបល់សម្រាប់ការបង្រៀន

ការសិក្សាព្រះគម្ពីរ

អ្នកគប្បីចាប់ផ្តើមដោយសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើមានភាពខុសគ្នាអ្វី រវាងមនុស្សម្នាក់ដែលអានព្រះគម្ពីរមរមន ហើយទទួលបាននូវទីបន្ទាល់ និង មនុស្សម្នាក់ដែលអានព្រះគម្ពីរមរមន ហើយមិនបានទទួលនូវទីបន្ទាល់នោះ: ? (អ្នកខ្លះគ្រាន់តែអានពាក្យ អ្នកផ្សេងទៀតអានដោយសេចក្តីជំនឿ ដោយមានបំណងដ៏ពិតប្រាកដ និង ដោយបើកដួងចិត្តរបស់គេចំពោះព្រះវិញ្ញាណបរិសុទ្ធ) ។
- តើមនុស្សម្នាក់រៀនពីសេចក្តីពិតខាងវិញ្ញាណដោយរបៀបណា ? (សូមគិតពីការសរសេរបញ្ជីនូវចម្លើយរបស់សិស្សទាំងអស់នៅលើក្តារខៀន ។ សូមត្រឡប់មកបញ្ជីនេះវិញ ក្រោយពីអានសេចក្តីថ្លែងការណ៍ដោយ អែលឌើរ ដេវីឌ អេ បែដណា ដូចខាងក្រោម) ។

សូមសរសេរនូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះ: នៅលើក្តារខៀន ដោយទុកចន្លោះនូវពាក្យដែលមានគូសបន្ទាត់ពីក្រោម ៖ « *ស្វែងរកការរៀនសូត្រ ដោយសារការសិក្សា និង ដោយសារសេចក្តីជំនឿផង* » ។

សូមរំឭកនូវអ្វីដែលសិស្សបានរៀននៅសប្តាហ៍នេះ: ដោយការអញ្ជើញពួកគេមកបំពេញនៅក្នុងចន្លោះទទេនេះ ។ ប្រសិនបើពួកគេត្រូវការជំនួយ សូមឲ្យពួកគេអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៨៨:១១៨ ។ សូមសួរពួកគេថា តើវាមានន័យយ៉ាងណា ដើម្បីស្វែងរកការរៀនសូត្រ ដោយសារការសិក្សា និង ដោយសារសេចក្តីជំនឿផង ។ នៅពេលអ្នកពិភាក្សារឿងនេះ សូមប្រាកដថាពួកគេយល់ថា **ការរៀនសូត្រ ដោយសារការសិក្សា និង ដោយសារសេចក្តីជំនឿផង តម្រូវឲ្យមានការខិតខំប្រឹងប្រែងផ្ទាល់ខ្លួន ។**

ដើម្បីជួយសិស្សយល់ថា ហេតុអ្វីបានជាការខិតខំប្រឹងប្រែង និង ការងារតម្រូវឲ្យមាន ក្នុងការរៀនសូត្រដំណឹងល្អ សូមឲ្យសិស្សម្នាក់អានការពន្យល់ខាងក្រោមដោយ អែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមអញ្ជើញសិស្សស្តាប់ ហើយរកនូវអ្វីដែលកើតឡើងនៅពេលយើងដាក់ការខិតខំ ក្នុងការរៀនសូត្រដោយព្រះវិញ្ញាណ ។

« អ្នករៀនម្នាក់ ដែលអនុវត្តសិទ្ធិជ្រើសរើសដោយការធ្វើ ស្របតាមគោលការណ៍ត្រឹមត្រូវ បានបើកដួងចិត្តរបស់គាត់ ចំពោះព្រះវិញ្ញាណបរិសុទ្ធ ហើយអញ្ជើញការបង្រៀនរបស់ទ្រង់ ការថ្លែងពីព្រះចេស្តា និង ការបញ្ជាក់ជាសាក្សី ។ ការរៀនសូត្រដោយសារសេចក្តីជំនឿ ត្រូវការការបន្ថែមខាងវិញ្ញាណ ខាងអារម្មណ៍ និង ខាងរាងកាយ ហើយមិនមែនគ្រាន់តែការទទួលដោយអកម្មនោះទេ » ។ (« ស្វែងរកការរៀនសូត្រដោយសារសេចក្តីជំនឿ » *Ensign* ខែ កញ្ញា ឆ្នាំ ២០០៧ ទំព័រ ៦៤) ។

សួរសិស្សថា ៖ តើអ្វីដែល អែលឌើរ បែដណា បាននិយាយ នឹងកើតឡើងចំពោះអ្នករៀន ដែលដាក់ការខិតខំក្នុងការរៀនសូត្រដោយវិញ្ញាណទេ ?

សូមអញ្ជើញសិស្សឲ្យចែកចាយនូវបទពិសោធន៍ ដែលពួកគេបានមាន នៅពេលដែលពួកគេបានខិតខំយ៉ាងពិសេសមួយខាងវិញ្ញាណ និង មានអារម្មណ៍ពីការកើនឡើងនៃភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ជាលទ្ធផលមួយ ។ អ្នកគប្បីបន្ថែមទីបន្ទាល់របស់អ្នកថា **ការខិតខំរបស់យើងចំពោះការសិក្សាដំណឹងល្អដោយ ការអធិស្ឋាន នឹងអញ្ជើញព្រះវិញ្ញាណបរិសុទ្ធទៅក្នុងដំណើរការរៀនសូត្រនេះ ។**

សូមសួរសិស្សថា ៖ តើរឿងជាក់លាក់អ្វីខ្លះ ដែលអ្នកអាចធ្វើនៅក្នុងឆ្នាំនេះ ដើម្បី « ស្វែងរកការរៀនសូត្រ . . . ដោយសារការសិក្សា និង ដោយសារសេចក្តីជំនឿផង » ?

ផែនការសង្គ្រោះ

សូមរំឭកនូវឈ្មោះផ្សេងៗនៃផែនការសង្គ្រោះ ដោយអញ្ជើញសិស្សឲ្យសរសេរនៅលើក្តារខៀននូវឈ្មោះដែលពួកគេបានកត់ត្រាទុកក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីរបស់ពួកគេ សម្រាប់ជាកិច្ចការ ១ នៃមេរៀនថ្ងៃទី ២ របស់ពួកគេ ។ ប្រសិនបើពួកគេត្រូវការជំនួយ សូមឲ្យពួកគេបើកទៅទំព័រឆ្លើយតប នៅក្នុងការណែនាំការសិក្សារបស់ពួកគេ ។

អ្នកគប្បីសួរថា ៖ តើឈ្មោះទាំងនេះ បង្រៀនដល់អ្នកអំពីគោលបំណងនៃផែនការសង្គ្រោះអ្វីខ្លះ ? (ផែនការរបស់ព្រះវរបិតាសួគ៌ ត្រូវបានរៀបចំឡើងដើម្បីនាំកូនចៅរបស់ទ្រង់ទៅកាន់ការសង្គ្រោះ និង សុភមង្គលដ៏នៅអស់កល្បជានិច្ច) ។

សូមពន្យល់ថា នឹងមាននូវឱកាសជាច្រើនពេញមួយឆ្នាំ ដើម្បីរៀនពីរបៀបដែលសេចក្តីពិតដែលយើងរៀនពីព្រះគម្ពីរមរមន ត្រូវនឹងផែនការនៃសុភមង្គលរបស់ព្រះវរបិតាសួគ៌ ។ អ្នកគប្បីសុំឲ្យសិស្សរកមើល និង គូសចំណាំនៅក្នុងគោលការណ៍ព្រះគម្ពីររបស់ពួកគេ ដែលទាក់ទងនឹងផែនការសង្គ្រោះ នៅពេលពួកគេសិក្សាឆ្នាំនេះ ។ សូមគិតពីការចែកនូវឧទាហរណ៍ពីរបី នូវអ្វីដែលពួកគេអាចរក នៅពេលពួកគេសិក្សា ។ សូមលើកទឹកចិត្តសិស្សឲ្យចែកចាយការរកឃើញរបស់ពួកគេជាមួយនឹងថ្នាក់ អំឡុងពេលឆ្នាំនេះ ។

ទំព័រចំណងជើង សេចក្តីផ្តើម និង ទីបន្ទាល់នៃសាក្សីទាំងឡាយ

សូមអញ្ជើញសិស្សឲ្យចូលរួមនៅក្នុងការដើរតួសម្តែង ដោយការស្រមៃថា ពួកគេនឹងឲ្យព្រះគម្ពីរមរមនមួយច្បាប់ ទៅនរណាម្នាក់ដែលមិនមែនជាសមាជិកនៃសាសនាចក្រ ។

សូមបែងចែកថ្នាក់ជាពីក្រុម ហើយឲ្យក្រុមមួយៗ រៀបចំសម្រាប់ការដើរតួសម្តែង ដោយការពិភាក្សាពីសំណួរ ដែលដាក់ឲ្យទៅក្រុមរបស់ពួកគេ ។ វាប្រហែលជួយច្រើន បើសរសេរសំណួរទាំងនេះ នៅលើក្តារខៀន មុនចាប់ផ្តើមថ្នាក់ ឬ ចែកឲ្យសិស្សម្នាក់ ៗ នូវក្រដាសសំណួរមួយ ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើល និង គូសចំណាំនូវព័ត៌មានដែលពួកគេមានអារម្មណ៍ថានឹងសំខាន់ដើម្បីចែកចាយ នៅពេលបង្រៀនអំពីព្រះគម្ពីរមរមន ។

សំណួរសម្រាប់ក្រុមទី ១ ៖

១. តើព្រះគម្ពីរមរមនគឺជាអ្វី ? (សូមមើលបឋកថា កថាខណ្ឌ ១–៣) ។

២. តើគោលបំណងនៃព្រះគម្ពីរមរមនគឺជាអ្វី ? (សូមមើលទំព័រចំណងជើង កថាខណ្ឌ ២) ។

៣. តើពរជ័យអ្វី ដែលមកពីការរស់នៅតាមគំនិត ឬ គោលការណ៍ដែលព្រះគម្ពីរមរមនបានបង្រៀន ? (សូមមើលបុព្វកថា កថាខណ្ឌ ៦) ។

សំណួរសម្រាប់ក្រុមទី ២ ៖

១. តើព្រះគម្ពីរមរមនបានចេញមកដោយរបៀបណា ? (សូមមើលបុព្វកថា កថាខណ្ឌ ៤–៥) ។

២. តើយើងអាចដឹងថា ព្រះគម្ពីរមរមនពិតដោយរបៀបណា ? (សូមមើលបុព្វកថា កថាខណ្ឌ ៨) ។

៣. តើមានអ្វីទៀត ដែលយើងអាចដឹងដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ? (សូមមើលបុព្វកថា កថាខណ្ឌចុងក្រោយគេ) ។

ក្រោយពីឲ្យពេលសិស្សរៀបចំរួចហើយ សូមជ្រើសរើសសិស្សម្នាក់ឲ្យតំណាង មនុស្សម្នាក់ដែលមិនមែនជាសមាជិកនៃសាសនាចក្រ ។ សុំអ្នកស្ម័គ្រចិត្តម្នាក់ពីក្រុមមួយៗ ដើម្បីជូនព្រះគម្ពីរមរមនមួយក្បាលទៅបុគ្គលនោះ ។ សូមលើកទឹកចិត្តសិស្សឲ្យប្រើចម្លើយនឹងសំណួរដែលក្រុមរបស់ពួកគេបានសិក្សា ដើម្បីបង្រៀនសិស្សទីមួយ អំពីព្រះគម្ពីរមរមន ។

នៅពេលពួកគេបញ្ចប់ការដើរតួសម្តែងរបស់ពួកគេ សូមសួរសិស្សក្នុងថ្នាក់ថា តើព័ត៌មានបន្ថែមអ្វីដែលពួកគេអាចចែកចាយ ប្រសិនបើពួកគេជាមនុស្សដែលឲ្យព្រះគម្ពីរមរមនមួយក្បាលនោះ ។ អ្នកក៏គប្បីសួរថា ៖ តើអ្នកបានរៀន ឬ ចាំអ្វីអំពីព្រះគម្ពីរមរមន អំឡុងពេលសកម្មភាពនេះ ?

នៅពេលសិស្សឆ្លើយតប សូមប្រាកដថា ពួកគេយល់ថា **ព្រះគម្ពីរមរមន គឺជាសាក្សីមួយថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។** សូមបញ្ជាក់ពីសារៈសំខាន់នៃការយកចិត្តទុកដាក់លើរបៀបដែលព្រះគម្ពីរមរមន ថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ។ បន្ថែមលើនេះ សូមពន្យល់ថា ការសិក្សាព្រះគម្ពីរមរមន នឹងជួយពួកគេឲ្យយល់ពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ហើយពង្រឹងទីបន្ទាល់របស់ពួកគេនៃសាសនាចក្ររបស់ទ្រង់ ។

សូមរំឭកដល់សិស្សថា **អ្នកសរសេរព្រះគម្ពីរមរមន បានឃើញជំនាន់របស់យើង ហើយបានសរសេរអ្វីដែលជាប្រយោជន៍ដល់យើងខ្លាំងបំផុត** (សូមមើល មរមន ៨:៣៥) ។

សូមសួរសិស្សថា ៖ តើអ្នកបានរៀនអ្វីខ្លះក្នុងសប្តាហ៍នេះ ដែលនឹងមានឥទ្ធិពលដល់របៀបដែលអ្នកសិក្សាព្រះគម្ពីរមរមន ?

សូមអញ្ជើញសិស្សបីបួននាក់ ឲ្យចែកចាយពីរបៀបដែលពួកគេគ្រោង ដើម្បីសម្រេចបាននូវការទទួលខុសត្រូវរបស់ពួកគេក្នុងការអានព្រះគម្ពីរមរមន អំឡុងពេលឆ្នាំសិក្សានេះ ។ សូមបញ្ចប់ដោយការចែកចាយអារម្មណ៍ និង ទីបន្ទាល់របស់អ្នកអំពីព្រះគម្ពីរមរមន និង ពីរបៀបដែលការសិក្សាព្រះគម្ពីរមរមន បានមានឥទ្ធិពលលើជីវិតរបស់អ្នក ។

ជំពូកបន្ទាប់ (នីហ្វៃទី១ ១–៦, ៩)

សូមសួរសិស្ស ប្រសិនបើពួកគេធ្លាប់បានដឹងថា អ្វីមួយត្រូវ ប៉ុន្តែពេលធ្វើវាទៅ ហាក់ដូចជាពិបាក ឬ ស្ទើរតែមិនអាចទៅរួច ។ សូមពន្យល់ថា នៅសប្តាហ៍ក្រោយ ពួកគេនឹងរកឃើញថា នីហ្វៃបានជួបប្រទះឧបសគ្គប្រភេទនោះ ហើយពួកគេនឹងរៀនពីរបៀបដែលគាត់ពឹងផ្អែកលើព្រះ ដើម្បីសម្រេចបាននូវអ្វីដែលមើលទៅហាក់ដូចជាមិនអាចធ្វើបាន ។

សេចក្តីផ្តើមអំពីគម្ពីរ

នីហ្វៃទីមួយ

ហេតុអ្វីសិក្សាគម្ពីរនេះ ?

នៅពេលសិស្សសិក្សា នីហ្វៃទី ១ ពួកគេនឹងរកឃើញថា « សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់ទាំងឡាយនៃព្រះអម្ចាស់ មានមកលើជនទាំងអស់ណាដែលព្រះទ្រង់បានជ្រើស ដោយសារសេចក្តីជំនឿរបស់ពួកគេ ដើម្បីធ្វើឲ្យគេខ្លាំងពូកែ » (នីហ្វៃទី ១ ១:២០) ។ ពួកគេក៏នឹងរៀនបានថា ព្រះមានព្រះទ័យចង់ប្រទានពរដល់កូនចៅរបស់ទ្រង់ ។ លីហៃ និង ប្រជាជនរបស់គាត់បានមានបទពិសោធន៍ពីសេចក្តីមេត្តាករុណា និង ពរជ័យពីព្រះ ដោយសារពួកគេធ្វើតាមព្រះបញ្ញត្តិរបស់ទ្រង់ ។ លីហៃ និង នីហ្វៃ បានស្វែងរកការណែនាំពីព្រះ ហើយទទួលបានការណែនាំនោះតាមរយៈសុបិនការនិមិត្ត លីអាហូណា និង ការណែនាំនៃព្រះវិញ្ញាណបរិសុទ្ធ ។ នីហ្វៃបានទទួល និង កត់ត្រានូវការនិមិត្តដ៏ធំសម្បើមមួយ ពីប្រវត្តិសាស្ត្ររបស់ផែនដីដែលបានបង្ហាញគាត់ពីព្រះបញ្ញានៃព្រះចំពោះកាលកិច្ចការទាំងឡាយ ដូចជា ពិធីបុណ្យជ្រមុជទឹក ការបម្រើ និង ការឆ្កាងនៃព្រះយេស៊ូវគ្រីស្ទ ការបំផ្លាញនៃសាសន៍នីហ្វៃ និង ជំនាន់ចុងក្រោយ ។ ព្រះបានជួយនីហ្វៃ និង បងប្អូនប្រុសរបស់គាត់ ឲ្យទទួលបានផ្នាំងលង្ហិន ដូច្នេះពួកគេអាចមានព្រះគម្ពីរ ។ ទ្រង់ក៏បានជួយសង្គ្រោះលីហៃ និង ប្រជាជនរបស់គាត់ពីគ្រោះទុរភិក្សនៅឯទីរហោស្ថាន និង ការបំផ្លាញនៅលើមហាសមុទ្រ ដោយនាំពួកគេមកដែនដីសន្យាប្រកបដោយសុវត្ថិភាព ។ នៅពេលសិស្សសិក្សាពីបទពិសោធន៍របស់នីហ្វៃ និង លីហៃនៅក្នុងសៀវភៅនេះ ពួកអាចរៀនពីរបៀបដើម្បីស្វែងរក និង ទទួលបាននូវពរជ័យពីស្ថានសួគ៌។

តើនរណាបានសរសេរគម្ពីរនេះ ?

កូនប្រុសរបស់លីហៃ គឺនីហ្វៃ បានសរសេរសៀវភៅនេះ ដើម្បីឆ្លើយតបនឹងបទបញ្ញត្តិរបស់ព្រះអម្ចាស់ថា គាត់ត្រូវរក្សាទុកនូវកំណត់ត្រាមួយពីប្រជាជនរបស់គាត់ ។ នីហ្វៃ ប្រហែលជាបានកើតនៅក្នុង ឬ ជិតទីក្រុងយេរូសាឡិម ។ គាត់បានរស់នៅទីនោះ អំឡុងពេលការបម្រើរបស់ព្យាការីយេរេមា និង ដ្រេកាលនៃស្តេចសេដេគា ។ នីហ្វៃ បានស្វែងរកទីបន្ទាល់របស់គាត់អំពីពាក្យសម្តីរបស់ឪពុករបស់គាត់ ទាក់ទងនឹងការបំផ្លាញក្រុងយេរូសាឡិម និង តម្រូវការឲ្យគ្រួសាររបស់ពួកគេចាកចេញពីទីក្រុង ។ នៅពេលគាត់បានបន្តស្វែងរក និង ធ្វើតាមការទូន្មានរបស់ព្រះអម្ចាស់ នីហ្វៃបានក្លាយជាឧបករណ៍នៅក្នុងព្រះហស្តរបស់ព្រះ ។ គាត់បានធ្វើតាម ហើយត្រឡប់ទៅក្រុងយេរូសាឡិមជាមួយនឹងបងៗរបស់គាត់ចំនួនពីរលើក —លើកទីមួយដើម្បីទៅយកផ្នាំងលង្ហិន និង លើកក្រោយដើម្បីបញ្ចុះបញ្ចូលគ្រួសាររបស់អ៊ីសម៉ាអែល ឲ្យមកចូលរួមជាមួយនឹងគ្រួសាររបស់លីហៃនៅក្នុងទីរហោស្ថាន ។ ដោយមានជំនួយពីព្រះអម្ចាស់ នីហ្វៃបានសង់សំពៅ ដែលបានយកគ្រួសារគាត់ និង គ្រួសារផ្សេងទៀតឆ្លងកាត់មហាសមុទ្រទៅកាន់ដែនដីសន្យា ។ នៅពេលលីហៃ បានទទួលមរណភាព ព្រះអម្ចាស់បានជ្រើសរើសនីហ្វៃឲ្យក្លាយជាអ្នកដឹកនាំលើប្រជាជនរបស់គាត់ ។

តើគម្ពីរនេះត្រូវបានសរសេរទៅកាន់នរណា ហើយហេតុអ្វី ?

នីហ្វៃ មានគំនិតសរសេរសម្រាប់មនុស្សបីពួក ៖ កូនចៅរបស់ឪពុកគាត់ ពាស្ត្រក្នុងសេចក្តីសញ្ញារបស់ព្រះអម្ចាស់នៅក្នុងសម័យចុងក្រោយ និង ប្រជាជនទាំងអស់ដែលនៅក្នុងពិភពលោកនេះ (សូមមើល នីហ្វៃទី ២ ៣៣:៣, ១៣) ។ គាត់បានសរសេរដើម្បីបញ្ចុះបញ្ចូលមនុស្សទាំងអស់ឲ្យមករកព្រះយេស៊ូវគ្រីស្ទ ហើយបានសង្គ្រោះ (សូមមើល នីហ្វៃទី១ ៦:៤) ។

តើនៅពេលណា ហើយនៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរឡើង ?

នីហ្វៃ បានសរសេរដំណើររឿងដែលក្លាយជានីហ្វៃទី ១ ប្រហែលជា ៥៧០ ឆ្នាំ ម. គ. ស. —គឺ ៣០ ឆ្នាំក្រោយពីគាត់ និង គ្រួសារបានចាកចេញពីទីក្រុងយេរូសាឡិម (សូមមើល នីហ្វៃទី២ ៥:៣០) ។ គាត់បានសរសេរគម្ពីរនេះ នៅពេលគាត់ស្ថិតនៅដែនដីនីហ្វៃ ។

តើមានលក្ខណៈសម្គាល់អ្វីខ្លះនៃគម្ពីរនេះ ?

នីហ្វៃទី ១ រួមមានដំណើររឿងជាច្រើននៃការជួបជាមួយនឹងទេវតាក្នុងសុបិន ការនិមិត្ត និង ទទួលវិវរណៈផ្ទាល់ ។ ជំនួបទាំងនេះបង្ហាញថា ព្រះបង្រៀន ណែនាំ និង ការពារអ្នកដែលស្វែងរកទ្រង់ ៖

- នៅពេលដែលលីហៃកំពុងតែអធិស្ឋាន បង្គោលដែលមានភ្លើងឆេះមួយផុសចេញមក ហើយគាត់ឃើញ និង ឮរឿងរ៉ាវជាច្រើនដែលធ្វើឲ្យគាត់ញាប់ញ័រ (សូមមើល នីហ្វៃទី១ ១:៦–៧) ។
- លីហៃទទួលបាននូវការនិមិត្តមួយដែលគាត់បានឃើញព្រះ ហើយអានចេញពីសៀវភៅមួយពីការព្យាករណ៍នៃការបំផ្លាញក្រុងយេរូសាឡិម និង សេរីភាពនៃប្រជាជនរបស់ទីក្រុងនេះ (សូមមើល នីហ្វៃទី១ ១:៨–១៤) ។
- ព្រះអម្ចាស់បានដាក់បញ្ញត្តិដល់លីហៃ ឲ្យចាកចេញជាមួយនឹងគ្រួសាររបស់គាត់ទៅក្នុងទីរហោស្ថាន (សូមមើល នីហ្វៃទី១ ២:១–២) ។
- ព្រះអម្ចាស់ ទូន្មានលីហៃឲ្យបញ្ជូនកូនប្រុសរបស់គាត់ត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ ដើម្បីយកផ្នាំងលង្ហិន (សូមមើល នីហ្វៃទី ១ ៣:២–៤) ។
- ទេវតាមួយអង្គ បាននាំមកនៅពេលលេមិន និង លេមយួល កំពុងតែវាយនីហ្វៃ និង សាំ(សូមមើល នីហ្វៃទី១ ៣:២៩) ។
- ព្រះអម្ចាស់ដាក់បញ្ញត្តិដល់ នីហ្វៃ និង បងៗគាត់ ត្រូវត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ ដើម្បីយកអ៊ីសម៉ាអែល និង គ្រួសាររបស់គាត់ (សូមមើល នីហ្វៃទី ១ ៧:១–២) ។
- លីហៃ និង នីហ្វៃ ទទួលបានការនិមិត្តដែលរួមមានដើមឈើជីវិត ការប្រសូត ការបម្រើ និង ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ប្រវត្តិនៃដែនដីសន្យា ការស្តារឡើងវិញនៃដំណឹងល្អ និង វិបត្តិរវាងពួកអារក្ស និង សាសនាចក្រនៃកូនចៀមនៃព្រះ (សូមមើល នីហ្វៃទី ១ ៨; ១១–១៤) ។
- នីហ្វៃ បានឃើញពីរបៀបដើម្បីសង់សំពៅ ដែលនឹងនាំប្រជាជនរបស់គាត់ ទៅដែនដីសន្យា (សូមមើល នីហ្វៃទី ១ ១៨:១) ។

នីហ្វៃទី ១ មាននូវដំណើររឿងនៃប្រជាជនមួយក្រុមដែលបានធ្វើដំណើរទៅដែនដីសន្យា ។ ក្រោយមក ព្រះគម្ពីរមរមនដាក់ឈ្មោះក្រុមពីរផ្សេងទៀត ដែលបានធ្វើដំណើរឆ្លងសមុទ្រមកកាន់ដែនដីសន្យាដែរ ៖ ប្រជាជនម៉ូសាយ (សូមមើល អេមណៃ ១:១៤–១៧) និង ប្រជាជនយ៉ារេឌ (សូមមើល អេធើរ ៦:៤–១២) ។

សៀវភៅនីហ្វៃទី ១ ក៏បានណែនាំពីចំណុចសំខាន់ពីរ ៖ ដាវ ឡាបាន់ និង ត្រីវិស័យមួយ ឬ អ្នកនាំផ្លូវ ហៅថា លីអាហូណា (សូមមើល នីហ្វៃទី ១ ១៨:១២; អាលម៉ា ៣៧:៣៨) ។ តាមរយៈលីអាហូណា ព្រះអម្ចាស់បានណែនាំគ្រួសាររបស់លីហៃ ឆ្លងកាត់ទីរហោស្ថាន និង ឆ្លងកាត់មហាសមុទ្រ ។ ដាវ ឡាបាន់ បានផ្ទេរបន្តដល់ជំនាន់ជាច្រើន រហូតដល់ចុងបញ្ចប់នៃអារ្យធម៌របស់សាសន៍នីហ្វៃ ។ ទាំងលីអាហូណា និង ដាវ ឡាបាន់ បានកប់ជាមួយនឹងផ្នាំងមាស ហើយវាត្រូវបានបង្ហាញដល់ យ៉ូសែប ស៊្មីធ និង ពួកសាក្សីបីនាក់ (សូមមើល គ. និង ស. ១៧:១–២) ។

គម្រោង

នីហ្វៃទី១ ១–៧ លីហៃ ដឹកនាំគ្រួសាររបស់គាត់ទៅកាន់ទីរហោស្ថាន ។ កូនប្រុសរបស់គាត់ ធ្វើតាមការបញ្ជារបស់ព្រះអម្ចាស់ ហើយត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ និង យកផ្នាំងលង្ហិនមក រួចត្រឡប់ទៅវិញម្តងទៀត ដើម្បីបញ្ចុះបញ្ចូលអ៊ីសម៉ាអែល និង គ្រួសាររបស់គាត់ឲ្យចូលរួមជាមួយនឹងពួកគេនៅក្នុងទីរហោស្ថាន ។

នីហ្វៃទី១ ៨–១៥ លីហៃ និង នីហ្វៃ ម្នាក់ៗទទួលបានការនិមិត្តមួយនៃដើមឈើជីវិត ។ នីហ្វៃ ចាំអំពីការនិមិត្តរបស់គាត់អំពីការបម្រើរបស់ព្រះអង្គសង្គ្រោះ និង ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលនាំទៅរកការស្តារឡើងវិញនៃដំណឹងល្អនៅក្នុងសម័យចុងក្រោយ ។

នីហ្វៃទី១ ១៦–១៨ ព្រះអម្ចាស់ ណែនាំលីហៃ និង គ្រួសាររបស់គាត់ពីការធ្វើដំណើររបស់ពួកគេឆ្លងកាត់ទីរហោស្ថាន និង ឆ្លងកាត់មហាសមុទ្រទៅកាន់ដែនដីសន្យា ។

នីហ្វៃទី១ ១៩–២២ នីហ្វៃ ព្យាករណ៍អំពីព្រះយេស៊ូវគ្រីស្ទ ហើយការខ្ចាត់ខ្ចាយ និង ការប្រមូលផ្តុំនៃអ៊ីស្រាអែល ។

នីហ្វៃទី១ ១

សេចក្តីផ្តើម

ព្រះគម្ពីរមរមន ចាប់ផ្តើមជាមួយនឹងលីហៃ ដែលបំពេញតួនាទីរបស់គាត់ជាព្យាការីម្នាក់ដោយស្មោះត្រង់ ។ លីហៃ គឺជាព្យាការីម្នាក់ក្នុងចំណោម « ព្យាការីជាច្រើន ដែលព្យាករណ៍ដល់ប្រជាជនថា ពួកគេត្រូវតែប្រែចិត្ត » (នីហ្វៃទី១ ១:៤) ។ នៅពេលគាត់បានព្យាករណ៍ពីការបំផ្លាញនៃទីក្រុងយេរូសាឡិម និង បានថ្លែងទីបន្ទាល់អំពីការប្រោសលោះ តាមរយៈព្រះមែស៊ី នោះមនុស្សជាច្រើន បានចំអកឡកឡឺយដាក់គាត់ និង ចង់សម្លាប់គាត់ ថែមទៀតផង ។ ទោះជាយ៉ាងណាក៏ដោយ លីហៃមានសេចក្តីរីករាយនៅក្នុងសេចក្តីមេត្តាករុណា និង អំណាចនៃការរំដោះរបស់ព្រះអម្ចាស់ ។ នៅពេលសិស្សរៀនអំពីការបម្រើរបស់លីហៃ នោះពួកគេកាន់តែយល់ដឹងថែមទៀតពីតួនាទីរបស់ព្យាការីសព្វថ្ងៃនេះ ។ នៅពេលពួកគេស្វែងរកកស្តុតាងនៃសេចក្តីមេត្តាករុណារបស់ព្រះ និង ចំណាប់អារម្មណ៍នៅក្នុងជីវិតរបស់ពួកគេ នោះទំនាក់ទំនងរបស់ពួកគេជាមួយនឹងទ្រង់នឹងកាន់តែស្និតរមួត ។

យោបល់សម្រាប់ការបង្រៀន

ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ

អ្នកអាចជួយសិស្សឲ្យបំពេញតួនាទីរបស់ពួកគេ នៅក្នុងដំណើរការរៀនដោយការលើកទឹកចិត្តពួកគេឲ្យសិក្សាព្រះគម្ពីរមរមនប្រចាំថ្ងៃ ។ សូមគិតដោយការអធិស្ឋានពីរបៀបដើម្បីជួយពួកគេឲ្យអភិវឌ្ឍទម្លាប់នៃការសិក្សាព្រះគម្ពីរប្រចាំថ្ងៃពេញមួយឆ្នាំ ។ ឃុរ។ម្តង អ្នកអាចចែកចាយទីបន្ទាល់របស់អ្នកអំពីពរជ័យនៃការសិក្សាព្រះគម្ពីរមរមនប្រចាំថ្ងៃ ។

នីហ្វៃទី១ ១:១–៣

នីហ្វៃចាប់ផ្តើមកំណត់ត្រារបស់គាត់

សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ១:១–៣ ដោយស្ងាត់ៗ ។ សុំឲ្យពួកគេស្វែងរកថា ហេតុអ្វីបានជានីហ្វៃសរសេរកំណត់ត្រារបស់គាត់ ។

- តើនីហ្វៃបានផ្តល់ហេតុផលអ្វីខ្លះចំពោះការកត់ត្រានៃបទពិសោធន៍របស់គាត់នេះ ?
- ហេតុអ្វីបានជាអ្នកគិតថា នីហ្វៃមានអារម្មណ៍ថា គាត់ជា « សំណាប់ដ៏ខ្លាំងរបស់ព្រះអម្ចាស់ » ទោះបីជាគាត់ទទួលរងនូវ « ការទុក្ខវេទនាទាំងនោះជាច្រើន » ក៏ដោយ ?

នីហ្វៃ១ ១:៤–២០

លីហៃ ទទួលបានការនិមិត្តមួយ ហើយព្រមានដល់ប្រជាជនថា យេរូសាឡិមនឹងត្រូវបានបំផ្លាញ ។

សូមអញ្ជើញសិស្សឲ្យគិតពីពេលមួយ នៅពេលឪពុកម្តាយរបស់ពួកគេព្រមានពួកគេពីគ្រោះថ្នាក់ ។

- ហេតុអ្វីបានជាឪពុកម្តាយរបស់អ្នក ព្រមានអ្នកពីគ្រោះថ្នាក់នេះ ?
- តើព្រះវរបិតាសួគ៌ ព្រមានកូនចៅរបស់ទ្រង់ដោយរបៀបណា ?

សូមពន្យល់ថា ខ្សែរឿងទីមួយនៅក្នុងព្រះគម្ពីរមរមន ចាប់ផ្តើមនៅពេលមួយ ពេលមនុស្សជាច្រើននៅក្នុងទីក្រុងយេរូសាឡិម ជាមនុស្សទុច្ចរិត ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១:៤ ។ សុំឲ្យសិស្សក្នុងថ្នាក់ស្វែងរករបៀបដែលព្រះអម្ចាស់ ព្រមានដល់ប្រជាជននៅក្នុងទីក្រុងយេរូសាឡិម ។

សូមពន្យល់ថា ឪពុករបស់នីហ្វៃ គឺលីហៃ បានចូលរួមនឹង « ព្យាការីជាច្រើន » ដែលបាននិយាយនៅក្នុងខគម្ពីរនេះ ។ គាត់បានព្រមានប្រជាជនថា ពួកគេត្រូវតែប្រែចិត្ត ។ ដើម្បីជួយសិស្សស្វែងរកនូវការព្រមាន និង ការបង្រៀនទាំងឡាយរបស់លីហៃ សូមរៀបចំសិស្សជាគូៗ ហើយគូនីមួយៗត្រូវអាន នីហ្វៃទី១ ១:៥–១៣ ។ សុំឲ្យពួកគេស្វែងរកអ្វីដែលលីហៃ បានឃើញនៅក្នុងការនិមិត្ត ដោយការគូសចំណាំព្រះគម្ពីររបស់ពួកគេ ឬ ការធ្វើបញ្ជីមួយនៅលើក្រដាស ។ ផ្តល់ពេលពីរបីនាទីដល់ដៃគូទាំងអស់ ដើម្បីពិភាក្សាពីសំណួរដូចខាងក្រោម ។ (អ្នកអាចសរសេរសំណួរនេះនៅលើក្តារខៀន) ។

- តើអ្នកមានអារម្មណ៍ដូចម្តេច ប្រសិនបើអ្នកបានឃើញការនិមិត្តថា ទីក្រុងរបស់អ្នកនឹងត្រូវបានបំផ្លាញ ?

បន្ទាប់ពីសកម្មភាព សូមអញ្ជើញសិស្សឲ្យមើល នីហ្វៃទី១ ១:១៥ ដោយស្ងាត់ៗ ដើម្បីស្វែងរកអារម្មណ៍របស់លីហៃ ក្រោយពីឃើញការនិមិត្តនេះ ។

- តើចម្លើយរបស់លីហៃ ចំពោះរឿងទាំងឡាយដែលគាត់បានឃើញមានអ្វីខ្លះ ?

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១: ១៤–១៥ ឲ្យឮៗ ។ សូមលើកទឹកចិត្តសិស្សទាំងឡាយឲ្យរកមើលហេតុផលថា ហេតុអ្វីបានជាលីហៃមានសេចក្តីរីករាយ ។ (អ្នកអាចត្រូវពន្យល់ថា ទោះបីជាលីហៃ បានដឹងថាទីក្រុងយេរូសាឡិមនឹងត្រូវបានបំផ្លាញបង់ក៏ដោយ ក៏គាត់បានឃើញថា អ្នកដែលទុកចិត្តលើព្រះនឹងមិនត្រូវស្លាប់នោះទេ) ។

- តើនៅពេលណាដែលអ្នកអាចសរសើរដល់ព្រះ ទោះបីជាអំឡុងពេលពិបាកយ៉ាងណានៅក្នុងជីវិតរបស់អ្នកក៏ដោយនោះ ?
- តើពរជ័យណាខ្លះ ដែលបានស្គាល់ថាជា « សេចក្តីល្អ និង សេចក្តីមេត្តាករុណា » របស់ព្រះ អំឡុងពេលលំបាក ?

សូមឲ្យសិស្សអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមឮៗ ៖

« ដូចជាព្យាការីពីបុរាណដែរ ព្យាការីបច្ចុប្បន្ននេះ ថ្លែងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ និង បង្រៀនដំណឹងល្អរបស់ទ្រង់ ។ ពួកគេផ្សព្វផ្សាយអំពីព្រះរាជបំណង និង បុគ្គលិកលក្ខណៈពិតរបស់ព្រះ ។ ពួកគាត់និយាយដោយក្លាហាន និង ច្បាស់ៗ ដោយចុះចូលនឹងអំពើបាប ហើយព្រមានដល់លទ្ធផលរបស់អំពើបាប ។ ពេលខ្លះ ពួកគាត់អាចត្រូវបានបំផុសគំនិតឲ្យព្យាករណ៍ពីព្រឹត្តិការណ៍ដែលកើតឡើងនៅពេលអនាគតសម្រាប់ជាប្រយោជន៍ដល់យើង » (*ពិតចំពោះសេចក្តីជំនឿ ៖ សេចក្តីយោងដំណឹងល្អ* ២០០៤ ទំព័រ ១២៩) ។

សូមបញ្ជាក់ថា លីហៃគឺជាគំរូមួយនៃសេចក្តីពិតដែល **ព្យាការីបានព្រមានទាស់នឹងអំពើបាប និង បង្រៀនពីសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវគ្រីស្ទ ។** (អ្នកអាចសរសេរសេចក្តីពិតនេះ នៅលើក្តារខៀន) ។

សូមឲ្យសិស្សអាន នីហ្វៃទី១ ១:១៩–២០ ។

- តើលីហៃបង្រៀនអ្វីខ្លះ ?
- តើប្រជាជនបានឆ្លើយតបនឹងការបង្រៀនរបស់លីហៃយ៉ាងដូចម្តេច ?
- ហេតុអ្វីក៏ប្រជាជនខ្លះ នៅក្នុងជំនាន់របស់យើង បដិសេធសារលិខិតមកពីព្យាការីរបស់ព្រះយ៉ាងដូច្នោះ ?
- តើអ្នកត្រូវបានប្រទានពរ ឬ បានការពារ ដោយសារអ្នកធ្វើតាមព្យាការីនោះ នៅពេលណាខ្លះ ?

ការរកមើលឃ្លាគន្លឹះ

របៀបមួយដើម្បីជួយសិស្ស ឲ្យទទួលបានបទពិសោធន៍កាន់តែប្រសើរ ក្នុងការអានព្រះគម្ពីរផ្ទាល់ខ្លួនប្រចាំថ្ងៃរបស់ពួកគេ គឺត្រូវបង្រៀនពួកគេឲ្យរកមើលឃ្លាគន្លឹះ ។ អ្នកសរសេរព្រះគម្ពីរមេរន ឧស្សាហ៍ប្រើឃ្លាគន្លឹះដើម្បីបញ្ជាក់លើមេរៀនដែលពួកគេព្យាយាមបង្ហាញ ឬ ដើម្បីសង្ខេបគោលការណ៍ដែលពួកគេបានបង្រៀន ឃ្លាដូចជា « ខ្ញុំនឹងបង្ហាញដល់អ្នកនូវ » « ម្ល៉ោះហើយ យើងឃើញថា » និង « ខ្ញុំនិយាយទៅអ្នករាល់គ្នា » ។ សូមលើកទឹកចិត្តសិស្សឲ្យយកចិត្តទុកដាក់លើមេរៀនណា ដែលមានឃ្លាបែបនេះ ។

នីហ្វៃទី១ ១:២០

នីហ្វៃថ្លែងទីបន្ទាល់អំពីសេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់

បង្ហាញថា នៅក្នុងប្រយោគទីពីរនៃ នីហ្វៃទី១ ១:២០ នីហ្វៃបានបកស្រាយដំណើររឿងរបស់គាត់ ដើម្បីចែកចាយសារលិខិតមួយជាមួយនឹងអ្នកដែលអានពាក្យសម្តីរបស់គាត់ ។ សូមឲ្យសិស្សអាន នីហ្វៃទី១ ១:២០ រៀងៗខ្លួន ដោយរកមើលនូវសារលិខិតដែលនីហ្វៃចង់ឲ្យយើងឃើញ ។ នៅពេលគេត្រូវការ សូមដឹកនាំចំណាប់អារម្មណ៍របស់ពួកគេលើឃ្លាដែលនីហ្វៃបានប្រើ ដើម្បីណែនាំសារលិខិតរបស់គាត់ (« ខ្ញុំ នីហ្វៃ នឹងបង្ហាញដល់អ្នកនូវ . . . ») ។

- តើការយកចិត្តទុកដាក់ខ្លាំងលើឃ្លាប្រភេទនេះ អាចជួយអ្នកនៅក្នុងការសិក្សាផ្ទាល់ខ្លួនរបស់អ្នក ពេលអានព្រះគម្ពីរមរមនយ៉ាងដូចម្តេច ?
- តើនីហ្វៃចង់បង្ហាញដល់យើងអ្វីខ្លះ ?

សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ១:២០ ឮៗ ។ សូមអញ្ជើញសិស្សផ្សេងទៀតអាន ម៉ូរ៉ូណៃ ១០:៣ ។ សុំឲ្យសិស្ស រកមើលនូវចំណុចស្រដៀងគ្នានៅក្នុងខគម្ពីរទាំងពីរនេះ ។

- តើគំនិតដូចគ្នាអ្វីខ្លះ ដែលនីហ្វៃ និង ម៉ូរ៉ូណៃ ចង់ឲ្យអ្នកអានព្រះគម្ពីរមរមនកត់សម្គាល់ ?

សូមជួយសិស្សរកមើលគោលការណ៍នេះ ៖ **សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់ ពង្រឹកចំពោះអ្នកដែលអនុវត្តសេចក្តីជំនឿលើទ្រង់ ។** (អ្នកអាចសរសេរគោលការណ៍នេះ នៅលើក្តារខៀន) ។

ដើម្បីជួយសិស្សយល់ពីអ្វីទៅជា សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់ និង របៀបដើម្បីស្គាល់សេចក្តីនោះនៅក្នុងជីវិតរបស់ពួកគេ សូមចែកចាយនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយ អែលឌើរ ដាវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់ គឺជាពរជ័យ កម្លាំង ការការពារ ការធានា ការណែនាំ សេចក្តីសប្បុរស ការលួងលោម ការគាំទ្រ និង អំណោយទានខាងវិញ្ញាណផ្ទាល់ខ្លួន និង ជាបុគ្គលបំផុត ដែលយើងទទួលបានពី និង ដោយសារ និង តាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទ ។ . . .

« . . . សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់ មិនមែនកើតឡើងដោយព្រោះៗ ឬ គ្រាន់តែដោយចៃដន្យនោះទេ ។ ភាពស្មោះត្រង់ និង ការគោរពប្រតិបត្តិ ជួយយើងឲ្យទទួលបាននូវអំណោយទានដ៏សំខាន់ទាំងនេះ ហើយជាញឹកញាប់ ពេលវេលារបស់ព្រះអម្ចាស់ នឹងជួយយើងឲ្យស្គាល់អំណោយទានទាំងនោះ ។

« យើងមិនអាចបន្ទាបតម្លៃ ឬ មើលរំលងព្រះចេស្តានៃសេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់បានទេ » (« សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់ » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៥ ទំព័រ ៩៩–១០០) ។

- តើអែលឌើរ បែដណា បានពន្យល់ឃ្លា « សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់ » យ៉ាងដូចម្តេច ?
- តើគំរូនៃសេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់អ្វីខ្លះ ដែលអ្នកមាន ឬ នរណាម្នាក់ដែលអ្នកស្គាល់មាន ?

ក្រោយពីសិស្សមានពេលឆ្លើយតបចំពោះសំណួរទាំងនេះហើយ សូមអញ្ជើញពួកគេពិចារណាពីរបៀបដែលពួកគេអាចស្គាល់សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់កាន់តែច្បាស់ជាងមុន នៅក្នុងជីវិតរបស់ពួកគេ ។ សូមលើកទឹកចិត្តពួកគេឲ្យស្គាល់កាន់តែច្បាស់ពីសេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់ ដែលបានវាតទីលើពួកគេ ។ អ្នកអាចផ្តល់ជាយោបល់ថា ពួកគេគួរតែកត់ត្រានូវបទពិសោធន៍របស់ពួកគេជាមួយនឹងសេចក្តីមេត្តាករុណាដ៏ទន់ភ្លន់ នៅក្នុងសៀវភៅកំណត់ហេតុផ្ទាល់ខ្លួនរបស់ពួកគេ ។ សូមគិតពីការឲ្យពេលវេលាមួយដល់ពួកគេ ដើម្បីសរសេរនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់អំពីរបៀបមួយ ឬ ពីរដែលព្រះអម្ចាស់ បានផ្តល់សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ទ្រង់មកលើពួកគេក្នុងពេលថ្មីៗនេះ ។

សូមបញ្ចប់ដោយការច្រាប់ជាថ្មីពីទីបន្ទាល់របស់នីហ្វៃ នៅក្នុងនីហ្វៃទី១ ១:២០ ដែលទាក់ទងនឹងសេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់ ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីភាពពិតនៃពរជ័យ និង ការថែទាំដោយផ្ទាល់ខ្លួនពីព្រះអម្ចាស់ ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលគំរូនៃសេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់ នៅក្នុងជីវិតរបស់ពួកគេ និង នៅក្នុងព្រះគម្ពីរមរមន ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី១ ១:២ ។ « ភាសារបស់ពួកសាសន៍អេស៊ីព្ទ »

នីហ្វៃបាននិយាយថា គាត់បានកត់ត្រារំណត់ត្រារបស់គាត់ជា « ភាសារបស់ពួកសាសន៍អេស៊ីព្ទ » (នីហ្វៃទី១ ១:២) ។ ប្រហែលជា ៤៧០ ឆ្នាំក្រោយមក ស្តេចបេនយ៉ាមីន បានបង្រៀនកូនប្រុសរបស់គាត់ជា « ភាសានៃពួកសាសន៍អេស៊ីព្ទ » (ម៉ូសាយ ១:១–៤) ។ ពាក្យថា « អក្សរអេស៊ីព្ទកែទម្រង់ » លេចឡើងនៅក្នុង មរមន ៩:៣២ ។ ម៉ូរ៉ូណៃ បានបង្ហាញថា មកដល់ជំនាន់របស់គាត់ ប្រហែល ១០០០ ឆ្នាំ ពីជំនាន់របស់លីហៃ និង នីហ្វៃ ប្រជាជនបានផ្លាស់ប្តូរអក្សរអេ សីព្ទិង ភាសាហេព្រើរ ដែលលីហៃ និង នីហ្វៃ បានប្រើ ។

នីហ្វៃទី១ ១:៤ ។ « ព្យាការីជាច្រើន »

នីហ្វៃ បាននិយាយថា « ព្យាការីជាច្រើន » បានមកក្នុងចំណោមប្រជាជនក្នុងទីក្រុង យេរូសាឡិម ។ យើងស្គាល់ យេរេមា , អូបាឌា , ណាហ៊ូម , ហាបាគុក និង សេផានា គឺជាព្យាការីក្នុងសម័យកាលជាមួយគ្នា ទាំងអស់ ដែលបានថ្លែងទីបន្ទាល់នៅក្នុងនគរយូដា ។ យេរេមា ៣៥:១៥ មាននូវយោបល់ស្រដៀងគ្នាអំពីព្យាការីជាច្រើន ដែលត្រូវបានបញ្ជូនដោយព្រះអម្ចាស់ដើម្បីទៅព្រមានដល់ប្រជាជន (សូមមើលផងដែរ របាក្យស្រទី២ ៣៦:១៥–១៦) ។

យេរេមា គឺជាព្យាការីដ៏ខ្លាំងពូកែម្នាក់ នៅក្នុងជំនាន់របស់លីហៃ និង នីហ្វៃ ហើយត្រូវបានលើកឡើងនៅក្នុង នីហ្វៃទី១ ៥:១៣ និង ៧:១៤ ។ គាត់បានបម្រើដល់សាសន៍យូដាពីឆ្នាំ ៦២៦ ដល់ ៥៨៦ ឆ្នាំ ម. គ. ស. ។ មិនដូចជាលីហៃ យេរេមាដែលបានស្នាក់នៅក្នុងទីក្រុង យេរូសាឡិម និង បានបន្តហៅប្រជាជនឲ្យធ្វើការប្រែចិត្តឡើយ (សូមមើល វចនានុក្រម ព្រះគម្ពីរបរិសុទ្ធ « យេរេមា ») ។ ក្រោយពីលីហៃបានចាកចេញពីទីក្រុងយេរូសាឡិម យេរេមាត្រូវបានជាប់ក្នុងគុក ។ អំឡុងពេលនៅក្នុងគុក គាត់បានសរសេរសៀវភៅបរិទេវ ដែលគាត់បានទួញពីការបំផ្លាញនៃទីក្រុងយេរូសាឡិម និង ការពិតដែលប្រជាជនមិនបានប្រែចិត្ត ។

គំនិតបន្ថែមទាំងឡាយសម្រាប់ការបង្រៀន

នីហ្វៃ១ ១:២–៣, ២០ ។ ការកត់ត្រាពីសេចក្តីមេត្តាករុណាដ៏ទន់ភ្លន់នៅក្នុងជីវិតរបស់យើង

- តើអ្វីជាតម្លៃនៃការកត់ត្រាបទពិសោធន៍របស់អ្នក នៅក្នុងសៀវភៅសៀវភៅកំណត់ហេតុ ?

នីហ្វៃ បានថ្លែងទីបន្ទាល់អំពីសេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះ នៅក្នុងជីវិតរបស់គាត់ ។ គាត់បានបង្រៀនថា អស់អ្នកដែលមានសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ អាចទទួលបានពរជ័យបែបនោះ ។ ប្រធាន ហិនរី ប៊ី អារីរិង នៃគណៈប្រធានទីមួយ បានពិពណ៌នាពីពេលមួយ នៅពេលដែលគាត់ត្រូវបានបំផុសឲ្យសរសេរនូវកស្តុតាងនៃសេចក្តីល្អរបស់ព្រះចំពោះគ្រួសាររបស់គាត់ ។

« ខ្ញុំបានត្រឡប់មកផ្ទះវិញយប់ ដោយការធ្វើការងារមួយរបស់ព្រះវិហារ ។ វាងងឹតទៅហើយ ។ ឪពុកក្មេករបស់ខ្ញុំ ដែលបានរស់នៅក្បែរយើង បានធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល ពេលខ្ញុំដើរសំដៅទៅទ្វារមុខផ្ទះខ្ញុំ ។ គាត់កំពុងលីបំពង់ទុយូមួយបាច់ ដោយដើរយ៉ាងលឿន ហើយស្លៀកពាក់ខោអាវការងាររបស់គាត់ ។ ខ្ញុំដឹងថា គាត់កំពុងធ្វើប្រព័ន្ធបូមទឹកមួយពីស្ទឹងមួយនៅខាងក្រោមមកដាក់ដីរបស់យើង ។

« គាត់បានញញឹម និយាយយ៉ាងស្រទន់ ហើយបន្ទាប់មកប្រញាប់ដើរហួសខ្ញុំទៅកន្លែងងងឹតដើម្បីបន្តការងាររបស់គាត់ ។ ខ្ញុំបោះជំហានពីរបីជំហានទៀតសំដៅទៅផ្ទះ ដោយគិតអំពីអ្វីដែលគាត់កំពុងធ្វើសម្រាប់យើង ហើយពេលដែលខ្ញុំទៅដល់មាត់ទ្វារ ខ្ញុំឮនៅក្នុងគំនិតរបស់ខ្ញុំ —មិនមែនជាសំឡេងរបស់ខ្ញុំនោះទេ —ពាក្យទាំងនេះគឺ ៖ ‹ ខ្ញុំមិនបានឲ្យ បទពិសោធន៍ទាំងនេះដល់អ្នក សម្រាប់ខ្លួនអ្នកនោះទេ ។ សូមសរសេរវាទុក › ។

« ខ្ញុំបានចូលក្នុងផ្ទះ ។ ខ្ញុំមិនបានចូលសម្រាន្តនោះទេ ។ ទោះបីជាខ្ញុំនឿយហត់ក៏ដោយ ក៏ខ្ញុំយកក្រដាសមក ហើយក៏ចាប់ផ្តើមសរសេរ ។ ហើយនៅពេលដែលខ្ញុំបានធ្វើ ខ្ញុំបានយល់ពីសារលិខិតដែលខ្ញុំបានឮនៅក្នុងគំនិតរបស់ខ្ញុំ ។ ខ្ញុំត្រូវកត់ត្រាសម្រាប់កូនៗរបស់ខ្ញុំអាននៅថ្ងៃណាមួយនាពេលអនាគត ពីរបៀបដែលខ្ញុំឃើញពរជ័យពីព្រះហស្តរបស់ព្រះចំពោះគ្រួសាររបស់យើង ។ . . .

« ខ្ញុំបានសរសេរពីរបីបន្ទាត់រាល់ថ្ងៃ អស់រាប់ឆ្នាំ ។ ខ្ញុំមិនដែលរំលងមួយថ្ងៃណាឡើយ មិនថាខ្ញុំនឿយហត់ប៉ុណ្ណា ឬ ថាវាព្រលឹមខ្លាំងយ៉ាងណាឡើយ ក៏ខ្ញុំនៅតែចាប់ផ្តើមថ្ងៃបន្ទាប់ដដែល ។ ពីមុនខ្ញុំសរសេរ ខ្ញុំសញ្ជឹងគិតពីសំណួរនេះសិន ៖ « តើខ្ញុំបានឃើញព្រះហស្តរបស់ព្រះ ឈោងមកប៉ះយើង ឬ កូនៗរបស់យើង ឬ គ្រួសាររបស់យើងថ្ងៃនេះទេ ? នៅពេលដែលខ្ញុំខំព្យាយាមធ្វើដូច្នេះ អ្វីមួយបានចាប់ផ្តើមកើតឡើង ។ នៅពេលខ្ញុំគិតពីថ្ងៃនេះ ខ្ញុំនឹងឃើញពីកស្តុតាងនៃអ្វីដែលព្រះបានធ្វើចំពោះយើងម្នាក់ក្នុងចំណោមយើង ដែលខ្ញុំមិនបានកត់សម្គាល់ពេលវេលាពេកពេលថ្ងៃនោះ » (« ឱ! សូមចងចាំ សូមចងចាំ » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៦៦–៦៧) ។

នីហ្វៃទី១ ១:៤–២០ ។ ភាពស្របគ្នារវាង លីហៃ និង យ៉ូសែប ស្ម៊ីធ

សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ១:៤–២០ដោយស្វែងរកព្រឹត្តិការណ៍ចម្បងពីរយ៉ាងពេលនេះ នៃជីវិតរបស់លីហៃ ។ បន្ទាប់មកសុំឲ្យពួកគេរាយការណ៍ឡើងវិញ យ៉ូសែប ស្ម៊ីធ —ប្រវត្តិ ១:១–៣៥ដោយរកមើលព្រឹត្តិការណ៍ចម្បងនៅក្នុងជីវិតរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ។ សុំឲ្យសិស្សរកមើលភាពស្របគ្នារវាងជីវិតរបស់លីហៃ និង ជីវិតរបស់យ៉ូសែប ស្ម៊ីធ ។ (ចម្លើយអាចរួមមាន ថាពួកគាត់ទាំងពីរនាក់បានស្វែងរកព្រះដោយការអធិស្ឋានដោយស្មោះស បានឃើញព្រះវរបិតា និង ព្រះរាជបុត្រា បានប្រាប់អ្នកដទៃអំពីការនិមិត្តរបស់ពួកគេ ត្រូវបដិសេធដោយមនុស្សជាច្រើន ត្រូវបានគំរាមកំហែងដល់ជីវិតរបស់ពួកគេ ត្រូវផ្លាស់ទីទៅកន្លែងថ្មីជាច្រើន ហើយបានដាក់ព្រះនៅលើអស់ទាំងទ្រព្យសម្បត្តិនៅលើពិភពលោក និង ការសរសើរពីពិភពលោក) ។

នីហ្វៃទី១ ២

សេចក្តីផ្តើម

ជំណើររឿងនៅក្នុង នីហ្វៃទី១ ជំពូក ២ បង្ហាញពីចម្លើយខុសគ្នាចំពោះព្រះបញ្ញត្តិមកពីព្រះអម្ចាស់ ។ លីហៃ បានធ្វើតាមបញ្ញត្តិរបស់ព្រះអម្ចាស់ ដើម្បីដឹកនាំគ្រួសាររបស់គាត់ទៅក្នុងទីរហោស្ថាន ។ ដោយប្រឈមមុខនឹងភាពលំបាកនៃបញ្ញត្តិនេះ លេមិន និង លេមយួលបានបះបោរ ។ ផ្ទុយទៅវិញ នីហ្វៃបានស្វែងរកសាក្សីបញ្ជាក់មួយ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ២:១–៧

ព្រះបានដាក់បញ្ញត្តិដល់លីហៃឲ្យចាកចេញទៅទីរហោស្ថាន

សុំឲ្យសិស្សគិតស្រមៃថា ឪពុកម្តាយរបស់ពួកគេបានប្រាប់ពួកគេថា គ្រួសាររបស់ពួកគេត្រូវតែចាកចេញពីផ្ទះរបស់គេនៅថ្ងៃស្អែក ដោយបោះបង់ចោលទ្រព្យសម្បត្តិស្ទើរតែទាំងអស់ ។ ពួកគេនឹងដើរទៅទីរហោស្ថាន ដោយគ្រាន់តែយកវត្ថុបម្រុងទុក ដែលពួកគេត្រូវការដើម្បីមានជីវិត ។

- តើអ្នកនឹងឆ្លើយតបយ៉ាងណា ?
- តើចម្លើយរបស់អ្នកផ្លាស់ប្តូរយ៉ាងណា ប្រសិនបើអ្នកដឹងថា ដាក់បញ្ញត្តិឲ្យចាកចេញទៅទីរហោស្ថានបានមកពីព្រះ ?

សូមអញ្ជើញឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ២:១–៦ ឲ្យឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ស្វែងរកហេតុផលដែលលីហៃ បានដឹកនាំគ្រួសាររបស់គាត់ទៅទីរហោស្ថាន ។

- តើព្រះបញ្ញត្តិអ្វី ដែលលីហៃបានទទួលមកពីព្រះអម្ចាស់ ? (សូមមើល នីហ្វៃទី១ ២:២) ។
- តើអ្នកអាចរៀនអ្វីពីការសម្រេចចិត្តរបស់លីហៃ អំពីអ្វីដែលត្រូវយក និង អ្វីដែលត្រូវទុកចោល ?

សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ២:៧ ឮៗ ។

- លីហៃ បានថ្លែងអំណរគុណដល់ព្រះអម្ចាស់ ក្រោយពីចាកចេញពីផ្ទះ និង ទ្រព្យសម្បត្តិរបស់គាត់ភ្លាម ។ តើយើងអាចរៀនអ្វីខ្លះពីការណ៍នេះ ?
- តើលីហៃមានអ្វី ដែលត្រូវមានអំណរគុណនោះ ?

សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមនេះ នៅលើក្តារខៀន ៖ ***នៅពេលដែលយើងស្មោះត្រង់ និង គោរពប្រតិបត្តិ ព្រះអម្ចាស់នឹងជួយយើងក្នុងពេលលំបាក ។***

- តើនៅពេលណាខ្លះ ដែលអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់បានជួយអ្នកក្នុងគ្រាលំបាក ? (សូមលើកទឹកចិត្តសិស្សឲ្យស្វែងរកការណែនាំពីព្រះវិញ្ញាណ ក្នុងការឆ្លើយតបនឹងសំណួរនេះ ។ ជួយពួកគេឲ្យយល់ថា ពួកគេមិនត្រូវការចែកចាយពីបទពិសោធន៍ដែលមានលក្ខណៈបុគ្គល ឬ ផ្ទាល់ខ្លួនពេកនោះទេ) ។

នីហ្វៃ១ ២:៨–១៥

លេមិន និង លេមយួល បានរអ៊ូរទាំទាស់នឹងឪពុករបស់ពួកគេ

សុំឲ្យសិស្ស សួរខ្លួនគេដោយស្ងាត់ៗ ថាតើពួកគេធ្លាប់មានរអ៊ូរទាំទេ ទាំងបញ្ចេញជាពាក្យសម្តី ឬ គិតក្នុងចិត្តក៏ដោយ អំពីព្រះបញ្ញត្តិមួយមកពីព្រះអម្ចាស់ ឬ អំពីសំណើរមួយមកពីឪពុកម្តាយ ឬ អ្នកដឹកនាំសាសនាចក្រ ។ សូមផ្តល់ពេលឲ្យគេដើម្បីគិតពីបទពិសោធន៍របស់ពួកគេ ។

- ហេតុអ្វីបានជាពេលខ្លះយើងរអ៊ូ នៅពេលយើងត្រូវបានប្រាប់ឲ្យធ្វើអ្វីមួយនោះ ?

សូមសរសេរ *ទន្លេ* និង *ច្រកភ្នំ* នៅលើក្តារខៀន ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ២:៨– ១០ ឲ្យឮៗ ។

- ហេតុអ្វីបានជាលីហៃ ចង់ឲ្យលេមិនក្លាយដូចជាទន្លេ ? ហេតុអ្វីបានជាគាត់ ចង់ឲ្យលេមយួលក្លាយដូចជាច្រកភ្នំ ? (អ្នកអាចសុំឲ្យសិស្សសរសេរចម្លើយរបស់ពួកគេ នៅលើក្តារខៀន ក្បែរពាក្យ *ទន្លេ* និង *ច្រកភ្នំ*) ។
- តើលីហៃព្យាយាមបង្រៀនលេមិន និង លេមយួលពីអ្វីខ្លះ ?

សុំឲ្យសិស្សអាន នីហ្វៃទី១ ២:១១–១៤ ដោយស្ងាត់ៗ។

- តើហេតុផលអ្វីខ្លះ ដែលលេមិន និង លេមយួល រអ៊ូរទាំទាស់នឹងឪពុករបស់ពួកគេ ?

- នៅក្នុង នីហ្វៃទី១ ២:១១ ពាក្យ *ការរីងទទឹង* សំដៅលើអំនួត ឬ ការចចេស ។ ហេតុអ្វីបានជាអារម្មណ៍អំនួត ពេលខ្លះនាំមនុស្សឲ្យអ៊ូដូច្នោះ ?
- ហេតុអ្វីបានជាអ្នកគិតថា ការអ៊ូ ពេលខ្លះចេញលទ្ធផល នៅពេលមនុស្សមិនយល់ពីទំនាក់ទំនងនៃព្រះ ?

សូមពន្យល់ថា ហេតុផលមួយ ដែលសាតាំងចង់ឲ្យយើងអ៊ូ គឺថា វាវាក់ងយើងពីការដើរតាមព្យាការីដែលនៅរស់ អ្នកដឹកនាំដែលទទួលការបំផុសផ្សេងទៀត និង ឪពុកម្តាយ ។ នៅផ្នែកមួយនៃការពិភាក្សារបស់អ្នក អ្នកអាចចែកចាយនូវប្រសាសន៍ដូចខាងក្រោម ដោយផ្អែកលើសេចក្តីថ្លែងការណ៍ ដោយអែលឌើរ អេច វ៉ូស ពីកមេន នៃក្រុមចិតសិបនាក់ថា ៖

« ការអ៊ូរទាំង រួមមាននូវជំហានបី ដែលជំហាននីមួយៗនាំទៅរកជំហានបន្ទាប់ទៀត នៅក្នុងផ្លូវទៅកាន់ការមិនគោរពប្រតិបត្តិ » ។ ទីមួយ មនុស្សចាប់ផ្តើមសួរ ។ ពួកគេសួរ « ដំបូងនៅក្នុងគំនិតផ្ទាល់របស់ពួកគេ » ហើយបន្ទាប់មក ពួកគេបណ្តុះសំណួរ « នៅក្នុងគំនិតរបស់អ្នកផ្សេងទៀត » ។ ទីពីរ អ្នកដែលរអ៊ូរទាំចាប់ផ្តើម « រកហេតុផល និង ដោះសារខ្លួនគេពីការធ្វើអ្វី ដែលពួកគេ ត្រូវ [បាន] បង្គាប់ឲ្យធ្វើ ។ . . . ហេតុដូច្នេះ ពួកគេដោះសារចំពោះការមិនគោរពប្រតិបត្តិ » ។ ការដោះសាររបស់ពួកគេ នាំទៅរកជំហានទីបី ៖ « ភាពខ្ជិលច្រអូសនៅក្នុងការធ្វើតាមព្រះបញ្ញត្តិរបស់លោកចៅហ្វាយ ។ . . .

« ខ្ញុំសូមអញ្ជើញឲ្យអ្នក ផ្តោតលើព្រះបញ្ញត្តិមកពីព្យាការីដែលនៅរស់ ដែលធ្វើឲ្យអ្នកខ្ជិលជាងគេបំផុត ។ តើអ្នកសួរ ថាតើព្រះបញ្ញត្តិនេះអនុវត្តបានចំពោះអ្នកដែរឬទេ ? តើអ្នកមានរកលេស ដោះសារនូវមូលហេតុបានជាអ្នកមិនអាចគោរពតាមព្រះបញ្ញត្តិនាពេលឥឡូវនេះទេ? តើអ្នកមានអារម្មណ៍ស្មុគស្មាញ ឬ ខឹងនឹងអ្នកដែលរំឭកអ្នកពីព្រះបញ្ញត្តិដែរឬទេ ? តើអ្នកមានខ្ជិលច្រអូសក្នុងការការក្សាព្រះបញ្ញត្តិដែរឬទេ ? សូមដឹងពីការបោកបញ្ឆោតនៃពួកសត្រូវ ។ សូមដឹងពីការអ៊ូរទាំ » (« សូមដឹងពីការអ៊ូរទាំ » *Ensign* ខែ វិច្ឆិកា ឆ្នាំ ២០០១ ទំព័រ ៨៥–៨៦) ។

សូមអញ្ជើញសិស្សឆ្លើយនូវសំណួរខាងក្រោម នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់ ៖

- តើអ្នកអាចធ្វើអ្វី ប្រសិនបើអ្នកឃើញថាខ្លួនអ្នក កំពុងស្ថិតក្នុងការអ៊ូរទាំអំពីព្យាការី និង ព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ?

នីហ្វៃ ២: ១៦–១៩

នីហ្វៃ ស្វែងរកចំណេះដឹងពីព្រះអម្ចាស់

សូមឲ្យសិស្សអាន និង សញ្ជឹងគិតពី នីហ្វៃ ២: ១៦ , ១៩ ដោយស្ងាត់ៗ។

- តើនីហ្វៃ ឆ្លើយតបនឹងសារលិខិតរបស់ឪពុករបស់គាត់យ៉ាងដូចម្តេច ?
- តើនៅពេលណាដែលអ្នកបានអំពាវនាវរកព្រះ និង មានអារម្មណ៍ថាដួងចិត្តរបស់អ្នកត្រូវបានបន្ទន់ ?

សូមផ្តល់ឱកាសដល់សិស្សដើម្បីប្រាប់អំពីពេលដែលព្រះអម្ចាស់ បានបន្ទន់ដួងចិត្តរបស់ពួកគេ (ប៉ុន្តែសូមរំឭកពួកគេថា ពួកគេមិនគួរមានអារម្មណ៍ថាត្រូវតែចែកចាយបទពិសោធន៍ដែលមានលក្ខណៈផ្ទាល់ខ្លួនពេកនោះទេ) ។ ជាងនេះទៅទៀត អ្នកអាចប្រាប់អំពីគ្រាមួយ នៅពេលដែលព្រះអម្ចាស់បានបន្ទន់ដួងចិត្តរបស់អ្នក ។ សូមបញ្ជាក់ដល់សិស្សថា **នៅពេលដែលយើងអំពាវនាវរកព្រះ ទ្រង់អាចបន្ទន់ដួងចិត្តរបស់យើងឲ្យជឿដល់ព្រះបន្ទូលរបស់ទ្រង់ ។**

សូមអាន នីហ្វៃទី១ ២:១៩ ឮៗ ។ សូមឲ្យសិស្សពន្យល់ដោសម្តីរបស់ខ្លួនគេ ពីអត្ថន័យនៃពាក្យ « យ៉ាងព្យាយាម » និង « ចិត្តសុភាពរាបសា » ។ សូមលើកទឹកចិត្តពួកគេឲ្យស្វែងរកព្រះអម្ចាស់ ដូចជានីហ្វៃបានធ្វើ ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ២:១៧–១៨ឮៗ ។

- តើគោលការណ៍អ្វីដែលយើងអាចរៀនពីចម្លើយខុសគ្នារបស់នីហ្វៃ សាំ លេមិន និង លេមយូល ?
- តើនៅពេលណាដែលពាក្យសម្តីរបស់សមាជិកគ្រួសារ ឬ មិត្តភក្តិណាម្នាក់ បានពង្រឹងសេចក្តីជំនឿរបស់អ្នក ដូចជាពាក្យសម្តីរបស់នីហ្វៃបានពង្រឹងដល់សេចក្តីជំនឿរបស់សាំ ?

នីហ្វៃ ២: ២០–២៤

អស់អ្នកដែលកាន់តាមព្រះបញ្ញត្តិទាំងឡាយនឹងចម្រើនឡើង

សូមឲ្យសិស្សអាន នីហ្វៃទី១ ២:២០–២១ ។ សូមអញ្ជើញពួកគេឲ្យរក ឬ គូសចំណាំនូវសេចក្តីសន្យា ដែលថា « ដរាបណាអ្នកកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង នោះអ្នកនឹងចម្រើនឡើង » ។ សូមពន្យល់ថា នៅពេលពួកគេសិក្សាព្រះគម្ពីរមរមន ពួកគេនឹងអានអំពីគំរូជាច្រើននៃសេចក្តីសន្យានេះ ដែលត្រូវបានបំពេញ ។

សូមគិតពីការចែកចាយនូវសេចក្តីថ្លែងការណ៍ខាងក្រោម ដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« ការប្រព្រឹត្តបត្តិ គឺជាក្រិត្យវិន័យទីមួយនៃស្ថានសួគ៌ ។ ការរីកចម្រើនទៅមុខទាំងអស់ ភាពឥតខ្ចោះទាំងអស់ សេចក្តីសង្គ្រោះទាំងអស់ ជំនឿស៊ប់ទាំងអស់ អ្វីៗទាំងអស់ ដែលត្រូវ និង យុត្តិធម៌ និង ពិត រឿងល្អៗទាំងអស់មកដល់អ្នកដែលរស់នៅតាមច្បាប់របស់ទ្រង់ ដែលអស់កល្បជានិច្ច ។ គ្មានអ្វី នៅក្នុងភាពអស់កល្បទាំងអស់ សំខាន់ជាងការកាន់តាមព្រះបញ្ញត្តិរបស់ព្រះនោះទេ » (*ព្រះវរមសីដែលបានសន្យា ៖ ការយាងមកលើកទីមួយនៃព្រះគ្រីស្ទ* [១៩៧៨], ១២៦) ។

សូមចែកចាយទីបន្ទាល់របស់អ្នកថា **ព្រះប្រទានពរដល់អស់អ្នកណាដែលគោរពប្រតិបត្តិតាម និង ស្មោះត្រង់ ។**ដូចជានីហ្វៃដែរ សិស្សអាចអភិវឌ្ឍនូវទំនុកចិត្តក្នុងការទទួលបាននូវការណែនាំមកពីព្រះអម្ចាស់ ។ សូមលើកទឹកចិត្តពួកគេឲ្យខិតខំព្យាយាមគោរពប្រតិបត្តិតាមច្រើនជាងនេះ និង ធ្វើតាមការណែនាំដែលពួកគេបានទទួលមកពីព្រះវិញ្ញាណបរិសុទ្ធ ។

សំណួរដែលនាំឲ្យមានការបំផុសគំនិត

ប្រធាន ហិនរី ប៊ី អារីង នៃគណៈប្រធានទីមួយ បានបង្រៀនថា សំណួរខ្លះ នាំឲ្យមានការបំផុសគំនិត ។ គាត់បានប្រឹក្សាដល់គ្រូបង្រៀនឲ្យសួរសំណួរ « ដែលនឹងនាំឲ្យបុគ្គលម្នាក់ៗ ស្វែងរកនូវការចងចាំរបស់ពួកគេអំពីអារម្មណ៍ទាំងឡាយ » ។ ការសួរសំណួរដែលអនុញ្ញាតឲ្យសិស្សគិតអំពីបទពិសោធន៍ពីអតីតកាល ជាជាងគ្រាន់តែចងចាំព័ត៌មាន អាចជួយពួកគេ អាចត្រូវបានបង្រៀនដោយព្រះវិញ្ញាណ ។ ប្រធានអារីង បាននិយាយថា ៖ « ង៉ង់ចាំដោយឈ្លាសវៃមួយស្របក់ មុនពេលហៅនរណាម្នាក់ឲ្យឆ្លើយ ។ ទោះបីជាអ្នកដែលមិននិយាយ ក៏គេនឹងកំពុងគិតអំពីបទពិសោធន៍ខាងវិញ្ញាណដែរ ។ នោះនឹងអញ្ជើញព្រះវិញ្ញាណបរិសុទ្ធ » (« ព្រះអម្ចាស់នឹងចម្រើនការប្រែតកាត់ » [សុន្ទរកថាថ្លែងទៅកាន់អ្នកអប់រំសាសនា CES នៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៨], ៦, si.lds.org) ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី១ ២:២–៦ ។ ផ្លូវដែលអាចធ្វើបានដោយ គ្រួសាររបស់លីហៃ

លីហៃ អាចត្រូវដឹកនាំគ្រួសាររបស់គាត់ទៅតាមសមុទ្រក្រហម នៅជិតឈូងសមុទ្រអាកាបា ប្រហែលជា ១៨០ ម៉ាយល៍ (២៩០ គីឡូម៉ែត្រ) ពីទីក្រុងយេរូសាឡិម ។ ការណ៍នេះ ត្រូវឲ្យធ្វើដំណើរកាត់តាមប្រទេសដ៏ក្តៅ និង សួតមួយ ដែលល្បីថាមានចោរវង់ចាំប្លន់អ្នកដំណើរ ដែលមិនបានរៀបចំស្រួលបួល ។ ក្រោយពីទៅដល់សមុទ្រក្រហម គ្រួសារនោះបានធ្វើដំណើរបីថ្ងៃទៀត មុនពេលបោះត្រសាលនៅឯច្រកភ្នំនៃទន្លេមួយ ។ ដំណើរមកពីទីក្រុងយេរូសាឡិម មកដល់ច្រកភ្នំនៃទន្លេនេះ អាចមានរយៈពេលប្រហែល ១៤ ថ្ងៃ ។ អ្នកអាចរំឭកសិស្សពីចម្ងាយ និង ពេលវេលាទាំងនេះ នៅពេលពួកគេអានអំពីនីហ្វៃ និង បងប្អូនប្រុសរបស់គាត់ ដែលធ្វើដំណើរមកកាន់ទីក្រុងយេរូសាឡិមវិញ ។

នីហ្វៃទី១ ២:៧ ការបង្ហាញការដឹងគុណដល់ព្រះអម្ចាស់

ការសរសើរពីលីហៃ ចំពោះការណែនាំ និង ការការពាររបស់ព្រះអម្ចាស់ ត្រូវបានបង្ហាញនៅក្នុង នីហ្វៃទី១ ២:៧ ៖ « គាត់បានសង់អាសនាមួយពីថ្ម និង បានថ្វាយដង្វាយដល់ព្រះអម្ចាស់ ហើយបានថ្លែងអំណរគុណដល់ព្រះអម្ចាស់ ជាព្រះរបស់យើង » ។ នេះគឺជាគំរូមួយក្នុងចំណោមគំរូជាច្រើន នៅក្នុងព្រះគម្ពីរមរមន នៅពេលដែលអ្នកធ្វើតាមដោយស្មោះត្រង់របស់ព្រះគ្រីស្ទ បានធ្វើយញ្ញបូជា និង ដង្វាយដុតដើម្បីបង្ហាញអំណរគុណដល់ព្រះ (សូមមើល ឧទាហរណ៍ នីហ្វៃទី១ ៧:២២ ; ម៉ូសាយ ២:៣ –៤) ។ ការបង្ហាញដោយស្មោះស្ម័គ្រនៃការដឹងគុណ និង ការគោរពតាមព្រះវរបិតាសួគ៌ គឺចាំបាច់ចំពោះកូនចៅរបស់ទ្រង់ទាំងអស់ ប្រសិនបើពួកគេចង់ឲ្យទ្រង់សប្បាយព្រះទ័យ (សូមមើល គ. និង ស. ៥៩:២១) ។

គំនិតបន្ថែមទាំងឡាយសម្រាប់ការបង្រៀន

នីហ្វៃទី១ ២:១–៣, ១៦–១៩ ។ ដួងចិត្តទន់ភ្លន់ និង វិវរណៈ

សូមរំឭកសិស្សថា នៅក្នុង នីហ្វៃទី១ ១ នីហ្វៃពិពណ៌នាពីវិវរណៈ ដែលលីហៃទទួលបានខណៈពេលដែលគាត់ « ស្តុងទៅក្នុងព្រះវិញ្ញាណ » (នីហ្វៃទី១ ១:៧) ។ នៅក្នុងការនិមិត្តនោះ លីហៃបានអានពីគម្ពីរមួយដែលមានការព្យាករណ៍ ហើយបានពោរពេញទៅដោយព្រះវិញ្ញាណ » (នីហ្វៃទី១ ១:១២) ។ នៅក្នុង នីហ្វៃទី១ ២ គោលគំនិតនៃវិវរណៈនៅបន្តនៅពេលដែលនីហ្វៃប្រាប់ពីឪពុករបស់គាត់ ដែលទទួលបាននូវការព្រមានមកពីព្រះអម្ចាស់នៅក្នុងការសុបិនមួយ (សូមមើល នីហ្វៃទី១ ២:១–៣) ។ នីហ្វៃក៏បានប្រាប់ពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់គាត់ ក្នុងការទទួលបាននូវវិវរណៈ និង ការធ្វើតាមសំឡេងនៃព្រះអម្ចាស់ ។

សូមបង្ហាញវត្ថុពីរ —វត្ថុមួយដែលទន់ និង ស្រូបទឹក (ដូចជាក្រណាត់មួយផ្ទាំង ឬ អេប៉ុងមួយ) និង មួយទៀតរឹង (ដូចជាថ្មមួយ) ។ បន្ទាប់មកសូមសួរសិស្សម្នាក់ឲ្យអាន នីហ្វៃទី១ ២:១៦– ១៩ ឲ្យឮៗ ។

- តើដួងចិត្តរបស់លីហៃ នីហ្វៃ និង សាំ ដូចជាវត្ថុទន់នេះ ដោយរបៀបណា ?
- តើដួងចិត្តរបស់លេមិន និង លេមយួល ដូចជាវត្ថុរឹងនេះ ដោយរបៀបណា ?
- តើលក្ខខណ្ឌខាងវិញ្ញាណនៃដួងចិត្តរបស់យើង មានឥទ្ធិពលយ៉ាងណា មកលើសមត្ថភាពរបស់យើងដើម្បីទទួលបាននូវវិវរណៈ ?

សូមជួយសិស្សឲ្យយល់ថា **ព្រះអម្ចាស់ បង្ហាញចំណេះដឹងដល់យើង នៅពេលដែលយើងស្វែងរកទ្រង់ដោយឧស្សាហ៍ព្យាយាម ។**នៅផ្នែកមួយនៃការពិភាក្សានេះ អ្នកអាចបែងចែកសិស្សជាដៃគូ ហើយឲ្យពួកគេអានចំណងជើងចូលថា « វិវរណៈ » នៅក្នុងវចនានុក្រមព្រះគម្ពីរបរិសុទ្ធ ។ សុំឲ្យពួកគេពិភាក្សាគ្នានូវសំណួរដូចខាងក្រោម ៖

- តើយើងអាចធ្វើអ្វីបានដើម្បីរៀបចំខ្លួនយើង ឲ្យទទួលបាននូវវិវរណៈពីព្រះអម្ចាស់ ?

នីហ្វៃទី១ ៣–៤

សេចក្តីផ្តើម

ព្រះអម្ចាស់បានដាក់បញ្ញត្តិដល់លីហៃ ឲ្យបញ្ជូនកូនប្រុសរបស់គាត់ត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ ដើម្បីទៅយកផ្នាំងលង្ហិនពីឡាបាន់ ។ លេមិន និង លេមយួល គិតថាពួកគេមិនអាចបំពេញតាមការបញ្ជានេះទេ ប៉ុន្តែនីហ្វៃបានមានសេចក្តីជំនឿថា ព្រះអម្ចាស់នឹងផ្តល់នូវមធ្យោបាយមួយសម្រាប់ពួកគេ ដើម្បីសម្រេចបាននូវអ្វីដែលទ្រង់ត្រូវការ ។ ថ្វីដ្បិតតែការដួបប្រទះនឹងការលំបាកដដែលៗក៏ដោយ ក៏នីហ្វៃនៅតែតស៊ូដោយកក្តីភាពក្នុងការធ្វើអ្វីដែលព្រះអម្ចាស់បានដាក់បញ្ញត្តិដល់គាត់ ។ ជាលទ្ធផល គាត់ត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ និង បានទទួលយកផ្នាំងនោះដោយជោគជ័យ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ៣:១–៩, ១៩–២០

កូនប្រុសរបស់លីហៃ ត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ ដើម្បីយកផ្នាំងលង្ហិន

សូមសរសេរនូវសេចក្តីថ្លែងការណ៍ខាងក្រោម នៅលើក្តារខៀន មុនពេលចាប់ផ្តើមការបង្រៀន ។ សុំឲ្យសិស្សជ្រើសរើសយកសេចក្តីថ្លែងការណ៍ដែលពិពណ៌នាពីរបៀបដែលពួកគេជឿថា ព្រះអម្ចាស់នឹងជួយយើង នៅពេលដែលទ្រង់ដាក់បញ្ញត្តិដល់យើងឲ្យធ្វើរឿងពិបាកនានា ។

នៅពេលអ្នកតស៊ូបំពេញតាមការបញ្ជាមួយ ឬ កិច្ចការពិបាកមួយមកពីព្រះអម្ចាស់ ទ្រង់នឹង ៖

ក. ផ្លាស់ប្តូរបញ្ញត្តិ ដើម្បីធ្វើឲ្យវាសាមញ្ញ និង ងាយស្រួលសម្រាប់អ្នកក្នុងការសម្រេចបាន ។

ខ. ប្រទានពរដល់ការខិតខំរបស់អ្នក ដោយការផ្តល់មធ្យោបាយមួយសម្រាប់អ្នក ដើម្បីបំពេញតាមការបញ្ជានោះ ទោះបីជាវាអាចនៅតែពិបាកក៏ដោយ ។

គ. ជ្រោមជ្រែង និង ធ្វើកិច្ចការទាំងអស់សម្រាប់អ្នក ។

ឃ. តម្រូវឲ្យអ្នកធ្វើវាទាំងអស់ ដោយខ្លួនអ្នកផ្ទាល់ ដោយគ្មានជំនួយអ្វីទាំងអស់ ។

សូមអញ្ជើញសិស្សពីរបីនាក់ ឲ្យចែកចាយចម្លើយដែលពួកគេបានជ្រើសរើស និង ហេតុផលរបស់ពួកគេក្នុងការរើសយកវា ។

សូមពន្យល់ថា មានរបៀបជាច្រើនដែលព្រះអម្ចាស់អាចប្រទានពរដល់អ្នកទាំងឡាយណាដែលតស៊ូ ដើម្បីបំពេញតាមការបញ្ជារបស់ទ្រង់ ។ នៅពេលសិស្សសិក្សាពីដំណើររឿងរបស់នីហ្វៃ នៅក្នុង នីហ្វៃទី១ ៣–៤សូមអញ្ជើញពួកគេ ឲ្យរកមើលគំរូនៃគោលការណ៍នេះ ។ សូមលើកទឹកចិត្តសិស្សដងដែរ ឲ្យកត់ចំណាំពីរបៀបដែលនីហ្វៃ និង បងប្អូនប្រុសរបស់គាត់ ឆ្លើយតបខុសគ្នាៗ ទៅនឹងឧបសគ្គទាំងឡាយ ។

សុំឲ្យសិស្សបីបួននាក់ ប្តូរវេនគ្នាអានឮៗពីក្នុង នីហ្វៃទី១ ៣:១–៩ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ ស្តាប់រកហេតុផល ដែលនីហ្វៃមានឆន្ទៈដើម្បីធ្វើអ្វីដែលឪពុករបស់គាត់បានសុំឲ្យគាត់ធ្វើ ។

លេមិន និង លេមយួល មានអារម្មណ៍ថា ការដាក់បញ្ជាឲ្យត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ ទៅយកផ្នាំងលង្ហិននោះ គឺជា « រឿងដ៏ពិបាកមួយ ដែល [លីហៃ] តម្រូវឲ្យពួកគេធ្វើ » (នីហ្វៃទី១ ៣:៥) ។ ដើម្បីជួយសិស្សយល់ពីហេតុផលខ្លះដែល លេមិន និង លេមយួល អាចមានអារម្មណ៍យ៉ាងនេះ អ្នកអាចរំឭកពួកគេថា ពួកគេបានធ្វើដំណើរក្នុងចម្ងាយដ៏ឆ្ងាយមួយពីទីក្រុងយេរូសាឡិមរួចមកហើយ ។

- ហេតុអ្វីបានជាអ្នកគិតថា នីហ្វៃមានឆន្ទៈដើម្បីធ្វើអ្វីដែលឪពុករបស់គាត់បានសុំឲ្យគាត់ធ្វើ ដោយគ្មានការអ៊ូរទាំសោះ ?

សូមជួយសិស្សនិយាយគោលការណ៍ ដែលនីហ្វៃថ្លែងទីបន្ទាល់នៅក្នុង នីហ្វៃទី១ ៣:៧ ម្តងទៀត ធ្វើជាប្រយោគ « ប្រសិនបើ-នោះ » ។ ឧទាហរណ៍ សិស្សអាចនិយាយថា **ប្រសិនបើយើងស្វែងរកដើម្បីធ្វើអ្វីដែលព្រះអម្ចាស់បានដាក់បញ្ញត្តិ នោះទ្រង់នឹងរៀបចំផ្លូវមួយសម្រាប់យើង ដើម្បីសម្រេចបានការណ៍នោះ ។**សូមបង្ហាញថា នីហ្វៃទី១ ៣:៧ គឺជាវគ្គចំណោះចំណានខគម្ពីរមួយ ។ សូមពន្យល់ថា សិស្សនឹងផ្តោតលើវគ្គចំណោះចំណានខគម្ពីរចំនួន ២៥ ពេញមួយឆ្នាំសិក្សានេះ (សម្រាប់ព័ត៌មានបន្ថែម សូមមើលឧបសម្ព័ន្ធនៅក្នុងសៀវភៅសិក្សានេះ) ។ ខយោងចំណោះចំណានខគម្ពីរចំនួន ២៥ ត្រូវបានចុះបញ្ជីនៅខាងក្រោយនៃប្រដាប់សៀតសៀវភៅនៃថ្នាក់សិក្ខាសាលា ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំវគ្គចំណោះចំណានខគម្ពីរ ជារបៀបដ៏ប្លែកមួយ ដូច្នេះពួកគេនឹងអាចចំណាំវគ្គនេះយ៉ាងងាយស្រួល ។

- នៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់ « រៀបចំផ្លូវមួយ » សម្រាប់អ្នកឲ្យកាន់តាមព្រះបញ្ញត្តិមួយរបស់ទ្រង់ ?

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ៣:២, ១៩ –២០ ឮៗ ។ សុំឲ្យសិស្សផ្សេងទៀតក្នុងថ្នាក់ផ្ទៀងស្តាប់ រកមើលឃ្លាណាដែលប្រាប់ពី មូលហេតុដែលផ្នាំងលង្ហិនមានតម្លៃយ៉ាងខ្លាំងចំពោះគ្រួសាររបស់លីហៃ និង កូនចៅរបស់ពួកគេ ។ (អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំឃ្លាទាំងនេះ នៅក្នុងព្រះគម្ពីររបស់ពួកគេ) ។ ក្រោយពីសិស្សបានចែកចាយនូវអ្វីដែលពួកគេបានរកឃើញ សូមពន្យល់ថា ផ្នាំង

នីហ្វៃទី១ ៣:៧ គឺជាវគ្គចំណោះចំណានខគម្ពីរមួយ ។ យោងទៅលើគំនិតបង្រៀនពីចំណោះចំណានខគម្ពីរនៅចុងមេរៀន ដើម្បីជួយសិស្សក្នុងចំណោះចំណាននៃវគ្គរបស់ពួកគេ ។

លង្ហិនទាំងនោះ គឺជាដំណើររឿងមួយនៃព្រះគម្ពីរពីបុរាណ ដែលរួមមានការសរសេរដូចគ្នាជាច្រើន និង ព័ត៌មានជាច្រើនដូចជាព្រះគម្ពីរសញ្ញាចាស់ផងដែរ ។

- ហេតុអ្វីបានជាអ្នកគិតថា អត្ថន័យនៃផ្ទាំងលង្ហិននេះ មានសារៈសំខាន់ល្មម សម្រាប់ឲ្យនីហ្វៃ និង បងប្អូនប្រុសរបស់គាត់ ត្រឡប់ទៅទីក្រុងយេរូសាឡិមវិញដើម្បីទៅយកវាមក ?
- តើព្រះគម្ពីរដែលមានសព្វថ្ងៃនេះ មានតម្លៃចំពោះអ្នកអ្វីខ្លះ ? ហេតុអ្វីបានជាវាមានតម្លៃចំពោះអ្នក ?

នីហ្វៃទី១ ៣: ១០–៣១

ឡាបាន់ បានលួចទ្រព្យសម្បត្តិរបស់លីហៃ និង ចង់សម្លាប់នីហ្វៃ និង បងប្អូនរបស់គាត់

សូមអញ្ជើញសិស្សពាក់កណ្តាលថ្នាក់ សិក្សាពីបំណងលើកទីមួយរបស់នីហ្វៃ និង បងៗរបស់គាត់ ក្នុងការយកផ្ទាំងលង្ហិននេះ (សូមមើល នីហ្វៃទី១ ៣: ១០–១៨) ។ សូមអញ្ជើញសិស្សពាក់កណ្តាលថ្នាក់ទៀត សិក្សាពីបំណងលើកទីពីរ (សូមមើល នីហ្វៃទី១៣:២១–៣១) ។ សុំឲ្យសិស្សម្នាក់ៗ ធ្វើការដោយឯករាជ្យ ហើយឆ្លើយនូវសំណួរខាងក្រោមនេះ ។ អ្នកអាចឲ្យពួកគេបំពេញកិច្ចការនេះ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់ របស់ពួកគេ ។ សូមបង្ហាញសំណួរទាំងនេះ នៅលើក្តារខៀន ឬ រៀបចំសំណួរនោះជាក្រដាសចែកសម្រាប់សិស្សម្នាក់ ។

១. តើនរណាបានទៅ ?

២. តើពួកគេបានធ្វើអ្វីខ្លះ ?

៣. តើពួកគេបានឆ្លើយតបយ៉ាងដូចម្តេច ក្រោយពីការប៉ុនប៉ងនោះបានបរាជ័យ ?

៤. សម្រាប់អ្នកដែលបានសិក្សានៅក្នុងការប៉ុនប៉ងលើកទីមួយ ៖ នីហ្វៃ និង បងៗរបស់គាត់ « ពិតជាមានចិត្តទុក្ខព្រួយជាខ្លាំង » ក្រោយពីពួកគេបានបរាជ័យ ក្នុងការយកនូវផ្ទាំងលង្ហិននោះ (សូមមើល នីហ្វៃទី១ ៣:១៤) ។ តើចម្លើយរបស់នីហ្វៃ ទៅនឹងការបរាជ័យនេះ ខុសពីចម្លើយរបស់បងប្អូនប្រុសរបស់គាត់យ៉ាងដូចម្តេច ? (សូមមើល នីហ្វៃទី១ ៣:១៥–១៦) ។

ចំពោះអ្នកដែលសិក្សាលើការប៉ុនប៉ងលើកទីពីរ ៖ លេមិន និង លេមយួល បានខឹងនឹងនីហ្វៃ ក្រោយពីការប៉ុនប៉ងលើកទីពីររបស់ពួកគេបានបរាជ័យ ។ ពួកគេបានវាយគាត់ ហើយនិយាយទៅគាត់ដោយទ្រគោះបោះបោក ។ ទោះបីជាក្រោយពីទេវតាបានសន្យាថា ព្រះអម្ចាស់នឹងប្រគល់ឡាបាន់ទៅក្នុងកណ្តាប់ដៃរបស់ពួកគេក៏ដោយ ក៏ពួកគេនៅតែបន្តរអ៊ូ និង សង្ស័យពីសមត្ថភាពរបស់ពួកគេក្នុងការបានជោគជ័យដដែល ។ តើកំហឹងរបស់លេមិន និង លេមយួល អាចមានឥទ្ធិពលដល់សមត្ថភាពរបស់ពួកគេក្នុងការជឿលើការសន្យារបស់ទេវតាយ៉ាងដូចម្តេច ? តើកំហឹង ការទាស់ទែង ការរអ៊ូ និង ការគ្មានជំនឿ រាំងរាំងយើងពីការយល់ពីសារលិខិតរបស់ព្រះសម្រាប់យើងយ៉ាងដូចម្តេច ? (សូមមើល នីហ្វៃទី ១ ៣:២៨–៣១; នីហ្វៃទី ៣ ១១:២៩) ។

៥. តើអ្នកទទួលបានទស្សនវិស័យជ្រៅជ្រះអ្វីខ្លះ មកពីខគម្ពីរដែលអ្នកបានសិក្សានេះ ?

ក្រោយពីសិស្សមានពេលគ្រប់គ្រាន់ ដើម្បីឆ្លើយតបនឹងសំណួរនេះ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីចម្លើយរបស់ពួកគេ ។

នីហ្វៃទី១ ៤:១–៣៨

នីហ្វៃទទួលបានផ្ទាំងលង្ហិននោះ

សុំឲ្យសិស្សរកសំណួរ ដែលលេមិន និង លេមយួល បានសួរនៅក្នុង នីហ្វៃទី១ ៣:៣១ ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ៤:១–៣ ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកនូវចម្លើយរបស់នីហ្វៃ ចំពោះសំណួររបស់បងៗរបស់គាត់ ។

- តើរឿងរបស់ម៉ូសេ ទាក់ទងនឹងសំណួររបស់លេមិន និង លេមយួលយ៉ាងដូចម្តេច ?

ប្រសិនបើសិស្សត្រូវការជំនួយក្នុងការឆ្លើយនូវសំណួរនេះ សូមពន្យល់ថា ម៉ូសេបានជួបប្រទះនឹងឧបសគ្គស្រដៀងគ្នាមួយ នៅពេលដែលគាត់ត្រូវបានសុំឲ្យនាំកូនចៅអ៊ីស្រាអែលចេញពីប្រទេសអេហ្ស៊ីប ។ ទោះបីជាការប៉ុនប៉ងដដែលក្តី ក៏ម៉ូសេមិនអាចបញ្ចុះបញ្ចូលឲ្យស្តេចជាវ៉ោន រំដោះកូនចៅអ៊ីស្រាអែលពីទាសភាពបានដដែល ។ ទោះយ៉ាងណាក្តី ក៏ម៉ូសេបានបន្តនៅក្នុងការធ្វើអ្វីដែលព្រះអម្ចាស់បានដាក់បញ្ជាតិដល់គាត់ ហើយព្រះអម្ចាស់បានផ្តល់ផ្លូវមួយដល់គាត់ ដើម្បីផ្តល់សេរីភាពដល់កូនចៅអ៊ីស្រាអែល ។ នីហ្វៃបានអនុវត្តគំរូរបស់ម៉ូសេ ចំពោះកាលៈទេសៈនៃគ្រួសាររបស់គាត់ ។ គាត់មានជំនឿចិត្តថា ព្រះក៏នឹងរៀបចំផ្លូវមួយសម្រាប់ពួកគេដែរ ។

- តើគោលការណ៍អ្វីដែលអ្នកបានរៀនពីការឆ្លើយតបរបស់នីហ្វៃទៅកាន់បងៗរបស់គាត់ ?

ទោះបីជាសិស្សអាចលើកឃ្លាចម្លើយរបស់ពួកគេខុសគ្នាបន្តិចបន្តួចក្តី ក៏ពួកគេគួរតែបង្ហាញថា **ប្រសិនបើយើងតស៊ូដោយភក្តីភាពក្នុងការធ្វើអ្វីដែលព្រះអម្ចាស់ត្រូវការ ដោយមិនគិតពីការលំបាក ទ្រង់នឹងរៀបចំផ្លូវមួយសម្រាប់យើង ដើម្បីសម្រេចបាននូវអ្វីដែលទ្រង់បានចេញបញ្ជា ។** (អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន ។)

សំដៅទៅសេចក្តីថ្លែងការណ៍ដែលអ្នកបានបង្ហាញលើក្តារខៀន នៅពេលចាប់ផ្តើមមេរៀន ។

- ឥឡូវនេះ អ្នកបានសិក្សាពីបទពិសោធន៍របស់នីហ្វៃ តើសេចក្តីថ្លែងការណ៍មួយណា ដែលអ្នកគិតថា បានសង្ខេបយ៉ាងល្អបំផុតពីគោលការណ៍ដែលអ្នកទើបតែរកឃើញ ?

នៅពេលដែលសិស្សសិក្សាពីសំណាល់នៃដំណើររឿងរបស់នីហ្វៃ សូមលើកទឹកចិត្តពួកគេឲ្យរកមើលការបញ្ជាក់ពីគោលការណ៍នេះ ដែលជាលទ្ធផលនៃសេចក្តីខ្ជាប់ខ្ជួនរបស់នីហ្វៃ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ៤:៤ –៦ឮៗ ។ អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំ នីហ្វៃទី១ ៤:៦ នៅក្នុងព្រះគម្ពីររបស់ពួកគេ ។

សូមជួយសិស្សឲ្យយល់ថា ព្រះអម្ចាស់អាចបំផុសគំនិតយើង ឲ្យធ្វើអ្វីមួយដោយគ្មានការបើកបង្ហាញភ្លាមៗ ពីរបៀប ពេលវេលា ឬ មូលហេតុដែលយើងគួរតែធ្វើវានោះទេ ។ នីហ្វៃ បានរៀបពីរបៀប ពេលវេលា និង មូលហេតុដែលព្រះអម្ចាស់ នឹងជួយគាត់ តែ*ក្រោយពី* គាត់បានអនុញ្ញាតឲ្យព្រះវិញ្ញាណបរិសុទ្ធ ណែនាំគាត់ និង *ក្រោយពី*គាត់បានសម្រេចថា ទៅមុខដោយសេចក្តីជំនឿ ។

សូមប្រាប់សិស្សថាប្រធាន ហារ៉ូល ប៊ី លី បានសង្កេតឃើញថា ជាញឹកញាប់យើងចង់ឃើញ « ចុងបញ្ចប់ពីដើមដំបូង » ឬ លទ្ធផល មុនពេលដែលយើងនឹងធ្វើតាមការណែនាំរបស់ព្រះអម្ចាស់ ។ គាត់បានប្រឹក្សាថា ៖

« អ្នកត្រូវតែរៀនដើរទៅចុងនៃពន្លឺ ហើយប្រហែលជាពីរបីជំហាន ទៅក្នុងភាពងងឹត ដែលមិនបានស្គាល់ ហើយអ្នកនឹងឃើញថា ពន្លឺនឹងលេចឡើង ហើយនៅពីមុខអ្នក » (នៅក្នុង Lucile C. Tate, *Boyd K. Packer: A Watchman on the Tower* [១៩៩៥] ទំព័រ ១៣៧–៣៨) ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ៤:៧ ឲ្យឮៗ ។

- នៅក្នុង នីហ្វៃទី១ ៤:៧ តើមានអ្វីដែលសំខាន់អំពីឃ្លា « ទោះយ៉ាងណាក៏ដោយ គង់តែខ្ញុំដើរតម្រង់ទៅមុខ » ?
- តើបទពិសោធន៍របស់នីហ្វៃបានបង្រៀនអ្វីខ្លះ អំពីទំនាក់ទំនងរវាងឆន្ទៈរបស់យើងដើម្បី « ទៅ ហើយធ្វើ » និង សមត្ថភាពរបស់យើងដើម្បីត្រូវបានដឹកនាំដោយព្រះអម្ចាស់ ?

សូមអញ្ជើញសិស្សបីបួននាក់ ប្តូរវេនគ្នាអានឮៗពី នីហ្វៃទី១ ៤:៨– ១៨ ។

- តើហេតុផលអ្វីដែលព្រះវិញ្ញាណផ្តល់ឲ្យនីហ្វៃនូវបញ្ញត្តិរបស់ព្រះអម្ចាស់ឲ្យសម្លាប់ឡាបាន់ចោល ?

សូមសង្ខេបនូវដំណើររឿងរបស់នីហ្វៃទាំងអស់ ក្នុងការទទួលបាននូវផ្ទាំងទាំងឡាយដោយជោគជ័យ (សូមមើល នីហ្វៃទី១ ៤:១៩–៣៨ ឬ សូមអញ្ជើញសិស្សម្នាក់ដែលស្គាល់រឿងនោះឲ្យនិយាយបន្ត ។ សុំឲ្យសិស្សរកមើលគោលការណ៍ ដែលពួកគេឃើញមានបង្ហាញនៅក្នុងការខិតខំចុងក្រោយនេះ ដើម្បីទទួលបាននូវផ្ទាំងទាំងនោះ ។ ក្រោយពីពួកគេផ្តល់នូវទស្សនវិស័យជ្រៅជ្រះរបស់ពួកគេ សូមបន្ថែមឧទាហរណ៍ទីបន្ទាល់របស់អ្នកថា **នៅពេលយើងអនុវត្តសេចក្តីជំនឿលើព្រះ ហើយស្វែងរកដើម្បីធ្វើអ្វីដែលទ្រង់បានដាក់បញ្ញត្តិ ទោះបីជានៅពេលដែលយើងមិនអាចមើលឃើញពីលទ្ធផលក្តី ទ្រង់នឹងដឹកនាំយើងដោយឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។**

ដើម្បីជួយសិស្សឲ្យកាន់តែមានទីបន្ទាល់ខ្លាំងពីគោលការណ៍នេះ សូមអញ្ជើញពួកគេឲ្យចែកចាយពីបទពិសោធន៍ពេលដែលពួកគេបានធ្វើសកម្មភាពដោយសេចក្តីជំនឿ ដោយពុំបានដឹងជាមុនពីរបៀប ឬ ពេលដែលព្រះនឹងជួយពួកគេ ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីស្ថានភាពមួយដែលពួកគេកំពុងជួបប្រទះនាពេលឥឡូវ ដែលតម្រូវការរបស់ព្រះអម្ចាស់វាពិបាកសម្រាប់ពួកគេ ។ សុំឲ្យពួកគេកត់ត្រានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេនូវអ្វីដែលពួកគេនឹងធ្វើដើម្បីបង្ហាញព្រះអម្ចាស់ ពីឆន្ទៈរបស់ពួកគេដើម្បី « ទៅ ហើយធ្វើ » នូវអ្វីដែលទ្រង់បានបញ្ជា ។ នៅពេលដែលពួកគេបានបញ្ចប់ការសរសេរ សូមបង្ហាញជំនឿចិត្តរបស់អ្នកថា នៅពេលយើងបង្ហាញសេចក្តីជំនឿរបស់យើង ព្រះអម្ចាស់នឹងជួយយើងឲ្យសម្រេចបាននូវអ្វីក៏ដោយ ដែលទ្រង់បានឲ្យយើងធ្វើ ។

ការអានព្រះគម្ពីរនៅក្នុងថ្នាក់

ការអានព្រះគម្ពីរនៅក្នុងថ្នាក់ អាចជួយសិស្សឲ្យយល់កាន់តែច្បាស់ពីខគម្ពីរដែលពួកគេកំពុងសិក្សា ។ វាក៏អាចជួយពួកគេមានជំនឿចិត្តកាន់តែខ្លាំងលើសមត្ថភាពរបស់ពួកគេ ដើម្បីអានព្រះគម្ពីរដោយខ្លួនគេផ្ទាល់ ។ ទោះយ៉ាងណាក៏ដោយ គ្រូបង្រៀនម្នាក់ មិនគួរបំបាក់មុខសិស្សសោះឡើយ ដោយបង្ខំគេឲ្យអានឮៗ ប្រសិនបើពួកគេមានអារម្មណ៍មិនស្រួលក្នុងការអាននោះ ។ មធ្យោបាយខ្លះ ដើម្បីអានព្រះគម្ពីរួមគ្នានៅក្នុងថ្នាក់រួមមាន ៖

១. សិស្សប្តូរវេនគ្នាអានឮៗ ។
២. គ្រូបង្រៀនអានឮៗ នៅពេលសិស្សអានព្រះគម្ពីរតាម ។
៣. សុំឲ្យសិស្សបីបួននាក់អាន នៅពេលសិស្សផ្សេងទៀត កំពុងនិយាយនៅក្នុងវគ្គនៃព្រះគម្ពីរមួយ ។
៤. សិស្សអានឮៗឲ្យគ្នាស្តាប់ទៅវិញទៅមក នៅក្នុងក្រុមតូចៗ ឬ ជាដៃគូ ។

ចំណេះចំណានខគម្ពីរ— នីហ្វៃទី១ ៣:៧

សូមសរសេរនៅលើក្តារខៀននូវពាក្យ *ការគោរពប្រតិបត្តិ សេចក្តីជំនឿ* និង *ការទុកចិត្ត* ។ សួរ ៖

- តើមានភស្តុតាងអ្វីបង្ហាញពីការគោរពប្រតិបត្តិ សេចក្តីជំនឿ និង ការទុកចិត្តរបស់នីហ្វៃ ដែលអ្នកមើលឃើញនៅក្នុង នីហ្វៃទី១ ៣ ?
- តើលក្ខណៈសម្បត្តិទាំងនេះអាចជួយនរណាម្នាក់ដែលត្រូវបានហៅឲ្យបម្រើបេសកកម្មយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សម្នាក់ៗ ឲ្យសរសេរសំបុត្រមួយទៅអ្នកផ្សព្វផ្សាយសាសនាម្នាក់ ដោយសួរអ្នកផ្សព្វផ្សាយសាសនានោះ ពីរបៀបដែលគាត់បានឃើញ នីហ្វៃទី១ ៣:៧ នៅក្នុងសកម្មភាព ។ សូមលើកទឹកចិត្តសិស្សឲ្យចែកចាយនូវចម្លើយខ្លះៗ ដែលពួកគេបានទទួលពីសំបុត្ររបស់ពួកគេ ។

កំណត់សម្គាល់ ៖ នៅចុងបញ្ចប់នៃមេរៀននីមួយៗ ដែលរួមមានវគ្គចំណេះចំណានខគម្ពីរមួយ អ្នកនឹងឃើញសកម្មភាពបន្ថែមមួយដែលរៀបចំឡើងដើម្បីជួយសិស្សឲ្យប៉ិនប្រសប់លើវគ្គនេះ ។ អ្នកអាចប្រើសកម្មភាពទាំងនេះ នៅពេលណាក៏បាន (សម្រាប់ព័ត៌មានបន្ថែម សូមមើលឧបសម្ព័ន្ធ និង *ការបង្រៀនដំណឹងល្អ និង ការរៀន*ពីសៀវភៅក្បួនខ្នាត) ។ ដោយសារលក្ខណៈ និង រយៈពេលនៃមេរៀនថ្ងៃនេះ អ្នកអាចប្រើសកម្មភាពនេះនៅថ្ងៃក្រោយ នៅពេលអ្នកមានពេលច្រើនជាងនេះ ។

នីហ្វៃទី១ ៥

សេចក្តីផ្តើម

នៅពេលដែល សារ៉ាយ ប្រពន្ធរបស់លីហៃ បានរង់ចាំកូនប្រុសរបស់នាងត្រឡប់មកពីទីក្រុងយេរូសាឡិមវិញ នាងមានការភ័យខ្លាចថា ពួកគេត្រូវបានសម្លាប់នៅក្នុងការខិតខំរបស់ពួកគេ ដើម្បីយកផ្នាំងមាសនោះមក ។ នៅពេលពួកគេត្រឡប់មកវិញជាមួយផ្នាំងមាសដោយសុវត្ថិភាព នាងទទួលបាននូវទីបន្ទាល់កាន់តែរឹងមាំថា ព្រះបានណែនាំ និង ការពារដល់គ្រួសាររបស់គាត់ ។ លីហៃ បានស្វែងយល់ផ្នាំងលង្ហិន និង ឃើញថាវាមានតម្លៃដ៏អស្ចារ្យចំពោះគ្រួសាររបស់គាត់ ។ នៅពេលដែលគាត់អានវា គាត់ពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ ហើយគាត់បានព្យាករណ៍ថា ព្រះគម្ពីរដែលពួកគេមាន នឹងត្រូវរក្សាទុកសម្រាប់កូនចៅរបស់គាត់ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ៥:១– ៩

កូនប្រុសរបស់លីហៃ ត្រឡប់ទៅគ្រួសាររបស់ពួកគេវិញដោយសុវត្ថិភាព នៅក្នុងទីរហោស្ថាន

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ៥:១–៣ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលហេតុផលដែលសារ៉ាយ ចាប់ផ្តើមត្អូញត្អែរ ។

- **តើសារ៉ាយត្អូញត្អែរអ្វីខ្លះ ? (ចម្លើយទាំងអស់ អាចរួមមាន លីហៃគឺជាបុរសដែលប្រកបដោយការនិមិត្ត ដែលគាត់បាននាំគ្រួសារចាកចេញចោលដែនដីនៃកេរ្តិ៍អាករបស់ពួកគេ ហើយថាគាត់បានសម្រេចចិត្ត ដែលអាចនាំទៅរកការបាត់បង់កូនប្រុសរបស់ពួកគេ ហើយថាអាចនាំទៅរកការស្លាប់ទៅក្នុងទីរហោស្ថាន) ។**

សុំឲ្យសិស្សគិតអំពីពេលមួយ ដែលពួកគេអាចត្អូញត្អែរអំពីស្ថានភាពមួយ ទោះបីជាពួកគេគ្មានព័ត៌មានទាំងអស់អំពីស្ថានភាពនោះក៏ដោយ ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ៥:៤– ៦ ឮៗ ។ សុំឲ្យសិស្សផ្តោតយកចិត្តទុកដាក់លើរបៀបដែល លីហៃឆ្លើយតបនឹងការត្អូញត្អែររបស់សារ៉ាយ។

- **តើអ្វីដែលធ្វើឲ្យអ្នកពេញចិត្តអំពី របៀបដែលលីហៃបានឆ្លើយតបទៅនឹងការត្អូញត្អែររបស់សារ៉ាយ ? (អ្នកអាចបង្ហាញថា លីហៃបានឆ្លើយតបដោយទីបន្ទាល់ និង ជឿជាក់លើព្រះអម្ចាស់ ជាជាងសេចក្តីភ័យខ្លាច ឬ ការសង្ស័យ ។ គាត់មិនបានឆ្លើយតបដោយខឹង ឬ ដោយគ្មានការអត់ធ្មត់នោះទេ) ។**
- **តើយើងអាចរៀនអ្វីខ្លះ មកពីការឆ្លើយតបរបស់លីហៃ ចំពោះសារ៉ាយ ?**

សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ៥:៧– ៩ ឮៗ ។

- **តើសារ៉ាយទទួលបានអ្វីពីបទពិសោធន៍នេះ ?**

នីហ្វៃទី១ ៥:១០–២២

លីហៃ ស្វែងយល់ផ្នាំងលង្ហិនទាំងឡាយ

សុំឲ្យសិស្សគិតពីអ្វីមួយដែលពួកគេនឹងគិតលះបង់ជីវិតរបស់ពួកគេដើម្បីទទួលបាន ឬ រក្សាទុក ។

សូមអញ្ជើញសិស្សម្នាក់ឲ្យធ្វើការសង្ខេប នីហ្វៃទី១ ៣ –៤ ហើយប្រាប់ពីការលះបង់ដែលគ្រួសាររបស់លីហៃបានធ្វើដើម្បីទទួលបានផ្នាំងលង្ហិនទាំងនោះ ។ (នីហ្វៃ និង បងប្អូនប្រុសរបស់គាត់ បានប្រថុយជីវិតរបស់ពួកគេ បានលះបង់ទ្រព្យសម្បត្តិរបស់ខ្លួន និង បានធ្វើដំណើរក្នុងរយៈចម្ងាយដ៏ឆ្ងាយ ។)

- **ហេតុអ្វីបានជាអ្នកគិតថា ការលះបង់បែបនោះគឺចាំបាច់ ?**

សូមពន្យល់ថា ក្រោយពីគ្រួសារនោះ បានធ្វើការលះបង់ និង ថ្លែងអំណរគុណដល់ព្រះអម្ចាស់ ភ្លាមនោះលីហៃបានចាប់ផ្តើមអានអត្ថន័យនៃផ្នាំងទាំងនោះ ។ សូមអញ្ជើញសិស្សបីឬនាក់ប្តូរវេនគ្នាអាន នីហ្វៃទី១ ៥:១១– ១៦ ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ស្វែងរកអ្វីដែលលីហៃបានរកឃើញនៅលើផ្នាំងលង្ហិនទាំងនោះ ។ អ្នកអាចកត់ត្រាចម្លើយរបស់ពួកគេនៅលើក្តារខៀនដោយសង្ខេប ។

សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ៥:១០ ដោយស្ងាត់ៗ។ សុំឲ្យពួកគេស្វែងរកពាក្យដែលពិពណ៌នាពីការអានព្រះគម្ពីររបស់ លីហៃ ។ (គាត់ « បានស្វែងយល់វា ») ។ សូមអញ្ជើញសិស្សឲ្យចាប់ដៃគូ ដើម្បីពិភាក្សានូវសំណួរដូចខាងក្រោមនេះ ៖

- **តើភាពខុសគ្នាអ្វីខ្លះ រវាងការស្វែងយល់ពីព្រះគម្ពីរ និង ការគ្រាន់តែអានព្រះគម្ពីរ ? (អ្នកអាចលើកទឹកចិត្តសិស្សឲ្យប្រាប់ពីពេលដែលពួកគេបានអានស្វែងយល់ព្រះគម្ពីរ) ។**

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយ អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« នៅពេលដែលខ្ញុំនិយាយថា ‹ សិក្សា › ខ្ញុំមានន័យអ្វីមួយ ជាជាងការគ្រាន់តែអាន ។ វាជារឿងល្អ ដែលពេលខ្លះអានសៀវភៅព្រះគម្ពីរមួយ នៅក្នុងពេលកំណត់ណាមួយ ដើម្បីទទួលបានន័យទូទៅនៃសារលិខិតរបស់វា ប៉ុន្តែសម្រាប់ការសន្ទនា អ្នកគួរតែយកចិត្តទុកដាក់លើចំនួនដែលអ្នកបានអាននៅពេលនោះ ជាងការគិតពីពេលវេលាដែលអ្នកចំណាយជាមួយព្រះគម្ពីរ ។ ខ្ញុំឃើញថា ពេលខ្លះអ្នកអានពីរបីខគម្ពីរ ឈប់ ដើម្បីសញ្ជឹងគិតអំពីខគម្ពីរនោះ សូមអានខគម្ពីរនេះម្តងទៀតដោយយកចិត្តទុកដាក់ ហើយនៅពេលអ្នកគិតពីន័យរបស់វា សូមអធិស្ឋានសម្រាប់ការយល់ដឹង សូរសំណូរនៅក្នុងគំនិតរបស់អ្នក រង់ចាំការបំផុសគំនិតខាងវិញ្ញាណ និង សរសេរទុកនូវការបំផុសគំនិត និង ទស្សនវិស័យជ្រៅជ្រះដែលនឹងមក ដូច្នេះអ្នកអាចចងចាំ និង រៀនបានច្រើនជាង ។ ការសិក្សារបៀបនេះ អ្នកប្រហែលមិនអានច្រើនជំពូក ឬ ច្រើនខគម្ពីរនោះទេនៅក្នុងរយៈពេលកន្លះម៉ោង ប៉ុន្តែអ្នកនឹងឲ្យកន្លែងមួយសម្រាប់ព្រះបន្ទូលនៃព្រះនៅក្នុងដួងចិត្តរបស់អ្នក ហើយទ្រង់នឹងមានព្រះបន្ទូលមកកាន់អ្នក ។ សូមចាំអំពីការពិពណ៌នារបស់អាលម៉ា ពីអារម្មណ៍ដែលថា ៖ ‹ វាចាប់ផ្តើមពង្រីកព្រលឹងរបស់ខ្ញុំ មែនហើយ វាចាប់ផ្តើមបំភ្លឺយោបល់របស់ខ្ញុំ មែនហើយ វាចាប់ផ្តើមមានរសជាតិឆ្ងាញ់ចំពោះខ្ញុំ › (អាលម៉ា ៣២:២៨) " ("When Thou Art Converted," *Ensign* ឬ ***លីអាហូណា*** ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ១១–១២) ។

សូមផ្តល់ពេលវេលាដល់សិស្សគិតពីការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។ សុំឲ្យពួកគេសរសេរនៅក្នុងសៀវភៅកំណត់ហេតុនូវការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ អំពីរបៀបដ៏មានន័យ ដែលពួកគេបានអានស្វែងយល់ព្រះគម្ពីរ ។ ក្រោយពីពួកគេបានសរសេរហើយ សូមអញ្ជើញពួកគេគិតពីរបៀបដែលពួកគេធ្វើឲ្យការសិក្សាព្រះគម្ពីររបស់ពួកគេកាន់តែប្រសើរឡើង ។ សុំឲ្យពួកគេជ្រើសរើសរបៀបមួយ ដើម្បីពង្រីកការស្វែងយល់ព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។ សូមលើកទឹកចិត្តពួកគេ ឲ្យសរសេរគោលដៅនេះទុកក្នុងសៀវភៅកំណត់ហេតុនូវការសិក្សាព្រះគម្ពីររបស់ពួកគេ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរតែចែកចាយនូវគោលដៅខ្លួនជាមួយនឹងនរណាម្នាក់ (ឧទាហរណ៍ ជាមួយអ្នក ឪពុកម្តាយ ឬ សិស្សផ្សេងទៀត) ដែលនឹងរំឭកពួកគេអំពីគោលដៅ និង លើកទឹកចិត្តគេឲ្យសម្រេចវាឲ្យបាន ។

សូមពន្យល់ថា ព្រះអម្ចាស់ប្រទានពរដល់លីហៃ ក្នុងស្វែងយល់ពីព្រះគម្ពីរ។ ដើម្បីជួយសិស្សរកឃើញពរជ័យទាំងនេះ សូមអញ្ជើញពួកគេអាន នីហ្វៃទី១ ៥:១៦– ២០ ដោយស្ងាត់ៗ។

- តើការស្វែងយល់ក្នុងថ្ងាំងលង្ហិននេះ មានឥទ្ធិពលដល់លីហៃយ៉ាងដូចម្តេច ?

សូមបញ្ជាក់ថា នៅពេលលីហៃ បានស្វែងយល់ពីព្រះគម្ពីរ គាត់បានពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ និង ទទួលបានវិវរណៈ « ទាក់ទងនឹងគ្រាប់ពូជរបស់គាត់ » (កូនចៅរបស់គាត់) ។ សូមបញ្ជាក់ដល់សិស្សថា **នៅពេលយើងស្វែងយល់ពីព្រះគម្ពីរ យើងអាចពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ និង ទទួលបានវិវរណៈ ។** ដូចគ្នាដែរ នៅពេលយើងលះបង់ពេលវេលា និង កម្លាំងរបស់យើងដើម្បីស្វែងយល់ពីព្រះគម្ពីរ ដូចដែលលីហៃបានធ្វើ យើងអាចទទួលបានកម្លាំងដើម្បីកាន់តាមព្រះបញ្ញត្តិរបស់ព្រះ ។

- តើអ្នកត្រូវបានប្រទានពរដោយសារការស្វែងយល់ពីព្រះគម្ពីរ ដោយរបៀបណា ?
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ខណៈដែលអ្នកសិក្សាព្រះគម្ពីរ ?

សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោម ដែលអែលឌើរ រ៉ូបឺត ឌី ហៃល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងទីបន្ទាល់ពីពរជ័យនៃការស្វែងយល់ពីព្រះគម្ពីរ ៖

« នៅពេលយើងចង់និយាយទៅកាន់ព្រះ នោះយើងអធិស្ឋាន ។ ហើយនៅពេលយើងចង់ឲ្យទ្រង់មានបន្ទូលមកកាន់យើង នោះយើងស្វែងយល់ពីព្រះគម្ពីរទាំងឡាយ ដ្បិតព្រះបន្ទូលរបស់ទ្រង់មានព្រះបន្ទូលតាមរយៈពួកព្យាការីរបស់ទ្រង់ ។ បន្ទាប់មក ទ្រង់នឹងបង្រៀនដល់យើងនៅពេលយើងស្តាប់តាមការបំផុសគំនិតទាំងឡាយនៃព្រះវិញ្ញាណបរិសុទ្ធ ។

« ប្រសិនបើអ្នកស្តាប់មិនឮសំឡេងមានបន្ទូលមកកាន់អ្នកថ្មីៗនេះទេ សូមត្រឡប់មកព្រះវិហារវិញ ហើយអានព្រះគម្ពីរម្តងទៀត ។ វាគឺជាខ្សែជីវិតខាងវិញ្ញាណ » (« Holy Scriptures: The Power of God unto Our Salvation, » *Ensign* ឬ ***លីអាហូណា*** ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ២៦–២៧) ។

សូមអាន នីហ្វៃទី១ ៥:២១ –២២ ។ ដោយសុំឲ្យសិស្សអានតាមនៅក្នុងព្រះគម្ពីររបស់គេ ។ នៅពេលអ្នកអាន សូមបញ្ជាក់លើពាក្យទាំងនេះ ៖ « វាជាក្រាជ្ញានៅក្នុងព្រះដែលយើងគួរតែយកវាតាមខ្លួនយើង នៅពេលយើងធ្វើដំណើរនៅក្នុងទីរហោស្ថាន » ។

- តើហេតុអ្វីបានជាវាជាការឈ្លាសវៃដល់យើង ក្នុងការយកព្រះគម្ពីរតាមខ្លួនយើង នៅពេលយើងធ្វើដំណើរ ?
- តើតាមរបៀបណាដែលយើងអាចយកព្រះគម្ពីរតាមខ្លួនយើងបាន ?

បង្ហាញថា លីហៃ និង គ្រួសាររបស់គាត់ ទទួលបានថ្ងាំងលង្ហិនតាមរយៈការលះបង់ដ៏អស្ចារ្យ ។ បើគ្មានព្រះគម្ពីរ លីហៃ និង គ្រួសាររបស់គាត់ នឹងមិនអាចមានជ័យជំនះនៅក្នុងដំណើររបស់ពួកគេបានទេ ។ សូមលើកទឹកចិត្តសិស្សឲ្យទុកព្រះគម្ពីរនៅនឹងខ្លួនគេ នៅពេលពួកគេធ្វើដំណើរក្នុងជីវិតរមែងស្លាប់របស់ពួកគេ ។

សូមអញ្ជើញសិស្ស ឲ្យគិតពីការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។ សូមគិតពីការអញ្ជើញសិស្សម្នាក់ដែលអានព្រះគម្ពីរទៀងទាត់ ដើម្បីផ្តល់ការលើកទឹកចិត្ត និង ទីបន្ទាល់ទៅកាន់មិត្តភក្តិរបស់គាត់ ។ សូមលើកទឹកចិត្តសិស្សឲ្យមានទម្លាប់ចំណាយពេលប្រចាំថ្ងៃដើម្បីស្វែងយល់ពីព្រះគម្ពីរ ។

កំណត់ចំណាំ ៖ ប្រវែងនៃមេរៀននេះ អាចឲ្យពេលធ្វើសកម្មភាពសម្រាប់ចំណេះចំណានខគម្ពីរខ្លះ ពីមេរៀនមុនបាន ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី១ ៥:១០– ២២ ។ តម្លៃព្រះគម្ពីរ

ដើម្បីបង្រៀនអំពីរបៀបដែលយើងអាចទទួលបានការណែនាំតាមរយៈការសិក្សាព្រះគម្ពីរ របស់យើង អែលឌើរ រ៉ូបឺត ឌី ហែល នៃក្លុំមនៃពួកសាវកដប់ពីរនាក់ បានចែកចាយនូវ ដំណើររឿងរបស់លីហៃក្នុងការស្វែងយល់ផ្នាំងលង្ហិននោះ ៖

« នៅពេលនីហ្វៃ និង បងៗរបស់គាត់ បានត្រឡប់មកវិញ [ពីទីក្រុងយេរូសាឡិមដោយ មានផ្នាំងលង្ហិន] លីហៃ ជាឪពុករបស់ពួកគេបានរីករាយ ។ គាត់បានចាប់ផ្តើមស្វែងយល់ ព្រះគម្ពីរដ៏បរិសុទ្ធនោះ ‹ តាំងពីដើម › ហើយ ‹ រកឃើញថា បញ្ជីប្រវត្តិទាំងនេះគឺគួរឲ្យចង់ បាន មែនហើយ ព្រមទាំងមានប្រយោជន៍ដ៏មហិមា . . . ដើម្បី [លីហៃ និង កូនចៅរបស់ គាត់] អាចរក្សាទុកនូវព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ មកដល់កូនចៅ [របស់ពួកគេ] › ។

« ជាការពិត ផ្នាំងលង្ហិននោះ គឺជាកំណត់ត្រារបស់ជូនតាលីហៃ រួមមានភាសា ពង្សាវតាររបស់ ពួកគេ ហើយសំខាន់ជាងនេះ នោះគឺដំណឹងល្អដែលបានបង្រៀនដោយព្យាការីដ៏បរិសុទ្ធរបស់ ព្រះ ។ នៅពេលដែលលីហៃបានស្វែងយល់ពីផ្នាំងនោះ គាត់បានដឹងពីអ្វីដែលយើងទាំងអស់ រៀន ដោយការសិក្សាព្រះគម្ពីរ ៖

« • តើយើងជានរណា ។

« • តើយើងអាចក្លាយជាអ្វី ។

« • ការព្យាករណ៍សម្រាប់យើង និង សម្រាប់កូនចៅរបស់យើង ។

« • ព្រះបញ្ញត្តិ ក្រិត្យវិន័យ ពិធីបរិសុទ្ធ និង សេចក្តីសញ្ញា ដែលយើងត្រូវតែរស់នៅតាម ដើម្បី ទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

« • និង របៀបដែលយើងត្រូវតែរស់នៅ ដើម្បីប្រកាន់ខ្ជាប់ ដល់ទីបញ្ចប់ និង ត្រឡប់ទៅកាន ព្រះវរបិតាសួគ៌របស់យើងដោយមានកិត្តិយស ។

« សេចក្តីពិតទាំងនេះ ដែលព្រះវរបិតាសួគ៌បានឲ្យទាំងលីហៃ និង នីហ្វៃ នូវការនិមិត្តយ៉ាង ច្បាស់ តំណាងឲ្យព្រះបន្ទូលនៃព្រះ ដូចជាដំបងដែកមួយនោះ គឺពិតជាមានសារៈសំខាន់ខ្លាំង ណាស់ ។ ទាំងឪពុក និង កូនប្រុសបានរៀនថា ការកាន់តាមការណែនាំដ៏រឹងមាំ មិនងាករេ ដ៏មានទំនុកចិត្តនេះ គឺជារបៀប*តែមួយគត់* ដើម្បីរស់នៅតាមផ្លូវត្រង់ ហើយតួចចង្អៀតនោះ ដែលដឹកនាំយើងទៅកាន់ព្រះអង្គសង្គ្រោះរបស់យើង » (« ព្រះគម្ពីរដ៏បរិសុទ្ធ ៖ អំណាចនៃ ព្រះ ចំពោះសេចក្តីសង្គ្រោះរបស់យើង » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ២៥) ។

នីហ្វៃទី១ ៥:១៨ –១៩ ។ ផ្នាំងលង្ហិនទាំងឡាយ

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃក្លុំមនៃពួកសាវកដប់ពីរនាក់ បានថ្លែងទីបន្ទាល់ពី សារៈសំខាន់នៃការទទួលបានផ្នាំងលង្ហិនរបស់គ្រួសារលីហៃ ៖

« គុណតម្លៃនៃផ្នាំងលង្ហិននោះ ចំពោះសាសន៍នីហ្វៃ មិនអាចត្រូវបានវាយតម្លៃហួសបាន ទេ ។ ដោយសារផ្នាំងទាំងនោះ ពួកគេអាចរក្សាទុកនូវភាសា (នីហ្វៃទី១ ៣:១៩) អារ្យធម៌ ភាគច្រើន និង ចំណេះដឹងខាងសាសនារបស់មនុស្ស ពីពេលដែលពួកគេបានចេញមក ។ នីហ្វៃទី១ ២២:៣០) ។ ផ្ទុយទៅវិញ សាសន៍មូឡេក ដែលត្រូវបានដឹកនាំឲ្យចេញពីទីក្រុង យេរូសាឡិម ប្រហែល ១១ ឆ្នាំក្រោយពីការចាកចេញរបស់លីហៃ និង អ្នកដែលគ្មាន កំណត់ត្រាប្រហាក់ប្រហែលនឹងផ្នាំងលង្ហិននោះ ក៏បានរស់នៅក្នុងការក្បត់សាសនា និង ឥតជំនឿ និង បាត់បង់នូវភាសា អារ្យធម៌ និង សាសនារបស់ពួកគេយ៉ាងឆាប់ហ័ស ។ (អោមណៃ ១៨– ១៨) ។

« ពីព្យាការីមួយ ទៅព្យាការីមួយ ហើយពីជំនាន់មួយទៅជំនាន់មួយ ផ្នាំងលង្ហិន ត្រូវបាន បន្តវេន ហើយបានរក្សាទុកដោយសាសន៍នីហ្វៃ ។ (ម៉ូសាយ ១:១៦; ២៨:២០; នីហ្វៃទី ៣ ១:២) ។ នៅថ្ងៃអនាគតខាងមុខ ដែលព្រះអម្ចាស់បានសន្យាដើម្បីនាំពួកគេមក ដោយ ច្បាស់តាមពេលវេលា និង នៅមានពន្លឺដើមរបស់វា និង ដំណើររឿងនៃព្រះគម្ពីរបានកត់ត្រា លើវា គឺត្រូវ ‹ ឆ្ពោះទៅមុខ ដល់គ្រប់សាសន៍ ពូជ ភាសា និង ប្រជាជន › ។ (អាលម៉ា ៣៧:៣–៥; នីហ្វៃទី១ ៥:១៨–១៩) » ។ (*គោលលទ្ធិនៃមរមន* កំណែលើកទី ២. [១៩៦៦] ទំព័រ ១០៣) ។

គំនិតបន្ថែមទាំងឡាយសម្រាប់ការបង្រៀន

នីហ្វៃទី១ ៥:២១ ។ ការស្វែងយល់ពីព្រះគម្ពីរ

សូមប្រៀង ឬ អានពាក្យថា « ពេលខ្ញុំស្វែងយល់គម្ពីរពិសិដ្ឋ » ជាមួយសិស្សក្នុងថ្នាក់ (ទំនុកដំកើង ទំព័រ ១៥៩) ។ សូមអញ្ជើញសិស្សរកមើលឃ្លានៅក្នុងទំនុកតម្កើង ដែល ពិពណ៌នាអំពីពរជ័យដែលមកតាមរយៈការស្វែងយល់ពីព្រះគម្ពីរ ។ សុំឲ្យសិស្សរកឃ្លាដែល មានន័យចំពោះពួកគេ ហើយចែកចាយពីមូលហេតុដែលពួកគេចូលចិត្តឃ្លាទាំងនេះ ។

អ្នកអាចអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយ ប្រធាន ម៉ារ៉ុន ជី រ៉មនី នៃគណៈប្រធាន ទី មួយ ៖

« នៅក្នុងផ្ទះរបស់យើង ខ្ញុំមានអារម្មណ៍ជឿជាក់ថា បើឪពុកម្តាយអានព្រះគម្ពីរមមនប្រកប ដោយការអធិស្ឋានជាទៀងទាត់ ទាំងពួកគេ និង កូនចៅរបស់ពួកគេ នោះព្រះវិញ្ញាណនៃ ព្រះគម្ពីរដ៏មហិមានោះនឹងមកបំពេញនៅក្នុងផ្ទះរបស់យើង ហើយនឹងអ្នកទាំងអស់ណា ដែលរស់នៅក្នុងនោះ ។ វិញ្ញាណនៃគារវភាព នឹងកើនឡើង ការគោរពគ្នាទៅវិញទៅមក និង ការគិតគូរដល់គ្នា នឹងកើនឡើង ។ វិញ្ញាណនៃការទាស់ទែងនឹងចាកចេញទៅ ។ ឪពុកម្តាយ នឹងទូន្មានកូនៗ ដោយក្តីស្រឡាញ់កាន់តែខ្លាំងឡើង និង ដោយភាពកាន់តែឈ្លាសវៃ ។ កូនៗ នឹងកាន់តែស្ទុះស្ទាឡើង និង គ្មានការរឹងរូសចំពោះការប្រឹក្សានោះទេ ។ សេចក្តីសុចរិត នឹងកើនឡើង ។ សេចក្តីជំនឿ សេចក្តីសង្ឃឹម និង សេចក្តីសប្បុរស —សេចក្តីស្រឡាញ់ដ៏ សុទ្ធសាធនៃព្រះគ្រីស្ទ —នឹងកើតមានច្រើននៅក្នុងផ្ទះ និង ជីវិតរបស់យើង ដោយនាំមកនូវ សេចក្តីសុខសាន្ត សេចក្តីអំណរ និង សុភមង្គលដែលកម្រើកឡើងនៅក្នុងពួកគេ » (នៅក្នុង របាយការណ៍សន្និសីទ ខែ មេសា ឆ្នាំ១៩៦០ ទំព័រ ១១២–១៣; ជកស្រង់ដោយ អ៊ែសរ៉ា ថាហ្វ បែនសឺន « Cleansing the Inner Vessel » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៦ ទំព័រ ៦) ។

មេរៀនទី ១០

នីហ្វៃទី១ ៦ និង ៩

សេចក្តីផ្តើម

ដូចដែលនីហ្វៃបាននិយាយថា « ត្បិតភាពពោរពេញនៃចេតនារបស់ខ្ញុំ គឺដើម្បីឲ្យខ្ញុំអាចបញ្ចុះបញ្ចូលមនុស្ស ឲ្យមកកាន់ព្រះនៃអ័ប្រាហាំ និង ព្រះនៃអ៊ីសាក និង ព្រះនៃយ៉ាកុប ហើយបានសង្គ្រោះ » (នីហ្វៃទី១ ៦:៤) ។ គាត់បានរក្សាទុកនូវកំណត់ត្រាពីផ្នាំង ៖ ផ្នាំងនីហ្វៃតូច និង ផ្នាំងនីហ្វៃធំ ។ ព្រះអម្ចាស់បានដាក់បញ្ញត្តិគាត់ ឲ្យសង្ខេបដំណើររឿងរបស់លីហៃ នៅលើផ្នាំងតូច (សូមមើល នីហ្វៃទី២ ៥:២៨ –៣១) ។ ក្រោយមក មរមន ត្រូវបានបំផុសគំនិតឲ្យរួមបញ្ចូលផ្នាំងតូចនៅក្នុងការចងក្រងព្រះគម្ពីរមរមន (សូមមើល ៣ក្យសម្តីនៃមរមន ១:៦–៧) ។ ទាំងនីហ្វៃ និង មរមន មិនបានដឹងពីមូលហេតុនោះទេ ប៉ុន្តែទាំងពីរនាក់បានធ្វើតាមការណែនាំនៃព្រះអម្ចាស់ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ៦

នីហ្វៃសរសេរដើម្បីបញ្ចុះបញ្ចូលមនុស្សទាំងអស់ ឲ្យមកកាន់ព្រះយេស៊ូវគ្រីស្ទ

សូមបង្ហាញសៀវភៅ ឬ រឿងសមរម្យបីបួន ដែលល្បីៗសម្រាប់យុវវ័យនាពេលបច្ចុប្បន្ន ។ សូមសួរសិស្សពីអារម្មណ៍របស់ពួកគេដែលជាគោលបំណងរបស់អ្នកនិពន្ធ ឬ អ្នកបង្កើតចំពោះសៀវភៅ ឬ រឿងនីមួយឡើង ។ សូមលើកព្រះគម្ពីរមរមនមួយក្បាលឡើង ។ សូមប្រាប់សិស្សថា នៅក្នុងនីហ្វៃទី១ ៦ នីហ្វៃបានពន្យល់ពីគោលបំណងរបស់គាត់ចំពោះការសរសេរកំណត់ត្រារបស់គាត់ ដែលនៅទីបញ្ចប់ក្លាយជាផ្នែកនៃព្រះគម្ពីរមរមន ។

សូមឲ្យសិស្សអាន នីហ្វៃទី ១ ៦:៣ –៦ ហើយស្វែងរក៣ក្យ និង ឃ្លា ដែលបង្ហាញពីបំណងរបស់នីហ្វៃក្នុងការរក្សាទុកនូវកំណត់ត្រារបស់គាត់ ។ (អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំ៣ក្យទាំងនេះ) ។

- ហេតុអ្វីបានជាវាមានសារៈសំខាន់ដែល នីហ្វៃបានសរសេររឿង « ដែលសព្វព្រះហឫទ័យដល់ព្រះ » និង មិនមែនជារឿង « ដែលបំពេញចិត្តលោកិយ » ដូច្នេះ ?
- តើអ្នកនឹងនិយាយពីបំណងរបស់នីហ្វៃជាសម្តីរបស់អ្នកផ្ទាល់យ៉ាងដូចម្តេច ? (វាអាចជាជំនួយដល់អ្នកដើម្បីពន្យល់ថា ឃ្លា « ព្រះនៃអ័ប្រាហាំ និង ព្រះនៃអ៊ីសាក និង ព្រះនៃយ៉ាកុប » សំដៅលើព្រះយេស៊ូវគ្រីស្ទ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរ *ព្រះយេស៊ូវគ្រីស្ទ* នៅក្នុងព្រះគម្ពីររបស់ពួកគេ ក្បែរនីហ្វៃទី១ ៦:៤ ។ អ្នកក៏អាចពន្យល់ថា ព្រះនាមព្រះយេហូវ៉ា ក៏សំដៅលើព្រះយេស៊ូវគ្រីស្ទដែរ ។ | សូមមើល នីហ្វៃទី១ ១៩:១០ ; នីហ្វៃទី២ ១១:៤, ៦– ៧ ; សូមមើលផងដែរ វចនានុក្រមព្រះគម្ពីរបរិសុទ្ធ « ព្រះគ្រីស្ទ » « ព្រះគ្រីស្ទ ព្រះនាម » |) ។

ដើម្បីជួយសិស្សឲ្យមានអំណរគុណថា ព្រះគម្ពីរមរមន គឺជាសក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ សូមអញ្ជើញពួកគេឲ្យបើកទៅលិបិក្រម និង មើលសង្ខេប៣ក្យក្បាលរឿងទាំងអស់ ដែលទាក់ទងនឹងព្រះយេស៊ូវគ្រីស្ទ ។ សុំឲ្យពួកគេរកមើលវិធីពីរបីដែលព្រះគម្ពីរមរមនបង្រៀនអំពីបេសកកម្មនៃព្រះអង្គសង្គ្រោះ ។

សូមអញ្ជើញសិស្សម្នាក់សរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***គោលបំណងមួយនៃព្រះគម្ពីរមរមន គឺដើម្បីបញ្ចុះបញ្ចូលមនុស្សទាំងអស់ដើម្បីឲ្យមកកាន់ព្រះយេស៊ូវគ្រីស្ទ ។***

- តើការយល់ពីគោលបំណងរបស់នីហ្វៃ ក្នុងការសរសេរនេះ មានឥទ្ធិពលលើការគ្រោងទុក សិក្សាព្រះគម្ពីរមរមនរបស់អ្នកនៅក្នុងឆ្នាំនេះ យ៉ាងដូចម្តេច ?

សូមចែកចាយពីរបៀបដែលព្រះគម្ពីរមរមន បានជួយអ្នកឲ្យខិតកាន់តែជិតទៅព្រះវរបិតាសួគ៌ និង ព្រះអង្គសង្គ្រោះ ។ សូមអញ្ជើញសិស្សឲ្យចែកចាយពីរបៀបដែលព្រះគម្ពីរមរមន បានមានឥទ្ធិពលដល់ជីវិតរបស់ពួកគេ និង បាននាំពួកគេខិតទៅជិតព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ សូមលើកទឹកចិត្តពួកគេ ឲ្យចែកចាយពីអារម្មណ៍របស់ពួកគេអំពីព្រះគម្ពីរមរមន និង ទីបន្ទាល់របស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ទ ជាមួយនឹងមិត្តភក្តិ ឬ សមាជិកគ្រួសាររបស់គេម្នាក់ក្នុងអំឡុងពេលបីបួនថ្ងៃទៀត ។

> *សូមពន្យល់ ចែកចាយ ឬ ថ្លែងទីបន្ទាល់នៅខាងក្រៅថ្នាក់រៀន*
>
> នៅពេលសិស្សចែកចាយពីទីបន្ទាល់របស់ពួកគេនៅខាងក្រៅថ្នាក់ ការយល់ពីសេចក្តីពិតរបស់ពួកគេដែលបានរៀននៅក្នុងថ្នាក់ នឹងកាន់តែសឹងជម្រៅ ។ សូមលើកទឹកចិត្តពួកគេឲ្យរកមើលឱកាសដើម្បីបង្រៀន និង ថ្លែងទីបន្ទាល់ពីគោលការណ៍នៃដំណឹងល្អ នៅពេលពួកគេទាក់ទងនឹងសមាជិកគ្រួសារ ហើយនិងមិត្តភក្តិរបស់ពួកគេ ។

នីហ្វៃទី១ ៩

នីហ្វៃ រក្សាផ្នាំងពីរដុំ

សូមបង្ហាញសៀវភៅប្រវត្តិសាស្ត្រមួយក្បាលទៅកាន់សិស្សក្នុងថ្នាក់ និង បញ្ជាក់ពីពេលវេលាដែលសៀវភៅនេះកត់ត្រា ។ បន្ទាប់មក សូមបង្ហាញសិស្សក្នុងថ្នាក់នូវប្រវត្តិសាស្ត្រផ្ទាល់ខ្លួន ទិន្នានុប្បវត្តិ ឬ សៀវភៅកំណត់ហេតុ ដែលកត់ត្រាពីរយៈពេលដូចគ្នានោះដែរ ។ (នៅពេលសមរម្យ សូមអានបទពិសោធន៍ខាងវិញ្ញាណចេញពីសៀវភៅកំណត់ហេតុ) ។

- តើអត្ថបទទាំងពីរនេះ ខុសគ្នាយ៉ាងដូចម្តេចពីរបៀបពួកគេក្នុងការកត់ត្រាប្រវត្តិសាស្ត្រ ?
- តើអត្ថបទមួយមានតម្លៃជាងអត្ថបទមួយទៀតឬ ? ដោយរបៀបណា ? (អត្ថបទនីមួយៗ មានតម្លៃក្នុងហេតុផលខុសៗគ្នា) ។

- តើអត្ថបទទាំងនេះ ប្រៀបធៀបជាមួយនឹងព្រះគម្ពីរមរមនយ៉ាងដូចម្តេច ?

សូមពន្យល់ថា នៅក្នុងនីហ្វៃទី១ ៩:១– ៥ នីហ្វៃប្រាប់អំពីការខិតខំរបស់គាត់ដើម្បីរក្សាទុកនូវកំណត់ត្រាទាំងឡាយនៅលើផ្ទាំងទាំងពីរនេះ ។

នៅក្នុងផ្ទាំងមួយ ដែលឥឡូវស្គាល់ថាជា ផ្ទាំងនីហ្វៃធំ គាត់បានកត់ត្រានូវ « ប្រវត្តិរបស់ប្រជាជន | របស់គាត់ | » (នីហ្វៃទី១ ៩:២) ។ ប្រវត្តិសាស្ត្រនេះ រួមមាន « ដំណើររឿងនៃរជ្ជកាលរបស់ស្តេចនានា និង សង្គ្រាម និង ការទាស់ទែងទាំងឡាយនៃប្រជាជន | របស់គាត់ | » (នីហ្វៃទី១ ៩:៤) ។ វាគឺជាកំណត់ត្រាទីមួយដែលនីហ្វៃបានកត់ ប៉ុន្តែវាមិនបានរួមបញ្ចូលនៅក្នុងអ្វីដែលយើងបច្ចុប្បន្នមានជាព្រះគម្ពីរមរមននោះទេ ។

នៅលើផ្ទាំងមួយទៀត ដែលឥឡូវយើងស្គាល់ថាជាផ្ទាំងនីហ្វៃតូច គាត់បានកត់ត្រា « ការបម្រើនៃប្រជាជន | របស់គាត់ | » (នីហ្វៃទី១ ៩:៣) ។ អ្នកអាចពន្យល់ថា ពាក្យ *ការបម្រើ* សំដៅលើការបង្រៀន និង សកម្មភាពខាងសាសនា ។ កំណត់ត្រារបស់នីហ្វៃ នៅក្នុងផ្ទាំងតូច ឥឡូវត្រូវបានរកឃើញនៅក្នុងសៀវភៅ នីហ្វៃទី១ និង នីហ្វៃទី២ ។

ដើម្បីជួយសិស្សឲ្យបែងចែកភាពខុសគ្នារវាងផ្ទាំងតូច និង ផ្ទាំងធំ នៅពេលពួកគេអានន៍ហ្វៃទី១ ៩ សូមសរសេរពាក្យខាងក្រោមនៅលើក្តារខៀន ៖ « *ផ្ទាំងទាំងនេះ* » = *ផ្ទាំងតូច* និង « *ផ្ទាំងផ្សេងទៀត* » = *ផ្ទាំងធំ* ។(អ្នកអាចផ្តល់យោបល់ថា សិស្សគួរតែសរសេរពាក្យទាំងនេះ នៅក្នុងព្រះគម្ពីររបស់គេ ក្បែរខគម្ពីរដែលសមស្រប) ។ នៅក្នុង នីហ្វៃទី១ ៩ ឃ្លា « ផ្ទាំងទាំងនេះ » តែងតែសំដៅលើផ្ទាំងតូច ។ ឃ្លា « ផ្ទាំងផ្សេងទៀត » សំដៅលើផ្ទាំងធំ ។

សុំឲ្យសិស្សអាន នីហ្វៃទី១ ៩:៣, ៥ –៦ ឮៗ ។

- តើនីហ្វៃបានផ្តល់ហេតុផលអ្វី អំពីការធ្វើផ្ទាំងតូច បន្ថែមលើផ្ទាំងធំ ? តើការពន្យល់ទាំងនេះ បង្ហាញពីសេចក្តីជំនឿរបស់នីហ្វៃលើព្រះអម្ចាស់ដោយរបៀបណា ?

សូមពន្យល់ថា ជិត ១០០០ ឆ្នាំក្រោយមក ព្យាការីមរមន បានធ្វើសេចក្តីសង្ខេប ឬ ចងក្រងរគ្គខ្លី នៃកំណត់ត្រាទាំងអស់ដែលបានសរសេរដោយប្រជាជនរបស់គាត់ ។ នេះក្លាយជាអ្វីដែលយើងហៅសព្វថ្ងៃនេះថាជា ព្រះគម្ពីរមរមន ។ នៅពេលដែលគាត់បានធ្វើសេចក្តីសង្ខេបនេះ គាត់បានរកឃើញផ្ទាំងនីហ្វៃតូច និង រួមបញ្ចូលវានៅក្នុងកំណត់ត្រារបស់គាត់ ។

សូមអញ្ជើញសិស្សម្នាក់អាន ពាក្យសម្តីនៃមរមន ១:៣ –៧ ឮៗ ។ សូមពន្យល់ថា មរមនបានសរសេរពាក្យទាំងនេះនៅប្រហែលឆ្នាំ ៣៨៥ គ. ស. នៅពេលចុងបញ្ចប់នៃសង្គ្រាម រវាងសាសន៍នីហ្វៃ និង សាសន៍លេមិន ។ នៅពេលសិស្សអានខគម្ពីរទាំងនេះ សូមឲ្យពួកគេរកមើលហេតុផលដែលមរមន បានផ្តល់ចំពោះការបញ្ចូលផ្ទាំងនីហ្វៃតូច នៅក្នុងសេចក្តីសង្ខេបរបស់គាត់ ។

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ម៉ាវីន ជេ អាស៊ុន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ពេលខ្លះ នៅពេលយើងត្រូវបានសុំឲ្យគោរពប្រតិបត្តិ យើងមិនដឹងពីមូលហេតុនោះទេ លើកលែងតែព្រះអម្ចាស់បានបញ្ជា ។ . . . នីហ្វៃ បានធ្វើតាមការណែនាំ ទោះបីជាគាត់មិនយល់ពេញលេញពីគោលបំណងដ៏ឈ្លាសវៃដ៏ដោយ ។ ការគោរពប្រតិបត្តិរបស់គាត់ ផ្តល់ជាពរជ័យដល់គ្រប់ជាតិពូជសាសន៍នៅទូទាំងពិភពលោក » (« តើនរណានឹងបាត់បង់ការច្រួតកាត់ ? » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ទំព័រ ៥១ ។

សូមបង្ហាញថា ដោយសារគំរូរបស់នីហ្វៃ និងមរមន យើងរៀនថា **យើងត្រូវកាន់តាមព្រះបញ្ញត្តិរបស់ព្រះ និង ធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណ ទោះបីជានៅពេលយើងមិនយល់ពេញលេញពីមូលហេតុចំពោះរឿងនោះក៏ដោយ ។**

- ហេតុអ្វីបានជាវាសំខាន់ដើម្បីកាន់តាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ និង ធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណ ទោះបីជានៅពេលយើងមិនយល់ពេញលេញពីមូលហេតុចំពោះរឿងនោះក្តី ?
- តើនៅពេលណាដែលអ្នកបានគោរពតាមព្រះអម្ចាស់ ឬ ធ្វើតាមការបំផុសគំនិតពិសេសណាមួយ ដោយពុំបានយល់ដឹងច្បាស់ពីមូលហេតុនោះ ?
- តើយើងអាចអភិវឌ្ឍទំនុកចិត្ត និង កម្លាំងចិត្តខ្លាំងជាងមុន ដើម្បីស្មោះត្រង់នឹងការណែនាំរបស់ព្រះដោយរបៀបណា ?

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងកាន់តាមតាមព្រះបញ្ញត្តិរបស់ព្រះ និង ធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ការយល់ដឹងរបស់យើងពីគោលបំណងនៅពីក្រោយការណ៍នោះនឹងរីកចម្រើនឡើង ហើយព្រះអម្ចាស់នឹងប្រទានពរដល់យើង សម្រាប់ការគោរពប្រតិបត្តិរបស់យើង ។

សុំឲ្យសិស្សម្នាក់អាន ការពន្យល់ខាងក្រោមឮៗ ។ (អ្នកអាចឲ្យសិស្សម្នាក់ៗនូវក្រដាសចម្លងតូចមួយសន្លឹក ដើម្បីឲ្យពួកគេអាចមើលតាម និង សៀតវានៅក្នុងព្រះគម្ពីររបស់គេ សម្រាប់ការយោងនៅថ្ងៃក្រោយ) ។

យ៉ាងហោចណាស់ ផ្នែកនៃ « គោលបំណងដ៏គតិបណ្ឌិត » របស់ព្រះអម្ចាស់ (នីហ្វៃទី១ ៩:៥ ; ពាក្យសម្តីនៃមរមន ១:៧) ក្នុងការដែលឲ្យនីហ្វៃរក្សាទុកកំណត់ត្រាទាំងពីរនោះ បានឃើញច្បាស់ នៅពេលដែលយ៉ូសែប ស៊្មីធ បានបកប្រែព្រះគម្ពីរមរមន ។ យ៉ូសែប បានបកប្រែដំបូងគេនូវសេចក្តីសង្ខេបរបស់មរមន ពីផ្ទាំងនីហ្វៃធំ ។ ម៉ាទីន ហារីស ដែលបានជួយយ៉ូសែប ចង់បង្ហាញការបកប្រែនេះទៅប្រពន្ធ និង គ្រួសាររបស់គាត់ ។ ដោយស្វាក់ស្ងើរ ព្យាការីបានអនុញ្ញាតឲ្យម៉ាទីន ខ្ចីអត្ថបទដែលសរសេរដោយដៃចំនួន ១១៦ ទំព័រនោះ ដែលបានបញ្ចប់រួចហើយនៅពេលនោះ ។ អត្ថបទទាំង ១១៦ ទំព័រនោះ ត្រូវបានគេលួចពីម៉ាទីន ហើយជាលទ្ធផល ផ្ទាំង យូរីម និង ធូមីម និង អំណោយទានដើម្បីបកប្រែ ត្រូវបានដកវិញជាបណ្តោះអាសន្នពីយ៉ូសែប ស៊្មីធ (សូមមើល គ. និង ស. ៣:១៤) ។

ក្រោយពី យ៉ូសែប ស៊្មីធ បានឆ្លងកាត់រយៈពេលនៃការកែប្រែចិត្ត (សូមមើល គ. និង ស. ៣:១០) ព្រះអម្ចាស់បានប្រាប់គាត់ មិនឲ្យបកប្រែសារឡើងវិញនូវចំណែកដែលបានបាត់នោះទេ (សូមមើល គ. និង ស. ១០:៣០) ។ ផ្ទុយទៅវិញ ទ្រង់បានបញ្ជាឲ្យគាត់បកប្រែផ្ទាំងនីហ្វៃតូច (សូមមើល គ. និង ស. ១០:៤១) ដែលមានរយៈពេលដូចគ្នា ។ គាត់បានប្រាប់យ៉ូសែបថា អស់អ្នកដែលបាន

យកអត្តបទ ១១៦ ទំព័រនោះ បានផ្លាស់ប្តូរពួកគេ និង មានគម្រោងដើម្បីប្រើវា ដើម្បីទម្លាក់តម្លៃកិច្ចការនេះ (សូមមើល គ. និង ស. ១០:១០– ១៩) ។ ព្រះអម្ចាស់បានដឹងព័ត៌មានការណ៍ទាំងនេះ ជាច្រើនឆ្នាំមុន ហើយបានផ្តល់កំណត់ត្រាទីពីរ ដើម្បីធ្វើឲ្យគម្រោងរបស់សាតាំងបរាជ័យ ។ (សូមមើល *History of the Church* ១:២០–២៣; គ. និង ស. ១០:៣៨–៤៦ ។)

សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ៩:៦ រៀង២ខ្លួន ។ សុំឲ្យពួកគេស្វែងរកគោលលទ្ធិ ដែលនីហ្វៃបង្រៀននៅក្នុងខគម្ពីរនេះ ។ សូមឲ្យសិស្សម្នាក់សរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***ព្រះទ្រង់ញាណគ្រប់ការណ៍ទាំងអស់ និង រៀបចំមធ្យោបាយមួយដើម្បីសម្រេចកិច្ចការរបស់ទ្រង់ទាំងអស់ ។***

- តើហេតុអ្វីបានជាវាមានអត្ថប្រយោជន៍ ដើម្បីដឹងថា « ព្រះអម្ចាស់ទ្រង់ញាណគ្រប់ការណ៍ទាំងអស់ពីដើមដំបូង » ? (នីហ្វៃទី១ ៩:៦ ; សូមមើលផងដែរ នីហ្វៃទី២ ៩:២០; ពាក្យសម្តីនៃមរមន ១:៧ ។)
- តើគោលលទ្ធិនេះ អាចមានឥទ្ធិពលលើរបៀបរស់នៅរបស់អ្នកយ៉ាងណាដែរ ? (នៅពេលសិស្សឆ្លើយសំណួរនេះ អ្នកអាចចែកចាយគំនិតរបស់អ្នកអំពី របៀបដែលគោលលទ្ធិនេះបានបង្កើនសេចក្តីជំនឿ សេចក្តីសង្ឃឹម និង ការទុកចិត្តរបស់អ្នកលើព្រះ) ។
- តើគោលលទ្ធិនេះ អាចជួយអ្នក នៅពេលអ្នកជួបនឹងបញ្ហាយ៉ាងដូចម្តេចខ្លះ ? (ចម្លើយដែលអាចមាន អាចថា យើងអាចស្វែងរកការលួងលោមនៅក្នុងការការពារដែលព្រះ អាចឃើញលទ្ធផលនៃឧបសគ្គ និង ការប្រកួតប្រជែងរបស់យើង ទោះបីជាយើងមិនអាចឃើញក្តី ។ ហើយតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ទ្រង់អាចប្រទានដល់យើងនូវកម្លាំង ការលួងលោម និង ការណែនាំដើម្បីយកឈ្នះ ឬ ស៊ូទ្រាំនឹងការលំបាកនៃជីវិត) ។

សូមបង្ហាញការជឿជាក់របស់អ្នកថា ព្រះទ្រង់ញាណគ្រប់ការណ៍ទាំងអស់ រួមមានអ្វីដែលល្អបំផុត សម្រាប់កូនចៅរបស់ទ្រង់ម្នាក់ ។ សូមជួយសិស្សឲ្យឃើញថា ពេញមួយជីវិតរបស់ពួកគេ ពួកគេនឹងជួបនឹងព្រះបញ្ញត្តិ និង ទទួលបាននូវការបំផុសគំនិតពីព្រះដែល ពួកគេមិនអាចដឹងច្បាស់លាស់នាពេលដំបូង ។ ការគោរពប្រតិបត្តិរបស់ពួកគេចំពោះព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ និង ការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធ នឹងប្រទានពរដល់ជីវិតរបស់ពួកគេផ្ទាល់ និង ជីវិតរបស់អ្នកដទៃទៀត ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី១ ៦:៤ ។ « ព្រះនៃអ័ប្រាហាំ និង ព្រះនៃអ៊ីសាក និង ព្រះនៃយ៉ាកុប »

ប្រធាន អែសរ៉ា ថាហ្វ ថែនសឺន បានពន្យល់ថា នៅពេលដែលព្រះគម្ពីរនិយាយពីព្រះនៃអ័ប្រាហាំ អ៊ីសាក និង យ៉ាកុប នោះបទគម្ពីរនោះសំដៅលើព្រះយេស៊ូវគ្រីស្ទ ៖ « យើងត្រូវតែចាំថានរណាជាព្រះយេស៊ូវ មុនពេលដែលទ្រង់បានប្រសូតមកនោះ ។ ទ្រង់គឺជាអង្គបង្កបង្កើតគ្រប់ការណ៍ទាំងអស់ ព្រះយេហូវ៉ាដ៏មហិមា កូនចៀមដែលបានសម្លាប់មុនការបង្កបង្កើតពិភពលោក ព្រះនៃអ័ប្រាហាំ អ៊ីសាក និង យ៉ាកុប ។ ទ្រង់ធ្លាប់ជា និង ជាព្រះដ៏បរិសុទ្ធនៃអ៊ីស្រាអែល » (« Five Marks of the Divinity of Jesus Christ » *Ensign* ខែ ធ្នូ ឆ្នាំ ២០០១ទំព័រ ១០) ។

នីហ្វៃទី១ ៩:៦) ។ ព្រះទ្រង់ញាណគ្រប់ការណ៍ទាំងអស់ពីដើមដំបូង

យើងអាចមានទំនុកចិត្តថា ព្រះទ្រង់ញាណគ្រប់ការណ៍ទាំងអស់ ។ « បើគ្មានការចេះដឹងពីគ្រប់ការណ៍ទាំងអស់ទេ នោះព្រះនឹងពុំអាចសង្គ្រោះចំណែកណាមួយនៃសត្វលោករបស់ទ្រង់បានទេ ដ្បិតដោយសារវាជាចំណេះដឹងដែលទ្រង់មានគ្រប់ការណ៍ទាំងអស់ ពីដើមដំបូងដល់ចុងបញ្ចប់ហើយ ទើបបណ្តាលឲ្យទ្រង់ផ្តល់នូវការយល់ដឹងនោះដល់កូនចៅរបស់ទ្រង់ ដែលពួកគេគឺជាអ្នកទទួលយកនូវជីវិតដ៏នៅអស់កល្បជានិច្ច ហើយប្រសិនបើវាមិនមែនសម្រាប់គំនិតដែលមាននៅក្នុងដួងចិត្តរបស់មនុស្សនោះ ដែលថាព្រះមានគ្រប់ចំណេះដឹងទាំងអស់ វានឹងមិនអាចទៅរួចសម្រាប់ពួកគេក្នុងការអនុវត្តសេចក្តីជំនឿនៅក្នុងទ្រង់នោះទេ » (*ការបង្រៀនពីសេចក្តីជំនឿ* [១៩៨៥] ទំព័រ ៥១–៥២) ។

មេរៀនសិក្សានៅផ្ទះ

នីហ្វៃទី១ ១–៦; ៩ (មេរៀនទី ២)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនការសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

ការសង្ខេបគោលលទ្ធិ និង គោលការណ៍ ខាងក្រោម សិស្សរៀននៅពេលពួកគេបានសិក្សា នីហ្វៃទី១ ១–៦; ៩ (មេរៀនទី ២) មិនត្រូវបានបម្រុងទុកសម្រាប់ បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីនេះតែប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកពិចារណាពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (នីហ្វៃទី១ ១)

នៅពេលសិស្សសិក្សាអំពីលីហៃ ដែលបានព្យាករណ៍ទៅដល់ប្រជាជន និង ព្រមានដល់ពួកគេឲ្យប្រែចិត្ត ពួកគេបានដឹងថា ព្យាការីបានព្រមានប្រឆាំងនឹងការធ្វើបាប និង បង្រៀនអំពីសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវគ្រីស្ទ ។ លើសពីនេះ ពួកគេបានដឹងថា សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់ ត្រូវពង្រីកចំពោះអស់អ្នកដែលអនុវត្តសេចក្តីជំនឿលើទ្រង់ ។

ថ្ងៃទី ២ (នីហ្វៃទី១ ២)

លីហៃ ឆ្លើយតបនឹងការបញ្ជារបស់ព្រះអម្ចាស់ឲ្យចាកចេញពីទីក្រុងយេរូសាឡិម ។ គាត់បានលើកឧទាហរណ៍ពីគោលការណ៍នោះថា នៅពេលយើងស្មោះត្រង់ និងប្រតិបត្តិនោះព្រះអម្ចាស់នឹងជួយយើងនៅក្នុងពេលជួបនឹងឧបសគ្គ ។ នីហ្វៃ បានបង្ហាញស្មារតីនៃការប្រតិបត្តិមួយ ហើយបានរៀនសម្រាប់ខ្លួនគាត់ថា នៅពេលយើងអំពាវនាវរកទ្រង់ ទ្រង់អាចបន្ទន់ដួងចិត្តរបស់យើងឲ្យជឿតាមព្រះបន្ទូលរបស់ទ្រង់បាន ។ សិស្សបានដឹងថា ព្រះនឹងប្រទានពរដល់អ្នកណាដែលគោរពប្រតិបត្តិ និង ស្មោះត្រង់ ។

ថ្ងៃទី ៣ (នីហ្វៃទី១ ៣–៤)

នៅពេលលីហៃ បានប្រាប់នីហ្វៃ និង បងរបស់គាត់អំពីការបញ្ជារបស់ព្រះចំពោះពួកគេ ដើម្បីត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ ដើម្បីទៅយកផ្ទាំងលង្ហិន នីហ្វៃបានឆ្លើយតបដោយការធ្វើទីបន្ទាល់ថា ប្រសិនបើយើងនឹងធ្វើអ្វីៗដែលព្រះអម្ចាស់បានបញ្ជា នោះទ្រង់នឹងរៀបចំផ្លូវមួយសម្រាប់យើងដើម្បីសម្រេចការណ៍នោះ ។ នីហ្វៃ និង បងៗរបស់គាត់ បានដឹងថា វាពិបាកដើម្បីធ្វើតាមបញ្ញត្តិរបស់ព្រះអម្ចាស់ ។ ការតាំងចិត្តរបស់នីហ្វៃ ក្នុងការត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ បានជួយសិស្សឲ្យយល់ថា នៅពេលយើងអនុវត្តសេចក្តីជំនឿលើព្រះ ហើយស្វែងរកដើម្បីធ្វើអ្វីដែលទ្រង់ដាក់បញ្ញត្តិ ទោះជាពេលយើងមិនអាចឃើញពីលទ្ធផលក៏ដោយ ក៏ទ្រង់នឹងដឹកនាំយើងដោយព្រះវិញ្ញាណបរិសុទ្ធដែរ ។

ថ្ងៃទី ៤ (នីហ្វៃទី១ ៥–៦; ៩)

នៅពេលសិស្សបានសិក្សាអំពីបទពិសោធន៍របស់លីហៃ ក្នុងការស្វែងយល់ពីផ្ទាំងលង្ហិន ពួកគេបានឃើញនូវគោលការណ៍ខាងក្រោម ៖ នៅពេលយើងស្វែងយល់ពីព្រះគម្ពីរ យើងអាចពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ និង ទទួលបាននូវវិវរណៈ ។ នៅពេលពួកគេបានរៀនពីគោលបំណងរបស់នីហ្វៃ នៅក្នុងការសរសេរកំណត់ត្រារបស់គាត់ សិស្សក៏បានរៀនពីគោលបំណងនៃព្រះគម្ពីរមរមន គឺដើម្បីបញ្ចុះបញ្ចូលមនុស្សទាំងអស់ឲ្យចូលមកកាន់ព្រះយេស៊ូវគ្រីស្ទ ។

សេចក្តីផ្តើម

មេរៀនសប្តាហ៍នេះ នឹងផ្តល់ដល់សិស្សនូវឱកាសដើម្បីវិលត្រឡប់ទៅវិញ និង ពិភាក្សាពីអ្វីដែលពួកគេបានរៀនពីគំរូរបស់គ្រួសារលីហៃ និង សកម្មភាពនៃសេចក្តីជំនឿរបស់ពួកគេ ។ នៅពេលអ្នកបង្រៀនមេរៀននេះ សូមបញ្ជាក់លើការគោរពប្រតិបត្តិដ៏ស្មោះត្រង់របស់នីហ្វៃ ចំពោះបញ្ញត្តិរបស់ព្រះអម្ចាស់ និង ការស្វែងរកដោយឧស្សាហ៍ព្យាយាមរបស់គាត់ ដើម្បីដឹងពីសេចក្តីពិតនៃ « អស់ទាំងពាក្យ ដែលបានពោលមកដោយឪពុករបស់ខ្ញុំ » (នីហ្វៃទី១ ២:១៦) ។ នៅពេលសិស្សធ្វើតាមគំរូនៃការគោរពប្រតិបត្តិរបស់នីហ្វៃ ពួកគេនឹងកសាងទីបន្ទាល់ផ្ទាល់ខ្លួនរបស់គេ អំពីដំណឹងល្អ ។

នៅក្នុងការបង្រៀនរបស់អ្នក សូមធ្វើតាមការដាស់តឿនរបស់អែលឌើរ ដៃហ្វ្រី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« យើងត្រូវតែធ្វើឲ្យការបង្រៀនដ៏ឧត្តមមានជីវិត និង មានពន្លឺឡើងវិញ នៅក្នុងសាសនាចក្រ — នៅផ្ទះ នៅពេលយើងឡើងនិយាយ នៅក្នុងការប្រជុំថ្នាក់ដឹកនាំរបស់យើង ហើយជាការពិតណាស់ នៅក្នុងថ្នាក់រៀន ។ ការបង្រៀនដែលបានទទួលការបំផុសគំនិត មិនដែលត្រូវបានក្លាយជាសិល្បៈដែលបាត់បង់មួយនៅក្នុងសាសនាចក្រឡើយ ហើយយើងត្រូវតែប្រាកដជាថា ការដែលយើងស្វែងរកវា មិនក្លាយជាប្រពៃណីមួយដែលបាត់បង់ដែរ ។ . . .

« . . . សូមឲ្យយើងតម្កើងឡើងនូវបទពិសោធក្នុងការបង្រៀន នៅក្នុងផ្ទះ និង នៅក្នុងសាសនាចក្រ និង បង្កើននូវពាល់ការខិតខំរបស់យើង ដើម្បីស្តាបនា និង ណែនាំ » (« គ្រូបង្រៀនមកពីព្រះ » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៨ ទំព័រ ២៥ ២៧) ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ១

ព្រះអម្ចាស់ ពង្រីកសេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ទ្រង់ទៅដល់អ្នកដែលស្មោះត្រង់

សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់ ត្រូវបានពង្រីកទៅដល់អស់អ្នកណាដែលអនុវត្តសេចក្តីជំនឿលើទ្រង់ ។*** សូមអញ្ជើញសិស្សអានសង្ខេបលើ នីហ្វៃទី១ ១ ហើយរកមើលខគម្ពីរ ដែលសេចក្តីពិតនេះ ត្រូវបានបង្រៀនចេញទៅនៅក្នុង ២០) ។

សូមសួរសំណួរខាងក្រោមនេះ ដើម្បីជួយសិស្សនឹកចាំ និង សង្ខេបពីអ្វីដែលពួកគេបានរៀននៅពេលពួកគេបានសិក្សានៅក្នុង នីហ្វៃទី១ ១–៦; ៩ នៅក្នុងសប្តាហ៍នេះ ។

- ចេញពីអ្វីដែលអ្នកបានរៀននៅក្នុងជំពូកទាំងឡាយដែលអ្នកបានសិក្សានៅក្នុងសប្តាហ៍នេះ តើព្រះអម្ចាស់បង្ហាញសេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ទ្រង់ទៅដល់លីហៃ និង គ្រួសាររបស់គាត់យ៉ាងដូចម្តេច ?
- តើគំរូនៃការគោរពប្រតិបត្តិ និង សេចក្តីជំនឿ ដែលបានបង្ហាញដោយលីហៃ និង គ្រួសាររបស់គាត់មានអ្វីខ្លះ ?
- តើនៅពេលណាដែលអ្នកបានឃើញ ព្រះអម្ចាស់បានបង្ហាញសេចក្តីមេត្តាករុណាដ៏ទន់ភ្លន់របស់ទ្រង់ចំពោះអ្នក ឬ ចំពោះនរណាម្នាក់ដែលអ្នកស្គាល់ ?

អ្នកអាចប្រាប់អំពីពេលមួយ នៅពេលដែលព្រះអម្ចាស់បានបង្ហាញសេចក្តីមេត្តាករុណាចំពោះអ្នក និង គ្រួសាររបស់អ្នក នៅពេលអ្នកបានធ្វើសកម្មភាពដោយមានសេចក្តីជំនឿ ឬ ចែកចាយបទពិសោធន៍មួយដែលអ្នកបានអាននៅក្នុងការបោះពុម្ពផ្សាយនៃសាសនាចក្រ ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលគំរូទាំងឡាយនៃព្រះអម្ចាស់ ក្នុងការបង្ហាញសេចក្តីមេត្តាករុណារបស់ទ្រង់ទៅដល់អ្នកដែលស្មោះត្រង់ នៅពេលពួកគេសិក្សាព្រះគម្ពីរមរមនពេញមួយឆ្នាំ ។

នីហ្វៃទី១ ២

ព្រះអម្ចាស់ អាចបន្ទន់ដួងចិត្តរបស់យើង ឲ្យជឿដល់ព្រះបន្ទូលរបស់ទ្រង់

សូមរំឭកសិស្សថា ក្រោយពីលីហៃត្រូវបានបញ្ជាឲ្យចាកចេញពីទីក្រុងយេរូសាឡិមជាមួយនឹងគ្រួសាររបស់គាត់ កូនបុស្សរបស់គាត់ នីហ្វៃ បានធ្វើការខំប្រឹងផ្ចាល់ខ្លួនមួយ ដើម្បីដឹង និង យល់ពីសេចក្តីពិតដ៏ពេញលេញនៃវិវរណៈរបស់ឪពុករបស់គាត់ ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ១ ២:១៦, ១៩ឲ្យឮៗ ។

សួរសិស្សថា ៖ ទោះបីជានីហ្វៃមិនបានគូញគ្រែក្តី តើមានកស្តុតាងអ្វី នៅក្នុងនីហ្វៃទី១ ២:១៦ ដែលថា ការចាកចេញពីទីក្រុងយេរូសាឡិម អាចជាការពិបាកសម្រាប់គាត់ ? (នីហ្វៃបានសរសេរអ្វីដែលគាត់បានអធិស្ឋានសម្រាប់ការយល់ ហើយព្រះអម្ចាស់បានបន្ទន់ដួងចិត្តរបស់គាត់ ។ តម្រុយនេះ គឺជាកស្តុតាងដែលថា ការចាកចេញពីទីក្រុងយេរូសាឡិម មិនមែនជារឿងងាយស្រួលសម្រាប់គាត់ ដូច្នេះព្រះអម្ចាស់បានជួយគាត់ឲ្យទទួលយកផ្នាំងនោះ) ។

សូមសួរ ៖ តើមានកស្តុតាងអ្វី ដែលអ្នកឃើញថា ទោះបីជាលីហៃ និង គ្រួសាររបស់គាត់គោរពប្រតិបត្តិដល់ព្រះអម្ចាស់យ៉ាងណាក្តី ជីវិតគឺនៅតែមិនងាយស្រួលសម្រាប់ពួកគេ ? (សូមមើល នីហ្វៃទី១ ២:៤, ១១) ។

សុំឲ្យសិស្សចែកចាយពីគំនិតដែលពួកគេមាន អំពីបំណងប្រាថ្នារបស់នីហ្វៃ និង អំពីអ្វីដែលគាត់បានធ្វើដែលនាំគាត់ឈានទៅការទទួលយកបញ្ញត្តិរបស់ព្រះអម្ចាស់ ដែលបានផ្តល់តាមរយៈឪពុករបស់គាត់ ។

សូមអញ្ជើញសិស្សពីរបីនាក់ ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេសម្រាប់ថ្ងៃទី ២ លំហាត់ទី ៤ ៖ សូមចែកចាយនូវគំរូមួយនៅពេល ដែលអ្នកបានអំពាវនាវរកព្រះវរបិតាសួគ៌ដូចជានីហ្វៃដែរ ហើយបានទទួលបទពិសោធន៍នូវការបន្ទន់ចិត្តរបស់អ្នក តាមរយៈព្រះវិញ្ញាណ ឬ នៅពេលមួយដែលអ្នកបានទទួលទីបន្ទាល់មួយអំពីអ្វីមួយដែលព្រះអម្ចាស់បានមានព្រះបន្ទូល ។

សូមចែកចាយទីបន្ទាល់ផ្ទាល់ខ្លួនរបស់អ្នកថា **នៅពេលដែលយើងអំពាវនាវដល់ព្រះ ទ្រង់អាចបន្ទន់ចិត្តរបស់យើង ឲ្យជឿលើព្រះបន្ទូលរបស់ទ្រង់ ។**

សុំឲ្យសិស្សគិតពីអ្វីដែលពួកគេអាចធ្វើ ដើម្បីពង្រឹងទីបន្ទាល់របស់ពួកគេ និង ទទួលបាននូវការធានាផ្ទាល់ខ្លួន ដូចជានីហ្វៃផងដែរ ។ សូមផ្តល់ឱកាសដល់ពួកគេ ឲ្យចែកចាយនូវគំនិតរបស់ពួកគេ ប្រសិនបើពួកគេចង់ចែកចាយ ។ សូមលើកទឹកចិត្តពួកគេ ឲ្យធ្វើសកម្មភាពតាមការគិត និង ការបំផុសគំនិតរបស់ពួកគេ ។

នីហ្វៃទី១ ៣–៤

ព្រះអម្ចាស់នឹងរៀបចំផ្លូវ នៅពេលយើងគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ដោយស្មោះត្រង់

សូមឲ្យសិស្សម្នាក់ធ្វើការជាមៃគូ ។ សូមសរសេរខគម្ពីរយោងខាងក្រោមនៅលើក្តារខៀន ៖ *នីហ្វៃទី១ ៣:៦ –៧* និង *នីហ្វៃទី១ ៤:៦ –១៣* ។សូមអញ្ជើញសិស្សអានវគ្គព្រះគម្ពីរ ហើយពិភាក្សានូវសំណួរខាងក្រោម ជាមួយនឹងមៃគូរបស់ខ្លួន ៖

- តើអ្នកគិតថា អ្វីទៅដែលសំខាន់អំពីប្រសាសន៍របស់នីហ្វៃថា « ទោះយ៉ាងណាក៏ដោយ គង់តែខ្ញុំដើរតម្រង់ទៅមុខ » ? (នីហ្វៃទី១ ៤:៧) ។
- តើសេចក្តីជំនឿរបស់នីហ្វៃ ធ្វើឲ្យគាត់អាចទទួលបានផ្នាំងលង្ហិននោះដោយរបៀបណា ?

ក្រោយពីសិស្សបានពិភាក្សាពីទស្សវិស័យជ្រៅជ្រះរបស់ពួកគេជាមួយនឹងមៃគូខ្លួនហើយ សូមពន្យល់ថា ព្រះអម្ចាស់អាចសុំឲ្យយើងធ្វើអ្វីមួយ ដូចដែលទ្រង់បានសុំនីហ្វៃ និង បងៗគាត់ ដោយគ្មានការបង្ហាញប្រាប់ពីមូលហេតុ ពេលវេលា ឬ របៀប ដែលយើងអាចធ្វើវា ដោយភ្លាមៗនោះទេ ។ នីហ្វៃបានដឹងពីមូលហេតុ ពេលវេលា និង របៀបដែលព្រះអម្ចាស់នឹងជួយដល់គាត់ នៅពេល*ក្រោយពី*គាត់បានអនុញ្ញាតឲ្យព្រះវិញ្ញាណ ដឹកនាំគាត់ និង *ក្រោយពី*គាត់បានសម្រេចថា នឹងដើរតម្រង់ទៅមុខ ដោយសេចក្តីជំនឿ ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា **នៅពេលយើងអនុវត្តសេចក្តីជំនឿក្នុងព្រះ ហើយស្វែងរកធ្វើអ្វីដែលទ្រង់បានបញ្ជា ទោះបីជាពេលយើងមិនអាចឃើញពីលទ្ធផលក្តី ក៏ទ្រង់នឹងដឹកនាំយើងដោយតទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធដែរ ។**

បើសិនជាមានពេល អ្នកអាចសួរសិស្សប្រសិនបើពួកគេមានសំណួរ ឬ ចង់ចែកចាយទស្សនវិស័យជ្រៅជ្រះរបស់ពួកគេពីការសិក្សាក្នុង នីហ្វៃទី១ ៥– ៦; ៩ នៅថ្ងៃទី ៤ នេះ ។ ឧទាហរណ៍ អ្នកអាចអញ្ជើញពួកគេឲ្យចែកចាយពីរបៀបដែលពួកគេឆ្លើយតបនឹងលំហាត់ទី ៤ ដែលពួកគេត្រូវសរសេរអំពីពេលមួយ នៅពេលដែលពួកគេបានស្វែងយល់ពីព្រះគម្ពីរ និង មានអារម្មណ៍ពីព្រះវិញ្ញាណនៃព្រះអម្ចាស់ ។

សូមបញ្ចប់ដោយ ការសុំសិស្សម្នាក់ឲ្យអានឮៗ (ឬ សូត្រក្រោយពីការទន្ទេញ) វគ្គចំណេះចំណានខគម្ពីរ នីហ្វៃទី១ ៣:៧ ។ បន្ទាប់មក សួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- តើគោលការណ៍អ្វី ដែលនីហ្វៃទី១ ៣:៧ បានបង្រៀនទាក់ទងនឹងការគោរពប្រតិបត្តិដល់បទបញ្ញត្តិរបស់ព្រះអម្ចាស់ ? (សិស្សគួរតែអាចបង្ហាញគោលការណ៍ដែលថា **ប្រសិនបើយើងស្វែងរកដើម្បីធ្វើអ្វីដែលព្រះអម្ចាស់បានដាក់បញ្ញត្តិដល់យើង ទ្រង់នឹងរៀបចំផ្លូវមួយសម្រាប់យើង ដើម្បីសម្រេចកិច្ចការនោះ ។**)
- យោងតាមអ្វីដែលអ្នកបានអាននៅក្នុង នីហ្វៃទី១ ១– ៦ និង ៩ តើអ្វីជាលទ្ធផលនៃការគោរពប្រតិបត្តិរបស់លីហៃ និង ការគោរពប្រតិបត្តិរបស់នីហ្វៃចំពោះបញ្ញត្តិរបស់ព្រះ ?
- តើនៅពេលណាដែលព្រះអម្ចាស់បានរៀបចំផ្លូវមួយដើម្បីជួយដល់អ្នក ក្នុងការគោរពព្រះបញ្ញត្តិមួយ ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតពីកន្លែងមួយ ដែលពួកគេអាចបង្ហាញនូវការគោរពប្រតិបត្តិរបស់គេចំពោះព្រះយ៉ាងពេញលេញ ។ អ្នកអាចចង់បញ្ចប់មេរៀន ដោយការថ្លែងទីបន្ទាល់ពីពរជ័យទាំងឡាយ ដែលបានមកក្នុងជីវិតរបស់អ្នកតាមរយៈការខិតខំរបស់អ្នកដើម្បីគោរពព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ។

មេរៀនក្រោយ (នីហ្វៃទី១ ៧– ១៤)

នៅក្នុងមេរៀនបន្ទាប់ សិស្សនឹងសិក្សាអំពីការនិមិត្តរបស់លីហៃ និង នីហ្វៃ ។ លីហៃ និង ទស្សនិមិត្តរបស់នីហ្វៃ អំពីដើមឈើជីវិត គឺអាចអនុវត្តបាននៅក្នុងជីវិតរបស់យើងសព្វថ្ងៃនេះ ។ ដំណើររឿងនៃទស្សនិមិត្តរបស់នីហ្វៃ រួមបញ្ចូលការរៀបរាប់ពីការប្រសូត ការបម្រើ និង ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ការរកឃើញ និង អាណានិគមរបស់អាមេរិកដោយសាសន៍ដទៃ និង ការបាត់បង់នូវសេចក្តីពិតដ៏មានសារៈសំខាន់ ពីព្រះគម្ពីរបរិសុទ្ធ និង ការស្តារឡើងវិញនូវសេចក្តីពិតនោះតាមរយៈព្រះគម្ពីរមរមន ។ ដំណើររឿងនៃទស្សនិមិត្តរបស់នីហ្វៃ រួមមានទាំងការរៀបរាប់ពីការស្តារឡើងវិញនៃដំណឹងល្អ ។

នីហ្វៃទី១ ៧

សេចក្តីផ្តើម

នីហ្វៃទី១ ៧រួមមានគំរូនៃការឧទ្ទិសរបស់នីហ្វៃដល់ព្រះ ។ នីហ្វៃបានគោរព នៅពេលព្រះអម្ចាស់បានបញ្ជាដល់គាត់ និង បងៗរបស់គាត់ ឲ្យត្រឡប់ទៅសុំអីសម៉ាអែល និង គ្រួសាររបស់គាត់ឲ្យចូលរួមជាមួយនឹងពួកគេ នៅក្នុទីរហោស្ថាន ដើម្បីពួកគេអាចរៀបការ និង ចិញ្ចឹមកូនៗ ។ ទោះជានៅពេលលេមិន និង លេមយួល ប្រឆាំងទាស់នឹងនីហ្វៃ ហើយបានព្យាយាមសម្លាប់គាត់ក្តី ក៏គាត់នៅតែស្មោះត្រង់ និង ព្យាយាមជួយពួកគេឲ្យស្មោះត្រង់ដដែល ។

ការប្រើការប្រកាសដល់ក្រុមគ្រួសារ

សិស្ទើរ ជូលី ប៊ី រ៉ោក ប្រធានសមាគមស្ត្រីសង្គ្រោះទូទៅ បានលើកទឹកចិត្តឲ្យគ្រូបង្រៀនថ្នាក់សិក្ខាសាលា និង ថ្នាក់វិទ្យាស្ថាន បង្រៀនអំពីសារៈសំខាន់នៃក្រុមគ្រួសារ និង ឲ្យប្រើការប្រកាសដល់ក្រុមគ្រួសារនៅក្នុងមេរៀនរបស់ពួកគេ ៖ « នៅក្នុងសាសនាចក្រនេះ កង្វល់ចម្បងមួយគឺ ដើម្បីបង្រៀន . . . គោលការណ៍ក្រុមគ្រួសារ គោលការណ៍ដែលនឹងបង្រៀន [សិស្ស] ដើម្បីបង្កើតគ្រួសារមួយ ដើម្បីបង្រៀនក្រុមគ្រួសារនោះ និង ដើម្បីរៀបចំគ្រួសារនោះសម្រាប់ពិធីការបរិសុទ្ធ និង សេចក្តីសញ្ញានានា ។ . . . « . . . នៅពេលអ្នកកំពុងបង្រៀនពួកគេ អ្នកអាចភ្ជាប់ទៅការបង្រៀនខាងក្រោយនឹងសេចក្តីថ្លែងការណ៍ និង ឃ្លាគន្លឹះ ដែលនៅក្នុងការប្រកាសចំពោះក្រុមគ្រួសារ ។ ការប្រកាស គឺមិនមែនជាមេរៀនមួយដែលឈរតែឯងនោះទេ » (« ការបង្រៀនគោលលទ្ធិនៃក្រុមគ្រួសារ » [ការផ្សាយតាមផ្កាយណេបនៃថ្នាក់សិក្ខាសាលា និង វិទ្យាស្ថាន នៃសាសនា ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០០៩] ទំព័រ ៥, si.lds.org) ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ៧:១– ៥

ព្រះអម្ចាស់បញ្ជាដល់នីហ្វៃឲ្យត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ ដើម្បីទៅយកអ៊ីសម៉ាអែល និង គ្រួសាររបស់គាត់

សូមបង្ហាញរូបភាពនៃគ្រួសារមីភរិយា និង កូនៗរបស់ពួកគេ ។ (អ្នកអាចប្រើរូបភាពគ្រួសាររបស់អ្នកផ្ទាល់ក៏បាន) ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ៧:១– ២ ឮៗ ។

- **តើព្រះអម្ចាស់បានបញ្ជាដល់កូនៗរបស់លីហៃឲ្យទៅធ្វើអ្វី ? តើសេចក្តីពិតអ្វីដែលយើងអាចរៀនពីការបញ្ជានេះ ?(សូមធ្វើយ៉ាងណាជួយសិស្សឲ្យយល់ថា ព្រះអម្ចាស់ដាក់បញ្ញត្តិដល់យើងឲ្យរៀបការ និង ចិញ្ចឹមកូនៗថ្វាយដល់ទ្រង់ ។)**

សូមរំឭកសិស្សថា វាអាចពិបាកធ្វើដំណើរយៈពេលបីបួនថ្ងៃ កាត់តាមទីរហោស្ថានសម្រាប់នីហ្វៃ និង បងៗរបស់គាត់ ដើម្បីត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ ។

- **ហេតុអ្វីបានជាអាពាហ៍ពិពាហ៍ និង គ្រួសារមានសារៈសំខាន់ដែលសមឲ្យនីហ្វៃ និង បងៗរបស់គាត់ធ្វើដំណើរត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ ដើម្បីជួបនឹងអ៊ីសម៉ាអែល និង គ្រួសាររបស់គាត់ ?**

មុនពេលបន្តមេរៀន អ្នកអាចឲ្យក្រដាស « កុម្រគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » មួយសន្លឹកដល់សិស្ស ឬ ឲ្យពួកគេត្រឡប់ទៅទំព័រនៃការប្រកាសនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ។

សុំឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមពី « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ។ សូមអញ្ជើញសិស្សស្តាប់ដោយប្រុងប្រយ័ត្ន ហើយរកកេមើលអ្វីដែលព្យាការីនៅសម័យចុងក្រោយទាំងឡាយ បានប្រកាសអំពីសារៈសំខាន់នៃអាពាហ៍ពិពាហ៍ ។

« យើង ជាគណៈប្រធានទីមួយ និង ក្រុមប្រឹក្សានៃពួកសាវកដប់ពីរនាក់ នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ សូមប្រកាសជាឱឡារិកថា អាពាហ៍ពិពាហ៍រវាងបុរស និងស្ត្រី គឺត្រូវបានតែងតាំងឡើងដោយព្រះ ហើយថាគ្រួសារជាផ្នែកដ៏សំខាន់មួយនៅក្នុងផែនការរបស់ព្រះដ៏បង្កបង្កើតសម្រាប់គោលដៅដ៏នៅអស់កល្បជានិច្ចនៃកូនចៅរបស់ទ្រង់ » (« ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Ensign*ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៩) ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយ នូវអ្វីដែលពួកគេបានរៀនពីសេចក្តីថ្លែងការណ៍នេះ ។ សូមប្រាកដថា ពួកគេយល់ថា គ្រួសារជាផ្នែកដ៏សំខាន់មួយ ចំពោះផែនការរបស់ព្រះដ៏បង្កបង្កើតសម្រាប់គោលដៅដ៏នៅអស់កល្បជានិច្ចរបស់យើង ។ សូមសង្កត់ធ្ងន់ថា នេះគឺជាហេតុផលមួយ ដែលព្រះអម្ចាស់បានបញ្ជាដល់នីហ្វៃ និង បងៗរបស់គាត់ឲ្យអញ្ជើញគ្រួសាររបស់អ៊ីសម៉ាអែល ឲ្យទៅជាមួយនឹងពួកគេ ។ សូមពន្យល់ផងដែរថា មូលហេតុដ៏មានសារៈសំខាន់បំផុតមួយ សម្រាប់ការរៀបការ គឺដើម្បីនាំកូនៗមកកាន់ពិភពលោក ។

- **តើអ្នកគិតថា វាមានន័យដូចម្តេចដើម្បីចិញ្ចឹមកូន « មកកាន់ព្រះអម្ចាស់ » ? (នីហ្វៃទី១ ៧:១) ។**

ក្រោយពីសិស្សបានឆ្លើយសំណួរនេះរួចហើយ សូមលើកទឹកចិត្តពួកគេឲ្យស្តាប់ទស្សនៈវិស័យជ្រៅជ្រះបន្ថែមទៀត នៅពេលអ្នកអានសេចក្តីថ្លែងការណ៍ខាងក្រោម ពីការប្រកាសដល់ក្រុមគ្រួសារ ។ ប្រសិនបើពួកគេមានក្រដាសការប្រកាសនោះ អ្នកអាចស្នើថា ពួកគេគួរតែគូសចំណាំពាក្យ និង ឃ្លាដែលសំខាន់ចំពោះពួកគេ ។

« យើងសូមប្រកាសថា ព្រះបញ្ញត្តិរបស់ព្រះសម្រាប់កូនចៅរបស់ទ្រង់ ដើម្បីបង្កើតកូនចៅឲ្យចម្រើនឡើងឲ្យមានពាសពេញលើផែនដី ។ . . .

« . . . ឪពុកម្តាយមានកាតព្វកិច្ចដ៏ពិសិដ្ឋ ដើម្បីចិញ្ចឹមបីបាច់កូនចៅរបស់ខ្លួនដោយក្តីស្រឡាញ់ និង សេចក្តីសុចរិត ផ្គត់ផ្គង់សេចក្តីត្រូវការ ទាំងខាងរូបកាយ និង ខាងវិញ្ញាណរបស់ពួកគេ និង បង្រៀនពួកគេឱ្យចេះស្រឡាញ់ និង បម្រើគ្នាទៅវិញទៅមក ចេះគោរពព្រះបញ្ញត្តិទាំងឡាយនៃព្រះ ហើយធ្វើជាពលរដ្ឋល្អ ចេះគោរពច្បាប់គ្រប់ទីកន្លែង ដែលពួកគេរស់នៅ ។ ស្វាមី និង ភរិយា —ម្តាយ និង ឪពុក— នឹងទទួលខុសត្រូវនៅចំពោះព្រះភ័ក្ត្រព្រះ តាមការប្រតិបត្តិនៃភារកិច្ចទាំងឡាយនេះ » (« ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ទំព័រ ១២៩) ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ៧:៣– ៥ ឮៗ ។

- តើដំណើររឿងនៅក្នុង នីហ្វៃទី១ ៧:៣– ៥ ជាគំរូនៃសេចក្តីពិតនៅក្នុង នីហ្វៃទី១ ៣:៧ យ៉ាងដូចម្តេច ? (សូមជួយសិស្សឲ្យឃើញថា ព្រះអម្ចាស់បានរៀបចំផ្លូវមួយសម្រាប់នីហ្វៃ និង បងប្អូនប្រុសរបស់គាត់ឲ្យគោរពតាមបញ្ញត្តិឲ្យរៀបការ និង មានកូន) ។
- តើយុវវ័យអាចរៀបចំខ្លួននាពេលឥឡូវនេះ ដើម្បីរៀបការ និង « ចិញ្ចឹម » កូនៗ នៅក្នុងដំណឹងល្អដោយរបៀបណា ?

នីហ្វៃទី១ ៧:៦ –១៥

ដោយប្រឈមនឹងការបះបោររបស់លេមិន និង លេមយួល នីហ្វៃថ្លែងទីបន្ទាល់អំពីព្រះចេស្តានៃព្រះអម្ចាស់ឲ្យដឹកនាំពួកគេទៅដែនដីសន្យា

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ៧:៦ –៧ ឮៗ ។

- ហេតុអ្វីបានជាលេមិន លេមយួល និង កូនរបស់អ៊ីសម៉ាអែលមួយចំនួនប្រឆាំងក្នុងពេលធ្វើដំណើរនៅក្នុងទីរហោស្ថាន ?

សូមលើកទឹកចិត្តសិស្សឲ្យគិតអំពី អ្វីដែលពួកអាចនិយាយចំពោះលេមិន លេមយួល និង កូនប្រុស និង កូនស្រីដែលបះបោររបស់អ៊ីសម៉ាអែល ដើម្បីបញ្ចុះបញ្ចូលពួកគេឲ្យបន្តដំណើររបស់ពួកគេទៅកាន់ដែនដីសន្យា ។ បន្ទាប់មក សុំឲ្យសិស្សអាន នីហ្វៃទី១ ៧:៨–១២ ដោយស្ងាត់ៗនិង ស្វែងយល់សំណួរដែលនីហ្វៃ បានសួរដល់លេមិន និង លេមយួល ។

- តើសេចក្តីពិតអ្វី ដែលនីហ្វៃបានចែកចាយ នៅពេលដែលគាត់បានសួរសំណួរទាំងនេះ ? (គាត់បានរំឭកបងប្អូនប្រុសរបស់គាត់អំពីពរជ័យ ដែលពួកគេបានទទួលរួចហើយពីព្រះអម្ចាស់ និង អំពីសមត្ថភាពរបស់ព្រះអម្ចាស់ក្នុងការបន្តប្រទានពរដល់ពួកគេ តាមរយៈសេចក្តីជំនឿរបស់ពួកគេ) ។
- ហេតុអ្វីបានជាវាសំខាន់សម្រាប់យើង ដើម្បីចងចាំសេចក្តីពិតទាំងនេះ ?

សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ៧:១៣–១៥ និង ស្វែងរកមើលលទ្ធផល ប្រសិនបើលេមិន លេមយួល និង កូនប្រុស និង កូនស្រីរបស់អ៊ីសម៉ាអែលដែលបះបោរ បានត្រឡប់ទៅកាន់ទីក្រុងយេរូសាឡិមវិញ ។

នីហ្វៃទី១ ៧:១៦–២២

នីហ្វៃ ត្រូវបានរំដោះដោយព្រះអម្ចាស់

សូមពន្យល់ថា ក្រោយពីនីហ្វៃ បានរំឭកដល់លេមិន និង លេមយួលអំពីការបំផ្លាញដែលនឹងកើតមកដល់អ្នកដែលនៅក្នុងទីក្រុងយេរូសាឡិម ពួកគេបែរជាខឹងនឹងគាត់ទៅវិញ ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ៧:១៦ ឮៗ ។ សុំឲ្យសិស្សថ្នាក់ គិតស្រមៃថាបាននៅក្នុងស្ថានភាពរបស់នីហ្វៃ ។

- តើអ្នកនឹងមានអារម្មណ៍យ៉ាងណា ប្រសិនបើអ្នកនៅក្នុងស្ថានភាពរបស់នីហ្វៃ ? តើអ្នកនឹងធ្វើអ្វី ?

សូមបង្ហាញថា នីហ្វៃបានឆ្លើយតបនឹងស្ថានភាពនេះ ដោយការអធិស្ឋានសុំជំនួយ ។ សុំឲ្យសិស្សម្នាក់អាន ការអធិស្ឋានរបស់នីហ្វៃនៅក្នុងនីហ្វៃទី១ ៧:១៧–១៨ ឮ ។

- តើនីហ្វៃបានអធិស្ឋានសុំអ្វី ? តើអ្នករកឃើញអ្វីដែលមានសារៈសំខាន់អំពីការអធិស្ឋានរបស់គាត់នេះ ?

នៅពេលសិស្សចែកចាយចម្លើយរបស់ពួកគេ សូមប្រាកដថា ពួកគេឃើញថា នីហ្វៃបានសុំឲ្យរំដោះ « តាមរយៈសេចក្តីជំនឿ [របស់គាត់] ។ » សូមបង្ហាញផងដែរថា នៅពេលដែលគាត់បានសុំការរំដោះពីបងៗរបស់គាត់ គាត់បានសុំព្រះឲ្យពង្រឹងគាត់ ដូច្នេះគាត់អាចយកចិត្តទុកដាក់លើបញ្ហានេះ ។ សូមពន្យល់ថា ការអធិស្ឋានដោយសេចក្តីជំនឿ មានន័យថា យើងអធិស្ឋានដោយទុកចិត្តលើព្រះអម្ចាស់ និង ដោយមានឆន្ទៈដើម្បីធ្វើសកម្មភាព ។ សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះ ដោយអែលឌើរ ដាវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« នីហ្វៃ គឺជាគំរូនៃមនុស្សម្នាក់ដែលបានស្គាល់ យល់ និង បានពឹងផ្អែកទៅលើអំណាចដែលប្រទានឲ្យមកពីព្រះអង្គសង្គ្រោះ ។ . . . សូមចងចាំពីការអធិស្ឋានរបស់នីហ្វៃ នៅក្នុងខទី ១៧ ៖ ‹ ឱ ព្រះអម្ចាស់អើយ ស្របតាមសេចក្តីជំនឿរបស់ទូលបង្គំដែលមានចំពោះទ្រង់ សូមព្រះអង្គរំដោះទូលបង្គំឲ្យរួចផុតពីកណ្តាប់ដៃបងៗទូលបង្គំផង *ព្រះពរសូមប្រទានកម្លាំងដល់ទូលបង្គំដើម្បីឲ្យទូលបង្គំអាចផ្តាច់ខ្សែ*ដែលចងទូលបង្គំនេះបាន › (នីហ្វៃទី ១ ៧:១៧ សង្កត់ន័យបន្ថែម) ។

« . . . ជាពិសេស វាគួរឲ្យចាប់អារម្មណ៍ ចំពោះខ្ញុំណាស់ ថានីហ្វៃមិនបានអធិស្ឋានសុំឲ្យស្ថានភាពរបស់គាត់បានផ្លាស់ប្តូរទេ ។ ផ្ទុយទៅវិញ គាត់បានអធិស្ឋានសុំកម្លាំង ដើម្បីផ្លាស់ប្តូរស្ថានភាពរបស់គាត់ ។ ហើយខ្ញុំសូមផ្តល់យោបល់ថា គាត់បានអធិស្ឋាននៅក្នុងរបៀបនេះដោយជាក់លាក់ ដោយសារគាត់បានដឹង និង បានយល់ និង បានមានបទពិសោធពីព្រះចេស្តានៃដង្វាយធួននៃព្រះអង្គសង្គ្រោះ ដែលអាចធ្វើអ្វីគ្រប់យ៉ាង » (« នៅក្នុងកម្លាំងនៃព្រះអម្ចាស់ » [Brigham Young University devotional address ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០១] ទំព័រ ៤, speeches.byu.edu) ។

សូមចែកចាយទីបន្ទាល់របស់អ្នកថា **ព្រះបានឆ្លើយតបនឹងការអធិស្ឋាន តាមរយៈសេចក្តីជំនឿរបស់យើង ។** សូមបង្ហាញថា នៅក្នុងស្ថានភាពនេះ ព្រះបានឆ្លើយតបនឹងការអធិស្ឋានរបស់នីហ្វៃ ស្ទើរតែភ្លាមៗ ។ ទោះយ៉ាងណាក្តី ការអធិស្ឋានមិនតែងតែត្រូវបានឆ្លើយតបតាមរបៀបនេះរហូតនោះទេ ។ ព្រះវរបិតាសួគ៌ ឆ្លើយតបនឹងការអធិស្ឋានតាមពេលវេលារបស់ទ្រង់ តាមរបៀបរបស់ទ្រង់ និង តាមរយៈព្រះឆន្ទៈរបស់ទ្រង់ ។ សូមផ្តល់ឱកាសដល់សិស្ស ដើម្បីថ្លែងទីបន្ទាល់អំពីអំណាចនៃការអធិស្ឋាន ដោយសួរសំណួរខាងក្រោមនេះដល់ពួកគេ ៖

- តើនៅពេលណាដែលអ្នកបានអធិស្ឋានដោយសេចក្តីជំនឿ និង ទទួលបានកម្លាំង ឬ ជំនួយមកពីព្រះអម្ចាស់ ដោយភ្លាម ឬ មួយរយៈពេលក្រោយមក ? (អ្នកអាចចែកចាយបទពិសោធមួយ ដែលអ្នកមានជាមួយនឹងគោលការណ៍នេះ) ។

សូមប្រាប់សិស្សថា ក្រោយពីនីហ្វៃត្រូវបានរំដោះពីចំណងរបស់គាត់ បងប្អូនប្រុសរបស់គាត់បានព្យាយាមវាយគាត់ម្តងទៀត ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ៧:១៩–២០ឮៗ ។

- តើនរណាជាអ្នកបញ្ចុះបញ្ចូលលេមិន និង លេមយូលឲ្យបញ្ឈប់ការព្យាយាមសម្លាប់នីហ្វៃ ?

សូមបង្ហាញថា ការអធិស្ឋានរបស់យើង ជាញឹកញាប់ត្រូវបានឆ្លើយតប ហើយសេចក្តីត្រូវការរបស់យើង ជាញឹកញាប់ត្រូវបានបំពេញតាមរយៈសកម្មភាពដ៏ស្មោះត្រង់ពីអ្នកដទៃ ។ នៅពេលសិស្សរបស់អ្នក សិក្សាពីខគម្ពីរដែលនៅមានក្នុង នីហ្វៃទី១ ៧ សូមអញ្ជើញសិស្សឲ្យកត់សម្គាល់ពីរបៀបដែលនីហ្វៃបានឆ្លើយតបនឹងបងប្រុសរបស់គាត់ ទោះបីជាក្រោយមក ពួកគេបានធ្វើចំពោះគាត់ក៏ដោយ ។ សុំឲ្យពួកគេគិតអំពីសំណួរខាងក្រោម ដោយមិនបាច់ឆ្លើយតបជាសំឡេងនោះទេ ៖

- តើអ្នកបានឆ្លើយតបដោយរបៀបណា នៅពេលអ្នកដទៃបានព្យាយាមធ្វើឲ្យអ្នកឈឺចាប់ ?

សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ៧:២១ ឮៗ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរតែគូសចំណាំសម្តីរបស់នីហ្វៃអំពីការអភ័យទោស ។

- តើវាមានន័យយ៉ាងដូចម្តេច ក្នុងការអភ័យទោសដោយស្មោះអស់ពីចិត្ត ? (ប្រសិនបើសិស្សមិនសូវប្រាកដ សូមពន្យល់ថា ពាក្យ *ដោយស្មោះ* មានន័យថាដោយស្មោះត្រង់ និង ដោយចំៗ) ។

- តើនីហ្វៃបានដាស់តឿនបងៗរបស់គាត់ឲ្យធ្វើអ្វី ? ហេតុអ្វីបានជាការប្រឹក្សានេះមានសារៈសំខាន់ ?

សូមថ្លែងទីបន្ទាល់ថា **ការសុំការអភ័យទោស និង ការអភ័យទោសដល់អ្នកដទៃ នាំមកនូវឯកភាព និង សេចក្តីសុខសាន្ត ។**សូមអញ្ជើញសិស្សគិតអំពីស្ថានភាព នៅក្នុងគ្រួសាររបស់ពួកគេ ដែលត្រូវការការអភ័យទោស ។

- ហេតុអ្វីបានជា ការអភ័យទោសមានសារៈសំខាន់ជាពិសេស នៅក្នុងគ្រួសាររបស់យើង ?

- សូមគិតអំពីពេលមួយ ដែលអ្នកបានអភ័យទោសដល់សមាជិកគ្រួសារម្នាក់ ឬ នៅពេលដែលសមាជិកគ្រួសារម្នាក់បានអភ័យទោសដល់អ្នក ។ តើវាមានឥទ្ធិពលដល់ទំនាក់ទំនងរបស់អ្នក និង បរិយាកាសនៅក្នុងផ្ទះរបស់អ្នកយ៉ាងណា ?

សូមបញ្ចប់ដោយ ការរំឭកសិស្សថា ព្រះអម្ចាស់បានដាក់បញ្ញត្តិដល់នីហ្វៃ និង បងៗរបស់គាត់ឲ្យរៀបការ និង មានគ្រួសារ ហើយថាព្រះអម្ចាស់តម្រូវឲ្យមានដូចគ្នានៅសព្វថ្ងៃនេះ ។ សូមថ្លែងទីបន្ទាល់ផងដែរថា ព្រះអម្ចាស់ឆ្លើយតបការអធិស្ឋានរបស់យើង និង ផ្តល់ដល់យើងនូវកម្លាំងដើម្បីយកឈ្នះការល់បាករបស់យើង ស្របតាមសេចក្តីជំនឿរបស់យើងលើទ្រង់ ។ សូមអញ្ជើញពួកគេឲ្យគិតពីរបៀបដែលពួកគេអាចអនុវត្តគោលការណ៍មួយ នៅក្នុងមេរៀននៅថ្ងៃនេះ ដើម្បីជួយគ្រួសាររបស់ពួកគេ ។

ការរំឭកឡើងវិញពីចំណេះចំណានខគម្ពីរ

កំណត់ចំណាំ ៖ ការរំឭកឡើងវិញពីចំណេះចំណានខគម្ពីរ ត្រូវបានប្រើតាមរយៈសៀវភៅណែនាំការសិក្សានេះ ។ ពួកគេណែនាំរបៀបផ្សេងៗ ដែលអ្នកអាចប្រើដើម្បីជួយសិស្សរំឭកឡើងវិញចំណេះចំណានខគម្ពីរជាប្រចាំ ។

ប្រវែងនៃមេរៀននេះ អាចឲ្យពេលសម្រាប់សកម្មភាពនៃការរំឭកឡើងវិញពីចំណេះចំណានខគម្ពីរខាងក្រោម ។ អ្នកអាចរៀបចំសកម្មភាពនៅពេលចាប់ផ្តើមការបង្រៀន នៅពេលសម្រាករវាងវគ្គនៃមេរៀន ឬ នៅពេលបញ្ចប់ការបង្រៀន ។ សូមធ្វើយ៉ាងណាជួយសង្កេតវាដើម្បីទុកពេលសម្រាប់មេរៀន ។ សម្រាប់សកម្មភាពរំឭកឡើងវិញផ្សេងទៀត សូមមើលឧបសម្ព័ន្ធ ។

នៅពេលសិស្សអាចរកវគ្គចំណេះចំណានខគម្ពីរដោយងាយស្រួល និង យល់ពីន័យ អត្ថបទ និង ការអនុវត្តន៍របស់វា នោះពួកគេនឹងមានជំនឿជាក់លើការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ សមត្ថភាពរបស់ពួកគេដើម្បីអនុវត្តគោលការណ៍ដំណឹងល្អ និង មានឱកាសដើម្បីបង្រៀនពីព្រះគម្ពីរ ។ សូមពិចារណានូវការប្រកាសខាងក្រោមដោយប្រធាន ហាវីដ ដបុលយូ ហ៊ីនធើរ ៖ « យើងសង្ឃឹមថា គ្មានសិស្សណាម្នាក់របស់អ្នក នឹងចាកចេញពីថ្នាក់របស់អ្នកដោយការភ័យខ្លាច ឬ ខ្មាស់គេ ឬ អាម៉ាស់មុខ ដែលពួកគេមិនអាចរកជំនួយដែលលពួកគេត្រូវការ ដោយសារពួកគេមិនដឹងពីព្រះគម្ពីរច្បាស់លាស់ ក្នុងការរកវគ្គត្រឹមត្រូវ » (« ការដាក់ទុនដ៏នៅអស់កល្បជានិច្ច » | និយាយទៅកាន់អ្នករបប់រំសាសនា CES នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៩៨| ទំព័រ ២ si.lds.org) ។

ដើម្បីជួយសិស្សដឹងក្នុងការរកវគ្គចំណេះចំណានខគម្ពីរ សូមអញ្ជើញពួកគេឲ្យយោងទៅប្រដាប់សៀវភៅចំណេះចំណានខគម្ពីរ រកមើលវគ្គចំណេះចំណានប្រាំដំបូងនៅក្នុងព្រះគម្ពីររបស់ពួកគេ ហើយអានវា ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំវគ្គចំណេះចំណានខគម្ពីរនៅក្នុងរបៀបផ្សេងៗគ្នា ដូច្នេះពួកគេនឹងអាចរកវគ្គនានាដោយងាយស្រួល ។

នីហ្វៃទី១ ៨

សេចក្តីផ្តើម

នៅក្នុង នីហ្វៃទី១ ៨ លីហៃប្រាប់ពីការនិមិត្តរបស់លោកអំពីដើមឈើជីវិត ។ នៅក្នុងការនិមិត្តនោះ លីហៃបានទទួលទានផ្លែនៃដើមជីវិត ដែលតំណាងឲ្យសេចក្តីស្រឡាញ់របស់ព្រះ និងព្រះពរដែលយើងអាចទទួលបាន តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ លីហៃ បានឃើញនូវក្រុមមនុស្សផ្សេងៗគ្នាជាច្រើន ។ ក្រុមខ្លះបានវង្វេង ហើយមិនបានទៅដល់ដើមឈើនោះទេ ។ អ្នកផ្សេងទៀត បានខ្មាស់អៀនក្រោយពីទទួលទាននូវផ្លែឈើនៃដើមឈើនោះ ហើយពួកគេបានធ្លាក់ទៅក្នុងផ្លូវហាមឃាត់ ហើយក៏បានវង្វេងបាត់ ។ អ្នកផ្សេងទៀត បានកាន់ខ្ជាប់ទៅនឹងដំបងដែក ទទួលទាននូវផ្លែឈើ ហើយនៅបន្តកក្តីភាព ហើយ ស្មោះត្រង់ ។ ក្រុមផ្សេងទៀត ជ្រើសរើសមិនស្វែងរកផ្លូវទៅកាន់ដើមជីវិតនោះឡើយ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ១ ៨: ១–១៨

លីហៃ បានទទួលការនិមិត្តមួយដែលគាត់បានទទួលទាននូវផ្លែឈើជីវិត និង អញ្ជើញគ្រួសាររបស់គាត់ឲ្យមកទទួលទានដែរ

សូមអញ្ជើញសិស្សឲ្យគិតអំពី ពេលដែលពួកគេមានអារម្មណ៍ពីសេចក្តីស្រឡាញ់របស់ព្រះវរបិតាសួគ៌ចំពោះពួកគេ ។ សុំឲ្យពួកគេពិចារណាដោយស្ងាត់ៗពីរបៀបដែលពួកគេជម្រើស មានឥទ្ធិពលដល់ភាពជិតស្និទ្ធរបស់ពួកគេនឹងព្រះ និង សមត្ថភាពរបស់ពួកគេក្នុងការមានអារម្មណ៍ពីសេចក្តីស្រឡាញ់របស់ទ្រង់ ។ ក្រោយពីផ្តល់ពេលវេលាដល់ពួកគេដើម្បីគិត សូមចែកចាយទីបន្ទាល់របស់អ្នកថា ព្រះវរបិតាសួគ៌ស្រឡាញ់ពួកគេម្នាក់ៗ ។ នៅពេលសិស្សក្នុងថ្នាក់សិក្សានៅក្នុង នីហ្វៃទី១ ៨ សូមលើកទឹកចិត្តសិស្សឲ្យរកមើលរឿងរ៉ាវដែលពួកគេអាចធ្វើ និង រឿងដែលពួកគេគួរតែជៀសវាង ប្រសិនបើពួកគេចង់ខិតទៅជិតព្រះ និង មានអារម្មណ៍ពីសេចក្តីស្រឡាញ់របស់ទ្រង់កាន់តែខ្លាំងជាងមុននៅក្នុងជីវិតរបស់ពួកគេ ។ (ដើម្បីជួយរៀបចំសិស្សសម្រាប់មេរៀននេះ អ្នកអាចអញ្ជើញពួកគេឲ្យច្រៀង « The Iron Rod »[*Hymns*ទំព័រ ២៧៤] នៅពេលចាប់ផ្តើមថ្នាក់) ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ៨:២ ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ស្វែងរកនូវបទពិសោធន៍អ្វីដែលលីហៃបានទទួល ភ្លាមៗបន្ទាប់ពីកូនប្រុសរបស់គាត់ បានត្រឡប់មកពីទីក្រុងយេរូសាឡិមវិញជាមួយនឹងថ្នាំងលង្ហិន ។ សុំឲ្យសិស្សពីរបីនាក់ ប្តូរវេនគ្នាអានឮៗនៅក្នុង នីហ្វៃទី១ ៨:៥ –១២ ។

- តើអ្វីទៅជាវត្ថុសំខាន់ នៅក្នុងការនិមិត្តរបស់លីហៃ ? (ដើមជីវិត និង ផ្លែនៃដើមនោះ) ។
- តើពាក្យ និង ឃ្លាអ្វីខ្លះ ដែលលីហៃបានប្រើ ដើម្បីពិពណ៌នាពីផ្លែឈើនោះ ? (សូមមើល នីហ្វៃទី១ ៨:១០–១១ អ្នកក៏អាចឲ្យសិស្សអាន នីហ្វៃទី១ ១១:៨–៩ ដើម្បីឃើញពីរបៀបដែលនីហ្វៃ បានពិពណ៌នាដើមឈើនោះ) ។

សូមពន្យល់ថា ជាញឹកញាប់ ព្រះអម្ចាស់ប្រើវត្ថុដែលយើងស្គាល់ ជាសញ្ញាដើម្បីជួយយើងឲ្យយល់ពីសេចក្តីពិតដ៏នៅអស់កល្បជានិច្ច ។ ដើម្បីជួយសិស្សឲ្យស្គាល់នូវអ្វីដែលដើមឈើ និង ផ្លែឈើនៅក្នុងសុបិនរបស់លីហៃតំណាងឲ្យ សូមអញ្ជើញសិស្សម្នាក់ អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ នែល អេ ម៉ាក់ស្វែល នៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ សុំឲ្យសិស្សក្នុងថ្នាក់ស្តាប់ដោយប្រុងប្រយ័ត្ន ហើយរកមើលនូវអ្វីដែលដើមឈើ និង ផ្លែឈើនោះតំណាងឲ្យ ។

« ដើមឈើជីវិត . . . គឺជាសេចក្តីស្រឡាញ់នៃព្រះ (សូមមើល នីហ្វៃទី១ ១១:២៥) ។ សេចក្តីស្រឡាញ់នៃព្រះសម្រាប់កូនចៅរបស់ទ្រង់ គឺត្រូវបានបង្ហាញយ៉ាងជ្រាលជ្រៅនៅក្នុងអំណោយទានរបស់ទ្រង់ ជាព្រះយេស៊ូវ ជាព្រះអង្គសង្គ្រោះរបស់យើង ៖ « ព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម្ល៉េះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយ » (យ៉ូហាន ៣:១៦) ។ ដើម្បីទទួលទានសេចក្តីស្រឡាញ់នៃព្រះ គឺត្រូវទទួលយកដង្វាយធួនរបស់ព្រះយេស៊ូវ និង ការដោះលែង និង សេចក្តីអំណរ ដែលវាអាចនាំមកបាន » (« មេរៀនស្តីអំពីលេមិន និង លេមយូល »*Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ទំព័រ ៨) ។

- យោងតាមអែលឌើរ ម៉ាក់ស្វែល ដើមឈើជីវិត តំណាងឲ្យសេចក្តីស្រឡាញ់នៃព្រះដែលបានបង្ហាញដល់យើង ជាពិសេសតាមរយៈអំណោយអ្វី ? (សូមជួយសិស្សឲ្យយល់ថា ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាការបង្ហាញដ៏អស្ចារ្យនៃសេចក្តីស្រឡាញ់របស់ព្រះចំពោះកូនចៅរបស់ទ្រង់ ។ នៅពេលមនុស្សនៅក្នុងទស្សនៈនិមិត្តរបស់លីហៃ បានទទួលទាននូវផ្លែនៃដើមជីវិត វាមានន័យថា ពួកគេកំពុងតែទទួលយកនូវពរជ័យនៃដង្វាយធួន) ។
- *ការដោះលែង* មានន័យថា ការរំដោះ ឬ សេរីភាព ។ តើដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទរំដោះយើងចេញពីសេវកភាព ហើយនាំយើងទៅកាន់សេចក្តីអំណរដោយរបៀបណា ?

ដើម្បីជួយសិស្សឲ្យស្គាល់គោលការណ៍មួយដែលបានបង្ហាញនៅក្នុង នីហ្វៃទី១ ៨:១០–១២ សុំឲ្យពួកគេស្វែងរកនៅក្នុង នីហ្វៃទី១ ៨:១១ នូវព្រះបន្ទូលដែលពិពណ៌នាអ្វីដែលលីហៃបានធ្វើ (« ខ្ញុំបានដើរចូលទៅបេះផ្លែឈើនោះ ហើយទទួលទាន ») ។ បន្ទាប់មក សុំឲ្យពួកគេស្វែងរកលទ្ធផលនៃសកម្មភាពរបស់គាត់នៅក្នុង នីហ្វៃទី១ ៨:១២ (« ព្រលឹងវិញ្ញាណរបស់ខ្ញុំក៏ពោរពេញទៅដោយ

សេចក្តីអំណរអតិបរមា ») ។ អ្នកក៏អាចបង្ហាញដល់សិស្សថា នៅក្នុងនីហ្វៃទី១ ៨:១០ លីហៃបានពិពណ៌នាផ្លែឈើថាជា « ផ្លែដ៏គួរធ្វើឲ្យមនុស្សសប្បាយរីករាយ » ។ (អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំឃ្លាទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។

- តើលីហៃមានអារម្មណ៍បែបណាចំពោះការទទួលបានបទពិសោធន៍ ក្រោយពីទទួលទានផ្លែឈើនោះ ?
- តើយើងអាច « ទទួលទាន » ដង្វាយធួន ដោយរបៀបណា ? (តាមរយៈដំណើរការនៃការប្រែចិត្ត) ។
- ហេតុអ្វីបានជាការទទួលទានផ្លែដង្វាយធួន បំពេញព្រលឹងរបស់យើងជាមួយនឹង « សេចក្តីអំណរជាអតិបរមា » ?

សូមចែកចាយទីបន្ទាល់របស់អ្នកថា ការចូលមករកព្រះយេស៊ូវគ្រីស្ទ និង ការទទួលទានផ្លែដង្វាយធួននាំមកផ្លែវសុភមង្គល និង សេចក្តីអំណរ ។(អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

- តើនៅពេលណាដែលដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ បាននាំមកផ្លែវសុភមង្គល និង សេចក្តីអំណរចំពោះជីវិតរបស់អ្នក ? (សូមរំឭកសិស្សថា ពួកគេមិនចាំបាច់ត្រូវចែកចាយបទពិសោធន៍ដែលមានលក្ខណៈផ្ទាល់ខ្លួនពេកនោះទេ) ។

នីហ្វៃ ៨:១៩–៣៥

នៅក្នុងការនិមិត្តរបស់គាត់ លីហៃបានឃើញក្រុមមនុស្សផ្សេងៗគ្នា និង ជោគជ័យ ឬ បរាជ័យរបស់ពួកគេនៅក្នុងការទៅដល់ដើមឈើជីវិត

សូមបង្ហាញរូបភាពនៃការសុបិនរបស់លីហៃ (៦២៦២០; *សៀវភៅរូបភាពដំណឹងល្អ* [២០០៩] ទំព័រ ៦៩) និង បង្ហាញនិមិត្តសញ្ញាដែលសិស្សក្នុងថ្នាក់បានពិភាក្សាគ្នា៖ ដើមឈើ និង ផ្លែឈើ ។ សូមពន្យល់ថា នៅក្នុងការនិមិត្តនេះ ព្រះអម្ចាស់ក៏បានប្រើនិមិត្តសញ្ញាផ្សេងទៀត ដើម្បីបង្រៀនលីហៃពីរបៀបដើម្បីចូលមកកាន់ព្រះយេស៊ូវគ្រីស្ទ ហើយទទួលទានផ្លែដង្វាយធួនរបស់ទ្រង់ ។ សូមសួរសិស្សថា តើនិមិត្តសញ្ញាណាទៀត ដែលពួកគេឃើញនៅក្នុងរូបភាពនេះ ។ (ចន្លើយអាចរួមមាន ទន្លេ ដំបងដែក អ័ព្ទនៃសេចក្តីងងឹត និង អគារដ៏ទូលាយ និង ស្ថិតនៅលើអាកាសខ្ពស់ពីដី) ។

សូមរំឭកសិស្សថា ព្រះអម្ចាស់បានបង្ហាញនីហ្វៃផ្លែវការនិមិត្តដូចគ្នា ។ ក្រោយមក នីហ្វៃបានកត់ត្រាផ្លែវអត្ថន័យនៃនិមិត្តសញ្ញា និង រូបភាពផ្សេងៗគ្នានៅក្នុងទស្សននិមិត្តនេះ (សូមមើល នីហ្វៃទី១ ១១, ១២ និង ១៥) ។

សូមរៀបចំតារាងខាងក្រោមជាក្រដាសសម្រាប់ចែក ឬ បង្ហាញវានៅលើក្តារខៀន មុនពេលចាប់ផ្តើមបង្រៀន ។ (សូមទុកកូឡោនខាងស្តាំឲ្យនៅទំនេរ លើកលែងតែខគម្ពីរយោង) ។ សូមអញ្ជើញសិស្សឲ្យប្រើសេចក្តីយោងបទគម្ពីរដែលបានផ្តល់ឲ្យ ដើម្បីស្តាប់នូវការបកប្រែនៃឆាតុនីមួយៗនៃទស្សននិមិត្តរបស់លីហៃ ។ សូមរំឭកឡើងវិញនិមិត្តសញ្ញាទីមួយ ដើមឈើជាមួយនឹងផ្លែឈើពណ៌ស រួមគ្នាជាថ្នាក់មួយ ។ សូមឲ្យសិស្សគិតពីរបីនាទីរៀងៗខ្លួន ដើម្បីរកន័យនៃនិមិត្តសញ្ញាដែលនៅសល់បួនទៀត ។ (អ្នកអាចស្នើថា ពួកគេគួរតែកត់ត្រាចម្លើយរបស់ពួកគេ នៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរខគម្ពីរដែលត្រូវគ្នា នៅក្នុងនីហ្វៃទី១ ៨) ។

និមិត្តសញ្ញានៅក្នុងទស្សននិមិត្តរបស់លីហៃ	ការបកប្រែដែលបានចែកចាយដោយនីហ្វៃ
នីហ្វៃទី១ ៨:១០–១២— ដើមឈើដែលមានផ្លែឈើពណ៌ស	នីហ្វៃទី១ ១១:២១–២៥(សេចក្តីស្រឡាញ់នៃព្រះ ពរជ័យនៃដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ)
នីហ្វៃទី១ ៨:១៣—ទន្លេទឹកមួយដ៏កខ្វក់	នីហ្វៃទី១ ១២:១៦; ១៥:២៦–២៩ (ភាពកខ្វក់ ជម្រៅនៃស្ថាននរក)
នីហ្វៃទី១ ៨:១៩—ដំបងដែក	នីហ្វៃទី១ ១១:២៥(ព្រះបន្ទូលនៃព្រះ)
នីហ្វៃទី១ ៨:២៣—អ័ព្ទនៃសេចក្តីងងឹត	នីហ្វៃទី១ ១២:១៧ (ការល្បួងពីអារក្ស)
នីហ្វៃទី១ ៨:២៦— អគារដ៏ទូលាយ និង នៅលើអាកាសខ្ពស់ពីដី	នីហ្វៃទី១ ១១:៣៥–៣៦; ១២:១៨(អំនួត និង ការគិតស្រមៃដ៏អសារឥតការនៃពិភពលោក)

សូមអញ្ជើញសិស្សឲ្យចែកចាយការបកស្រាយ ដែលពួកគេបានរកឃើញ ។ ដើម្បីជួយពួកគេឲ្យឃើញពីទំនាក់ទំនងគ្នានៃនីហ្វៃទី១ ៨ នៅក្នុងជីវិតរបស់ពួកគេ សូមសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ិចដ៍ ឃេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្តាប់ ហើយរកនូវមូលហេតុមួយ ដែលសំខាន់សម្រាប់ពួកគេ ដើម្បីសិក្សាពីទស្សននិមិត្តរបស់លីហៃ ៖

« អ្នកអាចគិតថា សុបិន ឬ ទស្សននិមិត្តរបស់លីហៃ គ្មានន័យពិសេសសម្រាប់អ្នកនោះទេ ប៉ុន្តែវាពិតជាមានន័យសម្រាប់អ្នក ។ អ្នកនៅក្នុងទស្សននិមិត្តនេះ យើងទាំងអស់គ្នាគឺនៅក្នុងនោះ ។ . . .

« សុបិន ឬ ទស្សននិមិត្តរបស់លីហៃ . . . មានអ្វីៗទាំងអស់ដែលពួកបរិសុទ្ធថ្ងៃចុងក្រោយ ត្រូវការដើម្បីយល់ពីការសោកល្បងនៃជីវិត » (« ការរកឃើញខ្លួនយើងនៅក្នុងសុបិនរបស់លីហៃ » *Ensign* ខែ សីហា ឆ្នាំ ២០១០ ទំព័រ ២២) ។

នៅពេលសិស្សសិក្សាពីអ្វីដែលនៅសល់នៃទស្សននិមិត្តនេះ សូមលើកទឹកចិត្តពួកគេឲ្យរកមើលមនុស្សនៅក្នុងទស្សននិមិត្តដែលអាចតំណាងឲ្យខ្លួនគេផ្ទាល់ ។ សូមបញ្ជាក់ប្រាប់ពួកគេថា មិនថាកន្លែងណាដែលពួកគេឃើញខ្លួនឯងនៅក្នុងទស្សននិមិត្តនោះទេ ពួកគេម្នាក់មានអំណាច និង សមត្ថភាពដើម្បីជ្រើសរើសឲ្យសាកសមនឹងពរជ័យនៃដង្វាយធួន ។

ការគូសចំណាំ និង ការកត់ត្រាទុកនៅក្នុងព្រះគម្ពីរ

សិស្សអាចទទួលបានប្រយោជន៍ពីការសរសេរសេចក្តីយោងបទគម្ពីរ ការបកប្រែនិមិត្តសញ្ញា និង ព័ត៌មានផ្សេងទៀត នៅតាមគែមទំព័រនៃព្រះគម្ពីររបស់ពួកគេ ។ ពួកគេក៏អាចទទួលបានប្រយោជន៍ពីការគូសពណ៌ចំណាំសេចក្តីយោងបទគម្ពីរនៅក្នុងលេខយោង ។ កំណត់ចំណាំបែបនោះអាចធ្វើជាអ្នករំឭក ដើម្បីជួយសិស្សឲ្យយល់ និង បង្រៀនពីព្រះគម្ពីរនៅក្នុងថ្ងៃអនាគត ។ កំណត់ចំណាំទាំងនេះអាចប្រើបាន និង ទុកបានយូរជាងព័ត៌មានដែលបានកត់ត្រានៅក្នុងសៀវភៅកំណត់ហេតុ ឬ នៅក្នុងក្រដាសដាច់ពីគ្នាមួយ ។ ទោះយ៉ាងណាក្តី អ្នកគួរតែគោរពសិទ្ធិជ្រើសរើសរបស់សិស្ស និង មិនត្រូវតម្រូវឲ្យពួកគេសរសេរនៅក្នុងព្រះគម្ពីររបស់ពួកគេនោះទេ ។ ផ្ទុយទៅវិញ សូមធ្វើការស្នើសុំ និង អនុញ្ញាតឲ្យសិស្សសម្រេចអ្វីដែលសមរម្យសម្រាប់គេ ។

សូមបែងចែកសិស្សជាពីរក្រុម ។ សូមពន្យល់ថា ក្រុមនីមួយៗនឹងរកមើលនូវរឿងខុសៗគ្នា នៅពេលសិស្សក្នុងថ្នាក់អាន នីហ្វៃទី១ ៨:២១–៣៣ រួមគ្នា ។

សុំឲ្យក្រុមទី ១ រកមើលចម្លើយចំពោះសំណួរខាងក្រោម ។ (មុនចាប់ផ្តើមបង្រៀន សូមសរសេរសំណួរទាំងនេះនៅលើក្តារខៀន ឬ នៅលើក្រដាសសម្រាប់ចែក) ។

- តើឧបសគ្គអ្វី ដែលមនុស្សនៅក្នុងទស្សនៈនិមិត្តរបស់លីហៃ បានជួបប្រទះ ?
- តើឧបសគ្គទាំងនោះតំណាងឲ្យអ្វី ?
- តើឧបសគ្គទាំងនេះ មានទម្រង់ជាអ្វីនៅសព្វថ្ងៃនេះ ?
- តើគោលការណ៍អ្វី ដែលអ្នកបានឃើញនៅក្នុងខគម្ពីរទាំងនេះ ?

សូមអញ្ជើញឲ្យក្រុមទី ២ រកមើលចម្លើយចំពោះសំណួរខាងក្រោមនេះ ។ (មុនចាប់ផ្តើមបង្រៀន សូមសរសេរសំណួរទាំងនេះនៅលើក្តារខៀន ឬ នៅលើក្រដាសសម្រាប់ចែក) ។

- តើអ្វីដែលបានជួយមនុស្សទាំងនោះ ឲ្យឈានទៅដល់ដើមឈើ និង ទទួលទានផ្លែឈើនោះ ?
- តើតាមរបៀបណា ដែលដំបងដែក ប្រៀបទៅនឹងព្រះបន្ទូលនៃព្រះ ?
- តើព្រះបន្ទូលនៃព្រះ ជួយយើងឲ្យយកឈ្នះលើឧបសគ្គនានា ដែលស្ថិតនៅលើផ្លូវទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ចដោយរបៀបណា ?
- តើគោលការណ៍អ្វី ដែលអ្នកឃើញនៅក្នុងខគម្ពីរទាំងនេះ ?

សូមអញ្ជើញសិស្សបីបួននាក់ ប្តូរវេនគ្នាអានឲ្យឮៗ នៅក្នុង នីហ្វៃទី១ ៨:២១–៣៣ ។ បន្ទាប់មក សូមអញ្ជើញសិស្សនៅក្នុងក្រុមទី ១ ឲ្យចែកចាយនូវចម្លើយរបស់ពួកគេចំពោះសំណួរដែលបានដាក់ឲ្យគេ ។ សូមឲ្យពួកគេចែកចាយនូវគោលការណ៍ ដែលពួកគេឃើញនៅក្នុងខគម្ពីរទាំងនេះផងដែរ ។ សូមធ្វើយ៉ាងណាជួយសិស្សឲ្យយល់ថា **អំនួត ជីវិតលោកិយ និង ការចុះចាញ់ការល្បួង អាចរារាំងយើងពីការទទួលបាននូវពរជ័យនៃដង្វាយធួន ។** សូមអញ្ជើញសិស្សឲ្យគិតអំពីរបៀបដែលឧបសគ្គទាំងនេះ អាចបង្អាក់ការរីកចម្រើនខាងវិញ្ញាណរបស់ពួកគេ ។

សុំឲ្យសិស្សនៅក្នុងក្រុមទី ២ ចែកចាយនូវចម្លើយរបស់ពួកគេចំពោះសំណួរដែលពួកគេត្រូវបានដាក់ឲ្យ ។ ក្រោយពីពិភាក្សាពីទស្សនវិស័យជ្រៅជ្រះរបស់ពួកគេហើយ សូមអញ្ជើញពួកគេចែកចាយនូវគោលការណ៍ដែលពួកគេឃើញនៅក្នុង នីហ្វៃទី១ ៨:២១–៣៣ ។ គោលការណ៍ដែលពួកគេរកឃើញ អាចរួមមានដូចតទៅ ៖

ប្រសិនបើយើងកាន់ខ្ជាប់តាមព្រះបន្ទូលនៃព្រះ វានឹងជួយយើង យកឈ្នះលើការល្បួង និង ឥទ្ធិពលខាងលោកិយ ។

ការកាន់ខ្ជាប់តាមព្រះបន្ទូលនៃព្រះ ជួយយើងឲ្យខិតកាន់តែជិតទៅរកព្រះអម្ចាស់ ហើយទទួលបាននូវពរជ័យនៃដង្វាយធួន ។

- នៅក្នុងនីហ្វៃទី១ ៨:២៤ និង ៣០ តើពាក្យសម្តីអ្វី ដែលពិពណ៌នាការខិតខំប្រឹងប្រែងរបស់ប្រជាជន ក្នុងការកាន់តាមដំបងដែក ហើយទៅដល់ដើមឈើនោះ ?
- តើអ្នកគិតថា វាមានន័យដូចម្តេចក្នុងការ « ប្រជ្រៀតទៅមុខ » ?
- តើអ្នកគិតថា វាមានន័យដូចម្តេចដើម្បីតោង និង កាន់ខ្ជាប់ជានិច្ចតាមព្រះបន្ទូលនៃព្រះ ? (អ្នកអាចពន្យល់ថា នៅក្នុងនីហ្វៃទី១ ៨:៣០ ពាក្យថា *ខ្ជាប់ជានិច្ច* មានន័យថា តោងជាប់យ៉ាងមាំ) ។
- តើហេតុអ្វីបានជាយើងគួរតែសិក្សាព្រះគម្ពីរជារៀងរាល់ថ្ងៃ ?

ក្រោយពីការពិភាក្សានូវសំណួរទាំងនេះ អ្នកអាចបង្ហាញថា នៅក្នុងទស្សនៈនិមិត្តនេះ មនុស្សខ្លះដូចជា លេមិន និង លេមយួល នឹងមិនទទួលទាននូវផ្លែឈើនោះទេ (សូមមើល នីហ្វៃទី១ ៨:២២–២៣, ៣៥–៣៨) ។ នេះតំណាងឲ្យការបដិសេធរបស់ពួកគេ ដើម្បីប្រែចិត្ត និង ទទួលទាននូវពរជ័យនៃដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ មនុស្សខ្លះបានធ្លាក់ ទោះជាបានទទួលទាននូវផ្លែឈើនោះហើយក៏ដោយ (សូមមើល នីហ្វៃទី១ ៨:២៥, ២៨) ។ ការណ៍នេះ រំឭកយើងថា ក្រោយពីយើងបានចាប់ផ្តើមទទួលយកនូវពរជ័យនៃដង្វាយធួនហើយ យើងត្រូវបន្តឧស្សាហ៍ព្យាយាម និង ស្មោះត្រង់ ដោយការប្រែចិត្តចេញពីអំពើបាបរបស់យើង ហើយព្យាយាមរក្សាសេចក្តីសញ្ញារបស់យើង ។ សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមគំរូរបស់មនុស្សដែល បានទទួលទានផ្លែឈើ ហើយនៅតែបន្តនៅក្បែរដើមឈើ (សូមមើល នីហ្វៃទី១ ៨:៣៣) ។

ដើម្បីជួយសិស្សឃើញពីរបៀបដែលគោលការណ៍នៅក្នុងទស្សនៈនិមិត្តរបស់លីហៃនេះ បានប្រទានពរដល់ជីវិតរបស់ពួកគេ សូមអញ្ជើញពួកគេឆ្លើយនូវសំណួរមួយក្នុងចំណោមសំណួរទាំងឡាយខាងក្រោម នៅក្នុងសៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ឬ សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់គេ ៖

- តើពេលណាដែលព្រះបន្ទូលនៃព្រះបានដឹកនាំអ្នក ឬ ជួយអ្នកឲ្យយកឈ្នះលើការល្បួង អំនួត ឬ ជីវិតលោកិយ ?
- តើនៅពេលណាដែលអ្នកទទួលអារម្មណ៍ពីសេចក្តីស្រឡាញ់នៃព្រះ ចំពោះអ្នក នៅពេលដែលអ្នកបានអាន ឬ បានស្តាប់តាមព្រះបន្ទូលរបស់ទ្រង់ ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយចម្លើយរបស់ពួកគេនៅក្នុងថ្នាក់ ។

សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តទៅលើអ្វីដែលពួកគេបានរៀន និង មានអារម្មណ៍ ពេលកំពុងសិក្សាក្នុងនីហ្វៃទី១ ៨ ដោយការដាក់គោលដៅជាក់លាក់មួយ ចាប់ផ្តើម ឬ បន្តដើម្បីអភិវឌ្ឍទម្លាប់មួយក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនប្រចាំថ្ងៃ ។ សូមចែកចាយជាមួយសិស្សនូវពរជ័យ ដែលបានមកនៅក្នុងជីវិតរបស់អ្នក តាមរយៈការសិក្សាព្រះគម្ពីរជាទៀងទាត់ ។

សូមលើកទឹកចិត្តឲ្យមានការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ

គ្មានរឿងតូចតាចណា ដែលមានឥទ្ធិពលយូរអង្វែងឲ្យធ្វើការល្អ ជាងការជួយសិស្សឲ្យអភិវឌ្ឍនូវទម្លាប់នៃការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនប្រចាំថ្ងៃនោះទេ ។ សូមលើកទឹកចិត្តសិស្ស ឲ្យញែកពេលវេលារាល់ថ្ងៃសម្រាប់ការសិក្សាព្រះគម្ពីរ ។ សូមផ្តល់ដល់សិស្សនូវឱកាសជាទៀងទាត់នៅក្នុងថ្នាក់ ដើម្បីចែកចាយនូវអ្វីដែលពួកគេកំពុងរៀន និង មានអារម្មណ៍ ពេលពួកគេសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនផងដែរ ។

នីហ្វៃទី១ ១០–១១

សេចក្តីផ្តើម

ក្រោយពីបានស្តាប់ដំណើររឿងទស្សននិមិត្តរបស់ឪពុកគាត់ លីហៃ នីហ្វៃចង់ឃើញ ឮ និង ដឹងដោយខ្លួនគាត់នូវរឿងដែលលីហៃបានឃើញ និង បានឮ (សូមមើល នីហ្វៃទី១ ១០:១៧) ។ អំឡុងពេលគាត់កំពុងតែគិតអំពីការបង្រៀនរបស់ឪពុករបស់គាត់ នីហ្វៃ « ត្រូវបាននាំទៅដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ » (នីហ្វៃទី១ ១១:១) ហើយទទួលបានទស្សននិមិត្តផ្ទាល់ខ្លួនគាត់ ។ ទស្សននិមិត្តនេះ ត្រូវបានរៀបរាប់ជាថ្មីនៅក្នុង នីហ្វៃទី១ ១១–១៤ ។

នៅក្នុងនីហ្វៃទី១ ១១ យើងបានអានអំពីដើមជីវិត ជំបងដៃក និង អគារដ៏ទូលាយ និង នៅលើអាកាសខ្ពស់ពីដី ក៏ដូចជាការប្រសូត ពិធីបុណ្យជ្រមុជទឹក ការបម្រើ និង ការឆ្កាងនៃព្រះអង្គសង្គ្រោះ ។ នៅពេលដែលនីហ្វៃបានឃើញរឿងទាំងនេះ គាត់បានស្គាល់ពីសេចក្តីស្រឡាញ់ដែលព្រះមានចំពោះកូនចៅរបស់ទ្រង់ ។

ការចែកចាយដោយអនាមិក

អ្នកអាចអញ្ជើញសិស្សឲ្យនិយាយដោយមិនប្រាប់ឈ្មោះ នៅក្នុងការសរសេរអ្វីដែលពួកគេបានជួបប្រទះ អំឡុងពេលការសិក្សាព្រះគម្ពីរប្រចាំថ្ងៃរបស់ពួកគេ ។ ប្រមូលចម្លើយរបស់ពួកគេ និង អានចម្លើយពីរបីទៅកាន់សិស្សក្នុងថ្នាក់ ។ ការស្តាប់ទីបន្ទាល់របស់សិស្សគ្នាឯង អាចជួយជម្រុញសិស្សផ្សេងទៀត ឲ្យសិក្សាផ្ទាល់ខ្លួនគេ ។ សិស្សខ្លះ ស្ងាក់ស្ទើរក្នុងការចែកចាយទីបន្ទាល់ និង បទពិសោធខាងវិញ្ញាណដោយឥតលាក់បាំង ដោយសារពួកគេមិនចង់ចេញមុខអួត ឬ ពួកគេខ្លាចអ្នកផ្សេងនឹងកាត់សេចក្តីគេ ឬ ចាត់ទុកថាបទពិសោធរបស់គេមិនសំខាន់ ។ ការរ៉ាយរ៉ាប់ដោយអនាមិក ធ្វើឲ្យសិស្សចែកចាយបទពិសោធខាងវិញ្ញាណដោយគ្មានការភ័យខ្លាច ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ១០:១–១៦

លីហៃ ព្យាករណ៍ពីព្រះមែស៊ី

សូមសង្ខេបដោយខ្លីៗពី នីហ្វៃទី១ ១០:១–១៦ ដោយប្រាប់សិស្សថា ក្រោយពីប្រាប់រឿងការនិមិត្តរបស់គាត់អំពីដើមជីវិតហើយ លីហៃក៏បានផ្តល់នូវការព្យាករណ៍មួយ ។ ទាំងនេះ រួមមានសេចក្តីលម្អិតពីពេលព្រះយេស៊ូវគ្រីស្ទនឹងមកកាន់ផែនដី (សូមមើល នីហ្វៃទី១ ១០:៤) ការជ្រមុជទឹករបស់ទ្រង់ដោយយ៉ូហាន បាទីស្ទ (សូមមើល នីហ្វៃទី១ ១០:៧– ១០) ការឆ្កាងរបស់ទ្រង់ និង ការមានព្រះជន្មរស់ឡើងវិញ (សូមមើល នីហ្វៃទី១ ១០:១១ និង ការធ្វើឲ្យខ្ចាត់ខ្ចាយ និង ការប្រមូលផ្តុំសាសន៍អ៊ីស្រាអែលដែលជិតកើតមាន (សូមមើល នីហ្វៃទី១ ១០:១២ –១៤) ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១០:៤–៦ឮឮ ។ (អ្នកអាចពន្យល់ថា *ព្រះមែស៊ី* គឺជា « ទម្រង់មួយនៃពាក្យរបស់ភាសាសេមីត និង ភាសាហេព្រើរ មានន័យថា ‹ អ្នកបានលាបតាំង › ។ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ព្រះយេស៊ូវ ត្រូវបានហៅថាជាព្រះគ្រីស្ទ ដែលជាភាសាក្រិច ប្រហាក់ប្រហែលនឹង *ព្រះមែស៊ី* ។វាមានន័យថា ព្យាការី សង្ឃ ស្តេច និង អ្នកវាយតម្លៃដែលបានលាបតាំង ដែលពួកយូដាទន្ទឹងរង់ចាំយ៉ាងអន្ទះសារនូវការយាងមករបស់ទ្រង់ » | ការណែនាំលើព្រះគម្ពីរ « ព្រះមែស៊ី » scriptures.lds.org ; សូមមើលផងដែរ វចនានុក្រមព្រះគម្ពីរបរិសុទ្ធ « ព្រះមែស៊ី » |) ។

- **យោងតាមការព្យាករណ៍របស់លីហៃ តើនៅពេលណាដែលព្រះអង្គសង្គ្រោះនឹងយាងមក ? (សូមមើល នីហ្វៃទី ១ ១០:៤) ។**
- **តើនឹងមានអ្វីកើតឡើងដល់មនុស្សលោក ប្រសិនបើពួកគេមិនពឹងលើព្រះអង្គសង្គ្រោះនោះទេ ? (សូមមើល នីហ្វៃទី១ ១០:៦) ។**

នីហ្វៃទី១ ១០:១៧–២២; ១១:១–៦

នីហ្វៃចង់ឃើញ ឮ និង ដឹងពីសេចក្តីពិតដែលឪពុករបស់គាត់បានបង្រៀន

សុំឲ្យសិស្សគិតអំពីគំរូខាងក្រោមនេះ ៖ មានបុរសវ័យក្មេងបីនាក់ បានចូលក្នុងការប្រជុំសាសនាចក្រតែមួយ ។ ក្រោយពីត្រឡប់មកដល់ផ្ទះវិញ បុរសវ័យក្មេងម្នាក់ មានអារម្មណ៍ថា ការប្រជុំនោះគួរឲ្យធុញទ្រាន់ និង ខាតពេលរបស់គាត់ណាស់ ។ បុរសម្នាក់ទៀតគិតថា ការប្រជុំនោះគឺល្អ ប៉ុន្តែមិនបានទទួលឥទ្ធិពលពីវានោះទេ ។ បុរសទីបី ត្រឡប់មកផ្ទះវិញ ត្រូវបានតម្កើងដោយព្រះវិញ្ញាណបរិសុទ្ធ និង ទទួលបានការបំផុសគំនិត និង ការណែនាំសម្រាប់ជីវិតរបស់គាត់ ហើយវាលើសពីអ្វីដែលបានបង្រៀននៅក្នុងការប្រជុំនោះទៅទៀត ។

- **តើវាអាចកើតមានដោយរបៀបណា ដែលបុរសវ័យក្មេងទាំងបីនាក់ អាចចូលរួមក្នុងការប្រជុំតែមួយ ប៉ុន្តែមានបទពិសោធខុសគ្នាបែបនេះ ?**

សូមពន្យល់ថា គំរូនេះ គឺស្រដៀងនឹងបទពិសោធន៍របស់លេមិន លេមយូល និង នីហ្វៃ នៅពេលដែលពួកគេបានឮការព្យាករណ៍របស់ឪពុករបស់ពួកគេ និង ដំណើររឿងនៃទស្សននិមិត្តរបស់គាត់ ។ លេមិន និង លេមយូល មិនបានយល់ពីសម្តីរបស់ឪពុករបស់ពួកគេនោះទេ ហើយបានឈ្លោះអំពីអ្វីដែលពួកគេបានឮ (សូមមើល នីហ្វៃទី១ ១៥:២) ។ ផ្ទុយទៅវិញ នីហ្វៃ បានទៅរកព្រះអម្ចាស់សម្រាប់ការយល់ដឹង ។ គាត់បានផ្តល់គំរូមួយដ៏ប្រសើរក្រៃលែង ពីរបៀបដើម្បីស្វែងរក និង ទទួលបាននូវវិវរណៈ ។

សូមប្រាប់សិស្សថា នៅពេលពួកគេសិក្សាពីបទពិសោធរបស់នីហ្វៃ ពួកគេនឹងរកឃើញនូវគោលការណ៍ ដែលនឹងជួយពួកគេឲ្យស្វែងរក និង ទទួលបាននូវវិវរណៈសម្រាប់ខ្លួន ។ សូមលើកទឹកចិត្តពួកគេ ឲ្យកត់សម្គាល់នូវរឿងដែលនីហ្វៃបានធ្វើ ដែលធ្វើឲ្យគាត់អាចទទួលបានវិវរណៈមួយស្រដៀងនឹងអ្វីដែលលីហៃទទួលបាន ។

សូមបំបែកសិស្សក្នុងថ្នាក់ជាបីក្រុម ។ សូមចាត់ឲ្យក្រុមនីមួយៗ នូវប្រភេទមួយ និង សំណួរមួយកុម្រចេញពីតារាងខាងក្រោម ។ (អ្នកអាចបង្ហាញតារាងនោះ នៅលើក្តារខៀន មុនចាប់ផ្តើមបង្រៀន) ។ សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ១០:១៧ និង ១១:១–៦ ដោយស្ងាត់ៗនិង រៀបចំចម្លើយសម្រាប់សំណួរដែលដាក់ឲ្យពួកគេនេះ ។

ចំណង់	តើនីហ្វៃមានចង់ឃើញ ឮ និង ដឹងពីអ្វី ? តើចំណង់របស់យើង ប៉ះពាល់ដល់សមត្ថភាពរបស់យើងក្នុងការទទួលបាននូវវិវរណៈដោយរបៀបណា ? តើខ្ញុំចង់ដឹងអ្វីពីព្រះអម្ចាស់ ?
ការជឿ	តើការជឿអ្វី ដែលនីហ្វៃបានបង្ហាញ នៅពេលដែលគាត់បានស្វែងរកវិវរណៈ ? តើការជឿទាំងនេះអាចមានឥទ្ធិពលយ៉ាងដូចម្តេច ដល់សមត្ថភាពរបស់យើងក្នុងការទទួលបាននូវវិវរណៈ ? តើខ្ញុំអាចបង្កើនទីបន្ទាល់ និង ការជឿរបស់ខ្ញុំលើព្រះយេស៊ូវគ្រីស្ទបានយ៉ាងដូចម្តេច ?
ការសញ្ជឹងគិត	តើមានអ្វីកើតឡើង នៅពេលនីហ្វៃបានអង្គុយសញ្ជឹងគិត ? ហេតុអ្វីបានជាការសញ្ជឹងគិតអាចនាំទៅរកវិវរណៈ ? តើខ្ញុំអាចធ្វើអ្វី ដើម្បីសញ្ជឹងគិតពីពាក្យសម្តីនៃព្យាការីដោយឧស្សាហ៍ព្យាយាមជាងនេះ ?

សូមអញ្ជើញសិស្សពីរបីនាក់ពីក្រុមនីមួយៗ ឲ្យផ្តល់ចម្លើយលើសំណួរដែលបានដាក់ឲ្យពីរដំបូងរបស់គេ ។ (អ្នកក៏អាចអញ្ជើញសិស្សឲ្យឆ្លើយនឹងសំណួរទីបី ប៉ុន្តែសូមប្រាប់ពួកគេថា ពួកគេមិនចាំបាច់ចែកចាយចម្លើយដែលមានលក្ខណៈផ្ទាល់ខ្លួនពេកនោះទេ) ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១០:១៩ ឮៗ ។

- **តើនរណា អាចដឹងពីសេចក្តីអាថ៌កំបាំងនៃព្រះបាន ?**
- **ដោយអំណាចអ្វី ដែលសេចក្តីអាថ៌កំបាំងនៃព្រះត្រូវបានបើកបង្ហាញ ?**
- **តើយើងត្រូវធ្វើដូចម្តេច ដើម្បីទទួលបានវិវរណៈដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ?**
- **តើអ្នកគិតថា វាមានន័យដូចម្តេចលើពាក្យ ការស្វែងរកដោយឧស្សាហ៍ព្យាយាម ?**
- **តើនីហ្វៃបានធ្វើអ្វីខ្លះ ដែលបង្ហាញថា គាត់កំពុងស្វែងរកដោយឧស្សាហ៍ព្យាយាមដើម្បីមើលឃើញ ឮ និង ដឹងនូវរឿងដែលឪពុករបស់គាត់បានបង្រៀន ?**

សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមនៅលើក្តារខៀន ៖

ព្រះបង្ហាញសេចក្តីពិតដល់ . . .

សុំសិស្សឲ្យសង្ខេបពីអ្វីដែលពួកគេបានរៀនចេញពីបទពិសោធរបស់នីហ្វៃ ដោយការបំពេញសេចក្តីថ្លែងការណ៍នៅលើក្តារខៀន ។ ខណៈពេលដែលសិស្សអាចជ្រើសរើសពាក្យខុសគ្នា ចម្លើយរបស់ពួកគេគួរចាប់យកនូវសេចក្តីពិតថា ព្រះបង្ហាញសេចក្តីពិតដល់អ្នកទាំងអស់ណាដែលស្វែងរកទ្រង់ដោយក្តីឧស្សាហ៍ព្យាយាម ។(អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមលើកទឹកចិត្តសិស្សឲ្យគិតអំពីពេលមួយ ដែលការស្វែងរកព្រះដោយឧស្សាហ៍ព្យាយាម បាននាំពួកគេឲ្យមានអារម្មណ៍ពីព្រះវិញ្ញាណរបស់ទ្រង់ និង ទទួលបានវិវរណៈ ។ (វាអាចមានប្រយោជន៍ក្នុងការនិយាយថា វិវរណៈអាចរួមមានការទទួលបានការណែនាំ នៅពេលធ្វើការសម្រេចចិត្ត ការកើននូវការយល់ដឹងបន្ថែម ការទទួលបានការលួងលោម ឬ ការទទួលបានការធានាថាអ្វីមួយពិត) ។ សូមអញ្ជើញសិស្សឲ្យចែកចាយពី បទពិសោធន៍របស់ខ្លួនជាមួយនឹងសិស្សក្នុងថ្នាក់ ។ អ្នកក៏អាចថ្លែងទីបន្ទាល់ពីអ្វីដែលអ្នកបានជួបប្រទះតាមរយៈការខិតខំរបស់អ្នកដើម្បីរកព្រះអម្ចាស់ដោយឧស្សាហ៍ព្យាយាមផងដែរ ។

នីហ្វៃទី ១ ១១:៧–៣៦

នីហ្វៃធ្វើជាសាក្សីអំពីការយាងចុះមកនៃព្រះ

សូមពន្យល់ទៅសិស្សថា នីហ្វៃបានបន្តសញ្ជឹងគិត និង ស្វែងរកការណែនាំដ៏ទេវភាព អំឡុងពេលការទទួលការនិមិត្តរបស់គាត់ ។ នៅពេលនីហ្វៃសុំរៀនដើម្បីបកស្រាយនៃដើមឈើដែលគាត់ និង ឪពុករបស់គាត់បានឃើញ ទេវតាមួយអង្គបានលេចមកឯគាត់ ដើម្បីជួយគាត់ ។ ទេវតានោះបានសួរថា « តើអ្នកយល់នំយពីដើមឈើ ដែលឪពុកអ្នកបានឃើញនោះទេ ? » (នីហ្វៃទី ១ ១១:២១) ។ សូមរំឭកឡើងវិញពីអត្ថន័យនៃដើមឈើ ដោយឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗ នៅក្នុងនីហ្វៃទី១ ១១:១៨–២៣ ។

- **តើនីហ្វៃបាននិយាយអ្វីខ្លះ ថាជាអត្ថន័យនៃដើមឈើនោះ ? (ក្រោយពីសិស្សឆ្លើយរួច អ្នកអាចបង្ហាញថា នីហ្វៃបានឃើញម៉ារី បីទាកយេស៊ូវ ហើយទេវតាស្គាល់ទារកនោះថាជា « ព្រះរាជបុត្រានៃព្រះវរបិតាដ៏នៅអស់កល្បជានិច្ច » ។ បន្ទាប់មក ទេវតាបានសួរនីហ្វៃពីអត្ថន័យនៃដើមឈើ ដើម្បីជួយគាត់ឲ្យឃើញថា វាតំណាងឲ្យព្រះយេស៊ូវគ្រីស្ទ ។ នៅពេលនីហ្វៃបានឆ្លើយថា វាតំណាងឲ្យ « សេចក្តីស្រឡាញ់នៃព្រះ » គាត់សំដៅលើសេចក្តីស្រឡាញ់នៃព្រះ ដូចដែលបានបង្ហាញតាមរយៈអំណោយជាព្រះរាជបុត្រារបស់ទ្រង់ ។ យើងទទួលបានសេចក្តីស្រឡាញ់នៃព្រះ ដោយការទទួលយកពរជ័យនៃដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ) ។**
- **តើនីហ្វៃ និង ទេវតាពិពណ៌នាសេចក្តីស្រឡាញ់នៃព្រះយ៉ាងដូចម្តេច ?**

សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ១១:១៦ ។ (សូមពន្យល់ថា ពាក្យថា *ការយាងចុះមក* មានន័យថាការចុះចេញដោយស្ម័គ្រចិត្តពីតួនាទីនៃតំណែងមួយ ឬ មុខងារដ៏ខ្ពស់មួយ ។ អ្នកអាចអញ្ជើញសិស្សឲ្យសរសេរការពន្យល់នេះ នៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ នីហ្វៃទី១ ១១:១៦) ។

សូមឲ្យសិស្សរកចម្លើយរបស់នីហ្វៃ ទៅនឹងសំណួររបស់ទេវតាដោយអាននៅក្នុង នីហ្វៃទី១ ១១:១៧ ឮៗ ។

- តើនីហ្វៃបានដឹងពីអ្វី ?
- តើអ្វីដែលគាត់មិនបានដឹង ?

ក្រោយពីនីហ្វៃបានឆ្លើយតបហើយ ទេវតាបានបង្ហាញគាត់នូវគំរូជាច្រើននៃការយាងចុះមកនៃព្រះ ដើម្បីជួយគាត់ឲ្យយល់ពីសេចក្តីស្រឡាញ់នៃព្រះ ។ សូមពន្យល់សិស្សថា « ការយាងចុះមកនៃព្រះ » សំដៅទាំងលើព្រះ ជាព្រះវរបិតា និង ព្រះយេស៊ូវគ្រីស្ទ ។

សូមចែកចាយនូវសេចក្តីថ្លែងការណ៍ខាងក្រោម ដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ដែលបានពន្យល់ពីការយាងចុះមកនៃព្រះ ជាព្រះវរបិតាសួគ៌របស់យើង ។

« ការយាងចុះមកនៃព្រះ ស្ថិតលើការពិតដែលថា ទ្រង់ ជាអង្គត្រូវបានតម្កើង បានយាងចុះមកពីបល្ល័ង្កដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់ មកក្លាយជាព្រះវរបិតានៃព្រះរាជបុត្រាខាងសាច់ឈាម » (*ព្រះមែស៊ីខាងសាច់ឈាម* [១៩៧៩], ១:៣១៤) ។

ដើម្បីជួយសិស្សឲ្យយល់ថា « ការយាងចុះមកនៃព្រះ » ក៏យោងទៅលើព្រះយេស៊ូវគ្រីស្ទដែរ សូមបង្ហាញរូបភាពការប្រសូតនៃព្រះយេស៊ូវ (៦២១១៦; *សៀវភៅរូបភាពដំណឹងល្អ* [២០០៩] ទំព័រ ៣០) ។ សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ១១:១៣–២១ ឮៗ ។ សូមអញ្ជើញសិស្សផ្សេងទៀត រកមើលអ្វីដែលខគម្ពីរទាំងនេះ ត្រូវនឹងរូបភាពនេះ ។ សុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ជេរីលដ៍ អិន ឡានដ៍ អតីតនៃក្រុមចិតសិបនាក់ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ស្តាប់ហើយរករបៀប ដែលព្រះអង្គសង្គ្រោះបង្ហាញសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះយើង ។

« នេះគឺជា ព្រះយេស៊ូវ —សមាជិកមួយអង្គនៃក្រុមព្រះ ជាកូនច្បងនៃព្រះវរបិតា ជាអង្គបង្កបង្កើត ជាព្រះយេហូវ៉ានៃព្រះគម្ពីរសញ្ញាចាស់— ឥឡូវចាកចេញពីស្ថានដ៏ទេវភាព និង បរិសុទ្ធរបស់ទ្រង់ ដកព្រះអង្គទ្រង់ចេញពីអ្វីទាំងអស់ដែលមានសិរីល្អ និង អានុភាព ហើយចូលក្នុងរាងកាយទាមកមួយដ៏តូច ដោយគ្មាននរណាជួយ គឺពីងលើម្តាយ និង ឪពុកខាងលោកិយរបស់ទ្រង់ទាំងស្រុង ។ ទ្រង់មិនគួរមកកាន់រាជវាំងនៃដែនដីដ៏ល្អបំផុត ហើយត្រូវ . . . ស្រោចដោយគ្រឿងអលង្ការ ប៉ុន្តែគួរមកក្នុងភាពនឹងដ៏តូចទាប នោះគឺគួរឲ្យភ្ញាក់ផ្អើល ។ ការឆ្ងល់បន្តិចថា ទេវតាគួរតែនិយាយទៅនីហ្វៃថា ‹ មើលចុះ ការយាងចុះមកនៃព្រះ ! › » (*ព្រះយេស៊ូវគ្រីស្ទ ជាកូនសៅទៅកាន់ផែនការសង្គ្រោះ* [១៩៩១] ទំព័រ ១៦) ។

- តើការប្រសូតរបស់ព្រះអង្គសង្គ្រោះ បង្ហាញសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះយើងយ៉ាងដូចម្តេច ?

សូមប្រាកដថា វាច្បាស់លាស់ថា ព្រះឆន្ទៈរបស់ព្រះអង្គសង្គ្រោះដើម្បីរស់នៅជាជីវិតរមែងស្លាប់ បង្ហាញពីសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះយើង ។

សូមបង្ហាញរូបភាពព្រះយេស៊ូវ លើកកូនស្រីរបស់យ៉ៃរ៉ុស (៦២២៣១; *សៀវភៅរូបភាពដំណឹងល្អ* ទំព័រ ៤១) និង ព្រះគ្រីស្ទព្យាបាលអ្នកឈឺនៅបេថែសដា (*សៀវភៅរូបភាពដំណឹងល្អ* ទំព័រ ៤២) ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១១:២៨ និង ៣១ ឮៗ ។ សូមលើកទឹកចិត្តសិស្សក្នុងថ្នាក់ឲ្យរកមើលរបៀប ដែលរូបភាពទាំងនេះស្រដៀងទៅនឹងខគម្ពីរនោះ ។

- តើនីហ្វៃបានឃើញនរណា ដែលព្រះអង្គសង្គ្រោះកំពុងបម្រើ និង ព្យាបាល ?
- តើសកម្មភាពរបស់ព្រះអង្គសង្គ្រោះបង្ហាញពីសេចក្តីស្រឡាញ់របស់ទ្រង់យ៉ាងដូចម្តេច ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ១១:៣២–៣៣ ឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ស្តាប់ហើយរកនូវគំរូដ៏ខ្ពស់បំផុតនៃសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ។

ក្រោយពីសិស្សចែកចាយនូវអ្វីដែលពួកគេបានរកឃើញ សូមបង្ហាញរូបភាពការឆ្កាង (៦២៥០៥; *សៀវភៅរូបភាពដំណឹងល្អ* ទំព័រ ៥៧) ។

សូមថ្លែងទីបន្ទាល់ថា **ការយាងចុះមកនៃព្រះយេស៊ូវគ្រីស្ទ បង្ហាញពីសេចក្តីស្រឡាញ់របស់ព្រះចំពោះយើង ។** ព្រះអង្គសង្គ្រោះ បានយាងចុះមករស់នៅជាជីវិតរមែងស្លាប់ ធ្វើការបម្រើ និង ព្យាបាលដល់អ្នកឈឺ និង អ្នករងទុក្ខ ហើយសុគតសម្រាប់អំពើបាបរបស់យើងទាំងអស់ ដើម្បីយើងអាចត្រឡប់ទៅផ្ទះទៅកាន់វត្តមាននៃព្រះវរបិតាសួគ៌វិញ ។

- តើការដឹងអំពីការយាងចុះមករបស់ព្រះអង្គសង្គ្រោះ និង សេចក្តីស្រឡាញ់របស់ទ្រង់ មានឥទ្ធិពលដល់អារម្មណ៍របស់អ្នកអំពីទ្រង់យ៉ាងដូចម្តេច ?

សូមបញ្ចប់ដោយការអញ្ជើញសិស្សឲ្យចែកចាយពីរបៀបដែលសេចក្តីស្រឡាញ់នៃព្រះគឺជា « ការគូរឲ្យប្រាថ្នាដ៏លើសលប់ជាងអ្វីៗទាំងអស់ » និង « សេចក្តីរីករាយបំផុត » ចំពោះពួកគេ (សូមមើល នីហ្វៃទី១ ១១:២២–២៣) ។ សូមថ្លែងទីបន្ទាល់ថា នៅពេលយើងធ្វើតាមគំរូរបស់នីហ្វៃ និង ស្វែងរកព្រះដោយឧស្សាហ៍ព្យាយាម យើងនឹងមានអារម្មណ៍ពីសេចក្តីស្រឡាញ់របស់ទ្រង់ និង ដកពិសោធន៍នូវសេចក្តីអំណរក្នុងការទទួលយកនូវពរជ័យ ដែលកើតមានតាមរយៈដង្វាយធួនរបស់ព្រះគ្រីស្ទ ។

សូមអញ្ជើញសិស្សឲ្យធ្វើតាមគំរូរបស់នីហ្វៃ នៅក្នុងការខិតខំប្រឹងដែលពួកគេធ្វើដើម្បីស្វែងរកនូវវិវរណៈ ។ សូមរំឭកពួកគេពីតួនាទីរបស់ពួកគេជាអ្នករៀន នៅក្នុងថ្នាក់សិក្ខាសាលា ហើយថាសេចក្តីជំនឿ និង ការខិតខំដែលពួកគេបានធ្វើក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនប្រចាំថ្ងៃរបស់ពួកគេ និង ការចូលរួមពីសិស្សក្នុងថ្នាក់ មានឥទ្ធិពលដល់សមត្ថភាពរបស់គេ ក្នុងការរៀនដោយព្រះវិញ្ញាណ ។

នីហ្វៃទី១ ១២ –១៣

សេចក្តីផ្តើម

ក្រោយពីនីហ្វៃ បានឃើញការបម្រើខាងសាច់ឈាម និង ដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ នៅក្នុងការនិមិត្តរបស់គាត់ គាត់បានឃើញថា ក្រោយពីសេចក្តីសុចរិតដែលមានបួនជំនាន់មក កូនចៅរបស់គាត់ នឹងក្លាយជាមានអំនួត ហើយថាពួកគេនឹងបង្អោនតាមការល្បួងរបស់អារក្ស និង ត្រូវបានបំផ្លាញចោលឡើយ ។ គាត់ក៏បានឃើញសេចក្តីទុច្ចរិតនៃអស់អ្នកដែលដើរតាមសាតាំង នៅក្នុងព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើម ។ គាត់បានឃើញថា ពួកគេនឹងជកចេញនូវសេចក្តីពិតដែលងាយយល់ និង មានតម្លៃពីព្រះគម្ពីរបរិសុទ្ធ បណ្តាលឲ្យមនុស្សជាច្រើនជំពប់ដួលខាងវិញ្ញាណ ។ ថ្វីបើទិដ្ឋភាពដ៏មានទុក្ខព្រួយទាំងនេះកើតមានក្តី ការនិមិត្តរបស់នីហ្វៃក៏បានផ្តល់ដល់គាត់នូវហេតុផលចំពោះក្តីសង្ឃឹមដ៏ផុងដែរ ។ គាត់បានឃើញថា ព្រះនឹងរៀបចំផ្លូវសម្រាប់ការស្តារឡើងវិញនៃដំណឹងល្អនៅក្នុងជំនាន់ចុងក្រោយ ។ គាត់ក៏បានធ្វើជាសាក្សីថា កំណត់ត្រានៃប្រជាជនរបស់គាត់ (ព្រះគម្ពីរមរមន) នឹងចេញមកនៅក្នុងជំនាន់ចុងក្រោយ ដើម្បីស្តារឡើងវិញនូវសេចក្តីពិតដ៏ច្បាស់ និងពិសេសៗដែលបានបាត់បង់ពីពិភពលោកនេះ ។

កំណត់ចំណាំ ៖ អ្នកប្រហែលជា មិនមានពេលគ្រប់គ្រាន់ ដើម្បីធ្វើតាមចំណុចទាំងអស់នៅក្នុងមេរៀននេះបានទេ ។ នៅពេលអ្នករៀបចំ សូមស្វែងរកការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីដឹងថាតើផ្នែកណានៃមេរៀននេះ ដែលសំខាន់បំផុត ហើយអាចអនុវត្តបានច្រើនបំផុតចំពោះសិស្សរបស់អ្នក ។ អ្នកអាចត្រូវធ្វើការសង្ខេបផ្នែកខ្លះនៃមេរៀននេះ ដើម្បីឲ្យមានពេលគ្រប់គ្រាន់ក្នុងការបង្រៀនគោលលទ្ធិ និង គោលការណ៍ដែលសំខាន់បំផុតពោរពេញដោយប្រសិទ្ធភាព ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ១២

នីហ្វៃមើលឃើញពីអនាគតរបស់សាសន៍នីហ្វៃ និង សាសន៍លេមិន

សូមសង្ខេប នីហ្វៃទី១ ១២ ដោយពន្យល់ថា ជំពូកនេះគឺជាការបន្តមួយពីការនិមិត្តរបស់នីហ្វៃ ។ នៅក្នុងនោះ ទេវតាបានបង្ហាញដល់នីហ្វៃនូវរបៀបដែលនិមិត្តសញ្ញានៅក្នុងការនិមិត្តនៃដើមជីវិត នឹងអនុវត្តចំពោះកូនចៅរបស់គាត់ ។ គាត់បានឃើញថា កូនចៅខ្លះរបស់គាត់ នឹងទទួលបានពរជ័យទាំងអស់ពីដង្វាយធួន ។ ទោះយ៉ាងណាក្តី នីហ្វៃក៏បានឃើញដែរថា កូនចៅរបស់គាត់ នឹងត្រូវបានបំផ្លាញនៅទីបញ្ចប់ដោយកូនចៅរបស់បងប្រុសគាត់ (សាសន៍លេមិន) ។ សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ១២:១៦–១៩ ។ សូមឲ្យគេរកមើលហេតុផលដែលនីហ្វៃត្រូវបានបំផ្លាញចោល (សូមមើល នីហ្វៃទី១ ១២:២៩) ។ សូមរំឭកសិស្សថា នៅពេលពួកគេអនុវត្តសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ពួកគេអាចយកឈ្នះលើអំនួត និង ការល្បួងបាន ។

នីហ្វៃទី១ ១៣:១– ៩

នីហ្វៃ មើលឃើញនូវព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើម

សុំឲ្យសិស្សលើកដៃឡើង ប្រសិនបើពួកគេចេះលេងកីឡា ។ សុំឲ្យពួកគេពីរបីនាក់ ចែកចាយពីកីឡាដែលពួកគេលេង ។ សូមពន្យល់ថា នៅក្នុងកីឡា ក្រុមទាំងឡាយ ជារឿយៗរៀបចំសម្រាប់ការប្រកួត ដោយការសិក្សាពីការលេង និង យុទ្ធសាស្ត្រពីអតីតកាលរបស់ក្រុមប្រជែង ។

- ហេតុអ្វីបានជាមានប្រយោជន៍ចំពោះក្រុមមួយ ដើម្បីសិក្សាពីយុទ្ធសាស្ត្ររបស់ក្រុមប្រជែង មុនពេលពួកគេប្រកួត ?

សូមពន្យល់ថា នីហ្វៃបានឃើញនៅក្នុងការនិមិត្តនូវបំណងប្រាថ្នា និង យុទ្ធសាស្ត្ររបស់អ្នកដែលប្រឆាំងនឹងសាសចក្រនៃព្រះយេស៊ូវគ្រីស្ទ នៅក្នុងថ្ងៃចុងក្រោយ ។ សូមលើកទឹកចិត្តសិស្សឲ្យស្វែងរកយុទ្ធសាស្ត្រទាំងនោះ នៅពេលពួកគេសិក្សានៅក្នុងជំពូកនេះ ដូច្នេះពួកគេអាចរៀបចំខ្លួន ដើម្បីស្គាល់នូវយុទ្ធសាស្ត្រ ហើយមិនត្រូវបានបោកបញ្ឆោតដោយយុទ្ធសាស្ត្រទាំងនោះឡើយ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអាន នីហ្វៃទី១ ១៣:១–៤, ៦ ឮៗ ។ សុំឲ្យសិស្សម្នាក់រកនូវក្រុមដែល នីហ្វៃបានឃើញថាបានបង្កើតឡើងក្នុងចំណោមសាសន៍ដទៃនៅក្នុងថ្ងៃចុងក្រោយ ។

ដើម្បីជួយសិស្សឲ្យយល់អត្ថន័យនៃខគម្ពីរទាំងនេះ សូមចែកចាយនូវវិចារណកថាខាងក្រោមដោយ អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី នៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ សុំឲ្យសិស្សស្តាប់ដោយប្រុងប្រយ័ត្ន និង រកនូវនិយមន័យមួយនៃព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើម ។

« ចំណងជើង *សាសនាចក្រនៃអារក្ស* និង *ព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើម* ត្រូវបានប្រើដើម្បីសម្គាល់អស់ទាំង. . . អង្គការដែលមានឈ្មោះ ឬ ទ្រង់ទ្រាយអ្វីក៏ដោយ — មិនថាខាងនយោបាយ ទស្សនវិជ្ជា វិស័យអប់រំ សេដ្ឋកិច្ច សង្គម ភាតរភាព ពលរដ្ឋ ឬ សាសនា— ដែលត្រូវបានធ្វើឡើងដើម្បីនាំមនុស្សនៅក្នុងផ្នែកមួយ ដែលនាំចេញពីព្រះ និង ក្រឹត្យវិន័យរបស់ទ្រង់ក្តី ហើយហេតុដូច្នេះ ចេញពីសេចក្តីសង្គ្រោះនៅក្នុងនគរនៃព្រះ » (*គោលលទ្ធិមរមន* កំណែទី ២. [១៩៦០], ១៣៧–៣៨) ។

សូមបញ្ជាក់ថា ឃ្លា « ព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើម » មិនសំដៅលើនិកាយ ឬ ព្រះវិហារជាក់លាក់ណាមួយ នោះទេ ។ វាសំដៅលើគ្រប់អង្គការណាទាំងអស់ដែលធ្វើឡើង ដើម្បីដឹកនាំមនុស្សឲ្យឃ្លាតចេញពីព្រះ និង ក្រឹត្យវិន័យរបស់ទ្រង់ ។

អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរឃ្លា *អង្គការទាំងអស់ ដែលធ្វើឡើងដើម្បីដឹកនាំមនុស្សឃ្លាតចេញពីព្រះ និង ក្រឹត្យវិន័យរបស់ទ្រង់* នៅមែទំព័រក្បែរ នីហ្វៃទី១ ១៣:៦ ។

សង្ខេប

អ្នកនឹងមិនមានពេលដើម្បីបង្រៀនគ្រប់អ្វីៗ នៅក្នុងវគ្គព្រះគម្ពីរមួយ ដោយបញ្ជាក់គ្រប់ចំណុចនោះទេ ។ ក្នុងឱកាសនេះ អ្នកអាចសង្ខេបខ្សែរឿង ឬ ការបង្រៀននៅក្នុងផ្នែកមួយនៃវគ្គព្រះគម្ពីរមួយ ដើម្បីឲ្យមានពេលល្មមទុកបង្រៀនពីអត្ថបទ គោលលទ្ធិ ឬ គោលការណ៍ដែលមានសារៈសំខាន់ជាងនេះ នៅក្នុងផ្នែកផ្សេងទៀតនៃវគ្គនេះ ។ ការសង្ខេប ជាជាងការលុបចោលនូវផ្នែកនៃវគ្គព្រះគម្ពីរមួយ នឹងជួយសិស្សឲ្យយល់កាន់តែច្បាស់ពីខ្សែរឿងទាំងមូល និង សារលិខិតនៃវគ្គនេះ ។

- ហេតុអ្វីអ្នកជឿថា វាសំខាន់ដើម្បីដឹងថា សាតាំងរៀបចំកម្លាំងរបស់វា ដើម្បីដឹកនាំយើងឃ្លាតចេញពីព្រះ និង ក្រឹត្យវិន័យរបស់ទ្រង់ ?

សូមពន្យល់ថា នីហ្វៃបានរៀបរាប់ពីព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើម ។ សូមអញ្ជើញសិស្សម្នាកអាន នីហ្វៃទី១ ១៣:៥– ៩ ឲ្យ ។

- តើអ្វីដែល អស់អ្នកនៅក្នុងព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើមចង់បាន ? (សូមមើល នីហ្វៃទី១ ១៣: ៧–៨) ។
- ដោយយោងតាម នីហ្វៃទី១ ១៣:៥, ៩ តើអ្នកដែលនៅក្នុងព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើមចង់សម្រេចបានអ្វីខ្លះ ? ហេតុអ្វី ? (អ្នកអាចសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ **សាតាំង និង អ្នកដើរតាមវា ចង់បំផ្លាញពួកបរិសុទ្ធនៃព្រះ និង នាំពួកគេទៅការន់ការជាប់ឃុំឃាំង ។**)
- តើការដឹងពីបំណងប្រាថ្នា និង គោលបំណងរបស់សាតាំង និង អ្នកដើរតាមវា ជួយយើងឲ្យប្រយុទ្ធនឹងពួកវាយ៉ាងដូចម្តេច ?

សូមប្រាប់សិស្សថា បន្តិចទៀតនៅក្នុងជំពូកនេះ ពួកគេនឹងរៀនអំពីរបៀបមួយដែលព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើម បានព្យាយាមបំផ្លាញអ្នកដែលស្វែងរកព្រះ ។

នីហ្វៃទី១ ១៣:១០–១៩

នីហ្វៃមើលឃើញព្រះហស្តរបស់ព្រះ នៅក្នុងការបង្កើតដែនដីសេរីភាពមួយ ដែលជំណឹងល្អនឹងត្រូវបានស្តារឡើងវិញ

សូមថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់បានបញ្ជាក់ថា កិច្ចការរបស់ទ្រង់នឹងទៅមុខ ទោះបីជាព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើមខិតខំធ្វើឲ្យប្រជាជនជំពប់ដួលខាងវិញ្ញាណក៏ដោយ ។ ទ្រង់ធ្វើដូច្នេះ ដោយការរៀបចំផ្លូវសម្រាប់ការស្តារឡើងវិញនៃជំណឹងល្អរបស់ទ្រង់ ។

សេចក្តីថ្លែងការណ៍ក្នុងបញ្ជីខាងក្រោម សង្ខេបពីព្រឹត្តិការណ៍សំខាន់ដែល នីហ្វៃបានឃើញនៅក្នុងការនិមិត្តរបស់គាត់ ។ សូមឲ្យសិស្សអាន នីហ្វៃទី១ ១៣:១០–១៩ និង ផ្ទូផ្គងព្រះគម្ពីរយោងនីមួយ ៗក្នុងបញ្ជីខាងក្រោម ទៅនឹងព្រឹត្តិការណ៍ដែលវាពណ៍នា ។ (អ្នកអាចបង្ហាញព្រះគម្ពីរយោងទាំងនេះ និង សេចក្តីថ្លែងការណ៍នៅលើក្តារខៀន មុនចាប់ផ្តើមបង្រៀន ។ ឬ អ្នកអាចធ្វើក្រដាសចែក ដែលមានព្រះគម្ពីរយោងទាំងនេះ និង សេចក្តីថ្លែងការណ៍ ។ ខាងក្រោម គឺជាព្រះគម្ពីរយោង ដែលបានផ្ទូផ្គងទៅនឹងសេចក្តីថ្លែងការណ៍ ដែលត្រឹមត្រូវ ។ ដើម្បីឲ្យសកម្មភាពនេះ បានជោគជ័យ អ្នកនឹងត្រូវផ្លាស់ប្តូរលំដាប់នៃសេចក្តីថ្លែងការណ៍ នៅពេលអ្នកបង្ហាញវានៅលើក្តារខៀន ឬ ដាក់វាលើក្រដាសចែក) ។

នីហ្វៃទី១ ១៣:១២ កូឡុំប៊ឹសបានធ្វើដំណើរទៅអាមេរិក
នីហ្វៃទី១ ១៣:១៣ ពួកអ្នកធម្មយាត្រា ចេញទូកទៅអាមេរិក ដើម្បីស្វែងរកសេរីភាពខាងសាសនា
នីហ្វៃទី១ ១៣:១៤ ជនជាតិអាមេរិកដើម ត្រូវបានបណ្តេញចេញពីដែនដីរបស់ពួកគេ
នីហ្វៃទី១ ១៣:១៥ សាសន៍ដទៃរីកចម្រើនឡើងនៅក្នុងអាមេរិក
នីហ្វៃទី១ ១៣:១៦ –១៩ ទោះបីជាកងទ័ពខ្មាំងសត្រូវមានចំនួនច្រើនក៏ដោយ កងទ័ពបដិវត្តន៍អាមេរិកបានជ័យជំនះ

នៅពេលសិស្សចែកចាយចម្លើយរបស់ពួកគេ អ្នកអាចលើកទឹកចិត្តពួកគេឲ្យសរសេរពាក្យ ឬ ឃ្លាគន្លឹះមួយនៅក្នុងព្រះគម្ពីររបស់ពួកគេ ក្បែរវគ្គនីមួយ ៗ ។ ជាឧទាហរណ៍ ពួកគេអាចសរសេរ *កូឡុំប៊ឹស* ក្បែរ នីហ្វៃទី១ ១៣:១២ ។

- ដោយយោងតាម នីហ្វៃទី១ ១៣:១២ ហេតុអ្វីបានជាកូឡុំប៊ឹស ធ្វើដំណើរទៅអាមេរិក ?
- យោងតាមនីហ្វៃទី១ ១៣:១៣ ហេតុអ្វីបានជាពួកអ្នកធម្មយាត្រាផ្លាស់ប្តូរលំនៅទៅអាមេរិក ?
- ដោយយោងតាម នីហ្វៃទី១ ១៣:១៥– ១៩ ហេតុអ្វីបានជាសាសន៍ដទៃរីកចម្រើន និង មានឯករាជ្យភាពពី « សាសន៍ផ្សេងទៀតទាំងអស់ » ?

សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យ ៗ ដោយប្រធាន យ៉ូសែប អេហ្ស ស្មឹធ ៖

« ជាតិអាមេរិកដ៏អស្ចារ្យនេះ ព្រះដ៏មានមហិទ្ធិឬទ្ធិបានលើកឡើងដោយអំណាចនៃព្រះហស្តដ៏មានគ្រប់ព្រះចេស្តា ដ៏ខ្ពស់បំផុតរបស់ទ្រង់ ដើម្បីវាអាចកើតមានន្ទគរនៃព្រះនៅថ្ងៃចុងក្រោយនៅលើផែនដី ។ ប្រសិនបើព្រះអម្ចាស់មិនបានរៀបចំផ្លូវដោយការដាក់គ្រឹះនៃជាតិដ៏រុងរឿងនេះទេ វានឹងមិនអាចកើតមាននោះទេ (នៅក្រោមច្បាប់ដ៏តឹងរ៉ឹង និង ការប្រកាន់សាសនានៃរដ្ឋាភិបាលនៃរាជានិយមរបស់ពិភពលោក) ក្នុងការដាក់គ្រឹះសម្រាប់ការមកដល់នៃនគរដ៏មហិមារបស់ទ្រង់ ។ ព្រះអម្ចាស់បានធ្វើការណ៍នេះ » (*គោលលទ្ធិនៃដំណឹងល្អ* 5th ed. [១៩៣៩], ទំព័រ ៤០៩) ។

សូមថ្លែងទីបន្ទាល់ថា **ព្រះអម្ចាស់បានរៀបចំផ្លូវមួយសម្រាប់ការស្តារឡើងវិញ** ដោយការស្តាបនាប្រទេសមួយ ឲ្យមានសេរីភាពខាងសាសនា ដែលទ្រង់អាចស្តារឡើងវិញនូវសាសនាចក្ររបស់ទ្រង់ ។ សូមថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់បានរៀបចំ ហើយនឹងបន្តរៀបចំផ្លូវមួយសម្រាប់ដំណឹងល្អដែលបានស្តារឡើងវិញរបស់ទ្រង់ បានចូលទៅដល់គ្រប់ជាតិសាសន៍ទាំងអស់ ។

ប្រសិនបើអ្នកកំពុងបង្រៀនមេរៀននេះនៅក្នុងប្រទេសមួយ ក្រៅពីសហរដ្ឋអាមេរិក សូមសួរ ៖

- តើព្រះអម្ចាស់បានរៀបចំផ្លូវមួយសម្រាប់ការបង្រៀនដំណឹងល្អដែលបានស្តារឡើងវិញ នៅក្នុងប្រទេសយើងដោយរបៀបណា ?

នីហ្វៃទី១ ១៣:២០–៤២

នីហ្វៃមើលឃើញពីសាសន៍ដទៃនៅថ្ងៃអនាគត ជាមួយនឹងព្រះគម្ពីរបរិសុទ្ធ ព្រះគម្ពីរមរមន និង ព្រះគម្ពីរនៅថ្ងៃចុងក្រោយ

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន នីហ្វៃទី១ ១៣:២០–២៤ ។ សុំឲ្យគាត់រកមើលវត្ថុដែលនីហ្វៃ បានឃើញពួកអាណានិគមអាមេរិកដើម « បាននាំចេញទៅក្នុងចំណោមពួកគេ » ។ សូមលើកព្រះគម្ពីរបរិសុទ្ធមួយក្បាលឡើង ហើយពន្យល់ថា វាគឺព្រះគម្ពីរនៅក្នុងការនិមិត្តរបស់នីហ្វៃ ។ អ្នកអាចអញ្ជើញសិស្សឲ្យសរសេរ *ព្រះគម្ពីរបរិសុទ្ធ* នៅគែមទំព័រក្បែរនីហ្វៃទី១ ១៣:២០ ។

សូមពន្យល់ថា ទេវតាបានបង្រៀននីហ្វៃថា ព្រះគម្ពីរបរិសុទ្ធ គឺជាកំណត់ត្រា « ដ៏មានតម្លៃ » (នីហ្វៃទី១ ១៣:២៣) ។ នៅពេលវិវរណៈជាច្រើននៅក្នុងព្រះគម្ពីរបរិសុទ្ធ ត្រូវបានកត់ត្រាពីដើមដំបូង វា « មានន័យភាពពោរពេញនៃដំណឹងល្អរបស់ព្រះអម្ចាស់ » (នីហ្វៃទី ១ ១៣:២៤) ។ សុំឲ្យសិស្សម្នាក់ឲ្យអាន នីហ្វៃទី១ ១៣:២៦–២៧ ឮៗ ។

- តើព្រះវិហារដ៏ធំ ហើយគួរខ្ពើមឆ្អើមនោះបានដកអ្វីខ្លះចេញពីព្រះគម្ពីរបរិសុទ្ធ ? ហេតុអ្វីបានជារឿងទាំងនេះ ត្រូវបានដកចេញ ?

សុំឲ្យសិស្សម្នាក់ឲ្យទៀតអាន នីហ្វៃទី១ ១៣:២៩ ឮៗ ។

- តើមានអ្វីកើតឡើង ដែលជាលទ្ធផលនៃការដកចេញនូវរឿងដ៏ច្បាស់ និងពិសេសៗ និង សេចក្តីសញ្ញាជាច្រើននៃព្រះអម្ចាស់ ពីព្រះគម្ពីរបរិសុទ្ធ ?

សូមឲ្យសិស្សបួននាក់ប្តូរវេនគ្នាអានឮៗ នៅក្នុង នីហ្វៃទី១ ១៣:៣៤–៣៦, ៣៩ ។ សុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះអម្ចាស់នឹងធ្វើ ដើម្បីជួយមនុស្សឲ្យយកឈ្នះលើការខិតខំនៃព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើម ។

- ដោយយោងតាម នីហ្វៃទី១ ១៣:៣៤ តើព្រះអម្ចាស់នឹងនាំអ្វីចេញមក ដោយសារតែសេចក្តីមេត្តាករុណារបស់ទ្រង់ ?
- យោងតាមនីហ្វៃទី១ ១៣:៣៥–៣៦ តើអ្វីនឹង « ត្រូវបានលាក់ទុក » ដើម្បីឲ្យបានចេញមកដល់ពួកសាសន៍ដទៃ ? (អ្នកអាចផ្តល់យោបល់ថា សិស្សគួរតែសរសេរក្បែរ នីហ្វៃទី១ ១៣:៣៥ ថា « សេចក្តីទាំងនេះ » សំដៅលើព្រះគម្ពីរមរមន) ។
- យោងតាម នីហ្វៃទី១ ១៣:៣៩ តើមានអ្វីផ្សេងទៀត ដែលព្រះអម្ចាស់នឹងនាំចេញមកនៅក្នុងជំនាន់ចុងក្រោយ បន្ថែមលើព្រះគម្ពីរមរមន ? តើ « ព្រះគម្ពីរផ្សេងទៀត » ដែលព្រះអម្ចាស់បាននាំចេញមក ជាផ្នែកនៃការស្តារឡើងវិញមានអ្វីខ្លះ ? (ព្រះគម្ពីរគោលលទ្ធិ និង សេចក្តីសញ្ញា ព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា និង ការបកប្រែរបស់យ៉ូសែប ស៊្មីធ ពីព្រះគម្ពីរបរិសុទ្ធ) ។

សូមអញ្ជើញសិស្សឲ្យអាន នីហ្វៃទី១ ១៣:៤០–៤១ ។ សូមឲ្យពួកគេរកមើលការពិពណ៌នាមួយអំពីអ្វីដែលព្រះគម្ពីរនៃការស្តារឡើងវិញ នឹងធ្វើឲ្យមនុស្សទាំងអស់ស្គាល់ ។ ក្រោយពីសិស្សចែកចាយអ្វីដែលពួកគេបានរកឃើញហើយ សូមលើកព្រះគម្ពីរបរិសុទ្ធឡើង ហើយសូមចែកចាយនូវទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតពេញលេញរបស់វា ។ សូមលើកព្រះគម្ពីរមរមនឡើង ហើយដាក់វាជាមួយនឹងព្រះគម្ពីរបរិសុទ្ធ ។ សូមថ្លែងទីបន្ទាល់ថា **ព្រះគម្ពីរមរមន និង ព្រះគម្ពីរនៅថ្ងៃចុងក្រោយ បានស្តារឡើងវិញនូវសេចក្តីពិតដ៏ច្បាស់ និងពិសេសៗដែលជួយយើងឲ្យដឹងថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ ហើយវាជួយយើងឲ្យដឹងពីរបៀបដើម្បីចូលមករកទ្រង់ ។**

សុំឲ្យសិស្សរកឃ្លាមួយនៅចុងឃ្លាក្នុង នីហ្វៃទី១ ១៣:៤១ ដែលពិពណ៌នាពីអ្វីដែលព្រះអម្ចាស់នឹងធ្វើ ជាមួយនឹងកំណត់ត្រានៃសាសន៍យូដា (ព្រះគម្ពីរបរិសុទ្ធ) និង កំណត់ត្រានៃកូនចៅរបស់នីហ្វៃ (ព្រះគម្ពីរមរមន) ។ សូមថ្លែងទីបន្ទាល់ថា កំណត់ត្រាទាំងនេះគឺ « ត្រូវបានតាំងឡើងជារបស់តែមួយ » (នីហ្វៃទី១ ១៣:៤១) និង បាន « រួមទៅជាមួយគ្នា » (នីហ្វៃទី២ ៣:១២) ដើម្បីជួយយើងឲ្យដឹងច្បាស់ពីរបៀបដើម្បីចូលមករកព្រះអង្គសង្គ្រោះ ។

ដើម្បីជួយសិស្សកោតសរសើរពីរបៀបដែលការស្តារឡើងវិញនៃសេចក្តីពិតដ៏ច្បាស់ និងពិសេសៗនេះ មានឥទ្ធិពលលើជីវិតរបស់ពួកគេ សូមអញ្ជើញពួកគេឲ្យសញ្ជឹងគិតសំណួរដូចខាងក្រោម ៖

- តើព្រះគម្ពីរមរមនបានមានឥទ្ធិពលយ៉ាងដូចម្តេចលើទីបន្ទាល់របស់អ្នកអំពីព្រះយេស៊ូវគ្រីស្ទ ហើយបានជួយអ្នកឲ្យចូលមកជិតទ្រង់ដោយរបៀបណា ?

ក្រោយពីផ្តល់ពេលវេលាឲ្យសិស្សគិតហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយចម្លើយរបស់ពួកគេ ។ អ្នកក៏អាចចែកចាយទីបន្ទាល់របស់អ្នកផ្ទាល់អំពីព្រះគម្ពីរមរមន និង ពីរបៀបដែលវាបានពង្រឹងទីបន្ទាល់របស់អ្នកអំពីព្រះយេស៊ូវគ្រីស្ទ និង បានជួយអ្នកឲ្យដឹងពីរបៀបដើម្បីចូលទៅរកទ្រង់ ។ នៅពេលអ្នកបញ្ចប់មេរៀន សូមអញ្ជើញឲ្យសិស្សសិក្សាព្រះគម្ពីរមរមនដោយយកចិត្តទុកដាក់ពេញមួយឆ្នាំ ដោយរកមើលការបង្រៀន និង ដំណើររឿងដែលពង្រឹងដល់ទីបន្ទាល់របស់ពួកគេ អំពីព្រះយេស៊ូវគ្រីស្ទ និង បង្រៀនពួកគេពីរបៀបដើម្បីចូលទៅរកទ្រង់ ។

នីហ្វៃទី១ ១៤

សេចក្តីផ្តើម

នីហ្វៃទី១ ១៤ បញ្ចប់ដំណើររឿងនៃទស្សនៈនិមិត្តរបស់នីហ្វៃ ។ នៅក្នុងផ្នែកនៃទស្សនៈនិមិត្តនេះ នីហ្វៃដឹងពីពរជ័យទាំងឡាយដែលបានសន្យាទៅដល់អស់អ្នកណា ដែលកែប្រែចិត្ត និងស្តាប់តាមព្រះអម្ចាស់ និង បណ្តាសាដែលនឹងមកលើពួកទុច្ចរិត ដែលពង្រឹងចិត្តរបស់ពួកគេទាស់នឹងព្រះអម្ចាស់ ។ នីហ្វៃក៏បានឃើញថា ព្រះអម្ចាស់នឹងជួយ និង ការពារដល់អស់អ្នកណាដែលរស់នៅដោយសុចរិត និង កាន់តាមសេចក្តីសញ្ញារបស់ពួកគេ ហើយថាទ្រង់នឹងបំផ្លាញព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើមរបស់ពួកអាក្ស ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ១៤:១–៧

នីហ្វៃឃើញពីលទ្ធផល សម្រាប់ជំនាន់ក្រោយនៃការគោរព ឬ ការមិនគោរពព្រះអម្ចាស់

សូមអញ្ជើញសិស្សបើកព្រះគម្ពីររបស់ពួកគេទៅ នីហ្វៃទី១ ១៤ ។ សូមពន្យល់ថា សព្វថ្ងៃនេះ ពួកគេនឹងបន្តសិក្សាទស្សនៈនិមិត្តរបស់នីហ្វៃ ។ សុំឲ្យសិស្សសញ្ជឹងគិតអំពីរបៀបដែលពួកគេនឹងបំពេញនូវប្រយោគខាងក្រោម ៖

ប្រសិនបើខ្ញុំធ្វើតាមព្រះអម្ចាស់ នោះ . . .

ប្រសិនបើខ្ញុំបដិសេធធ្វើតាមព្រះអម្ចាស់ នោះ . . .

នៅពេលសិស្សបានចែកចាយនូវចម្លើយរបស់ពួកគេ សូមបង្ហាញថាពាក្យ *ប្រសិនបើ* ស្តីអំពីជម្រើស ។ ដោយពឹងផ្អែកលើអ្វីដែលយើងជ្រើសរើស យើងទទួលនូវលទ្ធផលខុសគ្នា ។ សូមពន្យល់ថា នីហ្វៃបានឃើញជំនាន់ក្រោយ និង បានកត់ត្រាថា ប្រសិនបើពួកគេសុចរិត នោះពួកគេនឹងត្រូវបានប្រទានពរ ឬ ប្រសិនបើពួកគេជ្រើសរើសអំពើទុច្ចរិត នោះពួកគេនឹងត្រូវបណ្តាសា ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យគិតពីមេរៀន ថាការជ្រើសរើសដើម្បីគោរពតាមព្រះអម្ចាស់ បាននាំពួកគេឲ្យទទួលបាននូវពរជ័យ ។

សូមគូសឌីយ៉ាក្រាមខាងក្រោមនៅលើក្តារខៀន ៖

ប្រសិនបើ ⟶ នោះ ⟶

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ១៤:១–២ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់រក (១) ជម្រើសដែលនីហ្វៃបានបង្ហាញថា សាសន៍ដទៃអាចធ្វើបាន និង (២) ពរជ័យដែលនីហ្វៃបានឃើញ ដែលនឹងមកដល់សាសន៍ដទៃ ប្រសិនបើពួកគេធ្វើជម្រើសនោះ ។ នៅពេលសិស្សចែកចាយអ្វីដែលពួកគេបានរកឃើញ សូមបំពេញនៅក្នុងចន្លោះនៅលើក្តារខៀន ដូច្នេះវាមើលទៅដូចអ្វីដែលមានខាងក្រោមនេះ ៖

ប្រសិនបើ ពួកគេស្តាប់តាមកូនចៀមនៃព្រះ និង មិនបានពង្រឹងចិត្តរបស់ពួកគេ	នោះ ពួកគេគួរតែ . . . រាប់នៅក្នុងចំណោមពូជពង្សនៃអ៊ីស្រាអែល ជាមនុស្សដែលមានពរដោយរៀងរហូត មិនត្រូវបានធ្លាក់ចុះនៅក្នុងការជាប់ឃុំឃាំង

អ្នកអាចពន្យល់ថា នៅក្នុងព្រះគម្ពីរ ឃ្លា « ថ្មជំពប់ » (នីហ្វៃទី១ ១៤:១) ជាញឹកញាប់ សំដៅលើឧបសគ្គដែលរារាំងមនុស្សពីការធ្វើតាមព្រះអម្ចាស់ ។ ដើម្បីបាន « រាប់ក្នុងចំណោមវង្សអ៊ីស្រាអែល » (នីហ្វៃទី១ ១៤:២) មានន័យថាត្រូវបានរាប់ក្នុងចំណោមប្រជាជនសេចក្តីសញ្ញារបស់ព្រះអម្ចាស់ ។

- **ហេតុអ្វីបានជាវាសំខាន់ ដើម្បីរាប់ក្នុងចំណោមប្រជាជនសេចក្តីសញ្ញារបស់ព្រះអម្ចាស់ ? (ដើម្បីទទួលបាននូវពរជ័យនៃសេចក្តីសញ្ញាអ័ប្រាហាំ | សូមមើល គ. និង ស. ១៣២:៣០–៣១ |) ។**
- **តើវាមានន័យដូចម្តេចក្នុងការ « ស្តាប់តាមកូនចៀមនៃព្រះ » ?**
- **ក្នុងចំណោមរង្វាន់ចំពោះការគោរពប្រតិបត្តិ ដែលបានចុះបញ្ជីនៅក្តារខៀន តើរង្វាន់មួយណាដែលមានន័យបំផុតចំពោះអ្នក ? ហេតុអ្វី ?**
- **តើនៅពេលណាដែលអ្នកបានស្តាប់តាមព្រះអម្ចាស់ និង បានឃើញនូវពរជ័យរបស់ទ្រង់នៅក្នុងជីវិតរបស់អ្នក ? (សូមរំឭកសិស្សថាពួកគេមិនត្រូវការចែកចាយបទពិសោធដែលផ្ទាល់ខ្លួនខ្លាំងពេកទេ) ។**

នៅលើផ្នែកផ្សេងទៀតលើក្តារខៀន សូមគូសឌីយ៉ាក្រាមដូចខាងក្រោម ៖



ជំនួយចក្ខុ

សិស្សភាគច្រើន នឹងរៀនប្រសើរជាងនេះ និង ចងចាំបានយូរជាងនេះ នៅពេលអ្នកប្រើជំនួយចក្ខុដើម្បីបង្ហាញពីគំនិតនានា ។ ឌីយ៉ាក្រាមសាមញ្ញ ដូចអ្វីដែលបានបង្ហាញនៅក្នុងគំនិតនៃការបង្រៀននេះ នឹងងាយស្រួលគូរនៅលើក្តារខៀន ។ ឌីយ៉ាក្រាមបែបនេះ អាចជួយសិស្សឲ្យផ្តោតលើគំនិតសំខាន់នៅក្នុងព្រះគម្ពីរ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ១៤:៥–៧ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់ស្វែងរកនូវ (១) ពរជ័យដែលមកដល់អស់អ្នកណាដែលប្រែចិត្ត និង (២) លទ្ធផលអវិជ្ជមានដែលមកដល់អស់អ្នកណាដែលពង្រឹងដួងចិត្តរបស់ពួកគេ ។ សូមបំពេញឌីយ៉ាក្រាម នៅពេលអ្នកធ្វើលំហាត់ពីមុនៗ ។ (ប្រសិនបើមនុស្សព្រមប្រែចិត្ត « នោះនឹងបានស្រួលដល់ពួកគេហើយ » | នីហ្វៃទី១ ១៤:៥ | ហើយពួកគេនឹងទទួលបាន « សេចក្តីសុខសាន្ត និង ជីវិតដ៏នៅអស់កល្បជានិច្ច » | នីហ្វៃទី១ ១៤:៧ | ។ ប្រសិនបើមនុស្សពង្រឹងចិត្តរបស់ពួកគេ ពួកគេនឹង « ត្រូវវិនាស » | នីហ្វៃទី១ ១៤:៥ | និង « ត្រូវធ្លាក់ទៅក្នុងការជាប់ឃុំឃាំង » និង « សេចក្តីប៉ិនប្រិចបំផ្លាញ » | នីហ្វៃទី១ ១៤:៧ |) ។

នៅពេលសិស្សឆ្លើយតប អ្នកអាចពន្យល់ថា « កិច្ចការដ៏ធំ ហើយអស្ចារ្យ » ដែលបានលើកឡើងនៅក្នុងនីហ្វៃទី១ ១៤:៧ សំដៅលើការស្តារឡើងវិញនៃបព្វជិតភាព ដំណឹងល្អ និង សាសនាចក្ររបស់ព្រះអម្ចាស់នៅក្នុងថ្ងៃចុងក្រោយ ។

- តើសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយជា « កិច្ចការដ៏ធំ ហើយអស្ចារ្យ » ចំពោះអ្នកដោយរបៀបណា ? តើវានាំមកនូវសេចក្តីសុខសាន្តមកដល់អ្នកដោយវិធីណា ? តើវានាំសេចក្តីសង្ឃឹមមកដល់អ្នកចំពោះជីវិតដ៏នៅអស់កល្បជានិច្ចយ៉ាងដូចម្តេច ?

សូមគិតពីការឲ្យពេលទៅសិស្សដើម្បីសញ្ជឹងគិតដោយស្ងាត់ៗពីផ្លូវដែលបានគូសនៅលើក្តារខៀនដែលពួកគេកំពុងតែស្វែងរកថ្មីៗនេះ ។ សូមថ្លែងទីបន្ទាល់ថា **ការគោរពតាមព្រះអម្ចាស់ និង ការកែប្រែចិត្តពីអំពើបាបរបស់យើង នាំទៅរកពរជ័យដ៏មហិមា ។** អ្នកក៏អាចថ្លែងទីបន្ទាល់ថា ការពង្រឹងចិត្តរបស់យើង ទាស់នឹងព្រះអម្ចាស់ និង សាសនាចក្ររបស់ទ្រង់ នឹងនាំទៅរកការជាប់ឃុំឃាំង និង ការបំផ្លាញខាងវិញ្ញាណ ។

នីហ្វៃទី១ ១៤:៨–១៧

នីហ្វៃឃើញពីសង្គ្រាម រវាងសាសនាចក្រនៃកូនចៀមនៃព្រះ និង សាសនាចក្រដ៏ធំ និង គួរខ្ពើមឆ្អើម ។

សូមអញ្ជើញសិស្សឲ្យគិតស្រមៃថា ពួកគេទើបតែបានចុះបញ្ជីដើម្បីទៅធ្វើសង្គ្រាមមួយ ។

- តើអ្នកនឹងធ្វើអ្វីដើម្បីរៀបចំសម្រាប់សង្គ្រាមនោះ ?

សូមពន្យល់ថា ទេវតាបានបង្រៀននីហ្វៃអំពីសង្គ្រាមមួយដ៏អស្ចារ្យ ដែលនឹងកើតឡើងនៅក្នុងថ្ងៃចុងក្រោយ ។

សូមអញ្ជើញសិស្សបីនាក់ ឲ្យប្តូរវេនគ្នាអានឮៗ នៅក្នុងនីហ្វៃទី១ ១៤:៩–១១ ។ សុំឲ្យសិស្សក្នុងថ្នាក់ស្វែងរកក្រុមពីរដែលស្ថិតនៅក្នុងជម្លោះទាស់គ្នា ។ (អ្នកអាចរំឭកសិស្សថា ព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើម ប្រកាសដល់បុគ្គល ឬ ក្រុមខ្លះដែលដឹកនាំមនុស្សចេញឆ្ងាយពីព្រះ និង ច្បាប់របស់ទ្រង់) ។

- តើពាក្យ និង ឃ្លាណាដែលត្រូវបានប្រើដើម្បីពិពណ៌នា « ព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើម » ?
- យោងតាមទស្សនៈនិមិត្តរបស់នីហ្វៃ តើ « ព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើម » នឹងត្រូវបានរកឃើញនៅកន្លែងណា នៅក្នុងថ្ងៃចុងក្រោយ ?

សុំឲ្យសិស្សបីនាក់ទៀត ប្តូរវេនគ្នាអានឮៗនៅក្នុង នីហ្វៃទី១ ១៤:១២–១៤ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលមូលហេតុដែលយើងអាចមានសង្ឃឹមអំពីអនាគត ។

- យោងតាមនីហ្វៃទី១ ១៤:១២ តើព្រះវិហារណាមួយនឹងមានមនុស្សច្រើនជាង ?
- ហេតុអ្វីបានជាសាសនាចក្រនៃកូនចៀម នឹងមានមនុស្សតិចជាងសាសនាចក្រដ៏ធំ និង គួរខ្ពើមឆ្អើម ?
- យោងតាម នីហ្វៃទី១ ១៤:១៣ តើសាសនាចក្រដ៏ធំ និង គួរខ្ពើមឆ្អើម ប្រមូលផ្តុំហ្វូងមនុស្សជាច្រើនដើម្បីគោលបំណងអ្វី ?

សូមថ្លែងទីបន្ទាល់ថា យើងបានជាប់នៅក្នុងសង្គ្រាមដែលនីហ្វៃពិពណ៌នា—សង្គ្រាមខាងវិញ្ញាណនៅថ្ងៃចុងក្រោយប្រឆាំងនឹងអំពើអាក្រក់ ។ ក្នុងនាមជាសមាជិកនៃសាសនាចក្រនៃកូនចៀម យើងមានចំនួនច្រើន ហើយយើងត្រូវការជំនួយ ប្រសិនបើយើងត្រូវឲ្យឈ្នះប្រឆាំងនឹងកម្លាំងនៃអារក្ស ។

- តើអ្នកបានអានអ្វីនៅក្នុង នីហ្វៃទី១ ១៤:១៤ ដែលផ្តល់ឲ្យអ្នកនូវសេចក្តីសង្ឃឹម ?

សូមសង្កត់ធ្ងន់ថា សេចក្តីសន្យាដែលបានផ្តល់នៅក្នុងព្រះគម្ពីរទាំងនេះ អនុវត្តជាពិសេសចំពោះអ្នកណាដែលធ្វើ និង រក្សាសេចក្តីសញ្ញាជាមួយនឹងព្រះអម្ចាស់ ។ សូមរំឭកសិស្សថា ពួកគេបានចូលទៅក្នុងសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹកជាមួយនឹងព្រះអម្ចាស់ ។ សូមទាមទារការយកចិត្តទុកដាក់លើឃ្លា « ប្រដាប់អាវុធដោយសេចក្តីសុចរិត និង ដោយព្រះចេស្តានៃព្រះ » នៅក្នុងនីហ្វៃទី១ ១៤:១៤ ។

- តើឃ្លា « ប្រដាប់អាវុធដោយសេចក្តីសុចរិត និង ដោយព្រះចេស្តានៃព្រះ » មានន័យដូចម្តេចចំពោះអ្នក ?
- តើតាមរបៀបណាដែលការ « ប្រដាប់អាវុធដោយសេចក្តីសុចរិត និង ដោយព្រះចេស្តានៃព្រះ » អាចដូចជាការមានសព្វាវុធ និង អាវុធ នៅក្នុងសង្គ្រាមរបស់យើង ប្រឆាំងនឹងអំពើអាក្រក់ ?
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា អ្នកត្រូវបាន « ប្រដាប់អាវុធដោយសេចក្តីសុចរិត និង ដោយព្រះចេស្តានៃព្រះ » ? តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេចដែរ ?

សូមសួរសិស្សថា តើពួកគេនឹងសង្ខេបសារលិខិត នៅក្នុងនីហ្វៃទី១ ១៤:១–១៤ដោយរបៀបណា ។ សូមធ្វើយ៉ាងណា ពួកគេយល់ថា **ប្រសិនបើយើងរស់នៅដោយសុចរិត និង កាន់តាមសេចក្តីសញ្ញារបស់យើង នោះព្រះចេស្តានៃព្រះ នឹងជួយយើងឲ្យមានជ័យជំនះលើអំពើអាក្រក់ ។**

សូមអញ្ជើញសិស្សឲ្យវាយតម្លៃជីវិតរបស់ពួកគេ និង គិតថាតើពួកគេអាចធ្វើអ្វី ដើម្បីប្រដាប់អាវុធដោយសេចក្តីសុចរិត ។ សូមជម្រុញឲ្យពួកគេធ្វើសកម្មភាពតាមការបំផុសគំនិតដែលពួកគេបានទទួល ។ សូមធានាពួកគេថា នៅពេលពួកគេនៅតែស្មោះត្រង់ ពួកគេនឹងមាន

ឱកាសដើម្បីចូលទៅក្នុងព្រះវិហារបរិសុទ្ធដ៏ពិសិដ្ឋ និង ធ្វើសេចក្តីសញ្ញាបន្ថែមជាមួយនឹងព្រះអម្ចាស់ ។ សេចក្តីសន្យា និង សេចក្តីសញ្ញាដែលពួកគេធ្វើនៅទីនោះ នឹងនាំអំណាច ហើយការការពារដ៏អស្ចារ្យទៅក្នុងជីវិតរបស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១៤:៣–៤ឬ។ ។ សូមឲ្យសិស្សម្នាក់ទៀតអាន នីហ្វៃទី១ ១៤:១៥–១៧ឬ។ ។

- តើនឹងមានអ្វីកើតឡើងចំពោះព្រះវិហារដ៏ធំ និង គួរខ្ពើមឆ្អើម ?
- តើអ្វីដែលនឹងជាលទ្ធផលចុងក្រោយនៃសង្គ្រាមរវាងសាសនាចក្រនៃកូនចៀម (នគរនៃព្រះ) និង ថាមពលនៃអារក្ស ?
- តើការដឹងអំពីលទ្ធផលនៃការតស៊ូនេះ អាចជួយអ្នកយ៉ាងដូចម្តេច ?

សូមអានប្រាប់សិស្សក្នុងថ្នាក់នូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ិយដ៍ ឃេ ផាកគី នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ៖

« យើង | សមាជិកនៃសាសនាចក្រ | គឺជាចំណែកតូចមួយ នៅពេលប្រៀបធៀបទៅនឹងមនុស្សរាប់ពាន់លាននាក់នៅលើផែនដី ។ ប៉ុន្តែយើង គឺជាយើង ហើយយើងដឹងពីអ្វីដែលយើងដឹង ហើយយើងនឹងទៅមុខ ហើយផ្សព្វផ្សាយដំណឹងល្អ ។

« ព្រះគម្ពីរមរមន ប្រាប់ច្បាស់ថា យើងនឹងមិនដែលត្រូតត្រាដោយចំនួននោះទេ ។ ប៉ុន្តែយើងមានអំណាចនៃបព្វជិតភាព | សូមមើល នីហ្វៃទី១ ១៤:១៤| ។ . . .

« យើងអាច និង នៅក្នុងពេលកំណត់ច្បាស់ យើងនឹងមានឥទ្ធិពលលើមនុស្សជាតិទាំងអស់ ។ យើងនឹងត្រូវបានគេដឹងថា យើងជានរណា និង ហេតុអ្វីបានយើងធ្វើ ។ វាហាក់បីដូចជាអស់សង្ឃឹម វាពិតជាពិបាកខ្លាំងណាស់ ប៉ុន្តែវាមិនត្រឹមតែអាចធ្វើបាននោះទេ គឺវាច្បាស់ថា យើងនឹងឈ្នះលើសង្គ្រាម ប្រឆាំងនឹងសាតាំងនេះ » (« អំណាចនៃបព្វជិតភាព » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៧) ។

សូមធានាសិស្សថា **នគររបស់ព្រះ នឹងមានជ័យជំនះនៅក្នុងថ្ងៃចុងក្រោយ ។**សូមបង្ហាញការជឿជាក់ថា ពួកគេអាចទុកចិត្តលើព្រះ ហើយថាអំណាចរបស់ទ្រង់នឹងយកឈ្នះលើអំពើអាក្រក់ទាំងអស់ ។ សូមលើកទឹកចិត្តពួកគេ ឲ្យក្លាយជាកម្លាំងមួយសម្រាប់ការល្អ ក្នុងការមានឥទ្ធិពលដល់អ្នកដទៃ ។

នីហ្វៃទី១ ១៤:១៨–២៧

នីហ្វៃបានឃើញយ៉ូហាន អ្នកទទួលវិវរណៈ

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖

តើសាវកដប់ពីររបស់ព្រះអង្គសង្គ្រោះណាមួយ ដែលនីហ្វៃបានឃើញនៅក្នុងទស្សននិមិត្តនោះ ?

តើសាវកនេះ នឹងសរសេរអំពីអ្វី ?

ហេតុអ្វីបានជានីហ្វៃត្រូវបានដាក់បញ្ញត្តិមិនឲ្យសរសេរទស្សននិមិត្តរបស់គាត់ទាំងអស់ ?

សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ១៤:១៨–២៧ដោយស្ងាត់ៗ។ បន្ទាប់មកពិភាក្សាដោយខ្លីៗពីចម្លើយ ចំពោះសំណួរនៅលើក្តារខៀន ។

សូមពន្យល់ថា យោងយ៉ាងហោចណាស់ខគម្ពីរទាំងនេះសំដៅ លើផ្នែកនៃការសរសេររបស់យ៉ូហាននៅក្នុងព្រះគម្ពីរវិវរណៈ ។ គំនិតសំខាន់មួយនៃព្រះគម្ពីរនោះគឺថា ព្រះនឹងយកជ័យជំនះលើកម្លាំងនៃអារក្ស ។ ដូចជាយ៉ូហានដែរ នីហ្វៃក៏បានឃើញទស្សននិមិត្តមួយអំពីចុងបញ្ចប់នៃពិភពលោក ប៉ុន្តែគាត់ត្រូវបានបញ្ជាមិនឲ្យសរសេរការណ៍ទាំងនោះទេ ដោយសារយ៉ូហានបានទទួលខុសត្រូវធ្វើកិច្ចការនេះ ។ បើមានពេល អ្នកអាចបញ្ចប់មេរៀននេះ ដោយការពិភាក្សាខ្លីមួយ អំពីរបៀបដែលព្រះគម្ពីរបរិសុទ្ធ និង ព្រះគម្ពីរមរមនធ្វើការជាមួយគ្នាដើម្បី « តាំងនូវសេចក្តីពិត » ពីគ្នាទៅវិញទៅមក ហើយក្លាយជា « តែមួយ » (នីហ្វៃទី១ ១៣:៤០–៤១) ។

មេរៀនសិក្សានៅផ្ទះ

នីហ្វៃទី១ ៧–១៤ (មេរៀនទី ៣)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនមេរៀននៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបពីគោលលទ្ធិ និង សេចក្តីសញ្ញាខាងក្រោម ដែលសិស្សបានរៀននៅពេលពួកគេបានសិក្សានៅក្នុង នីហ្វៃទី១ ៧–១៤ (មេរៀនទី ៣) មិនត្រូវបានបម្រុងទុកសម្រាប់បង្រៀនជាផ្នែកមួយនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីសេចក្តីត្រូវការរបស់សិស្ស ។

ថ្ងៃទី១ (នីហ្វៃទី១ ៧)

នៅពេលសិស្សសិក្សាពីរបៀបដែលកូនប្រុសរបស់លីហៃ បានត្រឡប់ទៅទីក្រុងយេរូសាឡិមវិញទៅយកគ្រួសាររបស់អ៊ីសម៉ាអែលទៅជាមួយពួកគេទៅដែនដីសន្យា ពួកគេបានដឹងថា ព្រះអម្ចាស់បានបញ្ជាយើងឲ្យរៀបការ និង ចិញ្ចឹមកូនៗថ្វាយដល់ទ្រង់ ហើយថាព្រះទ្រង់ឆ្លើយតបការអធិស្ឋាន តាមរយៈសេចក្តីជំនឿរបស់យើង ។

ថ្ងៃទី២ (នីហ្វៃទី១ ៨)

សិស្សបានសិក្សាពីទស្សននិមិត្តរបស់លីហៃពីដើមជីវិត ។ ពួកគេបានដឹងថា ការចូលទៅរកព្រះយេស៊ូវគ្រីស្ទ និង ការទទួលដង្វាយធួនរបស់ទ្រង់ នាំមកនូវសុភមង្គល និង សេចក្តីអំណរ ។ នៅពេលពួកគេអានអំពីក្រុមមនុស្សផ្សេងៗ នៅក្នុងសុបិននោះ និង ជោគជ័យ រួមទាំងការបាត់ជ័យរបស់ពួកគេនៅក្នុងការដើរទៅដើមជីវិត និង ការទទួលទានផ្លែឈើ ពួកគេក៏បានរៀនពីគោលការណ៍ខាងក្រោម ៖ អំនួត ភាពលោកិយ និង ការចុះចាញ់តាមការល្បួង អាចរារាំងយើងពីការទទួលបានពរជ័យនៃដង្វាយធួន ។ ប្រសិនបើយើងកាន់ខ្ជាប់តាមព្រះបន្ទូលនៃព្រះ វានឹងជួយយើងឲ្យមានឈ្នះលើការល្បួង និង ឥទ្ធិពលខាងលោកិយ ។ ការកាន់ខ្ជាប់តាមព្រះបន្ទូលនៃព្រះ នឹងជួយយើងឲ្យខិតកាន់តែជិតទៅព្រះអម្ចាស់ និង ទទួលបាននូវពរជ័យនៃដង្វាយធួន ។

ថ្ងៃទី៣ (នីហ្វៃទី១ ១០–១១)

សិស្សបានរៀនពីអ្វីដែលបានកើតឡើង នៅពេលនីហ្វៃបានស្វែងរកចង់ « ឃើញ និង ឮ និង ដឹង » (នីហ្វៃទី១ ១០:៧) សម្រាប់ខ្លួនគាត់ នូវរឿងអ្វីៗដែលឪពុករបស់គាត់បានឃើញ ។ តាមរយៈគំរូរបស់នីហ្វៃ ពួកគេបានឃើញថា ព្រះនឹងបង្ហាញសេចក្តីពិតទៅដល់អ្នកណាដែលព្យាយាមស្វែងរកទ្រង់ ។ នីហ្វៃបានទទួលការនិមិត្តមួយដែលបានបង្រៀនពីសេចក្តីស្រឡាញ់របស់ព្រះចំពោះយើង ដែលបង្ហាញតាមរយៈអំណោយទានជាព្រះរាជបុត្រារបស់ទ្រង់ ។ សិស្សមានឱកាសមួយ ដើម្បីសរសេរទុកនូវអ្វីដែលមានន័យចំពោះពួកគេ ។

ថ្ងៃទី ៤ (នីហ្វៃទី១ ១២– ១៤)

នៅក្នុងសំណល់អំពីការនិមិត្តរបស់គាត់ នីហ្វៃបានឃើញពីរបៀបដែលព្រះអម្ចាស់បានរៀបចំផ្លូវសម្រាប់ការស្តារឡើងវិញ ។ គាត់បានដឹងថា សេចក្តីពិតដ៏ច្បាស់ និង ពិសេសៗនឹងត្រូវបានដកចេញពីព្រះគម្ពីរបរិសុទ្ធ ប៉ុន្តែថាព្រះគម្ពីរមរមន និង ព្រះគម្ពីរនៅថ្ងៃចុងក្រោយ នឹងស្តារឡើងវិញនូវសេចក្តីពិតដ៏ច្បាស់ និងពិសេសៗទាំងនោះ ដែលជួយយើងឲ្យដឹងថា ព្រះយេស៊ូវគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ ហើយវាជួយយើងឲ្យចូលមករកទ្រង់ ។ នីហ្វៃ ក៏បានឃើញជំនាន់ចុងក្រោយដែរ ។ សិស្សបានសញ្ជឹងគិតពីគោលការណ៍ថា នៅពេលយើងរស់នៅដោយសុចរិត និង រក្សាសេចក្តីសញ្ញាដ៏ពិសិដ្ឋ នោះព្រះចេស្តានៃព្រះនឹងជួយយើងឲ្យមានជោគជ័យលើអំពើអាក្រក់ ។

សេចក្តីផ្តើម

ការផ្តោតលើមេរៀនក្នុងសប្តាហ៍នេះ គឺជាទស្សននិមិត្តរបស់លីហៃនៅក្នុង នីហ្វៃទី១ ៨ ។ នៅពេលអ្នកបង្រៀនមេរៀននេះ សូមបញ្ជាក់លើសេចក្តីអំណរដែលដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ អាចនាំមកដល់ក្នុងជីវិតរបស់យើង និង របៀបដែលយើងអាចជួបនូវពរជ័យនៃដង្វាយធួនតាមរយៈការរស់នៅតាមព្រះបន្ទូលនៃព្រះ ។ សិស្សនឹងប្រើព្រះគម្ពីររបស់ពួកគេ ការណែនាំការសិក្សាសិស្ស និង សៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរតាមរយៈមេរៀននេះ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ៧

ព្រះអម្ចាស់បញ្ជាកូនប្រុសរបស់លីហៃ ឲ្យត្រឡប់ទៅទីក្រុងយេរូសាឡិមវិញទៅយកអ៊ីសម៉ាអែល និង គ្រួសាររបស់គាត់

សូមបង្ហាញរូបភាពគូស្វាមីរៀបការរួច និង កូនៗរបស់ពួកគេ — ប្រហែលជារូបភាពនៃគ្រួសារផ្ទាល់ខ្លួនរបស់អ្នកមួយ ឬ រូបរបស់សិស្សម្នាក់ ដែលអ្នកបានអញ្ជើញគេឲ្យយករូបភាពនោះមក ។

សូមសួរសិស្សថា ៖ ហេតុអ្វីបានជាគ្រួសារមានសារៈសំខាន់ចំពោះផែនការរបស់ព្រះ ក្នុងការសង្គ្រោះរបស់យើង ?

សូមអញ្ជើញសិស្សរំឭកឡើងវិញ និងសង្ខេប នីហ្វៃទី១ ៧:១–៥ ។ សូមសួរគោលការណ៍ណា ដែលពួកគេបានរៀនពីខគម្ពីរទាំងនេះ ។ (សិស្សអាចចែកចាយគោលការណ៍ផ្សេងៗគ្នា ។ គោលការណ៍ដែលបានបញ្ជាក់នៅក្នុងសៀវភៅសិក្សារបស់សិស្សគឺថា **ព្រះអម្ចាស់ងាក់បញ្ញត្តិដល់យើងឲ្យរៀបការ និងចិញ្ចឹមកូនៗយើងថ្វាយទៅទ្រង់ ។**)

នៅក្នុងមេរៀនរបស់ពួកគេសម្រាប់ថ្ងៃទី ១ សិស្សត្រូវបានសុំឲ្យសួរទៅឪពុក ឬ ម្តាយ អ្នកដឹកនាំសាសនាចក្រ ឬ គ្រូបង្រៀនដើម្បីស្នើរបៀបបីយ៉ាង ដែលយុវជនសព្វថ្ងៃនេះ អាចរៀបចំចំពោះអាពាហ៍ពិពាហ៍ និង ការចិញ្ចឹមកូន « ថ្វាយ ព្រះអម្ចាស់ » ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយនូវអ្វីដែលពួកគេបានរៀន ។

នីហ្វៃទី ១ ៨

លីហៃ មានការនិមិត្តពីដើមឈើជីវិត

សូមរំឭកសិស្សថា ក្រោយពីនីហ្វៃ និង បងប្រុសរបស់គាត់ បាននាំអ៊ីសម៉ាអែល និង គ្រួសាររបស់គាត់មកកាន់ទីរហោស្ថាន លីហៃបានមានសុបិនមួយ ។ នៅពេលសិស្សម្នាក់អាន នីហ្វៃទី១ ៨:១០–១៣ ឮៗ សូមឲ្យសិស្សម្នាក់ទៀត គូរអ្វីដែលខគម្ពីរនោះបានពិពណ៌នាដាក់លើក្តារខៀន ឬ នៅលើក្រដាសមួយ ។ ប្រសិនបើអ្នកមានអារម្មណ៍ថា វាសមរម្យដាងសម្រាប់សិស្សក្នុងថ្នាក់របស់អ្នក អ្នកអាចបង្ហាញរូបភាពនៃសុបិនសុបិនរបស់លីហៃ (៦២៦២០; *សៀវភៅរូបភាពដំណឹងល្អ* [២០០៩] ទំព័រ ៦៩) និង ឲ្យសិស្សរកមើលរូបផ្សេងៗក្នុងខគម្ពីរនោះ ។

សូមសួរសិស្សថា ៖ តើការពិពណ៌នារបស់លីហៃអ្វី ដែលធ្វើឲ្យផ្លែឈើនៃដើមនោះ ទាក់ទាញចិត្តអ្នកបាន ?

សូមរំឭកសិស្សថា ផ្លែឈើនៃដើមនោះ តំណាងឲ្យ « អំណោយទានដ៏មហិមាបំផុតនៃព្រះ » (នីហ្វៃទី១ ១៥:៣៦)—ពរជ័យនៃដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ប្រសិនបើអ្នកមានសិស្សម្នាក់គូររូបភាព អ្នកអាចសរសេរចំណាំពីអ្វីដែលផ្លែឈើនោះ តំណាងនៅគំនូរនោះ ។

សូមសួរសិស្សថា ៖ តើយើងអាចរៀនអ្វីពី នីហ្វៃទី១ ៨:១០–១៣ពីការទទួលបាននូវពរជ័យនៃដង្វាយធួន ? (ទោះបីជាសិស្ស អាចប្រើពាក្យខុសគ្នាដើម្បីបង្ហាញក៏ដោយ សូមប្រាកដថាគោលការណ៍ខាងក្រោមគឺច្បាស់ ៖ **ការចូលមករកព្រះយេស៊ូវគ្រីស្ទ និង ការទទួលទាននូវដង្វាយធួន នាំមកនូវសុភមង្គល និង សេចក្តីអំណរ ។** អ្នកអាចសរសេរគោលការណ៍នេះ នៅលើក្តារខៀន) ។

នៅក្នុងមេរៀនរបស់ពួកគេសម្រាប់ថ្ងៃទី ២ សិស្សត្រូវឆ្លើយនឹងសំណួរ « តើនៅពេលណាដែលជង្វាយរបស់ព្រះអង្គសង្គ្រោះ បាននាំមកនូវសុភមង្គល និង សេចក្តីអំណរមកក្នុងជីវិតរបស់អ្នក ? » សូមអញ្ជើញសិស្សបើកសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ហើយអានចម្លើយរបស់ពួកគេដោយស្ងាត់ៗ ។

ដើម្បីជួយសិស្សចែកចាយសេចក្តីពិត និង ទីបន្ទាល់ដ៏មានន័យជាមួយនឹងគ្នាទៅវិញទៅមក សូមលើកទឹកចិត្តសិស្សបីបួននាក់អាន ឬ ជជែកអំពីអ្វីដែលពួកគេបានសរសេរ ។ អ្នកក៏អាចប្រាប់អំពីគ្រាមួយ នៅពេលជង្វាយធួនបាននាំមកនូវសុភមង្គល និង សេចក្តីអំណរមកក្នុងជីវិតរបស់អ្នក ។

សូមពន្យល់ថា ទស្សនៈនិមិត្តរបស់លីហៃមិនត្រឹមតែបង្រៀនថា ជង្វាយធួននាំមកនូវសេចក្តីអំណរដ៏មហិមានោះទេ វាក៏បានបង្ហាញពីអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបាននូវពរជ័យនៃជង្វាយធួន ។ សូមអញ្ជើញសិស្សរ៉ឺកឡើងវិញ នីហ្វៃទី១ ៨:១៩–២៦និង គូសនិមិត្តសញ្ញាផ្សេងទៀត ចេញពីរនិមិត្តរបស់លីហៃ ឬ ឲ្យពួកគេរកនិមិត្តសញ្ញាផ្សេងទៀតនៅក្នុងរូបភាពសុបិនរបស់លីហៃ ។ នៅពេលពួកគេគូរ ឬ រកមើលនិមិត្តសញ្ញា សូមអញ្ជើញពួកគេឲ្យពន្យល់ពីន័យនៃនិមិត្តសញ្ញាដែលខុសគ្នា ។ (ប្រសិនបើពួកគេត្រូវការជំនួយ សូមលើកទឹកចិត្តពួកគេឲ្យប្រើតារាង ដែលពួកគេបានបំពេញនៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស ។)

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ៨:៣០ ឮៗ ។ បន្ទាប់មក សួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- តើអ្វីជាតួនាទីនៃដំបងដែក —ព្រះបន្ទូលនៃព្រះ —នៅក្នុងទស្សនៈនិមិត្តរបស់លីហៃ ?
- នៅពេលអ្នកសិក្សា នីហ្វៃទី១ ៨ តើអ្នកបានរៀនអ្វីខ្លះអំពីសារៈសំខាន់នៃព្រះបន្ទូលនៃព្រះ ?
- តើឃ្លាណានៅក្នុង នីហ្វៃទី១ ៨:៣០ បង្ហាញអ្វីដែលយើងត្រូវធ្វើ ដើម្បីទទួលបាននូវពរជ័យនៃជង្វាយធួន ?
- តើអ្នកគិតថា វាមានន័យដូចម្តេចដើម្បី « ប្រជ្រៀតគ្នាទៅមុខ ដោយកាន់ដំបងដែកយ៉ាងខ្ជាប់ជានិច្ច » ?

សូមសរសេរនៅលើក្តារខៀននូវគោលការណ៍នៃដំណឹងល្អពីរផ្សេងទៀត ដែលពួកគេបានសិក្សានៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្ស ៖ ***ប្រសិនបើយើងកាន់ខ្ជាប់តាមព្រះបន្ទូលនៃព្រះជានិច្ច វានឹងជួយយើងឲ្យយកឈ្នះលើការល្បួង និង ឥទ្ធិពលខាងលោកិយ ។ ការកាន់ខ្ជាប់តាមព្រះបន្ទូលនៃព្រះ ជួយយើងឲ្យខិតកាន់តែជិតទៅកព្រះអម្ចាស់ ហើយទទួលបាននូវពរជ័យនៃជង្វាយធួន ។***

សុំឲ្យសិស្សគិតស្រមៃថា ពួកគេគឺជាអ្នកផ្សព្វផ្សាយសាសនា និង មានឱកាសដើម្បីថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃការសិក្សាព្រះបន្ទូលរបស់ព្រះ និង រស់នៅតាមគោលការណ៍នោះ ។ សូមឲ្យពួកគេចែកចាយនូវអ្វីដែលពួកគេនឹងនិយាយ ដោយផ្អែកលើបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ ។ សូមគិតពីការចែកចាយអារម្មណ៍របស់អ្នកអំពីអំណាចនៃព្រះគម្ពីរ និង ពាក្យសម្តីរបស់ព្យាការីដែលបានជួយអ្នកឲ្យចូលមកកាន់តែជិតព្រះអង្គសង្គ្រោះ ។

នីហ្វៃទី១ ១០–១៤

ដោយសារតែសេចក្តីជំនឿ និង សេចក្តីព្យាយាមរបស់គាត់ នីហ្វៃទទួលបាននូវវិវរណៈផ្ទាល់ខ្លួនអំពីអ្វីៗទាំងឡាយដែលឪពុករបស់គាត់បានបង្រៀន និង រឿងផ្សេងៗជាច្រើនទៀត ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ១០:១៧, ១៩ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពរជ័យដែលកើតមាន នៅពេលយើងស្វែងរកការណែនាំរបស់ព្រះអម្ចាស់ដោយឧស្សាហ៍ព្យាយាម ។ សូមឲ្យសិស្សម្នាក់ ឬ ពីរនាក់ចែកចាយអ្វីដែលពួកគេគិត ថាមានន័យចំពោះពាក្យថា « ស្វែងរកដោយឧស្សាហ៍ព្យាយាម » ។ (អំឡុងពេលមេរៀនថ្ងៃទី ៣ របស់ពួកគេ ពួកគេត្រូវបានស្នើឲ្យសរសេរពីន័យវា នៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្សរបស់ពួកគេ) ។

សូមសង្កេប នីហ្វៃទី១ ១១– ១៤ ដោយនិយាយថា នីហ្វៃបានទទួលនូវវិវរណៈផ្ទាល់ខ្លួនដោយសារគាត់បានស្វែងរកព្រះអម្ចាស់ដោយឧស្សាហ៍ព្យាយាម ។ គាត់បានឃើញការបម្រើ និង ជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ (នីហ្វៃទី១ ១១) ការបំផ្លាញនៅថ្ងៃអនាគតរបស់ប្រជាជនគាត់ដោយសារតែអំនួត និង អំពើទុច្ចរិតរបស់ពួកគេ (នីហ្វៃទី១ ១២) ពួកអាណានិគមសាសន៍ដទៃពីដើមនៅដែនដីសន្យា និង ការស្តារឡើងវិញនូវសេចក្តីពិតដ៏ប្រសើរ និងពិសេសៗ (នីហ្វៃទី១ ១៣) និង ប្រជាជនដែលសុចរិតបានប្រឆាំងនឹងការងារនៃព្រះវិហារធំដ៏ និង គួរខ្ពើមឆ្អើមនៅក្នុងថ្ងៃចុងក្រោយ (នីហ្វៃទី១ ១៤) ។

កំណត់សម្គាល់ ៖ ដើម្បីរៀបចំសកម្មភាពខាងក្រោម អ្នកអាចរ៉ឺកឡើងវិញពីមេរៀនដែលឆ្លើយតបនឹងសៀវភៅសិក្សានេះ និង សម្ភារៈនៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សារបស់សិស្សសម្រាប់ថ្ងៃទី ៤ នៃមេរៀននេះ ។

សុំឲ្យសិស្សជ្រើសរើសជំពូកមួយ នៅក្នុងនីហ្វៃទី១ ១១– ១៤ ហើយធ្វើដូចខាងក្រោម ។ (អ្នកអាចឲ្យពួកគេធ្វើការណ៍នេះ នៅលើក្តារខៀន ឬ លើក្រដាសមួយ) ។

- សូមសរសេរសេចក្តីសង្ខេបមួយ នៃជំពូកដែលបានរើសនេះ ។
- សូមសរសេរគោលការណ៍ដ៏ណឹងល្អមួយ ដែលបានបង្រៀននៅក្នុងជំពូកនោះ ។ (ពួកគេអាចប្រើគោលការណ៍ដែលបានគូសចំណាំមួយ នៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សា ឬ រកមើលគោលការណ៍មួយដោយខ្លួនឯងគេផ្ទាល់) ។
- សូមសរសេររបៀបដែលគោលការណ៍នោះ អនុវត្តចំពោះយើងសព្វថ្ងៃនេះ ។

ក្រោយពីពួកគេមានពេលគ្រប់គ្រាន់ក្នុងការរៀបចំហើយ សូមអញ្ជើញសិស្សឲ្យចែកចាយអ្វីដែលពួកគេបានសរសេរ ។ សូមអញ្ជើញសិស្សម្នាក់ ឬ ពីរនាក់ឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីគោលការណ៍ ដែលពួកគេបានដឹង នៅពេលពួកគេសិក្សានីហ្វៃទី១ ៧ –១៤ នៅក្នុងសប្តាហ៍នេះ ។

ពីមុនឲ្យសិស្សក្នុងថ្នាក់របស់អ្នកចេញទៅ សូមកុំភ្លេចប្រមូលសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ និង តាមដានកិច្ចការខ្លះរបស់គេ ។

មេរៀនក្រោយ (នីហ្វៃទី១ ១៥–១៩)

នៅក្នុងមេរៀនក្រោយ សិស្សនឹងសិក្សាបន្ថែមទៀតអំពីឧបសគ្គរបស់លីហៃ និង រាស្ត្ររបស់គាត់ នៅពេលពួកគេបន្តដំណើរនៅក្នុងទីរហោស្ថាន និង ចេញនាវាទៅដែនដីសន្យា ។ សូមគិតស្រមៃពីការភ្ញាក់ផ្អើលរបស់ពួកគេ នៅពេលពួកគេក្រោកឡើងនៅពេលព្រឹកមួយ ហើយឃើញ « ដុំមូលមួយនៅលើដីដែលមានក្បូរក្បាច់ចម្លែក »—លីអាហូណា ។ តើលីអាហូណាធ្វើការដោយរបៀបណា ហើយតើវាណែនាំពួកគេដោយរបៀបណា ? ហេតុអ្វីបានជានីហ្វៃស្តីបន្ទោសដល់បងៗរបស់គាត់នៅក្នុងសំពៅ ? តើនីហ្វៃពិពណ៌នាដែនដីសន្យាយ៉ាងដូចម្តេចដែរ ?

នីហ្វៃទី ១ ១៥

សេចក្តីផ្តើម

ក្រោយពីនីហ្វៃ បានទទួលការនិមិត្តមួយ ស្រដៀងនឹងការនិមិត្តដែលឪពុករបស់គាត់បានទទួល គាត់បានត្រឡប់ទៅត្រសាលរបស់ឪពុកគាត់វិញ ។ នៅទីនោះ គាត់បានឃើញបងៗរបស់គាត់កំពុងឈ្លោះគ្នាអំពីការបង្រៀនរបស់លីហៃ ។ នីហ្វៃ បានស្តីបន្ទោសដល់បងៗរបស់គាត់ចំពោះចិត្តរឹងរូសរបស់ពួកគេ ហើយបានរំឭកពួកគេពីរបៀបដើម្បីទទួលបានវិវរណៈផ្ទាល់ខ្លួន ។ បន្ទាប់មក គាត់បានពន្យល់ពីការបង្រៀនរបស់លីហៃខ្លះៗអំពីមែកធម្មជាតិនៃដើមអុលីវ និង ន័យនៃការនិមិត្តរបស់លីហៃអំពីដើមឈើជីវិត ។ នីហ្វៃទី១ ១៥ ភាពផ្ទុយគ្នារវាង ការខិតខំជំនះស្មារតីរបស់នីហ្វៃ ដើម្បីរកសេចក្តីពិត ជាមួយនឹងការខិតខំតាមធម្មតានៃបងប្រុសរបស់គាត់ (សូមមើល នីហ្វៃទី១ ១៥:៥ –១១) ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ១៥:១–១១

បងៗរបស់នីហ្វៃ គួញត្អែរថា ពួកគេមិនយល់ពីទស្សនិមិត្តរបស់លីហៃនោះទេ

សុំឲ្យសិស្សរាយចុះសកម្មភាពចំនួនបីបួនដែលត្រូវការការខំប្រឹងខាងផ្នែករបស់យើង មុនពេលយើងអាចរីករាយនឹងលទ្ធផល ។ អ្នកអាចកត់ត្រាចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ (ចម្លើយទាំងអស់ អាចរួមមានកិច្ចការសាលា សួនច្បារ ការលេងឧបករណ៍ភ្លេង ការលេងកីឡា និង លំហាត់ប្រាណ ។ សូមអញ្ជើញសិស្សគិតអំពីគំរូ ដែលពួកគេបានមានបទពិសោធន៍) ។

- សម្រាប់សកម្មភាពដែលអ្នកគិតដល់ តើអ្នកឃើញទំនាក់ទំនងអ្វីរវាងការខំប្រឹងដែលអ្នកធ្វើ និង លទ្ធផលដែលមកតាមក្រោយ ?

ក្រោយពីសិស្សឆ្លើយនឹងសំណួរនេះហើយ សូមលើកទឹកចិត្តពួកគេឲ្យស្វែងរកគំរូស្រដៀងគ្នាមួយ នៅក្នុងមេរៀននេះ នៅពេលពួកគេសិក្សានៅក្នុងនីហ្វៃទី១ ១៥ ។

សូមប្រាប់សិស្សថា នីហ្វៃទី១ ១៥ ចាប់ផ្តើមដោយ នីហ្វៃត្រឡប់ទៅត្រសាលរបស់ឪពុកគាត់វិញ ក្រោយពីទទួលបានន័យវិវរណៈនិមិត្តមួយស្រដៀងនឹង ទស្សនិមិត្តរបស់លីហៃដែរ ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១៥:១–២, ៧ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលនីហ្វៃបានជូនប្រទៃ នៅពេលគាត់បានត្រឡប់ទៅត្រសាលរបស់ឪពុកគាត់វិញ ។

- តើនីហ្វៃបានរកឃើញអ្វី នៅពេលគាត់បានត្រឡប់ទៅត្រសាលរបស់ឪពុកគាត់វិញ ?
- តើបងប្អូនប្រុសរបស់នីហ្វៃឈ្លោះគ្នាអំពីរឿងអ្វី ? ហេតុអ្វី ?

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១៥:៣ ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់រកមើលហេតុផលដែលបងៗរបស់នីហ្វៃ ពិបាកនឹងយល់ពីរឿងដែលលីហៃបានបង្រៀនដល់ពួកគេ ។

- យោងតាម នីហ្វៃទី១ ១៥:៣ ហេតុអ្វីបានជាបងប្អូនប្រុសរបស់នីហ្វៃមានការលំបាក ក្នុងការយល់ពីរឿងដែលលីហៃបានបង្រៀនដល់ពួកគេ ?
- តើនីហ្វៃបានធ្វើអ្វី ដើម្បីដឹងពីសេចក្តីពិតខាងវិញ្ញាណ ? (ដើម្បីជួយសិស្សឲ្យឆ្លើយនឹងសំណួរនេះ អ្នកអាចឲ្យពួកគេអាន នីហ្វៃទី១ ១០:១៧) ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១៥:៨ ឮៗ ។

- សូមគិតថា នីហ្វៃទើបតែទទួលបានការនិមិត្តពីស្ថានសួគ៌ ជាការឆ្លើយតបទៅនឹងសំណួររបស់គាត់ (សូមមើល នីហ្វៃទី១ ១១–១៤) តើហេតុអ្វីបានជាវាធម្មតាចំពោះគាត់ ដើម្បីសួរបងៗរបស់គាត់ បើសិនជាពួកគេមានសំណួរអំពីព្រះអម្ចាស់ ?

សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ១៥:៩ ឮៗ ។ បន្ទាប់មក សុំឲ្យសិស្សម្នាក់ទៀតសរសេរន័យចម្លើយរបស់បងប្រុសនីហ្វៃនៅលើក្តារខៀន ៖

យើងមិនទាន់បានសូមទេ ដ្បិត ព្រះអម្ចាស់ ទ្រង់មិនបានធ្វើឲ្យយើងដឹងរឿងបែបនេះទេ ។

នៅលើក្តារខៀន សូមគូសបន្ទាត់នៅពីក្រោមឃ្លា « យើងមិនទានបានសូមទេ » ។

- តើបងៗរបស់នីហ្វៃ មិនបានធ្វើអ្វីខ្លះ ?

សូមសរសេរចម្លើយថា *(សុំដល់ព្រះអម្ចាស់ អធិស្ឋាន ឬ សួរព្រះអម្ចាស់)* ជាប្រយោគនៅលើក្តារខៀន ដូច្នេះគេអានថា ៖

យើងមិនបានសុំដល់ព្រះអម្ចាស់ ដ្បិតព្រះអម្ចាស់ទ្រង់មិនបានធ្វើឲ្យយើងដឹងរឿងបែបនេះទេ ។

(និយាយម្យ៉ាងទៀតថា « យើងមិនបានសួរទេ ពីព្រោះព្រះអម្ចាស់មិនបានមានបន្ទូលមកកាន់យើងទេ ») ។

- តើមានបញ្ហាអ្វី នៅក្នុងការគិតរបស់លេមិន និងលេមយួល ?

សូមប្រាកដថា សិស្សដឹងពីគុណវិបត្តិនៃការគិតរបស់បងប្រុសនីហ្វៃ ។ សូមអញ្ជើញពួកគេឲ្យរៀបចំ ឬ សរសេរប្រយោគនោះម្តងទៀតនៅលើក្តារខៀន ដូច្នេះវានឹងពិពណ៌នាយ៉ាងច្បាស់ពីមូលហេតុដែលបងប្រុសរបស់នីហ្វៃ មិនបានទទួលជំនួយពីព្រះអម្ចាស់ ឲ្យយល់

សំណួរស្វែងរក

សំណួរស្វែងរកដែលមានប្រសិទ្ធភាព អញ្ជើញសិស្សឲ្យស្វែងយល់ព្រះគម្ពីរកសេចក្តីលម្អិតអំពីខ្សែរឿង និង បង្កើតការយល់ជាមូលដ្ឋាននៃវគ្គព្រះគម្ពីរបស់ពួកគេ ។ ជារឿយៗ សំណួរទាំងនេះរួមមានពាក្យដូចជា *តើអ្វី តើពេលណា តើដោយរបៀបណា តើនៅកន្លែងណា* និង *តើហេតុអ្វី* ។ដោយសារសំណួរស្វែងរក ត្រូវការឲ្យសិស្សរកមើលព័ត៌មាននៅក្នុងព្រះគម្ពីរ វាជួយច្រើនក្នុងការស្នូរសំណួរបែបនេះ មុនពេលឲ្យសិស្សអានខគម្ពីរ ដែលមានចម្លើយឲ្យ ។ វាផ្តោតយកចិត្តទុកដាក់លើចំណាប់អារម្មណ៍របស់សិស្ស ក្នុងការស្វែងរកចម្លើយនៅក្នុងវគ្គព្រះគម្ពីរ នៅពេលយើងអាន ។

ពីការបង្រៀនរបស់លីហៃ ។ ចម្លើយដែលអាចមានដូចជា « ព្រះអម្ចាស់មិនបានឲ្យយើងដឹងរឿងបែបនេះទេ ដោយសារយើងមិនបានសុំដល់ទ្រង់ » និង « ដោយសារយើងមិនបានសូរដល់ព្រះអម្ចាស់ នោះទ្រង់នឹងមិនឲ្យយើងដឹងពីរឿងទាំងនេះទេ » ។

សុំឲ្យសិស្សម្នាក់អាន នីហ្ចៃទី១ ១៥:១០–១១ ឲ្យ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលសេចក្តីពិត ដែលនីហ្ចៃបានបង្រៀនដល់បង ៗរបស់គាត់ ដើម្បីជួយពួកគេឲ្យរៀនពីរបៀបដើម្បីទទួលបានចម្លើយមកពីព្រះ ។

- តើការប្រឹក្សាអ្វីដែលនីហ្ចៃបានផ្តល់ទៅបងប្រុសរបស់គាត់ ដើម្បីជួយពួកគេឲ្យយល់ពីពាក្យសម្តីរបស់ឪពុករបស់ពួកគេ និង ទទួលបានចម្លើយមកពីព្រះ ? (នីហ្ចៃ បានប្រឹក្សាបង ៗរបស់គាត់ កុំធ្វើចិត្តរបស់ពួកគេរឹងរូស ឲ្យសុំដោយសេចក្តីជំនឿ ឲ្យជឿថាពួកគេនឹងទទួលបានចម្លើយ និង ឲ្យឧស្សាហ៍ព្យាយាមក្នុងការកាន់តាមព្រះបញ្ញត្តិ ។ សូមជួយសិស្សឲ្យឃើញថា នីហ្ចៃបានដឹងពីតម្លៃនៃគោលការណ៍ទាំងនេះ ដោយសារគាត់បានធ្វើតាមវាដោយខ្លួនគាត់ និង បានទទួលវិវរណៈដែលជាលទ្ធផលមួយ) ។

ដើម្បីជួយសិស្សឲ្យស្គាល់គោលការណ៍ ចេញពីខគម្ពីរទាំងនេះ សូមសរសេរអ្វីខាងក្រោមនេះនៅលើក្តារខៀន ៖

ប្រសិនបើ . . . នោះ . . .

- ដោយផ្អែកលើអ្វីដែលយើងបានអាននៅក្នុង នីហ្ចៃទី១ ១៥:១០–១១ តើយើងអាចបំពេញប្រយោគនេះដោយរបៀបណា ?

សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរតែបង្ហាញការយល់ថា **ប្រសិនបើយើងសុំដល់ព្រះដោយនូវសេចក្តីជំនឿ និង គោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ នោះយើងនឹងរៀបចំដើម្បីទទួលវិវរណៈ និង ការណែនាំមកពីទ្រង់ ។** (អ្នកអាចសរសេរគោលការណ៍នេះ នៅលើក្តារខៀន) ។

សូមរៀបចំសំណួរខាងក្រោមទាំងនេះ ដាក់លើក្តារខៀន ឬ ជាក្រដាសសម្រាប់ចែកមុនបង្រៀនមេរៀន ៖

១. តើអ្នកអាចពន្យល់គោលការណ៍នេះ ដើម្បីជួយនរណាម្នាក់ឲ្យយល់ពីរបៀបដែលត្រូវបានបង្រៀនដោយព្រះអម្ចាស់ និង យល់ពីសេចក្តីពិតខាងវិញ្ញាណដោយរបៀបណា ?

២. តើការខិតខំផ្ទាល់ខ្លួនរបស់អ្នក បានប៉ះពាល់ដល់សមត្ថភាពរបស់អ្នកដើម្បីទទួលបានការណែនាំរបស់ព្រះអម្ចាស់ និង យល់ពីដំណឹងល្អយ៉ាងដូចម្តេច ?

សូមរៀបចំសិស្សជាគូ ៗ ។ នៅក្នុងដៃគូនីមួយ ៗ សូមឲ្យម្នាក់សញ្ជឹងគិតពីសំណួរទីមួយ និង ម្នាក់ទៀតសញ្ជឹងគិតអំពីសំណួរទីពីរ ។ សូមឲ្យពួកគេចែកចាយចម្លើយរបស់ពួកគេជាមួយនឹងគ្នាទៅវិញទៅមក ។ ក្រោយពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីពិភាក្សាចម្លើយរបស់ពួកគេហើយ សូមអញ្ជើញសិស្សពីរបីនាក់ចែកចាយគំនិតរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។ សូមបញ្ជាក់ថា ការខិតខំ និង បំណងប្រាថ្នារបស់យើងដើម្បីស្វែងរកការដឹកនាំពីព្រះវិញ្ញាណ អាចមានឥទ្ធិពលដ៏ដ៏សំខាន់ចំពោះទីបន្ទាល់របស់យើង និង ភាពជិតស្និទ្ធរបស់យើងទៅនឹងព្រះអម្ចាស់ ។

នីហ្ចៃទី១ ១៥:១២–២០

នីហ្ចៃពន្យល់ពីការខ្ចាត់ខ្ចាយ និង ការប្រមូលផ្តុំនៃអ៊ីស្រាអែល

សូមសង្ខេបដោយខ្លីៗនូវ នីហ្ចៃទី១ ១៥:១២–២០ ។ សូមពន្យល់ថា ដើម្បីជួយដោះស្រាយការប្រកែកគ្នារបស់បងប្រុសគាត់ នីហ្ចៃបានបង្រៀនពួកគេអំពី នំយនៃការព្យាករណ៍របស់លីហៃអំពី « មែកកំណើតទាំងឡាយនៃដើមអូលីវ » និង ពួកសាសន៍ដទៃ (សូមមើល នីហ្ចៃទី១ ១០:១២–១៤; ១៥:៧) ។ សូមពន្យល់ថា ដើមអូលីវតំណាងឲ្យវង្សអ៊ីស្រាអែល ។ ដោយសារគ្រួសាររបស់លីហៃ បានចាកចេញពីទីក្រុងយេរូសាឡិម ហើយបានបែកចេញពីវង្សអ៊ីស្រាអែលផ្សេងទៀត វាដូចជាមែកមួយដែលបានបាក់ចេញពីដើមអូលីវ (សូមមើល នីហ្ចៃទី១ ១៥:១២) ។ គាត់បានពន្យល់បន្ថែមទៀតថា នៅក្នុងថ្ងៃចុងក្រោយ ជាច្រើនឆ្នាំក្រោយពីកូនចៅរបស់លីហៃ បាន « ចុះអន់ថយក្នុងការឥតជំនឿ » (នីហ្ចៃទី១ ១៥:១៣) ភាពពេញលេញនៃដំណឹងល្អ នឹងត្រូវបានផ្តល់ទៅដល់ពួកសាសន៍ដទៃ ។ បន្ទាប់មក ពួកសាសន៍ដទៃនឹងនាំដំណឹងល្អមកកាន់កូនចៅរបស់លីហៃ តាមរយៈការស្តារឡើងវិញនូវចំណេះដឹងអំពីព្រះអង្គសង្គ្រោះរបស់ពួកគេ និង ចំពោះពរជ័យក្នុងសេចក្តីសញ្ញាឪពុករបស់ពួកគេ ។ ការណ៍នេះដូចជា ការប្រមូលផ្តុំ និង ការបំបៅជាប់នៃមែកទៅនឹងដើមអូលីវរបស់ពួកគេមកវិញ (សូមមើល នីហ្ចៃទី១ ១៥:១៣–១៧) ។ ការស្តារឡើងវិញនេះ នឹងកើតឡើងមិនត្រឹមតែសម្រាប់កូនចៅរបស់លីហៃប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ទាំងអស់គ្នានៃវង្សអ៊ីស្រាអែល (សូមមើល នីហ្ចៃទី១ ១៥:១៨–២០; សូមមើលផងដែរ នីហ្ចៃទី១ ១០:១២–១៤) ។

សូមថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់រក្សាសេចក្តីសន្យារបស់ទ្រង់ និង ចាំអំពីសេចក្តីសញ្ញាទាំងឡាយរបស់ទ្រង់ជាមួយនឹងកូនចៅរបស់ទ្រង់ ។ ទ្រង់ចង់ឲ្យទាំងអស់គ្នាទទួលបាននូវពរជ័យនៃដំណឹងល្អ ។

នីហ្ចៃទី១ ១៥:២១–៣៦

នីហ្ចៃឆ្លើយនឹងសំណួររបស់បងប្រុសរបស់គាត់ អំពីការនិមិត្តរបស់លីហៃ

សូមពន្យល់ថា នៅក្នុងការរំពឹកអំពី នីហ្ចៃទី១ ១៥ យើងអាននូវចម្លើយរបស់នីហ្ចៃចំពោះសំណួរបងប្រុសរបស់គាត់អំពីការនិមិត្តរបស់លីហៃ ។ នីហ្ចៃបានប្រើអ្វីដែលគាត់បានរៀននៅក្នុងការនិមិត្តផ្ទាល់ខ្លួនរបស់គាត់ ដើម្បីបង្រៀនពួកគេ ។

សូមបង្ហាញសេចក្តីថ្លែងការណ៍ខាងក្រោមនេះ ដោយប្រធាន អ៊ើសរ៉ា ថាហ្ចូ ប៊ើនសឹន នៅលើក្តារខៀន ឬ ជាក្រដាសសម្រាប់ចែក ។ សូមអញ្ជើញសិស្សទាយនូវពាក្យ ឬ ឃ្លាដែលគួរតែបំពេញនៅក្នុងប្រយោគនីមួយ ៗ ។

១. « នៅក្នុង _____ . . . យើងអាចរកបាននូវអំណាចដើម្បីតតាំងនឹងការល្បួង » ។

២. « មួយ _____ . . . មានអំណាចដើម្បីលើកកម្លាំងពួកបរិសុទ្ធ និង ប្រដាប់ពួកគេដោយព្រះវិញ្ញាណ » ។

៣. « របស់គាត់ _____ គឺជាអំណោយមួយដ៏មានតម្លៃបំផុត ដែលទ្រង់បានប្រទានឲ្យដល់យើង » ។

នៅពេលសិស្សពីរបីនាក់ បានចែកចាយនូវការទាយរបស់ពួកគេ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ១៥:២៣–២៤ឮៗ ។ សូមអញ្ជើញសិស្សឲ្យស្វែងរកឃ្លាមួយ នៅក្នុងវគ្គនេះ ដែលនឹងជួយពួកគេឲ្យបំពេញសេចក្តីថ្លែងការណ៍ដោយប្រធាន ថែនសឺន យ៉ាងត្រឹមត្រូវ ។ ក្រោយពីគេអានបានប្រើនខគម្ពីរហើយ សូមឲ្យសិស្សទស្សន៍ទាយម្តងទៀតនូវពាក្យ ឬ ឃ្លាដែលបំពេញនូវសេចក្តីថ្លែងការណ៍នីមួយៗ ។ សូមប្រាប់ចម្លើយត្រឹមត្រូវជាមួយនឹងសិស្សក្នុងថ្នាក់ ។ (ចម្លើយ ៖ ១—ព្រះបន្ទូលនៃព្រះ; ២— ព្រះបន្ទូលនៃព្រះ; ៣—ព្រះបន្ទូល ។ | សូមមើល « អំណាចនៃព្រះបន្ទូល » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៦ ទំព័រ ៨០, ៨២ ។ |)

សូមឲ្យសិស្សស្វែងយល់នៅក្នុង នីហ្វៃទី១ ១៥:២៤–២៥ដោយស្ងាត់ៗ។ សូមអញ្ជើញសិស្សពាក់កណ្តាលថ្នាក់ រកមើលនូវពរជ័យខ្លះក្នុងការធ្វើតាមព្រះបន្ទូលនៃព្រះនៅក្នុងខគម្ពីរទាំងនេះ ។ សុំឲ្យសិស្សពាក់កណ្តាលថ្នាក់ទៀត រកមើលពាក្យ ឬ ឃ្លាដែលស្មើពីរបៀបដែលយើងគួរតែធ្វើតាមព្រះបន្ទូលនៃព្រះ ដើម្បីទទួលបាននូវពរជ័យទាំងនោះ ។ សូមឲ្យក្រុមនីមួយៗ ចែកចាយនូវអ្វីដែលពួកគេបានរកឃើញ ។

- តើយើងត្រូវធ្វើអ្វី ដើម្បី « ស្តាប់ » « កាន់តាមខ្លាប់ » និង « គោរព » តាមព្រះបន្ទូលនៃព្រះ ? (ចម្លើយអាចរួមមាន ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ការស្តាប់ និង ការគោរពតាមការប្រឹក្សានៃអ្នកដឹកនាំសាសនាចក្រដែលត្រូវបានបំផុសគំនិត និង ការស្វែងរក និងការធ្វើតាមវិវរណៈផ្ទាល់ខ្លួន តាមរយៈការអធិស្ឋាន) ។

សូមអញ្ជើញសិស្សឲ្យនិយាយជាសម្ពីរបស់ខ្លួនឯងផ្ទាល់ នូវគោលការណ៍មួយដែលសង្ខេបអ្វីដែលខគម្ពីរទាំងនេះ បានបង្រៀនអំពីការសិក្សាព្រះគម្ពីរ និង ពរជ័យដែលវានាំមកដល់ក្នុងជីវិតរបស់យើង ។ ចម្លើយដែលអាចមានមួយ គឺ **ការសិក្សា និង ការធ្វើតាមព្រះបន្ទូលនៃព្រះប្រចាំថ្ងៃ ពង្រឹងយើងប្រឆាំងនឹងការល្បួងរបស់សាតាំង ។** ដើម្បីផ្តល់ឱកាសដល់សិស្ស ដើម្បីថ្លែងទីបន្ទាល់នៃគោលការណ៍នេះ សូមសួរ ៖

- តើនៅពេលណាដែលការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនប្រចាំថ្ងៃ បានពង្រឹងអ្នកប្រឆាំងនឹងការល្បួង ? (សូមរំឭកសិស្សថា ពួកគេមិនចាំបាច់ចែកចាយបទពិសោធដែលផ្ទាល់ខ្លួនពេកនោះទេ) ។

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ៉ូបឺត ឌី ហៃល នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« សេចក្តីពិតទាំងនេះ ពិតជាសំខាន់ណាស់ ដែលព្រះវរបិតាសួគ៌បានផ្តល់ទស្សននិមិត្តទៅដល់លីហៃ និង នីហ្វៃ យ៉ាងច្បាស់ ដែលតំណាងឲ្យព្រះបន្ទូលនៃព្រះ ជាដំបងដែកមួយ ។ ទាំងឪពុក និង កូនប្រុសបានដឹងថា ការកាន់តាមការដឹកនាំដ៏រឹងមាំ ដ៏ត្រង់ ដ៏ទុកចិត្តបាននេះ គឺជា របៀប*តែមួយគត់* ដើម្បីបន្តនៅលើផ្លូវដ៏ត្រង់ ហើយចង្អៀតនោះ ដែលនាំទៅរកព្រះអង្គសង្គ្រោះរបស់យើង (« ព្រះគម្ពីរដ៏បរិសុទ្ធ ៖ អំណាចនៃព្រះ ចំពោះសេចក្តីសង្គ្រោះរបស់យើង » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ២៥) ។

សូមរំឭកសិស្សថា នៅក្នុងទស្សននិមិត្តរបស់លីហៃ អ្នកដែលកាន់ខ្លាប់តាមដំបងដែកនេះ ត្រូវបានដឹកនាំដោយសុវត្ថិភាពកាត់អ័ព្ទនៃសេចក្តីងងឹត ដែលតំណាងឲ្យការល្បួងនៃអារក្ស (សូមមើល នីហ្វៃទី១ ១២:១៧) ។

សូមសង្កេបដោយខ្លីក្នុង នីហ្វៃទី ១៥:២៦ –២៩ ។ សូមប្រាប់សិស្សថា បងៗរបស់នីហ្វៃ បានសុំគាត់ឲ្យពន្យល់ពីន័យនៃទន្លេដែលឪពុករបស់ពួកគេបានឃើញនៅក្នុងទស្សននិមិត្តរបស់គាត់ ។ គាត់បានពន្យល់ថា វាតំណាងឲ្យស្ថាននរកដ៏អាក្រក់ដែលរៀបចំសម្រាប់ពួកទុច្ចរិត ដែលញែកពួកគេចេញពីព្រះ និង វាស្ត្រេរបស់ទ្រង់ ។

- តើនីហ្វៃបានសម្គាល់អ្វីអំពីទន្លេដែលហូរ ដែលឪពុករបស់គាត់មិនបានកត់សម្គាល់ ? (ទឹកនោះ កខ្វក់) ។

សូមពន្យល់ថា នៅក្នុង នីហ្វៃទី១ ១៥:៣៣–៣៦នីហ្វៃបង្រៀនអំពីយុត្តិធម៌នៃព្រះ និង ហេតុផលដែលពួកទុច្ចរិត នឹងត្រូវបំបែកចេញពីពួកសុចរិត ។ សូមអញ្ជើញសិស្សបីបួននាក់ ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង នីហ្វៃទី១ ១៥:៣៣–៣៦ ។

- ហេតុអ្វីបានជាពួកទុច្ចរិតនឹងត្រូវញែកចេញពីពួកសុចរិត ?
- តើការដឹងថាគ្មានមនុស្សណាមិនស្អាត អាចចូលក្នុងនគរនៃព្រះបានឡើយ បានជួយលេមិន និង លេមយូលបានយ៉ាងដូចម្តេច ?

សូមលើកទឹកចិត្តសិស្សឲ្យគិតពីគោលការណ៍ទាំងឡាយ ដែលពួកគេបានរៀននៅក្នុង នីហ្វៃទី១ ១៥ដោយការសញ្ជឹងគិតនូវសំណួរខាងក្រោមដោយស្ងាត់ៗ៖

- តើតាមរបៀបណា ដែលការនិមិត្តរបស់លីហៃ និង នីហ្វៃបានបង្ហាញពីចំណាប់ព្រះទ័យរបស់ព្រះមកលើលេមិន និង លេមយូល ? តើតាមរបៀបណា ដែលការនិមិត្តនោះបង្ហាញពីចំណាប់ព្រះទ័យរបស់ព្រះមកលើអ្នក ?
- តើអ្នកអាចធ្វើអ្វីបាន ដើម្បីអនុវត្តគោលការណ៍ទាំងឡាយ ដែលអ្នកបានរៀន នៅពេលអ្នកបានសិក្សានៅក្នុងជំពូកនេះ ? (អ្នកអាចអញ្ជើញសិស្សឲ្យសរសេរចម្លើយចំពោះសំណួរនេះ នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រានៅក្នុងថ្នាក់របស់ពួកគេ) ។

សូមគិតពីការបញ្ចប់មេរៀនដោយការអាន នីហ្វៃទី១ ១៥:២៥ ម្តងទៀតក្នុងថ្នាក់ ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីពរជ័យដែលមក នៅពេលយើងស្តាប់តាមព្រះបន្ទូលនៃព្រះ និង រក្សាព្រះបញ្ញត្តិរបស់ទ្រង់ ។ សូមបញ្ជាក់ដល់ពួកគេពីសេចក្តីស្រឡាញ់ដ៏មហិមាដែលព្រះមានសម្រាប់ពួកគេ ហើយថាទ្រង់នឹងប្រទានពរដល់ពួកគេនៅក្នុងការខិតខំក្នុងសេចក្តីសុចរិតរបស់ពួកគេ ។

នីហ្វៃទី១ ១៦

សេចក្តីផ្តើម

ក្រោយពីត្រូវបានចាក់ចុលនៅក្នុងដួងចិត្តរបស់ពួកគេដោយពាក្យសម្តីរបស់នីហ្វៃ លេមិន និង លេមយួល បានបន្ថាបខ្លួនពួកគេនៅចំពោះមុខព្រះអម្ចាស់ ។ គ្រួសារបានបន្តដំណើរ របស់ពួកគេនៅក្នុងទីរហោស្ថាន ហើយព្រះអម្ចាស់បានប្រទានពរដល់ពួកគេដោយមាន លីអាហូណា ដៃលតាមរយៈនោះទ្រង់បានដឹកនាំពួកគេនៅក្នុងដំណើររបស់ពួកគេ ។ នៅពេលពួកគេធ្វើដំណើរ ពួកគេបានជួបនឹងការលំបាក រួមមានការបាត់ធ្នូរបស់នីហ្វៃ ដៃល ជាមធ្យោបាយមួយដ៏ល្អបំផុតរបស់ពួកគេក្នុងការរកអាហារ ។ សមាជិកគ្រួសារភាគច្រើន— ទោះបីជាលីហៃ— បានចាប់ផ្តើមត្អូញត្អែរទាស់នឹងព្រះអម្ចាស់ ។ នីហ្វៃបានស្ងើបនោសបងៗ របស់គាត់ដៃលបានត្អូញត្អែរ គាត់បានធ្វើធ្នូថ្មីមួយ និង បានទៅប្រឹក្សាជាមួយនឹងឪពុករបស់ គាត់ អំពីកន្លែងដៃលគាត់គួរទៅបបាញ់ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ១៦:១–៦

នីហ្វៃឆ្លើយតបនឹងការត្អូញត្អែររបស់បងៗរបស់គាត់

សុំឲ្យសិស្សគិតអំពីគ្រាមួយ ដៃលពួកគេត្រូវបានគេស្តីបន្ទោសដោយបានធ្វើអ្វីមួយខុស និង អំពីរបៀបដៃលពួកគេបានឆ្លើយតប ។ បន្ទាប់មក សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ១៦:១ ឮៗ ។ មុនគាត់អាន សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្តាប់រកចម្លើយរបស់លេមិន និង លេមយួលចំពោះការបង្រៀនរបស់នីហ្វៃ ។ សូមរំឭកសិស្សថា នីហ្វៃបានបង្រៀនថា ពួកទុច្ចរិតនឹងត្រូវបានញែកចេញពីពួកបរិសុទ្ធ និង ត្រូវកាត់ចេញពីវត្តមានរបស់ព្រះ (សូមមើល នីហ្វៃទី១ ១៥:៣៣–៣៦) ។

សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ១៦:២ ដោយស្ងាត់ៗ។ អ្នករអាចប្រាប់ពួកគេឲ្យគូសចំណាំឃ្លាដៃលនីហ្វៃបានប្រើដើម្បីពិពណ៌នា ពី របៀប ដៃលមនុស្សមួយចំនួនឆ្លើយតបសេចក្តីពិត នៅពេលពួកគេមិនរស់នៅតាមការពិត ។

- តើអ្នកគិតថា វាមានន័យដូចម្តេចដៃលថា « អ្នកណាដៃលមានទោស រាប់សេចក្តីពិតទុកជាការពិបាក » ? តើអ្នកគិតថា អ្វីជាអត្ថន័យ នៃឃ្លា « វាកាត់ទំលុះគេរហូតដល់ដួងចិត្ត » ?
- តើរតាមរបៀបណាខ្លះ ដៃលយើងអាចឆ្លើយតប ប្រសិនបើសេចក្តីពិតមួយពិបាកទ្រាំ ?

សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ១៦:៣–៤ ដោយស្ងាត់ៗ ។ អ្នករអាចប្រាប់ពួកគេឲ្យគូសចំណាំពាក្យ *ប្រសិនរបើ* និង *នោះ* នៅក្នុង ខគម្ពីរទី ៣ ។ សូមលើកទឹកចិត្តពួកគេឲ្យរកមើលការប្រឹក្សាដៃលនីហ្វៃបានឲ្យទៅបងៗរបស់គាត់ អំពីរបៀបដៃលពួកគេគួរតែឆ្លើយតប ទៅនឹង « ការពិបាក » ដៃលគាត់បាននិយាយ ។ សូមអញ្ជើញសិស្សម្នាក់ពន្យល់ជាសម្តីរបស់គាត់ ពីអ្វីដៃលនីហ្វៃបានបង្រៀនទៅបងៗ របស់គាត់ ។

- យោងតាម នីហ្វៃទី១ ១៦:៥ តើបងប្អូនប្រុសរបស់នីហ្វៃបានឆ្លើយតបនឹងការណែនាំរបស់គាត់ដោយរបៀបណា ?
- តើនីហ្វៃទី១ ១៦:៥ ស្នើអ្វីខ្លះ អំពីរបៀបដៃលយើងគួរតែឆ្លើយតប នៅពេលដៃលសេចក្តីពិត « កាត់ទំលុះ | យើង | រហូតដល់ ដួងចិត្ត » ?

នីហ្វៃទី១ ១៦:៧–៣៣

ព្រះអម្ចាស់ ណែនាំគ្រួសាររបស់លីហៃតាមរយៈលីអាហូណា

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១៦:៩– ១០ ឮៗ ។ សូមបង្ហាញរូបភាពលើអាហូណា (៦២០៤១ ; *សៀវភៅរូបភាពដំណឹងល្អ* ២០០៩ ទំព័រ ៦៨) ។ សូមបង្ហាញការតំណាងរបស់វិចិត្រករនៃលើអាហូណា ។

- តើតាមរបៀបណាដៃលអ្នកគិតថាអំណោយមួយបែបនោះ នឹងជួយដល់លីហៃ និង គ្រួសាររបស់គាត់នៅក្នុងកាលៈទេសៈ របស់ពួកគេ ?

សូមអញ្ជើញសិស្សពីរបីនាក់ប្តូរវេនគ្នា អានឮៗនៅក្នុង នីហ្វៃទី១ ១៦:១៦–១៩ ។

- តើលីអាហូណាផ្តល់ផលប្រយោជន៍ដល់គ្រួសាររបស់លីហៃយ៉ាងដូចម្តេច ?
- ក្រោយពីគ្រួសាររបស់លីហៃបានទទួលលីអាហូណា តើការធ្វើដំណើររបស់ពួកគេងាយស្រួល ឬ លំបាក ? តើនីហ្វៃប្រាប់អ្វី នៅក្នុងនីហ្វៃទី១ ១៦:១៧–១៩ ដើម្បីគាំទ្រចម្លើយរបស់អ្នក ?
- ហេតុអ្វីបានជាអ្នកគិតថាមនុស្សសុចរិត ដូចជាលីហៃ និង នីហ្វៃ ពេលខ្លះត្រូវជួបប្រទះនឹងឧបសគ្គ ? (អ្នករអាចពន្យល់ថា ឧបសគ្គ ជាច្រើនដៃលយើងជួបប្រទះ មិនចាំបាច់តែជាលទ្ធផលនៃការជ្រើសរើសខុសនោះទេ ។ ផ្ទុយទៅវិញ វាគឺជាឱកាសដើម្បីរៀន និង រីក ចម្រើនឡើងជាផ្នែកនៃដំណើរខាងសាច់ឈាមរបស់យើង) ។

សូមអញ្ជើញសិស្សពាក់កណ្តាលថ្នាក់ឲ្យធ្វើការស្វែងយល់ នីហ្វៃទី១ ១៦:២០–២២ ដោយស្ងាត់ៗ ដោយស្វែងរកពីរបៀបដែលសមាជិកគ្រួសាររបស់លីហៃខ្លះ តបនឹងឧបសគ្គនៃការបាក់ធ្មរបស់នីហ្វៃ ។ សូមអញ្ជើញសិស្សពាក់កណ្តាលទៀតស្វែងយល់ នីហ្វៃទី១ ១៦:២៣–២៥, ៣០–៣២ ដោយស្វែងរកចម្លើយរបស់នីហ្វៃចំពោះឧបសគ្គនេះ និង ពីរបៀបដែលចម្លើយរបស់គាត់បានមានឥទ្ធិពលដល់គ្រួសាររបស់គាត់ ។ បន្ទាប់ពីក្រុមនីមួយៗ បានប្រាប់ពីអ្វីដែលពួកគេបានរកឃើញហើយ សូមសួរ ៖

- តើយើងអាចរៀនអ្វីខ្លះ តាមរយៈការប្រៀបធៀបចំពោះចម្លើយទាំងពីរនេះទៅនឹងឧបសគ្គដូចគ្នា ?
- ហេតុអ្វីបានជាវាសំខាន់ដែលនីហ្វៃបានទៅកាន់ឪពុករបស់គាត់សុំការណែនាំ ទោះបីជាលីហៃបានត្អូញត្អែរនោះ ? តើគោលការណ៍អ្វីដែលយើងអាចរៀនពីនេះ ដើម្បីអនុវត្តនៅក្នុងជីវិតរបស់យើង ? (អ្នកអាចពន្យល់ថា ដោយការទៅរកលីហៃសុំការណែនាំ នីហ្វៃបានបង្ហាញការគោរពចំពោះឪពុកខ្លួន និង ជួយគាត់ឲ្យត្រឡប់មកកាន់ព្រះអម្ចាស់វិញ ។ ការស្វែងរកការប្រឹក្សាពីឪពុកម្តាយ និង អ្នកដឹកនាំបព្វជិតភាព ដោយមិនគិតពីភាពមិនឥតខ្ចោះរបស់ពួកគេ គឺជារបៀបមួយនៃការគោរពពួកគេ និង អនុវត្តសេចក្តីជំនឿនៅក្នុងព្រះអម្ចាស់) ។
- តើគោលការណ៍បន្ថែមអ្វីខ្លះ ដែលយើងអាចរៀនពីចម្លើយរបស់នីហ្វៃចំពោះឧបសគ្គរបស់គ្រួសាររបស់គាត់ ? (នៅពេលសិស្សចែកចាយគំនិតរបស់ពួកគេ សូមគូសបញ្ជាក់ថា **ប្រសិនបើយើងធ្វើអ្វីទាំងអស់ដែលយើងអាច និង បានស្វែងរកការដឹកនាំពីព្រះអម្ចាស់ផងដែរ នោះទ្រង់នឹងជួយយើងឆ្លងកាត់ការលំបាកទាំងឡាយរបស់យើង ។**)

សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ១៦:២៦–២៩ៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលសេចក្តីលម្អិតអំពីរបៀបដែលព្រះអម្ចាស់បានប្រើប្រាស់លីអាហូណា ដើម្បីដឹកនាំគ្រួសាររបស់លីហៃ ។ ដើម្បីជួយសិស្សឲ្យយល់ និង អនុវត្តអ្វីដែលខគម្ពីរទាំងនេះបានបង្រៀនអំពីការទទួលបានការណែនាំពីព្រះអម្ចាស់ សូមសួរនូវសំណួរដូចខាងក្រោម ៖

- តើអ្វីជាភាពខុសគ្នារវាងការធ្វើតាមការដឹកនាំរបស់ព្រះអម្ចាស់តាមធម្មតា និង ការធ្វើតាមការដឹកនាំរបស់ព្រះអម្ចាស់ដោយសេចក្តីជំនឿ និង ការឧស្សាហ៍ព្យាយាម ?

សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ១៦:២៩, អាលម៉ា ៣៧:៦–៧ និង អាលម៉ា៣៧:៣៨–៤១ ដោយស្ងាត់ៗដោយរកគោលការណ៍មួយ ដែលត្រូវបានបង្រៀននៅក្នុងវគ្គទាំងបីនេះ ។

- តើគោលការណ៍អ្វីដែលត្រូវបានបង្រៀននៅក្នុងវគ្គទាំងបីនេះ ? (សូមបញ្ជាក់ថា សិស្សយល់ថា **តាមរយៈរបៀបតូចតាចទាំងឡាយ ព្រះអម្ចាស់អាចនាំមកនូវរឿងដ៏អស្ចារ្យជាច្រើនបាន ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- យោងតាមខគម្ពីរទាំងនេះ តើ « របៀបតូចតាចទាំងឡាយ » អ្វីខ្លះ ដែលព្រះអម្ចាស់បានផ្តល់ការណែនាំដល់យើង ?

សូមសរសេរសំណួរខាងក្រោមនៅក្តារខៀន ដោយបញ្ជាក់ឲ្យច្បាស់ថា សំណួរនីមួយៗបានបាត់៣ក្យ ឬ ឃ្លាមួយ ។ (អ្នកអាចធ្វើការណ៍នេះ មុនចាប់ផ្តើមការបង្រៀន) ។

១. តើរបៀបពីរ ឬ បីអ្វីខ្លះដែល . . . ដូចជាលីអាហូណា ?

២. តើរឿងអ្វីខ្លះដែលអាចបណ្តាលឲ្យយើងបាត់បង់សារលិខិតដ៏សំខាន់នេះពី . . . ?

៣. តើនៅពេលណាដែលអ្នកត្រូវបានប្រទានពរ ដោយការធ្វើតាមការណែនាំពី . . . ?

សូមបែងចែកសិស្សក្នុងថ្នាក់ជាបីក្រុម ជាមួយនឹងអ្នកដឹកនាំម្នាក់នៅក្នុងក្រុមនីមួយៗ ។ សូមឲ្យអ្នកដឹកនាំ នូវកិច្ចការខាងក្រោមមួយច្បាប់ម្នាក់ ដែលក្រុមរបស់ពួកគេនឹងសិក្សាពី « របៀបតូចតាច » ដែលព្រះអម្ចាស់ប្រើប្រាស់ដើម្បីណែនាំយើង ។ (ប្រសិនបើសិស្សក្នុងថ្នាក់របស់អ្នកមានចំនួនច្រើន អ្នកអាចបែងចែកសិស្សច្រើនជាងបីក្រុមដើម្បីកាត់បន្ថយទំហំរបស់ក្រុម ។ ប្រសិនបើអ្នកធ្វើដូច្នេះ អ្នកនឹងត្រូវឲ្យក្រុមមួយ ឬ ច្រើននូវកិច្ចការដូចគ្នា) ។

ក្រុមទី ១ ៖ ពរជ័យអយ្យកោ

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ថូម៉ាស អេស ម៉នសុន ទៅដល់ក្រុមនោះ ៖

« ព្រះអម្ចាស់ដដែល ដែលបានផ្តល់នូវលីអាហូណាដល់លីហៃ បានផ្តល់ដល់អ្នក និង ខ្ញុំនៅសព្វថ្ងៃនេះនូវអំណោយដ៏កម្រ និង ដ៏មានតម្លៃដើម្បីផ្តល់ការណែនាំដល់ជីវិតរបស់យើង ដើម្បីសម្គាល់គ្រោះថ្នាក់ជាប្រយោជន៍សម្រាប់សុវត្ថិភាពរបស់យើង និង ដើម្បីគូសផ្លូវ គឺជាផ្លូវមានសុវត្ថិភាព —មិនមែនទៅកាន់ដែនដីសន្ទានមួយ ប៉ុន្តែទៅផ្ទះនៅស្ថានសួគ៌យើងវិញ ។ អំណោយដែលខ្ញុំសំដៅលើនោះគឺជាពរជ័យអយ្យកោរបស់អ្នក ។ . . .

« . . . ពរជ័យរបស់អ្នក មិនមែនត្រូវបត់ទុកឲ្យស្អាត ហើយមូរទុកនោះទេ ។ វាមិនមែនត្រូវដាក់ស៊ុមទុក ឬ បោះពុម្ពទុកនោះទេ ។ ប៉ុន្តែវាត្រូវយកមកអាន ។ វាត្រូវតែទទួលបានក្តីស្រឡាញ់ ។ វាត្រូវតែបានធ្វើតាម ។ ពរជ័យអយ្យកោរបស់អ្នក នឹងជួយអ្នកនៅក្នុងគ្រាដ៏ងងឹត ។ វានឹងដឹកនាំអ្នក ឆ្លងកាត់គ្រោះថ្នាក់ក្នុងជីវិត ។ . . . ពរជ័យអយ្យកោរបស់អ្នក សម្រាប់អ្នក គឺជាលីអាហូណាផ្ទាល់ខ្លួនដើម្បីគូសផ្លូវរបស់អ្នក និងណែនាំផ្លូវរបស់អ្នក » (« ពរជ័យអយ្យកោរបស់អ្នក ៖ លីអាហូណានៃពន្លឺ » *Ensign*ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ៦៥– ៦៦) ។

សូមកែសម្រួលសំណួរទាំងនេះនៅលើក្តារខៀន ដូច្នេះវានឹងនិយាយអំពីពរជ័យអយ្យកោ ។ ជាក្រុមមួយ សូមពិភាក្សាសំណួរទាំងនេះ ។ សូមឲ្យមនុស្សម្នាក់នៅក្នុងក្រុមរបស់អ្នកចែកចាយជាមួយនឹងសិស្ស ក្នុងថ្នាក់នូវអ្វីដែលក្រុមរបស់អ្នកបានរៀន ។ សូមអញ្ជើញនរណាម្នាក់ពីក្រុមរបស់អ្នកផងដែរ ឲ្យចែកចាយបទពិសោធន៍របស់គាត់ពីសំណួរទី ៣ ។

ក្រុមទី ២ ៖ ព្រះគម្ពីរ និង ពាក្យសម្តីនៃព្យាការីថ្ងៃចុងក្រោយ

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដបុលយូ វ៉ូលហ្វ ឃើរ នៃក្រុមចិតសិបនាក់ ទៅដល់ក្រុមនោះ ៖

« ព្រះបន្ទូលនៃព្រះគ្រីស្ទ អាចជាលីអាហូណាផ្ទាល់ខ្លួន សម្រាប់យើងម្នាក់ៗ ដោយបង្ហាញយើងនូវផ្លូវដែលយើងត្រូវដើរ ។ ចូរយើងឈប់មានចិត្តខ្ជិលច្រអូស ដោយសារផ្លូវនោះងាយស្រួលទៀតទៅ ។ ចូរយើងទទួលព្រះបន្ទូលនៃព្រះគ្រីស្ទដោយសេចក្តីជំនឿ ដាក់ក្នុងគំនិត និង ដួងចិត្តរបស់យើង នៅពេលពួកគេបានកត់ទុកនៅក្នុងព្រះគម្ពីរដ៏ពិសិដ្ឋ និង នៅពេលពួកគេបានបន្លឺដោយព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈដែលនៅរស់ ។ ចូរយើងទទួលទានព្រះបន្ទូលនៃព្រះគ្រីស្ទដោយសេចក្តីជំនឿ និង ដោយក្តីឧស្សាហ៍ព្យាយាម ដោយសារព្រះបន្ទូលនៃព្រះគ្រីស្ទនឹងបានជាលីអាហូណាខាងវិញ្ញាណរបស់យើង ប្រាប់យើងនូវអ្វីទាំងអស់ដែលយើងគួរធ្វើ » (« ព្រះបន្ទូលនៃព្រះគ្រីស្ទ —លីអាហូណាខាងវិញ្ញាណរបស់យើង » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ៣៧) ។

សូមកែសម្រួលសំណួរទាំងនេះនៅលើក្តារខៀន ដូច្នេះវានឹងនិយាយអំពីព្រះគម្ពីរ និង ពាក្យសម្ពីនៃព្យាការីថ្ងៃចុងក្រោយ ។ ជាក្រុមមួយ សូមពិភាក្សាសំណួរទាំងនេះ ។ សូមឲ្យមនុស្សម្នាក់នៅក្នុងក្រុមរបស់អ្នកចែកចាយជាមួយនឹងសិស្ស ក្នុងថ្នាក់នូវអ្វីដែលក្រុមរបស់អ្នកបានរៀន ។ សូមអញ្ជើញនរណាម្នាក់ពីក្រុមរបស់អ្នកផងដែរ ឲ្យចែកចាយបទពិសោធរបស់គាត់ពីសំណួរទី ៣ ។

ក្រុមទី ៣ ៖ ព្រះវិញ្ញាណបរិសុទ្ធ

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ បែដណា នៃក្វរ៉ុមនៃពួកសាវកដប់ពីរនាក់ ទៅដល់ក្រុមនោះ ៖

« នៅពេលយើងខិតខំសម្របឥរិយាបថ និង សកម្មភាពរបស់យើងជាមួយនឹងភាពសុចរិត នោះព្រះវិញ្ញាណបរិសុទ្ធនឹងក្លាយជាលីអាហូណាដែលធ្លាប់ជារបស់លីហៃ និង គ្រួសាររបស់គាត់នៅក្នុងជំនាន់របស់ពួកគេ សម្រាប់យើងវិញ ។ កត្តាដ៏សំខាន់ដែលបណ្តាលឲ្យលីអាហូណាធ្វើការឲ្យលីហៃ ក៏នឹងអញ្ជើញព្រះវិញ្ញាណបរិសុទ្ធមកក្នុងជីវិតរបស់យើងដែរ ។ ហើយកត្តាដ៏ពិតដែលបណ្តាលឲ្យលីអាហូណា មិនឲ្យធ្វើការកាលពីបុរាណនោះ ក៏នឹងធ្វើឲ្យយើង យើងចេញពីព្រះវិញ្ញាណបរិសុទ្ធនៅសព្វថ្ងៃនេះដែរ » (« ថាយើងនឹងតែងតែមានព្រះវិញ្ញាណរបស់ទ្រង់នៅជាមួយនឹងយើង » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៦ ទំព័រ ៣០) ។

សូមកែសម្រួលសំណួរទាំងនេះនៅលើក្តារខៀន ដូច្នេះវានឹងនិយាយអំពីព្រះវិញ្ញាណបរិសុទ្ធ ។ ជាក្រុមមួយ សូមពិភាក្សាសំណួរទាំងនេះ ។ សូមឲ្យមនុស្សម្នាក់នៅក្នុងក្រុមរបស់អ្នកចែកចាយជាមួយនឹងសិស្ស ក្នុងថ្នាក់នូវអ្វីដែលក្រុមរបស់អ្នកបានរៀន ។ សូមអញ្ជើញនរណាម្នាក់ពីក្រុមរបស់អ្នក ឲ្យចែកចាយបទពិសោធរបស់គាត់ពីសំណួរទី ៣ ។

កំណត់សម្គាល់ចំពោះគ្រូបង្រៀន ៖ ប្រហែលក្រោយប្រាំមួយ ឬ ប្រាំបីនាទីមក សុំក្រុមនីមួយៗឲ្យបង្រៀនសិស្សក្នុងថ្នាក់ អំពីអ្វីដែលពួកគេបានរៀនពីការពិភាក្សារបស់ពួកគេ ។ អ្នកក៏អាចអញ្ជើញសិស្សឲ្យសរសេរនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ អំពីគ្រាមួយដែលព្រះអម្ចាស់បានដឹកនាំពួកគេតាមរយៈរបៀបតូចតាចទាំងឡាយ ។ សូមគិតអំពីការប្រាប់ពីគ្រាមួយ ពេលអ្នកទទួលបានការណែនាំពីព្រះអម្ចាស់តាមរយៈរបៀបតូចតាចទាំងឡាយ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី១ ១៦:១០ ។ លីអាហូណាផ្ទាល់ខ្លួន

ប្រធាន ស្តែនសើរ ដបុលយូ យឹមបឹល បានប្រៀបធៀបសតិសម្បជញ្ញៈរបស់យើងទៅនឹងលីអាហូណា ៖

« អ្នកត្រូវតែដឹងថា អ្នកមានអ្វីមួយដូចជាត្រីវិស័យ ដូចជាលីអាហូណា នៅក្នុងប្រព័ន្ធផ្ទាល់ខ្លួនរបស់អ្នក ។ គ្រប់កុមារទាំងអស់មានវា ។ នៅពេលគាត់មានអាយុប្រាំបីឆ្នាំ គាត់ដឹងត្រូវពីខុស ប្រសិនបើឪពុកម្តាយបានបង្រៀនគាត់បានល្អ ។ ប្រសិនបើគាត់ព្រងើយកន្តើយនឹងលីអាហូណា ដែលគាត់មាននៅក្នុងការធ្វើផ្ទាល់ខ្លួនរបស់គាត់ ទីបំផុតគាត់មិនអាចនឹងមានវាខ្សឹបមកកាន់គាត់នោះទេ ។ ប៉ុន្តែ ប្រសិនបើយើងចងចាំថា យើងគ្រប់គ្នាមានអ្វីដែលនឹងដឹកនាំគាត់ដោយត្រឹមត្រូវ សំពៅរបស់យើងនឹងមិនទៅផ្លូវខុស ហើយការរងទុក្ខនឹងកើតឡើង ហើយធ្នូនឹងមិនបាក់ ហើយគ្រួសារនឹងមិនស្រែកយំរកអាហារនោះទេ —ប្រសិនបើស្តាប់តាមការណែនាំពីលីអាហូណាផ្ទាល់ខ្លួនរបស់យើង ដែលយើងហៅថាសតិសម្បជញ្ញៈនោះ » (« លីអាហូណារបស់យើងផ្ទាល់ » *Ensign*ខែ វិច្ឆិកា ឆ្នាំ ១៩៧៦ ទំព័រ ៧៩) ។

មេរៀនទី ១៨

នីហ្វៃទី១ ១៧

សេចក្តីផ្តើម

ក្រោយពីការធ្វើដំណើរនៅក្នុងទីរហោស្ថានអស់រយៈពេលប្រាំបីឆ្នាំមក គ្រួសាររបស់លីហៃបានមកដល់តំបន់ឆ្នេរមួយដែលពួកគេហៅថា ដែនដីបរិបូរណ៍ ។ ក្រោយពីពួកគេបានស្ថាបនាខ្លួនគេនៅលើដែនដីបរិបូរណ៍ ព្រះអម្ចាស់បានបញ្ជាដល់នីហ្វៃឲ្យសង់សំពៅមួយ ។ នៅពេលបងប្អូនប្រុសរបស់គាត់បានដឹងពីអ្វីដែលគាត់ចង់ធ្វើ ពួកគេបានចំអកដល់គាត់ ហើយបន្ទាប់មកបានរអូ និង បដិសេធក្នុងការជួយធ្វើ ។ នីហ្វៃបានបង្រៀនបងប្អូនប្រុសរបស់គាត់ថា ទោះបីជាព្រះអម្ចាស់បានស្វែងរកដើម្បីមានព្រះបន្ទូលមកកាន់ពួកគេតាមរយៈសំឡេងដ៏តូចរហៀងនៃព្រះវិញ្ញាណក៏ដោយ ក៏អំពើទុច្ចរិតរបស់ពួកគេបានរាវាំងពួកគេមិនឲ្យមានអារម្មណ៍ពីព្រះបន្ទូលរបស់ទ្រង់ដែរ ។ គាត់បានស្តីបន្ទោសពួកគេ ចំពោះអំពើទុច្ចរិតរបស់ពួកគេ និង បានដាស់តឿនពួកគេឲ្យប្រែចិត្ត ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ១៧:១ – ៥១

គ្រួសាររបស់លីហៃ ធ្វើដំណើរទៅដែនដីបរិបូរណ៍ ជាកន្លែងដែលនីហ្វៃត្រូវបានបញ្ជាឲ្យសង់សំពៅមួយ

សូមគូរឌីយ៉ាក្រាមខាងក្រោមនៅលើក្តារខៀន ។

ងាយស្រួល ←——————→ ពិបាក

សុំឲ្យសិស្សគិតថា តើពួកគេនឹងពិពណ៍នាជីវិតរបស់ពួកគេនាពេលបច្ចុប្បន្ននេះថាងាយស្រួល ឬ ពិបាក និង ហេតុអ្វី ។ (អ្នកអាចលើកទឹកចិត្តសិស្សឲ្យពិភាក្សាអំពីចម្លើយរបស់ពួកគេជាមួយនឹងដៃគូម្នាក់ ។ ឬ សូមអញ្ជើញសិស្សបីបួននាក់ ចែកចាយនូវគំនិតរបស់ពួកគេនឹងសិស្សក្នុងថ្នាក់ទាំងមូល ។ សូមរំពឹកពួកគេថា ពួកគេមិនចាំបាច់ចែកចាយអ្វីដែលផ្ទាល់ខ្លួនពេកនោះទេ) ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១៧:១, ៤, ៦ ឲ ៗ ។ នៅពេលគាត់អាន សូមឲ្យសិស្សក្នុងថ្នាក់រកមើលពាក្ស និង ឃ្លាណាដែលបង្ហាញពីពេលដែលនីហ្វៃ និង គ្រួសាររបស់គាត់ បានចំណាយនៅក្នុងទីរហោស្ថាន ថាតើវាងាយស្រួល ឬ ពិបាក ។

- តើនីហ្វៃចាត់ទុកថាពេលវេលារបស់ពួកគេ នៅក្នុងទីរហោស្ថានថាងាយស្រួល ឬ ពិបាក ? តើពាក្សណាដែលបង្ហាញថា វាពិបាក ?

សូមពន្យល់ថា នីហ្វៃ និង គ្រួសាររបស់គាត់ ក៏ត្រូវបានប្រទានពរយ៉ាងច្រើន អំឡុងពេលនេះ ។ សូមអញ្ជើញសិស្សអានសង្ខេបនៅក្នុង នីហ្វៃទី១ ១៧:២, ៥, ១២–១៣ ដើម្បីរកមើលរបៀបខ្លះ ៗ ដែលនីហ្វៃ និង គ្រួសាររបស់គាត់ ត្រូវបានប្រទានពរអំឡុងពេលការធ្វើដំណើររបស់ពួកគេ ។ សុំឲ្យសិស្សពីរបីនាក់ ពន្យល់ពីអ្វីដែលពួកគេបានរកឃើញ ។

សូមប្រាប់សិស្សថា នីហ្វៃបានបង្រៀនគោលការណ៍មួយដែលពន្យល់ពីមូលហេតុដែលគ្រួសាររបស់គាត់ អាចត្រូវបានប្រទានពរអំឡុងពេលលំបាកនេះ ។ សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ១៧:៣ ដោយស្ងាត់ ៗ និង រកមើលគោលការណ៍ដែលចាប់ផ្តើមដោយពាក្ស *ប្រសិនបើ* ។ សូមពន្យល់ដោយសង្ខេបថា នៅក្នុងព្រះគម្ពីរ ពេលខ្លះ គោលការណ៍ត្រូវបាននិយាយនៅក្នុងទម្រង់ « ប្រសិនបើ - នោះ » ។ ពាក្ស *ប្រសិនបើ* បង្ហាញសកម្មភាពមួយ និង ពាក្ស *នោះ* បង្ហាញពីលទ្ធផល (វិជ្ជាមាន ឬ អវិជ្ជមាន) ដែលយើងនឹងជួប ជាលទ្ធផលនៃសកម្មភាពនោះ ។

ទោះបីជា នីហ្វៃទី១ ១៧:៣ មិនមានពាក្ស *នោះ* ក្តី ក៏វាបានពិពណ៍នាសកម្មភាពមួយ អមមកជាមួយនឹងពរជ័យខ្លះ ដែលនឹងជាលទ្ធផល ។ សុំឲ្យសិស្សប្រាប់ពីធាតុនៃគោលការណ៍ « ប្រសិនបើ - នោះ » ដែលពួកគេបានរកឃើញ ។ ពួកគេគួរតែនិយាយអ្វីដែលស្រដៀងនឹងអ្វីដូចខាងក្រោម ៖ **ប្រសិនបើយើងកាន់តាមព្រះបញ្ញត្តិ នោះព្រះអម្ចាស់នឹងពង្រឹងយើង និង ផ្តល់នូវមធ្យោបាយដល់យើងដើម្បីសម្រេចបានការណ៍នោះដែលទ្រង់បានបញ្ជា ។** (អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។ សូមអញ្ជើញសិស្សស្វែងរកភស្តុតាងនៃគោលការណ៍នេះ នៅពេលពួកគេសិក្សាពីបទពិសោធន៍របស់នីហ្វៃ និង នៅពេលពួកគេគិតអំពីជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ។

សូមចែកក្រដាសមួយ ដែលមានសំណួរដូចខាងក្រោម (ឬ សរសេរសំណួរនេះនៅលើក្តារខៀន មុនចាប់ផ្តើមការបង្រៀន) ៖

១. តើព្រះអម្ចាស់បានបញ្ជានីហ្វៃឲ្យធ្វើអ្វី ? (នីហ្វៃទី១ ១៧:៧–៨) តើនីហ្វៃបានឆ្លើយតបយ៉ាងដូចម្តេច ? (នីហ្វៃទី១ ១៧:៩–១១, ១៥–១៦) តើបងប្រុសរបស់គាត់បានឆ្លើយតបយ៉ាងដូចម្តេច ? (នីហ្វៃទី១ ១៧:១៧–២១)

២. តើព្រះអម្ចាស់បានជួយម៉ូសេឲ្យសម្រេចកិច្ចការដែលគាត់ត្រូវបានបញ្ជាឲ្យធ្វើយ៉ាងដូចម្តេច ? (នីហ្វៃទី១ ១៧:២៣–២៩)

៣. តើបងប្រុសរបស់នីហ្វៃ ប្រៀបដូចជាកូនចៅអ៊ីស្រាអែលដោយរបៀបណា ? (នីហ្វៃទី១ ១៧:៣០, ៤២)

៤. តើព្រះអម្ចាស់បានបញ្ជាអ្វីខ្លះ ដែលអាចពិបាកសម្រាប់ខ្ញុំ ?

៥. តើខ្ញុំអាចឆ្លើយតបដូចជានីហ្វៃ និង ម៉ូសេបានដោយរបៀបណា ? តើខ្ញុំអាចជៀសវាងកំហុសដូចបងប្រុសរបស់នីហ្វៃ និង កូនចៅនៃអ៊ីស្រាអែលបានយ៉ាងដូចម្តេច ?

សូមបង្ហាញសំណួរខាងលើ ដោយការពន្យល់ថាពួកគេនឹងជួយសិស្សឲ្យឃើញពីរបៀបដែលនីហ្វៃបានបន្តរស់នៅតាមគោលការណ៍នៅក្នុង នីហ្វៃទី១ ១៧:៣ ក្រោយពីគាត់បានមកដល់ដែនដីបរិបូរណ៍ ។ សំណួរទាំងនេះ ក៏នឹងជួយសិស្សឲ្យអនុវត្ត

សូមជួយសិស្សដឹងពីរបៀបដើម្បីស្គាល់គោលលទ្ធិ និង គោលការណ៍

នៅពេលអ្នកជួយសិស្សឲ្យដឹងពីរបៀបស្គាល់គោលលទ្ធិ និង គោលការណ៍នៅក្នុងព្រះគម្ពីរ ពួកគេនឹងអាចសិក្សាព្រះគម្ពីរមានប្រសិទ្ធភាពជាងនេះដោយខ្លួនឯង ។ សូមបង្រៀនសិស្សឲ្យរកមើលឃ្លាដូចជា « *ម្លោះហើយយើងឃើញ* » « *ហេតុដូច្នេះហើយ* » « *ហេតុដូច្នេះហើយ* » « *ត្បិតមើលចុះ* » ឬ « *ប្រសិនបើ . . . នោះ . . .* » ដែលជាញឹកញាប់ វាបង្ហាញពីគោលការណ៍ ឬ ប្រយោគនៃគោលលទ្ធិ ។

គោលការណ៍នេះទៅក្នុងជីវិតរបស់ពួកគេផងដែរ ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១៧:៧–៨ ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលនីហ្វៃត្រូវបានបញ្ជាឲ្យធ្វើ ។ សុំឲ្យសិស្សកត់ត្រាចម្លើយក្រោមសំណួរទី ១ នៅលើក្រដាស ឬ នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។

- តើព្រះបញ្ជត្តិនេះ ពិបាកចំពោះនីហ្វៃដោយរបៀបណា ?

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១៧:៩–១១និង សិស្សម្នាក់ទៀតអាន នីហ្វៃទី១ ១៧:១៥–១៦ឮៗ ។ មុនពេលពួកគេអាន សុំសិស្សក្នុងថ្នាក់ស្តាប់រកមើលនូវចម្លើយរបស់នីហ្វៃ ចំពោះព្រះបញ្ជត្តិដើម្បីសង់សំពៅមួយ ។

- តើអ្វីដែលធ្វើឲ្យអ្នកពេញចិត្តអំពីចម្លើយរបស់នីហ្វៃ ?

សូមឲ្យសិស្សសរសេរសេចក្តីសង្ខេបមួយអំពីចម្លើយរបស់នីហ្វៃ នៅក្រោមសំណួរទី ១ នៅលើក្រដាស ឬ នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។

សុំឲ្យសិស្សបីឬបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុងនីហ្វៃទី១ ១៧:១៧–២១ ។ សុំឲ្យសិស្សក្នុងថ្នាក់រកមើលពាក្យ និង ឃ្លាដែលបង្ហាញពីឥរិយាបថរបស់លេមិន និង លេមយូល ។ សូមឲ្យសិស្សសរសេរសេចក្តីសង្ខេបនៃចម្លើយរបស់លេមិន និង លេមយូល ចំពោះព្រះបញ្ជត្តិដើម្បីសង់សំពៅមួយ ។ សូមអញ្ជើញសិស្សម្នាក់ ឬ ពីរនាក់ឲ្យចែកចាយសេចក្តីសង្ខេបរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

សូមពន្យល់ថា នីហ្វៃបានឆ្លើយតបនឹងការត្អូញត្អែររបស់បងៗរបស់គាត់ ដោយការរំឭក ពួកគេថា ព្រះអម្ចាស់បានជួយម៉ូសេឲ្យសម្រេចបាននូវកិច្ចការដ៏លំបាកក្នុងការរំដោះកូនចៅអ៊ីស្រាអែលចេញពីសេវកភាព ។ នីហ្វៃក៏បានប្រៀបធៀបការមានចិត្តរឹងរូសរបស់បងៗ ទៅនឹងការមានចិត្តរឹងរូសរបស់កូនចៅអ៊ីស្រាអែល ។ សូមអញ្ជើញសិស្សសិក្សាវគ្គព្រះគម្ពីរ និង កត់ត្រាចម្លើយរបស់ពួកគេចំពោះសំណួរទី ២ និង ៣ ។ ដោយផ្អែកលើសេចក្តីត្រូវការរបស់សិស្សអ្នក អ្នកអាចឲ្យពួកគេធ្វើសកម្មភាពនេះរៀងៗខ្លួន ឬ ជាមួយនឹងដៃគូ ។

ក្រោយពីសិស្សបានបំពេញសំណួរទី ២ និង ៣ ហើយ សូមសួរ ៖

- តើព្រះអម្ចាស់បានជួយម៉ូសេ ឲ្យសម្រេចបានកិច្ចការដែលគាត់ត្រូវបានបញ្ជាឲ្យធ្វើដោយរបៀបណា ?
- តើអ្នកគិតថា គំរូរបស់ម៉ូសេអាចជួយនីហ្វៃបានដោយរបៀបណា ?
- តើតាមរបៀបណា ដែលបងប្រុសរបស់នីហ្វៃប្រៀបដូចជាកូនចៅអ៊ីស្រាអែល ?

សូមបង្ហាញថា នៅពេលដែលព្រះអម្ចាស់ឲ្យយើងតស៊ូនឹងកិច្ចការ ឬ ព្រះបញ្ញត្តិ យើងអាចជ្រើសរើសឆ្លើយតបដូចជានីហ្វៃបានឆ្លើយ ឬ យើងអាចឆ្លើយតបដូចជាលេមិន និង លេមយូល ។ សូមពន្យល់ថា ទោះបីជាព្រះបានបញ្ជាឲ្យយើងសម្រេចកិច្ចការដូចជាការសង់សំពៅមួយ ឬ ការឆ្លងសមុទ្រក្រហមក៏ដោយ ក៏ទ្រង់បានផ្តល់នូវព្រះបញ្ញត្តិ និង បានបញ្ជាយើងឲ្យសម្រេចកិច្ចការដែលមនុស្សខ្លះគិតថាវាពិបាក ។ ឧទាហរណ៍ ទ្រង់បានបញ្ជាយើងឲ្យបន្តគំនិតគុណធម៌ និង រក្សាថ្ងៃសិល្ប៍ទុកជាបរិសុទ្ធ ។ ទ្រង់សង្ឃឹមថាយើងធ្វើតាមការហៅបម្រើនៅក្នុងសាសនាចក្រ (ដូចជាគ្រូអំ ឬ ប្រធានថ្នាក់) និង បម្រើដល់អ្នកដទៃ ។ ទ្រង់ក៏សង្ឃឹមថាយើង រក្សាសេចក្តីសញ្ញារបស់យើង និង បន្តសកម្មនៅក្នុងសាសនាចក្រ ទោះជាប្រឈមមុខនឹងឧបសគ្គក៏ដោយ ។ សូមផ្តល់ពេលវេលាដល់សិស្សកត់ត្រានូវចម្លើយចំពោះសំណួរទី ៤ និង ៥ ។ សូមលើកទឹកចិត្តពួកគេឲ្យឆ្លើយតបនឹងសំណួរទី ៤ ដោយការសរសេរអំពីអ្វីដែលព្រះអម្ចាស់បានបញ្ជា ដែលវាអាចពិបាកចំពោះពួកគេ ។

ក្រោយពីសិស្សមានពេលគ្រប់គ្រាន់ក្នុងការសរសេរហើយ សូមអានការបង្ហាញពីសេចក្តីជំនឿរបស់នីហ្វៃនៅក្នុងនីហ្វៃទី១ ១៧:៥០ ឮៗ ។ បន្ទាប់មក សុំឲ្យសិស្សអាន នីហ្វៃទី១ ១៧:៥១ ដោយស្ងាត់ៗនិង ពិចារណាពីរបៀបដែលវាអាចអនុវត្តនៅក្នុងជីវិតរបស់ពួកគេ ។ សូមលើកទឹកចិត្តពួកគេឲ្យបន្ថែមឈ្មោះរបស់ពួកគេក្រោយពាក្យ *ខ្ញុំ* និង ជំនួសឃ្លា *សង់សំពៅ* ដោយកិច្ចការ ឬ ព្រះបញ្ញត្តិមួយដែលពួកគេគិតថាពិបាក ។ សូមគិតពីការអញ្ជើញសិស្សដែលមានអារម្មណ៍ស្រួលក្នុងការធ្វើដូច្នោះ ឲ្យអាននីហ្វៃទី១ ១៧:៥១ ឮៗ ជាមួយនឹងការជំនួសពាក្យដែលពួកគេបានធ្វើ ។ សូមបើកទៅម្តងទៀតទៅគោលការណ៍ដែលបានសរសេរលើក្តារខៀននេះ ។

- តើបទពិសោធន៍អ្វីដែលនីហ្វៃបានមាន ជាមួយនឹងគោលការណ៍នេះ ដែលផ្តល់ជំនឿចិត្តដល់គាត់ថា ព្រះអម្ចាស់នឹងជួយគាត់ឲ្យធ្វើតាមរាល់ព្រះបញ្ញត្តិ ?
- តើអ្នកមានបទពិសោធន៍អ្វី ដែលផ្តល់ជំនឿចិត្តដល់អ្នកថា ព្រះនឹងជួយអ្នកឲ្យសម្រេចបាននូវអ្វីក៏ដោយដែលទ្រង់បានបញ្ជាដល់អ្នក ?

សូមចែកចាយទីបន្ទាល់របស់អ្នកថា នៅពេលយើងកាន់តាមព្រះបញ្ញត្តិ ព្រះអម្ចាស់នឹងពង្រឹងយើង និង ផ្តល់មធ្យោបាយដល់យើងឲ្យសម្រេចបាននូវអ្វីៗដែលទ្រង់បានបញ្ជា ។

សូមគិតពីសេចក្តីត្រូវការរបស់សិស្សអ្នក នៅពេលអ្នកបង្រៀន

វាជាការឈ្លាសវៃ ដើម្បីសម្របវិធីបង្រៀន ដើម្បីជួយសិស្សឲ្យបំពេញតួនាទីរបស់ពួកគេជាអ្នករៀនសូត្របានជោគជ័យ ។ ជាឧទាហរណ៍ ប្រសិនបើសិស្សនឿយហត់ សូមគិតឲ្យពួកគេធ្វើការជាក្រុម ដើម្បីជួយពួកគេបន្តក្នុងការរៀនសូត្រ ។ ប្រសិនបើសិស្សមានកម្លាំង អ្នកអាចឲ្យពួកគេសិក្សារៀងៗខ្លួន ដើម្បីជួយពួកគេឲ្យបន្តខំធ្វើការ ។

នីហ្វៃទី១ ១៧:៤៥–៥៥

នីហ្វៃបានបន្ទោសលេមិន និង លេមយូលចំពោះអំពើទុច្ចរិតរបស់ពួកគេ

សូមបង្ហាញរូបភាពនីហ្វៃបង្ក្រាបបងប្អូនប្រុសដែលបះបោររបស់គាត់ (៦២០៤៤ ; *សៀវភៅរូបភាពដំណឹងល្អ* [២០០៩] ទំព័រ ៧០) ។ សូមអញ្ជើញសិស្សឲ្យសង្ខេបពីអ្វីដែលបានកើតឡើងនៅក្នុងរូបភាពនេះ ។ ប្រសិនបើសិស្សមិនមានចម្លើយទេ សូមអញ្ជើញពួកគេរកចម្លើយនៅក្នុង នីហ្វៃទី១ ១៧:៤៨, ៥៣–៥៤ ។

- យោងតាមនីហ្វៃទី១ ១៧:៥៣ តើហេតុអ្វីបានជាព្រះអម្ចាស់ធ្វើឲ្យបងប្រុសរបស់នីហ្វៃភាំងស្មារតី ? (អ្នកអាចឲ្យសិស្សយកចិត្តទុកដាក់លើលេខយោងលេខ ៥៣ *ក* ដើម្បីជួយពួកគេយល់ ពាក្យថា *ធ្វើឲ្យភាំងស្មារតី* នៅក្នុងបរិបទនេះ មានន័យថា « ធ្វើឲ្យញ័រ ឬ រន្ធត់ ») ។

សូមពន្យល់ថា ការភាំងស្មារតីដែលព្រះអម្ចាស់បានធ្វើដាក់លេមិន និង លេមយូលគឺគ្រាន់តែជារបៀបមួយក្នុងរបៀបជាច្រើន ដែលព្រះអម្ចាស់ទាក់ទងជាមួយនឹងពួកគេប៉ុណ្ណោះ ។ សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ១៧:៤៥ និង ស្វែងរករបៀបពីរបីដែលព្រះអម្ចាស់បានទាក់ទងជាមួយនឹងលេមិន និង លេមយូលកាលពីអតីតកាល ។

- តើព្រះអម្ចាស់បានទាក់ទងជាមួយនឹងលេមិន និង លេមយូលតាមរបៀបអ្វីខ្លះ ? តើរបៀបមួយណា ដែលមើលទៅហាក់ដូចជារបៀបមួយ ដែលជាទូទៅ ព្រះអម្ចាស់រកទាក់ទងជាមួយនឹងយើង ?

អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំប្រយោគខាងក្រោមនៅក្នុង នីហ្វៃទី១ ១៧:៤៥ ៖ « ព្រះមានបន្ទូលជាមួយនឹងអ្នកដោយសំឡេងតូចរហៀង ៗ » ។ សុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ិយដ៏ យេ ជាកកឺ នៃក្ការុ៉មនៃពួកសាវកដប់ពីរនាក់ ៖

« ព្រះវិញ្ញាណបរិសុទ្ធ បានមានព្រះបន្ទូលដោយសំឡេងមួយដែលអ្នក *មានអារម្មណ៍* ជាជាងអ្នក *ឮ* ។សំឡេងនេះ ត្រូវបានពិពណ៌នាថាជា ‹ សំឡេងតូចរហៀង › [គ. និង ស. ៨៥:៦] ។ ហើយនៅពេលយើងនិយាយអំពី ‹ ការស្តាប់ › តាមសំឡេងខ្សឹបនៃព្រះវិញ្ញាណ ភាគច្រើនគេសំដៅលើការបំផុសគំនិតខាងវិញ្ញាណ ដោយនិយាយថា ‹ ខ្ញុំមាន*អារម្មណ៍ថា* . . . › » (« វិវរណៈជ្ជាល់ខ្លួន ៖ អំណោយទាន ការសាកល្បង និង សេចក្តីសន្យា » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ទំព័រ ៦០) ។

អ្នកអាចអញ្ជើញសិស្សឲ្យសរសេរសេចក្តីពិតខាងក្រោមនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរនីហ្វៃទី១ ១៧:៤៥ ៖ **ព្រះវិញ្ញាណបរិសុទ្ធ មានព្រះបន្ទូលដោយសំឡេងតូចរហៀង ដែលយើងមានអារម្មណ៍ពីទ្រង់ជាជាងយើងអាចឮ ។**(ដើម្បីសង្កត់ធ្ងន់លើគោលការណ៍នេះ អ្នកអាចឲ្យសិស្សអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៨:២–៣) ។

- តើអ្នកមានអារម្មណ៍ពីសំឡេងតូចរហៀងនៃព្រះវិញ្ញាណបរិសុទ្ធ មានព្រះបន្ទូលទៅកាន់អ្នកនៅពេលណា ?
- តើអ្នកធ្វើអ្វីខ្លះ ដែលជួយអ្នកឲ្យមានអារម្មណ៍ និង ស្គាល់ពីសំឡេងតូចរហៀងនៃព្រះវិញ្ញាណបរិសុទ្ធនោះ ?

ក្រោយពីសិស្សបានឆ្លើយតបហើយ អ្នកអាចលើកទឹកចិត្តពួកគេឲ្យគូសឃ្លាខាងក្រោមនៅក្នុង នីហ្វៃទី១ ១៧:៤៥ ៖ « ប៉ុន្តែបងរាល់គ្នាមានចិត្តវក់វិញ ទើបមិនអាចចាប់អារម្មណ៍ពីព្រះបន្ទូលរបស់ព្រះអង្គឡើយ » ។ សូមឲ្យសិស្សអានប្រយោគទីមួយនៃ នីហ្វៃទី ១ ១៧:៤៥ និង រកមូលហេតុដែលលេមិន និង លេមយូលក្លាយជា « មានចិត្តវក់វី » ។ សូមអញ្ជើញពួកគេរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- ហេតុអ្វីបានជាការ « រហ័សធ្វើអំពើទុច្ចរិត » ធ្វើឲ្យលេមិន និង លេមយូលក្លាយជា « មានចិត្តវក់វី » ?
- តើអំពើបាបរបស់យើង អាចប៉ះពាល់ដល់សមត្ថភាពរបស់យើងក្នុងការមានអារម្មណ៍ពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធយ៉ាងដូចម្តេច ?

ក្រោយពីសិស្សបានឆ្លើយតបហើយ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ដែមស៍ អឺ ហ្វោស្ត ដែលបានបម្រើជាសមាជិកនៃគណៈប្រធានទីមួយ ៖

« ទូរស័ព្ទតូច ៗ ត្រូវបានប្រើសម្រាប់ទំនាក់ទំនងជាច្រើននៅក្នុងជំនាន់របស់យើង ។ ទោះយ៉ាងណាក្តី ជួនពេលខ្លះ យើងនឹងនៅស្ថិតនៅក្នុងតំបន់ដែលគ្មានសេវាទូរស័ព្ទ ។ នេះអាចកើតឡើង នៅពេលអ្នកប្រើទូរស័ព្ទដៃ ធ្វើដំណើរនៅក្រោមដី ឬ ជ្រលងជ្រោះ ឬ នៅពេលមានការជ្រែកចូលផ្សេងទៀត ។

« វាក៏កើតមានចំពោះការទាក់ទងដ៏ទេវភាពដូចគ្នាដែរ ។ . . . ជាញឹកញាប់ យើងដាក់ខ្លួនយើងនៅក្នុងកន្លែងចំណុចខូចខាងវិញ្ញាណ—កន្លែង និង ស្ថានភាពដែលរាវាំងសារដ៏ទេវភាព ។ ចំណុចខូចទាំងនេះខ្លះ រួមមានកំហឹង រូបអាសគ្រាម ការបំពាន ភាពអាត្មានិយម និង ស្ថានភាពផ្សេងទៀតដែលរាវាំងព្រះវិញ្ញាណ » (« តើអ្នកបានទទួលសារត្រឹមត្រូវទេ ? » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ៦៧) ។

ដើម្បីបញ្ចប់ សូមអញ្ជើញសិស្សឲ្យគិតអំពីសារដែលព្រះអម្ចាស់ចង់ទាក់ទងជាមួយនឹងពួកគេថ្មី ៗនេះ ។ សូមលើកទឹកចិត្តពួកគេឲ្យសញ្ជឹងគិតថាតើមាន « ចំណុចខូចខាងវិញ្ញាណ » ណាខ្លះ ដែលអាចរាវាំងពួកគេពីការទទួលបានទំនាក់ទំនងបែបនោះ ។ (អ្នកអាចឲ្យសិស្សសរសេរអំពីការណ៍នេះ នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ) ។ សូមថ្លែងទីបន្ទាល់ថា ព្រះវិញ្ញាណបរិសុទ្ធមានព្រះបន្ទូលដោយសំឡេងតូចរហៀង ដែលយើងមានអារម្មណ៍ជាជាងស្តាប់ឮ ។ សូមថ្លែងទីបន្ទាល់ផងដែរថា យើងអាចជួបបទពិសោធន៍នឹងទំនាក់ទំនងនេះ នៅពេលយើងស្វែងរកដើម្បីមានភាពសក្តិសមចំពោះការបំផុសគំនិតដ៏ទន់ភ្លន់ទាំងនេះ ។

នីហ្វៃទី១ ១៨

សេចក្តីផ្តើម

ដោយការធ្វើតាមការណែនាំរបស់ព្រះអម្ចាស់ នីហ្វៃ និង អ្នកផ្សេងទៀត បានបញ្ចប់ការសង់សំពៅ និង ចេញដំណើរទៅកាន់ដែនដីសន្យា ។ អំឡុងពេលធ្វើដំណើររបស់ពួកគេ លេមិន និង លេមយួល និង កូនប្រុសរបស់អ៊ីសម៉ាអែល និង ប្រពន្ធរបស់ពួកគេ បានបះបោរទាស់នឹងព្រះអម្ចាស់ ។ នៅពេលនីហ្វៃបានស្ទឹបន្ទោសពួកគេ លេមិន និង លេមយួលបានចងគាត់ដោយខ្សែជាប់ ។ ជាលទ្ធផល លីអាហូណាបានឈប់ដើរ ហើយពួកគេមិនអាចសម្រេចចាផ្លូវណាមួយត្រូវកាច់ចង្កូតសំពៅទៅនោះទេ ។ នៅពេលព្យុះដ៏ធំមួយបានមកគំរាមជីវិតគ្រប់គ្នានៅលើសំពៅ នោះពួកគេបានប្រែចិត្ត និង បានដោះលែងនីហ្វៃ ។ នីហ្វៃបានអធិស្ឋានដើម្បីឲ្យព្យុះស្ងប់ ហើយព្រះអម្ចាស់បានដឹកនាំដំណើររបស់ពួកគេម្តងទៀត ទៅកាន់ដែនដីសន្យា ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ១៨:១–៨

គ្រួសាររបស់លីហៃ រៀបចំចេញដំណើរតាមសមុទ្រទៅកាន់ដែនដីសន្យា

សូមសរសេរ ព្រះចេស្តារបស់ព្រះអម្ចាស់ និង *ការខិតខំរបស់ខ្ញុំ* នៅលើក្តារខៀន ។ សុំឲ្យសិស្សគិតអំពីបញ្ហាមួយ ដែលពួកគេកំពុងជួបប្រទះ ។ សូមអញ្ជើញពួកគេឲ្យជ្រើសរើសអ្វីដែល *(ព្រះចេស្តារបស់ព្រះអម្ចាស់* ឬ *ការខិតខំរបស់ខ្ញុំ)* អាចមានប្រសិទ្ធភាពជាងក្នុងការដោះស្រាយបញ្ហា និង សុំឲ្យពួកគេពន្យល់ពីមូលហេតុ ។ ក្រោយពីការពិភាក្សាដ៏ខ្លីមួយ សូមអញ្ជើញសិស្សរកមើលរបៀបដែលគំរូរបស់នីហ្វៃនៅក្នុង នីហ្វៃទី១ ១៨ អាចជួយពួកគេប្រឈមមុខនឹងឧបសគ្គដែលពួកគេជួបប្រទះ ។

សូមបង្ហាញរូបភាពលីហៃ និង ប្រជាជនរបស់គាត់ មកដល់ដែនដីសន្យា (៦២០៤៥ ; *សៀវភៅរូបភាពដំណឹងល្អ* [២០០៩] ទំព័រ ៧១) ។

សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ១៨:១–៨ ដោយស្ងាត់ៗ ។ សុំឲ្យពួកគេរកមើល (១) អ្វីដែលនីហ្វៃ និង គ្រួសាររបស់គាត់ធ្វើ ដើម្បីរៀបចំសម្រាប់ដំណើររបស់ពួកគេទៅកាន់ដែនដីសន្យា និង (២) អ្វីដែលព្រះអម្ចាស់បានធ្វើដើម្បីជួយដល់ពួកគេ ។

- ហេតុអ្វីបានជាអ្នកគិតថា វាសំខាន់ដែលនីហ្វៃបានទទួលវិវរណៈ « ពីពេលមួយទៅពេលមួយ » ?
- នៅក្នុង នីហ្វៃទី១ ១៨:២–៣ តើទំនាក់ទំនងអ្វី ដែលអ្នកបានឃើញរវាងសកម្មភាពរបស់នីហ្វៃ និង ជំនួយដែលគាត់បានទទួលមកពីព្រះអម្ចាស់ ?
- តើការណែនាំរបស់ព្រះអម្ចាស់ និង ការខិតខំផ្ទាល់ខ្លួនរបស់នីហ្វៃ មានសារៈសំខាន់យ៉ាងដូចម្តេច ក្នុងការបញ្ចប់ការសង់សំពៅ និង ការធ្វើដំណើរទៅកាន់ដែនដីសន្យា ?

សុំឲ្យសិស្សសង្កេបគោលការណ៍ពីរបី ដែលយើងអាចរៀនពីគំរូរបស់នីហ្វៃ ។ នៅពេលសិស្សមានឱកាសដើម្បីរកសេចក្តីពិត ដែលពួកគេបានរៀន សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ **ដើម្បីសម្រេចបានអ្វីដែលព្រះអម្ចាស់បានបញ្ជា យើងត្រូវស្វែងរកជំនួយរបស់ទ្រង់ និង បញ្ចេញការខិតខំរបស់យើងផ្ទាល់ ។**

- តើនៅពេលណាដែលអ្នកទទួលបានការណែនាំ ឬ ការដឹកនាំមកពីព្រះអម្ចាស់ ហើយត្រូវការការខិតខំប្រឹងផ្ទាល់របស់អ្នក ដើម្បីរក្សាព្រះបញ្ញត្តិមួយរបស់ទ្រង់ ?

សូមអញ្ជើញសិស្សកត់ត្រានូវចម្លើយរបស់គ្នាទៅវិញទៅមក ចំពោះសំណួរខាងលើនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ។

សូមបង្ហាញថា យើងទាំងអស់គ្នាត្រូវការជំនួយពីព្រះ ដើម្បីគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ និង ដើម្បីធ្វើតាមបទដ្ឋាននៃដំណឹងល្អដែលបានគ្រោងទុកនៅក្នុង *ដើម្បីកម្លាំងនៃយុវជន* ។(អ្នកអាចទទួលបាន និង សុំសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* មុនពេលចាប់ផ្តើម) ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលព្រះបញ្ញត្តិមួយ ឬ បទដ្ឋានដំណឹងល្អមួយ ដែលពួកគេត្រូវការជំនួយពីព្រះជាពិសេសក្នុងការគោរពតាម ។ សូមផ្តល់ពេលដើម្បីសរសេរនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេអំពី (១) អ្វីដែលពួកគេអាចធ្វើដើម្បីស្វែងរកជំនួយពីព្រះអម្ចាស់ ដើម្បីគោរពតាម និង (២) ការខិតខំផ្ទាល់ខ្លួនអ្វី ដែលពួកគេត្រូវការដើម្បីគោរពតាមវាបាន ។

នីហ្វៃទី១ ១៨:៩ –២៥

លេមិន និង លេមយួលបានដឹកនាំការបះបោរដែលរារាំងការធ្វើដំណើរទៅកាន់ដែនដីសន្យា

សូមសួរសំណួរខាងក្រោម ៖

- តើអ្នកគិតថា អ្វីជាហេតុផលមួយចំនួន ដែលយើងត្រូវជួបនឹងការលំបាក ?

ក្រោយពីការពិភាក្សាខ្លះៗ សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ អិល ថៃនី ខ្ពេតុន នៃក្រុមចិតសិបនាក់ ។ សុំឲ្យសិស្សក្នុងថ្នាក់ស្តាប់រកនូវហេតុផលបីយ៉ាងដែលអែលឌើរ ខ្ពេតុន បានផ្តល់ចំពោះការលំបាកដែលយើងបានជួបប្រទះ ៖

« តាមនំយទូទៅ បន្ទុករបស់យើងមកពីប្រភពបីយ៉ាង ។ [១] បន្ទុកខ្លះគឺជាលទ្ធផលធម្មជាតិនៃលក្ខខណ្ឌនៃពិភពលោក ដែលយើងរស់នៅ ។ ជំងឺតម្កាត់ ការពិការខាងរាងកាយ ខ្សល់ព្យុះ និង ការរញ្ជួយផែនដីដែលកើតឡើងពីពេលមួយទៅពេលមួយ នោះមិនមែនជាកំហុសរបស់យើងនោះទេ ។ . . .

« [២] បន្ទុកផ្សេងទៀត ត្រូវបានដាក់មកលើយើង ដោយការប្រព្រឹត្តខុសរបស់អ្នកដទៃ ។ ការបំពាន និង ការញ៉ៀន អាចធ្វើឲ្យគេហដ្ឋានក្លាយជាអ្វីមួយ ប៉ុន្តែគេហដ្ឋានគឺជាស្ថានសួគ៌មួយនៅលើផែនដីចំពោះសមាជិកគ្រួសារសុចរិត ។ អំពើបាប ប្រពៃណីខុសឆ្គង ការបង្ក្រាប និង បទល្មើស ពង្រាយដាក់បន្ទុកដល់ជនរងគ្រោះតាមផ្លូវនៃជីវិតគេ ។ . . .

« [៣] កំហុស និង កំសោយរបស់យើងផ្ទាល់ បង្កើតបញ្ហាដល់យើងជាច្រើន និង អាចដាក់បន្ទុកយ៉ាងធ្ងន់មកលើស្មារបស់យើង ។ បន្ទុកដ៏ស្មុគស្មាញភាគច្រើនដែលយើងដាក់មកលើខ្លួនយើង គឺជាបន្ទុកនៃអំពើបាប » (« ថាបន្ទុករបស់អ្នកនឹងត្រូវបានសម្រាល » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ១២–១៣) ។

សូមសរសេរនៅលើក្តារខៀន (១) *លក្ខខណ្ឌនៃពិភពលោក* (២) *ការប្រព្រឹត្តខុសរបស់អ្នកដទៃ* និង (៣) *កំហុស និងកំសោយរបស់យើងផ្ទាល់ ។*

សូមពន្យល់ថា ក្រោយពីគ្រួសាររបស់លីហៃបានចុះសំពៅធ្វើដំណើរកាត់សមុទ្រ លេមិន លេមយួល និង អ្នកផ្សេងទៀតបានជ្រើសរើសជម្រើសខុស ដែលនាំមកនូវការលំបាកដល់គ្រប់គ្នានៅលើសំពៅ ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ១ ១៨:៩ ព្ធ។ ។ សូមលើកទឹកចិត្តសិស្សឲ្យលើកដៃរបស់ពួកគេ នៅពេលពួកគេដឹងពីគំរូមួយរបស់នរណាម្នាក់ដែលរើសជម្រើសខុស ។

- តើជម្រើសខុសអ្វីដែលលេមិន លេមយួល ក្វនប្រុសរបស់អ៊ីសម៉ាអែល និង ប្រពន្ធរបស់ពួកគេបានធ្វើ ? ហេតុអ្វីបានជាវាខុស ?

សូមជួយសិស្សយល់ថា វាមិនមែនខុសដើម្បីរាំ ស្តាប់តន្ត្រី ឬ មានការសប្បាយ ប៉ុន្តែខគម្ពីរនេះបង្ហាញថាលេមិន លេមយួល និង អ្នកផ្សេងទៀតបានធ្វើនូវរឿងទាំងនេះ « ដោយមានភាពទ្រគោះហួសវិស័យ »(នីហ្វៃទី១ ១៨:៩) ។ សូមពន្យល់ថានៅក្នុងបរិបទនេះ *ពាក្យភាពទ្រគោះ* សំដៅលើភាពអាសគ្រាម ឬ គ្រោតគ្រាត ។ សត្រូវយើង អាចប្រើការរាំ តន្ត្រី និង របៀបដែលយើងនិយាយដើម្បីបំផ្លាញដួងចិត្ត និង គំនិតរបស់យើង និង នាំឲ្យយើងបាត់បង់ភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១៨:១០ ព្ធ។ ។

- ដោយយោងតាម នីហ្វៃទី១ ១៨:១០ តើនីហ្វៃបានភ័យខ្លាចអ្វីនឹងកើតឡើង ប្រសិនបើអ្នកដែលបះបោរមិនព្រមប្រែចិត្ត ?
- តើនីហ្វៃបានធ្វើអ្វី ដើម្បីព្យាយាមជួយពួកគេ ? (វាអាចមានប្រយោជន៍សម្រាប់សិស្សដើម្បីដឹងថាពាក្យ *ភាពម៉ឺងម៉ាត់* មានន័យថាភាពម៉ត់ចត់) ។

សូមអញ្ជើញសិស្សឲ្យគិតអំពីរបៀបដែលពួកគេនឹងឆ្លើយតប ប្រសិនបើសមាជិកគ្រួសារម្នាក់ ឬ អ្នកដឹកនាំសាសនាចក្រណាម្នាក់ បានសុំឲ្យពួកគេប្តូរតន្ត្រីដែលពួកគេកំពុងស្តាប់ របៀបពួកគេរាំ ឬ របៀបពួកគេនិយាយ ។ សូមលើកទឹកចិត្តពួកគេឲ្យសញ្ជឹងគិតថា តើពួកគេនឹងព្រមស្តាប់តាម ហើយផ្លាស់ប្តូរឬទេ ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១៨:១១ ព្ធ។ ។

- យោងតាម នីហ្វៃទី១ ១៨: ១០–១១ តើលេមិន និង លេមយួលបានឆ្លើយតបនឹងការប្រឹក្សារបស់នីហ្វៃយ៉ាងដូចម្តេច ?
- ហេតុអ្វីបានជាព្រះអម្ចាស់បានបណ្តោយឲ្យលេមិន និង លេមយួលចងនីហ្វៃ ?

សូមអញ្ជើញសិស្សបីបួននាក់ប្តូរវេនគ្នាអាននៅក្នុង នីហ្វៃទី១ ១៨:១២–១៤, ១៧–១៩ ព្ធ។ ។ សុំឲ្យសិស្សរកមើលពាក្យ និង ឃ្លាដែលបង្ហាញពីលទ្ធផលនៃអាកប្បកិរិយារបស់លេមិន និង លេមយួល ។ សូមអញ្ជើញសិស្សរកមើលគោលការណ៍នៃដំណឹងល្អ ដែលពួកគអាចរៀនពីដំណើរឿងនេះ ។ ចម្លើយមួយអាចថា **អំពើបាបនាំទៅរកការរងទុក្ខដល់ខ្លួនយើង និង ពេលខ្លះដល់អ្នកដទៃផងដែរ ។**ដើម្បីជួយសិស្សអនុវត្តគោលការណ៍នេះ អ្នកអាចសួរសំណួរដូចជា ៖

- តើសកម្មភាពបះបោរនៃមនុស្សពីរបីនាក់ ប៉ះពាល់ដល់ក្រុមទាំងមូលយ៉ាងដូចម្តេច ?
- តើជម្រើសដ៏ល្ងង់ខ្លៅ ឬ ដែលបះបោរទាំងនេះ អាចជ្រៀតជ្រែកដល់សមត្ថភាពយើងក្នុងការទទួលបានវិវរណៈដោយរបៀបណា ?

នៅផ្នែកនៃការពិភាក្សានេះ សូមគិតពីការអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន បិយដ៏ យេ ជាកកឺ នៃក្ងរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« យើងបានមើលគំរូនៃការមានគារវភាព និង ការគ្មានគារវភាពនៅក្នុងសាសនាចក្រ ។ ខណៈពេលដែលមនុស្សជាច្រើនត្រូវបានគេកោតសរសើរជាខ្លាំង យើងកំពុងតែរសាត់ព្រាត់ ។ យើងមានហេតុផលដើម្បីត្រូវគេព្រួយបារម្ភយ៉ាងខ្លាំង ។

« ពិភពលោកកាន់តែមានភាពរវល់ឡើង។ ។ ការស្លៀកពាក់ និង ការសម្អិតសម្អាង និង ការប្រព្រឹត្ត គឺកាន់តែធ្ងររលង់ និង កាន់តែមិនស្អាតស្អំ និង កាន់តែគ្មានរបៀបរៀបរយ ។ តន្ត្រីខ្លាំង។ . . . ជាមួយនឹងទំនុកថោកទាប បន្លឺឡើងតាមប្រដាប់បំពងសំឡេង ។ . . . ការប្រែប្រួលនៃរឿងទាំងនេះ ទទួលបានការយល់ព្រមយ៉ាងខ្លាំង និង មានឥទ្ធិពលមកលើយុវវ័យយើង ។ . . .

« ទំនោរនេះ ចំពោះសំឡេងកាន់តែខ្លាំង កាន់តែមានភាពសប្បាយ កាន់តែមានទំនាស់ មិនមានការការអត់ធ្មត់ មិនមានសេចក្តីថ្លៃថ្នូរ មិនមានរបៀបរបប គឺវាមិនមែនជារឿងចៃដន្យ ឬ ដោយគ្មានកំហុសនោះទេ ឬក៏ គ្មានការប៉ះទង្គិចដែរ ។

« ការចេញបញ្ជាលើកតំបូងត្រូវបានចេញដោយ មេបញ្ជាកម្មាក់ទប់ទល់នឹងការឈ្លានពានពីកងទ័ពមួយ គឺជាការស្ទះខ្សែរយៈទំនាក់ទំនងនៃអស់អ្នកដែលគាត់មានបំណងចង់យកជ័យជំនះលើ ។

« ការគ្មានគារវភាព បំពេញបំណងរបស់គូសត្រូវ ដោយការរាវាំងបណ្តាញដ៏ពិសិដ្ឋនៃវិវរណៈទាំងខាងគំនិត និង ខាងវិញ្ញាណ » (« គារវភាពអញ្ជើញវិវរណៈ » *Ensign*ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ទំព័រ ២២) ។

- ប្រសិនបើអ្នកក្លាយជាអ្នកបះបោរ និង អ្នកមិនគោរពប្រតិបត្តិ តើវាអាចប៉ះពាល់ដល់គ្រួសាររបស់អ្នកដោយរបៀបណា ? តើវាអាចប៉ះពាល់ដល់មិត្តភក្តិរបស់អ្នកដោយរបៀបណា ? តើវាអាចប៉ះពាល់ដល់សិស្សក្នុងថ្នាក់ ឬ ក្រុមរបស់អ្នកដោយរបៀបណា ?

សូមត្រឡប់ទៅចំណុចនៃភាពលំបាក។ ទាំងបីដែលបានសរសេរនៅលើក្តារខៀន ។ សូមពន្យល់ថា មេរៀនផ្សេង។ទៀតនៃជំពូកនេះ អាចជួយយើងឲ្យរៀនពីរបៀបដែលយើងគួរតែឆ្លើយតប នៅពេលជួបការលំបាកមកដល់ មិនថាពួកគេមានលទ្ធផលពីជម្រើសរបស់យើងផ្ទាល់ ឬ ជម្រើសរបស់អ្នកដទៃនោះទេ ។ សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ១៨:១៥–១៦, ២០–២៣ម្នាង។ខ្លួន ។ សូមលើកទឹកចិត្តពួកគេឲ្យរកមើលសេចក្តីពិតដែលអាចអនុវត្តនៅក្នុងស្ថានភាពទាំងពីរ ។ សូមឲ្យពួកគេចែកចាយជា៣ក្យសម្តីផ្ទាល់ខ្លួនគេនូវអ្វីដែលពួកគេបានរៀន ។ ចម្លើយរបស់ពួកគេ អាចរួមមាន ៖

យើងអាចសំឡឹងទៅព្រះ និង នៅបន្តស្មោះត្រង់ អំឡុងពេលយើងជួបនឹងឧបសគ្គ ។

ការអធិស្ឋាន អាចជួយយើងឲ្យរកបានសេចក្តីសុខសាន្ត ក្នុងគ្រាយើងជួបនឹងឧបសគ្គ ។

នៅពេលសិស្សចែកចាយគំនិតរបស់ពួកគេ សូមប្រាកដដើម្បីបញ្ជាក់ពីគំរូដ៏សុចរិតរបស់នីហ្វៃ អំឡុងពេលគាត់ជួបនឹងឧបសគ្គ ។ សូមអញ្ជើញសិស្សឲ្យអានទីបន្ទាល់ខាងក្រោមពីអែលឌើរ អិល វិតនី ក្លេតុន ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលអែលឌើរ ក្លេតុន បានប្រឹក្សាយើងឲ្យធ្វើ នៅពេលយើងជួបនឹងឧបសគ្គ ៖

« មិនថាការលំបាកដែលយើងជួបនៅក្នុងជីវិតជាលទ្ធផល នៃលក្ខខណ្ឌធម្មជាតិ ការប្រព្រឹត្តខុសរបស់អ្នកដទៃ ឬ ជាកំហុស និងការធ្លាក់របស់យើងផ្ទាល់នោះទេ យើងទាំងអស់គ្នាគឺជាកូនចៅរបស់ព្រះវរបិតាសួគ៌ជាទីស្រឡាញ់ ដែលបានបញ្ជូនយើងមកកាន់ផែនដីដែលជាផ្នែកនៃផែនការដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់ សម្រាប់ការលូតលាស់ និង ការរីកចម្រើនរបស់យើង ។ បទពិសោធន៍ពិសេសៗផ្ទាល់ខ្លួនរបស់យើង អាចជួយយើងឲ្យរៀបចំខ្លួនដើម្បីត្រឡប់ទៅរកទ្រង់វិញ ។ . . . យើងត្រូវតែធ្វើអ្វីៗដែលយើងអាច ដើម្បីទប់ទល់នឹងការលំបាករបស់យើង ‹ ឲ្យបានល្អ › | សូមមើល គ. និង ស. ១២១:៧–៨ | ។ . . .

« . . . ខ្ញុំដឹងថា នៅពេលយើងកាន់តាមព្រះបញ្ញត្តិរបស់ព្រះ និង សេចក្តីសញ្ញារបស់យើង ទ្រង់នឹងជួយយើងសម្រាលបន្ទុករបស់យើង ។ ទ្រង់នឹងពង្រឹងយើង ។ នៅពេលយើងប្រែចិត្ត ទ្រង់នឹងអភ័យទោសដល់យើង ដោយសេចក្តីសុខសាន្តនៃសម្បជញ្ញៈ និងសេចក្តីអំណរ » (« ដើម្បីឲ្យបន្ទុករបស់អ្នកនឹងត្រូវបានសម្រាល » ទំព័រ ១៣–១៤) ។

សូមអញ្ជើញសិស្សឲ្យគិតអំពីសេចក្តីពិតមួយ ដែលពួកគេបានរៀនពីមេរៀននេះ ។

- តើនៅពេលណាដែលអ្នកបានឃើញពីសេចក្តីពិតនេះកើតឡើង នៅក្នុងជីវិតរបស់អ្នក ឬ នៅក្នុងជីវិតរបស់នរណាម្នាក់ដែលអ្នកស្គាល់ ?

អ្នកអាចបន្ថែមទីបន្ទាល់របស់អ្នកថា ព្រះអាចជួយយើងឆ្លងកាត់ឧបសគ្គរបស់យើង នៅពេលយើងស្មោះត្រង់ និង នៅពេលយើងប្រែចិត្ត ហើយត្រឡប់មករកទ្រង់វិញ ។

ដើម្បីបញ្ចប់ សូមរំឭកសិស្សថា ទោះជាមានការលំបាកដែលនីហ្វៃ និង គ្រួសាររបស់គាត់បានជួបប្រទះក្តី ក៏នៅទីបំផុតពួកគេបានទៅដល់ដែនដីសន្យាដែរ ។ សូមថ្លែងទីបន្ទាល់ថា នៅពេលយើងស្វែងរកការដឹកនាំពីព្រះអម្ចាស់ និង ធ្វើការដោយឧស្សាហ៍ព្យាយាមក្នុងការធ្វើតាមនោះ យើងក៏អាចបំពេញដំណើរដែលព្រះអម្ចាស់បានបញ្ជូនយើងមកផែនដីដើម្បីបានទទួលបទពិសោធន៍ប្រកបដោយជោគជ័យផងដែរ ។

នីហ្វៃទី១ ១៩

សេចក្តីផ្តើម

នៅក្នុងជំពូកនេះ នីហ្វៃបានពន្យល់ថា មនុស្សខ្លះមិនបានគោរពដល់ព្រះនៃអ៊ីស្រាអែល ជាព្រះយេស៊ូវគ្រីស្ទឡើយ ។ តាមការប្រៀបធៀប ពួកគេបានជាន់ឈ្លីព្រះយេស៊ូវគ្រីស្ទនៅក្រោមជើងរបស់ពួកគេ ដោយពួកគេមិនរវល់នឹងទ្រង់ ហើយបដិសេធស្តាប់តាមការប្រឹក្សារបស់ទ្រង់ ។ នីហ្វៃ ក៏បាននិយាយទាក់ទងនឹងការបង្រៀនរបស់ព្យាការីពីបុរាណ ដែលបានព្យាករណ៍ថា អ្នកទាំងឡាយនោះដែលទទួលខុសត្រូវចំពោះការវាយ និង ការឆ្កាងព្រះអង្គសង្គ្រោះ ក៏ដូចជាកូនចៅរបស់ពួកគេ នឹងត្រូវបានខ្ចាត់ខ្ចាយ និង រងទុក្ខរហូតដល់ពួកគេបានប្រែជួងចិត្តរបស់គេទៅរកព្រះអម្ចាស់វិញ ។ នៅពេលនោះ ព្រះអម្ចាស់នឹង « នឹកឃើញសេចក្តីសញ្ញាទាំងឡាយ ដែលទ្រង់បានធ្វើជាមួយនឹងពួកអយ្យកោរបស់ពួកគេ » (នីហ្វៃទី១ ១៩:១៥) ។ នីហ្វៃបានពន្យល់ថា គាត់បានសរសេរឿងទាំងនេះ ដើម្បីបញ្ចុះបញ្ចូលដល់ប្រជាជនរបស់គាត់ ដើម្បីឲ្យនឹកចាំដល់ព្រះអម្ចាស់ និង ជឿដល់ទ្រង់ ។ គាត់ក៏បានបង្រៀនប្រជាជនរបស់គាត់ ឲ្យប្រៀបធៀបបទគម្ពីរទៅនឹងខ្លួនគេ ដើម្បីជួយពួកគេឲ្យជឿដល់ព្រះអម្ចាស់ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ១៩:១–១៩

នីហ្វៃកត់ត្រាការព្យាករណ៍អំពីព្រះយេស៊ូវគ្រីស្ទ ដើម្បីជួយប្រជាជនឲ្យចាំពីព្រះអង្គប្រោសលោះរបស់ពួកគេ ។

សូមលើកព្រះគម្ពីរមរមនមួយក្បាលឡើង ។ សូមសង្ខេប នីហ្វៃទី ១១៩:១–៤ដោយការពន្យល់ថា នីហ្វៃត្រូវបានបញ្ជាឲ្យធ្វើផ្ទាំងពីរ—មួយដើម្បីកត់ត្រាប្រវត្តិ (នៃសាសនា) ដ៏ពិសិដ្ឋមួយ និង មួយទៀតសម្រាប់ប្រវត្តិនៃលោកិយនៃប្រជាជនរបស់គាត់ ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១៩:៣, ៥–៦ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលនីហ្វៃបាននិយាយអំពីរឿងរ៉ាវ « ពិសិដ្ឋ » ។

- តើហេតុផលអ្វីខ្លះដែលនីហ្វៃបានផ្តល់ឲ្យ ចំពោះការរក្សាកំណត់ត្រាជារឿងមួយពិសិដ្ឋ ?

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១៩:៧ ឮៗ ។ មុនពេលគាត់អាន សូមពន្យល់ថា នៅក្នុងខគម្ពីរនេះ ឃ្លា « ព្រះនៃអ៊ីស្រាអែល » សំដៅទៅលើព្រះយេស៊ូវគ្រីស្ទ ។ ខគម្ពីរនេះ ក៏បានបញ្ចូលពាក្យ *គ្មានតម្លៃអ្វីសោះ* ដែលមានន័យថា « គ្មានអ្វីទាំងអស់ » ។ ដែលចាត់ទុកថានរណាម្នាក់គ្មានតម្លៃអ្វីសោះ គឺការប្រព្រឹត្តដាក់មនុស្សនោះដូចជាគាត់គ្មានន័យអ្វីសោះ ។

- ក្រោយពីការនិយាយ គាត់រៀបរាប់អំពីអ្វីដែលពិសិដ្ឋ តើនីហ្វៃបានចាប់ផ្តើមសរសេរអំពីអ្វី ?
- យោងតាម នីហ្វៃទី១ ១៩:៧ តើមនុស្សមួយចំនួនជាន់ឈ្លីព្រះអង្គសង្គ្រោះនៅក្រោមជើងរបស់ពួកគេ ឬ « ចាត់ទុកថាទ្រង់គ្មានតម្លៃអ្វីសោះ » ដោយរបៀបណា ?
- តើការបដិសេធក្នុងការស្តាប់តាមការប្រឹក្សារបស់ព្រះអម្ចាស់ ប្រៀបដូចជាការចាត់ទុកទ្រង់ថាគ្មានតម្លៃអ្វីសោះ ឬ ជាន់ឈ្លីទ្រង់នៅក្រោមជើងរបស់ខ្លួន ដោយរបៀបណា ?

សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ១៩:៨–១០ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលប្រជាជននឹងធ្វើដាក់ព្រះអង្គសង្គ្រោះ ដូចជាអ្វីមួយដែលគ្មានតម្លៃអ្វីសោះ អំឡុងពេលការបម្រើខាងសាច់ឈាមរបស់ទ្រង់ ។ (អ្នកអាចប្រាប់សិស្សឲ្យគូសពាក្យ និង ឃ្លាដែលពួកគេរកឃើញ) ។

- តើប្រជាជនបានចាត់ទុកព្រះអង្គសង្គ្រោះដូចជាអ្វីមួយដែលគ្មានតម្លៃអ្វីសោះ អំឡុងពេលការបម្រើខាងសាច់ឈាមរបស់ទ្រង់ដោយរបៀបណា ?
- តើសេចក្តីលម្អិតអ្វីខ្លះនៅក្នុងខគម្ពីរទាំងនេះដែលបង្ហាញថា ព្រះអង្គសង្គ្រោះមិនបានចាត់ទុកយើងថា ជា « អ្វីមួយដែលគ្មានតម្លៃសោះ » នោះ ? (សិស្សគួរតែយល់ថា ព្រះអង្គសង្គ្រោះបានរងទុក្ខអ្វីៗទាំងអស់ដែលទ្រង់បានធ្វើ « ដោយសារសេចក្តីសប្បុរសជាទីស្រឡាញ់របស់ទ្រង់ និង ការអត់ធ្មត់របស់ទ្រង់ចំពោះកូនចៅមនុស្ស ») ។
- នៅពេលអ្នកគិតអំពីខគម្ពីរទាំងនេះ តើអ្នកមានអារម្មណ៍យ៉ាងដូម្តេចចំពោះព្រះអង្គសង្គ្រោះ ?

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១៩:១៣–១៤ និង សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្យាការីសឹលសបាននិយាយ ដែលជាហេតុផលនាំឲ្យអស់អ្នកឆ្កាងព្រះអង្គសង្គ្រោះ (និង កូនចៅរបស់ពួកគេ) នឹង « ត្រូវបានវាយដោយប្រជាជនទាំងអស់ » ។

- តើហេតុផលអ្វីដែលសឹលសល់ចំពោះហេតុផលដែលអ្នកទាំងឡាយដែលបានឆ្កាងព្រះអង្គសង្គ្រោះ (និង កូនចៅរបស់ពួកគេ) នឹង « ត្រូវបានវាយដោយប្រជាជនទាំងអស់ » ?

សូមសរសេរប្រសាសន៍ខាងក្រោមនៅលើក្តារខៀន ៖ *ពួកគេបានវិបរិតចិត្តចេញ ។*

- តើអ្នកគិតថាវាមានន័យដូចម្តេច ក្នុងការបង្វែចិត្តរបស់មនុស្សម្នាក់ចេញពីព្រះអម្ចាស់ ?

ក្រោយពីសិស្សបានឆ្លើយហើយ សូមប្រាប់សិស្សក្នុងថ្នាក់ថា អ្នកចង់ឲ្យសិស្សបីបួននាក់ជួយបង្ហាញពីរបៀបដែលឃ្លានេះ អាចអនុវត្តចំពោះយើងនាសព្វថ្ងៃនេះ ។ សូមអញ្ជើញសិស្សបីបួននាក់ឡើងមកកាន់ក្តារខៀន ។ សុំឲ្យពួកគេម្នាក់សរសេរឧទាហរណ៍មួយនៃសកម្មភាពមួយដែលអាចបង្ហាញថា មនុស្សម្នាក់បានបង្វែចិត្តរបស់គាត់ចេញពីព្រះអម្ចាស់ ។ បន្ទាប់មកសុំឲ្យពួកគេពន្យល់អ្វីលទ្ធផល

ខ្លះៗ ដែលមកពីការបែរចិត្តរបស់មនុស្សម្នាក់ចេញពីអ្វីដែលពួកគេបានសរសេរនោះ ។ (ឧទាហរណ៍ សិស្សម្នាក់អាចសរសេរ *ឈប់ការសិក្សាព្រះគម្ពីរ* ហើយបន្ទាប់មកពន្យល់ថា លទ្ធផលមួយនៃសកម្មភាពនេះ គឺសមត្ថភាពថយចុះក្នុងការទទួលបានវិវរណៈ) ។

ក្រោយពីសិស្សបីឬនាក់បានពន្យល់ពីឧទាហរណ៍របស់ពួកគេហើយ សូមប្រាប់សិស្សក្នុងថ្នាក់ថា ដោយមិនគិតពីមូលហេតុដែលយើងអាចបង្វែចិត្តរបស់យើងចេញពីព្រះអម្ចាស់ យើងអាចជ្រើសរើសដើម្បីបែរដួងចិត្តរបស់យើងត្រឡប់មករកទ្រង់វិញ ។ សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ១៩:១៤–១៧ដោយស្ងាត់ៗដោយរកមើលការសន្យារបស់ព្រះអម្ចាស់ចំពោះអស់អ្នកណាដែលបង្វែចិត្តរបស់ពួកគេទៅរកទ្រង់វិញ ។

- តើនៅពេលណាដែលព្រះអម្ចាស់កម្ចាត់កម្ចាយអ៊ីស្រាអែល ? (នៅពេលដែលពួកគេបែរចិត្តរបស់ពួកគេចេញពីទ្រង់) ។
- តើនៅពេលណាដែលព្រះអម្ចាស់នឹងប្រមូលផ្តុំពួកអ៊ីស្រាអែលវិញ ? (នៅពេលដែលពួកគេបែរចិត្តរបស់ពួកគេទៅរកទ្រង់វិញ) ។
- តើព្រះអម្ចាស់បានមានព្រះបន្ទូលថាទ្រង់នឹងធ្វើដូចម្តេច ចំពោះអ្នកដែលមិនបែរចិត្តរបស់ពួកគេប្រឆាំងនឹងទ្រង់ទៀត ?
- តើអ្នកគិតថាវាមានន័យយ៉ាងណាថាព្រះអម្ចាស់នឹងនឹកឃើញពីប្រជាជនទាំងនេះ និង សេចក្តីសញ្ញាដែលទ្រង់បានធ្វើជាមួយនឹងឪពុករបស់ពួកគេ ?

សូមជួយសិស្សឲ្យយល់ថា ព្រះអម្ចាស់មិនដែលភ្លេចប្រជាជនទាំងនេះនោះទេ ។ ពួកគេបានរស់នៅតាមរបៀបមួយដែលទ្រង់មិនអាចពង្រីកពរជ័យទាំងអស់នៃដំណឹងល្អទៅដល់ពួកគេបាន ។ នៅពេលកូនចៅរបស់ពួកគេបែរចិត្តទៅរកទ្រង់ ព្រះអម្ចាស់សន្យាថានឹងនឹកចាំពួកគេ ប្រមូលពួកគេទៅក្នុងសាសនាចក្ររបស់ទ្រង់ និង ពង្រីកពរជ័យទាំងអស់នៃដំណឹងល្អទៅដល់ពួកគេ ។

- តើអ្នកគិតថាសេចក្តីសន្យានៅក្នុង ខ ១៥–១៧ មានន័យយ៉ាងដូចម្តេចចំពោះយើង ? (គំនិតមួយដែលគួរតែចេញពីការពិភាក្សានេះ គឺថា **នៅពេលយើងបែរចិត្តរបស់យើងទៅរកព្រះអម្ចាស់ ទ្រង់នឹងគោរពសេចក្តីសញ្ញាដែលយើងបានធ្វើជាមួយនឹងគាត់ ។**

សុំឲ្យសិស្សសញ្ជឹងគិតពីសំណួរខាងក្រោម ហើយសរសេរចម្លើយនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ។ (អ្នកអាចសរសេរសំណួរទាំងនេះនៅលើក្តារខៀន) ។

- តើសកម្មភាពប្រភេទណាដែលបង្ហាញថា អ្នក និង គ្រួសាររបស់អ្នកបានបែរចិត្តទៅរកព្រះអម្ចាស់វិញ ?
- តើនៅពេលណាដែលសកម្មភាពបែបនោះបានជួយអ្នក ឬ គ្រួសាររបស់អ្នកទទួលបាននូវពរជ័យពីព្រះអម្ចាស់ ?

សូមគិតអំពីការអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយ ចម្លើយរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។ សូមរំឭកពួកគេថា ពួកគេមិនចាំបាច់ចែកចាយនូវបទពិសោធន៍ផ្ទាល់ខ្លួនពេកនោះទេ ។

សូមពន្យល់ដោយសង្ខេបថា នីហ្វៃមានបំណងឲ្យកំណត់ត្រារបស់គាត់ទៅដល់សមាជិកទាំងអស់ នៃវង្សអ៊ីស្រាអែល —រួមទាំងយើងផង ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ១៩:១៨–១៩ និង សុំឲ្យសិស្សក្នុងថ្នាក់រកនូវអ្វីដែលនីហ្វៃចង់បញ្ចុះបញ្ចូលយើងឲ្យធ្វើ ។ សូមថ្លែងទីបន្ទាល់ថា នៅពេលយើងចងចាំព្រះអម្ចាស់ ហើយបែរចិត្តយើងទៅរកទ្រង់វិញ នោះទ្រង់នឹងប្រទានពរជ័យនៃដំណឹងល្អរបស់ទ្រង់ដល់យើង ។

នីហ្វៃ១ ១៩:២០–២៤

នីហ្វៃពន្យល់ពីមូលហេតុ ដែលគាត់បានប្រើព្រះគម្ពីរពីបុរាណបង្រៀនប្រជាជនរបស់គាត់

សូមចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ដែលដកស្រង់ចេញពីសុន្ទរកថាថ្លែងទៅកាន់អ្នកគ្រប់គ្រងប្រព័ន្ធអប់រំសាសនាចក្រ ៖

« ខ្ញុំនឹងសន្យាជាមួយអ្នកអំពីការអានព្រះគម្ពីរមរមនថា ៖ អ្នកនឹងជក់ចិត្តនឹងវា នៅពេលអ្នកយល់ថា ព្រះអម្ចាស់បានបង្កប់សារលិខិតរបស់ទ្រង់ទៅកាន់អ្នកនៅក្នុងព្រះគម្ពីរនេះ ។ នីហ្វៃ មរមន និង ម៉ូរ៉ូណៃ បានដឹងការណ៍នោះ ហើយអ្នកដែលដាក់វាចូលគ្នា បានដាក់ក្នុងសារលិខិតនោះសម្រាប់អ្នក ។ ខ្ញុំសង្ឃឹមថា អ្នកមានទំនុកចិត្តថាព្រះគម្ពីរនោះត្រូវបានសរសេរសម្រាប់សិស្សរបស់អ្នក ។ មានសារលិខិតសាមញ្ញ ចំៗ សម្រាប់ពួកគេដែលនឹងប្រាប់ពួកគេពីរបៀបដើម្បីធ្វើការផ្លាស់ប្តូរ ។ នោះគឺជាអ្វីដែលព្រះគម្ពីរនេះនិយាយអំពី ។ វាជាទីបន្ទាល់មួយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ និង ដង្វាយធួន ព្រមទាំងពីរបៀបដែលវាអាចធ្វើការនៅក្នុងជីវិតរបស់ពួកគេ ។ អ្នកនឹងមានបទពិសោធន៍មួយក្នុងឆ្នាំនេះ ពីអានុភាពនៃការផ្លាស់ប្តូរដែលមកដោយសារអំណាចនៃដង្វាយធួន ដោយសារការសិក្សាព្រះគម្ពីរនេះ » (« ព្រះគម្ពីរមរមននឹងផ្លាស់ប្តូរជីវិតរបស់អ្នក » *Ensign*ខែ កុម្ភៈ ឆ្នាំ ២០០៤ ទំព័រ ១១) ។

- នៅពេលអ្នកសិក្សាព្រះគម្ពីរមរមន តើវាមានប្រយោជន៍យ៉ាងណាដែលដឹងថា នីហ្វៃ មរមន និង ម៉ូរ៉ូណៃ បានបញ្ចូលសារលិខិតសម្រាប់អ្នក ?

សូមចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អែសរ៉ា ថាហ្វ ប៊ែនសឺន ៖

« ព្រះគម្ពីរមរមនត្រូវបានសរសេរសម្រាប់យើងនៅបច្ចុប្បន្ននេះ ។ ព្រះគឺជាអ្នកនិពន្ធព្រះគម្ពីរនេះ ។ វាគឺជាកំណត់ត្រាមួយនៃប្រជាជនដែលបានធ្លាក់ចុះ ត្រូវបានចងក្រងដោយបុរសដែលទទួលបានការបំផុសគំនិតសម្រាប់ពរជ័យរបស់យើង ។ ប្រជាជនទាំងនោះ មិនដែលមានព្រះគម្ពីរនេះទេ —វាគឺសម្រាប់យើង ។ មរមន ជាព្យាការីពីបុរាណដែលព្រះគម្ពីរនេះបានដាក់ឈ្មោះតាម គាត់បានសង្ខេបកំណត់ត្រាជាច្រើនសតវត្សរ៍ ។ ព្រះ ដែលដឹងទីចុងបំផុតតាំងពីដើមដំបូង បានប្រាប់គាត់ពីអ្វីដែលត្រូវបញ្ចូលនៅក្នុងសេចក្តីសង្ខេបរបស់គាត់ ដែលយើងនឹងត្រូវការសម្រាប់ជំនាន់របស់យើង » (« ព្រះគម្ពីរមរមនគឺជាព្រះបន្ទូលនៃព្រះ » *Ensign* ខែ មករា ឆ្នាំ ១៩៨៨ ទំព័រ ៣) ។

« បើសិនជាពួកលោកបានឃើញសម័យរបស់យើង និងបានជ្រើសរើសការណ៍ទាំងនោះដែលអាចមានតម្លៃអស្ចារ្យបំផុតដល់យើង តើនោះមិនមែនជារបៀបដែលយើងគួរតែសិក្សាព្រះគម្ពីរមរមនដែរទេឬអី ? យើងគួរតែសួរខ្លួនឯងជាញឹកញាប់ថា ‹ ហេតុអ្វីបានជា

ព្រះអម្ចាស់បំផុសគំនិតមរមន (ឬ ម៉រ៉ូណៃ ឬ អាលម៉ា) ឲ្យបញ្ចូលការណ៍នោះក្នុងបញ្ជីរបស់លោក ? តើមេរៀនអ្វីដែលខ្ញុំអាចរៀនពីនោះ ដើម្បីជួយខ្ញុំរស់នៅក្នុងពេលនេះ និង ជំនាន់នេះបាន ? » (« ព្រះគម្ពីរមរមន—មូលដ្ឋាននៃសាសនាចក្ររបស់យើង » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ៦) ។

សូមអញ្ជើញសិស្សក្នុងថ្នាក់អាន នីហ្វៃទី១ ១៩:២២-២៣ដោយស្ងាត់ស្ងៀម ដោយស្វែងរកការពិពណ៌នារបស់នីហ្វៃពីរបៀប ដែលគាត់បានជួយបងប្អូនប្រុសរបស់គាត់ ស្វែងរកនូវសារលិខិតសម្រាប់ខ្លួនគេនៅក្នុងព្រះគម្ពីរ ។

- តើលទ្ធលអ្វី ដែលនីហ្វៃសង្ឃឹមពីការប្រៀបធៀបបទគម្ពីរទៅនឹងខ្លួនគាត់ និង ប្រជាជនរបស់គាត់ ?
- តើពាក្យ *ប្រយោជន៍* មានន័យយ៉ាងដូចម្តេច ? (គុណប្រយោជន៍ ផលប្រយោជន៍ ការទទួលបានដ៏មានតម្លៃ) ។

សូមរៀបចំតារាងខាងក្រោមជាក្រដាសសម្រាប់ចែក ឬ បង្ហាញវានៅលើក្តារខៀន និង ឲ្យសិស្សចម្លងវាដាក់ក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។

ការប្រៀបធៀបបទគម្ពីរទៅនឹងខ្លួនយើង		ការអនុវត្តសេចក្តីពិតនៃព្រះគម្ពីរ	
តើស្ថានភាព ឬ កាល:ទេស:អ្វីខ្លះ ដែលត្រូវបានពិពណ៌នានៅក្នុងវគ្គព្រះគម្ពីរ ?	តើការណ៍នេះដូចជាស្ថានភាពនៅក្នុងជីវិតរបស់ខ្ញុំ ឬ នៅក្នុងពិភពលោកជុំវិញខ្ញុំយ៉ាងដូចម្តេច ?	តើសេចក្តីពិត ឬ សារលិខិតអ្វីដែលត្រូវបានបង្រៀននៅក្នុងវគ្គព្រះគម្ពីរនេះ ?	តើខ្ញុំអាចធ្វើតាមសេចក្តីពិត ឬ សារលិខិតនេះនៅក្នុងស្ថានភាពរបស់ខ្ញុំ ដោយរបៀបណា ?

ការប្រៀបធៀបបទគម្ពីរទៅនឹងខ្លួនយើង

គោលបំណងដ៏សំខាន់មួយនៃគ្រូបង្រៀនដ៏ណឹងល្អ គឺដើម្បីជួយសិស្សឲ្យរៀនប្រៀបធៀបបទគម្ពីរទៅនឹងខ្លួនគេ ។ គ្រូបង្រៀន អាចជួយសិស្សធ្វើការណ៍នេះ ដោយការសួរសំណួរដូចអ្វីដែលបានមាននៅក្នុងតារាង និង នៅក្នុងមេរៀននេះ: ។ នៅពេលអ្នកបង្រៀន សូមស្វែងរកឱកាសដើម្បីជួយសិស្សរៀនប្រៀបធៀបបទគម្ពីរទៅនឹងខ្លួនគេ ។

សូមបង្ហាញតារាង ដោយការពន្យល់ថា *ប្រៀបធៀប* មានន័យថា ប្រៀបប្រដូច ។ ការប្រៀបធៀបបទគម្ពីរទៅនឹងខ្លួនយើង មានន័យថា យើងប្រៀបប្រដូចកាល:ទេស:មួយនៅក្នុងព្រះគម្ពីរជាមួយនឹងស្ថានភាពមួយនៅក្នុងជីវិតរបស់យើងផ្ទាល់ ឬ នៅក្នុងពិភពលោកជុំវិញយើង ។ ការស្គាល់នូវភាពស្រដៀងគ្នារវាងកាល:ទេស:នៅក្នុងព្រះគម្ពីរ និង ស្ថានភាពនៅក្នុងជីវិតរបស់យើងផ្ទាល់ ជួយរៀបចំយើងឲ្យស្វែងរក និង អនុវត្តសេចក្តីពិតនៃព្រះគម្ពីរ ។ សេចក្តីពិតដូចគ្នានេះ ដែលអនុវត្តចំពោះមនុស្សដែលយើងបានអាននៅក្នុងព្រះគម្ពីរ អាចអនុវត្តចំពោះយើង នៅពេលយើងនៅក្នុងកាល:ទេស:ស្រដៀងគ្នា ។

ដើម្បីជួយសិស្សយល់ពីរបៀបដែលការប្រៀបធៀបនាំទៅរកការអនុវត្តន៍ សូមអញ្ជើញពួកគេបំពេញតារាងរបស់ពួកគេ នៅពេលអ្នករំឭកឡើងវិញនូវវគ្គចំណេះចំណានខគម្ពីរព្រះគម្ពីរមរមនដំបូងជាមួយនឹងពួកគេ នីហ្វៃទី១ ៣:៧ ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ៣:៧ ឮៗ ។

- តើនៅក្នុងកាល:ទេស:អ្វីដែលនីហ្វៃឆ្លើយតប នៅពេលគាត់បាននិយាយពាក្យទាំងនេះ: ? (គាត់ត្រូវបានសុំដោយព្យាការីម្នាក់ — ឪពុករបស់គាត់ លីហៃ— ឲ្យត្រឡប់ទៅទីក្រុងយេរូសាឡិមវិញដើម្បីទៅយកផ្ទាំងលង្ហិន ។ បងប្អូនប្រុសរបស់គាត់ បានត្អូញត្អែរអំពីការលំបាកនៃកិច្ចការនេះ) ។
- តើកាល:ទេស:របស់នីហ្វៃដូចជាស្ថានភាពមួយ នៅក្នុងជីវិតរបស់អ្នកយ៉ាងដូចម្តេច ? តើនៅពេលណាដែលព្រះអម្ចាស់សង្ឃឹមថាអ្នកនឹងធ្វើអ្វីមួយដែលលំបាក ?
- តើសេចក្តីពិតអ្វីដែលបានជួយនីហ្វៃនៅក្នុងស្ថានភាពរបស់គាត់ ? (នីហ្វៃបានដឹងថា នៅពេលណាព្រះអម្ចាស់ដាក់បញ្ញត្តិដល់កូនចៅមនុស្ស នោះទ្រង់នឹងរៀបចំផ្លូវដើម្បីឲ្យគេអាចសម្រេចនូវអ្វីៗនោះ:) ។
- តើអ្នកអាចធ្វើអ្វីបានដើម្បីធ្វើតាមសេចក្តីពិតនេះ: នៅក្នុងស្ថានភាពរបស់អ្នក ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយ ពីរបៀបដែលពួកគេប្រៀបធៀប នីហ្វៃទី១ ៣:៧ ទៅនឹងខ្លួនគេ និង ពីរបៀបដែលពួកគេអាចអនុវត្តវានៅក្នុងជីវិតរបស់ពួកគេ ។ (សូមរំឭកពួកគេថា ពួកគេមិនចាំបាច់ចែកចាយព័ត៌មានដែលផ្ទាល់ខ្លួនពេកនោះទេ) ។

ដើម្បីបញ្ចប់មេរៀននេះ: សូមលើកព្រះគម្ពីរមរមនមួយក្បាលឡើង ។ សូមរំឭកសិស្សថា នីហ្វៃបានគិតថាការសរសេររបស់គាត់ អំពីព្រះអង្គសង្គ្រោះថាជាការណ៍ដ៏ពិសិដ្ឋ និង មានតម្លៃធំមហិមាចំពោះខ្លួនគាត់ និង អ្នកដទៃ ។ សូមលើកទឹកចិត្តសិស្សឲ្យសិស្សសិក្សាព្រះគម្ពីរ និង ស្វែងរកសារលិខិតដែលព្រះអម្ចាស់ និង ព្យាការីរបស់ទ្រង់បានដាក់បញ្ចូលនៅក្នុងព្រះគម្ពីរសម្រាប់ពួកយើង ។ សូមថ្លែងទីបន្ទាល់ថា **នៅពេលយើងប្រៀបធៀបបទគម្ពីរទៅនឹងខ្លួនយើង យើងនឹងរៀន ហើយទទួលបានប្រយោជន៍ពីវាវិញ ។**

សូមលើកទឹកចិត្តសិស្សឲ្យសិក្សាព្រះគម្ពីរដោយខ្លួនគេផ្ទាល់ និង ស្វែងរកវគ្គដែលពួកគេអាចប្រៀបធៀបវាទៅនឹងខ្លួនគេ ។ ពួកគេអាចព្យាយាមបញ្ចូលឈ្មោះរបស់ពួកគេនៅក្នុងខគម្ពីរខ្លះ និង អានខគម្ពីរនោះ ហាក់ដូចជាព្រះអម្ចាស់ ឬ ព្យាការីរបស់ទ្រង់កំពុងនិយាយចំៗមកកាន់ពួកគេ ។ ឧទាហរណ៍ ពួកគេអាចអានផ្នែកទីមួយនៃ នីហ្វៃទី២ ៣១:២០ដូចនេះ: ៖ « ហេតុដូច្នេះហើយ អ្នករាល់គ្នា | បញ្ចូលឈ្មោះ | ត្រូវតែឈានទៅមុខដោយខ្ជាប់ខ្ជួននៅក្នុងព្រះគ្រីស្ទ » ។

អ្នកអាចចែកក្រដាសតារាងទទេ ឲ្យសិស្សប្រើនៅផ្ទះ: ។ សូមអញ្ជើញពួកគេឲ្យថា នៅពេលដែលពួកគេមកថ្នាក់រៀនលើកក្រោយ សូមឲ្យរៀបចំដើម្បីចែកចាយពីរបៀបដែលពួកគេប្រៀបធៀបបទគម្ពីរទាំងឡាយទៅនឹងខ្លួនគេ និង ពីរបៀបដែលពួកគេបានរៀន និង បានទទួលប្រយោជន៍ពីបទពិសោធន៍នេះ: ។

មេរៀនសិក្សានៅផ្ទះ

នីហ្វៃទី១ ១៥–១៩(មេរៀនទី ៤)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនការសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និង គោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេសិក្សា នីហ្វៃទី១ ១៥–១៩(មេរៀនទី ៤) មិនត្រូវបានបម្រុងទុកសម្រាប់បង្រៀនជាផ្នែកមួយនៃមេរៀនរបស់អ្នក ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍មួយចំនួនទាំងនេះតែប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (នីហ្វៃទី១ ១៥)

នីហ្វៃ និង បងប្អូនប្រុសរបស់គាត់ បានឆ្លើយតបខុសៗគ្នាទៅនឹងការព្យាការណ៍របស់លីហៃ ។ ដោយការសិក្សាពីសកម្មភាពរបស់នីហ្វៃ សិស្សឃើញថា ប្រសិនបើយើងសុំដល់ព្រះអម្ចាស់ដោយសេចក្តីជំនឿ និង គោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ យើងនឹងត្រូវបានរៀបចំឲ្យទទួលវិវរណៈ និង ការណែនាំមកពីទ្រង់ ។ នីហ្វៃបានពន្យល់ពីអត្ថន័យនៃដំបងដែក ដោយបង្ហាញថាការសិក្សា និង ការធ្វើតាមព្រះបន្ទូលនៃព្រះជារឿងរាល់ថ្ងៃ ជួយពង្រឹងយើងប្រឆាំងនឹងការល្បួងរបស់សាតាំង ។

ថ្ងៃទី ២ (នីហ្វៃទី១ ១៦)

ចេញពីប្រតិកម្មរបស់លេមិន និង លេមយួលទៅនឹងការបង្រៀនរបស់នីហ្វៃ សិស្សឃើញថា « អ្នកមានទោសភាប់សេចក្តីពិតទុកជាការពិបាក » (នីហ្វៃទី១ ១៦:២) ។ នៅពេលនីហ្វៃធ្វើបាក់ដ្ឋរបស់គាត់ គាត់បង្ហាញថា ប្រសិនបើយើងធ្វើអ្វីៗទាំងអស់ដែលយើងអាចធ្វើ និង ស្វែងរកការដឹកនាំពីព្រះអម្ចាស់ នោះព្រះអម្ចាស់នឹងជួយយើងឆ្លងកាត់ការពិបាករបស់យើង ។ ដោយការសិក្សាពីរបៀបដែលលីអាហូណាបានដឹកនាំគ្រួសាររបស់លីហៃ សិស្សដឹងថា « ដោយសារមធ្យោបាយដ៏តូចតាច នោះព្រះអម្ចាស់ទ្រង់អាចសម្រេចការណ៍យ៉ាងធំបាន » (នីហ្វៃទី១ ១៦:២៩) ។

ថ្ងៃទី ៣ (នីហ្វៃទី១ ១៧)

នីហ្វៃបានរៀបរាប់ពីការធ្វើដំណើររបស់គ្រួសារគាត់នៅក្នុងទីរហោស្ថាន និង ការមកដល់នៅដែនដីបរិបូណ៌ ។ នៅពេលគាត់ត្រូវបានបញ្ជាឲ្យសង់សំពៅ គាត់បានបង្ហាញថា ប្រសិនបើយើងរក្សាព្រះបញ្ញត្តិ នោះព្រះអម្ចាស់នឹងពង្រឹងយើង និង ផ្តល់មធ្យោបាយដល់យើងឲ្យសម្រេចបាននូវអ្វីដែលទ្រង់បានចេញបញ្ជា ។ ព្រះអម្ចាស់បានហៅបងប្រុសរបស់នីហ្វៃឲ្យប្រែចិត្តតាមរបៀបជាច្រើន ។ សិស្សដឹងថា ជាធម្មតា ព្រះវិញ្ញាណបរិសុទ្ធមានព្រះបន្ទូលដោយសំឡេងដ៏តូចរហៀងមួយ ដែលយើងមានអារម្មណ៍ជាជាងយើងឮ ។ ពួកគេសរសេរពីស្ថានភាព និង កន្លែងដែលនឹងរារាំងពួកគេពីការស្តាប់សំឡេងដ៏តូចរហៀង ។

ថ្ងៃទី ៤ (នីហ្វៃទី១ ១៨–១៩)

គំរូរបស់នីហ្វៃនៅក្នុងការសង់សំពៅ បានបង្ហាញសិស្សថាដើម្បីសម្រេចបានអ្វីដែលព្រះអម្ចាស់បានដាក់បញ្ជាត្តិ យើងត្រូវស្វែងរកជំនួយពីទ្រង់ និង បញ្ចេញកម្លាំងខ្លួនយើងផ្ទាល់ផងដែរ ។ ការសិក្សាពីដំណើររបស់គ្រួសារលីហៃទៅកាន់ដែនដីសន្យា បានបង្រៀនថា អំពើបាបនាំទៅរកការឈឺចុកដល់ខ្លួនយើង និង ពេលខ្លះដល់អ្នកដទៃថែមទៀត ។ គំរូរបស់នីហ្វៃនៅពេលដែលគាត់ត្រូវបានបងប្រុសរបស់គាត់ធ្វើបាប បានបង្រៀនថាយើងអាចសំឡឹងទៅព្រះ ហើយនៅបន្តស្មោះត្រង់ក្នុងពេលជួបឧបសគ្គ ហើយថាការអធិស្ឋានអាចជួយយើងរកឃើញសេចក្តីសុខសាន្តក្នុងពេលជួបឧបសគ្គនោះ ។

សេចក្តីផ្តើម

សប្តាហ៍នេះ សិស្សបានសិក្សាពីព្រឹត្តិការណ៍ដ៏សំខាន់ ដែលបានកើតឡើងនៅពេលគ្រួសាររបស់លីហៃបានធ្វើដំណើរកាត់ទីរហោស្ថាន និង ឆ្លងកាត់មហាសមុទ្រទៅកាន់ដែនដីសន្យា ។ មេរៀននេះ នឹងជួយសិស្សរំឭកឡើងវិញពីព្រឹត្តិការណ៍ទាំងនោះ និង ពិភាក្សា ព្រមទាំងផ្តែងទឹបន្ទាល់ពីគោលការណ៍ដែលពួកគេបានរៀន ។ សូមជួយសិស្សយល់ពីរបៀបដែលនីហ្វៃនៅតែបន្តស្មោះត្រង់នៅក្នុងកាលៈទេសៈលំបាក ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមគំរូរបស់គាត់ក្នុងការគោរពប្រតិបត្តិ និង ទុកចិត្តលើព្រះអម្ចាស់អំឡុងពេលគ្រាលំបាក ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី១ ១៥–១៨

នីហ្វៃ ជាគំរូក្នុងការគោរពប្រតិបត្តិ និង ទុកចិត្តលើព្រះអម្ចាស់ក្នុងគ្រាដែលមានឧបសគ្គ

ប្រសិនបើរូបភាពខាងក្រោមនៅមាន សូមរៀបចំបង្ហាញវា ៖

- លីអាហូណា (៦២០៤១; *សៀវភៅរូបភាពដំណឹងល្អ* [២០០៩] ទំព័រ ៦៨)
- នីហ្វៃបង្រៀបបងប្អូនប្រុសរបស់គាត់ ដែលបះបោរ (៦២០៤៤ ; *សៀវភៅរូបភាពដំណឹងល្អ* ទំព័រ ៧០)
- លីហៃ និង ប្រជាជនរបស់គាត់ បានមកដល់ដែនដីសន្យា (៦២០៤៥ ; *សៀវភៅរូបភាពដំណឹងល្អ* ទំព័រ ៧១)

ដើម្បីជួយសិស្សរំឭកឡើងវិញ និង យល់ពីសាច់រឿងនៃអ្វីដែលពួកគេបានសិក្សានៅសប្តាហ៍នេះ សូមបង្ហាញរូបភាពមួយចំនួន និង ឲ្យសិស្សដាក់រូបភាពនោះទៅតាមលំដាប់នៃកាល ។ សូមអញ្ជើញពួកគេឲ្យគិតស្រមៃថា ពួកគេគឺជាអ្នកបោះពុម្ពផ្សាយកាសែត ហើយត្រូវការសរសេរចំណងជើងពីរបីទៅប្រាំមួយពាក្យសម្រាប់រូបភាពនីមួយៗ ។ សូមបង្ហាញរូបភាពតាមលំដាប់លំដោយ និង សុំឲ្យសិស្សក្នុងថ្នាក់ឆ្លើយតបនឹងចំណងជើងមួយ ។ អ្នកអាចអានឮៗនូវសេចក្តីសង្ខេបជំពូកសម្រាប់ នីហ្វៃទី១ ១៥–១៨ ដើម្បីផ្តល់គំនិតខ្លះដល់ពួកគេ ។

ដើម្បីរៀបចំសិស្សឲ្យពិភាក្សា នីហ្វៃទី១ ១៥ សូមឲ្យពួកគេប្រាប់អំពីសកម្មភាពមួយដែលពួកគេចូលរួម ដែលតម្រូវឲ្យការខំប្រឹងខាងផ្នែករបស់ពួកគេ មុនពេលពួកគេអាចពេញចិត្តនឹងលទ្ធផល ។ ទាំងនេះអាចរួមមានសកម្មភាពដូចជាការងារសាលា ការលេងឧបករណ៍តន្ត្រី ឬ អត្តពលកម្ម ។

*សូមសរសេរ នីហ្វៃទី១ ១៥:២–៣, ៧–១១*នៅលើក្តារខៀន និង ផ្តល់ពេលវេលាដល់សិស្សអានខគម្ពីរទាំងនេះ ។ សូមសួរពួកគេពីមូលហេតុដែលបងៗរបស់នីហ្វៃ មិនបានទទួលការយល់ដូចគ្នានឹងនីហ្វៃ ក្នុងការទទួលបានវិវរណៈទាក់ទងនឹងវិវរណៈរបស់លីហៃ ។

ក្រោយពីស្តាប់ចម្លើយរបស់ពួកគេហើយ សូមជួយពួកគេស្វែងរកថា **ការទទួលបានការបំផុសគំនិត និង ការដឹកនាំពីព្រះអម្ចាស់ ជំបូងត្រូវការរស់នៅដោយសុចរិត ការខិតខំ និង សេចក្តីជំនឿនៅលើផ្នែករបស់យើង ។** អ្នកអាចបញ្ជាក់ពីគោលការណ៍នេះ ដោយការសរសេរវានៅលើក្តារខៀន ។

សុំឲ្យសិស្សសញ្ជឹងគិត និង ឆ្លើយនូវសំណួរខាងក្រោមនេះ ៖ តើបទពិសោធន៍អ្វីដែលអ្នកទទួលបានហើយបានជួយអ្នកដឹងថា គោលការណ៍នេះគឺពិត ?

សូមសរសេរ *ភាពភ្លៀវភ្លា* នៅលើក្តារខៀន ។ សូមសួរសិស្សថា តើវាមានន័យដូចម្តេចចំពោះពាក្យភាពភ្លៀវភ្លា ។ សូមសរសេរនៅលើក្តារខៀនក្រោមចម្លើយរបស់ពួកគេនូវពាក្យ ៖ *រឹងមាំ និង បំបែកមិនបាន នៅក្នុងស្ថានភាពល្អបំផុត ឬ មានសម្ភាធ* ។

ដើម្បីជួយសិស្សយល់ពីរបៀបដែលពាក្យ *ភាពភ្លៀវភ្លា* ទាក់ទងនឹងនីហ្វៃ សូមចាត់ឲ្យសិស្សអានជំពូកខាងក្រោម ម្នាក់មួយជំពូក ៖ នីហ្វៃទី១ ១៦, ១៧, ឬ ១៨ ។ ប្រសិនបើអ្នកមានសិស្សចំនួនច្រើន វាអាចជួយបានច្រើនដើម្បីដាក់សិស្សជាក្រុម និង ឲ្យពួកគេធ្វើការរួមគ្នាក្នុងមួយជំពូក ។

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ។ សូមលើកទឹកចិត្តសិស្សឲ្យប្រើជំពូកដែលបានដាក់ឲ្យពួកគេអាន និង សម្ភារសៀវភៅសិក្សារបស់សិស្សដែលទាក់ទងដើម្បីឆ្លើយនូវសំណួរទាំងនេះ ។

- *តើការសាកល្បងអ្វី ដែលនីហ្វៃបានជួបប្រទះនៅក្នុងជំពូកនេះ ដែលអ្នកបានរំឭកឡើងវិញ ?*

- *តើនីហ្វៃបានអនុវត្តសេចក្តីជំនឿនៅក្នុងកាល:ទេស:នោះបានយ៉ាងដូចម្តេច ? តើខគម្ពីរ ឬ ឃ្លាណាមួយ ដែលបង្ហាញភស្តុតាងថា សេចក្តីជំនឿរបស់នីហ្វៃមានភាពភ្លឺថ្លា ?*
- *តើគោលការណ៍ ដំណឹងល្អអ្វីខ្លះដែលត្រូវបានបង្ហាញនៅក្នុងជំពូកនេះ: ? តើបទពិសោធន៍អ្វីដែលអ្នកបានទទួលជាមួយនឹងគោលការណ៍ទាំងនេះ: ដែលបានបង្កើនទីបន្ទាល់របស់អ្នក ?*

សំផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់សិស្សដើម្បីបំពេញលំហាត់នេះ: ។ បន្ទាប់មក យ៉ាងហោចណាស់សុំសិស្សម្នាក់ ឲ្យអានជំពូកមួយម្នាក់ដើម្បីចែកចាយចម្លើយរបស់គាត់ ។ (ប្រសិនបើអ្នកមានសិស្សគ្រប់ អ្នកអាចមានសិស្សផ្សេងគ្នាដើម្បីចែកចាយចម្លើយចំពោះសំណួរមួយៗសម្រាប់ជំពូកនីមួយៗ) ។

សូមអញ្ជើញសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ័សុល អិម ណិលសុន នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ៖

« ហេតុអ្វីបានជាយើងត្រូវការសេចក្តីជំនឿដ៏ភ្លឺថ្លាបែបនោះ: ? ដោយសារថ្ងៃដ៏លំបាកនៅខាងមុខ ។ វាកម្រណាស់ដែលថ្ងៃអនាគតនឹងងាយស្រួល ឬ ល្អីល្អាញដើម្បីនៅជាពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏ស្មោះត្រង់នោះ: ។ យើងម្នាក់ៗ នឹងត្រូវបានសាកល្បង ។ . . . ការធ្វើទុក្ខបុកម្នេញ វាអាចបំបាក់អ្នកទៅក្នុងភាពខ្សោយដោយស្ងៀមស្ងាត់ ឬក៏អាចជម្រុញអ្នកឲ្យ ក្លាយជាគំរូ និង មានកម្លាំងនៅក្នុងជីវិតប្រចាំថ្ងៃរបស់អ្នក ។

« *របៀប*ដែលអ្នកដោះស្រាយឧបសគ្គនៅក្នុងជីវិត គឺជាផ្នែកនៃការអភិវឌ្ឍសេចក្តីជំនឿរបស់អ្នក ។ កម្លាំងទទួលបាន នៅពេលអ្នកចងចាំថា អ្នកមាននិស្ស័យនៃព្រះមួយ កើ្តមកតេកដ៏មានតម្លៃជាក់លាក់ » (« ប្រឈមមុខនឹងអនាគតដោយសេចក្តីជំនឿ » *Ensign* ឬ *លីអាហូណា* ខែឧសភា ឆ្នាំ ២០១១ ទំព័រ ៣៥–៣៦) ។

សូមអញ្ជើញសិស្សឲ្យចែកចាយគំនិតអំពីរបៀបដែលពួកគេអាចជួបនឹងឧបសគ្គនៃជីវិត និង ការសោកល្បងផ្ទាល់ខ្លួន ដូចជានីហ្វៃបានជួបដែរ ។

នីហ្វៃទី ១ ១៩

នីហ្វៃ កត់ត្រាការព្យាករណ៍អំពីព្រះយេស៊ូវគ្រីស្ទដើម្បីបញ្ចុះបញ្ចូលយើងឲ្យចងចាំដល់ទ្រង់

បើសិនជាមានពេល សុំសិស្សឲ្យរំឭកឡើងវិញពីអ្វីដែលពួកគេបានសរសេរនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរបស់ពួកគេសម្រាប់ថ្ងៃទី ៤ កិច្ចការទី ៥ ។ សូមសួរប្រសិនបើពួកគេមួយចំនួនមានឆន្ទៈចង់ចែកចាយអ្វីដែលពួកគេបានសរសេរអំពីសេចក្តីស្រឡាញ់របស់ពួកគេចំពោះព្រះអង្គសង្គ្រោះ: ។ បន្ទាប់មក សូមចែកចាយអារម្មណ៍របស់អ្នកអំពីព្រះអង្គសង្គ្រោះ: ។

នីហ្វៃស្រឡាញ់ព្រះអង្គសង្គ្រោះ: និង ចងចាំទ្រង់ពេលគាត់ជួបនឹងឧបសគ្គ ។ សូមថ្លែងទីបន្ទាល់ថា នៅពេលយើងស្រឡាញ់ និង ចងចាំព្រះអង្គសង្គ្រោះ: ទ្រង់នឹងជួយ និង គាំទ្រយើងនៅក្នុងឧបសគ្គរបស់យើង ។

ជំពូកបន្ទាប់ (នីហ្វៃទី១ ២០–នីហ្វៃទី២ ៣)

នៅក្នុងជំពូកបន្ទាប់ សិស្សនឹងសិក្សាពីពាក្យសម្តីចុងក្រោយខ្លះរបស់លីហៃទៅកាន់គ្រួសាររបស់គាត់ មុនពេលគាត់ស្លាប់ ។ ពួកគេក៏នឹងអានពីការព្យាករណ៍មួយពីបុរាណ ជាយូរពីមុនព្រះគ្រីស្ទអំពីព្យាការីយ៉ូសែប ស្ម៊ីធ ។

នីហ្វៃទី១ ២០–២២

សេចក្តីផ្តើម

នៅពេលនីហ្វៃបានបង្រៀនសមាជិកគ្រួសាររបស់គាត់ គាត់បានអានពីផ្នាំងលង្ហិន ដោយផ្តោតលើការព្យាករណ៍របស់អេសាយ អំពីការខ្ចាត់ខ្ចាយ និង ការប្រមូលនៃអ៊ីស្រាអែល ។ បន្ទាប់មក គាត់បានឆ្លើយតបនឹងសំណួរបងៗរបស់គាត់អំពីការព្យាករណ៍ទាំងនោះ ។ គាត់បានពន្យល់ថា ការព្យាករណ៍នេះបានអនុវត្តដោយចំៗចំពោះគ្រួសាររបស់ពួកគេ ។ ដោយប្រកាសពាក្យសម្តីរបស់អេសាយ នីហ្វៃបានថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់នឹងប្រមូលរាស្ត្រក្នុងសេចក្តីសញ្ញារបស់ទ្រង់មកវិញ—ថាទោះបីជាពេលរាស្ត្រនោះ មិនបានស៊ប់នៅតាមសេចក្តីសញ្ញារបស់ពួកគេក្តី ក៏ព្រះអម្ចាស់ស្រឡាញ់ពួកគេ និង អញ្ជើញពួកគេឲ្យប្រែចិត្ត និង ត្រឡប់មករកទ្រង់វិញ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ១ ២០

ព្រះអម្ចាស់ស្ដីបន្ទោសរាស្ត្ររបស់ទ្រង់ ហើយអញ្ជើញពួកគេឲ្យត្រឡប់មករកទ្រង់វិញ

សូមបង្ហាញសិស្សនូវរូបភាពអេសាយសរសេរអំពីការប្រសូតរបស់ព្រះគ្រីស្ទ (៦២៣៣៩ ; *សៀវភៅរូបភាពដំណឹងល្អ* ព.ស.២០០៩ ទំព័រ ២២) ។ សូមពន្យល់ថា គំនូរនេះពិពណ៌នាពីព្យាការីអេសាយ ដែលកំពុងសរសេរការព្យាករណ៍មួយអំពីការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមសួរពួកគេថា តើពួកគេប៉ុន្មាននាក់ដែលបានឮអំពីអេសាយ ។

សូមពន្យល់ថា អេសាយគឺជាព្យាការីម្នាក់ដែលបានរស់នៅក្នុងទីក្រុងយេរូសាឡិម និង បានព្យាករណ៍ទៅកាន់ប្រជាជនក្នុងរវាង ៧៤០ ឆ្នាំ ម. គ. ស. និង ៧០១ ឆ្នាំ ម. គ. ស. មិនយូរប៉ុន្មានមុនពេលលីហៃ និង គ្រួសាររបស់គាត់បានចាកចេញទៅកាន់ដែនដីសន្យារបស់ពួកគេ ។ នីហ្វៃបានសប្បាយរីករាយនៅក្នុងពាក្យរបស់អេសាយ និង បានប្រើការព្យាករណ៍របស់អេសាយដើម្បីបង្រៀនដល់គ្រួសាររបស់គាត់ (សូមមើល នីហ្វៃទី១ ១៩:២៣; នីហ្វៃទី២ ២៥:៥) ។ ដោយសារពាក្យសម្តីរបស់អេសាយ ជាកំណាព្យ និង ពោរពេញដោយនិមិត្តសញ្ញា ពេលខ្លះមនុស្សពិបាកយល់ក្នុងការបង្រៀនរបស់គេ ។ ទោះយ៉ាងណាក្តី យើងអាចទទួលបាននូវពរជ័យទាំងឡាយនៅពេលយើងសិក្សាពាក្យសម្តីរបស់គាត់ និង ព្យាយាមយល់ពីវា ។

សូមពន្យល់ថា នៅពេលនីហ្វៃបានបង្រៀនគ្រួសាររបស់គាត់ គាត់បានអានពាក្យសម្តីខ្លះរបស់អេសាយដែលបានបញ្ចូលនៅក្នុងផ្នាំងលង្ហិន ។ គាត់ធ្វើដូច្នេះ ដើម្បីគាត់ « អាចបញ្ចុះបញ្ចូលពួកគេឲ្យបានច្រើនថែមទៀត ឲ្យជឿដល់ព្រះអម្ចាស់ជាព្រះដ៏ប្រោសលោះរបស់ពួកគេ » (នីហ្វៃទី១ ១៩:២៣;សូមមើលផងដែរ ខគម្ពីរ ២៤) ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ២០:១–២ ឮៗ ។ មុនពួកគេអាន សូមពន្យល់ថា នៅក្នុងវគ្គនេះ អេសាយនិយាយទៅកាន់បុគ្គលដែលបានជ្រមុជទឹកដែលមិនបានស្មោះត្រង់ចំពោះសេចក្តីសញ្ញារបស់ពួកគេ ។ អ្នកអាចពន្យល់ឃ្លា « វង្សអ៊ីស្រាអែល » ដោយភ្ជាប់ឃ្លាខាងក្រោម ៖ ព្រះគម្ពីរសញ្ញាចាស់ រួមមានប្រវត្តិរបស់យ៉ាកុប ដែលជាកូនប្រុសរបស់អ៊ីសាក និង ជាចៅប្រុសរបស់អ័ប្រាហាំ ។ ព្រះអម្ចាស់បានឲ្យឈ្មោះយ៉ាកុបថាជា អ៊ីស្រាអែល (សូមមើល លោកុប្បត្តិ ៣២:២៨) ។ ពាក្យ « វង្សអ៊ីស្រាអែល » សំដៅលើកូនចៅរបស់យ៉ាកុប និង លើរាស្ត្រនៃសេចក្តីសញ្ញារបស់ព្រះអម្ចាស់ (សូមមើលវចនានុក្រមព្រះគម្ពីរបរិសុទ្ធ « អ៊ីស្រាអែល » និង « អ៊ីស្រាអែលនគរនៃ ») ។

សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ២០:៣–៤, ៨ដោយស្ងាត់ស្ងៀម ។ សុំឲ្យពួកគេស្វែងរកពាក្យ និង ឃ្លាដែលបង្ហាញថា វង្សនៃអ៊ីស្រាអែលមិនមានភាពស្មោះត្រង់ចំពោះព្រះអម្ចាស់នោះទេ ។ សូមលើកទឹកចិត្តសិស្សឲ្យចែកចាយនូវអ្វីដែលពួកគេរកឃើញ ។

សូមបង្ហាញដៃកមួយ ដែលពិបាកពត់ ។ សូមសួរសិស្សថាតើពួកគេគិតថាវាមានន័យដូចម្តេចចំពោះពាក្យថា ករបស់នរណាម្នាក់ « រឹងដូចជាច៏រឹងដែក » (នីហ្វៃទី១ ២០:៤) ។ សូមពន្យល់ថា ច៏រឹងមួយគឺជាសរសៃពួរមួយ ។ ដែកដែលមិនងាយពត់ គឺដូចជាមនុស្សដែលមានអំនួត នឹងមិនឱនក្បាលរបស់ពួកគេចុះដោយការបន្ទាបខ្លួននោះទេ ។ ឃ្លា « ច៏រឹងដែក » បង្ហាញថា មនុស្សជាច្រើននៅក្នុងវង្សអ៊ីស្រាអែល ពោរពេញដោយអំនួត ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ២០:២២ ឮៗ ។

- ហេតុអ្វីបានជាអ្នកគិតថា ពួកទុច្ចរិតគ្មានសេចក្តីសុខសាន្ត ?

សូមរំឭកសិស្សថា នៅពេលនីហ្វៃបានចែកចាយការព្យាករណ៍របស់អេសាយ គាត់បានជម្រុញឲ្យបងប្អូនប្រុសរបស់គាត់ « ប្រៀបធៀបពាក្យព្យាករណ៍ទាំងនោះទៅនឹងខ្លួនអ្នក » (នីហ្វៃទី១ ១៩:២៤) ។

- តើសមាជិកខ្លះរបស់គ្រួសារនីហ្វៃស្រដៀងគ្នាទៅនឹងប្រជាជនដែលអេសាយបានហៅឲ្យប្រែចិត្តដោយរបៀបណា ?

សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី១ ២០:១៤, ១៦, ២០ឮៗ ។

- តើព្រះអម្ចាស់ចង់ឲ្យរាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់ធ្វើ និង និយាយអ្វី ? (អ្នកអាចត្រូវពន្យល់ថា ការចាកចេញពីទីក្រុងបាប៊ីឡូន និង ស្រុករបស់ពួកខាល់ដេ គឺជានិមិត្តសញ្ញានៃការចាកចេញពីលោកិយភាព និង ការមកដល់ព្រះអម្ចាស់) ។

សូមអញ្ជើញសិស្សឲ្យចែកចាយនូវឧទាហរណ៍ដែលពួកគេបានឃើញពីមនុស្សដែលបានចូលមកព្រះអម្ចាស់ ហើយបានចាកចេញពីលោកិយភាព ។ សុំឲ្យសិស្សរក នីហ្វៃទី១ ២០:១៨ ដោយស្វែងរកពរជ័យដែលព្រះអម្ចាស់បានផ្តល់ទៅឲ្យអ្នកដែលចូលមកកាន់ទ្រង់ និង ស្តាប់តាមព្រះបញ្ញត្តិរបស់ទ្រង់ ។

- តើសេចក្តីសុខសាន្តអាចដូចជាទន្លេមួយដោយរបៀបណា ? តើភាពសុចរិតអាចដូចជាទឹករលកសមុទ្រយ៉ាងដូចម្តេច ?

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យសង្ខេបសេចក្តីពិត ដែលពួកគេបានរៀនពីនីហ្វៃទី១ ២០ ។ ទោះបីជាពួកគេអាចប្រើពាក្យខុសគ្នាក្តី សូមសូមធ្វើយ៉ាងណាជួយ ពួកគេឲ្យយល់ថា **ព្រះអម្ចាស់អញ្ជើញអ្នកដែលមិនគោរពប្រតិបត្តិឲ្យធ្វើការប្រែចិត្ត និង ត្រឡប់ទៅរកទ្រង់វិញ ។**

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរ អេស អុជដូហ្វ នៃគណៈប្រធានទីមួ ។ សូមអញ្ជើញសិស្សគិតអំពីរបៀបដែលវាទាក់ទងនឹងនីហ្វៃទី១ ២០ ។

« សាតាំង . . . ចង់ឲ្យយើងមានអារម្មណ៍ថា យើងទទួលបានហូសពីការអភ័យទោសទៅទៀត (សូមមើល វិវរណៈ ១២:១០) ។ សាតាំងចង់ឲ្យយើងគិតថា នៅពេលយើងមានបាន យើងបានកន្លងហូស ‹ ចំណុចមួយដែលមិនអាចត្រឡប់ទៅក្រោយបាន › —ថាវាយឺតពេលណាស់ក្នុងការផ្លាស់ប្តូរផ្លូវរបស់យើង ។ . . .

« . . . ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ គឺជាអំណោយមួយមកពីព្រះទៅកាន់កូនចៅរបស់ទ្រង់ឲ្យកែតម្រូវ និង យកឈ្នះលើលទ្ធផលនៃអំពើបាប ។ ព្រះទ្រង់ស្រឡាញ់កូនចៅរបស់ទ្រង់ទាំងអស់ ហើយទ្រង់នឹងមិនដែលឈប់ស្រឡាញ់ និង មានក្តីសង្ឃឹមលើពួកយើងឡើយ ។ . . .

« ព្រះគ្រីស្ទ បានមកសង្គ្រោះយើង ។ ប្រសិនបើយើងបានរើសយកផ្លូវខុសមួយ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទអាចធានាឲ្យយើងថា អំពើបាបគឺ*មិនមែន*ជាចំណុចមួយដែលមិនអាចត្រឡប់ទៅក្រោយវិញបាននោះទេ ។ ការត្រឡប់ទៅវិញដោយសុវត្ថិភាព គឺអាច ប្រសិនបើយើងនឹងធ្វើតាមផែនការរបស់ព្រះសម្រាប់សេចក្តីសង្គ្រោះរបស់យើង ។ . . .

« . . . *វាតែងតែ*មានចំណុចមួយដែលអាចត្រឡប់ទៅក្រោយវិញដោយសុវត្ថិភាព វាតែងតែមានសេចក្តីសង្ឃឹមជានិច្ច » (« ចំណុចមួយដែលអាចត្រឡប់ទៅក្រោយវិញដោយសុវត្ថិភាព »*Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ៩៩,១០១) ។

- តើសារលិខិតរបស់ប្រធាន អុជដូហ្វ ស្រដៀងទៅនឹងសារលិខិតរបស់អេសាយយ៉ាងដូចម្តេច ?

សូមថ្លែងទីបន្ទាល់ថា **ព្រះអម្ចាស់អញ្ជើញអ្នកដែលមិនគោរពប្រតិបត្តិឲ្យធ្វើការប្រែចិត្ត និង ត្រឡប់មករកទ្រង់វិញ ។**សូមធានាសិស្សថា ព្រះអម្ចាស់ស្រឡាញ់យើងម្នាក់ៗ និង តែងតែអញ្ជើញយើងឲ្យចូលមករកទ្រង់ ។ សូមអញ្ជើញពួកគេឲ្យគិតអំពីអ្វីដែលព្រះអម្ចាស់នឹងអញ្ជើញពួកគេឲ្យចាកចេញមក ដើម្បីពួកគេអាចចូលមករកទ្រង់បានកាន់តែពេញលេញ ។

នីហ្វៃទី១ ២១:១–១៧

អេសាយព្យាករណ៍ថា ព្រះយេស៊ូវគ្រីស្ទនឹងមិនអភ័យទោស ដល់វាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់នោះទេ ។

សូមសង្ខេបដោយខ្លី នីហ្វៃទី១ ២១:១–១៣ដោយការទាក់ទាញចំណាប់អារម្មណ៍របស់សិស្សទៅកាន់សេចក្តីថ្លែងការណ៍ពីរដំបូងនៅក្នុងការសង្ខេបជំពូក ៖ « ព្រះមែស៊ី នឹងជាពន្លឺមួយទៅកាន់សាសន៍ដទៃ ហើយទ្រង់នឹងរំដោះអ្នកជាប់ឃុំឃាំង » និង « អ៊ីស្រាអែលនឹងត្រូវបានប្រមូលផ្តុំដោយព្រះចេស្តានៅក្នុងថ្ងៃចុងក្រោយ » ។ សូមពន្យល់ថា នៅក្នុងខគម្ពីរ ១–១៣ ព្រះបន្ទូលនៃព្រះអម្ចាស់បង្ហាញពីសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះប្រជារាស្ត្ររបស់ទ្រង់ —ទាំងចំពោះអ្នកដែលបានក្បត់ និង បំភ្លេចទ្រង់ក្តី ។

នៅលើក្តារខៀន សូមសរសេរ***ព្រះអម្ចាស់ស្រឡាញ់យើង ហើយទ្រង់នឹងមិនដែលបំភ្លេចយើងនោះទេ ។***សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ២១:១៤ ឮៗ ។

- ហេតុអ្វីបានជាអ្នកគិតថា ពេលខ្លះមនុស្សមានអារម្មណ៍ថា ព្រះអម្ចាស់បានបំភ្លេចពួកគេចោល ?

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី១ ២១:១៥ –១៦ ឮៗ ។ បន្ទាប់មកសូមសួរសំណួរខាងក្រោមខ្លះ ឬ ទាំងអស់ ៖

- តើអេសាយបានបង្រៀនអ្វីខ្លះ ដោយការប្រៀបធៀបព្រះអង្គសង្គ្រោះទៅនឹងអ្នកម្តាយនៃទារកម្នាក់ ?
- តើពាក្យ *ភ្លាក់* បង្កប់ន័យអ្វី ? (អ្នកអាចបង្ហាញថា ជាធម្មតា យើងគិតថាការភ្លាក់លើថ្ម ឬ លោហៈធាតុតាមរបៀបមួយដែលនឹងជាប់បានយូរ) ។
- តើវាន័យដូចម្តេចចំពោះអ្នកដើម្បីភ្លាក់ « លើបាតព្រះហស្តរបស់ [ព្រះអង្គសង្គ្រោះ] » ?
- តើបទពិសោធន៍អ្វីដែលបានជួយអ្នកឲ្យដឹងថា ព្រះអម្ចាស់មិនបានបំភ្លេចអ្នកនោះទេ ?

នៅពេលសិស្សគិតអំពីសំណួរទាំងនេះ និង ស្តាប់ចម្លើយរបស់គ្នាទៅវិញទៅមក ពួកគេនឹងរៀបចំដើម្បីទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ ដែលថ្លែងទីបន្ទាល់អំពីព្រះអង្គសង្គ្រោះ ។ សូមចែកចាយនូវទីបន្ទាល់របស់អ្នកអំពីសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ។ សូមរំឭកសិស្សថា នីហ្វៃបានចែកចាយការព្យាករណ៍របស់អេសាយដើម្បីបញ្ចុះបញ្ចូលយើងឲ្យជឿលើព្រះអង្គប្រោសលោះ និង ដើម្បីជួយយើងឲ្យមានសេចក្តីសង្ឃឹម ។

> ***សូមឲ្យពេលវេលាដល់សិស្សគិត ។***
>
> នៅពេលអ្នកសួរសំណួរ សូមផ្តល់ពេលដល់សិស្សគិតអំពីចម្លើយរបស់ពួកគេ ។ សំណួរដែលមានប្រសិទ្ធភាពជាញឹកញាប់នាំទៅរកគំនិត និង ការពិចារណា ហើយសិស្សអាចត្រូវការពេលវេលា ដើម្បីរកចម្លើយនៅក្នុងព្រះគម្ពីរបស់ពួកគេ ឬ ដើម្បីគិតពីចម្លើយដ៏មានន័យ ។ ទោះបីជាចម្លើយរបស់សិស្សមិនឥតខ្ចោះក្តី ក៏សិស្សនឹងរៀនពីមេរៀនដ៏សំខាន់នៅពេលពួកគេគិតអំពីសេចក្តីពិតនៃដំណឹងល្អ និង ចែកចាយពីគំនិតរបស់ពួកគេ ។

នីហ្វៃទី១ ២១:១៨–២៦; ២២:១–២២

នីហ្វៃពន្យល់ពីការព្យាករណ៍របស់អេសាយនៃការខ្ចាត់ខ្ចាយ និង ការប្រមូលផ្តុំនៃអ៊ីស្រាអែល

ដាក់របស់បីបួន (ដូចជាពែង) រួមគ្នានៅលើតុ ឬ កៅអីមួយ ។ សូមប្រាប់សិស្សថា វត្ថុទាំងនេះតំណាងឲ្យក្រុមមនុស្ស ។ សូមពន្យល់ថា នីហ្វៃបានបង្រៀនថា អ៊ីស្រាអែលនឹងត្រូវបានខ្ចាត់ខ្ចាយទៅគ្រប់សាសន៍ទាំងអស់ ដោយសារពួកគេមានចិត្តរឹងរូសទាស់នឹងព្រះអង្គ

សង្គ្រោះ (សូមមើល នីហ្វៃទី១ ២២:១–៥) ។ នៅពេលអ្នកនិយាយ សូមផ្លាស់ប្តូរវត្ថុទាំងនោះទៅកាន់កន្លែងផ្សេងគ្នានៃបន្ទប់អ្នក ។ សូមពន្យល់ថា នេះជាប្រធានបទដ៏សំខាន់មួយចំពោះនីហ្វៃ ។ គ្រួសាររបស់គាត់ គឺជាផ្នែកមួយនៃការខ្ចាត់ខ្ចាយនោះ ។ ពួកគេត្រូវបានខ្ចាត់ខ្ចាយចេញពីទីក្រុងយេរូសាឡិម ផ្ទះរបស់ពួកគេ ដោយសារតែភាពទុច្ចរិតនៃប្រជាជនដែលរស់នៅក្នុងដែនដីនោះ ។

សូមអញ្ជើញសិស្សអាន នីហ្វៃទី១ ២១:២២–២៣ និង ២២:៦–៨ ដោយស្ងាត់ស្ងៀម ។ មុនពេលពួកគេអាន សូមពន្យល់ថា នីហ្វៃទី១ ២១ រួមបញ្ចូលការព្យាករណ៍មួយដោយអេសាយអំពីការប្រមូលផ្តុំនៃអ៊ីស្រាអែល និង ថានីហ្វៃទី១ ២២ រួមបញ្ចូលនូវការបង្រៀនរបស់នីហ្វៃអំពីការព្យាករណ៍របស់អេសាយ ។

- តើ « កិច្ចការដ៏អស្ចារ្យមួយ » ជាអ្វីដែលបានលើកឡើងនៅក្នុង នីហ្វៃទី១ ២២:៧–៨? (ការស្តារឡើងវិញនៃដំណឹងល្អ) ។
- តើការចែកចាយដំណឹងល្អអាចដូចជាការនាំអ្នកដទៃមកក្នុងរង្វង់ដៃយើង ឬ នៅលើស្មារបស់យើងយ៉ាងដូចម្តេច ?

ដើម្បីជួយសិស្សយល់ថា ការខ្ចាត់ខ្ចាយ និង ការប្រមូលផ្តុំនៃអ៊ីស្រាអែល អ្នកអាចអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ប្រ៊ីស អ័រ ម៉ាក់ខន់ឃី នៃក្លឹមនៃពួកសាវកដប់ពីរនាក់ ៖

« ហេតុអ្វីបានជាវង្សអ៊ីស្រាអែលត្រូវខ្ចាត់ខ្ចាយ ? ចម្លើយគឺច្បាស់ វាសាមញ្ញ ចេញពីវា នោះគ្មានការសង្ស័យអ្វីនោះទេ ។ ជីដូនជីតានៃសាសន៍អ៊ីស្រាអែលរបស់យើង ត្រូវបានខ្ចាត់ខ្ចាយ ដោយសារពួកគាត់បដិសេធដំណឹងល្អ ធ្វើឲ្យបព្វជិតភាពមិនបរិសុទ្ធ លះបង់ចេញពីសាសនាចក្រ និង ចាកចេញពីនគរ ។ . . .

« បន្ទាប់មក តើអ្វីដែលទាក់ទងនឹងការប្រមូលផ្តុំនៃអ៊ីស្រាអែល ? ការប្រមូលផ្តុំនៃអ៊ីស្រាអែល មាននៅក្នុងការជឿ និង ការទទួលយក និង ការរស់នៅដោយសុភមង្គលជាមួយគ្នាទាំងអស់ ដែលព្រះអម្ចាស់ធ្លាប់បានផ្តល់ឲ្យប្រជារាស្ត្រជម្រើសពីបុរាណរបស់ទ្រង់ ។ . . . វារួមមានការជឿតាមដំណឹងល្អ ការចូលរួមក្នុងសាសនាចក្រ និង ការមកក្នុងនគរ ។ . . . វាក៏អាចមានការប្រជុំនៅកន្លែងជ្រើសរើសមួយ ឬ ដែនដីនៃការថ្វាយបង្គំ » (*សាក្សីថ្មីមួយចំពោះមាគ៌ានៃសេចក្តីជំនឿ* [១៩៨៥] ទំព័រ ៥១៥) ។

សូមអាន នីហ្វៃទី១ ២២:៩–១២ ។ សូមពន្យល់ថា នៅពេលព្រះគម្ពីរលើកឡើងអំពីព្រះអម្ចាស់ « ព្រះហស្តរបស់ទ្រង់ » នោះវាសំដៅលើពេលព្រះអម្ចាស់ដែលបង្ហាញព្រះចេស្តារបស់ទ្រង់ ។

- នៅក្នុងនីហ្វៃទី១ ២២:១១ តើអ្វីដែលនីហ្វៃបាននិយាយថា ព្រះអម្ចាស់នឹងធ្វើនៅថ្ងៃចុងក្រោយដើម្បីបង្ហាញព្រះចេស្តារបស់ទ្រង់ ?
- តើការប្រមូលផ្តុំប្រជារាស្ត្រនៅក្នុងសាសនាចក្រនាំពួកគេចេញពីសេវកភាព និង ភាពងងឹតដោយរបៀបណា ?

សុំឲ្យសិស្សនាំយកវត្ថុទាំងអស់មកពីជុំវិញបន្ទប់ ហើយដាក់វាចូលគ្នានៅកន្លែងមួយ ។ សូមពន្យល់ថា ការប្រមូលផ្តុំអាចជាខាងវិញ្ញាណ និង ខាងសាច់ឈាម ។ នៅពេលយើងចែកចាយដំណឹងល្អជាមួយនឹងអ្នកដទៃ ហើយពួកគេត្រូវបានជ្រមុជទឹក និង ទទួលបាននូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ នោះពួកគេត្រូវបានប្រមូលខាងវិញ្ញាណមកក្នុងសាសនាចក្រនៃព្រះអម្ចាស់វិញ ។ សាសនាចក្រកាលពីដើមឡើយ អ្នកប្រែចិត្តថ្មីត្រូវបានសុំឲ្យរួបរួមគ្នាខាងសាច់ឈាមនៅកន្លែងមួយ (ឧទាហរណ៍ ក្រុងយើតឡង់ រដ្ឋអូហៃអូ រដ្ឋណៅវូ រដ្ឋអិលលីណោយ និង ទីក្រុងសលត៍ លេក រដ្ឋយូថាហ៍) ។ អ្នកប្រែចិត្តបច្ចុប្បន្ន ត្រូវបានលើកទឹកចិត្តឲ្យសាងសាសនាចក្រ នៅកន្លែងណាដែលពួកគេនៅ និង រួមគ្នានៅក្នុងសាខា វួដ និង ស្តេកក្នុងស្រុករបស់ពួកគេ ។

- យោងតាមនីហ្វៃទី១ ២២:២៥ តើពរជ័យអ្វីដែលមកដល់អ្នកដែលត្រូវបានប្រមូលផ្តុំដោយព្រះអម្ចាស់ ? តើអ្នកគិតថា « ដើម្បីក្លាយជាហ្វូងតែមួយ » មាននិយមដូចម្តេច ? (អ្នកអាចពន្យល់ថា ហ្វូងតែមួយ គឺជាកន្លែងមួយដែលហ្វូងចៀមមួយត្រូវបានការពារ) តើអ្នកគិតថា « ដើម្បីរកឃើញវាលស្មៅ » មាននិយមដូចម្តេច ?

នៅក្នុងជំនាន់របស់យើង ព្រះសុំឲ្យសមាជិកនៃសាសនាចក្រទាំងអស់ជួយគ្នាក្នុងការប្រមូលផ្តុំ « កូនចៅរបស់ទ្រង់មកពីទិសទាំងបួននៃផែនដី » (នីហ្វៃទី១ ២២:២៥) ។ សូមថ្លែងទីបន្ទាល់ថា **ព្រះអម្ចាស់សន្យាថានឹងស្តារឡើងវិញនូវដំណឹងល្អ និង ប្រមូលផ្តុំអ៊ីស្រាអែលនៅក្នុងថ្ងៃចុងក្រោយ ។**

- តើអ្នកគិតថាអ្នកដែលត្រូវបានប្រមូលផ្តុំ (អ្នកប្រែចិត្ត) នឹងមានអារម្មណ៍យ៉ាងណា អំពីអ្នកដែលបានប្រមូលផ្តុំពួកគេ (អ្នកដែលបានចែកចាយដំណឹងល្អជាមួយនឹងពួកគេ) ?
- តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីចែកចាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទជាមួយនឹងអ្នកដទៃ ?

សូមរំឭកសិស្សថា នីហ្វៃបានដកស្រង់សម្តីអេសាយដើម្បីជួយសមាជិកគ្រួសាររបស់គាត់មានសេចក្តីជំនឿ និង សេចក្តីសង្ឃឹមខ្លាំងជាងមុនទៅលើព្រះយេស៊ូវគ្រីស្ទ ។ ការព្យាករណ៍របស់អេសាយ និង ទីបន្ទាល់របស់នីហ្វៃអាចជួយយើងតាមរបៀបដូចគ្នា ។ សូមថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់នឹងមិនបំភ្លេចយើងឡើយ ហើយថាទ្រង់ព្យាយាមយ៉ាងសកម្មក្នុងការប្រមូលផ្តុំយើង ។

ការថ្លែងទីបន្ទាល់

អ្នកគួរតែថ្លែងទីបន្ទាល់អំពីគោលលទ្ធិជាក់លាក់ដែលអ្នកបង្រៀននៅក្នុងមេរៀននីមួយៗ មិនមែនគ្រាន់តែពីសេចក្តីពិតនៃដំណឹងល្អទូទៅនោះទេ ។ នៅពេលអ្នកថ្លែងទីបន្ទាល់ សូមចាំការប្រឹក្សានេះមកពីអែលឌើរ ជែហ្វ្រី អ័រ ហុឡិន នៃក្លឹមនៃពួកសាវកដប់ពីរនាក់ ៖ « សូមថ្លែងទីបន្ទាល់របស់អ្នកមកពីជម្រៅនៃដួងចិត្តរបស់អ្នក ។ វានឹងជារឿងដែលសំខាន់បំផុតដែលអ្នកនិយាយទៅកាន់ពួកគេពេញមួយម៉ោងពេញ ។ . . . ប្រសិនបើយើងថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលយើងបានបង្រៀន ព្រះនឹងបញ្ជាក់ដល់ដួងចិត្តយើង និង ដល់ដួងចិត្តនៃសិស្សរបស់យើងនូវសារលិខិតនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ » (« ការបង្រៀន និង ការរៀននៅក្នុងសាសនាចក្រ »*Ensign* ខែ មិថុនា ឆ្នាំ ២០០៧ ទំព័រ ១០៤–៥) ។

ការរំឭកឡើងវិញនៅក្នុងនីហ្វៃទី១

សូមយកពេលខ្លះរំឭកនីហ្វៃទី១ ឡើងវិញដោយការសុំឲ្យសិស្សរំឭកពីអ្វីដែលពួកគេបានរៀននៅក្នុងថ្នាក់សិក្ខាសាលា និង ការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេក្នុងឆ្នាំនេះ ។ អ្នកអាចលើកទឹកចិត្តពួកគេឲ្យរំឭកឡើងវិញពីការសង្កេតជំពូកនៅក្នុងនីហ្វៃទី១ ។ សុំឲ្យពួកគេរៀបចំចែកចាយអ្វីមួយពីសៀវភៅនីហ្វៃទី១ ដែលបានបំផុសពួកគេ ឬ ពង្រឹងសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបីបួននាក់ចែកចាយគំនិត និង អារម្មណ៍របស់ពួកគេ ។ សូមគិតពីការចែកចាយបទពិសោធន៍ផ្ទាល់របស់អ្នក អំពីរបៀបដែលការបង្រៀននៅក្នុងនីហ្វៃទី១ បានប្រទានពរដល់ជីវិតរបស់អ្នក ។

សេចក្តីផ្តើមអំពី

នីហ្វៃទីពីរ

ហេតុអ្វីសិក្សាសៀវភៅនេះ ?

សៀវភៅនីហ្វៃទី ២ នឹងជួយសិស្សយល់ពីគោលលទ្ធិនៃជំនឿដ៏ល្អជាមូលដ្ឋាន ដូចជាការធ្លាក់របស់លោកអ័ដាម ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និង សិទ្ធិជ្រើសរើស ។ បន្ថែមលើនេះ សៀវភៅនេះត្រូវបានបំពេញដោយការព្យាករណ៍មកពីនីហ្វៃ យ៉ាកុប និង អេសាយ ដែលជាសាក្សីពិសេសអំពីព្រះអង្គសង្គ្រោះ ។ ពួកគាត់បានព្យាករណ៍អំពីការស្តារឡើងវិញនៃជំនឿដ៏ល្អនៅថ្ងៃចុងក្រោយ ការខ្ចាត់ខ្ចាយ និង ការប្រមូលផ្តុំនៃស្រ្តេក្នុងសេចក្តីសញ្ញារបស់ព្រះ: ការយាងមកលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ការចេញមកនៃព្រះគម្ពីរមរមន និង សហស្សវត្សរ៍ ។ សៀវភៅនីហ្វៃទី ២ នេះក៏រួមមានការពន្យល់របស់នីហ្វៃអំពីគោលលទ្ធិរបស់ព្រះគ្រីស្ទ និង បញ្ចប់ដោយទីបន្ទាល់របស់នីហ្វៃអំពីព្រះអង្គសង្គ្រោះ ។

តើនរណាជាអ្នកសរសេរសៀវភៅនេះ ?

កូនប្រុសរបស់លីហៃ គឺនីហ្វៃ បានសរសេរសៀវភៅនេះ ។ នីហ្វៃគឺជាព្យាការីម្នាក់ និង ជាអ្នកដឹកនាំដ៏អស្ចារ្យទីមួយរបស់ប្រជាជននីហ្វៃ ក្រោយពីការបែកគ្នាពីសាសន៍លេមិនមក ។ ការសរសេរបស់គាត់បង្ហាញថា គាត់បានជួបនឹងព្រះចស្តាប្រោសលោះរបស់ព្រះអម្ចាស់ (សូមមើល នីហ្វៃទី ២ ៤:១៥–៣៥; ៣៣:៦)និង បានមានបំណងដោយអស់ពីដួងចិត្តរបស់គាត់ដើម្បីនាំមកនូវសេចក្តីសង្គ្រោះទៅកាន់ប្រជាជនរបស់គាត់ (សូមមើល នីហ្វៃទី ២ ៣៣:៣–៤) ។ ដើម្បីសម្រេចគោលបំណងនេះ គាត់បានបង្រៀនប្រជាជនរបស់គាត់ឲ្យជឿលើព្រះយេស៊ូវគ្រីស្ទ និង បានស្តាបនាព្រះវិហារបរិសុទ្ធមួយឡើង ។

តើសៀវភៅនេះត្រូវបានសរសេរទៅឲ្យនរណា ? ហេតុអ្វី ?

នីហ្វៃបានសរសេរដោយគិតអំពីក្រុមអ្នកអានបីក្រុមនៅក្នុងគំនិតរបស់គាត់ ៖ កូនចៅរបស់ឪពុកគាត់ រាស្ត្រក្នុងសេចក្តីសញ្ញារបស់ព្រះអម្ចាស់នៅក្នុងថ្ងៃចុងក្រោយ និង ប្រជាជនទាំងអស់នៅក្នុងពិភពលោកនេះ: (សូមមើល នីហ្វៃទី ២ ៣៣:៣, ១៣) ។ សៀវភៅនីហ្វៃទី ២ នេះ ត្រូវបានសរសេរនៅលើផ្នាំងតូចនៃនីហ្វៃ ដែលបានកំណត់ទុកដោយព្រះអម្ចាស់ឲ្យក្លាយជាកំណត់ត្រាមួយនៃ « ការបម្រើ និង ការព្យាករណ៍ » របស់នីហ្វៃ និង កូនចៅរបស់គាត់ (នីហ្វៃទី ១ ១៩:៣–៥) ។ នៅលើផ្នាំងទាំងនេះ នីហ្វៃបានសរសេរអំពី « រឿងទាំងឡាយនៃព្រលឹង [របស់គាត់] និង បទគម្ពីរភាគច្រើនដែលមានឆ្លាក់នៅលើផ្នាំងលង្ហិន ។ » គាត់បានពន្យល់ថា គាត់បានសរសេរ « ដើម្បីជាការចេះដឹង និង ជាប្រយោជន៍ដល់កូនចៅខ្ញុំ » (នីហ្វៃទី ២ ៤:១៥) ។ គាត់បានប្រកាសថា « យើងនិយាយអំពីព្រះគ្រីស្ទ យើងអរសប្បាយក្នុងព្រះគ្រីស្ទ យើងផ្សាយអំពីព្រះគ្រីស្ទ យើងព្យាករអំពីព្រះគ្រីស្ទ ហើយយើងសរសេរស្របតាមពាក្យព្យាករណ៍ទាំងឡាយរបស់យើង ដើម្បីឲ្យកូនចៅយើងអាចដឹងថា តើត្រូវស្វែងរកប្រភពណាមួយដើម្បីឲ្យបានផ្តាច់បាបរបស់ពួកគេ » (នីហ្វៃទី ២ ២៥:២៦) ។ គាត់បានបញ្ចប់កំណត់ត្រារបស់គាត់ ដោយការអញ្ជើញមនុស្សទាំងអស់ឲ្យ « ប្រុងស្តាប់តាមពាក្យ [របស់គាត់] ទាំងនេះចុះ ហើយជឿដល់ព្រះគ្រីស្ទចុះ » (នីហ្វៃទី ២ ៣៣:១០) ។

តើនៅពេលណា និង នៅកន្លែងណាដែលវាត្រូវបានសរសេរ ?

នីហ្វៃបានចាប់ផ្តើមការសរសេរដំណើររឿងដែលក្លាយជានីហ្វៃទី ២ នៅប្រហែលជា ៥៧០ ឆ្នាំមុនគ្រិស្តសករាជ គឺ ៣០ ឆ្នាំក្រោយពីគាត់ និង គ្រួសាររបស់គាត់បានចាកចេញពីទីក្រុងយេរូសាឡិម ។ គាត់បានសរសេរវា នៅពេលគាត់នៅក្នុងដែនដីនីហ្វៃ (សូមមើល នីហ្វៃទី ២ ៥:៨, ២៨–៣៤) ។

តើលក្ខណៈខុសផ្លែកអ្វីខ្លះនៃសៀវភៅនេះ ?

ទោះបីជានីហ្វៃគឺជាអ្នកសរសេរនីហ្វៃទី ២ ក្តី ក៏សៀវភៅនេះគឺជាការចងក្រងការបង្រៀនមួយមកពីប្រភពផ្សេង។ៗគ្នាដែរ ។ ដូចដែលបានបង្ហាញនៅក្នុងបញ្ជីខាងក្រោម ជំពូកជាច្រើននៅក្នុងសៀវភៅនេះរួមបញ្ចូលការដកស្រង់ពាក្យសម្តីមកពីព្យាការីជាច្រើននាក់ផ្សេងទៀត ។ ដោយសារលីហៃ យ៉ាកុប និង អេសាយបានឃើញព្រះយេស៊ូវគ្រីស្ទ ហើយបានធ្វើជាសាក្សីដល់ទ្រង់ នោះនីហ្វៃបានបញ្ចូលការបង្រៀនខ្លះរបស់ពួកគាត់នៅក្នុងការខិតខំមួយដើម្បីបញ្ចុះបញ្ចូលអ្នកអានឲ្យជឿដល់ព្រះយេស៊ូវគ្រីស្ទ ។ លីហៃ និង យ៉ាកុបក៏បានដកស្រង់ពាក្យសម្តីព្យាការីផ្សេងទៀតនៅក្នុងការបង្រៀនរបស់ពួកគេទៀតផងដែរ ។

- ការបង្រៀនរបស់លីហៃ ត្រូវបានកត់ត្រានៅក្នុង នីហ្វៃទី ២ ១–៤ ។ នៅក្នុងនីហ្វៃទី ២ ៣:៦–២១ លីហៃបានដកស្រង់ពាក្យសម្តីរបស់យ៉ូសែបនៃស្រុកអេហ្ស៊ីប ។
- ការបង្រៀនរបស់នីហ្វៃ ត្រូវបានកត់ត្រានៅក្នុង នីហ្វៃទី ២ ៤–៥ និង នីហ្វៃទី ២ ១១–៣៣ ។ នីហ្វៃបានដកស្រង់ពាក្យសម្តីរបស់អេសាយយ៉ាងច្រើននៅក្នុងនីហ្វៃទី ២ ១២–២៤ និង នីហ្វៃទី ២ ២៧ ។
- ការបង្រៀនរបស់យ៉ាកុប ត្រូវបានកត់ត្រានៅក្នុង នីហ្វៃទី ២ ៦–១០ ។ នៅក្នុង នីហ្វៃទី ២ ៦:៦–៧ និង នីហ្វៃទី ២ ៧–៨យ៉ាកុបបានដកស្រង់ពាក្យសម្តីអេសាយ ។

សៀវភៅនីហ្វៃទី ២ ក៏បានលើកឡើងពីការស្លាប់របស់លីហៃ (សូមមើល នីហ្វៃទី ២ ៤:១២) និង ការបែងចែកនៃកូនចៅរបស់លីហៃទៅជាប្រជាជនពីរ —សាសន៍លេមិន និង សាសន៍នីហ្វៃ (សូមមើល នីហ្វៃទី ២ ៥) ។

គម្រោងមេរៀន

នីហ្វៃទី ២ ១–៤ មុនពេលនៃការស្លាប់របស់គាត់បន្តិច លីហៃបានប្រឹក្សា និង ប្រទានពរដល់កូនចៅរបស់គាត់ ។

នីហ្វៃទី ២ ៤–៨ នីហ្វៃបានប្រមើលដោយពេញចិត្តនៅក្នុងព្រះអម្ចាស់ ។ គាត់ដឹកនាំអ្នកដើរតាមគាត់ទៅកាន់ដែនដីមួយដែលពួកគេហៅថា នីហ្វៃ ។ គាត់បានកត់ត្រាពីការបង្រៀនរបស់យ៉ាកុប អំពីការខ្ចាត់ខ្ចាយ និង ការប្រមូលផ្តុំនៃសាសន៍អ៊ីស្រាអែល ។

នីហ្វៃទី ២ ៩–១០ យ៉ាកុប បង្រៀនអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ គាត់ក៏បានព្យាករណ៍អំពីការបដិសេធរបស់សាសន៍យូដាចំពោះព្រះយេស៊ូវគ្រីស្ទ និង ការប្រមូលផ្តុំគ្នានៅថ្ងៃអនាគតរបស់សាសន៍យូដា និង សាសន៍ដទៃនៅក្នុងដែនដីសន្យា ។

នីហ្វៃទី ២ ១១–២៤ នីហ្វៃបង្ហាញក្តីរីករាយរបស់គាត់ក្នុងការថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ។ គាត់ដកស្រង់ការព្យាករណ៍របស់អេសាយ ទាក់ទងនឹងការខ្ចាត់ខ្ចាយ និង ការប្រមូលផ្តុំនៃអ៊ីស្រាអែល ការបន្ទាបនៃភាពអំនួត និង ការទុច្ចរិត មុនពេលការយាងមកជាលើកទីពីរ និង ការប្រសូត បេសកកម្ម និង ការគ្រងរាជ្យមួយពាន់ឆ្នាំនៃព្រះមែស៊ី ។

នីហ្វៃទី ២ ២៥–២៧ នីហ្វៃ ព្យាករណ៍អំពីការឆ្លងរបស់ព្រះអង្គសង្គ្រោះ ការរស់ឡើងវិញ និង ការទៅជួបសាសន៍នីហ្វៃ ការខ្ចាត់ខ្ចាយ និង ការប្រមូលផ្តុំនៃសាសន៍យូដា ការបំផ្លាញនៃសាសន៍នីហ្វៃ ការក្បត់សាសនា ការចេញមកនៃព្រះគម្ពីរមរមន និង ការស្តារឡើងវិញ ។

នីហ្វៃទី ២ ២៨–៣០ នីហ្វៃ ព្រមានទាស់នឹងអំពើទុច្ចរិតនៅថ្ងៃចុងក្រោយ គាត់ពន្យល់ពីតួនាទីនៅថ្ងៃអនាគតនៃព្រះគម្ពីរមរមន និង ការព្យាករណ៍អំពីការប្រមូលនៃព្រលឹងទៅក្នុងសេចក្តីសញ្ញា ។

នីហ្វៃទី ២ ៣១–៣៣ នីហ្វៃ បានជាស់តឿនយើងឲ្យធ្វើតាមព្រះគ្រីស្ទ ទទួលទានព្រះបន្ទូលរបស់ទ្រង់ និង តស៊ូដល់ទីបញ្ចប់ ។ គាត់ថ្លែងទីបន្ទាល់ថា គាត់បានសរសេរព្រះបន្ទូលនៃព្រះគ្រីស្ទ ។

នីហ្វៃទី២ ១

សេចក្តីផ្តើម

សេចក្តីពិតនៅក្នុង នីហ្វៃទី ២ ១ ត្រូវបាននិយាយដោយឪពុក និង អ្នកដឹកនាំដែលមានក្តីស្រឡាញ់ម្នាក់ ដែលជិតនឹងស្លាប់ ។ លីហៃបានអង្វរកូនប្រុសរបស់គាត់ កូនប្រុសរបស់អីសម៉ាអែល និង សួរ៉ាំឲ្យគោរពតាមព្រះបញ្ញត្តិរបស់ព្រះ ។ គាត់បានសន្យានឹងពួកគេថា ប្រសិនបើពួកគេរក្សាព្រះបញ្ញត្តិរបស់ព្រះ នោះពួកគេនឹងបានកែចម្រើននៅលើដែនដី ។ គាត់ក៏បានដាស់តឿនពួកគេឲ្យធ្វើតាមការដឹកនាំក្នុងនាមជាព្យាការីរបស់នីហ្វៃ ។

ការផ្តោតចិត្តទៅលើសិស្ស

អែលឌើរ រ៉ែឆាដ ជី. ស្កត នៃក្រុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ថា ការជួយសិស្សឲ្យទទួលបានការយល់ដឹង វាសំខាន់ជាងការបង្រៀនគ្រប់ចំណុចទាំងអស់នៅក្នុងគម្រោងមេរៀនមួយ ៖ « សូមចាំថា អាទិភាពដ៏ខ្ពស់បំផុតរបស់អ្នក គឺមិនមែនដើម្បីបង្រៀនគ្រប់ចំណុចទាំងអស់នោះទេ ប្រសិនបើនោះមានន័យថា វាមិនអាចទទួលយកបានទាំងអស់នោះ ។ សូមធ្វើនូវអ្វីដែលអ្នកអាចធ្វើដោយមានការយល់ដឹង . . . ប្រសិនបើគោលការណ៍គ្រឹះមួយត្រូវបានគេយល់ [និង] អនុវត្តតាម . . . នោះគោលដៅដ៏សំខាន់បំផុតបានសម្រេចហើយ » (« ដើម្បីយល់ និង រស់នៅតាមសេចក្តីពិត » » [និយាយទៅកាន់អ្នកអប់រំសាសនា CES នៅថ្ងៃទី ៨ខែ កុម្ភៈ ឆ្នាំ ២០០៥]ទំព័រ ២–៣si.lds.org) ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ១:១–២៣

លីហៃដាស់តឿនប្រជាជនរបស់គាត់ឲ្យរស់នៅដោយសុចរិត

សុំឲ្យសិស្សស្រមៃថា ពួកគេត្រូវចាកចេញពីសមាជិកគ្រួសាររបស់ពួកគេភ្លាមៗ និង ប្រហែលមិនអាចជួបនឹងពួកគេម្តងទៀតឡើយ ។

- ប្រសិនបើអ្នកត្រូវនិយាយពាក្យផ្តែផ្តាំចុងក្រោយខ្លះៗដល់គ្រួសារអ្នក តើអ្នកនឹងនិយាយអ្វី ? ហេតុអ្វី ?

ក្រោយពីស្តាប់សិស្សពីរបីនាក់រួចហើយ សូមពន្យល់ថាជំពូកទី ១–៤ នៃនីហ្វៃទី ២ រួមមានកំណត់ត្រារបស់នីហ្វៃអំពីការប្រឹក្សាចុងក្រោយបំផុតរបស់ឪពុករបស់គាត់ ។ មេរៀននេះ ផ្តោតទៅលើ នីហ្វៃទី ២ ១ ដែលរួមមានការប្រឹក្សាដែលលីហៃបានចែកចាយជាមួយនឹងកូនប្រុសរបស់គាត់ កូនប្រុសរបស់អីសម៉ាអែល និង សួរ៉ាំ ។

- តើហេតុអ្វីបានជាការប្រឹក្សាចុងក្រោយរបស់ឪពុក ឬ ព្យាការីម្នាក់មានសារសំខាន់យ៉ាងពិសេសម្ល៉ះនោះ ?

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ១:១–៥ឮៗ ។ សុំឲ្យសិស្សក្នុងថ្នាក់រក « រឿងដ៏អស្ចារ្យដែលព្រះអម្ចាស់បានធ្វើ » សម្រាប់គ្រួសាររបស់លីហៃ ។

- តើរឿងដ៏អស្ចារ្យទាំងនេះ បានបង្ហាញពីសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់បានយ៉ាងដូចម្តេច ?
- តើមានគំរូណាមួយដ៏អស្ចារ្យ ដែលព្រះអម្ចាស់បានធ្វើសម្រាប់អ្នក ឬ គ្រួសាររបស់អ្នក ?
- តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលអ្នកគិតអំពីសេចក្តីមេត្តាករុណារបស់ព្រះចំពោះអ្នក និង គ្រួសាររបស់អ្នក ?

នៅលើក្តារខៀនម្ខាង សូមសរសេរពាក្យ*សកម្មភាព* ។នៅលើក្តារខៀនម្ខាងទៀត សូមសរសេរពាក្យ*លទ្ធផល* ។សូមបែងចែកសិស្សជាពីរក្រុម ។ សូមអញ្ជើញក្រុមទីមួយអាន នីហ្វៃទី ២ ១:៦–៩ហើយក្រុមទីពីរអាន នីហ្វៃទី២ ១:១០–១២ ។ សុំឲ្យក្រុមទាំងពីរស្វែងរកសកម្មភាពដែលលីហៃបាននិយាយថា កូនចៅរបស់គាត់អាចធ្វើ ។ សុំឲ្យពួកគេរកមើលលទ្ធផលនៃសកម្មភាពទាំងនោះផងដែរ ។ ឧទាហរណ៍ លីហៃបាននិយាយថា ប្រសិនបើមនុស្សបម្រើព្រះអម្ចាស់តាមព្រះបញ្ញត្តិរបស់ទ្រង់ នោះដែនដីនោះនឹងជាដែនដីមួយនៃសេរីភាពសម្រាប់ពួកគេ (សូមមើល នីហ្វៃទី ២ ១:៧) ។ នៅពេលសិស្សចែកចាយចម្លើយរបស់ពួកគេ សុំឲ្យសិស្សម្នាក់សរសេរវានៅលើក្តារខៀន ។

- នៅពេលអ្នកសិក្សាចម្លើយនៅលើក្តារខៀន តើអ្នកនឹងសង្ខេបសារលិខិតរបស់លីហៃទៅកាន់គ្រួសាររបស់អ្នកដោយរបៀបណា ? (សិស្សអាចឆ្លើយដោយប្រើពាក្យខុសគ្នា ប៉ុន្តែសូមប្រាកដថា សារលិខិតខាងក្រោមវាច្បាស់ថា ៖ **ព្រះអម្ចាស់ប្រទានពរដល់យើង នៅពេលយើងកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ ហើយទ្រង់នឹងដកយកនូវពរជ័យ នៅពេលយើងមិនគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ។**)
- នៅក្នុងនីហ្វៃទី ២ ១:៩ ឃ្លា « ដែនដីនេះ » យោងលើប្រទេសអាមេរិក ។ តើព្រះអម្ចាស់បានសន្យាអ្វីខ្លះចំពោះអ្នកគោរព ប្រតិបត្តិដែលបានរស់នៅក្នុង « ដែនដីនេះ » ?

ដើម្បីជួយសិស្សយល់ពីអត្ថន័យនៃការប្រៀបធៀបន័យដែលលីហៃបានប្រើដើម្បីណែនាំកូនប្រុសរបស់គាត់ឲ្យកាន់តាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ សូមបង្ហាញនាឡិកាវេទ៍ ច្រវ៉ាក់ និង អ្វីមួយដែលមានដីប្រឡាក់លើវា (សូមប្រាកដថា សង្កត់ន័យលើដី មិនមែនវត្ថុនោះទេ) ។

សូមអញ្ជើញសិស្សអាន នីហ្វៃទី ២ ១:១៣–១៤ដោយស្ងាត់ស្ងៀម ដោយស្វែងរកមើលពាក្យ និង ឃ្លាដែលទាក់ទងនឹងវត្ថុទាំងបីនេះ ។ ក្រោយពីពួកគេបានអានហើយ សូមលើកវត្ថុនីមួយ ៗឡើង ហើយសុំឲ្យសិស្សចែកចាយនូវពាក្យ និង ឃ្លាដែលពួកគេបានរកឃើញ ។ (ចម្លើយអាចរួមមាន « ភ្ជាក់ឡើង » « ដំណេកនរក » « រលាស់ចោលនូវច្រវាក់ដ៏អប្រីយ៍ » « ច្រវាក់ចង » និង « ងើបឡើងពីធូលីដី » ។) សូមសួរសិស្សពីអ្វីដែលវាអាចមានន័យនៅក្នុង « ដំណេកដ៏លង់លក់ » ដែលចងដោយ « ច្រវាក់ដ៏អប្រិយ៍ » ឬ ត្រូវ « ងើបពីធូលីដី » ។

- នៅពេលលីហៃប្រើពាក្យ និង ឃ្លាទាំងនេះ តើគាត់កំពុងដាស់តឿនកូនប្រុសរបស់គាត់ឲ្យធ្វើអ្វី ? (ដើម្បីកែប្រែចិត្ត ដើម្បីផ្លាស់ប្តូរផ្លូវរបស់ពួកគេ ។)
- តើលីហៃបានព្រមានអ្វីខ្លះ ដែលនឹងកើតឡើង ប្រសិនបើកូនប្រុសរបស់គាត់មិនព្រម « រលាស់ចោលនូវច្រវាក់ [របស់ពួកគេ] ? (សូមមើល នីហ្វៃទី ២ ១:១៣) ។

សូមអញ្ជើញសិស្សឲ្យសិក្សានីហ្វៃទី ២ ១:១៤–១៨ដោយស្ងាត់ស្ងៀម ។ សូមពន្យល់ថា លីហៃបានផ្តល់ការប្រឹក្សានេះដោយសន្តានចិត្តល្អ និង សេចក្តីស្រឡាញ់ និង ដោយការបារម្ភដ៏ខ្លាំង (« អន្ទះសារ ») ចំពោះសុខុមាលភាពរបស់កូន ៗរបស់គាត់ ។ សុំឲ្យសិស្សស្វែងរកមូលហេតុដែលលីហៃចង់ឲ្យគ្រួសាររបស់គាត់កាន់តាមព្រះបញ្ញត្តិនៃព្រះអម្ចាស់ ។

- តើហេតុអ្វីបានជាលីហៃព្រួយបារម្ភពីកូនចៅរបស់គាត់ ? (គាត់ព្រួយបារម្ភអំពីលទ្ធផល ដែលពួកគេនឹងរងទុក្ខដោយសារតែសកម្មភាពរបស់ពួកគេ ហើយគាត់ចង់ឲ្យពួកគេទទួលបាននូវបទពិសោធន៍ពីសេចក្តីស្រឡាញ់នៃព្រះ ដូចដែលគាត់បានទទួល ។)

សុំឲ្យសិស្សអានរៀង ៗខ្លួននៅក្នុង នីហ្វៃទី ២ ១:១៥ ម្តងទៀត ។

- តើពរជ័យអ្វីដែលលីហៃបានទទួល ដោយសារតែភាពស្មោះត្រង់របស់គាត់ ?
- តើអ្នកមានអារម្មណ៍ហ៊ុពំទ្ធនៅក្នុងព្រះហស្តនៃសេចក្តីស្រឡាញ់របស់ព្រះ នៅពេលណា ?

សូមបំបែកសិស្សជាគូ ៗ ។ សុំឲ្យសិស្សម្នាក់នៅក្នុងគូនីមួយ ៗស្រាវជ្រាវ នីហ្វៃទី ២ ១:១៩–២២រកមើលសេចក្តីសន្យាដែលអាចបំផុសគំនិតកូនប្រុសរបស់លីហៃឲ្យកែប្រែចិត្ត ។ សុំឲ្យសិស្សម្នាក់ទៀតនៅក្នុងដៃគូនីមួយ ៗស្រាវជ្រាវខគម្ពីរដដែលរកមើលលទ្ធផលដែលលីហៃបាននិយាយថានឹងមក ប្រសិនបើកូនប្រុសរបស់គាត់ជ្រើសរើសបដិសេធការប្រឹក្សារបស់គាត់ ។ (អ្នកអាចសរសេរកិច្ចការនេះនៅលើក្តារខៀន ។) សុំឲ្យសិស្សរយៈពេលបី ឬ បួននាទីម្នាក់ ដើម្បីបំពេញកិច្ចការនេះ ហើយចែកចាយរបកគំហើញរបស់ពួកគេជាមួយនឹងគ្នាទៅវិញទៅមក ។ អ្នកអាចដើរមើលថ្នាក់ នៅពេលពួកគេរៀបរាប់ការរកឃើញរបស់គេ ដូច្នេះអ្នកអាចជួយណែនាំការពិភាក្សារបស់ពួកគេ ។

សូមអានឧបសគ្គរបស់លីហៃនៅក្នុង នីហ្វៃទី ២ ១:២៣ ឲ ៗទៅកាន់សិស្ស ។ អ្នកអាចអញ្ជើញសិស្សឲ្យគូសចំណាំខគម្ពីរនេះ ។ អ្នកក៏អាចលើកទឹកចិត្តពួកគេឲ្យសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេអំពីរឿងមួយដែលពួកគេគួរតែធ្វើដើម្បី « ភ្ជាក់ឡើង » ឬ « រលាស់ចោលនូវច្រវាក់ » ឬ « ងើបពីធូលីដី » ដើម្បីពួកគេអាចទទួលបាននូវពរជ័យដែលលីហៃបាននិយាយប្រាប់នោះ ។

- តើវាមានន័យដូចម្តេចចំពោះអ្នកក្នុងការ « ពាក់សេចក្តីសុចរិតទុកជាប្រដាប់បាំងដើមទ្រូង » ? (សូមមើល គ. និង ស. ២៧:១៥–១៨ ។)

នីហ្វៃទី ២ ១:២៤–៣២

លីហៃបានដាស់តឿនកូនប្រុសរបស់គាត់ឲ្យធ្វើតាមការដឹកនាំបែបព្យាការីរបស់នីហ្វៃ

សូមពន្យល់ថា លីហៃបានបង្រៀនអំពីប្រភពមួយនៃកម្លាំង និង ការបំផុសគំនិតដែលព្រះអម្ចាស់បានផ្តល់ដល់គ្រួសាររបស់គាត់ ។ សូមអញ្ជើញសិស្សស្វែងរកប្រភពនោះនៅក្នុង នីហ្វៃទី ២ ១:២៤ ។ (ប្រភពនោះគឺនីហ្វៃ ដែលបានបម្រើដូចជាព្យាការីរបស់ពួកគេក្រោយពីលីហៃបានស្លាប់ទៅ ។)

សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ១:២៥–២៨ឲ ៗ ។ សុំឲ្យសិស្សរកមើលមូលហេតុដែលលីហៃបានផ្តល់ដល់ប្រជាជន ដើម្បីឲ្យពួកគេធ្វើតាមនីហ្វៃ ។

- តើគុណសម្បត្តិអ្វីខ្លះ ដែលលីហៃបានញ្ជាក់ នៅពេលគាត់បាននិយាយអំពីការដឹកនាំរបស់នីហ្វៃ ? ហេតុអ្វីបានជាអ្នកទុកចិត្តលើអ្នកដឹកនាំម្នាក់ដែលមានគុណសម្បត្តិទាំងនេះ ?
- តើនៅពេលណាដែលអ្នកបានឃើញអ្នកដឹកនាំសាសនាចក្រ ធ្វើជាគំរូនូវគុណសម្បត្តិទាំងនេះ ?

សូមអញ្ជើញសិស្សអាន នីហ្វៃទី ២ ១:៣០–៣២ដោយស្ងាត់ ៗ ។ សុំឲ្យពួកគេស្វែងរកសេចក្តីសន្យាដែលលីហៃបានផ្តល់ទៅសូរុំ ។

- តើអ្នករកឃើញសេចក្តីសន្យាអ្វីខ្លះ ?
- តើសេចក្តីសន្យាទាំងនេះអាចអនុវត្តចំពោះយើង និង គ្រួសាររបស់យើង នៅពេលយើងធ្វើតាមព្យាការីបានយ៉ាងដូចម្តេច ?

ក្រោយពីការពិភាក្សានេះ សូមប្រាកដថា សិស្សយល់ថា **នៅពេលយើងធ្វើតាមអ្នកទាំងឡាយណាអ្នកព្រះបានហៅឲ្យដឹកនាំយើង យើងនឹងត្រូវបានប្រទានពរឲ្យរីកចម្រើន និង មានសុវត្ថិភាពខាងវិញ្ញាណ** ។ដើម្បីគាំទ្រគោលការណ៍នេះ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីពរជ័យដែលបានមក នៅពេលយើងធ្វើតាមអ្នកដឹកនាំសាសនាចក្ររបស់យើង ។

ការប្រៀបធៀបន័យនៅក្នុងព្រះគម្ពីរ

ការប្រៀបធៀប គឺជារូបភាពនៃការនិយាយមួយបែប ដែលពាក្យ ឬ ឃ្លាមួយពិពណ៌នាអំពីវត្ថុ ឬ សកម្មភាពមួយ ដោយមិនមានការទាក់ទងនឹងន័យត្រង់របស់វត្ថុ ឬ សកម្មភាពនោះទេ ។ ឧទាហរណ៍ កូនប្រុសរបស់លីហៃមិនមែនប្រឡាក់ដោយដីតាមន័យត្រង់នោះទេ នៅពេលដែលលីហៃបានប្រាប់ពួកគេឲ្យ « ចូរភ្ជាក់ឡើង ! ហើយងើបពីធូលីដី » (នីហ្វៃទី ២ ១:១៤) ។ ជារឿយ ៗ ព្រះអម្ចាស់ និង ព្យាការីរបស់ទ្រង់បានប្រើការប្រៀបធៀបន័យនៅក្នុងការបង្រៀនរបស់ពួកគាត់ដើម្បីជួយយើងឲ្យភ្ជាប់ទៅនឹងគោលការណ៍ដំណឹងល្អ ។ ការប្រៀបធៀបទាំងនេះ អាចជួយជាអ្នករំឲ្យកដ៏មានអំណាច ។ នៅពេលអ្នកពិភាក្សាអំពីការប្រៀបធៀបន័យ សូមជួយសិស្សផ្តោតលើន័យខាងវិញ្ញាណដែលទាក់ទងដោយពាក្យនោះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ២ ១:២២ « សេចក្តីបំផ្លិចបំផ្លាញដ៏អស់កល្បជានិច្ច »

នៅក្នុង នីហ្វៃទី ២ ១:២២ លីហៃបាននិយាយអំពី « សេចក្តីបំផ្លិចបំផ្លាញដ៏អស់កល្បជានិច្ច នៃព្រលឹង និង ទាំងរូបកាយដែរ ។ » សេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន យ៉ូសែប ហ្វីងឌីង ស្មីធ អាចជួយអ្នកពន្យល់ប្រសាសន៍របស់លីហៃ ៖

« សេចក្តីបំផ្លិចបំផ្លាញ មិនមែនមានន័យថាការសូន្យសុងនោះទេ ។ យើងដឹងដោយសារយើងត្រូវបានបង្រៀននៅក្នុងវិវរណៈនៃព្រះអម្ចាស់ ថាព្រលឹងមួយមិនអាចត្រូវបានបំផ្លាញបានឡើយ ។

« រាល់ព្រលឹងវិញ្ញាណទាំងអស់ដែលបានកើតមកក្នុងពិភពលោកនេះ នឹងទទួលបានការរស់ឡើងវិញ និង អមតភាព ហើយត្រូវស៊ូទ្រាំជារៀងរហូតតទៅ ។ ដូច្នេះ ការបំផ្លិចបំផ្លាញ មិនមែនមានន័យថា ការសូន្យសុងនោះទេ ។ នៅពេលព្រះអម្ចាស់មានព្រះបន្ទូលថា ពួកគេនឹងត្រូវបានបំផ្លាញ នោះទ្រង់មានន័យថា ពួកគេត្រូវបានបណ្តេញចេញពីវត្តមានរបស់ទ្រង់ នោះពួកគេនឹងត្រូវកាត់ចេញពីវត្តមាននៃពន្លឺ និង សេចក្តីពិត ហើយនឹងមិនត្រូវទទួលបានអភ័យឯកសិទ្ធិនៃការតម្កើងនេះទេ ហើយនោះគឺជាការបំផ្លិចបំផ្លាញ » (*គោលលទ្ធិនៃការសង្គ្រោះ* ចងក្រងដោយប្រ៊ូស អ័រ ម៉ាក់ខនឃើ ៣ វ៉ុល ។ [១៩៥៤–៥៦]២:២២៧–២៨) ។

នីហ្វៃទី ២ ១:២៨ ។ « បើសិនជាអ្នករាល់គ្នាប្រុងស្តាប់តាមសំឡេងរបស់នីហ្វៃ អ្នករាល់គ្នានឹងមិនត្រូវវិនាសឡើយ »

លីហៃបានសន្យាថា អស់អ្នកដែលនឹង « ប្រុងស្តាប់តាមសំឡេងរបស់នីហ្វៃ » នឹងត្រូវបានប្រទានពរ (សូមមើល នីហ្វៃទី ២ ១:២៨) ។ ដើម្បីអានអំពីសេចក្តីសន្យាទាំងឡាយ ដែលព្រះអម្ចាស់បានធ្វើជាមួយនឹងអស់អ្នកដែលធ្វើតាមព្យាការីដែលនៅរស់នៅក្នុងជំនាន់របស់យើង សូមមើល គោលលទ្ធិ និង សេចក្តីសញ្ញា ២១:៥–៦ ។

ប្រធាន ណែលហ្សុន រ្ទុនជ្រុព្ធ បានមានប្រសាសន៍ថា ៖ « ខ្ញុំសង្ឃឹមថា យើងអាចដេញតាមផ្លូវដែលជាក់ចុះសម្រាប់យើងទាំងអស់គ្នាបាន ដោយសារអ្នកបម្រើរបស់ព្រះអម្ចាស់ ជ្បិតប្រសិនបើយើងធ្វើការណ៍នេះ ខ្ញុំដឹងថា យើងនឹងមានសុវត្ថិភាពនៅក្នុងពិភពលោកនេះ ហើយទទួលបាននូវសុភមង្គល និង ការតម្កើងនៅក្នុងពិភពដែលនឹងមកខាងមុខ ។ . . . ប្រសិនបើយើងស្មោះត្រង់ ពួកគាត់នឹងនាំយើងទៅតាមផ្លូវនៃជីវិត ហើយដរាបណាយើងមានសេចក្តីជំនឿជឿដល់ការណែនាំរបស់ពួកគាត់ នៅក្នុងការបង្រៀននៃព្រះវិញ្ញាណបរិសុទ្ធតាមរយៈពួកគាត់ យើងនឹងនៅលើផ្លូវដែលមានសុវត្ថិភាពជានិច្ច ហើយនឹងជឿជាក់ថាបានង្វាន់របស់យើង » (*ការបង្រៀនរបស់ប្រធាននៃសាសនាចក្រ ៖ ណែលហ្សុន រ្ទុនជ្រុព្ធ* [២០០៤] ទំព័រ ១៩៩) ។

នីហ្វៃទី ២ ២ (ផ្នែកទី ១)

សេចក្តីផ្តើម

នីហ្វៃទី ២ ២ រួមមានការបន្តពីការបង្រៀនរបស់លីហៃ ពីមុនពេលគាត់ស្លាប់បន្តិច ។ ការនិយាយដោយចំៗទៅកាន់កូនប្រុសរបស់គាត់ យ៉ាកុប នោះលីហៃបានថ្លែងទីបន្ទាល់អំពីព្រះសមត្ថភាពរបស់ព្រះអម្ចាស់ដើម្បីធ្វើឲ្យសេចក្តីទុក្ខទាំងឡាយរបស់យើងក្លាយទៅជាផលប្រយោជន៍ដល់យើងវិញ ។ ពេលនិយាយទៅកាន់កូនប្រុសរបស់គាត់ទាំងអស់ គាត់បានបង្រៀនអំពីការធ្លាក់នៃអ័ដាម —ហេតុអ្វីបានជាវាចាំបាច់ និង របៀបដែលវាជះឥទ្ធិពលដល់មនុស្សជាតិ— និង អំពីតម្រូវការចំពោះដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ (លីហៃក៏បានបង្រៀនអំពីគោលលទ្ធិនៃការជ្រើសរើសផងដែរ ។ គោលលទ្ធិនេះ នឹងត្រូវបាននិយាយនៅក្នុងមេរៀនក្រោយ ។)

យោបល់សម្រាប់ការបង្រៀន

សូមជួយសិស្សឲ្យមើលឃើញថា ព្រះគម្ពីរទាក់ទងនឹងពួកគេ

របៀបដ៏មានប្រសិទ្ធភាពបំផុតមួយដើម្បីជួយសិស្សរៀបចំរៀន គឺដោយសុំឲ្យពួកគេសញ្ជឹងគិតអំពីសំណួរ ឬ ស្ថានភាពមួយដែលទាក់ទងនឹងពួកគេ ហើយថានឹងត្រូវបានឆ្លើយតបនៅក្នុងព្រះគម្ពីរមកពីអ្វីដែលអ្នកកំពុងបង្រៀន ។ វានឹងជួយសិស្សឲ្យសិក្សាព្រះគម្ពីរដោយមានគោលបំណង ។

នីហ្វៃទី ២ ២:១–៤

លីហៃនិយាយទៅកាន់យ៉ាកុបអំពីឧបសគ្គ និង ពរជ័យនានា

ដើម្បីជួយសិស្សឃើញថា នីហ្វៃទី ២ ២ទាក់ទងនៅក្នុងជីវិតរបស់ពួកគេ សូមឲ្យពួកគេគិតអំពីនរណាម្នាក់ដែលពួកគេស្គាល់ ដែលបានជួបប្រទះនឹងការលំបាក ឬ ទុក្ខវេទនាយ៉ាងខ្លាំង ។ សូមអញ្ជើញពួកគេឲ្យសញ្ជឹងគិតអំពីអ្វីដែលពួកគេអាចនិយាយដើម្បីលើកទឹកចិត្តបុគ្គលនោះ ។ សុំឲ្យពួកគេរៀបចំដើម្បីចែកចាយគំនិតរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

សូមពន្យល់ថា នីហ្វៃទី ២ ២ រួមមានកំណត់ត្រាមួយអំពីលីហៃ ដែលនិយាយទៅកាន់កូនប្រុសម្នាក់ដែលបានជួបប្រទះនឹងការលំបាក ។ សូមអញ្ជើញសិស្សអាន នីហ្វៃទី ២ ២:១ ដោយស្ងាត់ស្ងៀម ។ សុំឲ្យពួកគេស្វែងរកថាតើកូនប្រុសម្នាក់ណាដែលលីហៃបានបង្រៀន (យ៉ាកុប) និង អ្វីដែលបានបង្កឲ្យកូនប្រុសរបស់គាត់រងទុក្ខ (ការទ្រគោះរបស់បងៗរបស់គាត់) ។ បន្ទាប់មក សុំឲ្យសិស្សអាន នីហ្វៃទី ២ ២:២–៣ដោយស្ងាត់ស្ងៀម ។ អ្នកអាចផ្តល់យោបល់ថា ពួកគេគួរតែគូសចំណាំ៣ក្យ និង ឃ្លាទាំងឡាយដែលពិពណ៌នាអ្វីដែលព្រះអម្ចាស់នឹងធ្វើសម្រាប់យ៉ាកុប ។

សុំឲ្យសិស្សចែកចាយឃ្លាដែលពួកគេបានរកឃើញ ។ បន្ទាប់មក សូមសួរនូវសំណួរខាងក្រោមនេះ ដើម្បីជួយពួកគេឲ្យយល់ថា **ព្រះអម្ចាស់អាចធ្វើឲ្យការឈឺចាប់ទាំងឡាយរបស់យើងក្លាយទៅជាផលប្រយោជន៍ដល់យើងវិញ ៖**

- តើឃ្លា « ធ្វើឲ្យសេចក្តីទុក្ខទាំងឡាយរបស់ពួកគេក្លាយទៅជាផលប្រយោជន៍ដល់អ្នកវិញ » មានន័យយ៉ាងដូចម្តេចចំពោះអ្នក ? (អ្នកគួរតែពន្យល់ថា *ធ្វើឲ្យក្លាយជា* មានន័យថាឧទ្ទិស ឬ ធ្វើឲ្យបរិសុទ្ធ ។)
- តើនៅពេលណាដែលអ្នកបានឃើញថា ព្រះអម្ចាស់អាចធ្វើឲ្យសេចក្តីទុក្ខទាំងឡាយរបស់យើងក្លាយទៅជាផលប្រយោជន៍ដល់យើង វិញ ?

នីហ្វៃទី ២ ២:៥–២៥

លីហៃបង្រៀនកូនៗរបស់គាត់អំពីការធ្លាក់ និង អំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ

សូមពន្យល់ថា លីហៃបានបង្រៀនយ៉ាកុប និង កូនៗគាត់ផ្សេងទៀតអំពីការធ្លាក់របស់លោកអ័ដាម និង នាងអេវ៉ា ។ អ្នកគួរតែពន្យល់ថា ឃ្លា « ការធ្លាក់ » សំដៅលើលក្ខខណ្ឌដែលបានធ្លាក់លើលោកអ័ដាម និង នាងអេវ៉ា ហើយនិង កូនចៅរបស់ពួកគេ ដោយសារតែការជ្រើសរើសរបស់អ័ដាម និង អេវ៉ាដើម្បីទទួលទានផ្លែឈើហាមឃាត់នៅក្នុងសួនច្បារអេដែន ។

- តើជម្រើសអ្វីដែលព្រះអម្ចាស់បានផ្តល់ទៅឲ្យលោកអ័ដាម និង នាងអេវ៉ានៅក្នុងសួនច្បារអេដែន ? (ទ្រង់បានអនុញ្ញាតឲ្យពួកគេជ្រើសរើសថាត្រូវទទួលទាន ឬ មិនទទួលទាននូវផ្លែឈើហាមឃាត់នោះ ។)
- យោងតាម នីហ្វៃទី ២ ២:១៥ហេតុអ្វីបានជាព្រះអម្ចាស់ទ្រង់ប្រទានដល់ពួកគេនូវជម្រើសនេះ ? (« ដើម្បីធ្វើឲ្យគោលបំណងដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់មកដល់ទីបញ្ចប់នៃមនុស្ស ។ » អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំឃ្លានេះ ។)
- តើគោលបំណងដ៏នៅអស់កល្បជានិច្ចរបស់ព្រះសម្រាប់យើងមានអ្វីខ្លះ ? (ដើម្បីផ្តល់ឲ្យយើងនូវឱកាសដើម្បីទទួលបាននូវជីវិតដ៏អស់កល្បជានិច្ច និង ក្លាយដូចជាទ្រង់ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរកំណត់ចំណាំមួយនៅក្នុងព្រះគម្ពីររបស់ពួកគេអំពីការណ៍នេះ ក្បែរឃ្លា « គោលបំណងដ៏នៅអស់កល្បជានិច្ច » ។ អ្នកក៏អាចចង់ឲ្យពួកគេអាន ម៉ូសេ ១:៣៩ ។)

សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ដោយទុកប្រអប់ពីរខាងក្រោមនៅទំនេរ ។ (អ្នកអាចស្នើថា សិស្សគួរតែចម្លងតារាងនេះចូលក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ។)

ដោយគ្មានការធ្លាក់	ដោយសារការធ្លាក់
អ្វីៗសព្វសារពើដែលបានបង្កើតឡើងនឹងនៅក្នុងសណ្ឋានដើមដដែល បន្ទាប់ពីបានបង្កើតមក (សូមមើល នីហ្វៃទី ២ ២:២២) ។ លោកអ័ដាម និង នាងអេវ៉ានឹងពុំមានកូនចៅនោះទេ (សូមមើល នីហ្វៃទី ២ ២:២៣) ។ អ័ដាម និង អេវ៉ានឹងនៅក្នុងភាពឆោតល្ងង់ ដោយមិនស្គាល់សេចក្តីអំណរ ឬ សេចក្តីទុក្ខវេទនា អំពើល្អ ឬ អំពើបាបឡើយ (សូមមើល នីហ្វៃទី ២ ២:២៣) ។	លោកអ័ដាម និង នាងអេវ៉ាត្រូវបានបណ្តេញចេញពីសួនច្បារដើម្បីទៅក្លរាស់នៅលើផែនដី (សូមមើល នីហ្វៃទី ២ ២:១៩) ។ លោកអ័ដាម និង នាងអេវ៉ាបានបង្កើតកូន —គ្រួសារទាំងឡាយនៃអស់ទាំងផែនដី (សូមមើល នីហ្វៃទី ២ ២:២០) ។ លោកអ័ដាម និង នាងអេវ៉ា និង កូនចៅរបស់ពួកគេមានបទពិសោធន៍ពីជីវិតខាងសាច់ឈាម រួមមានសេចក្តីទុក្ខវេទនា សេចក្តីអំណរ និង សមត្ថភាពដើម្បីធ្វើអំពើល្អ និង ប្រព្រឹត្តអំពើបាប (សូមមើល នីហ្វៃទី ២ ២:២៣, ២៥) ។ យើងត្រូវមាននឹងសេចក្តីស្លាប់ខាងសាច់ឈាម និង ខាងវិញ្ញាណ (សូមមើល នីហ្វៃទី ២ ៩:៦;ហេលេមិន ១៤:១៦) ។

សូមអញ្ជើញសិស្សម្នាក់ឡើងមកក្តារខៀន និង ធ្វើជាអ្នកសរសេរសម្រាប់ថ្នាក់ ។ សុំឲ្យសិស្សស្រាវជាវ្រ នីហ្វៃទី ២ ២:១៩–២៥ដោយស្ងាត់ស្ងៀម ដោយស្វែងរក (១) លទ្ធផលដែលនឹងកើតមាន ប្រសិនបើលោកអ័ដាម និង នាងអេវ៉ាមិនបានទទួលទានផ្លែដែលហាមឃាត់ និង មិនបានធ្លាក់ទេ និង (២) លទ្ធផលដែលចេញមកពីការធ្លាក់ ។ សុំឲ្យអ្នកសរសេរកត់ត្រានូវចម្លើយរបស់សិស្សនៅក្នុងតារាង ។ ចម្លើយអាចរួមមានអ្វីដែលបានកត់ត្រានៅខាងលើ (លើកលែងតែសាច់រឿងអំពីសេចក្តីស្លាប់ខាងសាច់ឈាម និង ខាងវិញ្ញាណ ដែលនឹងត្រូវបានបន្ថែមតាមក្រោយ) ។

សូមអញ្ជើញសិស្សឲ្យរំឭកចម្លើយរបស់ពួកគេនៅក្រោមចំណងជើង « ដោយគ្មានការធ្លាក់ » ។

- **តើក្នុខណ្ឌនៅក្នុងសួនច្បារអេដែន បានរារាំងលោកអ័ដាម និងនាង អេវ៉ាពីការីកចម្រើននៅក្នុងផែនការសង្គ្រោះរបស់ព្រះវរបិតាសួគ៌យ៉ាងដូចម្តេច ? (សូមមើល នីហ្វៃទី ២ ២:២២–២៣) ។**

សូមអញ្ជើញសិស្សរំឭកបញ្ជីនៅក្រោមចំណងជើង « ដោយសារការធ្លាក់ » ។ សូមប្រាកដថា ពួកគេយល់ថា ដោយសារយើងគឺជាកូនចៅរបស់លោកអ័ដាម និង នាងអេវ៉ា នោះយើងត្រូវទទួលលក្ខខណ្ឌដែលបានមកដល់ពួកគេ ក្រោយពីការធ្លាក់នោះ (សូមមើល នីហ្វៃទី ២ ២:២១) ។

- **ឃ្លា « ក្លរាស់នៅលើផែនដី » មានន័យថា ក្រោយពីលោកអ័ដាម និង នាងអេវ៉ាត្រូវបានបណ្តេញចេញពីសួនច្បារ នោះពួកគេត្រូវធ្វើការដើម្បីទទួលបានអាហារ ។ តើអ្នកគិតថា ការងារជួយយើងឲ្យរីកចម្រើននៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌យ៉ាងដូចម្តេច ?**
- **តើការមានកូនចៅជួយអ័ដាម និង អេវ៉ាឲ្យក្លាយដូចជាព្រះវរបិតាសួគ៌យ៉ាងដូចម្តេច ? តើតាមរបៀបណាដែលគ្រួសារមានសារៈសំខាន់នៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌ ?**
- **តើឱកាសដើម្បីទទួលបានសេចក្តីអំណរ និង សេចក្តីទុក្ខវេទនាអាចជួយយើងឲ្យរីកចម្រើននៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌យ៉ាងដូចម្តេច ?**

ក្រោយពីពិភាក្សាសំណួរទាំងនេះហើយ សូមសង្កត់ធ្ងន់ថា ការធ្លាក់របស់អ័ដាម និង អេវ៉ាគឺជាផ្នែកមួយដ៏សំខាន់នៃផែនការសុភមង្គលរបស់ព្រះវរបិតាសួគ៌ ។

នីហ្វៃទី ២ ២:២៥សំដៅលើគំនិតក្នុងការបង្រៀនចំណុះចំណានខគម្ពីរនៅចុងបញ្ចប់នៃមេរៀន ដើម្បីជួយសិស្សឲ្យចេះចាំវគ្គនេះ ។

សូមចង្អុលបង្ហាញថា នីហ្វៃទី ២ ២:២៥ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំវាទុក ។ ដោយសារខគម្ពីរនេះខ្លី អ្នកអាចយកពេលដើម្បីជួយសិស្សឲ្យទន្ទេញវាបាន ។

សូមពន្យល់ថា ទោះបីជាការធ្លាក់បានបើកផ្លូវសម្រាប់យើងឲ្យរីកចម្រើនក្តី ក៏វានាំឲ្យការឈឺចាប់ ការរងទុក្ខ អំពើបាប និង សេចក្តីស្លាប់មកកាន់ពិភពលោកដែរ ។ ដើម្បីជួយសិស្សពង្រីកការយល់ដឹងរបស់ពួកគេអំពីសេចក្តីពិតនេះ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ៩:៦ ឮៗ ។ បន្ទាប់មក សុំឲ្យម្នាក់ទៀតអាន ហេលេមិន ១៤:១៥–១៧ ឮៗ ។ សុំឲ្យសិស្សរកមើលលទ្ធផលនៃការធ្លាក់ដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ ។

- **តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះអំពីការធ្លាក់ ? (វានាំមកនូវសេចក្តីស្លាប់ខាងសាច់ឈាម ដែលជាសេចក្តីស្លាប់ខាងរូបកាយ ហើយសេចក្តីស្លាប់ខាងវិញ្ញាណ ដែលជាសភាពមួយដែលត្រូវបានកាត់ចេញពីវត្តមាននៃព្រះ ។ សូមសរសេរ *យើងត្រូវជួបនឹងសេចក្តីស្លាប់ខាងសាច់ឈាម និង ខាងវិញ្ញាណ* នៅលើក្តារខៀនក្រោម « ដោយសារការធ្លាក់ » ។)**

ដើម្បីជួយសិស្សឲ្យគិតអំពី របៀបដែលពួកគេបានជួបនឹងលទ្ធផលនៃការធ្លាក់ដែលបានសរសេរនៅលើក្តារខៀន សូមលើកទឹកចិត្តពួកគេឲ្យសញ្ជឹងគិតដោយស្ងាត់ស្ងៀមនូវសំណួរខាងក្រោម ។ (សូមអានសំណួរយឺតៗ ហើយឈប់នៅចន្លោះសំណួរដើម្បីឲ្យសិស្សមានពេលគ្រប់គ្រាន់គិត ។)

- **តើអ្វីខ្លះជាមូលហេតុនៃសេចក្តីទុក្ខវេទនានៅក្នុងជីវិតនេះ ?**
- **តើហេតុអ្វីបានជាសេចក្តីស្លាប់ជាផ្នែកមួយចាំបាច់នៃផែនការសង្គ្រោះ ?**
- **តើបញ្ហា និង ទុក្ខសោកទាំងឡាយអាចជួយយើងឲ្យរៀន និង រីកចម្រើនដោយរបៀបណា ?**

សូមពន្យល់ថា នៅពេលយើងយល់ពីរបៀបដែលការធ្លាក់ប៉ះពាល់ដល់យើង នោះយើងនឹងយល់ថា យើងត្រូវការដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ សូមអានសុន្ទរកថាខាងក្រោមនេះ ដែលថ្លែងដោយប្រធាន អែសរ៉ា ថាហ្វ ប៊ែនសឺន ៖

« វាដូចជាមនុស្សម្នាក់ដែលមិនត្រូវការអាហារ រហូតដល់គាត់ឃ្លាន ដូច្នេះគាត់ក៏មិនត្រូវការការសង្គ្រោះពីព្រះគ្រីស្ទដែរ រហូតដល់គាត់ដឹងថាហេតុអ្វីបានជាគាត់ត្រូវការព្រះគ្រីស្ទ ។

« គ្មាននរណាម្នាក់ដឹងគ្រប់គ្រាន់ និង ពេញលេញថាហេតុអ្វីបានជាគាត់ត្រូវការព្រះគ្រីស្ទនោះទេ រហូតដល់គាត់យល់ និង ទទួលយកគោលលទ្ធិនៃការឆ្លាក់ និង ឥទ្ធិពលរបស់វាមកលើមនុស្សជាតិទាំងអស់ ។ ហើយគ្មានសៀវភៅណានៅក្នុងពិភពលោកនេះ ពន្យល់អំពីគោលលទ្ធិដ៏សំខាន់នេះបានច្បាស់ដូចជាព្រះគម្ពីរមរមននោះទេ » (« ព្រះគម្ពីរមរមន និង គោលលទ្ធិ និង សេចក្តីសញ្ញា » *Ensign*ខែ ឧសភា ឆ្នាំ ១៩៨៧ ទំព័រ ៨៥) ។

ក្រោយពីសិស្សមានពេលគ្រប់គ្រាន់សញ្ជឹងគិតអំពីសំណួរទាំងនេះហើយ សូមបង្ហាញរូបភាពព្រះអង្គសង្គ្រោះមួយ ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា **តាមរយៈដង្វាយធួន ព្រះយេស៊ូវគ្រីស្ទបានសង្គ្រោះយើងចេញពីឥទ្ធិពលនៃការឆ្លាក់ និង ផ្តល់នូវការសង្គ្រោះចេញពីអំពើបាបរបស់យើង ។**

សូមអញ្ជើញសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង នីហ្វៃទី ២ ២:៥–១០, ២១និង អាលម៉ា ៧:១១–១៣ ។ សុំឲ្យសិស្សរកឃ្លានៅក្នុងខគម្ពីរទាំងនេះដែលបង្ហាញអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើដើម្បីសង្គ្រោះយើងចេញពីឥទ្ធិពលនៃការឆ្លាក់ និង ចេញពីអំពើបាបផ្ទាល់ខ្លួនយើង ។ (ទាក់ទងនឹងខ ៩ អ្នកគ្រូតែពន្យល់ថាឃ្លា « អង្ករ » មាននិយថា អង្ករជំនួសមនុស្សម្នាក់ទៀត ឬ ធ្វើសកម្មភាពជំនួសកន្លែងមនុស្សម្នាក់ទៀត ។) ដើម្បីជួយសិស្សវិភាគឃ្លាដែលពួកគេបានរកឃើញ សូមសួរ ៖

- តើឃ្លាណានៅក្នុងខគម្ពីរទាំងនេះ ដែលបង្ហាញថាតាមរយៈដង្វាយធួន នោះព្រះអង្គសង្គ្រោះនឹងសង្គ្រោះយើងចេញពីសេចក្តីស្លាប់ខាងសាច់ឈាម ?
- តើឃ្លាណាដែលបង្ហាញថា ព្រះអង្គសង្គ្រោះនឹងសង្គ្រោះយើងចេញពីសេចក្តីស្លាប់ខាងវិញ្ញាណ (ការកាត់ចេញពីវត្តមាននៃព្រះ) ?
- តើឃ្លាណាដែលបង្ហាញថា ព្រះអង្គសង្គ្រោះអាចសង្គ្រោះយើងចេញពីអំពើបាបរបស់យើង ?
- តើឃ្លាណាដែលបង្ហាញថា ព្រះអង្គសង្គ្រោះអាចជួយយើងឆ្លងកាត់ពេលមានឧបសគ្គដូចជា ជំងឺ និង ការឈឺចាប់ ?

យោងតាមនីហ្វៃទី ២ ២:៧–៩, ២១តើយើងត្រូវធ្វើអ្វីដើម្បីទទួលបានឪពរជ័យទាំងអស់ដែលមានតាមរយៈដង្វាយធួន ? (ទាក់ទងនឹងខ ៧ អ្នកគ្រូតែពន្យល់ថា មនុស្សម្នាក់ដែលមាន « ដួងចិត្តសោកសង្រេង និង វិញ្ញាណទន់ទាប » គឺជាមនុស្សបន្ទាបខ្លួន និង ត្រៀមខ្លួនជាស្រេចដើម្បីធ្វើតាមព្រះឆន្ទៈព្រះ ។ មនុស្សបែបនោះមានអារម្មណ៍សោកស្តាយយ៉ាងខ្លាំងចំពោះអំពើបាប និង មានបំណងចង់ប្រែចិត្តដោយអស់ពីចិត្ត ។)

ក្រោយពីការពិភាក្សាសំណួរទាំងនេះហើយ សូមឲ្យសិស្សពិនិត្យខគម្ពីរដែលដាក់ឲ្យអានដោយស្ងាត់ស្ងៀម ដោយស្វែងរកឃ្លាដែលមានន័យចំពោះពួកគេជាពិសេស ។ សុំឲ្យសិស្សចែកគ្នាជាដៃគូ និង ចែកចាយឃ្លាដែលពួកគេបានជ្រើសរើសជាមួយគ្នា ។ សូមអញ្ជើញពួកគេឲ្យចែកចាយថា ហេតុអ្វីបានជាឃ្លាទាំងនេះមានន័យចំពោះពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ ឬ ពីរនាក់ឲ្យសង្ខេបប្រាប់ថ្នាក់ពីមូលហេតុដែលការឆ្លាក់ គឺជាផ្នែកដ៏សំខាន់មួយនៃផែនការសង្គ្រោះរបស់ព្រះវរបិតាសួគ៌ ។ បន្ទាប់មក សូមឲ្យពួកគេចែកចាយអារម្មណ៍របស់ពួកគេអំពីរបៀបដែលដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទជួយសង្គ្រោះយើងចេញពីការឆ្លាក់ ។

ចំណេះចំណានខគម្ពីរ—នីហ្វៃទី ២ ២:២៥

កំណត់សម្គាល់ ៖ សូមគិតអំពីការប្រើសកម្មភាពខាងក្រោមដើម្បីជួយសិស្សឲ្យប្រើ នីហ្វៃទី ២ ២:២៥ នៅពេលពួកគេបង្រៀនដំណឹងល្អ ។ ដោយសារតែលក្ខណៈ និង ថិរវេលានៃមេរៀនថ្ងៃនេះ អ្នកអាចប្រើសកម្មភាពនេះនៅថ្ងៃផ្សេងទៀត នៅពេលអ្នកមានពេលវេលាធ្វើ ។

សូមអញ្ជើញសិស្សឲ្យរៀបចំមេរៀនមួយអំពីគោលលទ្ធិនៃការឆ្លាក់ ដោយប្រើនីហ្វៃទី ២ ២:២៥ ។ ពួកគេអាចបង្រៀនមេរៀននេះនៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ ឬ នៅតាមសកម្មភាពផ្សេងទៀត ។ សូមសួរសិស្សពីរបីនាក់ ប្រសិនបើពួកគេចង់រាយការណ៍ពីបទពិសោធន៍របស់ពួកគេក្រោយពីពួកគេបានបង្រៀន ។ សូមអនុញ្ញាតឲ្យសិស្សចាប់ផ្តើមការរៀបចំរបស់ពួកគេនៅក្នុងថ្នាក់ បើសិនមានពេល ។

នីហ្វៃទី ២ ២ (ផ្នែកទី ២)

សេចក្តីផ្តើម

មេរៀនពីមុននៅក្នុង នីហ្វៃទី ២ ២ ផ្តោតលើការឆ្លាក់របស់អ័ដាម និង អេវ៉ា និង ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ មេរៀននេះ ផ្តោតលើការបង្រៀនរបស់លីហៃ អំពីគោលលទ្ធិនៃសិទ្ធិជ្រើសរើស រួមមានសេចក្តីពិតដែលយើងមានសេរីភាពដើម្បីជ្រើសរើសឥស្សរភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចតាមរយៈព្រះយេស៊ូវគ្រីស្ទ ។

នៅក្នុងមេរៀននេះ សិស្សនឹងមានឱកាសដើម្បីបង្រៀនគ្នាទៅវិញទៅមក ។ មុនចាប់ផ្តើមថ្នាក់ សូមរៀបចំក្រដាសសម្រាប់ចែកឲ្យសិស្សដែលមាននូវការណែនាំនៅក្នុងមេរៀននេះ ។ ដោយសុំនឹងការណែនាំនីមួយៗ ដូច្នេះអ្នកអាចជួយសិស្ស នៅពេលពួកគេរៀបចំបង្រៀន ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ២:១១–១៨, ២៥–៣០

លីហៃបង្រៀនអំពីសិទ្ធិជ្រើសរើស និង លទ្ធផលនៃជម្រើសរបស់យើង

នីហ្វៃទី ២ ២:២៧ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមយោងទៅលើគំនិតក្នុងការបង្រៀនចំណេះចំណានខគម្ពីរ នៅចុងបញ្ចប់នៃមេរៀនដើម្បីជួយសិស្សក្នុងផ្នែកចំណេះចំណានខគម្ពីររបស់ពួកគេនៃវគ្គនេះ ។

សូមរំឭកសិស្សដោយខ្លីៗថា នៅក្នុងមេរៀនមុន ពួកគេបានរៀនពីការបង្រៀនរបស់លីហៃនៅក្នុង នីហ្វៃទី ២ អំពីការឆ្លាក់របស់អ័ដាម និង អេវ៉ា និង ពរជ័យពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ជម្រើសរបស់អ័ដាម និង អេវ៉ាធ្វើឲ្យយើងអាចមកកាន់ផែនដី (សូមមើល នីហ្វៃទី ២ ២:២៥) ជាកន្លែងដែលយើងបានជួបនឹងបទពិសោធន៍ឡាយឡំនឹងទុក្ខសោក ការឈឺចាប់ និង សេចក្តីស្លាប់ ។ **តាមរយៈដង្វាយធួន ព្រះយេស៊ូវគ្រីស្ទអាចសង្គ្រោះយើងចេញពីការឆ្លាក់ និង ផ្តល់ឲ្យយើងនូវការប្រោសលោះចេញពីអំពើបាបរបស់យើង** (សូមមើល នីហ្វៃទី ២ ២:២៦) ។ ដោយសារដង្វាយធួន **យើងមានសេរីភាពដើម្បីជ្រើសរើសយកឥស្សរភាព និង ជីវិតដ៏នៅអស់កល្បជានិច្ច ឬ ការជាប់ឃុំឃាំង និង សេចក្តីស្លាប់** (សូមមើល នីហ្វៃទី ២ ២:២៧) ។

សូមពន្យល់ថា នៅពេលសិស្សបន្តការសិក្សារបស់ពួកគេក្នុងនីហ្វៃទី ២ ២ នៅក្នុងមេរៀននេះ ពួកគេនឹងមានឱកាសដើម្បីបង្រៀនគ្នាទៅវិញទៅមក អំពីគោលការណ៍នៃសិទ្ធិជ្រើសរើសដែលលីហៃបានពន្យល់ទៅកាន់កូនប្រុសរបស់គាត់ យ៉ាកុប ។ សូមបំបែកសិស្សទៅជាបួនក្រុម ។ សូមឲ្យក្រុមនីមួយៗនូវការណែនាំខាងក្រោម ដើម្បីជួយពួកគេរៀបចំបង្រៀន (មុនពេលចាប់ផ្តើមថ្នាក់ សូមរៀបចំក្រដាសសម្រាប់ចែកឲ្យសិស្សដែលមានការណែនាំទាំងនេះ) ។ ប្រសិនបើថ្នាក់មានសិស្សតិចជាងបួននាក់ សូមឲ្យការណែនាំមួយទៅសិស្សម្នាក់ និង បង្រៀនអ្វីដែលមាននៅសល់នៅក្នុងការណែនាំដោយខ្លួនអ្នក ។

ការណែនាំនីមួយៗ រួមមានកិច្ចការប្រាំ ។ សូមលើកទឹកចិត្តសិស្សទាំងអស់ឲ្យចូលរួមដោយ ការធានាថាបុគ្គលម្នាក់ៗនៅក្នុងក្រុមមួយៗនឹងទទួលបាននូវកិច្ចការមួយ ។ នៅក្នុងក្រុមដែលមានសមាជិកច្រើនជាងប្រាំនាក់ សិស្សអាចចែកកិច្ចការគ្នាបាន ។ នៅក្នុងក្រុមដែលមានគ្នាតិចជាងប្រាំនាក់ មានអ្នកខ្លះនឹងត្រូវធ្វើកិច្ចការច្រើនជាងមួយ ។ សូមប្រាប់សិស្សថា ពួកគេនឹងមានពេលប្រហែលបីនាទីដើម្បីរៀបចំមេរៀន ហើយថាក្រុមនីមួយៗនឹងមានពេលប្រហែលប្រាំនាទីដើម្បីបង្រៀន ។

ក្រុមទី ១ ៖ ព្រះទ្រង់បង្កើតយើងដើម្បីធ្វើអំពើ

ក. សូមលើកថ្មមួយឡើងពីខាងមុខថ្នាក់រៀន ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ២:១៤ឮៗ ។ មុនពេលគាត់ ឬ នាងអាន សូមឲ្យសិស្សស្វែងរកការពិពណ៌នារបស់លីហៃអ្វីពីរប្រភេទដែលព្រះបានបង្កើតនៅលើស្ថានសួគ៌ និង នៅលើផែនដី ។ (« អ្វីៗសព្វសារពើដែលត្រូវធ្វើអំពើ និង អ្វីៗសព្វសារពើដែលត្រូវទទួលរងអំពើ ។ ») សូមសួរ ៖ តើខគម្ពីរនេះទាក់ទងនឹងយើង និង ថ្មនោះយ៉ាងដូចម្តេច ? (យើងត្រូវបានបង្កើតមកដើម្បីធ្វើអំពើ ខណៈដែលថ្មនោះត្រូវបានបង្កើតមកដើម្បីទទួលរងអំពើ ។ ដូចជាការបង្កើតផ្សេងៗទៀតដែរ ថ្មមិនអាចធ្វើអំពើដោយខ្លួនឯងបានទេ ។)

ខ. សុំឲ្យសិស្សម្នាក់អានប្រយោគទីមួយនៅក្នុងនីហ្វៃទី ២ ២:១៦ ។ សូមសួរសិស្ស ៖ នៅក្នុងផែនការសង្គ្រោះរបស់ព្រះវរបិតាសួគ៌ តើហេតុអ្វីបានជាអ្នកគិតថាវាសំខាន់ដែលយើងត្រូវធ្វើអំពើឲ្យខ្លួនយើង ? ក្រោយពីសិស្សបានឆ្លើយហើយ សូមសួរ ៖ តើពេលខ្លះយើងរង់ចាំដើម្បីទទួលរងអំពើ ជាជាងការធ្វើអំពើឲ្យខ្លួនយើងដោយរបៀបណា ?

គ. សូមសរសេរ *គ. និង ស. ៥៨:២៦–២៨* នៅលើក្តារខៀន ។ សូមអញ្ជើញសិស្សបើកទៅវគ្គគម្ពីរនេះ ។ សូមនាំពួកគេអានវាឮមគ្នាឮៗ ។

ឃ. សូមសួរ ៖ តើយើងអាចរៀនអ្វីខ្លះពី គោលលទ្ធិ និង សេចក្តីសញ្ញា ៥៨:២៦–២៨ អំពីការធ្វើអំពើឲ្យខ្លួនយើង ? តើរបៀបណាខ្លះដែលយើងអាចស្វែងរកដើម្បីភ្ជាប់ខ្លួនយើងដោយការខ្វាយខ្វល់ក្នុងការនាំមកនូវសេចក្តីសុចរិតដ៏ខ្លាំងនោះ ? តើនៅពេលណាដែលអ្នកបានឃើញការព្យាយាមរបស់អ្នកក្នុងការនាំមកនូវសេចក្តីសុចរិតដ៏ខ្លាំងបែបនោះ ? (បន្ទាប់ពីសិស្សម្នាក់ ឬ ពីរនាក់ផ្តល់ចម្លើយរួច អ្នកក៏អាចចែកចាយនូវបទពិសោធន៍មួយដែរ ។)

ង. សូមចែកទីបន្ទាល់របស់អ្នកអំពីសារសំខាន់នៃការធ្វើអំពើឲ្យខ្លួនយើង និង ការស្វែងរកដើម្បីនាំមកនូវសេចក្តីសុចរិតដ៏ខ្លាំង ។

ក្រុមទី ២ ៖ ការល្បួងល្អ និង ការល្បួងអាក្រក់

ក. សូមអញ្ជើញសិស្សម្នាក់អានប្រយោគទីពីរនៅក្នុង នីហ្វៃទី ២ ២:១៦ ។ សូមសួរសិស្ស ៖ តើពាក្យ *ល្បួង* មានន័យដូចម្តេច ? (អញ្ជើញ បញ្ចុះបញ្ចូល ឬ អូសទាញ ។)

ខ. សូមសួរសិស្ស ៖ តើរបៀបណាខ្លះដែលព្រះវរបិតាសួគ៌ល្បួងយើងឲ្យធ្វើការល្អ ? (សិស្សអាចនិយាយពីការបំផុសគំនិតមកពីព្រះវិញ្ញាណបរិសុទ្ធ ពរជ័យដែលបានសន្យាពេលគោរពតាមព្រះបញ្ញត្តិ និង ការបង្រៀននៃព្យាការីថ្ងៃចុងក្រោយ ។)

គ. សូមអាន នីហ្វៃទី ២ ២:១៧–១៨ ឮៗ ហើយសូមអញ្ជើញសិស្សអានតាមនៅក្នុងព្រះគម្ពីររបស់ពួកគេ ។ សុំឲ្យពួកគេស្វែងរកអ្វីដែលអារក្សស្វែងរកពីយើងទាំងអស់គ្នា ។ (វាចង់ឲ្យយើងវេទនា ។)

ឃ. សូមសួរ ៖ តើអ្នកអាចដឹងដោយរបៀបណាថា តើការល្បួងមួយណាដែលមកពីព្រះ ហើយថាមួយណាមកពីអារក្ស ? (ដោយសារជាផ្នែកនៃការពិភាក្សានេះ អ្នកអាចបើកទៅ ម៉ូរ៉ូណៃ ៧:១៦–១៧) ។ ក្រោយពីសិស្សបានឆ្លើយរួចហើយ សូមសួរ ៖ តើឧទាហរណ៍អ្វីខ្លះនៃរឿងទាំងឡាយដែលល្បួងមនុស្សឲ្យធ្វើអាក្រក់ និង វានាំទៅរកសេចក្តីវេទនា ?

ង. សូមចែកចាយទីបន្ទាល់របស់អ្នកអំពីការល្បួងរបស់ព្រះដែលនាំទៅរកអំពើល្អ និង សុភមង្គល ហើយការល្បួងរបស់អារក្សនាំទៅរកអំពើទុច្ចរិត និង សេចក្តីវេទនា ។ ដោយសារជាផ្នែកនៃការទីបន្ទាល់ អ្នកអាចចែកចាយបទពិសោធន៍មួយដើម្បីបង្ហាញពីរបៀបដែលអ្នកដឹងថានេះគឺពិត ។

ក្រុមទី ៣ ៖ យើងត្រូវទទួលខុសត្រូវចំពោះជម្រើសរបស់យើង

ក. សូមអានសេចក្តីថ្លែងការណ៍នេះទៅកាន់សិស្ស ៖

« អ្នកមានសេរីភាពក្នុងការជ្រើសរើស និង ការប្រព្រឹត្ត ប៉ុន្តែអ្នកគ្មានសេរីភាពដើម្បីជ្រើសរើសលទ្ធផលនៃទង្វើរបស់អ្នកឡើយ ។ លទ្ធផលប្រហែលជាមិនកើតឡើងក្នុងពេលភ្លាមៗ តែវានឹងតែងតែអន្ទោលតាមជានិច្ច » (*ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងដំណឹងល្អ* [២០០៤] ទំព័រ ១៩៤) ។

សូមសួរ ៖ តើឧទាហរណ៍អ្វីខ្លះនៃលទ្ធផលដែលប្រហែលជាមិនកើតឡើងភ្លាមៗទេ តែវានឹងអន្ទោលតាមជានិច្ច ? (ចម្លើយមួយដែលអាចនោះគឺថា ជំងឺមហារីកជាញឹកញាប់វាមកពីការជក់បារី ។)

ខ. សូមអញ្ជើញសិស្សអាន នីហ្វៃទី ២ ២:២៦–២៧ ដោយស្ងាត់ស្ងៀម ដោយស្វែងរកពាក្យ និង ឃ្លាដែលបង្ហាញពីលទ្ធផលនៅថ្ងៃអនាគតនៃជម្រើស ដែលយើងជ្រើសរើសក្នុងពេលឥឡូវនេះ ។ សុំឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ (ចម្លើយអាចរួមមាន « ការដាក់ទោសនៃច្បាប់នៅថ្ងៃដ៏អស្ចារ្យ និង ចុងក្រោយ » « ឥស្សរភាព » « ជីវិតដ៏នៅអស់កល្បជានិច្ច » « ការជាប់ឃុំឃាំង » « សេចក្តីស្លាប់ » និង « សេចក្តីរងទុក្ខវេទនា » ។) សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន ។

គ. សូមសួរ ៖ ហេតុអ្វីបានជាអ្នកគិតថា វាសំខាន់ចំពោះយើងដើម្បីយល់ពីលទ្ធផលនៃជម្រើសរបស់យើងនៅក្នុងជីវិតនេះ ? ក្រោយពីសិស្សបានឆ្លើយរួចហើយ សូមសួរ ៖ តើការដឹងពីលទ្ធផលទាំងនេះអាចជម្រុញយើងឲ្យរើសជម្រើសដ៏សុចរិតបានយ៉ាងដូចម្តេច ?

ឃ. សូមចង្អុលបង្ហាញថា នៅក្នុងនីហ្វៃទី ២ ២:២៧ លីហៃបាននិយាយថា យើង « មានសិទ្ធិនឹងរើសយកឥស្សរភាព » ។ សូមសួរ ៖ តាមបទពិសោធន៍របស់អ្នក តើជម្រើសដ៏សុចរិតជួយយើងឲ្យនៅតែមានសិទ្ធិនឹងរើសដោយរបៀបណា ? តើអ្នកអាចផ្តល់ជាឧទាហរណ៍ពីចំណុចនេះបានទេ ? (សូមរៀបចំឲ្យច្បាស់ថាស្រេច ដើម្បីចែកចាយឧទាហរណ៍ផ្ទាល់ខ្លួនអ្នក ។)

ង. សូមចែកចាយទីបន្ទាល់របស់អ្នកថា យើងត្រូវទទួលខុសត្រូវចំពោះព្រះចំពោះជម្រើសរបស់យើង ហើយថាលទ្ធផលនោះតែងតែមកពីជម្រើសរបស់យើងជានិច្ច ។

ក្រុមទី ៤ ៖ ការជ្រើសរើសខាងផ្នែកល្អ

ក. សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ២:២៨ ឮៗ ។ សុំឲ្យសិស្សស្វែងរករឿងបួនយ៉ាង ដែលលីហៃចង់ឲ្យទៅកូនប្រុសរបស់គាត់ ។ ក្រោយពីគេអានខគម្ពីរនេះរួចហើយ សូមអញ្ជើញសិស្សចែកចាយនូវអ្វីដែលពួកគេបានរកឃើញ ។

ខ. សូមសួរ ៖ តើមានរបៀបអ្វីខ្លះដែលយើងអាចមើលទៅកាន់អ្នកជាកណ្តាលដ៏អស្ចារ្យ ជាព្រះយេស៊ូវគ្រីស្ទ ដើម្បីជួយយើងឲ្យជ្រើសរើសសុចរិតត្រឹមត្រូវ ?

គ. សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ២:២៩ ឮៗ ។ សូមសួរសិស្ស ៖ តើជម្រើសរបស់យើងអាចផ្តល់អំណាចដល់អារក្សឲ្យចាប់ឃុំឃាំងយើងដោយរបៀបណា ? ដោយសារជាផ្នែកនៃការពិភាក្សានេះ សូមចង្អុលបង្ហាញថាការល្បួងរបស់សាតាំងជាច្រើនសំដៅទៅលើ « ឆន្ទៈខាងសាច់ឈាម » ឬ ចំណង់ខាងរូបកាយរបស់យើង ។ នៅពេលមនុស្សចុះចាញ់តាមការល្បួងទាំងនេះ ពួកគេអាចញៀននឹងសារធាតុ និង ដំណើរប្រព្រឹត្តដ៏គ្រោះថ្នាក់ទាំងនេះ ។ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ័សុល អិម ណិលសុន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ចេញពីការពិសោធដំបូងមួយ គេគិតថាវាមិនសំខាន់ នោះវដ្តដ៏សាហាវមួយអាចកើតឡើងជាបន្តបន្ទាប់ ។ ចេញពីការសាកល្បងក្លាយទៅជាទម្លាប់មួយ ។ ចេញពីទម្លាប់ មកជាការពឹងផ្អែក ។ ចេញពីការពឹងផ្អែក មកជាការញៀន ។ ការចាប់យករបស់វា គឺបន្តិចម្តងៗ ។ ច្រវាក់ទាសករនៃទម្លាប់នោះ គឺតូចណាស់ដើម្បីស្តាល់វា រហូតដល់វារឹងមាំខ្លាំងបែកចេញមក ។ . . . ក្រោយមក ការញៀនធ្វើឲ្យបាត់បង់សិទ្ធិជ្រើសរើស » (« Addiction or Freedom » *Ensign*ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ទំព័រ ៦–៧) ។

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីភាពសុចរិតដែលនាំទៅកាន់សេរីភាព គេចពីទម្លាប់ និង ការញៀនដ៏មានគ្រោះថ្នាក់ ។

ឃ. សូមអាន នីហ្វៃទី ២ ២:៣០ ទៅកាន់សិស្សក្នុងថ្នាក់ ។ នៅពេលដែលពួកគេស្តាប់តាមនោះ សូមអញ្ជើញពួកគេផ្តោតលើពាក្យទាំងនេះ ៖ « ខ្ញុំបានជ្រើសរើសខាងផ្នែកល្អ ។ » សូមសួរ ៖ តើសេចក្តីថ្លែងការណ៍នេះបានបង្រៀនអ្វីខ្លះអំពីលីហៃ ?

ង. សុំឲ្យសិស្សសញ្ជឹងគិតអំពីសំណួរខាងក្រោម ៖ តើនរណាខ្លះដែលអ្នកស្គាល់ដែល « បានជ្រើសរើសខាងផ្នែកល្អ » ដូចជាលីហៃ ? តើអ្នកនឹងធ្វើតាមគំរូរបស់មនុស្សនេះដោយរបៀបណា ? ក្រោយពីសិស្សមានពេលគ្រប់គ្រាន់សញ្ជឹងគិតហើយ សូមឲ្យសិស្សម្នាក់ ឬពីរនាក់ចែកចាយគំនិតរបស់ពួកគេ ។ បន្ទាប់មក សូមចែកចាយគំនិតផ្ទាល់របស់អ្នក ។

កំណត់សម្គាល់ចំពោះគ្រូបង្រៀន ៖ ដើម្បីបញ្ចប់ សូមអញ្ជើញសិស្សសញ្ជឹងគិតថាតើ ជម្រើសរបស់ពួកគេកំពុងនាំពួកគេទៅកាន់ឥស្សរភាព និង ជីវិតដ៏នៅអស់កល្បជានិច្ច ឬ ទៅកាន់ការជាប់ឃុំឃាំង សេចក្តីស្លាប់ខាងវិញ្ញាណ និង សេចក្តីទុក្ខវេទនា ។ សូមបញ្ជាក់សិស្សថា ជម្រើសដែលមិនល្អណាដែលពួកគេអាចបានធ្វើហើយ អាចយកឈ្នះបានតាមរយៈសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងការប្រែចិត្ត ។ សូមថ្លែងទីបន្ទាល់អំពីព្រះអង្គសង្គ្រោះ ដង្វាយធួនរបស់ទ្រង់ និង សមត្ថភាពរបស់ទ្រង់ដើម្បីពង្រឹងយើងនៅក្នុងការខិតខំរបស់យើង ដើម្បីធ្វើសជម្រើសដែលនឹងនាំទៅរកសុភមង្គល និង ជីវិតដ៏នៅអស់កល្បជានិច្ច ។

ចំណេះចំណានខគម្ពីរ—នីហ្វៃទី ២ ២:២៧

ដើម្បីជួយសិស្សទន្ទេញចាំ នីហ្វៃទី ២ ២:២៧ សូមសរសេរអក្សរទីមួយនៃពាក្យនីមួយៗនៅលើក្តារខៀន តាមដូចខាងក្រោម ៖ *ហ ម ស ស ត ស ហ អ ស ត ជ ដ ព ដ ជ ក ច ដ ម ។ ហ ព ម ស ន រ យ ក ជ យ ន ក ស ស ក ជ យ ន អ រ អ ; ត វ ព ធ ម ទ ម ទ វ ដ វ ដ ។* (អ្នកក៏អាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំវគ្គនេះ នៅក្នុងរបៀបមួយដែលប្លែក ដូច្នេះពួកគេនឹងអាចរកវាឃើញលឿន ។)

សូមឲ្យសិស្សទន្ទេញ នីហ្វៃទី ២ ២:២៧ រួមគ្នា (ដោយប្រើព្រះគម្ពីររបស់ពួកគេតាមត្រូវការ) រហូតដល់ពួកគេអាចចាំខគម្ពីរទាំងមូលដោយប្រើតែអក្សរទីមួយដើម្បីជួយដល់ពួកគេ ។ បន្ទាប់មក សូមលុបអក្សរបឋមបួន ហើយឲ្យពួកគេទន្ទេញបទគម្ពីររួមគ្នាម្តងទៀត ។ សូមបន្តដំណើរការនេះ រហូតដល់អក្សរទាំងអស់លុបចេញ ហើយសិស្សអាចទន្ទេញចាំខគម្ពីរទាំងមូលរត់មាត់ ។ ដោយសារជាផ្នែកនៃការពិភាក្សា អ្នកអាចចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមពីអែលឌើរ រីឆាដ ជី ស្កត នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖ « បទគម្ពីរដែលចងចាំមួយ ក្លាយជាមិត្តដែលចេះអត់ធ្មត់ស៊ូទ្រាំដែលមិនអាចបំបាក់ដោយវគ្គនៃពេលវេលាឡើយ » (« អំណាចនៃព្រះគម្ពីរ » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៦) ។

កំណត់សម្គាល់ ៖ អ្នកអាចមានពេលប្រើប្រាស់សកម្មភាពនេះ នៅពេលចំណុចខ្លះក្នុងមេរៀននេះ ។ ប្រសិនបើអ្នកមិនមានពេលទេ សូមគិតថានឹងប្រើវានៅក្នុងមេរៀនក្រោយទៀត ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ២ ២:២៩ ។ « ចំណង់ខាងសាច់ឈាម និង សេចក្តីអាក្រក់ដែលនៅក្នុងនោះ »

ខគម្ពីរនេះ មិនមែនមានន័យថា រូបកាយរបស់យើងគឺជាសេចក្តីអាក្រក់នោះទេ ។ ជាជាងនោះ វាពិពណ៌នាពីផ្នែកមួយនៃស្ថានភាពធ្លាក់របស់យើង ។ *ពិតចំពោះសេចក្តីជំនឿ* រួមមានការពន្យល់នេះ ៖ « នៅក្នុងស្ថានភាពធ្លាក់នេះ យើងមានបែតិ្តមួយនៅក្នុងខ្លួនយើង ។ យើងគឺជាកូនចៅខាងវិញ្ញាណរបស់ព្រះ ដោយសក្តានុពលដើម្បីឲ្យ ‹ អ្នករាល់គ្នាបានចំណែកជានិស្ស័យនៃព្រះ › (ពេត្រុសទី ២ ១:៤) ។ ទោះយ៉ាងណាក្តី ‹ យើងខ្ញុំនេះ មិនសក្តិសមនៅចំពោះ [ព្រះអង្គ] ទេ ; ដោយសារការធ្លាក់ នោះធម្មជាតិនៃយើងខ្ញុំបានក្លាយទៅជាអាក្រក់ជានិច្ច › (អេធើរ ៣:២) ។ យើងត្រូវខំប្រឹងជានិច្ចដើម្បីយកឈ្នះលើចំណង់ និង បំណងដែលមិនសុចរិត » (*ពិតចំពោះសេចក្តីជំនឿ ៖ ឯកសារយោងដំណឹងល្អ*[២០០៤]ទំព័រ ៥៧) ។

នីហ្វៃទី ២៣

សេចក្តីផ្តើម

នីហ្វៃទី ២៣រួមមានពាក្យសម្តីរបស់លីហៃទៅកាន់កូនពៅរបស់គាត់ គឺយ៉ូសែប ។ លីហៃបានរ៉ាយរ៉ាប់ការព្យាករណ៍ដោយ យ៉ូសែបនៃស្រុកអេសីព្ទ ទាក់ទងនឹងតួនាទីរបស់ព្យាការីយ៉ូសែប ស្ម៊ីធ ការចេញមកនៃព្រះគម្ពីរមរមន និង ការស្តារឡើងវិញនៃដំណឹងល្អ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ៣:១–២៥

លីហៃរៀបរាប់ពីការព្យាករណ៍ដោយ យ៉ូសែបនៃស្រុកអេហ្ស៊ីបអំពីព្យាការីយ៉ូសែប ស្ម៊ីធ ។

មុនចាប់ផ្តើមថ្នាក់ សូមគូរឌីយ៉ាក្រាមខាងក្រោមនៅលើក្តារខៀន ។

ដើម្បីឲ្យសិស្សយល់ពីការបង្រៀននៅក្នុង នីហ្វៃទី ២ ៣ នេះ សូមប្រាប់ពួកគេថា ជំពូកនេះរួមមានសាច់រឿងអំពីបុរសបួននាក់ដែលមាន



នាមដូចគ្នា ។ សូមអញ្ជើញសិស្សស្រាវជ្រាវព្រះគម្ពីរយោងដែលនៅខាងក្រោមរូបភាពនៅលើក្តារខៀនឲ្យលឿន ដើម្បីសម្រេចថានរណាតំណាងឲ្យរូបភាពមួយៗ ។ នៅពេលសិស្សម្នាក់រកឃើញចម្លើយហើយ សូមឲ្យគាត់ ឬ នាងសរសេរវានៅលើក្តារខៀន ។ (រូបភាពទីមួយតំណាងឲ្យ យ៉ូសែបជាកូនប្រុសរបស់លីហៃ ។ ទីពីរ តំណាងឲ្យព្យាការី យ៉ូសែប ដែលត្រូវបានលក់ទៅឯអេហ្ស៊ីប ប្រហែលជា ១៧០០ ឆ្នាំមុនការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ។ ទីបី តំណាងឲ្យព្យាការី យ៉ូសែប ស្ម៊ីធ ។ ទីបួន តំណាងឲ្យ យ៉ូសែប ស្ម៊ីធ សឺញ៉ូរ ។)

សូមបង្ហាញរូបភាពមួយរបស់ព្យាការី យ៉ូសែប ស្ម៊ីធ ដូចជាបងប្រុស យ៉ូសែប (៦២១៦១; *សៀវភៅរូបភាពដំណឹងល្អ* [២០០៩] លេខ ៨៧) ។ សូមប្រាប់សិស្សថា ភាគច្រើននៃនីហ្វៃទី ២ ៣ ផ្តោតសំខាន់លើការព្យាករណ៍ដោយ យ៉ូសែបនៃស្រុកអេហ្ស៊ីបអំពីព្យាការី យ៉ូសែប ស្ម៊ីធ ។

សូមអញ្ជើញសិស្សបីនាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង នីហ្វៃទី ២ ៣:៦–៨ ។ សុំឲ្យសិស្សស្វែងរកពាក្យ និង ឃ្លាដែលយ៉ូសែបនៃស្រុកអេហ្ស៊ីប បានប្រើដើម្បីពិពណ៌នាយ៉ូសែប ស្ម៊ីធ និង កិច្ចការដែលគាត់នឹងសម្រេចបាន ។ (អ្នកគួរតែពន្យល់ថា នៅពេលដែលយ៉ូសែបនៃស្រុកអេហ្ស៊ីប បានប្រើឃ្លា « ផលនៃពោះលោក » គាត់សំដៅទៅកូនចៅរបស់គាត់ ។) នៅលើក្តារខៀន ខាងក្រោមរូបភាពដែលតំណាងឲ្យយ៉ូសែប ស្ម៊ីធ សូមសរសេរពាក្យ និង ឃ្លាដែលសិស្សរកឃើញ ។ ពួកគេគួរតែស្វែងរកឃ្លាដូចជា « អ្នកមើលឆុតដ៏ជម្រើសចំពោះផលនៃពោះរបស់ខ្ញុំ » « បានតម្កើងខ្ពស់ » « ដើម្បីនាំឲ្យពួកគេស្គាល់នូវសេចក្តីសញ្ញាទាំងឡាយ » និង « យើងនឹងធ្វើឲ្យគាត់ទៅជាធំនៅចំពោះភ្នែកយើង ។ »

- **នៅពេលយើងបានសិក្សា នីហ្វៃទី ២ ៣:៦–៨ តើអ្នកបានរៀនអ្វីខ្លះអំពីព្យាការី យ៉ូសែប ស្ម៊ីធ ? (សូមជួយសិស្សឲ្យយល់ថា ព្រះអម្ចាស់បានលើកព្យាការី យ៉ូសែប ស្ម៊ីធ ឡើង ដើម្បី ជួយនាំមកនូវការស្តារឡើងវិញនៃដំណឹងល្អ ។)**

សូមអញ្ជើញសិស្សអាន នីហ្វៃទី ២ ៣:១១–១៥ដោយស្ងាត់ស្ងៀម ។ សុំឲ្យពួកគេស្រាវជ្រាវរកឃ្លាបន្ថែមទៀត អំពីអ្វីដែលព្រះនឹងសម្រេចបានតាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ ។ នៅពេលដែលពួកគេមានពេលគ្រប់គ្រាន់ដើម្បីសិក្សាខគម្ពីរទាំងនេះហើយ សូមសួរពីអ្វីដែលពួកគេបានរកឃើញ ។ សូមបន្តែមចម្លើយរបស់ពួកគេទៅលើបញ្ជីនៅលើក្តារខៀនខាងក្រោមរូបភាពដែលតំណាងឲ្យព្យាការី យ៉ូសែប ស្ម៊ីធ ។ (ចម្លើយអាចរួមមាន « នាំពាក្យរបស់យើង » « ចេញពីភាពទន់ខ្សោយ អ្នកនោះនឹងត្រូវបានធ្វើឲ្យមាំមួន » « អ្នកណាដែលស្វែងរកបំផ្លាញលោក នោះនឹងត្រូវបំផ្លាញចោល » និង « ត្រូវបានហៅ . . . តាមឈ្មោះឪពុកលោក ។ »)

ដើម្បីជួយសិស្សយល់បន្ថែមទៀត និង សញ្ជឹងគិតអំពីតួនាទីរបស់ព្យាការី យ៉ូសែប ស្ម៊ីធ នៅក្នុងការស្តារឡើងវិញនៃដំណឹងល្អ សូមអាន នីហ្វៃទី ២ ៣:១១ ឮៗ ដោយផ្តល់ការសង្កត់ធ្ងន់ពិសេសទៅលើឃ្លា « អំណាចឲ្យនាំពាក្យរបស់យើង » ។

- តើឧទាហរណ៍អ្វីខ្លះនៃព្រះបន្ទូលរបស់ព្រះដែលយ៉ូសែប ស៊្មីធ បាននាំមក ? (ចម្លើយអាចរួមមាន ព្រះគម្ពីរមរមន , គោលលទ្ធិ និង សេចក្តីសញ្ញា , មុក្តាដ៏មានតម្លៃមហិមា , ការបកប្រែរបស់យ៉ូសែប ស៊្មីធ និង ការបង្រៀនផ្ទាល់របស់ព្យាការី ។)

នៅក្នុងវគ្គនៃការពិភាក្សានេះ សូមប្រាកដដើម្បីបង្ហាញថា យ៉ូសែបនៃស្រុកអេហ្ស៊ីប បានព្យាករណ៍ថា ព្យាការី យ៉ូសែប ស៊្មីធ នឹងនាំមកនូវព្រះគម្ពីរមរមន ។ អ្នកគួរតែពន្យល់ថា នីហ្វៃទី ២ ៣:១២ បានលើកឡើងសៀវភៅពីរ ៖ សៀវភៅសរសេរដោយកូនចៅរបស់យ៉ូសែបនៃស្រុកអេហ្ស៊ីប គឺជាព្រះគម្ពីរមរមន និង សៀវភៅដែលសរសេរដោយកូនចៅសាសន៍យូដា គឺជាព្រះគម្ពីរបរិសុទ្ធ ។ អ្នកអាចចង់ផ្តល់យោបល់ថា សិស្សគួរតែកត់ត្រាការពន្យល់ទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

សូមអញ្ជើញសិស្សស្រាវជ្រាវរកឃ្លានៅក្នុង នីហ្វៃទី ២ ៣:១២ ដែលពិពណ៌នាឥទ្ធិពលដែលព្រះគម្ពីរមរមន និង ព្រះគម្ពីរបរិសុទ្ធនឹងមានលើពិភពលោក នៅពេលដែលទាំងពីរ « ត្រូវបានរួមទៅជាមួយគ្នា ។ » (ឧទាហរណ៍ សិស្សអាចស្វែងរក « ការផ្ទាល់ផ្ទាលនូវគោលលទ្ធិច្បាស់លាស់ទាំងឡាយ » « ការបង្ក្រាបការទាស់ទែងគ្នាទាំងប៉ុន្មាន » និង « ការបង្កើតឲ្យមានសេចក្តីសុខសាន្ត ។ »)

ដើម្បីជួយសិស្សឲ្យគិតអំពីរបៀបដែលព្រះគម្ពីរមរមន បានមានឥទ្ធិពលនៅក្នុងជីវិតរបស់ពួកគេ សូមសួរ ៖

- តើនៅពេលណាដែលអ្នកមានបទពិសោធន៍អំពីអំណាចនៃព្រះគម្ពីរមរមននៅក្នុងជីវិតរបស់អ្នក ឬ បានឃើញឥទ្ធិពលរបស់វានៅក្នុងជីវិតរបស់មិត្តភក្តិ ឬ សមាជិកគ្រួសារ ?

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ៣:១៥ឮៗ ។ សូមឲ្យថ្នាក់ផ្តល់ការយកចិត្តទុកដាក់ជាពិសេសទៅលើឃ្លា « នាំប្រជាជនខ្ញុំទៅកាន់សេចក្តីសង្គ្រោះ » ។

- តើតាមរបៀបណាដែលព្រះគម្ពីរមរមនបានជួយនាំប្រជាជនទៅកាន់សេចក្តីសង្គ្រោះ ?
- តើព្រះគម្ពីរមរមនបានធ្វើឲ្យមានភាពខុសគ្នាអ្វីខ្លះនៅក្នុងជីវិតរបស់អ្នក ?

ដើម្បីជួយសិស្សឲ្យយល់ និង កោតសរសើរបេសកកម្មដែលបានតែងតាំងតាំងពីមុនលោកិយមកម៉្លេះចំពោះព្យាការី យ៉ូសែប ស៊្មីធ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមឮៗដោយប្រធាន ព្រិកហាំ យ៉ង់ ៖

« វាគឺជាច្បាប់នៅក្នុងការប្រឹក្សាអំពីភាពដ៏អស់កល្បជានិច្ច ជាយូរយារមកហើយ ពីមុនពេលគ្រឹះនៃផែនដីត្រូវបានដាក់ ថាគាត់គឺជាយ៉ូសែប ស៊្មីធ គួរតែជាបុរស នៅក្នុងគ្រាកាន់កាប់ត្រួតត្រាចុងក្រោយបំផុតនៃពិភពលោក ដើម្បីនាំមកនូវព្រះបន្ទូលរបស់ព្រះដល់មនុស្សលោក ហើយទទួលភាពពេញលេញនៃកូនសោទាំងឡាយ និងអំណាចនៃបព្វជិតភាពនៃព្រះរាជបុត្រារបស់ព្រះ ។ព្រះអម្ចាស់បានទតមើលគាត់ និង ឪពុករបស់គាត់ ហើយដល់ជីតារបស់គាត់ ហើយដល់បុព្វបុរសរបស់ពួកគេរាប់ត្រឡប់ . . . ដល់លោកអ័ដាម ។ ទ្រង់បានទតមើលគ្រួសារនោះ និង ខ្សែលោហិតនោះ ដោយសារវាបានត្រាច់ចរពីប្រភពរបស់វាទៅដល់កំណើតរបស់បុរសនោះ ។

គាត់ត្រូវបានតែងតាំងពីកាលនៅក្នុងភាពអស់កល្បដើម្បីគ្រប់គ្រងលើគ្រាកាន់កាប់ត្រួតត្រាចុងក្រោយនេះ » (*Discourses of Brigham Young,* sel. John A. Widtsoe [១៩៥៤] ទំព័រ ១០៨) ។

សូមសង្ខេបនីហ្វៃទី ២ ៣:១៦–២៤ ដោយការពន្យល់ថា យ៉ូសែបនៃស្រុកអេហ្ស៊ីបបានប្រៀបធៀបយ៉ូសែប ស៊្មីធ ទៅនឹងម៉ូសេ ។ សូមឲ្យសិស្សស្វែងរកពាក្យ និង ឃ្លាដែលពិពណ៌នាព្យាការី យ៉ូសែប ស៊្មីធ នៅក្នុងនីហ្វៃទី ២ ៣:២៤ ។ នៅពេលពួកគេចែកចាយពាក្យ និង ឃ្លាទាំងឡាយដែលពួកគេបានរកឃើញ សូមបន្ថែមចម្លើយរបស់ពួកគេទៅលើបញ្ជីលើក្តារខៀននោះ ។

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោម ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ។ សុំសិស្សឲ្យស្តាប់រកសេចក្តីពិតដែលបានបង្ហាញតាមរយៈព្យាការី យ៉ូសែប ស៊្មីធ ៖

« សូមអនុញ្ញាតឲ្យខ្ញុំលើកឡើងនូវគោលលទ្ធិ និង ការអនុវត្តន៍ពីរបីក្នុងចំណោមគោលលទ្ធិ និង ការអនុវត្តន៍ជាច្រើនដែលបែងចែកយើងចេញពីសាសនាចក្រផ្សេងទៀតទាំងអស់ និង អ្វីៗទាំងអស់ដែលបានមកពីវិវរណៈទៅដល់ព្យាការីយុគជំទង់ [យ៉ូសែប ស៊្មីធ] ។ . . .

« ចំណេះដឹងនៃអាទិទេព ។ . . .

« ព្រះគម្ពីរមរមន ។ . . .

« . . . បព្វជិតភាពដែលបានស្តារឡើងវិញ ។ . . .

« . . . ផែនការសម្រាប់ជីវិតគ្រួសារដ៏នៅអស់កល្បជានិច្ច ។ . . .

« ភាពសុចរិតនៃកូនក្មេងតូចៗ ។ . . .

« . . . គោលលទ្ធិនៃសេចក្តីសង្គ្រោះដ៏អស្ចារ្យសម្រាប់មរណជន ។ . . .

« លក្ខណៈដ៏នៅអស់កល្បជានិច្ចរបស់មនុស្ស ។ . . .

« . . . គោលការណ៍នៃវិវរណៈនាសម័យទំនើប ។ . . .

« . . . អំឡុងពេលខ្លីនៃអាយុជីវិត ៣៨ និង មួយឆ្នាំកន្លះរបស់គាត់ មានការចាក់បង្ហូរនូវចំណេះដឹង អំណោយទាន និង គោលលទ្ធិដ៏ឥតប្រៀបផ្ទឹមបានតាមរយៈគាត់ » («រឿងដ៏អស្ចារ្យដែលព្រះបានបើកសម្តែង » *Ensign*ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៥ ទំព័រ ៨០–៨៣) ។

សូមអញ្ជើញសិស្សបន្ថែមបញ្ជីរបស់ប្រធាន ហ៊ិងគ្លី ទៅលើបញ្ជីនៅលើក្តារខៀន ។

សុំឲ្យសិស្សអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៥:៣ ព.ឯ ។ សូមពន្យល់ថា អែលឌើរ យ៉ូហាន ថេលើរ នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ដែលក្រោយមកបានក្លាយជាប្រធានទីបីនៃសាសនាចក្រ បានសរសេរពាក្យទាំងនេះមិនយូរប៉ុន្មានក្រោយពីមរណភាពរបស់ព្យាការី យ៉ូសែប ស៊្មីធ ។ សុំឲ្យសិស្សស្វែងរកចំណុចទាំងអស់ដែលមាននៅក្នុងខគម្ពីរនេះ ដែលពួកគេអាចបន្ថែមលើបញ្ជីនៅលើក្តារខៀន ។ សូមបន្ថែមចម្លើយរបស់ពួកគេទៅលើបញ្ជី ។

សុំឲ្យពេលវេលាដល់សិស្សរំឭកបញ្ជីនៅលើក្តារខៀន ។ សូមអញ្ជើញពួកគេឲ្យសញ្ជឹងគិតពីអ្វីដែលពួកគេបានរៀនអំពីតួនាទី របស់ព្យាការី យ៉ូសែប ស៊្មីធ ។ សូមអញ្ជើញពួកគេគិតអំពីអ្វីដែលពួកគេដឹង និង មានអារម្មណ៍អំពីព្យាការីដោយការសរសេរចម្លើយមួយចំពោះសំណួរមួយក្នុងចំណោមសំណួរខាងក្រោមនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ៖

- តើអ្នកបានរៀន ឬ មានអារម្មណ៍អ្វីនៅថ្ងៃនេះ ដែលបានពង្រឹងទីបន្ទាល់របស់អ្នកអំពីព្យាការី យ៉ូសែប ស៊្មីធ ?
- តើយ៉ូសែប ស៊្មីធ បានធ្វើ បង្រៀន ឬ ស្តារឡើងវិញអ្វីខ្លះដែលអ្នកមានអារម្មណ៍ថា « ជាប្រយោជន៍ដ៏ធំ » (នីហ្វៃទី ២ ៣:៧) ចំពោះអ្នក ?

សូមបំបែកសិស្សធ្វើការជាគូៗ ។ សូមលើកទឹកចិត្តពួកគេឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីព្យាការី យ៉ូសែប ស៊្មីធ ជាមួយគ្នាទៅវិញទៅមក ។ ប្រសិនបើអ្នកមានពេល អ្នកអាចលើកទឹកចិត្តសិស្សខ្លះឲ្យចែកចាយជាមួយនឹងថ្នាក់ទាំងមូល ។ សូមចែកចាយទីបន្ទាល់ផ្ទាល់ខ្លួនរបស់អ្នកថា ព្រះបានលើក យ៉ូសែប ស៊្មីធ ឡើងឲ្យនាំមកនូវការស្តារឡើងវិញ ។ សូមអញ្ជើញសិស្សរបស់អ្នក ឲ្យស្វែងរករបៀប ដើម្បីចែកចាយទីបន្ទាល់របស់ពួកគេអំពីព្យាការី យ៉ូសែប ស៊្មីធ និង ព្រះគម្ពីរមរមនជាមួយនឹងអ្នកដទៃដែលពោរពេញដោយការអធិស្ឋាន ជាពិសេសមិត្តភក្តិ និង គ្រួសាររបស់ពួកគេ ។

សំណួរអំពីអារម្មណ៍

ប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយបានប្រឹក្សាដល់គ្រូបង្រៀនទាំងអស់ឲ្យសួរសំណួរដែល « អញ្ជើញបុគ្គលម្នាក់ៗឲ្យស្រាវជ្រាវរកការចង់ចាំរបស់ពួកគេអំពីអារម្មណ៍ ។ » គាត់បានមានប្រសាសន៍ថា « ក្រោយពីសួរហើយ យើងអាចរង់ចាំដោយឆ្លាតវៃមួយរយៈសិន មុនពេលការហៅនរណាម្នាក់ឲ្យឆ្លើយតប ។ ទោះបីជាអ្នកដែលមិនបាននិយាយសោះ នឹងបានគិតអំពីបទពិសោធន៍ខាងវិញ្ញាណ ។ នោះនឹងអញ្ជើញព្រះវិញ្ញាណ » (« ព្រះអម្ចាស់នឹងបន្ថែមការច្រូតកាត់ » [និយាយទៅកាន់អ្នកអប់រំសាសនា CES នៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៧] ទំព័រ ៦ si.lds.org) ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ២ ៣:១២ ។ របៀបដែលព្រះគម្ពីរមរមន និង ព្រះគម្ពីរបរិសុទ្ធនឹង « ត្រូវរួមទៅជាមួយគ្នា »

មិនយូរក្រោយពីការផ្សព្វផ្សាយជាសាធារណៈនៃការបោះពុម្ពរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៃព្រះគម្ពីរបរិសុទ្ធរបស់ស្តេចយ៉ាកុប ដោយមានការណែនាំតាមប្រធានបទរបស់វា និង លេខយោងរបស់វាដែលយោងលក់ការងារតាមបទដ្ឋានទាំងអស់ ប្រធាន ប៊ិចម៍ យេ ផាកគឺ នៃក្លុំមនៃពួកសាវកដប់ពីរនាក់បានពន្យល់ថា ៖ « ព្រះគម្ពីរសញ្ញាចាស់ និង ព្រះគម្ពីរសញ្ញាថ្មី . . . និង ព្រះគម្ពីរមរមន . . . ឥឡូវគឺត្រូវត្រាប់ចូលគ្នាក្នុងរបៀបមួយដែល នៅពេលអ្នកអានយ៉ាងផ្ទិតផ្ទង់លើមួយ នោះអ្នកនឹងត្រូវទាក់ចិត្តទៅមួយទៀត ។ នៅពេលអ្នករៀនពីមួយ អ្នកនឹងត្រូវបានបំភ្លឺដោយមួយទៀត ។ ពួកគេពិតជារបស់មួយនៅក្នុងដៃរបស់យើង » (« ព្រះគម្ពីរ » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨២ ទំព័រ ៥៣) ។

នីហ្វៃទី ២ ៣:១៨ ។ តើនរណាជាអ្នកនិយាយ ?

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃក្លុំមនៃពួកសាវកដប់ពីរនាក់បានផ្តល់យោបល់លើអត្តសញ្ញាណរបស់មនុស្សដែលត្រូវបាននិយាយអំពីនៅក្នុង នីហ្វៃទី ២ ៣:១៨ ។ ៣ក្យនៅក្នុងវង្វង់ក្រចកគឺជាការបន្ថែមរបស់អែលឌើរ ម៉ាក់ខន់ឃី ។ គាត់បានមានប្រសាសន៍ថា ៖ « សូមកត់ចំណាំ៣ក្យទាំងនេះរបស់ព្រះអម្ចាស់ ៖ ‹ ហើយយើង មើលចុះ យើងនឹងប្រទានដល់គាត់ [មរមន] ដើម្បីឲ្យគាត់សរសេរ៣ក្យរបស់ផលនៃពោះអ្នក [សាសន៍លេមិន] សម្រាប់ផលនៃពោះអ្នក [សាសន៍នីហ្វៃ] ហើយអ្នកនិយាយពីពោះអ្នកនឹងប្រកាសរឿងនោះ ។ នោះគឺជាអ្វីដែលមរមនបានសរសេរទុកជាព្រះគម្ពីរមរមន ប៉ុន្តែអ្វីដែលគាត់បានសរសេរនោះ ត្រូវបានដកចេញពីការសរសេរនៃព្យាការីសាសន៍នីហ្វៃ ហើយការសរសេរទាំងនេះ ដោយត្រូវបានចងក្រងទៅជាសៀវភៅមួយ ត្រូវបានបកប្រែដោយព្យាការីយ៉ូសែប ស៊្មីធ និង ត្រូវបាននាំចេញមកដោយគាត់ទៅដល់សាសន៍លេមិន » (*A New Witness for the Articles of Faith* [១៩៨៥] ទំព័រ ៤២៦) ។

មេរៀនសិក្សានៅផ្ទះ

នីហ្វៃទី ១ ២០–នីហ្វៃទី ២ ៣ (មេរៀនទី ៥)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀននៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនការសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និង គោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេសិក្សាក្នុង នីហ្វៃទី ១ ២០ ដល់ នីហ្វៃទី ២ ៣ (មេរៀនទី ៥) មិនមែនមានបំណងដើម្បីត្រូវបានបង្រៀនជាផ្នែកមួយនៃមេរៀនរបស់អ្នក ។ មេរៀនដែលអ្នកបង្រៀនសម្រាប់មេរៀនទី ៥ ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីទាំងនេះ ។ សូមធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណ នៅពេលអ្នកគិតអំពីតម្រូវការនៃសិស្សរបស់អ្នក ។

ថ្ងៃទី ១ (នីហ្វៃទី ១ ២០–២២)

នៅពេលនីហ្វៃបានដកស្រង់ការព្យាករណ៍ខ្លះរបស់អេសាយទៅកាន់បងប្រុសរបស់គាត់ សិស្សបានដឹងថា ព្រះអម្ចាស់អញ្ជើញអ្នកដែលមិនបានគោរពដើម្បីប្រែចិត្ត និង ត្រឡប់ទៅកទ្រង់វិញ ។ នេះបង្ហាញយើងថា ព្រះអម្ចាស់ស្រឡាញ់យើង និង មិនដែលបំភ្លេចយើងនោះទេ ។ សិស្សក៏បានដឹងដែរថា ទោះបីជាអ៊ីស្រាអែលនឹងត្រូវបានខ្ចាត់ខ្ចាយដោយសារការមិនគោរពតាមរបស់ពួកគេ នោះព្រះអម្ចាស់បានសន្យាថានឹងស្តារឡើងវិញនូវដំណឹងល្អ និង ប្រមូលផ្តុំអ៊ីស្រាអែលនៅក្នុងថ្ងៃចុងក្រោយ ។

ថ្ងៃទី ២ (នីហ្វៃទី ២ ១)

សិស្សបានសិក្សាការបង្រៀនចុងក្រោយរបស់លីហៃទៅកាន់គ្រួសាររបស់គាត់ មុនពេលគាត់បានស្លាប់ ។ លីហៃបានសង្កត់ធ្ងន់ថា ព្រះអម្ចាស់បានប្រទានពរយើង នៅពេលយើងរក្សាព្រះបញ្ញត្តិរបស់ទ្រង់ ហើយថាទ្រង់នឹងឈប់ប្រទានពរ នៅពេលយើងមិនគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ។ នៅពេលលីហៃបានដឹងថា គាត់នឹងស្លាប់ឆាប់ៗ នោះគាត់បានជាស់តឿនគ្រួសាររបស់គាត់ឲ្យធ្វើតាមនីហ្វៃ ។ សិស្សបានឃើញថា នៅពេលយើងធ្វើតាមអ្នកដែលព្រះបានហៅឲ្យដឹកនាំយើង យើងនឹងត្រូវបានប្រទានពរឲ្យមានការរីកចម្រើន និង សុវត្ថិភាពខាងវិញ្ញាណ ។

ថ្ងៃទី ៣ (នីហ្វៃទី ២ ២)

លីហៃបានពន្យល់ដល់កូនប្រុសរបស់គាត់ យ៉ាកុប ពីសេចក្តីពិតគ្រឹះពីរ ៖ (១) ថាការធ្លាក់របស់អ័ដាម និង អេវ៉ាគឺជាផ្នែកមួយដ៏សំខាន់នៃផែនការសុភមង្គលរបស់ព្រះវរបិតាសួគ៌ និង (២) ថាតាមរយៈដង្វាយធួន ព្រះយេស៊ូវគ្រីស្តអាចសង្គ្រោះយើងចេញពីឥទ្ធិពលនៃការធ្លាក់ និង ផ្តល់នូវការប្រោសលោះចេញពីអំពើបាបរបស់យើង ។ លីហៃបានពន្យល់ថា ជាលទ្ធផលនៃការធ្លាក់ និង ដង្វាយធួន យើងមានសេរីភាពដើម្បីជ្រើសរើសឥស្សរភាព និងជីវិតដ៏នៅអស់កល្បជានិច្ច ឬ ការជាប់ឃុំឃាំង និងសេចក្តីស្លាប់ (សូមមើល នីហ្វៃទី ២ ២:២៧) ។

ថ្ងៃទី ៤ (នីហ្វៃទី ២ ៣)

ដោយនិយាយទៅកាន់កូនប្រុសរបស់គាត់ យ៉ូសែប លីហៃបាននិយាយដល់ការព្យាករណ៍របស់យ៉ូសែបនៃស្រុកអេហ្ស៊ីបដែលបានកើយឮនៅលើផ្ទាំងលង្ហិន ។ ការព្យាករណ៍នេះ បានទាយទុកជាមុនថា ព្រះអម្ចាស់បានតម្កើងព្យាការី យ៉ូសែប ស្ម៊ីធ ឡើងដើម្បីជួយនាំមកនូវការស្តារឡើងវិញដំណឹងល្អ ។ សិស្សត្រូវបានសុំឲ្យសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេអំពីរបៀបដែលការរួមចំណែករបស់ព្យាការីយ៉ូសែប ស្ម៊ីធ បានទៅជាប្រយោជន៍ដ៏ធំដល់ពួកគេ ។

សេចក្តីផ្តើម

មេរៀននេះ មានបំណងដើម្បីជួយសិស្សយល់ពីគោលបំណងដ៏នៅអស់កល្បជានិច្ចរបស់ព្រះ ។ លីហៃបានដឹងថា កូនចៅរបស់គាត់អាចធ្វើការជ្រើសរើសដែលនឹងនាំពួកគេទៅរកសេចក្តីអំណរឥស្សរភាព និង ជីវិតដ៏នៅអស់កល្បជានិច្ច ប្រសិនបើពួកគេយល់ និង ជឿលើគោលលទ្ធិគន្លឹះ — ដូចជា ការធ្លាក់ ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ សិទ្ធិជ្រើសរើស និង ការគោរពប្រតិបត្តិ (សូមមើល នីហ្វៃទី ២ ២:២៥, ២៧) ។ សូមលើកទឹកចិត្តសិស្សឲ្យជ្រើសរើសជីវិតដ៏នៅអស់កល្បជានិច្ចដើម្បីនៅទីបញ្ចប់ ពួកគេអាច « ត្រូវបានឱបក្រសោបជាអង្វែងតទៅ ដោយព្រះពាហុនៃសេចក្តីស្រឡាញ់របស់ [ព្រះ] » (នីហ្វៃទី ២ ១:១៥) ដូចជាលីហៃដែរ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ១–២

មុនពេលគាត់ស្លាប់ លីហៃបានជាស់តឿនកូនៗរបស់គាត់ឲ្យកាន់តាមព្រះបញ្ញត្តិរបស់ព្រះ និង បង្រៀនដល់ពួកគេនូវគោលលទ្ធិគ្រឹះអំពីផែនការសង្គ្រោះ

សូមចាប់ផ្តើមដោយការឲ្យសិស្សអានប្រយោគចុងក្រោយគេនៅក្នុងនីហ្វៃទី ២ ៣:២៥ (« ចូរនឹកចាំពាក្យរបស់ឪពុកដ៏ជិតស្លាប់នេះចុះ ») ។ សូមសួរពួកគេថា តើការយកចិត្តទុកដាក់លើការប្រឹក្សារបស់សមាជិកគ្រួសារម្នាក់អាចផ្លាស់ប្តូរបានយ៉ាងដូចម្តេច ប្រសិនបើពួកគេដឹងថាបុគ្គលនោះជិតស្លាប់ហើយ ។

សកម្មភាពខាងក្រោមអាចជួយសិស្សឲ្យយល់កាន់តែច្បាស់ពីសេចក្តីពិតដែលលីហៃបានសង្កត់ធ្ងន់នៅក្នុងពាក្យពាក្យសម្តីចុងក្រោយរបស់គាត់ទៅកាន់គ្រួសាររបស់គាត់ ។ វាក៏នឹងអនុញ្ញាតឲ្យពួកគេចែកចាយជាមួយគ្នាទៅវិញទៅមក ពីរបៀបដែលសេចក្តីពិតទាំងនេះអាចជួយពួកគេឲ្យធ្វើតាមផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់សេចក្តីសង្គ្រោះរបស់ពួកគេ ។

១. សូមឲ្យវគ្គព្រះគម្ពីរខាងក្រោមដល់សិស្សម្នាក់ៗ ឬ ជាដៃគូ ៖ នីហ្វៃទី ២ ១:១៦–២០ ; នីហ្វៃទី ២ ២:៦–១០ ; នីហ្វៃទី ២ ២:១៩–២០, ២២–២៥ ; និង នីហ្វៃទី ២ ២:១១–១៣ ,២៧–២៩ ។ (ប្រសិនបើអ្នកមានសិស្សតិចជាងបួននាក់ អ្នកអាចសម្របសម្រួលសកម្មភាពនេះដោយដាក់ឲ្យសិស្សម្នាក់អានវគ្គព្រះគម្ពីរច្រើនជាងមួយ ដោយជ្រើសរើសវគ្គតិចជាងមុនដើម្បីពិភាក្សា ។)

២. នៅពេលសិស្សសិក្សាវគ្គទាំងនេះ សូមឲ្យពួកគេឆ្លើយតបនឹងសំណួរខាងក្រោមនៅក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ។ (អ្នកអាចគិតសរសេរសំណួរនេះនៅលើក្តារខៀន ។)

ក. តើសេចក្តីពិតគន្លឹះណាមួយ ដែលលីហៃបានបង្រៀន ?

ខ. ហេតុអ្វីបានជាសេចក្តីពិតទាំងនេះសំខាន់សម្រាប់និរន្តរ៍ភាពនៃសុខុមាលភាពយើង ?

៣. ក្រោយពីផ្តល់ពេលឲ្យសិស្សបំពេញកិច្ចការរបស់ពួកគេហើយ សូមអញ្ជើញសិស្សម្នាក់ៗ ឬ ដៃគូឲ្យរាយការណ៍អំពីអ្វីដែលពួកគេបានរកឃើញ ។ សូមលើកទឹកចិត្តសិស្សឲ្យបានកាន់តែច្រើនតាមដែលអាចធ្វើបាន ឲ្យចែកចាយពីអ្វីដែលពួកគេបានរកឃើញ និង ពីមូលហេតុដែលវាមានន័យចំពោះពួកគេ ។

ក្រោយពីសកម្មភាពនេះ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***ការធ្លាក់របស់អ័ដាម និង អេវ៉ាគឺជាផ្នែកមួយដ៏សំខាន់នៃផែនការសុភមង្គលរបស់ព្រះវរបិតាសួគ៌ ។***

សូមចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន យ៉ូសែបហ្វីលឌីង ស្ម៊ីធ ៖

« អ័ដាមគ្រាន់តែធ្វើនូវអ្វីដែលគាត់ត្រូវធ្វើតែប៉ុណ្ណោះ ។ គាត់ទទួលទានផ្លែឈើនោះដោយសារហេតុផលល្អមួយ ហើយនោះគឺដើម្បីបើកទ្វារដើម្បីនាំអ្នក និង ខ្ញុំ និង គ្រប់គ្នាផ្សេងទៀតមកកាន់ពិភពលោកនេះ ។ . . .

« . . . ប្រសិនបើវាមិនមែនដោយសារអ័ដាមទេនោះ ខ្ញុំនឹងមិនអាចនៅទីនេះបានទេ ។ អ្នកនឹងមិនអាចនៅទីនេះនោះទេ ។ យើងនឹងត្រូវរង់ចាំនៅស្ថានសួគ៌ក្នុងសភាពជាវិញ្ញាណ » (នៅក្នុងរបាយការណ៍សន្និសីទ ខែ តុលា ឆ្នាំ ១៩៦៧ ទំព័រ ១២១–២២) ។

សូមសួរសិស្សនូវសំណួរខាងក្រោម ៖

- តើអ្វីខ្លះជាលទ្ធផលនៃការធ្លាក់ ដែលលីហៃបានពិពណ៌នានៅក្នុង នីហ្វៃទី ២ ២:២១–២៤ ?
- តើលទ្ធផលទាំងនេះអាចធ្វើឲ្យវាអាចទៅរួចសម្រាប់យើងដើម្បីកែចម្រើន ស្របទៅតាមផែនការរបស់ព្រះវរបិតាសួគ៌សម្រាប់សេចក្តីសង្គ្រោះរបស់យើងយ៉ាងដូចម្តេច ?

សូមបន្ថែមសេចក្តីពិតខាងក្រោមជាក់លើក្តារខៀន ៖ ***តាមរយៈដង្វាយធួន ព្រះយេស៊ូវគ្រីស្ទអាចសង្គ្រោះយើងចេញពីការធ្លាក់ និង ផ្តល់ការព្រមសោះចេញពីអំពើបាបរបស់យើង ។***

ដើម្បីជួយសិស្សឲ្យទទួលបាននូវការយល់ដឹងកាន់តែជ្រៅជ្រះអំពីសេចក្តីពិតនេះ សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយ អែលឌើរ យ៉ូសែប ប៊ី. វ៉ែតលីន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ដែលជាទង្វើមួយនៃសេចក្តីស្រឡាញ់ដ៏សុទ្ធសាធ បានយកឈ្នះលើឥទ្ធិពលនៃការធ្លាក់ និង ផ្តល់នូវផ្លូវសម្រាប់មនុស្សទាំងអស់ឲ្យត្រឡប់ទៅកាន់វត្តមាននៃព្រះវិញ ។ ដោយសារតែជាផ្នែកនៃដង្វាយធួន ព្រះអង្គសង្គ្រោះបានយកឈ្នះលើសេចក្តីស្លាប់ខាងសាច់ឈាម និង ផ្តល់នូវអមតភាពសម្រាប់មនុស្សគ្រប់គ្នាជាកូនចៅរបស់ព្រះ តាមរយៈការរស់ឡើងវិញ ។ ទ្រង់ក៏បានយកឈ្នះលើសេចក្តីស្លាប់ខាងវិញ្ញាណ និង ផ្តល់ជាសមត្ថភាពមួយនៃជីវិតដ៏នៅអស់កល្បជានិច្ច ជីវិតដែលព្រះរស់នៅ និង ជាអំណោយទានមួយដ៏អស្ចារ្យបំផុតក្នុងចំណោមអំណោយទានដ៏អស្ចារ្យបំផុតនៃព្រះ » (« គ្រីស្ទានៅក្នុងជំនឿ និង សកម្មភាព » *Ensign*ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ទំព័រ ៧១) ។

សូមសួរសិស្ស ៖ តើពរជ័យអ្វីខ្លះដែលមកពីដង្វាយធួន ?

ដើម្បីជួយសិស្សយល់ពីសារសំខាន់នៃសិទ្ធិជ្រើសរើសនៅក្នុងផែនការរបស់ព្រះវរបិតាសួគ៌ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ នែល អេ. ម៉ាក់ស្វែល នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ដោយគ្មានវត្តមាននៃការជ្រើសរើស ដោយគ្មានសិទ្ធិសេរីភាពរបស់យើងក្នុងការជ្រើសរើស និង ដោយគ្មានការផ្ទុយគ្នាទេ នោះក៏គ្មានការបិតនៅពិតប្រាកដដែរ ។ . . . វាជាការពិតមួយដែលយើងមិនអាចធំលូតលាស់ខាងវិញ្ញាណ ឬ ដោយហេតុនោះមានការរីកចម្រើនពិតប្រាកដ លើកលែងតែ និង ទាល់តែយើងធ្វើការប្រើប្រាស់ដោយឆ្លាតវៃលើសិទ្ធិជ្រើសរើសខាងសាច់ឈាមរបស់យើង » (*សំពាធមួយទៀតនៃការសរសើរ* [១៩៩៩]ទំព័រ ៨០) ។

សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***យើងមានសិទ្ធិនឹងរើសយកឥស្សរភាព និង ជីវិតដ៏នៅអស់កល្បជានិច្ច ឬ ក៏រើសយកការជាប់ឃុំឃាំង និង សេចក្តីស្លាប់ ។***

សុំឲ្យសិស្សបើកទៅកិច្ចការទី ៤ នៅថ្ងៃទី ៣ នៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យពន្យល់អ្វីដែលពួកគេបានរៀនអំពីសិទ្ធិជ្រើសរើសពីក្នុង នីហ្វៃទី ២ ២:២៦–២៩ ។

សូមអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយព្យាការី យ៉ូសែប ស្ម៊ីធ ៖

« ដើម្បីទទួលបានសេចក្តីសង្គ្រោះ យើងមិនគ្រាន់តែមិនត្រូវធ្វើរឿងខ្លះៗនោះទេ ប៉ុន្តែមិនធ្វើនូវអ្វីៗដែលព្រះបានបញ្ជា » (*ការបង្រៀនរបស់ប្រធាននៃសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* [២០០៧] ទំព័រ ១៦១) ។

ដើម្បីជួយសិស្សយល់ពីសារសំខាន់នៃការគោរពប្រតិបត្តិ អ្នកអាចសួរសំណួរខាងក្រោម ៖

- ហេតុអ្វីបានជាអ្នកគិតថា លីហៃបានបញ្ជាក់លើការគោរពប្រតិបត្តិនៅក្នុងបណ្តាំចុងក្រោយគាត់ទៅកាន់គ្រួសាររបស់គាត់ មុនពេលគាត់ស្លាប់ ?
- តើបទពិសោធន៍អ្វីដែលអ្នកបានមានដែលបានជួយអ្នកឲ្យដឹងថា **ព្រះអម្ចាស់ប្រទានពរយើងនៅពេលយើងកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ ហើយថាទ្រង់នឹងឈប់ប្រទានពរយើង នៅពេលយើងមិនកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់នោះ** ? (សូមបន្ថែមសេចក្តីពិតនេះទៅលើបញ្ជីនៅលើក្តារខៀន ។)

ដើម្បីបញ្ចប់មេរៀននេះ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ិយដ៍ ឃេ. ផាកគឺ ជាប្រធាននៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ការគោរពប្រតិបត្តិគឺជាឱសថខាងវិញ្ញាណដ៏មានអំណាច ។ វាគឺជាឱសថមួយដ៏ខ្លាំងព្យាបាលគ្រប់ជំងឺ » (« Balm of Gilead » *Ensign*ខែ វិច្ឆិកា ឆ្នាំ ១៩៨៧ ទំព័រ ១៨) ។

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីស្រឡាញ់របស់ព្រះសម្រាប់សិស្សរបស់អ្នក និង អំពីបំណងរបស់ទ្រង់ដើម្បីជួយពួកគេឲ្យយកឈ្នះលើឥទ្ធិពលនៃការធ្លាក់ និង ទទួលបានជីវិតដ៏អស់កល្បជានិច្ច ។

មេរៀនក្រោយ (នីហ្វៃទី ២ ៤–១០)

ក្រោយពីលីហៃស្លាប់ លេមិន និង លេមយួលបានព្យាយាមសម្លាប់នីហ្វៃម្តងទៀត ។ តើព្រះអម្ចាស់បានផ្តល់ការព្រមានអ្វីពេលបានសង្គ្រោះជីវិតរបស់នីហ្វៃ ? ផងដែរ តើនឹងមានអ្វីកើតឡើងចំពោះរាងកាយ និង វិញ្ញាណរបស់យើង ប្រសិនបើគ្មានដង្វាយធួនទេនោះ ? សិស្សនឹងរកឃើញចម្លើយទៅនឹងសំណួរនេះ នៅក្នុងនីហ្វៃទី ២ ៩:៧–៩ ។

នីហ្វៃទី ២ ៤

សេចក្តីផ្តើម

ក្រោយពីការស្លាប់របស់លីហៃ លេមិន និង លេមយួលបានខឹងនឹងនីហ្វៃ « ពីព្រោះតែសេចក្តីជាស់តឿនរបស់ព្រះអម្ចាស់ » ដែលនីហ្វៃបាននិយាយទៅកាន់ពួកគេ (សូមមើល នីហ្វៃទី ២ ៤:១៣–១៤) ។ ដោយមានបញ្ហានឹងតរិយោបថ និង សកម្មភាពរបស់បងប្រុសរបស់គាត់ និង ដោយសារភាពកម្សោយ និង អំពើបាបផ្ទាល់ខ្លួនរបស់គាត់ នីហ្វៃបានកត់ត្រានូវអារម្មណ៍របស់គាត់នៅក្នុងភាសាដ៏បំផុស និង មានកាព្យចាប់ចួនល្អ ។ គាត់បានពិពណ៌នាសេចក្តីស្រឡាញ់របស់គាត់ចំពោះព្រះគម្ពីរ និង ការដឹងគុណរបស់គាត់ចំពោះពរជ័យនានា និង កម្លាំងដែលគាត់បានទទួលមកពីព្រះអម្ចាស់ (សូមមើល នីហ្វៃទី ២ ៤:១៥–៣៥) ។

ការសរសេរនៅលើក្តារខៀន

ការដកស្រង់ ឬ សំណួរដែលបង្ក នូវការបំផុសគំនិតមួយនៅលើក្តារខៀន អាចជួយសិស្សឲ្យចាប់អារម្មណ៍នៅក្នុងមេរៀនមួយ និង នៅបន្តការយកចិត្តទុកដាក់របស់ពួកគេ ។ អ្នកក៏អាចឃើញថាវាជួយច្រើនក្នុងការដាក់សម្ភារមេរៀនដូចជាខយោងព្រះគម្ពីរ តារាងនានា និង ឌីយ៉ាក្រាមនៅលើក្តារខៀន ។ ដោយផ្អែកលើចិរវេលា និង ការប្រើប្រាស់សម្ភារ អ្នកអាចដាក់វាលើក្តារខៀន មុនពេលចាប់ផ្តើមថ្នាក់ ។ វាអាចជួយអ្នកសន្សំពេលក្នុងថ្នាក់ និង បៀសវាងការរំខានដែលមិនចាំបាច់ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ៤:១–១១

លីហៃប្រឹក្សា និង ប្រទានពរដល់គ្រួសាររបស់គាត់

មុនចាប់ផ្តើមថ្នាក់ សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖

ប្រសិនបើអ្នកជាជីដូនដ៏ស្មោះត្រង់ម្នាក់ ហើយកូនរបស់អ្នកមិនបានរស់នៅតាមបទដ្ឋានដំណឹងល្អទេ តើអ្នកនឹងអប់រំចៅរបស់អ្នកយ៉ាងណា ?

សូមចាប់ផ្តើមដោយការអញ្ជើញសិស្សឲ្យឆ្លើយតបនឹងសំណួរនៅលើក្តារខៀន ។ ក្រោយពីសិស្សឆ្លើយហើយ សូមសួរ ៖

- **តើឪពុកម្តាយ និង ជីដូនជីតាមានទំនួលខុសត្រូវអ្វីខ្លះក្នុងការបង្រៀន និង ការប្រឹក្សាដល់កូនៗ ហើយនិង ចៅៗរបស់ពួកខ្លួន ?**

ដោយសារជាផ្នែកនៃការពិភាក្សានេះ អ្នកអាចអាន ឬ សុំឲ្យសិស្សអានសេចក្តីថ្លែងការណ៍ខាងក្រោម ៖

« ឪពុកម្តាយមានកាតព្វកិច្ចដ៏ពិសិដ្ឋ ដើម្បីចិញ្ចឹមបីបាច់កូនចៅរបស់ខ្លួនដោយក្តីស្រឡាញ់ និងដោយសេចក្តីសុចរិត ផ្គត់ផ្គង់សេចក្តីត្រូវការ ទាំងខាងរូបកាយ និងខាងវិញ្ញាណរបស់ពួកគេ និងបង្រៀនពួកគេឱ្យចេះស្រឡាញ់ និងបម្រើគ្នាទៅវិញទៅមក ចេះគោរពព្រះបញ្ញត្តិទាំងឡាយនៃព្រះ ហើយធ្វើជាពលរដ្ឋល្អ ចេះគោរពច្បាប់គ្រប់ទីកន្លែង ដែលពួកគេរស់នៅ ។ ស្វាមី និងភរិយា—ម្តាយ និង ឪពុក—នឹងទទួលខុសត្រូវនៅចំពោះព្រះភ័ក្ត្រព្រះ តាមការប្រតិបត្តិនៃភារកិច្ចទាំងឡាយនេះ ។ . . . ញាតិសន្តានក្រុមគ្រួសារ គួរតែជួយគាំទ្រ នៅពេលមានសេចក្តីត្រូវការ » (« ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Ensign*ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២៩) ។

សូមបង្ហាញនីហ្វៃទី ២ ៤ ដោយការពន្យល់ថា មុនពេលលីហៃស្លាប់ គាត់បានប្រឹក្សាដល់កូនចៅរបស់គាត់ឲ្យកាន់តាមព្រះបញ្ញត្តិរបស់ព្រះ ។ សូមអញ្ជើញសិស្សអាន នីហ្វៃទី ២ ៤:៣–១១ដោយស្វែងរកមនុស្សដែលលីហៃបានបង្រៀន និង ការប្រឹក្សាដែលគាត់បានផ្តល់ដល់ពួកគេ ។

- **តើលីហៃបានបង្រៀនដល់នរណាដែរ ? (សូមមើល នីហ្វៃទី ២ ៤:៣, ៨, ១០–១១ ។)**
- **តើលីហៃបានផ្តល់សេចក្តីសន្យាអ្វីដល់កូនចៅរបស់លេមិន និង លេមយួល ? (សូមមើល នីហ្វៃទី ២ ៤:៧, ៩) ។**
- **ដោយផ្អែកលើនីហ្វៃទី ២ ៤:៥ តើអ្នកនឹងនិយាយអ្វីទៅ ដែលជាទំនួលខុសត្រូវដែលព្រះអម្ចាស់បានផ្តល់ទៅឲ្យឪពុកម្តាយ ? (សិស្សអាចប្រើពាក្យខុសៗគ្នាដើម្បីឆ្លើយតបនឹងសំណួរនេះ ប៉ុន្តែសូមប្រាកដថាពួកគេយល់ថា ឪពុកម្តាយមានទំនួលខុសត្រូវដែលព្រះបានដាក់ឲ្យមួយដើម្បីបង្រៀនដំណឹងល្អដល់កូនចៅរបស់ពួកគេ ។)**
- **តើសេចក្តីពិតអ្វីខ្លះដែលអ្នកបានរៀនពីឪពុកម្តាយ ឬ ជីដូនជីតារបស់អ្នក ?**

សូមលើកទឹកចិត្តសិស្សឲ្យក្លាយជាចំណងដ៏រឹងមាំនៅក្នុងច្រវាក់នៃគ្រួសាររបស់ពួកគេ —ដើម្បីរស់នៅតាមដំណឹងល្អ និង រៀបចំដើម្បីក្លាយជាឪពុកម្តាយដ៏សុចរិត ។ អ្នកអាចបង្ហាញរូបភាពដែលមានចំណងជើង « ចូរធ្វើជាចំណងដ៏រឹងមាំមួយ » (សូមមើល http://lds.org/liahona/2003/09/poster?lang=eng) ។

នីហ្វៃទី ២ ៤:១២–៣៥

នីហ្វៃបានទទួលស្គាល់ភាពកម្សោយរបស់គាត់ និង បានបង្ហាញទំនុកចិត្តរបស់គាត់លើព្រះអម្ចាស់ ។

នៅលើក្តារខៀន សូមសរសេរ *ព្រលឹងខ្ញុំរត្អែកអរចំពោះ* . . .

សុំឲ្យសិស្សសរសេរឃ្លានេះនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ និង ដើម្បីបញ្ចប់សេចក្តីថ្លែងការណ៍ ដោយសរសេរចុះនូវរឿងដែលត្រេកអរដល់ព្រលឹងរបស់ពួកគេ ។

សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ៤:១៥–១៦ឮៗដើម្បីដឹងពីរបៀបដែលនីហ្វៃបានបំពេញឃ្លានេះ ។

- **តើរឿងអ្វីខ្លះដែលយើងអាចធ្វើ ប្រសិនបើព្រលឹងយើងត្រេកអរនៅក្នុងព្រះគម្ពីរ ?**

- តើវាន័យដូចម្តេចចំពោះអ្នកក្នុងការត្រេកអរនៅក្នុងរឿងអ្វីៗរបស់ព្រះអម្ចាស់ ?
- នីហ្វៃបាននិយាយថា ដួងចិត្តរបស់គាត់សញ្ជឹងគិតអំពីរឿងអ្វីៗដែលគាត់បានឃើញ និង បានឮ ។ តើការណ៍នេះមានអត្ថន័យយ៉ាងណាចំពោះអ្នក ?

សូមចង្អុលបង្ហាញថា នីហ្វៃបានទទួលបទពិសោធន៍សេចក្តីអំណរយ៉ាងអស្ចារ្យនៅក្នុងជីវិតរបស់គាត់ ។ ទោះយ៉ាងណាក្តី គាត់ក៏បានជួបប្រទះនឹងទុក្ខលំបាកផងដែរ ។ សូមឲ្យសិស្សអាន នីហ្វៃទី ២ ៤:១២–១៣ដោយស្ងាត់ស្ងៀមដើម្បីស្វែងរកឧបសគ្គខ្លះៗដែលនីហ្វៃបានប្រឈមមុខនៅពេលនោះក្នុងជីវិតរបស់គាត់ ។ (ការស្លាប់របស់លីហៃ និង កំហឹងរបស់លេមិន លេមយួល និង កូនបុស្សរបស់អ៊ីសម៉ាអែល ។)

ឧបសគ្គជាច្រើនរបស់នីហ្វៃបានមកពីសកម្មភាព និង ឥរិយាបថរបស់បងៗគាត់ ។ ប៉ុន្តែនីហ្វៃក៏មានអារម្មណ៍សោកសៅ ដោយសារតែភាពកម្សោយផ្ទាល់ខ្លួនរបស់គាត់ ។ សូមសរសេរលើក្តារខៀន *ចិត្តខ្ញុំសោកសៅព្រោះតែ* . . .

សូមអញ្ជើញសិស្សអាន នីហ្វៃទី ២ ៤:១៧–១៨ ហើយរកមើលមូលហេតុដែលនីហ្វៃមានអារម្មណ៍សោកសៅ ។

នៅពេលសិស្សមានពេលអានខគម្ពីរទាំងនេះហើយ សូមស្នូរពួកគេនូវអ្វីដែលពួកគេបានរកឃើញ ។ សូមនាំចំណាប់អារម្មណ៍របស់ពួកគេលើពាក្យ *វេទនា សាច់ឈាម* និង *រំខាន* នៅក្នុងខគម្ពីរទាំងនេះ ។ សូមពន្យល់ថាពាក្យ *វេទនា* មាននិយមថាទុក្ខលំបាក ឬ មានគុណភាពអន់ ។ នៅក្នុងព្រះគម្ពីរពាក្យ *សាច់ឈាម* ជាញឹកញាប់សំដៅលើភាពកម្សោយដែលយើងមាន ដោយសារយើងរស់នៅក្នុងសភាពដែលធ្លាក់មួយ ។ ពាក្យ *រំខាន* មាននិយមថាឡោមព័ទ្ធ ឬ សង្កត់ពីគ្រប់ទិសទីទាំងអស់ ។

- តើតំរូវអ្វីខ្លះនៃការលំបាកដែលអាចរំខានយើង ? (ចម្លើយអាចរួមមានបញ្ហានៅផ្ទះ សម្ពាធពីមិត្តភក្តិ កិច្ចការសាលាដែលពិបាក និង ការល្បួងទាំងឡាយ ។)

សុំឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ៤:១៩ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំសេចក្តីថ្លែងការណ៍ថា « ទោះជាយ៉ាងណាក៏ដោយ គង់តែខ្ញុំស្គាល់អ្នកដែលខ្ញុំទុកចិត្ត ។ » សូមចង្អុលបង្ហាញថា នៅក្នុងនីហ្វៃទី ២ ៤:១៩ ពាក្យពាក្យសម្តីរបស់នីហ្វៃផ្លាស់ប្តូរពីភាពក្រៀមក្រំទៅជាសេចក្តីសង្ឃឹម ។

- តើអ្នកគិតថា នីហ្វៃចង់មាននិយមយ៉ាងណា នៅពេលគាត់បាននិយាយថា « ខ្ញុំស្គាល់អ្នកដែលខ្ញុំទុកចិត្ត » ?
- តើការចងចាំព្រះអម្ចាស់ និង ការណ៍ល្អរបស់ទ្រង់អាចជួយយើងក្នុងពេលយើងបាក់ទឹកចិត្តយ៉ាងដូចម្តេច ?

សូមអាន នីហ្វៃទី ២៤:២០–២៥ ឮៗ ។ សុំឲ្យសិស្សអានតាមនៅក្នុងព្រះគម្ពីររបស់ពួកគេ ។ សូមអញ្ជើញពួកគេឲ្យស្វែងរកពាក្យ និង ឃ្លាដែលបង្ហាញថា **ព្រះគាំទ្រអ្នកដែលដាក់ទីទុកចិត្តរបស់ពួកគេលើទ្រង់ ។**

- តើពាក្យ ឬ ឃ្លាណាមួយនៅក្នុង នីហ្វៃទី ២ ៤:២០–២៥ដែលអ្នកឃើញថាមានន័យខ្លាំង ? ហេតុអ្វី ?
- សូមគិតអំពីពេលមួយ នៅពេលដែលព្រះអម្ចាស់គាំទ្រអ្នក ឬ ជួយអ្នកនៅក្នុងពេលលំបាកមួយ ។ តើទ្រង់បានជួយអ្នកដោយរបៀបណា ? តើបទពិសោធន៍នោះបានជះឥទ្ធិពលលើអ្នកយ៉ាងដូចម្តេច ?

វាអាចជួយច្រើនបើផ្តល់ពេលដល់សិស្សគិតអំពីបទពិសោធន៍បែបនោះ ហើយកត់ត្រាវាទុកក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។ សិស្សក៏អាចទទួលបានប្រយោជន៍ ប្រសិនបើអ្នកប្រាប់អំពីពេលមួយដែលព្រះបានគាំទ្រ ឬ ទ្រទ្រង់អ្នក ។

សូមជួយសិស្សយល់ថា សមត្ថភាពរបស់នីហ្វៃក្នុងការចងចាំ និង កោតសរសើរដល់អ្វីដែលព្រះបានធ្វើសម្រាប់គាត់នៅក្នុងអតីតកាល បានផ្តល់សេចក្តីសង្ឃឹមដល់គាត់ និង បានលើកទឹកចិត្តគាត់ឲ្យក្លាយជាមនុស្សល្អជាងមុន ។ សូមអញ្ជើញសិស្សអាន នីហ្វៃទី ២ ៤:២៦–៣០ដោយស្ងាត់ស្ងៀម ដោយស្វែងរកពីរបៀបដែលបទពិសោធន៍របស់នីហ្វៃបានជះឥទ្ធិពលដល់បំណងប្រាថ្នារបស់គាត់ចង់ក្លាយជាសុចរិត ។ សុំឲ្យសិស្សពីរបីនាក់ចែកចាយនូវអ្វីដែលពួកគេរកឃើញ ។

សុំឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពីក្នុង នីហ្វៃទី ២ ៤:៣០–៣៥ ។ សូមរកមើលការតាំងចិត្តដែលនីហ្វៃបានធ្វើចំពោះព្រះអម្ចាស់ និង ពរជ័យដែលគាត់បានសុំនៅក្នុងថ្នាក់ ។

- តើយើងអាចរៀនអ្វីពីការអធិស្ឋាននេះ ដែលអាចជួយយើងក្នុងការអធិស្ឋានផ្ទាល់ខ្លួនរបស់យើង ? (សិស្សអាចប្រើពាក្យខុសៗគ្នាក្នុងការឆ្លើយនឹងសំណួរនេះ ប៉ុន្តែសូមប្រាកដថាពួកគេយល់ថា **ការអធិស្ឋានដោយចិត្តស្មោះ អាចពង្រឹងការតាំងចិត្តរបស់យើងឲ្យយកឈ្នះលើអំពើបាប និង ការបាក់ទឹកចិត្ត ។**)

សូមអញ្ជើញសិស្សឲ្យគិតអំពីពេលមួយដែលការអធិស្ឋានបានជួយដល់ពួកគេឲ្យយកឈ្នះលើអំពើបាប ឬ ការបាក់ទឹកចិត្ត ។ អ្នកអាចផ្តល់យោបល់ថា ពួកគេគួរតែចែកចាយនូវបទពិសោធន៍របស់ពួកគេ ឬ កត់ត្រាវាទុកនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។

សូមឲ្យពេលបន្តិចទៅសិស្ស ឲ្យស្វែងរកវគ្គមួយនៅក្នុង នីហ្វៃទី ២ ៤ ដែលឆ្លុះបញ្ចាំងនូវបំណងប្រាថ្នាមួយដែលពួកគេមាន ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ. បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ ពីរបៀបដែលការអធិស្ឋានអាចចិញ្ចឹមការជំនាត់ខាងវិញ្ញាណ ៖

« ប្រហែលមានរឿងនានានៅក្នុងចរិតរបស់យើង ដំណើរប្រព្រឹត្តរបស់យើង ឬ ទាក់ទងនឹងការធំលូតលាស់ខាងវិញ្ញាណរបស់យើងអំពីអ្វីមួយដែលយើងត្រូវប្រឹក្សាជាមួយនឹងព្រះវរបិតាសួគ៌នៅក្នុងការអធិស្ឋានពេលព្រឹក ។ ក្រោយពីការបង្ហាញអំណរគុណត្រឹមត្រូវចំពោះពរជ័យដែលបានទទួលហើយ យើងអង្វរសុំការយល់ដឹង ការដឹកនាំ និង ជំនួយដើម្បីធ្វើរឿងអ្វីៗដែលយើងមិនអាចធ្វើដោយកម្លាំងរបស់យើងផ្ទាល់តែឯង ។ ឧទាហរណ៍ នៅពេលយើងអធិស្ឋាន យើងអាច ៖

« • គិតអំពីឱកាសទាំងនោះនៅពេលដែលយើងបាននិយាយដោយគ្រោតគ្រាត ឬ មិនសមរម្យទៅកាន់អ្នកដែលយើងស្រឡាញ់ខ្លាំងបំផុត ។

« • ទទួលស្គាល់ថា យើងដឹងច្រើនជាងនេះ ប៉ុន្តែយើងមិនមែនតែងតែធ្វើតាមអ្វីដែលយើងដឹងនោះទេ ។

ការអានព្រះគម្ពីរឮៗ

យូរៗម្តង សូមអានវគ្គព្រះគម្ពីរឮៗទៅកាន់សិស្សរបស់អ្នក ។ ការណ៍នេះហុចឱកាសមួយដល់ពួកគេឲ្យឮ និង ទទួលអារម្មណ៍ពីសេចក្តីស្រឡាញ់របស់អ្នកចំពោះព្រះគម្ពីរ ហើយវាអាចជម្រុញពួកគេឲ្យអានព្រះគម្ពីរដោយខ្លួនគេ ។ វាក៏អាចផ្តល់ឱកាសបញ្ជាក់ប្រាកដថាចំណុច សេចក្តីពិត ឬ ការអនុវត្តន៍ជាក់លាក់មួយត្រូវបានបញ្ជាក់សង្កត់ន័យ ។ សិស្សក៏នឹងទទួលបានប្រយោជន៍ពីការអានព្រះគម្ពីរឮៗពីគ្នាទៅវិញទៅមក ហើយសូម្បីតែនៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។

« • បង្ហាញការសោកស្តាយចំពោះភាពកម្សោយរបស់យើង និង ចំពោះការដែលមិនបានស្រាតចោលនូវជីវិតខាងសាច់ឈាមដោយអស់ពីចិត្តជាងមុន ។

« • ប្តេជ្ញាដើម្បីដឹកនាំជីវិតរបស់យើងតាមព្រះអង្គសង្គ្រោះយ៉ាងពេញលេញជាងមុន ។

« • អង្វរសុំកម្លាំង ខ្លាំងជាងមុនដើម្បីធ្វើ និង ក្លាយជាមនុស្សល្អជាងមុន » (« អធិស្ឋានជានិច្ច » *Ensign*ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៤១) ។

សូមបញ្ចប់ដោយយោងទៅឃ្លាដែលអ្នកបានសរសេរនៅលើក្តារខៀនពីពេលមុននៅក្នុងមេរៀននេះ (« ព្រលឹងរបស់ខ្ញុំត្រេកអរចំពោះ . . . » និង « ចិត្តខ្ញុំសោកសៅព្រោះតែ . . . ») ។ សូមបង្ហាញជំនឿចិត្តរបស់អ្នកថា ទោះបីជានៅពេលយើងជួបនឹងស្ថានភាពលំបាកក្តី ក៏យើងអាចមានសុភមង្គល និង សេចក្តីសុខសាន្តដែរ នៅពេលយើងស្វែងរកជំនួយពីព្រះអម្ចាស់ ។

ការរំឭកចំណេះចំណានខគម្ពីរ

កំណត់សម្គាល់ ៖ ចិរវេលានៃមេរៀននេះ អាចអនុញ្ញាតពេលឲ្យមានសកម្មភាពរំឭកចំណេះចំណានខគម្ពីរខាងក្រោម ។ អ្នកអាចដឹកនាំសកម្មភាពនៅពេលចាប់ផ្តើមថ្នាក់ នៅពេលសម្រាករវាងវគ្គនៃមេរៀននេះ ឬ នៅពេលបញ្ចប់ថ្នាក់ក៏បាន ។ សូមប្រាកដថា ធ្វើវាដោយខ្លីដើម្បីទុកពេលសម្រាប់មេរៀន ។ សម្រាប់សកម្មភាពរំឭកផ្សេងទៀត សូមមើលឧបសម្ព័ន្ធនៅចុងបញ្ចប់នៃសៀវភៅសិក្សានេះ ។

ការធ្វើលំហាត់អាចជួយសិស្សឲ្យចាំនូវអ្វីដែលពួកគេបានរៀន និង វាស់វែងបាននូវការចេះដឹងរបស់ពួកគេ ។ សូមជ្រើសរើសវគ្គចំណេះចំណានខគម្ពីរថ្មីពីរបី ហើយសូមអញ្ជើញសិស្សអាន និង គូសចំណាំវានៅក្នុងព្រះគម្ពីររបស់ពួកគេ ។ បន្ទាប់មកសូមឲ្យលំហាត់ផ្តាល់មាត់ដល់ពួកគេមួយលើវគ្គបទគម្ពីរទាំងនោះ និង វគ្គចំណេះចំណានខគម្ពីរផ្សេងទៀតដែលពួកគេបានរៀនរួចហើយ ។ សម្រាប់វគ្គនីមួយៗ សូមអានពាក្យ ឬ ឃ្លាគន្លឹះពីប្រដាប់សៀតសៀវភៅថ្នាក់សិក្ខាសាលា ។ បន្ទាប់មក សុំឲ្យសិស្សរកវគ្គដែលត្រូវនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ២ ៤:១៦–៣៥ ។ ការយកឈ្នះលើអំពើបាប និង ភាពកម្សោយរបស់យើង

នៅពេលយើងសិក្សាអំពីការអង្វរករជំនួសត្រង់របស់នីហ្វៃទៅកាន់ព្រះឲ្យជួយគាត់យកឈ្នះលើអំពើបាប និង ភាពកម្សោយរបស់គាត់ យើងឃើញថា យើងអាចរកទ្រង់បានចំពោះជំនួយដូចគ្នានោះដែរ ។ ពាក្យពាក្យសម្តីរបស់នីហ្វៃត្រូវបានប្រកាសនៅក្នុងពាក្យសម្តីរបស់ព្យាការីនៅថ្ងៃចុងក្រោយ ។

ព្យាការីយ៉ូសែប ស្ម៊ីធ បានបង្រៀនថា ៖

« កាលណាមនុស្សកាន់តែខិតជិតទៅរកភាពឥតខ្ចោះ គំនិតរបស់គាត់កាន់តែច្បាស់ ហើយសេចក្តីអំណាររបស់គាត់កាន់តែខ្លាំង រហូតដល់គាត់បានយកឈ្នះលើអំពើអាក្រក់នៃជីវិតរបស់គាត់ និង បំបាត់រាល់ចំណង់ធ្វើអំពើបាប » (*ការបង្រៀនរបស់ប្រធាននៃសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* [២០០៧] ទំព័រ ២១០–១១) ។

អែលឌើរ រីឆាដ ជី. ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានថ្លែងទីបន្ទាល់អំពីពរជ័យដែលយើងទទួលបាន នៅពេលយើងប្រែចិត្ត ៖

« ហេតុអ្វីបានជាព្រះវរបិតាសួគ៌របស់យើង និង ព្រះរាជបុត្រារបស់ទ្រង់បានបញ្ជាយើងឲ្យធ្វើការប្រែចិត្ត ? ដោយសារ ពួកទ្រង់ស្រឡាញ់យើង ។ ទ្រង់ដឹងថា យើងទាំងអស់គ្នានឹងរំលងច្បាប់ជំនៅអស់កល្បជានិច្ច ៖ មិនថាវាតូច ឬ ធំ សេចក្តីយុត្តិធម៌តម្រូវថា រាល់ច្បាប់ដែលរំលងទាំងអស់នឹងពេញចិត្ត ដើម្បីរក្សាសេចក្តីសន្យានៃសេចក្តីអំណារនៅក្នុងជីវិតនេះ និង ឯកសិទ្ធិនៃការត្រឡប់ទៅកាន់ព្រះវរបិតាសួគ៌នៅស្ថានសួគ៌វិញ ។ ប្រសិនបើមិនពេញចិត្តទេ នៅក្នុងថ្ងៃនៃការកាត់សេចក្តី សេចក្តីយុត្តិធម៌នឹងបណ្តាលឲ្យយើងត្រូវបិទចេញពីវត្តមាននៃព្រះ ហើយត្រូវនៅក្រោមការត្រួតត្រារបស់សាតាំង [សូមមើល នីហ្វៃទី ២ ៩:៨–១០; នីហ្វៃទី ២ ២:៥] ។

« វាគឺជាថៅហ្វាយរបស់យើង និង ទង្វើប្រោសលោះរបស់ទ្រង់ទេ ដែលធ្វើឲ្យយើងអាចចៀសវាងពីការដាក់ទោសបែបនោះបាន ។ វាធ្វើបានតាមរយៈសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ទ្រង់ និង ការស៊ូទ្រាំនៅក្នុងសេចក្តីសុចរិតរហូតដល់ទីបញ្ចប់ ។

« តើអ្នកនឹងឱបក្រសោបភាពជំពេញលេញនៃអំណាចប្រោសលោះ នៃការប្រែចិត្តនៅក្នុងជីវិតរបស់អ្នក ដើម្បីអ្នកអាចមានសេចក្តីសុខសាន្ត និង សេចក្តីអំណារខ្លាំងជាងនេះ ដែរឬទេ ? អារម្មណ៍នៃការជ្រួលច្របល់ និង ការអន់ចិត្តជាញឹកញាប់ជាសញ្ញានៃការត្រូវការការប្រែចិត្តមួយ ។ ការខ្វះការដឹកនាំខាងវិញ្ញាណដែលអ្នកស្វែងរកនៅក្នុងជីវិតរបស់អ្នកក៏អាចមកពីការមិនធ្វើតាមច្បាប់ ។ ប្រសិនបើត្រូវការ ការប្រែចិត្តយ៉ាងពេញលេញនឹងដាក់ជីវិតរបស់អ្នករួមគ្នា ។ វានឹងដោះស្រាយរាល់ការឈឺចាប់ខាងវិញ្ញាណដ៏ស្មុគស្មាញទាំងអស់ដែលមកពីការរំលង ។ ប៉ុន្តែនៅក្នុងជីវិតនេះ វាមិនអាចព្យាបាលលទ្ធផលនៃរាងកាយខ្លះដែលអាចកើតឡើងមកពីអំពើបាបធ្ងន់ធ្ងរនោះទេ ។ សូមឆ្លាតវៃ និង រស់នៅយ៉ាងល្អឡើងទាត់នៅក្នុងព្រំដែននៃភាពសុចរិត ដែលកំណត់ដោយព្រះអម្ចាស់ » (« ផ្លូវទៅកាន់សេចក្តីសុខសាន្ត និង សេចក្តីអំណារ » *Ensign*ខែ វិច្ឆិកា ឆ្នាំ ២០០០ ទំព័រ ២៥) ។

មេរៀនទី ២៧

នីហ្វៃទី ២ ៥

សេចក្តីផ្តើម

ដោយគោរពតាមការព្រមានរបស់ព្រះអម្ចាស់ នីហ្វៃ និង អ្នកដើរតាមគាត់បានបំបែកខ្លួនពីលេមិន លេមយួល និង កូនប្រុសរបស់អឺសម៉ាអែល ។ ពួកគេរស់នៅដោយសេចក្តីសុចរិត និង សុភមង្គល ខណៈដែលអ្នកដើរតាមលេមិន និង លេមយួលបានកាត់ខ្លួនគេចេញពីព្រះអម្ចាស់ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ៥:១–៨

ព្រះបំបែកអ្នកដើរតាមនីហ្វៃ ចេញពីអ្នកដើរតាមលេមិន និង លេមយួល

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីបញ្ហា និង ការសម្រេចចិត្តលំបាកខ្លះ ៗដែលពួកគេជួបប្រទះ ។ សូមលើកទឹកចិត្តពួកគេឲ្យទុកឧបសគ្គផ្ទាល់ខ្លួនទាំងនេះនៅក្នុងចិត្ត នៅពេលពួកគេសិក្សាពីរបៀបដែលនីហ្វៃឆ្លើយតបនឹងឧបសគ្គទាំងនោះ ។ សូមរំពឹកពួកគេថា នៅពេលលីហៃបានស្លាប់ នីហ្វៃត្រូវបានទុកឲ្យក្លាយជាអ្នកដឹកនាំខាងវិញ្ញាណនៃគ្រួសាររបស់គាត់ ។ សូមឲ្យសិស្សអាន នីហ្វៃទី ២ ៥:១–៤ដោយស្ងាត់ស្ងៀមដើម្បីស្វែងរកឧបសគ្គដែលនីហ្វៃបានជួបប្រទះ ។

- ដោយយោងតាមនីហ្វៃទី ២ ៥:១ តើនីហ្វៃបានធ្វើអ្វីដើម្បីជួយសម្រេចរកដំណោះស្រាយមួយចំពោះឧបសគ្គរបស់គាត់ ?
- តើលេមិន និង លេមយួលបានខំរកធ្វើអ្វីខ្លះ ទោះបីជាក្រោយពេលដែលនីហ្វៃបានអធិស្ឋានសុំជំនួយហើយក្តី ?

នៅពេលសិស្សរាយការណ៍ចម្លើយរបស់ខ្លួន អ្នកអាចបង្ហាញថា ការអធិស្ឋានរបស់យើងមិនអាចតែងតែទទួលបានចម្លើយភ្លាម ៗ ឬ តាមរបៀបដែលយើងចង់បានរហូតនោះទេ ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ៥:៥–៨ ឲ ៗ ។ សុំឲ្យសិស្សអានតាម ដោយស្វែងរកអ្វីដែលព្រះអម្ចាស់បានធ្វើដើម្បីជួយនីហ្វៃ និង អ្នកដើរតាមរបស់គាត់ ។

សុំឲ្យសិស្សសង្ខេបអ្វីដែលពួកគេបានរៀនពីក្នុង នីហ្វៃទី ២ ៥:១–៨ ។ សេចក្តីពិតមួយដែលអ្នកអាចសង្កត់ធ្ងន់លើគឺថា **ព្រះអម្ចាស់ដឹកនាំអ្នកដែលស្វែងរកទ្រង់ដោយស្មោះត្រង់ពេលអធិស្ឋាន ។** ដោយទាក់ទងនឹងខគម្ពីរទាំងនេះ សូមសួរសំណួរខាងក្រោម ៖

- ហេតុអ្វីបានជាវាសំខាន់ក្នុងការបន្តស្មោះត្រង់ នៅពេលការអធិស្ឋានរបស់យើងមិនទាន់បានឆ្លើយតបភ្លាម ៗ ឬ តាមរបៀបដែលយើងចង់បានក្តី ?
- តើព្រះអម្ចាស់អាចប្រទានដល់យើងនូវការព្រមានតាមរបៀបណាខ្លះ ?

នៅពេលសិស្សឆ្លើយនឹងសំណួរនេះរួច សូមគិតពីការអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ីយដ៍ ឃេ. ជាកកឺ នៃក្ងរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« យើងមិនអាចចាប់ផ្តើមនៅលើផ្លូវខុសមួយ ដោយគ្មានការព្រមានបដិសេធពីដំបូងនោះទេ » (ដកស្រង់នៅក្នុងKenneth Johnson "Yielding to the Enticings of the Holy Spirit" *Ensign*ខែ វិច្ឆិកា ឆ្នាំ ២០០២ ទំព័រ ៩០) ។

- តើយើងអាចធ្វើតាមគំរូរបស់នីហ្វៃដោយរបៀបណា នៅពេលយើងជួបនឹងឧបសគ្គ ?

ដោយសារជាផ្នែកនៃការពិភាក្សារបស់សិស្សក្នុង នីហ្វៃទី ២ ៥:១–៨សូមបង្ហាញថា ការបំបែកសាសន៍នីហ្វៃចេញពីសាសន៍លេមិន គឺជាលទ្ធផលនៃការដែលលេមិន និង លេមយួលស្អប់នីហ្វៃ ។ ការបំបែកនេះ បន្តដល់រាប់សតវត្សរ៍ រួមនឹងការដែលកូនចៅរបស់លេមិន និង លេមយួលបង្រៀនកូនចៅរបស់ពួកគេឲ្យស្អប់កូនចៅរបស់នីហ្វៃ (សូមមើល ម៉ូសាយ ១០:១២–១៧) ។

នីហ្វៃទី ២ ៥:៩–១៨, ២៦–២៧

សាសន៍នីហ្វៃរស់នៅតាមរបៀបនៃសុភមង្គល

សូមដឹកនាំសិស្សអាន នីហ្វៃទី ២ ៥:២៧ ឲ ៗរួមគ្នា ។ អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំខគម្ពីរនេះទុក ។ សូមសរសេរពាក្ស *សុភមង្គល* នៅលើក្តារខៀន ។

- តើអ្នកគិតថា វាមានន័យដូចម្តេច ដើម្បីរស់នៅ « តាមរបៀបនៃសុភមង្គល » ?

សុំឲ្យសិស្សម្នាក់អានឲ ៗ នូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយ អែលឌើរ ម៉ាលីន ឃេ. ជែនសិន នៃក្រុមចិតសិប ៖

« គោលការណ៍ និង សេចក្តីពិតដែលមិនអាចផ្លាស់ប្តូរមួយចំនួន នាំមកនូវសុភមង្គលដល់ជីវិតរបស់យើង ។

« ដោយសារហេតុផលនោះហើយ បីបួនឆ្នាំកន្លងទៅ វគ្គព្រះគម្ពីរមរមនបានទាញការចាប់អារម្មណ៍របស់ខ្ញុំ ។ . . . នីហ្វៃបានស្ថាបនាសង្គមមួយដែលបានរកឃើញក្នុងសេចក្តីពិតនៃដំណឹងល្អ ហើយចេញពីសង្គមនោះ គាត់បាននិយាយថា ‹ ហើយហេតុការណ៍បានកើតឡើងថា ពួកយើងបានរស់នៅតាមរបៀបនៃសុភមង្គល › (នីហ្វៃទី ២ ៥:២៧) ។ វគ្គនេះ បានបំផុសខ្ញុំយ៉ាងជ្រាលជ្រៅ ។

សូមហៅសិស្សចំណ្មោះ

នៅពេលអ្នកសុំឲ្យសិស្សម្នាក់អាន ឬ ចូលរួមនៅក្នុងការពិភាក្សាមួយ សូមហៅគាត់ ឬ នាងចំណ្មោះ ។ វានឹងជួយបង្កើនបរិយាកាសរៀនសូត្រមួយប្រកបដោយសេចក្តីស្រឡាញ់ និង ការគោរព ។

. . . ខ្ញុំឆ្ងល់ . . . តើធាតុផ្សំមួយៗនៃសង្គម និង ជីវិតដ៏រីករាយពិតមួយអាចនឹងទៅជាអ្វី ហើយខ្ញុំបានចាប់ផ្តើមស្វែងរកតម្រុយនានាពីការសរសេររបស់នីហ្វៃ ។ ខ្ញុំ . . . សូមអញ្ជើញអ្នកឲ្យធ្វើការការស្រាវជ្រាវផ្ទាល់ខ្លួនអ្នកដោយខ្លួនឯង ។ វាអាចជាការដេញតាមពេញមួយជីវិត និង ដ៏មានតម្លៃមួយ . . . ។

« . . . គំរូ និង ធាតុផ្សំដូចគ្នានៃជីវិតប្រចាំថ្ងៃដែលអាចជួយនីហ្វៃ និង ប្រជាជនរបស់គាត់ឲ្យរីករាយរយៈពេល ៥៦០ ឆ្នាំ មុនពេលព្រះគ្រីស្ទ នឹងមានដំណើរការស្មើគ្នាល្អនៅសព្វថ្ងៃនេះដែរ » (« ការរស់នៅតាមរបៀបនៃសុភមង្គល » *Ensign*ខែ ធ្នូ ឆ្នាំ ២០០២ ទំព័រ ៥៦, ៦១) ។

សូមលើកទឹកចិត្តសិស្សឲ្យទទួលយកការអញ្ជើញរបស់អែលឌើរ ជែនសិន ។ សុំឲ្យពួកគេអាននីហ្វៃទី ២ ៥:៦, ១០–១៨, ២៦–២៧ដោយស្ងាត់ស្ងៀម ដោយស្វែងរកមើល « ធាតុនៃសង្គម និង ជីវិតដ៏រីករាយពិតមួយ » ។ អ្នកអាចស្នើថា ពួកគេគូរតែគូសចំណាំគោលការណ៍ដែលរួមចំណែកដល់សុភមង្គលនៃសាសន៍នីហ្វៃ ។ បន្ទាប់ពីពេលពីរបីនាទី ក្រោយមកសូមអញ្ជើញសិស្សពីរបីនាក់ឲ្យសរសេរអ្វីដែលពួកគេរកឃើញនៅលើក្តារខៀន ។ (ចម្លើយអាចរួមមាន នីហ្វៃ និង អ្នកដើរតាមរបស់គាត់បានទៅជាមួយនឹងគ្រួសាររបស់ពួកគេ | សូមមើល ខ ៦ | បានគោរពព្រះអម្ចាស់ | សូមមើល ខ ១០ | បានធ្វើការខ្លាំងដើម្បីគាំទ្រខ្លួនគេ | សូមមើល ខ ១១, ១៥–១៧ | បានយកព្រះគម្ពីរទៅជាមួយនឹងពួកគេ | សូមមើល ខ ១២ | បានកសាងព្រះវិហារបរិសុទ្ធមួយ | សូមមើល ខ ១៦ | និង បានធ្វើតាមអ្នកដឹកនាំដ៏សុចរិត | សូមមើល ខ ១៨, ២៦ | ។)

> ***ការចែកចាយគំនិត និង អារម្មណ៍***
>
> នៅពេលយុវជនបង្ហាញគំនិត និង អារម្មណ៍របស់ពួកគេអំពីគោលការណ៍នៃជំណឿងល្អ នោះពួកគេអញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យជួយសិក្សាជម្រៅការយល់ដឹងរបស់ពួកគេ និង ពង្រឹងនូវទីបន្ទាល់របស់ពួកគេ ។ អ្នកអាចជួយឲ្យការណ៍នេះកើតមានឡើងនៅក្នុងថ្នាក់ដោយការលើកទឹកចិត្តសិស្សឲ្យពន្យល់ពីគោលការណ៍នៃជំណឿងល្អជាពាក្យពាក្យសម្តីផ្ទាល់របស់ពួកគេ ។ អ្នកក៏អាចអញ្ជើញសិស្សឲ្យចែកចាយបទពិសោធន៍ដែលទាក់ទង និង សមរម្យនានា ហើយឲ្យថ្លែងទីបន្ទាល់អំពីអ្វីដែលពួកគេដឹងដោយសារតែបទពិសោធន៍ទាំងនេះ ។

សូមអញ្ជើញសិស្សជ្រើសរើសគោលការណ៍មួយ ឬ ពីរនៅលើក្តារខៀន ហើយចែកចាយពីរបៀបដែលគោលការណ៍ទាំងនេះបានជួយដល់ពួកគេ « ឲ្យរស់នៅតាមរបៀបនៃសុភមង្គល » ។

ដោយផ្អែកលើអ្វីដែលសិស្សសង្កេតឆ្ងល់ អ្នកអាចតាមដានជាមួយនឹងសំណួរពីរបីដូចខាងក្រោម ៖

- យោងតាមនីហ្វៃទី ២ ៥:១០–១១, ១៦តើពរជ័យអ្វីខ្លះ ដែលប្រជាជនទទួលបានដោយសារពួកគេបានរក្សាព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ? តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់បានគង់នៅជាមួយនឹងអ្នក ? តើឥទ្ធិពលរបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់អ្នកបានជួយជ្រោមជ្រែងដល់សុភមង្គលរបស់អ្នកយ៉ាងដូចម្តេចខ្លះ ?
- តើព្រះវិហារបរិសុទ្ធអាចជួយប្រជាជន « ឲ្យរស់នៅតាមរបៀបនៃសុភមង្គល » បានយ៉ាងដូចម្តេច ? តើព្រះវិហារបរិសុទ្ធបាននាំមកនូវសុភមង្គលដ៏អស្ចារ្យជាងនេះដល់អ្នក ឬ អ្នកណាម្នាក់ដែលអ្នកស្គាល់ដោយរបៀបណា ?
- តើការខិតខំធ្វើការងារបានជួយដល់សុភមង្គលតាមវិធីណាខ្លះ ?

សូមអញ្ជើញសិស្សឲ្យសង្កេតអ្វីដែលពួកគេបានរៀនអំពីរបៀបដើម្បីបង្កើនសុភមង្គលរបស់ពួកគេ ។ ទោះបីជាសិស្សអាចចែកចាយគោលការណ៍ខុសគ្នាក្តី សូមប្រាកដថា ពួកគេយល់ថា **នៅពេលដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទក្លាយជាផ្លូវជីវិតរបស់យើង នោះយើងនឹងបង្កើននូវសុភមង្គល ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន ។

សូមអញ្ជើញសិស្សពិនិត្យមើលជីវិតរបស់ពួកគេ ហើយសម្រេចអ្វីមួយដែលពួកគេនឹងធ្វើដើម្បីរស់នៅឲ្យកាន់តែពេញលេញជាងនេះ « តាមរបៀបនៃសុភមង្គល » ។ សូមលើកទឹកចិត្តពួកគេឲ្យសរសេរសកម្មភាពនេះនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍ និង ការអនុវត្តន៍ដែលបាននាំមកនូវសុភមង្គលដល់ជីវិតរបស់អ្នក ។

នីហ្វៃទី ២៥:១៩–២៥

សាសន៍លេមិនត្រូវបានដាក់បណ្តាសាដោយសារតែការមិនគោរពប្រតិបត្តិតាមរបស់ពួកគេ

សូមអញ្ជើញសិស្សអាននីហ្វៃទី ២ ៥:១៩–២៤ ដោយស្ងាត់ស្ងៀម ដោយស្វែងរកមើលនូវភាពខុសគ្នារវាងរបៀបដែលសាសន៍លេមិនរស់នៅ និង របៀបដែលសាសន៍នីហ្វៃបានរស់នៅ ។

- យោងតាមនីហ្វៃទី ២ ៥:២០តើអ្វីខ្លះជាលទ្ធផលនៃការមិនគោរពប្រតិបត្តិតាមរបស់សាសន៍លេមិន ?

សូមប្រាកដថា សិស្សយល់ថា ការដាក់បណ្តាសាដែលបាននិយាយនៅក្នុងជំពូកនេះ គឺជាការកាត់ចេញពីព្រះ ។ ការប្រែប្រួលនៃស្បែករបស់ពួកគេ គឺជាគំនូសចំណាំ ឬ សញ្ញាសម្គាល់តែមួយគត់នៃការដាក់បណ្តាសា ។ ដើម្បីបញ្ជាក់ចំណុចនេះ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះ ដោយប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ៖

« ស្បែកក្រមៅត្រូវបានជាប់លើសាសន៍លេមិន ដូច្នេះពួកគេអាចត្រូវបានបំបែកពីសាសន៍នីហ្វៃ និង ដើម្បីចៀសវាងការលាយឡំនៃប្រជាជនទាំងពីរ ។ ស្បែកក្រមៅគឺជាសញ្ញាសម្គាល់នៃការដាក់បណ្តាសា ។ បណ្តាសាគឺជាការបណ្តេញចេញនៃព្រះវិញ្ញាណនៃព្រះអម្ចាស់ ។ . . .

« ស្បែកក្រមៅរបស់អស់អ្នកដែលបានចូលមកក្នុងសាសនាចក្រ គឺលែងត្រូវចាត់ទុកថាជាសញ្ញាមួយនៃបណ្តាសាទៀតហើយ ។ អ្នកដែលប្រែចិត្តជាច្រើនទាំងនេះ គឺសប្បាយរីករាយ និង មានព្រះវិញ្ញាណនៃព្រះអម្ចាស់ » (*ចម្លើយចំពោះសំណួរក្នុងដំណឹងល្អ*comp. Joseph Fielding Smith Jr. វ៉ុល ៥ ។ ។១៩៥៧–៦៦|៣:១២២–២៣) ។

- តើនីហ្វៃទី ២ ៥:២១ ជួយអ្នកយល់ពីមូលហេតុដែលលេមិនត្រូវបានកាត់ចេញពីព្រះអម្ចាស់យ៉ាងដូចម្តេច ? (អ្នកអាចពន្យល់ថា ថ្មដែកភ្លើងគឺជាថ្មដ៏រឹងមួយ ។ នៅក្នុងការនិយាយថា សាសន៍លេមិន « បានក្លាយទៅជារឹងដូចជាថ្មដែកភ្លើង » នីហ្វៃបានសង្កត់ធ្ងន់ពីភាពរឹងរូសនៃចិត្តរបស់ពួកសាសន៍លេមិន)។
- តើព្រះអម្ចាស់បានផ្តល់ការព្រមានអ្វីខ្លះអំពីសាសន៍នីហ្វៃដែលរៀបការនឹងសាសន៍លេមិនដែលបានបដិសេធដំណឹងល្អ ? (សូមមើលនីហ្វៃទី ២ ៥:២៣) ។

- ហេតុអ្វីបានជាវាសំខាន់ដើម្បីដៀសវាងការណាត់ជួប និង ការរៀបការជាមួយនឹងអ្នកដែលមិនស្តាប់តាមព្រះអម្ចាស់ ? តើអ្នកគិតថាឥទ្ធិពលដែលមនុស្សដែលអ្នកណាត់ជួបជាគូ ហើយនៅទីបញ្ចប់រៀបការជាមួយនោះ នឹងប៉ះពាល់ដល់ការខិតខំរបស់អ្នកក្នុងការរស់នៅតាមដំណឹងល្អយ៉ាងដូចម្តេច ? (វាប្រហែលអាចជួយបានច្រើនដើម្បីរំឭកសិស្សថា គណៈប្រធានទីមួយបានទូន្មានថា « សូមជ្រើសរើសណាត់ជួបតែអ្នកណាដែលមានបទដ្ឋានសីលធម៌ខ្ពស់ និង អ្នកអាចរក្សាបទដ្ឋានរបស់អ្នកនៅក្នុងការជួបគ្នានោះ » [*ដើម្បីកម្លាំងនៃយុវជន* (កូនសៀវភៅ ២០១១) ទំព័រ ៤] ។
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពី នីហ្វៃទី ២ ៥:២០–២៤? (នៅពេលសិស្សចែកចាយគោលការណ៍នានា សូមធានាថា **ពួកគេយល់ថា នៅពេលមនុស្សពង្រឹងចិត្តរបស់ពួកគេទាស់នឹងព្រះអម្ចាស់ នោះពួកគេនឹងបំបែកខ្លួនគេចេញពីទ្រង់ហើយ**) ។

សូមសង្កត់ធ្ងន់ថា នីហ្វៃទី ២ ៥ បង្ហាញពីការផ្ទុយគ្នាដ៏ខ្លាំងរវាងសាសន៍នីហ្វៃ និង សាសន៍លេមិន ។ យើងអាចជ្រើសរើសយកគំរូមួយណាដែលយើងនឹងធ្វើតាមបាន ។ សូមលើកទឹកចិត្តសិស្សឲ្យចាំពីអ្វីដែលពួកគេបានប្តេជ្ញា ថាពួកគេនឹងធ្វើអ្វីៗដើម្បីរស់នៅឲ្យបានពេញលេញជាងមុន « តាមរបៀបនៃសុភមង្គល » ។ សូមបង្ហាញទំនុកចិត្តរបស់អ្នកថា ពួកគេអាចធ្វើតាមគំរូរបស់នីហ្វៃ និង ពិតជារីករាយយ៉ាងប្រាកដ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ២ ៥:១៦ ។ « ខ្ញុំ នីហ្វៃ បានសាងព្រះវិហារបរិសុទ្ធមួយ »

អែលឌើរ ម៉ាលីន ឃេ ជែនសិន នៃក្រុមចិតសិបនាក់បានពន្យល់ពីរបៀបដែលការចូលព្រះវិហារបរិសុទ្ធ នាំទៅរកសុភមង្គល ៖

« នីហ្វៃបានសរសេរថា ‹ ហើយ ខ្ញុំ នីហ្វៃ បានសាងព្រះវិហារបរិសុទ្ធមួយ › (នីហ្វៃទី ២ ៥:១៦) ។ ព្រះវិហារបរិសុទ្ធរបស់នីហ្វៃអាចខុសគ្នាខ្លះៗពីព្រះវិហារបរិសុទ្ធរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយរបស់យើង ប៉ុន្តែគោលបំណងដ៏ចម្បងរបស់វាគឺពិតជាដូចគ្នា ៖ ដើម្បីបង្រៀន និង ណែនាំកូនចៅរបស់ព្រះ ទាក់ទងនឹងផែនការរបស់ទ្រង់សម្រាប់សុភមង្គលរបស់ពួកគេ និង ដើម្បីផ្តល់ពិធីបរិសុទ្ធ និង សេចក្តីសញ្ញាដែលសំខាន់ចំពោះការមកដល់នៃសុភមង្គលនោះ ។

« ក្រោយពីការរស់នៅលើផែនដីដ៏ល្អនេះអស់រយៈពេលជាងប្រាំទសវត្សរ៍មក ខ្ញុំអាចនិយាយដោយស្មោះត្រង់ថា មនុស្សដែលមានភាពចាស់ទុំខាងវិញ្ញាណ និង រីករាយជាងគេបំផុតដែលខ្ញុំស្គាល់នោះ គឺជាអ្នកទៅព្រះវិហារបរិសុទ្ធធ្វើការយ៉ាងឧស្សាហ៍ព្យាយាម ។ មានហេតុផលល្អសម្រាប់ការណ៍នោះ ។ វាគឺនៅក្នុងព្រះវិហារបរិសុទ្ធ ដែលមានការសម្អាតពេញលេញនៃកម្មវិធីរបស់ព្រះសម្រាប់យើង ដែលត្រូវបានប្រាប់ និង ប្រាប់សារជាថ្មីដល់យើង ដែលការប្រាប់នីមួយៗបាននាំមកនូវការយល់ និង ការប្តេជ្ញាដ៏ខ្លាំងជាងមុនទៅដល់ជីវិតរស់នៅតាមផ្លូវរបស់ទ្រង់ ។ . . .

« ការសោកល្បងដ៏ល្អមួយអំពីការធ្វើរបស់យើងថាបានល្អយ៉ាងណានៅក្នុងដំណើរស្វែងចូលទៅរកព្រះគ្រីស្ទ អាចជារបៀបដែលយើងមានអារម្មណ៍អំពីព្រះវិហារបរិសុទ្ធ និង បទពិសោធន៍របស់យើងនៅទីនោះ ។ *ព្រះវិហារបរិសុទ្ធ* អាចជាវេរិចនៈសព្ទនឹង *សុភមង្គល* និង *សេចក្តីអំណរ* ។ វាគឺសម្រាប់នីហ្វៃ និង ប្រជាជនរបស់គាត់ » (« ការរស់នៅតាមរបៀបនៃសុភមង្គល » *Ensign* ខែ ធ្នូ ឆ្នាំ ២០០២ ទំព័រ ៦០) ។

នីហ្វៃទី ២ ៦–៨

សេចក្តីផ្តើម

នៅពេលនីហ្វៃបានកត់ត្រាការបម្រើរបស់ប្រជាជនគាត់ គាត់រួមបញ្ចូលការបង្រៀនដោយប្អូនប្រុសរបស់គាត់ យ៉ាកុប រយៈពេលពីរថ្ងៃ ។ ការបង្រៀនត្រូវបានរកឃើញនៅក្នុង នីហ្វៃទី ២ ៦–១០ហើយនេះគឺជាមេរៀនទីមួយក្នុងចំណោមមេរៀនបីអំពីវា ។ នៅដើមដំបូងនៃការបង្រៀន យ៉ាកុបបានអានការព្យាករណ៍របស់អេសាយដែលទាក់ទងនឹងការខ្ចាត់ខ្ចាយ និងការប្រមូលផ្តុំនៃអ៊ីស្រាអែល ដែលបង្ហាញថា « ព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់នឹងបំពេញសេចក្តីសញ្ញាទាំងឡាយរបស់ទ្រង់ ដែលទ្រង់បានធ្វើជាមួយនឹងកូនចៅព្រះអង្គ » (នីហ្វៃទី ២ ៦:១២) ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ៦

យ៉ាកុបថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់នឹងចងចាំរាស្ត្រក្នុងសេចក្តីសញ្ញារបស់ទ្រង់

ដើម្បីជួយសិស្សឃើញថា ការបង្រៀនរបស់យ៉ាកុបទាក់ទងនឹងជីវិតរបស់ពួកគេ សូមឲ្យពួកគេសញ្ជឹងគិតអំពីរបៀបដែលពួកគេនឹងប្រតិកម្ម ប្រសិនបើមិត្តភក្តិ ឬ សមាជិកគ្រួសារម្នាក់ធ្វើដាក់គេដោយមិនមានសណ្តានចិត្ត បានបដិសេធមិនជឿអ្វីដែលពួកគេបាននិយាយ ឬ បានបង្ហាញតាមរយៈសកម្មភាព ឬ ឥរិយាបថរបស់ពួកគេថា ទំនាក់ទំនងនេះលែងមានសារសំខាន់ចំពោះពួកគេទៀតហើយ ។

សុំឲ្យសិស្សសញ្ជឹងគិតដោយស្ងាត់ស្ងៀមនូវសំណួរខាងក្រោម ៖

- តើអ្នកធ្លាប់បង្ហាញសកម្មភាព ឬ ឥរិយាបថដូចគ្នានេះទៅកាន់ព្រះអម្ចាស់ដែរឬទេ ?

សូមពន្យល់ថា នៅក្នុងនីហ្វៃទី២ ៦–៨យើងឃើញពីរបៀបដែលព្រះអម្ចាស់ឆ្លើយតបនឹងអ្នកដែលបានបែរចេញពីទ្រង់ ។ ជំពូកទាំងនេះរួមមានកំណត់ត្រារបស់នីហ្វៃនៃផ្នែកនៃការបង្រៀនមួយដោយប្អូនប្រុសរបស់គាត់ យ៉ាកុប ។ ការបង្រៀនរបស់យ៉ាកុបទាំងអស់ត្រូវបានកត់ត្រានៅក្នុងនីហ្វៃទី២ ៩–១០ ។ ជំពូកទាំងនេះនឹងត្រូវបង្រៀននៅក្នុងមេរៀនពីរក្រោយទៀត ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ៦:៣–៤និង ៩:១, ៣ ឮៗ ។ សុំឲ្យសិស្សស្វែងរកហេតុផលដែលយ៉ាកុបផ្តល់ការបង្រៀននេះ ។

សូមអញ្ជើញសិស្សម្នាក់សម្តែងជាគ្រូបង្រៀន ។ សុំឲ្យគាត់ ឬ នាងសរសេរចំណងជើងថា *គោលបំណងនៃការបង្រៀនរបស់យ៉ាកុប* នៅលើក្តារខៀន ។ បន្ទាប់មក សុំឲ្យសិស្សចែកចាយពីអ្វីដែលពួកគេបានរកឃើញនៅក្នុងខគម្ពីរទាំងឡាយដែលទើបតែបានអានរួច ។ សុំឲ្យគ្រូបង្រៀនសរសេរចម្លើយរបស់ពួកគេនៅក្រោមចំណងជើងនោះ ។ សូមជួយសិស្សឲ្យឃើញថា យ៉ាកុបបានបង្រៀនប្រជាជនរបស់គាត់ដើម្បី « សុខុមាលភាពដល់ព្រលឹងទាំងឡាយ [របស់ពួកគេ] » (នីហ្វៃទី ២ ៦:៣) ។ គាត់ចង់ជួយពួកគេ « សរសើរតម្កើងដល់ព្រះនាមនៃព្រះ [របស់ពួកគេ] » (នីហ្វៃទី ២ ៦:៤) « ដឹងអំពីសេចក្តីសញ្ញាទាំងឡាយនៃព្រះអម្ចាស់ » (នីហ្វៃទី ២ ៩:១) និង « បានត្រេកអរ និង ងើយក្បាលអ្នកឡើងជាដរាប » (នីហ្វៃទី ២ ៩:៣) ។ សូមធានាថា គោលបំណងទាំងនេះត្រូវរួមបញ្ចូលនៅក្នុងបញ្ជីរបស់សិស្ស ។ សូមស្នើថា នៅពេលសិស្សសិក្សាពីការបង្រៀនរបស់យ៉ាកុប ពួកគេអាចស្វែងរកការបង្រៀនដែលជួយបំពេញគោលបំណងទាំងនេះ ។

សូមថតចម្លងបន្ទាត់ពេលវេលាខាងក្រោមនៅលើក្តារខៀន ។ (អ្នកអាចថតចម្លងវា មុនពេលចាប់ផ្តើមថ្នាក់ ។) សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ៦:៤ ។ សូមចង្អុលបង្ហាញថា យ៉ាកុបបានចាប់ផ្តើមការបង្រៀនរបស់គាត់ដោយការនិយាយថា គាត់នឹងនិយាយអំពីលក្ខខណ្ឌដែលមាននៅក្នុងជំនាន់របស់គាត់ ហើយនឹងមាននៅក្នុងអនាគត (« រឿងដែលមាន និង រឿងដែលនឹងកើតឡើង ») ។



សូមចង្អុលទៅលេខ ១ នៅលើបន្ទាត់ពេលវេលា ។

- នៅក្នុង នីហ្វៃទី ២ ៦:៨ តើយ៉ាកុបនិយាយអ្វីខ្លះដែលបានកើតឡើងដល់សាសន៍យូដា នៅក្នុងទីក្រុងយេរូសាឡិម ដោយសារពួកគេបានងាកចេញពីព្រះអម្ចាស់ ? (អ្នកខ្លះត្រូវស្លាប់ និង ខ្លះត្រូវបានចាប់ជាឈ្លើយសឹក ។ អ្នកអាចរំឭកសិស្សថា លីហៃ យេរេមា និង ព្យាការីផ្សេងទៀតបានព្យាករណ៍ថា រឿងទាំងនេះនឹងកើតឡើង ។ ការព្យាករណ៍ទាំងនេះ ត្រូវបានបំពេញប្រហែលនៅក្នុង ៥៨៧ មុន.គ.ស. នៅពេលប្រជាជនបាប៊ីឡូនបានឈ្លានពានបានជោគជ័យលើទីក្រុងយេរូសាឡិម និង ចាប់បានពួកសាសន៍យូដាជាច្រើនជាឈ្លើយសឹកទៅទីក្រុងបាប៊ីឡូន ។ សូមមើល « កាលប្រវត្តិ » នៅក្នុងវចនានុក្រមព្រះគម្ពីរបរិសុទ្ធសម្រាប់កាលបរិច្ឆេទនេះ និង កាលបរិច្ឆេទផ្សេងទៀត ។)

សូមចង្អុលទៅលេខ ២ ។

- យោងទៅតាមឃ្លាទីមួយនៃនីហ្វៃទី ២ ៦:៩ តើនៅទីបញ្ចប់នឹងមានអ្វីកើតឡើងចំពោះកូនចៅរបស់សាសន៍យូដាដែលត្រូវបានចាប់ជាឈ្លើយនៅក្នុងទីក្រុងបាប៊ីឡូន ? (ពួកគេនឹងត្រឡប់ទៅទីក្រុងយេរូសាឡិម ។ ការព្យាករណ៍នេះ ត្រូវបានបំពេញនៅប្រហែលឆ្នាំ ៥៣៧ មុន.គ.ស. នៅពេលស្តេចស៊ីរូសអនុញ្ញាតឲ្យសាសន៍យូដាត្រឡប់ទៅកាន់ដែនដីកំណើតរបស់ពួកគេវិញ ។)

សូមចង្អុលទៅលេខ ៣ ហើយសូមពន្យល់ថា យ៉ាកុបបានព្យាករណ៍ថា ព្រះអង្គសង្គ្រោះនឹងរស់នៅជាជីវិតខាងសាច់ឈាមរបស់ទ្រង់ក្នុងចំណោមប្រជាជនយូដា ។

- នៅក្នុងនីហ្វៃទី ២ ៦:៩–១០ តើឃ្លាណាមួយដែលពិពណ៌នាពីរបៀបដែលសាសន៍យូដាខ្លះបានប្រតិកម្ម និង មានអារម្មណ៍ ចំពោះព្រះអង្គសង្គ្រោះ អំឡុងពេលការបម្រើជាសាច់ឈាមរបស់ទ្រង់ ? (ចម្លើយអាចរួមមាន « វាយទ្រង់ » « ឆ្កាងទ្រង់ » និង « ធ្វើចត្តិរឹងរូស ហើយក្បាលរឹងទាស់នឹង » ទ្រង់ ។)
- យោងតាម នីហ្វៃទី ២ ៦:១០–១១តើនឹងមានអ្វីកើតឡើងដល់សាសន៍យូដាដែលនឹងបដិសេធព្រះមែស៊ី ? (ពួកគេនឹងត្រូវឈឺចាប់ខាងសាច់ឈាម ត្រូវបានខ្ចាត់ខ្ចាយ ត្រូវបានគេវាយដំ និង ត្រូវគេស្អប់ ។)

សូមអញ្ជើញសិស្សអាននីហ្វៃទី ២៦:៦–៧, ១១–១២, ១៤, ១៧ដោយស្ងាត់ស្ងៀម ។ អ្នកអាចពន្យល់ថា នៅក្នុងខទី ៦–៧ យ៉ាកុបអានការព្យាករណ៍មួយរបស់អេសាយអំពីការស្តារឡើងវិញនៃដំណឹងល្អ និង ការប្រមូលផ្តុំនៃវង្សអ៊ីស្រាអែល ។ សូមឲ្យសិស្សរកឃ្លាដែលពិពណ៌នាពីរបៀបដែលព្រះអម្ចាស់នឹងឆ្លើយទៅនឹងវង្សអ៊ីស្រាអែល រាស្ត្រក្នុងសេចក្តីសញ្ញារបស់ព្រះអម្ចាស់ ទោះបីជាពួកគេនឹងបដិសេធទ្រង់ក្តី ។ សុំឲ្យសិស្សចែកចាយឃ្លាដែលពួកគេបានរកឃើញ ។ សូមជួយពួកគេឲ្យយល់ពីន័យនៃឃ្លាពីរបីនេះ ដោយការសួរសំណួរខាងក្រោម ៖

- នៅក្នុងនីហ្វៃទី ២ ៦:៧ តើអ្នកគិតថា « រង់ចាំ » ព្រះអម្ចាស់ មានន័យដូចម្តេចដែរ ?
- យ៉ាកុបបានសន្យាថា « ព្រះអម្ចាស់នឹងមានសេចក្តីមេត្តាករុណា » ដល់អ៊ីស្រាអែល (នីហ្វៃទី ២ ៦:១១) ។ តើឃ្លាខ្លះដែលអ្នកបានរកឃើញ យោងទៅលើសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់តាមរបៀបណា ?
- យ៉ាកុបក៏បានសន្យាថា ព្រះអម្ចាស់នឹង « ប្រុងចាំជួយ » អ៊ីស្រាអែល (នីហ្វៃទី ២ ៦:១៤) ។ តើអ្នកគិតថា វាមានន័យយ៉ាងណាចំពោះព្រះអង្គសង្គ្រោះដើម្បីប្រុងចាំជួយនរណាម្នាក់ ?
- យោងតាមនីហ្វៃទី ២ ៦:១១–១២, ១៤តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីទទួលបានសេចក្តីមេត្តាករុណាពីព្រះអម្ចាស់ ?

នៅពេលសិស្សចែកចាយអំពីការយល់ដឹងរបស់ពួកគេ សូមប្រាកដថា **ពួកគេយល់ថា ព្រះអម្ចាស់មានសេចក្តីមេត្តាករុណាដល់អស់អ្នកណាដែលត្រឡប់ទៅរកទ្រង់ ។**

សូមបង្ហាញថា នៅក្នុងនីហ្វៃទី ២ ៦ យ៉ាកុបប្រាប់អំពីការដែលព្រះអម្ចាស់មានសេចក្តីមេត្តាករុណាដល់រាស្ត្រក្នុងសេចក្តីសញ្ញារបស់ទ្រង់ ទោះបីជាក្រោយពេលដែលពួកគេបានក្លាយជាទុច្ចរិតខ្លាំងក៏ដោយ ។ សូមធានាសិស្សថា ប្រសិនបើព្រះអម្ចាស់មានសេចក្តីមេត្តាករុណាដល់ប្រជាជនទាំងនេះ ទ្រង់ប្រាកដជានឹងមានសេចក្តីមេត្តាករុណាចំពោះយើងម្នាក់ៗ នៅពេលយើងចូលមករកទ្រង់ ហើយរក្សាសេចក្តីសញ្ញារបស់យើងជាមួយនឹងទ្រង់ ។ សូមអញ្ជើញសិស្សឲ្យពិចារណាពីរបៀបដែលព្រះអម្ចាស់មានសេចក្តីមេត្តាករុណាទៅកាន់ពួកគេ ។ សូមឲ្យពួកគេសរសេរឃ្លាខាងក្រោមនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ៖ *ខ្ញុំដឹងថា ព្រះអម្ចាស់មានសេចក្តីមេត្តាករុណា ពីព្រោះ ។ . . .* បន្ទាប់មក សូមអញ្ជើញពួកគេសរសេរគំនិត និង អារម្មណ៍របស់ពួកគេឲ្យបំពេញប្រយោគនេះ ។ ក្រោយពីពួកគេមានពេលគ្រប់គ្រាន់សរសេរហើយ អ្នកអាចអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអ្វីដែលពួកគេបានសរសេរ ។

> *ការសរសេរពង្រីកការចែកចាយ*
>
> នៅពេលអ្នកអញ្ជើញសិស្សឲ្យឆ្លើយតបនឹងសំណួរមួយនៅក្នុងការសរសេរ មុនពេលចែកចាយគំនិតរបស់ពួកគេជាមួយនឹងថ្នាក់ នោះអ្នកបានផ្តល់ពេលដល់ពួកគេឲ្យផ្តើមគំនិតគេ និង ទទួលបានការបំផុសពីព្រះវិញ្ញាណបរិសុទ្ធ ។ សិស្សអាចមិនហ៊ានចែកចាយគំនិតរបស់ពួកគេ នៅពេលពួកគេបានសរសេរជាលើកដំបូងនោះ ហើយអ្វីដែលពួកគេចែកចាយ ជាញឹកញាប់ វានឹងមានន័យខ្លាំងជាង ។

នីហ្វៃទី ២ ៧–៨

យ៉ាកុបចែកចាយនូវការព្យាករណ៍របស់អេសាយ អំពីសមត្ថភាពរបស់ព្រះអង្គសង្គ្រោះក្នុងការប្រោសលោះរាស្ត្រក្នុងសេចក្តីសញ្ញារបស់ទ្រង់

សូមពន្យល់ថា នៅក្នុងនីហ្វៃទី ២ ៧និង៨យ៉ាកុបបានអានការព្យាករណ៍មួយមកពីការសរសេររបស់អេសាយ ។ ជំពូកទី ៧ រួមមានព្រះបន្ទូលរបស់ព្រះអម្ចាស់ទៅកាន់វង្សអ៊ីស្រាអែលដែលត្រូវបានខ្ចាត់ខ្ចាយ និង នៅក្នុងការជាប់ឃុំឃាំងដែលជាលទ្ធផលនៃអំពើបាបរបស់ពួកគេ ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ៧:១ ។ អ្នកអាចអញ្ជើញសិស្សឲ្យគូសចំណាំសំណួរដែលព្រះអម្ចាស់បានសួរ ។

ដើម្បីជួយសិស្សឲ្យយល់សំណួរនៅក្នុងខគម្ពីរទី ១ សូមពន្យល់ថា ឃ្លា « បណ្តេញអ្នកចេញ » « សំបុត្រលះលែងរបស់ម្តាយអ្នក » និង « បានលក់អ្នក » សំដៅលើគំនិតនៃការមិនធ្វើតាម ឬ ការគោរពយ៉ាងត្រឹមត្រូវតាមសេចក្តីសញ្ញាមួយ ។ សូមជួយសិស្សឲ្យយល់ថា សំណួររបស់ព្រះអម្ចាស់អាចនិយាយម្យ៉ាងទៀតដូចខាងក្រោមថា ៖ « តើយើងបានបែរចេញពីអ្នកឬ ? តើយើងបានបំភ្លេចសេចក្តីសញ្ញាដែលយើងបានធ្វើឬ ? »

- តើអ្វីជាចម្លើយចំពោះសំណួរទាំងនេះ ? (ចម្លើយគឺ ទេ ។ ព្រះអម្ចាស់នឹងមិនដែលងាកចេញពីយើង ឬ បំភ្លេចសេចក្តីសញ្ញាដែលទ្រង់បានធ្វើនោះទេ ។)
- យោងតាមឃ្លាបញ្ចប់នៃនីហ្វៃទី ២ ៧:១ ហេតុអ្វីបានជាប្រជាជនទាំងនេះត្រូវបានបំបែកចេញពីព្រះអម្ចាស់ ហើយរងទុក្ខនៅក្នុងការជាប់ឃុំឃាំង ? (ដោយសារតែពួកគេបានធ្វើអំពើបាប និង បានបែរចេញពីព្រះអម្ចាស់ ។)

សូមបង្ហាញថា នៅក្នុង នីហ្វៃទី ២ ៧:២ ព្រះអម្ចាស់បានសួរមួយសំណួរទៀតដែលអាចជួយយើងឲ្យឃើញថា ទ្រង់ចង់ជួយយើង ហើយថា ទ្រង់មានអំណាចដើម្បីធ្វើដូច្នោះបាន ។ សូមអញ្ជើញសិស្សរក និង គូសបន្ទាត់ពីក្រោមសំណួរ ។ (« តើដៃយើងបានរួញខ្លីនឹងជួយលោះអ្នកមិនបាន ឬ តើយើងគ្មានអំណាចនឹងដោះឲ្យរួចទេឬអី ? »)

ដើម្បីជួយសិស្សយល់សំណួរនេះ សូមសួរពួកគេពីរបៀបដែលពួកគេនឹងរៀបសំណួរនេះឡើងវិញជាសម្តីរបស់ពួកគេផ្ទាល់ ។ (ប្រសិនបើពួកគេមានការពិបាកយល់ឃ្លា « តើដៃយើងបានរុញខ្លីឬ » សូមអញ្ជើញសិស្សម្នាក់ហុចដៃរបស់គាត់ ឬ នាងឲ្យទៅសិស្សម្នាក់ទៀតចាប់ ហាក់ដូចជាហុចដៃផ្តល់ជំនួយ ។ បន្ទាប់មក សុំឲ្យសិស្សទីមួយ « បង្រួញ » ដៃរបស់គាត់ ឬ នាង ដោយបង្ហាញគំនិតចង់ដកជំនួយ ឬ ដកដៃមកវិញ ។) សិស្សអាចនិយាយសំណួររបស់ព្រះអម្ចាស់ឡើងវិញ ដោយការនិយាយអ្វីមួយដូចនេះ ៖ « តើខ្ញុំដកដៃវិញ ឬ តើខ្ញុំមិនអាចឈោងទៅជួយសង្គ្រោះអ្នកបានឬអី ? តើអ្នកជឿថា ខ្ញុំមានអំណាចសង្គ្រោះអ្នកដែរឬទេ ?

សូមប្រាប់សិស្សថា ដើម្បីឆ្លើយនឹងសំណួរនេះ នីហ្វៃទី ២ ៧ និង៨ ទាំងអស់ រួមមានគំរូជាច្រើនដែលបង្ហាញពីបំណងរបស់ព្រះអង្គសង្គ្រោះដើម្បីប្រោសលោះរាស្ត្រក្នុងសេចក្តីសញ្ញារបស់ទ្រង់ និង គំរូដែលបង្ហាញថា ទ្រង់មានអំណាចដើម្បីដូច្នោះមែន ។

ដើម្បីជួយសិស្សរកឃើញភស្តុតាងដែល **ព្រះអង្គសង្គ្រោះមានបំណងចង់ប្រោសលោះរាស្ត្រក្នុងសេចក្តីសញ្ញារបស់ទ្រង់ និង អំណាចដើម្បីធ្វើដូច្នោះមែន** សូមបែងចែកវគ្គព្រះគម្ពីរខាងក្រោមជាប្រាំមួយផ្នែកនៅក្នុងនីហ្វៃទី ២ ៨ ក្នុងចំណោមក្រុមសិស្សនោះ ៖ ខគម្ពីរទី ១–៣, ៤–៦, ៧–៨, ១០–១១, ១២–១៣, និង ១៤–១៦ ។ (ប្រសិនបើអ្នកមានសិស្ស ១២ នាក់ ឬ ច្រើនជាងនេះនៅក្នុងថ្នាក់របស់អ្នក សូមចាត់ចែងវគ្គមួយៗទៅដៃគូ ឬ ក្រុមតូចៗផ្សេងទៀត ។ ប្រសិនបើអ្នកមានសិស្សតិចជាង ១២ នាក់ សូមចាត់ចែងវគ្គព្រះគម្ពីរច្រើនជាងមួយទៅដល់ក្រុមខ្លះ ។) សុំឲ្យក្រុមនីមួយៗរកឃ្លាមួយនៅក្នុងវគ្គដែលគេអាន ឬ វគ្គដែលបង្ហាញពីបំណងរបស់ព្រះអម្ចាស់ក្នុងការប្រោសលោះយើង និង អំណាចរបស់ទ្រង់ដើម្បីធ្វើដូច្នោះ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញក្រុមនីមួយៗអានឃ្លាដែលពួកគេបានជ្រើសរើសទៅកាន់ថ្នាក់ ។ សុំឲ្យពួកគេចែកចាយនូវអ្វីដែលពួកគេបានរៀនពីវគ្គនេះ ។ អ្នកអាចអញ្ជើញសិស្សគ្រូសចំណាំឃ្លាដែលមិត្តភក្តិរបស់ពួកគេបានចែកចាយ ។

ដើម្បីបញ្ចប់ សូមបើកទៅបញ្ជីនៃគោលបំណងរបស់យ៉ាកុប ដែលបានសរសេរនៅលើក្តារខៀន ។ សូមអញ្ជើញសិស្សគិតអំពីសេចក្តីសញ្ញាដែលពួកគេបានធ្វើជាមួយនឹងព្រះអម្ចាស់ និង ពរជ័យដែលទ្រង់បានសន្យានឹងពួកគេ នៅពេលពួកគេកាន់តាមសេចក្តីសញ្ញាទាំងនោះ ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីភាពស្មោះត្រង់របស់ព្រះអម្ចាស់ចំពោះយើង និង សេចក្តីសញ្ញារបស់ទ្រង់ជាមួយនឹងយើង ហើយសូមថ្លែងទីបន្ទាល់អំពីសេចក្តីមេត្តាករុណា និង ការប្រោសលោះដែលយើងអាចទទួលបាន នៅពេលយើងស្មោះត្រង់ចំពោះសេចក្តីសញ្ញារបស់យើងជាមួយនឹងទ្រង់ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ២ ៦:២ ។ តើអំណាចបព្វជិតភាពអ្វីដែលលីហៃ នីហ្វៃ និង យ៉ាកុបបានកាន់ ?

យ៉ាកុបបាននិយាយថា គាត់ត្រូវ « បានហៅពីព្រះ ហើយបានតែងតាំងឡើងតាមរបៀបដ៏បរិសុទ្ធរបស់ទ្រង់ » ហើយថាគាត់បាន « ញែកចេញដោយបងប្រុស [របស់គាត់] គឺនីហ្វៃ » (នីហ្វៃទី ២ ៦:២) ។ នៅពេលគាត់និយាយអំពី « របៀបដ៏បរិសុទ្ធ » នេះ គាត់សំដៅទៅលើបព្វជិតភាពមុលគីស្សាដែក ។ ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធសរសេរថា « សាសន៍នីហ្វៃបានគ្រប់គ្រងដោយគុណធម៌នៃបព្វជិតភាពមីលគីស្សាដែកពីជំនាន់របស់លីហៃមកដល់ជំនាន់នៃការយាងមករបស់ព្រះអង្គសង្គ្រោះក្នុងចំណោមពួកគេ » (*Answers to Gospel Questions,* comp. យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ជុញ្ញ៉ា ៥ vols ។ [១៩៥៧–៦៦] ១:១២៤) ។

នីហ្វៃទី ២ ៨ ។ ការប្រមូលផ្តុំនៅថ្ងៃចុងក្រោយ

ការព្យាករណ៍របស់អេសាយបានដកស្រង់នៅក្នុង នីហ្វៃទី ២ ៨ និយាយពីការប្រមូលផ្តុំអ៊ីស្រាអែលនៅថ្ងៃចុងក្រោយ ។ អែលឌើរ ប្រ៊ូស អ័រ. ម៉ាក់ខនឃី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនអំពីលក្ខណៈខាងវិញ្ញាណនៃការប្រមូលផ្តុំនេះ ៖

« បន្ទាប់មក តើអ្វីដែលទាក់ទងនឹងការប្រមូលផ្តុំអ៊ីស្រាអែល ? ការប្រមូលផ្តុំអ៊ីស្រាអែលមានក្នុងការជឿ និង ការទទួល និង ការរស់នៅដោយសុខុមនឹងអ្វីទាំងអស់ដែលព្រះអម្ចាស់ធ្លាប់បានផ្តល់ដល់ប្រជាជនជម្រើសពីបុរាណរបស់ទ្រង់ ។ វារួមបញ្ចូលនូវការមានសេចក្តីជំនឿរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ការប្រែចិត្ត ការទទួលបុណ្យជ្រមុជទឹក និង ការទទួលអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ និង ការកាន់តាមព្រះបញ្ញត្តិនៃព្រះ ។ វារួមមានការជឿលើដំណឹងល្អ ការចូលរួមក្នុងសាសនាចក្រ និង ការចូលមកក្នុងនគរ ។ វារួមមានការទទួលបព្វជិតភាពដ៏បរិសុទ្ធ ការទទួលបានអំណោយទានពិសិដ្ឋនៅទីដ៏បរិសុទ្ធដោយព្រះចេស្តាពីទីខ្ពស់ និង ការទទួលបាននូវពរជ័យទាំងអស់ពីអ័ប្រាហាំ អ៊ីសាក និង យ៉ាកុប តាមរយៈពិធីបរិសុទ្ធនៃអាពាហ៍ពិពាហ៍ខាងសេឡេស្ទាល » (*A New Witness for the Articles of Faith* [ឆ្នាំ ១៩៨៥] ទំព័រ ៥១៥) ។

នីហ្វៃទី ២ ៩:១–២៦

សេចក្តីផ្តើម

នៅក្នុងទេសនកថាមួយដល់សាសន៍នីហ្វៃ យ៉ាកុបបានចាប់ផ្តើមដោយការដកស្រង់ការព្យាករណ៍របស់អេសាយខ្លះៗ អំពីព្រះអម្ចាស់ដែលប្រោសលោះប្រជាជនក្នុងសេចក្តីសញ្ញារបស់ទ្រង់ ។ ផ្នែកនៃទេសនកថារបស់យ៉ាកុបនេះ មាននៅក្នុង នីហ្វៃទី ២ ៦–៨ (សូមមើល មេរៀនទី ២៨ នៅក្នុងសៀវភៅសិក្សានេះ) ។ ការបន្តនៃទេសនកថាពីថ្ងៃនេះ មាននៅក្នុង នីហ្វៃទី ២ ៩–១០ ។ ក្រោយពីការដកស្រង់ពីអេសាយ យ៉ាកុបបានចែកចាយទីបន្ទាល់ផ្ទាល់ខ្លួនគាត់ អំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ —អំពីព្រះចេស្តារបស់ព្រះអង្គសង្គ្រោះ ដើម្បីសង្គ្រោះយើងពីឥទ្ធិពលនៃការធ្លាក់ និង លទ្ធផលនៃអំពើបាបរបស់យើង ។ ប្រធាន យ៉ូសែប ហ្វីលឌីង ស្មីធ បានបង្រៀនថា នីហ្វៃទី ២ ៩ រួមមាន « សេចក្តីថ្លែងដ៏បំភ្លឺបំផុតមួយដែលធ្លាប់បានធ្វើទាក់ទងនឹងដង្វាយធួន » ។ គាត់មានប្រសាសន៍ថា « វាគួរតែបានអានដោយប្រុងប្រយ័ត្នដោយមនុស្សគ្រប់គ្នាក្នុងការស្វែងរកសេចក្តីសង្គ្រោះ » (*Answers to Gospel Questions* comp. យ៉ូសែប ហ្វីលឌីង ស្មីធ ជុញ្ញ័រ ៥ vols ។ [១៩៥៧–៦៦]៤:៥៧) ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ៩:១–៩

យ៉ាកុបពន្យល់ពីឥទ្ធិពលនៃការធ្លាក់

មុនពេលចាប់ផ្តើមរៀន ចូរសរសេរពាក្យ *វិរូបដ៏គួរស្ញែងខ្លាច* នៅកណ្តាលក្តារខៀន ។

ចាប់ផ្តើមមេរៀនដោយពន្យល់ថានីហ្វៃទី ២ –៩ មានបន្តទេសនកថាដែលសិស្សសិក្សានៅមេរៀនមុន ។ សូមរំឭកសិស្សថា នៅក្នុងផ្នែកដំបូងនៃទេសនកថានេះ មាននៅក្នុង នីហ្វៃទី ២ ៦–៨ យ៉ាកុបបានដកស្រង់ពីអេសាយដើម្បីបង្រៀនអំពីសេចក្តីមេត្តាករុណារបស់ព្រះអង្គសង្គ្រោះ និង ព្រះចេស្តារបស់ទ្រង់ក្នុងការរំដោះប្រជាជនក្នុងសេចក្តីសញ្ញារបស់ទ្រង់ពីស្ថានភាពបាត់បង់ និង ខ្ចាត់ខ្ចាយរបស់ពួកគេ ។ នៅពេលគាត់បានបន្តទេសនកថារបស់គាត់ យ៉ាកុបបានបង្រៀនពីរបៀបដែលព្រះអង្គសង្គ្រោះយើងទាំងអស់គ្នាចេញពីស្ថានភាពធ្លាក់ និង ពោរពេញដោយអំពើបាបរបស់យើង ។

សូមទាញយកចំណាប់អារម្មណ៍របស់សិស្សលើឃ្លា ដែលអ្នកបានសរសេរនៅលើក្តារខៀន ។

- **តើមានគិតដល់អ្វី នៅពេលអ្នកគិតអំពីវិរូបដ៏គួរស្ញែងខ្លាចមួយ ?**

ដើម្បីឆ្លើយនឹងសំណួរនេះ សិស្សអាចនិយាយពីសត្វចម្លែកក្នុងការស្រមៃបាន ។ ប្រសិនបើពួកគេឆ្លើយ សូមពន្យល់ថា អ្វីៗដែលពិតអាចគួរឲ្យខ្លាចជាង សត្វចម្លែកក្នុងការស្រមៃ ដោយសារវាអាចនាំមកនូវការឈឺដ៏យូរអង្វែង ។ សូមប្រាប់សិស្សថា យ៉ាកុបបានប្រើឃ្លា « វិរូបដ៏គួរស្ញែងខ្លាច » ដើម្បីពិពណ៌នាពីលក្ខខណ្ឌមួយដែលយើងទាំងអស់គ្នានឹងជួប និង ការឈឺចាប់ដ៏អស់កល្បដែលអាចជាលទ្ធផលពីវា ។ សូមឲ្យសិស្សអាន នីហ្វៃទី ២ ៩:១០ដោយស្ងាត់ៗ ដោយស្វែងរកធាតុផ្សំពីរនៃវិរូបដែលយ៉ាកុបបានពិពណ៌នានោះ ។ នៅពេលសិស្សចែកចាយពីអ្វីដែលពួកគេរកឃើញ សូមបន្តែមចម្លើយលើក្តារខៀនដូចដែលបានបង្ហាញនៅខាងក្រោម ៖

ដើម្បីជួយសិស្សឲ្យយល់ពីការប្រើពាក្យរបស់យ៉ាកុបដូចជា *សេចក្តីស្លាប់* និង *ស្ថាននរក* សូមពន្យល់ថា ពាក្យទាំងពីរនេះសំដៅលើការបែកមួយប្រភេទ ។ នៅពេលយ៉ាកុបប្រើពាក្យ *សេចក្តីស្លាប់* នៅក្នុងទេសនកថានេះ គាត់បានសំដៅទៅលើ « សេចក្តីស្លាប់នៃ



រូបកាយ » ដែលជាការបែកនៃរូបកាយខាងសាច់ឈាមពីវិញ្ញាណ ។ នៅពេលគាត់បានប្រើពាក្យ *ស្ថាននរក* គាត់បានយោងទៅលើ « សេចក្តីស្លាប់នៃវិញ្ញាណ » ដែលជាការបែករបស់មនុស្សម្នាក់ពីវត្តមាននៃព្រះ ។ នៅក្នុងព្រះគម្ពីរ ការបែកនេះជារឿយៗគឺសំដៅទៅលើ « សេចក្តីស្លាប់នៃវិញ្ញាណ » ។

សូមអញ្ជើញសិស្សអាន នីហ្វៃទី ២ ៩:៦ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេស្វែងរកមូលហេតុនៃសេចក្តីស្លាប់នៃរូបកាយ និង សេចក្តីស្លាប់នៃវិញ្ញាណ ។

- **តើមានព្រឹត្តិការណ៍អ្វីដែលនាំឲ្យមានសេចក្តីស្លាប់នៃរូបកាយ និង សេចក្តីស្លាប់នៃវិញ្ញាណដល់យើងទាំងអស់គ្នានោះ ? (អ្នកគួរតែពន្យល់ថា ជាលទ្ធផលពីការធ្លាក់ មនុស្សទាំងអស់ត្រូវបានកាត់ចេញពីវត្តមាននៃព្រះ ហើយមនុស្សទាំងអស់នឹងត្រូវស្លាប់ខាងរូបកាយនៅទីបំផុត ។**

សូមពន្យល់ថា នៅក្នុង នីហ្វៃទី ២ ៩:៧–៩យ៉ាកុបបង្រៀនពីអ្វីដែលនឹងកើតឡើងដល់យើង ប្រសិនបើគ្មានដង្វាយធួន ហើយឥទ្ធិពលនៃការធ្លាក់នោះនៅតែមានជារៀងរហូត ។ ដើម្បីរៀបចំសិស្សឲ្យសិក្សាពីខគម្ពីរទាំងនេះ អ្នកអាចឲ្យនិយមន័យពាក្យពីរបីនៅក្នុងខទី

៧ ៖ នៅពេលយ៉ាកុបបាននិយាយអំពី « សេចក្តីជំនុំជម្រះទីមួយដែលធ្លាក់មកលើមនុស្ស » គាត់សំដៅទៅលើលទ្ធផលនៃការធ្លាក់របស់អ័ដាម និង អេវ៉ា ។ នៅពេលគាត់និយាយអំពី « ការពុករលួយ » គាត់សំដៅលើរូបកាយខាងសាច់ឈាមរបស់យើង ដែលនឹងស្លាប់ ។ នៅពេលគាត់និយាយអំពី « មិនអាចពុករលួយ » គាត់សំដៅទៅលើរូបកាយដែលរស់ឡើងវិញរបស់យើង ដែលនឹងរស់នៅជារៀងរហូត ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ៩:៧–៩ឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្វែងរកឃ្លាដែលពិពណ៌នាពីអ្វីដែលនឹងកើតឡើងដល់រូបកាយ និង វិញ្ញាណរបស់យើង ប្រសិនបើសេចក្តីស្លាប់នៃរូបកាយ និង សេចក្តីស្លាប់នៃវិញ្ញាណនៅតែមានជារៀងដរាបទៅ ។

- ប្រសិនបើគ្មានដង្វាយធួនទេ តើនឹងមានអ្វីកើតឡើងដល់រូបកាយរបស់យើង ?
- ប្រសិនបើគ្មានដង្វាយធួនទេ តើនឹងមានអ្វីកើតឡើងដល់វិញ្ញាណរបស់យើង ?

ដើម្បីបញ្ជាក់ពីអ្វីដែលនឹងជាជោគវាសនារបស់យើង បើសិនជាគ្មានដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទទេនោះ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមឮៗ ដោយអែលឌើរ ឌី. ថត គ្រីស្តូហ្វឺសិននៃក្រុមប្រឹក្សាដប់ពីរនាក់ ។

« ប្រសិនបើការបែកចេញពីព្រះរបស់យើង និង សេចក្តីស្លាប់នៃរូបកាយរបស់យើងកើតមានជាដរាប នោះសិទ្ធិជ្រើសរើសខាងសីលធម៌នឹងគ្មានន័យអ្វីទាំងអស់ ។ មែនហើយ យើងនឹងមានសេរីភាពក្នុងការជ្រើសរើស ប៉ុន្តែតើវាបានប្រយោជន៍អ្វី ? លទ្ធផលចុងក្រោយនឹងដូចគ្នាជានិច្ច មិនថាសកម្មភាពរបស់យើងយ៉ាងណានោះទេ ៖ សេចក្តីស្លាប់ដោយគ្មានសង្ឃឹមពីការរស់ឡើងវិញ និង គ្មានសេចក្តីសង្ឃឹមពីស្ថានសួគ៌នោះ ។ មិនថាយើងអាចជ្រើសដើម្បីក្លាយជាល្អ ឬ អាក្រក់ប៉ុណ្ណាទេ យើងទាំងអស់គ្នានឹងបញ្ចប់ទៅជា ‹ ពួកពលបរិវារនៃអារក្ស › ។ | នីហ្វៃទី ២ ៩:៩។| » (« Moral Agency" *Ensign*| មិថុនា ឆ្នាំ ២០០៩ ទំព័រ ៥០) ។

នីហ្វៃទី ២ ៩:១០–២៦

យ៉ាកុបបង្រៀនថា តាមរយៈដង្វាយធួន ព្រះអង្គសង្គ្រោះនឹងរំដោះយើងចេញពីឥទ្ធិពលនៃការធ្លាក់ និង ផ្តល់ឲ្យយើងនូវការអភ័យទោសពីអំពើបាបរបស់យើង ។

សូមឲ្យសិស្សអាន នីហ្វៃទី ២ ៩:១០ ម្តងទៀត ។

- យោងតាមខគម្ពីរនេះ តើព្រះបានរៀបចំអ្វីសម្រាប់យើង ?

សូមបញ្ជាក់ថា សារលិខិតសំខាន់របស់យ៉ាកុបនៅក្នុងទេសនាថានេះគឺថា ព្រះបានរៀបចំ « ផ្លូវសម្រាប់ឲ្យយើងរំដោះខ្លួនចេញពីក្រញ៉ាំនៃ . . . សេចក្តីស្លាប់ និង ស្ថាននរក » ។ ការរំដោះនេះ—ចេញពីសេចក្តីស្លាប់នៃរូបកាយ និង នៃវិញ្ញាណដែលនាំមកដោយការធ្លាក់—ត្រូវបានធានាដោយសារការពលិកម្មនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។

សូមបែងចែកសិស្សក្នុងថ្នាក់ជាពីរក្រុម ។ សូមអញ្ជើញក្រុមទីមួយអាន នីហ្វៃទី ២ ៩:៥, ១៩–២១ ដោយស្ងាត់ស្ងៀម ដោយស្វែងរកការពិពណ៌នានៃការពលិកម្មរបស់ព្រះអង្គសង្គ្រោះសម្រាប់យើង ។ សូមអញ្ជើញក្រុមទីពីរអាន នីហ្វៃទី ២ ៩:១១–១២, ១៥, ២២ដោយស្ងាត់ស្ងៀម ដោយស្វែងរកឃ្លាអំពីព្រះយេស៊ូវគ្រីស្ទ ដែលបានសង្គ្រោះយើងចេញពីសេចក្តីស្លាប់នៃរូបកាយ ។ (វាអាចជួយច្រើន បើសរសេរសេចក្តីយោងទាំងនេះដាក់នៅលើក្តារខៀន) ។

នៅពេលសិស្សមានពេលវេលាអាន សូមសួរក្រុមទីមួយនូវសំណួរដូចខាងក្រោម ៖

- តើព្រះអង្គសង្គ្រោះស្ម័គ្រព្រះទ័យដើម្បីរងទុក្ខអ្វីខ្លះ ដើម្បីទ្រង់អាចរំដោះយើងចេញពីសេចក្តីស្លាប់នៃរូបកាយ និង នៃវិញ្ញាណនោះ ? តើការពិពណ៌នាអ្វីដែលអ្នកឃើញថា មានអត្ថន័យខ្លាំងដល់អ្នក ?
- យ៉ាកុបបានបញ្ជាក់ថា ព្រះយេស៊ូវគ្រីស្ទបានរងនូវការឈឺចាប់នៃមនុស្សទាំងអស់ ។ តើការណ៍នេះមានអត្ថន័យយ៉ាងណាចំពោះអ្នក ? តើចំណេះដឹងនេះ មានឥទ្ធិពលយ៉ាងណាដល់អារម្មណ៍របស់អ្នកអំពីព្រះអង្គសង្គ្រោះ ? (ដើម្បីជួយសិស្សឲ្យសញ្ជឹងគិតអំពីទំហំនៃការពលិកម្មរបស់ព្រះអង្គសង្គ្រោះ អ្នកអាចបញ្ឈប់ការពិភាក្សាបន្តិច ហើយបញ្ជាក់ថា ព្រះអង្គសង្គ្រោះបានរងនូវការឈឺចាប់នៃមនុស្សទាំងអស់ដែលបានរស់នៅ ព្រមទាំងអ្នកដែលនឹងមករស់នៅលើផែនដីនេះ ។ ដើម្បីជួយសិស្សឲ្យសញ្ជឹងគិតអំពីលក្ខណៈផ្ទាល់នៃការពលិកម្មរបស់ព្រះអង្គសង្គ្រោះ សូមពិចារណាពីការអញ្ជើញពួកគេឲ្យសរសេរឈ្មោះរបស់ពួកគេនៅក្បែររឹមទំព័រជិត នីហ្វៃទី ២ ៩:២១ធ្វើជាការរំឭកមួយថា ព្រះអង្គសង្គ្រោះបានរងនូវការឈឺចាប់របស់ពួកគេ) ។

សូមសួរក្រុមទីពីរនូវសំណួរខាងក្រោម ៖

- តើឃ្លាអ្វីដែលអ្នករកឃើញអំពីព្រះយេស៊ូវគ្រីស្ទដែលបានសង្គ្រោះយើងចេញពីសេចក្តីស្លាប់នៃរូបកាយ ?
- យោងតាម នីហ្វៃទី ២ ៩:២២ តើនរណានឹងត្រូវរស់ឡើងវិញ ហើយនាំត្រឡប់ទៅកាន់វត្តមាននៃព្រះវិញ ?

សូមបើកត្រឡប់ទៅឃ្លា « រឿបដ៏គួរស្ញែងខ្លាច » នៅលើក្តារខៀន ។ សូមអញ្ជើញសិស្សនិយាយជាពាក្យសម្តីរបស់ពួកគេផ្ទាល់ ពីអ្វីដែលយ៉ាកុបបានបង្រៀនអំពីរបៀបដែលយើងអាចត្រូវបានសង្គ្រោះចេញពី « រឿប » នេះ ។ សូមធានាថា សិស្សយល់ថា **តាមរយៈដង្វាយធួនព្រះយេស៊ូវគ្រីស្ទនឹងរំដោះមនុស្សជាតិទាំងអស់ចេញពីសេចក្តីស្លាប់នៃរូបកាយ និង នៃវិញ្ញាណដែលនាំមកដោយសារការធ្លាក់ ។**សូមអញ្ជើញសិស្សម្នាក់សរសេរសេចក្តីពិតនេះនៅលើក្តារខៀន ។

សូមរំឭកសិស្សថា បន្ថែមលើការរំដោះមនុស្សជាតិទាំងអស់ចេញពីសេចក្តីស្លាប់នៃរូបកាយ និង នៃវិញ្ញាណដែលបណ្តាលមកពីការធ្លាក់ ព្រះយេស៊ូវគ្រីស្ទអាចរំដោះយើងចេញពីសេចក្តីស្លាប់នៃវិញ្ញាណដែលបណ្តាលមកពីអំពើបាបរបស់យើងផ្ទាល់ ។

សូមពន្យល់ថា យ៉ាកុបបានពិពណ៌នាស្ថានភាពរបស់មនុស្សដែលមានអំពើបាបដែលឈរនៅពីមុខព្រះ ។ សូមអញ្ជើញសិស្សឲ្យស្វែងរកការពិពណ៌នាទាំងនេះ ខណៈពេលដែលសិស្សម្នាក់អាន នីហ្វៃទី ២ ៩:១៥–១៦, ២៧ឮៗ ។

- តើយ៉ាកុបបានពិពណ៌នាស្ថានភាពរបស់មនុស្សដែលមានអំពើបាបដែលឈរនៅពីមុខព្រះយ៉ាងដូចម្តេច ?

សូមពន្យល់ថា យ៉ាកុបក៏បានពិពណ៌នាពីស្ថានភាពរបស់មនុស្សដែលបរិសុទ្ធដែលឈរនៅពីមុខព្រះដែរ ។ សូមអញ្ជើញសិស្សឲ្យស្វែងរកការពិពណ៌នាទាំងនេះ ខណៈពេលដែលសិស្សម្នាក់អាន នីហ្វៃទី ២ ៩:១៤, ១៨ឮៗ ។

- តើយ៉ាកុបបានពិពណ៌នាស្ថានភាពរបស់មនុស្សដែលបរិសុទ្ធដែលឈរនៅពីមុខព្រះយ៉ាងដូចម្តេច ?

សូមបង្ហាញថា ខណៈពេលដែលការរំដោះពីការធ្លាក់គឺជាអំណោយទានមួយដល់មនុស្សជាតិគ្រប់រូប ការរំដោះរបស់យើងចេញពីលទ្ធផលនៃអំពើបាបរបស់យើង ពឹងផ្អែកមួយផ្នែកលើបំណងប្រាថ្នា និង សកម្មភាពរបស់យើង ។ សូមសរសេរអ្វីខាងក្រោមដាក់លើក្តារខៀន ៖ *តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ នោះយើងអាចយកឈ្នះលើលទ្ធផលនៃអំពើបាបរបស់យើង នៅពេលយើង . . .*

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ៩:២១, ២៣–២៤ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកឃ្លានានាដើម្បីបំពេញប្រយោគនៅលើក្តារខៀននេះ ។

- យោងតាមខគម្ពីរទាំងនេះ តើអ្នកនឹងបំពេញប្រយោគនេះដោយរបៀបណា ? (**ចម្លើយរបស់សិស្សគួរឆ្លុះបញ្ចាំងពីការបំពេញប្រយោគខាងក្រោមដូចជា ៖ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ នោះយើងអាចយកឈ្នះលើលទ្ធផលនៃអំពើបាបរបស់យើង នៅពេលយើងមានសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ប្រែចិត្ត ទទួលបុណ្យជ្រមុជទឹក និង តស៊ូដល់ទីបញ្ចប់ ។** នៅពេលពួកគេចែកចាយចម្លើយរបស់ពួកគេ សូមបំពេញសេចក្តីថ្លែងការណ៍នៅលើក្តារខៀន) ។

សូមបញ្ចប់មេរៀននេះ ដោយការជ្រើសរើសសកម្មភាពមួយខាងក្រោម ។ សកម្មភាពទាំងពីរមានគោលបំណងដើម្បីជួយសិស្សឲ្យគិតអំពីអត្ថន័យដែលដង្វាយធួនរបស់ព្រះអង្គសង្គ្រោះមានន័យដល់ពួកគេ ហើយដើម្បីចែកចាយអារម្មណ៍របស់ពួកគេអំពីទ្រង់ ។

១ .សូមឲ្យសិស្សមើលត្រួសៗក្នុង នីហ្វៃទី ២ ៩:១–២២ ហើយរកខគម្ពីរទាំងអស់ដែលចាប់ផ្តើមដោយ៣ក្យថា *ខ្ញុំ* ។ សូមអញ្ជើញសិស្សអានប្រយោគទីមួយនៃខគម្ពីរទាំងនោះឮៗ ។

សូមអញ្ជើញសិស្សសរសេរប្រយោគស្រដៀងគ្នានៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ដោយពិពណ៌នាពីអារម្មណ៍របស់ពួកគេផ្ទាល់ អំពីការដឹងគុណចំពោះព្រះអង្គសង្គ្រោះ និង ការពលិកម្មរបស់ទ្រង់សម្រាប់ពួកគេ ។ សូមឲ្យពួកគេធ្វើតាមគំរូរបស់យ៉ាកុបដោយចាប់ផ្តើមប្រយោគនីមួយៗដោយ៣ក្យ *ខ្ញុំ* និងបញ្ចប់ដោយឧទានសញ្ញាមួយ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយប្រយោគរបស់ពួកគេ បើតាមដែលសមរម្យ ។ សូមធានាថា ពួកគេយល់ថា ពួកគេមិនចាំបាច់មានអារម្មណ៍ថា មានកាតព្វកិច្ចដើម្បីចែកចាយអារម្មណ៍ ឬ បទពិសោធន៍ណាដែលសម្ងាត់ ឬ ផ្ទាល់ខ្លួនខ្លាំងនោះទេ ។

២ .សូមច្រៀង ឬ អាន៣ក្យក្នុងបទ « ខ្ញុំឆ្ងល់យ៉ាងអស្ចារ្យ » ទាំងអស់គ្នាក្នុងថ្នាក់ (*ទំនុកតម្កើង ទំព័រ ២២*) ឬ ទំនុកតម្កើងផ្សេងទៀតអំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ សូមអញ្ជើញសិស្សជ្រើសរើសឃ្លាពីក្នុងទំនុកតម្កើងដែលបង្ហាញពីអារម្មណ៍របស់ពួកគេអំពីព្រះអង្គសង្គ្រោះ និង ការពលិកម្មដង្វាយធួនរបស់ទ្រង់ ។ សូមអនុញ្ញាតឲ្យពួកគេប្រាប់សិស្សក្នុងថ្នាក់អំពីឃ្លាដែលពួកគេបានរើស ហើយពន្យល់ពីមូលហេតុដែលពួកគេសរសើរដល់ឃ្លាទាំងនោះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ២ ៩:៧ ។ តើអ្វីនឹងជាឥទ្ធិពលនៃការធ្លាក់ដោយគ្មានដង្វាយធួននោះ ?

អែលឌើរ ឌី. ថត គ្រីស្តុហ្វឺសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ពីអ្វីដែលនឹងជាជោគវាសនារបស់យើង បើគ្មានដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទទេនោះ ។

« ដូចជាសេចក្តីស្លាប់ដែលនឹងបំផ្លាញយើង ហើយធ្វើឲ្យសិទ្ធិជ្រើសរើសរបស់យើងគ្មានន័យដែរ ប៉ុន្តែបើមិនដោយសារសេចក្តីសង្គ្រោះរបស់ព្រះគ្រីស្ទ និង ដោយសារព្រះគុណរបស់ទ្រង់ទេ នោះអំពើបាប និង ជម្រើសដ៏អាក្រក់របស់យើងនឹងទម្លាក់យើងឲ្យវង្វេងជារៀងរហូតទៅ ។ វាគ្មានផ្លូវណាក្នុងការសងស្បើយបានយ៉ាងពេញលេញពីកំហុសរបស់យើង និង ការមិនស្អាតនោះទេ យើងមិនអាចរស់នៅម្តងទៀតនៅក្នុងវត្តមាននៃ [ព្រះ] បានទេ ។

« . . . យើងត្រូវការព្រះអង្គសង្គ្រោះ អ្នកកណ្តាលដែលអាចយកឈ្នះលើឥទ្ធិពលនៃអំពើបាប និង កំហុសរបស់យើងដើម្បីពួកគេមិនចាំបាច់ត្រូវវិនាសដល់ស្លាប់ទៀត ។ ដោយសារតែដង្វាយធួនរបស់ព្រះគ្រីស្ទទើបយើងអាចសងស្បើយពីជម្រើសដ៏អាក្រក់ទាំងឡាយ ហើយបានធ្វើយុត្តិកម្មនៅក្រោមច្បាប់ឲ្យក្លាយបានដូចជាយើងមិនបានធ្វើបាបដែរ » (« Moral Agency » *Ensign* ខែ មិថុនា ឆ្នាំ ២០០៩ ទំព័រ ៥) ។

មេរៀនទី ៣០

នីហ្វៃទី ២ ៩:២៧–៥៤និង នីហ្វៃទី ២ ១០

សេចក្តីផ្តើម

ក្រោយពីការថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទនឹងរំដោះមនុស្សជាតិទាំងអស់ចេញពីឥទ្ធិពលនៃការធ្លាក់ ហើយថាទ្រង់នឹងប្រទានការអភ័យទោសដល់យើងចេញពីអំពើបាបរបស់យើង នោះយ៉ាកុបបានបញ្ចប់ទេសនកថារបស់គាត់ ។ គាត់បានព្រមានទាស់នឹងឥរិយាបថ និង សកម្មភាពដែលនាំទៅរកការបែកពីព្រះអម្ចាស់ ហើយគាត់បានថ្លែងទីបន្ទាល់អំពីឥរិយាបថ និង សកម្មភាពដែលនាំឲ្យមនុស្សមករកព្រះគ្រីស្ទ ហើយបានសង្ត្រោះ ។ នៅថ្ងៃបន្ទាប់ យ៉ាកុបបានធ្វើម្តងទៀតថា ទោះបីជាវង្សនៃអ៊ីស្រាអែលនឹងត្រូវខ្ចាត់ខ្ចាយដោយសារតែអំពើបាបក្តី ព្រះអម្ចាស់ក៏នឹងចងចាំដល់សេចក្តីសញ្ញារបស់ទ្រង់ជាមួយនឹងពួកគេ ហើយប្រមូលផ្តុំពួកគេ នៅពេលពួកគេប្រែចិត្ត ហើយត្រឡប់មកកាន់ទ្រង់វិញ ។ យ៉ាកុបបានព្យាករណ៍អំពីការធ្តាងព្រះយេស៊ូវគ្រីស្ទ ។ គាត់ក៏បានព្យាករណ៍ដែរថា ដែនដីសន្យារបស់ប្រជាជានរបស់គាត់នឹងជាកន្លែងនៃសេរីភាពមួយ ការពារប្រឆាំងនឹងជាតិទាំងអស់ ហើយមានសេរីភាពពីការគ្រងរាជ្យនៃស្តេចនានា ។ យ៉ាកុបបានដាស់តឿនប្រជាជនរបស់គាត់ឲ្យសម្រុះសម្រួលខ្លួនពួកគេទៅតាមបំណងនៃព្រះ ហើយចាំថាពួកគេអាចបានសង្ត្រោះតែតាមរយៈព្រះគុណរបស់ព្រះតែប៉ុណ្ណោះ ។

បង្រៀនដោយព្រះវិញ្ញាណ

ក្នុងនាមជាគ្រូបង្រៀនដំណឹងល្អម្នាក់ អ្នកត្រូវស្វែងរកការណែនាំពីព្រះវិញ្ញាណ បរិសុទ្ធពេលអ្នករៀបចំមេរៀន និង ពេលបង្រៀន ។ « ព្រះវិញ្ញាណត្រូវបានប្រទានដល់អ្នក ដោយពាក្យអធិស្ឋាននៃសេចក្តីជំនឿ ហើយបើសិនជាអ្នករាល់គ្នាមិនបានទទួលព្រះវិញ្ញាណទេ នោះអ្នករាល់គ្នានឹងមិនត្រូវបង្រៀនឡើយ » (គ. និង ស. ៤២:១៤) ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ៩:២៧–៥៤

យ៉ាកុបអញ្ជើញមនុស្សទាំងអស់ឲ្យមករកព្រះគ្រីស្ទ ហើយព្រមានអំពីឥរិយាបថ និង សកម្មភាពដែលបំបែកយើងពីព្រះអម្ចាស់

សូមសរសេរឃ្លាទាំងនេះនៅលើក្តារខៀន *ហេតុអ្វីបានជាខ្ញុំត្រូវការជំនួយ* និង *តើខ្ញុំត្រូវធ្វើអ្វី* ។សូមឲ្យសិស្សក្នុងថ្នាក់ស្រមៃពីមនុស្សម្នាក់ដែលមានជំងឺយ៉ាងធ្ងន់ធ្ងរមួយ ។

- ហេតុអ្វីបានជាវាសំខាន់ដល់មនុស្សនេះ ដើម្បីយល់ពីជំនួយដែលគេត្រូវរក ?
- ហេតុអ្វីបានជាវាសំខាន់ដល់មនុស្សនេះដែរ ដើម្បីយល់ពីអ្វីដែលគេត្រូវធ្វើដើម្បីទទួលបានជំនួយ ?
- តើអ្វីនឹងជាលទ្ធផល បើសិនជាមនុស្សនេះយល់ពីតម្រូវការដើម្បីរកជំនួយ ប៉ុន្តែមិនយល់ពីអ្វីដែលត្រូវធ្វើដើម្បីទទួលបានជំនួយនោះ ?

សូមរំពឹកសិស្សថា នៅក្នុងមេរៀនមុន ៗ ពួកគេបានសិក្សាពីឥទ្ធិពលនៃការធ្លាក់ និង លទ្ធផលនៃអំពើបាបរបស់យើង ដោយការរៀនពីមូលហេតុដែលយើងត្រូវការព្រះអង្គសង្ត្រោះ ។ សូមថ្លែងទីបន្ទាល់ថា ទ្រង់ចង់ជួយយើង ហើយរំដោះយើងចេញពីអំពើបាបរបស់យើង ។ សូមឲ្យសិស្សគិតថាតើ ពួកគេដឹងពីអ្វីដែលពួកគេត្រូវធ្វើដើម្បីទទួលបាននូវពរជ័យទាំងអស់នៃដង្វាយធ្ងនដែរទេ ។

សូមពន្យល់ថា យ៉ាកុបចង់ជួយប្រជាជនរបស់គាត់ឲ្យជ្រើសរើស « ផ្លូវទៅឯជីវិតដ៏នៅអស់កល្បជានិច្ច » (នីហ្វៃទី ២ ១០:២៣) ។ គាត់បានជួយពួកគេឲ្យយល់ថា ពួកគេនឹងទទួលបាននូវជីវិតដ៏អស់កល្បជានិច្ច បើសិនជាពួកគេនឹង « មករកព្រះអម្ចាស់ » (នីហ្វៃទី ២ ៩:៤១) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន នីហ្វៃទី ២ ៩:៤១ឲ ៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកការពិពណ៌នារបស់យ៉ាកុបអំពី « ផ្លូវ » ដែលយើងគួរដើរតាម ។

- តើវាមានន័យយ៉ាងណាដើម្បីមករកព្រះអម្ចាស់ ? (អ្នកអាចលើកទឹកចិត្តសិស្សឲ្យស្រមៃពីជីវិតរបស់ពួកគេជាផ្លូវមួយ ។ សូមឲ្យពួកគេសញ្ជឹងគិតដោយស្ងាត់ស្ងៀមពីកន្លែងដែលផ្លូវរបស់ពួកគេកំពុងទៅ ។ តើជម្រើសរបស់ពួកគេកំពុងនាំពួកគេឲ្យខិតទៅជិតព្រះអង្គសង្ត្រោះដែរឬទេ ?
- តើពាក្យអ្វី ដែលយ៉ាកុបបានប្រើដើម្បីពិពណ៌នាពី « ផ្លូវ » នោះ ? តើពាក្យ *ចង្អៀត* និង *សន្ទឹងត្រង់* បង្រៀនអ្វីអំពីរបៀបដែលយើងគួរតែរស់នៅ ?

សូមបង្ហាញថា ទាក់ទងនឹងផ្លូវចង្អៀត និង សន្ទឹងត្រង់នេះ យ៉ាកុបបានប្រើរូបភាពនៃទ្វារមួយ ។ គាត់សំដៅទៅលើព្រះអង្គសង្ត្រោះ ជាអ្នកឆ្មាំទ្វារនោះ ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា យើងអាចបានអភ័យទោសពីអំពើបាបរបស់យើង ហើយទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចតែតាមរយៈព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធ្ងនរបស់ទ្រង់ប៉ុណ្ណោះ ។ អ្វី ៗយើងធ្វើដែលនាំទៅរកជីវិតដ៏អស់កល្បជានិច្ច —រួមមានពិធីបរិសុទ្ធដែលយើងទទួល ការអធិស្ឋានដែលយើងធ្វើ ទីបន្ទាល់ដែលយើងចែកចាយ និង របៀបដែលយើងរស់នៅ— ត្រូវតែធ្វើឡើងនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។

- ហេតុអ្វីបានជាវាសំខាន់ដល់អ្នកថា ព្រះអង្គសង្ត្រោះ « មិនជួលបាវបម្រើនៅទីនោះឡើយ » ? (អ្នកអាចបង្ហាញថា ព្រះអម្ចាស់ហៅអ្នកបម្រើ ដូចជាបឹស្សព និង ប្រធានស្តេកនានា ធ្វើជាចៅក្រមនៃប្រជាជនដើម្បីឲ្យធ្វើសកម្មភាពជំនួសទ្រង់ ។ ទោះយ៉ាងណាក្តី ទ្រង់នឹងជាចៅក្រមចុងក្រោយរបស់យើង ហើយនឹងផ្តល់ការអនុម័តចុងក្រោយស្របតាមរបៀបដែលយើងរស់នៅ) ។
- តើការដឹងថា ព្រះអម្ចាស់ « មិនអាចបន្ថំបានឡើយ » អាចមានឥទ្ធិពលយ៉ាងណាដល់ការខិតខំរបស់យើងដើម្បីមករកទ្រង់ ?

សូមពន្យល់ថា តាមរយៈសំណល់នៃ នីហ្វៃទី ២ ៩ ការបង្រៀនរបស់យ៉ាកុបជួយយើងឲ្យយល់ពីរបៀបដែលឥរិយាបថ និង សកម្មភាពរបស់យើងជះឥទ្ធិពលដល់សមត្ថភាពយើងដើម្បីមករកព្រះអង្គសង្ត្រោះ ។ ឥរិយាបថ និង សកម្មភាពខ្លះ ជួយយើងឲ្យមករកព្រះគ្រីស្ទតែខ្លះទៀតរាវាំងយើងមិនឲ្យមករកទ្រង់ឡើយ ។

ដើម្បីជួយសិស្សឲ្យស្វែងរកឥរិយាបថ និង សកម្មភាពទាំងនេះខ្លះ សូមគូរបន្ទាត់ឈរមួយពុះក្តារខៀនជាពីរ ។ នៅផ្នែកម្ខាងនៃបន្ទាត់នោះ សូមសរសេរ *ការឃ្លាតឆ្ងាយខ្លួនយើងពីព្រះគ្រីស្ទ* ។ខាងក្រោមនោះ សូមសរសេរ ៖

១ . នីហ្វៃទី ២ ៩:២៧–៣៣

២ .នីហ្វៃទី ២ ៩:៣៤–៣៩

នៅផ្នែកម្ខាងទៀតនៃបន្ទាត់នោះ សូមសរសេរ *ការមករកព្រះគ្រីស្ទ* ។ខាងក្រោមនោះ សូមសរសេរ ៖

៣ .នីហ្វៃទី ២ ៩:២៣, ៣៩, ៤២, ៤៥–៤៦

៤ .នីហ្វៃទី ២ ៩:៤៩–៥២

សូមឲ្យលេខមួយដល់សិស្សម្នាក់ៗ ចន្លោះលេខពី ១ ដល់ ៤ ។ សូមអញ្ជើញសិស្សអានខគម្ពីរទាំងនោះដោយស្ងាត់ៗ ដែលទាក់ទងនឹងលេខការងារចាត់តាំងរបស់ពួកគេ ។ សូមឲ្យសិស្សដែលបានចាត់តាំងពីក្រុម ១ ដល់ ២ស្វែងរកឥរិយាបថ និង សកម្មភាពដែលអាចធ្វើឲ្យយើងឃ្លាតចេញពីព្រះអង្គសង្គ្រោះ ។ សូមឲ្យសិស្សដែលបានចាត់តាំងពីក្រុម ៣ ដល់ ៤ស្វែងរកឥរិយាបថ និង សកម្មភាពដែលជួយយើងឲ្យមករកព្រះអង្គសង្គ្រោះ ហើយទទួលបាននូវពរជ័យនៃដង្វាយធួនរបស់ទ្រង់ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំការរកឃើញរបស់ពួកគេនៅក្នុងព្រះគម្ពីររបស់គេ ។

កិច្ចការសរសេរនៅលើក្តារខៀន

នៅពេលសិស្សត្រូវបានចាត់តាំងឲ្យអានក្រុមខគម្ពីរ វាអាចជួយច្រើនបើអ្នកសរសេរសេចក្តីយោងទាំងឡាយនៅលើក្តារខៀន ។ វានឹងជួយសិស្សឲ្យចាំពីអ្វីដែលពួកគេបានសុំឲ្យធ្វើ និង ជួយការពារមិនឲ្យច្រឡំពីកិច្ចការ ។

បន្ទាប់ពីបីបួននាទីក្រោយមក សូមអញ្ជើញអ្នកស្ម័គ្រចិត្តពីក្រុមទី ១ និង ក្រុមទី ២ ឲ្យមកកាន់ក្តារខៀន ហើយសរសេរពីឥរិយាបថ និង សកម្មភាពដែលពួកគេបានរកឃើញថាបានធ្វើឲ្យយើងឃ្លាតពីព្រះអង្គសង្គ្រោះ ។ សូមពិភាក្សាពីការព្រមានខ្លះរបស់យ៉ាកុប ដោយសួរសំណួរខាងក្រោមខ្លះៗ ឬ សួរទាំងអស់ ៖

នីហ្វៃទី ២ ៩:២៨–២៩

នីហ្វៃទី ២ ៩:២៨–២៩ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមបើកទៅគំនិតនៅចុងមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណាននៃវគ្គរបស់ពួកគេ ។

- យ៉ាកុបបាននិយាយពីការសិក្សា និង ប្រាក់ ដែលទាំងពីរអាចជាការណ៍ល្អ ។ តើជម្រើសរបស់យើងអំពីការសិក្សា និង ប្រាក់អាចរារាំងយើងពីការមករកព្រះអម្ចាស់ដោយរបៀបណា ? (សូមបង្ហាញថា នីហ្វៃទី ២ ៩:២៨–២៩គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំវគ្គនេះ) ។
- តើអ្នកគិតថា វាមានន័យយ៉ាងណាដែលជាមនុស្សថ្លង់ ឬ ខ្វាក់ខាងវិញ្ញាណនោះ ? (សូមមើល នីហ្វៃទី ២ ៩:៣១–៣២) ។
- ឃ្លាថា « ចិត្តមិនកាត់ស្បែក » (នីហ្វៃទី ២ ៩:៣៣)សំដៅទៅលើអ្នកដែលមិនបានបើកចិត្តចំពោះព្រះ និង ជាអ្នកដែលមិនមានឆន្ទៈធ្វើតាមសេចក្តីសញ្ញារបស់ទ្រង់ ។ តើលក្ខខណ្ឌនេះរារាំងយើងមិនឲ្យទទួលបានពរជ័យពេញលេញនៃដង្វាយធួនដោយរបៀបណា ?
- តើទម្រង់នៃការថ្វាយបង្គំរបស់ណាកអ៊ីខ្លះ នៅសព្វថ្ងៃនេះ ? (សូមមើល នីហ្វៃទី ២ ៩:៣៧) ។

សូមអញ្ជើញសិស្សពីក្រុមទី ៣ និង ក្រុមទី ៤ ឡើងមកកាន់ក្តារខៀន ហើយសរសេរឥរិយាបថ និង សកម្មភាពដែលពួកគេរកឃើញដែលនឹងនាំយើងមកកាន់ព្រះអង្គសង្គ្រោះ ហើយជួយយើងឲ្យទទួលបានពរជ័យនៃដង្វាយធួន ។ ដើម្បីជួយសិស្សឲ្យវិភាគពីអ្វីដែលពួកគេបានរកឃើញ សូមសួរសំណួរខាងក្រោមខ្លះៗ ឬ សំណួរទាំងអស់ ៖

- នៅក្នុង នីហ្វៃទី ២ ៩:២៣ យ៉ាកុបបានរំឭកយើងអំពីការបញ្ជារបស់ព្រះអម្ចាស់ឲ្យប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ។ តើការរំឭកសេចក្តីសញ្ញាបុណ្យជ្រមុជទឹកតាមរយៈពិធីសាក្រាម៉ង់ ជួយយើងឲ្យមករកព្រះអម្ចាស់ និង ទទួលបានពរជ័យនៃដង្វាយធួនរបស់ទ្រង់ដោយរបៀបណា ?
- តើអ្នកគិតថា វាមានន័យដូចម្តេចចំពោះ « គំនិតដែលជាប់ទៅខាងវិញ្ញាណ » ? (នីហ្វៃទី ២ ៩:៣៩) ។ តើសកម្មភាពអ្វីខ្លះ ដែលអាចជួយយើងឲ្យមានគំនិតដែលជាប់ទៅខាងវិញ្ញាណ ?
- តើវាមានន័យយ៉ាងណាដែលថា « បែរចេញពីអំពើបាបទាំងឡាយរបស់អ្នករាល់គ្នាចុះ » ? (នីហ្វៃទី ២ ៩:៤៥) ។
- តើអ្នកគិតថា យ៉ាកុបមានន័យយ៉ាងណា នៅពេលគាត់និយាយថា រកទឹក បរិភោគ និង « បានត្រែកអរនៅក្នុងការធាត់ចុះ » ? (សូមមើល នីហ្វៃទី ២ ៩:៥០–៥១) ។ អ្នកអាចពន្យល់ថា ខគម្ពីរទាំងនេះយោងទៅលើការចិញ្ចឹមថៃទាំខាងវិញ្ញាណ) ។

សូមថ្លែងទីបន្ទាល់ថា **នៅពេល យើងមករកព្រះអម្ចាស់ ហើយរស់នៅតាមព្រះរាជបំណងរបស់ទ្រង់ យើងនឹងទទួលបាននូវពរជ័យដ៏ពេញលេញនៃដង្វាយធួន** ។សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន ពីខាងលើបញ្ជីដែលសិស្សបានធ្វើ ។

សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតពីភស្តុតាង ដែលពួកគេបានឃើញពីគោលការណ៍នេះនៅក្នុងជីវិតរបស់ពួកគេ ។ សូមអញ្ជើញពួកគេឲ្យសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពីរបៀបដែលពួកគេបានមកកាន់តែជិតព្រះអង្គសង្គ្រោះ តាមរយៈឥរិយាបថ និង សកម្មភាពមួយ ឬ ច្រើនជាងនេះនៅក្នុងបញ្ជីទីពីរលើក្តារខៀន ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរ (ប៉ុន្តែសូមជួយពួកគេឲ្យយល់ថា ពួកគេមិនគួរមានអារម្មណ៍ថាត្រូវចែកចាយបទពិសោធន៍ដែលផ្ទាល់ខ្លួន ឬ ឯកជនពេកនោះទេ) ។

នីហ្វៃទី ២ ១០

យ៉ាកុបបានលើកទឹកចិត្តដល់ប្រជាជនរបស់គាត់ឲ្យអរសប្បាយ ហើយមករកព្រះអម្ចាស់ ។

សូមសួរសិស្ស បើសិនជាពួកគេធ្លាប់បានទទួលអំណោយមួយដែលមានអត្ថន័យជាពិសេស ដោយសារនរណាម្នាក់បានឆ្លងកាត់ការខិតខំយ៉ាងខ្លាំង ឬ បានលះបង់អ្វីមួយដើម្បីផ្តល់អំណោយនោះ ។ សូមគិតពីការអញ្ជើញសិស្សម្នាក់ ឬ ពីរនាក់ឲ្យភ្ជាប់នឹងបទពិសោធន៍របស់ពួកគេ ។

- តើយើងអាចបង្ហាញពីការដឹងគុណសម្រាប់អំណោយបែបនោះដោយរបៀបណា ?
- តើយើងអាចបង្ហាញពីការដឹងគុណចំពោះអំណោយនៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះដោយរបៀបណា ?

សូមពន្យល់ថា បន្ទាប់ពីថ្ងៃដែលយ៉ាកុបបានធ្វើទេសនកថារបស់គាត់អំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទហើយ គាត់បានថ្លែងទីបន្ទាល់អំពីការរំដោះពីលទ្ធផលនៃអំពើបាបរបស់ព្រះអម្ចាស់ម្តងទៀត ។ គាត់បានបង្រៀនប្រជាជនរបស់គាត់អំពីរបៀបដែលពួកគេគួរឆ្លើយតបនឹងអំណោយនៃដង្វាយធួននេះ ។

សូមសង្ខេប នីហ្វៃទី ២ ១០:១–១៩ដោយពន្យល់ថា យ៉ាកុបបាននិយាយម្តងទៀតថា ទោះបីជាវង្សនៃអ៊ីស្រាអែលនឹងត្រូវខ្ចាត់ខ្ចាយដោយសារតែអំពើបាបក្តី ក៏ព្រះអម្ចាស់នឹងចងចាំសេចក្តីសញ្ញារបស់ទ្រង់ ជាមួយនឹងពួកគេ ហើយប្រមូលផ្តុំពួកគេ នៅពេលពួកគេប្រែចិត្ត ហើយត្រឡប់មកកាន់ទ្រង់វិញ ។ អ្នកអាចបង្ហាញថា នីហ្វៃទី ២ ១០:៣គឺជាខគម្ពីរដំបូងនៅក្នុងព្រះគម្ពីរមរមនដែលប្រើចំណងជើង *ព្រះគ្រីស្ទ* នៅក្នុងការសំដៅទៅព្រះអង្គសង្គ្រោះ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ១០:២០, ២៣–២៥ ឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្វែងរកអ្វីដែលយ៉ាកុបបានដាស់តឿនយើងឲ្យធ្វើ ដើម្បីឆ្លើយតបនឹងអំណោយនៃដង្វាយធួន ។ អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំអ្វីដែលពួកគេរកឃើញនៅក្នុងខគម្ពីរទាំងនេះ ។ សូមអញ្ជើញពួកគេឲ្យចែកចាយអ្វីដែលពួកគេរកឃើញ ។

សូមរៀបចំក្រដាសដែលមានសំណួរខាងក្រោមសម្រាប់ចែក (ឬ សរសេរសំណួរនេះនៅលើក្តារខៀន មុនពេលចាប់ផ្តើមថ្នាក់) ។ សូមអញ្ជើញសិស្សឲ្យជ្រើសយកសំណួរមួយ ហើយចែកចាយពីគំនិត និង អារម្មណ៍របស់ពួកគេអំពីសំណួរនោះជាមួយនឹងដៃគូរបស់គេ ។

- ក្រោយពីបានគិតអំពីអ្វីដែលយើងបានសិក្សាអំពីព្រះអង្គសង្គ្រោះ តើអ្នកចង់ចងចាំអ្វីអំពីទ្រង់ជារៀងរហូត ?
- ហេតុអ្វីបានជាការប្រែចិត្តជារបៀបមួយដ៏សំខាន់ដើម្បីបង្ហាញការដឹងគុណរបស់យើងចំពោះអ្វីដែលព្រះអម្ចាស់បានធ្វើសម្រាប់យើង ?
- តើអ្នកបានរៀនអ្វីខ្លះ អំពីព្រះអង្គសង្គ្រោះដែលជួយអ្នកឲ្យមានសេចក្តីសង្ឃឹម ?

សូមបញ្ចប់ដោយការពន្យល់ថា ពាក្យ *សម្រុះសម្រួល* នៅក្នុងនីហ្វៃទី ២ ១០:២៤ មានន័យថា ការនាំមនុស្ស ឬ អ្វីៗទាំងអស់មកស្រុះស្រួល ឬ ព្រមព្រៀងជាមួយនឹងគ្នាទៅវិញទៅមក ។ ជាឧទាហរណ៍ មិត្តភក្តិពីរនាក់គួរតែសម្រុះសម្រួលជាមួយនឹងគ្នាក្រោយពីការមិនព្រមព្រៀងគ្នាមួយ ។

- តើអ្នកគិតថា វាមានន័យដូចម្តេចដើម្បីសម្រុះសម្រួលខ្លួនយើងទៅតាមបំណងរបស់ព្រះ ?

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីអ្វីដែលពួកគេបានរៀន និង មានអារម្មណ៍ នៅពេលពួកគេបានសិក្សា និង បានពិភាក្សាក្នុង នីហ្វៃទី ២ ៩–១០ ។ សូមអញ្ជើញពួកគេឲ្យស្វែងរកការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីជួយពួកគេឲ្យសម្រេចអ្វីមួយដែលពួកគេនឹងធ្វើដើម្បីសម្រុះសម្រួលខ្លួនគេទៅតាមបំណងនៃព្រះ ហើយទទួលយកពរជ័យនៃដង្វាយធួនបន្ថែមឲ្យពេញលេញជាងនេះ ។ ជាឧទាហរណ៍ សិស្សម្នាក់អាចប្តេជ្ញាស្តាប់តាមពាក្យដំបូន្មានជាក់លាក់នៃព្រះ (សូមមើល នីហ្វៃទី ២ ៩:២៩) បែរចេញពីអំពើបាបជាពិសេសមួយ (សូមមើល នីហ្វៃទី ២ ៩:៤៥) ឬ រកផ្លូវមួយដើម្បីនឹកចាំដល់ព្រះអង្គសង្គ្រោះញឹកញាប់ជាងមុនពេញមួយថ្ងៃ (សូមមើល នីហ្វៃទី ២ ១០:២០) ។ សូមលើកទឹកចិត្តសិស្សឲ្យធ្វើអ្វីដែលចាំបាច់ដើម្បី « សម្រុះសម្រួល | ខ្លួន | គេទៅតាមបំណងនៃព្រះ: » (នីហ្វៃទី ២ ១០:២៤) ។ សូមថ្លែងទីបន្ទាល់អំពីពរជ័យនៃការធ្វើដូច្នោះ ។

ចំណេះចំណានខគម្ពីរ—នីហ្វៃទី ២ ៩:២៨–២៩

កំណាត់ចំណាំ ៖ សកម្មភាពខាងក្រោមគឺរៀបចំឡើង ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានរបស់ពួកគេនៃ នីហ្វៃទី ២ ៩:២៨–២៩ ។ ដោយសារតែរយៈពេលនៃមេរៀនថ្ងៃនេះ អ្នកអាចប្រើសកម្មភាពនេះនៅថ្ងៃផ្សេងទៀត នៅពេលដែលអ្នកមានពេលជាងនេះ ។

សូមដឹកនាំសិស្សក្នុងថ្នាក់ឲ្យអាន នីហ្វៃទី ២ ៩:២៨–២៩ ឮៗទាំងអស់គ្នា ។

- តើរណ្តៅណាខ្លះដែលអាចដាក់អន្ទាក់យើង នៅពេលយើងស្វែងរកការរៀនសូត្រ ? តើយើងអាចស្វែងរកការរៀនសូត្រ ប៉ុន្តែចៀសវាងពីអន្ទាក់ទាំងនេះដោយរបៀបណា ?
- តើអ្វីដែលអាចជួយយើងឲ្យ « ស្តាប់តាមពាក្យដំបូន្មាននៃព្រះ » ខណៈពេលដែលយើងស្វែងរកការរៀនសូត្រនោះ ?

សូមលើកទឹកចិត្តសិស្សឲ្យបន្តការចូលរួមនៅក្នុងថ្នាក់សិក្ខាសាលាឥឡូវនេះ ហើយដើម្បីគ្រោងចូលរួមថ្នាក់វិទ្យាស្ថាន បន្ទាប់ពីពួកគេបញ្ចប់ពីថ្នាក់សិក្ខាសាលា ។

មេរៀនសិក្សានៅផ្ទះ

នីហ្វៃទី ២ ៤–១០ (មេរៀនទី ៦)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនតាមផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបនៃគោលលទ្ធិ និង គោលការណ៍ខាងក្រោមដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា នីហ្វៃទី ២៤–១០ (មេរៀនទី ៦) មិនមែនមានបំណងបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតទៅលើគោលលទ្ធិ និង គោលការណ៍ទាំងនេះតែពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកពិចារណាពីតម្រូវការសិស្សរបស់អ្នក ។

ថ្ងៃទី ១ (នីហ្វៃទី ២ ៤–៥)

នៅពេលសិស្សសិក្សា នីហ្វៃទី ២ ៤ ពួកគេបានផ្តោតលើគោលការណ៍ដែលព្រះគាំទ្រដល់អស់អ្នកដែលបានដាក់ការទុកចិត្តរបស់ពួកគេលើទ្រង់ (សូមមើល នីហ្វៃទី ២ ៤:១២–៣៥) ហើយបានសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេអំពីរបៀបមួយដែលពួកគេនឹងបង្កើនការទុកចិត្តរបស់ពួកគេទៅលើព្រះ ។ នៅក្នុង នីហ្វៃទី ២ ៥ ពួកគេបានឃើញគំរូនៃសេចក្តីពិតខាងក្រោម ៖ សុវត្ថិភាពមានមកតាមរយៈការគោរពប្រតិបត្តិតាមវិរាណៈនៃព្រះ (សូមមើល នីហ្វៃទី ២ ៥:១–៨) ។ នៅពេលដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ក្លាយជាផ្លូវនៃជីវិតរបស់យើង យើងនឹងបង្កើនសុភមង្គលហើយ (សូមមើល នីហ្វៃទី ២ ៥:៩–១៨, ២៦–២៧) ។ សិស្សបានពិនិត្យមើលជីវិតរបស់ពួកគេ ហើយសម្រេចអ្វីមួយដែលពួកគេនឹងធ្វើដើម្បីរស់នៅឲ្យបានពេញលេញជាងនេះ « តាមរបៀបនៃសុភមង្គល » ។

ថ្ងៃទី ២ (នីហ្វៃទី ២ ៦–៨)

នៅក្នុងមេរៀននេះ សិស្សបានរៀនថា ព្រះអម្ចាស់មានមេត្តាករុណាដល់អស់អ្នកណាដែលត្រឡប់ទៅកាន់ទ្រង់វិញ (សូមមើល នីហ្វៃទី ២ ៦) ។ ពួកគេសញ្ជឹងគិតអំពីរបៀបដែលព្រះអម្ចាស់បានមានសេចក្តីមេត្តាករុណាចំពោះពួកគេ ។ ពួកគេក៏បានរៀនដែរថា ព្រះអង្គសង្គ្រោះចង់ប្រោសលោះប្រជាជនក្នុងសេចក្តីសញ្ញារបស់ទ្រង់ ហើយទ្រង់មានគ្រប់ទាំងព្រះចេស្តាដើម្បីធ្វើដូច្នោះ (សូមមើល នីហ្វៃទី ២ ៧–៨) ។

ថ្ងៃទី ៣ (នីហ្វៃទី ២ ៩)

នៅពេលសិស្សចាប់ផ្តើមការសិក្សារបស់គេលើ នីហ្វៃទី ២ ៩ ពួកគេបានរៀនពីអ្វីដែលនឹងកើតឡើង បើសិនជាគ្មានជង្វាយធួនទេនោះ ។ ពួកគេក៏បានសិក្សាពីសេចក្តីពិតខាងក្រោមនេះដែរ ៖ ជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទរំដោះមនុស្សជាតិទាំងអស់ចេញពីសេចក្តីស្លាប់ខាងរូបកាយ និង ខាងវិញ្ញាណដែលកើតមកដោយសារការធ្លាក់ (សូមមើល នីហ្វៃទី ២ ៩:១–២២) ។ តាមរយៈជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ យើងអាចយកឈ្នះលើលទ្ធផលនៃអំពើបាបរបស់យើង បើសិនជាយើងមានសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ប្រែចិត្ត ជ្រមុជទឹក ហើយតស៊ូដល់ទីបញ្ចប់ (សូមមើល នីហ្វៃទី ២ ៩:១៤–២៧) ។ សិស្សបានសរសេរកថាខណ្ឌមួយដែលបង្ហាញពីអារម្មណ៍របស់ពួកគេ អំពីការពេលិកម្មរបស់ព្រះអង្គសង្គ្រោះសម្រាប់ពួកគេ ។

ថ្ងៃទី ៤ (នីហ្វៃទី ២ ៩–១០)

នៅពេលសិស្សបានសិក្សាសំណល់នៃ នីហ្វៃទី ២ ៩ ហើយបានសិក្សាពី នីហ្វៃទី ២ ១០ ពួកគេបានសញ្ជឹងគិតថា តើជម្រើសមួយណារបស់ពួកគេអាចបំបែកពួកគេចេញពីព្រះអម្ចាស់ ហើយជម្រើសមួយណាដែលជួយពួកគេឲ្យមកកាន់តែជិតទ្រង់ ។ ពួកគេបានរៀនថា នៅពេលយើងជ្រើសរើសដើម្បីមកកព្រះអម្ចាស់ ហើយរស់នៅស្របតាមបំណងរបស់ទ្រង់ យើងនឹងទទួលបានពរជ័យដ៏ពេញលេញនៃជង្វាយធួន ។

សេចក្តីផ្តើម

ក្នុងចំណោមសេចក្តីពិតដ៏សំខាន់ជាច្រើនដែលសិស្សបានសិក្សាក្នុងសប្តាហ៍នេះ សូមបញ្ជាក់ពីសារៈសំខាន់នៃជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមអធិស្ឋានសម្រាប់ការណែនាំ ទាក់ទងនឹងរបៀបដែលអ្នកអាចជួយពួកគេឲ្យយល់ និង ទុកចិត្តលើជង្វាយធួនបានល្អបំផុត ។ នៅពេលអ្នកបង្រៀន សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតអំពីអ្វីដែលពួកគេត្រូវធ្វើ ដើម្បីទទួលបានពរជ័យទាំងឡាយនៃជង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ។

កំណត់ចំណាំ ៖ នៅពេលអ្នករៀបចំមេរៀនប្រកបដោយការអធិស្ឋាន សូមគិតពីតម្រូវការសិស្សរបស់អ្នក —ជាពិសេសតម្រូវការនៃអស់អ្នកទាំងឡាយណាដែលអាចកំពុងតែជួប ។ នៅពេលអ្នកអធិស្ឋានសម្រាប់សិស្សម្នាក់ៗ និង សម្រាប់ការណែនាំពីរបៀបបង្រៀនពួកគេអំពីគោលលទ្ធិ និងគោលការណ៍ដែលរកឃើញនៅក្នុងព្រះគម្ពីរឲ្យបានល្អបំផុតនោះ ព្រះវិញ្ញាណបរិសុទ្ធនឹងបំផុសគំនិតអ្នកឲ្យដឹងពីរបៀបដើម្បីបំពេញតម្រូវការរបស់សិស្សហើយ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ៤–៥

នីហ្វៃបង្ហាញការទុកចិត្តរបស់គាត់ទៅលើព្រះអម្ចាស់ ; ព្រះអម្ចាស់បំបែកសាសន៍នីហ្វៃចេញពីសាសន៍លេមិន ; សាសន៍នីហ្វៃរស់នៅតាមរបៀបនៃសុភមង្គល

សូមចម្លងព័ត៌មាននៅក្នុងតារាងខាងក្រោមដាក់លើក្តារខៀន ឬ សូមរៀបចំវាជាក្រដាសសម្រាប់ចែក ។

នីហ្វៃទី ២ ៤	នីហ្វៃទី ២ ៥
១ .សូមអានក្បាលដំពូក ហើយសូមរៀបចំសង្ខេបដំពូកនេះជាពាក្យសម្តីខ្លួនផ្ទាល់ ។ ២ .សូមអាន នីហ្វៃទី ២ ៤:១៩ ហើយសូមពន្យល់ពីអត្ថន័យដែលអ្នកគិតចំពោះពាក្យ ដើម្បី « ស្គាល់អ្នកដែលខ្ញុំទុកចិត្ត » ។ ៣ .សូមអានពីការចុះកំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នកសម្រាប់ថ្ងៃទី ១ កិច្ចការទី ៤ ហើយសូមរៀបចំចែកចាយរបៀបមួយដែលអ្នកនឹងបង្កើនការទុកចិត្តរបស់អ្នកទៅលើព្រះអម្ចាស់ ។	១ .សូមអានក្បាលដំពូក ហើយសូមរៀបចំសង្ខេបដំពូកនេះជាពាក្យសម្តីខ្លួនផ្ទាល់ ។ ២ .សូមអាន នីហ្វៃទី ២ ៥:២៧ ហើយសូមពន្យល់ពីអត្ថន័យដែលអ្នកគិតចំពោះពាក្យ ដើម្បីរស់នៅ « តាមរបៀបនៃសុភមង្គល » ។ ៣ .សូមអានពីការចុះកំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នកសម្រាប់ថ្ងៃទី ១ កិច្ចការទី ៦ ។ សូមរៀបចំចែកចាយសកម្មភាព ឬ គំរិយាបថមួយរបស់សាសន៍នីហ្វៃ និង ពីរបៀបដែលការធ្វើសកម្មភាពដដែល ឬ ការមានគំរិយាបថដូចគ្នាជះឥទ្ធិពលមកលើសុភមង្គលរបស់អ្នក ។

សូមបែងចែកសិស្សក្នុងថ្នាក់ជាពីរក្រុម ។ សូមឲ្យសិស្សពាក់កណ្តាលរៀបចំបង្រៀនអ្វីដែលនៅក្រោម នីហ្វៃទី ២ ៤ និង សិស្សផ្សេងទៀតរៀបចំបង្រៀនអ្វីដែលនៅក្រោមនីហ្វៃទី ២ ៥ ។

សូមចាត់គូសិស្សមួយដែលបានចាត់តាំងក្នុង នីហ្វៃទី ២ ៤ ជាមួយនឹងសិស្សម្នាក់ដែលបានចាត់តាំងក្នុង នីហ្វៃទី ២ ៥ ។ សូមអញ្ជើញសិស្សឲ្យចែកចាយជាមួយនឹងដៃគូរបស់ពួកគេអំពីអ្វីៗដែលពួកគេបានរៀបចំសម្រាប់កិច្ចការរបស់ពួកគេ ។

នីហ្វៃទី ២ ៦–៨

យ៉ាកុបបានព្យាករណ៍អំពីការខ្ចាត់ខ្ចាយ និង ការប្រមូលផ្តុំនៃអ៊ីស្រាអែល ហើយបានដកស្រង់ការព្យាករណ៍របស់អេសាយនៃភាពសច្ចៈរបស់ព្រះអង្គសង្គ្រោះចំពោះប្រជាជនក្នុងសេចក្តីសញ្ញា ។

សូមរំឭកសិស្សថា នីហ្វៃទី ២ ៦–៩ គឺជាថ្ងៃទីមួយនៃទេសនកថាមួយដែលយ៉ាកុបបានធ្វើដល់ប្រជាជនរបស់គាត់ ។ ថ្ងៃទីពីរនៃការបង្រៀនរបស់គាត់បានបន្តនៅក្នុង នីហ្វៃទី ២ ១០ ។ នៅក្នុង នីហ្វៃទី ២ ៦ យ៉ាកុបបានព្យាករណ៍ថា សាសន៍យូដានឹងបដិសេធព្រះអម្ចាស់ ហើយត្រូវបានខ្ចាត់ខ្ចាយ ។ សូមឲ្យសិស្សអាន នីហ្វៃទី ២ ៧:១–២ ហើយសូមអញ្ជើញពួកគេឲ្យនិយាយឡើងវិញនូវអ្វីដែលវាមានជាពាក្យសម្តីរបស់ពួកគេផ្ទាល់ ។

នីហ្វៃទី ២ ៩

យ៉ាកុបបង្រៀនពីរបៀបដែលជង្វាយធួនរបស់ព្រះអង្គសង្គ្រោះរំដោះយើងចេញពីឥទ្ធិពលនៃការធ្លាក់ និង លទ្ធផលនៃអំពើបាប

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះ ដែលថ្លែងដោយប្រធាន អែសរ៉ា ថាហ្វ ប៊ែនសឹន ៖

« ដូចជាមនុស្សម្នាក់ដែលមិនសូវឃ្លានអាហារ រហូតដល់គាត់ឃ្លាន ដូច្នេះគាត់នឹងមិនចង់បានសេចក្តីសង្គ្រោះរបស់ព្រះគ្រីស្ទទេ រហូតដល់គាត់ដឹងពីមូលហេតុដែលគាត់ត្រូវការព្រះគ្រីស្ទជាមុនសិន ។

« គ្មាននរណាម្នាក់ដឹងបានគ្រប់គ្រាន់ និង សមរម្យលួមពីមូលហេតុដែលគាត់ត្រូវការព្រះគ្រីស្ទនោះទេ រហូតដល់គាត់យល់ និង ទទួលយកគោលលទ្ធិនៃការធ្លាក់ និង ឥទ្ធិពលរបស់វាមកលើមនុស្សជាតិទាំងអស់ ។ ហើយគ្មានគម្ពីរណាផ្សេងទៀតនៅក្នុងពិភពលោកនេះ ដែលពន្យល់ពីគោលលទ្ធិដ៏សំខាន់នេះបានច្បាស់ល្អដូចជាព្រះគម្ពីរមេមននោះទេ » (« The Book of Mormon and the Doctrine and Covenants »*Ensign*ខែ ឧសភា ឆ្នាំ ១៩៨៧ ទំព័រ ៨៥) ។

សូមឲ្យសិស្សស្រមៃថា មានមិត្តម្នាក់បានសួរថា « ហេតុអ្វីបានជាយើងត្រូវការព្រះអង្គសង្គ្រោះ ? » សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរៀបចំឆ្លើយសំណួរនេះ ដោយផ្អែកលើអ្វីដែលពួកគេបានរៀននៅក្នុង នីហ្វៃទី ២ ៩ ។ សូមឲ្យពួកគេរំឭក នីហ្វៃទី ២ ៩:៧–១០, ១៩–២២ សម្រាប់ចម្លើយមួយ ។ សូមឲ្យសិស្សចែកចាយពីចម្លើយរបស់ពួកគេទៅនឹងសំណួរនេះ ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ពីរបៀបដែលព្រះយេស៊ូវគ្រីស្ទ អាចសង្គ្រោះយើងចេញពីលទ្ធផលនៃការធ្លាក់ សូមអានអ្វីដែលស្រដៀងគ្នាដោយប្រធាន យ៉ូសែប ហ្វីងឌីង ស្ម៊ីធ នៅក្នុងសម្ភារមេរៀនសម្រាប់ នីហ្វៃទី ២ ៩:១០–២៧ នៅក្នុងមេរៀនទី ៦ ៖ ថ្ងៃទី ៣ នៅក្នុងសៀវភៅសិក្សាសម្រាប់សិស្ស ។ អ្នកអាចគិតពីការអញ្ជើញសិស្សម្នាក់ឲ្យគូសនៅលើក្តារខៀន ឬ នៅលើក្រដាសមួយសន្លឹកអំពីអ្វីដែលប្រធានស្ម៊ីធ បានពិពណ៌នា ។ បើសិនជាអ្នកជ្រើសរើសឲ្យមានសិស្សម្នាក់គូសនៅលើក្តារខៀន ឬ នៅលើក្រដាសមួយសន្លឹក អ្នកអាចអញ្ជើញសិស្សនោះឲ្យពន្យល់ពីការគូសនោះផងដែរ ។

សូមអញ្ជើញសិស្សឲ្យគិតអំពីអារម្មណ៍ផ្ទាល់របស់ពួកគេអំពីការជាប់អន្ទាក់នៅក្នុងរណ្តៅដ៏ជ្រៅមួយ ហើយត្រូវបែកចេញពីព្រះដោយសារតែជម្រើសដែលពួកគេបានធ្វើនោះ ។ សូមពន្យល់ថា បើសិនជាវាមិនមែនដោយសារជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទនោះទេ វានឹងគ្មានឱកាសសម្រាប់ការប្រែចិត្ត នឹងគ្មានសេចក្តីសង្ឃឹម ហើយគ្មានមនុស្សណាម្នាក់អាចចៀសផុតពីលទ្ធផលនៃអំពើបាបទាំងនេះបានទេ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ៩:២១–២៣ ហើយសូមឲ្យសិស្សពីរបីនាក់ពន្យល់ពីខគម្ពីរនេះជាពាក្យសម្តីខ្លួនផ្ទាល់ ។ ទោះបីជាពួកគេអាចនិយាយវាខុសៗគ្នាក្តី ក៏សូមប្រាកដថាសេចក្តីពិតខាងក្រោមនេះគឺច្បាស់ ៖ **តាមរយៈជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ យើងអាចយកឈ្នះលើលទ្ធផលនៃអំពើបាបរបស់យើង ។**

សូមពន្យល់ថា ឱកាសដ៏អស្ចារ្យមួយមានជាមួយនឹងការប្រជុំជាក្រុមនេះ គឺជាពេលដែលអាចចែកចាយអារម្មណ៍ និង ទី បន្ទាល់ ។ សូមអញ្ជើញសិស្សឲ្យចែកចាយអារម្មណ៍ និង ទី បន្ទាល់របស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ទ និង ជង្វាយធួនរបស់ទ្រង់ ។ ប្រសិនបើពួកគេពិបាកចែកចាយ អ្នកអាចឲ្យពួកគេអានអ្វីដែលពួកគេបានសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេសម្រាប់ថ្ងៃទី ៣ កិច្ចការទី ៤ ។ អ្នកអាចបន្ថែមទីបន្ទាល់របស់អ្នកទៅលើទីបន្ទាល់របស់ពួកគេ ។

សូមឲ្យសិស្សក្នុងថ្នាក់ស្រមៃថា នរណាម្នាក់បានកើតរោគដ៏ធ្ងន់ធ្ងរមួយ ។ បន្ទាប់មក សូមពិភាក្សាសំនួរដូចខាងក្រោមនេះ ៖

- ហេតុអ្វីបានជាវាសំខាន់ដើម្បីឲ្យមនុស្សនេះយល់ពីតម្រូវការដើម្បីសុំជំនួយ ?
- ហេតុអ្វីបានជាវាសំខាន់ដើម្បីឲ្យមនុស្សនេះក៏យល់ពីអ្វីដែលត្រូវធ្វើដើម្បីទទួលបានជំនួយនោះផងដែរ ?
- តើអ្វីនឹងជាលទ្ធផល បើសិនជាមនុស្សនេះយល់ពីតម្រូវការដើម្បីរកជំនួយ ប៉ុន្តែមិនយល់ពីអ្វីដែលត្រូវធ្វើដើម្បីទទួលបានជំនួយនោះ ?

សូមសួរសិស្សថា តើពួកគេដឹងពីអ្វីដែលពួកគេត្រូវធ្វើដើម្បីទទួលបានពរជ័យទាំងឡាយនៃជង្វាយធួនដែរទេ ។ សូមរំឭកពួកគេថា ពួកគេបានសិក្សា នីហ្វៃទី ២ ៩:២៣, ៤២–៥២ ហើយបានស្គាល់សកម្មភាព និង គំរិយាបថជាច្រើនដែលជួយយើងឲ្យមករកព្រះគ្រីស្ទ ហើយអញ្ជើញព្រះចេស្តានៃការពលិកម្មដ៏ធួនរបស់ទ្រង់មកក្នុងជីវិតរបស់យើង ។ សូមឲ្យពួកគេរំឭកពីព្រះគម្ពីរដែលពួកគេបានគូសចំណាំ និង បញ្ជីដែលពួកគេបានសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេអំពីរឿងទាំងនោះ ដែលនាំយើងទៅរកព្រះអង្គសង្គ្រោះ (ថ្ងៃទី ៤ កិច្ចការទី ១) ។ សូមអញ្ជើញសិស្សឲ្យចែកចាយពីរបៀបដែលសកម្មភាព និង គំរិយាបថទាំងនេះមួយ ឬ ច្រើនបាននាំឲ្យពួកគេខិតកាន់តែជិតទៅរកព្រះអង្គសង្គ្រោះ ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា គោលការណ៍ខាងក្រោមដែលបង្រៀននៅក្នុងខគម្ពីរទាំងនេះ នឹងជួយយើងឲ្យទទួលបាននូវពរជ័យដ៏ពេញលេញនៃជង្វាយធួន ។

នីហ្វៃទី ២ ១០

យ៉ាកុបលើកទឹកចិត្តប្រជាជនរបស់គាត់ឲ្យអរើកពាយ ហើយមករកព្រះអម្ចាស់

សូមអាន នីហ្វៃទី ២ ១០:២៣–២៤ជាមួយនឹងសិស្ស ។ សូមរំឭកសិស្សថា នៅថ្ងៃទី ៣ កិច្ចការទី ៦ ពួកគេត្រូវបានអញ្ជើញឲ្យសម្រេចពីអ្វីមួយដែលពួកគេនឹងធ្វើដើម្បីសម្រុះសម្រួលខ្លួនគេទៅតាមបំណងនៃព្រះ ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមការអញ្ជើញនេះ ។

សូមឲ្យសិស្សចែកចាយទស្សនវិស័យបន្ថែមដែលពួកគេបានទទួលពីដំណឹកទាំងឡាយដែលពួកគេបានសិក្សានៅក្នុងសប្តាហ៍នេះ ។ បើមានពេលវេលា សូមបញ្ចប់មេរៀនក្នុងសប្តាហ៍នេះដោយការច្រៀង ឬ ការអានពាក្យក្នុងទំនុកតម្កើងជាមួយគ្នាក្នុងបទ « ខ្ញុំឆ្ងល់យ៉ាងអស្ចារ្យ » (*ទំនុកតម្កើង* ទំព័រ ២២) ឬ ទំនុកតម្កើងផ្សេងទៀតអំពីជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីសារៈសំខាន់នៃការមករកព្រះអង្គសង្គ្រោះ និង ភាពពិតនៃពរជ័យនៃជង្វាយធួន ។

មេរៀនបន្ទាប់ (នីហ្វៃទី ២ ១១–២៥)

នៅពេលសិស្សសិក្សាពី នីហ្វៃទី ២ ១១–២៥ នៅសប្តាហ៍បន្ទាប់នេះ ពួកគេនឹងស្គាល់ពាក្យពាក្យសម្តីខ្លះរបស់អេសាយ និង របៀបដែលគាត់បានឃើញជំនាន់របស់យើង ហើយបានព្រមានយើងដោយផ្អែកលើអ្វីដែលគាត់បានឃើញ ។ ការព្រមានរបស់គាត់ខ្លះ ទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ របៀបរស់នៅ និង គំរិយាបថរបស់យើង ។ សូមលើកទឹកចិត្តសិស្សឲ្យអាន ហើយប្រមូលយកអ្វីដែលពួកគេអាចពីក្នុង នីហ្វៃទី ២ ១១–២៥ ទោះបីជាពួកគេមិនយល់គ្រប់ពាក្យក្តី ។

មេរៀនទី ៣១

នីហ្វៃទី ២ ១១ និង ១៦

សេចក្តីផ្តើម

នៅក្នុង នីហ្វៃទី ២ ១១ នីហ្វៃបានបង្ហាញសេចក្តីស្រឡាញ់របស់គាត់ចំពោះពាក្យពាក្យសម្តីរបស់អេសាយ ។ គាត់ក៏បានថ្លែងទីបន្ទាល់ថា យ៉ាកុប និង អេសាយបានឃើញ « ព្រះដ៏ប្រោសលោះ ដូចជាខ្ញុំបានឃើញទ្រង់ដែរ » (នីហ្វៃទី ២ ១១:២) ។ នីហ្វៃទី ២ ១៦រួមមានដំណើររឿងរបស់អេសាយអំពីការសម្ភាតអំពើបាបរបស់គាត់ ហើយបានហៅថាជាព្យាការីម្នាក់ នៅពេលគាត់ « បានឃើញ . . . ព្រះអម្ចាស់ទ្រង់គង់លើបល្ល័ង្កនៅទីខ្ពស់ » (សូមមើល នីហ្វៃទី ២ ១៦:១, ៥–៨) ។ ទាំងនីហ្វៃ និង យ៉ាកុបបានបង្រៀនពីតម្លៃនៃការប្រៀបធៀបការសរសេររបស់អេសាយទៅនឹងខ្លួនយើង (សូមមើល នីហ្វៃទី ១ ១៩:២៣; នីហ្វៃទី ២ ៦:៥; ១១:២) ហើយព្រះអម្ចាស់បានប្រកាសថា « ពាក្យពេចន៍របស់អេសាយជាពាក្យដ៏មហិមា » (នីហ្វៃទី ៣ ២៣:១) ។ នីហ្វៃទី ២ ១១ រួមមានការពន្យល់របស់នីហ្វៃខ្លះៗសម្រាប់ការរាប់បញ្ចូលការព្យាករណ៍របស់អេសាយនៅក្នុងកំណត់ត្រារបស់គាត់ ហេតុដូច្នេះហើយ វាធ្វើជាសេចក្តីផ្តើមមួយចំពោះពាក្យពេចន៍របស់អេសាយនៅក្នុង នីហ្វៃទី ២ ១២–២៤ ។ នីហ្វៃទី ២ ២៥ធ្វើជាសេចក្តីបញ្ចប់មួយចំពោះជំពូកទាំងនេះ ដែលរួមមានពាក្យទូន្មានរបស់នីហ្វៃពីរបៀបដើម្បីយល់ពាក្យពេចន៍របស់អេសាយ (សូមមើល មេរៀនទី ៣៥ នៅក្នុងសៀវភៅសិក្សានេះ) ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ១១–២៥

នីហ្វៃបង្ហាញការត្រេកអររបស់គាត់នៅក្នុងការថ្លែងទីបន្ទាល់ថា សេចក្តីសង្គ្រោះមកតាមរយៈព្រះយេស៊ូវគ្រីស្ទ

សូមអញ្ជើញសិស្សបីនាក់ឲ្យសរសេរដោយស្ងាត់ស្ងៀមនូវប្រយោគមួយម្នាក់ អំពីអ្វីដែលបានកើតឡើងលើកចុងក្រោយបង្អស់ដែលសិស្សក្នុងថ្នាក់បានជួប ។ សូមកុំអនុញ្ញាតឲ្យពួកគេប្រៀបធៀប ឬ ពិភាក្សាពីអ្វីដែលពួកគេកំពុងសរសេរឡើយ ។ ដើម្បីបង្ហាញពីគុណសម្បត្តិនៃការមានសាក្សីលើសពីម្នាក់ សូមឲ្យសិស្សបីនាក់អានប្រយោគរបស់ពួកគេព្ធ ។ ក្រោយពីសិស្សទីមួយបានអានប្រយោគរបស់គេហើយ សូមសួរសិស្សក្នុងថ្នាក់ បើសិនវាជាការតំណាងពេញលេញមួយនៃអ្វីដែលបានកើតឡើងនៅក្នុងថ្នាក់របស់ពួកគេលើកមុន ។ បន្ទាប់មកសូមឲ្យសិស្សទីពីរចែកចាយប្រយោគរបស់គេ ហើយសួរថាតើវាជាការតំណាងដ៏ពេញលេញមួយនៃថ្នាក់របស់ពួកគេលើកមុនឬទេ ។ ក្រោយពីសិស្សទីបីអានហើយ សូមសួរសំណួរដដែល ។

- តើមានគុណសម្បត្តិអ្វីខ្លះ ពេលមានសាក្សីជាច្រើន ?

សូមពន្យល់ថា ព្រះអម្ចាស់បានហៅព្យាការីទាំងឡាយឲ្យធ្វើជាសាក្សីដល់ទ្រង់ដល់ពិភពលោក ។ សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតពីអត្ថន័យដែលវាមានចំពោះពួកគេ ពេលព្ធព្យាការីទាំងឡាយថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ។

សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***ដោយការសិក្សាពីទីបន្ទាល់របស់ព្យាការីអំពីព្រះយេស៊ូវគ្រីស្ទ យើងអាចពង្រឹងសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ ហើយអររីករាយនៅក្នុងទ្រង់ ។***

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ១១:២–៣ ។

- យោងតាមខគម្ពីរទាំងនេះ តើនីហ្វៃ អេសាយ និង យ៉ាកុបបានជួបបទពិសោធន៍អ្វីដែលអាចជួយពួកគេឲ្យក្លាយជាសាក្សីដ៏ពិសេសនៃព្រះយេស៊ូវគ្រីស្ទ ?
- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីមានសាក្សីម្នាក់នៃព្រះយេស៊ូវគ្រីស្ទមកពីព្យាការីជាច្រើននោះ ? (សូមមើលផងដែរ ម៉ូសាយ ១៣:៣៣–៣៥ ។)

សូមអញ្ជើញសិស្សឲ្យអានច្បាល ៗក្នុងជួរទីមួយនៃខគម្ពីរនីមួយ ៗក្នុង នីហ្វៃទី ២ ១១:៤–៦ ដោយស្វែងរកឃ្លាមួយដែលនីហ្វៃបាននិយាយសារឡើងវិញនៅក្នុងខគម្ពីរមួយ ៗនេះ ។

- តើពាក្យ « ត្រេកអរចំពោះ » អ្វីមួយ មានន័យយ៉ាងដូចម្តេច ? (អ្នកអាចពន្យល់ថា ពាក្យ *ត្រេកអរ* ស្នើពីអារម្មណ៍មួយដែលជ្រៅជាងការគ្រាន់តែចូលចិត្ត ឬ ការចាប់អារម្មណ៍លើអ្វីមួយ ។ វាបង្កប់ពីបទពិសោធន៍មួយនៃសេចក្តីអំណរ និង ការពេញចិត្ត) ។

សូមឲ្យសិស្សអាន នីហ្វៃទី ២ ១១:៤–៧ ដោយស្ងាត់ស្ងៀម ដោយស្វែងរកអ្វី ៗដែលធ្វើឲ្យនីហ្វៃត្រេកអរ ។ បន្ទាប់មកសូមបែងចែកសិស្សក្នុងថ្នាក់ជាដៃគូ ។ សូមឲ្យសិស្សចែកចាយពីឃ្លាដែលបំផុសគំនិតដល់ពួកគេខ្លាំងបំផុត និង ប្រាប់ពីមូលហេតុផង ។ សូមអញ្ជើញពួកគេឲ្យចែកចាយពីអ្វីដែលធ្វើឲ្យពួកគេត្រេកអរ ឬ ដឹកនាំពួកគេទៅកាន់ការអររីករាយអំពីព្រះយេស៊ូវគ្រីស្ទផងដែរ ។

សូមអាន នីហ្វៃទី ២ ១១:៨ ព្ធ ៗ ហើយសូមឲ្យសិស្សស្វែងរកពីមូលហេតុមួយដែលនីហ្វៃបានរួមបញ្ចូលការសរសេររបស់អេសាយនៅក្នុងកំណត់ត្រារបស់គាត់ ។

- តើនីហ្វៃបានសង្ឃឹមពីប្រជាជនរបស់គាត់ និង អ្នកអានព្រះគម្ពីរមរមនក្នុងពេលអនាគត ថានឹងជួបបទពិសោធន៍អ្វី នៅពេលពួកគេអានពាក្យពេចន៍របស់អេសាយ ?

បញ្ជីខាងក្រោមផ្តល់នូវគំរូខ្លះអំពីមូលហេតុដែលនីហ្វៃបានរួមបញ្ចូលការសរសេររបស់អេសាយនៅក្នុងកំណត់ត្រារបស់គាត់ ៖

១ .អេសាយបានឃើញព្រះអង្គសង្គ្រោះ ដូចជានីហ្វៃ និង យ៉ាកុបដែរ (សូមមើល នីហ្វៃទី ២ ១១:២–៣; សូមមើលផងដែរ នីហ្វៃទី ២ ១៦:១–៥ ដែលរួមបញ្ចូលនូវការពិពណ៍នារបស់អេសាយអំពីទស្សនៈនិមិត្តមួយដែលគាត់បានឃើញព្រះអង្គសង្គ្រោះ) ។

ការយល់ពីអេសាយ

គ្រូបង្រៀន និង សិស្សទាំងឡាយអាចពិបាកយល់ពីពាក្យពេចន៍របស់អេសាយនៅក្នុងព្រះគម្ពីរមរមន ។ ប្រធាន បិយដ៍ យេ. ផាកកឺ នៃក្លុ៉មនៃពួកសាវកដប់ពីរនាក់ បានទទួលស្គាល់ថា នៅពេលយើងសិក្សាព្រះគម្ពីរមរមន ជំពូកទាំងនេះអាចមើលទៅដូចជារបាំងមួយ ។ បន្ទាប់មកគាត់បានមានប្រសាសន៍ថា ៖ « ចូរកុំឈប់អានឡើយ ! » សូមបន្តទៅមុខឆ្លងកាត់ជំពូកដែលពិបាកយល់ទាំងនេះ . . . ទោះបីជាអ្នកយល់ពីវាបានតិចតួចក្តី ។ សូមបន្ត ប្រសិនបើអ្វីទាំងអស់ដែលអ្នកបានធ្វើគ្រាន់តែមើលត្រួសៗ ហើយរកមើលតែការបំផុសគំនិតត្រង់នេះបន្តិចត្រង់នោះបន្តិចនោះ » (« The Things of My Soul »*Ensign*ខែ ឧសភា ឆ្នាំ ១៩៨៦ ទំព័រ ៦១) ។

២ .នីហ្វៃបានត្រេកអរចំពោះការថ្លែងទីបន្ទាល់អំពីព្រះគ្រីស្ទ ហើយអេសាយក៏បានថ្លែងទីបន្ទាល់អំពីព្រះគ្រីស្ទដែរ (សូមមើល នីហ្វៃទី ២ ១១:៤, ៦; សូមមើលផងដែរ នីហ្វៃទី ២ ១៧:១៤និង ១៩:៦–៧ គំរូពីរនៃការព្យាករណ៍របស់អេសាយអំពីព្រះអង្គសង្គ្រោះ) ។

៣ .នីហ្វៃបានត្រេកអរចំពោះសេចក្តីសញ្ញានៃព្រះអម្ចាស់ (សូមមើល នីហ្វៃទី ២ ១១:៥) ។ ការព្យាករណ៍របស់អេសាយ បានទាក់ទងទៅនឹងសេចក្តីសញ្ញានៃព្រះអម្ចាស់ ។ ឧទាហរណ៍ គាត់បានព្យាករណ៍អំពីកិច្ចការព្រះវិហារបរិសុទ្ធនៅជំនាន់ចុងក្រោយ (សូមមើល នីហ្វៃទី ២ ១២:១–៣) ។

សូមពន្យល់ថា នៅក្នុងមេរៀននេះ និង មេរៀនបីបន្ទាប់ទៀត សិស្សនឹងសិក្សា ព្រមទាំងពិភាក្សាពីពាក្យពេចន៍របស់អេសាយនៅក្នុងនីហ្វៃទី ២ ១២–២៤ ។ សូមលើកទឹកចិត្តពួកគេឲ្យស្វែងរកសេចក្តីពិតនៅក្នុងជំពូកទាំងនេះ ដែលពង្រឹងទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះ ហើយជួយពួកគេឲ្យអរអរគុណក្នុងទ្រង់ ។ សូមអញ្ជើញសិស្សឲ្យចែកចាយខគម្ពីរដែលពួកគេចូលចិត្តខ្លះ ពីជំពូកទាំងនេះជាមួយនឹងសមាជិកគ្រួសារ និង មិត្តភក្តិរបស់ពួកគេ ។

នីហ្វៃទី ២ ១៦

អេសាយត្រូវបានហៅឲ្យបម្រើជាព្យាការីម្នាក់

សូមពន្យល់ថា សិស្សក្នុងថ្នាក់នឹងសិក្សានៅក្នុង នីហ្វៃទី ២ ១៦ បន្ទាប់ពីនេះ ដោយសារវាមាននូវដំណើរទស្សនៈនិមិត្តមួយរបស់អេសាយ ដែលគាត់បានទទួលការហៅបម្រើជាព្យាការី ។ ដើម្បីជួយសិស្សរៀបចំឲ្យយល់ពីទស្សនៈនិមិត្តនេះ សូមពន្យល់ថាការសរសេររបស់អេសាយរួមមានភាសាប្រៀបធៀប ។ ព្រះគម្ពីរគឺជាសម្ប៉ាទៅដោយនិមិត្តសញ្ញា ប្រភេទនានា និង សំនួនពាក្យប្រៀបធៀបជាច្រើន ។ សូមបង្ហាញថា ខគម្ពីរមួយដែលពួកគេបានអានពីមុនមក នីហ្វៃបាននិយាយថា « អស់ទាំងអ្វីដែលព្រះទ្រង់បានប្រទានដល់មនុស្សចាប់តាំងពីកំណើតលោកិយមក គឺជាគំរូអំពី [ព្រះយេស៊ូវគ្រីស្ទ] » (នីហ្វៃទី ២ ១១:៤) ។ ការប្រើនិមិត្តសញ្ញា និង ប្រភេទ គឺជារបៀបមួយដែលព្រះគម្ពីរបង្រៀនយើងអំពីបេសកកម្មសង្គ្រោះរបស់ព្រះអម្ចាស់ ។

សូមសរសេរពាក្យ និង ឃ្លាខាងក្រោមដាក់លើក្តារខៀន ៖ *រំភាយព្រះពស្ត្រ សេរភីម (ពួកទេវតា) ដែលម្នាក់ៗមានស្លាបប្រាំមួយ រំលែងរងើកភ្លើង ។*

សូមសួរសិស្សថា តើគំនិតអ្វីដែលមកក្នុងចិត្តរបស់ពួកគេ នៅពេលពួកគេឃើញ ឬ ឮពាក្យទាំងនេះ ។ ក្រោយពីការពិភាក្សាដ៏ខ្លីមួយ សូមពន្យល់ថាអេសាយបានប្រើពាក្យទាំងនេះនៅក្នុងដំណើរនៃការហៅបម្រើរបស់គាត់ឲ្យធ្វើជាព្យាការីនៃព្រះ ។ (សូមព្យាយាមជួយសិស្សឲ្យយល់ពីអត្ថន័យដែលអេសាយចង់ប្រាប់ ។ សូមប្រយ័ត្នក្រែងវិភាគហួសពីអត្ថន័យនៃភាសាប្រៀបធៀបនេះ ។ ផ្ទុយទៅវិញ សូមជួយសិស្សឲ្យឃើញពីរបៀបដែលសារលិខិតរបស់អេសាយអាចអនុវត្តនៅក្នុងជីវិតរបស់យើង) ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ១៦:១ ។ (ប្រសិនបើសិស្សមានកំណែរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៃព្រះគម្ពីរបរិសុទ្ធនៃកំណែថ្មីរបស់ស្តេច ជេម អ្នកអាចឲ្យពួកគេបើកទៅ អេសាយ ៦ ដែលមានលេខយោង និង ជំនួយក្នុងការសិក្សាដែលនឹងជួយបន្ថែមការយល់អំពីវគ្គព្រះគម្ពីរដែលត្រូបដណ្តប់នៅក្នុងមេរៀននេះ) ។

សូមពន្យល់ថា នៅក្នុងខគម្ពីរនេះពាក្យ *រំភាយព្រះពស្ត្រ* យោងទៅលើជាយសំពត់ ឬ សំពត់នៃអាវជាយមួយ ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ១៦:២–៣ឮៗ ។ សូមពន្យល់ថា « សេរភីម » គឺជាទេវតាដែលរស់នៅក្នុងវត្តមាននៃព្រះ (សូមមើល វចនានុក្រមព្រះគម្ពីរបរិសុទ្ធ « សេរភីម ») ។

- តើស្លាបទាំងប្រាំមួយនៃសេរភីមនោះអាចតំណាងឲ្យអ្វី ? (អ្នកអាចស្នើថា សិស្សគួរតែអាន គោលលទ្ធិ និង សេចក្តីសញ្ញា ៧៧:៤ សម្រាប់ជាតម្រុយ ។ រូបភាពនៃស្លាបនេះ គឺជានិមិត្តសញ្ញានៃអំណាចដើម្បីទៅមុខ និង ធ្វើសកម្មភាព) ។
- តើពាក្យអ្វីដែលបង្ហាញពីឥរិយាបថរបស់សេរភីមចំពោះព្រះអម្ចាស់ ?
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថាមានឥរិយាបថស្រដៀងគ្នានេះចំពោះព្រះ ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ១៦:៤ និង វិវរណៈ ១៥:៨ ឮ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកអត្ថន័យនៃឃ្លាថា « បានពេញទៅដោយផ្សែង » ។ (អ្នកគួរតែជួយសិស្សឲ្យយល់ថា ផ្សែងតំណាងឲ្យវត្តមាន ព្រះចេស្តា និង សិរីល្អនៃព្រះអម្ចាស់) ។ សូមពិចារណាអំពីការស្នើឲ្យសិស្សសរសេរ វិវរណៈ ១៥:៨ នៅរឹមទំព័រនៃព្រះគម្ពីររបស់ពួកគេក្បែរ នីហ្វៃទី ២ ១៦:៤ ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ១៦:៥ ឮ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកឃ្លាដែលបង្ហាញពីអារម្មណ៍របស់អេសាយនៅក្នុងវត្តមាននៃព្រះអម្ចាស់ ។ (ប្រសិនបើមានកំណែរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៃព្រះគម្ពីរបរិសុទ្ធនៃកំណែថ្មីរបស់ស្តេច ជេម សូមឲ្យសិស្សស្វែងរកអេសាយ ៦:៥ លេខយោង *ក* និង *ខ*)។

- តើអ្នកគិតថា អេសាយចង់មានន័យយ៉ាងណា នៅពេលលោកបាននិយាយថា « ខ្ញុំត្រូវវិនាសជាពិត ត្បិតខ្ញុំជាមនុស្សមានបបូរមាត់មិនស្អាត » ? (អ្នកគួរតែពន្យល់ថា នៅក្នុង អេសាយ ៦:៥ ពាក្យ *វិនាស* គឺត្រូវបានបកប្រែមកពីពាក្យភាសាហេព្រើរមួយដែលមានន័យថា « កាត់ចេញ » ហើយឃ្លា *បបូរមាត់មិនស្អាត*សំដៅទៅលើវិចារណញ្ញាណរបស់អេសាយ នៃអំពើបាបរបស់គាត់ និង អំពើបាបនៃប្រជាជនគាត់ ។ អេសាយបានបង្ហាញថា គាត់មានអារម្មណ៍មិនសំគ្តិសមដើម្បីនៅក្នុងវត្តមាននៃព្រះអម្ចាស់) ។

សូមផ្តល់ពេលដល់សិស្សឲ្យសញ្ជឹងគិតពីមូលហេតុដែលធ្វើឲ្យអេសាយអាចមានអារម្មណ៍បែបនេះ ។ សូមពន្យល់ថា ព្យាការីជាច្រើនបានបង្ហាញពីអារម្មណ៍មិនគ្រប់គ្រាន់ដែលពួកគេមាន នៅពេលពួកគេទទួលបានការហៅរបស់ខ្លួន ។ ប្រធាន ស្ពែនស៊ើរ ដបុលយូ. ឃីមបឺល បានពិពណ៌នាការហៅទូរស័ព្ទដែលប្រធាន ជេ. រ៉ូប៊ីន ក្លាក ជុញ្ញ័រ នៃគណៈប្រធានទីមួយបានប្រាប់គាត់ថា គាត់បានហៅទូរស័ព្ទទៅកូរ៉ុមនៃពួកដប់ពីរនាក់ ៖

« ឱ ! បងប្រុស ក្លាក ! មិនមែនខ្ញុំឬ ? អ្នកនិយាយថា មិនមែនខ្ញុំឬ ? វាប្រាកដជាមានបញ្ហាខ្លះហើយ ។ ខ្ញុំប្រាកដជាមិនអាចស្តាប់អ្នកបានច្បាស់ហើយ ។ នៅពេលនោះ ខ្ញុំក៏បានដួលពីកៅអីទៅលើឥដ្ឋ ។ . . .

« ឱ ! បងប្រុស ក្លាក ! វាមើលទៅហាក់ដូចជាមិនអាចទៅរួចទាល់តែសោះ ។ ខ្ញុំ ពិតជាខ្សោយ ហើយតូច ហើយមានកម្រិត និង មិនមានសមត្ថភាព ›» (អែឌវើដ អិល. ឃឹមបឹល និង អេនឌ្រូ អឹ ឃឹមបឹល ជុញ្ញ៉រ ;*ស្តែនសើរ ដបុលយូ ឃឹមបឹល ៖ ប្រធាននៃសាសនាចក្រនៃព្រះយេស្ទិវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយទីដប់ពីរ*[ឆ្នាំ ១៩៧៧] ទំព័រ ១៨៩) ។

សូមជួយសិស្សឲ្យយល់ថា អេសាយ ជាបុរសដ៏សុចរិតម្នាក់ មានអារម្មណ៍ថា « ត្រូវវិនាស » និង « មិនស្អាត » នៅក្នុងវត្តមាននៃព្រះអម្ចាស់ ។ តើនរណាខ្លះនៅក្នុងចំណោមយើង ដែលមិនមានអារម្មណ៍ថាមិនស័ក្តិសមពេលឈរនៅខាងមុខព្រះ ?

សូមចម្លងសេចក្តីពិតខាងក្រោមដាក់លើក្តារខៀន ៖ ***យើងអាចបានស្អាតពីភាពមិនស័ក្តិសមរបស់យើង តាមរយៈដង្វាយធួននៃព្រះយេស្ទិវគ្រីស្ទ ។***

បើសិនជាអាច សូមបង្ហាញសិស្សនូវធ្យូង ឬ ឈើឆេះហើយមួយដុំ ។ សូមសួរពួកគេថា តើវានឹងមើលទៅដូចជាអ្វី បើវាទើបតែបានយកចេញពីភ្លើងភ្លាមនោះ ។

- តើនឹងមានអ្វីកើតឡើងដល់នរណាម្នាក់ដែលបានប៉ះធ្យូងក្តៅនោះ ?

សូមអាន នីហ្វៃទី ២១៦:៦–៧ ព្ធ ។ សូមឲ្យសិស្សអានតាមដោយស្ងាត់ ។ ដោយស្វែងរកបទពិសោធន៍របស់អេសាយទាក់ទងនឹងរង៉ើកភ្លើងមួយ ។ (ប្រសិនបើមានកំណែរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៃព្រះគម្ពីរបរិសុទ្ធ កំណែថ្មីរបស់ស្តេច ជេម សូមឲ្យសិស្សស្វែងរកអេសាយ ៦:៦ លេខយោង *a*និង អេសាយ ៦:៧ លេខយោង *a* និង *b*) ។

- យោងតាម នីហ្វៃទី ២ ១៦:៧ តើវាមានន័យយ៉ាងណា នៅពេលដែលទេវតាបានប៉ះបបូរមាត់របស់អេសាយជាមួយនឹងធ្យូងក្តៅមួយក្នុងន័យប្រៀបធៀបនោះ ? (អ្នកគួរតែពន្យល់ថា រង៉ើកភ្លើងគឺជានិមិត្តសញ្ញានៃការសម្អាតមួយ ។ នៅពេលទេវតានៅក្នុងវិវរណៈរបស់អេសាយបានប៉ះបបូរមាត់របស់គាត់ដោយធ្យូងនោះ វាតំណាងថា ព្រះអម្ចាស់បានសម្អាតភាពមិនស័ក្តិសមរបស់អេសាយ និងបានអភ័យទោសដល់គាត់ចំពោះអំពើបាបរបស់គាត់) ។

សូមឲ្យពេលដល់សិស្សពីរបីនាទី ដើម្បីគិតអំពីពេលដែលពួកគេមានអារម្មណ៍អំពីអំណាចសម្អាតនៃដង្វាយរបស់ព្រះយេស្ទិវគ្រីស្ទ ។

សូមអញ្ជើញសិស្សឲ្យអាន នីហ្វៃទី ២ ១៦:៨–១៣ដោយស្ងាត់ស្ងៀម ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសង្ខេបពីអ្វីដែលព្រះអម្ចាស់បានមានព្រះបន្ទូលអំពីការបម្រើរបស់អេសាយក្នុងចំណោមប្រជាជន ។ (អ្នកគួរតែពន្យល់ថា ព្រះអម្ចាស់បានទូន្មានដល់អេសាយថា ការផ្សព្វផ្សាយរបស់គាត់ដល់សាសន៍អឺស្រាអែលដែលបះបោរនោះនឹងត្រូវបានគេបដិសេធយ៉ាងខ្លាំង ប៉ុន្តែក៏បានទូន្មានដែរថា គាត់ត្រូវបន្តផ្សព្វផ្សាយរហូតដល់ « ផ្ទះទាំងប៉ុន្មានផងឥតមានមនុស្ស ដរាបដល់ស្រុកនេះបានទៅជាទីស្ងាត់ឈឹងទាំងអស់ទៅ » ។ និយាយម៉ាងទៀតថា ព្រះអម្ចាស់នឹងបន្តបេសកកម្មនៃសេចក្តីសង្គ្រោះរបស់ទ្រង់យ៉ាងល្អ តាមរយៈអ្នកបម្រើរបស់ទ្រង់ « ដរាបណាពេលវេលានៅមាន ហើយតើនឹងមានផែនដីឬ ឬតើនឹងមានមនុស្សម្នាក់នៅលើផែនដីដែលនឹងបានសង្គ្រោះឬ » [មរ៉ូណៃ ៧:៣៦]) ។

សូមពន្យល់ថា អេសាយបានក្លាយជាសាក្សីដ៏មានអំណាចម្នាក់ចំពោះព្រះអម្ចាស់យេស្ទិវគ្រីស្ទ និង ដំណឹងល្អរបស់ទ្រង់ ។ សូមថ្លែងទីបន្ទាល់ថា ព្រះអង្គសង្គ្រោះគឺពិត ហើយអាចអភ័យទោសដល់យើងចំពោះអំពើបាបរបស់យើង ហើយថានៅពេលយើងជួបនឹងព្រះចេស្តានៃដង្វាយធួននៅក្នុងជីវិតរបស់យើង យើងក៏អាចក្លាយជាសាក្សីរបស់ព្រះអង្គសង្គ្រោះផងដែរ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ២ ១៦:២–៣ ។ តើទេវតាមានស្លាបដែរឬទេ ?

« ទេវតារបស់ព្រះ មិនមានស្លាបនោះទេ » (យ៉ូសែប ស្មឺធ នៅក្នុង *History of the Church,* ៣:៣៩២) ។ បន្ទាប់មក ហេតុអ្វីបានជាអេសាយពិពណ៍នាថាទេវតាមានស្លាបទៅវិញ ? អែលឌើរ ប្រូស អ័រ. ម៉ាក់ខន់ឃី បានពន្យល់ថា ការពិពណ៍នានេះគឺជាការប្រៀបធៀប ៖ « ការពិតដែលថា អង្គដ៏បរិសុទ្ធទាំងនេះត្រូវបានបង្ហាញដល់គាត់ ថាមានស្លាបគឺធ្វើជានិមិត្តសញ្ញាដ៏សាមញ្ញអំពី ‹ អំណាច ដើម្បីបន្តទៅមុខ ដើម្បីធ្វើសកម្មភាពរបស់ពួកគេ។ ល ។ › ថាជាករណីនៅក្នុងទស្សនៈនិមិត្តដែលអ្នកផ្សេងបានទទួលផងដែរ ។ (គ. និង ស. ៧៧:៤) ។ » (គោលលទ្ធិមរមន កំណែលើកទីពីរ [ឆ្នាំ ១៩៦៦] ទំព័រ ៧០៣) ។

នីហ្វៃទី ២ ១២–១៥

សេចក្តីផ្តើម

អេសាយបានដាក់ទោសភាពទុច្ចរិតនៃមនុស្សក្នុងជំនាន់របស់គាត់ ក៏ដូចជាភាពទុច្ចរិតនៃមនុស្សជាច្រើននៅក្នុងជំនាន់ចុងក្រោយ ។ គាត់បានព្រមានទាស់នឹងការហៅការអាក្រក់ថាល្អ ហើយការល្អថាអាក្រក់ ។ គាត់ក៏បានបញ្ជាក់ពីការស្តារឡើងវិញនៃដំណឹងល្អនៅក្នុងជំនាន់ចុងក្រោយ រួមមានទាំងសារៈសំខាន់នៃព្រះវិហារបរិសុទ្ធ និង សារៈសំខាន់នៃការស្អាតស្អំពីអំពើបាបនៃពិភពលោក ។ សម្រាប់ព័ត៌មានបន្ថែមអំពីអេសាយ សូមមើលមេរៀនទី ២១ នៅក្នុងសៀវភៅសិក្សានេះ ។

ការរក្សាការយកចិត្តទុកដាក់របស់សិស្ស

សំណើខាងក្រោមអាចជួយអ្នកឲ្យរក្សាការយកចិត្តទុកដាក់របស់សិស្សនៅក្នុងថ្នាក់ ៖ (១) ជួយសិស្សឲ្យឃើញពីរបៀបដែលមេរៀននេះ អាចអនុវត្តបាននៅក្នុងជីវិតរបស់ពួកគេ ។ (២) ផ្លាស់ប្តូរការបន្ទន់សំឡេងរបស់អ្នក នៅពេលអ្នកបង្រៀន ។ (៣) រក្សាក្រសែភ្នែកជាមួយនឹងសិស្ស ។ (៤) ប្រសិនបើអាច សូមដើរជុំវិញថ្នាក់រៀន នៅពេលអ្នកបង្រៀន ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ១២–១៥

អេសាយញែកពួកអ៊ីស្រាអែលដ៏ទុច្ចរិត ចេញពីពួកអ៊ីស្រាអែលដែលសុចរិតចេញពីគ្នា

ដើម្បីជួយសិស្សឲ្យយល់ពីបរិបទនៃមេរៀនថ្ងៃនេះ សូមចាប់ផ្តើមថ្នាក់ដោយការរំឭកពួកគេថា នៅក្នុងមេរៀនមុនៗ ពួកគេបានរៀនអំពីការហៅរបស់អេសាយឲ្យក្លាយជាព្យាការីម្នាក់ ។ ថ្ងៃនេះ ពួកគេនឹងរៀនអំពីមនុស្សដែលគាត់បានបង្រៀន ។

សូមជួយសិស្សឲ្យយល់ថា នៅពេលអេសាយពិពណ៌នាពីសកម្មភាពដែលប្រជាជនក្នុងសេចក្តីសញ្ញារបស់ព្រះអម្ចាស់នៅក្នុងជំនាន់របស់គាត់ គាត់ក៏បានពិពណ៌នាពីមនុស្សខ្លះនៅក្នុងជំនាន់របស់យើងផងដែរ ។ អែលឌើរ ដាល្លិន អេក. អូកស៍ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ថា ៖ « ព្រះគម្ពីរអេសាយមានការព្យាករណ៍ជាច្រើនដែលមើលទៅមានការបំពេញជាច្រើន ។ . . . ការពិតដែលថាការព្យាករណ៍ទាំងនេះជាច្រើនអាចមានអត្ថន័យជាច្រើន បានគូសបញ្ជាក់ពីសារៈសំខាន់នៃការស្វែងរកវិវរណៈរបស់យើងពីព្រះវិញ្ញាណបរិសុទ្ធដើម្បីជួយយើងឲ្យបកប្រែពីវិវរណៈទាំងនោះ» (« Scripture Reading and Revelation » *Ensign*ខែ មករា ឆ្នាំ ១៩៩៥ ទំព័រ ៨) ។

មុនចាប់ផ្តើមថ្នាក់ សូមថតចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ឬ រៀបចំវាជាក្រដាសសម្រាប់ចែកមួយ ។ សូមទុកចន្លោះល្មមសម្រាប់ឲ្យសិស្សសរសេរនៅក្នុងកូឡោននីមួយៗ ។

	នីហ្វៃទី ២ ១២:៥–១២, ១៧–១៩ ; ១៣:៨–៩	នីហ្វៃទី ២ ១៣:១៦–២៦
តើឥរិយាបថ និង ការអនុវត្តន៍អ្វីខ្លះ ដែលឆ្លុះបញ្ចាំងពីអំពើបាបរបស់មនុស្សទាំងនេះ ?		
តើនឹងមានអ្វីកើតឡើងដល់មនុស្សទាំងនេះ ដែលជាលទ្ធផលនៃអំពើបាបរបស់ពួកគេ ?		

សូមពន្យល់ថា តារាងនេះនឹងជួយសិស្សក្នុងថ្នាក់ឲ្យពិនិត្យមើលលទ្ធផលនៃសកម្មភាពរបស់មនុស្សដែលរស់នៅជុំយពីសេចក្តីសញ្ញារបស់ពួកគេ ។

សូមបែងចែកសិស្សក្នុងថ្នាក់ជាពីរក្រុម ។ សូមឲ្យសិស្សក្រុមទីមួយសិក្សាក្នុង នីហ្វៃទី ២ ១២:៥–១២, ១៧–១៩ ; ១៣:៨–៩ ។ សូមឲ្យសិស្សក្រុមមួយទៀតសិក្សាក្នុង នីហ្វៃទី ២ ១៣:១៦–២៦ ។ សូមអញ្ជើញសិស្សឲ្យអានខគម្ពីរដែលដាក់ឲ្យដល់ពួកគេ ហើយរកមើលចម្លើយចំពោះសំណួរទាំងពីរនៅក្នុងកូឡោនខាងឆ្វេងនៃតារាងនេះ ។ ប្រសិនបើដាក់តារាងនេះបង្ហាញលើក្តារខៀន សូមអញ្ជើញសិស្សម្នាក់មកពីក្រុមនីមួយៗឲ្យសរសេរចម្លើយរបស់ពួកគេនៅក្នុងកូឡោនដែលសមរម្យមួយ ។ ប្រសិនបើតារាងនេះត្រូវចែកជាក្រដាស សូមឲ្យសិស្សកត់ចម្លើយរបស់ពួកគេនៅលើក្រដាសរបស់ពួកគេនោះ ។

សូមពន្យល់ដល់ក្រុមទីពីរថា អេសាយបានព្យាករណ៍ពីលទ្ធផលចំពោះសំលៀកបំពាក់ឆើតឆាយ និង សកម្មភាពរបស់ស្ត្រីខាងលោកិយនៅក្នុងជំនាន់ផ្ទាល់របស់លោក និង ក្នុងពេលអនាគត ។ នីហ្វៃទី ២ ១៣:១៦–២៦ ពិពណ៌នាពីអ្វីដែលគាត់បានឃើញ ។ ទោះបីជាអេសាយបាននិយាយជាក់លាក់ថា « ពួកកូនស្រីនៃក្រុងស៊ីយ៉ូន » ពាក្យពេចន៍របស់គាត់ក៏អាចអនុវត្តបានចំពោះពួកបុរសដែរ ។ (អ្នកអាចចង់បង្ហាញថា ការព្យាករណ៍នៅក្នុង នីហ្វៃទី ២ ១៤:១ មិនមែនអំពីពហុភាពាហ៍ពិពាហ៍នោះទេ ។ វាគឺអំពីបុរសដែលបានស្លាប់នៅក្នុងសង្គ្រាមដែលបានពិពណ៌នានៅក្នុង នីហ្វៃទី ២ ១៣:២៥–២៦ ដែលបានទុកឲ្យស្ត្រីជាច្រើននៅជាស្ត្រីមេម៉ាយ ។

ក្រោយពីសិស្សមានពេលឆ្លើយសំណួរក្នុងតារាងនេះគ្រប់គ្រាន់ហើយ សូមសួរ ៖

- តើអំពើបាបណាខ្លះដែលមនុស្សទាំងនេះបានប្រព្រឹត្ត ? (ចម្លើយអាចរួមមាន ភាពឆ្មើងឆ្មៃ ការគោរពរូបសំណាក ភាពលោកិយ និង ភាពអសារឥតការ) ។ តើឃ្លាមួយណាដែលបង្ហាញថា មនុស្សទាំងនេះមានទោសដោយសារអំពើបាបទាំងនេះ ? តើអ្វីខ្លះជាលទ្ធផលនៃអំពើបាបទាំងនេះ ?
- អេសាយបាននិយាយពីស្រុកដែល « ពោរពេញដោយរូបព្រះ » (នីហ្វៃទី ២ ១២:៨) ។ តើមានទម្រង់នៃរូបសំណាកអ្វីខ្លះ នាពេលសព្វថ្ងៃនេះ ?

ដោយសារជាផ្នែកនៃការពិភាក្សានេះ សូមអានការទូន្មានខាងក្រោមមកពីប្រធាន ស្ពែនសើរ ដបុលយូ. ឃឹមបឹល ៖

« រូបសំណាកសម័យទំនើប ឬ រូបព្រះខុសឆ្គងអាចមានទម្រង់ដូចជា សំលៀកបំពាក់ ផ្ទះ ជំនួញ ម៉ាស៊ីន រថយន្ត ទូកកំសាន្ត និង សម្ភារៈបួតផ្សេងទៀតជាច្រើនមកពីផ្លូវទៅកាន់ភាពជាព្រះ ។ . . . យុវជនជាច្រើនបានសម្រេចចូលរៀនមហាវិទ្យាល័យ នៅពេលពួកគេគួរតែបម្រើបេសកកម្មមុននោះ ។ បរិញ្ញាបត្រ និង ទ្រព្យសម្បត្តិ និង សន្តិសុខ ដែលមកតាមរយៈបេសកកម្ម លេចឡើងយ៉ាងទាក់ទាញរហូតដល់បេសកកម្មធ្លាក់មកលំដាប់ទីពីរ ។ . . . មនុស្សជាច្រើនគោរពការបរបាញ់ ដំណើរកំសាន្តស្ងួចត្រី វិស្សមកាល ពេលវេលាពិចនិចចុងសប្តាហ៍ និង ការចេញទៅក្រៅ ។ អ្នកផ្សេងទៀតមានល្បែងកីឡា បាល់បោះ បាល់ទាត់ ល្បែងប្រកួតលនឹងសត្វគោ ឬ ការលេងកូនហ្គោលជារូបព្រះរបស់ពួកគេ ។ . . . នៅតែមានរូបភាពផ្សេងទៀត ដែលមនុស្សគោរពគឺអំណាច និង កិត្យានុភាព »
(*The Miracle of Forgiveness* | ឆ្នាំ ១៩៦៩ | ទំព័រ ៤០–៤១) ។

- អេសាយបានព្យាករណ៍អំពីប្រជាជនដែលនឹងបង្ហាញការឆ្មើងឆ្មៃ និង ភាពខាងលោកិយរបស់ពួកគេ តាមរបៀបដែលពួកគេស្លៀកពាក់ ។ តើយើងអាចចាំយាមទាស់នឹងឥរិយាបថ និង ការនិយមរបស់លោកិយដោយរបៀបណា ?

សូមសរសេរពាក្យ *វេទនា ដាក់លើក្តារខៀន* ។សូមពន្យល់ថាពាក្យ *វេទនា*សំដៅទៅលើទុក្ខសោក និង ការរងទុក្ខ ។ ពេលខ្លះ ព្យាការីពីបុរាណជាច្រើន បានប្រើពាក្យនេះដើម្បីបញ្ជាក់ពីលទ្ធផលនៃអំពើបាប ។ (សិស្សអាចចងចាំពីការឃើញពាក្យនេះមានច្រើនដែលនៅក្នុងនីហ្វៃទី ២ ៩:២៧–៣៨ ។) សូមអញ្ជើញសិស្សឲ្យស្តាប់ ពេលអ្នកអាន នីហ្វៃទី ២ ១៥:១៨–២៣ឮ ។ (អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំពាក្យ *វេទនា* និង ឃ្លាដែលពិពណ៌នាសកម្មភាព និង ឥរិយាបថដែលនឹងនាំមកនូវទុក្ខសោក និង ការរងទុក្ខ ។ អ្នកក៏អាចស្នើថា ពួកគេគួរតែសរសេរនិយមន័យនៃពាក្យ *វេទនា* នៅក្បែរទំព័រក្បែរខគម្ពីរទាំងនេះ) ។

- តើ នីហ្វៃទី ២ ១៥:២០ មានអត្ថន័យចំពោះអ្នកយ៉ាងដូចម្តេចដែរ ?
- តើអ្នកបានឃើញមនុស្សដែលហៅ « ការអាក្រក់ថាល្អ ហើយការល្អថាអាក្រក់ » នៅក្នុងជំនាន់របស់យើងដោយរបៀបណា ?

សូមប្រាប់សិស្សថា ឥឡូវនេះ ពួកគេនឹងអានអំពីមនុស្សមួយក្រុមដែលបានរក្សាសេចក្តីសញ្ញារបស់ពួកគេ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន នីហ្វៃទី ២ ១៤:២–៤ ឮ ។ សូមឲ្យសិស្សទាំងអស់ក្នុងថ្នាក់ស្វែងរកការពិពណ៌នារបស់អេសាយអំពីក្រុមមនុស្សនេះ ។

- តើពាក្យ ឬ ឃ្លាណាដែលបង្ហាញថា ក្រុមនេះខុសពីក្រុមផ្សេងទៀត ដែលយើងបានពិនិត្យមកនោះ ? (សូមគិតពីការសរសេរចម្លើយរបស់សិស្សដាក់លើក្តារខៀន) ។

សូមឲ្យសិស្សអាន នីហ្វៃទី ២ ១៤:៥–៦ដោយស្ងាត់ស្ងៀម ដោយស្វែងរកកន្លែងបីដែលអេសាយបានលើកឡើងដែលនឹងផ្តល់ការការពារខាងវិញ្ញាណ ។ សូមប្រាកដថា សិស្សស្គាល់ និង យល់ពីពាក្យ *ទី លំនៅ* (ផ្ទះ ឬ គេហដ្ឋាន) *ទី ប្រជុំ* (កន្លែងប្រជុំ ដូចជាសាខា វួដ ឬ ស្តេក) និង *រោងបារាំ* (ព្រះវិហារបរិសុទ្ធ) ។ សូមពន្យល់ថា « ពពក និង ផ្សែងនៅវេលាថ្ងៃ ហើយភ្លើងដ៏ឆេះបំភ្លឺនៅវេលាយប់ » សំដៅទៅលើការការពារ និង ការណែនាំដែលម៉ូសេ និង ប្រជាជនរបស់គាត់បានទទួលពីព្រះអម្ចាស់នៅក្នុងទីរហោស្ថាន (សូមមើលនិក្ខមនំ ១៣:២១–២២) ។ ពាក្យទាំងនេះរំឭកយើងពីការការពារ និង ការណែនាំដែលយើងអាចទទួលបានពីព្រះអម្ចាស់ ។ សូមបង្ហាញផងដែរថា អេសាយបានប្រៀបធៀបព្រះវិហារបរិសុទ្ធទៅនឹងជម្រកការពារមួយពីកំដៅ និង ជា « ទី បាំងខ្លួន » ឬ ជម្រកពីព្យុះ និង ភ្លៀង ។

- តើនៅពេលណាដែលអ្នកមានអារម្មណ៍ពីការការពារ ឬ ការណែនាំរបស់ព្រះអម្ចាស់នៅក្នុងផ្ទះ ឬ សាសនាចក្ររបស់អ្នក ?
- តើនៅពេលណាដែលអ្នកបានឃើញការសម្រាក ឬ ការការពារខាងវិញ្ញាណនៅក្នុងព្រះវិហារបរិសុទ្ធ ?
- តើមនុស្សប្រភេទណាដែលនឹងរស់នៅក្នុងផ្ទះ ហើយថ្វាយបង្គំនៅក្នុងព្រះវិហារ និង ព្រះវិហារបរិសុទ្ធដែលបានពិពណ៌នានៅក្នុងខគម្ពីរទី ៥–៦ ?
- តើយើងអាចធ្វើអ្វីបានខ្លះ ដើម្បីធ្វើឲ្យផ្ទះ និង សាខា ឬ វួដរបស់យើងជាកន្លែងការពារប្រឆាំងនឹងពិភពលោក ?

សូមសង្ខេបជំពូកទី ១២–១៥ ដោយការពន្យល់ថា នៅក្នុងជំពូកទាំងនេះ យើងនឹងរៀនថា **ការរក្សាសេចក្តីសញ្ញារបស់យើងនាំមកពរជ័យនៃការការពារខាងវិញ្ញាណ ខណៈពេលដែលការធ្វើខុសនឹងសេចក្តីសញ្ញាទុកយើងឲ្យនៅដោយគ្មានការការពារពីព្រះអម្ចាស់ ។** សូមធានាសិស្សថា ពួកគេអាចបង្កើតនៅក្នុងជីវិតផ្ទាល់របស់ពួកគេនូវបរិស្ថានមួយដូចដែលបានពិពណ៌នានៅក្នុងនីហ្វៃទី ២ ១៤:៥–៦ ។

នីហ្វៃទី ២ ១២:១–៥ ; ១៥:២៦

អេសាយព្យាករណ៍អំពីព្រះវិហារបរិសុទ្ធ និង សាសនាចក្ររបស់ព្រះអម្ចាស់ ដែលនឹងស្ថាបនាឡើងនៅក្នុងថ្ងៃចុងក្រោយ

សូមគូសឌីយ៉ាក្រាមខាងក្រោមនៃរូបភ្នំមួយ និង ព្រះវិហារបរិសុទ្ធមួយនៅលើក្តារខៀន ៖

- តើអ្វីជាភាពស្រដៀងគ្នាខ្លះៗរវាងភ្នំមួយ និង ព្រះវិហារបរិសុទ្ធមួយ ? (ចម្លើយខ្លះអាចរួមមាន ទាំងពីរគឺមានត្រកូលខ្ពស់ និង មានអំណាច ហើយទាំងពីរនោះបំផុសគំនិតយើងឲ្យមើលទៅស្ថានសួគ៌ខាងលើ) ។



សូមអញ្ជើញសិស្សឲ្យអាន នីហ្វៃទី ២ ១២:២–៥ដោយស្ងាត់ស្ងៀម ដោយស្វែងរកអ្វីដែលព្រះបានសន្យាថានឹងស្ថាបនានៅក្នុងជំនាន់ចុងក្រោយ និង ពីរបៀបដែលវានឹងប្រទានពរដល់ជីវិតរបស់មនុស្ស ។

- តើ៣ក្យ « ភ្នំនៃព្រះអម្ចាស់ » យោងទៅលើអ្វី ? (វាមានសេចក្តីយោងជាក់លាក់ទៅព្រះវិហារបរិសុទ្ធ សលត៍ លេក ប៉ុន្តែវាក៏អាចយោងទៅលើព្រះវិហារបរិសុទ្ធដែលព្រះអម្ចាស់បានស្ថាបនានៅក្នុងជំនាន់ចុងក្រោយ) ។
- តើពរជ័យអ្វីខ្លះចេញមកពី « ដំណាក់នៃព្រះអម្ចាស់ » នៅក្នុងជំនាន់ចុងក្រោយនោះ ? (គោលការណ៍មួយដែលសិស្សអាចរកឃើញនោះគឺថា **ព្រះបានស្ថាបនាព្រះវិហារបរិសុទ្ធដើម្បីបង្រៀនយើងអំពីផ្លូវរបស់ទ្រង់ និង ដើម្បីជួយយើងឲ្យដើរនៅក្នុងផ្លូវរបស់ទ្រង់** | សូមមើល នីហ្វៃទី ២ ១២:៣ |) ។
- តើព្រះវិហារបរិសុទ្ធជួយយើងឲ្យដើរតាមផ្លូវរបស់ព្រះអម្ចាស់ដោយរបៀបណា ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដែលប្រធាន ហ្គរដុន ប៊ី. ហ៊ិងគ្លី បានថ្លែងអំពីសារៈសំខាន់នៃព្រះវិហារបរិសុទ្ធ ៖

« អគារដ៏ឯក និង អស្ចារ្យទាំងនេះ ព្រមទាំងពិធីបរិសុទ្ធដែលបម្រើនៅខាងក្នុងនោះ តំណាងឲ្យចុងបំផុតនៃការគោរពរបស់យើង ។ ពិធីបរិសុទ្ធទាំងនេះ ក្លាយជាការបង្ហាញសាសនារបស់យើងដ៏ជ្រាលជ្រៅបំផុត ។ ខ្ញុំសូមជម្រុញប្រជាជនរបស់យើងគ្រប់ទីកន្លែង ដោយមានការបញ្ចុះបញ្ចូលទាំងអស់ដែលខ្ញុំអាចមាន ដើម្បីឲ្យរស់នៅដោយស័ក្តិសមដើម្បីកាន់បំណ្ណចូលព្រះវិហារបរិសុទ្ធមួយ ដើម្បីពង្រឹងមនុស្សម្នាក់ ហើយចាត់ទុកវាថាជាវត្ថុដ៏មានតម្លៃបំផុតមួយ និង ដើម្បីខិតខំប្រឹងបន្ថែមទៀតដើម្បីទៅដំណាក់របស់ព្រះអម្ចាស់ និង ទទួលទានព្រះវិញ្ញាណ និង ពរជ័យដែលមាននៅក្នុងទីនោះ » (Of Missions, Temples, and Stewardship »*Ensign*ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ៥៣) ។

- តើព្រះវិហារបរិសុទ្ធអាចជួយយើងឲ្យចៀសវាងពីលទ្ធផលនៃភាពទុច្ចរិតដែលបានពិពណ៌នានៅក្នុង នីហ្វៃទី ២ ១២–១៥ ដោយរបៀបណា ? (ចម្លើយអាចរួមមានដូចខាងក្រោម ៖ ការធ្វើ និង ការរក្សាសេចក្តីសញ្ញានៃព្រះវិហារបរិសុទ្ធពង្រឹងយើង និង ជ្រួសារបស់យើងប្រឆាំងនឹងភាពទុច្ចរិត ។ ការថ្វាយបង្គំព្រះវិហារបរិសុទ្ធជាទៀងទាត់ រំឭកយើងពីព្រះអង្គសង្គ្រោះ ការពលិកម្មដ៏ឆ្ងន់របស់ទ្រង់ និង សេចក្តីសញ្ញាដែលយើងបានធ្វើ ។ នៅពេលយើងរស់នៅដោយស័ក្តិសមដើម្បីកាន់បំណ្ណចូលព្រះវិហារបរិសុទ្ធ យើងមានសេចក្តីសង្ឃឹមសម្រាប់ពរជ័យនៃជីវិតដ៏នៅអស់កល្បជានិច្ច ។ សេចក្តីសង្ឃឹមនោះជម្រុញយើងឲ្យបន្តរស់នៅដោយសុចរិត) ។
- តើព្រះវិហារបរិសុទ្ធបានបំផុសគំនិត និង ប្រទានពរដល់អ្នកដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ១៥:២៦ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលឃ្លាដែលបង្ហាញពីអ្វីដែលព្រះអម្ចាស់នឹង « លើក » ដើម្បីប្រមូលប្រជាជននៅជំនាន់ចុងក្រោយនោះ ។ សូមពន្យល់ថាពាក្យ *ទង់ជ័យ*យោងទៅលើបទដ្ឋានមួយ ទង់មួយ ឬ បដាមួយដែលបានប្រើជាចំនុចប្រមូល ឬ ជាសញ្ញាមួយដើម្បីបង្រួបបង្រួម ជាពិសេសនៅក្នុងសង្គ្រាម ។

- តើអ្វីជា « ទង់ជ័យសម្រាប់ពូកសាសន៍ » ដែលអេសាយបានព្យាករណ៍ដល់នោះ ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ៖

« ទង់ជ័យនោះ | គឺជា | សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពូកបរិសុទ្ធថ្ងៃចុងក្រោយ ដែលត្រូវបានស្ថាបនាសម្រាប់សម័យចុងក្រោយដែលវានឹងមិនត្រូវបានបំផ្លាញម្តងទៀត ឬ ផ្តល់ទៅដល់មនុស្សផ្សេងទៀតឡើយ ។ វាគឺជាព្រឹត្តិការណ៍ដ៏អស្ចារ្យ ដែលពិភពលោកបានឃើញ តាំងពីថ្ងៃដែលព្រះប្រោសលោះបានលើកឈើឆ្កាងឡើង ហើយបានធ្វើដង្វាយធួនដ៏និរន្តរ៍ និង ដ៏អស់កល្បជានិច្ច ។ វាមានន័យចំពោះមនុស្សជាតិច្រើនជាងអ្វីៗផ្សេងទៀត ដែលបានកើតឡើងតាំងពីថ្ងៃនោះមក » (*គោលលទ្ធិនៃសេចក្តីសង្គ្រោះ* វ៉ុលទី ៣ ។ | ១៩៥៤–៥៦ |៣:២៥៤–៥៥) ។

- តើសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពូកបរិសុទ្ធថ្ងៃចុងក្រោយជា « ទង់ជ័យសម្រាប់ពូកសាសន៍ » ដោយរបៀបណា ?
- តើពរជ័យអ្វីខ្លះដែលបានមកក្នុងជីវិតរបស់អ្នក ដោយសារតែសមាជិកភាពរបស់អ្នកនៅក្នុងសាសនាចក្រ ?
- សូមគិតអំពីពរជ័យទាំងអស់ដែលអ្នកបានទទួល និង សេចក្តីពិតទាំងឡាយដែលអ្នកបានរៀនក្នុងនាមជាសមាជិកនៃសាសនាចក្រម្នាក់ ។ តើអ្វីទៅជាសេចក្តីពិតមួយដែលអ្នកអាចចែកចាយជាមួយនឹងអ្នកដទៃ ដែលអាចជួយពូកគេឲ្យប្រមូលផ្តុំទៅកាន់ « ទង់ជ័យសម្រាប់ពូកសាសន៍ » ?

សូមថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់បានប្រទានពរដល់យើង ដោយផ្តល់ជំនួយដ៏អស្ចារ្យដើម្បីឲ្យរស់នៅក្នុងជំនាន់ចុងក្រោយដោយជោគជ័យ ។ ទ្រង់នឹងប្រទានពរ និង ញែកអស់អ្នកទាំងឡាយដែលជ្រើសរើសដើម្បីមករកទ្រង់ ។ នៅពេលយើងធ្វើ និង ផ្តល់កិត្តិយសដល់សេចក្តីសញ្ញាជាមួយនឹងទ្រង់ ទ្រង់នឹងជួយយើងឲ្យដើរតាមផ្លូវរបស់ទ្រង់ ។

នីហ្វៃទី ២ ១៧–២០

សេចក្តីផ្តើម

នៅក្នុង នីហ្វៃទី ២១៧–២០ នីហ្វៃបានកត់ត្រាពីដំណើររឿងមួយរបស់អេសាយ ក្នុងការព្យាយាមបញ្ចុះបញ្ចូលស្តេចយូដា និង ប្រជាជនរបស់គាត់ឲ្យទុកចិត្តលើព្រះអម្ចាស់ជាជាងការចុះសម្រុងនឹងលោកិយ ។ ដោយប្រើនិមិត្តរូប និង ស្រមោល អេសាយបានព្យាករណ៍ទាក់ទងនឹងព្រឹត្តិការណ៍នៃជំនាន់ផ្ទាល់របស់គាត់ ការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ និង ការបំផ្លាញនៃពួកទុច្ចរិតពេលការយោងមកជាលើកទី ពីរនៃព្រះអម្ចាស់ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ១៧–១៨ ; ១៩:១–៧

ប្រជាជននៃនគរយូដា មិនបានដាក់ការទុកចិត្តទៅលើព្រះយេស៊ូវគ្រីស្ទនោះទេ

សូមចាប់ផ្តើមថ្នាក់ដោយការសុំសិស្សឲ្យរៀបរាប់ចំណងជើងពិពណ៌នាពីព្រះយេស៊ូវគ្រីស្ទឲ្យបានច្រើនតាមដែលពួកគេអាចធ្វើបាន ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ បន្ទាប់មកសូមអញ្ជើញពួកគេឲ្យអាន នីហ្វៃទី ២ ១៧:១៤ ។ សូមបន្ថែមចំណងជើង *អេម៉ាញូអែល* ទៅលើការរៀបរាប់នៅលើក្តារខៀន ឬ សូមគូសរង្វង់ជុំវិញវា ប្រសិនបើវាមានរួចហើយ ។ សូមអញ្ជើញសិស្សឲ្យរកអត្ថន័យនៃឈ្មោះនេះនៅក្នុង ម៉ាថាយ ១:២៣ ឬ នៅក្នុងវចនានុក្រមព្រះគម្ពីរបរិសុទ្ធ ។

- តើចំណងជើង *អេម៉ាញូអែល នេះមានន័យយ៉ាងដូចម្តេច* ?(« ព្រះអង្គ ទ្រង់គង់ជាមួយនឹងយើងខ្ញុំ ») ។

សូមបង្ហាញថា សារៈសំខាន់ចុងក្រោយបំផុតនៃការព្យាករណ៍របស់អេសាយអំពីអេម៉ាញូអែល ត្រូវបានរកឃើញនៅក្នុង ម៉ាថាយ ១:១៨–២៥ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានវគ្គនេះឮៗ ។

- តើការព្យាករណ៍របស់អេសាយអំពីអេម៉ាញូអែលត្រូវបានបំពេញដោយរបៀបណា ?
- តើនៅពេលណាដែលអ្នកបានឃើញភាពពិតនៃព្រះអម្ចាស់ជាអេម៉ាញូអែល ឬ « ព្រះអង្គ ទ្រង់គង់ជាមួយនឹងយើងខ្ញុំ » នៅក្នុងជីវិតរបស់អ្នក ?

សូមពន្យល់ថា នីហ្វៃទី ២ ១៩:៦–៧ គឺជាការព្យាករណ៍ដ៏ល្បីល្បាញមួយបំផុតអំពីព្រះអង្គសង្គ្រោះ ។ សូមអានវគ្គនេះឲ្យបានឮ ។ សូមបង្ហាញថា វគ្គនេះមានចំណងជើងជាច្រើនសម្រាប់ព្រះយេស៊ូវគ្រីស្ទ ។ (ប្រសិនបើចំណងជើងទាំងនេះណាមួយ មិនទាន់មាននៅលើក្តារខៀននោះទេ សូមបន្ថែមវា) ។

- តើចំណងជើងទាំងនេះណាមួយ ដែលពិពណ៌នាពីអារម្មណ៍របស់អ្នកអំពីព្រះអង្គសង្គ្រោះ ? ហេតុអ្វី ?

មុនពេលអ្នកបង្រៀនមេរៀននេះទាំងអស់ សូមឲ្យសាវតាប្រវត្តិខ្លះៗសម្រាប់នីហ្វៃទី ២ ១៧–១៨ ដល់សិស្ស ។ សូមពន្យល់ថា ជំពូកទាំងនេះ ជាញឹកញាប់យោងទៅលើជាតិសាសន៍តូចបី —យូដា អ៊ីស្រាអែល និង ស៊ីរី— និង ស្តេចរបស់ពួកវា ក៏ដូចជាយោងទៅលើចក្រភពអាសស៊ើរ ដែលចង់ឈ្លានពានជាតិសាសន៍បីតូចនេះ ។ ប្រសិនបើសិស្សមានកំណែព្រះគម្ពីរបរិសុទ្ធរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយ វាអាចជួយបានច្រើនដោយឲ្យពួកគេបើកទៅផែនទី ១, ៣ និង ៥ ដែលបង្ហាញពីតំបន់ភូមិសាស្ត្រដែលសំដៅទៅលើនៅក្នុងជំពូកទាំងនេះ ។ អ្នកក៏អាចជួយសិស្សឲ្យយល់ពីបរិបទនៃជំពូកទាំងនេះដោយការបង្ហាញតារាងខាងក្រោម (ដកស្រង់ចេញពី Victor L. Ludlow, *Isaiah: Prophet, Seer, and Poet* | ឆ្នាំ ១៩៨២ | ទំព័រ ១៤០) ។ សូមបើកទៅវា ពេលត្រូវការក្នុងពេលបង្រៀនមេរៀន ។

ប្រទេស	យូដា	ស៊ីរី	អ៊ីស្រាអែល
រាជធានី	យេរូសាឡិម	ដាម៉ាស	សាម៉ារី
ដែនដី ឬ កុលសម្ព័ន្ធសំខាន់	យូដា	អេភ្រាអិម	អេប្រាអិម
អ្នកដឹកនាំ	អេហាស (ស្តេច) នៃវង្សដាវីឌ	រេស៊ីន (ស្តេច)	ពេកា (ស្តេច) បុត្ររេម៉ាលា

សូមសរសេរពាក្យ*សម្ព័ន្ធមិត្ត* នៅលើក្តារខៀន ។

- តើអ្វីជាសម្ព័ន្ធមិត្ត ? (ចម្លើយអាចរួមមាន សមាគម សហគមន៍ សន្ធិសញ្ញា ឬ កតិកាសញ្ញា) ។
- តើហេតុផលអ្វីខ្លះដែលជាតិមួយ អាចស្វែងរកសម្ព័ន្ធមិត្តជាមួយនឹងជាតិផ្សេងទៀតនោះ ?

សូមពន្យល់ថា អំឡុងពេលការបម្រើរបស់ព្យាការីអេសាយនៅក្នុងនគរយូដា ស្តេចនៃអ៊ីស្រាអែល និង ស៊ីរី ចង់ឲ្យស្តេចអាហាសនៃស្រុកយូដាចូលរួមជាមួយនឹងពួកគេជាសម្ព័ន្ធមិត្តប្រឆាំងនឹងចក្រភពដ៏មានអំណាចអាសស៊ើរ ។ នៅពេលស្តេចអាហាសបដិសេធ

អ៊ីស្រាអែល និង ស៊ីរី បានវាយប្រហារស្រុកយូដាដើម្បីបង្ខំឲ្យចូលសម្ព័ន្ធមិត្តនឹងគ្នា និង ដាក់អ្នកដឹកនាំផ្សេងទៀតលើបល្ល័ង្ករបស់ស្រុកយូដា (សូមមើល នីហ្វៃទី ២ ១៧:១, ៦) ។ នីហ្វៃទី ២ ១៧–១៨ ពិពណ៌នាពីការទូន្មានដែលព្យាការី អេសាយបានផ្តល់ដល់ស្តេច អាហាស នៅពេលដែលស្តេចនោះបានព្យាយាមសម្រេចចិត្តពីរបៀបដែលការពារស្រុកយូដា ប្រឆាំងនឹងការគំរាមកំហែងដែលធ្វើដោយ អ៊ីស្រាអែល ស៊ីរី និង អាសស៊ើរនេះ ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ១៧:១–២ ។

- តើអ្នកគិតថាវាមានន័យយ៉ាងណាដែរ កាលដែលអាហាស « មានព្រះទ័យចំប្រប់ ព្រមទាំងចិត្តរបស់ពួករាស្ត្រទ្រង់ផង ប្រៀបដូចជាដើមឈើនៅព្រៃ ដែលត្រូវខ្យល់បក់ » ? (អាហាស និង រាស្ត្ររបស់ទ្រង់ មានការភ័យខ្លាច ហើយមិនប្រាកដអំពីអ្វីដែលត្រូវធ្វើក្រោយពេលអ៊ីស្រាអែល និង ស៊ីរីបានវាយលុកពួកគេ) ។

សូមពន្យល់ថា ដោយសារតែអាហាសខ្លាចអ៊ីស្រាអែល និង ស៊ីរី ទ្រង់បានពិចារណាបង្កើតជាសម្ព័ន្ធមិត្តនឹងអាសស៊ើរ ដើម្បីការពារនគររបស់ទ្រង់ (សូមមើល របាក្សត្រទី ២ ១៦:៧) ។ អេសាយបានប្រាប់អាហាសថា ប្រសិនបើទ្រង់ (អាហាស) ដាក់សេចក្តីជំនឿទៅលើព្រះអម្ចាស់ ជាជាងការធ្វើការចុះសម្រុងខាងនយោបាយ នោះព្រះអម្ចាស់នឹងការពារនគរយូដា ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ១៧:៣–៨ ឮៗ ។ (ប្រសិនបើមានកំណែរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៃព្រះគម្ពីរបរិសុទ្ធ នៃកំណែថ្មីរបស់ស្តេច ជេម សូមអញ្ជើញសិស្សឲ្យអាន អេសាយ ៧:៤ លេខយោង *a* ។ ប្រសិនបើមិនមានទេ សូមពន្យល់ថាឃ្លា *កន្ទុយខសទាំងពីរ* សំដៅទៅលើគោមដែលឆេះអស់ ។ ព្រះអម្ចាស់បានមានព្រះបន្ទូលជាសំខាន់ថា « ចូរកុំភ័យនឹងការវាយលុកនេះឡើយ ។ ស្តេចទាំងពីរនោះ ជិតអស់ភ្លើងហើយ » ។ អ៊ីស្រាអែល និង ស៊ីរីបានចំណាយកម្លាំងរបស់ពួកគេ ។ ពួកគេនឹងត្រូវបានកម្ទេចក្នុងពេលឆាប់ៗនេះដោយអាសស៊ើរ ហើយនឹងលែងមានការគំរាមកំហែងមកលើយូដាទៀតហើយ ។

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗក្នុង នីហ្វៃទី ២ ១៧:៩, ១៧–២៥ ។ នៅពេលពួកគេអាន សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកអ្វីដែលព្រះអម្ចាស់បានបើកបង្ហាញថានឹងកើតឡើងដល់ប្រជាជនយូដា ប្រសិនបើពួកគេពឹងផ្អែកលើសម្ព័ន្ធមិត្តខាងនយោបាយ ជាជាងការទុកចិត្តលើព្រះអម្ចាស់នោះ ។

- យោងតាមខគម្ពីរទាំងនេះ តើនឹងមានអ្វីកើតឡើង ប្រសិនបើអាហាសមិនបានទុកចិត្តទៅលើព្រះអម្ចាស់ទេនោះ ? (យូដា នឹងត្រូវបានបំផ្លាញ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន នីហ្វៃទី ២ ១៧:១០–១២ឮៗ ។ (អ្នកអាចត្រូវការពន្យល់ថា នៅពេលអេសាយបានដឹកនាំអាហាសឲ្យសុំទីសម្គាល់មួយនោះ គាត់ពិតជាអង្វរដល់អាហាសឲ្យស្វែងរកការទូន្មានពីព្រះអម្ចាស់ពាក់ព័ន្ធនឹងបញ្ហារបស់គាត់ ។ នៅពេលអាហាសបដិសេធ ទ្រង់បានមានបន្ទូលថា ទ្រង់មិនត្រូវការជំនួយពីព្រះ និង ហើយថាទ្រង់មានបំណងពឹងផ្អែកទៅលើការកាត់សេចក្តីផ្ទាល់របស់ទ្រង់) ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ១៧:១៣–១៤ ។ សូមដឹកនាំសិស្សឲ្យកត់ចំណាំម្តងទៀតលើពាក្យ *អេម៉ាញូអែល* នៅក្នុង នីហ្វៃទី ២ ១៧:១៤ និង អត្ថន័យវា « ព្រះអង្គ ទ្រង់គង់ជាមួយនឹងយើងខ្ញុំ » ។

- ហេតុអ្វីបានជាវាសំខាន់សម្រាប់អាហាសដើម្បីចង់ឲ្យព្រះគង់នៅជាមួយនឹងទ្រង់ អំឡុងពេលវិបត្តិក្នុងមាតុភូមិរបស់ទ្រង់ ?
- ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីត្រឡប់ទៅកាន់ព្រះអម្ចាស់វិញ ជាជាងពឹងផ្អែកលើប្រាជ្ញារបស់យើង ?

សូមអាន នីហ្វៃទី ២ ១៨:៥–៨ ឮៗដល់សិស្ស ។ នៅពេលអ្នកអានខគម្ពីរទី ៦ សូមពន្យល់ថាពាក្យ *ស៊ីឡោម* ពេលខ្លះសំដៅទៅលើព្រះយេស៊ូវគ្រីស្ទ ។ នៅពេលអ្នកអានខគម្ពីរទី៨ សូមពន្យល់ឃ្លា « ឡើងត្រឹមក » ដោយបង្ហាញថាក្បាល ឬ រាជធានីនៃស្រុកយូដាគឺយេរូសាឡិម ។ អេសាយបានព្យាករណ៍ថាអាសស៊ើរ នឹងឈ្លានពានមកដល់កំពែងនៃក្រុងយេរូសាឡិម—និយាយម្យ៉ាងទៀតថាក-នៃទីក្រុង ។ ការព្យាករណ៍នេះត្រូវបានបំពេញនៅពេលទាហានអាសស៊ើរ ១៨៥,០០០ នាក់ចូលមកវាយលុកក្រុងយេរូសាឡិម ដោយឈប់នៅកំពែងទីក្រុង ។ ព្រះអម្ចាស់បានការពារាស្ត្ររបស់ទ្រង់ដោយការបញ្ជូនទេវតាមួយមកបំផ្លាញកងទ័ពដែលឈ្លានពាននោះ។ (សូមមើល ពង្សាវតារក្សត្រទី ២ ១៩:៣២–៣៥) ។

សូមអញ្ជើញសិស្សអាន នីហ្វៃទី ២ ១៨:៩–១០ ដោយសូប់ស្ងាត់ ដោយស្វែងរកការព្រមានរបស់ព្រះអម្ចាស់ចំពោះអស់អ្នកណាដែលខិតខំដើម្បីប្រឆាំងនឹងពួកយូដា ។

- តើអ្វីនឹងជាលទ្ធផលដល់អស់អ្នកទាំងឡាយណាដែលវាយប្រឆាំងនឹងពួកយូដា ?
- យោងតាម នីហ្វៃទី ២ ១៨:១០ ហេតុអ្វីបានជាជាតិទាំងនេះត្រូវបានបំផ្លាញបង់ ?

សូមរំឭកសិស្សថា ស្តេចអាហាសបានភ័យខ្លាចការគំរាមកំហែងពីពួកអ៊ីស្រាអែល និង ស៊ីរី ហើយទ្រង់បានគិតអំពីការរួមកម្លាំងនឹងអាសស៊ើរ ។ សូមអញ្ជើញសិស្សអាន នីហ្វៃទី ២ ១៨:១១–១៣ ដោយស្ងាត់ៗ ។

- តើព្រះអម្ចាស់បានមានព្រះបន្ទូលអ្វីខ្លះ ទាក់ទងថាតើពួកយូដាគួរតែបង្កើតសហព័ន្ធមួយ (ចូលជាមួយនឹងអាសស៊ើរ) ឬអត់ ?
- តើអេសាយបានប្រាប់ប្រជាជនឲ្យដាក់ការទុកចិត្តរបស់ពួកគេទៅលើនរណា ?

ដើម្បីជួយសិស្សឲ្យអនុវត្តជំពូកទាំងនេះនៅក្នុងជីវិតរបស់ពួកគេ សូមសួរ ៖

- តើអ្វីខ្លះជាគ្រោះថ្នាក់នៃការដាក់ការទុកចិត្តរបស់យើងទៅលើអំណាច និង ឥទ្ធិពលខាងលោកិយ ជាជាងទៅលើព្រះអម្ចាស់ ? (សូមលើកទឹកចិត្តសិស្សឲ្យគិតអំពីស្ថានភាពទាំងឡាយ ដែលអាចល្បួងពួកគេឲ្យធ្វើការសម្រេចចិត្តដោយផ្អែកលើការភ័យខ្លាច) ។
- តើអ្នកងាកទៅរកកម្លាំងពីព្រះពេលណា កាលដែលអ្នកត្រូវបានគេចាប់ល្បួងឲ្យត្រឡប់ទៅកាន់ប្រភពផ្សេងទៀតនោះ ? តើព្រះជួយអ្នកដោយរបៀបណា ? តើអ្នកបានរៀនអ្វីខ្លះចេញពីបទពិសោធន៍នេះ ?

សូមថ្លែងទីបន្ទាល់ថា **ព្រះនឹងគង់នៅជាមួយនឹងយើង នៅពេលយើងទុកចិត្តលើទ្រង់ ទោះបីជានៅក្នុងពេលលំបាក និង ភ័យខ្លាចក្តី ។** (អ្នកអាចសរសេរគោលការណ៍នេះដាក់លើក្តារខៀន ។)

នីហ្វៃទី ២ ១៩:៨–២១ ; ២០:១–២២

អេសាយបានពិពណ៌នាពីការបំផ្លាញពួកទុច្ចរិត ពេលការយោងមកជាលើកទីពីរ

> ***ការសង្ខេប***
>
> ពេលខ្លះ អ្នកនឹងមិនអាចបង្រៀនពីវគ្គព្រះគម្ពីរទាំងមូលដែលបានដាក់ឲ្យសម្រាប់មួយថ្ងៃបានទេ ។ សូមកុំបាក់ទឹកចិត្ត ។ នៅពេលវគ្គព្រះគម្ពីរធំគ្របដណ្តប់លើជំពូកជាច្រើន អ្នកគួរតែសង្ខេបព្រឹត្តិការណ៍ទាំងឡាយ កាលណាសាច់រឿង និង ពេលខ្លះគោលលទ្ធិដែរ ។ ក្បាលជំពូកជាច្រើន សម្ភារមកពីសៀវភៅមេរៀន និង ទស្សនៈវិស័យ ចេញពីការសិក្សាផ្ទាល់ខ្លួនរបស់អ្នក នឹងជួយអ្នកក្នុងការរៀបចំសង្ខេបដោយមានប្រសិទ្ធភាព ។

សូមសង្ខេបបរិបទប្រវត្តិសាស្ត្រនៃ នីហ្វៃទី ២ ១៩–២០ដោយការពន្យល់ថា អាហាសបានបដិសេធការទូន្មានរបស់អេសាយ ហើយបានជ្រើសរើសបង្កើតជាមួយនឹងអាសស៊ើរ (សូមមើល ពង្សាវតារក្សត្រទី ២ ១៦:៧–២០) ។ ស្រុកយូដាបានក្លាយជាស្រុកចំណុះមួយ ដោយជូនសួយសារអាករដល់អាសស៊ើរសម្រាប់ការការពារប្រឆាំងនឹងការគំរាមកំហែងរបស់ស្រុកស៊ីរី និង អ៊ីស្រាអែល ។ ដូចដែលអេសាយបានព្យាករណ៍ ទីបំផុតអាសស៊ើរបានឈ្លានពានគរតូចៗទាំងបីនេះ ស្រុកដាម៉ាស (ស៊ីរី) នៅក្នុងឆ្នាំ ៧៣២មុន.គ.ស. និង ស្រុកសាម៉ារី (អ៊ីស្រាអែល) នៅក្នុងឆ្នាំ ៧២២មុន.គ.ស. អាសស៊ើរក៏បានគ្រប់គ្រងលើស្រុកយូដាទាំងអស់ លើកលែងតែក្រុងយេរូសាឡិម ត្រឹមឆ្នាំ ៧០១មុន.គ.ស. ។

សូមពន្យល់ថា នៅពេលអាសស៊ើរដណ្តើមបានស្រុកស៊ីរី និង អ៊ីស្រាអែល ហើយបានឡោមព័ទ្ធរដ្ឋធានីរបស់យូដា គឺក្រុងយេរូសាឡិម នោះអាហាសលែងជាស្តេចនៃស្រុកយូដាទៀតហើយ ។ ស្តេចដ៏សុចរិតមួយអង្គ គឺហេសេគា ពេលនោះបានឡើងគ្រងបល្ល័ង្ក ។ ដោយសារហេសេគាបានដាក់ការទុកចិត្តរបស់ទ្រង់ទៅលើព្រះអម្ចាស់ នោះព្រះអម្ចាស់បានការពារទីក្រុងយេរូសាឡិមមិនឲ្យកងទ័ពអាសស៊ើរឡោមព័ទ្ធបានឡើយ ។ ពេលយប់មកដល់ ទេវតារបស់ព្រះអម្ចាស់បានដុតផ្សែងពីលើជម្រំរបស់អាសស៊ើរ ។ នាពេលព្រឹកកងទ័ព ១៨៥,០០០ នាក់នៅក្នុងជួរកងទ័ពអាសស៊ើរ ត្រូវបានរកឃើញថា ស្លាប់ទាំងអស់ (សូមមើល ពង្សាវតារក្សត្រទី ២ ១៩:៣៤–៣៥ ; របាក្សត្រទី ២ ៣២:២១; អេសាយ ៣៧:៣៦) ។

ការព្យាករណ៍របស់អេសាយនៅក្នុង នីហ្វៃទី ២ ១៩–២០ ផ្តោតទៅលើការដាក់ទោសដែលនឹងមកដល់ពួកអ៊ីស្រាអែល និង ពួកយូដាដោយដៃរបស់អាសស៊ើរ ។ អេសាយបានព្រមានអ៊ីស្រាអែលថា ការបំផ្លាញ និង ការជាប់ឃុំឃាំងនឹងមកដល់ពួកគេក្នុងពេលឆាប់ៗនេះ ហើយគាត់បានព្យាករណ៍ពីការវាយលុកមួយក្រោយទៀតទៅលើស្រុកយូដា ។ ការព្យាករណ៍អំពីព្រះមែស៊ីនៅក្នុង នីហ្វៃទី ២ ១៧–១៨ ត្រូវបានសរសេរបន្ថែមទៀតនៅក្នុង នីហ្វៃទី ២ ១៩–២០ ។ ការព្យាករណ៍អំពីអេម៉ាញូអែលត្រូវបានអធិប្បាយនៅក្នុង នីហ្វៃទី ២ ១៩ ពេលដែលអេសាយបានសន្យាពីពន្លឺថ្មី និង អ្នកដឹកនាំថ្មីម្នាក់ ៖ ហេសេគា នៃប្រវត្តិសាស្ត្រ និង ព្រះមែស៊ីនៃព្យាការី ។ នេះគឺជាគំរូមួយនៃការព្យាករណ៍មួយដោយមានការបំពេញពីរដង ។ វាក៏ជាគំរូនៃនិមិត្តរូបមួយ ដែលមាននំយថាព្រឹត្តិការណ៍មួយធ្វើជាការព្យាករណ៍មួយអំពីព្រឹត្តិការណ៍ក្នុងអនាគតកាល ។ ការព្យាករណ៍របស់អេសាយអំពីការបំផ្លាញស្រុកអាសស៊ើរនៅក្នុងនីហ្វៃទី ២ ២០គឺជានិមិត្តរូបមួយនៃការបំផ្លាញពួកទុច្ចរិតពេលការយាងមកជាលើកទីពីរ ។

សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមដាក់លើក្តារខៀន ៖ *នីហ្វៃទី ២ ១៩:១២, ១៧, ២១ ; ២០:៤* ។សូមឲ្យសិស្សស្វែងរកឃ្លាមួយដែលនិយាយដដែលៗនៅក្នុងខគម្ពីរទាំងនេះ ។ សូមសរសេរឃ្លានោះនៅលើក្តារខៀន ។ (« *គង់តែសេចក្តីខ្ចាល់របស់ទ្រង់មិនទាន់បែរចេញនៅឡើយ គឺព្រះហស្តទ្រង់នៅតែលូកមកទៀត* » ។សូមពន្យល់ថា ខគម្ពីរទាំងនេះគឺនិយាយអំពីលទ្ធផលដែលមកដល់រាស្ត្រដែលបះបោរប្រឆាំងនឹងព្រះអម្ចាស់ ហើយបដិសេធមិនព្រមប្រែចិត្ត ។ ពួកគេបង្ហាញការមិនសព្វព្រះទ័យរបស់ព្រះអម្ចាស់ជាមួយនឹងមនុស្សដែលបន្តនៅក្នុងអំពើបាប ។

សូមពន្យល់ថា នៅក្នុងវគ្គព្រះគម្ពីរផ្សេងទៀត ពាក្យស្រដៀងគ្នាទាំងឡាយត្រូវបានប្រើដើម្បីបង្ហាញសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់ចំពោះអ្នកទាំងឡាយណាដែលនឹងប្រែចិត្ត ។ ទោះបីជាទ្រង់គឺជាព្រះនៃសេចក្តីយុត្តិធម៌ក្តី ក៏ទ្រង់មាននិរន្តរ៍ភាពនៃសេចក្តីមេត្តាករុណាចំពោះអស់អ្នកដែលនឹងមករកទ្រង់ដែរ ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ២៨:៣២ ឮៗ ។ បន្ទាប់មកសូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ចំពោះអ្នកទាំងអស់គ្នាដែលគិតថាអ្នកវង្វេង ឬ គ្មានក្តីសង្ឃឹម ឬ ដែលគិតថាអ្នកបានធ្វើរឿងច្រើនពេកហួតដល់ខុសខ្លាំងក្នុងពេលដ៏យូរ ចំពោះអ្នកគ្រប់គ្នាដែលព្រួយបារម្ភថា អ្នកជាប់នៅកន្លែងណាមួយនៅលើវាលដ៏ត្រជាក់នៃជីវិត ហើយបានខ្ចប់រទេះតូចរបស់អ្នកនៅតាមផ្លូវ នោះសន្និសីទនេះបញ្ជាការទប់ដោយប្រឹងប្រែងតស៊ូរបស់ព្រះយេហូវ៉ាថា ‹ ព្រះហស្ត | របស់យើង | ចេះតែលូកមកទៀត ›| សូមមើល អេសាយ ៥:២៥ ; ៩:១៧, ២១ | ។ ព្រះអម្ចាស់បានមានព្រះបន្ទូលថា ‹ យើងលូកដៃទៅរកពួកគេ | គង់តែពួកគេ | នៅតែមិនទទួលស្គាល់យើងដែរ ; ទោះជាយ៉ាងណាក៏ដោយ គង់តែយើងនឹងមេត្តាករុណាដល់ពួកគេដែរ . . . បើសិនជាពួកគេប្រែចិត្ត ហើយមករកយើង ត្បិតដៃយើងនៅតែលូករាល់ៗថ្ងៃ ព្រះអម្ចាស់ដ៏ជាព្រះនៃពួកពលបរិវារទ្រង់មានព្រះបន្ទូលថាដូច្នោះ ›| នីហ្វៃទី ២ ២៨:៣២ | ។ សេចក្តីមេត្តាករុណារបស់ទ្រង់តស៊ូជារឿងដរាប ហើយព្រះហស្តរបស់ទ្រង់នៅតែលូកមករហូត ។ សប្បុរសធម៌មិនដែលផុតរលត់ឡើយរបស់ទ្រង់នោះ គឺជាសេចក្តីស្រឡាញ់ដ៏បរិសុទ្ធនៃព្រះគ្រីស្ទ ដែលសេចក្តីមេត្តានឹងតស៊ូទោះជាក្នុងពេលកម្លាំងផ្សេងទៀតទាំងអស់ត្រូវលិចបាត់ក្តី | សូមមើល ម៉ូរ៉ូណៃ ៧:៤៦–៤៧ | » (« Prophets in the Land Again »*Ensign*ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ១០៦–៧) ។

សូមអញ្ជើញសិស្សឲ្យរៀបរាប់ដោយផ្ទាល់មាត់ នូវសេចក្តីពិតមួយ ដែលពួកគេបានរៀនពីខគម្ពីរទាំងនេះ ។ (សូមប្រាកដថាសិស្សយល់ថា **ព្រះយេស៊ូវគ្រីស្ទគឺជាព្រះនៃការកាត់សេចក្តី និង សេចក្តីមេត្តាករុណា ។ សេចក្តីមេត្តាករុណារបស់ទ្រង់ ត្រូវលាតសន្ធឹងទៅអស់អ្នកទាំងឡាយណាដែលប្រែចិត្ត ហើយកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់**) ។

- តើអ្នកនឹងអនុវត្តគោលការណ៍នេះនៅក្នុងជីវិតរបស់អ្នកដោយរបៀបណា ?

អេសាយបានព្យាករណ៍ថា នៅក្នុងថ្ងៃចុងក្រោយរាស្ត្ររបស់ព្រះអម្ចាស់នឹងត្រឡប់ទៅកាន់ទ្រង់វិញ ហើយឈប់ពឹងលើសមាគមដែលមិនមែនជារបស់ជងព្រះដើម្បីមានសុវត្ថិភាព និង សេចក្តីសុខសាន្តទៀតហើយ ។ ប្រសិនបើសិស្សមានកំណែរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៃព្រះគម្ពីរបរិសុទ្ធ នៃកំណែថ្មីរបស់ស្តេច ជេម សូមអញ្ជើញសិស្សឲ្យអាន អេសាយ ១០:២០ លេខយោង *c* ហើយសូមពន្យល់ពីអត្ថន័យនៃពាក្យថា *ពឹងផ្អែកលើ* ។អ្នកអាចពន្យល់ថា នៅក្នុងបរិបទនេះពាក្យ *ពឹងផ្អែកលើ* មាននំយថាពឹងពាក់លើ ពឹងផ្អែកលើ ឬ ដាក់ទំនុកចិត្តទៅលើអ្វីមួយ ឬ នរណាម្នាក់ ។ សូមធានាសិស្សថា នៅពេលយើងដាក់ទំនុកចិត្តរបស់យើងទៅលើព្រះអម្ចាស់ យើងមិនចាំបាច់ភ័យខ្លាចការជំនុំជំរះដែលនឹងមកដល់ប្រជាជនលើផែនដីដែលនាំទៅរកការយាងមកជាលើកទីពីរនោះទេ ។

មេរៀនទី ៣៤

នីហ្វៃទី ២ ២១–២៤

សេចក្តីផ្តើម

ការព្យាករណ៍របស់អេសាយជាច្រើននៅក្នុងព្រះគម្ពីរមរមន គឺអំពីជំនាន់ចុងក្រោយនេះ ។ គាត់បានព្យាករណ៍អំពីការស្តារឡើងវិញនៃជំណឹងល្អ ព្យាការីយ៉ូសែប ស្មីធ ការយាងមកជាលើកទីពីរ និង ការបំផ្លាញពួកទុច្ចរិត ។ គាត់បានព្យាករណ៍ថា ព្រះអម្ចាស់នឹង « លើកទង់មួយឡើងសម្រាប់សាសន៍ទាំងឡាយ » ដើម្បីប្រមូលរាស្ត្ររបស់ទ្រង់ នៅក្នុងជំនាន់ចុងក្រោយ (សូមមើល នីហ្វៃទី ២ ២១:១១–១២) ។ អេសាយក៏បានថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់នឹងយកឈ្នះលើសាតាំង និង បើកទ្វារទៅក្នុងសហស្សវត្សរ៍ ជាពេលនៃសេចក្តីសុខសាន្ត និង សេចក្តីអំណរ ។

ការថ្លែងទីបន្ទាល់

ទីបន្ទាល់មួយ គឺជាការប្រកាសនៃសេចក្តីជំនឿដ៏សាមញ្ញ និង ចំៗ ។ នៅពេលអ្នករៀបចំបង្រៀនមេរៀននីមួយៗ សូមអធិស្ឋានសុំព្រះវិញ្ញាណដើម្បីជួយអ្នកឲ្យដឹងថា ពេលណាត្រូវថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលអ្នកកំពុងពិភាក្សា ។ អ្នកអាចត្រូវបានបំផុសគំនិតឲ្យថ្លែងទីបន្ទាល់ជាច្រើនដង អំឡុងពេលមេរៀន មិនមែនត្រឹមថ្លែងនៅពេលបញ្ចប់ប៉ុណ្ណោះទេ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ២១:១–៥, ១០–១២

អេសាយបានព្យាករណ៍អំពីការស្តារឡើងវិញនៃជំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនៅថ្ងៃចុងក្រោយ

សូមបង្ហាញរូបភាពម៉ូណៃលេចមកឯយ៉ូសែប ស្មីធនៅក្នុងបន្ទប់របស់គាត់ (៦២៤៩២ ; *សៀវភៅរូបភាពដំណឹងល្អ* [ឆ្នាំ ២០០៩] លេខ ៩១) ។ សូមពន្យល់ថា នៅពេលម៉ូណៃបានលេចមកឯយ៉ូសែប ស្មីធ ជាលើកដំបូង « លោកបានស្រង់ពាក្យពីជំពូកទី ១១ ក្នុងគម្ពីរអេសាយថា ពាក្យព្យាករណ៍នេះជិតនឹងបានសម្រេចហើយ » (យ៉ូសែប ស្មីធ—ប្រវត្តិ ១:៤០) ។ ការព្យាករណ៍នៅក្នុង អេសាយជំពូកទី ១១ ត្រូវបានរកឃើញនៅក្នុង នីហ្វៃទី ២ ២១ ។

សូមអញ្ជើញសិស្សឲ្យអាន នីហ្វៃទី ២ នីហ្វៃទី ២១:១ដោយស្ងាត់ស្ងៀម ។ សូមនាំការយកចិត្តទុកដាក់របស់ពួកគេទៅឃ្លាមួយ « លំពង់មួយនឹងដុះចេញពីគល់របស់អឺសាយ » ។ បន្ទាប់មកសូមអញ្ជើញពួកគេឲ្យអាន នីហ្វៃទី ២ ២១:១០ដោយស្ងាត់ស្ងៀម ។ សូមនាំការយកចិត្តទុកដាក់របស់ពួកគេទៅឃ្លាមួយ « ឬសរបស់អឺសាយ » ។ អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំឃ្លាទាំងនេះ ។ សូមពន្យល់ថា ព្យាការីយ៉ូសែប ស្មីធ បានទទួលវិវរណៈមួយអំពីឃ្លាទាំងនេះ ។ សូមអញ្ជើញសិស្សឲ្យបើកទៅ គោលលទ្ធិ និង សេចក្តីសញ្ញា ១៣:១–៦ ។ សូមអានវគ្គនេះព្ធៗ ។ មុនពេលអ្នកអាន សូមឲ្យសិស្សអានតាម ហើយស្វែងរកអត្ថន័យនៃឃ្លានេះ ។ អ្នកអាចសរសេរអត្ថន័យទាំងនេះនៅលើក្តារខៀន ដូចបានបង្ហាញនៅខាងក្រោម ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរអត្ថន័យទាំងនេះ នៅក្នុងព្រះគម្ពីររបស់ពួកគេ ។

គល់របស់អឺសាយ—ព្រះយេស៊ូវគ្រីស្ទ

លំពង់—អ្នកបម្រើនៃព្រះគ្រីស្ទ « ដែលមានអំណាចដ៏ខ្លាំងដាក់មកលើអ្នកបម្រើនោះ »

ឬសរបស់អឺសាយ—បុគ្គលម្នាក់នៅក្នុងជំនាន់ចុងក្រោយ ដែលនឹងកាន់បព្វជិតភាព និង « ក្ងនសោទាំងឡាយនៃនគរ »

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ប្រ្ធិស អ័រ. ម៉ាក់ខន់ឃី នៃក្ងរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកអត្តសញ្ញាណនៃ « លំពង់ » និង « ឬសរបស់អឺសាយ » ។

« តើយើងនិយាយខុសថាព្យាការីដែលបានលើកឡើងនៅទីនេះគឺជាយ៉ូសែប ស្មីធ ដែលបានមានបព្វជិតភាព ដែលបានទទួលក្ងនសោទាំងឡាយនៃនគរ និង ដែលបានលើកទង់ដើម្បីប្រមូលរាស្ត្ររបស់ព្រះអម្ចាស់នៅក្នុងគ្រាកាន់កាប់ត្រួតត្រាឬ ? ហើយតើគាត់មិនមែនជា ‹ អ្នកបម្រើនៅក្នុងព្រះហស្តនៃព្រះគ្រីស្ទ ដែលជាពួជពង្សរបស់អឺសាយខ្លះ និង ពួជពង្សរបស់អេប្រាអិមខ្លះ ឬ ជាវង្សនៃយ៉ូសែបដែលមានអំណាចដ៏ខ្លាំងដាក់មកលើអ្នកបម្រើនោះ ទេឬអី › ? » (*The Millennial Messiah: The Second Coming of the Son of Man* [ឆ្នាំ ១៩៨២] ទំព័រ ៣៣៩–៤០) ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ២១:១០, ១២ព្ធៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពាក្យ និង ឃ្លាដែលទាក់ទងនឹងយ៉ូសែប ស្មីធ និង ការស្តារឡើងវិញនៃជំណឹងល្អ និង សាសនាចក្ររបស់ព្រះអម្ចាស់ ។ មុនពេលសិស្សអាន អ្នកអាចរំពឹកពួកគេថា ពាក្យ *ទង់*សំដៅទៅលើបទដ្ឋានមួយ ទង់មួយ ឬ បដាដែលបានប្រើជាចំណុចប្រមូលផ្ទុំមួយ ឬ ជាសញ្ញាសម្គាល់មួយដើម្បីរួបរួម (សូមមើលមេរៀនទី ៣២) ។

- តើកិច្ចការរបស់យ៉ូសែប ស្មីធ បានបំពេញការព្យាករណ៍ដែលទាក់ទងនឹងឬសរបស់អឺសាយដោយរបៀបណា ?
- តើយើងប្រមូលផ្ទុំគ្នានាសព្វថ្ងៃនេះ ក្នុងនាមជាសមាជិកសាសនាចក្រដោយរបៀបណា ? តើយើងលើកទង់ឡើងដើម្បីជួយអ្នកដទៃឲ្យដឹងពីកន្លែងប្រមូលផ្ទុំដោយរបៀបណា ?

សូមថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់បានស្តារដំណឹងល្អរបស់ទ្រង់ និង សាសនាចក្ររបស់ទ្រង់ឡើងវិញ តាមរយៈព្យាការី យ៉ូសែប ស្មីធ ហើយឥឡូវនេះកំពុងប្រមូលផ្ទុំរាស្ត្ររបស់ទ្រង់នៅជំនាន់ចុងក្រោយ ។

នីហ្វៃទី ២ ២១:៦–៩ ; ២២

អេសាយពិពណ៌នាពីសហស្សវត្សរ៍

សូមឲ្យសិស្សស្រមៃថា មិត្តម្នាក់ដែលជាសមាជិកនៃព្រះវិហារផ្សេងទៀតបានសួរពួកគេពីអ្វីដែលពួកគេជឿអំពីសហស្សវត្សរ៍ ។ សូមឲ្យពួកគេសិក្សា នីហ្វៃទី ២ ២១:៦–៩និង ២២:១–៦ ដោយស្វាត់ស្ងៀម ដោយស្វែងរកសេចក្តីពិតដែលពួកគេអាចចែកចាយនៅក្នុងការសន្ទនាមួយបែបនោះ ។ សូមអញ្ជើញពួកគេឲ្យសរសេរគំនិតរបស់ពួកគេនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ។ ដើម្បីជួយសិស្សឲ្យពិភាក្សាពីអ្វីដែលពួកគេបានរកឃើញ សូមសួរសំណួរទាំងនេះខ្លះៗ ឬ សួរទាំងអស់ ៖

- តើការពិពណ៌នានៅក្នុង នីហ្វៃទី ២ ២១:៦–៨ ស្មើអ្វីខ្លះពីលក្ខខណ្ឌនៅលើផែនដីអំឡុងពេលសហស្សវត្សរ៍ ?
- យោងតាមនីហ្វៃទី ២ ២១:៩ ហេតុអ្វីបានជាផែនដីនឹងជាកន្លែងមួយនៃសេចក្តីសុខសាន្ត អំឡុងពេលសហស្សវត្សរ៍ ? សូមជួយសិស្សឲ្យយល់ថា **អំឡុងពេលសហស្សវត្សរ៍ ផែនដីនឹងជាកន្លែងមួយនៃសេចក្តីសុខសាន្ត ដោយសារវានឹងពោរពេញទៅដោយចំណេះដឹងអំពីព្រះអម្ចាស់) ។**
- តើចំណេះដឹងអំពីព្រះអម្ចាស់អាចជួយយើងឲ្យរស់នៅពេញដោយសេចក្តីសុខសាន្តជាងនេះក្នុងពេលឥឡូវនេះដោយរបៀបណា ?
- នៅក្នុង នីហ្វៃទី ២ ២២:១–៦ អេសាយបានពិពណ៌នាពីវិញ្ញាណនៃការថ្វាយបង្គំ ដែលមនុស្សនឹងមានអំឡុងពេលសហស្សវត្សរ៍ ។ តើយើងអាចអភិវឌ្ឍគំរិយាបថដូចគ្នានោះនៅសព្វថ្ងៃដោយរបៀបណា ?
- តើទិដ្ឋភាពនៃសហស្សវត្សរ៍អ្វីខ្លះ ដែលអ្នកចង់មាននៅក្នុងជីវិតរបស់អ្នកនាពេលឥឡូវនេះ ? (សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតអំពីអ្វីដែលពួកគេអាចធ្វើ ដើម្បីឲ្យទទួលបាននូវពរជ័យទាំងនេះខ្លះៗនៅក្នុងជីវិតរបស់ពួកគេ) ។

នីហ្វៃទី ២ ២៣–២៤

អេសាយបង្រៀនថា ពួកទុច្ចរិតនឹងត្រូវស្លាប់ ហើយថាព្រះអម្ចាស់នឹងមានសេចក្តីមេត្តាករុណាមកលើវាស្ត្រេរបស់ទ្រង់

សូមពន្យល់ថា នៅក្នុងនីហ្វៃទី ២ ២៣ អេសាយព្យាករអំពីការបំផ្លិចបំផ្លាញនៃទី ក្រុងបាប៊ីឡូន ហើយប្រៀបធៀបការបំផ្លាញនេះទៅនឹងការបំផ្លាញនៃពួកទុច្ចរិត នាពេលការយាងមកជាលើកទី ពីររបស់ព្រះអង្គសង្គ្រោះ ។ សូមអញ្ជើញសិស្សឲ្យអាន « បាប៊ីឡូន » នៅក្នុងវចនានុក្រមព្រះគម្ពីរបរិសុទ្ធ ។ សូមពន្យល់ថា នៅក្នុងវគ្គព្រះគម្ពីរខ្លះៗពាក្យថា *បាប៊ីឡូន*សំដៅជាទូទៅទៅលើភាពទុច្ចរិតនៃពិភពលោក ។ អេសាយបានព្យាករថា ការបំផ្លិចបំផ្លាញដ៏មហិមានឹងកើតឡើងទៅលើពួកទុច្ចរិតនៅក្នុងទីក្រុងបាប៊ីឡូន និង នៅក្នុងថ្ងៃចុងក្រោយបំផុត ។

ដើម្បីជួយសិស្សឲ្យស្គាល់ពីលទ្ធផលចំពោះពួកទុច្ចរិតនៅក្នុងថ្ងៃចុងក្រោយ សូមឲ្យពួកគេអាន នីហ្វៃទី ២ ២៣:១, ៥–៩, ១១, ១៥, ១៩ និង ២២ដោយស្វាត់ៗ ។

សូមពន្យល់ថា អេសាយបានបង្ហាញការឆ្លាក់របស់លូស៊ីហ្វើរ ឬ សាតាំង ថាជាការបង្ហាញមួយទៀតអំពីរបៀបដែលពួកទុច្ចរិតនឹងត្រូវស្លាប់ ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ២៤:១២–១៦ ឮៗ ។

- តើឃ្លាណានៅក្នុងខគម្ពីរទាំងនេះ ដែលបង្ហាញពីការអួតអាងរបស់សាតាំង ?
- តើនីហ្វៃទី ២ ២៤:១៦ បង្ហាញពីរបៀបដែលយើងនឹងមានអារម្មណ៍ពីសាតាំងយ៉ាងដូចម្តេច ប្រសិនបើយើងអាចឃើញវា តើវាជានរណានោះ ?

សូមអញ្ជើញសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន ៖

« នៅក្នុងក្រុមប្រឹក្សាជីវិតមុនជីវិតលើផែនដីនេះ លូស៊ីហ្វើរបានឆ្លាក់ដោយសារតែអំនួតថាជា [បុត្រានៃពេលព្រឹក › ។ (នីហ្វៃទី ២ ២៤:១២–១៥; សូមមើលផងដែរ គ . និង ស . ៧៦:២៥–២៧; ម៉ូសេ ៤:៣ ។) . . . នៅក្នុងក្រុមប្រឹក្សាជីវិតមុនផែនដី លូស៊ីហ្វើរ បានដាក់សំណើរវាប្រកួតប្រជែងនឹងផែនការរបស់ព្រះរបិតាដែលបានប្រឹក្សាដោយព្រះយេស៊ូវគ្រីស្ទ ។ (សូមមើល ម៉ូសេ ៤:១–៣ ។) វាចង់បានកិត្តិយសលើសមនុស្សទាំងអស់ ។ (សូមមើលនីហ្វៃទី ២ ២៤:១៣ ។) ជារួមមក បំណងប្រាថ្នាដ៏អំនួតរបស់វាគឺដើម្បីទម្លាក់ព្រះចេញពីរាជបល្ល័ង្ក ។ (សូមមើល គ. និង ស. ២៩:៣៦; ៧៦:២៨ ។) » (« Beware of Pride» *Ensign*ខែ ឧសភា ឆ្នាំ ១៩៨៩ ទំព័រ ៤–៥) ។

សូមទាញយកចំណាប់អារម្មណ៍របស់សិស្ស ទៅលើព្រះបន្ទូលនៃព្រះអម្ចាស់នៅចុងបញ្ចប់នៃនីហ្វៃទី ២ ២៣:២២ ថា ៖ « យើងនឹងអាណិតអាសូរដល់រាស្ត្រយើង តែពួកទុច្ចរិតត្រូវតែវិនាស ។ » អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំការប្រកាសនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។ (សូមកត់ចំណាំថា ប្រយោគចុងក្រោយនៅក្នុងខគម្ពីរនេះ មិនមាននៅក្នុងខគម្ពីរដែលទាក់ទងនៅក្នុងគម្ពីរអេសាយនៅក្នុងព្រះគម្ពីរកំណែរបស់ស្តេចជេម នោះទេ ។ វាបង្ហាញថា ផ្នាំងលង្ហិនមានព័ត៌មានខ្លះដែលមិនមាននៅក្នុងព្រះគម្ពីរបរិសុទ្ធ ។)

- តើអ្នកគិតថា ការនៅក្នុងចំណោមរាស្ត្ររបស់ព្រះអម្ចាស់ មានអត្ថន័យយ៉ាងណា ?

សូមឲ្យសិស្សបីបួននាក់អាន នីហ្វៃទី ២ ២៤:១–៧, ២៤–២៧ឮៗ ដោយប្តូរវេនគ្នាអានមួយ ឬ ពីរខម្នាក់ ។ សូមអញ្ជើញសិស្សទាំងអស់គ្នារកមើលសេចក្តីសន្យាដែលព្រះអម្ចាស់បានប្រទានដល់រាស្ត្ររបស់ទ្រង់ ។ សូមលើកទឹកចិត្តពួកគេឲ្យចែកចាយការសង្កេតនានារបស់ពួកគេជាមួយគ្នាទៅវិញទៅមក ។ អ្នកអាចគិតពីការឲ្យសិស្សម្នាក់សរសេរការសង្កេតទាំងនេះដាក់លើក្តារខៀន ។

- តើសារលិខិតអ្វី ដែលខគម្ពីរទាំងនេះចែកចាយសម្រាប់អស់អ្នកដែលបានរងទុក្ខដោយសារតែអំពើទុច្ចរិតរបស់ប្រជាជននោះ ?
- តើមានភស្តុតាងនៃសុភមង្គល និង សេចក្តីសង្ឃឹមអ្វី ដែលអ្នកបានឃើញនៅក្នុងខគម្ពីរទាំងនេះ ?

សូមប្រាកដថា សិស្សយល់ថា ព្រះអម្ចាស់នឹងមានសេចក្តីមេត្តាករុណាមកលើប្រជាជនរបស់ទ្រង់ ប៉ុន្តែពួកទុច្ចរិតត្រូវវិនាស ។ សូមជួយសិស្សឲ្យយល់ថា ការព្យាករណ៍របស់អេសាយនៅក្នុង នីហ្វៃទី ២ ២១–២៤ ឆ្លុះបញ្ចាំងពីសារលិខិតដ៏សំខាន់មួយនៃព្រះគម្ពីរមរមនថា —ពួកអ្នកដែលស្តាប់តាមបង្គាប់នឹងរីកចម្រើនឡើង ហើយអ្នកដែលមិនស្តាប់បង្គាប់នឹងត្រូវវិនាស ។ សូមថ្លែងទីបន្ទាល់ថា យើងអាចរស់នៅដោយសុចរិត និង រីកចម្រើនឡើងនាពេលសព្វថ្ងៃនេះ នៅពេលយើងសង្ឃឹមដល់ថ្ងៃសហស្សវត្សរ៍ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ២ ២១:១ ។ « ហើយមែកមួយដែលចេញពីឫសលោកនឹងកើតមានផលផ្លែ »

អែលឌើរប្រ៊ូស អ័រ. ម៉ាក់ខនឃី នៃក្រុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ពីមែកដែលបានលើកឡើងនៅក្នុង នីហ្វៃទី ២ ២១:១ នេះថា ៖

« ព្រះយេហូវ៉ា ទ្រង់មានបន្ទូលថា មើល នឹងមានគ្រាមកដល់ ដែលយើងនឹងបង្កើតឲ្យដាវីឌមានលំពង់សុចរិតមួយ លំពង់នោះទ្រង់នឹងសោយរាជ្យទុកដូចជាស្តេច ហើយនឹងប្រព្រឹត្តដោយវាងវៃ . . . › (យេរេមា ២៣:៣–៦) ។ រួមសេចក្តីមក ស្តេចដែលនឹងសោយរាជ្យដោយផ្ទាល់នៅលើផែនដីអំឡុងពេលសហស្សវត្សរ៍ នឹងជាមែកដែលកើតឡើងពីរង្សដាវីឌ ។ ទ្រង់នឹងធ្វើការកាត់សេចក្តី និង សេចក្តីយុត្តិធម៌នៅលើផែនដីទាំងមូល ដោយសារទ្រង់គឺជាព្រះអម្ចាស់យេហូវ៉ា គឺទ្រង់នេះហើយដែលយើងហៅថា ព្រះគ្រីស្ទ ។ ដែលមែករបស់ដាវីឌគឺជាព្រះគ្រីស្ទនោះ គឺពិតជាច្បាស់ល្អឥតខ្ចោះ ។ ឥឡូវនេះ យើងគួរយើញថា ទ្រង់ក៏ត្រូវបានហៅថា ដាវីឌ ថាទ្រង់គឺជាដាវីឌថ្មីម្នាក់ ជាដាវីឌដ៏អស់កល្បម្នាក់ ដែលនឹងសោយរាជ្យជារៀងរហូតនៅលើបល្ល័ង្កនៃបុព្វបុរសពីបុរាណរបស់ទ្រង់ [សូមមើល យេរេមា ៣០:៨–៩] » (*The Promised Messiah: The First Coming of Christ* [ឆ្នាំ ១៩៧៨] ទំព័រ ១៩៣) ។

គំនិតបន្ថែមទាំងឡាយសម្រាប់ការបង្រៀន

នីហ្វៃទី ២ ២១:៩ ។ « គ្រប់ទាំងអស់នឹងស្គាល់ព្រះអម្ចាស់ពាសពេញលើផែនដី »

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ២១:៩ ឮៗ ។ សូមចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ជាល្លិន អេក. អូក នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« នៅក្នុងជំនាន់របស់យើង យើងកំពុងជួបនឹងបន្ទុះនៃចំណេះដឹងអំពីពិភពលោក និងប្រជាជននៅលើពិភពលោកនេះ ។ ប៉ុន្តែប្រជាជនលើពិភពលោកមិនបានជួបនឹងការពង្រីកចំណេះដឹងដ៏ប្រៀបធៀបមួយអំពីព្រះ និង ផែនការរបស់ទ្រង់សម្រាប់កូនចៅរបស់ទ្រង់នោះទេ ។ នៅក្នុងបញ្ហានោះ អ្វីដែលពិភពលោកត្រូវការនោះគឺមិនមែនជាអាហារូបករណ៍ និងបច្ចេកវិទ្យានោះទេ ប៉ុន្តែត្រូវការជាងនូវភាពសុចរិត ហើយនិង វិវរណៈ ។ ខ្ញុំរង់ចាំដល់ថ្ងៃនោះដែលបានព្យាករណ៍ដោយអេសាយ នៅពេល ‹គ្រប់ទាំងអស់នឹងស្គាល់ព្រះអម្ចាស់ពាសពេញលើផែនដី › ។ (អេសាយ ១១:៩; នីហ្វៃទី ២ ២១:៩ ។) » (« Alternate Voices » *Ensign* ខែ ឧសភា ១៩៨៩ ឆ្នាំ ៣០) ។

- យោងតាមអែលឌើរ អូក តើពិភពលោកត្រូវការអ្វី ?
- តើយើងអាចជួយនាំមកនូវការបំពេញនៃការព្យាករណ៍របស់អេសាយដោយរបៀបណា ?

នីហ្វៃទី ២ ២៥

សេចក្តីផ្តើម

ដោយបន្តសង្កត់ធ្ងន់លើសារៈសំខាន់នៃការព្យាករណ៍របស់អេសាយ នីហ្វៃបានពន្យល់ថា មនុស្សគ្រប់គ្នាដែលមានព្រះវិញ្ញាណនៃការព្យាករណ៍អាចយល់ និង កោតសរសើរដល់ពាក្យពេចន៍របស់អេសាយ ។ គាត់បានចែកចាយពីគោលបំណងនៃការសរសេររបស់គាត់ ៖ « ដើម្បីបញ្ចុះបញ្ចូលកូនចៅយើង និង បងប្អូនយើងផង ដើម្បីឲ្យជឿដល់ព្រះគ្រីស្ទ ហើយឲ្យស្រុះស្រួលនឹងព្រះ ៖ » (នីហ្វៃទី ២២៥:២៣) ។ គាត់បានអញ្ជើញដល់មនុស្សទាំងអស់គ្នាឲ្យជឿដល់ព្រះយេស៊ូវគ្រីស្ទ និង ដើម្បី « ថ្វាយបង្គំទ្រង់ឲ្យអស់ពីសមត្ថភាព អស់ពីគំនិត និង អស់ពីកម្លាំង [របស់ពួកគេ] ហើយអស់ពីព្រលឹងទាំងមូល [របស់ពួកគេ] » (នីហ្វៃទី ២២៥:២៩) ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ២៥:១–៨

នីហ្វៃបង្រៀនថា យើងអាចយល់ពាក្យពេចន៍របស់អេសាយ នៅពេលយើងមានវិញ្ញាណនៃការព្យាករណ៍

សូមបង្ហាញមេសោមួយ ដែលមិនអាចបើកបាន បើគ្មានកូនសោនោះ (ឬ សូមគូសរូបភាពមួយនៃមេសោមួយ និង កូនសោនៅលើក្តារខៀន) ។ សូមបង្ហាញថា នៅពេលមនុស្សចង់ទុកវត្ថុមានតម្លៃឲ្យមានសុវត្ថិភាព ជារឿយៗពួកគេចាក់សោវាទុក ។ ពួកគេអាចទុកតែកូនសោសម្រាប់ចាក់ ឬ ពួកគេអាចឲ្យកូនសោចម្លងទៅមិត្តភក្តិដែលគេទុកចិត្តម្នាក់ ឬ សមាជិកគ្រួសារម្នាក់ ។



សូមពន្យល់ថា នីហ្វៃបានដឹងថាការព្យាករណ៍របស់អេសាយគឺ « មានប្រយោជន៍ដ៏ធំ » (នីហ្វៃទី ២ ២៥:៨) ។ ទោះជាយ៉ាងណាក្តី គាត់មិនបានលាក់វាជាការណ៍សម្ងាត់នោះទេ ។ គាត់ថែមទាំងបានបង្រៀនអំពីកូនសោសម្រាប់គ្រប់គ្នា ដែលចង់ចាក់សោយល់ពីអត្ថន័យនៃពាក្យពេចន៍របស់អេសាយ ។ សូមអញ្ជើញសិស្សម្នាក់អានប្រយោគទីមួយនៅក្នុង នីហ្វៃទី ២ ២៥:៤ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលកូនសោដើម្បីយល់ពីពាក្យពេចន៍របស់អេសាយ ។

- តើអ្នករកឃើញកូនសោអ្វី ? (« វិញ្ញាណនៃការព្យាករណ៍ ។ »)

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យក្នុងការមាន « វិញ្ញាណនៃការព្យាករណ៍ » សូមអានសេចក្តីថ្លែងការណ៍ខាងក្រោម ដកស្រង់ចេញពីសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ៖

« ការព្យាករណ៍មួយរួមមានពាក្យពេចន៍ ឬ ការសរសេរបំផុសគំនិតដ៏ទេវភាព ដែលមនុស្សម្នាក់ទទួលបានតាមរយៈវិវរណៈមកពីព្រះវិញ្ញាណបរិសុទ្ធ ។ ទីបន្ទាល់អំពីព្រះយេស៊ូវ គឺជាវិញ្ញាណនៃការព្យាករណ៍ (វិវរណៈ ១៩:១០) ។ ការព្យាករណ៍មួយអាចជាប់ទាក់ទងទៅនឹងអតីតកាល បច្ចុប្បន្នកាល ឬ អនាគត ។ នៅពេលមនុស្សម្នាក់ព្យាករ កាត់និយាយ ឬ សរសេរអ្វីដែលព្រះចង់ឲ្យគាត់ដឹងសម្រាប់ការណ៍ល្អផ្ទាល់ខ្លួន ឬ ការណ៍ល្អសម្រាប់អ្នកដទៃ ។ បុគ្គលគ្រប់គ្នាអាចទទួលបានការព្យាករណ៍ ឬ វិវរណៈសម្រាប់ជីវិតផ្ទាល់របស់ពួកគេ » (ការណែនាំពីព្រះគម្ពីរ « ការព្យាករណ៍ , ព្យាករ » scriptures.lds.org) ។

សូមជួយសិស្សឲ្យដឹងថា ការយល់របស់ពួកគេអំពីពាក្យពេចន៍របស់អេសាយនឹងកើនឡើងនៅពេលពួកគេ (១) ស្វែងរកការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ និង (២) មានទីបន្ទាល់មួយអំពីព្រះយេស៊ូវគ្រីស្ទ និង បំណងប្រាថ្នាមួយចង់រៀនអំពីទ្រង់ ។ នៅពេលពួកគេយល់ពីពាក្យពេចន៍របស់អេសាយតាមរបៀបនេះ សូមស្វែងរករបៀបដែលការព្យាករណ៍របស់គាត់ផ្តែងទីបន្ទាល់អំពីព្រះអង្គសង្គ្រោះជានិច្ច នោះពួកគេអាចយល់ពីអ្វីដែលព្រះចង់ឲ្យពួកគេដឹង សម្រាប់ការណ៍ល្អផ្ទាល់របស់ពួកគេ ឬ សម្រាប់ការណ៍ល្អរបស់អ្នកដទៃ ។

សូមបង្ហាញថា នីហ្វៃបានចែកចាយគំនិតផ្សេងទៀតដែលអាចជួយជាជំនួយដល់យល់ដឹងរបស់យើងអំពីពាក្យពេចន៍របស់អេសាយ ។ សូមឲ្យសិស្សអាន នីហ្វៃទី ២ ២៥:១ ដោយស្ងាត់ៗ ដោយស្វែងរកពីហេតុផលដែលប្រជាជនជាច្រើនរបស់នីហ្វៃពិបាកយល់ពីការព្យាករណ៍របស់អេសាយ ។

- តើអ្នករកឃើញអ្វី ? (ពួកគេមិនបានដឹង « ទាក់ទងរបៀបនៃការព្យាករណ៍ក្នុងចំណោមប្រជាជនយូដា » នោះទេ) ។
- ដោយផ្អែកលើអ្វីដែលអ្នកបានអានពីពាក្យពេចន៍របស់អេសាយ តើអ្វីខ្លះជាលក្ខណៈនៃការព្យាករណ៍របស់សាសន៍យូដាពីបុរាណ ? (ចម្លើយអាចរួមមានថា អេសាយ និង ព្យាការីផ្សេងទៀតបានប្រើនិមិត្តសញ្ញា និង ភាសាកំណាព្យ) ។
- នៅពេលអ្នកអានពាក្យពេចន៍របស់អេសាយ តើហេតុអ្វីបានជាវាមានប្រយោជន៍ដើម្បីដឹងពីរបៀបនៃការព្យាករណ៍នេះ ?

សូមពន្យល់ថា គំនិតដ៏មានប្រយោជន៍ផ្សេងទៀតត្រូវបានរកឃើញនៅក្នុង នីហ្វៃទី ២ ២៥:៥–៦ ។ សូមអញ្ជើញសិស្សម្នាក់អានខគម្ពីរទាំងនេះឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកបទពិសោធន៍ដែលនីហ្វៃជួប ដែលបានជួយគាត់ឲ្យយល់ពីពាក្យពេចន៍របស់អេសាយ ។

- តើអ្នកគិតថា ហេតុអ្វីបានជាវាបានជួយដល់នីហ្វៃឲ្យរស់នៅក្នុងទីក្រុងយេរូសាឡិម ? ដោយផ្អែកលើអ្វីដែលអ្នកបានអានពីពាក្យពេចន៍របស់អេសាយ តើអ្នកគិតថាហេតុអ្វីបានជាវាមានប្រយោជន៍សម្រាប់នីហ្វៃដើម្បីមាន « របៀបនៃការណ៍ទាំងឡាយរបស់ពួកសាសន៍យូដា » និង ដើម្បី « ស្គាល់នូវភូមិភាគជុំវិញ » យេរូសាឡិម ?
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីទទួលបានចំណេះដឹងនៃរឿងទាំងនេះ ? (យើងអាចសិក្សាពីវប្បធម៌ ប្រវត្តិសាស្ត្រ និង ភូមិសាស្ត្រនៃអ៊ីស្រាអែលពីបុរាណ) ។

សូមអាន នីហ្វៃទី ២ ២៥:៧–៨ ដល់សិស្ស ។ នៅពេលអ្នកអាន សូមបង្ហាញថាការព្យាករណ៍របស់អេសាយនឹងជាប្រយោជន៍ដ៏ធំដល់យើង នៅពេលយើងដឹងថាពួកវាត្រូវបានបំពេញហើយ ។ ដើម្បីបង្ហាញពីសេចក្តីពិតនេះ សូមសួរ ៖

- នៅប៉ុន្មានថ្ងៃចុងក្រោយនេះ តើការព្យាករណ៍អ្វីខ្លះដែលយើងបានសិក្សាដែលត្រូវបានបំពេញរួចរាល់ហើយនោះ ? (សិស្សអាចចាំពីការព្យាករណ៍ទាំងឡាយអំពីព្រះវិហារបរិសុទ្ធសលត៍ លេក | សូមមើល នីហ្វៃទី ២ ១២:២–៣ | , ការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ | សូមមើល នីហ្វៃទី ២ ១៩:៦ | និង យ៉ូសែប ស៊្មីធ | សូមមើល នីហ្វៃទី ២ ២១:១, ១០ |) ។ តើការព្យាករណ៍ទាំងនេះក្លាយជាមានអត្ថន័យខ្លាំង នៅពេលអ្នកដឹងថាពួកវាត្រូវបានបំពេញហើយនោះ ដោយរបៀបណា ?

ដើម្បីបញ្ចប់ផ្នែកនៃមេរៀននេះ សូមបង្ហាញទំនុកចិត្តរបស់អ្នកថា សិស្សអាចពង្រីកនូវការយល់ដឹងរបស់ពួកគេអំពីពាក្យពេចន៍របស់អេសាយ នៅពេលពួកគេស្វែងរកវិញ្ញាណនៃការព្យាករណ៍ ។ សូមបង្ហាញថា ពួកគេអាចពង្រីកការយល់ដឹងរបស់ពួកគេតាមរយៈការសិក្សាមួយពីរបៀបនៃការព្យាករណ៍របស់សាសន៍យូដាពីបុរាណ និង ពីវប្បធម៌ ប្រវត្តិសាស្ត្រ និង ភូមិសាស្ត្ររបស់អ៊ីស្រាអែលពីបុរាណ ។

នីហ្វៃទី ២ ២៥:៩–១៩

នីហ្វៃព្យាករណ៍អំពីការខ្ចាត់ខ្ចាយ និង ការប្រមូលផ្តុំនៃសាសន៍យូដា

សូមសង្ខេប នីហ្វៃទី ២ ២៥:៩–១៩ ដោយនិយាយថា នីហ្វៃបានព្យាករណ៍អំពីសាសន៍យូដា និង ដែនដីកំណើតរបស់ពួកគេនៅក្នុងទីក្រុងយេរូសាឡិម និង តំបន់ជុំវិញ ។ គាត់បាននិយាយថា សាសន៍យូដាដែលត្រូវបានចាប់ជាឈ្លើយទៅក្រុងបាប៊ីឡូន ក្រោយពីការបំផ្លាញទីក្រុងយេរូសាឡិមហើយនោះ នឹងត្រឡប់ទៅកាន់ « ដែនដីនៃកេរ្តិ៍អាកររបស់ពួកគេ » (សូមមើល នីហ្វៃទី ២ ២៥:៩–១១) ។ ព្រះយេស៊ូវគ្រីស្ទ ព្រះមែស៊ី នឹងរស់នៅក្នុងចំណោមពួកគេ ប៉ុន្តែមនុស្សជាច្រើនបានបដិសេធទ្រង់ ហើយឆ្កាងទ្រង់ (សូមមើល នីហ្វៃទី ២ ២៥:១២–១៣) ។ ក្រោយពីការសុគត និង ការរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះ ទីក្រុងយេរូសាឡិមនឹងត្រូវបានបំផ្លាញម្តងទៀត ហើយសាសន៍យូដានឹងត្រូវខ្ចាត់ខ្ចាយ និង ត្រូវបានបំបែកឲ្យខ្ចាត់ព្រាត់ដោយពួកសាសន៍ដទៃ (សូមមើល នីហ្វៃទី ២ ២៥:១៤–១៥) ។ ទីបញ្ចប់ ពួកគេនឹងជឿលើព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធួនរបស់ទ្រង់ ហើយព្រះអម្ចាស់នឹងតាំងពួកគេឡើងវិញ « ពីស្ថានភាពវង្វេង និង ភាពធ្លាក់ » (សូមមើល នីហ្វៃទី ២ ២៥:១៦–១៩) ។

នីហ្វៃទី ២ ២៥:២០–៣០

នីហ្វៃថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ

សូមឲ្យសិស្សគិតអំពីរបៀបដែលពួកគេអាចឆ្លើយតបនឹងនរណាម្នាក់ដែលនិយាយថា ពួកបរិសុទ្ធថ្ងៃចុងក្រោយមិនបានជឿទៅលើព្រះយេស៊ូវគ្រីស្ទនោះទេ ។ អ្នកអាចសុំឲ្យសិស្សម្នាក់ ឬ ពីរនាក់ប្រាប់ដោយសង្ខេបអំពីបទពិសោធន៍ដែលពួកគេបានមាន នៅពេលមនុស្សផ្សេងបានប្រណាំងប្រជែងពីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ ។ នៅពេលសិស្សអាន និង ពិភាក្សា នីហ្វៃទី ២ ២៥:២០–៣០ សូមអញ្ជើញពួកគេឲ្យស្វែងរកវគ្គនានាដែលពួកគេអាចចែកចាយនៅក្នុងស្ថានភាពបែបនោះបាន ។

សូមឲ្យសិស្សស្វែងរក « ផ្លូវត្រឹមត្រូវ » នៅក្នុងនីហ្វៃទី ២ ២៥:២៨–២៩ ។ ក្រោយពីពួកគេបានរកឃើញថា « ផ្លូវត្រឹមត្រូវ គឺត្រូវជឿទៅលើព្រះគ្រីស្ទ ហើយមិនត្រូវបដិសេធទ្រង់នោះ » សូមសរសេរនៅលើក្តារខៀនពី*អ្វីលេហេតុនៃការជឿទៅលើព្រះយេស៊ូវគ្រីស្ទគឺជាផ្លូវត្រឹមត្រូវ* ។បន្ទាប់មក សូមឲ្យសិស្សម្នាក់ៗស្រាវជ្រាវ នីហ្វៃទី ២ ២៥:២០, ២៣–២៦ ដោយស្វែងរកពីមូលហេតុដែលថាការជឿទៅលើព្រះយេស៊ូវគ្រីស្ទគឺជាផ្លូវត្រឹមត្រូវ ។ សូមអញ្ជើញពួកគេឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ក្រោមចំណងជើងដែលអ្នកបានសរសេរ ។ ចម្លើយអាចរួមមានដូចខាងក្រោម ៖

សេចក្តីសង្គ្រោះមកតាមរយៈព្រះយេស៊ូវគ្រីស្ទតែប៉ុណ្ណោះ ។

ដោយសារតែព្រះយេស៊ូវគ្រីស្ទ យើងអាចត្រូវបានសង្គ្រោះដោយព្រះគុណ ក្រោយពីអ្វីទាំងអស់ដែលយើងអាចធ្វើបាន ។

តាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ យើងអាចទទួលបានការផ្តាច់បាបរបស់យើង ។

> **នីហ្វៃទី ២ ២៥:២៣, ២៦** គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំវានៅក្នុងព្រះគម្ពីររបស់ពួកគេ ។ សូមបើកទៅគំនិតសម្រាប់ការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណាននៅវគ្គនេះ ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ២៥:២៣ និងនីហ្វៃទី ២ ១០:២៤ឮៗ ។ សូមបង្ហាញថា ខគម្ពីរទាំងនេះរួមមានពាក្យ *ស្រុះស្រួល* ដែលមានន័យដើម្បីនាំមនុស្ស ឬ វត្ថុនានាមកជាសុខស្រួល ឬ ព្រមព្រៀងនឹងគ្នា ។

- នៅក្នុងខគម្ពីរទាំងពីរនេះ ព្យាការីលើកទឹកចិត្តយើងឲ្យស្រុះស្រួលខ្លួនយើងទៅនឹងព្រះ ។ តើអ្នកគិតថា វាមានន័យយ៉ាងណាដែរ ?

សូមពន្យល់ថា ខគម្ពីរទាំងពីរនេះក៏រួមមានពាក្យ *ព្រះគុណ* ។ព្រះគុណគឺជាអំណោយមួយមកពីព្រះវរបិតាសួគ៌ដែលបានប្រទានតាមរយៈព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ។ ពាក្យ *ព្រះគុណ* ដូចដែលបានប្រើនៅក្នុងព្រះគម្ពីរ សំដៅជាចម្បងទៅលើ

អំណាចដែលអាចធ្វើអ្វីគ្រប់យ៉ាង និង ការព្យាបាលខាងវិញ្ញាណដែលបានផ្តល់តាមរយៈសេចក្តីមេត្តាករុណា និង សេចក្តីស្រឡាញ់របស់ព្រះយេស៊ូវគ្រីស្ទ ។

- តើនីហ្វៃទី ២ ១០:២៤ និង ២៥:២៣ បង្រៀនអ្វីខ្លះអំពីទំនាក់ទំនងរវាងព្រះគុណ និង ការខិតខំរបស់យើង ?

សូមអញ្ជើញសិស្សឲ្យអនុវត្តអ្វីដែលពួកគេបានរៀន ដោយការសរសេរចម្លើយទៅនឹងសំណួរខាងក្រោមនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ អ្នកអាចសរសេរសំណួរនៅលើក្តារខៀន ។

- តើវាមានន័យចំពោះអ្នកយ៉ាងណា ដើម្បីបានសង្គ្រោះដោយព្រះគុណនោះ ?

ដើម្បីជួយសិស្សឲ្យយល់ពីការពោលអះអាងរបស់នីហ្វៃនៅក្នុង នីហ្វៃទី ២ ២៥:២៤–២៥ថា ច្បាប់បានស្លាប់ចំពោះប្រជាជនរបស់គាត់ សូមពន្យល់ថា គាត់យោងទៅលើច្បាប់ម៉ូសេ ។ ច្បាប់នោះ ដោយមានប្រព័ន្ធរបស់វានៃការប្រារព្ធ ពិធីបុណ្យ និមិត្តសញ្ញា និង បញ្ញត្តិ ដែលរួមមានការធ្វើយញ្ញបូជាសត្វ គឺនៅតែមានអនុវត្តអំឡុងជំនាន់របស់នីហ្វៃ ។ នីហ្វៃ និង អ្នកផ្សេងបានដឹងថា ច្បាប់នេះនឹងត្រូវបានបំពេញតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ក្រោយពីដង្វាយធួន សាវកបស់ព្រះអង្គសង្គ្រោះលែងត្រូវកាន់តាមច្បាប់ម៉ូសេទៀតហើយ ។ ប៉ុន្តែសាសន៍នីហ្វៃដែលស្មោះត្រង់ជាច្រើននៅបន្តគោរពតាមច្បាប់នេះនៅពេលនេះ ទោះជាដឹងថាច្បាប់នាពេលបច្ចុប្បន្ននេះនឹងត្រូវជំនួសនៅថ្ងៃណាមួយនោះក៏ដោយ ។

នៅពេលនីហ្វៃបាននិយាយថា ច្បាប់នេះបានស្លាប់ដល់គាត់ និង អ្នកផ្សេង គាត់ចង់មានន័យថា ច្បាប់នេះនឹងមិនសង្គ្រោះពួកគេនោះទេ ។ ពួកគេបានរក្សាច្បាប់នេះ ដោយសារពួកគេចង់ក្លាយជាមនុស្សដែលគោរពតាម ហើយដោយសារពួកគេបានដឹងថាច្បាប់នេះបានបង្ហាញពួកគេដល់ព្រះយេស៊ូវគ្រីស្ទ ដែលនឹងនាំសេចក្តីសង្គ្រោះមកដល់ពួកគេ ។

- តើយើងអាចរៀនអ្វីខ្លះពី នីហ្វៃទី ២ ២៥:២៣–២៦ អំពីមូលហេតុដែលយើងត្រូវរក្សាព្រះបញ្ញត្តិទាំងឡាយនោះ ?
- តើអ្នកនឹងធ្វើអ្វីខ្លះដើម្បី « និយាយអំពីព្រះគ្រីស្ទ » និង « អរអរការាយក្នុងព្រះគ្រីស្ទ » ? (នីហ្វៃទី ២ ២៥:២៦) ។ តើអ្នកនឹងធ្វើអ្វីដើម្បីជួយអ្នកដទៃឲ្យជឿលើព្រះគ្រីស្ទ ?

សូមឲ្យសិស្សចែកចាយពីវគ្គដែលពួកគេបានរកឃើញថា នឹងជួយពួកគេឲ្យឆ្លើយនឹងការនិយាយថា ពួកបរិសុទ្ធថ្ងៃចុងក្រោយមិនបានជឿទៅលើព្រះយេស៊ូវគ្រីស្ទទេនោះ ។ សូមឲ្យពួកគេប្រាប់អំពីមូលហេតុដែលពួកគេចូលចិត្តវគ្គគម្ពីរទាំងនេះ ។

សូមថ្លែងទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតដែលអ្នកបានពិភាក្សានៅថ្ងៃនេះ ។ អ្នកក៏អាចឲ្យឱកាសដល់សិស្សដើម្បីថ្លែងទីបន្ទាល់អំពីសេចក្តីពិតទាំងនេះដែរ ។

សូមលើកទឹកចិត្តសិស្សឲ្យចែកចាយទីបន្ទាល់

នៅពេលសិស្សស្តាប់ទីបន្ទាល់គ្នាទៅវិញទៅមកអំពីសេចក្តីពិតនៃដំណឹងល្អ ពួកគេអាចពង្រីកការយល់ដឹងរបស់ពួកគេអំពីគោលការណ៍នៃដំណឹងល្អ និង បំណងរបស់ពួកគេដើម្បីអនុវត្តគោលការណ៍ទាំងនេះនៅក្នុងជីវិតរបស់ពួកគេ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេនៅក្នុងថ្នាក់ដោយការសួរសំណួរដោយចាប់ផ្តើមជាមួយនឹងឃ្លាដូចជា « តើអ្នកទទួលបានទីបន្ទាល់របស់អ្នកអំពី . . . ដោយរបៀបណា» ឬ « តើនៅពេលណាដែលអ្នកដឹងលើកដំបូងថា . . . » ឬ « តើអ្នកពន្យល់ឬ ថ្លែងទីបន្ទាល់អំពី . . . ដោយរបៀបណា » ។ ក្រោយពីសិស្សម្នាក់បានថ្លែងទីបន្ទាល់នៃសេចក្តីពិតហើយនោះ អ្នកអាចសួរថា « តើមាននរណាទៀតដែលអាចថ្លែងទីបន្ទាល់អំពីសេចក្តីពិតនេះ ? »

ចំណេះចំណានខគម្ពីរ— នីហ្វៃទី ២ នីហ្វៃទី ២៥:២៣, ២៦

កំណត់ចំណាំ ៖ សូមគិតពីការប្រើគំនិតក្នុងការបង្រៀនដូចខាងក្រោម អំឡុងពេលផ្នែកចុងក្រោយបង្អស់នៃមេរៀននេះ ។ ប្រសិនបើអ្នកមិនមានពេលវេលាដើម្បីប្រើគំនិតនេះនៅក្នុងមេរៀននេះទេ អ្នកអាចប្រើវានៅក្នុងមេរៀនក្រោយទៀតជាការរំឭកបាន ។

ដើម្បីជួយសិស្សឲ្យទន្ទេញចាំ នីហ្វៃទី ២ ២៥:២៦ ជាខគម្ពីរមួយនៅក្នុងវគ្គចំណេះចំណានខគម្ពីរនេះ សូមសរសេរដូចខាងក្រោមនៅលើក្តារខៀន ៖

និយាយ

អរអរការាយ

ផ្សាយ

ព្យាការ

សរសេរ

ដើម្បីឲ្យកូនចៅយើង . . .

តើត្រូវស្វែងរកប្រភពណាមួយ . . .

ដើម្បីឲ្យបានផ្គាច់ចាប . . .

សូមអញ្ជើញសិស្សឲ្យប្រើពាក្យបង្ហាញនៅលើក្តារខៀនដើម្បីទន្ទេញ នីហ្វៃទី ២ ២៥:២៦ ។ ក្រោយពីការសូត្រខគម្ពីរនេះឡើងវិញពីរបីដងហើយ សូមសួរបើសិនជាមាននរណាមួយនៅក្នុងថ្នាក់ចង់សាកសូត្រខគម្ពីរនេះដោយចាំមាត់ ។ បន្ទាប់មក សូមអញ្ជើញសិស្សទាំងអស់គ្នានៅក្នុងថ្នាក់ទន្ទេញខគម្ពីរនេះរួមគ្នា ដោយមិនមើលទៅក្តារខៀន ។ ដើម្បីបញ្ចប់ អ្នកអាចស្នើថា វាមានតម្លៃក្នុងការស្តាប់ដោយប្រុងប្រយ័ត្ននៅពេលឪពុកម្តាយ អ្នកដឹកនាំ និង គ្រូបង្រៀនទាំងឡាយបម្រើដើម្បីបញ្ចុះបញ្ចូលយើងឲ្យសំឡឹងទៅព្រះអង្គសង្គ្រោះ ។

សូមចែកក្រដាសមួយសន្លឹកដល់សិស្សម្នាក់ៗ ។ សូមអញ្ជើញសិស្សឲ្យសរសេរសំបុត្រមួយទៅកូនៗរបស់ពួកគេនាពេលអនាគត ដោយលើកទឹកចិត្តពួកគេឲ្យដាក់ជីវិតរបស់ពួកគេជាស្នូលលើព្រះយេស៊ូវគ្រីស្ទ ។ សិស្សអាចចង់ដាក់សំបុត្ររបស់ពួកគេនៅក្នុងព្រះគម្ពីររបស់ពួកគេ ដើម្បីទុកវាសម្រាប់អនាគត ។

មេរៀនសិក្សានៅផ្ទះ

នីហ្វៃទី២ ១១–២៥ (មេរៀនទី ៧)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនការសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

ការសង្ខេបខាងក្រោមនៃគោលលទ្ធិ និង គោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេសិក្សា នីហ្វៃទី ២ ១១–២៥ (មេរៀនទី ៧) មិនមែនធ្វើឡើងដើម្បីបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីតែប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកពិចារណាពីតម្រូវការសិស្សរបស់អ្នក ។

ថ្ងៃទី ១ (នីហ្វៃទី២ ១១–១៦)

អេសាយបានពិពណ៌នាពីអំនួត និង ភាពទុច្ចរិតរបស់សាសន៍អ៊ីស្រាអែលពីបុរាណ និង ការកាត់សេចក្តីដែលរង់ចាំពួកគេ ។ គាត់ក៏បានព្យាករពីព្រះវិហារបរិសុទ្ធមួយដែលនឹងត្រូវកសាងឡើងនៅក្នុងថ្ងៃចុងក្រោយ និង បានបង្រៀនថា ព្រះបានស្តាប់នាព្រះវិហារបរិសុទ្ធដើម្បីបង្រៀនយើងពីរបៀបរបស់ទ្រង់ និង ជួយយើងឲ្យដើរនៅក្នុងផ្លូវរបស់ទ្រង់ ។ អេសាយបានឃើញព្រះអម្ចាស់ និង ត្រូវបានសម្អាតចេញពីអំពើបាប ។ ចេញពីបទពិសោធន៍របស់អេសាយ សិស្សបានដឹងថា យើងអាចត្រូវបានសម្អាតចេញពីភាពមិនស័ក្តិសមរបស់យើងបានតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។

ថ្ងៃទី ២ (នីហ្វៃទី២ ១៧–២០)

អេសាយបានដាក់ទោសនគរយូដាដោយសារការមិនបានដាក់ទីទុកចិត្តរបស់ពួកគេទៅលើព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ សិស្សបានដឹងថា ព្រះនឹងគង់នៅជាមួយនឹងយើង នៅពេលយើងដាក់ទីទុកចិត្តទៅលើទ្រង់ ទោះជាអំឡុងពេលពិបាក និង ភ័យខ្លាចក្តី ។ អេសាយបានពិពណ៌នាពីការបំផ្លាញនៃពួកទុច្ចរិត នាពេលយាងមកជាលើកទីពីរ និង បានបង្រៀនថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះនៃការកាត់សេចក្តី និង សេចក្តីមេត្តាករុណាមួយ ហើយសេចក្តីមេត្តាករុណារបស់ទ្រង់ត្រូវបានសន្ធឹងទៅដល់អស់អ្នកទាំងឡាយណាដែលប្រែចិត្ត និង កាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ ។

ថ្ងៃទី ៣ (នីហ្វៃទី២ ២១–២៤)

នៅក្នុងមេរៀននេះ សិស្សបានដឹងថា ព្រះយេស៊ូវគ្រីស្ទ នឹងកាត់សេចក្តីនៅក្នុងភាពសុចរិត ហើយថានៅទីបញ្ចប់ តាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ ព្រះអម្ចាស់នឹងស្តារឡើងវិញនូវសាសនាចក្ររបស់ទ្រង់ដើម្បីប្រមូលវាស្រួរបស់ទ្រង់នៅក្នុងថ្ងៃចុងក្រោយនោះ ។ នីហ្វៃក៏ពីការព្យាចំពោះការព្យាកររបស់លោកអេសាយថា អំឡុងសហសវត្សន៍ភាពសុខសាន្ត និងចំណេះដឹងអំពីព្រះអម្ចាស់នឹងមានពេញផែនដី ។ សិស្សត្រូវបានលើកទឹកចិត្តឲ្យគិតអំពីសេចក្តីពិតនេះ និងរបៀបដែលពួកគេអាចបានរៀបចំកាន់តែល្អសម្រាប់គ្រានេះ ។

ថ្ងៃទី ៤ (នីហ្វៃទី២ ២៥)

នៅពេលនីហ្វៃសង្ខេបសារលិខិតសំខាន់នៃការសរសេររបស់អេសាយ គាត់បានព្រមានពីសេចក្តីពិតសាមញ្ញដែលទាក់ទងនឹងកិច្ចការរបស់ព្រះក្នុងចំណោមកូនចៅមនុស្ស ថា ៖ ព្រះយេស៊ូវគ្រីស្ទគឺជានាមតែមួយគត់នៅក្រោមមេឃនេះ ៖ « ដែលមនុស្សអាចបានសង្គ្រោះ » (នីហ្វៃទី ២ ២៥:២០) ហើយព្រះយេស៊ូវគ្រីស្ទគឺជាប្រភពតែមួយគត់ដែលយើងអាចសង្ឃឹងទៅសម្រាប់ការផ្តាច់បាបរបស់យើង ។ នីហ្វៃចង់ឲ្យមនុស្សគ្រប់គ្នាដឹងថា ប្រសិនបើយើងធ្វើ « អ្វីៗទាំងអស់ដែលយើងអាចធ្វើបាន » នោះព្រះយេស៊ូវគ្រីស្ទនឹងប្រទានពរដល់យើងដោយព្រះគុណ —ជាជំនួយ និង កម្លាំងដ៏ទេវភាព (សូមមើល នីហ្វៃទី ២ ២៥:២៣) ។

សេចក្តីផ្តើម

សប្តាហ៍នេះ សិស្សបានសិក្សាពីជំពូកជម្រើសក្នុងអេសាយដែលនីហ្វៃបានបញ្ចូលនៅក្នុងការសរសេររបស់គាត់ ។ ប្រធាន ប៊ិចដ៍ ឃេ. ផាកគី នៃក្រុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍អំពីជំពូកអេសាយទាំងនេះថា ៖ « ចូរកុំឈប់អានឡើយ ! ចូរខិតខំអានឱ្យផុតជំពូកដ៏ពិបាកយល់ទាំងឡាយនោះ ដែលជាការព្យាការណ៍នៃព្រះគម្ពីរសញ្ញាចាស់នោះ ទោះបីជាអ្នកអាចយល់វាតែបន្តិចក៏ដោយ ។ សូមបន្តអាន ប្រសិនបើអ្វីទាំងអស់ដែលអ្នកធ្វើគ្រាន់តែអានត្រួសៗ ហើយគ្រាន់តែប្រមែប្រមូលការបំផុសពីនេះ ពីនោះ » (« The Things of My Soul » *Ensign*ខែ ឧសភា ឆ្នាំ ១៩៨៦ ទំព័រ ៦១) ។

នៅពេលអ្នកជួបនឹងសិស្សនៅសប្តាហ៍នេះ សូមលើកទឹកចិត្តពួកគេឲ្យអត់ធ្មត់នៅពេលពួកគេសិក្សាពាក្យពេចន៍របស់អេសាយ ។ អ្នកក៏អាចអញ្ជើញពួកគេឲ្យចែកចាយពីរបៀបដែលការសរសេររបស់អេសាយបានជួយដល់ពួកគេ « លើកចិត្តគេឡើង ហើយអរសប្បាយ » នៅក្នុងភាពល្អរបស់ព្រះ (នីហ្វៃទី ២ ១១:៨) ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ១១–២៥

នីហ្វៃដកស្រង់ការព្យាករណ៍របស់អេសាយអំពីព្រះយេស៊ូវគ្រីស្ទ

សូមបង្ហាញកែវពង្រីកមួយ ឬ សូមគូសរូបភាពកែវពង្រីកមួយនៅលើក្តារខៀន ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន នីហ្វៃទី ២ ២៥:១៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកអ្វីដែលនីហ្វៃ « ពង្រីក » ។ សូមពន្យល់ថា ហេតុផលមួយដែលនីហ្វៃបានកត់ត្រាពាក្យពេចន៍របស់អេសាយដែលត្រូវបានរកឃើញនៅក្នុង នីហ្វៃទី ២ ១១–២៥ គឺដើម្បីពង្រីកនាម ការបម្រើ និង ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទនៅក្នុងជីវិតរបស់អ្នកទាំងឡាយណាដែលបានអានពាក្យរបស់នីហ្វៃ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ១១:៤–៨ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកឃ្លាដែលសម្គាល់គោលបំណងរបស់នីហ្វៃក្នុងការដកស្រង់ពាក្យពេចន៍របស់អេសាយ ។

នៅក្នុងការសិក្សានៅផ្ទះរបស់ពួកគេ សិស្សត្រូវសុំឲ្យគូសសម្គាល់នាម « ព្រះគ្រីស្ទ » រាល់ពេលដែលវាលេចនៅក្នុង នីហ្វៃទី ២ ២៥:២០–៣០ ។ សូមអញ្ជើញពួកគេឲ្យបើកទៅ នីហ្វៃទី ២ ២៥:២៨–២៩ ហើយរកមើលឃ្លាមួយដែលច្រំដែលនៅក្នុងខគម្ពីរទាំងនេះ ។ (« ផ្លូវត្រឹមត្រូវគឺជឿដល់ព្រះគ្រីស្ទ ហើយមិនបដិសេធទ្រង់ឡើយ ») ។

សូមសួរសិស្ស ៖ តើបទពិសោធន៍អ្វីនៅក្នុងជីវិតអ្នកដែលបានបង្រៀនអ្នកថា ការជឿលើ និង ការធ្វើតាមព្រះយេស៊ូវគ្រីស្ទគឺជាផ្លូវត្រឹមត្រូវដើម្បីរស់នៅនោះ ?

បញ្ជីខាងក្រោមរួមមានសេចក្តីពិត គោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលសិស្សបានសិក្សានៅក្នុង នីហ្វៃទី ២ ១១–២៥ នៅសប្តាហ៍នេះ ។ សូមសរសេរប្រយោគប្រាំបួនខាងក្រោមដាក់លើក្តារខៀន ឬ សូមបញ្ចូលវានៅក្នុងក្រដាសចែកឲ្យសិស្សម្នាក់ ។ សូមអញ្ជើញសិស្សឲ្យអានបញ្ជី ហើយស្វែងរកសេចក្តីពិត គោលលទ្ធិ និង គោលការណ៍ទាំងនេះនៅក្នុងខគម្ពីរដាក់មកនេះ ។

ការយល់ពីការបង្រៀនរបស់អេសាយនៅក្នុងជំនាន់របស់យើង

១ .ព្រះបានស្តាប់នាព្រះវិហារបរិសុទ្ធដើម្បីបង្រៀនយើងពីរបៀបរបស់ទ្រង់ និង ដើម្បីជួយយើងឲ្យដើរតាមផ្លូវរបស់ទ្រង់ (សូមមើល នីហ្វៃទី ២ ១២:២–៣) ។

២ .យើងអាចត្រូវបានសម្អាតចេញពីភាពមិនស័ក្តិសមរបស់យើងតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល នីហ្វៃ២ ១៦:៥–៧) ។

៣ .ព្រះនឹងគង់នៅជាមួយនឹងយើង នៅពេលយើងទុកចិត្តលើទ្រង់ ទោះបីជាក្នុងពេលលំបាក និង ភ័យខ្លាចក្តី (សូមមើល នីហ្វៃ២ ១៧:៤, ៧, ១៤) ។

៤ .ព្រះយេស៊ូវគ្រីស្ទគឺជាព្រះនៃការកាត់សេចក្តី និង សេចក្តីមេត្តាករុណាមួយ ។ សេចក្តីមេត្តាករុណារបស់ទ្រង់ ត្រូវបានពង្រីកទៅអស់អ្នកទាំងឡាយណាដែលប្រែចិត្ត និង កាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ (សូមមើល នីហ្វៃ២ ១៩:១២, ១៧, ២១; ២០:៤) ។

៥ .ព្រះអម្ចាស់បានស្តារឡើងវិញនូវដំណឹងល្អរបស់ទ្រង់ និង សាសនាចក្ររបស់ទ្រង់តាមរយៈ ព្យាការីយ៉ូសែប ស្ម៊ីធ ហើយឥឡូវនេះកំពុងប្រមូលប្រជាជនរបស់ទ្រង់នៅក្នុងជំនាន់ចុងក្រោយ (សូមមើល នីហ្វៃទី ២ ២១:១០, ១២) ។

៦ .ពេលថ្ងៃសហស្សវត្សរ៍មកដល់ ផែនដីនឹងក្លាយជាកន្លែងមួយដែលមានសន្តិភាព ដោយសារវានឹងពោរពេញទៅដោយចំណេះដឹងអំពីព្រះអម្ចាស់ (សូមមើល នីហ្វៃទី ២ ២១:៦–៩) ។

៧ .ព្រះអម្ចាស់នឹងអាណិតអាសូរដល់រាស្ត្ររបស់ទ្រង់ តែពួកទុច្ចរិតត្រូវតែវិនាស (សូមមើល នីហ្វៃទី ២ ២៣:២២) ។

ការបង្រៀនរបស់នីហ្វៃ

៨ .ដោយសារតែព្រះយេស៊ូវគ្រីស្ទ យើងអាចបានសង្គ្រោះដោយព្រះគុណបន្ទាប់ពីអ្វីៗទាំងអស់ដែលយើងអាចធ្វើបាន (សូមមើល នីហ្វៃទី ២ ២៥:២៣) ។

៩ .តាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ យើងអាចទទួលបានការផ្តាច់បាបរបស់យើង (សូមមើល នីហ្វៃទី ២ ២៥:២៦) ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើអ្នកឃើញគោលគំនិតអ្វី នៅក្នុងការបង្រៀនទាំងនេះពីអេសាយ និង នីហ្វៃ ? (គោលគំនិតដែលអាចមានគឺ ៖ ព្រះវរបិតាសួគ៌បានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ដើម្បីពង្រីកសេចក្តីសង្គ្រោះ និង សេចក្តីសុខសាន្តដល់កូនចៅរបស់ទ្រង់ ។ យើងអាចទុកចិត្តលើព្រះនៅគ្រប់កាលៈទេសៈទាំងអស់ ។ ព្រះវិហារបរិសុទ្ធបង្រៀនយើងអំពីព្រះ) ។
- តើប្រយោគទាំងប្រាំបួននេះមួយណា ដែលអ្នកឃើញថាមានន័យបំផុតនោះ ? ហេតុអ្វី ?

សូមចាត់តាំងសិស្សម្នាក់ឲ្យតាមគោលលទ្ធិ ឬ គោលការណ៍មួយចេញពីបញ្ជីខាងលើ ហើយសូមឲ្យសិស្សធ្វើដូចខាងក្រោម ៖

១ .អានវគ្គព្រះគម្ពីរដែលគោលលទ្ធិ ឬ គោលការណ៍បានដកយកមក ។

២ .ឆ្លើយសំណួរនេះ ៖ តើគោលលទ្ធិ ឬ គោលការណ៍នេះអាចជួយអ្នកឲ្យ « ត្រេកអរ » នៅក្នុងព្រះអម្ចាស់បានដោយរបៀបណា ? (សូមមើល នីហ្វៃទី ២ ១១:៤–៦) ។

៣ .សូមគិតអំពីកាលៈទេសៈមួយដែលការមានចំណេះដឹងអំពីគោលលទ្ធិ ឬ គោលការណ៍នេះអាចនាំសេចក្តីសង្ឃឹម និង កម្លាំងមកដល់អ្នក ។

សូមអញ្ជើញសិស្សឲ្យចែកចាយគំនិតរបស់ពួកគេ ។ នៅពេលពួកគេធ្វើដូច្នោះ អ្នកអាចសួរថា « តើមាននរណាទៀតមានទីបន្ទាល់ ឬ ការយល់ដឹងមួយអំពីអ្វីដែលទើបតែបានបង្រៀននេះ ? »

ការឲ្យពួកគេចែកចាយការយល់ដឹង និង ទីបន្ទាល់នឹងបញ្ជាក់ពីសេចក្តីពិតដល់ដួងចិត្តរបស់ពួកគេ និង ដល់ដួងចិត្តរបស់មិត្តភក្តិរបស់ពួកគេ ។ សូមអរគុណពួកគេសម្រាប់ការចូលរួម ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ២៥:១៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់អានតាមដោយស្វែងរកហេតុផលដែលនីហ្វៃត្រេកអរនៅក្នុងការពង្រីកព្រះនាមរបស់ព្រះអម្ចាស់ ។ សូមឲ្យសិស្សប្រាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមអញ្ជើញសិស្សម្នាក់អានទីបន្ទាល់ខាងក្រោមដោយប្រធាន ចូម៉ាស អេស. ម៉នសុន ៖

« ខ្ញុំជឿថាគ្មាននរណាម្នាក់ក្នុងចំណោមយើងអាចនឹកស្មានដល់អំពីអ្វីដែលព្រះគ្រីស្ទបានធ្វើសម្រាប់យើងនៅក្នុងច្បារគែតសេម៉ានីនោះទេ ប៉ុន្តែខ្ញុំមានអំណរដោរៀងរាល់ថ្ងៃក្នុងជីវិតរបស់ខ្ញុំចំពោះពលិកម្មដ៏ធួនរបស់ទ្រង់ជំនួសយើង ។

« នៅវិនាទីចុងក្រោយ ទ្រង់អាចត្រឡប់ក្រោយបាន ។ ប៉ុន្តែទ្រង់មិនបានត្រឡប់ទេ ។ ទ្រង់បានឆ្លងកាត់អ្វីៗទាំងអស់ ដើម្បីឲ្យទ្រង់អាចសង្គ្រោះអ្វីៗទាំងអស់បាន ។ ដោយការធ្វើដូច្នោះ ទ្រង់ប្រទានដល់យើងនូវជីវិតដែលហួសពីការរស់នៅក្នុងជីវិតរមែងស្លាប់នេះ ។ ទ្រង់បានលើកយើងចេញពីការធ្លាក់របស់អ័ដាម ។

« ខ្ញុំមានអំណរគុណចំពោះទ្រង់ ដោយអស់ពីជម្រៅនៃព្រលឹងរបស់ខ្ញុំ ។ ទ្រង់បានបង្រៀនយើងពីរបៀបដើម្បីរស់នៅ ។ ទ្រង់បានបង្រៀនយើងពីរបៀបដើម្បីស្លាប់ ។ ទ្រង់បានធានាសេចក្តីសង្គ្រោះរបស់យើង » (« At Parting » *Ensign* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ១១៤) ។

សូមសួរ ៖ តើមានភាពស្រដៀងគ្នាអ្វីដែលអ្នកឃើញរវាង៣ក្យរបស់នីហ្វៃនៅក្នុង នីហ្វៃទី ២ ២៥:១៣និង ៣ក្យ៣ក្យសម្តីរបស់ប្រធានម៉នសុន ?

សូមបញ្ចប់មេរៀនថ្ងៃនេះដោយការសុំសិស្សឲ្យពិចារណ៍នាពីរបៀបដែលពួកបរិសុទ្ធថ្ងៃចុងក្រោយ យៃក្មេង អាចពង្រីកព្រះនាមរបស់ព្រះអម្ចាស់ ។ ក្រោយពីសិស្សបានឆ្លើយហើយ សូមលើកទឹកចិត្តពួកគេឲ្យពង្រីកព្រះនាមរបស់ព្រះអម្ចាស់ជារៀងរាល់ថ្ងៃ ។

មេរៀនក្រោយ (នីហ្វៃទី ២ ២៦–៣១)

នៅក្នុងមេរៀនក្រោយ សិស្សនឹងសិក្សាការព្យាករណ៍របស់នីហ្វៃខ្លះអំពីថ្ងៃចុងក្រោយ ។ នីហ្វៃបានឃើញថា សាសនាចក្រខុសឆ្គងទាំងឡាយ និង ការរួមគំនិតសម្ងាត់ទាំងឡាយនឹងមានច្រើន ។ គាត់ក៏បានឃើញថា ព្រះអម្ចាស់នឹងធ្វើ « ការណ៍មួយយ៉ាងអស្ចារ្យ ហើយចម្លែក » (នីហ្វៃទី ២ ២៧:២៦) ហើយថាមនុស្សជាច្រើនបានបដិសេធព្រះគម្ពីរមរមន ដោយសារពួកគេបានមានព្រះគម្ពីរបរិសុទ្ធរួចហើយ ។ បន្ថែមលើនេះ នីហ្វៃបានពន្យល់ពីគោលលទ្ធិរបស់ព្រះគ្រីស្ទ ។

នីហ្វៃទី ២ ២៦

សេចក្តីផ្តើម

នីហ្វៃបានព្យាករថា កូនចៅរបស់គាត់នឹងត្រូវព្រះយេស៊ូវគ្រីស្ទដែលបានរស់ឡើងវិញយាងមកជួបនៅថ្ងៃណាមួយ ហើយថាក្រោយពីបានជួបនឹងបទពិសោធន៍នេះ ពួកគេបានរស់នៅអស់បីជំនាន់ក្នុងភាពសុចរិត ។ ទោះជាយ៉ាងណាក្តី នីហ្វៃបានសោកសៅដែលនៅក្នុងជំនាន់ទីបួននៃពួកកូនចៅរបស់គាត់ ខ្លះបានធ្លាក់ចេញពីសេចក្តីសុចរិត បដិសេធព្រះមែស៊ី ហើយទីបំផុតក៏ត្រូវបានបំផ្លាញបង់ទៅ ។ នីហ្វៃបានព្រមានអស់អ្នកដែលរស់នៅក្នុងជំនាន់ចុងក្រោយពីអំនួត ការរួមគំនិតសម្ងាត់នានា និង ឧបាយកលផ្នែកសង្ឃ ។ គាត់បានបង្រៀនថា ព្រះអម្ចាស់ស្រឡាញ់មនុស្សទាំងអស់ ហើយអញ្ជើញពួកគេឲ្យមករកទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ២៦:១–១៣

នីហ្វៃព្យាករថា ប្រជាជនរបស់គាត់នឹងត្រូវបានបំផ្លាញ ដោយសារពួកគេនឹងបដិសេធព្រះយេស៊ូវគ្រីស្ទ

សូមសរសេរលើក្តារខៀននូវឃ្លា ការកាត់សេចក្តីរបស់ព្រះ ។

- តើនៅពេលណាដែលអ្នកឃើញ ឬ ឮឃ្លានេះ តើមានគំនិតអ្វីចូលមកក្នុងចិត្តអ្នក ?

សូមពន្យល់ថា ទោះបីជាមនុស្សជាច្រើនមានគំនិតអវិជ្ជមាននៅពេលពួកគេបានឃើញពាក្យទាំងនេះក្តី ក៏ការកាត់សេចក្តីនៃព្រះពិតជានាំមកនូវពរជ័យដល់មនុស្សជាច្រើនមែន ។ នៅក្នុង នីហ្វៃទី ២ ២៦ យើងអានអំពីលទ្ធផលដែលសេចក្តីយុត្តិធម៌បាននាំមកដល់ពួកទុច្ចរិត និង ដល់ពួកសុចរិត ។

ដើម្បីបង្កើតបរិបទសម្រាប់សារលិខិតដ៏សំខាន់នៃ នីហ្វៃទី ២ ២៦ នេះ សូមពន្យល់ថា នីហ្វៃបាននិយាយថាទីសម្គាល់ជាច្រើននឹងអមមកជាមួយនឹងការប្រសូត ការសុគត និង ការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ គាត់បានព្យាករថា មនុស្សជាច្រើននឹងត្រូវវិនាសភ្លាម មិនយូរក្រោយមកពីការសុគតរបស់ព្រះអង្គសង្គ្រោះ ដោយសារពួកគេបានបណ្តេញពួកព្យាការី និង អ្នកដើរតាមដ៏ស្មោះត្រង់របស់ព្រះយេស៊ូវគ្រីស្ទដែលបានរស់នៅក្នុងចំណោមពួកគេ ។ គាត់ក៏បានព្យាករថា ទោះបីជាក្រោយពីមានការយាងមករបស់ព្រះអង្គសង្គ្រោះដែលបានរស់ឡើងវិញហើយក្តី ភាគច្រើននៃកូនចៅរបស់គាត់បាន « រើសឲ្យកិច្ចការទាំងឡាយនៃសេចក្តីងងឹតជាជាងពន្លឺ » ហើយនឹងត្រូវបានបំផ្លាញ ។ (សូមមើល នីហ្វៃទី ២ ២៦:១–១១) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន នីហ្វៃទី ២ ២៦:៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកប្រតិកម្មរបស់នីហ្វៃចំពោះការនិមិត្តនៃការបំផ្លាញប្រជាជននេះ ។ សូមអញ្ជើញសិស្សឲ្យចែកចាយនូវអ្វីដែលពួកគេបានរកឃើញ ។ អ្នកអាចស្នើថា ពួកគេគួរតែគូសចំណាំការប្រកាសរបស់នីហ្វៃនៅចុងឃ្លានៃខគម្ពីរនេះ ៖ « ផ្លូវរបស់ទ្រង់ពិតជាត្រឹមត្រូវមែន ។ »

- តើប្រយោគ « ផ្លូវរបស់ទ្រង់ពិតជាត្រឹមត្រូវមែន » មានន័យយ៉ាងណាដែរចំពោះអ្នក ? (អ្នកគួរតែពន្យល់ថា នរណាម្នាក់ដែលត្រឹមត្រូវ នឹងតែងតែធ្វើដាក់មនុស្សផ្សេងដោយយុត្តិធម៌) ។

ក្រោយពីការជួយសិស្សឲ្យយល់ថា សេចក្តីយុត្តិធម៌របស់ព្រះតម្រូវឲ្យថា ពួកទុច្ចរិតនឹងត្រូវដាក់ទោសចំពោះសកម្មភាពរបស់ពួកគេ សូមពន្យល់ថាសេចក្តីយុត្តិធម៌របស់ព្រះក៏តម្រូវថា ពួកសុចរិតនឹងត្រូវបានរង្វាន់ចំពោះសកម្មភាពរបស់ពួកគេដែរ ។ ដោយសារជាផ្នែកនៃការពន្យល់នេះ អ្នកអាចអញ្ជើញសិស្សឲ្យអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣០:២០–២១ ។ សូមឲ្យសិស្សអាន នីហ្វៃទី ២ ២៦:៨–៩, ១៣ ដោយស្វែងរកពរជ័យដែលនីហ្វៃបាននិយាយថានឹងមកដល់កូនចៅសុចរិតរបស់គាត់ ។

- នៅក្នុងខទី ៨ និង ១៣ តើឃ្លាណាដែលពិពណ៌នាពីសកម្មភាពនៃពួកសុចរិតនោះ ?
- តើនៅពេលណាដែលអ្នកបានធ្វើជាសាក្សីពីពរជ័យដែលបានលើកឡើងនៅក្នុងខគម្ពីរទី ១៣ នោះ ? តើមានរបៀបខុសគ្នាណាខ្លះដែលព្រះអម្ចាស់បានសម្តែងព្រះអង្គទ្រង់ដល់យើង ?

សូមសរសេរគោលការណ៍ខាងក្រោមដាក់លើក្តារខៀន ៖ ***នៅពេលយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ទ្រង់នឹងសម្តែងព្រះអង្គទ្រង់ដល់យើងដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។***

- តើការដឹងពីសេចក្តីពិតនេះ អាចបង្កើនសេចក្តីជំនឿរបស់អ្នកទៅលើព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?

នីហ្វៃទី ២ ២៦:១៤–៣៣

នីហ្វៃព្យាករទាកទងនឹងថ្ងៃចុងក្រោយ ហើយអញ្ជើញមនុស្សទាំងអស់ឲ្យមករកព្រះគ្រីស្ទ

សូមសង្ខេប នីហ្វៃទី ២ ២៦:១៤–១៩ដោយការពន្យល់ថា នីហ្វៃបានព្យាករថា ព្រះគម្ពីរមរមនឹងលេចចេញមកនៅក្នុងថ្ងៃចុងក្រោយ អំឡុងពេលពេលមួយនៅពេលមនុស្សជាច្រើននឹងមានអំនួត និង មិនមានជំនឿ ។

សូមឲ្យសិស្សគិតអំពីពេលមួយ នៅពេលពួកគេជំពប់នឹងអ្វីមួយ (ឬ អ្នកអាចឲ្យពួកគេស្រមៃថាបានជំពប់នឹងឧបសគ្គមួយនៅក្នុងទីងងឹត) ។ សូមអញ្ជើញពួកគេឲ្យស្រាវជ្រាវ នីហ្វៃទី ២ ២៦:២០–២១ យ៉ាងស្ងាត់ស្ងៀម ដោយស្វែងរកឧបសគ្គដែលមនុស្សអាចនឹងជំពប់នៅក្នុងថ្ងៃចុងក្រោយនេះ ។

- យោងតាម នីហ្វៃទី ២ ២៦:២០–២១ តើឧបសគ្គអ្វីខ្លះដែលនីហ្វៃបានឃើញដែលនឹងបណ្តាលឲ្យសាសន៍ដទៃជំពប់ដួលនោះ ?
- តើគំរូនៃឧបសគ្គផ្សេងទៀតណាខ្លះដែលសាតាំងប្រើដើម្បីដឹកនាំមនុស្សឲ្យជំពប់នោះ ?

សូមពន្យល់ថា បន្ថែមលើការដាក់ « ថ្មជំពប់ » នៅលើផ្លូវរបស់យើងដើម្បីដឹកនាំយើងចេញពីព្រះ សាតាំងចង់ចងយើងទៀតផង ។ សូមលើកសរសៃអំបោះមួយសរសៃឡើង ហើយអញ្ជើញសិស្សឲ្យមើល នីហ្វៃទី ២ ២៦:២២ ដោយស្វែងរកអ្វីដែលនីហ្វៃបានសរសេរអំពីវត្ថុស្រដៀងគ្នានេះ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យឡើងមកខាងមុខថ្នាក់ ។ សូមចងកដៃសិស្សនោះរួមគ្នានឹងសរសៃអំបោះមួយសរសៃប៉ុណ្ណោះដោយចងរលង់ ។ សូមឲ្យគាត់ផ្តាច់អំបោះនោះ ។ សូមបន្តដំណើរការនេះ ពេលនេះដោយចងអំបោះជុំវិញកដៃគាត់បីបួនជុំ ។ សូមបន្តធ្វើដូច្នេះ រហូតដល់សិស្សនោះមិនអាចផ្តាច់អំបោះនោះបាន —ដោយដាស់តឿនសិស្សឲ្យប្រយ័ត្នកុំឲ្យមានរបួស ។ (ប្រសិនបើអ្នកមិនមានអំបោះទេ អ្នកអាចឲ្យសិស្សស្រមៃពីការបង្ហាញនេះបាន) ។ សូមឲ្យសិស្សសិក្សា នីហ្វៃទី ២ ២៦:២២ ដោយស្វែងរកពីរបៀបដែលខគម្ពីរទាក់ទងនឹងការបង្ហាញនេះ ។

- នៅក្នុង នីហ្វៃទី ២ ២៦:២២ តើអ្វីដែលសំខាន់អំពីឃ្លា « រហូតដល់វាចងពួកគេ » ? តើខគម្ពីរនេះបង្រៀនអ្នកអ្វីខ្លះ អំពីរបៀបដែលសាតាំងធ្វើការនោះ ?
- តើអ្នកធ្លាប់បានឃើញសាតាំងដឹកនាំមនុស្សដោយ « ខ្សែដាប់ » ដោយរបៀបណា ? (ដាប់ គឺជាសម្ភារមួយដែលគេប្រើដើម្បីធ្វើសំពត់ម៉្យាង) ។
- តើអំពើបាបទាំងនេះមួយណា (ខ្សែដាប់) ដែលអ្នកគិតថាមានគ្រោះថ្នាក់បំផុតដល់មនុស្សអាយុស្របាលអ្នក ?

សូមរំឭកសិស្សថា សាតាំងល្បួងយើងឲ្យធ្វើកិច្ចការខាងភាពងងឹត ដើម្បីវាអាចចងយើង ហើយនាំយើងចេញពីផ្លូវនៃសេចក្តីសុចរិត ។ សូមពន្យល់ថា ខគម្ពីរចុងក្រោយគេនៅក្នុង នីហ្វៃទី ២ ២៦ បង្ហាញពីភាពផ្ទុយគ្នាមួយរវាងផ្លូវរបស់សាតាំង និង ផ្លូវរបស់ព្រះ ។ សូមឲ្យសិស្សអាន នីហ្វៃទី ២ ២៦:២៣–២៨ដោយស្ងាត់ស្ងៀម ។

- យោងតាមខគម្ពីរទាំងនេះ តើព្រះអម្ចាស់ធ្វើកិច្ចការដោយរបៀបណា ? តើអ្វីជាគោលបំណងទាំងអស់ដែលព្រះអម្ចាស់ធ្វើនេះ ? (អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំថ្មែកនៃ នីហ្វៃទី ២ ២៦:២៤ ដែលបង្រៀនថា **អ្វីៗគ្រប់យ៉ាងដែលព្រះអម្ចាស់ធ្វើ គឺសម្រាប់ជាប្រយោជន៍ដល់មនុស្សលោក**) ។

សូមឲ្យសិស្សគិតអំពីពេលមួយនៅពេលពួកគេមានអារម្មណ៍ថាបាក់ទឹកចិត្ត ឬ ឃ្លាតឆ្ងាយពីព្រះអម្ចាស់ ។ ដើម្បីជួយសិស្សឲ្យមានអារម្មណ៍ថា សារលិខិតរបស់នីហ្វៃអំពីសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ អនុវត្តនៅក្នុងជីវិតរបស់ពួកគេ សូមអញ្ជើញពួកគេឲ្យសិក្សា នីហ្វៃទី ២ ២៦:២៤–២៨, ៣៣ ។ អ្នកអាចស្នើថា ពួកគេគួរតែគូសចំណាំពាក្យ *ទាំងអស់ ណាម្នាក់* និង *មិន* (លើកលែងតែគំរូទីមួយនៃពាក្យ *មិន* នៅក្នុងខគម្ពីរទី ៣៣) ។ សូមឲ្យសិស្សចំណាយពេលពីរបីនាទីអានប្រយោគនេះដែលមានពាក្យទាំងនេះសារឡើងវិញ ។

សូមឲ្យសិស្សម្នាក់ៗបែរទៅសិស្សផ្សេងទៀតក្នុងថ្នាក់ ហើយពិភាក្សាដោយខ្លីៗពីអ្វីដែលយើងអាចយល់ពីខគម្ពីរទាំងនេះ ។ ក្រោយពីសិស្សបានចែកចាយគំនិតរបស់ពួកគេជាមួយនឹងគ្នាហើយ សូមគិតពីការអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីគំនិតសំខាន់បំផុតនៃការសន្ទនារបស់ពួកគេ ។ គំនិតសំខាន់បំផុតមួយដែលអាចចេញមកពីការពិភាក្សាគ្នានេះគឺថា **ព្រះអម្ចាស់ស្រឡាញ់មនុស្សទាំងអស់គ្នា ហើយអញ្ជើញឲ្យមនុស្សទាំងអស់ចូលមករកទ្រង់ ហើយទទួលទានសេចក្តីសង្គ្រោះរបស់ទ្រង់ ។** អ្នកអាចសរសេរប្រយោគនេះដាក់លើក្តារខៀន ។ អ្នកក៏អាចអញ្ជើញសិស្សឲ្យសរសេរចម្លើយចំពោះសំណួរខាងក្រោមនេះនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេររបស់ពួកគេដែរ ៖

- តើនៅពេលណាដែលអ្នកបានស្គាល់សេចក្តីល្អរបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់អ្នក ?
- តើវាអាចជួយអ្នកឲ្យដឹងថា ព្រះអម្ចាស់ស្រឡាញ់មនុស្សទាំងអស់គ្នា ហើយអញ្ជើញមនុស្សទាំងអស់ឲ្យចូលមករកទ្រង់ដោយរបៀបណា ?

ដើម្បីបញ្ចប់ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន នីហ្វៃទី ២ ២៦:២៥, ៣៣ ឮៗ ។ មុនពេលគាត់ ឬនាងអាន សូមស្នើថា សិស្សគួរតែគូសចំណាំឃ្លាដែលលើកទឹកចិត្តដល់ពួកគេ ។ ដើម្បីជួយសិស្សឲ្យឃើញពីការអនុវត្តន៍បន្ថែមមួយនៅក្នុងខគម្ពីរនេះ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរ អេស. អុជដូហ្វ នៃគណៈប្រធានទីមួយ ៖

« ខ្ញុំសង្ឃឹមថា យើងស្វាគមន៍ និង ស្រឡាញ់កូនចៅរបស់ព្រះទាំងអស់ រួមទាំងអស់អ្នកណាដែលអាចស្លៀកពាក់ មើល និយាយ ឬ គ្រាន់តែធ្វើរឿងអ្វីៗខុសគ្នានោះ ។ វាមិនល្អទេ ដែលធ្វើឲ្យអ្នកដទៃមានអារម្មណ៍ថាពួកគេមិនគ្រប់គ្រាន់នោះ ។ ចូរយើងលើកអ្នកទាំងឡាយដែលនៅជុំវិញយើងឡើង ។ ចូរយើងសន្ទឹងដៃស្វាគមន៍ឡើង ។ ចូរយើងផ្តល់ដល់បងប្អូនប្រុសស្រីនៅក្នុងសាសនាចក្ររបស់យើងនូវរង្វាស់ដ៏ពិសេសមួយនៃមនុស្សធម៌ សេចក្តីមេត្តាករុណា និង សប្បុរសធម៌ ដើម្បីឲ្យពួកគេមានអារម្មណ៍ថាពួកគេបានរកឃើញផ្ទះមួយក្នុងពេលដ៏យូរនៅទីបញ្ចប់នេះ ។ . . .

« វាហាក់ដូចជាត្រឹមត្រូវ និង សមរម្យតែថា យើងលាតត្រដាងដល់អ្នកផ្សេងដូចជាយើងមានបំណងដោយស្មោះអស់ពីចិត្តសម្រាប់ខ្លួនយើងដែរ ។

« ខ្ញុំមិនបានស្នើថា យើងទទួលយកអំពើបាប ឬ មើលរំលងអំពើអាក្រក់នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់យើងឬ នៅក្នុងពិភពលោកនោះទេ ។ ហេតុដូច្នេះហើយ នៅក្នុងបំណងដ៏អោះមុតរបស់យើង ពេលខ្លះយើងយល់ច្រឡំអំពើបាបជាមួយនឹងអ្នកធ្វើបាប ហើយយើងដាក់ទោសលឿនពេក ហើយដោយមានសេចក្តីមេត្តាករុណាតិចតួចបំផុត ។ . . .

ការអញ្ជើញសិស្សឲ្យធ្វើសកម្មភាព

ជាធម្មតា ការបង្រៀនដ៏មានប្រសិទ្ធិភាពរួមមានការអញ្ជើញឲ្យធ្វើសកម្មភាពមួយចំពោះគោលការណ៍ដែលបានបង្រៀនហើយ ។ ប្រសិនបើចំណេះដឹងអំពីគោលការណ៍នៃដំណឹងល្អមួយត្រូវបានសិក្សា ប៉ុន្តែមិនបានធ្វើសកម្មភាពនោះទេ ការសិក្សានោះមិនបានពេញលេញឡើយ ។ ការអញ្ជើញឲ្យធ្វើសកម្មភាពអាចមកពីគ្រូបង្រៀន ហើយវាកាន់តែមានអំណាចដាងនេះនោះគឺមកពីព្រះវិញ្ញាណបរិសុទ្ធ ។

« . . . ចូរឲ្យដួងចិត្ត និង ដៃរបស់យើងលាតសន្ធឹងចេញនៅក្នុងសេចក្តីមេត្តាករុណាចំពោះអ្នកដទៃ ដោយសារមនុស្សគ្រប់រូបកំពុងដើរនៅលើផ្លូវដ៏ពិបាករៀងខ្លួនគាត់ » (« You Are My Hands » *Ensign*ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៦៨–៦៩) ។

- **តើយើងអាចអនុវត្ត នីហ្វៃទី ២ ២៦:៣៣ ហើយនិងការបង្រៀនរបស់ប្រធាន អុបដូហ្វ នោះ ដោយរបៀបណាខ្លះ ?**

សូមអញ្ជើញសិស្សឲ្យគិតអំពីអ្វីដែលពួកគេអាចធ្វើដើម្បីជួយអ្នកដទៃដែលត្រូវការជំនួយ ហើយជួយពួកគេឲ្យមានអារម្មណ៍ពីសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ ។

គំនិតជំនួយបន្ថែមដល់ការបង្រៀន

នីហ្វៃទី ២ ២៦:២៩–៣១ ។ នីហ្វៃព្រមានពីអំពើបាបនៃឧបាយកលផ្នែកសង្ឃ

សូមសរសេរឈ្មោះខាងក្រោមដាក់លើក្តារខៀន ៖ *សេរេម នីហ្វរ កូរីហ្វរ* ។សូមសួរសិស្សពីអ្វីដែលពួកគេដឹងអំពីបុរសទាំងនេះ ។ ប្រសិនបើសិស្សពិបាកឆ្លើយ សូមពន្យល់ដោយសង្ខេបថា បុរសទាំងនេះបានព្យាយាមដឹកនាំមនុស្សចេញពីសេចក្តីជំនឿទៅលើព្រះរបស់ស៊ូវគ្រីស្ទ ។ ពួកគេជាប់ទោសនៃអំពើបាបឧបាយកលផ្នែកសង្ឃ ។

នីហ្វៃបានព្រមានប្រជាជនរបស់គាត់ —និង ពួកយើងដែលរស់នៅក្នុងជំនាន់ចុងក្រោយ— អំពីឧបាយកលផ្នែកសង្ឃ ។ សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ២៦:២៩–៣១ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកនិយមន័យមួយនៃពាក្យឧបាយកលផ្នែកសង្ឃ ។

- តើអ្វីជាគោលដៅរបស់មនុស្សដែលពាក់ព័ន្ធនឹងឧបាយកលផ្នែកសង្ឃ ?

អែលឌើរ អិម. រ័សុល បាឡឺដ នៃក្រុមនៃពួកសាវកដប់ពីរនាក់បានហាមប្រាមថា ឧបាយកលផ្នែកសង្ឃអាចកើតឡើងនៅក្នុងសាសនាចក្របាន ។ សូមឲ្យសិស្សម្នាក់អានការប្រឹក្សារបស់គាត់ ៖

« ចូរយើងប្រយ័ត្ននឹងព្យាការីក្លែងក្លាយ និង គ្រូបង្រៀនក្លែងក្លាយ ទាំងបុរស និងស្ត្រី ដែលជាអ្នកប្រកាសតែងតាំងខ្លួនឯងពីគោលលទ្ធិនៃសាសនាចក្រ ហើយដែលស្វែងរកដើម្បីពង្រីកជំណឹងល្អដ៏ខុសឆ្គងរបស់ពួកគេ និង ទាក់ទាញអ្នកដើរតាមដោយការឧបត្ថម្ភការរួបរួមគំនិតសៀវភៅ និង កំណត់ហេតុដែលមានអត្ថន័យប្រកួតនឹងគោលលទ្ធិគ្រិះនៃសាសនាចក្រ ។ សូមប្រយ័ត្ននឹងអស់អ្នកទាំងឡាយណាដែលនិយាយ និង ផ្សព្វផ្សាយផ្ទុយនឹងព្យាការីដ៏ពិតរបស់ព្រះ និង ដែលបានញុះញង់ឲ្យអ្នកដទៃប្តូរសាសនាយ៉ាងសកម្មដោយការធ្វេសប្រហែសចំពោះសុខុមាលភាពដ៏អស់កល្បជានិច្ចរបស់អស់អ្នកទាំងឡាយដែលពួកគេបានទាក់ទាញចិត្តនោះ ។ ដូចជានីហ្វរ និង កូរីហ្វរនៅក្នុងព្រះគម្ពីរមរមនដែរ ពួកគេពឹងផ្អែកលើការផ្តល់ហេតុផលយ៉ាងឆ្លាតដើម្បីបោកបញ្ឆោត និង ល្បួងអ្នកដទៃឲ្យទៅតាមទស្សនៈរបស់ពួកគេ ។ ពួកគេ ‹ តាំងខ្លួនឡើងជាពន្លឺដល់មនុស្សលោកដើម្បីឲ្យពួកគេអាចបានកម្រៃ និង ការសរសើរតម្កើងពីមនុស្សលោក ប៉ុន្តែពួកគេមិនស្វែងរកសុខុមាលភាពនៃក្រុងស៊ីយ៉ូនឡើយ › (នីហ្វៃទី ២ ២៦:២៩) » (« Beware of False Prophets and False Teachers » *Ensign*ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ទំព័រ ៦៣) ។

- តើសមាជិកសាសនាចក្រអាចធ្លាក់ទៅក្នុងអន្ទាក់នៃឧបាយកលផ្នែកសង្ឃបានដោយរបៀបណា ?
- ដោយយោងតាម នីហ្វៃទី ២ ២៦:៣០ តើអ្វីដែលអាចការពារពួកយើងពីឧបាយកលផ្នែកសង្ឃបាន ? (សូមជួយសិស្សឲ្យយល់ថា យើងអាចចៀសវាងពីអំពើបាបនៃឧបាយកលផ្នែកសង្ឃដោយការមានសប្បុរសធម៌ចំពោះមនុស្សគ្រប់រូបទាំងអស់) ។

នីហ្វៃទី ២ ២៧

សេចក្តីផ្តើម

ដោយសំដៅទៅលើពាក្យពេចន៍របស់អេសាយញឹកញាប់ នីហ្វៃបានព្យាករថា ព្រះអម្ចាស់នឹង « ធ្វើការណ៍មួយយ៉ាងអស្ចារ្យ ហើយចម្លែក » នៅក្នុងថ្ងៃចុងក្រោយ ។ កិច្ចការដ៏អស្ចារ្យនេះ នឹងជាការស្តារឡើងវិញនូវដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ ចំណុចស្នូលនៃការព្យាករណ៍របស់នីហ្វៃ គឺជាការលេចចេញមកនៃព្រះគម្ពីរមរមន ។ នីហ្វៃបានព្យាករថា សាក្សីទាំងឡាយនឹងបានឃើញព្រះគម្ពីរមរមន ហើយធ្វើទីបន្ទាល់អំពីសេចក្តីពិតពេញលេញរបស់វា ។ គាត់ក៏បានថ្លែងទីបន្ទាល់អំពីតួនាទីមូលដ្ឋានរបស់ព្រះគម្ពីរមរមន ដែលនឹងសម្តែងនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់នៅក្នុងថ្ងៃចុងក្រោយ —ថាវានឹងជាអំណោយដ៏អព្ភូតហេតុមួយចំពោះពិភពលោក ។ (*កំណត់ចំណាំ* ៖ នីហ្វៃទី ២ ២៧ ស្របគ្នាយ៉ាងល្អនឹង អេសាយ ២៩ ។ នៅក្នុងការកែសម្រួលព្រះគម្ពីរបរិសុទ្ធនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ លេខយោងនៅក្នុង អេសាយ ២៩ ផ្តល់ជាការយល់ដឹងដ៏មានប្រយោជន៍សម្រាប់ការសិក្សានៃជំពូកទាំងពីរ) ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ២៧:១–៥

នីហ្វៃព្យាករថា នៅក្នុងថ្ងៃចុងក្រោយ ផែនដីនឹងត្រូវពេញដោយអំពើទុច្ចរិត

សូមបង្ហាញវត្ថុដូចខាងក្រោមនេះ ៖ កំប៉ុងថ្នាំបំបាត់ក្លិនមួយ ថ្នាំដុសធ្មេញមួយបំពង់ និង សាប៊ូមួយដុំ ឬ មួយកំប៉ុង ។ សូមពន្យល់ថា វត្ថុនីមួយៗធ្វើឡើងដើម្បីជាដំណោះស្រាយមួយចំពោះបញ្ហាមួយ ។ សូមឲ្យសិស្សស្វែងរកបញ្ហាដែលវត្ថុនីមួយៗធ្វើដើម្បីដោះស្រាយនោះ ។ (អ្នកអាចជ្រើសរើសប្រើវត្ថុផ្សេងទៀតដែលអាចចាត់ទុកថាជាដំណោះស្រាយចំពោះបញ្ហាជាក់លាក់មួយ) ។

សូមពន្យល់ថា ការព្យាករណ៍របស់នីហ្វៃនៅក្នុង នីហ្វៃទី ២ ២៧ ច្រាប់ពីបញ្ហាដែលកើតមាននៅក្នុងជំនាន់របស់យើង ។ គាត់បានបង្រៀនថា មនុស្សនឹងជំពប់ខាងវិញ្ញាណដោយសារតែអំពើទុច្ចរិតរបស់ពួកគេ ទើបពួកគេរងទុក្ខនឹងភាពខ្វាក់ខាងវិញ្ញាណ ហើយទើបពួកគេបដិសេធព្យាការីទាំងឡាយ ។ នីហ្វៃក៏បានព្យាករអំពីអ្វីដែលព្រះនឹងធ្វើដើម្បីដោះស្រាយបញ្ហាទាំងនេះ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអាន នីហ្វៃទី ២ ២៧:១–៥ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកពាក្យ និង ឃ្លាដែលរៀបរាប់ពីបញ្ហាខ្លះនៅថ្ងៃចុងក្រោយ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយឃ្លាដែលពួកគេបានរកឃើញ ។ ដើម្បីជួយសិស្សឲ្យវិភាគឃ្លាទាំងនេះ អ្នកអាចសួរសំណួរខាងក្រោមទាំងនេះ ៖

- **តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « ស្រវឹងនឹងអំពើទុច្ចរិត » ?**
- **នៅក្នុង នីហ្វៃទី ២ ២៧:៣ មនុស្សខ្លះនៅក្នុងជំនាន់ចុងក្រោយ គឺប្រៀបដូចជាមនុស្សឃ្លានម្នាក់ដែលបានយល់សប្តិឃើញថាខ្លួនបានបរិភោគ ឬ មនុស្សស្រេកម្នាក់ដែលបានយល់សប្តិថាបានផឹក ប៉ុន្តែលុះភ្ញាក់ឡើង ហើយមានអារម្មណ៍ថាព្រលឹងរបស់គេនៅតែមានសម្រែក ។ តើយើងអាចរៀនអ្វីចេញពីការណ៍នេះ ? (ការបរិភោគ ឬ ការផឹកនៅក្នុងសុបិនមួយ បំពេញចិត្តមិនបានយូរនោះទេ ហើយសម្រេចមិនបានអ្វីទាំងអស់ ដោយសារអ្នកឃ្លាន ឬ អ្នកស្រេកនោះនៅតែបន្តនៅក្នុងសុបិន ។ ដូចគ្នាដែរ អស់អ្នកដែល « ច្បាំងនឹងភ្នំស៊ីយ៉ូន » នឹងបំពេញចិត្តមិនបានយូរនោះទេ ហើយពួកគេក៏មិនបានសម្រេចអ្វីទាំងអស់ដ៏មានអត្ថន័យអ្វីដែរ) ។**
- **តើអ្នកគិតថាឃ្លា « អ្នករាល់គ្នាបានបិទភ្នែក » មានអត្ថន័យដូចម្តេចដែរ ?**

ដើម្បីជួយសិស្សឲ្យស្គាល់នូវសេចក្តីពិតនៃដំណឹងល្អនៅក្នុង នីហ្វៃទី ២ ២៧:១–៥ សូមអញ្ជើញពួកគេឲ្យសង្ខេបនូវអ្វីដែលពួកគេបានរៀនពីខគម្ពីរទាំងនេះ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ សូមប្រាកដថាសិស្សយល់ថា នៅក្នុងថ្ងៃចុងក្រោយ មនុស្សជាច្រើននឹងពោរពេញទៅដោយអំពើទុច្ចរិត ហើយនឹងបដិសេធព្យាការីទាំងឡាយ ។

- **តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីដឹងពីការព្យាករណ៍នេះ និង ការបំពេញរបស់វា ?**

នីហ្វៃទី ២ ២៧:៦–២៣

នីហ្វៃព្យាករអំពីការចេញមកនៃព្រះគម្ពីរមរមន

សូមអញ្ជើញសិស្សឲ្យអាន នីហ្វៃទី ២ ២៧:៦–៧ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេស្វែងរកអ្វីមួយដែលព្រះអម្ចាស់បានផ្តល់ដើម្បីជួយដោះស្រាយបញ្ហាខាងវិញ្ញាណរបស់មនុស្សនៅក្នុងជំនាន់ចុងក្រោយ ។

- **តើព្រះអម្ចាស់បានផ្តល់អ្វីខ្លះ ?**
- **តើព្រះគម្ពីរនេះមានអ្វីខ្លះ ?**
- **តើព្រះគម្ពីរអ្វីដែលអ្នកគិតថា ខគម្ពីរទាំងនេះកំពុងពិពណ៌នា ? (ដើម្បីជួយសិស្សឆ្លើយនឹងសំណួរនេះបាន អ្នកអាចស្នើថា ពួកគេគួរតែបើកមើលសេចក្តីយោងព្រះគម្ពីរដែលមានរាយបញ្ជីនៅក្នុង នីហ្វៃទី ២ ២៧:៦ លេខយោង *b* ។ អ្នកក៏អាចចង់ពន្យល់ថា ឃ្លា « ពួកអ្នកដែលបានលង់លក់ » សំដៅទៅលើព្យាការីដែលបានទទួលមរណភាពទៅហើយ ដែលបានរក្សាកំណត់ត្រាដែលក្លាយជាព្រះគម្ពីរមរមន ។)**

> *សំណួរដែលនាំទៅរកការវិភាគ*
>
> ដោយការប្រើសំណួរវិភាគទាំងឡាយ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគិតអំពីអត្ថន័យនៃខគម្ពីរដែលពួកគេកំពុងសិក្សា ។ ជាធម្មតា អ្នកគួរតែសួរសំណួរទាំងនេះ ក្រោយពីសិស្សសុំនឹងខគម្ពីរទាំងនេះសិន ។ ជាញឹកញាប់ សំណួរវិភាគចាប់ផ្តើមដោយឃ្លាដូចជា « ហេតុអ្វីបានជាអ្នកគិតថា » ឬ « តើអ្នកគិតថាយ៉ាងម៉េចដែរ » ។ ឧទាហរណ៍ អ្នកអាចសួរថា « តើអ្នកគិតថា (ឃ្លា ឬ ពាក្យ) នេះមានន័យយ៉ាងម៉េចដែរ ?

សូមលើកព្រះគម្ពីរមរមនមួយក្បាលឡើង ។ សូមពន្យល់ថា ព្រះអម្ចាស់បាននាំចេញមកនូវព្រះគម្ពីរនេះដើម្បីជួយកែតម្រូវបញ្ហានៅក្នុងថ្ងៃចុងក្រោយ និង ដើម្បីនាំមកនូវពន្លឺទៅកាន់ពិភពលោកដ៏ងងឹងមួយ ។ ព្រះអម្ចាស់បានបើកសម្តែងសេចក្តីលម្អិតដែលទាក់ទងនឹងការលេចចេញមកនៃព្រះគម្ពីរមរមនដល់ពូកព្យាការីពីបុរាណ ។ នីហ្វៃបានកត់ត្រាសេចក្តីលម្អិតទាំងនេះនៅក្នុង នីហ្វៃទី ២ ២៧ ។ សូមពន្យល់ថា ការព្យាករស្រដៀងគ្នាមួយត្រូវបានរកឃើញនៅក្នុង អេសាយ ២៩ ។ (អ្នកអាចពន្យល់ថា មនុស្សខ្លះបានផ្តាំផ្ញើព្រះគម្ពីរមរមនដោយសារពីមូលហេតុដែលព្រះគម្ពីរបរិសុទ្ធមិនបានលើកឡើងពីវា ។ សូមបង្ហាញថា ការព្យាករណ៍នៅក្នុងអេសាយ ២៩ បង្ហាញថា ព្រះគម្ពីរបរិសុទ្ធពិតជាបានថ្លែងទីបន្ទាល់អំពីព្រះគម្ពីរមរមនមែន) ។

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ២ ២៧:១២–១៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកអ្នកដែលនីហ្វៃបាននិយាយថា នឹងត្រូវបានអនុញ្ញាតឲ្យឃើញព្រះគម្ពីរនោះ ។

- តើនរណាខ្លះជាសាក្សីទាំងបីនាក់ដែលត្រូវបានអនុញ្ញាតឲ្យឃើញព្រះគម្ពីរមរមន « ដោយព្រះចេស្តានៃព្រះ » ? (លោកអូលីវើរ ខៅឌើរី លោកដាវីឌ វិតមើរ និង លោកម៉ាទិន ហារីស ។ សូមមើល « ទីបន្ទាល់នៃពូកសាក្សីបីនាក់ » ព្រះគម្ពីរមរមន) ។

សូមបង្ហាញថា នីហ្វៃបានលើកឡើងពីអ្នកផ្សេង « ពីរបីនាក់ » ទៀតដែលនឹងត្រូវបានអនុញ្ញាតឲ្យមើលព្រះគម្ពីរផងដែរ ។

- តើអ្នកគិតថា នរណាជាសាក្សីផ្សេងទៀតទាំងនេះ ? (អ្នកគួរតែរំឭកសិស្សអំពីពូកសាក្សីបន្ថែមប្រាំបីនាក់នៃព្រះគម្ពីរមរមន ។ សូមមើល « ទីបន្ទាល់នៃពូកសាក្សីប្រាំបីនាក់ » ព្រះគម្ពីរមរមន) ។

សូមបង្ហាញថា នីហ្វៃទី ២ ២៧:១៤លើកឡើងថា ព្រះអម្ចាស់នឹង « តាំងព្រះបន្ទូលនៃត្រង់ » ដោយ « មាត់នៃពូកសាក្សីទាំងប៉ុន្មានដែលទ្រង់យល់ថាល្អគ្រប់គ្រាន់សម្រាប់ទ្រង់ហើយ » ។

- តើអ្នកគិតថា នីហ្វៃចង់មានន័យអ្វី នៅពេលគាត់និយាយថា សាក្សីទាំងឡាយនឹងតាំងព្រះបន្ទូលនៃព្រះឡើង ? (អស់អ្នកដែលទទួលបាន និង ទទួលយកព្រះបន្ទូលនៃព្រះតាមរយៈព្រះគម្ពីរមរមន នឹងចែកចាយវាជាមួយនឹងអ្នកដទៃ និង ថ្លែងទីបន្ទាល់ពីសេចក្តីពិតពេញលេញរបស់វា) ។)
- តើសាក្សីទាំងនេះអាចជានរណា ?
- ដើម្បីជួយសិស្សឲ្យកោតសរសើរថា ពូកគេក៏អាចក្លាយជាសាក្សីនៃសេចក្តីពិតពេញលេញនៃព្រះគម្ពីរមរមននេះបានដែរនោះ អ្នកអាចអញ្ជើញពូកគេឲ្យសរសេរឈ្មោះរបស់ពូកគេនៅក្រមទំព័រក្បែរ នីហ្វៃទី ២ ២៧:១៤ ។ តើសមាជិកនៃសាសនាចក្រម្នាក់ៗ រួមទាំងអ្នកដែរ អាចជួយតាំងសេចក្តីពិតនៃព្រះគម្ពីរមរមនដោយរបៀបណា ?
- តើនៅពេលណាដែលអ្នកបានចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះគម្ពីរមរមនជាមួយនឹងអ្នកដទៃនោះ ?

ការតាមដាន

សូមឲ្យសិស្សរាយការណ៍ពីការអញ្ជើញ និង កិច្ចការពីមុនៗម្តងម្កាល ។ ការណ៍នេះអនុញ្ញាតឲ្យសិស្សចែកចាយពីបទពិសោធន៍ផ្ទៃមានផ្សេងៗ ហើយវាអាចផ្តល់ការជម្រុញសម្រាប់សិស្សខ្លះដើម្បីធ្វើតាមតាមរយៈការអញ្ជើញទាំងឡាយដែលអ្នកបានធ្វើចំពោះពួកគេ ។ វាក៏អនុញ្ញាតឲ្យអ្នកផ្តល់ការយកចិត្តទុកដាក់ជាពិសេសចំពោះការណ៍ល្អ ដែលបានកើតឡើងនៅពេលសិស្សបានធ្វើសកម្មភាពតាមការអញ្ជើញ និង កិច្ចការទាំងឡាយនោះ ។

នៅក្នុងមេរៀនមុនៗ អ្នកអាចលើកទឹកចិត្តសិស្សឲ្យចែកចាយទីបន្ទាល់របស់ពូកគេអំពីព្រះគម្ពីរមរមនជាមួយនឹងនរណាម្នាក់ផ្សេងទៀត ។ ប្រសិនបើអ្នកបានធ្វើ សូមតាមដានលើកិច្ចការនោះ ដោយការអញ្ជើញសិស្សបីបួននាក់ឲ្យចែកចាយពីអ្វីដែលពូកគេបានធ្វើ ។ សូមលើកទឹកចិត្តសិស្សឲ្យបន្តស្វែងរកឱកាសនានាដើម្បីចែកចាយទីបន្ទាល់របស់ពូកគេអំពីព្រះគម្ពីរមរមនជាមួយនឹងអ្នកផ្សេង រួមទាំងអស់អ្នកដែលមានសេចក្តីជំនឿផ្សេងគ្នាផងដែរ ។

សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ។ (ដើម្បីសន្សំពេល អ្នកអាចធ្វើការណ៍នេះមុនចាប់ផ្តើមបង្រៀន) ។)

	ការព្យាករណ៍របស់នីហ្វៃអំពីអ្វីដែលបុរសនោះនឹងធ្វើ	ឈ្មោះរបស់បុរសនោះ	ការបំពេញនៃការព្យាករណ៍ យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៦៣–៦៥
បុរសទីមួយ (មិនបានរៀន ») នីហ្វៃទី ២ ២៧:៩, ១៥, ១៩			
បុរសទីពីរ (« អ្នកផ្សេង ») នីហ្វៃទី ២ ២៧:១៥, ១៧			
បុរសទីបី (« បានរៀន ») នីហ្វៃទី ២ ២៧:១៥–១៨			

សូមបំបែកសិស្សទៅជាគូ ។ សូមពន្យល់ថា ដៃគូនីមួយៗនឹងសិក្សាពីការព្យាករណ៍មួយដែលទាក់ទងនឹងការចេញមកនៃព្រះគម្ពីរមរមន ក៏ដូចជាការបំពេញនៃការព្យាករណ៍នោះផងដែរ ។ សូមឲ្យសិស្សចម្លងតារាងនោះដាក់ក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពូកគេ ហើយសរសេរចម្លើយដោយប្រើសេចក្តីយោងព្រះគម្ពីរដែលបានផ្តល់ឲ្យ ។ (អ្នកអាចពន្យល់ថា ពាក្យ *អក្សរ* ដែលមាននៅក្នុង យ៉ូសែប ស្ម៊ីធ— ប្រវត្តិ ១:៦៣–៦៥ យោងទៅលើសំណៅដែលបានឆ្លាក់នៅលើថ្ងាំងមាសទាំងនោះដែលជាប្រភពបកប្រែនៃព្រះគម្ពីរមរមន) ។ នៅពេលសិស្សបានបញ្ចប់ហើយ សូមអញ្ជើញពូកគេឲ្យចែកចាយចម្លើយរបស់ពូកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

- ដោយយោងតាម នីហ្វៃទី ២ ២៧:១៥ និង យ៉ូសែប ស្ម៊ីធ— ប្រវត្តិ ១:៦៤ តើនរណាគឺជាបុរសដែលបានរៀន ដែលម៉ាទិន ហារីសបានដកយកពាក្យទាំងឡាយនៃព្រះគម្ពីរនោះ ? (ឆាលឡេស អាន់តុន)

- តើមនុស្សម្នាក់ដែលគ្មានការការសិក្សាអប់រំត្រឹមត្រូវ ដូចជា យ៉ូសែប ស៊្មីធ ជាដើម អាចជាអ្នកល្អប្រសើរដើម្បីធ្វើការបកប្រែព្រះគម្ពីរ មរមនជាជាងអ្នកប្រាជ្ញម្នាក់ដូចជាឆាលឡេស អាន់តុន បានដោយរបៀបណា ?

សូមឲ្យសិស្សអាន នីហ្វៃទី ២ ២៧:២០–២១ ដោយស្ងាត់ស្ងៀម ដោយស្វែងរកឃ្លាមួយដែលច្រំដែលនៅក្នុងខគម្ពីរនីមួយៗ ។ (« យើងអាចធ្វើកិច្ចការរបស់យើងបាន ») ។

- តើឃ្លា « យើងអាចធ្វើកិច្ចការរបស់យើងបាន » មានន័យយ៉ាងណាចំពោះអ្នកដែរ ?
- តើការស្ដារឡើងវិញនៃដំណឹងល្អ និង ការចេញមកនៃព្រះគម្ពីរមរមន ជាការបញ្ជាក់មួយថា ព្រះអាចធ្វើកិច្ចការរបស់ទ្រង់បានដោយរបៀបណា ?
- តើគោលការណ៍ណាខ្លះ ដែលត្រូវបានបង្រៀនដោយខគម្ពីរទាំងនេះ ? (នៅពេលសិស្សចែកចាយគំនិតរបស់ពួកគេ សូមសង្កត់ធ្ងន់ថា **ការចេញមកនៃព្រះគម្ពីរមរមនគឺជារបៀបមួយដែលព្រះនឹងសម្រេចកិច្ចការរបស់ទ្រង់នៅក្នុងជំនាន់ចុងក្រោយនេះ**) ។
- តើការបំពេញនៃការព្យាករណ៍នេះពង្រឹងទីបន្ទាល់របស់អ្នកអំពីព្រះគម្ពីរមរមន និង តួនាទីរបស់វានៅក្នុងការស្ដារឡើងវិញនៃសាសនាចក្ររបស់ព្រះអម្ចាស់ដោយរបៀបណា ?

នីហ្វៃទី ២ ២៧:២៤–៣៥

នីហ្វៃព្យាករអំពីឥទ្ធិពលវិជ្ជមាននៃដំណឹងល្អដែលបានស្ដារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ និង ព្រះគម្ពីរមរមន

សូមអាន នីហ្វៃទី ២ ២៧:២៤–២៦ ឲ្យឮៗ ខណៈសិស្សអានតាមនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

- តើអ្នកចាំថាបានឮពាក្យទាំងនេះពីមុនមកដែរទេ ? ប្រសិនបើធ្លាប់ តើនៅកន្លែងណា ? (ប្រសិនបើសិស្សមិនអាចឆ្លើយបាន សូមពន្យល់ថាព្រះអម្ចាស់បានប្រើពាក្យស្រដៀងគ្នានេះ នៅពេលទ្រង់បានមានព្រះបន្ទូលទៅកាន់យ៉ូសែប ស៊្មីធ នៅក្នុងព្រៃពិសិដ្ឋ ; សូមមើល យ៉ូសែប ស៊្មីធ— ប្រវត្តិ ១:១៩) ។

សូមលើកវត្ថុមួយដែលអ្នកបង្ហាញនៅពេលចាប់ផ្ដើមមេរៀននេះឡើង ហើយសូមរំឭកសិស្សថា វាត្រូវបានបង្កើតដើម្បីដោះស្រាយបញ្ហាជាក់លាក់មួយ ។

- នៅក្នុង នីហ្វៃទី ២ ២៧:២៥ តើបញ្ហាអ្វីដែលព្រះអម្ចាស់មានបន្ទូលថា នឹងមាននៅក្នុងចំណោមប្រជាជនក្នុងថ្ងៃចុងក្រោយនេះ ? (អ្នកអាចសរសេរចម្លើយរបស់សិស្សដាក់លើក្ដារខៀន) ។

សូមរំឭកសិស្សអំពីបញ្ហាខាងវិញ្ញាណផ្សេងទៀតនៅថ្ងៃចុងក្រោយដែលបានលើកឡើងនៅក្នុង នីហ្វៃទី ២ ២៧:៥ ។ (អ្នកអាចបន្ថែមពាក្យ *អំពើទុច្ចរិត ការខ្វាក់ខាងវិញ្ញាណ* និង *ការបដិសេធព្យាការីទាំងឡាយ* ទៅលើបញ្ជីនៅលើក្ដារខៀនបាន) ។

- តើព្រះគម្ពីរមរមន និង ការស្ដារឡើងវិញនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ជួយដោះស្រាយបញ្ហាទាំងនេះដោយរបៀបណា ?

សូមឲ្យសិស្សអាន នីហ្វៃទី ២ ២៧:២៩–៣០, ៣៤–៣៥ ដោយស្ងាត់ស្ងៀម ដោយស្វែងរករបៀបដែលព្រះអម្ចាស់បានមានបន្ទូលថា ដំណឹងល្អដែលបានស្ដារឡើងវិញ និង ព្រះគម្ពីរមរមននឹងប្រទានពរដល់ប្រជាជននៅថ្ងៃចុងក្រោយ ។ សូមអញ្ជើញសិស្សម្នាក់រាប់ពីពរជ័យទាំងនេះដាក់លើក្ដារខៀន ។

- ដោយយោងតាម នីហ្វៃទី ២ ២៧:២៩ ព្រះគម្ពីរមរមននឹងជួយ « ភ្នែករបស់មនុស្សខ្វាក់ . . . មើលឃើញពីក្នុងសភាពជាងងឹត ហើយស្ងួតសុង ។ » តើអ្នកគិតថាវាមានន័យយ៉ាងណាដែរ ?

ដើម្បីជួយសិស្សឲ្យយល់ថា **ព្រះគម្ពីរមរមន និង ដំណឹងល្អដែលបានស្ដារឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ នាំមកនូវសេចក្ដីអំណរ និង ការយល់ដឹងដល់អស់អ្នកទាំងឡាយណាដែលសិក្សា និង ទទួលយកវា** ។ សូមលើកទឹកចិត្តសិស្សឲ្យស្វែងរកដំណោះស្រាយចំពោះឧបសគ្គរបស់ពួកគេនៅក្នុងព្រះគម្ពីរមរមន ហើយចែកចាយទីបន្ទាល់របស់ពួកគេអំពីព្រះគម្ពីរមរមនជាមួយនឹងអ្នកដទៃ ។

នីហ្វៃទី២ ២៨

សេចក្តីផ្តើម

នីហ្វៃបានព្យាករអំពីលក្ខខណ្ឌឧបសគ្គខ្លះៗនៅក្នុងជំនាន់ចុងក្រោយ រួមមានទាំងការបង្រៀនខុសឆ្គង និង អំនួតនៃសាសនាចក្រជាច្រើនដែលបានរីកដុះដាលឡើង ។ គាត់បានបង្រៀនពីរបៀបដើម្បីស្គាល់គោលលទ្ធិក្លែងក្លាយ និង គរិយាបថខាងលោកិយ ហើយគាត់បានព្រមានពីរបៀបដែលសាតាំងនឹងព្យាយាមដើម្បីទាក់ទាញយើងពីសេចក្តីសុចរិត ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ២៨:១–១៩

នីហ្វៃរៀបរាប់ពីសាសនាចក្រក្លែងក្លាយ និង លទ្ធិក្លែងក្លាយទាំងឡាយនៅជំនាន់របស់យើង

សូមគូសទីសម្គាល់នៃការព្រមានដែលស្រដៀងគ្នានៅក្នុងវប្បធម៌របស់អ្នក នៅលើក្តារខៀន ។ ឧទាហរណ៍ អ្នកអាចគូសរូបសញ្ញាចរាចរណ៍មួយ ឬ ក៏និមិត្តសញ្ញាទំនាក់ទំនងមួយដែលធាតុជាក់លាក់មួយ គឺបង្កគ្រោះថ្នាក់ ឬ ដែលពុល ។

- **តើអ្វីជាគោលបំណងនៃសញ្ញាទាំងនេះ ?**

សូមពន្យល់ថា ព្រះគម្ពីរមរមនអាចជួយយើងឲ្យឃើញពីសញ្ញាព្រមានទាំងឡាយនៃឥទ្ធិពលដែលគ្រោះថ្នាក់ខាងវិញ្ញាណ ។ ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន បានពន្យល់ថា គោលបំណងមួយនៃព្រះគម្ពីរមរមនគឺដើម្បីផ្សាយពីរបៀបដែលឧបសគ្គ និង សត្រូវផ្សេងទៀតរបស់ព្រះគ្រីស្ទនឹងធ្វើការនៅក្នុងជំនាន់ចុងក្រោយ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ែនសឺន ៖

« ព្រះគម្ពីរមរមនសម្តែងសេចក្តីពិតចំពោះសត្រូវទាំងឡាយនៃព្រះគ្រីស្ទ ។ វាបញ្ចូលលទ្ធិក្លែងក្លាយទាំងឡាយ ។ . . . វាពង្រឹងពួកអ្នកដើរតាមព្រះគ្រីស្ទដោយរាបសាប្រឆាំងនឹងការចចាំដ៏អាក្រក់ យុទ្ធសាស្ត្រ និង គោលលទ្ធិនៃអារក្សនៅក្នុងជំនាន់របស់យើង ។ ប្រភេទនៃអ្នកក្បត់សាសនានៅក្នុងព្រះគម្ពីរមរមនគឺស្រដៀងនឹងប្រភេទដែលមាននាសព្វថ្ងៃនេះ » (« The Book of Mormon Is the Word of God » *Ensign*ខែ មករា ឆ្នាំ ១៩៨៨ ទំព័រ ៣) ។

- **តើព្រះគម្ពីរមរមនបង្ហាញពីសត្រូវនៃព្រះគ្រីស្ទដោយរបៀបណា ? (វាមានដំណើររឿងរបស់ប្រជាជនដែលបានព្យាយាមដឹកនាំអ្នកដទៃឲ្យលែងមានសេចក្តីជំនឿទៅលើព្រះគ្រីស្ទ ។ វាអនុញ្ញាតឲ្យយើងមើលឃើញកំហុស និង លទ្ធិក្លែងក្លាយរបស់ពួកគេ) ។**
- **តើព្រះគម្ពីរមរមនពង្រឹងយើង ប្រឆាំងនឹងឧបសគ្គនោះដោយរបៀបណា ?**

សូមថ្លែងទីបន្ទាល់ថា ព្រះគម្ពីរមរមនបង្ហាញលទ្ធិក្លែងក្លាយរបស់ពួកអារក្ស និង ពង្រឹងយើងប្រឆាំងនឹងការចចាំដ៏អាក្រក់របស់វាទាំងឡាយ ។សូមពន្យល់ថា សិស្សនឹងឃើញគំរូមួយនៃរឿងនេះនៅក្នុង នីហ្វៃទី ២ ២៨ ។ ជំពូកនេះ រួមមានការព្យាករណ៍មួយរបស់នីហ្វៃអំពីថ្ងៃចុងក្រោយ ។ នៅក្នុងការព្យាករណ៍នេះ នីហ្វៃបានព្រមានអំពីការបង្រៀនក្លែងក្លាយដែលនឹងកើតមានទូទៅនៅក្នុងជំនាន់របស់យើង ។

> **នីហ្វៃទី ២ ២៨:៧–៩**
> គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរនៃវគ្គនេះ ។

សូមអញ្ជើញសិស្សឲ្យសិក្សា នីហ្វៃទី ២ ២៨:៣–៩ ដោយស្ងាត់ៗ ដោយស្វែងរកការព្រមានរបស់នីហ្វៃអំពីការបង្រៀនក្លែងក្លាយទាំងនោះ ។ សូមបង្ហាញថា នីហ្វៃទី ២ ២៨:៧–៩ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំវគ្គនេះឲ្យលេចដាច់ពីគេ ដើម្បីពួកគេអាចរកវាឃើញដោយងាយស្រួល ។ ក្រោយពីសិស្សមានពេលសិក្សាវគ្គនេះគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សបីបួននាក់ឡើងមកកាន់ក្តារខៀន ។ សូមឲ្យពួកគេម្នាក់ៗសរសេរការបង្រៀន ឬ លទ្ធិក្លែងក្លាយមួយពីក្នុងវគ្គនេះ ដោយដាក់ខគម្ពីរដែលវាដកស្រង់ផង ។ បន្ទាប់មកសូមសួរសិស្សផ្សេងទៀត ថាតើពួកគេបានសម្គាល់ឃើញការបង្រៀន ឬ លទ្ធិក្លែងក្លាយផ្សេងទៀតនៅក្នុងវគ្គនេះទេ ។ ប្រសិនបើពួកគេមាន សូមអញ្ជើញពួកគេឲ្យបន្ថែមទៅលើបញ្ជីនៅលើក្តារខៀននោះ ។

ដើម្បីជួយសិស្សឲ្យពិភាក្សាពីគោលលទ្ធិ និង លទ្ធិក្លែងក្លាយពីរបីទាំងនេះ សូមសួរសំណួរដូចខាងក្រោម ៖

- **តើអ្វីជាឧទាហរណ៍សម័យទំនើបមួយ នៃលទ្ធិក្លែងក្លាយទាំងនេះមួយ ? (សូមធានាថា សិស្សក្នុងថ្នាក់មិនបញ្ចេញឈ្មោះជាក់លាក់ណាមួយនៃសាសនាចក្រផ្សេង នៅពេលពួកគេឆ្លើយតបនឹងសំណួរនេះ) ។**
- **តើលទ្ធិក្លែងក្លាយនេះ រារាំងមនុស្សមិនឲ្យធ្វើតាមផែនការរបស់ព្រះវរបិតាសួគ៌របស់យើងដោយរបៀបណា ?**

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ២៨:១២–១៤ ឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ស្វែងរកការព្រមានរបស់នីហ្វៃអំពីអ្វីដែលនឹងកើតឡើងចំពោះសាសនាចក្រ និង មនុស្សនៅថ្ងៃចុងក្រោយជាច្រើនដោយសារតែអំនួត និង គោលលទ្ធិក្លែងក្លាយទាំងឡាយ ។

- **តើអំនួត និង ការបង្រៀនក្លែងក្លាយជះឥទ្ធិពលលើមនុស្សយ៉ាងណាដែរ ?**
- **ហេតុអ្វីបានជា « ពួកអ្នកដើរតាមព្រះគ្រីស្ទដោយរាបសា » មិនត្រូវបានដឹកនាំឲ្យវង្វេងដោយសារអំនួត និង ភាពទុច្ចរិត ? តើយើងអាចចៀសវាងការបោកបញ្ឆោតដោយ « សិក្ខាបទទាំងឡាយនៃមនុស្ស » ដោយរបៀបណា ? (អ្នកគួរតែពន្យល់ថាឃ្លា « សិក្ខាបទទាំងឡាយនៃមនុស្ស » យោងទៅលើការបង្រៀនរបស់មនុស្ស— ផ្ទុយពីការបង្រៀនរបស់ព្រះអម្ចាស់) ។**

សូមអញ្ជើញសិស្សឲ្យអាន នីហ្វៃទី ២ ២៨:១៥–១៦, ១៩ ដោយស្ងាត់ស្ងៀម ដោយស្វែងរកលទ្ធផលនៃការបង្រៀនក្លែងក្លាយទាំងឡាយ ។

- តើពាក្ស ឬ ឃ្លាអ្វីខ្លះ ដែលអ្នកឃើញនៅក្នុងខគម្ពីរទាំងនេះដែលរៀបរាប់ពីលទ្ធផលនៃអំនួត និង ការបង្រៀនក្លែងក្លាយនោះ ?

នីហ្វៃទី ២ ២៨:២០–៣២

នីហ្វៃព្រមានអំពីរបៀបដែលសាតាំងព្យាយាមបោកបញ្ឆោតយើង

សូមចែកចាយរឿងខាងក្រោមជាមួយនឹងសិស្ស ៖

ខណៈពេលដែលមានកិច្ចការនៅក្នុងទ្វីបអាហ្វ្រិក ប្រធាន ប៊ិយដ៍ ឃេ. ផាកកឺ បានទៅមើលសត្វនៅទីបម្រុងល្បែងមួយ ។ គាត់បានកត់សម្គាល់ថា សត្វនៅក្នុងប្រហោងទឹករាក់មួយមានការភិតភ័យ ។ នៅពេលគាត់ស្វរអ្នកមគ្គុទេសន៍ពីមូលហេតុដែលសត្វនេះមិនផឹកទឹក នោះអ្នកមគ្គុទេសន៍បាននិយាយថា គឺដោយសារមានសត្វក្រពើ ។ ប្រធាន ផាកកឺ បាននឹកឃើញថា ៖

« ខ្ញុំដឹងថា គាត់ប្រាកដជានិយាយលេងហើយ នោះខ្ញុំបានស្វរគាត់ដោយម៉ឺងម៉ាត់ថា ‹ តើមានបញ្ហាអ្វី ? › ចម្លើយម្តងទៀតនោះគឺ ៖ ‹ ក្រពើ › ។ . . .

« គាត់អាចនិយាយថា ខ្ញុំមិនជឿគាត់ទេ ហើយគាត់សម្រេចចិត្ត តាមដែលខ្ញុំគិត ថាគាត់នឹងបង្រៀនមេរៀនមួយដល់ខ្ញុំ ។ យើងបានបើកឡានទៅកន្លែងផ្សេងទៀត ដែលមានឡានចតនៅលើទំនប់មួយពីលើប្រហោងភក់ដែលយើងអាចមើលទៅក្រោមបាន ។ គាត់បាននិយាយថា ‹ នៅទីនោះ › ។ ‹ មើលខ្លួនឯងទៅ › ។

« ខ្ញុំមិនអាចមើលឃើញអ្វីទេ លើកលែងតែភក់ ទឹកបន្តិច និង សត្វដែលភ័យនោះនៅពីចម្ងាយ ។ ហើយបន្ទាប់មក ខ្ញុំបានឃើញវាម្តងទាំងអស់ !—ក្រពើមួយដ៏ធំ ដែលដេកនៅក្នុងភក់នោះ រង់ចាំសត្វដែលភ្លេចខ្លួនខ្លះ ៗស្រេកទឹកខ្លាំង ដែលនឹងមកផឹកទឹកនោះ ។

« ភ្លាមនោះ ខ្ញុំក្លាយជាអ្នកជឿមួយ ! នៅពេលគាត់អាចឃើញថា ខ្ញុំចង់ស្តាប់ហើយ គាត់បានបន្តមេរៀននោះ ។ គាត់បាននិយាយថា ‹ មានក្រពើជាច្រើននៅពេញឧទ្យាននេះ មិនមែនមានតែនៅក្នុងទន្លេនោះទេ › ។ យើងមិនមានទឹកណាដែលគ្មានក្រពើមួយក្បាល នៅកន្លែងណាមួយក្បែរវានោះទេ ហើយអ្នកគួរតែជឿវាទៅ › ។ . . .

« ពេលធ្វើដំណើរមួយទៀតទៅទ្វីបអាហ្វ្រិក ខ្ញុំបានពិភាក្សាបទពិសោធន៍នេះជាមួយនឹងអ្នកតម្រួតល្បែងមួយនៅឧទ្យានផ្សេងទៀត ។ . . .

« ពេលនោះ គាត់បានបង្ហាញខ្ញុំពីកន្លែងមួយដែលធ្លាប់កើតមានសោកនាដកម្មមួយ ។ យុវជនម្នាក់មកពីប្រទេសអង់គ្លេស បានធ្វើការនៅក្នុងសណ្ឋាគារមួយសម្រាប់រដូវនោះ ។ ទោះបីជាមានការព្រមានដ៏ខ្ជាប់ខ្ជួន និង ដដែលក្តី គាត់បានទៅកាន់របងជាប់គ្នាដើម្បីពិនិត្យមើលអ្វីមួយដែលកាត់ថ្លុកទឹករាក់ដែលមិនបានគ្របលើស្បែកជើងកីឡាតិន្នីសរបស់គាត់នោះ ។

អ្នកតម្រួតបាននិយាយថា « ‹ គាត់មិនបានឈានពីរជំហានទៅមុខទេ មុនពេលដែលក្រពើមួយត្របាក់គាត់នោះ ហើយយើងមិនអាចធ្វើអ្វីបានដើម្បីសង្ត្រោះគាត់នោះទេ › » (« Spiritual Crocodiles » *Ensign* ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ៣០–៣១) ។

- តើអ្វីដែលបណ្តាលឲ្យយុវជននេះធ្លាក់ទៅជាចំណីដល់សត្វក្រពើនោះ ? តើគាត់អាចចៀសវាងសោកនាដកម្មនេះបានដោយរបៀបណា ? (ដោយការគោរពតាមការព្រមានដែលគាត់បានទទួលនោះ) ។

សូមអញ្ជើញសិស្សម្នាក់អានការទូន្មានខាងក្រោមពីប្រធាន ផាកកឺ ឲ្យពួ ៗ ៖

« អ្នកទាំងឡាយណាដែលនៅពីមុខអ្នកក្នុងជីវិតនេះ បានស្ទង់ពីប្រហោងទឹកនោះបន្តិច ហើយបាននិយាយប្រាប់ព្រមានអំពីសត្វក្រពើទាំងនោះ ។ មិនមែនគ្រាន់តែក្រពើដ៏ធំ ប្រផេះនោះដែលអាចខាំអ្នកទៅជាចំណែកនោះទេ ប៉ុន្តែ*ក្រពើខាងវិញ្ញាណ* ពិតជាគ្រោះថ្នាក់ជាង និង បោកបញ្ឆោតជាង ហើយអាចមើលឃើញតិចជាង វាមានគ្រោះថ្នាក់ជាងល្ងួនទាំងឡាយដែលបន្លំបានយ៉ាងល្អនៅទ្វីបអាហ្វ្រិកទៅទៀត ។

« ក្រពើខាងវិញ្ញាណទាំងនេះ អាចសម្លាប់ ឬ ធ្វើឲ្យវិញ្ញាណអ្នកខូចបាន ។ វាអាចបំផ្លាញសេចក្តីសុខសាន្តក្នុងគំនិតអ្នក និង សេចក្តីសុខសាន្តក្នុងគំនិតរបស់អ្នកទាំងឡាយណាដែលស្រឡាញ់អ្នក ។ នោះគឺជាអ្វីដែលត្រូវព្រមានប្រឆាំង ហើយវាកម្រមានកន្លែងទឹកណានៅក្នុងជីវិតរមែងស្លាប់នេះនាពេលឥឡូវនេះ ដែលវាមិនត្រូវបានរំខានដោយក្រពើទាំងនោះណាស់ » (« Spiritual Crocodiles » ទំព័រ ៣១) ។

- តើក្រពើនៅក្នុងរឿងរបស់ប្រធាន ផាកកឺ ស្រដៀងគ្នាទៅនឹងការល្បួង និង វិធីរបស់សាតាំងដោយរបៀបណា ? តើការព្រមានអ្វីខ្លះដែលយើងទទួលបានដើម្បីជួយយើងឲ្យចៀសវាងពីគ្រោះថ្នាក់ខាងវិញ្ញាណនោះ ?

សូមអាន នីហ្វៃទី ២ ២៨:១៩ ពួ ៗ ខណៈពេលដែលសិស្សអានតាមដែរ ។ បន្ទាប់មកសូមសរសេរនៅលើក្តារខៀនថា *សាតាំងចង់ចាប់យើងឲ្យនៅក្នុងអំណាចរបស់វាដោយ* . . .

សូមពន្យល់ថា នៅពេលនីហ្វៃបានបន្តការព្យាករណ៍របស់គាត់ គាត់បាននិយាយអំពីវិធីដែលសាតាំងបានប្រើប្រឆាំងនឹងយើងនៅក្នុងជំនាន់ចុងក្រោយនេះ ។ សូមបំបែកសិស្សទៅជាគូ ។ សូមឲ្យដៃគូនីមួយ ៗអាន នីហ្វៃទី ២ ២៨:២០–២៩ ដោយស្វែងរករបៀបដើម្បីបំពេញប្រយោគនៅលើក្តារខៀន ។

ការប្រើរឿង

រឿងមួយអាចជួយទាក់ទាញសិស្ស ដោយការបង្កើតចំណាប់អារម្មណ៍ និង ការជួយពួកគេឲ្យចូលរួមនៅក្នុងដំណើរការរៀនសូត្រតាមរយៈការស្តាប់តាមបទពិសោធន៍របស់អ្នកដទៃ ។ រឿងក៏អាចជួយសិស្សឲ្យឃើញពីរបៀបដែលគោលការណ៍នៃដំណឹងល្អ អនុវត្តនៅក្នុងជីវិតរបស់មនុស្សផងដែរ ។

ក្រោយពីពីរបីនាទីហើយ សូមអញ្ជើញដៃគូទាំងអស់ឲ្យរៀបរាប់ពីរបៀបដែលពួកគេបានបំពេញប្រយោគនៅលើក្តារខៀននោះ ។ ដោយសារជាផ្នែកនៃការពិភាក្សានេះ សូមប្រាកដថា សិស្សយល់ថា **សាតាំងប្រើវិធីជាច្រើនដើម្បីព្យាយាមគ្រប់គ្រងយើង ដូចជាដោយចាក់រុកយើងឲ្យមានកំហឹង ធ្វើឲ្យស្ងៀម និង ឲ្យយើងងងុយដេក ហើយបញ្ឆោតយើង ។**

- តើគំរូអ្វីខ្លះដែលសាតាំងព្យាយាម « ចាក់រុក [មនុស្ស] ឲ្យពួកគេមានកំហឹងទាស់នឹងអ្វីដែលជាល្អវិញ » នោះ ? តើកំហឹងបំភាន់មនុស្សអំពីអ្វីដែលល្អ និង អ្វីដែលអាក្រក់ដោយរបៀបណា ?
- តើអ្នកគិតថា ហេតុអ្វីបានជាវាមានគ្រោះថ្នាក់សម្រាប់មនុស្សដែល « បានស្រូលទាំងអស់នៅក្រុងស៊ីយ៉ូន » គិតថាគ្មានការរីកចម្រើនណាដែលចាំបាច់ទេនោះ ? តើអ្នកគិតថា ហេតុអ្វីបានជាសាតាំងអាចនាំមនុស្សបែបនោះ « ដោយប្រុងប្រយ័ត្នចុះទៅស្ថាននរក » ?
- តើវាមានន័យយ៉ាងណាដែរ ដើម្បីបញ្ឆោតនរណាម្នាក់នោះ ? (ផ្តល់ការសរសើរ និង ការពេញចិត្តដែលមិនស្មោះត្រង់) ។ តើអ្នកគិតថា ហេតុអ្វីបានជាការបញ្ឆោតអាចនាំមនុស្សខ្លះឃ្លាតចេញពីព្រះអម្ចាស់ ?
- ហេតុអ្វីបានជាសាតាំងព្យាយាមបញ្ចុះបញ្ចូលមនុស្សថា វាមិនមានរាងកាយទេ ?
- តើយើងអាចអាចធ្វើអ្វីខ្លះ ដើម្បីការពារយើងកុំឲ្យមានកំហឹងនោះ ? តើយើងអាចការពារប្រឆាំងនឹងអារម្មណ៍ថា ស្រូលទាំងអស់ដោយរបៀបណា ? តើយើងអាចការពារប្រឆាំងនឹងការបញ្ឆោតដោយរបៀបណា ?

ដើម្បីបញ្ចប់មេរៀន សូមប្រាប់សិស្សថា នៅចុងបញ្ចប់នៃនីហ្វៃទី ២ ២៨ រួមមានការព្រមានចុងក្រោយមួយ និង ការធានាមួយមកពីព្រះអម្ចាស់ ។ សូមអញ្ជើញសិស្សអាន នីហ្វៃទី ២ ២៨:៣០–៣២ ដោយស្ងាត់ស្ងៀម ។

- ព្រះអម្ចាស់ផ្តល់កិត្តិយសចំពោះសិទ្ធិជ្រើសរើសរបស់យើង និង ការខិតខំរបស់យើងដើម្បីរៀនពីទ្រង់ ។ ដោយយោងតាម នីហ្វៃទី ២ ២៨:៣០ ទ្រង់បង្រៀនយើង « មួយបន្ទាត់ម្តង ។ មួយសិក្ខាបទម្តង ។ » ។ តើការណ៍នេះមានអត្ថន័យយ៉ាងណាចំពោះអ្នក ? យោងតាមខគម្ពីរនេះ យើងមានអ្វីកើតឡើងចំពោះអ្នកទាំងឡាយណាដែលនិយាយថា « យើងមានលួមគ្រប់គ្រាន់ហើយ » នោះ ?
- នៅក្នុង នីហ្វៃទី ២ ២៨:៣២ ព្រះអម្ចាស់មានបន្ទូលទៅកាន់ប្រជាជនដែលបានបដិសេធទ្រង់ ។ នៅក្នុងខគម្ពីរនេះ តើអ្នកគិតថាទ្រង់ចង់មានន័យយ៉ាងណា នៅពេលទ្រង់មានបន្ទូលថា « យើងលូកដៃទៅរកពួកគេពីថ្ងៃមួយទៅថ្ងៃមួយទៀត » នោះ ? (នៅក្នុងខគម្ពីរនេះ ព្រះអម្ចាស់ប្រាប់ពីសេចក្តីមេត្តាករុណារបស់ទ្រង់ និង បំណងរបស់ទ្រង់ដើម្បីជួយយើងរាល់ថ្ងៃនៅពេលយើងចង់ដើរតាមបំណងរបស់ទ្រង់ ទោះបីជាយើងបានបដិសេធទ្រង់កាលពីមុនមកក្តី ។ សូមជួយសិស្សឲ្យយល់ថា **ព្រះអម្ចាស់នឹងមានសេចក្តីមេត្តាករុណាចំពោះមនុស្សទាំងអស់ដែលបានប្រែចិត្ត និង ចូលមករកទ្រង់**) ។

សូមសរសេរឃ្លាខាងក្រោមដាក់លើក្តារខៀន ៖ *ដោយសារតែអ្វីដែលខ្ញុំបានរៀននៅថ្ងៃនេះ ខ្ញុំនឹង . . .* ។ សូមអញ្ជើញសិស្សឲ្យបញ្ចប់ប្រយោគនេះនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេររបស់ពួកគេ ដោយការរៀបរាប់ពីអ្វីដែលពួកគេនឹងធ្វើ ដែលជាលទ្ធផលនៃការសិក្សាការព្យាករណ៍របស់នីហ្វៃនៅក្នុង នីហ្វៃទី ២ ២៨ ។ អ្នកអាចអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអ្វីដែលពួកគេបានសរសេរជាមួយនឹងសិស្សក្នុងថ្នាក់ ។ ទោះជាយ៉ាងណាក្តី សូមធានាថា ពួកគេយល់ថា ពួកគេមិនគួរមានអារម្មណ៍ថាត្រូវចែកចាយគំនិត ឬ បទពិសោធន៍ដែលផ្ទាល់ខ្លួន ឬ ឯកជនពេកនោះទេ ។

សូមថ្លែងទីបន្ទាល់ថា ដោយមានការណែនាំ និង កម្លាំងពីព្រះអម្ចាស់ នោះយើងអាចយកឈ្នះលើការល្បួងបាន ។ ហើយទោះបីជានៅពេលយើងធ្វើបាប ព្រះអម្ចាស់នឹងមានសេចក្តីមេត្តាករុណាដល់យើង ប្រសិនបើយើងបានប្រែចិត្តដោយស្មោះនោះ ។

ចំណេះចំណានខគម្ពីរ—នីហ្វៃទី ២ ២៨:៧–៩

សូមពន្យល់ថា ពេលខ្លះមនុស្សរកមូលហេតុចំពោះអំពើបាបដោយប្រាប់ខ្លួនគេថា គ្រប់គ្នាក៏កំពុងធ្វើវាដែរ ឬ ថាពួកគេអាចប្រែចិត្តពេលក្រោយបាន ។ សូមបំបែកសិស្សជាក្រុមតូចៗ ។ សូមអញ្ជើញក្រុមទាំងឡាយអាន នីហ្វៃទី ២ ២៨:៧–៩ រួមគ្នា ដោយស្វែងរកពាក្យ និង ឃ្លាទាំងឡាយដែលទាក់ទងទៅនឹងលទ្ធិក្លែងក្លាយទាំងនេះ ។ សូមអញ្ជើញសិស្សឲ្យពិភាក្សាពីសំណួរដូចខាងក្រោមនៅក្នុងក្រុមរបស់ពួកគេ (អ្នកអាចសរសេរសំណួរនេះនៅលើក្តារខៀនមុនពេលចាប់ផ្តើមបង្រៀន) ៖

- តើអ្វីជាគ្រោះថ្នាក់នៃការប្រព្រឹត្ត « អំពើបាបបន្តិចបន្តួច » មួយ ?
- តើព្រះនឹងកែតម្រូវការប្រព្រឹត្តរបស់យើងឲ្យទៅជាតូច ឬ អំពើបាបមិនញឹកញាប់ទេ ? (សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១:៣១ សម្រាប់ការយល់ដឹងបន្ថែមទៀត) ។
- តើមនុស្សម្នាក់អាច « ជិះជាន់មនុស្សផ្សេងដោយសារសំដីរបស់គេ » បានដោយរបៀបណា ? តើពេលខ្លះយើងអាច « ជីករណ្តៅទុកដាក់អ្នកជិតខាងខ្លួន [របស់យើង] » ដោយរបៀបណា ?

សូមអញ្ជើញក្រុមនីមួយៗឲ្យសរសេរខគម្ពីរនេះសារឡើងវិញ ជាភាសាដែលមនុស្សអាចប្រើនៅសព្វថ្ងៃនេះ ដើម្បីបញ្ចុះបញ្ចូលមនុស្សក្មេងៗឲ្យធ្វើតាមគោលលទ្ធិត្លត់ៗទាំងនេះ ។

សូមឲ្យសិស្សគិតអំពីពេលនានាដែលពួកគេបានក្បាកម្លាំងខាងវិញ្ញាណរបស់ពួកគេប្រឆាំងនឹងលទ្ធិក្លែងក្លាយនៅសាលា នៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ឬ ពីមិត្តភក្តិ ។ សូមអញ្ជើញពួកគេឲ្យសរសេរអំពីបទពិសោធន៍ទាំងនេះនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ។ សូមគិតពីការសុំសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរនោះ ។

កំណត់ចំណាំ ៖ អ្នកអាចប្រើគំនិតនេះអំឡុងពេលមេរៀន នៅពេលអ្នកណែនាំវគ្គចំណេះចំណានខគម្ពីរ ឬ អ្នកអាចប្រើវានៅចុងបញ្ចប់នៃមេរៀននេះ ។

នីហ្វៃទី ២ ២៩–៣០

សេចក្តីផ្តើម

នីហ្វៃបានព្យាករអំពីការស្តារដំណឹងល្អឡើងវិញនៅថ្ងៃចុងក្រោយ ដែលព្រះអម្ចាស់បានមានព្រះបន្ទូលថានឹងជា « ការណ៍មួយដ៏អស្ចារ្យ » (នីហ្វៃទី ២ ២៩:១) ។ នីហ្វៃបានថ្លែងទីបន្ទាល់ថា នៅក្នុងថ្ងៃចុងក្រោយ ព្រះគម្ពីរទាំងអស់នឹងធ្វើការរួមគ្នាដើម្បីបង្ហាញថា ព្រះចងចាំដល់កូនចៅរបស់ទ្រង់ ។ គាត់បានព្យាករថា មនុស្សជាច្រើននឹងបដិសេធព្រះគម្ពីរមរមន ប៉ុន្តែអស់អ្នកទាំងឡាយដែលជឿ នឹងត្រូវបានប្រមូលផ្តុំនៅក្នុងសាសនាចក្រ ។ បន្ថែមលើនេះ គាត់បានបង្រៀនថា ប្រជាជនក្នុងសេចក្តីសញ្ញារបស់ព្រះគឺជាអស់អ្នកណាដែលប្រែចិត្ត និង ជឿលើព្រះរាជបុត្រានៃព្រះ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ២៩

នីហ្វៃព្យាករថា នៅក្នុងថ្ងៃចុងក្រោយ មនុស្សជាច្រើននឹងបដិសេធព្រះគម្ពីរមរមន

សូមអញ្ជើញសិស្សឲ្យស្រមៃថា មានមិត្តម្នាក់នៅសាលាបានសួរដោយស្មោះថា « ហេតុអ្វីបានជាពួកមរមនមានព្រះគម្ពីរបរិសុទ្ធផ្សេងដូច្នេះ ? » អ្នកអាចសុំសិស្សឲ្យលើកដៃឡើង ប្រសិនបើពួកគេត្រូវបានគេសួរសំណួរដូចគ្នាបែបនេះ ។ បន្ទាប់មក សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីរបៀបដែលពួកគេឆ្លើយតបនឹងសំណួរនោះ ។

សូមពន្យល់ថា នីហ្វៃបានផ្តល់ចម្លើយខ្លះចំពោះសំណួរនេះ ដោយការកត់ត្រាព្រះបន្ទូលរបស់ព្រះអម្ចាស់អំពីតួនាទី នៃព្រះគម្ពីរមរមននៅក្នុងថ្ងៃចុងក្រោយនៃការស្តារឡើងវិញនៃដំណឹងល្អ ដែលព្រះអម្ចាស់បានហៅថាជា « ការណ៍មួយដ៏អស្ចារ្យ » ។ សូមអញ្ជើញសិស្សឲ្យអាន នីហ្វៃទី ២ ២៩:១–២ ដោយស្ងាត់ស្ងៀម ហើយស្វែងរកអ្វីដែលព្រះបន្ទូលរបស់ព្រះអម្ចាស់នឹងធ្វើនៅក្នុងថ្ងៃចុងក្រោយ ។ (ពួកគេបាន « ចេញទៅ » ដល់ពួជរបស់នីហ្វៃ ឬ កូនចៅទាំងឡាយ ហើយពួកគេក៏បាន « ហួចហៅទៅដល់ចុងផែនដី ») ។ ប្រធានអែសរ៉ា ថាហ្វ ប៊ែនសឹន បានពន្យល់ថា « យើងជាសមាជិកនៃសាសនាចក្រ និង ជាពិសេសពួកអ្នកផ្សព្វផ្សាយសាសនា ត្រូវតែជា ‹ អ្នកហួចហៅ › ឬ អ្នកប្រាប់ និង អ្នកថ្លែងទីបន្ទាល់អំពីព្រះគម្ពីរមរមនទៅកាន់ចុងផែនដី » (« The Book of Mormon Is the Word of God »*Ensign*ខែ ឧសភា ឆ្នាំ ១៩៧៥ ទំព័រ ៦៥) ។

សូមពន្យល់ថាពាក្យ *ទង់ជ័យ* នៅក្នុង នីហ្វៃទី ២ ២៩:២ យោងទៅលើរបស់មួយដែលប្រើដើម្បីប្រមូល និង បង្រួបបង្រួម ប្រជាជន ។ ជាញឹកញាប់ ទង់ជាតិត្រូវបានហៅថាជាទង់ជ័យ ។ (សូមមើលការពន្យល់ពាក្យ *ទង់ជ័យ* នៅក្នុងមេរៀនទី ៣២) ។

- **យោងតាម នីហ្វៃទី ២ ២៩:២ តើអ្វីជា « ទង់ជ័យ » ដែលនឹងចេញទៅ « ដល់ចុងផែនដី » ដើម្បីប្រមូលរាស្ត្ររបស់ព្រះអម្ចាស់ ? (ព្រះគម្ពីរមរមន —ពាក្យរបស់ពួជនីហ្វៃ ឬ កូនចៅរបស់គាត់) ។**
- **យោងតាម នីហ្វៃទី ២ ២៩:១–២ តើអ្វីជាគោលបំណងរបស់ព្រះអម្ចាស់សម្រាប់ការផ្តល់ព្រះគម្ពីរបន្ថែម ដូចជាព្រះគម្ពីរមរមន ? (សូមជួយសិស្សឲ្យយល់ថា ព្រះអម្ចាស់ផ្តល់ព្រះគម្ពីរជាសាក្សីទីពីរមួយ ហើយដើម្បីប្រមូលរាស្ត្រទៅកាន់សេចក្តីសញ្ញារបស់ទ្រង់) ។**

នៅលើក្តារខៀន សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ជែហ្វ្រី អ័រ. ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ (ពី*Christ and the New Covenant: The Messianic Message of the Book of Mormon* ៖ ឆ្នាំ ១៩៩៧ ៖ ទំព័រ ៤) ។ ៖

> *« ព្រះគម្ពីរមរមន គឺជាសេចក្តីថ្លែងដ៏ខ្ពស់ជាងគេនៃសេចក្តីសញ្ញារបស់ព្រះជាមួយនឹងកូនចៅ និង សេចក្តីស្រឡាញ់របស់ទ្រង់សម្រាប់កូនចៅទ្រង់នៅលើផែនដីនេះ ។ » (អែលឌើរ ជែហ្វ្រី អ័រ. ហូឡិន)*

សូមពន្យល់ថានៅក្នុង នីហ្វៃទី ២ ២៩ ពាក្យថា *សាសន៍ដទៃ*យោងទៅលើប្រជាជនដែលមិនមែនជាវង្សនៃអ៊ីស្រាអែល ។ ពាក្យថា *សាសន៍យូដា*យោងទៅលើប្រជាជនដែលជាវង្សនៃអ៊ីស្រាអែល រួមមានគ្រួសារ និង កូនចៅរបស់លីហៃដែរ ។ សូមឲ្យសិស្សអាន នីហ្វៃទី ២ ២៩:៣–៦ដោយស្ងាត់ស្ងៀម ដោយស្វែងរកប្រតិកម្មរបស់ពួកសាសន៍ដទៃខ្លះដែលអាចមានចំពោះព្រះគម្ពីរបន្ថែមនេះ ។

- **តើអ្នកខ្លះនឹងមានប្រតិកម្មចំពោះព្រះគម្ពីរបន្ថែមនេះយ៉ាងណាដែរ ?**
- **តើព្រះអម្ចាស់បានមានព្រះបន្ទូលអ្វីខ្លះ អំពីប្រជាជនដែលមានប្រតិកម្មរបៀបនេះ ?**

សូមពន្យល់ថា នីហ្វៃពោរពេញដោយការព្យាករណ៍នៅក្នុងការពិពណ៌នារបស់គាត់អំពីប្រតិកម្មរបស់ប្រជាជនចំពោះព្រះគម្ពីរមរមន ។ ប្រជាជននាសព្វថ្ងៃនេះ បង្ហាញការសង្ស័យជាច្រើនអំពីព្រះគម្ពីរមរមន ដោយសារពួកគេមានព្រះគម្ពីរបរិសុទ្ធរួចហើយ ។

សូមចាត់តាំងសិស្សឲ្យសិក្សា នីហ្វៃទី ២២៩:៧–១១ជាដៃគូ ។ សូមអញ្ជើញពួកគេឲ្យស្វែងរកគោលបំណងរបស់ព្រះអម្ចាស់ក្នុងការឲ្យព្រះគម្ពីរបន្ថែមទៀតលើព្រះគម្ពីរបរិសុទ្ធ ។ ក្រោយពីរបីនាទី សូមពួកគេឲ្យចែកចាយពីអ្វីដែលពួកគេបានរកឃើញ ។ ចម្លើយដែលអាចមានគឺថា (១) ព្រះអម្ចាស់ចងចាំប្រជាជនទាំងអស់ និង បញ្ជូនព្រះបន្ទូលរបស់ទ្រង់ទៅគ្រប់ជាតិសាសន៍ទាំងអស់ (សូមមើលខគម្ពីរទី ៧) ; (២) ព្រះអម្ចាស់មានព្រះបន្ទូលនូវសារលិខិតដដែលទៅដល់ជាតិសាសន៍ទាំងអស់ ហើយព្រះគម្ពីរមរមន គឺជាសាក្សីទី ពីរមួយចំពោះសេចក្តីពិតនៅក្នុងព្រះគម្ពីរបរិសុទ្ធ (សូមមើលខគម្ពីរទី ៨) ; (៣) ព្រះអម្ចាស់តែងតែនៅដដែល ហើយទ្រង់មានបន្ទូល

សិស្សអនុវត្ត

នៅពេលអ្នកសុំឲ្យសិស្សអនុវត្តការពន្យល់ពីសេចក្តីពិតនៃដំណឹងល្អ នោះអ្នកផ្តល់ឱកាសមួយដល់ពួកគេដើម្បីទទួលបានការយល់ដឹងមួយជ្រាលជ្រៅជាងនេះអំពីសេចក្តីពិតទាំងនោះ និង រៀបចំបង្រៀនដំណឹងល្អដល់អ្នកដទៃ ។ (សូមចាំថា ត្រូវរក្សាតុល្យភាពរបស់អ្នកនៅក្នុងការប្រើរបៀបបង្រៀននេះ ។ គ្រូបង្រៀនមិនគួរបោះបង់តួនាទីរបស់ពួកគេចោល ហើយឲ្យសិស្សយកម៉ោងបង្រៀនក្នុងថ្នាក់នោះទេ) ។

ស្របតាមបំណងរបស់ទ្រង់ (សូមមើលខគម្ពីរទី ៩) ; (៤) កិច្ចការរបស់ព្រះមិនទាន់បានសម្រេចនៅឡើយទេ ហើយទ្រង់នឹងបន្តមានព្រះបន្ទូលដើម្បីសម្រេចកិច្ចការរបស់ទ្រង់ (សូមមើលខគម្ពីរទី ៩) ;(៥) ប្រជាជនមិនគួរស្មានថា ព្រះគម្ពីរបរិសុទ្ធមានន្ទូវព្រះបន្ទូលរបស់ព្រះអម្ចាស់ទាំងអស់ ឬ ថាព្រះអម្ចាស់មិនបានបណ្តាលឲ្យមានព្រះបន្ទូលថែមទៀតឲ្យកត់ត្រានោះ (សូមមើលខគម្ពីរទី ១០) ; និង (៦) ព្រះអម្ចាស់បញ្ជាប្រជាជននៅគ្រប់ជាតិទាំងអស់ឲ្យកត់ត្រាព្រះបន្ទូលរបស់ទ្រង់ (សូមមើល(ខគម្ពីរទី ១១) ។ តើម្បីជួយសិស្សឲ្យសង្ខេប និង អនុវត្តន្ទូវអ្វីដែលពួកគេបានរៀនពីផ្នែកនៃមេរៀននេះ សូមសួរសំណួរខាងក្រោមនេះខ្លះ ឬ ទាំងអស់ ៖

- តើនីហ្វៃទី ២ ២៩ អាចត្រូវបានប្រើដើម្បីដោះស្រាយការព្រួយបារម្ភអំពីព្រះគម្ពីរមរមនថាជាព្រះគម្ពីរបន្ថែមមួយដោយរបៀបណា ?
- តើខគម្ពីរទាំងនេះបានបង្កើនការកោតសរសើររបស់អ្នកសម្រាប់ព្រះគម្ពីរមរមនដោយរបៀបណា ?

សូមបែងចែកសិស្សជាដៃគូម្តងទៀត ។ សូមឲ្យពួកគេអនុវត្តការឆ្លើយសំណួរថា « ហេតុអ្វីបានជាពួកមរមនមានព្រះគម្ពីរបរិសុទ្ធមួយទៀត ? » សូមអញ្ជើញសិស្សម្នាក់ឲ្យសួរសំណួរ ហើយម្នាក់ទៀតឆ្លើយសំណួរនេះ ។ បន្ទាប់មក សូមឲ្យពួកគេប្តូរតួនាទីគ្នា ហើយធ្វើការពិភាក្សាគ្នានេះម្តងទៀត ។ នៅចុងបញ្ចប់នៃសកម្មភាពនេះ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគិតអំពីមនុស្សដែលពួកគេស្គាល់ដែលអាចមានជលប្រយោជន៍ពីការពិភាក្សាមួយនៃគោលការណ៍ទាំងនេះ និង ឲ្យស្វែងរកការណែនាំមកពីព្រះវិញ្ញាណបរិសុទ្ធអំពីរបៀបដើម្បីនិយាយជាមួយនឹងមនុស្សទាំងនេះ ។

នៅពេលអ្នកបញ្ចប់ផ្នែកនៃមេរៀននេះ សូមធានាថាសិស្សយល់ថា **ព្រះអម្ចាស់ចងចាំមនុស្សទាំងអស់ ហើយនឹងបញ្ជូនព្រះបន្ទូលរបស់ទ្រង់ចេញទៅដល់ពួកគេ ។**

នីហ្វៃទី ២ ៣០:១–៨

នីហ្វៃពន្យល់អំពីតួនាទី នៃព្រះគម្ពីរមរមននៅក្នុងថ្ងៃចុងក្រោយ

សូមពន្យល់ថា ក្រោយពីបានបង្រៀនថា ព្រះនឹងចងចាំវង្សនៃអ៊ីស្រាអែល នីហ្វៃបានព្រមានប្រជាជនរបស់គាត់មិនឲ្យគិតថាពួកគេសុចរិតជាងសាសន៍ដទៃឡើយ ។ គាត់ក៏បានរំឭកពួកគេថា មនុស្សទាំងអស់អាចក្លាយជារាស្ត្រក្នុងសេចក្តីសញ្ញារបស់ព្រះ ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ៣០:២ឮៗ ហើយសូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យស្វែងរករឿងពីរដែលយើងត្រូវតែធ្វើ ដើម្បីក្លាយជាផ្នែកនៃរាស្ត្រក្នុងសេចក្តីសញ្ញារបស់ព្រះ ។ សូមអញ្ជើញសិស្សឲ្យចែកចាយអ្វីដែលពួកគេរកឃើញ ។ សូមធានាថា ពួកគេយល់ថា **យើងក្លាយជាផ្នែកនៃរាស្ត្រក្នុងសេចក្តីសញ្ញារបស់ព្រះ នៅពេលយើងប្រែចិត្ត និង ជឿលើព្រះយេស៊ូវគ្រីស្ទ ។**

សូមពន្យល់ថានៅក្នុង នីហ្វៃទី ២ ៣០:៣ នីហ្វៃពិពណ៌នាពីរបៀបមួយដែលព្រះអម្ចាស់ប្រមូលរាស្ត្ររបស់ទ្រង់ទៅកាន់សេចក្តីសញ្ញានៅក្នុងថ្ងៃចុងក្រោយ ។ សូមអញ្ជើញសិស្សឲ្យអាន នីហ្វៃទី ២ ៣០:៣ ដោយស្ងាត់ស្ងៀម និង ស្វែងរកដំណើរការនេះ ។ (ព្រះអម្ចាស់បញ្ជូនមកន្ទូវព្រះគម្ពីរមរមន ។ មនុស្សជាច្រើនជឿលើព្រះគម្ពីរមរមន ហើយចែកចាយវាជាមួយនឹងអ្នកផ្សេង) ។ អ្នកអាចបង្ហាញថា នីហ្វៃបានលើកឡើងជាពិសេសថា ពាក្យនៃព្រះគម្ពីរមរមននឹងត្រូវបាននាំមក « ទៅដល់សំណល់នៃពូជយើង » ដែលមានន័យថាជាកូនចៅរបស់លីហៃ ។

សូមលើកទឹកចិត្តសិស្សឲ្យអាន នីហ្វៃទី ២ ៣០:៤–៨ ដោយស្ងាត់ស្ងៀម ដោយស្វែងរកឃ្លាដែលបង្ហាញពីរបៀបមនុស្សនឹងត្រូវបានប្រទានពរ នៅពេលពួកគេទទួលបានព្រះគម្ពីរមរមន ។

- តើកូនចៅរបស់លីហៃនឹងត្រូវបានប្រទានពរ នៅពេលពួកគេរៀនអំពីបព្វបុរសរបស់ពួកគេដោយរបៀបណា ?
- តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះ អំពីឥទ្ធិពលដែលព្រះគម្ពីរមរមនអាចមានមកលើមនុស្សទាំងអស់ ?

សូមធានាថា សិស្សយល់ថា **ព្រះគម្ពីរមរមនអាចជួយមនុស្សទាំងអស់ឲ្យស្គាល់ព្រះយេស៊ូវគ្រីស្ទ និង រស់នៅតាមដំណឹងល្អរបស់ទ្រង់ ។**អ្នកអាចសរសេរប្រយោគនេះនៅលើក្តារខៀន ។

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីជួយអ្នកដទៃឲ្យស្គាល់ព្រះយេស៊ូវគ្រីស្ទតាមរយៈព្រះគម្ពីរមរមន ?
- តើព្រះគម្ពីរមរមនបានជួយអ្នកឲ្យស្គាល់ព្រះអង្គសង្គ្រោះដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យភ្ជាប់បទពិសោធន៍មួយដែលពួកគេមាន ក្នុងការចែកចាយព្រះគម្ពីរមរមន ។ សូមលើកទឹកចិត្តសិស្សឲ្យអធិស្ឋានរកឱកាសដើម្បីចែកចាយព្រះគម្ពីរមរមនជាមួយនឹងអ្នកដទៃ ។

នីហ្វៃទី ២ ៣០:៩–១៨

នីហ្វៃពន្យល់អំពីស្ថានភាពនៃផែនដីអំឡុងពេលសហស្សវត្សរ៍

សូមពន្យល់ថា នីហ្វៃក៏បានព្យាករទាក់ទងនឹងសហស្សវត្សរ៍ —១០០០ ឆ្នាំ ក្រោយពីការយាងមកជាលើកទី ពីររបស់ព្រះអង្គសង្គ្រោះផងដែរ ។

សូមសង្ខេប នីហ្វៃទី ២ ៣០:៩–១០ ដោយការពន្យល់ថា នៅពេលព្រះអម្ចាស់យាងមកជាលើកទី ពីរ ពួកទុច្ចរិតនឹងត្រូវបានបំផ្លាញ ។ សូមឲ្យសិស្សអាន នីហ្វៃទី ២ ៣០:១២–១៨ដោយស្ងាត់ស្ងៀម ដោយស្វែងរកការពិពណ៌នាអំពីជីវិតអំឡុងពេលសហស្សវត្សរ៍ ។ សូមអញ្ជើញសិស្សឲ្យស្រមៃថា ពួកគេកំពុងសរសេរអត្ថបទកាសែតមួយអំឡុងពេលសហស្សវត្សរ៍ ដោយពិពណ៌នាពីស្ថានភាពមួយដែលពួកគេបានរកឃើញ ។ សូមឲ្យពួកគេសរសេរចំណងជើងសម្រាប់អត្ថបទនោះ ហើយចែកចាយចំណងជើងរបស់ពួកគេជាមួយនឹងគ្នាទៅវិញទៅមក ។

- ក្នុងចំណោមស្ថានភាពសហស្សវត្សរ៍ដែលអ្នកបានសិក្សានៅក្នុងនីហ្វៃទី ២ តើមួយណាដែលអ្នកទន្ទឹងរង់ចាំខ្លាំងបំផុតនោះ ? ហេតុអ្វី ?

សូមដឹកនាំការយកចិត្តទុកដាក់របស់សិស្សទី ប្រយោគខាងក្រោមនៅក្នុង នីហ្វៃទី ២ ៣០:១៨ ៖ « អារក្សសាតាំងនឹងគ្មានអំណាចទៅលើដួងចិត្តនៃកូនចៅមនុស្សទៀតទេ គឺអស់រយៈពេលជាយូរយារ » ។ អ្នកអាចស្នើថា សិស្សគូរតែគូសចំណាំប្រយោគនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

- ហេតុអ្វីបានជាវាមានប្រយោជន៍ដើម្បីដឹងថា សេចក្តីសុចរិតនឹងមានជ័យជំនះលើសេចក្តីទុច្ចរិតនៅទី បញ្ចប់នោះ ?

ក្រោយពីសិស្សបានឆ្លើយហើយ សូមថ្លែងទីបន្ទាល់ថា **អារក្សសាតាំងនឹងគ្មានអំណាចទៅលើដួងចិត្តនៃកូនចៅមនុស្សអំឡុងពេលសហស្សវត្សរ៍ឡើយ ហើយសេចក្តីសុចរិត និង សេចក្តីសុខសាន្តនឹងយកឈ្នះ ។**សូមអញ្ជើញសិស្សម្នាក់ឲ្យអានឲ្យ ៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ចច យ្យូ ខានុន នៃគណៈប្រធានទីមួយ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមូលហេតុ ដែលអារក្សសាតាំងនឹងគ្មានអំណាចអំឡុងពេលសហស្សវត្សរ៍ ។

« យើងនិយាយអំពីសាតាំងដែលត្រូវគេចង ។ សាតាំងនឹងត្រូវចងដោយព្រះចេស្តានៃព្រះ ប៉ុន្តែវានឹងត្រូវចងដោយការសម្រេចចិត្តរបស់វាស្ត្រនៃព្រះដែលមិនបានស្តាប់តាមវា ដែលមិនត្រូវបានគ្រប់គ្រងដោយវាផងដែរ ។ ព្រះអម្ចាស់នឹងមិនចងវា ហើយយកអំណាចរបស់វាចេញពីផែនដី ខណៈពេលដែលមានបុរស និង ស្ត្រីដែលមានបំណងឲ្យវាគ្រប់គ្រងនោះ ។ នោះគឺផ្ទុយទៅនឹងផែនការសង្ត្រោះ ។ ការដកហូតសិទ្ធិជ្រើសរើសរបស់មនុស្សចេញពីគេ គឺផ្ទុយទៅនឹងគោលបំណងនៃព្រះរបស់យើង ។ មានពេលមួយនៅលើទ្វីបនេះ ដែលយើងមានដំណើររឿងមួយ នៅពេលប្រជាជនសុចរិតខ្លាំង រហូតដល់សាតាំងគ្មានអំណាចនៅក្នុងចំណោមពួកគេ ។ ជិតបួនជំនាន់កន្លងទៅនៅក្នុងសេចក្តីសុចរិត ។ ពួកគេបានរស់នៅដោយបរិសុទ្ធភាព ហើយបានស្លាប់ដោយគ្មានអំពើបាបឡើយ ។ នោះគឺតាមរយៈការបដិសេធរបស់ពួកគេដើម្បីធ្វើឲ្យសាតាំងចុះចាញ់ ។ វាមិនត្រូវបានកត់ត្រាថា សាតាំងគ្មានអំណាចនៅផ្នែកផ្សេង ៗទៀតនៃផែនដីអំឡុងពេលនោះទេ ។ យោងតាមប្រវត្តិសាស្ត្រទាំងអស់ដែលយើងមានជាកម្មសិទ្ធិរបស់យើង សាតាំងបានមានអំណាចដូចគ្នាទៅលើមនុស្សដែលមានបំណងស្តាប់តាមវា ។ ប៉ុន្តែនៅក្នុងដែនដីនេះ វាមិនមានអំណាចអ្វីឡើយ ហើយវាត្រូវចងពិតមែន ។ ខ្ញុំជឿថា នេះនឹងជាការណីមួយនៅក្នុងសហស្សវត្សរ៍ ហើយខ្ញុំផ្អែកលើវា នៅពេលខ្ញុំធ្វើតាមស្ថានភាពដ៏រីករាយនោះដែលត្រូវបានពិពណ៌នានៅក្នុងកំណត់ត្រាដែលខ្ញុំបាននិយាយនេះ ។ ខ្ញុំសង្ឃឹមថា មុនពេលសាតាំងត្រូវគេចងទាំងស្រុង ពួកទុច្ចរិតនឹងត្រូវបានបំផ្លាញ » (នៅក្នុងរបាយការណ៍សន្ទិសីទ ខែ តុលា ឆ្នាំ ១៨៩៧ ទំព័រ ៦៥) ។

- តើសាតាំងនឹងត្រូវចង ក្នុងពេលសហស្សវត្សរ៍ដោយរបៀបណា ?

សូមលើកទឹកចិត្តសិស្សឲ្យរស់នៅដោយសុចរិត ដូច្នេះឧបសគ្គនឹងគ្មានអំណាចមកលើពួកគេនោះទេ ។

គំនិតជំនួយបន្ថែមសម្រាប់ការបង្រៀន

នីហ្វៃទី ២ ២៩:១២–១៤ ។ តើអ្វីខ្លះ ជាពរជ័យនៃកំណត់ត្រាខាងព្រះគម្ពីរបន្ថែម ?

សូមឲ្យសិស្សអាន នីហ្វៃទី ២ ២៩:១២–១៤ ដោយស្ងាត់ស្ងៀម ដោយស្វែងរកអ្វីដែលនឹងកើតឡើងនៅក្នុងថ្ងៃចុងក្រោយជាមួយនឹងព្រះបន្ទូលទាំងអស់ដែលព្រះបានបញ្ជាឲ្យសរសេរពេញទាំងផែនដី ។

- តើអ្នកគិតថា មនុស្សខុសគ្នាក្នុងពិភពលោកនេះ នឹងទទួលប្រយោជន៍ពីការមានកំណត់ត្រារបស់គ្នាទៅវិញទៅមកដោយរបៀបណា ?

អែលឌើរ នែល អេ. ម៉ាក់ស្វែល នៃក្លុ៉មនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា កំណត់ត្រាផ្សេងទៀតនឹងចេញមកដើម្បីថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ៖

« ព្រះគម្ពីរដែលបាត់ទៅ គឺនៅក្នុងចំណោមរតនសម្បត្តិដែលមិនទាន់ចេញមកនៅឡើយ ។ ជាងម្ភៃព្រះគម្ពីរនៃគម្ពីរទាំងនេះ ត្រូវបានលើកឡើងនៅក្នុងព្រះគម្ពីរដែលនៅមាន ។ ប្រហែលវគ្គមុនគេ និង ច្រើនជាងគេបង្អស់ នឹងជាកំណត់ត្រានៃកុលសម្ព័ន្ធនៃអ៊ីស្រាអែលដែលបានបាត់ទៅ (សូមមើល នីហ្វៃទី ២ ២៩:១៣) ។ យើងមិនដឹងសូម្បីតែការជិតចេញមកនៃសាក្សីទី បីសម្រាប់ព្រះគ្រីស្ទ លើកលែងតែតាមរយៈព្រះគម្ពីរមរមនដ៏មានតម្លៃប៉ុណ្ណោះជាសាក្សីទីពីររបស់ព្រះគ្រីស្ទ ! ហេតុដូច្នេះហើយ កំណត់ត្រាទី បីដ៏ពិសិដ្ឋទាំងអស់នេះ នឹងបំពេញសេចក្តីពិតនៃវត្ថុទាំងបី ។ បន្ទាប់មក គឺដូចជាអ្នកគង្វាលដ៏ឥតខ្ចោះបាននិយាយដែរថា ‹ ពាក្យរបស់យើង ក៏នឹងប្រមូលមកតែមួយដែរ › (ខគម្ពីរទី ១៤) ។ វានឹងមាន ‹ ចៀមមួយហ្វូង និង អ្នកគង្វាលមួយ › (នីហ្វៃទី ១ ២២:២៥) ក្នុងការភ្ជាប់គ្នាទាំងមូលរួមគ្នានៃគ្រាកាន់កាប់ពួកគ្រីស្ទានទាំងអស់នៃប្រវត្តិសាស្ត្រមនុស្សជាតិ (សូមមើល គ . និង ស . ១២៨:១៨) » (« God Will Yet Reveal »*Ensign*ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ទំព័រ ៥២) ។

នីហ្វៃទី ២ ៣១

សេចក្តីផ្តើម

ជាច្រើនឆ្នាំមុនពេលព្រះយេស៊ូវគ្រីស្ទប្រសូត នីហ្វៃបានទទួលវិវរណៈមួយអំពីពិធីបុណ្យជ្រមុជទឹករបស់ព្រះអង្គសង្គ្រោះ ។ នៅពេលនីហ្វៃបានប្រាប់ប្រជាជនរបស់គាត់អំពីវិវរណៈនេះ គាត់បានបង្រៀនអ្វីដែលគាត់ហៅថា « គោលលទ្ធិនៃព្រះគ្រីស្ទ » — ដែលថាដើម្បីទទួលបាននូវជីវិតដ៏នៅអស់កល្បជានិច្ច យើងត្រូវតែអនុវត្តសេចក្តីជំនឿរបស់យើងនៅក្នុងព្រះយេស៊ូវគ្រីស្ទ ប្រែចិត្តពីអំពើបាបរបស់យើង ទទួលពិធីបុណ្យជ្រមុជទឹក ទទួលព្រះវិញ្ញាណបរិសុទ្ធ និងតស៊ូដល់ទីបញ្ចប់ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃ ២ ៣១:១-១៣

នីហ្វៃបង្រៀនថា នៅពេលយើងទទួលពិធីបុណ្យជ្រមុជទឹក យើងនឹងធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ

សូមចាប់ផ្តើមថ្នាក់ដោយការសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- តើអ្នកចងចាំអ្វីខ្លះអំពីពិធីបុណ្យជ្រមុជទឹករបស់អ្នក ? តើអ្នកបានមានអារម្មណ៍យ៉ាងណាដែរ នៅពេលអ្នកបានទទួលបានបុណ្យជ្រមុជទឹកនោះ ?

សូមពន្យល់ថា នៅពេលសិស្សបានជ្រមុជទឹក ពួកគេកំពុងធ្វើតាមគំរូមួយដែលតែងតែជាផ្នែកមួយនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទជានិច្ច ។ នីហ្វៃបានប្រើឃ្លាមួយចំនួនដើម្បីយោងទៅគំរូនេះ ។ សូមអញ្ជើញសិស្សឲ្យស្រាវជ្រាវរកឃ្លាមួយដែលមាននៅក្នុង នីហ្វៃទី ២ ៣១:២ និង នីហ្វៃទី ២ ៣១:២១ ។ ក្រោយពីពួកគេបានរកឃើញឃ្លាថា « គោលលទ្ធិនៃព្រះគ្រីស្ទ » ហើយ សូមសួរថា ៖

- តើពាក្យ ឬ ឃ្លាអ្វីនៅក្នុង នីហ្វៃទី ២ ៣១:២, ២១ ដែលស្នើពីសារៈសំខាន់នៃ « គោលលទ្ធិនៃព្រះគ្រីស្ទ » នេះ ? (ចម្លើយអាចរួមមាន « ខ្ញុំត្រូវតែនិយាយអំពី » « គ្មានផ្លូវឯណាទៀតទេ » និង « គោលលទ្ធិតែមួយ ហើយពិត ») ។

សូមបង្ហាញរូបភាព យ៉ូហាន បាទី ស្ទ ជ្រមុជទឹកឲ្យព្រះយេស៊ូវ (៦២១៣៣ ; *សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ | លេខ ៣៥) ។ សូមអញ្ជើញសិស្សឲ្យសិក្សា នីហ្វៃទី ២ ៣១:៥–៩ ដោយស្ងាត់ស្ងៀម ដោយស្វែងរកឃ្លាដែលបញ្ជាក់ពីមូលហេតុព្រះយេស៊ូវគ្រីស្ទត្រូវជ្រមុជទឹក ។ (អ្នកអាចស្នើថា ពួកគេគួរតែគូសចំណាំឃ្លាទាំងនេះទុក) ។ ក្រោយពីរបីនាទី មក សូមឲ្យសិស្សអានឃ្លាដែលពួកគេបានរកឃើញនោះ ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដែរដើម្បី « បំពេញសេចក្តីសុចរិតគ្រប់យ៉ាង » នោះ ? (ក្រោយពីសិស្សបានឆ្លើយហើយ អ្នកអាចពន្យល់ថា វាមានន័យថាការកាន់តាមព្រះបញ្ញត្តិទាំងឡាយ ។ ប្រធាន យ៉ូសែប អេហ្វ. ស្ម៊ីធ បាននិយាយថា « ដើម្បីបំពេញសេចក្តីសុចរិតគ្រប់យ៉ាង » គឺត្រូវ « បំពេញច្បាប់ » | នៅក្នុងរបាយការណ៍សន្និសីទ ខែ មេសា ឆ្នាំ ១៩១២ ទំព័រ ៩ |) ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ៣១:១០–១២ ឮៗ ។

- តើខគម្ពីរទាំងនេះពន្យល់ពីសារៈសំខាន់នៃពិធីបុណ្យជ្រមុជទឹកដោយរបៀបណា ? (នីហ្វៃបង្រៀនថា ពិធីបុណ្យជ្រមុជទឹកគឺជាព្រះបញ្ញត្តិមួយមកពីព្រះវរបិតាសួគ៌ ដែលវាតម្រូវដើម្បីទទួលបានអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ហើយថាវាចាំបាច់ខំឲ្យអស់ពីការខិតខំរបស់យើងដើម្បីធ្វើតាមព្រះយេស៊ូវគ្រីស្ទ) ។

សូមឲ្យសិស្សសង្ខេបពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលពួកគេបានរៀនពី នីហ្វៃទី ២ ៣១:៥–១២ ។ នៅពេលពួកគេចែកចាយគំនិតរបស់ពួកគេ សូមធានាថា ពួកគេយល់ពីគោលការណ៍ដូចខាងក្រោមនេះ ៖

ព្រះយេស៊ូវគ្រីស្ទបានធ្វើជាគំរូដ៏ឥតខ្ចោះនៃការគោរពប្រតិបត្តិសម្រាប់យើងឲ្យធ្វើតាម ។

យើងត្រូវតែធ្វើតាមព្រះយេស៊ូវគ្រីស្ទ ទទួលបុណ្យជ្រមុជទឹក និង ទទួលព្រះវិញ្ញាណបរិសុទ្ធ ។

ទោះបីជាគ្មានអំពើបាបក្តី ព្រះយេស៊ូវគ្រីស្ទក៏នៅតែត្រូវជ្រមុជទឹកដើម្បីបំពេញសេចក្តីសុចរិតគ្រប់យ៉ាងដែរ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ៣១:១៣ឮៗ ។ សូមដឹកនាំការយកចិត្តទុកដាក់របស់សិស្សទៅលើឃ្លាថា « ដោយពេញចិត្តប្រាថ្នា » « ពុំមានការលាក់ពុត ឬ ការបោកបញ្ឆោតនៅចំពោះព្រះឡើយ » និង « ដោយស្មោះអស់ពីចិត្ត » ។ អ្នកអាចស្នើថា ពួកគេគួរតែគូសចំណាំឃ្លាទាំងនេះទុក ។

- តើឃ្លាទាំងនេះមានន័យយ៉ាងណាចំពោះអ្នក ? (អ្នកអាចបង្ហាញថា ឃ្លាទាំងបីនេះសំដៅទៅលើតម្រូវការដើម្បីស្មោះត្រង់នៅក្នុងការខិតខំរបស់យើងដើម្បីអនុវត្តសេចក្តីជំនឿទៅលើព្រះអង្គសង្គ្រោះ ប្រែចិត្តពីអំពើបាបរបស់យើង និង ធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់អំពីរបៀបដើម្បីធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះតាមស្ថានភាពជាច្រើននោះ សូមសួរសំណួរដូចខាងក្រោម ៖

- តើឃ្លាទាំងនេះអាចអនុវត្តចំពោះសកម្មភាពដូចជា ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ និង ការទៅព្រះវិហារដោយរបៀបណា ?
- តើមានភាពខុសគ្នាអ្វីរវាង « ការនិយាយអធិស្ឋាន » និង ការអធិស្ឋាន « ដោយពេញចិត្តប្រាថ្នា » នោះ ?

- តើមានភាពខុសគ្នាអ្វីរវាងការទទួលទានសាក្រាម៉ង់នំប៉័ង និង ការទទួលទានសាក្រាម៉ង់នំប៉័ង « ដោយស្មោះអស់ពីចិត្ត » នោះ ?
- តើមានភាពខុសគ្នាអ្វីរវាងការនិយាយថាអ្នកសុំទោសអំពីអ្វីមួយដែលអ្នកបានធ្វើ និង ការប្រែចិត្ត « ដោយពេញចិត្តក្រាថ្នា » នោះ ?

នីហ្វៃទី ២ ៣១:១៤–២១

នីហ្វៃបង្រៀនថា ក្រោយពីពិធីបុណ្យជ្រមុជទឹក យើងត្រូវទទួលព្រះវិញ្ញាណបរិសុទ្ធ ហើយបន្តធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ ៖

សូមពន្យល់ថា នីហ្វៃបាននិយាយអំពីទ្វារមួយចូលទៅផ្លូវមួយ ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ៣១:១៧–១៨ ឲ្យឮៗ ។ នៅពេលសិស្សអានចប់ហើយ សូមគូសរូបសាមញ្ញមួយដូចខាងក្រោមនៅលើក្តារខៀន ៖



រូប

រូបនៅលើក្តារខៀន អាចជួយសិស្សឲ្យយល់ពីគំនិតអ្ស់បីយនេះបាន ។ នៅពេលអ្នកគូសនៅលើក្តារខៀន សូមចងចាំថា គំនូរដែលសាមញ្ញជាធម្មតា វាប្រសើរជាងរូបស្មុគស្មាញមួយ ។ ជាធម្មតា វាគឺជាគំនិតដ៏ល្អមួយដើម្បីគូសរូបនេះសាកពីបីដង មុនពេលសិស្សមកដល់ក្នុងថ្នាក់ ។ ប្រសិនបើអ្នកមិនប្រសប់គូរូបលើក្តារខៀននោះទេ សូមគិតសុំឲ្យសិស្សម្នាក់គូរឲ្យអ្នក ។

- ដោយផ្អែកលើ នីហ្វៃទី ២ ៣១:១៧ តើអ្វីជាទ្វារទៅ ? (ការប្រែចិត្ត និង ពិធីបុណ្យជ្រមុជទឹក ។ *សូមសរសេរ ការប្រែចិត្ត និង ពិធីបុណ្យជ្រមុជទឹក* ពីក្រោមទ្វារនោះ) ។ តើការប្រែចិត្ត និង ពិធីបុណ្យជ្រមុជទឹកដូចជាទ្វារមួយដោយរបៀបណា ?
- ដោយយោងតាម នីហ្វៃទី ២ ៣១:១៨ តើផ្លូវនោះនាំទៅរកអ្វី ? (ជីវិតដ៏នៅអស់កល្បជានិច្ច ។ *សូមសរសេរ ជីវិតដ៏នៅអស់កល្បជានិច្ច* នៅចុងបញ្ចប់នៃផ្លូវនោះ ។ អ្នកគួរតែពន្យល់ថាឃ្លា « ជីវិតដ៏នៅអស់កល្បជានិច្ច » សំដៅទៅលើការតម្កើងឡើងនៅក្នុងនគរសេឡេស្ទាល) ។
- នីហ្វៃបានបង្រៀនថា ក្រោយពីពិធីបុណ្យជ្រមុជទឹកហើយ យើងនឹងទទួលបានអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ (សូមមើល នីហ្វៃទី ២ ៣១:១៣–១៤) ។ ដោយយោងតាម នីហ្វៃទី ២ ៣១:១៧–១៨ តើព្រះវិញ្ញាណបរិសុទ្ធធ្វើអ្វីសម្រាប់យើង ? (សូមជួយសិស្សឲ្យយល់ថា **ព្រះវិញ្ញាណបរិសុទ្ធធ្វើជាសាក្សីដល់ព្រះវរបិតា និង ព្រះរាជបុត្រា និង នាំមកនូវការផ្តាច់បាបមួយ) ។**
- ហេតុអ្វីបានជាវាចាំបាច់សម្រាប់យើងដើម្បីទទួលបានទីបន្ទាល់មួយអំពីព្រះវរបិតា និង ព្រះរាជបុត្រាតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ?

ដើម្បីជួយសិស្សឲ្យយល់ពីតួនាទីរបស់ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងការផ្តាច់បាប អ្នកគួរតែពន្យល់ឃ្លា « បុណ្យជ្រមុជដោយភ្លើង និង ដោយព្រះវិញ្ញាណបរិសុទ្ធ » (នីហ្វៃទី ២ ៣១:១៣–១៤ ; សូមមើលផងដែរខគម្ពីរទី ១៧) ។ សូមអញ្ជើញសិស្សម្នាក់ឲ្យអានន្ទរសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ. បែដណា នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកនូវអ្វីដែលមានអត្ថន័យ ក្នុងការជ្រមុជដោយភ្លើង និង ដោយព្រះវិញ្ញាណបរិសុទ្ធ ។

« ទ្វារនៃពិធីបុណ្យជ្រមុជទឹក នាំទៅរកផ្លូវតូច ហើយចង្អៀត ។ . . .

« យើងត្រូវបានបញ្ជា និង ណែនាំឲ្យរស់នៅដូច្នោះ ដើម្បីឲ្យស្ថានភាពធ្លាក់របស់យើងត្រូវប្តូរតាមរយៈអំណាចបន្សុទ្ធនៃព្រះវិញ្ញាណបរិសុទ្ធ ។ ប្រធាន ម៉ារ៉ុន ជី. រ៉មនី បានបង្រៀនថា បុណ្យជ្រមុជភ្លើងដោយព្រះវិញ្ញាណបរិសុទ្ធ ‹ បានប្រែចិត្ត | យើង | ឲ្យជឿពីភាពខាងសាច់ឈាម ទៅភាពខាងវិញ្ញាណ ។ វាសម្អាត ព្យាបាល និង បន្សុទ្ធព្រលឹង ។ . . . សេចក្តីជំនឿទៅលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ការប្រែចិត្ត និង ពិធីបុណ្យជ្រមុជទឹក ទាំងអស់គឺជាការដំបូង និង ត្រូវការជាមុនចំពោះវា ប៉ុន្តែ | បុណ្យជ្រមុជដោយភ្លើង | គឺជាការបំពេញមួយ ។ ដើម្បីទទួលបាន | បុណ្យជ្រមុជដោយភ្លើងនេះ | គឺដើម្បីឲ្យសំលៀកបំពាក់របស់មនុស្សម្នាក់ត្រូវបានសម្អាតនៅក្នុងព្រះលោហិតដ៏ថ្លៃនៃព្រះយេស៊ូវគ្រីស្ទ › (*Learning for the Eternities,* comp. George J. Romney | ឆ្នាំ ១៩៧៧ | ទំព័រ ១៣៣ ; សូមមើលផងដែរនីហ្វៃទី ៣ ២៧:១៩–២០) ។

« ហេតុដូច្នេះហើយ នៅពេលយើងត្រូវបានកើតម្តងទៀត ហើយតស៊ូដើម្បីឲ្យមានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយនឹងយើងជានិច្ច នោះព្រះវិញ្ញាណបរិសុទ្ធនឹងបន្សុទ្ធ និង សម្រិតព្រលឹងយើងដោយសារភ្លើង (សូមមើល នីហ្វៃទី ២ ៣១:១៣–១៤ , ១៧) ។ ទី បំផុត យើងត្រូវឈរដោយស្អាតនៅចំពោះព្រះ » (« Clean Hands and a Pure Heart » *Ensign*ឬ*លីអាហូណា*ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៨១) ។

- តើអែលឌើរ ប៊ែដណា និង ប្រធាន រ៉ូមនី បាននិយាយថា « បុណ្យជ្រមុជដោយភ្លើង » ធ្វើអ្វីខ្លះសម្រាប់យើង ?
- តើពរជ័យបន្ថែមទាំងឡាយអ្វីខ្លះ ដែលយើងអាចទទួលបានតាមរយៈឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ?
- តើអ្នក « តស៊ូដើម្បីឲ្យមានព្រះវិញ្ញាណរបស់ទ្រង់ » គង់នៅជាមួយនឹងអ្នកជានិច្ចដោយរបៀបណា ?
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះវិញ្ញាណបរិសុទ្ធកំពុងធ្វើសក្ខីភាពនៅក្នុងជីវិតរបស់អ្នក ?

សូមពន្យល់ថានៅក្នុង នីហ្វៃទី ២ ៣១:១៨ ពាក្យ *គួច* មាននំយថា ចង្អៀត តឹងតែង ច្បាស់លាស់ និង មិនឲ្យមានការរៀចវេរឡើយ ។ នីហ្វៃបានប្រើពាក្យនេះដើម្បីរៀបរាប់ពីផ្លូវដែលយើងត្រូវតែដើរតាម ក្រោយពីធ្វើបុណ្យជ្រមុជទឹកហើយ ដើម្បីទទួលបាននូវជីវិតដ៏នៅអស់កល្បជានិច្ច ។ សូមឲ្យសិស្សសញ្ជឹងគិតដោយស្ងប់ស្ងាត់នូវសំណួរខាងក្រោមនេះ ៖

- តើយើងត្រូវធ្វើអ្វីខ្លះ ក្រោយពីជ្រមុជទឹកហើយ ដើម្បីបន្តនៅលើផ្លូវទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ចនោះ ?

នៅពេលសិស្សសញ្ជឹងគិតអំពីសំណួរនេះ សូមអញ្ជើញពួកគេឲ្យស្វែងរកចម្លើយនៅក្នុង នីហ្វៃទី ២ ៣១:១៥–១៦, ១៩–២១ ។ អ្នកអាចស្នើថា ពួកគេគួរតែគូសចំណាំពាក្យ ឬ ឃ្លាដែលពន្យល់ពីអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបាននូវជីវិតដ៏នៅអស់កល្បជានិច្ច ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានគូសចំណាំនោះ ។ នៅពេលពួកគេឆ្លើយ សូមសរសេរចម្លើយរបស់ពួកគេដាក់លើក្តារខៀន ។ រូបរបស់អ្នក គួរតែមើលទៅដូចនេះ ៖



នីហ្វៃទី ២ ៣១:១៩–២០ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងវគ្គនៃចំណេះចំណានខគម្ពីរនេះ ។

សូមធានាថា សិស្សយល់ថា **ប្រសិនបើយើងរស់នៅតាមគោលលទ្ធិនៃព្រះគ្រីស្ទ យើងនឹងទទួលបាននូវជីវិតដ៏នៅអស់កល្បជានិច្ច ។** ដើម្បីបញ្ចប់មេរៀននេះ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ២ ៣១:២០ ឮៗ ។ សូមបង្ហាញថា នីហ្វៃទី ២ ៣១:១៩–២០ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំវគ្គនេះឲ្យប្លែកពីគេ ដើម្បីពួកគេអាចរកវាឃើញដោយងាយស្រួល ។ សូមអញ្ជើញពួកគេឲ្យឆ្លើយនឹងសំណួរមួយខាងក្រោមនេះ នៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេ ៖

- ដោយផ្អែកលើអ្វីដែលអ្នកបានសិក្សានៅក្នុងមេរៀននេះ តើអ្វីដែលផ្តល់ក្តីសង្ឃឹមថា អ្នកអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចនោះ ?
- តើសេចក្តីសញ្ញាដែលអ្នកបានធ្វើនៅពេលជ្រមុជទឹក បានជះឥទ្ធិពលលើជីវិតរបស់អ្នកដូចម្តេចខ្លះ ?

ចំណេះចំណានខគម្ពីរ—នីហ្វៃទី ២ ៣១:១៩–២០

សូមចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រីឆាដ ជី. ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« អំណាចដ៏អស្ចារ្យ អាចមកពីការទន្ទេញចាំព្រះគម្ពីរ ។ ដើម្បីទន្ទេញចាំព្រះគម្ពីរមួយ គឺត្រូវបង្កើតមិត្តភាពមួយថ្មី ។ វាដូចជាការរកឃើញបុគ្គលថ្មីមួយដែលអាចជួយក្នុងពេលត្រូវការ ផ្តល់ការបំផុសគំនិត និង ការលួងលោម និង ជាប្រភពមួយនៃការជម្រុញសម្រាប់ការផ្លាស់ប្តូរដែលចាំបាច់ » («The Power of Scripture » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៦) ។

នៅលើបដាមួយ (ឬ ក្រដាសមួយសន្លឹក) *សូមសរសេរ ខ្ញុំបានទន្ទេញចាំ នីហ្វៃទី ២ ៣១:១៩–២០ ។*សូមដាក់បដានោះនៅកន្លែងមួយដែលសិស្សគ្រប់គ្នាមើលឃើញវា ។ សូមប្រជែងសិស្សឲ្យទន្ទេញវគ្គនេះដោយខ្លួនឯង ឬ ជាមួយនឹងគ្រួសាររបស់ពួកគេ ។ សូមអញ្ជើញពួកគេឲ្យចុះហត្ថលេខាលើបដានោះនៅថ្ងៃបន្ទាប់ ពេលពួកគេបានទន្ទេញចាំវគ្គនេះហើយ ។ ប្រសិនបើពួកគេធ្វើការជាមួយនឹងគ្រួសាររបស់ពួកគេដើម្បីទន្ទេញវា ពួកគេក៏អាចសរសេរឈ្មោះសមាជិកគ្រួសាររបស់ពួកគេដាក់លើបដានោះបានដែរ ។ សូមចាំថាត្រូវកែតម្រូវការប្រជែងនេះដល់សមត្ថភាព និង កាលៈទេសៈរបស់បុគ្គលដើម្បីឲ្យសិស្សម្នាក់ៗអាចបានជោគជ័យ ។

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីគុណតម្លៃនៃការទន្ទេញចាំព្រះគម្ពីរ ដូចជា នីហ្វៃទី២ ៣១:១៩–២០ ដែលមានពាក្យនៃក្តី សង្ឃឹមនេះ ។

កំណត់ចំណាំ ៖ ដោយសារតែលក្ខណៈ និង ចិរវេលានៃមេរៀនថ្ងៃនេះ អ្នកអាចប្រើសកម្មភាពនេះនៅថ្ងៃក្រោយ នៅពេលដែលអ្នកមានពេលគ្រប់គ្រាន់ ។

មេរៀនសិក្សានៅផ្ទះ

នីហ្វៃទី ២ ២៦–៣១ (មេរៀនទី ៨)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀននៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនការសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និង គោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេសិក្សាក្នុង នីហ្វៃទី ២ ២៦–៣១ (មេរៀនទី ៨) មិនមែនមានបំណងដើម្បីត្រូវបានបង្រៀនជាផ្នែកមួយនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីទាំងនេះទេ ។ សូមធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណ នៅពេលអ្នកគិតអំពីតម្រូវការនៃសិស្សរបស់អ្នក ។

ថ្ងៃទី ១ (នីហ្វៃទី ២ ២៦–២៧)

សិស្សបានសិក្សាពីការព្យាករណ៍ទាំងឡាយរបស់នីហ្វៃដែលទាក់ទងនឹងថ្ងៃចុងក្រោយ ។ ពួកគេបានដឹងថា អ្វីៗដែលព្រះអម្ចាស់ធ្វើ គឺដើម្បីជាប្រយោជន៍ដល់ពិភពលោក ហើយថាព្រះអម្ចាស់ទ្រង់ស្រឡាញ់មនុស្សទាំងអស់ ហើយអញ្ជើញទាំងអស់គ្នាឲ្យមករកទ្រង់ ហើយទទួលទានសេចក្តីសង្គ្រោះរបស់ទ្រង់ ។ សិស្សក៏បានរកឃើញពីសេចក្តីពិតថា ការចេញមកនៃព្រះគម្ពីរមរមនគឺជារបៀបមួយដែលព្រះនឹងសម្រេចកិច្ចការរបស់ទ្រង់នៅក្នុងថ្ងៃចុងក្រោយ ។ បន្ថែមលើនេះ ពួកគេបានដឹងថា ព្រះគម្ពីរមរមន និង ដំណឹងល្អដែលបានស្តារឡើងវិញនោះ នឹងនាំមកនូវសេចក្តីអំណរ និង ការយល់ដឹងដល់អស់អ្នកទាំងឡាយណាដែលសិក្សា និង ទទួលយកវា ។

ថ្ងៃទី២ (នីហ្វៃទី ២ ២៨)

ខណៈពេលដែលកំពុងសិក្សាពីការព្រមានរបស់នីហ្វៃអំពីការបង្រៀនក្លែងក្លាយទូទៅនៅក្នុងថ្ងៃចុងក្រោយនោះ សិស្សបានដឹងថា ព្រះគម្ពីរមរមនបង្ហាញពីលទ្ធិក្លែងក្លាយរបស់អារក្ស និង ពង្រឹងយើងទាស់នឹងការចនាដ៏អាក្រក់របស់វា ។ លើសពីនេះ ពួកគេបានដឹងពីរបៀបដែលសាតាំងប្រើវិធីសាស្ត្រជាច្រើនដើម្បីព្យាយាមគ្រប់គ្រងយើង ដូចជាការចាក់រុកឲ្យយើងមានកំហឹង ការបង្ក្រាបយើង និង បំពេរយើង និង ការបញ្ឆោតយើង ។

ថ្ងៃទី៣ (នីហ្វៃទី ២ ២៩–៣០)

សិស្សបានដឹងថា ព្រះអម្ចាស់ផ្តល់ព្រះគម្ពីរមកដើម្បីប្រមូលវាស្ត្រេទៅកាន់សេចក្តីសញ្ញារបស់ទ្រង់ ហើយថាព្រះគម្ពីរមរមនអាចជួយមនុស្សទាំងអស់ឲ្យស្គាល់ព្រះយេស៊ូវគ្រីស្ទ និង រស់នៅតាមដំណឹងល្អរបស់ទ្រង់ ។ ព្រះអម្ចាស់បានបង្ហាញនីហ្វៃថា មនុស្សជាច្រើននៅថ្ងៃចុងក្រោយនឹងបដិសេធព្រះគម្ពីរមរមន ។ សិស្សមានឱកាសមួយដើម្បីគិតអំពីជីវិតផ្ទាល់របស់ពួកគេ និង ពីរបៀបដែលសហគមន៍របស់គេនឹងខុសគ្នាយ៉ាងណា អំឡុងពេលសហស្សវត្សរ៍ ដោយសារអារក្សសាតាំងនឹងគ្មានអំណាចមកលើដួងចិត្តនៃកូនចៅមនុស្សទៀតឡើយ ហើយសេចក្តីសុចរិត និង សេចក្តីសុខសាន្តនឹងយកឈ្នះ ។

ថ្ងៃទី៤ (នីហ្វៃទី ២ ៣១)

សេចក្តីពិតខាងក្រោមដែលទាក់ទងនឹងគោលលទ្ធិនៃព្រះគ្រីស្ទ និង គំរូរបស់ព្រះអង្គសង្គ្រោះត្រូវបានបញ្ជាក់ថា ៖ ព្រះយេស៊ូវគ្រីស្ទ បានបំពេញសេចក្តីសុចរិតគ្រប់យ៉ាង ដោយការគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះវរបិតា ហើយយើងត្រូវតែធ្វើតាមគំរូនៃការគោរពប្រតិបត្តិរបស់ព្រះយេស៊ូវគ្រីស្ទ ដោយការជ្រមុជទឹក និង ការទទួលព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះវិញ្ញាណបរិសុទ្ធធ្វើបន្ទាល់អំពីព្រះវរបិតា និង អំពីព្រះរាជបុត្រា ហើយនាំមកនូវការផ្តាច់បាប ។ ប្រសិនបើយើងរស់នៅតាមគោលលទ្ធិនៃព្រះគ្រីស្ទ យើងនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

សេចក្តីផ្តើម

មេរៀននេះបញ្ជាក់ថា គ្រប់អ្វីទាំងអស់ដែលព្រះវរបិតាសួគ៌ធ្វើ គឺដើម្បីជាប្រយោជន៍ដល់ពិភពលោក និង ត្រូវបានជម្រុញដោយសេចក្តីស្រឡាញ់ចំពោះកូនចៅរបស់ទ្រង់ ។ មេរៀននេះ ក៏នឹងប៉ះដល់របៀបដែលព្រះគម្ពីរមរមនបង្ហាញពីការបង្រៀនក្លែងក្លាយរបស់សាតាំងដែលមានជាទូទៅ នៅក្នុងជំនាន់របស់យើង និង ពីរបៀបដែលជីវិតដ៏នៅអស់កល្បជានិច្ចមកដល់អស់អ្នកទាំងឡាយណាដែលធ្វើតាមគោលលទ្ធិនៃព្រះគ្រីស្ទ ។

យោបល់សម្រាប់ការបង្រៀន

សូមសួរសិស្សថា តើពួកគេមានគំនិត ឬ ការយល់ដឹងអ្វីចេញពីការសិក្សាព្រះគម្ពីររបស់ពួកគេដែលអាចចែកចាយជាមួយនឹងសិស្សក្នុងថ្នាក់ទេ មុនពេលអ្នកចាប់ផ្តើមមេរៀននេះ: ។ សូមលើកទឹកចិត្តសិស្សឲ្យសួរសំណួរណាដែលពួកគេមាន អំពីអ្វីដែលពួកគេបានសិក្សាហើយ ។ សូមអញ្ជើញពួកគេឲ្យសរសេរនូវការបំផុសគំនិតខាងវិញ្ញាណ ដែលពួកគេបានទទួល នៅពេលពួកគេអាន និង សញ្ជឹងគិតអំពីព្រះគម្ពីរ និង កិច្ចការរបស់វា ។ ការណ៍នេះនឹងអញ្ជើញវិញ្ញាណនៃការព្យាករណ៍ទៅក្នុងជីវិតរបស់ពួកគេ ។

សូមឲ្យសិស្សជួយអ្នកសរសេរចម្លើយខ្លះចំពោះសំណួរខាងក្រោមនៅលើក្តារខៀន ឬ នៅលើក្រដាសមួយសន្លឹក ៖ ប្រសិនបើអ្នកដឹងថា ពេលវេលារបស់អ្នកនៅលើផែនដីនេះ ជិតដល់ទីបញ្ចប់ហើយ ហើយថាអ្នកអាចសរសេរសំបុត្រមួយដែលកូនចៅរបស់អ្នក និង មនុស្សទូទាំងពិភពលោកនឹងអាននោះ: តើអ្នកនឹងពីរសយកប្រធានបទអ្វីមកបញ្ចូលនៅក្នុងលិខិតរបស់អ្នកនោះ: ?

សូមអញ្ជើញសិស្សឲ្យមើលត្រួសៗក្នុង នីហ្វៃទី ២ ២៦–៣១និង កំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេដើម្បីមើលពីប្រធានបទអ្វីដែលនីហ្វៃបាននិយាយ ខណៈដែលគាត់ជិតបញ្ចប់ជីវិតរបស់គាត់ហើយនោះ: ។ សូមប្រៀបធៀបអ្វីដែលពួកគេរកឃើញ ជាមួយនឹងចម្លើយដែលពួកគេសរសេរនៅលើក្តារខៀន ។ ការខ្ចួនចុងក្រោយគេរបស់នីហ្វៃ ត្រូវសរសេរឡើងសម្រាប់ពួកយើងដែលរស់នៅក្នុងជំនាន់ចុងក្រោយ និង មានទូវតម្រុយដើម្បីជួយយើងឲ្យស្គាល់នូវសេចក្តីពិត ចៀសវាងថ្ម ជំពប់របស់សាតាំង ហើយធ្វើតាមគោលលទ្ធិនៃព្រះយេស៊ូវគ្រីស្ទ ។

នីហ្វៃទី ២ ២៦

ក្រោយពីនីហ្វៃព្យាករទាក់ទងនឹងការបំផ្លាញនៃប្រជាជនរបស់គាត់ហើយ គាត់បានព្យាករអំពីថ្ងៃចុងក្រោយ និង អញ្ជើញមនុស្សទាំងអស់ឲ្យមករកព្រះគ្រីស្ទ

សូមអញ្ជើញសិស្សឲ្យអាន នីហ្វៃទី ២ ២៦:២៩–៣១ ហើយស្វែងរកវិធីសាស្ត្ររបស់សាតាំង មួយដែលនីហ្វៃបានព្រមានយើងនោះ: ។ បន្ទាប់ពីសិស្សពីរបីនាក់ឆ្លើយនឹងអ្វីដែលពួកគេបាន រកឃើញហើយ សូមសួរនូវសំណួរខាងក្រោម ៖

- យោងតាម នីហ្វៃទី ២ ២៦:២៩ តើអ្វីជាឧបាយកលផ្នែកសង្ឃ ?
- តើអ្វីទៅដែលហាក់ដូចជាការជម្រុញមនុស្សខ្លះឲ្យធ្វើឧបាយកលផ្នែកសង្ឃ ?
- តើព្រះអម្ចាស់សង្ឃឹមឲ្យយើងត្រូវបានជម្រុញដោយអ្វី នៅពេលយើងបម្រើនៅក្នុងសាសនាចក្រ ? តើអ្នកមានស្គាល់នរណាម្នាក់ ដែលធ្វើជាគំរូល្អសម្រាប់ការណ៍នេះដែរឬទេ ?

សូមរំឭក នីហ្វៃទី២ ២៦:២៣–២៨, ៣៣ និង ថ្ងៃទី ១ កិច្ចការទី ៣ ។ សូមសួរ ៖ តើអ្វីដែលជម្រុញព្រះអម្ចាស់នៅក្នុងការងាររបស់ទ្រង់ ?

ក្រោយពីសិស្សពីរបីនាក់បានឆ្លើយហើយ សូមឲ្យសិស្សក្នុងថ្នាក់អានសំណួរខាងក្រោម ៖

- តើឃ្លាអ្វីនៅក្នុង នីហ្វៃទី ២ ២៦:២៣–២៨, ៣៣ បង្រៀនយើងថា **ព្រះអម្ចាស់ស្រឡាញ់មនុស្សទាំងអស់ ហើយអញ្ជើញទាំងអស់គ្នាឲ្យមករកទ្រង់ និង ទទួលទានសេចក្តីសង្គ្រោះរបស់ទ្រង់** ហើយថា**អ្វីគ្រប់យ៉ាងដែលព្រះអម្ចាស់ធ្វើ គឺដើម្បីជាប្រយោជន៍ដល់ពិភពលោកនោះ:** ?

- ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីរៀនលើកទឹកចិត្តដោយសេចក្តីស្រឡាញ់សម្រាប់អ្នកដទៃ ជាជាងដោយសេចក្តីលោភលន់ ឬ បំណងប្រាថ្នាដើម្បីទទួលបានការសរសើរពីអ្នកដទៃនោះ ?
- តើអ្នកគិតថា យើងអាចមានសេចក្តីសប្បុរស សេចក្តីស្រឡាញ់ និង ភាពដូចជាព្រះគ្រីស្ទច្រើនជាងមុន នៅក្នុងការងារសាសនាចក្ររបស់យើង ដោយរបៀបណា ?

នីហ្វៃទី ២ ២៨

នីហ្វៃព្រមានពីការបោកបញ្ឆោតទាំងឡាយរបស់អារក្សសាតាំង

សូមប្រាប់សិស្សថា នៅក្នុងនីហ្វៃទី ២ ២៨ នីហ្វៃបានបន្តបង្ហាញលទ្ធិក្លែងក្លាយដែលបានបង្រៀនដោយពួកអារក្ស ។ សូមរំឭកពី « លទ្ធិក្លែងក្លាយ ឥតខ្លឹមសារ ហើយឥតប្រយោជន៍ » ដែលបានពិពណ៌នានៅក្នុង នីហ្វៃទី ២ ២៨:៣–៩ ហើយសូមសួរសំណួរខាងក្រោមដល់សិស្ស ។ ពួកគេអាចបញ្ចូលចម្លើយនានាដែលពួកគេបានសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ក្នុងសប្តាហ៍កន្លងទៅ ។

- តើ « ជិះជាន់មនុស្សផ្សេងដោយសារសំដីរបស់គេ » មានន័យយ៉ាងណាដែរ ? (នីហ្វៃទី ២ ២៨:៨) ។ (ឧទាហរណ៍ទាំងឡាយអាចរួមមានការចំអកដល់អ្នកដទៃ និង ការពោលខុស ឬ ការពន្លើសអ្វីដែលអ្នកផ្សេងបាននិយាយ) ។
- តើមនុស្សសព្វថ្ងៃនេះ « ជីករណ្តៅ » (នីហ្វៃទី ២ ២៨:៨) ទុកជាក់អ្នកជិតខាងរបស់ពួកគេដោយរបៀបណា ?
- តើមានគ្រោះថ្នាក់អ្វីខ្លះ ពេលព្យាយាមលាក់អំពើបាបទាំងឡាយពីព្រះអម្ចាស់ ឬ ជាក់កិច្ចការរបស់យើងនឹងនៅក្នុងទីងងឹតនោះ ? (សូមមើល នីហ្វៃទី ២ ២៨:៩) ។
- តើអ្នកគិតថា ការបង្រៀនក្លែងក្លាយអ្វីនៅក្នុង នីហ្វៃទី ២ ២៨:៣–៩ដែលបំផ្លាញយុវវ័យខ្លាំងបំផុតនោះនាសព្វថ្ងៃនេះ ? តើអ្នកគិតថា ហេតុអ្វីបានជាវាមានគ្រោះថ្នាក់ ? តើយុវវ័យត្រូវបានល្បួងដោយការបង្រៀនក្លែងក្លាយនោះដោយរបៀបណា ? (សូមមើល ថ្ងៃទី ២ កិច្ចការទី ១) ។

សូមរំឭក នីហ្វៃទី ២ ២៨:២០–២៣ និង រឿងរបស់ប្រធាន ប៊ិចម៍ ឃេ. ផាកកឺ អំពីក្រពើខាងវិញ្ញាណពីមេរៀននៅថ្ងៃទី ២ ។ សូមអញ្ជើញសិស្សឲ្យចែកចាយជាមួយនឹងសិស្សក្នុងថ្នាក់ អំពីទីសម្គាល់នៃការព្រមានដែលពួកគេបានគូសនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ (ថ្ងៃទី ២ កិច្ចការទី ៥) ដែលបង្ហាញពីគ្រោះថ្នាក់ខាងវិញ្ញាណ ដែលពួកគេគិតថា យុវវ័យត្រូវបានព្រមាននៅបច្ចុប្បន្ននេះ ។

សូមសួរ ៖ ក្នុងចំណោមរឿងទាំងអស់ដែលនីហ្វៃអាចសរសេរ នៅពេលគាត់បញ្ចប់កំណត់ត្រារបស់គាត់ តើអ្នកគិតថា ហេតុអ្វីបានជាគាត់សរសេរអំពីការបោកបញ្ឆោត និង វិធីសាស្ត្ររបស់សាតាំង ? (អ្នកអាចថ្លែងទីបន្ទាល់អំពីជំនួយ និង កម្លាំងដែលយើងទទួលបានដើម្បីតតាំងនឹងវិធីសាស្ត្ររបស់សាតាំង នៅពេលយើងសិក្សាព្រះគម្ពីរមេរមនដោយប្រុងប្រយ័ត្ន) ។

នីហ្វៃទី ២ ៣១

នីហ្វៃបង្រៀនពីរបៀបដែលព្រះអង្គសង្គ្រោះធ្វើជាគំរូដ៏ឥតខ្ចោះសម្រាប់យើង

សូមគូសរូបភាពផ្លូវដ៏សាមញ្ញមួយ ដែលនាំទៅកាន់ទ្វារមួយ ។ សូមអញ្ជើញសិស្សឲ្យអាន នីហ្វៃទី ២ ៣១:១៧–១៨ហើយស្វែងរកពីរបៀបដែលនីហ្វៃបានប្រើរូបភាពផ្លូវមួយ និង ទ្វារមួយនេះដើម្បីបញ្ជាក់ពីរបៀបតែមួយគត់ដើម្បីមករកព្រះយេស៊ូវគ្រីស្ទ ។ បន្ទាប់មក សូមសួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- យោងតាមខគម្ពីរទាំងនេះ តើទ្វារ និង ផ្លូវនេះតំណាងឲ្យអ្វី ? (ទ្វារតំណាងឲ្យការប្រែចិត្ត ពិធីបុណ្យជ្រមុជទឹក និង ការទទួលព្រះវិញ្ញាណបរិសុទ្ធ) ។
- ចេញពីអ្វីដែលអ្នកបានរៀននៅក្នុងការសិក្សាផ្ទាល់ខ្លួនរបស់អ្នកក្នុង នីហ្វៃទី ២ ៣១ ហេតុអ្វីបានជាការទទួលព្រះវិញ្ញាណបរិសុទ្ធយោងថាជា « បុណ្យជ្រមុជដោយភ្លើង » ? (សូមមើល នីហ្វៃទី២ ៣១:១៣; សូមមើលផងដែរក្នុង ខគម្ពីរទី ១៧) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន នីហ្វៃទី ២ ៣១:១៩–២១ ឮៗ ។ សូមឲ្យសិស្សស្វែងរកអ្វីដែលតម្រូវឲ្យយើងធ្វើ បន្ទាប់ពីយើងឆ្លងកាត់ « ទ្វារ » ហើយនោះ ។ ក្រោយពីសិស្សបានឆ្លើយចំពោះអ្វីដែលពួកគេបានរកឃើញហើយ សូមសួរសំណួរខាងក្រោមនេះ ៖

- តើអ្នកគិតថា នីហ្វៃចង់មានន័យយ៉ាងណា នៅពេលគាត់សរសេរ « នេះគឺជាគោលលទ្ធិនៃព្រះគ្រីស្ទ » ? (នីហ្វៃទី ២ ៣១:២១) ។
- ដោយគិតពិអ្វីដែលអ្នកបានសិក្សានៅថ្ងៃនេះ តើអ្នកគិតថា ព្រះវរបិតាសួគ៌ចង់ឲ្យអ្នកធ្វើអ្វីខ្លះដើម្បីជួយអ្នកឲ្យបន្តទៅមុខលើផ្លូវតូច ហើយចង្អៀតនោះ ? (អ្នកអាចលើកទឹកចិត្តសិស្សឲ្យជាក់គោលដៅដើម្បីឆ្លើយតបទៅនឹងសំណួរនេះ) ។

មេរៀនបន្ទាប់ (នីហ្វៃទី ២ ៣២–យ៉ាកុប ៤)

តើអ្នកចូលចិត្តបរិភោគឬទេ ? នៅក្នុងមេរៀនក្រោយ សិស្សនឹងរៀនអំពីអត្ថន័យនៃការ « ទទួលទាននូវព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ » (នីហ្វៃទី ២ ៣២:៣) ។ តើព្យាការីគួរតែកែតម្រូវប្រជាជនដែលចាប់ផ្តើមទទួលឥទ្ធិពលដោយសេចក្តីស្រឡាញ់ទ្រព្យសម្បត្តិ ឬ ដោយមនុស្សដែលមិនគោរពតាមច្បាប់ព្រហ្មចារីយភាពដោយរបៀបណា ? សូមកត់ចំណាំពីរបៀបដែលយ៉ាកុបនិយាយពីបញ្ហាទាំងនេះ ។

នីហ្វៃទី ២ ៣២

សេចក្តីផ្តើម

ក្រោយពីការបង្រៀនអំពី « ផ្លូវតូច ហើយចង្អៀតនោះដែលនាំទៅរកជីវិតដ៏អស់កល្ប ជានិច្ច » ហើយ (នីហ្វៃទី ២ ៣១:១៨) នីហ្វៃបានដឹងថា ប្រជាជនរបស់គាត់ឆ្ងល់ពីអ្វី ពួកគេគួរធ្វើ ក្រោយពីចាប់ផ្តើមដើរលើផ្លូវនោះហើយ ។ គាត់បានឆ្លើយនឹងសំណួររបស់ពួកគេ ដោយការលើកទឹកចិត្តពួកគេឲ្យ « ទទួលទាននូវព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ » និង « អធិស្ឋានជានិច្ច » (នីហ្វៃទី ២ ៣២:៣, ៩) ។ គាត់បានធានាពួកគេថា ប្រសិនបើពួកគេធ្វើនូវរឿងទាំងនេះ ព្រះវិញ្ញាណបរិសុទ្ធនឹងជួយពួកគេឲ្យដឹងពីអ្វីដែលត្រូវធ្វើ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ៣២:១–៧

នីហ្វៃបានទូន្មានយើងឲ្យស្វែងរកការដឹកនាំដ៏ទេវភាពតាមរយៈព្រះបន្ទូលនៃព្រះយេស៊ូវគ្រីស្ទ និង ការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ

សូមអញ្ជើញសិស្សឲ្យគិតអំពីពេលមួយ នៅពេលពួកគេបានពន្យល់ពីរបៀបដើម្បីចេញពីកន្លែងមួយទៅកន្លែងមួយទៀត ។ សូមឲ្យពួកគេពន្យល់ពីមូលហេតុដែលវាមានទាំងភាពងាយស្រួល ឬ ពិបាកដើម្បីផ្តល់ការដឹកនាំនោះ ។

សូមរំឭកសិស្សថា នៅក្នុងមេរៀនមុនៗ ពួកគេបានសិក្សាពីការដឹកនាំដែលនីហ្វៃបានផ្តល់ដល់ប្រជាជនរបស់គាត់ ។ ក្រោយពីការចែកចាយការដឹកនាំទាំងនេះ គាត់បាននិយាយថា « នេះគឺជាផ្លូវ » (នីហ្វៃទី ២ ៣១:២១) ។ ដើម្បីជួយសិស្សឲ្យរំឭកពីអ្វីដែលពួកគេបានរៀនហើយ សូមសួរសំណួរខាងក្រោមនេះ ៖

- ប្រសិនបើយើងធ្វើតាមការដឹកនាំរបស់នីហ្វៃ តើវានឹងដឹកនាំយើងទៅកន្លែងណា ? (ទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច ; សូមមើល នីហ្វៃទី ២ ៣១:២០) ។
- ដោយយោងតាម នីហ្វៃទី ២ ៣១:១៧–១៨ តើយើងចាប់ផ្តើមនៅលើផ្លូវដែលនាំទៅរកជីវិតដ៏នៅអស់កល្បជានិច្ចដោយរបៀបណា ?

សូមពន្យល់ថា នីហ្វៃទី ២ ៣២ គឺជាការបន្តការបង្រៀនរបស់នីហ្វៃមួយនៅក្នុង នីហ្វៃទី ២ ៣១ ។ សូមឲ្យសិស្សមើលក្នុង នីហ្វៃទី ២ ៣២:១ស្វែងរកសំណួរមួយដែលប្រជាជនរបស់នីហ្វៃមាន ទាក់ទងនឹងអ្វីដែលគាត់បានបង្រៀនពួកគេនោះ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យបង្ហាញសំណួរនេះជាពាក្យសម្តីរបស់ពួកគេផ្ទាល់ ។ (សូមធានាថា សិស្សយល់ថា ប្រជាជនឆ្ងល់ពីអ្វីដែលពួកគេគួរតែធ្វើ ក្រោយពីបានចាប់ផ្តើមដើរលើផ្លូវទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន នីហ្វៃទី ២ ៣២:២–៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកចម្លើយរបស់នីហ្វៃចំពោះសំណួររបស់ប្រជាជនគាត់ ។ សូមបង្ហាញថា នីហ្វៃទី ២ ៣២:៣ គឺជាវគ្គចំណោះចំណានខគម្ពីរមួយ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំវាឲ្យផ្លែពីគេ ដើម្បីពួកគេអាចរកវាបានដោយងាយស្រួល ។

- តើពាក្យអ្វីនៅក្នុង នីហ្វៃទី ២ ៣២:៣ ដែលពិពណ៌នាពីរបៀបដែលយើងទទួលព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ ? តើការទទួលទានអាហារ ខុសគ្នាពីការពិសាសម្រន់ដូចម្តេចខ្លះ ?
- តើអ្នកគិតថា « ទទួលទាននូវព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ » មានន័យដូចម្តេច ?
- តើនីហ្វៃបាននិយាយអ្វី ដែលនឹងជាលទ្ធផលនៅពេលយើងទទួលទានព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ ?
- តើកន្លែងណាខ្លះដែលយើងអាចរកបានព្រះបន្ទូលទាំងឡាយនៃព្រះយេស៊ូវគ្រីស្ទ ? (ចម្លើយអាចរួមមាន ព្រះគម្ពីរ ពាក្យពាក្យសម្តីនៃព្យាការីសម័យទំនើប និង ការបំផុសគំនិតមកពីព្រះវិញ្ញាណបរិសុទ្ធ) ។

សូមធានាថា សិស្សយល់ថា **នៅពេលយើងទទួលទានព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទនឹងប្រាប់យើងពីអ្វីៗទាំងអស់ដែលយើងត្រូវធ្វើ ។**

ដើម្បីជួយសិស្សឲ្យគិតអំពីរបៀបដែលពួកគេទទួលទានព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទបានល្អនោះ សូមអានបញ្ជីខាងក្រោម ដោយឈប់បន្ទាប់ពីអានវាមួយៗហើយ ។ សូមឲ្យសិស្សចម្លងបញ្ជីនេះទៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ឬ ដាក់លើក្រដាសមួយសន្លឹក ។

១ .ការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន

២ .ការប្រជុំសាក្រាម៉ង់

៣ .សន្និសីទទូទៅ

៤ .ការសិក្សាព្រះគម្ពីរជាគ្រួសារ

៥ .ថ្នាក់សិក្ខាសាលា

៦ .រាត្រីជួបជុំក្រុមគ្រួសារ

> **នីហ្វៃទី ២ ៣២:៣** គឺជាវគ្គចំណោះចំណានខគម្ពីរមួយ ។ សូមបើកទៅគំនិតសម្រាប់ការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណោះចំណាននៅវគ្គនេះ ។

៧ .ការប្រជុំក្លុំមបព្វជិតភាពអើរ៉ុន ឬ ថ្នាក់យុវនារី

៨ .ការអធិស្ឋានផ្ទាល់ខ្លួន

សូមអញ្ជើញសិស្សឲ្យគិតអំពីរបៀបដែលពួកគេស្វែងរកព្រះបន្ទូលទាំងឡាយនៃព្រះយេស៊ូវគ្រីស្ទបានល្អនៅក្នុងវគ្គទាំងនេះមួយៗ ។ សម្រាប់ពាក្យនីមួយៗ សូមឲ្យពួកគេសរសេរ *ទទួលទានអាហារពិសាសម្រន់* ឬ *អត់អាហារ* ។ឧទាហរណ៍ សិស្សម្នាក់អាចទទួលទានក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនបាន ប៉ុន្តែគ្រាន់តែជាអាហារសម្រន់នៅក្នុងសន្និសីទទូទៅ ។ សិស្សម្នាក់ដែលមិនបានយកចិត្តទុកដាក់នៅក្នុងការប្រជុំសាក្រាម៉ង់អាចសរសេរពាក្យ *អត់អាហារ* នៅក្បែរពាក្យនោះ ។

សូមឲ្យសិស្សជ្រើសរើសសកម្មភាពមួយដែលពួកគេកំពុងតែ « ពិសាសម្រន់ » ឬ « ឃ្លាន » ក្នុងពេលថ្មីៗនេះ ហើយសូមអញ្ជើញពួកគេឲ្យដាក់គោលដៅដែលនឹងជួយពួកគេឲ្យ « ទទួលទានព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ » ជាងនៅក្នុងវគ្គនោះ ។ (អ្នកអាចលើកទឹកចិត្តពួកគេឲ្យគិតអំពីកាតព្វកិច្ចរបស់ពួកគេចំពោះព្រះ ឬ គោលដៅអភិវឌ្ឍន៍ខ្លួនដែលទាក់ទងនឹងគោលដៅទាំងនេះ) ។

ដើម្បីពង្រឹងការយល់ដឹងរបស់សិស្សអំពីទំនួលខុសត្រូវរបស់ពួកគេក្នុងការស្វែងរកការណែនាំផ្ទាល់ខ្លួនពីព្រះវិញ្ញាណបរិសុទ្ធ សូមឲ្យពួកគេអាន នីហ្វៃទី ២ ៣២:៤–៧ ដោយស្ងាត់ស្ងៀម ។ បន្ទាប់មក សូមឲ្យពួកគេពិភាក្សាសំណួរខាងក្រោមជាមួយនឹងដៃគូគេ ។ (អ្នកអាចផ្តល់សំណួរទាំងនេះជាក្រដាសមួយសន្លឹក ឬ សរសេរវាដាក់លើក្តារខៀន មុនពេលចាប់ផ្តើមថ្នាក់រៀន) ។

- នៅក្នុងខគម្ពីរទី ៤ តើអ្នកគិតថាពាក្យ « សូម » ឬ « គោះ » មានន័យយ៉ាងណាដែរ ? តើអ្វីទៅដែលនីហ្វៃបាននិយាយថាជាផលដល់អ្នកទាំងឡាយណាដែលមិនសូម ឬ គោះនោះ ?
- តើពរជ័យអ្វីដែលនីហ្វៃបានសន្យាថា យើងអាចមាននៅពេលយើងទទួលបានព្រះវិញ្ញាណបរិសុទ្ធ ?
- ហេតុអ្វីបានជានីហ្វៃទួញសោកសម្រាប់ប្រជាជនរបស់គាត់ ?

សូមបង្ហាញទំនុកចិត្តរបស់អ្នកថា នៅពេលសិស្សទទួលទានព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទព្រះវិញ្ញាណបរិសុទ្ធនឹងជួយពួកគេឲ្យដើរតាមផ្លូវទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច ។

នីហ្វៃទី ២ ៣២:៨–៩

នីហ្វៃទូន្មានយើងឲ្យអធិស្ឋានជានិច្ច

សូមពន្យល់ថា នីហ្វៃបន្ទាប់មកទៀតនោះបានផ្តោតទៅលើរឿងមួយដែលយើងអាចធ្វើ ដើម្បីទទួលបានន្ទូវព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ ។ សូមអញ្ជើញសិស្សឲ្យអាន នីហ្វៃទី ២ ៣២:៨ ដោយស្ងាត់ស្ងៀម ដោយស្វែងរកអ្វីដែលនីហ្វៃបាននិយាយថា យើង ត្រូវធ្វើនោះ ។ ក្រោយពីពួកគេបានរកឃើញចម្លើយហើយ សូមសួរសំណួរខាងក្រោមនេះដើម្បីជួយពួកគេឲ្យសញ្ជឹងគិតអំពី សារៈសំខាន់នៃការអធិស្ឋាន ៖

- តើអ្នកគិតថា ហេតុអ្វីបានជាព្រះវិញ្ញាណបរិសុទ្ធចង់ឲ្យយើងអធិស្ឋាន ?
- តើអ្នកគិតថា ហេតុអ្វីបានជាសាតាំងមិនចង់ឲ្យយើងអធិស្ឋាន ? តើសាតាំងព្យាយាមបញ្ចុះបញ្ចូលដល់ប្រជាជនដើម្បីកុំឲ្យអធិស្ឋានដោយរបៀបណា ?

នីហ្វៃទី ២ ៣២:៨–៩
គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមបើកទៅគំនិតសម្រាប់ការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណាននៅវគ្គនេះ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន នីហ្វៃទី ២ ៣២:៩ឮៗ ។ សូមបង្ហាញថា នីហ្វៃទី ២ ៣២:៨–៩ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំវាឲ្យផ្សែកពីគេ ដើម្បីពួកគេអាចបើករកវាដោយស្រួល ។

- តើយើងគួរអធិស្ឋានញឹកញាប់ប៉ុណ្ណាដែរ ? តើអ្នកគិតថា « អធិស្ឋានជានិច្ច » មានន័យយ៉ាងណាដែរ ?

សូមចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ. បែដណា នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ។ (ប្រសិនបើអាច សូមថតចម្លងការដកស្រង់ពាក្យសម្តីនេះ ដើម្បីឲ្យសិស្សអាចអានតាម ហើយផ្តោតលើប្រសាសន៍របស់អែលឌើរ បែដណា ។ ប្រសិនបើអ្នកថតចម្លង សូមកត់ចំណាំថា ការដកស្រង់ពាក្យសម្តីនេះត្រូវបន្តនៅក្នុងមេរៀនពេលក្រោយទៀត បន្ទាប់ពីមានការពិភាក្សាដ៏ខ្លីមួយ ។ សូមបញ្ចូលផ្នែកនៃសេចក្តីថ្លែងការណ៍នោះផងដែរ) ។ សូមអញ្ជើញសិស្សឲ្យស្តាប់ការទូន្មានរបស់អែលឌើរ បែដណា ពីរបៀបដើម្បី « អធិស្ឋានជានិច្ច » ។

« វាអាចមានរឿងជាច្រើននៅក្នុងលក្ខណៈរបស់យើង ក្នុងដំណើរប្រព្រឹត្តរបស់យើង ឬ ទាក់ទងនឹងការធំធាត់ខាងវិញ្ញាណរបស់យើង ដែលយើងត្រូវប្រឹក្សាជាមួយនឹងព្រះវរបិតាសួគ៌នៅក្នុងការអធិស្ឋាននាពេលព្រឹក ។ . . .

« យើងបន្តអធិស្ឋាននៅក្នុងចិត្តយើងសម្រាប់ជំនួយ និង ការណែនាំជាបន្ត គ្រប់ការងារពេញមួយថ្ងៃ ។ . . .

« យើងកត់ចំណាំអំឡុងពេលថ្ងៃជាក់លាក់នេះថា មានឱកាសជាច្រើនដែលជាធម្មតា យើងមានទំនោរនិយាយពាក្យមិនពិរោះ តែយើងមិនបាននិយាយនោះទេ ; ឬ យើងអាចចង់ផ្ទុះកំហឹង ប៉ុន្តែយើងមិនបានធ្វើនោះទេ ។ យើងសំឡឹងរកជំនួយ និង កម្លាំងពីស្ថានសួគ៌ ហើយស្គាល់ចម្លើយចំពោះការអធិស្ឋានរបស់យើងដោយភាពរបស ។ ទោះបីជានៅក្នុងពេលនៃការទទួលស្គាល់ ក៏យើងអធិស្ឋានដោយស្ងាត់សម្រាប់ការដឹងគុណ » (« Pray Always » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៤១–៤២) ។

ដើម្បីជួយសិស្សឲ្យសញ្ជឹងគិតពីការទូន្មាននេះ សូមសួរ ៖

- តើអ្នកអាចគិតអំពីពេលនៅថ្ងៃនេះ ឬ ថ្ងៃកន្លងទៅថ្មីៗនេះ ពេលអ្នកអាចធ្វើតាមសំណើរនេះមកពីអែលឌើរ បែដណា ? (អ្នកអាចសុំឲ្យសិស្សសញ្ជឹងគិតពីសំណួរនេះដោយស្ងាត់ស្ងៀម ជាជាងការឆ្លើយឮៗ) ។

សូមបន្តអានការទូន្មានរបស់អែលឌើរ បែដណា ៖

« នៅចុងបញ្ចប់នៃថ្ងៃរបស់យើង យើងលុតជង្គង់ចុះម្តងទៀត ហើយរាយការណ៍ទៅព្រះវរបិតាយើងវិញ ។ យើងរំឭកពីព្រឹត្តិការណ៍ថ្ងៃនោះ ហើយបង្ហាញអំណរគុណជាខ្លាំងសម្រាប់ពរជ័យទាំងឡាយ និង ជំនួយដែលយើងបានទទួល ។ យើងប្រែចិត្ត ហើយដោយមានជំនួយមកពីព្រះវិញ្ញាណនៃព្រះអម្ចាស់ យើងស្គាល់របៀបដែលយើងអាចធ្វើ ហើយក្លាយជាល្អជាងនេះនៅថ្ងៃស្អែក ។ ហេតុដូច្នេះហើយ ការអធិស្ឋានពេលល្ងាចរបស់យើងចាក់គ្រឹះ និង ជាការបន្តមួយនៃការអធិស្ឋានពីពេលព្រឹករបស់យើង ។ ហើយការអធិស្ឋានពេលល្ងាចរបស់យើង ក៏ជាការរៀបចំមួយសម្រាប់ការអធិស្ឋានពេលព្រឹកដ៏មានន័យដែរ ។

« ការអធិស្ឋានពេលព្រឹក និង ពេលល្ងាច —និង ការអធិស្ឋានទាំងអស់ដែលនៅចន្លោះនោះ— គឺមិនមែនជាព្រឹត្តិការណ៍ដែលមិនទាក់ទងគ្នា ឬ ដាច់ៗពីគ្នានោះទេ ប៉ុន្តែ វាភ្ជាប់រួមគ្នារាល់ថ្ងៃ ហើយឆ្លងថ្ងៃ សប្តាហ៍ ខែ និង ឆ្នាំទៀតផង ។ នេះគឺជាផ្នែកដែលយើងបំពេញតាមការដាស់តឿនពីព្រះគម្ពីរឲ្យ ‹ អធិស្ឋានជានិច្ច › (លូកា ២១:៣៦; នីហ្វៃទី ៣ ១៨:១៥, ១៨; គ. និង ស. ៣១:១២) ។ ការអធិស្ឋានដ៏មានន័យបែបនោះ គឺជាឧបករណ៍ក្នុងការទទួលបានពរជ័យដ៏ខ្ពស់បំផុតដែលព្រះទុកក្នុងឃ្លាំងសម្រាប់កូនចៅដ៏ស្មោះត្រង់របស់ទ្រង់ » (« Pray Always » ទំព័រ ៤២) ។

ដើម្បីជួយសិស្សឲ្យយល់ពីផ្នែកមុននៃ នីហ្វៃទី ២ ៣២:៩ សូមពន្យល់ថាពាក្យ *ញែកចេញជាបរិសុទ្ធ* មានន័យថា « ឧទ្ទិស ធ្វើឲ្យបរិសុទ្ធ ឬ ក្លាយជាសុចរិត » (Guide to the Scriptures « Consecrate, Law of Consecration » scriptures.lds.org) ។

- ហេតុអ្វីបានជាយើងត្រូវអធិស្ឋាន នៅពេលណាយើង « ធ្វើអ្វីចំពោះព្រះអម្ចាស់ » ?
- តើអ្នកគិតថា វាមានន័យយ៉ាងណាចំពោះព្រះអម្ចាស់ ដើម្បីញែកចេញជាបរិសុទ្ធចំពោះអ្វីដែលយើងធ្វើ ដើម្បីបានជាសុខុមាលភាពដល់ព្រលឹងរបស់យើង ?
- តើការទូន្មានរបស់អែលឌើរ បែដណា អាចជួយយើងឲ្យរស់នៅតាមជីវិតមួយដែលបានញែកចេញជាបរិសុទ្ធជាងនេះដោយរបៀបណា ?

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងអធិស្ឋានជានិច្ច យើងអាចធ្វើអ្វីៗទាំងអស់ដែលព្រះអម្ចាស់ចង់ឲ្យយើងធ្វើដើម្បីបានជាសុខុមាលភាពដល់ព្រលឹងរបស់យើង ។

ដើម្បីសង្ខេបអ្វីដែលសិស្សបានពិភាក្សានៅក្នុងមេរៀននេះ សូមចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយ អែលឌើរស្តែនស៊ើរ ជេ. ខនឌី នៃពួកចិតសិបនាក់ ៖

« អ្នកអាចជូបនឹងការសម្រេចចិត្តដែលទាក់ទងនឹងបេសកកម្ម ការងារអនាគតរបស់អ្នក និង ទី បញ្ចប់គឺអាពាហ៍ពិពាហ៍ ។ នៅពេលអ្នកអានព្រះគម្ពីរ ហើយអធិស្ឋានសម្រាប់ការណែនាំ អ្នកមិនអាចឃើញចម្លើយដោយពិតប្រាកដក្នុងទម្រង់ជាអក្សរចោះពុម្ពលើក្រដាសនោះទេ ប៉ុន្តែនៅពេលអ្នកអាន អ្នកនឹងទទួលបានការបំផុសគំនិតដ៏ប្លែកមួយ និងការបំផុសគំនិតទាំងឡាយ ហើយដូចដែលបានសន្យា ព្រះវិញ្ញាណបរិសុទ្ធ ‹ នឹងបង្ហាញដល់អ្នក នូវគ្រប់អ្វីទាំងអស់ដែលអ្នកត្រូវធ្វើ › ។ | នីហ្វៃទី ២ ៣២:៥ ។ | » (« Becoming a Great Benefit to Our Fellow Beings » *Ensign* ខែ ឧសភា ឆ្នាំ ២០០២ ទំព័រ ៤៥) ។

ចំណេះចំណានខគម្ពីរ—នីហ្វៃទី ២ ៣២:៣

សូមសួរសិស្សថា តើវាអាចចំណាយពេលយូរប៉ុណ្ណាដើម្បីទន្ទេញឲ្យចាំ នីហ្វៃទី ២ ៣២:៣ ប្រសិនបើពួកគេទន្ទេញវារាល់ពេលដែលពួកគេទទួលទានអាហារនោះ ។ សូមជំរុញពួកគេឲ្យរំឭកព្រះគម្ពីរនេះ —ទទួលទានព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ—រាល់ពេលដែលពួកគេពិសាអាហារក្នុងរយៈពេលពីរបីថ្ងៃទៀត ។ ក្រោយពីពួកគេបានទន្ទេញខគម្ពីរនេះហើយ សូមអញ្ជើញពួកគេឲ្យរាយការណ៍ពីចំនួនដងដែលគេចំណាយពេលពិសាអាហារនោះ ។

ចំណេះចំណានខគម្ពីរ—នីហ្វៃទី ២ ៣២:៨–៩

សូមសួរសិស្សថា តើពួកគេធ្លាប់ព្យាយាមអធិស្ឋាននៅក្នុងចិត្តពួកគេរយៈពេលមួយថ្ងៃពេញ ឬ មួយសប្តាហ៍ពេញដែរឬទេ ។ សូមអញ្ជើញពួកគេឲ្យចែកចាយពីបទពិសោធន៍របស់ពួកគេ ។ សូមអញ្ជើញឲ្យសិស្សក្នុងថ្នាក់គិតពីរបៀបដែលពួកគេអាច « អធិស្ឋានជានិច្ច » សម្រាប់រយៈពេល ២៤ ម៉ោងក្រោយនេះ ។ សូមជំរុញពួកគេឲ្យធ្វើវា ហើយរាយការណ៍ពីបទពិសោធន៍របស់ពួកគេនៅពេលចាប់ផ្តើមថ្នាក់លើកក្រោយ ។

កំណត់ចំណាំ ៖ ប្រសិនបើអ្នកមិនមានពេលដើម្បីប្រើគំនិតក្នុងការបង្រៀនទាំងនេះនៅក្នុងមេរៀននេះទេ សូមគិតពីការប្រើវាជាការរំឭកនៅក្នុងមេរៀនក្រោយៗទៀត ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ២ ៣២:២ ។ តើវាមានន័យយ៉ាងណាដែរ ដើម្បីនិយាយដោយភាសានៃពួកទេវតានោះ ?

ខ្លះអាចគិតពីអត្ថន័យនៃការ « និយាយដោយភាសានៃពួកទេវតា » ។ ប្រធាន ប៊ិចម៍ ឃេ ផាកគឺ បានបង្រៀនថា ការនិយាយដោយភាសានៃពួកទេវតា « មានន័យសាមញ្ញថា អ្នកអាចនិយាយដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ » (« The Gift of the Holy Ghost: What Every Member Should Know » *Ensign* ខែ សីហា ឆ្នាំ ២០០៦ ទំព័រ ៥០) ។

នីហ្វៃទី ២ ៣៣

សេចក្តីផ្តើម

នីហ្វៃបានបញ្ចប់កំណត់ត្រារបស់គាត់ដោយការប្រកាសថា ពាក្យពាក្យសម្តីដែលសរសេររបស់គាត់ថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និង បញ្ចុះបញ្ចូលមនុស្សឲ្យធ្វើល្អ ហើយកាន់ខ្ជាប់ជាបដល់ចុងបំផុត ។ គាត់បាននិយាយថា ទោះបីជាគាត់បានសរសេរ « នៅក្នុងភាពទន់ខ្សោយ » ក្តី ក៏ការសរសេររបស់គាត់នឹងមាន « តម្លៃដ៏ធំ » និង « បានធ្វើជាខ្លាំង » សម្រាប់អស់អ្នកទាំងឡាយដែលនឹងអានវាផងដែរ (សូមមើល នីហ្វៃទី ២ ៣៣:៣–៤) ។ គាត់បានថ្លែងទីបន្ទាល់ថា ការសរសេររបស់គាត់គឺជា « ព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ » ហើយថាប្រជាជននឹងទទួលខុសត្រូវចំពោះព្រះចំពោះចម្លើយរបស់ពួកគេទៅកាន់ការសរសេរនោះ (សូមមើល នីហ្វៃទី ២ ៣៣:១០–១៥) ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ២ ៣៣:១–២

នីហ្វៃបង្រៀនអំពីព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធក្នុងការនាំសេចក្តីពិតទៅដល់ដួងចិត្តរបស់យើង

សូមគូសរូបភាពដូចខាងក្រោមនេះនៅលើក្តារខៀន ៖



- តើមានភាពខុសគ្នាយ៉ាងណារវាងសារលិខិតមួយដែល *ទៅដល់* ដួងចិត្តរបស់នរណាម្នាក់ និង សារលិខិតមួយដែល *ទៅក្នុង* ដួងចិត្តរបស់នរណាម្នាក់នោះ?

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន នីហ្វៃទី ២ ៣៣:១ ឮៗ ។ បន្ទាប់មក សូមឲ្យសិស្សសញ្ជឹងគិតពីសំណួរខាងក្រោមដោយស្ងាត់ស្ងៀម ។

- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដែលព្រះវិញ្ញាណបរិសុទ្ធនាំសេចក្តីពិត *ទៅដល់* ដួងចិត្តរបស់យើង ប៉ុន្តែមិនមែន *ទៅក្នុង* ដួងចិត្តរបស់យើងនោះ ?

នៅពេលសិស្សសញ្ជឹងគិតអំពីសំណួរនេះ សូមអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ. បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ សូមពន្យល់ថា នៅក្នុងសេចក្តីថ្លែងការណ៍នេះ អែលឌើរបែដណា កំពុងនិយាយអំពី នីហ្វៃទី ២ ៣៣:១ ។

« សូមកត់ចំណាំពីរបៀបដែលព្រះចេស្តានៃព្រះវិញ្ញាណនាំសារលិខិត *ទៅដល់* ប៉ុន្តែមិនមែនចាំបាច់ *ទៅក្នុង* ដួងចិត្តនោះទេ ។ « គ្រូបង្រៀនម្នាក់អាចពន្យល់ បង្ហាញ លួងលោម ហើយធ្វើទីបន្ទាល់ និងធ្វើយ៉ាងដូច្នោះដោយមានអំណាច និងប្រសិទ្ធភាពខាងវិញ្ញាណ ។ នៅទីបញ្ចប់ ទោះជាយ៉ាងណាក្តី អត្ថន័យនៃសារលិខិតមួយ និង សាក្សីនៃព្រះវិញ្ញាណបរិសុទ្ធបានទំលុះទៅក្នុងដួងចិត្ត បើសិនជាអ្នកទទួលនោះអនុញ្ញាតឲ្យវាចូលទៅនោះ » (« Seek Learning by Faith »| សុន្ទរកថាថ្លែងទៅកាន់អ្នកអប់រំសាសនា CES នៅថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ | ទំព័រ ១ si.lds.org) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ជេរីល អិន. ឡាន នៃពួកចិតសិបនាក់ ៖

« ហេតុអ្វីបានជាគ្រាន់តែ *ទៅដល់* ដួងចិត្ត ? សិទ្ធិជ្រើសរើសរបស់បុគ្គល គឺពិសិដ្ឋខ្លាំងណាស់ដែលព្រះអរិបិតាសួគ៌នឹងមិនដែលបង្ខំដល់ដួងចិត្តរបស់មនុស្សនោះទេ ទោះបីជាដោយព្រះចេស្តាដ៏និរន្តរ៍របស់ទ្រង់ទាំងអស់ក្តី ។ . . . ព្រះអនុញ្ញាតឲ្យយើងក្លាយជាអ្នកយាម ឬអ្នកចាំទ្វារ នៃដួងចិត្តផ្ទាល់របស់យើង ។ ដោយសារឆន្ទៈសេរីរបស់យើងផ្ទាល់ យើងត្រូវតែបើកដួងចិត្តរបស់យើងចំពោះព្រះវិញ្ញាណ » (« Opening Our Hearts » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៨ ទំព័រ ៣៣) ។

- តើអ្វីដែលសម្រេចថាតើសារលិខិតមួយចូលក្នុងដួងចិត្តរបស់មនុស្សម្នាក់ដោយរបៀបណា ?
- តើនៅពេលណាដែលអ្នកបានមានអារម្មណ៍ថា សារលិខិតដំណឹងល្អមួយបានចូលក្នុងដួងចិត្តរបស់អ្នក ? តើការណ៍នេះប្រាប់អ្វីខ្លះដល់អ្នកអំពីដួងចិត្តអ្នកនាពេលនោះ ?

សូមឲ្យសិស្សអាន នីហ្វៃទី ២ ៣៣:២ដោយស្ងាត់ស្ងៀម ដោយស្វែងរកពីរបៀបដែលមនុស្សជាច្រើនឆ្លើយតបនឹងព្រះវិញ្ញាណបរិសុទ្ធនៅពេលពួកគេមានចិត្តរីងស្ងួត ។ អ្នកអាចពន្យល់ថា ពាក្យ « ឥតប្រយោជន៍ » មានន័យថា « គ្មានអ្វីទាំងអស់ » ។ ដើម្បី « រាប់ | ការសរសេរទាំងឡាយ | ទុកជារបស់ឥតប្រយោជន៍ទៅវិញ » គឺគិតថាវាឥតមានតម្លៃអ្វីទេ ។

- តើអ្វីខ្លះជាដំណើរប្រព្រឹត្ត និង ឥរិយាបថរបស់មនុស្សដែលមានចិត្តរីងស្ងួតនោះ ?

- សម្រាប់អ្នក តើអ្វីជាសារលិខិតនៃ នីហ្វៃទី ២ ៣៣:២ ? (សិស្សអាចឆ្លើយថា យើងជ្រើសរើសដើម្បីបើកក៏បាន ឬ បិទដួងចិត្តរបស់យើងក៏បានចំពោះការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ។ សូមប្រាកដថា ពួកគេយល់ថា **នៅពេលយើងបើកដួងចិត្តរបស់យើង នោះសារលិខិតមកពីព្រះវិញ្ញាណបរិសុទ្ធអាចចូលមកក្នុងដួងចិត្តរបស់យើងបាន**) ។

មុនពេលបន្តមេរៀនទៅមុខទៀត សូមទុកពេលឲ្យសិស្សបន្តិចដើម្បីពិចារណាដោយស្ងប់ស្ងាត់ពីស្ថានភាពនៃដួងចិត្តរបស់ពួកគេ ហើយដើម្បីសម្រេចថាតើពួកគេកំពុងអនុញ្ញាតឲ្យសារលិខិតនៃសេចក្តីពិតចូលមកក្នុងដួងចិត្តរបស់ពួកគេដែរទេ ។

នីហ្វៃទី ២ ៣៣:៣–១៥

នីហ្វៃពន្យល់ពីគោលបំណងនៃកំណត់ត្រារបស់គាត់ និង សេចក្តីសង្ឃឹមរបស់គាត់ថា អ្នកអានរបស់គាត់នឹងជឿលើព្រះគ្រីស្ទ

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖

នីហ្វៃទី ២ ៣៣:៣—ខ្ញុំអធិស្ឋានឥតដាច់សម្រាប់ . . .

នីហ្វៃទី ២ ៣៣:៤—ខ្ញុំដឹង . . .

នីហ្វៃទី ២ ៣៣:៦—ខ្ញុំសរសើរតម្កើង . . .

នីហ្វៃទី ២ ៣៣:៧—ខ្ញុំមាន . . .

សូមអញ្ជើញសិស្សឲ្យអាន នីហ្វៃទី ២ ៣៣:៣–៧ ដោយស្ងាត់ស្ងៀម ដោយស្វែងរកសេចក្តីសង្ឃឹមទាំងឡាយរបស់នីហ្វៃសម្រាប់អ្នកទាំងឡាយណាដែលនឹងអានពាក្យរបស់គាត់ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យឡើងមកក្តារខៀន ហើយបំពេញប្រយោគទាំងឡាយដោយប្រើពាក្យខ្លួនគេផ្ទាល់ ឬ ពាក្យរបស់នីហ្វៃ ។ (ឃ្លាពីរបីនៅលើក្តារខៀន នាំទៅរកចម្លើយច្រើនជាងមួយ) ។

- តើយើងអាចពង្រឹងទីបន្ទាល់ផ្ទាល់ខ្លួនរបស់យើងអំពីព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធួនរបស់ទ្រង់ដោយរបៀបណា ?

សូមឲ្យសិស្សប្រាំនាក់ប្តូរវេនគ្នាអានឮៗនៅក្នុង នីហ្វៃទី ២ ៣៣:១០–១៤ ។ សូមឲ្យសិស្សក្នុងថ្នាក់អានតាម ដោយស្វែងរកឃ្លានៅក្នុងការលោរបស់នីហ្វៃដែលមានអត្ថន័យខ្លាំងដល់ពួកគេ ។ អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំឃ្លាទាំងនេះទុក ។

- តើឃ្លាមួយណាដែលមានអត្ថន័យខ្លាំងចំពោះអ្នក ? ហេតុអ្វី ?
- ប្រសិនបើមនុស្សជឿលើព្រះគ្រីស្ទ តើពួកគេនឹងមានអារម្មណ៍យ៉ាងណាអំពីព្រះគម្ពីរមរមន ? (សូមមើល នីហ្វៃទី ២ ៣៣:១០) ។
- តើនីហ្វៃបានព្រមានថានឹងមានអ្វីខ្លះកើតឡើង ចំពោះអស់អ្នកណាដែលបដិសេធពាក្យទាំងឡាយរបស់គាត់ ? (នៅពេលសិស្សឆ្លើយនឹងសំណួរនេះហើយ អ្នកអាចស្នើថា ពួកគេក៏គួរតែគិតអំពីរបៀបដែលពួកគេនឹងមានអារម្មណ៍នៅក្នុងវត្តមាននៃព្រះអម្ចាស់ ប្រសិនបើពួកគេជឿ និង បានធ្វើតាមពាក្យទាំងឡាយរបស់នីហ្វៃ និង ព្យាការីផ្សេងទៀត) ។

សូមឲ្យសិស្សអាន នីហ្វៃទី ២ ៣៣:១៥ ដោយស្ងាត់ស្ងៀម ហើយសញ្ជឹងគិតពីពាក្យចុងក្រោយរបស់នីហ្វៃថា ៖ « ខ្ញុំត្រូវតែគោរពធ្វើតាម » ។ បន្ទាប់មក សូមផ្តល់ពេលពីរបីនាទី ដល់ពួកគេឲ្យមើលត្រឡប់ទៅក្រោយវិញ តាមរយៈនីហ្វៃទី ១ និង ២ ដោយស្វែងរកគំរូទាំងឡាយនៃការគោរពប្រតិបត្តិរបស់នីហ្វៃ ។ ក្រោយពេលពីរបីនាទី សូមឲ្យសិស្សចែកចាយពីអ្វីដែលពួកគេបានរកឃើញ ។ ចម្លើយអាចរួមមាន ៖ ការចាកចេញពីទីក្រុងយេរូសាឡិម ការត្រឡប់ទៅទីក្រុងយេរូសាឡិមវិញដើម្បីទៅយកផ្ទាំងលង្ហិន ការត្រឡប់ទៅទីក្រុងយេរូសាឡិមវិញម្តងទៀតដើម្បីសុំឲ្យគ្រួសាររបស់អ៊ីសម៉ាអែលចូលរួមជាមួយនឹងពួកគេ ការរក្សាផ្ទាំងទាំងពីរនោះ ការធ្វើតាមការដឹកនាំនៅលើលើអាហារណា ការសាងសង់ពោមួយ ការធ្វើដំណើរទៅដែនដីសន្យា ការបែកចេញពីលេមិន និង លេមយួល និង ការដឹកនាំប្រជាជនរបស់គាត់នៅក្នុងសេចក្តីសុចរិត ។ នៅពេលសិស្សផ្តល់ឧទាហរណ៍ខ្លះ អ្នកអាចសរសេរវានៅលើក្តារខៀន ។

សូមសរសេរដូចខាងក្រោមដាក់លើក្តារខៀន ៖ *ខ្ញុំត្រូវតែ . . .*

សូមអញ្ជើញសិស្សឲ្យបំពេញប្រយោគនេះនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេររបស់ពួកគេ ។ សូមបង្ហាញទំនុកចិត្តរបស់អ្នកថា ពួកគេអាចជ្រើសរើសដើម្បីគោរពតាមបាន ។ សូមចែកចាយគំនិតរបស់អ្នក អំពីរបៀបដែលពាក្យរបស់នីហ្វៃអាចជួយពួកគេឲ្យពង្រឹងនូវសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ និង បង្កើនសមត្ថភាពរបស់ពួកគេដើម្បីធ្វើល្អ ។

ការលើកទឹកចិត្តសិស្សឲ្យនិយាយពីសេចក្តីពិតទាំងឡាយ

សិស្សទទួលបានប្រយោជន៍ពីឱកាសញឹកញាប់ដើម្បីចែកចាយនូវគំនិត និង អារម្មណ៍របស់ពួកគេ ពន្យល់ពីគោលការណ៍ជំណឹងល្អ និង ថ្លែងទីបន្ទាល់ពីសេចក្តីពិត ។ អែលឌើរ រីឆាត ជី. ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានសង្កេតថា « នៅពេលសិស្សបាននិយាយពីសេចក្តីពិតទាំងឡាយ ពួកគេត្រូវបានបញ្ជាក់នៅក្នុងព្រលឹងរបស់ពួកគេ ហើយពង្រឹងដល់ទីបន្ទាល់ផ្ទាល់ខ្លួនរបស់ពួកគេ » (« To Understand and Live Truth » [សុន្ទរកថាថ្លែងទៅកាន់អ្នកអប់រំសាសនាសឺ. អ៊ី. អេស.នៅថ្ងៃទី ៤ខែ កុម្ភៈ ឆ្នាំ ២០០៥] ទំព័រ ៣ si.lds.org) ។ ទោះជាយ៉ាងណាក្តី ខណៈពេលដែលវាសំខាន់ដើម្បីផ្តល់ឱកាសដល់សិស្សឲ្យចែកចាយ ពួកគេមិនគួរមានអារម្មណ៍ថាត្រូវបានបង្ខំ ឬ នៅក្រោមសម្ពាធឲ្យធ្វើដូច្នោះនោះឡើយ ។

ការរំឭកនីហ្វៃទី ២ ឡើងវិញ

សូមចំណាយពេលខ្លះដើម្បីជួយសិស្សឲ្យរំឭកនីហ្វៃទី ២ ឡើងវិញ ។ សូមឲ្យពួកគេគិតអំពីអ្វីដែលពួកគេបានរៀនពីគម្ពីរនេះ ទាំងនៅក្នុងថ្នាក់សិក្ខាសាលា និង នៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់របស់ពួកគេ ។ ប្រសិនបើចាំបាច់ សូមលើកទឹកចិត្តពួកគេឲ្យមើលត្រួសៗក្នុងនីហ្វៃទី ២ ដើម្បីជួយពួកគេឲ្យចងចាំវិញ ។ សូមឲ្យពួកគេរៀបចំចែកចាយអ្វីមួយពីនីហ្វៃទី ២ ដែលបានបំផុសគំនិតពួកគេឲ្យធ្វើល្អ និង មានសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ដូចដែលនីហ្វៃបាននិយាយ (សូមមើល នីហ្វៃទី ទី ២ ៣៣:៤) ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបីបួននាក់ចែកចាយនូវគំនិត និង អារម្មណ៍របស់ពួកគេ ។

សូមចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមអំពីទំនួលខុសត្រូវដែលយើងមានដើម្បីអានព្រះគម្ពីរមរមន និង អំពីពរជ័យទាំងឡាយដែលមកក្នុងជីវិតរបស់យើង នៅពេលយើងបំពេញការទទួលខុសត្រូវនេះ ៖

ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ បានមានប្រសាសន៍ថា ៖ « ចំពោះខ្ញុំ វាហាក់ដូចជាសមាជិកសាសនាចក្រគ្រប់រូបនឹងមិនដែលទទួលបានការពេញចិត្តឡើយ រហូតដល់គាត់បានអានព្រះគម្ពីរមរមនម្តងហើយម្តងទៀត ហើយពិចារណាពីវាយ៉ាងពេញលេញ ដើម្បីឲ្យគាត់អាចថ្លែងជាសាក្សីថា វាគឺពិតជាកំណត់ត្រាមួយដែលមានការបំផុសគំនិតពីព្រះដ៏មានមហិទ្ធិឫទ្ធិ ហើយថាប្រវត្តិសាស្ត្ររបស់វាគឺជារឿងពិត » (នៅក្នុងរបាយការណ៍សន្និសីទ ខែ តុលា ឆ្នាំ ១៩៦១ ទំព័រ ១៨) ។

ប្រធាន ហ្គរដុន ប៊ី. ហិងគ្លី បានបង្រៀនថា ប្រសិនបើសមាជិកទាំងឡាយនៃសាសនាចក្រអានព្រះគម្ពីរមរមន « នឹងមានរង្វាស់បន្តែមមួយនៃព្រះវិញ្ញាណនៃព្រះអម្ចាស់មកក្នុងជីវិត ។ របស់ពួកគេ ។ និង នៅក្នុងផ្ទះ ។ របស់ពួកគេ ។ នោះការតាំងចិត្តដ៏រឹងមាំមួយដើម្បីដើរដោយការគោរពប្រតិបត្តិតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ និង ទីបន្ទាល់កាន់តែរឹងមាំអំពីភាពពិតដែលនៅរស់របស់ព្រះរាជបុត្រានៃព្រះ » (« A Testimony Vibrant and True »*Ensign*ខែ **សីហា ឆ្នាំ ២០០៥ ទំព័រ ៦**) ។

ដើម្បីបញ្ចប់មេរៀននេះ អ្នកអាចគិតពីការចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនមួយជាទីបន្ទាល់ថា ពាក្យទាំងឡាយរបស់នីហ្វៃនៅក្នុងជំពូកនេះត្រូវបានបំពេញនៅក្នុងជីវិតរបស់អ្នក ។

សេចក្តីផ្តើមពី

គម្ពីរយ៉ាកុប

ហេតុអ្វីបានជាត្រូវសិក្សាគម្ពីរនេះ ?

តាមរយៈការសិក្សាគម្ពីរយ៉ាកុប សិស្សអាចរៀនមេរៀនដ៏សំខាន់ជាច្រើនពីបុរសម្នាក់ដែលមានសេចក្តីជំនឿយ៉ាងមុតមាំទៅលើព្រះយេស៊ូវគ្រីស្ទ ។ យ៉ាកុបបានថ្លែងទីបន្ទាល់ម្តងហើយម្តងទៀតអំពីព្រះអង្គសង្គ្រោះហើយបានអញ្ជើញប្រជាជនរបស់គាត់និងអស់អ្នកទាំងឡាយណាដែលបានអានពាក្យទាំងឡាយរបស់គាត់ឲ្យប្រែចិត្ត ។ គាត់បានបង្រៀននិងបង្ហាញពីសារៈសំខាន់នៃការបំពេញការហៅបម្រើដែលមកពីព្រះអម្ចាស់ដោយឧស្សាហ៍ព្យាយាម ។ គាត់បានព្រមានដល់ប្រជាជនរបស់គាត់អំពីគ្រោះថ្នាក់នៃអំនួតទ្រព្យសម្បត្តិនិងភាពអសីលធម៌ ។ យ៉ាកុបក៏បានដកស្រង់ និងបញ្ចេញយោបល់លើដំណើររឿងប្រៀបធៀបរបស់សិណ្ឌសអំពីដើមអូលីវដែលបង្ហាញពីការខិតខំដ៏មិនចេះនឿយហត់របស់ព្រះអង្គសង្គ្រោះដើម្បីនាំមកនូវសេចក្តីសង្គ្រោះដល់កូនចៅរបស់ព្រះទាំងអស់និងផ្តល់សេចក្តីសង្ឃឹមមួយអំពីទំនាក់ទំនងរបស់ព្រះជាមួយនឹងវង្សនៃអ៊ីស្រាអែល ។ នៅក្នុងការប្រឈមមុខរបស់គាត់នឹងសេរេមជាអ្នកប្រឆាំងនឹងព្រះគ្រីស្ទយ៉ាកុបបានបង្ហាញពីរបៀបដើម្បីឆ្លើយតបដោយសុចរិតទៅនឹងអស់អ្នកទាំងឡាយណាដែលបានសួរឬរិះគន់សេចក្តីជំនឿរបស់យើង ។

តើនរណាបានសរសេរគម្ពីរនេះ ?

យ៉ាកុបដែលជាកូនប្រុសទីប្រាំរបស់សាព៌ាយនិងលីហៃបានសរសេរគម្ពីរនេះ ។ គាត់បានកើតនៅក្នុងទីរហោស្ថានអំឡុងពេលការធ្វើដំណើរគ្រួសារគាត់ទៅកាន់ដែនដីសន្យា ។ កាលពីគាត់នៅវ័យក្មេងយ៉ាកុប « បានរងទុក្ខវេទនានិងការសោកសៅដ៏ច្រើនដោយព្រោះការទ្រគោះរបស់បងៗ [គាត់] » (នីហ្វៃទី២ ២:១) ។ ទោះជាយ៉ាងណាក្តីលីហៃបានសន្យានឹងយ៉ាកុបថាព្រះនឹង « ធ្វើឲ្យសេចក្តីវេទនាទាំងឡាយ [របស់គាត់] ក្លាយទៅជាផលប្រយោជន៍ដល់ [គាត់] វិញ » ហើយថាគាត់នឹងចំណាយពេលរបស់គាត់ « ក្នុងការបម្រើព្រះ [របស់គាត់] » (នីហ្វៃទី២ ២:២–៣) ។ កាលគាត់នៅវ័យក្មេង យ៉ាកុបបានឃើញសិរីល្អរបស់ព្រះអង្គសង្គ្រោះ (សូមមើល នីហ្វៃទី២ ២:៣–៤) ។ នីហ្វៃបានតែងតាំងយ៉ាកុបជាសង្ឃ និង ជាគ្រូម្នាក់នៃសាសន៍នីហ្វៃ (សូមមើល នីហ្វៃទី២ ៥:២៦) ហើយក្រោយមកបានប្រគល់ដល់គាត់នូវផ្ទាំងនីហ្វៃតូចមួយ (សូមមើល យ៉ាកុប ១:១–៤) ។ ក្នុងនាមជាអ្នកដឹកនាំបព្វជិតភាព និង គ្រូដ៏ស្មោះត្រង់ម្នាក់ យ៉ាកុបបានធ្វើការដោយឧស្សាហ៍ព្យាយាមដើម្បីបញ្ចុះបញ្ចូលប្រជាជនរបស់គាត់ឲ្យជឿដល់ព្រះគ្រីស្ទ (សូមមើល យ៉ាកុប ១:៧) ។ គាត់បានទទួលវិវរណៈជាច្រើនទាក់ទងនឹងព្រះអង្គសង្គ្រោះ បានជួបនឹងការបម្រើរបស់ពួកទេវតា បានឮសំឡេងរបស់ព្រះអម្ចាស់ (សូមមើល យ៉ាកុប ៧:៥) ហើយបានឃើញព្រះប្រោសលោះរបស់គាត់ (សូមមើល នីហ្វៃទី២ ១១:២–៣) ។ យ៉ាកុបគឺជាឪពុករបស់អេណុស ដែលគាត់បានប្រគល់ផ្ទាំងឲ្យ មុនពេលគាត់ស្លាប់ ។

តើគម្ពីរនេះត្រូវបានសរសេរទៅឲ្យនរណា ហើយហេតុអ្វី ?

នីហ្វៃបានណែនាំយ៉ាកុបឲ្យកត់ត្រាការបង្រៀន វិវរណៈ និងការព្យាករណ៍ដ៏ពិសិដ្ឋទាំងឡាយ « ដោយយល់ដល់ព្រះគ្រីស្ទ ហើយដោយយល់ដល់ប្រជាជនរបស់យើង » (យ៉ាកុប ១:៤) ។ យ៉ាកុបបានគោរពតាមការណែនាំនេះ ហើយបានរក្សាការសរសេរទាំងឡាយដែលគាត់ « ចាត់ទុកថាជារឿងដ៏ពិសេសបំផុត » (យ៉ាកុប ១:២) ។ គាត់បានសរសេរថា ៖ « យើងខំព្យាយាមដើម្បីឆ្លាក់ពាក្យទាំងនេះ នៅលើផ្ទាំងដោយសង្ឃឹមថា បងប្អូនជាទីស្រឡាញ់របស់យើង និង កូនចៅយើងនឹងទទួលពាក្យទាំងនេះដោយចិត្តអរគុណ ។ . . . ព្រោះដោយគោលបំណងនេះហើយ ដែលយើងបានសរសេររឿងទាំងនេះ ដើម្បីឲ្យគេដឹងថា យើងបានដឹងអំពីព្រះគ្រីស្ទ ហើយយើងបានសង្ឃឹមដល់សិរីល្អរបស់ទ្រង់ជាច្រើនរយឆ្នាំមុនទ្រង់យាងមកម្ល៉េះ » (យ៉ាកុប ៤:៣–៤) ។ យ៉ាកុបបានអធិប្បាយលើគំនិតចម្បងមួយនៃការសរសេររបស់គាត់ នៅពេលគាត់បាននិយាយថា « ហេតុអ្វីបានជាមិននិយាយអំពីជង្វាយធួននៃព្រះគ្រីស្ទ ហើយទទួលការចេះដឹងដោយឥតខ្ចោះអំពីព្រះអង្គ . . . ? » (យ៉ាកុប ៤:១២) ។

តើវាបានសរសេរនៅពេលណា ហើយនៅកន្លែងណា ?

គម្ពីរយ៉ាកុបចាប់ផ្តើមប្រហែលជានៅក្នុងឆ្នាំ ៥៤៤ ម.គ.ស. នៅពេលនីហ្វៃបានប្រគល់ផ្ទាំងតូចដល់យ៉ាកុប ។ វាបញ្ចប់ក៏ទាក់ទងនឹងចុងបញ្ចប់នៃជីវិតរបស់យ៉ាកុប នៅពេលលោកបានបន្តផ្ទាំងនេះទៅដល់កូនប្រុសរបស់គាត់ គឺអេណុស ។ យ៉ាកុបបានសរសេរកំណត់ត្រានេះ ខណៈពេលគាត់រស់នៅក្នុងដែនដីនីហ្វៃ ។

តើមានលក្ខណៈពិសេសអ្វីខ្លះនៅក្នុងគម្ពីរនេះ ?

គម្ពីរយ៉ាកុប ផ្តល់ព័ត៌មានដែលទាក់ទងនឹងការគ្រប់គ្រងសាសន៍នីហ្វៃបន្ទាប់ពីនីហ្វៃបានស្លាប់ទៅ ។ នីហ្វៃបានតែងតាំងបុរសម្នាក់ឲ្យបន្តពីគាត់ ធ្វើជាស្តេច និង ជាអ្នកគ្រប់គ្រងលើប្រជាជននេះ ខណៈពេលដែលយ៉ាកុប និងប្អូនប្រុសរបស់គាត់យ៉ូសែបបានបន្តធ្វើជាអ្នកដឹកនាំខាងវិញ្ញាណលើសាសន៍នីហ្វៃ ។ លក្ខណៈពិសេសមួយទៀតនៃគម្ពីរនេះគឺ ការដាក់ទោសរបស់យ៉ាកុបចំពោះការអនុវត្តពហុភាពាហ៍ពិពាហ៍ដែលមិនមានសិទ្ធិអំណាច ។ សេចក្តីយោងតែមួយគត់ចំពោះបញ្ហានេះនៅក្នុងព្រះគម្ពីរមរមន មាននៅក្នុងយ៉ាកុបជំពូកទី ២ ។ គម្ពីរយ៉ាកុបក៏រួមមានជំពូកដែលវែងជាងគេបំផុតនៅក្នុងព្រះគម្ពីរមរមន ដែរ គឺយ៉ាកុបជំពូកទី ៥ ដែលមានជំណើររឿងប្រៀបធៀបរបស់សិណ្ឌសអំពីដើមអូលីវ ។ បន្ថែមលើនេះ គម្ពីរយ៉ាកុបកត់ត្រាពីគំរូដំបូងគេបំផុតនៃការព្រមានដោយផ្ទាល់ពីព្យាការីក្នុងព្រះគម្ពីរមរមនដល់សាសន៍នីហ្វៃចំៗជំទាស់នឹងអំនួត—អំពើបាបដែលបណ្តាលឲ្យមានការបំផ្លាញនៅទីបញ្ចប់របស់ពួកគេ (សូមមើល យ៉ាកុប ២:១២–២២; ម៉ូរ៉ូណៃ ៨:២៧) ។ វាក៏បានកត់ត្រាអំពីការលេចឡើងដំបូងនៃអ្នកប្រឆាំងនឹងព្រះគ្រីស្ទក្នុងចំណោមប្រជាជននីហ្វៃ ។

គម្រោង

យ៉ាកុប ១ យ៉ាកុបគោរពតាមការបញ្ជារបស់នីហ្វៃដើម្បីរក្សាកំណត់ត្រាដ៏ពិសិដ្ឋមួយ ។ នីហ្វៃស្លាប់ ។ យ៉ាកុប និង យ៉ូសែប បានបម្រើនៅក្នុងចំណោមប្រជាជន ដោយបង្រៀនពួកគេនូវព្រះបន្ទូលនៃព្រះ ។

យ៉ាកុប ២–៣ ពេលនិយាយនៅព្រះវិហារបរិសុទ្ធ យ៉ាកុបព្រមានដល់សាសន៍នីហ្វៃអំពីអំនួត ការស្រឡាញ់ទ្រព្យសម្បត្តិ និង ភាពអសីលធម៌ ។

យ៉ាកុប ៤–៦ យ៉ាកុបថ្លែងទីបន្ទាល់អំពីព្រះគ្រីស្ទ ហើយបានដកស្រង់ដំណើររឿងប្រៀបធៀបរបស់សិណ្ឌសនៃដើមអូលីវ ។ គាត់លើកទឹកចិត្តប្រជាជនរបស់គាត់ឲ្យប្រែចិត្ត ទទួលនូវសេចក្តីមេត្តាករុណាពីព្រះអម្ចាស់ និង រៀបចំខ្លួនសម្រាប់ការជំនុំជំរះ ។

យ៉ាកុប ៧ ដោយមានជំនួយពីព្រះអម្ចាស់ យ៉ាកុបបានផ្ចាញ់ផ្ចាលសេរេម ជាអ្នកប្រឆាំងនឹងព្រះគ្រីស្ទ ។ គាត់លើកឡើងពីវិបត្តិរវាងសាសន៍នីហ្វៃ និង សាសន៍លេមិន ហើយបានបន្តផ្ទាំងតូចទៅឲ្យអេណុស ។

យ៉ាកុប ១–យ៉ាកុប ២:១១

សេចក្តីផ្តើម

ក្រោយពីការស្លាប់របស់នីហ្វៃ សាសន៍នីហ្វៃបានចាប់ផ្តើម « បណ្តោយខ្លួនឲ្យប្រព្រឹត្តអំពើទុច្ចរិត » នៅក្រោមរជ្ជកាលរបស់ស្តេចថ្មីមួយអង្គ (យ៉ាកុប ១:១៥) ។ យ៉ាកុប និងប្អូនប្រុសរបស់គាត់ គឺយ៉ូសែប ត្រូវបានតែងតាំងដោយនីហ្វៃឲ្យធ្វើជាសង្ឃ និង គ្រូនៃប្រជាជន ហើយពួកគេបានធ្វើការដោយឧស្សាហ៍ព្យាយាមដើម្បីបញ្ចុះបញ្ចូលប្រជាជនឲ្យប្រែចិត្ត ហើយមកកាន់ព្រះគ្រីស្ទ ។ យ៉ាកុបបានគោរពតាមការបញ្ជារបស់នីហ្វៃ ដើម្បីកត់ត្រាការបង្រៀន វិវរណៈ និង ការព្យាករណ៍ដ៏ពិសិដ្ឋទាំងឡាយនៅលើផ្ទាំងតូច ។

យោបល់សម្រាប់ការបង្រៀន

យ៉ាកុប ១:១–៨

យ៉ាកុបកត់ត្រាសេចក្តីពិតដ៏ពិសិដ្ឋ និង ធ្វើការដើម្បីជួយដល់អ្នកដទៃឲ្យមកកាន់ព្រះយេស៊ូវគ្រីស្ទ

សូមឲ្យសិស្សផ្តល់ឧទាហរណ៍នានានៃភាពខុសៗគ្នានៃអ្នកដឹកនាំបព្វជិតភាពទាំងឡាយ ។ (ចម្លើយអាចរួមមាន ព្យាការី និង សាវកអ្នកដឹកនាំសិទ្ធិអំណាចទូទៅ ប្រធានស្តេក ប៊ីស្សព និង ប្រធានក្រុម) ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយសង្ខេបៗពីរបៀបខ្លះៗ ដែលអ្នកដឹកនាំបព្វជិតភាពទាំងឡាយបានប្រទានពរដល់ជីវិតរបស់ពួកគេតាមរយៈការបម្រើបព្វជិតភាព ។

សូមពន្យល់ថា នីហ្វៃបានតែងតាំងប្អូនប្រុសក្មេងរបស់គាត់ យ៉ាកុប និង យ៉ូសែប ជាសង្ឃ និង គ្រូនៃប្រជាជននេះ (សូមមើល នីហ្វៃទី២ ៥:២៦; យ៉ាកុប ១:១៨) ។ នៅពេលនីហ្វៃជិតដល់ចុងបញ្ចប់នៃជីវិតរបស់គាត់ហើយ គាត់បានឲ្យយ៉ាកុបទទួលបន្ទុកលើផ្ទាំងទាំងឡាយដែលមានកំណត់ត្រានៃប្រជាជនរបស់ពួកគេ ។

សូមអញ្ជើញសិស្សឲ្យអាន យ៉ាកុប ១:១–៤ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើលអ្វីដែលនីហ្វៃបានបញ្ជាដល់យ៉ាកុបឲ្យកត់ត្រានៅលើផ្ទាំងនេះ និង ពីមូលហេតុផង ។ (អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំការណែនាំរបស់នីហ្វៃទៅដល់យ៉ាកុប) ។ ក្រោយពីសិស្សមានពេលអានគ្រប់គ្រាន់ហើយ សូមអញ្ជើញពួកគេពីរបីនាក់ឲ្យប្រាប់សិស្សក្នុងថ្នាក់ពីអ្វីដែលពួកគេបានរកឃើញ ។

ប្រសិនបើសិស្សមិនបានលើកឡើងទេ សូមបង្ហាញឃ្លាចុងក្រោយគេបង្អស់នៃ យ៉ាកុប ១:៤— « ដោយយល់ដល់ប្រជាជនរបស់យើង » ។

- តើឃ្លា « ដោយយល់ដល់ប្រជាជនរបស់យើង » មានអត្ថន័យយ៉ាងណាដែរ ? (ដើម្បីជាប្រយោជន៍ដល់ពួកគេ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ាកុប ១:៥–៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះអម្ចាស់បានបើកសម្តែងដល់យ៉ាកុប និង យ៉ូសែប ថានឹងជួយពួកគេឲ្យបង្រៀនដល់ប្រជាជនរបស់ពួកគេ ។ (អ្នកអាចពន្យល់ថា « សេចក្តីបារម្ភដ៏ខ្លាំង » សំដៅលើការព្រួយជាខ្លាំងរបស់ពួកគេទៅលើប្រជាជននេះ) ។

- តើព្រះអម្ចាស់បានបើកសម្តែងអ្វីខ្លះ ដល់យ៉ាកុប និង យ៉ូសែប ? (ទ្រង់បានបង្ហាញពួកគេពីអ្វីដែលនឹងកើតឡើងដល់សាសន៍នីហ្វៃនៅក្នុងពេលអនាគត ហើយទ្រង់បានសម្តែងពីសេចក្តីលម្អិតអំពីការយាងមកនៃព្រះគ្រីស្ទ) ។
- តើការដឹងពីរឿងទាំងនេះអាចជួយយ៉ាកុប និង យ៉ូសែបនៅក្នុងការបង្រៀនប្រជាជនរបស់ពួកគេដោយរបៀបណា ?

សូមសរសេរពាក្យ *បញ្ចុះបញ្ចូល* នៅលើក្តារខៀន ។ សូមឲ្យសិស្សអាន យ៉ាកុប ១:៧–៨ដោយស្ងាត់ៗ ដោយរកមើលនូវអ្វីដែលយ៉ាកុប និង យ៉ូសែបចង់បញ្ចុះបញ្ចូលប្រជាជនរបស់គេឲ្យធ្វើនោះ ។ (អ្នកអាចស្នើថា សិស្សគួរតែគូសចំណាំនូវអ្វីដែលពួកគេបានរកឃើញនោះ) ។ សូមអញ្ជើញសិស្សពីរបួននាក់ឲ្យសរសេរនៅលើក្តារខៀន នូវរឿងមួយដែលពួកគេរកឃើញ ។

យោងតាមអ្វីដែលសរសេរនៅលើក្តារខៀននោះ សូមអញ្ជើញសិស្សឲ្យចង្អុលទៅឃ្លាមួយ ឬ ពីរដែលពួកគេចង់យល់បន្ថែមទៀត ។ នៅពេលសិស្សចង្អុលទៅឃ្លាទាំងនេះហើយ សូមសាកសួរក្រែងមានសិស្សផ្សេងទៀតអាចជួយពន្យល់ថាបាន ។ នៅក្នុងការពិភាក្សានេះ និយមន័យខាងក្រោមអាចជួយបានច្រើន ៖

« ចូលក្នុងសេចក្តីសម្រាករបស់ទ្រង់ » —ការចូលក្នុងសេចក្តីសម្រាករបស់ព្រះអម្ចាស់ មានន័យថាការរីករាយនឹងសេចក្តីសុខសាន្តនៅក្នុងជីវិតនេះ និង ការទទួលបាននូវ « ភាពពោរពេញនៃសិរីល្អ [របស់ព្រះ] នៅក្នុងជីវិតបន្ទាប់ពីជីវិតនេះ (គ . និង ស . ៨៤:២៤) ។

« យល់ដល់សារៈប្រយោជន៍នៃការសុគត [របស់ព្រះគ្រីស្ទ] » —និយមន័យមួយនៃ *យល់ដល់សារៈប្រយោជន៍* គឺមើល ឬ ពិនិត្យដោយប្រុងប្រយ័ត្ន ។ នៅពេលយ៉ាកុបបានសរសេរថា គាត់ចង់បញ្ចុះបញ្ចូលប្រជាជនឲ្យ « ជឿដល់ព្រះគ្រីស្ទ យល់ដល់សារៈប្រយោជន៍នៃការសុគតរបស់ទ្រង់ » គាត់អាចមានន័យថា គាត់ចង់ឲ្យពួកគេពិនិត្យពិដង្វាយរបស់ព្រះយេស៊ូវគ្រីស្ទដោយប្រុងប្រយ័ត្ន យល់ពីសារៈសំខាន់របស់វា និង ទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនមួយអំពីវា ។

« លើឈើឆ្កាងទ្រង់ » —ឃ្លានេះសំដៅទៅលើឆន្ទៈរបស់យើងដើម្បីបដិសេធចំពោះខ្លួនឯងទៅនឹងការមិនការដឹកនាំពីព្រះ និង ចំណង់ខាងលោកិយ ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ (សូមមើល ការបកប្រែដោយយ៉ូសែប ស្ទីធ ម៉ាថាយ ១៦:២៦ [នៅក្នុង ម៉ាថាយ ១៦:២៤ លេខយោង *d*] ; លូកា ៩:២៣; នីហ្វៃទី២ ៩:១៨) ។ វាក៏សំដៅទៅលើឆន្ទៈរបស់យើងក្នុងការកាន់ខ្ជាប់ និង ពលិកម្ម នៅពេលយើងធ្វើតាមព្រះអង្គសង្គ្រោះ ។

ការពន្យល់ពាក្យ និង ឃ្លាពិបាក

នៅពេលអ្នកជួយសិស្សឲ្យយល់ពីពាក្យ និង ឃ្លាពិបាកទាំងឡាយក្នុងព្រះគម្ពីរ ពួកគេអាចនឹងអនុវត្តវានៅក្នុងជីវិតរបស់ពួកគេឲ្យកាន់តែល្អប្រសើរ ។ នៅពេលព្យាយាមពន្យល់ពាក្យ ឬ ឃ្លាពិបាកមួយ វាអាចជួយបានច្រើនបើអ្នកប្រើវចនានុក្រមមួយ ឬក៏សិក្សាពាក្យ ឬ ឃ្លានោះ នៅពេលវាលេចឡើងនៅកន្លែងណាមួយនៅក្នុងព្រះគម្ពីរ ។

« ស៊ូរងនូវការអាម៉ាស់នៃមនុស្សលោក »—ឃ្លានេះសំដៅទៅលើការកាន់តាមព្រះបញ្ញត្តិទាំងឡាយ ថ្វីបើមានសម្ពាធពីពិភពលោក ការអាម៉ាស់ និង ការប្រឆាំងជំទាស់ដែលមកដល់សិស្សរបស់ព្រះយេស៊ូវគ្រីស្ទជាញឹកញាប់ក្តី ។

សូមឲ្យសិស្សសង្ខេបនូវអ្វីដែលពួកគេបានរៀនពី យ៉ាកុប ១:១–៨ អំពីទំនួលខុសត្រូវរបស់អ្នកដឹកនាំបព្វជិតភាពទាំងឡាយ ។ នៅពេលសិស្សចែកចាយគំនិតរបស់ពួកគេ សូមបញ្ជាក់ថា **អ្នកដឹកនាំបព្វជិតភាពទាំងឡាយធ្វើការដោយឧស្សាហ៍ព្យាយាមដើម្បីជួយយើងឲ្យមកអ្នកព្រះគ្រីស្ទ ។**(អ្នកអាចសរសេរគោលការណ៍នេះដាក់លើក្តារខៀនបាន) ។

- តើអ្នកដឹកនាំបព្វជិតភាពទាំងឡាយរបស់យើង ធ្វើការដើម្បីជួយយើងឲ្យមកអ្នកព្រះគ្រីស្ទដោយរបៀបណា ?

សូមផ្តល់ពេលពីរបីនាទីដល់សិស្សឲ្យសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេអំពីរបៀបដែលព្យាការី ឬ អ្នកដឹកនាំបព្វជិតភាពទាំងឡាយផ្សេងទៀតបានជួយពួកគេនៅក្នុងតំបន់មួយ ឬ ពីរដែលពួកគេបានឃើញនៅក្នុង យ៉ាកុប ១:៧–៨ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអ្វីដែលពួកគេបានសរសេរ ។ សូមរំឭកពួកគេថា ពួកគេមិនចាំបាច់ចែកចាយអ្វីៗដែលវាផ្ទាល់ខ្លួន ឬ ឯកជនពេកនោះទេ) ។

យ៉ាកុប ១:៩–២:១១

យ៉ាកុបព្រមានដល់ប្រជាជនអំពីសេចក្តីទុច្ចរិតរបស់ពួកគេ

សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតអំពីសំណួរខាងក្រោម អំឡុងពេលរៀនមេរៀននេះ ៖

- ហេតុអ្វីបានជាអ្នកដឹកនាសាសនាចក្រទាំងឡាយព្រមានយើងពីអំពើបាប ?

យ៉ាកុបបានកត់ត្រាថា ក្រោយពីការស្លាប់របស់បងប្រុសគាត់ នីហ្វៃ នោះប្រជាជនបានចាប់ផ្តើមបណ្តោយទៅតាមការធ្វើអំពើទុច្ចរិតមួយចំនួន ។ សូមអញ្ជើញសិស្សឲ្យអាន យ៉ាកុប ១:១៥–១៦ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើលបញ្ហាបីយ៉ាងដែលធ្វើឲ្យយ៉ាកុបព្រួយបារម្ភ ។ (នៅពេលសិស្សឆ្លើយរួចហើយ អ្នកអាចសរសេរពាក្យ *ភាពអសីលធម៌ ភាពលោភលន់នៃលោកិយ* និង *អំនួត* នៅលើក្តារខៀន) ។

សូមឲ្យសិស្សអាន យ៉ាកុប ១:១៧–១៩ ដោយស្ងាត់ៗ ដោយរកមើលអ្វីដែលយ៉ាកុប និង យ៉ូសែបបានធ្វើដើម្បីជួយប្រជាជនរបស់គាត់ ។ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដែរ ក្នុងការទទួលបាន « ភារកិច្ចមួយមកពីព្រះអម្ចាស់ » ? (យ៉ាកុប១:១៧) ។ (ដើម្បីរៀនពីអ្វីដែលព្រះអម្ចាស់ចង់ឲ្យយើងធ្វើ) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ជែហ្វ្រីអ័រ.ហូឡិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់និងស្វែងរករបៀបដែលអ្នកដឹកនាំសាសនាចក្រស្វែងរកភារកិច្ចរបស់ពួកគេមកពីព្រះអម្ចាស់ នៅពេលពួកគេរៀបចំបង្រៀននៅក្នុងសន្និសីទទូទៅ ៖

« ប្រហែលអ្នកបានដឹងហើយ (ប៉ុន្តែប្រសិនបើអ្នកមិនបានដឹងទេ អ្នកគួរតែដឹង) ថា ដោយមានករណីលើកលែងតិចតួចបំផុត នោះគ្មានបុរស ឬ ស្ត្រីណាដែលនិយាយ | នៅក្នុងសន្និសីទទូទៅ | ត្រូវបានផ្តល់ប្រធានបទមួយឲ្យនោះទេ ។ ម្នាក់ៗត្រូវតមអាហារ និងអធិស្ឋាន សិក្សា និងស្វែងរក ចាប់ផ្តើម និងឈប់ ហើយចាប់ផ្តើមម្តងទៀត រហូតដល់គាត់មានទំនុកចិត្តថា សម្រាប់សន្និសីទនេះ នៅពេលនេះ វាគឺជាប្រធានបទមួយដែលព្រះអម្ចាស់ចង់ឲ្យអ្នកនិយាយនោះថ្លែងដោយមិនគិតអំពីបំណងផ្ទាល់ខ្លួន ឬ ការពេញចិត្តឯកជននោះទេ ។ . . . ម្នាក់ៗបានយំព្រួយបារម្ភ និង បានស្វែងរកការដឹកនាំរបស់ព្រះអម្ចាស់ដោយស្មោះអស់ពីចិត្តដើម្បីដឹកនាំគំនិត និង ការនិយាយរបស់គាត់ » (« An Ensign to the Nations » *Ensign*ឬ*លីអាហូណា*ខែ ឧសភា ឆ្នាំ ២០១១ទំព័រ ១១១) ។

- តើអ្នកនិយាយនៅក្នុងសន្និសីទទូទៅធ្វើអ្វីខ្លះ ដើម្បីស្វែងរកភារកិច្ចរបស់ពួកគេមកពីព្រះអម្ចាស់នោះ ?
- ហេតុអ្វីបានជាវាសំខាន់ដើម្បីយល់ថា អ្នកដឹកនាំសាសនាចក្រទាំងឡាយចង់បង្រៀនយើងនូវអ្វីដែលព្រះអម្ចាស់ចង់ឲ្យយើងដឹងនោះ ? តើការចាំពីរឿងនេះ អាចមានឥទ្ធិពលមកលើឥរិយាបថរបស់យើងយ៉ាងណាដែរ នៅពេលយើងស្តាប់ពួកគាត់បង្រៀន ?
- យោងតាម យ៉ាកុប ១:១៩ តើអ្វីខ្លះជាទំនួលខុសត្រូវរបស់យ៉ាកុប និង យ៉ូសែប ? (នៅពេលសិស្សឆ្លើយ សូមប្រាកដថាពួកគេយល់ថា **អ្នកដឹកនាំបព្វជិតភាពទាំងឡាយមានទំនួលខុសត្រូវដ៏ទេវភាពដែលបានផ្តល់ទៅឲ្យពួកគាត់ដើម្បីបង្រៀននូវព្រះបន្ទូលនៃព្រះ និងព្រមានអំពីអំពើបាប ។**អ្នកអាចសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- ហេតុអ្វីបានជាវាគឺជាពរជ័យមួយដើម្បីមានឪពុកម្តាយ និង អ្នកដឹកនាំសាសនាចក្រដែលព្រមានយើងពីឥរិយាបថ និង អាកប្បកិរិយាដែលពោរពេញដោយអំពើបាបនោះ ?
- តើយ៉ាកុបបានប្រើពាក្យអ្វីខ្លះ ដើម្បីពិពណ៌នាពីរបៀបដែលពួកគេត្រូវបង្រៀន ? តើនឹងមានផលវិបាកអ្វី បើសិនជាពួកគេមិនបានបំពេញការទទួលខុសត្រូវរបស់ពួកគេនោះ ?

សូមឲ្យសិស្សគិតថាតើពួកគេមានអារម្មណ៍យ៉ាងណា ប្រសិនបើពួកគេនៅក្នុងតំណែងជាអ្នកដឹកនាំមួយដូចជាយ៉ាកុប ហើយត្រូវបំផុសគំនិតឲ្យហៅប្រជាជនឲ្យធ្វើការប្រែចិត្តពីអំពើអសីលធម៌ ភាពខាងលោកិយ និង អំនួតនោះ ។ សូមបែងចែកសិស្សទៅជាគូៗ ។ សូមអញ្ជើញដៃគូទាំងអស់ឲ្យប្តូរវេនគ្នាអានឲ្យគ្នាទៅវិញទៅមកក្នុង យ៉ាកុប ២:១–៣, ៦–៧, ១០–១១ ។ សូមឲ្យពួកគេរកមើលឃ្លាដែលបង្ហាញពីអារម្មណ៍របស់យ៉ាកុប អំពីកិច្ចការរបស់គាត់ក្នុងការហៅប្រជាជនឲ្យប្រែចិត្ត ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សឲ្យចែកចាយការរកឃើញរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

- តើឃ្លាទាំងនេះបង្ហាញអ្វីខ្លះ៖ អំពីអារម្មណ៍របស់យ៉ាកុបចំពោះការហៅប្រជាជនគាត់ឲ្យប្រែចិត្ត ? (សូមធ្វើយ៉ាងណាជួយសិស្សឲ្យយល់ថា ទោះបីជាយ៉ាកុបឃើញថាការទទួលខុសត្រូវរបស់គាត់ពិបាកក្តី ក៏គាត់នៅតែធ្វើវា ដោយសារគាត់យកចិត្តទុកដាក់នឹងប្រជាជនរបស់គាត់ និង ដោយសារគាត់ចង់គោរពតាមបញ្ញត្តិរបស់ព្រះ) ។

សូមបញ្ចប់ ដោយឲ្យសិស្សសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេអំពី (១) អ្វីដែលអ្នកដឹកនាំសាសនាចក្រទាំងឡាយបានបង្រៀនពួកគេក្នុងពេលថ្មីៗនេះ និង ពីរបៀបដែលពួកគេអាចអនុវត្តវានៅក្នុងជីវិតរបស់ពួកគេ ឬ (២) របៀបដែលពួកគេអាចអនុវត្តអ្វីដែលពួកគេបានរៀននៅថ្ងៃនេះនៅក្នុងការហៅបម្រើរបស់ពួកគេនៅក្នុងថ្នាក់ ឬ គណៈប្រធានក្រុម ក្នុងការទទួលខុសត្រូវរបស់ពួកគេជាគ្រូបង្រៀនតាមផ្ទះ ឬ នៅក្នុងឱកាសដឹកនាំផ្សេងៗទៀត ។ (អ្នកអាចសរសេរការណែនាំទាំងនេះនៅលើក្តារខៀន) ។ សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមការទូន្មានរបស់អ្នកដឹកនាំបព្វជិតភាពរបស់ពួកគេ ។ សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់របស់អ្នក អំពីគោលការណ៍ដែលបានបង្រៀននៅក្នុងមេរៀននេះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

យ៉ាកុប ១:១៩ ។ « យើងបានតម្កើងការងាររបស់យើងថ្វាយព្រះអម្ចាស់ »

ប្រធាន ចូម៉ាស អេស. ម៉នសុន បានពន្យល់អត្ថន័យក្នុងការតម្កើងការហៅបម្រើមួយ ៖

« តើការតម្កើងការហៅបម្រើមួយមានន័យយ៉ាងដូចម្តេច ? វាមានន័យថា ដើម្បីកសាងវាដោយសេចក្តីថ្លៃថ្នូរ និង សារប្រយោជន៍ ធ្វើឲ្យវាមានកិត្តិយស និង បានលើកសរសើរនៅក្នុងកែវភ្នែកនៃមនុស្សគ្រប់រូប ពង្រីក និង ពង្រឹងវា ឲ្យពន្លឺនៃស្ថានសួគ៌រះឡើងតាមរយៈវាដើម្បីយល់ដល់សារៈប្រយោជន៍នៃមនុស្សផ្សេងទៀត ។

« ហើយតើមនុស្សម្នាក់តម្កើងការហៅមួយដោយរបៀបណា ? វាសាមញ្ញណាស់ គឺតាមរយៈការបំពេញការបម្រើដែលទាក់ទងទៅនឹងការហៅនោះ ។ អែលឌើរម្នាក់តម្កើងការហៅតែងតាំងជាអែលឌើរតាមរយៈការរៀនពីអ្វីដែលជាកាតព្វកិច្ចរបស់គាត់ ក្នុងនាមជាអែលឌើរ ហើយបន្ទាប់មកដោយការធ្វើវា ។ អែលឌើរក៏ដូចជាឪកុន គ្រូបង្រៀន សង្ឃ ប៊ីស្សព និងបុគ្គលណាម្នាក់ដែលកាន់តំណែងនៅក្នុងបព្វជិតភាពនោះផងដែរ » (« The Sacred Call of Service » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៥ ទំព័រ ៥៤) ។

យ៉ាកុប ១:១៩; ២:២ ។ « ទទួលអំពើបាបទាំងឡាយរបស់ប្រជាជនមកលើក្បាលខ្លួន »

អស់អ្នកទាំងឡាយណាដែលមានកាតព្វកិច្ចដឹកនាំនៅក្នុងសាសនាចក្រ ទទួលនូវទំនួលខុសត្រូវដ៏ខ្សឹកខ្សួលមួយ ។ យ៉ាកុបបានបង្រៀនថា នៅពេលអ្នកដឹកនាំធ្វេសប្រហែសមិនបានបង្រៀនព្រះបន្ទូលនៃព្រះទៅដល់អស់អ្នកណាដែលពួកគេត្រូវបានហៅឲ្យដឹកនាំទេនោះ ពួកគេមានទំនួលខុសត្រូវមួយចំណែកចំពោះអំពើបាបទាំងឡាយរបស់ប្រជាជន ។ នៅពេលនិយាយទៅកាន់បងប្អូនប្រុសនៃបព្វជិតភាព ប្រធាន ចន ថេលើរ បានលម្អិតពីទំនួលខុសត្រូវដែលយ៉ាកុបបានពិពណ៌នានោះថា ៖

« ប្រសិនបើអ្នកមិនតម្កើងការហៅបម្រើរបស់អ្នកទេ ព្រះនឹងដាក់អ្នកឲ្យទទួលខុសត្រូវដល់អ្នកទាំងឡាយណាដែលអ្នកអាចបានសង្គ្រោះ ឲ្យអ្នកបំពេញកាតព្វកិច្ចរបស់អ្នក » (*ការបង្រៀននៃប្រធានសាសនាចក្រ ៖ ចន ថេលើរ* [ឆ្នាំ ២០០១] ទំព័រ ១៦៤) ។

ប្រធាន ហាហ្វប៊ី.ប្រោន នៃគណៈប្រធានទីមួយ ដែលក្រោយមកបានអធិប្បាយលើសេចក្តីថ្លែងការណ៍របស់ប្រធានថេលើរថា ៖

« នេះគឺជាប្រយោគដ៏ប្រជែងមួយ ។ ប្រសិនបើខ្ញុំបាត់បង់អ្វីដែលខ្ញុំអាចបានធ្វើពីនេះតទៅដោយសារហេតុផលនៃអំពើបាបនៃកម្រៃ ឬ ការបំភ្លេចចោល ខ្ញុំផ្ទាល់ត្រូវតែរងទុក្ខ ហើយដោយគ្មានសង្ឃឹមនោះ គឺព្រមជាមួយនឹងមនុស្សជាទីស្រឡាញ់របស់ខ្ញុំទៅជាមួយនឹងខ្ញុំ ។ ប៉ុន្តែបើខ្ញុំមិនបានធ្វើកិច្ចការរបស់ខ្ញុំជាប៊ីស្សព ប្រធានស្តេក ប្រធានបេសកកម្ម ឬ អ្នកមានសិទ្ធិអំណាចទូទៅនៃសាសនាចក្រម្នាក់ ប្រសិនបើពួកយើងណាមួយមិនបានបង្រៀន ដឹកនាំ ណែនាំ និង ជួយសង្គ្រោះអ្នកទាំងឡាយណាដែលនៅក្រោមការដឹកនាំរបស់យើង និងនៅក្នុងយុត្តាធិការរបស់យើងទេនោះ ព្រះអម្ចាស់នឹងដាក់យើងឲ្យទទួលខុសត្រូវ បើសិនជាពួកគេត្រូវបាត់ដៃលមកពីកំហុសរបស់យើងនោះ » (នៅក្នុងរបាយការណ៍សន្និសីទ ខែ តុលា ឆ្នាំ ១៩៦២ ទំព័រ ៨៤) ។

យ៉ាកុប ២:៨ ។ « ព្រះបន្ទូលនៃព្រះ . . . ធ្វើឲ្យជាស្បើយព្រលឹងដែលមានរបួសឈឺចាប់ »

នៅពេលព័ត៌មានថ្មីពិបាកនឹងយល់ ឬ ខ្ញោនដល់អ្នករៀនដំណឹងល្អទាំងឡាយ វាល្អសម្រាប់ពួកគេដើម្បីស្វែងរកចម្លើយមកពីព្រះ ដែលទ្រង់ជ្រាបគ្រប់ការណ៍ទាំងអស់ ជាជាងការទៅធ្វើការស្រាវជ្រាវទូទៅមួយនៅតាមអ៊ិនធើណិត ឬ ទៅរកឯកសារដែលសរសេរប្រឆាំងនឹងពួកមរមន ។ ការទៅរកចម្លើយពីព្រះដោយផ្ទាល់ បង្ហាញពីសេចក្តីជំនឿរបស់យើងទៅលើទ្រង់ និង អនុញ្ញាតឲ្យយើងទទួលបាននូវចម្លើយតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ យើងក៏ត្រូវបើកព្រះគម្ពីរ និង អានសម្តីរបស់សាវក និង ព្យាការីថ្ងៃចុងក្រោយទាំងឡាយ ដែលអាចឆ្លើយនឹងសំណួរពិបាកៗទាំងឡាយ ហើយអាចព្យាបាលរបួសដែលឈឺចាប់បាន ។ ព្រះគម្ពីរខាងក្រោមបង្រៀនយើងពីកន្លែងដែលគួរទៅ និង ពីអ្វីដែលយើងគួរធ្វើ នៅពេលយើងមានសំណួរ ឬ កង្វល់ដែលមានឧបសគ្គទាំងឡាយ ៖

យ៉ាកុប ២:៨—« ព្រះបន្ទូលនៃព្រះ . . . ធ្វើឲ្យជាស្បើយព្រលឹងដែលមានរបួសឈឺចាប់ » ។

យ៉ាកុប ១:៥–៦—« បើអ្នករាល់គ្នាណាមួយខ្វះប្រាជ្ញា មានតែសូមដល់ព្រះ . . . នោះទ្រង់នឹងប្រទានឲ្យ ។ តែត្រូវឲ្យអ្នកនោះសូមដោយចិត្តជឿ » ។

ម៉ូរ៉ូណៃ ១០:៥—« ដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ នោះអ្នករាល់គ្នាអាចស្គាល់សេចក្តីពិតនៃគ្រប់ការណ៍ទាំងអស់ » ។

យ៉ាកុប ២:១២–៣៥

សេចក្តីផ្តើម

ដោយពិតចំពោះការទទួលខុសត្រូវរបស់គាត់ ក្នុងនាមជាអ្នកដឹកនាំបព្វជិតភាពម្នាក់ យ៉ាកុប បានហៅប្រជាជនរបស់គាត់ឲ្យប្រែចិត្ត ដោយព្រមានពួកគេអំពីអំពើបាបនៃសេចក្តីឆ្មើងឆ្មៃ និង ភាពអសីលធម៌ខាងផ្លូវភេទ ។ គាត់បានបង្រៀនអំពីគ្រោះថ្នាក់ និង ផលវិបាកនៃអំពើបាបទុំទៅទាំងពីរនេះ ។

យោបល់សម្រាប់ការបង្រៀន

យ៉ាកុប ២:១២–២១

យ៉ាកុបដាក់ទោសដល់ប្រជាជនរបស់គាត់ចំពោះសេចក្តីឆ្មើងឆ្មៃរបស់ពួកគេ

សូមសរសេរអ្វីដែលមានខាងក្រោមនៅលើក្តារខៀន ៖ *លុយកាក់ ប្រាជ្ញា មិត្តភក្តិ ទេពកោសល្យ ចំណេះដឹងខាងដំណឹងល្អ* ។សូមអញ្ជើញសិស្សឲ្យគិតអំពីពរជ័យដែលព្រះអម្ចាស់បានប្រទានដល់ពួកគេនៅក្នុងរឿងទាំងនេះ ។ សូមលើកទឹកចិត្តពួកគេឲ្យសញ្ជឹងគិតអំពីរបៀបដែលពួកគេមានអារម្មណ៍អំពីពរជ័យទាំងនេះ នៅពេលពួកគេសិក្សាយ៉ាកុបជំពូកទី ២ ។

សូមឲ្យសិស្សម្នាក់អាន យ៉ាកុប ២:១២–១៣ ឮៗ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ទាំងអស់ឲ្យអានតាម ដោយរកមើលអ្វីដែលសាសន៍នីហ្វៃភាគច្រើនកំពុងតែស្វែងរកនោះ ។

ក្រោយពីសិស្សបានឆ្លើយតបហើយ សូមបង្ហាញថា យ៉ាកុបបានប្រាប់ប្រជាជនរបស់គាត់ថា ពួកគេបានទទួលទ្រព្យសម្បត្តិតាមរយៈ « បាតដៃនៃទិព្វញ្ញាណ » ។ អ្នកអាចពន្យល់ថាពាក្យ *ទិព្វញ្ញាណ*សំដៅទៅលើព្រះ ។

- **ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីចាំថា ពរជ័យរបស់យើងទាំងអស់បានមកពីព្រះវរបិតាសួគ៌របស់យើង ?**
- **យោងតាម យ៉ាកុប ២:១៣ ហេតុអ្វីបានជាសាសន៍នីហ្វៃភាគច្រើនត្រូវបានលើកខ្លួនឡើងនៅក្នុងភាពឆ្មើងឆ្មៃ ?**

សូមអញ្ជើញសិស្សម្នាក់ឲ្យអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ខៀលើរអេស.អុជដូហ្វ នៃគណៈប្រធានទីមួយ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកការយល់ដឹងអំពីអត្ថន័យនៃការលើកខ្លួនឡើងក្នុងការឆ្មើងឆ្មៃ ៖

« នៅចំណុចស្នូលរបស់វា ការឆ្មើងឆ្មៃគឺជាអំពើបាបមួយនៃការប្រៀបធៀប ដោយសារទោះបីជាធម្មតាវាចាប់ផ្តើមដោយ ‹ មើលថាខ្ញុំអស្ចារ្យប៉ុណ្ណា និង ថាខ្ញុំបានធ្វើរឿងដ៏អស្ចារ្យអ្វីខ្លះ › វាតែងតែមើលទៅដូចជាបញ្ចប់ដោយ ‹ ហេតុដូច្នេះហើយ ខ្ញុំល្អជាងអ្នក › ។ . . .

« . . . នេះគឺជាអំពើបាបនៃការ ‹ អរព្រះគុណព្រះ ដែលខ្ញុំពិសេសជាងអ្នក › ។ នៅចំណុចស្នូលរបស់វា គឺជាបំណងប្រាថ្នាដើម្បីបានគេសរសើរ ឬ មានគេច្រណែន ។ វាគឺជាអំពើបាបនៃការលើកស៊ីរីល្អខ្លួនឯង » (« Pride and the Priesthood »*Ensign*ឬ*លីអាហូណា*ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ៥៦) ។

សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតដោយស្ងាត់ស្ងៀម ថាតើពួកគេធ្លាប់មានទោសពីអំពើបាបនៃការគិតថាពួកគេល្អជាងអ្នកផ្សេងទៀតទេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ាកុប ២:១៤–១៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលឃ្លាដែលបង្ហាញពីផលវិបាកនៃការឆ្មើងឆ្មៃ ។ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- **តើអ្នកគិតថា ហេតុអ្វីបានជាការឆ្មើងឆ្មៃមានអំណាចដើម្បី « បំផ្លាញព្រលឹងទាំងឡាយ [របស់យើង] បាន» ? (យ៉ាកុប២:១៦) ។**

សូមអញ្ជើញសិស្សឲ្យអាន យ៉ាកុប ២:១៧–២១ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើលឃ្លាដែលបង្រៀនពីរបៀបដែលយើងអាចយកឈ្នះលើការឆ្មើងឆ្មៃ និង ឥរិយាបថដែលមិនសមរម្យអំពីទ្រព្យសម្បត្តិសម្ភារ ។ អ្នកអាចស្នើថាពួកគេគួរតែគូសចំណាំឃ្លាដែលពួកគេរកឃើញ ។ ក្រោយពីពួកគេបានសិក្សាខគម្ពីរទាំងនេះហើយសូមអញ្ជើញពួកគេឲ្យជ្រើសរើសឃ្លាមួយដែលពួកគេបានរកឃើញ ។ សូមផ្តល់ឱកាសដល់សិស្សបីបួននាក់ឲ្យពន្យល់ពីរបៀបដែលឃ្លាដែលពួកគេបានជ្រើសរើសនេះអាចជួយយើងឲ្យយកឈ្នះលើការឆ្មើងឆ្មៃឬក៏ឥរិយាបថដែលមិនសមរម្យនានាចំពោះទ្រព្យសម្បត្តិសម្ភារ ។ (នៅផ្នែកនៃសកម្មភាពនេះអ្នកក៏អាចស្នើថាសិស្សគួរតែអានវគ្គព្រះគម្ពីរដូចខាងក្រោម ៖របាក្យត្រទី១ ៣:១១–១៣; ម៉ាកុស ១០:១៧–២៧ឬមទាំងការបកប្រែដោយយ៉ូសែបស៊្មីតនៅក្នុងលេខយោងទី ២៧ *a*; នីហ្វៃទី២ ២៦:៣១; អាលម៉ា ៣៩:១៤; គ . និងស . ៦:៧) ។

- **តើអ្នកគិតថាការស្វែងរកនគរព្រះមានន័យដូចម្តេចដែរ ? តើអ្នកគិតថាការទទួលបានសេចក្តីសង្ឃឹមនៅក្នុងព្រះគ្រីស្ទមានន័យដូចម្តេចដែរ ?**
- **តើការស្វែងរកនគរព្រះនិងការទទួលបានសេចក្តីសង្ឃឹមនៅក្នុងព្រះគ្រីស្ទអាចជះឥទ្ធិពលដល់ឥរិយាបថរបស់យើងចំពោះទ្រព្យសម្បត្តិនិងកម្មសិទ្ធិលើទ្រព្យសម្បត្តិដូចម្តេចដែរ ?**

សូមឲ្យសិស្សស្រមៃពីរបៀបដែលពួកគេនឹងសង្ខេបចំណុចសំខាន់នៃយ៉ាកុប២:១២–២១សម្រាប់សិស្សម្នាក់ដែលមិនបានមករៀននៅថ្ងៃនេះ ។ សូមផ្តល់ឱកាសដល់សិស្សពីរឬបីនាក់ឲ្យចែកចាយនូវអ្វីដែលពួកគេនឹងនិយាយ ។ សិស្សអាននិយាយពីគោលការណ៍ពិត

ទាំងឡាយផ្សេងគ្នា ។ សូមប្រាកដថាពួកគេយល់ថា**យើងអាចស្វែងរកនគរព្រះលើសអស់ទាំងចំណាប់អារម្មណ៍ផ្សេងៗទៀតបាន** ។សូមផ្តល់ពេលដល់សិស្សឲ្យសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅកត់ត្រាក្នុងថ្នាក់របស់ពួកគេអំពីរបៀបមួយដែលពួកគេអាចប្រើពរជ័យនិងឱកាសនានាដែលព្រះអម្ចាស់បានប្រទានដល់ពួកគេឲ្យកសាងនគរព្រះនិងប្រទានពរដល់ជីវិតរបស់អ្នកដទៃ ។

ការបង្រៀនអំពីច្បាប់ព្រហ្មចារីយភាព

នៅពេលបង្រៀនអំពីច្បាប់ព្រហ្មចារីយភាពសូមមានការគោរពដ្ឋិមាន និង មានភាពច្បាស់លាស់នៅក្នុងការណែនាំរបស់អ្នក ។ នៅពេលអ្នកបន្តត្រឹមត្រូវតាមសម្ភារមេរៀនហើយធ្វើតាមការណែនាំពីព្រះវិញ្ញាណបរិសុទ្ធអ្នកនឹងអាចជួយសិស្សឲ្យយល់ពីអ្វីដែលពួកគេត្រូវធ្វើដើម្បីកាន់តាមច្បាប់ព្រហ្មចារីយភាព ។

យ៉ាកុប២:២២–៣៥

យ៉ាកុបបានស្តីបន្ទោសដល់មនុស្សដែលបានបំពានលើច្បាប់ព្រហ្មចារីយភាព

សូមសរសេរនៅលើក្តារខៀនន្ទវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធានអែសរ៉ាថាហ្វ៍ប៊ែនសឺន ៖

« ការរុកគួននៃអំពើបាបនៃជំនាន់នេះគឺ . . . »

សូមអញ្ជើញសិស្សឲ្យគិតអំពីរបៀបដែលប្រធានប៊ែនសឺនអាចបញ្ចប់ប្រយោគនេះ ។ បន្ទាប់មកសូមអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះ ៖

« ការរុកគួននៃអំពើបាបនៃជំនាន់នេះគឺភាពអសីលធម៌ខាងផ្លូវភេទ ។ ព្យាការីយ៉ូសែបបាននិយាយថា នេះនឹងជាប្រភពនៃការល្បួងកាន់តែខ្លាំងក្លាឡើងកាន់តែមានការប៉ះទង្គិចកាន់តែច្រើនឡើង ហើយកាន់តែពិបាកជាងមុនសម្រាប់ពួកអែលឌើរនៃអ៊ីស្រាអែលជាជាងអ្នកដទៃទៀត » (*The Teachings of Ezra Taft Benson* | ឆ្នាំ១៩៨៨ |ទំព័រ ២៧៧) ។

សូមអញ្ជើញសិស្សឲ្យអានយ៉ាកុប២:២២–២៣, ២៨ដោយស្ងាត់ស្ងៀមដោយរកមើលពាក្យនិងឃ្លាដែលយ៉ាកុបបានប្រើដើម្បីរៀបរាប់ពីភាពធ្ងន់ធ្ងរនៃភាពអសីលធម៌ខាងផ្លូវភេទ ។ (អ្នកអាចពន្យល់ថាពាក្យ*សហាយស្មន់*សំដៅទៅលើអំពើបាបខាងផ្លូវភេទ) ។ សូមឲ្យសិស្សចែកចាយពាក្យនិងឃ្លាដែលពួកគេរកឃើញ ។

ដើម្បីជួយសិស្សឲ្យយល់ពីច្បាប់ព្រហ្មចារីយភាពសូមអានសេចក្តីថ្លែងការណ៍ខាងក្រោមមកពីកូនសៀវភៅ*ដើម្បីកម្លាំងនៃយុវជន* ។ សូមឲ្យសិស្សស្តាប់រកសកម្មភាពដែលពួកគេត្រូវចៀសវាង ។

« បទដ្ឋានរបស់ព្រះអម្ចាស់ដែលទាក់ទងទៅនឹងភាពបរិសុទ្ធខាងផ្លូវភេទគឺមានភាពច្បាស់លាស់ និងគ្មានការផ្លាស់ប្តូរ ។ ចូរកុំឱ្យមានទំនាក់ទំនងផ្លូវភេទជាមួយអ្នកណាមុនអាពាហ៍ពិពាហ៍ ហើយចូរមានសេចក្តីស្មោះត្រង់ទាំងស្រុងចំពោះប្តី ឬប្រពន្ធរបស់អ្នកក្រោយពេលអាពាហ៍ពិពាហ៍ ។ . . .

« ចូរកុំធ្វើអ្វីដែលអាចដឹកនាំឲ្យមានការរំលងខាងផ្លូវភេទ ។ ចូរប្រព្រឹត្តជាមួយនឹងអ្នកដទៃដោយការគោរព មិនត្រូវប្រើដូចជារបស់ដើម្បីបំពេញតណ្ហា និងចំណង់ដ៏អាត្មានិយមនោះឡើយ ។ មុនពេលរៀបអាពាហ៍ពិពាហ៍ ចូរកុំចូលរួមក្នុងការថើបដែលធ្វើឲ្យមានតណ្ហាដេកលើមនុស្សម្នាក់ទៀត ឬប៉ះពាល់លើផ្នែកនៃខ្លួនប្រាណណាដែលមិនសមរម្យ ឬពិសិដ្ឋរបស់មនុស្សម្នាក់ទៀតនោះ ទោះដោយមានឬដោយមិនមានសម្លៀកបំពាក់ក្តី ។ ចូរកុំធ្វើអ្វីដែលដាស់ឡើងនូវចំណង់ខាងផ្លូវភេទ ។ ចូរកុំបង្កើតអារម្មណ៍ទាំងនោះនៅក្នុងរាងកាយរបស់អ្នកផ្ទាល់ឡើយ » (*ដើម្បីកម្លាំងនៃយុវជន* | កូនសៀវភៅឆ្នាំ ២០១១ |ទំព័រ៣៥–៣៦) ។

សូមបង្ហាញថាយោងតាមយ៉ាកុប២:២៣–២៤មនុស្សខ្លះនៅក្នុងជំនាន់របស់យ៉ាកុបបានព្យាយាមយកលេសពីអំពើបាបខាងផ្លូវភេទរបស់ពួកគេ ។

- តើពេលខ្លះមនុស្សចង់រកលេសដោះសារនូវភាពអសីលធម៌ខាងផ្លូវភេទនាបច្ចុប្បន្ននេះដោយរបៀបណាដែរ ?
- តើមានអ្វីខ្លះដែលយុវជនអាចធ្វើដើម្បីចៀសវាងពីការយកឈ្នះដោយការល្បួងខាងផ្លូវភេទបាននោះ ? (ចម្លើយអាចរួមមានការអធិស្ឋានសម្រាប់កម្លាំងការទាក់ទងជាមួយនឹងមិត្តល្អការជ្រើសរើសការកំសាន្តត្រឹមត្រូវនិងការចៀសវាងពីស្ថានភាពនិងកន្លែងណាដែលធ្វើឲ្យមានការល្បួង) ។

អ្នកអាចបង្ហាញថាអំពើបាបមួយរបស់សាសន៍នីហ្វៃលេចឡើងជាការមិនបានអនុញ្ញាតឲ្យអនុវត្តពហុអាពាហ៍ពិពាហ៍ ។ សូមអញ្ជើញសិស្សឲ្យអានយ៉ាកុប២:២៧–៣០ដោយស្ងាត់ៗ ។ មុនពេលពួកគេអានអ្នកអាចពន្យល់ថាពាក្យ*ស្រីស្នំ*សំដៅទៅស្ត្រីម្នាក់ដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយនឹងបុរសម្នាក់ទៀតប៉ុន្តែដែលមានឋានៈទាបជាងឋានៈជាភរិយាម្នាក់ ។

- ដោយយោងតាមយ៉ាកុប ២:២៧តើ « ព្រះបន្ទូលនៃព្រះអម្ចាស់ » ទាក់ទងអ្វីទៅនឹងការមានប្រពន្ធច្រើនជាងមួយនោះ ? (សូមប្រាកដថាវាច្បាស់ថាចាប់តាំងពីដើមមកព្រះអម្ចាស់បានបញ្ជាថាបុរសម្នាក់ត្រូវរៀបការនឹងស្ត្រីម្នាក់ ។ សូមមើលផងដែរគ . និង ស . ៤៩:១៥–១៦) ។

សូមពន្យល់ថាពហុអាពាហ៍ពិពាហ៍ដែលមិនមានការអនុញ្ញាតគឺជាគំរូមួយនៃសហាយស្មន់ឬអំពើបាបខាងផ្លូវភេទ ។ នៅក្នុងព្រះនេត្រព្រះអំពើបាបខាងផ្លូវភេទគឺជាអំពើបាបដ៏ធ្ងន់ធ្ងរណាស់ ។

- ដោយយោងតាមយ៉ាកុប ២:៣០តើនៅពេលណាដែលប្រជាជនរបស់ព្រះអម្ចាស់ត្រូវបានអនុញ្ញាតឲ្យអនុវត្តពហុអាពាហ៍ពិពាហ៍បាននោះ ? (នៅពេលដែលព្រះអម្ចាស់បញ្ជាឲ្យធ្វើវា) ។

សូមបង្ហាញថានៅពេលខ្លះនៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោកព្រះអម្ចាស់បានបញ្ជាប្រជាជនរបស់ទ្រង់ឲ្យអនុវត្តពហុអាពាហ៍ពិពាហ៍ ។ ឧទាហរណ៍ ពហុអាពាហ៍ពិពាហ៍ត្រូវបានអនុវត្តនៅក្នុងជំនាន់ព្រះគម្ពីរសញ្ញាចាស់ដោយអ័ប្រាហាំ និង សារ៉ា (សូមមើល លោកុប្បត្តិ ១៦:១–៣; គ . និង ស . ១៣២:៣៤–៣៥, ៣៧) និង ដោយចៅប្រុសរបស់ពួកគេគឺ យ៉ាកុប (សូមមើល គ . និង ស . ១៣២:៣៧) ហើយវាត្រូវបានអនុវត្តក្នុងពេលមួយអំឡុងពេលជំនាន់ដើមនៃពេលសាសនាចក្របានស្តារឡើងវិញ ដំបូងដោយយ៉ូសែបស៊្មីធ (សូមមើល គ . និង ស . ១៣២:៣២–៣៣, ៥៣) ។

ដើម្បីបញ្ជាក់ថា ភាពអសីលធម៌ខាងផ្លូវភេទមានឥទ្ធិពលមួយបំផ្លាញដល់គ្រួសារ សូមអាន យ៉ាកុប ២:៣១–៣៥ ឮៗ ។ សូមឲ្យសិស្សអានតាម ដោយរកមើលផលវិបាកខ្លះៗនៃភាពអសីលធម៌នេះ ។ សូមបង្ហាញថា ទោះបីជាយ៉ាកុបនិយាយតែអំពីបុរសក្តី ច្បាប់ព្រហ្មចារីយភាពក៏មានសារៈសំខាន់ស្មើគ្នាចំពោះស្ត្រីដែរ ។

- យោងតាមយ៉ាកុប តើគ្រួសារអាចត្រូវរងឥទ្ធិពលដោយរបៀបណា នៅពេលសមាជិកគ្រួសារម្នាក់បំពានលើច្បាប់ព្រហ្មចារីយភាព ? តើការណ៍នេះជួយពន្យល់ពីមូលហេតុដែលបំពានលើច្បាប់ព្រហ្មចារីយភាព គឺជាអំពើបាបដ៏ធ្ងន់ធ្ងរមួយដោយរបៀបណា ?
- យុវវ័យខ្លះយកលេសថា ពួកគេអាចរំលងច្បាប់ព្រហ្មចារីយភាពបានដោយសារសកម្មភាពរបស់ពួកគេមិនបានធ្វើឲ្យអ្នកផ្សេងទៀតឈឺចាប់នោះទេ ។ តើភាពអសីលធម៌របស់មនុស្សម្នាក់ អាចជះឥទ្ធិពលដល់មនុស្សផ្សេងទៀតដោយរបៀបណា ?

ដើម្បីបញ្ចប់ការពិភាក្សាអំពីផលវិបាកនៃអំពើបាបខាងផ្លូវភេទនេះ សូមគិតពីការអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រីឆាដជី.ស្កត នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ។ សូមអញ្ជើញសិស្សស្តាប់រកផលវិបាកនៃភាពអសីលធម៌ខាងផ្លូវភេទ ។

« ទង្វើស្និទ្ធស្នាលទាំងនោះត្រូវព្រះអម្ចាស់ហាមឃាត់ពីខាងក្រៅ ការតស៊ូនឹងការល្បួងផ្លាំនៃអាពាហ៍ពិពាហ៍ ដោយសារពួកគេធ្វើឲ្យខូចបំណងរបស់ទ្រង់ ។ នៅក្នុងសេចក្តីសញ្ញាអាពាហ៍ពិពាហ៍ដ៏ពិសិដ្ឋ ទំនាក់ទំនងបែបនេះគឺស្របតាមផែនការរបស់ទ្រង់ ។ នៅពេលជួបនឹងរបៀបផ្សេងៗទៀត ពួកគេប្រឆាំងនឹងឆន្ទៈរបស់ទ្រង់ ។ វាបង្កឲ្យមានគ្រោះថ្នាក់ខាងអារម្មណ៍ និង ខាងវិញ្ញាណធ្ងន់ធ្ងរ ។ ទោះបីជាអ្នកធ្វើនោះមិនយល់ថាវាកំពុងតែកើតឡើងឥឡូវនេះក៏ដោយ តែពួកគេនឹងដឹងពេលក្រោយ ។ ភាពអសីលធម៌ខាងផ្លូវភេទបង្កើតជារបាំងមួយទាស់នឹងឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធជាមួយនឹងសមត្ថភាពលើកតម្កើង ការប៉ិន និង បង្កើនកម្លាំងទាំងអស់ ។ វាបណ្តាលឲ្យមានការកម្រើកខាងរាងកាយ និង ខាងអារម្មណ៍យ៉ាងខ្លាំងក្លា ។ ពេលនោះវាបង្កើតអារម្មណ៍ដែលមិនអាចអូសបន្លាយបាន ដែលនាំអ្នកប្រព្រឹត្តល្មើសទៅកាន់អំពើបាបដ៏ធ្ងន់ធ្ងរជាងនេះកាន់តែខ្លាំង ។ វាបង្កើតជាភាពអាត្មាយម ហើយអាចបង្កើតជាទង្វើខឹងសម្បារ ដូចជាអំពើហិង្សាការរំលូតកូន ហិង្សាផ្លូវភេទ និង បទល្មើសហិង្សាផ្សេងៗ ។ ការដាស់អារម្មណ៍បែបនោះ អាចនាំទៅរកទង្វើរួមភេទដូចគ្នា ហើយវាគឺជាទង្វើដ៏ខុសឆ្គង និង ខុសខ្លាំងមែនទែន » (« Making the Right Choices » *Ensign*ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ទំព័រ ៣៨) ។

សូមអញ្ជើញសិស្សឲ្យរំឭកពីដើមនៃ យ៉ាកុប ២:២៨ ហើយរកមើលអ្វីដែលព្រះអម្ចាស់បានសព្វព្រះទ័យនោះ ។ (អ្នកអាចស្នើថា សិស្សគួរគូសចំណាំនូវអ្វីដែលពួកគេរកឃើញ ។ សូមប្រាកដថា ពួកគេយល់ថា **ព្រះអម្ចាស់សព្វព្រះទ័យនឹងព្រហ្មចារីយភាព) ។**

- ដោយផ្អែកលើអ្វីដែលយើងបានពិភាក្សានៅថ្ងៃនេះ តើអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់សព្វព្រះទ័យនឹងព្រហ្មចារីយភាព ?

សូមពិចារណាពីការបង្ហាញរូបភាពមួយនៃក្រុមគ្រួសាររបស់អ្នក ។ សូមថ្លែងទីបន្ទាល់នៃពរជ័យដែលបានមកដល់អ្នក និង គ្រួសាររបស់អ្នក នៅពេលអ្នកបានរស់នៅតាមច្បាប់ព្រហ្មចារីយភាពរបស់ព្រះអម្ចាស់ ។ សូមបញ្ជាក់ថា អំណាចដើម្បីមានកូនចៅ គឺជាអំណោយដ៏អស្ចារ្យមួយមកពីព្រះវរបិតានៅស្ថានសួគ៌របស់យើង នៅពេលវាត្រូវបានប្រើនៅក្នុងព្រំដែនដែលទ្រង់បានដាក់នោះ ។ សូមលើកទឹកចិត្តសិស្សឲ្យរក្សាភាពបរិសុទ្ធ និង ស្អាតស្អំ ដើម្បីព្រះអម្ចាស់អាច « សព្វព្រះហឫទ័យនឹងព្រហ្មចារីយភាព » (យ៉ាកុប ២:២៨) ។

ដើម្បីជួយសិស្សឲ្យចែកចាយទីបន្ទាល់របស់ពួកគេអំពីការរស់នៅតាមច្បាប់ព្រហ្មចារីយភាព អ្នកអាចសួរសំណួរខាងក្រោមនេះ ៖

- បើមានមនុស្សម្នាក់និយាយថា ច្បាប់ព្រហ្មចារីយភាពគឺហួសសម័យ ហើយមិនចាំបាច់ទៀតទេតើអ្នកនឹងនិយាយយ៉ាងដូម្តេច ? (នៅពេលសិស្សឆ្លើយនឹងសំណួរនេះ សូមបំផុសគំនិតពួកគេឲ្យថ្លែងទីបន្ទាល់អំពីពរជ័យនៃការកាន់តាមច្បាប់ព្រហ្មចារីយភាព មិនមែនគ្រាន់តែគ្រោះថ្នាក់នៃការមិនគោរពតាមវានោះទេ) ។

សូមប្រាប់សិស្សថា អ្នកមានទំនុកចិត្តថា ពួកគេអាចស្អាតស្អំខាងសីលធម៌ ។ សូមបញ្ជាក់ថា ប្រសិនបើពួកគេបានធ្វើបាបខុសនឹងច្បាប់ព្រហ្មចារីយភាព ពួកគេគ្រាន់តែស្វែងរកជំនួយពីប៊ីស្សព ឬ ប្រធានសាខារបស់ពួកគេ ដែលអាចជួយពួកគេឲ្យប្រែចិត្ត ហើយក្លាយជាស្អាតស្អំតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។

យ៉ាកុប ៣–៤

សេចក្តីផ្តើម

នៅក្នុងយ៉ាកុប ជំពូកទី ៣ យើងអានសេចក្តីសន្និដ្ឋាននៃទេសនាកថាមួយដែលយ៉ាកុបបានផ្តល់ដល់ប្រជាជនរបស់គាត់ ។ យ៉ាកុបបានផ្តល់ពាក្យលួងលោមដោយសង្ខេប និង សេចក្តីសន្យាដល់អ្នកបរិសុទ្ធនៅក្នុងដួងចិត្ត ។ គាត់ក៏បានស្តីបន្ទោសដល់អ្នកធ្មើងធ្មៃ និង អ្នកមិនបរិសុទ្ធនៅក្នុងចំណោមប្រជាជនរបស់គាត់ ដោយព្រមានពួកគេអំពីផលវិបាកដែលនឹងមក បើសិនជាពួកគេមិនព្រមប្រែចិត្តទេនោះ ។ យ៉ាកុប ជំពូកទី ៤មាននូវពាក្យដែលយ៉ាកុប ត្រូវបានបំផុសគំនិតឲ្យសរសេរសម្រាប់ប្រជាជនដែលនឹងអានកំណត់ត្រារបស់គាត់នៅថ្ងៃណាមួយ ។ គាត់បានថ្លែងទីបន្ទាល់អំពីជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និង បានជាស់តឿនអ្នកអានរបស់គាត់ឲ្យស្រុះស្រួលខ្លួនគេនឹងព្រះ ជាព្រះវរបិតាតាមរយៈជង្វាយធួន ។ គាត់បានប្រាប់អំពីសាសន៍យូដាដែលបានបដិសេធព្រះយេស៊ូវគ្រីស្ទ និង ភាពច្បាស់លាស់នៃដំណឹងល្អរបស់ទ្រង់ដោយប្រើសំឡេងព្រមាន ។

យោបល់សម្រាប់ការបង្រៀន

យ៉ាកុប ៣

យ៉ាកុបបានលួងលោម និង ប្រឹក្សាដល់អ្នកបរិសុទ្ធក្នុងដួងចិត្ត ហើយជាស់សតិឲ្យអ្នកដទៃប្រែចិត្ត

សូមអញ្ជើញសិស្សឲ្យគិតអំពីដំបូន្មានអ្វីដែលពួកគេអាចផ្តល់ដល់មនុស្សនៅក្នុងស្ថានភាពខាងក្រោមនេះ ៖

១ .យុវនារីម្នាក់កំពុងតស៊ូរស់នៅដោយសុចរិត ប៉ុន្តែរងទុក្ខដោយសារឪពុករបស់នាងញៀនគ្រឿងស្រវឹង ។

២ .យុវជនម្នាក់ខិតខំអស់ពីសមត្ថភាពរបស់គាត់ដើម្បីរស់នៅតាមដំណឹងល្អ ប៉ុន្តែជួបនឹងឧបសគ្គជាច្រើនដោយសារតែការលែងលះរបស់ឪពុកម្តាយគាត់ ។

៣ .យុវនារីដ៏ឈ្លាសវៃម្នាក់ ព្យាយាមស្រឡាញ់គ្រួសាររបស់នាង ប៉ុន្តែពិបាកនៅផ្ទះដោយសារតែភាពអាត្មានិយម និង សកម្មភាពដែលមិនបានពិចារណាទាំងឡាយរបស់ប្អូនស្រីនាង ។

សូមអញ្ជើញសិស្សឲ្យអានប្រយោគទីមួយនៃ យ៉ាកុប ៣:១ដោយស្ងាត់ៗ ។ សូមឲ្យពួកគេស្វែងរកនរណាដែលយ៉ាកុបនិយាយដំបូងគេនៅក្នុងជំពូកនេះ ។

សូមពន្យល់ថា យ៉ាកុបបាននិយាយដោយចំៗទៅកាន់ប្រជាជនដែលមានទោសអំពីការឆ្មើងឆ្មៃ និង អំពើបាបខាងផ្លូវភេទនោះ ។ បន្ទាប់មកគាត់បានបែរការយកចិត្តទុកដាក់របស់គាត់ទៅកាន់ប្រជាជនសុចរិត ដែលកំពុងតែជួបនឹងឧបសគ្គដោយសារតែភាពទុច្ចរិតរបស់អ្នកដទៃ ។ សូមអញ្ជើញសិស្សអាន យ៉ាកុប ៣:១ដោយស្ងាត់ៗ ។ សូមឲ្យពួកគេរកមើលរឿងបួន ដែលយ៉ាកុបបានសុំឲ្យពួកអ្នកបរិសុទ្ធនៅក្នុងដួងចិត្តធ្វើ ។

- តើរឿងទាំងបួននោះមានអ្វីខ្លះ ដែលយ៉ាកុបបានដាស់តឿនឲ្យពួកអ្នកបរិសុទ្ធនៅក្នុងដួងចិត្តធ្វើ ? (« ចូរមើលទៅព្រះដោយមានគំនិតរឹងប៉ឹង . . . អធិស្ឋានដល់ព្រះអង្គដោយមានសេចក្តីជំនឿដ៏លើសលប់ ងើបក្បាលឡើង ហើយទទួលព្រះបន្ទូលដ៏ផ្អែមល្ហែមនៃព្រះ ហើយទទួលទានន្លង់សេចក្តីស្រឡាញ់របស់ទ្រង់ចុះ ») ។ តើយ៉ាកុបបានសន្យាអ្វីដល់អ្នកមានចិត្តបរិសុទ្ធ ប្រសិនបើពួកគេនៅតែស្មោះត្រង់នោះ ? (ការលួងលោមដល់គ្រាដែលមានទុក្ខលំបាក និង ការការពារពីសត្រូវ) ។
- តើអ្នកគិតថាយើងអាចធ្វើអ្វីបានខ្លះដើម្បីទទួលបានព្រះបន្ទូលនៃព្រះ ?

ទាក់ទងនឹងសំណូរអំពីសេចក្តីសន្យារបស់យ៉ាកុបចំពោះអ្នកមានចិត្តបរិសុទ្ធសូមធានាថាសិស្សយល់ថា**ព្រះនឹងលួងលោមអ្នកមានចិត្តបរិសុទ្ធនៅក្នុងសេចក្តីលំបាករបស់ពួកគេ ។**អ្នកអាចត្រូវពន្យល់ថាពាក្យ*លួងលោម*មានន័យថាលួងលោមនរណាម្នាក់ដែលក្រៀមក្រំឬមានកង្វល់ ។ ដើម្បីជួយសិស្សឲ្យសញ្ជឹងគិតនិងអនុវត្តសេចក្តីពិតនេះសូមសួរ ៖

- តើព្រះអម្ចាស់លួងលោមអ្នកដោយរបៀបណា ?
- តើការអធិស្ឋានដោយសេចក្តីជំនឿបានជួយអ្នកអំឡុងពេលមានឧបសគ្គដោយរបៀបណា ?
- តើនៅពេលណាដែលព្រះបន្ទូលរបស់ព្រះបានជួយអ្នកឲ្យមានអារម្មណ៍ពីសេចក្តីស្រឡាញ់របស់ទ្រង់ ?

សូមពន្យល់ថាក្រោយពីបាននិយាយទៅអ្នកមានចិត្តបរិសុទ្ធហើយយ៉ាកុបបាននិយាយទៅកាន់អស់អ្នកទាំងឡាយណាដែលមិនមានចិត្តបរិសុទ្ធម្តងទៀត ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានយ៉ាកុប៣:៣–៤ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលយ៉ាកុបបានសុំឲ្យពួកមិនមានចិត្តបរិសុទ្ធធ្វើ ។

- តើនឹងមានអ្វីកើតឡើងប្រសិនបើប្រជាជនរបស់យ៉ាកុបមិនព្រមប្រែចិត្តនោះ ?

សូមបង្ហាញថាយ៉ាកុបបាននិយាយថាសាសន៍លេមិនបានរស់នៅសុចរិតជាងប្រជាជននីហ្វៃខ្លះនៅពេលនេះ ។ សូមឲ្យសិស្សអានយ៉ាកុប៣:៥–៧ដោយស្ងាត់ស្ងៀមដោយរកមើលរបៀបទាំងឡាយដែលសាសន៍លេមិនគឺសុចរិតជាងប្រជាជននីហ្វៃខ្លះនោះ ។

- តើសាសន៍លេមិនសុចរិតជាងប្រជាជននីហ្វៃខ្លះតាមរបៀបណាខ្លះ ?
- តើគោលការណ៍អ្វីដែលអ្នកបានរៀនពី យ៉ាកុប៣:៧ អំពីទំនាក់ទំនងជាគ្រួសារ ? (**ប្តីនិងប្រពន្ធត្រូវស្រឡាញ់គ្នាទៅវិញទៅមកហើយឪពុកម្តាយត្រូវស្រឡាញ់កូនៗរបស់ខ្លួន) ។**
- តើមានផលវិបាកអ្វីខ្លះ ដែលអាចកើតឡើងនៅពេលសមាជិកគ្រួសារមិនបានស្រឡាញ់គ្នាទៅវិញទៅមក ហើយមិនបានបំពេញទំនួលខុសត្រូវគ្រួសាររបស់ពួកគេនោះ ?

សូមឲ្យសិស្សអាន យ៉ាកុប ៣:១០ ដោយស្ងាត់ស្ងៀម ដោយរកមើលការព្រមានដែលយ៉ាកុបបានផ្តល់ឲ្យជាក់លាក់ទៅដល់ឪពុកជាសាសន៍នីហ្វៃទាំងឡាយ ។

- តើយ៉ាកុបបានផ្តល់ការព្រមានអ្វីខ្លះដល់ឪពុកជាសាសន៍នីហ្វៃទាំងឡាយ ?
- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់សម្រាប់សមាជិកគ្រួសារទាំងឡាយដើម្បីធ្វើជាគំរូល្អសម្រាប់គ្នាទៅវិញទៅមកនោះ ?

សូមអាន យ៉ាកុប ៣:១១–១២ ឮៗដល់សិស្ស ។ អ្នកអាចពន្យល់ថា នៅក្នុងខទី ១១ ឃ្លាថា « ដាស់សមត្ថភាពទាំងឡាយនៃព្រលឹងអ្នកឲ្យភ្ញាក់ឡើង » សំដៅទៅលើតម្រូវការឲ្យភ្ញាក់ឡើងខាងវិញ្ញាណ ។ នៅក្នុង យ៉ាកុប ៣:១២ ឃ្លា « ការកំផិត និង ការអាសអាភាស » សំដៅទៅលើអំពើបាបខាងផ្លូវភេទទាំងឡាយ ។ នៅពេលអ្នកអានខគម្ពីរទាំងនេះ សូមបញ្ជាក់អំពី « ផលដ៏ធ្ងន់ធ្ងរ » នៃអំពើបាបខាងផ្លូវភេទទាំងនេះ ។ បន្ថែមលើនេះ សូមរំឭកសិស្សអំពីសេចក្តីសន្យាទាំងឡាយរបស់យ៉ាកុប ចំពោះអ្នកមានចិត្តបរិសុទ្ធ (សូមមើល យ៉ាកុប ៣:១–២) ។ សូមជួយសិស្សឲ្យយល់ថារបៀបដ៏ល្អបំផុតដើម្បីទទួលបានពរជ័យដែលបានសន្យាទាំងនោះ គឺត្រូវតែមានចិត្តបរិសុទ្ធជានិច្ច ។ ទោះជាយ៉ាងណាក្តី មនុស្សដែលបានប្រព្រឹត្តអំពើបាបខាងផ្លូវភេទទាំងឡាយ អាចស្វែងរកជំនួយពីប៊ីស្សព ឬ ប្រធានសាខារបស់ពួកគេ ដែលនឹងជួយពួកគេឲ្យប្រែចិត្ត ក្លាយជាស្អាតតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និង ទទួលបានពរជ័យដែលបានសន្យាទាំងឡាយដល់ពួកដែលមានចិត្តបរិសុទ្ធ ។

យ៉ាកុប ៤

យ៉ាកុបថ្លែងទីបន្ទាល់ថា តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ យើងអាចបានស្រុះស្រួលនឹងព្រះ

មុនចាប់ផ្តើមថ្នាក់ សូមដាក់រូបភាពតូចមួយនៃព្រះយេស៊ូវគ្រីស្ទនៅចំកណ្តាលក្តារខៀន ។ នៅជុំវិញរូបភាពនោះ សូមសរសេរពាក្យពីរបីដែលតំណាងឲ្យរឿងទាំងឡាយដែលអាចទាក់ទាញមនុស្សពីព្រះអង្គសង្គ្រោះ និង ដំណឹងល្អរបស់ទ្រង់ ។ ឧទាហរណ៍ អ្នកអាចរួមបញ្ចូលរឿងល្អៗខ្លះ—ដូចជា ការអប់រំ កីឡា និង មិត្តភក្តិ— ដែលសំខាន់ ប៉ុន្តែដែលមិនគួរក្លាយជាការផ្តោតចម្បងនៅក្នុងជីវិតរបស់យើងនោះទេ ។ អ្នកក៏អាចសរសេរពីរឿងផ្សេងៗផងដែរ —ដូចជា រឿងអាសអាភាស តន្ត្រីមិនសមរម្យ និង ថ្នាំញៀន— ដែលប៉ះពាល់ដល់វិញ្ញាណរបស់យើង និង នាំយើងចេញឆ្ងាយពីព្រះអង្គសង្គ្រោះ ។

សូមឲ្យសិស្សបើកទៅ យ៉ាកុប៤:១៤ ។ សូមពន្យល់ថា ខគម្ពីរនេះរួមមានឃ្លា « ដោយមើលហួសទីដៅ » ។ អែលឌើរ នែលអេ. ម៉ាក់ស្វែល នៃក្រុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថានៅក្នុងខគម្ពីរនេះ « ទីដៅគឺជាព្រះគ្រីស្ទ » (« Jesus of Nazareth, Savior and King »*Ensign* ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤៥) ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរឃ្លានេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ យ៉ាកុប ៤:១៤ ។

ក្រោយពីការចែកចាយការពន្យល់នេះហើយ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ាកុប ៤:១៤–១៥ ឮៗ ។

- តើអ្នកគិតថា វាអាចមានន័យយ៉ាងណាក្នុងការមើលហួសទីដៅ ? (ការដាក់ជីវិតរបស់យើងនៅលើអ្វីផ្សេងទៀតសំខាន់ជាងព្រះអង្គសង្គ្រោះ និងដំណឹងល្អរបស់ទ្រង់) ។
- យោងតាមយ៉ាកុប តើតរិយោបថ និង សកម្មភាពអ្វីខ្លះដែលរារាំងសាសន៍យូដាពីការទទួលយកព្រះយេស៊ូវគ្រីស្ទ ?

សូមពន្យល់ថា ខណៈដែលយ៉ាកុបបាននិយាយសំដៅយ៉ាងជាក់លាក់ទៅលើអំពើបាបនៃប្រជាជនយូដាខ្លះៗ ចំណែកខ្លះនៃ យ៉ាកុប ៤:១៤–១៥ ក៏អាចអនុវត្តចំពោះយើងផងដែរ ហើយអាចធ្វើជាការព្រមានមួយដល់យើង ។ ដើម្បីជួយសិស្សឲ្យឃើញពីការអនុវត្តនេះ សូមសួរសំណួរខាងក្រោមនេះ ៖

- ហេតុអ្វីបានជាពេលខ្លះមនុស្សបដិសេធ « ព្រះបន្ទូលដ៏ច្បាស់លាស់ទាំងនេះ » ហើយស្វែងរកអ្វីៗដែលពួកគេមិនអាចយល់បានទៅវិញ ? តើមានគ្រោះថ្នាក់អ្វីខ្លះនៃការមើលហួសសេចក្តីពិតសាមញ្ញនៃដំណឹងល្អនោះ ?
- តើយើងអាចបន្ថែមអ្វីទៅលើក្តារខៀនថាជាគំរូផ្សេងទៀតនៃការទាក់ទាញនានាចេញពីព្រះអង្គសង្គ្រោះ និង ដំណឹងល្អរបស់ទ្រង់ ? (សូមបន្ថែមចម្លើយរបស់សិស្សទៅលើពាក្យដែលអ្នកបានសរសេរួចហើយនោះ ដាក់លើក្តារខៀន) ។

សូមលុបពាក្យ ដែលអ្នកបានសរសេរនៅលើក្តារខៀន ហើយសរសេរសំណួរខាងក្រោម ៖ *តើយើងអាចធ្វើអ្វីបានខ្លះ ដើម្បីមិនមើលហួសទីដៅ ប៉ុន្តែបន្តផ្តោតលើព្រះយេស៊ូវគ្រីស្ទ ?*

សូមសរសេរខគម្ពីរយោងខាងក្រោមនៅលើក្តារខៀន ៖ *យ៉ាកុប ៤:៤–៥; យ៉ាកុប ៤:៦–៧; យ៉ាកុប ៤:៨–៩; យ៉ាកុប ៤:១០; យ៉ាកុប ៤:១១–១៣* ។សូមពន្យល់ថា នៅក្នុង យ៉ាកុប ៤ យ៉ាកុបចែកចាយគោលការណ៍ដែលអាចជួយយើងឲ្យនៅផ្តោតលើព្រះយេស៊ូវគ្រីស្ទ ។ សូមចាត់តាំងសិស្សឲ្យធ្វើការជាដៃគូ ហើយរកមើលគោលការណ៍ទាំងនេះនៅក្នុងវគ្គព្រះគម្ពីរមួយដែលមាននៅលើក្តារខៀន ។ (ដោយពឹងលើចំនួនសិស្សនៅក្នុងថ្នាក់របស់អ្នក អ្នកអាចចាត់តាំងវគ្គនីមួយៗដល់សិស្សជាដៃគូនោះច្រើនជាងមួយគូ ។ ឬ អ្នកអាចត្រូវសុំឲ្យដៃគូមួយអានច្រើនជាងមួយវគ្គ) ។

ក្រោយពីពីរបីនាទី សូមអញ្ជើញសិស្សឲ្យរាយការណ៍អំពីចម្លើយរបស់ពួកគេ ។ នៅពេលពួកគេធ្វើដូច្នោះ អ្នកអាចសួរសំណួរដើម្បីជួយពួកគេឲ្យគិតជ្រៅជាងនេះអំពីអ្វីដែលពួកគេបានរៀននៅក្នុងខគម្ពីរទាំងនេះ ។ ដើម្បីជួយអ្នកឲ្យដឹកនាំការពិភាក្សានេះ សំណួរខាងក្រោមត្រូវបានរៀបចំយោងតាមខគម្ពីរដែលបានចាត់តាំង ៖

- យ៉ាកុប ៤:៤–៥ ។ តើទីបន្ទាល់របស់ព្យាការីទាំងឡាយបានជួយអ្នកឲ្យផ្តោតលើព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ? តើអ្នកត្រូវបានពង្រឹងដោយទីបន្ទាល់របស់មនុស្សផ្សេងទៀតអំពីព្រះអង្គសង្គ្រោះដោយរបៀបណា ? យ៉ាកុបបាននិយាយថា ការគោរពប្រតិបត្តិរបស់ប្រជាជនគាត់តាមច្បាប់ម៉ូសេមានប្រសិទ្ធភាពនៅក្នុង « ការតម្រង់ព្រលឹង | របស់ពួកគេ | ទៅកាន់ » ព្រះអម្ចាស់ ។ តើការខិតខំប្រឹងប្រែងរបស់យើងដើម្បីទទួលបានពិធីបរិសុទ្ធនៃបព្វជិតភាព និង កាន់តាមព្រះបញ្ញត្តិទាំងឡាយតម្រង់ព្រលឹងរបស់យើងទៅកាន់ព្រះអម្ចាស់ដោយរបៀបណា ?
- យ៉ាកុប ៤:៦–៧ ។ តើវិរណៈដល់ព្យាការីទាំងឡាយជួយយើងឲ្យទទួលបានសេចក្តីសង្ឃឹម និង សេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ? តើវិរណៈផ្ទាល់ខ្លួន ឬ សាក្សីខាងវិញ្ញាណដែលអ្នកបានទទួល ពង្រឹងសេចក្តីជំនឿរបស់អ្នកដោយរបៀបណាដែរ ? តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីចងចាំថា វាមានតែតាមរយៈព្រះគុណរបស់ព្រះអម្ចាស់ប៉ុណ្ណោះដែលយើងអាចធ្វើការរបស់ទ្រង់បាននោះ ?
- យ៉ាកុប ៤:៨–៩ ។ តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីទទួលស្គាល់ថា កិច្ចការរបស់ព្រះអម្ចាស់គឺ « ធំ ហើយអស្ចារ្យមែន » ? តើកិច្ចការរបស់ព្រះអង្គសង្គ្រោះជាព្រះដ៏បង្កើតផែនដីដ៏ឥតទ្រឹមលដល់ទីបន្ទាល់របស់អ្នកអំពីទ្រង់ដោយរបៀបណា ? តើវាមានន័យយ៉ាងណាចំពោះអ្នកដើម្បី « កុំមើលងាយដល់វិរណៈទាំងឡាយនៃព្រះឡើយ ?» តើយើងអាចបង្ហាញដល់ព្រះអម្ចាស់ថា យើងផ្តល់តម្លៃដល់វិរណៈដែលទ្រង់បានប្រទានដោយរបៀបណា ?
- យ៉ាកុប ៤:១០ ។ តើគំរូអ្វីខ្លះអំពីរបៀបដែលមនុស្សម្នាក់អាច « មិនចង់ទូន្មានដល់ព្រះអម្ចាស់ឡើយ ប៉ុន្តែទទួលដំបូន្មានពីព្រះហស្តរបស់ទ្រង់វិញ » នោះ ?
- យ៉ាកុប ៤:១១–១៣ ។ ដូចដែលបានលើកឡើងនៅក្នុងមេរៀនទី ៣៥ ពាក្យ *ស្រុះស្រួល* មានន័យថាការនាំមកនូវការត្រូវគ្នា ។ តើដង្វាយធួនជួយយើងឲ្យចូលជាឆ្លងតែមួយនឹងព្រះវរបិតាសួគ៌យើងដោយរបៀបណា ? យ៉ាកុបបានរំឭកយើងអំពីសារៈសំខាន់នៃការបង្រៀនអំពីដង្វាយធួនដោយសួរថា « ហេតុអ្វីបានជាមិននិយាយដល់ដង្វាយធួននៃព្រះគ្រីស្ទ . . . ? » តើយើងអាចធ្វើតាមគោលការណ៍នេះ នៅពេលយើងចែកចាយទីបន្ទាល់របស់យើងជាមួយនឹងអ្នកដទៃ និង នៅពេលយើងមានឱកាសផ្សេងៗដើម្បីបង្រៀនដំណឹងល្អដោយរបៀបណា ? នៅពេលយើងចែកចាយទីបន្ទាល់របស់យើង តើហេតុអ្វីបានជាវាសំខាន់ដើម្បីផ្តែងទីបន្ទាល់តាមរបៀបមួយដែលមនុស្សអាចយល់បាន ? តើព្រះវិញ្ញាណជួយយើងឲ្យសម្រេចការណ៍នេះដោយរបៀបណា ?

ជាលទ្ធផលនៃការពិភាក្សានេះ សូមប្រាកដថាសេចក្តីពិតខាងក្រោមនេះមានភាពជាក់ច្បាស់ ៖ **តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ យើងអាចពោរពេញដោយសេចក្តីសង្ឃឹម និង ស្រុះស្រួលខ្លួនយើងជាមួយនឹងព្រះ ។**

សូមចែកចាយអារម្មណ៍នៃអំណរគុណរបស់អ្នកចំពោះព្រះអង្គសង្គ្រោះ និង ដង្វាយធួនរបស់ទ្រង់ ។ សូមថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទគឺជា « ទីដៅ » ដែលយើងគួរតែដាក់ជីវិតរបស់យើងផ្តោតលើ ។ ដើម្បីបញ្ចប់មេរៀននេះ សូមឲ្យសិស្សគិតពីអ្វីដែលពួកគេនឹងធ្វើ ដើម្បីផ្តោតចិត្តលើព្រះអង្គសង្គ្រោះពេញរយៈពេលពីរបីថ្ងៃទៀត ។ អ្នកអាចស្មើថា ពួកគេគួរតែសរសេរគម្រោងរបស់ពួកគេនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមគិតពីការអញ្ជើញពួកគេពីរបីនាក់ឲ្យប្រាប់សិស្សក្នុងថ្នាក់អំពីអ្វីដែលពួកគេបានគ្រោងនឹងធ្វើ ។

ការរំឭកចំណេះចំណានខគម្ពីរ

ការធ្វើដដែលៗជួយសិស្សឲ្យចាំនូវទីតាំងនៃវគ្គចំណេះចំណានខគម្ពីរ ។ របៀបមួយដើម្បីលើកទឹកចិត្តឲ្យមានការធ្វើដដែលៗនេះ គឺត្រូវប្រើកាតចំណេះចំណានខគម្ពីរ (លេខកូដកាត ១០៤៥៩ ; ក៏មានផងដែរជាឯកសារ PDF នៅ si.lds.org) ។ ប្រសិនបើអ្នកមិនមានកាតទាំងនេះទេ សូមជួយសិស្សឲ្យបង្កើតកាតផ្ទាល់ខ្លួនគេ ដោយមានពាក្យគន្លឹះមកពីវគ្គនៅម្ខាងនៃកាតនីមួយៗ និង សេចក្តីយោងនៅម្ខាងទៀត ។ សូមបែងចែកសិស្សឲ្យធ្វើការជាដៃគូ ។ សូមឲ្យពួកគេចំណាយពេលពីរបីនាទីសួរគ្នាទៅវិញទៅមកនូវអ្វីដែលមាននៅក្នុងកាតនោះ ។ ជាឧទាហរណ៍ សិស្សម្នាក់អាចអានពាក្យគន្លឹះ ខណៈពេលដែលសិស្សផ្សេងទៀតគិតពីសេចក្តីយោងបទគម្ពីរ ។ សូមអញ្ជើញសិស្សឲ្យប្រើកាតទាំងនេះញឹកញាប់ ដើម្បីសួរខ្លួនគេ និង សួរគ្នាទៅវិញទៅមក ។

កំណត់ចំណាំ ៖ ប្រវែងពេលនៃមេរៀននេះ អាចឲ្យមានពេលសម្រាប់សកម្មភាពនៃការរំឭកចំណេះចំណានខគម្ពីរនេះបាន ។ អ្នកអាចដឹកនាំសកម្មភាពនោះនៅពេលចាប់ផ្តើមថ្នាក់រៀន នៅពេលសម្រាកម្តងរវាងផ្នែកនៃមេរៀន ឬក៏នៅចុងបញ្ចប់នៃថ្នាក់ក៏បាន ។ សូមធ្វើឲ្យសកម្មភាពនេះឲ្យខ្លី ដើម្បីមានពេលសម្រាប់បង្រៀនមេរៀន ។ សម្រាប់សកម្មភាពរំឭកផ្សេងទៀត សូមមើលឧបសម្ព័ន្ធនៅក្នុងសៀវភៅសិក្សានេះ ។

មេរៀនសិក្សានៅផ្ទះ

នីហ្វៃទី២ ៣២–យ៉ាកុប ៤ (មេរៀនទី ៩)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនការសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនការសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីគោលលទ្ធិ និង គោលការណ៍នានាដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សាក្នុង នីហ្វៃទី២ ៣២–យ៉ាកុប ៤ (មេរៀនទី ៩) មិនមានបំណងដើម្បីត្រូវបានបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការសិស្សរបស់អ្នក ។

ថ្ងៃទី១ (នីហ្វៃទី២ ៣២)

នៅពេលសិស្សបានសិក្សា នីហ្វៃទី២ ៣២ ពួកគេបានដឹងថា នៅពេលយើងទទួលទានព្រះបន្ទូលនៃព្រះគ្រីស្ទ នោះព្រះបន្ទូលនៃព្រះគ្រីស្ទនឹងប្រាប់យើងពីអ្វីៗទាំងអស់ដែលយើងគួរតែធ្វើ ។ ពួកគេក៏បានដឹងថា នៅពេលយើងអធិស្ឋានជានិច្ច យើងនឹងអាចធ្វើអ្វីទាំងអស់ដែលព្រះអម្ចាស់ចង់ឲ្យយើងធ្វើដើម្បីជាប្រយោជន៍ដល់សុខុមាលភាពនៃព្រលឹងរបស់យើង ។ មេរៀននេះអញ្ជើញសិស្សឲ្យសហការលើសពី ២៤ ម៉ោងនូវអ្វីដែលពួកគេបានដឹងអំពីការអធិស្ឋានជានិច្ចនោះ ។

ថ្ងៃទី ២ (នីហ្វៃទី២ ៣៣)

នៅក្នុងមេរៀនអំពីទីបន្ទាល់ចុងក្រោយរបស់នីហ្វៃនេះ សិស្សបានរៀនថា យើងគួរជ្រើសរើសបើក ឬ មិនបើកដួងចិត្តរបស់យើងចំពោះការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ។ ពួកគេក៏បានរំឭកពីនីហ្វៃទី ១ និង នីហ្វៃទី ២ ដោយជ្រើសរើសវគ្គព្រះគម្ពីរមួយដែលបានបំផុសពួកគេឲ្យធ្វើការល្អ ឬ ជឿលើព្រះគ្រីស្ទ ។

ថ្ងៃទី ៣ (យ៉ាកុប ១–២)

នៅក្នុងមេរៀនរបស់ពួកគេអំពី យ៉ាកុប ១–២ សិស្សបានដឹងថា អ្នកដឹកនាំបព្វជិតភាពបានបម្រើដោយឧស្សាហ៍ព្យាយាម ដើម្បីជួយយើងឲ្យចូលមកកាន់ព្រះគ្រីស្ទ ហើយថាពួកគាត់បានទទួលការទទួលខុសត្រូវដ៏ទេវភាពមួយដើម្បីបង្រៀនព្រះបន្ទូលនៃព្រៃ: និងព្រមានអំពីអំពើបាប ។ តាមរយៈការសិក្សាអំពីទេសនកថារបស់យ៉ាកុបដល់ប្រជាជនរបស់គាត់ សិស្សបានដឹងថាយើងគួរស្វែងរកនគរព្រះមុនស្វែងរកទ្រព្យសម្បត្តិផ្សេងៗទាំងអស់ ។ ពួកគេបានសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេអំពីរបៀបមួយដែលពួកគេអាចប្រើពរជ័យទាំងឡាយ និង ឱកាសនានាដែលព្រះអម្ចាស់បានប្រទានដល់ពួកគេឲ្យកសាងនគរព្រះ និង ប្រទានពរដល់ជីវិតរបស់អ្នកដទៃទៀត ។ ពួកគេក៏បានផ្តោតលើសេចក្តីពិតដែលព្រះអម្ចាស់បានសព្វព្រះទ័យនៅក្នុងបរិសុទ្ធភាពរបស់មនុស្សទាំងអស់ ទាំងបុរស និង ស្ត្រី ។ ពួកគេត្រូវបានសុំឲ្យគិតអំពីរបៀបដែលការរស់នៅតាមច្បាប់ព្រហ្មចារីយភាព ប្រទានពរដល់គ្រួសារ និង ធ្វើឲ្យព្រះអម្ចាស់សព្វព្រះទ័យ ។

ថ្ងៃទី ៤ (យ៉ាកុប ៣–៤)

នៅពេលសិស្សបន្តសិក្សាពីទេសនកថារបស់យ៉ាកុបហើយ ពួកគេបានដឹងថា ព្រះនឹងលួងលោមពួកអ្នកមានចិត្តបរិសុទ្ធនៅក្នុងសេចក្តីវេទនារបស់ពួកគេ ។ មេរៀននេះផ្តោតលើគោលលទ្ធិនេះ ៖ តាមរយៈជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ យើងអាចត្រូវបានពោរពេញទៅដោយសេចក្តីសង្ឃឹម ហើយស្រុះស្រួលខ្លួនយើងនឹងព្រះ ។ សិស្សបានសរសេរអំពីមូលហេតុផ្ទាល់ខ្លួនរបស់ពួកគេសម្រាប់ការចង់ថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និង ជង្វាយធួនរបស់ទ្រង់ ។

សេចក្តីផ្តើម

មេរៀននេះ នឹងជួយសិស្សឲ្យយល់ថា នីហ្វៃបានថ្លែងទីបន្ទាល់អំពីបេសកកម្មរបស់ព្រះយេស៊ូវគ្រីស្ទ ។ សិស្សនឹងមានឱកាសមួយដើម្បីចែកចាយពីរបៀបដែលពាក្យពេចន៍របស់យ៉ាកុប អាចជួយពួកគេឲ្យយកឈ្នះលើសេចក្តីឆ្មើងឆ្មៃ និង ប្រើពរជ័យរបស់ពួកគេដែលបានមកពីព្រះដើម្បីកសាងនគររបស់ទ្រង់ ។ ពួកគេនឹងមានឱកាសមួយដើម្បីប្រើប្រាស់គោលការណ៍ និង គោលលទ្ធិទាំងឡាយដែលពួកគេបានរៀននៅក្នុង យ៉ាកុប ២ ដើម្បីពិភាក្សាពីសារៈសំខាន់នៃការគោរពតាមច្បាប់ព្រហ្មចារីយភាពរបស់ព្រះអម្ចាស់ ។ ពួកគេនឹងពិភាក្សាពីរបៀបដើម្បីរកមើលឱកាសដើម្បីនិយាយអំពីព្រះយេស៊ូវគ្រីស្ទ និង ជង្វាយធួន ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី២ ៣២–៣៣

នីហ្វៃទូន្មានយើងឲ្យស្វែងរកការដឹកនាំពីព្រះ តាមរយៈព្រះបន្ទូលនៃព្រះយេស៊ូវគ្រីស្ទ

សូមចាប់ផ្តើមមេរៀននេះ ដោយការសួរសំណួរខាងក្រោមនេះ ៖

- តើកីឡា ឬ សកម្មភាពអ្វីជាចំណូលចិត្តមួយរបស់អ្នក ?
- តើជំនាញមូលដ្ឋានអ្វីដែលអ្នកត្រូវតែអនុវត្តឲ្យបានញឹកញាប់ ដើម្បីធ្វើឲ្យអ្នកលេងកីឡា ឬ សកម្មភាពនោះ ?
- តើនឹងមានអ្វីកើតឡើង ប្រសិនបើនរណាម្នាក់ធ្វេសប្រហែសមិនបានអនុវត្តជំនាញមូលដ្ឋានគ្រឹះទាំងនោះ ?

សូមប្រាប់សិស្សក្នុងថ្នាក់ថា មានសកម្មភាពជាមូលដ្ឋានគ្រឹះដែលអញ្ជើញព្រះវិញ្ញាណបរិសុទ្ធដើម្បីផ្តល់ការណែនាំមកពីព្រះវរបិតារបស់យើងដែលគង់នៅស្ថានសួគ៌ដល់យើង ។ សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ឬ រៀបចំវាជាក្រដាសសម្រាប់ចែករំលែកមួយ ។

ការអធិស្ឋាន	ការទទួលការណែនាំមកពីព្រះវិញ្ញាណបរិសុទ្ធ	ការសិក្សាព្រះគម្ពីរ
នីហ្វៃទី២ ៣២:៨–៩	នីហ្វៃទី២ ៣២:៥; ៣៣:១–២	នីហ្វៃទី២ ៣២:៣; ៣៣:៤

សូមឲ្យសិស្សម្នាក់ៗជ្រើសរើសសកម្មភាពមួយ នៅក្នុងតារាង ហើយអានវគ្គព្រះគម្ពីរដែលឆ្លើយតបនោះ ។ សូមបែងចែកសិស្សក្នុងថ្នាក់ទៅជាដៃគូ ឬ ក្រុមតូចៗ ។ សូមឲ្យសិស្សប្តូរវេនគ្នាចែកចាយពីរបៀបដែលការអធិស្ឋាន ការទទួលការណែនាពីព្រះវិញ្ញាណបរិសុទ្ធ និង ការសិក្សាព្រះគម្ពីរបានជួយពួកគេឲ្យទទួលបានការណែនាំមកពីព្រះ ។

អ្នកអាចសុំសិស្សឲ្យរាយការណ៍ពីការណែនាំរបស់អែលឌើរ ដេវីឌអេ.បៃដណា អំពីការបញ្ជាឲ្យអធិស្ឋានជានិច្ចនោះបានជួយដល់ពួកគេ ។ អ្នកក៏អាចសួរពួកគេពីរបៀបដែលការអធិស្ឋានរបស់ពួកគេត្រូវបានធ្វើឲ្យប្រសើរឡើង ដោយកិច្ចការសេហការនូវអ្វីដែលពួកគេបានរៀនអំពីការអធិស្ឋានជានិច្ចនោះក្នុងរយៈពេល ២៤ ម៉ោង ។ (ទាំងនេះគឺជាកិច្ចការមកពីថ្ងៃទី ១) ។

យ៉ាកុប ១–២

យ៉ាកុបបានដាក់ទោសដល់ប្រជាជនរបស់គាត់ដោយសារសេចក្តីស្រឡាញ់ទ្រព្យសម្បត្តិ សេចក្តីឆ្មើងឆ្មៃ និង អំពើអសីលធម៌ខាងផ្លូវភេទរបស់ពួកគេ ។

សូមសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ៖ *ដោយសារមនុស្សខ្លះមានច្រើនជាង . . . អ្នកផ្សេង ពួកគេអាចមានអារម្មណ៍ត្រូវបានល្បួងឲ្យជឿថាពួកគេល្អជាងអ្នកដទៃ ។*

សូមអញ្ជើញសិស្សឲ្យស្មើពាក្យផ្សេងៗដែលអាចបំពេញប្រយោគនេះ ។ ចម្លើយដែលអាចមានគឺ ប្រាក់ ភាពមានបាន សមត្ថភាពខាងតន្ត្រី ជំនាញអត្តពលកម្ម ទេពកោសល្យ សាលា ប្រាជ្ញា ឱកាសលូតលាស់ឡើង ចំណេះដឹងពីដំណឹងល្អ និង សម្ភារនានា ។ សូមអញ្ជើញសិស្សឲ្យគិតដោយស្ងាត់ៗថាប្រយោគនេះ ជាមួយនឹងពាក្យផ្សេងៗទៀតដែលពួកគេបានស្មើនោះ ធ្លាប់បានជាការពិតចំពោះពួកគេ ។

សូមរំឲ្យកសិស្សថា ដោយសារតែសេចក្តីស្រឡាញ់របស់យ៉ាកុបដល់ប្រជាជនរបស់គាត់ និងការគោរពរបស់គាត់ដល់បទបញ្ញត្តិរបស់ព្រះអម្ចាស់ គាត់បានព្រមានប្រជាជនរបស់គាត់អំពីអំពើទុច្ចរិត និង អំពើបាបរបស់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យអាន យ៉ាកុប ២:១២–១៣ ហើយណែនាំពីរបៀបដែលពួកគេអាចបំពេញប្រយោគនេះនៅលើក្តារខៀន ដូច្នេះវានឹងពិពណ៍នាពីសាសន៍នីហ្វៃខ្លះៗអំឡុងពេលការបម្រើរបស់យ៉ាកុប ។

សូមអញ្ជើញសិស្សឲ្យអាន យ៉ាកុប ២:១៧–២១ ហើយរកពាក្យទូន្មានដែលអាចជួយពួកគេឲ្យយកឈ្នះលើសេចក្តីឆ្មើងឆ្មៃ ។ (ពួកគេអាចគូសចំណាំពាក្យទូន្មានទាំងនេះនៅក្នុងការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ) ។ សូមអញ្ជើញសិស្សឲ្យចែកចាយពាក្យទូន្មានខ្លះៗដែលពួកគេបានរកឃើញ ហើយពន្យល់ពីរបៀបដែលការទូន្មាននេះអាចជួយពួកគេឲ្យយកឈ្នះលើសេចក្តីឆ្មើងឆ្មៃ ។

សូមពន្យល់ថា ខគម្ពីរទាំងនេះបង្រៀនពីសេចក្តីពិតខាងក្រោមនេះ ៖ **យើងគួរតែស្វែងរកនគរព្រះលើសពីទ្រព្យសម្បត្តិផ្សេងៗទាំងអស់ ។**សូមអញ្ជើញសិស្សបីបួននាក់ឲ្យចែកចាយរបៀបមួយដែលពួកគេអាចប្រើពរជ័យទាំងនេះ និង ឱកាសនានាដែលព្រះអម្ចាស់បានប្រទានដល់ពួកគេឲ្យកសាងនគរព្រះ និង ប្រទានពរដល់អ្នកដទៃ ។

ដើម្បីរៀបចំសិស្សឲ្យរំឲ្យកការបង្រៀនរបស់យ៉ាកុបអំពីភាពបរិសុទ្ធខាងផ្លូវភេទ សូមអញ្ជើញពួកគេឲ្យស្រមៃថា មាននរណាម្នាក់បានសួរពួកគេពីមូលហេតុដែលពួកគេជឿលើការរស់នៅតាមច្បាប់ព្រហ្មចារីយភាព ។ សូមឲ្យសិស្សអាន យ៉ាកុប ២:២៨–៣៥រកជំនួយដើម្បីឆ្លើយតបនឹងសំណួរនេះ ។ វាអាចជួយបានច្រើនបើរំឲ្យកពួកគេថា ពួកគេបានរៀនពីសេចក្តីពិតដូចខាងក្រោម ដែលជាផ្នែកនៃការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ ៖ **ព្រះអម្ចាស់សព្វព្រះទ័យនឹងព្រហ្មចារីយភាព ។**ពួកគេក៏បានសិក្សាពីផលវិបាកនៃភាពអសីលធម៌ខាងផ្លូវភេទ ដែលបានពិពណ៍នានៅក្នុងខគម្ពីរទាំងនេះ ។ សូមអញ្ជើញសិស្សឲ្យចែកចាយពីរបៀបដែលពួកគេអាចពន្យល់ ដោយផ្តែកលើ យ៉ាកុប ២:២៨–៣៥ ពីរបៀបដែលពួកគេឆ្លើយនឹងសំណួរនេះ ។

សូមសួរ ៖ យោងតាម យ៉ាកុប ២:២៧តើអ្វីជា « ព្រះបន្ទូលនៃព្រះអម្ចាស់ » ដែលទាក់ទងនឹងការមានប្រពន្ធច្រើនជាងមួយ ? (សូមប្រាកដថា វាច្បាស់ថា ព្រះអម្ចាស់បានបញ្ជាថា បុរសម្នាក់ត្រូវរៀបការជាមួយនឹងភរិយាម្នាក់តែប៉ុណ្ណោះ) ។

សូមបង្ហាញថា នៅពេលខ្លះក្នុងប្រវត្តិសាស្ត្រនៃពិភពលោក ព្រះអម្ចាស់បានបញ្ជារាស្ត្ររបស់ទ្រង់ឲ្យអនុវត្តពហុអាពាហ៍ពិពាហ៍ ។ ជាឧទាហរណ៍ ពហុអាពាហ៍ពិពាហ៍ត្រូវបានអនុវត្តនៅក្នុងជំនាន់ព្រះគម្ពីរសញ្ញាចាស់ដោយអ័ប្រាហាំ និង សារ៉ាយ (សូមមើល លោកុប្បត្តិ១៦:១–៣; គ. និង ស . ១៣២:៣៤–៣៥ ,៣៧)និង ដោយកូនប្រុសរបស់ពួកគេ អឺសាក និង ចៅប្រុសគេ យ៉ាកុប (សូមមើល គ .និង ស. ១៣២:៣៧) ហើយវាក៏ត្រូវបានអនុវត្តផងដែរសម្រាប់ជំនាន់មួយអំឡុងពេលសម័យដំបូងនៃពេលសាសនាចក្របានស្តារឡើងវិញ ដោយចាប់ផ្តើមពីព្យាការី យ៉ូសែប ស្មីធ (សូមមើល គ. និង ស. ១៣២:៣២–៣៣, ៥៣) ។ ទោះជាយ៉ាងណាក្តី នៅក្នុងឆ្នាំ ១៨៩០ ព្រះបានបញ្ជាដល់ព្យាការីរបស់ទ្រង់ វិលហ្វូឌវូឌដ្រុព្ធ ឲ្យបញ្ចប់ការអនុវត្តពហុអាពាហ៍ពិពាហ៍នេះ (សូមមើល គ. និង ស. សេចក្តីប្រកាសជាផ្លូវការទី ១) ។

សូមឲ្យពេលវេលាដល់សិស្សដើម្បីគិតពីរបៀបនៃការជ្រើសរើសដែលពួកគេបានធ្វើដើម្បីបានបរិសុទ្ធ និង ស្អាតស្អំនឹងធ្វើឲ្យព្រះអម្ចាស់សព្វព្រះទ័យ និង ដល់អ្នកដទៃផងដែរ ។ សូមអញ្ជើញពួកគេឲ្យពន្យល់ពីរបៀបដែលការកាន់តាមច្បាប់ព្រហ្មចារីយភាពពេលនេះ នឹងប្រទានពរដល់ពួកគេ និង គ្រួសាររបស់ពួកគេ —ឥឡូវនេះ និង នៅក្នុងពេលអនាគត ។ សូមពន្យល់ពីរបៀបដែលការកាន់តាមច្បាប់ព្រហ្មចារីយភាព បានប្រទានពរដល់អ្នក និង គ្រួសាររបស់អ្នក ។

យ៉ាកុប ៣–៤

យ៉ាកុបបានលើកទឹកចិត្តដល់ប្រជាជនរបស់គាត់ឲ្យប្រែចិត្ត និង មានសេចក្តសង្ឃឹមថាពួកគេអាចត្រឡប់ទៅកាន់វត្តមាននៃព្រះបាន

សូមដាក់រូបភាពតូចមួយនៃព្រះយេស៊ូវគ្រីស្ទ នៅកណ្តាលក្តារខៀន នៅលើបដាមួយ ឬ ក្រដាសមួយសន្លឹក ។ នៅជុំវិញរូបភាពនោះ សូមសរសេរពីរបីពាក្យដែលតំណាងឲ្យរឿងដែលអាចទាក់ទាញមនុស្សចេញពីព្រះអង្គសង្គ្រោះ និង ដំណឹងល្អរបស់ទ្រង់ ។ សូមឲ្យសិស្សបើកទៅយ៉ាកុប ៤:១៤ ។ សូមពន្យល់ថា ខគម្ពីរនេះរួមមានឃ្លា « មើលហួសទីដៅ » ។ សូមសួរពួកគេពីអត្ថន័យ « ទីដៅ » ដែលខគម្ពីរនេះចង់សំដៅលើ ។ (អែលឌើរ នែលអេ.ម៉ាក់ស្វែល នៃក្លុ៉ម៉នៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា « ទីដៅគឺជាព្រះគ្រីស្ទ » [« Jesus of Nazareth, Savior and King »*Ensign* ខែ ធ្នូ ឆ្នាំ ២០០៧ ទំព័រ ៤៥]) ។ ក្រោយពីការចែកចាយការពន្យល់នេះហើយ សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ាកុប ៤:១៤–១៥ ឬៗ ។

សូមសួរ ៖ តើអ្នកគិតថា ហេតុអ្វីបានជាវាអាចមានន័យយ៉ាងណា ក្នុងការមើលហួសទីដៅ? (ដើម្បីដាក់ជីវិតរបស់យើងឲ្យចំកណ្តាលលើព្រះអង្គសង្គ្រោះ និង ដំណឹងល្អរបស់ទ្រង់ ជាជាងនៅលើអ្វីៗផ្សេងទៀត) ។

សូមអញ្ជើញសិស្សឲ្យអាន យ៉ាកុប ៤:៤–១២ ហើយរកមើលមូលហេតុបីបួនដែលយ៉ាកុបជឿលើព្រះយេស៊ូវគ្រីស្ទ និង ពីមូលហេតុដែលគាត់ដឹងថា វាសំខាន់ដើម្បីឲ្យអ្នកដទៃស្គាល់ពីដង្វាយធួន ។ ជាលទ្ធផលនៃការពិភាក្សានេះ សូមប្រាកដថា សេចក្តីពិតខាងក្រោមនេះមានភាពច្បាស់លាស់ ៖ **តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចពោរពេញទៅដោយសេចក្តីសង្ឃឹម និង ស្រុះស្រួលខ្លួនយើងជាមួយនឹងព្រះ ។**

សូមចែកចាយអារម្មណ៍របស់អ្នកអំពីការដឹងគុណចំពោះព្រះអង្គសង្គ្រោះ និង ដង្វាយធួនរបស់ទ្រង់ ។ សូមថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទគឺជា « ទីដៅ » ដែលយើងគួរតែដាក់ជីវិតរបស់យើងផ្តោតលើ ។ សូមបញ្ចប់មេរៀននេះ ដោយសូមឲ្យសិស្សគិតពីអ្វីដែលពួកគេនឹងធ្វើ ដើម្បីផ្តោតលើព្រះអង្គសង្គ្រោះពេញរយៈពេលពីរបីថ្ងៃទៀត ។

មេរៀនបន្ទាប់ (យ៉ាកុប ៥ ដល់ អោមណៃ)

សូមសួរសិស្ស ៖ តើអ្វីទៅជាអ្នកប្រឆាំងនឹងព្រះគ្រីស្ទ ? តើអ្នកនឹងឆ្លើយតបនឹងអ្នកប្រឆាំងនឹងព្រះគ្រីស្ទដោយរបៀបណា ? នៅពេលអ្នកអានព្រះគម្ពីរនៅក្នុងមេរៀនបន្ទាប់នេះ សូមកត់សម្គាល់ពីអ្វីដែលយ៉ាកុប បាននិយាយ និង បានធ្វើនៅពេលប្រឈមមុខនឹងសេរេម ដែលជាអ្នកប្រឆាំងនឹងព្រះគ្រីស្ទ ។ ផងដែរ សូមរកមើលពរជ័យដែលអេណុសបានទទួល ដោយសារគាត់បានស្វែងរកព្រះដោយអស់ពីចិត្តរបស់គាត់ ដោយការអធិស្ឋានទាំងថ្ងៃទាំងយប់ ។ សូមរកមើលមូលហេតុដែលសាសន៍នីហ្វៃបានចាកចេញពីដែនដីកេរ៉ុម៉រតកដំបូងរបស់ពួកគេ ហើយចូលរួមជាមួយនឹងសាសន៍មូលេក ។

យ៉ាកុប ៥:១–៥១

សេចក្តីផ្តើម

នៅក្នុងការបង្រៀនប្រជាជនរបស់គាត់ យ៉ាកុបបានដកស្រង់ការប្រៀបធៀបដើមអូលីវស្រុក និង ដើមអូលីវព្រៃ ដែលត្រូវបានប្រាប់ពីដំបូងដោយព្យាការីម្នាក់ឈ្មោះ សឺណូស ហើយត្រូវបានបញ្ចប់នៅក្នុងផ្នាំងលង្ហិន ។ យ៉ាកុបបានប្រើការប្រៀបធៀបនេះដើម្បីបង្រៀនថា ព្រះអម្ចាស់នឹងស្វែងរកដើម្បីនាំសេចក្តីសង្គ្រោះមកដល់ប្រជាជនទាំងអស់ —ថ្វីបើអស់អ្នកដែលនៅក្នុងចំណោមការស្រ្តេក្នុងសេចក្តីសញ្ញារបស់ទ្រង់ ដែលបានបែរចេញពីទ្រង់ក៏ដោយ ។ ដោយសារតែជំណីរឿងជំរឹងនៃយ៉ាកុប ជំពូកទី ៥ វាត្រូវបានបែងចែកទៅជាពីរមេរៀន ។

យោបល់សម្រាប់ការបង្រៀន

យ៉ាកុប ៥:១–១៤

យ៉ាកុបដកស្រង់សម្តីរបស់សឺណូស ដែលបានប្រៀបធៀបវង្សអ៊ីស្រាអែល ទៅនឹងដើមអូលីវស្រុកមួយដើម

សូមគិតអំពីការចាប់ផ្តើមមេរៀននេះ ដោយការអានឧទាហរណ៍ពីយុវវ័យខាងក្រោមដែលឆ្ងល់ពីចំណងរបស់ព្រះអម្ចាស់ដើម្បីអភ័យទោសដល់អំពើបាបរបស់ពួកគេ ៖

- អ្នកកាន់បព្វជិតភាពវ័យក្មេងម្នាក់ បានអភិវឌ្ឍទម្លាប់ដ៏មានបាបមួយ ។ គាត់ជឿថា អ្នកផ្សេងទៀតអាចត្រូវបានអភ័យទោស ប៉ុន្តែគាត់សង្ស័យពីព្រះអម្ចាស់ថានឹងទទួលយកការប្រែចិត្តរបស់គាត់ឬទេ ។
- យុវនារីម្នាក់ បានរំលងក្រឹត្យវិន័យមួយ ។ នាងមានអារម្មណ៍ថាមានទោស មានអារម្មណ៍មិនល្អចំពោះខ្លួននាង ហើយឆ្ងល់ថាតើព្រះអម្ចាស់នៅតែស្រឡាញ់នាងឬយ៉ាងណា ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីសំណួរខាងក្រោមដោយគ្មានចម្លើយជាសំឡេង ៖

- តើអ្នកមានឆ្ងល់អំពីបំណងរបស់ព្រះអម្ចាស់ក្នុងការអភ័យទោសដល់អ្នកចំពោះអំពើបាបរបស់អ្នកដែរឬទេ ?

សូមពន្យល់ថា យ៉ាកុបបានព្យាករថា សាសន៍យូដានឹងបដិសេធព្រះយេស៊ូវគ្រីស្ទ (សូមមើល យ៉ាកុប ៤:១៥) ។ គាត់ក៏បានបង្រៀនថា ព្រះយេស៊ូវគ្រីស្ទនឹងបន្តធ្វើការដើម្បីឲ្យមានសេចក្តីសង្គ្រោះដល់ប្រជាជនរបស់ទ្រង់ ទោះបីជាក្រោយពេលពួកគេបានបដិសេធទ្រង់ក្តី (សូមមើល យ៉ាកុប ៤:១៧–១៨) ។ ដើម្បីបង្ហាញពីសេចក្តីពិតនេះ យ៉ាកុបបានដកស្រង់ពីការប្រៀបធៀបមួយដែលផ្តល់ដោយព្យាការីម្នាក់ឈ្មោះ សឺណូស ។ ការប្រៀបធៀបមួយប្រើជាចរិតភ្ជុ វត្ថុ និង សកម្មភាពជាតំណាងជាច្រើនដើម្បីបង្រៀនពីសេចក្តីពិតទាំងឡាយ ។ នៅពេលសិស្សសិក្សាពីការប្រៀបធៀបនេះ ពួកគេអាចរៀនពីមេរៀនដ៏សំខាន់អំពីបំណងរបស់ព្រះយេស៊ូវគ្រីស្ទដើម្បីជួយដល់អ្នកទាំងឡាយណាដែលបានបែរចេញពីទ្រង់ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ាកុប ៥:១–២ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលនរណាដែលសឺណូសកំពុងនិយាយជាមួយនោះ (វង្សអ៊ីស្រាអែល) ។ អ្នកអាចពន្យល់ថា នៅពេលព្យាការីយ៉ាកុបក្នុងព្រះគម្ពីរសញ្ញាចាស់ បានធ្វើសេចក្តីសញ្ញាជាមួយនឹងព្រះអម្ចាស់ នោះព្រះអម្ចាស់បានផ្លាស់ប្តូរឈ្មោះរបស់គាត់ទៅជាអ៊ីស្រាអែលវិញ ។ ឃ្លា « វង្សនៃអ៊ីស្រាអែល » សំដៅទៅលើកូនចៅរបស់យ៉ាកុប និង ដល់មនុស្សទាំងអស់ដែលបានទទួលបុណ្យជ្រមុជទឹក ហើយបានធ្វើសេចក្តីសញ្ញាជាមួយនឹងព្រះអម្ចាស់ ។

- តើនរណាខ្លះនៅក្នុងថ្នាក់នេះ ដែលជាសមាជិកម្នាក់នៃវង្សនៃអ៊ីស្រាអែល ? (អ្នកអាចពន្យល់ថា សមាជិកសាសនាចក្រដែលបានជ្រមុជទឹកទាំងអស់ គឺជាផ្នែកនៃវង្សនៃអ៊ីស្រាអែល ។ ពួកគេគឺជាផ្នែកនៃការប្រៀបធៀបនេះនៅក្នុង យ៉ាកុបជំពូកទី ៥) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ៥:៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលសឺណូសបានប្រើនៅក្នុងការប្រៀបធៀបរបស់គាត់ ដើម្បីតំណាងឲ្យវង្សអ៊ីស្រាអែល ។ ក្រោយពីសិស្សបានរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញហើយ សូមពន្យល់ថាដើមអូលីវគឺពិតជាមានតម្លៃខ្លាំងនៅក្នុងជំនាន់អ៊ីស្រាអែលពីបុរាណដែលជាជំនាន់សឺណូសបានរស់នៅនោះ ។ អូលីវត្រូវបានប្រើប្រាស់សម្រាប់អាហារ ហើយប្រេងអូលីវត្រូវបានប្រើសម្រាប់ការចម្អិនម្ហូប និង ជាថ្នាំពេទ្យ និង ជាប្រេងសម្រាប់ចង្កៀង ។ ដើមអូលីវត្រូវការការថែទាំខ្លាំង ហើយធ្វើការខ្លាំងដើម្បីជួយវាឲ្យដុះបានផ្លែល្អ ។ សូមបង្ហាញថា ការប្រៀបធៀបនេះ ដើមអូលីវស្រុកគឺស្ថិតនៅក្នុងចំការអូលីវមួយដែលតំណាងឲ្យពិភពលោក ។

- យោងតាម យ៉ាកុប ៥:៣ តើមានអ្វីចាប់ផ្តើមកើតឡើងចំពោះដើមអូលីវស្រុក ? តើភាពពុកផុយនៃដើមនោះតំណាងឲ្យអ្វី ? (សូមលើកទឹកចិត្តសិស្សឲ្យប្រើលេខយោង ៣ *យ* ដើម្បីឆ្លើយតបនឹងសំណួរនេះ) ។
- តើអ្វីជាការក្បត់សាសនា ? (ការបែរចេញពីព្រះអម្ចាស់ និង ដំណឹងល្អរបស់ទ្រង់) ។

សូមអញ្ជើញសិស្សឲ្យអាន យ៉ាកុប ៥:៤–៦ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេគិតថា នរណាជាម្ចាស់ចំការនេះ ហើយតើសកម្មភាពរបស់គាត់ក្នុងការកាត់លួស ការជ្រោយគល់ និង ការដាក់ជីដើមនោះអាចតំណាងឲ្យអ្វី ។ បន្ទាប់មក សូមឲ្យពួកគេពន្យល់ពីអ្វីដែលពួកគេគិតថានិមិត្តរូបទាំងនេះតំណាងឲ្យ ។ (អ្នកអាចជួយពួកគេឲ្យយល់ថា ម្ចាស់ចំការតំណាងឲ្យព្រះយេស៊ូវគ្រីស្ទ ។ ការកាត់លួស ការជ្រោយគល់ និង ការដាក់ជីនោះ តំណាងឲ្យការខិតខំរបស់ព្រះអម្ចាស់ដើម្បីជួយយើងឲ្យទទួលបានពរជ័យទាំងឡាយនៃដង្វាយធួនរបស់ទ្រង់ និង ការខិតខំរបស់ព្យាការីនានាដើម្បីបង្រៀន និង ហៅប្រជាជនទាំងនោះឲ្យប្រែចិត្ត) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ជែហ្វ្រីអ័រ.ហូឡិន នៃក្លុំមនៃពួកសាវកដប់ពីរនាក់ថា ៖

« ការប្រៀបធៀបដូចដែលបានដំណាលដោយយ៉ាកុបនេះ គឺមកពីដើមដំបូងដែលមានបំណងចាប់អំពីព្រះគ្រីស្ទ ។ . . . សូម្បីតែព្រះអម្ចាស់នៃចំការ និង អ្នកបម្រើរបស់ទ្រង់ខិតខំដាក់ជី កាត់លូស បន្សុទ្ធ ហើយបើមិនដូច្នេះទេនឹងមិនធ្វើឲ្យមានផ្លែដល់ដើមទាំងនោះតាមទំហំអ្វីសមនឹងរឿងប្រវត្តិសាស្ត្រខ្លីមួយជំពូកនៃការខ្វាត់ខ្វាយ និង ការប្រមូលនៃអ៊ីស្រាអែល នោះអត្ថន័យដ៏ជ្រៅជាងនេះនៃដង្វាយធួនបង្គប់ និង បន្ទាយកិច្ចការរបស់ពួកគេ » (*Christ and the New Covenant: The Messianic Message of the Book of Mormon* | ឆ្នាំ ១៩៩៧ | ទំព័រ ១៦៥) ។

ដើម្បីជួយសិស្សឲ្យឃើញពីរបៀបដែលការប្រៀបធៀបនេះបង្ហាញពីកង្វល់របស់ព្រះអម្ចាស់ដល់ពួកគេនោះ សូមបង្រៀនពួកគេថាពួកគេអាចជំនួសឈ្មោះរបស់ពួកគេនៅក្នុងសេចក្តីយោងដល់ដើមអូលីវបាន ។ អ្នកអាចបង្ហាញការណ៍នេះ ដោយការឲ្យជាឧទាហរណ៍ខាងក្រោមនេះមកពី យ៉ាកុប ៥:៧ ៖ « យើងព្រួយចិត្តដែលយើងត្រូវខាតបង់ | ឈ្មោះរបស់អ្នក | នេះទៅ » ។ សូមពន្យល់ថានៅពេលយើងបញ្ចូលឈ្មោះរបស់យើងនៅក្នុង យ៉ាកុប ជំពូកទី ៥ នៅក្នុងកន្លែងដែលមានន័យខ្លាំង និង ភាពសមរម្យនោះ យើងអាចដឹងបានច្រើនអំពីការព្រួយរបស់ព្រះអម្ចាស់ចំពោះយើង ។

សូមបង្ហាញតារាងខាងក្រោមនេះ ។ សូមពន្យល់ថា វាមានរាយបញ្ជីនូវអត្ថន័យនៃនិមិត្តរូបនៅក្នុងការប្រៀបធៀបរបស់សឺណូស ។ (អ្នកអាចថតចម្លងតារាងនេះជាក្រដាសចែកដល់សិស្ស ឬ សូមឲ្យសិស្សចម្លងតារាងនេះដាក់ក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ) ។

យ៉ាកុប ជំពូកទី ៥ ៖ ការប្រៀបធៀបនៃដើមអូលីវស្រុក និង ដើមអូលីវព្រៃ	
និមិត្តរូប	**អត្ថន័យដែលអាចមាន**
ដើមអូលីវស្រុក	វង្សនៃអ៊ីស្រាអែល ពាស្តេក្នុងសេចក្តីសញ្ញារបស់ព្រះ
ចំការ	ពិភពលោក
ពុក	អំពើបាប និង ការក្បត់សាសនា
ព្រះអម្ចាស់ និង ម្ចាស់ចំការ	ព្រះយេស៊ូវគ្រីស្ទ
ការកាត់លូស ការជ្រោយគល់ និង ការដាក់ជី	ការខិតខំរបស់ព្រះអម្ចាស់ដើម្បីជួយមនុស្សឲ្យទទួលបានពរជ័យនៃដង្វាយធួនរបស់ទ្រង់
អ្នកបម្រើរបស់ម្ចាស់ចំការ	ព្យាការីរបស់ព្រះអម្ចាស់
មែក	ក្រុមមនុស្ស
ដើមអូលីវព្រៃ	សាសន៍ដទៃ —អ្នកទាំងឡាយណាដែលមិនបានធ្វើសេចក្តីសញ្ញាជាមួយនឹងព្រះអម្ចាស់ ។ ក្រោយមកនៅក្នុងការប្រៀបធៀបនេះ ដើមអូលីវធម្មជាតិក្លាយជាដើមអូលីវព្រៃ ដែលតំណាងឲ្យចំណែកនៃវង្សនៃអ៊ីស្រាអែលដែលបានធ្លាក់ទៅក្នុងការក្បត់សាសនា ។
ការបំបៅជាប់ និង ការបណ្តុះមែក	ការខ្វាត់ខ្វាយ និង ការប្រមូលផ្តុំនៃរាស្ត្រក្នុងសេចក្តីសញ្ញារបស់ព្រះអម្ចាស់ ។ បន្ថែមលើនេះ ការបំបៅមែកអូលីវព្រៃជាប់នឹងដើមអូលីវស្រុក តំណាងឲ្យការប្រែចិត្តជឿនៃអ្នកទាំងឡាយណាដែលក្លាយជាផ្នែកនៃរាស្ត្រក្នុងសេចក្តីសញ្ញារបស់ព្រះអម្ចាស់ ។
មែកដែលឆេះ	ការកាត់សេចក្តីរបស់ព្រះដល់ពួកទុច្ចរិត
ផ្លែ	ជីវិត ឬកិច្ចការរបស់មនុស្ស

សូមឲ្យសិស្សម្នាក់អាន យ៉ាកុប ៥:៧, ៩–១០ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលម្ចាស់ចំការបានធ្វើបន្ទាប់មកទៀតដើម្បីសង្គ្រោះដើមអូលីវស្រុក ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។ (អ្នកអាចត្រូវការពន្យល់ថា ការបំបៅគឺជាការបញ្ចូលមែកមួយដែលមកពីដើមឈើមួយទៅជាប់នឹងដើមឈើខុសគ្នាមួយទៀត ។ ការបំបៅនៅក្នុងខគម្ពីរទាំងនេះ តំណាងឲ្យការខិតខំរបស់ព្រះអម្ចាស់ដើម្បីជួយដល់សាសន៍ដទៃ ឲ្យក្លាយជាផ្នែកនៃរាស្ត្រក្នុងសេចក្តីសញ្ញារបស់ទ្រង់តាមរយៈពិធីបុណ្យជ្រមុជទឹក និង ការប្រែចិត្ត ។ ការដុតមែកខ្លះចោល តំណាងឲ្យការកាត់សេចក្តីរបស់ព្រះអម្ចាស់ដល់ពួកសមាជិកនៃវង្សនៃអ៊ីស្រាអែលដែលទុច្ចរិតបំផុត) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ាកុប ៥:១១ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលភស្តុតាងនៃការព្រួយបារម្ភរបស់ម្ចាស់ចំការដល់បុសនៃដើមអូលីវស្រុក ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

សូមរំឭកសិស្សថា យ៉ាកុប ៥:៦ និយាយថាដើមអូលីវស្រុកបានចាប់ផ្តើមបង្កើតមែកទន់ខ្ចីទាំងឡាយ ។ សូមឲ្យសិស្សម្នាក់អាន យ៉ាកុប ៥:៨, ១៣–១៤ ឮៗ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលម្ចាស់ចំការបានធ្វើជាមួយនឹងមែកទាំងនេះ ។ អ្នកក៏អាចសុំឲ្យពួកគេគិតពីរបៀបដែលដំណើរគ្រួសាររបស់លីហៃផ្តល់ជាគំរូមួយនៃសកម្មភាពរបស់ម្ចាស់ចំការនៅក្នុង យ៉ាកុប ៥:៨, ១៣–១៤ ។

យ៉ាកុប ៥:១៥–៤០

ម្ចាស់ចំការ និង អ្នកបម្រើរបស់គាត់ធ្វើការដើម្បីជួយចំការឲ្យដាំបានផ្លែល្អ

សូមបំបែកសិស្សក្នុងថ្នាក់ជាពីរក្រុម ។ សូមចាត់តាំងក្រុមទីមួយឲ្យសិក្សាក្នុង យ៉ាកុប ៥:១៥–២៨ ហើយក្រុមទីពីរសិក្សាក្នុង យ៉ាកុប ៥:២៩–៤០ ។ សូមឲ្យសិស្សធ្វើតាមអ្វីដែលមានខាងក្រោម នៅពេលពួកគេសិក្សា (អ្នកអាចសរសេរការណែនាំទាំងនេះនៅលើក្តារខៀន) ៖

១ .សូមសង្ខេបអ្វីដែលបានកើតឡើងនៅក្នុងចំការ និង អ្វីដែលអាចតំណាងឲ្យវា ។

២ .សូមរកឃ្លាដែលបង្ហាញពីការខិតខំរបស់ម្ចាស់ចំការ ដើម្បីការពារដើមអូលីវស្រុក (ឬ ធម្មជាតិ) និង មែករបស់វា ។

ក្រោយពីសិស្សមានពេលគ្រប់គ្រាន់ដើម្បីសិក្សាខគម្ពីរដែលបានចាត់តាំងរបស់ពួកគេហើយ សូមឲ្យពួកគេសង្ខេបអ្វីដែលបានកើតឡើងនៅក្នុងចំការ និង ពន្យល់ពីអ្វីដែលវាអាចតំណាងឲ្យ ។ សូមចាប់ផ្តើមជាមួយនឹងសិស្សដែលបានសិក្សា យ៉ាកុប ៥:១៥–២៨ ។ ខាងក្រោមនេះ គឺជាគំរូនៃសេចក្តីសង្ខេប និង ការបកប្រែ ។

យ៉ាកុប ៥:១៥–២៨ ។ អ្វីដែលបានកើតឡើង ៖ មែកទាំងអស់ដែលបានបំបៅ នាំមកនូវផ្លែល្អ ។ ទោះជាយ៉ាងណាក្តី មែកមួយ ថ្វីបើបានដាំនៅផ្នែកល្អមួយនៃចំការក្តី ក៏វានាំមកនូវទាំងផ្លែស្រុក និង ផ្លែព្រៃ ។ អ្វីដែលវាអាចតំណាង ៖ ផ្លែល្អ ឬ ផ្លែស្រុកពេញចំការស្ទើរតែទាំងអស់ តំណាងឲ្យភាពសុចរិតនៅលើផែនដី អំឡុងពេលព្រះគ្រីស្ទ និង សាវករបស់ទ្រង់ ។ មែកដែលបាននាំមកនូវផ្លែល្អខ្លះ និង ផ្លែអូលីវព្រៃខ្លះ តំណាងឲ្យកូនចៅដ៏សុចរិត និង ទុច្ចរិតរបស់លីហៃ ។

យ៉ាកុប ៥:២៩–៤០ ។ អ្វីដែលបានកើតឡើង ៖ ផ្លែទាំងអស់ពេញមួយចំការ ក្លាយជាខូចរលួយអស់រលីង ។ អ្វីដែលរឿងអាចតំណាង ៖ ភាពរលួយនៃផ្លែទាំងអស់ តំណាងឲ្យការក្បត់សាសនាដ៏ធំ អំឡុងពេលពេញលេញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដែលត្រូវបានបាត់បង់ពីផែនដី បន្ទាប់ពីការបម្រើរបស់សាវកព្រះគ្រីស្ទនៅលើផែនដីមក ។

ក្រោយពីក្រុមទាំងពីរបានចែកចាយសេចក្តីសង្ខេបទាំងនេះហើយ សូមសួរ ៖

- តើឃ្លាអ្វីដែលបង្ហាញពីការខិតខំរបស់ម្ចាស់ចំការដើម្បីរក្សាដើមអូលីវស្រុក និង មែករបស់វា ? តើនេះបង្ហាញអ្វីអំពីអារម្មណ៍របស់ព្រះអម្ចាស់ចំពោះរាស្ត្រក្នុងសេចក្តីសញ្ញារបស់ទ្រង់ ?
- នៅពេលយើងបានពិភាក្សាពីការប្រៀបធៀបនេះ តើអ្នកបានរៀនអ្វីខ្លះ អំពីព្រះយេស៊ូវគ្រីស្ទ ជាម្ចាស់ចំការនោះ ? (នៅក្នុងចំណោមសេចក្តីពិតជាច្រើនដែលត្រូវបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ សិស្សគួរយល់ថា **ព្រះអម្ចាស់ស្រឡាញ់យើង ហើយធ្វើការដោយឧស្សាហ៍ព្យាយាមសម្រាប់សេចក្តីសង្គ្រោះរបស់យើង**) ។
- តើការប្រៀបធៀបនេះទាក់ទងនឹងគំរូនៅពេលចាប់ផ្តើមមេរៀននេះ អំពីយុវជនពីរនាក់ដែលបានឆ្ងល់អំពីបំណងរបស់ព្រះអម្ចាស់ក្នុងការអភ័យទោសដល់អំពើបាបរបស់ពួកគេនោះដោយរបៀបណា ?

យ៉ាកុប ៥:៤១–៥១

ម្ចាស់ចំការកើតទុក្ខចំពោះចំការរបស់គាត់

សូមអញ្ជើញសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាអានឮៗនៅក្នុង យ៉ាកុប ៥:៤១–៤២, ៤៦–៥០ ។ (អ្នកអាចបង្ហាញថាឃ្លា « ភាពខ្ពស់ពេកនៃដើមឈើនោះ » នៅក្នុង យ៉ាកុប ៥:៤៨ អាចសំដៅទៅលើសេចក្តីឆ្អើងឆ្មៃ) ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលឃ្លាដែលបង្ហាញពីសេចក្តីស្រឡាញ់របស់ម្ចាស់ចំការ និង ការព្រួយបារម្ភចំពោះចំការរបស់គាត់ និង ទុក្ខព្រួយរបស់គាត់ នៅពេលដើមឈើនោះមិនផ្តល់ផ្លែល្អនោះ ។ សូមអញ្ជើញសិស្សឲ្យចែកចាយឃ្លាមកពីខគម្ពីរទាំងនេះដែលមានអត្ថន័យជាពិសេសដល់ពួកគេ និង ឲ្យគេពន្យល់ពីមូលហេតុដែលឃ្លានេះមានអត្ថន័យដល់ពួកគេ ។ ក្រោយពីសិស្សបានចែកចាយហើយ សូមសួរសិស្សក្នុងថ្នាក់ថា ៖

- តើការយកចិត្តទុកដាក់របស់ម្ចាស់ចំការដល់ចំការរបស់គាត់ តំណាងឲ្យសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ចំពោះយើងដោយរបៀបណា ?
- តើអ្វីខ្លះជាគំរូមកពីព្រះគម្ពីរ ឬ មកពីជីវិតរបស់អ្នក ដែលបង្ហាញថា ព្រះអម្ចាស់បន្តស្រឡាញ់ និង ចៃទាំដល់មនុស្សទាំងអស់ ទោះបីជាក្រោយពីពួកគេបានបែរចេញពីទ្រង់ក្តីនោះ ?

ដើម្បីបញ្ចប់ សូមរំឭកសិស្សថា ម្ចាស់ចំការបានគិតពីការកាត់ដើមឈើទាំងអស់ចោល ដោយសារផ្លែពីដើមឈើទាំងអស់បានរលួយ ទោះបីជាគាត់បានខំថែទាំយ៉ាងណាក្តី (សូមមើល យ៉ាកុប ៥:៤៩) ។

- តើអ្នកគិតថា ម្ចាស់ចំការនឹងលះបង់ចំការរបស់គាត់ចោលឬទេ ? ហេតុអ្វីបោះបង់ ឬ ហេតុអ្វីមិនបោះបង់ ?

ក្រោយពីសិស្សបានចែកចាយពីចម្លើយរបស់ពួកគេហើយ សូមអាន យ៉ាកុប ៥:៥១ ដល់សិស្សក្នុងថ្នាក់ ។ សូមថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់ទ្រង់ស្រឡាញ់យើង និង បង្ហាញពីសេចក្តីមេត្តាករុណា និង អណាត់អត់ធ្មត់ដ៏អស្ចារ្យ ដោយសារទ្រង់បានធ្វើការដើម្បីជួយយើងឲ្យមករកទ្រង់ និង នាំឲ្យមានកិច្ចការសុចរិតទាំងឡាយ ។ សូមពន្យល់ថា មេរៀនបន្ទាប់នេះ នឹងរួមមានការពិភាក្សាអំពីការខិតខំចុងក្រោយរបស់ម្ចាស់ចំការដើម្បីសង្គ្រោះចំការរបស់គាត់ ។

យ៉ាកុប ៥:៥២–៧៧; យ៉ាកុប ៦

សេចក្តីផ្តើម

នៅក្នុងមេរៀនមុន សិស្សបានចាប់ផ្តើមសិក្សាការប្រៀបធៀបរបស់សឺណូសអំពីដើមអូលីវស្រុក និង ដើមអូលីវព្រៃ ។ នៅក្នុងមេរៀននេះ៖ ពួកគេនឹងសិក្សាអំពីផ្នែកចុងក្រោយនៃការប្រៀបធៀប ដែលម្ចាស់ចំការបានធ្វើការជាមួយនឹងអ្នកបម្រើរបស់គាត់ជាលើកចុងក្រោយ ដើម្បីជួយដើមឈើនោះឲ្យមានផ្លែល្អ ។ ពួកគេក៏នឹងសិក្សាអំពី យ៉ាកុប ៦ ដែលយ៉ាកុបបាននិយាយអំពីការប្រៀបធៀបនោះ និង ជាសត្យាប្រជាជនរបស់គាត់ឲ្យប្រែចិត្ត ។

យោបល់សម្រាប់ការបង្រៀន

យ៉ាកុប ៥:៥២–៦០

នៅក្នុងការប្រៀបធៀបអំពីដើមអូលីវស្រុក និង ដើមអូលីវព្រៃនេះ៖ ម្ចាស់ចំការបានសង្គ្រោះដើមឈើនោះ ហើយបានជួយវាឲ្យមានផ្លែល្អ

មុនពេលសិស្សមកដល់ សូមគូសរូបភាពដើមឈើបីដើមនៅលើក្តារខៀន ។



សូមចាត់តាំងសិស្សឲ្យធ្វើការជាដៃគូ

ការធ្វើការជាដៃគូ អាចផ្តល់ឱកាសឲ្យសិស្សដើម្បី « បង្រៀនគ្នាទៅវិញទៅមកអំពីគោលលទ្ធិនៃនគរ » (គ. និង ស. ៨៨:៧៧) ។ សូមគិតបន្តិចនៅក្នុងការសម្រេចរបស់អ្នកអំពីសិស្សណាដែលអ្នកចាត់តាំងឲ្យធ្វើការរួមគ្នានោះ៖ —សិស្សខ្លះអាចជួយ ឬ ខ្លះអាចរំខាន បើសិនជាពួកគេជាដៃគូជាមួយគ្នានោះ ។

សូមរំឭកសិស្សថា នៅក្នុងមេរៀនមុន ពួកគេបានចាប់ផ្តើមសិក្សាការប្រៀបធៀបរបស់សឺណូសអំពីដើមអូលីវស្រុក និង ដើមអូលីវព្រៃនៅក្នុង យ៉ាកុប ៥ ។ នៅចុងបញ្ចប់នៃមេរៀននោះ៖ ដើមឈើទាំងអស់នៅក្នុងចំការបាននាំមកនូវផ្លែអាក្រក់ (សូមមើល យ៉ាកុប ៥:៣០–៤២) ។ នេះតំណាងឲ្យការក្បត់សាសនាដ៏ធំ ។

ដើម្បីរំឭកពីមេរៀនមុន សូមបែងចែកសិស្សក្នុងថ្នាក់ជាដៃគូ ។ សូមឲ្យដៃគូនីមួយៗពិភាក្សាគ្នាពីចម្លើយរបស់ពួកគេចំពោះប្រយោគដែលមិនពេញលេញខាងក្រោម (អ្នកអាចសរសេរប្រយោគទាំងនេះនៅលើក្តារខៀន) ៖

១ .ម្ចាស់ចំការតំណាងឲ្យ . . .

២ .ការខិតខំរបស់ម្ចាស់ចំការ ដើម្បីសង្គ្រោះដើមឈើរបស់គាត់តំណាងឲ្យ . . .

៣ .រឿងមួយដែលខ្ញុំបានរៀនអំពីព្រះយេស៊ូវគ្រីស្ទមកពីពាក្យ ឬ សកម្មភាពរបស់ម្ចាស់ចំការនោះគឺ . . .

៤ .ក្រោយពីដើមឈើទាំងអស់ និង ផ្លែក្នុងចំការនោះបានប្រែទៅជារលួយ នោះម្ចាស់ចំការសម្រេចចិត្តថា . . .

ក្រោយពីសិស្សបានពិភាក្សាពីប្រយោគទាំងនេះជាដៃគូហើយ សូមសង្ខេបខ្លីៗអំពីចម្លើយរបស់ពួកគេក្នុងថ្នាក់ទាំងអស់គ្នា ។ នៅពេលសិស្សរាយការណ៍អំពីចម្លើយរបស់ពួកគេពីប្រយោគពីរដំបូងនោះ សូមប្រាកដថាវាមានភាពច្បាស់លាស់ថា ម្ចាស់ចំការតំណាងឲ្យព្រះយេស៊ូវគ្រីស្ទ ហើយថាការខិតខំរបស់គាត់ដើម្បីសង្គ្រោះដើមឈើរបស់គាត់តំណាងឲ្យការខិតខំរបស់ព្រះអង្គសង្គ្រោះដើម្បីជួយវាស្ត្រេរបស់ទ្រង់ឲ្យត្រឡប់ទៅកាន់ទ្រង់វិញ ។ សិស្សអាចចែកចាយពីមេរៀនដ៏មានតម្លៃផ្សេងគ្នា នៅពេលពួកគេបំពេញប្រយោគទីបី ។ សូមឲ្យសិស្សពិនិត្យមើលចម្លើយរបស់ពួកគេចំពោះប្រយោគទីបួនដោយមើលនៅក្នុង យ៉ាកុប ៥:៥១ ដែលនិយាយថា ម្ចាស់ចំការសម្រេចចិត្តប្រណីដល់ចំការរបស់គាត់ « បន្តិចទៀត » ។

សូមពន្យល់ថា មេរៀនថ្ងៃនេះគ្របដណ្តប់លើចំណែកចុងបញ្ចប់នៃការប្រៀបធៀបនេះ ដែលតំណាងឲ្យថ្ងៃចុងក្រោយ រួមទាំងការស្តារឡើងវិញនៃដំណឹងល្អផងដែរ ។

សូមបង្ហាញថា ម្ចាស់ចំការសម្រេចចិត្តថាសង្គ្រោះចំការនោះ ដោយការបំបៅមែកជាច្រើនទៀត ។ សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗនៅក្នុង យ៉ាកុប ៥:៥២–៥៨ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់ឲ្យរកមើលអ្វីដែលម្ចាស់ចំការបានធ្វើ ដើម្បីបណ្តុះមែក និង ឫសទាំងនោះ ។ (សូមជួយសិស្សឲ្យឃើញថា ម្ចាស់ចំការបំបៅមែកនោះពីដើមធម្មជាតិទៅនឹងដើមដំបូងរបស់វាវិញ —ដើមដែលតំណាងឲ្យវង្សនៃអ៊ីស្រាអែល ។ បន្ទាប់មក គាត់បានបំបៅមែកនានាពីដើមឈើនោះទៅនឹងដើមធម្មជាតិផ្សេងទៀត ។ គាត់ក៏បានកាត់ចោលមែកដែលល្ងីល្ងើបំផុតបោះទៅក្នុងភ្លើង ។ អ្នកអាចប្រើដើមឈើនៅលើក្តារខៀន ដើម្បីបង្ហាញពីការពន្យល់នេះ ។ ឧទាហរណ៍ អ្នកអាចលុបមែកមួយពីដើមមួយ ហើយគូរមែកថ្មីមួយនៅលើដើមមួយទៀត) ។

សូមអញ្ជើញសិស្សម្នាក់អាន យ៉ាកុប ៥:៥៩ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់ និងស្វែងរកអ្វីដែលម្ចាស់ចំការ បានសង្ឃឹមលើសកម្មភាពទាំងនេះថានឹងជួយដល់ឫសដើមឈើនោះ ។

- តើម្ចាស់ចំការបានសង្ឃឹមថា នឹងមានអ្វីកើតឡើងដល់ឫសនោះ ? (គាត់ចង់ឲ្យវា « មានកម្លាំង ») ។

សូមរំឭកសិស្សថា នៅពេលនេះ ដើមឈើទាំងអស់បានដុះផ្លែអាក្រក់ ដែលតំណាងឲ្យពិភពលោកទាំងមូលដែលស្ថិតនៅក្នុងសភាពមួយនៃការក្បត់សាសនា ។ សូមពន្យល់ថា នៅពេលឫសវាមានកម្លាំង មែកផ្សេងៗពេញមួយចំការនឹងផ្លាស់ប្តូរ « ក្រែងមែកល្អ អាចឈ្នះលើមែកអាក្រក់បាន » (យ៉ាកុប ៥:៥៩) ។

សូមប្រាកដថា សិស្សយល់ថា ខគម្ពីរទាំងនេះបង្រៀនថា **ឥទ្ធិពលនៃសេចក្តីសញ្ញារបស់ដំណឹងល្អធ្វើឲ្យក្មួនចៅរបស់ព្រះអរិហន្តស្វគ៌យកឈ្នះលើអំពើបាប និង នាំមកនូវសេចក្តីសុចរិតបាន ។**

- តើសេចក្តីសញ្ញានៃដំណឹងល្អអាចពង្រឹងយើងបានដោយរបៀបណា ? តើសេចក្តីសញ្ញារបស់អ្នកបានមានឥទ្ធិពលទៅលើជីវិតរបស់អ្នកដោយរបៀបណា ? (អ្នកអាចចែកចាយអារម្មណ៍របស់អ្នក និង ថ្លែងទីបន្ទាល់អំពីគោលការណ៍នេះ) ។

យ៉ាកុប ៥:៦១–៧៧

ម្ចាស់ចំការធ្វើការនៅក្នុងចំការជាមួយនឹងអ្នកបម្រើរបស់គាត់

សូមអញ្ជើញសិស្សឲ្យអាន យ៉ាកុប ៥:៦១–៦២ ដោយស្ងាត់ៗ ដោយរកមើលអ្វីដែលម្ចាស់ចំការបានណែនាំអ្នកបម្រើរបស់គាត់ឲ្យធ្វើ និង មូលហេតុដែលគាត់បានសុំឲ្យពួកគេធ្វើវា ។

- អ្នកបម្រើនាពេលដំបូងក្នុងរឿងប្រៀបធៀបនេះ តំណាងឲ្យព្យាការីនៃព្រះអម្ចាស់ ។ តើនរណាអាចត្រូវបានតំណាងឲ្យហ្វូងអ្នកបម្រើនៅក្នុងយ៉ាកុប ៥:៦១ ? (សូមជួយសិស្សឲ្យមើលឃើញថា អ្នកបម្រើទាំងនេះអាចតំណាងឲ្យសមាជិកសាសនាចក្រទាំងអស់ ៖ ព្យាការី និង សាវក អ្នកដឹកនាំទូទៅ និង អ្នកដឹកនាំសាសនាចក្រក្នុងស្រុក អ្នកផ្សព្វផ្សាយសាសនា គ្រូបង្រៀនតាមផ្ទះ គ្រូបង្រៀនសួរសុខទុក្ខ និង នរណាក៏ដោយដែលចូលរួមនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់) ។
- តើអ្វីដែលសំខាន់អំពីពាក្យ *យើង របស់យើង* និង *ពួកយើង* នៅក្នុង យ៉ាកុប ៥:៦១–៦២ ? (ព្រះអម្ចាស់ធ្វើការជាមួយនឹងយើង ។ យើងមិនបានទុកឲ្យធ្វើកិច្ចការរបស់ទ្រង់តែម្នាក់ឯងនោះទេ) ។
- យោងតាម យ៉ាកុប ៥:៦២តើអ្វីដែលពិសេសអំពីពេលដែលអ្នកបម្រើទាំងនេះត្រូវបានហៅឲ្យបម្រើ ? (វាគឺជា « លើកចុងក្រោយបង្អស់ » ដែលម្ចាស់ចំការនឹងកាត់លូសចំការនោះ ។ ព្យាការីបានសំដៅ « លើកចុងក្រោយបង្អស់ » នេះថាជា « គ្រាកាន់កាប់ព្រួតត្រានៃពេលពេញកំណត់ » ។ ឧទាហរណ៍ សូមមើល អេភេសូ ១:១០ និង គ. និង ស. ១២៨:២០) ។

ដើម្បីជួយសិស្សឲ្យឃើញពីរបៀបដែលផ្នែកនៃការប្រៀបធៀបនេះទាក់ទងនឹងពួកគេ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេន អេល. ឡាសិន នៃក្រុមចិតសិបនាក់ ៖

« [ឥឡូវនេះ] គឺជាពេលវេលាដែលព្រះអម្ចាស់ និង អ្នកបម្រើរបស់គាត់នឹងធ្វើការខិតខំធ្វើការខ្លាំងលើកចុងក្រោយដើម្បីនាំសារលិខិតនៃសេចក្តីពិតទៅដល់មនុស្សទាំងអស់នៅលើផែនដី និង អប់រំក្មួនចៅអ៊ីស្រាអែលពីបុរាណដែលបានបាត់បង់អត្តសញ្ញាណពិតរបស់ខ្លួន ។ . . .

« អ្នកបានចុះមកផែនដី នៅពេលគ្រិះបានដាក់ចុះសម្រាប់កិច្ចការដ៏អស្ចារ្យនេះ ។ ដំណឹងល្អត្រូវបានស្តារឡើងវិញសម្រាប់ជំនាន់ចុងក្រោយ ។ សាសនាចក្រត្រូវបានស្តាបនានៅស្ទើរតែគ្រប់ផ្នែកនៃពិភពលោក ។ ឈុតឆាកនេះត្រូវដាក់ឲ្យអនុមត៌សម្រាប់ថ្ងាំងវិនាកដម្មចុងក្រោយបង្អស់ ។ អ្នកនឹងជាអ្នកសម្តែងដ៏សំខាន់ ។ អ្នកគឺជាអ្នកបម្រើនៅក្នុងចំណោមអ្នកបម្រើចុងក្រោយបង្អស់នៅក្នុងចំការនោះ ។ . . . នេះគឺជាការបម្រើដែលអ្នកត្រូវបានជ្រើសរើសឲ្យធ្វើ » (« A Royal Generation »*Ensign*ខែ ឧសភា ឆ្នាំ ១៩៨៣ ទំព័រ ៣៣) ។

- តើវាមានឥទ្ធិពលដល់អ្នកយ៉ាងណាដែរ ដោយដឹងថាអ្នកត្រូវបានហៅឲ្យបម្រើជាមួយនឹងព្រះអម្ចាស់ អំឡុងពេលចុងក្រោយនៃការបម្រើនេះ ?
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់បានធ្វើការជាមួយអ្នក នៅពេលអ្នកបានចូលរួមនៅក្នុងកិច្ចការរបស់ទ្រង់ ?
- តើអ្នកមានឱកាសអ្វីខ្លះដើម្បីបម្រើដល់ព្រះអម្ចាស់ និង ជួយដល់អ្នកដទៃឲ្យនាំមកនូវ « ផ្លែល្អ » ? (សិស្សអាចនិយាយអំពីការហៅឲ្យបម្រើ និង កិច្ចការក្នុងសាសនាចក្ររបស់ពួកគេ ទំនួលខុសត្រូវរបស់ពួកគេដើម្បីជួយដល់សមាជិកគ្រួសារ មិត្តភក្តិ និង អ្នកដទៃឲ្យខិតចូលទៅជិតព្រះអង្គសង្គ្រោះ និង ឱកាសដែលពួកគេនឹងមានដើម្បីបម្រើដល់ព្រះអម្ចាស់ ជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង) ។

សូមសរសេរ *យ៉ាកុប ៥:៧០–៧៥* នៅលើក្តារខៀន ។ សូមណែនាំខគម្ពីរទាំងនេះដោយការពន្យល់ថា វាបង្រៀនអំពីទំនាក់ទំនងដែលព្រះអម្ចាស់មានជាមួយនឹងអ្នកបម្រើរបស់ទ្រង់ ។ ពួកគេក៏បានពិពណ៌នាពីអ្វីដែលព្រះអម្ចាស់ និង អ្នកបម្រើរបស់ទ្រង់អាចសម្រេចបាន តាមរយៈកិច្ចការរបស់ពួកគេរួមគ្នានោះផងដែរ។ សូមអញ្ជើញសិស្សឲ្យអានខគម្ពីរទាំងនេះដោយស្ងាត់ៗ ហើយជ្រើសរើសខគម្ពីរមួយដែលផ្តល់ជាការពិពណ៌នាដែលពួកគេចូលចិត្តអំពីទំនាក់ទំនងរបស់ព្រះអម្ចាស់ជាមួយនឹងអ្នកបម្រើទ្រង់ ។ ក្រោយពីសិស្សមានពេលអានហើយ សូមអញ្ជើញពួកគេពីរបីនាក់ឲ្យនិយាយពីខគម្ពីរដែលពួកគេបានជ្រើសរើស មូលហេតុដែលពួកគេចូលចិត្តវា និង ពីរបៀបដែលវាអាចជួយពួកគេ នៅពេលពួកគេបម្រើដល់ព្រះអម្ចាស់ ។

នៅពេលសិស្សចូលរួមនៅក្នុងសកម្មភាពនេះ សូមប្រាកដថាពួកគេយល់ថា **ព្រះអម្ចាស់សន្យានឹងយើងថាមានសេចក្តីអំណរ នៅពេលយើងធ្វើការជាមួយនឹងទ្រង់ ដើម្បីសម្រេចកិច្ចការរបស់ទ្រង់ ។**ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់អំពី យ៉ាកុប ៥:៧០–៧៥សូមគិតពីការសួរសំណួរខ្លះដូចខាងក្រោម ៖

- តើម្ចាស់ចំការបានសន្យាអ្វីខ្លះ ដល់អ្នកទាំងឡាយណាដែលធ្វើការជាមួយនឹងទ្រង់នោះ ? (សូមមើល យ៉ាកុប ៥:៧១, ៧៥) ។ តើនៅពេលណាដែលអ្នកមានអារម្មណ៍អំណរនៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ ?

- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដែលអ្នកបម្រើបានធ្វើការ « ដោយសមត្ថភាពរបស់ពួកគេ » និង « ដោយអស់ទាំងសេចក្តីព្យាយាម » នោះ ? (សូមមើល យ៉ាកុប ៥:៧២, ៧៤) ។ តើមេរៀនអ្វីដែលអ្នកអាចយកចេញពីឃ្លាទាំងនេះ នៅពេលអ្នកបម្រើដល់ព្រះអម្ចាស់ ?

សូមបញ្ចប់ផ្នែកនៃមេរៀននេះ ដោយការសុំសិស្សឲ្យឆ្លើយតបនឹងសំណួរខាងក្រោមនេះ នៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ (អ្នកអាចសរសេរវានៅលើក្តារខៀន) ៖

- នៅពេលអ្នកគិតពីឱកាសរបស់អ្នកដើម្បីបម្រើដល់ព្រះអម្ចាស់ តើអ្នកនឹងអនុវត្តសេចក្តីពិតទាំងឡាយដែលយើងបានពិភាក្សានៅក្នុង យ៉ាកុប ជំពូក ៥ យ៉ាងដូចម្តេច ?

ក្រោយពីសិស្សបានមានពេលសរសេរគ្រប់គ្រាន់ហើយ អ្នកអាចសុំឲ្យពួកគេម្នាក់ ឬ ពីរនាក់ឡើងអានចម្លើយរបស់ពួកគេដល់សិស្សក្នុងថ្នាក់ ។

យ៉ាកុប ៦

យ៉ាកុបបង្រៀនអំពីសេចក្តីមេត្តាករុណា និង សេចក្តីយុត្តិធម៌នៃព្រះអម្ចាស់ និង អញ្ជើញឲ្យប្រជាជនរបស់គាត់ប្រែចិត្ត

សូមបង្ហាញសង្ខេប ៗអំពី យ៉ាកុប ៦ ដោយការពន្យល់ថាវាមានសេចក្តីសង្ខេបរបស់យ៉ាកុបអំពីសេចក្តីពិតទាំងឡាយដែលមានសារៈសំខាន់មកពីរឿងប្រៀបធៀបអំពីដើមអូលីវស្រុក និង ដើមអូលីវព្រៃ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន យ៉ាកុប ៦:៤–៦ ។ សូមឲ្យសិស្សពាក់កណ្តាលថ្នាក់រកមើលអ្វីដែលយ៉ាកុបចង់ឲ្យប្រជាជនរបស់គាត់រៀនអំពីព្រះអម្ចាស់ ។ (ថាទ្រង់នឹកចាំដល់ប្រជាជនរបស់ទ្រង់ ថាទ្រង់ « បានចូលជាប់នឹង [ពួកគេ] » ហើយថា « ព្រះពាហុនៃសេចក្តីមេត្តាករុណារបស់ទ្រង់លាចេញមករក [ពួកគេ] » ។ អ្នកអាចពន្យល់ថា នៅក្នុងវគ្គនេះពាក្យ *ចូលជាប់* មានន័យថា នៅក្បែរជាប់គ្នានឹងអ្វីមួយ ឬ នរណាម្នាក់) ។ សូមឲ្យសិស្សពាក់កណ្តាលថ្នាក់ទៀតរកមើលអ្វីដែលយ៉ាកុបបានលើកទឹកចិត្តដល់ប្រជាជនរបស់គាត់ឲ្យធ្វើដែលជាលទ្ធផលនៃការដឹងនេះ ។ (កុំឲ្យធ្វើចិត្តគេរឹងរូស ប្រែចិត្ត ចូលមករកព្រះអម្ចាស់ « ដោយអស់ពីដួងចិត្ត » ហើយ « តោងជាប់ទៅនឹងព្រះ ដូចជាទ្រង់ចូលជាប់នឹង [ពួកគេ] ដែរ ») ។ ក្រោយពីសិស្សបានប្រាប់សិស្សផ្សេងទៀតពីអ្វីដែលពួកគេបានរៀនហើយ សូមសួរ ៖

- តើយ៉ាកុបបានពិពណ៌នាពីព្រះអម្ចាស់ដោយរបៀបណា ? តើវាមានន័យយ៉ាងណាដល់អ្នកថា « ព្រះពាហុនៃសេចក្តីមេត្តាករុណារបស់ទ្រង់លាចេញមករកអ្នក » ?
- តើអ្នកបានរៀនអ្វីខ្លះ អំពីព្រះអម្ចាស់ក្នុងរឿងប្រៀបធៀបអំពីដើមអូលីវដែលបានបង្ហាញអំពីរបៀបដែលទ្រង់បានចូលជាប់នឹងអ្នក ? តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីបង្ហាញថាអ្នកនឹងតោងជាប់នឹងព្រះអម្ចាស់នោះ ?

សូមសង្ខេប យ៉ាកុប ៦:៧–១០ ដោយការពន្យល់ថាក្រោយពីយើងត្រូវបាន « ចិញ្ចឹមឲ្យរស់ដោយព្រះបន្ទូលដ៏ល្អនៃព្រះ » នោះយើងមិនត្រូវដួលផ្លែអាក្រក់មកនោះទេ ។ យើងត្រូវធ្វើតាមពាក្យរបស់ព្យាការី ។ ប្រសិនបើយើងមិនព្រមប្រែចិត្តនោះទេ យ៉ាកុបបានព្រមានថា យើងនឹងត្រូវទទួលខុសត្រូវចំពោះអំពើបាបរបស់យើងនៅថ្ងៃជំនុំជម្រះរបស់ព្រះអម្ចាស់ ។ សូមលើកទឹកចិត្តសិស្សឲ្យអាន យ៉ាកុប ៦:១១–១៣ដោយស្ងាត់ស្ងៀម ហើយរកមើលការទូន្មានចុងក្រោយរបស់យ៉ាកុប ។ ក្រោយពីពួកគេបានចែកចាយនូវអ្វីដែលពួកគេបានរកឃើញហើយ សូមសួរ ៖

- ហេតុអ្វីបានជាវាជាការឆ្លាតវៃដើម្បីជ្រើសរើសធ្វើការប្រែចិត្ត ហើយរៀបចំនាពេលឥឡូវនេះដើម្បីឈរនៅចំពោះព្រះភ័ក្ត្រនៃព្រះអម្ចាស់ និង ត្រូវបានកាត់សេចក្តីដោយទ្រង់នោះ ?

សូមបញ្ជាក់ថា យើងគឺជាមនុស្សឆ្លាតវៃ បើយើងរៀបចំពីពេលឥឡូវនេះសម្រាប់ការកាត់សេចក្តីដោយការប្រែចិត្ត និង ការទទួលបានសេចក្តីមេត្តាករុណាពីព្រះអម្ចាស់ ។

ដើម្បីបញ្ចប់មេរៀននេះ សូមបញ្ជាក់ថាការប្រែចិត្ត មិនត្រឹមតែរៀបចំយើងសម្រាប់ការកាត់សេចក្តីនៅថ្ងៃចុងក្រោយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចបម្រើដល់ព្រះអម្ចាស់នាពេលឥឡូវនេះផងដែរ ។ សូមថ្លែងទីបន្ទាល់ដល់សិស្សថា ព្រះអម្ចាស់ចង់ឲ្យពួកគេបម្រើជាមួយនឹងទ្រង់ ហើយស្វែងរកសេចក្តីអំណរជាមួយនឹងទ្រង់ ហើយថាពួកគេអាចបានសំក្តិសមដើម្បីធ្វើដូច្នោះ នៅពេលពួកគេគោរពតាមព្រះបញ្ញត្តិប្រែចិត្ត ហើយទទួលបានសេចក្តីមេត្តាករុណារបស់ទ្រង់ ។

គំនិតបន្ថែមទាំងឡាយសម្រាប់ការបង្រៀន

យ៉ាកុប ៥ ។ បទបង្ហាញជាវីដេអូ

នៅពេលអ្នកបង្រៀនមេរៀនទី ៤៧ អ្នកអាចបង្ហាញពីផ្នែកចុងបញ្ចប់នៃការចាក់វីដេអូនេះបាន « The Olive Tree Allegory » ដែលត្រូវបានរកឃើញនៅក្នុង DVD ដែលមានចំណងជើងថា *Book of Mormon DVD Presentations 1–19* ។អ្នកអាចបង្ហាញផ្នែកនេះអំឡុងពេលវគ្គទីពីរនៃមេរៀននេះ ក្រោយពីរៀនពីសេចក្តីថ្លែងការណ៍ដោយអែលឌើរ ជេន អេល. ឡាសិន ។

យ៉ាកុប ៧

សេចក្តីផ្តើម

យ៉ាកុបបានពឹងផ្អែកទៅលើព្រះអម្ចាស់ និង នៅលើទីបន្ទាល់ដ៏មិនអាចធ្វើឲ្យរង្គោះរង្គើបានរបស់គាត់ដើម្បីយកឈ្នះទៅលើគំនិតខុសឆ្គង និង អំណះអំណាងរបស់សេរេម ជាអ្នកដែលប្រឆាំងនឹងព្រះគ្រីស្ទ ។ គាត់បានទទួលកម្លាំងជាពិសេសមកពីបទពិសោធន៍ពីអតីតកាលដែលបានពង្រឹងសេចក្តីជំនឿរបស់គាត់ទៅលើព្រះយេស៊ូវគ្រីស្ទ ។ គាត់ក៏បានពឹងផ្អែកទៅលើការណែនាំមកពីព្រះវិញ្ញាណបរិសុទ្ធ ចំណេះដឹងរបស់គាត់អំពីព្រះគម្ពីរ និង ពាក្យរបស់ព្យាការី និង ទីបន្ទាល់របស់គាត់អំពីព្រះយេស៊ូវគ្រីស្ទ ។ នៅពេលសេរេមបានទាមទារចង់បានទីសម្គាល់មួយដែលបង្ហាញភស្តុតាងអំពីពាក្យរបស់យ៉ាកុប នោះគាត់ត្រូវបានវាយដោយព្រះ ។ យ៉ាកុបបានបញ្ចប់កំណត់ត្រារបស់គាត់ដោយការពិពណ៌នាអំពីរបៀបដែលសាសន៍នីហ្វៃបានទុកចិត្តទៅលើព្រះអម្ចាស់ នៅពេលពួកគេបានចម្រើនកម្លាំងខ្លួនគេទាស់នឹងពួកសាសន៍លេមិន ។ មុនពេលយ៉ាកុបស្លាប់ គាត់បានបន្តឲ្យផ្នាំងតូចនោះទៅដល់កូនប្រុសរបស់គាត់គឺ អេណុស ។

យោបល់សម្រាប់ការបង្រៀន

យ៉ាកុប ៧:១–១៤

យ៉ាកុបពឹងផ្អែកទៅលើព្រះអម្ចាស់ នៅពេលគាត់ជួបនឹងសេរេម ជាអ្នកប្រឆាំងនឹងព្រះគ្រីស្ទ

មុនពេលចាប់ផ្តើមថ្នាក់ សូមសរសេរនៅលើក្តារខៀននូវសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ រ៉ូបឺតឌី.ហៃល នៃក្រុមនៃពួកសាវកដប់ពីរនាក់ (បានដកស្រង់ពី « Christian Courage: The Price of Discipleship »*Ensign* *ឬលីអាហ្គូណាខែ* **វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៧២) ៖

> ***« ការសោកល្បួងដ៏អស្ចារ្យមួយនៅក្នុងជីវិតរមែងស្លាប់នេះមក នៅពេលសេចក្តីជំនឿរបស់យើងនៅមានមន្ទិល ឬ ការរិះគន់នៅឡើយ » (អែលឌើរ រ៉ូបឺតឌី.ហៃល) ។***

សូមឲ្យសិស្សគិតអំពីគ្រាដែលមាននរណាម្នាក់សង្ស័យ ឬ រិះគន់សេចក្តីជំនឿរបស់ពួកគេ ។ សូមអញ្ជើញពួកគេបីបួននាក់ឲ្យចែកចាយពីរបៀបដែលពួកគេមានអារម្មណ៍ នៅពេលហេតុការណ៍នោះកើតឡើង ។ អ្នកក៏អាចចែកចាយដោយសង្ខេបអំពីបទពិសោធន៍មួយក្នុងជីវិតរបស់អ្នកដែរ ។

សូមពន្យល់ថា យ៉ាកុប ៧ ប្រាប់ពីបទពិសោធន៍របស់យ៉ាកុបជាមួយនឹងសេរេម ជាអ្នកប្រឆាំងនឹងព្រះគ្រីស្ទ ។ (អ្នកអាចពន្យល់ថា អ្នកប្រឆាំងនឹងព្រះគ្រីស្ទម្នាក់គឺជា « នរណាម្នាក់ ឬ អ្វីមួយដែលបន្លំដំណឹងល្អដ៏ពិត ឬ ផែនការសង្គ្រោះ ហើយថាការបើក ឬ ការប្រឆាំងជំទាស់លាក់បាំងទៅនឹងព្រះគ្រីស្ទ » [Bible Dictionary, “Antichrist”]) ។ សេរេមបានទៅរកយ៉ាកុប ដើម្បីផ្តាំផ្ញើលសេចក្តីជំនឿរបស់គាត់ ។

សូមអញ្ជើញសិស្សឲ្យអាន យ៉ាកុប ៧:១–៥ ដោយស្ងាត់ៗ ។ សូមឲ្យពួកគេរក (១) អ្វីដែលសេរេមព្យាយាមធ្វើ និង (២) របៀបដែលគាត់ព្យាយាមសម្រេចគោលដៅរបស់គាត់នោះ ។ ក្រោយពីសិស្សបានអានចប់ហើយ សូមឲ្យពួកគេពិពណ៌នាពីអ្វីដែលពួកគេបានរៀនអំពីសេរេមនោះ ។ អ្នកអាចសួរសំណួរខាងក្រោមខ្លះដើម្បីពង្រីកការពិភាក្សានេះ ៖

- **តើសេរេមមានឥទ្ធិពលអ្វីខ្លះទៅលើប្រជាជននេះ ?**
- **តើអ្នកឃើញអ្វីខ្លះនៅក្នុង យ៉ាកុប ៧:១–៥ ដែលរំពួកអ្នកអំពីពេលដែលអ្នកផ្សេងបានសង្ស័យ ឬ រិះគន់សេចក្តីជំនឿរបស់អ្នក ? (នៅពេលអ្នកពិភាក្សាសំណួរនេះ អ្នកអាចត្រូវជួយសិស្សឲ្យយល់ថា មិនមែនមនុស្សទាំងអស់ដែលសង្ស័យ ឬ រិះគន់សេចក្តីជំនឿរបស់យើងមានចិត្តដូចគ្នានឹងសេរេមនោះទេ ។ ខណៈពេលដែលមនុស្សខ្លះដូចជាសេរេម បានចង់បំផ្លាញសេចក្តីជំនឿដោយចេតនា អ្នកដទៃអាចសង្ស័យពីសេចក្តីជំនឿរបស់យើង ដោយសារពួកគេឆ្ងល់ ឬ ដោយសារពួកគេត្រូវគេប្រាប់ខុសអំពីជំនឿរបស់យើង) ។**
- **ហេតុអ្វីបានជាពេលខ្លះវាពិបាកដើម្បីការពារសេចក្តីជំនឿរបស់យើងទាស់នឹងមនុស្សប្រភេទសេរេមនេះ ?**

សូមចម្លងសេចក្តីយោងនៃព្រះគម្ពីរខាងក្រោម និង សេចក្តីថ្លែងការណ៍នេះដាក់លើក្តារខៀន ។ (ដើម្បីសន្សំពេលវេលា អ្នកអាចថតចម្លងអ្វីៗទាំងអស់នេះដាក់លើក្តារខៀន មុនពេលចាប់ផ្តើមថ្នាក់ ។ អ្នកក៏អាចរៀបចំវាជាក្រដាសចែកឲ្យសិស្សជងដែរ) ។

១. យ៉ាកុប ៧:៥	*ក. ថ្លែងទីបន្ទាល់អំពីព្រះគម្ពីរ និង ពាក្យសម្តីរបស់ព្យាការី ។*
២.យ៉ាកុប ៧:៨	*ខ. ទុកលទ្ធផលនៅក្នុងព្រះហស្តរបស់ព្រះ ។*
៣. យ៉ាកុប ៧:១០–១១	*គ. ទុកចិត្តលើការណែនាំ និង កម្លាំងមកពីព្រះវិញ្ញាណបរិសុទ្ធ ។*
៤. យ៉ាកុប ៧:១២	*ឃ. នឹកចាំពីបទពិសោធន៍កាលពីអតីតកាលដែលបានពង្រឹងសេចក្តីជំនឿរបស់គាត់ ។*
៥. យ៉ាកុប ៧:១៣–១៤	*ង. ចែកចាយទីបន្ទាល់ដែលគាត់បានទទួលតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។*

សូមអញ្ជើញសិស្សឲ្យចែកចាយពីបទពិសោធន៍

នៅពេលសិស្សចែកចាយពីបទពិសោធន៍ដ៏បំផុសទាំងឡាយ វាអញ្ជើញព្រះវិញ្ញាណនៃព្រះអម្ចាស់មកក្នុងថ្នាក់រៀន ។ នៅពេលសិស្សស្តាប់ពីបទពិសោធន៍ និង ទីបន្ទាល់របស់មិត្តភក្តិរបស់ពួកគេ នោះទីបន្ទាល់របស់ពួកគេត្រូវបានពង្រឹង ហើយពួកគេរៀនពីរបៀបថ្មីដើម្បីអនុវត្តគោលការណ៍ដំណឹងល្អនានានៅក្នុងជីវិតរបស់ពួកគេ ។ ជាធម្មតា វាគ្រប់គ្រាន់ដើម្បីមានសិស្សពីម្នាក់ទៅបីនាក់ឲ្យចែកចាយបទពិសោធន៍នេះ ។ សូមចៀសវាងការហៅសិស្សពីរបីនាក់ដដែលឲ្យចែកចាយរាល់ថ្ងៃ សូមព្យាយាមឲ្យគ្រប់គ្នាបានចូលរួម ។

សូមពន្យល់ថា ខគម្ពីរនៅក្នុងបញ្ជីនេះពិពណ៌នាអំពីចម្លើយរបស់យ៉ាកុប នៅពេលសេរេមបានថ្កាញ់ថ្កាលជំនឿរបស់យើង ។ សេចក្តីថ្លែងការណ៍នៅលើខាងស្តាំ តំណាងឲ្យចម្លើយរបស់យ៉ាកុប ប៉ុន្តែវាដាក់មិនតាមលំដាប់ ហើយត្រូវតែផ្គូផ្គងទៅតាមខគម្ពីរដែលស្របគ្នា ។ សូមអញ្ជើញសិស្សបីបួននាក់ឲ្យប្តូរវេនគ្នាអានឮៗពីក្តារ យ៉ាកុប ៧:៥–១៤ ។ នៅពេលពួកគេអាន សូមឲ្យពួកគេឈប់បន្ទាប់ពីអានវគ្គមួយៗដែលសរសេរនៅលើក្តារខៀនចប់ហើយ ។ សូមឲ្យសិស្សផ្គូផ្គងវគ្គនីមួយៗទៅនឹងប្រយោគដែលត្រូវគ្នារបស់វា ។ អ្នកអាចអញ្ជើញសិស្សម្នាក់ឲ្យឡើងមកកាន់ក្តារខៀន ហើយគូសបន្ទាត់ពីខាងសេចក្តីយោងព្រះគម្ពីរ ទៅកាន់ប្រយោគដែលត្រូវគ្នានោះ ។ (ចម្លើយ ៖ ១-ឃ ; ២-គ ; ៣-ក ; ៤-ង ; ៥-ខ) ។

នៅពេលសិស្សបញ្ចប់សកម្មភាពផ្គូផ្គងនេះហើយ សូមសួរ ៖

- តើគោលការណ៍អ្វីដែលអ្នកបានឃើញថា ត្រូវបានបង្រៀននៅក្នុងខគម្ពីរដែលយើងទើបតែបានអាននេះ ?

ប្រសិនបើគ្មាននរណាម្នាក់សួរវាទេ សូមធ្វើប្រាកដថាសិស្សយល់ថា **នៅពេលយើងពឹងផ្អែកទៅលើព្រះអម្ចាស់ នោះយើងអានយកឈ្នះលើឧបសគ្គចំពោះសេចក្តីជំនឿរបស់យើង ។** (អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមពន្យល់ថា ចម្លើយរបស់យ៉ាកុបចំពោះសេរេម ផ្តល់ជាឧទាហរណ៍មួយដល់យើងដើម្បីធ្វើតាម នៅពេលយើងឆ្លើយតបទៅនឹងអ្នកណាដែលសួរ ឬ រិះគន់សេចក្តីជំនឿរបស់យើង ។

សំណួរតាមដានដែលសរសេរនៅខាងក្រោមនេះ ធ្វើឡើងដើម្បីជួយសិស្សឲ្យគិតបានជ្រៅជ្រះជាងនេះអំពីអ្វីដែលយ៉ាកុបបានធ្វើដើម្បីទុកចិត្តទៅលើព្រះអម្ចាស់ ។ ការឆ្លើយទៅនឹងសំណួរទាំងនេះ នឹងផ្តល់ឱកាសឲ្យសិស្សដើម្បីបង្ហាញ និង ថ្លែងទីបន្ទាល់ពីរបៀបដែលសកម្មភាពដូចគ្នានេះបានជួយពួកគេ នៅពេលអ្នកផ្សេងបានថ្កាញ់ថ្កាលសេចក្តីជំនឿរបស់ពួកគេ ។ វាក៏នឹងជួយពួកគេឲ្យរៀនពីរបៀបដើម្បីឆ្លើយតបដោយសមរម្យទៅនឹងឧបសគ្គចំពោះសេចក្តីជំនឿរបស់ពួកគេនាពេលអនាគត ។ ដោយសារមានសំណួរច្រើនទៀតនៅខាងក្រោម ដែលអ្នកមិនអាចមានពេលគ្រប់គ្រាន់ដើម្បីសួរនៅក្នុងថ្នាក់បាន សូមជ្រើសរើសតែសំណួរពីរបីប៉ុណ្ណោះដើម្បីសួរនៅក្នុងការពិភាក្សារបស់អ្នក ។ នៅពេលអ្នកធ្វើដូច្នេះ សូមស្វែងរកការណែនាំពីព្រះវិញ្ញាណបរិសុទ្ធ ហើយចាំពីបទពិសោធន៍ដែលសិស្សបានចែកចាយនៅពេលចាប់ផ្តើមថ្នាក់ដំបូង ។ អ្នកក៏អាចគិតពីការសួរសិស្សអំពីអ្វីដែលសកម្មភាពរបស់យ៉ាកុបណាមួយ ដែលពួកគេចង់ពិភាក្សាបន្ថែមទៀតនោះ ។

សូមសួរសំណួរតាមដាន

នៅពេលអ្នកសួរសំណួរតាមដាន វាផ្តល់ឲ្យសិស្សនូវឱកាសមួយដើម្បីបង្ហាញពីអ្វីដែលពួកគេបានរៀន ពង្រីកការយល់ដឹងរបស់ពួកគេបន្ថែមទៀត ហើយគិតអំពីរបៀបដែលសេចក្តីពិតនៃដំណឹងល្អទាំងឡាយទាក់ទងទៅនឹងជីវិតរបស់ពួកគេ ។ សូមប្រយ័ត្នកុំប្រញាប់អានតាមបញ្ជីសំណួរតាមដានដ៏វែងឡើយ ។ ជាធម្មតា វាប្រសើរជាងដើម្បីសួរពីរបីសំណួរ ហើយឲ្យពេលវេលាសិស្សឆ្លើយតបដោយបានគិតពិចារណានោះ ។

- តើមានអ្វីកើតឡើងដល់យ៉ាកុប នៅក្នុងអតីតកាលដែលធ្វើឲ្យសេចក្តីជំនឿរបស់គាត់មិនអាចរង្គោះរង្គើបាន ? (សូមមើល យ៉ាកុប ៧:៥) ។
- តើអ្វីជាបទពិសោធន៍ខ្លះៗ ដែលបានពង្រឹងដល់សេចក្តីជំនឿរបស់អ្នក ? (អ្នកអាចផ្តល់ពេលដល់សិស្សឲ្យសញ្ជឹងគិតអំពីសំណួរនេះមុនពេលសំឲ្យពួកគេឲ្យឆ្លើយ ។ សូមធានាពួកគេថា ពួកគេមិនចាំបាច់ចែកចាយបទពិសោធន៍ណាដែលថ្កាល់ខ្លួនពេកនោះទេ) ។ តើការនឹកចាំពីបទពិសោធន៍ទាំងនេះ អាចជួយអ្នកនៅពេលនរណាម្នាក់សង្ស័យ ឬ រិះគន់សេចក្តីជំនឿរបស់អ្នកដោយរបៀបណា ?
- តើនៅពេលណាដែលព្រះវិញ្ញាណបរិសុទ្ធបានជួយអ្នកឲ្យឆ្លើយនឹងសំណួរ ឬ ការរិះគន់អំពីសេចក្តីជំនឿរបស់អ្នកនោះ ? (សូមមើល យ៉ាកុប ៧:៨) ។
- តើទម្លាប់ប្រចាំថ្ងៃមួយនៃការសិក្សាព្រះគម្ពីរ និង ពាក្យសម្តីនៃព្យាការីថ្ងៃចុងក្រោយនោះ អាចជួយអ្នកនៅពេលអ្នកផ្សេងសួរ ឬ រិះគន់សេចក្តីជំនឿរបស់អ្នកដោយរបៀបណា ? (សូមមើល យ៉ាកុប ៧:១០–១១ ។)
- តើនៅពេលណាដែលអ្នកបានចែកចាយទីបន្ទាល់របស់អ្នកជាមួយនឹងនរណាម្នាក់ ដែលមានសំណួរ ឬ ការរិះគន់សេចក្តីជំនឿរបស់អ្នកនោះ ? (សូមមើល យ៉ាកុប ៧:១២) ។ តើអ្វីគឺជាលទ្ធផល ?
- នៅពេលសេរេមបានទាមទារអ្វីសម្តាល់មួយ ហេតុអ្វីបានជាវាជាការឆ្លាតវៃចំពោះយ៉ាកុបដែលទុកលទ្ធផលឲ្យនៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ជាជាងការស្វែងរកបង្ហាញភស្តុតាងពីភាពពេញលេញនៃសេចក្តីពិតនៃទីបន្ទាល់ផ្ទាល់គាត់នោះ ? (សូមមើល យ៉ាកុប ៧:១៤) ។ តើវាបានជួយអ្នកឲ្យដឹងថា វាមិនចាំបាច់ចំពោះអ្នកដើម្បីបង្ហាញភស្តុតាងអំពីភាពពេញលេញនៃសេចក្តីពិតនៃទីបន្ទាល់របស់អ្នកទៅដល់អស់អ្នកណាដែលបានថ្កាញ់ថ្កាលសេចក្តីជំនឿរបស់អ្នកដោយរបៀបណា ?

យ៉ាកុប ៧:១៥–២៧

ក្រោយពីសេរេមត្រូវបានវាយឲ្យគេហើយ គាត់បានសារភាពពីអំពើបាបរបស់និង គាត់ ថ្លែងទីបន្ទាល់អំពីសេចក្តីពិត ហើយបន្ទាប់មកក៏បានស្លាប់ទៅ ដោយដឹកនាំក្រុមពួកសាសន៍នីហ្វៃឲ្យត្រឡប់ទៅរកព្រះអម្ចាស់វិញ

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ៉ូបឺតឌី.ហៃល ៖

« រយៈពេលជាច្រើនឆ្នាំមក យើងដឹងថា ឧបសគ្គចំពោះសេចក្តីជំនឿរបស់យើងគឺមិនមែនថ្មីនោះទេ ហើយវាក៏មិនងាយជុតទៅភ្លាមៗដែរ ។ ប៉ុន្តែ *សិស្សពិតរបស់ព្រះគ្រីស្ទ ឃើញពីឱកាសនៅក្នុងចំណោមការប្រឆាំងជំទាស់នោះ ។* . . .

« . . . សំណាងល្អ ព្រះអម្ចាស់ដឹងពីដួងចិត្តនៃអ្នកចោទប្រកាន់យើង និង របៀបដែលយើងអាចឆ្លើយតបទៅកាន់ពួកគេវិញដោយមានប្រសិទ្ធភាពបំផុត ។ *នៅពេលសិស្សដ៏ពិតស្វែងរកការណែនាំមកពីព្រះវិញ្ញាណ នោះពួកគេទទួលបានការបំផុសគំនិតដែលទាក់ទងនឹងរឿងប្រឈមនីមួយៗ ។* ហើយនៅគ្រប់ការប្រឈមនីមួយៗ *សិស្សដ៏ពិតឆ្លើយតបតាមរបៀបដែលអញ្ជើញព្រះវិញ្ញាណនៃព្រះអម្ចាស់* » (« Christian Courage: The Price of Discipleship » ទំព័រ ៧២–៧៣ ; អក្សរព្រួតជាងកសារដើម) ។

- តើអ្នកគិតថា « ឃើញពីឱកាសនៅក្នុងចំណោមការប្រឆាំងជំទាស់នោះ » មានន័យយ៉ាងណាដែរ ? (នៅពេលសិស្សឆ្លើយតបទៅនឹងសំណួរនេះ សូមជួយពួកគេឲ្យយល់ថា អំពើល្អអាចផ្តល់លទ្ធផល នៅពេលយើងឆ្លើយតបទៅនឹងឧបសគ្គរបស់យើងតាមរបៀបផ្សេងៗ ដែលអញ្ជើញព្រះវិញ្ញាណនៃព្រះអម្ចាស់) ។

សូមបែងចែកសិស្សទៅជាដៃគូ ។ សូមឲ្យដៃគូនីមួយៗអាន យ៉ាកុប ៧:១៥–២៣ ដោយរកមើលអ្វីៗដែលល្អដែលជាលទ្ធផលមកពីរឿងប្រឈមរបស់យ៉ាកុបជាមួយនឹងសេរេម ។ ក្រោយពីសិស្សអានចប់ហើយ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យពន្យល់ពីអ្វីដែលពួកគេបានរកឃើញ ។ សូមគិតអំពីការប្រើសំណួរខាងក្រោមខ្លះៗ ដើម្បីជួយសិស្សឲ្យវិភាគខគម្ពីរទាំងនេះ ៖

- តើភស្តុតាងអ្វីដែលអ្នកឃើញថា យ៉ាកុបបានសង្ឃឹមថារឿងប្រឈមរបស់គាត់ជាមួយនឹងសេរេមនឹងជួយដល់អ្នកដទៃនោះ ? (សូមមើល យ៉ាកុប ៧:២២ ។ សូមជួយសិស្សឲ្យយល់ថា យ៉ាកុបបានអធិស្ឋានសម្រាប់ក្រុមមនុស្សសាសន៍នីហ្វៃដែលបានធ្វើជាសាក្សីអំពីការសារភាពរបស់សេរេម និង ការស្លាប់របស់គាត់) ។
- យោងតាម យ៉ាកុប ៧:២៣ តើរឿងប្រឈមរបស់យ៉ាកុបជាមួយនឹងសេរេម ទីបំផុតនឹងមានឥទ្ធិពលលើក្រុមមនុស្សនោះយ៉ាងដូចម្តេចដែរ ?
- តើសេចក្តីពិតអ្វីដែលយើងអាចរៀនពីលទ្ធផលនៃការប្រឈមរបស់យ៉ាកុបជាមួយនឹងសេរេមនេះ ? (សិស្សអាចរកបានចម្លើយជាច្រើនចំពោះសំណួរនេះ ។ អ្នកខ្លះអាចស្មើពីគោលការណ៍ដែលបានសរសេរនៅខាងក្រោមនេះ) ។

  ព្យាការីទាំងអស់ថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ។

  នៅពេលយើងឆ្លើយតបទៅនឹងសំណួរ ឬ ការរិះគន់នានាអំពីសេចក្តីជំនឿរបស់យើងតាមរបៀបដែលអាចអញ្ជើញព្រះវិញ្ញាណ នោះយើងអាចជួយអ្នកដទៃឲ្យបែរទៅរកព្រះអង្គម្ចាស់បាន ។

  ព្យាការីជួយយើងឲ្យស្គាល់ និង យកឈ្នះលើការបោកបញ្ឆោតរបស់សាតាំង ។

  អស់អ្នកដែលបះបោរទាស់នឹងព្រះ ហើយផ្សព្វផ្សាយយ៉ាងសកម្មប្រឆាំងនឹងសេចក្តីពិត នឹងជួបទុរវាសវិបាកយ៉ាងធ្ងន់ធ្ងរមកពីព្រះអម្ចាស់ ។

  ការសិក្សាព្រះគម្ពីរ នឹងជួយយើងឲ្យចៀសវាងពីការត្រូវគេបោកបញ្ឆោតបាន ។

នៅពេលសិស្សរកឃើញគោលការណ៍ដូចជាអ្វីដែលបានសរសេរនៅខាងលើនេះ សូមគិតពីការសួរសំណួរតាមដានដើម្បីជួយពួកគេឲ្យអនុវត្តគោលការណ៍ទាំងនេះនៅក្នុងជីវិតរបស់ពួកគេ ។

- តើការរស់នៅតាមគោលការណ៍នេះ អាចជួយអ្នកដោយរបៀបណា ?
- តើការដឹងពីគោលការណ៍នេះ អាចជួយអ្នកឲ្យជួយអ្នកដទៃដោយរបៀបណា ?
- តើអ្នកអាចអនុវត្តគោលការណ៍នេះនៅក្នុងជីវិតរបស់អ្នកដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យឆ្លើយតបទៅនឹងសំណួរខាងក្រោមនេះ នៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ៖

- តើរឿងមួយដែលអ្នកនឹងចាប់ផ្តើមធ្វើ (ឬ បន្តធ្វើ) ដើម្បីជួយអ្នកឲ្យរៀបចំសម្រាប់ពេលមួយ នៅពេលនរណាម្នាក់ថ្កាញ់ថ្កាលសេចក្តីជំនឿរបស់អ្នកនោះ គឺជាអ្វី ?

សូមចែកចាយទីបន្ទាល់របស់អ្នកថា យើងអាចយកឈ្នះដោយជោគជ័យលើឧបសគ្គចំពោះសេចក្តីជំនឿរបស់យើង នៅពេលយើងធ្វើតាមគំរូរបស់យ៉ាកុបក្នុងការទុកចិត្តលើព្រះអម្ចាស់ ។

ការរំឭកក្នុងគម្ពីរ យ៉ាកុប

សូមយកពេលខ្លះៗជួយសិស្សឲ្យរំឭកពីសៀវភៅយ៉ាកុបនេះ ។ សូមឲ្យពួកគេគិតអំពីអ្វីដែលពួកគេបានរៀនពីសៀវភៅនេះ ទាំងនៅក្នុងថ្នាក់សិក្ខាសាលា និង នៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់ពួកគេ ។ ប្រសិនបើចាំបាច់ សូមអញ្ជើញពួកគេឲ្យមើលត្រួសៗលើជំពូកទាំងប្រាំពីរនៃសៀវភៅយ៉ាកុប ដើម្បីជួយឲ្យពួកគេចងចាំ ។ សូមឲ្យពួកគេរៀបចំចែកចាយអ្វីមួយអំពីយ៉ាកុប ឬ ការសរសេរបស់គាត់ដែលបានធ្វើឲ្យពួកគេចាប់អារម្មណ៍ ។ អ្នកអាចរំឭកពួកគេថា យ៉ាកុបបានកើតនៅក្នុងទីរហោស្ថាន នៅក្នុងដែនដីបរិបូរណ៍ (នៅជិតសមុទ្រក្រហម) ហើយគាត់បានស្លាប់នៅក្នុងដែនដីនីហ្វៃ ។ គាត់ក៏ត្រូវបានប្រទានពរដោយលើហែជងដែរ (សូមមើល នីហ្វៃទី២ ២:១–៤) ហើយគាត់បានឃើញព្រះអង្គសង្គ្រោះ (សូមមើល នីហ្វៃទី២ ១១:៣) ។ បងប្រុសរបស់គាត់ នីហ្វៃ បានបញ្ជូលទេសនកថារបស់គាត់ខ្លះនៅលើផ្ទាំងនីហ្វៃតូច (សូមមើល នីហ្វៃទី២ ៦–១០) ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញសិស្សបីបួននាក់ឲ្យចែកចាយនូវគំនិត និង អារម្មណ៍របស់ពួកគេ ។ សូមគិតពីការចែកចាយទីបន្ទាល់របស់អ្នកអំពីរបៀបដែលគំរូ និង ការបង្រៀនរបស់យ៉ាកុបបានប្រទានពរដល់ជីវិតរបស់អ្នក ។

អំពីអេណុស

ហេតុអ្វីត្រូវសិក្សាអំពីនេះ ?

គម្ពីរអេណុសបង្ហាញពីព្រះចេស្តានៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីលាងសម្អាតមនុស្សពីអំពើបាប និង ធ្វើឲ្យពួកគេពេញលេញ ។ អេណុសតស៊ូនៅចំពោះព្រះ ដោយការអធិស្ឋានដ៏ខ្លាំងក្លា មុនពេលអំពើបាបរបស់គាត់ត្រូវបានអភ័យទោសឲ្យនោះ ។ បន្ទាប់មក គាត់បានអធិស្ឋានសម្រាប់សុខុមាលភាពខាងវិញ្ញាណដល់សាសន៍នីហ្វៃ និង សាសន៍លេមិន ហើយគាត់បានចំណាយពេលនៅសល់ក្នុងជីវិតរបស់គាត់បម្រើសម្រាប់សេចក្តីសង្គ្រោះរបស់ពួកគេ ។ នៅពេលសិស្សសិក្សាគម្ពីរអេណុស ពួកគេអាចកេរឃើញនូវមេរៀនដ៏សំខាន់អំពីការអធិស្ឋាន ការប្រែចិត្ត និង វិវរណៈ ។ ពួកគេក៏អាចដឹងថា នៅពេលបុគ្គលម្នាក់ៗទទួលបានពរជ័យនៃដង្វាយធួន នោះពួកគេនឹងមានបំណងដើម្បីចែកចាយនូវពរជ័យទាំងនោះជាមួយនឹងអ្នកដទៃដែរ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

អេណុស កូនប្រុសរបស់យ៉ាកុប និង ជាចៅប្រុសរបស់លីហៃ និង សារ៉ា បានសរសេរគម្ពីរនេះ ។ អេណុសបានកត់ត្រាថា ឪពុករបស់គាត់បានបង្រៀនគាត់ « តាមដំបូន្មាន និង សេចក្តីដាស់តឿនរបស់ព្រះអម្ចាស់ » (អេណុស ១:១) ។ នៅជិតចុងបញ្ចប់នៃជីវិតរបស់គាត់ អេណុសបានសរសេរថា គាត់បានប្រកាសពី « សេចក្តីពិតដែលមាននៅក្នុងព្រះគ្រីស្ទ » អស់មួយជីវិតរបស់គាត់ (អេណុស ១:២៦) ។ មុនពេលការស្លាប់របស់គាត់ អេណុសបានបន្តផ្នាំងនីហ្វៃតូចទៅឲ្យកូនប្រុសរបស់គាត់ គឺយ៉ារ៉ុម (សូមមើល យ៉ារ៉ុម ១:១) ។ អេណុសបានបញ្ចប់កំណត់ត្រារបស់គាត់ ដោយការនិយាយថា គាត់បានអរីកឈរនៅក្នុងថ្ងៃ នៅពេលដែលគាត់បានឈរនៅចំពោះព្រះភ័ក្ត្រព្រះប្រោសលោះរបស់គាត់ ។ គាត់បានប្រកាសថា « ខណៈនោះ ខ្ញុំនឹងបានឃើញព្រះភក្ត្រទ្រង់ ដោយសេចក្តីសោមនស្ស ហើយព្រះអង្គនឹងមានព្រះបន្ទូលមកខ្ញុំថា ៖ ចូរមករកយើងចុះ អ្នកមានពរហើយ មានទីកន្លែងមួយដែលបានរៀបចំសម្រាប់អ្នកនៅក្នុងវិមានរបស់ព្រះវរបិតាយើង » (អេណុស ១:២៧) ។

តើគម្ពីរនេះត្រូវបានសរសេរសម្រាប់អ្នកណា ហើយហេតុអ្វី ?

នៅពេលអេណុសទទួលបានផ្នាំងតូចពីឪពុករបស់គាត់ គាត់បានសន្យានឹងឆ្លាក់ទុកតែការសរសេរដែលគាត់គិតថាមានតម្លៃបំផុត ដែលរួមមានការបង្រៀនដ៏ពិសិដ្ឋ វិវរណៈ និង ការព្យាករណ៍ (សូមមើល យ៉ាកុប ១:១–៤; ៧:២៧) ។ អេណុសបានដឹងថា ប្រជាជនរបស់គាត់ គឺសាសន៍នីហ្វៃ នឹងត្រូវបំផ្លាញនៅទីបញ្ចប់ ។ គាត់បានអធិស្ឋានថា ព្រះអម្ចាស់នឹងរក្សាបញ្ជីនៃសាសន៍នីហ្វៃមួយ « ដើម្បីវាអាចបានយកចេញមកផ្សាយក្នុងពេលអនាគតដល់ពួកសាសន៍លេមិន ដើម្បីក្រែងពួកគេអាចបាននាំមកឯសេចក្តីសង្គ្រោះ » (អេណុស ១:១៣) ។

តើនៅពេលណា និង នៅកន្លែងណាដែលវាត្រូវបានសរសេរនោះ ?

អេណុសបានបញ្ចប់កំណត់ត្រារបស់គាត់ ដោយការប្រកាសថា ១៧៩ ឆ្នាំបានកន្លងទៅចាប់តាំងពីលីហៃបានចាកចេញពីទីក្រុងយេរូសាឡិម (សូមមើល អេណុស ១:២៥) ។ នោះវាបញ្ជាក់ពីកាលបរិច្ឆេទនៃការសរសេររបស់គាត់ថា រវាងប្រហែលឆ្នាំ ៥៤៤មុន.គ.ស. (នៅពេលយ៉ាកុបបានបញ្ចប់កំណត់ត្រារបស់គាត់) និង ឆ្នាំ ៤២១ មុន.គ.ស. អេណុសបានសរសេរកំណត់ត្រានេះ ពេលកំពុងរស់នៅក្នុងដែនដីនីហ្វៃ ។

តើមានផ្នែកខុសគ្នាអ្វីខ្លះនៅក្នុងគម្ពីរនេះ ?

គម្ពីរអេណុសបង្ហាញពីគំរូមួយដែលបង្ហាញពីរបៀបដែលបុគ្គលអាចទទួលបានពរជ័យនៃដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និង ចែកចាយនូវពរជ័យទាំងនោះជាមួយនឹងអ្នកដទៃ ។ ជំពូងអេណុសត្រូវបានបង្រៀនអំពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល អេណុស ១:១, ៣) ។ បន្ទាប់មក គាត់បានទទួលស្គាល់តម្រូវការរបស់គាត់ចំពោះព្រះអង្គសង្គ្រោះ ហើយបានអធិស្ឋានសម្រាប់ការអភ័យទោស (សូមមើល អេណុស ១:២–៤) ។ បន្ទាប់មកទៀត ក្រោយពីការទទួលបានការផ្តាច់បាបរបស់គាត់ហើយ គាត់បានអធិស្ឋាន និង បានបម្រើដោយឧស្សាហ៍ព្យាយាមដើម្បីនាំអ្នកផ្សេងមកឯសេចក្តីសង្គ្រោះ ។ (សូមមើល អេណុស ១:៥–២៧) ។ គំរូនេះលេចចេញឡើងពាសពេញក្នុងព្រះគម្ពីរមរមន ។ គំរូរួមមាន អាលម៉ា (សូមមើលម៉ូសាយ ១៧:១–២; ១៨:១–២)អាលម៉ាតូច និង កូនប្រុសរបស់ម៉ូសាយ (សូមមើលម៉ូសាយ ២៧–២៨) និង ឡាម៉ូណៃ និង ប្រជាជនរបស់គាត់ (សូមមើលអាលម៉ា ១៨–១៩) ។

លើសពីនេះទៀត គម្ពីរអេណុសគឺជាគម្ពីរដំបូងដែលពិពណ៌នាពីសេចក្តីលម្អិតនៃស្ថានភាពក្បត់សាសនានៃកូនចៅរបស់លេមិន និង លេមយួល (សូមមើល អេណុស ១:២០) ។ វាក៏បានលើកឡើងដៃថាមាន « ព្យាការីជាច្រើនណាស់ » នៅក្នុងចំណោមពួកសាសន៍នីហ្វៃ ទោះបីជាភាគច្រើននៃសាសន៍នីហ្វៃជា « ប្រជាជនរឹងចចេស » ដែលត្រូវដាស់តឿនជាញឹកញយ « ដើម្បីធ្វើឲ្យពួកគេកោតខ្លាចដល់ព្រះអម្ចាស់ » (អេណុស ១:២២–២៣) ។

គម្រោង

អេណុស ១:១–៨ អេណុសអធិស្ឋានសម្រាប់ការផ្តាច់បាបរបស់គាត់ ហើយទទួលបានការអភ័យទោសដោយសារតែសេចក្តីជំនឿរបស់គាត់ទៅលើព្រះយេស៊ូវគ្រីស្ទ ។

អេណុស ១:៩–១៨ អេណុសអធិស្ឋានសម្រាប់ប្រជាជននីហ្វៃ និង ប្រជាជនលេមិន ហើយបានសុំឲ្យព្រះអម្ចាស់រក្សាបញ្ជីនៃសាសន៍នីហ្វៃទុក ។

អេណុស ១:១៩–២៤ អេណុសពិពណ៌នាពីសេចក្តីទុច្ចរិតរបស់ពួកសាសន៍លេមិន និង ភាពចចេសរឹងរូសរបស់ពួកសាសន៍នីហ្វៃ ។ គាត់ និង ព្យាការីផ្សេងទៀតបានធ្វើការយ៉ាងខ្លាប់ខ្ជួនសម្រាប់សេចក្តីសង្គ្រោះរបស់ពួកគេ ។

អេណុស ១:២៥–២៧ អេណុសបញ្ចប់កំណត់ត្រារបស់គាត់ ហើយបានសរសេរអំពីការធានាពីជីវិតដ៏នៅអស់កល្បជានិច្ចដែលគាត់បានទទួលតាមរយៈព្រះប្រោសលោះរបស់គាត់ ។

អេណុស

សេចក្តីផ្តើម

ក្រោយពីបានឆ្លុះបញ្ចាំងពីពាក្យសម្តីរបស់ឪពុកគាត់ អេណុសបានអធិស្ឋាន និង បានទទួលបានការផ្តាច់បានរបស់គាត់ ។ បន្ទាប់មក គាត់បានអធិស្ឋានសម្រាប់សុខុមាលភាពខាងវិញ្ញាណនៃសាសន៍នីហ្វៃ និង សាសន៍លេមិន ហើយបានចំណាយពេលនៃជីវិតរបស់គាត់ធ្វើការបម្រើសម្រាប់សេចក្តីសង្គ្រោះរបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

អេណុស ១:១–៨

ក្រោយពីបានឆ្លុះបញ្ចាំងពីពាក្យសម្តីរបស់ឪពុកគាត់អេណុសបានអធិស្ឋាននិងបានទទួលបានការផ្តាច់បានរបស់គាត់

សូមសរសេរពាក្យ *ព្រលឹងខ្ញុំស្រេកឃ្លាន* នៅលើក្តារខៀន ។ សូមអញ្ជើញសិស្សឲ្យគិតអំពីពេលមួយ ដែលពួកគេមានអារម្មណ៍ថាស្រេកឃ្លានយ៉ាងខ្លាំង ។

- តើពាក្យអ្វីខ្លះដែលអ្នកនឹងប្រើដើម្បីពិពណ៌នាអារម្មណ៍ដែលអ្នកមាន នៅពេលអ្នកស្រេកឃ្លាននោះ ? (សិស្សអាចពិពណ៌នាពីការស្រេកឃ្លានថាជាអារម្មណ៍មួយនៃភាពទទេស្អាត ឈឺចាប់ ទន់ខ្សោយ ឬ មានបំណងចង់បរិភោគឲ្យបាន) ។
- តើមនុស្សម្នាក់អាចមានន័យយ៉ាងណា ដោយនិយាយឃ្លាថា « ព្រលឹងខ្ញុំស្រេកឃ្លាន » ? (អារម្មណ៍នៃភាពទទេស្អាត ការឈឺចាប់ ឬ ភាពទន់ខ្សោយខាងវិញ្ញាណ ឬ បំណងមួយដែលចង់ឆ្អែតខាងវិញ្ញាណ) ។

សូមអញ្ជើញសិស្សឲ្យគិតអំពីពេលមួយ នៅពេលព្រលឹងរបស់ពួកគេបានស្រេកឃ្លាន ។ សូមពន្យល់ថា ថ្ងៃនេះពួកគេនឹងសិក្សាពីបទពិសោធន៍របស់មនុស្សម្នាក់ដែលមានព្រលឹងស្រេកឃ្លាន ។ សូមបង្ហាញរូបភាព អេណុសអធិស្ឋាន (៦២៦០៤ ; *សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ | ទំព័រ ៧២) ។

- តើអ្នកដឹងអ្វីខ្លះ អំពីមនុស្សនៅក្នុងរូបភាពនេះ ? (ប្រសិនបើសិស្សមិនសូវប្រាកដទេ សូមពន្យល់ថា នេះគឺជារូបភាពមួយរបស់អេណុស ដែលជាចៅប្រុសរបស់លីហៃ និង សារ៉ា និង ជាកូនប្រុសរបស់យ៉ាកុប ។ គាត់បានទទួលឆ្នាំងតូច ភ្លាមៗមុនពេលឪពុករបស់គាត់ស្លាប់ | សូមមើល យ៉ាកុប ៧:២៧ |) ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន អេណុស ១:១, ៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពីរបៀប ដែលយ៉ាកុបបានមានឥទ្ធិពលទៅលើអេណុស ។ សូមអញ្ជើញសិស្សពីរបីនាក់ប្រាប់សិស្សក្នុងថ្នាក់ពីអ្វីដែលពួកគេរកឃើញ ។

សូមបង្ហាញពីតារាងខាងក្រោមនៅលើក្តារខៀន ។ (ដើម្បីសន្សំពេលវេលា អ្នកអាចបិទតារាងនោះនៅលើក្តារខៀន មុនពេលចូលរៀន) ។ តារាងនោះធ្វើឡើងដើម្បីជួយក្រុមសិស្សនីមួយៗឲ្យផ្តោតលើសេចក្តីលម្អិតខុសៗគ្នានៃបទពិសោធន៍របស់អេណុស នៅពេលពួកគេសិក្សាក្នុង អេណុស ១:២–៨ ។

អ្វីដែលអេណុសប្រាថ្នា	អ្វីដែលអេណុសធ្វើ	លទ្ធផលនៃអ្វីដែលអេណុសបានធ្វើ
អេណុស ១:២ អេណុស ១:៣	អេណុស ១:២ អេណុស ១:៤ អេណុស ១:៨	អេណុស ១:៥ អេណុស ១:៦ អេណុស ១:៨

សូមពន្យល់ថា នៅពេលអេណុសបានគិតអំពីការបង្រៀនរបស់ឪពុកគាត់ គាត់បានមានបទពិសោធន៍ពីអារម្មណ៍ខាងវិញ្ញាណដែលបាននាំគាត់ឲ្យធ្វើទង្វើរមួយចំនួន ដែលបានផ្តល់ជាលទ្ធផលមួយចំនួនត្រឡប់មកវិញនៅក្នុងជីវិតរបស់គាត់ ។

សូមបំបែកសិស្សក្នុងថ្នាក់ជាបីក្រុម ។ សូមអាន អេណុស ១:២–៨ ឮៗ ។ នៅពេលអ្នកអាន សូមឲ្យក្រុមមួយរកមើលឃ្លាដែលបង្ហាញពីបំណងប្រាថ្នារបស់អេណុស ។ សូមអញ្ជើញក្រុមពីរកមើលអ្វីដែលអេណុសបានធ្វើ ។ សូមឲ្យក្រុមបីរកមើលលទ្ធផលនៃបំណងប្រាថ្នា និង សកម្មភាពរបស់អេណុស ។ (សូមបង្ហាញថា ខគម្ពីរដែលសរសេរនៅលើតារាងរួមមានទង្វើព័ត៌មានដែលទាក់ទងដល់កិច្ចការនៃក្រុមនីមួយៗ) ។

ក្រោយពីអ្នកបានបញ្ចប់ការអាន អេណុស ១:២–៨ ហើយ សូមអញ្ជើញសិស្សនៅក្នុងក្រុមទីមួយឲ្យរាយការណ៍ពីឃ្លាដែលពួកគេបានរកឃើញ ដែលទាក់ទងទៅនឹងបំណងប្រាថ្នារបស់អេណុស ។ នៅពេលសិស្សបានលើកឡើងពីឃ្លាទាំងនេះ សូមឲ្យពួកគេសរសេរឃ្លានេះនៅលើក្តារខៀន ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំឃ្លាទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។ សិស្សអាចលើកឃ្លាមួយចំនួនដូចជា « ការផ្តាច់បាបរបស់ខ្ញុំ » « ជីវិតដ៏នៅអស់កល្បជានិច្ច » និង « សេចក្តីអំណររបស់ពួកបរិសុទ្ធ » ។

ក្រោយពីបំពេញនៅក្នុងកូឡោនទីមួយហើយ សូមអញ្ជើញសិស្សក្នុងថ្នាក់អានត្រួសៗដើមដំបូងនៃ អេណុស ១:៤ ។ សូមឲ្យពួកគេរកមើលអ្វីដែលអេណុសបានជួប ដូចដែលពាក្យសម្តីរបស់ឪពុកគាត់ « អំពីជីវិតដ៏អស់កល្បជានិច្ច និង សេចក្តីអំណរនៃពួកបរិសុទ្ធបានជ្រួតជ្រាបទៅក្នុងដួងចិត្ត | គាត់ | » (អេណុស ១:៣) ។ សិស្សគួរកត់ចំណាំឃ្លា « ហើយព្រលឹងខ្ញុំស្រេកឃ្លាន » ។ (អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំឃ្លានេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។

ការរកសេចក្តីលម្អិតនៅក្នុងវគ្គព្រះគម្ពីរដែលនានា

សិស្សខ្លះមានអារម្មណ៍ថាតានតឹងនៅពេលពួកគេត្រូវបានសុំឲ្យរកមើលសេចក្តីលម្អិតជាច្រើននៅក្នុងវគ្គព្រះគម្ពីរដ៏វែងមួយ ។ ដើម្បីជួយសិស្សទាំងនេះ សូមបែងចែកសិស្សក្នុងថ្នាក់ជាបីបួនក្រុម ។ សូមដឹកនាំក្រុមនីមួយៗឲ្យរកមើលភាពលម្អិតខុសគ្នាមួយនៅក្នុងវគ្គដ៏វែងមួយនេះ ។ នេះអាចជួយសិស្សឲ្យផ្តោតទៅលើគំនិតសំខាន់ នៅពេលពួកគេអាន ។ វាក៏ផ្តល់ឱកាសដល់ពួកគេឲ្យបង្រៀនគ្នាទៅវិញទៅមកអំពីព័ត៌មានលម្អិតសំខាន់នានាដែលពួកគេរកឃើញនៅក្នុងព្រះគម្ពីរ ។

- តើការឆ្លុះបញ្ចាំងអំពីការបង្រៀនរបស់ព្យាការី ទាក់ទងនឹងជីវិតដ៏នៅអស់កល្បជានិច្ច និង សេចក្តីអំណររបស់ពួកបរិសុទ្ធ អាចបណ្តាលឲ្យព្រលឹងរបស់មនុស្សម្នាក់ស្រេកឃ្លានបានដោយរបៀបណា ? (វាអាចជួយមនុស្សម្នាក់ឲ្យមានបំណងចង់មានភាពស័ក្តិសមដើម្បីនៅជាមួយនឹងព្រះអម្ចាស់ និង បំណងចង់បានសុភមង្គលដែលមកពីការរស់នៅតាមដំណឹងល្អ) ។

សូមបង្ហាញថា អេណុសក៏ចង់បានការផ្តាច់បាបរបស់គាត់ដែរ ។ សូមពន្យល់ថាឃ្លា « ព្រលឹងខ្ញុំស្រេកឃ្លាន » អាចបង្ហាញពីអារម្មណ៍មួយនៃភាពទទេស្អាតខាងវិញ្ញាណ ដែលជាលទ្ធផលមកពីអំពើបាប ។ វាក៏អាចបង្ហាញពីការចង់បានខ្លាំងរបស់មនុស្សម្នាក់ ដើម្បីខិតទៅជិតព្រះអម្ចាស់ ហើយរៀនពីទ្រង់ ។

- ហេតុអ្វីបានជាអំពើបាបបណ្តាលឲ្យយើងមានអារម្មណ៍ថាទទេស្អាតខាងវិញ្ញាណ ? (អំពើបាបបណ្តាលឲ្យព្រះវិញ្ញាណបរិសុទ្ធចាកចេញពីយើងទៅ ហើយយើងមានអារម្មណ៍ថាឃ្លាតឆ្ងាយពីព្រះអម្ចាស់) ។

ដើម្បីជួយសិស្សឲ្យភ្ជាប់បទពិសោធន៍របស់អេណុសទៅនឹងបទពិសោធន៍ខ្លួនគេ សូមឲ្យពួកគេគិតដោយស្ងាត់ៗថាតើពួកគេមានអារម្មណ៍ដូចគ្នាខ្លះនៃការស្រេកឃ្លានខាងវិញ្ញាណដែលអេណុសបានពិពណ៌នាដែរឬទេ ។

ដើម្បីជួយសិស្សក្នុងថ្នាក់ឲ្យឃើញពីអ្វីដែលអេណុសបានធ្វើ ដើម្បីបំពេញការស្រេកឃ្លានខាងវិញ្ញាណរបស់គាត់ សូមអញ្ជើញសិស្សក្នុងក្រុមពីរឲ្យរាយការណ៍ពីការរកឃើញរបស់ពួកគេ និង កត់ចម្លើយរបស់ពួកគេដាក់លើក្តារខៀន ។ ចម្លើយគួរមានដូចខាងក្រោមនេះ ៖ « ការពុះពារ . . . ចំពោះព្រះ » , « បានអំពាវនាវដល់ព្រះអង្គដោយការអធិស្ឋានដ៏ខ្លាំង » និង « [អនុវត្ត] សេចក្តីជំនឿទៅលើព្រះគ្រីស្ទ » ។

- តើឃ្លា « ការពុះពារ . . . ចំពោះព្រះ » អាចពិពណ៌នាពីការខិតខំរបស់មនុស្សម្នាក់ដើម្បីទទួលការផ្តាច់បាបដោយរបៀបណា ? (សូមបង្ហាញថា អេណុសមិនបានពុះពារ *ជាមួយ* ព្រះនោះទេ ប៉ុន្តែ *ចំពោះ* ព្រះដោយការអធិស្ឋាន ។ ការពុះពារនេះបង្ហាញពីការតស៊ូរបស់អេណុស ដើម្បីបង្ហាញដល់ព្រះវរបិតាសួគ៌ពីភាពស្មោះសរនៃបំណងប្រាថ្នារបស់គាត់ និង ឆន្ទៈរបស់គាត់ក្នុងការប្រែចិត្ត ដោយការផ្លាស់ប្តូរចាំបាច់នានានៅក្នុងជីវិតរបស់គាត់) ។ ហេតុអ្វីបានជា *ការពុះពារ* ជាពាក្យល្អមួយដើម្បីពិពណ៌នាពីការខិតខំរបស់យើងក្នុងការប្រែចិត្ត ?
- នៅក្នុង អេណុស ១:៤ តើមានភស្តុតាងអ្វីដែលអ្នកបានឃើញថា អេណុសបានស្មោះត្រង់ នៅពេលគាត់ស្វែងរកការផ្តាច់បាបរបស់គាត់នោះ ? (អ្នកអាចត្រូវជួយសិស្សឲ្យយល់ថា *ការខ្វល់អង្វរ* មានន័យថាការសុំដោយបន្ទាបខ្លួន និង ដោយបំណងដ៏ខ្លាំងអស្ចារ្យ) ។
- តើយើងអាចបង្ហាញពីក្តីស្មោះត្រង់របស់យើង នៅពេលយើងស្វែងរកការអភ័យទោសពីព្រះអម្ចាស់ដោយរបៀបណា ? (អ្នកអាចបង្ហាញថា ការអធិស្ឋានរបស់យើងមិនចាំបាច់យូរដូចជាការអធិស្ឋានរបស់អេណុសនោះទេ ប៉ុន្តែវាត្រូវតែមានចិត្តស្មោះស) ។

ដើម្បីជួយសិស្សក្នុងថ្នាក់ឲ្យឃើញពីលទ្ធផលនៃអ្វីដែលអេណុសបានធ្វើនោះ សូមអញ្ជើញសិស្សក្នុងក្រុមបីឲ្យរាយការណ៍ពីការរកឃើញរបស់ពួកគេ ហើយកត់ចម្លើយរបស់ពួកគេដាក់លើក្តារខៀន ។ ចម្លើយគួរមានដូចខាងក្រោមនេះ ៖ « បាបទាំងឡាយរបស់អ្នកត្រូវបានអត់ទោសឲ្យហើយ » « ទោសរបស់ខ្ញុំបានបំបាត់ចោលទៅ » និង « សេចក្តីជំនឿរបស់អ្នកបានជួយសង្គ្រោះអ្នកហើយ » ។ (អ្នកអាចពន្យល់ថា ការបានជួយសង្គ្រោះ មានន័យថាបានព្យាបាល ឬ ធ្វើឲ្យបរិសុទ្ធចេញពីអំពើបាប ។)

- យោងតាម អេណុស ១:៧–៨តើអ្វីដែលធ្វើឲ្យអេណុសត្រូវបានអភ័យទោស ហើយបានសង្គ្រោះនោះ ? (សេចក្តីជំនឿរបស់គាត់ទៅលើព្រះយេស៊ូវគ្រីស្ទ) ។
- តើមេរៀនអ្វីដែលយើងអាចរៀនពីអេណុស អំពីដំណើរការនៃការទទួលបានការអភ័យទោស ចំពោះអំពើបាបរបស់យើងនោះ ? (បន្ថែមលើសេចក្តីពិតផ្សេងទៀត ដែលសិស្សអាចលើកឡើង សូមប្រាកដថាពួកគេយល់ថា **នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ អំពើបាបរបស់យើងអាចត្រូវបានអត់ឱនឲ្យ ហើយយើងអាចបានជួយសង្គ្រោះ ។** ហេតុអ្វីបានជាការអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទចាំបាច់សម្រាប់យើង ដើម្បីទទួលបានពរជ័យទាំងនេះ ? (ព្រះយេស៊ូវគ្រីស្ទបានធ្វើដង្វាយធួនសម្រាប់អំពើបាបរបស់យើង ។ វាមានតែតាមរយៈដង្វាយធួនរបស់ទ្រង់ទេ ដែលយើងអាចត្រូវបានជួយសង្គ្រោះនោះ) ។
- យោងតាម អេណុស ១:៥–៦ តើអេណុសដឹងថា គាត់ត្រូវបានអភ័យទោសឲ្យដោយរបៀបណា ? (អ្នកអាចបង្ហាញថា សំឡេងដែលបានលើកឡើងនៅក្នុង អេណុស ១:៥ គឺជាសំឡេងមួយដែលបានមកដល់ក្នុងគំនិតរបស់អេណុស [សូមមើល អេណុស ១:១០]) ។
- តើអ្នកអាចដឹងថា អ្នកត្រូវបានអភ័យទោសឲ្យចំពោះបាបរបស់អ្នកដោយរបៀបណា ?

នៅផ្នែកនាំការពិភាក្សានៃសំណួរចុងបញ្ចប់ខាងលើ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរអេស.អុជដូហ្វ នៃគណៈប្រធានទីមួយ ៖

« នៅពេលយើងពិតជាបានប្រែចិត្តនោះ ព្រះគ្រីស្ទនឹងដកចេញនូវបន្ទុកនៃទោសដែលជាបាបទាំងឡាយរបស់យើង ។ យើងអាចដឹងដោយខ្លួនឯងថា យើងត្រូវបានអត់ឱនឲ្យ ហើយបានធ្វើឲ្យស្អាត ។ ព្រះវិញ្ញាណបរិសុទ្ធនឹងបញ្ជាក់ពីការណ៍នេះដល់យើង ។ ទ្រង់គឺជាអ្នកញែកឲ្យបរិសុទ្ធ ។ គ្មានទីបន្ទាល់ណាផ្សេងទៀតនៃការអភ័យទោស អាចអស្ចារ្យជាងនេះនោះទេ » (« Point of Safe Return » *Ensign* ឬ*លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ១០១) ។

- ហេតុអ្វីបានជាវាជួយបានច្រើនដើម្បីដឹងថា ព្រះគ្រីស្ទនឹងដកចេញនូវបន្ទុកនៃទោសចំពោះអំពើបាបរបស់យើង ក្រោយពីយើងបានប្រែចិត្តដោយពិតហើយនោះ ?

សូមឲ្យសិស្សសញ្ជឹងគិតដោយស្ងាត់ៗនូវសំណួរខាងក្រោមនេះ ៖

- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់បានអភ័យទោសដល់អំពើបាបរបស់អ្នក ?
- តើអ្នកបានអនុវត្តសេចក្តីជំនឿនៅក្នុងដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?
- តើអ្នកដឹងថា អ្នកត្រូវបានអភ័យទោសដោយរបៀបណា ?
- តើអ្នកធ្លាប់មានអារម្មណ៍ពីការអភ័យទោសរបស់ព្រះអម្ចាស់នាពេលថ្មីៗនេះដែរឬទេ ?

សូមថ្លែងទីបន្ទាល់ថា យើងនឹងត្រូវបានអភ័យទោស នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយពិតជាបានប្រែចិត្តពីអំពើបាបរបស់យើងនោះ ។ ដោយសារតែព្រះអង្គសង្គ្រោះ ទោសរបស់យើងអាចត្រូវបានលាងចេញ ហើយយើងអាចបានសង្គ្រោះ ។

អេណុស ១:៩–២៧

អេណុសបានអធិស្ឋានសម្រាប់សុខុមាលភាពខាងវិញ្ញាណដល់សាសន៍នីហ្វៃ និង សាសន៍លេមិន ហើយគាត់បានធ្វើការដោយឧស្សាហ៍ព្យាយាមសម្រាប់សេចក្តីសង្គ្រោះរបស់ពួកគេ

សូមគូសឌីយ៉ាក្រាមខាងក្រោមនេះដាក់លើក្តារខៀន ។ សូមពន្យល់ថា ក្រោយពីអេណុសបានអធិស្ឋានសម្រាប់ខ្លួនគាត់ហើយ គាត់បានពង្រីកការអធិស្ឋានរបស់គាត់ដើម្បីបញ្ចូលការថ្លែងសម្រាប់សុខុមាលភាពរបស់អ្នកដទៃ ។ សូមចាត់តាំងសិស្សឲ្យធ្វើការជាដៃគូ ។ សូមអញ្ជើញសិស្សក្នុងគូនីមួយៗឲ្យប្តូរវេនគ្នាអានឮៗពីក្នុង អេណុស ១:៩–១៤ ។ សូមឲ្យពួកគេរកមើលក្រុមមនុស្សពីរក្រុមដែលអេណុសបានអធិស្ឋានឲ្យ និង អ្វីដែលគាត់បានអធិស្ឋានសម្រាប់រឿងនីមួយៗ ។ នៅពេលសិស្សរាយការណ៍ពីអ្វីដែលពួកគេរៀន សូមបន្ថែមពាក្យ *សាសន៍នីហ្វៃ* និង *សាសន៍លេមិន* នៅក្នុងកន្លែងសញ្ញាសំណួរនៅក្នុងគំនូរឌីយ៉ាក្រាមនោះ ។



- យោងតាម អេណុស ១:១៤ តើអ្វីគឺជាបំណងរបស់សាសន៍លេមិនចំពោះសាសន៍នីហ្វៃ ?
- តើយើងរៀនអ្វីខ្លះ អំពីអេណុសពីការអធិស្ឋានរបស់គាត់សម្រាប់សាសន៍លេមិន ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហាវីដ ដបុលយូ.ហឺនធើរ ។ សូមឲ្យសិស្សស្តាប់និងរកមើលនូវរបៀបដែលវាទាក់ទងនឹងបទពិសោធន៍របស់អេណុស ៖

« ពេលណាដែលយើងជួបប្រទះនឹងពរជ័យនៃដង្វាយធួននៅក្នុងជីវិតរបស់យើង នោះយើងមិនអាចទប់មិនខ្វាយខ្វល់ដល់សុខុមាលភាពរបស់បងប្អូនយើងនោះទេ ។ . . .

« ទីសម្គាល់ដ៏អស្ចារ្យមួយនៃការប្រែចិត្តជឿជាក់ខ្លួនរបស់មនុស្សម្នាក់ គឺជាបំណងប្រាថ្នាដើម្បីចែកចាយដំណឹងល្អជាមួយនឹងអ្នកផ្សេង » (*The Teachings of Howard W. Hunter,* ed. Clyde J. Williams | ឆ្នាំ ១៩៩៧ | ទំព័រ ២៤៨–៤៩) ។

- តើសេចក្តីថ្លែងការណ៍នេះទាក់ទងនឹងបទពិសោធន៍របស់អេណុសដោយរបៀបណា ? (អេណុសបានបង្ហាញថា **នៅពេលយើងជួបនឹងពរជ័យនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងចង់ជួយអ្នកដទៃឲ្យទទួលបានសេចក្តីសង្គ្រោះ** ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។)

សូមឲ្យសិស្សសិក្សា អេណុស ១:១២, ១៥–២០ ដោយស្ងាត់ៗ ដោយស្វែងរកអ្វីដែលអេណុសបានបង្ហាញអំពីទំនាក់ទំនងរវាងការអធិស្ឋាន សេចក្តីជំនឿ និង សេចក្តីឧស្សាហ៍ព្យាយាម ។

- តើអ្នកគិតថា ការអធិស្ឋានដោយសេចក្តីជំនឿមានន័យយ៉ាងណា ?
- យោងតាម អេណុស ១:១២, ១៩–២០ តើអេណុសបានបង្ហាញពីសេចក្តីឧស្សាហ៍អំឡុងពេល និង ក្រោយពេលការអធិស្ឋានរបស់គាត់ដោយរបៀបណា ?
- តើយើងអាចរៀនអ្វីខ្លះ អំពីការអធិស្ឋានចេញពីគំរូរបស់អេណុស ? (សិស្សគួរតែអាចឃើញថា **ព្រះអម្ចាស់ឆ្លើយតបនឹងការអធិស្ឋានរបស់យើង ស្របតាមសេចក្តីជំនឿរបស់យើង និង សេចក្តីឧស្សាហ៍ព្យាយាមយើង**) ។

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលពួកគេអាចធ្វើតាមគំរូរបស់អេណុស សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមនៅលើក្តារខៀន ឬ ផ្តល់ជាក្រដាសចែកដល់ពួកគេ ។ សូមអញ្ជើញសិស្សឲ្យជ្រើសរើសប្រយោគមួយ ហើយឆ្លើយនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។

១ ដូចជាអេណុសដែរ ខ្ញុំចង់ទទួលបានការលាងបាបខ្ញុំ ។ ខ្ញុំនឹងបង្ហាញដល់ព្រះអម្ចាស់ថា ខ្ញុំស្មោះសនៅក្នុងបំណងប្រាថ្នានេះដោយ . . .

២ ដូចជាអេណុសដែរ ខ្ញុំចង់ជួយសមាជិកគ្រួសារ និង មិត្តភក្តិរបស់ខ្ញុំឲ្យមករកព្រះគ្រីស្ទ ។ មនុស្សម្នាក់ដែលខ្ញុំនឹងជួយគឺ . . . ខ្ញុំនឹងស្វែងរកជួយមនុស្សនេះដោយ . . .

៣ អេណុសបានអធិស្ឋានសម្រាប់សាសន៍លេមិន ដែលត្រូវចាត់ទុកថាជាសត្រូវរបស់គាត់ ។ ដូចជាអេណុសដែរ ខ្ញុំចង់បង្ហាញសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ទៅដល់អ្នកទាំងឡាយណាដែលមិនមានសណ្តានចិត្តចំពោះខ្ញុំ ។ របៀបមួយដែលខ្ញុំនឹងធ្វើការណ៍នេះគឺ . . .

ក្រោយពីសិស្សបានបញ្ចប់ការសរសេរហើយ សូមឲ្យសិស្សម្នាក់អាន អេណុស ១:២៦–២៧ ។ សូមអញ្ជើញសិស្សក្នុងថ្នាក់រកមើលភស្តុតាងនៃសេចក្តីអំណរ ដែលអេណុសបានជួបដោយសារតែការខិតខំរបស់គាត់នោះ ។ ក្រោយពីសិស្សបានរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញហើយ សូមលើកទឹកចិត្តពួកគេឲ្យសម្រេចនូវអ្វីដែលពួកគេបានសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។ សូមថ្លែងទីបន្ទាល់ថា នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចទទួលបានការអភ័យទោស និង សេចក្តីអំណរ ហើយបំណងរបស់យើងក្នុងការជួយដល់អ្នកដទៃឲ្យមករកព្រះគ្រីស្ទ នឹងកើនឡើង ។

សេចក្តីផ្តើមអំពី

គម្ពីរយ៉ារ៉ុម

ហេតុអ្វីបានជាត្រូវសិក្សាគម្ពីរនេះ ?

នៅពេលសិស្សសិក្សាសៀវភៅយ៉ារ៉ុម ពួកគេនឹងយើញថា ព្រះបានរក្សាសេចក្តីសន្យារបស់ទ្រង់ក្នុងការប្រទានពរដល់អ្នកទាំងឡាយណាដែលកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ ។ ពួកគេក៏នឹងរៀនអំពីការខិតខំរបស់ស្តេច ព្យាការី គ្រូបង្រៀន និង ពួកសង្ឃសាសន៍នីហ្វៃនៃជំនាន់របស់យ៉ារ៉ុម ដើម្បីជួយប្រជាជនឲ្យប្រែចិត្ត និង ចៀសវាងការបំផ្លាញ ។

តើនរណាបានសរសេរគម្ពីរនេះឡើង ?

កូនប្រុសរបស់អេណុស គឺយ៉ារ៉ុម បានសរសេរគម្ពីរនេះ ។ ដូចជាឪពុករបស់គាត់ —និង ដូចជាជីតារបស់គាត់គឺ យ៉ាកុប និង ជីតាទួតរបស់គាត់គឺលោក លីហៃ ដែរ —យ៉ារ៉ុមបានមានវិញ្ញាណនៃការព្យាករណ៍ និង វិវរណៈ (សូមមើល យ៉ារ៉ុម ១:២) ។ នៅពេលគាត់បានបញ្ចប់កំណត់ត្រារបស់គាត់ គាត់បានប្រគល់ផ្ទាំងនោះទៅដល់កូនប្រុសរបស់គាត់ អោមណៃ ។

តើគម្ពីរនេះត្រូវបានសរសេរទៅដល់អ្នកណា ហើយហេតុអ្វី ?

យ៉ារ៉ុមបាននិយាយថា គាត់បានសរសេរ « ស្របតាមបញ្ជាពីឪពុក [គាត់] គឺអេណុស ដើម្បីឲ្យពង្សាវតារ [របស់ពួកគេ] អាចបានកត់ទុក » (យ៉ារ៉ុម ១:១) ។ គាត់ក៏បានបង្ហាញថា កំណត់ត្រារបស់គាត់ « ត្រូវបានសរសេរកត់ត្រាទុក . . . ដើម្បីជាប្រយោជន៍ដល់បងប្អូន គាត់ គឺពួកសាសន៍លេមិន » (យ៉ារ៉ុម ១:២ ; សូមមើលផងដែរ អេណុស ១:១៣–១៨) ។ យ៉ារ៉ុមមិនបានកត់ត្រាការព្យាករណ៍ និង វិវរណៈផ្ទាល់ខ្លួនរបស់គាត់នោះទេ ដោយសារគាត់ជឿថាអ្វីដែលបានសរសេរដោយអយ្យកោរបស់គាត់គឺល្មមគ្រប់គ្រាន់ « ដើម្បីបើកសម្តែងប្រាប់នូវផែនការនៃសេចក្តីសង្គ្រោះ » ហើយ (យ៉ារ៉ុម ១:២) ។ ផ្ទុយទៅវិញ គាត់បានពិពណ៌នាពីការងាររបស់ពួកអ្នកដឹកនាំសាសន៍នីហ្វៃ អំឡុងពេលនៃការបម្រើរបស់គាត់ ។ អ្នកដឹកនាំទាំងនេះ « សុទ្ធតែជាមនុស្សខ្លាំងពូកែ ដែលមានសេចក្តីជំនឿជឿដល់ព្រះអម្ចាស់ » (យ៉ារ៉ុម ១:៧) ដែលបានបន្តសុំឲ្យប្រជាជនប្រែចិត្ត និង កាន់តាមព្រះបញ្ញត្តិ (សូមមើល យ៉ារ៉ុម ១:៣–៥, ១០–១២) ។ យ៉ារ៉ុមបានសង្កេតឃើញថា នៅពេលមនុស្សជ្រើសរើសដើម្បីធ្វើតាមការទូន្មានរបស់អ្នកដឹកនាំដ៏សុចរិតរបស់ពួកគេ ពួកគេបានរីកចម្រើន ហើយអាចលើកកម្លាំងខ្លួនគេទាស់នឹងសាសន៍លេមិនបាន ។ គាត់បានថ្លែងទីបន្ទាល់ថា « ព្រះបន្ទូលនៃព្រះអម្ចាស់ត្រូវបានបញ្ជាក់នូវអ្វីដែលទ្រង់មានព្រះបន្ទូលទៅកាន់ពួកអយ្យកោយើងពីមុនថា ៖ ដរាបណាអ្នករាល់គ្នាកាន់តាមបញ្ញត្តិទាំងឡាយរបស់យើង នោះអ្នករាល់នឹងបានចម្រើនឡើងនៅលើដែនដី » (យ៉ារ៉ុម ១:៩; សូមមើលផងដែរ នីហ្វៃទី១ ២:១៩–២០) ។

តើនៅពេលណា និង នៅកន្លែងណាដែលវាត្រូវបានសរសេរនោះ ?

គម្ពីរយ៉ារ៉ុមគ្របដណ្តប់ប្រហែល ៥៩ ឆ្នាំ ប្រហែលពីឆ្នាំ ៤២០ ម. គ. ស. ដល់ ឆ្នាំ ៣៦១ ម. គ. ស. (សូមមើល អេណុស ១:២៥; យ៉ារ៉ុម ១:១៣) ។ វាត្រូវបានសរសេរនៅក្នុងដែនដីនីហ្វៃ ។

តើមានផ្នែកខុសគ្នាអ្វីខ្លះនៅក្នុងគម្ពីរនេះ ?

គម្ពីរយ៉ារ៉ុម គឺជាគម្ពីរដ៏ខ្លីបំផុតនៅក្នុងព្រះគម្ពីរមរមន ។ គម្ពីរនេះផ្តល់សេចក្តីលម្អិតអំពីការរីកចម្រើននៃអារ្យធម៌សាសន៍នីហ្វៃ ដោយនិយាយថាពួកគេបាន « កើនចំនួនជាច្រើន ហើយបានរាលពាសពេញលើផ្ទៃដែនដី » (យ៉ារ៉ុម ១:៨) ។ ពួកគេក៏បានក្លាយទៅជាអ្នកមានធនធានដ៏លើសលប់ ហើយបានមានជំនាញធ្វើការខាងវិស័យឈើក្បាច់ និង ដែក ការសាងសង់អគារ ប៊ុនប្រសប់ផ្នែកខាងគ្រឿងម៉ាស៊ីន និង ធ្វើឧបករណ៍ ព្រមទាំងគ្រឿងសាស្ត្រាវុធគ្រប់យ៉ាង (សូមមើល យ៉ារ៉ុម ១:៨) ។

គម្រោង

យ៉ារ៉ុម ១:១–២ យ៉ារ៉ុមទទួលបានផ្ទាំងមាស និង បានពន្យល់ពីគោលបំណងរបស់គាត់ក្នុងការសរសេរនេះ ។

យ៉ារ៉ុម ១:៣–១២ យ៉ារ៉ុមកត់ត្រាការបំពេញសេចក្តីសន្យារបស់ព្រះអម្ចាស់ក្នុងការប្រទានពរ និង ចម្រើនសាសន៍នីហ្វៃឡើង នៅពេលពួកគេបានរក្សាព្រះបញ្ញត្តិរបស់ទ្រង់ ។ គាត់បានថ្លែងទីបន្ទាល់អំពីព្រះចេស្តានៃព្រះអង្គសង្គ្រោះដើម្បីសង្គ្រោះមនុស្សចេញពីអំពើបាបតាំងពីមុនការបម្រើរបស់ទ្រង់ខាងសាច់ឈាមទៅទៀតដែលអនុញ្ញាតឲ្យមនុស្ស « ជឿដល់ទ្រង់ . . . ហាក់ដូចជាទ្រង់បានយាងមករួចហើយដូច្នោះ » (យ៉ារ៉ុម ១:១១) ។

យ៉ារ៉ុម ១:១៣–១៥ យ៉ារ៉ុមបាននិយាយថា ដំណើររឿងនៃសង្គ្រាមរវាងសាសន៍នីហ្វៃ និង សាសន៍លេមិនត្រូវបានសរសេរនៅលើផ្ទាំងធំរបស់នីហ្វៃ ។ គាត់បានបន្តប្រគល់ផ្ទាំងតូចទៅឲ្យកូនប្រុសរបស់គាត់ អោមណៃ ។

សេចក្តីផ្តើមអំពី

គម្ពីរអោមណៃ

ហេតុអ្វីបានជាត្រូវសិក្សាគម្ពីរនេះ ?

តាមរយៈការសិក្សារបស់ពួកគេអំពីគម្ពីរអោមណៃ សិស្សនឹងដឹងថា ព្រះអម្ចាស់បានការពារសាសន៍នីហ្វៃដែលសុចរិត និងបានដឹកនាំពួកគេឲ្យទៅដល់ដែនដីសាវ៉ាហិមឡា (សូមមើល អោមណៃ ១:៧, ១២–១៣) ។ ពួកគេក៏នឹងដឹងអំពីក្រុមផ្សេងទៀត —សាសន៍មូលេក (ឬ ប្រជាជនសាវ៉ាហិមឡា) និងសាសន៍យ៉ារេឌ— ដែលព្រះអម្ចាស់បានដឹកនាំទៅដល់ដែនដីសន្យា ។

តើនរណាបានសរសេរគម្ពីរនេះ ?

គម្ពីរអោមណៃត្រូវបានសរសេរដោយបុរសប្រាំនាក់ខុសគ្នា ៖ អោមណៃ អ័ម៉ារុន កេមីស អ័ប៊ីណាដុម និង អាម៉ាលេកៃ ។ អោមណៃគឺជាកូនប្រុសរបស់យ៉ារ៉ុម និង ជាចៅលួតប្រុសម្នាក់របស់លីហៃ និង សារ៉ា ។ គាត់បានពិពណ៌នាខ្លួនគាត់ផ្ទាល់ថាជា « មនុស្សទុច្ចរិត » ម្នាក់ដែល « ពុំបានកាន់តាម . . . ព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់ » (អោមណៃ ១:២) ។ អ័ម៉ារុន (កូនប្រុសរបស់អោមណៃ) កេមីស (ប្អូនប្រុសរបស់អ័ម៉ារុន) និង អ័ប៊ីណាដុម (កូនប្រុសរបស់កេមីស) ម្នាក់ៗបានកត់បន្ថែមបន្តិចបន្តួចលើផ្ទាំងនោះ ។ កូនប្រុសរបស់អ័ប៊ីណាដុម គឺអាម៉ាលេកៃ បានសរសេរគម្ពីរអោមណៃភាគច្រើន និង ជាមនុស្សចុងក្រោយគេដែលបានសរសេរនៅលើផ្ទាំងនីហ្វៃតូចនេះ ។ គាត់បានប្រគល់បន្តផ្ទាំងនេះទៅដល់ស្តេចបេនយ៉ាមីន ។

តើគម្ពីរនេះត្រូវសរសេរទៅដល់អ្នកណា និងហេតុអ្វី ?

អោមណៃបាននិយាយថា គាត់ត្រូវបាន « បញ្ជាពីឪពុក [គាត់] គឺយ៉ារ៉ុម ថា [គាត់] ត្រូវសរសេរ . . . ដើម្បីរក្សាពង្សាវតារ [របស់ពួកគេ] ទុកឲ្យបានគង់វង្ស » (អោមណៃ ១:១) ។ ប្រយោគនេះស្នើថា អោមណៃបានសរសេរដើម្បីជាប្រយោជន៍ដល់កូនចៅរបស់គាត់ ។ អ្នកនិពន្ធបីនាក់បន្ទាប់មកទៀតនៅក្នុងគម្ពីរអោមណៃនោះ មិនបាននិយាយពីអ្នកអានជាក់លាក់ណាមួយ ឬ និយាយពីគោលបំណងនៃការសរសេររបស់គេនោះទេ ។ ប៉ុន្តែការអញ្ជើញរបស់អាម៉ាលេកៃសម្រាប់មនុស្សទាំងអស់ឲ្យ « ចូរមករកព្រះគ្រីស្ទ . . . ហើយទទួលទាននូវសេចក្តីសង្គ្រោះរបស់ទ្រង់ » (អោមណៃ ១:២៦) បង្ហាញថា គាត់បានព្រួយបារម្ភអំពីសេចក្តីសង្គ្រោះរបស់អ្នកទាំងឡាយណាដែលបានអានពាក្យរបស់គាត់ ។

តើនៅពេលណា និង នៅកន្លែងណាដែលគេសរសេរគម្ពីរនេះ ?

អ្នកនិពន្ធផ្សេងៗគ្នានៃគម្ពីរអោមណៃនេះ ពេលខ្លះបានសរសេរនៅចន្លោះឆ្នាំ ៣៦១ ម. គ. ស. និង ឆ្នាំ ១៣០ ម. គ. ស. ។ អ្នកនិពន្ធបួននាក់ចុងបង្អស់ បានសរសេរនៅក្នុងដែនដីនីហ្វៃ ។ អាម៉ាលេកៃបានសរសេរបញ្ជីរបស់គាត់ នៅក្នុងដែនដីសាវ៉ាហិមឡា ។

តើមានផ្នែកខុសគ្នាអ្វីខ្លះនៅក្នុងគម្ពីរនេះ ?

សៀវភៅអោមណៃ គឺជាគម្ពីរចុងក្រោយគេនៃផ្ទាំងតូចរបស់នីហ្វៃ ។ អោមណៃបានចំណាយពេលយូរជាងគម្ពីរផ្សេងៗទៀតនៅក្នុងផ្ទាំងតូចនេះ ។ នៅក្នុងព្រះគម្ពីរមរមនទាំងមូល មានតែគម្ពីរ នីហ្វៃទី ៤ និង អេធើរប៊ុណ្ណោះដែលមានរយៈពេលយូរជាងរយៈពេលសរសេរគម្ពីរអោមណៃ ។

គម្ពីរអោមណៃក៏ផ្តល់ព័ត៌មានលម្អិតស្តីពីរជ្ជកាលស្តេចម៉ូសាយទីមួយ ដែលជាបិតារបស់ស្តេចបេនយ៉ាមីន និង ជាជីតារបស់ស្តេចម៉ូសាយទីពីរផងដែរ ។ ស្តេចម៉ូសាយទីមួយបានដឹកនាំសាសន៍នីហ្វៃសុចរិត ចេញពីដែនដីនីហ្វៃ ហើយបានបង្រួបបង្រួមពួកគេជាមួយនឹងប្រជាជនសាវ៉ាហិមឡា (សូមមើល អោមណៃ ១:១២–២៣) ។ គម្ពីរអោមណៃបង្ហាញថា ព្រះអម្ចាស់បានដឹកនាំប្រជាជនសាវ៉ាហិមឡា (ក៏ត្រូវស្គាល់ថាជាប្រជាជនម៉ូលេក) ចេញមកពីទីក្រុងយេរូសាឡិមទៅកាន់ដែនដីសន្យា ក្រោយពីលីហៃ និង គ្រួសាររបស់គាត់បានចាកចេញពីទីក្រុងយេរូសាឡិមមិនយូរប៉ុន្មាន (សូមមើល អោមណៃ ១:១៥) ។

អោមណៃគឺជាគម្ពីរទីមួយនៅក្នុងព្រះគម្ពីរមរមន ដែលបានលើកឡើងពីសាសន៍យ៉ារេឌ ។ វាក៏បានលើកឡើងផងដែរថា មានសាសន៍នីហ្វៃមួយចំនួនបានចាកចេញពីដែនដីសាវ៉ាហិមឡាដើម្បីត្រឡប់ទៅដែនដីនីហ្វៃវិញ ដោយបានប្រាប់ទុកជាមុននូវព្រឹត្តិការណ៍ដែលបានរៀបរាប់នៅក្នុង ម៉ូសាយ ៧–២៤ ។ នៅចុងបញ្ចប់ គម្ពីរអោមណៃបានណែនាំឲ្យស្គាល់ពីស្តេចបេនយ៉ាមីន ហើយបានពន្យល់ពីមូលហេតុដែលអាម៉ាលេកៃបានទុកបញ្ជីជ័ពិសិដ្ឋនៅនឹងទ្រង់ (សូមមើល អោមណៃ ១:២៥) ។

គម្រោង

អោមណៃ ១:១–៣ អោមណៃបានពិពណ៌នាពីគ្រានៃសេចក្តីសុខសាន្ត និង សង្គ្រាមរវាងសាសន៍នីហ្វៃ និងសាសន៍លេមិន ។

អោមណៃ ១:៤–១១ អ័ម៉ារុន កេមីស និង អ័ប៊ីណាដុម សរសេរនៅលើផ្ទាំងតូចរបស់នីហ្វៃ ។ នៅពេលនេះ សាសន៍នីហ្វៃស្ថិតនៅក្នុងស្ថានភាពក្បត់សាសនាមួយ ។

អោមណៃ ១:១២–៣០ អាម៉ាលេកៃកត់ត្រាព្រឹត្តិការណ៍សំខាន់ៗដែលបានកើតឡើង នៅក្នុងរជ្ជកាលនៃស្តេចម៉ូសាយ និង ស្តេចបេនយ៉ាមីន ។ គាត់អញ្ជើញមនុស្សទាំងអស់ឲ្យមករកព្រះគ្រីស្ទ ។



យ៉ារ៉ុម និង អោមណៃ

សេចក្តីផ្តើម

គម្ពីរយ៉ារ៉ុម និង អោមណៃ មាននូវការសរសេរចុងក្រោយនៅក្នុងផ្នាំងតូចរបស់នីហ្វៃ ។ យ៉ារ៉ុមបានទទួលផ្នាំងនោះពីឪពុករបស់គាត់ អេណុស ហើយបានកត់ត្រានូវការលំបាក និង ពរជ័យរបស់សាសន៍នីហ្វៃ និង ពរជ័យនៅក្នុងរយៈពេលប្រហែលជា ៦០ ឆ្នាំ ។ បន្ទាប់មក គាត់បានប្រគល់បន្តផ្នាំងនេះឲ្យទៅកូនប្រុសរបស់គាត់ឈ្មោះ អោមណៃ ។ គម្ពីរអោមណៃ រួមមានការសរសេររបស់អ្នករក្សាបញ្ជីសាសន៍នីហ្វៃជ្រាំនាក់ខុសៗគ្នា ហើយមានរយៈពេលប្រហែលជា ២៣០ ឆ្នាំ ។ អាម៉ាលេកៃ ជាអ្នកសរសេរចុងក្រោយគេនៅក្នុងគម្ពីរអោមណៃ បានបញ្ចប់ការកត់ត្រារបស់គាត់ដោយការអញ្ជើញមួយឲ្យ « មករកព្រះគ្រីស្ទ . . . ហើយថ្វាយព្រលឹងអ្នកទាំងមូល ជាដង្វាយថ្វាយដល់ទ្រង់ » (អោមណៃ ១:២៦) ។

យោបល់សម្រាប់ការបង្រៀន

យ៉ារ៉ុម ១:១–១៥

យ៉ារ៉ុមពិពណ៌នាពីរបៀបដែលសាសន៍នីហ្វៃបានចម្រើនឡើង នៅពេលពួកគេកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះអម្ចាស់

សូមអានសេចក្តីថ្លែងការណ៍ដូចខាងក្រោមនេះរបស់ប្រធាន ខៀថើរ អេស អុជដូហ្វ នៃគណៈប្រធានទីមួយ ។ ប្រសិនបើអាចធ្វើបាន សូមបង្ហាញរូបភាពរបស់ប្រធាន ខៀថើរ អេស អុជដូហ្វ នៅពេលអ្នកអាន ៖

« ខ្ញុំនៅចាំពេលដែលខ្ញុំបានរៀបចំខ្លួនដើម្បីទទួលការហ្វឹកហ្វឺនជាអ្នកបើកបរយន្តហោះចម្បាំង ។ យើងបានចំណាយពេលយ៉ាងច្រើនសម្រាប់ការហ្វឹកហ្វឺនដ៏បង្ករបស់យើងខាងយោធានៅក្នុងការហាត់ប្រាណ ។ ខ្ញុំនៅតែមិនច្បាស់ថា ហេតុអ្វីបានជាការត់មិនចេះចប់មិនចេះហើយត្រូវបានចាត់ទុកថា ជាផ្នែករៀបចំខ្លួនមួយដ៏សំខាន់ក្នុងការក្លាយជាអ្នកបើកបរយន្តហោះឡើយ ។ ទោះយ៉ាងណាក្តី យើងនៅតែរត់ ហើយរត់ទៀត ។

« នៅពេលខ្ញុំកំពុងរត់ ខ្ញុំចាប់ផ្តើមសម្គាល់ឃើញនូវអ្វីដែលធ្វើឲ្យខ្ញុំមិនសុខក្នុងចិត្ត ។ ម្តងហើយម្តងទៀត ខ្ញុំត្រូវបានរត់វ៉ាដោយមនុស្សដែលជក់បារី ផឹកស្រា និង បានធ្វើរឿងគ្រប់យ៉ាងដែលផ្ទុយពីដំណឹងល្អ ហើយជាពិសេសចំពោះពាក្យគតិបណ្ឌិត ។

« ខ្ញុំនៅចងចាំបានពីគំនិតថា ‹ ចាំបន្តិច ! តើខ្ញុំគួរតែអាចរត់ និង មិនបារម្ភមែនទេឬ ? ប៉ុន្តែខ្ញុំ*បាន*បារម្ភ ហើយខ្ញុំត្រូវបានរត់វ៉ា ដោយមនុស្សដែលមិនគោរពតាមពាក្យគតិបណ្ឌិតយ៉ាងពិតប្រាកដ ។ ខ្ញុំសារភាពថា វាពិតជាបានធ្វើឲ្យចិត្តខ្ញុំនៅមិនស្ងប់សុខឡើយនៅពេលនោះ ។ ខ្ញុំបានសួរខ្លួនឯងថា តើការសន្យានោះពិតដែរឬអត់ ? » (« បន្តដោយភាពអត់ធន់ » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៥៨) ។

សូមអញ្ជើញសិស្សឲ្យគិតថាតើពួកគេធ្លាប់មានអារម្មណ៍ស្មុគស្មាញស្រដៀងគ្នានេះ ដោយឆ្ងល់ពីរបៀបដែលព្រះអម្ចាស់បំពេញសេចក្តីសន្យារបស់ទ្រង់ដើម្បីប្រទានពរដល់ពួកគេ ពេលពួកគេបានកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ដែរទេ ។

សូមសរសេរពាក្យ *បញ្ជាក់* នៅលើក្តារខៀន ហើយសូមឲ្យសិស្សពន្យល់ពីន័យរបស់ពាក្យនេះ (ដើម្បីបញ្ជាក់ ឬ បង្ហាញភស្តុតាងថាអ្វីមួយគឺពិត) ។ សូមពន្យល់ថា យ៉ារ៉ុម ដែលជាកូនប្រុសរបស់អេណុស បានប្រើពាក្យ *បញ្ជាក់* នៅពេលគាត់បានសរសេរអំពីសេចក្តីសន្យាមួយដែលបានផ្តល់ទៅបុព្វជនរបស់គាត់ ។ សូមឲ្យសិស្សអាន យ៉ារ៉ុម ១:៩ ដោយស្ងាត់ៗ ដោយរកមើលសេចក្តីសន្យារបស់ព្រះអម្ចាស់ដែលត្រូវបានបញ្ជាក់ ។ (អ្នកអាចស្នើថា សិស្សគួរគូសចំណាំសេចក្តីសន្យានេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។ សូមបញ្ជាក់ថា សិស្សបានស្គាល់ប្រយោគ « ដរាបណាអ្នករាល់គ្នាកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់យើង នោះអ្នករាល់គ្នានឹងបានចម្រើនឡើងនៅលើដែនដី » ។

សូមសរសេរសេចក្តីយោងព្រះគម្ពីរ និង សំណួរខាងក្រោមនៅលើក្តារខៀន ។ (ដើម្បីសន្សំពេលវេលា អ្នកអាចសរសេរវានៅលើក្តារខៀនមុនពេលចាប់ផ្តើមបង្រៀន) ។

យ៉ារ៉ុម ១:៤–៥, ៨	តើមានគំរូណាខ្លះ បញ្ជាក់ពីរបៀបដែលសាសន៍នីហ្វៃបានគោរពតាម និង របៀបដែលពួកគេត្រូវបានប្រទានពរនោះ ?
យ៉ារ៉ុម ១:៧, ១០–១២	តើអ្នកដឹកនាំ និង ព្យាការីទាំងឡាយបានជួយដល់សាសន៍នីហ្វៃឲ្យគោរព និង រីកចម្រើនឡើងដោយរបៀបណា ?
អោមណៃ ១:៥–៧	តើសេចក្តីសន្យារបស់ព្រះ ក្រោយមកបញ្ជាក់តាមរបៀបខុសគ្នាយ៉ាងដូចម្តេច ?

សូមបែងចែកសិស្សទៅក្រុម ដែលមួយក្រុមមានសមាជិកបីនាក់ ។ សូមចាត់តាំងសេចក្តីយោងព្រះគម្ពីរមួយនៅលើក្តារខៀនដល់សមាជិកម្នាក់ៗនៅក្នុងក្រុមនីមួយៗ ។ សូមឲ្យសិស្សអានវគ្គព្រះគម្ពីររបស់ពួកគេដែលបានចាត់ឲ្យ ដោយស្ងាត់ៗ ដោយរកមើលចម្លើយចំពោះសំណួរត្រូវគ្នានោះ ។ បន្ទាប់មក សូមផ្តល់ពេលមួយ ឬ ពីរនាទីដល់បុគ្គលម្នាក់ៗនៅក្នុងក្រុម ដើម្បីសង្ខេបនូវអ្វីដែលគេបានអាន

សូមបង្ហាញរូបភាពនៃអ្នកដឹកនាំសាសនាចក្រ

ការបង្ហាញរូបភាពនៃអ្នកដឹកនាំសាសនាចក្រ នៅពេលអ្នកបង្រៀនប្រសាសន៍របស់ពួកលោកនឹងជួយសិស្សឲ្យស្គាល់អ្នកទាំងឡាយណាដែលព្រះអម្ចាស់បានហៅឲ្យធ្វើជាព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈ ។ វាក៏នឹងជួយបង្កើនចំណាប់អារម្មណ៍របស់សិស្សទៅលើប្រសាសន៍របស់ពួកលោកផងដែរ ។ ប្រសិនបើអ្នកគ្រោងប្រើសេចក្តីថ្លែងការណ៍មួយមកពីសុន្ទរកថាសន្និសីទទូទៅ សូមពិចារណាធ្វើការបង្ហាញវាដោយប្រើវីដេអូ ឬ ជាសំឡេង ដែលមាននៅ LDS.org ។

ហើយឆ្លើយនឹងសំណូរដែលបានដាក់នោះ ។ សូមអញ្ជើញសិស្សម្នាក់ ឬ ពីរនាក់ឲ្យសង្ខេបប្រាប់ដល់សិស្សក្នុងថ្នាក់អំពីសេចក្តីពិតមួយដែលពួកគេបានរៀនពីការសិក្សា និង ការពិភាក្សាព្រះគម្ពីរទាំងនេះ ។ នៅពេលសិស្សផ្តល់ចម្លើយរបស់ពួកគេ សូមធានាថា ពួកគេយល់ថា **នៅពេលយើងគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ នោះយើងនឹងរីកចម្រើនឡើង ។**

- ដោយផ្អែកលើអ្វីដែលអ្នកបានរៀនពីបទពិសោធន៍របស់សាសន៍នីហ្វៃ តើមានរបៀបណាខ្លះដែលព្រះនឹងប្រទានពរដល់អ្នកទាំងឡាយណាដែលគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ?

ដើម្បីពង្រឹងគោលការណ៍នេះ សូមរំឭកសិស្សក្នុងថ្នាក់អំពីបទពិសោធន៍របស់ប្រធាន អុជដូហ្ស នៅពេលគាត់ឆ្ងល់ថាតើការសន្យារបស់ព្រះអម្ចាស់ដែលបានប្រទាននៅក្នុងពាក្យគតិបណ្ឌិតនោះត្រូវបានបញ្ចាក់ទេ ។ បន្ទាប់មក សូមអានសេចក្តីថ្លែងការណ៍ទាំងអស់របស់គាត់ ៖

« ចម្លើយមិនបានមកភ្លាមនោះទេ ។ ប៉ុន្តែទីបំផុត ខ្ញុំបានរៀនថា ការសន្យារបស់ព្រះមិនមែនសុទ្ធតែត្រូវបានបំពេញភ្លាមៗ ឬ នៅក្នុងរបៀបដែលយើងរំពឹងទុកនោះទេ វាមកដល់តាមពេលវេលារបស់ទ្រង់ និង របៀបរបស់ទ្រង់ ។ ប៉ុន្មានឆ្នាំក្រោយមក ខ្ញុំអាចឃើញភស្តុតាងនៃពរជ័យខាងរូបកាយ ដែលបានកើតឡើងចំពោះអ្នកដែលបានគោរពច្បាប់គតិបណ្ឌិត—ជាងនេះទៅទៀត ពរជ័យខាងវិញ្ញាណដែលបានមកភ្លាមតាមការស្តាប់បង្គាប់ព្រះបញ្ញត្តិព្រះ ។ មើលត្រឡប់ទៅក្រោយវិញ ខ្ញុំដឹងច្បាស់ថា ការសន្យារបស់ព្រះអម្ចាស់តែងតែប្រាកដច្បាស់ជានិច្ច បើទោះមិនតែងតែកើតឡើងភ្លាមៗក៏ដោយ » (« បន្តដោយភាពអត់ធន់ » ទំព័រ ១០៨) ។

សូមអញ្ជើញសិស្សឲ្យសញ្ជឹងគិតអំពីសំណូរខាងក្រោមនេះ ៖

- តើនៅពេលណាដែលព្រះអម្ចាស់បានប្រទានពរ ឬ បានធ្វើឲ្យអ្នករីកចម្រើន ដោយសារការកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់នោះ ? ចេញពីបទពិសោធន៍របស់អ្នក តើអ្នកមានទីបន្ទាល់អ្វីដែលអាចចែកចាយអំពីព្រះអម្ចាស់ និង ការសន្យារបស់ទ្រង់ ?

ការផ្តោតលើគោលលទ្ធិ និង គោលការណ៍ទាំងឡាយ

ខណៈពេលការពិតទាក់ទងនឹងប្រវត្តិសាស្ត្រ និង កូមិសាស្ត្រអាចសំខាន់ក្នុងការសាងបរិបទព្រះគម្ពីរដែលអ្នកបង្រៀន នោះមេរៀនគួរផ្តោតលើការជួយសិស្សឲ្យរកឃើញ យល់ និង អនុវត្តគោលលទ្ធិ និង គោលការណ៍នៃជំនឿដ៏ល្អ ។ សូមយកចិត្តទុកដាក់កុំឲ្យធ្វេសប្រហែសលើគោលលទ្ធិដែលបានបង្រៀននៅក្នុងអោមណៃ ដោយការចំណាយពេលខ្លាំងពេកក្នុងប្រវត្តិសាស្ត្រ និង កូមិសាស្ត្រ ។

អោមណៃ ១:១–៣០

អ្នករក្សាបញ្ជីរ៉ាយរ៉ាប់ពីប្រវត្តិសាសន៍នីហ្វៃ

សូមបង្ហាញដោយសង្ខេបនូវគម្ពីរអោមណៃដោយពន្យល់ថា វាត្រូវបានសរសេរដោយកូនចៅរបស់យ៉ារ៉ុម ហើយវាមានរយៈពេលប្រហែលជា ២៣០ ឆ្នាំ ។ សូមអញ្ជើញសិស្សឲ្យអានគម្ពីរអោមណៃត្រួសៗ ដើម្បីរកមើលឈ្មោះមនុស្សដែលបានរក្សាថ្នាំងតូចបន្ទាប់ពីយ៉ារ៉ុមទៅ ។ ដើម្បីជួយសិស្សឲ្យរកឃើញឈ្មោះបានលឿន សូមគិតពីការផ្តល់សេចក្តីយោងព្រះគម្ពីរដូចខាងក្រោមនេះ ៖ អោមណៃ ១:១, ៤, ៨, ១០, ១២, ២៥ ។

សូមពន្យល់ថា គម្ពីរអោមណៃរៀបរាប់ពីព្រឹត្តិការណ៍សំខាន់ៗជាច្រើននៅក្នុងប្រវត្តិសាស្ត្ររបស់ប្រជាជននៅក្នុងព្រះគម្ពីរមរមន ។ វាលើកឡើងអំពីប្រជាជនសាវ៉ាហិមឡា (ក៏ស្គាល់ថាជា ប្រជាជន ម៉ូលេក) និង កូរីអានទុមើរ (សាសន៍យ៉ារ៉ែឌចុងក្រោយគេ) ហើយវាក៏បានរៀបរាប់ដោយសង្ខេបពីរបៀបដែលសាសន៍នីហ្វៃបានតាំងលំនៅជាថ្មីនៅដែនដីសាវ៉ាហិមឡា ហើយបានរួមគ្នាជាមួយនឹងសាសន៍ម៉ូលេក ។ អ្នកអាចឲ្យសិស្សមើលកាលប្រវត្តិនៅលើវត្ថុសៀតនៃព្រះគម្ពីរមរមន (លេខកូដសម្គារ ៣២៣៣៦) ហើយជួយពួកគេឲ្យរកមើលការលេចឡើងរួមគ្នារបស់សាសន៍នីហ្វៃ និង សាសន៍ម៉ូលេក ។ សូមឲ្យសិស្សដាក់វត្ថុសៀតសៀវភៅនេះលើឈ្មោះ កូរីអានទុមើរ នៅក្រោមចំណងជើង « សាសន៍យ៉ារ៉ែឌ » ផងដែរ ។



នៅលើក្តារខៀន សូមគូសដែនទីដែលបង្ហាញនៅលើទំព័រនេះ ប៉ុន្តែសូមកុំបញ្ចូលព្រួញទៅក្នុងនោះ ។ សូមលើកទឹកចិត្តសិស្សឲ្យចម្លងដែនទីនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។

សូមរំឭកសិស្សថា នៅក្នុងជំនាន់របស់នីហ្វៃ សាសន៍នីហ្វៃបានចែកដាច់ពីសាសន៍លេមិន ហើយបានអាស្រ័យនៅក្នុងទីតាំងដែលពួកគេហៅថា ដែនដីនីហ្វៃ ។ នៅលើដែនទី សូមគូសសញ្ញាព្រួញមួយពីដែនដីនៃកេរ្តិ៍អាករដំបូងទៅកាន់ដែនដីនីហ្វៃ ។ សូមឲ្យសិស្សអាន អោមណៃ ១:១២–១៣ ដោយស្ងាត់ស្ងៀម ហើយរកមើលពីរបៀបដែលសាសន៍នីហ្វៃបានមករស់នៅក្នុងដែនដីសាវ៉ាហិមឡា ។ នៅពេលសិស្សបង្ហាញពីអ្វីដែលពួកគេបានរកឃើញហើយ សូមគូសសញ្ញាព្រួញមួយចេញពីដែនដីនីហ្វៃ ទៅកាន់ដែនដីសាវ៉ាហិមឡា ។ សូមបង្ហាញថា អោមណៃ ១:១២–១៣ បង្រៀនថា **ព្រះអម្ចាស់ផ្តល់ការណែនាំដល់ពួកសុចរិត ។**

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន អោមណៃ ១:១៤–១៩ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលភាពស្រដៀងគ្នា និង ភាពខុសគ្នារវាងសាសន៍នីហ្វៃ និង ប្រជាជនដែលពួកគេរកឃើញនៅក្នុងដែនដីសាវ៉ាហិមឡា ។ សូមអញ្ជើញសិស្សពីរបីនាក់ ឲ្យបង្ហាញពីអ្វីដែលពួកគេបានរៀន ។

សូមសង្ខេប អោមណៃ ១:២០–២២ ដោយពន្យល់ថា ប្រជាជនសាវ៉ាហិមឡាបានជួបនឹងកូរីអានទុមើរដែលជាមនុស្សម្នាក់ក្នុងចំណោមមនុស្សពីរនាក់ដែលនៅរស់ចុងក្រោយគេក្នុងជាតិសាសន៍យ៉ារ៉ែឌ (ម្នាក់ទៀត គឺជាព្យាការីអេធើរ) ។ នៅលើដែនទី សូមបង្ហាញពីដែនដីនៃនិទាសកម្ម ហើយពន្យល់ថានេះគឺជាកន្លែងមួយនៅក្នុងដែនដីភាគខាងជើង ដែលមាន « ឆ្អឹងរបស់ប្រជាជនយ៉ារ៉ែឌនៅរាយប៉ាយ » ក្រោយពីពួកគេត្រូវបានបំផ្លាញ (អោមណៃ ១:២២) ។ សូមប្រាប់សិស្សថា ពួកគេនឹងរៀនអំពីសាសន៍យ៉ារ៉ែឌនៅពេលពួកគេសិក្សាគម្ពីរអេធើរ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរ *សាសន៍យ៉ារ៉ែឌ* នៅក្នុងព្រះគម្ពីររបស់ពួកគេនៅក្បែរ អោមណៃ ១:២០–២២ ។

សូមគូសសញ្ញាព្រួញមួយដែលចេញពីដែនដីសាវ៉ាហិមឡា ទៅកាន់ដែនដីនីហ្វៃ ហើយបន្ទាប់មក ត្រឡប់មកកាន់ដែនដីសាវ៉ាហិមឡាវិញ ។ សូមគូសសញ្ញាព្រួញមួយទៀតពីដែនដីសាវ៉ាហិមឡា ដែលចេញពីទិសដៅមួយទៅកាន់ដែនដីនីហ្វៃ ។ សូមសួរសិស្សបើសិនជាពួកគេអាចពន្យល់ថាតើព្រួញទាំងពីរនេះតំណាងឲ្យអ្វី ។ ប្រសិនបើពួកគេត្រូវការជំនួយ សូមសង្ខេប អោមណៃ ១:២៧–៣០ ដោយពន្យល់ថាក្រុមពីរដែលមកពីដែនដីសាវ៉ាហិមឡាមានបំណងចង់ត្រឡប់ទៅកាន់ដែនដីនីហ្វៃវិញ ។ ក្រុមទីមួយខកខានមិនបានទៅ ហើយបានត្រឡប់ទៅកាន់ដែនដីសាវ៉ាហិមឡាវិញ ។ នៅពេលអាម៉ាលេកៃបានបិទកំណត់ត្រារបស់គាត់ គាត់បានលើកឡើងថា គាត់មិនបានដឹងពីជោគវាសនានៃក្រុមទីពីរនោះទេ ។ សូមប្រាប់សិស្សថា ពួកគេនឹងរៀនអំពីក្រុមនេះ គឺប្រជាជនសឺនិព្ធ នៅពេលពួកគេសិក្សាគម្ពីរម៉ូសាយ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរ *ប្រជាជនសឺនិព្ធ* នៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អោមណៃ ១:២៩–៣០ ។

សូមពន្យល់ថា ព្រះគម្ពីរមរមនមិនបានអះអាងថាជាកំណត់ត្រានៃប្រជាជនទាំងអស់ ដែលបានរស់នៅដែនដីអាមេរិកពីបុរាណនោះទេ ។ ក្រៅពីសាសន៍យ៉ារ៉ែឌ ម៉ូលេក និង ក្រុមរបស់លីហៃ វាអាចមានក្រុមប្រជាជនផ្សេង ៗដែលបានមកដល់ទ្វីបអាមេរិក ។

សូមពន្យល់ថា នៅពេលសាសន៍អាម៉ាលេកៃបានបញ្ចប់កំណត់ត្រារបស់គាត់ គាត់បានសរសេរការអញ្ជើញដ៏មានសារៈសំខាន់ទៅដល់អស់អ្នកណាដែលនឹងអានពាក្យពេចន៍របស់គាត់ ។ សូមឲ្យសិស្សអានការអញ្ជើញរបស់អាម៉ាលេកៃនៅក្នុង អោមណៃ ១:២៥–២៦ ដោយស្ងាត់ស្ងៀម ដោយរកមើលគំនិតមួយដែលគាត់បាននិយាយដដែល ៗបីដង ។ (អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំអ្វី ដែលពួកគេបានរកឃើញ) ។

- តើការមករកព្រះគ្រីស្ទ មានន័យយ៉ាងដែរចំពោះអ្នក ?

សូមបង្ហាញថា នៅផ្នែកនៃការអញ្ជើញរបស់អាម៉ាលេកៃឲ្យមកកាន់ព្រះគ្រីស្ទ គាត់បានទូន្មានយើងឲ្យធ្វើនូវរឿងជាក់លាក់មួយចំនួន ។ សូមសរសេរអ្វីដូចខាងក្រោមនៅលើក្តារខៀន ៖

មករកព្រះគ្រីស្ទ ហើយ . . .

សូមឲ្យសិស្សបើកទៅ អោមណៃ ១:២៥–២៦ ម្តងទៀត ។ សូមអញ្ជើញសិស្សបីបួននាក់ឲ្យបំពេញប្រយោគនៅលើក្តារខៀន ដោយប្រើឃ្លាដែលដកស្រង់ពីខគម្ពីរទាំងនេះ ។

- ដោយយោងតាម អោមណៃ ១:២៦ តើយើងនឹងត្រូវបានប្រទានពរចំពោះការធ្វើតាមរឿងទាំងនេះដោយរបៀបណា ? (សូមជួយសិស្សឲ្យយល់ថា **ប្រសិនបើយើងមករកព្រះគ្រីស្ទ ហើយតស៊ូដល់ទីបញ្ចប់ យើងនឹងត្រូវបានសង្ក្រោះ ។** អ្នកអាចនឹងសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមឲ្យសិស្សជ្រើសរើសឃ្លាមួយនៃឃ្លាទាំងឡាយដែលមាននៅលើក្តារខៀន ។ សូមអញ្ជើញពួកគេឲ្យសរសេរ ឬ គ្រោងការនិយាយខ្លីមួយនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ដែលពួកគេអាចផ្តល់នៅក្នុងការប្រជុំសាក្រាម៉ង់ អំពីរបៀបដែលពួកគេអាចមករកព្រះគ្រីស្ទតាមរបៀបនោះ ។ សូមផ្តល់យោបល់ថា ការនិយាយរបស់ពួកគេអាចរួមមាន ៖ (១) ការអាន អោមណៃ ១:២៥–២៦ និង ការពន្យល់ជាសម្ពីខ្លួនឯងនូវឃ្លាដែលពួកគេបានជ្រើសរើស (២) ការអានព្រះគម្ពីរបន្ថែមដែលបញ្ជាក់ ឬ បន្ថែមអត្ថន័យទៅដល់ឃ្លា (៣) ការចែកចាយបទពិសោធន៍ដែលទាក់ទងគ្នាមួយមកពីជីវិតរបស់ពួកគេ ឬ មកពីជីវិតរបស់មនុស្សដែលពួកគេស្គាល់ ឬ (៣) ការចែកចាយនូវគំនិត អារម្មណ៍ និង ទីបន្ទាល់របស់ពួកគេ ។ (អ្នកអាចសរសេរនូវយោបល់ទាំងនេះនៅលើក្តារខៀន ចែកក្រដាសមួយសន្លឹកឲ្យពួកគេ ឬ អានព្ធ ៗដល់ពួកគេ ដើម្បីពួកគេអាចសរសេរវានៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ) ។

សូមផ្តល់ពេលដល់សិស្សពីប្រាំមួយទៅប្រាំពីរនាទី ដើម្បីរៀបចំការនិយាយរបស់ពួកគេ ។ សូមអញ្ជើញសិស្សបីបួននាក់ ឲ្យចែកចាយនូវការនិយាយរបស់ពួកគេនៅចំពោះមុខសិស្សទាំងឡាយ ។ (ប្រសិនបើគ្មានពេលសម្រាប់ធ្វើវាទេ សូមគិតពីការសុំឲ្យសិស្សខ្លះចែកចាយការនិយាយរបស់ពួកគេនៅពេលចាប់ផ្តើមមេរៀនក្រោយ ឬ នៅផ្នែកនៃការប្រជុំក្នុងថ្នាក់នៅពេលក្រោយទៀត ។ អ្នកក៏អាចលើកទឹកចិត្តពួកគេឲ្យចែកចាយនូវការនិយាយរបស់ពួកគេ ក្នុងពេលរាត្រីជួបជុំក្រុមគ្រួសារ ឬ នៅក្នុងការសន្ទនាជាមួយនឹងសមាជិកគ្រួសារ ឬ មិត្តភក្តិ) ។ ដើម្បីបញ្ចប់ សូមចែកចាយទីបន្ទាល់របស់អ្នកថា ប្រសិនបើយើងមករកព្រះគ្រីស្ទ ហើយកាន់ខ្ជាប់ដរាបដល់ចុងបំផុត នោះយើងនឹងត្រូវបានសង្ក្រោះ ។

ការរំឲ្យកចំណេះចំណានខគម្ពីរ

សូមណែនាំដល់សិស្សនូវវគ្គចំណេះចំណានខគម្ពីរថ្មី ៗពីរបី ។ ដើម្បីធ្វើដូច្នោះបាន សូមសរសេរសេចក្តីយោងបីបួននៅលើក្តារខៀន ហើយសុំឲ្យសិស្សចំណាំកន្លែង ហើយអានវគ្គនោះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។ អ្នកក៏អាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំវាតាមរបៀបប្លែកពីគេ ដើម្បីឲ្យពួកគេងាយនឹងរកមើល ។ ដើម្បីជួយសិស្សឲ្យចងចាំនូវសេចក្តីយោង និង ពាក្យគន្លឹះនៅក្នុងវគ្គនេះ សូមគិតពីការប្រើសកម្មភាព « អនុវត្តគោលដៅ » នៅក្នុងឧបសម្ព័ន្ធចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។

កំណត់ចំណាំ ៖ អ្នកអាចប្រើសកម្មភាពនេះនៅថ្ងៃក្រោយទៀត នៅពេលអ្នកមានពេលច្រើនជាងនេះ ។

មេរៀនសិក្សានៅផ្ទះ

យ៉ាកុប ៥–អោមណៃ (មេរៀនទី ១០)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីគោលលទ្ធិ និង គោលការណ៍ដែលសិស្សបានរៀននៅពេលពួកគេបានសិក្សា យ៉ាកុប ៥– អោមណៃ (មេរៀនទី ១០) មិនមានគោលបំណងដើម្បីនឹងក្លាយជាផ្នែកណាមួយនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតទៅលើតែគោលលទ្ធិ និង គោលការណ៍ពិបើនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសអំពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកពិចារណាអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (យ៉ាកុប ៥–៦)

នៅក្នុងមេរៀនរបស់ពួកគេអំពីរូបាធិដ្ឋាននៃដើមអូលីវនៅក្នុង យ៉ាកុប ៥នោះសិស្សបានផ្តោតទៅលើគោលការណ៍ថា ព្រះអម្ចាស់ស្រឡាញ់យើង ហើយធ្វើការយ៉ាងអំណាត់សម្រាប់សេចក្តីសង្គ្រោះរបស់យើង ។ សិស្សបានកត់ត្រាពីអ្វីដែលពួកគេបានរៀនពី យ៉ាកុប ៥ ទាក់ទងទៅនឹងសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ចំពោះពួកគេ ។ នៅក្នុង យ៉ាកុប ៦ សិស្សបានរៀនថា យើងឈ្លាសវៃដើម្បីរៀបចំក្នុងពេលឥឡូវចំពោះការជំនុំជម្រះដោយការប្រែចិត្ត និង ការទទួលយកសេចក្តីមេត្តាពីព្រះអម្ចាស់ ។

ថ្ងៃទី ២ (យ៉ាកុប ៧)

សិស្សបានសិក្សាអំពីការជួបប្រទះរបស់យ៉ាកុបនឹងសេរេម ដែលជាអ្នកប្រឆាំងនឹងព្រះគ្រីស្ទ ។ ពួកគេបានរៀនថា នៅពេលយើងពឹងផ្អែកទៅលើព្រះអម្ចាស់ នោះយើងអាចយកឈ្នះលើឧបសគ្គទាំងឡាយដែលទាស់នឹងសេចក្តីជំនឿរបស់យើង ។ ចេញពីឧទាហរណ៍របស់យ៉ាកុប ពួកគេក៏បានរៀនថា យើងមិនអាចត្រូវរង្គោះរង្គើសេចក្តីជំនឿរបស់យើងឡើយ ប្រសិនបើទីបន្ទាល់របស់យើងចាក់គ្រឹះទៅលើវិរាណៈ និង បទពិសោធន៍ខាងវិញ្ញាណដ៏ពិតនោះ ។ បន្ថែមលើនេះទៅទៀត សិស្សបានឃើញការបង្ហាញនៃគោលការណ៍ថា នៅពេលយើងឆ្លើយតបទៅនឹងសំណូរ ឬ ការរិះគន់នៃសេចក្តីជំនឿរបស់យើងតាមរបៀបមួយដែលអញ្ជើញព្រះវិញ្ញាណ នោះយើងអាចជួយអ្នកដទៃទៀតឲ្យបែរមករកព្រះអម្ចាស់បាន ។ សិស្សបានសរសេរអំពីរបៀបដែលពួកគេនឹងអនុវត្តគោលការណ៍មួយដែលពួកគេបានរកឃើញនៅក្នុង យ៉ាកុប ៧:១៥–២៣ ។

ថ្ងៃទី ៣ (អេណុស)

ចេញពីគំរូរបស់អេណុស សិស្សបានរៀនថា នៅពេលយើងអនុវត្តសេចក្តីជំនឿតាមព្រះគ្រីស្ទ នោះអំពើបាបរបស់យើងអាចត្រូវបានអភ័យទោស ហើយយើងអាចត្រូវបានធ្វើឲ្យពេញលេញ ។ ពួកគេក៏បានរៀនដែរថា នៅពេលយើងទទួលបានពរជ័យពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងចង់ជួយអ្នកផ្សេងទៀតឲ្យទទួលបានសេចក្តីសង្គ្រោះដែរ ។ សិស្សបានសរសេរអំពីរបៀបមួយដែលពួកគេអាចនឹងអនុវត្តគោលការណ៍ទាំងនេះ ។

ថ្ងៃទី ៤ (យ៉ារ៉ុម និង អោមណៃ)

នៅក្នុងការសិក្សារបស់ពួកគេអំពីយ៉ារ៉ុម និង អោមណៃ សិស្សបានរកឃើញនូវសេចក្តីពិតដូចខាងក្រោមនេះ ៖ នៅពេលយើងគោរពតាមព្រះបញ្ញត្តិនៃព្រះ យើងនឹងរីកចម្រើន ។ ពួកគេបានកត់ត្រាពីរបៀបដែលព្រះអម្ចាស់បានប្រទានពរដល់ពួកគេ ក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ សិស្សក៏បានសិក្សាដោយសង្ខេបអំពីការធ្វើចំណាកស្រុករបស់សាសន៍នីហ្វៃទៅកាន់ដែនដីសាំាហិមឡា ហើយបានស្គាល់ប្រជាជនសាំាហិមឡា យ៉ារ៉ែម និង សាសន៍នីហ្វៃមួយក្រុម (ប្រជាជនសឺរិន្ទ) ដែលបានត្រឡប់ទៅកាន់ដែនដីនីហ្វៃវិញ ។ សិស្សបានរៀនអំពីគោលការណ៍ខាងក្រោម ៖ ប្រសិនបើយើងមកកាន់ព្រះគ្រីស្ទ ហើយតស៊ូដល់ទីបញ្ចប់ នោះយើងនឹងត្រូវបានសង្គ្រោះ ។ ពួកគេបានបញ្ចប់មេរៀននេះដោយការសរសេរការនិយាយមួយដែលមានរយៈពេលពីមួយទៅពីរនាទី តាមរបៀបមួយដែលអាម៉ាលេកៃបានលើកទឹកចិត្តយើងឲ្យមកកាន់ព្រះគ្រីស្ទ ។

សេចក្តីផ្តើម

នៅក្នុងមេរៀននេះ សិស្សនឹងមានឱកាសដើម្បីគិតអំពីស្រឡាញ់របស់ព្រះអម្ចាស់ចំពោះពួកគេដូចដែលបានបង្ហាញនៅក្នុង យ៉ាកុប ៥ ។ ប្រសិនបើមានពេល អ្នកក៏អាចបង្រៀនពួកគេពី យ៉ាកុប ៥ អំពីតួនាទីរបស់ពួកគេជាអ្នកបម្រើរបស់ព្រះអម្ចាស់ ។ សិស្សនឹងអាចពិភាក្សាអំពីសេចក្តីពិតពី យ៉ាកុប ៧ ដែលអាចជួយពួកគេ នៅពេលអ្នកជំទាស់រ ឬ រិះគន់ដល់សេចក្តីជំនឿរបស់ពួកគេ ។ ពួកគេក៏នឹងមានឱកាសដើម្បីប្រាប់សិស្សក្នុងថ្នាក់អំពីរបៀបដែលពួកគេបានអនុវត្តអ្វីដែលពួកគេបានរៀនពីគម្ពីរអេណុសដែរ ។ លើសពីនេះទៅទៀត សិស្សអាចចែកចាយអ្វីដែលពួកគេបានរៀបចំអំពីវិធីដែលយើងអាចយកចិត្តទុកដាក់លើការអញ្ជើញនៅក្នុងអោមណៃឲ្យមកកាន់ព្រះគ្រីស្ទ ។ ប្រសិនបើអ្នកចង់ឲ្យពួកគេធ្វើដូច្នោះ វាអាចជួយអ្នកបើអ្នកស្នើសុំសិស្សបីបួននាក់ជាមុន ហើយអញ្ជើញពួកគេឲ្យរៀបចំដើម្បីចែកចាយការនិយាយរបស់ពួកគេនៅក្នុងថ្នាក់ ។

យោបល់សម្រាប់ការបង្រៀន

យ៉ាកុប ៥–៦

យ៉ាកុបដកស្រង់រឿងប្រៀបប្រដូចពីដើមអូលីវ ដើម្បីបង្ហាញថា ព្រះអម្ចាស់ធ្វើការដោយអំណាត់សម្រាប់សេចក្តីសង្គ្រោះរបស់យើង

សូមរំឭកសិស្សថា នៅក្នុងរឿងប្រៀបធៀបនៃដើមអូលីវនេះ មែកដែលចេញពីដើមអូលីវត្រូវបានខ្ចាត់ខ្ចាយក្នុងចំការទាំងមូល ។ រឿងនេះតំណាងឲ្យការខ្ចាត់ខ្ចាយនៃប្រជាជនក្នុងសេចក្តីសញ្ញារបស់ព្រះ —វង្សនៃអ៊ីស្រាអែល— ពេញផែនដីទាំងមូល ។ ទោះយ៉ាងណាក្តី នៅទីបញ្ចប់ដើមអូលីវទាំងអស់នៅក្នុងចំការបានក្លាយជាពុកផុយ (សូមមើល យ៉ាកុប ៥:៤៦) ។ សូមពន្យល់ថា នេះគឺតំណាងឲ្យរយៈពេលនៃការក្បត់សាសនាដ៏ធំ ។

សូមអញ្ជើញសិស្សឲ្យអាន យ៉ាកុប ៥:៦១–៦២ ដោយស្ងាត់ស្ងៀម ដោយរកមើលអ្វីដែលព្រះអម្ចាស់បានបញ្ជាឲ្យអ្នកបម្រើរបស់ទ្រង់ (ព្យាការីរបស់ទ្រង់) ធ្វើដើម្បីជួយដើមអូលីវទាំងឡាយបង្កើតបានផ្លែល្អម្តងទៀត ។ បន្ទាប់មក សួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- តើអ្នកគិតថា « អ្នកបម្រើ» ទាំងនេះអាចសំដៅទៅលើអ្នកណា ? (អ្នកដឹកនាំសាសនាចក្រ អ្នកផ្សព្វផ្សាយសាសនា និង សមាជិកសាសនាចក្រទាំងឡាយ ។)
- តើអ្វីដែលប្លែកអំពីពេលវេលា ដែលអ្នកបម្រើទាំងនេះត្រូវបានហៅឲ្យបម្រើ ?

សូមពន្យល់ដោយខ្លីថា ការខិតខំទាំងនេះតំណាងឲ្យការប្រមូលនៃសាសន៍អ៊ីស្រាអែល ។ ដើម្បីជួយសិស្សឲ្យយល់ថា ពួកគេគឺជាផ្នែកមួយនៃក្រុមអ្នកបម្រើដែលត្រូវបានហៅឲ្យបម្រើនៅក្នុងចំការរបស់ព្រះអម្ចាស់នោះ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយ អែលឌើរ វេន អេល. ឡាសិន នៃក្រុមចិតសិបនាក់ ។ សូមឲ្យសិស្សស្តាប់ ហើយស្វែងរកអ្នកណាដែលជា «អ្នកបម្រើចុងក្រោយនៅក្នុងចំការ» ។

« [ឥឡូវនេះ] គឺជាពេលវេលាដែលព្រះអម្ចាស់ និង អ្នកបម្រើរបស់ទ្រង់នឹងខិតខំធ្វើការយ៉ាងខ្លាំងក្លាចុងក្រោយដើម្បីនាំសារនៃសេចក្តីពិតទៅដល់ប្រជាជនទាំងឡាយនៅលើផែនដីនេះ ហើយដើម្បីកែប្រែកូនចៅនៃវង្សអ៊ីស្រាអែលពីបុរាណ ដែលបានបាត់បង់អត្តសញ្ញាណពិតរបស់ខ្លួន ។ . . .

« អ្នកបានមកកាន់ផែនដី នៅពេលដែលគេបានចាក់គ្រឹះក្នុងកិច្ចការដ៏អស្ចារ្យនេះ ។ ដំណឹងល្អត្រូវបានស្តារឡើងវិញសម្រាប់ពេលចុងក្រោយបង្អស់ ។ សាសនាចក្រត្រូវបានស្ថាបនាឡើងនៅក្នុងតំបន់នានាស្ទើរតែទូទាំងពិភពលោក ។ ដំណាក់កាលនេះ គឺបង្កើតឡើងសម្រាប់ទិដ្ឋភាពដ៏ក្រៀមក្រំចុងក្រោយ ដែលនឹងត្រូវអនុម័ត ។ អ្នកនឹងក្លាយជាអ្នកលេងដ៏សំខាន់ ។ អ្នកស្ថិតនៅក្នុងចំណោមអ្នកធ្វើការចុងក្រោយបង្អស់នៅក្នុងចំការ ។ . . . នេះគឺជាការបម្រើចំពោះអ្វីដែលអ្នកបានជ្រើសរើស» (« ជំនាន់រាជវង្សមួយ» *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៣ ទំព័រ ៣៣) ។

សូមសួរសំណួរដូចខាងក្រោម ៖

- តើអ្នកណាដែលអែលឌើរ ឡាសិន បាននិយាយថាជាអ្នកបម្រើ ឬ «អ្នកធ្វើការចុងក្រោយបង្អស់» ដែលត្រូវបានហៅឲ្យធ្វើការនៅក្នុងចំការនោះ ?
- តើដែលអ្នកមានឱកាសអ្វីខ្លះដើម្បីបម្រើដល់ព្រះអម្ចាស់ និង ជួយអ្នកដទៃឲ្យមាន «ផ្លែល្អ» ?

សូមអាន យ៉ាកុប ៥:៧១ ឮៗទាំងអស់គ្នានៅក្នុងថ្នាក់ ។ សូមអញ្ជើញសិស្សឲ្យរកអ្វីដែលព្រះអម្ចាស់បានសន្យាដល់អ្នកដែលបានបម្រើជាមួយនឹងទ្រង់ ។ សូមសួរសិស្សអំពីពេលដែលពួកគេបានមានអារម្មណ៍ថាបានទទួលពរជ័យចំពោះការខិតខំរបស់ពួកគេក្នុងការបម្រើដល់ព្រះអម្ចាស់ ។

យ៉ាកុប ៧

យ៉ាកុបពឹងផ្អែកទៅលើព្រះអម្ចាស់ នៅពេលគាត់ជួបនឹងសេរេម ហើយដឹកនាំសាសន៍នីហ្វៃមួយក្រុមធំឲ្យត្រឡប់មកកាន់ព្រះអម្ចាស់វិញ

កំណត់ចំណាំ ៖ នៅក្នុង យ៉ាកុប ៧ សិស្សបានរៀនអំពីរបៀបដែលយ៉ាកុបយកឈ្នះការប្រឆាំងនឹងសេចក្តីជំនឿរបស់គាត់ទៅលើព្រះយេស៊ូវគ្រីស្ទ ពីបុរសម្នាក់ឈ្មោះ សេរេម ដែលជាអ្នកប្រឆាំងព្រះគ្រីស្ទ ។ ខណៈពេលដែលមេរៀននេះមិនបានផ្តោតទៅលើបទពិសោធន៍របស់យ៉ាកុបទល់នឹងសេរេម អ្នកអាចអញ្ជើញសិស្សឲ្យសង្កេតពីព្រឹត្តិការណ៍ ហើយស្វែងរកសេចក្តីពិតមួយដែលពួកគេបានរៀនពីគំរូរបស់យ៉ាកុប ។ ជាពិសេស អ្នកអាចសង្កត់ធ្ងន់អំពីសេចក្តីពិតដែល **យើងមិនអាចត្រូវបានរង្គោះរង្គើនៅក្នុងសេចក្តីជំនឿរបស់យើង ប្រសិនបើទីបន្ទាល់របស់យើងស្ថិតលើវិវរណៈ និងបទពិសោធន៍ខាងវិញ្ញាណដ៏ពិតនោះ ។**

អេណុស

ក្រោយពីទទួលបានការផ្តាច់បាបហើយ អេណុសបានអធិដ្ឋានសម្រាប់អ្នកផ្សេង និងធ្វើការដើម្បីសេចក្តីសង្គ្រោះរបស់ពួកគេ



សូមគូសឌីយ៉ាក្រាមនេះនៅលើក្តារខៀន ឬ នៅលើក្រដាសមួយសន្លឹក ។ សូមឲ្យសិស្សពន្យល់ពីរបៀបដែលវាទាក់ទងទៅនឹងបទពិសោធន៍របស់អេណុស ។

សូមបែងចែកសិស្សជាបីក្រុម ។ (ប្រសិនបើអ្នកមានសិស្សតិច ក្រុមមួយអាចមានគ្នាតែម្នាក់ ។) សូមឲ្យក្រុមទីមួយអាន អេណុស ១:៤–៦ ហើយរៀបចំដើម្បីពន្យល់ពីសេចក្តីពិតមួយ ដែលយើងអាចរៀនពីការអធិដ្ឋានរបស់អេណុសសម្រាប់ខ្លួនគាត់ ។ សូមឲ្យក្រុមទីពីរអាន អេណុស ១:៩–១០ ហើយរៀបចំដើម្បីពន្យល់ពីសេចក្តីពិតមួយ ដែលយើងអាចរៀនពីចំណែកនៃការអធិដ្ឋានរបស់អេណុស ។ សូមអ្នកនៅក្នុងក្រុមទីបីអាន អេណុស ១:១១–១៤ ហើយរៀបចំដើម្បីពន្យល់ពីសេចក្តីពិតមួយ ដែលយើងអាចរៀនពីចំណែកនៃការអធិដ្ឋានរបស់អេណុស ។ បន្ទាប់មក សូមឲ្យសមាជិកម្នាក់នៃក្រុមនីមួយៗចែកចាយពីអ្វីដែលពួកគេបានរៀបចំ ។ សូមឲ្យសិស្សរំឭកអំពីថ្ងៃទី ៣ កិច្ចការទី ៩ នៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ហើយសូមអញ្ជើញឲ្យសិស្សពីរបីនាក់ចែកចាយពីរបៀបដែលពួកគេបានជ្រើសរើសដើម្បីអនុវត្តតាមសេចក្តីពិតទាំងឡាយពីគម្ពីរអេណុស ។

យ៉ារ៉ុម និង អោមណៃ

អ្នករក្សាកំណត់ត្រា រៀបរាប់ពីការគេស៊ូ និង ពរជ័យទាំងឡាយរបស់សាសន៍នីហ្វៃ

ប្រសិនបើសិស្សមានសំណួរអំពីចំណាកស្រុករបស់សាសន៍ផ្សេងទៀតទៅកាន់ដែនដីនៃលោកខាងលិច អ្នកអាចពិភាក្សាជាមួយនឹងពួកគេអំពីរឿងនោះនៅក្នុងសៀវភៅណែនាំការសិក្សារបស់សិស្សអំពី អោមណៃ ១:១–៣០ រួមទាំងសេចក្តីថ្លែងការណ៍ដោយប្រធាន អានថូនី ជបុលយូ អាយវិនស៍ នៃគណៈប្រធានទីមួយ ។

សូមអញ្ជើញសិស្សឲ្យរំឭកអំពីការនិយាយដែលពួកគេបានរៀបចំអំពីការមកកាន់ព្រះគ្រីស្ទ (ថ្ងៃទី ៤ កិច្ចការទី ៤) ។ ប្រសិនបើមានពេល អ្នកអាចឲ្យសិស្សបីបួននាក់ចែកចាយការនិយាយទៅកាន់សិស្សក្នុងថ្នាក់ ។ ប្រសិនបើអ្នកស្នើសុំសិស្សជាមុនឲ្យចែកចាយការនិយាយរបស់គេ សូមប្រាកដថាទុកពេលគ្រប់គ្រាន់សម្រាប់ពួកគេនិយាយ ។

សូមប្រាកដថា អ្នកអរគុណដល់សិស្សចំពោះការចូលរួមរបស់ពួកគេ ។ សូមថ្លែងទីបន្ទាល់អំពីសេចក្តីស្រឡាញ់របស់ព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទដែលមានចំពោះសិស្សម្នាក់ៗ ហើយសូមបញ្ជាក់ដល់ពួកគេថា នៅពេលពួកគេមកកាន់ព្រះគ្រីស្ទដោយព្រលឹងទាំងមូល ពួកគេនឹងត្រូវបានសង្គ្រោះនៅក្នុងនគររបស់ទ្រង់ ។

មេរៀនបន្ទាប់ (៣ក្យសំដីនៃមរមន–ម៉ូសាយ ៦)

នៅក្នុងមេរៀនបន្ទាប់ សិស្សនឹងអានអំពីទេវតាមួយអង្គរបស់ព្រះដែលបានលេចចំពោះស្តេចបេនយ៉ាមីន ដោយបានបង្គាប់ទ្រង់ និង ប្រាប់ទ្រង់ពីអ្វីដែលត្រូវនិយាយទៅកាន់ប្រជាជនរបស់ទ្រង់ (សូមមើល មូសាយ ៣) ។ ស្តេចបេនយ៉ាមីនបានថ្លែងពាក្យទាំងនេះទៅកាន់ប្រជាជនរបស់ទ្រង់ ដែលបានទទួលបទពិសោធន៍ផ្លាស់ប្តូរដ៏ធំមួយនៅក្នុងដួងចិត្តរបស់ពួកគេ ។

សេចក្តីផ្តើមអំពី

ពាក្យសម្តីនៃមរមន

ហេតុអ្វីបានជាសិក្សាគម្ពីរនេះ ?

តាមរយៈការសិក្សាពាក្យសម្តីនៃមរមន សិស្សអាចបង្កើនសេចក្តីជំនឿរបស់ពួកគេថា « ព្រះអម្ចាស់ទ្រង់ជ្រាបនូវគ្រប់ការណ៍ទាំងអស់ » (ពាក្យសម្តីនៃមរមន ១:៧) ហើយថាទ្រង់ដឹកនាំអ្នកបម្រើរបស់ទ្រង់ឲ្យសម្រេចនូវគោលបំណងរបស់ទ្រង់ ។ ជាដំណើររឿងប្រវត្តិសាស្ត្រមួយ គម្ពីរនេះធ្វើជាស្ពានរវាងផ្ទាំងនីហ្វៃតូច (នីហ្វៃទី ១ –អោមណៃ) និង សេចក្តីសង្ខេបរបស់មរមនពីផ្ទាំងនីហ្វៃធំ (ម៉ូសាយ –នីហ្វៃទី ៤) ។ វាអាចជួយដល់សិស្សឲ្យយល់កាន់តែច្បាស់នូវអ្វីដែលមរមនបានសង្ខេប នៅពេលគាត់បានចងក្រងព្រះគម្ពីរមរមន ។ វាក៏ណែនាំដល់សិស្សនូវសេចក្តីជំនឿ និង សមិទ្ធិផលរបស់ស្តេចបេនយ៉ាមីនផងដែរ ។

តើអ្នកណាជាអ្នកសរសេរគម្ពីរនេះ ?

មរមនបានសរសេរគម្ពីរនេះ ។ គាត់គឺជាព្យាការី អ្នកថែរក្សាកំណត់ត្រា និង ជាអ្នកសង្ខេប ហើយជាអ្នកចងក្រងព្រះគម្ពីរមរមន ។ គាត់ក៏ជាឪពុកដ៏សុចរិតម្នាក់ និង ជាអ្នកដឹកនាំកងទ័ពក្នុងចំណោមសាសន៍នីហ្វៃដែរ ។ ព្យាការីមរ៉ូណៃគឺជាកូនប្រុសរបស់គាត់ ។

តើគម្ពីរនេះត្រូវបានសរសេរទៅដល់អ្នកណា ហើយហេតុអ្វី ?

មរមនបាននិយាយទៅដល់អ្នកអាននាពេលអនាគត ដោយមានក្តីសង្ឃឹមថា ការសរសេររបស់គាត់ និង ការសរសេររបស់កូនប្រុសគាត់ មរ៉ូណៃ «នឹងមានប្រយោជន៍ដល់ពួកគេ» (ពាក្យសំដីនៃមរមន ១:២) ។ ជាពិសេស គាត់បានសរសេរដើម្បីជាប្រយោជន៍ដល់សាសន៍លេមិន ។ គាត់បាននិយាយអំពីពួកគេថា «ការអធិស្ឋានរបស់ខ្ញុំដល់ព្រះ គឺអំពីបងប្អូនខ្ញុំ ដើម្បីសូមឲ្យពួកគេអាចបានស្គាប់ព្រះម្តងទៀត មែនហើយគឺស្គាល់នូវសេចក្តីប្រោសលោះនៃព្រះគ្រីស្ទ ដើម្បីសូមឲ្យពួកគេអាចបានត្រឡប់ទៅជាប្រជាជនដ៏គួរស្រឡាញ់ដូចមុន» (ពាក្យសំដីនៃមរមន ១:៨) ។

តើគម្ពីរនេះត្រូវបានសរសេរនៅពេលណា ហើយនៅកន្លែងណា ?

មរមនបានសរសេរគម្ពីរនេះប្រហែលនៅឆ្នាំ ៣៨៥ គ.ស ក្រោយពីបាន «យើញដល់ការបំផ្លិចបំផ្លាញស្ទើរតែទាំងអស់នៃប្រជាជនរបស់គាត់ គឺសាសន៍នីហ្វៃ៤៧» (ពាក្យសំដីនៃមរមន ១:១) ។ មរមនមិនបានកត់ត្រាពីទីកន្លែងរបស់គាត់ នៅពេលគាត់សរសេរគម្ពីរនេះនោះទេ ។

តើគម្ពីរនេះមានលក្ខណៈខុសគ្នាអ្វីខ្លះ ?

គម្ពីរដ៏ខ្លីនេះ បង្ហាក់លំដាប់តាមកាលវេលានៃគម្ពីរនានាដែលនៅពីដើមដំបូងនៃព្រះគម្ពីរមរមន ។ មរមនបានសរសេរគម្ពីរនេះជាង ៥០០ ឆ្នាំក្រោយពីអាម៉ាលេកៃបានបញ្ចប់គម្ពីរអោមណៃ ។ នៅក្នុងគម្ពីរនេះ មរមនបានពន្យល់ដោយខ្លីអំពីការចងក្រងរបស់គាត់ និង ការសង្ខេបនៃកំណត់ត្រាប្រជាជនរបស់គាត់ ។ ដើម្បីយល់ពីការពន្យល់របស់គាត់ វានឹងជួយឲ្យចងចាំថា ព្រះអម្ចាស់បានបញ្ជាដល់នីហ្វៃឲ្យធ្វើផ្ទាំងពីរសម្រាប់គោលបំណង « ដ៏ពិសេស » និង « ដ៏ឈ្លាសវៃ » មួយ (សូមមើល នីហ្វៃទី ១ ៩:៣, ៥) ។ ផ្ទាំងមួយ ជាញឹកញាប់ត្រូវបានហៅថា ផ្ទាំងធំ រួមមាននូវប្រវត្តិសាស្ត្រខាងលោកិយអំពីសាសន៍នីហ្វៃ ខណៈពេលដែលផ្ទាំងមួយទៀត ជាញឹកញាប់ត្រូវបានហៅថា ផ្ទាំងតូច រួមមានកំណត់ត្រាដ៏ពិសិដ្ឋនៃការបង្រៀន វិវរណៈ និង ការព្យាករណ៍របស់សាសន៍នីហ្វៃ (សូមមើល នីហ្វៃទី១ ៩:២–៤; យ៉ាកុប ១:៣–៤) ។

មរមនបានរកឃើញផ្ទាំងនីហ្វៃតូច ក្រោយពីគាត់បានសង្ខេបផ្នែកនៃផ្ទាំងធំរួចហើយ (សូមមើល ពាក្យសំដីនៃមរមន ១:៣) ។ ដោយដឹកនាំដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ មរមនបានបញ្ចូលនូវផ្ទាំងតូចជាមួយនឹងការសង្ខេបរបស់គាត់ពីផ្ទាំងធំ ។ គាត់ធ្វើដូច្នេះ « ដើម្បីគោលបំណងដ៏ឈ្លាសវៃមួយ » ដោយយោងតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ (សូមមើល ពាក្យសំដីនៃមរមន ១:៤–៧) ។

ជាច្រើនឆ្នាំក្រោយមក ហេតុផលមួយចំពោះការបំផុសគំនិតនេះបានឃើញច្បាស់ ។ នៅពេលយ៉ូសែប ស្មីធ ចាប់ផ្តើមបកប្រែព្រះគម្ពីរមរមន គាត់បានចាប់ផ្តើមជាមួយនឹងសេចក្តីសង្ខេបរបស់មរមនពីផ្ទាំងនីហ្វៃធំ—ប្រវត្តិសាស្ត្រនៃលោកិយ ។ ម៉ាទីន ហារីស ដែលជាអ្នកសរសេរផ្នែកនេះនៃការបកប្រែរបស់ព្យាការីបានបាត់ ១១៦ ទំព័រនៃសៀវភៅនោះ ។ ព្រះអម្ចាស់បានបង្ហាញដល់យ៉ូសែប ស្មីធ ថាមនុស្សទុច្ចរិតបានយកសៀវភៅទាំងនោះ ហើយបានផ្លាស់ប្តូរពាក្យជាច្រើន (សូមមើល គ . និង ស . ១០:៨–១០) ។ ប្រសិនបើយ៉ូសែប បានបកប្រែសៀវភៅដូចគ្នាម្តងទៀតនោះ មនុស្សទាំងនោះនឹងអះអាងថាគាត់មិនមែនជាព្យាការីនោះទេ ដោយសារគាត់មិនអាចបកប្រែគម្ពីរតាមរបៀបដូចគ្នាជាលើកទីពីរ (សូមមើល គ . និង ស . ១០:១១–១៩) ។ ព្រះអម្ចាស់បានបញ្ជាយ៉ូសែបមិនឲ្យបកប្រែផ្នែកនោះម្តងទៀតនោះទេ ប៉ុន្តែត្រូវបកប្រែផ្ទាំងនីហ្វៃតូចដែលមរមនបានបញ្ចូលនូវសេចក្តីសង្ខេបរបស់គាត់ពីផ្ទាំងធំនោះ (សូមមើល គ. និង ស. ១០:៣០–៤៥) ។ ហេតុដូច្នេះហើយ ពាក្យសំដីនៃមរមនជួយយើងឲ្យឃើញពីរបៀបដែលព្រះអម្ចាស់បានរៀបចំផ្លូវមួយដើម្បីមិនឲ្យផែនការរបស់មនុស្សទុច្ចរិតបានសម្រេច ហើយដើម្បីបញ្ចូលព្រះគម្ពីរដែលមិនត្រឹមតែមានពេលវេលាដូចគ្នានឹងសៀវភៅដែលបាត់នោះទេ ប៉ុន្តែថែមទាំងបានផ្តល់ « យោបល់ជ្រាលជ្រៅទៅទៀតអំពីដំណឹងល្អ [របស់ព្រះអម្ចាស់] » (គ . និង ស . ១០:៤៥) ។ អែលឌើរ ដែហ្វ្រីអ៉រ ហូឡិន នៃក្សុំមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖ « ជាក់ស្តែង វានឹងរីកពយប្រសិនបើនរណាម្នាក់រកឃើញសៀវភៅដើមទាំង ១១៦ ទំព័រនៃព្រះគម្ពីរមរមនដែលបានបាត់នៅថ្ងៃណាមួយនោះ ។ ប៉ុន្តែមិនថាសៀវភៅនោះមានអ្វីក៏ដោយវាមិនអាចសំខាន់ ឬ មានគ្រឹះរឹងមាំដល់គោលបំណងនៃព្រះគម្ពីរមរមនជាងការបង្រៀនទាំងឡាយ . . . ដែលបានកត់ត្រានៅលើផ្ទាំងតូចនោះទេ " (*ព្រះគ្រីស្ទ និង សញ្ញាថ្មី ៖ សារនៃព្រះមែស៊ីនៃព្រះគម្ពីរមរមន* [ឆ្នាំ ១៩៩៧] ទំព័រ ៣៥–៣៦) ។

បន្ថែមទៅលើការចែកចាយនូវការយល់ច្បាស់អំពីការចងក្រងកំណត់ត្រាដ៏ពិសិដ្ឋនៃប្រជាជនរបស់គាត់ មរមនបានផ្តល់ការពិពណ៌នាសង្ខេបមួយអំពីការបម្រើរបស់ស្តេចបេនយ៉ាមីន (សូមមើល ពាក្យសម្តីនៃមរមន ១:១០–១៨) ។ ការពិពណ៌នានេះជួយក្ជាប់ផ្ទាំងនីហ្វៃតូចជាមួយនឹងសេចក្តីសង្ខេបរបស់មរមនពីផ្ទាំងធំ ។ ស្តេចបេនយ៉ាមីនត្រូវបានលើកឡើងនៅសេចក្តីសន្ទិដ្ឋាននៃគម្ពីរអោមណៃ ដែលជាគម្ពីរចុងក្រោយគេនៅក្នុងផ្ទាំងតូច (សូមមើល អោមណៃ ១:២៣–២៥) ។ គម្ពីរម៉ូសាយដែលជាគម្ពីរដំបូងគេដែលយើងមាននូវសេចក្តីសង្ខេបរបស់មរមនពីផ្ទាំងធំ ដោយចាប់ផ្តើមជាមួយការរៀបរាប់ទាក់ទងនឹងការបញ្ចប់នៃរជ្ជកាលរបស់ស្តេចបេនយ៉ាមីន និង ការបម្រើរបស់ទ្រង់ (សូមមើល ម៉ូសាយ ១:១, ៩) ។

គម្រោង

ពាក្យសម្តីនៃមរមន ១:១–៩ មរមនរកឃើញផ្ទាំងនីហ្វៃតូច ហើយបញ្ចប់វាដោយសេចក្តីសង្ខេបពីផ្ទាំងធំរបស់គាត់ ។

ពាក្យសម្តីនៃមរមន ១:១០–១៨ មរមនសង្ខេបពីរជ្ជកាលនៃស្តេចបេនយ៉ាមីន ។

សេចក្តីផ្តើមអំពី

គម្ពីរម៉ូសាយ

ហេតុអ្វីបានជាសិក្សាអំពីគម្ពីរនេះ ?

នៅក្នុងការសិក្សារបស់ពួកគេអំពីគម្ពីរម៉ូសាយ សិស្សនឹងអានអំពីទីបន្ទាល់ដ៏មានឥទ្ធិពលពីបេសកកម្មរបស់ព្រះយេស៊ូវគ្រីស្ទ ។ ពួកគេក៏នឹងរៀនអំពីប្រជាជន ដែលព្រះអម្ចាស់បានដោះលែងពីសេវកភាពនៃអំពើបាប ឬ ពីការជិះជាន់ខាងរាងកាយ ។ ជាងនេះទៅទៀត សិស្សនឹងរៀនពីរបៀបដែលការខិតខំដ៏សុចរិតនៃបុគ្គលម្នាក់ៗដូចជា ស្តេចបេនយ៉ាមីន អ័ប៊ីណាដៃ និង អាលម៉ា បាននាំមកនូវពរជ័យដ៏ធំអស្ចារ្យដល់អ្នកដទៃទៀត ។ ផ្ទុយទៅវិញ សិស្សនឹងឃើញពីរបៀបដែលការជ្រើសរើសខុសរបស់បុគ្គលម្នាក់ៗដូចជា ស៊ីនិព្ធ និង កូនប្រុសរបស់គាត់ ស្តេចណូអេ បាននាំមកនូវលទ្ធផលអវិជ្ជមានជាច្រើនដល់ខ្លួនគេ និង ប្រជាជនរបស់ពួកគេ ។

តើអ្នកណាសរសេរគម្ពីរនេះ ?

មរមនបានចងក្រង និង សង្ខេបកំណត់ត្រារបស់អ្នកសរសេរផ្សេងទៀតជាច្រើន ដើម្បីបង្កើតជាគម្ពីរម៉ូសាយ ។ គម្ពីរនេះជាក់ឈ្មោះតាម ម៉ូសាយ ដែលជាកូនប្រុសម្នាក់របស់ស្តេចបេនយ៉ាមីន ។ ម៉ូសាយគឺជាព្យាការី អ្នកមើលឆុត អ្នកព្យាករ និង ជាស្តេចមួយអង្គដែលគ្រប់គ្រងនៅក្នុងសាវ៉ាហិមឡាប្រហែលពីឆ្នាំ ១២៤ម.គ.ស. ដល់ឆ្នាំ ៩១ ម.គ.ស. ។ ទ្រង់មាននាមតាមអយ្យកោរបស់ទ្រង់នាម ម៉ូសាយ ដែលជាស្តេចនៃសាវ៉ាហិមឡាដែរ (សូមមើល អោមណៃ ១:១២–១៣, ១៩) ។

មរមនបានដកស្រង់ចេញពីកំណត់ត្រាមួយចំនួន ដើម្បីចងក្រងជាគម្ពីរម៉ូសាយ ។ គាត់បានសង្ខេប និង ដកស្រង់ពីកំណត់ត្រាដែលបានរក្សាទុកដោយម៉ូសាយនៅលើផ្ទាំងនីហ្វៃធំ ដែលបានពិពណ៍នាលម្អិតអំពីប្រវត្តិសាស្ត្ររបស់សាសន៍នីហ្វៃនៅក្នុងដែនដីសាវ៉ាហិមឡា (សូមមើល ម៉ូសាយ ១–៧; ២៥–២៩) ។ គាត់ក៏បានដកស្រង់ពីកំណត់ត្រារបស់ស៊ីនិព្ធ ដែលរៀបរាប់ពីប្រវត្តិសាស្ត្រនៃប្រជាជនស៊ីនិព្ធចាប់ពីពេលដែលពួកគេបានចាកចេញពីដែនដីសាវ៉ាហិមឡា រហូតដល់ពួកគេបានត្រឡប់មកវិញ (សូមមើល ម៉ូសាយ ៧–២២) ។ លើសពីនេះទៅទៀត មរមនបានដកស្រង់ និង សង្ខេបផ្នែកជាច្រើនពីការសរសេររបស់អាលម៉ា ដែលបានរក្សាទុកពាក្យសម្ពីរបស់អ័ប៊ីណាដៃ និង បានទុកនូវកំណត់ត្រាមួយនៃប្រជាជនផ្ទាល់របស់លោក (សូមមើល ម៉ូសាយ ១៧:៤; ១៨; ២៣–២៤) ។

តើគម្ពីរនេះត្រូវបានសរសេរសម្រាប់អ្នកណា ហើយតើហេតុអ្វី ?

មរមនមិនបានវ៉ាយវ៉ាប់គម្ពីរម៉ូសាយទៅដល់អ្នកអាន ឬ រដ្ឋជាក់លាក់ណាមួយ ថាហេតុអ្វីបានជាគាត់សរសេរគម្ពីរនេះនោះទេ ។ ទោះជាយ៉ាងណាក្តី គម្ពីរម៉ូសាយបានដើរតួយ៉ាងសំខាន់ដល់គោលបំណងទាំងឡាយនៃព្រះគម្ពីរមរមន ដើម្បីធ្វើជាសាក្សីថា— ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ និង ដើម្បីធ្វើឲ្យសេចក្តីសញ្ញារបស់ព្រះអម្ចាស់បានត្រូវគេស្គាល់ (សូមមើល ទំព័រចំណងជើងនៃព្រះគម្ពីរមរមន) ។ គម្ពីរម៉ូសាយរួមមានសេចក្តីថ្លែងសំខាន់ពីរអំពីបេសកកម្មរបស់ព្រះយេស៊ូវគ្រីស្ទ ៖ ៣ក្យសម្ពីនៃស្តេចបេនយ៉ាមីននៅក្នុង ម៉ូសាយ ២–៥ និង ៣ក្យសម្ពីរបស់អ័ប៊ីណាដៃនៅក្នុង ម៉ូសាយ ១២–១៦ ។ បន្ថែមលើនេះ គម្ពីរម៉ូសាយបង្ហាញឡើងវិញពីសារៈសំខាន់ក្នុងការបង្កើត និង ការកាន់តាមសេចក្តីសញ្ញាជាមួយនឹងព្រះអម្ចាស់ (សូមមើល ម៉ូសាយ ៥:៥–៩; ១៨:៥–១០; ២១:៣១–៣២; ២៤:១៣–១៥; ២៥:១៦–១៨; ២៦:២០) ។

តើគម្ពីរនេះត្រូវបានសរសេរនៅពេលណា និង នៅកន្លែងណា ?

កំណត់ត្រាដើមដែលធ្វើជាប្រភពសម្រាប់គម្ពីរម៉ូសាយ ហាក់ត្រូវបានសរសេរនៅរវាងឆ្នាំ ២០០ ម.គ.ស. និង ឆ្នាំ ៩១ ម.គ.ស. ។ មរមនបានសង្ខេបកំណត់ត្រាទាំងនោះក្នុងពេលរវាងឆ្នាំ ៣៤៥ គ.ស និង ឆ្នាំ ៣៨៥ គ.ស ។ មរមនមិនបានកត់ត្រាពីទីកន្លែងរបស់គាត់ នៅពេលគាត់បានចងក្រងគម្ពីរនេះទេ ។

តើគម្ពីរនេះមានលក្ខណៈខុសគ្នាអ្វីខ្លះ ?

ម៉ូសាយគឺជាគម្ពីរទីមួយនៅក្នុងព្រះគម្ពីរមរមន ដែលជាសេចក្តីសង្ខេបមួយពីផ្ទាំងនីហ្វៃធំ ។ វាផ្តល់នូវការបង្រៀនដែលទាក់ទងនឹងសមត្ថភាពនៃអ្នកមើលឆុតម្នាក់ (សូមមើល ម៉ូសាយ ៨:១៣–១៨; ២៨:១០–១៧) ។ បន្ថែមលើនេះ គម្ពីរម៉ូសាយគឺមានតែមួយនៅក្នុងការរៀបរាប់ពីបទពិសោធន៍នានា និង ការធ្វើដំណើររបស់សាសន៍នីហ្វៃនៃក្រុមបែកពីគ្នា—អ្នកដែលនៅក្នុងដែនដីសាវ៉ាហិមឡា អ្នកដែលត្រូវបានគ្រប់គ្រងដោយស៊ីនិព្ធ ណូអេ និង លិមហៃនៅក្នុងដែនដីនីហ្វៃ ហើយនិងអ្នកដែលបានរត់ចេញពីដែនដីនីហ្វៃជាមួយនឹងអាលម៉ា ។ ដើម្បីរៀនឲ្យច្បាស់ជាងនេះអំពីក្រុមទាំងនេះ អ្នកអាចយោងទៅសេចក្តីសង្ខេបនៃការធ្វើដំណើរទាំងឡាយនៅក្នុង ម៉ូសាយ ៧–២៤ ដែលមាននៅក្នុងសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។

គម្ពីរម៉ូសាយពិពណ៍នាពីការរួបរួមនៃប្រជាជនដែលត្រូវបានដឹកនាំដោយលិមហៃ និង អាលម៉ាជាមួយនឹងសាសន៍នីហ្វៃនៅក្នុងដែនដីសាវ៉ាហិមឡាផងដែរ (សូមមើល ម៉ូសាយ ២៥:១–១៣) ។ វាក៏ផ្តល់នូវសេចក្តីលម្អិតអំពីការគ្រប់គ្រងនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៅទូទាំងដែនដីសាវ៉ាហិមឡា (សូមមើល ម៉ូសាយ ២៥:១៤–២៤; ២៦) ។ ជាទីបញ្ចប់ គម្ពីរម៉ូសាយណែនាំពីរដ្ឋកាលនៃពួកចៅក្រម (សូមមើល ម៉ូសាយ ២៩) ។

គម្រោង

ម៉ូសាយ ១–៥ ស្តេចបេនយ៉ាមីនចាត់តាំងកូនប្រុសរបស់ទ្រង់ ម៉ូសាយ ជាអ្នកបន្តរាជ្យរបស់ទ្រង់ ហើយប្រទាននូវដំណើររឿងនៃរដ្ឋកាលរបស់ទ្រង់ ។ បេនយ៉ាមីនបង្រៀនអំពីព្រះយេស៊ូវគ្រីស្ទ ហើយបានអញ្ជើញប្រជាជនរបស់ទ្រង់ឲ្យចូលមកក្នុងសេចក្តីសញ្ញាមួយជាមួយនឹងព្រះ ។

ម៉ូសាយ ៦–៨ ម៉ូសាយចាប់ផ្តើមរដ្ឋកាលរបស់គាត់ ។ អាំម៉ូន និង អ្នក ១៥ នាក់ទៀតស្វែងរកកូនចៅនៃប្រជាជនរបស់ស៊ីនិព្ធនៅក្នុងដែនដីនីហ្វៃ ។ អាំម៉ូនជួបនឹងស្តេចលិមហៃ ចៅប្រុសរបស់ស៊ីនិព្ធ ហើយបានរៀនពីរបៀបដែលប្រជាជនត្រូវបានធ្លាក់ទៅក្នុងសេវកភាព ។

ម៉ូសាយ ៩–១៧ ប្រវត្តិសាស្ត្រមួយអំពីប្រជាជនរបស់ស៊ីនិព្ធត្រូវបានផ្តល់ ។ ក្រោយពីការស្លាប់របស់ស៊ីនិព្ធ កូនប្រុសរបស់គាត់ ណូអេ គ្រប់គ្រងនៅក្នុងសេចក្តីទុច្ចរិត ។ អ័ប៊ីណាដៃថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ហើយជាស់តឿនស្តេចណូអេ និង ប្រជាជនរបស់ទ្រង់ឲ្យប្រែចិត្ត ។ អ័ប៊ីណាដៃត្រូវកាត់ទោសដោយភ្លើង ។

ម៉ូសាយ ១៨–២០ អាលម៉ា ជាសង្ឃម្នាក់របស់ស្តេចណូអេ បានប្រែចិត្ត ។ គាត់បង្រៀនដំណឹងល្អ ហើយបានរត់ចេញជាមួយនឹងអ្នកដើរតាមគាត់ទៅកាន់វាលរហោស្ថាន ។ សាសន៍នីហ្វៃនៅក្នុងដែនដីនីហ្វៃត្រូវបានវាយប្រហារដោយសាសន៍លេមិន ហើយត្រូវបានដាក់នៅក្នុងសេវកភាព ។ ណូអេត្រូវបានប្រជាជនរបស់ទ្រង់សម្លាប់ ហើយត្រូវបានស្នងដោយកូនប្រុសរបស់ទ្រង់ លិមហៃ ។

ម៉ូសាយ ២១–២២ លិមហៃ និង ប្រជាជនរបស់ទ្រង់ បានកែប្រែចិត្ត ។ ព្រះអម្ចាស់បានដោះលែងពួកគេចេញពីសេវកភាព ហើយអាំម៉ូនដឹកនាំពួកគេទៅកាន់ដែនដីសាវ៉ាហិមឡា ។

ម៉ូសាយ ២៣–២៤ អាលម៉ា និង អ្នកដើរតាមគាត់បានបង្កើតទីក្រុងហេឡាម ។ ពួកគេត្រូវបានដាក់នៅក្នុងសេវកភាពដោយសាសន៍លេមិន ហើយត្រូវបានកាត់ទោសដោយអាមូឡុន និង បងប្អូនរបស់គាត់ ដែលជាពួកសង្ឃពីមុនរបស់ស្តេចណូអេ ។ ព្រះអម្ចាស់ដោះលែងអាលម៉ា និង ប្រជាជនរបស់គាត់ ហើយដឹកនាំពួកគេទៅកាន់ដែនដីសាវ៉ាហិមឡា ។

ម៉ូសាយ ២៥–២៩ សាសន៍នីហ្វៃរួបរួមគ្នានៅក្នុងការដឹកនាំរបស់ម៉ូសាយ ហើយអាលម៉ាដឹកនាំសាសនាចក្រ ។ កូនប្រុសរបស់អាលម៉ា ឈ្មោះអាលម៉ា (ជាញឹកញាប់ត្រូវបានហៅថា អាលម៉ាជាកូន) និង កូនប្រុសរបស់ម៉ូសាយបានប្រែចិត្តជឿ ។ មុនពេលម៉ូសាយសុគត ទ្រង់ស្ថាបនារដ្ឋកាលនៃពួកចៅក្រម ។

ពាក្យសម្តីនៃមរមន –ម៉ូសាយ ១

សេចក្តីផ្តើម

គម្ពីរដែលមានចំណងជើងថា ពាក្យសម្តីនៃមរមន ជួយជាស្ពានមួយរវាងផ្នាំងនីហ្វៃតូច និង សេចក្តីសង្ខេបពីផ្នាំងនីហ្វៃធំរបស់មរមន ។ នៅក្នុងគម្ពីរនេះ គម្ពីរដែលមរមនបានសរសេរជិត ៤០០ ឆ្នាំក្រោយពីការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ មរមនបានពន្យល់ថា គាត់បានស្វែងរកការដឹកនាំពីព្រះ ហើយត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធអំពីអ្វីដែលត្រូវកត់ចុលទៅក្នុងកំណត់ត្រារបស់គាត់ ។ គាត់ក៏បានលើកឡើងពីស្តេចបេនយ៉ាមីន និង ផ្តល់តម្លៃអំពីហេតុផលដែលស្តេចបេនយ៉ាមីនបានមានឥទ្ធិពលយ៉ាងខ្លាំងទៅលើប្រជាជនរបស់ទ្រង់ ។ ម៉ូសាយ ១ រួមមានការបង្រៀនខ្លះៗរបស់ស្តេចបេនយ៉ាមីនដល់កូនប្រុសរបស់ទ្រង់ ។ ទ្រង់បានបង្រៀនពួកគេថា ព្រះគម្ពីរជួយយើងឲ្យចងចាំដល់ព្រះ និង កាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

ពាក្យសម្តីនៃមរមន ១:១–១១

មរមនថ្លែងទីបន្ទាល់ថា ព្រះបានរក្សាទុកនូវកំណត់ត្រាផ្សេងទៀតសម្រាប់គោលបំណងដ៏ឈ្លាសវៃមួយ

សូមឲ្យសិស្សគិតអំពីពេលមួយ នៅពេលព្រះវិញ្ញាណបានបំផុសពួកគេឲ្យធ្វើអ្វីមួយ ។ អ្នកអាចឲ្យពួកគេសរសេរអំពីបទពិសោធន៍នេះ នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ ដើម្បីជួយពួកគេឲ្យគិតអំពីបទពិសោធន៍នេះ អ្នកអាចចែកចាយពីបទពិសោធន៍ផ្ទាល់ខ្លួនដ៏ខ្លីមួយ ។ សូមឲ្យសិស្សដឹងថា វគ្គបន្តទៀតនៅក្នុងមេរៀននេះ អ្នកនឹងសួរពួកគេពីរបីនាក់ឲ្យចែកចាយពីបទពិសោធន៍របស់ខ្លួនជាមួយនឹងសិស្សក្នុងថ្នាក់ ។

សូមពន្យល់ដល់សិស្សថា ថ្ងៃនេះពួកគេនឹងសិក្សាពីគំរូរបស់នរណាម្នាក់ ដែលបានធ្វើតាមការបំផុសគំនិត ទោះបីជាគាត់មិនបានយល់ពីហេតុផលទាំងអស់ថាហេតុអ្វីបានជាគាត់ត្រូវធ្វើតាមនោះទេ ។

សូមឲ្យសិស្សបើកទៅពាក្យសម្តីនៃមរមន ហើយស្វែងរក (នៅគែមខាងក្រោមទំព័រ ឬ នៅក្នុងសេចក្តីសង្ខេបជំពូក) កាលបរិច្ឆេទដែលប៉ាន់ស្មាន នៅពេលមរមនបានសរសេរគម្ពីរនេះ ។ សូមឲ្យពួកគេប្រៀបធៀបកាលបរិច្ឆេទនោះ ជាមួយនឹងកាលបរិច្ឆេទសម្រាប់គម្ពីរអេមណៃ និង ម៉ូសាយ ។

- តើយើងបានរៀនអ្វីខ្លះអំពីពាក្យសម្តីនៃមរមនពីកាលបរិច្ឆេទទាំងនេះ ?

សូមបង្ហាញរូបភាពមរមនសង្ខេបផ្នាំងទាំងទ្បាយ (៦២៥២០ *សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ | លេខ ៧៣) ។ សូមអញ្ជើញសិស្សម្នាក់អាន ពាក្យសម្តីនៃមរមន ១:១–២ ឮៗ ។ សូមជួយសិស្សឲ្យយល់ថា មរមនបានសរសេរគម្ពីរដែលមានចំណងជើងថា ពាក្យសម្តីនៃមរមន ក្រោយពីព្រឹត្តិការណ៍ជាច្រើននៃព្រះគម្ពីរមរមនបានកើតឡើង ។ សូមពន្យល់ថា ពាក្យសម្តីនៃមរមនជួយយើងឲ្យយល់ថា ព្រះគម្ពីរមរមនត្រូវបានចងក្រងពីកំណត់ត្រាផ្សេងៗជាច្រើន ។ វាក៏បង្ហាញផងដែរថា វិវរណៈបានដឹកនាំដំណើរការនេះ ។

សូមជួយសិស្សឲ្យមើលឃើញពីរបៀបដែលពាក្យសម្តីនៃមរមន ផ្នាំងចំណារតូចរបស់នីហ្វៃ និង សេចក្តីសង្ខេបរបស់មរមនពីផ្នាំងចំណារធំរបស់នីហ្វៃប្រសព្វគ្នាយ៉ាងណានៅក្នុងព្រះគម្ពីរមរមននោះ សូមគិតពីការបង្ហាញដល់សិស្សនូវតារាងមានចំណងជើងថា " ផ្នាំងទាំងទ្បាយ និង ទំនាក់ទំនងរបស់ពួកគេទៅនឹងព្រះគម្ពីរមរមនដែលបានបោះពុម្ព " នៅក្នុងសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។ អ្នកក៏អាចរៀបចំនូវជំនួយដូចខាងក្រោមមុនចាប់ផ្តើមថ្នាក់ដែរ ៖

ប្រមូលសៀវភៅពីរក្បាល និង ក្រដាសមួយសន្លឹក ។ សៀវភៅមួយគួរតែក្រាស់ជាងសៀវភៅមួយទៀតពីរដង ។ នៅលើខ្នងនៃសៀវភៅស្តើង សូមភ្ជាប់ក្រដាសមួយសរសេរថា *ផ្នាំងចំណារតូចរបស់នីហ្វៃ* ។នៅលើខ្នងនៃសៀវភៅក្រាស់ សូមភ្ជាប់ក្រដាសមួយសរសេរថា *សេចក្តីសង្ខេបរបស់មរមនពីផ្នាំងចំណារធំរបស់នីហ្វៃ* ។នៅលើក្រដាសមួយសន្លឹកនោះ សូមសរសេរថា *ពាក្យសម្តីនៃមរមន* ។

ដើម្បីប្រើជំនួយនេះនៅក្នុងថ្នាក់ សូមលើកសៀវភៅតំណាងឲ្យសេចក្តីសង្ខេបពីផ្នាំងនីហ្វៃធំរបស់មរមន ។ សូមពន្យល់ថា កំណត់ត្រាទាំងទ្បាយនៅក្នុងផ្នាំងនីហ្វៃធំគឺជាប្រភពចម្បងដល់ព្រះគម្ពីរមរមន ។ ចេញពីសេចក្តីសង្ខេបរបស់មរមនលើកំណត់ត្រានេះ យ៉ូសែប ស៊្មីធ បានបកប្រែគម្ពីរម៉ូសាយ អាលម៉ា ហេលេមិន នីហ្វៃទី ៣ និង នីហ្វៃទី ៤ ។

សូមអញ្ជើញសិស្សឲ្យអាន ពាក្យសម្តីនៃមរមន ១:៣ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើលអ្វីដែលមរមនបានរកឃើញ ក្រោយពីគាត់បានសង្ខេបផ្នែកមួយនៃផ្នាំងនីហ្វៃធំហើយ ។ នៅពេលសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ សូមជួយពួកគេឲ្យយល់ឃ្លាថា" ផ្នាំងទាំងនេះ " សំដៅទៅលើផ្នាំងនីហ្វៃតូច ។ សូមលើកសៀវភៅឡើង ដើម្បីជាតំណាងឲ្យផ្នាំងនីហ្វៃតូច ។ សូមពន្យល់ថា ចេញពីកំណត់ត្រានេះ យ៉ូសែប ស៊្មីធ បានបកប្រែគម្ពីរនីហ្វៃទី ១ ដល់គម្ពីរអេមណៃ ។

សូមឲ្យសិស្សអាន ពាក្យសម្តីនៃមរមន ១:៤–៦ ដើម្បីរៀនពីរបៀបដែលមរមនមានអារម្មណ៍អំពីផ្នាំងនីហ្វៃតូច ។

- តើមរមនបានរកឃើញអ្វីដែលរីករាយនៅក្នុងផ្នាំងនីហ្វៃតូច ?
- តើមរមនបានធ្វើអ្វី ជាមួយនឹងផ្នាំងនីហ្វៃតូច ?

ដើម្បីបង្ហាញថា មរមនបានបញ្ចូលផ្នាំងនីហ្វៃតូចជាមួយនឹងសេចក្តីសង្ខេបរបស់គាត់ពីផ្នាំងនីហ្វៃធំ សូមដាក់សៀវភៅស្តើងនៅលើសៀវភៅក្រាស់ ។

សូមអញ្ជើញសិស្សម្នាក់អាន ពាក្យសម្តីនៃមរមន ១:៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកហេតុផលរបស់មរមនដែលគាត់បានបញ្ចូលផ្នាំងនីហ្វៃតូចជាមួយនឹងសេចក្តីសង្ខេបរបស់គាត់ពីផ្នាំងនីហ្វៃធំ ។

- ហេតុអ្វីបានជាមរមនបញ្ចូលផ្នាំងនីហ្វៃតូចជាមួយនឹងសេចក្តីសង្ខេបរបស់គាត់ពីផ្នាំងនីហ្វៃធំ ? (គាត់បានធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណ ។) តើគាត់យល់ពីហេតុផលទាំងអស់ដែលគាត់ត្រូវធ្វើតាមឬទេ ?

សូមជួយសិស្សឲ្យយល់ថា មរមនបានយល់ពីហេតុផលមួយចំនួន ថាហេតុអ្វីបានជាផ្នាំងតូចអាចមានសារៈសំខាន់ ។ គាត់បានស្គាល់ពីតម្លៃខាងវិញ្ញាណដ៏អស្ចារ្យនៃផ្នាំងនោះ ហើយបានរីករាយនឹងការព្យាករណ៍អំពីព្រះយេស៊ូវគ្រីស្ទដែលគម្ពីរនោះមាន (សូមមើល ពាក្យសម្តីនៃមរមន ១:៤–៦) ។ ទោះជាយ៉ាងណាក្តី គាត់មិនបានដឹងពីហេតុផលទាំងអស់ថាហេតុអ្វីគាត់ត្រូវបញ្ចូលវាបន្ថែមលើផ្នែកនៃផ្នាំងធំ ដែលមានពេលវេលាប្រវត្តិសាស្ត្រដូចគ្នានោះទេ ។ (ដើម្បីអានអំពីហេតុផលមួយដែលមរមនមិនបានដឹងនៅពេលនោះ សូមមើលសេចក្តីផ្តើមអំពីពាក្យសម្តីនៃមរមននៅក្នុងសៀវភៅណែនាំនេះ) ។

សូមឲ្យសិស្សរំឭក ពាក្យសម្តីនៃមរមន ១:៧ ដោយស្ងាត់ស្ងៀម ដោយរកមើលពីគោលលទ្ធិទាំងឡាយដែលមរមនបានបង្រៀនអំពីព្រះអម្ចាស់ ។ សូមប្រាកដថា ពួកគេយល់ថា **ព្រះអម្ចាស់ទ្រង់ជ្រាបគ្រប់ការណ៍ទាំងអស់** ហើយថា**ព្រះអម្ចាស់អាចធ្វើការតាមរយៈយើង ដើម្បីសម្រេចនូវព្រះឆន្ទៈរបស់ទ្រង់** ។

- តើគោលលទ្ធិទាំងនេះអាចជួយមរមនឲ្យធ្វើសកម្មភាពតាមការបំផុសគំនិត ដែលគាត់បានទទួលដោយរបៀបណា ?
- តើសេចក្តីពិតទាំងនេះអាចជួយអ្នក នៅពេលអ្នកទទួលការបំផុសគំនិតពីព្រះវិញ្ញាណដោយរបៀបណា ?

សូមលើកទឹកចិត្តសិស្សឲ្យរំឭកពីស្ថានភាពដែលពួកគេបានសរសេរ ឬ គិតនៅពេលចាប់ផ្តើមថ្នាក់ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្រាប់ពីការបំផុសដែលពួកគេបានទទួល ពីរបៀបដែលពួកគេធ្វើសកម្មភាពតាមការបំផុសគំនិតទាំងនោះ ហើយអ្វីដែលបានកើតឡើងជាលទ្ធផល ។ (សូមប្រាកដថា ពួកគេយល់ថា ពួកគេមិនចាំបាច់មានអារម្មណ៍ថាត្រូវតែចែកចាយពីបទពិសោធន៍ដែលវាផ្ទាល់ខ្លួន ឬ ឯកជននោះទេ) ។ នៅពេលសិស្សចែកចាយបទពិសោធន៍របស់ពួកគេ អ្នកអាចសួរនូវសំណួរមួយចំនួនដូចខាងក្រោម ៖

- តើអ្នកដឹងពីអ្វីដែលនឹងកើតឡើងទេ ប្រសិនបើអ្នកធ្វើតាមការបំផុសនេះ ?
- តើអ្វីដែលធ្វើឲ្យអ្នកសម្រេចចិត្ត និង មានសេចក្តីជំនឿដើម្បីធ្វើសកម្មភាពតាមការបំផុសគំនិតនោះ ?

សូមលើកសៀវភៅដែលតំណាងឲ្យសេចក្តីសង្ខេបរបស់មរមនពីផ្នាំងធំ ជាមួយនឹងសៀវភៅដែលតំណាងឲ្យផ្នាំងនីហ្វៃតូចដែលនៅពីលើវានោះ ។ បន្ទាប់មក សូមលើកក្រដាសមួយសន្លឹកដែលតំណាងឲ្យពាក្យសម្តីនៃមរមន ។

- តើពាក្យសម្តីនៃមរមនប្រសព្វគ្នានឹងកំណត់ត្រាផ្សេងទៀតទាំងនេះត្រង់ណា ?

នៅពេលសិស្សឆ្លើយ សូមដាក់ក្រដាសតំណាងឲ្យពាក្យសម្តីនៃមរមន នៅចន្លោះសៀវភៅទាំងនេះ ។ សូមពន្យល់ថា ពាក្យសម្តីនៃមរមនធ្វើជាស្ពានមួយដែលភ្ជាប់ដំណើរសាច់រឿងរវាងផ្នាំងចំណារតូចរបស់នីហ្វៃ និង សេចក្តីសង្ខេបរបស់មរមនពីផ្នាំងចំណារធំរបស់នីហ្វៃ ។

សូមអញ្ជើញសិស្សម្នាក់អាន ពាក្យសម្តីនៃមរមន ១:៨ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកអ្វីដែលមរមនសង្ឃឹមថានឹងជាលទ្ធផលនៃការធ្វើតាមការបំផុសគំនិតឲ្យបញ្ចូលផ្នាំងចំណារតូចរបស់នីហ្វៃនៅក្នុងការចងក្រងកំណត់ត្រារបស់គាត់ ។

សូមបញ្ជាក់ថា ការសរសេរទាំងអស់ដែលសិស្សបានសិក្សាកន្លងមកនៅក្នុងឆ្នាំនេះ ក្នុងព្រះគម្ពីរមរមន (នីហ្វៃទី១ –អោមណៃ) អាចមានចំពោះពួកគេ ដោយសារមរមនបានធ្វើតាមការបំផុសខាងវិញ្ញាណឲ្យបញ្ចូលផ្នាំងចំណារតូចនោះ ។

- តើការគោរពតាមរបស់មរមនចំពោះការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធបានប្រទានពរដល់ជីវិតរបស់អ្នកដោយរបៀបណា ?
- តើការបង្រៀនអ្វីខ្លះនៅក្នុងនីហ្វៃទី ១ ដល់អោមណៃ ដែលអ្នកមានសេចក្តីអំណរចំពោះនោះ ? ហេតុអ្វីបានជាអ្នកមានសេចក្តីអំណរចំពោះការបង្រៀនទាំងនោះ ?
- សូមគិតអំពីឆន្ទៈរបស់មរមនក្នុងការធ្វើតាមការបំផុសគំនិតខាងវិញ្ញាណ ។ តើឆន្ទៈរបស់យើងក្នុងការធ្វើតាមការបំផុសគំនិតខាងវិញ្ញាណ ជះឥទ្ធិពលដល់ជីវិតរបស់យើងយ៉ាងណាខ្លះ ? តើឆន្ទៈនេះអាចជះឥទ្ធិពលដល់ជីវិតរបស់អ្នកដទៃដោយរបៀបណា ? (សូមពន្យល់ថា ព្រះអម្ចាស់អាចប្រទានពរដល់អ្នកដទៃ តាមរយៈយើងនៅពេលយើងធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ។)

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងមានភក្តីភាពចំពោះការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នោះព្រះអម្ចាស់នឹងធ្វើការ " នៅក្នុង | យើង | ដើម្បីធ្វើទៅតាមឆន្ទៈរបស់ទ្រង់ " (ពាក្យសម្តីនៃមរមន ១:៧) ។

ពាក្យសម្តីនៃមរមន ១:១២–១៨

ស្តេចបេនយ៉ាមីនបង្កើតសន្តិភាពនៅក្នុងដែនដី

សូមសរសេរ ពីការទាស់ទែងទៅជាសន្តិភាព នៅលើក្តារខៀន ។ សូមពន្យល់ថា ពាក្យសម្តីនៃមរមន ១:១២–១៨ ណែនាំពីរជ្ជកាលនៃស្តេចបេនយ៉ាមីន ។ បុរសដ៏សុចរិតនេះបានជួបប្រទះនឹងឧបសគ្គជាច្រើននៅក្នុងពេលគាត់បម្រើជាព្យាការីម្នាក់ និង ជាស្តេចនៃប្រជាជន ។ សូមបែងចែកសិស្សជាដៃគូ ហើយអាន ពាក្យសម្តីនៃមរមន ១:១២–១៨ ជាមួយនឹងដៃគូរបស់ពួកគេ ។ សូមឲ្យពួកគេរកនូវអ្វីដែលស្តេចបេនយ៉ាមីន និង ព្យាការីផ្សេងទៀតបានធ្វើដើម្បីបង្កើតសន្តិភាពនៅក្នុងដែនដី ។

ក្រោយពីសិស្សមានពេលអានរួចហើយ សូមឲ្យសិស្សម្នាក់ៗសរសេរប្រយោគមួយនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ដែលសង្ខេបនូវអ្វីដែលស្តេចបេនយ៉ាមីន និង ប្រជាជនរបស់ទ្រង់បានធ្វើ ដើម្បីផ្លាស់ប្តូរពីការទាស់ទែងគ្នាទៅជាសន្តិភាព ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យសរសេរប្រយោគរបស់ពួកគេនៅលើក្តារខៀន ។ ការសង្ខេបរបស់សិស្សអាចស្រដៀងគ្នាទៅនឹងប្រយោគដូចខាងក្រោម ៖

នៅពេលយើងធ្វើតាមការដឹកនាំដ៏បំផុសរបស់ព្យាការី យើងអាចបង្កើតនូវសន្តិភាព ។

នៅក្នុងកម្លាំងនៃព្រះអម្ចាស់ យើងអាចយកឈ្នះលើឧបសគ្គទាំងឡាយ ។

យើងត្រូវបានហៅឲ្យបម្រើដោយអស់ពីកម្លាំងរបស់យើង ដើម្បីបង្កើតសន្តិភាព ។

សូមទាញចំណាប់អារម្មណ៍របស់សិស្សទៅលើ ពាក្យសម្តីនៃមរមន ១:១៧ ដែលមរមនបាននិយាយថា ស្តេចបេនយ៉ាមីន និង " មនុស្សបរិសុទ្ធជាច្រើននៅលើដែនដី . . . បានថ្លែងព្រះបន្ទូលនៃព្រះប្រកបដោយអានុភាព និង សិទ្ធិអំណាច " ។ សូមពន្យល់ថា នៅក្នុងមេរៀនពីរបីបន្ទាប់ទៀត សិស្សនឹងសិក្សាពីការបង្រៀនដោយស្តេចបេនយ៉ាមីន ដែលលើកឧទាហរណ៍ពីអានុភាព និង អំណាចនៃការបង្រៀនរបស់គាត់ ។

> ***សូមឲ្យសិស្សប្រើពាក្យផ្ទាល់ខ្លួនរបស់ពួកគេ***
>
> នៅពេលសិស្សបង្ហាញពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ដែលពួកគេរកឃើញនៅក្នុងព្រះគម្ពីរ សូមកុំនិយាយថាចម្លើយរបស់ពួកគេខុស ដោយសារតែពួកគេមានចម្លើយខុសពីពាក្យដែលបានប្រើនៅក្នុងសៀវភៅណែនាំនេះនោះឡើយ ។ ទោះជាយ៉ាងណាក្តី ប្រសិនបើប្រយោគរបស់សិស្សម្នាក់ខុសពីគោលលទ្ធិ វាជាការទទួលខុសត្រូវរបស់អ្នកដើម្បីជួយគេដោយទន់ភ្លន់ក្នុងការកែតម្រូវប្រយោគនោះ ។ ការធ្វើដូច្នោះអាចផ្តល់នូវបទពិសោធន៍ក្នុងការសិក្សាដ៏សំខាន់ ដោយសារយើងបានរក្សាបរិយាកាសប្រកបដោយក្តីស្រឡាញ់ និង ទំនុកចិត្ត ។

ម៉ូសាយ ១:១–៨

ស្តេចបេនយ៉ាមីនបង្រៀនកូនប្រុសរបស់គាត់ពីសារៈសំខាន់នៃព្រះគម្ពីរ

សូមឲ្យសិស្សស្រមៃថា ពួកគេមិនដែលស្គាល់អ្វីបន្តិចសោះអំពីព្រះគម្ពីរ ។

- តើជីវិតរបស់អ្នកនឹងទៅជាយ៉ាងណា ប្រសិនបើអ្នកមិនដែលមានព្រះគម្ពីរនោះ ?
- តើសេចក្តីពិតណាមួយដែលពិបាកបំផុតដែលអ្នកមិនអាចរស់នៅដោយគ្មានវាបាន ?

សូមណែនាំដោយសង្ខេបអំពីគម្ពីរម៉ូសាយ ។ សូមពន្យល់ថា ដើមដំបូងនៃគម្ពីរនេះបង្ហាញពីបំណងប្រាថ្នារបស់ស្តេចបេនយ៉ាមីនចំពោះកូនប្រុសរបស់ទ្រង់ឲ្យបន្តរៀនពីព្រះគម្ពីរ (សូមមើល ម៉ូសាយ ១:២) ។ នៅពេលដែលស្តេចបេនយ៉ាមីនបានបង្រៀនបុត្រារបស់ទ្រង់ ទ្រង់បានពន្យល់ពីរបៀបដែលជីវិតរបស់ពួកគេនឹងខុសគ្នាយ៉ាងណា ប្រសិនបើពួកគេមិនដែលបានទទួលព្រះគម្ពីរនោះ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអាន ម៉ូសាយ ១:៣–៨ ឮៗ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលសាសន៍នីហ្វៃត្រូវបានប្រទានពរ ដោយសារពួកគេបានមានព្រះគម្ពីរ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរៀន ។

- តើតាមរបៀបណាដែលស្តេចបេនយ៉ាមីនជឿថា ព្រះគម្ពីរនឹងជួយបុត្រារបស់ទ្រង់នោះ ?
- តើអ្វីជាទំនាក់ទំនងរវាងការសិក្សាព្រះគម្ពីរដោយម៉ត់ចត់ និង ការកាន់តាមព្រះបញ្ញត្តិនៃព្រះ ដូចដែលស្តេចបេនយ៉ាមីនបានលើកឡើងនោះ ? (ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាដើម្បីប្រាប់ពីចម្លើយរបស់ពួកគេក៏ដោយ ពួកគេគួររកឃើញនូវសេចក្តីពិតដូចខាងក្រោមនេះ ៖ **ការសិក្សាព្រះគម្ពីរដោយហ្មត់ចត់ជួយយើងឲ្យដឹង និង កាន់តាមព្រះបញ្ញត្តិទាំងឡាយ ។** អ្នកអាចផ្តល់យោបល់ថា សិស្សគួរសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ ម៉ូសាយ ១:៣–៨) ។
- តើនៅពេលណាដែលការសិក្សាព្រះគម្ពីរបានជួយអ្នកឲ្យកាន់តាមព្រះបញ្ញត្តិទាំងឡាយនោះ ?

សូមចែកចាយទីបន្ទាល់របស់អ្នកថា ព្រះគម្ពីរគឺពិត ហើយថាព្រះគម្ពីរជួយយើងឲ្យកាន់តាមព្រះបញ្ញត្តិទាំងឡាយ ។

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ។ (អ្នកអាចសរសេរវាពីមុនចាប់ផ្តើមថ្នាក់) ។

តើស្តេចបេនយ៉ាមីនបានគ្រោងប្រកាសអ្វី អំពីបុត្រារបស់ទ្រង់ ម៉ូសាយ ?

តើស្តេចបេនយ៉ាមីនបានមានបន្ទូលអ្វីខ្លះអំពី " ឈ្មោះមួយ " ដែលរំលែកមនុស្សចេញពីគ្នា ?

ហេតុអ្វីបានជាសាសន៍នីហ្វៃមិនបានត្រូវបំផ្លាញដោយសាសន៍លេមិន ?

តើរបស់អ្វី ដែលស្តេចបេនយ៉ាមីនបានសុំឲ្យម៉ូសាយថែរក្សានោះ ?

សូមឲ្យសិស្សមានពេលមួយនាទី ហើយឃើញថាតើពួកគេអាចរកឃើញចម្លើយប៉ុន្មានចំពោះសំណួរទាំងនេះនៅក្នុង ម៉ូសាយ ១:១០–១៨ ។

ក្រោយពីសិស្សបានឆ្លើយដោយសង្ខេបទៅនឹងសំណួរទាំងនេះហើយ សូមបង្ហាញថានៅក្នុងមេរៀនពីរបីក្រោយទៀតពួកគេនឹងសិក្សាពីការបង្រៀនដែលស្តេចបេនយ៉ាមីនបានធ្វើទៅកាន់ប្រជាជនរបស់ទ្រង់ " ឈ្មោះមួយ ដែលនឹងមិនត្រូវលុបចោលបានឡើយ លើកលែងតែដោយការរំលង " (ម៉ូសាយ ១:១២) ។

ម៉ូសាយ ២

សេចក្តីផ្តើម

នៅពេលស្តេចបេនយ៉ាមីនជិតចូលទីវង្គត ទ្រង់មានបំណងប្រាថ្នាចង់បង្រៀនប្រជាជនរបស់ទ្រង់ជាលើកចុងក្រោយ ។ ការបង្រៀនរបស់ទ្រង់ ដែលត្រូវបានកត់ត្រានៅក្នុង ម៉ូសាយ ២ គឺជាប្រធានបទនៃមេរៀននេះ និង មេរៀនទី ៥៣–៥៥ ។ ពេលចាប់ផ្តើមបង្រៀន ទ្រង់បានប្រាប់ពីការបម្រើរបស់ទ្រង់ដល់ប្រជាជន ដោយបញ្ជាក់ថាយើងបម្រើដល់ព្រះ នៅពេលយើងបម្រើដល់អ្នកដទៃ ។ ទ្រង់ក៏បានថ្លែងទីបន្ទាល់អំពីស្ថានភាពជំរឹកឃាយនៃអស់អ្នកណាដែលកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ។

ការចែកចាយសេចក្តីសង្ខេបនៃសេចក្តីថ្លែងជ័រជែង

សៀវភៅណែនាំមេរៀននេះ ផ្តល់ការយកចិត្តទុកដាក់ពិសេសទៅដល់សេចក្តីថ្លែងប្រកបដោយការព្យាករពិសេសទាំងឡាយដូចជា ម៉ូសាយ ២–៥ ។ សេចក្តីថ្លែងទាំងនេះ ជាញឹកញាប់ត្រូវបានបង្រៀននៅក្នុងមេរៀនជាច្រើនដង ។ វាអាចជួយផ្តល់ជាសេចក្តីសង្ខេបខ្លីនៃសេចក្តីថ្លែងទាំងនេះ ។ នៅក្នុងមេរៀនថ្ងៃនេះ សេចក្តីសង្ខេបមេរៀនអាចជួយសិស្សឲ្យទទួលបាននូវការយល់ច្បាស់លាស់ជាងមុនអំពីគោលបំណងនៃទេសកថារបស់ស្តេចបេនយ៉ាមីន និង “ ការផ្លាស់ប្តូរដ៏ធំ ” ដែលប្រជាជនបានទទួលនៅក្នុងដួងចិត្តរបស់ពួកគេ នៅពេលពួកគេបានស្តាប់ (សូមមើល ម៉ូសាយ ៥:២) ។

យោបល់សម្រាប់ការបង្រៀន

កំណត់ចំណាំ ៖ ការសង្ខេបខាងក្រោមអាចជួយអ្នកបាន ប្រសិនបើអ្នកជ្រើសរើសដើម្បីផ្តល់សេចក្តីសង្ខេបនៃសេចក្តីថ្លែងរបស់ស្តេចបេនយ៉ាមីននៅពេលចាប់ផ្តើមថ្នាក់ ។

មកដល់ចុងបញ្ចប់នៃព្រះជន្មរបស់ទ្រង់ ស្តេចបេនយ៉ាមីនបានថ្លែងទៅកាន់ប្រជាជនក្នុងនគរទ្រង់នៅក្បែរព្រះវិហារបរិសុទ្ធនៅក្នុងដែនដីសារ៉ាហិមឡា ។ ទ្រង់បានប្រាប់ពីដំណើររឿងនៃការបម្រើរបស់ទ្រង់ទៅដល់ប្រជាជន និង ពីមនសិការដ៏ច្បាស់របស់ទ្រង់ចំពោះព្រះ ហើយទ្រង់បានបង្ហាញបុត្រារបស់ទ្រង់ ម៉ូសាយ ថាជាស្តេចថ្មីរបស់ប្រជាជននេះ ។ នៅក្នុងសេចក្តីថ្លែងចុងក្រោយរបស់ទ្រង់ ដែលមាននៅក្នុង ម៉ូសាយ ២–៥ ស្តេចបេនយ៉ាមីន បានចែកចាយសារលិខិតអំពីប្រធានបទជាច្រើនរួមមាន សារៈសំខាន់នៃការបម្រើអ្នកដទៃ ការជំពាក់ដ៏អស់កល្បរបស់យើងទៅដល់ព្រះវរបិតាសួគ៌ ការបម្រើខាងសាច់ឈាម និង ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ តម្រូវការដើម្បីស្រាតចោលនូវភាពខាងសាច់ឈាមចេញ ការជឿលើព្រះសម្រាប់សេចក្តីសង្គ្រោះ ការចែករំលែកដល់អ្នកក្រ ការទទួលបានការផ្តាច់បាប និង ការក្លាយជាបុត្រា និង បុត្រីនៃព្រះគ្រីស្ទតាមរយៈសេចក្តីជំនឿ និង ការបន្តធ្វើល្អជានិច្ច ។ នៅក្នុងកំណាត់ចំណាំពិសេស ម៉ូសាយ ៣ រួមមានសារលិខិតមួយដែលស្តេចបេនយ៉ាមីនបានទទួលពីទេវតាមួយអង្គ ។

ម៉ូសាយ ២:១–៩

គ្រួសារជាច្រើនប្រមូលផ្តុំគ្នា ហើយរៀបចំដើម្បីទទួលព្រះបន្ទូលរបស់ស្តេចបេនយ៉ាមីន

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀនផ្នែកខាងលើ ៖ *នរណា ? កន្លែងណា ? អ្វី ? ហេតុអ្វី ?*

សូមឲ្យសិស្សស្វែងរកនៅក្នុង ម៉ូសាយ ២:១–៦ ដោយស្ងៀមស្ងាត់ ដោយរកមើលសេចក្តីលម្អិតដែលឆ្លើយតបនឹងសំណួរនៅលើក្តារខៀន ។ ក្រោយពីពួកគេបានអានហើយ សូមអញ្ជើញសិស្សបីបួននាក់សរសេរសេចក្តីលម្អិតដែលពួកគេមានឲ្យបានច្រើនតាមដែលគេអាចនៅក្រោមសំណួរនីមួយៗលើក្តារខៀន ។ (អ្នកអាចពន្យល់ថា ប្រជាជនបានរៀបចំទទួលព្រះបន្ទូលរបស់ស្តេចបេនយ៉ាមីនដោយការលះបង់ទាក់ទងនឹងច្បាប់ម៉ូសេ ។ ក្នុងការលះបង់នេះ ប្រជាជនបានបង្ហាញការដឹងគុណដល់ព្រះ ហើយថ្វាយខ្លួនគេដល់ទ្រង់ ។)

សូមអញ្ជើញសិស្សឲ្យអាន ម៉ូសាយ ២:៩ ដោយស្ងាត់ស្ងៀម ដោយរកមើលពាក្យ និង ឃ្លាដែលបង្ហាញពីអ្វីដែលស្តេចបេនយ៉ាមីនចង់ឲ្យប្រជាជនធ្វើ នៅពេលពួកគេស្តាប់ពាក្យសម្តីរបស់ទ្រង់ ។

- ចេញពីពាក្យ និង ឃ្លាដែលពួកគេបានរកឃើញ តើអ្នកគិតថា ស្តេចបេនយ៉ាមីនមានព្រះទ័យយ៉ាងណាអំពីសារលិខិតរបស់ទ្រង់ ?
- យោងតាមផ្នែកចុងក្រោយនៃ ម៉ូសាយ ២:៩ តើស្តេចបេនយ៉ាមីនជឿថានឹងមានអ្វីកើតឡើង ប្រសិនបើប្រជាជនបើកត្រចៀក និង ដួងចិត្តរបស់ពួកគេស្តាប់តាមសារលិខិតរបស់ទ្រង់នោះ ?
- តើអ្នកគិតថា វាមានន័យយ៉ាងណា ដើម្បីបើកត្រចៀក និង ដួងចិត្តរបស់យើងស្តាប់តាមអ្នកដែលត្រូវបានហៅឲ្យបង្រៀន ?

សូមលើកទឹកចិត្តសិស្សឲ្យចងចាំពីការអញ្ជើញរបស់ស្តេចបេនយ៉ាមីន នៅពេលពួកគេសិក្សាសារលិខិតរបស់ទ្រង់ និង នៅពេលពួកគេស្តាប់តាមពាក្យសម្តីរបស់ព្យាការីថ្ងៃចុងក្រោយទាំងឡាយ ។

ម៉ូសាយ ២:១០–២៨

ស្តេចបេនយ៉ាមីនបង្រៀនអំពីសារៈសំខាន់នៃការបម្រើព្រះ និង ការបម្រើគ្នាទៅវិញទៅមក និង អំពីការជំពាក់ដ៏អស់កល្បរបស់យើងចំពោះព្រះ

សូមបង្ហាញសិស្សពីរូបភាពស្តេចបេនយ៉ាមីន ដែលថ្លែងទៅកាន់ប្រជាជនរបស់ទ្រង់ (៦២២៩៨ *សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ | លេខ ៧៨) ។ សូមរំឭកសិស្សថា ស្តេចបេនយ៉ាមីនបានហៅប្រជាជនរបស់ទ្រង់ឲ្យមកជួបជុំគ្នាដើម្បីប្រកាសថា បុត្រារបស់ទ្រង់ ម៉ូសាយ នឹងសោយរាជ្យបន្តជាស្តេច និង ដាក់ឲ្យពួកគេនូវ “ ឈ្មោះមួយដល់ប្រជាជននេះដើម្បីឲ្យគេអាចញែកចេញពីប្រជាជនទាំងអស់ដែលព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បាននាំចេញពីដែនដីយេរូសាឡិម ” (សូមមើល ម៉ូសាយ ១:៩–១២) ។

សូមអាន ម៉ូសាយ ២:១០–១៥ ឮៗក្នុងថ្នាក់ ។ សូមឲ្យសិស្សស្វែងរកឃ្លាដែលបង្ហាញពីការបារម្ភរបស់ស្តេចបេនយ៉ាមីនអំពីការបម្រើប្រជាជន មិនមែនអំពីកិត្តិនាម ឬ ការទទួលស្គាល់ផ្ទាល់ខ្លួនរបស់ទ្រង់ឡើយ ។ សូមអញ្ជើញពួកគេឲ្យលើកដៃឡើង នៅពេលពួកគេឮ

ឃ្លាមួយនៃឃ្លាទាំងនេះ ។ នៅពេលពួកគេលើកដៃ សូមឈប់អានសិន ហើយសុំឲ្យពួកគេពន្យល់ពីអ្វីដែលពួកគេបានរកឃើញ និង ពីអ្វីដែលវាបង្ហាញអំពីស្តេចបេនយ៉ាមីន ។

នៅផ្នែកនៃការពិភាក្សានេះ សូមចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហាវីដ ដបុលយូ ហ៊ីនធើរ ៖

“ សូមកុំបារម្ភខ្លាំងពេកពីកិត្តិនាម ។ . . . វាសំខាន់ដែលត្រូវបានគេសរសើរ ។ ប៉ុន្តែការផ្តោតរបស់យើងគួរតែនៅលើសេចក្តីសុចរិត មិនមែនការល្បីល្បាញទេ ផ្តោតលើការបម្រើ មិនមែនកិត្តិនាមនោះទេ ” (“ To the Women of the Church,” *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩២ ទំព័រ ៩៦) ។

សូមឲ្យសិស្សអាន ម៉ូសាយ ២:១៦–១៧ ដោយស្ងាត់ស្ងៀម ហើយរកនូវអ្វីដែលស្តេចបេនយ៉ាមីនចង់ឲ្យប្រជាជនរបស់ទ្រង់រៀន ។ សូមជួយពួកគេឲ្យឃើញថា **នៅពេលយើងបម្រើដល់អ្នកដទៃ នោះយើងបម្រើដល់ព្រះ ។** សូមសរសេរប្រយោគនេះនៅលើក្តារខៀន ។ សូមបង្ហាញថា ម៉ូសាយ ២:១៧ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកគួរលើកទឹកចិត្តដល់សិស្សឲ្យគូសចំណាំវគ្គនេះតាមរបៀបមួយដែលពួកគេនឹងអាចរកវាឃើញដោយងាយស្រួល ។

> **ម៉ូសាយ ២:១៧** គឺជាវគ្គចំណេះចំណានខគម្ពីរ ។ សូមបើកទៅគំនិតទាំងឡាយសម្រាប់ការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានវគ្គនេះ ។

សូមឲ្យសិស្សគិតអំពីពេល ដែលពួកគេបានបម្រើដល់អ្នកដទៃ ។

- នៅពេលដែលអ្នកបម្រើដល់អ្នកដទៃ តើអ្នកក៏អាចបម្រើដល់ព្រះដោយរបៀបណា ?
- តើនៅពេលណាដែលមានអ្នកដទៃបានប្រទានពរដល់ជីវិតអ្នក តាមរយៈការបម្រើ ? នៅពេលពួកគេបម្រើអ្នក តើពួកគេក៏បានបម្រើដល់ព្រះដោយរបៀបណា ?

សូមឲ្យសិស្សបីបួននាក់ឆ្លាស់គ្នាអាន ម៉ូសាយ ២:១៨–២៤, ៣៤ ឮៗ ។

- ហេតុអ្វីបានជាស្តេចបេនយ៉ាមីនហៅខ្លួនទ្រង់ និង ប្រជាជនរបស់ទ្រង់ថាជា “ អ្នកបម្រើដ៏ឥតប្រយោជន៍ ” ? (អ្នកអាចពន្យល់ថា ប្រជាជនយកដួលចំណេញ នៅពេលពួកគេទទួលបានច្រើនជាងពួកគេចាយ ។ យើងគឺជាអ្នកបម្រើដ៏ឥតប្រយោជន៍ចំពោះព្រះវរបិតាសួគ៌របស់យើង ដោយសារតម្លៃនៃពរជ័យដែលទ្រង់បានប្រទានដល់យើងនោះតែងតែលើសលប់ជាងតម្លៃនៃការបម្រើដែលទ្រង់បានទទួលពីយើង ។)
- តើពរជ័យអ្វីខ្លះដែលអ្នកបានទទួល ហើយអ្នកមានអារម្មណ៍ថានៅជំពាក់ដល់ព្រះ ?
- ហេតុអ្វីបានជាវាសំខាន់ដើម្បីដឹងថាយើង “ ជាប់ជំពាក់គុណដ៏អស់កល្បជានិច្ច ” ដល់ព្រះ ? (ចម្លើយអាចរួមមាន នៅពេលយើងដឹងថា យើងជាប់ជំពាក់គុណដល់ព្រះ នោះការដឹងគុណរបស់យើងនឹងកើនឡើង យើងមានបំណងចង់កាន់តាមព្រះបញ្ញត្តិទាំងឡាយ ហើយយើងចង់បម្រើដល់អ្នកដទៃកាន់តែខ្លាំង ។)

សូមពន្យល់ថា នៅក្នុង ម៉ូសាយ ២:៣៤ ពាក្យ *តបស្នងគុណ* មានន័យថា ឲ្យ ឬ ប្រគល់ឲ្យវិញ ។ សូមអញ្ជើញសិស្សឲ្យគិតពីរបៀបដែលពួកគេអាច “ តបស្នងគុណដល់ | ព្រះវរបិតាសួគ៌ | នូវអ្វីដែល | ពួកគេ | មាន ” ។ សូមថ្លែងទីបន្ទាល់ថា នៅពេលយើងកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ហើយស្វែងរកការបម្រើដោយចិត្តស្មោះ នោះទ្រង់នឹងប្រទានពរដល់យើង ។

ម៉ូសាយ ២:២៩–៤១

ស្តេចបេនយ៉ាមីនបានជាស់តឿនប្រជាជនរបស់ទ្រង់ឲ្យគោរពតាមព្រះ

សូមសរសេរ *ប្រយ័ត្ន* នៅលើក្តារខៀន ។ សូមឲ្យសិស្សប្រាប់អំពីពេលដែលពួកគេបានឃើញសញ្ញាមួយ ដែលប្រើពាក្យនេះ ឬក៏ទាក់ទងនឹងគំនិតនេះ ។ សូមបង្ហាញថា ការហាមក្រាមបែបនោះអាចការពារយើង ឬ ជួយសង្គ្រោះជីវិតរបស់យើង ។

សូមឲ្យសិស្សអាន ម៉ូសាយ ២:៣២–៣៣, ៣៦–៣៨ ដោយស្ងាត់ស្ងៀម ដោយរកមើលអ្វីដែលស្តេចបេនយ៉ាមីនបានប្រាប់ប្រជាជនរបស់ទ្រង់ឲ្យប្រយ័ត្ន ។ អ្នកអាចត្រូវពន្យល់ថា នៅក្នុង ម៉ូសាយ ២:៣៣ ពាក្យ *ការវេទនា* សំដៅទៅលើទុក្ខសោក និង ការសោកសង្រេង ។

- តើការហាមក្រាមអ្វីខ្លះ ដែលស្តេចបេនយ៉ាមីនបានប្រាប់ទៅប្រជាជនរបស់ទ្រង់ ?
- តើយើងអាចដឹងដោយរបៀបណា ថាយើងកំពុងចាប់ផ្តើមធ្វើតាមវិញ្ញាណខុសឆ្គងនោះ ? ហេតុអ្វីបានជាវាសំខាន់ដើម្បីដឹងពីការខុសឆ្គងនោះជាមុន ?
- យោងតាម ម៉ូសាយ ២:៣៨ តើអ្វីខ្លះជាផលវិបាកទៅដល់អ្នកដែលស្លាប់នៅក្នុងអំពើបាបរបស់ពួកគេ ?

អ្នកអាចបញ្ជាក់បន្ថែមពីការបង្រៀននេះនៅក្នុង ម៉ូសាយ ២:៣៦ ថាបុគ្គលម្នាក់ៗអាចលែងមានព្រះវិញ្ញាណនៃព្រះអម្ចាស់ ដោយសារអាកប្បកិរិយាផ្ទាល់របស់គេ ។ អែលឌើរ ដេវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់បានថ្លែងអំពីសារៈសំខាន់ក្នុងការដឹងនៅពេលយើងអាចលែងមានព្រះវិញ្ញាណ ៖

“ យើងគួរ . . . ព្យាយាមយល់ដឹង នៅពេលយើង ‹ ដកខ្លួនថយចេញពីព្រះវិញ្ញាណនៃព្រះអម្ចាស់ ដើម្បីកុំឲ្យព្រះវិញ្ញាណមានកន្លែងនៅក្នុងខ្លួន| យើង | ទៀតឡើយ ដើម្បីណែនាំ | យើង | ទៅតាមផ្លូវទាំងឡាយខាងប្រាជ្ញាដើម្បី | យើង | អាចបានពរចម្រើនឡើង ហើយស្ថិតស្ថេរជាប់នៅ › (ម៉ូសាយ ២:៣៦) ។ . . .

“ . . . ប្រសិនបើអ្វីមួយដែលយើងគិត ឃើញ ឮ ឬ ធ្វើឲ្យយើងចាកចេញពីព្រះវិញ្ញាណនៃព្រះ នោះយើងគួរឈប់គិត មើល ស្តាប់ ឬ ធ្វើរឿងនោះទៀត ។ ប្រសិនបើរឿងនោះមានបំណងដើម្បីកំសាន្ត ឧទាហរណ៍ ធ្វើឲ្យយើងលែងជិតស្និទ្ធនឹងព្រះវិញ្ញាណបរិសុទ្ធទៀត នោះវាប្រាកដណាស់ថាការកំសាន្តប្រភេទនោះគឺមិនមែនសម្រាប់យើងនោះទេ ។ ដោយសារព្រះវិញ្ញាណមិនអាចនៅជាមួយនឹងអ្វីដែលអាសគ្រាម គ្រោតគ្រាត ឬ ក្រអឺតក្រទមនោះទេ ដូច្នេះវាជាក់ច្បាស់ថាអ្វីបែបនោះគឺមិនមែនសម្រាប់យើងនោះទេ ។ ដោយសារយើងឃ្លាតឆ្ងាយពីព្រះវិញ្ញាណនៃព្រះ នៅពេលយើងធ្វើសកម្មភាពនានាដែលយើងដឹងថាយើងគួរតែចេញ នោះរឿងបែបនោះគឺ

ពិតជាមិនមែនសម្រាប់យើងនោះទេ " (" ដើម្បីឲ្យយើងតែងតែមានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយនឹងយើង " *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៦ ទំព័រ ៣០) ។

- តើអែលឌើរ បៃដណា បាននិយាយថាអ្វី ដែលនឹងគម្លាតយើងពីព្រះវិញ្ញាណបរិសុទ្ធ ?
- តើយើងអាចដឹង នៅពេលយើងឃ្លាតខ្លួនយើងពីព្រះវិញ្ញាណបរិសុទ្ធដោយរបៀបណា ?

សូមសរសេរពាក្យ *ចងចាំ* និង *ពិចារណា* នៅលើក្តារខៀន ក្បែរពាក្យ *ប្រយ័ត្ន* ។

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២:៤០–៤១ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលស្តេចបេនយ៉ាមីនចង់ឲ្យប្រជាជនរបស់ទ្រង់ពិចារណា និង អ្វីដែលទ្រង់ចង់ឲ្យពួកគេចងចាំ ។ នៅពេលសិស្សឆ្លើយ អ្នកអាចបញ្ជាក់ការបង្រៀនរបស់ស្តេចបេនយ៉ាមីនដោយការសរសេរនូវសេចក្តីពិតដូចខាងក្រោមនៅលើក្តារខៀន ៖ ***ប្រសិនបើយើងកាន់តាមព្រះបញ្ញត្តិទាំងឡាយ នោះយើងនឹងត្រូវបានប្រទានពរខាងសាច់ឈាម និង ខាងវិញ្ញាណ ។***

- តើនៅពេលណាដែលអ្នកបានធ្វើទីបន្ទាល់ ឬ ទទួលបទពិសោធន៍ពីសុភមង្គលដែលមកពីការគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ?

សូមថ្លែងទីបន្ទាល់អំពីសេចក្តីពិតនៃអ្វីដែលសិស្សបានពិភាក្សានៅថ្ងៃនេះ ។ សូមបញ្ចប់ដោយការលើកទឹកចិត្តសិស្សឲ្យដាក់គោលដៅជាក់លាក់ដើម្បីគោរពឲ្យបានខ្ជាប់ខ្ជួនជាងមុននៅក្នុងរឿងណាដែលពិបាកសម្រាប់ពួកគេ ឬ ខិតខំពង្រឹងខ្លួននៅក្នុងបញ្ហាណាមួយដែលមាននៅក្នុងការអភិវឌ្ឍផ្ទាល់ខ្លួន (សម្រាប់យុវនារី) ឬ កាតព្វកិច្ចចំពោះព្រះ (សម្រាប់យុវជន) ។

ចំណេះចំណានខគម្ពីរ —ម៉ូសាយ ២:១៧

សូមអញ្ជើញសិស្សឲ្យអាន ម៉ូសាយ ២:១៧, ម៉ាថាយ ២២:៣៦–៤០ និង ម៉ាថាយ ២៥:៤០ ។ វគ្គនៅក្នុងម៉ាថាយជួយបរិយាយពីគោលលទ្ធិ ជួយបន្ថែមការយល់ដឹង និង បញ្ជាក់ពីអត្ថន័យនៃ ម៉ូសាយ ២:១៧ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យភ្ជាប់ទំនាក់ទំនងខគម្ពីរដោយការសរសេរ *ម៉ាថាយ ២២:៣៦–៤០* ក្បែរ ម៉ូសាយ ២:១៧, *ម៉ាថាយ ២៥:៤០* ក្បែរ ម៉ាថាយ ២២:៣៦–៤០, និង *ម៉ូសាយ ២:១៧* ក្បែរ ម៉ាថាយ ២៥:៤០ ។

សូមឲ្យសិស្សពីរបីនាក់ប្រាប់ពីពេលដែលពួកគេបានមានអារម្មណ៍ថា ពួកគេបានកំពុងបម្រើព្រះដោយការបម្រើដល់អ្នកដទៃ ។

សូមអញ្ជើញឲ្យសិស្សបម្រើនរណាម្នាក់ មុនពេលចាប់ផ្តើមថ្នាក់សិក្ខាសាលាលើកក្រោយ ។ សូមជូរយោបល់ថា ពួកគេគួររៀបចំចែកចាយបទពិសោធន៍របស់ខ្លួនក្នុងកិច្ចការនេះ (ប៉ុន្តែសូមប្រាកដថា ពួកគេយល់ថា ពួកគេមិនចាំបាច់មានអារម្មណ៍ថាត្រូវចែកចាយបទពិសោធន៍ផ្ទាល់ខ្លួន ឬ ឯកជនពេកនោះទេ) ។

អ្នកក៏អាចសុំឲ្យសិស្សទន្ទេញ ម៉ូសាយ ២:១៧ មុនពេលអ្នកជួបគ្នាលើកក្រោយទៀតដែរ ។

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងបម្រើអ្នកដទៃដោយស្មោះស យើងបម្រើដល់ព្រះអម្ចាស់ ។

កំណត់ចំណាំ ៖ ដោយសារតែលក្ខណៈនិងរយៈពេលនៃមេរៀននេះ អ្នកអាចប្រើសកម្មភាពនេះនៅថ្ងៃក្រោយ នៅពេលអ្នកមានពេលបន្ថែម ។

វិចារណកថា និង ព័ត៌មានសាច់រឿង

ម៉ូសាយ ២:៣៣, ៣៨–៣៩ ។ " ទោសដ៏អស់កល្ប " " ភ្លើងដែលពន្លត់មិនបាន " និង " ការទុក្ខវេទនាដ៏មិនចេះចប់មិនចេះហើយ "

នៅក្នុងការព្រមានមួយអំពីលទ្ធផលនៃការបះបោរទាស់នឹងព្រះ ស្តេចបេនយ៉ាមីនបានប្រើឃ្លា " ទោសដ៏អស់កល្ប " (ម៉ូសាយ ២:៣៣), " ភ្លើងដែលពន្លត់មិនបាន " (ម៉ូសាយ ២:៣៨), និង " ការទុក្ខវេទនាដ៏មិនចេះចប់មិនចេះហើយ " (ម៉ូសាយ ២:៣៩) ។ ដើម្បីយល់កាន់តែច្បាស់អំពីពាក្យទាំងនេះ សូមមើលព្រះបន្ទូលនៃព្រះអម្ចាស់នៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១៩:៦–១២ ។

ម៉ូសាយ ៣

សេចក្តីផ្តើម

ដោយបន្តថ្លែងព្រះបន្ទូលទ្រង់ទៅកាន់ប្រជាជន ស្តេចបេនយ៉ាមីនបានដកស្រង់ព្រះបន្ទូលរបស់ទេវតាដែលបានមានបន្ទូលមកកាន់ទ្រង់ ទាក់ទងនឹងការបម្រើរបស់ព្រះយេស៊ូវគ្រីស្ទ ។ ស្តេចបេនយ៉ាមីនបានថ្លែងទីបន្ទាល់ថា តាមរយៈសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ និងការប្រែចិត្ត នោះអស់អ្នកដែលមានបាបអាចទទួលបានសេចក្តីសង្គ្រោះ ។ ទ្រង់ក៏បានបង្រៀនថា តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះបុគ្គលម្នាក់ៗដែលមានបំណងទៅតាមការលួងលោមនៃព្រះវិញ្ញាណបរិសុទ្ធ “ ឲ្យសម្រាតភាពខាងសាច់ឈាមចេញ ហើយក្លាយទៅជាអ្នកបរិសុទ្ធវិញ ” (ម៉ូសាយ ៣:១៩) ។

យោបល់សម្រាប់ការបង្រៀន

កំណត់ចំណាំ ៖ **ប្រសិនបើក្នុងមេរៀនមុន អ្នកបានលើកទឹកចិត្តឲ្យសិស្សទន្ទេញ និង អនុវត្ត ម៉ូសាយ ២:១៧ ហើយ សូមផ្តល់ឱកាសដល់ពួកគេឲ្យចែកចាយពីបទពិសោធន៍របស់ពួកគេនៅក្នុងថ្នាក់ ។ សូមប្រយ័ត្នកុំយកពេលច្រើនពេកក្នុងការរំឭកនេះ ។ សូមទុកពេលសមល្មមដើម្បីពិភាក្សាពីគោលលទ្ធិ និង គោលការណ៍នានានៅក្នុង ម៉ូសាយ ៣ ។**

ម៉ូសាយ ៣:១–១០

ស្តេចបេនយ៉ាមីនបានមានបន្ទូលពីព្រះបន្ទូលរបស់ទេវតាអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ

សូមបង្ហាញកែវទទេមួយ និង ប្រដាប់ដាក់ទឹកមួយ ។ សូមឲ្យសិស្សម្នាក់បង្ហាញថា តើគេនឹងចាក់ទឹកច្រើនប៉ុណ្ណាទៅក្នុងកែវឲ្យនរណាម្នាក់ដែលគ្រាន់តែចង់ភ្លក់ទឹកនោះ ។ បន្ទាប់មក សូមឲ្យសិស្សនោះបង្ហាញថា តើគេនឹងចាក់ទឹកច្រើនប៉ុណ្ណាសម្រាប់អ្នកដែលចង់ញ៉ាំទឹកឲ្យឆ្អែត ។ សូមឲ្យសិស្សគិតអំពីសំណួរខាងក្រោមនេះ ៖

- **ប្រសិនបើទឹកតំណាងឲ្យសេចក្តីអំណរ តើអ្នកនឹងចង់ចាក់ប៉ុណ្ណាទៅក្នុងកែវរបស់អ្នក ?**

សូមពន្យល់ដល់សិស្សថា ការបង្រៀននៅក្នុង ម៉ូសាយ ៣ នឹងជួយពួកគេឲ្យឃើញថាពួកគេអាចពោរពេញដោយសេចក្តីអំណរច្រើនប៉ុណ្ណា ។

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ៣:២–៥ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលប្រភពនៃសារលិខិតរបស់ស្តេចបេនយ៉ាមីននៅក្នុង ម៉ូសាយ ៣ ។

សូមបញ្ជាក់ថា ម៉ូសាយ ៣ រួមមាននូវការប្រកាសរបស់ទេវតាអំពី “ ដំណឹងដ៏រីករាយមួយពីសេចក្តីអំណរយ៉ាងអស្ចារ្យ ” (ម៉ូសាយ ៣:៣) ។ សូមឲ្យសិស្សពីរបីនាក់ឆ្លាស់វេនគ្នាអានឮៗនៅក្នុង ម៉ូសាយ ៣:៥–១០ ។ សូមឲ្យសិស្សរកមើលពាក្យ ឬ ឃ្លាដែលជួយពួកគេឲ្យកោតសរសើរដល់ការបម្រើរបស់ព្រះយេស៊ូវគ្រីស្ទកាន់តែខ្លាំង ។ អ្នកអាចផ្តល់យោបល់ថា ពួកគេគួរតែគូសចំណាំពាក្យ និង ឃ្លាទាំងនេះ ។ សូមអញ្ជើញសិស្សឲ្យចែកចាយនូវពាក្យ និង ឃ្លាទាំងឡាយដែលពួកគេរកឃើញ ។

- **តើម៉ូសាយ ៣:៧ ជួយអ្នកឲ្យយល់អំពីបេសកកម្មរបស់ព្រះអង្គសង្គ្រោះដូចម្តេចខ្លះ ?**
- **តើអ្នកគិតថា ហេតុអ្វីបានជាទេវតាបាននិយាយថា សារលិខិតនេះនឹងនាំមកនូវសេចក្តីអំណរយ៉ាងអស្ចារ្យ ?**

សូមឲ្យសិស្សសរសេរការសង្ខេបមួយបន្ទាត់ពី ម៉ូសាយ ៣:៥–១០ នៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ ក្រោយពីពួកគេមានពេលសរសេរគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីដែលពួកគេបានសរសេរ ។ សេចក្តីសង្ខេបរបស់សិស្សអាចបង្ហាញពីការយល់អំពីការបង្រៀនរបស់ទេវតាថា **ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខ ដើម្បីឲ្យយើងអាចត្រូវបានសង្គ្រោះចេញពីអំពើបាបរបស់យើង ។**

អ្នកអាចតាមដានចម្លើយរបស់សិស្សជាមួយនឹងសំណួរខាងក្រោម ៖

- **តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលអ្នកគិតអំពីអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើសម្រាប់អ្នក ?**

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់អំពីការរងទុក្ខរបស់ព្រះអង្គសង្គ្រោះ សូមចែកចាយនូវសេចក្តីថ្លែងការណ៍ដូចខាងក្រោមដោយអែលឌើរ ជេម អិ ថាល់មេហ្គ នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

“ ការឈឺចាប់របស់ព្រះគ្រីស្ទនៅក្នុងសួនច្បារ គឺមិនមានគំនិតណាមួយអាចយល់បាន ទាំងខាងកម្លាំង និង មូលហេតុទេ ។ . . . ទ្រង់បានស៊ូទ្រាំ និង ថ្លៃក្នុងការរែកទុក្ខដែលមិនដូចជាអ្នកផ្សេងទៀត ដែលបានរស់នៅលើផែនដីអាចយល់បាន ។ វាមិនមែនជាការឈឺចាប់ខាងសាច់ឈាម ហើយក៏មិនមែនការតានតឹងខាងអារម្មណ៍តែមួយមុខនោះទេ ដែលធ្វើឲ្យទ្រង់រងទុក្ខបែបនោះ រហូតដល់ចេញឈាមតាមរន្ធញើសទាំងអស់ ប៉ុន្តែវាជាការថ្លៃខាងដួងព្រលឹងវិញ្ញាណក្នុងនាមជាព្រះ ដែលអាចយល់ពីការនេះ ។ . . . នៅក្នុងពេលថ្លៃនោះ ព្រះគ្រីស្ទបានជួប និង យកឈ្នះលើការភ័យខ្លាចទាំងអស់ដែលសាតាំង ‹ ជាចៅហ្វាយរបស់លោកកិយនេះ › អាចដាក់ទោស ។ . . . តាមរបៀបខ្លះ ការពិតដាក់ស្តែង និង គួរឲ្យខ្លាចដែលមនុស្សមិនអាចយល់បាន ព្រះអង្គសង្គ្រោះបានយកមកដាក់លើអង្គទ្រង់នូវអំពើបាបទាំងឡាយនៃមនុស្សជាតិ តាំងពីអំដាមទៅដល់ទីបញ្ចប់នៃពិភពលោក ” (*Jesus the Christ* ការបោះពុម្ពលើកទី ៣ | ឆ្នាំ ១៩១៦ |, ទំព័រ ៦១៣) ។

សូមសួរសំណួរដែលឲ្យសិស្សចែកចាយពីអារម្មណ៍ និង ទីបន្ទាល់របស់ពួកគេ

ដើម្បីជួយសិស្សឲ្យរៀបចំចែកចាយពីអារម្មណ៍ និង ទីបន្ទាល់របស់ពួកគេ សូមគិតពីការសួរសំណួរដែលនឹងជួយពួកគេឲ្យគិតអំពីបទពិសោធន៍ណាដែលពួកគេបានមានជាមួយនឹងគោលការណ៍ ឬ គោលលទ្ធិនានាដែលបានពិភាក្សារួចហើយ ។ អ្នកអាចនិយាយថា “ តើអ្នកអាចដឹងថា . . . យ៉ាងដូចម្តេច ? ” ឬ “ តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា . . . ? ” បន្ទាប់មក សូមឲ្យពួកគេចែកចាយពីបទពិសោធន៍ និង អារម្មណ៍របស់ពួកគេ ។ ពេលសិស្សទទួលយកការអញ្ជើញនេះ វានឹងជួយឲ្យព្រះវិញ្ញាណបរិសុទ្ធថ្លែងទីបន្ទាល់ពីសេចក្តីពិតទៅដល់ពួកគេ និង ទៅដល់មិត្តរួមថ្នាក់របស់ពួកគេ ។

ម៉ូសាយ ៣:១១–២៧

ស្តេចបេនយ៉ាមីនបានថ្លែងទីបន្ទាល់ថា តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ យើងអាចសម្រាតភាពខាងសាច់ឈាមចេញ ហើយក្លាយជាអ្នកបរិសុទ្ធ ។

សូមប្រាប់សិស្សថា ស្តេចបេនយ៉ាមីនបានចែកចាយនូវការពិពណ៌នារបស់ទេវតាអំពីក្រុមមនុស្សខុសគ្នា និង ពីរបៀបដែលដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទអនុវត្តដល់ក្រុមនីមួយៗ ។ សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ។ សូមឲ្យសិស្សអាន ម៉ូសាយ ៣:១១–១៣, ១៦ ដោយស្ងាត់ស្ងៀម ដោយរកមើលចម្លើយចំពោះសំណួរខាងក្រោមនេះ ៖

តើដង្វាយធួនអនុវត្តដោយរបៀបណា ៖

ចំពោះអ្នកដែលស្លាប់ដោយមិនដឹងអំពីដំណឹងល្អ ?

ចំពោះអ្នកដែលបះបោរទាស់នឹងព្រះ និង ធ្វើអំពើបាបដោយចេតនា ?

ចំពោះកូនក្មេងដែលស្លាប់ មុនពេលពួកគេមានអាយុដែលត្រូវទទួលខុសត្រូវ ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សចែកចាយចម្លើយរបស់ពួកគេនឹងសំណួរទាំងនេះ ។ (ដើម្បីជួយពួកគេឲ្យឆ្លើយនឹងសំណួរទីមួយ អ្នកអាចឲ្យពួកគេអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៧:៧–១០។ ដើម្បីជួយពួកគេឆ្លើយនឹងសំណួរទីបី អ្នកអាចឲ្យពួកគេអាន មរ៉ូណៃ ៨:៨, ១៧ និង គោលលទ្ធិ និង សេចក្តីសញ្ញា ២៩:៤៦–៤៧ ។

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាលិន អេក អូក នៃក្រុមប្រឹក្សានៃពួកសាវកដប់ពីរនាក់អំពីឥទ្ធិពលនៃដង្វាយធួនចំពោះកូនចៅរបស់ព្រះវរបិតាសួគ៌ទាំងអស់ ៖

“ យើង . . . បានអានថា ‹ព្រះលោហិតរបស់ទ្រង់ក៏នឹងធ្វើឲ្យធួននឹងបាបនៃអស់អ្នកណា . . . ដែលស្លាប់ទៅដោយមិនបានដឹងអំពីព្រះហឫទ័យនៃព្រះចំពោះពួកគេ ឬ ក៏អស់អ្នកណាដែលមានបាបដោយសារល្ងង់ខ្លៅ › (ម៉ូសាយ ៣:១១) ។ ដូចគ្នាដែរ ‹ ព្រះលោហិតនៃព្រះគ្រីស្ទនឹងធ្វើឲ្យធួននឹងបាបរបស់ | ពួកកូនក្មេង | ដែរ › (ម៉ូសាយ ៣:១៦) ។ ការបង្រៀនទាំងនេះថា អំណាចនៃដង្វាយធួនដែលធ្វើឲ្យរស់ឡើងវិញ និង លាងសម្អាតនោះ គឺបដិសេធអ្វីទាំងអស់ដែលអះអាងថា ព្រះគុណនៃព្រះ សង្គ្រោះតែអ្នកដែលត្រូវបានជ្រើសរើសមួយចំនួនតូចប៉ុណ្ណោះ ។ ព្រះគុណរបស់ទ្រង់គឺសម្រាប់ទាំងអស់គ្នា ។ ក្នុងព្រះគម្ពីរមរមន ការបង្រៀនទាំងនេះបានពង្រីកការយល់ដឹងរបស់យើង និង បំភ្លឺការយល់របស់យើងអំពីសេចក្តីស្រឡាញ់ដល់មនុស្សទាំងអស់របស់ព្រះ និង អំពីឥទ្ធិពលដ៏ធំធេងនៃដង្វាយធួនរបស់ទ្រង់សម្រាប់មនុស្សទាំងអស់នៅគ្រប់ទីកន្លែង ” (“ មនុស្សទាំងអស់គ្រប់ទីកន្លែង ” *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៦ ទំព័រ ៧៧) ។

- តើគោលការណ៍អ្វីដែលយើងបានរៀនពី ម៉ូសាយ ៣:១២ អំពីរបៀបដែលដង្វាយធួនអនុវត្តចំពោះយើង ? (**យើងនឹងត្រូវបានសង្គ្រោះចេញពីអំពើបាបរបស់យើង នៅពេលយើងអនុវត្តសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ ហើយប្រែចិត្ត**) ។
- យោងតាមខនេះ តើនឹងមានអ្វីកើតឡើង ដល់អស់អ្នកណាដែលជ្រើសរើសមិនអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយមិនប្រែចិត្តនោះ ?

ម៉ូសាយ ៣:១៩ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានលើវគ្គនេះ ។

សូមបង្ហាញថា ម៉ូសាយ៣:១៩ គឺជាវគ្គខគម្ពីរចំណេះចំណាន ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំវគ្គនេះតាមរបៀបមួយ ដែលពួកគេអាចរកវាឃើញដោយងាយស្រួល ។ សូមយកចិត្តទុកដាក់ជងដៃរទៅលើ ម៉ូសាយ ៣:១៩ ចំពោះការប្រើពាក្យរបស់ទេវតាថា “ មនុស្សខាងសាច់ឈាម ” ។ ដើម្បីជួយសិស្សឲ្យយល់ឃ្លានេះ សូមអានការពន្យល់ខាងក្រោមពីក្នុងការណែនាំអំពីព្រះគម្ពីរ ៖

មនុស្សខាងសាច់ឈាមគឺជា “ មនុស្សដែលជ្រើសរើសដើម្បីត្រូវរងឥទ្ធិពលដោយតណ្ហា បំណងប្រាថ្នា ការចង់បាន និង ញាណនៃសាច់ឈាម ជាជាងដោយការបំផុសពីព្រះវិញ្ញាណបរិសុទ្ធ ។ មនុស្សបែបនោះ អាចយល់ពីរឿងខាងសាច់ឈាម ប៉ុន្តែមិនមែនខាងវិញ្ញាណនោះទេ ។ មនុស្សគ្រប់គ្នាគឺជាសាច់ឈាម ឬ ចេះស្តាប់ដោយសារតែការធ្លាក់របស់អ័ដាម និង អេវ៉ា ។ បុគ្គលម្នាក់ៗត្រូវតែកើតម្តងទៀត តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ” (ការណែនាំអំពីព្រះគម្ពីរ “ មនុស្សខាងសាច់ឈាម” scriptures.lds.org) ។

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ។ សូមឲ្យសិស្សរកមើលចម្លើយចំពោះសំណួរដែលពួកគេអានដោយស្ងាត់ស្ងៀមនៅក្នុង ម៉ូសាយ ៣:១៩ ។

តើទេវតាពិពណ៌នាទំនាក់ទំនងរបស់មនុស្សខាងសាច់ឈាមជាមួយនឹងព្រះយ៉ាងដូចម្តេច ?

យោងតាមខនេះ តើយើងអាចសម្រាតចេញនូវភាពសាច់ឈាមដោយរបៀបណា ?

សូមបង្ហាញថា តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ មនុស្សម្នាក់មិនត្រឹមតែអាចឈប់ពី “ ភាពខាងសាច់ឈាម” ប៉ុណ្ណោះទេ គេអាចធ្វើច្រើនជាងនេះ ។ គេនឹង “ ក្លាយជាអ្នកបរិសុទ្ធ” ។ បន្ថែមលើការសង្គ្រោះយើងចេញពីអំពើបាប ព្រះអង្គសង្គ្រោះផ្លាស់ប្តូរយើងទៅជាមនុស្សដែលប្រសើរជាងដែលយើងអាចក្លាយទៅជាទៅទៀត ។ ទ្រង់ជួយយើងឲ្យក្លាយដូចជាទ្រង់ ។ ដើម្បីជួយសិស្សឲ្យយល់ពីគោលលទ្ធិនេះ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ បែដណា នៃក្រុមប្រឹក្សានៃពួកសាវកដប់ពីរនាក់ ៖

“ គឺជាអ្នកដែលមានដៃស្អាត និង ចិត្តបរិសុទ្ធដែលត្រូវមានដើម្បីឡើងទៅឯភ្នំនៃព្រះយេហូវ៉ា និង ឈរនៅក្នុងទីបរិសុទ្ធរបស់ទ្រង់បាន | សូមមើល ទំនុកតម្កើង ២៤:៣–៤ | ។

" ខ្ញុំសូមស្មើថា ដៃត្រូវបានសម្អាតដោយសារដំណើរការនៃការសម្រាតចេញនូវភាពខាងសាច់ឈាម និង ដោយការយកឈ្នះអំពើបាប និង ឥទ្ធិពលអាក្រក់ទាំងឡាយនៅក្នុងជីវិតរបស់យើងតាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ។ ចិត្តត្រូវបានធ្វើឲ្យបរិសុទ្ធ នៅពេលយើងទទួលនូវកម្លាំងពង្រឹងពីទ្រង់ក្នុងការធ្វើល្អ និង ក្លាយជាមនុស្សប្រសើរជាងមុន ។ បំណងប្រាថ្នាស្អាតស្អំ និង អំពើល្អរបស់យើងទាំងអស់ មិនអាចធ្វើឲ្យដៃស្អាត និង ចិត្តបរិសុទ្ធនោះទេ ទោះជាវាសំខាន់ប៉ុណ្ណាក្តី ។ វាគឺជាដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទដែលធ្វើមានទាំង *អំណាចសម្អាត និង សង្គ្រោះ* ដែលជួយយើងឲ្យយកឈ្នះលើអំពើបាប និង *អំណាចធ្វើឲ្យបរិសុទ្ធ និង ពង្រឹង* ដែលជួយយើងឲ្យប្រសើរឡើងជាងដែលយើងអាចធ្វើបានដោយការពឹងផ្អែកតែលើកម្លាំងផ្ទាល់របស់យើង ។ ដង្វាយធួនដ៏មហិមានេះ គឺ សម្រាប់ទាំងអ្នកមានបាប និង សម្រាប់អ្នកបរិសុទ្ធនៅក្នុងចំណោមយើងគ្រប់គ្នា " (ដៃស្អាត និង ចិត្តបរិសុទ្ធ " *Ensign* ឬ *លេអាហូណា*, ខែ វិច្ឆិកា ឆ្នាំ ២០០៧, ទំព័រ ៨២) ។

ដើម្បីជួយសិស្សឲ្យសង្ខេបគោលលទ្ធិដែលពួកគេបានរៀនពី ម៉ូសាយ ៣:១៩ សូមសួរ ៖

- តើសេចក្តីពិតនៃដំណឹងល្អអ្វីខ្លះ ដែលអ្នកបានរកឃើញនៅក្នុង ម៉ូសាយ ៣:១៩ ?

សិស្សអាចសរសេរនូវគោលលទ្ធិបីបួនពីខគម្ពីរនេះ រួមមានដូចខាងក្រោម ៖

មនុស្សខាងសាច់ឈាមគឺជាសត្រូវដល់ព្រះ ។

នៅពេលយើងទោរទន់ទៅតាមការល្បួងលោមនៃព្រះវិញ្ញាណបរិសុទ្ធ យើងអាចសម្រាតចេញនូវភាពខាងសាច់ឈាម ។

តាមរយៈដង្វាយធួននៃព្រះគ្រីស្ទ យើងអាចសម្រាតចេញនូវភាពខាងសាច់ឈាម ហើយក្លាយជាអ្នករបរិសុទ្ធ ។

សូមឲ្យសិស្សឆ្លើយនឹងសំណួរមួយក្នុងចំណោមសំណួរខាងក្រោមនេះទៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។ (អ្នកអាចសរសេរសំណួរដែលមាននៅលើក្តារខៀនទាំងនេះមុនចាប់ផ្តើមថ្នាក់ សូមរៀបចំក្រដាសទុកចែកដល់សិស្សដោយមានសំណួរ ឬ សូមអានសំណួរយើតៗដើម្បីឲ្យសិស្សអាចសរសេរវាចូលនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។)

- តើអ្នកអាចធ្វើបានដើម្បីកាន់តែទោរទន់ជាងនេះ " ទៅតាមការល្បួងលោមនៃព្រះវិញ្ញាណបរិសុទ្ធ" ? តើអ្នកនឹងធ្វើអ្វីនៅសប្តាហ៍ក្រោយដើម្បីពង្រឹងនៅក្នុងផ្នែកនេះនៃជីវិតរបស់អ្នក ?
- តើអាកប្បកិរិយាកូនក្មេងអ្វីខ្លះដែលមាននៅក្នុង ម៉ូសាយ ៣:១៩ ដែលអ្នកត្រូវអភិវឌ្ឍខ្លាំងបំផុតនោះ ? តើអ្នកនឹងធ្វើអ្វីនៅសប្តាហ៍ក្រោយ ដើម្បីជួយអ្នកពង្រីកអាកប្បកិរិយានោះ ?

ដើម្បីជួយសិស្សឲ្យកាន់តែមានសេចក្តីកោតសរសើរដល់ដង្វាយធួននៃព្រះអង្គសង្គ្រោះ សូមអាន ម៉ូសាយ ៣:២៣–២៦ ដល់ពួកគេ ។ សូមពន្យល់ថា ឃ្លា " ពែងនៃការពិរោធនៃព្រះ " នៅក្នុងខទី ២៦ សំដៅលើការរងទុក្ខចុងក្រោយនៃអស់អ្នកណាដែលប្រព្រឹត្តអំពើបាបដោយចេតនា ហើយមិនប្រែចិត្ត ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៩:១៦–១៩ ។ សូមឲ្យសិស្សស្តាប់ហើយរកមើលពាក្យ *ពែង* នៅក្នុងខទី ១៨ ។

- តើព្រះយេស៊ូវគ្រីស្ទបានធ្វើអ្វីខ្លះ ដើម្បីកុំឲ្យយើងផឹកនូវ " ពែងនៃការពិរោធនៃព្រះ " ? (ទ្រង់បានផឹកពែងនោះដោយអង្គទ្រង់ ដោយលើកដាក់មកលើអង្គទ្រង់នូវការដាក់ទោសព្រោះអំពើបាបរបស់យើង ។ ប្រសិនបើយើងពិតជាប្រែចិត្ត នោះយើងនឹងមិនត្រូវរងទុក្ខការដាក់ទោសនោះទេ ។)

សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតទាំងឡាយដែលបានពិភាក្សានៅក្នុងមេរៀននេះ ។

ចំណេះចំណានខគម្ពីរ—ម៉ូសាយ ៣:១៩

ដើម្បីជួយសិស្សឲ្យទន្ទេញ ម៉ូសាយ ៣:១៩ សូមបែងចែកសិស្សជាគូៗ ។ សូមឲ្យពួកគេអាន ម៉ូសាយ ៣:១៩ ឮៗ មួយពាក្យម្តងៗ ដោយប្តូរវាល់ពាក្យបន្ទាប់ជាមួយនឹងដៃគូរបស់គេ ។ សូមឲ្យពួកគេធ្វើលំហាត់នេះពីរបីដងសារឡើងវិញ ។ អ្នកអាចបន្ថែមសកម្មភាពដោយឲ្យដៃគូនីមួយៗអានពីរ ឬ បីពាក្យម្តង ។

ការធ្វើសកម្មភាពនេះសារឡើងវិញ នឹងជួយសិស្សឲ្យស៊ាំនឹងបរិបទនៃខគម្ពីរនេះ ហើយវានឹងងាយសម្រាប់សិស្សក្នុងការចាំខគម្ពីរទាំងមូល ។ សូមលើកទឹកចិត្តសិស្សឲ្យទន្ទេញ ម៉ូសាយ ៣:១៩ ឲ្យចាំដោយខ្លួនពួកគេ ។

កំណត់ចំណាំ ៖ ដោយសារតែលក្ខណៈ និង ប្រវែងនៃមេរៀននេះ អ្នកអាចប្រើសកម្មភាពចំណេះចំណានខគម្ពីរនៅថ្ងៃក្រោយ នៅពេលអ្នកមានពេលច្រើន ។

ម៉ូសាយ ៤

សេចក្តីផ្តើម

បន្ទាប់ពីការបង្រៀនរបស់ស្តេចបេនយ៉ាមីន ប្រជាជនបានប្រែចិត្ត និង ទទួលយកនូវការផ្តាច់បាបរបស់ពួកគេ ។ ពួកគេ " ក៏ពោរពេញទៅដោយសេចក្តីអំណរ " និង មាន " សេចក្តីសុខសាន្តក្នុងសតិសម្បជញ្ញៈ " (ម៉ូសាយ ៤:៣) ។ ស្តេចបេនយ៉ាមីនបានបន្តបង្រៀនពួកគេ ដោយជួយពួកគេឲ្យយល់ពីអ្វីដែលពួកគេត្រូវធ្វើដើម្បី " ទទួលបានការផ្តាច់បាប [របស់ពួកគេ] " (ម៉ូសាយ ៤:១២) ។ ដោយការធ្វើដូច្នោះ ទ្រង់បានប្រៀបធៀបពួកគេទៅនឹងអ្នកសុំទាន ដោយពឹងផ្អែកលើព្រះសម្រាប់សេចក្តីសង្គ្រោះ ។ ទ្រង់ក៏បានព្រមានពួកគេអំពីគ្រោះថ្នាក់នៃការធ្វេសប្រហែសក្នុងការមើលថែគំនិត ពាក្យសំដី និង សកម្មភាពរបស់ពួកគេដែរ ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ៤:១–៨

ប្រជាជនរបស់ស្តេចបេនយ៉ាមីនទទួលបានការផ្តាច់បាបរបស់ពួកគេ និង ត្រូវពោរពេញដោយសេចក្តីអំណរ និង សន្តិភាព ។

សូមឲ្យសិស្សសញ្ជឹងគិតអំពីសំណួរខាងក្រោមនេះ ៖

- តើយើងអាចដឹងថា យើងត្រូវបានអភ័យទោសចំពោះអំពើបាបរបស់យើងដោយរបៀបណា ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហារ៉ុល ប៊ី លី ៖

" ប្រសិនបើពេលនោះមកដល់ នៅពេលអ្នកបានធ្វើនូវអ្វីៗទាំងអស់ដែលអ្នកអាចធ្វើដើម្បីប្រែចិត្តចេញពីអំពើបាបរបស់អ្នក មិនថាអ្នកជានរណា អ្នកនៅកន្លែងណា ហើយបានធ្វើការសងថ្លៃ និង ការឆ្កំុសងវិញអស់ពីសមត្ថភាពរបស់អ្នក ប្រសិនបើវាជាអ្វីមួយដែលប៉ះពាល់ដល់សមាជិកភាពរបស់អ្នកនៅក្នុងសាសនាចក្រ ហើយអ្នកបានទៅរកអ្នកមានសិទ្ធិអំណាចត្រឹមត្រូវ បន្ទាប់មកអ្នកនឹងចង់បានចម្លើយនៃការបញ្ជាក់នោះ ថាតើព្រះអម្ចាស់បានទទួលយកអ្នកទេ ។ នៅក្នុងព្រលឹងដែលខ្ទាយខ្ទប់របស់អ្នក ប្រសិនបើអ្នកស្រាវជ្រាវ ហើយអ្នករកឃើញសេចក្តីសុខសាន្តក្នុងសតិសម្បជញ្ញៈ ដោយការបញ្ជាក់នោះ អ្នកអាចដឹងថា ព្រះអម្ចាស់បានទទួលយកការប្រែចិត្តរបស់អ្នក " (" Stand Ye in Holy Places," *Ensign* ខែ កក្កដា ឆ្នាំ ១៩៧៣ ទំព័រ ១២២) ។

សូមរំឭកសិស្សថា ស្តេចបេនយ៉ាមីនបានចែកចាយពាក្យរបស់ទេវតាអំពីរបៀបដើម្បីទទួលបានការផ្តាច់បាប ។ អ្នកអាចរំឭកពួកគេជាពិសេសអំពីបន្ទូលរបស់ទេវតាអំពីភាពខាងសាច់ឈាមជាសត្រូវនៃព្រះ និង អំពីលទ្ធផលដែលរង់ចាំដល់អស់អ្នកដែលស្លាប់ដោយមិនបានប្រែចិត្តពីអំពើបាបរបស់ពួកគេ (សូមមើល ម៉ូសាយ ៣:១៩, ២៣–២៧) ។

សូមឲ្យសិស្សអាន ម៉ូសាយ ៤:១–២ ដោយស្ងាត់ស្ងៀម ដោយរកមើលឃ្លាដែលបង្ហាញពីរបៀបដែលប្រជាជនរបស់ស្តេចបេនយ៉ាមីនបានឆ្លើយតបទៅនឹងពាក្យសម្តីរបស់ទេវតា ។ សូមឲ្យសិស្សចែកចាយឃ្លាដែលពួកគេរកឃើញ ។ ប្រសិនបើសិស្សត្រូវការជំនួយដើម្បីយល់ពីឃ្លា " ភាពខាងសាច់ឈាម " សូមពន្យល់ថាពាក្យ *សាច់ឈាម* គឺផ្ទុយពី *វិញ្ញាណ* ។ វាសំដៅលើចំណង់ខាងសាច់ឈាមរបស់យើង ជាជាងចំណងប្រាថ្នាខាងវិញ្ញាណរបស់យើងដើម្បីខិតទៅជិតព្រះអម្ចាស់ ។ អ្នកអាចឲ្យសិស្សអាន អាលម៉ា ៤១:១១ ហើយបន្ទាប់មកសូមឲ្យគេពន្យល់ឃ្លា " ស្ថានភាពខាងសាច់ឈាម " ជាសម្តីខ្លួនឯងផ្ទាល់ ។ ដើម្បីជួយសិស្សឲ្យយល់ឃ្លា " អន់ជាងធ្ងលីដីទៅទៀត " សូមឲ្យពួកគេអាន ហេលេមិន ១២:៤–៨ ។ បន្ទាប់មក សូមឲ្យពួកគេពន្យល់ជាសម្តីខ្លួនឯងពីរបៀបដែលនរណាម្នាក់ដែលបរិសេធមិនព្រមធ្វើតាមការប្រឹក្សាពីព្រះអម្ចាស់អាចត្រូវបានចាត់ទុកថា អន់ជាងធ្ងលីដីទៅទៀត ។ សូមធានាថា ពួកគេយល់ថាព្រះវរបិតាសួគ៌មិនបានចាត់ទុកកូនចៅរបស់ទ្រង់ថាអន់ជាងធ្ងលីដីនោះទេ ។

សូមបង្ហាញថា នៅពេលដែលមនុស្សស្គាល់ពីអំពើបាបរបស់ពួកគេ ពួកគេប្រែចិត្ត ដោយបង្ហាញសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធួនរបស់ទ្រង់ ។ សូមឲ្យសិស្សអាន ម៉ូសាយ ៤:៣ ឮៗ ។ សូមឲ្យសិស្សយកចិត្តទុកដាក់លើរបៀបដែលមនុស្សបានដឹងថាពួកគេត្រូវបានអភ័យទោសចំពោះអំពើបាបរបស់ពួកគេ ។

- យោងតាម ម៉ូសាយ ៤:៣ តើអារម្មណ៍បែបណាកើតមានចំពោះអស់អ្នកដែលទទួលបានការអភ័យទោសពីព្រះអម្ចាស់ ?
- មនុស្សទទួលបាននូវការផ្តាច់បាបរបស់ពួកគេ ដោយសារតែ " សេចក្តីជំនឿដ៏ខ្លាំងក្លាដែលពួកគេមានទៅលើព្រះយេស៊ូវគ្រីស្ទ" ។ តើសកម្មភាពអ្វីខ្លះ ដែលបង្ហាញពីសេចក្តីជំនឿរបស់ពួកគេ ? (សូមមើល ម៉ូសាយ ៤:១–២ ។)
- ចេញពីសម្តីរបស់អ្នកផ្ទាល់ តើយើងអាចរៀនអ្វីពី ម៉ូសាយ ៤:១–៣ អំពីការទទួលបានការផ្តាច់បាបរបស់យើង ? (ចម្លើយមួយអាចថា **នៅពេលយើងអនុវត្តសេចក្តីទៅលើព្រះយេស៊ូវគ្រីស្ទ ហើយប្រែចិត្តដោយចិត្តស្មោះ យើងនឹងទទួលបានការផ្តាច់បាបរបស់យើង ។** អ្នកអាចឲ្យសិស្សគូសចំណាំពាក្យ និង ឃ្លាគន្លឹះនៅក្នុង ម៉ូសាយ ៤:១–៣ ដែលបញ្ជាក់ពីគោលការណ៍នេះ ។)

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ នែល អិល អាន់ឌើរសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ដោយសង្កេបពីអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបានការផ្តាច់បាប ៖

" នៅពេលយើងសារភាពអំពើបាបរបស់យើងដោយស្មោះត្រង់ ស្គារឡើងវិញនូវអ្វីដែលយើងអាចធ្វើចំពោះអ្នកដែលយើងធ្វើខុស ហើយលះបង់អំពើបាបរបស់យើងដោយការកាន់តាមព្រះបញ្ញត្តិទាំងឡាយ នោះយើងនឹងនៅក្នុងដំណាក់កាលនៃការទទួលបានការអភ័យទោស ។ ស្របតាមពេលវេលា យើងនឹងមានអារម្មណ៍ថា ភាពតានតឹងនៃទុក្ខព្រួយយើងបានថយចុះ ដោយការ ‹ ដកយកទោសចេញពីក្នុងចិត្តយើង › (អាលម៉ា ២៤:១០) និង ការនាំមកនូវ ‹ សេចក្តីសុខសាន្តក្នុងសតិសម្បជញ្ញៈ › (ម៉ូសាយ ៤:៣) ។

" សម្រាប់អស់អ្នកណាដែលពិតជាបានប្រែចិត្ត ប៉ុន្តែហាក់ដូចជាមិនអាចមានអារម្មណ៍ធូរស្បើយ ៖ សូមបន្តកាន់តាមព្រះបញ្ញត្តិ ។ ខ្ញុំសូមសន្យាថា អ្នកនឹងទទួលបានការធូរស្បើយតាមពេលវេលារបស់ព្រះអម្ចាស់ ។ ការព្យាបាលក៏ត្រូវការពេលវេលាដែរ " ("ប្រែចិត្ត . . . ដើម្បីឲ្យយើងអាចព្យាបាលអ្នក " *Ensign* ឬ *លេអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤២) ។

សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពីអ្វីដែលពួកគេបានរៀនអំពីការប្រែចិត្ត នៅពេលពួកគេបានពិភាក្សា ម៉ូសាយ ៤:១–៣ ។ សូមឲ្យពួកគេសរសេរអំពីរបៀបដែលពួកគេអាចអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នៅពេលពួកគេស្វែងរកការផ្តាច់បាបទាំងឡាយរបស់ពួកគេផងដែរ ។

សូមពន្យល់ថា ក្រោយពីបានធ្វើជាសាក្សីដល់អាកប្បកិរិយាប្រែចិត្តរបស់ប្រជាជន ស្តេចបេនយ៉ាមីនបានរំឭកពួកគេអំពីការពឹងផ្អែករបស់ពួកគេទៅលើព្រះអម្ចាស់ ។ សូមឲ្យសិស្សបីបួននាក់ឆ្លាស់គ្នាអានឮៗពី ម៉ូសាយ ៤:៤–៨ ។ សូមឲ្យសិស្សរកមើលអ្វីដែលស្តេចបេនយ៉ាមីនចង់ឲ្យប្រជាជនរបស់ទ្រង់យល់ ក្រោយពីពួកគេបានទទួលការផ្តាច់បាបរបស់ពួកគេហើយ ។

- យោងតាមខគម្ពីរទាំងនេះ តើអ្វីដែលជា " មធ្យោបាយតែមួយគត់ដែលនឹងនាំមកនូវសេចក្តីសង្គ្រោះ | ដល់យើង | " ?

ក្រោយពីសិស្សបានឆ្លើយនឹងសំណួរនេះហើយ សូមឲ្យពួកគេរំឭក ម៉ូសាយ ៤:៤–៨ ដោយស្ងាត់ស្ងៀម ដោយរកមើលឃ្លាដែលពិពណ៌នាប្រជាជនដែលទទួលបានសេចក្តីសង្គ្រោះ ។ អ្នកអាចស្នើថា ពួកគេគួរគូសចំណាំឃ្លាទាំងនេះ ។ សូមគិតពីការសួរសំណួរខាងក្រោមនេះ ៖

- តើអ្នកគិតថា ដើម្បី " ព្យាយាមក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយ | របស់ព្រះអម្ចាស់ | មានន័យយ៉ាងណា ?
- តើសកម្មភាពអ្វីខ្លះ ដែលបង្ហាញថា មនុស្សម្នាក់បាន " ដាក់ទីទុកចិត្តរបស់ខ្លួនទៅលើព្រះអម្ចាស់ " ?
- តើតាមរបៀបណាដែលអ្នកឃើញពី " សេចក្តីល្អសប្បុរសនៃព្រះ" និង " ព្រះចេស្តាដ៏ឥតប្រៀបផ្ទឹមបាន" របស់ទ្រង់ ?

សូមបង្ហាញថា ការប្រែចិត្ត និង ការគោរពតាមត្រូវការការខិតខំ និង ការព្យាយាមច្រើនពីយើង ។ ទោះជាយ៉ាងណាក្តី មិនថាយើងធ្វើការខ្លាំងប៉ុណ្ណាទេ យើងមិនអាចទទួលបានការអភ័យទោសពីអំពើបាបរបស់យើង និង អំណោយនៃសេចក្តីសង្គ្រោះដោយគ្មានដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទឡើយ ។

ម៉ូសាយ ៤:៩–៣០

ស្តេចបេនយ៉ាមីនបង្រៀនពីរបៀបដើម្បីទទួលបានការផ្តាច់បាប

សូមសរសេរ *ការទទួលបានការផ្តាច់បាប* នៅលើក្តារខៀន ។ សូមប្រាប់សិស្សថា ក្រោយពីប្រជាជនបានទទួលការផ្តាច់បាបរបស់ពួកគេហើយ ស្តេចបេនយ៉ាមីនបានបង្រៀនពួកគេពីរបៀបទទួល ឬ រក្សាសភាពស្អាត និង បរិសុទ្ធនោះ ។

- ហេតុអ្វីបានជាវាក៏មានសារសំខាន់ដល់យើងម្នាក់ៗដើម្បីដឹងដែរនោះ ?

សូមឲ្យសិស្សស្រាវជ្រាវ ម៉ូសាយ ៤:៩–១១ ដោយស្ងាត់ស្ងៀម ដោយរកមើលអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបានការផ្តាច់បាបរបស់យើង ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សចែកចាយអ្វីដែលពួកគេបានរកឃើញ ។ សូមគិតពីការសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ ចម្លើយអាចរួមមាន យើងត្រូវចងចាំពីភាពអស្ចារ្យនៃព្រះ បន្ទាបខ្លួន អធិស្ឋានរាល់ថ្ងៃ និង ស្ថិតស្ថេរនៅក្នុងសេចក្តីជំនឿ ។

សូមគិតពីការសួរសំណួរខាងក្រោម ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ និង អនុវត្តអ្វីដែលពួកគេបានអាន ។

- ស្តេចបេនយ៉ាមីនបានបង្រៀនថា យើងត្រូវ " ជឿដល់ព្រះចុះ " (ម៉ូសាយ ៤:៩) ។ ទ្រង់ក៏បាននិយាយអំពីការភ្លក់នូវសេចក្តីស្រឡាញ់របស់ព្រះ និង តែងតែចងចាំនូវ " ភាពមហិមានៃព្រះ" (ម៉ូសាយ ៤:១១) ។ តើបទពិសោធន៍អ្វីដែលបានជួយអ្នកឲ្យយល់ថា ព្រះគឺពិត និង មានព្រះចេស្តា ហើយថាទ្រង់ស្រឡាញ់អ្នក ?
- តើការចងចាំពីព្រះចេស្តា សេចក្តីល្អ និង សេចក្តីស្រឡាញ់របស់ព្រះ ជះឥទ្ធិពលដល់ឆន្ទៈរបស់យើងក្នុងការគោរពដល់ទ្រង់យ៉ាងដូចម្តេច ?

សូមអាន ម៉ូសាយ ៤:១២ ឮៗដល់សិស្ស ។ សូមឲ្យពួកគេរកមើលនៅក្នុងខគម្ពីរនេះ នូវ ពរជ័យទាំងឡាយដែលកើតមានចំពោះអ្នកទាំងឡាយណា ដែលធ្វើតាមការបង្រៀននៅក្នុង ម៉ូសាយ ៤:៥–១១ ។

សូមពន្យល់ថា ម៉ូសាយ ៤:១៣–១៦ រួមមាននូវការពិពណ៌នារបស់ស្តេចបេនយ៉ាមីនអំពីប្រជាជនដែលទទួលបានការផ្តាច់បាបរបស់ពួកគេ ។ សូមបែងចែកសិស្សក្នុងថ្នាក់ជាបីក្រុម ។ សូមឲ្យក្រុមទីមួយអាន ម៉ូសាយ ៤:១៣ ក្រុមទីពីរអាន ម៉ូសាយ ៤:១៤–១៥ និង ក្រុមទីបីអាន ម៉ូសាយ ៤:១៦ ។ សូមឲ្យសិស្សអានខគម្ពីរដែលបានដាក់រៀង ។ខ្លួន ហើយរកមើលអាកប្បកិរិយា និង គុណសម្បត្តិដែលស្តេចបេនយ៉ាមីនបានពិពណ៌នាពីអ្នកដែលស្វែងរកដើម្បីទទួលបានការផ្តាច់បាបរបស់ពួកគេ ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។ នៅពេលពួកគេធ្វើដូច្នោះ សូមបញ្ជាក់សេចក្តីពិតថា **ប្រសិនបើយើងបន្ទាបខ្លួន ចំពោះព្រះ ហើយខិតខំអភិវឌ្ឍអាកប្បកិរិយាឲ្យដូចជាព្រះគ្រីស្ទ នោះយើងអាចទទួលបាន**

ការផ្តាច់បាបរបស់យើង ។សូមជួយសិស្សឲ្យអនុវត្តនូវអ្វីដែលពួកគេកំពុងរៀន ដោយការសួរសំណួរមួយ ឬ ពីរខាងក្រោម នៅពេលអាកប្បកិរិយា ឬ គុណសម្បត្តិនីមួយ ៗត្រូវបានលើកឡើង ៖

- ហេតុអ្វីបានជាអ្នកគិតថា អាកប្បកិរិយា (គុណសម្បត្តិ) នេះជួយក្នុងការទទួលបានការផ្តាច់បាបរបស់យើង ?
- តើនៅពេលណាដែលអ្នកបានឃើញគំរូនៃអាកប្បកិរិយា (គុណសម្បត្តិ) នេះ ?

ស្តេចបេនយ៉ាមីនបានប្រើភាពស្រដៀងគ្នាដ៏មានអំណាចនេះដែលអាចជួយសិស្សឲ្យមានអំណរដល់ពរជ័យទាំងឡាយដែលពួកគេបានទទួលពីព្រះអម្ចាស់ ហើយជម្រុញពួកគេឲ្យអភិវឌ្ឍអាកប្បកិរិយាទាំងឡាយដែលពួកគេបានសិក្សានៅក្នុង ម៉ូសាយ ៤:១៣–១៦ ។ សូមឲ្យសិស្សអាន ម៉ូសាយ ៤:១៦–២៣ ដោយស្ងាត់ស្ងៀម ។

- ដោយយោងតាមស្តេចបេនយ៉ាមីន តើយើងទាំងអស់គ្នាជាអ្នកសុំទានដោយរបៀបណា ?
- តើការយល់នេះអាចជួយយើងឲ្យមានចិត្តមេត្តាអ្នកដទៃជាងមុនដោយរបៀបណា ?
- សម្រាប់អ្នកទាំងឡាយណាដែលមិនអាចដាក់ទានដល់អ្នកសុំទាន ឬ សម្រាប់អ្នកណាដែលមានតិចតួចដើម្បីឲ្យ តើស្តេចបេនយ៉ាមីនបានចែកចាយការប្រឹក្សានៅក្នុង ម៉ូសាយ ៤:២៤–២៦ អ្វីខ្លះ ?
- នៅក្នុងសាសនាចក្រសព្វថ្ងៃនេះ តើការផ្តល់ដង្វាយតមអាហារជួយយើងឲ្យធ្វើតាមការប្រឹក្សានៅក្នុង ម៉ូសាយ ៤:២៦ ដោយរបៀបណា ? តើយុវវ័យអាចចូលរួមនៅក្នុងដង្វាយតមអាហារដោយរបៀបណា ? (ចម្លើយអាចរួមមាន ពួកគេអាចតមអាហារ អ្នកខ្លះអាចបង់ដង្វាយតមអាហារ ហើយអ្នកកាន់អំណាចបព្វជិតអើរ៉ុននៅក្នុងផ្នែកខ្លះនៃពិភពលោកប្រមូលដង្វាយតមអាហារពីសមាជិកវួដ ឬ សាខា ។)

សូមបង្ហាញថា ដោយមានអ្វី ៗល្អទាំងអស់ដែលយើងត្រូវបានសុំឲ្យធ្វើ ពេលខ្លះវាអាចពិបាកមានតុល្យភាពនៅក្នុងជីវិតរបស់យើង ។ សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ៤:២៧ ព្ទ ៗ ។

- តើអ្នកគិតថា ការធ្វើអ្វី ៗទាំងអស់នៅក្នុង " ប្រាជ្ញា និង របៀបរៀបរយ" មានន័យយ៉ាងដូចម្តេច ?
- តើការប្រឹក្សានេះអាចជួយអ្នកដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ៤:២៩–៣០ ព្ទ ៗ ។ សូមបង្ហាញថា ម៉ូសាយ ៤:៣០ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំសារលិខិតនេះតាមរបៀបមួយដែលពួកគេអាចរកវាដោយងាយស្រួល ។

- តើអ្វីជាទំនាក់ទំនងរវាងគំនិត ពាក្យសម្ពី និង សកម្មភាពរបស់យើង ? តើយើងអាចធ្វើអ្វីខ្លះ ដើម្បីមើលថែខ្លួនយើង ? តើយើងអាចជួយគ្នាទៅវិញទៅមកតាមរបៀបណា ?

សូមគិតពីការឲ្យសិស្សសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេពីរបីនាទី អំពីរបៀបដែលគោលការណ៍នៅក្នុង ម៉ូសាយ ៤:៩–៣០ អាចជួយពួកគេ នៅពេលពួកគេខិតខំដើម្បីទទួលបានការផ្តាច់បាបរបស់ពួកគេ ។ សូមថ្លែងទីបន្ទាល់អំពីសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ចំពោះពួកគេគ្រប់គ្នា និង អំពីបំណងប្រាថ្នារបស់ទ្រង់ឲ្យពួកគេប្រែចិត្ត និង ទទួលបានការផ្តាច់បាប ។

ម៉ូសាយ ៤:៣០ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមបើកទៅយោបល់ក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីររបស់ពួកគេ ។

ការសរសេរពីចំណាប់អារម្មណ៍

អែលឌើរ រីឆាដ ជី ស្តត នៃក្លុ៉មនៃពួកសាវកដប់ពីរនាក់បានលើកទឹកចិត្តសិស្សឲ្យសរសេរចំណាប់អារម្មណ៍ដែលពួកគេទទួលបាន ៖ " អភិវឌ្ឍជំនាញក្នុងការរៀន ដោយអ្វីដែលអ្នកឃើញ ហើយជាពិសេសដោយអ្វីដែលព្រះវិញ្ញាណបរិសុទ្ធបានបំផុសគំនិតអ្នក ។ . . . សូមសរសេរនូវអ្វីដែលសំខាន់ដែលអ្នករៀនពីព្រះវិញ្ញាណទុកនៅក្នុងកន្លែងសុវត្ថិភាពមួយ ។ អ្នកនឹងឃើញថា នៅពេលអ្នកសរសេរចំណាប់អារម្មណ៍ដ៏មានតម្លៃនានា ជាញឹកញាប់នឹងមានអ្វីជាច្រើនចេញមក" ("To Acquire Knowledge and the Strength to Use It Wisely," *Ensign* ខែ មិថុនា ឆ្នាំ ២០០២, ទំព័រ ៣២) ។

ចំណេះចំណានខគម្ពីរ—ម៉ូសាយ ៤:៣០

ដើម្បីជួយសិស្សឲ្យយល់ពីទំនាក់ទំនងរវាងគំនិត ពាក្យសម្ពី និង សកម្មភាពទាំងឡាយ ដែលបានបង្ហាញនៅក្នុង ម៉ូសាយ ៤:៣០ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អែសរ៉ា ថាហ្ស ប៊ែនសឹន ៖

" គិតពីគំនិតស្អាតស្អំ ។ អ្នកដែលមានគំនិតស្អាតស្អំ មិនធ្វើអំពើកខ្វក់នោះទេ ។ អ្នកមិនត្រឹមតែទទួលខុសត្រូវចំពោះមុខព្រះចំពោះសកម្មភាពរបស់អ្នកប៉ុណ្ណោះទេ ប៉ុន្តែព្រមទាំងចំពោះគំនិតរបស់អ្នកដែរ ។ ដូច្នេះ សូមរស់នៅដោយសេចក្តីថ្លៃថ្នូរ នៅពេលគំនិត និង សកម្មភាពរបស់អ្នកត្រូវបានសម្តែងចេញនៅក្នុងសាសនាចក្ររបស់អ្នក ។ សុភាសិតបុរាណមួយគឺនៅតែពិតថា ពេលអ្នកសាបព្រោះគំនិត នោះអ្នកច្រូតបានសកម្មភាព អ្នកសាបព្រោះសកម្មភាព នោះអ្នកច្រូតបានទម្លាប់ អ្នកសាបព្រោះទម្លាប់ នោះអ្នកច្រូតបានចរិត ហើយចរិតរបស់អ្នកកំណត់ពីជោគវាសនាដ៏អស់កល្បរបស់អ្នក ។ ‹ ដ្បិតគេគិតក្នុងចិត្តយ៉ាងណា គេក៏យ៉ាងនោះដែរ› " (នៅក្នុងរបាយការណ៍សន្ទិសីទ ខែ តុលា ឆ្នាំ ១៩៦៤ ទំព័រ ៦០;ដកស្រង់ពី សុភាសិត ២៣:៧) ។

សូមពន្យល់ថា ពន្លឺ និង ភាពងងឹត មិនអាចស្ថិតនៅក្នុងកន្លែងដូចគ្នានៅពេលតែមួយបានទេ ។ ពន្លឺបណ្តេញភាពងងឹត ។ ឧទាហរណ៍តន្ត្រីសមរម្យ រូបភាពដែលបំផុសគំនិត សកម្មភាពត្រឹមត្រូវល្អ និង គំនិត និង ពាក្យសម្ពីស្អាតស្អំ នឹងអញ្ជើញព្រះវិញ្ញាណមកក្នុងជីវិតរបស់យើង និង បណ្តេញគំនិតមិនស្អាតស្អំចេញពីគំនិតរបស់យើង ។ សូមជួយសិស្សឲ្យយល់ថា ពួកគេអាចប្រឆាំងនឹងភាពងងឹតដោយបំភ្លឺជីវិតរបស់គេ ។

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីរក្សាគំនិត ពាក្យសម្ពី និង សកម្មភាពរបស់យើងឲ្យនៅស្អាតបាត ?

សូមលើកទឹកចិត្តសិស្សឲ្យបង្កើតគម្រោងជាក់លាក់ដើម្បីបំភ្លឺជីវិតរបស់ពួកគេ ។ អ្នកអាចឲ្យពួកគេសរសេរគម្រោងរបស់ពួកគេនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។

ម៉ូសាយ ៥–៦

សេចក្តីផ្តើម

ម៉ូសាយ ៥ រួមមានសេចក្តីបញ្ចប់នៃការនិយាយរបស់ស្តេចបេនយ៉ាមីនទៅដល់ប្រជាជនរបស់ទ្រង់ កំណត់ត្រាដែលចាប់ផ្តើមនៅក្នុង ម៉ូសាយ ២ ។ ជាលទ្ធផលនៃសេចក្តីជំនឿរបស់ពួកគេទៅលើពាក្យសម្តីរបស់ស្តេចបេនយ៉ាមីន ប្រជាជនបានទទួលបទពិសោធន៍នៃការផ្លាស់ប្តូរដួងចិត្តដ៏ជំអស្ចារ្យមួយ ។ ពួកគេបានចូលទៅក្នុងសេចក្តីសញ្ញាជាមួយនឹងព្រះ ហើយបានលើកដាក់មកលើខ្លួនគេនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។ ដូចដែលបានកត់ត្រានៅក្នុង ម៉ូសាយ ៦ ស្តេចបេនយ៉ាមីនបានផ្ទេរនគររបស់ទ្រង់ទៅបុត្រារបស់ទ្រង់ ម៉ូសាយ ដែលគ្រប់គ្រងស្របតាមគំរូព្រះបិតារបស់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ៥:១–៤

ប្រជាជនរបស់ស្តេចបេនយ៉ាមីនពិពណ៌នាពីការផ្លាស់ប្តូរដ៏ធំដែលពួកគេបានទទួលតាមរយៈព្រះវិញ្ញាណ

មុនចាប់ផ្តើមថ្នាក់ សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ។

តើអ្នកធ្លាប់មានអារម្មណ៍ថា អ្នកត្រូវផ្លាស់ប្តូរខាងវិញ្ញាណដែរឬទេ ?

តើអ្នកបានធ្វើអ្វីខ្លះ ?

ប្រសិនបើអ្នកមានបទពិសោធន៍ពីការផ្លាស់ប្តូរ តើអ្នកបានបន្តការផ្លាស់ប្តូរនោះមកដល់សព្វថ្ងៃនេះទេ ?

សូមឲ្យសិស្សឆ្លើយនឹងសំណួរទាំងនេះនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ បន្ទាប់មកសូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

“ សារៈសំខាន់នៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទតម្រូវឲ្យមានការផ្លាស់ប្តូរជាមូលដ្ឋាន និង អចិន្ត្រៃយ៍នៅក្នុងនិស្ស័យរបស់យើង ដែលកើតមានតាមរយៈការពឹងផ្អែករបស់យើងទៅលើ ‹ បុណ្យគុណ និង សេចក្តីមេត្តាករុណា និង ព្រះគុណនៃព្រះមែស៊ីដ៏បរិសុទ្ធ › (នីហ្វៃទី ២ ២:៨) ។ នៅពេលយើងជ្រើសរើសធ្វើតាមលោកចៅហ្វាយ យើងជ្រើសរើសដើម្បីផ្លាស់ប្តូរ —ដើម្បីកើតខាងវិញ្ញាណ ” (“ អ្នកត្រូវតែកើតជាថ្មីម្តងទៀត ” *Ensign* ឬ *លេអាហូណា* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ២០) ។

អ្នកអាចស្នើថា សិស្សគួរសរសេរការដកស្រង់ខាងក្រោមនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ ម៉ូសាយ ៥:២ ឬ នៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ៖ *“ នៅពេលយើងជ្រើសរើសធ្វើតាមលោកចៅហ្វាយ យើងជ្រើសរើសដើម្បីផ្លាស់ប្តូរ ” (អែលឌើរ ដេវីឌ អេ បែដណា) ។*

- តើយើងជ្រើសរើសដើម្បីផ្លាស់ប្តូរតាមរបៀបណា នៅពេលយើងជ្រើសរើសដើម្បីធ្វើតាមព្រះយេស៊ូវគ្រីស្ទ ?

សូមឲ្យសិស្សរំឭក ម៉ូសាយ ២–៤ ពីរបីនាទី ។ អ្នកអាចស្នើថា ពួកគេគួរអានសេចក្តីសង្ខេបនៃជំពូក ។ សូមសួរពួកគេថា តើពួកគេចង់ចាំអ្វីពីបរិបទនៃជំពូកទាំងនេះ ។ បន្ទាប់មកសូមឲ្យពួកគេអាន ម៉ូសាយ ៥:១ ដោយស្ងាត់ស្ងៀម ។

- តើស្តេចបេនយ៉ាមីនចង់ដឹងអ្វីពីប្រជាជនរបស់ទ្រង់ ?

សូមឲ្យសិស្សអាន ម៉ូសាយ ៥:២–៥ ដោយស្ងាត់ស្ងៀម ដោយរកមើលចម្លើយរបស់ប្រជាជនចំពោះសំណួររបស់ស្តេចបេនយ៉ាមីន ។ មុនពេលសិស្សអាន អ្នកអាចពន្យល់ថា នៅក្នុងខទី ២ ពាក្យ *បំណាង* សំដៅលើនិស្ស័យរបស់បុគ្គលម្នាក់ៗ —បំណងប្រាថ្នា និង អារម្មណ៍របស់គេ ។ ក្រោយពីពួកគេបានអានហើយ សូមសួរសំណួរខាងក្រោមដើម្បីជួយពួកគេឲ្យវិភាគខគម្ពីរ ៖

- តើប្រជាជនបាននិយាយអ្វី អំពីបំណងរបស់ពួកគេ ?
- តើអ្វីដែលនាំមកនូវការផ្លាស់ប្តូរនេះនៅក្នុងបំណងរបស់ពួកគេ ? (ពួកគេបានជឿលើការបង្រៀនរបស់ស្តេចបេនយ៉ាមីនអំពីព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធួន ហើយព្រះវិញ្ញាណបានផ្លាស់ប្តូរដួងចិត្តរបស់ពួកគេ ។)

សូមបញ្ជាក់ថា ការផ្លាស់ប្តូរនៃដួងចិត្តគឺមិនមែនត្រឹមតែផ្លាស់ប្តូរអាកប្បកិរិយានោះទេ ។ នៅពេលយើងទទួលបានបទពិសោធន៍នៃការផ្លាស់ប្តូរដួងចិត្ត យើងនឹងក្លាយជាមនុស្សថ្មី ដែលបានផ្លាស់ប្តូរតាមរយៈអំណាចនៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ។ ដើម្បីជួយសិស្សឲ្យយល់ពីសេចក្តីពិតនេះ សូមអញ្ជើញសិស្សម្នាក់ឲ្យអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

“ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទហ៊ឺព័ទ្ធច្រើនជាងការចៀសវាង ការយកឈ្នះ និង ការសម្អាតពីអំពើបាប និង ឥទ្ធិពលអាក្រក់ទាំងឡាយនៅក្នុងជីវិតរបស់យើង វាក៏សំខាន់ដែលតម្រូវឲ្យមានការធ្វើល្អ ការធ្វើជាមនុស្សល្អ និង បានប្រសើរជាងនេះ ។ . . . ការផ្លាស់ប្តូរដ៏ធំនេះមិនមែនជាលទ្ធផលសាមញ្ញនៃការធ្វើការខ្លាំង ឬ ការអភិវឌ្ឍវិន័យផ្ទាល់ខ្លួនដ៏អស្ចារ្យនោះទេ ។ ប៉ុន្តែវាជាលទ្ធផលនៃការផ្លាស់ប្តូរជាមូលដ្ឋាននៅក្នុងបំណងប្រាថ្នា ការជម្រុញ និង ធម្មជាតិរបស់យើងដែលធ្វើកើតឡើងតាមរយៈដង្វាយធួននៃព្រះគ្រីស្ទជាព្រះអម្ចាស់ ។ គោលបំណងខាងវិញ្ញាណរបស់យើងគឺត្រូវយកឈ្នះទាំងអំពើបាប និង ចំណង់ចង់ធ្វើបាប ទាំងស្មាមប្រឡាក់ និងអំណាចនៃអំពើបាប ” (ដៃស្អាត និង ចិត្តបរិសុទ្ធ ” *Ensign* ឬ *លេអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៨១–៨២) ។

- តើអ្នកគិតថា ហេតុអ្វីបានជាយើងត្រូវការដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទដើម្បីផ្លាស់ប្តូរយ៉ាងពិតប្រាកដនោះ ?

សូមធ្វើឲ្យសិស្សមានចំណាប់អារម្មណ៍ ទៅលើឃ្លា " ដោយសារតែព្រះវិញ្ញាណនៃព្រះអម្ចាស់ដ៏មានគ្រប់ព្រះចេស្តា " នៅក្នុង ម៉ូសាយ ៥:២ ។ អ្នកអាចត្រូវឲ្យនិយមន័យពាក្យ *ដ៏មានគ្រប់ព្រះចេស្តា* ដែលមានន័យថា អំណាចទាំងឡាយ ។

- តើយើងអាចរៀនអ្វីខ្លះពី ម៉ូសាយ ៥:២–៤ អំពីរបៀបដែលយើងអាចទទួលបាននូវការផ្លាស់ប្តូរដ៏ធំនៅក្នុងជីវិតរបស់យើង ?

នៅពេលសិស្សពិភាក្សាសំណួរនេះ សូមប្រាកដថាពួកគេយល់ថា **នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយទទួលបានព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចទទួលបាននូវការផ្លាស់ប្តូរដ៏ធំក្នុងដួងចិត្ត ។**

សូមពន្យល់ថា ការទទួលបានការផ្លាស់ប្តូរដ៏ធំក្នុងដួងចិត្តគឺជាដំណើរការមួយដែលកើតឡើងពេញមួយជីវិតរបស់យើង វាមិនមែនជាព្រឹត្តិការណ៍តែម្តងនោះទេ ។ សូមអានសុន្ទរកថាខាងក្រោមនេះ ដែលថ្លែងដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសិន ៖

ការប្រែក្លាយដូចជាព្រះគ្រីស្ទគឺជាការស្វែងរកពេញមួយជីវិត ហើយជាញឹកញាប់វាជាប់ទាក់ទងទៅនឹងការរីកចម្រើន និង ការផ្លាស់ប្តូរដែលមានសភាពយឺត ស្ទើតែពុំអាចដឹងបាន » ។ . . .

" . . . ការប្រែចិត្តដ៏ពិត ទាក់ទងនឹងការផ្លាស់ប្តូរដួងចិត្ត វាមិនគ្រាន់តែជាការផ្លាស់ប្តូរអាកប្បកិរិយាប៉ុណ្ណោះទេ ។ . . . ការប្រែចិត្តភាគច្រើនមិនទាក់ទងនឹងការផ្លាស់ប្តូរដ៏ខ្លាំង ឬ សោកនាដកម្មទេ ប៉ុន្តែវាជាការផ្លាស់ប្តូរបន្តមួយជំហានម្តងមួយជំហានម្តង និង ជាសកម្មភាពបន្តឥតដាច់ឆ្ពោះទៅកាន់ភាពជាព្រះ" ("A Mighty Change of Heart," *Ensign* ខែ តុលា ឆ្នាំ ១៩៨៩ ទំព័រ ៥) ។

ដើម្បីជួយសិស្សឲ្យអនុវត្តគោលការណ៍នេះ ហើយវាយតម្លៃដំណើររបស់ពួកគេក្នុងការទទួលបានការផ្លាស់ប្តូរដ៏ធំមួយក្នុងដួងចិត្តគេ សូមឲ្យពួកគេឆ្លើយតបនឹងសំណួរខាងក្រោមនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ៖ (អ្នកអាចសរសេរសំណួរទាំងនេះនៅលើក្តារខៀនមុនចាប់ផ្តើមថ្នាក់ រៀបចំក្រដាសដោយមានសំណួរចែកឲ្យសិស្ស ឬ អានសំណួរយើយៗឲ្យសិស្សកត់ចូលនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។)

- តើបំណងរបស់អ្នកត្រូវបានផ្លាស់ប្តូរដោយរបៀបណា នៅពេលអ្នកបានធ្វើតាមព្រះអង្គសង្គ្រោះ ?
- តើអ្នកត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យព្រះអម្ចាស់បន្តជួយអ្នកទទួលបានការផ្លាស់ប្តូរនេះ ?

សូមឲ្យឱកាសដល់សិស្សម្នាក់ ឬ ពីរនាក់ចែកចាយចម្លើយរបស់ពួកគេ ។ សូមប្រាកដថា ពួកគេយល់ថា ពួកគេមិនមែនត្រូវតែចែកចាយបទពិសោធន៍ ឬ អារម្មណ៍ដែលផ្ទាល់ខ្លួន ឬ ឯកជនពេកនោះទេ ។

ម៉ូសាយ ៥:៥–១៥

ប្រជាជនរបស់ស្តេចបេនយ៉ាមីនចូលទៅក្នុងសេចក្តីសញ្ញាជាមួយនឹងព្រះ ហើយទទួលបានឈ្មោះថ្មីមួយ

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ៥:៥ ឮៗ ។ សូមឲ្យសិស្សរកមើលអ្វីដែលប្រជាជនរបស់ស្តេចបេនយ៉ាមីនមានឆន្ទៈនឹងធ្វើដោយសារតែដួងចិត្តរបស់ពួកគេត្រូវបានផ្លាស់ប្តូរ ។

- តើប្រជាជនមានឆន្ទៈនឹងធ្វើអ្វីខ្លះនាពេលឥឡូវ ដោយសារបំណងរបស់ពួកគេត្រូវបានផ្លាស់ប្តូរតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ?

ដើម្បីជួយសិស្សឲ្យយល់ពីសេចក្តីសញ្ញាកាន់តែច្បាស់ សូមឲ្យគេសិក្សាប្រធានបទនេះផ្ទាល់ខ្លួនពីរបីនាទី ។ អ្នកអាចស្នើថា ពួកគេគួរសិក្សាប្រធានបទនេះនៅក្នុងវចនានុក្រមព្រះគម្ពីរបរិសុទ្ធ ឬ *ពិតចំពោះសេចក្តីជំនឿ* ឬ ឲ្យពួកគេរកមើលគម្ពីរពីប្រធានបទនេះនៅក្នុងលិបិក្រមព្រះគម្ពីរមរមន ឬ ព្រះគម្ពីរបរ្យមបញ្ចូលគ្នា ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សធ្វើការជាដៃគូ ហើយពន្យល់ពីសេចក្តីសញ្ញាដល់គ្នាទៅវិញទៅមកជាសម្តីខ្លួនឯងផ្ទាល់ ។

- តើពាក្យ ឬ ឃ្លាណាមួយនៅក្នុង ម៉ូសាយ ៥:៥ បង្ហាញពីភាពស្មោះត្រង់នៃបំណងប្រាថ្នារបស់ប្រជាជនដើម្បីធ្វើ និង រក្សាសេចក្តីសញ្ញាជាមួយនឹងព្រះ ? (ចម្លើយអាចមាន " ធ្វើតាមឆន្ទៈរបស់ទ្រង់" , " ក្នុងគ្រប់កិច្ចការទាំងអស់" និង " ថ្ងៃដែលនៅសល់ទាំងអស់របស់យើង" ។)
- តើពាក្យ ឬ ឃ្លាណាមួយនៅក្នុង ម៉ូសាយ ៥:៥ រំឭកអ្នកអំពីសេចក្តីសន្យាដែលយើងរំឭករាល់ពេលដែលយើងទទួលទានសាក្រាម៉ង់ ?
- តើអ្នកគិតថា ការធ្វើនិងការរក្សាតាមសេចក្តីសញ្ញាជួយយើងបន្តនៅក្នុងដំណើរការនៃការទទួលបានការផ្លាស់ប្តូរដួងចិត្តដោយរបៀបណា ?

សូមឲ្យសិស្សអាន ម៉ូសាយ ១:១១ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើលមូលហេតុមួយដែលស្តេចបេនយ៉ាមីនបានប្រមូលប្រជាជនឲ្យជុំគ្នា ។ (ដើម្បីដាក់ឈ្មោះមួយ) ។ សូមពន្យល់ថា ម៉ូសាយ ៥:៧–១៥ កត់ត្រាការពន្យល់របស់ស្តេចបេនយ៉ាមីនអំពីឈ្មោះដែលទ្រង់បានសន្យាថានឹងដាក់ឲ្យប្រជាជនរបស់ទ្រង់ ។ សូមឲ្យសិស្សអានត្រួសៗក្នុង ម៉ូសាយ ៥:៧–១៤ ពីរបីនាទី ដោយរកមើលពាក្យ *ឈ្មោះ* និង *ត្រូវបានហៅ* ។អ្នកអាចស្នើថា សិស្សគួរគូសចំណាំពាក្យទាំងនេះរាល់ពេលដែលគេឃើញវា ។

សូមឲ្យសិស្សពីរបីនាក់ប្រាប់ពីហេតុផលដែលពួកគេត្រូវបានដាក់ឈ្មោះរបស់ពួកគេ ។ ឧទាហរណ៍ អ្នកអាចឲ្យពួកគេប្រាប់អំពីរបៀបដែលឪពុកម្តាយរបស់ពួកគេដាក់ឈ្មោះគេ ឬ អ្នកអាចសួរថាឈ្មោះរបស់គេមានអត្ថន័យជាក់លាក់ណាមួយទេ ។ បន្ទាប់មក សូមសួរសិស្សក្នុងថ្នាក់ ៖

- តើអ្វីជាសារៈសំខាន់នៃឈ្មោះមួយ ? (សូមសង្កេតចម្លើយរបស់សិស្សចំពោះសំណួរនេះនៅលើក្តារខៀន ។ ចម្លើយអាចរួមមានឈ្មោះគឺជារបៀបដែលយើងត្រូវបានគេស្គាល់ វាទាក់ទងនឹងអត្តសញ្ញាណរបស់យើង វាគឺជារបៀបដែលយើងត្រូវបានញែកចេញពីអ្នកដទៃ ហើយវាជាញឹកញាប់មានន័យនូវកិត្តិយស និង ការអំពាវនាវដែលជាប់ពាក់ព័ន្ធនឹងឈ្មោះនោះ) ។

សូមឲ្យសិស្សពន្យល់

ក្នុងពេលនោះ សូមឲ្យសិស្សពន្យល់ពីគោលលទ្ធិ និង គោលការណ៍នានាដល់គ្នាទៅវិញទៅមក ។ ដោយការធ្វើដូច្នោះ អ្នកនឹងជួយសិស្សឲ្យពង្រឹងនូវសេចក្តីជំនឿរបស់ពួកគេ ហើយបង្កើនការយល់ដឹងអំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ អ្នកក៏អាចជួយពួកគេរៀនពីរបៀបដើម្បីចែកចាយសេចក្តីពិតនៃដំណឹងល្អជាមួយនឹងអ្នកដទៃដែរ ។

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ៥:៧–៨ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលឈ្មោះដែលស្តេចបេនយ៉ាមីនបានដាក់ដល់ប្រជាជនទ្រង់ ។ សូមឲ្យពួកគេរកមើលពាក្យ និង ឃ្លាដែលបង្ហាញពីសារសំខាន់នៃឈ្មោះផងដែរ ។ អ្នកអាចលើកទឹកចិត្តពួកគេឲ្យគូសចំណាំពាក្យ និង ឃ្លាទាំងនេះ ។

- តើឈ្មោះអ្វីដែលស្តេចបេនយ៉ាមីនបានដាក់ឲ្យប្រជាជនរបស់ទ្រង់ ?
- តើពាក្យ និង ឃ្លាអ្វីដែលអ្នកបានកត់សម្គាល់ ? តើពាក្យ និង ឃ្លាទាំងនោះបង្រៀនអ្វីខ្លះដល់អ្នក អំពីព្រះនាមនៃព្រះគ្រីស្ទ ?
- តើយើងលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទនៅពេលណា ? (សូមប្រាកដថាសិស្សយល់ថា **យើងលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ នៅពេលយើងធ្វើ និងក្សាសេចក្តីសញ្ញាដ៏ពិសិដ្ឋនានា**) ។

នៅពេលសិស្សពិភាក្សាខគម្ពីរទាំងនេះ ពួកគេអាចត្រូវការជំនួយដើម្បីយល់ពីគោលលទ្ធិដែលថា យើងអាចក្លាយជា " បុត្រាបុត្រីរបស់ព្រះគ្រីស្ទ" (ម៉ូសាយ ៥:៧) ។ អ្នកអាចបង្ហាញថា ឪពុកម្នាក់លះបង់ជីវិតសម្រាប់កូន ។ យើងគឺជាកូនចៅខាងវិញ្ញាណរបស់ព្រះវរបិតាសួគ៌ ។ យើងក៏ជាកូនចៅរបស់ឪពុកនៅលើផែនដី ដែលមានម្តាយរបស់យើងផ្តល់ឱកាសដល់យើងឲ្យរស់នៅលើផែនដីខាងរូបកាយសាច់ឈាម ។ ដោយសំដៅលើ ម៉ូសាយ ៥:៧ ប្រធាន យ៉ូសែប ហ្វីលឌីង ស្មីធ បានបង្រៀនថា ព្រះយេស៊ូវគ្រីស្ទក៏ " ក្លាយជាព្រះបិតារបស់យើងដែរ" ដោយសារទ្រង់ " ផ្តល់ឲ្យយើងនូវជីវិត ជីវិតដ៏អស់កល្បជានិច្ច តាមរយៈដង្វាយធួនដែលទ្រង់បានធ្វើសម្រាប់យើង" ។ ប្រធាន ស្មីធ បានពន្យល់ថា " យើងក្លាយជាបុត្រា និង បុត្រីនៃព្រះយេស៊ូវគ្រីស្ទ តាមរយៈសេចក្តីសញ្ញានៃការគោរពតាមរបស់យើងចំពោះទ្រង់" (*Doctrines of Salvation,* comp. ប្រ្រីស អ័រ ម៉ាក់ខន់ឃី, វ៉ុលទី ៣ ។ |១៩៥៤–៥៦|, ១:២៩) ។

សូមឲ្យសិស្សមើលទៅពាក្យនៅលើក្តារខៀន ដែលពិពណ៌នាអំពីសារសំខាន់នៃឈ្មោះ ។

- តើពាក្យទាំងឡាយនៅលើក្តារខៀនអាចជួយយើងឲ្យយល់ពីសារសំខាន់នៃការលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?

សូមឲ្យសិស្សអាន ម៉ូសាយ ៥:៩–១៣ ដោយស្ងាត់ស្ងៀម ដោយរកមើលការប្រឹក្សាបន្ថែមពីស្តេចបេនយ៉ាមីនអំពីការលើកដាក់នូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកលើខ្លួនយើង ។ អ្នកអាចស្នើថា សិស្សគួរអានខគម្ពីរទាំងនេះ ហាក់ដូចជាស្តេចបេនយ៉ាមីនកំពុងនិយាយទៅកាន់ពួកគេម្នាក់ៗ ។ សូមឲ្យសិស្សធ្វើការជាដៃគូ ហើយសូមឲ្យពួកគេពិភាក្សាអំពីសំណួរខាងក្រោមដោយផ្អែកលើអ្វីដែលពួកគេបានអាន ។ (អ្នកអាចសរសេរសំណួរទាំងនេះនៅលើក្តារខៀន ឬ ចែកជាក្រដាសដល់ពួកគេ) ។

- សូមគិតអំពីសារៈសំខាន់នៃការលើកដាក់ព្រះនាមនៃព្រះគ្រីស្ទមកលើខ្លួនយើង ។ តើអ្នកគិតថា ការមានព្រះនាមនៃព្រះគ្រីស្ទសរសេរនៅក្នុងដួងចិត្តរបស់អ្នកមានអត្ថន័យយ៉ាងដូចម្តេច ? តើពរជ័យអ្វីខ្លះ ដែលមកដល់អ្នកមានព្រះនាមនៃព្រះគ្រីស្ទសរសេរនៅក្នុងដួងចិត្តរបស់ពួកគេ ?
- សូមគិតអំពីមនុស្សដែលអ្នកស្គាល់ ដែលគោរពដល់ព្រះនាមនៃព្រះគ្រីស្ទ ។ តើមនុស្សទាំងនេះបានធ្វើអ្វីខ្លះ ដើម្បីបង្ហាញពីគារវភាព និង សេចក្តីស្រឡាញ់ដែលពួកគេមានចំពោះព្រះនាមនៃព្រះគ្រីស្ទ ?

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ៥:១៥ ឮៗ ។ សូមអញ្ជើញសិស្សឲ្យរកមើលសកម្មភាពដែលបង្ហាញពីអ្នកដែលគោរពតាមសេចក្តីសញ្ញារបស់ពួកគេ ។

- តើសំណួរណាខ្លះ ដែលយើងអាចសួរខ្លួនឯងដើម្បីវាយតម្លៃពីទំហំដែលយើងបានលើកដាក់ព្រះនាមនៃព្រះគ្រីស្ទមកលើខ្លួនយើង ?

សូមចែកចាយនូវអារម្មណ៍របស់អ្នកអំពី អត្ថន័យនៃការលើកដាក់ព្រះនាមនៃព្រះគ្រីស្ទមកលើខ្លួនអ្នក ។ សូមថ្លែងទីបន្ទាល់ពីសារៈសំខាន់នៃការធ្វើដូច្នេះនៅក្នុងជីវិតរបស់អ្នក ។

ម៉ូសាយ ៦:១–៧

ម៉ូសាយចាប់ផ្តើមរជ្ជកាលរបស់ទ្រង់ជាស្តេច

សូមឲ្យសិស្សអាន ម៉ូសាយ ៦:១–៣ ដោយស្ងាត់ស្ងៀម ដោយរកមើលអ្វីដែលស្តេចបេនយ៉ាមីនបានធ្វើ មុនពេលទ្រង់បានចាកចេញពីហ្វូងមនុស្ស ។

- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីកត់ត្រាឈ្មោះប្រជាជនទាំងអស់ដែលបានចូលទៅក្នុងសេចក្តីសញ្ញា ? ហេតុអ្វីបានជាស្តេចបេនយ៉ាមីនតែងតាំងសង្ឃក្នុងចំណោមប្រជាជន ?

សូមពន្យល់ថា ក្រោយពីការនិយាយទៅកាន់ប្រជាជនហើយ ស្តេចបេនយ៉ាមីនបានប្រគល់នគរទៅឲ្យបុត្រាទ្រង់ ម៉ូសាយ ។ បីឆ្នាំក្រោយមក ស្តេចបេនយ៉ាមីនបានសុគត ។ សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ៦:៦–៧ ឮៗ។ សូមឲ្យសិស្សរកមើលពាក្យ និង ឃ្លាដែលបង្ហាញថា ម៉ូសាយបានធ្វើតាមគំរូនៃបិតារបស់ទ្រង់ ហើយបានជួយប្រជាជនរបស់ទ្រង់ឲ្យបន្តទទួលការផ្លាស់ប្តូរនៃដួងចិត្តដ៏ធំរបស់ពួកគេ ។

មេរៀនសិក្សានៅផ្ទះ

ពាក្យសម្តីនៃមរមន –ម៉ូសាយ ៦ (មេរៀនទី ១១)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីគោលលទ្ធិ និង គោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេសិក្សាពាក្យសម្តីនៃមរមន ម៉ូសាយ ៦ (មេរៀនទី ១១) មិនមែនប្រើសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ពាក្យសម្តីនៃមរមន–ម៉ូសាយ ២)

ដោយការសិក្សាពីបទពិសោធន៍របស់មរមនក្នុងការធ្វើតាមព្រះវិញ្ញាណ និង ការរួមបញ្ចូលផ្នាំងចំណារតូចរបស់នីហ្វៃ ជាមួយនឹងកំណត់ត្រារបស់គាត់ សិស្សបានដឹងថា ព្រះអម្ចាស់ទ្រង់ជាប្រទូរគ្រប់ការណ៍ទាំងអស់ ។ ស្តេចបេនយ៉ាមីនបានបង្រៀនថា ប្រសិនបើសាសន៍នីហ្វៃមិនបានមានព្រះគម្ពីរនោះទេ ពួកគេនឹងវង្វេងនៅក្នុងការឥតជំនឿ ហើយថាការសិក្សាព្រះគម្ពីរជួយយើងឲ្យដឹង និង កាន់តាមព្រះបញ្ញត្តិទាំងឡាយ ។ ទ្រង់បានបង្រៀនប្រជាជនរបស់ទ្រង់អំពីគោលការណ៍ដ៏សំខាន់ដូចជា ៖ នៅពេលយើងបម្រើដល់អ្នកដទៃ នោះយើងបម្រើដល់ព្រះ ។ នៅពេលយើងបានជំពាក់គុណដល់ព្រះ នោះយើងនឹងចង់បម្រើដល់អ្នកដទៃ ហើយការដឹងគុណរបស់យើងនឹងកើនឡើង ។ ប្រសិនបើយើងកាន់តាមព្រះបញ្ញត្តិទាំងឡាយ នោះយើងនឹងត្រូវបានប្រទានពរទាំងខាងសាច់ឈាម និង ខាងវិញ្ញាណ ។

ថ្ងៃទី ២ (ម៉ូសាយ ៣)

ស្តេចបេនយ៉ាមីនបានពន្យល់ពីពាក្យសម្តីរបស់ទេវតា ដែលបាននាំមក “ សេចក្តីអំណរយ៉ាងអស្ចារ្យ ” អំពីការយាងមកនៃព្រះអម្ចាស់នៅក្នុងភាពខាងសាច់ឈាម ។ សិស្សបានរៀនថា វាត្រូវបានព្យាករណ៍ឃ្លាជាង ១០០ ឆ្នាំមុនពេលព្រឹត្តិការណ៍បានកើតឡើងថា ព្រះយេស៊ូវគ្រីស្តបានឯកទុក្ខដើម្បីឲ្យយើងអាចត្រូវបានសង្គ្រោះចេញពីអំពើបាបរបស់យើង ។ យើងអាចត្រូវបានសង្គ្រោះចេញពីអំពើបាបរបស់យើង នៅពេលយើងអនុវត្តសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ត ហើយប្រែចិត្ត ។ ប្រសិនបើយើងទោទន់ទៅតាមការល្បួងលោមនៃព្រះវិញ្ញាណបរិសុទ្ធ យើងអាចយកឈ្នះភាពខាងសាច់ឈាមតាមរយៈជង្វាយធួននៃព្រះយេស៊ូវគ្រីស្ត ។

ថ្ងៃទី ៣ (ម៉ូសាយ ៤)

សារលិខិតរបស់ស្តេចបេនយ៉ាមីនបានបំពេញប្រជាជនរបស់ទ្រង់ដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ ។ សិស្សបានរៀនថា នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ត ហើយប្រែចិត្តដោយស្មោះស យើងនឹងទទួលបាននូវការផ្តាច់បាប ។ ស្តេចបេនយ៉ាមីនបានបង្រៀនប្រជាជនរបស់ទ្រង់ថា ប្រសិនបើយើងបន្ទាបខ្លួនចំពោះមុខព្រះ ហើយខិតខំអភិវឌ្ឍអាកប្បកិរិយាឲ្យដូចជាព្រះគ្រីស្ត នោះយើងអាចទទួលការផ្តាច់បាបរបស់យើង ។

ថ្ងៃទី ៤ (ម៉ូសាយ ៥–៦)

នៅពេលពួកគេអានអំពីការផ្លាស់ប្តូរដែលបានមានដល់ប្រជាជនរបស់ស្តេចបេនយ៉ាមីន សិស្សបានដឹងថា នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ត ហើយទទួលព្រះវិញ្ញាណបរិសុទ្ធ នោះយើងអាចទទួលបានការផ្លាស់ប្តូរក្នុងដួងចិត្តដ៏ជំនំ ។ ប្រជាជនរបស់ស្តេចបេនយ៉ាមីនដែលបានធ្វើសេចក្តីសញ្ញាថានឹងធ្វើតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយ បង្ហាញថា យើងបានលើកដាក់ព្រះនាមនៃព្រះយេស៊ូវគ្រីស្តមកលើខ្លួនយើង នៅពេលយើងធ្វើ និង រក្សាសេចក្តីសញ្ញាជំពិសិដ្ឋនានា ។

សេចក្តីផ្តើម

មេរៀននេះនឹងជួយសិស្សឲ្យយល់ពីការបង្រៀនរបស់ស្តេចបេនយ៉ាមីនទៅដល់បុត្រា និង ប្រជាជនរបស់ទ្រង់បីឆ្នាំ មុនពេលទ្រង់សុគត ។ ស្តេចបេនយ៉ាមីនបានបង្រៀនប្រជាជនរបស់ទ្រង់ ពីរបៀបដើម្បីទទួល និងរក្សាការផ្តាច់បាបរបស់ពួកគេដោយការអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ត ។

យោបល់សម្រាប់ការបង្រៀន

ពាក្យសម្តីនៃមរមន

នីហ្វៃ និង មរមនបង្ហាញពីទំនុកចិត្តរបស់ពួកគេទៅលើព្រះ

សូមអញ្ជើញសិស្សម្នាក់អាន នីហ្វៃទី ១ ៩:២–៣ ដើម្បីរំឭកសិស្សថា នីហ្វៃត្រូវបានបញ្ជាឲ្យបង្កើតផ្នាំងចំណារពីរ ។ សូមជួយពួកគេឲ្យយល់ថា នៅក្នុងវគ្គនេះ ឃ្លា “ ផ្នាំងទាំងនេះ” សំដៅទៅលើផ្នាំងចំណារតូចរបស់នីហ្វៃ ដែលរួមមានកំណត់ត្រាអំពីអ្វីៗដ៏ពិសិដ្ឋយ៉ាងសំខាន់ ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ១ ៩:៤ ឮៗ ។ សូមឲ្យសិស្សរកមើលគោលបំណងនៃផ្នាំងចំណារធំ (ដំណើររឿងនៃរជ្ជកាលរបស់ស្តេច និង សង្គ្រាមរបស់ប្រជាជន) ។

សូមរំឭកសិស្សថា នៅពេលមរមនសង្ខេបផ្នាំងចំណារធំរបស់នីហ្វៃ គាត់បានរកឃើញផ្នាំងចំណារតូចក្នុងចំណោមកំណត់ត្រាផ្សេងទៀត ។ គាត់ត្រូវបានបំផុសដោយព្រះវិញ្ញាណបរិសុទ្ធឲ្យបញ្ចូលនូវអ្វីដែលគាត់បានរកឃើញនៅលើផ្នាំងតូចជាមួយនឹងសេចក្តីសង្ខេបរបស់គាត់ ទោះបីជាគាត់មិនបានដឹងពីហេតុផលក៏ដោយ (សូមមើល ពាក្យសម្តីនៃមរមន១:៧) ។

សូមអញ្ជើញសិស្សពាក់កណ្តាលថ្នាក់ឲ្យអាន នីហ្វៃទី ១ ៩:៥–៦ ឲ្យដឹងពីហេតុផលដែលនីហ្វៃត្រូវបានបញ្ជាឲ្យធ្វើផ្នាំងតូច ។ សូមឲ្យសិស្សពាក់កណ្តាលថ្នាក់ទៀតអាន ពាក្យសម្តីនៃមរមន ១:៦–៧ ឲ្យដឹងថាហេតុអ្វីមរមនបានសម្រេចបញ្ចូលផ្នាំងតូចនៅក្នុងសេចក្តីសង្ខេបរបស់គាត់ ។ ក្រោយពីសិស្សរាយការណ៍ហើយ សូមសួរពួកគេថាវគ្គទាំងនេះអំពីនីហ្វៃ និង មរមនបង្រៀនពួកគេអ្វីខ្លះអំពីព្រះអម្ចាស់ ។ (សិស្សអាចប្រើពាក្យផ្សេងៗគ្នា ប៉ុន្តែសូមប្រាកដថាពួកគេបង្ហាញការយល់ដឹងថា **ព្រះអម្ចាស់ទ្រង់ជ្រាបគ្រប់ការណ៍ទាំងអស់** ។

- តើអ្វីជា “ គោលបំណងដ៏ឈ្លាសវៃ” នាពេលអនាគតដែលនីហ្វៃ និង មរមនសំដៅលើ ? (ព្រះអម្ចាស់ទ្រង់បានជ្រាបថា នៅឆ្នាំ ១៨២៨ ផ្នាំងតូចនឹងជំនួសព្រះគម្ពីរមរមនដែលបាត់ទាំង ១១៦ ទំព័រនោះ ។ សូមមើល មេរៀនទី ៦ ថ្ងៃទី ១ នៅក្នុងសៀវភៅណែនាំការសិក្សាសិស្ស ។)
- តើការយល់ដឹងរបស់អ្នកថាព្រះអម្ចាស់ជ្រាបគ្រប់ការណ៍ទាំងអស់នៅក្នុងពេលអនាគត អាចផ្តល់សេចក្តីជំនឿឲ្យអ្នកគោរពតាមការបំផុសគំនិតខាងវិញ្ញាណដែលអ្នកទទួលដោយរបៀបណា ?

ប្រសិនបើអ្នកគិតថាអ្នកត្រូវការពេលច្រើនលើផ្នែកនៃមេរៀននេះ សូមសួរសិស្សថាតើពួកគេអាចចែកចាយនូវបទពិសោធន៍ពេលដែលពួកគេបានមានអារម្មណ៍បំផុសដោយព្រះវិញ្ញាណដើម្បីធ្វើអ្វីមួយ ហើយមិនបានដឹងពីគោលបំណងនៃការបំផុសគំនិតនោះរហូតដល់ពេលក្រោយមកទេ ។

ម៉ូសាយ ១

ស្តេចបេនយ៉ាមីនហៅប្រជាជនឲ្យជួបជុំគ្នា

សូមពន្យល់ថា ផ្នាំងនីហ្វៃតូចរួមមាននូវប្រវត្តិសាស្ត្រនៃសាសន៍នីហ្វៃពីការបម្រើរបស់លីហៃរហូតដល់ពេលដែលស្តេចម៉ូសាយបានរួបរួមប្រជាជននីហ្វៃ និង សាភ័ហិមឡាចូលគ្នា និង ពេលដែលបុត្រារបស់ម៉ូសាយ បេនយ៉ាមីន គ្រងរាជ្យលើនគរក្នុងសេចក្តីសុចរិត ។ ស្តេចបេនយ៉ាមីនត្រូវទទួលបន្ទុកលើកំណត់ត្រាដ៏ពិសិដ្ឋទាំងឡាយ ។ (សូមមើល អេមណៃ ១:២៣, ២៥ ។)

នៅជិតពេលបញ្ចប់ជីវិតរបស់ស្តេចបេនយ៉ាមីន ទ្រង់បានសុំឲ្យបុត្រារបស់ទ្រង់ ម៉ូសាយ ប្រមូលប្រជាជនឲ្យជួបជុំគ្នា ។ សូមឲ្យសិស្សអាន ម៉ូសាយ ១:១០–១១ ហើយរកមើលមូលហេតុដែលស្តេចបេនយ៉ាមីនចង់និយាយទៅកាន់ប្រជាជន ។ (ទ្រង់ចង់ប្រកាសថា ម៉ូសាយនឹងគ្រងរាជ្យជាស្តេចបន្ត ហើយដើម្បីដាក់ឈ្មោះដល់ប្រជាជន ។)

ម៉ូសាយ ២–៦

ស្តេចបេនយ៉ាមីនបង្រៀនប្រជាជនរបស់ទ្រង់អំពីជង្វាយធួននៃព្រះអង្គសង្គ្រោះ

សូមបង្ហាញដល់សិស្សនូវរូបភាពស្តេចបេនយ៉ាមីនមានព្រះបន្ទូលទៅកាន់ប្រជាជនរបស់ទ្រង់ (៦២២៩; *សៀវភៅរូបភាពដំណឹងល្អ* [ឆ្នាំ ២០០៩], លេខ ៧៤) ។ សូមអាន ម៉ូសាយ ២:១២–១៩ ទៅកាន់សិស្ស ។ សូមអញ្ជើញសិស្សឲ្យលើកដៃ នៅពេលពួកគេរកឃើញឃ្លាដែលបង្ហាញពីចរិតលក្ខណៈរបស់ស្តេចបេនយ៉ាមីន ។ នៅពេលសិស្សលើកដៃ សូមឈប់អានសិន ហើយសូមឲ្យពួកគេពន្យល់ពីអ្វីដែលពួកគេបានរកឃើញ និង ពីរបៀបដែលវាលាតត្រដាងពីចរិតលក្ខណៈរបស់ស្តេចបេនយ៉ាមីន ។

អ្នកអាចសួរសិស្សអំពីអ្វីដែលពួកគេបានរៀនអំពីការបម្រើនៅក្នុង ម៉ូសាយ ២:១៧ ។ (ចម្លើយរបស់សិស្សគួរឆ្លុះបញ្ចាំងពីការយល់ដឹងថា **នៅពេលយើងបម្រើដល់អ្នកដទៃ យើងបម្រើដល់ព្រះ)។** អ្នកក៏អាចឲ្យសិស្សសូត្រ ម៉ូសាយ ២:១៧ ដែលជាវគ្គចំណេះចំណានខគម្ពីរ ។ សូមគិតពីការអញ្ជើញសិស្សឲ្យចែកចាយពីរបៀបដែលពួកគេបានបម្រើព្រះដោយការបម្រើដល់អ្នកដទៃនាពេលថ្មីៗនេះ ។

សូមសរសេរវគ្គព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ឬ នៅលើក្រដាសមួយ ។ សូមកុំសរសេរចម្លើយនៅក្នុងវង់ក្រចក ។ សូមឲ្យសិស្សម្នាក់ៗរំឭកពីវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមរំឭកពួកគេថា ការបង្រៀនរបស់ស្តេចបេនយ៉ាមីនផ្តោតទៅលើប្រធានបទ ៖ “ សេចក្តីសង្គ្រោះមកដល់កូនចៅ មានតែមធ្យោបាយមួយប៉ុណ្ណោះ គឺដោយតាមរយៈព្រះនាមនៃព្រះគ្រីស្ទ ជាព្រះអម្ចាស់ដ៏មានគ្រប់ព្រះចេស្តា” (ម៉ូសាយ ៣:១៧) ។ វគ្គព្រះគម្ពីរនីមួយៗបង្រៀនអ្វីមួយអំពីប្រធានបទនេះ ។

១. ម៉ូសាយ ២:២០–២៥, ៣៤ ។ (នៅពេលយើងទទួលស្គាល់ការជំពាក់គុណរបស់យើងចំពោះព្រះ ការដឹងគុណរបស់យើងនឹងកើនឡើង ។)

២. ម៉ូសាយ ៣:៧–១១, ១៧–១៨ ។ (ព្រះយេស៊ូវគ្រីស្ទរងទុក្ខដើម្បីឲ្យយើងអាចត្រូវបានសង្គ្រោះចេញពីអំពើបាបរបស់យើង ។ ប្រសិនបើយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្តតាមរយៈការប្រែចិត្ត យើងអាចត្រូវបានសង្គ្រោះចេញពីអំពើបាបរបស់យើង) ។

៣. ម៉ូសាយ ៣:១២–១៦, ១៩–២១ ។ (ប្រសិនបើយើងទោរទន់ទៅតាមការលួងលោមនៃព្រះវិញ្ញាណបរិសុទ្ធ តាមរយៈជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ យើងអាចយកឈ្នះលើភាពខាងសាច់ឈាម ហើយក្លាយជាអ្នកបរិសុទ្ធ) ។

៤. ម៉ូសាយ ៤:៥–៨, ១៩–២១, ២៦ ។ (ប្រសិនបើយើងបន្ទាបខ្លួននៅចំពោះមុខព្រះ ហើយខិតខំអភិវឌ្ឍអាកប្បកិរិយាឲ្យដូចជាព្រះគ្រីស្ទ យើងអាចទទួលបានការផ្តាច់បាប ។)

ក្រោយពីសិស្សមានពេលគ្រប់គ្រាន់ហើយ សូមឲ្យពួកគេរាយការណ៍អំពីអ្វីដែលពួកគេបានរៀនទៅកាន់សិស្សក្នុងថ្នាក់ ឬ នៅក្នុងក្រុមតូច ។ បន្ទាប់មក សូមឲ្យសិស្សបីបួននាក់ជ្រើសរើសគោលការណ៍មួយ ហើយពន្យល់ពីរបៀបដែលពួកគេអាចអនុវត្តវានៅក្នុងជីវិតរបស់ពួកគេ ។

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ៤:១–៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់តាមដានស្តាប់ ដោយរកមើលពីរបៀបដែលប្រជាជនឆ្លើយតបទៅនឹងពាក្យរបស់ស្តេចបេនយ៉ាមីន ។ បន្ទាប់មក សូមអញ្ជើញសិស្សផ្សេងទៀតឲ្យអាន ម៉ូសាយ ៥:១–២, ៥–៨ ឮៗ ។ សូមឲ្យសិស្សរកមើលពីរបៀបដែលយើងលើកដាក់នូវព្រះនាមនៃព្រះអម្ចាស់មកលើខ្លួនយើង ។ សូមប្រាកដថាសិស្សយល់ពីគោលការណ៍នេះ ៖ **យើងលើកដាក់នូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកលើខ្លួនយើង នៅពេលយើងធ្វើ និង រក្សាសេចក្តីសញ្ញាជ័ពិសិដ្ឋ ។**អ្នកអាចរំឭកសិស្សថា មូលហេតុមួយដែលស្តេចបេនយ៉ាមីនបានប្រមូលផ្តុំប្រជាជនរួមគ្នា គឺដើម្បីបង្រៀនពួកគេអំពីការធ្វើសេចក្តីសញ្ញា ។ ទ្រង់ក៏បានតែងតាំងបុត្រារបស់ទ្រង់ ម៉ូសាយ ទៅជាស្តេចលើប្រជាជនដែរ (សូមមើល ម៉ូសាយ ៦:៣) ។

ដើម្បីបញ្ចប់ សូមសួរសិស្សថាតើពួកគេចង់ចែកចាយពីអារម្មណ៍ដែលពួកគេមានអំពីការលើកដាក់នូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកលើខ្លួនគេនៅពេលជ្រមុជទឹកទេ ។ សូមឲ្យពួកគេសញ្ជឹងគិតអំពីសំណួរខាងក្រោម ៖

- តើអ្នកអាចអនុវត្តគោលការណ៍ទាំងឡាយពីការនិយាយរបស់ស្តេចបេនយ៉ាមីនដោយផ្ទាល់ខ្លួនយ៉ាងដូចម្តេច ?
- តើវាមានន័យយ៉ាងណាចំពោះអ្នក ក្នុងការលើកដាក់នូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកលើខ្លួនអ្នក ?

អ្នកក៏អាចថ្លែងទីបន្ទាល់អំពីសេចក្តីអំណរដែលមានតាមរយៈការជឿទៅលើព្រះយេស៊ូវគ្រីស្ទ និងការពឹងផ្អែកលើជង្វាយធួនរបស់ទ្រង់ ។

មេរៀនបន្ទាប់ (ម៉ូសាយ ៧–១៧)

សូមសួរសិស្សថា ៖ តើអ្នកនឹងក្រោកឈរសម្រាប់ព្រះយេស៊ូវគ្រីស្ទ ទោះបីជាការធ្វើដូច្នោះមានន័យថា អ្នកនឹងត្រូវស្លាប់ទេ ? សូមប្រាប់សិស្សថា សប្តាហ៍ក្រោយពួកគេនឹងសិក្សាពីការបង្រៀនរបស់ព្យាការីអ័ប៊ីណាដៃ ។ សូមលើកទឹកចិត្តពួកគេឲ្យរកមើលសារលិខិតដែលអ័ប៊ីណាដៃចង់ប្រាប់ដល់សាសន៍នីហ្វៃ ទោះបីជាគាត់ដឹងថា គាត់ត្រូវស្លាប់ក៏ដោយ ។

ម៉ូសាយ ៧–៨

សេចក្តីផ្តើម

ប្រហែលជា ៨០ ឆ្នាំ មុនពេលបុត្រារបស់ស្តេចបេនយ៉ាមីន ម៉ូសាយ ក្លាយជាស្តេច មានបុរសម្នាក់ឈ្មោះ សីនិព្ធ ដែលបានដឹកនាំសាសន៍នីហ្វៃមួយក្រុមពីដែនដីសារ៉ាហិមឡាទៅរស់នៅក្នុងដែនដីនីហ្វៃ ដែលពួកគេគិតថាជា “ ដែនដីនៃមរតករបស់ពួកគេ” (សូមមើល អេមណៃ ១:២៧–៣០) ។ ស្តេចម៉ូសាយបានបញ្ជាបុរសម្នាក់ឈ្មោះ អាំម៉ូន ឲ្យដឹកនាំក្រុមតូចមួយទៅកាន់ដែនដីនីហ្វៃដើម្បីដឹងអំពីដោគាសនារបស់ក្រុមសីនិព្ធ ។ អាំម៉ូន និង អ្នកដើរតាមគាត់បានរកឃើញកូនចៅនៃក្រុមសីនិព្ធរស់នៅក្នុងសេរីភាពនៃសាសន៍លេមិន ។ ចៅប្រុសរបស់សីនិព្ធ លិមហៃ គឺជាស្តេចរបស់ពួកគេ ។ ការមកដល់របស់អាំម៉ូន បាននាំមកនូវសេចក្តីសង្ឃឹមដល់លិមហៃ និង ប្រជាជនរបស់គាត់ ។ លិមហៃបានសួរអាំម៉ូនថា តើគាត់អាចបកប្រែចារឹកនៅលើផ្ទាំងមាស ២៤ ដែលប្រជាជនរបស់គាត់បានរកឃើញទេ ។ អាំម៉ូនបានពន្យល់ថា ស្តេចនៅក្នុងដែនដីសារ៉ាហិមឡា ស្តេចម៉ូសាយ គឺជាអ្នកមើលធុតម្នាក់ដែលអាចបកប្រែកំណត់ត្រាបុរាណទាំងនោះបាន ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ៧

អាំម៉ូនរកឃើញដែនដីលីហៃ-នីហ្វៃ ហើយដឹងពីរបៀបដែលប្រជាជនរបស់ស្តេចលិមហៃធ្លាក់ក្នុងសេរីភាព

សូមសរសេរពាក្យនេះនៅលើក្តារខៀន ៖ ទុក្ខព្រួយ ៖ មានអារម្មណ៍សោកស្តាយ ឬ ក្រៀមក្រំ

- តើមូលហេតុអ្វីខ្លះ ដែលប្រជាជនអាចទុក្ខព្រួយ ?

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ៧:២៤ ឮៗ ហើយសូមឲ្យសិស្សផ្សេងទៀតមើលតាម ។ សូមបង្ហាញឃ្លា « ការណ៍អស់ទាំងនេះក៏ព្រោះតែសេចក្តីទុច្ចរិត៧» ។ សូមពន្យល់ថា ខគម្ពីរនេះសំដៅលើកាលៈទេសៈដែលកើតឡើងដោយសារតែជម្រើសមិនសុចរិតរបស់ក្រុមមនុស្សមួយក្រុម ។ សូមឲ្យសិស្សសញ្ជឹងគិតថាតើ ពួកគេធ្លាប់បានទុក្ខព្រួយក្នុងស្ថានភាពមួយ ដែលបានកើតឡើង « ក៏ព្រោះតែសេចក្តីទុច្ចរិត» ទេ ។ សូមពន្យល់ថា ថ្ងៃនេះពួកគេនឹងសិក្សា ម៉ូសាយ ៧–៨ ដើម្បីរៀនអំពីស្តេចមួយឈ្មោះ លិមហៃ និង មូលហេតុនៃការសោកស្តាយរបស់ប្រជាជននោះ ។ សូមឲ្យសិស្សរកមើលអ្វីដែលលិមហៃបានលើកទឹកចិត្តដល់ប្រជាជនរបស់គាត់ឲ្យធ្វើដើម្បីយកឈ្នះលើការសោកសង្រេងរបស់ពួកគេ ។

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ៧:១ ឮៗ ។ សូមឲ្យសិស្សរកមើលកន្លែងពីរដែលបានលើកឡើងនៅក្នុងខគម្ពីរនេះ ។ សូមចម្លងឌីយ៉ាក្រាមទីមួយដែលអមមកជាមួយនឹងមេរៀននេះនៅលើក្តារខៀន ហើយសូមឲ្យសិស្សចម្លងដាក់ក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេដែរ ។ នៅពេលអ្នកប្រើឌីយ៉ាក្រាមនេះ សូមពន្យល់ថា សាសនាចក្រគ្មានទីតាំងផ្លូវការអំពីភូមិសាស្ត្រនៃព្រះគម្ពីរមរមន ក្រៅតែពីហេតុការណ៍ដែលបានកើតឡើងនៅក្នុងដែនដីអាមេរិកទេ ។

សូមរំឭកពីដំណើរនៅក្នុង ម៉ូសាយ ៧–២៤



កំណត់ចំណាំ ៖ ក្នុងពេលសិក្សារបស់ពួកគេអំពីគម្ពីរម៉ូសាយ សិស្សនឹងបន្ថែមសេចក្តីលម្អិតនៅក្នុងឌីយ៉ាក្រាមរបស់ពួកគេ ។ សូមធានាថា ពួកគេមានកន្លែងគ្រប់គ្រាន់ដើម្បីបន្ថែមសេចក្តីលម្អិតទាំងនេះ សូមចម្លងឌីយ៉ាក្រាមនេះនៅលើក្តារខៀនដូចដែលបានបង្ហាញ ។ សូមបង្ហាញកន្លែងទំនេរ មុនពេលសិស្សចាប់ផ្តើមគូរ ។ (ឌីយ៉ាក្រាមពេញលេញគឺនៅក្នុងសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។)

សូមពន្យល់ថា នៅពេលគ្រួសាររបស់លីហៃបានមកដល់ដែនដីសន្យា ពួកគេបានស្តាប់បានខ្លួនគេនៅក្នុងដែនដីនីហ្វៃ (ពេលខ្លះសំដៅលើដែនដីលីហៃ-នីហ្វៃ ឬ ដែនដីនៃមរតកដំបូង) ។ ភ្លាមៗក្រោយពីលីហៃបានស្លាប់ ព្រះអម្ចាស់បានបញ្ជាឲ្យនីហ្វៃរត់ចេញទៅក្នុងទីរហោស្ថាន ដោយនាំយកជាមួយអ្នកណាដែលព្រមមកតាមគាត់ ។ ប្រជាជននីហ្វៃបានបន្តរស់នៅក្នុងដែនដីនីហ្វៃ ប៉ុន្តែត្រូវបានបែងចែកពីអ្នកដែលធ្វើតាមលេមិន និង លេមយួល ។ ច្រើនឆ្នាំក្រោយមក ព្រះអម្ចាស់បានបញ្ជាឲ្យក្រុមសាសន៍នីហ្វៃមួយក្រុមរត់ចេញពីដែនដីនីហ្វៃ ។ នៅទីបញ្ចប់ក្រុមនេះបានតាំងលំនៅក្នុងដែនដីមួយឈ្មោះ សារ៉ាហិមឡា ដែលនៅខាងជើងនៃដែនដីនីហ្វៃ ។

ច្រើនជំនាន់ក្រោយមក បុរសម្នាក់ឈ្មោះសីនិព្ធបាននាំក្រុមសាសន៍មួយក្រុមទៅកាន់ដែនដីនីហ្វៃដើម្បី « កាន់កាប់ដែនដីនៃមរតករបស់ពួកគេ » (សូមមើល អេមណៃ ១:២៧–៣០) ។ សីនិព្ធធ្លាប់ជាផ្នែកនៃក្រុមផ្សេងទៀត ដែលបានបរាជ័យក្នុងការថែរក្សាដែនដីនៅក្នុងតំបន់នោះ (សូមមើល ម៉ូសាយ ៩:១–២) ។ សូមឲ្យសិស្សគូសសញ្ញាព្រួញមួយពីដែនដីសារ៉ាហិមឡាទៅកាន់ដែនដីនីហ្វៃ ហើយសរសេរថា « ក្រុមសាសន៍នីហ្វៃដឹកនាំដោយសីនិព្ធ » ។ ក្រុមនេះ បានចាកចេញពីដែនដីសារ៉ាហិមឡាប្រហែល ៨០ ឆ្នាំមុនពេលម៉ូសាយក្លាយជាស្តេច ។

សូមឲ្យសិស្សអាន ម៉ូសាយ ៧:១ ម្តងទៀត ដោយរកមើលអ្វីដែលម៉ូសាយចង់ដឹង ។ ក្រោយពីពួកគេរាយការណ៍ហើយ សូមឲ្យពួកគេអាន ម៉ូសាយ ៧:២–៣ ដើម្បីរកមើលអ្វីដែលម៉ូសាយបានធ្វើដើម្បីទទួលបានចម្លើយចំពោះសំណួររបស់គាត់ ។ សូមឲ្យសិស្សគូសសញ្ញាព្រួញទីពីរពីដែនដីសារ៉ាហិមឡាទៅកាន់ដែនដីនីហ្វៃ តំណាងដោយដំណើរនៃក្រុមស្រាវជ្រាវដឹកនាំដោយអាំម៉ូន ហើយសរសេរវាដូច្នោះ ។

សូមសង្ខេប ម៉ូសាយ ៧:៤–១១ ដោយការពន្យល់ថា អាំម៉ូនបានរកឃើញទីក្រុងដែលកូនចៅប្រជាជនសឺរិនឌូដែលបានរស់នៅក្រោមរាជ្យចៅប្រុសរបស់សឺរិនឌូ គឺលិមហៃ ។ លិមហៃបានឃើញក្រុមរបស់អាំម៉ូននៅខាងក្រៅកំពែងទីក្រុង ។ ដោយគិតថា ពួកគេគឺជាពួកសង្ឃទុច្ចរិតមួយចំនួនរបស់ឪពុករបស់គាត់ដែលបានស្លាប់ ណូអេ គាត់បានឲ្យអ្នកយាមចាប់ពួកគេ ហើយដាក់គុកពួកគេ (សូមមើល ម៉ូសាយ ២១:២៣) ។ គាត់បានសួរពួកគេពីរថ្ងៃក្រោយមក ។ សូមឲ្យសិស្សអាន ម៉ូសាយ ៧:១២–១៥ ដោយស្ងាត់ស្ងៀម ដោយរកមើលប្រតិកម្មរបស់លិមហៃ នៅពេលគាត់ដឹងថាអាំម៉ូនគឺជានរណា ហើយថាគាត់មកពីណា ។



- ហេតុអ្វីបានជាលិមហៃរីករាយយ៉ាងខ្លាំងដែលដឹងថា អាំម៉ូនមកពីដែនដីសារ៉ាហិមឡា ?

សូមមើលទៅពាក្យ *ទូញយំ* នៅលើក្តារខៀនម្តងទៀត ។ សូមសង្ខេប ម៉ូសាយ ៧:១៦–១៩ដោយការពន្យល់ថា ស្តេចលិមហៃបានប្រមូលប្រជាជនរបស់គាត់ជុំគ្នាដើម្បីឲ្យស្គាល់អាំម៉ូន ដើម្បីនិយាយទៅកាន់ពួកគេអំពីមូលហេតុនៃការសោកសង្រេងនិងការក្រៀមក្រំរបស់ពួកគេ ហើយដើម្បីជួយគេឲ្យដឹងពីកន្លែងទៅកាន់ការដោះលែង ។

សូមសរសេរពាក្យ *មូលហេតុ* នៅលើក្តារខៀននៅក្រោមនិយមន័យពាក្យ *ទូញយំ* ។សូមឲ្យសិស្សបីបួននាក់ឆ្លាស់វេនគ្នាអានព្រឹត្តិ ម៉ូសាយ ៧:២០–២៨ ។ សូមឲ្យសិស្សរកមើលសកម្មភាពដែលលិមហៃបានស្គាល់ថាជា មូលហេតុនៃការសោកល្បួង និង ទុក្ខសោករបស់ប្រជាជនគាត់ ។ (វាអាចជួយបានច្រើនបើប្រាប់សិស្សថា ព្យាការីដែលបានលើកឡើងនៅក្នុង ម៉ូសាយ ៧:២៦ គឺជាអ័ប៊ីណាដៃ ដែលត្រូវបានកាត់ទោសដោយភ្លើងអំឡុងពេលរជ្ជកាលនៃឪពុករបស់លិមហៃ ស្តេចណូអេ ។) ក្រោយពីអានខគម្ពីរហើយ សូមឲ្យសិស្សពីរបីនាក់សរសេរនៅលើក្តារខៀននូវអ្វីដែលពួកគេបានរកឃើញនៅក្រោមចំណងជើង *មូលហេតុ* ។

- តើអ្វីខ្លះដែលហាក់ដូចជាមូលហេតុសំខាន់នៃទុក្ខសោករបស់ប្រជាជននេះ ? (សេចក្តីទុច្ចរិត ឬ អំពើបាប ។)

សូមឲ្យសិស្សអាន ម៉ូសាយ ៧:២៩–៣២ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេជ្រើសរើសឃ្លាមួយដែលបង្ហាញពីការយល់ដឹងរបស់លិមហៃនៃទំនាក់ទំនងរវាងអំពើបាបរបស់ប្រជាជន និង ទុក្ខសោករបស់ប្រជាជន ។ (អ្នកអាចពន្យល់ថាពាក្យ *អង្កាម* សំដៅលើសំបកសល់ក្រោយពីស្រូវត្រូវបានញែកចេញពីដើមស្រូវ ។ នៅក្នុង ម៉ូសាយ ៧:៣០ « ច្រូតកាត់អង្កាម » មានន័យថា ទទួលបានអ្វីមួយដែលឥតប្រយោជន៍ ។) សូមឲ្យសិស្សពីរបីនាក់អាន និង ពន្យល់ឃ្លាដែលពួកគេបានជ្រើសរើស ។

- តើការទទួលស្គាល់លទ្ធផលនៃអំពើបាបរបស់យើងអាចជួយយើងដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ៧:៣៣ ឮៗ ។ សូមឲ្យសិស្សរកមើលអ្វីដែលលិមហៃបានដាស់តឿនដល់ប្រជាជនរបស់គាត់ឲ្យធ្វើ ។

- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីលិមហៃ និង ប្រជាជនរបស់គាត់អំពីឥទ្ធិពលនៃការទទួលស្គាល់ និង ការមានអារម្មណ៍សោកសៅចំពោះអំពើបាបរបស់យើង ? (នៅពេលសិស្សរកឃើញសេចក្តីពិតពីជំពូកនេះហើយ សូមជួយពួកគេឲ្យឃើញថា **ការទទួលស្គាល់ និង ការមានអារម្មណ៍សោកសៅចំពោះអំពើបាបរបស់យើងអាចដឹកនាំយើងឲ្យត្រឡប់មករកព្រះអម្ចាស់ដើម្បីទទួលបានការដោះលែង ។**អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍នេះកាន់តែច្បាស់ សូមឲ្យពួកគេស្រមៃថា ពួកគេមានអ្នកជាទីស្រឡាញ់ម្នាក់ដែលមានអារម្មណ៍ស្តាយក្រោយចំពោះអំពើបាបរបស់គេ ហើយដែលចង់ប្រែចិត្ត ហើយត្រឡប់មករកព្រះអម្ចាស់វិញ ប៉ុន្តែមិនដឹងពីរបៀបដើម្បីត្រឡប់មកវិញ ។ សូមថ្លែងទីបន្ទាល់ថា ការប្រឹក្សារបស់លិមហៃដល់ប្រជាជនរបស់គាត់នៅក្នុង ម៉ូសាយ ៧:៣៣ រួមមានគន្លឹះដើម្បីយកឈ្នះលើទុក្ខសោក និង ការស្តាយក្រោយដែលមានមកជាមួយនឹងអំពើបាប ។ សូមឲ្យសិស្សអាន ម៉ូសាយ ៧:៣៣ ដោយស្ងាត់ស្ងៀម ដោយរកមើលឃ្លាដែលជួយនរណាម្នាក់ឲ្យដឹងពីរបៀបដើម្បី « ត្រឡប់មករកព្រះអម្ចាស់» វិញ ។ (អ្នកអាចស្នើថា ពួកគេគួរគូសចំណាំឃ្លាទាំងនេះ ។)

ក្រោយមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយឃ្លាដែលពួកគេចាប់អារម្មណ៍ ។ សូមឲ្យសិស្សពន្យល់ពីអត្ថន័យនៃឃ្លាដែលគេបានជ្រើសរើសដោយ (១) និយាយជាសម្តីខ្លួនគេ ឬ (២) ផ្តល់ឧទាហរណ៍ពីសកម្មភាព ឬ អាកប្បកិរិយារបស់នរណាម្នាក់ដែលខិតខំអនុវត្តគោលការណ៍ដែលត្រូវបានបង្ហាញដោយឃ្លានោះ ។

សូមឲ្យសិស្សសញ្ជឹងគិតថាតើពួកគេមានអំពើបាបដែលពួកគេមិនបានប្រែចិត្ត ដែលអាចនាំឲ្យមានការសោកសៅ និង ការស្តាយក្រោយដល់ពួកគេ និង អ្នកដែលពួកគេស្រឡាញ់ដែរទេ ។ សូមឲ្យសិស្សសរសេរចម្លើយមួយចំពោះសំណួរខាងក្រោមនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ៖

- តើអ្នកអាចអនុវត្ត ម៉ូសាយ ៧:៣៣ នៅក្នុងជីវិតរបស់អ្នកសព្វថ្ងៃដោយរបៀបណា ?

សូមចែកចាយទីបន្ទាល់របស់អ្នកថា នៅពេលយើងត្រឡប់មករកព្រះអម្ចាស់ដោយដួងចិត្តស្មោះស ទ្រង់នឹងដោះលែងយើងពីការទូញយំដែលបណ្តាលមកពីអំពើបាបរបស់យើង ។

ម៉ូសាយ ៨

អាំម៉ូនបានរៀនពីផ្នាំងមាសទាំង ២៤ ហើយប្រាប់ដល់លិមហៃអំពីអ្នកមើលឆុតម្នាក់ដែលអាចបកប្រែចារឹកដែលពួកគេមាន

សូមឲ្យសិស្សពីរនាក់ឡើងមកខាងមុខថ្នាក់ ។ បិទភ្នែកសិស្សម្នាក់ ហើយបន្ទាប់មកសូមដាក់សៀវភៅ ឬក្រដាសមួយ ឬ របស់អ្វីដែលគ្មានគ្រោះថ្នាក់នៅលើដីក្នុងថ្នាក់អ្នក ។ សូមឲ្យសិស្សម្នាក់ទៀតនិយាយប្រាប់ដើម្បីជួយសិស្សទីមួយដើរកាត់ថ្នាក់ដោយមិនប៉ះរបស់ណាមួយនៅលើដី ។ បន្ទាប់មក សូមឲ្យសិស្សទីពីរបិទភ្នែក ។ សូមរៀបរបស់នៅលើដីម្តងទៀត ហើយឲ្យសិស្សទីមួយប្រាប់ពីទិសដៅម្តង ។ ទោះយ៉ាងណាក្តី ពេលនេះសិស្សដែលបិទភ្នែកនឹងមិនស្តាប់តាមការណែនាំដោយមានចេតនា ។ (សូមនិយាយទៅកាន់សិស្សនេះដោយសម្ងាត់មុនពេលចាប់ផ្តើមថ្នាក់ ហើយសូមឲ្យគេមិនស្តាប់ការណែនាំ) ។

- តើអ្វីជាតម្លៃនៃការស្តាប់តាមនរណាម្នាក់ ដែលអាចមើលឃើញអ្វីដែលយើងមិនអាចមើលឃើញ ?

សូមសង្ខេប ម៉ូសាយ ៨:៥–១២ ដោយការពន្យល់ថា មុនពេលអាំម៉ូនមកដល់ លិមហៃបានចាត់បេសកជនម្នាក់ឲ្យទៅសុំជំនួយពីដែនដីសារ៉ាហិមឡា ។ ក្រុមនេះបានដើរនៅក្នុងទីរហោស្ថាន ដោយរកដែនដីសារ៉ាហិមឡាមិនឃើញ ពួកគេបែរជា រកឃើញសំណល់នៃអារ្យធម៌ដែលត្រូវបានគេបំផ្លាញ ។ នៅទីនោះពួកគេបានរកឃើញផ្នាំងមាស ២៤ ផ្នាំងដោយមានអក្សរចារឹកនៅលើផ្នាំងទាំងនោះ ។ (អ្នកអាចពន្យល់ថា ទីក្រុងដែលត្រូវបានខ្ទេចខ្ទីដែលបានរកឃើញដោយប្រជាជនលិមហៃនោះ គឺជាសំណល់ពីអារ្យធម៌នៃពួកសាសន៍យ៉ារ៉ែឌ ។ កំណត់ត្រានៃសាសន៍យ៉ារេឌ ដែលត្រូវបានយកពីផ្នាំងមាស ២៤ផ្នាំងនោះ គឺត្រូវបានបញ្ចូលនៅក្នុងព្រះគម្ពីរមរមនជាគម្ពីរអេធើរ) ។ សូមបន្តែមការធ្វើដំណើរនេះទៅក្នុងឌីយ៉ាក្រាមនៅលើក្តារខៀន ដូចដែលបានបង្ហាញនៅក្នុងគំនូសក្នុងទំព័រនេះ ។ សូមឲ្យសិស្សបន្តែមគំនូសនៃការធ្វើដំណើរនោះទៅក្នុងតារាងរបស់គេផងដែរ ។ សូមពន្យល់ថា ស្តេចលិមហៃចង់យល់ពីការសរសេរដែលមានចារឹកនៅលើផ្នាំងមាស ២៤ផ្នាំងនោះ ។ គាត់សុំឲ្យអាំម៉ូនជួយ បើអាំម៉ូនស្គាល់នរណាម្នាក់ដែលអាចបកប្រែវាបាន ។

សេចក្តីសង្ខេបនៃការធ្វើដំណើរក្នុង ម៉ូសាយ ៧–២៤



សូមឲ្យសិស្សម្នាក់អានចម្លើយរបស់អាំម៉ូននៅក្នុង ម៉ូសាយ ៨:១៣–១៥ ។ សូមឲ្យសិស្សរកមើលហេតុផលដែលអាំម៉ូនបានប្រើដើម្បីណែនាំមនុស្សម្នាក់ដែលមានអំណាចដើម្បីបកប្រែកំណត់ត្រាបែបនោះ ។ សូមឲ្យសិស្សអាន ម៉ូសាយ ៨:១៦–១៩ ដោយស្ងាត់ស្ងៀម ដោយរកមើលសមត្ថភាពបន្តែមរបស់អ្នកមើលឆុត ។ សូមឲ្យសិស្សបីបួននាក់ប្រាប់ពីអ្វីដែលពួកគេបានរកឃើញ ។

សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***ព្រះអម្ចាស់ប្រទាន ពួកព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈដើម្បីជាប្រយោជន៍ដល់មនុស្សជាតិ ។***

- តើអ្នកមើលឆុតប៉ុន្មានដែលយើងមាននៅលើដែនដីសព្វថ្ងៃនេះ ? (ដប់ប្រាំ—សមាជិកនៃគណៈប្រធានទីមួយ និង ក្រុមនៃពួកសាវកដប់ពីរនាក់ ។)
- តើអ្វីខ្លះដែលព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈបានប្រាប់ដល់យើង ? (ប្រសិនបើសិស្សពិបាកឆ្លើយ សូមសួរថា តើអ្នកមើលឆុតណាដែលប្រាប់យើងអំពីប្រធានបទដូចជា អាពាហ៍ពិពាហ៍និងគ្រួសារ ការអប់រំ ការកំសាន្តនិងព័ត៌មាន ឬ ភាពបរិសុទ្ធខាងផ្លូវភេទ) ។
- តើជីវិតរបស់អ្នកត្រូវបានប្រទានពរដោយព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈជំនាន់ថ្មីដោយរបៀបណា ?

អ្នកអាចប្រាប់អំពីរបៀបដែលព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈបានប្រទានពរដល់ជីវិតរបស់អ្នក ។ សូមឲ្យសិស្សអាន និង សញ្ជឹងគិតអំពីសុន្ទរកថាសន្និសីទថ្មីៗនេះ ដោយសមាជិកម្នាក់នៃគណៈប្រធានទីមួយ ឬ ក្រុមនៃពួកសាវកដប់ពីរនាក់ ហើយធ្វើតាមការប្រឹក្សានៅក្នុងសុន្ទរកថានោះ ។

ម៉ូសាយ ៩–១០

សេចក្តីផ្តើម

អំឡុងពេលរជ្ជកាលនៃស្តេចបេនយ៉ាមីន សិនិព្វបានដឹកនាំក្រុមសាសន៍នីហ្វៃមួយក្រុមចេញពីដែនដីសារ៉ាហិមឡាទៅតាំងលំនៅក្នុងចំណោមសាសន៍លេមិននៅក្នុងដែនដីនីហ្វៃ ។ ម៉ូសាយ ៩–២២រួមមានដំណើររឿងនៃបទពិសោធន៍នៃប្រជាជនទាំងនេះ ។ ស្តេចនៃសាសន៍លេមិនបានអនុញ្ញាតឲ្យប្រជាជនសិនិព្វតាំងលំនៅក្នុងចំណោមពួកគេ ដោយសារទ្រង់បានគ្រោងជាសម្ងាត់នឹងដាក់ពួកគេក្រោមសេវកភាព ។ ប្រពៃណីដ៏ខុសឆ្គងរបស់សាសន៍លេមិន និងការស្អប់ដល់សាសន៍នីហ្វៃនៅទីបញ្ចប់បានបង្កជាសង្គ្រាម ។ ប្រជាជនរបស់សិនិព្វពឹងលើព្រះអម្ចាស់ដើម្បីមានកម្លាំង ហើយពួកគេអាចបណ្តេញសាសន៍លេមិនចេញពីដែនដីរបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ៩:១–១៣

សិនិព្វដឹកនាំក្រុមសាសន៍នីហ្វៃមួយក្រុមត្រឡប់ទៅកាន់ដែនដីនីហ្វៃវិញ

សូមឲ្យសិស្សគិតអំពីពេលមួយដែលពួកគេចង់បានអ្វីមួយយ៉ាងខ្លាំង ។ សូមឲ្យសិស្សពីរបីនាក់ប្រាប់អំពីបទពិសោធន៍ទាំងនេះ ។ សូមពន្យល់ថា ថ្ងៃនេះពួកគេនឹងរៀនអំពីបុរសម្នាក់ដែលចង់បានអ្វីមួយយ៉ាងខ្លាំង រហូតដល់ធ្វើឲ្យគាត់មិនបានគិតឃើញពីផលវិបាកដែលអាចកើតឡើងមកពីបំណងប្រាថ្នារបស់គាត់ ។

សូមឲ្យសិស្សមើលទៅឌីយ៉ាក្រាមនៃការធ្វើដំណើរ ដែលពួកគេបានចាប់ផ្តើមគូរកាលពីមេរៀនមុន ។ សូមរំឭកពួកគេថា បុរសម្នាក់ឈ្មោះអាំម៉ូនបានដឹកនាំក្រុមមួយដែលបានធ្វើដំណើរពីដែនដីសារ៉ាហិមឡា ហើយបានរកឃើញលិមហៃ និង ប្រជាជនរបស់គាត់នៅក្នុងដែនដីនីហ្វៃ ។ (អ្នកអាចពន្យល់ថា ព្រះគម្ពីរមរមនប្រាប់ពីបុរសពីរនាក់ឈ្មោះ អាំម៉ូន ។ បុរសម្នាក់គឺជាអ្នកដែលសិស្សនឹងរៀននៅថ្ងៃនេះ ។ បុរសម្នាក់ទៀតគឺជាកូនប្រុសរបស់ម៉ូសាយដែលក្លាយជាអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យម្នាក់ដល់ពួកសាសន៍លេមិន ។ សិស្សនឹងចាប់ផ្តើមអានអំពីគាត់នៅក្នុង ម៉ូសាយ ២៧ ។) សូមឲ្យសិស្សបើកទៅ ម៉ូសាយ ៧–៨ ហើយរកមើលកាលបរិច្ឆេទដែលមាននៅចុងទំព័រ ឬ នៅក្នុងសេចក្តីសង្ខេបនៃជំពូក (ប្រហែល ១២១ មុន.គ.ស.) ។ សូមឲ្យពួកគេប្រៀបធៀបកាលបរិច្ឆេទនោះជាមួយនឹងកាលបរិច្ឆេទនៅក្នុង ម៉ូសាយ ៩ (ប្រហែល ២០០ មុន.គ.ស. ប្រហែល ៨០ ឆ្នាំមុន) ។ សូមសួរបើសិនជាមាននរណាម្នាក់អាចពន្យល់ពីការផ្លាស់ប្តូរភ្លាម ៗនៅក្នុងកាលបរិច្ឆេទនោះ ។

> ***កាលបរិច្ឆេទនៅក្នុងលេខរយោង និង សេចក្តីសង្ខេបនៃជំពូក***
>
> សូមបង្ហាញសិស្សថា កាលបរិច្ឆេទប្រហែលគ្នាលេចឡើងនៅចុងទំព័រនីមួយៗ (ឬ នៅក្នុងសេចក្តីសង្ខេបនៃជំពូក) នៃព្រះគម្ពីរមរមនដើម្បីជួយបង្កើតជាបរិបទប្រវត្តិសាស្ត្រនៃហេតុការណ៍ដែលពិពណ៌នាក្នុងទំព័រទាំងនោះ ។ នៅពេលសិស្សចាប់ផ្តើមស្គាល់ពីកាលបរិច្ឆេទទាំងនេះហើយ ពួកគេនឹងឃើញពីរបៀបដែលព្រឹត្តិការណ៍ដែលបានពិពណ៌នានៅក្នុងព្រះគម្ពីរមរមនមានទំនាក់ទំនងនឹងគ្នា ហើយនឹងទំនាក់ទំនងទៅនឹងហេតុការណ៍ផ្សេងទៀតនៅក្នុងប្រវត្តិសាស្ត្រ ។

សូមពន្យល់ថាពី ម៉ូសាយ ៨ ដល់ ម៉ូសាយ ៩ សាច់រឿងបានត្រឡប់ ៨០ ឆ្នាំដើម្បីប្រាប់ពីដំណើររឿងនៃជីតារបស់ស្តេចលិមហៃ គឺសិនិព្វ ។ សូមឲ្យសិស្សម្នាក់អានបុព្វកថារបស់មរមនឮៗដល់កំណត់ត្រារបស់សិនិព្វនៅដើមដំបូងនៃ ម៉ូសាយ ៩ ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់ទៀតអាន ម៉ូសាយ ៩:១–២ ឮៗ ។

សូមឲ្យសិស្សបន្ថែមព្រួញមួយទៅលើឌីយ៉ាក្រាមរបស់ពួកគេដែលតំណាងឲ្យការធ្វើដំណើរដោយក្រុមទីមួយដែលចេញពីសារ៉ាហិមឡាទៅកាន់ដែនដីនីហ្វៃ ។ សូមបង្ហាញថា សិនិព្វគឺជាផ្នែកនៃក្រុមនេះ ។ ដូចដែលបង្ហាញនៅលើឌីយ៉ាក្រាមក្នុងទំព័រនេះ គំនូសព្រួញបង្ហាញថាក្រុមនេះក៏បានត្រឡប់ទៅកាន់សារ៉ាហិមឡាវិញដែរ ។ សូមសរសេរថា « សាសន៍នីហ្វៃខ្លះចង់ទាមទារដែនដីនីហ្វៃវិញ៨៧.» ។ (សម្រាប់ឌីយ៉ាក្រាមទាំងមូលពេញលេញ សូមមើលសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។)

សេចក្តីសង្ខេបនៃការធ្វើដំណើរនៅក្នុង ម៉ូសាយ ៧–២៤



សូមឲ្យសិស្សផ្សេងទៀតអាន ម៉ូសាយ ៩:៣–៤ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាមដោយរកមើល (១) អ្វីដែលសិនិព្វចង់បានយ៉ាងខ្លាំង និង (២) អ្វីដែលគាត់កម្រនឹងចងចាំ ។

- តើការចង់បានយ៉ាងខ្លាំងមានន័យដូចម្តេច ? (ចំណាប់អារម្មណ៍យ៉ាងខ្លាំង ឬ ការចង់បានអ្វីមួយពន់ពេកក្រៃ ។)
- តើអ្នកគិតថា ការកម្រនឹងចងចាំព្រះអម្ចាស់មានន័យយ៉ាងណា ?

សូមពន្យល់ថា ដោយសារសិនិព្វចង់បានយ៉ាងខ្លាំង ហើយកម្រនឹងចងចាំព្រះអម្ចាស់ គាត់បានធ្វើខុស ។ សូមឲ្យសិស្សអាន ម៉ូសាយ ៩:៥–៧, ១០ ដោយរកមើលកំហុសនោះ ។

- តើសិនិព្វបានបរាជ័យក្នុងការឃើញអ្វី ដោយសារតែបំណងចង់បានយ៉ាងខ្លាំងរបស់គាត់ក្នុងការទទួលបានដែនដីនីហ្វៃ ?
- តើគ្រោះថ្នាក់នៃការចង់បានខ្លាំងពេក ពេលធ្វើការសម្រេចចិត្តមានអ្វីខ្លះ ?
- តើគ្រោះថ្នាក់នៃការសម្រេចចិត្តដោយគ្មានការប្រឹក្សាពីព្រះអម្ចាស់មានអ្វីខ្លះ ?

សូមសង្ខេប ម៉ូសាយ ៩:១១–១៣ ដោយការប្រាប់សិស្សថា ១២ឆ្នាំក្រោយមក ប្រជាជនរបស់សិនិព្វបានរីកចម្រើនយ៉ាងខ្លាំងរហូតដល់ធ្វើឲ្យស្តេចសាសន៍លេមិនភ័យថាទ្រង់

នឹងមិនអាចដាក់ពួកគេនៅក្នុងសេរីភាពទៀត ដូច្នេះទ្រង់ « បានចាប់ផ្តើមចាក់រុកប្រជាជនរបស់ទ្រង់ឲ្យទាស់នឹងប្រជាជន [របស់ សឺនិព្វ] » (ម៉ូសាយ ៩:១៣) ។

ម៉ូសាយ ៩:១៤–១០:២២

សាសន៍លេមិនចង់ដាក់ប្រជាជនរបស់សឺនិព្វនៅក្នុងសេរីភាព

សូមសរសេរពាក្យ និង ឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *កិច្ចការសាលា ការទប់ទល់នឹងការល្បួង បញ្ហាជាមួយនឹងមិត្តភក្តិ ការដឹកនាំការងារ វិបត្តិជាមួយនឹងសមាជិកគ្រួសារ កីឡា* ។ (ដោយពឹងលើតម្រូវការ និង ចំណាប់អារម្មណ៍របស់សិស្ស អ្នកអាចបន្ថែម៣ក្យផ្សេងទៀតក្នុងបញ្ជីនេះ ។)

សូមឲ្យសិស្សម្នាក់មកខាងមុខថ្នាក់ ហើយលាតដៃរបស់គេ ។ សូមដាក់វត្ថុតូចមួយ ដូចជាសៀវភៅ ឬ ថ្មលើដៃរបស់សិស្ស ហើយសុំឲ្យគេទ្រាំ ។ សូមពន្យល់ថា វត្ថុនេះតំណាងឲ្យឧបសគ្គដែលបានសរសេរនៅលើក្តារខៀន ។ សូមសួរសិស្ស ៖

- **តើក្នុងផ្នែកមួយណាដែលអ្នកចង់បានកម្លាំង និង ការគាំទ្របន្ថែមនោះ ?**

សូមដាក់បន្ថែមវត្ថុអ្វីមួយ ឬ ពីរទៀតទៅលើដៃទាំងពីររបស់សិស្ស ។ សូមសួរសិស្ស ៖

- **តើអ្នកមានអារម្មណ៍ថា អ្នកកំពុងទ្រច្រើនពេកទេ ហើយអ្នកចង់មានកម្លាំងបន្ថែមទៀតដើម្បីទប់ទល់នឹងឧបសគ្គរបស់អ្នកទេ ?**

សូមឲ្យសិស្សពីរនាក់មកខាងមុខថ្នាក់ ហើយជួយទ្រដៃរបស់សិស្សដែលកំពុងទ្រវត្ថុនោះ ។ សូមពន្យល់ថា មេរៀនទាំងមូលនៅថ្ងៃនេះគឺអំពីក្រុមមនុស្សមួយក្រុមដែលឃើញថាពួកគេត្រូវការជំនួយកម្លាំងបន្ថែម ។ សូមស្នើថា ក្នុងមេរៀននេះទាំងមូល សិស្សនឹងស្វែងរកវិធីដែលពួកគេអាចទទួលកម្លាំងបន្ថែមនៅក្នុងជីវិតរបស់ពួកគេ ។ (សូមអញ្ជើញសិស្សដែលបានមកខាងមុខថ្នាក់ឲ្យត្រឡប់ទៅកាន់កន្លែងរបស់គេវិញ) ។

សូមពន្យល់ថា ម៉ូសាយ ៩ និង ១០ រៀបរាប់ប្រាប់ពីរដងពីពេលវេលាដែលសាសន៍លេមិនបានមកច្បាំងនឹងសឺនិព្វ និង ប្រជាជនរបស់គាត់ ។ សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ប៉ុន្តែសូមកុំចម្លងចម្លើយនៅក្នុងវង់ក្រចកឡើយ ។ សូមប្រាប់សិស្សថា ពួកគេនឹងអានវគ្គព្រះគម្ពីរនៅក្នុងតារាងនេះ ដោយរកមើលចម្លើយចំពោះសំណួរតាមក្បាលនៃតារាងនោះ ។ សូមអញ្ជើញសិស្សពាក់កណ្តាលថ្នាក់ឲ្យប្រើវគ្គនេះនៅក្នុងជួរទីមួយដើម្បីរកចម្លើយ ទាក់ទងនឹងសឺនិព្វនិងប្រជាជនរបស់គាត់ ។ សូមអញ្ជើញសិស្សពាក់កណ្តាលថ្នាក់ទៀតឲ្យអានវគ្គនៅក្នុងជួរទីពីរដើម្បីរកចម្លើយទាក់ទងនឹងសាសន៍លេមិន ។ សូមឲ្យសិស្សម្នាក់ពីក្រុមនីមួយ ៗសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន នៅពេលពួកគេរកឃើញចម្លើយហើយ ។

	តើប្រជាជនបានធ្វើអ្វីដើម្បីរៀបចំខ្លួន ?	តើពួកគេបានធ្វើអ្វីខ្លះដើម្បីដាក់ទីទុកចិត្តទៅលើព្រះអម្ចាស់ ?	តើអ្វីជាលទ្ធផល ?
សឺនិព្វ និង ប្រជាជនរបស់គាត់	ម៉ូសាយ ៩:១៤–១៦; ១០:១–២, ៧, ៩–១០ (ពួកគេប្រដាប់អាវុធ និង បានចេញទៅច្បាំង) ។	ម៉ូសាយ ៩:១៧; ១០:១៩ (ពួកគេបានអធិស្ឋាន និង ចងចាំថាព្រះអម្ចាស់បានដោះលែងដូនតារបស់ពួកគេ) ។	ម៉ូសាយ ៩:១៨; ១០:២០ (ព្រះអម្ចាស់បានពង្រឹងដល់ពួកគេ ហើយពួកគេបានជោគជ័យក្នុងការបណ្តេញសាសន៍លេមិនចេញពីដែនដី) ។
សាសន៍លេមិន	ម៉ូសាយ ១០:៦–៨ (ពួកគេប្រដាប់អាវុធលើខ្លួនគេ និង បានចេញទៅច្បាំង) ។	ម៉ូសាយ ១០:១១ (គ្មានអ្វីទាំងអស់ ។ ពួកគេពឹងផ្អែកទៅលើកម្លាំងរបស់គេផ្ទាល់ប៉ុណ្ណោះ) ។	ម៉ូសាយ ១០:១៩–២០ (សាសន៍លេមិនត្រូវបានបណ្តេញចេញពីដែនដីដោយការកាប់សម្លាប់ដ៏ធំ) ។

ក្រោយពីសិស្សបំពេញតារាងហើយ សូមសួរ ៖

- **តើអ្នកអាចឃើញពីភាពដូចគ្នា និង ភាពខុសគ្នាអ្វីខ្លះពីរបៀបដែលប្រជាជនរបស់សឺនិព្វ និង សាសន៍លេមិនបានទៅច្បាំងក្នុងចម្បាំងរបស់ពួកគេ ?**
- **តើសេចក្តីពិតអ្វីដែលយើងអាចរៀនពីការប្រៀបធៀបនេះ ?**

សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ *ព្រះអម្ចាស់នឹងពង្រឹងកម្លាំងដល់យើង នៅពេលយើងធ្វើអ្វីៗទាំងអស់ដែលយើងអាច ហើយដាក់ទីទុកចិត្តរបស់យើងទៅលើទ្រង់ ។*

សូមមើលទៅឧបសគ្គដែលបានសរសេរនៅលើក្តារខៀន ហើយសូមរំឭកសិស្សពីកម្មវត្ថុនៃមេរៀននេះ ។

- **តើអ្នកគិតថា គោលការណ៍នេះអាចអនុវត្តចំពោះឧបសគ្គមួយចំនួនទាំងនេះបានដោយរបៀបណា ?**

សូមគិតពីការប្រើឧទាហរណ៍ខាងក្រោមដើម្បីជួយឲ្យសិស្សគិតអំពីរបៀបដែលពួកគេអាចធ្វើដោយខ្លួនរបស់ពួកគេ ហើយទុកចិត្តទៅលើព្រះអម្ចាស់ នៅពេលពួកគេស្វែងរកកម្លាំង ៖

១. អ្នកមានការប្រលងមួយដ៏សំខាន់ដែលនឹងធ្វើនៅសាលា ហើយអ្នកចង់បានកម្លាំងដើម្បីធ្វើបានល្អ ។

២. អ្នកបានខិតខំដើម្បីបោះចោលទម្លាប់អាក្រក់ ហើយអ្នកមានអារម្មណ៍ថា អ្នកមិនរឹងមាំគ្រប់គ្រាន់ដើម្បីធ្វើវាតែម្នាក់ឯងទេ ។

៣. អ្នកកំពុងមានការលំបាកនៅក្នុងគ្រួសាររបស់អ្នក ហើយអ្នកមានអារម្មណ៍ថា អ្នកមិនអាចទប់ទល់នឹងការទទួលអារម្មណ៍ដ៏ខ្លាំងដោយគ្មានជំនួយខ្លះនោះទេ ។

សូមឲ្យសិស្សរំឭក ម៉ូសាយ ៩:១៨ បីជូរដំបូង ។ (អ្នកអាចស្នើថា ពួកគេគូរគូសចំណាំជូរនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។

- តើនៅពេលណាដែលអ្នកទទួលបានសេចក្តីពិតដែលបានបង្ហាញនៅក្នុងជូរទាំងនេះ ?

អ្នកអាចចែកចាយបទពិសោធន៍របស់អ្នកមួយដែលបង្ហាញពីឆន្ទៈរបស់ព្រះអម្ចាស់ក្នុងការពង្រឹងកម្លាំងដល់យើង នៅពេលយើងធ្វើអ្វីៗទាំងអស់ដែលយើងអាច ហើយដាក់ទីទុកចិត្តរបស់យើងទៅលើទ្រង់ ។

សូមពន្យល់ថា មុនពេលសិនិព្វនិងប្រជាជនរបស់គាត់បានទៅធ្វើចម្បាំងជាលើកទីពីរ សិនិព្វបានពន្យល់ដល់ប្រជាជនរបស់គាត់ពីមូលហេតុដែលសាសន៍លេមិនស្អប់ដល់សាសន៍នីហ្វៃ ។ សូមសរសេរពាក្យ *ខឹង* និង *បានគេធ្វើខុសដាក់* នៅលើក្តារខៀន ហើយសូមសួរសិស្សថា តើពួកគេអាចពន្យល់ពីអត្ថន័យនៃពាក្យទាំងនេះបានឬទេ ។ (ខឹង គឺជាកំហឹងយ៉ាងខ្លាំង ; ត្រូវបានគេធ្វើខុសដាក់គឺដែលត្រូវគេប្រមាថ ឬ ជួបនឹងការមិនស្មើភាព ឬ នៅក្នុងរបៀបមួយមិនយុត្តិធម៌) ។

ដើម្បីជួយសិស្សឲ្យមើលឃើញថា **ការត្រូវបានគេធ្វើខុសដាក់ ការចងកំហឹង និង ការបដិសេធមិនអភ័យទោស អាចប៉ះពាល់ដល់ច្រើនជំនាន់** សូមបែងចែកសិស្សជាដៃគូ ហើយសូមឲ្យដៃគូនីមួយៗអាន ម៉ូសាយ ១០:១២–១៨ ។ សូមឲ្យពួកគេរកមើលមូលហេតុដែលកូនចៅលេមិន និង លេមយូលបន្តស្អប់ដល់កូនចៅនីហ្វៃ ។

ក្រោយពីដៃគូមួយៗបានអានខគម្ពីររួមគ្នាហើយ សូមឲ្យពួកគេពិភាក្សាចម្លើយចំពោះសំណួរខាងក្រោម ។ (សូមគិតពីការសរសេរសំណួរនៅលើក្តារខៀន ពេលសិស្សអានខគម្ពីរ ឬ ចែកក្រដាសដែលមានសំណួរដល់ដៃគូសិស្សនីមួយៗ) ។

- ហេតុអ្វីបានជាសាសន៍លេមិនស្អប់សាសន៍នីហ្វៃខ្លាំងម្ល៉េះ ?
- តើនរណាជាអ្នកឈឺចាប់ នៅពេលយើងខឹង ឬ បដិសេធមិនព្រមអភ័យទោសនោះ ?
- តើកំហឹងរបស់មនុស្សម្នាក់អាចជះឥទ្ធិពលដល់គ្រួសាររបស់គេនាពេលឥឡូវ និង នៅក្នុងអនាគតដោយរបៀបណា ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដូណល អិល ហាលស្ត្រម នៃក្រុមចិតសិបនាក់ ។ សូមឲ្យសិស្សស្តាប់ហើយរកមើលអ្វីដែលយើងអាចធ្វើ នៅពេលយើងមានអារម្មណ៍ថាត្រូវបានគេធ្វើខុសដាក់ឬ ខឹងនឹងនរណាម្នាក់ ។

« ប្រសិនបើអ្នកមានអារម្មណ៍ថា អ្នកត្រូវបានគេធ្វើខុសដាក់—ដោយនរណាម្នាក់ (សមាជិកគ្រួសារ មិត្តភក្តិ សមាជិកសាសនាចក្រ ផ្សេងទៀត អ្នកដឹកនាំសាសនាចក្រ អ្នកធ្វើការជាមួយ) ឬ ដោយអ្វីមួយ (ការស្លាប់នៃមនុស្សជាទីស្រឡាញ់ បញ្ហាសុខភាព ការប្រែក្រឡាស់ផ្នែកហិរញ្ញវត្ថុ ការបំពាន ការញៀន) —សូមដោះស្រាយបញ្ហានោះដោយផ្ទាល់ ហើយដោយអស់ពីកម្លាំងទាំងអស់ដែលអ្នកមាន ។ . . . ហើយ ដោយគ្មានការពន្យារពេល សូមបែរទៅរកព្រះអម្ចាស់ ។ សូមអនុវត្តសេចក្តីជំនឿទាំងអស់ដែលអ្នកមានទៅលើទ្រង់ ។ សូមឲ្យទ្រង់រំលែកទុក្ខរបស់អ្នក ។ សូមឲ្យព្រះគុណរបស់ទ្រង់អាចសម្រាលបន្ទុករបស់អ្នក ។ . . . សូមកុំឲ្យកាលៈទេសៈខាងលោកិយបង្ខូចអ្នកខាងវិញ្ញាណ » (« សូមបែរទៅរកព្រះអម្ចាស់» *Ensign* ឬ *លេអាហ្គណា*, ខែ ឧសភា ឆ្នាំ ២០១០, ទំព័រ ៨០) ។

សូមឲ្យសិស្សសញ្ជឹងគិតពីសំណួរខាងក្រោម ៖ (អ្នកអាចលើកទឹកចិត្តពួកគេឲ្យសរសេរចម្លើយរបស់ពួកគេនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ) ។

- តើអ្នកមានអារម្មណ៍ថាត្រូវបានគេធ្វើខុសដាក់ឬ មានអារម្មណ៍ខឹងនឹងនរណាម្នាក់ទេ ?
- តើអ្នកអាចទៅរកអ្នកណាដើម្បីជួយអ្នកក្នុងការខិតខំដើម្បីអភ័យទោស ? តើអ្នកអាចចៀសវាងអារម្មណ៍នៃកំហុស និង កំហឹងនាពេលអនាគតដោយរបៀបណា ?

សូមឲ្យសិស្សគិតអំពីពេលមួយ នៅពេលពួកគេបានអភ័យទោសដល់នរណាម្នាក់ ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយពីអារម្មណ៍ដែលបានអភ័យទោសដល់គេ ហើយលែងមានអារម្មណ៍មានកំហុស ឬ កំហឹងទៀត ។ សូមគិតពីការចែកចាយទីបន្ទាល់របស់អ្នកផ្ទាល់អំពី ការស្វែងរកជំនួយរបស់ព្រះអម្ចាស់ដើម្បីអភ័យទោសដល់អ្នកដទៃ ។

ម៉ូសាយ ១១–១២:១៧

សេចក្តីផ្តើម

ដោយសារអំនួតរបស់ស្តេចណូអេ និង ការរស់នៅដ៏ចលាចលដែលបានដឹកនាំប្រជាជនរបស់ទ្រង់ជាច្រើនទៅក្នុងសេចក្តីទុច្ចរិត ព្រះអម្ចាស់បានបញ្ជូនព្យាការីអ័ប៊ីណាដៃឲ្យមកព្រមានស្តេចណូអេ និង ប្រជាជនរបស់ទ្រង់ ។ អ័ប៊ីណាដៃបានព្រមានពួកគេថា ពួកគេនឹងត្រូវបានដាក់នៅក្នុងសេរភាព ប្រសិនបើពួកគេមិនប្រែចិត្តនោះទេ ។ ប្រជាជនបានជ្រើសរើសមិនស្តាប់តាមការព្រមាននោះ ហើយស្តេចណូអេបានបញ្ជាឲ្យគេចាប់អ័ប៊ីណាដៃដាក់គុក ។

សូមសម្របមេរៀននេះទៅតាមតម្រូវការរបស់សិស្ស

មេរៀនភាគច្រើនរួមមានសេចក្តីពិតនៃព្រះគម្ពីរច្រើនជាងអ្វីដែលអ្នកអាចបង្រៀនក្នុងពេលដែលអ្នកមាន ។ នៅពេលអ្នកសិក្សាព្រះគម្ពីរ និង កម្មវិធីសូមស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធដើម្បីដឹងថាតើគោលលទ្ធិ និង គោលការណ៍មួយណាដែលសំខាន់បំផុតសម្រាប់សិស្សរបស់អ្នកដើម្បីរៀន និង ពិភាក្សានៅក្នុងមេរៀននេះ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងជួយអ្នកឲ្យសម្របមេរៀននីមួយៗទៅតាមតម្រូវការរបស់សិស្ស ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ១១:១–១៩

ស្តេចណូអេដឹកនាំប្រជាជនរបស់ទ្រង់ទៅក្នុងសេចក្តីទុច្ចរិត

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀនមុនពេលចាប់ផ្តើមថ្នាក់ ៖

តើអ្នកនឹងឆ្លើយតបដោយរបៀបណា ប្រសិនបើឪពុកម្តាយរបស់អ្នកបាននិយាយថា មិត្តភក្តិរបស់អ្នកមួយចំនួនកំពុងមានឥទ្ធិពលអាក្រក់មកលើអ្នក ?

តើអ្នកនឹងឆ្លើយតបយ៉ាងណា ប្រសិនបើអ្នកដឹកនាំសាសនាចក្រម្នាក់បាននិយាយថា សកម្មភាពដែលអ្នកចូលចិត្តមួយកំពុងរារាំងដល់ការរីកចម្រើនខាងវិញ្ញាណរបស់អ្នក ?

តើអ្នកនឹងឆ្លើយតបយ៉ាងណា ប្រសិនបើព្យាការីបាននិយាយប្រាប់ពីការកំសាន្តមួយចំនួនទាស់នឹងអ្វីដែលអ្នកចូលចិត្ត ?

សូមឲ្យសិស្សសញ្ជឹងគិតពីសំណួរទាំងនេះដោយស្ងាត់ស្ងៀម ។ បន្ទាប់មកសូមសួរ ៖

- ហេតុអ្វីបានជាស្ថានភាពទាំងនេះពិបាក ?
- តើអ្នកអាចធ្វើអ្វីដើម្បីធ្វើតាមការប្រឹក្សារបស់ឪពុកម្តាយ ឬ អ្នកដឹកនាំរបស់អ្នកនៅក្នុងស្ថានភាពដូចនេះ ?
- ហេតុអ្វីបានជាមនុស្សសុចរិតមានឆន្ទៈធ្វើតាមការប្រឹក្សា ទោះបីជាតម្រូវឲ្យមានការផ្លាស់ប្តូរដ៏លំបាកក្នុងជីវិតរបស់ពួកគេក្តី ?

សូមពន្យល់ថា នៅក្នុងមេរៀននេះ សិស្សនឹងរៀនអំពីក្រុមមនុស្សមួយក្រុមដែលមិនមានឆន្ទៈធ្វើតាមការប្រឹក្សាមកពីព្យាការីម្នាក់ ។

ដើម្បីជ្រាបបរិបទនៃមេរៀននេះ សូមរំឭកសិស្សថាស៊ីនិព្វបានដឹកនាំមនុស្សមួយក្រុមទៅកាន់ដែនដីនីហ្វៃ កន្លែងដែលពួកគេត្រូវបានដាក់ទៅក្នុងសេរភាពដោយសាសន៍លេមិន ។ ទោះបីជាភាពចង់បានរបស់ស៊ីនិព្វបានដឹកនាំគាត់ឲ្យឆ្ងាត់ទៅក្នុងការបោកបញ្ឆោតរបស់ពួកសាសន៍លេមិនក៏ដោយ គាត់គឺជាបុរសដ៏ល្អម្នាក់ ហើយគាត់បានបង្រៀនប្រជាជនរបស់គាត់ឲ្យដាក់ទីទុកចិត្តរបស់ពួកគេទៅលើព្រះអម្ចាស់ ។ មុនពេលស៊ីនិព្វស្លាប់ គាត់បានផ្ទេរនគរទៅឲ្យកូនប្រុសរបស់គាត់ ណូអេ ។ (សូមមើល ម៉ូសាយ ៩–១០) ។

សូមពន្យល់ថា ណូអេគឺជាមនុស្សដ៏ទុច្ចរិតម្នាក់ ។ ដើម្បីបង្ហាញថាភាពទុច្ចរិតរបស់គាត់ជះឥទ្ធិពលដល់ប្រជាជនគាត់ប៉ុណ្ណា សូមឲ្យសិស្សធ្វើការជាពីរក្រុម ។ សូមឲ្យក្រុមទីមួយអាន ម៉ូសាយ ១១:១–២, ៥–៧ ហើយសូមឲ្យក្រុមទីពីរអាន ម៉ូសាយ ១១:១៤–១៩ ។ សូមឲ្យទាំងពីរក្រុមរកមើលសេចក្តីលម្អិតនៃភាពទុច្ចរិតរបស់ស្តេចណូអេដែលបានជះឥទ្ធិពលដល់ប្រជាជន ។ សូមជួយសិស្សឲ្យវិភាគខគម្ពីរទាំងនេះ ដោយការសួរសំណួរដូចខាងក្រោម ៖

- តើអ្នកគិតថា ហេតុអ្វីបានជាប្រជាជនចង់គាំទ្រណូអេនៅក្នុងភាពទុច្ចរិតរបស់គាត់ ?
- ហេតុអ្វីបានជា « សំដីផ្អែមល្ហែមឥតប្រយោជន៍ បញ្ចើចបញ្ចើ » អាចដឹកនាំប្រជាជនឲ្យត្រូវបានបោកបញ្ឆោត ? (នៅពេលសិស្សពិភាក្សាពីសំណួរនេះ អ្នកអាចបង្ហាញថា សំដីផ្អែមល្ហែមបញ្ចើចបញ្ចើគឺជាការសរសើរមិនពិត ជាទូទៅនិយាយដើម្បីបញ្ចុះបញ្ចូលមនុស្សដែលចូលចិត្តការសរសើរ) ។
- ចេញពីដំណើររឿងនៃប្រជាជនរបស់ស្តេចណូអេ តើយើងអាចរៀនអ្វីខ្លះ អំពីរបៀបដែលយើងអាចឆ្លើយតបទៅនឹងសំដីផ្អែមល្ហែមឥតប្រយោជន៍ បញ្ចើចបញ្ចើ ? (នៅពេលយើងជឿលើសំដីផ្អែមល្ហែមឥតប្រយោជន៍ បញ្ចើចបញ្ចើរបស់អ្នកដទៃ យើងបើកខ្លួនយើងឲ្យត្រូវគេដឹកនាំខុស ។)
- តើយើងអាចធ្វើអ្វី នៅពេលមនុស្សទាំងអស់នៅជុំវិញយើងកំពុងរស់នៅក្នុងភាពមិនសុចរិត ?

ម៉ូសាយ ១១:២០–១២:១៧

អ័ប៊ីណាដៃព្រមានដល់ប្រជាជនថា ពួកគេនឹងត្រូវបានដាក់នៅក្នុងសេរភាព បើសិនជាពួកគេមិនប្រែចិត្តទេនោះ

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ១១:២០ ឮៗ ។

- តើព្រះអម្ចាស់បានធ្វើអ្វីដើម្បីជួយដល់ប្រជាជនរបស់ស្តេចណូអេ ? (ទ្រង់បានបញ្ជូនព្យាការីដើម្បីប្រាប់ពួកគេឲ្យប្រែចិត្ត ។)

សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***ព្រះបញ្ជូនព្យាការីដើម្បីជួយយើងឲ្យប្រែចិត្ត និង ចៀសវាងក្តីទុក្ខវេទនា*** ។ សូមពន្យល់ថា ព្រះអម្ចាស់បានបញ្ជូនអ័ប៊ីណាដៃពីរដងដើម្បីព្រមានដល់ប្រជាជន ។

សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ។ សូមទុកចន្លោះល្មមដើម្បីសរសេរការសង្ខេបមួយនៅក្រោមសេចក្តីយោងព្រះគម្ពីរនីមួយៗ ។

	សារលិខិតរបស់អ័ប៊ីណាដៃ	ប្រតិកម្មរបស់ប្រជាជន
ការព្រមានទីមួយ	ម៉ូសាយ ១១:២០–២៥	ម៉ូសាយ ១១:២៦–២៩
ការព្រមានទីពីរ	ម៉ូសាយ ១២:១–៨	ម៉ូសាយ ១២:៩–១៧

ដើម្បីជួយសិស្សឲ្យយល់ពីសារលិខិតរបស់អ័ប៊ីណាដៃ សូមឲ្យពួកគេពាក់កណ្តាលថ្នាក់អាន ម៉ូសាយ ១១:២០–២៥ ដែលប្រាប់ពីការព្រមានទីមួយរបស់អ័ប៊ីណាដៃ ហើយសូមឲ្យពួកគេពាក់កណ្តាលទៀតអាន ម៉ូសាយ ១២:១–៨ ដែលប្រាប់ពីការព្រមានទីពីររបស់គាត់ ។ សូមឲ្យសិស្សក្នុងក្រុមនីមួយៗសង្ខេបពីសារលិខិតរបស់អ័ប៊ីណាដៃ ខណៈពេលសិស្សម្នាក់សរសេរការសង្ខេបរបស់ពួកគេនៅលើក្តារខៀនដែលត្រូវនឹងសេចក្តីយោង ។

- តើអ្នកឃើញពីភាពខុសគ្នាអ្វីខ្លះរវាងការព្រមានទាំងពីររបស់អ័ប៊ីណាដៃ ?

ដើម្បីជួយសិស្សឲ្យឃើញពីភាពខុសគ្នាទាំងនេះ សូមយកចិត្តទុកដាក់លើ ម៉ូសាយ ១១:២០–២៥ ហើយអានឃ្លា « លើកលែងតែពួកគេប្រែចិត្ត » និង « លើកលែងតែប្រជាជននេះប្រែចិត្ត » ។ អ្នកអាចលើកទឹកចិត្តពួកគេឲ្យគូសចំណាំឃ្លាទាំងនេះ ។ បន្ទាប់មកសូមលើកទឹកចិត្តពួកគេឲ្យរកភាពខុសគ្នារវាងពាក្យនៅក្នុងឃ្លាទាំងនេះ និង ពាក្យនៅក្នុង ម៉ូសាយ ១២:១–៨ ។ អ្នកអាចស្នើថាសិស្សគួរយកចិត្តទុកដាក់ជាពិសេសទៅលើពាក្យ *នឹង* និង *នឹងត្រូវ* នៅក្នុងខគម្ពីរទាំងនេះ ។ (សូមជួយសិស្សឲ្យឃើញថា ប្រជាជនអាចជៀសចេញពីលទ្ធផលទាំងនេះបាន ប្រសិនបើពួកគេបានប្រែចិត្តក្រោយពីការព្រមានលើកទីមួយ ។ ដោយសារប្រជាជនបដិសេធមិនព្រមប្រែចិត្ត លទ្ធផលបានមកដល់ ហើយខ្លាំងក្លានៅក្នុងការព្រមានលើកទីពីររបស់អ័ប៊ីណាដៃ ។)

- តើភាពខុសគ្នាទាំងនេះបង្រៀនអ្នកអ្វីខ្លះ អំពីលទ្ធផលនៃការមិនគោរពដល់ការព្រមានរបស់ព្យាការី ?
- តើមានគ្រោះថ្នាក់អ្វីខ្លះនៃការរឹងទទឹងនៅក្នុងអំពើបាបរបស់យើង ហើយមិនព្រមប្រែចិត្តនោះ ?

ដើម្បីជួយសិស្សឲ្យយល់ពីប្រតិកម្មរបស់ប្រជាជនចំពោះសារលិខិតរបស់អ័ប៊ីណាដៃ សូមសិស្សពាក់កណ្តាលថ្នាក់អាន ម៉ូសាយ ១១:២៦–២៩ ដោយកត់សម្គាល់ពីប្រតិកម្មរបស់ប្រជាជន និងស្តេចរបស់គេចំពោះសារលិខិតលើកទីមួយរបស់អ័ប៊ីណាដៃ ។ សូមឲ្យសិស្សពាក់កណ្តាលទៀតអាន ម៉ូសាយ ១២:៩–១៧ ដោយកត់សម្គាល់ពីប្រតិកម្មចំពោះសារលិខិតលើកទីពីររបស់អ័ប៊ីណាដៃ ។ សូមឲ្យសិស្សក្នុងក្រុមនីមួយៗសង្ខេបពីប្រតិកម្មទាំងឡាយ នៅពេលសិស្សម្នាក់សរសេរពីការសង្ខេបនោះនៅក្នុងតារាង ។

- តើអ្នកគិតថា ហេតុអ្វីបានជាប្រជាជនតបដោយកំហឹងចំពោះអ័ប៊ីណាដៃ ដែលបានព្យាយាមជួយដល់ពួកគេ ? តើអ្នកគិតថា ហេតុអ្វីបានជាពួកគេការពារដល់ស្តេចណូអេ ដែលបានដឹកនាំគេទៅកាន់ទុក្ខវេទនា ?
- នៅក្នុង ម៉ូសាយ ១១:២៩ យើងអានថា « ភ្នែករបស់ប្រជាជនខ្វាក់» ។ តើប្រជាជននេះខ្វាក់និងសេចក្តីពិតដោយរបៀបណា ?

នៅពេលសិស្សពិភាក្សាពីសំណួរទាំងនេះ សូមជួយពួកគេឲ្យស្គាល់គោលការណ៍ខាងក្រោម ៖ **អំពើបាបអាចធ្វើឲ្យយើងខ្វាក់ពីការស្គាល់សេចក្តីពិតនៃសម្តីរបស់ព្យាការី** ។ សូមពន្យល់ថា នៅក្នុងភាពខ្វាក់របស់ពួកគេ ប្រជាជនបានគិតថា ស្តេចណូអេគឺជាមិត្តរបស់ពួកគេ ហើយថាអ័ប៊ីណាដៃគឺជាសត្រូវ តែតាមពិតទៅវាផ្ទុយខុសពីនេះ ។ សូមឲ្យសិស្សសញ្ជឹងគិតដោយស្ងៀមស្ងាត់ចំពោះសំណួរខាងក្រោម ៖

- តើអ្នកធ្លាប់បានខឹង ឬ ការពារកំហុសរបស់អ្នក នៅពេលនរណាម្នាក់កែតម្រូវអ្នក ទោះបីជាអ្នកដឹងថាពួកគេត្រូវក៏ដោយទេ ?
- តើអ្នកអាចធ្វើអ្វីដើម្បីទទួលយកការប្រឹក្សារបស់សមាជិកគ្រួសារ ពួកអ្នកដឹកនាំសាសនាចក្រក្នុងស្រុក និង ព្យាការីនៅពេលពួកគេណែនាំអ្នកពីរបៀបដើម្បីធ្វើតាមព្រះបន្ទូលនៃព្រះ ?

សូមបង្ហាញថា មនុស្សជាច្រើនលើកទឹកចិត្តយើងឲ្យរស់នៅតាមព្រះបន្ទូលនៃព្រះ ។ ដើម្បីជួយសិស្សឲ្យគិតបានវែងឆ្ងាយពីរបៀបដើម្បីឆ្លើយតបដោយសមរម្យចំពោះអ្នកដែលណែនាំយើងឲ្យផ្លាស់ប្តូរ ឬ ប្រែចិត្ត សូមត្រឡប់ទៅកាន់សំណួរទាំងបីដែលអ្នកបានសរសេរនៅលើក្តារខៀនមុនចាប់ផ្តើមថ្នាក់ ។ សូមឲ្យសិស្សឆ្លើយតបនឹងសំណួរមួយនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ នៅពេលពួកគេមានពេលសរសេរគ្រប់គ្រាន់ហើយ សូមឲ្យពួកគេពីរបីនាក់ប្រាប់ពីពេលមួយដែលពួកគេត្រូវបានប្រទានពរ ដោយសារពួកគេបានធ្វើតាមការណែនាំពីឪពុកម្តាយ ឬ អ្នកដឹកនាំ ។ សូមលើកទឹកចិត្តពួកគេឲ្យស្វែងរក និងធ្វើតាមការណែនាំរបស់ឪពុកម្តាយ អ្នកដឹកនាំសាសនាចក្រក្នុងស្រុក និង ព្យាការី ។

សូមឲ្យសិស្សសរសេរនៅលើក្តារខៀន

នៅពេលសិស្សសរសេរនៅលើក្តារខៀន អ្នកអាចនិយាយ និង បន្តការពិភាក្សាទៀត ។ ការធ្វើដូច្នេះនឹងទាញនូវចំណាប់អារម្មណ៍របស់សិស្សទៅលើក្តារខៀន ហើយបណ្តុះឲ្យមានការចូលរួម ។ សូមរំឭកសិស្សថា ពួកគេមិនចាំបាច់សរសេរចម្លើយទាំងមូលទេ— គ្រាន់តែសរសេរពាក្យគន្លឹះពីរបីពាក្យរបស់អ្នកនិយាយទៅបានហើយ ។ ដើម្បីបង្កើនការចូលរួម អ្នកអាចឲ្យសិស្សម្នាក់សរសេរពីរបីនាទី ហើយបន្ទាប់មកឲ្យសិស្សម្នាក់ទៀតមានឱកាសធ្វើជាអ្នកសរសេរដែរ ។

ការរំឭកចំណេះចំណានខគម្ពីរ

ការយល់របស់សិស្សអំពីវគ្គក្នុងព្រះគម្ពីរនឹងកើនឡើង នៅពេលពួកគេបង្កើតសំណួរផ្ទាល់ខ្លួនអំពីវគ្គនោះ ។ សូមឲ្យសិស្សធ្វើការរួមគ្នាជាថ្នាក់ ឬជាក្រុមតូចៗ ដើម្បីសរសេរតម្រុយដែលចង្អុលទៅវគ្គចំណេះចំណានខគម្ពីរពិសេសៗ ។ (អ្នកអាចជ្រើសរើសក្រុមនៃវគ្គចំណេះចំណានខគម្ពីរមួយ ដែលអ្នកចង់ឲ្យសិស្សរៀន ឬ រំឭក ។) បន្ទាប់មក សូមឲ្យពួកគេអានតម្រុយរបស់ពួកគេប្រាប់អ្នក ។ អ្នកនឹងទទួលបានពិន្ទុ ប្រសិនបើអ្នកទាយវគ្គចំណេះចំណានខគម្ពីរបានត្រូវ ។ សិស្សក្នុងថ្នាក់នឹងទទួលបានពិន្ទុ ប្រសិនបើអ្នកមិនអាចទាយបានត្រូវទេនោះ ។

កំណត់ចំណាំ ៖ ប្រសិនបើអ្នកមិនមានពេលប្រើសកម្មភាពនេះជាផ្នែកនៃមេរៀននេះទេ អ្នកអាចប្រើវានៅថ្ងៃក្រោយ ។ សម្រាប់សកម្មភាពរំឭកផ្សេងទៀត សូមមើលសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។

ម៉ូសាយ ១២:១៨–១៤:១២

សេចក្តីផ្តើម

នៅពេលស្តេចណូអេ និង ពួកសង្ឃរបស់ទ្រង់បានសួរអ័ប៊ីណាដៃ ព្យាការីបានស្តីបន្ទោសដល់ពួកគេថាមិនបានបង្រៀន ឬ កាន់តាមព្រះបញ្ញត្តិទាំងឡាយ ។ ស្តេចណូអេបានបញ្ជាឲ្យពួកសង្ឃរបស់ទ្រង់សម្លាប់អ័ប៊ីណាដៃ ប៉ុន្តែព្រះបានការពារអ័ប៊ីណាដៃ ហើយបានផ្តល់អំណាចដល់គាត់ឲ្យបន្តសារលិខិតរបស់គាត់ ។ ដោយដកស្រង់ពីអេសាយ អ័ប៊ីណាដៃបានថ្លែងទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ និង ជង្វាយធួនរបស់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ១២:១៨–១៣:២៦

អ័ប៊ីណាដៃស្តីបន្ទោសដល់ស្តេចណូអេ និង ពួកសង្ឃរបស់ទ្រង់ថាមិនបានសង្កេត និង បង្រៀនព្រះបញ្ញត្តិទាំងឡាយ

ដើម្បីចាប់ផ្តើមមេរៀននេះ សូមសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ៖

ខ្ញុំដឹងថាវាមានន័យយ៉ាងណាក្នុងការរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

ខ្ញុំរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

សូមឲ្យសិស្សគិតដោយស្ងៀមស្ងាត់ថាប្រយោគទាំងនេះពិពណ៌នាដល់ពួកគេបានល្អប៉ុណ្ណាដោយប្រើរង្វាស់ពី ១ ដល់ ១០ (ដោយ ១០ តំណាងឲ្យថាប្រយោគនេះពិណពណ៌នាដល់ពួកគេបានល្អបំផុត) ។

- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីអាចធ្វើតាមប្រយោគទាំងពីរនេះ ?

សូមពន្យល់ថា នៅពេលសិស្សពិភាក្សាពីសម្តីរបស់អ័ប៊ីណាដៃ ពួកគេនឹងរៀនបន្ថែមពីសារសំខាន់នៃការដឹង និង ការរស់នៅតាមដំណឹងល្អ ។ សូមរំឭកពួកគេថា នៅក្នុងមេរៀនមុន ពួកគេបានពិភាក្សាពីដំណើររឿងនៃស្តេចណូអេ និង ពួកសង្ឃរបស់ទ្រង់ដែលបានដាក់អ័ប៊ីណាដៃក្នុងគុកដោយសារតែការព្យាករណ៍របស់គាត់ប្រឆាំងនឹងពួកគេ (សូមមើល ម៉ូសាយ ១២:១–១៧) ។ សូមសង្ខេប ម៉ូសាយ ១២:១៨–២៤ ដោយការពន្យល់ថាអ័ប៊ីណាដៃក្រោយមកត្រូវបាននាំទៅចំពោះព្រះភ័ក្ត្រស្តេចណូអេ និង ពួកសង្ឃរបស់ទ្រង់ ។ ពួកសង្ឃបានសួរគាត់ ដោយព្យាយាមបំភាន់គាត់ឲ្យនិយាយអ្វីដែលពួកគេអាចចាប់កំហុសប្រឆាំងនឹងគាត់វិញ ។ បន្ទាប់មកសង្ឃម្នាក់បានសុំគាត់ឲ្យពន្យល់ពីវគ្គព្រះគម្ពីរមួយ ។

សូមឲ្យសិស្សអាន ម៉ូសាយ ១២:២៥–៣០ ដោយស្ងាត់ៗដោយរកមើលមូលហេតុរបស់អ័ប៊ីណាដៃក្នុងការស្តីបន្ទោសដល់ស្តេចណូអេ និង ពួកសង្ឃរបស់ទ្រង់ ។ ក្រោយពីសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញហើយ សូមសួរ ៖

- អ័ប៊ីណាដៃបាននិយាយថា ស្តេចណូអេ និង ពួកសង្ឃរបស់ទ្រង់បានបង្ខូចផ្លូវទាំងឡាយនៃព្រះអម្ចាស់ (សូមមើល ម៉ូសាយ ១២:២៦) ។ និយាយម្យ៉ាងទៀតថា ពួកគេបានធ្វើឲ្យរឿងដ៏ពិសិដ្ឋពុករលួយ ហើយចាកចេញពីផ្លូវដែលរស់នៅដ៏ត្រឹមត្រូវ ។ តើស្តេចណូអេ និង ពួកសង្ឃរបស់ទ្រង់មានទោសពីការបង្ខូចផ្លូវទាំងឡាយនៃព្រះអម្ចាស់ដោយរបៀបណា ?

ដើម្បីជួយសិស្សឲ្យឆ្លើយនឹងសំណួរនេះ អ្នកអាចបង្ហាញថា ពួកសង្ឃបាននិយាយថា សេចក្តីសង្គ្រោះបានមកដោយច្បាប់របស់ម៉ូសេ (សូមមើល ម៉ូសេ ១២:៣២) ។ ទោះជាយ៉ាងណាក្តី ពួកគេមិនបានកាន់តាមព្រះបញ្ញត្តិទាំងដប់ ដែលជាផ្នែកនៃច្បាប់នោះទេ ហើយពួកគេមិនបានបង្រៀនប្រជាជនឲ្យកាន់តាមព្រះបញ្ញត្តិទាំងឡាយទេ (សូមមើល ម៉ូសាយ ១១:១–១៥; ១២:២៧–២៩, ៣៧; ១៣:២៥–២៦) ។

សូមចង្អុលទៅប្រយោគនៅលើក្តារខៀន ។

- ពីរង្វាស់ ១ ដល់ ១០ តើអ្នកគិតថាប្រយោគនីមួយៗពិពណ៌នាពីស្តេចណូអេ និង ពួកសង្ឃរបស់ទ្រង់បានល្អប៉ុណ្ណា ?

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ១២:៣១–៣៣ ឮៗ ។ សូមសិស្សឲ្យកំណត់រកមើលគោលការណ៍ដែលអ័ប៊ីណាដៃបានបង្រៀនដល់ស្តេចណូអេ និង ពួកសង្ឃរបស់ទ្រង់ ។ (គាត់បានបង្រៀនថា **ប្រសិនបើយើងកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ យើងនឹងត្រូវបានសង្គ្រោះ ។**)

សូមចែកចាយឧទាហរណ៍ខាងក្រោមផ្តល់ដោយអែលឌើរ អេហ្ស មែលវិន ហាមម៉ុន នៃក្រុមចិតសិបនាក់ ។ សូមលើកទឹកចិត្តសិស្សឲ្យផ្ទៀងស្តាប់នូវសារៈសំខាន់នៃការដឹង និង ការកាន់តាមព្រះបញ្ញត្តិទាំងឡាយ ។

« ជាច្រើនឆ្នាំកន្លងទៅ មានអ្នកត្រឡប់ពីផ្សព្វផ្សាយសាសនាម្នាក់បានឈរយ៉ាងក្លាហាននៅក្នុងការប្រជុំសាក្រាម៉ង់ ហើយបានថ្លែងឮៗថា គាត់ដឹងតាមរយៈការសិក្សាព្រះគម្ពីររបស់គាត់ថា ដំណឹងល្អគឺការពិត ហើយថាគាត់នឹងលះបង់ជីវិតរបស់គាត់សម្រាប់ព្រះអម្ចាស់ និង សាសនាចក្ររបស់ទ្រង់ ។ ពីរសប្តាហ៍ក្រោយមក គាត់បានឈរនៅចំពោះមុខប៊ីស្សពនៃវួដសិស្សរបស់គាត់ ដោយខ្មាស់អៀន និង ភ័យខ្លាច ដោយសារគាត់បានសារភាពថា នៅពេលទន់ខ្សោយគាត់បានបាត់បង់គុណធម៌របស់គាត់ ។ យ៉ាងណាក្តី ការលះបង់របស់គាត់ចំពោះព្រះអម្ចាស់ដែលបានថ្លែងនោះ បែរទៅជាភ្លេចដោយសារភាពភ្លើតភ្លើនដ៏ត្រេកត្រអាលរបស់គាត់ ។ ទោះបីជាសិស្សម្នាក់នៃព្រះបន្ទូលនៃព្រះ គាត់ក៏មិនបានភ្ជាប់ការសិក្សារបស់គាត់ទៅនឹងការអនុវត្តជាក់ស្តែងរាល់ថ្ងៃ បន្ទាបខ្លួន រស់នៅដូចជាព្រះគ្រីស្ទនោះទេ ។

« យុវនារីដ៏ស្រស់ស្អាតម្នាក់បានដើរតាមផ្លូវនៃតម្រូវការទាំងអស់ដើម្បីទទួលបានមេដាយយុវនារី ។ គោលដៅផ្ទាល់ខ្លួនរបស់នាងត្រូវបានសរសេរដោយឫត្តចត់ និង ដាក់ប្រុងប្រយ័ត្ននៅក្នុងកំណត់ត្រាចងចាំរបស់នាង ។ ដោយភាពមុតមាំ នាងបានសរសេរថា នឹងដើរលេងជាគូរតែជាមួយនឹងយុវជនណាដែលសក្តិសមម ហើយស្វែងរកមនុស្សពិសេសម្នាក់នោះ ដើម្បីអាចនាំនាងទៅព្រះវិហារបរិសុទ្ធបាន ។ នៅពេលនាងអាយុដប់ប្រាំបីឆ្នាំ នាងបានភ្លេចគោលដៅរបស់នាង នាងបានរត់តាមយុវជនម្នាក់ដែលមិនមែនជាសមាជិកនៃសាសនាចក្រ ។ មានមនុស្សជាច្រើនដែលស្រឡាញ់នាងបានយំ—ឪពុកម្តាយ គ្រូបង្រៀន និង មិត្តភក្តិរបស់នាង ។ នាងបានធ្លាក់ទៅក្នុងទីដ៏អាក្រក់រវាងតម្រូវការនៃច្បាប់ និង តថភាពនៃភាពជាសិស្សដ៏ពិត » (“Eliminating the Void between Information and Application,” ការចាក់ផ្សាយការហ្វឹកហ្វឺនតាមផ្កាយរណប CES ខែ សីហា ឆ្នាំ ២០០៣ ទំព័រ ១៧, si.lds.org) ។

- ហេតុអ្វីបានជាការដឹងពីព្រះបញ្ញត្តិទាំងឡាយមិនគ្រប់គ្រាន់ដើម្បីធ្វើឲ្យយើងសាកសមនឹងសេចក្តីសង្គ្រោះ ?

ការអានតាម

ការអានតាមព្រះគម្ពីរអាចជួយសិស្សឲ្យឃើញមនុស្ស និង ព្រឹត្តិការណ៍នៅក្នុងព្រះគម្ពីរ ។ សូមលើកទឹកចិត្តសិស្សដោយធ្វើឲ្យបទពិសោធន៍នេះជាបទពិសោធន៍មួយដ៏មានចំណាប់អារម្មណ៍ ហើយរីករាយ ដោយមិនបង្ខូចដល់តាពពិសិដ្ឋនៃហេតុការណ៍ក្នុងព្រះគម្ពីរឡើយ ។

សូមបង្ហាញរូបភាពអ័ប៊ីណាដៃឈរនៅចំពោះព្រះភ័ក្ត្រស្តេចណូអេ (៦២០៤២; *សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ |, លេខ ៧៥ ។ សូមឲ្យសិស្សពិពណ៌នាអ្វីដែលបានកើតឡើងនៅក្នុងរូបភាពនោះ ។ (ស្តេចបានបញ្ជាឲ្យសម្លាប់អ័ប៊ីណាដៃ ។ ព្រះអម្ចាស់បានការពារអ័ប៊ីណាដៃ ។) ដើម្បីជួយសិស្សឲ្យយល់ពីដំណើររឿងនេះ សូមគិតឲ្យសិស្សបីនាក់ឈរ ហើយសម្តែងតាមការអាន ។ សិស្សម្នាក់នឹងធ្វើជាអ្នកនិទាន ។ សិស្សទីពីរនឹងអានពាក្យរបស់ស្តេចណូអេ ។ សិស្សទីបីនឹងអានពាក្យរបស់អ័ប៊ីណាដៃ ។ ដំបូង សូមឲ្យអ្នកនិទាន និង សិស្សដែលសម្តែងជាស្តេចណូអេអានផ្នែករបស់ពួកគេនៅក្នុង ម៉ូសាយ ១៣:១–២ ។ បន្ទាប់មក សូមឲ្យសិស្សសម្តែងជាអ័ប៊ីណាដៃឆ្លើយតបដោយ ម៉ូសាយ ១៣:៣–៤ ។ បន្ទាប់មក អ្នកនិទាននឹងអាន ម៉ូសាយ ១៣:៥–៦ ។ បន្ទាប់មកសិស្សដែលសម្តែងជាអ័ប៊ីណាដៃនឹងបញ្ចប់ដោយ ម៉ូសាយ ១៣:៧–១១ ។

សូមឲ្យសិស្សយកចិត្តទុកដាក់លើ ម៉ូសាយ ១៣:១១ ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាក្នុងការមានព្រះបញ្ញត្តិទាំងឡាយឆ្លាក់ក្នុងដួងចិត្តរបស់យើងនោះ ? (សូមជួយសិស្សឲ្យយល់ថា ការមានព្រះបញ្ញត្តិទាំងឡាយឆ្លាក់ក្នុងដួងចិត្តរបស់យើង យើងត្រូវដឹង *និង* រស់នៅតាមដំណឹងល្អ ។)

សូមបង្ហាញថា មុនពេលស្តេចណូអេចង់សម្លាប់អ័ប៊ីណាដៃ អ័ប៊ីណាដៃបានចាប់ផ្តើមសូត្រវគ្គព្រះគម្ពីរមួយដែលប្រហែលជាស្តេច និង ពួកសង្ឃនោះស្គាល់ ហើយនោះគឺជាភស្តុតាងនៃអំពើទុច្ចរិតរបស់ពួកគេ ។ សូមឲ្យសិស្សអាន ម៉ូសាយ ១២:៣៤–៣៦ ដោយស្ងាត់ស្ងៀមដើម្បីឃើញថា ព្រះគម្ពីរដែលអ័ប៊ីណាដៃបានអានដល់ស្តេចណូអេ និង ពួកសង្ឃនោះមើលទៅពួកគេស្គាល់ ។ សូមជួយពួកគេឲ្យឃើញថា អ័ប៊ីណាដៃបានចាប់ផ្តើមសូត្រព្រះបញ្ញត្តិទាំងដប់ប្រការ ។

សូមគូរថ្ងាំងថ្មីធំទទេពីរនៅលើក្តារខៀន ។ សូមឲ្យសិស្សម្នាក់សរសេរព្រះបញ្ញត្តិមួយនៃព្រះបញ្ញត្តិទាំងដប់ប្រការនៅលើថ្ងាំងមួយក្នុងចំណោមថ្ងាំងទាំងនេះ ។ សូមឲ្យសិស្សហុចដីសដល់សិស្សផ្សេងទៀតឲ្យសរសេរព្រះបញ្ញត្តិទាំងដប់ប្រការផ្សេងទៀត ។ សូមធ្វើដូច្នេះរហូតដល់សិស្សបានសរសេរអ្វីដែលពួកគេអាចចាំទាំងអស់ ។ សូមឲ្យពួកគេត្រួតពិនិត្យមើលចម្លើយរបស់ពួកគេក្នុង ម៉ូសាយ ១២:៣៤–៣៦ និង ១៣:១២–២៤ ។ អ្នកអាចលើកទឹកចិត្តពួកគេឲ្យគូសចំណាំព្រះបញ្ញត្តិទាំងដប់ប្រការនៅក្នុងខគម្ពីរទាំងនេះ និង នៅក្នុង និក្ខមនំ ២០:៣–១៧ (វគ្គចំណេះចំណានខគម្ពីរ) ។



សូមចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហ្គរដិន ប៊ី ហ៊ីងគ្លី ៖

« ព្រះបញ្ញត្តិទាំងដប់ប្រការត្រូវបានសរសេរដោយព្រះហស្តនៃព្រះយេហូវ៉ានៅលើថ្ងាំងថ្មដើម្បីសេចក្តីសង្គ្រោះ និងសុវត្ថិភាព ដើម្បីមានសុខសន្តិភាព និងសុភមង្គលដល់កូនចៅអ៊ីស្រាអែល និង សម្រាប់ជំនាន់ទាំងឡាយដែលនឹងមកក្រោយពួកគេ » (“ Our Solemn Responsibilities,” *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ទំព័រ ៥១) ។

សូមលើកទឹកចិត្តសិស្សឲ្យរំឭកព្រះបញ្ញត្តិទាំងដប់ប្រការ ហើយគិតដោយស្ងាត់ស្ងៀមពីការខិតខំផ្ទាល់ខ្លួនរបស់ពួកគេក្នុងការកាន់តាមព្រះបញ្ញត្តិនេះ ។

ម៉ូសាយ ១៣:២៧–១៤:១២

អ័ប៊ីណាដៃបង្រៀនអំពីសេចក្តីសង្គ្រោះតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ

សូមសរសេរដូចខាងក្រោមនៅលើក្តារខៀន (អ្នកអាចសរសេរមុនពេលចាប់ផ្តើមថ្នាក់) ។ សូមឲ្យសិស្សគិតអំពីអ្វីដែលអាចសរសេរក្នុងចន្លោះនោះ ។

> « *ក្រោយពីការគោរព និង កិច្ចការល្អរបស់យើងទាំងអស់ យើងមិនអាចត្រូវបានសង្គ្រោះពីសេចក្តីស្លាប់ ឬ ពីឥទ្ធិពលនៃអំពើបាបរៀងខ្លួនបានទេ បើគ្មាន . . . »*

សូមអានសេចក្តីថ្លែងការណ៍ដោយអែលឌើរ ដាល្លិន អេក អូក ខាងក្រោមឮៗ ៖

« ក្រោយពីការគោរព និង កិច្ចការល្អរបស់យើងទាំងអស់ យើងមិនអាចត្រូវបានសង្គ្រោះពីសេចក្តីស្លាប់ ឬ ពីឥទ្ធិពលនៃអំពើបាបរៀងខ្លួនបានទេ បើគ្មានព្រះគុណដែលពង្រីកដោយដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ព្រះគម្ពីរមរមនបញ្ជាក់វាយ៉ាងច្បាស់ ។ ព្រះគម្ពីរបានបង្រៀនថា ‹ សេចក្តីសង្គ្រោះពុំមែនបានមកដោយសារក្រិត្យវិន័យតែប៉ុណ្ណោះទេ › (ម៉ូសាយ ១៣:២៨) ។ និយាយម្យ៉ាងទៀតថា សេចក្តីសង្គ្រោះមិនមែនមកដោយគ្រាន់តែការកាន់តាមព្រះបញ្ញត្តិប៉ុណ្ណោះទេ ។ . . . ទោះបីជាអ្នកដែលខិតខំគោរព និងបម្រើដល់ព្រះដោយអស់ពីចិត្ត កម្លាំង គំនិត និង ពលំក៏នៅតែជា ‹ អ្នកបម្រើដ៏ឥតប្រយោជន៍ដែរ › (ម៉ូសាយ ២:២១) ។ មនុស្សមិនអាចរកបានសេចក្តីសង្គ្រោះដោយខ្លួនឯងបានទេ » (« សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ » *Ensign* ខែ មិនា ឆ្នាំ ១៩៩៤ ទំព័រ ៦៧) ។

សូមបំពេញប្រយោគនៅលើក្តារខៀនដោយការសរសេរ *ព្រះគុណដែលពង្រីកដោយដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ* ។បន្ទាប់មក សូមឲ្យសិស្សពីរបីនាក់ឆ្លាស់វេនគ្នាអានឮៗពី ម៉ូសាយ ១៣:២៨, ៣២–៣៥ ។ សូមឲ្យសិស្សរកមើល៣ក្យ និង ឃ្លាដែលទាក់ទងនឹងសេចក្តីថ្លែងការណ៍របស់អែលឌើរ អូក ។ សូមឲ្យសិស្សបីបួននាក់ចែកចាយនូវអ្វីដែលពួកគេបានរកឃើញ ។ (ចម្លើយអាចរួមមាន « ដង្វាយធួន» « ការប្រោសលោះនៃព្រះ» « ការយាងមកនៃព្រះមែស៊ី» និង ការសន្យាដែល « ព្រះអង្គទ្រង់| នឹង |យាងមកក្នុងចំណោមកូនចៅមនុស្ស» ។)

សូមពន្យល់ថា សម្តីរបស់អ័ប៊ីណាដៃអំពី « ក្រិត្យវិន័យ» នៅក្នុង ម៉ូសាយ ១៣:២៨ និង ៣២ គឺជាសេចក្តីយោងដល់ក្រឹត្យវិន័យនៃម៉ូសេដែលរួមមានច្បាប់ពីងពាំងទាក់ទងនឹងការបូជា បុណ្យ និង ការធ្វើផ្សេងទៀត ។ ក្រិត្យវិន័យត្រូវបានផ្តល់ដើម្បីជួយសាសន៍អ៊ីស្រាអែលឲ្យចងចាំដល់ព្រះ ហើយសម្លឹងមើលទៅដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ពេលកន្លងមក សាសន៍អ៊ីស្រាអែលជាច្រើនមិនបានយល់ពីតួនាទីរបស់ព្រះយេស៊ូវគ្រីស្ទជាព្រះអង្គសង្គ្រោះរបស់ពួកគេទេ ដោយគិតថាពួកគេអាចបានសង្គ្រោះដោយគ្រាន់តែតាមរយៈការគោរពតាមក្រិត្យវិន័យម៉ូសេ ។

- អ័ប៊ីណាដៃបានថ្លែងទីបន្ទាល់ថា **គ្មាននរណាម្នាក់អាចត្រូវបានសង្គ្រោះ លើកលែងតែតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ** (សូមមើល ម៉ូសាយ ១៣:២៨, ៣២) ។ ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីយល់ពីសេចក្តីពិតនេះ ?

សូមពន្យល់ថា នៅពេលអ័ប៊ីណាដៃបាននិយាយទៅកាន់ស្តេចណូអេ និង ពួកសង្ឃ គាត់បានដកស្រង់សការព្យាករណ៍ខ្លះរបស់អេសាយអំពីព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សអាន ម៉ូសាយ ១៤:៣–១២ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើល៣ក្យ ឬ ឃ្លាដែលពិពណ៌នាអ្វីដែលព្រះអង្គសង្គ្រោះបានធ្វើដើម្បីនាំមកនូវសេចក្តីសង្គ្រោះ ។

ក្រោយពីសិស្សបានសិក្សាខគម្ពីរទាំងនេះពីរបីនាទីហើយ សូមឲ្យពួកគេចែកចាយអ្វីដែលពួកគេបានរកឃើញ ។ អ្នកអាចសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ ដើម្បីជួយសិស្សឲ្យគិតអំពីសេចក្តីទុក្ខព្រួយ និង ការសោកស្តាយដែលព្រះអង្គសង្គ្រោះបានមានចំពោះពួកគេ ហើយដើម្បីជួយគេឲ្យគិតអំពីការរងទុក្ខរបស់ទ្រង់សម្រាប់អំពើបាបរបស់ពួកគេ សូមអាននូវប្រយោគខាងក្រោមនេះដល់ពួកគេ ។ សូមឲ្យពួកគេបំពេញប្រយោគទាំងនេះក្នុងគំនិតរបស់គេ ៖

ព្រះយេស៊ូវគ្រីស្ទបានយកការសោកស្តាយរបស់ខ្ញុំដូចជា . . .

ព្រះយេស៊ូវគ្រីស្ទបានឈឺចាប់ និង រងរបួសជំនួសឲ្យការរំលងរបស់ខ្ញុំដូចជា . . .

សូមសួរសិស្សថាតើប្រយោគខាងក្រោមមានន័យយ៉ាងណាដល់ពួកគេ ៖ « ហើយយើងរាល់គ្នាបានប្រោសឲ្យជាដោយសារស្នាមរំពាត់នៅអង្គទ្រង់» (ម៉ូសាយ ១៤:៥) ។ អ្នកអាចពន្យល់ថា៣ក្យ *ស្នាមរំពាត់* សំដៅជាពិសេសទៅលើស្នាមរបួសដែលនៅលើព្រះកាយនៃព្រះយេស៊ូវគ្រីស្ទ នៅពេលទ្រង់ត្រូវបានគេធ្វើបាប ឬ វាយនឹងរំពាត់ (សូមមើល យ៉ូហាន ១៩:១) ។ ជាទូទៅ ៣ក្យនេះសំដៅទៅលើការរងទុក្ខទាំងឡាយរបស់ទ្រង់ ។

ក្រោយពីសិស្សបានចែកចាយពីអារម្មណ៍របស់ពួកគេអំពីប្រយោគនេះហើយ សូមថ្លែងទីបន្ទាល់ថាតាមរយៈការរងទុក្ខរបស់ព្រះអង្គសង្គ្រោះ និង ការខិតខំផ្ទាល់របស់យើងដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយ យើងអាចទទួលបានសេចក្តីសុខសាន្ត និង ការអភ័យទោសនៅក្នុងជីវិតនេះ និង សេចក្តីសង្គ្រោះនៅក្នុងជីវិតខាងមុខ (សូមមើល គ.&ស. ៥៩:២៣; មាត្រានៃសេចក្តីជំនឿ ១:៣) ។ សូមឲ្យសិស្សបង្ហាញសេចក្តីស្រឡាញ់ និង ការកោតសរសើររបស់គេចំពោះព្រះអង្គសង្គ្រោះដោយការកាន់តាមព្រះបញ្ញត្តិទាំងឡាយ ។

មេរៀនទី ៦០

ម៉ូសាយ ១៥–១៧

សេចក្តីផ្តើម

នៅពេលអ័ប៊ីណាដៃបានបន្តបង្រៀនដល់ស្តេចណូអេ និង ពួកសង្ឃរបស់ទ្រង់ គាត់បានថ្លែងទីបន្ទាល់អំពីតួនាទីរបស់ព្រះយេស៊ូវគ្រីស្ទជាព្រះប្រោសលោះ ។ សង្ឃម្នាក់របស់ស្តេចណូអេគឺ អាលម៉ា បានជឿតាមអ័ប៊ីណាដៃ ។ ស្តេចណូអេបានបណ្តេញអាលម៉ាចេញពីតុលាការរបស់ទ្រង់ ហើយបានបញ្ជាអ្នកបម្រើរបស់ទ្រង់ឲ្យសម្លាប់គាត់ ប៉ុន្តែអាលម៉ាបានរត់ចេញ ហើយបានកត់ត្រាការបង្រៀនដែលគាត់បានស្តាប់ពីអ័ប៊ីណាដៃ ។ ក្រោយពីអ័ប៊ីណាដៃបានចែកចាយសារលិខិតដែលព្រះអម្ចាស់បានបញ្ជូនគាត់ឲ្យធ្វើហើយ ស្តេចណូអេ និងពួកសង្ឃរបស់ទ្រង់បានគំរាមថានឹងសម្លាប់គាត់ ប្រសិនបើគាត់មិនព្រមបដិសេធអ្វីដែលគាត់បាននិយាយទេនោះ។ ដោយបដិសេធមិនព្រមបដិសេធទីបន្ទាល់របស់គាត់ គាត់បាន « រងទុក្ខដល់ស្លាប់ដោយភ្លើងឆេះ» ហើយ " បានបិទត្រានូវការពិតនៃពាក្យសំដីរបស់ខ្លួនដោយសេចក្តីស្លាប់របស់គាត់" (ម៉ូសាយ ១៧:២០) ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ១៥–១៦

អ័ប៊ីណាដៃបង្រៀនអំពីតួនាទីរបស់ព្រះយេស៊ូវគ្រីស្ទជាព្រះប្រោសលោះ

សូមឲ្យសិស្សរកមើលពាក្យ *នឹងប្រោសលោះ បានប្រោសលោះ* និង *សេចក្តីប្រោសលោះ* នៅក្នុង ម៉ូសាយ ១៥–១៦ ពីរបីនាទី ។ អ្នកអាចស្នើថា ពួកគេគូសចំណាពាក្យទាំងនេះ ។ សូមពន្យល់ថា នៅពេលទម្រង់ខុសគ្នានៃពាក្យតែមួយត្រូវបានសរសេរម្តងហើយម្តងទៀតនៅក្នុងវគ្គនៃព្រះគម្ពីរ វាអាចជាសញ្ញាថាពាក្យនោះសំខាន់ចំពោះសារលិខិតរបស់អ្នកសរសេរនោះ ។ សូមលើកទឹកចិត្តសិស្សឲ្យមើលការបង្រៀនរបស់អ័ប៊ីណាដៃអំពីការត្រូវបានសង្គ្រោះនៅក្នុងមេរៀនថ្ងៃនេះ ។

ដើម្បីជួយសិស្សឲ្យយល់ពីតួនាទីរបស់ព្រះយេស៊ូវគ្រីស្ទជាព្រះប្រោសលោះ សូមគូសរូបភាពខាងក្រោមនៅលើក្តារខៀន ៖



អ្នកធ្វើខុស

ការពិន័យ

ការដាក់ទោស

សូមចង្អុលទៅពាក្យ « អ្នកធ្វើខុស» ហើយសូមឲ្យសិស្សស្រមៃថា ពួកគេបានប្រព្រឹត្តបទល្មើសមួយ ។ ពួកគេត្រូវបានកាត់ទោសឲ្យបង់ថ្លៃពិន័យដ៏ច្រើនទុកជាការដាក់ទោស ហើយគ្មានផ្លូវស្របច្បាប់ និង ស្មោះត្រង់ណាដែលពួកគេអាចចៀសវាងមិនបង់ថ្លៃពិន័យដោយខ្លួនគេបាននោះទេ ។ សូមសួរសិស្សពីអារម្មណ៍ដែលនឹងជួបការជាកពិន័យបែបនោះ ។ បន្ទាប់មក សូមឲ្យពួកគេស្រមៃថា សមាជិកគ្រួសារម្នាក់ ឬ មិត្តភក្តិម្នាក់ចេញបង់ថ្លៃពិន័យជំនួសឲ្យគេ ។

- តើអ្នកនឹងមានអារម្មណ៍ចំពោះមនុស្សនេះយ៉ាងណាដែរ ?

សូមពន្យល់ថា ក្នុងការបង់ថ្លៃពិន័យនោះ សមាជិកគ្រួសារម្នាក់ ឬ មិត្តភក្តិនោះនឹងសង្គ្រោះដល់ពួកគេពីការដាក់ទោសរបស់ពួកគេ ។ ពាក្យ *ប្រោសលោះ* មានន័យថារំដោះពីបំណុល ឬ ដាក់ឲ្យមានសេរីភាពដោយការបង់ថ្លៃលោះ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរនិយមន័យទាំងនេះនៅក្បែរខគម្ពីរមួយនៅក្នុង ម៉ូសាយ ១៥ ដែលមានទម្រង់មួយនៃពាក្យ *ប្រោសលោះ* ។

សូមសរសេរ *យើង* នៅក្រោម *អ្នកធ្វើខុស* ។ សូមសរសេរ *យុត្តិធម៌* នៅក្រោម *ការដាក់ទោស* ។សូមពន្យល់ថា ដោយសារយើងមានបាប ហើយមិនធ្វើតាមច្បាប់នៃព្រះ យើងត្រូវបានដាក់ទោស ។ និយាយម្យ៉ាងទៀតថា យើងត្រូវតែជួបនឹងការទាមទារនៃយុត្តិធម៌ ។ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រីឆាដ ជី ស្តត នៃក្វរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សស្តាប់រកនូវលទ្ធផលខ្លះនៃការមិនធ្វើតាមច្បាប់របស់ព្រះ ។

« យុត្តិធម៌ . . . តម្រូវថារាល់ការបំពានក្រិត្យវិន័យ ទាំងអស់ត្រូវបានបំពេញ ។ នៅពេលអ្នកគោរពតាមច្បាប់របស់ព្រះ អ្នកនឹងត្រូវបានប្រទានពរ ប៉ុន្តែគ្មានការខិតខំបន្ថែមណាដែលអាចត្រូវបានសង្គ្រោះដើម្បីបំពេញច្បាប់ទាំងឡាយដែលអ្នកមិនបានធ្វើតាមនោះទេ ។ ប្រសិនបើមិនបានដោះស្រាយទេ ច្បាប់ដែលគេមិនធ្វើតាមនោះអាចបណ្តាលឲ្យជីវិតរបស់អ្នកកើតទុក្ខ ហើយនឹងធ្វើឲ្យអ្នកត្រឡប់ទៅរកព្រះវិញមិនបានឡើយ» (« ដង្វាយធួនអាចផ្តល់ឲ្យអ្នកនូវសេចក្តីសុខសាន្ត និង សុភមង្គល » *Ensign* ឬ *លេអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ៤២) ។

- យោងតាមអែលឌើរ ស្តត តើលទ្ធផលអ្វីខ្លះដែលជាលទ្ធផលនៃការមិនធ្វើតាមច្បាប់នៃព្រះ ?

នៅពេលសិស្សរកមើលលទ្ធផលនៃការមិនធ្វើតាមច្បាប់នៃព្រះ សូមលុបពាក្យ *ការជាកពិន័យ* ពីលើក្តារខៀន ។ នៅកន្លែងលុបនោះ សូមសរសេរ *ទុក្ខវេទនា* និង *ការកាត់ចេញពីវត្តមាននៃព្រះ* ។សូមឲ្យសិស្សអាន ម៉ូសាយ ១៥:១, ៨–៩ ដោយស្ងាត់ៗ ។ អ្នកអាចសូរសំណួរខាងក្រោមនេះដើម្បីជួយសិស្សឲ្យយល់ពីគោលលទ្ធិខ្លះនៅក្នុងខគម្ពីរទាំងនេះ ៖

- ពាក្យ *អង្វរ* សំដៅលើមនុស្សម្នាក់ដែលមកនៅចន្លោះមនុស្សពីរនាក់ ឬ មនុស្សពីរក្រុម ដើម្បីជួយពួកគេឲ្យមានការស្រុះស្រួលគ្នា ឬនិយាយម្យ៉ាងទៀតថា ដើម្បីឲ្យមានក្តីសុខនឹងគ្នា ។ តើអ្នកគិតថា វាមានន័យយ៉ាងណា ដែលថាព្រះយេស៊ូវគ្រីស្ទបានមក « អង្វរ » ជំនួសយើង ?
- ពាក្យ *នៅចន្លោះ* មានន័យថា នៅរវាង ។ តើអ្នកគិតថា ការដែលព្រះអង្គសង្គ្រោះឈរ « នៅចន្លោះ | ពួកយើង | និង សេចក្តីយុត្តិធម៌» មានន័យយ៉ាងណា ? តើអ្នកគិតថា វាមានន័យយ៉ាងណា ដើម្បីបំពេញ « ការទាមទារទាំងឡាយនៃសេចក្តីយុត្តិធម៌» ?

សូមជួយសិស្សឲ្យយល់ថា សេចក្តីយុត្តិធម៌ទាមទារឲ្យយើងទទួលការដាក់ទោសចំពោះអំពើបាបរបស់យើង ។ ព្រះអង្គសង្គ្រោះមិនបានលុបការទាមទារទាំងឡាយនៃសេចក្តីយុត្តិធម៌ឡើយ ទ្រង់បានឈរនៅចន្លោះពួកយើង និង សេចក្តីយុត្តិធម៌ដើម្បីបំពេញការទាមទារទាំងឡាយនៃសេចក្តីយុត្តិធម៌ ដោយការទទួលយកការដាក់ទោសជំនួសយើង ។ ទ្រង់បានបង់ថ្លៃដើម្បីប្រោសលោះយើង —ដើម្បីដោះលែងយើងចេញពីការដាក់ទោស ។ នៅលើក្តារខៀន សូមដាក់រូបភាពព្រះអង្គសង្គ្រោះ (ដូចជារូបភាពមានចំណងជើងថា ព្រះអម្ចាស់យេស៊ូវគ្រីស្ទ | ៦៤០០១ |) នៅចន្លោះពាក្យអ្នកធ្វើខុស និង ការដាក់ទោស ។



អ្នកធ្វើខុស
ពួកយើង



ការដាក់ទោស
យុត្តិធម៌
ទុក្ខវេទនា
ការកាត់ចេញពីវត្តមាននៃព្រះ

សូមឲ្យសិស្សអាន ម៉ូសាយ ១៥:៥–៧ ដោយស្ងាត់ស្ងៀម ដោយគិតអំពីតម្លៃដែលព្រះយេស៊ូវគ្រីស្ទបានបង់ដើម្បីប្រោសលោះពួកគេ ដើម្បីឈរនៅចន្លោះពួកគេ និង ការទាមទារទាំងឡាយនៃសេចក្តីយុត្តិធម៌ ។

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖

អ្នកដែលជ្រើសរើសដើម្បីបានប្រោសលោះ	*អ្នកដែលបដិសេធដើម្បីបានប្រោសលោះ*
ម៉ូសាយ ១៥:១១–១២	ម៉ូសាយ ១៦:២–៥, ១២

សូមបែងចែកសិស្សជាពីរក្រុម ។ សូមឲ្យសិស្សមួយក្រុមអាន ម៉ូសាយ ១៥:១១–១២ ដោយរកមើលលក្ខណៈនៃមនុស្សដែលជ្រើសរើសដើម្បីបានប្រោសលោះ ។ សូមឲ្យសិស្សមួយក្រុមទៀតអាន ម៉ូសាយ ១៦:២–៥, ១២ ដោយរកមើលលក្ខណៈនៃមនុស្សដែលបដិសេធដើម្បីបានប្រោសលោះ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សក្រុមទីមួយចែកចាយនូវអ្វីដែលពួកគេបានរកឃើញ ។

- ដោយយោងតាម ម៉ូសាយ ១៥:១១–១២ តើនរណានឹងត្រូវបានប្រោសលោះពីអំពើបាបរបស់ពួកគេ ? (សូមប្រាកដថា សិស្សយល់ថា **ព្រះយេស៊ូវគ្រីស្ទបំពេញការទាមទារទាំងឡាយនៃសេចក្តីយុត្តិធម៌សម្រាប់អ្នកណាដែលស្តាប់តាមពាក្យសម្តីរបស់ព្យាការី ជឿលើអំណាចប្រោសលោះរបស់ទ្រង់ និង ប្រែចិត្តពីអំពើបាបរបស់ពួកគេ ។**)

សូមពន្យល់ថា តម្លៃដែលព្រះអង្គសង្គ្រោះបានបង់គឺជាអំណោយផ្តាល់ខ្លួនមួយសម្រាប់អ្នកណាដែលនឹងជ្រើសរើសដើម្បីសក្តិសមសម្រាប់សេចក្តីសង្គ្រោះ ដោយការប្រែចិត្ត និង ការខិតខំកាន់តាមព្រះបញ្ញត្តិទាំងឡាយ និង សេចក្តីសញ្ញារបស់ពួកគេជាមួយនឹងព្រះអម្ចាស់ ។

ដើម្បីបញ្ជាក់ពីលក្ខណៈផ្ទាល់នៃដង្វាយធួន សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ម៉ូសាយ ១៥:១០ ឮៗ ។ បន្ទាប់មក សូមនាំចំណាប់អារម្មណ៍របស់សិស្សទៅលើឃ្លា « នោះទ្រង់នឹងទតឃើញពូជរបស់ទ្រង់ហើយ » នៅក្នុងខគម្ពីរនោះ ។ អ្នកអាចស្នើថា ពួកគេគួរគូសចំណាំឃ្លានេះ ។ សូមពន្យល់ថានៅក្នុងខគម្ពីរនេះ ពាក្យ *ពូជ* សំដៅលើកូនចៅ ។

- តើនៅពេលណាដែលយើងបានដឹងពីការក្លាយជា « កូនចៅនៃព្រះគ្រីស្ទ» ? សូមរំឭកសិស្សពីពាក្យសម្តីរបស់ស្តេចបេនយ៉ាមីនលើប្រធានបទនេះ ដែលមាននៅក្នុង ម៉ូសាយ ៥ ។ សូមមើលជង្ហែរ មេរៀនទី ៥៥ ។)

អ្នកអាចស្នើថា សិស្សគួរដាក់ជាខ្លួនគេពី ម៉ូសាយ ១៥:១០ ដោយការសរសេរឈ្មោះរបស់ពួកគេនៅក្នុងកន្លែងឃ្លា « ពូជទ្រង់» ។ សូមអញ្ជើញពួកគេឲ្យសញ្ជឹងគិតមួយភ្លែត ពីអ្វីដែលការណ៍នេះមានន័យដល់ពួកគេ ។

- តើការបង្រៀននេះជះឥទ្ធិពលដល់ការយល់ដឹងរបស់អ្នកអំពីដង្វាយធួនដោយរបៀបណា ?

សូមឲ្យសិស្សដែលអាន ម៉ូសាយ ១៦:២–៥, ១២ ចែកចាយអ្វីដែលពួកគេបានរកឃើញពីអ្នកដែលបដិសេធមិនទទួលយកការប្រោសលោះ ។ ដើម្បីបញ្ជាក់ពីភាពធ្ងន់ធ្ងរនៃការបដិសេធមិនទទួលយកការប្រោសលោះ សូមឲ្យសិស្សទាំងអស់អាន ម៉ូសាយ ១៦:៥ ដោយស្ងាត់ៗ ។

- តើមានអ្វីកើតឡើងដល់រូបភាពនៅលើក្តារខៀន ប្រសិនបើអ្នកធ្វើខុសនៅតែទទឹងនៅក្នុងអំពើបាប ហើយបដិសេធមិនព្រមប្រែចិត្ត ? (នៅពេលសិស្សឆ្លើយតប សូមដកយូបភាពនៃព្រះយេស៊ូវគ្រីស្ទចេញពីឌីយ៉ាក្រាម ។ អ្នកអាចបញ្ជាក់ថា សម្រាប់មនុស្សបែបនេះ វា « ដូចជាគ្មានសេចក្តីប្រោសលោះឡើយ» ។)

សូមឲ្យសិស្សអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៩:១៦–១៧ ដើម្បីរកមើលអ្វីដែលនឹងកើតឡើងដល់អ្នកដែលបដិសេធមិនព្រមប្រែចិត្ត ហើយទទួលយកសេចក្តីប្រោសលោះរបស់ព្រះអង្គសង្គ្រោះ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរ *គ. & ស. ១៩:១៦–១៧* នៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ ម៉ូសាយ ១៦:៥ ។

សូមដាក់រូបភាពព្រះអង្គសង្គ្រោះទៅកន្លែងដើមលើក្តារខៀនវិញ ។

- តើសេចក្តីពិតអ្វីដែលអ្នកបានរៀននៅថ្ងៃនេះ អំពីអ្នកប្រោសលោះរបស់អ្នក ?

ក្រោយពីសិស្សបានឆ្លើយតបនឹងសំណួរនេះហើយ សូមពន្យល់ថា បន្ថែមលើការបង្រៀនដែលថាព្រះអង្គសង្គ្រោះបានប្រោសលោះយើងពីការដាក់ទោសចំពោះអំពើបាបរបស់យើង អ័ប៊ីណាដៃបានបង្រៀនថា ព្រះអង្គសង្គ្រោះបានប្រោសលោះយើងចេញពីសេចក្តីស្លាប់ ។ សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី ម៉ូសាយ ១៦:៦–១១ ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា **ដោយសារតែដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ មនុស្សទាំងអស់នឹងត្រូវបានរស់ឡើងវិញ** ។អ្នកក៏អាចចង្អុលបង្ហាញថា អ្នកសុចរិតនឹងត្រូវបានរស់ឡើងវិញទៅកាន់ស្ថានភាពនៃសុភមង្គល ។

សូមឲ្យសិស្សសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពីអារម្មណ៍ចំពោះព្រះប្រោសលោះរបស់ពួកគេ និង អ្វីដែលពួកគេនឹងធ្វើដើម្បីឲ្យពួកគេនឹងទទួលបាននូវសេចក្តីប្រោសលោះដែលទ្រង់បានផ្តល់ ។

ម៉ូសាយ ១៧

អាលម៉ាជឿដល់អ័ប៊ីណាដៃ ហើយត្រូវបានកាត់ចេញ; អ័ប៊ីណាដៃត្រូវបានគេដុត

សូមសួរសិស្ស ៖

- តើអ្នកធ្លាប់ឃើញនរណាម្នាក់ក្រោកឈរ សម្រាប់អ្វីដែលត្រូវនៅពេលវាពិបាកសម្រាប់ពួកគេដើម្បីធ្វើដូច្នោះទេ ? តើមានរឿងអ្វីកើតឡើង ?

សូមបង្ហាញរូបភាពអ័ប៊ីណាដៃនៅចំពោះមុខស្តេចណូអេ (៦២០៤២; *សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ | លេខ ៧៥) ។ សូមសង្ខេប ម៉ូសាយ ១៧:១–៦ ដោយការពន្យល់ថានៅពេលអ័ប៊ីណាដៃបានបញ្ចប់សារលិខិតរបស់គាត់ សង្ឃម្នាក់ឈ្មោះអាលម៉ាបានព្យាយាមដើម្បីបញ្ចុះបញ្ចូលដល់ស្តេចថា អ័ប៊ីណាដៃបាននិយាយពីការពិត ហើយគួរត្រូវដោះលែង ។ ស្តេចបានបណ្តេញអាលម៉ាចេញ ហើយឲ្យអ្នកបម្រើសម្លាប់គាត់ ។ អាលម៉ាបានលាក់ខ្លួន ហើយបានសរសេរនូវពាក្យសម្តីរបស់អ័ប៊ីណាដៃ ។ បីថ្ងៃក្រោយមក ស្តេចនិងពួកសង្ឃរបស់ទ្រង់បានកាត់ទោសអ័ប៊ីណាដៃដល់ស្លាប់ ។

សូមឲ្យសិស្សធ្វើការជាដៃគូ ។ សូមឲ្យពួកគេសិក្សាវគ្គព្រះគម្ពីរខាងក្រោមនេះជាមួយនឹងដៃគូរបស់ពួកគេ ៖ ម៉ូសាយ ១៧:៧–១០ ដែលនិយាយអំពីជម្រើសរបស់អ័ប៊ីណាដៃ និង ម៉ូសាយ ១៧:១១–១២, ដែលនិយាយអំពីជម្រើសរបស់ស្តេចណូអេ ។ សូមឲ្យពួកគេប្រៀបធៀបជម្រើសរបស់អ័ប៊ីណាដៃ និង ជម្រើសរបស់ស្តេចណូអេ ។ សូមឲ្យពួកគេពិភាក្សាសំណួរខាងក្រោមនេះ ។ (អ្នកអាចសរសេរសំណួរនេះលើក្តារខៀន ។)

- តើអ្នកគិតថា ហេតុអ្វីបានជាពាក្យសម្តីរបស់អ័ប៊ីណាដៃជះឥទ្ធិពលដល់ស្តេចណូអេ នូវអ្វីដែលពួកគេបានធ្វើ ? (សូមមើល ម៉ូសាយ ១៧:១១ ។) តើពួកសង្ឃរបស់ស្តេចណូអេបានជះឥទ្ធិពលដល់ទ្រង់ដោយរបៀបណា ? (សូមមើល ម៉ូសាយ ១៧:១២–១៣ ។)
- តើមេរៀនអ្វីដែលយើងអាចរៀនពីគំរូរបស់អ័ប៊ីណាដៃ ? (ចម្លើយមួយដែលសិស្សអាចមានគឺ **យើងអាចស្មោះត្រង់ចំពោះព្រះក្នុងគ្រប់កាលៈទេសៈទាំងអស់** ។)

ប្រសិនបើអាច សូមចែកសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហ្គរដិន ប៊ី ហ៊ីងគ្លី ដល់សិស្ស ៖

សូមរឹងមាំ—នៅក្នុងការឈរចំពោះការត្រឹមត្រូវ ។“យើងរស់នៅក្នុងសម័យនៃការសម្រុះសម្រួល ។ នៅក្នុងស្ថានភាពដែលយើងជួបប្រទះរាល់ថ្ងៃ យើងដឹងថាអ្វីដែលត្រូវ ។ . . . យើងត្រូវតែពង្រឹងកម្លាំងដើម្បីធ្វើតាមការជឿជាក់របស់យើង» (“ Building Your Tabernacle,” *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩២ ទំព័រ ៥២) ។

អ្នកអាចឲ្យសិស្សសរសេរ *ខ្ញុំនឹងស្មោះត្រង់ចំពោះព្រះក្នុងគ្រប់កាលៈទេសៈទាំងអស់* នៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ ម៉ូសាយ ១៧:៩–១២ ។ សូមធ្វើឲ្យសិស្សមានចំណាប់អារម្មណ៍ទៅលើ ពាក្យចុងក្រោយរបស់អ័ប៊ីណាដៃ ដែលមាននៅក្នុង ម៉ូសាយ ១៧:១៩— « ឱព្រះអង្គអើយ សូមព្រះអង្គទទួលយកព្រលឹងរបស់ទូលបង្គំផង» ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ១៧:២០ ឮៗ ។

- តើអ្វីដែលធ្វើឲ្យអ្នករំភើបអំពីពាក្យចុងក្រោយរបស់អ័ប៊ីណាដៃ ?

សូមឲ្យសិស្សឆ្លើយនឹងសំណួរខាងក្រោម នៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ។

- តើអ្នកនឹងធ្វើអ្វីដើម្បីស្មោះត្រង់ចំពោះព្រះក្នុងគ្រប់កាលៈទេសៈទាំងអស់ ?

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបីបួននាក់ចែកចាយអ្វីដែលពួកគេបានសរសេរ ។ សូមសួរផងដែរ បើសិស្សខ្លះចង់ចែកចាយអ្វីដែលដំណឹងល្អមានន័យដល់ពួកគេ និង អ្វីដែលពួកគេបានធ្វើកាលពីមុនដើម្បីនៅស្មោះត្រង់ចំពោះព្រះអម្ចាស់ក្នុងពេលពិបាកនានា ។ សូមបញ្ចប់ដោយទីបន្ទាល់របស់អ្នក ។

មេរៀនសិក្សានៅផ្ទះ

ម៉ូសាយ ៧–១៧ (មេរៀនទី ១២)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

ការសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

ការសង្ខេបខាងក្រោមនៃគោលលទ្ធិ និង គោលការណ៍នានាដែលសិស្សបានរៀននៅពេលពួកគេបានសិក្សា ម៉ូសាយ ៧–១ (មេរៀនទី ១២) មិនមែនប្រើសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតលើតែគោលការណ៍ពីរបីប៉ុណ្ណោះនៃគោលលទ្ធិ និង គោលការណ៍ទាំងនេះ ។ សូមធ្វើតាមការបំផុសពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ម៉ូសាយ ៧–៨)

នៅពេលពួកគេបានសិក្សា ម៉ូសាយ ៧–៨ សិស្សបានផ្តោតអារម្មណ៍ទៅលើទំនាក់ទំនងរវាងសេចក្តីទុច្ចរិត និង សេរភាព ។ ពួកគេក៏បានរៀនផងដែរអំពីពាក្យសម្តីរបស់ស្តេចលីមហៃថា ការទទួលស្គាល់សេចក្តីទុច្ចរិតរបស់យើង និង មានអារម្មណ៍សោកស្តាយចំពោះការណ៍នោះដឹកនាំយើងទៅរកព្រះអម្ចាស់សម្រាប់ការដោះលែង ។ អាំម៉ូនធានាដល់លីមហៃថា ព្រះអម្ចាស់នឹងផ្តល់ព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈដើម្បីផ្តល់ប្រយោជន៍ដល់មនុស្សជាតិ ។

ថ្ងៃទី ២ (ម៉ូសាយ ៩–១០)

សិស្សបានរៀនបន្ថែមទៀតអំពីរបៀបដែលក្រុមសាសន៍នីហ្វៃមួយ ដែលត្រូវបានហៅថាប្រជាជនរបស់សីនិព្វ បានស្នាក់នៅក្នុងចំណោមសាសន៍លេមិន ។ សេចក្តីពិតខាងក្រោមត្រូវបានបង្ហាញ នៅពេលសីនិព្វនិងប្រជាជនរបស់គាត់បានចេញទៅច្បាំងនឹងសាសន៍លេមិនដែលធ្វើចម្បាំង ៖ ព្រះអម្ចាស់នឹងពង្រឹងយើង នៅពេលយើងធ្វើអ្វីទាំងអស់ដែលយើងអាច និង ដាក់ទីទុកចិត្តរបស់យើងទៅលើទ្រង់ ។

ថ្ងៃទី ៣ (ម៉ូសាយ ១១–១៤)

ស្តេចណូអេបានដឹកនាំប្រជាជនរបស់ទ្រង់ឲ្យធ្វើអំពើគួរខ្ពើមឆ្អើម និង អំពើទុច្ចរិត ។ សិស្សបានរកឃើញថា ព្រះបញ្ជូនព្យាការីដើម្បីជួយយើងឲ្យប្រែចិត្ត ចៀសចេញពីទុក្ខវេទនា និង ទទួលបាននូវសេចក្តីសង្គ្រោះ ។ តាមរយៈការបង្រៀនរបស់ព្យាការីអ័ប៊ីណាដៃ សិស្សបានរៀនថា ប្រសិនបើយើងគោរពតាមព្រះបញ្ញត្តិនៃព្រះ នោះយើងនឹងត្រូវបានសង្គ្រោះ ។ ពួកគេក៏បានរៀនថា ជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទគឺជាប្រភពនៃសេចក្តីសង្គ្រោះ ។

ថ្ងៃទី ៤ (ម៉ូសាយ ១៥–១៧)

មុនពេលទុក្ខកម្មរបស់គាត់ អ័ប៊ីណាដៃបានប្រកាសយ៉ាងមុតមាំថា ជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទបំពេញដល់ការទាមទារទាំងឡាយនៃសេចក្តីយុត្តិធម៌សម្រាប់អ្នកទាំងឡាយណាដែលជឿលើអំណាចប្រោសលោះនៃព្រះអង្គសង្គ្រោះ ប្រែចិត្តពីអំពើបាបរបស់ពួកគេ ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយ ។ អ័ប៊ីណាដៃក៏បានបង្រៀនថា ដោយសារតែជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ មនុស្សទាំងអស់នឹងត្រូវបានរស់ឡើងវិញ ។ តាមរយៈការសិក្សាពីគោលលទ្ធិទាំងនេះ សិស្សបានគិតពីសារសំខាន់នៃការពឹងផ្អែកទៅលើព្រះអង្គសង្គ្រោះ ហើយស្មោះត្រង់នឹងព្រះនៅក្នុងគ្រប់កាលៈទេសៈទាំងអស់ ។

សេចក្តីផ្តើម

ម៉ូសាយ ៧–១៧ពិពណ៌នាអំពីការធ្វើដំណើរដោយច្រើន និង បទពិសោធន៍របស់បុគ្គលជាច្រើន ព្រមទាំងក្រុមមនុស្សទាំងឡាយ ។ ជម្រើសរបស់សីនិព្វដើម្បីដឹកនាំក្រុមសាសន៍នីហ្វៃមួយក្រុមទៅរស់នៅក្នុងចំណោមប្រជាជនលេមិន មានឥទ្ធិពលទៅលើសាសន៍ទាំងពីរ ។ ឧទាហរណ៍ប្រជាជនរបស់សីនិព្វ និង កូនចៅរបស់ពួកគេបានជួបនឹងការសោកល្អង ការក្បត់សាសនា សេរភាព ការកើតជាថ្មីខាងវិញ្ញាណ និង ការដោះលែង ។ ផ្នែកទីមួយនៃមេរៀននេះនឹងផ្តល់ឲ្យសិស្សនូវឱកាសមួយដើម្បីរៀបរាប់ពីឈ្មោះ ទីកន្លែង និង ហេតុការណ៍នានាដែលពួកគេបានសិក្សាកាលពីសប្តាហ៍មុន ។ ផ្នែកទីពីរនៃមេរៀននេះនឹងជួយដល់សិស្សឲ្យស្គាល់ពីបាវចនាដ៏សំខាន់ៗនៃសារលិខិតរបស់ព្យាការីអ័ប៊ីណាដៃទៅកាន់ប្រជាជន—ព្រះយេស៊ូវគ្រីស្ទ និងជង្វាយធួនរបស់ទ្រង់ ។ វាគឺជាសារលិខិតដែលអ័ប៊ីណាដៃនឹងលះបង់ជីវិតសម្រាប់ការណ៍នោះ ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ៧–១៧

ការរំឭកពីទីតាំង និង គោលលទ្ធិប្រវត្តិសាស្ត្រ

ដើម្បីជួយអ្នកពន្យល់ពីហេតុការណ៍នៅក្នុងមេរៀននេះ សូមរំឭកតារាងនៅក្នុង « សេចក្តីសង្ខេបនៃ ម៉ូសាយ ៧–២៤» នៅក្នុងមេរៀនទី ១២ ថ្ងៃទីមួយនៃសៀវភៅណែនាំការសិក្សារបស់សិស្ស ។ សូមឲ្យសិស្សអាន ម៉ូសាយ ៧:១–២ ហើយឲ្យពួកគេរកឈ្មោះដីពីរដែលបានលើកឡើង ។ សូមឲ្យពួកគេពន្យល់ពីមូលហេតុនៃក្រុមសាសន៍នីហ្វៃខុសគ្នាចង់ធ្វើដំណើរពីដែនដីមួយទៅដែនដីមួយទៀត ។

សូមសរសេរឈ្មោះនៃដែនដីពីរនោះនៅចុងម្ខាងៗលើក្តារខៀន (ឬ លើក្រដាសមួយ) ៖

ដែនដីសារ៉ាហិមឡា	ដែនដីនីហ្វៃ (លីហៃ-នីហ្វៃ)

សំណួរខាងក្រោមអាចជួយ នៅពេលអ្នកនិងសិស្សរំឭកពីហេតុការណ៍នានា ។ សូមសរសេរឈ្មោះមនុស្សនៅលើក្តារខៀនពេលអ្នកពិភាក្សា ។ អ្នកអាចប្រើសំណួរខាងក្រោមទាំងអស់ ឬ ខ្លះៗ ដោយពឹងលើមតិរបស់សិស្ស ៖

- ហេតុអ្វីបានជាសីនិព្វចង់ចាកចេញពីដែនដីសារ៉ាហិមឡា ? (សូមមើល ម៉ូសាយ ៩:១, ៣ ។)
- តើសីនិព្វ ណូអេ និង លីមហៃទាក់ទងគ្នាយ៉ាងណាខ្លះ ? (សូមមើល ម៉ូសាយ ៧:៩ ។)
- តើស្តេចណូអេ ជាស្តេចប្រភេទណា ? (សូមមើល ម៉ូសាយ ១១:១–៥, ១១ ។)
- តើព្រះបានធ្វើអ្វីខ្លះដើម្បីបញ្ចុះបញ្ចូលស្តេចណូអេ និង ប្រជាជនរបស់ទ្រង់ឲ្យប្រែចេញពីអំពើទុច្ចរិត និង អំពើគួរខ្ពើមឆ្អើមដ៏ខ្លាំងរបស់ពួកគេ ? (ទ្រង់បានបញ្ជូនព្យាការីរបស់ទ្រង់អ័ប៊ីណាដៃ ឲ្យហៅពួកគេឲ្យប្រែចិត្ត ។)
- តើអ្នកអាចប្រាប់យើងអំពីអាលម៉ាបានទេ ? (ចម្លើយអាចរួមមាន គាត់គឺជាសង្ឃម្នាក់របស់ស្តេចណូអេ គាត់ជឿ និង សរសេរនូវពាក្យសម្តីរបស់អ័ប៊ីណាដៃ ហើយគាត់បានគេចចេញដើម្បីកុំឲ្យត្រូវគេសម្លាប់ ។)
- ហេតុអ្វីបានជាម៉ូសេ និង អេសាយសំខាន់នៅក្នុងជំពូកទាំងនេះ ទោះបីជាពួកគេបានរស់នៅតាំងពីយូរមុនអ័ប៊ីណាដៃ និង នៅឯផ្នែកផ្សេងទៀតនៃពិភពលោក ?
- ហេតុអ្វីបានជាលីមហៃបញ្ជូនមនុស្សរបស់គាត់ ៤៣ នាក់ទៅកាន់ទីរហោស្ថាន ? (លីមហៃ និង ប្រជាជនរបស់ទ្រង់ស្ថិតនៅក្នុងសេរភាពដល់សាសន៍លេមិន ហើយស្វែងរកជំនួយពីប្រជាជនសារ៉ាហិមឡា ។) តើពួកគេបានរកឃើញអ្វី ជំនួសឲ្យការរកឃើញសារ៉ាហិមឡានោះ ? (ពួកគេបានរកឃើញអារ្យធម៌ដែលត្រូវបានបំផ្លាញ និង ផ្នាំងមាស ២៤ ដោយមានចារឹកនៅលើនោះផង ។)

- តើអាំម៉ូន និង មនុស្ស ១៥ នាក់ទៀតបានធ្វើអ្វី ? (ពួកគេត្រូវបានបញ្ជូនដោយម៉ូសាយឲ្យទៅមើលអ្វីដែលបានកើតឡើងដល់ប្រជាជនសីនិឡ ។ ពួកគេបានឃើញកូនចៅនៃប្រជាជននោះនៅក្នុងសេរ៉កភាព ។ ចៅប្រុសរបស់សីនិឡ លីមហៃ គឺជាស្តេចរបស់ពួកគេ ។)
- តើនរណាដែលបានធ្វើជាស្តេចនៅក្នុងដែនដីសារ៉ាហិមឡា និង ជាព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈ ? (ម៉ូសាយ ។) ហេតុអ្វីបានជាតួនាទីរបស់គាត់ជាអ្នកមើលឆុតសំខាន់ចំពោះលីមហៃ ? (លីមហៃបានដឹងថា ម៉ូសាយអាចបកប្រែចារឹកនៅលើផ្ទាំងមាស ២៤ ផ្ទាំងបាន ។)

សូមបង្ហាញថា ប្រហែលជា ៨០ ឆ្នាំកន្លងទៅរវាងសីនិឡ និង ប្រជាជនរបស់គាត់បានចាកចេញពីសារ៉ាហិមឡា ហើយការមកដល់របស់អាំម៉ូន និង អ្នករួមដំណើរ ជាមួយគាត់នៅក្នុងដែនដីនីហ្វៃ ។

ក្រោយពីការជួយសិស្សឲ្យយល់កាន់តែច្បាស់ពីដំណើររឿងប្រវត្តិសាស្ត្រហើយ សូមរំឭកពួកគេថាមានមនុស្សផ្សេងទៀតដែលពួកគេបានសិក្សានៅសប្តាហ៍នេះដែលឈ្មោះនោះមិនទាន់បានសរសេរនៅលើក្តារខៀននៅឡើយទេ ។

សូមឲ្យសិស្សម្នាក់ៗអាន ម៉ូសាយ ១៦:៦–៨ ហើយរកឈ្មោះបុគ្គលនោះ ។ សូមប្រាប់សិស្សថា ទោះបីជាផ្នែកនៃព្រះគម្ពីរមមុននេះពេញទៅដោយប្រវត្តិសាស្ត្រជាច្រើនក្តី វាក៏ប្រាប់ពីគោលលទ្ធិនៃសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវគ្រីស្ទដែរ ។

ដើម្បីបញ្ជាក់ពីសារសំខាន់នៃសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវគ្រីស្ទ សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ឬ ចែកជាក្រដាសដល់សិស្ស ។ សូមឲ្យសិស្សធ្វើការដៃគូដើម្បីសិក្សាសេចក្តីយោងព្រះគម្ពីរដែលសរសេរនៅក្នុងតារាងនោះ ហើយពិភាក្សាអ្វីដែលពួកគេបានរកឃើញ ។ ដោយសារតែសំណួរនៃការអនុវត្តខ្លះមានលក្ខណៈផ្ទាល់ខ្លួនខ្លាំង សិស្សអាចសម្រេចថានឹងឆ្លើយឮៗទៅកាន់គ្នាទៅវិញទៅមក សរសេរចម្លើយនោះនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេ ឬ គិតពីចម្លើយដោយស្ងៀមស្ងាត់ ។

ដើម្បីជួយសិស្សឲ្យគិតពីអ្វីដែលពួកគេបានសិក្សានៅក្នុងសកម្មភាពព្រះគម្ពីរនេះ និង មេរៀនរបស់ពួកគេសម្រាប់សប្តាហ៍នេះ សូមសួរ ៖ តើគោលការណ៍ និង គោលលទ្ធិនានាដែលអ្នកបានសិក្សានៅសប្តាហ៍នេះ បានជួយអ្នកឲ្យមើលទៅការផ្តោចំបាបរបស់អ្នកយ៉ាងដូចម្តេច ?

សូមឲ្យឱកាសដល់សិស្សថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ។

របៀបមួយដែលអ្នកអាចបញ្ចប់មេរៀននៅថ្ងៃនេះគឺត្រូវអាន ម៉ូសាយ ១៦:១៣–១៥ ហើយចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីត្រូវការ របស់យើងចំពោះព្រះអង្គសង្គ្រោះ ។ របៀបមួយទៀតគឺអ្នកត្រូវបញ្ជាក់ដល់សិស្សរបស់អ្នកអំពីគោលលទ្ធិ ឬ គោលការណ៍ពីរដែលពួកគេបានរៀននៅសប្តាហ៍នេះ ៖ ថា**ជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទគឺជាប្រភពនៃសេចក្តីសង្គ្រោះ** ហើយថា **ព្រះយេស៊ូវគ្រីស្ទបំពេញនូវការទាមទារទាំងឡាយនៃសេចក្តីយុត្តិធម៌សម្រាប់អ្នកទាំងឡាយណាដែលនឹងប្រែចិត្ត ។**

មេរៀនបន្ទាប់ (ម៉ូសាយ ១៨–២៥)

ម៉ូសាយ ១៨–២៥ បង្ហាញពីរបៀបដែលក្រុមពីរបានរត់ចេញពីសេរ៉កភាពរបស់សត្រូវ ពួកគេហើយត្រឡប់ទៅសារ៉ាហិមឡាវិញដោយសុវត្ថិភាព ។ អ្នកនឹងរៀនពីរបៀបដែលព្រះបានដឹកនាំក្រុមនីមួយៗឲ្យរត់ចេញ ។ ក្រុមមួយបានធ្វើតាមគម្រោងរបស់គេឯងដែលត្រូវឲ្យអ្នកយាមស្រវឹង ហើយក្រុមផ្សេងទៀតរត់ចេញដោយការធ្វើតាមអាលម៉ាខណៈពេលសាសន៍លេមិនកំពុងដេក ។ តើអ្នកណាដែលធ្វើឲ្យសាសន៍លេមិនដេក ?

បទគម្ពីរ	អ្វីដែលត្រូវរក	សំណួរអនុវត្ត
ម៉ូសាយ ៧:៣៣	តើយើងត្រូវបានដោះលែងចេញពីសេរ៉កភាពខាងវិញ្ញាណ និងខាងសាច់ឈាមដោយរបៀបណា ?	ចេញពីចំណុចទាំងបីដែលលីមហៃបានបញ្ជាក់ តើចំណុចមួយណាដែលអ្នកមានអារម្មណ៍ថា អ្នកត្រូវធ្វើការពង្រឹងវានៅពេលនេះ ?
(ម៉ូសាយ ១៣:១១) ។	ហេតុអ្វីបានជាស្តេចណូអេ និង ប្រជាជនរបស់ទ្រង់ជាច្រើនមិនយល់ពីបេសកកម្មរបស់ព្រះយេស៊ូវគ្រីស្ទ ។	តើកស្តូតាងអ្វីខ្លះនៅក្នុងជីវិតរបស់អ្នកថា ព្រះបញ្ញត្តិត្រូវបានឆ្លាក់នៅក្នុងដួងចិត្តរបស់អ្នក ? តើអ្នកអាចសិក្សា និង បង្រៀនពីសេចក្តីសុចរិតតាមរបៀបណាខ្លះ ?
ម៉ូសាយ ១៤:៣–៧	ពាក្យ និង ឃ្លាដ៏មានន័យអំពីការរងទុក្ខរបស់ព្រះអង្គសង្គ្រោះ និងការបដិសេធ ។	តើមនុស្សស្អប់ និង បដិសេធ ព្រះអង្គសង្គ្រោះនាសព្វថ្ងៃនេះដោយរបៀបណា ? តើអ្នកខ្លះលាក់មុខរបស់គេពីទ្រង់ដោយរបៀបណា ? តើអ្នកខ្លះធ្វើផ្ទុយតាមរបៀបណា ?
ម៉ូសាយ ១៥:៦–៩, ១១	តើអ្វីដែលព្រះយេស៊ូវគ្រីស្ទ « មិនធ្វើតាម» និង អ្វីដែលទ្រង់ « ទទួលបាន» ; ហើយតើអ្វីដែលយើងទទួលបានដោយសារការលះបង់របស់ព្រះអង្គសង្គ្រោះ ។	តើព្រះអម្ចាស់បានធ្វើអន្តរាគមន៍ជំនួសអ្នកថ្មីៗនេះដោយរបៀបណា ? តើទ្រង់បានឈរនៅចន្លោះអ្នក និង ការទាមទារទាំងឡាយនៃសេចក្តីយុត្តិធម៌ដោយរបៀបណា ?

ម៉ូសាយ ១៨

សេចក្តីផ្តើម

ក្រោយពីអ័ប៊ីណាដៃស្លាប់ អាលម៉ាបានបង្រៀនពាក្យសម្តីរបស់អ័ប៊ីណាដៃដោយសម្ងាត់ក្នុងចំណោមប្រជាជន ។ អ្នកដែលជឿតាមគាត់ បានប្រមូលផ្តុំគ្នានៅឯទឹកនៃមរមនដើម្បីរៀនបន្ថែម ។ អាលម៉ាបានចែកចាយសារលិខិតនៃ « ការប្រែចិត្ត និង សេចក្តីប្រោសលោះ និង សេចក្តីជំនឿទៅលើព្រះអម្ចាស់ » (ម៉ូសាយ ១៨:៧) ។ អ្នកដែលបានទទួលការបង្រៀនរបស់គាត់ ហើយបានប្រែចិត្តចេញពីអំពើបាបរបស់ពួកគេបានចូលទៅក្នុងសេចក្តីសញ្ញានៃការជ្រមុជទឹក ។ ប្រជាជនមានជំនឿទៅលើសេចក្តីសញ្ញានេះ ហើយពួកគេបានជួយគ្នាទៅវិញទៅមកខាងសាច់ឈាម និង ខាងវិញ្ញាណ ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ១៨:១–១៦

អាលម៉ាបង្រៀន និង ជ្រមុជទឹកដល់ប្រជាជន

សូមបង្ហាញរូបភាពអ័ប៊ីណាដៃនៅចំពោះមុខស្តេចណូអេ (៦២០៤២; *សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ | លេខ ៧៥) ។ សូមចង្អុលទៅពួកសង្ឃនៅខាងក្រោយរូបភាព ។ សូមពន្យល់ថា ម៉ូសាយ ១៨ ប្រាប់ពីបទពិសោធន៍របស់អាលម៉ា ដែលជាសង្ឃម្នាក់របស់ស្តេចណូអេ ។



សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ១៨:១, ៣–៦ ឮៗ ។ សូមឲ្យសិស្សរកមើលអ្វីដែលអាលម៉ាបានធ្វើ ក្រោយពីស្តាប់ឮទីបន្ទាល់របស់អ័ប៊ីណាដៃហើយ ។ ក្រោយពីសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរៀនហើយ សូមឲ្យពួកគេមើលទៅឱយ៉ាក្រោមរបស់ពួកគេដែលបង្ហាញពីសេចក្តីសង្ខេបនៃការធ្វើដំណើរនៅក្នុង ម៉ូសាយ ៧–២៤ ។ សូមណែនាំពួកគេឲ្យគូសទឹកនៃមរមននៅក្នុងកន្លែងសមរម្យ ។ (សម្រាប់ឱយ៉ាក្រមពេញលេញ សូមមើលសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។)

សូមពន្យល់ថា អាលម៉ាមានបំណងចំពោះការបង្រៀនរបស់គាត់ដើម្បីរៀបចំប្រជាជនដល់ពិធីបុណ្យជ្រមុជទឹក ។ សូមឲ្យសិស្សគិតអំពីពិធីបុណ្យជ្រមុជទឹករបស់ពួកគេ ។ ដើម្បីជួយពួកគេឲ្យសញ្ជឹងគិតពីអ្វីដែលពិធីបុណ្យជ្រមុជទឹករបស់គេមានន័យចំពោះគេ អ្នកអាចសួរសំណួរដូចខាងក្រោម ៖

- តើអ្នកនៅចាំអ្វីខ្លះអំពីបទពិសោធន៍របស់អ្នក ?
- តើឪពុកម្តាយ គ្រូបង្រៀន និង អ្នកដឹកនាំរបស់អ្នកជួយអ្នកឲ្យរៀបចំពិធីបុណ្យជ្រមុជទឹកដោយរបៀបណា ?
- តើអ្នកកោតសរសើរដល់អ្វីច្រើនជាងគេអំពីពិធីបុណ្យជ្រមុជទឹកនាពេលឥឡូវនេះ ជាងពេលដែលអ្នកទទួលពិធីបុណ្យជ្រមុជទឹកនោះ ?

សូមពន្យល់ថា រឿងនៃការបង្រៀនរបស់អាលម៉ា និង ការជ្រមុជទឹកដល់ប្រជាជននៅឯទឹកនៃមរមនអាចជួយយើងឲ្យទទួលបានការយល់ដឹងបន្ថែមទៀតអំពីសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹក ។

សូមឲ្យសិស្សអាន ម៉ូសាយ ១៨:២, ៧ ដោយស្ងៀមស្ងាត់ ដោយរកមើលអ្វីដែលអាលម៉ាបានបង្រៀនដល់ប្រជាជន នៅពេលគាត់បានរៀបចំពួកគេសម្រាប់ពិធីបុណ្យជ្រមុជទឹក ។

- យោងតាមខគម្ពីរទាំងនេះ តើគោលលទ្ធិ និង គោលការណ៍មួយណាដែលអាលម៉ាបានសង្កត់ធ្ងន់លើនោះ ?
- តើអ្នកគិតថា ការយល់ដឹងពីសេចក្តីពិតទាំងនេះអាចជួយមនុស្សខ្លះឲ្យរៀបចំសម្រាប់ពិធីបុណ្យជ្រមុជទឹកដោយរបៀបណា ?

ដើម្បីជួយសិស្សឲ្យយល់ពីអ្វីដែលពួកគេអាចធ្វើដើម្បីកាន់តាមសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹក និង ដើម្បីជួយពួកគេឲ្យកោតសរសើរដល់ពរជ័យដែលពួកគេនឹងទទួលបានជាលទ្ធផល សូមចម្លងតារាងខាងក្រោមនេះនៅលើក្តារខៀន ៖ សូមកុំបញ្ចូលប្រយោគ ឬ សេចក្តីយោងព្រះគម្ពីរនៅពាក់កណ្តាលខាងក្រោមនៃតារាងនេះ ។

ខ្ញុំនឹង . . .	*ព្រះសន្យា . . .*
សូមជួយទទួលបន្ទុកគ្នាទៅវិញទៅមកដើម្បីឲ្យបន្ទុកនោះបានស្រាល ។ (សូមមើល ម៉ូសាយ ១៨:៨) ។ សូមទួញយំជាមួយនឹងអ្នកណាដែលទួញយំ (សូមមើល ម៉ូសាយ ១៨:៩) ។ សូមកំសាន្តទុក្ខដល់អស់អ្នកណាដែលកំពុងត្រូវការកំសាន្តទុក្ខ (សូមមើល ម៉ូសាយ ១៨:៩) ។ ឈរជាសាក្សីដល់ព្រះនៅគ្រប់ពេល និង គ្រប់សេចក្ដី និង គ្រប់ទីកន្លែង (សូមមើល ម៉ូសាយ ១៨:៩) ។ បម្រើព្រះអង្គ ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ (សូមមើល ម៉ូសាយ ១៨:៩) ។	ដើម្បីឲ្យខ្ញុំអាចបានប្រោសលោះដោយព្រះ (សូមមើល ម៉ូសាយ ១៨:៩) ។ ហើយខ្ញុំបានរាប់ជាមួយនឹងពួកអ្នកនៃដំណើរអស់ឡើងវិញទីមួយ (សូមមើល ម៉ូសាយ ១៨:៩) ។ ដើម្បីឲ្យខ្ញុំអាចមានជីវិតដ៏នៅអស់កល្បជានិច្ច (សូមមើល ម៉ូសាយ ១៨:៩) ។ ទ្រង់ស្រោចព្រះវិញ្ញាណទ្រង់មកលើខ្ញុំយ៉ាងបរិបូរណ៍ (សូមមើលម៉ូសាយ ១៨:១០) ។

សូមពន្យល់ថា មុនពេលអញ្ជើញប្រជាជនឲ្យជ្រមុជទឹក អាលម៉ាបាននិយាយទៅកាន់ពួកគេអំពីអាកប្បកិរិយា និង សកម្មភាពដែលនឹងបង្ហាញថាពួកគេបានរួចរាល់ដើម្បីធ្វើ និង កាន់តាមសេចក្ដីសញ្ញានេះជាមួយនឹងព្រះអម្ចាស់ ។ (អ្នកអាចចង់រំឭកសិស្សថា សេចក្ដីសញ្ញាគឺជាកិច្ចព្រមព្រៀងមួយរវាងព្រះ និង មនុស្ស ប៉ុន្តែថាព្រះ និង មនុស្ស « មិនបានធ្វើសកម្មភាពស្មើគ្នានៅក្នុងកិច្ចព្រមព្រៀងនោះទេ ។ ព្រះបានប្រទានលក្ខខណ្ឌនៃសេចក្ដីសញ្ញា ហើយមនុស្សទទួលព្រមធ្វើអ្វីដែលទ្រង់សុំពួកគេឲ្យធ្វើ ។ បន្ទាប់មក ព្រះសន្យានឹងមនុស្សពីពរជ័យមួយចំនួនចំពោះការគោរពតាមរបស់ពួកគេ » [Guide to the Scriptures, “Covenant,” scriptures.lds.org] ។ សម្រាប់ការពន្យល់នៅថ្ងៃចុងក្រោយនៃតម្រូវការសម្រាប់ការជ្រមុជទឹក សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ២០:៣៧ ។)

សូមចែកសិស្សក្នុងថ្នាក់ជាពីរក្រុម ។ សូមឲ្យក្រុមទីមួយអាន ម៉ូសាយ ១៨:៨–១១ រកអ្វីដែលអាលម៉ាបានបង្រៀនថា យើងត្រូវមានឆន្ទៈធ្វើពេលយើងជ្រមុជទឹក ។ សូមឲ្យក្រុមទីពីរអានវគ្គដដែល ហើយរករបៀបដែលព្រះអម្ចាស់បានសន្យាថានឹងប្រទានពរដល់យើង ប្រសិនបើយើងរក្សាសេចក្ដីសញ្ញារបស់យើង ។ ក្រោយពីសិស្សមានពេលសិក្សាខគម្ពីរហើយ សូមឲ្យពួកគេបីបួននាក់ឡើងមកកាន់ក្តារខៀន ហើយសរសេរនូវអ្វីដែលពួកគេបានរកឃើញក្នុងកូឡោនត្រឹមត្រូវ ។

ដើម្បីជួយសិស្សឲ្យកោតសរសើរដល់សេចក្ដីសញ្ញាជ្រមុជទឹករបស់ពួកគេ សូមសួរ ៖

- **តើសកម្មភាព និង អាកប្បកិរិយាអ្វីខ្លះនៅក្នុងកូឡោនទីមួយមានន័យដល់អ្នក ?**
- **ហេតុអ្វីបានជាការសន្យានានាដែលសរសេរនៅក្នុងកូឡោនទីពីរសំខាន់ចំពោះអ្នក ?**

សូមឲ្យសិស្សអាន ម៉ូសាយ ១៨:១២–១៦ ដោយស្ងាត់ៗដោយរកមើលពីរបៀបដែលអាលម៉ា និង ប្រជាជនរបស់គាត់ត្រូវបានប្រទានពរ នៅពេលពួកគេធ្វើសេចក្ដីសញ្ញាថានឹងបម្រើដល់ព្រះអម្ចាស់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ អ្នកអាចបង្ហាញថា អាលម៉ាត្រូវបានពោរពេញដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ នៅពេលគាត់បានរៀបចំជ្រមុជទឹកហេឡាម ហើយថាទាំងអាលម៉ានិងហេឡាមត្រូវបានពោរពេញដោយព្រះវិញ្ញាណ នៅពេលពិធីបុណ្យជ្រមុជទឹកត្រូវបានបញ្ចប់ ដោយបង្ហាញថាព្រះអម្ចាស់បានចាប់ផ្តើមបំពេញសេចក្ដីសញ្ញារបស់ទ្រង់រួចរាល់ហើយ ដើម្បីស្រោចព្រះវិញ្ញាណរបស់ទ្រង់មកលើប្រជាជន ។

សូមចែកចាយទីបន្ទាល់របស់អ្នកថា យើងទទួលព្រះវិញ្ញាណនៃព្រះអម្ចាស់ និង ការសន្យានៃជីវិតដ៏នៅអស់កល្បជានិច្ចដោយការធ្វើ និង ការកាន់តាមសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក ។

ម៉ូសាយ ១៨:១៧–៣០

អាលម៉ាបង្កើតសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទក្នុងចំណោមប្រជាជន

សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី. អារិង នៃគណៈប្រធានទីមួយ ៖

« ពីថ្ងៃនៃបុណ្យជ្រមុជទឹកតាមរយៈបង្គោលខាងវិញ្ញាណនៃជីវិតរបស់យើង យើងបានធ្វើការសន្យាជាមួយនឹងព្រះ ហើយទ្រង់បានសន្យាជាមួយនឹងយើង ។ ទ្រង់តែងតែរក្សាការសន្យារបស់ទ្រង់ដែលបានផ្តល់តាមរយៈអ្នកបម្រើមានសិទ្ធិអំណាចរបស់ទ្រង់ ប៉ុន្តែវាជាការសាកល្បងយ៉ាងសំខាន់នៃជីវិតរបស់យើងដើម្បីឃើញថា យើងនឹងធ្វើ ហើយកាន់តាមសេចក្ដីសញ្ញារបស់យើងជាមួយនឹងទ្រង់ឬយ៉ាងណា » (« សាក្សីនៃព្រះ » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ទំព័រ ៣០) ។

សូមឲ្យសិស្សមើលទៅតារាងនៅលើក្តារខៀន ។ សូមពន្យល់ថា ពួកគេនឹងរៀនបន្តិចទៀតនេះអំពីរបៀបដែលប្រជាជនរបស់អាលម៉ារស់នៅតាមរយៈសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក និង ពីរបៀបដែលពួកគេត្រូវបានប្រទានពរដោយសារការធ្វើដូច្នោះ ។ សូមឲ្យសិស្សធ្វើការជាពីរក្រុម ។ សូមឲ្យក្រុមទីមួយសិក្សា ម៉ូសាយ ១៨:១៧–២៣ ហើយក្រុមទីពីរសិក្សា ម៉ូសាយ ១៨:២៤–៣០ ។ នៅពេលពួកគេអាន សូមឲ្យក្រុមទាំងពីររកមើលរបៀបខ្លះដែលអាលម៉ាបានបង្រៀនប្រជាជនពីរបៀបដែលពួកគេគួររស់នៅដើម្បីកាន់តាមសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹក ។ សូមឲ្យសិស្សម្នាក់ៗពីក្រុមនីមួយៗរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ចែកចាយដល់ដៃគូដែលពួកគេបានរើសពីក្រុមមួយទៀត ។ ឬ សូមឲ្យមានតំណាងពីក្រុមនីមួយៗរាយការណ៍ពីអ្វីដែលគេបានរៀនដល់សិស្សក្នុងថ្នាក់ទាំងអស់ ។

- តើសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់អ្នក ជះឥទ្ធិពលដល់របៀបដែលអ្នករស់នៅរាល់ថ្ងៃដោយរបៀបណា ? (សូមគិតពីការឲ្យសិស្សឆ្លើយនឹងសំណួរនេះ ដោយការនិយាយអំពីរបៀបដែលសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់ពួកគេជះឥទ្ធិពលដល់របៀបដែលពួកគេប្រព្រឹត្តជាមួយនឹងសមាជិកគ្រួសារ ប្រភេទនៃការកំសាន្តដែលពួកគេជ្រើសរើស ឬ របៀបដែលពួកគេទាក់ទងនឹងមិត្តភក្តិរបស់គេ ។)

សូមឲ្យសិស្សរំឭក ម៉ូសាយ ១៨:១៧, ២២, ២៩ ដើម្បីរក៣ក្យ និង ឃ្លាដែលបង្ហាញពីរបៀបដែលប្រជាជនត្រូវបានប្រទានពរដោយការកាន់តាមសេចក្តីសញ្ញារបស់ពួកគេ ។ សូមសរសេរនូវពរជ័យលើក្តារខៀនពីក្រោមតារាងនៃសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹក ។ (អ្នកអាចត្រូវរំឭកសិស្សថា ឃ្លា « កូនចៅនៃព្រះ » (ម៉ូសាយ ១៨:២២) មានសេចក្តីយោងទៅការក្លាយជា អ្នកគ្រងមរតកនៃជីវិតដ៏អស់កល្បជានិច្ចរបស់យើងតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ (សូមមើល ម៉ូសាយ ៥:៦–៨, ១៥) ។)

ដើម្បីជួយសិស្សឲ្យឃើញថា **ពរជ័យដ៏អស្ចារ្យមកដល់អ្នកដែលកាន់តាមសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹក** សូមឲ្យសិស្សមើលទៅតារាងលើក្តារខៀន ហើយសួរ ៖

- តើអ្នកបានឃើញមិត្តភក្តិ សមាជិកគ្រួសារ ឬ សមាជិកវួដរបស់អ្នកត្រូវបានប្រទានពរដោយការកាន់តាមសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់ពួកគេដោយរបៀបណា ?
- តើព្រះអម្ចាស់បានប្រទានពរដល់អ្នកដោយការកាន់តាមសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់អ្នកដោយរបៀបណា ?

សូមថ្លែងទីបន្ទាល់របស់អ្នកអំពីរបៀបនៃការកាន់តាមសេចក្តីសញ្ញាបាននាំមកនូវពរជ័យក្នុងជីវិតអ្នក ។

ម៉ូសាយ ១៨:៣១–៣៥

អ្នកដែលនៅក្នុងសាសនាចក្រត់ចេញពីការកាប់សម្លាប់របស់ស្តេចណូអេ

សូមសង្ខេប ម៉ូសាយ ១៨:៣១–៣៣ ដោយការពន្យល់ថា ថ្ងៃមួយ នៅពេលអាលម៉ានិងប្រជាជនរបស់គាត់បានរួបរួមគ្នាស្តាប់ព្រះបន្ទូលនៃព្រះអម្ចាស់ អ្នកបម្រើរបស់ស្តេចណូអេបានរកឃើញពួកគេ ។ បន្ទាប់មកស្តេចបានបញ្ជូនទ័ពរបស់ទ្រង់ឲ្យកម្ចាយពួកគេ ។

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ១៨:៣៤ ឮៗ ។ សូមចង្អុលទៅលេខយោង *ក* ដែលឲ្យអ្នកអានបើកទៅ ម៉ូសាយ ២៣:១ ។ (អ្នកអាចឲ្យសិស្សគូសចំណាំលេខយោងនោះ ។) សូមពន្យល់ថាដំណើររឿងក្នុង ម៉ូសាយ ១៨:៣៤ បន្តនៅក្នុង ម៉ូសាយ ២៣:១ ក្រោយជំពូក ១៩–២២ កត់ត្រាពីបទពិសោធន៍នៃប្រជាជនលីមហៃ ។ សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២៣:១–២ ឮៗ ។

- តើអាលម៉ា « បានប្រាប់ជាមុន » ពីគ្រោះថ្នាក់ដែលប្រជាជនរបស់គាត់នឹងជួបដោយរបៀបណា ?

សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***ព្រះអម្ចាស់បានព្រមានពួកសុចរិត នៅពេលពួកគេស្ថិតក្នុងគ្រោះថ្នាក់ ។*** (អ្នកអាចឲ្យសិស្សសរសេរគោលការណ៍នេះនៅគែមទំព័រក្បែរ ម៉ូសាយ ១៨:៣៤ ។) ដើម្បីបង្ហាញពីសេចក្តីពិតនេះ សូមអានរឿងខាងក្រោមដោយអែលឌើរ នែល អិល អាន់ឌើរសិន នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ៖

« ការធ្វើជាភ្នាក់ងារពិសេសម្នាក់របស់ FBI មិត្តភក្តិរបស់ខ្ញុំបានសើបសង្កេតពីក្រុមបទល្មើសគិតទុកជាមុនក្នុងការនាំថ្នាំញៀនខុសច្បាប់ទៅកាន់សហរដ្ឋអាមេរិក ។

« នៅក្នុងឱកាសមួយ គាត់និងភ្នាក់ងារផ្សេងទៀតបានទៅអគារមួយ ដែលពួកគេជឿថាជាកន្លែងអ្នកជួញដូរថ្នាំញៀនចែកចាយថ្នាំកូកាអ៊ីន ។ មិត្តភក្តិរបស់ខ្ញុំប្រាប់ពីអ្វីដែលបានកើតឡើង ៖

« យើងបានគោះទ្វារនៃអ្នកជួញដូរថ្នាំញៀន ។ ជនសង្ស័យបានបើកទ្វារ ហើយពេលឃើញយើង គេបានព្យាយាមលាក់អ្វីនៅខាងក្រោយខ្នង ។ ប៉ុន្តែវាយឺតពេលទៅហើយ យើងអាចឃើញកូកាអ៊ីននៅលើតុគេ ។

« បុរសម្នាក់ និង ស្ត្រីម្នាក់ដែលអង្គុយនៅតុនោះបានយកកូកាអ៊ីនចេញពីតុភ្លាម ។ យើងបានឃាត់គេមិនឲ្យបំផ្លាញភស្តុតាងនោះទេ ដូច្នេះខ្ញុំក៏រុញជនសង្ស័យជួញដូរថ្នាំញៀនដែលពាំងទ្វារទៅម្ខាងភ្លាម ។ នៅពេលខ្ញុំរុញគេ ភ្នែកខ្ញុំនឹងភ្នែកគេសម្លឹងគ្នា ។ ដោយចម្លែក គេមិនបានបញ្ចេញថាគេខឹង ឬ ខ្លាចនោះទេ ។ គេបានញញឹមមកកាន់ខ្ញុំ ។

« ភ្នែកគេ និង ស្នាមញញឹមដ៏ស្រស់បានបញ្ជាក់ច្រាប់ខ្ញុំថា គាត់មិនអីទេ ដូច្នេះខ្ញុំក៏ដើរទៅកាន់តុនោះ ។ ឥឡូវនេះ ជនសង្ស័យនៅពីក្រោយខ្ញុំ ។ ពេលនោះ ខ្ញុំមានអារម្មណ៍ចម្លែកដ៏ខ្លាំងក្នុងគំនិតខ្ញុំថា ៖ " សូមប្រយ័ត្នមនុស្សអាក្រក់នៅពីក្រោយភ្នែកដែលស្រទន់នោះ" ។

« ‹ ខ្ញុំក៏បែរក្រោយភ្លាមទៅមើលជនសង្ស័យ ។ ដៃរបស់គាត់ដាក់ក្នុងហោប៉ាវដ៏ធំខាងមុខរបស់គេ ។ តាមសភាវគតិភ្លាមនោះ ខ្ញុំបានចាប់ដៃគេ ហើយទាញចេញពីហោប៉ាវរបស់គេ ។ ពេលនោះទើបខ្ញុំឃើញថា គាត់បានលាក់នៅក្នុងដៃរបស់គាត់ នូវកាំភ្លើងពាក់កណ្តាលស្វ័យប្រវត្តិរៀបនឹងបាញ់ ។ សកម្មភាពរំដើមរំជួលមួយប្រាវបានកើតឡើង ហើយខ្ញុំបានដាក់ខ្មោះបុរសនោះ ។ › . . .

« . . . ព្រះវិញ្ញាណបរិសុទ្ធបានព្រមានមិត្តរបស់ខ្ញុំពីគ្រោះថ្នាក់ដល់រូបកាយ ព្រះវិញ្ញាណបរិសុទ្ធក៏នឹងព្រមានអ្នកអំពីគ្រោះថ្នាក់ខាងវិញ្ញាណដែរ » (" Beware of the Evil behind the Smiling Eyes," *Ensign* ឬ ***លេអាហូណា*** ខែ ឧសភា ឆ្នាំ ២០០៥ ទំព័រ ៤៦–៤៧) ។

សូមបញ្ជាក់ថា ព្រះអម្ចាស់បានព្រមានជាញឹកញាប់ដល់ពួកសុចរិតអំពីគ្រោះថ្នាក់ដែលជិតកើតមានឡើង ប៉ុន្តែយើងមិនគួរស្មានថាយើងជាមនុស្សមិនសុចរិត ប្រសិនបើយើងមិនមានអារម្មណ៍ពីការព្រមានពីព្រះវិញ្ញាណបរិសុទ្ធរាល់ពេលដែលយើងជួបប្រទះនឹងកាលៈទេសៈដ៏គ្រោះថ្នាក់ ។

- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់បានព្រមានអ្នកពីគ្រោះថ្នាក់ខាងសាច់ឈាម ឬ ខាងវិញ្ញាណ ? (ក្រោយពីសិស្សចែកចាយពីបទពិសោធន៍របស់ពួកគេ អ្នកអាចចង់ចែកចាយបទពិសោធន៍មួយរបស់អ្នក ។)

ម៉ូសាយ ១៩–២០

សេចក្តីផ្តើម

ក្រោយពីអាលម៉ា និង ប្រជាជនរបស់គាត់បានគេចពីកងទ័ពរបស់ស្តេចណូអេ ស្តេចណូអេ និង ប្រជាជនរបស់ទ្រង់បានចាប់ផ្តើមរងទុក្ខនឹងលទ្ធផលនៃភាពមិនសុចរិតរបស់ពួកគេ ដូចដែលបានព្យាករណ៍ដោយអ័ប៊ីណាដៃ— ពួកគេត្រូវបានវាយប្រហារ និង ដាក់ក្នុងសេរភាពដោយសាសន៍លេមិន ហើយស្តេចណូអេបានរងទុក្ខដល់សុគតដោយភ្លើង ។ កូនប្រុសរបស់ណូអេ លីមហៃ បានក្លាយជាស្តេចបន្ទាប់ពីណូអេសុគត ។ នៅពេលពួកសង្ឃរបស់ស្តេចណូអេពីមុនបានចាប់ពង្រត់កូនស្រីនៃសាសន៍លេមិនមួយក្រុម សាសន៍លេមិនបានបន្ធោសដល់ប្រជាជនរបស់លីមហៃ ហើយបានរៀបចំដើម្បីវាយលុកពួកគេ ។ ប្រជាជនរបស់លីមហៃបានប្តាំងដោយក្លាហាន ហើយពួកគេបានរងរបួស ហើយបានចាប់យកស្តេចនៃសាសន៍លេមិន ។ លីមហៃបាននាំសន្តិភាពដល់ស្តេចសាសន៍លេមិន ដែលក្រោយមកបានបញ្ចុះបញ្ចូលប្រជាជនរបស់ខ្លួនឲ្យត្រឡប់ទៅដែនដីខ្លួនវិញដោយសេចក្តីសុខសាន្ត ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ១៩–២០

សាសន៍នីហ្វៃនៅក្នុងដែនដីលីហៃ-នីហ្វៃបានទទួលនូវការបំពេញនៃការព្យាករណ៍របស់អ័ប៊ីណាដៃ

សូមឲ្យសិស្សគិតពីពេលមួយ ដែលនរណាម្នាក់បានព្រមានដល់ពួកគេពីគ្រោះថ្នាក់មួយដែលពួកគេមិនអាចមើលឃើញ ។ សូមឲ្យពួកគេប្រាប់ពីរបៀបដែលពួកគេត្រូវបានប្រទានពរ ដោយសារពួកគេបានធ្វើតាមការព្រមាននោះ ។ សូមជួយសិស្សឲ្យពិភាក្សាពីគោលបំណងនៃការព្រមានដោយការសួរសំណួរខាងក្រោម ៖

- **តើអ្វីជាគោលបំណងនៃការព្រមាននោះ ? តើនរណាដែលព្រមានអ្នកអំពីរឿងដែលអ្នកមិនគួរធ្វើ ឬ រឿងដែលអាចធ្វើឲ្យអ្នកគ្រោះថ្នាក់ ?**
- **តើព្រះលាតត្រដាងការព្រមានខាងវិញ្ញាណដល់សាសនាចក្ររបស់ទ្រង់ដល់អ្នកណា ?**

សូមរំឭកសិស្សថា ព្រះអម្ចាស់បានបញ្ជូនអ័ប៊ីណាដៃឲ្យទៅព្រមានសាសន៍នីហ្វៃអំពីលទ្ធផលនៃអំពើបាបរបស់ពួកគេ ។ ដើម្បីជួយសិស្សឲ្យរំឭកពីការព្យាករណ៍របស់អ័ប៊ីណាដៃដល់សាសន៍នីហ្វៃនៅក្នុងដែនដីលីហៃ-នីហ្វៃ សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ។ សូមប្រាកដថា អ្នកទុកកន្លែងល្មមឲ្យសិស្សសរសេរនៅក្រោមវគ្គនៃសេចក្តីយោងព្រះគម្ពីរនីមួយៗ ។

ការព្យាករណ៍អំពីប្រជាជនរបស់ស្តេចណូអេ (ម៉ូសាយ ១២:១–២; ១៧:១៧)	ការបំពេញ (ម៉ូសាយ ១៩:១០, ១៤–១៥; ២០:២០; ២១:២–៤)
ការព្យាករណ៍អំពីស្តេចណូអេ (ម៉ូសាយ ១២:៣; ១៧:១៨)	ការបំពេញ (ម៉ូសាយ ១៩:១៨–២០)

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ១២:១–២ ឮៗ ។ សូមឲ្យសិស្សរកនូវអ្វីដែលអ័ប៊ីណាដៃបានព្យាករណ៍ថានឹងកើតឡើងដល់ប្រជាជនរបស់ស្តេចណូអេ ដោយសារពួកគេមិនព្រមប្រែចិត្ត ។ សូមឲ្យសិស្សម្នាក់សរសេរលទ្ធផលទាំងនេះនៅក្នុងប្រអប់នៅខាងឆ្វេងផ្នែកខាងលើនៃតារាងនៅលើក្តារខៀន ។ សូមឲ្យសិស្សផ្សេងទៀតអាន ម៉ូសាយ ១២:៣ ឮៗ ។ សូមឲ្យសិស្សរកមើលអ្វីដែលអ័ប៊ីណាដៃបានព្យាករណ៍ថានឹងកើតឡើងដល់ស្តេចណូអេ ។ សូមឲ្យសិស្សម្នាក់សរសេរលទ្ធផលនេះនៅក្នុងតារាង ។

ដើម្បីជួយសិស្សឲ្យគិតអំពីសារសំខាន់នៃការព្រមានខាងវិញ្ញាណដែលយើងទទួលតាមរយៈព្យាការី សូមចែកចាយនូវរឿងខាងក្រោមដោយអែលឌើរ ដេវីឌ អ ស្តូន នៃក្រុមចិតសិបនាក់ ៖

« នាព្រឹកថ្ងៃអាទិត្យមួយ ជាងមួយឆ្នាំកន្លងទៅ យើងបានក្រោកឡើងនាថ្ងៃដ៏ល្អក្នុងទីក្រុង សានតូ ដូមីងហ្គូ នៃសាធារណរដ្ឋដូមីនីកាំង ។ ព្រះអាទិត្យនាំសមុទ្រការីប៊ីនបានរះ ហើយផ្ទៃមេឃស្រឡះ ។ ខ្យល់ដ៏ស្រទន់បានបក់មក ស្ទើរមិនធ្វើឲ្យស្លឹករឈើរង្គើ វាក្តៅល្មម ហើយសុខសាន្ត និង ស្ងប់ស្ងាត់ ។ ប៉ុន្តែឆ្ងាយឯនាយសមុទ្រ លើសពីការមើលឃើញដោយភ្នែកយើងខាងសាច់ឈាមនាថ្ងៃនោះ ព្យុះដ៏កំណាចបានមក ដែលមិនអាចទប់ទល់បាន ។ មជ្ឈមណ្ឌលខ្យល់ព្យុះ ដោយមានការទទួលខុសត្រូវដើម្បីតាមដាន និង ព្យាករណ៍ផ្លូវនៃខ្យល់ព្យុះចច បានប្រាប់ពីព័ត៌មានជាបន្តបន្ទាប់ភ្លាមៗដែលមាននៅក្នុងអ៊ិនធើណិត ។ នៅក្នុងព្រឹកដ៏សន្តិភាព ស្ងប់ស្ងាត់នោះ ដោយក្រសែភ្នែកដែល ឃើញ ទៅលើផ្ទៃមេឃ ខ្ញុំបានឃើញផ្លូវនៃព្យុះដែលបានព្យាករណ៍នោះ សំដៅមកបេះដូងនៃទីក្រុងសានតូ ដូមីងហ្គូ ដូចជាព្រួញមួយ ។

« នៅក្នុងរយៈពេល ៤៨ ម៉ោង ព្យុះនោះបានបក់បោកកោះយ៉ាងខ្លាំង . . . ដោយកំណាច ដោយបន្សល់នូវការបំផ្លាញ ភាពងងឹត និងការស្លាប់ដោយការបោកបក់ដ៏ខ្លាំងនោះ ។ . . .

« ការខូចខាត និងការបំផ្លាញ និងការស្លាប់ដ៏ក្រៃលែងពីគ្រោះមហន្តរាយនៃកម្លាំងខាងសាច់ឈាមដ៏ខ្លាំងនេះអាចកើតឡើង ការបំផ្លិចបំផ្លាញដែលខ្លាំងជាងនេះទៅទៀត នៅក្នុងជីវិតរបស់មនុស្សគឺខ្យល់ព្យុះខាងវិញ្ញាណ ។ កម្លាំងដ៏ខ្លាំងទាំងនេះជាញឹកញាប់បណ្តាលឲ្យមានការខូចខាតយ៉ាងខ្លាំងជាងខ្យល់ព្យុះកំបុតត្បូងខាងសាច់ឈាមទៅទៀត ដោយសារវាបំផ្លាញព្រលឹងយើង ហើយឆក់យើងពីការអំពឹង និង ការសន្យាដ៏នៅអស់កល្បជានិច្ចរបស់យើង ។ . . .

« ប៉ុន្តែយើងក៏មានអ្នកយាមខ្យល់ព្យុះខាងវិញ្ញាណដែរ អ្នកទាំងឡាយដែលត្រូវបានហៅឲ្យឃ្លាំមើល និង ព្រមាន ដោយជួយយើងឲ្យចៀសចេញពីការខូចខាតខាងវិញ្ញាណ ការបំផ្លាញ ហើយនិងសេចក្តីស្លាប់ ។ អ្នកយាមរបស់យើងនៅលើប៉ម ដែលយើងស្គាល់ថាជាសាវក និង ព្យាការី ។ ពួកគាត់គឺជាភ្នែកខាងវិញ្ញាណរបស់យើងនៅលើមេឃ ហើយតាមរយៈការបំផុសគំនិត និង ការយល់ដឹង និង ប្រាជ្ញាដ៏បរិសុទ្ធ ពួកគាត់ដឹងពីផ្លូវដែលព្យុះទាំងនេះអាចនឹងមក ។ ពួកគាត់បន្តបន្លឺសំឡេងដើម្បីព្រមានដល់យើងអំពីលទ្ធផលដ៏សោកសៅនៃការរំលងដ៏ចចេស និង គ្មានត្រាប្រណីនៃព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ។ ការព្រងើយនឹងការព្រមានទាំងនេះដោយមានចេតនា គឺត្រូវរងទុក្ខ សោកស្តាយ និង បំផ្លាញ ។ ការធ្វើតាមពួកគាត់ គឺធ្វើតាមអ្នកបម្រើដែលត្រូវបានជ្រើសរើសរបស់ព្រះអម្ចាស់ទៅកាន់កន្លែងសុខស្ងាត់ និង សំបូរសប្បាយខាងវិញ្ញាណ » (" Spiritual Hurricanes " *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ទំព័រ ៣១–៣២) ។

• តើរឿងនេះទាក់ទងនឹងតួនាទីរបស់អ័ប៊ីណាដៃក្នុងចំណោមប្រជាជនរបស់ស្តេចណូអេដោយរបៀបណា ?

សូមប្រាប់សិស្សថា សកម្មភាពខាងក្រោមនឹងជួយពួកគេឲ្យស្គាល់សាច់រឿងនៃ ម៉ូសាយ ១៩–២០ ហើយឃើញពីការបំពេញនៃការព្យាករណ៍របស់អ័ប៊ីណាដៃនៅក្នុងជំពូកទាំងនេះ ។ ក្រោយពីសកម្មភាពនេះ សិស្សនឹងបំពេញកូឡោនខាងស្តាំនៃតារាងលើក្តារខៀន ។

សូមសរសេរប្រយោគដប់មួយខាងក្រោមនៅលើក្តារខៀនមុនចាប់ផ្តើមថ្នាក់ ឬ សូមរៀបចំវាជាក្រដាសចែកឲ្យសិស្ស ។ សូមឲ្យសិស្សអាន ម៉ូសាយ ១៩–២០ ។ នៅពេលពួកគេអាន សូមឲ្យពួកគេដាក់លេខតាមលំដាប់នៃព្រឹត្តិការណ៍ក្នុងបញ្ជី ។ អ្នកអាចប្រាប់សិស្សថាការសង្ខេបជំពូកទាំងឡាយផ្តល់នូវតម្រុយដែលអាចជួយបាន ។

_____ *គេខានចង់សម្លាប់ស្តេចណូអេ ។*

_____ *ស្ត្រីសាសន៍នីហ្វៃ និង កូនចៅគេបានអង្វរដល់សាសន៍លេមិនកុំឲ្យសម្លាប់ពួកគេ ។*

_____ *ស្តេចណូអេរងទុក្ខដល់ស្លាប់ដោយសារភ្លើង ។*

_____ *កងទ័ពសាសន៍លេមិនមកដល់ព្រំដែនសេមឡុន ។*

_____ *ពួកសង្ឃរបស់ស្តេចណូអេបានចាប់យកកូនស្រីសាសន៍លេមិន ២៤ នាក់ ។*

_____ *ស្តេចសាសន៍លេមិនបានអង្វរដល់កងទ័ពរបស់ទ្រង់ឲ្យទុកជីវិតដល់ប្រជាជនរបស់លីមហៃ ។*

_____ *ស្តេចណូអេ និង មនុស្សខ្លះរបស់ទ្រង់បានរត់ចេញពីសាសន៍លេមិន ដោយទុកប្រពន្ធ និងកូនពួកគេចោល ។*

_____ *លីមហៃបញ្ជាប្រជាជនរបស់គាត់កុំឲ្យសម្លាប់ស្តេចសាសន៍លេមិន ។*

_____ *មានសេចក្តីសុខសាន្តរវាងសាសន៍នីហ្វៃ និង សាសន៍លេមិនរយៈពេលពីរឆ្នាំ ។*

_____ *លីមហៃបានសន្យាថា ប្រជាជនរបស់គាត់នឹងបង់របស់ទ្រព្យរបស់ពួកគេពាក់កណ្តាលទៅដល់សាសន៍លេមិន ។*

_____ *សាសន៍នីហ្វៃវាយបកចំពោះការវាយប្រហាររបស់សាសន៍លេមិន ហើយចាប់បានស្តេចសាសន៍លេមិន ។*

សូមឲ្យសិស្សបំពេញសកម្មភាពរយៈពេលប្រាំទៅដប់នាទី ។ បន្ទាប់មក សូមប្រើបញ្ជីនេះដើម្បីរំពឹកខ្សែរឿងនៃ ម៉ូសាយ ១៩–២០ ។ (លំដាប់នៃហេតុការណ៍ដែលត្រូវ គឺចាប់ពីខាងលើនៃបញ្ជី គឺមានដូចតទៅ ៖ ១, ៤, ៥, ២, ៨, ១១, ៣, ១០, ៧, ៦, ៩ ។)

សូមឲ្យសិស្សមើលទៅតារាងនៅលើក្តារខៀន ។ សូមឲ្យសិស្សក្នុងថ្នាក់ធ្វើការជាពីរក្រុម ។ សូមឲ្យក្រុមមួយអាន ម៉ូសាយ ១៩:១០, ១៤–១៥; ២០:២០; ២១:២–៤ ដើម្បីរកមើលពីរបៀបដែលការព្យាករណ៍របស់អ័ប៊ីណាដៃអំពីប្រជាជនរបស់ស្តេចណូអេត្រូវបានបំពេញ ។ សូមឲ្យក្រុមទីពីរអាន ម៉ូសាយ ១៩:១៨–២០ ដើម្បីរកមើលពីរបៀបដែលការព្យាករណ៍របស់អ័ប៊ីណាដៃអំពីស្តេចណូអេត្រូវបានបំពេញ ។ សូមឲ្យសិស្សម្នាក់ពីក្រុមនីមួយៗសង្ខេបពីរបៀបដែលការព្យាករណ៍របស់អ័ប៊ីណាដៃត្រូវបានបំពេញ ។ សូមឲ្យសិស្សម្នាក់ទៀតសរសេរការសង្ខេបរបស់ពួកគេនៅក្នុងតារាង ។

សូមឲ្យសិស្សអាន ម៉ូសាយ ២០:២១ ដោយស្ងាត់ៗ ។

• តើអ្វីទៅដែលគេខានបាននិយាយ ថាជាមូលហេតុនៃការរងទុក្ខរបស់ប្រជាជននោះ ?

សូមឲ្យសិស្សពន្យល់ជាសម្តីខ្លួនឯងពីអ្វីដែលគេខានចង់ឲ្យប្រជាជនយល់ ។ ខណៈដែលពួកគេអាចប្រើពាក្យខុសគ្នា សិស្សគួរបង្ហាញការយល់ថា **ការបដិសេធព្រះបន្ទូលនៃអ្នកបម្រើរបស់ព្រះអម្ចាស់នាំមកនូវការរងទុក្ខ និង ការសោកសង្រែង ។**(អ្នកអាចសរសេរគោលការណ៍នេះលើក្តារខៀន ។)

សូមប្រាប់សិស្សថា ព្រះអម្ចាស់បានប្រទានការព្រមានស្រដៀងគ្នានេះទៅដល់អ្នកនៅក្នុងថ្ងៃចុងក្រោយដែលមិនបានស្តាប់តាមសំឡេងរបស់ទ្រង់ ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្តីសញ្ញា ១៣៣:៧០–៧២ ឮៗ ។ អ្នកអាចស្នើថា សិស្សគួរសរសេរសេចក្តីយោងនេះនៅតែមទំព័រនៃព្រះគម្ពីររបស់ពួកគេក្បែរ ម៉ូសាយ ២០:២១ ។

• តើព្យាការី និង ពួកសាវកបង្រៀនអ្វីខ្លះនៅក្នុងជំនាន់របស់យើង ដែលនឹងជួយយើងឲ្យចៀសវាងពីការរងទុក្ខ និង ការសោកសង្រែង ? តើពួកគាត់បង្រៀនអ្វីខ្លះ ដែលនឹងជួយនាំយើងទៅកាន់សេចក្តីសុខសាន្ត និងសុភមង្គល ហើយជួយយើងឲ្យត្រឡប់ទៅកាន់វត្តមានរបស់ព្រះ ? (អ្នកអាចបង្ហាញដល់សិស្សនូវការចោះពុម្ពសន្និសីទទូទៅថ្មីៗមួយពី *Ensign* និង និយាយអំពីចំណងជើងខ្លះៗនៃសុន្ទរកថាដែលថ្លែងដោយព្យាការី ។

សូមឲ្យសិស្សប្រាប់ពីពេលដែលពួកគេត្រូវបានប្រទានពរ ដោយសារពួកគេបានធ្វើតាមការប្រឹក្សារបស់អ្នកដឹកនាំសាសនាចក្រ ។

ដើម្បីជួយសិស្សឲ្យយល់ថា ការគោរពតាមពាក្យរបស់ព្យាការីអាចនាំមកនូវសន្តិភាព និង ជួយយើងឲ្យត្រឡប់ទៅកាន់វត្តមានរបស់ព្រះវិញ សូមចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ៉ូបឺត ឌី ហែល នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« សុវត្ថិភាពខាងវិញ្ញាណរបស់យើងស្ថិតលើការបែរទៅរកសំឡេងដ៏ច្បាស់របស់ព្យាការីដែលនៅរស់របស់យើង ។ ប្រសិនបើយើងស្តាប់តាមសំឡេងរបស់គាត់ ហើយគោរពតាមការណែនាំរបស់គាត់ យើងនឹងអាចរស់នៅដូចដែលព្រះគ្រីស្ទចង់ឲ្យយើងរស់នៅ ហើយស៊ូទ្រាំដល់ទីបញ្ចប់ដើម្បីនៅថ្ងៃមួយ យើងជាមួយនឹងគ្រួសាររបស់យើងនឹងត្រឡប់ទៅកាន់វត្តមាននៃព្រះវរបិតាសួគ៌របស់យើង និង ព្រះអង្គសង្គ្រោះយេស៊ូវគ្រីស្ទ » (" Hear the Prophet's Voice and Obey ," *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៥ ឆ្នាំ ១៧) ។

សូមបញ្ចប់មេរៀននេះដោយការថ្លែងទីបន្ទាល់ពីសេចក្តីសុខសាន្ត និង សុវត្ថិភាពខាងវិញ្ញាណដែលមកពីការធ្វើតាមការប្រឹក្សានៃអ្នកបម្រើរបស់ព្រះអម្ចាស់ ។

ការរំឭកចំណោះចំណានខគម្ពីរ

ប្រសិនបើមានពេល អ្នករាចរំឭកវគ្គចំណោះចំណានខគម្ពីរដែលអ្នកបានបង្រៀនកន្លងមកនៅឆ្នាំនេះ ដើម្បីជួយសិស្សឲ្យចងចាំពាក្យគន្លឹះនៅក្នុងវគ្គនីមួយៗ ។

សូមឲ្យសិស្សរំឭកវគ្គចំណោះចំណានខគម្ពីរដែលពួកគេបានរៀនកន្លងមកក្នុងឆ្នាំសិក្សានេះពីរបីនាទី ។ សូមឲ្យសិស្សម្នាក់មកខាងមុខថ្នាក់ជាមួយនឹងព្រះគម្ពីររបស់គេ ។ សូមឲ្យសិស្សបើកទៅវគ្គចំណោះចំណានខគម្ពីរមួយ ដោយមិនបង្ហាញវាដល់នរណាផ្សេងទៀត ។ (ប្រសិនបើមានកាតចំណោះចំណានខគម្ពីរ អ្នកអាចឲ្យសិស្សប្រើវា ។) សូមឲ្យសិស្សសរសេរពាក្យមួយពីវគ្គចំណោះចំណានខគម្ពីរនៅលើក្តារខៀន ។ (សូមលើកទឹកចិត្តសិស្សឲ្យជ្រើសរើសពាក្យគន្លឹះពីវគ្គ ជាជាងការបំបែកពាក្យឲ្យតិចដូចជា *និង* ឬ *។*សូមឲ្យសិស្សផ្សេងទៀតរកក្នុងព្រះគម្ពីររបស់ពួកគេនូវវគ្គចំណោះចំណានខគម្ពីរដែលពួកគេគិតពីពាក្យដែលចេញមកនោះ ។ ប្រសិនបើគ្មាននរណាអាចរកវគ្គត្រូវដោយប្រើពាក្យមួយនោះទេ សូមឲ្យសិស្សសរសេរពាក្យផ្សេងទៀតពីវគ្គចំណោះចំណានខគម្ពីរនៅលើក្តារខៀន ។ សូមធ្វើដូច្នេះដដែល រហូតដល់យ៉ាងហោចណាស់សិស្សម្នាក់រកឃើញវគ្គដែលត្រូវ ។ សូមឲ្យសិស្សទាំងអស់ក្នុងថ្នាក់ផ្សេងទៀតបើកទៅវគ្គនោះ ហើយសូមឲ្យសិស្សទន្ទេញវាអូមគ្នា ។ បន្ទាប់មក សូមធ្វើសកម្មភាពនេះសារឡើងវិញជាមួយនឹងសិស្សផ្សេងទៀត ហើយពីរសាវគ្គចំណោះចំណានខគម្ពីរផ្សេងទៀត ។

ម៉ូសាយ ២១–២២

សេចក្តីផ្តើម

ក្រោយពីបរាជ័យបីដងក្នុងការរំដោះខ្លួនគេពីសេវកភាពនៃសាសន៍លេមិន នៅទីបញ្ចប់ ប្រជាជនរបស់លិមហៃបានបែរទៅរកព្រះអម្ចាស់ឲ្យដោះលែងពួកគេ ។ ក្រោយមក អាំម៉ូន និង បងប្អូនប្រុសរបស់គាត់បានមកដល់ក្នុងដែនដីលីហៃ-នីហ្វៃ ។ ក្រោយពី ការធ្វើសេចក្តីសញ្ញាថានឹងបម្រើដល់ព្រះអម្ចាស់ ប្រជាជនរបស់លិមហៃបានគេចចេញពី សេវកភាពរបស់សាសន៍លេមិន ហើយអាំម៉ូនបានដឹកនាំពួកគេទៅសារ៉ាហិមឡា ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ២១:១–២២

ក្រោយពីប្រជាជនរបស់លិមហៃបះបោរប្រឆាំងនឹងសាសន៍លេមិន ហើយត្រូវបានបង្ក្រាបបីដងមក ពួកគេបានបន្ទាបខ្លួនចំពោះមុខព្រះអម្ចាស់ ហើយចាប់ផ្តើមវិលត្រឡប់

សូមសរសេរពាក្យ *ការជាប់ឃុំឃាំង* និង *ការដោះលែង* នៅលើក្តារខៀន ។

- តើអ្នកស្រមៃពីអ្វីនៅពេលអ្នកគិតពីពាក្យទាំងនេះ ?
- តើអារម្មណ៍អ្វីដែលអ្នកគិតដល់ ដែលទាក់ទងនឹងពាក្យទាំងនេះ ?
- តើពាក្យទាំងនេះអាចមានអ្វីខ្លះ ដែលទាក់ទងនឹងដែនការនៃសេចក្តីសង្គ្រោះ ?

សូមពន្យល់ថា ម៉ូសាយ ២១–២៤ រួមមានដំណើររឿងនៃក្រុមមនុស្សពីរក្រុមដែលស្ថិតក្នុងការជាប់ឃុំឃាំងដល់កម្លាំងនៃសាសន៍លេមិន ហើយទីបំផុតត្រូវបានដោះលែងដោយព្រះអម្ចាស់ ។ នៅក្នុង ម៉ូសាយ ២១–២២ យើងអានអំពីលិមហៃ និង ប្រជាជនរបស់គាត់ ដែលធ្លាក់ក្នុងសេវកភាព ដែលជាលទ្ធផលនៃអំពើទុច្ចរិតរបស់ពួកគេ ។ ការជាប់ឃុំឃាំងខាងសាច់ឈាមរបស់ពួកគេឆ្លុះបញ្ចាំងពីការជាប់ឃុំឃាំងខាងវិញ្ញាណដែលពួកគេទទួលដោយសារតែអំពើបាបរបស់ពួកគេ ។ ដំណើររឿងនៃក្រុមទីពីរនេះ នៅក្នុង ម៉ូសាយ ២៣–២៤ នឹងមាននៅមេរៀនបន្ទាប់ទៀត ។ វាប្រាប់ពីប្រជាជនរបស់អាលម៉ា ដែលទទួលបទពិសោធន៍នៃការជាប់ឃុំឃាំង និង សេចក្តីទុក្ខវេទនា ក្រោយពីពួកគេទទួលបុណ្យជ្រមុជទឹក ។ រឿងទាំងពីរបង្រៀនពីសេចក្តីពិតដ៏សំខាន់អំពីព្រះចេស្តារបស់ព្រះអម្ចាស់ ក្នុងការដោះលែងយើងពីអំពើបាប និង សេចក្តីទុក្ខវេទនា ។ សូមលើកទឹកចិត្តសិស្សឲ្យគិតអំពីព្រះចេស្តារបស់ព្រះអម្ចាស់ក្នុងការដោះលែងយើងចេញពីអំពើបាប នៅពេលពួកគេសិក្សាពីការជាប់ឃុំឃាំង និង ការដោះលែងរបស់ប្រជាជននៅក្នុង ម៉ូសាយ ២១–២២ ។

សូមឲ្យសិស្សអាន ម៉ូសាយ ២១:២–៦ ស្ងាត់ៗ ។ សូមឲ្យពួកគេរកមើលពាក្យ និង ឃ្លាដែលពិពណ៌នាពីអ្វីដែលលិមហៃនិងប្រជាជនរបស់គាត់ជួប និងពីអារម្មណ៍ដែលពួកគេមានអំពីវា ។ សូមបញ្ជាក់ពីការលំបាកដែលប្រជាជនរបស់លិមហៃបានជួប អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំឃ្លា « ហើយគ្មានផ្លូវណាដែលគេអាចដោះខ្លួន » នៅក្នុង ម៉ូសាយ ២១:៥ ។

- តើសេចក្តីលម្អិតអ្វីខ្លះនៅក្នុង ម៉ូសាយ ២១:៦ ស្នើថា ប្រជាជនមិនទាន់បានបន្ទាបខ្លួនគេ ហើយបែរទៅរកព្រះអម្ចាស់នោះ ?
- តើដំណោះស្រាយអ្វីដែលប្រជាជនរបស់លិមហៃស្នើដើម្បីស្វែងរកការធូរស្បើយពីសេចក្តីទុក្ខវេទនារបស់ពួកគេ ?

សូមសង្ខេប ម៉ូសាយ ២១:៧–១២ ដោយការប្រាប់សិស្សថា ប្រជាជនរបស់លិមហៃបានទៅច្បាំងបីដងដើម្បីដោះលែងខ្លួនគេពីសាសន៍លេមិន ប៉ុន្តែពួកគេបានចាញ់ ហើយរងទុក្ខនឹងការចាត់បង់ដ៏ច្រើនរាល់ដង ។

- តើមានផ្លូវណាខ្លះ ដែលប្រជាជនអាចធ្វើក្រោយពីបំណងមិនបានជោគជ័យលើកទីបីរបស់ពួកគេក្នុងការដោះលែងខ្លួនគេនោះ ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី ម៉ូសាយ ២១:១៣–១៦ ដើម្បីរៀនពីរបៀបដែលប្រជាជនបានឆ្លើយតប ។ សូមពិចារណាពីការសួរសំណួរខាងក្រោមនេះមួយចំនួន ឬ ទាំងអស់ ៖

- តើប្រជាជនបានផ្លាស់ប្តូរដោយរបៀបណា ក្រោយពីការបរាជ័យលើកទីបីរបស់ពួកគេ ?
- យោងតាម ម៉ូសាយ ២១:១៥ ហេតុអ្វីបានជាព្រះអម្ចាស់ក្រនឹងឮការអធិស្ឋានរបស់ពួកគេ ?
- នៅក្នុង ម៉ូសាយ ១១:២៣–២៥ តើអំប៉ិលណាដៃបានប្រាប់អ្វីដល់ប្រជាជន ថាពួកគេនឹងត្រូវធ្វើមុនពេលព្រះអម្ចាស់នឹងឮដល់ការអធិស្ឋានរបស់ពួកគេឲ្យដោះលែងនោះ ?
- ទោះបីជាប្រជាជនមិនត្រូវបានដោះលែងដោយភ្លាមៗពីការជាប់ឃុំឃាំងក្តី តើព្រះអម្ចាស់បានប្រទានពរដល់ពួកគេ នៅពេលពួកគេចាប់ផ្តើមប្រែចិត្តដោយរបៀបណា ? (នៅពេលសិស្សឆ្លើយ សូមលើកទឹកចិត្តពួកគេឲ្យគូសចំណាំឃ្លា « ចាប់ផ្តើមចម្រើនឡើងបន្តិចម្តងៗ » នៅក្នុង ម៉ូសាយ ២១:១៦ ។)
- តើការណ៍នេះបង្រៀនអ្វីខ្លះ អំពីអ្វីដែលព្រះអម្ចាស់នឹងធ្វើនៅពេលប្រជាជនបន្ទាបខ្លួនគេ ចាប់ផ្តើមប្រែចិត្ត និង សុំជំនួយពីទ្រង់ ?

សូមសង្ខេប ម៉ូសាយ ២១:១៦–២២ ដោយការពន្យល់ថា អំឡុងពេលដែលប្រជាជនរបស់លីមហៃស្ថិតក្នុងសេរភាព ព្រះអម្ចាស់បានចម្រើនពួកគេដើម្បីឲ្យពួកគេមិនសេក្រឃ្លាន ។ ព្រមទាំងគ្មាន « ការអំខានឆាឆៅគ្នារវាងពួកលេមិន និងប្រជាជនរបស់លីមហៃទៀតឡើយ » (ម៉ូសាយ ២១:២២) ។

សូមឲ្យសិស្សនិយាយពីគោលការណ៍ដែលពួកគេបានរៀនពីដំណើររឿងនៃប្រជាជនរបស់លីមហៃ ។ ទោះបីជាសិស្សអាចចែកចាយគោលការណ៍ខុសគ្នាក្តី សូមប្រាកដថា ពួកគេយល់ថា **នៅពេលយើងបន្ទាបខ្លួនយើង អំពាវនាវដល់ព្រះអម្ចាស់ ហើយប្រែចិត្តពីអំពើបាបរបស់យើង ទ្រង់នឹងឮការអធិស្ឋានរបស់យើង ហើយបញ្ឈប់បន្ទុកនៃអំពើបាបរបស់យើងតាមពេលវេលារបស់ទ្រង់ផ្ទាល់ ។**(អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន ។ អ្នកក៏អាចឲ្យសិស្សសរសេរនៅក្នុងព្រះគម្ពីរបស់ពួកគេក្បែរ ម៉ូសាយ ២១:១៥–១៦ ឬ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ) ។

- តើអ្នកគិតថា យើងអាចទទួលបានប្រយោជន៍ពីការរង់ចាំឲ្យព្រះអម្ចាស់ដោះលែងយើងពីបន្ទុកនៃអំពើបាបរបស់យើងយ៉ាងដូចម្តេច ?

ដើម្បីជួយសិស្សឲ្យអនុវត្តអ្វីដែលពួកគេបានរៀន សូមឲ្យពួកគេគិតពីសំណួរខាងក្រោមនេះមួយសន្ទុះ ហើយសរសេរចម្លើយនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរបស់ពួកគេ ។ (អ្នកអាចសរសេរសំណួរនៅលើក្តារខៀន) ។

- តើអ្នកធ្វើអ្វី ដើម្បីស្វែងរកព្រះចេស្តារបស់ព្រះអម្ចាស់ដើម្បីដោះលែងពីអំពើបាបរបស់អ្នក ?
- តើអ្នកត្រូវបាន « ចម្រើនឡើងបន្តិចម្តងៗ » តាមរបៀបណាខ្លះ នៅពេលអ្នកបានស្វែងរកជំនួយរបស់ព្រះអម្ចាស់ ?

ម៉ូសាយ ២១:២៣–២២:១៦

លីមហៃ អាំម៉ូន និង គេឌានបានសាមគ្គីគ្នាដើម្បីជួយប្រជាជនឲ្យរួចផុតពីសេរភាព និង ត្រឡប់ទៅដែនដីសាភ៉ាហិមឡាវិញ

កំណត់ចំណាំ ៖ អ្នកអាចរំឭកសិស្សថា ម៉ូសាយ ៧ និង ៨ រួមមាននូវដំណើររឿងអំពីអាំម៉ូន និងបងប្អូនប្រុសរបស់គាត់ក្នុងការស្វែងរកស្តេចលីមហៃ និងប្រជាជនរបស់គាត់ ។ ជំពូក ១៤ បន្ទាប់ទៀត ម៉ូសាយ ៩–២២ ប្រាប់ពីប្រវត្តិសាស្ត្រនៃប្រជាជនរបស់លីមហៃ ដោយចាប់ផ្តើមប្រមាណជា ៨០ ឆ្នាំមុនពេលអាំម៉ូនបានរកឃើញពួកគេ ។ ប្រវត្តិសាស្ត្រនេះបញ្ចប់ដោយការប្រាប់ជាថ្មីពីហេតុការណ៍ខ្លះដែលមាននៅក្នុងជំពូកមុនៗ ។ ដោយសារមូលហេតុនេះហើយ បរិបទភាគច្រើននៃ ម៉ូសាយ ២១:២៣–៣០ មាននៅក្នុងមេរៀនអំពី ម៉ូសាយ ៧–៨ និង ម៉ូសាយ ១៨ ។ ដើម្បីជួយសិស្សឲ្យចងចាំពីហេតុការណ៍ដែលបានកត់ត្រានៅក្នុង ម៉ូសាយ ២១:២៣–៣០ វាអាចផ្តល់ជាអត្ថប្រយោជន៍ដល់អ្នកក្នុងការរំឭកដោយខ្លីៗនៃការធ្វើដំណើរទាំងមូលក្នុង ម៉ូសាយ ៧–២៤ នៅក្នុងសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។

សូមរំឭកសិស្សថា ប្រជាជនរបស់លីមហៃទទួលស្គាល់ថា សេចក្តីទុក្ខវេទនារបស់ពួកគេមកពីពួកគេបានបដិសេធការអញ្ជើញរបស់ព្រះអម្ចាស់ឲ្យប្រែចិត្ត (សូមមើល ម៉ូសាយ ១២:១–២; ២០:២១) ។ ដោយចំណេះដឹងអំពីអំពើបាបរបស់ពួកគេនេះ ប្រជាជនរបស់លីមហៃបានចាប់ផ្តើមដំណើរការនៃការប្រែចិត្ត និង ការប្រែចិត្តជឿ ។ សូមចែកចាយនិយមន័យខាងក្រោមនៃការប្រែចិត្ត ៖

« [ការប្រែចិត្ត] គឺសំខាន់ចំពោះសុភមង្គលរបស់អ្នកនៅក្នុងជីវិតនេះ និង ពេញទាំងភាពអស់កល្ប ។ ការប្រែចិត្តគឺជាសំខាន់ជាងការគ្រាន់តែដឹងពីការធ្វើខុស ។ វាជាការផ្លាស់ប្តូរនៃចិត្ត និងគំនិត ។ . . . វាមានការបែរចេញពីអំពើបាប ហើយទៅរកព្រះសុំការអភ័យទោស ។ វាត្រូវបានជម្រុញដោយសេចក្តីស្រឡាញ់ដល់ព្រះ និង បំណងដ៏ស្មោះត្រង់ក្នុងការគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ » (*ពិតចំពោះសេចក្តីជំនឿ ៖ សេចក្តីយោងនៃដំណឹងល្អ* [ឆ្នាំ ២០០៤ [ទំព័រ ១៣២) ។

សូមឲ្យសិស្សអាន ម៉ូសាយ ២១:៣២–៣៥ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរក ៣ក្យ និង ឃ្លាដែលបង្ហាញថា លីមហៃ និង ប្រជាជនរបស់គាត់បានប្រែចិត្ត ហើយបែរផ្លូងចិត្តរបស់ពួកគេទៅរកព្រះអម្ចាស់ ។ អ្នកអាចស្នើថា ពួកគេគូរគូសចំណាំ ៣ក្យ និង ឃ្លាទាំងនេះ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីដែលពួកគេរកឃើញ ។ (ចម្លើយរបស់ពួកគេអាចរួមមាន លីមហៃ និង ប្រជាជនរបស់គាត់ជាច្រើនបានចូលទៅក្នុងសេចក្តីសញ្ញាដើម្បីបម្រើព្រះ ហើយកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ ថាពួកគេចង់ទទួលបុណ្យជ្រមុជទឹក ហើយថាពួកគេនឹងបម្រើព្រះដោយអស់ពីចិត្តរបស់ពួកគេ) ។

សកម្មភាពខាងក្រោមនឹងជួយសិស្សឲ្យឃើញថា ព្រះអម្ចាស់បានជួយប្រជាជនរបស់លីមហៃឲ្យរួចពីសេរភាព នៅពេលពួកគេគោរពដល់សេចក្តីសញ្ញាក្នុងការបម្រើដល់ទ្រង់ ហើយកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ ។ សូមសរសេរសំណួរខាងក្រោម និង សេចក្តីយោងព្រះគម្ពីរនៅលើក្តារខៀនមុនចាប់ផ្តើមថ្នាក់ ។

តើការមកដល់របស់អាំម៉ូន និង បងប្អូនប្រុសរបស់គាត់ជាចម្លើយមួយដល់ការអធិស្ឋានរបស់ប្រជាជនលីមហៃដោយរបៀបណា ? (សូមមើល ម៉ូសាយ ៧:១៨–១៩, ១៨–២០; ២១:១៤–១៥, ២២–២៤) ។

បន្ថែមលើការស្វែងរកជំនួយរបស់ព្រះអម្ចាស់តាមរយៈការអធិស្ឋាន តើប្រជាជនរបស់លីមហៃបានធ្វើអ្វីខ្លះ ដោយការដឹកនាំពីគេឌានដើម្បីបានដោះលែង ? (សូមមើល ម៉ូសាយ ២១:៣៦; ២២:១–១០) ។

តើសេចក្តីលម្អិតអ្វីខ្លះនៅក្នុងខគម្ពីរទាំងនេះ ដែលបង្ហាញថាព្រះអម្ចាស់បានជួយដល់ប្រជាជនរបស់លីមហៃឲ្យរួចខ្លួនដោយសុវត្ថិភាព ? (សូមមើល ម៉ូសាយ ២២:១១–១៦; ២៥:១៥–១៦) ។

សូមបែងចែកសិស្សជាបីក្រុម ។ សូមឲ្យក្រុមនីមួយៗរៀបចំឆ្លើយនឹងសំណួរមួយនៅលើក្តារខៀនដោយការសិក្សាវគ្គព្រះគម្ពីរដែលមាននោះ ។ ពីរបីនាទីក្រោយមក សូមឲ្យសិស្សម្នាក់ពីក្រុមនីមួយៗរាយការណ៍ពីចម្លើយដែលពួកគេបានរៀបចំ ។ ការណ៍នេះក៏នឹងជាពេលល្អមួយដើម្បីឲ្យសិស្សបន្ថែម « ប្រជាជនរបស់លិមហៃរត់ចេញ » ទៅលើឪយ៉ាក្រាមរបស់ពួកគេអំពីសេចក្តីសង្ខេបនៃការធ្វើដំណើរនៅក្នុង ម៉ូសាយ ៧–២៤ ។ (សម្រាប់ឪយ៉ាក្រាមពេញលេញ សូមមើលសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។) អ្នកក៏អាចឲ្យសិស្សបើកទៅប្រដាប់ដាក់ក្នុងព្រះគម្ពីរមរមនដើម្បីរកអ្វីដែលនឹងកើតឡើងនៅទីបញ្ចប់ដល់ប្រជាជនរបស់លិមហៃ (សូមមើល ម៉ូសាយ ២២:១៣–១៤) ។

សូមបង្ហាញថា ខណៈពេលយើងមិនត្រូវការស្វែងរកការដោះលែងពីសេរភាពខាងសាច់ឈាម ដូចជាប្រជាជនរបស់លិមហៃ យើងទាំងអស់គ្នាត្រូវការការដោះលែងពីអំពើបាប ។

- តើអ្នកបានរៀនអ្វីខ្លះពី ម៉ូសាយ ២១–២២ ដែលនឹងផ្តល់ការលើកទឹកចិត្តដល់នរណាម្នាក់ដែលត្រូវទទួលបទពិសោធន៍ពីព្រះចេស្តានៃព្រះអម្ចាស់ដើម្បីដោះលែងយើងពីអំពើបាប ?

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីព្រះចេស្តានៃព្រះអម្ចាស់ដើម្បីដោះលែងយើងពីអំពើបាប ។ សូមបញ្ជាក់ថា នៅពេលយើងបន្ទាបខ្លួន ស្រែកហៅរកព្រះអម្ចាស់ ហើយប្រែចិត្តពីអំពើបាបរបស់យើង ទ្រង់នឹងឮការអធិស្ឋានរបស់យើង ហើយបញ្ឈប់បន្ទុកនៃអំពើបាបរបស់យើងតាមពេលវេលារបស់ទ្រង់ផ្ទាល់ ។

សេចក្តីសង្ខេបនៃការធ្វើដំណើរនៅក្នុង ម៉ូសាយ ៧–២៤



វិចារណកថា និង ព័ត៌មានសាច់រឿង

ម៉ូសាយ ២១:១៥, ២៩–៣០ ។ ការរងទុក្ខដែលមកពីអំពើបាប អាចបម្រើដល់គោលបំណង

នៅពេលយើងបដិសេធអំពើបាប ហើយបដិសេធមិនព្រមប្រែចិត្ត ដូចជាប្រជាជនរបស់ស្តេចលិមហៃ យើងនាំមកនូវការឈឺចាប់បន្ថែមដល់ខ្លួនយើង —ពេលខ្លះខាងរាងកាយ ហើយជានិច្চកាលខាងវិញ្ញាណផងដែរ ។ អែលឌើរ ឌេន អេហ្វ រីឆាត នៃក្រុមចិតសិបនាក់បានពន្យល់ពីរបៀបដែលការឈឺចាប់អាចជាផ្នែកចាំបាច់មួយនៃការព្យាបាល និង ការធំធាត់ខាងវិញ្ញាណរបស់យើង ។

« ការឈឺចាប់គឺជាខ្នាតនៃដំណើរការព្យាបាល ។ ជាញឹកញាប់ វាបង្រៀនយើងពីការអត់ធ្មត់ ។ . . .

« អែលឌើរ អូសុន អែហ្វ វិតនី បានសរសេរថា ៖ ‹ គ្មានការឈឺចាប់ដែលយើងរងទុក្ខ គ្មានការសោកល្បួងដែលយើងទទួលបទពិសោធន៍ក្លាយជាឥតប្រយោជន៍នោះទេ ។ វាជួយផ្គត់ផ្គង់ដល់ការអប់រំរបស់យើង ដល់ការអភិវឌ្ឍនៃគុណសម្បត្តិដូចជា ការអត់ធ្មត់ សេចក្តីជំនឿ ការរឹងប៉ឹង និង ការបន្ទាបខ្លួន ។ . . . វាតាមរយៈសេចក្តីសោកសៅ និងការរងទុក្ខ ការលំបាក និង ទុក្ខព្រួយ ដែលយើងទទួលបានការអប់រំដែលយើងមកទីនេះដើម្បីទទួល ។ ›

« ដូចគ្នាដែរ អែលឌើរ រ៉ូបឺត ឌី ហែល បានមានប្រសាសន៍ថា ៖

« ការឈឺចាប់ធ្វើឲ្យយើងមានការបន្ទាបខ្លួន ដែលធ្វើឲ្យយើងសញ្ជឹងគិត ។ វាជាបទពិសោធន៍មួយដែលខ្ញុំមានសេចក្តីអំណរដែលបានសូទ្រាំ ។ . . .

« ‹ ខ្ញុំបានដឹងថា ការឈឺចាប់ខាងសាច់ឈាម និង ការព្យាបាលខាងរាងកាយ . . . គឺមានភាពស្រដៀងគ្នាយ៉ាងខ្លាំងនឹងការឈឺចាប់ខាងវិញ្ញាណ និង ការព្យាបាលដល់ព្រលឹងតាមដំណើរការនៃការប្រែចិត្ត › » (« ជង្វាយធួនព្យាបាលរាល់ការឈឺចាប់ទាំងអស់ » *Ensign* ឬ *លេអាហូណា* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ១៥) ។

ម៉ូសាយ ២១:១៥–១៦ ។ តើអាកប្បកិរិយារបស់អ្នកមានអ្វីខ្លះ អំឡុងពេលទុក្ខវេទនា ?

អែលឌើរ រីឆាត ជី ស្កត នៃក្រុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនអំពីអាកប្បកិរិយាដែលយើងគួរខិតខំចៀសវាង និង អាកប្បកិរិយាដែលយើងគួរខិតខំអភិវឌ្ឍអំឡុងពេលទុក្ខវេទនារបស់យើង ៖

« ព្រះអម្ចាស់នឹងផ្តល់ការធូរស្បើយដោយព្រះចេស្តាដ៏ទេវភាព នៅពេលអ្នកស្វែងរកការដោះលែងដោយការបន្ទាបខ្លួ និង *សេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ* ។

« សូមកុំនិយាយថា ‹ គ្មាននរណាម្នាក់យល់ពីចិត្តខ្ញុំទេ ; ខ្ញុំមិនអាចដោះស្រាយបានទេ ឬ ខ្ញុំមិនអាចទទួលបានជំនួយដែលខ្ញុំត្រូវការទេ › ។ សម្តីទាំងនេះគឺជាការបរាជ័យផ្ទាល់ខ្លួន ។ គ្មាននរណាម្នាក់អាចជួយអ្នក ដោយគ្មានសេចក្តីជំនឿ និងការខិតខំប្រឹងពីខាងផ្នែកអ្នកនោះទេ ។ ការធំធាត់ផ្ទាល់ខ្លួនរបស់អ្នកត្រូវការវា ។ សូមកុំស្វែងរកជីវិតដ៏មានសើរភាពមួយចេញពីការមិនស្រណុកស្រួល ការឈឺចាប់ មានសម្ពាធ ឧបសគ្គ ឬ ទុក្ខសោក សម្រាប់អ្នកដែលជាឧបករណ៍ដែលព្រះវរបិតាដ៏ទីស្រឡាញ់ប្រើដើម្បីបណ្តុះការធំធាត់ និង ការយល់ដឹងផ្ទាល់ខ្លួនរបស់យើងឡើយ ។ ដូចដែលព្រះគម្ពីរបញ្ជាក់ម្តងហើយម្តងទៀតយ៉ាងជាក់ច្បាស់ថា អ្នកនឹងទទួលបានជំនួយ នៅពេលអ្នកអនុវត្ត*សេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ* ។ . . . សេចក្តីជំនឿទៅលើព្រះគ្រីស្ទមានន័យថា យើងទុកចិត្តទ្រង់ យើងទុកចិត្តលើការបង្រៀនរបស់ទ្រង់ ។ ការណ៍នោះនាំទៅរកក្តីសង្ឃឹម ហើយក្តីសង្ឃឹមនាំមកនូវសប្បុរសធម៌ សេចក្តីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ —អារម្មណ៍ដ៏សន្តិភាពនោះ ដែលមកនៅពេលយើងមានអារម្មណ៍ពីការបារម្ភរបស់ទ្រង់ ក្តីស្រឡាញ់របស់ទ្រង់ និង សមត្ថភាពរបស់ទ្រង់ក្នុងការព្យាបាលយើង ឬ បញ្ឈប់បន្ទុករបស់យើងដោយព្រះចេស្តាព្យាបាលរបស់ទ្រង់ » (" To Be Healed ," *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៤ ទំព័រ ៨) ។

ម៉ូសាយ ២៣–២៤

សេចក្តីផ្តើម

ក្រោយពីអាលម៉ា និង ប្រជាជនរបស់គាត់បានរួចចេញពីកងទ័ពរបស់ស្តេចណូអេ ពួកគេបានបង្កើតទីក្រុងដ៏សុចរិតមួយ ។ ទោះបីជាពួកគេបានក្លាយជាអ្នកប្រែចិត្តដល់ដំណឹងល្អក្តី ពួកគេជួបនូវសេចក្តីទុក្ខវេទនា និងឧបសគ្គ ។ សាសន៍លេមិនបានដាក់ពួកគេក្នុងសេរីភាព ។ នៅពេលអាលម៉ា និង ប្រជាជនរបស់គាត់អនុវត្តសេចក្តីជំនឿ និងការអត់ធ្មត់ ព្រះអម្ចាស់បានបញ្ឈប់បន្ទុករបស់ពួកគេ ហើយទីបញ្ចប់បានដោះលែងពួកគេចេញពីសេរីភាព ។ (សូមកត់ចំណាំថា ម៉ូសាយ ២៣–២៤ មានរយៈពេលប្រហែលគ្នានឹង ម៉ូសាយ ១៩–២២ ដែរ ។)

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ២៣:១–២០

ព្រះអម្ចាស់បានជួយដល់អាលម៉ា និង ប្រជាជនរបស់ទ្រង់ឲ្យរត់ចេញពីកងទ័ពរបស់ស្តេចណូអេ ហើយស្ថាបនាទីក្រុងដ៏សុចរិតមួយឡើង

សូមបង្ហាញរូបភាពអាលម៉ាជ្រមុជទឹកនៅក្នុងទឹកនៃមរមនដល់សិស្ស (៦២៣៣២; *សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ | លេខ ៧៦) ។ សូមឲ្យសិស្សម្នាក់ប្រាប់ដល់ថ្នាក់ពីអ្វីដែលគេស្គាល់បុរសដែលជ្រមុជទឹកឲ្យអ្នកផ្សេងនៅក្នុងរូបភាពនោះ ។ (ប្រសិនបើសិស្សពិបាកឆ្លើយ អ្នកអាចស្នើថា ពួកគេគួរអានការសង្ខេបក្នុងជំពូកនៃ ម៉ូសាយ ១៨ ដើម្បីរំឭកពួកគេពីរឿងរបស់អាលម៉ា និងប្រជាជនរបស់គាត់នៅឯទឹកនៃមរមន) ។

សូមឲ្យសិស្សធ្វើការជាដៃគូ ។ សូមឲ្យដៃគូនីមួយៗប្តូរវេនគ្នាអានឲ្យគ្នាស្តាប់ទៅវិញទៅមកចាប់ពី ម៉ូសាយ ២៣:១–៥, ១៩ ។ សូមឲ្យពួកគេរកមើលឃ្លាដែលបង្ហាញពីរបៀបដែលព្រះអម្ចាស់ប្រទានពរដល់អាលម៉ា និង ប្រជាជនរបស់គាត់ នៅពេលពួកគេបានប្រែចិត្ត ហើយជ្រើសរើសដើម្បីរស់នៅដោយសុចរិត ។ (អ្នកអាចស្នើថា ពួកគេគួរគូសចំណាំឃ្លាទាំងនេះ) ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។

សេចក្តីសង្ខេបនៃការធ្វើដំណើរនៅក្នុង ម៉ូសាយ ៧–២៤



សូមឲ្យសិស្សមើលទៅឌីយ៉ាក្រាមរបស់ពួកគេដែលបង្ហាញពីសេចក្តីសង្ខេបនៃការធ្វើដំណើរនៅក្នុង ម៉ូសាយ ៧–២៤ ។ សូមណែនាំពួកគេឲ្យគូសដែនដីហេឡាម នៅលើឌីយ៉ាក្រាមរបស់ពួកគេក្នុងកន្លែងសមរម្យលួម ។ សូមឲ្យពួកគេគូសសញ្ញាព្រួញមួយពីទឹកនៃមរមនទៅដែនដីហេឡាមជាងដែរ ហើយសូមឲ្យពួកគេសរសេរលើព្រួញនេះថា « អាលម៉ា និង ប្រជាជនរបស់គាត់ចាកចេញ » ។ (សម្រាប់ឌីយ៉ាក្រាមពេញលេញ សូមមើលទៅសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ) ។

សូមពន្យល់ដោយខ្លីៗថានៅក្នុង ម៉ូសាយ ២៣:៦–១៤ យើងអានថា អាលម៉ាបានបដិសេធសំណើររបស់ប្រជាជនគាត់ថា គាត់គឺជាស្តេចរបស់ពួកគេ ។ សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២៣:៩–១០, ១២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលការពិពណ៌នារបស់អាលម៉ាអំពីឥទ្ធិពលដែលស្តេចណូអេបានមានលើគាត់ និង ប្រជាជនរបស់គាត់ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។

- តើឃ្លា « ធ្លាក់ទៅក្នុងអន្ទាក់ » និង « ជាប់ចំណងទាំងឡាយនៃអំពើទុច្ចរិត » បង្រៀនអ្វីខ្លះអំពីឥទ្ធិពលនៃអំពើបាប ?
- ហេតុអ្វីបានជាវាជួយដល់យើង ពេលយើងស្គាល់ពីឥទ្ធិពលដែលបានដឹកនាំយើងឲ្យធ្វើបាបក្នុងអតីតកាល ?
- ក្រោយពីយើងប្រែចិត្ត ហេតុអ្វីបានជាវាអាចជាការសំខាន់ដើម្បីចាំពីការប្រែចិត្តមាន « ការឈឺចាប់ » ប៉ុណ្ណោះ ?

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២៣:១៣ ឮៗ ។ សូមបង្ហាញពីការប្រឹក្សារបស់អាលម៉ាឲ្យ « ឈរឲ្យរឹងប៉ឹងក្នុងឥស្សរភាពនេះដែលធ្វើឲ្យអ្នករាល់គ្នាមានសេរីដោយ៉ាងនោះដែរ » ។

- តើការប្រឹក្សានេះអនុវត្តដល់ដំណើរការនៃការប្រែចិត្តដោយរបៀបណា ? (សូមជួយសិស្សឲ្យយល់ថា នៅពេលព្រះអម្ចាស់បានដោះលែងយើងពីអំពើបាប ហើយយើងទទួលបានសេរីភាពនៃការអភ័យទោស យើងត្រូវតែរើសយកជម្រើសសុចរិតដើម្បីបន្តសេរីភាពនេះ) ។

សូមឲ្យសិស្សអាន ម៉ូសាយ ២៣:១៤–១៨ ដោយស្ងាត់ស្ងៀម ដោយរកមើលរឿងខ្លះដែលអាលម៉ាបានបង្រៀនដល់ប្រជាជនឲ្យធ្វើដើម្បីបន្តសេរីភាពរបស់ពួកគេ ។ សូមឲ្យសិស្សពីរបីនាក់រាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២៣:១៩–២០ ឮៗ ។ សូមឲ្យសិស្សរកមើលឃ្លាដែលបង្ហាញថា ព្រះអម្ចាស់បានប្រទានពរដល់ប្រជាជន នៅពេលពួកគេបានជ្រើសរើសដើម្បីរស់នៅដោយសុចរិត (« ចម្រើនឡើងជាអតិបរមា ») ។

- តើអ្នកនឹងសង្ខេបពីអ្វីដែលអ្នកបានរៀនពីបទពិសោធន៍របស់អាលម៉ា និង ប្រជាជនរបស់គាត់ដោយរបៀបណា ? (ក្នុងចំណោមសេចក្តីពិតផ្សេងទៀត សិស្សអាចនិយាយថា **នៅពេលយើងប្រែចិត្ត ហើយជ្រើសរើសរស់នៅដោយសុចរិត ព្រះអម្ចាស់នឹងប្រទានពរដល់យើង ហើយឲ្យយើងមានសេរីភាពពីចំណងនៃសេចក្តីទុក្ខវិតទាំងឡាយ ។**)
- តើអ្នកបានឃើញពីគោលការណ៍នេះត្រូវបានបំពេញនៅក្នុងជីវិតរបស់អ្នក ឬ ជីវិតរបស់មិត្តភក្តិ ឬ សមាជិកគ្រួសារអ្នកនៅពេលណា ? (សូមរំឭកសិស្សថា ពួកគេមិនចាំបាច់ចែកចាយពីបទពិសោធន៍ដែលផ្ទាល់ខ្លួន ឬ ឯកជនពេកនោះទេ ។)

ម៉ូសាយ ២៣:២១–២៩

កងទ័ពលេមិន និង ពួកសង្ឃដ៏ទុច្ចរិតរបស់ស្តេចណូអេបានដាក់អាលម៉ា និង ប្រជាជនរបស់គាត់ក្នុងសេវកភាព ។

ដើម្បីជួយសិស្សឲ្យយល់ថា អ្នកដែលសុចរិតត្រូវតែបន្តជួបនឹងឧបសគ្គ សូមឲ្យសិស្សគិតពីពេលមួយក្នុងជីវិតរបស់ពួកគេ នៅពេលពួកគេអាចភ្ជាប់នឹងសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រីឆាត ជី ស្តុត នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ការសាកល្បង . . . គឺជាការចាំបាច់ ទោះបីជានៅពេលអ្នករស់នៅដោយស្អាតស្អំ ដ៏សុចរិត ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយ | របស់ព្រះ | ក្តី ។ គឺនៅពេលអ្វីទាំងអស់មើលទៅល្អ ជាញឹកញាប់ឧបសគ្គមកយ៉ាងច្រើនដែលអនុវត្តក្នុងពេលទន្ទឹមគ្នា » (« ទុកចិត្តលើព្រះអម្ចាស់ » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ទំព័រ ១៦) ។

សូមឲ្យសិស្សអាន ម៉ូសាយ ២៣:២១–២២ ដើម្បីរកមើលមូលហេតុដែលព្រះអម្ចាស់ឲ្យអ្នកដែលជ្រើសរើសរស់នៅដោយសុចរិត ជួបនឹងការសាកល្បង និង ឧបសគ្គនានា ។ នៅពេលសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ សូមជួយពួកគេឲ្យយល់ថា **ព្រះអម្ចាស់នឹងសាកល្បងការអត់ធ្មត់ និង សេចក្តីជំនឿរបស់យើង ដើម្បីជួយយើងឲ្យបង្កើនការទុកចិត្តរបស់យើងទៅលើទ្រង់ ។**

សូមឲ្យសិស្សសរសេរសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ សូមឲ្យពួកគេសញ្ជឹងគិតអំពីសំណួរទាំងនេះ នៅពេលពួកគេសិក្សា ម៉ូសាយ ២៣ ទាំងមូល ។ ពួកគេមិនគួរសរសេរចម្លើយរបស់ពួកគេរហូតដល់អ្នកបំផុសពួកគេឲ្យធ្វើដូច្នោះនៅពេលក្រោយទៀតក្នុងមេរៀន ។

- តើឧបសគ្គអ្វីខ្លះដែលអ្នកបានជួបនាពេលថ្មីៗនេះ ?
- តើអ្នកអាចអនុវត្តសេចក្តីជំនឿ និង ការទុកចិត្តទៅលើព្រះ ពេលអ្នកជួបនឹងឧបសគ្គដោយរបៀបណា ?

សូមឲ្យសិស្សអាន ម៉ូសាយ ២៣:២៣–២៩ ។ សូមឲ្យពួកគេរកមើលរបៀបដែលអាលម៉ា និង ប្រជាជនរបស់គាត់ត្រូវបានសាកល្បង និង អ្វីដែលពួកគេបានធ្វើដើម្បីបង្ហាញការទុកចិត្តរបស់ពួកគេទៅលើព្រះ ។

- តើការអធិស្ឋាន និង ការធ្វើតាមការប្រឹក្សារបស់ព្យាការីជួយយើងក្នុងពេលមានឧបសគ្គដោយរបៀបណា ? (ពួកគាត់អាចជួយយើងឲ្យបង្កើនការអត់ធ្មត់ និង សេចក្តីជំនឿ ។ ពួកគាត់ក៏អាចជួយយើងឲ្យទទួលបាននូវកម្លាំង វិវរណៈផ្ទាល់ខ្លួន សន្តិភាព និង ទំនុកចិត្ត ដើម្បីឲ្យយើងអាចស៊ូទ្រាំនឹងឧបសគ្គរបស់យើង ឬ ស្វែងរកការដោះលែងពីឧបសគ្គនោះ ។)

ម៉ូសាយ ២៣:៣០–២៤:២៥

អាលម៉ា និង ប្រជាជនរបស់គាត់រងការកាត់ទោស ប៉ុន្តែព្រះអម្ចាស់បញ្ឈប់បន្ទុករបស់ពួកគេ ហើយបានដោះលែងពួកគេដោយអព្ភូតហេតុ

ដើម្បីជួយសិស្សឲ្យយល់ពីទំនាក់ទំនងរបស់អាម៉ូឡុនជាមួយនឹងសាសន៍នីហ្វៃ និងស្តេចរបស់ពួកគេ សូមសង្ខេប ម៉ូសាយ ២៣:៣០–៣៩ និង ២៤:១–៧ ។ សូមពន្យល់ថា អាម៉ូឡុនគឺជាអ្នកដឹកនាំពួកសង្ឃដ៏ទុច្ចរិតរបស់ស្តេចណូអេ ដែលបានកាត់អាលម៉ាចេញដោយសារគាត់បានគាំទ្រអ័ប៊ីណាដៃ ។ អាម៉ូឡុន ជាមួយនឹងពួកសង្ឃដ៏ទុច្ចរិតផ្សេងទៀត និង ប្រពន្ធសាសន៍លេមិនរបស់ពួកគេ បានចូលរួមនឹងសាសន៍លេមិន ។ អាម៉ូឡុន ទទួលបានប្រយោជន៍ពីស្តេចនៃសាសន៍លេមិន ដែលក្រោយមកបានតែងតាំងគាត់ឲ្យគ្រប់គ្រងលើសាសន៍នីហ្វៃទាំងអស់ក្នុងដែនដីហេឡាម រួមមានប្រជាជនរបស់អាលម៉ាដែរ ។

សូមឲ្យសិស្សម្នាក់មកខាងមុខថ្នាក់ ហើយសូមឲ្យគេស្តាយកាតាបទទេ ។ (សិស្សនឹងត្រូវការព្រះគម្ពីររបស់គេ ។) សូមសួរសិស្សថាតើវាងាយស្រួលប៉ុណ្ណាដើម្បីស្តាយកាតាបទទេពេញមួយថ្ងៃនោះ ។ សូមឲ្យសិស្សនេះអាន ម៉ូសាយ ២៤:៨–១១ ឮៗ ។ រាល់ពេលសិស្សអានអំពីអ្វីមួយដែលជាឧបសគ្គដល់អាលម៉ា និងប្រជាជនរបស់គាត់ សូមដាក់ថ្មមួយ ឬរបស់ធ្ងន់អ្វីមួយទៅក្នុងកាតាបនោះ ។ នៅពេលសិស្សបានអានចប់ សូមសួរគាត់ថា តើវាងាយស្រួលប៉ុណ្ណាក្នុងការស្តាយកាតាបពេញដោយរបស់ធ្ងន់ពេញមួយថ្ងៃនោះ ។ (សិស្សគួរនៅខាងមុខថ្នាក់ដដែល ហើយស្តាយកាតាបធ្ងន់នោះ រហូតដល់ប្រាប់ឲ្យអង្គុយចុះ) ។ សូមសួរសិស្សក្នុងថ្នាក់ ៖

- តើថ្ម ឬ របស់ធ្ងន់ដែលនៅក្នុងកាតាបតំណាងឲ្យអ្វីនៅក្នុងជីវិតរបស់យើង ?
- តើបន្ទុកប្រភេទនេះជះឥទ្ធិពលដល់យើងដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២៤:១០–១២ ឮៗ ។ សូមឲ្យសិស្សរកមើលអ្វីដែលប្រជាជនរបស់អាលម៉ាបានធ្វើ ដើម្បីទទួលបានជំនួយដល់បន្ទុករបស់ពួកគេ ។ សូមឲ្យសិស្សពន្យល់អ្វីដែលគេរកឃើញ ។

ការចូលរួមរបស់សិស្ស

ការសុំឲ្យសិស្សចូលរួមក្នុងសកម្មភាពខាងមុខថ្នាក់ ជួយឲ្យសិស្សទាំងអស់មានអារម្មណ៍សកម្មជាងមុនក្នុងការរៀនសូត្រ ដោយសារមិត្តភក្តិរបស់គេបានជួយក្នុងការបង្រៀន ។ នៅពេលអ្នកសុំឲ្យសិស្សចូលរួមនៅខាងមុខថ្នាក់ក្នុងរយៈពេលយូរ សូមឲ្យពួកគេយកព្រះគម្ពីររបស់ពួកគេមកជាមួយ ដើម្បីពួកគេអាចនៅបន្តចូលរួមក្នុងការអាន និងពិភាក្សាព្រះគម្ពីរជាមួយនឹងសិស្សផ្សេងទៀត ។

- តើការអធិស្ឋានអាចជួយយើង នៅពេលយើងមានបន្ទុកលំបាកដោយរបៀបណា ?
- នៅពេលយើងជួបនឹងឧបសគ្គ ហេតុអ្វីបានជាវាជួយលួងលោមពេលដឹងថា ព្រះដឹងពី « គំនិតនៃដួងចិត្ត [របស់យើង] » ?

សូមឲ្យសិស្សអាន ម៉ូសាយ ២៤:១៣–១៥ ដើម្បីរកមើលអ្វីដែលបានកើតឡើងដល់ប្រជាជនរបស់អាលម៉ា នៅពេលពួកគេបន្តអធិស្ឋានដើម្បីសុំជំនួយ ។

- តើព្រះអម្ចាស់បានសន្យាថានឹងធ្វើអ្វីសម្រាប់ប្រជាជនរបស់អាលម៉ា ? (នៅពេលសិស្សឆ្លើយ អ្នកអាចសុំឲ្យម្នាក់ ឬ ពីរនាក់ទៀត លើកបាតកាតាបដើម្បីសម្រាលបន្ទុកនៃការស្តាយរបស់សិស្សនោះ—ដើម្បីតំណាងឲ្យពេលព្រះអម្ចាស់អាចសម្រាលបន្ទុករបស់យើង) ។ តើការសន្យានេះទាក់ទងនឹងសេចក្តីសញ្ញាដែលពួកគេបានធ្វើនៅឯទឹកនៃមរមនដោយរបៀបណា ? (សូមមើល ម៉ូសាយ ១៨:៨–១០ ។)
- ហេតុអ្វីបានជាវាជួយដល់អ្នកដើម្បីដឹងថា ព្រះអម្ចាស់មិនតែងតែដកបន្ទុករបស់យើងភ្លាមៗ ឬ ដកយកទុក្ខវេទនារបស់អ្នកភ្លាមទេ ?
- តើយើងអាចរៀនអ្វីខ្លះ ពីរបៀបដែលអាលម៉ា និង ប្រជាជនរបស់គាត់ឆ្លើយតបនឹងការសាកល្បងរបស់ពួកគេ ?
- តើនៅពេលណាដែលអ្នកបានមានអារម្មណ៍ថា ព្រះអម្ចាស់បានប្រទានដល់អ្នកនូវកម្លាំងដើម្បីស៊ូទ្រាំនឹងការសាកល្បង ឬ ការរែកបន្ទុកនោះ ?

សូមឲ្យសិស្សអាន ម៉ូសាយ ២៤:១៦–១៧, ២១ ដោយស្ងាត់ៗ ។ សូមឲ្យពួកគេរកមើលពាក្យ និង ឃ្លាដែលពិពណ៌នាបន្ថែមទៀតពីរបៀបដែលប្រជាជនបានឆ្លើយតបនឹងការសាកល្បងរបស់ពួកគេ និង ពីរបៀបដែលព្រះអម្ចាស់បានជួយដល់ពួកគេ ។ សូមឲ្យសិស្សម្នាក់ ឬ ពីរនាក់ពន្យល់ជាសម្ដីខ្លួនឯងពីទំនាក់ទំនងដែលពួកគេឃើញរវាងសកម្មភាពរបស់ប្រជាជន និង សកម្មភាពរបស់ព្រះអម្ចាស់ ។ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***នៅពេលយើងធ្វើតាមឆន្ទៈរបស់ព្រះអម្ចាស់ដោយអត់ធ្មត់ ទ្រង់នឹងពង្រឹងយើង ហើយដោះលែងយើងពីការសាកល្បងរបស់យើងតាមពេលវេលារបស់ទ្រង់ ។***

សូមឲ្យសិស្សដែលបានមកខាងមុខថ្នាក់ ទម្លាក់កាតាបចុះ ។ សូមឲ្យគេពិពណ៌នាពីអារម្មណ៍ដែលមានសេរីភាពពីបន្ទុកនោះ ។ សូមឲ្យសិស្សដដែលនោះអាន ម៉ូសាយ ២៤:២១–២២ ។ អ្នកអាចសុំឲ្យសិស្សនោះចែកចាយពីរបៀបដែលគេអាចភ្ជាប់ទៅនឹងអ្វីដែលប្រជាជនបានធ្វើនៅក្នុងខគម្ពីរទាំងនេះ ។

សូមសង្ខេប ម៉ូសាយ ២៤:១៨–២៥ ដោយការពន្យល់ថា អាលម៉ា និង ប្រជាជនរបស់គាត់អាចរត់ចេញ ដោយសារព្រះអម្ចាស់បានបណ្តាលឲ្យសាសន៍លេមិនបានដេកលង់លក់យ៉ាងខ្លាំង ។ បន្ទាប់មក ព្រះអម្ចាស់បានដឹកនាំអាលម៉ា និង ប្រជាជនរបស់គាត់ទៅកាន់ដែនដីសារ៉ាហិមឡា នៅពេលស្តេចម៉ូសាយបានស្វាគមន៍ដល់ពួកគេដោយសេចក្តីអំណរ ។ អាលម៉ា និង ប្រជាជនរបស់គាត់ " បានថ្វាយអំណរគុណរបស់គេដល់ព្រះ" ដោយដឹងថា " គ្មានអ្នកណាម្នាក់អាចដោះពួកគេបានឡើយ លើកលែងតែព្រះអម្ចាស់ ជាព្រះរបស់គេប៉ុណ្ណោះ" (ម៉ូសាយ ២៤:២១; សូមមើលផងដែរ ម៉ូសាយ ២៥:១៦) ។

លើឌីយ៉ាក្រាមរបស់ពួកគេបង្ហាញពីសេចក្តីសង្ខេបនៃការធ្វើដំណើរនៅក្នុង ម៉ូសាយ ៧–២៤ សូមឲ្យសិស្សគូរសញ្ញាព្រួញមួយពីដែនដីហេឡាម ទៅកាន់ដែនដីសារ៉ាហិមឡា ។ សូមឲ្យសិស្សសរសេរលើការធ្វើដំណើរនេះថា " ប្រជាជនរបស់អាលម៉ារត់ចេញ" ។

ដើម្បីបញ្ចប់ សូមឲ្យសិស្សសរសេរចម្លើយនឹងសំណួរពីរដែលពួកគេបានសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេពីមុនៗក្នុងមេរៀននេះ ។ សូមឲ្យពួកគេគិតអំពីឧបសគ្គ និង របៀបដែលពួកគេអាចអនុវត្តសេចក្តីជំនឿ និងទីទុកចិត្តទៅលើព្រះដើម្បីជួយពួកគេឲ្យស៊ូទ្រាំ ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា ប្រសិនបើយើងធ្វើតាមព្រះឆន្ទៈនៃព្រះអម្ចាស់ដោយអត់ធ្មត់ ទ្រង់នឹងពង្រឹងយើង ហើយដោះលែងយើងចេញពីឧបសគ្គរបស់យើងតាមពេលវេលារបស់ទ្រង់ ។ អ្នកក៏អាចឲ្យសិស្សចែកឧទាហរណ៍ពីរបៀបដែលព្រះអម្ចាស់បានពង្រឹងដល់ពួកគេក្នុងពេលគេមានឧបសគ្គដែរ ។

សេចក្តីសង្ខេបនៃការធ្វើដំណើរនៅក្នុង ម៉ូសាយ ៧–២៤



ម៉ូសាយ ២៥

សេចក្តីផ្តើម

ម៉ូសាយ ២៥ផ្តល់នូវការបញ្ចប់មួយដល់ដំណើររឿងនៃប្រជាជនរបស់សឺនិព្វ (សូមមើល ម៉ូសាយ ៧–២៤) ។ ប្រជាជនរបស់លិមហៃ និង អ្នកដើរតាមអាលម៉ាបានត្រឡប់ទៅកាន់ដែនដីសារ៉ាហិមឡា ហើយត្រូវបានរួបរួមដោយសុវត្ថិភាពនៅក្រោមការគ្រប់គ្រងរបស់ស្តេចម៉ូសាយ ។ បន្ទាប់ពីក្រុមទាំងពីរនេះបានមកដល់ នោះលិមហៃ និង ប្រជាជនរបស់គាត់បានទទួលបុណ្យជ្រមុជទឹក ។ ស្តេចម៉ូសាយបានឲ្យអាលម៉ានូវសិទ្ធិអំណាចដើម្បីស្ថាបនាសាសនាចក្រ ទូទាំងដែនដីហើយគ្រប់គ្រងកិច្ចការនៃសាសនាចក្ររបស់ព្រះក្នុងចំណោមប្រជាជននីហ្វៃ ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ២៥:១–១៣

អ្នកដែលផ្តុំគ្នានៅក្នុងដែនដីសារ៉ាហិមឡារួបរួមគ្នា ហើយក្លាយជាសាសន៍នីហ្វៃ

សូមឲ្យសិស្សគិតពីដំណើររឿងដែលពួកគេបានអាន ឬ បានឮ ដែលបង្ហាញពីរបៀប ព្រះអម្ចាស់បានជួយដល់នរណាម្នាក់ដោយការផ្តល់ការដឹកនាំ កម្លាំង ការការពារ ឬ ការដោះលែង ។ អ្នកស្មើថា ពួកគេគួរគិតពីដំណើររឿងនៅក្នុងព្រះគម្ពីរ ប្រវត្តិនៃសាសនាចក្រ ឬ ជីវិតរបស់សមាជិកគ្រួសារ ឬ មិត្តភក្តិ ។ ជាឧទាហរណ៍ សូមចែកចាយរឿងដែលបានប្រាប់ដោយយុវនារីម្នាក់ដែលដើរខាងមុខគេនៃក្រុមរបស់នាង ហើយបានដើរចុះភ្នំក្នុងពេលសកម្មភាពទៅក្រៅកំសាន្តរបស់វួដ ៖

“ សំឡេងព្រមានមួយ ដែលរឹងមាំប៉ុន្តែស្រទន់ បាននិយាយថា ‹ ត្រឡប់ទៅខាងក្រោយ › ។ ខ្ញុំស្ទើរតែព្រងើយនឹងវា ប៉ុន្តែវាបានឮមកម្តងទៀត ។ លើកនេះ ខ្ញុំបានស្តាប់តាម ហើយត្រឡប់ទៅក្នុងក្រុមវិញ ។ នៅពេលយើងដើរចុះ យើងបានឃើញក្របីដ៏ធំពីរដើរយ៉ាងលឿន យ៉ាងកម្រោលមកលើភ្នំ ។ ក្របីធំជាងគេបានចាប់ផ្តើមទន្ទ្រានជើងនឹងដី ពេលវាស់ឡើងមកកាន់យើង ។ . . . អ្នកដឹកនាំបព្វជិតភាពរបស់យើងបានបង្អាក់វា ហើយយើងអាចឡើងលើរបងទៅទីសុវត្ថិភាព ។

“ នៅពេលយើងបានចូលជំរុំម្តងទៀត ខ្ញុំបានដឹងថា ប្រសិនបើខ្ញុំមិនបានស្តាប់តាមការព្រមានពីព្រះវិញ្ញាណនោះទេ ខ្ញុំអាចត្រូវបានរងរបួសយ៉ាងធ្ងន់ធ្ងរ ឬ អាចស្លាប់ផងក៏ថាបាន ។ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌យកចិត្តទុកដាក់ពីខ្ញុំ ហើយបានការពារខ្ញុំឲ្យមានសុវត្ថិភាព ។ ខ្ញុំពិតជាមានអំណរគុណដល់ព្រះអម្ចាស់សម្រាប់ការព្រមាននោះខ្លាំងណាស់ ។ បទពិសោធន៍នេះបានពង្រឹងទីបន្ទាល់របស់ខ្ញុំ ហើយបានឲ្យខ្ញុំស្រឡាញ់ព្រះអម្ចាស់កាន់តែខ្លាំងឡើង ” (“ Turn Back,” *New Era,* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ៤៧) ។

សូមឲ្យសិស្សម្នាក់ ឬ ពីរនាក់ចែកចាយរឿងមួយដែលពួកគេគិតថាវាបង្ហាញពីសេចក្តីល្អ និង អំណាចរបស់ព្រះនៅក្នុងជីវិតរបស់នរណាម្នាក់ទៀត ។ សូមសួរសិស្សថា ៖

- តើវាជួយអ្នកឲ្យស្តាប់តាមគំរូនៃសេចក្តីល្អរបស់ព្រះ និង ព្រះចេស្តាទ្រង់នៅក្នុងជីវិតរបស់អ្នកដទៃដោយរបៀបណា ?

សូមសង្ខេប ម៉ូសាយ ២៥:១–៦ ដោយការពន្យល់ថា ក្រោយពីប្រជាជនរបស់លិមហៃ និង ប្រជាជនរបស់អាលម៉ា (អ្នកទាំងនោះជាកូនចៅនៃប្រជាជនរបស់សឺនិព្វ) បានរត់ចេញពីសេរភាព ហើយបានរួបរួមជាមួយប្រជាជនដែលកំពុងរស់នៅក្នុងដែនដីសារ៉ាហិមឡា ស្តេចម៉ូសាយបានអានកំណត់ត្រារបស់ពួកគេដល់ប្រជាជនទាំងអស់ ។ សូមឲ្យសិស្សអាន ម៉ូសាយ ២៥:៧ ដោយស្ងាត់ៗ ដោយអកមើលចម្លើយទូទៅពីប្រជាជនចំពោះដំណើររឿងនៃការទាក់ទងរបស់ព្រះជាមួយនឹងប្រជាជនរបស់សឺនិព្វ ។ សូមឲ្យសិស្សម្នាក់ចែកចាយនូវអ្វីដែលគេបានរកឃើញ ។

សូមចម្លងតារាងខាងក្រោមនៅលើក្តារខៀន ។ សូមពន្យល់ថា នៅក្នុង ម៉ូសាយ ២៥:៨–១១ យើងរៀនបន្តែមអំពីរបៀបដែលប្រជាជនបានឆ្លើយតបនឹងដំណើររឿងរបស់ប្រជាជនសឺនិព្វ និងប្រជាជនរបស់អាលម៉ា ។ សូមឲ្យសិស្សអានសេចក្តីយោងព្រះគម្ពីរដើម្បីរកមើលអ្វីដែលប្រជាជនបានឮ និង ពីអារម្មណ៍ដែលពួកគេបានមានអំពីវា ។ ចម្លើយសម្រាប់សេចក្តីយោងទីមួយ ត្រូវបានផ្តល់នៅក្នុងវង់ក្រចកជាឧទាហរណ៍ ។

	អ្វីដែលប្រជាជនបានឮ	អារម្មណ៍ដែលប្រជាជនបានមាន
ម៉ូសាយ ២៥:៨	(ពួកគេបានឮពីរបៀបដែលប្រជាជនរបស់លិមហៃត្រូវបានដោះលែងពីសេរភាព) ។	(វាធ្វើឲ្យពួកគេពោរពេញដោយសេចក្តីអំណរដ៏ខ្លាំង) ។
ម៉ូសាយ ២៥:៩		
ម៉ូសាយ ២៥:១០		
ម៉ូសាយ ២៥:១១		

នៅពេលសិស្សមានពេលគ្រប់គ្រាន់ដើម្បីសិក្សាសេចក្តីយោងព្រះគម្ពីរនេះហើយ សូមឲ្យសិស្សពីរបីនាក់សរសេរនៅលើក្តារខៀនពីអ្វីដែលពួកគេបានរកឃើញ ។ សូមឲ្យសិស្សសង្ខេបអ្វីដែលពួកគេបានរៀនពី ម៉ូសាយ ២៥:៨–១១ ដោយការនិយាយពីគោលការណ៍ពីរគ្នេះដែលពួកគេអាចអនុវត្តដល់ខ្លួនគេ ។ នៅពេលសិស្សឆ្លើយតប សូមឲ្យពួកគេដឹងថា **ដោយការសិក្សាកំណត់ត្រានៃការទាក់ទងរបស់ព្រះជាមួយនឹងអ្នកដទៃ យើងអាចមានអារម្មណ៍រីករាយ និង ដឹងគុណសម្រាប់សេចក្តីល្អរបស់ព្រះ** ។(នៅពេលសិស្សអានខគម្ពីរទាំងនេះ ពួកគេក៏អាចកត់សម្គាល់ពីការសោកសៅ និងការបាត់បង់ដែលជាលទ្ធផលនៃអំពើបាប) ។

- តើប្រភពអ្វីដែលយើងអាចត្រឡប់ទៅរៀនពីបទពិសោធន៍របស់អ្នកដទៃជាមួយនឹងសេចក្តីល្អរបស់ព្រះ ? (សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ ចម្លើយអាចមាន ព្រះគម្ពីរ សុន្ទរកថានាសន្និសីទទូទៅ ទស្សនាវដ្តីនៃសាសនាចក្រ ជីវប្រវត្តិនៃអ្នកដឹកនាំសាសនាចក្រ និងអ្នកដទៃ និង ពង្សប្រវត្តិ) ។

សូមអញ្ជើញឲ្យសិស្សគិតអំពីពេលដែលពួកគេបានរៀនពីសេចក្តីល្អរបស់ព្រះដល់អ្នកដទៃពីប្រភពដែលបានសរសេរនៅលើក្តារខៀននេះ ។

- តើអ្នកបានទទួលប្រយោជន៍ពីការរៀនពីសេចក្តីល្អរបស់ព្រះដល់អ្នកដទៃពីប្រភពមួយនៃប្រភពទាំងនេះដោយរបៀបណា ?
- តើអ្នកគិតថា អ្វីដែលមានឥទ្ធិពលក្នុងរយៈពេលវែងដល់នរណាម្នាក់ដែលរៀនពីសេចក្តីល្អរបស់ព្រះជាទៀងទាត់នៅក្នុងការទាក់ទងរបស់ទ្រង់ជាមួយនឹងអ្នកដទៃ ?

សូមលើកទឹកចិត្តសិស្សឲ្យមានពេលសម្រាប់ខ្លួនគេដើម្បីជ្រើសរើសប្រភពមួយដែលសរសេរនៅលើក្តារខៀន ហើយស្រាវជ្រាវរករឿងដែលបំផុសគំនិតនៃសេចក្តីល្អរបស់ព្រះ ។

ម៉ូសាយ ២៥:១៤–២៤

អាលម៉ាស្ថាបនាសាសនាចក្រនៃព្រះទូទាំងដែនដីនីហ្វៃ

ដើម្បីរៀបចំសិស្សឲ្យសិក្សាពីការរៀបចំ និង ការបង្រៀននៃសាសនាចក្រក្នុងសាសន៍នីហ្វៃ សូមសួរ ៖

- តើនៅពេលណាដែលអ្នកបានចូលរួមក្នុងវួដ ឬ សាខានៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ជាជាងវួដ ឬ សាខានៃផ្ទះរបស់អ្នក ? តើភាពស្រដៀងគ្នាអ្វីខ្លះដែលអ្នកបានកត់សម្គាល់រវាងវួដ ឬ សាខានៃផ្ទះរបស់អ្នក និង វួដ ឬ សាខាដែលបានទៅលេង ?
- តើវាជួយឲ្យឃើញថាការរៀបចំ និង ការបង្រៀននៃសាសនាចក្រដូចគ្នានៅគ្រប់វួដ ឬ សាខានៃសាសនាចក្រយ៉ាងណាខ្លះ ?

សូមសង្ខេប ម៉ូសាយ ២៥:១៤–១៧ ដោយការពន្យល់ថា ក្រោយពីម៉ូសាយបាននិយាយ និងអានដល់ប្រជាជន គាត់បានអញ្ជើញអាលម៉ាឲ្យបង្រៀនដល់ពួកគេ ។ បន្ទាប់មក ស្តេចលីមហៃនិងប្រជាជនរបស់គាត់បានស្នើឲ្យមានការជ្រមុជទឹក ។ អាលម៉ាបានជ្រមុជទឹកឲ្យពួកគេ ហើយបានចាប់ផ្តើមរៀបចំសាសនាចក្រទូទាំងដែនដី ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី ម៉ូសាយ ២៥:១៨–២២ ។ សូមឲ្យសិស្សរកមើលពីរបៀបដែលសាសនាចក្រត្រូវបានរៀបចំ និង គ្រប់គ្រងក្នុងចំណោមសាសន៍នីហ្វៃនៅក្នុងជំនាន់របស់អាលម៉ា ។ ដើម្បីជួយសិស្សឲ្យយល់ថា **ការរៀបចំនៃសាសនាចក្រធានាថាសមាជិកទាំងអស់អាចទទួលបានសេចក្តីពិត** សូមសួរសំណួរដូចខាងក្រោម ៖

- តើសាសនាចក្រក្នុងចំណោមសាសន៍នីហ្វៃដូចគ្នានឹងសាសនាចក្រសព្វថ្ងៃនេះដោយរបៀបណា ? (យើងមានវួដ និង សាខាដែលដូចជា " ក្រុមផ្សេងៗគ្នា " ដែលបានលើកឡើងនៅក្នុង ម៉ូសាយ ២៥:២១ ។ ប្រធានសាខា ប៊ីស្សព និង ប្រធានស្តេកគឺដូចជាពួកសង្ឃ និងគ្រូបង្រៀនដែលគ្រប់គ្រងសាសនាចក្រនៅក្នុងជំនាន់របស់អាលម៉ា ។)
- យោងតាម ម៉ូសាយ ២៥:១៥–១៦, ២២ តើសេចក្តីពិតអ្វីខ្លះដែលពួកសង្ឃ និងគ្រូបង្រៀនទាំងឡាយនៃសាសនាចក្របញ្ជាក់នៅក្នុងជំនាន់របស់ម៉ូសាយ ? (អ្នកអាចបង្ហាញថា ព្រះអម្ចាស់បានប្រទានការណែនាំស្រដៀងគ្នាដល់ឪពុកម្តាយ អ្នកដឹកនាំសាសនាចក្រ និង អ្នកផ្សព្វផ្សាយសាសនានៅក្នុងថ្ងៃចុងក្រោយ ។ [សូមមើល គ. & ស. ១៥:៦; ១៩:៣១; ៦៨:២៥។])
- ហេតុអ្វីបានជាវាសំខាន់ដើម្បីបន្តបង្រៀនការប្រែចិត្ត និង សេចក្តីជំនឿទៅលើព្រះ ?

សូមឲ្យសិស្សអាន ម៉ូសាយ ២៥:២៣–២៤ ដោយរកមើលឃ្លាដែលបង្ហាញពីពរជ័យដែលទទួលដោយអ្នកដែលបានចូលរួមសាសនាចក្រនៃព្រះ ។

- តើប្រជាជនទាំងនេះត្រូវបានប្រទានពរ ជាលទ្ធផលនៃការជ្រមុជទឹក និងការចូលរួមក្នុងសាសនាចក្រនៃព្រះដោយរបៀបណា ?
- តើព្រះអម្ចាស់បានប្រទានពរដល់អ្នកតាមរយៈសមាជិកភាពរបស់អ្នកនៅក្នុងសាសនាចក្រដោយរបៀបណា ?

សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***នៅពេលយើងលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ហើយរស់នៅស្របតាមនោះ ព្រះអម្ចាស់នឹងស្រោចព្រះវិញ្ញាណរបស់ទ្រង់មកលើយើង ។***

សូមថ្លែងទីបន្ទាល់ថា ពរជ័យទាំងឡាយដែលពួកគេបានជួបក្នុងនាមជាសមាជិកនៃសាសនាចក្រអាចកើនឡើង នៅពេលពួកគេរក្សាសេចក្តីសញ្ញារបស់ពួកគេ ហើយទទួលព្រះវិញ្ញាណ ។

សូមថ្លែងទីបន្ទាល់អំពីពរជ័យដែលបានសន្យាទាំងឡាយ

បងប្រុស រ៉ូសែល ធី អូសហ្គូស្សជ័ប ប្រធាននៃសាលាអាទិត្យទូទៅ បានចែកចាយនូវគំរូដ៏សាមញ្ញមួយសម្រាប់ការបង្រៀនដ៏មានឥទ្ធិពល ៖ (១) បង្រៀនគោលលទ្ធិគ្រឹះ, (២) អញ្ជើញអ្នករៀនឲ្យធ្វើសកម្មភាព និង (៣) ថ្លែងទីបន្ទាល់អំពីពរជ័យដែលបានសន្យាទាំងឡាយ (សូមមើល "Teaching Helps Save Lives," *Ensign* ឬ *លេអាហូណា*, ខែ វិច្ឆិកា ឆ្នាំ ២០០៩, ទំព័រ ១៥) ។ នៅពេលអ្នកថ្លែងទីបន្ទាល់អំពីការសន្យាទាំងឡាយដែលមាននៅក្នុងព្រះគម្ពីរ និងប្រសាសន៍របស់ព្យាការីថ្ងៃចុងក្រោយ នោះសិស្សអាចមានអារម្មណ៍កាន់តែបានជម្រុញខ្លាំងឡើងឲ្យអនុវត្តនូវអ្វីដែលពួកគេបានរៀន ។

វិចារណកថា និង ព័ត៌មានសាច់រឿង

ម៉ូសាយ ២៥:១៧–២២ ។ សិទ្ធិអំណាចបព្វជិតភាពក្នុងចំណោមសាសន៍នីហ្វៃ

ព្រះគម្ពីរមរមនមិនបានផ្តល់សេចក្តីលម្អិតជាក់លាក់អំពីបព្វជិតភាពដែលបានកាន់ ដោយពួកព្យាការី និង បងប្អូនប្រុសផ្សេងទៀតក្នុងចំណោមសាសន៍នីហ្វៃ និង សាសន៍លេមិនឡើយ ។ ទោះយ៉ាងណាក្តី សេចក្តីរៀបចំពោះពិធីការបរិសុទ្ធទាំងឡាយ និង របៀបវារៈដែលសាសនាចក្រត្រូវបានដឹកនាំផ្តល់នូវភស្តុតាងគ្រប់គ្រាន់ថា ពួកគេបានមានបព្វជិតភាពមែលគីស្សាដែក ។ ប្រធាន យ៉ូសែប ហ្វីលឌីង ស្មីធ បានបង្រៀនថា “ បព្វជិតភាពដែល [សាសន៍នីហ្វៃ] បានមាន ហើយដែលពួកគេគ្រប់គ្រងតាមគឺជាបព្វជិតភាព ក្រោយពី *ការបញ្ជាដ៏បរិសុទ្ធ* ការបញ្ជានៃបុត្រានៃព្រះ [សូមមើល អាលម៉ា ១៣:១–២០] ។ បព្វជិតភាពដ៏ខ្ពស់ជាងនេះអាចគ្រប់គ្រងរាល់ពិធីការទាំងឡាយនៃដំណឹងល្អ ” ((*Doctrines of Salvation,* បានបោះពុម្ពដោយ ប្រ៊ូស អ័រ ម៉ាក់ខនយើ វ៉ុលទី ៣ ។ [ឆ្នាំ ១៩៥៤–៥៦], ៣:៨៧) ។

សម្រាប់ព័ត៌មានបន្ថែមអំពីអំណាចបព្វជិតភាពនៅក្នុងព្រះគម្ពីរមរមន សូមមើលវិចារណកថា និង ព័ត៌មានសាច់រឿងសម្រាប់ ម៉ូសាយ ១៨ ។

មេរៀនសិក្សានៅផ្ទះ

ម៉ូសាយ ១៨–២៥ (មេរៀនទី ១៣)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនការសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា ម៉ូសាយ ១៨–២៥ (មេរៀនទី ១៣) មិនមែនត្រូវយកមកបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះទេ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និងគោលការណ៍ពីរបីនេះប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ម៉ូសាយ ១៨)

ក្រោយពីការស្លាប់របស់អ័ប៊ីណាដៃ អាលម៉ាបានប្រែចិត្ត ហើយបានបង្រៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដល់អ្នកដទៃនៅឯទឹកនៃមរមន ។ តាមរយៈការសិក្សាពីបទពិសោធន៍នេះ សិស្សបានរៀនថា យើងទទួលបានព្រះវិញ្ញាណនៃព្រះអម្ចាស់ និង ការសន្យានៃជីវិតដ៏នៅអស់កល្បជានិច្ច ដោយការធ្វើ និងការកាន់តាមសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹក ហើយថាពរជ័យដ៏អស្ចារ្យបានមកដល់អ្នកដែលកាន់តាមសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹក ។

ថ្ងៃទី ២ (ម៉ូសាយ ១៩–២០)

ក្រោយពីស្តេចណូអេ និង ប្រជាជនរបស់ទ្រង់បានបដិសេធការបង្រៀនរបស់អាលម៉ា ហើយចង់សម្លាប់អាលម៉ា និង អ្នកដើរតាមគាត់នោះ ពួកគេត្រូវបានវាយប្រហារដោយសាសន៍លេមិន ។ ស្តេចណូអេត្រូវបានសម្លាប់ដោយប្រជាជនរបស់ទ្រង់ ហើយកូនប្រុសរបស់ទ្រង់លីមហៃបានក្លាយជាស្តេច ។ នៅពេលសិស្សអានពីរបៀបដែលប្រជាជនរបស់លីមហៃត្រូវបានដាក់នៅក្នុងសេរ៉កភាពដោយសាសន៍លេមិន ពួកគេបានរៀនថា ការបដិសេធពាក្យសម្តីរបស់អ្នកបម្រើរបស់ព្រះអម្ចាស់នាំមកនូវការរងទុក្ខ និងការសោកសៅ ។ ពួកគេត្រូវបានលើកទឹកចិត្តឲ្យគិតពីពេលមួយដែលពួកគេបានជួបនឹងសន្តិភាព និង សុវត្ថិភាពខាងវិញ្ញាណដោយការធ្វើតាមការប្រឹក្សានៃអ្នកបម្រើរបស់ព្រះអម្ចាស់ ។

ថ្ងៃទី ៣ (ម៉ូសាយ ២១–២៤)

សិស្សបានរៀនថា អាលម៉ា និង ប្រជាជនរបស់គាត់ ទោះបីសុចរិតក្តី ក៏ត្រូវបានដាក់នៅក្នុងសេរ៉កភាពដោយសាសន៍លេមិនដែរ ។ សិស្សបានធ្វើតារាងមួយនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេដែលប្រៀបធៀបសេរ៉កភាព និង ការដោះលែងនៃលីមហៃ និងប្រជាជនរបស់គាត់ជាមួយនឹងសេរ៉កភាព និង ការដោះលែងនៃអាលម៉ា និងប្រជាជនរបស់គាត់ ។ ជំណើរឿងនៃប្រជាជនរបស់លីមហៃបានបង្រៀនថា នៅពេលយើងចង់ធ្វើតាម និង រក្សាសេចក្តីសញ្ញា ព្រះអម្ចាស់នឹងផ្តល់របៀបមួយសម្រាប់ការដោះលែងយើង ។ ពីក្រុមរបស់អាលម៉ា សិស្សបានរៀនថា នៅពេលយើងធ្វើតាមឆន្ទៈរបស់ព្រះអម្ចាស់ដោយអត់ធ្មត់ ទ្រង់នឹងពង្រឹងយើង ហើយដោះលែងយើងពីការសោកល្វងរបស់យើងតាមពេលវេលារបស់ទ្រង់ ។

ថ្ងៃទី ៤ (ម៉ូសាយ ២៥)

ក្រោយពីប្រជាជនរបស់លីមហៃ និង ប្រជាជនរបស់អាលម៉ាបានរួបរួមគ្នាដោយសុវត្ថិភាពនៅក្រោមការគ្រប់គ្រងរបស់ស្តេចម៉ូសាយលើដែនដីសាធារណៈហើយ ជំណើររឿងរបស់ពួកគេត្រូវបានអានដល់ប្រជាជនទាំងអស់ ។ សិស្សបានរៀនថា ដោយការសិក្សាកំណត់ត្រានៃការទាក់ទងរបស់ព្រះជាមួយនឹងអ្នកដទៃ យើងអាចមានអារម្មណ៍ពីសេចក្តីអំណរ និង ការដឹងគុណសម្រាប់សេចក្តីល្អរបស់ព្រះ ។ នៅពេលសិស្សសញ្ជឹងគិតពីរបៀបដែលសមាជិកភាពក្នុងសាសនាចក្រក្នុងជំនាន់នៃសាសន៍នីហ្វៃស្រដៀងគ្នានឹងសមាជិកភាពនៃសាសនាចក្រនាពេលសព្វថ្ងៃនេះ ពួកគេបានរៀនថា នៅពេលយើងលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ហើយស៊ប់នៅតាមនោះ ព្រះអម្ចាស់នឹងប្រទានពរដល់យើងដោយព្រះវិញ្ញាណរបស់ទ្រង់ ។ សិស្សបានសរសេរអំពីការមានឆន្ទៈដើម្បីលើកដាក់មកលើខ្លួនគេនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ធ្វើឲ្យមានភាពខុសគ្នានៅក្នុងជីវិតរបស់ពួកគេ ។

សេចក្តីផ្តើម

ការប្រៀបធៀប និង ការបញ្ច្រាសពីបទពិសោធន៍នៃប្រជាជនរបស់អាលម៉ា និង ប្រជាជនរបស់លីមហៃអាចជួយសិស្សឲ្យរកឃើញពីគោលការណ៍ដ៏មានតម្លៃដែលទាក់ទងនឹងប្រភពនៃឧបសគ្គនានារបស់យើង និង ពីរបៀបដែលយើងអាចត្រូវបានដោះលែងពីទុក្ខព្រួយតាមរយៈសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ ។ សូមជួយសិស្សឲ្យដឹងថា នៅពេលពួកគេធ្វើតាម និងរក្សាសេចក្តីសញ្ញាដ៏ពិសិដ្ឋ ទុកចិត្តទៅលើព្រះអម្ចាស់ និង អំពាវនាវហៅទ្រង់សុំជំនួយដោយបន្ទាបខ្លួន នោះទ្រង់នឹងពង្រឹងពួកគេ ហើយដោះលែងពួកគេចេញពីទុក្ខព្រួយរបស់ពួកគេតាមរបៀបរបស់ទ្រង់ និង តាមពេលវេលារបស់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ១៨

អាលម៉ាបង្រៀនដំណឹងល្អដល់ប្រជាជននៃស្តេចណូអេ ហើយមានមនុស្សជាច្រើនប្រែចិត្ត និងមានបំណងចង់ទទួលបុណ្យជ្រមុជទឹក

សូមឲ្យសិស្សគិតអំពីបុណ្យជ្រមុជទឹករបស់ពួកគេផ្ទាល់ ។ សូមឲ្យពួកគេចែកចាយពីសេចក្តីលម្អិតខ្លះដែលគេនៅចងចាំអំពីបទពិសោធន៍របស់ពួកគេ ។ បន្ទាប់មក សូមបង្ហាញ រូបភាពអាលម៉ាជ្រមុជទឹកនៅក្នុងទឹកនៃមរមន ប្រសិនបើមានរូបភាពនេះ (៦២៣៣២; *សៀវភៅរូបភាពដំណឹងល្អ* [ឆ្នាំ ២០០៩] លេខ ៧៦) ហើយសូមឲ្យពួកគេនឹកចាំពីហេតុការណ៍ដែលបានរៀបរាប់នៅក្នុងម៉ូសាយ ១៨:៨–១១ ។ សូមសួរសិស្សថា តើពួកគេបានយល់ពីគោលបំណងនៃការជ្រមុជទឹក និងសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹក នៅពេលពួកគេបានធ្វើបុណ្យជ្រមុជទឹកទេ ។

ក្រោយពីសិស្សបានពិភាក្សាពីដំណើររឿងនៅក្នុង ម៉ូសាយ ១៨ សូមឲ្យពួកគេត្រឡប់ទៅថ្ងៃទីមួយ កិច្ចការទីមួយនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរបស់ពួកគេ ដែលពួកគេបានគូសឌីយ៉ាក្រាមពីអ្វីដែលអាលម៉ាបានបង្រៀនអំពីសេចក្តីសញ្ញានៃបុណ្យជ្រមុជទឹកដូចបានពន្យល់នៅក្នុង ម៉ូសាយ១៨:៨–១១ ។ សូមឲ្យសិស្សម្នាក់គូសឌីយ៉ាក្រាមរបស់គេជាថ្មីនៅលើក្តារខៀន

ឬ ចែកចាយវាដល់សិស្សក្នុងថ្នាក់ ហើយសូមឲ្យសិស្សផ្សេងទៀត ប្រសិនបើពួកគេមានអ្វីបន្ថែមដល់ក្នុងកូឡោន " ខ្ញុំសន្យា" និង " ព្រះសន្យា" ។ បន្ទាប់មក សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ឬ នៅលើក្រដាសមួយថា ៖ ***យើងទទួលបានព្រះពិភ្លើណានៃព្រះអម្ចាស់ និង ការសន្យានៃជីវិតដ៏នៅអស់កល្បជានិច្ច ដោយការធ្វើ និង ការកាន់តាមសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹក*** ។អ្នកអាចស្នើថា សិស្សគួរសរសេរគោលការណ៍នេះនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ របស់ពួកគេក្បែរ ម៉ូសាយ ១៨:៨–១១ ។

សូមសួរ ៖ តើការយល់ដឹងរបស់អ្នកអំពីសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹកជះឥទ្ធិពលដល់បំណងរបស់អ្នកឲ្យកាន់តាមសេចក្តីសញ្ញានេះដោយរបៀបណា ?

ម៉ូសាយ ១៩–២៤

ប្រជាជនរបស់លិមហៃ និង អ្នកដើរតាមអាលម៉ាត្រូវបានដោះលែងពីសេវកភាពនៃសាសន៍លេមិន

សូមឲ្យសិស្សម្នាក់អានប្រយោគទីមួយដោយអែលឌើរ រីឆាត ជី ស្តត នៃក្រុមនៃពួកសាវកដប់ពីរនាក់ក្នុងមេរៀនថ្ងៃទីបីនៃមេរៀននេះ នៅក្នុងសៀវភៅណែនាំការសិក្សាសិស្ស ។ សូមសួរសិស្សថា តើអែលឌើរ ស្តត បាននិយាយអ្វីជាប្រភេទពីរនៃឧបសគ្គដែលយើងជួបនៅក្នុងជីវិតរបស់យើង ។ (ពួកគេគួរគូសបន្ទាត់ពីក្រោមឃ្លានោះនៅក្នុងសៀវភៅណែនាំរបស់ពួកគេ) ។ សូមសរសេរ *ឧបសគ្គដែលមកពីការរំលង* និង *ការបន្សុទ្ធដែលមកពីការសោកល្បង* នៅលើក្តារខៀន ។

សូមឲ្យសិស្សរំឭកពីចម្លើយរបស់ពួកគេនៅថ្ងៃទីបី កិច្ចការទីមួយនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ របស់ពួកគេ ។ បន្ទាប់មកសូមសរសេរ *ប្រជាជនរបស់លិមហៃ* នៅក្រោម " ឧបសគ្គដែលមកពីការរំលង " (សូមមើល ម៉ូសាយ ១៩:១០, ២៥–២៨; ២០:២០–២១) និង *ប្រជាជនរបស់អាលម៉ា* នៅក្រោម " ការបន្សុទ្ធដែលមកពីការសោកល្បង " (សូមមើល ម៉ូសាយ ២៣:១៨–២១) ។ សូមឲ្យសិស្សសរសេរនៅលើក្តារខៀនពីឧទាហរណ៍ខ្លះៗនៃរបៀបដែលប្រជាជនសព្វថ្ងៃនេះអាចជួបនឹងប្រភេទនៃឧបសគ្គទាំងនេះនីមួយៗ ។

នៅពេលអ្នករំឭកគោលការណ៍ទាំងនេះជាមួយនឹងសិស្សរបស់អ្នក សូមសរសេរវានៅលើក្តារខៀន ។

សូមឲ្យសិស្សអាន ម៉ូសាយ ២១:១៣–១៦ ជាដៃគូ ។ សូមឲ្យពួកគេរកមើលពាក្យ និង ឃ្លាដែលបង្រៀនថា ***នៅពេលយើងបន្ទាបខ្លួន រំស្រែកហៅដល់ព្រះអម្ចាស់ ហើយប្រែចិត្តពីអំពើបាបរបស់យើង នោះព្រះនឹងឮដល់ការអធិស្ឋានរបស់យើង ហើយបញ្ឈប់បន្ទុកនៃអំពើបាបរបស់យើងតាមពេលវេលារបស់ទ្រង់*** ។សូមឲ្យសិស្សចែកចាយពីរបៀបដែលពួកគេគិតដល់នរណាម្នាក់ដែលអាចអនុវត្តគោលការណ៍នេះ ប្រសិនបើពួកគេកំពុងជួបនឹងឧបសគ្គនេះនៅលើក្តារខៀន ។

សូមឲ្យសិស្សអាន ម៉ូសាយ ២១:៣១–៣២, ៣៥ ហើយសង្ខេបពីការរត់ចេញរបស់ប្រជាជនលិមហៃនៅក្នុង ម៉ូសាយ ២២ ដើម្បីបង្ហាញថា ***នៅពេលយើងធ្វើសេចក្តីសញ្ញាដើម្បីបម្រើដល់ព្រះ ហើយកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ ព្រះអម្ចាស់នឹងផ្តល់នូវរបៀបមួយសម្រាប់ការដោះលែងរបស់យើង*** ។អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរគោលការណ៍នេះនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ របស់ពួកគេក្បែរ ម៉ូសាយ ២១:៣១–៣៥ ។

ដើម្បីរំឭកគោលការណ៍មួយដែលសិស្សបានរៀនពីការសិក្សាអំពីប្រជាជនរបស់អាលម៉ា សូមឲ្យសិស្សម្នាក់សង្ខេបដំណើររឿងពីរបៀបដែលប្រជាជនរបស់អាលម៉ាត្រូវបានដាក់ក្នុងសេវកភាពដោយសាសន៍លេមិន (សូមមើល ម៉ូសាយ ២៣:២៥–២៤:១១) ។ សូមឲ្យសិស្សពីរបីនាក់ឆ្លាស់វេនគ្នាអានឮៗពី ម៉ូសាយ ២៤:១២–១៧ ។ សូមឲ្យពួកគេបង្ហាញពាក្យ ឬ ឃ្លាដែលបង្រៀនថា ***នៅពេលយើងធ្វើតាមឆន្ទៈរបស់ព្រះអម្ចាស់ដោយអត់ធ្មត់ នោះទ្រង់នឹងពង្រឹងយើង ហើយដោះលែងយើងពីឧបសគ្គរបស់យើងទាំងឡាយតាមពេលវេលារបស់ទ្រង់*** ។អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំពាក្យ ឬ ឃ្លាសំខាន់ៗនៅក្នុងខគម្ពីរទាំងនេះ ។

សូមចម្លងឧទាហរណ៍ខាងក្រោមដាក់លើក្តារខៀន ឬ រៀបចំវាដាក់ក្រដាសចែកដល់សិស្ស ។ សូមឲ្យសិស្សពន្យល់ពីរបៀបដែលពួកគេអាចប្រើសេចក្តីពិតដែលពួកគេបានរៀនពីការសិក្សាអំពីប្រជាជនរបស់លិមហៃ និង ប្រជាជនរបស់អាលម៉ាដើម្បីជួយដល់មនុស្សនៅក្នុងឧទាហរណ៍ទាំងនេះ ។

1. មិត្តភក្តិម្នាក់បានទទួលស្គាល់តម្រូវការដើម្បីប្រែចិត្ត ហើយបានទទួលបទពិសោធន៍ពីអារម្មណ៍ដ៏ខ្លាំងនៃភាពមិនសក្តិសម និង ការបាក់ទឹកចិត្ត ដោយគិតថាប្រសិនបើគេអាចយកឈ្នះការល្បួង និង អារម្មណ៍មានទោសទាំងឡាយ ។ តើអ្នកអាចប្រើដំណើររឿងរបស់ប្រជាជនលិមហៃដើម្បីផ្តល់ការលើកទឹកចិត្តដល់មិត្តភក្តិរបស់អ្នក និង ផ្តល់សេចក្តីសង្ឃឹមឲ្យប្រែចិត្តដោយរបៀបណា ? (អ្នកអាចលើកទឹកចិត្តសិស្សឲ្យរកមើលខគម្ពីរដាក់លាក់នៅក្នុង ម៉ូសាយ ២១ ដែលពួកគេអាចចែកចាយជាមួយនឹងមិត្តភក្តិរបស់ពួកគេ ។ សូមឲ្យសិស្សពន្យល់ពីមូលហេតុដែលពួកគេគិតដល់ខគម្ពីរដែលពួកគេបានជ្រើសរើសនេះ ថានឹងជួយដល់មិត្តភក្តិគេ) ។
2. មិត្តម្នាក់មានចរិតរស់រាយ ហើយខិតខំរស់នៅតាមបទដ្ឋាននៃដំណឹងល្អ ។ មានមនុស្សខ្លះមិនចង់ទាក់ទងនឹងមិត្តនេះទេ ដោយនិយាយថា គេនោះ " ល្អពេក" សម្រាប់ពួកគេ ។ តើអ្នកអាចប្រើដំណើររឿងនៃប្រជាជនរបស់អាលម៉ាដើម្បីជួយមិត្តរបស់អ្នកឲ្យទុកចិត្តទៅលើព្រះអម្ចាស់ និង ស្វែងរកកម្លាំងនិងការលួងលោមពេលមានឧបសគ្គនេះដោយរបៀបណា ? (អ្នកអាចលើកទឹកចិត្តសិស្សឲ្យស្វែងរកខគម្ពីរដាក់លាក់នៅក្នុង ម៉ូសាយ ២៤ ដែលពួកគេអាចចែកចាយជាមួយនឹងមិត្តគេ ។ សូមឲ្យពួកគេពន្យល់ពីមូលហេតុដែលពួកគេគិតថាខគម្ពីរដែលពួកគេបានជ្រើសរើសនេះនឹងជួយបាន) ។

សូមឲ្យសិស្សប្រាប់ពីពេលដែលពួកគេ ឬ មនុស្សដែលពួកគេស្គាល់បានធ្វើជាសាក្សីពីព្រះចេស្តានៃការដោះលែងរបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់ពួកគេ ។ (សូមប្រយ័ត្នថា អ្នកមិនលើកទឹកចិត្ត ឬ ឲ្យសិស្សចែកចាយពីការរំលងពីអតីតកាលដែលមិនសមរម្យនៅក្នុងថ្នាក់ឡើយ) ។ សូមលើកទឹកចិត្តសិស្សឲ្យរក្សាសេចក្តីសញ្ញារបស់ពួកគេ អំពាវនាវដល់ព្រះអម្ចាស់ដើម្បីសុំជំនួយ ហើយទុកចិត្តលើព្រះចេស្តានៃការដោះលែងរបស់ទ្រង់ចំពោះឧបសគ្គអ្វីក៏ដោយដែលពួកគេនឹងជួបនៅក្នុងជីវិត ។ សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះចេស្តារបស់ព្រះអម្ចាស់ក្នុងការដោះលែងយើងពីឧបសគ្គ និងការលំបាកនានាដែលមកពីការរំលងរបស់យើងផ្ទាល់ ឬ មកពីការសោកល្បងដែលចង់បន្សុទ្ធយើងផង ។

មេរៀនបន្ទាប់ទៀត (ម៉ូសាយ ២៦–អាលម៉ា ៤)

នៅក្នុងសប្តាហ៍ក្រោយ សិស្សនឹងរៀនអំពីទេវតាមួយដែលត្រូវបានបញ្ជូនមកដើម្បីបញ្ឈប់អាលម៉ាជាកូន ពីការបំផ្លាញសាសនាចក្រ ។ ពួកគេនឹងសិក្សាពីអ្វីដែលបានកើតឡើងដល់អាលម៉ាក្រោយពីបទពិសោធន៍នេះ និង អានការបង្រៀនដ៏សំខាន់ៗមួយចំនួនអំពីកំណើតខាងវិញ្ញាណដែលមាននៅក្នុងព្រះគម្ពីរ ។ នៅពេលស្តេចម៉ូសាយបានសុគត អាលម៉ាត្រូវបានជ្រើសរើសជាអ្នកដឹកនាំសាសន៍នីហ្វៃ ។ អាំលីសៃ ជាបុរសដ៏ទុច្ចរិតម្នាក់បានព្យាយាមទម្លាក់គាត់ ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលអ្វីដែលអាលម៉ាបានធ្វើ ដើម្បីអញ្ជើញព្រះចេស្តានៃការដោះលែងរបស់ព្រះអម្ចាស់នៅក្នុងស្ថានភាពនេះ ។

មេរៀនទី ៦៦

ម៉ូសាយ ២៦

សេចក្តីផ្តើម

អំឡុងពេលរជ្ជកាលរបស់ម៉ូសាយ មានមនុស្សជាច្រើននៃជំនាន់ដែលកំពុងពេញវ័យ —អ្នកដែលជាកូនតូចៗនៅពេលស្តេចបើនយ៉ាមីនបានធ្វើសុន្ទរកថាលើកចុងក្រោយរបស់គាត់—មិនបានជឿតាមការបង្រៀននៃសាសនាចក្រ ហើយបានបដិសេធពុំព្រមស្រែកហៅរកព្រះអម្ចាស់ ។ យុវវ័យដែលមិនជឿទាំងនេះ បានជះឥទ្ធិពលដល់សមាជិកផ្សេងទៀតនៃសាសនាចក្រឲ្យធ្វើអំពើបាបដ៏ធ្ងន់ធ្ងរ ។ អ្នករំលងទាំងនេះជាច្រើនត្រូវបាននាំមកចំពោះមុខអាលម៉ា អ្នកដឹកនាំសាសនាចក្រ ។ អាលម៉ាមិនដឹងថាត្រូវធ្វើអ្វីទេពីជំបូងនោះ ប៉ុន្តែទីបំផុតគាត់បានសុំឲ្យព្រះអម្ចាស់ដឹកនាំគាត់ពីរបៀបដើម្បីកាត់ទោសសមាជិកដែលមិនគោរពតាមនេះ ។ ព្រះអម្ចាស់បានប្រាប់ពីជំណើរការដែលអាលម៉ាគួរធ្វើតាម ក្នុងការដោះស្រាយនឹងសមាជិកនៃសាសនាចក្រដែលត្រូវទទួលខុសត្រូវចំពោះអំពើបាបរបស់ពួកគេ ។ អាលម៉ាក៏បានរៀនពីសេចក្តីមេត្តារបស់ព្រះ និង ឆន្ទៈក្នុងការអក័យទោសដល់អ្នកដែលប្រែចិត្ត ។ អាលម៉ាបានធ្វើតាមការប្រឹក្សារបស់ព្រះអម្ចាស់ ហើយបាននាំការបញ្ជាដល់សាសនាចក្រ ។

ការបង្រៀនយុវវ័យ

ប្រធាន ជេ រ៉ូប៊ីន ក្លាក ជុញ្ញ័រ នៃគណៈប្រធានទីមួយបានបង្រៀនថា ៖

« យុវវ័យនៃសាសនាចក្រមានការស្រែកឃ្លាននូវអាហារផ្សេងៗខាងវិញ្ញាណ ពួកគេឃ្លានដើម្បីរៀនដំណឹងល្អ ហើយពួកគេចង់ឲ្យវាបានបរិសុទ្ធ រឹងមាំខ្លាំង ។ . . .

“ . . . អ្នកមិនចាំបាច់ត្រូវលាក់បាំងសេចក្តីពិតខាងសាសនាដោយស្បែគ្របមួយនៃការណ៍របស់លោកិយឡើយ អ្នកអាចនាំសេចក្តីពិតទាំងនេះទៅកាន់ [ពួកគេ] ដោយបើកចំហ » (*The Charted Course of the Church in Education,* rev ។ ed. [pamphlet, ១៩៩៤], ៣, ៩) ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ២៦:១–៦

មនុស្សជាច្រើននៃជំនាន់ដែលកំពុងពេញវ័យមិនបានជឿតាមដំណឹងល្អទេ ហើយបានដឹកនាំអ្នកដទៃឲ្យធ្វើអំពើបាប

មុនចាប់ផ្តើមថ្នាក់ សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖

តើអ្នកពិពណ៍នាទីបន្ទាល់របស់អ្នកនៅថ្ងៃនេះដោយរបៀបណា ?

តើអ្នកចង់ឲ្យទីបន្ទាល់របស់អ្នករីកចម្រើនតាមរបៀបណា ?

សូមឲ្យសិស្សឆ្លើយតបនឹងសំណួរទាំងនេះនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ ក្រោយពីមានពេលល្មមហើយ សូមពន្យល់ថា ម៉ូសាយ ២៦ រួមមានដំណើររឿងមួយអំពីក្រុមប្រជាជនមួយដែលមិនបានធ្វើអ្វីដែលពួកគេត្រូវធ្វើដើម្បីថែទាំទីបន្ទាល់របស់ពួកគេនោះទេ ។ ជាលទ្ធផល សេចក្តីជំនឿរបស់ពួកគេទៅលើព្រះមិនបានអភិវឌ្ឍ ហើយពួកគេបានដឹកនាំសមាជិកសាសនាចក្រជាច្រើនទៅក្នុងអំពើបាប និង កំហុសឆ្គង ។ សូមស្នើថា នៅពេលសិស្សសិក្សាពីរឿងនេះ ពួកគេគួរគិតពីអ្វីដែលវាបានបង្រៀនអំពីការអភិវឌ្ឍ និង ការពង្រឹងដល់ទីបន្ទាល់របស់ពួកគេ ។

សូមអញ្ជើញសិស្សម្នាក់ឲ្យអាន ម៉ូសាយ ២៦:១–៣ ឲ្យ ។ បន្ទាប់មក សូមសួរសិស្សថា ៖

- តើជម្រើសអ្វីដែលមនុស្សជាច្រើននៃជំនាន់ដែលកំពុងពេញវ័យបានធ្វើ ? (ពួកគេជ្រើសរើសមិនជឿលើប្រពៃណីនៃឱពុកម្តាយរបស់ពួកគេ) ។
- តើអ្នកគិតថា ហេតុអ្វីបានជាការឥតជំនឿរបស់មនុស្សរាវាំងសមត្ថភាពរបស់ពួកគេក្នុងការ “ យល់ពីព្រះបន្ទូលរបស់ព្រះ” ? (ម៉ូសាយ ២៦:៣) ។

សូមពន្យល់ថា ការជឿ (ឬ ការមានបំណងក្នុងការជឿ) ដឹកនាំទៅរកសកម្មភាពដែលពង្រឹងដល់ទីបន្ទាល់របស់យើង ។ ផ្ទុយទៅវិញនៅពេលមនុស្សជ្រើសរើសមិនជឿ ពួកគេក៏ជ្រើសរើសមិនធ្វើនូវរឿងមួយចំនួនដែលនឹងជួយដល់ពួកគេឲ្យអភិវឌ្ឍទីបន្ទាល់ដ៏រឹងមាំដែរ ។ សូមឲ្យសិស្សអាន ម៉ូសាយ ២៦:៣–៤, ៦ ដោយស្ងាត់ៗ ។ សូមឲ្យសិស្សពាក់កណ្តាលថ្នាក់រកមើលអ្វីដែលពួកជំនាន់ដែលកំពុងពេញវ័យមិនចង់ធ្វើ ដោយសារតែការឥតជំនឿរបស់ពួកគេ ។ សូមឲ្យសិស្សពាក់កណ្តាលថ្នាក់ទៀតរកមើលនូវលទ្ធផលនៃការឥតជំនឿនេះ ។

- តើពួកជំនាន់ដែលកំពុងពេញវ័យបានបដិសេធមិនធ្វើអ្វីខ្លះ ដោយសារតែការឥតជំនឿរបស់ពួកគេ ?
- តើមានឥទ្ធិពលអ្វីខ្លះនៃការឥតជំនឿរបស់ពួកគេ ?

ក្រោយពីសិស្សបានពិភាក្សាពីសំណួរទាំងនេះហើយ សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ដើម្បីអភិវឌ្ឍ និង រក្សាទីបន្ទាល់មួយយើងត្រូវ . . .*

សូមឲ្យសិស្សម្នាក់អានពួនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ។ សូមឲ្យសិស្សស្តាប់ និង រកនូវរបៀបដើម្បីបំពេញឃ្លានៅលើក្តារខៀន ។

“ ទីបន្ទាល់ត្រូវការការថែទាំដោយការអធិស្ឋានដោយក្តីជំនឿ ការស្រេកឃ្លាននូវព្រះបន្ទូលរបស់ព្រះក្នុងព្រះគម្ពីរ និង ការគោរពតាមសេចក្តីពិតដែលយើងបានទទួល ។ មានគ្រោះថ្នាក់នៅក្នុងការមិនបានអធិស្ឋាន ។ មានគ្រោះថ្នាក់ដល់ទីបន្ទាល់របស់យើងនៅក្នុងការគ្រាន់តែសិក្សា និង ការអានព្រះគម្ពីរធម្មតា ។ ពួកវាជាប្រូតេអីនដ៏ចាំបាច់សម្រាប់ទីបន្ទាល់របស់យើង ។ . . .

“ ការខ្ជាប់ខ្ជួនទៅនឹងព្រះបន្ទូលនៃព្រះ ការអធិស្ឋានដោយអស់ពីចិត្ត និង ការគោរពតាមព្រះបញ្ញត្តិរបស់ព្រះត្រូវតែបានអនុវត្តរាល់ពេល និង ជាបន្តបន្ទាប់ដើម្បីឲ្យទីបន្ទាល់របស់អ្នករីកចម្រើន និង ធំធាត់ ” (“ ទីបន្ទាល់ដ៏រស់រវើក ,” *Ensign* ឬ *លេអាហូណា*, ខែ ឧសភា ឆ្នាំ ២០១១, ទំព័រ ១២៧) ។

- តើការអនុវត្តអ្វីដែលប្រធាន អារ៉ារ៉ុង បានបញ្ជាក់ថានឹងជួយដល់យើងឲ្យចិញ្ចឹមដល់ទីបន្ទាល់របស់យើងនោះ ? (នៅពេលសិស្សរកឃើញការអនុវត្តទាំងនេះហើយ សូមបញ្ជូលវានៅក្នុងប្រយោគនៅលើក្តារខៀន ៖ ***ដើម្បីអភិវឌ្ឍ និង ថែទាំទីបន្ទាល់មួយ យើងត្រូវខ្ជាប់ខ្ជួនទៅនឹងព្រះបន្ទូលនៃព្រះ អធិស្ឋានដោយសេចក្តីជំនឿ និង គោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ។***)
- តើការអនុវត្តទាំងនេះបានជះឥទ្ធិពលដល់ទីបន្ទាល់របស់អ្នកដោយរបៀបណា ?

សូមឲ្យសិស្សអាន ម៉ូសាយ ២៦:៥–៦ ដោយស្ងាត់ៗ ដោយរកមើលពីរបៀបដែលយ៉ូរ៉ីយឥតជំនឿបានជះឥទ្ធិពលដល់សមាជិកនៃសាសនាចក្រខ្លះ ។

- សូមគិតពីប្រយោគខាងក្រោម ៖ " វាជាការចាំបាច់ថា អស់អ្នកណាដែលនៅក្នុងសាសនាចក្រដែលប្រព្រឹត្តអំពើបាបនោះសាសនាចក្រត្រូវព្រមានដាស់តឿន " (ម៉ូសាយ ២៦:៦) ។ តើអ្នកគិតថា វាមានន័យយ៉ាងណា ? (វាចាំបាច់សម្រាប់សមាជិកសាសនាចក្រដែលបានប្រព្រឹត្តអំពើបាបដើម្បីត្រូវបានព្រមាន និង ទទួលខុសត្រូវ) ។

ម៉ូសាយ ២៦:៧–១៤

អាលម៉ាសុំការណែនាំពីព្រះអម្ចាស់ពីរបៀបដើម្បីកាត់ទោសដល់អ្នកណាដែលធ្វើអំពើបាប

សូមឲ្យសិស្សស្រមៃមើលថាតើវាមានសភាពបែបណា ក្នុងការធ្វើជាប៊ីស្សពនៃវួដមួយដែលមានសមាជិក ធ្វើអំពើបាបធ្ងន់ធ្ងរ ហើយមិនបានប្រែចិត្តនោះ ។ សូមឲ្យសិស្សសញ្ជឹងគិតដោយស្ងៀមស្ងាត់ ពីអ្វីដែលពួកគេនឹងធ្វើនៅក្នុងស្ថានភាពនេះ ។ តើពួកគាត់នឹងបំពេញការទទួលខុសត្រូវរបស់ពួកគេដើម្បីដោះស្រាយនឹងសមាជិកដែលត្រូវទទួលខុសត្រូវចំពោះអំពើបាបរបស់ពួកគេ និង ដើម្បីជួយពួកគេឲ្យប្រែចិត្តដោយរបៀបណា ? សូមពន្យល់ថា អាលម៉ា ជាអ្នកដឹកនាំនៃសាសនាចក្រ បានជួបនឹងឧបសគ្គដូចគ្នានេះ ។

សូមសង្ខេប ម៉ូសាយ ២៦:៧–១២ ដោយការពន្យល់ថា អ្នកដែលបានធ្វើបាបត្រូវបាននាំមកជួបនឹងអាលម៉ា ។ គ្មានអ្វីដូចនេះ បានកើតឡើងពីមុនមកទេនៅក្នុងសាសនាចក្រ ហើយអាលម៉ាមិនដឹងពីអ្វីដែលត្រូវធ្វើនោះទេ ។ គាត់បានសម្រេចចិត្តបញ្ជូនអ្នករំលងទាំងឡាយទៅកាន់ស្តេចម៉ូសាយឲ្យកាត់ទោស ។ ស្តេចម៉ូសាយបានបញ្ជូនពួកគេឲ្យទៅអាលម៉ាវិញ ដែលបានកាន់សិទ្ធិអំណាចមកពីព្រះក្នុងការកាត់ទោសសមាជិកសាសនាចក្រណាដែលបានធ្វើអំពើបាប ។

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២៦:១៣–១៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពីអារម្មណ៍ដែលអាលម៉ាមានអំពីការទទួលខុសត្រូវរបស់គាត់ក្នុងការកាត់សេចក្តីដល់អ្នកដែលបានធ្វើអំពើបាប ។

- នៅពេលដែលអាលម៉ាមានអារម្មណ៍ថាជួបបញ្ហាក្នុងកាតព្វកិច្ចរបស់គាត់ក្នុងការកាត់សេចក្តីអ្នករំលងទាំងឡាយ តើគាត់បានធ្វើអ្វីខ្លះ ?
- ហេតុអ្វីបានជាវាសំខាន់ដើម្បីដឹងថា ប៊ីស្សព និង ប្រធានសាខាស្វែងរក និង ទទួលនូវការដឹកនាំពីព្រះអម្ចាស់ នៅពេលជួយដល់អ្នកដែលបានធ្វើអំពើបាប ?

ម៉ូសាយ ២៦:១៥–៣២

ព្រះអម្ចាស់បានបង្ហាញដល់អាលម៉ាពីរបៀបដើម្បីដោះស្រាយនឹងសមាជិកនៃសាសនាចក្រឲ្យទទួលខុសត្រូវចំពោះអំពើបាបរបស់ពួកគេ ហើយដាក់ចេញនូវលក្ខខណ្ឌនៃការប្រែចិត្ត

ដើម្បីជួយសិស្សឲ្យយល់បរិបទក្នុង ម៉ូសាយ ២៦:១៥–៣២ សូមបង្ហាញថា ខគម្ពីរទាំងនេះរួមមានចម្លើយរបស់ព្រះអម្ចាស់ចំពោះសំណួររបស់អាលម៉ាទាក់ទងនឹងអ្វីដែលគាត់គួរធ្វើចំពោះអ្នករំលងទាំងឡាយ ។ នៅពេលសិស្សសិក្សាពីចម្លើយរបស់ព្រះអម្ចាស់ សូមលើកទឹកចិត្តពួកគេឲ្យរកមើលគោលការណ៍ និងគោលលទ្ធិទាំងឡាយណាដែលជួយពួកគេឲ្យយល់កាន់តែច្បាស់ពីតួនាទីនៃចៅក្រមបព្វជិតភាព ដូចជាប៊ីស្សព និង ប្រធានសាខា (និង សម្រាប់អ្នកកាន់បព្វជិតភាពមីលគីស្សាដែក ប្រធានស្តេក មណ្ឌល និង ប្រធានបេសកកម្ម) ។ សូមឲ្យពួកគេរកមើលគោលការណ៍ និង គោលលទ្ធិអំពីការស្វែងរកការអភ័យទោសផងដែរ ។

សូមឲ្យសិស្សអាន ម៉ូសាយ ២៦:១៧–២៨ ដោយស្ងាត់ៗ ដោយកត់សម្គាល់ពីពេលនីមួយៗដែលព្រះអម្ចាស់បានប្រើពាក្យ *របស់យើង* ឬ *យើង* ។ អ្នកអាចស្នើថា សិស្សគួរគូសពាក្យទាំងនេះចំណាំទុករាល់ពេលពួកគេជួប ។ បន្ទាប់មក សូមសួរសិស្សថា ៖

- នៅក្នុង ម៉ូសាយ ២៦:១៧–២៨ តើពាក្យ *យើង* និង *របស់យើង* ស្មើអ្វីអំពីកន្លែងរបស់ព្រះអម្ចាស់នៅក្នុងដំណើរការនៃការប្រែចិត្តនោះ ? (អ្នកអាចឲ្យសិស្សចែកចាយពីឃ្លា ឬ ខគម្ពីរជាក់លាក់ដែលគាំទ្រដល់ចម្លើយរបស់ពួកគេ ។)
- តើសេចក្តីពិតអ្វីដែលយើងអាចរៀនពី ម៉ូសាយ ២៦:២០–២១ អំពីតួនាទីរបស់អ្នកបម្រើនៃព្រះអម្ចាស់នៅក្នុងដំណើរការនៃការប្រែចិត្ត ? (សូមជួយសិស្សឲ្យយល់ថា **អ្នកដឹកនាំបព្វជិតភាពតំណាងឲ្យព្រះអម្ចាស់** ហើយថា **នៅក្នុងករណីអំពើបាបធ្ងន់ធ្ងរ ប៊ីស្សព និង ប្រធានសាខាអាចជួយយើងឲ្យប្រែចិត្ត និង ទទួលបានការអភ័យទោស**) ។
- តើប៊ីស្សព ឬ ប្រធានសាខាអាចជួយអ្នកដែលតស៊ូនឹងអំពើបាប និង ការល្បួងដោយរបៀបណា ?

សូមពន្យល់ថា ព្រះអម្ចាស់បានបង្រៀនអាលម៉ាអំពីអ្វីដែលអ្នកស្វែងរកការអភ័យទោសត្រូវធ្វើដើម្បីទទួលបានការប្រែចិត្ត ។ សូមឲ្យសិស្សអាន ម៉ូសាយ ២៦:២៩–៣២ ជាដៃគូ ហើយរកមើលគោលការណ៍ដែលជួយដល់ពួកគេឲ្យយល់ពីអ្វីដែលព្រះអម្ចាស់តម្រូវឲ្យយើងធ្វើ នៅពេលយើងប្រែចិត្ត ។

ក្រោយពីសិស្សមានពេលសិក្សាខគម្ពីរទាំងនេះហើយ សូមឲ្យសិស្សបីបួននាក់សរសេរនៅលើក្តារខៀន ដោយប្រើពាក្យគេផ្ទាល់ ពីគោលការណ៍ដែលពួកគេបានរកឃើញ ។ ចម្លើយរបស់ពួកគេអាចមានដូចខាងក្រោម ៖

ការសារភាពនៃអំពើបាបដឹកនាំទៅរកការអភ័យទោស ។

ព្រះអម្ចាស់នឹងអភ័យទោសដល់អស់អ្នកណាដែលប្រែចិត្តដោយស្មោះអស់ពីចិត្ត ។

យើងត្រូវអភ័យទោសដល់អ្នកដទៃដើម្បីទទួលបានការអភ័យទោសពីព្រះអម្ចាស់ ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ពីគោលការណ៍នេះ សូមសួរសំណួរខាងក្រោមខ្លះ ឬ ទាំងអស់ ៖

- នៅក្នុង ម៉ូសាយ ២៦:២៩ តើអ្វីជាអត្ថន័យនៃឃ្លា " ទទួលសារភាពនូវអំពើបាបទាំងឡាយរបស់ខ្លួនចំពោះអ្នក និង ចំពោះយើង " ? (អ្នកអាចត្រូវបង្ហាញថា នៅក្នុងខគម្ពីរនេះ ពាក្យ *អ្នក* សំដៅលើអាលម៉ា) ។
- នៅពេលនរណាម្នាក់បានធ្វើអំពើបាបដ៏ធ្ងន់ធ្ងរ តើអ្នកគិតថា ហេតុអ្វីបានជាមនុស្សនោះត្រូវសារភាពដល់ព្រះអម្ចាស់ និង ដល់អ្នកដឹកនាំសាសនាចក្រដ៏សមរម្យ ? (ការរំលងដ៏ធ្ងន់ធ្ងរ ដូចជាការរំលងច្បាប់ព្រហ្មចារីភាព អាចមានគ្រោះថ្នាក់ដល់សមាជិកភាពក្នុងសាសនាចក្ររបស់បុគ្គលនោះ ។ ហេតុដូច្នេះហើយ នៅក្នុងករណីបែបនោះ បុគ្គលម្នាក់ត្រូវសារភាពអំពើបាបទៅដល់ព្រះអម្ចាស់ និង អ្នកតំណាងរបស់ទ្រង់នៅក្នុងសាសនាចក្រ ។ ប៊ីស្សព និង ប្រធានសាខាកាន់កូនសោបព្វជិតភាពដើម្បីជួយដល់អ្នកណាដែលបានធ្វើបាប ហើយស្វែងរកការអភ័យទោស ។ ខណៈពេលដែលមានតែព្រះអម្ចាស់អាចអភ័យទោសដល់អំពើបាបនោះ អ្នកដឹកនាំបព្វជិតភាពដើរតួគាំទ្រក្នុងការជួយមនុស្សដែលបានទទួលការអភ័យទោសនោះ ។ ពួកគេរក្សាការសម្ងាត់នៃការសារភាពទាំងឡាយ ហើយជួយអ្នកដែលសារភាពនោះឆ្លងកាត់ដំណើរការនៃការប្រែចិ) ។
- តើអ្នកគិតថា វាមានន័យយ៉ាងណាដល់អ្នកណាម្នាក់ដែលប្រែចិត្ត " ដោយស្មោះអស់ពីចិត្ត " នោះ ? (ម៉ូសាយ ២៦:២៩) ។
- តើអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់តម្រូវឲ្យយើងអភ័យទោសដល់អ្នកដទៃនោះ ? តើការប្រែចិត្ត និង ការអភ័យទោសដល់អ្នកដទៃទាក់ទងគ្នាដោយរបៀបណា ? (សូមមើល នីហ្វៃទី៣ ១៣:១៤–១៥; គ. និង ស. ៦៤:៨–១១) ។
- ចំពោះអ្នកដែលមានអារម្មណ៍ថា អំពើបាបរបស់ពួកគេមិនអាចត្រូវបានអភ័យទោសឲ្យទេ តើឃ្លានៅក្នុងខគម្ពីរទាំងនេះអាចផ្តល់ការលើកទឹកចិត្ត ឬ ការលួងលោមដល់នរណាម្នាក់ដែលចង់ប្រែចិត្តដោយរបៀបណា ?

ម៉ូសាយ ២៦:៣៣–៣៩

អាលម៉ាគោរពតាមការប្រឹក្សារបស់ព្រះអម្ចាស់ ដោយកាត់ទោសដល់អ្នកដែលបានធ្វើអំពើបាប និង នាំឲ្យមានរបៀបរៀបរយឡើងវិញនៅក្នុងសាសនាចក្រ

សូមពន្យល់ថា ម៉ូសាយ ២៦:៣៣–៣៧ ប្រាប់ពីរបៀបដែលអាលម៉ា បានធ្វើតាមការណែនាំរបស់ព្រះអម្ចាស់ ដោយកាត់សេចក្តីសមាជិកសាសនាចក្រដែលបានធ្វើអំពើបាប ហើយបាននាំមកនូវរបៀបរៀបរយឡើងវិញនៅក្នុងសាសនាចក្រ ។ សូមឲ្យសិស្សអាន ម៉ូសាយ ២៦:៣៤–៣៧ ដោយស្ងាត់ៗ ដោយរកមើលលទ្ធផលនៃការខិតខំរបស់អាលម៉ាក្នុងការធ្វើតាមការប្រឹក្សារបស់ព្រះអម្ចាស់ ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា នៅពេលយើងប្រែចិត្ត ហើយរស់នៅដោយសុចរិត យើងអាចមានសន្តិភាពនៅក្នុងចិត្តយើង និង រីកចម្រើនខាងវិញ្ញាណ ។

ម៉ូសាយ ២៧

សេចក្តីផ្តើម

អាលម៉ាជាកូន និង កូនប្រុសរបស់ស្តេចម៉ូសាយបានបះបោរទាស់នឹងឪពុករបស់ពួកគេ និងព្រះអម្ចាស់ ហើយបានចង់បំផ្លាញសាសនាចក្រនៃព្រះថែមទៀត ។ ការខិតខំរបស់ពួកគេបានបញ្ចប់នៅពេលទេវតាមួយ ដែលបានបញ្ជូនមកជាចម្លើយដល់ការអធិស្ឋានរបស់ពួកសុចរិត បានហៅពួកគេឲ្យប្រែចិត្ត ។ ជាលទ្ធផលនៃបទពិសោធន៍ដ៏អស្ចារ្យហេតុនេះ ពួកគេបានកើតម្តងទៀតតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ហើយពួកគេបានធ្វើដំណើរទូទាំងដែនដីសារ៉ាហិមឡាដើម្បីផ្សព្វផ្សាយដំណឹងល្អ ហើយជួសជុលនូវការរងខូចខាតដែលពួកគេបានធ្វើ ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ២៧:១–២២

ទេវតាមួយហៅអាលម៉ាជាកូន និង កូនប្រុសរបស់ម៉ូសាយទាំងឡាយឲ្យប្រែចិត្ត

ដើម្បីផ្តល់បរិបទនៃមេរៀននេះ សូមសង្ខេប ម៉ូសាយ ២៧:១–៧ ដោយការពន្យល់ថា អ្នកឥតជំនឿជាច្រើននៅក្នុងដែនដីសារ៉ាហិមឡាបានចាប់ផ្តើមកាត់ទោសអ្នកដែលនៅក្នុងសាសនាចក្រ ។ ក្រោយពីស្តេចម៉ូសាយបានចេញនូវសេចក្តីប្រកាសមួយហាមឃាត់នូវសកម្មភាពបែបនោះ ប្រជាជនភាគច្រើនបានគោរពតាម ហើយសន្តិភាពត្រូវបានស្តារឡើងវិញ ។ ទោះយ៉ាងណាក្តី ប្រជាជនខ្លះបន្តព្យាយាមបំផ្លាញសាសនាចក្រ ។ មនុស្សប្រាំនាក់នោះមាន កូនប្រុសរបស់អាលម៉ា គឺអាលម៉ា និង ពួកបុត្រារបស់ស្តេចម៉ូសាយ អាំម៉ូន អើរ៉ុន អោមណើរ និង ហិមណៃ ។ កូនប្រុសរបស់អាលម៉ា គឺអាលម៉ា ជាញឹកញាប់ត្រូវបានហៅថាជា អាលម៉ាជាកូន ។

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២៧:៨–១០ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពាក្យ ឬ ឃ្លាដែលប្រាប់ពីអាលម៉ាជាកូន និងពួកបុត្រារបស់ស្តេចម៉ូសាយ ។

- តើឆ្នែកអ្វីនៃការពិពណ៌នាពីអាលម៉ាជាកូន និង ពួកបុត្រារបស់ស្តេចម៉ូសាយធ្វើឲ្យអ្នកចាប់អារម្មណ៍បំផុតនោះ ? ហេតុអ្វី ? (សូមសរសេរពាក្យ និង ឃ្លានៅលើក្តារខៀន ពេលសិស្សប្រាប់ពីវា ។ សូមទុកចន្លោះនៅលើក្តារខៀនដើម្បីបង្កើតបញ្ជីទីពីរនៅក្នុងមេរៀនក្រោយពីការណ៍នេះ) ។

សូមឲ្យសិស្សសញ្ជឹងគិតសំណួរខាងក្រោមដោយស្ងៀមស្ងាត់ ៖

- ប្រសិនបើអ្នកបានរស់នៅក្នុងដែនដីសារ៉ាហិមឡាពេលនេះ តើអ្នកគិតថា អ្នកនឹងឆ្លើយតបចំពោះសកម្មភាពរបស់អាលម៉ាជាកូន និងពួកបុត្រារបស់ស្តេចម៉ូសាយដោយរបៀបណា ?

សូមបង្ហាញរូបភាពការប្រែចិត្តរបស់អាលម៉ាជាកូន (*សៀវភៅរូបភាពដំណឹងល្អ* [២០០៩], លេខ. ៧៧) ។ សូមឲ្យសិស្សអានដោយស្ងាត់ៗក្នុង ម៉ូសាយ ២៧:១១–១៣ ដែលជាដំណើររឿងបង្ហាញនៅក្នុងគំនូរនេះ ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២៧:១៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលមូលហេតុដែលទេវតាបានមកជួបនឹងអាលម៉ា និង កូនប្រុសរបស់ម៉ូសាយ ។

- តើខគម្ពីរនេះបង្រៀនអំពីរបៀបដែលយើងអាចជួយអ្នកដទៃដែលស៊ូទ្រាំអ្វីខ្លះ ? (សូមប្រាកដថា សិស្សយល់ថា **ព្រះអម្ចាស់ឆ្លើយតបនឹងការអធិស្ឋានដោយក្តីជំនឿរបស់យើងសម្រាប់អ្នកដទៃ ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន ហើយស្នើឲ្យសិស្សសរសេរវាចូលក្នុងព្រះគម្ពីររបស់ពួកគេក្បែរ ម៉ូសាយ ២៧:១៤ ។ អ្នកក៏អាចស្នើថា ពួកគេគូរបន្ថែមសេចក្តីយោងឆ្លងទៅ យ៉ាកុប ៥:១៦ ដែរ ។ សូមបង្ហាញថា ព្រះអម្ចាស់ឆ្លើយតបនឹងការអធិស្ឋានរបស់យើងមិនមែនសម្រាប់តែអ្នកដែលស៊ូទ្រាំខាងវិញ្ញាណប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់អ្នកដែលមានឧបសគ្គ និងតម្រូវការផ្សេងទៀត) ។

- តើនៅពេលណាដែលការអធិស្ឋានរបស់នរណាម្នាក់ធ្វើឲ្យមានភាពខុសគ្នានៅក្នុងជីវិតរបស់អ្នក ?
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ការអធិស្ឋានរបស់អ្នកបានធ្វើឲ្យមានភាពខុសគ្នានៅក្នុងជីវិតរបស់នរណាម្នាក់ ?

សូមលើកទឹកចិត្តសិស្សឲ្យបន្តអធិស្ឋានសម្រាប់អ្នកដទៃ ។ សូមថ្លែងទីបន្ទាល់ថា ដំណើររឿងនៃអាលម៉ាជាកូន និង ពួកបុត្រារបស់ម៉ូសាយគឺជាភស្តុតាងដែលព្រះអម្ចាស់ឮដល់ការអធិស្ឋានរបស់យើងជំនួសឲ្យអ្នកដទៃ ។ ទ្រង់នឹងមិនរំលងសិទ្ធនៃអ្នកដែលយើងអធិស្ឋានឲ្យនោះទេ ប៉ុន្តែទ្រង់នឹងឮការអធិស្ឋានរបស់យើង ហើយទ្រង់នឹងឆ្លើយតបតាមរបៀបរបស់ទ្រង់ និង តាមពេលវេលារបស់ទ្រង់ ។

សូមឲ្យសិស្សម្នាក់ក្រោកឈរទៅខាងមុខថ្នាក់ ហើយអាន ម៉ូសាយ ២៧:១៥–១៦ ឮៗ ។ សូមពន្យល់ថា ទាំងនេះគឺជាពាក្យរបស់ទេវតាដែលមកជួបនឹងអាលម៉ា និងកូនប្រុសរបស់ម៉ូសាយ ។ សូមបញ្ជាក់ថា ទេវតាបាននិយាយ " ដោយសូរផ្គរលាន់ ដែលធ្វើឲ្យដែនដីកក្រើកនៅត្រង់កន្លែងដែលពួកគេឈរ " (ម៉ូសាយ ២៧:១១) ។

- តើអ្វីដែលធ្វើឲ្យអ្នករំភើបអំពីអ្វីដែលទេវតាបានធ្វើ និងនិយាយ ? ហេតុអ្វីបានជាវាធ្វើឲ្យអ្នករំភើប ?

សូមសង្ខេប ម៉ូសាយ ២៧:១៩–២២ ដោយការពន្យល់ថា ក្រោយពីទេវតាបានចែកចាយសារលិខិតរបស់ទ្រង់ហើយ អាលម៉ាមិនអាចហើបមាត់បានឡើយ បានក្លាយទៅជាអស់កម្លាំង ហើយត្រូវបានគេសែងគាត់ទៅដោយឥតកម្រើករហូតដល់គេដាក់គាត់ចុះនៅខាងមុខឪពុកគាត់ (សូមមើល ម៉ូសាយ ២៧:១៩) ។ នៅពេលឪពុករបស់អាលម៉ាបានឮពីអ្វីដែលបានកើតឡើង គាត់ " បានអរើករាយ ព្រោះ

> ***ការបង្រៀនដោយព្រះវិញ្ញាណបរិសុទ្ធ***
>
> ព្រះអម្ចាស់បានមានបន្ទូលថា យើងត្រូវ " ផ្សាយដំណឹងល្អ [របស់ទ្រង់] ដោយសារព្រះវិញ្ញាណគឺព្រះដ៏ជាជំនួយដែលបានចាត់ឲ្យចេញទៅបង្រៀនពីសេចក្តីពិត " (គ. & ស. ៥០:១៤) ។ នៅពេលអ្នកបង្រៀន សូមស្វែងរកការដឹកនាំពីព្រះវិញ្ញាណ ដើម្បីជួយអ្នកសម្របមេរៀននេះទៅតាមតម្រូវការសិស្សរបស់អ្នក ។

លោកដឹងថា នោះគឺជាព្រះចេស្តានៃព្រះ " (ម៉ូសាយ ២៧:២០) ។ គាត់បានចាត់ឲ្យពួកបណ្តាជនប្រមូលគ្នាមក " ដើម្បីគេអាចធ្វើជាសាក្សីចំពោះអ្វីៗដែលព្រះអម្ចាស់ទ្រង់បានធ្វើដល់កូនប្រុសរបស់លោក " (ម៉ូសាយ ២៧:២១) ។ គាត់ក៏បានចាត់ពួកសង្ឃប្រជុំគ្នា ហើយពួកគេបានតមអាហារ និងអធិស្ឋានឲ្យកូនប្រុសរបស់លោកអាចទទួលបានកម្លាំង និង អាចនិយាយបានវិញ (សូមមើល ម៉ូសាយ ២៧:២២) ។

ម៉ូសាយ ២៧:២៣–៣១

អាលម៉ាជាកូនបានប្រែចិត្ត ហើយបានកើតជាថ្មីម្តងទៀត

សូមត្រឡប់ទៅបញ្ជីដែលពិពណ៌នាពីអាលម៉ា និងកូនប្រុសរបស់ម៉ូសាយដែលអ្នកបានសរសេរនៅលើក្តារខៀនពីមុននោះ ។ សូមសរសេរលើបញ្ជីនោះថា *ពីមុន* ។សូមសរសេរ *ក្រោយមក* នៅលើផ្នែកម្ខាងទៀតនៃក្តារខៀន ។ សូមឲ្យសិស្សអាន ម៉ូសាយ ២៧:២៣–២៤, ២៨–៣៩ ដោយរកមើលពាក្យ និងឃ្លាដែលបង្ហាញពីរបៀបដែលអាលម៉ាបានផ្លាស់ប្តូរ ។ សូមផ្តល់ឱកាសដល់សិស្សពីរបីនាក់ឲ្យសរសេរពាក្យ និង ឃ្លាទាំងនេះនៅលើក្តារខៀន ។

- យោងតាម ម៉ូសាយ ២៧:២៤ និង ២៨ តើអាលម៉ាបានធ្វើអ្វី ដែលបានដឹកនាំទៅរកការផ្លាស់ប្តូរ ? តើព្រះអម្ចាស់បានធ្វើអ្វី ? នៅពេលយើងស្វែងរកការផ្លាស់ប្តូរ និង ធ្វើតាមព្រះអង្គសង្គ្រោះ ហេតុអ្វីបានជាវាសំខាន់ដើម្បីយល់ពីអ្វីដែលយើងត្រូវធ្វើនោះ ? ហេតុអ្វីបានជាវាសំខាន់ដើម្បីយល់ពីអ្វីដែលព្រះអម្ចាស់នឹងធ្វើសម្រាប់យើង ?
- តើការរៀនពីបទពិសោធន៍របស់អាលម៉ាបានជួយនរណាម្នាក់ដែលគិតថា គាត់មិនអាចត្រូវបានអភ័យទោសឲ្យដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២៧:២៥–២៦ ឮៗ ។ សូមឲ្យសិស្សរកមើលគោលលទ្ធិ ដែលព្រះអម្ចាស់បានបង្រៀនដល់អាលម៉ា ។ (ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាក្តី សូមប្រាកដថា ពួកគេយល់ថា **យើងម្នាក់ៗត្រូវតែកើតជាថ្មីតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទម្តងទៀត ។** អ្នកអាចសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមពន្យល់ថា ដើម្បីបានកើតជាថ្មីម្តងទៀត មានន័យថាដើម្បីឲ្យមានព្រះវិញ្ញាណនៃព្រះអម្ចាស់ បណ្តាលឲ្យមានការផ្លាស់ប្តូរនៅក្នុងដួងចិត្តរបស់មនុស្សម្នាក់ ដើម្បីឲ្យគេគ្មានបំណងប្រាថ្នាដើម្បីធ្វើអាក្រក់ទៀត ប៉ុន្តែដើម្បីមានបំណងស្វែងរករឿងនៃព្រះវិញ (សូមមើល ម៉ូសាយ ៥:២) ។

ការចែកចាយសេចក្តីថ្លែងការណ៍របស់ព្យាការី

នៅពេលការជជែកស្រង់មួយរឿង វាអាចជួយដល់អ្នកច្រើន ពេលអ្នកចែកវាជាក្រដាស ឬ សរសេរវានៅលើក្តារខៀន ។ ដោយគ្មានជំនួយបែបនេះទេ សិស្សអាចដាច់អារម្មណ៍ ឬ ពិបាកយល់ ។

អ្នកក៏អាចនឹងពន្យល់ថា ទោះបីជាការផ្លាស់ប្តូរយ៉ាងខ្លាំងនៃដួងចិត្ត ពិតជាបានកើតឡើងភ្លាមៗដល់អាលម៉ា និង កូនប្រុសរបស់អាលម៉ាក៏ពួកយើងភាគច្រើនត្រូវបានផ្លាស់ប្តូរតាមរយៈដង្វាយធួនជាបន្តបន្ទាប់ដែរ ។ វាគឺជាដំណើរការ ជាជាងហេតុការណ៍មួយ ។ ដើម្បីជួយសិស្សឲ្យយល់ពីគោលលទ្ធិនេះកាន់តែច្បាស់ សូមឲ្យពួកគេម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អែសរ៉ា ថាហ្វ ប៊ែនសឺន ៖

" យើងត្រូវតែប្រយ័ត្នប្រយែង នៅពេលយើងស្វែងរកដើម្បីក្លាយឲ្យកាន់តែដូចជាព្រះ ថាយើងមិនទៅជាបាក់ទឹកចិត្ត និង បាត់បង់ក្តីសង្ឃឹមនោះទេ ។ ការប្រែក្លាយដូចជាព្រះគ្រីស្ទគឺជាការស្វែងរកពេញមួយជីវិត ហើយជាញឹកញាប់វាជាប់ទាក់ទងទៅនឹងការរីកចម្រើន និងការផ្លាស់ប្តូរដែលមានសភាពយឺត ស្ទើរតែពុំអាចដឹងបាន ។ ព្រះគម្ពីរបានកត់ត្រានូវដំណើររឿងដែលគួរចងចាំនៃជីវិតរបស់មនុស្សដែលផ្លាស់ប្តូរយ៉ាងខ្លាំង ក្នុងមួយពព្រិចភ្នែក ដូចជាបានកើតឡើងដល់ ៖ អាលម៉ាជាកូនប៉ុលនៅតាមផ្លូវទៅទីក្រុងដាម៉ាសអេណុស ដែលបានអធិស្ឋានដល់យប់ជ្រៅស្តេចឡាម៉ូណៃ ។ គំរូដ៏អស្ចារ្យនៃអំណាចក្នុងការផ្លាស់ប្តូរបែបនេះ ទោះបីជាអ្នកដែលបានធ្លាក់ជ្រៅក្នុងអំពើបាបបានផ្តល់ទំនុកចិត្តថា ដង្វាយធួនអាចជំរះបាន ទោះបីជាអ្នកបានធ្លាក់ទៅក្នុងអំពើបាបដ៏ធ្ងន់ធ្ងរបំផុតក៏ដោយ ។

" ប៉ុន្តែយើងត្រូវប្រយ័ត្ន នៅពេលយើងពិភាក្សាពីគំរូដ៏អស្ចារ្យទាំងនេះ ។ ទោះបីជាពួកគេមានពិត និង មានអំណាច ពួកគេគឺជាករណីលើកលែងជាជាងក្បួនច្បាប់ ។ សម្រាប់រាល់ករណីរបស់ប៉ុល អេណុស និង ស្តេចឡាម៉ូណៃ មានមនុស្សជាច្រើនរយពាន់នាក់ដែលស្វែងរកដំណើរការនៃការប្រែចិត្តស៊ប់ស្ងាត់ជាង មិនអាចមើលដឹងជាងឆ្ងាយណាស់ ។ ពីមួយថ្ងៃទៅមួយថ្ងៃ ពួកគេខិតទៅជិតព្រះអម្ចាស់កាន់តែខ្លាំង ពួកគេកសាងជីវិតដូចជាព្រះដោយការដឹងតិចតួច ។ ពួកគេរស់នៅជីវិតដ៏ស៊ប់ស្ងាត់នៃសេចក្តីល្អ ការបម្រើ និង ការប្តេជ្ញា " (" A Mighty Change of Heart," *Ensign* ខែ តុលា ឆ្នាំ ១៩៨៩, ទំព័រ ៥) ។

ក្រោយពីសិស្សចែកចាយពីអ្វីដែលពួកគេបានរៀនពីសេចក្តីថ្លែងការណ៍នេះហើយ សូមឲ្យពួកគេឆ្លើយនឹងសំណួរខាងក្រោមមួយនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេរយៈពេលពីរបីនាទី ។ (អ្នកអាចសរសេរសំណួរទាំងនេះនៅលើក្តារខៀនមុនចាប់ផ្តើមថ្នាក់ រៀបចំជាក្រដាសចែកឲ្យសិស្ស ឬ អានសំណួរយឺតៗដើម្បីឲ្យសិស្សអាចសរសេរវាចូលក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ) ។

- តើអ្នកត្រូវបានផ្លាស់ប្តូរតាមរយៈដង្វាយធួន នៅពេលអ្នកបានប្រែចិត្ត ហើយបានធ្វើអស់ពីសមត្ថភាពដើម្បីធ្វើតាមព្រះអង្គសង្គ្រោះដោយរបៀបណា ?
- តើអ្វីជារឿងមួយដែលអ្នករាល់គ្នាអាចធ្វើដើម្បីមកកាន់ព្រះអម្ចាស់ពេញលេញ ដើម្បីអ្នកអាចត្រូវបានផ្លាស់ប្តូរតាមរយៈដង្វាយធួន ?

សូមឲ្យសិស្សពីរបីនាក់ចែកចាយពីអ្វីដែលពួកគេបានសរសេរ ហើយប្រាប់ពីការផ្លាស់ប្តូរដែលអាចកើតឡើងមកលើយើង នៅពេលយើងប្រែចិត្ត និងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ។ (សូមរំឭកសិស្សថា ពួកគេមិនចាំបាច់ចែកចាយអ្វីដែលផ្ទាល់ខ្លួន ឬ ឯកជនពេកនោះទេ ។ សូមប្រាកដថា ពួកគេយល់ថា ពួកគេមិននិយាយអំពីអំពើបាបរបស់ពួកគេពីអតីតកាលឡើយ) ។

ម៉ូសាយ ២៧:៣២–៣៧

អាលម៉ាជាកូន និង កូនប្រុសរបស់ម៉ូសាយបានធ្វើដំណើរទូទាំងដែនដី ដោយខិតខំប៉ះប៉ូវនូវការខូចខាតដែលពួកគេបានធ្វើ ហើយពង្រឹងដល់សាសនាចក្រ

សូមពន្យល់ថា ការប្រែចិត្តដ៏ពិតគឺជាការផ្លាស់ប្តូរនៃដួងចិត្ត មិនមែនគ្រាន់តែការប្តេជ្ញាចិត្តថាឈប់ធ្វើអ្វីមួយខុសឆ្គងនោះទេ ។ សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២៧:៣២–៣៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលអាលម៉ា និងកូនប្រុសរបស់ម៉ូសាយបានធ្វើ ដែលលើសពីការឈប់ធ្វើនូវអ្វីដែលពួកគេបានធ្វើខុសនោះ ។

- **តើភស្តុតាងអ្វីខ្លះ ដែលអ្នកឃើញថា អាលម៉ានិងកូនប្រុសរបស់ម៉ូសាយបានផ្លាស់ប្តូរពិតមែន ?**
- **តើយើងអាចរៀនអ្វីខ្លះពីគំរូរបស់ពួកគេ ?**

ចម្លើយសិស្សអាចរួមមានដូចខាងក្រោម៖

ទោះបីជាអ្នកដែលប្រឆាំងទាស់នឹងព្រះអម្ចាស់ និង ការបង្រៀនរបស់ទ្រង់ក្តី ក៏អាចត្រូវបានអភ័យទោសឲ្យដែរ ។

ដើម្បីប្រែចិត្តដោយពិតប្រាកដ មនុស្សម្នាក់ត្រូវតែធ្វើអ្វីដែលអាចធ្វើបាន ដើម្បីប៉ះប៉ូវការខូចខាតដែលគេបានធ្វើ ។(អ្នកអាចពន្យល់ថា ពេលខ្លះយើងប្រើពាក្យ *ការសងវិញ* ដើម្បីសំដៅលើសកម្មភាពនៃការប៉ះប៉ូវការខូចខាតដែលបានធ្វើ ហើយកែតម្រូវជម្រើសដែលមិនឆ្លាតរបស់យើង) ។

តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ យើងអាចត្រូវបានផ្លាស់ប្តូរទៅកាន់សភាពមួយនៃសេចក្តីសុចរិត ។

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់ថា ដំណើររឿងរបស់អាលម៉ា និង ពួកបត្រាររបស់ម៉ូសាយគឺជាគំរូមួយនៃអំណាចនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទដើម្បីផ្លាស់ប្តូរយើង ។ សូមថ្លែងទីបន្ទាល់អំពីបំណងរបស់ព្រះអង្គសង្គ្រោះដើម្បីអភ័យទោសដល់អស់អ្នកណាដែលអនុវត្តសេចក្តីជំនឿទៅលើទ្រង់ ហើយស្វែងរកដើម្បីធ្វើតាមទ្រង់ ដូចជាយុវជនទាំងនេះដែរ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

ម៉ូសាយ ២៧:២៥ ។ កើតជាថ្មី

អែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពិពណ៌នាពីដំណើរការនៃការកើតជាថ្មី ៖

“ យើងចាប់ផ្តើមដំណើរការនៃការកើតជាថ្មីម្តងទៀតតាមរយៈការអនុវត្តសេចក្តីជំនឿទៅលើព្រះគ្រីស្ទ ការប្រែចិត្តពីអំពើបាបរបស់យើង និង ការជ្រមុជទឹកដោយការពន្លិចសម្រាប់ការផ្តាច់បាបដោយអ្នកដែលមានសិទ្ធិអំណាចបព្វជិតភាព ។

“ . . . ក្រោយពីយើងងើបចេញពីទឹកនៃការជ្រមុជនោះ ព្រលឹងរបស់យើងត្រូវបានបន្តជ្រមុជ ហើយជោគជាំទៅដោយសេចក្តីពិត និង ពន្លឺនៃដំណឹងល្អរបស់ព្រះអង្គសង្គ្រោះ ។ ការជ្រមុជយូរៗម្តង និង រាក់ទៅក្នុងគោលលទ្ធិនៃព្រះគ្រីស្ទ និង ការចូលរួមដោយផ្ទែកនៅក្នុងសាសនាចក្រដែលត្រូវបានស្តារឡើងវិញរបស់ទ្រង់មិនអាចបង្កើតការផ្លាស់ប្តូរខាងវិញ្ញាណដែលអាចឲ្យយើងដើរក្នុងជីវិតដ៏ថ្មីនេះឡើយ ។ ជាជាងនេះ ការស្មោះនឹងសេចក្តីសញ្ញា ការបន្តការប្តេជ្ញា និង ការលះបង់ព្រលឹងយើងទាំងមូលទៅដល់ព្រះគឺតម្រូវឲ្យមាន ប្រសិនបើយើងត្រូវទទួលពរជ័យនៃភាពអស់កល្បជានិច្ចនោះ ។ . . .

“ ការពន្លិចទាំងស្រុង និង ការជោគជាំដោយដំណឹងល្អរបស់ព្រះអង្គសង្គ្រោះគឺជាជំហានដ៏សំខាន់នៅក្នុងដំណើរការនៃការកើតជាថ្មី ” (“ អ្នកត្រូវកើតជាថ្មីម្តងទៀត ,” *Ensign* ឬ *លេអាហូណា,* ខែ ឧសភា ឆ្នាំ ២០០៧, ទំព័រ ២១) ។

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី ក៏ជាកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ថា ៖

“ យើងកើតជាថ្មី នៅពេលយើងស្លាប់ដោយការពាក់ព័ន្ធនឹងភាពមិនសុចរិត និង នៅពេលយើងរស់នៅពាក់ព័ន្ធនឹងរឿងនៃព្រះវិញ្ញាណ ។ ប៉ុន្តែការណ៍នោះមិនកើតឡើងភ្លាមៗ ក្នុងមួយពក្រិចភ្នែកនោះទេ ។ នោះ . . . គឺជាដំណើរការមួយ ។ ការកើតជាថ្មីគឺជារឿងសន្សឹមៗ លើកលែងតែមានគំរូដ៏ពិសេសពីរបីដែលជាអព្ភូតហេតុដ៏ខ្លាំងរហូតដល់ពួកគេត្រូវបានសរសេរនៅក្នុងព្រះគម្ពីរ ។ ដរាបណាភាពទុទៅនៃសមាជិកនៃសាសនាចក្រពាក់ព័ន្ធ យើងត្រូវកើតជាថ្មីម្តងទៀតតាមកម្រិត ហើយយើងត្រូវកើតជាថ្មីម្តងទៀតទៅកាន់ពន្លឺបន្ថែម និង ចំណេះដឹងបន្ថែម ព្រមទាំងបំណងប្រាថ្នាសម្រាប់សេចក្តីសុចរិតបន្ថែម នៅពេលយើងកាន់តាមព្រះបញ្ញត្តិទាំងឡាយ ។ . . .

“ ក្នុងនាមជាសមាជិកនៃសាសនាចក្រ ប្រសិនបើយើងតម្រង់ផ្លូវមួយដែលនាំទៅរកជីវិតដ៏អស់កល្បជានិច្ច; ប្រសិនបើយើងចាប់ផ្តើមដំណើរការនៃការកើតជាថ្មីខាងវិញ្ញាណ ហើយកំពុងដើរទៅទិសដៅដ៏ត្រឹមត្រូវ ប្រសិនបើយើងធ្វើផែនការដើម្បីបន្សុទ្ធព្រលឹងរបស់យើង ហើយបន្តិចម្តងៗយើងនឹងទៅកាន់ទិសដៅនោះ ប្រសិនបើយើងដាក់ទិសដៅដើម្បីភ្លាយជាឥតខ្ចោះ ហើយមួយជំហានម្តងៗ និង មួយឃ្លាម្តងៗ យើងធ្វើឲ្យព្រលឹងរបស់យើងឥតខ្ចោះ ដោយការយកឈ្នះលើពិភពលោក បន្ទាប់មកវាពិតជាត្រូវបានជានាថា —គ្មានសំណួរថា ទោះជាមានអ្វីកើតឡើងក៏ដោយ — យើងនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។ ទោះបីជាយើងមានការកើតជាថ្មីខាងវិញ្ញាណខាងមុខយើង ការឥតខ្ចោះខាងមុខយើង ការបន្សុទ្ធយ៉ាងពេញលេញខាងមុខយើងក្តី ប្រសិនបើយើងតម្រង់ទិស និងធ្វើតាមវាដោយអស់ពីលទ្ធភាពរបស់យើងនៅក្នុងជីវិតនេះ នោះនៅពេលយើងចេញពីជីវិតនេះ យើងនឹងបន្តនៅក្នុងផ្លូវដែលដូចគ្នាទៀត ” (“ Jesus Christ and Him Crucified,” *Brigham Young University 1976 Speeches,* ខែ វិច្ឆិកា ទី ៥, ឆ្នាំ ១៩៧៦, ទំព័រ ៥–៦, speeches.byu.edu) ។

ម៉ូសាយ ២៨–២៩

សេចក្តីផ្តើម

ដោយបានប្រែចិត្តជឿ ពួកបុត្រារបស់ស្តេចម៉ូសាយបានមានបំណងដ៏ខ្លាំងដើម្បីបង្រៀនដំណឹងល្អដល់សាសន៍លេមិន ។ ក្រោយពីការសុំដល់ព្រះអម្ចាស់ និង ការទទួលបានការធានាថា ពួកគេនឹងត្រូវបានប្រទានពរដោយជោគជ័យ និង ការការពារ ម៉ូសាយបានអនុញ្ញាតឲ្យពួកគេទៅ ។ ក្នុងពេលដូចគ្នានេះ ម៉ូសាយខិតខំថែរក្សាកំណត់ត្រាដ៏ពិសិដ្ឋដែលបានបន្តដល់គាត់ ។ គាត់បានបកប្រែកំណត់ត្រាសាសន៍យ៉ារ៉ែត ហើយបន្ទាប់មកប្រគល់កំណត់ត្រាទាំងអស់ដល់អាលម៉ាជាកូន ។ ដោយសារកូនប្រុសរបស់គាត់បានបោះបង់ឱកាសដើម្បីក្លាយជាស្តេច គាត់បានបង្កើតប្រព័ន្ធចៅក្រមជាទម្រង់ថ្មីនៃការគ្រប់គ្រងនៅក្នុងដែនដី ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ២៨:១–៩

កូនប្រុសរបស់ម៉ូសាយមានបំណងចង់បង្រៀនដល់សាសន៍លេមិន

មុនចាប់ផ្តើមថ្នាក់ សូមសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ៖

១. ខ្ញុំមានបំណងដ៏ស្មោះសរសម្រាប់សុភមង្គលដ៏អស់កល្បជានិច្ចដល់អ្នកដទៃ ។

២. ខ្ញុំនឹងលះបង់ដើម្បីជួយដល់អ្នកដទៃ ។

៣. ខ្ញុំមានបំណងដើម្បីចែកចាយដំណឹងល្អដល់អ្នកដទៃ ។

ដើម្បីចាប់ផ្តើមថ្នាក់ សូមឲ្យសិស្សប្រើប្រយោគនៅលើក្តារខៀនដើម្បីវាយតម្លៃពីខ្លួនគេដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេប្រើរង្វាស់ខ្នាតពី ១ ដល់ ១០ ដោយដាក់លេខ ១ ដើម្បីបង្ហាញថា ប្រយោគនោះមិនបានពិពណ៌នាពួកគេខ្លាំងឡើយ ហើយដាក់លេខ ១០ ដើម្បីបង្ហាញថា ប្រយោគនោះបានពិពណ៌នាពួកគេពិតជាត្រូវខ្លាំង ។

សូមឲ្យសិស្សអាន ម៉ូសាយ ២៧:៨–១០ ដោយស្ងៀមស្ងាត់ ។

- តើអាលម៉ា និង ពួកបុត្រារបស់ម៉ូសាយនឹងដាក់រង្វាស់ខ្នាតដូចគ្នានេះក្នុងពេលនេះនៅក្នុងជីវិតរបស់ពួកគេដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២៨:១–៤ ឮៗ ។

- តើកូនប្រុសរបស់ម៉ូសាយនឹងដាក់រង្វាស់ខ្នាតដូចគ្នានេះ ក្រោយពីការប្រែចិត្តជឿរបស់ពួកគេដោយរបៀបណា ? តើឃ្លាមួយណានៅក្នុង ម៉ូសាយ ២៨:១–៤ បង្ហាញថាពួកគេបានផ្លាស់ប្តូរខ្លាំងប៉ុណ្ណា ?
- ហេតុអ្វីបានជាបំណងរបស់កូនប្រុសរបស់ម៉ូសាយបានផ្លាស់ប្តូរ ? (ពួកគេបានអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ បានប្រែចិត្តពីអំពើបាបរបស់ពួកគេទាំងអស់ ហើយបានប្រែចិត្តជឿ; សូមមើល ម៉ូសាយ ២៧:៣៤–៣៦ ។ អ្នកក៏អាចបើកទៅ ម៉ូសាយ ២៨:៤ ដើម្បីបង្ហាញពីរបៀបដែលព្រះវិញ្ញាណនៃព្រះអម្ចាស់បានជះឥទ្ធិពលដល់ពួកគេ ។)
- ចេញពីអ្វីដែលអ្នកបានរៀនអំពីសាសន៍លេមិននៅពេលនេះនៅក្នុងប្រវត្តិសាស្ត្ររបស់ពួកគេ តើមានការលំបាកអ្វីខ្លះដែលអ្នកផ្សព្វផ្សាយសាសនាអាចជួបក្នុងចំណោមពួកគេ ?
- យោងតាម ម៉ូសាយ ២៨:២ តើអ្វីដែលកូនប្រុសរបស់ម៉ូសាយបានជឿលើការបង្រៀនរបស់ពួកគេ ថាអាចធ្វើឲ្យមានភាពខុសគ្នានៅក្នុងជីវិតរបស់សាសន៍លេមិន ?
- តើការប្រែចិត្តជឿនៃកូនប្រុសរបស់ម៉ូសាយបានជះឥទ្ធិពលដល់បំណងប្រាថ្នារបស់ពួកគេដើម្បីចែកចាយដំណឹងល្អដោយរបៀបណា ? តើគោលការណ៍អ្វីដែលយើងអាចរៀនពីបទពិសោធន៍របស់ពួកគេ ? (សូមសង្កេតចម្លើយរបស់សិស្ស ដោយការសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***នៅពេលការប្រែចិត្តជឿរបស់យើងចាក់ឫសជ្រៅ នោះបំណងប្រាថ្នារបស់យើងដើម្បីចែកចាយដំណឹងល្អកើនឡើង ។***

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាលីន អេក អ្នក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរប្រយោគនេះនៅគែមទំព័រនៃព្រះគម្ពីររបស់ពួកគេក្បែរ ម៉ូសាយ ២៨:១–៤ ។

" កម្លាំងនៃបំណងប្រាថ្នារបស់យើងដើម្បីចែកចាយដំណឹងល្អ គឺជាកត្តាជម្រុញមួយដ៏អស្ចារ្យចំពោះកម្រិតនៃការប្រែចិត្តជឿផ្ទាល់ខ្លួនរបស់យើង " (" Sharing the Gospel ," *Ensign* ខែ វិច្ឆិកា ឆ្នាំ ២០០១, ទំព័រ ៧) ។

សូមឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលបំណងរបស់ពួកគេចែកចាយដំណឹងល្អជាមួយនឹងអ្នកដទៃបានកើនឡើង នៅពេលពួកគេបានខិតកាន់តែជិតព្រះអម្ចាស់ ។

- តើបទពិសោធន៍អ្វីខ្លះនៅក្នុងជីវិតរបស់អ្នក បានដឹកនាំអ្នកឲ្យចង់ចែកចាយដំណឹងល្អជាមួយនឹងអ្នកដទៃ ?

សូមឲ្យសិស្សស្រមៃថា ពួកគេស្គាល់យុវជនម្នាក់ដែលជាសមាជិកនៃសាសនាចក្រម្នាក់ ប៉ុន្តែមានបំណងតិចតួចដើម្បីបម្រើបេសកកម្មពេញម៉ោង ។

- តើយុវជននេះអាចធ្វើអ្វីខ្លះ ដើម្បីបង្កើនបំណងរបស់គាត់ដើម្បីចែកចាយដំណឹងល្អ ? (នៅពេលសិស្សចែកចាយពីការយល់ដឹងរបស់ពួកគេ សូមលើកទឹកចិត្តដល់ពួកគេឲ្យនឹកចាំពីអ្វីដែលបានពង្រឹងដល់ការប្រែចិត្តជឿរបស់ពួកគេលើដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ និង ពីរបៀបដែលពួកគេអាចស្មើសកម្មភាព ឬ បទពិសោធន៍ដូចគ្នានេះដល់យុវជននេះ ។ សូមជួយពួកគេឲ្យឃើញថា ការប្រែចិត្តជឿដ៏ខ្លាំងដឹកនាំទៅរកបំណងដែលកើនឡើងមួយដើម្បីចែកចាយដំណឹងល្អជាមួយនឹងអ្នកដទៃ ។)

អ្នកអាចនឹងពន្យល់ពីរបៀបដែលអ្នកបានទទួលបំណងប្រាថ្នា ដើម្បីបង្រៀនដំណឹងល្អដល់អ្នកដទៃ ។ នៅពេលអ្នកធ្វើដូច្នោះ សូមគិតពីការចែកចាយទីបន្ទាល់របស់អ្នកថា នៅពេលយើងខិតជិតព្រះអម្ចាស់ ហើយមានអារម្មណ៍ពីព្រះវិញ្ញាណរបស់ទ្រង់ នោះបំណងរបស់យើងដើម្បីចែកចាយដំណឹងល្អដល់អ្នកដទៃនឹងកើនឡើង ។

សូមឲ្យសិស្សអាន ម៉ូសាយ ២៨:៥–៨ ហើយរកមើលពីមូលហេតុដែលម៉ូសាយអនុញ្ញាតឲ្យកូនប្រុសរបស់គាត់ទៅបម្រើបេសកកម្មដ៏មានគ្រោះថ្នាក់បែបនោះ ។

- នៅក្នុងចម្លើយដល់ការអធិស្ឋានរបស់ម៉ូសាយ តើពរជ័យអ្វីខ្លះដែលព្រះអម្ចាស់បានសន្យាដល់កូនប្រុសរបស់ម៉ូសាយ ?

ស្ថានភាពជីវិតពិត

ការភ្ជាប់គោលការណ៍ដំណឹងល្អមួយទៅនឹងស្ថានភាពជីវិតពិតមួយ អាចជួយសិស្សឲ្យវិភាគគោលការណ៍នេះ ហើយទទួលស្គាល់ការទាក់ទងវានៅក្នុងជីវិតរបស់ពួកគេ ។ អ្នកអាចណែនាំសិស្សថា កាលណាគេឆ្លើយតបដ៏ស្មោះត្រង់នឹងគំរូបែបនេះ កាន់តែខ្លាំង នោះវាកាន់តែមានប្រសិទ្ធិភាពនៅក្នុងជំណើរការរៀនរបស់ពួកគេ ។

ម៉ូសាយ ២៨:១០–២០

ម៉ូសាយបកប្រែផ្នាំងនៃសាសន៍យ៉ារ៉ែឌ ហើយប្រគល់កំណត់ត្រាដ៏ពិសិដ្ឋនោះដល់អាលម៉ា

សូមគូសដូចខាងក្រោមមលើក្តារខៀន ៖





សូមចង្អុលទៅរូបភាពមកុដ ហើយសូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២៨:១០ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលបញ្ហាមួយដែលស្តេចមាននៅពេលកូនប្រុសរបស់គាត់ចេញទៅបេសកកម្ម ។ (ទ្រង់ត្រូវការអ្នកនរណាម្នាក់ឲ្យជំនួសកន្លែងរបស់ទ្រង់ជាស្តេច) ។

សូមសង្ខេប ម៉ូសាយ ២៨:១១–១៩ ដោយការពន្យល់ថា ម៉ូសាយបានចាស់ ហើយគាត់បានបែរចំណាប់អារម្មណ៍ខ្លះចំពោះកំណត់ត្រាដ៏ពិសិដ្ឋដែលត្រូវបានប្រគល់ដល់គាត់ ៖ កំណត់ត្រាទាំងឡាយដែលឪពុករបស់គាត់បានឲ្យគាត់ ហើយបានប្រាប់គាត់ឲ្យរក្សា និងកំណត់ត្រាដែលស្តេចលិមហៃបានឲ្យដល់គាត់ ។ ក្នុងសមត្ថភាពរបស់គាត់ជាអ្នកមើលឆុតម្នាក់ គាត់បានបកប្រែកំណត់ត្រានៃសាសន៍យ៉ារ៉ែឌ —ផ្នាំងដែលបានរកឃើញដោយក្រុមដែលស្តេចលិមហៃបានបញ្ជូនឲ្យទៅរកដែនដីសារ៉ាហិមឡា (សូមមើល ម៉ូសាយ ៨:៧–៩) ។ សូមធ្វើឲ្យសិស្សមានចំណាប់អារម្មណ៍ទៅលើ រូបភាពនៃផ្នាំងមាសនៅលើក្តារខៀន ។

សូមពន្យល់ថា បន្ថែមលើការចាត់តាំងអ្នកដឹកនាំសម្រាប់នគរ ម៉ូសាយក៏ត្រូវការចាត់តាំងអ្នកថែរក្សាផ្នាំងទាំងនោះដែរ ។ សូមឲ្យសិស្សអាន ម៉ូសាយ ២៨:២០ ដោយស្ងាត់ៗ ។

- តើអ្នកណាដែលបានទទួលកំណត់ត្រាដ៏ពិសិដ្ឋនោះ ?
- ហេតុអ្វីបានជាអាលម៉ាជាជម្រើសដ៏ល្អដើម្បីថែរក្សាកំណត់ត្រាទាំងនេះ ?

ម៉ូសាយ ២៩

ប្រជាជនធ្វើតាមការណែនាំរបស់ម៉ូសាយ ដើម្បីស្ថាបនានូវប្រព័ន្ធចៅក្រម ជាទម្រង់នៃការគ្រប់គ្រងរបស់ពួកគេ

សូមឲ្យសិស្សលើកដៃ ប្រសិនបើពួកគេចង់ក្លាយជាស្តេច ឬ ម្ចាស់ក្សត្រីនោះ ។ សូមឲ្យសិស្សម្នាក់មកខាងមុខថ្នាក់ ហើយឈរក្បែរមកុដដែលបានគូសនៅលើក្តារខៀន (ឬ សូមដាក់ក្រដាសដាវាងមកុដនៅលើក្បាលគេ) ។ សូមឲ្យសិស្សនោះពិពណ៌នាពីប្រយោជន៍ដែលគេនឹងទទួលបានពីការធ្វើជាស្តេច ឬ ម្ចាស់ក្សត្រីនោះ ។

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២៩:១–៣ ឮៗ ។

- តើប្រជាជនចង់ឲ្យនរណាក្លាយជាស្តេចរបស់ពួកគេ ?
- តើកូនប្រុសរបស់ម៉ូសាយបានលះបង់អ្វីខ្លះ ដើម្បីពួកគេអាចបង្រៀនដល់សាសន៍លេមិន ?
- តើឱកាសអ្វីខ្លះដែលយុវជន និងយុវនារីលះបង់ ឬ ផ្តាកសព្វថ្ងៃនេះដើម្បីពួកគេអាចបម្រើបេសកកម្ម ?

សូមសង្ខេប ម៉ូសាយ ២៩:៤–១០ ដោយការពន្យល់ថា ស្តេចម៉ូសាយបានបារម្ភថា ការតែងតាំងស្តេចថ្មីអាចដឹកនាំទៅរកការទាស់ទែងហើយថែមទាំងអាចជាសង្គ្រាមផង ។ គាត់ក៏បាននិយាយពីបញ្ហាផ្សេងទៀតដែលអាចកើតមាន ប្រសិនបើស្តេចដែលមិនសុចរិតឡើងកាន់អំណាចនោះ ។ សូមឲ្យសិស្សអាន ម៉ូសាយ ២៩:១៦–១៨ ហើយរកមើលបញ្ហាទាំងនោះ ។

សូមពន្យល់ថា ស្តេចម៉ូសាយបានស្នើថា ការគ្រប់គ្រងសាសន៍នីហ្វៃមិនគួរត្រូវគ្រប់គ្រងដោយស្តេចទៀតទេ ។ ផ្ទុយទៅវិញ គាត់បានស្នើឲ្យប្រព័ន្ធចៅក្រម ដោយមានចៅក្រមដែលត្រូវបានជ្រើសរើសដោយសំឡេងរបស់ប្រជាជន ។

សូមឲ្យសិស្សអាន ម៉ូសាយ ២៩:១១, ២៥ ដោយស្ងាត់ៗ ដោយរកមើលពីរបៀបដែលចៅក្រមត្រូវកាត់សេចក្តីប្រជាជន ។ (“ យោងតាមព្រះបញ្ញត្តិនៃព្រះ ” និង “ យោងតាមច្បាប់ដែលបានផ្តល់ដល់អ្នកដោយឪពុករបស់យើង ”) ។

សូមសរសេរ *ម៉ូសាយ ២៩:២៦–២៧, ៣០, ៣៣–៣៤, ៣៧–៣៨* នៅលើក្តារខៀន ។ សូមបែងចែកសិស្សក្នុងថ្នាក់ជាដៃគូ ។ សូមឲ្យសិស្សរកមើលខគម្ពីរទាំងនេះ ហើយរកមើលការទទួលខុសត្រូវរបស់ប្រជាជននៅក្នុងការគ្រប់គ្រងដែលបានស្នើដោយស្តេចម៉ូសាយ ។ បន្ទាប់មក សូមឲ្យដៃគូនីមួយៗពិភាក្សានូវសំណួរខាងក្រោម ។ (អ្នកក៏អាចសរសេរសំណួរទាំងនេះនៅលើក្តារខៀន ឬ ចែកជាក្រដាសដល់ពួកគេ) ។

- យោងតាមស្តេចម៉ូសាយ តើមានប្រយោជន៍អ្វីខ្លះដែលមកតាមរយៈការសម្រេចចិត្ត ដោយសំឡេងរបស់ប្រជាជន ? (គាត់បាននិយាយថា សំឡេងរបស់ប្រជាជនជាទូទៅមិនមានបំណងចង់បានអ្វីដែល “ ផ្ទុយនឹងអ្វីដែលត្រឹមត្រូវនោះទេ ” ។ គាត់ក៏បាននិយាយអំពីតម្រូវការដល់ប្រជាពលរដ្ឋទាំងអស់ក្នុងការចែករំលែកនូវបន្ទុកនៃការគ្រប់គ្រងរបស់ពួកគេ ហើយដើម្បីមាន “ ឱកាសស្មើគ្នា ”) ។
- តើលទ្ធផលអ្វីដែលនឹងមក ប្រសិនបើសំឡេងរបស់ប្រជាជនបានជ្រើសរើសភាពទុច្ចរិតនោះ ? (ការកាត់សេចក្តីរបស់ព្រះនឹងមកដល់ពួកគេ ហើយពួកគេនឹងត្រូវបានបំផ្លាញ) ។
- នៅក្នុង ម៉ូសាយ ២៩:៣៤ តើអ្នកគិតថា អ្វីជាអត្ថន័យនៃឃ្លា “ មនុស្សគ្រប់រូបអាចផ្ទុកចំណែករបស់ខ្លួន ” ? តើឃ្លានេះអាចអនុវត្តដល់ការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋក្នុងការចូលរួមនៅក្នុងការគ្រប់គ្រងក្នុងស្រុក និង ជាតិរបស់ពួកគេដោយរបៀបណា ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយ អែលឌើរ នែល អេ ម៉ាក់ស្វែល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

“ ដោយសារអ្វីកើតឡើងនៅក្នុងការធ្លាក់ចុះនៃវប្បធម៌ ទាំងអ្នកដឹកនាំ និងអ្នកធ្វើតាមត្រូវតែទទួលខុសត្រូវ ។ . . . វាងាយស្រួលដើម្បីរិះគន់ដល់អ្នកដឹកនាំអាក្រក់ ប៉ុន្តែយើងមិនគួរឲ្យអ្នកដើរតាមមានផ្លូវទំនេរនោះទេ ” (“ Repent of [Our] Selfishness,” *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៩, ទំព័រ ២៤) ។

- ហេតុអ្វីបានជាវាសំខាន់ចំពោះអ្នកដឹកនាំ និងអ្នកធ្វើតាមដើម្បីទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេ ?
- តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីគាំទ្រដល់ច្បាប់ និង អ្នកដឹកនាំដ៏សុចរិតនោះ ? (អ្នកអាចឲ្យសិស្សបើកទៅ មាត្រានៃសេចក្តីជំនឿ ១:១២) ។

សូមបង្ហាញការធានារបស់អ្នកថា ខណៈពេលដែលមិនមែនគ្រប់ប្រទេសទាំងអស់នៅក្នុងពិភពលោកនេះមានឱកាសដើម្បីជ្រើសរើសអ្នកដឹកនាំរបស់ពួកគេផ្ទាល់ ព្រះអម្ចាស់នឹងតែងតែជួយអ្នកដែលទុកចិត្តលើទ្រង់ មិនថាពួកគេរស់នៅទីកន្លែងណានោះទេ ។

សូមឲ្យសិស្សម្នាក់អាន ម៉ូសាយ ២៩:៤១–៤៣ ឮៗ ។

- តើប្រជាជនបានជ្រើសរើសអ្នកណាដើម្បីក្លាយជាចៅក្រមសំខាន់ទីមួយ ? តើគាត់បានរស់នៅពេញមួយជីវិតគាត់ជាអ្នកដឹកនាំដ៏យុត្តិធម៌ និង សុចរិតដែរឬទេ ? តើអ្វីដែលជាលទ្ធផលនៃការដឹកនាំរបស់គាត់ ?

សូមឲ្យសិស្សពន្យល់ជាពាក្យសម្តីរបស់ពួកគេពីអ្វីដែលពួកគេបានរៀនពី ម៉ូសាយ ២៩ ។ ពួកគេអាចរកឃើញសេចក្តីពិតខ្លះដូចខាងក្រោម ៖

ការដឹកនាំមិនសុចរិតអាចនាំមកនូវការទាស់ទែងគ្នា និង អំពើបាប ។

វាមិនទូទៅនោះទេ ដែលសំឡេងរបស់ប្រជាជនជ្រើសរើសអ្វីមួយដែលមិនសុចរិតនោះ ។

ប្រសិនបើប្រជាជនជ្រើសរើសយកសេចក្តីទុច្ចរិត ការកាត់សេចក្តីនៃព្រះនឹងធ្លាក់មកលើពួកគេ ។

មនុស្សម្នាក់ៗមានកាតព្វកិច្ចមួយដើម្បីធ្វើតាមច្បាប់ និង អ្នកដឹកនាំដែលសុចរិត ។

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីគោលការណ៍នៅក្នុងមេរៀនថ្ងៃនេះ ។

ការរំឭកពីម៉ូសាយ

សូមចំណាយពេលដើម្បីជួយសិស្សឲ្យរំឭកពីព្រះគម្ពីរម៉ូសាយ ។ សូមឲ្យពួកគេគិតអំពីអ្វីដែលពួកគេបានរៀនពីគម្ពីរនេះ ទាំងនៅក្នុងថ្នាក់សិក្ខាសាលា និង ក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន ។ ប្រសិនបើចាំបាច់ សូមឲ្យពួកគេអានសង្ខេបៗពីគម្ពីរនេះដើម្បីជួយពួកគេឲ្យចងចាំ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបីបួននាក់ចែកចាយពីគំនិត និង អារម្មណ៍របស់ពួកគេអំពីអ្វីមួយនៅក្នុងគម្ពីរនេះ ដែលបានធ្វើឲ្យពួកគេរំភើបនោះ ។

សេចក្តីផ្តើមអំពី

គម្ពីរអាលម៉ា

ហេតុអ្វីបានជាត្រូវសិក្សាគម្ពីរនេះ ?

តាមរយៈការសិក្សាគម្ពីរអាលម៉ា សិស្សនឹងរៀនអំពីព្រះយេស៊ូវគ្រីស្ទ និង ភាពចាំបាច់នៃដង្វាយធួនរបស់ទ្រង់ និង ការរស់ឡើងវិញក្នុងផែនការណ៍នៃសេចក្តីសង្គ្រោះ ។ ពួកគេក៏នឹងរៀនអំពីអំណាចនៃព្រះបន្ទូលរបស់ព្រះក្នុងការយកឈ្នះលើល្បិចកលផ្នែកសង្ឃ គោលលទ្ធិក្លែងក្លាយ អំពើបាប ការស្តប់ និង ការក្បត់សាសនា និង ដើម្បីដឹកនាំបុគ្គលៗម្នាក់ឲ្យទទួលបទពិសោធន៍នៃការផ្លាស់ប្តូរដ្ឋេងចិត្តដ៏ធំ ។ សិស្សអាចយល់ដឹង និងបំផុសគំនិត នៅពេលពួកគេអានអំពីការខិតខំប្រឹងប្រែងរបស់អ្នកផ្សព្វផ្សាយសាសនាអាលម៉ា អាម៉ូលេក និង បុត្រារបស់ម៉ូសាយ ក៏ដូចជាការប្រែចិត្តជឿ និងភក្តីភាពនៃសាសន៍ប្រឆាំងនីហ្វៃលីហៃ (ប្រជាជននៃអាំម៉ូន) ផងដែរ ។ នៅពេលពួកគេសិក្សាពីដំណូកទាំងឡាយ ដែលរៀបរាប់យ៉ាងល្អិតល្អន់ពីសង្គ្រាមរវាងសាសន៍នីហ្វៃ និង សាសន៍លេមិន ពួកគេអាចរៀនពីគោលការណ៍ដែលនឹងដឹកនាំពួកគេនៅក្នុងពេលជ្រួលច្របល់ដែលពួកគេរស់នៅ ហើយជួយគេឲ្យយកឈ្នះលើចម្បាំងផ្ទាល់ខ្លួនប្រឆាំងនឹងបច្ចាមិត្ត ។

តើនរណាបានសរសេរគម្ពីរនេះ ?

មរមនបានចងក្រង និង សង្ខេបកំណត់ត្រាទាំងឡាយពីផ្នាំងនីហ្វៃធំ ដើម្បីបង្កើតជាគម្ពីរអាលម៉ា ។ គម្ពីរនេះដាក់ឈ្មោះតាមអាលម៉ា ដែលជាកូនប្រុសរបស់អាលម៉ា ដែលជាញឹកញាប់ត្រូវបានហៅថា អាលម៉ាជាកូន ។ នៅពេលស្តេចម៉ូសាយបានបង្កើតរជ្ជកាលនៃពួកចៅក្រមក្នុងចំណោមសាសន៍នីហ្វៃហើយ អាលម៉ាជាកូនបានក្លាយជាមេចៅក្រមទីមួយ ហើយបានបន្តពីឪពុករបស់គាត់ជាសង្ឃជាន់ខ្ពស់គ្រប់គ្រងសាសនាចក្រ (សូមមើល ម៉ូសាយ ២៩:៤២) ។ ទីបញ្ចប់ គាត់បានលាលែងពីតំណែងរបស់គាត់ជាមេចៅក្រម ដើម្បីថ្វាយខ្លួន “ ទាំងស្រុងទៅលើតំណែងនៃសង្ឃជាន់ខ្ពស់ ” និង “ ដើម្បីប្រកាសប្រាប់ព្រះបន្ទូលនៃព្រះដល់ប្រជាជន ” នៅទូទាំងដែនដីនីហ្វៃ (អាលម៉ា ៤:២០; ៥:១) ។ មរមនបានប្រើកំណត់ត្រានៃការបម្រើរបស់អាលម៉ា (សូមមើល អាលម៉ា ១–៤៤) និង ការសរសេររបស់កូនប្រុសអាលម៉ា ហេលេមិន (សូមមើល អាលម៉ា ៤៥–៦២) និង សិបឡុន (សូមមើល អាលម៉ា ៦៣) ដើម្បីធ្វើជាគម្ពីរអាលម៉ា ។

តើសៀវភៅនេះត្រូវសរសេរទៅដល់អ្នកណា និងហេតុអ្វី ?

មរមនមិនបាននិយាយដល់អ្នកអានជាក់លាក់ណាមួយ ឬ និយាយពីមូលហេតុដែលគាត់សរសេរវានៅក្នុងគម្ពីរអាលម៉ានេះឡើយ ។ ទោះជាយ៉ាងណាក្តី ការបង្រៀនដ៏ច្រើននៃគម្ពីរនេះអំពីបេសកកម្មប្រោសលោះរបស់ព្រះអង្គសង្គ្រោះ បានរួមចំណែកដល់គោលបំណងដ៏សំខាន់នៃព្រះគម្ពីរមរមន ដែលត្រូវថ្លែងទីបន្ទាល់ “ ថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ជាព្រះដ៏នៅអស់កល្បជានិច្ច ” (ទំព័រចំណងជើងនៃព្រះគម្ពីរមរមន ; សូមមើលផងដែរ អាលម៉ា ៥; ៧; ១៣; ៣២–៣៤; ៣៦; ៣៩–៤២) ។

តើនៅពេលណា និង នៅកន្លែងណាដែលគេសរសេរគម្ពីរនេះ ?

កំណត់ត្រាដើមដែលត្រូវបានប្រើជាប្រភពសម្រាប់គម្ពីរអាលម៉ាត្រូវបានសរសេរប្រហែលនៅរវាងឆ្នាំ ឆ្នាំ ៩១ មុន គ. ស. និង ៥២ មុន គ. ស. មរមនបានសង្ខេបកំណត់ត្រាទាំងនោះក្នុងពេលរវាងឆ្នាំ ៣៨៥ក្រោយគ្រិស្តសករាជនិង ឆ្នាំ ៣៨៥ ក្រោយគ្រិស្តសករាជ ។ មរមនមិនបានកត់ត្រាពីទីកន្លែងដែលគាត់នៅនៅពេលគាត់បានចងក្រងគម្ពីរនេះទេ ។

តើមានផ្នែកខុសគ្នាអ្វីខ្លះនៅក្នុងគម្ពីរនេះ ?

ទោះបីជាគម្ពីរអាលម៉ា ជាគម្ពីរដែលវែងជាងគេបំផុតនៅក្នុងព្រះគម្ពីរមរមន ពាក់ព័ន្ធតែក្នុងរយៈពេល ៣៩ ឆ្នាំប៉ុណ្ណោះ—ប្រហែល ឆ្នាំ ៩១ មុន គ. ស. ដល់ ៥២ មុន គ. ស. ។ គម្ពីរនេះប្រាប់ពីគំរូដំបូងនៃកិច្ចការផ្សព្វផ្សាយសាសនាដ៏មានជោគជ័យក្នុងចំណោមពួកសាសន៍លេមិន ។ វាក៏បានប្រាប់ពីភក្តីភាពនៃសាសន៍លេមិនដែលបានប្រែចិត្តជឿក្នុងការកាន់តាមសេចក្តីសញ្ញារបស់ពួកគេ (សូមមើល អាលម៉ា ២៣:៦–៧; ២៤) ។ បន្ថែមលើនេះ គម្ពីរអាលម៉ារួមមានការបង្រៀនអំពីគោលលទ្ធិនៃការតែងតាំងពីមុនកំណើតលោកិយ និង ការបម្រើរបស់មីលគីស្សាដែក (សូមមើល អាលម៉ា ១៣) ; អំណាចនៃព្រះបន្ទូលរបស់ព្រះ (សូមមើលអាលម៉ា ៣១) ; របៀបដើម្បីអភិវឌ្ឍសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ (សូមមើលអាលម៉ា ៣២–៣៤) ; ភាពតឹងរ៉ឹងនៃការមិនធ្វើតាមច្បាប់នៃព្រហ្មចារីយភាព(សូមមើលអាលម៉ា ៣៩) ; សភាពនៃវិញ្ញាណទាំងឡាយក្រោយពីការស្លាប់ (សូមមើលអាលម៉ា ៤០) ; គោលលទ្ធិនៃការរស់ឡើងវិញ និង ការស្តារឡើងវិញ (សូមមើល អាលម៉ា ៤០–៤១) និង តួនាទីនៃសេចក្តីយុត្តិធម៌ និង សេចក្តីមេត្តាករុណាក្នុងផែនការនៃសេចក្តីប្រោសលោះរបស់ព្រះវរបិតាសួគ៌ (សូមមើល អាលម៉ា ៤២) ។ គម្ពីរនេះក៏រួមមាននូវការណែនាំរបស់ព្រះអម្ចាស់ទាក់ទងនឹងការការពារខ្លួន និង យុត្តិកម្មនៃសង្គ្រាម (សូមមើល អាលម៉ា ៤៣:៤៥–៤៧) ។

គម្រោង

អាលម៉ា ១–៣ នីហ្វៃចាប់ផ្តើមឧបាយកលសង្ឃក្នុងចំណោមសាសន៍នីហ្វៃ ។ អាលម៉ាដឹកនាំសាសន៍នីហ្វៃសុចរិតក្នុងការការពារខ្លួនគេប្រឆាំងនឹងអាំលីសៃ និង អ្នកដើរតាមគាត់ដែលបានរួមគ្នានឹងកងទ័ពសាសន៍លេមិន ។ ក្រោយពីឧកញ៉ាបំណងក្នុងការធ្វើជាស្តេច និង ដើម្បីបំផ្លាញសាសនាចក្ររបស់អាំលីសៃ សាសន៍នីហ្វៃបានយកឈ្នះលើកងទ័ពសាសន៍លេមិនម្តងទៀត ។

អាលម៉ា ៤–១៦ អាលម៉ាលាលែងពីតំណែងជាចៅក្រមសំខាន់ ។ គាត់បានធ្វើដំណើរទូទាំងដែនដីនីហ្វៃដើម្បីប្រឆាំងនឹងអំណត និង ភាពទុច្ចរិតដោយការបង្រៀនព្រះបន្ទូលនៃព្រះ ។ អាម៉ូលេកបានចូលរួមនឹងអាលម៉ាហើយពួកគេបង្រៀនអំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ការរស់ឡើងវិញ និង តម្រូវការមានសេចក្តីជំនឿទៅលើព្រះអម្ចាស់ និងការប្រែចិត្ត ។ សីអ៊ែរ៉ុមបានប្រែចិត្តជឿ និងជ្រមុជទឹក ។

អាលម៉ា ១៧–២៨ បុត្រាទាំងឡាយនៃម៉ូសាយ និង អ្នកដទៃបានបង្រៀនព្រះបន្ទូលនៃព្រះក្នុងចំណោមសាសន៍លេមិននៅក្នុងដែនដីនីហ្វៃ ។ មនុស្សរាប់ពាន់នាក់បានប្រែចិត្តជឿដល់ព្រះអម្ចាស់ ។ អ្នកប្រែចិត្តជឿបានបោះបង់អរិភាពប្រជាប់សង្គ្រាមរបស់ពួកគេចោល ហើយទៅរស់នៅក្នុងចំណោមសាសន៍នីហ្វៃ ។ មនុស្សជាច្រើនបានស្លាប់នៅក្នុងសង្គ្រាមដ៏ធំមួយរវាងសាសន៍នីហ្វៃ និងសាសន៍លេមិន ។

អាលម៉ា ២៩–៤២ អាលម៉ាមានបំណងនាំព្រលឹងទាំងឡាយឲ្យប្រែចិត្ត ។ គាត់បានធ្វើឲ្យកូរីហ្គរ ដែលជាអ្នកប្រឆាំងនឹងព្រះគ្រីស្ទជ្រប់មុខ ។ ខណៈពេលបង្រៀនដល់សាសន៍សូរ៉ា មានក្រុមអ្នកបែកចេញពីសាសន៍នីហ្វៃមួយក្រុមបានជំទាស់ អាលម៉ាប្រៀបធៀបព្រះបន្ទូលរបស់ព្រះទៅនឹងគ្រាប់ពូជមួយដែលត្រូវតែថែទាំដោយសេចក្តីជំនឿ ។ អាម៉ូលេកថ្លែងទីបន្ទាល់អំពីដង្វាយធួនហើយបានបង្រៀនដល់សាសន៍សូរ៉ាឲ្យអនុវត្តសេចក្តីជំនឿដើម្បីមានការប្រែចិត្ត ។ អាលម៉ាប្រឹក្សាដល់បុគ្គលម្នាក់ៗនិង ចែកចាយទីបន្ទាល់ដល់កូនប្រុសរបស់គាត់ ហេលេមិន សិបឡុន និង កូរីអានតុន ។ អាលម៉ាបន្តកំណត់ត្រាដ៏ពិសិដ្ឋឲ្យហេលេមិនទុក ។ គាត់បង្រៀនអំពីពិភពវិញ្ញាណបន្ទាប់ពីជីវិតនេះទៅ ការរស់ឡើងវិញ និង តួនាទីនៃសេចក្តីយុត្តិធម៌ និងសេចក្តីមេត្តាករុណានៅក្នុងផែនការរបស់ព្រះ ។

អាលម៉ា ៤៣–៤៥ ដោយបានបង្កឲ្យមានកំហឹងដោយសារក្រុមអ្នកបែកចេញពីសាសន៍នីហ្វៃ នោះសាសន៍លេមិនបានមកធ្វើសង្គ្រាមនឹងសាសន៍នីហ្វៃ ។ ម៉ូរ៉ូណៃដឹកនាំសាសន៍នីហ្វៃឲ្យយកឈ្នះលើកងទ័ពរបស់សេរ៉ាហិមណា ។ អាលម៉ាបាននិយាយ និងប្រទានពរដល់ហេលេមិន ព្យាករណ៍ពីការបំផ្លាញដល់សាសន៍នីហ្វៃ ហើយបានចាកចេញពីដែនដីទៅ ។

អាលម៉ា ៤៦–៦៣ ម៉ូរ៉ូណៃ លីហៃ ទីអានតុម ហេលេមិន និង ពេហូរ៉ានដឹកនាំសាសន៍នីហ្វៃឲ្យមានជ័យជំនះលើកងទ័ពសាសន៍លេមិនដែលគ្រប់គ្រងដោយអាម៉ាលិកាយ និង អាំម៉ូរុន ។ ម៉ូរ៉ូណៃ និង ពេហូរ៉ានក៏បង្ក្រាបការបះបោរនៃក្រុមអ្នកបែកចេញពីសាសន៍នីហ្វៃដែលជំទាស់ឡើងដែលត្រូវបានស្គាល់ថាជា ស្តេច-ប្រជាជន ។ សិបឡុនទទួលកំណត់ត្រានៃសាសន៍នីហ្វៃ ហើយក្រោយមកប្រគល់កំណត់ត្រានោះដល់កូនប្រុសរបស់ហេលេមិន ឈ្មោះ ហេលេមិន ។ កងទ័ពរបស់ម៉ូរ៉ូណៃហាយកឈ្នះលើសាសន៍នីហ្វៃក្នុងចម្បាំងផ្សេងទៀត ។

អាលម៉ា ១–២

សេចក្តីផ្តើម

មិនយូរប៉ុន្មានក្រោយពីអាលម៉ាបានក្លាយជាមេចៅក្រម បុរសម្នាក់ឈ្មោះនីហ្វរបានប្រកាសខ្លួនគេថាជា អ្នកបង្រៀនក្នុងចំណោមប្រជាជន ។ គាត់និយាយប្រឆាំងនឹងសាសនាចក្រ និងគោលលទ្ធិទាំងឡាយ ហើយគាត់បានបញ្ចុះបញ្ចូលមនុស្សជាច្រើនឲ្យជឿលើគាត់ ហើយបានផ្តល់ប្រាក់ដល់គាត់ ។ នៅពេលនីហ្វរបានសម្លាប់គេឌាន ដែលជាសមាជិកដ៏ស្មោះត្រង់នៃសាសនាចក្រម្នាក់ គាត់ត្រូវបាននាំមកខាងមុខអាលម៉ា ។ ដោយឃើញថានីហ្វរមានទោសពីបទឧបាយកលផ្នែកសង្ឃ និង ពីការព្យាយាមជម្រុញឲ្យមានឧបាយកលផ្នែកសង្ឃដោយអរុណ នោះអាលម៉ាបានកាត់ទោសគាត់ដល់ស្លាប់ ។ សាសនាចក្របានរីកចម្រើន ដោយដឹកនាំដោយពួកសង្ឃដ៏ឧស្សាហ៍ព្យាយាម និងបន្ទាបខ្លួន ប៉ុន្តែឧបាយកលផ្នែកសង្ឃនៅតែបន្ត ។ អាំលីសៃ ដែលជាបុរសដ៏ទុច្ចរិតម្នាក់ ក្រោយពីទទួលបានបញ្ជាពីនីហ្វរហើយ បានប្រមូលការគាំទ្រក្នុងចំណោមមនុស្សជាច្រើន ហើយបានព្យាយាមក្លាយជាស្តេចនៃសាសន៍នីហ្វៃ ប៉ុន្តែបានបរាជ័យ ។ គាត់និងអ្នកដើរតាមគាត់បានបដិវត្តន៍ បានមកទាស់នឹងសាសន៍នីហ្វៃដើម្បីធ្វើចម្បាំង ហើយទីបំផុតបានរួបរួមកម្លាំងរបស់ពួកគេនឹងកងទ័ពសាសន៍លេមិន ។ ដោយបានពង្រឹងដោយព្រះអម្ចាស់ សាសន៍នីហ្វៃបានបាត់បង់ជាច្រើន ប៉ុន្តែបានយកឈ្នះលើការវាយប្រហារនៃកងទ័ពទាំងនេះ ។

ការប្រើសៀវភៅណែនាំសាសនាចក្រ និងការសម្របតាមមេរៀន

សៀវភៅណែនាំសាសនាចក្រត្រូវបានរៀបចំដោយយកចិត្តទុកដាក់ដើម្បីធានាថា គោលលទ្ធិនៃសាសនាចក្រទាំងឡាយត្រូវបានរក្សាដោយបរិសុទ្ធ ។ សូមគិតដោយយកចិត្តទុកដាក់នូវការបង្រៀនពីរោបល់ទាំងឡាយនៅក្នុងសៀវភៅណែនាំនេះ ដែលនឹងជួយអ្នកឲ្យស្មោះត្រង់នឹងគោលបំណងរបស់ព្យាការីដែលបានកត់ត្រាព្រះគម្ពីរ ។ ទោះយ៉ាងណាក្តី អ្នកអាចសម្របមេរៀននេះទៅតាមតម្រូវការ និងកាលៈទេសៈនៃសិស្សរបស់អ្នក ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ១

ជំនួសឲ្យការរាលដាលនៃឧបាយកលផ្នែកសង្ឃ និង ការកាត់ទោស មានមនុស្សជាច្រើននៅខ្ជាប់ខ្ជួនក្នុងសេចក្តីជំនឿ

សូមសរសេរពាក្យ *ប្រជាប្រិយ* នៅលើក្តារខៀន ។

- តើគ្រោះថ្នាក់អ្វីខ្លះនៃការស្វែងរកប្រជាប្រិយភាព ? តើគ្រោះថ្នាក់អ្វីខ្លះនៃការធ្វើតាមមនុស្ស ដោយសារតែពួកគេមានប្រជាប្រិយភាពនោះ ?

សូមពន្យល់ថា បុរសឈ្មោះនីហ្វរ មានប្រជាប្រិយភាពដល់មនុស្សខ្លះនៅក្នុងដែនដីសារ៉ាហិមឡា ។ សូមឲ្យសិស្សអាន អាលម៉ា ១:២–៦ ដោយស្វាត់ស្ងៀម ដោយរកមើលអ្វីដែលនីហ្វរបានបង្រៀន និង ពីរបៀបដែលប្រជាជនឆ្លើយតបនឹងការបង្រៀននោះ ។ ក្រោយពីសិស្សបានរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញហើយ សូមគិតពីការសួរសំណួរដូចខាងក្រោម ៖

- ហេតុអ្វីបានជាការបង្រៀនរបស់នីហ្វរនៅក្នុងអាលម៉ា ១:៤ គ្រោះថ្នាក់ ? (ប្រសិនបើសិស្សពិបាកឆ្លើយនឹងសំណួរនេះ សូមបង្ហាញថា នីហ្វរបានបង្រៀនថា " មនុស្សទាំងអស់ | នឹង | មានជីវិតដ៏អស់កល្បជានិច្ច " មិនថាពួកគេធ្វើអ្វីនោះទេ ។ ការបង្រៀននេះមិនគិតដល់តម្រូវការនៃការប្រែចិត្ត ពិធីការនានា និង ការកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ: ។ សូមមើលផងដែរ អាលម៉ា ១៥:១៥) ។
- តើលទ្ធផលអ្វីខ្លះដែលអាចមានដល់មនុស្សម្នាក់ ដែលជឿលើគោលលទ្ធិនេះ: ?
- តើជោគជ័យរបស់នីហ្វរបានជៈឥទ្ធិពលដល់គាត់វិញដោយរបៀបណា ? (សូមមើល អាលម៉ា ១:៦) ។

សូមសង្ខេប អាលម៉ា ១:៧–១៥ ដោយការពន្យល់ថា ថ្ងៃមួយនីហ្វរបានទៅបង្រៀនដល់ក្រុមមួយនៃអ្នកដើរតាមរបស់គាត់ នៅពេលគាត់បានជួបនឹងគេឌាន ដែលបានជួយដោះលែងប្រជាជនលីមហៃពីសេវកភាព ហើយដែលកំពុងបម្រើជាគ្រូបង្រៀនម្នាក់នៅក្នុងសាសនាចក្រ ។ នីហ្វរ " បានចាប់ផ្តើមប្រកែកជាមួយនឹង | គេឌាន | យ៉ាងខ្លាំង ដើម្បីគាត់អាចដឹកនាំមនុស្សនៃសាសនាចក្រឲ្យវង្វេងផ្លូវ តែ | គេឌាន | បានតទល់នឹងគាត់ដោយព្រមានដាស់តឿនគាត់ដោយព្រះបន្ទូលទាំងឡាយនៃព្រះ " (អាលម៉ា ១:៧) ។ នីហ្វរបានខឹងជាខ្លាំងហើយបានទាញដាវរបស់គាត់ ហើយបានសម្លាប់គេឌាន ។ ប្រជាជននៃសាសនាចក្របានចាប់នីហ្វរទៅជូបនឹងអាលម៉ាដែលជាចៅមេក្រម ដើម្បីឲ្យកាត់សេចក្តីចំពោះទោសរបស់គាត់ ។ អាលម៉ាបានកាត់ទោសនីហ្វរដល់ស្លាប់ ហើយនីហ្វរ " បានទទួលការស្លាប់ដ៏ឃោរឃៅ " (អាលម៉ា ១:១៥) ។ អ្នកអាចត្រូវពន្យល់ថា *ឃោរឃៅ* មានន័យថា ដែលអាប់កេរ្តិ៍ឈ្មោះ: ខ្មាស់គេ ឬ ដែលគ្មានកិត្តិយស ។

សូមអញ្ជើញឲ្យសិស្សអានជូរពីរបីដំបូងនៃ អាលម៉ា ១:១២ រកមើលពាក្យដែលអាលម៉ាបានប្រើដើម្បីពិពណ៌នាអ្វីដែលនីហ្វរបានបង្កើតដល់ប្រជាជននេះជាលើកទីមួយ ។ សូមអញ្ជើញឲ្យសិស្សមើលទៅលេខយោង ១២*ក* ។ សូមឲ្យពួកគេបើកទៅលេខយោងទីមួយដែលមាន ៖ នីហ្វៃទី ២ ២៦:២៩ ។ សូមឲ្យពួកគេអានខគម្ពីរនេះដោយស្ងៀមស្ងាត់ ។

- តាមគំនិតរបស់អ្នក តើអ្វីជាឧបាយកលផ្នែកសង្ឃ ? តើអ្នកគិតថា វាមានន័យយ៉ាងណាពេលមនុស្ស " តាំងខ្លួនឡើងជាពន្លឺដល់មនុស្សលោក " នោះ: ? ហេតុអ្វីបានជាការណ៍នេះមានគ្រោះថ្នាក់ ?
- តើការបង្រៀនរបស់នីហ្វរជាគំរូមួយនៃឧបាយកលផ្នែកសង្ឃដោយរបៀបណា ?
- យោងតាមអាលម៉ា តើអ្វីដែលនឹងកើតឡើងដល់ប្រជាជន ប្រសិនបើឧបាយកលផ្នែកសង្ឃត្រូវបានជម្រុញនៅក្នុងចំណោមពួកគេ ?
- តើអ្នកគិតថា ហេតុអ្វីបានជាវាល្បួងដល់មនុស្សដើម្បីបង្រៀន ដើម្បីឲ្យអ្នកផ្សេងនឹងសរសើរដល់ពួកគេ ?

សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ១:១៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពីរបៀប និង មូលហេតុដែលឧបាយកលផ្នែកសង្ឃបានបន្តរាលដាល ទោះបីជាក្រោយពីការស្លាប់របស់នីហ្គ័រកដោយ ។ ក្រោយពីសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ហើយ សូមសួរ ៖

- យោងតាម អាលម៉ា ១:១៦ តើគោលបំណងរបស់មនុស្សដែលអនុវត្តឧបាយកលផ្នែកសង្ឃគឺជាអ្វី ? (ពួកគេធ្វើវា " ដើម្បីចង់បានទ្រព្យសម្បត្តិ និង យសសក្តិ " —និយាយម្យ៉ាងទៀតថា ដើម្បីទទួលបានប្រាក់ និង ប្រជាប្រិយភាព) ។

សូមពន្យល់ថា ឧបាយកលផ្នែកសង្ឃ និងឥទ្ធិពលរបស់វាបានជាប់នឹងប្រជាជននីហ្វៃអស់រយៈពេលជាច្រើនឆ្នាំ (សូមមើល អាលម៉ា ២:១៥:១៥; ២៤:២៨) ។ សូមបង្ហាញថា នៅក្នុងជំនាន់របស់យើង យើងត្រូវដឹងពីឧបាយកលផ្នែកសង្ឃ នៅក្នុងសាសនាចក្រក៏ដូចជាក្រៅសាសនាចក្រផងដែរ ។ យើងមិនគួរឲ្យខ្លួនយើងត្រូវបានបោកបញ្ឆោតដោយមនុស្សដែលអនុវត្តឧបាយកលផ្នែកសង្ឃនោះទេ ។ យើងក៏គួរប្រុងប្រយ័ត្នពីអាកប្បកិរិយា និង សកម្មភាពនៃឧបាយកលផ្នែកសង្ឃនៅក្នុងការខិតខំរបស់យើងផ្ទាល់ដើម្បីបង្រៀនដំណឹងល្អដែរ ។

- តើអ្នកមានឱកាសអ្វីខ្លះដើម្បីបង្រៀនដំណឹងល្អ ? (សូមជួយសិស្សឲ្យមើលឃើញថា ពួកគេមានឱកាសជាច្រើនដើម្បីបង្រៀនដំណឹងល្អ ។ ពួកគេបង្រៀនដល់គ្នាទៅវិញទៅមក នៅពេលពួកគេចូលរួមនៅក្នុងថ្នាក់សិក្ខាសាលា និងនៅក្នុងក្លុំម និងថ្នាក់របស់ពួកគេ ។ ពួកគេអាចបង្រៀនគ្រួសាររបស់ពួកគេនៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ ។ យុវជនបម្រើជាគ្រូបង្រៀនតាមផ្ទះ ។ យុវនារី និងយុវជនអាចត្រូវបានសុំឲ្យនិយាយនៅក្នុងការប្រជុំសាក្រាម៉ង់ ។ ពួកគេអាចចែកចាយដំណឹងល្អជាមួយនឹងអ្នកដទៃនាពេលឥឡូវ ហើយពួកគេអាចរៀបចំដើម្បីទៅបម្រើបេសកកម្មពេញម៉ោង) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាវីឌ អេ បែដណា នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ៖

" អ្វីៗដែលអ្នក ឬ ខ្ញុំធ្វើជាអ្នកបង្រៀនដែលនាំយកការយកចិត្តទុកដាក់ដល់ខ្លួនដោយដឹងច្បាស់ និង មានចេតនា—នៅក្នុងសារលិខិតដែលយើងបង្ហាញ តាមរបៀបដែលយើងប្រើ ឬ តាមរបៀបថ្នាល់ខ្លួនយើង— គឺជាទម្រង់មួយនៃឧបាយកលផ្នែកសង្ឃដែលរារាំងដល់ការបង្រៀនដ៏មានឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ " ("Seek Learning by Faith," *Ensign*, ខែ កញ្ញា ឆ្នាំ ២០០៧, ឆ្នាំ ៦៦–៦៧) ។

សូមបញ្ជាក់ថា ប្រសិនបើយើងនាំការយកចិត្តទុកដាក់ដោយចេតនាមករកខ្លួនយើងនៅក្នុងការខិតខំរបស់យើងដើម្បីបង្រៀនដំណឹងល្អនោះ យើងនឹងរារាំងការបង្រៀនដ៏មានឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។

សូមអានបញ្ជីខាងក្រោមស្តីពីមូលហេតុដែលមនុស្សអាចមាន នៅពេលពួកគេបង្រៀន ។ សូមអញ្ជើញសិស្សឲ្យពិភាក្សាពីមូលហេតុមួយណាដែលអាចជាគំរូនៃឧបាយកលផ្នែកសង្ឃ និង ប្រាប់ពីមូលហេតុ ។

ដើម្បីដឹកនាំអ្នកដទៃទៅកាន់ព្រះអង្គសង្គ្រោះ ។

ដើម្បីបង្ហាញថា វាសប្បាយយ៉ាងណា ។

ដើម្បីជួយដល់អ្នកដទៃឲ្យមានអារម្មណ៍ពីព្រះវិញ្ញាណ ។

ដើម្បីអួតពីការចេះដឹងរបស់ពួកគេ ។

ដើម្បីជួយអ្នកដទៃឲ្យអនុវត្តសេចក្តីពិតនៃដំណឹងល្អនៅក្នុងជីវិតរបស់ពួកគេ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ១:២៦–២៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលពួកសង្ឃនៃព្រះបានធ្វើខុសគ្នាពីនីហ្វៃ ។

- តើគំរូនៃសង្ឃសាសន៍នីហ្វៃអាចជួយយើងឲ្យចៀសវាងពីឧបាយកលផ្នែកសង្ឃដោយរបៀបណា ?
- តើពួកសង្ឃទាំងនេះបានបង្ហាញការស្មោះត្រង់របស់ពួកគេទៅដល់ព្រះដោយរបៀបណា ?

សូមពន្យល់ថា ឧបាយកលផ្នែកសង្ឃបានដឹកនាំទៅរកការទាស់ទែងគ្នា និង ការកាត់ទោសក្នុងចំណោមពួកសាសន៍នីហ្វៃ ។ ដើម្បីជួយសិស្សឲ្យរៀបចំសិក្សា អាលម៉ា ១:១៩–៣៣ សូមសួរសំណួរខាងក្រោម ៖

- តើនៅពេលណាដែលអ្នកបានឃើញមនុស្សនិយាយដឹងឮ ចំអក ឬ កាត់សេចក្តីដល់អ្នកដែលកាន់តាមព្រះបញ្ញត្តិនៃព្រះ ?
- តើអ្នកធ្លាប់ត្រូវគេដឹងឮ ចំអក ឬ បៀតបៀនពេលកាន់តាមព្រះបញ្ញត្តិដែរឬទេ ? បើធ្លាប់ តើអ្នកបានឆ្លើយតបដោយរបៀបណា ?

សូមអញ្ជើញឲ្យសិស្សអាន អាលម៉ា ១:១៩–២០ ដោយស្ងាត់ៗ ដោយរកមើលគំរូនៃសមាជិកនៃសាសនាចក្រដែលត្រូវបានគេកាត់សេចក្តី ។ ក្រោយពីសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញហើយ សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ហើយសូមអញ្ជើញឲ្យសិស្សចម្លងសំណួរនោះទៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ សូមឲ្យពួកគេមានពេលអានវគ្គព្រះគម្ពីរដោយស្ងាត់ស្ងៀម ហើយឆ្លើយនឹងសំណួរដោយខ្លួនគេ ។

យោងតាម អាលម៉ា ១:២១–២៤ តើសមាជិកខ្លះឆ្លើយតបនឹងការកាត់សេចក្តីដោយរបៀបណា ? តើអ្វីខ្លះជាលទ្ធផលនៃសកម្មភាពរបស់ពួកគេ ?

យោងតាម អាលម៉ា ១:២៥–៣១ តើសមាជិកផ្សេងទៀតនៃសាសនាចក្របានរស់នៅ ដោយមិនអើពើនឹងការកាត់សេចក្តីដោយរបៀបណា ? តើពួកគេបានទទួលពរជ័យអ្វីខ្លះ ?

នៅពេលសិស្សមានពេលគ្រប់គ្រាន់ដើម្បីសិក្សាវគ្គទាំងនេះហើយ សូមសួរពួកគេថា តើយើងអាចរៀនអ្វីខ្លះពីវគ្គនេះ ។ សិស្សអាចរកឃើញគោលការណ៍ខាងក្រោមនេះខ្លះ ឬ ទាំងអស់ ៖

ទោះបីជានៅពេលដែលមនុស្សនៅជុំវិញយើងមិនគោរពតាម យើងអាចនៅបន្តនឹងនរ ហើយខ្ជាប់ខ្ជួនក្នុងការកាន់តាមព្រះបញ្ញត្តិ ។ នៅពេលយើងរស់នៅតាមដំណឹងល្អ យើងអាចមានសន្តិភាពនៅក្នុងជីវិតយើង ទោះបីជាយើងត្រូវបានគេកាត់សេចក្តីក៏ដោយ ។

- តើនៅពេលណាដែលអ្នកបានឃើញថា គោលការណ៍ទាំងនេះពិតនោះ ?

អាលម៉ា ២

អាំលីសៃ និង អ្នកដទៃបានបះបោរ ហើយទីបញ្ចប់បានចូលរួមនឹងសាសន៍លេមិនដើម្បីធ្វើសង្គ្រាមនឹងសាសន៍នីហ្វៃ

សូមពន្យល់ថា ប្រហែលបួនឆ្នាំក្រោយពីការស្លាប់របស់នីហ្វៃមក សាសន៍នីហ្វៃបានជួបនឹងបុរសទុច្ចរិតម្នាក់ទៀតដែលអាចទទួលបានការគាំទ្រយ៉ាងមានប្រជាប្រិយភាព ។ សូមឲ្យសិស្សធ្វើការជាដៃគូ ។ នៅក្នុងដៃគូនីមួយៗ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ២:១–៧ ខណៈពេលសិស្សម្នាក់ទៀតអាន អាលម៉ា ២:៨–១៨ ។ សូមណែនាំឲ្យសិស្សរៀបចំចំណងជើងនៃព័ត៌មានដោយផ្អែកលើខគម្ពីររបស់ពួកគេ ដោយពិពណ៌នាពីអ្វីដែលប្រជាជនសុចរិតបានធ្វើដើម្បីឈរប្រឆាំងភាពទុច្ចរិត ។ ក្រោយពីបួន ឬ ប្រាំនាទី សូមអញ្ជើញឲ្យសិស្សចែកចាយពីចំណងជើងជាមួយនឹងដៃគូរបស់គេ ។ អ្នកអាចសុំឲ្យសិស្សពីរបីនាក់ចែកចាយចំណងជើងរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។

សូមសួរសំណួរខាងក្រោមដើម្បីប្រាកដថាសិស្សយល់ពីខគម្ពីរដែលពួកគេបានសិក្សា ៖

- តើអាំលីសៃចង់ធ្វើអ្វីខ្លះ ?
- យោងតាម អាលម៉ា ២:១៨ តើហេតុអ្វីបានជាសាសន៍នីហ្វៃអាចបញ្ឈប់ការចង់ក្លាយជាស្តេចរបស់អាំលីសៃ ? (“ ព្រះអង្គម្ចាស់ទ្រង់បានចម្រើនកម្លាំងដល់ដៃរបស់ពួកនីហ្វៃដែរ ។ ” អ្នកអាចលើកទឹកចិត្តឲ្យសិស្សគូសចំណាំប្រយោគនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។)

សូមឲ្យសិស្សសរសេរគំរូនៃអំពើទុច្ចរិតដែលយុវជនជួបប្រទះសព្វថ្ងៃនេះ ។ ពួកគេអាចនិយាយពីការល្បួង ហើយពួកគេក៏អាចនិយាយពីឧបសគ្គដែលពួកគេជួបដោយសារតែអំពើទុច្ចរិតរបស់អ្នកដទៃ ។ នៅពេលពួកគេបន្តសិក្សា អាលម៉ា ២ សូមអញ្ជើញឲ្យពួកគេសញ្ជឹងគិតអំពីរបៀបដែលពួកគេអាចទទួលបានជំនួយរបស់ព្រះអម្ចាស់ ដើម្បីយកឈ្នះលើការល្បួង និងឧបសគ្គទាំងឡាយដែលពួកគេជួប ។

សូមពន្យល់ថា អ្នកចម្បាំងសាសន៍នីហ្វៃបានយកឈ្នះលើសង្គ្រាមជាច្រើនដងលើអាំលីសៃ ប៉ុន្តែពួកគេបានភ្លាក់ផ្អើលពេលឃើញថាសំណល់នៃប្រជាជនអាំលីសៃបានចូលរួមនឹងកងទ័ពរបស់សាសន៍លេមិន (សូមមើល អាលម៉ា ២:១៩–២៥) ។ មុនពេលកងទ័ពសាសន៍នីហ្វៃអាចត្រឡប់មកកាន់ទីក្រុងសារ៉ាហិមឡាវិញ កងទ័ពរួបរួមនោះបានវាយប្រហារពួកគេ ។ សូមឲ្យសិស្សអាន អាលម៉ា ២:២៧ រកមើលឃ្លាមួយដែលបង្ហាញពីទំហំនៃកងទ័ពរួបរួមគ្នានៃសាសន៍លេមិន និងសាសន៍អាំលីសៃនោះ ។

សូមអញ្ជើញឲ្យសិស្សឈប់មួយសន្ទុះ ហើយស្រមៃពីអ្វីដែលពួកគេគិត ហើយពីរបៀបដែលពួកគេមានអារម្មណ៍ ប្រសិនបើពួកគេជាផ្នែកមួយនៃកងទ័ពសាសន៍នីហ្វៃ ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ២:២៨–៣១, ៣៦ ឮៗ ហើយសុំសិស្សក្នុងថ្នាក់រកមើលរបៀបដែលសង្គ្រាមនោះបញ្ចប់ ។ ក្រោយពីសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញហើយ អ្នកអាចស្នើថា ពួកគេគូរគូសចំណាំពាក្យ *ទទួលកម្លាំង* និង ពាក្យ*បានចម្រើនកម្លាំង* នៅក្នុងខគម្ពីរទាំងនេះ ។

- យោងតាម អាលម៉ា ២:២៨ ហេតុអ្វីបានជាព្រះអម្ចាស់បានចម្រើនកម្លាំងដល់ពួកសាសន៍នីហ្វៃ ? (សិស្សអាចចែកចាយចម្លើយខុសគ្នាដល់សំណួរនេះ ។ សូមឲ្យពួកគេរកមើលគោលការណ៍ខាងក្រោមនេះ ៖ **នៅពេលយើងស្រែកហៅរកព្រះឲ្យជួយយើងឈរប្រឆាំងនឹងអំពើទុច្ចរិត ទ្រង់នឹងចម្រើនកម្លាំងដល់យើង ។**
- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីទទួលបានកម្លាំងពីព្រះដើម្បីឈរប្រឆាំងនឹងអំពើទុច្ចរិត ជាជាងការឲ្យឥទ្ធិពលដ៏ទុច្ចរិតបំផ្លាញជីវិតរបស់យើងទាំងអស់ ?
- តើអ្នកអាចធ្វើតាមគំរូរបស់អាលម៉ា នៅពេលអ្នកឈរប្រឆាំងនឹងអំពើទុច្ចរិតដោយរបៀបណា ?

សូមអញ្ជើញឲ្យសិស្សសរសេរចម្លើយចំពោះសំណួរខាងក្រោមនេះ ៖

- តើព្រះអម្ចាស់បានចម្រើនកម្លាំងដល់អ្នក នៅពេលអ្នកបានជួបនឹងអំពើទុច្ចរិតដោយរបៀបណា ?
- តើរបៀបមួយដែលអ្នកអាចឈរប្រឆាំងនឹងអំពើទុច្ចរិតនាពេលឥឡូវនេះគឺជាអ្វី ?

នៅពេលដែលសិស្សមានពេលសរសេរហើយ សូមអញ្ជើញឲ្យពួកគេពីរបីនាក់ចែកចាយចម្លើយរបស់ពួកគេ ។ អ្នកអាចចង់ចែកចាយចម្លើយរបស់អ្នកក៏បាន ។ សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមគំរូនៃសាសន៍នីហ្វៃ —ដើម្បីអធិស្ឋានសុំជំនួយពីព្រះអម្ចាស់ដើម្បីឲ្យមានភាពសាកសមនឹងត្រូវបានចម្រើនកម្លាំងដោយព្រះនៅក្នុងការខិតខំរបស់ពួកគេ ។ សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់ថា ព្រះនឹងចម្រើនកម្លាំងដល់យើង នៅពេលយើងឈរប្រឆាំងនឹងអំពើទុច្ចរិត ។

អាលម៉ា ៣–៤

សេចក្តីផ្តើម

ក្រោយពីបានចូលរួមនឹងកងទ័ពសាសន៍លេមិនហើយ ពួកអាំលីសៃបានញែកខ្លួនពួកគេចេញពីសាសន៍នីហ្វៃ ដោយមានការគូសសញ្ញាក្រហមនៅលើថ្ងាស់របស់ពួកគេ ។ ពួកអាំលីសៃ និង សាសន៍លេមិនបានធ្វើចម្បាំងនឹងសាសន៍នីហ្វៃ ហើយ “ ព្រលឹងរាប់៣ន់ និង រាប់មឺន ” បានស្លាប់នៅក្នុងសង្គ្រាម (សូមមើល អាលម៉ា ៣:២៦) ។ ការដេញតាមសង្គ្រាមនេះ សាសន៍នីហ្វៃជាច្រើនបានបន្ទាបខ្លួនគេ ហើយ “ ត្រូវបានភ្ញាក់ឡើង ដោយនឹកឃើញដល់ការកិច្ចរបស់ខ្លួន ” (អាលម៉ា ៤:៣) ។ ប្រហែលជា ៣,៥០០ នាក់ត្រូវបានជ្រមុជទឹក ហើយចូលរួមនៅក្នុងសាសនាចក្រ ។ ទោះជាយ៉ាងណាក្តី នៅក្នុងឆ្នាំក្រោយមក សមាជិកសាសនាចក្រជាច្រើនបានមានអំនួត ហើយចាប់ផ្តើមបៀតបៀនអ្នកដទៃ ។ ទាក់ទងនឹងសេចក្តីទុច្ចរិតនេះ អាលម៉ាបានលាលែងពីកាតព្វកិច្ចរបស់គាត់ ជាមេចៅក្រម ហើយបានបន្តបម្រើជាសង្ឃជាន់ខ្ពស់លើសាសនាចក្រ ។ នៅក្នុងសមត្ថភាពនេះ គាត់បានគ្រោងធ្វើដំណើរក្នុងតំបន់ ដោយថ្លែងទីបន្ទាល់ដ៏បរិសុទ្ធ និង ហៅប្រជាជនឲ្យមកប្រែចិត្ត ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៣:១–១៩

សាសន៍នីហ្វៃបានទាស់នឹងសាសន៍អាំលីសៃ និង សាសន៍លេមិន

សូមបែងចែកសិស្សទាំងឡាយជាក្រុមតូចៗ ។ សូមចែកក្រដាសមួយដល់ក្រុមនីមួយៗ ដោយមានពាក្យដូចខាងក្រោមសរសេរលើក្រដាសនោះថា ៖ *សំលៀកបំពាក់ ម្ហូតសក់ ក្រវិល និង គ្រឿងអលង្ការ ការសាក់ស្បែក* ។សូមឲ្យក្រុមទាំងឡាយពិភាក្សាពីសារលិខិតអ្វីដែលប្រជាជនអាចផ្ញើ ដោយមានចេតនា ឬ ដោយអចេតនា ជាមួយនឹងពាក្យទាំងនេះ ។

សូមរំឭកសិស្សថា សាសន៍អាំលីសៃបានបែងចែកពីសាសន៍នីហ្វៃ ហើយបានចូលរួមនឹងកងទ័ពសាសន៍លេមិន (សូមមើល អាលម៉ា ២) ។ សូមអញ្ជើញឲ្យសិស្សអាន អាលម៉ា ៣:៤ ហើយរកមើលពីរបៀបដែលអាំលីសៃបានផ្លាស់ប្តូររូបរាងរបស់ពួកគេ ។

- **តើសាសន៍អាំលីសៃចង់ “ ញែកចេញពី” អ្នកណា ?**
- **តើប្រជាជនខ្លះនាពេលសព្វថ្ងៃនេះអាចញែកខ្លួនគេចេញពីពួកសុចរិត តាមរយៈរូបរាងខាងក្រៅរបស់ពួកគេដោយរបៀបណា ? (នៅពេលសិស្សឆ្លើយតប សូមប្រាកដថា វាច្បាស់ថា មនុស្សខ្លះមានចេតនាផ្លាស់ប្តូររូបរាងរបស់ពួកគេដើម្បីញែកខ្លួនគេចេញពីពួកសុចរិត ឬ បះបោរទាស់នឹងបទដ្ឋាននៃសាសនាចក្រ ។ អ្នកផ្សេងទៀតធ្វើតាមទំនោរនៃលោកិយ ដោយមិនបានដឹងថា ពួកគេកំពុងផ្ញើរសារលិខិតអំពីខ្លួនគេ) ។**

សូមពន្យល់ថា នៅពេលសាសន៍អាំលីសៃបានគូសចំណាំនៅលើថ្ងាសរបស់ពួកគេ ដើម្បីញែកខ្លួនគេចេញពីសាសន៍នីហ្វៃ ពួកគេបានបង្ហាញថា ពួកគេបាននាំបណ្តាសារបស់សាសន៍លេមិនមកលើខ្លួនគេដែរ ។ សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮពី អាលម៉ា ៣:១៤–១៩ ។ សូមជួយឲ្យសិស្សក្នុងថ្នាក់វិភាគខគម្ពីរទាំងនេះ ដោយការស្វែងរំណួរខាងក្រោមខ្លះឬទាំងអស់ ៖

- **តើឃ្លានៅក្នុង អាលម៉ា ៣:១៨ ពិពណ៌នាសកម្មភាព និង អាកប្បកិរិយារបស់សាសន៍អាំលីសៃចំពោះព្រះអ្វីខ្លះ ? (“ បះបោរចេញមុខមកទាស់នឹងព្រះ ”) ។**
- **តើសាសន៍អាំលីសៃបាននាំយកទង្វាយបណ្តាសាមួយ “ មកលើខ្លួនគេ ” ដោយរបៀបណា ? (អាលម៉ា ៣:១៩) ។**
- **តើសេចក្តីពិតអ្វីខ្លះ ដែលយើងអាចរៀនពីខគម្ពីរទាំងនេះ ? (ចម្លើយអាចរួមមាន **អ្នកដែលចេញមុខមកទាស់នឹងព្រះ នាំយកលទ្ធផលអវិជ្ជមានមកលើខ្លួនគេ** ហើយថា **ប្រសិនបើយើងត្រូវបានញែកចេញពីព្រះ វាគឺដោយសារយើងបានញែកខ្លួនយើងចេញពីទ្រង់**) ។**

ដើម្បីជួយសិស្សឲ្យយល់ពីសារសំខាន់នៃការញែកខ្លួនគេចេញពីផ្លូវសុចរិត សូមសួរសំណួរខាងក្រោម ៖

- **តើរបៀបណាខ្លះ ដែលយើងអាចបង្ហាញតាមរយៈសំលៀកបំពាក់ និង រូបរាងរបស់យើងថា យើងគឺជាសិស្សនៃព្រះយេស៊ូវគ្រីស្ទ នោះ ? (ប្រសិនបើសិស្សពិបាកឆ្លើយនឹងសំណួរនេះ អ្នកអាចឲ្យពួកគេអានវគ្គ “ សំលៀកបំពាក់ និង រូបរាងខាងក្រៅ ” នៅក្នុង *ដើម្បីកម្លាំងនៃយុវជន*| ឆ្នាំ ២០១១ |, ទំព័រ ៦–៨ ។ សូមបញ្ជាក់ថា ទីបន្ទាល់ខាងក្នុងរបស់យើងអំពីដំណឹងល្អគួរមានឥទ្ធិពលតាមរយៈសំលៀកបំពាក់ និង រូបរាងរបស់យើង) ។)**

សូមលើកទឹកចិត្តឲ្យបង្ហាញថា ពួកគេធ្វើតាមព្រះអម្ចាស់ នៅពេលពួកគេមានជម្រើសប្រចាំថ្ងៃ រួមមានជម្រើសពីការស្លៀកពាក់ និង រូបរាងរបស់ពួកគេ ។ សូមបញ្ជាក់ថា **តាមរយៈសំលៀកបំពាក់ និងរូបរាងរបស់យើង យើងអាចញែកខ្លួនយើងថាជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។**

អាលម៉ា ៣:២០–២៧

មនុស្សរាប់ពាន់នាក់ត្រូវស្លាប់នៅក្នុងសង្គ្រាមមួយរវាងសាសន៍នីហ្វៃ និង សាសន៍លេមិន និង សាសន៍អាំលីសៃ

សូមសង្ខេប អាលម៉ា ៣:២០–២៥ ដោយការនិយាយថា សាសន៍នីហ្វៃបានបង្ក្រាបសាសន៍លេមិន ប៉ុន្តែទាំងសងខាងរងទុក្ខនូវការស្លាប់មនុស្សរាប់ពាន់នាក់ ។ សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ៣:២៦–២៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលមេរៀនមួយដែលមរមនចង់ឲ្យយើងយល់ ។

- យោងតាមខគម្ពីរទាំងនេះ តើរង្វាន់អ្វីនឹងមកដល់អ្នកដែលគោរពតាមព្រះអម្ចាស់ ?
- តើលទ្ធផលអ្វីដែលមកដល់អ្នកដែលមិនធ្វើតាមព្រះអម្ចាស់នោះ ?

ដោយសង្ខេប អ្នកអាចសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ **យើងទទួលបានសុភមង្គល ឬ ការរងទុក្ខផ្អែកលើអ្នកណាដែលយើងជ្រើសរើសគោរពតាម ។**

សូមអញ្ជើញឲ្យសិស្សគិតអំពីពរជ័យដែលមកពីការជ្រើសរើសធ្វើតាមព្រះអម្ចាស់ ។

- តើពរជ័យអ្វីខ្លះដែលអ្នកបានទទួលពីព្រះអម្ចាស់ នៅពេលអ្នកបានជ្រើសរើសធ្វើតាមទ្រង់ ?

អាលម៉ា ៤:១–១៤

ក្រោយពីមួយរយៈនៃការរីកចម្រើននៃសាសនាចក្រ សមាជិកនៃសាសនាចក្របានមានអំណួត ហើយទាស់នឹងគ្នាទៅវិញទៅមក

សូមសរសេរពាក្យ *បន្ទាបខ្លួន* និង *អំនួត* នៅលើក្តារខៀន ។

- តើការបន្ទាបខ្លួនមានន័យដូចម្តេច ? (ការបន្ទាបខ្លួនគឺជាការដែលអាចបង្រៀនបាន ហើយទទួលស្គាល់ដោយការដឹងគុណពីការពឹងផ្អែករបស់យើងទៅលើព្រះអម្ចាស់ —ដើម្បីយល់ថា យើងត្រូវការជំនួយរបស់ទ្រង់ជានិច្ច) ។

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮពី អាលម៉ា ៤:១–៥ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលភស្តុតាង ដែលថាសាសន៍បានបន្ទាបខ្លួន ។ នៅពេលសិស្សពន្យល់ពីអ្វីដែលពួកគេបានរកឃើញ វាអាចជួយច្រើន ដើម្បីបង្ហាញថា យើងមិនត្រូវរងទុក្ខនឹងសោកនាដកម្មដើម្បីចេះបន្ទាបខ្លួននោះទេ —យើងអាចជ្រើសរើសដើម្បីបន្ទាបខ្លួន ។

សូមបង្ហាញថា ការពិពណ៌នានៃសាសន៍នីហ្វៃនៅក្នុង អាលម៉ា ៤:៦គឺខុសគ្នាពីការពិពណ៌នានៅក្នុង អាលម៉ា ៤:៣–៥ ។ សូមចង្អុលទៅពាក្យ *អំនួត* នៅលើក្តារខៀន ។

- តើអំណួតមានន័យដូចម្តេច ? (អំនួតគឺជាពាក្យផ្ទុយនឹងការបន្ទាបខ្លួន ។ មនុស្សដែលអួតដាក់ខ្លួនគេផ្ទុយពីគ្នាទៅវិញទៅមក ហើយផ្ទុយពីព្រះ ។ ពួកគេដាក់ខ្លួនគេលើអ្នកនៅជុំវិញខ្លួនគេ ហើយធ្វើតាមបំណងរបស់ពួកគេផ្ទាល់ជាជាងបំណងរបស់ព្រះ) ។

សូមអញ្ជើញឲ្យសិស្សពាក់កណ្តាលថ្នាក់អាន អាលម៉ា ៤:៦–៨ ដោយស្ងាត់ៗ ហើយសិស្សពាក់កណ្តាលថ្នាក់ទៀតអាន អាលម៉ា ៤:៩–១២ ដោយស្ងាត់ៗ ។ សូមឲ្យក្រុមទាំងពីររកមើលសកម្មភាពនៃអំនួតនៃប្រជាជននីហ្វៃខ្លះ និង ពីរបៀបដែលសកម្មភាពទាំងនោះប៉ះពាល់ដល់អ្នកដទៃ ។ ក្រោយមានពេលគ្រប់គ្រាន់ហើយ សូមឲ្យក្រុមទាំងពីរប្រាប់ពីអ្វីដែលពួកគេបានរកឃើញ ។

- តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះអំពីរបៀបដែលអំនួតជះឥទ្ធិពលលើរបៀបដែលពួកគេប្រព្រឹត្តដាក់អ្នកដទៃនោះ ?
- តើការព្រមានអ្វីខ្លះដែលអ្នកឃើញនៅក្នុង អាលម៉ា ៤:១០ ? (សូមប្រាកដថា សិស្សយល់ថា **ប្រសិនបើយើងធ្វើគំរូមិនសុចរិតសកម្មភាពរបស់យើងអាចរារាំងដល់អ្នកដទៃពីការទទួលយកដំណឹងល្អ) ។**

សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ៤:១៣–១៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលឧទាហរណ៍ពីរបៀបដែលប្រជាជននីហ្វៃខ្លះបន្ទាបខ្លួន ទោះបីជានៅពេលអ្នកដទៃមានអំនួតក្តី ។

- តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះ អំពីរបៀបដែលការបន្ទាបខ្លួនជះឥទ្ធិពលដល់របៀបដែលយើងប្រព្រឹត្តនឹងអ្នកដទៃនោះ ?

សូមបញ្ជាក់ថា **ការសម្រេចចិត្តរបស់យើងដើម្បីបន្ទាបខ្លួន ឬ មានអំណួតជះឥទ្ធិពលដល់យើង និងអ្នកដទៃ ។** បើមានពេល សូមអញ្ជើញឲ្យសិស្សសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពីបទពិសោធន៍ដែលពួកគេមានដែលបង្ហាញពីសេចក្តីពិតនៃប្រយោគនេះ ។

អាលម៉ា ៤:១៥–២០

អាលម៉ាលាលែងពីតំណែងជាមេចៅក្រម ដើម្បីគាត់អាចលះបង់ពេលវេលារបស់គាត់ហៅប្រជាជនឲ្យប្រែចិត្ត

សូមអញ្ជើញឲ្យសិស្សស្រមៃថា ពួកគេស្ថិតនៅក្នុងកន្លែងរបស់អាលម៉ា ។ ពួកគេគឺជាមេចៅក្រម ហើយមានមនុស្សជាច្រើនមានអំនួតហើយបៀតបៀនអ្នកដែលនៅបន្តការបន្ទាបខ្លួន ។

- តើអ្នកអាចធ្វើអ្វីដើម្បីជួយមនុស្សឲ្យផ្លាស់ប្តូរ ?

សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ៤:១៥–១៩ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលអាលម៉ាបានជ្រើសរើសធ្វើ ។

- តើអាលម៉ាបានសម្រេចចិត្តធ្វើអ្វី ? (គាត់បានសម្រេចចិត្តលះបង់តំណែងរបស់គាត់ជាមេចៅក្រម ដើម្បីគាត់អាចលះបង់ពេលវេលារបស់គាត់បង្រៀនដល់ប្រជាជន) ។

- តើឃ្លា " ការធ្វើទីបន្ទាល់ដ៏បរិសុទ្ធ " (អាលម៉ា ៤:១៩) បានស្នើអ្វីអំពីរបៀបដែលអាលម៉ានឹងបង្រៀន ?
- តើនៅពេលណាដែលអ្នកបានឮមនុស្សថ្លែង " ទីបន្ទាល់ដ៏បរិសុទ្ធ" នោះ ? តើបទពិសោធន៍ទាំងនេះបានជះឥទ្ធិពលដល់អ្នកដោយរបៀបណា ?
- តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនពីគំរូរបស់អាលម៉ានៅក្នុង អាលម៉ា ៤:១៩ ?

ចម្លើយរបស់សិស្សចំពោះសំណួរនេះអាចរួមមានដូចខាងក្រោម ៖

ការបំពេញភាតពូកិច្ចខាងវិញ្ញាណរបស់យើង អាចតម្រូវឲ្យមានការលះបង់ ។

ការថ្លែងទីបន្ទាល់ដ៏បរិសុទ្ធជួយអ្នកដទៃឲ្យខិតទៅជិតព្រះ ។

សូមលើកទឹកចិត្តសិស្ស ឲ្យរកមើល ទីបន្ទាល់ដ៏បរិសុទ្ធរបស់អាលម៉ា នៅពេលពួកគេអាន អាលម៉ា ៥–១៦ នៅក្នុងការសិក្សាផ្ទាល់ខ្លួនរបស់ពួកគេ និង នៅពេលពួកគេពិភាក្សាពីជំពូកទាំងនេះនៅក្នុងមេរៀនបន្ទាប់ទៀត ។ សូមលើកទឹកចិត្តពួកគេផងដែរឲ្យយកចិត្តទុកដាក់លើឥទ្ធិពលនៃទីបន្ទាល់របស់អាលម៉ាដែលបានមានទៅលើប្រជាជន ។

សូមអញ្ជើញឲ្យសិស្សរកមើលលើសពីនេះទៀត

រាល់ពេល សូមបញ្ចប់មេរៀនដោយការឲ្យសិស្សនូវអ្វីមួយដើម្បីរកមើលនៅក្នុងព្រះគម្ពីរ ។ ការស្នើបែបនោះអាចជួយពួកគេឲ្យផ្តោតលើការសិក្សាផ្ទាល់ខ្លួន ហើយអាចជួយពួកគេឲ្យយល់ដឹងពីរបៀបដែលជំពូកមួយទាក់ទងនឹងជំពូកមួយទៀត ឬ ក្រុមជំពូកមួយទៀត ។

ការរំឭកចំណេះចំណានខគម្ពីរ

សូមណែនាំដល់សិស្សនូវវគ្គចំណេះចំណានខគម្ពីរពីរបីថ្មីបន្ថែម ឬក៏រំឭកវគ្គចំណេះចំណានខគម្ពីរពីរបីដែលពួកគេបានចាំហើយ ។ សូមរៀបចំសំណួរដែលនឹងជួយពួកគេឲ្យរកឃើញគោលការណ៍នៅក្នុងវគ្គនោះ ។ សូមអញ្ជើញឲ្យពួកគេសរសេរគោលដៅមួយនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពីអ្វីដែលពួកគេនឹងធ្វើដើម្បីរស់នៅកាន់តែប្រសើរដោយសារគោលការណ៍មួយនោះ ។ សូមដាក់ពេលវេលាជាក់លាក់ឲ្យពួកគេបំពេញគោលដៅរបស់ពួកគេ ហើយសូមឲ្យពួកគេរៀបចំដើម្បីរាយការណ៍ដល់សមាជិកក្នុងថ្នាក់ ឬ សិស្សក្នុងថ្នាក់ទាំងមូលពីអ្វីដែលពួកគេបានធ្វើហើយ ។

កំណាត់ចំណាំ ៖ ប្រសិនបើអ្នកមិនមានពេលដើម្បីប្រើសកម្មភាពនេះជាផ្នែកនៃមេរៀននេះទេ សូមប្រើវានៅពេលក្រោយ ។ សម្រាប់សកម្មភាពរំឭកផ្សេងទៀត សូមមើលសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អាលម៉ា ៣:៦–១៧ ។ ការគូស និង បណ្តាសា

នៅពេលសិស្សសិក្សា អាលម៉ា ៣ ពួកគេអាចមានសំណួរអំពីការគូស និងបណ្តាសាដែលបានដាក់លើសាសន៍លេមិន ។ អ្នកអាចពន្យល់ថា មានភាពខុសគ្នារវាងការគូស និង បណ្តាសា ។ ការគូសដែលនៅលើសាសន៍លេមិនគឺជាស្បែកខ្មៅ (សូមមើល អាលម៉ា ៣:៦) ។ គោលបំណងនៃការគូសនេះគឺដើម្បីញែកចេញ និង បំបែកសាសន៍លេមិនពីសាសន៍នីហ្វៃ (សូមមើល អាលម៉ា ៣:៨) ។ បណ្តាសា ដែលធ្ងន់ធ្ងរជាងនេះនោះ គឺជាសភាពនៃ " ការកាត់ចេញពីវត្តមាននៃព្រះអម្ចាស់ " (នីហ្វៃទី ២៥:២០) ។ សាសន៍លេមិន និង សាសន៍អាំលីសៃបានទាំបណ្តាសានេះមកលើខ្លួនគេ ដោយសារតែការបះបោររបស់ពួកគេទាស់នឹងព្រះ (សូមមើល នីហ្វៃទី ២៥:២០; អាលម៉ា ៣:១៨–១៩) ។ ទោះបីជាស្បែកខ្មៅត្រូវបានប្រើដើម្បីតំណាងនៃការគូសនៃបណ្តាសាដែលបានដាក់លើសាសន៍លេមិនក្តី ព្រះគម្ពីរមេរមនបង្រៀនថា ព្រះអម្ចាស់ " ពុំបដិសេធអ្នកណាម្នាក់ដែលមករកទ្រង់ឡើយ គឺទាំងខ្មៅនិងស ទាំងបាវគេនិងសេរី ទាំងប្រុសនិងស្រី . . . មនុស្សទាំងអស់ក៏ដូចគ្នានៅចំពោះព្រះ " (នីហ្វៃទី ២ ២៦:៣៣) ។ ជំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទគឺសម្រាប់គ្រប់គ្នា ។ សាសនាចក្រមិនយល់ព្រមនឹងការរើសអើងពូជសាសន៍យ៉ាងច្បាស់ រួមមានការរើសអើងនានា និង គ្រប់ប្រភេទកាលពីអតីតកាល ដោយបុគ្គលទាំងក្នុងនិងក្រៅសាសនាចក្រ ។ ប្រធានហ្គរដុន ប៊ី ហ៊ិងគ្លី បានប្រកាសថា ៖

" គ្មាននរណាម្នាក់ដែលបង្ខូចការថ្លែងនេះ ទាក់ទងនឹងអ្នកដែលមានសាសន៍ផ្សេងទៀតអាចគិតថាខ្លួនគេជាសិស្សដ៏ពិតនៃព្រះគ្រីស្ទនោះទេ ។ ហើយក៏គ្មាននរណាម្នាក់អាចគិតថាខ្លួនគេមានក្តីសុខដោយការបង្រៀននៃសាសនាចក្រដែរ ។ . . .

" ចូរយើងទាំងអស់គ្នាទទួលស្គាល់ថា យើងម្នាក់គឺជាបុត្រា ឬ បុត្រីនៃព្រះវរបិតារបស់យើង នៅលើស្ថានសួគ៌ ដែលស្រឡាញ់កូនចៅទាំងអស់របស់ទ្រង់ " (" The Need for Greater Kindness," *Ensign*ឬ*លីអាហូណា*,ខែ ឧសភា ឆ្នាំ ២០០៦, ទំព័រ ៥៨) ។ សម្រាប់ជំនួយបន្ថែមលើប្រធានបទនេះ សូមមើលមេរៀនទី ២៧ ។

មេរៀនសិក្សានៅផ្ទះ

ម៉ូសាយ ២៦–អាលម៉ា ៤ (មេរៀនទី ១៤)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនការសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនការសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីគោលលទ្ធិ និង គោលការណ៍នានាដែលសិស្សបានរៀន នៅពេលពួកគេបានសិក្សា ម៉ូសាយ ២៦–អាលម៉ា ៤ (មេរៀនទី ១៤) មិនមែនមានបំណងដើម្បីត្រូវបានបង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកនោះឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ម៉ូសាយ ២៦)

ដោយការសិក្សាអំពីជំនាន់នៃសាសន៍នីហ្វៃដែលមិនបានអភិវឌ្ឍទីបន្ទាល់នៃដំណឹងល្អ សិស្សបានរកឃើញថា ដើម្បីអភិវឌ្ឍ និងរក្សាទីបន្ទាល់មួយ យើងត្រូវខ្ជាប់ខ្ជួននឹងព្រះបន្ទូលនៃព្រះ អធិស្ឋានដោយសេចក្តីជំនឿ និង គោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ។ ចេញពីការខិតខំរបស់អាលម៉ាដើម្បីជួយដល់អ្នកដទៃឲ្យប្រែចិត្ត សិស្សបានរៀនថា ព្រះអម្ចាស់នឹងអភ័យទោសដល់អ្នកដែលប្រែចិត្តដោយស្មោះពីដួងចិត្តរបស់គេ ។

ថ្ងៃទី ២ (ម៉ូសាយ ២៧)

នៅពេលសិស្សបានសិក្សាពីការប្រែចិត្តជឿរបស់អាលម៉ាជាកូន និង កូនប្រុសរបស់ម៉ូសាយទាំងឡាយ ពួកគេបានរៀននូវសេចក្តីពិតនៃដំណឹងល្អបីខាងក្រោម ៖ ព្រះអម្ចាស់ឆ្លើយតបនឹងការអធិស្ឋានដ៏ស្មោះត្រង់របស់យើងសម្រាប់អ្នកដទៃ ប៉ុន្តែនៅតែផ្តល់សិទ្ធិសេរីភាពដល់ពួកគេ យើងម្នាក់ៗត្រូវតែកើតជាថ្មីម្តងទៀតតាមរយៈ ជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និង ដើម្បីប្រែចិត្តដ៏ពិតប្រាកដ បុគ្គលម្នាក់ត្រូវតែធ្វើនូវអ្វីៗដែលអាចដើម្បីជួសជុលនូវការខូចខាតដែលគេបានធ្វើ ។ សិស្សបានកត់ត្រានៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេពីរបៀបដែលពួកគេបានផ្លាស់ប្តូរតាមរយៈ ជង្វាយធួន ។

ថ្ងៃទី ៣ (ម៉ូសាយ ២៨–២៩)

នៅពេលសិស្សបានសិក្សាអំពីបំណងប្រាថ្នាំរបស់បុត្រាទាំងឡាយរបស់ម៉ូសាយដើម្បីបង្រៀនដំណឹងល្អដល់សាសន៍លេមិន ពួកគេបានរៀនថា នៅពេលការប្រែចិត្តជឿរបស់យើងបានសឺជម្រៅ បំនងរបស់យើងដើម្បីចែកចាយដំណឹងល្អនឹងកើនឡើង ។ ពួកគេក៏បានសរសេរអំពីបទពិសោធន៍ដែលពួកគេបានមាន ដែលជួយពួកគេឲ្យចង់ចែកចាយដំណឹងល្អ ។ សិស្សបានអានអំពីការផ្លាស់ប្តូររបស់សាសន៍នីហ្វៃនៅក្នុងរដ្ឋាភិបាល និង បានរៀនថា ពលរដ្ឋមានកាតព្វកិច្ចដើម្បីធ្វើតាមច្បាប់ និង អ្នកដឹកនាំត្រឹមត្រូវ ។

ថ្ងៃទី ៤ (អាលម៉ា ១–៤)

ដោយការសិក្សាពីគំរូនៃសាសន៍នីហ្វៃដែលបានបន្ទាបខ្ជួន សិស្សបានរៀនថា នៅពេលយើងរស់នៅតាមដំណឹងល្អ យើងអាចមានសន្តិភាពនៅក្នុងជីវិតរបស់យើង ទោះបីជាយើងត្រូវបានគេបៀតបៀនក្តី ។ នៅពេលពួកគេអានអំពីការបះបោររបស់សាសន៍អាំលីសៃ ពួកគេបានរកឃើញថា យើងទទួលបានសុភមង្គល ឬ សេចក្តីទុក្ខវេទនានោះវាពឹងលើអ្នកដែលយើងជ្រើសរើសគោរពតាម ។ អាលម៉ាគឺជាគំរូមួយនៃមនុស្សម្នាក់ដែលបានជ្រើសរើសគោរពតាមព្រះអម្ចាស់ ។ ការលះបង់ដ៏ឥតនឿយហត់របស់គាត់ដើម្បីហៅឲ្យសាសន៍នីហ្វៃដែលមានអំនួតប្រែចិត្តបានជួយសិស្សឲ្យឃើញថា អ្នកបម្រើរបស់ព្រះអម្ចាស់ថ្លៃងទីបន្ទាល់ និង ហៅអ្នកធ្វើអំពើបាបឲ្យប្រែចិត្ត ។

សេចក្តីផ្តើម

មេរៀននេះឲ្យសិស្សរំឲ្យកពីគោលការណ៍នៃការប្រែចិត្ត និង សញ្ជឹងគិតអំពីតម្រូវរបស់យើងដើម្បីផ្លាស់ប្តូរតាមរយៈ ជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ —ដូចជាអាលម៉ាជាកូន និង បុត្រាទាំងឡាយនៃស្តេចម៉ូសាយ ។ សូមអធិស្ឋានដើម្បីមានការដឹកនាំដើម្បីដឹងពីរបៀបដែលអ្នកអាចជួយដល់សិស្សបានខ្លាំងបំផុត ដើម្បីស្វែងរកការផ្លាស់ប្តូរនេះនៅក្នុងជីវិតរបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

ម៉ូសាយ ២៦

អាលម៉ាទទួលបានការបំផុសគំនិតអំពីរបៀបដើម្បីកាត់សេចក្តីអ្នកដែលធ្វើអំពើបាបដ៏ធ្ងន់ធ្ងរ

ដើម្បីចាប់ផ្តើមមេរៀននេះ សូមអញ្ជើញឲ្យសិស្សម្នាក់អានសេចក្តីសង្ខេបជំពូកនៅដើមដំបូងនៃ ម៉ូសាយ ២៦ ។ សូមអានពីស្ថានភាពខាងក្រោមនេះដល់សិស្ស ។ សូមឲ្យសិស្សគិតអំពីអ្វីដែលពួកគេអាចធ្វើដើម្បីជួយដល់មនុស្សនៅក្នុងស្ថានភាពនីមួយៗ ។

១. យុវនារីម្នាក់បានប្រព្រឹត្តអំពើបាបមួយដ៏ធ្ងន់ធ្ងរ ប៉ុន្តែនាងខ្លាចមិនហ៊ាននិយាយជាមួយនឹងប៊ីស្សពរបស់នាង ។

២. យុវជនម្នាក់បានមានបំណងប្រែចិត្ត ប៉ុន្តែគាត់មិនដឹងពីរបៀប ។

៣. យុវនារីម្នាក់បានធ្វើអំពើបាបមួយដែលនាងបានធ្វើមកម្តងទៀត ហើយនាងបារម្ភថា ព្រះអម្ចាស់នឹងមិនអភ័យទោសដល់នាងទៀតឡើយ ។

៤. យុវជនម្នាក់សម្រេចចិត្តប្រែចិត្ត ប៉ុន្តែគាត់មិនព្រមអភ័យទោសដល់អ្នកដែលបានធ្វើខុសនឹងគាត់ឡើយ ។

សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖ *ម៉ូសាយ ២៦:២១–២៣, ២៩–៣១* ។សូមពន្យល់ដល់សិស្សថា ខគម្ពីរទាំងនេះកត់ត្រានូវវិវរណៈរបស់ព្រះអម្ចាស់ដល់អាលម៉ាអំពីប្រជាជនដែលបានធ្វើអំពើបាបធ្ងន់ធ្ងរ ។ សូមអញ្ជើញឲ្យសិស្សអានខគម្ពីរទាំងនេះ ហើយរកមើលគោលការណ៍មួយយ៉ាងតិច ដែលអាចជួយដល់បុគ្គលមួយៗដែលបានពិពណ៌នានៅក្នុងបញ្ជីខាងលើ ។ សូមឲ្យសិស្សបីបួននាក់ចែកចាយចម្លើយរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។ អ្នកក៏អាចចែកចាយចម្លើយមួយ និង ទីបន្ទាល់របស់អ្នកអំពីគោលការណ៍មួយនៃការប្រែចិត្តដែលមាននៅក្នុង ម៉ូសាយ ២៦ ។

សូមរំឲ្យកសិស្សថា ពួកគេបានគ្រោងដើម្បីអនុវត្តគោលការណ៍មួយដែលពួកគេបានរៀនពី ម៉ូសាយ ២៦ ក្នុងការព្យាយាមរបស់ពួកគេផ្ទាល់ដើម្បីប្រែចិត្ត ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមគម្រោងរបស់ពួកគេ ។

ម៉ូសាយ ២៧–២៨

អាលម៉ាជាកូន និង បុត្រាទាំងឡាយរបស់ម៉ូសាយប្រែចិត្ត ហើយកើតជាថ្មីម្តងទៀត

ដើម្បីផ្តល់គំរូនៃនរណាម្នាក់ដែលបានជួបបទពិសោធន៍នៃការផ្លាស់ប្តូរដូងចិត្តដ៏ធំដល់សិស្ស សូមអញ្ជើញឲ្យពួកគេពីរបីនាក់ប្តូរវេនគ្នាអានឲ្យៗនូវបទពិសោធន៍ខាងក្រោមដោយអែលឌើរ ខេស យេ. ហីលប៊ីហ្គ នៃក្រុមចិតសិបនាក់ ៖

“ [អែលឌើរវ័យក្មេងម្នាក់ដែលកំពុងបម្រើនៅទ្វីបអឺរ៉ុបភាគខាងកើត] និង ដៃគូរបស់គាត់បានរកឃើញ និងបង្រៀនដល់បុរសវ័យកណ្តាលឈ្មោះ អឺវ៉ាន ។ . . . អ្នករៀនរបស់ពួកគេចេញមកពីប្រវត្តិដ៏ពិបាក ដូចដែលបានឃើញលើសំលៀកបំពាក់ដ៏ល្អរបស់គាត់ ពុកចង្ការស្រមូវ និង អាកប្បកិរិយាស្ទាក់ស្ទើរ ។ ជីវិតពិបាក និង មិនសូវល្អចំពោះគាត់ទេ ។

“ ដោយគ្មានការហ្វឹកហ្វឺនខាងសាសនាចពីមុន អ៊ីវ៉ានមានរឿងជាច្រើនដែលត្រូវយកឈ្នះ ។ ការអនុវត្តដែលមិនស្របនឹងដំណឹងល្អដែលបានស្តារឡើងវិញ ត្រូវបានដាក់នៅដោយឡែក ។ គោលការណ៍ថ្មីជាច្រើនដែលត្រូវទទួលយក ហើយបន្ទាប់មកអនុវត្តតាម ។ អ៊ីវ៉ានចង់រៀន ហើយគាត់បានរៀបចំខ្លួនគាត់ដោយឧស្សាហ៍ព្យាយាមសម្រាប់ពិធីបុណ្យជ្រមុជទឹក និងការបញ្ជាក់របស់គាត់ ។ សំលៀកបំពាក់របស់គាត់នៅតែពិបាកមើល ហើយពុកចង្ការរបស់គាត់នៅតែស្រមូរ ប៉ុន្តែគាត់បានទទួលយកជំហានទីមួយ ។ មិនយូរប៉ុន្មានបន្ទាប់ពីការជ្រមុជទឹករបស់អ៊ីវ៉ាន អ្នកផ្សព្វផ្សាយសាសនាក៏បានផ្លាស់ប្តូរតំបន់ ។ គាត់បានសង្ឃឹមថា គាត់អាចជួបនឹងអ៊ីវ៉ានម្តងទៀត ។

“ ប្រាំមួយខែក្រោយមក ប្រធានបេសកកម្មបានចាត់តាំងអែលឌើរដ៏ក្មេងម្នាក់នោះទៅសាខាពីមុនរបស់គាត់ ។ ដោយភ្ញាក់ផ្អើល ប៉ុន្តែទន្ទឹងចង់ត្រឡប់ទៅវិញ អែលឌើរនោះជាមួយនឹងដៃគូរបស់គាត់ បានមកការប្រជុំសាក្រាម៉ង់ពីព្រលឹមនៅថ្ងៃអាទិត្យទីមួយនៃការត្រឡប់មកសាខាដើមវិញរបស់គាត់ ។ . . .

“ អែលឌើរបានស្គាល់ស្ទើរគ្រប់គ្នានៅក្នុងការប្រជុំតូចមួយ ។ ទោះជាយ៉ាងណាក្តី គាត់បានរកដោយឥតប្រយោជន៍ក្នុងចំណោមបុរសដែលគាត់ និងដៃគូរបស់គាត់បានបង្រៀន និង ជ្រមុជទឹកកាលពីប្រាំមួយខែមុន ។ អារម្មណ៍អន់ចិត្ត និង ក្រៀមក្រំបានលេចឡើងនៅលើមុខរបស់អែលឌើរនោះ ។ . . .

“ ការភ័យខ្លាច និង ការឆ្គុះបញ្ចាំងរបស់អែលឌើរត្រូវបានបង្កាក់ដោយការមកដល់នៃបុរសដែលមិនស្គាល់ម្នាក់ ដែលប្រញាប់មកឱបអ្នកផ្សព្វផ្សាយសាសនានោះ ។ បុរសដែលបានកោរពុកចង្ការយ៉ាងស្អាតបានមានស្នាមញញឹមពោរពេញដោយទំនុកចិត្ត និង មានសេចក្តីល្អដ៏ប្លាស់ចែងចាំងពីទឹកមុខរបស់គាត់ ។ ដោយពាក់អាវសេ និង ក្រវ៉ាត់កចងយ៉ាងធ្ងៃត្ងន់ គាត់បានមករៀបចំសាក្រាម៉ង់សម្រាប់ការប្រជុំដ៏តូចនាព្រឹកថ្ងៃសិល្ប៍នោះ ។ រហូតដល់បុរសនោះចាប់ផ្តើមនិយាយទើបអែលឌើរនោះស្គាល់គាត់ ។ គាត់ជាអ៊ីវ៉ានថ្មី មិនមែនអ៊ីវ៉ានពីមុនដែលពួកគេបានបង្រៀន និង ជ្រមុជទឹកនោះទេ ។ អែលឌើរបានឃើញតំណាងនៅក្នុងមិត្តភក្តិរបស់គាត់នូវអត្ថហេតុនៃសេចក្តីជំនឿ ការប្រែចិត្ត និង ការអភ័យទោស គាត់បានឃើញភាពពិតនៃដង្វាយធួន ។

“ . . . [អ៊ីវ៉ាន] បានទទួលបទពិសោធន៍នៃ ‹ ការផ្លាស់ប្តូរនៅក្នុងដួងចិត្ត ›(អាលម៉ា ៥:២៦) គ្រប់គ្រាន់សម្រាប់ទាំងត្រូវជ្រមុជទឹក និង បន្តទៅមុខក្នុងដំណើរដ៏បន្សន្ទាប់នៃការប្រែចិត្តជឿ ” (“Experiencing a Change of Heart,” *Ensign,* ខែ មិថុនា ឆ្នាំ ២០០៨, ឆ្នាំ ២៩–៣១) ។

សូមសួរ ៖ តើមានកស្តុតាងអ្វីនៅក្នុងរឿងនេះ ដែលបង្ហាញពីរបៀបដែលអ៊ីវ៉ានបានផ្លាស់ប្តូរ ? (សូមប្រាកដថា វាច្បាស់ថា ការផ្លាស់ប្តូរខាងក្រៅដែលអ៊ីវ៉ានបានធ្វើ គឺជាការបង្ហាញនៃការផ្លាស់ប្តូរដ៏ជ្រាលជ្រៅមួយនៅខាងក្នុងខ្លួនគាត់ ។)

សូមរំឭកសិស្សថា ម៉ូសាយ ២៧ ពិពណ៌នាពីបទពិសោធន៍ផ្សេងទៀតនៃការផ្លាស់ប្តូរតាមរយៈដង្វាយធួន ។ សូមអញ្ជើញឲ្យសិស្សម្នាក់ក្រោកឈរនៅខាងមុខថ្នាក់ ហើយសង្ខេបម៉ូសាយ ២៧ ។ ប្រសិនបើមាន សិស្សក៏អាចបង្ហាញរូបភាពនៃការប្រែចិត្តជឿរបស់អាលម៉ាជាកូន (*សៀវភៅរូបភាពដំណឹងល្អ* [ឆ្នាំ ២០០៩], លេខ ៧៧) ។ សូមឲ្យសិស្សផ្សេងទៀតអានម៉ូសាយ ២៧:២៤–២៦ ។ បន្ទាប់មក សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្នកដែលត្រូវតែផ្លាស់ប្តូរតាមរយៈដង្វាយធួន ឬ “ កើតពីព្រះ” ។ នៅពេលសិស្សឆ្លើយ ពួកគេគួរបង្ហាញពីការយល់ដឹងនៃសេចក្តីពិតដូចខាងក្រោម ៖ **ពួកយើងម្នាក់ៗត្រូវតែកើតជាថ្មីម្តងទៀតតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។**

សូមសួរ ៖ តើអ្នកឃើញនរណាម្នាក់ផ្លាស់ប្តូរទៅជាល្អជាងមុនតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?

សូមអញ្ជើញឲ្យសិស្សសញ្ជឹងគិតពីសំណួរដែលអ្នកផ្សព្វផ្សាយសាសនានៅក្នុងរឿងបានសួរខ្លួនគាត់ ក្រោយពីការជួបជាថ្មីនឹងអ៊ីវ៉ានថា ៖ “ តើ “ ការផ្លាស់ប្តូរនៅក្នុងដួងចិត្ត ” មួយដែលខ្ញុំបានជួបកាលពីប្រាំមួយខែមុននោះមានច្រើនប៉ុណ្ណា ? . . . ‘ តើខ្ញុំបាន “ កើតជាថ្មីម្តងទៀត ” ឬ ? ’ ” (ដកស្រង់នៅក្នុង ខេស ឃេ ហ៊ីលប៊ីហ្គ “Experiencing a Change of Heart,” ៣១) ។

សូមអញ្ជើញឲ្យសិស្សអាន ម៉ូសាយ ២៧:២៤, ២៨ដោយរកមើលអ្វីដែលអាលម៉ាបានធ្វើ និងអ្វីដែលព្រះអម្ចាស់បានធ្វើដើម្បីនាំមកនូវការផ្លាស់ប្តូរនៅក្នុងអាលម៉ា ។ សូមឲ្យពួកគេពន្យល់ពីមូលហេតុដែលពួកគេជឿថា បុគ្គលម្នាក់ៗ និង ព្រះអម្ចាស់ត្រូវចូលរួមទាំងសងខាងនៅក្នុងការផ្លាស់ប្តូរនៅក្នុងដួងចិត្តដ៏ខ្លាំងមួយ ។

សូមរំឭកសិស្សថា ពួកគេបានបំពេញក្នុងតារាងមួយដោយឃ្លាដែលបង្ហាញពីភាពខុសគ្នានៅក្នុងអាលម៉ាពីមុន និង ក្រោយពីការផ្លាស់ប្តូរនៅក្នុងចិត្តរបស់គាត់ (នៅក្នុងមេរៀននៃថ្ងៃទី ២) ។ កិច្ចការទីពីរ សម្រាប់ថ្ងៃទីពីរ សិស្សបានសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេនូវឃ្លាមួយក្នុងកូឡោន “ ក្រោយមក” ដែលពួកគេសង្ឃឹមថានឹងពិពណ៌នាវាពេញមួយជីវិតរបស់ពួកគេ និង ពន្យល់ពីមូលហេតុ ។ សូមអញ្ជើញឲ្យសិស្សបីបួននាក់ចែកចាយពីអ្វីដែលពួកគេបានសរសេរ ។ សូមថ្លែងទីបន្ទាល់ថា ការផ្លាស់ប្តូរនៅក្នុងចិត្តដ៏ខ្លាំងមួយ អាចកើតមានដល់យើងតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។

សូមឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេបានផ្លាស់ប្តូរតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ សូមអញ្ជើញឲ្យពួកគេចែកចាយនូវគំនិតរបស់ពួកគេ ប្រសិនបើពួកគេចង់ ។ អ្នកក៏អាចចែកចាយពីរបៀបដែលអ្នកបានផ្លាស់ប្តូរតាមរយៈដង្វាយធួនដែរ ។

សូមលើកទឹកចិត្តដល់សិស្សឲ្យខិតខំឆ្ពោះទៅការទទួលបាននូវការផ្លាស់ប្តូរនៅក្នុងចិត្ត ដើម្បីពួកគេអាចខិតទៅជិតព្រះអម្ចាស់ និង អនុញ្ញាតឲ្យដង្វាយធួនផ្លាស់ប្តូរជីវិតរបស់ពួកគេ ។

សូមចម្លងតារាងខាងក្រោមលើក្តារខៀនមុនពេលចាប់ផ្តើមថ្នាក់ ឬ សូមកូពីដល់សិស្សមួយៗម្នាក់ ។

ម៉ូសាយ ២៧:៣២–៣៧	ម៉ូសាយ ២៨:១–៤
តើអាលម៉ា និង បុត្រាទាំងឡាយនៃស្តេចម៉ូសាយបានផ្លាស់ប្តូរដោយរបៀបណា ? តើគោលការណ៍អ្វីដែលអ្នកបានរៀនពីខគម្ពីរទាំងនេះ ? តើអ្នកគិតថា ហេតុអ្វីបានជាការសេងវិញគឺជាផ្នែកដ៏សំខាន់មួយនៃការប្រែចិត្ត ?	តើបុត្រាទាំងឡាយរបស់ស្តេចម៉ូសាយបានផ្លាស់ប្តូរដោយរបៀបណា ? តើគោលការណ៍អ្វីដែលអ្នកបានរៀនពីខគម្ពីរទាំងនេះ ? តើបទពិសោធន៍អ្វីនៅក្នុងជីវិតរបស់អ្នកដែលបានដឹកនាំអ្នកឲ្យចង់ចែកចាយដំណឹងល្អជាមួយនឹងអ្នកដទៃ ?

សូមឲ្យសិស្សពាក់កណ្តាលថ្នាក់ឆ្លើយចឹងសំណួរនៅក្នុងកូឡោនទីមួយនៃតារាង និង សិស្សផ្សេងទៀតឆ្លើយនឹងសំណួរនៅក្នុងកូឡោនទីពីរ ។ សូមឲ្យសិស្សម្នាក់ៗធ្វើការរៀងៗខ្លួន ។ សូមអញ្ជើញឲ្យសិស្សពីរបីនាក់ពិភ្រក្សាទីមួយៗ រាយការណ៍ពីចម្លើយរបស់ពួកគេ ។

សូមអញ្ជើញឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេអាចធ្វើការសេងវិញចំពោះអំពើបាបរបស់ពួកគេ ហើយបង្កើនចំណង់ដើម្បីចែកចាយដំណឹងល្អជាមួយនឹងអ្នកដទៃ ។

ម៉ូសាយ ២៩; អាលម៉ា ៤

ព្រះបានប្រទានពរដល់សាសន៍នីហ្វៃដែលនៅបន្តភាពសុចរិតនៅក្នុងពេលនៃការបៀតបៀន

សូមរំឭកសិស្សថា ជំពូកទីមួយនៃអាលម៉ាពិពណ៌នាពីពេលនៃការពិបាក និង ការបៀតបៀនដល់សាសន៍នីហ្វៃសុចរិត ។ សូមអញ្ជើញឲ្យសិស្សអាន អាលម៉ា ១:២៥, ២៧ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើលអ្វីដែលសាសន៍នីហ្វៃទាំងនេះបានធ្វើ អំឡុងពេលនៃការបៀតបៀន ។

សូមបង្ហាញថា ព្រះអម្ចាស់បានប្រទានពរដល់សាសន៍នីហ្វៃសុចរិត ដើម្បីឲ្យពួកគេបានចម្រើនឡើងជាងអ្នកដែលទុច្ចរិត (សូមមើល អាលម៉ា ១:២៩–៣២) ។ សូមឲ្យសិស្សខិតខំធ្វើតាមគំរូនៃសាសន៍នីហ្វៃដ៏ស្មោះត្រង់ទាំងនេះ នៅពេលពួកគេជួបនឹងការលំបាកនៅក្នុងជីវិតរបស់ពួកគេ ។

មេរៀនបន្ទាប់ទៀត (អាលម៉ា ៥–១០)

តើអ្នកដឹងថា តើអ្នកបានកើតជាថ្មីម្តងទៀតដោយរបៀបណា ? តើវាមានន័យយ៉ាងណា ដើម្បីកើតជាថ្មីម្តងទៀត ? នៅពេលសិស្សសិក្សា អាលម៉ា ៥–១០ ពួកគេនឹងរកឃើញសំណួរខ្លះដែលពួកគេអាចសួរដល់ខ្លួនគេដើម្បីវាយតម្លៃថាតើពួកគេបានកើតជាថ្មីម្តងទៀត និង ទទួលបទពិសោធន៍នៃការផ្លាស់ប្តូរចិត្តដ៏ខ្លាំងមួយ ។ បន្ថែមលើនេះ ពួកគេនឹងទទួលបានការយល់ដឹងដ៏ខ្លាំងអំពីជម្រៅ និងអំណាចនៃដង្វាយធួន ។

អាលម៉ា ៥:១–៣៦

សេចក្តីផ្តើម

នៅពេលសាសនាចក្រត្រូវបានគម្រាមដោយការទាស់ទែងផ្ទៃក្នុង និង អំពើទុច្ចរិត (សូមមើល អាលម៉ា ៤:៩–១១) អាលម៉ាបានលះបង់តំណែងចៅក្រមដើម្បីគាត់អាចផ្តោតលើការខិតខំរបស់គាត់លើការពង្រឹងសាសនាចក្រ ។ គាត់បានចេញដំណើរទៅបេសកកម្មមួយដើម្បីប្រាប់ដល់ប្រជាជននីហ្វៃដោយ " ការថ្លែងទីបន្ទាល់ដ៏បរិសុទ្ធទាស់នឹងពួកគេ " (អាលម៉ា ៤:១៩) ។ អាលម៉ាបានចាប់ផ្តើមបេសកកម្មរបស់គាត់ដោយការព្រួកដល់ប្រជាជនសាវ៉ាហិមឡា ដែលព្រះអម្ចាស់បានដោះលែងអយ្យកោរបស់ពួកគេពីសេវកភាពខាងរាងកាយ និងខាងវិញ្ញាណ ។ គាត់បានលើកទឹកចិត្តពួកគេឲ្យរៀបចំសម្រាប់ថ្ងៃចុងក្រោយនៃការជំនុំជម្រះដោយការជឿលើព្រះបន្ទូលនៃព្រះ ហើយវាយតម្លៃលើស្ថានភាពខាងវិញ្ញាណនៃដួងចិត្តរបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៥:១–១៤

អាលម៉ាប្រាប់ពីការប្រែចិត្តជឿនៃឪពុករបស់គេ និង អ្នកដទៃដែលធ្វើតាមគាត់

សូមសរសេរពាក្យ *ផ្លាស់ប្តូរ* នៅលើក្តារខៀន ។ សូមឲ្យសិស្សចែកចាយពីគំរូនៃរបៀបដែលប្រជាជនអាចផ្លាស់ប្តូររូបរាងរបស់ពួកគេ ឬ អាកប្បកិរិយារបស់ពួកគេ ។ សូមអញ្ជើញឲ្យពួកគេពន្យល់ពីអ្វីដែលអាចដឹកនាំទៅរក ឬ នាំមកនូវការផ្លាស់ប្តូរទាំងនេះខ្លះដល់មនុស្ស ។

សូមរំឭកសិស្សថា អាលម៉ាបានអធិប្បាយពីសេចក្តីទុច្ចរិតដែលបានចាប់ផ្តើមរីកធំឡើងនៅក្នុងចំណោមសាសន៍នីហ្វៃ ។ គាត់អាចឃើញថា ប្រសិនបើពួកគេមិនផ្លាស់ប្តូរទេនោះ ពួកគេនឹងលះបង់នូវពរជ័យដែលបានសន្យានៃសេចក្តីសញ្ញាទាំងឡាយដែលពួកគេបានធ្វើ ។ គាត់លះបង់តំណែងចៅក្រម ហើយពលីខ្លួនគាត់ដើម្បីបម្រើដល់ប្រជាជន និង ហៅពួកគេឲ្យប្រែចិត្ត ។ គាត់បានចាប់ផ្តើមដោយការបង្រៀនដល់ប្រជាជនសាវ៉ាហិមឡា ។

សូមអញ្ជើញឲ្យសិស្សបីឬបួននាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៥:៣–៦ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលហេតុការណ៍ដែលអាលម៉ាបានបញ្ជាក់ នៅពេលគាត់បានចាប់ផ្តើមបង្រៀនដល់ប្រជាជន ។

- **តើវាអាចជួយដល់ប្រជាជនរបស់អាលម៉ា ឲ្យស្តាប់តាមដំណើររឿងនៃសេវកភាព ការដោះលែង និង ការប្រែចិត្តជឿនៃឪពុករបស់អាលម៉ា និង អ្នកដែលបានធ្វើតាមគាត់ដោយរបៀបណា ?**
- **សូមមើល អាលម៉ា ៥:៧ ។ យោងតាមខគម្ពីរនេះ តើការផ្លាស់ប្តូរចិត្តប្រភេទណាដែលបានកើតឡើងនៅក្នុងជីវិតរបស់ឪពុកអាលម៉ា និង ប្រជាជនរបស់គាត់ ?**

នៅលើក្តារខៀន សូមបន្ថែមពាក្យ *នៃដួងចិត្ត* ក្រោយពាក្យ *ផ្លាស់ប្តូរ* ដូច្នេះវាអានថា *ផ្លាស់ប្តូរដួងចិត្ត* ។

- **តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីទទួលបាន " ការផ្លាស់ប្តូរនៃដួងចិត្ត" ? (ដើម្បីជួយសិស្សឲ្យឆ្លើយនឹងសំណួរនេះ អ្នកអាចប្រាប់ពួកគេថា អែលឌើរ ជែរ៉ល អិន ឡាន នៃក្រុមចិតសិបនាក់បានបង្រៀនថា នៅក្នុងព្រះគម្ពីរពាក្យ *ដួងចិត្ត* ជាញឹកញាប់សំដៅលើ " ភាពពិត នៅក្នុងបុគ្គល " ["Understanding Scriptural Symbols," *Ensign*, ខែ តុលា ឆ្នាំ ១៩៨៦, ទំព័រ ២៥]) ។**
- **តើភាពខុសគ្នាអ្វីរវាងការផ្លាស់ប្តូរនៃដួងចិត្ត និង ប្រភេទនៃការផ្លាស់ប្តូរដែលយើងពិភាក្សានៅពេលដំបូងនៃមេរៀននេះ ?**

សូមពន្យល់ថា នៅក្នុង អាលម៉ា ៥:៧–៩, ១៤ អាលម៉ាបានប្រើឃ្លាខុសគ្នាដែលពិពណ៌នាអ្វីដែលជាការផ្លាស់ប្តូរនៃដួងចិត្ត ។ សូមបន្ថែមឃ្លានៅលើក្តារខៀន ដូច្នេះវាអានថា *ការផ្លាស់ប្តូរនៃដួងចិត្តគឺដូចជា . . .*

សូមឲ្យសិស្សអាន អាលម៉ា ៥:៧–៩, ១៤ ដោយស្ងាត់ៗ ដោយរកមើលការពិពណ៌នារបស់អាលម៉ាពីអ្វីដែលការផ្លាស់ប្តូរនៃដួងចិត្តដូច ។ សូមអញ្ជើញឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។ នៅពេលសិស្សរាយការណ៍ សូមបន្ថែមឃ្លានេះទៅលើក្តារខៀន ។ (បញ្ជីរបស់អ្នកអាចមើលទៅដូចខាងក្រោមនេះ ៖ *ការផ្លាស់ប្តូរក្នុងដួងចិត្តគឺដូចជា . . . ការភ្ញាក់ពីការលង់លក់ដ៏ខ្លាំងមួយ ការពោរពេញដោយពន្លឺ ការមានសេរីភាពពីចំណងទាំងឡាយ ការពង្រីកព្រលឹងរបស់អ្នក ការច្រៀងអំពីការប្រោសលោះនៃសេចក្តីស្រឡាញ់ ការកើតពីព្រះ ការទទួលព្រះភ័ក្ត្ររបស់ព្រះអម្ចាស់នៅក្នុងទឹកមុខរបស់អ្នក* ។

- **តើការផ្លាស់ប្តូរនៅក្នុងដួងចិត្តអាចដូចជាការពិពណ៌នាដែលបានសរសេរនៅលើក្តារខៀនយ៉ាងដូចជា ?**
- **តើការផ្លាស់ប្តូរនៅក្នុងដួងចិត្តអាចត្រូវបានឃើញក្នុងសកម្មភាពរបស់មនុស្សដោយរបៀបណា ? តើការផ្លាស់ប្តូរនៅក្នុងដួងចិត្តពេលខ្លះអាចកត់សម្គាល់បាននៅក្នុងទឹកមុខរបស់នរណាម្នាក់ដោយរបៀបណា ? (អ្នកអាចសុំសិស្សឲ្យពិពណ៌នាពីរបាង ឬ អាការៈរបស់នរណាម្នាក់ដែលពួកគេដឹងថា ពួកគេមានអារម្មណ៍ថាបាន " ទទួលព្រះភ័ក្ត្រ [របស់ព្រះអម្ចាស់] នៅក្នុងទឹកមុខ [របស់គេ] ") ។**

សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ៥:១០ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលសំណួរបីដែលអាលម៉ាបានសួរដល់ប្រជាជន ។ (អ្នកអាចចង់ស្នើថា សិស្សគួរគូសចំណាំនូវសំណួរទាំងនេះ) ។ ការអានសំណួរទាំងនេះនឹងជួយដល់សិស្សឲ្យស្វែងរកនៅក្នុងខគម្ពីរបន្តបន្ទាប់នូវកត្តាដែលដឹកនាំអាលម៉ា និងប្រជាជនរបស់គាត់ឲ្យទទួលបានការផ្លាស់ប្តូរនៅក្នុងដួងចិត្តដ៏ធំ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ៥:១១–១៣ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលបាននាំមកនូវការផ្លាស់ប្តូរនៅក្នុងដួងចិត្តដ៏ធំរបស់ឪពុកអាលម៉ា និងអ្នកដើរតាមគាត់ ។ (ជំនឿរបស់ពួកគេទៅលើព្រះបន្ទូលនៃព្រះ និង ដោយការពង្រីក សេចក្តីជំនឿ និងការទុកចិត្តរបស់ពួកគេទៅលើព្រះ ។ អ្នកក៏អាចបង្ហាញពីឥទ្ធិបឡនៃព្រះបន្ទូលនៃព្រះដែលបានលើកឡើងនៅក្នុង អាលម៉ា ៥:៥, ៧) ។

- តើទំនាក់ទំនងអ្វីដែលអ្នកឃើញរវាងការជឿទៅលើព្រះបន្ទូលនៃព្រះ និង ការទទួលបានការផ្លាស់ប្តូរនៅក្នុងដួងចិត្តនោះ ? (សូមជួយឲ្យសិស្សរកមើលគោលការណ៍ខាងក្រោម ៖ **នៅពេលយើងជឿលើព្រះបន្ទូលនៃព្រះ ហើយអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចទទួលបានការផ្លាស់ប្តូរនៅក្នុងដួងចិត្តដ៏ធំមួយ ។** សូមបញ្ជាក់ថា ព្រះបន្ទូលនៃព្រះដែលបានបង្រៀនដោយអ័ប៊ីណាដៃ និង អាលម៉ាបានផ្តោតលើសេចក្តីសង្គ្រោះដែលមកតាមរយៈព្រះយេស៊ូវគ្រីស្ទ (សូមមើលម៉ូសាយ ១៦:៤–៩; ១៨:១–២)) ។

សូមពន្យល់ថា របៀបផ្សេងទៀតដើម្បីបង្ហាញថា នរណាម្នាក់បានទទួលការផ្លាស់ប្តូរនៅក្នុងចិត្តដ៏ធំ គឺនិយាយថា ពួកគេបានកើតជាថ្មីម្តងទៀត ។ សូមជួយសិស្សឲ្យយល់ថា " ការកើតពីព្រះ " ឬ " កើតជាថ្មីម្តងទៀត " សំដៅលើការផ្លាស់ប្តូរដែលបុគ្គលម្នាក់បានទទួលនៅពេលពួកគេទទួលយកព្រះយេស៊ូវគ្រីស្ទ ហើយចាប់ផ្តើមជីវិតថ្មីមួយជាសិស្សរបស់ទ្រង់ ។ ដើម្បីជួយសិស្សឲ្យយល់ថា ការទទួលការផ្លាស់ប្តូរនៅក្នុងចិត្តដ៏ធំមួយ ឬ ការកើតជាថ្មីម្តងទៀត គឺភាគច្រើនជាដំណើរការបន្តឥតដាច់មួយ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

" អ្នករាល់គ្នាអាចសួរថា ហេតុអ្វីបានជាការផ្លាស់ប្តូរដ៏ធំនេះមិនកើតឡើងបានញឹកញាប់ជាងនេះដល់ខ្ញុំ ? . . . សម្រាប់ពួកយើងភាគច្រើន ការផ្លាស់ប្តូរគឺជាការបន្តឥតដាច់ ហើយវាកើតឡើងជារៀងរហូត ។ ការកើតជាថ្មីម្តងទៀត . . . គឺជាដំណើរការមួយ ជាជាងហេតុការណ៍មួយ ។ ហើយការភ្ជាប់នៅក្នុងដំណើរការនោះ គឺជាគោលបំណងដ៏សំខាន់នៃជីវិតរមែងស្លាប់ " (" ការកើតជាថ្មី ," *Ensign* ឬ *លេខអាហ្វណា*, ខែ ឧសភា ឆ្នាំ ២០០៨, ទំព័រ ៧៨) ។

- តើនៅពេលណាដែលអ្នកមានអារម្មណ៍ពីការផ្លាស់ប្តូរនៅក្នុងដួងចិត្តរបស់អ្នក នៅពេលអ្នកបានខិតខំរស់នៅតាមព្រះបន្ទូលនៃព្រះនោះ ?
- តើអ្នកនឹងពិពណ៌នាពីអារម្មណ៍ និងសកម្មភាពដែលអមមកជាមួយនឹងការផ្លាស់ប្តូរនៅក្នុងដួងចិត្តដោយរបៀបណា ?
- តើដួងចិត្តរបស់អ្នកបានផ្លាស់ប្តូរ នៅពេលអ្នកបានសិក្សាព្រះគម្ពីរមមនៅក្នុងថ្នាក់សិក្ខាសាលាឆ្នាំនេះដោយរបៀបណា ?

សូមឲ្យសិស្សមានពេលពីរបីនាទីដើម្បីសរសេរនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពីរឿងមួយ ឬ ពីរដែលពួកគេនឹងធ្វើដើម្បីរស់នៅកាន់តែដូចជាងនេះទៅនឹងព្រះបន្ទូលនៃព្រះ ។

អាកម៉ា ៥:១៥–៣៦

អាលម៉ាបង្រៀនថា ការផ្លាស់ប្តូរនៅក្នុងដួងចិត្តមួយដ៏ធំ តម្រូវឲ្យចូលទៅក្នុងនគរនៃស្ថានសួគ៌

សូមឲ្យសិស្សនីមួយៗមានក្រដាសដែលរួមមាននូវតារាងដូចខាងក្រោម ឬ សូមបង្ហាញតារាងនេះនៅលើក្តារខៀនដើម្បីឲ្យសិស្សចម្លងតាម ។

ក្រាបកំណត់ត្រាបេះដូងខាងវិញ្ញាណ										
	អាលម៉ា ៥:១៥		អាលម៉ា ៥:១៦	អាលម៉ា ៥:១៩		អាលម៉ា ៥:២៦	អាលម៉ា ៥:២៧			អាលម៉ា ៥:២៨
ជានិច្ចកាល										
ស្ទើរតែគ្រប់ពេល										
ជាធម្មតា										
ពេលខ្លះ										
កម្រ បើឆ្លាប់										

សូមពន្យល់ថា ឧបករណ៍វាស់ចង្វាក់បេះដូងគឺជាតារាងចង្វាក់មួយដែលវេជ្ជបណ្ឌិតពេលខ្លះប្រើដើម្បីវាយតម្លៃ ឬ គ្រប់គ្រងការធ្វើការនៃបេះដូងខាងសាច់ឈាមរបស់យើង ។ វាជួយពួកគេឲ្យរកឃើញបញ្ហា ឬ ស្ថានភាពដែលត្រូវការការព្យាបាល ។

សូមប្រាប់សិស្សថា ក្រោយពីអាលម៉ាបានបង្រៀនថា ព្រះបន្ទូលនៃព្រះបានដឹកនាំឪពុករបស់គាត់ និងអ្នកដទៃឲ្យទទួលបានការផ្លាស់ប្តូរនៅក្នុងដួងចិត្តដ៏ធំហើយ គាត់បានសួរប្រជាជននូវសំណួរដែលនឹងជួយពួកគេឲ្យវាយតម្លៃពីស្ថានភាពនៃដួងចិត្តរបស់គេផ្ទាល់ ។ សូមអញ្ជើញឲ្យសិស្សអាន អាលម៉ា ៥:១៤ ដោយស្ងាត់ៗ ដោយរកមើលសំណួរបីដែលអាលម៉ាបានសួរដល់ប្រជាជន ។ (អ្នកអាចស្នើថា សិស្សគួរគូសចំណាំសំណួរទាំងនេះ) ។

សូមឲ្យសិស្សមានពេលដើម្បីសញ្ជឹងគិត

ការឲ្យសិស្សមានពេលសញ្ជឹងគិតក្នុងថ្នាក់គឺជារបៀបមួយដើម្បីជួយពួកគេឲ្យរៀនដោយព្រះវិញ្ញាណ ។ អំឡុងពេលនេះ សូមចៀសវាងការសួរសំណួរបន្ថែម ផ្តល់ការណែនាំ ឬ ការសន្ទនាថ្មីដែលនឹងរំខានដល់ពួកគេ ។

សូមពន្យល់ថា អាលម៉ាបានសួរសំណួរបីបួនទៀតដើម្បីជួយដល់ប្រជាជនរបស់គាត់ឲ្យគិតពីស្ថានភាពនៃដួងចិត្តរបស់ពួកគេ ។ សូមអញ្ជើញឲ្យសិស្សចំណាយពេលពីរបីនាទីសិក្សា និង សញ្ជឹងគិតអំពីវគ្គព្រះគម្ពីរដែលមាននៅលើឧបករណ៍កំណត់ចង្កាក់បេះដូងខាងវិញ្ញាណ ។ សូមលើកទឹកចិត្តពួកគេឲ្យគូសចំណាំប្រអប់នៅក្នុងតារាងដែលពិពណ៌នាពីអារម្មណ៍ដែលពួកគេមានទាក់ទងនឹងសំណួរនៅក្នុងវគ្គនីមួយៗបានល្អបំផុត ។ (សូមចំណាំថា ខគម្ពីរខ្លះមានសំណួរច្រើនជាងមួយ) ។ ដោយសារតែលក្ខណៈផ្ទាល់ខ្លួននៃសកម្មភាពនេះ សិស្សអាចមិនគួរចែកចាយចម្លើយរបស់ពួកគេដល់សិស្សក្នុងថ្នាក់នោះទេ ។

នៅពេលសិស្សបានបំពេញឧបករណ៍កំណត់ចង្កាក់បេះដូងហើយ សូមអញ្ជើញឲ្យពួកគេអាន អាលម៉ា ៥:២៩–៣១ ដោយស្ងាត់ៗ ដោយរកមើលសំណួរពីរបីទៀតដែលអាលម៉ាបានសួរដើម្បីជួយប្រជាជនគាត់ឲ្យវាយតម្លៃដួងចិត្តរបស់ពួកគេ ។ (អ្នកអាចស្នើថា សិស្សអាចសួរសំណួរខុសគ្នាបន្តិចដើម្បីអនុវត្តចំពោះខ្លួនគេ ៖ “ តើខ្ញុំពុំទាន់ចោលចិត្តច្រណែនទេឬ ? ” “ តើខ្ញុំបានចំអកឡកឡឺយដល់អ្នកដទៃទេ ? ” “ តើខ្ញុំបានគរការបៀតបៀនទៅលើអ្នកដទៃទេ ? ”

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៥:១៧–១៨, ២០–២៥ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលមូលហេតុដែលដួងចិត្តរបស់យើងត្រូវតែបានផ្លាស់ប្តូរដើម្បីរៀបចំសម្រាប់ថ្ងៃនៃការជំនុំជម្រះ ។ សូមសួរសំណួរខាងក្រោមដើម្បីជួយសិស្សឲ្យយល់ថា **ដោយការទទួលបានការផ្លាស់ប្តូរនៅក្នុងដួងចិត្តមួយ យើងរៀបចំខ្លួនយើងដើម្បីទទួលកន្លែងមួយនៅក្នុងនគរនៃស្ថានសួគ៌ ៖**

- តើពាក្យ និងឃ្លាអ្វីដែលអាលម៉ាបានប្រើដែលពិពណ៌នាពីស្ថានភាពដែលអ្នកនឹងស្ថិតនៅ នៅពេលអ្នកឈរនៅចំពោះមុខព្រះដើម្បីកាត់សេចក្តីនោះ ? (នៅពេលសិស្សឆ្លើយនឹងសំណួរនេះ អ្នកអាចនាំការយកចិត្តទុកដាក់ទៅលើ អាលម៉ា ៥:១៦, ១៩ ។
- តើការទទួលបានការផ្លាស់ប្តូរនៅក្នុងដួងចិត្តមួយនាពេលនេះ នឹងជួយរៀបចំអ្នកដើម្បីទទួលបានកន្លែងមួយនៅក្នុងនគរស្ថានសួគ៌ដោយរបៀបណា ?

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖ (អ្នកអាចសរសេរវានៅលើក្តារខៀនមុនចាប់ផ្តើមថ្នាក់) ។

តើព្រះអម្ចាស់បានអញ្ជើញយើងឲ្យធ្វើអ្វី ?

តើអ្វីជាលទ្ធផលនៃការទទួលយក ឬ បដិសេធការអញ្ជើញនេះ ?

តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះអំពីព្រះអង្គសង្គ្រោះ ?

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៥:៣៣–៣៦ឮៗ ខណៈពេលសិស្សផ្សេងទៀតរកមើលចម្លើយចំពោះសំណួរនៅលើក្តារខៀន ។ សូមអញ្ជើញឲ្យសិស្សចែកចាយចម្លើយដែលពួកគេរកឃើញ ។

សូមបញ្ចប់ដោយការឲ្យសិស្សសរសេរវាពីរបីនាទី ។ សូមឲ្យពួកគេជ្រើសរើសខគម្ពីរមួយ ឬ ឃ្លាមួយពី អាលម៉ា ៥:១–៣៦ ។ សូមអញ្ជើញឲ្យពួកគេសរសេរអំពីអ្វីដែលខគម្ពីរ ឬ ឃ្លានេះមានន័យដល់ពួកគេ និង ពីរបៀបដែលពួកគេអាចធ្វើអ្វីដែលវាស្នើសុំនៅពេលពួកគេស្វែងរកដើម្បីឲ្យមានការផ្លាស់ប្តូរនៅក្នុងដួងចិត្តគេតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ សូមថ្លែងទីបន្ទាល់ថា ប្រសិនបើយើងបន្តទទួលការផ្លាស់ប្តូរនៅក្នុងដួងចិត្ត និង នាំមកនូវកិច្ចការនៃសេចក្តីសុចរិត យើងនឹងត្រូវបានរៀបចំដើម្បីចូលទៅក្នុងនគរនៃព្រះ ។

អាលម៉ា ៥:៣៧–៦២

សេចក្តីផ្តើម

នៅពេលអាលម៉ាបានបន្តបង្រៀននៅក្នុងដែនដីសារ៉ាហិមឡា គាត់បានព្រមានប្រជាជនថា ការសម្រេចចិត្តដើម្បីធ្វើតាម ឬ បដិសេធពាក្យសម្តីរបស់គាត់បាននាំមកនូវលទ្ធផលដ៏ធ្ងន់ធ្ងរជាច្រើន ។ អាលម៉ាក៏បានប្រៀបធៀបព្រះយេស៊ូវគ្រីស្ទទៅនឹងអ្នកគង្វាលចៀមដ៏ល្អម្នាក់ ដែលបានហៅពួកគេ ហើយចង់នាំពួកគេត្រឡប់ទៅកាន់ហ្វូងរបស់ទ្រង់វិញ ។ គាត់បានលើកទឹកចិត្តប្រជាជនឲ្យប្រែចិត្ត ហើយចៀសវាងអ្វីដែលមិនស្អាតនៃពិភពលោក ដើម្បីឲ្យពួកគេអាចគ្រងនគរស្ថានសួគ៌ជាមរតក ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៥:៣៧–៤២, ៥៣–៦២

អាលម៉ាព្រមានដល់ពួកទុច្ចរិត ហើយអញ្ជើញអ្នកទាំងអស់គ្នាឲ្យស្តាប់តាមសំឡេងនៃអ្នកគង្វាលល្អ

សូមបង្ហាញរូបភាព ព្រះយេស៊ូវបីចៀមដែលបាត់មួយ (*សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ |, លេខ ៦៤) ។

- តើតាមរបៀបណាដែលព្រះអង្គសង្គ្រោះជាអ្នកគង្វាលដ៏ល្អ ?

ក្រោយពីសិស្សពីរបីនាក់បានឆ្លើយហើយ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន ៖

“ នៅជំនាន់របស់ព្រះយេស៊ូវ អ្នកគង្វាលចៀមសាសន៍ប៉ាឡេស្ទីនត្រូវបានកត់ចំណាំចំពោះការការពារចៀមរបស់គាត់ ។ មិនដូចជាអ្នកគង្វាលចៀមសម័យទំនើបទាំងឡាយអ្នកគង្វាលនោះតែងតែដើរពីមុខហ្វូងចៀមជានិច្ច ។ គាត់បានដឹកនាំពួកវា ។ អ្នកគង្វាលស្គាល់ចៀមនីមួយៗ ហើយជាធម្មតាដាក់ឈ្មោះឲ្យចៀមមួយៗ ។ ចៀមស្គាល់សំឡេងរបស់គាត់ ហើយទុកចិត្តគាត់ ហើយនឹងមិនដើរតាមជនចម្លែកនោះទេ ។ ហេតុដូច្នេះហើយ នៅពេលឮសំឡេងហៅ ចៀមនោះនឹងរត់មករកគាត់ ។ (សូមមើលយ៉ូហាន ១០:១៤, ១៦) . . .

“ ព្រះយេស៊ូវបានប្រើការបង្ហាញសាមញ្ញនេះពីជំនាន់របស់ទ្រង់ដើម្បីប្រកាសថា ទ្រង់គឺជាអ្នកគង្វាលដ៏ល្អ ជាអ្នកគង្វាលដ៏ពិត ។ ដោយសារតែក្តីស្រឡាញ់របស់ទ្រង់ចំពោះបងប្អូនប្រុសស្រីរបស់ទ្រង់ ទ្រង់នឹងដាក់ចុះនូវព្រះជន្មរបស់ទ្រង់ដោយមានឆន្ទៈ និង ដោយស្ម័គ្រចិត្តសម្រាប់ពួកគេ ” (“A Call to the Priesthood: ‘Feed My Sheep,’ ” *Ensign*, ខែ ឧសភា ឆ្នាំ ១៩៨៣, ទំព័រ ៤៣; សូមមើលផងដែរ John R. Lasater, “Shepherds of Israel,” *Ensign*, ខែ ឧសភា ឆ្នាំ ១៩៨៨, ទំព័រ ៧៤–៧៥) ។

សូមជួយសិស្សឲ្យចងចាំពីបរិបទនៃ អាលម៉ា ៥ ដោយការពន្យល់ថា អាលម៉ាបានទៅបង្រៀនដល់ប្រជាជនសារ៉ាហិមឡា ដែលបីដូចជា “ ចៀមដែលគ្មានអ្នកគង្វាល ” (អាលម៉ា ៥:៣៧) ។ សូមឲ្យសិស្សនឹកនាំពីឧបសគ្គដែលប្រជាជនសារ៉ាហិមឡាបានជួប និងអ្វីដែលអាលម៉ាបានលើកទឹកចិត្តពួកគេឲ្យធ្វើ ។ អ្នកអាចរំឭកដោយសង្ខេបពីខគម្ពីរគន្លឹះបីឬនពីមេរៀនមុន ដូចជា អាលម៉ា ៥:១៤–២០ ដើម្បីជួយសិស្សឲ្យចងចាំពីព័ត៌មាននេះខ្លះៗ ។ សូមធានាថា សិស្សយល់ថា ប្រជាជនសារ៉ាហិមឡាគឺស្ថិតនៅក្នុងស្ថានភាពដ៏អាក្រក់មួយដោយសារតែអំពើទុច្ចរិតរបស់ពួកគេ (សូមមើល អាលម៉ា ៧:៣) ។

សូមអញ្ជើញឲ្យសិស្សពីរ ឬ បីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៥:៣៧–៤២ ។ សូមឲ្យសិស្សរកមើលរបៀបដែលមនុស្សម្នាក់អាចប្រាប់ថាគេជាចៀមរបស់ព្រះអង្គសង្គ្រោះមួយដែរឬយ៉ាងណា ។ ក្រោយពីសិស្សបានចែកចាយអ្វីដែលពួកគេបានរកឃើញហើយ សូមសួរសំណួរខាងក្រោម ៖

- តើប្រជាជនដូចជាចៀមដែលត្រូវការអ្នកគង្វាលមួយដោយរបៀបណា ?
- យោងតាម អាលម៉ា ៥:៣៧–៣៨ តើអ្នកគង្វាលចៀមល្អបង្ហាញក្តីស្រឡាញ់របស់គាត់ និង ការបារម្ភដល់ចៀមរបស់គាត់ដោយរបៀបណា ? (គាត់បន្តស្រែកហៅពួកគេដោយឈ្មោះផ្ទាល់របស់គាត់) ។
- យោងតាម អាលម៉ា ៥:៤១ តើយើងអាចប្រាប់ថា យើងកំពុងស្តាប់តាមសំឡេងនៃអ្នកគង្វាលល្អដោយរបៀបណា ?
- តើកិច្ចការអ្វីខ្លះដែលអាចបង្ហាញថា មនុស្សម្នាក់កំពុងធ្វើតាមអ្នកគង្វាលល្អនោះ ?

ក្រោយពីសិស្សបានឆ្លើយតបហើយ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន ដែលបានពិពណ៌នាពីបុរស និងស្ត្រីទាំងឡាយដែលពិតជាធ្វើតាមព្រះយេស៊ូវគ្រីស្ទមែន ។ (អ្នកអាចចង់រៀបចំសេចក្តីថ្លែងការណ៍នេះជាច្បាប់ចម្លងដល់សិស្សម្នាក់ៗ) ។

“ នៅពេលអ្នកជ្រើសរើសធ្វើតាមព្រះគ្រីស្ទ អ្នកជ្រើសរើសដើម្បីបានផ្លាស់ប្តូរ ។ . . .

“ បុរស | និង ស្ត្រី | ផ្លាស់ប្តូរសម្រាប់ព្រះគ្រីស្ទនឹងត្រូវបានបញ្ជាដោយព្រះគ្រីស្ទ ។ . . .

“ ឆន្ទៈរបស់ពួកគេនឹងស្របតាមឆន្ទៈរបស់ទ្រង់ ។ (សូមមើលយ៉ូហាន ៥:៣០) ។

“ ពួកគេតែងតែធ្វើនូវអ្វីៗដែលធ្វើឲ្យព្រះអម្ចាស់សព្វព្រះហឫទ័យ ។ (សូមមើលយ៉ូហាន ៨:២៩) ។)

“ ពួកគេមិនត្រឹមតែនឹងស្លាប់ដើម្បីព្រះអម្ចាស់នោះទេ ប៉ុន្តែអ្វីដែលសំខាន់ជាងនេះនោះគឺ ពួកគេចង់រស់នៅដើម្បីទ្រង់ ។

“ ចូលក្នុងផ្ទះរបស់ពួកគេ ហើយរូបភាពនានានៅលើជញ្ជាំង សៀវភៅនៅលើធ្នើរ តន្ត្រីចាក់បន្ទរ សម្ដីនិងសកម្មភាពរបស់ពួកគេបង្ហាញថា ពួកគេជាគ្រិស្តសាសនិក ។

“ ពួកគេឈរជាសាក្សីដល់ព្រះនៅគ្រប់ពេល និងគ្រប់សេចក្ដី និងគ្រប់ទីកន្លែង ។ (សូមមើល ម៉ូសាយ ១៨:៩) ។

“ ពួកគេមានព្រះគ្រីស្ទនៅក្នុងគំនិតដោយសារពួកគេមើលទៅទ្រង់ពេលគិតអ្វីៗទាំងអស់ ។ (សូមមើល គ. & ស. ៦:៣៦) ។

“ ពួកគេមានព្រះគ្រីស្ទនៅក្នុងចិត្តរបស់ពួកគេ ដោយសារក្ដីស្រឡាញ់របស់ពួកគេបានដាក់ទៅលើទ្រង់ជារៀងរហូត ។ (សូមមើល អាលម៉ា ៣៧:៣៦) ។

“ ស្ទើតែរាល់សប្ដាហ៍ដែលយើងទទួលទានសាក្រាម៉ង់ ហើយធ្វើជាសាក្សីថ្មីដល់ព្រះវរបិតាសួគ៌ដ៏អស់កល្បរបស់ពួកគេថា ពួកគេនឹងលើកដាក់មកលើខ្លួនគេនូវព្រះនាមនៃព្រះរាជបុត្រារបស់ទ្រង់ តែងតែចងចាំទ្រង់ជានិច្ច ហើយកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។ (សូមមើលម៉ូរ៉ូណៃ ៤:៣) ។ ” (“Born of God,” *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៨៥, ទំព័រ ៥, ៦–៧) ។

សូមអញ្ជើញឲ្យសិស្សអាន អាលម៉ា ៥:៤៣–៥៦ ដោយស្ងាត់ៗ ដោយរកមើលឥរិយាបថ និងសកម្មភាពនានាដែលធ្វើឲ្យពិបាកដល់នរណាម្នាក់ដើម្បីស្ដាប់តាមសំឡេងរបស់ព្រះអង្គសង្គ្រោះ ។ ពីរបីនាទីក្រោយមក សូមអញ្ជើញឲ្យសិស្សពីរបីនាក់សរសេរពីការរកឃើញរបស់ពួកគេនៅលើក្ដារខៀន ។ សូមឲ្យពួកគេសរសេរចម្លើយរបស់ពួកគេ ដើម្បីពួកគេអាចបំពេញចន្លោះនៅលើក្ដារខៀនតាមដែលអាចធ្វើបាន ។ សូមឲ្យពួកគេបន្ថែមនូវឥរិយាបថ ឬ សកម្មភាពផ្សេងទៀតដែលពួកគេបានឃើញនៅជុំវិញពួកគេដែលធ្វើឲ្យវាពិបាកដើម្បីស្ដាប់តាមសំឡេងនៃព្រះអង្គសង្គ្រោះ ។ (ចម្លើយរបស់សិស្សអាចរួមមាន ការដាក់ដោយឡែក ។ ការព្រងើយកន្តើយ ។ នឹងការបង្រៀនរបស់ព្រះ អំនួត ការឥតប្រយោជន៍ ការដាក់ដួងចិត្តយើងលើទ្រព្យសម្បត្តិ និង វត្ថុដ៏មានតម្លៃ ការគិតថាយើងប្រសើរជាងអ្នកដទៃ ការបៀតបៀនពួកសុចរិត ឬ ការមិនរាប់រកអ្នកក្រីក្រ និងអ្នកត្រូវការ ។ អ្នកអាចនាំការយកចិត្តទុកដាក់របស់សិស្សទៅលើការប្រើពាក្យដដែលរបស់អាលម៉ា *ប្រឹង* ដែលបញ្ជាក់ថា ប្រជាជនសារ៉ាហិមឡាប្រឹងនៅក្នុងអាកប្បកិរិយា និងឥរិយាបថដ៏មានបាបទាំងនេះ ។

សូមទុកកន្លែងខ្លះដើម្បីសរសេរនៅកណ្ដាលក្ដារខៀនដោយការលុបចេញនូវផ្នែកខ្លះនៃចម្លើយរបស់សិស្ស ។ នៅកន្លែងនោះ សូមសរសេរ *អ្វីតាមសំឡេងនៃអ្នកគង្វាលល្អ* ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ៥:៥៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលឃ្លាដែលបង្រៀនពីរបៀបដែលយើងគួរឆ្លើយតបនឹងឥទ្ធិពលអាក្រក់ ។ (“ ចូរអ្នករាល់គ្នាចេញពីពួកទុច្ចរិតមក” “ ញែកខ្លួន” ហើយ “ ចូរកុំប៉ះពាល់ដល់វត្ថុទាំងឡាយដែលឥតស្អាតរបស់ពួកនោះឡើយ”) ។ អ្នកអាចស្នើឲ្យសិស្សគូសចំណាំឃ្លាទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។ សូមបង្ហាញថា ឃ្លាទាំងនេះបញ្ជាក់ពីតម្រូវការដើម្បីចៀសវាងពីអ្វីៗដែលពុករលួយ ឬ បំពុលយើងខាងវិញ្ញាណឡើយ ។ ដើម្បីជួយសិស្សឲ្យពិភាក្សាពីរបៀបដែលពួកគេអាចងាកចេញពីការរំខានទាំងឡាយ ចៀសវាងពីឥទ្ធិពលអាក្រក់ទាំងឡាយ និង ធ្វើតាមសំឡេងនៃអ្នកគង្វាលល្អ សូមសួរសំណួរដូចខាងក្រោម ៖

- តើយុវជនបរិសុទ្ធថ្ងៃចុងក្រោយម្នាក់អាចធ្វើអ្វីខ្លះ ដើម្បីនៅញែកចេញពីពួកទុច្ចរិត ? (ដើម្បីបញ្ជាក់ចម្លើយរបស់សិស្ស សូមគិតពីការចែកចាយគំរូវិជ្ជមានមួយដែលអ្នកបានឃើញនៅក្នុងគំរូរបស់សិស្សមួយក្នុងថ្នាក់ ។ អ្នកក៏អាចអញ្ជើញឲ្យសិស្សចែកចាយគំរូល្អៗដែលពួកគេបានឃើញនៅក្នុងចំណោមគ្នា) ។
- យោងតាម អាលម៉ា ៥:៥៦–៥៧ តើអ្វីខ្លះជាលទ្ធផលនៃការប្រឹងនៅក្នុងអំពើទុច្ចរិត ? (**ប្រសិនបើយើងប្រឹងនៅក្នុងអំពើទុច្ចរិត យើងនឹងមិនអាចឮសំឡេងនៃអ្នកគង្វាលល្អ ហើយយើងមិនអាចត្រូវបានរាប់ចូលក្នុងចំណោមពួកសុចរិតឡើយ) ។**

ប្រសិនបើមានពេល សូមឲ្យសិស្សមានពេលពីរបីនាទីដើម្បីសញ្ជឹងគិតពីសំណួរខាងក្រោម ។ អ្នកអាចឲ្យពួកគេឆ្លើយនឹងសំណួរនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។

- តើព្រះអម្ចាស់នឹងឲ្យអ្នកធ្វើអ្វីដើម្បីទទួលយកការអញ្ជើញរបស់ទ្រង់ឲ្យមកកាន់ទ្រង់នោះ ? (អ្នកអាចស្នើថា ចម្លើយអាចជាអ្វីមួយដែលពួកគេមានអារម្មណ៍ថាត្រូវធ្វើអ្វីល្អជាងនេះ ឬ វាអាចជាអ្វីមួយដែលពួកគេត្រូវឈប់ធ្វើ) ។

សូមអញ្ជើញឲ្យសិស្សអាន អាលម៉ា ៥:៥៨–៦២ ដោយស្ងាត់ៗ ដោយរកមើលពរជ័យដែលបានសន្យាដល់អស់អ្នកណាដែលរួបរួមគ្នាជាមួយនឹងព្រះអម្ចាស់ និងប្រជាជនរបស់ទ្រង់ ។ (អ្នកអាចស្នើថា សិស្សគួរគូសចំណាំពរជ័យទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។

- តើអ្នកនឹងសង្ខេបសេចក្ដីសន្យារបស់ព្រះអម្ចាស់ដល់អស់អ្នកណាដែលស្ដាប់តាមសំឡេងរបស់ទ្រង់ដោយរបៀបណា ? (ទោះបីជាសិស្សអាចស្នើគោលការណ៍ខុសៗគ្នាក្ដី សូមប្រាកដថា ពួកគេយល់ថា **ប្រសិនបើយើងធ្វើតាមសំឡេងរបស់ព្រះអម្ចាស់ ។ អ្នកគង្វាលល្អ ។ យើងនឹងត្រូវបានរួបរួមគ្នានៅក្នុងនគររបស់ទ្រង់ ។**អ្នកអាចសរសេរគោលការណ៍នេះនៅលើក្ដារខៀន) ។
- តើទម្លាប់អ្វីដែលអ្នកបានអភិវឌ្ឍដែលជួយអ្នកឲ្យស្ដាប់តាមសំឡេងនៃអ្នកគង្វាលល្អ ?
- តើទម្លាប់ទាំងនេះបានជួយអ្នកឲ្យមិនយកចិត្តទុកដាក់នឹងឥទ្ធិពលអាក្រក់ទាំងឡាយដែលបានសរសេរនៅលើក្ដារខៀនដោយរបៀបណា ?

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងស្ដាប់តាមព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ យើងនឹងស្ថិតនៅក្នុងចំណោមពួកសុចរិត ដែលរួបរួមគ្នានៅក្នុងនគររបស់ព្រះអម្ចាស់ ។

អាលម៉ា ៥:៤៣–៥២

អាលម៉ាបំពេញការទទួលខុសត្រូវរបស់គាត់ដើម្បីបង្រៀនពីការប្រែចិត្ត

សូមឲ្យសិស្សសរសេរញាណរាងកាយទាំងប្រាំ (ការមើលឃើញ សំឡេង ការប៉ះ ក្លិន និង រសជាតិ) ។ សូមគិតពីការនាំរបស់ខ្លះដែលនឹងឲ្យសិស្សប្រើញាណទាំងនេះ ។

- តើអ្វីខ្លះដែលអ្នកបានរៀនពីញាណទាំងប្រាំរបស់អ្នកនីមួយៗ ?
- តើមានរបៀបណាមួយដើម្បីដឹង ឬ រៀនពីអ្វីមួដោយគ្មានការប្រើញាណទាំងប្រាំរបស់អ្នកឬទេ ?

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៥:៤៤–៤៨ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលអាលម៉ាបាននិយាយថា គាត់បានដឹង និង ពីរបៀបដែលគាត់បាននិយាយថាគាត់បានដឹងពីវា ។

- យោងតាម អាលម៉ា ៥:៤៨ តើអាលម៉ាបានដឹងអ្វី ?
- តើអាលម៉ាបាននិយាយអ្វី ដែលជាប្រភពនៃទីបន្ទាល់របស់គាត់នោះ ?
- តើអាលម៉ាបានធ្វើអ្វីខ្លះ ដើម្បីទទួលបានសាក្សីនេះពីព្រះវិញ្ញាណបរិសុទ្ធ ?
- តើការអធិស្ឋាន និង ការតមអាហារអាចជួយយើងឲ្យទទួលបាន ឬ ពង្រឹងទីបន្ទាល់មួយអំពីដំណឹងល្អដោយរបៀបណា ?
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ទីបន្ទាល់របស់អ្នកត្រូវបានពង្រឹងតាមរយៈការអធិស្ឋាន ឬ ការតមអាហារនោះ ?

សូមថ្លែងទីបន្ទាល់ថា **យើងអាចដឹងពីខ្លួនយើង តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គប្រោសលោះនៃមនុស្សជាតិ** ។ដើម្បីបញ្ជាក់ពីសារៈសំខាន់នៃការស្វែងរក និង ការទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនមួយថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះប្រោសលោះនៃមនុស្សជាតិ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ អិម រ័សុល បាឡឺដ នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

" ទីបន្ទាល់របស់បុគ្គល ផ្ទាល់ខ្លួននៃសេចក្តីពិតពីដំណឹងល្អ ជាពិសេសជីវិតទេវភាព និង បេសកកម្មនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ គឺសំខាន់ចំពោះជីវិតដ៏អស់កល្បរបស់យើង ។ . . . និយាយម្យ៉ាងទៀតថា ជីវិតដ៏អស់កល្បជានិច្ចត្រូវបានព្យាករណ៍ទៅលើបុគ្គលផ្ទាល់ខ្លួនរបស់យើង ចំណេះដឹងផ្ទាល់ខ្លួននៃព្រះវរបិតារបស់យើងនៅលើស្ថានសួគ៌ និង ព្រះរាជបុត្រាដ៏បរិសុទ្ធរបស់ទ្រង់ ។ ការដឹងដោយសាមញ្ញអំពីវា គឺមិនគ្រប់គ្រាន់នោះទេ ។ យើងត្រូវតែមានបទពិសោធន៍ផ្ទាល់ខ្លួន ខាងវិញ្ញាណដើម្បីបោះយុថ្កាក្នុងខ្លួនយើង ។ ទាំងនេះមកតាមរយៈការស្វែងរកពួកគេតាមរបៀបមួយដ៏ខ្លាំង មានគំនិតតែមួយដូចជាមនុស្សឃ្លានម្នាក់ស្វែងរកអាហារ "("Feasting at the Lord's Table," *Ensign,*ខែ ឧសភា ឆ្នាំ ១៩៩៦, ទំព័រ ៨០) ។

សូមឲ្យសិស្សមានពេលសរសេរចម្លើយរបស់ពួកគេចំពោះសំណួរខាងក្រោម ។ សូមលើកទឹកចិត្តពួកគេផងដែរឲ្យសរសេរពីអ្វីដែលពួកគេនឹងធ្វើដើម្បីទទួលបាន ឬ ពង្រឹងទីបន្ទាល់របស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ទ ។ លើកទឹកចិត្ត ពួកគេឲ្យសម្រេចគោលដៅរបស់ពួកគេ ទោះបីជាវាត្រូវការ " ជាច្រើនថ្ងៃ " ក្តី (អាលម៉ា ៥:៤៦) ។

- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះវិញ្ញាណបរិសុទ្ធធ្វើសាក្សីដល់អ្នកថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះប្រោសលោះនៃពិភពលោក ?

សូមអញ្ជើញឲ្យសិស្សអាន អាលម៉ា ៥:៤៩–៥២ ដោយស្ងាត់ៗ ដោយរកមើលអ្វីដែលអាលម៉ាបានប្រាប់ដល់ប្រជាជនថា ពួកគេត្រូវធ្វើដើម្បីរៀបចំគ្រែងនគរស្ថានសួគ៌ជាមរតក ។

- ហេតុអ្វីបានជាការប្រែចិត្តសំខាន់ដើម្បីចូលទៅក្នុងនគរនៃព្រះ ?

ដើម្បីជួយសិស្សឲ្យអនុវត្តការបង្រៀនរបស់អាលម៉ា អំពីការរៀបចំចូលទៅក្នុងនគរព្រះ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាលិន អេក អូកស៍ នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

" តើនឹងមានអ្វីកើតឡើង បើថ្ងៃស្អែកជាថ្ងៃនៃការយាងមករបស់ទ្រង់ ? ប្រសិនបើយើងបានដឹងថា យើងនឹងជួបព្រះអម្ចាស់នៅថ្ងៃស្អែក—តាមរយៈការស្លាប់តាមពេលវេលារបស់យើង ឬ តាមរយៈការយាងដោយឥតព្រាងទុករបស់ទ្រង់ —តើយើងនឹងធ្វើអ្វីនៅថ្ងៃនេះ ? តើការសារភាពអ្វីដែលអ្នកយើងនឹងធ្វើ ? តើការអនុវត្តអ្វីដែលយើងនឹងមិនបន្តទៀតនោះ ? តើរឿងអ្វីដែលយើងនឹងដោះស្រាយ ? តើយើងនឹងអភ័យទោសដល់អ្វី ? តើយើងនឹងថ្លែងទីបន្ទាល់អំពីអ្វី ?

" ប្រសិនបើយើងនឹងធ្វើរឿងទាំងនោះដូច្នោះ ហេតុអ្វីបានជាយើងមិនធ្វើនាពេលឥឡូវ ? ហេតុអ្វីបានជាយើងមិនស្វែងរកសន្តិភាពខណៈពេលសន្តិភាពអាចទទួលបាននោះ ? (" ការរៀបចំសម្រាប់ការយាងជាលើកទីពីរ " *Ensignឬរេលអាហ្វណា*,ខែ ឧសភា ឆ្នាំ ២០០៤, ទំព័រ ៩) ។

សូមបញ្ចប់ដោយការឲ្យសិស្សមានពេលសញ្ជឹងគិតពីអ្វីដែលពួកគេនឹងត្រូវផ្លាស់ប្តូរនៅក្នុងជីវិតរបស់ពួកគេដើម្បីរៀបចំទៅជួបនឹងព្រះអង្គសង្គ្រោះ ហើយចូលទៅក្នុងនគររបស់ទ្រង់ ។ សូមឲ្យពួកគេសរសេរពីគំនិត និងអារម្មណ៍របស់ពួកគេ ដើម្បីឲ្យពួកគេអាចអានជាថ្មីពីគំនិតរបស់ពួកគេនាពេលក្រោយមក និង ត្រូវបានរំឭកឲ្យធ្វើតាមតាមរយៈការបំផុសគំនិតដែលពួកគេបានទទួល ។

សូមលើកទឹកចិត្តឲ្យមានការអនុវត្ត

ប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា " គោលបំណង [នៃការបង្រៀនដំណឹងល្អ] គឺដើម្បីបំផុសគំនិតដល់បុគ្គលដើម្បីគិតដល់ មានអារម្មណ៍ដល់ ហើយបន្ទាប់មកធ្វើអ្វីមួយអំពីគោលការណ៍នៃដំណឹងល្អដែលនៅរស់ " (នៅក្នុងរបាយការណ៍សន្និសីទខែ តុលា ឆ្នាំ ១៩៧០, ទំព័រ ១០៧) ។ នៅពេលអ្នកបង្រៀនពីគោលការណ៍ដំណឹងល្អដល់សិស្ស សូមអញ្ជើញឲ្យពួកគេធ្វើតាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធនៅក្នុងការជ្រើសរើសរបៀបដែលពួកគេអាចពង្រីកការប្រព្រឹត្តរបស់ពួកគេ ហើយពង្រឹងសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ ។

អាលម៉ា ៦–៧

សេចក្តីផ្តើម

ក្រោយពីការដាក់សាសនាចក្រឲ្យមានរបៀបនៅក្នុងទីក្រុងសារ៉ាហិមឡាហើយ អាលម៉ាបានទៅទីក្រុងរបស់គេឌាន ។ គាត់បានឃើញថា ប្រជាជននៅទីនោះមានកត្តិភាពដាងប្រជាជននៅសារ៉ាហិមឡាពីមុនទៅទៀត ។ ហេតុដូច្នេះហើយ សារលិខិតរបស់គាត់នៅក្នុងគេឌានខុសពីសារលិខិតនៅក្នុងសារ៉ាហិមឡា ។ គាត់បានលើកទឹកចិត្តប្រជាជនឲ្យបន្តពឹងផ្អែកទៅលើព្រះអម្ចាស់ ហើយស្វែងរកអនុវត្តជង្វាយធួនរបស់ទ្រង់នៅក្នុងជីវិតរបស់ពួកគេ ។ គាត់បានថ្លែងទីបន្ទាល់ថា ព្រះអង្គសង្គ្រោះបានលើកដាក់មកលើអង្គទ្រង់នូវការស្លាប់ និងអំពើបាបរបស់យើង ហើយថាទ្រង់ក៏បានលើកដាក់លើអង្គទ្រង់នូវការឈឺចាប់ ការរងទុក្ខ ជំងឺ និង ពិការភាពរបស់យើង ថាទ្រង់អាចដឹងពីរបៀបដើម្បីជួយយើង ។

បង្រៀនពីព្រះគម្ពីរ

ក្នុងការខិតខំរៀបចំរបស់យើង គ្រូបង្រៀនដំណឹងល្អខ្លះបានជ្រកស្រង់ប្រភពក្រៅពីព្រះគម្ពីរ ។ ខណៈពេលដែលប្រភពបន្ថែមខ្លះ ដូចជាសៀវភៅណែនាំនេះ អាចជួយដល់អ្នក សូមផ្តោតលើការបង្រៀនដោយផ្ទាល់ពីពីអត្ថបទព្រះគម្ពីរមុនតែមួយ ។ ការណ៍នេះនឹងអនុញ្ញាតឲ្យព្រះវិញ្ញាណបរិសុទ្ធធ្វើទីបន្ទាល់ជាសាក្សីដល់សិស្សរបស់អ្នក ទាក់ទងនឹងសេចក្តីពិតនៃព្រះគម្ពីរ និងតម្លៃនៃការសិក្សាវា ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៦

អាលម៉ារៀបចំសាសនាចក្រនៅក្នុងទីក្រុងសារ៉ាហិមឡាឲ្យមានរបៀប ហើយទៅបង្រៀនក្នុងទីក្រុងគេឌាន

មុនចាប់ផ្តើមមេរៀន សូមឲ្យសិស្សម្នាក់រៀបចំចែកចាយដោយសង្ខេបដល់សិស្សក្នុងថ្នាក់ នូវរបៀបខ្លះដែលគេមានអារម្មណ៍ថាបានប្រទានពរសម្រាប់ការខិតខំរបស់គេដើម្បីមកកាន់ព្រះវិហារ ។ ដើម្បីចាប់ផ្តើមមេរៀន សូមឲ្យសិស្សដដែលនោះមកកាន់ខាងមុខថ្នាក់ ហើយចែកចាយនូវគំនិតដែលគេបានរៀបចំ ។ អ្នកក៏អាចចែកចាយពីរបៀបដែលអ្នកត្រូវបានប្រទានពរតាមរយៈការចូលរួមក្នុងសាសនាចក្រ ។

សូមណែនាំ អាលម៉ា ៦ ដោយការពន្យល់ថា ជំពូកនេះបង្រៀនពីរបៀបដែលអាលម៉ា និងអ្នកដឹកនាំបព្វជិតភាពដទៃទៀតពង្រឹងសាសនាចក្រនៅក្នុងដែនដីសារ៉ាហិមឡា ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៦:៤–៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលសមាជិកនៃសាសនាចក្រក្នុងដែនដីសារ៉ាហិមឡាបានធ្វើសម្រាប់អ្នកដែលមិនបានស្គាល់ព្រះ ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរៀន ។

សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***សាសនាចក្រត្រូវបានស្ថាបនាសម្រាប់សុខុមាលភាពនៃប្រជាជនទាំងឡាយ*** ។ដើម្បីជួយសិស្សឲ្យគិតពីរបៀបដែលសេចក្តីពិតនេះអាចជះឥទ្ធិពលដល់ជីវិតរបស់ពួកគេ សូមសួរ ៖

- តើអ្នកគិតថា សាសនាចក្រសព្វថ្ងៃនេះអាចប្រទានពរដល់អ្នកដែលមិនស្គាល់ព្រះដោយរបៀបណា

សូមឲ្យសិស្សគិតអំពីនរណាម្នាក់ដែលត្រូវដឹងពីព្រះជាងមុន ។ បុគ្គលនេះអាចជាសមាជិកនៃសាសនាចក្រ ឬ សមាជិកនៃអ្នកមានជំនឿផ្សេងទៀត ។ សូមថ្លែងទីបន្ទាល់ពីពរជ័យដែលយើងទទួលបាន ដោយសារយើងជាសមាជិកនៃសាសនាចក្រ ហើយសូមលើកទឹកចិត្តសិស្សឲ្យអញ្ជើញអ្នកដទៃដើម្បីចែកចាយនូវពរជ័យទាំងនោះ ។

អាលម៉ា ៧:១–១៣

អាលម៉ាព្យាករណ៍ពីការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ

សូមឲ្យសិស្សធ្វើការជាដៃគូ ។ សូមឲ្យដៃគូនីមួយៗពិភាក្សាពីចម្លើយរបស់ពួកគេចំពោះសំណួរខាងក្រោម ៖

- តើហេតុការណ៍អនាគតកាលណាខ្លះដែលអ្នកនឹងមានអារម្មណ៍រំភើបនោះ ?

ក្រោយពីដៃគូមានពេលល្មមក្នុងការពិភាក្សាចម្លើយចំពោះសំណួររបស់ពួកគេហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយចម្លើយរបស់គេដល់សិស្សក្នុងថ្នាក់ ។ បន្ទាប់មក សូមពន្យល់ថា ក្រោយពីអាលម៉ាបានរៀបចំសាសនាចក្រឲ្យមានរបៀបរៀបរយក្នុងដែនដីសារ៉ាហិមឡាហើយ គាត់បានទៅកាន់ទីក្រុងគេឌាន ។ គាត់បានប្រាប់ប្រជាជននៅទីនោះថា ក្នុងចំណោមអ្វីៗទាំងអស់ដែលនឹងកើតឡើងនៅក្នុងពេលអនាគត មានរឿងមួយដែល " សំខាន់ជាងរឿងទាំងអស់ " (អាលម៉ា ៧:៧) ។ គាត់បានបង្រៀនគោលការណ៍នានាដែលនឹងជួយដល់ប្រជាជនឲ្យរៀបចំសម្រាប់ពរជ័យទាំងឡាយដែលនឹងមក ដោយសារតែហេតុការណ៍អនាគតនេះ ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៧:៣–៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលក្តីសង្ឃឹមដែលអាលម៉ាមាន អំពីប្រជាជននៅក្នុងទីក្រុងគេឌាន ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់ទៀតអាន អាលម៉ា ៧:១៨–១៩ ឮៗ ។ សូមឲ្យសិស្សពិពណ៌នាអ្វីដែលអាលម៉ាបានរៀនពីការបំផុសគំនិតអំពីប្រជាជនគេឌាន ។

សូមឲ្យសិស្សអាន អាលម៉ា ៧:៧, ៩–១០ដោយស្ងាត់ៗ ដោយរកមើលហេតុការណ៍ដែលអាលម៉ាមានអារម្មណ៍ថាសំខាន់ជាងគេដើម្បីឲ្យប្រជាជនដឹងនោះ ។

- យោងតាមអាលម៉ា តើអ្វីជា " រឿងមួយដែលសំខាន់ជាងគេ " ជាងរឿងផ្សេងទៀតដែលនឹងកើតឡើងនោះ ? តើអ្នកគិតថា ហេតុអ្វីបានជាការយាងមកនៃព្រះអង្គសង្គ្រោះ គឺជាហេតុការណ៍ដ៏សំខាន់ជាងគេក្នុងពេលទាំងឡាយ ?
- តើអ្នកគិតថា ហេតុអ្វីបានជាអាលម៉ាប្រាប់ដល់ប្រជាជនដែលបានជឿ និងមានសេចក្តីជំនឿដ៏រឹងមាំរួចហើយថាពួកគេត្រូវតែប្រែចិត្ត ?

អាលម៉ា ៧:១១–១៣
គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមបើកទៅគំនិតក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរលើវគ្គនេះ ។

សូមពន្យល់ថា បន្ទាប់ពីនោះមក អាលម៉ាបានបង្រៀនពីមូលហេតុនៃការយាងមកនៃព្រះយេស៊ូវគ្រីស្ទ គឺជាហេតុការណ៍ដ៏សំខាន់បំផុតក្នុងចំណោមប្រវត្តិសាស្ត្រមនុស្សជាតិទាំងឡាយ ។ សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៧:១១–១៣ ។ សូមអញ្ជើញឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយរកមើលអ្វីដែលព្រះអង្គសង្គ្រោះបានលើកដាក់ទៅលើអង្គទ្រង់សម្រាប់យើងនោះ ។ (អ្នកអាចពន្យល់ថា *ជួយ* មានន័យថា ផ្តល់ជំនួយ ឬ ទៅជួយដល់នរណាម្នាក់) ។

សូមបង្ហាញថា អាលម៉ា ៧:១១–១៣ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ អ្នកអាចស្នើថា សិស្សគួរគូសចំណាំវគ្គនេះតាមរបៀបមួយដែលពួកគេអាចរកវាឃើញដោយងាយ ។

សូមសរសេរចម្លើយរបស់សិស្ស ជាចំណងជើងលើក្តារខៀន ។ ចម្លើយអាចរួមមាន *ការឈឺចាប់ សេចក្តីវេទនា ការល្បួង ជំងឺ ការស្លាប់ ការរងទុក្ខ (ភាពទន់ខ្សោយ ឬ អសមត្ថភាព)* និង *អំពើបាប* ។

អ្នកអាចស្នើថា សិស្សគួរគូសចំណាំឃ្លា " គ្រប់បែបយ៉ាង " នៅក្នុង អាលម៉ា ៧:១១ ។ សូមឲ្យពួកគេលើកពីឧទាហរណ៍នៃស្ថានភាពនីមួយៗដែលបានសរសេរនៅលើក្តារខៀន ។ នៅពេលសិស្សផ្តល់ឧទាហរណ៍ សូមសរសេរវាពីក្រោមចំណងជើងដែលសឹក្គា ។ (ឧទាហរណ៍ *ជំងឺមហារីក* អាចសរសេរនៅក្រោម *ជំងឺ* ហើយ*អសមត្ថភាពខាងរាងកាយ* អាចសរសេរនៅក្រោម*ការរងទុក្ខ* ។)

សូមអញ្ជើញឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយ អែលឌើរ ប្រ៊ុស ស៊ី ហាហ្វែន នៃក្រុមចិតសិបនាក់ ៖

" ដង្វាយធួនមិនមែនសម្រាប់តែអ្នកមានបាបនោះទេ " ("Beauty for Ashes: The Atonement of Jesus Christ," *Ensign,* ខែ មេសា ឆ្នាំ ១៩៩០, ទំព័រ ៧) ។ អ្នកអាចសរសេរសេចក្តីថ្លែងការណ៍នេះនៅលើក្តារខៀន ហើយសុំឲ្យសិស្សសរសេរវាក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ៧:១១–១៣ ។

- ដោយផ្អែកលើអ្វីដែលយើងបានអាននៅក្នុង អាលម៉ា ៧:១១–១៣ តើអ្នកគិតថា អែលឌើរ ហាហ្វែន ចង់មានន័យយ៉ាងណា នៅពេលគាត់និយាយថា " ដង្វាយធួនមិនមែនសម្រាប់តែអ្នកមានបាបនោះទេ " ?

សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខដើម្បីសង្គ្រោះយើងពីអំពើបាប និង សេចក្តីស្លាប់ ហើយដើម្បីជួយយើងឲ្យឆ្លងកាត់ឧបសគ្គទាំងឡាយនៃជីវិតខាងសាច់ឈាម ។***

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ពីរបៀបដែលពួកគេអាចពឹងផ្អែកទៅលើដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដៃប្រ៊ី អ័រ ហូឡិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

" តើអ្នកប្រឈមទ្រនឹងបិសាចនៃការញៀន— ថ្នាំជក់ ឬ ថ្នាំញៀន ឬ ល្បែង ឬ ជំងឺបណ្តោះអាសន្នដ៏សាហាវនៃកាមសាស្ត្រ ? . . . តើអ្នកមានទ្រឡឹងនឹងការបញ្ជាក់ពីភេទ ឬ ការស្វែងរកការគោរពថ្លាល់ខ្លួនទេ ? តើអ្នក—ឬនរណាម្នាក់ដែលអ្នកស្រឡាញ់—ប្រឈមមុខនឹងជំងឺ ឬសម្ពាធ ឬការស្លាប់ទេ ? មិនថាជំហានផ្សេងទៀតដែលអ្នកអាចត្រូវដើរដើម្បីដោះស្រាយបញ្ហាទាំងនេះទេ សូម *ដំបូងបំផុត* នោះចូលមកកាន់ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ សូមទុកចិត្តលើសេចក្តីសន្យានៃស្តាន្ទគ៌ ។ . . .

" ការពឹងផ្អែកទៅលើលក្ខណៈដ៏មានក្តីមេត្តាករុណារបស់ព្រះនេះ គឺនៅក្នុងស្នូលនៃដំណឹងល្អ ដែលព្រះគ្រីស្ទបានបង្រៀន ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ដង្វាយធួនរបស់ព្រះអង្គសង្គ្រោះលើកយើងមិនត្រឹមតែឲ្យចេញពីបន្ទុកនៃអំពើបាបរបស់យើងនោះទេ ប៉ុន្តែថែមទាំងចេញពីបន្ទុកនៃការសោកសៅ និង ទុក្ខសោករបស់យើង ជំងឺបេះដូងរបស់យើង និង ការឈឺចាប់របស់យើង ។ | សូមមើលអាលម៉ា ៧:១១–១២ ។ | តាំងពីដើមដំបូង ការទុកចិត្តទៅលើជំនួយបែបនោះ គឺត្រូវឲ្យយើងទាំងមូលហេតុ និង ផ្លូវមួយដើម្បីពង្រីក ការជម្រុញដើម្បីដាក់ចុះនូវបន្ទុករបស់យើង ហើយលើកដាក់នូវសេចក្តីសង្គ្រោះរបស់យើង " ("Broken Things to Mend," *Ensign*ឬ*លេខអាហ្វណា,*ខែ ឧសភា ឆ្នាំ ២០០៦, ទំព័រ ៧០–៧១) ។

- តើការយល់ពី អាលម៉ា ៧:១១–១៣ អាចជួយយើង នៅពេលយើងប្រឈមមុខនឹងឧបសគ្គដោយរបៀបណា ?

ដើម្បីបង្ហាញពីរបៀបខ្លះដែលយើងអាចទទួលជំនួយ និង កម្លាំងតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ សូមអានស្ថានភាពខាងក្រោមនេះ ។ ក្រោយពីការអានស្ថានភាពនីមួយៗហើយ សូមឲ្យសិស្សពន្យល់ពីរបៀបដែលព្រះយេស៊ូវគ្រីស្ទ តាមរយៈដង្វាយធួនរបស់ទ្រង់អាចជួយដល់បុគ្គលនោះឲ្យប្រឈមមុខនឹងឧបសគ្គបែបនោះ ។

១. យុវនារីម្នាក់ស្ថិតក្នុងគ្រោះថ្នាក់ចរាចរណ៍ដែលធ្វើឲ្យជើងរបស់នាងពិការ ។

២. យុវជនម្នាក់ត្រូវខ្ចាស់គេនឹងជម្រើសដែលអាក្រក់ខ្លះដែលគាត់បានធ្វើ ។ គាត់មានអារម្មណ៍ពិបាកចិត្ត និង គ្មានតម្លៃ ។

៣. ឪពុករបស់យុវជនម្នាក់ បានស្លាប់នាពេលថ្មីៗនេះ ហើយយុវជននោះបានប្តូរលំនៅទៅទីក្រុងថ្មីមួយជាមួយនឹងម្តាយរបស់គាត់ ។ គាត់មានអារម្មណ៍ក្រៀមក្រំ និងឯកោ ហើយគាត់មិនអាចឃើញពីរបៀបដែលអ្វីៗនឹងអាចដូចដើមម្តងទៀតនោះទេ ។

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីអំណាចនៃដង្វាយធួន និង ចម្ងាយដែលដង្វាយធួនអាចទៅដល់ ។ បន្ទាប់មកសូមឲ្យសិស្សមានពេលពីរបីនាទីដើម្បីឆ្លើយនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេចំពោះសំណួរមួយខាងក្រោមនេះ ។ (អ្នកអាចសរសេរសំណួរទាំងនេះនៅលើក្តារខៀនមុនចាប់ផ្តើមថ្នាក់ សូមរៀបចំជាក្រដាសដោយមានសំណួរចែកដល់សិស្ស ឬ អានសំណួរយឺតៗដើម្បីឲ្យសិស្សអាចចម្លងវា ។)

- តើនៅពេលណាដែលដង្វាយធួនបានជួយអ្នក ឬ នរណាម្នាក់ដែលអ្នកស្គាល់តាមរបៀបមួយដែលបានលើកឡើងនៅក្នុង អាលម៉ា ៧:១១–១៣ ?
- តើអ្នកនឹងធ្វើអ្វីដើម្បីពឹងផ្អែកទៅលើដង្វាយធួន នៅពេលអ្នកប្រឈមមុខនឹងឧបសគ្គទាំងឡាយ ?

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ចែកចាយដល់សិស្សក្នុងថ្នាក់នូវអ្វីដែលពួកគេបានសរសេរ ។ (សូមរំឭកពួកគេថា ពួកគេមិនចាំបាច់ចែកចាយនូវអ្វីៗដែលផ្ទាល់ខ្លួន ឬ ឯកជនពេកនោះទេ) ។

អាលម៉ា ៧:១៤–២៧

អាលម៉ាលើកទឹកចិត្តដល់ប្រជាជនឲ្យបន្តដើរតាមផ្លូវទៅនគរនៃព្រះ

ដើម្បីរំឭកសិស្សពីរបៀបដែលអាលម៉ាបានពិពណ៌នាស្ថានភាពខាងវិញ្ញាណនៃប្រជាជនគេខាន សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ៧:១៩ ឮៗ ។ សូមសង្កត់ធ្ងន់ថា ប្រជាជន " កំពុងនៅលើផ្លូវដែលនាំទៅរកនគរនៃព្រះ " ។ សូមពន្យល់ថា អាលម៉ាចង់ជួយពួកគេឲ្យបន្តនៅលើផ្លូវនោះ ។

ដើម្បីជួយសិស្សឲ្យឃើញថា **ដោយការរស់នៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ យើងដើរតាមផ្លូវដែលនាំទៅរកនគរនៃព្រះ:** សូមគូសផ្លូវមួយនៅលើក្តារខៀន ។ នៅដើមដំបូងនៃផ្លូវនេះ: សូមសរសេរ *ភាពខាងសាច់ឈាម* ។នៅចុងបញ្ចប់នៃផ្លូវនេះ: សូមសរសេរ *នគរនៃព្រះ:* ។សូមឲ្យសិស្សធ្វើការជាពីរក្រុម ។ សូមអញ្ជើញឲ្យក្រុមទីមួយសិក្សា អាលម៉ា ៧:១៤–១៦ ហើយក្រុមទីពីរសិក្សា អាលម៉ា ៧:២២–២៤ ។ សូមឲ្យក្រុមទាំងពីរពិនិត្យមើលអ្វីដែលយើងត្រូវ *ធ្វើ* ហើយអ្វីដែលយើងត្រូវ *ក្លាយជា* ដើម្បីដើរតាមផ្លូវដែលនាំទៅរកនគរនៃព្រះ: ។

ក្រោយពីសិស្សមានពេលអានគ្រប់គ្រាន់ហើយ សូមអញ្ជើញឲ្យពួកគេពីរបីនាក់ឡើងមកកាន់ក្តារខៀន ។ សូមឲ្យពួកគេសរសេរតាមផ្លូវនូវសកម្មភាព និងឥរិយាបថនានាដែលពួកគេរកឃើញដែលនាំទៅរកនគរព្រះ: ។ អ្នកអាចសួរសិស្សថា តើសកម្មភាព ឬឥរិយាបថអ្វីខ្លះតាមផ្លូវនេះដែលមានន័យដល់ពួកគេ ។ អ្នកក៏អាចសុំឲ្យពួកគេគិតអំពីរបៀបដែលពួកគេអាចធ្វើតាមផ្លូវនេះនៅក្នុងជីវិតរបស់ពួកគេ ។ សូមថ្លែងទីបន្ទាល់ថា នៅពេលយើងរស់នៅដោយស្មោះត្រង់ យើង " កំពុងនៅលើផ្លូវដែលនាំទៅរកនគរនៃព្រះ" ហើយ (អាលម៉ា ៧:១៩) ។

ចំណេះចំណានខគម្ពីរ—អាលម៉ា ៧:១១–១៣

ដោយសារ អាលម៉ា ៧:១១–១៣ គឺជាវគ្គចំណេះចំណានខគម្ពីរដ៏វែងមួយ វាអាចពិបាកសម្រាប់សិស្សក្នុងការចងចាំវា ។ ប៉ុន្តែភាសារបស់អាលម៉ារួមមាននូវពាក្យជាក់លាក់ដែលអាចជួយឲ្យសិស្សចងចាំពេញមួយជីវិតរបស់ពួកគេនូវអំណាច និង ការអាចទៅដល់នៃដង្វាយធួន ។ ដើម្បីជួយសិស្សឲ្យចងចាំពាក្យគន្លឹះទាំងនេះ: សូមសរសេរបរិបទនៃ អាលម៉ា ៧:១១–១៣ នៅលើក្តារខៀនមុនចាប់ផ្តើមថ្នាក់ ដោយដាក់ចន្លោះទទេសម្រាប់ពាក្យគន្លឹះខាងក្រោម នៅពេលវាលេចឡើង ៖ *ការឈឺចាប់ ទុក្ខវេទនា ការល្បួង ជំងឺ សេចក្តីស្លាប់ ជំងឺឈឺចាប់ អំពើបាប អំពើរំលងទាំងឡាយ* ។(ឧទាហរណ៍ ការសរសេររបស់អ្នកអំពី អាលម៉ា ៧:១១ នឹងចាប់ផ្តើមដូចនេះ ៖ *" ហើយទ្រង់នឹងយាងទៅ ដោយ . . . និង . . . និង . . . គ្រប់បែបយ៉ាង")* ។

នៅពេលអ្នកអាន អាលម៉ា ៧:១១–១៣ ឮៗទាំងអស់គ្នាក្នុងថ្នាក់ សូមឲ្យសិស្សបំពេញពាក្យដែលចន្លោះនោះ ។ ក្រោយពីអ្នកបានធ្វើដូច្នេះពីរបីដងហើយ សូមសួរសិស្សថាតើពួកគេអាចសរសេរនៅលើក្រដាសមួយនូវពាក្យដែលបង្ហាញពីអ្វីដែលព្រះអង្គសង្គ្រោះបានលើកដាក់មកលើអង្គទ្រង់សម្រាប់ពួកគេ ។ សូមអញ្ជើញឲ្យសូមឲ្យសិស្សចងចាំជានិច្ចពីអ្វីដែលព្រះយេស៊ូវគ្រីស្ទបានធ្វើសម្រាប់ពួកគេ ដើម្បីនៅពេលពួកគេជួបនឹងឧបសគ្គទាំងឡាយ នោះពួកគេអាចមានសេចក្តីជំនឿខ្លាំងជាងនេះនៅក្នុង " អំណាចនៃការដោះលែងរបស់ទ្រង់" ។

កំណត់ចំណាំ ៖ អ្នកអាចយកពេលពីរបីនាទីពេលចាប់ផ្តើមដំបូងនៃថ្នាក់លើកក្រោយរបស់អ្នកដើម្បីឃើញថា សិស្សនៅអាចចាំពាក្យគន្លឹះទាំងនេះទាក់ទងនឹងការទៅដល់ដ៏អស្ចារ្យនៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ។

អាលម៉ា ៨

សេចក្តីផ្តើម

ក្រោយពីមនុស្សជាច្រើនបានទទួលយកសារលិខិតរបស់អាលម៉ានៅក្នុងដែនដីសារ៉ាហិមឡា គេឌាន និង ដែនដីមេលេកហើយ ប្រជាជនរបស់អាំម៉ូណៃហាបានបដិសេធអាលម៉ា ហើយបានដេញគាត់ចេញពីទីក្រុងរបស់ពួកគេ ។ នៅពេលអាលម៉ារងទុក្ខពីសេចក្តីទុច្ចរិតនៃប្រជាជនទាំងនេះ ទេវតាជដែលនោះដែលបានមកជួបគាត់ និងបុត្រាទាំងឡាយនៃស្តេចម៉ូសាយបានមកជួបនឹងគាត់ម្តងទៀត ។ ទេវតាបានសរសើរអាលម៉ាដល់កក្តីភាពរបស់គាត់ ហើយបានបញ្ជាឲ្យគាត់ត្រឡប់ទៅកាន់ដែនដីអាំម៉ូណៃហា ។ អាលម៉ាបានគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដោយស្មោះត្រង់ ហើយព្រះអម្ចាស់បានហៅ អាម៉ូលេក ដើម្បីជួយគាត់នៅក្នុងការបម្រើរបស់គាត់ ។ អាលម៉ា និង អាម៉ូលេកបានចេញទៅបង្រៀនប្រជាជនអាំម៉ូណៃហាដោយស្មោះត្រង់ ដោយពោរពេញទៅដោយព្រះវិញ្ញាណបរិសុទ្ធ និង អំណាចដើម្បីធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៨:១–៦

មនុស្សជាច្រើននៅក្នុងដែនដីមេលេកទទួលយកសារលិខិតរបស់អាលម៉ា និងត្រូវបានជ្រមុជទឹក

សូមឲ្យសិស្សលើកដៃ ប្រសិនបើពួកគេមានសាច់ញាតិ ឬ មិត្តភក្តិដែលបានបម្រើបេសកកម្មសម្រាប់សាសនាចក្រ ។ សូមឲ្យសិស្សពីរឬបីនាក់ចែកចាយពីបទពិសោធន៍ដែលសាច់ញាតិ ឬមិត្តភក្តិរបស់ពួកគេទាក់ទងនឹងពួកគេ ដែលបង្ហាញពីរបៀបដែលអ្នកផ្សព្វផ្សាយសាសនាមានអារម្មណ៍ នៅពេលសារលិខិតរបស់ពួកគេត្រូវបានទទួលយកនោះ ។ (អ្នកក៏អាចឲ្យសិស្សប្រាប់ពីពេលដែលនរណាម្នាក់ទទួលយកការខិតខំរបស់ពួកគេដើម្បីចែកចាយដំណឹងល្អដែរ ។ អ្នកក៏អាចចែកចាយពីបទពិសោធន៍មួយផ្ទាល់របស់អ្នកដែរ ។)

សូមឲ្យសិស្សអាន អាលម៉ា ៨:១–៥ ដោយស្ងៀមស្ងាត់ ។ សូមឲ្យពួកគេរកមើលទីក្រុងបី ដែលអាលម៉ាបានបង្រៀនដំណឹងល្អ ។ សូមសរសេរឈ្មោះនៃទីក្រុងទាំងបីនោះនៅលើក្តារខៀន ។ (*ទីក្រុងសារ៉ាហិមឡា គេឌាន និង មេលេក* ។)

- តើអ្វីជាលទ្ធផលនៃការបង្រៀនរបស់អាលម៉ានៅក្នុងទីក្រុងទាំងបីនេះ ? (អ្នកអាចស្នើថា សិស្សគួរបើកទៅសេចក្តីសង្ខេបនៃជំពូកសម្រាប់ អាលម៉ា ៦–៨ ដើម្បីជួយពួកគេឲ្យឆ្លើយនឹងសំណួរនេះ ។)

សូមបង្ហាញថា ទោះបីជាប្រជាជននៃទីក្រុងទាំងនេះបានទទួលយកសារលិខិតរបស់អាលម៉ាក្តី ក៏ការបម្រើផ្សព្វផ្សាយសាសនារបស់គាត់មិនមែនគ្មានឧបសគ្គនោះទេ ។

អាលម៉ា ៨:៧–៣២

ក្រោយពីអាលម៉ាត្រូវបានបដិសេធនៅក្នុងដែនដីអាំម៉ូណៃហាមក ព្រះអម្ចាស់បញ្ជាគាត់ឲ្យត្រឡប់ទៅវិញ

សូមសួរសិស្សថាតើសាច់ញាតិ ឬ មិត្តភក្តិរបស់ពួកគេដែលបានបម្រើបេសកកម្មពេញម៉ោងនោះធ្លាប់បានឃើញមនុស្សបដិសេធសារលិខិតនៃដំណឹងល្អទេ ។ សូមគិតពីការអញ្ជើញឲ្យសិស្សពីរបីនាក់ប្រាប់ពីរបៀបដែលសាច់ញាតិ ឬ មិត្តភក្តិរបស់ពួកគេបានឆ្លើយតបនឹងបទពិសោធន៍បែបនោះ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យប្តូរវេនគ្នាអានឮៗពី អាលម៉ា ៨:៧–១៤ ។ សូមលើកទឹកចិត្តសិស្សឲ្យគិតអំពីរបៀបដែលអាលម៉ាអាចមានអារម្មណ៍ នៅពេលគាត់បានព្យាយាមបង្រៀនដំណឹងល្អទៅដល់ប្រជាជនអាំម៉ូណៃហា ។ នៅពេលសិស្សអានខគម្ពីរទាំងនេះ សូមឲ្យពួកគេឈប់បន្តិចដើម្បីឆ្លើយនឹងសំណួរដូចខាងក្រោម ៖

- តើខគម្ពីរទាំងនេះប្រាប់យើងអំពីចរិតរបស់អាលម៉ាដូចម្តេចខ្លះ ? (សូមមើល អាលម៉ា ៨:៨–១០ ។)
- តើអ្នកអាចឆ្លើយតបនឹងការប្រព្រឹត្តដែលអាលម៉ាបានទទួលដោយរបៀបណា ? (សូមមើល អាលម៉ា ៨:១១–១៣) ។
- តើប្រតិកម្មរបស់អាលម៉ាអាចស្រដៀង ឬ ខុសពីប្រតិកម្មរបស់អ្នកនៅក្នុងស្ថានភាពដូចគ្នាដោយរបៀបណា ? (សូមមើល អាលម៉ា ៨:១៤ ។ អ្នកអាចស្នើថា ការសម្រេចចិត្តរបស់អាលម៉ាដើម្បីបន្តកិច្ចការរបស់ព្រះអម្ចាស់នៅក្នុងទីក្រុងរបស់អើរ៉ុនបានបង្ហាញថា គាត់បានមានសេចក្តីជំនឿទៅលើព្រះអម្ចាស់ ហើយថាគាត់មិនបានឈប់នោះទេ) ។

សូមបង្ហាញថា ទោះបីជាការអធិស្ឋានរបស់អាលម៉ាសម្រាប់ប្រជាជនអាំម៉ូណៃហាស្មោះអស់ពីចិត្តក្តី (សូមមើល អាលម៉ា ៨:១០) សំណើររបស់គាត់មិនត្រូវបានផ្តល់ឲ្យភ្លាមៗនោះទេ ។ (ប្រជាជនខ្លះនៅក្នុងដែនដីអាំម៉ូណៃហាបានប្រែចិត្តក្រោយមក ។ សូមមើល អាលម៉ា ១៩:១) ។

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ័សុល អិម ណិលសុននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

" ខ្ញុំទទួលស្គាល់ថា ពេលខ្លះ ការអធិស្ឋានដ៏គោរពខ្លាំងបំផុតរបស់យើងខ្លះអាចមើលទៅមិនមានចម្លើយនោះទេ ។ យើងឆ្ងល់ថា ‹ ហេតុអ្វី ? › ខ្ញុំដឹងពីអារម្មណ៍នោះ ! ខ្ញុំដឹងពីការភ័យខ្លាច និង ទឹកភ្នែកនៃពេលបែបនោះ ។ ប៉ុន្តែខ្ញុំក៏ដឹងដែរថា ការអធិស្ឋានរបស់យើងមិនដែលបានត្រូវចោះបង់ឡើយ ។ សេចក្តីជំនឿរបស់យើងមិនដែលត្រូវបានគេមិនកោតសរសើរនោះទេ ។ ខ្ញុំដឹងថា ការរំពឹងទុករបស់ព្រះវរបិតាសួគ៌ាដែលប្រកបដោយការញាណដឹង គឺធំទូលាយខ្លាំងជាងការរំពឹងទុករបស់យើងឆ្ងាយណាស់ ។ ខណៈពេលដែលយើងដឹងពីបញ្ហាខាងជីវិតសាច់ឈាមរបស់យើង និង ការឈឺចាប់ហើយ ទ្រង់ដឹងពីភាពរីកចម្រើនអមតភាពរបស់យើង និង សក្តានុពល " ("Jesus Christ—the Master Healer," *Ensign* ឬ *លេខអាហ្វណា*, ខែ វិច្ឆិកា ឆ្នាំ ២០០៥, ទំព័រ ៨៦) ។

- តើអែលឌើរណែនសិនបានបង្រៀនអ្វីខ្លះ ដែលអាចជួយយើងឲ្យមានសេចក្តីជំនឿ ទោះបីជានៅពេលការអធិស្ឋានដ៏សុចរិតរបស់យើងមិនត្រូវបានឆ្លើយតបភ្លាមៗក្តី ឬ តាមរបៀបដែលយើងសង្ឃឹម ឬរំពឹងទុកក្តី ?

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៨:១៤–១៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់អានតាម ដោយរកមើលសារលិខិតដែលលួងលោមនៅក្នុងសម្តីរបស់ទេវតា និង សម្រាប់ការបញ្ជាដែលអាចមានការលំបាកក្នុងការគោរពតាមសម្រាប់អាលម៉ា ។

- តើសម្តីរបស់ទេវតានៅក្នុង អាលម៉ា ៨:១៥ អាចលួងលោមដល់អាលម៉ាដោយរបៀបណា ? តើសម្តីរបស់ទេវតាអាចលួងលោមដល់អ្នកដោយរបៀបណា ?
- ហេតុអ្វីបានជាវាអាចពិបាកសម្រាប់អាលម៉ាដើម្បីគោរពតាមនៅក្នុងស្ថានភាពបែបនេះ ?

សូមឲ្យសិស្សអាន អាលម៉ា ៨:១៨ ដោយរកមើលពាក្យដែលពិពណ៌នាពីរបៀបដែលអាលម៉ាឆ្លើយតបនឹងការបញ្ជារបស់ព្រះអម្ចាស់ឲ្យត្រឡប់ទៅកាន់ទីក្រុងអាំម៉ូណៃហាវិញ ។ (អ្នកអាចស្នើថា សិស្សគូរគូសចំណាំពាក្យ *យ៉ាងរួសរាន់*) ។

- តើយើងអាចរៀនអ្វីខ្លះអំពីអាលម៉ាពីការពិតដែលគាត់បានត្រឡប់ទៅកាន់ដែនដីអាំម៉ូណៃហាយ៉ាងរួសរាន់នោះ ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ។ សូមឲ្យសិស្សស្តាប់រកមើលពីរបៀបដែលយើងអាចទទួលបានប្រយោជន៍ពីការគោរពតាមព្រះអម្ចាស់យ៉ាងលឿន ៖

« មិនថាយើងមានសេចក្តីជំនឿក្នុងការគោរពព្រះខ្លាំងប៉ុណ្ណាទេក្នុងពេលឥឡូវនេះ យើងនឹងនៅតែត្រូវពង្រឹងវាយ៉ាងខ្ជាប់ខ្ជួន និងបន្តផ្តល់កម្លាំងដល់វាដោយឥតឈប់ឈរ ។ យើងអាចធ្វើការណ៍នោះបាន ដោយការសម្រេចចិត្តនាពេលឥឡូវនេះដើម្បីគោរពតាមលឿនជាងមុន និង ស៊ូទ្រាំបានខ្លាំងជាងមុន ។ ការរៀនដើម្បីចាប់ផ្តើមឆាប់ៗ និងដើម្បីមានភាពនឹងនឹង គឺជាកូនសោទាំងឡាយ ដើម្បីរៀបចំខាងព្រលឹងវិញ្ញាណ ។ . . .

" . . . ព្រះវរបិតាសួគ៌ាជាទីស្រឡាញ់របស់យើង និង បុត្រាជាទីស្រឡាញ់របស់ទ្រង់បានផ្តល់ជំនួយទាំងឡាយដល់យើង ដែលពួកទ្រង់អាចធ្វើ ដើម្បីឆ្លងការសាកល្បងនៃជីវិតដែលបានដាក់ឲ្យយើងនេះ ។ ប៉ុន្តែយើងត្រូវតែសម្រេចចិត្តដើម្បីគោរពតាម ហើយធ្វើតាមវា ។ នៅពេលយើងសាងសេចក្តីជំនឿដើម្បីឆ្លងការសាកល្បងនៃការគោរពក្នុងពេលនេះ និង អស់ទាំងជម្រើសប្រចាំថ្ងៃទាំងឡាយរបស់យើង ។ យើងអាចសម្រេចចិត្តឥឡូវដើម្បីធ្វើវាយ៉ាងឆាប់ មិនថាអ្វីដែលព្រះបានសុំឲ្យធ្វើនោះទេ ។ ហើយយើងអាចសម្រេចចិត្តដើម្បីនៅនឹងននៅក្នុងការសាកល្បងក្នុងការគោរពដ៏តូចដែលកសាងសេចក្តីជំនឿដើម្បីនាំយើងឆ្លងកាត់ការសាកល្បងដ៏ធំមហិមា ដែលនឹងមកយ៉ាងពិតប្រាកដ " ("Spiritual Preparedness: Start Early and Be Steady," *Ensign*, ខែ វិច្ឆិកា ឆ្នាំ ២០០៥, ទំព័រ ៣៨, ៤០) ។

- យោងតាមប្រធាន អាវរិង តើអ្វីនឹងកើតឡើងដល់សេចក្តីជំនឿរបស់យើង នៅពេលយើងជ្រើសរើសដើម្បីគោរពតាមព្រះអម្ចាស់យ៉ាងឆាប់នោះ ?
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថាសេចក្តីជំនឿរបស់អ្នកទៅលើព្រះអម្ចាស់ត្រូវបានពង្រឹងដោយសារតែការគោរពដ៏ឆាប់ និង ខ្ជាប់ខ្ជួនរបស់អ្នកនោះ ?

សម្រាប់ស្ថានភាពខាងក្រោមនីមួយៗ សូមសួរសិស្សពីរបៀបដែលការគោរពតាមការបំផុសគំនិតអាចប្រទានពរដល់ពួកគេ ៖

១. នៅពេលយុវនារីម្នាក់ចាកចេញពីសាលា ម្តាយរបស់នាងបានសុំឲ្យនាងពាក់អាវដែលសមរម្យជាងនេះ ។

២. នៅក្នុងការសម្ភាសន៍មួយជាមួយនឹងប៊ីស្សព សង្ឃថ្មីម្នាក់ត្រូវបានដាក់ឲ្យធ្វើសៀវភៅកាតពួកិច្ចចំពោះព្រះដើម្បីទទួលបានរង្វាន់ ។

៣. អ្នកផ្សព្វផ្សាយសាសនាពីរនាក់មានអារម្មណ៍រំភើបអំឡុងពេលគ្រោងការណ៍ប្រចាំថ្ងៃរបស់ពួកគេ ដើម្បីទៅសួរសុខទុក្ខគ្រួសារអសកម្មមួយ ដែលម្តាយរបស់ពួកគេមិនមែនជាសមាជិកនៃសាសនាចក្រ ។

> ***ការអានក្នុងការសម្តែង***
>
> សិស្សអាចយល់កាន់តែច្បាស់ពីគោលការណ៍នៃដំណឹងល្អ ដោយការសម្តែងរឿងពីព្រះគម្ពីរ ។ សូមលើកទឹកចិត្តសិស្សឲ្យធ្វើឲ្យបទពិសោធន៍នេះគួរឲ្យចាប់អារម្មណ៍ និងរីករាយដោយមិនមានការដេកចេញនូវភាពពិសិដ្ឋនៃហេតុការណ៍ដែលបានបង្ហាញនៅក្នុងព្រះគម្ពីរឡើយ ។

សូមពន្យល់ថា ព្រះអម្ចាស់បានប្រទានពរដល់អាលម៉ាចំពោះការគោរពភ្លាមរបស់គាត់ ។ សូមឲ្យសិស្សបីនាក់មកខាងមុខថ្នាក់ដើម្បីធ្វើការសម្តែង នៃការជួបរវាងអាលម៉ា និង អាំម៉ូលេកនៅក្នុង អាលម៉ា ៨:១៩–២៦ ។ សូមឲ្យសិស្សម្នាក់អានសម្តីរបស់អាលម៉ា សិស្សទីពីរអានសម្តីរបស់អាំម៉ូលេក ហើយសិស្សទីបីអានពាក្យដើម្បីប្រាប់ពីសាច់រឿង ។ សូមលើកទឹកចិត្តសិស្សឲ្យអានផ្នែករបស់ពួកគេដោយអារម្មណ៍ដែលពួកគេគិតថាអាលម៉ា និង អាំម៉ូលេកអាចទទួលបាន ។

ក្រោយពីការសម្តែង សូមសួរ ៖

- តើព្រះអម្ចាស់បានប្រទានពរដល់អាលម៉ាចំពោះការគោរពតាមដោយរបៀបណា ?
- តើបទពិសោធន៍របស់អាលម៉ាជាមួយនឹងអាំម៉ូលេក ជាការបង្ហាញថាព្រះអម្ចាស់បានឮ និងឆ្លើយតបនឹងការអធិស្ឋានរបស់អាលម៉ាដោយរបៀបណា ? (សូមមើល អាលម៉ា ៨:១០ ។)

- តើគោលការណ៍អ្វីដែលយើងអាចរៀនពីបទពិសោធន៍របស់អាលម៉ា ? (សិស្សអាចនិយាយពីគោលការណ៍ខុសៗគ្នា ។ ចម្លើយមួយអាចថា **នៅពេលយើងឆ្លើយដោយរហ័សទៅនឹងព្រះបន្ទូលរបស់ព្រះអម្ចាស់ ទ្រង់នឹងជួយយើងឲ្យគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ។**)

សូមឲ្យសិស្សអាន អាលម៉ា ៨:២៧–៣២ ដោយស្ងាត់ៗ ដោយរកមើលភស្តុងតាងបន្ថែមដែលថា ប្រសិនបើយើងស្មោះត្រង់ និងឧស្សាហ៍ព្យាយាម ព្រះអម្ចាស់នឹងជួយយើងឲ្យគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ។

- តើឧបសគ្គអ្វីខ្លះដែលអាលម៉ា និងអាម៉ូលេកបានជួប នៅពេលពួកគេបានចេញទៅបង្រៀនដល់ប្រជាជននោះ ? (សូមមើល អាលម៉ា ៨:២៨–២៩ ។ ប្រជាជនបានក្លាយជាទុច្ចរិតខ្លាំងជាងមុន ហើយព្រះអម្ចាស់បានបញ្ជាឲ្យអាលម៉ា និងអាម៉ូលេកបេះពួកគេឲ្យប្រែចិត្ត ។)
- តើព្រះអម្ចាស់បានជួយអាលម៉ា និងអាម៉ូលេកដោយរបៀបណា ? (សូមមើល អាលម៉ា ៨:៣០–៣១ ។ ពួកគេបានពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ និង ទទួលបានអំណាចពីស្ថានសួគ៌ដើម្បីការពារពួកគេ ។ អ្នកអាចស្នើថា សិស្សគួរគូសចំណាំការពិពណ៌នានៃពរជ័យទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់បានជួយដល់អ្នក នៅពេលអ្នកបានស្មោះត្រង់ និងឧស្សាហ៍នោះ ?

សូមឲ្យសិស្សសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហាវីដ ដបុលយូ ហ៊ីនធើរ នៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬសៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ៖

“ ពិតប្រាកដណាស់ថា ព្រះអម្ចាស់ស្រឡាញ់ការសម្រេចចិត្តដ៏ឥតរួញរាក្នុងការគោរពតាមការណែនាំរបស់ទ្រង់ ជាងអ្វីៗទាំងអស់ ” (“ Commitment to God,” *Ensign,* **ខែ វិច្ឆិកា ឆ្នាំ ១៩៨២**, ទំព័រ ៥៨) ។

បន្ទាប់សូមឲ្យពួកគេមានពេលពីរបីនាទីសរសេរចម្លើយមួយចំពោះសំណួរខាងក្រោម ៖

- តើអ្វីដែលអ្នកនឹងធ្វើថ្ងៃនេះ ដើម្បីបង្ហាញដល់ព្រះវរបិតាសួគ៌ថា អ្នកនឹងគោរពតាមការណែនាំរបស់ទ្រង់យ៉ាងរហ័ស ហើយបម្រើទ្រង់ដោយស្មោះត្រង់ និងឧស្សាហ៍នោះ ?

សូមថ្លែងទីបន្ទាល់ពីពរជ័យដែលយើងទទួលបាន នៅពេលយើងធ្វើតាមការណែនាំរបស់ព្រះអម្ចាស់ដោយស្មោះត្រង់ ។ អ្នកក៏អាចឲ្យឱកាសដល់សិស្សដើម្បីចែកចាយទីបន្ទាល់របស់ពួកគេអំពីសេចក្តីពិតនេះដែរ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អាលម៉ា៨:១០ ។ “ ការអធិស្ឋានដ៏ខ្លាំង ”

ឃ្លា “ ការអធិស្ឋានដ៏ខ្លាំង ” បង្ហាញពីទំនាក់ទំនងដ៏មានអំណាចពោរពេញដោយក្តីជំនឿជាមួយនឹងព្រះ ។ អែលឌើរ យ៉ូសែប ប៊ី. វ៉ឹតលីន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានស្នើពីរបៀបដែលយើងអាចវាយតម្លៃ និង ស្វែងរកដើម្បីពង្រឹងកម្លាំងនៃការអធិស្ឋានរបស់យើង ៖

“ តើខ្ញុំអាចសុំឲ្យអ្នកថ្ងៃនេះគិតពីប្រសិទ្ធភាពនៃការអធិស្ឋានរបស់អ្នកទេ ? តើអ្នកគិតថា អ្នកនៅជិតប៉ុណ្ណាទៅនឹងព្រះវរបិតាសួគ៌របស់អ្នក ? តើអ្នកគិតថា ការអធិស្ឋានរបស់អ្នកត្រូវបានឆ្លើយតបទេ ? តើអ្នកមានអារម្មណ៍ថា ពេលដែលអ្នកចំណាយលើការអធិស្ឋានពង្រឹង និងលើកកម្លាំងដល់ព្រលឹងអ្នកទេ ? តើមានកន្លែងសម្រាប់ការកែចម្រើនទេ ?

“ មានមូលហេតុជាច្រើនដែលការអធិស្ឋានរបស់យើងខ្វះអំណាច ។ ពេលខ្លះវាក្លាយជាទម្លាប់ ។ ការអធិស្ឋានរបស់យើងក្លាយជាពាក់កំភែល នៅពេលយើងនិយាយពាក្យដដែលតាមរបៀបស្រដៀងគ្នាច្រើនដែលៗញឹកញាប់ រហូតដល់ពាក្យទាំងឡាយក្លាយជាការទន្ទេញមួយជាជាងការទំនាក់ទំនង ។ នេះគឺជាអ្វីដែលព្រះអង្គសង្គ្រោះបានពិពណ៌នាថាជា ‹ ពាក្យឥតប្រយោជន៍ផ្ទួនៗ › (ម៉ាថាយ ៦:៧) ។ ការអធិស្ឋានបែបនោះ ទ្រង់មានបន្ទូលថា នឹងមិនឮតេ ។ . . .

“ តើការអធិស្ឋានរបស់អ្នកពេលខ្លះ ស្តាប់ទៅ និងមានអារម្មណ៍ថាដូចគ្នាទេ ? តើអ្នកធ្លាប់អធិស្ឋានដូចជាម៉ាស៊ីនទេ ពាក្យដែលហូរចេញមកដូចជាកាត់ពីម៉ាស៊ីនមួយ ? តើពេលខ្លះអ្នកធុញនឹងខ្លួនអ្នក នៅពេលអ្នកអធិស្ឋានទេ ?

“ ការអធិស្ឋានដែលមិនបញ្ជាពីគំនិតរបស់អ្នកភាគច្រើន នឹងកម្រទទួលបានការយកចិត្តទុកដាក់ពីព្រះវរបិតាសួគ៌របស់យើងណាស់ ។ នៅពេលអ្នកឃើញថាខ្លួនអ្នកចូលក្នុងទម្លាប់មួយនឹងការអធិស្ឋានរបស់អ្នក សូមឈប់ក្រោយ ហើយគិត ។ សូមតាំងអារម្មណ៍មួយសន្ទុះពីអ្វីដែលអ្នកពិតជាមានអំណរចំពោះការណ៍នោះ ” (“Improving Our Prayers,” [Brigham Young University devotional address, Jan. 21, 2003], ២, speeches.byu.edu) ។

អាលម៉ា ៩–១០

សេចក្តីផ្តើម

អាលម៉ា និង អាម៉ូលេកបានជោគជ័យបន្តិចបន្តួចពីការបង្រៀនដល់ប្រជាជនអាំម៉ូណៃហា ដោយសារអារក្សសាតាំងបាន “ ក្តាប់ជាប់នូវដួងចិត្តនៃប្រជាជន ” (សូមមើលអាលម៉ា ៨:៩) ។ ពួកគេជាច្រើនបានមានដួងចិត្តដ៏រឹងទទឹងទាស់នឹងដំណឹងល្អ ហើយពួកគេបដិសេធការអញ្ជើញឲ្យប្រែចិត្តរបស់អាលម៉ា និង អាម៉ូលេក ។ យ៉ាងណាក៏ដោយ ក៏អាលម៉ា និងអាម៉ូលេកបានហៅពួកគេឲ្យប្រែចិត្តដោយស្មោះត្រង់ ដោយថ្លែងទីបន្ទាល់ថា ដោយសារពួកគេត្រូវបានបង្រៀនពីសេចក្តីពិត ហើយបានទទួលនូវអំណាចនៃព្រះ៖ ព្រះអម្ចាស់បានព្រមានថាពួកគេនឹងក្លាយជាសុចរិតជាងសាសន៍លេមិន ដែលមិនត្រូវបានបង្រៀនពីសេចក្តីពិតសោះនោះ ។ អាលម៉ា និងអាម៉ូលេកបានបង្រៀនថា ប្រសិនបើប្រជាជនអាំម៉ូណៃហាមិនព្រមប្រែចិត្តទេ ពួកគេនឹងត្រូវប្រឈមមុខនឹងការបំផ្លាញ ។ ពួកគេក៏បានបង្រៀនប្រជាជនថា សេចក្តីប្រោសលោះអាចមានតែតាមរយៈព្រះយេស៊ូវគ្រីស្ទតែប៉ុណ្ណោះ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៩

អាលម៉ាបានព្រមានដល់ប្រជាជនអាំម៉ូណៃហាឲ្យប្រែចិត្ត ហើយរៀបចំសម្រាប់ការយាងមកនៃព្រះយេស៊ូវគ្រីស្ទ

សូមបង្ហាញរឿងខាងក្រោម ៖ សិស្សពីរនាក់មកដល់សាលា ហើយត្រូវបស់ពួកគេប្រកាសថា ពួកគេត្រូវធ្វើការប្រឡងដោយភ្ញាក់ផ្អើលមួយ ។ សិស្សទីមួយបានមករៀនរាល់ថ្ងៃ ប៉ុន្តែសិស្សទីពីរមិនបានមករៀនកាលពីពីរសប្តាហ៍មុនដោយសារគាត់ឈឺ ។

- **តើសិស្សមួយណាដែលអ្នកគិតថា នឹងប្រឡងបានល្អជាងនោះ ?**

សូមឲ្យសិស្សអានច្បាលៗ អាលម៉ា ៩:១–៧ ដោយរកមើលពាក្យ និងឃ្លាដែលបង្ហាញពីថាប្រជាជនអាំម៉ូណៃហាបានយល់ពីដំណឹងល្អ និង អំណាចនៃព្រះបានខ្លាំងប៉ុណ្ណា ។ សូមឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៩:៨–១៣ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពាក្យ និងឃ្លាដែលបង្ហាញថាតើប្រជាជនទាំងនេះត្រូវបានបង្រៀនពីដំនឹងល្អ ឬ បានដឹងពីអំណាចនៃព្រះ ។ (ចម្លើយអាចរួមមាន “ អ្នករាល់គ្នាភ្លេច ” និង “ តើអ្នករាល់គ្នាមិនចាំទេឬថា ”) ។

- **តើប្រជាជនអាំម៉ូណៃហាធ្លាប់បានរៀនដំណឹងល្អ ឬ ត្រូវបានបង្រៀនដំណឹងល្អអំពីអំណាចនៃព្រះទេ ?**
- **តើមូលហេតុអ្វីខ្លះដែលប្រជាជនដែលត្រូវបានបង្រៀនដំណឹងល្អអាចភ្លេចពីអ្វីដែលពួកគេបានរៀន ឬ មិនយល់ពីអ្វីដែលពួកគេត្រូវបានបង្រៀននោះ ?**

សូមឲ្យសិស្សអានច្បាលៗ អាលម៉ា ៨:៩, ១១; ៩:៥, ៣០; និង ១២:១០–១១ ដោយរកមើលពាក្យ និងឃ្លាដែលស្មើពីមូលហេតុដែលប្រជាជនអាំម៉ូណៃហាបានភ្លេច ឬ មិនបានយល់ពីអ្វីដែលពួកគេត្រូវបានបង្រៀន ។ (“ អារក្សសាតាំងបានក្តាប់ជាប់នូវដួងចិត្ត [របស់ពួកគេ] ” ; “ ពួកគេធ្វើឲ្យចិត្តគេរឹងរូស ” និង “ ពួកគេមានចិត្តរឹងរូស ហើយក្បាលរឹង ” “ ដួងចិត្ត [របស់ពួកគេ] រឹងរូសទាស់នឹងព្រះបន្ទូលនៃព្រះ ”) ។

សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ហើយសូមឲ្យសិស្សចម្លងវាចូលក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ (សូមប្រាកដថាអ្នកបានទុកកន្លែងទំនេរដើម្បីសរសេរវា) ។

	សាវតាខាងវិញ្ញាណនៃប្រជាជន	អ្វីដែលព្រះអម្ចាស់បានរំពឹងពីប្រជាជន ហើយនិងអ្វីដែលព្រះអម្ចាស់បានសន្យាដល់ប្រជាជន
សាសន៍លេមិន (អាលម៉ា ៩:១៤–១៧)		
ប្រជាជនអាំម៉ូណៃហា (អាលម៉ា ៩:១៨–២៤)		

សូមឲ្យសិស្សធ្វើការជាដៃគូ ។ សូមឲ្យដៃគូនីមួយៗបំពេញតារាងដោយប្រើការយោងព្រះគម្ពីរ ។ ក្រោយពីពួកគេបានបំពេញតារាងហើយ សូមឲ្យសិស្សសរសេរប្រយោគមួយនៅក្រោមតារាងរបស់ពួកគេដើម្បីសង្ខេបអ្វីដែលពួកគេបានរៀន ។ សូមឲ្យពួកគេពីរបីនាក់ចែកចាយអ្វីដែលពួកគេបានសរសេរ ។ សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែចម្លើយរបស់ពួកគេគួរតែឆ្លុះបញ្ចាំងពីសេចក្តីពិតខាងក្រោម ៖ ព្រះអម្ចាស់រំពឹងថាទទួលបានការគោរពដ៏ខ្លាំងពីអ្នកដែលបានទទួលចំណេះដឹង និង ពរជ័យនៃដំណឹងល្អ ។ដើម្បីជួយសិស្សឲ្យឃើញពីរបៀបដែលគោលការណ៍នេះអនុវត្តក្នុងជីវិតគេបាន សូមសួរសំណួរខាងក្រោម ៖

- តើអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់បានមានក្តីសង្ឃឹមខ្ពស់សម្រាប់ប្រជាជនអាំម៉ូណៃហា ?
- ហេតុអ្វីបានជាវាយុត្តិធម៌សម្រាប់ព្រះអម្ចាស់ក្នុងការមានក្តីសង្ឃឹមខ្ពស់សម្រាប់អ្នកដែលបានទទួលចំណេះដឹង និង ពរជ័យនៃដំណឹងល្អនោះ ?

សូមបង្ហាញឃ្លា " ប្រជាជនដ៏សំណប់ជាខ្លាំងនៃព្រះ " នៅក្នុង អាលម៉ា ៩:២០ ។ (អ្នកអាចស្នើថា សិស្សគួរគូសចំណាំឃ្លានេះ) ។

- តើសមាជិកនៃសាសនាចក្រសព្វថ្ងៃនេះជា " ប្រជាជនដ៏សំណប់ជាខ្លាំងនៃព្រះ " ដោយរបៀបណា ?
- យោងតាម អាលម៉ា ៩:១៩–២៣ តើអំណោយទាន និងពរជ័យអ្វីខ្លះដែលសាសន៍នីហ្វៃបានមាន (រួមមានប្រជាជនអាំម៉ូណៃហាដែរ) បទពិសោធន៍ ដោយសារពួកគេគឺជាប្រជាជនសេចក្តីសញ្ញារបស់ព្រះអម្ចាស់ ?
- តើអំណោយទាន និងពរជ័យអ្វីខ្លះដែលអ្នកបានទទួល ដោយសារអ្នកគឺជាសមាជិកនៃសាសនាចក្រនៃព្រះអម្ចាស់ ?
- តើអ្វីខ្លះដែលព្រះអម្ចាស់បានរំពឹងពីយើង ដោយសារតែអំណោយទាន និងពរជ័យដែលយើងបានទទួលពីទ្រង់នោះ ?

សូមឲ្យសិស្សពាក់កណ្តាលថ្នាក់សិក្សា អាលម៉ា ៩:២៤–២៧ រៀង។ខ្លួន ហើយអ្នកពាក់កណ្តាលថ្នាក់ទៀតសិក្សា អាលម៉ា ៩:២៨–៣០ រៀង។ខ្លួនដែរ ។ សូមឲ្យសិស្សរៀបចំសង្ខេបវគ្គដែលគេអានជាសម្តីរបស់គេផ្ទាល់ ។ សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ដើម្បីណែនាំពួកគេ នៅពេលពួកគេរៀបចំការសង្ខេបរបស់ពួកគេ ៖

តើភស្តុតាងអ្វីដែលអ្នកឃើញនៅក្នុងខគម្ពីរទាំងនេះថា ព្រះអម្ចាស់រំពឹងការគោរពខ្លាំងជាងពីអ្នកដែលមានចំណេះដឹងច្រើនជាងពីដំណឹងល្អ ?

តើពរជ័យអ្វីដែលអាលម៉ាបានរំពឹកដល់ប្រជាជនថាពួកគេអាចទទួលបាននោះ ?

តើអាលម៉ាបាននិយាយអ្វីដល់ប្រជាជន ថាពួកគេត្រូវធ្វើដើម្បីទទួលបានពរជ័យទាំងនេះ ?

ក្រោយពីសិស្សមានពេលអានគ្រប់គ្រាន់ហើយ សូមឲ្យសិស្សម្នាក់ពីក្រុមនីមួយ។ក្នុងថ្នាក់ សង្ខេប វគ្គដែលបានដាក់ឲ្យអាន ។ បន្ទាប់មក សូមសួរសិស្ស ៖

- តើយើងអាចស្មោះត្រង់នឹងពន្ធ និង ចំណេះដឹងដែលយើងបានទទួលតាមរបៀបណាខ្លះ ? (សិស្សអាចឆ្លើយថា ការសិក្សាព្រះគម្ពីរ ការបង្ហាញការដឹងគុណដល់ព្រះសម្រាប់ពរជ័យរបស់យើង ការថ្លែងទីបន្ទាល់របស់យើងជាទៀងទាត់ ការចូលរួមក្នុងការប្រជុំសាសនាចក្រប្រចាំសប្តាហ៍ ការសរសេរក្នុងកំណត់ហេតុ ជាដើម) ។

> ***សូមឲ្យសិស្សសង្ខេប***
>
> នៅពេលអ្នកសុំសិស្សឲ្យសង្ខេបក្រុមខគ្ពីរ អ្នកកំពុងឲ្យពួកគេវិភាគព្រះគម្ពីរដោយយកចិត្តទុកដាក់ជាងមុន ។ ប្រសិនបើអ្នកមានអារម្មណ៍ថា សិស្សម្នាក់បានលែងចំណុចសំខាន់នៅក្នុងការសង្ខេបរបស់គេ អ្នកអាចសុំឲ្យសិស្សផ្សេងទៀតមើល បើសិនបើជាគេមានចំណុចសំខាន់បន្ថែម ។

អាលម៉ា ១០:១–១២

អាម៉ូលេកគោរពតាមការហៅរបស់ព្រះអម្ចាស់ និង ទទួលយកការហៅដ៏ទេវភាពរបស់អាលម៉ា

សូមពន្យល់ថា ក្រោយពីអាលម៉ាបាននិយាយទៅកាន់ប្រជាជនហើយ ពួកគេបានខឹង និងចង់ដាក់គុកគាត់ ។ អាម៉ូលេកបាននិយាយទៅកាន់ប្រជាជនដោយក្លាហាន ហើយបានបន្ថែមទីបន្ទាល់របស់គាត់ទៅលើទីបន្ទាល់របស់អាលម៉ា ។ (សូមមើល អាលម៉ា ៩:៣១–៣៤ ។) សូមសង្ខេប អាលម៉ា ១០:១–៤ ដោយការពន្យល់ថា អាម៉ូលេកគឺជាកូនចៅនៃនីហ្វៃ ។ គាត់គឺជាបុរសដែលខិតខំធ្វើការខ្លាំង ដែលមានសុខភាពដ៏រឹងមាំ ។ គាត់ក៏ជាមនុស្សល្បីល្បាញដែរ ហើយក៏ " ពុំខ្វះមនុស្សរាប់អាន " នៅក្នុងចំណោមសាច់ញាតិ និង មិត្តជាច្រើនរបស់គាត់ (សូមមើលអាលម៉ា ១០:៤) ។ ទោះជាយ៉ាងណាក្តី គាត់មិនបានរស់នៅតាមសេចក្តីពិតនៃដំណឹងល្អដែលគាត់ត្រូវបានបង្រៀននោះទេ ។

- តើអ្នកគិតថា ហេតុអ្វីបានជាវាអាចជួយដល់អាម៉ូលេក ដែលជាមនុស្សល្បីល្បាញនៅក្នុងសហគមន៍ ក្នុងការជួយអមអាលម៉ា ?

សូមសួរសិស្សថាតើគេក្រោកពីគេងនាព្រឹកនេះដោយរបៀបណា ។ (ឧទាហរណ៍ តើពួកគេភ្ញាក់ដោយសារម៉ោងរោទ៍ ឬ ដោយសារសមាជិកគ្រួសារដាស់ពួកគេ ? ប្រសិនបើអ្នកមានម៉ោងរោទ៍ ឬ រូបភាពនៃម៉ោងរោទ៍មួយ សូមបង្ហាញវា ។) សូមសិស្សថា តើពួកគេត្រូវបាន " ហៅ " ប៉ុន្មានដងដើម្បីឲ្យក្រោកពីគ្រែ ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ១០:៥–៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលចម្លើយរបស់អាម៉ូលេកចំពោះ " ការហៅឲ្យភ្ញាក់ឡើង " ខាងវិញ្ញាណដែលគាត់បានទទួលពីព្រះអម្ចាស់ ។

- តើអ្នកគិតថា អាម៉ូលេកចង់មានន័យយ៉ាងណា នៅពេលគាត់និយាយថា " ខ្ញុំធ្វើជាមិនឮ " និង " ខ្ញុំធ្វើជាមិនដឹង " ?
- តើព្រះអម្ចាស់ហៅយើងតាមរបៀបណា ? (ចម្លើយអាចរួមមាន ការបំផុសពីព្រះវិញ្ញាណបរិសុទ្ធ ការណែនាំពីឪពុកម្តាយ និងអ្នកដឹកនាំសាសនាចក្រ និង ការហៅបម្រើក្នុងសាសនាចក្រ) ។

សូមឲ្យសិស្សអាន អាលម៉ា ១០:៧–១០ ដោយស្ងាត់ៗ ដោយរកមើលចំនុចសំខាន់នៃការបើកទីបន្ទាល់របស់អាម៉ូលេកទៅដល់ប្រជាជនរបស់គាត់ ។

- តើបទពិសោធន៍របស់អាម៉ូលេកបានរៀបចំគាត់ឲ្យក្លាយជាសាក្សីទីពីរម្នាក់នៃសរលេខិតរបស់អាលម៉ាទៅកាន់ប្រជាជនអាំម៉ូណៃហាដោយរបៀបណា ?
- តើអ្នកគិតថា ការសម្រេចចិត្តរបស់អាម៉ូលេកក្នុងការគោរពតាម ធ្វើឲ្យមានការខុសគ្នានៅក្នុងជីវិតរបស់ដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ១០:១១–១២ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបផ្សេងទៀតដែលត្រូវបានជៈឥទ្ធិពលដោយការសម្រេចចិត្តរបស់អាម៉ូលេកដើម្បីគោរពតាមការហៅរបស់ព្រះអម្ចាស់ ។ សូមឲ្យពួកគេចែកចាយអ្វីដែលពួកគេរកឃើញ ។

សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***នៅពេលយើងស្តាប់ និង គោរពតាមការហៅរបស់ព្រះអម្ចាស់ ពរជ័យនានានឹងមកកាន់យើង និង អ្នកដទៃ ។*** (អ្នកអាចស្នើថា សិស្សគួរសរសេរគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ១០:១១–១២) ។ ដើម្បីជួយសិស្សឲ្យមានអារម្មណ៍ពីសេចក្តីពិត និង សារសំខាន់នៃគោលការណ៍នេះ សូមសួរ ៖

- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា អ្នកត្រូវបានប្រទានពរដោយសារអ្នកបានគោរពតាមការហៅពីព្រះអម្ចាស់ ?
- តើអ្នកបានឃើញពរជ័យនានាមកកាន់អ្នកដទៃ ដោយសារអ្នក ឬនរណាម្នាក់ទៀតបានឆ្លើយតបនឹងការហៅរបស់ព្រះអម្ចាស់ដោយរបៀបណា ?
- តើបទពិសោធន៍ទាំងនេះជះឥទ្ធិពលដល់បំណងប្រាថ្នារបស់អ្នកឲ្យស្តាប់តាម និង គោរពតាមការហៅពីព្រះអម្ចាស់ដោយរបៀបណា ?

អាលម៉ា ១០:១៣–៣២

អាំម៉ូលេកឆ្លើយតបនឹងអ្នកដែលប្រឆាំងនឹងគាត់ ហើយបានជាស់តឿនប្រជាជនឲ្យប្រែចិត្ត

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖

១. ខឹងសម្បារ និង ប្រកែកការពារខ្លួន

២. សង្ស័យពីសារសំខាន់នៃការណែនាំ

៣. រិះគន់មនុស្សដែលផ្តល់ដំបូន្មាន

៤. ស្តី ឬ តវ៉ានឹងដំបូន្មាន

៥. ការស្តាប់ និងគោរពតាមដោយបន្ទាបខ្លួន

សូមឲ្យសិស្សគិតដោយស្ងាត់ស្ងៀមថាតើឃ្លាមួយណានៅលើក្តារខៀនដែលដូចគ្នាខ្លាំងនឹងរបៀបដែលពួកគេអាចឆ្លើយតប ប្រសិនបើឪពុក ឬម្តាយ ឬអ្នកដឹកនាំសាសនាចក្របានកែតម្រូវពួកគេ ឬ សុំឲ្យពួកគេផ្លាស់ប្តូរអ្វីមួយដែលពួកគេកំពុងធ្វើ ។

- តើមូលហេតុអ្វីខ្លះដែលមនុស្សអាចឆ្លើយតបនឹងការកែតម្រូវតាមរបៀបទាំងនេះ ?

សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖ *អាលម៉ា ៩:២–៣; អាលម៉ា៩:៤–៥; អាលម៉ា១០:១៣, ១៦–១៧; អាលម៉ា១០:២៤, ២៨–៣០*

សូមឲ្យសិស្សជ្រើសរើសវគ្គមួយនៅលើក្តារខៀនដើម្បីសិក្សារៀងខ្លួន ។ សូមឲ្យពួកគេរកមើលរបៀបដែលវគ្គព្រះគម្ពីរពិពណ៌នាពីប្រជាជនអាំម៉ូណែហាឆ្លើយតបនឹងសារលិខិតរបស់អាលម៉ា និងអាំម៉ូលេក ។ សូមឲ្យពួកគេជ្រើសរើសឃ្លានៅលើក្តារខៀនដែលបង្ហាញយ៉ាងច្បាស់បំផុតពីចម្លើយរបស់ប្រជាជន ។ ក្រោយពីមានពេលល្មមហើយ សូមឲ្យសិស្សពន្យល់ពីចម្លើយមួយណាក្នុងចំណោមចម្លើយទាំងប្រាំនៅលើក្តារខៀនដែលត្រូវគ្នាបំផុតនឹងវគ្គដែលពួកគេបានសិក្សា ។

- ហេតុអ្វីបានជាចម្លើយឫទ្ធដំបូងនៅលើក្តារខៀនមានគ្រោះថ្នាក់ខាងវិញ្ញាណ ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ១០:១៩–២៣ ។ សូមលើកទឹកចិត្តពួកគេឲ្យរកមើលអ្វីដែលអាម៉ូលេកបានបង្រៀនអំពីលទ្ធផលនៃអំពើបាប និងនៃការបណ្តេញពួកសុចរិតចេញ ។

ដើម្បីជួយសិស្សឲ្យគិតពីលទ្ធផលដ៏មិនល្អនៃការមិនប្រែចិត្តពីអំពើបាបរបស់យើង សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធានហ្គរដុន ប៊ី ហ៊ិងគ្លី ៖

" មានអំពើអាក្រក់ច្រើនណាស់នៅគ្រប់ទីកន្លែង ។ ការឈ្លង ដោយមានឥទ្ធិពលបន្តិចម្តងៗរបស់វា គឺមាននៅក្បែរយើងគ្រប់ទីកន្លែង ។ ដោយអកុសល យើងបាត់បង់មនុស្សខ្លះដោយហេតុមកពីកម្លាំងបំផ្លាញទាំងនេះ ។ យើងកើតទុក្ខចំពោះអ្នកដែលបានត្រូវបានបាត់បង់ ។ យើងចេញទៅជួយដល់ពួកគេ សង្គ្រោះពួកគេ ប៉ុន្តែក្នុងករណីជាច្រើនការអង្វរជួយរបស់យើងត្រូវបានច្រានចេញ ។ ការសោកស្តាយនោះគឺជាផ្លូវដែលពួកគេនឹងដើរ ។ វាជារបៀបដែលដឹកនាំទៅរកការបំផ្លាញ " (" My Testimony," *Ensign*, ខែ ឧសភា ឆ្នាំ ២០០០, ទំព័រ ៦៩) ។

- តើលទ្ធផលនៃការបំផ្លិចបំផ្លាញអ្វីខ្លះដែលមកដល់បុគ្គល ឬ ក្រុមមនុស្ស នៅពេលពួកគេមិនគោរពតាមព្រះបញ្ញត្តិនៃព្រះមានអ្វីខ្លះ ?

បើសិនមានពេល សូមឲ្យសិស្សសរសេរចម្លើយចំពោះសំណួរខាងក្រោម ៖

- តើសេចក្តីពិតដែលអ្នកបានរៀនពីមេរៀនថ្ងៃនេះអាចប្រទានពរដល់អ្នកដោយរបៀបណា ?

មេរៀនសិក្សានៅផ្ទះ

អាលម៉ា ៥–១០ (មេរៀនទី ១៥)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនការសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេសិក្សា អាលម៉ា ៥–១០(មេរៀនទី ១៥) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀន ផ្តោតតែលើគោលលទ្ធិ និងគោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការនៃសិស្សរបស់អ្នក ។

ថ្ងៃទី ១ (អាលម៉ា ៥:១–៣៦)

នៅពេលសិស្សសិក្សាពីការបង្រៀនរបស់អាលម៉ាដល់ប្រជាជនសាវ៉ាហិមឡា ពួកគេបានរកឃើញថា នៅពេលយើងជឿលើព្រះបន្ទូលនៃព្រះ និងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ យើងអាចទទួលបាននូវការផ្លាស់ប្តូរដ៏ធំនៅក្នុងដួងចិត្ត ។ នៅពេលសិស្សឆ្លើយនឹងសំណួររបស់អាលម៉ា ពួកគេក៏បានរៀនដែរថា ដោយការទទួលបាននូវការផ្លាស់ប្តូរនៅក្នុងដួងចិត្ត យើងរៀបចំខ្លួនយើងដើម្បីទទួលកន្លែងមួយនៅក្នុងនគរស្ថានសួគ៌ ។

ថ្ងៃទី ២ (អាលម៉ា ៥:៣៧–៦២)

នៅពេលសិស្សសិក្សាពីផ្នែកទីពីរនៃ អាលម៉ា ៥ ពួកគេបានរៀនពីគោលការណ៍ទាំងនេះ ៖ ប្រសិនបើយើងធ្វើតាមសំឡេងនៃព្រះអម្ចាស់ (អ្នកគង្វាលល្អ) យើងនឹងត្រូវបានរួបរួមនៅក្នុងនគររបស់ទ្រង់ ។ យើងអាចដឹងពីខ្លួនយើង តាមរយៈព្រះវិញ្ញាណបរិសុទ្ធថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះប្រោសលោះនៃមនុស្សជាតិ ។

ថ្ងៃទី ៣ (អាលម៉ា ៦–៧)

ដោយការសិក្សា អាលម៉ា ៦ សិស្សបានរៀនថានៅក្នុងជំនាន់របស់នីហ្វៃ និង ក្នុងជំនាន់របស់យើង សាសនាចក្រត្រូវបានស្តាបនាឡើងសម្រាប់សុខុមាលភាពនៃមនុស្សទាំងអស់ ។ ចេញពីការបង្រៀនរបស់អាលម៉ាដល់ប្រជាជនក្នុងដែនដីគេឧាន សិស្សបានរៀនថា ព្រះយេស៊ូវគ្រីស្ទបានរងទុក្ខដើម្បីសង្គ្រោះយើងចេញពីអំពើបាប និងសេចក្តីស្លាប់ និង ដើម្បីជួយយើងតាមរយៈឧបសគ្គទាំងឡាយនៃជីវិតខាងសាច់ឈាម ។ ពួកគេក៏បានរៀនដែរថា ដោយការរស់នៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ យើងធ្វើតាមផ្លូវទៅកេនគរនៃព្រះ ។

ថ្ងៃទី ៤ (អាលម៉ា ៨–១០)

ដោយការសិក្សាអំពីឆន្ទៈរបស់អាលម៉ាក្នុងការត្រឡប់ទៅកាន់ប្រជាជនអាំម៉ូណៃហាក្រោយពីពួកគេត្រូវបានបដិសេធលោកហើយ សិស្សបានរៀនថា នៅពេលយើងឆ្លើយតបយ៉ាងរហ័សទៅនឹងព្រះបន្ទូលរបស់ព្រះអម្ចាស់ ទ្រង់នឹងជួយយើងឲ្យគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ។ អាលម៉ាបានហៅប្រជាជនឲ្យប្រែចិត្ត និងបង្រៀនពួកគេអំពីតម្រូវការដើម្បីរៀបចំសម្រាប់ការយោងមករបស់ព្រះអង្គសង្គ្រោះ ។ ចេញពីបទពិសោធន៍របស់អាម៉ូលេកជាមួយនឹងទេវតា សិស្សបានរៀនថា នៅពេលយើងស្តាប់ និងគោរពតាមការហៅរបស់ព្រះអម្ចាស់ ពរជ័យនឹងមកដល់យើង និងអ្នកដទៃ ។

សេចក្តីផ្តើម

នៅក្នុងមេរៀននេះ សូមជួយសិស្សឲ្យផ្តោតលើគោលការណ៍ដែលអាចនាំទៅរកការផ្លាស់ប្តូរដួងចិត្ត ។ សូមរកមើលរបៀបដើម្បីជួយពួកគេឲ្យពឹងផ្អែកលើព្រះបន្ទូលនៃព្រះ ហើយបង្កើនទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៥:១–៣៦

អាលម៉ាបង្រៀនថា ការផ្លាស់ប្តូរនៅក្នុងដួងចិត្តដ៏ខ្លាំងមួយតម្រូវឲ្យចូលទៅក្នុងនគរស្ថានសួគ៌

សូមសរសេរពាក្យ *ការផ្លាស់ប្តូរ* នៅលើក្តារខៀន ឬ នៅលើក្រដាសមួយ ។ សូមឲ្យសិស្សចែកចាយគំរូនៃរបៀបដែលប្រជាជនអាចផ្លាស់ប្តូរ ដូចជានៅក្នុងរាងកាយ អាកប្បកិរិយា ឬ គំរិយាបថរបស់ពួកគេ ។ សូមឲ្យពួកគេពន្យល់ពីអ្វីដែលអាចបណ្តាលឲ្យប្រជាជនមានការផ្លាស់ប្តូរទាំងនេះ ។

សូមឲ្យសិស្សអាន អាលម៉ា ៥:១៤ ហើយរកសំណួរបីដែលអាលម៉ាបានសួរប្រជាជនសាវ៉ាហិមឡាដើម្បីឲ្យគិតពិចារណា ។ សូមគិតពីការអញ្ជើញសិស្សពីរបីនាក់ឲ្យពិពណ៌នាពីអត្ថន័យនៃ “ ការផ្លាស់ប្តូរដ៏ធំនៅក្នុងដួងចិត្ត ” ។

សូមឲ្យសិស្សអាន អាលម៉ា ៥:៣–៧ ហើយរកមើលអ្វីដែលអាលម៉ាបានប្រាប់ដល់ប្រជាជនសាវ៉ាហិមឡាដែលបានជួយរៀបចំដួងចិត្តគេឲ្យផ្លាស់ប្តូរ ។

អាលម៉ាបានប្រាប់ប្រជាជនសាវ៉ាហិមឡាអំពីការប្រែចិត្តជឿរបស់ឪពុកគាត់ និងអ្នកដទៃ ក៏ដូចជាការរំដោះពួកគេចេញពីសេវកភាព ។ សូមសួរ ៖ តើអ្នកគិតថា ការរៀនអំពីបទពិសោធន៍ទាំងនេះបានជួយប្រជាជនឲ្យរៀបចំដើម្បីទទួលបានការផ្លាស់ប្តូរនៃដួងចិត្តមួយដោយរបៀបណា ? (អ្នកអាចរំឭកសិស្សថា ពួកគេបានសរសេរចម្លើយមួយចំពោះសំណួរនេះនៅក្នុងមេរៀនសម្រាប់ថ្ងៃទីមួយ នៅក្នុងសៀវភៅណែនាំការសិក្សាសិស្សរបស់ពួកគេ) ។

សូមសួរថា បើមានសិស្សម្នាក់ចង់ចែកចាយបទពិសោធន៍មួយដែលដឹកនាំទៅរកការផ្លាស់ប្តូរនៅក្នុងដួងចិត្តរបស់គេ ។ អ្នកអាចចង់ចែកចាយបទពិសោធន៍មួយផ្ទាល់ខ្លួន ។ អ្នកក៏អាចរំឭកសិស្សអំពីសេចក្តីថ្លែងការណ៍ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន (នៅក្នុងមេរៀនសម្រាប់ថ្ងៃទីមួយនៅក្នុងសៀវភៅណែនាំការសិក្សាសិស្ស) ។ សូមពន្យល់ថា សម្រាប់មនុស្សភាគច្រើន ការផ្លាស់ប្តូរដ៏ខ្លាំងនៅក្នុងដួងចិត្តរបស់យើងកើតឡើងបន្តិចម្តងៗ នៅពេលយើងរៀន និងធំធាត់នៅក្នុងដំណឹងល្អ ។

សូមឲ្យសិស្សមើលទៅក្នុងតារាង “ អាលម៉ា ៥ឧបករណ៍កំណត់ចង្អាក់បេះដូងខាងវិញ្ញាណ ” នៅក្នុងមេរៀនសម្រាប់ថ្ងៃទីមួយនៅក្នុងសៀវភៅណែនាំការសិក្សាសិស្ស ។ សូមឲ្យពួកគេរំឭកព្រះគម្ពីរខ្លះនៅក្នុង អាលម៉ា ៥ ដែលនៅក្នុងតារាងនោះ ។ បន្ទាប់មក សួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- តើសំណួររបស់អាលម៉ាមួយណាដែលមានន័យពិសេសដល់អ្នក ?
- តើសំណួរទាំងនេះអាចជួយបុគ្គលម្នាក់ឲ្យទទួលបានការផ្លាស់ប្តូរនៅក្នុងដួងចិត្តមួយដោយរបៀបណា ?

សូមពន្យល់ដល់សិស្សថា ព្រះអង្គសង្គ្រោះចង់ឲ្យមនុស្សទាំងអស់ចូលមករកទ្រង់ជាខ្លាំង ហើយទទួលបានការផ្លាស់ប្តូរនៅក្នុងដួងចិត្តមួយដ៏ខ្លាំងដើម្បីឲ្យពួកគេអាចទទួលបានជីវិតជំនៅអស់កល្បជានិច្ច ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៥:៣៣–៣៦ ឮៗ ។ សូមសួរ ៖

- តើព្រះអម្ចាស់បានអញ្ជើញយើងឲ្យធ្វើអ្វី ?
- តើង្វាន់អ្វីសម្រាប់ការទទួលយកការអញ្ជើញរបស់ទ្រង់នោះ ?

អាលម៉ា ៥:៤៣–៥២

អាលម៉ាប្រាប់ពីរបៀបដែលគាត់បានទទួលទីបន្ទាល់ និងបង្រៀនអំពីការប្រែចិត្ត

សូមពន្យល់ថា ដើម្បីលើកទឹកចិត្តដល់ប្រជាជនសារ៉ាហិមឡាឲ្យស្វែងរកការផ្លាស់ប្តូរនៅក្នុងដួងចិត្ត អាលម៉ាបានថ្លែងទីបន្ទាល់របស់លោក និង បានពន្យល់ពីរបៀបដែលលោកបានទទួលវា ។ ចេញពីការប្រឹក្សារបស់គាត់ យើងអាចដឹងពីរបៀបដើម្បីទទួល ឬ ពង្រឹងដល់ទីបន្ទាល់របស់យើង ។ សូមឲ្យសិស្សអាន អាលម៉ា ៥:៤៥–៤៨ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើលអ្វីដែលអាលម៉ាបាននិយាយថា គាត់បានដឹង ។ សូមសួរពួកគេផងដែរឲ្យរកមើលចម្លើយរបស់អាលម៉ាទៅនឹងសំណួរ " ហើយតើអ្នករាល់គ្នាគិតស្មានថា ខ្ញុំដឹងរឿងទាំងនោះយ៉ាងប្រាកដដូចម្តេចដែរ " ?

សូមឲ្យសិស្សចែកចាយអ្វីដែលពួកគេបានរៀន ហើយសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ សូមសរសេរគោលការណ៍នេះផងដែរ ៖ ***យើងអាចដឹងពីខ្លួនយើងតាមរយៈព្រះវិញ្ញាណបរិសុទ្ធថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះដ្រោសលោះនៃមនុស្សជាតិ ។***

សូមជួយសិស្សឲ្យយល់ថា ថ្ងៃមួយទីបន្ទាល់របស់ពួកគេនឹងត្រូវជួបនឹងឧបសគ្គដោយនរណាម្នាក់ឬអ្វីមួយ ។ ការណ៍នេះអាចកើតមានរួចហើយ ។ ការប្រឹក្សារបស់អាលម៉ាផ្តល់របៀបមួយដល់យើងដើម្បីឲ្យឈរយ៉ាងរឹងមាំ និង ខ្លាំងក្លាថ្វីបើមានឧបសគ្គចំពោះទីបន្ទាល់របស់យើងក្តី ។ សូមគិតពីការប្រាប់ពីពេលមួយ ដែលអ្នកបានជួបនឹងឧបសគ្គចំពោះទីបន្ទាល់របស់អ្នក ហើយបានយកឈ្នះវា ឬ ពេលមួយដែលនរណាម្នាក់ដែលអ្នកស្គាល់បានជួបនឹងឧបសគ្គបែបនោះ ។ អ្នកក៏អាចចែកចាយបទពិសោធន៍មួយពីសុន្ទរកថាក្នុងសន្និសីទទូទៅមួយ ឬ អត្ថបទទស្សនាវដ្តីសាសនាចក្រមួយ ។ អ្នកក៏អាចឲ្យសិស្សចែកចាយបទពិសោធន៍មួយបែបនោះដែរ ។

សូមពន្យល់ថា អាលម៉ាបានចេញទៅបង្រៀនប្រជាជនអំពីការប្រែចិត្ត ។ អ្នកអាចឲ្យសិស្សម្នាក់អាន អាលម៉ា ៥:៥០ ហើយនិងសេចក្តីថ្លែងការណ៍ដោយអែលឌើរ ដាលិន អេក អូកស៍ ដែលមាននៅក្នុងមេរៀនទី ១៥ ថ្ងៃទីពីរនៃសៀវភៅណែនាំការសិក្សារបស់សិស្ស ។ សូមឲ្យសិស្សចែកចាយគំនិតរបស់ពួកគេអំពីមូលហេតុដែលពួកគេគួរស់នៅរាល់ថ្ងៃ ដូចដែលយើងកំពុងរៀបចំទៅជួបនឹងព្រះអម្ចាស់ ។

អាលម៉ា ៧–១០

អាលម៉ាបង្រៀននៅក្នុងដែនដីគេឌាន និង ដែនដីអាំម៉ូណៃហា

សូមបង្ហាញស្ថានភាពដូចខាងក្រោម ហើយសូមឲ្យសិស្សគិតក្នុងចិត្ត នៅពេលពួកគេរំឭកការបង្រៀនរបស់អាលម៉ាដល់ប្រជាជនគេឌាន ៖

១. យុវនារីម្នាក់យល់ថា ជង្វាយធួនអាចជួយឲ្យយកឈ្នះលើអំពើបាប ប៉ុន្តែនាងបានដឹងថានាងមានជំងឺធ្ងន់ធ្ងរមួយ ហើយគិតថា ជង្វាយធួនមិនអាចជួយនាងបានទេ ។

២. យុវជនម្នាក់តស៊ូ ដោយសារឪពុកម្តាយរបស់គាត់បានលែងលះគ្នា ប៉ុន្តែគាត់មិនបានស្វែងរកជំនួយពីព្រះអង្គសង្គ្រោះឡើយ ។

៣. យុវនារីម្នាក់ខិតខំគ្រប់គ្រងកំហឹងរបស់នាង ។ នាងមិនបានគិតពីរបៀបដែលជង្វាយធួនអាចជួយដល់នាងនោះទេ ។

សូមឲ្យសិស្សអាន អាលម៉ា ៧:១១–១៣ ហើយរំឭកពីស្ថានភាពដែលព្រះអង្គសង្គ្រោះនឹង " លើកដាក់មកលើ " អង្គទ្រង់សម្រាប់ជាប្រយោជន៍ដល់យើង ។ សូមឲ្យសិស្សពីរបីនាក់សង្ខេបពីអ្វីដែលខគម្ពីរទាំងនេះបង្រៀនអំពីជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ សូមលើកទឹកចិត្តសិស្សផងដែរឲ្យមើលទៅតារាងដែលបង្ហាញពីស្ថានភាពខ្លះដែលយើងឯទុក្ខខាងសាច់ឈាម (នៅក្នុងមេរៀនសម្រាប់ថ្ងៃទីបីនៅក្នុងសៀវភៅណែនាំការសិក្សារបស់សិស្ស) ។

សូមពន្យល់ដល់សិស្សថា តាមរយៈអំណាចនៃជង្វាយធួន ការឈឺចាប់ និងភាពល្វីងនៃការឈឺចាប់ក្នុងជីវិតអាចត្រូវបានយកចេញពីយើង ។ សូមប្រាកដថាសិស្សយល់ពីគោលការណ៍នេះ ៖ **ព្រះយេស៊ូវគ្រីស្ទបានឯទុក្ខដើម្បីសង្គ្រោះយើងចេញពីអំពើបាប និងសេចក្តីស្លាប់ និងដើម្បីជួយយើងឲ្យឆ្លងកាត់ឧបសគ្គទាំងឡាយនៃជីវិតរមែងស្លាប់នេះ ។**

សូមឲ្យសិស្សចែកចាយអ្វីដែលពួកគេនឹងនិយាយទៅកាន់យុវជន និងយុវនារីនៅក្នុងស្ថានភាពទាំងបីដែលអ្នកបានលើកឡើងនេះ។ សូមសួរ ៖ តើការបង្រៀនរបស់អាលម៉ាអំពីជង្វាយធួនអាចអនុវត្តដល់ស្ថានភាពទាំងនេះដោយរបៀបណា ?

សូមរំឭកសិស្សពីរូបភាពទាំងបី និងសេចក្តីយោងព្រះគម្ពីរអំពីអាលម៉ានៅក្នុងដែនដីអាំម៉ូណៃហា (នៅក្នុងមេរៀនសម្រាប់ថ្ងៃទីបួន នៅក្នុងសៀវភៅណែនាំការសិក្សារបស់សិស្ស) ដែលពួកគេបានសិក្សា និងសរសេរចំណងជើងឲ្យនោះ ។ អ្នកអាចសុំឲ្យសិស្សពីរបីនាក់ចែកចាយចំណងជើងដែលពួកគេបានសរសេរអំពីបទពិសោធន៍របស់អាលម៉ាជាមួយនឹងទេវតា ។ សូមឲ្យសិស្សចែកចាយពីអារម្មណ៍របស់ពួកគេអំពីរបៀបដែលបទពិសោធន៍នេះទាក់ទងនឹងគោលការណ៍ខាងក្រោម ៖ **នៅពេលយើងឆ្លើយតបយ៉ាងរហ័សទៅនឹងព្រះបន្ទូលនៃព្រះអម្ចាស់ ទ្រង់នឹងជួយយើងឲ្យគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ។**

មេរៀនបន្ទាប់ (អាលម៉ា ១១–១៦)

សូមឲ្យសិស្សគិតអំពីសំណួរខាងក្រោម នៅពេលពួកគេរៀបចំសិក្សាកិច្ចការសម្រាប់សប្តាហ៍ក្រោយ ៖ តើអ្នកមានអារម្មណ៍យ៉ាងណា ប្រសិនបើអ្នកត្រូវបានបង្ខំឲ្យមើលមនុស្សសុចរិតត្រូវគេសម្លាប់ ដោយសារតែសេចក្តីជំនឿរបស់ពួកគេទៅលើព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់នោះ ? តើអ្នកគិតថា អាលម៉ានិងអាម៉ូលេកមានអារម្មណ៍យ៉ាងណាពេលឃើញការណ៍នេះកើតឡើង ? តើពួកគេបាននិយាយអ្វីដល់គ្នាទៅវិញទៅមក នៅពេលពួកគេបានឃើញការណ៍នេះកើតឡើង ? តើពួកគេបានធ្វើអ្វី ?

អាលម៉ា ១១

សេចក្តីផ្តើម

នៅពេលអាលម៉ា និងអាម៉ូលេកបានបន្តបង្រៀនដល់ប្រជាជនអាំម៉ូណៃហា ចៅក្រមផ្នែកច្បាប់ម្នាក់ឈ្មោះសឺអែសរ៉ុម បានផ្តល់ប្រាក់ដល់អាម៉ូលេកឲ្យបដិសេធនឹងវត្តមាននៃព្រះ ។ សឺអែសរ៉ុមក៏បានព្យាយាមក្រឡាស់ពាក្យរបស់អាម៉ូលេក និង បានបង្ខូចការបង្រៀនរបស់គាត់អំពីព្រះយេស៊ូវគ្រីស្ទ ។ នៅពេលអាម៉ូលេកបានការពារខ្លួនគាត់ទាស់នឹងការប៉ុនប៉ងរបស់សឺអែសរ៉ុមដែលចង់សម្លាប់គាត់ គាត់បានថ្លែងទីបន្ទាល់ថា សេចក្តីសង្គ្រោះចេញពីអំពើបាបមកតែតាមរយៈព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ។ អាម៉ូលេកក៏បានថ្លែងទីបន្ទាល់ថា មនុស្សទាំងអស់នឹងត្រូវរស់ឡើងវិញ ហើយនឹងបាននាំមក " ហៅឲ្យឆ្លើយខាងមុខវេទិកានៃព្រះគ្រីស្ទជាព្រះរាជបុត្រា និង ព្រះវរបិតាដ៏ជាព្រះ និងព្រះវិញ្ញាណបរិសុទ្ធ " នៅថ្ងៃជំនុំជម្រះ (" អាលម៉ា ១១:៤៤) ។

យោបល់សម្រាប់ការបង្រៀន

សូមអញ្ជើញព្រះវិញ្ញាណបរិសុទ្ធ

សូមលើកទឹកចិត្តសិស្សឲ្យអញ្ជើញឲ្យមានឥទ្ធិពលពីព្រះវិញ្ញាណបរិសុទ្ធខណៈពេលពួកគេសិក្សាព្រះគម្ពីរ រួមគ្នា ។ សកម្មភាពខ្លះដែលអញ្ជើញព្រះវិញ្ញាណមាន ការអធិស្ឋានដោយស្មោះ ការបង្រៀនពីព្រះគម្ពីរ ការថ្លែងទីបន្ទាល់ ការបង្ហាញសេចក្តីស្រឡាញ់ដល់ព្រះនិងអ្នកដទៃ និង ការចែកចាយបទពិសោធន៍ខាងវិញ្ញាណ ។ ក្នុងវិការនេះ អ្នកអាចមានអារម្មណ៍បំផុសឲ្យជួយសិស្សឲ្យស្គាល់ពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធអំឡុងពេលមេរៀននេះ ។

អាលម៉ា ១១:១–២៥

អាម៉ូលេកបដិសេធការល្បួងរបស់សឺអែសរ៉ុមក្នុងការបដិសេធមិនទទួលស្គាល់វត្តមាននៃព្រះ

សូមឲ្យសិស្សគិតអំពីអ្វីមួយ ដែលពួកគេមានដែលមានតម្លៃខ្លាំងដល់ពួកគេ ដែលពួកគេនឹងមិនលក់វាឡើយ ។ សូមឲ្យសិស្សពីរបីនាក់ប្រាប់ពីអ្វីដែលពួកគេបានគិតដល់ ហើយនិងមូលហេតុដែលរបស់ទាំងនោះមានតម្លៃខ្លាំងដល់ពួកគេ ។

សូមពន្យល់ថា អាលម៉ា ១១ បន្តដំណើររឿងនៃអាលម៉ា និងអាម៉ូលេកដែលបង្រៀនប្រជាជនអាំម៉ូណៃហា ។ នៅពេលអាម៉ូលេកបានបង្រៀន គាត់ត្រូវបានដេញដោលដោយចៅក្រមផ្នែកច្បាប់ឈ្មោះថា សឺអែសរ៉ុម ដែលបានផ្តល់ប្រាក់ជាថ្នូរនឹងអ្វីមួយដែលមានតម្លៃបំផុតដល់អាម៉ូលេក ។

សូមឲ្យសិស្សសិក្សា អាលម៉ា ១១:២១–២២ ដើម្បីរកមើលតម្លៃប្រាក់ដែលសឺអែសរ៉ុមបានផ្តល់ដល់អាម៉ូលេក និងពីមូលហេតុផង ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរៀន ។

សូមបង្ហាញថា ការពន្យល់របស់មរមនអំពីប្រព័ន្ធរូបិយវត្ថុសាសន៍នីហ្វៃនៅក្នុង អាលម៉ា ១១:៤–១៩ ជួយយើងឲ្យយល់ពីទំហំនៃការស្វែកប៉ាន់របស់សឺអែសរ៉ុម ។ សូមជួយសិស្សឲ្យយល់ថា *អុនវៃ* ជាចំណែកនៃប្រាក់ដែលមានតម្លៃបំផុត (សូមមើល អាលម៉ា ១១:៦, ១១–១៣) ។ មួយអុនតែស្មើនឹងប្រាក់ខែប្រហែលមួយសប្តាហ៍សម្រាប់ចៅក្រមម្នាក់ (សូមមើល អាលម៉ា ១១:៣, ១១–១៣) ដែលមានន័យថា ប្រាំមួយអុនតែស្មើនឹងប្រាក់ខែប្រហែលប្រាំមួយសប្តាហ៍សម្រាប់ចៅក្រម ។

- **ហេតុអ្វីបានជាការផ្តល់របស់សឺអែសរ៉ុមទាក់ទាញដល់មនុស្សខ្លះ ?**

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ១១:២៣–២៥ ឮៗ ។

- **តើចម្លើយរបស់អាម៉ូលេកបង្ហាញអ្វីខ្លះអំពីគាត់ ?**
- **យោងតាម អាលម៉ា ១១:២៥ តើសឺអែសរ៉ុមបានគ្រោងធ្វើអ្វី ប្រសិនបើអាម៉ូលេកទទួលយកការផ្តល់ឲ្យរបស់គាត់នោះ ? តើភាពស្រដៀងគ្នាទៅនឹងអ្វីដែលសាតាំងធ្វើ នៅពេលមនុស្សចាញ់ក្នុងការល្បួងរបស់គាត់មានដូចម្តេចខ្លះ ?**

ដើម្បីជួយសិស្សឲ្យរកមើលពីរបៀបដែលអាម៉ូលេកអាចប្រឆាំងនឹងសំណើររបស់សឺអែសរ៉ុម សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ខ្ញុំនឹងពុំ . . . អ្វីដែលផ្ទុយនឹងព្រះវិញ្ញាណនៃព្រះអម្ចាស់ឡើយ ។*

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ១១:២២ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពាក្យដែលអាម៉ូលេកបានប្រើដើម្បីបំពេញប្រយោគនេះ ។

- **តើមានពាក្យផ្សេងទៀតអ្វីខ្លះដែលយើងអាចដាក់ក្នុងចន្លោះនោះដែលអាចជួយយើងឲ្យពឹងផ្អែកលើព្រះវិញ្ញាណបរិសុទ្ធដើម្បីប្រឆាំងនឹងការល្បួង ? (" ធ្វើ" " គិត" ឬ " មើល") ។**

សូមឲ្យសិស្សនិយាយពីគោលការណ៍មួយដោយផ្អែកលើ អាលម៉ា ១១:២២ ដែលអាចជួយពួកគេឲ្យចងចាំពីរបៀបដែលពួកគេអាចយកឈ្នះលើការល្បួង ។ ខណៈពេលដែលចម្លើយរបស់សិស្សអាចខុសគ្នា ពួកគេគួរបង្ហាញពីគោលការណ៍ដូចខាងក្រោម ៖ <u>នៅពេលយើងពឹងផ្អែកទៅលើព្រះវិញ្ញាណបរិសុទ្ធ យើងអាចយកឈ្នះលើការល្បួង ។**</u>(អ្នកអាចស្នើថា សិស្សគួរសរសេរគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ១១:២២) ។**

- **តើអ្នកគិតថា ការឆាប់ធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធអាចជួយយើងឲ្យយកឈ្នះលើការល្បួងដោយរបៀបណា ?**

សូមអានការប្រឹក្សាខាងក្រោមពីប្រធាន ប៊ិយដ៏ ឃេ ជាកគី នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ៖

" ប្រសិនបើអ្នកធ្លាក់ក្នុងរឿងដែលអ្នកមិនគួរទៅ ឬ ប្រសិនបើអ្នកទាក់ទងនឹងមនុស្សដែលទាញអ្នកចេញទៅក្នុងទិសដៅខុស នោះជាពេលដែលអ្នកមានឯករាជ្យភាព ពេលប្រើឯកសិទ្ធិរបស់អ្នក ។ សូមស្តាប់តាមសំឡេងនៃព្រះវិញ្ញាណ ហើយអ្នកនឹងមិនដែលត្រូវរង្វេងឡើយ ។

" . . . ក្នុងនាមជាអ្នកបម្រើរបស់ព្រះអម្ចាស់ម្នាក់ ខ្ញុំសន្យាថា អ្នកនឹងត្រូវបានការពារ និង ចាំងពីការវាយប្រហារនៃឧបសគ្គនានា *ប្រសិនបើ* អ្នកគោរពតាមការបំផុសគំនិតដែលមកពីព្រះវិញ្ញាណបរិសុទ្ធ " (" Counsel to Youth," *Ensign* ឬ *លេខអាហ្វណា*, ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ១៨) ។

សូមលើកទឹកចិត្តអ្នករៀនឲ្យអនុវត្ត

ប្រសិនបើចំណេះដឹងអំពីគោលការណ៍ដ៏ណែនាំល្អមួយត្រូវបានរៀន តែមិនបានអនុវត្តនោះទេ ការរៀននោះមិនបានពេញលេញនោះទេ ។ ការអនុវត្តកើតឡើងនៅពេលបុគ្គលម្នាក់ទទួលយកសេចក្តីពិតដាក់នៅក្នុងចិត្ត និង គំនិតរបស់គេ ហើយបន្ទាប់មកធ្វើតាមសេចក្តីពិតនោះ ។ សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមការបំផុសនៃព្រះវិញ្ញាណដែលពួកគេទទួល ដើម្បីអនុវត្តសេចក្តីពិតនៃដំណឹងល្អដែលពួកគេរៀន ។

ដើម្បីជួយសិស្សឲ្យយល់ និងមានអារម្មណ៍ពីសារៈសំខាន់នៃការបំផុសគំនិតខាងក្រោមនៃព្រះវិញ្ញាណបរិសុទ្ធ សូមសួរសំណួរខាងក្រោម ៖

- តើស្ថានភាពណាខ្លះដែលយុវជនអាចត្រូវបានល្បួងឲ្យធ្វើដូចទៅនឹងទីបន្ទាល់របស់ពួកគេ ?
- តើអ្នកធ្វើអ្វីខ្លះដើម្បីពឹងផ្អែកលើព្រះវិញ្ញាណបរិសុទ្ធ ? តើការណ៍នោះជួយអ្នកដោយរបៀបណា ?
- តើនៅពេលណាដែលព្រះវិញ្ញាណបរិសុទ្ធបានជួយអ្នកឲ្យយកឈ្នះលើការល្បួង ?

សូមលើកទឹកចិត្តសិស្សឲ្យ អនុវត្ត អ្វីដែលពួកគេបានរៀនដោយការចងចាំពីគំរូរបស់អាម៉ូលេកនៅពេលពួកគេត្រូវបានល្បួងឲ្យចុះចាញ់លើជំនឿរបស់ពួកគេលើកក្រោយ ។ សូមថ្លែងទីបន្ទាល់ថា នៅពេលពួកគេរស់នៅដោយសាកសមនឹងដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ពួកគេអាចទទួលបានទំនុកចិត្តដ៏ខ្លាំងជាងមុន ដើម្បីឈរសម្រាប់សេចក្តីពិត និង យកឈ្នះលើការល្បួង ។

អាលម៉ា ១១:២៦–៤០

អាម៉ូលេកថ្លែងទីបន្ទាល់ពីព្រះរាជបុត្រានៃព្រះ និង យកឈ្នះលើការល្បួងរបស់ស៊ីអែសរ៉ុមក្នុងការបង្ខូចពាក្យសម្តីរបស់គាត់

សូមសួរសិស្សថា តើមាននរណាធ្លាប់ព្យាយាមសួរ ឬ បដិសេធនឹងជំនឿរបស់ពួកគេតាមរយៈអំណះអំណាង ឬ ការបំភាន់ទេ ។ សូមឲ្យសិស្សម្នាក់ ឬ ពីរនាក់ចែកចាយពីបទពិសោធន៍របស់ពួកគេ ។

សូមពន្យល់ថា ក្រោយពីស៊ីអែសរ៉ុមបានបរាជ័យក្នុងការឲ្យអាម៉ូលេកបដិសេធមិនទទួលស្គាល់វត្តមាននៃព្រះហើយ គាត់បានផ្លាស់ប្តូរវិធីសាស្ត្រ និងចាប់ផ្តើមវាយប្រហារលើសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទរបស់អាម៉ូលេក ។

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ១១:២៦–៣៥ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលស៊ីអែសរ៉ុមបានព្យាយាមដើម្បីក្រឡាស់ពាក្យសម្តីរបស់អាម៉ូលេក ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេបានរកឃើញ ។ បន្ទាប់មក សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ១១:៣៦–៣៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ចំណាំពីរបៀបដែលអាម៉ូលេកតែតម្រូវកំហុសដែលស៊ីអែសរ៉ុមបានបង្រៀន ។ សូមអញ្ជើញឲ្យសិស្សមើលទៅ លេខយោង ៣៨*ក* ។ (អ្នកអាចស្នើថា សិស្សគួរគូសចំណាំលេខយោង ៣៨*ក* នៅក្នុងព្រះគម្ពីររបស់ពួកគេ ។) សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៥:១០–១១ ឮៗ ។

- ហេតុអ្វីបានជាវាមិនអាចសង្គ្រោះនៅក្នុងអំពើបាបរបស់យើងនោះ ? តើអ្វីជាភាពខុសគ្នារវាងការបានសង្គ្រោះនៅក្នុងអំពើបាបរបស់យើង និង ការបានសង្គ្រោះចេញពីអំពើបាបរបស់យើង ?

សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ១១:៤០ ឮៗ ។ សូមពន្យល់ថា ខគម្ពីរនេះរួមមានគោលការណ៍មួយដែលយើងត្រូវធ្វើតាមដើម្បីត្រូវបានសង្គ្រោះចេញពីអំពើបាបរបស់យើង ។ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***នៅពេលយើងជឿលើព្រះយេស៊ូវគ្រីស្ទ យើងអាចត្រូវបានប្រោសលោះចេញពីអំពើបាបរបស់យើង ។***

- តើវាមានន័យដល់អ្នកយ៉ាងណាក្នុងការជឿលើព្រះយេស៊ូវគ្រីស្ទនោះ ?
- ហេតុអ្វីបានជាយើងត្រូវជឿលើព្រះយេស៊ូវគ្រីស្ទដើម្បីបានសង្គ្រោះចេញពីអំពើបាបរបស់យើង ?

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទដឹកនាំទៅរកសេចក្តីប្រោសលោះតាមរយៈការប្រែចិត្ត សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរ អេស អុជដូហ្វ នៃគណៈប្រធានទីមួយ ៖

" យើងត្រូវការសេចក្តីជំនឿដ៏រឹងមាំមួយនៅក្នុងព្រះគ្រីស្ទដើម្បីអាចប្រែចិត្ត ។ សេចក្តីជំនឿរបស់យើងត្រូវរួមមាន ‹ គំនិតដ៏ត្រឹមត្រូវមួយអំពីចរិតលក្ខណៈ ភាពឥតខ្ចោះ និង ឥរិយាបថ | របស់ព្រះ | › (*Lectures on Faith* [១៩៨៥], ៣៨) ។ ប្រសិនបើយើងជឿថា ព្រះទ្រង់ជ្រាបនូវការណ៍ទាំងឡាយ ស្រឡាញ់យើង និងមានសេចក្តីមេត្តាករុណា យើងនឹងអាចដាក់ការទុកចិត្តរបស់យើងទៅលើទ្រង់សម្រាប់សេចក្តីសង្គ្រោះរបស់យើងដោយគ្មានរុញរាឡើយ ។ សេចក្តីជំនឿទៅលើព្រះគ្រីស្ទនឹងផ្លាស់ប្តូរគំនិត ជំនឿ និង អាកប្បកិរិយារបស់យើងដែលមិនត្រូវគ្នានឹងឆន្ទៈរបស់ព្រះ " (" Point of Safe Return," *Ensign* ឬ *លេខអាហ្វណា*, ខែ ឧសភា ឆ្នាំ ២០០៧, ទំព័រ ១០០) ។

សូមឲ្យសិស្សធ្វើការជាដៃគូ ។ សូមឲ្យដៃគូនីមួយៗប្តូរវេនគ្នាពន្យល់ដល់គ្នាទៅវិញទៅមកពីរបៀបដែលពួកគេនឹងឆ្លើយតប ប្រសិនបើយុវជនម្នាក់បានសួរគេនូវសំណួរដូចខាងក្រោម ៖ (អ្នកអាចសរសេរសំណួរទាំងនេះនៅលើក្តារខៀន ។)

- ហេតុអ្វីបានជាខ្ញុំត្រូវជឿលើព្រះយេស៊ូវគ្រីស្ទដើម្បីប្រែចិត្ត និង ត្រូវបានសង្គ្រោះចេញពីអំពើបាបរបស់ខ្ញុំ ?
- តើការមានសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទបានជួយអ្នកឲ្យប្រែចិត្តដោយរបៀបណា ?

សូមថ្លែងទីបន្ទាល់ថា ដោយការមានសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ យើងអាចប្រែចិត្ត ត្រូវបានសង្គ្រោះពីអំពើបាបរបស់យើង និង ទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

អាលម៉ា ១១:៤១–៤៦

អាម៉ូរលេកបង្រៀនអំពីការរស់ឡើងវិញ និង ការជំនុំជម្រះនៃមនុស្សជាតិទាំងឡាយ

ដើម្បីជួយសិស្សឲ្យគិតពីមូលហេតុដែលវាសំខាន់ដើម្បីដឹងថា យើងនឹងត្រូវបានរស់ឡើងវិញ និងជំនុំជម្រះនៅទីបញ្ចប់ សូមសួរ ៖

- តើនរណាម្នាក់អាចរស់នៅដោយខុសគ្នាយ៉ាងណា ប្រសិនបើពួកគេជឿថា គ្មានជីវិតបន្ទាប់ពីសេចក្តីស្លាប់នោះ ?

សូមសរសេរពាក្យ *ការរស់ឡើងវិញ* និង *ការជំនុំជម្រះ* នៅលើក្តារខៀន ។ សូមអញ្ជើញឲ្យសិស្សសិក្សា អាលម៉ា ១១:៤១–៤៥ ដោយស្ងាត់ៗ ដោយរកមើលព័ត៌មានឲ្យបានច្រើនតាមដែលគេអាចធ្វើបានអំពីការរស់ឡើងវិញ និង ការជំនុំជម្រះ ។ នៅពេលសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ សូមប្រាកដថា ឃ្លាមួយនៅលើក្តារខៀនបានពាំនាំសេចក្តីពិតថា ទីបញ្ចប់ប្រជាជនទាំងឡាយដែលរស់នៅលើផែនដីនឹងត្រូវបានរស់ឡើងវិញ ។ សូមបង្ហាញថា និយមន័យសាមញ្ញនៃការរស់ឡើងវិញនៅក្នុង អាលម៉ា ១១:៤៥ ៖ “ ដើម្បីកុំឲ្យពួកគេស្លាប់ទៀតឡើយ វិញ្ញាណរបស់ពួកគេនឹងមករួមជាមួយនឹងរូបកាយពួកគេវិញ ហើយពុំអាចបែកគ្នាបានទៀតឡើយ ” ។ (អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំឃ្លានេះ) ។ ក្រោយពីសិស្សបានរាយការណ៍ពីអ្វីដែលពួកគេបានរៀនហើយ អ្នកអាចស្នើថា ពួកគេគួរសរសេរសេចក្តីពិតខាងក្រោមនៅលើទំព័រក្នុងព្រះគម្ពីររបស់ពួកគេ ៖ **តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ មនុស្សទាំងអស់នឹងត្រូវបានសង្គ្រោះ និងជំនុំជម្រះតាមកិច្ចការរបស់ពួកគេ ។**

- តើសេចក្តីពិតមួយណានៅលើក្តារខៀនដែលជម្រុញអ្នកឲ្យរៀបចំទៅជួបនឹងព្រះ ?
- ហេតុអ្វីបានជាសេចក្តីពិតទាំងឡាយអំពីការរស់ឡើងវិញនាំមកនូវសន្តិភាព និងសេចក្តីសង្ឃឹមដល់ពួកសុចរិត ?

សូមអញ្ជើញឲ្យសិស្សអាន ដោយស្ងាត់ៗ ដោយរកមើលឥទ្ធិពលនៃការបង្រៀនរបស់អាម៉ូលេកចំពោះស៊ីអែសរ៉ុម ។

- តើអ្នកគិតថា ហេតុអ្វីបានជានរណាម្នាក់អាចប្រតិកម្មរបៀបនេះចំពោះការបង្រៀនរបស់អាម៉ូលេក ?
- តើការបង្រៀនមួយណានៅក្នុង អាលម៉ា ១១:៤១–៤៥ ដែលអ្នកគិតថា អាចមានបញ្ហាដល់ស៊ីអែសរ៉ុម ? ហេតុអ្វី ?

សូមថ្លែងទីបន្ទាល់ថា ដោយសារតែដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ មនុស្ស*ទាំងអស់*នឹងត្រូវបានរស់ឡើងវិញ ហើយឈរនៅចំពោះមុខព្រះ “ ដើម្បីជំនុំជម្រះស្របតាមកិច្ចការទាំងឡាយដែលខ្លួនបានប្រព្រឹត្ត ” (អាលម៉ា ១១:៤៤) ។ សូមផ្តល់ពេលឲ្យសិស្សសញ្ជឹងគិតអំពីអ្វីដែលពួកគេបានរៀន និង ពីរបៀបដែលវាទាក់ទងនឹងពួកគេ ។ បន្ទាប់មកសូមឲ្យពួកគេសរសេរចម្លើយចំពោះសំណួរខាងក្រោមនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ (អ្នកអាចសរសេរសំណួរទាំងនេះនៅលើក្តារខៀន) ។

- តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលអ្នកគិតអំពីការរស់ឡើងវិញ និង ការទទួលការជំនុំជម្រះ ?
- តើអ្នកត្រូវធ្វើអ្វីខ្លះដើម្បីរៀបចំដើម្បីឈរនៅចំពោះមុខព្រះ ?
- តើសេចក្តីជំនឿរបស់អ្នកដែលថា អ្នកនឹងត្រូវបានរស់ឡើងវិញ និងត្រូវបានជំនុំជម្រះដោយឥទ្ធិពលដល់របៀបដែលអ្នកជ្រើសរើសរស់នៅរាល់ថ្ងៃដោយរបៀបណា ?

វិចារណកថា និង ព័ត៌មានសាច់រឿង

អាលម៉ា ១១:៣៨–៣៩ ។ តើព្រះយេស៊ូវគ្រីស្ទជាព្រះវរបិតាដ៏អស់កល្បជានិច្ចដោយរបៀបណា ?

ប្រសិនបើសិស្សត្រូវការជំនួយដើម្បីយល់ពីរបៀបដែលព្រះយេស៊ូវគ្រីស្ទអាចជាព្រះរាជបុត្រានៃព្រះ និង ព្រះវរបិតាដ៏អស់កល្បជានិច្ច អ្នកអាចបង្រៀន ឬ រំឭកពីគំនិតបន្ថែមទាំងឡាយសម្រាប់ការបង្រៀនសម្រាប់ ម៉ូសាយ ១៥:១–៩នៅក្នុងមេរៀនទី ៦០ ។

អាលម៉ា ១២

សេចក្តីផ្តើម

ក្រោយពីពាក្យសម្តីរបស់អាម៉ូលេកបានធ្វើឲ្យសីអែសរ៉ុម " ចាប់ផ្តើមញ័ររន្ធត់ ដោយដឹងនូវកំហុសរបស់ខ្លួន " (អាលម៉ា ១២:១) អាលម៉ាបានឈរភ្លឺកចំពោះអ្វីដែលអាម៉ូលេកបានបង្រៀន ។ អាលម៉ាបានផ្តោតលើសេចក្តីពិតដែលនឹងជួយដល់ប្រជាជនអាំម៉ូណៃហា ឲ្យប្រែចិត្តពីដួងចិត្តដ៏រឹងរបស់ពួកគេ និង អំពើបាបផ្សេងទៀត ។ គាត់បានបញ្ជាក់ពីអន្ទាក់ដែលមិនអាចមើលឃើញរបស់សាតាំង ការជំនុំជម្រះដែលនឹងធ្លាក់ដល់ពួកទុច្ចរិត និង ផែនការនៃសេចក្តីប្រោសលោះ ដែលកើតមានដល់អ្នកដែលប្រែចិត្ត ដើម្បីទទួលបានការអភ័យទោសចំពោះអំពើបាបរបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ១២:១–៧

អាលម៉ាអធិប្បាយពីផែនការរបស់សីអែសរ៉ុម —និង ផែនការនៃការលួង— ដល់ប្រជាជនអាំម៉ូណៃហា

សូមធ្វើតាមការបង្ហាញខាងក្រោមដើម្បីចងអន្ទាក់ដោយខ្សែ ។ សូមបង្ហាញពីរបៀបដែលអន្ទាក់ទាក់ដោយការដាក់ជាវង្វង់ពីមុខស្មុគ្រាប់ ឬ អាហារនៅលើតុ ។ សូមឲ្យសិស្សម្នាក់ឈោងទៅយកអាហារកាត់អន្ទាក់នោះ ។ នៅពេលគេធ្វើដូច្នោះ សូមបន្តឹងអន្ទាក់ ។ (សូមប្រយ័ត្នកុំធ្វើឲ្យសិស្សឈឺ) ។



សូមអញ្ជើញឲ្យសិស្សម្នាក់រំឭកដល់សិស្សក្នុងថ្នាក់ពីរបៀបដែលសីអែសរ៉ុមបានព្យាយាមទាក់អាម៉ូលេកឲ្យចូលក្នុងអន្ទាក់ (សូមមើល អាលម៉ា ១១:២១–២៥) ។ សូមពន្យល់ថា ក្រោយពីអាម៉ូលេកបានដឹងពីបំណងរបស់សីអែសរ៉ុមហើយបានឆ្លើយតបនឹងគាត់ហើយ អាលម៉ាក៏បានឈរថ្លែងដល់សីអែសរ៉ុម និង ប្រជាជនដែលបានស្តាប់ (សូមមើល អាលម៉ា ១២:១–២) ។ សូមអញ្ជើញឲ្យសិស្សអាន អាលម៉ា ១២:៣–៦ ដោយស្ងាត់ៗ ដោយរកមើលពាក្យ និងឃ្លាដែលអាលម៉ាបានប្រើដើម្បីពិពណ៌នាពីវិធីសាស្ត្ររបស់សីអែសរ៉ុម ។ (អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំពាក្យ និងឃ្លាទាំងនេះ) ។ សូមអញ្ជើញឲ្យពួកគេរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។

- **តើគម្រោងរបស់អ្នកណាដែលសីអែសរ៉ុមធ្វើតាមនោះ ?**
- **តើអាលម៉ាបាននិយាយអ្វីដែលជាបំណងរបស់អារក្ស ?**
- **តើអ្វីដែលធ្វើឲ្យអាលម៉ាមើលធ្លុះផែនការនេះ ?**

សូមអញ្ជើញឲ្យសិស្សនិយាយពីគោលការណ៍ដែលសង្ខេបពីអ្វីដែលពួកគេបានរៀនពី អាលម៉ា ១២:៣ អំពីរបៀបដែល ពួកគេអាចរៀនពីការបោកបញ្ឆោតនៃការលួង ។ ទោះបីជាសិស្សអាចប្រើពាក្យផ្សេងគ្នាក្តី ពួកគេគួររកឃើញនូវគោលការណ៍ខាងក្រោម ៖ ព្រះវិញ្ញាណបរិសុទ្ធអាចជួយយើងឲ្យដឹងពីការបោកបញ្ឆោតនៃការលួង ។អ្នកអាចរំឭកសិស្សថា នៅក្នុងមេរៀនមុន ពួកគេបានរៀនថា នៅពេលយើងពឹងផ្អែកទៅលើព្រះវិញ្ញាណបរិសុទ្ធ យើងអាចយកឈ្នះលើការល្បួងបាន ។ សូមពន្យល់ថា ដើម្បីយកឈ្នះលើការល្បួង ឬ ការបោកបញ្ឆោត ដំបូងយើងត្រូវស្គាល់វា និង ផលប៉ះពាល់ដែលវាអាចនាំមកដល់យើង ។ បន្ទាប់មក យើងត្រូវធ្វើអ្វីៗទាំងឡាយដែលយើងអាចដើម្បីចៀសវាងពីវា ។

- **តើនៅពេលណាដែលព្រះវិញ្ញាណបរិសុទ្ធបានជួយអ្នកឲ្យដឹង និង ចៀសពីការល្បួង ? (ក្រោយពីសិស្សបានឆ្លើយតបហើយ អ្នកក៏អាចចែកចាយពីបទពិសោធន៍មួយផ្ទាល់ខ្លួនអ្នកដែរ) ។**

សូមឲ្យសិស្សមានពេលពីរបីនាទីសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពីរបៀបដែលពួកគេអាចបង្កើនការដឹងរបស់ពួកគេចំពោះការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យពួកគេអាចដឹង និងចៀសវាងពីអន្ទាក់នៃការល្បួង ។

អាលម៉ា ១២:៨–១៨

អាលម៉ាបង្រៀនអំពីការជំនុំជម្រះចុងក្រោយនៃមនុស្សទាំងឡាយ

សូមឲ្យសិស្សគិតអំពីការងារដែលពួកគេចាប់អារម្មណ៍ចង់បាន ។ សូមអញ្ជើញឲ្យពួកគេពីរបីនាក់និយាយអំពីការងារដែលពួកគេចាប់អារម្មណ៍ ។ សូមឲ្យពួកគេស្មានពីចំនួនដែលពួកគេអាចបង់ថ្លៃមហាវិទ្យាល័យ សាកលវិទ្យាល័យ ឬ សាលាជំនួញដើម្បីទទួលបានចំណេះដឹង និង ជំនាញដែលតម្រូវឲ្យមានដើម្បីមានជោគជ័យក្នុងការងារនោះ ។ សូមអញ្ជើញឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍

ខាងក្រោមដោយអែលឌើរ ដាវីឌ អេ បៃដណា នៃក្លឹមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកពាក្យ " ការបង់ថ្លៃ" ដែលអែលឌើរ បៃដណា បាននិយាយថាយើងត្រូវបង់ដើម្បីទទួលបានចំណេះដឹងខាងវិញ្ញាណ ។

" ការយល់ដឹងខាងវិញ្ញាណ . . . មិនអាចត្រូវបានឲ្យដល់ [យើង] ដោយងាយស្រួលទេ ។ ការបង់ថ្លៃនៃការព្យាយាម និង ការរៀនដោយការសិក្សានិងដោយសេចក្តីជំនឿជឿងត្រូវបានបង់ដើម្បីទទួលបានចំណេះដឹងបុគ្គល ‹ ផ្ទាល់ខ្លួន › បែបនោះ ។ មានតែតាមរបៀបនេះប៉ុណ្ណោះ ដែលអ្វីដែលត្រូវបានស្គាល់នៅក្នុងគំនិតក៏អាចមានអារម្មណ៍ក្នុងចិត្តដែរ " (" Watching with All Perseverance," *Ensign* ឬ *លេខអាហ្វណា*, ខែ ឧសភា ឆ្នាំ ២០១០, ទំព័រ ៤) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ១២:៧–៨ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលភស្តុងតាងដែលស៊ីអែសរ៉ុមបានចាប់ផ្តើមបង " ថ្លៃ " ខាងវិញ្ញាណដែលតម្រូវធ្វើដើម្បីទទួលបានចំណេះដឹងខាងវិញ្ញាណ ។ សូមអញ្ជើញឲ្យសិស្សពន្យល់ពីអ្វីដែលពួកគេឃើញនៅក្នុងខគម្ពីរទាំងនេះដែលបង្ហាញពីដួងចិត្តរបស់ស៊ីអែសរ៉ុម បានចាប់ផ្តើមផ្លាស់ប្តូរ ។

សូមបង្ហាញថា ស៊ីអែសរ៉ុមបានសួរអាលម៉ាន្ទូវសំណួរមួយអំពីការរស់ឡើងវិញ ។ ជាជាងឆ្លើយនឹងសំណួរនោះភ្លាមៗ អាលម៉ាបានបង្រៀនគាត់អំពីការទទួលបានចំណេះដឹងខាងវិញ្ញាណ ។ សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ១២:៩–១១ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលអាលម៉ាបានបង្រៀនដល់ស៊ីអែសរ៉ុមអំពីការទទួលបានចំណេះដឹងខាងវិញ្ញាណ ។ សូមពន្យល់ថា " អាថ៌កំបាំងនៃព្រះគឺជាសេចក្តីពិតខាងវិញ្ញាណដែលដឹងតែតាមរយៈវិវរណៈប៉ុណ្ណោះ . . . ចំពោះអ្នកដែលគោរពតាមដំណឹងល្អ " (Guide to the Scriptures, "Mysteries of God," scriptures.lds.org) ។ (អ្នកអាចសរសេរប្រយោគនេះនៅលើក្តារខៀន ។ អ្នកក៏អាចស្មើថា សិស្សគួរសរសេរវានៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ១២:៩) ។

សូមឲ្យសិស្សបង្ហាញជាសម្តីខ្លួនឯងពីអ្វីដែល អាលម៉ា ១២:៩ បង្រៀនអំពីអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបានសេចក្តីពិតខាងវិញ្ញាណ ។ (សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែចម្លើយរបស់ពួកគេគួរបង្ហាញថា **ព្រះអម្ចាស់បង្ហាញសេចក្តីពិតខាងវិញ្ញាណដល់យើង តាមរយៈការគោរព និង សេចក្តីឧស្សាហ៍ព្យាយាមដែលយើងធ្វើតាមព្រះបន្ទូលរបស់ទ្រង់ ។** អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ១២:៩) ។

- តើអ្វីជាទំនាក់ទំនងរវាងស្ថានភាពនៃដួងចិត្តយើង និង សមត្ថភាពយើងដើម្បីទទួលបានសេចក្តីពិតខាងវិញ្ញាណ ?

នៅក្នុង អាលម៉ា ១២:១០–១១ សូមបង្ហាញពីលទ្ធផលបញ្ច្រាសគ្នាសម្រាប់អ្នកដែលមិនបានធ្វើឲ្យដួងចិត្តគេរឹងទទឹងទាស់នឹងសេចក្តីពិត និង អ្នកដែលបានធ្វើឲ្យចិត្តរឹងទទឹង ។

- តើការដឹងពីលទ្ធផលទាំងនេះជះឥទ្ធិពលដល់បំណងរបស់អ្នកក្នុងការស្វែងរកចំណេះដឹងខាងវិញ្ញាណខ្លាំងជាងនេះដោយរបៀបណា ?

សូមពន្យល់ថា ក្រោយពីអាលម៉ាបានបង្រៀនពីរបៀបដែលយើងដឹងពីសេចក្តីពិតខាងវិញ្ញាណ គាត់បានឆ្លើយតបនឹងសំណួរដែលស៊ីអែសរ៉ុមបានសួរពីមុនមក ។ សូមឲ្យសិស្សស្វែងរកសំណួររបស់ស៊ីអែសរ៉ុមម្តងទៀតនៅក្នុង អាលម៉ា ១២:៨ ជាសម្តីខ្លួនឯង ។ សូមអញ្ជើញឲ្យពួកគេអានអាលម៉ា ១២:១២–១៥ ដោយស្ងាត់ៗ ដោយរកមើលអ្វីដែលអាលម៉ាបានបង្រៀនដល់ស៊ីអែសរ៉ុមអំពីការស់ឡើងវិញ និង សេចក្តីជំនុំជម្រះ ។ ខណៈពេលដែលសិស្សកំពុងអាន សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *យើងនឹងត្រូវទទួលខុសត្រូវនៅចំពោះមុខព្រះសម្រាប់ . . . . . និង . . . របស់យើង ។*

នៅពេលសិស្សបានអានចប់ហើយ សូមឲ្យពួកគេបំពេញប្រយោគនៅលើក្តារខៀន ៖ ***យើងនឹងត្រូវទទួលខុសត្រូវនៅចំពោះមុខព្រះសម្រាប់គំនិត ពាក្យសម្តី និង កិច្ចការទាំងឡាយរបស់យើង ។***

- តើអ្នកគិតថា សេចក្តីពិតនេះអាចមានឥទ្ធិពលដល់ស៊ីអែសរ៉ុមដោយរបៀបណា ? (សូមឲ្យសិស្សបើកទៅ អាលម៉ា ១៤:៦និង ១៥:៣ដើម្បីរកចម្លើយ) ។ តើអ្នកគិតថា ហេតុអ្វីបានជាសេចក្តីពិតនេះមានឥទ្ធិពលដ៏ខ្លាំងដល់ស៊ីអែសរ៉ុម ? (អ្នកអាចបង្ហាញថា ស៊ីអែសរ៉ុមបានបារម្ភមិនត្រឹមតែចំពោះខ្លួនគាត់នោះទេ ។ គាត់បានបារម្ភអំពីប្រជាជនដែលគាត់បានដឹកនាំដើរក្នុងផ្លូវខុស) ។
- តើគំនិត ពាក្យសម្តី និង កិច្ចការបែបណាដែលប្រជាជនបានស៊ូតាម ដែលគេអាចដាក់ទោសខ្លួនគេ ប្រសិនបើពួកគេមិនប្រែចិត្តទេនោះ ? (ដើម្បីជួយសិស្សឲ្យគិត និង ពិភាក្សាពីរបៀបដែលជម្រើសរបស់ពួកគេលើការកំសាន្ត និង តន្ត្រីអាចជះឥទ្ធិពលដល់គំនិត ពាក្យសម្តី និង កិច្ចការរបស់ពួកគេ អ្នកអាចបើកទៅលើការប្រឹក្សាអំពីការកំសាន្ត និងតន្ត្រីនៅក្នុង *ដើម្បីកម្លាំងនៃយុវជន*) ។
- តើនឹងមានភាពខុសគ្នាបែបនាំក្នុងជម្រើសប្រចាំថ្ងៃរបស់អ្នក ប្រសិនបើអ្នកចងចាំពីសេចក្តីពិតដែលបានសរសេរនៅលើក្តារខៀន ?

សូមបង្ហាញពីសេចក្តីយោងក្នុងព្រះគម្ពីរទៅ ម៉ូសាយ ៤:៣០នៅក្នុងអាលម៉ា ១២:១៤, លេខយោង ១៤ក,ហើយសូមអញ្ជើញឲ្យសិស្សម្នាក់អានម៉ូសាយ ៤:៣០ឮៗ ។ (អ្នកអាចស្មើថា សិស្សគួរគូសចំណាំសេចក្តីយោងព្រះគម្ពីរនេះ) ។ ប្រសិនបើមានពេល សូមឲ្យសិស្សបើកទៅអ្វីដែលអ្នកបានសរសេរអំពីការបង្កើនញាណដឹងរបស់គេចំពោះការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ ។ សូមអញ្ជើញឲ្យពួកគេបន្តែមគំនិតពីរបីទៀតអំពីរបៀបដែលការយល់ដឹងពីការទូលខុសត្រូវផ្ទាល់ខ្លួនរបស់ពួកគេចំពោះមុខព្រះជះឥទ្ធិពលដល់បំណងប្រាថ្នារបស់ពួកគេដើម្បីស្តាប់ និងចៀសវាងពីការល្បួង ។

អាលម៉ា ១២:១៩–៣៧

អាលម៉ាពន្យល់ពីរបៀបដែលផែនការនៃសេចក្តីប្រោសលោះជួយយើងឲ្យយកឈ្នះលើឥទ្ធិពលនៃការធ្លាក់

សូមឲ្យសិស្សមើលរូបភាពអ័ដាម និង អេវ៉ាគោរពដល់រូបព្រះ (*សៀវភៅរូបភាពដំណឹងល្អ* [ឆ្នាំ ២០០៩], លេខ ៤) ។ សូមពន្យល់ថា បុរសម្នាក់ឈ្មោះ អាន់ទីអូណា ដែលជាមេត្រួតត្រាម្នាក់ក្នុងដែនដីអាំម៉ូណៃហា បានសួរសំណួរទាក់ទងនឹងអ្វីដែលអាលម៉ា និង អាម៉ូលេក

សូមជួយសិស្សម្នាក់ៗ

អំឡុងពេលកិច្ចការក្នុងថ្នាក់ សូមដើរមើលសិស្សដោយស្ងាត់ៗដើម្បីជួយសិស្សធ្វើកិច្ចការ ឬ ជួយពួកគេឲ្យនៅធ្វើកិច្ចការនោះ ។ ការធ្វើដូច្នោះនឹងផ្តល់ឱកាសដល់អ្នក ដើម្បីពង្រឹងទំនាក់ទំនងជាមួយនឹងសិស្សម្នាក់ៗ និង យល់ពីតម្រូវការរបស់ពួកគេកាន់តែច្បាស់ ។

បានបង្រៀនអំពីការរស់ឡើងវិញ ។ គាត់បានសូរអាលម៉ាពីរបៀបដែលមនុស្សអានក្លាយទៅជាអមតភាព ។ (សូមមើល អាលម៉ា ១២:២០–២១) ។

សូមសូរសិស្សពីទំនុកចិត្តដែលពួកគេនឹងមានពេលពន្យល់ដល់នរណាម្នាក់ដែលមិនមែនជាសមាជិកនៃសាសនាចក្រ ពីរបៀបដែលយើងអាចត្រូវបានប្រោសលោះពីការធ្លាក់ ។ ដើម្បីជួយពួកគេឲ្យត្រៀមជាស្រេចដើម្បីបង្រៀនពីសេចក្តីពិតនេះដល់នរណាផ្សេងទៀត សូមឲ្យពួកគេរៀនគម្ពីរនៅក្នុងតារាងខាងក្រោម ហើយសរសេរអ្វីដែលពួកគេបានរៀននៅក្នុងកូឡោនដែលត្រូវ ។ (អ្នកអាចចម្លងតារាងនេះនៅលើក្តារខៀន មុនចាប់ផ្តើមថ្នាក់ ។ សូមអញ្ជើញឲ្យសិស្សចម្លងវាទៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ) ។

ឥទ្ធិពលនៃការធ្លាក់ (អាលម៉ា ១២:២២, ២៤)	អ្វីដែលព្រះបានធ្វើដើម្បីនាំមកនូវការប្រោសលោះរបស់យើង (អាលម៉ា ១២:២៤–២៥, ២៨–៣៣)	អ្វីដែលយើងត្រូវធ្វើដើម្បីត្រូវបានប្រោសលោះ (អាលម៉ា ១២:២៤, ៣០, ៣៤, ៣៧)

នៅពេលសិស្សបំពេញក្នុងតារាង ពួកគេខ្លះអាចត្រូវការជំនួយរបស់អ្នក ។ (របៀបមួយដើម្បីជួយសិស្សឲ្យយល់ពីព្រះគម្ពីរគឺ ត្រូវបង្ហាញដល់ពួកគេនូវលេខយោង ។ ជាឧទាហរណ៍ សេចក្តីយោងព្រះគម្ពីរដែលបានផ្តល់នៅក្នុងលេខយោង ២២គ អាចជួយសិស្សឲ្យយល់ពីអត្ថន័យសម្រាប់មនុស្សទាំងអស់ដែលបានវង្វេង និងធ្លាក់) ។ នៅពេលសិស្សបានបំពេញតារាងហើយ សូមសូរនូវសំណួរខាងក្រោម ៖ (អ្នកអាចសរសេរសំណួរទាំងនេះនៅលើក្តារខៀនមុនពេលចាប់ផ្តើមថ្នាក់ ដើម្បីឲ្យសិស្សអាចគិតពីចម្លើយរបស់ពួកគេ នៅពេលពួកគេបំពេញក្នុងតារាងនេះ) ។

- តើដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទអនុញ្ញាតឲ្យយើងយកឈ្នះលើឥទ្ធិពលនៃការធ្លាក់ដោយរបៀបណា ? (ដោយសារតែដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ យើងនឹងយកឈ្នះលើការស្លាប់ខាងរាងកាយទាំងឡាយតាមរយៈការរស់ឡើងវិញ ។ ហើយតាមរយៈដង្វាយធួនរបស់ព្រះអង្គសង្ក្រោះ និង ការប្រែចិត្តរបស់យើង យើងអាចត្រឡប់ទៅកាន់ព្រះពីស្ថានភាព " វង្វេង និង ធ្លាក់ " របស់យើង) ។
- យោងតាម អាលម៉ា ១២:២៤ តើអាលម៉ាបានបង្រៀនអ្វី ដែលជាបំណងនៃជីវិតនេះ ? (គាត់បាននិយាយថា **ជីវិតនេះគឺជាពេលវេលាសម្រាប់យើងប្រុងប្រៀបទៅជួបនឹងព្រះ** ។អ្នកអាចស្នើថា សិស្សគួរគូសចំណាំឃ្លានៅក្នុង អាលម៉ា ១២:២៤ ដែលបង្រៀនពីសេចក្តីពិតនេះ) ។

ដើម្បីជួយសិស្សឲ្យអនុវត្តអ្វីដែលពួកគេបានរៀន សូមសូរសំណួរដូចខាងក្រោមនេះ ៖

- តើការដឹងពីគោលបំណងនៃជីវិតបានជួយដឹកនាំអ្នកដោយរបៀបណា ?
- តើសេចក្តីជំនឿរបស់អ្នកទៅលើព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទបានជួយអ្នកប្រុងប្រៀបទៅជួបនឹងទ្រង់ដោយរបៀបណា ?

សូមបញ្ចប់ដោយទីបន្ទាល់របស់អ្នកថា ឥឡូវនេះជាពេលវេលាប្រុងប្រៀបទៅជួបនឹងព្រះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អាលម៉ា ១២:២៤ " ស្ថានភាពពិសោធន៍ "

នៅក្នុងព្រះគម្ពីរទាំងឡាយ ពាក្យ " ស្ថានភាពពិសោធន៍ " ឬ " ពេលវេលាពិសោធន៍ " លេចឡើងតែនៅក្នុងព្រះគម្ពីរអាលម៉ាប៉ុណ្ណោះ (សូមមើល អាលម៉ា ១២:២៤; ៤២:៤, ១០, ១៣) ។ អែលឌើរ អិល ថម ភែរី នៃក្លុ៉ម៉ានៃពួកសាវកដប់ពីរនាក់បានពិពណ៍នាពីពេលវេលាពិសោធន៍នេះ ៖

" គោលបំណងដ៏ចម្បងនៃជីវិតលើផែនដីនេះគឺត្រូវអនុញ្ញាតឲ្យវិញ្ញាណរបស់យើង ដែលបានស្ថិតនៅពីមុនពិភពលោកនោះម្លិះ រួបរួមនឹងរាងកាយយើងមួយរយៈក្នុងឱកាសដ៏អស្ចារ្យខាងសាច់ឈាម ។ ទំនាក់ទំនងនៃធាតុទាំងពីរនេះរួមគ្នាបានផ្តល់ឲ្យយើងនូវអភ័យឯកសិទ្ធិក្នុងការលូតលាស់ ការអភិវឌ្ឍ និង ការធំធាត់តាមដែលយើងអាចធ្វើបានដោយសារមានវិញ្ញាណ និងរាងកាយរួបរួមគ្នាប៉ុណ្ណោះ ។ ដោយមានរាងកាយរបស់យើង យើងឆ្លងកាត់ឧបសគ្គមួយចំនួនក្នុងអ្វីដែលហៅថាជាស្ថានភាពនៃការរស់នៅរបស់យើង ។ នេះគឺជាពេលវេលាមមួយដើម្បីរៀន និង សាកល្បងដើម្បីបង្ហាញថាខ្លួនយើងសាកសមនឹងឱកាសដ៏អស់ក្បលទាំងឡាយ ។ វាគឺជាផ្នែកទាំងឡាយនៃផែនការដ៏ទេវភាពដែលព្រះវរបិតារបស់យើងមានសម្រាប់កូនចៅរបស់ទ្រង់ " ("Proclaim My Gospel from Land to Land," *Ensign*,ខែ ឧសភា ឆ្នាំ ១៩៨៩, ទំព័រ ១៤) ។

មេរៀនទី ៧៨

អាលម៉ា ១៣

សេចក្តីផ្តើម

តើនៅពេលណាដែលអាលម៉ាបានបង្រៀនដល់ប្រជាជនបះបោរអាំម៉ូណៃហាដំបូងបំផុត ពួកគេបានទាស់នឹងគាត់ ដោយសួរថា " តើលោកជាអ្នកណា " ? ហើយបានសួរដល់អំណាចរបស់លោក (សូមមើល អាលម៉ា ៩:១–៦) ។ ពួកគេស្ថិតក្នុងស្ថានភាពនៃការក្បត់សាសនា ដោយធ្វើតាមបញ្ជារបស់នីហូរ —ជាឧបាយកលផ្នែកសង្ឃ ដោយមានគោលដៅចង់បានប្រយោជន៍ផ្ទាល់ខ្លួន (សូមមើល អាលម៉ា ១:២–១៥; ១៥:១៥; ១៦:១១) ។ ផ្ទុយទៅនឹងការបង្រៀនរបស់នីហូរ អាលម៉ាបានបង្រៀនពួកគេអំពី " បព្វជិតភាពថ្នាក់ខ្ពស់នៃការបញ្ជាដ៏បរិសុទ្ធនៃព្រះ " ដោយមានគោលដៅដើម្បីជួយអ្នកផ្សេងទៀតឲ្យប្រែចិត្ត និង ចូលទៅក្នុងទីសម្រាកនៃព្រះអម្ចាស់ (សូមមើល អាលម៉ា ១៣:៦) ។ គាត់បានសំអាងលើគំរូរបស់មីលគីស្សាដែក ដែលបានបង្រៀនពីសេចក្តីជំនឿ និងការប្រែចិត្ត ហើយបានជួយប្រជាជនរបស់គាត់ឲ្យរស់នៅក្នុងសេចក្តីសុខសាន្ត ។ អាលម៉ាក៏បានបង្រៀនអំពីជីវិតមុនផែនដី និងការតែងតាំងពីមុនកំណើតលោកិយមក ។ គាត់បានបញ្ចប់ទេសនកថារបស់គាត់ ដោយការអញ្ជើញប្រជាជនឲ្យស្តាប់តាមពាក្យសម្តីរបស់គាត់ ដើម្បីពួកគេអាចរៀបចំចូលទៅក្នុងទីសម្រាកនៃព្រះអម្ចាស់ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ១៣:១–១២

អាលម៉ាបង្រៀនប្រជាជនអាំម៉ូណៃហាអំពីការហៅបម្រើជាពួកសង្ឃជាន់ខ្ពស់

សូមពន្យល់ថា អាលម៉ា ១៣ រួមមានការបង្រៀនរបស់អាលម៉ាអំពីក្រុមមនុស្សមួយដែលជាប្រយោជន៍ដ៏ធំដល់សាសនាចក្រ ។ តាមពិតទៅ សមាជិកទាំងអស់នៃសាសនាចក្របានទទួលពរជ័យតាមរយៈការបម្រើនៃប្រជាជនទាំងនេះ ។

សូមប្រាប់សិស្សថា ពួកគេស្គាល់ប្រជាជនដែលជាផ្នែកមួយនៃក្រុមនេះ ។ បន្ទាប់មក សូមឲ្យសិស្សអាន អាលម៉ា ១៣:១ ដោយស្ងាត់ៗ ដើម្បីសម្រេចថា ប្រជាជនទាំងនេះជានរណា ។ ក្រោយពីពួកគេបានមានពេលគ្រប់គ្រាន់អានខគម្ពីរនេះហើយ សូមស្នើថា ពួកគេក៏គួរអាន អាលម៉ា ១៣:១០, ១៤ និង គោលលទ្ធិ និង សេចក្តីសញ្ញា ១០៧:១–៣ ។ អ្នកអាចស្នើថា ពួកគេគួរសរសេរសេចក្តីយោងទាំងនេះនៅរឹមទំព័រក្បែរ អាលម៉ា ១៣:១ ។

សូមបង្ហាញថា អាលម៉ាបាននិយាយអំពីពួកសង្ឃដែលធ្វើតាមការបញ្ជានៃព្រះរាជបុត្រានៃព្រះ ដែលជាអំណាចបព្វជិតភាពមីលគីស្សាដែក ។ និយាយម្យ៉ាងទៀតថា គាត់បាននិយាយពីបុរសដែលបានកាន់អំណាចនៃពួកសង្ឃជាន់ខ្ពស់នៅក្នុងអំណាចបព្វជិតភាពមីលគីស្សាដែក ។ សូមអញ្ជើញឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ប្រ្វិស អ័រ ម៉ាក់ខន់យីនៃក្វរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

" ប្រជាជននីហ្វៃទាំងនេះ ដែលស្មោះត្រង់ និងពិតក្នុងការកាន់តាមច្បាប់នៃម៉ូសេ បានមានអំណាចបព្វជិតភាពមីលគីស្សាដែក ដែលមានន័យថា ពួកគេក៏បានមានភាពពេញលេញនៃដំណឹងល្អដែរ ។ . . . ព័ត៌មានដ៏ច្បាស់បំផុតខ្លះរបស់យើងអំពីអំណាចបព្វជិតភាពមីលគីស្សាដែកមាននៅក្នុង អាលម៉ា ១៣ " (*The Promised Messiah* [ឆ្នាំ ១៩៧៨], ទំព័រ ៤២១) ។

- តើពរជ័យអ្វីខ្លះដែលមកក្នុងជីវិតរបស់អ្នក តាមរយៈអំណាចបព្វជិតភាពមីលគីស្សាដែក ? (សិស្សអាចនិយាយពីអំណោយទាន នៃព្រះវិញ្ញាណបរិសុទ្ធ ពរជ័យអយ្យកោ ពរជ័យនៃបព្វជិតភាពផ្សេងទៀត ការដឹកនាំនៃអ្នកមានសិទ្ធិអំណាចទូទៅ ការដឹកនាំនៃអ្នកដឹកនាំក្នុងស្រុកដូចជា ប៊ីស្សព ឬ ប្រធានសាខា និង ពរជ័យដែលពួកគេទទួលបានតាមរយៈសេចក្តីសញ្ញាដែលឱពុកម្តាយរបស់ពួកគេបានធ្វើនៅក្នុងព្រះវិហារបរិសុទ្ធ ។ ពួកគេក៏អាចលើកឡើងពីពិធីបុណ្យជ្រមុជទឹក និង ពិធីសាក្រាម៉ង ដែលធ្វើឡើងដោយអ្នកមានសិទ្ធិអំណាចនៃបព្វជិតភាពអើរ៉ុន ប៉ុន្តែនៅក្នុងការដឹកនាំពីអ្នកដឹកនាំអំណាចបព្វជិតភាពមីលគីស្សាដែក) ។

សូមបង្ហាញសំណួរខាងក្រោមនៅលើក្តារខៀន ឬ សរសេរសំណួរលើក្រដាសចែកដល់សិស្ស ។ សូមឲ្យសិស្សមានពេលអាន អាលម៉ា ១៣:២–១០ ហើយរកមើលចម្លើយចំពោះសំណួរ ។

តើនៅពេលណាដែលអ្នកកាន់អំណាចបព្វជិតភាពមីលគីស្សាដែកត្រូវបានហៅ និង រៀបចំលើកដំបូង ? (សូមមើល អាលម៉ា ១៣:៣–៥) ។

តើកាតព្វកិច្ចអ្វីដែលអ្នកកាន់អំណាចបព្វជិតភាពមីលគីស្សាដែកទាំងអស់ត្រូវមាន ? (សូមមើល អាលម៉ា ១៣:៦) ។

តើឃ្លាណានៅក្នុង អាលម៉ា ១៣:៧ ពិពណ៌នាពីអំណាចបព្វជិតភាពមីលគីស្សាដែក ?

តើលក្ខខណ្ឌណាខ្លះសម្រាប់ការទទួលបានការតែងតាំងក្នុងអំណាចបព្វជិតភាពមីលគីស្សាដែក ? (សូមមើល អាលម៉ា ១៣:១០) ។

នៅពេលសិស្សបានពេលរកចម្លើយទៅនឹងសំណួរហើយ សូមឲ្យពួកគេរាយការណ៍ពីចម្លើយរបស់ពួកគេ ។ អ្នកអាចកត់ត្រាចម្លើយរបស់ពួកគេនៅលើក្តារខៀន ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ និង ពិភាក្សាពីអ្វីដែលពួកគេបានអានហើយ សូមគិតពីការសួរសំណួរខាងក្រោម ៖

បង្រៀនសិស្ស មិនមែនចំណុចមេរៀនទេ

អទិភាពចម្បងរបស់អ្នកគឺ ដើម្បីជួយសិស្សឲ្យយល់ពីសេចក្តីពិតនៃដំណឹងល្អ ហើយអនុវត្តសេចក្តីពិតទាំងនោះក្នុងជីវិតរបស់ពួកគេ ។ សូមចៀសវាងការល្បួងនានាឲ្យប្រញាប់បញ្ចប់មេរៀនមួយ ដើម្បីឲ្យតែអ្នកបានបង្រៀនគ្រប់ចំណុចទាំងអស់នោះទេ ។ សូមចាំថា អ្នកកំពុងបង្រៀនសិស្ស មិនមែនចំណុចមេរៀននោះទេ ។

- តើការបម្រើនៃអ្នកកាន់បព្វជិតភាពជួយយើងឲ្យដឹងពីរបៀបដើម្បីពឹងទៅលើព្រះយេស៊ូវគ្រីស្ទសម្រាប់ការប្រោសលោះតាមរបៀបណា ? (សូមមើល អាលម៉ា ១៣:២, ៨, ១៦។ តាមរយៈគំរូរបស់ពួកគេ និង ការបង្រៀនទាំងឡាយ និង តាមរយៈពិធីការដែលពួកគាត់បានធ្វើ ពួកគាត់បានបង្ហាញយើងទៅដល់ព្រះអង្គសង្គ្រោះ) ។
- តើអាលម៉ាចង់មានន័យយ៉ាងណា នៅពេលគាត់បាននិយាយថា ពួកសង្ឃជាន់ខ្ពស់ត្រូវបាន " ហៅ ហើយរៀបចំទុកចាប់តាំងពីកំណើតលោកិយមក " ? (អាលម៉ា ១៣:៣) ។ (គាត់ចង់មានន័យថា មនុស្សខ្លះត្រូវបានហៅតាំងពីមុនកំណើតលោកិយមក ដើម្បីទទួលបានអំណាចបព្វជិតភាពមួយចំនួន) ។

ដើម្បីជួយសិស្សឲ្យយល់ពីការហៅពីមុនកំណើតលោកិយមក និង ពីរបៀបដែលវាអនុវត្តនៅក្នុងជីវិតរបស់ពួកគេ អ្នកអាចសុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោម ។

ព្យាការី យ៉ូសែប ស៊្មីធ បានបង្រៀន ៖ " បុរសទាំងឡាយដែលទទួលបានការហៅបម្រើដល់ប្រជាជនក្នុងពិភពលោកនេះ ត្រូវបានតែងតាំងឲ្យទៅគោលបំណងដ៏សំខាន់នោះនៅក្នុងក្រុមប្រឹក្សាដ៏អស្ចារ្យលើស្ថានសួគ៌ ពីមុនពិភពលោកនេះកកើតម៉្លេះ ។ ខ្ញុំគិតថា ខ្ញុំត្រូវបានតែងតាំងមកក្នុងអំណាចនេះនៅក្នុងក្រុមប្រឹក្សាដ៏អស្ចារ្យនោះ " (*Teachings of Presidents of the Church: Joseph Smith* | ឆ្នាំ ២០០៧ |, ទំព័រ ៥១១) ។

ប្រធាន ស្ពែនសើរ ដបុលយូ ឃីមប៊ឹល បានបង្រៀនថា ៖ « មុនពេលយើងមកទីនេះ ស្ត្រីដែលប្រកបដោយជំនឿត្រូវបានផ្តល់នូវកិច្ចការដ៏ជាក់លាក់ទាំងឡាយ ខណៈដែលមនុស្សប្រុសដែលមានជំនឿត្រូវបានតែងតាំងជាមុនចំពោះការងារបព្វជិតភាពដ៏ជាក់លាក់ទាំងឡាយ ។ ខណៈពេលដែលយើងមិនចងចាំពីការណ៍ជាក់លាក់នាពេលឥឡូវ ការណ៍នេះមិនបានផ្លាស់ប្តូរនូវភាពពិតដ៏អស្ចារ្យនៃអ្វីដែលយើងធ្លាប់បានយល់ព្រមនោះទេ " (*Teachings of Presidents of the Church: Spencer W. Kimball* | ឆ្នាំ ២០០៦ |, ទំព័រ ២១៥–១៦) ។

- តើ អាលម៉ា ១៣:៣ បង្រៀនអំពីអ្វីដែលយើងត្រូវធ្វើដើម្បីបំពេញតាមបេសកកម្មពីមុនកំណើតលោកិយរបស់យើង ?
- នៅពេលដែលបុរសម្នាក់ត្រូវបានតែងតាំងឲ្យមានអំណាចបព្វជិតភាព តើការតែងតាំងនោះគួរមានន័យយ៉ាងណាដល់គាត់ ? (សូមមើលអាលម៉ា ១៣:៨ ។ សូមកំណត់ចំណាំថា សំណួរនេះអាចឆ្លើយដោយយុវនារីក៏ដូចជាយុវជនដែរ ។ យុវជនអាចទទួលប្រយោជន៍ពីការស្តាប់ចម្លើយរបស់យុវនារី) ។

សូមឲ្យសិស្សអាន អាលម៉ា ១៣:១១–១២ដោយស្ងាត់ៗ ដោយរកមើលរបៀបដែលអ្នកកាន់អំណាចបព្វជិតភាពមីលគីស្សាដែក ដែលអាលម៉ាបានលើកឡើង ត្រូវបានផ្លាស់ប្តូរតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដែល " សំលៀកបំពាក់របស់នរណាម្នាក់ | ត្រូវបាន | បោកឲ្យសស្អាត តាមរយៈឈាមនៃកូនចៀម " ?
- តើអ្នកគិតថា ហេតុអ្វីបានជាអ្នកកាន់អំណាចបព្វជិតភាពមីលគីស្សាដែកត្រូវផ្លាស់ប្តូរតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ? តើយើងអាចធ្វើតាមគំរូរបស់ពួកគាត់ដោយរបៀបណា ?

សូមរំឭកសិស្សថា អាលម៉ាបានបង្រៀនពីសេចក្តីពិតទាំងនេះដល់ប្រជាជននៅក្នុងដែនដីអាំម៉ូណៃហា ។ ប្រជាជនទាំងនេះជាច្រើន " ជាពួកអ្នកដែលកាន់តាមជំនឿនៃនីហ្វៃ " (អាលម៉ា ១៤:១៨; ១៥:១៥) ដែលមានន័យថា ពួកគេបានធ្វើតាមការបង្រៀនរបស់នីហ្វៃ ។ នីហ្វៃគឺជាបុរសម្នាក់ដែលបានបង្កើតការបញ្ជាខុសឆ្គងមួយ ដែលអាលម៉ាបានហៅថាជា " ឧបាយកលផ្នែកសង្ឃ " (សូមមើល អាលម៉ា ១:១២–១៥) ។

- តើអ្នកកាន់អំណាចបព្វជិតភាពមីលគីស្សាដែកដ៏ស្មោះត្រង់ខុសគ្នាពីអ្នកដែលធ្វើតាមការបង្រៀនរបស់នីហ្វៃដោយរបៀបណា ? (អ្នកអាចអញ្ជើញឲ្យសិស្សរំឭក អាលម៉ា ១:២–៦ ដោយរកមើលភាពផ្ទុយគ្នារវាងឧបាយកលផ្នែកសង្ឃរបស់នីហ្វៃ និង អំណាចបព្វជិតភាពមីលគីស្សាដែក) ។
- ប្រជាជនអាំម៉ូណៃហាត្រូវបានបង្រៀនអំពីអំណាចបព្វជិតភាពមីលគីស្សាដែកពីមុនមក ហើយបានទទួលពរជ័យតាមរយៈអំណាចបព្វជិតភាពមីលគីស្សាដែកនេះ (សូមមើល អាលម៉ា ៩:២១; ១៣:៩) ។ តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់សម្រាប់ប្រជាជនអាំម៉ូណៃហាដើម្បីត្រូវរំឭកពីអ្វីដែលពួកគេធ្លាប់បានរៀនពីមុនមកអំពីអំណាចបព្វជិតភាពមីលគីស្សាដែក ?
- តើអ្នកបានរៀនអ្វីខ្លះអំពីអំណាចបព្វជិតភាពនេះនៅក្នុងមេរៀននេះកន្លងមក ? (ខណៈពេលដែលសិស្សអាចនិយាយពីសេចក្តីពិតមួយចំនួន ចម្លើយរបស់ពួកគេគួរបង្ហាញថា **ពិធីការបព្វជិតភាព និង ការបម្រើរបស់អ្នកកាន់បព្វជិតភាពជួយយើងឲ្យដឹងពីរបៀបដើម្បីពឹងទៅលើព្រះយេស៊ូវគ្រីស្ទសម្រាប់សេចក្តីប្រោសលោះ**) ។

អ្នកអាចស្នើថា សិស្សគួរសរសេរគោលការណ៍នេះ និង គោលការណ៍ផ្សេងទៀតដែលពួកគេបានរកឃើញនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ ប្រសិនបើមានពេល សូមឲ្យពួកគេសរសេរពីរបៀបដែលគោលការណ៍ទាំងនេះអាចជះឥទ្ធិពលដល់របៀបដែលពួកគេគិតអំពីអំណាច និង ពរជ័យនៃបព្វជិតភាព ។

អាលម៉ា ១៣:១៣–២០

អាលម៉ាបង្រៀនអំពីមីលគីស្សាដែក សង្ឃជាន់ខ្ពស់ដ៏អស្ចារ្យម្នាក់ដែលបានស្តាបនាសេចក្តីសុខសាន្តក្នុងចំណោមប្រជាជនគាត់ ។

សូមសរសេរពាក្យ និងឃ្លាទាំងនេះនៅលើក្តារខៀន ៖ *សង្ឃជាន់ខ្ពស់ ស្តេច អនុវត្តសេចក្តីជំនឿដ៏ខ្លាំង បង្រៀនពីការប្រែចិត្ត ស្តាបនាសេចក្តីសុខសាន្ត ព្រះអម្ចាស់នៃសេចក្តីសុខសាន្ត សោយរាជ្យក្រោមព្រះបិតារបស់ទ្រង់* ។សូមសម្រាកក្រោយពីការសរសេរពាក្យ ឬ ឃ្លានីមួយៗដើម្បីឲ្យសិស្សទស្សន៍ទាយ ដោយមិនមើលក្នុងព្រះគម្ពីររបស់ពួកគេ រកមើលអ្នកដែលអាលម៉ាបានពិពណ៌នាដោយពាក្យ និង

ឃ្លាទាំងនេះ ។ (គាត់បានពិពណ៌នាពីមីលគីស្សាដែក) ។ ប្រសិនបើសិស្សទាយមិនត្រូវ នៅពេលអ្នកបានសរសេរនូវពាក្យ និងឃ្លាទាំងអស់នេះនៅលើក្តារខៀនហើយ សូមឲ្យពួកគេអាន អាលម៉ា ១៣:១៤ ។

ប្រសិនបើសិស្សខ្លះទាយថា អាលម៉ាបានកំពុងនិយាយអំពីព្រះយេស៊ូវគ្រីស្ទ សូមសួរគេថា ហេតុអ្វីបានជាការពិពណ៌នាពីសង្ឃជាន់ខ្ពស់ដ៏សុចរិតម្នាក់អាចរំឭកពួកគេអំពីព្រះអង្គសង្គ្រោះ ។ សូមជួយពួកគេឲ្យយល់ថា អ្នកកាន់អំណាចបព្វជិតភាពមីលគីស្សាដែកគឺ “ តទៅតាមរបៀបនៃព្រះរាជបុត្រា ដែលជាព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា (”អាលម៉ា ១៣:៩; សូមមើលផងដែរគ. និង ស. ១០៧:២–៤) ។ សូមបង្ហាញថា អ្នកកាន់អំណាចបព្វជិតភាពមីលគីស្សាដែកគួរព្យាយាមធ្វើតាមគំរូរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងការបម្រើរបស់ពួកគេ និង ការបង្រៀនរបស់ពួកគេ ។ សូមរំឭកសិស្សផងដែរថា ពិធីការដែលធ្វើឡើងដោយសិទ្ធិអំណាចបព្វជិតភាពមីលគីស្សាដែកជួយយើងឲ្យខិតទៅជិតព្រះអង្គសង្គ្រោះកាន់តែខ្លាំង ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ១៣:១៤–១៩ ឮៗ ។ សូមលើកទឹកចិត្តសិស្សក្នុងថ្នាក់ឲ្យគិតអំពីរបៀបដែលប្រជាជនទុច្ចរិតនៃដែនដីអាំម៉ូណៃហាអាចទទួលបានប្រយោជន៍ពីការរៀនអំពីមីលគីស្សាដែក ។

- នៅក្នុងអាលម៉ា ១៣:១៧ តើពាក្យណាដែលរៀបរាប់ពីប្រជាជនរបស់មីលគីស្សាដែក ? តើប្រជាជនទាំងនេះស្រដៀងគ្នាទៅនឹងប្រជាជនអាំម៉ូណៃហាដោយរបៀបណា ? (សូមមើល អាលម៉ា ៨:៩; ៩:៨) ។
- តើមីលគីស្សាដែកបានធ្វើអ្វីខ្លះ ក្នុងនាមជាអ្នកដឹកនាំប្រជាជនរបស់គាត់ ? តើការដឹកនាំរបស់គាត់ជះឥទ្ធិពលដល់ប្រជាជនដោយរបៀបណា ? តើឥទ្ធិពលនេះខុសពីឥទ្ធិពលនៅក្នុងដែនដីអាំម៉ូណៃហាដែលធ្វើតាមការបង្រៀនរបស់នីហ្វរដោយរបៀបណា ? (សូមមើលអាលម៉ា ៨:១៧; ១០:២៧, ៣២) ។

សូមអញ្ជើញឲ្យសិស្សសង្ខេប អាលម៉ា ១៣:១៦–១៨ ដោយបង្ហាញពីសេចក្តីពិតដែលខគម្ពីរទាំងនេះបង្រៀនអំពីការទទួលខុសត្រូវរបស់អ្នកដឹកនាំបព្វជិតភាព ។ នៅពេលពួកគេសង្ខេប សូមប្រាកដថាពួកគេបង្ហាញថា **អ្នកដឹកនាំបព្វជិតភាពជួយយើងឲ្យពឹងទៅលើព្រះយេស៊ូវគ្រីស្ទ ឲ្យប្រែចិត្ត និង រស់នៅដោយសេចក្តីសុខសាន្ត ។**(អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរការសង្ខេបរបស់ពួកគេនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ១៣:១៦–១៨) ។ សូមបង្ហាញថា អ្នកដឹកនាំសាសនាចក្រផ្សេងទៀត ដូចជាអ្នកដឹកនាំសមាគមសង្គ្រោះស្ត្រី និង អ្នកដឹកនាំយុវនារី គឺជាអ្នកចូលរួមដ៏សំខាន់នៅក្នុងការខំប្រឹងប្រែងនេះ ។ ដោយការបម្រើជាមួយនឹងអ្នកដឹកនាំបព្វជិតភាព ពួកគេជួយដឹកនាំបុគ្គល និង គ្រួសារទាំងឡាយឲ្យមករកព្រះគ្រីស្ទ ។

- តើអ្នកត្រូវបានប្រទានពរ តាមរយៈការបម្រើនៃអ្នកដឹកនាំសាសនាចក្រដោយរបៀបណា ?

អាលម៉ា ១៣:២១–៣១

អាលម៉ាអញ្ជើញប្រជាជនឲ្យស្តាប់តាមសំឡេងរបស់ព្រះអម្ចាស់ ហើយចូលទៅក្នុងទីសម្រាករបស់ទ្រង់

សូមអញ្ជើញឲ្យសិស្សរកមើលគំនិតមួយដែលលើកឡើងដដែលៗនៅក្នុង អាលម៉ា ១៣:១២, ១៣, ១៦, ២៩ ។ ពួកគេគួររក៣ពាក្យ *សេចក្តីសម្រាក* និង ឃ្លា “ សេចក្តីសម្រាកនៃព្រះអម្ចាស់ ” ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសគំនិតនេះនៅក្នុងខគម្ពីរនីមួយៗ ។ ដើម្បីជួយសិស្សឲ្យយល់ពីអ្វីដែលវាមានន័យ ក្នុងការចូលទៅក្នុងសេចក្តីសម្រាករបស់ព្រះអម្ចាស់នៅក្នុងជីវិតនេះ និងក្រោយពីយើងស្លាប់ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោម ៖

“ ព្យាការីពីបុរាណនិយាយពី ‹ ការចូលទៅក្នុងសេចក្តីសម្រាករបស់ព្រះ ›| សូមមើលអាលម៉ា ១២:៣៤; គ . & ស . ៨៤:២៣–២៤ | ; តើវាមានន័យយ៉ាងណា ? ចំពោះគំនិតរបស់ខ្ញុំ វាមានន័យថា ការចូលទៅក្នុងចំណេះដឹង និង សេចក្តីស្រឡាញ់របស់ព្រះ ការមានសេចក្តីជំនឿទៅលើគោលបំណង និងផែនការរបស់ទ្រង់ ចំពោះកម្រិតដែលយើងដឹងថាយើងត្រូវ ហើយថាយើងមិនមែនកំពុងស្វែងរកអ្វីផ្សេងទៀតនោះទេ ” (យ៉ូសែប អេហ្វ ស្ម៊ីធ, *Teachings of Presidents of the Church: Joseph F. Smith* | ឆ្នាំ ១៩៩៨ |, ទំព័រ ៥៦) ។

“ ពួកបរិសុទ្ធពិតប្រាកដចូលទៅក្នុង *សេចក្តីសម្រាកនៃព្រះអម្ចាស់* ខណៈពេលជីវិតនេះ និង ដោយការគោរពតាមសេចក្តីពិត នោះពួកគេបន្តនៅក្នុងសភាពមានពរជ័យនោះ រហូតដល់ពួកគេសម្រាកជាមួយនឹងព្រះអម្ចាស់នៅក្នុងស្ថានសួគ៌ ។ . . . សេចក្តីសម្រាកនៃព្រះអម្ចាស់ នៅក្នុងភាពអស់កល្បជានិច្ច គឺដើម្បីមានជីវិតដ៏នៅអស់កល្បជានិច្ច ដើម្បីទទួលបានភាពពេញលេញនៃសិរីល្អរបស់ព្រះអម្ចាស់ ” (ប្រ៊ូស អ័រ ម៉ាក់ខនឃី, *Mormon Doctrine,* ២nd ed. | ឆ្នាំ ១៩៦៦ |, ទំព័រ ៦៣៣) ។

សូមពន្យល់ថា អាលម៉ាបានដាស់តឿនប្រជាជនអាំម៉ូណៃហាឲ្យប្រែចិត្ត និង រៀបចំសម្រាប់ការយាងមកនៃព្រះគ្រីស្ទ (សូមមើលអាលម៉ា ១៣:២១–២៦) ។ បន្ទាប់មក គាត់បានចែកចាយនូវគោលការណ៍ទាំងឡាយដែលពួកគេត្រូវធ្វើតាមដើម្បីចូលទៅក្នុងសេចក្តីសម្រាករបស់ព្រះអម្ចាស់ ។

សូមឲ្យសិស្សអាន អាលម៉ា ១៣:២៧ ស្ងាត់ៗ ។

- តើពាក្យនៅក្នុង អាលម៉ា ១៣:២៧ បង្ហាញពីរបៀបដែលអាលម៉ាបានមានអារម្មណ៍យ៉ាងណាអំពីប្រជាជន និង អំពីសារលិខិតរបស់គាត់ ?

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ១៣:២៧–២៩ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលគោលការណ៍ដែលអាលម៉ាសង្ឃឹមថា ប្រជាជននឹងធ្វើតាម ។ បន្ទាប់មក សូមឲ្យសិស្សសរសេរគោលការណ៍ទាំងនោះដែលពួកគេបានរកឃើញ ។ ជាឧទាហរណ៍ ពួកគេអាចនិយាយថា **នៅពេលយើងឆ្លើយតបដោយបន្ទាបខ្លួនទៅនឹងការអញ្ជើញឲ្យកែប្រែចិត្ត នោះព្រះវិញ្ញាណនឹងដឹកនាំយើងទៅក្នុងសេចក្តីសម្រាកនៃព្រះអម្ចាស់ ។**

សូមអញ្ជើញឲ្យសិស្សសរសេរគោលការណ៍ដែលទាក់ទងនឹងរបៀបដែលពួកគេនឹងធ្វើតាមការប្រឹក្សានៅក្នុង អាលម៉ា ១៣:២៧–២៩ ។ សូមថ្លែងទីបន្ទាល់ថា យើងអាចចូលទៅក្នុងសេចក្តីសម្រាកនៃព្រះអម្ចាស់នៅក្នុងជីវិតនេះ និង នៅក្នុងជីវិតខាងមុខ នៅពេលយើងធ្វើតាមគោលការណ៍ទាំងឡាយដែលអាលម៉ាបានបង្រៀន ។

អាលម៉ា ១៤

សេចក្តីផ្តើម

ក្រោយពីឮអាលម៉ា និងអាម៉ូលេកបង្រៀនហើយ ប្រជាជនអាំម៉ូណៃហាខ្លះបានជឿ ហើយបានប្រែចិត្ត ។ ប្រជាជនភាគច្រើនបានខឹង ហើយបានព្យាយាមសម្លាប់អាលម៉ា អាម៉ូលេក និងអ្នកដែលជឿលើពាក្យសម្តីរបស់ពួកគេ ។ អាលម៉ា និង អាម៉ូលេកត្រូវបានចាប់ខ្លួន សាកសួរ ហើយនៅទីបញ្ចប់ត្រូវបានគេដាក់គុក ។ ប្រជាជនដ៏ទុច្ចរិតនៅក្នុងដែនដី អាំម៉ូណៃហាបានបណ្តេញអ្នកដែលបានជឿ ហើយបានដុតប្រពន្ធ កូនចៅ និង ព្រះគម្ពីររបស់ពួកគេ ខណៈពេលដែលអាលម៉ា និង អាម៉ូលេកត្រូវបានគេចាប់បង្ខំឲ្យមើលនូវស្ថានភាពនោះ ។ ជាច្រើនថ្ងៃក្រោយមក ព្រះអម្ចាស់បានដោះលែងអាលម៉ា និងអាម៉ូលេកពីគុក ហើយបានបំផ្លាញអ្នកដឹកនាំទុច្ចរិតនៃដែនដីអាម៉ូណៃហា ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ១៤:១–១៣

អាលម៉ា និងអាម៉ូលេកត្រូវបានគេដាក់គុក ហើយប្រជាជនអាំម៉ូណៃហាដែលបានជឿត្រូវបានបណ្តេញចេញ ឬ ដុត

សូមអញ្ជើញឲ្យសិស្សគិតអំពីឧបសគ្គដែលពួកគេបានជួប ឬ កំពុងប្រឈមមុខនាពេលនេះ ។ បន្ទាប់មក សូមអញ្ជើញឲ្យសិស្សម្នាក់អានប្រយោគខាងក្រោមឮៗ ។

“ ឧបសគ្គចេញមកពីប្រភពខុសគ្នា ។ ពេលខ្លះអ្នកអាចជួបនឹងឧបសគ្គដែលជាលទ្ធផលនៃអំនួត និង ការមិនគោរពផ្តាច់ខ្លួនរបស់អ្នក ។ ឧបសគ្គទាំងនេះអាចចៀសវាងបានតាមរយៈការរស់នៅដោយសុចរិត ។ ឧបសគ្គផ្សេងទៀតជាធម្មតាគឺជាផ្នែកនៃជីវិតធម្មជាតិ ហើយពេលខ្លះអាចមកនៅពេលអ្នកកំពុងរស់នៅដោយសុចរិត ។ ឧទាហរណ៍ អ្នកអាចជួបនឹងឧបសគ្គពេលឈឺ ឬ ភាពមិនប្រាកដ ឬ ការស្លាប់នៃមនុស្សជាទីស្រឡាញ់ ។ ពេលខ្លះឧបសគ្គអាចមកដោយសារតែជម្រើសដ៏ខ្សត់របស់អ្នកដទៃ និង សម្ពីនិងសកម្មភាពដែលធ្វើឲ្យរងទុក្ខ ។

“ ជោគជ័យ និងសុភមង្គលរបស់អ្នក ទាំងពេលឥឡូវនេះ និងពេលដ៏អស់កល្បជានិច្ច ពឹងជាខ្លាំងទៅលើចម្លើយរបស់អ្នកចំពោះការលំបាកនៃជីវិតនោះ ” (*True to the Faith: A Gospel Reference* [២០០៤], ៨–៩) ។

សូមពន្យល់ថា នៅក្នុងមេរៀនថ្ងៃនេះ សិស្សនឹងពិភាក្សាអំពីដំណើររឿងនៃប្រជាជនដែលជួបនឹងឧបសគ្គដ៏ធ្ងន់ធ្ងរ ។ ឧបសគ្គទាំងនេះភាគច្រើនត្រូវបានរងទុក្ខដោយសារអ្នកដទៃ ។ សូមលើកទឹកចិត្តសិស្សឲ្យគិតពីរបៀបដែលសេចក្តីពិត ដែលពួកគេនឹងពិភាក្សានៅក្នុងមេរៀននេះ ទាក់ទងដល់ពួកគេ មិនថាឧបសគ្គអ្វីដែលពួកគេអាចនឹងជួបនោះទេ ។

សូមសរសេរពាក្យខាងក្រោមនៅលើក្តារខៀន ៖

សូមអញ្ជើញឲ្យសិស្សបីឬបួននាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ១៤:១–១០ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលឧទាហរណ៍ពីការរងទុក្ខដែលប្រជាជនបានជួបដូចបានសរសេរនៅលើក្តារខៀន ។

អាលម៉ា និង អាម៉ូលេក *សីរ៉ៃអែសរ៉ុម* *បុរសដែលប្រែចិត្តជឿ* *ស្ត្រី និង កូនក្មេងដែលប្រែចិត្តជឿ*

- **តើប្រជាជនទាំងនេះបានរងទុក្ខអ្វីខ្លះ ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន) ។**

សូមបង្ហាញថា នៅពេលអាម៉ូលេកបានឃើញស្ត្រី និងកូនក្មេងរងទុក្ខ គាត់បានចង់អនុវត្តអំណាចនៃបព្វជិតភាពដើម្បីជួយដល់ពួកគេ ។ សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ១៤:១១ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលចម្លើយរបស់អាលម៉ាទៅនឹងការស្នើសុំរបស់អាម៉ូលេក ។

- **ហេតុអ្វីបានជាព្រះអម្ចាស់អនុញ្ញាតឲ្យស្ត្រី និងកូនក្មេងទាំងនេះត្រូវបានគេដុត ? (អ្នកអាចត្រូវពន្យល់ថា នៅក្នុងខគម្ពីរនេះឃ្លា “ ទ្រង់ទ្រាំ ” មានន័យថា “ ទ្រង់អនុញ្ញាតិឲ្យ ” ។ ព្រះអម្ចាស់បានអនុញ្ញាតឲ្យប្រជាជនរងទុក្ខដើម្បីឲ្យការស្លាប់របស់ពួកគេអាចឈរជាសាក្សីទាស់នឹងអ្នកដែលបានសម្លាប់ពួកគេ ។ សូមមើលផងដែរ អាលម៉ា ៦០:១៣) ។**
- **យោងតាមអាលម៉ា តើស្ត្រី និងកូនក្មេងទាំងឡាយអាចត្រូវបានប្រទានពរចំពោះការទុកចិត្តរបស់ពួកគេទៅលើព្រះអម្ចាស់ដោយរបៀបណា ?**

អ្នកអាចត្រូវបញ្ជាក់ថា នៅក្នុងគំរូដ៏ជាក់លាក់នេះ វាជាឆន្ទៈរបស់ព្រះអម្ចាស់ដើម្បីឲ្យប្រជាជនរងទុក្ខ ។ ទោះជាយ៉ាងណាក្តី នេះមិនមែនជាករណីទូទៅជានិច្ចនោះទេ ។ សូមបញ្ជាក់ជាមួយសិស្សថា ព្រះអម្ចាស់ស្រឡាញ់ពួកគេ ហើយចង់ឲ្យពួកគេរីករាយ ហើយមានសេចក្តីសុខសាន្តនៅក្នុងជីវិតរបស់ពួកគេ ។ ប្រសិនបើពួកគេត្រូវឈឺចាប់ ឬ គេធ្វើតាមរបៀបណា ពួកគេគួរស្វែងរកជំនួយពីឪពុកម្តាយ ឬ អ្នកដឹកនាំសាសនាចក្រដើម្បីឲ្យពួកគាត់អាចជួយដោះស្រាយបញ្ហានោះ ។

- **តើមូលហេតុផ្សេងទៀតណាខ្លះដែលព្រះអម្ចាស់អាចឲ្យយើងរងទុក្ខ ? (ចម្លើយអាចរួមមាន ទ្រង់ចង់ឲ្យយើងយល់ពីលទ្ធផលនៃការសម្រេចចិត្តដ៏មិនឆ្លាតវៃ ថាទ្រង់ចង់ឲ្យយើងអភិវឌ្ឍការអត់ធ្មត់ ថាទ្រង់ចង់ឲ្យយើងបង្កើនសេចក្តីមេត្តាករុណាសម្រាប់អ្នកដទៃដែលរងទុក្ខ ហើយថាទ្រង់ចង់ឲ្យយើងយល់ថា យើងត្រូវពឹងផ្អែកលើទ្រង់) ។**

សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***នៅពេលយើងទុកចិត្តទៅលើព្រះអម្ចាស់ ទ្រង់នឹងពង្រឹងយើងពេលយើងមានឧបសគ្គ*** ។បន្ទាប់មក សូមឲ្យសិស្សម្នាក់អាន អាលម៉ា ១៤:១២–១៣ ឮៗ ។

- តើពាក្យសម្តីរបស់អាលម៉ាបានបង្ហាញពីការទុកចិត្តរបស់គាត់ទៅលើព្រះអម្ចាស់ដោយរបៀបណា ?

អ្នកអាចសុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយ អែលឌើរ រីឆាដ ជី ស្កុត នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ៖

" គំរូរបស់អាលម៉ា និងអាម៉ូលេកជួយយ៉ាងច្រើន ។ ខណៈពេលខំតស៊ូធ្វើល្អក្នុងចំណោមប្រជាជនអាំម៉ូណៃហា ពួកគេត្រូវបានគេចាប់ ។ អាម៉ូលេកបានទុកចិត្តដៃគូដ៏ពិសេសរបស់គាត់គឺ អាលម៉ា ដែលបានដឹកនាំគាត់ឲ្យមានទំនុកចិត្តលើព្រះអម្ចាស់ជាខ្លាំង ។ ដោយត្រូវបានបង្ខំឲ្យមើលស្ត្រី និងកូនក្មេងត្រូវដុតដោយភ្លើង អាម៉ូលេកបាននិយាយថា ‹ ប្រហែលជាគេនឹងដុតយើងដែរ › ។ អាលម៉ាបានឆ្លើយថា ៖ ‹ *ចូរទុកឲ្យការណ៍នេះកើតឡើងស្របតាមព្រះហឫទ័យនៃព្រះអម្ចាស់ចុះ* › —គោលការណ៍ដ៏សំខាន់ ។ ‹ ប៉ុន្តែ . . . កិច្ចការរបស់យើងមិនទានចប់នៅឡើយទេ ហេតុនេះហើយគេពុំដុតយើងទេ › (អាលម៉ា ១៤:១២–១៣; សេចក្តីបញ្ជាក់បន្ថែម) " ("To Be Healed," *Ensign*,ខែ ឧសភា ឆ្នាំ ១៩៩៤, ទំព័រ ៨) ។

" ជីវិតនេះគឺជាបទពិសោធន៍មួយនៅក្នុងការទុកចិត្តដ៏ខ្លាំង —ការទុកចិត្តទៅលើព្រះយេស៊ូវគ្រីស្ទ ។ . . . ទុកចិត្តមានន័យថា គោរពដោយឆន្ទៈដោយមិនដឹងពីទីបញ្ចប់នៃការចាប់ផ្តើមនោះទេ (សូមមើល វិវរណៈ ៣:៥–៧) ។ ដើម្បីជំនះជល់ផ្លែ ការទុកចិត្តរបស់អ្នកទៅលើព្រះអម្ចាស់ត្រូវតែមានអំណាចជាង ហើយតស៊ូជាងទំនុកចិត្តរបស់អ្នកទៅលើអារម្មណ៍ និងបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នក " (" Trust in the Lord," *Ensign*,ខែ វិច្ឆិកា ឆ្នាំ ១៩៩៥, ទំព័រ ១៧) ។

សូមពន្យល់ថានៅក្នុង អាលម៉ា ១៤:១៤–២៩ សិស្សនឹងមើលឃើញគំរូជាច្រើនរបស់អាលម៉ា និង អាម៉ូលេកក្នុងការទុកចិត្តទៅលើព្រះអម្ចាស់ ។ ពួកគេក៏នឹងឃើញពីរបៀបដែលព្រះអម្ចាស់នឹងពង្រឹងដល់ពួកគេដើម្បីឲ្យពួកគេអាចធ្វើកិច្ចការរបស់ទ្រង់ ។

អាលម៉ា ១៤:១៤–២៩

ព្រះបានដោះលែងអាលម៉ា និងអាម៉ូលេកពីគុក ហើយបានបំផ្លាញអ្នកដឹកនាំទុច្ចរិតជាច្រើននៃដែនដីអាំម៉ូណៃហា

សូមបែងចែកសិស្សជាពីរក្រុម ។ សូមឲ្យក្រុមទីមួយសិក្សា អាលម៉ា ១៤:១៤–១៩ ខណៈពេលដែលក្រុមទីពីរសិក្សា អាលម៉ា ១៤:២០–២៥ ។ សូមឲ្យក្រុមទាំងពីរកត់ចំណាំអ្វីដែលអាលម៉ា និង អាម៉ូលេកបានរងទុក្ខពេលនៅក្នុងដៃអ្នកដឹកនាំទុច្ចរិតនៃដែនដីអាំម៉ូណៃហា ។ នៅពេលសិស្សបានមានពេលអានគ្រប់គ្រាន់ហើយ សូមឲ្យពួកគេចែកចាយអ្វីដែលពួកគេបានរកឃើញ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀនក្រោម " អាលម៉ា និង អាម៉ូលេក " ។

- តើឧបសគ្គមួយណាខ្លះដែលពិបាកបំផុតសម្រាប់អ្នក ? ហេតុអ្វី ?
- តើនៅពេលណាដែលអ្នកបានឃើញប្រជាជនរងទុក្ខនឹងឧបសគ្គ ទោះបីជាពួកគេតស៊ូដើម្បីក្លាយជាអ្នកសុចរិតក្តី ?

សូមអញ្ជើញឲ្យសិស្សប្តូរវេនអានឮៗពី អាលម៉ា ១៤:២៥–២៩ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលលអ្វីដែលព្រះអម្ចាស់បានធ្វើដើម្បីដោះលែងអាលម៉ា និង អាម៉ូលេកពីគុក ។ ដើម្បីជួយសិស្សឲ្យរកឃើញ និងយល់ពីគោលការណ៍ទាំងឡាយនៅក្នុងខគម្ពីរនេះ សូមសួរពួកគេខ្លះ ឬ ពួកគេទាំងអស់គ្នានូវសំណួរដូចតទៅនេះ ៖

- ហេតុអ្វីបានជាអាលម៉ា និង អាម៉ូលេករកទទួលបានអំណាច និងកម្លាំងពីព្រះអម្ចាស់ ? (សូមមើលអាលម៉ា ១៤:២៦, ២៨) ។
- តើគោលការណ៍អ្វីដែលយើងអាចរៀនពីគំរូនៅក្នុងគុករបស់អាលម៉ា និង អាម៉ូលេក ? (ចម្លើយរបស់សិស្សអាចខុសគ្នា ប៉ុន្តែពួកគេគួរបង្ហាញពីសេចក្តីពិតថា **ប្រសិនបើយើងធ្វើតាមព្រះអម្ចាស់ដោយសេចក្តីជំនឿ ទ្រង់នឹងពង្រឹងយើងនៅក្នុងសេចក្តីទុក្ខវេទនារបស់យើង ហើយដោះលែងយើងតាមរបៀបរបស់ទ្រង់ និង តាមពេលវេលាផ្ទាល់របស់ទ្រង់** ។អ្នកអាចស្នើថា សិស្សគួរគូសចំណាំឃ្លានៅក្នុង អាលម៉ា ១៤:២៦, ២៨ ដែលបញ្ជាក់ពីគោលការណ៍នេះ) ។
- តើរបៀបណាខ្លះដែលប្រជាជនអាចអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទអំឡុងពេលពិបាកនោះ ?

សូមអញ្ជើញឲ្យសិស្សចែកចាយបទពិសោធន៍ដែលពួកគេបានមាន នៅពេលពួកគេបានធ្វើជាសាក្សីនូវកម្លាំងដែលអាចកើតមានក្នុងជីវិតរបស់យើង នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយរង់ចាំដល់ទ្រង់ដោយបន្ទាបខ្លួន ។ ពួកគេអាចចែកចាយបទពិសោធន៍ ផ្ទាល់ខ្លួនរបស់ពួកគេ ឬ បទពិសោធន៍ពីជីវិតមនុស្សដែលពួកគេស្គាល់ ។ អ្នកក៏អាចចែកចាយបទពិសោធន៍មួយពីជីវិតរបស់អ្នក ឬ ជីវិតរបស់នរណាម្នាក់ដែលលអ្នកស្គាល់ ។

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់ពីអំណាចរបស់ព្រះអម្ចាស់ដើម្បីផ្តល់កម្លាំងដល់យើង ហើយដោះលែងយើងពីឧបសគ្គទាំងឡាយនៅក្នុងរបៀប និង ពេលវេលាផ្ទាល់របស់ទ្រង់ ។ សូមធានាសិស្សថា នៅពេលយើងទុកចិត្តទៅលើឆន្ទៈរបស់ព្រះអម្ចាស់ ទ្រង់នឹងបង្កើនកម្លាំង និងអំណាចរបស់យើងឲ្យតស៊ូនឹងការលំបាកទាំងឡាយ ។

បទពិសោធន៍ផ្ទាល់ខ្លួន

សិស្សនឹងទទួលបានប្រយោជន៍ពីការស្តាប់តាមបទពិសោធន៍ផ្ទាល់ខ្លួនពីគ្នាទៅវិញទៅមក ។ សូមលើកទឹកចិត្តពួកគេឲ្យចែកចាយបទពិសោធន៍តាមរបៀបមួយដែលនឹងអញ្ជើញឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ហើយដែលនឹងដឹកនាំពួកគេឲ្យធ្វើតាមព្រះអង្គសង្គ្រោះ ។ សូមព្រមានពួកគេកុំឲ្យចែកចាយបទពិសោធន៍ដែលផ្ទាល់ខ្លួន ឬ ឯកជនពេកដែលអាចនាំឲ្យពិបាក ឬ រងការអាម៉ាស់ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អាលម៉ា ១៤:៧–១១ ។ “ ព្រះអម្ចាស់ទ្រង់ទទួលយកពួកគេឡើងទៅឯទ្រង់ ”

ទោះបីជាយើងសោកស្តាយនឹងការស្លាប់នៃពួកសុចរិត ក៏យើងរីករាយនឹងការដឹងពីរង្វាន់របស់ពួកគេនៅលើពិភពវិញ្ញាណដែរ (សូមមើល អាលម៉ា ៤០:១២) និងស្ថានភាពចុងបំផុតរបស់ពួកគេនៅក្នុងនគរសេឡេស្ទាល (សូមមើល គ . & ស . ៧៦:៥០–៧០) ។ ព្រះអម្ចាស់បានមានបន្ទូលថា “ អស់អ្នកណាដែលស្លាប់ក្នុងយើង នោះនឹងមិនត្រូវភ្លក់សេចក្តីស្លាប់ឡើយ ត្បិតសេចក្តីស្លាប់នឹងបានទៅជាសេចក្តីផ្អែមល្ហែមដល់ពួកគេវិញ ” (គ . & ស . ៤២:៤៦) ។ ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ បានពន្យល់ថា ៖

“ វាពិតថា ខ្ញុំខ្សោយដៃលនឹងត្រូវយំនៅពេលមិត្ត និង សាច់ញាតិរបស់ខ្ញុំស្លាប់ ។ ខ្ញុំអាចយំ នៅពេលខ្ញុំឃើញអ្នកដទៃរងទុក្ខ ។ ខ្ញុំមានសេចក្តីមេត្តានៅក្នុងព្រលឹងខ្ញុំសម្រាប់កូនចៅមនុស្ស ។ ខ្ញុំអាចយំជាមួយនឹងពួកគេនៅពេលពួកគេយំ ខ្ញុំអាចរីករាយនឹងពួកគេនៅពេលពួកគេរីករាយ ប៉ុន្តែខ្ញុំមិនមានអ្វីត្រូវទួញយំ ហើយក៏គ្មានអ្វីត្រូវក្រៀមក្រំដោយសារការស្លាប់មកក្នុងពិភពលោកនេះឡើយ ។ . . . សេចក្តីភ័យខ្លាចទាំងអស់នៃការស្លាប់នេះត្រូវបានលុបចេញពីពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ពួកគេគ្មានការភ័យខ្លាចនឹងការស្លាប់ខាងសាច់ឈាមឡើយ ដោយសារពួកគេដឹងថា នៅពេលសេចក្តីស្លាប់មកដល់ពួកគេដោយការរំលងរបស់អ័ដាម ដូច្នេះដោយសេចក្តីសុចរិតរបស់ព្រះយេស៊ូវគ្រីស្ទនោះជីវិតនឹងមកកាន់ពួកគេវិញ ហើយទោះបីជាពួកគេស្លាប់ ក៏ពួកគេនឹងរស់ឡើងវិញម្តងទៀតដែរ ។ ដោយទទួលបានចំណេះដឹងនេះ ពួកគេមានសេចក្តីអំណរទោះបីជាក្នុងសេចក្តីស្លាប់ក្តី ដោយសារពួកគេដឹងថាពួកគេនឹងរស់ឡើងវិញម្តងទៀត ហើយនឹងជួបគ្នាទៀតបន្ទាប់ពីផ្នូរនេះ ” (នៅក្នុងរបាយការណ៍សន្និសីទ ខែ តុលា ឆ្នាំ ១៨៩៩, ទំព័រ ៧០) ។

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់យីនៃក្រុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖

“ ពេលខ្លះប្រជាជនរបស់ព្រះអម្ចាស់ត្រូវបានគេតាមចាប់ និង តាមសម្លាប់ ។ ពេលខ្លះទ្រង់ឲ្យពួកបរិសុទ្ធដ៏ស្មោះត្រង់របស់ទ្រង់នៅទ្រាំ និង រងទុក្ខដោយចេតនា ទាំងខាងសាច់ឈាម និងខាងវិញ្ញាណ ដើម្បីបញ្ជាក់ពួកគេគ្រប់ការណ៍ទាំងអស់ ហើយដើម្បីឃើញថាពួកគេនឹងគោរពតាមសេចក្តីសញ្ញារបស់ទ្រង់ ទោះបីជាដល់ស្លាប់ក្តី ថាពួកគេអាចត្រូវបានឃើញថាសាកសមនឹងជីវិតដ៏នៅអស់កល្បជានិច្ច ។ ប្រសិនបើការណ៍នោះកើតដល់ពួកយើងច្រើន សូមឲ្យការណ៍នោះកើតឡើងចុះ ” (“The Dead Who Die in the Lord,” *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៧៦, ទំព័រ ១០៨) ។

អាលម៉ា ១៥–១៦

សេចក្តីផ្តើម

ក្រោយពីព្រះអម្ចាស់បានដោះលែងអាលម៉ា និង អាម៉ូលេកពីគុកហើយ ពួកគេបានទៅបង្រៀនប្រជាជននៅក្នុងទីក្រុងសីដូម ។ នៅទីនោះពួកគេឃើញថា អ្នកជឿដែលបានត្រូវគេបណ្តេញចេញពីដែនដីអាំម៉ូណៃហា រួមមានសីអែសរ៉ុម ដែលបានរងទុក្ខខាងរាងកាយ និង ខាងវិញ្ញាណដោយសារតែអំពើបាបរបស់គាត់ ។ នៅពេលសីអែសរ៉ុមបានប្រកាសពីសេចក្តីជំនឿរបស់គាត់ទៅលើព្រះយេស៊ូវគ្រីស្ទ អាលម៉ាបានព្យាបាលគាត់ ហើយបានជ្រមុជទឹកឲ្យគាត់ ។ អាលម៉ាបានស្ថាបនាសាសនាចក្រនៅក្នុងទីក្រុងសីដូម ហើយបន្ទាប់មកគាត់បានត្រឡប់ទៅដែនដីសារ៉ាហិមឡាវិញជាមួយនឹងអាម៉ូលេក ។ ក្នុងការបំពេញតាមការព្យាករណ៍របស់អាលម៉ា សាសន៍លេមិនបានបំផ្លាញទីក្រុងអាំម៉ូណៃហានៅថ្ងៃមួយ ។ លើសពីនេះ សាសន៍លេមិនបានចាប់យកសាសន៍នីហ្វៃខ្លះពីដែនដីជុំវិញនោះ ។ ដោយការជ្រើសរើសធ្វើតាមការដឹកនាំនៃការព្យាករណ៍របស់អាលម៉ា កងទ័ពសាសន៍នីហ្វៃបានដោះលែងអ្នកទោស ហើយបានបណ្តេញពួកសាសន៍លេមិនចេញពីដែនដី ។ អំឡុងពេលសន្តិភាព អាលម៉ា អាម៉ូលេក និងអ្នកជំទែជាច្រើនទៀតបានពង្រឹងសាសនាចក្រទូទាំងដែនដីនីហ្វៃ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ១៥

អាលម៉ាព្យាបាលសីអែសរ៉ុម បង្កើតសាសនាចក្រនៅក្នុងទីក្រុងសីដូម ហើយត្រឡប់ទៅជាមួយនឹងអាម៉ូលេកទៅកាន់ដែនដីសារ៉ាហិមឡាវិញ

ដើម្បីជួយសិស្សឲ្យចងចាំពីមនុស្ស និង ហេតុការណ៍សំខាន់ទាំងឡាយដែលមាននៅក្នុង អាលម៉ា ១១–១៤ សូមសរសេរពាក្យខាងក្រោមនៅលើក្តារខៀន ៖

សីអែសរ៉ុម

អ៊ុនទី

ភ្លើង

អាលម៉ា

អាម៉ូលេក

អាំម៉ូណៃហា

សូមឲ្យសិស្សមានពេលមួយនាទីដើម្បីព្យាយាមប្រើឈ្មោះទាំងអស់ និង ពាក្យនៅលើក្តារខៀនសង្ខេបពីហេតុការណ៍ដែលមាននៅក្នុង អាលម៉ា ១១–១៤ ។ (អ្នកអាចស្នើថា ពួកគេគួរបើកទៅសេចក្តីសង្ខេបជំពូកសម្រាប់ជំនួយ) ។ ក្រោយពីសិស្សពីរបីនាក់បានឆ្លើយហើយ សូមលុបពាក្យទាំងអស់ចេញ លើកលែងពាក្យ *សីអែសរ៉ុម* ។

សូមពន្យល់ថា ក្រោយពីការចាកចេញពីដែនដីអាំម៉ូណៃហា អាលម៉ា និងអាម៉ូលេកបានមកទីក្រុងសីដូម ដែលពួកគេបានរកឃើញអ្នកជឿដែលត្រូវបានបណ្តេញចេញពីដែនដីអាំម៉ូណៃហា រួមមានសីអែសរ៉ុមដែរ ។ សូមអញ្ជើញឲ្យសិស្សអាន អាលម៉ា ១៥:៣–៥ ដោយស្ងាត់ៗ ដោយរកមើលពាក្យ និងឃ្លាដែលពិពណ៌នាពីស្ថានភាពរបស់សីអែសរ៉ុម ។ នៅពេលសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀននៅក្រោមឈ្មោះរបស់សីអែសរ៉ុម ។

- **ហេតុអ្វីបានជាអ្នកគិតថាកំហុសរបស់សីអែសរ៉ុមបានដឹកនាំគាត់ឲ្យរងទុក្ខទាំងខាងវិញ្ញាណ និងខាងសាច់ឈាម ? តើមនុស្សនៅក្នុងស្ថានភាពនេះត្រូវធ្វើអ្វីខ្លះដើម្បីផ្លាស់ប្តូរស្ថានភាពរបស់ពួកគេ ?**
- **តើសីអែសរ៉ុមបានស្វែងរកជំនួយពីអ្នកណា ? (សូមមើល អាលម៉ា ១៥:៤) ។ តើអ្នកគិតថា ហេតុអ្វីបានជាគាត់បានរកអាលម៉ា និងអាម៉ូលេក ? (ចម្លើយអាចរួមមាន គាត់បានទុកចិត្តពួកគេ ហើយថាគាត់បានដឹងថា ពួកគេគឺជាបុរសនៃព្រះ ហើយមានសិទ្ធិអំណាចបព្វជិតភាព) ។**

សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ១៥:៦–១០ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពាក្យដែលអាលម៉ាបាននិយាយដើម្បីជួយសីអែសរ៉ុមអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធួនរបស់ទ្រង់ ។

- **តើអ្នកគិតថា ហេតុអ្វីបានជាសីអែសរ៉ុមត្រូវការអនុវត្តអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ និង ដង្វាយធួនរបស់ទ្រង់មុនពេលគាត់ត្រូវបានព្យាបាល ?**

សូមឲ្យសិស្សអាន អាលម៉ា ១៥:១១–១២ ដោយស្ងាត់ៗដើម្បីរកមើលអ្វីដែលកើតឡើងដល់សីអែសរ៉ុម ។ នៅពេលពួកគេមានពេលអានគ្រប់គ្រាន់ហើយ សូមលុបពាក្យនិងឃ្លាទាំងអស់ចេញពីក្តារខៀននៅក្រោមឈ្មោះរបស់សីអែសរ៉ុម ។

- **តើភស្តុតាងអ្វីដែលអ្នកឃើញថា សីអែសរ៉ុមបានប្រែចិត្ត និងបានទទួលសេចក្តីមេត្តាករុណាពីព្រះអម្ចាស់ ? (គាត់ត្រូវបានព្យាបាលតាមរយៈសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ គាត់បានជ្រមុជទឹក ហើយគាត់បានចាប់ផ្តើមធ្វើការល្អ) ។**

សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***តាមរយៈសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ យើងអាចត្រូវបានព្យាបាល និង ពង្រឹង ។***

សូមបង្ហាញថា ដោយជាអ្នកដឹកនាំបព្វជិតភាពម្នាក់ អាលម៉ាមិនបានដឹកនាំការយកចិត្តទុកដាក់ទៅលើខ្លួនគាត់ឡើយ ។ គោលបំណងរបស់ទ្រង់នៅក្នុងការសន្ទនាជាមួយនឹងស៊ីអែសរ៉ុមនេះ គឺដើម្បីជួយស៊ីអែសរ៉ុមឲ្យអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ និង ដើម្បីទទួលបានសេចក្តីមេត្តាករុណាតាមរយៈដង្វាយធួន ។ ដើម្បីបង្ហាញរបៀបមួយដែលអ្នកដឹកនាំបព្វជិតភាពរបស់យើងជួយយើងឲ្យទទួលបានពរជ័យនៃដង្វាយធួន សូមអានបទពិសោធន៍ខាងក្រោមដែលចែកចាយដោយអែលឌើរ ជេ អ៊ី ជែនសិន នៃក្រុមពួកចិតសិបនាក់ ៖

“ ខណៈពេលកំពុងបម្រើជាប៊ីស្សពម្នាក់ ខ្ញុំបានធ្វើជាសាក្សីនៃពរជ័យនៃដង្វាយធួននៅក្នុងជីវិតនៃសមាជិកសាសនាចក្រដែលបានរំលងច្បាប់ដ៏ធ្ងន់ធ្ងរ ។ . . .

“ យុវជននៅលើវ័យក្មេងម្នាក់នៅក្នុងវួដរបស់យើងបានណាត់ជួបនឹងយុវនារីម្នាក់ ។ ពួកគេបានធ្វើឲ្យសេចក្តីស្រឡាញ់របស់ពួកគេមិនអាចគ្រប់គ្រងបាន ។ គាត់បានមកជួបនឹងខ្ញុំដើម្បីប្រឹក្សា និងជួយ ។ ដោយផ្អែកលើអ្វីដែលបានសារភាព និង ការបំផុសនៃព្រះវិញ្ញាណមកកាន់ខ្ញុំ ក្នុងចំណោមរឿងផ្សេងទៀត គាត់មិនត្រូវបានអនុញ្ញាតឲ្យទទួលទានសាក្រាម៉ង់ក្នុងពេលមួយកំណត់ ។ យើងបានជួបជាទៀងទាត់ដើម្បីធានាថា ការប្រែចិត្តបានកើតឡើង ហើយក្រោយពីពេលមួយសមស្របហើយ ខ្ញុំបានឲ្យគាត់ទទួលទានសាក្រាម៉ង់វិញ ។

“ នៅពេលខ្ញុំបានអង្គុយលើវេទិកានៃការប្រជុំសាក្រាម៉ង់ ភ្នែករបស់ខ្ញុំក្រឡេកទៅគាត់ នៅពេលគាត់ទទួលយកសាក្រាម៉ង់ដោយស្អាតស្អំ ។ ខ្ញុំសូមធ្វើជាសាក្សីពីដៃនៃសេចក្តីមេត្តាករុណា សេចក្តីស្រឡាញ់ និងសុវត្ថិភាពដែលព័ទ្ធជុំវិញគាត់ នៅពេលការព្យាបាលនៃដង្វាយធួនបានលូងលោមព្រលឹងរបស់គាត់ ហើយបានលើកបន្ទុកឡើង ដោយផ្តល់នូវការអភ័យទោស សេចក្តីសុខសាន្ត និងសុភមង្គលដែលបានសន្យា ” (“Arms of Safety,” *Ensign*ឬ*លេខអាហ្វណា*,ខែ វិច្ឆិកា ឆ្នាំ ២០០៨, ទំព័រ ៤៩) ។

សូមថ្លែងទីបន្ទាល់ថា ប៊ីស្សពនិងអ្នកដឹកនាំបព្វជិតភាពផ្សេងទៀតអាចជួយយើងឲ្យទទួលបានសេចក្តីមេត្តាករុណា និង កម្លាំងដែលយើងត្រូវការតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។

ដើម្បីជួយសិស្សឲ្យឃើញថា អ្នកដឹកនាំសាសនាចក្របម្រើដល់ក្រុមមនុស្ស និងបុគ្គល សូមឲ្យពួកគេសិក្សា អាលម៉ា ១៥:១៣–១៨ ។ សូមឲ្យពួកគេធ្វើការជាដៃគូ ។ សូមឲ្យសិស្សម្នាក់ក្នុងដៃគូនីមួយៗសិក្សា អាលម៉ា ១៥:១៣–១៥, ១៧ ដោយរកមើលរបៀបដែលប្រជាជនសីដូមត្រូវបានប្រទានពរតាមរយៈការបម្រើរបស់អាលម៉ា ។ សូមឲ្យសិស្សម្នាក់ទៀតនៅក្នុងដៃគូនីមួយៗសិក្សា អាលម៉ា ១៥:១៦, ១៨ ដោយរកមើលរបៀបដែលអាម៉ូណេកត្រូវបានប្រទានពរតាមរយៈការបម្រើរបស់អាលម៉ា ។ ក្រោយពីពួកគេបានមានពេលគ្រប់គ្រាន់ហើយ សូមអញ្ជើញឲ្យពួកគេពន្យល់ដល់គ្នាទៅវិញទៅមកពីអ្វីដែលពួកគេបានរកឃើញ ។

សូមអញ្ជើញឲ្យដៃគូទាំងអស់គិតពីរបៀបបីទៅប្រាំដែលអ្នកដឹកនាំសាសនាចក្រសព្វថ្ងៃនេះអាចជួយក្រុម និងបុគ្គលទាំងឡាយ ។ សូមលើកទឹកចិត្តសិស្សឲ្យគិតអំពីការទទួលខុសត្រូវថ្មាល់របស់ពួកគេជាអ្នកដឹកនាំនៅក្នុងក្លុ៉មបព្វជិតភាព និង ថ្នាក់យុវនារីរបស់ពួកគេ ។ សូមឲ្យដៃគូនីមួយៗចែកចាយគំនិតរបស់ពួកគេមួយដល់សិស្សក្នុងថ្នាក់ ។

អាលម៉ា ១៦:១–១២

សាសន៍លេមិនបំផ្លាញដែនដីអាំម៉ូណៃហា ប៉ុន្តែមិនអាចបង្ក្រាបសាសន៍នីហ្វៃដែលធ្វើតាមការណែនាំរបស់អាលម៉ាបាន

សូមឲ្យសិស្សគិតពេលមួយដែលពួកគេមានអារម្មណ៍ភ្ញាក់ផ្អើលើ ឬ ខ្លាចមួយរំពេច ។ អ្នកអាចសុំឲ្យសិស្សម្នាក់ ឬ ពីរនាក់ចែកចាយពីបទពិសោធន៍របស់ពួកគេ ។ សូមអញ្ជើញឲ្យសិស្សអាន អាលម៉ា ១៦:១–៣ ដោយស្ងាត់ៗ ដោយរកមើលរបៀបដែលសាសន៍នីហ្វៃនៅក្នុងដែនដីអាម៉ូណៃហាបានភ្ញាក់ផ្អើល និង មូលហេតុដែលពួកគេខ្លះហាក់ដូចជាភ័យខ្លាច ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ (បើចាំបាច់ សូមជួយពួកគេឲ្យឃើញថា សាសន៍លេមិនបានវាយប្រហារទីក្រុងអាំម៉ូណៃហាភ្លាម ហើយបានបំផ្លាញប្រជាជនមុនពេលសាសន៍នីហ្វៃអាចតតាំងនឹងពួកគេបានដោយកងទ័ព) ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ១៦:៤–៦ ឮ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលកន្លែងដែលពួកនីហ្វៃសុចរិតស្វែងរកការដឹកនាំ ។ សូមឲ្យសិស្សម្នាក់ទៀតអាន អាលម៉ា ១៦:៧–៨ ឮៗខណៈពេលសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលលទ្ធផលដ៏ឆ្ងាយដែលពួកគេបានទទួល ។

- តើការដឹកនាំដោយការព្យាករណ៍របស់អាលម៉ាបានជួយដល់សាសន៍នីហ្វៃដោយរបៀបណា ?
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពីដំណើររឿងនេះ ? (សិស្សអាចរកឃើញគោលការណ៍ផ្សេងៗគ្នា ។ សូមប្រាកដថា ពួកគេយល់ថា ***នៅពេលយើងស្វែងរក និង ធ្វើតាមការដឹកនាំពីព្យាការីរបស់ព្រះអម្ចាស់ ព្រះអម្ចាស់នឹងពង្រឹង និងការពារដល់យើង ។***សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើយុវជនណាត្រូវបានប្រទានពរ នៅពេលពួកគេធ្វើតាមការដឹកនាំនៃការព្យាករណ៍ដោយរបៀបណា ? (ដើម្បីជួយសិស្សឲ្យឆ្លើយតបនឹងសំណួរនេះ សូមគិតពីការឲ្យពួកគេបើកទៅផ្នែកពីរ ឬ បីនៅក្នុងសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ។ សូមអញ្ជើញឲ្យពួកគេឆ្លើយនឹងសំណួរនេះ ទាក់ទងនឹងផ្នែកនីមួយៗដែលអ្នកជ្រើសរើស) ។

សូមឲ្យសិស្សគិតពីបទពិសោធន៍ដែលការដឹកនាំនៃការព្យាករណ៍បានជួយដល់ពួកគេឲ្យជ្រើសរើសត្រឹមត្រូវនៅក្នុងស្ថានភាពលំបាក ។ សូមអញ្ជើញឲ្យសិស្សពីរបីនាក់ចែកចាយពីបទពិសោធន៍របស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។ (សូមប្រាកដថា ពួកគេយល់ថា ពួកគេមិនចាំបាច់ចែកចាយពីបទពិសោធន៍ដែលថ្នាល់ខ្លួន ឬ ឯកជនពេកនោះទេ) ។ អ្នកក៏អាចចែកចាយពីបទពិសោធន៍របស់អ្នកថ្នាល់ខ្លួន

ដែរ ។ ដើម្បីបញ្ជាក់ពីសេចក្តីពិតថា ពាក្យសម្តីរបស់ព្យាការីតែងតែត្រូវបានបំពេញ អ្នកអាចបង្ហាញថា អាលម៉ា ១៦:៩–១១ បង្ហាញពីការបំពេញនៃការព្យាករណ៍របស់អាលម៉ាអំពីប្រជាជនអាំម៉ូណៃហា (សូមមើល អាលម៉ា ៩:១២) ។

អាលម៉ា ១៦:១៣–២១

អាលម៉ា អាមូលេក និង អ្នកផ្សេងទៀតកសាងសាសនាចក្រក្នុងចំណោមសាសន៍នីហ្វៃ

នៅពេលសិស្សបញ្ចប់ការសិក្សា អាលម៉ា ១៦ សូមលើកទឹកចិត្តពួកគេឲ្យរកមើលគំរូនៃគោលការណ៍ពីរដែលអ្នកបានសរសេរនៅលើក្តារខៀន ។ សូមសង្ខេប អាលម៉ា ១៦:១៣–១៥ ដោយការពន្យល់ថា អាលម៉ា និងអាមូលេកបានបន្តបង្រៀនព្រះបន្ទូលនៃព្រះទូទាំងដែនដី ដោយមានជំនួយពីអ្នកដទៃ “ ដែលត្រូវបានជ្រើសរើសសម្រាប់កិច្ចការ ” (អាលម៉ា ១៦:១៥) ។ សូមអញ្ជើញឲ្យសិស្សអាន អាលម៉ា ១៦:១៦–២១ ដោយសូាត់ស្ងៀម ដោយរកមើលលទ្ធផលនៃការខិតខំទាំងនេះ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សប្រាប់អំពីអ្វីដែលពួកគេបានរកឃើញ ។ សូមសួរពួកគេពីរបៀបដែលគំរូទាំងនេះបង្ហាញពីគោលការណ៍មួយ ឬ ទាំងពីរដែលបានសរសេរនៅលើក្តារខៀន ។

សូមបញ្ចប់មេរៀនដោយការលើកទឹកចិត្តសិស្សឲ្យចម្លងគោលការណ៍មួយក្នុងចំណោមពីរទៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ សូមអញ្ជើញឲ្យពួកគេសរសេរសេចក្តីសង្ខេបអំពីអ្វីដែលពួកគេបានរៀនថ្ងៃនេះអំពីគោលការណ៍នោះ ។ សូមឲ្យពួកគេសរសេរអំពីរបៀបដែលពួកគេគ្រោងអនុវត្តអ្វីដែលពួកគេបានរៀនផងដែរ ។

ការរំឲ្យលចំណេះចំណានខគម្ពីរ

មេរៀននេះបញ្ជាក់ពីចំណុចពាក់កណ្តាលផ្លូវនៅក្នុងការបង្រៀនឆ្នាំនេះ ។ ដើម្បីជួយសិស្សឲ្យបញ្ជាក់ពីចំណេះដឹងរបស់ពួកគេអំពីវគ្គចំណេះចំណានខគម្ពីរ សូមគិតពីការឲ្យពួកគេនូវលំហាត់ ឬ ការប្រលងដើម្បីវាស់ពីការចេះដឹងដែលពួកគេមាននឹងវគ្គចំណេះចំណានខគម្ពីរដែលអ្នកបានបង្រៀនក្នុងថ្នាក់ ។ អ្នកអាចរៀបចំលំហាត់ពាក្យ ឬ ការសរសេរសាមញ្ញ ដូចជាការឲ្យតម្រុយពីវត្ថុសិកក្នុងសៀវភៅសម្រាប់ចំណាំថ្នាក់សិក្ខាសាលា និង ការឲ្យសិស្សសរសេរសេចក្តីយោងត្រឹមត្រូវ ឬ អ្នកអាចគិតពីការដឹកនាំការរំឲ្យកមួយនៃវគ្គខ្លះដែលសិស្សបានចាំ ។ អ្នកអាចប្រាប់សិស្សអំពីលំហាត់ ឬ ការប្រឡងជាមុន ដើម្បីឲ្យពួកគេអាចរៀបចំសម្រាប់វា ។

កំណត់ចំណាំ ៖ ប្រសិនបើអ្នកមិនមានពេលប្រើសកម្មភាពនេះជាផ្នែកនៃមេរៀននេះទេ អ្នកអាចប្រើវានៅថ្ងៃក្រោយ ។ សម្រាប់សកម្មភាពរំឲ្យកផ្សេងទៀត សូមមើលសេចក្តីបន្ថែមនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អាលម៉ា ១៥:៣–៥ ។ ការរងទុក្ខខាងសាច់ឈាមបណ្តាល់ដោយការមិនស្រួលខាងវិញ្ញាណ

ខណៈពេលដែលសឺអែសរ៉ុមបានប្រែចិត្ត អំពើបាបរបស់គាត់ “ បានធ្វើឲ្យគំនិតគាត់កើតទុក្ខរហូតដល់ធ្វើឲ្យគាត់ឈឺជាខ្លាំងដោយគ្មានច្រកចេញ ” (អាលម៉ា ១៥:៣) ។ ប្រធានបិយដ៍ ឃេ ផាកកឺនៃក្លរ៉ុមនៃពួកសាវកដប់ពីរនាក់បាននិយាយអំពីភាពពិតនៃការរងទុក្ខខាងសាច់ឈាមដែលអាចបណ្តាលមកពីការមិនស្រួលខាងវិញ្ញាណ ៖

“ ខ្ញុំ [ធ្លាប់] បានសួរវេជ្ជបណ្ឌិតនៃគ្រួសារពីពេលវេលារបស់គាត់ក្នុងការលះបង់ដោយសុទ្ធសាធចំពោះការព្យាបាលការមិនស្រួលខាងរាងកាយ ។ គាត់មានការអនុវត្តដ៏ធំ ហើយក្រោយពីការគិតដ៏ម៉ត់ចត់ គាត់បានឆ្លើយតបថា ‹ មិនច្រើនជាង ២០ ភាគរយនោះទេ ។ ពេលវេលាផ្សេងទៀតដែលខ្ញុំធ្វើការនឹងបញ្ហាដែលប៉ះពាល់ខ្លាំងក្លាដល់សុខុមាលភាពខាងរាងការយនៃអ្នកជំងឺរបស់ខ្ញុំ ប៉ុន្តែមិនមែនកើតពីក្នុងរាងកាយនោះទេ ។ ›

“ ‹ ការមិនស្រួលខាងរាងកាយទាំងនេះ › វេជ្ជបណ្ឌិតបានបញ្ចប់ថា ‹ គឺគ្រាន់តែជារោគសញ្ញានៃប្រភេទខ្លះនៃបញ្ហា › ។

“ នៅក្នុងជំនាន់ថ្មីៗនេះ ជំងឺមួយហើយមួយទៀតជ៏ចម្បងបានត្រូវគេគ្រប់គ្រង់ ឬ ព្យាបាល ។ ជំងឺចម្បងខ្លះនៅតែបន្ត ប៉ុន្តែឥឡូវយើងហាក់ដូចជាអាចធ្វើអ្វីខ្លះដល់វាភាគច្រើន ។

“ មាននផ្នែកផ្សេងទៀតនៃយើង មិនមែនច្បាស់ខ្លាំង ប៉ុន្តែពិតជាមានមែននៅក្នុងរាងកាយយើង ។ ផ្នែកមើលមិនឃើញក្នុងខ្លួនយើងនេះ ត្រូវបានរៀបរាប់ថាជាគំនិត អារម្មណ៍ បញ្ញាកំហឹង និង អ្វីផ្សេងទៀតជាច្រើន ។ វាកម្រនឹងពិពណ៍នាថាជាវិញ្ញាណណាស់ ។

“ ប៉ុន្តែមាន *វិញ្ញាណ* នៅក្នុងមនុស្ស ការព្រងើយកន្តើយនឹងវា គឺដូចជាការព្រងើយកន្តើយនឹងតថភាពដែរ ។ ក៏មានការមិនស្រួលខាងវិញ្ញាណដែរ ហើយជំងឺខាងវិញ្ញាណដែលអាចបង្កឲ្យមានការរងទុក្ខដ៏ខ្លាំង ។

“ រាងកាយ និង វិញ្ញាណនៃមនុស្សត្រូវនៅរួមគ្នា ” (“ The Balm of Gilead,” *Ensign,*ខែ វិច្ឆិកា ឆ្នាំ១៩៧៧, ទំព័រ ៥៩) ។

មេរៀនសិក្សានៅផ្ទះ

អាលម៉ា ១១–១៦ (មេរៀនទី ១៦)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនការសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនការសិក្សានៅផ្ទះ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេសិក្សា អាលម៉ា ១១–១៦(មេរៀនទី ១៦) មិនមែនសម្រាប់បង្រៀន ជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (អាលម៉ា ១១)

តាមរយៈគំរូរបស់អាមូលេកដែលបានទាស់នឹងសឺអែសរ៉ុម សិស្សបានរៀនថា នៅពេលយើងពឹងផ្អែកទៅលើព្រះវិញ្ញាណបរិសុទ្ធ យើងអាចយកឈ្នះលើការល្បួង ។ នៅក្នុងការបង្រៀនសឺអែសរ៉ុម និងប្រជាជនអាម៉ូណៃហា អាមូលេកបានសង្កត់ធ្ងន់នូវគោលលទ្ធិ ខាងក្រោមទាក់ទងនឹងតួនាទីរបស់ព្រះអង្គសង្គ្រោះ ៖ សេចក្តីជំនឿដ៏ពិតទៅលើ ព្រះយស៊ូវគ្រីស្ទចាប់ផ្តើមដល់ដំណើរការនៃការប្រោសលោះពីអំពើបាបរបស់យើង ។ តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ មនុស្សទាំងអស់នឹងត្រូវរស់ឡើងវិញ ហើយ ជំនុំជម្រះស្របតាមកិច្ចការរបស់ពួកគេ ។

ថ្ងៃទី ២ (អាលម៉ា ១២)

ដូចជាអាមូលេកដែរ អាលម៉ាបានបង្រៀនសឺអែសរ៉ុម និងប្រជាជនអាម៉ូណៃហា ។ គាត់បានពន្យល់ពីបំណងរបស់អារក្ស និង បានប្រកាសថា សឺអែសរ៉ុមស្ថិតនៅក្នុង អំណាចរបស់អារក្ស ។ អាលម៉ា និង អាមូលេកបានធ្វើជាគំរូថា ព្រះវិញ្ញាណបរិសុទ្ធ អាចជួយយើងឲ្យស្គាល់ពីការល្បួងនៃឧបសគ្គបាន ។ អាលម៉ាបានជួយប្រជាជនឲ្យ យល់ថា ព្រះអម្ចាស់បង្ហាញសេចក្តីពិតខាងវិញ្ញាណដល់យើងតាមរយៈការគោរព និង ការឧស្សាហ៍ដែលយើងធ្វើតាមព្រះបន្ទូលរបស់ទ្រង់ ។ គាត់ក៏បានបង្រៀនពីសេចក្តីជំនុំជម្រះលើកចុងក្រោយ ដោយពន្យល់ថាយើងនឹងត្រូវទទួលខុសត្រូវចំពោះមុខ ព្រះចំពោះពាក្យ កិច្ចការ និង គំនិតរបស់យើង ។ គាត់បានបញ្ជាក់ថា ជីវិតរមែងស្លាប់ គឺជាពេលវេលាសម្រាប់យើងប្រុងប្រៀនទៅជួបនឹងព្រះ ។

ថ្ងៃទី ៣ (អាលម៉ា ១៣)

អាលម៉ាបានរំឲ្យកសឺអែសរ៉ុម និងប្រជាជនថា ព្រះបានតែងតាំងអ្នកកាន់បព្វជិតភាពពីកំណើតនៃលោកិយមកម្លេ៉ះ ។ មនុស្សដែលអនុវត្តសេចក្តីជំនឿដ៏ខ្លាំង ហើយជ្រើសរើសសុចរិតភាពទទួលបានបព្វជិតភាពមីលគីស្សាដែកដើម្បីនាំអ្នកដទៃទៅកាន់ព្រះ ។ សិស្សបានរៀនអំពីមីលគីស្សាដែក និងប្រជាជនរបស់គាត់ ហើយបានផ្ទុះបញ្ចាំងលើ សេចក្តីពិតនេះ ៖ នៅពេលយើងផ្លើយតបដោយបន្ទាបខ្លួនទៅនឹងការអញ្ជើញឲ្យប្រែចិត្ត ព្រះវិញ្ញាណបរិសុទ្ធនឹងដឹកនាំយើងទៅក្នុងសេចក្តីសម្រាករបស់ព្រះអម្ចាស់ ។

ថ្ងៃទី ៤ (អាលម៉ា ១៤–១៦)

សិស្សអានអំពីស្ត្រី និងកូនក្មេងសុចរិតដែលស្លាប់ក្នុងដៃនៃមនុស្សទុច្ចរិត ។ ពួកគេ សញ្ជឹងអំពីប្រយោគនៃការព្យាករណ៍ដែលបង្រៀនថា ព្រះអម្ចាស់អនុញ្ញាតឲ្យពួកសុចរិត រងទុក្ខក្នុងដៃពួកទុច្ចរិតដើម្បីឲ្យសេចក្តីជំនុំជម្រះរបស់ទ្រង់អាចមានយុត្តិធម៌ ។ សិស្ស បានសង្កេតនៅក្នុងជីវិតរបស់អាលម៉ា និងអាមូលេកថា នៅពេលយើងទុកចិត្តទៅលើ ព្រះអម្ចាស់ ទ្រង់នឹងពង្រឹងយើងពេលមានឧបសគ្គ ។ ប្រសិនបើយើងហៅទ្រង់ដោយ សេចក្តីជំនឿ ទ្រង់នឹងពង្រឹងយើងនៅក្នុងការលំបាករបស់យើង ហើយដោះលែងយើង តាមរបៀបរបស់ទ្រង់ និង តាមពេលវេលារបស់ទ្រង់ផ្ទាល់ ។

សេចក្តីផ្តើម

នៅពេលអាលម៉ា អាមូលេកចាប់ផ្តើមបង្រៀនប្រជាជនអាំម៉ូណៃហា ពួកគេបានជួបនឹង ការប្រឆាំង ។ ក្រោយពីពួកគេបានពន្យល់នូវសេចក្តីពិតដ៏អស់កល្បជានិច្ចជាច្រើន មនុស្សជាច្រើន “ បានចាប់ផ្តើមប្រែចិត្ត ហើយពិចារណាមើលបទគម្ពីរទាំងឡាយ ” (អាលម៉ា ១៤:១) ។ ដំណើររឿងនៅក្នុង អាលម៉ា ១១–១៦បង្ហាញពីមនុស្សដែលលះបង់មានឆន្ទៈនឹងធ្វើទីបន្ទាល់របស់ ពួកគេសម្រាប់សេចក្តីពិត ។ ជំពូកទាំងនេះក៏ផ្តល់នូវកស្តុតាងថា នៅពេលពួកទុច្ចរិត “ បណ្តេញ ពួកសុចរិតចេញ ” ព្រះអម្ចាស់នឹងវាយពួកគេ “ ដោយអំណត់អត់ ដោយជំងឺអាសន្នរោគ និងដោយ ជាវ ” (អាលម៉ា ១០:២៣) ។ អាលម៉ា និងអាមូលេកបានព្រមានដល់ប្រជាជនអាំម៉ូណៃហា ថា ប្រសិនបើពួកគេមិនព្រមប្រែចិត្តទេ សេចក្តីជំនុំជម្រះនៃព្រះនឹងមកដល់ពួកគេ ។ ដោយ ការបដិសេធការហៅឲ្យប្រែចិត្ត ប្រជាជនអាម៉ូណៃហាក្រោយមកត្រូវបានបំផ្លាញដោយកងទ័ពនៃ សាសន៍លេមិន ។

មេរៀននេះនឹងផ្តោតលើ អាលម៉ា ១៤–១៥ ។ បន្ថែមលើនេះ អ្នកអាចបង្រៀន ឬ រំឲ្យកសេចក្តីពិត ពីជំពូកផ្សេងទៀតដែលបានដាក់សម្រាប់សប្តាហ៍នេះ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ១៤–១៥

ព្រះប្រទានពរដល់អស់អ្នកដែលទុកចិត្តលើទ្រង់នៅក្នុងសេចក្តីទុក្ខវេទនារបស់ពួកគេ

សូមគិតពីការចាប់ផ្តើមមេរៀនថ្ងៃនេះដោយការលើកឡើងពីគ្រោះថ្នាក់នាពេលថ្មីៗនេះដែលមនុស្ស សុចរិតបានរងទុក្ខដោយសារតែជម្រើសរបស់អ្នកដទៃ ។ ឬ អ្នកអាចសុំឲ្យសិស្សចែកចាយពីគំរូ ពីព្រះគម្ពីរនៃមនុស្សសុចរិតដែលត្រូវស្លាប់ដោយសារតែទីបន្ទាល់របស់ពួកគេអំពីជំណឹងល្អ ។ ក្រោយពីពិភាក្សាពីគំរូពីរបីហើយ សូមអញ្ជើញឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឲ្យៗពី អាលម៉ា ១៤:៧–១១និងអាលម៉ា ៦០:១៣ ។

សូមសួរ ៖ តើមូលហេតុអ្វីខ្លះដែលមាននៅក្នុងខគម្ពីរនេះដែលប្រាប់ពីមូលហេតុដែលពួកសុចរិត ពេលខ្លះត្រូវបានឲ្យរងទុក្ខនៅក្នុងដៃនៃពួកទុច្ចរិត ? (សេចក្តីពិតមួយដែលសិស្សបានរៀន ខណៈពេលសិក្សាក្នុងផ្នែកនៃ អាលម៉ា ១៤ គឺថា **ព្រះអម្ចាស់អនុញ្ញាតឲ្យពួកសុចរិតរងទុក្ខក្នុងដៃ នៃពួកទុច្ចរិតដើម្បីឲ្យសេចក្តីជំនុំជម្រះរបស់ទ្រង់អាចមានសេចក្តីយុត្តធម៌) ។**

សូមពន្យល់ថា សេចក្តីយុត្តិធម៌និងសេចក្តីមេត្តាករុណារបស់ព្រះមានលើសពីសេចក្តីស្លាប់ដើម្បី ទទួលខុសត្រូវដល់អ្នកដែលបានធ្វើបាប និង ដើម្បីបង្ហាញសេចក្តីមេត្តាករុណាដល់ពួកសុចរិត ។ បន្ទាប់មក សូមចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ដែមស៍ អឺ ហ្វោស្ត នៃ គណៈប្រធានទីមួយ ៖

“ ការរងទុក្ខទាំងអស់នេះពិតជាអាចមិនយុត្តិធម៌ ប្រសិនបើអ្វីៗបានបញ្ចប់ត្រឹមសេចក្តីស្លាប់ ប៉ុន្តែ វាមិនបញ្ចប់ត្រឹមនោះទេ ។ ជីវិតគឺមិនដូចជាការសម្តែងតែម្តងនោះទេ ។ វាមានបីវគ្ត ។ យើង បានមានវគ្គពីអតីតកាលមួយ នៅពេលយើងបាននៅក្នុងជីវិតមុនផែនដីនេះ ហើយឥឡូវនេះយើង មានវគ្គបច្ចុប្បន្នកាលដែលជាជីវិតរមែងស្លាប់ ហើយយើងនឹងមានវគ្គអនាគតកាលមួយ នៅពេល យើងត្រឡប់ទៅរកព្រះវិញ ។ . . . យើងត្រូវបានបញ្ជូនមកក្នុងជីវិតរមែងស្លាប់នេះដើម្បីត្រូវបាន សាកល្បង ហើយនឹងលមើល [សូមមើលអ័ប្រាហាំ ៣:២៥] ។ . . .

“ ការរងទុក្ខពីអតីតកាល និង បច្ចុប្បន្នកាលរបស់យើងមិនអាច ដូចជាសាវកប៉ុលបាននិយាយថា ‹ ជាសេចក្តីមិនគួរប្រៀបផ្ទឹមនឹងសិរីល្អដែលនឹងបើកសម្តែងមកឲ្យយើងរាល់គ្នាឃើញនោះទេ › [រ៉ូម ៨:១៨] នៅក្នុងភាពដ៏អស់កល្បជានិច្ច ។ ‹ ត្បិតបន្ទាប់ពីមានការវេទនាដ៏ច្រើន នោះទើបបាន ព្រះពរ ។ ហេតុដូច្នោះហើយថ្ងៃនោះនឹងមកដល់ កាលអ្នករាល់គ្នានឹងត្រូវបានពាក់សិរីល្អដ៏ច្រើន ទុកជាមកុដ › [គ . & ស . ៥៨:៤] ។ ដូច្នេះការវេទនាមានប្រយោជន៍នៅក្នុងន័យនេះ ដែលថាវា ជួយឲ្យបានទៅក្នុងនគរសេឡេស្ទាល ។ . . .

" វាមិនប៉ុន្មាននោះទេចំពោះអ្វីដែលបានកើតឡើងដល់យើង ប៉ុន្តែរបៀបដែលយើងតស៊ូនឹងអ្វីដែលកើតឡើងដល់យើងទើបច្រើន " (" Where Do I Make My Stand? " *Ensign ឬ លេខាហូណា,* ខែ វិច្ឆិកា ឆ្នាំ ២០០៤, ទំព័រ ១៩–២០) ។

សូមពន្យល់ថា ការរងទុក្ខ និងការវេទនាអាចជួយយើងឲ្យទទួលបានសិរីល្អដោយការពង្រឹងសេចក្តីជំនឿរបស់យើង ។ ការបន្ទរស្មោះត្រង់អំឡុងពេលមានឧបសគ្គ និងការលំបាកបង្ហាញពីការទុកចិត្តដ៏ខ្លាំងទៅលើព្រះ និងផែនការរបស់ទ្រង់ ហេតុដូច្នេះហើយវាពង្រឹងសេចក្តីជំនឿរបស់យើង និង សមត្ថភាពរបស់យើងដើម្បីតស៊ូដល់ទីបញ្ចប់ ។

សូមសួរសំណួរខាងក្រោម ៖

- តើការមានទីបន្ទាល់អំពីផែនការនៃសេចក្តីសង្គ្រោះ រួមមានជីវិតមុនផែនដីនេះ និង ជីវិតក្រោយផែនដីនេះ អាចបញ្ឈប់ការរងទុក្ខដែលយើងជួបនៅក្នុងជីវិតរមែងស្លាប់នេះដោយរបៀបណា ?
- ការគិតពីអ្វីដែលអ្នកបានសិក្សានៅក្នុងសប្តាហ៍នេះនៅក្នុង អាលម៉ា ១៤–១៥ តើតាមរបៀបណាដែលពួកសុចរិតត្រូវបានប្រទានពរនៅក្នុងការវេទនារបស់ពួកគេ ?
- នៅក្នុងពេលមានការវេទនា តើយើងអាចបង្ហាញថា យើងទុកចិត្តលើព្រះដោយរបៀបណា ?

សូមឲ្យសិស្សប្រៀបធៀបសំណួរដែលអាលម៉ាបានសួរនៅក្នុង អាលម៉ា ១៤:២៦ ទៅនឹងសំណួរដែលយ៉ូសែប ស៊្មីធ បានសួរនៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១២១:៣ ។ បន្ទាប់មកសូមសួរ ៖ យោងតាម អាលម៉ា ១៤:២៦ តើអាលម៉ា និងអាមូលេកអាចយកឈ្នះលើការវេទនារបស់ពួកគេដោយរបៀបណា ?

សូមពន្យល់ថា នៅពេលព្យាការី យ៉ូសែប ស៊្មីធ បានជាប់គុកក្នុងផ្ទៃមីសួរីដោយអយុត្តិធម៌ គាត់បានសួរសំណួរដែលបានកត់ត្រានៅក្នុង គោលលទ្ធិ និង សេចក្តីសញ្ញា ១២១:៣ ។ មិនដូចជាអាលម៉ា និងអាមូលេក គាត់មិនត្រូវបានដោះលែងភ្លាមៗពីគុកនោះទេ ។ តើយើងអាចរៀនអ្វីខ្លះពីចម្លើយរបស់ព្រះទៅនឹងការអធិស្ឋានរបស់គាត់ ? (សូមមើលគ . & ស . ១២១:៧–៩; ១២២:៨–៩) ។ សេចក្តីពិតខាងក្រោមត្រូវបានបញ្ជាក់នៅសប្តាហ៍នេះនៅក្នុងការសិក្សាផ្ទាល់ខ្លួនរបស់សិស្ស ៖ **ប្រសិនបើយើងហៅកព្រះអម្ចាស់ដោយសេចក្តីជំនឿ ទ្រង់នឹងពង្រឹងយើងនៅក្នុងការវេទនារបស់យើង ហើយដោះលែងយើងតាមរបៀបរបស់ទ្រង់ និង តាមពេលវេលារបស់ទ្រង់ផ្ទាល់ ។**

សូមសួរសំណួរខាងក្រោម ៖

- តើព្រះអម្ចាស់បានជួយអ្នក នៅពេលអ្នកបានជួបនឹងឧបសគ្គដោយរបៀបណា ?
- តើអ្វីដែលជួយអ្នកឲ្យធ្វើតាមឆន្ទៈរបស់ទ្រង់ និងទទួលយកការកំណត់ពេលរបស់ទ្រង់ ?

សូមជួយសិស្សឲ្យយល់ថា ទាំងសីអែសរ៉ុម និងអាមូលេកបានទុកចិត្តលើព្រះនៅក្នុងវេទនារបស់ពួកគេ ហើយត្រូវបានផ្តល់រង្វាន់ទៅតាមឆន្ទៈរបស់ទ្រង់ និងតាមពេលវេលារបស់ទ្រង់ផ្ទាល់ ។

សូមឲ្យសិស្សពាក់កណ្តាលថ្នាក់អាន អាលម៉ា ១៥:៥–១២ ហើយសូមរកព័ត៌មានអំពីសីអែសរ៉ុមដែលបង្ហាញពីការកែចម្រើននៃការទុកចិត្តរបស់គាត់ទៅលើព្រះអម្ចាស់ ។ សូមឲ្យសិស្សពាក់កណ្តាលថ្នាក់ទៀតសិក្សា អាលម៉ា ១៥:១៦, ១៨ ហើយរកមើលព័ត៌មានអំពីអ្វីដែលអាមូលេកបានលះបង់ដើម្បីបម្រើដល់ព្រះអម្ចាស់ ។

សូមលើកទឹកចិត្តសិស្សឲ្យទុកចិត្តលើព្រះអម្ចាស់ ហើយទទួលយកឆន្ទៈរបស់ទ្រង់ និងការកំណត់ពេលវេលារបស់ទ្រង់នៅពេលពួកគេជួបនឹងការលំបាក និងការវេទនា ។ សូមធានាពួកគេថា ព្រះពង្រឹកអំណាចរបស់ទ្រង់ និងដៈឥទ្ធិពលតាមរបៀបដ៏អព្ភូតហេតុ និងផ្ទាល់ខ្លួនជាច្រើន ។

ការរំឭកចំណេះចំណានខគម្ពីរ

មេរៀននេះបង្ហាញពីចំណុចពាក់កណ្តាលនៃកម្មវិធីសិក្សាថ្នាក់សិក្ខាសាលាព្រះគម្ពីរមរមន ។ ដើម្បីពង្រឹងការខិតខំរបស់សិស្សឲ្យរៀន និងយល់ពីវគ្គចំណេះចំណានខគម្ពីរ សូមគិតពីការឲ្យពួកគេធ្វើលំហាត់មួយដើម្បីស្វែងពីការដឹងរបស់ពួកគេក្នុងជប់បីវគ្គដែលពួកគេបានសិក្សាកន្លងមក ។ នេះអាចជាលំហាត់ផ្ទាល់មាត់ ឬ សរសេរសាមញ្ញដោយឲ្យសិស្សនូវតម្រុយមួយពីខគម្ពីរសិក្សាក្នុងសៀវភៅសម្រាប់ចំណាំ ហើយឲ្យពួកគេសរសេរពីសេចក្តីយោងនោះ ឬ វាអាចជាការរំឭកមួយពីវគ្គខ្លះដែលពួកគេបានចាំហើយ ។ ប្រវែងនៃមេរៀននេះអាចសល់ពេលខ្លះសម្រាប់លំហាត់ក្នុងសប្តាហ៍នេះ ឬ អ្នកអាចប្រកាសថានឹងមានលំហាត់នៅមេរៀនក្រោយ ដើម្បីឲ្យសិស្សអាចរៀបចំទុក ។

មេរៀនបន្ទាប់ (អាលម៉ា ១៧–២៤)

បុត្រានៃស្តេចម៉ូសាយចេញទៅផ្សព្វផ្សាយដល់ប្រជាជនដែលទុច្ចរិត និងកាចសាហាវ ។ ដំបូងពួកគេរងទុក្ខជាខ្លាំង ប៉ុន្តែនៅពេលពួកគេបង្រៀនដំណឹងល្អដល់សាសន៍លេមិន នោះអព្ភូតហេតុកើតឡើង ។ សូមកត់ចំណាំពីរបៀបដែលភាពស្មោះត្រង់ដែលអាំម៉ូនមានដល់ព្រះ និងស្តេចនាំមកនូវសេចក្តីសុចរិតជាខ្លាំង ។

អាលម៉ា ១៧

សេចក្តីផ្តើម

នៅក្នុងការរៀបចំបង្រៀនដំណឹងល្អដល់សាសន៍លេមិន បុត្រានៃស្តេចម៉ូសាយបានស្វែងរកការដឹកនាំពីព្រះអម្ចាស់ដោយការតមអាហារ និងការអធិស្ឋាន ។ ព្រះអម្ចាស់លួងលោមពួកគេ ហើយបានសន្យាថា ពួកគេនឹងក្លាយជាគ្រឿងឧបករណ៍នៅក្នុងព្រះហស្តទ្រង់ “ ដល់ការសង្គ្រោះព្រលឹងជាច្រើន ” (អាលម៉ា ១៧:១១) ។ ពីមុនទ្រង់បានសន្យានឹងពួកគេថា តាមរយៈវិវរណៈដល់បិតារបស់ពួកគេ ថាទ្រង់នឹង “ ដោះ [ពួកគេ] ឲ្យរួចផុតពីកណ្តាប់ដៃនៃពួកលេមិន ” (ម៉ូសាយ ២៨:៧) ។ ដោយត្រូវបានពង្រឹងដោយការសន្យារបស់ព្រះអម្ចាស់ និង ដោយទុកចិត្តថា ពួកគេនឹងជួបគ្នាម្តងទៀតនៅថ្ងៃណាមួយ នោះពួកគេបានបែកគ្នាដើម្បីចែកចាយដំណឹងល្អនៅតំបន់ខុសគ្នា ។ អាំម៉ូនបានចេញទៅដែនដីសីសម៉ាអែល ដែលគាត់បានរៀបចំបង្រៀនដល់ប្រជាជនដោយការបម្រើដល់ស្តេចរបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ១៧:១–១៦

ពួកបុត្រានៃស្តេចម៉ូសាយសិក្សាព្រះគម្ពីរ អធិស្ឋាន ហើយតមអាហារដើម្បីពួកគេអាចដឹងពីព្រះបន្ទូលរបស់ព្រះ និងបង្រៀនដោយអំណាច

មុនចាប់ផ្តើមថ្នាក់ សូមសរសេរនូវប្រយោគមិនពេញលេញខាងក្រោមលើក្តារខៀន ៖ “ *អ្វីដែលសំខាន់ចម្បងបំផុតដែលអ្នកអាចធ្វើដើម្បីរៀបចំសម្រាប់ការហៅបម្រើ / បេសកកម្មមួយ / គឺត្រូវ* . . . ” (អ្នកនឹងត្រូវបើកទៅចំណុចនេះពេលក្រោយបន្តិចទៀតនៅក្នុងមេរៀននេះ) ។

សូមសួរសិស្សថា តើពួកគេបានទៅជួបនៅពេលសាច់ញាត់ ឬ មិត្តភក្តិបានត្រឡប់មកផ្ទះពីបេសកកម្មក្រោយពីការបម្រើដោយស្មោះត្រង់ដែរទេ ។ សូមអញ្ជើញឲ្យសិស្សពីរបីនាក់ពិពណ៌នាពីចរិតលក្ខណៈដូចនឹងព្រះគ្រីស្ទនៃពួកអ្នកផ្សព្វផ្សាយទាំងនេះ នៅពេលពួកគេបានត្រឡប់មកវិញ ។

- តើការផ្លាស់ប្តូរវិជ្ជមានអ្វីខ្លះដែលអ្នកបានឃើញពីពួកគេក្រោយពីបេសកកម្មរបស់ពួកគេ ? តើអ្នកគិតថា អ្វីដែលបណ្តាលឲ្យមានការផ្លាស់ប្តូរទាំងនេះ ?

ការរំឭកបរិបទ

ការរំឭកពីព័ត៌មានក្នុងបរិបទអាចបន្ថែមការយល់ដឹងកាន់តែជ្រៅដល់សិស្សអំពីហេតុការណ៍មួយ ឬ ការបង្រៀនមួយនៅក្នុងព្រះគម្ពីរ ។ នៅពេលអ្នកជួយសិស្សឲ្យរំឭកពីរឿងទាំងនេះ សូមផ្តល់នូវសេចក្តីយោងជាក់លាក់ដើម្បីជួយគេឲ្យរកនូវព័ត៌មានដែលពួកគេត្រូវការ ។

សូមពន្យល់ថា ក្រោយពីការបង្រៀនដំណឹងល្អអស់រយៈពេល ១៤ ឆ្នាំនៅក្នុងដែនដីនីហ្វៃ បុត្រានៃស្តេចម៉ូសាយបានត្រឡប់មកកាន់ដែនដីសារ៉ាហិមឡាវិញ នៅពេលពួកគេបានរួបរួមនឹងអាលម៉ា ។ ប្រសិនបើសិស្សត្រូវការ ការរំឭកឡើងវិញខ្លី ៗ នៃរឿងរបស់អាលម៉ា និងបុត្រារបស់ស្តេចម៉ូសាយ សូមសួរ ៖

- តើទំនាក់ទំនងអ្វីរវាងអាលម៉ា និងបុត្រានៃស្តេចម៉ូសាយ ? (ប្រសិនបើសិស្សត្រូវការជំនួយដើម្បីឆ្លើយនឹងសំណួរនេះ សូមគិតពីការសុំគេឲ្យអានសេចក្តីសង្ខេបជំពូកក្នុង ម៉ូសាយ ២៧) ។

សូមពន្យល់ថា ខណៈពេលដែលអាលម៉ាបានបង្រៀនពីការប្រែចិត្ត និងស្តាបនាសាសនាចក្រក្នុងចំណោមសាសន៍នីហ្វៃនៅក្នុងដែនដីសារ៉ាហិមឡា និងដែនដីផ្សេងទៀត បុត្រានៃស្តេចម៉ូសាយបានបង្រៀនដំណឹងល្អទៅដល់សាសន៍លេមិននៅក្នុងដែនដីនីហ្វៃ ។ (អ្នកអាចចង់សំដៅទៅខគម្ពីរសិក្សាក្នុងសៀវភៅសម្រាប់ចំណាំនៃព្រះគម្ពីរមរមន ជាផ្នែកនៃការពន្យល់នេះ) ។ ឈ្មោះនៃពួកបុត្រានៃស្តេចម៉ូសាយមានន័យថា អាំម៉ូន អើរ៉ុន អោមណើរ និង ហិមណៃ (សូមមើលម៉ូសាយ ២៧:៣៤) ។ អាលម៉ា ១៧–២៦រៀបរាប់ពីបទពិសោធន៍បេសកកម្មរបស់ពួកគេ ។

សូមអញ្ជើញឲ្យសិស្សម្នាក់អាន អាលម៉ា ១៧:១–២ ឮៗ ។

- តើអាលម៉ាបានមានអារម្មណ៍យ៉ាងណា នៅពេលគាត់បានឃើញមិត្តភក្តិរបស់គាត់ម្តងទៀតនោះ ? តើអ្នកគិតថា ហេតុអ្វីបានជាគាត់មានអារម្មណ៍យ៉ាងនេះ ?

សូមដឹកនាំការយកចិត្តទុកដាក់សិស្សទៅលើប្រយោគដែលមិនពេញលេញនៅលើក្តារខៀនពីមុនថ្នាក់ចាប់ផ្តើម ។ សូមអញ្ជើញឲ្យសិស្សស្នើពីរបៀបដែលអាចបំពេញក្នុងប្រយោគនេះ ។ បន្ទាប់មក សូមចែកចាយដល់ពួកគេនូវរបៀបដែលអែលឌើរ ដេវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់បានបំពេញប្រយោគនេះ ៖ “ អ្វីដែលសំខាន់ចម្បងបំផុតដែលអ្នកអាចធ្វើដើម្បីរៀបចំសម្រាប់ការហៅបម្រើ / បេសកកម្មមួយ / គឺត្រូវ *ក្លាយជា* អ្នកផ្សព្វផ្សាយសាសនាជាយូរ ពីមុនអ្នក *ចេញទៅ* បេសកកម្ម ” (“ Becoming a Missionary,” *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៥, ទំព័រ ៤៥) ។ សូមបំពេញប្រយោគនេះនៅលើក្តារខៀន ។

សូមបង្ហាញថា របៀបមួយដែលយើងអាចដឹងពីរបៀបដើម្បីក្លាយជាអ្នកផ្សព្វផ្សាយសាសនាគឺត្រូវរៀនអំពីការបម្រើនៃអ្នកផ្សព្វផ្សាយសាសនាដ៏ស្មោះត្រង់នៅក្នុងព្រះគម្ពីរ ។ សូមអញ្ជើញឲ្យសិស្សក្នុងថ្នាក់អានដោយស្ងាត់ៗក្នុង អាលម៉ា ១៧:២–៤ ដោយរកមើលមូលហេតុដែលពួកបុត្រានៃម៉ូសាយបានជោគជ័យក្នុងការនាំប្រជាជនឲ្យដឹងពីសេចក្តីពិត ។

- តើពួកបុត្រានៃម៉ូសាយបានធ្វើអ្វីខ្លះដែលបានជួយពួកគេឲ្យក្លាយជាអ្នកផ្សព្វផ្សាយសាសនាដ៏មានជោគជ័យ ? (ចង្អៀយអាចរួមមានពួកគេ “ សិក្សាព្រះគម្ពីរដោយឧស្សាហ៍ព្យាយាម ” អធិស្ឋាន និង តមអាហារ) ។

- តើពរជ័យអ្វីខ្លះដែលពួកគេបានទទួលដោយសារតែការសិក្សា ការតមអហារ និង ការអធិស្ឋានរបស់ពួកគេ ? (នៅពេលសិស្សឆ្លើយតបនឹងសំណួរនេះ សូមជួយពួកគេឲ្យរកមើលគោលការណ៍ខាងក្រោម ៖ **នៅពេលយើងសិក្សាព្រះគម្ពីរ អធិស្ឋាន និងតមអាហារ នោះយើងអាចទទួលបានព្រះវិញ្ញាណបរិសុទ្ធ និងបង្រៀនដោយអំណាច**) ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ បែដណា ដោយបញ្ជាក់ពីអ្វីដែលយើងអាចធ្វើដើម្បីក្លាយជាអ្នកផ្សព្វផ្សាយសាសនា ៖

" អ្នកអាចបង្កើនបំណងចង់របស់អ្នកបម្រើព្រះ (សូមមើល គ . និង ស .៤:៣) ហើយអ្នកអាចចាប់ផ្តើមគិតដូចជាអ្នកផ្សព្វផ្សាយសាសនាគិត អានអ្វីដែលអ្នកផ្សព្វផ្សាយសាសនាអាន អធិស្ឋានដូចជាអ្នកផ្សព្វផ្សាយសាសនាអធិស្ឋាន និងមានអារម្មណ៍ដូចជាអ្នកផ្សព្វផ្សាយសាសនាមាន ។ អ្នកអាចចៀសវាងពីឥទ្ធិពលខាងលោកិយដែលបណ្តាលឲ្យព្រះវិញ្ញាណបរិសុទ្ធចាកចេញបាន ហើយអ្នកអាចបង្កើនទំនុកចិត្តក្នុងការស្តាប់ និងការឆ្លើយតបទៅនឹងការបំផុសនៃព្រះវិញ្ញាណ ។ មួយបន្ទាត់ម្តងមួយបន្ទាត់ម្តង និងមួយសិក្ខាបទម្តងមួយសិក្ខាបទម្តង នៅទីនេះបន្តិច និងទីនោះបន្តិច អ្នកអាចក្លាយជាអ្នកផ្សព្វផ្សាយសាសនាដែលអ្នកចង់ក្លាយជា និង ជាអ្នកផ្សព្វផ្សាយសាសនាដែលព្រះអង្គសង្គ្រោះរំពឹងទុក ។ . . .

" ការរៀបចំដែលខ្ញុំរៀបរាប់នេះមិនមែនសំដៅលើការបម្រើបេសកកម្មរបស់អ្នកពេលអាយុ ១៩ ឬ ២០ ឬ ២១ ឆ្នាំនោះទេ ។ . . . អ្នកកំពុងរៀបចំសម្រាប់កិច្ចការផ្សព្វផ្សាយសាសនាពេញមួយជីវិត ។ . . . យើងគឺតែងតែជាអ្នកផ្សព្វផ្សាយសាសនា " (" Becoming a Missionary," ៤៦) ។

ដើម្បីជួយសិស្សឲ្យអនុវត្តគោលការណ៍ទាំងឡាយដែលបានបង្រៀនដោយអែលឌើរ បែដណា និងដែលមាននៅក្នុង អាលម៉ា ១៧:២–៤ សូមឲ្យពួកគេសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពីអ្វីដែលពួកគេនឹងធ្វើដើម្បីក្លាយជាអ្នកផ្សព្វផ្សាយសាសនា មុនពេលពួកគេត្រូវបានហៅឲ្យបម្រើ ។

សូមអញ្ជើញឲ្យសិស្សអាន អាលម៉ា ១៧:៩ ស្ទាត់ៗ ដោយរកមើលអ្វីដែលបុត្រាទាំងឡាយនៃស្តេចម៉ូសាយ និងដៃរបស់ពួកគេបានអធិស្ឋានសុំ ។ ក្រោយពីសិស្សបានរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញហើយ សូមឲ្យពួកគេអាន អាលម៉ា ១៧:១០–១២ ដោយរកមើលចម្លើយរបស់ព្រះអម្ចាស់ចំពោះការអធិស្ឋានរបស់ពួកគេ ។

- តើអ្នកគិតថា ហេតុអ្វីបានជាដួងចិត្តរបស់ពួកគេ " មានសេចក្តីក្លាហានឡើង " នៅពេលពួកគេបានទទួលចម្លើយពីព្រះអម្ចាស់ចំពោះការអធិស្ឋានរបស់ពួកគេ ?
- អាលម៉ា ១៧:១១រួមមានសេចក្តីសន្យារបស់ព្រះអម្ចាស់ថា ទ្រង់នឹងយកអ្នកផ្សព្វផ្សាយសាសនាទាំងឡាយជាគ្រឿងឧបករណ៍នៅក្នុងព្រះហស្តរបស់ទ្រង់ ។ តើការណ៍នេះមានអត្ថន័យយ៉ាងណាចំពោះអ្នក ? តើយើងអាចក្លាយជាគ្រឿងឧបករណ៍នៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់តាមវិធីណា ?
- ព្រះអម្ចាស់បានណែនាំអ្នកផ្សព្វផ្សាយសាសនាទាំងនេះឲ្យ " បង្ហាញនូវគំរូល្អទាំងឡាយ " (អាលម៉ា ១៧:១១) ។ តើអ្នកគិតថា ហេតុអ្វីបានជាការបង្ហាញនូវគំរូល្អគឺជាផ្នែកដ៏សំខាន់នៃកិច្ចការផ្សព្វផ្សាយសាសនារបស់ពួកគេ ? (នៅពេលសិស្សចែកចាយចម្លើយរបស់ពួកគេ សូមជួយពួកគេឲ្យរកមើលនូវគោលការណ៍ខាងក្រោម ៖ **នៅពេលយើងបង្ហាញគំរូល្អ ព្រះអម្ចាស់អាចយកយើងធ្វើជាគ្រឿងឧបករណ៍នៅក្នុងព្រះហស្តរបស់ទ្រង់** ។អ្នកអាចសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- តើប្រជាជនអាចរៀនអ្វីខ្លះអំពីដំណឹងល្អ នៅពេលពួកគេឃើញពីគំរូល្អទាំងឡាយរបស់យើង ?
- តើនៅពេលណាដែលគំរូល្អរបស់អ្នកដទៃបានជួយដល់អ្នក ?

សូមថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃការធ្វើជាគំរូល្អ ហើយសូមលើកទឹកចិត្តសិស្សឲ្យធ្វើជាគំរូល្អដល់អ្នកនៅជុំវិញពួកគេ ។ ប្រសិនបើអ្នកអាចគិតពីពេលជាក់លាក់ណាដែលអ្នកបានឃើញសិស្សបង្ហាញគំរូល្អ អ្នកអាចសរសើរដល់សិស្សនោះចំពោះអ្វីដែលពួកគេបានធ្វើ ។ ទោះជាយ៉ាងណាក្តី សូមកុំចែកចាយការសរសើរទូទៅ ឬ មិនច្បាស់លាស់ ដែលអាចមើលទៅហាក់មិនស្មោះត្រង់ ។

ឲ្យសិស្សអាន អាលម៉ា ១៧:១៣–១៦ ដោយស្ទាត់ៗ ដោយគិតអំពីការលំបាកនៃការបង្រៀនដល់សាសន៍លេមិននៅពេលនោះ ។

- ហេតុអ្វីបានជាពួកបុត្រាទាំងឡាយនៃស្តេចម៉ូសាយមានឆន្ទៈនឹងរងការលំបាក ហើយចូលទៅក្នុងចំណោមសាសន៍លេមិន ? (សូមមើលអាលម៉ា ១៧:១៦; សូមមើលផងដែរម៉ូសាយ ២៨:១–៣) ។

អាលម៉ា ១៧:១៧–៣៩

អាំម៉ូនក្លាយជាអ្នកបម្រើម្នាក់របស់ស្តេចឡាម៉ូណៃ ហើយនឹងមើលថែដល់ហ្វូងសត្វរបស់ទ្រង់

សូមសង្ខេប អាលម៉ា ១៧:១៨–២០ ដោយការពន្យល់ថា មុនពេលអ្នកផ្សព្វផ្សាយសាសនាទាំងនេះបានបែងចែកទៅបង្រៀនដំណឹងល្អនៅក្នុងតំបន់ខុសៗគ្នា អាំម៉ូនបានបង្រៀនពួកគេ ហើយបានប្រទានពរដល់ពួកគេ ។ បន្ទាប់មក គាត់បានទៅកាន់ដែនដីមួយហៅថាអ៊ីសម៉ាអែល ។ នៅពេលគាត់បានចូលទៅក្នុងដែនដីនោះ គាត់ត្រូវបានគេចាប់ ហើយយកទៅជូបនឹងស្តេច ។ សូមឲ្យសិស្សពីរនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ១៧:២១–២៥ ។

- តើអ្នកគិតថា អ្វីទៅជាការសំខាន់ដែលអាំម៉ូនបានប្រាប់ដល់ស្តេចថា « ទូលបង្គំនឹងធ្វើជាអ្នកបម្រើរបស់ទ្រង់ » ? (អាលម៉ា ១៧:២៥) ។
- តើនៅពេលណាដែលអ្នកបានឃើញការបម្រើដែលនាំទៅរកឱកាសដើម្បីចែកចាយដំណឹងល្អ ?

សូមសង្ខេបខ្លីៗនូវ អាលម៉ា ១៧:២៦–២៧ ដោយការពន្យល់ថា ខណៈពេលដែលអាំម៉ូនកំពុងមើលហ្វូងចៀមរបស់ស្តេច នោះមានក្រុមសាសន៍លេមិនបានមកធ្វើឲ្យហ្វូងចៀមខ្ចាត់ខ្ចាយ ។

សូមបែងចែកសិស្សទៅជាក្រុមដែលមានគ្នាបីនាក់ ។ សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖ *អាលម៉ា ១៧:២៨–៣២; អាលម៉ា ១៧:៣៣–៣៥; អាលម៉ា ១៧:៣៦–៣៩* ។ សូមឲ្យសិស្សក្នុងក្រុមនីមួយៗចែកវគ្គទាំងនេះរៀងៗខ្លួន ។ សូមឲ្យសិស្សអានវគ្គដែលដាក់ឲ្យដោយស្ងាត់ៗ ដោយរកមើលចម្លើយទៅនឹងសំណួរខាងក្រោម ។ (អ្នកអាចសរសេរសំណួរទាំងនេះនៅលើក្តារខៀន) ។

- តើមានអ្វីកើតឡើងនៅក្នុងវគ្គនៃរឿងរបស់អ្នក ?
- តើការណ៍នេះអាចជួយរៀបចំប្រជាជនឲ្យទទួលដំណឹងល្អដោយរបៀបណា ?
- តើអាំម៉ូនបង្ហាញអត្តចរិតអ្វីខ្លះ ?

សូមឲ្យក្រុមទាំងឡាយមានពេលពិភាក្សាពីចម្លើយរបស់ពួកគេ ។ បន្ទាប់មក សូមសួរ ៖

- តើយើងអាចរៀនអ្វីខ្លះពីដំណើររឿងនេះ ? (សិស្សអាចចែកចាយចម្លើយខុសគ្នា ។ ឧទាហរណ៍ ពួកគេអាចនិយាយថា **តាមរយៈការបម្រើ យើងអាចជួយអ្នកដទៃឲ្យរៀបចំទទួលយកដំណឹងល្អ** ឬថា **នៅពេលយើងនៅក្នុងការបម្រើដល់ព្រះអម្ចាស់ យើងអាចមានទំនុកចិត្ត និង មានសុទិដ្ឋិនិយម** ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរគោលការណ៍ទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។

សូមអញ្ជើញឲ្យសិស្សសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរបស់ពួកគេនូវអ្វីដែលពួកគេអាចធ្វើដើម្បីបង្ហាញគំរូល្អក្នុងការរស់នៅតាមដំណឹងល្អ ។ សម្រាប់យុវនារី គោលដៅនេះអាចជួយពួកគេឲ្យបំពេញក្នុងបទពិសោធន៍នៃគុណសម្បត្តិបន្ថែមនៅក្នុងសៀវភៅការអភិវឌ្ឍខ្លួននៅក្រោមចំណងជើងថា « កិច្ចការល្អ » ។ សម្រាប់ពួកបព្វជិតភាព គោលដៅនេះអាចជួយពួកគេឲ្យរៀន និងបំពេញកាតព្វកិច្ចរបស់ពួកគេដូចដែលបានរៀបរាប់នៅក្នុងសៀវភៅកាតព្វកិច្ចចំពោះព្រះក្រោមចំណងជើងថា « កាតព្វកិច្ចបព្វជិតភាព » និង « អញ្ជើញមនុស្សទាំងអស់ឲ្យមករកព្រះគ្រីស្ទ » ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អាលម៉ា ១៧ ។ ការបម្រើបេសកកម្មពេញម៉ោងដោយយុវនារី និងយុវជន

ប្រធាន ថូម៉ាស អេស. ម៉នសុន បានផ្តល់នូវការប្រឹក្សាខាងក្រោមដល់យុវជន និងយុវនារីទាក់ទងនឹងការទទួលខុសត្រូវដើម្បីបម្រើបេសកកម្មពេញម៉ោង ៖

« ចំពោះយុវជននៃបព្វជិតភាពអើរ៉ុន និងចំពោះយុវនារីដែលចម្រើនវ័យ ៖ ខ្ញុំសូមនិយាយម្តងទៀតនូវអ្វីដែលព្យាការីបានបង្រៀនជាយូរមកហើយ—ថារាល់យុវជនដែលសាកសមមានសមត្ថភាពគ្រប់រូបគួររៀបចំបម្រើបេសកកម្ម ។ ការបម្រើជាអ្នកផ្សព្វផ្សាយសាសនាគឺជាកាតព្វកិច្ចរបស់បព្វជិតភាព—ជាកាតព្វកិច្ចដែលព្រះអម្ចាស់រំពឹងចង់បានពីយើង ជាអ្នកដែលត្រូវបានប្រទានឲ្យនូវអ្វីៗជាច្រើន ។ « យុវជនទាំងឡាយ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យរៀបចំខ្លួនបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ សូមរក្សាខ្លួនអ្នកឲ្យស្អាតស្អំ បរិសុទ្ធ និងមានភាពសក្តិសមដើម្បីធ្វើជាតំណាងរបស់ព្រះអម្ចាស់ ។ សូមរក្សាសុខភាព និងកម្លាំងរបស់អ្នក ។ សូមសិក្សាព្រះគម្ពីរ ។ សូមចូលរួមថ្នាក់សិក្ខាសាលា ឬថ្នាក់វិទ្យាស្ថានបើសិនជាមានថ្នាក់រៀបចំឡើង ។ សូមយល់ដឹងពីក្បួនខ្នាតរបស់អ្នកផ្សព្វផ្សាយសាសនា*ប្រកាសដំណឹងល្អរបស់យើង* » ។

« សូមនិយាយដល់ប្អូនស្រីទាំងឡាយ ៖ ខណៈពេលដែលអ្នកមិនមានការទទួលខុសត្រូវបព្វជិតភាពដូចគ្នានឹងយុវជនដើម្បីបម្រើជាជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង អ្នកក៏អាចចូលរួមចំណែកដែលមានតម្លៃដូចគ្នាជាជាអ្នកផ្សព្វផ្សាយសាសនាដែរ ហើយយើងសូមស្វាគមន៍ការបម្រើរបស់អ្នក » (« កាលយើងជួបគ្នាម្តងទៀត » *Ensign*ឬ*លីអាហូណា*ខែវិច្ឆិកា ឆ្នាំ ២០១០, ទំព័រ ៥–៦) ។

អាលម៉ា ១៨

សេចក្តីផ្តើម

ស្តេចឡាម៉ូណៃបានតាក់ផ្តើលនឹងអំណាចដែលអាំម៉ូនបានបង្ហាញនៅក្នុងការការពារដល់ហ្វូងចៀមរបស់ទ្រង់ ។ ទ្រង់ថែមទាំងជឿថា អាំម៉ូនគឺជាវិញ្ញាណដ៏អស្ចារ្យ ។ អាំម៉ូនបានយល់ពីគំនិតរបស់ស្តេចដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ហើយអាំម៉ូនបានចាប់ផ្តើមបង្រៀនទ្រង់អំពីដំណឹងល្អ ។ ស្តេចឡាម៉ូណៃបានជឿអ្វីដែលអាំម៉ូនបានបង្រៀន បានទទួលស្គាល់ពីតម្រូវការដើម្បីមានព្រះអង្គសង្គ្រោះ បានព្រះកន្សែងសុំក្តីមេត្តាករុណាពីព្រះអម្ចាស់ ហើយបានយកឈ្នះដោយព្រះវិញ្ញាណ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ១៨:១–១១

ស្តេចឡាម៉ូណៃស្ទើចនឹងភក្តីភាពរបស់អាំម៉ូន

ការអំពុកដ៏ខ្លីមួយអំពីដំណើររឿងនៅចុងបញ្ចប់នៃ អាលម៉ា ១៧ នឹងជួយសិស្សឲ្យឃើញពីបរិបទនៃ អាលម៉ា ១៨. ។ ក៏នឹងជួយពួកគេឲ្យយល់ពីសារលិខិតនៅក្នុង អាលម៉ា ១៨ ដែរ ។ ដើម្បីរំពុក អាលម៉ា ១៧ សូមសួរសិស្សថា តើប្រយោគខាងក្រោមនេះត្រូវ ឬក៏ខុស ។ អ្នកអាចឲ្យពួកគេសរសេរចម្លើយរបស់ពួកគេ ។

១. ដោយសារតែស្តេចឡាំម៉ូណៃពេញចិត្តអាំម៉ូន ទ្រង់បានប្រទានបុត្រីរបស់ទ្រង់ឲ្យធ្វើជាភរិយារបស់អាំម៉ូន ។ (ពិត ។ (សូមមើល អាលម៉ា ១៧:២៤) ។

២. អាំម៉ូនបាននិយាយថា គាត់ចង់ក្លាយជាអ្នកបម្រើរបស់ស្តេច ។ (ពិត ។ សូមមើលអាលម៉ា ១៧:២៥) ។

៣. អាំម៉ូនបានខ្លាចស្លាប់ នៅពេលក្រុមសាសន៍លេមិនបានធ្វើឲ្យហ្វូងចៀមរបស់ស្តេចខ្ចាត់ខ្ចាយ ។ (ខុស ។ សូមមើល អាលម៉ា ១៧:២៨–៣០) ។

៤. ដោយអំណាចដ៏អស្ចារ្យ អាំម៉ូនបានបណ្តេញសាសន៍លេមិន ហើយបានកាត់ដៃរបស់អ្នកដែលបានលើកដំបងវាយគាត់ ។ (ពិត ។ (សូមមើល អាលម៉ា ១៧:៣៧–៣៨) ។

ក្រោយពីធ្វើលំហាត់នេះហើយ សូមប្រាកដថា សិស្សដឹងពីចម្លើយដែលត្រូវ ។

សូមសួរសិស្សថា តើពួកគេធ្លាប់ខ្លាច ឬ មានអារម្មណ៍មិនស្រួល ឬ ថាតើពួកគេធ្លាប់មានអារម្មណ៍ថាកិច្ចការ ឬភាពកិច្ចមួយពិបាកខ្លាំងសម្រាប់ពួកគេក្នុងការសម្រេចបានទេ ។ សូមប្រាប់ពួកគេថា នៅក្នុងមេរៀនថ្ងៃនេះ ពួកគេនឹងរៀនពីគោលការណ៍ដែលនឹងជួយពួកគេក្នុងស្ថានភាពបែបនោះ ។

សូមចែកសិស្សជាពីរក្រុម ។ សូមឲ្យក្រុមទីមួយអាន អាលម៉ា ១៨:១–៤ ហើយក្រុមទីពីរអាន អាលម៉ា ១៨:៨–១១ ។ នៅពេលពួកគេអាន សូមឲ្យពួកគេគិតពីភក្តីភាពរបស់អាំម៉ូនបានរៀបចំផ្លូវសម្រាប់គាត់ទៅបង្រៀនឡាម៉ូណៃ និងប្រជាជនរបស់ទ្រង់ ។ នៅពេលពួកគេមានពេលអានល្មមហើយ សូមសួរសំណួរខាងក្រោមនេះ ៖

- តើគំនិតអ្វីខ្លះស្តេច និងអ្នកបម្រើរបស់ទ្រង់មានចំពោះអត្តសញ្ញាណរបស់អាំម៉ូន ?
- យោងតាម អាលម៉ា ១៨:២, ៤ តើអ្វីដែលស្តេចឡាម៉ូណៃបានគិតថាគោលបំណងរបស់អាំម៉ូនបានកំពុងបំពេញ ? (ដាក់ទោសប្រជាជនដោយសារតែឃាតកម្មរបស់ពួកគេ និងដើម្បីកុំឲ្យឡាម៉ូណៃសម្លាប់អ្នកបម្រើរបស់ទ្រង់ច្រើនទៀត) ។
- យោងតាម អាលម៉ា ១៨:១០ តើអ្វីដែលធ្វើឲ្យឡាម៉ូណៃមានសេចក្តីអស្ចារ្យដល់អាំម៉ូន ក្រៅពីអំណាចដែលបានបង្ហាញនៅក្នុងការការពារដល់ហ្វូងចៀមនោះ ? (អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំពាក្យ *ចិត្តស្មោះត្រង់* និង *មានចិត្តស្មោះត្រង់*) ។

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *នៅពេលយើងបម្រើដល់អ្នកដទៃដោយចិត្តស្មោះត្រង់ . . .*

សូមឲ្យសិស្សគិតពីរបៀបដែលពួកគេអាចបំពេញប្រយោគនេះ នៅពេលពួកគេបន្តការសិក្សាលើ អាលម៉ា ១៨ ។

សូមរៀបចំសិស្សសម្រាប់ការសម្តែងដល់អ្នកអានជាមុន

នៅក្នុងពេលល្ងាចរបស់អ្នកអាន អ្នកចូលរួមមិនចូលរួមនោះទេ ។ ទោះជាយ៉ាងណាក្តី ពួកគេគួររៀបចំអានផ្នែករបស់ពួកគេតាមរបៀបមួយដ៏ច្បាស់ និងមានអត្ថន័យ ។ សូមប្រាកដថាពួកគេយល់ពីតួនាទីរបស់ពួកគេ ហើយមានពេលគ្រប់គ្រាន់ដើម្បីសិក្សាផ្នែករបស់ពួកគេ ។ អ្នកអាចដាក់កិច្ចការជាមុនដើម្បីពួកគេអាចស្គាល់ពីដំណើរឿង និងអនុវត្តការអានផ្នែករបស់ពួកគេ ។

អាលម៉ា១៨:១២–៤៣

នៅពេលអាំម៉ូនបង្រៀនពីផែនការនៃសេចក្តីប្រោសលោះ ឡាម៉ូណៃទទួលស្គាល់តម្រូវការដើម្បីមានព្រះអង្គសង្គ្រោះ

ដើម្បីជួយសិស្សឲ្យយល់ពីអំណាចនៃការបង្រៀនរបស់អាំម៉ូន និងការផ្លាស់ប្តូរដ៏អស្ចារ្យដែលស្តេចឡាម៉ូណៃបានចាប់ផ្តើមទទួល សូមបង្ហាញ អាលម៉ា ១៨:១២–៣៥ ជារោងល្ខោនរបស់អ្នកអាន ។ សូមជ្រើសរើសសិស្សបួននាក់ ហើយផ្តល់ផ្នែកមួយដល់គេម្នាក់ៗ ។ សូមឲ្យម្នាក់ធ្វើជាអ្នកអាន ហើយសូមឲ្យបីនាក់ទៀតអានពាក្យរបស់អាំម៉ូន ស្តេចឡាម៉ូណៃ និងអ្នកបម្រើម្នាក់របស់ស្តេច ។ សូមគិតពីការជួយសិស្សឲ្យរៀបចំដោយការឲ្យផ្នែកទាំងឡាយដល់ពួកគេជាមុន ប្រហែលជាមួយថ្ងៃមុនពេលមកថ្នាក់ ឬ ពីមុនចាប់ផ្តើមរៀន ។

សូមឲ្យសិស្សបួននាក់អានផ្នែករបស់ពួកគេនៅក្នុង អាលម៉ា ១៨:១២–១៥ ។ សូមឲ្យសិស្សអានតាមនៅក្នុងព្រះគម្ពីររបស់ពួកគេ ដោយរកមើលឥទ្ធិពលនៃការបម្រើរបស់អាំម៉ូនបានមានដល់ឡាម៉ូណៃ ។ ក្រោយពីអាន ខ ១៥ ហើយ សូមបញ្ឈប់ការសម្តែងរបស់អ្នកអានបន្តិច ហើយសូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

- តើអ្នកគិតថា ហេតុអ្វីបានជាឡាម៉ូណៃស្ងៀមស្ងាត់នៅពីមុខអាំម៉ូន ? (ប្រសិនបើត្រូវការ សូមជួយសិស្សឲ្យចាំថា ឡាម៉ូណៃបានខ្លាចដោយសារតែការសម្លាប់ដែលទ្រង់បានធ្វើ និង ដោយសារទ្រង់បារម្ភថា អាំម៉ូនគឺជាវិញ្ញាណដ៏អស្ចារ្យ ហើយបានមកដើម្បីដាក់ទោសទ្រង់) ។

សូមបន្តការសម្តែង ដោយការអញ្ជើញអ្នកចូលរួមឲ្យអានផ្នែករបស់ពួកគេនៅក្នុង អាលម៉ា ១៨:១៦–២១ ។ សូមលើកទឹកចិត្តសិស្សឲ្យរកមើលភស្តុតាងដែលអំណាចនៃព្រះបាននៅក្នុងអាំម៉ូន ។

- តើព្រះវិញ្ញាណនៃព្រះបានជួយអាំម៉ូននៅក្នុងស្ថានភាពនេះដោយរបៀបណា ?
- តើឡាម៉ូណៃចង់ដឹងអ្វីពីអាំម៉ូន ?
- មកដល់ចំណុចនេះនៃដំណើររឿង តើឡាម៉ូណៃបានដឹងអ្វីខ្លះពីអាំម៉ូន ? (ទ្រង់ដឹងថា អាំម៉ូនបានធ្វើការដោយអំណាចដ៏អស្ចារ្យ ហើយអាចដឹងពីគំនិតរបស់មនុស្សផ្សេងទៀត) ។

សូមឲ្យសិស្សមើលទៅប្រយោគមិនពេញលេញដែលអ្នកបានសរសេរនៅលើក្តារខៀន ៖ *នៅពេលយើងបម្រើដល់អ្នកដទៃដោយចិត្តស្មោះត្រង់* . . .

- ដោយផ្អែកលើអ្វីដែលយើងបានរៀននៅថ្ងៃនេះពី អាលម៉ា ១៧–១៨ តើអ្នកអាចបំពេញប្រយោគនេះដោយរបៀបណា ? (សិស្សអាចឆ្លើយតបតាមរបៀបខុសៗគ្នា ។ ដើម្បីសង្ខេបចម្លើយរបស់ពួកគេ សូមបំពេញប្រយោគនៅលើក្តារខៀនដូចខាងក្រោម ៖ ***នៅពេលយើងបម្រើដល់អ្នកដទៃដោយមានចិត្តស្មោះត្រង់ យើងអាចជួយពួកគេរៀបចំដើម្បីទទួលសេចក្តីពិតទាំងឡាយនៃដំណឹងល្អ ។***

សូមអញ្ជើញឲ្យអ្នកចូលរួមអានផ្នែករបស់ពួកគេនៅក្នុង អាលម៉ា ១៨:២២–៣២ ។ សូមឲ្យសិស្សអានតាម ដោយរកមើលសេចក្តីពិតជាក់លាក់ដែលអាំម៉ូនបានបង្រៀនដល់ឡាម៉ូណៃ ។ អ្នកអាចស្នើថា សិស្សគួរគូសចំណាំសេចក្តីពិតទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។ បន្ទាប់មក សូមឲ្យពួកគេរៀបរាប់ពីសេចក្តីពិតដែលពួកគេបានរកឃើញ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។

សូមអញ្ជើញឲ្យអ្នកចូលរួមអានផ្នែករបស់ពួកគេនៅក្នុង អាលម៉ា ១៨:៣៣–៣៥ ។ សូមឲ្យសិស្សរកមើលពីរបៀបដែលអាំម៉ូនបានពន្យល់ពីសមត្ថភាពរបស់គាត់ក្នុងការដឹងពីគំនិតរបស់ស្តេច និងពីសមត្ថភាពរបស់គាត់ដើម្បីការពារដល់ហ្វូងចៀមរបស់ស្តេច ។ ក្រោយពីអ្នកចូលរួមនៅក្នុងការសម្តែងរបស់អ្នកអានបានបញ្ចប់ការអានហើយ សូមអរគុណដល់ពួកគេសម្រាប់ជំនួយរបស់ពួកគេ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ ដើម្បីជួយសិស្សឲ្យឃើញពីរបៀបដែលព្រះបានប្រទានពរដល់អាំម៉ូនដើម្បីអាចបម្រើដល់ឡាម៉ូណៃ និងប្រជាជនរបស់ទ្រង់ សូមសួរ ៖

- តើអាំម៉ូនអាចធ្វើអ្វីខ្លះដែលហួសពីសមត្ថភាពធម្មតារបស់គាត់ ?

សូមបង្ហាញថា នៅពេលអាំម៉ូនកំពុងបម្រើដល់ស្តេចឡាម៉ូណៃ គាត់ក៏បានបម្រើដល់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្តដែរ ។ សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *នៅពេលយើងបម្រើដល់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្តដោយមានចិត្តស្មោះត្រង់* . . .

- ដោយផ្អែកលើអ្វីដែលអ្នកបានរៀនពីគំរូរបស់អាំម៉ូន តើអ្នកនឹងបំពេញប្រយោគនេះដោយរបៀបណា ? (សិស្សអានឆ្លើយខុសៗគ្នា ។ ដើម្បីសង្ខេបចម្លើយរបស់ពួកគេ សូមបំពេញប្រយោគនេះនៅលើក្តារខៀនដូចខាងក្រោម ៖ ***នៅពេលយើងបម្រើដល់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្តដោយមានចិត្តស្មោះត្រង់ នោះសមត្ថភាពរបស់យើងក្នុងការធ្វើកិច្ចការរបស់ទ្រង់នឹងកើនឡើង) ។***
- តើគោលការណ៍នេះអាចអនុវត្តដោយរបៀបណា ដល់នរណាម្នាក់ដែលមានខ្លាច ឬ មានអារម្មណ៍មិនសូប ឬ អ្នកដែលមានអារម្មណ៍ថាកិច្ចការ ឬកាតព្វកិច្ចមួយពិបាកធ្វើខ្លាំង ?
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្តបានជួយដល់អ្នកដើម្បីធ្វើកិច្ចការរបស់ទ្រង់នោះ ? (អ្នកអាចប្រាប់អំពីរបៀបដែលព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្តបានបង្កើនសមត្ថភាពរបស់អ្នកក្នុងកិច្ចការរបស់ទ្រង់ ។ ឬ អ្នកអាចចែកចាយគំរូមួយពីជីវិតរបស់នរណាម្នាក់ទៀត) ។

ដើម្បីជួយសិស្សឲ្យអនុវត្តគោលការណ៍នេះ សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ។ សូមឲ្យសិស្សសរសេរចម្លើយរបស់ពួកគេចំពោះសំណួរមួយ ។

តើគោលការណ៍នេះអាចជួយអ្នកក្នុងការទទួលខុសត្រូវនាពេលឥឡូវ និងនាពេលអនាគតរបស់អ្នកដោយរបៀបណា ?

តើអ្នកអាចមានចិត្តស្មោះត្រង់ខ្លាំងជាងនេះដោយរបៀបណា ដើម្បីអ្នកអាចមានអារម្មណ៍ថា ព្រះអម្ចាស់បង្កើនសមត្ថភាពរបស់អ្នកដើម្បីធ្វើកិច្ចការរបស់ទ្រង់ ?

សូមពន្យល់ថា ការដែលអាំម៉ូនឈានទៅបង្រៀនដល់ឡាម៉ូណៃនៅក្នុង អាលម៉ា ១៨:៣៦–៣៩ វាគឺជាគំរូមួយដែលត្រូវបានប្រើដោយអ្នកផ្សព្វផ្សាយសាសនានាសព្វថ្ងៃនេះ ។ គាត់បានបង្រៀនអំពីផែនការនៃសេចក្តីប្រោសលោះ រួមមានការបង្កើត ការធ្លាក់របស់អ័ដាម និងអេវ៉ា និងដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សគិតពីសំណួរខាងក្រោម ៖

- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីបង្រៀនអំពីការបង្កើត និងការធ្លាក់ នៅពេលយើងបង្រៀនអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ វ័សុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« មុនពេលយើងអាចយល់ពីដង្វាយធួននៃព្រះគ្រីស្ទ . . . យើងត្រូវតែយល់ជាមុនពីការធ្លាក់នៃអ័ដាម ។ ហើយមុនពេលយើងអាចយល់ពីការធ្លាក់របស់អ័ដាម យើងត្រូវយល់ជាមុនពីការបង្កើត ។ ធាតុដ៏សំខាន់ទាំងបីនៃផែនការនៃសេចក្តីសង្គ្រោះទាក់ទងគ្នាទៅវិញទៅមក ។ . . .

« . . . ជីវិតដ៏នៅអស់កល្បជានិច្ច ដែលអាចកើតមានបានដោយសារដង្វាយធួន គឺជាគោលបំណងដ៏ចម្បងនៃការបង្កើត »
(« “Atonement,” *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៦, ទំព័រ ៣៣, ៣៥) ។

ប្រសិនបើគោលលទ្ធិទាំងបីនេះមិនទាន់បានសរសេរនៅលើក្តារខៀនទេ សូមបន្តែមវាទៅលើបញ្ជីដែលអ្នកបានសរសេរពេលសម្តែងនោះ ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ១៨:៣៦–៣៩ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលធាតុនៃការបង្កើត ការធ្លាក់ និងដង្វាយធួននៅក្នុងការបង្រៀនរបស់អាំម៉ូនដល់ឡាម៉ូណៃ ។ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើការរៀនពីគោលលទ្ធិនៃការបង្កើត ការធ្លាក់ និងដង្វាយធួនបានជួយដល់ឡាម៉ូណៃឲ្យស្គាល់ពីតម្រូវការដើម្បីមានព្រះអង្គសង្គ្រោះដោយរបៀបណា ?

សូមឲ្យសិស្សអាន អាលម៉ា ១៨:៤០–៤៣ ស្ងាត់ៗ ដោយរកមើលអ្វីដែលឡាម៉ូណៃបានអធិស្ឋានសុំជាការឆ្លើយតបទៅនឹងការបង្រៀនរបស់អាំម៉ូន ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំការសុំរបស់ឡាម៉ូណៃ ។

- តើការអធិស្ឋានរបស់ឡាម៉ូណៃបានបង្ហាញអ្វីខ្លះ ថាទ្រង់បានយល់ពីអង្គទ្រង់ និងប្រជាជនរបស់ទ្រង់ ? (ទ្រង់បានយល់ថា ពួកគេបានមានបាប ហើយត្រូវការការអភ័យទោស) ។
- តើយើងអាចរៀនអ្វីខ្លះពីឡាម៉ូណៃ អំពីអ្វីដែលកើតឡើងនៅពេលយើងយល់ថា យើងត្រូវការព្រះអង្គសង្គ្រោះនោះ ? (នៅពេលសិស្សឆ្លើយនឹងសំណួរនេះ សូមជួយពួកគេឲ្យស្គាល់គោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងយល់ពីតម្រូវការដើម្បីមានព្រះអង្គសង្គ្រោះ យើងនឹងចង់ប្រែចិត្ត ។** អ្នកអាចអញ្ជើញសិស្សឲ្យសរសេរគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ១៨:៤០–៤១ ។ សូមបង្ហាញថា ខណៈពេលដែលបទពិសោធន៍ផ្ទាល់ខ្លួនយើងម្នាក់ៗអំពីការប្រែចិត្តអាចខុសគ្នា យើងទាំងអស់គ្នាអាចធ្វើតាមគំរូរបស់ស្តេចឡាម៉ូណៃនៅពេលយើងទូលសុំនូវសេចក្តីមេត្តាករុណាពីព្រះដោយស្មោះត្រង់នោះ) ។

សូមឲ្យសិស្សសរសេរចម្លើយរបស់ពួកគេទៅនឹងសំណួរខាងក្រោមនេះ ៖

- តើអ្នកអាចធ្វើអ្វីខ្លះ ដែលនឹងជួយអ្នកឲ្យចងចាំពីតម្រូវការរបស់អ្នកដើម្បីមានព្រះអង្គសង្គ្រោះ ?

វិចារណកថា និង ព័ត៌មានសាច់រឿង

អាលម៉ា ១៨:៣៦–៣៩ ។ ការបង្រៀនពីផែនការនៃសេចក្តីសង្គ្រោះ

នៅពេលអាំម៉ូនបានបង្រៀនឡាម៉ូណៃ « គាត់បានចាប់ផ្តើមនិយាយអំពីការបង្កបង្កើតលោកិយ » ហើយបន្ទាប់មក គាត់បានបង្រៀន « ទាក់ទងនឹងការធ្លាក់នៃអ័ដាម » (អាលម៉ា ១៨:៣៦) ។ ចុងបញ្ចប់ គាត់ « បានអធិប្បាយប្រាប់គេ [ស្តេច និងអ្នកបម្រើរបស់ទ្រង់] អំពីផែនការនៃសេចក្តីប្រោសលោះ » ជាពិសេស « ឲ្យដឹងអំពីការយាងមកនៃព្រះគ្រីស្ទ » (អាលម៉ា ១៨:៣៩) ។ ដូចគ្នាដែរ អើរ៉ុនបានបង្រៀនគោលលទ្ធិទាំងនេះដល់បិតារបស់ឡាម៉ូណៃ (សូមមើល អាលម៉ា ២២:១២–១៤) ។

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានហៅគោលទ្ធិគ្រឹះទាំងនេះ—ការបង្កបង្កើត ការធ្លាក់ និងដង្វាយធួន—ថាជា « សរសៃដ៏អស់កល្បជានិច្ចបី » និងជា « ហេតុការណ៍ដ៏អស្ចារ្យដែលធ្លាប់កើតឡើងនៅក្នុងភពដ៏អស់កល្បជានិច្ចទាំងអស់ » ។ គាត់បានពន្យល់ ៖

« ប្រសិនបើយើងអាចទទួលបានការយល់ដឹងពីវា បន្ទាប់មកស្នូលដ៏អស់កល្បជានិច្ចទាំងមូលនៃអ្វីៗទាំងអស់នឹងកើតមានតាមរបៀបវា ហើយយើងនឹងនៅក្នុងតំណែងមួយធ្វើការដើម្បីទទួលបានសេចក្តីសង្គ្រោះរបស់យើង ។ . . .

« . . . សរសៃទាំងបីនេះគឺជាគ្រឹះដែលអ្វីៗទាំងអស់សង់លើ ។ ដោយគ្មានសរសៃណាមួយនោះអ្វីៗទាំងអស់នឹងបាត់បង់គោលបំណង និងអត្ថន័យរបស់វា ហើយផែនការ និងការចងានៃព្រះនឹងក្លាយជាអសារបង់ » (« The Three Pillars of Eternity » [Brigham Young University devotional address, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៨១], ទំព័រ ១, speeches.byu.edu) ។

អែលឌើរ វ៉ៃសុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ពីរបៀបដែលធាតុនីមួយៗនៃផែនការនេះសំខាន់ប៉ុណ្ណា ។

« ផែនការតម្រូវឲ្យមានការបង្កបង្កើត ហើយថាជំនួសមកវិញវាត្រូវការទាំងការធ្លាក់ និងដង្វាយធួន ។ ទាំងនេះគឺជាធាតុជាមូលដ្ឋានបីនៃផែនការ ។ ផែនការនៃពិភពស្ថានសួគ៌ចេញមកពីព្រះ ។ ជីវិតរមែងស្លាប់ និងសេចក្តីស្លាប់មកកាន់ពិភពលោកនេះតាមរយៈការធ្លាក់របស់អ័ដាម ។ ជីវិតរមែងស្លាប់ និងការអោចមានជីវិតដ៏អស់កល្បជានិច្ចត្រូវបានផ្តល់ដោយដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ការបង្កបង្កើត ការធ្លាក់ និងដង្វាយធួនត្រូវបានគ្រោងទុកជាយូរ ពីមុនកិច្ចការដាក់ស្តែងនៃការបង្កបង្កើតបានចាប់ផ្តើម » (« “The Creation,” *Ensign,* ខែ ឧសភា ឆ្នាំ ២០០០, ទំព័រ ៨៤) ។

បន្ថែមលើការបង្រៀនគោលលទ្ធិដដែលនេះ អាំម៉ូននិងអើរ៉ុនបានប្រើរបៀបស្រដៀងគ្នានៅក្នុងការបង្រៀនរបស់ពួកគេ ។ ពួកគេបានបង្រៀនយ៉ាងសាមញ្ញ តាមរបៀបមួយដែលអ្នកស្តាប់របស់ពួកគេអាចយល់បាន (សូមមើល អាលម៉ា ១៨:២៤–៣០; ២២:៧–១១) ។ ពួកគេបានបង្រៀនចេញពីព្រះគម្ពីរ (សូមមើល អាលម៉ា ១៨:៣៦–៣៩; ២២:១២–១៤) ។ ការបង្រៀនរបស់ពួកគេបានដឹកនាំអ្នកដទៃឲ្យអធិស្ឋាន (សូមមើល អាលម៉ា ១៨:៤០–៤១; ២២:១៥–១៨) ។

អាលម៉ា ១៩–២០

សេចក្តីផ្តើម

ស្តេចឡាម៉ូណៃបានទទួលនូវការផ្លាស់ប្តូរក្នុងដួងចិត្ត ដែលនាំទៅរកការប្រែចិត្តជឿរបស់មហេសីទ្រង់ និងប្រជាជនជាច្រើនរបស់ទ្រង់ ។ បន្ទាប់មក អាំម៉ូន និងស្តេចឡាម៉ូណៃបានធ្វើដំណើរទៅមិឌដូណៃដើម្បីដោះលែងបងប្អូនប្រុសដែលជាប់គុករបស់អាំម៉ូន ។ នៅតាមផ្លូវ ពួកគាត់បានជួបនឹងបិតារបស់ឡាម៉ូណៃ ជាស្តេចនៃអស់ទាំងដែនដី ។ ព្រះអង្គបានរំកើបដោយសម្តីរបស់ឡាម៉ូណៃ និងអាំម៉ូន ដោយកម្លាំងរបស់អាំម៉ូន និងដោយសេចក្តីស្រឡាញ់របស់អាំម៉ូនចំពោះឡាម៉ូណៃ ។ ដួងចិត្តរបស់ទ្រង់ត្រូវបានបន្ទន់ ហើយទ្រង់បានជានាជាប់ពួកគេថា បងប្អូនប្រុសរបស់អាំម៉ូននឹងត្រូវដោះលែងពីគុក ។ ទ្រង់បង្ហាញពីបំណងប្រាថ្នាដើម្បីរៀនអំពីពាក្យដែលទ្រង់បានឮពីបុត្រារបស់ទ្រង់ និងអាំម៉ូន ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ១៩

ស្តេចឡាម៉ូណៃ និងប្រជាជនជាច្រើនរបស់ទ្រង់ប្រែចិត្ត ហើយបានជ្រមុជទឹក

សូមសួរសិស្ស ៖

- **នៅពេលដែលអ្នកទម្លាក់ថ្មទៅក្នុងអាងទឹកមួយ តើនឹងមានអ្វីកើតឡើងលើទឹកនោះ ?**

នៅពេលសិស្សរៀបរាប់ពីឥទ្ធិពលនៃថ្មដែលធ្លាក់ទៅក្នុងទឹក សូមគូសតារាងដូចខាងក្រោមនៅលើក្តារខៀន ដោយរំលងពាក្យទាំងឡាយ ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖

ដោយការចែកចាយទីបន្ទាល់របស់យើង និងការបង្ហាញគំរូដ៏សុចរិត យើងអាច . . .

សូមឲ្យសិស្សចាំប្រយោគនេះពេលរៀនមេរៀននេះ ហើយគិតពីរបៀបដែលពួកគេអាចបំពេញវា ។

- **តើសកម្មភាពរបស់បុគ្គលម្នាក់អាចដូចជាថ្មដែលបានធ្លាក់ទៅក្នុងទឹកនោះដោយរបៀបណា ? (សូមជួយសិស្សឲ្យយល់ថា ដូចជារលកដែលកើតពីការទម្លាក់ថ្មនោះដែរ មនុស្សផ្សេងទៀតអាចទទួលឥទ្ធិពលពីសកម្មភាពរបស់យើង) ។**

សូមសរសេរ *អាំម៉ូន* នៅក្នុងរង្វង់ទីមួយនៅក្នុងតារាង ។

- **តើនរណាដែលអាំម៉ូនបានបង្រៀនដំបូងគេបង្អស់ ? (ប្រសិនបើសិស្សត្រូវការជំនួយក្នុងការឆ្លើយនឹងសំណួរនេះ អ្នកអាចផ្តល់យោបល់ថា ពួកគេគួរអំពូកសេចក្តីសង្ខេបជំពូកនៃ អាលម៉ា ១៨ ។ សូមសរសេរ *ស្តេចឡាម៉ូណៃ* នៅលើរង្វង់ទីពីរក្នុងតារាង) ។**

សូមសង្ខេប អាលម៉ា ១៨:៤០–៤៣ និង ១៩:១–៥ ដោយការពន្យល់ថា នៅពេលស្តេចឡាម៉ូណៃបានស្តាប់តាមអាំម៉ូន ទ្រង់បានទទួលស្គាល់ពីអំពើបាបរបស់ទ្រង់ផ្ទាល់ និងពីតម្រូវការរបស់ទ្រង់ដើម្បីមានព្រះអង្គសង្គ្រោះ ។ ទ្រង់បានព្រះកន្សែងសុំឲ្យព្រះអម្ចាស់មេត្តាករុណា ហើយបន្ទាប់មកបានដួលទៅលើដី ។ ដោយជឿថា ទ្រង់បានស្លាប់ អ្នកបម្រើរបស់ទ្រង់បានយកទ្រង់ឲ្យទៅព្រះមហេសីទ្រង់ ហើយបានដាក់ទ្រង់នៅលើក្រលាបនុំ ។ ពីរថ្ងៃពីរយប់ក្រោយមក អ្នកបម្រើហៀបនឹងយកព្រះកាយរបស់ទ្រង់ទៅឯស្ពប នៅពេលម្ចាស់ក្សត្រីបានមានបន្ទូលថា ទ្រង់ចង់និយាយជាមួយនឹងអាំម៉ូន ។ ទ្រង់គិតថា ឡាម៉ូណៃមិនទាន់សុគតនោះទេ ហើយទ្រង់ចង់ឲ្យអាំម៉ូនទៅជួបនឹងព្រះអង្គ ។

សូមឲ្យសិស្សអាន អាលម៉ា ១៩:៦ ដោយស្ងាត់ៗ ដោយរកមើលឃ្លាមួយដែលពួកគេមានអារម្មណ៍ថា ពិពណ៌នាពីបទពិសោធន៍របស់ស្តេចឡាម៉ូណៃបានយ៉ាងល្អពិសេសជាងគេ ។ សូមហៅឲ្យសិស្សពីរបីនាក់អានឃ្លាដែលពួកគេបានជ្រើសរើស ។ សូមសួរពួកគេថា ហេតុអ្វីបានជាពួកគេបានរើសយកឃ្លាពិសេសទាំងនោះ ។

សូមសរសេរ *ម្ចាស់ក្សត្រី* នៅក្នុងរង្វង់បន្ទាប់នៅលើតារាង ។ សូមឲ្យសិស្សសិក្សា អាលម៉ា ១៩:៧–១១ ដើម្បីឃើញពីរបៀបដែលបទពិសោធន៍នេះជះឥទ្ធិពលដល់ម្ចាស់ក្សត្រី ។

- **តើយើងអាចរៀនអ្វីខ្លះពីម្ចាស់ក្សត្រីចេញពីខគម្ពីរទាំងនេះ ? (ចម្លើយអាចរួមមាន ទ្រង់ស្រឡាញ់ព្រះស្វាមីទ្រង់ ថាទ្រង់ទុកចិត្តអាំម៉ូន ហើយថាទ្រង់បានមានសេចក្តីជំនឿដ៏ខ្លាំង) ។**

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ១៩:១២–១៤ ឮៗ ។ សូមឲ្យសិស្សផ្សេងទៀតមើលតាម ដោយយកចិត្តទុកដាក់ជាពិសេសដល់ការបង្ហាញពីសេចក្តីជំនឿរបស់ស្តេចឡាម៉ូណៃ ។

- តើសេចក្តីពិតអ្វីខ្លះដែលស្តេចឡាម៉ូណៃបានរៀនអំឡុងពេលពីរថ្ងៃមុននេះ ?
- ស្តេចឡាម៉ូណៃ ម្ចាស់ក្សត្រី និងអាំម៉ូន « ត្រូវបានស្រោចដោយព្រះវិញ្ញាណ » និង « ពោរពេញទៅដោយសេចក្តីអំណរ » ។ តើនៅពេលណាដែលអ្នកមានអារម្មណ៍ពីឥទ្ធិពលនៃព្រះវិញ្ញាណតាមរបៀបមួយដ៏មានឥទ្ធិពល ? តើនៅពេលណាដែលអ្នកមានអារម្មណ៍សេចក្តីអំណរដ៏ខ្លាំង ?

សូមសរសេរ *អ្នកបម្រើរបស់ស្តេចឡាម៉ូណៃ* នៅលើរង្វង់បន្ទាប់នៅលើតារាង ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ១៩:១៥–១៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលភស្តុតាងដែលអ្នកបម្រើទាំងនេះបានបែរទៅរកព្រះ ។

- តើពាក្យ និងឃ្លាអ្វីខ្លះដែលបង្ហាញថា អ្នកបម្រើបានបែរទៅរកព្រះ ?

សូមសរសេរ *អ័ប៊ីស* នៅលើរង្វង់បន្ទាប់ ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ១៩:១៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពីរបៀបដែលអ័ប៊ីសទទួលឥទ្ធិពលពីហេតុការណ៍ទាំងនេះ ។

- តើអ័ប៊ីសបានធ្វើអ្វី ? តើនាងបានសង្ឃឹមថានឹងមានអ្វីកើតឡើងដោយសារតែសកម្មភាពរបស់នាងនោះ ?

សូមគិតពីឲ្យការឲ្យសិស្សមានឱកាសសង្ខេប អាលម៉ា ១៩:១៨–២៨ ។ សូមឲ្យពួកគេមានពេលអានខគម្ពីរទាំងនេះដោយស្ងាត់ៗ ។ បន្ទាប់មក សូមឲ្យមានអ្នកស្ម័គ្រចិត្តម្នាក់ដើម្បីប្រាប់ពីរឿងនេះជាសម្តីផ្ទាល់ខ្លួន ។ សូមឲ្យសិស្សផ្សេងទៀតជួយ ។ នៅពេលចាំបាច់ សូមជួយពួកគេឲ្យរួមបញ្ចូលនូវព័ត៌មានខាងក្រោម ៖ ក្រោយពីបានឮដំណឹងល្អពីអ័ប៊ីស ប្រជាជនបានប្រមូលផ្តុំគ្នានៅក្នុងដំណាក់របស់ស្តេច ។ នៅពេលពួកគេបានឃើញអាំម៉ូន ស្តេច ម្ចាស់ក្សត្រី និងអ្នកបម្រើបានដួលសន្លប់ មានការទាស់ទែងគ្នាដ៏ខ្លាំងមួយក្នុងចំណោមពួកគេ ។ បុរសម្នាក់បានព្យាយាមសម្លាប់អាំម៉ូន ប៉ុន្តែគាត់បានដួលស្លាប់ពេលប៉ុនប៉ង ។ អ្នកខ្លះបានអះអាងថា អាំម៉ូនគឺជាវិញ្ញាណដ៏អស្ចារ្យ ហើយអ្នកផ្សេងបាននិយាយថា គាត់គឺជាបិសាចមួយ ។ នៅពេលអ័ប៊ីសបានឃើញការទាស់ទែងទាំងអស់នេះដែលកើតពីការនាំប្រជាជនរបស់នាងមកជុំគ្នា នាងក្រៀមក្រំយ៉ាងខ្លាំង ។

សូមឲ្យសិស្សគិតពីអ្វីដែលពួកគេអាចធ្វើនៅក្នុងស្ថានភាពរបស់អ័ប៊ីស ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់អាន អាលម៉ា ១៩:២៩ ឮៗ ។

- តើសកម្មភាពរបស់អ័ប៊ីសបានបង្ហាញពីកម្លាំងនៃទីបន្ទាល់របស់នាងដោយរបៀបណា ? តើម្ចាស់ក្សត្រីបានបង្ហាញថា ទ្រង់បានទទួលទីបន្ទាល់មួយដោយរបៀបណា ?

សូមអាន អាលម៉ា ១៩:៣០–៣៦ ឮៗ ។ សូមឲ្យសិស្សអានតាម ហើយគិតពីឥទ្ធិពលនៃទីបន្ទាល់របស់អាំម៉ូន និងគំរូដែលបានមានដល់អ្នកដទៃ ។

សូមសរសេរ *សាសន៍លេមិនផ្សេងទៀតជារច្រើន* នៅក្នុងរង្វង់ចុងក្រោយនៅលើតារាង ។

សូមឲ្យសិស្សបំពេញប្រយោគដែលអ្នកបានសរសេរនៅលើក្តារខៀនពីពេលមុន ។ គោលការណ៍មួយដែលពួកគេអាចបង្ហាញគឺថា **ដោយការចែកចាយទីបន្ទាល់របស់យើង និងការបង្ហាញគំរូដ៏សុចរិត យើងអាចជួយអ្នកដទៃឲ្យបែរទៅរកព្រះអម្ចាស់ ។**

- តើនៅពេលណាដែលគំរូ ឬ ទីបន្ទាល់របស់នរណាម្នាក់បានជះឥទ្ធិពលដល់អ្នកសម្រាប់ការល្អ ?

សូមឲ្យសិស្សសញ្ជឹងគិតអំពីរបៀបដែលទីបន្ទាល់ និងគំរូរបស់ពួកគេអាចជះឥទ្ធិពលដល់សមាជិកគ្រួសារ មិត្តភក្តិ និងសហគមន៍របស់ពួកគេ ។ សូមឲ្យពួកគេសរសេរចម្លើយមួយទៅនឹងសំណួរខាងក្រោមនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ៖

- តើអ្នកអាចធ្វើអ្វីខ្លះនៅថ្ងៃនេះ ដែលអាចមានឥទ្ធិពលល្អដល់មនុស្សនៅជុំវិញអ្នក ?

សូមលើកទឹកចិត្តសិស្សដើម្បីអនុញ្ញាតឲ្យទីបន្ទាល់ និងគំរូដ៏សុចរិតរបស់ពួកគេមានឥទ្ធិពលដល់អ្នកដទៃ ដូចជាថ្មមួយធ្វើឲ្យមានរលកនៅក្នុងត្រពាំងមួយ ។ សូមប្រាប់សិស្សថា នៅក្នុងមេរៀនក្រោយ (មេរៀនទី ៨៥) អ្នកអាចសុំឲ្យពួកគេរៀបរាប់ពីការខំប្រឹងរបស់ពួកគេ ។

អាលម៉ា ២០

បិតារបស់ស្តេចឡាម៉ូណៃចង់រៀនអំពីដំណឹងល្អ ហើយចាប់ផ្តើមទទួលបានការផ្លាស់ប្តូរនៅក្នុងចិត្ត

សូមឲ្យសិស្សគិតពីពេលមួយដែលពួកគេបានមានអារម្មណ៍ថា ពួកគេរងនូវការអាក្រក់ ឬការមិនយុត្តិធម៌ ។

សូមពន្យល់ថា អាំម៉ូន និងស្តេចឡាម៉ូណៃបានជួបនឹងស្ថានភាពមួយដែលពួកគេរងការប្រព្រឹត្តដ៏អាក្រក់ ។ សូមបង្ហាញថា យើងអាចរៀនពីមេរៀនដ៏សំខាន់អំពីចម្លើយរបស់ពួកគេទៅនឹងរបៀបដែលពួកគេត្រូវបានគេប្រព្រឹត្តដាក់ ។

ដើម្បីជួយសិស្សឲ្យស្គាល់ពីដំណើររឿងនៅក្នុង អាលម៉ា ២០ សូមសង្ខេប អាលម៉ា ២០:១–៧ ដូចខាងក្រោម ៖ ស្តេចឡាម៉ូណៃចង់យកអាំម៉ូនទៅជួបនឹងបិតាទ្រង់ ដែលជាស្តេចនៃអស់ទាំងដែនដី ។ ព្រះអម្ចាស់បានបង្ហាញដល់អាម៉ូនថា អាំម៉ូនមិនគួរទៅទេ ដោយសារបិតារបស់ស្តេចឡាម៉ូណៃនឹងព្យាយាមសម្លាប់គាត់ ។ ព្រះអម្ចាស់ក៏បានបង្ហាញថា បងប្រុសរបស់អាំម៉ូនគឺ អើរ៉ុន និងដៃគូពីនាក់បានជាប់គុកនៅក្នុងដែនដីមិឌដូណៃ ។ អាំម៉ូនចង់ដោះលែងបងប្អូនប្រុសរបស់គាត់ ។ ដោយឮថា អាំម៉ូនបានដឹងពីការណ៍ទាំងនេះដោយវិវរណៈ ស្តេចឡាម៉ូណៃបានជួយដល់អាំម៉ូនដើម្បីរំដោះបងប្អូនប្រុសរបស់គាត់ ។

មុនចាប់ផ្តើមថ្នាក់ សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ឬ នៅលើក្រដាសមួយសម្រាប់សិស្សម្នាក់ៗ ។

១. អាលម៉ា ២០:៨–១៣	តើអ្នកមានអារម្មណ៍យ៉ាងណា ប្រសិនបើអ្នកនៅក្នុងតំណែងរបស់អាំម៉ូន ហើយនរណាម្នាក់បានចោទអ្នកថាជាមនុស្សកុហក និងជាចោរនោះ ?
២. អាលម៉ា ២០:១៤–១៦	តើយើងអាចរៀនមេរៀនអ្វីខ្លះពីការឆ្លើយតបរបស់ស្តេចឡាម៉ូណៃចំពោះបិតារបស់ទ្រង់ ?
៣. អាលម៉ា ២០:១៧–២៥	នៅពេលដែលបិតារបស់ស្តេចឡាម៉ូណៃបានឃើញថា អាំម៉ូនអាចសម្លាប់ទ្រង់ តើទ្រង់បានផ្តល់អ្វីដល់អាំម៉ូន ? តើអាំម៉ូនបានសុំអ្វីវិញទៅ ?
៤. អាលម៉ា ២០:២៦–២៧	តើសេចក្តីស្រឡាញ់របស់អាំម៉ូនចំពោះស្តេចឡាម៉ូណៃបានជះឥទ្ធិពលដល់បិតារបស់ទ្រង់ដោយរបៀបណា ? តើពាក្យរបស់អាំម៉ូន និងស្តេចឡាម៉ូណៃបានជះឥទ្ធិពលដល់បិតារបស់ស្តេចឡាម៉ូណៃតាមរបៀបណា ?

សូមឲ្យធ្វើការជាគូៗ ។ នៅក្នុងភាពជាដៃគូនេះ សូមឲ្យពួកគេអានខគម្ពីរដែលមាននៅក្នុងជួរទី ១–២ ហើយសូមពិភាក្សាពីចម្លើយចំពោះសំណួរដែលមានមកជាមួយនោះ ។ សូមលើកទឹកចិត្តពួកគេឲ្យរៀបចំដើម្បីចែកចាយចម្លើយរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ទាំងមូល ។

ក្រោយពីសិស្សបានពិភាក្សាពីជួរទី ១–២ ជាដៃគូហើយ សូមឲ្យពួកគេពីរបីនាក់រៀបរាប់ពីអ្វីដែលពួកគេបានរៀន ។ បន្ទាប់មក សូមសួរ ៖

- **តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពីខគម្ពីរទាំងនេះ ? (សិស្សអាចចែកចាយចម្លើយជាច្រើន ប៉ុន្តែសូមជួយពួកគេឲ្យឃើញពីគោលការណ៍ខាងក្រោម ៖ *យើងអាចថ្លែងទីបន្ទាល់របស់យើងដោយពាក្យ និងគំរូ ទោះបីជានៅពេលអ្នកផ្សេងព្យាយាមបញ្ចុះបញ្ចូលយើងឲ្យធ្វើអ្វីដែលខុសឆ្គងក៏ដោយ ។*អ្នកអាចផ្តល់យោបល់ថា ពួកគេគួរសរសេរគោលការណ៍នេះក្បែរ អាលម៉ា ២០:១៥) ។**

សូមឲ្យដៃគូទាំងឡាយសិក្សាខគម្ពីរដែលមាននៅក្នុងជួរទី ៣–៤ ហើយពិភាក្សាពីសំណួរដែលអមមកនោះ ។ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។ បន្ទាប់មក សូមសួរ ៖

- **តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពីខគម្ពីរទាំងនេះ ? (*ទោះបីជាសិស្សអាចចែកចាយពីគោលការណ៍ជាច្រើនក្តី សូមប្រាកដថាគោលការណ៍ខាងក្រោមត្រូវបានបញ្ចាក់ច្បាស់ ៖ នៅពេលយើងបង្ហាញសេចក្តីស្រឡាញ់ និងបង្រៀនពីសេចក្តីពិត យើងអាចជួយអ្នកដទៃឲ្យបន្ទន់ដួងចិត្តរបស់ពួកគេ ហើយទទួលយកដំណឹងល្អ ។*អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរគោលការណ៍នៅក្បែរ អាលម៉ា ២០:២៦–២៧) ។**

សូមឲ្យសិស្សចែកចាយពីបទពិសោធន៍ដែលពួកគេបានមាន ដែលបង្ហាញពីសេចក្តីពិតមួយនៃគោលការណ៍ដែលពួកគេបានរកឃើញនៅក្នុង អាលម៉ា ២០ ។ អ្នកក៏អាចចែកចាយពីបទពិសោធន៍មួយរបស់អ្នកដែរ ។

សូមបញ្ចប់ដោយការលើកទឹកចិត្តសិស្សឲ្យស្វែងរកការដឹកនាំពីព្រះវិញ្ញាណអំពីរបៀបដែលពួកគេអាចអនុវត្តគោលការណ៍ទាំងពីរនេះនៅក្នុងជីវិតរបស់ពួកគេ ។

អាលម៉ា ១៧–២២

សេចក្តីផ្តើម

បងប្រុសរបស់អាំម៉ូនគឺ អើរ៉ុន បានបង្រៀនពួកសាសន៍អាម៉ាលេកៃ ប៉ុន្តែពួកគេបានបដិសេធសារលិខិតរបស់គាត់អំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ បន្ទាប់មក គាត់បានបង្រៀននៅក្នុងមិទ្ធជូណៃ ជាកន្លែងដែលនៅទីបញ្ចប់គាត់ និងដៃគូរបស់គាត់ខ្លះត្រូវបានគេដាក់គុក ។ ពួកគេបាននៅបន្តស្មោះត្រង់អំឡុងពេលមានឧបសគ្គ ហើយពួកគេបានបន្តបេសកកម្មរបស់ពួកគេដើម្បីចែកចាយដំណឹងល្អ ក្រោយពីអាំម៉ូន និងស្តេចឡាម៉ូណៃបានធានាពីការដោះលែងរបស់ពួកគេ ។ ក្រោយពីបិតារបស់ស្តេចឡាម៉ូណៃត្រូវបានរៀបចំតាមរយៈគំរូរបស់អាំម៉ូន ទ្រង់បានរៀនពីអើរ៉ុនអំពីរបៀបដើម្បី « កើតពីព្រះ » (អាលម៉ា ២២:១៥) ។ បិតារបស់ស្តេចឡាម៉ូណៃបានរៀនថា ដោយការប្រែចិត្តពីអំពើបាបរបស់ទ្រង់ នោះទ្រង់អាចមកស្គាល់ព្រះ ហើយនៅទីបញ្ចប់នឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

យោបល់សម្រាប់ការបង្រៀន

សូមជួយសិស្សឲ្យអនុវត្តគោលលទ្ធិ និង គោលការណ៍ទាំងឡាយ

សូមសម្រេចចិត្តប្រកបដោយការអធិស្ឋានពីរបៀបដើម្បីជួយសិស្សឲ្យរកឃើញ និងអនុវត្តនូវគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៅក្នុងមេរៀនមួយ យោងតាមកាលៈទេសៈរៀងៗខ្លួនរបស់ពួកគេ ។

អាលម៉ា ២១

អើរ៉ុម និងបងប្អូនប្រុសរបស់គាត់បង្រៀនដំណឹងល្អ ទោះបីជាមានឧបសគ្គ និងការជាប់គុកក្តី

សូមសួរសិស្សថា តើពួកគេធ្លាប់មានអារម្មណ៍ថា ពួកគេកំពុងកាន់តាមព្រះបញ្ញត្តិទាំងឡាយអស់ពីសមត្ថភាពពួកគេហើយ ប៉ុន្តែនៅតែជួបនឹងឧបសគ្គ ឬ មានអារម្មណ៍បាក់ទឹកចិត្តទេ ។ សូមឲ្យពួកគេនិយាយពីស្ថានភាពខ្លះដែលមនុស្សអាចយល់ពីអារម្មណ៍នោះ ។

សូមពន្យល់ថា ខណៈពេលដែលអាំម៉ូនបានទទួលជោគជ័យក្នុងការបង្រៀនដល់ស្តេចឡាម៉ូណៃ និងប្រជាជនរបស់ទ្រង់ អើរ៉ុននិងដៃគូរបស់គាត់បានជួបនឹងឧបសគ្គដ៏ធំនៅក្នុងផ្នែកនៃដែនដីខុសគ្នា ។ នៅពេលសិស្សសិក្សាពីគំរូរបស់អើរ៉ុន និងដៃគូរបស់គាត់ សូមលើកទឹកចិត្តពួកគេឲ្យរកមើលមេរៀនដែលអាចជួយពួកគេ នៅពេលពួកគេជួបនឹងឧបសគ្គ ឬ មានអារម្មណ៍បាក់ទឹកចិត្ត ។

សូមសរសេរសេចក្តីយោងខាងក្រោមនៅលើក្តារខៀន ៖ *អាលម៉ា២១:១–៤; អាលម៉ា ២១:៥–៨; អាលម៉ា២១:៩–១១; អាលម៉ា២១:១២–១៥;*និង*អាលម៉ា២០:២៩–៣០* ។សូមបែងចែកសិស្សទៅជាប្រាំក្រុម ។ សូមឲ្យក្រុមនីមួយៗអានវគ្គមួយៗដែលបានសរសេរនៅលើក្តារខៀន ។ សូមឲ្យសិស្សរៀបចំផ្តល់ការសង្ខេបខ្លីមួយអំពីវគ្គដែលពួកគេអាន ហើយពិពណ៌នាពីការលំបាកនានាដែលអើរ៉ុន និងដៃគូរបស់គាត់បានជួប ។ ក្រោយពីបីនាទី សូមឲ្យសិស្សពីក្រុមនីមួយៗចែកចាយនូវអ្វីដែលពួកគេបានរកឃើញ ។

- តើអើរ៉ុន និងបងប្អូនប្រុសរបស់គាត់បានតស៊ូនឹងឧបសគ្គដោយរបៀបណា ? (សូមមើលអាលម៉ា ២០:២៩; ២១:៩, ១២, ១៥) ។
- ឧបសគ្គមួយដែលអើរ៉ុនបានជួបគឺ ការប្រឆាំងពីពួកសាសន៍អាម៉ាលេកៃ នៅពេលគាត់បានបង្រៀនដល់ពួកគេ (សូមមើល អាលម៉ា ២១:៥–១០) ។ តើយើងអាចធ្វើអ្វីខ្លះ ប្រសិនបើនរណាម្នាក់ចង់ឈ្លោះនឹងយើងអំពីសាសនា ឬ ប្រឆាំងនឹងជំនឿរបស់យើង ?

សូមរំឭកសិស្សពីសំណួរនៅពេលចាប់ផ្តើមមេរៀននេះ: ។ អើរ៉ុន និងបងប្អូនប្រុសរបស់គាត់បានធ្វើការខ្លាំងដើម្បីធ្វើអ្វីដូចដែលព្រះអម្ចាស់បានដឹកនាំពួកគេ ប៉ុន្តែពួកគេនៅតែជួបនឹងការលំបាក ។ សូមឲ្យសិស្សគិតដោយស្ងៀមស្ងាត់ពីរបៀបដែលពួកគេអាចមានអារម្មណ៍ប្រសិនបើពួកគេបានជួបនូវអ្វីដែលអើរ៉ុន និងដៃគូរបស់គាត់បានជួបនោះ: ។ តើពួកគេអាចធ្វើអ្វីខ្លះ: ក្រោយពីការងងុយក្តួ និងការជាប់គុកដោយសារតែដំណឹងល្អខណៈពេលនៅឆ្ងាយពីផ្ទះ: ? អ្នកអាចសួរពួកគេថា តើពួកគេនឹងចង់ទៅផ្ទះទេ ។

សូមសរសេរនូវគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ ***ប្រសិនបើយើងតស៊ូនឹងឧបសគ្គទាំងឡាយដោយស្មោះត្រង់នោះ ព្រះអម្ចាស់នឹងជួយយើងឲ្យធ្វើកិច្ចការរបស់ទ្រង់*** ។សូមឲ្យសិស្សអាន អាលម៉ា ២១:១៦–១៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ទាំងអស់មើលតាម ដោយរកមើលពី របៀបដែលព្រះអម្ចាស់បានជួយដល់អើរ៉ុន និងបងប្អូនប្រុសរបស់គាត់ឲ្យធ្វើកិច្ចការរបស់ទ្រង់ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

ដើម្បីជួយសិស្សឲ្យអនុវត្តគោលការណ៍ដែលបានសរសេរនៅលើក្តារខៀននេះ: សូមសួរគេថា តើកិច្ចការប្រភេទណាដែលព្រះមានសម្រាប់ឲ្យពួកគេធ្វើនាពេលឥឡូវនេះ: ហើយថាតើមានឧបសគ្គអ្វីខ្លះដែលពួកគេអាចជួបពេលព្យាយាមសម្រេចនូវកិច្ចការនេះ: ។ (អ្នកអាចបង្ហាញថា បន្ថែមលើកិច្ចការផ្សព្វផ្សាយសាសនា សិស្សអាចចូលរួមនៅក្នុងកិច្ចការរបស់ព្រះដោយការចូលរួមការប្រជុំក្នុងព្រះវិហារ ការបំពេញតាមការហៅបម្រើ និងកិច្ចការ ការបម្រើដល់អ្នកដទៃ ការពង្រឹងទីបន្ទាល់របស់ពួកគេ និងការក្លាយកាន់តែដូចជាព្រះគ្រីស្ទ) ។

សូមឲ្យសិស្សចែកចាយពីរបៀបដែលពួកគេបានដឹងថា គោលការណ៍ដែលអ្នកបានសរសេរនៅលើក្តារខៀននេះពិត ។ អ្នកអាចចែកចាយទីបន្ទាល់របស់អ្នកអំពីរបៀបដែលព្រះអម្ចាស់នឹងជួយយើងឲ្យសម្រេចបានកិច្ចការរបស់ទ្រង់ នៅពេលយើងតស៊ូឆ្លងកាត់ឧបសគ្គទាំងឡាយដោយចិត្តស្មោះត្រង់ ។ សូមឲ្យសិស្សនិយាយពីឧទាហរណ៍នៃពេលណាមួយក្នុងអនាគតកាល ដែលពួកគេគិតថាពួកគេអាចនឹងត្រូវតស៊ូឆ្លងកាត់ឧបសគ្គនានា នៅពេលពួកគេធ្វើកិច្ចការរបស់ព្រះអម្ចាស់ ។

សូមសង្ខេប អាលម៉ា ២១:១៨–២៣ ដោយការពន្យល់ថា ក្រោយពីការជួយធានាថានឹងមានដោះលែងអើរ៉ុន និងបងប្អូនប្រុសរបស់គាត់ចេញពីគុកហើយ អាំម៉ូន និងស្តេចឡាម៉ូណៃបានត្រឡប់ទៅកាន់ដែនដីអ័ីសម៉ាអែលវិញ ជាកន្លែងដែលពួកគាត់បានបន្តបង្រៀនដំណឹងល្អ ។ ស្តេចឡាម៉ូណៃបានផ្តល់នូវសេរីភាពខាងសាសនាដល់ប្រជាជនរបស់ទ្រង់ ។

អាលម៉ា ២២

អើរ៉ុនបង្រៀនដំណឹងល្អដល់បិតារបស់ស្តេចឡាម៉ូណៃ ដែលជឿ និងកើតពីព្រះ

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖

ហេតុអ្វីបានជាអ្នកចង់ទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ?

តើអ្នកនឹងមានឆន្ទៈលះបង់អ្វីខ្លះ ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ?

សូមពន្យល់ថា « ជីវិតដ៏នៅអស់កល្បជានិច្ច ឬ ភាពតម្កើងឡើង គឺដើម្បីគ្រងកន្លែងមួយនៅក្នុងលំដាប់ខ្ពស់បំផុតនៃនគរសេឡេស្ទាល ជាកន្លែងដែលយើងនឹងរស់នៅក្នុងវត្តមាននៃព្រះ ហើយបន្តរស់នៅជាក្រុមគ្រួសារ (សូមមើល គ . និង ស . ១៣១:១–៤) ។ . . . អំណោយនេះអាចកើតមានឡើងតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ » (*ពិតចំពោះសេចក្តីជំនឿ ៖ សេចក្តីរៀបរាងដំណឹងល្អ* [ឆ្នាំ ២០០៤], ទំព័រ ៥២) ។ សូមប្រាប់សិស្សដោយខ្លីៗពីមូលហេតុដែលអ្នកចង់ទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។ នៅពេលអ្នកធ្វើដូច្នោះ អ្នកអាចបង្ហាញរូបថតមួយនៃគ្រួសាររបស់អ្នក និងរូបភាពមួយនៃព្រះអង្គសង្គ្រោះ ។ បន្ទាប់មក សូមឲ្យសិស្សសញ្ជឹងគិតពីសំណួរនៅលើក្តារខៀន នៅពេលពួកគេសិក្សា អាលម៉ា ២២រួមគ្នា ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ២២:១ ឮៗ ។

- តើអ្នកចង់ចាំអ្វីខ្លះអំពីបិតារបស់ស្តេចឡាម៉ូណៃពីមេរៀនមុន ? (អ្នកអាចឲ្យសិស្សម្នាក់សង្ខេប អាលម៉ា ២០ ។)
- យោងតាម អាលម៉ា ២០:២៧ តើបិតារបស់ស្តេចឡាម៉ូណៃបានសុំឲ្យអាំម៉ូនធ្វើអ្វី ? (បង្រៀនទ្រង់ ។)

សូមសង្ខេប អាលម៉ា ២២:២–៣ ដោយការពន្យល់ថា ទោះបីជាបិតារបស់ស្តេចឡាម៉ូណៃចង់ឃើញអាំម៉ូន នឹងត្រូវបានបង្រៀនដោយគាត់ក្តី ក៏គាត់នៅតែចង់រៀននៅពេលអើរ៉ុនមកបង្រៀនគាត់ទៅវិញ ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ២២:៥–៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាមដោយរកមើលអ្វីដែលបិតារបស់ស្តេចឡាម៉ូណៃចង់ដឹង ។ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមបែងចែកសិស្សទាំងឡាយជាក្រុមតូចៗ ។ សូមឲ្យក្រុមទាំងឡាយអាន អាលម៉ា ២២:៧–១៤ រួមគ្នា ហើយធ្វើជាតារាងនៃគោលលទ្ធិដែលអើរ៉ុនបានបង្រៀនដល់បិតារបស់ស្តេចឡាម៉ូណៃ ។ (ឧទាហរណ៍ ពួកគេអាចនិយាយថា គាត់បានបង្រៀនអំពីការបង្កបង្កើត ការធ្លាក់ និង ដង្វាយធួន ។) ក្រោយពីក្រុមទាំងអស់បានចងក្រងជាតារាងរៀងៗខ្លួនហើយ សូមឲ្យសិស្សម្នាក់ចែកចាយដល់សិស្សក្នុងថ្នាក់នូវតារាងនៃគោលលទ្ធិដែលក្រុមរបស់គេបានបង្កើត ។ អ្នកអាចសុំឲ្យសិស្សនោះសរសេរតារាងរបស់គេនៅលើក្តារខៀន ។ បន្ទាប់មក សូមឲ្យសិស្សផ្សេងទៀតសរសេរគោលលទ្ធិបន្ថែមនានាដែលក្រុមរបស់គេបានមាន ។

- តើគោលលទ្ធិទាំងនេះឆ្លើយតបនឹងសំណួររបស់ស្តេចនៅក្នុង អាលម៉ា ២២:៦ ដោយរបៀបណា ?

សូមឲ្យសិស្សសិក្សា អាលម៉ា ២២:១៥ ដោយស្ងាត់ៗ ដោយរកមើលអ្វីដែលបិតារបស់ស្តេចឡាម៉ូណៃមានព្រះឆន្ទៈនឹងលះបង់ដើម្បីទទួលបានឪវាទសេចក្តីអំណរ និងជីវិតដ៏នៅអស់កល្បជានិច្ច ។

- តើអ្នកមានគំនិតអ្វីខ្លះ នៅពេលអ្នកគិតពីអ្វីស្តេចនឹងលះបង់នោះ ?

សូមបង្ហាញថា ទោះបីជាស្តេចមានឆន្ទៈនឹងលះបង់កម្មសិទ្ធិទាំងអស់ដែលទ្រង់មានក្តី ក៏អើរ៉ុនបានបង្រៀនទ្រង់អំពីការលះបង់ដ៏អស្ចារ្យដែលគាត់ត្រូវធ្វើ ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ២២:១៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកមើលអ្វីដែលអើរ៉ុនបាននិយាយពីអ្វីដែលស្តេចត្រូវធ្វើ ។

- តើអើរ៉ុនបាននិយាយអ្វីខ្លះ ដែលព្រះអង្គត្រូវធ្វើនោះ ? (ប្រែចិត្តពីអំពើបាបរបស់ទ្រង់ និង អធិស្ឋានទៅព្រះដោយសេចក្តីជំនឿ ។)

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ២២:១៧–១៨ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលចម្លើយរបស់ស្តេចទៅនឹងការណែនាំរបស់អើរ៉ុន ។

- តើព្រះអង្គបានបង្ហាញពីបំណងប្រាថ្នារបស់ទ្រង់ដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចដោយរបៀបណា ?
- តើអ្នកគិតថា « បោះបង់ចោល » អស់ទាំងអំពើបាបរបស់យើងមានអត្ថន័យយ៉ាងណា ? តើអ្នកគិតថា ហេតុអ្វីបានជាវាចាំបាច់ដើម្បីប្រែចិត្តពី *អស់ទាំង* អំពើបាបរបស់យើង មិនមែនគ្រាន់តែអំពើបាប*ខ្លះ*ៗនោះទេ ? (សូមជួយសិស្សឲ្យយល់ថា វាត្រូវការពេលវេលាសម្រាប់បុគ្គលម្នាក់ប្រែចិត្តពីអំពើរបស់គេទាំងអស់ ។)
- តើយើងអាចរៀនអ្វីខ្លះ ពីបិតារបស់ស្តេចឡាម៉ូណៃអំពីការរៀបចំសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ? (ខណៈពេលដែលសិស្សអាចប្រើពាក្យខុសៗគ្នា សូមប្រាកដថា ពួកគេយល់ពីសេចក្តីពិតទាំងអស់នេះ ៖ **យើងត្រូវតែមានឆន្ទៈបោះបង់អស់ទាំងអំពើបាបរបស់យើងទាំងឡាយដើម្បីរៀបចំសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ។** អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំឃ្លា « ទូលបង្គំនឹងបោះបង់ចោលអស់ទាំងអស់អំពើបាបរបស់ទូលបង្គំដើម្បីឲ្យបានស្គាល់ទ្រង់ » នៅក្នុង អាលម៉ា ២២:១៨ ។)

សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាលិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទលើកទឹកចិត្តយើងឲ្យផ្លាស់ប្តូរ ។ ‹ ប្រែចិត្ត › គឺជាសារលិខិតដែលត្រូវបាននិយាយជាញឹកញាប់បំផុត ហើយការប្រែចិត្តមានន័យថា ការលះបង់នូវការអនុវត្តទាំងអស់របស់យើង—ផ្ទាល់ខ្លួន គ្រួសារ វប្បធម៌ និង ជាតិ—ដែលផ្ទុយទៅនឹងព្រះបញ្ញត្តិទាំងឡាយនៃព្រះ ។ គោលបំណងនៃដំណឹងល្អគឺដើម្បីផ្លាស់ប្តូរមនុស្សធម្មតាទៅជាពលរដ្ឋនៃសេឡេស្ទាល ហើយវាតម្រូវឲ្យផ្លាស់ប្តូរ » (« Repentance and Change » *Ensign* ឬ *លេខអាហ្វណា*, ខែ វិច្ឆិកា ឆ្នាំ ២០០៣, ទំព័រ ៣៧) ។

សូមបង្ហាញថា មនុស្សខ្លះឆ្ងល់ថាតើពួកគេអាចប្រែចិត្ត និងផ្លាស់ប្តូរយ៉ាងពិតប្រាកដឬទេ ។ សំណួរមួយទៀតគឺថាតើព្រះអម្ចាស់នឹងអភ័យទោសដល់ពួកគេទេ ។ ដើម្បីជួយសិស្សដែលអាចមានការបារម្ភទាំងនេះ សូមអានសេចក្តីថ្លែងការណ៍ដូចតទៅនេះដោយសិស្ស អេលែន អេស ដាល់ថុន ប្រធានយុវនារីទូទៅ ៖

« តើអ្នកមានអ្វីខ្លះនៅក្នុងជីវិតរបស់អ្នកដែលអ្នកត្រូវផ្លាស់ប្តូរនោះ ? អ្នកអាចធ្វើវាបាន ។ អ្នកអាចប្រែចិត្តដោយសារតែការលះបង់ឲ្យធួនដ៏មហិមារបស់ព្រះអង្គសង្គ្រោះ ។ ទ្រង់បានធ្វើឲ្យវាកើតមានសម្រាប់អ្នក និងខ្ញុំដើម្បីផ្លាស់ប្តូរ ដើម្បីក្លាយជាបរិសុទ្ធ និងស្អាតម្តងទៀត និងដើម្បីក្លាយដូចជាទ្រង់ ។ ហើយទ្រង់បានសន្យាថា នៅពេលយើងធ្វើដូច្នោះ ទ្រង់នឹងលែងចាំអំពើបាប និងកំហុសរបស់យើងទៀតហើយ » (« Now Is the Time to Arise and Shine! » *Ensign* ឬ *លេខាហ្វណា*, ខែ ឧសភា ឆ្នាំ ២០១២, ទំព័រ ១២៤) ។

សូមពន្យល់ថា នៅពេលយើងអនុវត្តសេចក្តីជំនឿ ហើយប្រែចិត្តចេញអំពើបាបរបស់យើង នោះយើងនឹងសាកសមដើម្បីទទួលបាននូវពិធីការបព្វជិតភាព និងសេចក្តីសញ្ញានានាដែលជួយយើងឲ្យរៀបចំសម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ។

សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេនូវចម្លើយចំពោះសំណួរខាងក្រោម ។ (អ្នកអាចសរសេរសំណួរនេះនៅលើក្តារខៀន ឬ អានវាយឺតៗដើម្បីឲ្យសិស្សអាចកត់ត្រាទុក ។)

- ចេញពីអ្វីដែលអ្នកបានរៀនអំពីអ្វីដែលតម្រូវឲ្យមានដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច តើអ្នកមានអារម្មណ៍ថា តើព្រះអម្ចាស់នឹងសុំអ្នកឲ្យធ្វើអ្វីនៅថ្ងៃនេះ ដើម្បីឲ្យអ្នកអាចខិតទៅកាន់តែជិតនឹងទ្រង់ ?

នៅពេលសិស្សបានមានពេលល្មមដើម្បីគិត និងសរសេរហើយ សូមសួរ ៖

- តើមានភស្តុតាងអ្វីខ្លះដែលអ្នកឃើញថា ស្តេចបានប្រែចិត្តជឿដល់ព្រះអម្ចាស់ ? (សូមរំឭកសិស្សថា ស្តេចបានផ្លាស់ប្តូរពីការចង់សម្លាប់បុត្រារបស់ទ្រង់ទៅជាចង់លះបង់នគរទាំងមូលរបស់ទ្រង់ ហើយនិងអំពើបាបទាំងឡាយរបស់ទ្រង់ដើម្បីកើតពីព្រះ ។)

សូមសង្ខេប អាលម៉ា ២២:១៩–២១ ដោយការពន្យល់ថា ក្រោយពីស្តេចបានយកឈ្នះដោយព្រះវិញ្ញាណ អ្នកបម្រើរបស់ទ្រង់បានរត់មក ហើយបានប្រាប់ម្ចាស់ក្សត្រីពីអ្វីទាំងអស់ដែលបានកើតឡើង ។ ព្រះនាងក្រេវក្រោធ ហើយបានបញ្ជាអ្នកបម្រើឲ្យសម្លាប់អើរ៉ុន និងបងប្អូនប្រុសរបស់គាត់ ។ ដោយខ្លាចអំណាចរបស់អ្នកផ្សព្វផ្សាយសាសនាសាសន៍នីហ្វៃ អ្នកបម្រើបានបដិសេធមិនធ្វើ ។ ម្ចាស់ក្សត្រីក៏ខ្លាចដែរ ប៉ុន្តែទ្រង់បានសម្រេចថានឹងសម្លាប់សាសន៍នីហ្វៃចោល ។ ទ្រង់បានបញ្ជាអ្នកបម្រើឲ្យទៅនាំប្រជាជនឲ្យទៅសម្លាប់អើរ៉ុន និងដៃគូរបស់គាត់ ។

សូមឲ្យសិស្សអាន អាលម៉ា ២២:២២–២៦ ដោយស្ងាត់ៗ ដោយរកមើលសកម្មភាពដែលអើរ៉ុន និងស្តេចបានធ្វើ ដើម្បីឲ្យម្ចាស់ក្សត្រី និងអ្នកផ្សេងទៀតក៏អាចប្រែចិត្ត ហើយទទួលបានសេចក្តីអំណរដែរ ។ សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីការប្រែចិត្ត និងពរជ័យនៃការផ្លាស់ប្តូរតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។

ការរំឭកចំណេះចំណានខគម្ពីរ

យុវវ័យអាចរៀនដើម្បីប្រើព្រះគម្ពីរដើម្បីបង្រៀនសេចក្តីពិតនៃដំណឹងល្អ ។ សូមបែងចែកសិស្សជាដៃគូ ហើយសូមឲ្យដៃគូនីមួយៗរៀបចំការបង្ហាញពីមួយទៅពីរនាទី ដែលពួកគេបង្រៀនពីគោលលទ្ធិត្រីៈមួយ ដែលអ្នកនឹងដាក់ឲ្យពួកគេធ្វើ ។ សូមឲ្យពួកគេប្រើវគ្គចំណេះចំណានខគម្ពីរយ៉ាងហោចណាស់មួយក្នុងការបង្រៀនពីគោលលទ្ធិនោះ ។ សូមឲ្យពួកគេគិតពីការប្រើការពន្យល់ ឧទាហរណ៍ បទពិសោធន៍ និងទីបន្ទាល់នៅក្នុងការបង្រៀនផងដែរ ។ សិស្សទាំងពីរនៅក្នុងដៃគូនីមួយៗគួរចូលរួមក្នុងការបង្ហាញនោះ ។ ក្រោយពីមានពេលរៀបចំហើយ សូមឲ្យដៃគូពីរ ឬបីបង្រៀនដល់សិស្សក្នុងថ្នាក់ ។ សូមគិតពីសុំឲ្យដៃគូផ្សេងទៀតធ្វើការបង្ហាញ អំឡុងពេលការប្រជុំលើក្រោយ ឬ ក្រោយពីមេរៀនដ៏ខ្លីមួយ ។

កំណត់ចំណាំ ៖ ប្រសិនបើអ្នកមិនមានពេលសម្រាប់ធ្វើសកម្មភាពនេះជាផ្នែកនៃមេរៀនទេ អ្នកអាចប្រើវានៅថ្ងៃក្រោយ ។ សម្រាប់សកម្មភាពរំឭកផ្សេងទៀត សូមមើលឧបសម្ព័ន្ធនៅចុងបញ្ចប់នៃសៀវភៅនេះ ។

អាលម៉ា ២៣–២៤

សេចក្តីផ្តើម

បន្ទាប់ពីការប្រែចិត្តរបស់ទ្រង់ ស្តេចនៃសាសន៍លេមិនបានប្រកាសពីសេរីភាពខាងសាសនាក្នុងចំណោមប្រជាជនរបស់ទ្រង់ ។ ការប្រកាសនេះអនុញ្ញាតឲ្យអើរ៉ុន និងបងប្អូនប្រុសរបស់គាត់អាចបង្រៀនដំណឹងល្អ និងបង្កើតសាសនាចក្រនៅក្នុងទីក្រុងទាំងឡាយនៃសាសន៍លេមិន ។ សាសន៍លេមិនរាប់ពាន់នាក់ត្រូវបានផ្លាស់ប្រែចិត្ត ហើយមិនដែលធ្លាក់ចុះឡើយ ។ សាសន៍លេមិនដែលបានប្រែចិត្តទាំងនេះ បានធ្វើនូវសេចក្តីសញ្ញាមួយដើម្បីបោះបង់ចោលនូវអំពើសង្គ្រាមទាំងឡាយរបស់គេ ហើយពួកគេបានញែកខ្លួនគេចេញពីសាសន៍លេមិនដែលមិនបានប្រែចិត្តជឿ ដោយការហៅខ្លួនគេថា សាសន៍អាន់តៃ-នីហ្វៃ-លីហៃ ។ នៅពេលសាសន៍លេមិនដែលមិនបានប្រែចិត្តវាយប្រហារពួកគេ សាសន៍អាន់តៃ-នីហ្វៃ-លីហៃខ្លះបានលះបង់ជីវិតរបស់ពួកគេដើម្បីរក្សានូវសេចក្តីសញ្ញា ។

កំណត់ចំណាំ ៖ នៅក្នុងមេរៀនទី ៨៣អ្នកអាចបានលើកទឹកចិត្តសិស្សឲ្យអនុញ្ញាតឲ្យទីបន្ទាល់ និងគំរូដ៏សុចរិតរបស់ពួកគេជះឥទ្ធិពលដល់អ្នកដទៃ ដូចជាថ្មមួយធ្វើឲ្យមានរលកនៅក្នុងត្រពាំង ។ ប្រសិនបើអ្នកបានធ្វើហើយ សូមគិតពីការចាប់ផ្តើមមេរៀននេះ ដោយការសុំឲ្យសិស្សរៀបរាប់ពីការខំប្រឹងរបស់ពួកគេ ។

ការតាមដានលើការអញ្ជើញ

នៅពេលគ្រូបង្រៀនតាមដានលើការអញ្ជើញ និងកិច្ចការទាំងឡាយដែលបានដាក់ពីមេរៀនមុនមក សិស្សនឹងយល់ ហើយមានអារម្មណ៍ពីសារៈសំខាន់នៃការធ្វើតាមគោលការណ៍ដ៏ទេវភាព និង ការអនុវត្តវានៅក្នុងជីវិតក្រៅពីក្នុងថ្នាក់រៀន ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ២៣

សាសន៍លេមិនរាប់ពាន់នាក់ត្រូវបានប្រែចិត្តជឿដល់ព្រះអម្ចាស់

សូមគូសរូបភាពនៃមនុស្សពីរនាក់នៅលើក្តារខៀន (រូបភាពមនុស្សគូសសាមញ្ញទៅល្មមហើយ) ។ បន្ទាប់មក សូមអាននូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រីឆាដ ជី ស្កត នៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកនូវការពិពណ៌នារបស់អែលឌើរ ស្កត នៃប្រភេទមនុស្សពីរខុសគ្នា ។

« យើងម្នាក់ៗបានសង្កេតឃើញពីរបៀបដែលបុគ្គលខ្លះឆ្លងកាត់ជីវិតដោយធ្វើនូវអ្វីដែលត្រូវបានយ៉ាងខ្ជាប់ខ្ជួន ។ ពួកគេមើលទៅរីករាយ ហើយថែមទាំងពេញចិត្តនឹងជីវិតទៀត ។ នៅពេលជម្រើសដ៏ល្អបំផុតត្រូវបានសម្រេច ពួកគេហាក់ដូចជាសម្រេចនូវអ្វីដែលត្រូវមិនខុសគ្នាទេ ទោះបីជាមានជម្រើសដ៏ទាក់ទាញមានច្រើនដល់ពួកគេក្តី ។ យើងដឹងថា ពួកគេអាចត្រូវជាប់ការល្បួង ប៉ុន្តែពួកគេហាក់ដូចជាឃើញការល្បួងនោះច្បាស់ ។ ដូចគ្នាដែរ យើងបានសង្កេតឃើញពីរបៀបដែលអ្នកស្បែងមិនសូវក្លាហានក្នុងការសម្រេចចិត្ត ។ នៅក្នុងបរិយាកាសដ៏មានអំណាចខាងវិញ្ញាណ ពួកគេបានធ្វើល្អជាង ផ្លាស់ប្តូរផ្លូវនៃជីវិតរបស់ពួកគេ បោះបង់នូវទម្លាប់ដ៏ទន់ខ្សោយចោល ។ ពួកគេស្មោះត្រង់ខ្លាំងណាស់នៅក្នុងការប្តេជ្ញាចិត្តដើម្បីផ្លាស់ប្តូរ ប៉ុន្តែពួកគេនឹងត្រឡប់ទៅធ្វើអ្វីដែលពួកគេបានសម្រេចថានឹងបោះបង់ចោលនោះវិញភ្លាមៗដែរ ។

« តើវាគឺជាអ្វី ដែលធ្វើឲ្យមានភាពខុសគ្នានៅក្នុងជីវិតនៃក្រុមទាំងពីរនេះ ? តើអ្នកអាចរើសយកជម្រើសដែលត្រូវយ៉ាងខ្ជាប់ខ្ជួនដោយរបៀបណា ?» (« Full Conversion Brings Happiness »*Ensign,*ខែ ឧសភា ឆ្នាំ ២០០២, ទំព័រ ២៤) ។

សូមសួរសិស្សថា តើពួកគេអាចបញ្ចាក់ពីរូបភាពទាំងពីរនៅលើក្តារខៀនដោយផ្អែកលើប្រសាសន៍របស់អែលឌើរ ស្កត ដោយរបៀបណា ។ សូមបញ្ជាក់ហៅរូបមួយនៅលើក្តារខៀន *មានចិត្តស្មោះត្រង់* និងរូបមួយទៀតថា *មិនខ្ជាប់ខ្ជួន* ។សូមសួរសិស្សថា តើពួកគេឆ្លើយនឹងសំណួរដែលអែលឌើរ ស្កត បានសួរដោយរបៀបណា ៖

- « តើវាគឺជាអ្វី ដែលធ្វើឲ្យមានភាពខុសគ្នានៅក្នុងជីវិតនៃក្រុមទាំងពីរនេះ ?
- តើអ្នកអាចរើសយកជម្រើសត្រឹមត្រូវយ៉ាងខ្ជាប់ខ្ជួនដោយរបៀបណា ?»

នៅពេលសិស្សក្នុងថ្នាក់សិក្សា អាលម៉ា ២៣–២៤ សូមលើកទឹកចិត្តសិស្សឲ្យគិតអំពីអ្វីដែលជម្រុញឲ្យសមាជិកជាច្រើននៃសាសនាចក្រនៅតែបន្តពិត និងស្មោះត្រង់ពេញមួយជីវិតរបស់ពួកគេ ។

សូមសង្ខេប អាលម៉ា ២៣:១–៥ដោយការពន្យល់ថា ក្រោយពីស្តេចនៃសាសន៍លេមិនត្រូវបានប្រែចិត្តជឿ ទ្រង់បានចេញសេចក្តីប្រកាសដល់ប្រជាជនដែលប្រកាសថា ពួកគេគួរអនុញ្ញាតឲ្យអើរ៉ុន និងបងប្អូនប្រុសរបស់គាត់បង្រៀនព្រះបន្ទូលនៃព្រះទូទាំងដែនដីដោយគ្មានការបង្អាក់ និងដោយគ្មានការព្យាបាទ ។ សេចក្តីប្រកាសនេះធ្វើឲ្យអ្នកផ្សព្វផ្សាយសាសនាទាំងឡាយអាចបង្កើតសាសនាចក្រក្នុងចំណោមសាសន៍លេមិន ។ ជាលទ្ធផល សាសន៍លេមិនរាប់ពាន់នាក់ត្រូវបានប្រែចិត្តជឿ ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ២៣:៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរឿងពីរដែលបានជួយនាំឲ្យមានការប្រែចិត្តជឿនៃសាសន៍លេមិន ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដែលអាំម៉ូន និងបងប្អូនប្រុសរបស់គាត់បានបង្រៀនសាសន៍លេមិន « ទាក់ទងនឹងវិញ្ញាណនៃវិវរណៈ និង ការព្យាករណ៍ » ?
- តើអ្នកគិតថា « ព្រះចេស្តានៃព្រះដែល [បាន]សម្តែងអព្ភូតហេតុ » នៅក្នុងចំណោមសាសន៍លេមិន មានន័យដូចម្តេច ?

- តើនៅពេលណាដែលអ្នកបានទទួលព្រះចេស្តានៃព្រះដើម្បីជួយអ្នកឲ្យប្រែចិត្តជឿ ? តើនៅពេលណាដែលអ្នកបានឃើញពីព្រះចេស្តានៃព្រះធ្វើការដើម្បីជួយដល់នរណាម្នាក់ទៀតឲ្យប្រែចិត្តជឿ ?

សូមឲ្យសិស្សអាន អាលម៉ា ២៣:៦ ម្តងទៀត ដោយរកមើលឃ្លាដែលពិពណ៌នាពីសាសន៍លេមិនដែលបានជឿលើការបង្រៀនរបស់អាំម៉ូន និងបងប្អូនប្រុសរបស់គាត់ ។ (សូមប្រាកដថា សិស្សយល់ថា សាសន៍លេមិនទាំងនេះត្រូវ « បានប្រែចិត្តជឿដល់ព្រះអម្ចាស់ » មិនមែនដល់សាសនាចក្រ ឬ ដល់អ្នកផ្សព្វផ្សាយសាសនាដែលបានបង្រៀនដល់ពួកគេនោះឡើយ ។ សូមប្រាកដផងដែរថា សិស្សយល់ថា ប្រជាជនទាំងនេះ « មិនដែលបានធ្លាក់ចុះនោះឡើយ » ។ សូមសរសេរ *បានប្រែចិត្តជឿដល់ព្រះអម្ចាស់* និង *មិនដែលបានធ្លាក់ចុះនោះឡើយ* នៅលើក្តារខៀន នៅក្រោមរូបភាពដែលសរសេរថា *មានចិត្តស្មោះត្រង់*) ។

- នៅពេលយើងជួបនឹងស្ថានភាពពិបាក និង ឧបសគ្គ តើហេតុអ្វីបានជាវាសំខាន់ដែលយើងត្រូវប្រែចិត្តជឿដល់ព្រះអម្ចាស់ ជាជាងដល់មនុស្ស ឬគំនិតផ្សេងទៀតនោះ ?

សូមឲ្យសិស្សអាន អាលម៉ា ២៣:៧, ១៦–១៨ ដោយស្ងាត់ៗ ដោយរកមើលពាក្យ និងឃ្លាដែលផ្តល់នូវភស្តុតាងអំពីការប្រែចិត្តជឿរបស់សាសន៍លេមិន ។ សូមឲ្យសិស្សរាយការណ៍ពីអ្វីដែលពួកគេរកឃើញ ។ អ្នកអាចសរសេរពាក្យ និងឃ្លាទាំងនេះនៅលើក្តារខៀន នៅក្រោមរូបភាពដែលសរសេរថា *មានចិត្តស្មោះត្រង់* ។ដើម្បីជួយសិស្សឲ្យវិភាគខគម្ពីរទាំងនេះកាន់តែខ្លាំង អ្នកអាចសួរសំណួរដូចខាងក្រោម ៖

- តើបំណងប្រាថ្នារបស់ប្រជាជនចង់មានឈ្មោះថ្មីមួយ ជាភស្តុតាងថា ពួកគេបានផ្លាស់ប្តូរដោយរបៀបណា ?
- តើអ្នកទាំងឡាយដែលបានប្រែចិត្តជឿសព្វថ្ងៃនេះអាច « ញែកចេញ » ពីអ្នកដទៃដោយរបៀបណា ?
- យោងតាម អាលម៉ា ២៣:១៨ សាសន៍លេមិនដែលបានប្រែចិត្តជឿបានចាប់ផ្តើមឧស្សាហ៍ព្យាយាម និងរួសរាយនឹងសាសន៍នីហ្វៃ ។ នៅពេលបុគ្គលម្នាក់ព្យាយាមប្រែចិត្ត ឬផ្លាស់ប្តូរជីវិតរបស់គេ តើវាអាចជួយដល់គេដើម្បីទាក់ទងនឹងមនុស្សផ្សេងទៀតដែលបានប្រែចិត្តជឿហើយដោយរបៀបណា ?

សូមសរសេរពាក្យខាងក្រោមនៅលើក្តារខៀន ៖ *ការប្រែចិត្តជឿមានន័យថា . . .*

សូមឲ្យសិស្សសង្ខេបអ្វីដែលពួកគេបានរៀនពី អាលម៉ា ២៣ ដោយការបំពេញប្រយោគនៅលើក្តារខៀន ។ សិស្សអាចប្រើពាក្យខុសគ្នាក្នុងចម្លើយរបស់ពួកគេ ប៉ុន្តែពួកគេគួរបង្ហាញនូវសេចក្តីពិតដូចខាងក្រោម ៖ **ការប្រែចិត្តជឿមានន័យថា ការផ្លាស់ប្តូរ និងការក្លាយជាបុគ្គលថ្មីមួយតាមរយៈអំណាចនៃព្រះ ។**សូមបំពេញប្រយោគនៅលើក្តារខៀន ។

សូមឲ្យសិស្សមើលទៅពាក្យ *មានចិត្តស្មោះត្រង់*និង*មិនខ្ជាប់ខ្ជួន* នៅលើក្តារខៀន ។ សូមលើកទឹកចិត្តពួកគេឲ្យគិតពីពាក្យមួយ ដែលពិពណ៌នាបានល្អបំផុតពីលំដាប់នៃការប្រែចិត្តរបស់ពួកគេ ។

អាលម៉ា ២៤

សាសន៍ អាន់តៃ-នីហ្វៃ-លីហៃ ធ្វើសេចក្តីសញ្ញាថានឹងមិនប្រើអាវុធម្តងទៀតនោះឡើយ

សូមឲ្យសិស្សគិតដោយស្ងៀមស្ងាត់ ថាតើពួកគេធ្លាប់បានប្តេជ្ញាចិត្តដើម្បីចៀសវាងការប្រព្រឹត្តកំហុស ឬ អំពើបាបមួយចំនួនដដែល ប៉ុន្តែក្រោយមកបានធ្វើនូវកំហុស ឬ អំពើបាបនោះម្តងទៀតទេ ។ សូមពន្យល់ថា ប្រសិនបើពួកគេធ្លាប់មាន សូមឲ្យពួកគេបន្តព្យាយាមពង្រឹងវាឡើង ។ នៅពេលពួកគេសិក្សា អាលម៉ា ២៤ ពួកគេនឹងរៀនពីសេចក្តីពិតដែលនឹងជួយពួកគេ ។

សូមសង្ខេប អាលម៉ា ២៤:១–៥ ដោយការពន្យល់ថា ពួកសាសន៍អាម៉ាលេកៃ និងពួកសាសន៍អាម៉ូឡុន ដែលជាសាសន៍នីហ្វៃពីមុននោះ បានចាក់រុកនឹងសាសន៍លេមិនជាច្រើនឲ្យខឹងសម្បារនឹងស្តេចរបស់ពួកគេ និងសាសន៍អាន់តៃនីហ្វៃលីហៃផ្សេងទៀត ។ ដោយកំហឹង សាសន៍លេមិនទាំងនេះបានរៀបចំវាយប្រហារនឹងពួកសាសន៍អាន់តៃនីហ្វៃលីហៃ ។ នៅក្នុងពេលបញ្ហានេះ ស្តេចនៃសាសន៍អាន់តៃនីហ្វៃលីហៃបានសុគត ។ នគរត្រូវបានប្រទានទៅដល់បុត្រាមួយអង្គរបស់ទ្រង់ ។ អាំម៉ូនបានប្រមូលផ្តុំស្តេចថ្មី និងជាមួយនឹងស្តេចឡាម៉ូណៃ និងអ្នកផ្សេងទៀតឲ្យមកប្រឹក្សានឹងគ្នា និងសម្រេចពីរបៀបដើម្បីការពារខ្លួនគេប្រឆាំងនឹងសាសន៍លេមិន ។

សូមឲ្យសិស្សអាន អាលម៉ា ២៤:៦ ដោយស្ងាត់ៗ ដោយរកមើលអ្វីដែលសាសន៍អាន់តៃនីហ្វៃលីហៃ បានសម្រេចថាពួកគេនឹងមិនធ្វើ ។ ក្រោយពីសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ហើយសូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮពី អាលម៉ា ២៤:៧–១០, ១២–១៤ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយស្តាប់រកមើលពីរបៀបទាំងឡាយដែលស្តេចនៃសាសន៍អាន់តៃនីហ្វៃលីហៃ បានទទួលស្គាល់ថា ព្រះបានប្រទានពរដល់ពួកគេ ។

- យោងតាម អាលម៉ា ២៤:៩ តើអ្វីជាអំពើបាបមួយរបស់សាសន៍អាន់តៃនីហ្វៃលីហៃដែលបានប្រព្រឹត្តកាលពីមុន ?
- យោងតាម អាលម៉ា ២៤:១៣ ហេតុអ្វីបានជាពួកគេបដិសេធមិនប្រយុទ្ធនឹងសង្គ្រាមនេះ ?

សូមបែងចែកសិស្សក្នុងថ្នាក់ជាពីរក្រុម ។ សូមឲ្យក្រុមទីមួយអាន អាលម៉ា ២៤:១១, ១៥ ដោយរកមើលឃ្លាដែលបង្ហាញពីការខំប្រឹងរបស់សាសន៍អាន់តៃនីហ្វៃលីហៃដើម្បីប្រែចិត្ត ។ សូមឲ្យក្រុមទីពីរអាន អាលម៉ា ២៤:១៦–១៩ដោយរកមើលអ្វីដែលសាសន៍អាន់តៃ-នីហ្វៃលីហៃបានធ្វើដើម្បីធានាថា ពួកគេនឹងនៅតែស្អាតស្អំ ។ ក្រោយពីសិស្សមានពេលអានហើយ សូមឲ្យពួកគេចែកចាយនូវអ្វីដែលពួកគេបានរកឃើញ ។ អ្នកអាចប្រើសំណួរខាងក្រោមដើម្បីនាំមកនូវគំនិតបន្ថែម ៖

- តើអ្នកគិតថា ស្តេចមានន័យយ៉ាងណា នៅពេលទ្រង់បានមានបន្ទូលថា « ការណ៍ទាំងអស់នេះហើយ ដែលយើងរាល់គ្នាអាចធ្វើ . . . ដើម្បីប្រែចិត្ត » ? (អាលម៉ា ២៤:១១) ។ (ឃ្លានេះបង្ហាញពីការខំប្រឹង និងការប្តេជ្ញាដ៏ខ្លាំងរបស់សាសន៍អាន់តៃនីហ្វៃ-លីហៃដើម្បីប្រែចិត្តពីអំពើបាបរបស់ពួកគេ) ។

- ពាក្យ *ទីបន្ទាល់* លេចឡើងបីដងនៅក្នុង អាលម៉ា ២៤:១៥–១៦, ១៨ ។ តើការកប់អាវុធរបស់ពួកគេទៅក្នុងដីធ្វើជាទីបន្ទាល់មួយយ៉ាងណាដែរ ? (វាបានបង្ហាញដល់ប្រជាជនផ្សេងទៀត និងដល់ព្រះថា ពួកគេពិតជាបានលះបង់ ឬ បោះបង់ចោលនូវអំពើបាបរបស់ពួកគេមែន ។)

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ស្ពែនសើរ ដបុលយូ ឃឹមបឹល ៖

« ដើម្បីបោះបង់ចោលអំពើបាប យើងមិនអាចគ្រាន់តែចង់បានស្ថានភាពដ៏ប្រសើរនោះទេ ។ . . . គេត្រូវតែប្រាកដថា គេមិនត្រឹមតែបានបោះបង់ចោលនូវអំពើបាបនោះទេ ប៉ុន្តែថែមទាំងបានផ្លាស់ប្តូរនូវស្ថានភាពជុំវិញអំពើបាបនោះទៀតផង ។ គេគួរចៀសវាងនូវកន្លែង និងស្ថានភាព និងកាលៈទេសៈនានាដែលអំពើបានកើតឡើង ដោយសារវាអាចនឹងកើតឡើងម្តងទៀតបានយ៉ាងខ្លាំងបំផុត ។ គេត្រូវតែបោះបង់មនុស្សដែលបានប្រព្រឹត្តអំពើបាបនោះ ។ គេមិនមែនស្អប់មនុស្សដែលទាក់ទងនោះទេ ប៉ុន្តែគេត្រូវតែចៀសវាងពីពួកគេ និងអ្វីៗទាំងឡាយដែលពាក់ព័ន្ធនឹងអំពើបាបនោះ » (*The Miracle of Forgiveness* | ឆ្នាំ ១៩៦៩ | ទំព័រ ១៧១–៧២) ។

- តើសាសន៍អាន់តៃ-នីហ្វៃ-លីហៃបានធ្វើអ្វីខ្លះ ដើម្បីចៀសវាងនូវស្ថានភាព និងមនុស្សដែលអាចទាក់ទាញពួកគេឲ្យប្រព្រឹត្តអំពើបាបពីមុនរបស់ពួកគេ ?

អ្នកអាចឲ្យសិស្សមានពេលគិតថា តើមានកាលៈទេសៈណាខ្លះដែលជីវិតរបស់ពួកគេ ត្រូវការការផ្លាស់ប្តូរដើម្បីប្រែចិត្ត និងបោះបង់អំពើបាបមួយដែលពួកគបានតស៊ូនឹងលះបង់ ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ប្រសិនបើយើង . . . ព្រះនឹង . . .*

សូមឲ្យសិស្សរំឭក អាលម៉ា ២៤:១០–១៨ ដោយរកមើលរបៀបដែលពួកគេអាចបំពេញប្រយោគនៅលើក្តារខៀនបាន ។ (អ្នកអាចផ្តល់យោបល់ថា សិស្សគួរសរសេរប្រយោគមួយដូចខាងក្រោមនៅក្នុងព្រះគម្ពីររបស់ពួកគេ ៖ **ប្រសិនបើយើងធ្វើនូវអ្វីៗទាំងអស់ដែលយើងអាចដើម្បីប្រែចិត្តនោះ ព្រះនឹងបោះចោលនូវកំហុសរបស់យើង ហើយជួយយើងឲ្យនៅតែស្អាតស្អំ**) ។

សូមឲ្យសិស្សបើកទៅ អាលម៉ា ២៤:១៧ ។

- តើគំរូអ្វីខ្លះនៃអាវុធនៃការបះបោរ (សូមមើល អាលម៉ា ២៣:៧) ដែលមនុស្សអានដាក់ចុះ ឬ កប់ចោល នៅពេលពួកគេបានប្រែចិត្តជឿដល់ព្រះអម្ចាស់ ? (សូមជួយសិស្សឲ្យឃើញថា អាវុធនៃការបះបោរអាចរួមមាន ឥរិយាបថ ឬសកម្មភាពដ៏មានបាបដែលមនុស្សត្រូវតែលះបង់ដើម្បីបានប្រែចិត្តជឿដល់ព្រះអម្ចាស់) ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដៃហ្វ្រី អ័រ ហូឡិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« វាពិតជាចំណាយពេលដ៏យូរដើម្បីប្រែចិត្តគឺដូចជា ពេលអ្នកនិយាយថា ‹ ខ្ញុំនឹងផ្លាស់ប្តូរ ›—ហើយអ្នកនឹងធ្វើវា ។ មែនហើយ នឹងមានបញ្ហាក្នុងពេលអនុវត្ត ហើយនឹងមានការផ្តុំឡើងវិញ ។ អ្នកអាចចំណាយពេលគួរសម—ពិតហើយថា អ្នកត្រូវតែចំណាយពេលនោះ—ពេញមួយជីវិតរបស់អ្នកដើម្បីបញ្ឈប់ការប្រែចិត្តរបស់អ្នក ដោយការមានជាអចិន្ត្រៃយ៍ » (« For Times of Trouble »*New Era,*ខែ តុលា ឆ្នាំ ១៩៨០ ទំព័រ ១១–១២) ។

សូមឲ្យសិស្សពន្យល់ពីសកម្មភាពរបស់យុវជន ឬ យុវនារីម្នាក់ដែលអាចធ្វើដើម្បីចៀសវាងពីការធ្វើអំពើបាបខាងក្រោមនីមួយៗច្រំដែល ៖ ការរំលងពាក្យនៃប្រាជ្ញាវាងវៃ ការមើលរឿងអាសអាភាស និងការមិនមានចិត្តល្អដល់បងប្អូនបង្កើតឯង ។

សូមឲ្យសិស្សស្រមៃពីអារម្មណ៍ដែលសាសន៍អាន់តៃ-នីហ្វៃ-លីហៃអាចមាន ក្រោយពីពួកគេបានកប់អាវុធរបស់ពួកគេចោល ហើយបន្ទាប់មកបានដឹងថា កងទ័ពសាសន៍លេមិននឹងមកវាយប្រហារពួកគេ ។ សូមឲ្យសិស្សគិតពីស្ថានភាពនេះ នៅពេលពួកគេអានអាលម៉ា ២៤:២០–២២ ដោយស្ងាត់ៗ ។

សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***នៅពេលយើងរក្សាសេចក្តីសញ្ញារបស់យើង យើងអាចជួយអ្នកដទៃឲ្យប្រែចិត្តជឿបាន ។*** សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ២៤:២៣–២៧ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពាក្យ ឬ ឃ្លាដែលបង្រៀនពីគោលការណ៍ដែលបានសរសេរនៅលើក្តារខៀន ។

- តើដំណើររឿងនេះជះឥទ្ធិពលដល់បំណងប្រាថ្នារបស់អ្នកដើម្បីរក្សាសេចក្តីសញ្ញារបស់អ្នកដោយរបៀបណា ?
- តើយើងអាចធ្វើអ្វីខ្លះដើម្បីពង្រឹងបំណងប្រាថ្នា និងសមត្ថភាពរបស់យើងដើម្បីរក្សាសេចក្តីសញ្ញា ដែលយើងបានធ្វើជាមួយនឹងព្រះអម្ចាស់ ?

សូមឲ្យសិស្សចែកចាយបទពិសោធន៍ខ្លះៗ ដែលពួកគេបានមានអំពីគោលការណ៍នៅលើក្តារខៀននេះ ។ សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍ដែលបានបង្រៀននៅក្នុងមេរៀននេះ ។

មេរៀនសិក្សានៅផ្ទះ

អាលម៉ា ១៧–២៤ (មេរៀនទី ១៧)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀននៅពេលពួកគេសិក្សា អាលម៉ា១៧–២៤(មេរៀនទី ១៧) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។ សូមធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (អាលម៉ា ១៧–១៨)

ចេញពីគំរូរបស់អាំម៉ូន និងបងប្អូនប្រុសរបស់គាត់ដែលបានបង្រៀនដល់សាសន៍លេមិន សិស្សបានរៀនថា ដោយការសិក្សាព្រះគម្ពីរ ការអធិស្ឋាន និងការតមអាហារ យើងអាចទទួលបានព្រះវិញ្ញាណបរិសុទ្ធ និងបង្រៀនអ្នកដទៃដោយអំណាច ។ ការបម្រើរបស់អាំម៉ូនដល់ស្តេចឡាម៉ូណៃក៏បានបង្រៀនពីចំណែកដ៏សំខាន់មួយនៃការបម្រើរបស់អ្នកផ្សព្វផ្សាយសាសនា—ថានៅពេលយើងបង្ហាញគំរូដ៏ល្អៗ ព្រះអម្ចាស់អាចធ្វើឲ្យយើងក្លាយជាគ្រឿងឧបករណ៍នៅក្នុងព្រះហស្តរបស់ទ្រង់ ។ សិស្សអាចយើញថា ការបម្រើរបស់អាំម៉ូនដល់ស្តេចឡាម៉ូណៃបានរៀបចំអ្នកដឹកនាំសាសន៍លេមិន និងអ្នកដទៃឲ្យទទួលយកដំណឹងល្អ ។ ការប្រែចិត្តជឿរបស់ស្តេចឡាម៉ូណៃបង្រៀនថា នៅពេលយើងយល់ពីតម្រូវការរបស់យើងដើម្បីមានព្រះអង្គសង្គ្រោះ យើងនឹងចង់ប្រែចិត្ត ។

ថ្ងៃទី ២ (អាលម៉ា ១៩–២០)

សិស្សបានរៀនថា ទីបន្ទាល់របស់អាំម៉ូន និងគំរូដ៏សុចរិតបានជួយឲ្យបិតារបស់ស្តេចឡាម៉ូណៃបែរទៅរកព្រះអម្ចាស់ ។ ពួកគេក៏បានរៀនថា សកម្មភាពបង្ហាញក្តីស្រឡាញ់របស់យើងអាចដឹកនាំអ្នកដទៃឲ្យបន្ទន់ដួងចិត្តគេ ហើយចង់ដឹងពីសេចក្តីពិត ។

ថ្ងៃទី៣ (អាលម៉ា២១–២២)

ដំណើររឿងនៃការបម្រើបេសកកម្មរបស់អើរ៉ុនបានជួយសិស្សឲ្យយើញថា ប្រសិនបើយើងតស៊ូដោយស្មោះត្រង់ឆ្លងកាត់ឧបសគ្គរបស់យើង ព្រះអម្ចាស់នឹងជួយយើងឲ្យធ្វើកិច្ចការរបស់ទ្រង់ ។ អើរ៉ុនបានជួយបិតារបស់ស្តេចឡាម៉ូណៃឲ្យយល់ថា ទ្រង់អាចទទួលបានសេចក្តីសង្គ្រោះតែតាមរយៈព្រះគុណនៃព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ ។ ដូចជាស្តេចដែរ យើងត្រូវតែមានឆន្ទៈលះងប់នូវអំពើបាបរបស់យើងទាំងអស់ដើម្បីបានផ្លាស់ប្តូរខាងវិញ្ញាណ និងកើតពីព្រះ ។

ថ្ងៃទី ៤ (អាលម៉ា ២៣–២៤)

សាសន៍លេមិនរាប់ពាន់នាក់ដែលបានទទួលយកដំណឹងល្អ បានបង្ហាញថាការប្រែចិត្តគឺជាការផ្លាស់ប្តូរខាងវិញ្ញាណមួយ—ការក្លាយជាមនុស្សថ្មីម្នាក់តាមរយៈអំណាចនៃព្រះ ។ តាមរយៈគំរូរបស់សាសន៍លេមិនដែលក្លាយជាសាសន៍អាន់តៃ-នីហ្វៃ-លីហៃ នោះសិស្សបានរៀនថា ប្រសិនបើយើងធ្វើនូវអ្វីៗទាំងអស់ដែលយើងអាចដើម្បីប្រែចិត្ត ព្រះនឹងបោះចោលនូវកំហុសរបស់យើង ហើយជួយយើងឲ្យនៅតែស្អាតស្អំ ។ ការប្រែចិត្តជឿរបស់សាសន៍លេមិនបង្ហាញថា យើងអាចជួយអ្នកដទៃឲ្យប្រែចិត្តជឿ នៅពេលយើងមានសេចក្តីជំនឿ ។

សេចក្តីផ្តើម

ពួកបុត្រាទាំងបួនរបស់ស្តេចម៉ូសាយបានពីសដើម្បីបោះបង់ឱកាស និងភាពស្តុកស្តម្ភនៅឯផ្ទះ ដើម្បីពួកទ្រង់អាចបង្រៀនដំណឹងល្អដល់ពួកសាសន៍លេមិន ។ ដំណើររឿងនៃពួកអ្នកផ្សព្វផ្សាយសាសនាទាំងបួននេះបង្ហាញពីរបៀបដែលសិស្សអាចរៀបចំបង្រៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដល់អ្នកដទៃបានយ៉ាងមានប្រសិទ្ធភាព ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ១៧–២២

អាំម៉ូន និងបងប្អូនប្រុសរបស់គាត់បង្រៀនដល់ស្តេចសាសន៍លេមិនពីអង្គ

មុនចាប់ផ្តើមថ្នាក់ សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ឬ នៅលើក្រដាសមួយ ៖ « *រឿងដ៏សំខាន់បំផុតមួយដែលអ្នកអាចធ្វើដើម្បីរៀបចំសម្រាប់ការហៅបម្រើ [បេសកកម្មមួយ] គឺ . . .* »

សូមឲ្យសិស្សពីរបីនាក់ប្រាប់ថាវាដូចជាអ្វី នៅពេលពួកគេបានយើញសមាជិកគ្រួសារមួយ ឬ មិត្តភក្តិម្នាក់ត្រឡប់មកពីការបម្រើបេសកកម្មពេញម៉ោងមួយដោយមានចិត្តស្មោះត្រង់ ។ បន្ទាប់មក សូមសួរសិស្សថា ៖ តើបុគ្គលនោះមានលក្ខណៈខុសប្លែកអ្វីខ្លះ ក្រោយពីបេសកកម្មរបស់គាត់ ? តើអ្នកគិតថា អ្វីដែលបណ្តាលឲ្យមានការផ្លាស់ប្តូរនេះ ?

សូមសួរសិស្សថា តើពួកគេនឹងបំពេញប្រយោគនៅលើក្តារខៀនយ៉ាងដូចម្តេច ។ ក្រោយពីសិស្សឆ្លើយហើយ សូមចែកចាយដល់ពួកគេនូវរបៀបដែលអែលឌើរ ដេវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បំពេញប្រយោគនេះ ៖ « រឿងដ៏សំខាន់បំផុតមួយដែលអ្នកអាចធ្វើដើម្បីរៀបចំសម្រាប់ការហៅបម្រើ [បេសកកម្មមួយ] គឺ*ក្លាយជា*អ្នកផ្សព្វផ្សាយសាសនាម្នាក់ជាយូរពីមុនពេលដែលអ្នក*ចេញទៅ*បេសកកម្ម » (“ Becoming a Missionary,” *Ensign*ឬ*លេអាហូណា*ខែ វិច្ឆិកា ឆ្នាំ ២០០៥,ទំព័រ ៤៥) ។

សូមសួរ ៖ តើយុវជន និងយុវនារីអាចធ្វើតាមការប្រឹក្សារបស់អែលឌើរ បែដណា ហើយក្លាយជាអ្នកផ្សព្វផ្សាយសាសនាពីមុនពេលពួកគេបម្រើបេសកកម្មពេញម៉ោងតាមរបៀបណាខ្លះ ?

សូមចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ថូម៉ាស អេស. ម៉នសុន ៖

« ការបម្រើជាអ្នកផ្សព្វផ្សាយសាសនាគឺជាភាតព្វកិច្ចរបស់បព្វជិតភាព—ជាភាតព្វកិច្ចដែលព្រះអម្ចាស់រំពឹងចង់បានពីយើង ជាអ្នកដែលត្រូវបានប្រទានឲ្យនូវអ្វីៗជាច្រើន ។ យុវជនទាំងឡាយ ខ្ញុំសូមលើកទឹកចិត្តអ្នកឲ្យរៀបចំខ្លួនបម្រើជាអ្នកផ្សព្វផ្សាយសាសនា ។ សូមក្សាខ្លួនអ្នកឲ្យស្អាតស្អំបរិសុទ្ធ និងមានភាពសក្តិសមដើម្បីធ្វើជាតំណាងរបស់ព្រះអម្ចាស់ ។ សូមក្សាសុខភាព និងកម្លាំងរបស់អ្នក ។ សូមសិក្សាព្រះគម្ពីរ ។ សូមចូលរួមថ្នាក់សិក្ខាសាលា ឬថ្នាក់វិទ្យាស្ថាន បើមាន ។ សូមយល់ដឹងពីក្បួនខ្នាតរបស់អ្នកផ្សព្វផ្សាយសាសនា*ប្រកាសដំណឹងល្អរបស់យើង* » ។

« សូមនិយាយដល់ប្អូនស្រីទាំងឡាយ ៖ ខណៈពេលដែលអ្នកមិនមានការទទួលខុសត្រូវបព្វជិតភាពដូចគ្នានឹងយុវជនដើម្បីបម្រើជាអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង អ្នកក៏អាចចូលរួមចំណែកដែលមានតម្លៃដូចគ្នាជាអ្នកផ្សព្វផ្សាយសាសនាដែរ ហើយយើងសូមស្វាគមន៍ការបម្រើរបស់អ្នក » (« កាលយើងជួបគ្នាម្តងទៀត » *Ensign*ឬ*លេអាហូណា*ខែ វិច្ឆិកា ឆ្នាំ ២០១០, ទំព័រ ៦) ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ព្រះអម្ចាស់នឹងប្រទានពរដល់យើងដោយព្រះវិញ្ញាណបរិសុទ្ធ និងអំណាចដើម្បីបង្រៀនព្រះបន្ទូលរបស់ទ្រង់ នៅពេលយើង . . .*

សូមបំបែកសិស្សក្នុងថ្នាក់ទៅជាបួនក្រុមៗ ។ សូមឲ្យក្រុមនីមួយៗអានខ្គៀព្រះគម្ពីរខាងក្រោមនេះមួយ ៖ អាលម៉ា ១៧:១–៤; អាលម៉ា១៧:៩–១៣; អាលម៉ា១៧:១៩–២៥; ១៨:១–៩; អាលម៉ា១៧:២៦–៣០ ។ (សូមសម្របសកម្មភាពនេះ ប្រសិនបើអ្នកមានសិស្សតិច) ។

សូមឲ្យសិស្សអានវគ្គរបស់ពួកគេដោយស្ងាត់ស្ងៀម ដោយរកមើលអ្វីដែលពួកបុត្រារបស់ម៉ូសាយបានធ្វើដែលបានប្រទានពរដល់ពួកទ្រង់ដោយព្រះវិញ្ញាណបរិសុទ្ធ និងដោយអំណាច នៅពេលទ្រង់បានបង្រៀនដំណឹងល្អ ។ សូមពន្យល់ថា នៅពេលសិស្សអានចប់ហើយ អ្នកត្រូវសុំឲ្យពួកគេចែកចាយនូវអ្វីដែលពួកគេបានរកឃើញ និងពីរបៀបដែលពួកគេនឹងបំពេញប្រយោគនៅលើក្តារខៀន ។

ក្រោយពីមានពេលល្មហើយ សូមឲ្យសិស្សម្នាក់ពីក្រុមនីមួយៗពន្យល់ពីអ្វីដែលពួកបុត្រាទាំងឡាយរបស់ម៉ូសាយបានធ្វើ និងពីរបៀបដែលសមាជិកក្រុមទាំងអស់បំពេញគោលការណ៍នៅលើក្តារខៀន ។ ចម្លើយរបស់សិស្សអាចរួមមានដូចខាងក្រោម ៖ សិក្សាព្រះគម្ពីរ អធិស្ឋាននិងតមអាហារ អត់ធ្មត់ បង្ហាញគំរូល្អ ទុកចិត្តលើព្រះអម្ចាស់ បម្រើដល់អ្នកដទៃដោយឧស្សាហ៍ ហើយស្រឡាញ់អ្នកដទៃដូចជាបងប្អូនប្រុសស្រីរបស់អ្នក ។ នៅពេលសិស្សចែកចាយចម្លើយរបស់ពួកគេ សូមសរសេរវានៅលើក្តារខៀន ។ សូមឲ្យសិស្សពន្យល់ពីរបៀបដែលពួកគេគិតអំពី សកម្មភាព ឬគុណសម្បត្តិនីមួយៗអាចជួយបុគ្គលម្នាក់ឲ្យចែកចាយដំណឹងល្អឲ្យកាន់តែមានប្រសិទ្ធភាព ។

ប្រសិនបើមានសិស្សរបស់អ្នកណាម្នាក់ប្រែចិត្តជឿដល់ដំណឹងល្អ ក្រោយពីបានបង្រៀនដោយអ្នកផ្សព្វផ្សាយសាសនាពេញម៉ោង អ្នកអាចសុំឲ្យពួកគេចែកចាយពីអារម្មណ៍ដែលពួកគេបានមាននៅពេលពួកគេបានរៀនដំណឹងល្អនោះ ។

សូមរំឭកសិស្សថា ក្រោយពីអាំម៉ូនបានការពារដល់ហ្វូងចៀមរបស់ស្តេចហើយ ស្តេចឡាម៉ូណៃបានមានសេចក្តីអស្ចារ្យនឹងអំណាចរបស់អាំម៉ូន ក៏ដូចជាការគោរព និងភាពស្មោះត្រង់របស់គាត់ក្នុងការបំពេញតាមការបញ្ជារបស់ទ្រង់ (សូមមើល អាលម៉ា ១៨:៨–១០) ។ ស្តេចឡាម៉ូណៃត្រូវបានរៀបចំដើម្បីរៀនពីសារលិខិតដែលអាំម៉ូនបានមកដើម្បីចែកចាយនឹងទ្រង់ ។ សូមឲ្យសិស្សប្តូរវេនគ្នាអានឮពី អាលម៉ា ១៨:២៤–២៩ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពីរបៀបដែលអាំម៉ូនបានបណ្តុះការយល់ដឹងដល់ស្តេចឡាម៉ូណៃអំពីព្រះ ដើម្បីឲ្យគាត់ឲ្យរៀបចំឡាម៉ូណៃឲ្យយល់ពីគោលលទ្ធិដ៏ពិត ។

សូមសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- ប្រសិនបើអ្នកបាននិយាយអំពីព្រះជាមួយនឹងមិត្តភក្តិដែលមានសេចក្តីជំនឿផ្សេងទៀត តើអ្នកអាចប្រើសេចក្តីជំនឿរបស់អ្នកចែកចាយដល់គ្នា ដូចជាអាំម៉ូនបានធ្វើដោយរបៀបណា ? តើការខំប្រឹងនេះអាចជួយមិត្តភក្តិរបស់អ្នកដោយរបៀបណា ?
- តើប្រធានបទដំណឹងល្អផ្សេងទៀតណាខ្លះ ដែលអ្នកអាចនិយាយជាមួយនឹងមិត្តភក្តិរបស់អ្នក ដើម្បីបើកឱកាសដើម្បីចែកចាយដំណឹងល្អដល់ពួកគេនោះ ?

សូមរំឭកសិស្សថា ស្តេចឡាម៉ូណៃបានទទួលព្រមស្តាប់ពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដូចជាបិតារបស់ទ្រង់ដែរ ។ សូមឲ្យសិស្សម្នាក់អានឮៗពី អាលម៉ា ១៨:៣៩–៤១—ចម្លើយរបស់ស្តេចឡាម៉ូណៃក្នុងការរៀនអំពីព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សម្នាក់ទៀតអាន អាលម៉ា ២២:១៤–១៨—ចម្លើយរបស់បិតាស្តេចឡាម៉ូណៃ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាមនៅក្នុងព្រះគម្ពីររបស់គេ ហើយរកមើលភាពស្រដៀងគ្នាពីចម្លើយរបស់ស្តេចទាំងនេះ ។

សូមសួរ ៖ តើស្តេចទាំងពីរចង់ធ្វើអ្វី នៅពេលពួកទញ្ជរង់បានរៀនអំពីព្រះយេស៊ូវគ្រីស្ទ ?

សូមពន្យល់ថា ស្តេចឡាម៉ូណៃ និងបិតារបស់ទ្រង់ត្រូវបានប៉ះដោយព្រះវិញ្ញាណតាមរយៈការបង្រៀនរបស់អ្នកផ្សព្វផ្សាយសាសនា ។ ជាលទ្ធផល ពួកគេចង់បាននូវពរជ័យនៃដំណឹងល្អ ហើយចង់លះបង់អំពើបាបរបស់ទ្រង់ចោល ហើយប្រែចិត្ត ។ សូមរំឭកសិស្សពីសេចក្តីពិតដែលពួកគេសិក្សានៅសប្តាហ៍នេះ ៖ **យើងត្រូវមានឆន្ទៈលះបង់អំពើបាបរបស់យើងទាំងអស់ចោល ដើម្បីបានផ្លាស់ប្តូរខាងវិញ្ញាណ ហើយកើតពីព្រះ ។**

សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ដោយអែលឌើរ ដាល្លិន អេក អ៊ុក ដែលមាននៅក្នុងសៀវភៅណែនាំការសិក្សារបស់ពួកគេ ៖ « ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទលើកទឹកចិត្តយើងឲ្យផ្លាស់ប្តូរ ។ ‹ ប្រែចិត្ត › គឺជាសារលិខិតដ៏ញឹកញាប់បំផុតរបស់វា ហើយការប្រែចិត្តមានន័យថា ការលះបង់នូវការអនុវត្តទាំងអស់របស់យើង—ផ្ទាល់ខ្លួន គ្រួសារ ប្រុជម៌ និង ជាតិ—ដែលផ្ទុយទៅនឹងព្រះបញ្ញត្តិទាំងឡាយនៃព្រះ ។ គោលបំណងនៃដំណឹងល្អគឺដើម្បីផ្លាស់ប្តូរមនុស្សធម្មតាទៅជាពលរដ្ឋនៃសេឡេស្ទាល ហើយវាតម្រូវឲ្យផ្លាស់ប្តូរ » (« Repentance and Change »*Ensign*ឬ*លេអាហូណា*ខែ វិច្ឆិកា ឆ្នាំ ២០០៣, ទំព័រ ៣៧) ។

សូមឲ្យសិស្សគិតអំពីជីវិតរបស់ពួកគេ ហើយគិតថាតើពួកគេត្រូវលះបង់អំពើបាបទាំងឡាយណាខ្លះដើម្បីផ្លាស់ប្តូរខាងវិញ្ញាណ ដូចជាស្តេចឡាម៉ូណៃ និងបិតារបស់ទ្រង់ដែរ ។ សូមបញ្ចប់ដោយការចែកចាយការលើកទឹកចិត្ត និងទីបន្ទាល់របស់អ្នកថា នៅពេលយើងមានឆន្ទៈលះបង់អំពើបាបរបស់យើង ព្រះអម្ចាស់នឹងជួយយើងឲ្យផ្លាស់ប្តូរ និងលូតលាស់ឡើង ។

មេរៀនបន្ទាប់ (អាលម៉ា ២៥–៣២)

សូមឲ្យសិស្សគិតពីសំណួរនេះ ៖ តើអ្នកនឹងនិយាយដល់នរណាម្នាក់ដែលជាអ្នកប្រឆាំងនឹងព្រះគ្រីស្ទអ្វីខ្លះ ? នៅក្នុងមេរៀនបន្ទាប់ សិស្សនឹងរៀនពីរបៀបដែលអាលម៉ាបានឆ្លើយនឹងសំណួរនេះ ហើយបានចំអកដល់កូរីហូរ ដែលជាអ្នកប្រឆាំងនឹងព្រះគ្រីស្ទ ។ បន្ថែមលើនេះ ពួកគេនឹងរៀនបន្ថែមអំពីសេចក្តីជំនឿ នៅពេលពួកគេអានអំពីរបៀបដែលអាលម៉ា និងអ្នកដទៃបានខិតខំបង្រៀនដល់ពួកសាសន៍ស្លាំដែលក្បត់ ដែលបង្ខូចផ្លូវនៃព្រះអម្ចាស់ ។

អាលម៉ា ២៥–២៦

សេចក្តីផ្តើម

ក្រោយពីបំផ្លាញនៃទីក្រុងអាម៉ូណៃហា ហើយសាសន៍លេមិនបានធ្វើសង្គ្រាមជាច្រើនទៀតជាមួយនឹងសាសន៍នីហ្វៃ ហើយបានបង្ក្រាបទៅវិញ ។ ដោយរងទុក្ខនឹងការបាត់បង់ដ៏ខ្លាំង ពួកសាសន៍លេមិនជាច្រើនបានជាក់ចុះអារម្មណ៍របស់ពួកគេចុះពីសង្គ្រាម បានប្រែចិត្ត ហើយបានចូលរួមនឹងពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃ ។ នៅពេលពួកបុត្រានៃស្តេចម៉ូសាយ និងដៃគូរបស់គេបានបញ្ចប់បេសកកម្ម ១៤ឆ្នាំរបស់ពួកទ្រង់ក្នុងចំណោមសាសន៍លេមិន អាំម៉ូនបានសរសើរដល់ព្រះអម្ចាស់ ហើយបានបង្ហាញអំណរដ៏ងគុណសម្រាប់ពរជ័យនៃការក្លាយជាគ្រឿងឧបករណ៍ក្នុងព្រះហស្តរបស់ព្រះ ដើម្បីនាំដំណឹងល្អទៅដល់សាសន៍លេមិន ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ២៥:១–១២

ការព្យាករណ៍របស់អ័ប៊ីណាដៃ និងអាលម៉ាត្រូវបានបំពេញ

មុនចាប់ផ្តើមថ្នាក់ សូមចម្លងតារាងខាងក្រោមនៅលើក្តារខៀន ៖

ការព្យាករណ៍	ការបំពេញនៃការព្យាករណ៍
អាលម៉ា ៩:១២ ។ តើអាលម៉ាបានព្យាករណ៍ដល់ប្រជាជនអាំម៉ូណៃហាអ្វីខ្លះ ?	អាលម៉ា ២៥:១–២ (សូមមើលផងដែរអាលម៉ា ១៦:២–៣, ៩–១១)
ម៉ូសាយ ១៧:១៤–១៩ ។ តើអ័ប៊ីណាដៃបានព្យាករណ៍ថានឹងមានអ្វីកើតឡើងដល់កូនចៅរបស់ស្តេចណូអេ និងពួកសង្ឃរបស់ទ្រង់ ?	អាលម៉ា ២៥:៤–៩

សូមសរសេរពាក្យ *ទុកចិត្ត* នៅលើក្តារខៀន ។ សូមឲ្យសិស្សប្រាប់ឈ្មោះមនុស្សខ្លះដែលយើងទុកចិត្តជាញឹកញាប់ ។ (ចម្លើយអាចមានព្រះអម្ចាស់ ព្យាការី ឪពុកម្តាយ គ្រូបង្រៀន និងអ្នកបង្វឹក) ។ សូមសួរសិស្ស ៖

- ហេតុអ្វីបានជាវាងាយស្រួលដើម្បីទុកចិត្តបុគ្គលខ្លះជាជាងអ្នកដទៃ ?
- ក្នុងចំណោមប្រជាជននៅលើផែនដីសព្វថ្ងៃនេះ តើនរណាដែលអ្នកងាយទុកចិត្តបំផុតនោះ ?

សូមប្រាប់សិស្សថា អាលម៉ា ២៥ រួមមានភស្តុតាងថា ព្រះបន្ទូលរបស់ព្រះអម្ចាស់ដល់ព្យាការីនឹងតែងតែត្រូវបានបំពេញ ។ សូមពន្យល់ថា សិស្សនឹងប្រើតារាងនៅលើក្តារខៀនដើម្បីសិក្សាពីការព្យាករណ៍ពីរដោយព្យាការីពីព្រះគម្ពីរមរមន និងការបំពេញនៃការព្យាករណ៍ទាំងនោះ ។ សូមឲ្យសិស្សចម្លងតារាងចូលក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ នៅក្នុងតារាងទីមួយ សូមឲ្យពួកគេសរសេរចម្លើយទៅនឹងសំណួរ ដោយប្រើសេចក្តីយោងនៃព្រះគម្ពីរដែលផ្តល់ឲ្យ ។ នៅក្នុងតារាងទីពីរ សូមឲ្យពួកគេសរសេរអំពីការបំពេញនៃការព្យាករណ៍ ។ សូមឲ្យសិស្សពីរបីនាក់រៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ២៥:១១–១២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលមរមនបាននិយាយថានឹងកើតឡើងតាមពាក្យរបស់អ័ប៊ីណាដៃ ។ អ្នកអាចស្មើថា សិស្សគួរចំណាំឃ្លា « ពាក្យទាំងនេះត្រូវបានបញ្ជាក់ » នៅក្នុង ខទី ១២ ។

- តើឃ្លា « ពាក្យទាំងនេះត្រូវបានបញ្ជាក់ » មានន័យយ៉ាងដូចម្តេច ?

អ្នកអាចផ្តល់យោបល់ថា សិស្សគួរសរសេរ *គ . និង ស . ១:៣៨* នៅក្នុងព្រះគម្ពីររបស់ពួកគេនៅក្បែរ អាលម៉ា ២៥:១២ ។ សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និងសេចក្តីសញ្ញា ១:៣៨ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលឃ្លាមួយដែលស្រដៀងទៅនឹងឃ្លា « ពាក្យទាំងនេះត្រូវបានបញ្ជាក់ » ។ (« ពាក្យទាំងអស់នឹងបានសម្រេច ») ។

- តើយើងរៀនអ្វីខ្លះពី អាលម៉ា ២៥:១–១២អំពីការព្យាករណ៍ និងសេចក្តីសន្យាទាំងឡាយដែលធ្វើដោយព្យាការីនោះ ? (សូមសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ ***ពាក្យដ៏បំផុសរបស់ព្យាការីទាំងឡាយនឹងត្រូវបានសម្រេច ។***)

សូមបង្ហាញថា គំរូនៅក្នុងតារាងទាំងនេះបង្ហាញថា ការព្រមានរបស់ព្យាការីដល់ពួកមិនសុចរិតនឹងតែងតែបានសម្រេចជានិច្ច ។ ព្យាការីក៏ចែកចាយសេចក្តីសន្យាដល់អ្នកទាំងឡាយណាដែលនឹងបែរទៅរកព្រះអម្ចាស់ដែរ ។ សេចក្តីសន្យាទាំងនេះក៏នឹងបានសម្រេចដែរ ។ ដើម្បីជួយសិស្សឲ្យឃើញពីការអនុវត្តនៃគោលការណ៍នេះនៅក្នុងជីវិតរបស់ពួកគេ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយ

គណៈប្រធានទីមួយពី *ដើម្បីកម្លាំងនៃយុវជន* ។សូមឲ្យសិស្សស្តាប់រកនូវសេចក្តីសន្យាទាំងឡាយចំពោះអ្នកទាំងឡាយណាដែលក្បាបទដ្ឋាននៅក្នុងកូនសៀវភៅនេះ ។

« បទដ្ឋាននៅក្នុងកូនសៀវភៅនេះនឹងជួយអ្នកក្នុងការជ្រើសរើសដ៏សំខាន់ៗទាំងឡាយដែលអ្នកកំពុងតែធ្វើនាពេលឥឡូវនេះ ហើយនឹងធ្វើនាពេលអនាគត ។ យើងសូមសន្យាថា នៅពេលដែលអ្នកគោរពតាមសេចក្តីសញ្ញាទាំងឡាយដែលអ្នកបានធ្វើ និងបទដ្ឋានទាំងនេះ នោះអ្នកនឹងត្រូវបានប្រទានពរជ័យដោយមានភាពជាដៃគូពីព្រះវិញ្ញាណបរិសុទ្ធ សេចក្តីជំនឿរបស់អ្នកនឹងលូតលាស់កាន់តែខ្លាំង ហើយអ្នកនឹងរីករាយជាមួយនឹងសុភមង្គលកាន់តែខ្លាំង » (*ដើម្បីកម្លាំងនៃយុវជន* ⏐ កូនសៀវភៅ ឆ្នាំ ២០១១ ⏐, ☒) ។

- តើគណៈប្រធានទីមួយបានសន្យាអ្វីខ្លះ ?
- តើអ្នកបានឃើញការសន្យាទាំងនេះបានបំពេញនៅពេលណា ?

អាលម៉ា ២៥:១៣–១៧

ពួកសាសន៍លេមិនជាច្រើនប្រែចិត្ត ហើយចូលរួមនឹងពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃ

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ២៥:១៣–១៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលពួកសាសន៍លេមិនជាច្រើនបានធ្វើ ក្រោយពីពួកគេបានដឹងថា ពួកគេមិនអាចបង្ក្រាបសាសន៍នីហ្វៃបាន ។

- តើអ្វីដែលធ្វើឲ្យអ្នករំភើបអំពីសកម្មភាពរបស់សាសន៍លេមិន ?

សូមឲ្យសិស្សអាន អាលម៉ា ២៥:១៧ដោយស្ងាត់ៗ ដោយរកមើលអារម្មណ៍របស់ពួកបុត្រារបស់ម៉ូសាយអំពីជោគជ័យដែលពួកទ្រង់បានទទួលក្នុងចំណោមសាសន៍លេមិន ។

- តើជោគជ័យរបស់ពួកបុត្រារបស់ម៉ូសាយ ជាគំរូនៃពាក្យរបស់ព្រះអម្ចាស់ថាបានសម្រេចដោយរបៀបណា ? (ប្រសិនបើសិស្សត្រូវការជំនួយក្នុងការឆ្លើយនឹងសំណួរនេះ សូមឲ្យពួកគេបើកទៅ ម៉ូសាយ ២៨:៥–៧ និង អាលម៉ា ១៧:១១) ។

អាលម៉ា ២៦

អាំម៉ូនរីករាយនឹងសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់ដល់គាត់ និងបងប្អូនប្រុសរបស់គាត់ និងដល់សាសន៍លេមិន

សូមបង្ហាញឧបករណ៍ខ្លះៗ (ដូចជា ញញួរ ទុលវែស ក ចិច ឬខ្មៅដៃ ជក់គំនូរ កន្ត្រៃមួយគូ កុំព្យូទ័រ និងឧបករណ៍តន្ត្រីមួយ) ។ សូមពន្យល់ថា ពាក្យផ្សេងទៀតសម្រាប់ពាក្យ *របស់* គឺ*ឧបករណ៍* ។

- តើអ្វីខ្លះដែលសិប្បករ ឬវិចិត្រករដ៏ជំនាញអាចធ្វើ ជាមួយនឹងឧបករណ៍ត្រឹមត្រូវ ?
- តើអ្នកគិតថា វាមានន័យយ៉ាងណាដល់អ្នកខ្លះដែលជាឧបករណ៍នៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ?

សូមឲ្យសិស្សពីរបីផ្លាស់ប្តូរវេនគ្នាអានឮពី អាលម៉ា ២៦:១–៥, ១២ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលអាំម៉ូន និងអ្នកផ្សព្វផ្សាយសាសនារបស់គាត់ជាឧបករណ៍នៅក្នុងព្រះហស្តរបស់ព្រះ ។

- តើព្រះអម្ចាស់បានសម្រេចអ្វីខ្លះ តាមរយៈអាំម៉ូន អ្នកផ្សព្វផ្សាយសាសនារបស់គាត់ ?
- តើអ្នកនឹងថា អាលម៉ា ២៦:១២ ឡើងវិញដោយរបៀបណា ? តើប្រសាសន៍របស់អាំម៉ូននៅក្នុងខនេះទាក់ទងនឹងការក្លាយជាឧបករណ៍នៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ដោយរបៀបណា ?

សូមឲ្យសិស្សអាន អាលម៉ា ២៦:១១, ១៣, ១៦ ដោយស្ងាត់ៗ ដោយរកមើលពេលវេលាទាំងអស់ដែលពាក្យ *សេចក្តីអំណរ* និង *អរអរីករាយ* លេចឡើង ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំពាក្យទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ២៦:១៣–១៦ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលមូលហេតុដែលអាំម៉ូនបានផ្តល់សម្រាប់ការអរអរីករាយរបស់គាត់ ។

- ហេតុអ្វីបានជាអាំម៉ូនបានអរអរីករាយ ?
- តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពីខគម្ពីរទាំងនេះ ? (សិស្សអាចនិយាយពីគោលការណ៍ខុសគ្នាជាច្រើន ។ គោលការណ៍ខាងក្រោមអាចធ្វើជាសេចក្តីសង្ខេបមួយនៃចម្លើយរបស់ពួកគេ ៖ **យើងអរអរីករាយ ដោយសារយើងបម្រើដល់ព្រះអម្ចាស់ និងកូនចៅរបស់ទ្រង់ដោយមានចិត្តស្មោះត្រង់** ។អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើអ្នកគិតថា ហេតុអ្វីបានជាយើងអរអរីករាយ នៅពេលយើងនៅក្នុងការបម្រើដល់ព្រះអម្ចាស់ ?

សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោម និងសំណួរនៅលើក្តារខៀន ។ (សូមគិតពីការសរសេរវាមុនពេលចាប់ផ្តើមថ្នាក់) ។ សូមបែងចែកសិស្សជាគូៗ ។ សូមឲ្យដៃគូនីមួយៗជ្រើសរើស និងអានវគ្គមួយ ហើយពិភាក្សាពីចម្លើយទៅនឹងសំណួរដែលមាន ។

អាលម៉ា ២៦:១៧–២០ ។ តើអាំម៉ូន និងបងប្អូនប្រុសរបស់គាត់ជាមនុស្សប្រភេទណា មុនពេលពួកគេបានប្រែចិត្តជឿនោះ ?

អាលម៉ា២៦:២៣–២៥ ។ យោងតាមអ្វីដែលសាសន៍នីហ្វៃបានប្រាប់ដល់អាំម៉ូន និងបងប្អូនប្រុសរបស់គាត់ តើពួកសាសន៍លេមិនដូចជាអ្វីមុនពេលពួកគេបានប្រែចិត្តជឿនោះ ?

សូមផ្តល់ពេលសម្រាប់សិស្សពីរបីនាក់ពន្យល់ពីចម្លើយរបស់ពួកគេទៅនឹងសំណួរទាំងនេះ ។ សូមឲ្យសិស្សអាន អាលម៉ា ២៦:២៣–២៩ដោយស្ងាត់ៗ ដោយរកមើលឧបសគ្គដែលអាំម៉ូន និងបងប្អូនប្រុសរបស់គាត់ បានជួបនៅក្នុងការបម្រើដល់ព្រះអម្ចាស់ និងសាសន៍លេមិន ។

- តើឧបសគ្គមួយណាដែលអ្នកគិតថា ពួកអ្នកផ្សព្វផ្សាយសាសនាអាចជួបនាពេលសព្វថ្ងៃនេះ ?
- យោងតាម អាលម៉ា ២៦:២៧, ៣០ តើអ្វីដែលបានជម្រុញដល់អាំម៉ូន និងពួកអ្នកផ្សព្វផ្សាយសាសនារបស់គាត់ឲ្យបន្តបម្រើ ? (ការលួងលោម និងសេចក្តីសន្យាពីព្រះអម្ចាស់ និងបំណងប្រាថ្នាដើម្បីក្លាយជា « មាគ៌ាក្នុងការសង្គ្រោះព្រលឹងខ្លះ ») ។

សូមឲ្យសិស្សអាន អាលម៉ា ២៦:៣១–៣៤ដោយស្ងាត់ៗ ដោយរកមើលលទ្ធផលខ្លះនៃការបម្រើរបស់ពួកបុត្រារបស់ម៉ូសាយ ។ នៅពេលពួកគេបានមានពេលអានគ្រប់គ្រាន់ហើយ សូមឲ្យពួកគេចែកចាយអ្វីដែលពួកគេរកឃើញ ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ២៦:៣៥–៣៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយគិតពីមូលហេតុដែលពួកគេត្រូវអរសប្បាយនៅក្នុងសេចក្តីល្អរបស់ព្រះ ។

- តើសារលិខិតអ្វីដែលអ្នកឃើញនៅក្នុងខគម្ពីរទាំងនេះ ?

សូមបង្ហាញថា សារលិខិតមួយនៅក្នុងខគម្ពីរទាំងនេះគឺថា **ព្រះអម្ចាស់មានមេត្តាករុណាដល់មនុស្សទាំងអស់ដែលប្រែចិត្ត ហើយជឿដល់ព្រះនាមរបស់ទ្រង់ ។**ដើម្បីជួយសិស្សឲ្យដឹងពីសេចក្តីពិត និងពីសារៈសំខាន់នៃគោលការណ៍នេះ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយ ប្រធាន ប៊ិយដ៏ ឃេ ងាកកី នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ៖

« សំបុត្រមកពីអ្នកដែលបានធ្វើខុសដ៏ខ្លាំង ។ ពួកគេសួរថា ‹ តើខ្ញុំអាច *ត្រូវ* បានអភ័យទោសឲ្យទេ ?

« ចម្លើយគឺ *បាន !*

« ដំណឹងល្អបង្រៀនយើងថា ការបានធូរស្រាលពីទារុណកម្ម និងកំហុស អាចទទួលបានតាមការប្រែចិត្ត ។ ការសង្គ្រោះសម្រាប់អ្នកទាំងនោះដែលគេចពីការមានគ្រោះធ្ងន់ ក្រោយពីដឹងភាពពេញលេញ វាគ្មានទម្លាប់ គ្មានការញៀន គ្មានការបះបោរ គ្មានការរំលង គ្មានកំហុសដែលជាគំរូពីការសន្យានៃការអភ័យទោសដ៏ពេញលេញនោះទេ » (« The Brilliant Morning of Forgiveness » *Ensign,*ខែ វិច្ឆិកា ឆ្នាំ ១៩៩៥, ទំព័រ ១៩) ។

សូមថ្លែងទីបន្ទាល់អំពីអំណាចនៃដង្វាយធួនដែលផ្តល់ការអភ័យទោសដល់អំពើបាប ធំឬតូច ដល់អ្នកទាំងឡាយដែលមានសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ហើយប្រែចិត្ត ។ សូមថ្លែងទីបន្ទាល់ផងដែរអំពីសេចក្តីអំណរដែលមកក្នុងជីវិតរបស់យើង នៅពេលយើងធ្វើជាឧបករណ៍នៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ។

អាលម៉ា ២៧–២៩

សេចក្តីផ្តើម

នៅពេលសាសន៍លេមិនមិនបានជោគជ័យក្នុងការវាយប្រហារលើសាសន៍នីហ្វៃ ពួកគេបានបង្វែរកំហឹងទៅកាន់ពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃ ។ ដោយសារតែសេចក្តីសញ្ញាដែលពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃបានធ្វើថានឹងមិនបង្ហូរឈាមអ្នកដទៃទៀតទេនោះ ពួកគេបានបដិសេធមិនបានលើកអាវុធការពារពួកគេឡើយ ។ អាំម៉ូនបានដឹកនាំពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃទៅកាន់ដែនដីសាវ៉ាហិមឡា ជាកន្លែងដែលពួកគេបានទទួលការការពារពីសាសន៍នីហ្វៃ ហើយក្លាយជាទៅប្រជាជនអាំម៉ូន ។ នៅពេលសាសន៍នីហ្វៃបានការពារប្រជាជនអាំម៉ូនកុំឲ្យសាសន៍លេមិនសម្លាប់នោះ សាសន៍នីហ្វៃ និងសាសន៍លេមិនរាប់ពាន់នាក់បានស្លាប់នៅក្នុងសង្គ្រាម ។ ថ្វីបើមានការសោកសង្រេងពីការស្លាប់នៃមនុស្សជាទីស្រឡាញ់របស់សាសន៍នីហ្វៃ ពួកគេជាច្រើនបាននៅតែមានក្តីសង្ឃឹម និងសេចក្តីអំណរទៅលើសេចក្តីសន្យារបស់ព្រះអម្ចាស់ថា ពួកសុចរិតនឹង « ត្រូវបានប្រោសឡើងវិញដើម្បីទៅនៅខាងស្តាំព្រះហស្តនៃព្រះនៅក្នុងស្ថានភាពនៃសុភមង្គលដ៏មិនចេះចប់មិនចេះហើយ » (អាលម៉ា ២៨:១២) ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ២៧

អាំម៉ូនដឹកនាំប្រជាជនអាន់តៃ-នីហ្វៃ-លីហៃទៅកាន់តំបន់សុវត្ថិភាពក្នុងចំណោមសាសន៍នីហ្វៃ

សូមឲ្យសិស្សលើកដៃ ប្រសិនបើពួកគេធ្លាប់មាននរណាម្នាក់បានសន្យានឹងពួកគេ ហើយបន្ទាប់មកភ្លេចសន្យានោះទេ ។ បន្ទាប់មក សូមឲ្យពួកគេលើកដៃ ប្រសិនបើពួកគេធ្លាប់សន្យានឹងនរណាម្នាក់ ហើយរក្សាការសន្យានោះ ។

- **តើអ្នកមានអារម្មណ៍យ៉ាងណា ចំពោះមនុស្សដែលរក្សាការសន្យារបស់ពួកគេ ? ហេតុអ្វី ?**
- **តើអ្នកគិតថា ព្រះអម្ចាស់មានព្រះទ័យយ៉ាងណាអំពីអ្នកដែលរក្សាការសន្យារបស់ពួកគេចំពោះទ្រង់នោះ ?**

សូមណែនាំ អាលម៉ា ២៧ដោយការពន្យល់ថា ក្រោយពីសាសន៍លេមិនបានបរាជ័យក្នុងការព្យាយាមបំផ្លាញសាសន៍នីហ្វៃ ពួកគេបានវាយប្រហារពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃ គឺពួកសាសន៍លេមិនដែលបានប្រែចិត្តតាមរយៈការបម្រើរបស់អាំម៉ូន និងបងប្អូនប្រុសរបស់គាត់ ។ សូមឲ្យសិស្សប្រាប់ពីអ្វីដែលពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃបានធ្វើដើម្បីបង្ហាញដល់ព្រះអម្ចាស់ថា ពួកគេនឹងកាន់តាមសេចក្តីសញ្ញារបស់ពួកគេថានឹងពុំ « ប្រើគ្រឿងសាស្ត្រាវុធសម្រាប់ការខ្ចាយឈាមមនុស្សទៀតទេ » (អាលម៉ា ២៤:១៨) ។ (ពួកគេបានកប់គ្រឿងសាស្ត្រាវុធសង្គ្រាមរបស់ពួកគេ) ។ ដើម្បីរកឃើញពីការប្តេជ្ញាចិត្តនៃពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃបានមានដើម្បីរក្សាការសន្យារបស់ពួកគេ សូមឲ្យសិស្សម្នាក់អានឮៗក្នុង អាលម៉ា ២៧:២–៣ ។ (អ្នកក៏អាចផ្តល់យោបល់ថា សិស្សគួរអាន អាលម៉ា ២៤:១៨–១៩ ហើយសរសេរសេចក្តីយោងនេះនៅគែមទំព័រក្បែរ អាលម៉ា ២៧:៣) ។

- **ប្រសិនបើអ្នកជាប្រជាជនម្នាក់នៃពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃ តើវានឹងពិបាកយ៉ាងណាសម្រាប់អ្នក ដើម្បីរក្សាសេចក្តីសញ្ញារបស់អ្នក ហើយមិនទៅច្បាំងដើម្បីការពារខ្លួនអ្នក និងមនុស្សជាទីស្រឡាញ់របស់អ្នកនោះ ?**

សូមឲ្យសិស្សអាន អាលម៉ា ២៧:៤–១០ ស្ងាត់ៗ ដោយរកមើលអ្វីដែលអាំម៉ូនបានស្នើសុំឲ្យធ្វើ ដើម្បីការពារដល់ពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃ និងដើម្បីជួយពួកគេឲ្យរក្សាសេចក្តីសញ្ញារបស់ពួកគេ ។ សូមឲ្យសិស្សម្នាក់សង្ខេបវគ្គនេះ ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ២៧:១១–១២ ឮ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលការណែនាំដែលអាំម៉ូនបានទទួលពីព្រះអម្ចាស់ ។ សូមពន្យល់ថា ពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃបានទៅតាមអាំម៉ូនទៅកាន់ដែនដីសាវ៉ាហិមឡា (សូមមើល អាលម៉ា ២៧:១៣–១៥) ។ (អ្នកក៏អាចសង្ខេប អាលម៉ា ២៧:១៦–១៩ ដោយបង្ហាញថា វានៅក្នុងកាលៈទេសៈទាំងនេះដែលអាំម៉ូន និងពួកបុត្រារបស់ម៉ូសាយបានរួបរួមនឹងអាលម៉ា ដូចដែលបានប្រាប់នៅក្នុង អាលម៉ា១៧:១–៤) ។

សូមពន្យល់ថា មេចៅក្រមនៃសាសន៍នីហ្វៃបានសួរដល់ប្រជាជនថា តើពួកគេនឹងអនុញ្ញាតឲ្យពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃរស់នៅក្នុងចំណោមពួកគេទេ ។ សូមឲ្យសិស្សអាន អាលម៉ា ២៧:២២–២៤ ស្ងាត់ៗ ដោយរកមើលចម្លើយរបស់ពួកសាសន៍នីហ្វៃដល់ការប្រកាសរបស់មេចៅក្រម ។

- **តើពួកសាសន៍នីហ្វៃបាននិយាយដោយរបៀបណា ថាពួកគេនឹងជួយដល់ពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃ ?**
- **តើអ្នកគិតថា ហេតុអ្វីបានជាពួកសាសន៍នីហ្វៃមានចិត្តចង់ការពារសត្រូវពីមុនរបស់ពួកគេ ?**

សូមឲ្យសិស្សអាន អាលម៉ា ២៧:២៦ដោយស្ងាត់ៗដើម្បីរកមើលពីអ្វីដែលពួកសាសន៍បានចាប់ផ្តើមហៅដល់ពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃ ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮពី អាលម៉ា ២៧:២៧–៣០ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលប្រជាជនអាំម៉ូនបានដឹង ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- **តើប្រជាជនអាំម៉ូនធ្វើឲ្យអ្នករំភើបលើអ្វីខ្លះ ? ហេតុអ្វី ?**
- **តើ អាលម៉ា ២៧:២៧–៣០ បង្រៀនអ្វីខ្លះអំពីទំនាក់ទំនងរវាងការប្រែចិត្តជឿដល់ព្រះអម្ចាស់ និងការកាន់តាមសេចក្តីសញ្ញា ?**
  (សិស្សអាចប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរបង្ហាញថា ពួកគេយល់ពីសេចក្តីពិតខាងក្រោម ៖ នៅពេលយើងប្រែចិត្តជឿដល់

ព្រះអម្ចាស់ដោយពេញលេញ យើងរក្សាសេចក្តីសញ្ញាទាំងឡាយដែលយើងបានធ្វើជាមួយនឹងទ្រង់ ។ អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

- តើនរណានៅក្នុងជីវិតរបស់អ្នក ជាគំរូនៃគោលការណ៍នេះ ?

អាលម៉ា ២៨

ពួកសាសន៍នីហ្វៃបានបង្ក្រាបដល់ពួកសាសន៍លេមិននៅក្នុងចម្បាំងដ៏ខ្លាំងក្លាមួយ

សូមបង្ហាញថា ទោះបីជាសាសន៍នីហ្វៃជាច្រើនបានមានចិត្តស្មោះត្រង់ ក៏ពួកគេនៅតែជួបនឹងឧបសគ្គដ៏លំបាក ។

សូមពន្យល់ថា ប្រធាន ថូម៉ាស អេស. ម៉នសុន បានចែកចាយនូវរឿងខាងក្រោមអំពីបទពិសោធន៍មួយដែលគាត់បានមាននៅក្នុងយុវវ័យគាត់ ។ ក្រោយពីបានឮថាមិត្តរបស់គាត់ អាសើរ ជាតុន បានស្លាប់នៅក្នុងសង្គ្រាមលោកលើកទីពីរ ថូម៉ាស អេសម៉ុនវ័យក្មេងបានទៅសួរសុខទុក្ខម្តាយរបស់អាសើរ ដែលមិនមែនជាសមាជិកនៃសាសនាចក្រ ។ ក្រោយមក គាត់បានរំឭកថា ៖

« ពន្លឺបានចាកចេញពីជីវិតរបស់អ្នកស្រី ជាតុន ។ គាត់បាននឹករកនៅក្នុងភាពងងឹតសូន្យសុង និងពិបាកចិត្តយ៉ាងខ្លាំង ។

« ដោយការអធិស្ឋាននៅក្នុងចិត្តខ្ញុំ ខ្ញុំបានសុំនឹងការទៅលេងផ្ទះគ្រួសារជាតុន ដោយគិតក្នុងចិត្តថាតើពាក្យនៃការលួងលោមណាដែលគួរនិយាយពីមាត់ខ្ញុំដែលគ្រាន់តែជាក្មេងប្រុសម្នាក់ ។

« ទ្វារបានបើក ហើយអ្នកស្រីជាតុនបានឱបខ្ញុំដូចជាគាត់បានឱបកូនប្រុសរបស់គាត់ដែរ ។ ផ្ទះបានក្លាយជាសាលប្រជុំ នៅពេលដែលម្តាយដែលរងទុក្ខដោយបាត់កូន និងក្មេងប្រុសម្នាក់បានលុតជង្គង់អធិស្ឋាន។

« ពេលងើបពីការអធិស្ឋាន អ្នកស្រីជាតុនបានមើលមកខ្ញុំ ហើយបាននិយាយថា ៖ ‹ ថមមី ខ្ញុំមិនមែនជាសមាជិកនៃសាសនាចក្រណាទេ ប៉ុន្តែឯងគឺជាសមាជិកម្នាក់ ។ សូមប្រាប់ខ្ញុំមកថា តើអាសើរនឹងរស់ម្តងទៀតទេ ? › » (« អ្នកស្រី ជាតុន —រឿងបន្ត »*Ensign*ឬ*លេអាហូណា*,ខែ វិច្ឆិកា ឆ្នាំ ២០០៧, ទំព័រ ២២) ។

- តើអ្នកនឹងឆ្លើយតបសំណួរអ្នកស្រីជាតុនដោយរបៀបណា ?

សូមអានចម្លើយរបស់ប្រធាន ម៉នសុន ៖

« ដោយដឹងអស់ពីចិត្តខ្ញុំ ខ្ញុំបានថ្លែងទីបន្ទាល់ដល់គាត់ថា អាសើរនឹងពិតជារស់ឡើងវិញម្តងទៀត » (« អ្នកស្រី ជាតុន—រឿងបន្ត » ទំព័រ ២២) ។

- តើការដឹងពីផែនការនៃសេចក្តីសង្គ្រោះផ្លាស់ប្តូរការគិតរបស់អ្នកដែលបានបាត់បង់មនុស្សជាទីស្រឡាញ់ដោយរបៀបណា ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮពី អាលម៉ា ២៨:១–៣ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពីតម្លៃដែលសាសន៍នីហ្វៃបានជួយដល់ប្រជាជនអាំម៉ូនដើម្បីរក្សាសេចក្តីសញ្ញារបស់ពួកគេ ។ សូមឲ្យសិស្សអាន អាលម៉ា ២៨:៤–៦ ដោយស្ងាត់ៗ ដោយរកមើលពីរបៀបដែលការស្លាប់យ៉ាងច្រើនបានប៉ះពាល់ដល់សាសន៍នីហ្វៃ ។ សូមឲ្យសិស្សសិក្សា អាលម៉ា ២៨:១១–១២ រកមើលមូលហេតុដែលប្រជាជនខ្លះអាចភ័យខ្លាច នៅពេលមនុស្សជាទីស្រឡាញ់ស្លាប់ ខណៈពេលដែលអ្នកផ្សេងទៀតអាចមានសេចក្តីសង្ឃឹមនោះ ។

- ហេតុអ្វីបានជាមនុស្សខ្លះអាចភ័យខ្លាច នៅពេលដែលមនុស្សជាទីស្រឡាញ់ស្លាប់ ?
- ហេតុអ្វីបានជាមនុស្សខ្លះអាចមានសេចក្តីសង្ឃឹម នៅពេលដែលមនុស្សជាទីស្រឡាញ់ស្លាប់ ? (សិស្សអាចប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរបង្ហាញថា **នៅពេលយើងមានសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ និងសេចក្តីសន្យានៃព្រះអម្ចាស់ យើងអាចមានសេចក្តីសង្ឃឹម និងសេចក្តីអំណរនៅក្នុងពេលនៃការស្លាប់នោះ) ។**

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ ម្ល៉ៃ*ហើយ យើងឃើញ* . . .

សូមសួរសិស្សថាតើពួកគេនឹងបំពេញប្រយោគដោយផ្អែកលើអ្វីដែលពួកគេបានសិក្សានៅក្នុង អាលម៉ា ២៨យ៉ាងដូចម្តេច ។

ក្រោយពីសិស្សបានមានពេលឆ្លើយហើយ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ២៨:១៣–១៤ ។ សូមឲ្យសិស្សប្រៀបធៀបចម្លើយរបស់ពួកគេទៅនឹងគោលការណ៍ដែលបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ ។ (អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំឃ្លា « ម្ល៉ៃហើយ យើងឃើញ » រាល់ពេលដែលមានពាក្យនេះនៅក្នុងខគម្ពីរ ។ សូមពន្យល់ថា មរមនបានប្រើឃ្លានេះជាញឹកញាប់ដើម្បីបង្ហាញពីមេរៀនដ៏សំខាន់ ដែលយើងអាចរៀនពីដំណើររឿងនៅក្នុងព្រះគម្ពីរមរមន) ។

- តើអ្វីដែលអ្នកបានអាននៅក្នុង អាលម៉ា ២៧–២៨ ដែលគាំទ្រដល់ប្រយោគ « ម្ល៉ៃហើយ យើងឃើញថា » របស់មរមន ?
- តើនៅពេលណាដែលអ្នកបានឃើញនរណាម្នាក់ជួបនឹងការស្លាប់របស់ខ្លួនគេផ្ទាល់ ឬ ការស្លាប់របស់មនុស្សជាទីស្រឡាញ់ម្នាក់ដោយមានក្តីសង្ឃឹម ដោយសារតែសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទទេ ?
- តើអ្នកនឹងពន្យល់ពីការរស់ឡើងវិញដើម្បីជួយដល់នរណាម្នាក់ឲ្យមានសេចក្តីសង្ឃឹមដើម្បីប្រឈមមុខនឹងការស្លាប់របស់គេ ឬ ការស្លាប់របស់មនុស្សជាទីស្រឡាញ់ម្នាក់ដោយរបៀបណា ?

អាលម៉ា ២៩

អាលម៉ាអួតនៅក្នុងការនាំព្រលឹងទៅរកព្រះ

សូមប្រាប់សិស្សថា អាលម៉ា ២៩ រួមមានការបង្ហាញរបស់អាលម៉ាពីបំណងប្រាថ្នារបស់គាត់ដើម្បីក្លាយជាគ្រឿងឧបករណ៍នៅក្នុងព្រះហស្តរបស់ព្រះអម្ចាស់ ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ២៩:១–៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលអាលម៉ាអាច

សូមជួយសិស្សឲ្យដឹងពីគោលការណ៍ដែលបានបង្រៀននៅក្នុងព្រះគម្ពីរ

ក្នុងករណីខ្លះ គោលការណ៍នៃដំណឹងល្អដែលបានបង្រៀននៅក្នុងព្រះគម្ពីរត្រូវបាននាំដោយឃ្លា « ម្ល៉ៃហើយ យើងឃើញថា » ។ ជាឧទាហរណ៍ នៅក្នុង អាលម៉ា ២៨:១៣–១៤ មរមនប្រើ « ម្ល៉ៃហើយ យើងឃើញថា » ដើម្បីទាញចំណាប់អារម្មណ៍ទៅលើគោលការណ៍ដែលយើងអាចរៀនពីបទពិសោធន៍របស់អាំម៉ូន និងពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃ ។ សូមបង្រៀនសិស្សថា នៅពេលពួកគេសិក្សា និងសញ្ជឹងគិតអំពីព្រះគម្ពីរ ពួកគេអាចរកឃើញនូវគោលការណ៍ដោយខ្លួនឯងដោយការសួរខ្លួនគេថា « តើខគម្ពីរទាំងនេះបង្រៀនខ្ញុំពីអ្វី ?»

នឹងបានធ្វើ ប្រសិនបើគាត់អាចបំពេញ « បំណងចិត្ត [របស់គាត់] » ។ (គាត់នឹង « ប្រកាស [ដល់មនុស្សគ្រប់រូបដូចជាផ្ដួរលាន់នូវការប្រែចិត្ត ») ។

- យោងតាម អាលម៉ា ២៩:២ ហេតុអ្វីបានជាអាលម៉ាមានបំណងនេះ ?

សូមឲ្យសិស្សអាន អាលម៉ា ២៩:៤–៥ ដោយស្ងាត់ៗ ដោយរកមើលអ្វីដែលព្រះអម្ចាស់ផ្ដល់ដល់អ្នកដែលមានបំណងសុចរិត ។ (ប្រសិនបើសិស្សត្រូវការជំនួយក្នុងការឆ្លើយនឹងសំណួរនេះ អ្នកអាចបង្ហាញឃ្លា « ខ្ញុំដឹងថា ទ្រង់បានផ្ដល់ដល់មនុស្សយោងតាមបំណងរបស់ពួកគេ» ។ សូមពន្យល់ថា **ប្រសិនបើយើងប៉ងអ្វីដែលសុចរិត ព្រះអម្ចាស់នឹងប្រទានពរយើងស្របតាមបំណងទាំងនេះ ។**សូមបង្ហាញថា ប្រសិនបើបំណងសុចរិតរបស់យើងទាំងអស់មិនបានបំពេញនៅក្នុងជីវិតនេះទេ វានឹងត្រូវបានបំពេញនៅក្នុងភាពដ៏អស់កល្បជានិច្ច) ។

សូមឲ្យសិស្សសិក្សា អាលម៉ា ២៩:១០, ១៤, ១៦ រៀងៗខ្លួន ដោយរកមើលពរជ័យដែលអាលម៉ាបានទទួល នៅពេលដែលគាត់បានជួយអ្នកដទៃឲ្យមករកព្រះគ្រីស្ទ ។ សូមឲ្យសិស្សចែកចាយអ្វីដែលពួកគេរកឃើញ ។

- តើពាក្យណាដែលអាលម៉ាបានប្រើដើម្បីរៀបរាប់ពីអារម្មណ៍អំពីការជួយដល់អ្នកដទៃឲ្យមករកព្រះគ្រីស្ទនោះ ? (អ្នកអាចផ្ដល់យោបល់ថា សិស្សគួរគូសចំណាំការប្រើពាក្យនីមួយៗ *សេចក្ដីអំណរ* នៅក្នុងខគម្ពីរទាំងនេះ) ។
- តើគោលការណ៍អ្វីដែលយើងអាចរៀនពីបទពិសោធន៍របស់អាលម៉ា ក្នុងការជួយអ្នកដទៃឲ្យប្រែចិត្ត និងមករកព្រះយេស៊ូវគ្រីស្ទនោះ ? (សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរបង្ហាញថា ពួកគេយល់ពីគោលការណ៍ខាងក្រោមនេះ ៖ **យើងនឹងទទួលបានសេចក្ដីអំណរ នៅពេលយើងជួយអ្នកដទៃឲ្យប្រែចិត្ត និងមករកព្រះយេស៊ូវគ្រីស្ទ) ។**
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថាមានអំណរដែលមកពីការជួយអ្នកដទៃឲ្យមករកព្រះគ្រីស្ទ ?

សូមលើកទឹកចិត្តសិស្សឲ្យរកឱកាសដើម្បីជួយអ្នកអ្នកដទៃឲ្យមករកព្រះយេស៊ូវគ្រីស្ទ ។ សូមគិតពីការចែកចាយបទពិសោធន៍បេសកកម្មដ៏មានអំណររបស់អ្នកផ្ទាល់ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អាលម៉ា ២៨:១១–១២ ។ ការរកឃើញនូវសេចក្ដីសុខសាន្ត នៅពេលសេចក្ដីស្លាប់កើតឡើង

អែលឌើរ រ័សុល អិម ណិលសុននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បាននិយាយអំពីរបៀបដែលសកម្មភាពរបស់យើងនៅក្នុងជីវិតនេះអាចនាំមកនូវសេចក្ដីសុខសាន្តដល់យើង នៅពេលសេចក្ដីស្លាប់កើតឡើង ៖

« បងប្អូនប្រុសស្រីទាំងឡាយ យើងរស់នៅដើម្បីស្លាប់ ហើយយើងស្លាប់ដើម្បីរស់នៅ—នៅក្នុងពិភពផ្សេងទៀត ។ ប្រសិនបើយើងរៀបចំបានល្អ នឹងគ្មានការភ័យខ្លាចចំពោះសេចក្ដីស្លាប់នោះទេ ។ ចេញពីទស្សនវិស័យដ៏អស់កល្បជានិច្ចមួយ សេចក្ដីស្លាប់គឺភ័យខ្លាចចំពោះអ្នកដែលមិនបានរៀបចំដើម្បីទៅជួបនឹងព្រះ ។

« ឥឡូវនេះគឺជាពេលដើម្បីរៀបចំ ។ បន្ទាប់មក នៅពេលសេចក្ដីស្លាប់មកដល់ យើងអាចទៅដល់សិរីល្អសេឡេស្ទាលដែលព្រះវរបិតាសួគ៌បានរៀបចំសម្រាប់កូនចៅដ៏ស្មោះត្រង់របស់ទ្រង់ ។ ទន្ទឹមនឹងពេលនោះ សម្រាប់អ្នកដែលកើតទុក្ខដែលនៅបន្តលើផែនដី . . . ចំណងនៃសេចក្ដីស្លាប់ត្រូវបានស្រាយដោយសេចក្ដីជំនឿដ៏ខ្ជាប់ខ្ជួនទៅលើព្រះគ្រីស្ទ ពន្លឺដ៏ឥតខ្ចោះនៃសេចក្ដីសង្ឃឹម សេចក្ដីស្រឡាញ់របស់ព្រះ និងរបស់មនុស្សទាំងឡាយ និងបំណងប្រាថ្នាដ៏ជ្រាលជ្រៅដើម្បីបម្រើដល់ពួកគេ » (« Now Is the Time to Prepare » *Ensign*ឬ*លេអាហូណា*,ខែ ឧសភា ឆ្នាំ ២០០៥, ទំព័រ ១៨) ។

អែលឌើរ វីលហ្វត ដបុលយូ អាន់ឌើរសិន នៃពួកចិតសិបនាក់បានប្រាប់ពីរបៀបដែលមិត្តភក្តិខ្លះប្រឈមនឹងសេចក្ដីស្លាប់របស់ឪពុករបស់ពួកគេ ៖

« ថ្មីៗនេះមិត្តជាទីស្រឡាញ់របស់ខ្ញុំម្នាក់បានស្លាប់ដោយសារជំងឺមហារីក ។ គាត់ និងគ្រួសារគឺជាមនុស្សដែលមានសេចក្ដីជំនឿដ៏ខ្លាំង ។ វាបានបំផុសគំនិត ពេលឃើញពីរបៀបដែលសេចក្ដីជំនឿរបស់ពួកគេបាននាំពួកគេឆ្លងកាត់ពេលដ៏លំបាកខ្លាំងនេះ ។ ពួកគេបានពោរពេញដោយសេចក្ដីសុខសាន្តក្នុងដួងចិត្ត ដែលបន្ត និងពង្រឹងដល់ពួកគេ ។ ដោយមានការអនុញ្ញាតពីពួកគេ ខ្ញុំចង់អានសំបុត្រាពីសមាជិករបស់គ្រួសារម្នាក់ដែលបានសរសេរក្រោយពីថ្ងៃដែលឪពុករបស់នាងបានស្លាប់ ៖

« ‹ ពីរបីថ្ងៃមុនពិតជាពិបាកខ្លាំងណាស់ ។ . . . កាលពីយប់មិញ នៅពេលយើងបានប្រជុំគ្នានៅក្បែរប៉ា ព្រះវិញ្ញាណនៃព្រះអម្ចាស់បានមកយ៉ាងច្បាស់ ហើយពិតជាបានធ្វើជាអ្នកលួងលោមដល់យើងយ៉ាងប្រាកដ ។ យើងមានសេចក្ដីសុខសាន្ត ។ . . . វាជារឿងដ៏លំបាកបំផុតសម្រាប់ពួកយើងគ្រប់គ្នា ប៉ុន្តែយើងមានអារម្មណ៍សុខសាន្តដោយដឹងថា . . . ព្រះវរបិតារបស់យើងដែលគង់នៅឯស្ថានសួគ៌បានសន្យាថា យើងនឹងរស់នៅជាមួយគ្នាជាគ្រួសារម្ដងទៀត ។ ក្រោយពីវេជ្ជបណ្ឌិតបានប្រាប់ប៉ានៅក្នុងមន្ទីរពេទ្យថា គ្មានអ្វីដែលអាចធ្វើបានទៀតទេ គាត់បានសម្លឹងមកយើងទាំងអស់គ្នាដោយមានសេចក្ដីជំនឿដ៏ឥតខ្ចោះ និងមានសួរដោយរឹងមាំថា « តើមាននរណាម្នាក់នៅក្នុងបន្ទប់នេះមានបញ្ហានឹងផែនការនៃសេចក្ដីសង្គ្រោះទេ ??» យើង . . . មានសេចក្ដីអំណរចំពោះឪពុក និងម្ដាយដែលបានបង្រៀនយើងឲ្យមានការទុកចិត្តដ៏ឥតខ្ចោះទៅលើផែនការនេះ › » (« The Rock of Our Redeemer »*Ensign*ឬ*លេអាហូណា*,ខែ ឧសភា ឆ្នាំ ២០១០, ទំព័រ ១៧–១៨) ។

អាលម៉ា ៣០

សេចក្តីផ្តើម

ក្រោយពីសង្គ្រាមដ៏ធំមួយរវាងសាសន៍នីហ្វៃ និងសាសន៍លេមិន សេចក្តីសុខសាន្តបានកើតមាននៅក្នុងដែនដី ។ ប្រហែលជាពីរឆ្នាំក្រោយមក បុរសម្នាក់ឈ្មោះ កូរីហូរបានចាប់ផ្តើមបង្រៀនថា គ្មានព្រះទេ ថានឹងគ្មានព្រះគ្រីស្តឡើយ ហើយថាគ្មានអំពើបាបនោះទេ ។ គាត់ស្អប់អ្នកដឹកនាំនៃសាសនាចក្រ ដោយប្រកាសថាពួកគេបានកំពុងបង្រៀនពីសណ្តាប់ដ៏ឆ្គួតលីលា ។ ការបង្រៀនដ៏ខុសឆ្គងរបស់គាត់បានដឹកនាំមនុស្សជាច្រើនឲ្យប្រព្រឹត្តអំពើបាបដ៏ធ្ងន់ធ្ងរ ។ កូរីហូរត្រូវបាននាំទៅជួបនឹងអាលម៉ា ដែលបានថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ហើយបានបង្រៀនថាអ្វីៗទាំងអស់ថ្លែងទីបន្ទាល់អំពីព្រះបង្កបង្កើតដ៏អស្ចារ្យ ។ នៅទីបញ្ចប់ កូរីហូរមិនអាចនិយាយរួចដោយសារអំណាចនៃពាក្យ ហើយបានដឹងពីសេចក្តីពិត ។ ទោះជាយ៉ាងណាក្តី នៅពេលគាត់បានស្នើសុំឲ្យគាត់និយាយរួចវិញ អាលម៉ាបានបដិសេធដោយនិយាយថា គាត់នឹងបង្រៀនគោលលទ្ធិខុសម្តងទៀត ប្រសិនបើគាត់អាចនិយាយរួចនោះ ។ កូរីហូរបានសុំទានអាហារពេញមួយជីវិតរបស់គាត់ រហូតដល់គាត់ត្រូវបានក្រុមអ្នកបែកចេញពីសាសន៍នីហ្វៃ ដែលហៅថាសាសន៍សូរ៉ាំ បានវាយគាត់ស្លាប់ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៣០:១–១៨

កូរីហូរ ជាអ្នកដែលប្រឆាំងនឹងព្រះគ្រីស្ទ ចំអកដល់គោលលទ្ធិនៃព្រះគ្រីស្ទ

មុនចាប់ផ្តើមបង្រៀន សូមចោះរន្ធតូចមួយនៃបាតកំប៉ុងសូដា ហើយឲ្យវាហៀរចេញចោលចុះ: ។ សូមបង្ហាញកំប៉ុងដល់សិស្សក្នុងថ្នាក់ដោយមិនប្រាប់ថាវាទទេនោះទេ ។ សូមសួរថា តើនរណាចង់បានវា ហើយតើពួកគេនឹងហ៊ានចំណាយប៉ុន្មានសម្រាប់វា ។ សូមឲ្យសិស្សម្នាក់ឈានមកខាងមុខ ពិនិត្យមើលកំប៉ុង ហើយប្រាប់សិស្សក្នុងថ្នាក់នូវអ្វីដែលមាននៅខាងក្នុង ។ (ជំនួសឲ្យកំប៉ុងសូដា អ្នកក៏អាចប្រើប្រអប់ទទេមួយ កាតាបមួយ ឬប្រអប់កាដូទទេមួយដែលជាធម្មតាវាមានអ្វីដែលសិស្សនឹងចូលចិត្ត) ។

- **តើការបង្រៀនខុសឆ្គងដូចជាកំប៉ុងសូដានេះដោយរបៀបណា ? (ជាញឹកញាប់ វាទាក់ទាញពីខាងក្រៅ ប៉ុន្តែខាងក្នុងវាទទេស្អាត) ។**

សូមពន្យល់ថា នៅក្នុងមេរៀនថ្ងៃនេះ សិស្សនឹងរៀនអំពីបុរសម្នាក់ឈ្មោះកូរីហូរ ។ នៅពេលសិស្សសិក្សា អាលម៉ា ៣០ សូមលើកទឹកចិត្តពួកគេឲ្យគិតពីរបៀបដែលការបង្រៀនរបស់កូរីហូរបានធ្វើឲ្យគាត់ និងអ្នកដទៃទទេស្អាតខាងវិញ្ញាណ ។

សូមប្រាប់សិស្សថា ក្រោយពីសង្គ្រាមនឹងសាសន៍លេមិនហើយ ប្រជាជនអាំម៉ូន (ពួកសាសន៍អាន់តៃ-នីហ្វៃ-លីហៃ) និងពួកសាសន៍នីហ្វៃបានមានសេចក្តីសុខសាន្តមួយរយៈ ។ បន្ទាប់មក កូរីហូរបានរំខានដល់សេចក្តីសុខសាន្តរបស់ពួកគេ ។ សូមឲ្យសិស្សអានអាលម៉ា ៣០:៦, ១២ ដោយរកមើលពាក្យមួយដែលរៀបរាប់ពីបុរសនេះ ។ (ពាក្យនោះគឺ *អ្នកទទឹងនឹងព្រះគ្រីស្ទ* ។ សូមពន្យល់ថា និយមន័យមួយនៃពាក្យនេះគឺ « នរណាម្នាក់ ឬ អ្វីមួយដែលបន្លំដែនការនៃសេចក្តីសង្គ្រោះនៃដំណឹងល្អដ៏ពិត ហើយដែលប្រឆាំងនឹងព្រះគ្រីស្ទដោយបើកចំហរ ឬ ដោយសម្ងាត់ » (Guide to the Scriptures, “Antichrist,” scriptures.lds.org) ។

សូមរៀបចំលំហាត់ខាងក្រោមជាក្រដាស ឬ សរសេរនៅលើក្តារខៀនមុនចាប់ផ្តើមថ្នាក់ ។ ប្រសិនបើអ្នកសរសេរនៅលើក្តារខៀន សូមឲ្យសិស្សចម្លងវាទៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ វានឹងជួយពួកគេឲ្យឃើញពីរបៀបដែលសាតាំង និងអ្នកទាំងឡាយដែលបម្រើវា ប្រើគោលលទ្ធិខុសឆ្គងដើម្បីទាក់ទាញយើងឲ្យធ្វើអំពើបាប ។

ការបង្រៀនខុសឆ្គងរបស់កូរីហូរ ជាជនទទឹងនឹងព្រះគ្រីស្ទ

ការបង្រៀនខុសឆ្គង	សារលិខិត
១. អាលម៉ា ៣០:១៣–១៤	. អ្នកមិនអាចដឹងពីអ្វីមួយថាពិត រហូតដល់អ្នកឃើញវា ។ ហេតុដូច្នេះហើយ អ្នកមិនអាចដឹងថា នឹងមានព្រះគ្រីស្តនោះទេ ។
២. អាលម៉ា ៣០:១៥	. គ្មានរឿងបែបនោះជាអំពើបាបនោះទេ ។ គ្មានបទដ្ឋានជាសកលណាថាអ្វីជាការត្រូវ ឬខុសនោះទេ ។
៣. អាលម៉ា ៣០:១៦	. ប្រជាជនរីកចម្រើនដោយការខិតខំផ្ទាល់របស់ពួកគេតែឯង ។ គ្មានរឿងបែបនោះថាជាដង្វាយធួននោះទេ ។
៤. អាលម៉ា ៣០:១៧ (ការចាប់ផ្តើមដោយ « មនុស្សគ្រប់រូបបានចម្រើនឡើង . . . »)	. វាមិនអាចទៅរួចឡើយដែលដឹងអំពីអ្វីៗដែលនឹងកើតឡើងនៅក្នុងអនាគតកាលនោះ ដូច្នេះអ្នកមិនគួរជឿលើព្រះគ្រីស្ទ ឬធ្វើតាមពាក្យនៃមនុស្សដែលនិយាយថាពួកគេជាព្យាការីនោះទេ ។

ការបង្រៀនខុសឆ្គង	សារលិខិត
៥. អាលម៉ា ៣០:១៧ (ចាប់ផ្តើមដោយ « អ្វីៗក៏ដោយដែលមនុស្សបានប្រព្រឹត្តិ . . . »)	. ការអភ័យទោសនៃអំពើបាបគឺជាគំនិតដ៏ឆ្កួតលីលាមួយ ដែលចេញមកពីសណ្តាប់ដ៏ខុសឆ្គង ។
៦. អាលម៉ា ៣០:១៨	. គ្មានជីវិតក្រោយពីការស្លាប់នោះទេ ដូច្នេះយើងមិនត្រូវបារម្ភពីការកោតសេចក្តីក្រោយពីជីវិតនេះឡើយ ។

សូមបែងចែកសិស្សជាដៃគូ ។ សូមឲ្យពួកគេអាន អាលម៉ា ៣០:១២–១៨ រួមគ្នា ។ សូមណែនាំពួកគេឲ្យផ្គូផ្គងការបង្រៀនខុសរបស់កូរីហូរ ដែលនៅផ្នែកខាងឆ្វេងនៃលំហាត់ទៅនឹងសារលិខិតនៃការបង្រៀនទាំងនោះដែលនៅខាងស្តាំ ។ (ចម្លើយ ៖ ១–ឃ, ២–ក, ៣–ង, ៤–គ, ៥–ខ, ៦–ច) ។

ដើម្បីជួយសិស្សឲ្យវិភាគការបង្រៀនរបស់កូរីហូរ និងអនុវត្តអ្វីដែលពួកគេរៀន សូមសួរសំណួរខាងក្រោម ៖

- **តើការបង្រៀនអ្វីខ្លះដែលអ្នកបានប្រឆាំង ដូចជាការបង្រៀនរបស់កូរីហូរនេះ ?**
- **យោងតាម អាលម៉ា ៣០:១៨តើការបង្រៀនរបស់កូរីហូរអ្វីខ្លះដែលដឹកនាំប្រជាជនឲ្យធ្វើ ?**
- **តើអ្នកគិតថា ហេតុអ្វីបានជាការបង្រៀនទាំងនេះដឹកនាំប្រជាជនឲ្យចុះចាញ់នឹងការល្បួង ?**
- **តើយើងអាចរៀនអ្វីបានខ្លះពីខគម្ពីរទាំងនេះ អំពីគ្រោះថ្នាក់នៃគោលលទ្ធិដ៏ខុសឆ្គងនោះ ? (សូមជួយសិស្សឲ្យដឹងពីគោលការណ៍ខាងក្រោម ៖ សាតាំងប្រើគោលលទ្ធិខុសឆ្គងដើម្បីទាក់ទាញយើងឲ្យធ្វើអំពើបាប) ។**

សូមឲ្យសិស្សស្រមៃថាខ្លួនគេនៅក្នុងស្ថានភាពដូចខាងក្រោម ៖

មិត្តភក្តិម្នាក់អញ្ជើញអ្នកឲ្យលេងល្បែងវីដេអូ ។ នៅពេលអ្នកមកដល់ផ្ទះមិត្តរបស់អ្នក អ្នកដឹងថា ល្បែងនោះគឺហិង្សា ហើយថាវាមានលក្ខណៈនៃការស្មៀកពាក់មិនសមរម្យ ។ នៅពេលអ្នកស្ទាក់ស្ទើរនឹងលេងល្បែងនោះ មិត្តរបស់អ្នកសុំអ្នកឲ្យពន្យល់ពីមូលហេតុដែលអ្នកមិនចង់លេង ។

- **តើអ្នកនឹងនិយាយថាដូចម្តេច ? (សិស្សអាចពន្យល់ថា ល្បែងនោះរំលងបទដ្ឋាននៃសេចក្តីជំនឿរបស់ពួកគេ) ។**
- **ប្រសិនបើមិត្តរបស់អ្នកចាប់ផ្តើមរិះគន់សេចក្តីជំនឿរបស់អ្នក ដោយនិយាយថា វាកម្រិតសេរីភាពរបស់អ្នក តើអ្នកនឹងឆ្លើយតបយ៉ាងណា ?**

អាលម៉ា ៣០:១៩–៦០

កូរីហូរទាមទារទីសម្គាល់មួយពីអាលម៉ា ហើយបានគរដោយអំណាចនៃព្រះ

សូមសង្ខេប អាលម៉ា ៣០:១៩–៣០ ដោយការពន្យល់ថា កូរីហូរបានបង្រៀនគោលលទ្ធិខុសឆ្គងនៅក្នុងទីក្រុងនៃសាសន៍នីហ្វៃបីខុសគ្នា ។ នៅទីបញ្ចប់ គាត់ត្រូវបាននាំទៅជួបនឹងមេចៅក្រមនៃដែនដី និងនៅមុខអាលម៉ា ដែលជាអ្នកដឹកនាំនៃសាសនចក្រ ។ អ្នកអាចបង្ហាញថា អំណះអំណាងចម្បងរបស់កូរីហូរមួយគឺថា អ្នកដឹកនាំសាសនាចក្របានដាក់ប្រជាជននៅក្នុងសេរីភាព—ដោយសាសនារបស់ពួកគេបានយកសេរីភាពចេញពីប្រជាជន ។ គាត់ក៏បានចោទអ្នកដឹកនាំសាសនាចក្រពីបទការចង់បានផលចំណេញផ្ទាល់ខ្លួនពីការបម្រើរបស់ប្រជាជន ។

សូមឲ្យសិស្សអាន អាលម៉ា ៣០:៣១ដោយស្ងាត់ៗ ដោយរកមើលការចោទប្រកាន់ដែលកូរីហូរបានធ្វើទាស់នឹងអាលម៉ា និងអ្នកដឹកនាំផ្សេងទៀតនៅក្នុងសាសនាចក្រ ។

សូមឲ្យសិស្សអាន អាលម៉ា ៣០:៣២–៣៥ ដើម្បីរកមើលនូវរបៀបដែលអាលម៉ាឆ្លើយតបនឹងកូរីហូរ ។

- **តើអ្នកបានឃើញពីសេចក្តីពិតនៃចម្លើយរបស់អាលម៉ានៅក្នុងជីវិតនៃអ្នកដឹកនាំសាសនាចក្រដោយរបៀបណា ?**

សូមឲ្យសិស្សពីរនាក់មកខាងមុខថ្នាក់ ។ សូមឲ្យពួកគេអាន អាលម៉ា ៣០:៣៧–៤៥ ឮ ដោយមានម្នាក់អានសម្តីរបស់អាលម៉ា និងម្នាក់ទៀតអានសម្តីរបស់កូរីហូរ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលអាលម៉ាបង្ហាញជាភស្តុតាងនៃការមានព្រះមួយអង្គ ។

- **តើភស្តុតាងអ្វីដែលអាលម៉ាបានផ្តល់សម្រាប់បញ្ជាក់ជាការមានព្រះ ? នៅពេលសិស្សឆ្លើយតប អ្នកអាចសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ អ្នកក៏អាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំវានៅក្នុងព្រះគម្ពីររបស់ពួកគេដែរ ។ ជាផ្នែកនៃការពិភាក្សានេះ សូមបញ្ជាក់ថា អ្វីៗទាំងអស់ថ្លែងទីបន្ទាល់អំពីព្រះ ។**
- **ក្នុងចំណោមភស្តុតាងដែលអាលម៉ាបានបញ្ជាក់ តើមួយណាដែលមានអំណាចជាពិសេសដល់អ្នក ? ហេតុអ្វី ?**

សូមឲ្យពេលសិស្សពីរបីនាទីដើម្បីសរសេរ ។ សូមឲ្យពួកគេសរសេរនូវភស្តុតាងដែលពួកគេបានឃើញដែល « ធ្វើជាសាក្សីថា មានព្រះមួយអង្គ » (អាលម៉ា ៣០:៤៤) ។ សូមឲ្យសិស្សបីបួននាក់ចែកចាយនូវបញ្ជីរបស់ពួកគេដល់សិស្សក្នុងថ្នាក់ ។

- **តើភស្តុតាងទាំងនេះជះឥទ្ធិពលដល់អ្នកដោយរបៀបណា ? តើវាអាចពង្រឹងដល់សេចក្តីជំនឿ និងទីបន្ទាល់របស់អ្នកតាមវិធីណា ?**

សូមសង្ខេប អាលម៉ា ៣០:៤៦–៥០ ដោយការពន្យល់ថាកូរីហ្សូរនៅតែមិនទទួលយកនូវទីសម្គាល់ទាំងឡាយដែលគាត់បានទទួល គាត់បានទាមទារថា អាលម៉ាត្រូវបង្ហាញគាត់ពីទីសម្គាល់មួយនៃការមានព្រះ ។ ជាចម្លើយ កូរីហ្សូរបានក្លាយជាគរដោយអំណាចនៃព្រះ ។ ដោយដឹងពីអំណាចរបស់ព្រះ កូរីហ្សូរបានសរសេរអំពីមូលហេតុដែលគាត់បានបង្រៀនប្រឆាំងនឹងព្រះជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សម្នាក់អានឮនូវការពន្យល់របស់កូរីហ្សូរនៅក្នុង អាលម៉ា ៣០:៥១–៥៣ ។

- តើអ្នកគិតថា កូរីហ្សូរមានន័យយ៉ាងណា នៅពេលគាត់បាននិយាយថា គាត់បានបង្រៀនអ្វីដែល « ធ្វើឲ្យស្តប់ស្តល់ដល់តំនិតខាងរូបកាយ » ? (អ្នកអាចពន្យល់ថា ការបង្រៀនរបស់កូរីហ្សូរគ្រាប់ពីបំណងខាងរូបកាយដ៏មិនសុចរិតរបស់ប្រជាជនជាជាងបំណងខាងវិញ្ញាណដ៏សុចរិតរបស់ពួកគេ) ។

សូមសង្ខេប អាលម៉ា ៣០:៥៤–៥៩ ដោយការពន្យល់ថា កូរីហ្សូរបានសុំឲ្យអាលម៉ាអធិស្ឋានដើម្បីឲ្យបណ្តាសាអាចដោះចេញពីគាត់ ។ អាលម៉ាបានបដិសេធ ដោយនិយាយថា ប្រសិនបើកូរីហ្សូរអាចនិយាយបានវិញ គាត់នឹងបង្រៀននូវគោលលទ្ធិខុសឆ្គងម្តងទៀតដល់ប្រជាជន ។ កូរីហ្សូរត្រូវបានបណ្តេញចេញ ហើយបានដើរពីផ្ទះមួយទៅផ្ទះមួយសុំអាហារ ។ នៅទីបញ្ចប់គាត់បានទៅជួបនឹងពួកសាសន៍សារ៉ាហិមឡា ដែលបានបែកចែកពីសាសន៍នីហ្វៃ ហើយគាត់ត្រូវបានវាយដល់ស្លាប់ ។

សូមឲ្យសិស្សអាន អាលម៉ា ៣០:៦០ ដោយស្ងាត់ៗ ដោយរកមើលគោលការណ៍ដែលមរមនបង្រៀន ។

- តើគោលការណ៍អ្វីដែលមរមនបង្រៀននៅក្នុងខគម្ពីរនេះ ?

សូមប្រាកដថាសិស្សយល់ថា « **អារក្សនឹងមិនគាំទ្រកូនចៅរបស់វា ។ អ្នកដើរតាមវា ។ នៅថ្ងៃចុងក្រោយនោះទេ** » ។

- តើការណ៍នេះខុសពីរបៀបដែលព្រះវរបិតាស្ងួត និងព្រះយេស៊ូវគ្រីស្ទយកចិត្តទុកដាក់ពីយើងដោយរបៀបណា ? (នៅពេលសិស្សពិភាក្សាពីសំណួរនេះ អ្នកអាចឲ្យពួកគេអានអាលម៉ា ៣៦:៣) ។

សូមថ្លែងទីបន្ទាល់ពីសេចក្តីពិតដែលអ្នក និងសិស្សបានពិភាក្សានៅក្នុងមេរៀននេះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អាលម៉ា ៣០:៥២ ។ « ខ្ញុំបានដឹងជាហួតមក មានព្រះមួយអង្គមែន »

អែលឌើរ រ៉ូបឺត ឌី ហៃលនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនអំពីសារសំខាន់នៃការទទួលស្គាល់ទីសម្គាល់ដែលយើងបានទទួលទាក់ទងនឹងសេចក្តីពិតនៃដំណឹងល្អ ៖

« ប្រសិនបើយើងមិនលះបង់ដើម្បីទទួលឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធទេ យើងនឹងឈរនៅក្នុងគ្រោះថ្នាក់នៃការក្លាយដូចជាកូរីហ្សូរ ជាជនទទឹងនឹងព្រះគ្រីស្ទនៅក្នុងព្រះគម្ពីរមរមន ។ កូរីហ្សូរមិនត្រឹមតែមិនជឿលើព្រះទេ ប៉ុន្តែគាត់ថែមទាំងចំអកដល់ព្រះអង្គសង្គ្រោះ ជង្វាយធួន និងវិញ្ញាណនៃការព្យាករណ៍ ដោយបង្រៀនខុសឆ្គងថា គ្មានព្រះ និងគ្មានព្រះគ្រីស្ទឡើយ ។

« កូរីហ្សូរមិនគ្រាន់តែចង់បដិសេធព្រះ ហើយដើរតាមផ្លូវគាត់ផ្ទាល់ខ្លួនដោយស្ងាត់ៗនោះទេ ។ គាត់បានចំអកដល់អ្នកជឿ និងទាមទារថា ព្យាការីអាលម៉ាត្រូវបង្ហាញដល់គាត់នូវទីសម្គាល់មួយនៃការរស់នៅ និងអំណាចរបស់ព្រះ ។ ចម្លើយរបស់អាលម៉ាគឺមានន័យដល់សព្វថ្ងៃដូចកាលពីជំនាន់នោះដែរ ៖ ‹ អ្នកបានទទួលទីសម្គាល់ល្មមគ្រប់គ្រាន់ហើយ តើអ្នកចង់សាកល្បងព្រះរបស់អ្នកធ្វើអ្វី ? តើអ្នកនៅតែនិយាយថា ចូរបង្ហាញខ្ញុំនូវទីសម្គាល់មួយនៅពេលដែលអ្នកមានទីបន្ទាល់នៃបងប្អូនរបស់អ្នកអស់ទាំងនេះ និងអស់ទាំងពួកព្យាការីដ៏បរិសុទ្ធផងឬ ? បទគម្ពីរទាំងឡាយត្រូវបានបើកត្រដាងនៅចំពោះអ្នក មែនហើយ ហើយគ្រប់ការណ៍ទាំងអស់បង្ហាញថា មានព្រះមួយអង្គមែន មែនហើយ ហើយសូម្បីតែផែនដី និងរបស់សព្វសារពើដែលនៅលើផ្ទៃផែនដីមែនហើយ និងចលនារបស់ផែនដី មែនហើយ ព្រមទាំងពិភពទាំងអស់ដែលធ្វើចលនាតាមទម្រង់ធម្មតារបស់គេ ក៏ធ្វើជាសាក្សីថា មានព្រះបង្កបង្កើតដ៏មហិមាមួយអង្គ › ។ [អាលម៉ា ៣០:៤៤] ។

« នៅទីបញ្ចប់ កូរីហ្សូរត្រូវបានផ្តល់នូវទីសម្គាល់មួយ ។ គាត់បានក្លាយទៅជាគ ។ ‹ហើយ កូរីហ្សូរបានលូកដៃមកសរសេរថា ៖ . . . ខ្ញុំដឹងថា គ្មានអ្វីសោះឡើយលើកលែងតែព្រះចេស្តានៃព្រះប៉ុណ្ណោះដែលអាចនាំការណ៍នេះមកលើខ្ញុំបាន មែនហើយ ហើយខ្ញុំបានដឹងជាហួតមកថា មានព្រះមួយអង្គមែន › ។ [អាលម៉ា ៣០:៥២] ។

« បងប្អូនប្រុសស្រី អ្នកអាចដឹងនៅក្នុងជម្រៅនៃព្រលឹងរបស់អ្នកច្បាស់ហើយ ថាព្រះទ្រង់នៅរស់ ។ អ្នកមិនអាចដឹងគ្រប់ការណ៍ទាំងអស់អំពីទ្រង់ឡើយ ហើយក៏មិនយល់ពីរបៀបរបស់ទ្រង់ទាំងអស់ដែរ ប៉ុន្តែពន្លឺនៃសេចក្តីជំនឿស្ថិតនៅក្នុងអ្នក រង់ចាំដើម្បីជាស់ និងធ្វើឲ្យមានកម្លាំងខ្លាំងឡើងដោយព្រះវិញ្ញាណនៃព្រះ និងពន្លឺនៃព្រះគ្រីស្ទ ដែលអ្នកបានកើតនោះ » (« Seeking to Know God, Our Heavenly Father, and His Son, Jesus Christ » *Ensign* ឬ *លេអាហូណា*, ខែ វិច្ឆិកា ឆ្នាំ ២០០៩, ទំព័រ ៣១–៣២) ។

មេរៀនទី ៨៩

អាលម៉ា ៣១

សេចក្តីផ្តើម

អាលម៉ាបានដឹងថា ក្រុមសាសន៍នីហ្វៃប្រឆាំងមួយក្រុមដែលហៅថា សាសន៍សូរាំបានវង្វេងពីសេចក្តីពិតនៃដំណឹងល្អ ហើយបានធ្លាក់ទៅក្នុងការអនុវត្តខុស ។ ដោយកើតទុក្ខនឹងការរៀបរាប់ពីភាពទុច្ចរិតទាំងនេះ អាលម៉ាបាននាំក្រុមអ្នកផ្សព្វផ្សាយសាសនាមួយក្រុមទៅបង្រៀនព្រះបន្ទូលនៃព្រះដល់ពួកសាសន៍សូរាំ ។ អាលម៉ា និងដៃគូរបស់គាត់បានសង្កេតពីការគោរពដែលក្បត់នឹងសាសនារបស់ពួកសាសន៍សូរាំ ការនិយមនឹងសម្ភារ និងអំនួតរបស់ពួកគេ ។ អាលម៉ាបានអធិស្ឋានដោយអស់ពីចិត្តថា ព្រះអម្ចាស់នឹងលួងលោមដល់គាត់ និងដៃគូរបស់គាត់ នៅពេលពួកគេប្រឈមមុខនឹងឧបសគ្គនេះ ហើយថាពួកគេនឹងមានជ័យជំនះក្នុងការនាំពួកសាសន៍សូរាំត្រឡប់មកកាន់ព្រះអម្ចាស់វិញ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៣១:១–៧

អាលម៉ា និងដៃគូរបស់គាត់ចាកចេញពីសាវ៉ាហិមឡាដើម្បីបង្រៀនព្រះបន្ទូលនៃព្រះដល់ពួកសាសន៍សាវ៉ាហិមឡាដែលក្បត់សាសនា

សូមឲ្យសិស្សគីតអំពីអ្វីដែលពួកគេនឹងធ្វើ ប្រសិនបើមិត្ត ឬ សមាជិកគ្រួសារម្នាក់បានចាប់ផ្តើមវង្វេងចេញពីការរស់នៅតាមដំណឹងល្អ ។

- តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីជួយបុគ្គលនេះឲ្យត្រឡប់មកកាន់សាសនាចក្រវិញ ? តើអ្នកអាចដាស់បុគ្គលនេះឲ្យចាំពីបំណងដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយដោយរបៀបណា ? តើអ្នកអាចបែរទៅរកជំនួយពីនរណា ដើម្បីជួយដល់សមាជិកគ្រួសារ ឬ មិត្តម្នាក់នេះរបស់អ្នក ?

សូមប្រាប់សិស្សថា មេរៀនថ្ងៃនេះសង្កត់ធ្ងន់ពីរបៀបដែលអាលម៉ា និងអ្នកដទៃជាច្រើននាក់ទៀតបានព្យាយាមជួយដល់ក្រុមមនុស្សមួយក្រុមដែលបានវង្វេងពីដំណឹងល្អ ។ សូមជួយឲ្យសិស្សម្នាក់អាន អាលម៉ា ៣១:១–៤ ឲ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកនូវការបារម្ភដែលអាលម៉ា និងអ្នកដទៃបានមានដល់ពួកសាសន៍សូរាំ ។

- តើអារម្មណ៍របស់អាលម៉ាយ៉ាងណាដែរ នៅពេលគាត់បានឲ្យអំពីភាពទុច្ចរិតនៃពួកសាសន៍សូរាំ ?
- ហេតុអ្វីបានជាពួកសាសន៍នីហ្វៃបានចាប់ផ្តើមខ្លាច ដោយសារតែពួកសាសន៍សូរាំ ?

សូមឲ្យសិស្សស្រមៃថា ពួកគេមានឱកាសដើម្បីណែនាំដល់អាលម៉ាពីរបៀបដើម្បីដោះស្រាយការព្ជួយបារម្ភរបស់គាត់អំពីពួកសាសន៍សាវ៉ាហិមឡា ។ សូមសួរសិស្សថា តើពួកគេនឹងផ្តល់យោបល់ឲ្យគាត់ធ្វើអ្វី ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣១:៥ ឲ ៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកមើលអ្វីដែលអាលម៉ាបានដឹង ដែលនឹងជារបៀបដ៏មានប្រសិទ្ធភាពដើម្បីជួយដល់ពួកសាសន៍សូរាំ ។

- តើអាលម៉ាបានសម្រេចចិត្តធ្វើអ្វីដើម្បីជួយដល់ពួកសាសន៍សូរាំ ?
- តើអ្នកគិតថា ហេតុអ្វីបានជាព្រះបន្ទូលនៃព្រះមានព្រះចេស្តាជាងកម្លាំង ឬ វិធីសាស្ត្រដទៃទៀតនៅក្នុងការខំប្រឹងជួយប្រជាជនឲ្យផ្លាស់ប្តូរ ?

ដោយផ្អែកលើ អាលម៉ា ៣១:៥ តើយើងអាចរៀនអ្វីខ្លះអំពីព្រះចេស្តានៃព្រះបន្ទូលនៃព្រះនៅក្នុងជីវិតរបស់យើង ? (សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេរកឃើញនូវសេចក្តីពិតខាងក្រោម ៖ **នៅពេលយើងសិក្សាព្រះបន្ទូលនៃព្រះ វានឹងដឹកនាំយើងឲ្យធ្វើអ្វីដែលត្រូវ** ។អ្នកអាចសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ពីព្រះចេស្តានៃព្រះបន្ទូលនៃព្រះក្នុងការជួយយើងឲ្យធ្វើអ្វីដែលត្រូវ សូមចែកចាយនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ីយដ៏ យេ ជាកកឺ នៃក្រុ៉ម៉នៃពួកសាវកដប់ពីរនាក់ ។ (អ្នកអាចសរសេរសេចក្តីថ្លែងការណ៍នេះនៅលើក្តារខៀន ឬ រៀបចំជាក្រដាសមួយ) ។

« គោលលទ្ធិពិតត្រូវបានយល់ច្បាស់ វាកែប្រែឥរិយាបថ និងចរិតរបស់មនុស្ស ។

« ការសិក្សាពីគោលលទ្ធិនៃដំណឹងល្អនឹងអភិវឌ្ឍឥរិយាបថបានលឿនជាងការសិក្សាពីឥរិយាបថ ដើម្បីអភិវឌ្ឍឥរិយាបថទៅទៀត ។ . . . ដូច្នេះហើយបានជាយើងផ្តោតទៅលើការសិក្សាគោលលទ្ធិនៃដំណឹងល្អយ៉ាងខ្លាំង » (« Little Children »*Ensign,*ខែ វិច្ឆិកា ឆ្នាំ ១៩៨៦, ទំព័រ ១៧) ។

សូមឲ្យសិស្សប្រាប់ពីពេលមួយដែលពួកគេ ឬ នរណាម្នាក់ដែលពួកគេស្គាល់ទទួលបានបំណងប្រាថ្នាដ៏ខ្លាំងមួយដើម្បីធ្វើអ្វីដែលត្រូវដោយសារតែព្រះគម្ពីរ ឬ ការបង្រៀនរបស់អ្នកដឹកនាំសាសនាចក្រ ។

សូមសង្ខេប អាលម៉ា ៣១:៦–៧ ដោយការប្រាប់សិស្សថា ជាលទ្ធផលនៃទំនុកចិត្តរបស់អាលម៉ាទៅលើព្រះចេស្តានៃព្រះបន្ទូលនៃព្រះគាត់និងអ្នកផ្សេងប្រាំពីរនាក់ទៀតបានចេញទៅបង្រៀនដំណឹងល្អដល់ពួកសាសន៍សូរាំ ។

អាលម៉ា ៣១:៨–២៣

ពួកសាសន៍សូរ៉ាំអធិស្ឋាន និងថ្វាយបង្គំតាមរបៀបមួយដ៏ខុសឆ្គង

សូមប្រាប់សិស្សថា នៅពេលអាលម៉ា និងដៃគូរបស់គាត់បានចេញទៅក្នុងចំណោមពួកសាសន៍សូរ៉ាំ ពួកគេបានអង្កេតឃើញថា ប្រជាជនកំពុងគោរពតាមព្រះតាមរបៀបមួយដ៏ប្លែកមួយ ។

សូមឲ្យសិស្សអាន អាលម៉ា ៣១:៨–១១ ដោយស្ងាត់ៗ ដោយរកមើលពាក្យ និងឃ្លាដែលពិពណ៌នាពីការថ្វាយបង្គំរបស់ពួកសាសន៍សូរ៉ាំ ។ សូមបង្ហាញថា លេខយោង ១០ *ក* ផ្តល់យោបល់ថាឃ្លា « ការប្រព្រឹត្តទាំងឡាយនៃសាសនាចក្រ » គឺទាក់ទងនឹងពិធីការទាំងឡាយ ក៏ដូចជា « ការអធិស្ឋាន និងការទូលអង្វរដល់ព្រះជារៀងរាល់ថ្ងៃ » ។

- យោងតាម ខគម្ពីរទី ១០តើពួកសាសន៍សូរ៉ាំបានកំពុងធ្វើអ្វីដែលធ្វើឲ្យពួកគេងាយនឹងចាញ់ការល្បួង ?
- តើយើងអាចរៀនអ្វីខ្លះ ពីកំហុសរបស់ពួកសាសន៍សូរ៉ាំក្នុងការ « បន្តការអធិស្ឋាន និងការទូលអង្វរដល់ព្រះជារៀងរាល់ថ្ងៃ » នោះ ? (ចម្លើយរបស់សិស្សអាចខុសគ្នា ប៉ុន្តែពួកគេគួរបង្ហាញថា **ការខិតខំរបស់យើងប្រចាំថ្ងៃក្នុងការអធិស្ឋាន និងកាន់តាមព្រះបញ្ញត្តិនឹងពង្រឹងយើងឲ្យប្រឆាំងនឹងការល្បួង ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន ។ អ្នកក៏អាចផ្តល់យោបល់ថា សិស្សគួរសរសេរវានៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ៣១:៩–១១) ។
- តើនៅពេលណាដែលអ្នកបានឃើញថា ការអធិស្ឋានប្រចាំថ្ងៃអាចជួយយើងឲ្យតស៊ូនឹងការល្បួងបាន ?

ជាផ្នែកនៃការពិភាក្សារបស់សិស្សពីសំណួរនេះ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ៉ូលុន ជី. ក្រាវិន នៃពួកចិតសិបនាក់ ៖

« អំឡុងពេលច្រើនឆ្នាំកន្លងទៅ នៅពេលខ្លះខ្ញុំត្រូវបានសុំដោយបងប្អូនប្រុសដើម្បីជួយជាមួយនឹងសមាជិកដែលប្រែចិត្តនៃសាសនាចក្រ ហើយសម្ភាសន៍ពួកគេអំពីការស្តារឡើងវិញនៃពរជ័យព្រះវិហារបរិសុទ្ធរបស់ពួកគេ ។ ការណ៍នេះតែងតែជាបទពិសោធន៍រីកចម្រើនខាងវិញ្ញាណមួយដើម្បីស្តារឡើងវិញនូវពរជ័យនៃមនុស្សដ៏អស្ចារ្យទាំងនោះដែលបានប្រែចិត្ត ។ ខ្ញុំបានសួរដល់ពួកគេខ្លះនូវសំណួរថា ‹ តើមានអ្វីខ្លះបានកើតឡើងនៅក្នុងជីវិតរបស់អ្នក ដែលបណ្តាលឲ្យអ្នកបាត់បង់សមាជិកភាពរបស់អ្នកនៅក្នុងសាសនាចក្រមួយរយៈបណ្តោះអាសន្ននោះ › ? ដោយពោរពេញដោយទឹកភ្នែក ពួកគេបានឆ្លើយតប ៖ ‹ ខ្ញុំមិនបានគោរពតាមគោលការណ៍គ្រឹះនៃដំណឹងល្អ ៖ ការអធិស្ឋាន ការមកព្រះវិហារជាប្រចាំសប្តាហ៍ ការបម្រើក្នុងសាសនាចក្រ និងការសិក្សាដំណឹងល្អ ។ ពេលនោះ ខ្ញុំបានចាញ់ការល្បួង ហើយបានបាត់បង់ការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ › » (« Temptation »*Ensign,*ខែ ឧសភា ឆ្នាំ ១៩៩៦, ទំព័រ ៧៦) ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣១:១២–១៨ ឮៗ ។ បន្ទាប់មក សូមឲ្យសិស្សផ្សេងទៀតអាន អាលម៉ា ៣១:១៥–១៨ ឮៗ ។ មុនពេលសិស្សទីពីរអាន សូមឲ្យសិស្សក្នុងថ្នាក់គិតអំពីរបៀបដែលពួកគេនឹងឆ្លើយតប ប្រសិនបើពួកគេបានឮនរណាម្នាក់អធិស្ឋានតាមរបៀបនេះ ។

- តើការបារម្ភអ្វីខ្លះដែលអ្នកនឹងមាន ប្រសិនបើអ្នកបានឮនរណាម្នាក់អធិស្ឋានតាមរបៀបនេះ ?
- តើគោលលទ្ធិដ៏ខុសឆ្គងអ្វីខ្លះដែលពួកសាសន៍សូរ៉ាំបានទន្ទេញនៅក្នុងការអធិស្ឋានរបស់ពួកគេ ?
- តើឥរិយាបថរបស់ពួកសាសន៍សូរ៉ាំចំពោះមនុស្សដទៃមានអ្វីខ្លះ ? (អ្នកអាចទាញចំណាប់អារម្មណ៍សិស្សទៅលើភាពញឹកញាប់ដែលពាក្យ *យើង (ជាប្រធាន)* និង *យើង (ជាកម្មបទ)* លេចឡើងនៅក្នុងការអធិស្ឋានរបស់ពួកសាសន៍សូរ៉ាំ) ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣១:១៩–២៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយស្វែងរកមើលបញ្ហាផ្សេងទៀតដែលទម្លាប់នៃការថ្វាយបង្គំរបស់ពួកសាសន៍សូរ៉ាំ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើការផ្លាស់ប្តូរអ្វីខ្លះ ដែលអ្នកគិតថា ពួកសាសន៍សូរ៉ាំត្រូវធ្វើដើម្បីឲ្យការថ្វាយបង្គំរបស់ពួកគេមានគារវភាព និងសព្វព្រះហឫទ័យដល់ព្រះអម្ចាស់ ?

សូមពន្យល់ថា យើងថ្វាយបង្គំដល់ព្រះដោយប្រគល់នូវសេចក្តីស្រឡាញ់ ការគោរព និងការលះបង់របស់យើងដល់ទ្រង់ ។ (អ្នកអាចសរសេរពីធាតុនៃការថ្វាយបង្គំទាំងនេះនៅលើក្តារខៀន) ។ យើងគួរថ្វាយបង្គំមិនត្រឹមតាមរយៈឥរិយាបថ និងសកម្មភាពរបស់យើងនៅពេលយើងអធិស្ឋាន តមអាហារ និងចូលរួមក្នុងសាសនាចក្រប៉ុណ្ណោះទេ ប៉ុន្តែយើងត្រូវគោរពតាមរយៈឥរិយាបថ និងសកម្មភាពជារៀងរាល់ថ្ងៃ ។ សូមលើកទឹកចិត្តសិស្សឲ្យវាយតម្លៃការយកចិត្តទុកដាក់ និងភាពស្មោះត្រង់នៃការថ្វាយបង្គំរបស់ពួកគេផ្ទាល់ ។

សូមឲ្យសិស្សរកនូវរបៀបផ្សេងទៀត ដែលយើងអាចថ្វាយបង្គំដល់ព្រះដោយសមរម្យ ។ សូមឲ្យពួកគេមានពេលចែកចាយគំនិតរបស់ពួកគេ ។ អ្នកអាចឲ្យសិស្សម្នាក់សរសេរគំនិតទាំងនេះនៅលើក្តារខៀន ។

- តើឥរិយាបថអ្វីខ្លះដែលយើងគួរប្រព្រឹត្ត នៅពេលយើងថ្វាយបង្គំ ? តើយើងអាចរក្សាឥរិយាបថនោះជារៀងរាល់ថ្ងៃដោយរបៀបណា ?

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលឥរិយាបថរបស់យើងប៉ះពាល់ដល់ការថ្វាយបង្គំរបស់យើង សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយ ដាលិន អេក អូក នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

សូមលើកទឹកចិត្តសិស្សឲ្យដាក់គោលដៅដើម្បីអនុវត្តអ្វីដែលពួកគេរៀន

ប្រធាន ថូម៉ាស អេស. ម៉នសុន បានបង្រៀនពីសារសំខាន់នៃការអញ្ជើញសិស្សឲ្យធ្វើសកម្មភាពលើអ្វីដែលពួកគេបានរៀននៅក្នុងថ្នាក់រៀន ៖ « គោលដៅនៃការបង្រៀនដ៏ណឹងល្អ . . . គឺមិនមែន ‹ ចាក់នូវទ្រឹស្តី › ទៅក្នុងគំនិតនៃសិស្សក្នុងថ្នាក់នោះទេ ។ . . . *គោលដៅគឺដើម្បីបំផុសគំនិតបុគ្គលម្នាក់ឲ្យគិតទទួលអារម្មណ៍ ហើយបន្ទាប់មកធ្វើអ្វីម៉្យាងអំពីការរស់នៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ* ។ . . .

« ខ្ញុំឮ ហើយខ្ញុំភ្លេច ;

« ខ្ញុំឃើញ ហើយខ្ញុំចាំ ;

ខ្ញុំធ្វើ ហើយខ្ញុំរៀន » (នៅក្នុងរបាយការណ៍សន្និសីទ ខែ តុលា ឆ្នាំ ១៩៧០, ទំព័រ ១០៧–៨) ។

« ជារឿយៗ ការថ្វាយបង្គំរួមមានន័យវសកម្មភាព ប៉ុន្តែការថ្វាយបង្គំដ៏ពិតប្រាកដជានិច្চកាលទាក់ទងនឹងឥរិយាបថនៃគំនិតជាពិសេស ។

« ឥរិយាបថនៃការថ្វាយបង្គំរំពួកឲ្យមានអារម្មណ៍ដ៏ជ្រាលជ្រៅនៃស្មោះត្រង់ ការស្រឡាញ់ និងការកោតសរសើរ ។ ការថ្វាយបង្គំរួមបញ្ចូលនូវសេចក្តីស្រឡាញ់ និងការគោរពក្នុងសភាពមួយនៃការលះបង់ដែលនាំវិញ្ញាណរបស់យើងឲ្យខិតកាន់តែជិតទៅនឹងព្រះ » (*Pure in Heart* | ឆ្នាំ ១៩៨៨ |, ទំព័រ ១២៥) ។

សូមឲ្យសិស្សសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេនូវការវាយតម្លៃខ្លីមួយនៃទម្លាប់នៃការថ្វាយបង្គំផ្ទាល់ខ្លួនរបស់គេថ្មីៗនេះ និង ឥរិយាបថនៃការថ្វាយបង្គំរបស់គេនៅក្នុងប្រភេទខាងក្រោម ៖ ការអធិស្ឋានផ្ទាល់ខ្លួនប្រចាំថ្ងៃ ការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនប្រចាំថ្ងៃ ការគោរពតាមព្រះបញ្ញត្តិទាំងឡាយ និងការទៅព្រះវិហារ និងការទទួលយកសាក្រាម៉ង់រាល់សប្តាហ៍ ។ សូមឲ្យសិស្ស ដាក់គោលដៅមួយ ដើម្បីពង្រីកសមត្ថភាពនៃការថ្វាយបង្គំផ្ទាល់ខ្លួនប្រចាំថ្ងៃរបស់ពួកគេ ។

អាលម៉ា ៣១:២៤–៣៨

អាលម៉ាអធិស្ឋានសម្រាប់កម្លាំង និងជ័យជំនះក្នុងការនាំសាសន៍សូរ៉ាំត្រឡប់មកកាន់ព្រះអម្ចាស់វិញ

សូមឲ្យសិស្សអាន អាលម៉ា ៣១:២៤–២៥ ដោយស្ងាត់ៗ ដោយរកមើលឥរិយាបថ និងអាកប្បកិរិយាដែលមានក្នុងការក្បត់សាសនារបស់សាសន៍សូរ៉ាំ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថា នៅពេលអាលម៉ាបានឃើញពីភាពទុច្চរិតនៃសាសន៍សូរ៉ាំ គាត់បានអធិស្ឋាន ។ សូមឲ្យសិស្សធ្វើការជាដៃគូ ។ សូមឲ្យដៃគូទាំងឡាយសិក្សា អាលម៉ា ៣១:២៦–៣៥ និងពិភាក្សាពីសំណួរខាងក្រោម ។ (អ្នកអាចចែកសំណួរនេះជាក្រដាស ឬ សរសេរវានៅលើក្តារខៀនមុនចាប់ផ្តើមថ្នាក់) ។

- តើអ្វីជាការផ្តោតនៃការអធិស្ឋានរបស់សាសន៍សូរ៉ាំ ? (ពួកគេបានផ្តោតលើខ្លួនពួកគេ) ។
- តើអ្វីជាការផ្តោតនៃការអធិស្ឋានរបស់អាលម៉ា ? (គាត់បានផ្តោតលើការជួយអ្នកដទៃ ។ ទោះបីជានៅពេលគាត់បានអធិស្ឋានសម្រាប់ខ្លួនគាត់ និងដៃគូគាត់ ក៏គាត់នៅតែសុំកម្លាំងដើម្បីបម្រើដល់សាសន៍សូរ៉ាំ) ។
- តើធាតុនៃការអធិស្ឋានរបស់អាលម៉ាអ្វីខ្លះ ដែលអ្នកចង់អនុវត្តនៅក្នុងការអធិស្ឋានរបស់អ្នកផ្ទាល់ ?

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖

ប្រសិនបើយើងអធិស្ឋាន ហើយធ្វើសកម្មភាពដោយសេចក្តីជំនឿ . . .

សូមពន្យល់ថា ក្រោយពីអាលម៉ាបានអធិស្ឋានសុំជំនួយក្នុងការទៅបង្រៀនពួកសាសន៍សូរ៉ាំហើយ គាត់និងដៃគូរបស់គាត់បានចាប់ផ្តើមបម្រើ « ដោយពុំគិតពីខ្លួនគេឡើយ » (អាលម៉ា ៣១:៣៧) ។ សូមឲ្យសិស្សអាន អាលម៉ា ៣១:៣៦–៣៨ ដោយស្ងាត់ៗ ដោយរកមើលពរជ័យដែលបានមកដល់អាលម៉ា និងដៃគូរបស់គាត់ នៅពេលពួកគេបានទទួលនូវពរជ័យបព្វជិតភាព និងបង្រៀនដំណឹងល្អ ។ (អ្នកអាចពន្យល់ថានៅក្នុង អាលម៉ា ៣១:៣៦ ឃ្លា « បានទះដៃទៅលើពួកគេ » សំដៅលើការដាក់ដៃលើ ។ សូមមើលលេខយោង ៣៦ខ) ។

- តើពរជ័យអ្វីខ្លះបានកមកដល់អាលម៉ា និងដៃគូរបស់គាត់ដោយសារតែការអធិស្ឋាន និងសកម្មភាពរបស់ពួកគេ ?

ដោយផ្អែកលើអ្វីដែលអ្នកបានរៀនពីគំរូរបស់អាលម៉ា និងដៃគូរបស់គាត់ តើអ្នកនឹងបំពេញប្រយោគនៅលើក្តារខៀនយ៉ាងដូចម្តេច ? (សិស្សអាចឆ្លើយចម្លើយផ្សេងគ្នាដែលវាជាចម្លើយត្រឹមត្រូវ ។ សូមសង្កេតចម្លើយរបស់ពួកគេដោយបំពេញប្រយោគនៅលើក្តារខៀន ៖ ***ប្រសិនបើយើងអធិស្ឋាន និងធ្វើសកម្មភាពដោយសេចក្តីជំនឿ ព្រះអម្ចាស់នឹងពង្រឹងយើងនៅក្នុងឧបសគ្គរបស់យើង) ។***

សូមពន្យល់ថា បន្ទាប់ពីការអធិស្ឋានរបស់គាត់ អាលម៉ា និងដៃគូរបស់គាត់បានបង្ហាញសេចក្តីជំនឿដោយការទៅធ្វើការ និងទុកចិត្តលើព្រះអម្ចាស់ក្នុងការផ្តល់ដល់ពួកគេ នៅពេលពួកគេបានបម្រើដល់ទ្រង់ ។ សូមឲ្យសិស្សធ្វើតាមគំរូរបស់អាលម៉ាក្នុងការអធិស្ឋានដោយសេចក្តីជំនឿ ។

អាលម៉ា ៣២

សេចក្តីផ្តើម

ក្រោយពីធ្វើជាសាក្សីដល់ការក្បត់សាសនារបស់ពួកសាសន៍សូរ៉ាំក្នុងទម្រង់នៃការថ្វាយបង្គំអាលម៉ានិងដៃគូរបស់គាត់បានចាប់ផ្តើមបង្រៀនព្រះបន្ទូលនៃព្រះដល់ពួកសាសន៍សូរ៉ាំ ។ ពួកគេចាប់ផ្តើមទទួលបានជោគជ័យខ្លះក្នុងចំណោមប្រជាជន ដែលក្រីក្រ និងដែលត្រូវបានកាត់ចេញពីសាលប្រជុំរបស់ពួកគេ ។ ដោយការប្រៀបធៀបព្រះបន្ទូលនៃព្រះទៅនឹងគ្រាប់ពូជមួយ អាលម៉ាបានបង្រៀនប្រជាជនពីរបៀបដើម្បីទទួលបានព្រះបន្ទូលនៃព្រះ និងបង្កើនសេចក្តីជំនឿរបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៣២:១–១៦

ពួកសាសន៍សូរ៉ាំដែលបន្ទាបខ្លួនបង្ហាញថា ពួកគេបានរៀបចំដើម្បីស្តាប់តាមព្រះបន្ទូលនៃព្រះ

សូមឲ្យសិស្សស្រមៃថា អ្នកគឺជាមិត្តម្នាក់ដែលបានសួរគេពីរបៀបដែលអ្នកអាចដឹងថា តើដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទគឺពិត ។ សូមសួរពួកគេថា តើពួកគេគួរនិយាយអ្វីដើម្បីជួយអ្នកឲ្យទទួលបានទីបន្ទាល់មួយ ។

ក្រោយពីសិស្សចែកចាយគំនិតរបស់ពួកគេហើយ សូមសរសេរនៅលើក្តារខៀន *របៀបទទួល និងពង្រឹងទីបន្ទាល់* ។ សូមប្រាប់ថា ពេញមួយមេរៀននេះ អ្នកនឹងសរសេរនូវគោលការណ៍ និងទស្សនវិស័យដែលពួកគេនឹងរកឃើញអំពីរបៀបទទួល និងពង្រឹងទីបន្ទាល់ ។

សូមរំឭកសិស្សថា អាលម៉ានិងបងប្អូនប្រុសរបស់គាត់បានអង្គេតឃើញពីការថ្វាយបង្គំខុសឆ្គងរបស់ពួកសាសន៍សូរ៉ាំ ជាក្រុមក្បត់មួយនៃពួកសាសន៍នីហ្វៃ ។ ដោយសារតែការសោកស្តាយរបស់គាត់ចំពោះភាពទុច្ចរិតរបស់ប្រជាជន គាត់បានអធិស្ឋានសុំការលួងលោម និងកម្លាំងដើម្បីអាចបង្រៀនដល់ពួកគេ ។ (សូមមើល អាលម៉ា ៣១) ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣២:១–៣ ឮៗ។ សូមឲ្យសិស្សក្នុងថ្នាក់ស្វែងរកមើលតើក្រុមសាសន៍សូរ៉ាំមួយណាដែលបានបង្ហាញចំណាប់អារម្មណ៍ទៅលើសារលិខិតរបស់ពួកអ្នកផ្សព្វផ្សាយសាសនា ។ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- យោងតាម អាលម៉ា ៣២:៣ តើប្រជាជនទាំងនេះកំសត់ដោយរបៀបណា ? (« ពួកគេមានសេចក្តីកំសត់ខាងអ្វីៗនៃលោកិយ ហើយពួកគេក៏កំសត់ក្នុងដួងចិត្តដែរ ») ។
- តើអ្នកគិតថា « សេចក្តីកំសត់ក្នុងដួងចិត្ត » មានន័យយ៉ាងណា ?

ដើម្បីជួយសិស្សឲ្យឆ្លើយនឹងសំណួរនេះ សូមឲ្យពួកគេបីបួននាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៣២:៤–១២ ។ (សិស្សអាចផ្តល់យោបល់ថា សេចក្តីកំសត់ក្នុងដួងចិត្តរួមមានការបន្ទាបខ្លួន ការប្រែចិត្ត និងការត្រៀមខ្លួនដើម្បីស្តាប់តាមព្រះបន្ទូលនៃព្រះ) ។

- តើសំណួរនៅក្នុង អាលម៉ា ៣២:៥ បង្ហាញថា ពួកសាសន៍សូរ៉ាំមានសេចក្តីកំសត់ក្នុងដួងចិត្តដោយរបៀបណា ?
- តើភាពក្រីក្របានដឹកនាំពរជ័យសម្រាប់ក្រុមនៃសាសន៍សូរ៉ាំនេះដោយរបៀបណា ?
- តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះអំពីការទទួលបាន និងការពង្រឹងនូវទីបន្ទាល់មួយ ? (នៅពេលសិស្សចែកចាយគោលការណ៍ខុសគ្នា សូមសរសេរវានៅក្រោមចំណងជើងនៅលើក្តារខៀន ។ សូមប្រាកដថា ពួកគេរកឃើញនូវគោលការណ៍ខាងក្រោម ៖ **ការបន្ទាបខ្លួនរៀបចំយើងឲ្យទទួលព្រះបន្ទូលនៃព្រះ**) ។
- ហេតុអ្វីបានជាការបន្ទាបខ្លួនសំខាន់នៅក្នុងដំណើរការនៃការទទួលបាន និងការពង្រឹងនូវទីបន្ទាល់មួយ ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៣២:១៣–១៦ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបពីរខុសគ្នាដែលមនុស្សអាចបន្ទាបខ្លួន ។ (មនុស្សអាចជ្រើសរើសដើម្បីបន្ទាបខ្លួន ឬ ពួកគេអាចត្រូវបានបង្ខំឲ្យបន្ទាបខ្លួន) ។

- តើយើងអាចរៀនអ្វីខ្លះអំពីការបន្ទាបខ្លួនពីខគម្ពីរទាំងនេះ ? (សូមជួយសិស្សឲ្យរកឃើញនូវគោលការណ៍ខាងក្រោម ៖ **យើងត្រូវបានប្រទានពរច្រើនជាង នៅពេលយើងជ្រើសរើសដើម្បីបន្ទាបខ្លួនជាងនៅពេលយើងត្រូវបានបង្ខំឲ្យបន្ទាបខ្លួន** ។ តើអ្នកគិតថា ហេតុអ្វីបានជាវាប្រសើរជាងក្នុងការជ្រើសរើសដើម្បីបន្ទាបខ្លួន ?
- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីបន្ទាបខ្លួនអ្នក « ដោយសារតែព្រះបន្ទូល » ? (អាលម៉ា ៣២:១៤) ។ តើការណ៍នេះអាចអនុវត្តដល់ឥរិយាបថរបស់យើងនៅក្នុងសាសនាចក្រ ថ្នាក់សិក្ខាសាលា ឬ ការសិក្សាព្រះគម្ពីរជាគ្រួសារដោយរបៀបណា ?

អាលម៉ា ៣២:១៧–៤៣

អាលម៉ាបង្រៀនដល់ពួកសាសន៍សូរ៉ាំពីរបៀបសេចក្តីជំនឿរបស់ពួកគេ

សូមពន្យល់ថា អាលមារកឃើញគំនិតដ៏ខុសឆ្គងមួយ ដែលមនុស្សជាច្រើនមានអំពីការទទួលបាននូវទីបន្ទាល់មួយ ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣២:១៧–១៨ ឮៗ ខណៈពេលដែលសិស្សផ្សេងទៀតស្វែងរកនូវគំនិតដ៏ខុសឆ្គងនេះ ។

- តើគំនិតដ៏ខុសឆ្គងអ្វី ដែលមនុស្សជាច្រើនបានមានអំពីការទទួលបាននូវទីបន្ទាល់ ?
- តើវាខុសអ្វីនឹងការទាមទារទីសម្គាល់មួយមុនពេលជឿនោះ ? (អ្នកអាចរំឭកសិស្សពីគំរូរបស់សេរេមនៅក្នុង យ៉ាកុប ៧:១៣–១៦ និង គំរូរបស់កូរីហ្សូរនៅក្នុង អាលម៉ា ៣០:៤៣–៥២ ។ អ្នកក៏អាចឲ្យពួកគេអាន គោលលទ្ធិ និងសេចក្តីសញ្ញា ៦៣:៩ ដើម្បីបញ្ជាក់ថា ទីសម្គាល់ជាច្រើនគឺជាលទ្ធផលនៃសេចក្តីជំនឿ មិនមែនជាអ្វីដែលយើងអាចទាមទារមុនពេលយើងមានសេចក្តីជំនឿនោះទេ) ។

អាលម៉ា ៣២:២១ គឺជាវគ្គចំណុះចំណានខគម្ពីរមួយ ។ សូមយោងទៅគំនិតនៃការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះដើម្បីជួយសិស្សក្នុងការចងចាំវគ្គចំណុះចំណានខគម្ពីរនេះ ។

សូមពន្យល់ថា អាលម៉ាបានបង្រៀនប្រជាជនថា អ្វីដែលជាសេចក្តីជំនឿ ។ សូមឲ្យសិស្សអាន អាលម៉ា ៣២:២១ ដោយស្ងាត់ៗ ដោយរកមើលនិយមន័យរបស់អាលម៉ានៃសេចក្តីជំនឿ ។ សូមបង្ហាញថា ខគម្ពីរនេះគឺជាវគ្គចំណុះចំណានខគម្ពីរមួយ ។ អ្នកអាចណែនាំសិស្សឲ្យគូសចំណាំវាតាមរបៀបមួយ ដើម្បីឲ្យគេងាយនឹងរកវាឃើញ ។

សូមឲ្យសិស្សអាន អាលម៉ា ៣២:២២ ដោយស្ងាត់ៗ ដោយរកមើលការប្រឹក្សាពីបរៀបដើម្បីទទួលបាន និងពង្រឹងទីបន្ទាល់ ។ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមបន្ថែម *ចងចាំសេចក្តីមេត្តាករុណានៃព្រះ* និង *ជឿលើព្រះបន្ទូលនៃព្រះ* ទៅលើបញ្ជីនៅលើក្តារខៀន ។

- ហេតុអ្វីបានជាសកម្មភាពទាំងនេះសំខាន់នៅក្នុងការអភិវឌ្ឍសេចក្តីជំនឿរបស់យើង ?

សូមពន្យល់ថា ដើម្បីជួយដល់ពួកសាសន៍សូរ៉ាំឲ្យយល់ពី របៀបជឿដល់ព្រះបន្ទូលនៃព្រះ អាលម៉ាបានស្នើថា ពួកគេគួរធ្វើការពិសោធមួយ ។

- ហេតុអ្វីបានជាប្រជាជនធ្វើនូវការពិសោធវិទ្យាសាស្ត្រ ? (ដើម្បីស្វែងរកថាតើ ទ្រឹស្តី ឬគំនិតមួយពិតឬទេ) ។

សូមឲ្យសិស្សរៀបរាប់ពីការពិសោធដែលពួកគេបានធ្វើនៅក្នុងថ្នាក់វិទ្យាសាស្ត្រ ឬ កន្លែងផ្សេងទៀត ។ សូមជួយពួកគេឲ្យឃើញថា ការពិសោធតម្រូវឲ្យអ្នកស្រាវជ្រាវធ្វើសកម្មភាព មិនមែនគ្រាន់តែការទស្សន៍ទាយ ។ ដំណើរការនៃការទទួលបាន ឬ ពង្រឹងនូវទីបន្ទាល់មួយក៏តម្រូវឲ្យមានសកម្មភាពដែរ ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣២:២៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលនូវការពិសោធដែលអាលម៉ាបានអញ្ជើញពួកសាសន៍សូរ៉ាំឲ្យធ្វើ ។ សូមបន្ថែម *ការពិសោធដល់ពាក្យសម្តី* ទៅលើបញ្ជីនៅលើក្តារខៀន ។

- តើអ្នកគិតថា អាលម៉ាចង់មានន័យយ៉ាងណា នៅពេលគាត់បាននិយាយថា « ធ្វើការពិសោធដល់ពាក្យសម្តី [របស់គាត់] » ?
- តើអ្នកគិតថា អាលម៉ាចង់មានន័យយ៉ាងណា នៅពេលគាត់បាននិយាយថា « ភ្ញាក់ឡើង ហើយដាស់សមត្ថភាពទាំងឡាយរបស់ខ្លួន » ? (អ្នកអាចពន្យល់ថាពាក្យ *សមត្ថភាពទាំងឡាយ* សំដៅទៅលើសមត្ថភាពរបស់យើងក្នុងការគិត និងធ្វើសកម្មភាព និងសម្រេចបាននូវអ្វីៗ ។ អាលម៉ាអញ្ជើញប្រជាជនឲ្យធ្វើសកម្មភាពលើពាក្យសម្តីរបស់គាត់ ។ អ្នកអាចបន្ថែម *ភ្ញាក់ឡើង រហ័យដាស់សមត្ថភាពទាំងឡាយរបស់ខ្លួន* ទៅលើបញ្ជីនៅលើក្តារខៀន) ។
- តើអ្នកគិតថា វាមានន័យយ៉ាងណាក្នុងការ « អនុវត្តសេចក្តីជំនឿមួយភាគតូច » ?

ដើម្បីជួយសិស្សឲ្យរកឃើញនូវរបៀបដែលពួកគេអាចចាប់ផ្តើមអនុវត្តការពិសោធនេះនៅក្នុងជីវិតរបស់ពួកគេ សូមឲ្យពួកគេអានអាលម៉ា ៣២:២៨ ដោយស្ងាត់ៗ ។

- តើអាលម៉ាបានប្រៀបធៀបអ្វីទៅនឹងព្រះបន្ទូលនៃព្រះ ? (គ្រាប់ពូជមួយ) ។
- តើអ្វីខ្លះជាប្រភពនៃព្រះបន្ទូលរបស់ព្រះ ? (ចម្លើយអាចរួមមាន ព្រះគម្ពីរ ការបង្រៀនរបស់ព្យការីថ្ងៃចុងក្រោយទាំងឡាយ និងវិវរណៈផ្ទាល់ខ្លួនពីព្រះវិញ្ញាណបរិសុទ្ធ) ។
- តើអាលម៉ាបាននិយាយថាយើងត្រូវតែធ្វើអ្វីនឹង « គ្រាប់ពូជ » នេះ ?

សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន ។ អ្នកអាចសរសេរវានៅក្រោម *ការពិសោធដល់ពាក្យសម្តី* ដែលអ្នកបានសរសេរពីមុនមកនោះ ។ បញ្ជីអាចរួមមានន័យធាតុដូចខាងក្រោម ៖

១. ទុកកន្លែងសម្រាប់ឲ្យពាក្យសម្តី (ឬ គ្រាប់ពូជ) នោះអាចដុះនៅក្នុងចិត្តរបស់អ្នក ។

២. កុំបោះពាក្យសម្តីចោលដោយការឥតជំនឿរបស់អ្នក ។

៣. ចាប់អារម្មណ៍ថា ពាក្យសម្តីនោះរីកឡើងនៅក្នុងអ្នក ។

ដើម្បីជួយសិស្សឲ្យយល់ពីអ្វីដែលពួកគេបានអានអំពីការពិសោធនេះ សូមសួរសំណួរខាងក្រោម ៖

- តើព្រះបន្ទូលនៃព្រះដូចជាគ្រាប់ពូជមួយដែលអាចដុះនៅក្នុងដួងចិត្តរបស់យើងដោយរបៀបណា ? (ចម្លើយអាចរួមមាន វាអាចដុះឡើង វាអាចពង្រឹងយើង និង យើងត្រូវថែទាំវា) ។

នៅពេលសិស្សពិភាក្សាពីការប្រៀបធៀបនៃព្រះបន្ទូលនៃព្រះទៅនឹងគ្រាប់ពូជមួយ សូមឲ្យពួកគេអាន អាលម៉ា ៣៣:២២–២៣ ដោយស្ងាត់ៗ ។ មុនពេលពួកគេអាន សូមឲ្យពួកគេរកមើលការពន្យល់របស់អាលម៉ានៃ « ព្រះបន្ទូលនេះ » ។ សូមជួយពួកគេឲ្យឃើញថា វាសំដៅទៅលើព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « ទុកកន្លែងមួយ » សម្រាប់ព្រះបន្ទូលបានដុះនៅក្នុងទ្រូងរបស់យើង ? (សូមមើល អាលម៉ា ៣២:២៨ ។ ចម្លើយអាចរួមមាន យើងត្រូវបើកដួងចិត្តរបស់យើង ហើយថាយើងត្រូវទុកកន្លែងនៅក្នុងជីវិតរបស់យើង សម្រាប់ការសិក្សាព្រះគម្ពីរ) ។
- តើអ្នកគិតថា វាមានន័យយ៉ាងណាដែលមានអារម្មណ៍ថា ព្រះបន្ទូលនៃព្រះ « រីកដុះឡើង » នៅក្នុងខ្លួនអ្នក ? ប្រសិនបើព្រះបន្ទូលនៃព្រះរីកដុះឡើងក្នុងខ្លួនអ្នក តើនឹងមានអ្វីកើតឡើងដល់ទីបន្ទាល់ និងសេចក្តីជំនឿរបស់អ្នកបន្ទាប់ពីនោះ ?
- តើនៅពេលណាដែលព្រះបន្ទូលនៃព្រះពង្រីកព្រលឹងរបស់អ្នក និងបំភ្លឺការយល់ដឹងរបស់អ្នកនោះ ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានពី អាលម៉ា ៣២:២៩–៣៤ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពាក្យ និងឃ្លាដែលពិពណ៌នាពីអ្វីដែលយើងរៀនអំពីព្រះបន្ទូលនៃព្រះ ។ បន្ទាប់មក សូមឲ្យសិស្សអានពាក្យ និងឃ្លាទាំងឡាយដែលពួកគេបានរកឃើញ ហើយពន្យល់ពីមូលហេតុដែលពួកគេបានជ្រើសរើសឃ្លាទាំងនោះ ។ សូមយោងទៅរូបភាពនៅលើក្តារខៀន ហើយសួរសួរ ៖

- ហេតុអ្វីបានជាសេចក្តីជំនឿរបស់យើងមិនទាន់បានឥតខ្ចោះ ក្រោយពីបានពិសោធហើយនោះ ? តើអ្នកគិតថា យើងត្រូវធ្វើអ្វីខ្លះទៀត ដើម្បីទទួលបានទីបន្ទាល់ជារៀងរហូតមួយនៃដំណឹងល្អ ?
- តើដំណើរនៃការជួយបណ្តុះដើមឈើមួយ ដូចគ្នានឹងដំណើរនៃការពង្រឹងទីបន្ទាល់មួយដោយរបៀបណា ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮពី អាលម៉ា ៣២:៣៥–៤០ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលការប្រឹក្សារបស់អាលម៉ា អំពីរបៀបដើម្បីបំពេញការពិសោធនេះ ។

- យោងតាម អាលម៉ា ៣២:៣៧–៤០ តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យសេចក្តីជំនឿរបស់យើងទៅលើព្រះបន្ទូលនៃព្រះបន្តរីកចម្រើន ? (សូមបន្ថែម *ថែទាំព្រះបន្ទូល* ទៅលើបញ្ជីនៅលើក្តារខៀន) ។
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីថែទាំព្រះបន្ទូល ? (ចម្លើយអាចរួមមានថា យើងអាចសិក្សាព្រះគម្ពីរជារៀងរាល់ថ្ងៃ អធិស្ឋានសុំការដឹកនាំនៅពេលយើងសិក្សា រកមើលរបៀបដែលព្រះគម្ពីរ និងការបង្រៀនទាំងឡាយរបស់ព្យាការីថ្ងៃចុងក្រោយអាចអនុវត្តនៅក្នុងជីវិតរបស់យើង ហើយចែកចាយអ្វីដែលយើងរៀន) ។
- តើនឹងមានអ្វីកើតឡើង នៅពេលយើងធ្វេសប្រហែសនឹងដើមឈើ ឬ មិនបានថែទាំវាឲ្យបានល្អ ? តើនឹងមានអ្វីកើតឡើង នៅពេលយើងធ្វេសប្រហែសនឹងព្រះបន្ទូលនៃព្រះ ដែលបានដាំនៅក្នុងទ្រូងយើង ?

សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ នូវអ្វីដែលពួកគេបានរៀនពីអាលម៉ា ៣២ អំពីរបៀបដើម្បីទទួល និងពង្រឹងទីបន្ទាល់មួយ ។ អ្នកក៏អាចផ្តល់យោបល់ថា ពួកគេគួរសរសេរការសង្ខេបទាំងនេះទៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ៣២:៣៧–៤៣ ។

សូមឲ្យសិស្សចែកចាយអ្វីដែលពួកគេបានសរសេរ ។ នៅពេលពួកគេចែកចាយ សូមប្រាកដថាពួកគេបង្ហាញថា **ប្រសិនបើយើងថែទាំព្រះបន្ទូលរបស់ព្រះដោយឧស្សាហ៍ព្យាយាមនៅក្នុងដួងចិត្តរបស់យើង នោះសេចក្តីជំនឿ និងទីបន្ទាល់របស់យើងលើព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់នឹងលូតលាស់ឡើង ។**

សូមឲ្យសិស្សអាន អាលម៉ា ៣២:៤១–៤៣ ដោយរកមើលការពិពណ៌នារបស់អាលម៉ាអំពីដើមឈើ និងផ្លែឈើ ។

- តើមានកន្លែងណាទៀតនៅក្នុងព្រះគម្ពីរមរមនដែលមានការពិពណ៌នាពីដើមឈើមួយដែលមានផ្លែដែល « មានរសជាតិផ្អែមបំផុត គឺផ្អែមជាងអ្វីៗទាំងអស់ » ? (អ្នកអាចរំឭកសិស្សអំពីការពិពណ៌នានៃដើមឈើជីវិតនៅក្នុង នីហ្វៃទី ១ ៨:១១–១២នីហ្វៃទី ១ ១១:៩–២៤) ។
- នៅក្នុងការនិមិត្តរបស់លីហៃ និងនីហ្វៃអំពីដើមឈើជីវិត តើដើមឈើ និងផ្លែឈើនោះតំណាងឲ្យអ្វី ? (ដើមឈើតំណាងឲ្យសេចក្តីស្រឡាញ់នៃព្រះ ដូចដែលបានបង្ហាញតាមរយៈព្រះអង្គសង្គ្រោះ និងដង្វាយធួនរបស់ទ្រង់ ហើយផ្លែឈើតំណាងឲ្យពរជ័យដែលយើងអាចទទួលបានតាមរយៈដង្វាយធួន ។ សូមមើលមេរៀនទី ១២ នៅក្នុងសៀវភៅនេះ) ។
- នៅក្នុងការនិមិត្តរបស់លីហៃ និងនីហ្វៃ តើមនុស្សដើរទៅដល់ដើមឈើដោយរបៀបណា ? (ដោយការកាន់តាមដំបងដែក ដែលតំណាងឲ្យព្រះបន្ទូលនៃព្រះ) ។ តើការណ៍នេះដូចជាការប្រៀបធៀបរបស់អាលម៉ា អំពីព្រះបន្ទូលនៃព្រះទៅនឹងគ្រាប់ពូជដោយរបៀបណា ?

សូមឲ្យសិស្សពីរបីនាក់ចែកចាយពីរបៀបដែលពួកគេបានធ្វើតាមការអនុវត្តដែលបានពិពណ៌នានៅក្នុង អាលម៉ា ៣២ ។ សូមសួរពួកគេថា តើការអនុវត្តនេះបានជះឥទ្ធិពលដល់ជីវិតគេយ៉ាងណាដែរ ។ សូមគិតពីការចែកចាយបទពិសោធន៍របស់អ្នកផ្ទាល់ នៅពេលអ្នកមានអារម្មណ៍ពីព្រះចេស្តានៃព្រះបន្ទូលនៃព្រះ ។

ចំណេះចំណានខគម្ពីរ—អាលម៉ា ៣២:២១

សូមឲ្យសិស្សប្រើ អាលម៉ា ៣២:២១ ដើម្បីសម្រេចពីរបៀបដែលមនុស្សនៅក្នុងស្ថានភាពខាងក្រោមកំពុងអនុវត្តសេចក្តីជំនឿ ឬ មិនអនុវត្តសេចក្តីជំនឿ ។

១. យុវនារីម្នាក់ចង់បានភស្តុងតាងខាងរូបកាយថា ព្រះគម្ពីរមរមនគឺពិត មុនពេលនាងជឿលើព្រះគម្ពីរនេះ ។

២. យុវជនម្នាក់ឮថា យុវជនដ៏សាកសមទាំងអស់ត្រូវបម្រើបេសកកម្មពេញម៉ោង ។ ទោះបីជាគ្រួសារគាត់ក្រីក្រក្តី ក៏គាត់បានសម្រេចចិត្តថានឹងបម្រើ និងរៀបចំដើម្បីបម្រើដែរ ។

៣. យុវនារីម្នាក់ចង់ស្អាតស្អំពីអំពើបាបរបស់នាង តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ នាងដឹងថា នាងត្រូវសោរភាពការរំលងខ្លះដល់ប៊ីស្សពរបស់នាងដើម្បីបានប្រែចិត្តពេញលេញ ។ នាងបានណាត់ជួបនឹងប៊ីស្សពរបស់នាង ។

កំណត់ចំណាំ ៖ អ្នកអាចប្រើគំនិតនេះពេលបង្រៀនមេរៀននេះ នៅពេលអ្នកបង្ហាញពីវគ្គចំណេះចំណាននខគម្ពីរ ឬ អ្នកអាចប្រើវានៅចុងបញ្ចប់នៃមេរៀន ។

មេរៀនសិក្សានៅផ្ទះ

អាលម៉ា ២៥–៣២ (មេរៀនទី ១៨)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀននៅពេលពួកគេសិក្សា អាលម៉ា ២៥–៣២(មេរៀនទី ១៨) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។ សូមធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាបរិសុទ្ធ នៅពេលអ្នកគិតពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (អាលម៉ា ២៥–២៩)

សិស្សបានរៀនពីគោលការណ៍ខាងក្រោម នៅពេលពួកគេបានសិក្សាអំពីសេចក្តីអំណរ របស់អាំម៉ូននៅក្នុងជ័យជំនះដែលគាត់ និងបងប្អូនប្រុសរបស់គាត់បានទទួលក្នុង ការបង្រៀនដំណឹងល្អ ៖ នៅពេលយើងបន្ទាបខ្លួន ព្រះអម្ចាស់នឹងពង្រឹងយើង ហើយប្រើយើងជាគ្រឿងឧបករណ៍នៅក្នុងព្រះហស្តរបស់ទ្រង់ យើងទទួលបានសេចក្តីអរសប្បាយ នៅពេលយើងបម្រើព្រះអម្ចាស់ និងកូនចៅរបស់ទ្រង់ដោយស្មោះត្រង់ ។ នៅពេលពួកសាសន៍លេមិនបានប្រែចិត្តជឿលើដំណឹងល្អ ហើយបានបដិសេធមិនលើកអាវុធ សិស្សបានរៀនថា នៅពេលយើងពិតជាបានប្រែចិត្តជឿដោយពេញលេញទៅលើព្រះអម្ចាស់ យើងនឹងរក្សាសេចក្តីសញ្ញាដែលយើងបានធ្វើជាមួយនឹងទ្រង់ ។ ចេញពីគំរូរបស់អាលម៉ា សិស្សដឹងថា យើងនឹងទទួលបានសេចក្តីអំណរ នៅពេលយើងជួយដល់អ្នកដទៃឲ្យប្រែចិត្ត និងមករកព្រះយេស៊ូវគ្រីស្ទ ។

ថ្ងៃទី ២ (អាលម៉ា ៣០)

ដោយការអានអំពីការបង្រៀនរបស់កូរីហូរ ជាជនជំទាស់នឹងព្រះគ្រីស្ទ នោះសិស្សបានរៀនថា សាតាំងប្រើនូវគោលលទ្ធិខុសឆ្គងដើម្បីទាក់ទាញយើងឲ្យប្រព្រឹត្តអំពើបាប ។ អាលម៉ាបានឆ្លើយតបនឹងការបង្រៀនរបស់កូរីហូរដោយការប្រកាសថា អ្វីៗទាំងអស់ថ្លែងទីបន្ទាល់អំពីព្រះថាជាព្រះដ៏បង្កបង្កើតដ៏អស្ចារ្យ ។ ក្រោយពីអានថា កូរីហូរត្រូវបានវាយដល់ស្លាប់ សិស្សបានយល់ថា គោលការណ៍ដែលបានកត់ត្រារបស់មរមនគឺ ៖ « អារក្សពុំដែលគាំទ្រដល់កូនចៅរបស់វា [អ្នកដើរតាមរបស់វា]ទេ នៅថ្ងៃចុងក្រោយបង្អស់ » (អាលម៉ា ៣០:៦០) ។

ថ្ងៃទី ៣ (អាលម៉ា ៣១)

នៅពេលសិស្សអានអំពីបំណងរបស់អាលម៉ាដើម្បីជួយដល់ពួកសាសន៍សូរ៉ាំចេញពីការក្បត់សាសនា ពួកគេបានរៀនពីគោលការណ៍ខាងក្រោម ៖ នៅពេលយើងសិក្សាព្រះបន្ទូលនៃព្រះ វានឹងដឹកនាំយើងឲ្យធ្វើអ្វីដែលត្រូវ ។ ការខិតខំរាល់ថ្ងៃដើម្បីអធិស្ឋាន និងការតាមព្រះបញ្ញត្តិទាំងឡាយពង្រឹងយើងឲ្យប្រឆាំងនឹងការល្បួង ។ ប្រសិនបើយើងអធិស្ឋាន និងធ្វើសកម្មភាពដោយសេចក្តីជំនឿ នោះយើងនឹងទទួលបានជំនួយដ៏ទេវភាពក្នុងឧបសគ្គរបស់យើងទាំងឡាយ ។

ថ្ងៃទី ៤ (អាលម៉ា ៣២)

នៅពេលសិស្សអានអំពីជោគជ័យរបស់អាលម៉ានៅក្នុងការបង្រៀនដល់ប្រជាជនក្រីក្រក្នុងចំណោមពួកសាសន៍សូរ៉ាំ សិស្សបានដឹងថា ការបន្ទាបខ្លួនរៀបចំយើងឲ្យទទួលព្រះបន្ទូលរបស់ព្រះ ។ អាលម៉ាបានបង្រៀនការអនុវត្តសេចក្តីជំនឿទៅនឹងការដាំគ្រាប់ពូជមួយ និងការថែទាំវា ។ សិស្សបានរៀនថា ប្រសិនបើយើងថែទាំសេចក្តីជំនឿយើងទៅលើព្រះបន្ទូលរបស់ព្រះក្នុងចិត្តយើងដោយឧស្សាហ៍ព្យាយាម នោះសេចក្តីជំនឿ និងទីបន្ទាល់របស់យើងលើព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់នឹងកើនឡើង ។

សេចក្តីផ្តើម

សូមចាប់ផ្តើមមេរៀននេះដោយសកម្មភាពមួយ ដើម្បីជួយសិស្សឲ្យស្វែងរកដើម្បីក្លាយជាគ្រឿងឧបករណ៍នៅក្នុងព្រះហស្តរបស់ព្រះ ។ ទោះជាយ៉ាងណាក្តី ភាពចម្រុងនៃមេរៀននេះនឹងផ្តោតលើលទ្ធផលនៃការជឿ និងការអនុវត្តលើគំនិតខុសឆ្គង ដែលផ្ទុយទៅនឹងការជឿ និងការអនុវត្តលើព្រះបន្ទូលនៃព្រះ ដូចដែលបានបង្ហាញនៅក្នុង អាលម៉ា ៣០–៣២ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ២៥–២៩

អាំម៉ូន និងពួកបុត្រានៃម៉ូសាយរុងរឿងក្នុងព្រះអម្ចាស់ នៅពេលសាសន៍លេមិនជាច្រើនបានប្រែចិត្តជឿលើដំណឹងល្អ

ដូចដែលបានកត់ត្រានៅក្នុង អាលម៉ា ២៦ អាំម៉ូន និងបងប្អូនប្រុសរបស់គាត់បានរីករាយនឹងជោគជ័យរបស់ពួកគេក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។ សូមឲ្យសិស្សអាន អាលម៉ា ២៦:១–៤, ១១–១៣ ហើយរកមើលអ្វីដែលអាំម៉ូន និងបងប្អូនប្រុសរបស់គាត់សម្រេចបាន និងរបៀបដែលពួកគេអាចសម្រេចបានវា ។ សូមរំឭកសិស្សថា ខគម្ពីរទាំងនេះបង្រៀនពីគោលការណ៍ខាងក្រោម ៖ **នៅពេលយើងបន្ទាបខ្លួនយើង ព្រះអម្ចាស់នឹងពង្រឹងយើង ហើយប្រើយើងជាគ្រឿងឧបករណ៍នៅក្នុងព្រះហស្តរបស់ទ្រង់ ។**

អាលម៉ា ៣០

កូរីហូរសើចចំអកដល់គោលលទ្ធិរបស់ព្រះគ្រីស្ទ

សូមបង្ហាញដល់សិស្សនូវគ្រាប់ពូជមួយ ។ សូមឲ្យពួកគេសរសេរឧទាហរណ៍នៃអ្វីដែលពួកគេចូលចិត្ត ដែលដុះពីគ្រាប់ពូជ ។ ផ្ទុយទៅនឹងរុក្ខជាតិ ផ្លែឈើ និងបន្លែខ្លះដែលសិស្សអាចលើកឡើង សូមបង្ហាញថា វាអាចកើតមានថា គ្រាប់ពូជមួយអាចដុះលើដើមឈើមួយ ដែលមានផ្លែល្វីង ឬថែមទាំងពុល ឬ ថាវាអាចលាយឡំនឹងដើមឈើល្អផ្សេងទៀត ។

សូមសរសេរពាក្យ *គំនិត* និង*សេចក្តីជំនឿ* នៅលើក្តារខៀនហើយសូមសួរ ៖ តើគំនិត ឬសេចក្តីជំនឿមួយអាចដូចជាគ្រាប់ពូជមួយដោយរបៀបណា ?

សូមពន្យល់ថា នៅពេលសិស្សសិក្សា និងពិភាក្សាក្នុង អាលម៉ា ៣០–៣២ នៅក្នុងថ្នាក់ថ្ងៃនេះ ពួកគេនឹងបញ្ជាសលទ្ធផលនៃការធ្វើតាមគំនិតខុសឆ្គងទៅនឹងលទ្ធផលនៃការធ្វើតាមព្រះបន្ទូលនៃព្រះ ។

សូមឲ្យសិស្សពន្យល់ថាកូរីហូរជានរណា ។ សូមឲ្យពួកគេអាន អាលម៉ា ៣០:១២–១៨, ២៣ ហើយរកមើលគំនិតខុសឆ្គងដែលកូរីហូរបានបង្រៀន ។ ក្រោយពីពួកគេមានពេលអានហើយ សូមឲ្យពួកគេសរសេរនៅលើក្តារខៀន ឬក្រដាសមួយនូវគំនិតខុសឆ្គងរបស់កូរីហូរដែលពួកគេគិតថាអាចមានគ្រោះថ្នាក់ជាពិសេសដល់សេចក្តីជំនឿខាងសាសនារបស់នរណាម្នាក់ ។ បន្ទាប់មក សួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- តើសកម្មភាពណាខ្លះដែលគំនិតទាំងនេះអាចដឹកនាំទៅ ? (នៅពេលសិស្សឆ្លើយតប សូមបង្ហាញថាគំនិតមួយដែលនាំទៅរកសកម្មភាព គឺជាដូចជាគ្រាប់ពូជមួយដែលដុះលើដើមឈើ) ។
- យោងតាម អាលម៉ា ៣០:១៨ តើការបង្រៀនរបស់កូរីហូរបានដឹកនាំប្រជាជនឲ្យធ្វើអ្វីខ្លះ ? (នៅពេលសិស្សឆ្លើយ សូមបញ្ជាក់ថា **សាតាំងប្រើគោលលទ្ធិខុសឆ្គងដើម្បីទាក់ទាញយើងឲ្យធ្វើអំពើបាប) ។**

សូមឲ្យសិស្សម្នាក់សង្ខេបអ្វីដែលបានកើតឡើងដល់កូរីហូរ ។ (ប្រសិនបើសិស្សត្រូវការជំនួយ សូមឲ្យពួកគេប្រើសេចក្តីសង្ខេបក្បាលជំពូកនៃ អាលម៉ា ៣០ ឬអាន អាលម៉ា ៣០:៥២–៥៣, ៥៩–៦០) ។

អាលម៉ា ៣១

អាលម៉ាដឹកនាំបេសកកម្មមួយដើម្បីជួយដល់ពួកសាសន៍សូរ៉ាំដែលក្បត់សាសនា

សូមរំឭកសិស្សថា ពួកសាសន៍សូរ៉ាំបានជឿលើគំនិតដ៏ខុសឆ្គង ហើយបានធ្លាក់ទៅក្នុងការអនុវត្តដ៏ខុសឆ្គង ឬ ដែលក្បត់សាសនា ។ នៅក្នុង អាលម៉ា ៣១:៥ យើងរៀនថា **នៅពេលយើងសិក្សាព្រះបន្ទូលនៃព្រះ វានឹងដឹកនាំយើងឲ្យធ្វើអ្វីដែលត្រូវ ។**

អាលម៉ា ៣២

អាលម៉ាបង្រៀនដល់ប្រជាជននៃសាសន៍សូរ៉ាំក្រីក្រពីរបៀបដើម្បីអនុវត្តសេចក្តីជំនឿ

សូមរំឭកសិស្សថា ទោះបីជាពួកសាសន៍សូរ៉ាំជាច្រើនបានបដិសេធមិនទទួលព្រះបន្ទូលនៃព្រះក្តី ក៏អាលម៉ាបានចាប់ផ្តើមមានជោគជ័យក្នុងចំណោមពួកអ្នកក្រីក្រ ។ គាត់បានបង្រៀនពួកគេអំពីរបៀបដើម្បីអនុវត្តសេចក្តីជំនឿ ។ សូមឲ្យសិស្សរំឭក អាលម៉ា ៣២:២១ ជាចំណេះចំណានខគម្ពីរមួយ ។ សូមឲ្យពួកគេពន្យល់ពីអ្វីដែលខគម្ពីរនេះបង្រៀនពួកគេអំពីសេចក្តីជំនឿ ។

សូមរំឭកសិស្សថា អាលម៉ាបានប្រើគ្រាប់ពូជមួយដើម្បីបង្រៀនអំពីដំណើរការនៃការអភិវឌ្ឍសេចក្តីជំនឿ ។ បន្ទាប់មក សួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- តើឃ្លាណានៅក្នុង អាលម៉ា ៣២:២៨ បង្ហាញថាគ្រាប់ពូជមួយ ឬ នៅក្នុងករណីនេះ ព្រះបន្ទូលនៃព្រះគឺល្អនោះ ?
- តើឥទ្ធិពលអ្វីដែលព្រះបន្ទូលនៃព្រះបានមានមកលើយើង នៅពេលយើងអនុញ្ញាតឲ្យវាបានដុះនៅក្នុងទ្រូងយើងនោះ ?

សូមប្រាប់សិស្សថា អាលម៉ាបានសុំឲ្យពួកសាសន៍សូរ៉ាំពិសោធជាមួយនឹងព្រះបន្ទូល ឬ ដាំវានៅក្នុងចិត្តគេដោយការជឿលើវា ហើយធ្វើសកម្មភាពតាម ។ សូមឲ្យសិស្សអាន អាលម៉ា ៣៣:២២–២៣ ដោយរកមើល « ពាក្យសម្តី » ដែលអាលម៉ាចង់ឲ្យប្រជាជនដាំនៅក្នុងចិត្តរបស់ពួកគេជាពិសេសនោះ ។ អ្នកអាចណែនាំសិស្សឲ្យសរសេរខគម្ពីរទាំងនេះជាសេចក្តីយោងក្បែរនឹង អាលម៉ា ៣២:២៨ ។

សូមឲ្យសិស្សអាន អាលម៉ា ៣២:២៨–២៩, ៣១, ៣៧, ៤១–៤៣ ដោយរកមើលង្វាន់ដែលយើងនឹងទទួលពីការជឿ និងការអនុវត្តតាមព្រះបន្ទូលនៃព្រះ ។ នៅពេលសិស្សឆ្លើយ សូមប្រាកដថាគោលការណ៍ខាងក្រោមនេះបានបញ្ជាក់ច្បាស់ ៖ **ប្រសិនបើយើងថែទាំសេចក្តីជំនឿរបស់យើងទៅលើព្រះបន្ទូលរបស់ព្រះនៅក្នុងដួងចិត្តយើងដោយឧស្សាហ៍ព្យាយាមនោះ សេចក្តីជំនឿ និងទីបន្ទាល់របស់យើងលើព្រះយេស៊ូវគ្រីស្ទ និងជំណឹងល្អរបស់ទ្រង់នឹងកើនឡើង ។**

ដើម្បីបញ្ចប់មេរៀននេះ សូមឲ្យសិស្សចែកចាយចម្លើយរបស់ពួកគេចំពោះមេរៀនទី ៤ កិច្ចការទី ៤ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ —អំពីលទ្ធផលដែលពួកគេបានឃើញនៅក្នុងជីវិតរបស់គេ នៅពេលពួកគេបានធ្វើតាមការពិសោធរបស់អាលម៉ាដែលបានពិពណ៌នានៅក្នុង អាលម៉ា ៣២ ។

មេរៀនបន្ទាប់ (អាលម៉ា ៣៣–៣៩)

តើគ្រោះថ្នាក់អ្វី នៃការពន្យារពេលប្រែចិត្ត ? អាមូលេកឆ្លើយនឹងសំណួរនេះ ហើយផ្តល់នូវការព្រមានមួយ ។ អាលម៉ាក៏ណែនាំដល់កូនប្រុសរបស់គាត់ពីរនាក់ នៅពេលគាត់ជិតដល់ចុងបញ្ចប់នៃជីវិតរបស់គាត់ ។ គាត់ផ្តល់នូវសេចក្តីលម្អិតអំពីការផ្លាស់ប្រែចិត្តជឿ—ការផ្លាស់ប្តូរពីនរណាម្នាក់ដែលជំទាស់នឹងព្រះ ទៅជានរណាម្នាក់ដែលប្រឈុនដើម្បីព្រះ —និងអំពីអារម្មណ៍របស់គាត់ នៅពេលគាត់បានមានសេរីភាពពីអំពើខុសឆ្គង និងការឈឺចាប់នៃអំពើបាបរបស់គាត់ ។

អាលម៉ា ៣៣

សេចក្តីផ្តើម

ក្រុមសាសន៍សូរ៉ាំមួយក្រុមចង់ដឹងពីរបៀបដើម្បីធ្វើតាមការប្រឹក្សារបស់អាលម៉ា ក្នុងការដាំព្រះបន្ទូលនៃព្រះអម្ចាស់នៅក្នុងចិត្តគេ និងអនុវត្តសេចក្តីជំនឿ ។ ដោយប្រើព្រះគម្ពីរ អាលម៉ាបានបង្រៀនប្រជាជនអំពីការថ្វាយបង្គំ ការអធិស្ឋាន និងសេចក្តីមេត្តាករុណាដែលយើងអាចទទួលបានពីព្រះ ដោយសារតែព្រះអង្គសង្គ្រោះ ។ គាត់បានណែនាំប្រជាជនឲ្យមើលទៅព្រះយេស៊ូវគ្រីស្ទ ហើយជឿលើព្រះចេស្តានៃដង្វាយធួន ។

កំណត់ចំណាំ ៖ មេរៀនទី ៩៤ ផ្តល់នូវឱកាសមួយសម្រាប់សិស្សបីនាក់ឡើងមកបង្រៀន ។ អ្នកអាចរើសសិស្សបីនាក់ឥឡូវនេះ ហើយឲ្យដល់ពួកគេនូវច្បាប់ចម្លងនៃចំណែកនៃមេរៀនទី ៩៤ ដែលបានរៀបចំខុសដើម្បីឲ្យពួកគេអាចរៀបចំមេរៀន ។ សូមលើកទឹកចិត្តពួកគេឲ្យសិក្សាមេរៀននេះប្រកបដោយការអធិស្ឋាន ហើយស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យពួកគេនឹងដឹងពីរបៀបដើម្បីសម្របមេរៀននេះទៅនឹងតម្រូវការរបស់មិត្តរួមថ្នាក់ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៣៣

អាលម៉ាបង្រៀនដល់ពួកសាសន៍សូរ៉ាំឲ្យចាប់ផ្តើមជឿលើព្រះយេស៊ូវគ្រីស្ទ

សូមសរសេរពាក្យ *អនុវត្ត* នៅលើក្តារខៀន ។

- តើការអនុវត្តអ្វីមួយ មានន័យយ៉ាងណា ? (នៅពេលសិស្សឆ្លើយនឹងសំណួរនេះ អ្នកអាចសុំឲ្យសិស្សម្នាក់បង្ហាញពីរបៀបដើម្បីបង្វឹកដៃរបស់គេ ប្រហែលដោយការធ្វើអាហ្វង់ ឬ បង្វឹកជើងគាត់ ប្រហែលដោយការរត់នៅនឹងកន្លែង) ។

សូមឲ្យសិស្សអាន អាលម៉ា ៣៣:១ ដោយស្ងាត់ៗ ដោយរកមើលការបង្វឹកដែលសាសន៍សូរ៉ាំចង់យល់ ។ ក្រោយពីសិស្សរៀបរាប់អ្វីដែលពួកគេបានរកឃើញហើយ សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖ *តើយើងអនុវត្តសេចក្តីជំនឿដោយរបៀបណា* ?សូមឲ្យសិស្សរកមើលចម្លើយយ៉ាងហោចណាស់បីទៅនឹងសំណួរនេះ នៅពេលពួកគេសិក្សា និងពិភាក្សាអំពី អាលម៉ា ៣៣ ។

សូមពន្យល់ថា នៅពេលអាលម៉ាបានចាប់ផ្តើមឆ្លើយនឹងសំណួររបស់ពួកសាសន៍សូរ៉ាំអំពីរបៀបដើម្បីអនុវត្តសេចក្តីជំនឿ គាត់បានកែតម្រូវគំនិតដ៏ខុសឆ្គងមួយដែលពួកគេបានមានអំពីការថ្វាយបង្គំ ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣៣:២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលគំនិតខុសឆ្គងរបស់ពួកសាសន៍សូរ៉ាំអំពីការថ្វាយបង្គំព្រះ ។

- ហេតុអ្វីបានជាពួកសាសន៍សូរ៉ាំទាំងនេះគិតថា ពួកគេមិនអាចថ្វាយបង្គំព្រះបាន ? (ដោយសារពួកគេមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងសាលាប្រជុំ) ។

សូមឲ្យសិស្សសង្កេតអ្វីដែលពួកគេបានរៀននៅក្នុង អាលម៉ា ៣១ អំពីទម្រង់នៃការថ្វាយបង្គំរបស់ពួកសាសន៍សូរ៉ាំ ។ (សូមមើល អាលម៉ា ៣១:២២–២៣ ។ ពួកសាសន៍សូរ៉ាំបានផ្តល់នូវការអធិស្ឋានដ៏ដងែលម្តងក្នុងមួយសប្តាហ៍នៅក្នុងសាលាប្រជុំ ហើយពួកគេមិនដែលនិយាយអំពីព្រះម្តងទៀតអំឡុងពេលសប្តាហ៍ឡើយ) ។

- ហេតុអ្វីបានជាការចូលរួមក្នុងព្រះវិហារជាផ្នែកមួយដ៏សំខាន់នៃការថ្វាយបង្គំរបស់យើង ? តើរបៀបណាខ្លះ ដែលយើងអាចថ្វាយបង្គំដល់ព្រះ បន្ថែមលើការទៅចូលរួមការប្រជុំក្នុងព្រះវិហារជារៀងរាល់សប្តាហ៍នោះ ?

សូមពន្យល់ថា អាលម៉ាបានដកស្រង់ការបង្រៀនរបស់ព្យាការីម្នាក់ឈ្មោះ សឺឡាស ដើម្បីកែតម្រូវគំនិតខុសឆ្គងរបស់ពួកសាសន៍សូរ៉ាំអំពីការថ្វាយបង្គំព្រះ ។ សូមឲ្យសិស្សអាន អាលម៉ា ៣៣:៣ ដោយស្ងាត់ៗ ដោយរកមើលពាក្យដែលអាលម៉ាបានប្រើជំនួសនឹងពាក្យ *ថ្វាយបង្គំ* ។ (ពាក្យនោះគឺ *អធិស្ឋាន*) ។

សូមឲ្យសិស្សអាន អាលម៉ា ៣៣:៤–១០ ដោយស្ងាត់ៗ ដោយរកមើលកាលៈទេសៈនីមួយដែលសឺឡាសបាននិយាយថា គាត់បានអធិស្ឋាន ។

- តើនៅពេលណា និងនៅកន្លែងណាដែលសឺឡាសបានអធិស្ឋាន ?
- តើអាលម៉ាបានបង្រៀនអ្វីអំពីការថ្វាយបង្គំ នៅពេលគាត់បានដកស្រង់សម្តីរបស់សឺឡាស ? (សូមជួយសិស្សឲ្យរកមើលសេចក្តីពិតខាងក្រោម ៖ **យើងអាចថ្វាយបង្គំព្រះបន្តឥតដាច់តាមរយៈការអធិស្ឋាន**) ។

សូមយោងទៅសំណួរនៅលើក្តារខៀន ៖ *តើយើងអនុវត្តសេចក្តីជំនឿដោយរបៀបណា* ?នៅក្រោមសំណួរនោះ សូមសរសេរ *អធិស្ឋានជានិច្ច* ។

- តើការអធិស្ឋានគឺជាការអនុវត្តសេចក្តីជំនឿទៅលើព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទតាមរបៀបណា ?
- តើនៅពេលណាដែលអ្នកបានអធិស្ឋាននៅក្នុងស្ថានភាពមួយដូចជាស្ថានភាពដែលសឺឡាសបានលើកឡើង ? តើការអធិស្ឋានរបស់អ្នកត្រូវបានឆ្លើយតបដោយរបៀបណា ? (សូមរំឭកសិស្សថា ពួកគេមិនចាំបាច់ចែកចាយបទពិសោធន៍ដែលផ្ទាល់ខ្លួន ឬ ឯកជនពេកនោះទេ) ។

សូមឲ្យសិស្សរំឭក អាលម៉ា ៣៣:៤–៥, ៨–៩ ដោយស្ងៀមស្ងាត់ ។ សូមឲ្យពួកគេរកមើលឃ្លាដែលបាននិយាយអំពីសេចក្តីមេត្តាករុណារបស់ព្រះ (ដូចជា « ព្រះអង្គប្រកបដោយសេចក្តីមេត្តាករុណា » និង « ព្រះអង្គបានប្រកបដោយសេចក្តីមេត្តាករុណា ») ។

ដើម្បីជួយសិស្សឲ្យឃើញពីទំនាក់ទំនងរវាងដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និងសេចក្តីមេត្តាករុណានៃព្រះវរបិតា សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣៣:១១–១៦ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលឃ្លាមួយថា លេចឡើងប្លន់ដងនៅក្នុងខគម្ពីរទាំងនេះ ។ (ឃ្លានោះគឺ « ដោយសារព្រះរាជបុត្រារបស់ព្រះអង្គ » ។ អ្នកអាចណែនាំសិស្សឲ្យគូសចំណាំឃ្លានេះ) ។

- តើអ្នកគិតថា សឺណូសចង់មានន័យយ៉ាងណា នៅពេលគាត់បាននិយាយថា « ព្រះអង្គបានបង្វែរសេចក្តីជំនុំជម្រះរបស់ព្រះអង្គចេញ ដោយសារព្រះរាជបុត្រារបស់ព្រះអង្គ » ? (សូមជួយសិស្សឲ្យរកឃើញសេចក្តីពិតខាងក្រោម ៖ **យើងទទួលបានសេចក្តីមេត្តាករុណារបស់ព្រះវរបិតាស្ងួគ៌ រួមមានការអភ័យទោសដល់អំពើបាបរបស់យើង ដោយសារតែដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ** ។ អ្នកអាចឲ្យសិស្សសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេនៅក្បែរ អាលម៉ា ៣៣:១១–១៦) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់អំពីសេចក្តីមេត្តាករុណាដែលយើងអាចទទួលបានតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ សូមគិតពីការចែកចាយរឿងខាងក្រោមដែលដកស្រង់ដោយ ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ៖

« គ្រូបង្រៀនបាននិយាយថា ‹ អរុណសួស្តីក្មេងៗ យើងមកដឹកនាំសាលា › ។ ពួកគេបានស្រែក ហើយបានសើចអស់សំឡេង ។ ‹ ឥឡូវ ខ្ញុំចង់បានសាលាដ៏ល្អមួយ ប៉ុន្តែខ្ញុំសារភាពថា ខ្ញុំមិនដឹងពីរបៀបដើម្បីធ្វើវា រហូតដល់អ្នកជួយដល់ខ្ញុំ ។ សូមគិតថា យើងមានច្បាប់ពីរបី ។ អ្នកប្រាប់ខ្ញុំ ហើយខ្ញុំនឹងសរសេរវានៅលើក្តារខៀន › ។

« សិស្សម្នាក់បានស្រែកថា ‹ ហាមលួច ! › សិស្សម្នាក់ទៀតបានឆ្លើយថា ‹ មកទាន់ពេល › ។ ទីបញ្ចប់ ច្បាប់ដប់បានលេចឡើងនៅលើក្តារខៀន ។

« គ្រូបង្រៀនបាននិយាយថា ‹ ឥឡូវនេះ ច្បាប់មួយមិនល្អទេ រហូតដល់មានការពិន័យអមមកជាមួយ ។ តើយើងគួរធ្វើអ្វីនឹងអ្នកដែលរំលងច្បាប់ ? ›

« សិស្សក្នុងថ្នាក់បានឆ្លើយថា ‹ សូមវាយខ្នងគាត់ដប់ដងដោយមិនឲ្យគាត់ពាក់អាវក្រៅ › ។

« ‹ ប្អូន វាធ្ងន់ធ្ងរខ្លាំងណាស់ ។ តើអ្នកប្រាកដថា អ្នកត្រៀមខ្លួនប្រឈមនឹងវាហើយឬ ? › សិស្សម្នាក់ទៀតបានឆ្លើយថា ‹ ខ្ញុំគាំទ្រប្រធានបទនេះ › ហើយគ្រូបង្រៀនបាននិយាយថា ‹ អញ្ចឹង យើងនឹងធ្វើតាមវាទាំងអស់គ្នា ! សិស្សទាំងអស់គ្នា ចូរមានរបៀប ! ›

« មួយកន្លងទៅ ‹ ថម ធំ › បានដឹងថា គាត់បាត់អាហារថ្ងៃត្រង់របស់គាត់ ។ ចោរនោះត្រូវចាប់បាន— ក្មេងក្មេងតូចដ៏ឆ្លាតម្នាក់ អាយុប្រហែលដប់ឆ្នាំ ។ ‹ យើងបានរកឃើញចោរ ហើយគាត់ត្រូវតែពិន័យយោងតាមច្បាប់របស់អ្នក— វាយដប់រំពាត់លើខ្នង ។ ជិម ឡើងមកនេះ ! › គ្រូបង្រៀនបាននិយាយ ។

« កូនសិស្សដ៏តូចនោះ ដោយញ័រខ្លាច បានឡើងមកយឺតៗដោយមានពាក់អាវក្រៅដ៏ធំចិចជិតដល់កគាត់ ហើយបានសុំអង្វរថា ‹ លោកគ្រូ លោកគ្រូអាចវាយខ្ញុំយ៉ាងខ្លាំងតាមដែលលោកគ្រូចង់ ប៉ុន្តែខ្ញុំសូមអង្វរ សូមកុំដោះអាវខ្ញុំចេញអី ! › *កំណត់ចំណាំ ៖* អ្នកអាចពន្យល់ថា នៅក្នុងរឿងនេះពាក្យ *វាយ* មានន័យថា វាយដំនរណាម្នាក់ ។

« គ្រូបង្រៀនបាននិយាយថា ‹ ដោះអាវក្រៅចេញ › ។ ‹ ឯងបានជួយបង្កើតច្បាប់ទាំងនោះដែរ ! ›

« ‹ ឱ! លោកគ្រូ សូមកុំឲ្យខ្ញុំដោះអាវក្រៅអី ! › គាត់បានចាប់ផ្តើមដោះឡើងអាវក្រៅ ហើយតើគ្រូបង្រៀនបានឃើញអ្វី ? ក្មេងប្រុសនោះគ្មានអាវស៊ីមីពាក់ទេ ហើយបានបង្ហាញនូវរូបកាយដ៏តូចសុទ្ធឆ្អឹង ។

« ‹ តើខ្ញុំអាចវាយកូនក្មេងនេះដោយរបៀបណា ? › គ្រូបង្រៀនបានគិត ។ ‹ ប៉ុន្តែខ្ញុំត្រូវតែធ្វើវា ខ្ញុំត្រូវតែធ្វើអ្វីមួយ ប្រសិនបើខ្ញុំត្រូវរក្សាសាលានេះនោះ ។ › អ្វីៗទាំងអស់បានក្លាយជាស្ងាត់ដូចចោរលួចសេះ ។

« ‹ តើឯងកើតអីបានជាមិនពាក់អាវស៊ីមី ជិម ? ›

« គាត់បានឆ្លើយថា ‹ ឪពុករបស់ខ្ញុំបានស្លាប់ ហើយម្តាយរបស់ខ្ញុំក្រខ្លាំងណាស់ ។ ខ្ញុំមានតែអាវស៊ីមីមួយគត់ ហើយម្តាយខ្ញុំបានបោកវាថ្ងៃនេះ ហើយខ្ញុំបានពាក់អាវក្រៅធំរបស់បងប្រុសខ្ញុំដើម្បីកុំឲ្យរងារ ។ ›

« គ្រូបង្រៀនបានស្ងាក់ស្ងើរ ដោយមានកាន់ដំបងនឹងដៃ ។ ពេលនោះភ្លាម ‹ ថមដ៏ធំ › បានលោតមកខាងមុខ ហើយបាននិយាយថា ‹ លោកគ្រូ ប្រសិនបើលោកគ្រូមិនជំទាស់ទេ ខ្ញុំនឹងទទួលការវាយនេះជំនួសជិម ។ ›

« ‹ ល្អណាស់ មានច្បាប់ជាក់លាក់មួយ ដែលបុគ្គលម្នាក់អាចធ្វើជាអ្នកជំនួសបុគ្គលម្នាក់ទៀតបាន ។ តើអ្នកទាំងអស់គ្នាយល់ព្រមទេ ? ›

« ថមបានដោះអាវស៊ីមីចេញ ហើយក្រោយពីវាយបានប្រាំរំពាត់ រំពាត់ក៏បាក់ ! គ្រូបង្រៀនបានខ្ចប់មុខគាត់នឹងដៃ ហើយបានគិតថា ‹ តើខ្ញុំអាចបញ្ចប់កិច្ចការដ៏អាក្រក់នេះដោយរបៀបណា ? › បន្ទាប់មក គាត់បានឮសិស្សក្នុងថ្នាក់យំ ហើយតើគាត់បានឃើញអ្វី ? ជិមដ៏តូចនោះបានឡើងមក ហើយបានចាប់ដៃទាំងពីររបស់ថមឱបជុំវិញករបស់គាត់ ។ ‹ ថម ខ្ញុំសុំទោសដែលខ្ញុំបានលួចអាហាររបស់ឯង ប៉ុន្តែខ្ញុំពិតជាឃ្លានខ្លាំងណាស់ ។ ថម ខ្ញុំនឹងស្រឡាញ់ឯង រហូតដល់ខ្ញុំស្លាប់ ដោយសារឯងបានទទួលការវាយរបស់ខ្ញុំជំនួសខ្ញុំ ! មែនហើយ ខ្ញុំនឹងស្រឡាញ់ឯងជារៀងរហូតទៅ ! › » | អ្នកនិពន្ធអនាមិក ។ |

ក្រោយពីដកស្រង់រឿងនេះហើយ ប្រធាន ហ៊ិងគ្លី បានមានប្រសាសន៍ថា « ដើម្បីដកយកឃ្លាមួយពីរឿងដ៏សាមញ្ញនេះ ព្រះយេស៊ូវព្រះប្រោសលោះរបស់ខ្ញុំបានយក ‹ ការវាយរបស់ខ្ញុំពីខ្ញុំ › ហើយការវាយរបស់អ្នកពីអ្នក » (« The Wondrous and True Story of Christmas » *Ensign,* ខែ ធ្នូ ឆ្នាំ ២០០០, ទំព័រ ៤) ។

- តើដំណើររឿងនេះទាក់ទងនឹងការបង្រៀនរបស់អាលម៉ាអំពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះដោយរបៀបណា ? (បើសិនជាចាំបាច់ សូមពន្យល់ថា បំណងរបស់ថមដើម្បី « យកនូវការវាយរបស់ជិម » តំណាងឲ្យដង្វាយធួន ។ ព្រះអង្គសង្គ្រោះបានយកនូវការដាក់ទោសចំពោះអំពើបាបរបស់យើងដាក់លើអង្គទ្រង់ ដើម្បីឲ្យយើងនឹងមិនត្រូវរងទុក្ខការដាក់ទោសនោះ ប្រសិនបើយើងប្រែចិត្ត) ។

សូមរកមើលពាក្យ និងឃ្លាដដែល ។
ព្យាការីបញ្ជាក់ជាញឹកញាប់ពីសេចក្តីពិតតាមរយៈការនិយាយម្តងហើយម្តងទៀត ។ នៅពេលសិស្សរកមើលពាក្យឃ្លា និងគំនិតដដែលទាំងឡាយ សូមឲ្យពួកគេឲ្យគិតពីសេចក្តីពិតដែលអ្នកនិពន្ធកំពុងបង្រៀន និងមូលហេតុបានជាវាសំខាន់ដើម្បីយល់ពីវា ។

សូមពន្យល់ថា ក្រោយពីការដកស្រង់សម្តីរបស់សឺណូស អាលម៉ាបានដកស្រង់សម្តីរបស់សឺណុក ជាព្យាការីម្នាក់ទៀត ។ សូមអាន អាលម៉ា ៣៣:១៥–១៦ ឮដល់សិស្ស ។ សូមបញ្ជាក់ពីការមិនសព្វព្រះទ័យនៃព្រះវរបិតាសួគ៌ នៅពេលមនុស្សបដិសេធមិនព្រមយល់ពីអ្វីដែលព្រះរាជបុត្រារបស់ទ្រង់បានធ្វើសម្រាប់ពួកគេ ។

សូមឲ្យសិស្សអាន អាលម៉ា ៣៣:១២–១៤ ដោយស្ងាត់ៗ ដោយរកមើលប្រភពដៃលអាលម៉ាបានប្រើនៅពេលគាត់បានចែកចាយការបង្រៀននេះ ។

- ហេតុអ្វីបានជាអាលម៉ាយល់ពាក្យសម្តីរបស់សឺណូស និងសឺណុក ? (ដោយសារសម្តីទាំងនោះនៅក្នុងព្រះគម្ពីរ ។ អ្នកអាចបង្ហាញថាសម្តីរបស់អាលម៉ានៅក្នុងខទី ១២ និង ទី១៤ ផ្តល់យោបល់ថា ពួកសាសន៍ស្លាំក៏បានទទួលព្រះគម្ពីរទាំងនេះដែរ ។ សូមបញ្ជាក់ថា **ព្រះគម្ពីរផ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ**) ។

នៅពីក្រោមសំណួរនៅលើក្តារខៀន សូមសរសេរ *សិក្សា និងជឿលើព្រះគម្ពីរ* ។

សូមបង្ហាញថា អាលម៉ាយោងទៅលើដំណើររឿងក្នុងព្រះគម្ពីរមួយទៀតដើម្បីជួយពួកសាសន៍ស្លាំឲ្យអភិវឌ្ឍសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ។ សូមបង្ហាញរូបភាពម៉ូសេ និងរូបពស់ធ្វើពីលង្ហិន (៦២២០២ *សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ |, លេខ ១៦) ។ សូមសង្ខេបដំណើររឿងនេះដោយការពន្យល់ថា នៅពេលម៉ូសេបានដឹកនាំពួកសាសន៍អ៊ីស្រាអែលទៅក្នុងវាលរហោស្ថាន មានមនុស្សជាច្រើនបានចាប់ផ្តើមបះបោរប្រឆាំងនឹងគាត់ និងព្រះអម្ចាស់ ។ ឆ្លើយតបនឹងការមិនគោរពនេះ ព្រះអម្ចាស់បានឲ្យពស់ពិសដែលចឹកមនុស្សទៅ ។ ប្រជាជនបានទៅសុំម៉ូសេឲ្យជួយ ។ ម៉ូសេបានអធិស្ឋាន ហើយត្រូវបានណែនាំឲ្យធ្វើរូបពស់នោះលើសសរដើម្បីឲ្យប្រជាជនមើល ។ គាត់បានគោរពតាម ដោយធ្វើរូបពស់នោះពីលង្ហិន ។ (សូមមើល ជនគណនា ២១:៤–៩) ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣៣:១៩–២០ ឮ ។ សូមអញ្ជើញឲ្យសិស្សរកមើលអ្វីដែលបានកើតឡើងដល់អ្នកដែលបានមើលទៅរូបពស់ធ្វើពីលង្ហិននោះ ហើយតើមានអ្វីបានកើតឡើងដល់អ្នកដែលបានជ្រើសរើសមិនព្រមមើល ។

- យោងតាម អាលម៉ា ៣៣:២០ តើហេតុអ្វីបានជាមនុស្សជាច្រើនមិនព្រមមើល ?

សូមឲ្យសិស្សសញ្ជឹងគិតថាតើពួកគេនឹងជ្រើសរើសដើម្បីមើលទេ ប្រសិនបើពួកគេនៅក្នុងស្ថានភាពនោះ ។

សូមបង្ហាញរូបភាពនៃការឆ្លាង (៦២៥០៥ *សៀវភៅរូបភាពដំណឹងល្អ* លេខ ៥៧) ។ សូមពន្យល់ថា រូបពស់ធ្វើពីលង្ហិននៅលើសសរនោះគឺជា « និមិត្តរូប » មួយ (អាលម៉ា ៣៣:១៩) ។ និយាយម្យ៉ាងទៀតថា វាគឺជានិមិត្តរូបនៃអ្វីមួយ ដែលនឹងកើតឡើងនៅក្នុងពេលអនាគត ។ វាតំណាងឲ្យព្រះយេស៊ូវគ្រីស្ទនៅលើឈើឆ្កាង (សូមមើល យ៉ូហាន ៣:១៤) ។

សូមឲ្យសិស្សអាន អាលម៉ា ៣៣:២១–២៣ ដោយស្ងាត់ៗ ដោយរកមើលពីរបៀបដែលអាលម៉ាបានប្រដូចរឿងនេះទៅនឹងពួកសាសន៍ស្លាំ ។ ក្រោយពីសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញហើយ សូមយោងទៅសំណួរនៅលើក្តារខៀនម្តងទៀត ៖ *តើយើងអាចអនុវត្តសេចក្តីជំនឿបានដោយរបៀបណា* ?

- តើដំណើររឿងនៃពួកសាសន៍អ៊ីស្រាអែល និងរូបពស់ធ្វើពីលង្ហិនអាចបង្រៀនអ្វីខ្លះ អំពីអ្វីដែលយើងត្រូវធ្វើដើម្បីបានព្យាបាលខាងវិញ្ញាណ ?
- តើ អាលម៉ា ៣៣:២២–២៣ ឆ្លើយនឹងសំណួរនេះដោយរបៀបណា ? (សិស្សគួរបង្ហាញពីសេចក្តីពិតខាងក្រោម ៖ **យើងអនុវត្តសេចក្តីជំនឿដោយការជ្រើសរើសជឿលើព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់**) ។

នៅពីក្រោមសំណួរនៅលើក្តារខៀន សូមសរសេរ *ជឿលើព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់* ។

- តើសកម្មភាព ឬ ឥរិយាបថអ្វីខ្លះដែលអ្នកឃើញនៅក្នុងប្រជាជនដែលជឿលើដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ?

ដើម្បីបញ្ជាក់ថា សេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទគឺជាជម្រើសមួយដែលយើងធ្វើ សូមទាញចំណាប់អារម្មណ៍របស់សិស្សទៅលើឃ្លាខាងក្រោមនៅក្នុង អាលម៉ា ៣៣:២៣ ៖ « ហើយការណ៍អស់ទាំងនេះ អ្នករាល់គ្នាអាចធ្វើបាន បើសិនជាអ្នករាល់គ្នាចង់ធ្វើ ។ » អ្នកអាចណែនាំសិស្សឲ្យគូសចំណាំឃ្លានេះ ។

សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមនៅលើក្តារខៀន ហើយសូមពីការណែនាំសិស្សឲ្យសរសេរវានៅក្នុងព្រះគម្ពីររបស់ពួកគេ ។ (សេចក្តីថ្លែងការណ៍មាននៅក្នុង « Inquire of the Lord » | សន្ទរកថាថ្លែងទៅកាន់អ្នកអប់រំសាសនា CES នៅថ្ងៃទី ២ខែ កុម្ភៈឆ្នាំ ២០០១ |, ទំព័រ ១, si.lds.org) ។

« កូនម្នាក់ៗនៅក្នុងជំនាន់នីមួយៗជ្រើសរើសសេចក្តីជំនឿ ឬ ការមិនជឿ ។ សេចក្តីជំនឿមិនមែនជាមរតកនោះទេ វាគឺជាជម្រើសមួយ» (ប្រធាន ហិនរី ប៊ី អាវរិង) ។

សូមឲ្យសិស្សឆ្លើយនឹងសំណួរខាងក្រោមមួយនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ (អ្នកអាចសរសេរសំណួរទាំងនេះនៅលើក្តារខៀនមុនចាប់ផ្តើមបង្រៀន សូមរៀបចំជាក្រដាសមួយដោយមានសំណួរ ឬ អានសំណួរយឺតៗដើម្បីឲ្យសិស្សកត់ត្រាវា) ។

- តើជម្រើសរបស់អ្នកដើម្បីជឿលើព្រះអង្គសង្គ្រោះបានជះឥទ្ធិពលដល់ជីវិតប្រចាំថ្ងៃរបស់អ្នកដោយរបៀបណា ?
- តើការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនបានពង្រឹងដល់សេចក្តីជំនឿរបស់អ្នកទៅលើព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?
- តើការអធិស្ឋាន និងការថ្វាយបង្គំប្រចាំថ្ងៃបានពង្រឹងដល់សេចក្តីជំនឿរបស់អ្នកទៅលើព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?
- តើអ្នកមានអារម្មណ៍ថា ព្រះវរបិតាសួគ៌នឹងចង់ឲ្យអ្នកធ្វើអ្វី ដើម្បីអនុវត្តសេចក្តីជំនឿដ៏អស្ចារ្យជាងនេះ ?

សូមឲ្យសិស្សពីរបីនាក់ចែកចាយចម្លើយរបស់ពួកគេ ។ សូមថ្លែងទីបន្ទាល់អំពីសារៈសំខាន់នៃការជ្រើសរើសជឿលើព្រះអង្គសង្គ្រោះ ។

អាលម៉ា ៣៤–៣៥

សេចក្តីផ្តើម

ក្រោយពីអាលម៉ាបានបង្រៀនដល់ពួកសាសន៍សូរ៉ាំឲ្យជឿលើព្រះរាជបុត្រានៃព្រះ អាមូលេក បានប្រកាសពីទីបន្ទាល់ផ្ទាល់របស់គាត់លើព្រះយេស៊ូវគ្រីស្ទ ដោយផ្តល់ជាសាក្សីទីពីរ ។ អាមូលេក ជាដៃគូរបស់អាលម៉ា បានបញ្ជាក់ថា ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទគឺចាំបាច់សម្រាប់សេចក្តីសង្គ្រោះដល់មនុស្សទាំងអស់ ហើយថាបុគ្គលទាំងឡាយអាចទទួលបានពរជ័យទាំងឡាយនៃដង្វាយធួន នៅពេលពួកគេអនុវត្តសេចក្តីជំនឿហូតដល់មានការប្រែចិត្ត ។ ពួកសាសន៍សូរ៉ាំជាច្រើនបានគោរពតាមការអញ្ជើញរបស់អាលម៉ាដើម្បីប្រែចិត្ត ។ នៅពេលពួកសាសន៍សូរ៉ាំដែលបានប្រែចិត្តត្រូវបានបណ្តេញចេញពីដែនដីដោយសារពួកអ្នកដឹកនាំ និងពួកសង្ឃជ៏ទុច្ចរិតរបស់ពួកគេ ពួកសាសន៍នីហ្វៃ និងប្រជាជនអាំម៉ូនបានផ្តល់អាហារ សំលៀកបពាក់ និងដែនដីសម្រាប់មរតកដល់ពួកគេ ។ ជាលទ្ធផល ពួកសាសន៍លេមិន និងពួកសាសន៍សូរ៉ាំដែលមិនបានប្រែចិត្តបានចាប់ផ្តើមរៀបចំធ្វើចម្បាំងនឹងពួកសាសន៍នីហ្វៃ និងប្រជាជនអាំម៉ូន ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៣៤:១–១៤

អាមូលេកបង្រៀនដល់ពួកសាសន៍សូរ៉ាំអំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ

សូមសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន មុនចាប់ផ្តើមបង្រៀន ។ សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅ ឬ ក្រដាសមួយថាតើពួកគេគិតថាប្រយោគនីមួយៗត្រូវ ឬក៏ខុស ។

១. នៅពេលព្រះយេស៊ូវគ្រីស្ទបានសុគតសម្រាប់អំពើបាបរបស់មនុស្សជាតិ ទ្រង់បានរងទុក្ខតែសម្រាប់មនុស្សសុចរិតតែប៉ុណ្ណោះ ។

២. មនុស្សទាំងអស់ត្រូវការដង្វាយធួន ដើម្បីត្រូវបានសង្គ្រោះ ។

៣. មនុស្សណាក៏ដោយអាចស្លាប់ ឬ បង់ជំនួសអំពើបាបនៃមនុស្សផ្សេងទៀត ។

ក្រោយពីសិស្សបានមានពេលកត់ត្រាចម្លើយរបស់ពួកគេហើយ សូមរំឭកពួកគេថា អាលម៉ាបានបង្រៀនដល់ក្រុមសាសន៍សូរ៉ាំមួយក្រុមពីរបៀបដើម្បីទទួលបានព្រះបន្ទូលនៃព្រះ ហើយអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ (សូមមើល អាលម៉ា ៣២–៣៣) ។ សូមសង្ខេប អាលម៉ា ៣៤:១–៧ ដោយការពន្យល់ថា អាមូលេកបានធ្វើតាមអាលម៉ាដោយការចែកចាយទីបន្ទាល់ផ្ទាល់ខ្លួនរបស់គាត់អំពីព្រះអង្គសង្គ្រោះ ។ សូមឲ្យសិស្សសិក្សាពីការបង្រៀនរបស់អាមូលេកនៅក្នុង អាលម៉ា ៣៤:៨–៩, ១១ ដោយស្ងាត់ៗ ដោយរកមើលឃ្លាដែលបង្ហាញថាតើប្រយោគនីមួយៗនៅលើក្តារខៀនត្រូវ ឬក៏ខុស ។ បន្ទាប់មក សូមរំឭកប្រយោគទាំងឡាយទាំងអស់គ្នា ។ ចម្លើយត្រឹមត្រូវគឺ ៖

១. ខុស —« ទ្រង់នឹងធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃមនុស្សលោក » (អាលម៉ា ៣៤:៨) ។

២. ត្រូវ— « នោះត្រូវតែមានដង្វាយធួនមួយកើតឡើង បើពុំនោះសោតទេមនុស្សលោកទាំងអស់នឹងពុំអាចចៀសផុតពីសេចក្តីវិនាសបានឡើយ » (អាលម៉ា ៣៤:៩) ។

៣. ខុស— « គ្មានមនុស្សណាម្នាក់អាចបូជាលោហិតរបស់ខ្លួនផ្ទាល់ ដែលនឹងធ្វើឲ្យធួននឹងអំពើបាបទាំងឡាយនៃជនដទៃបានឡើយ » (អាលម៉ា ៣៤:១១) ។

ក្រោយពីសិស្សបានពិភាក្សាចម្លើយនឹងប្រយោគទី ៣ហើយ សូមសួរ ៖

- **តើអ្នកគិតថា ហេតុអ្វីបានជាព្រះយេស៊ូវគ្រីស្ទគឺជាអង្គតែម្នាក់គត់ដែលអាចធ្វើឲ្យធួនសម្រាប់អំពើបាបនៃពិភពលោក ?**

ដើម្បីជួយសិស្សឲ្យឆ្លើយនឹងសំណួរនេះ សូមឲ្យពួកគេអាន អាលម៉ា ៣៤:១០, ១៤ ដោយស្ងាត់ៗ ។ បន្ទាប់មក សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ័សុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« ដង្វាយធួនរបស់ទ្រង់គឺនិរន្តរ៍ —គ្មានទីបញ្ចប់ឡើយ ។ វាក៏ជានិរន្តរ៍ដែលមនុស្សជាតិទាំងអស់នឹងត្រូវបានសង្គ្រោះពីសេចក្តីស្លាប់ដែលមិនចេះចប់ ។ វាជានិរន្តរ៍ក្នុងន័យការរងទុក្ខដ៏ខ្លាំងមហិមារបស់ទ្រង់ ។ . . . វាជានិរន្តរ៍ក្នុងបរិបទ —វាត្រូវធ្វើតែម្តងសម្រាប់មនុស្សទាំងអស់ ។ ហើយសេចក្តីមេត្តាករុណានៃដង្វាយធួនពន្រីកមិនត្រឹមតែដល់ចំនួនមនុស្សដ៏និរន្តរ៍ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងដល់ចំនួនដ៏និរន្តរ៍នៃពិភពលោកទាំងឡាយដែលត្រូវបានបង្កើតដោយទ្រង់ ។ វាជានិរន្តរ៍លើសពីការស្មាននៃរង្វាស់របស់មនុស្ស ឬ លើសពីការយល់ដឹងខាងសាច់ឈាម ។

« ព្រះយេស៊ូវគឺជាអង្គតែមួយគត់ ដែលអាចផ្តល់នូវដង្វាយធួនជានិរន្តរ៍មួយបែបនោះបាន ដោយសារទ្រង់បានប្រសូតម្តាយជាសាច់ឈាមម្នាក់ និង ពីព្រះវរបិតាខាងវិញ្ញាណ ។ ដោយសារតែការប្រសូត្រដែលមានតែមួយគត់នោះ ព្រះយេស៊ូវគឺជាអង្គដ៏និរន្តរ៍មួយ » (« The Atonement »*Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៦, ទំព័រ ៣៥) ។

« យោងតាមច្បាប់ដ៏អស់កល្បជានិច្ច ដង្វាយធួននោះត្រូវការការលះបង់ផ្ទាល់ខ្លួនដោយការធ្វើជាមនុស្សខាងវិញ្ញាណអមតដែលអាចស្លាប់បាន ។ ហើយទ្រង់ត្រូវតែសុគត ហើយទទួលយកនូវរាងកាយរបស់ទ្រង់ផ្ទាល់ម្តងទៀត ។ ព្រះអង្គសង្គ្រោះគឺជាអង្គតែមួយគត់ដែលអាចសម្រេចការណ៍នេះបាន ។ ដោយសារអំណាចរបស់ទ្រង់ ទ្រង់ទទួលបានអំណាចចេះស្លាប់ ។ ដោយសារពីព្រះវរបិតារបស់ទ្រង់

សូមបង្រៀនដោយព្រះវិញ្ញាណ ហើយថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ

សូមធ្វើអ្វីទាំងឡាយដែលអ្នកអាចដើម្បីបង្កើតបរិយាកាសមួយដែលសិស្សអាចត្រូវបានបង្រៀនដោយព្រះវិញ្ញាណបរិសុទ្ធ ។ របៀបដ៏មានន័យបំផុតមួយដើម្បីបង្កើតបរិយាកាសបែបនោះគឺ ត្រូវផ្តោតលើគំរូ និងការពិភាក្សារបស់អ្នកលើព្រះអង្គសង្គ្រោះ សូមថ្លែងទីបន្ទាល់អំពីទ្រង់ឲ្យបានញឹកញាប់ ហើយសូមផ្តល់ឱកាសដល់សិស្សឲ្យថ្លែងទីបន្ទាល់អំពីទ្រង់ ។

ទ្រង់បានទទួលអំណាចដើម្បីឈ្នះលើសេចក្តីស្លាប់ » (« Constancy amid Change »*Ensign*,ខែ វិច្ឆិកា ឆ្នាំ ១៩៩៣, ទំព័រ ៣៤) ។

- តើការបង្រៀនរបស់អាម៉ូលេក និងសេចក្តីថ្លែងការណ៍របស់អែលឌើរ ណែលសុន បានជួយយើងឲ្យយល់ពីមូលហេតុដែលព្រះយេស៊ូវគ្រីស្ទគឺជាអង្គតែមួយគត់ដែលអាចធ្វើឲ្យធួនសម្រាប់អំពើបាបនៃពិភពលោកដោយរបៀបណា ?
- តើអ្នកសង្កេបអ្វីដែលអ្នកបានរៀនកន្លងមកពី អាលម៉ា ៣៤ អំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ? (សិស្សអាចឆ្លើយនូវសេចក្តីពិតផ្សេងទៀត ប៉ុន្តែសូមប្រាកដថា ពួកគេយល់ថា **ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទដ៏និរន្តរ៍ និងអស់កល្បជានិច្ចធ្វើឲ្យសេចក្តីសង្គ្រោះកើតមានសម្រាប់មនុស្សជាតិទាំងអស់**) ។

ដើម្បីជួយសិស្សឲ្យកោតសរសើរពីភាពចាំបាច់នៃដង្វាយធួននៅក្នុងផែនការនៃសេចក្តីសង្គ្រោះរបស់ព្រះវរបិតាសួគ៌កាន់តែខ្លាំង សូមគិតពីការប្រើសកម្មភាពខាងក្រោម ។ អ្នកអាចសម្របសកម្មភាពនេះឲ្យស្របនឹងតម្រូវការ និងចំណាប់អារម្មណ៍របស់សិស្សដែលអ្នកបង្រៀន ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *សូមស្រមៃថាជីវិតគ្មាន . . .*

សូមកាន់វត្ថុមួយ ដែលយុវវ័យជាច្រើនផ្តល់តម្លៃ (ដូចជាទូរស័ព្ទដៃមួយ) ហើយសូមសួរ ៖

- តើអ្នកស្រមៃថា ជីវិតនឹងទៅជាយ៉ាងណាបើគ្មានវត្ថុនេះ ?

បន្ទាប់មក សូមលើកដប ឬ កែវទឹកមួយ (ឬអ្វីមួយដែលចាំបាច់ដើម្បីចិញ្ចឹមជីវិត) ។

- តើជីវិតនឹងទៅជាយ៉ាងណាបើគ្មានទឹកទេនោះ ?

ក្រោយពីសិស្សបានពិភាក្សាពីភាពចាំបាច់នៃទឹកហើយ សូមបំពេញប្រយោគនៅលើក្តារខៀន ដើម្បីឲ្យវាអាចទៅលើដូចខាងក្រោម ៖ *សូមស្រមៃថាជីវិតគ្មានដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។*

- តើជីវិតនឹងខុសគ្នាយ៉ាងណា បើសិនដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ? (សូមផ្តល់ពេលឲ្យសិស្សសញ្ជឹងគិតពីសំណួរនេះ៖ មុនពេលឲ្យសិស្សឆ្លើយ ។ ប្រសិនបើមានពេល អ្នកអាចឲ្យពួកគេសរសេរចម្លើយទៅនឹងសំណួរនេះ) ។

អាលម៉ា ៣៤:១៥–៤១

អាលម៉ាបង្រៀនដល់ពួកសាសន៍សូរ៉ាំពីរបៀបដើម្បីអនុវត្តសេចក្តីជំនឿចំពោះការប្រែចិត្ត

សូមបង្ហាញថា ទោះបីជាព្រះយេស៊ូវគ្រីស្ទបានធ្វើដង្វាយធួនសម្រាប់មនុស្សទាំងអស់ក្តី យើងមិនមែនទទួលបានពរជ័យរបស់វាទាំងអស់ដោយស្វ័យប្រវត្តិនោះទេ ។ អាម៉ូលេកបានបង្រៀនអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបានពរជ័យទាំងអស់ដែលមានតាមរយៈដង្វាយធួន ។ សូមឲ្យសិស្សអាន អាលម៉ា ៣៤:១៥–១៧ ដោយស្ងាត់ៗ ហើយរកមើលឃ្លាមួយដែលអាម៉ូលេកបាននិយាយបួនដង ។ (« សេចក្តីជំនឿចំពោះការប្រែចិត្ត ។ »)

- តើយើងអាចរៀនអ្វីខ្លះពី អាលម៉ា ៣៤:១៥–១៧ អំពីអ្វីដែលយើងត្រូវធ្វើដើម្បីទទួលបានពរជ័យពេញលេញនៃដង្វាយធួន ? (សូមប្រាកដថា សិស្សយល់ថា **ដើម្បីទទួលបានពរជ័យពេញលេញនៃដង្វាយធួន យើងត្រូវអនុវត្តសេចក្តីជំនឿចំពោះការប្រែចិត្ត**) ។
- តើអ្នកគិតថា សេចក្តីជំនឿចំពោះការប្រែចិត្តមានន័យយ៉ាងណា ?

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃសេចក្តីជំនឿចំពោះការប្រែចិត្ត សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរ អេស អុជដូហ្វ នៃគណៈប្រធានទីមួយ ៖

« យើងត្រូវការសេចក្តីជំនឿដ៏រឹងមាំមួយទៅលើព្រះគ្រីស្ទដើម្បីអាចប្រែចិត្ត ។ . . . សេចក្តីជំនឿលើព្រះគ្រីស្ទនឹងផ្លាស់ប្តូរគំនិត ជំនឿ និងអាកប្បកិរិយារបស់យើងដែលមិនស្របនឹងឆន្ទៈរបស់ព្រះ ។ . . . ការប្រែចិត្តមានន័យថា ការផ្លាស់ប្តូរនៃគំនិត និងដួងចិត្ត —យើងឈប់ធ្វើអ្វីដែលខុស ហើយយើងចាប់ផ្តើមធ្វើអ្វីដែលត្រូវ » (« Point of Safe Return » *Ensign*ឬ*លេអាហូណា*,ខែ ឧសភា ឆ្នាំ ២០០៧, ទំព័រ ១០០) ។

- តើហេតុអ្វីបានជាវាសំខាន់ដើម្បីយល់ថា ការប្រែចិត្តតម្រូវឲ្យយើងមិនត្រឹមតែឈប់ធ្វើនូវអ្វីដែលខុសប៉ុណ្ណោះទេ ប៉ុន្តែយើងត្រូវចាប់ផ្តើមធ្វើអ្វីដែលត្រូវ ?
- យោងតាម អាលម៉ា ៣៤:១៦ តើលទ្ធផលអ្វីនឹងមក នៅពេលយើងអនុវត្តសេចក្តីជំនឿចំពោះការប្រែចិត្ត ?
- តើនឹងមានអ្វីកើតឡើង ប្រសិនបើយើងមិនអនុវត្តសេចក្តីជំនឿចំពោះការប្រែចិត្តទេនោះ ? (អ្នកអាចពន្យល់ថា « ការស្របនឹងច្បាប់ដ៏ពេញលេញនៃតម្រូវការនៃយុត្តិធម៌ » មានន័យថាត្រូវរងទុក្ខនូវលទ្ធផលពេញលេញចំពោះអំពើបាបរបស់យើង និងបាត់បង់ពរជ័យនៃជីវិតដ៏អស់កល្បជានិច្ច) ។
- យោងតាម អាលម៉ា ៣៤:១៧ តើអ្វីមួយដែលយើងអាចធ្វើដើម្បីសេចក្តីជំនឿចំពោះការប្រែចិត្ត ?

សូមឲ្យសិស្សអាន អាលម៉ា ៣៤:១៧–២៨ ដោយស្ងាត់ៗ ។ សូមឲ្យពួកគេរកមើលអ្វីដែលអាម៉ូលេកបានបង្រៀនដល់ពួកសាសន៍សូរ៉ាំអំពីការអធិស្ឋាន ដោយរួមមាននៅពេលណាអធិស្ឋាន និងតើត្រូវអធិស្ឋានសុំអ្វី ។

- តើអាម៉ូលេកបានបង្រៀនអំពីការអធិស្ឋានដែលទាក់ទងនឹងជីវិតរបស់អ្នកអ្វីខ្លះ ? តើអ្នកគិតថា ហេតុអ្វីបានជាការអធិស្ឋានជាផ្នែកមួយដ៏សំខាន់នៃការអនុវត្តសេចក្តីជំនឿចំពោះការប្រែចិត្ត ?
- អាម៉ូលេកបាននិយាយថា ការអធិស្ឋានរបស់យើងនឹងមិនបានផ្តល់ប្រយោជន៍អ្វីដល់យើង ឬ គ្មានន័យអ្វីសម្រាប់យើងទេ ប្រសិនបើយើងមិនជួយអ្នកដទៃជុំវិញយើង (សូមមើល អាលម៉ា ៣៤:២៨) ។ តើអ្នកគិតថា ហេតុអ្វីបានជាវាពិត ?

ដើម្បីជួយសិស្សឲ្យគិតពីរបៀបបន្ថែមដែលយើងអាចអនុវត្តសេចក្តីជំនឿចំពោះការប្រែចិត្ត សូមឲ្យពួកគេឆ្លើយនឹងឧទាហរណ៍ខាងក្រោម ៖

១. យុវជនម្នាក់បានបង្កើនទម្លាប់នៃការប្រើភាសាមិនសមរម្យ ។ តើរបៀបណាខ្លះ ដែលគាត់ងាយបង្ហាញសេចក្តីជំនឿចំពោះការប្រែចិត្ត ដើម្បីមានសេរីភាពពីទម្លាប់នេះ ? (ចម្លើយអាចរួមមានការអធិស្ឋានសុំជំនួយ ការសុំឲ្យសមាជិកគ្រួសារ និងមិត្តភក្តិជួយ និងការចូលរួមក្នុងសកម្មភាពដែលអញ្ជើញឲ្យមានព្រះវិញ្ញាណ) ។

២. យុវនារីម្នាក់ និងយុវជនម្នាក់បានពាក់ព័ន្ធនឹងទំនាក់ទំនងដែលមិនសមរម្យមួយ ។ ពួកគេបានមានអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធបំផុតគំនិតដល់ពួកគេថា ត្រូវបញ្ចប់ទំនាក់ទំនងនេះភ្លាម ។ តើការធ្វើតាមការបំផុសនេះអាចតំណាងឲ្យសេចក្តីជំនឿចំពោះការប្រែចិត្តដោយរបៀបណា ? តើជំហានផ្សេងទៀតអ្វីខ្លះ ដែលពួកគេត្រូវធ្វើដើម្បីក្រាកដថា ពួកគេស្ថិតនៅលើផ្លូវដើម្បីបំពេញតាមការប្រែចិត្ត ? (ចម្លើយអាចរួមមានការស្វែងរកការដឹកនាំពីប៊ីស្សព ឬប្រធានសាខា និងការអធិស្ឋានសុំកម្លាំង និងការអភ័យទោស) ។

- តើការពន្យារពេលមានន័យយ៉ាងណា ? តើមូលហេតុអ្វីខ្លះ ដែលធ្វើឲ្យមនុស្សពន្យារពេល ?

សូមឲ្យសិស្សអាន អាលម៉ា ៣៤:៣៣ ដោយស្ងាត់ៗ ដោយរកមើលអ្វីដែលអាមូលេកបានព្រមានដល់ពួកសាសន៍សូរ៉ាកុំឲ្យពន្យារពេលធ្វើ ។ សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮពី អាលម៉ា ៣៤:៣២–៣៥ ។ នៅពេលពួកគេអាន សូមឲ្យសិស្សក្នុងថ្នាក់រកមើលលទ្ធផលនៃការពន្យារពេលការប្រែចិត្តរបស់យើង ។ នៅពេលសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរៀន សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***ជីវិតនេះគឺជាពេលវេលាសម្រាប់យើងដើម្បីរៀបចំទៅជួបនឹងព្រះ ។***

- តើអ្នកនឹងពន្យល់ពីសេចក្តីពិតនេះដល់នរណាម្នាក់ដោយរបៀបណា ?
- សូមស្រមៃថា អ្នកមានមិត្តម្នាក់ដែលមិនគោរពតាមព្រះបញ្ញត្តិខ្លះដោយមានចេតនា ប៉ុន្តែគ្រោងដើម្បីប្រែចិត្តក្រោយមក ។ តើអ្នកនឹងបង្រៀនមិត្តភក្តិនេះអ្វីខ្លះ ដោយផ្អែកលើអ្វីដែលអ្នកបានរៀនពីអាលម៉ា ៣៤:៣២–៣៥ ?

សូមពន្យល់ថា អាមូលេកមិនត្រឹមតែបានព្រមានពីលទ្ធផលនៃការពន្យារពេលនៃការប្រែចិត្តប៉ុណ្ណោះទេ គាត់ក៏បានបង្រៀនអំពីពរជ័យនៃការជ្រើសរើសដើម្បីប្រែចិត្តនាពេលឥឡូវ ។ សូមឲ្យសិស្សអាន អាលម៉ា ៣៤:៣០–៣១ ដោយស្ងាត់ៗ ហើយរកមើលពរជ័យនេះ ។

- នៅក្នុង អាលម៉ា ៣៤:៣១ តើការធានាអ្វីដែលត្រូវបានផ្តល់ទៅដល់អ្នកដែលប្រែចិត្តនាពេលឥឡូវ ? (« រំពេចនោះ ផែនការនៃសេចក្តីប្រោសលោះដ៏មហិមានឹងបានមកដល់អ្នក ») ។

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ិយដ៍ ឃេ ផាកគឺនៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« អ្នកមិនចាំបាច់ដឹងអ្វីៗមុនពេលព្រះចេស្តានៃដង្វាយធួននឹងធ្វើសម្រាប់អ្នកនោះទេ ។ សូមមានសេចក្តីជំនឿលើព្រះគ្រីស្ទ ; វាចាប់ផ្តើមធ្វើកិច្ចការនោះនៅថ្ងៃដែលអ្នកសុំ ! » (« Washed Clean »*Ensign,*ខែ ឧសភា ឆ្នាំ ១៩៩៧, ទំព័រ ១០) ។

- តើការយល់ពីការធានានេះនឹងជួយដល់យើងដោយរបៀបណា ? តើអ្នកមានអារម្មណ៍ថាដង្វាយធួនចាប់ផ្តើមធ្វើការសម្រាប់អ្នកនៅពេលអ្នកបានចាប់ផ្តើមទុកចិត្តលើវាតាមរបៀបណា ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហារ៉ុល ប៊ី លី ។ សូមឲ្យសិស្សស្តាប់រកនូវអ្វីដែលប្រធាន លី បានហៅថាជា « ព្រះបញ្ញត្តិដ៏សំខាន់បំផុត » ។

« ឥឡូវនេះ ប្រសិនបើអ្នកបានប្រព្រឹត្តខុស សូមចាប់ផ្តើមថ្ងៃនេះជាថ្ងៃនៃការផ្លាស់ប្តូរជីវិតរបស់អ្នក ។ សូមផ្លាស់ប្តូរអ្វីដែលអ្នកកំពុងធ្វើខុសនោះ ។ ព្រះបញ្ញត្តិដ៏សំខាន់បំផុតក្នុងចំណោមព្រះបញ្ញត្តិទាំងឡាយនៃព្រះគឺ ការណ៍នោះ ដែលអ្នកកំពុងមានការលំបាកបំផុតក្នុងការរក្សានៅថ្ងៃនេះ ។ ប្រសិនបើវាជាការណ៍មួយអំពីភាពមិនស្មោះត្រង់ ប្រសិនបើវាជាការណ៍មួយអំពីភាពមិនបរិសុទ្ធ ការមិនប្រាប់សេចក្តីពិត ថ្ងៃនេះគឺជាថ្ងៃសម្រាប់អ្នកដើម្បីធ្វើការនោះ រហូតដល់អ្នកអាចបានយកឈ្នះលើភាពទន់ខ្សោយនោះ ។ . . . សូមធ្វើវាឲ្យត្រឹមត្រូវ ហើយបន្ទាប់មកអ្នកចាប់ផ្តើមការណ៍មួយទៀតដែលពិបាកបំផុតសម្រាប់អ្នកដើម្បីធ្វើតាម » (*Teachings of Presidents of the Church: Harold B. Lee* | ឆ្នាំ ២០០០ |, ទំព័រ ៣០) ។

- យោងតាម ប្រធាន លី តើអ្វីគឺជាព្រះបញ្ញត្តិដ៏សំខាន់បំផុត ? ហេតុអ្វី ?

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ។ សូមឲ្យសិស្សបំពេញវានៅក្នុងសៀវភៅកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។

ថ្ងៃនេះ ព្រះបញ្ញត្តិដ៏សំខាន់បំផុតសម្រាប់ខ្ញុំគឺ . . .

ខ្ញុំនឹងចាប់ផ្តើមនាពេលឥឡូវដើម្បីអនុវត្តសេចក្តីជំនឿចំពោះការប្រែចិត្តដោយ . . .

អាលម៉ា ៣៥

ពួកសាសន៍សូរ៉ាដែលប្រែចិត្តទៅរស់នៅក្នុងចំណោមពួកសុចរិត

សូមសង្ខេប អាលម៉ា ៣៥ ដោយការពន្យល់ថា ពួកសាសន៍សូរ៉ាជាច្រើនបានប្រែចិត្តពីអំពើបាបរបស់ពួកគេ ។ ពួកគេត្រូវបានបណ្តេញចេញពីដែនដីដោយពួកអ្នកគ្រប់គ្រង និងពួកសង្ឃដ៏ទុច្ចរិតរបស់ពួកគេ ហើយពួកគេបានទៅរស់នៅក្នុងដែនដីយើស៊ុនជាមួយនឹងប្រជាជនអាំម៉ូន ។ ប្រជាជនអាំម៉ូនបានផ្តល់ដែនដីឲ្យពួកគេ ហើយពួកសាសន៍នីហ្វៃបានបញ្ជូនកងទ័ពទៅការពារពួកគេ ។

សូមថ្លែងទីបន្ទាល់ថា យើងអាចទទួលបានពរជ័យនៃដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ នៅពេលដែលយើងអនុវត្តសេចក្តីជំនឿចំពោះការប្រែចិត្ត ។ សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមគំរូនៃប្រជាជនអាំម៉ូន និងសាសន៍នីហ្វៃ ដោយការបង្ហាញសន្ដានចិត្ត និងការផ្តល់ការគាំទ្រដល់អ្នកដែលស្វែងរកដើម្បីប្រែចិត្ត ។

មេរៀនទី ៩៣

អាលម៉ា ៣៦

សេចក្តីផ្តើម

ក្រោយពីបេសកកម្មរបស់គាត់ចំពោះពួកសាសន៍សូរាំ អាលម៉ាបានណែនាំដល់កូនប្រុសរបស់ម្នាក់ៗ ។ ការណែនាំរបស់គាត់ដល់កូនប្រុសរបស់គាត់មាននៅក្នុង អាលម៉ា ៣៦និង៣៧ ។ អាលម៉ាបានថ្លែងទីបន្ទាល់ដល់ហេលេមិនថា ព្រះនឹងដោះលែងអ្នកដែលដាក់ទីទុកចិត្តទៅលើទ្រង់ ។ ដើម្បីបង្ហាញសេចក្តីពិតនេះ អាលម៉ាបានរៀបរាប់ពីបទពិសោធន៍របស់គាត់ជាច្រើនឆ្នាំកន្លងទៅ នៅពេលគាត់ត្រូវបានដោះលែងពីការឈឺចាប់នៃអំពើបាបរបស់គាត់តាមរយៈ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ គាត់ក៏បានប្រាប់ពីការខិតខំរបស់គាត់ដើម្បីនាំអ្នកដទៃឲ្យមកកាន់ព្រះគ្រីស្ទ និងទទួលបាននូវសេចក្តីអំណរនៃការប្រែចិត្តសម្រាប់ខ្លួនគេ ។

កំណត់ចំណាំ ៖ មេរៀនទី ៩៤ផ្តល់នូវឱកាសមួយសម្រាប់សិស្សបីនាក់ដើម្បីបង្រៀន ។ ប្រសិនបើអ្នកមិនទាន់បានរើសសិស្សទេ អ្នកអាចរើសសិស្សបីនាក់ឥឡូវ ហើយឲ្យពួកគេនូវច្បាប់ចម្លងនៃចំណែកនាំមេរៀនទី ៩៤ដែលបានរៀបចំដើម្បីឲ្យពួកគេអាចរៀបចំមេរៀននោះ ។ សូមលើកទឹកចិត្តពួកគេឲ្យសិក្សាមេរៀននេះប្រកបដោយការអធិស្ឋាន ហើយស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យពួកគេអាចដឹងពីរបៀបដើម្បីសម្របមេរៀននេះ ទៅនឹងតម្រូវការនៃមិត្តរួមថ្នាក់របស់គេ ។

សូមលើកទឹកចិត្តសិស្សឲ្យអធិស្ឋានសុំការដឹកនាំ នៅពេលបំពេញកិច្ចការនេះ

នៅពេលអ្នកដាក់កិច្ចការឲ្យសិស្ស ដូចជាការបង្រៀនផ្នែកមួយនៃមេរៀន សូមលើកទឹកចិត្តពួកគេឲ្យអធិស្ឋានសុំការដឹកនាំ នៅពេលពួកគេបំពេញកិច្ចការរបស់ពួកគេ ។ ការលើកទឹកចិត្តរបស់អ្នកនឹងបង្កើនទំនុកចិត្តរបស់គេ ដើម្បីឲ្យពួកគេអាចទទួលបានការបំភ្លឺតាមរយៈ ព្រះវិញ្ញាណ (សូមមើល គ .និង ស . ៦:១៤–១៥) ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៣៦:១–៥

អាលម៉ាបង្រៀនហេលេមិនអំពីព្រះចេស្តានៃព្រះក្នុងការដោះលែង

សូមឲ្យសិស្សគិតអំពីរបៀបវិជ្ជមានដែលទីបន្ទាល់ ឬ ការបង្រៀនដ៏ជាក់លាក់មួយពីឪពុកម្តាយដែលមានឥទ្ធិពលដល់ពួកគេ ។ សូមឲ្យសិស្សម្នាក់ ឬ ពីរនាក់ចែកចាយគំនិតរបស់ពួកគេដល់សិស្សផ្សេងទៀត ។

សូមពន្យល់ថា ជំពូកទី ៣៦–៤២ នៅក្នុងគម្ពីរអាលម៉ា រួមមានការណែនាំពីអាលម៉ាដល់កូនប្រសរបស់គាត់ទាំងឡាយ ។ ជំពូកទី ៣៦–៣៧ត្រូវបាននិយាយដល់លេហលេមិន ជំពូកទី ៣៨ត្រូវបាននិយាយដល់ សិ៊បឡុន ហើយជំពូកទី ៣៩–៤២ត្រូវបាននិយាយដល់ កូរីអានតុន ។

សូមលើកទឹកចិត្តសិស្សឲ្យស្រមៃថាខ្លួនគេនៅក្នុងតំណែរបស់ហេលេមិន នៅពេលគាត់បានស្តាប់ទីបន្ទាល់របស់ឪពុកគាត់នៅក្នុង អាលម៉ា ៣៦:១–៥ ។ សូមឲ្យសិស្សអានខគម្ពីរទាំងនេះដោយស្ងាត់ៗ ដោយរកមើលអ្វីដែលធ្វើឲ្យពួកគេរំភើបអំពីទីបន្ទាល់របស់អាលម៉ា ។

- នៅក្នុងខគម្ពីរទាំងនេះ តើអ្វីដែលធ្វើឲ្យអ្នករំភើបបំផុត ? ហេតុអ្វី ?

អាលម៉ា ៣៦:៦–២២

អាលម៉ារៀបរាប់ពីការបះបោររបស់គាត់ ហើយពន្យល់ពីរបៀបដែលគាត់បានទទួលការអភ័យទោស ។

សូមពន្យល់ថា ដោយធ្វើជាទីបន្ទាល់បន្ថែមទៀតនៃព្រះចេស្តានៃព្រះដើម្បីដោះលែងដល់អ្នកដែលបានដាក់ទីទុកចិត្តរបស់ពួកគេទៅលើទ្រង់ អាលម៉ាបានចែកចាយបទពិសោនធ៍របស់គាត់ពេលបានដោះលែងពីការឈឺចាប់នៃអំពើបាបរបស់គាត់ ។ សូមឲ្យសិស្សអានត្រួសៗក្នុង អាលម៉ា ៣៦:៦–៩ និងសង្ខេបអ្វីដែលបានកើតឡើងដល់អាលម៉ា នៅពេលគាត់និងពួកបុត្រារបស់ម៉ូសាយបានចេញទៅរៀបនឹងបំផ្លាញសាសនាចក្រ ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣៦:១០ ពួៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពីរយៈពេលដែលអាលម៉ាបានរងទុក្ខពីអំពើបាបរបស់គាត់ ។ សូមពន្យល់ថា នៅក្នុង អាលម៉ា ៣៦:១១–១៧ យើងទទួលបានដំណើររឿងដ៏លម្អិតច្រើនអំពីអ្វីដែលអាលម៉ាបានជួបអំឡុងពេលបីថ្ងៃ និងបីយប់នៃការរងទុក្ខរបស់គាត់ ជាងអ្វីដែលយើងដឹងនៅក្នុងដំណើររឿងផ្សេងទៀតនៃការប្រែចិត្តរបស់គាត់ (សូមមើល ម៉ូសាយ ២៧និងអាលម៉ា ៣៨) ។ សូមឲ្យសិស្សធ្វើការជាដៃគូ ។ សូមឲ្យដៃគូទាំងឡាយសិក្សា អាលម៉ា ៣៦:១១–១៧ ដោយរកមើលសម្ពីរបស់អាលម៉ានៃការភ័យខ្លាច ឬការឈឺចាប់ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគូរគូសចំណាំអ្វីដែលពួកគេរកឃើញ ។ សូមឲ្យសិស្សរៀបរាប់ពីពាក្យ និងឃ្លាទាំងឡាយដែលពួកគេរកឃើញ ។ (អ្នកអាចសរសេរវានៅលើក្តារខៀន ។) អ្នកអាចសូរសំណួរខាងក្រោមដើម្បីធ្វើឲ្យសិស្សយល់កាន់តែច្បាស់អំពីពាក្យ និងឃ្លាដែលពួកគេរៀបរាប់ ។

- តើអ្នកគិតថា ឃ្លា (ឬពាក្យ) នោះមានន័យយ៉ាងណា ? តើអ្វីដែលបណ្តាលឲ្យអាលម៉ាមានអារម្មណ៍យ៉ាងនោះ ?

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់អំពីពាក្យ *ញាំញី កើតទុក្ខ*និង*ការទុក្ខវេទនា* សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធានបិយដ៏ ឃេ ជាកកឺនៃក្ងរុ៉ម់នៃពួកសាវកដប់ពីរនាក់ ៖

« *ញាំញី* មានន័យថា ‹ ដាក់ទោស › ។ ពីបុរាណកាល ទ្រុងគឺជាគម្រោងដែលជនរងគ្រោះត្រូវដាក់កជើង និងកដៃចងជាប់នឹងប្រដាប់រវៃដែលវាអាចបណ្តាលឲ្យមានការឈឺចាប់ជាខ្លាំង ។

« រនាស់គឺជាគម្រោងដែលមានដែកគោលនៅជាប់នឹងវា ។ នៅពេលវាអូសរាស់កាត់ដី វាជីកបំបែកដីទៅជាបំណែកតូចៗ ។ ព្រះគម្ពីរនិយាយពីព្រលឹង និងគំនិតដែល ‹ កើតទុក្ខ › នឹងការជាប់ទោសជាញឹកញាប់ ។

« *ការទុក្ខវេទនា* មានន័យថា ‹ ត្របាញ់ចូលគ្នា › ជារបៀបដាក់ទោសដ៏ឈឺចាប់ជាខ្លាំង ដែលសូម្បីតែអ្នកសុចរិតក៏នឹងសារភាពដែរ » (« The Touch of the Master's Hand »*Ensign,*ខែ ឧសភា ឆ្នាំ ២០០១, ទំព័រ ២៣) ។

- តើបទពិសោធន៍របស់អាលម៉ាអាចបង្រៀនយើងអ្វីខ្លះអំពីឥទ្ធិពលនៃអំពើបាប ? (សូមជួយសិស្សឲ្យរកឃើញសេចក្តីពិតខាងក្រោមនេះ ៖ **អំពើបាបដឹកនាំទៅរកការឈឺចាប់ ការរងទុក្ខ និងការសោកស្តាយដ៏ខ្លាំងបំផុត) ។**
- តើវាបានប្រាប់ថា អាលម៉ាបានជួបនឹងការឈឺចាប់ និងការសោកស្តាយចំពោះអំពើបាបរបស់គាត់ភ្លាម ៗបន្ទាប់ពីការប្រព្រឹត្តវាទេ ? តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីយល់ថា យើងមិនអាចមានអារម្មណ៍ពីឥទ្ធិពលនៃអំពើបាបរបស់យើងភ្លាម ៗនោះទេ ?

សូមឲ្យសិស្សសញ្ជឹងគិតអំពីបទពិសោនធ៍ដែលពួកគេបានមានអារម្មណ៍ពីការឈឺចាប់ ឬការសោកស្តាយចំពោះអំពើបាបរបស់ពួកគេ ។ បន្ទាប់មក សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ជាកកឺ ៖

« យើងម្នាក់ ៗយ៉ាងហោចណាស់បានភ្លក់នូវការឈឺចាប់នៃសតិសម្បជញ្ញៈដែលកើតក្រោយពីកំហុសរបស់យើង ។ . . .

« ប្រសិនបើអ្នកពោរពេញដោយអារម្មណ៍ក្រៀមក្រំដោយសារកំហុស ឬការបាក់ទឹកចិត្ត ដោយសារការបរាជ័យ ឬការអាម៉ាស់ នោះមានការព្យាបាលមួយ » (« The Touch of the Master's Hand » ទំព័រ ២២) ។

សូមបង្ហាញថា ខណៈពេលដែលអាលម៉ាកំពុងមានអារម្មណ៍ឈឺចាប់ដ៏ខ្លាំង និងការសោកស្តាយចំពោះអំពើបាបរបស់គាត់ គាត់បានចងចាំដល់ការព្យាបាលការឈឺចាប់របស់គាត់ ។

- យោងតាម អាលម៉ា ៣៦:១៧ តើគាត់បានចងចាំអ្វី ?

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣៦:១៨ ពួ ៗ ។ សូមឲ្យសិស្សរកមើលអ្វីដែលអាលម៉ាបានធ្វើដើម្បីធ្វើសកម្មភាពតាមការបង្រៀនរបស់ឪពុកគាត់ ។ ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាប់នូវខគម្ពីរទាំងនេះ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដែហ្ស្រី អ័រ ហូឡិននៃក្រុ៉មនៃពួកសាវកដប់ពីរនាក់ ៖

« អាលម៉ាបានរំភើបនឹងការបង្រៀនរបស់ឪពុកគាត់ ប៉ុន្តែវាសំខាន់ជាពិសេសថា ការព្យាការណ៍ដែលគាត់បានចងចាំគឺជាការណ៍មួយដែលទាក់ទងនឹង ‹ ការយាងមកនៃព្រះយេស៊ូវគ្រីស្ទតែមួយ ជាព្រះរាជបុត្រានៃព្រះ ដែលត្រូវធ្វើឲ្យធួននឹងអំពើបាបនៃពិភពលោក › ។ (អាលម៉ា ៣៦:១៧) ។ នោះគឺជាព្រះនាម ហើយនោះគឺជាសារលិខិតដែលមនុស្សគ្រប់រូបត្រូវតែពួ ។ . . . មិនថាការអធិស្ឋានណាផ្សេងទៀតដែលយើងបានធ្វើ មិនថាតម្រូវការផ្សេងទៀតដែលយើងមាន អ្វី ៗទាំងអស់គឺពឹងផ្អែកលើការអង្វរកនោះ ៖ ‹ ឱ ព្រះយេស៊ូវអើយ ព្រះអង្គជាព្រះរាជបុត្រានៃព្រះ សូមព្រះអង្គមានសេចក្តីមេត្តាករុណាមកលើទូលបង្គំផង › ។ ទ្រង់ត្រូវបានរៀបចំឲ្យផ្តល់សេចក្តីមេត្តាករុណានោះ ។ ទ្រង់បានប្រទានជីវិតរបស់ព្រះអង្គផ្ទាល់ដើម្បីផ្តល់សេចក្តីមេត្តាករុណា » (*However Long and Hard the Road* [ឆ្នាំ ១៩៨៥], ទំព័រ ៨៥) ។

- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីមិនគ្រាន់តែរៀនអំពីព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសុំរកពរជ័យនៃដង្វាយធួនរបស់ទ្រង់ផងដែរ ?

សូមណែនាំសិស្សឲ្យគិតដោយស្ងាត់ ៗថា តើពួកគេបានអធិស្ឋានដើម្បីទទួលបានពរជ័យនៃដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ រួមមានទាំងពរជ័យនៃការអភ័យទោសផងដែរឬទេ ។

សូមឲ្យសិស្សសិក្សា អាលម៉ា ៣៦:១៩–២២ ដោយស្ងាត់ ៗ ដោយរកមើលពាក្យ និងឃ្លាដែលរៀបរាប់ពីរបៀបដែលអារម្មណ៍របស់អាលម៉ាបានផ្លាស់ប្តូរក្រោយពីគាត់បានអធិស្ឋានសុំសេចក្តីមេត្តាករុណា ។

- តើពាក្យ ឬ ឃ្លាណាដែលអ្នករកឃើញថា បានពិពណ៌នាពីអារម្មណ៍ដែលអាលម៉ាបានផ្លាស់ប្តូរ ?

សូមសួរសំណួរខាងក្រោមអំពីពាក្យ និងឃ្លានីមួយ ៗដែលសិស្សបានរកឃើញ ៖

- តើឃ្លា (ឬ ពាក្យ) នោះបង្រៀនអ្នកអំពីព្រះចេស្តានៃដង្វាយធួននៃព្រះអង្គសង្រ្គោះអ្វីខ្លះ ? (នៅពេលសិស្សឆ្លើយ សូមជួយពួកគេឲ្យឃើញថា មិនមែនគ្រាន់តែការឈឺចាប់របស់អាលម៉ាត្រូវបានដកចេញពីគាត់ទេ ប៉ុន្តែគាត់ថែមទាំងពោរពេញដោយសេចក្តីអំណរទៀតផង ។)

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *ប្រសិនបើយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ នោះទ្រង់នឹង . . .*

- ចេញពីបទពិសោធន៍របស់អាលម៉ា តើយើងអាចរៀនអ្វីដែលព្រះអម្ចាស់ធ្វើសម្រាប់យើង នៅពេលយើងពិតជាប្រែចិត្តនោះ ? (សិស្សអាចចែកចាយគោលការណ៍ខុសគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេបង្ហាញថា **ប្រសិនបើយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ នោះទ្រង់នឹងដោះលែងយើងពីការឈឺចាប់នៃអំពើបាបរបស់យើង ហើយបំពេញយើងដោយសេចក្តីអំណរ ។**អ្នកអាចបំពេញប្រយោគនៅលើក្តារខៀន) ។
- តើយើងអាចធ្វើអ្វីដើម្បីអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យយើងអាចត្រូវដោះលែងពីអារម្មណ៍នៃការឈឺចាប់ ឬការសោកស្តាយដែលបង្កដោយអំពើបាបរបស់យើង ?

សូមអានស្ថានភាពខាងក្រោមពួ ៗ ហើយសូមឲ្យសិស្សគិតពីរបៀបដែលពួកគេនឹងឆ្លើយតប ៖

មិត្តម្នាក់ដែលបានកំពុងអានព្រះគម្ពីរមរមនបង្ហាញការបារម្ភអំពីពាក្យសម្ពីរបស់អាលម៉ាក្នុង អាលម៉ា ៣៦:១៩ ។ មិត្តរបស់អ្នកសួរអ្នកថា « ប្រសិនបើខ្ញុំអាចចាំអំពើបាបរបស់ខ្ញុំ និងនៅតែមានអារម្មណ៍សោកស្តាយចំពោះវា តើវាមានន័យថា ខ្ញុំមិនត្រូវបានអភ័យទោសឲ្យមែនទេ ? »

សូមឲ្យសិស្សពន្យល់ពីរបៀបដែលបទពិសោធន៍របស់អាលម៉ាទាក់ទងនឹងស្ថានភាពនេះ ។ ក្រោយពីសិស្សបានឆ្លើយហើយ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរ អេស្ង អុជដូហ្ស នៃគណៈប្រធានទីមួយ ៖

« សាតាំងនឹងព្យាយាមធ្វើឲ្យយើងជឿថា អំពើបាបរបស់យើងនៅតែមិនបានត្រូវអភ័យទោសឲ្យដោយសារ *យើង* អាចចងចាំវា ។ សាតាំងគឺជាមនុស្សកុហក វាព្យាយាមធ្វើឲ្យទស្សនវិស័យរបស់យើងព្រិល ហើយដឹកនាំយើងចេញពីផ្លូវនៃការប្រែចិត្ត និងការអភ័យទោស ។ ព្រះមិនបានសន្យាថា *យើង* នឹងមិនចងចាំដល់អំពើបាបរបស់យើងនោះទេ ។ ការចងចាំនឹងជួយយើងឲ្យចៀសវាងការធ្វើកំហុសដដែលៗម្តងទៀត ។ ប៉ុន្តែប្រសិនបើយើងនៅតែបន្តពិត និងស្មោះត្រង់ នោះការចងចាំងអំពើបាបរបស់យើងនឹងត្រូវលុបឆ្លងតាមពេលវេលា ។ ការណ៍នេះនឹងជាផ្នែកនៃដំណើរការការព្យាបាល និងការបន្សុទ្ធដ៏ចាំបាច់ ។ អាលម៉ាបានថ្លែងទីបន្ទាល់ថា ក្រោយពីគាត់បានស្រែករកព្រះយេស៊ូវសុំសេចក្តីមេត្តាករុណា គាត់នៅតែអាចចាំពីអំពើបាបរបស់គាត់ ប៉ុន្តែការចងចាំអំពើបាបរបស់គាត់មិនបានធ្វើឲ្យគាត់ពិបាក និងដាក់ទោសគាត់ទៀតឡើយ ដោយសារគាត់បានដឹងថា គាត់ត្រូវបានអភ័យទោស (សូមមើល អាលម៉ា ៣៦:១៧–១៩) ។

« វាគឺជាការទទួលខុសត្រូវរបស់យើងដើម្បីចៀសវាងអ្វីៗដែលនឹងនាំយកនូវការចងចាំដ៏មានបាបចាស់ទាំងឡាយ ។ នៅពេលយើងបន្ត មាន ‹ ចិត្តសង្រេង និងវិញ្ញាណទន់ទាប › (នីហ្វៃទី ៣ ១២:១៩) យើងអាចទុកចិត្តថាព្រះនឹង ‹ លែងចងចាំ | អំពើបាបរបស់យើង | ទៀតហើយ › » (« Point of Safe Return » *Ensign* ឬ *លេអាហូណា*, ខែ ឧសភា ឆ្នាំ ២០០៧, ទំព័រ ១០១) ។

- ដោយផ្អែកលើប្រសាសន៍របស់ប្រធាន អុជដូហ្ស តើអ្នកនឹងពន្យល់ថា « ការអស់កើតទុក្ខដោយការនឹកឃើញអំពើបាបរបស់ខ្លួនទៀតទៅ » ដោយរបៀបណា ? (អាលម៉ា ៣៦:១៩) ។

សូមថ្លែងទីបន្ទាល់ថា ប្រសិនបើយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ នោះទ្រង់នឹងដោះលែងយើងពីការឈឺចាប់នៃអំពើបាបរបស់យើង ហើយបំពេញយើងដោយសេចក្តីអំណរ ។ សូមលើកទឹកចិត្តសិស្សឲ្យគិតអំពីរបៀបដែលពួកគេអាចអនុវត្តអ្វីដែលពួកគេបានរៀនពីបទពិសោធន៍របស់អាលម៉ា ។ បើមានពេល សូមឲ្យសិស្សច្រៀងបទ « ខ្ញុំរកក្តីសុខឯណា ? » (ទំនុកតម្កើង ទំព័រ ៦៩) ។

អាលម៉ា ៣៦:២៣–៣០

អាលម៉ាពន្យល់ពីមូលហេតុដែលគាត់បម្រើដោយឥតឈប់ឈរ ដើម្បីនាំអ្នកដទៃឲ្យទទួលការប្រែចិត្ត

ដើម្បីជួយសិស្សឲ្យយល់ពីមូលហេតុដែលអាលម៉ាបានបម្រើដើម្បីនាំអ្នកដទៃឲ្យទទួលការប្រែចិត្ត សូមគិតពីការប្រើសកម្មភាពខាងក្រោម ។ (ប្រសិនបើវាមិនអាចអនុវត្តសកម្មភាពនេះសម្រាប់ថ្នាក់របស់អ្នកបានទេ អ្នកអាចរៀបរាប់ពីសកម្មភាពនេះបាន) ។

សូមបង្ហាញបង្អែម (ដូចជានំ ឬ ស្ករគ្រាប់) ហើយសួរថា តើនរណាម្នាក់ក្នុងថ្នាក់នេះចូលចិត្តបង្អែមប្រភេទនេះ ។ សូមខាំមួយម៉ាត់ ហើយសូមពិពណ៌នាថាតើវាឆ្ងាញ់យ៉ាងណា ។ សូមប្រាប់សិស្សក្នុងថ្នាក់ថា បង្អែមនេះឆ្ងាញ់ខ្លាំងណាស់ ដែលអ្នកត្រូវចែកចាយវាដល់សិស្សក្នុងថ្នាក់ទាំងមូល ។ សូមបង្ហាញបង្អែមដដែលបន្តែមទៀត ហើយសួរថា តើនរណាផ្សេងទៀតចង់ហូបវា ។ សូមចែកចាយបង្អែមនេះដល់មនុស្សគ្រប់គ្នាដែលចង់ហូបវា ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣៦:២៣–២៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរបៀបដែលសកម្មភាពនៃការភ្លក់នេះទាក់ទងនឹងបទពិសោធន៍របស់អាលម៉ាបន្ទាប់ពីការប្រែចិត្តជឿរបស់គាត់ ។

- តើសកម្មភាពរបស់អាលម៉ាស្រដៀងនឹងសកម្មភាពនៃការភ្លក់នេះដោយរបៀបណា ? តើអាលម៉ាបានចង់ឲ្យអ្នកដទៃភ្លក់អ្វី ?

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣៦:២៥–២៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលការខិតខំរបស់អាលម៉ាដើម្បីបង្រៀនដំណឹងល្អជះឥទ្ធិពលដល់គាត់ និងអ្នកដទៃ ។

- តើការបង្រៀនរបស់អាលម៉ាបានជះឥទ្ធិពលដល់គាត់ និងអ្នកដទៃដោយរបៀបណា ?
- តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីឧទាហរណ៍ទាំងនេះ ? (សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែសូមប្រាកដថាពួកគេបង្ហាញថា **យើងអាចទទួលបានសេចក្តីអំណរដ៏អស្ចារ្យ នៅពេលយើងស្វែងរកនាំអ្នកដទៃមកកាន់ព្រះគ្រីស្ទ**) ។

សូមសង្ខេប អាលម៉ា ៣៦:២៧–៣០ ដោយការពន្យល់ថា អាលម៉ាបានថ្លែងទីបន្ទាល់ម្តងទៀតដល់ហេលេមិនថា ព្រះអម្ចាស់នឹងដោះលែងអ្នកដែលដាក់ទីទុកចិត្តរបស់ពួកគេលើទ្រង់ ។ សូមថ្លែងទីបន្ទាល់អំពីសេចក្តីអំណរដែលយើងអាចទទួលបាន នៅពេលយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងនៅពេលយើងណែនាំអ្នកដទៃឲ្យធ្វើដូច្នោះដែរ ។ ដើម្បីជួយសិស្សឲ្យអនុវត្តអ្វីដែលពួកគេបានរៀនពី អាលម៉ា ៣៦សូមឲ្យពួកគេបំពេញសកម្មភាពខាងក្រោមមួយ ។ (អ្នកអាចសរសេរវានៅលើក្តារខៀន) ។

១. សូមគិតថាតើអ្នកបានមានអារម្មណ៍ថាព្រះអង្គសង្គ្រោះដោះលែងអ្នកពីអំពើបាប ហើយបំពេញអ្នកដោយសេចក្តីអំណរទេ ។ សូមពន្យល់អ្វីដែលអ្នកនឹងធ្វើ ដើម្បីឲ្យអ្នកអាចទទួលបានពរជ័យទាំងនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក ។

២. សូមគិតដល់នរណាម្នាក់ (ដូចជា មិត្តភក្តិ បងប្អូនបង្កើត ឬ សមាជិកវួដម្នាក់) ដែលអាចទទួលប្រយោជន៍ពីទីបន្ទាល់របស់អ្នកអំពីព្រះអង្គសង្គ្រោះ ។ សូមសរសេរសំបុត្រមួយទៅបុគ្គលនេះ ហើយបញ្ចូលនូវទីបន្ទាល់របស់អ្នកអំពីរបៀបដែលព្រះយេស៊ូវគ្រីស្ទអាចដោះលែងយើងចេញពីការឈឺចាប់នៃអំពើបាប ហើយបំពេញយើងដោយសេចក្តីអំណរ ។

អាលម៉ា ៣៧

សេចក្តីផ្តើម

អាលម៉ាបានបន្តការណែនាំដល់កូនប្រុសរបស់គាត់ ហេលេមិន និងបានឲ្យហេលេមិនទទួលខុសត្រូវលើកំណត់ត្រាដ៏ពិសិដ្ឋទាំងឡាយ ។ គាត់បានរំឭកហេលេមិនថា ព្រះគម្ពីរបានក្លាយជារបៀបនៃការនាំពួកសាសន៍លេមិនរាប់ពាន់នាក់មកកាន់ព្រះអម្ចាស់រួចហើយ ហើយគាត់បានព្យាករណ៍ថា ព្រះអម្ចាស់បានមានព្រះបំណងដ៏មហិមាសម្រាប់កំណត់ត្រានេះនៅក្នុងអនាគតកាល ។ អាលម៉ាបានបង្រៀនកូនប្រុសរបស់គាត់អំពីអ្វីដែលត្រូវបង្រៀនដល់ប្រជាជន ។ ដោយការប្រៀបធៀបព្រះបន្ទូលនៃព្រះគ្រីស្ទទៅនឹងលេអាហូណា គាត់បានបំផុសហេលេមិនអំពីសារសំខាន់នៃការរកមើលវាសម្រាប់ការដឹកនាំ ។

កំណត់ចំណាំ ៖ មេរៀននេះផ្តល់នូវឱកាសមួយសម្រាប់សិស្សបីនាក់ដើម្បីបង្រៀនដល់សិស្សក្នុងថ្នាក់ ។ ដើម្បីជួយរៀបចំសិស្សទាំងនេះឲ្យបង្រៀន សូមចែកវគ្គចម្លងដៃលគេត្រូវបង្រៀនមួយដល់សិស្សម្នាក់ៗមួយថ្ងៃ ឬពីរថ្ងៃជាមុន ។ ឬ អ្នកអាចជ្រើសរើសដើម្បីបង្រៀនវគ្គទាំងនេះដោយខ្លួនឯង ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៣៧

អាលម៉ាប្រគល់កំណត់ត្រាទាំងឡាយដល់ហេលេមិន ណែនាំគាត់ឲ្យរក្សាព្រះបញ្ញត្តិទាំងឡាយ ហើយរំឭកគាត់ថា លេអាហូណាជួយតាមរយៈសេចក្តីជំនឿ

សូមចម្លងតារាងខាងក្រោមនៅលើក្តារខៀន ៖

កិច្ចការតូចតាច និងងាយ	⟶	ឥទ្ធិពលដ៏ខ្លាំង

សូមឲ្យសិស្សសរសេរនៅលើក្តារខៀននូវកិច្ចការតូចតាច និងងាយៗនានាដែលមានអានុភាពដ៏ខ្លាំងសម្រាប់ការល្អនៅក្នុងជីវិតរបស់ពួកគេ ។ អ្នកអាចសុំឲ្យពួកគេពន្យល់ពីចម្លើយរបស់ពួកគេ ។

សូមពន្យល់ថា អាលម៉ា ៣៧ រួមមានការណែនាំរបស់អាលម៉ាដើម្បីជួយដល់កូនប្រុសរបស់គាត់ហេលេមិនឲ្យរៀបចំដើម្បីក្លាយជាអ្នកថែរក្សាកំណត់ត្រាដ៏ពិសិដ្ឋបន្ទាប់ ។ អាលម៉ាបង្រៀនគាត់អំពីតួនាទីនៃកិច្ចការតូចតាច និងងាយនានានៅក្នុងកិច្ចការរបស់ព្រះអម្ចាស់ ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣៧:៦–៧ ឮៗ ។

តើយើងរៀនអ្វីខ្លះពីខគម្ពីរទាំងនេះអំពីតម្លៃ « កិច្ចការតូចតាច និងងាយ » ? (សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរបង្ហាញសេចក្តីពិតថា ព្រះអម្ចាស់ធ្វើការតូចតាច និងងាយ មានន័យថានាំមកនូវគោលបំណងដ៏អស់កល្បរបស់ទ្រង់ ។)

សូមឲ្យសិស្សអាន អាលម៉ា ៣៧:១–៥ ដោយស្ងាត់ៗ ដោយរកមើលគំរូនៃកិច្ចការតូចតាច និងងាយមួយដែលអាចមានឥទ្ធិពលដ៏ខ្លាំងក្នុងជីវិតរបស់មនុស្ស (កំណត់ត្រាដ៏ពិសិដ្ឋ ឬ ព្រះគម្ពីរ) ។ ក្រោយពីសិស្សរៀបរាប់អ្វីដែលពួកគេបានរកឃើញហើយ សូមសរសេរពាក្យ *ព្រះគម្ពីរ* នៅលើក្តារខៀននៅក្រោម *កិច្ចការតូចតាច និងងាយ* ។

សូមឲ្យសិស្សសិក្សា អាលម៉ា ៣៧:៨–១០ រកមើលរបៀបដែលព្រះគម្ពីរបានមានឥទ្ធិពលដល់ប្រជាជននៃព្រះគម្ពីរមរមន ។ នៅពេលសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ អ្នកអាចសរសេរចម្លើយរបស់ពួកគេនៅក្រោម *ឥទ្ធិពលដ៏ខ្លាំង* ។

- **តើព្រះគម្ពីរបានមានឥទ្ធិពលលើជីវិតរបស់អ្នកតាមរបៀបណា ?**

សូមសង្ខេប អាលម៉ា ៣៧:១១–៣២ ដោយការពន្យល់ថា អាលម៉ាបានបង្រៀនហេលេមិនថា ព្រះអម្ចាស់នឹងបង្ហាញព្រះចេស្តារបស់ទ្រង់ក្នុងពេលការលេចចេញនៃព្រះគម្ពីរមរមន ។ គាត់បានឲ្យហេលេមិនធ្វើតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ និងរក្សាកំណត់ត្រាដោយប្រុងប្រយ័ត្ន ។ គាត់ក៏បានបង្រៀនហេលេមិនឲ្យប្រើកំណត់ត្រាដើម្បីបង្រៀនប្រជាជន និងចៀសវាងការបង្ហាញសេចក្តីលម្អិតទាំងអស់នៃសេចក្តីទុច្ចរិតរបស់សាសន៍យ៉ាំរេឌ និងការបង្ហាញពីការបំផ្លាញ ។

សូមឲ្យសិស្សសិក្សា អាលម៉ា ៣៧:១៣–១៦ ដោយស្ងាត់ៗ ដោយរកមើលគោលការណ៍ដែលអាលម៉ាបានបង្រៀនហេលេមិន នៅពេលគាត់បានឲ្យហេលេមិនទទួលបន្ទុកលើកំណត់ត្រាទាំងឡាយ ។ (សិស្សអាចចែកចាយគោលការណ៍ជាច្រើន ប៉ុន្តែសូមប្រាកដថាចម្លើយរបស់ពួកគេបង្ហាញថា ប្រសិនបើយើងគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ទ្រង់នឹងជួយយើងឲ្យសម្រេចនូវភារកិច្ចរបស់យើង ។ អ្នកអាចសួរពីរបៀបដែលគោលការណ៍នេះទាក់ទងនឹងគំនិតថា កិច្ចការតូចតាច និងងាយអាចមានឥទ្ធិពលដ៏ខ្លាំង) ។

មេរៀននេះទាំងស្រុងត្រូវបានបង្កើតដើម្បីបង្រៀនដោយសិស្សបីនាក់ ។ ប្រសិនបើមានសិស្សច្រើន សូមឲ្យគ្រូបង្រៀនដែលជាសិស្សនោះផ្លាស់ទៅកន្លែងបីខុសគ្នានៅក្នុងបន្ទប់ ។ សូមបំបែកសិស្សជាបីក្រុម ។ សូមឲ្យក្រុមនីមួយៗយកព្រះគម្ពីរ សៀវភៅសរសេរ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ និងប៊ិច ឬខ្មៅដៃ ហើយប្រជុំគ្នានឹងគ្រូបង្រៀនដែលជាសិស្សម្នាក់ ។ ក្រោយពីគ្រូបង្រៀនដែលជាសិស្សនោះបានបញ្ចប់មេរៀនរបស់ពួកគេហើយ ក្រុមនឹងត្រូវប្តូរ ។ ប្រសិនបើមានសិស្សតិច គ្រូបង្រៀនដែលជាសិស្សអាចប្តូរវេនគ្នាបង្រៀនដល់សិស្សក្នុងថ្នាក់ទាំងមូល ។ ក្នុងករណីទាំងពីរ គ្រូបង្រៀនដែលជាសិស្សអាចចំណាយពេលប្រហែលប្រាំពីរនាទីដើម្បីបង្រៀនមេរៀន និងដឹកនាំការពិភាក្សា ។

គ្រូបង្រៀនដែលជាសិស្សទី ១—អាលម៉ា ៣៧:៣៣–៣៤

សូមឲ្យសិស្សដែលជាមិត្តរបស់អ្នកគិតអំពីអ្នកដឹកនាំក្នុងសាសនាចក្រក្នុងស្រុក ឬ អ្នកមានសិទ្ធិអំណាចទូទៅដែលបានបង្រៀនពួកគេនូវអ្វីដែលបានធ្វើឲ្យមានភាពខុសគ្នានៅក្នុងជីវិតរបស់ពួកគេ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីដែលអ្នកដឹកនាំនេះបានបង្រៀន និងបៀបដែលវាបានជះឥទ្ធិពលដល់ពួកគេ ។ អ្នកអាចចែកចាយគំរូមួយពីជីវិតរបស់អ្នក ។

សូមឲ្យសិស្សពីរនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៣៧:៣៣–៣៤ ។ សូមឲ្យសិស្សផ្សេងទៀតមើលតាម ដោយរកមើលអ្វីដែលអាលម៉ាបានបង្រៀនដល់ហេលេមិនឲ្យបង្រៀនដល់ប្រជាជន ។ អ្នកអាចស្នើថា ពួកគេគូរចំណាំឃ្លា « បង្រៀនពួកគេ » និង « បង្រៀនពួកគេឲ្យ » នៅពេលពួកគេអាន ។ នៅលើក្តារខៀន ឬ ក្រដាសមួយ សូមសរសេរ *ការបង្រៀនរបស់អ្នកដឹកនាំសាសនាចក្រ* ។នៅពេលសិស្សបានបញ្ចប់ការអានខគម្ពីរហើយ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។ សូមសរសេរចម្លើយរបស់ពួកគេក្រោម *ការបង្រៀនរបស់អ្នកដឹកនាំសាសនាចក្រ* ។សូមសួរសំណួរខាងក្រោម ៖

- តើការបង្រៀនទាំងនេះអាចជួយដល់យើងសព្វថ្ងៃនេះជាពិសេសដោយរបៀបណា ? ហេតុអ្វី ?

សូមឲ្យសិស្សដែលជាមិត្តរបស់អ្នកមើលទៅឃ្លាក្នុង អាលម៉ា ៣៧:៣៤ ដើម្បីរកមើលពរជ័យអ្វីដែលមកពីការធ្វើតាមការបង្រៀនរបស់អ្នកដឹកនាំសាសនាចក្រ ។ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***ដោយការធ្វើតាមការបង្រៀនរបស់អ្នកដឹកនាំសាសនាចក្រ យើងអាចនឹងបានសេចក្តីសង្រ្គោះដល់ព្រលឹងរបស់យើង*** ។សូមសួរពួកគេថាតើ « បានសេចក្តីសង្រ្គោះដល់ព្រលឹងរបស់យើង » មានន័យយ៉ាងណា ? (ចម្លើយអាចរួមមានការមានសេរីភាពពីលទ្ធផលនៃអំពើបាប ការទទួលបានសន្តិភាពពីព្រះវិញ្ញាណ និងការទទួលបានពរជ័យឲ្យមានកម្លាំងដើម្បីតស៊ូ និងយកឈ្នះនូវឧបសគ្គទាំងឡាយ) ។

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីរបៀបដែលគោលការណ៍នេះពិតនៅក្នុងជីវិតរបស់អ្នក ។ ប្រសិនបើអ្នកមានពេលបន្ថែម សូមឲ្យអ្នកដទៃចែកចាយទីបន្ទាល់របស់ពួកគេអំពីគោលការណ៍នេះ ។

គ្រូបង្រៀនដែលជាសិស្សទី ១—អាលម៉ា ៣៧:៣៥–៣៧

សូមពន្យល់ដល់សិស្សដែលជាមិត្តរបស់អ្នកថា វាជាទូទៅសម្រាប់អ្នកដែលដាំដើមឈើតូចៗត្រូវតែចង ឬ ទាក់កូនឈើតូចនោះទៅនឹងមែកមួយ ហើយបន្ទាប់មកស្រាយវាចេញ នៅពេលដើមឈើនោះធំ ។ សូមសួរពួកគេថា ហេតុអ្វីបានជាពួកគេគិតថា វាត្រូវធ្វើដូច្នោះ ។ បន្ទាប់មក សូមអានរឿងខាងក្រោមអំពីដើមឈើមួយដែលប្រធាន គរដុន ប៊ី ហ៊ិងគ្លី បានដាំនៅក្នុងសួនច្បាររបស់គាត់ ៖

ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានដាំកូនឈើមួយក្បែរផ្ទះរបស់គាត់ ក្រោយពីគាត់បានរៀបការរួច ។ គាត់មិនសូវយកចិត្តទុកដាក់នឹងវាប៉ុន្មានទេ នៅពេលច្រើនឆ្នាំកន្លងទៅ ។ ថ្ងៃមួយ គាត់បានកត់សម្គាល់ឃើញថា ដើមឈើនោះទ្រេត ហើយទ្រេទៅទិសខាងលិច ។ គាត់បានព្យាយាមទាញវាឲ្យត្រង់ ប៉ុន្តែដើមវាធំពេក ។ គាត់បានព្យាយាមដោយប្រើខ្សែពួរមួយ និងរ៉កជាច្រើនដើម្បីតម្រង់វា ប៉ុន្តែវាមិនពត់សោះឡើង ។ ទីបញ្ចប់ គាត់បានយករណារ ហើយកាត់មែកដ៏ធ្ងន់ដែលទោរទៅទិសខាងលិច ដោយបន្សល់នូវស្នាមរណារដ៏អាក្រក់ ។ ក្រោយមក គាត់បាននិយាយអំពីដើមឈើនោះ ៖

« ជាកន្លះសតវត្សរ៍កន្លងទៅ តាំងពីខ្ញុំបានដាំដើមឈើនោះ ។ . . . កាលពីថ្ងៃនោះ ខ្ញុំបានមើលទៅដើមឈើនោះម្តងទៀត ។ វាធំ ។ វាង វាល្អជាងមុន ។ វាជាគ្រឿងលម្អដ៏អស្ចារ្យមួយដល់ផ្ទះ ។ ប៉ុន្តែរបួសដ៏ធ្ងន់ធ្ងរនៃយុវវ័យរបស់វា និងការកាត់ដ៏ហិង្សាដែលខ្ញុំបានធ្វើដើម្បីតម្រង់វាគឺខ្លាំងណាស់ ។

« នៅពេលវាត្រូវបានដាំដំបូង គឺអំបោះតែមួយសរសៃនឹងអាចទប់វាឲ្យនៅនឹងកន្លែងពេលមានខ្យល់ខ្លាំង ។ ខ្ញុំអាច ហើយខ្ញុំគួរតែបានចងខ្សែនោះដោយកម្លាំងបន្តិចបន្តួចប៉ុណ្ណោះ ។ ប៉ុន្តែខ្ញុំមិនបានធ្វើវាទេ ហើយវាបានទោរទៅតាមកម្លាំងដែលបានបក់បោកវា » (« Bring Up a Child in the Way He Should Go »*Ensign,*ខែ វិច្ឆិកា ឆ្នាំ ១៩៩៣, ទំព័រ ៥៩) ។

> **អាលម៉ា ៣៧:៣៥**គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ អ្នកអាចជួយសិស្សនឹងចំណេះចំណានខគម្ពីរនេះដោយការឲ្យពួកគេបំពេញកិច្ចការនៅចុងបញ្ចប់នៃមេរៀនថ្ងៃនេះ ។

សូមឲ្យសិស្សអានការបង្រៀនរបស់អាលម៉ាដល់ហេលេមិននៅក្នុង អាលម៉ា ៣៧:៣៥ ។ សូមឲ្យពួកគេឲ្យគិតអំពីបៀបដែលខគម្ពីរនេះទាក់ទងនឹងបទពិសោធន៍របស់ប្រធាន ហ៊ិងគ្លី ជាមួយនឹងដើមឈើនោះ ។

សូមឲ្យសិស្សសង្កេត អាលម៉ា ៣៧:៣៥ ជាសម្តីខ្លួនឯង ។ (ចម្លើយរបស់ពួកគេអាចបង្ហាញថា **យើងគួររៀននៅក្នុងយុវវ័យយើងដើម្បីកាន់តាមព្រះបញ្ញត្តិនៃព្រះ** ។ សូមឲ្យពួកគេឆ្លើយសំណួរខាងក្រោមជាដៃរ ។ (អ្នកអាចសរសេរសំណួរនៅលើក្តារខៀន ឬ អានវាយឺតៗដើម្បីឲ្យសិស្សកត់វា) ។

- តើអ្នកគិតថា ភាពខុសគ្នាអ្វីខ្លះដែលកើតមាននៅក្នុងជីវិតរបស់មនុស្សម្នាក់ដើម្បីរៀនកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ខណៈពេលនៅក្មេងនៅឡើយ ?
- តើអ្នកអាចគិតដល់មនុស្សដែលបានត្រូវប្រទានពរពេញមួយជីវិតរបស់គេ ដោយសារពួកគេបានរៀនដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយនៅក្នុងយុវវ័យរបស់ពួកគេទេ ? សូមសរសេរអំពីរបៀបដែលពួកគេត្រូវបានប្រទានពរ ។

សូមឲ្យសិស្សពីរបីនាក់រៀបរាប់ពីអ្វីដែលពួកគេបានសរសេរ ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣៧:៣៦–៣៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ទាំងអស់មើលតាម ដោយរកមើលការណែនាំដាក់លាក់ដែលអាចជួយពួកគេឲ្យកាន់តាមព្រះបញ្ញត្តិ ខណៈពេលពួកគេនៅក្មេងទេ ។

- តើការធ្វើតាមការណែនាំនេះអាចជួយអ្នកឲ្យកាន់តាមព្រះបញ្ញត្តិប្រចាំថ្ងៃដោយរបៀបណា ?
- តើអ្នកព្យាយាមដាក់ព្រះអម្ចាស់ជំបូងនៅក្នុងគំនិត ពាក្យសម្តី ទង្វើ និងសេចក្តីស្រឡាញ់របស់អ្នកតាមរបៀបណា ? (សូមលើកទឹកចិត្តសិស្សឲ្យគិតពីរបៀបដែលពួកគេអាចរីកចម្រើន) ។

សូមចែកចាយអារម្មណ៍អំពីរបៀបដែលការប្រឹក្សាជាមួយនឹងព្រះអម្ចាស់បានជួយអ្នកឲ្យកាន់តាមព្រះបញ្ញត្តិ ។ សូមលើកទឹកចិត្តសិស្សដែលជាមិត្តរបស់អ្នកប្រឹក្សាជាមួយនឹងព្រះអម្ចាស់ក្នុងគ្រប់ការណ៍ទាំងឡាយដែលគេធ្វើ ។

គ្រូបង្រៀនដែលជាសិស្សទី ១—អាលម៉ា ៣៧:៣៨–៤៥

សូមបង្ហាញរូបភាពលេអាហូណា (៦២០៤១; *សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ | លេខ ៦៨) ។ សូមរំឭកសិស្សដែលជាមិត្តរបស់អ្នកអំពីត្រីវិស័យដែលព្រះអម្ចាស់បានប្រើដើម្បីជួយដល់គ្រួសាររបស់លីហៃឲ្យធ្វើដំណើរឆ្លងទៅដែនដីសន្យា ។ នៅក្នុង អាលម៉ា ៣៧:៣៨ យើងរៀនថា ត្រីវិស័យត្រូវបានហៅថា លីអាហូណា ។ សូមពន្យល់ថា អាលម៉ាបាននិយាយអំពីលេអាហូណាដើម្បីបង្រៀនហេលេមិនពីគោលការណ៍ដ៏សំខាន់មួយអំពីរបៀបដែលព្រះអម្ចាស់ណែនាំកូនចៅរបស់ទ្រង់ ។

សូមពន្យល់ដល់សិស្សដែលជាមិត្តរបស់អ្នកថា អ្នកនឹងស្តាប់ពួកគេនូវសំណួរខ្លះ ហើយបន្ទាប់មកឲ្យពួកគេប្តូរវេនគ្នាអានខគម្ពីរពីរបីខ្ទង់ដែលគ្រប់គ្នារកមើលចម្លើយ ។ សូមឲ្យពួកគេឆ្លើយនឹងសំណួរនីមួយៗក្រោយពីបានអានវគ្គព្រះគម្ពីរដែលពាក់ព័ន្ធហើយ ។

- តើលេអាហូណាបានដំណើរការដោយរបៀបណា ? (សូមមើលអាលម៉ា ៣៧:៣៨–៤០ ។)
- ហេតុអ្វីបានជាលេអាហូណាបានឈប់ដំណើរការនៅពេលខ្លះ ? (សូមមើល អាលម៉ា ៣៧:៤១–៤២ ។)
- តើយើងអាចប្រៀបធៀបលេអាហូណាទៅនឹងព្រះបន្ទូលនៃព្រះគ្រីស្ទដោយរបៀបណា ? (សូមមើល អាលម៉ា ៣៧:៤៣–៤៥ ។)

អ្នកអាចពន្យល់ថា នៅក្នុងខគម្ពីរទាំងនេះពាក្យ *ស្រមោល* និង *គំរូ* សំដៅលើ « មនុស្សម្នាក់ ព្រឹត្តិការណ៍ ឬ បុណ្យមួយដែលស្រដៀងទៅនឹងមនុស្ស ព្រឹត្តិការណ៍ ឬ បុណ្យមួយទៀតដែលសំខាន់ជាខ្លាំងដែលត្រូវតែធ្វើតាម ។ . . . គំរូដ៏ពិតនឹងមានចំណុចស្រដៀងគ្នាដ៏គួរឲ្យកត់សម្គាល់ បង្ហាញភស្តុតាងនៃការប្រជុំដ៏ទេវភាព និងជាការព្យាករណ៍ដល់ហេតុការណ៍នៃអនាគតកាល » (Joseph Fielding McConkie, *Gospel Symbolism* | ឆ្នាំ ១៩៨៥ |, ទំព័រ ២៧៨) ។ ជម្រើសដើម្បីធ្វើតាម ឬមិនធ្វើតាមការដឹកនាំនៃលីអាហូណាគឺដូចជាជម្រើសរបស់យើងអំពីរបៀបដែលយើងឆ្លើយតបទៅនឹងការដឹកនាំដែលមកតាមរយៈព្រះបន្ទូលនៃព្រះគ្រីស្ទដែរ ។

- តើយើងអាចស្វែងរកព្រះបន្ទូលនៃព្រះគ្រីស្ទនៅកន្លែងណា ? (ចម្លើយអាចរួមមានព្រះគម្ពីរ ពាក្យសម្តីនៃព្យាការីថ្ងៃចុងក្រោយ ពរជ័យអយ្យកោ និងការបំផុសនៃព្រះវិញ្ញាណ ។)

សូមឲ្យសិស្សដែលជាមិត្តរបស់អ្នកសង្ខេបសម្តីរបស់អាលម៉ានៅក្នុង អាលម៉ា ៣៧:៣៨–៤៥ ជាពិសេសនៅក្នុងខទី ៤៤–៤៥ ។ ការពិភាក្សានេះគួររួមបញ្ចូលនូវសេចក្តីពិតខាងក្រោម ៖ **ប្រសិនបើយើងធ្វើតាមព្រះបន្ទូលនៃព្រះយេស៊ូវគ្រីស្ទ វានឹងដឹកនាំយើងឲ្យទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។**

សូមចែកចាយរបៀបដែលព្រះបន្ទូលនៃព្រះគ្រីស្ទបានជះឥទ្ធិពលដល់អ្នកខាងវិញ្ញាណ និងរបៀបដែលវាជួយអ្នកឲ្យបន្តទៅរកជីវិតដ៏នៅអស់កល្បជានិច្ច ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគិតពីការទទួលពរជ័យអយ្យកោមួយ ឬ ប្រសិនបើពួកគេបានទទួលរួចហើយ សូមអានវាជាទៀងទាត់ និងប្រកបដោយការអធិស្ឋាន ។

កំណត់ចំណាំដល់គ្រូបង្រៀន ៖ ក្រោយពីសិស្សបញ្ចប់ការបង្រៀនផ្នែកនៃមេរៀនរបស់ពួកគេហើយ សូមថ្លែងអំណរគុណដល់ពួកគេ ហើយបើមានពេល សូមឲ្យសិស្សពីរបីនាក់ថ្លែងទីបន្ទាល់អំពីគោលការណ៍មួយដែលពួកគេបានរៀននៅថ្ងៃនេះ ។ អ្នកក៏អាចចែកចាយទីបន្ទាល់របស់សអ្នកអំពីគោលការណ៍ទាំងនេះដែរ ។ សូមបញ្ចប់ដោយការឲ្យសិស្សក្នុងថ្នាក់មើលតាម នៅពេលអ្នកអាន អាលម៉ា ៣៧:៤៦–៤៧ ឮៗ ។

ចំណេះចំណានខគម្ពីរ—អាលម៉ា ៣៧:៣៥

កំណត់ចំណា ៖ សកម្មភាពយកទៅផ្ទះខាងក្រោមនឹងរៀបចំសិស្សសម្រាប់ការចាប់ផ្តើមនៃមេរៀនបន្ទាប់ (អាលម៉ា ៣៨) ។ សូមរៀបគម្រោងពេលវេលាក្នុងថ្នាក់ដើម្បីពន្យល់ពីកិច្ចការដល់សិស្ស និងប្រាប់ពួកគេពីគម្រោងរបស់អ្នកដើម្បីតាមដានបទពិសោធន៍របស់ពួកគេនៅលើកក្រោយពេលអ្នកជួបគ្នា ។

សូមបង្ហាញថា អាលម៉ា ៣៧:៣៥ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ អ្នកអាចណែនាំសិស្សឲ្យគូសចំណាំវាដើម្បីឲ្យពួកគេងាយនឹងរកវាឃើញ ។ សូមឲ្យពួកគេទន្ទេញវគ្គនេះនៅផ្ទះយប់នេះ ហើយសូត្រវាដល់ឪពុកម្តាយ ឬមជ្ឈឹមវ័យដែលគេទុកចិត្តផ្សេងទៀត ។ (ឬពួកគេអាចអានខគម្ពីរនេះជាមួយនឹងមជ្ឈឹមវ័យម្នាក់ ។) សូមលើកទឹកចិត្តពួកគេឲ្យសុំឲ្យមជ្ឈឹមវ័យនោះសរសំណួរខាងក្រោម ។ (អ្នកអាចឲ្យសិស្សសរសេរសំណួរទាំងនេះនៅលើក្រដាសយកទៅផ្ទះ ។)

តើការគោរពតាមព្រះបញ្ញត្តិនៃព្រះបានជួយអ្នកដោយរបៀបណា ?

តើដំបូន្មានអ្វី ដែលអ្នកមានសម្រាប់ខ្ញុំដែលអាចជួយខ្ញុំឲ្យឆ្លាតជាងនេះនៅក្នុងយុវវ័យរបស់ខ្ញុំ ?

សូមប្រាប់សិស្សថា អ្នកនឹងសុំឲ្យពួកគេរៀបរាប់ពីបទពិសោធន៍របស់ពួកគេអំឡុងពេលរៀនលើកក្រោយ ។

អាលម៉ា ៣៨

សេចក្តីផ្តើម

សិបឡុនបានបម្រើជាមួយនឹងឪពុករបស់គាត់ អាលម៉ា ជាអ្នកផ្សព្វផ្សាយសាសនាក្នុងចំណោមពួកសាសន៍ស៊ូរ៉ាំ (សូមមើលអាលម៉ា ៣១:៧) ។ ក្រោយពីបេសកម្មនេះ អាលម៉ាបានបង្ហាញសេចក្តីអំណរនៅក្នុងការខ្ជាប់ខ្ជួន និងសេចក្តីស្មោះត្រង់ដែលសិបឡុនបានបង្ហាញ ខណៈពេលដែលរងទុក្ខនឹងការកាត់ទោស ។ អាលម៉ាក៏បានថ្លែងទីបន្ទាល់ដល់សិបឡុនអំពីព្រះចេស្តារបស់ព្រះអង្គសង្គ្រោះនៃការដោះលែង និងបានផ្តល់ការប្រឹក្សាទាក់ទងនឹងការបន្តការខិតខំប្រឹងរបស់សិបឡុនក្នុងការបង្រៀនដំណឹងល្អ ។

ការតាមដានក្រោយពីការដាក់កិច្ចការ

នៅពេលអ្នកតាមដានសិស្សពីការអញ្ជើញពីមេរៀនមុនក្នុងការអនុវត្តគោលការណ៍ដំណឹងល្អ អ្នកនឹងផ្តល់ឱកាសដល់ពួកគេឲ្យថ្លែងទីបន្ទាល់នៃពរជ័យដែលមកពីការរស់នៅតាមដំណឹងល្អ ។ នៅពេលសិស្សចែកចាយអ្វីដែលពួកគេបានទទួលបទពិសោធន៍ នៅពេលពួកគេបានអនុវត្តសេចក្តីពិតនៃដំណឹងល្អ ពួកគេនឹងពង្រឹងទីបន្ទាល់របស់ពួកគេ និងជួយពង្រឹងដល់ទីបន្ទាល់របស់អ្នកដទៃ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៣៨:១–៣

អាលម៉ាបង្ហាញសេចក្តីអំណរចំពោះសេចក្តីស្មោះត្រង់របស់សិបឡុន

ប្រសិនបើអ្នកបានអញ្ជើញសិស្សឲ្យធ្វើសកម្មភាពអនុវត្តនៅផ្ទះនៅ ចុងបញ្ចប់នៃមេរៀនមុន សូមរំឭកពួកគេអំពីសំណួរពីរដែលអ្នកបានឲ្យពួកគេសួរឪពុកម្តាយរបស់ពួកគេ ឬ មជ្ឈិមវ័យដែលគេទុកចិត្តផ្សេងទៀត ៖

- តើការគោរពតាមព្រះបញ្ញត្តិនៃព្រះបានជួយអ្នកដោយរបៀបណា ?
- តើដំបូន្មានអ្វីដែលអ្នកមានសម្រាប់ខ្ញុំ ដែលអាចជួយខ្ញុំឲ្យឆ្លងវែងមុននៅក្នុងយុវវ័យរបស់ខ្ញុំ ?

សូមឲ្យសិស្សរាយការណ៍ពីបទពិសោធន៍របស់ពួកគេនឹងសកម្មភាពនេះ ។ ក្រោយពីសិស្សបានចែកចាយហើយ សូមសួរ ៖

- តើបទពិសោធន៍នេះបានជះឥទ្ធិពលដល់បំណងប្រាថ្នារបស់អ្នកដើម្បីកាន់តាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ដោយរបៀបណា ?

សូមពន្យល់ថា អាលម៉ា ៣៨ កត់ត្រានូវការណែនាំដែលអាលម៉ាបានធ្វើដល់កូនប្រុសរបស់គាត់ សិបឡុន ។ សូមឲ្យសិស្សម្នាក់អានអាលម៉ា ៣៨:១–៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលឃ្លាដែលពិពណ៌នាពីរបៀបដែលអាលម៉ាមានអារម្មណ៍អំពីសិបឡុន និងមូលហេតុ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើយើងអាចរៀនអ្វីខ្លះពី អាលម៉ា ៣៨:២–៣ អំពីឥទ្ធិពលដែលកូនចៅសុចរិតអាចមានលើឪពុកម្តាយរបស់ពួកគេ ? (សិស្សអាចមានចម្លើយខុសៗគ្នា ។ សូមធានាថា ពួកគេរកឃើញនូវសេចក្តីពិតថា **នៅពេលយុវវ័យខ្ជាប់ខ្ជួន និងស្មោះត្រង់ក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយ ពួកគេអាចនាំមកនូវសេចក្តីអំណរដ៏អស្ចារ្យដល់ឪពុកម្តាយរបស់ពួកគេ**) ។
- តើនៅពេលណាដែលឪពុកម្តាយរបស់អ្នកមានអារម្មណ៍ពីសេចក្តីអំណរ ដោយសារតែការសម្រេចចិត្តដ៏ល្អមួយដែលអ្នកបានធ្វើ ឬដោយសារតែការខិតខំរបស់អ្នកក្នុងការរស់នៅតាមដំណឹងល្អនោះ ?
- តើការខិតខំរបស់អ្នកក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយជះឥទ្ធិពលដល់ទំនាក់ទំនងរបស់អ្នកនឹងឪពុកម្តាយរបស់អ្នកដោយរបៀបណា ?

អ្នកអាចចែកចាយគំរូមួយអំពីរបៀបដែលគ្រួសាររបស់អ្នក បានជះឥទ្ធិពលដោយជម្រើសដ៏សុចរិតនៃកូនចៅនៅក្នុងគ្រួសារនោះ ។

អាលម៉ា ៣៨:៤–៩

អាលម៉ាថ្លែងទីបន្ទាល់អំពីព្រះចេស្តានៃព្រះអង្គសង្គ្រោះក្នុងការដោះលែង

សូមពន្យល់ថា អាលម៉ាបានរំឭកសិបឡុនថា ពួកគេបានទទួលទាំងព្រះចេស្តារបស់ព្រះអង្គសង្គ្រោះនៃការដោះលែង ។ សូមរៀបចំតារាងខាងក្រោមជាក្រដាសមួយ ឬ បង្ហាញវានៅលើក្តារខៀន ហើយសូមឲ្យសិស្សចម្លងវាចូលក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។

	សិបឡុន (អាលម៉ា ៣៨:៤–៥)	អាលម៉ា (អាលម៉ា ៣៨:៦–៨)
តើគាត់ត្រូវបានដោះលែងចេញពីអ្វី ?		
ហេតុអ្វីបានជាគាត់បានទទួលពរជ័យនៃការដោះលែង ?		
តើយើងអាចរៀនអ្វីខ្លះពីបទពិសោធន៍របស់គាត់ ?		

សូមបំពេញតារាងក្នុងថ្នាក់ទាំងមូល ឬ សូមឲ្យសិស្សបំពេញវាជាដៃគូ ។ សូមឲ្យសិស្សយោងទៅវគ្គព្រះគម្ពីរ ដែលមាននៅក្នុងតារាងនៅពេលពួកគេឆ្លើយនឹងសំណួរទាំងឡាយ ។ សូមលើកទឹកចិត្តពួកគេឲ្យរួមបញ្ចូលអ្វីដែលពួកគេបានដឹងរួចហើយអំពីព្រះអម្ចាស់ក្នុងការដោះលែងសិបឡុន (សូមមើល អាលម៉ា ៣៨:២–៣) និង អាលម៉ា (សូមមើលម៉ូសាយ ២៧; អាលម៉ា ៣៦) ។ ក្រោយពីសិស្សបំពេញតារាងហើយ សូមសួរសំណួរខាងក្រោមដើម្បីជួយពួកគេឲ្យពិភាក្សាពីគោលការណ៍ដែលពួកគេបានរៀន ៖

- តើយើងអាចរៀនអ្វីខ្លះពីបទពិសោធន៍របស់សិបឡុន ? (សិស្សអាចរកឃើញគោលការណ៍ខុសគ្នា ។ សូមប្រាកដថា ពួកគេរកឃើញសេចក្តីពិតខាងក្រោម ៖ **ប្រសិនបើយើងទ្រាំនឹងអ្វីៗទាំងអស់ដោយសេចក្តីអត់ធ្មត់ និងទុកចិត្តលើព្រះ ទ្រង់នឹងដោះលែងយើងពីឧបសគ្គ បញ្ហា និងការរងទុក្ខទាំងឡាយ ហើយលើកយើងឡើងនៅថ្ងៃចុងក្រោយបង្អស់) ។**
- តើយើងអាចរៀនអ្វីខ្លះពីបទពិសោធន៍របស់អាលម៉ា ? (ទោះបីជាសិស្សអាចឆ្លើយខុសៗគ្នា សូមប្រាកដថា ពួកគេបង្ហាញថា **ដើម្បីទទួលបានការផ្តាច់បាបរបស់យើង និងរកសេចក្តីសុខសាន្តដល់ព្រលឹងរបស់យើង យើងត្រូវអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងស្វែងរកសេចក្តីមេត្តាករុណារបស់ទ្រង់) ។**

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣៨:៩ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលអាលម៉ាចង់ឲ្យកូនប្រុសរបស់គាត់រៀនអំពីព្រះអង្គសង្គ្រោះ ។

- ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីដឹងថា ព្រះយេស៊ូវគ្រីស្ទគឺជា « ផ្លូវ ឬមធ្យោបាយតែមួយគត់ ដែលនាំឲ្យ | យើង | បានសង្គ្រោះ » ?
- តើអ្នកបានទទួលការដោះលែងតាមរយៈព្រះចេស្តារបស់ព្រះអង្គសង្គ្រោះតាមរបៀបណា ? (អ្នកអាចឲ្យពេលដល់សិស្សសញ្ជឹងគិតអំពីសំណួរនេះ មុនពេលសុំឲ្យពួកគេឆ្លើយ) ។ តើអ្នកបានធ្វើអ្វីខ្លះ ដើម្បីស្វែងរកការដោះលែង ?

សូមផ្តល់ពេលខ្លះដល់សិស្សឲ្យសញ្ជឹងគិតអំពីរបៀបដែលពួកគេអាចរកឃើញជំនួយរបស់ព្រះអម្ចាស់ក្នុងឧបសគ្គផ្ទាល់ខ្លួនមួយ ។

អាលម៉ា ៣៨:១០–១៥

អាលម៉ាណែនាំសិបឡុនឲ្យបន្តការបង្រៀនដំណឹងល្អ និងអភិវឌ្ឍឥរិយាបថដ៏សុចរិតទាំងឡាយ

សូមពន្យល់ថា អាលម៉ាលើកទឹកចិត្តសិបឡុនឲ្យអភិវឌ្ឍគុណសម្បត្តិដែលនឹងជួយគាត់ នៅពេលគាត់បន្តបង្រៀនដំណឹងល្អ និងបម្រើដល់អ្នកដទៃ ។ ការប្រឹក្សារបស់អាលម៉ាដល់សិបឡុន អាចអនុវត្តដល់មនុស្សគ្រប់រូបដែលចង់បម្រើ បង្រៀន ឬ ជះឥទ្ធិពលដល់អ្នកដទៃសម្រាប់សេចក្តីល្អ ។ សូមឲយសិស្សអាន អាលម៉ា ៣៨:១០–១៥ ដោយស្ងាត់ៗ ដោយរកមើលការណែនាំដែលនឹងជួយដល់ពួកគេជាពិសេស ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំអ្វីដែលពួកគេរកឃើញ ។

សូមឲ្យសិស្សនូវច្បាប់ចម្លងនៃការណែនាំការសិក្សានៅចុងបញ្ចប់នៃមេរៀននេះ ។ សូមពន្យល់ថា នៅពេលពួកគេប្រើការណែនាំពួកគេនឹងឃើញពីរបៀបដែល **ការខិតខំប្រឹងរបស់យើងដើម្បីអភិវឌ្ឍឥរិយាបថដ៏សុចរិតនឹងរៀបចំយើងឲ្យបង្រៀន និងបម្រើដល់អ្នកដទៃ ។** សូមឲ្យពួកគេជ្រើសរើសការប្រឹក្សារបស់អាលម៉ាមួយផ្នែកនៅក្នុងកូឡោនខាងឆ្វេងនៃការណែនាំ ហើយបំពេញនូវសកម្មភាពរៀនដែលត្រូវគ្នានឹងកូឡោនខាងស្តាំ ។ (ប្រសិនបើអ្នកមិនអាចបង្ហាញការណែនាំការសិក្សានោះទេ សូមសម្របសកម្មភាព ដោយការដឹកនាំសិស្សឲ្យពិភាក្សា និងប្រើព័ត៌មាននៅក្នុងការណែនាំការសិក្សាជាធនធានមួយ) ។

> *សូមសម្របសកម្មភាពនៃការរៀនទាំងឡាយ*
>
> របៀបបង្រៀនដែលមាននៅក្នុងសៀវភៅណែនាំនេះគឺជាការផ្តល់យោបល់ ។ សូមប្រើប្រាជ្ញាដើម្បីសម្របវាតាមកាលៈទេសៈរបស់អ្នក និងតាមតម្រូវការនៃសិស្សម្នាក់ៗ និងសិស្សក្នុងថ្នាក់ទាំងមូល ។ សូមស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធដោយការអធិស្ឋាន ។

នៅពេលសិស្សមានពេលល្មមដើម្បីបំពេញសកម្មភាពនៃការរៀនមួយនៃសកម្មភាពទាំងឡាយនៅក្នុងសៀវភៅណែនាំការសិក្សានេះ សូមគិតពីការសុំឲ្យពួកគេបើបួនចែកចាយអ្វីដែលពួកគេបានរៀនពីសកម្មភាពនេះ និងរបៀបដែលពួកគេគ្រោងដើម្បីអនុវត្តវា ។ ប្រសិនបើអ្នកឲ្យបានចែកដល់សិស្សនូវច្បាប់ចម្លងនៃសៀវភៅណែនាំការសិក្សា សូមលើកទឹកចិត្តពួកគេឲ្យយកវាទៅផ្ទះ ហើយរៀនបន្ថែមទៀតអំពីការប្រឹក្សារបស់អាលម៉ាដល់សិបឡុន ។

សៀវភៅណែនាំការសិក្សាសម្រាប់ អាលម៉ា ៣៨:១០–១២

សូមមើលផ្នែកខុសៗគ្នានៃការប្រឹក្សារបស់អាលម៉ាខាងក្រោម ហើយសូមរើសយកការប្រឹក្សាមួយដែលអ្នកចង់អភិវឌ្ឍ ។ សូមបំពេញសកម្មភាពនៃការរៀនដែលត្រូវគ្នា ដើម្បីជួយអ្នកឲ្យអនុវត្តការប្រឹក្សានេះនៅក្នុងជីវិតរបស់អ្នក ។

ការប្រឹក្សារបស់អាលម៉ា	សកម្មភាពនៃការរៀន
« ចូរមានការព្យាយាម ហើយចេះទប់ចិត្តក្នុងគ្រប់ការណ៍ទាំងអស់ » (អាលម៉ា ៣៨:១០) ។	ការព្យាយាមគឺជាការខិតខំដ៏ខ្ជាប់ខ្ជួន ប្រុងប្រយ័ត្ន និងប្រកបដោយមនសិការ ។ ការចេះទប់ចិត្ត គឺ « ការចេះប្រើការយល់យោគនៅក្នុងគ្រប់ការណ៍ទាំងអស់ ឬ ការអនុវត្តការគ្រប់គ្រងខ្លួនឯង » (Kent D. Watson « Being Temperate in All Things »*Ensign*ឬ*លេអាហូណា*,ខែ វិច្ឆិកា ឆ្នាំ ២០០៩, ទំព័រ ៣៨) ។ សូមសរសេរអំពីមូលហេតុនៃលក្ខណៈទាំងពីរនេះចាំបាច់ នៅពេលមនុស្សម្នាក់បង្រៀនដំណឹងល្អ និងបម្រើដល់អ្នកដទៃ នៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ របស់អ្នក ។ សូមសរសេរផងដែរអំពីផ្នែកខ្លះនៃជីវិតរបស់អ្នក ដែលអ្នកអាចព្យាយាម ឬចេះទប់ចិត្ត ជាងនេះ និងអំពីរបៀបដែលការអភិវឌ្ឍផ្នែកទាំងនោះនឹងជួយអ្នកឲ្យបង្រៀន និងបម្រើដល់អ្នកដទៃ ឲ្យមានប្រសិទ្ធិភាពជាងមុន ។
« ចូរឲ្យយើញថា កូន មិនលើកខ្លួនឡើងទៅជាឆ្មើងឆ្មៃ ; . . .ចូរកុំអួតអាង » (អាលម៉ា ៣៨:១១) ។	ធាតុមួយនៃអំនួតគឺការដាក់ការទុកចិត្តដ៏សម្បើមលើខ្លួនឯង ជាជាងលើព្រះ ។ អំនួតក៏យើញ ច្បាស់ នៅពេលមនុស្សម្នាក់គិតថា គាត់ខ្លាំងជាង ឬសំខាន់ជាងអ្នកដទៃ ។ សូមសរសេរនៅក្នុង កំណត់ហេតុសិក្សាព្រះគម្ពីររបស់អ្នកអំពីអ្វីដែលអាចកើតឡើង ប្រសិនបើសមាជិកសាសនាចក្រម្នាក់ មានអំនួតនឹងការហៅបម្រើរបស់គេ ។ អែលឌើរ រ៉ូបឺត ឌី ហែលនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បាន បង្រៀនថា « សិស្សក៏ពិតនិយាយដោយទំនុកចិត្តដ៏ស្ងប់ស្ងាត់ មិនមែនដោយអំនួតអួតអាងនោះទេ » (« Christian Courage: The Price of Discipleship »*Ensign*ឬ*លេអាហូណា*,ខែ វិច្ឆិកា ឆ្នាំ ២០០៨, ទំព័រ ៧៣) ។ សូមគិតពីនរណាម្នាក់ដែលអ្នកស្គាល់ ដែលបង្រៀនដំណឹងល្អ « ទំនុកចិត្តដ៏ស្ងប់ស្ងាត់ » ។ នៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរ អំពីមនុស្សនេះ និងឥទ្ធិពលដែលការបង្រៀនរបស់គេបានមានលើអ្នក ។ សូមសរសេរផងដែរនូវ របៀបមួយ ឬពីរដែលអ្នកនឹងត្រូវចៀសវាងអំនួត ។
« ចូរប្រើសេចក្តីក្លាហាន ប៉ុន្តែ កុំកោងកាច» (អាលម៉ា ៣៨:១២) ។	សូមអានប្រសាសន៍របស់សាវកប៉ុលនៅក្នុង កីលីព ១:១៤ (នៅក្នុងព្រះគម្ពីរសញ្ញាថ្មី) ដើម្បី យើញពីរបៀបដែលអ្នកបម្រើរបស់ព្រះអាចបង្ហាញសេចក្តីក្លាហាន ។ ប្រធាន ដែមស៍ អឺ ហ្វោស្ត នៃគណៈប្រធានទីមួយបានបង្រៀនពីរបៀបដែលយើងអាចចៀសវាងការកោងកាច ៖ « ខ្ញុំមិនជឿ ថា យើងមិនចាំបាច់ត្រូវនិយាយ . . . ឲ។ សម្រុក ឬ គ្មានស្មារតីពេលយើងបង្រៀន [ដល់កិច្ចការ អ្នកផ្សព្វផ្សាយសាសនា] នោះទេ » (នៅក្នុង James P. Bell, *In the Strength of the Lord: The Life and Teachings of James E. Faust* [ឆ្នាំ ១៩៩៩], ៣៧៣) ។ នៅក្នុង សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក សូមសរសេរអំពីរបៀបដែលមនុស្សម្នាក់អាច ក្លាហានដោយមិនកោងកាច ។ សូមសរសេររបៀបដ៏ជាក់លាក់មួយ ដែលអ្នកនឹងអនុវត្តការប្រឹក្សា ដើម្បីក្លាហាន ប៉ុន្តែមិនកោងកាច ។ សូមសរសេរផងដែរអំពីរបៀបដែលការប្រឹក្សានេះអាចជួយអ្នក ឲ្យមានជោគជ័យក្នុងការបង្រៀន និងបម្រើដល់អ្នកដទៃ ។
« ចូរទប់អស់ទាំងតណ្ហា របស់កូន » (អាលម៉ា ៣៨:១២) ។	ការទប់មានន័យថា ការបញ្ឈប់ ដឹកនាំ ឬ គ្រប់គ្រង ។ តណ្ហាគឺជាអារម្មណ៍ដ៏ខ្លាំងមួយ ។ សូម សញ្ជឹងគិតពីសំណួរខាងក្រោម ហើយសូមសរសេរចម្លើយរបស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុ ការសិក្សាព្រះគម្ពីររបស់អ្នក ៖ តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីទប់អស់ទាំង តណ្ហារបស់យើង ? តើអ្នកគិតថា ការទប់អស់ទាំងតណ្ហារបស់អ្នកអាចជួយអ្នកឲ្យពោរពេញដោយ សេចក្តីស្រឡាញ់ដោយរបៀបណា ? តើអ្នកនឹងធ្វើអ្វីដើម្បីធ្វើតាមការប្រឹក្សារបស់អាលម៉ា ដើម្បីទប់ អស់ទាំងតណ្ហារបស់អ្នក ?
« ចូរទប់ខ្លួនកុំឲ្យធ្លាក់ទៅក្នុង ការខ្ជិលច្រអូស » (អាលម៉ា ៣៨:១២) ។	សូមរំឲ្យកវគ្គព្រះគម្ពីរដែលមាននៅក្នុងលិបិក្រមសម្រាប់បណ្តុំព្រះគម្ពីរក្រោមពាក្យ « ការខ្ជិលច្រអូស ខ្ជិលច្រអូស » ។ សូមរកមើលការប្រឹក្សអំពីអត្ថន័យនៃពាក្យខ្ជិលច្រអូស និងអំពីពាក្យផ្ទុយនឹង ខ្ជិលច្រអូស ។ សូមរើសយកខគម្ពីរពីរដែលមាននៅក្នុងតារាង ហើយសិក្សាវា ។ សូមសរសេរនៅក្នុង សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់អ្នក អំពីអ្វីដែលអ្នករៀនពីខគម្ពីរទាំងឡាយដែលអ្នក បានរើស ។ សូមសរសេរអំពីរបៀបដែលការប្រឹក្សានេះដើម្បីបញ្ឈប់ពីភាពខ្ជិលច្រអូស នឹងជួយអ្នក ឲ្យបង្រៀន និងបម្រើដល់អ្នកដទៃឲ្យកាន់តែមានប្រសិទ្ធិភាពជាងមុន ។ ជាទីបញ្ចប់ សូមសរសេរ របៀបដ៏ជាក់លាក់មួយដែលអ្នកនឹងបញ្ឈប់ភាពខ្ជិលច្រអូស ។

មេរៀនសិក្សានៅផ្ទះ

អាលម៉ា ៣៣–៣៨ (មេរៀនទី ១៩)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀននៅពេលពួកគេសិក្សា អាលម៉ា ៣៣–៣៨(មេរៀនទី ១៩) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (អាលម៉ា ៣៣–៣៥)

អាលម៉ាបង្រៀនដល់ពួកសាសន៍សាំថា យើងអាចថ្វាយបង្គំដល់ព្រះជាបន្តឥតដាច់តាមរយៈការអធិស្ឋាន ។ បន្ទាប់មក អាលម៉ាបានបង្រៀនថា យើងទទួលបានសេចក្តីមេត្តាករុណារបស់ព្រះវរបិតាសួគ៌ ដោយរួមមានការអភ័យទោសចំពោះអំពើបាបរបស់យើង ដោយសារតែជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ អាមូឡេកបានបង្រៀនដល់សាសន៍សាំថា ជង្វាយធួនជំនិន្នៅ និងជំអស់កល្បជានិច្ចរបស់ព្រះយេស៊ូវគ្រីស្ទផ្តល់នូវការសង្គ្រោះដល់មនុស្សទាំងអស់ ។ សិស្សក៏បានរៀនដែរថា ដើម្បីទទួលបានពរជ័យជំពេញលេញនៃជង្វាយធួន យើងត្រូវអនុវត្តសេចក្តីជំនឿចំពោះការប្រែចិត្ត ។

ថ្ងៃទី ២ (អាលម៉ា ៣៦)

ចេញពីដំណើររឿងរបស់អាលម៉ានៃការប្រែចិត្តជឿរបស់គាត់ សិស្សបានរៀនថា អំពើបាបអាចដឹកនាំទៅរកការឈឺចាប់ និងការសោកស្តាយជំខ្លាំង ។ លើសពីនេះ ពួកគេបានរៀនថា ប្រសិនបើយើងអនុវត្តសេចក្តីជំនឿលើជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ទ្រង់នឹងដោះលែងយើងពីការឈឺចាប់នៃអំពើបាបរបស់យើង ហើយបំពេញយើងដោយសេចក្តីអំណរ ។ ដូចជាអាលម៉ាដែរ យើងអាចទទួលបានសេចក្តីអំណរជំអស្ចារ្យ នៅពេលយើងខំនាំអ្នកដទៃឲ្យមកកាន់ព្រះគ្រីស្ទ ។

ថ្ងៃទី ៣ (អាលម៉ា ៣៧)

អាលម៉ាបានឲ្យកូនប្រុសរបស់គាត់ ហេលេមិន ទទួលបន្ទុករក្សា និងការពារកំណត់ត្រាជំពិសិដ្ឋទាំងឡាយ ។ ដោយការសិក្សាពាក្យសម្តីរបស់អាលម៉ា សិស្សបានរៀនថា ដើម្បីនាំមកនូវគោលបំណងជំអស់កល្បរបស់ទ្រង់ ព្រះអម្ចាស់ធ្វើការតាមរបៀបតូចតាច និងងាយ ។ ពួកគេក៏បានរៀនដែរថា ប្រសិនបើយើងគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ យើងនឹងរីកចម្រើន ។ អាលម៉ាបានបង្រៀនកូនប្រុសរបស់គាត់ថា យើងគួររៀននៅក្នុងយុវវ័យរបស់យើងដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ហើយថាប្រសិនបើយើងគោរពតាមព្រះបន្ទូលនៃព្រះយេស៊ូវគ្រីស្ទ វានឹងដឹកនាំយើងឲ្យទទួលបានជីវិតជំនៅអស់កល្បជានិច្ច ។

ថ្ងៃទី ៤ (អាលម៉ា ៣៨)

នៅពេលសិស្សបានសិក្សាពីការប្រឹក្សារបស់អាលម៉ាដល់សិបឡុន ពួកគេបានរៀនថា នៅពេលពួកគេចាប់ផ្តើមខ្ជាប់ខ្ជួន និងស្មោះត្រង់នៅក្នុងយុវវ័យរបស់ពួកគេដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយ ពួកគេអាចនាំមកនូវសេចក្តីអំណរជំអស្ចារ្យដល់ឪពុកម្តាយរបស់ពួកគេ ។ អាលម៉ាបានថ្លែងទីបន្ទាល់ដល់កូនប្រុសរបស់គាត់ថា ព្រះនឹងដោះលែងបុគ្គលម្នាក់ៗពីឧបសគ្គ បញ្ហា និងសេចក្តីវេទនាទាំងឡាយ នៅពេលពួកគេទ្រាំនឹងអ្វីៗទាំងអស់ដោយសេចក្តីអត់ធ្មត់ និងទុកចិត្តលើទ្រង់ ។ អាលម៉ាក៏បានថ្លែងទីបន្ទាល់ថា ដើម្បីទទួលបានការផ្តាច់បាបរបស់យើង និងទទួលបានសេចក្តីសុខសាន្តដល់ព្រលឹងរបស់យើង យើងត្រូវតែអំពាវនាវដល់ព្រះអម្ចាស់សុំសេចក្តីមេត្តាករុណា ។ ទីបញ្ចប់ សិស្សបានរៀនថា ការអភិវឌ្ឍតរិយាបថជំសុចរិតនឹងរៀបចំយើងឲ្យបង្រៀន និងបម្រើដល់អ្នកដទៃ ។

សេចក្តីផ្តើម

អាលម៉ាបានបង្រៀនដល់ពួកសាសន៍សូរ៉ាំថា ជង្វាយធួនគឺ « និន្នៅ និងអស់កល្បជានិច្ច » (អាលម៉ា ៣៤:១០) ។ សិស្សបានរៀនពីសេចក្តីពិតនេះនៅក្នុងការសិក្សាប្រចាំសប្តាហ៍របស់ពួកគេ ហើយមេរៀននេះនឹងផ្តល់ដល់ពួកគេនូវឱកាសបន្ថែមទៀតដើម្បីយល់ និងកោតសរសើរដល់ជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៣៣–៣៥

អាលម៉ា និងអាមូឡេកបង្រៀនដល់ពួកសាសន៍សូរ៉ាំអំពីជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ

សូមសួរ ៖ ហេតុអ្វីបានជាព្រះយេស៊ូវគ្រីស្ទគឺជាអង្គតែមួយគត់ ដែលអាចធួនសម្រាប់អំពើបាបនៃពិភពលោក ?

សូមរំឭកសិស្សថា ជាផ្នែកនៃកិច្ចការប្រចាំសប្តាហ៍របស់ពួកគេ សូមអាន អាលម៉ា ៣៤:១០–១៤ ហើយគូសចំណាំឃ្លាដែលរួមមានពាក្យ *និន្នៅ* និង*អស់កល្ប* ។សូមឲ្យសិស្សម្នាក់អានខគម្ពីរទាំងនេះឮៗ ហើយបន្ទាប់មកសូមឲ្យសិស្សចែកចាយឃ្លាដែលពួកគេបានរកឃើញ ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ័សុល អិម ណិលសុននៃក្រុមនៃពួកសាវកដប់ពីរនាក់ដើម្បីជួយពួកគេឲ្យយល់ពីរបៀបដែលជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទគឺនិន្នៅ និងអស់កល្ប ៖

« ជង្វាយធួនរបស់ទ្រង់គឺនិន្នៅ —ដោយគ្មានទីបញ្ចប់ឡើយ ។ វាក៏ជានិន្នៅរវែងដែលមនុស្សជាតិទាំងអស់នឹងត្រូវបានសង្គ្រោះពីសេចក្តីស្លាប់ដែលមិនចេះចប់ ។ វាជានិន្នៅក្នុងន័យការរងទុក្ខដ៏ខ្លាំងមហិមារបស់ទ្រង់ ។ . . . វាជានិន្នៅក្នុងបរិបទ —វាត្រូវធ្វើតែម្តងសម្រាប់មនុស្សទាំងអស់ ។ ហើយសេចក្តីមេត្តាករុណានៃជង្វាយធួនពង្រីកមិនត្រឹមតែដល់ចំនួនមនុស្សជំនិន្នៅប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងដល់ចំនួនជំនិន្នៅនៃពិភពលោកទាំងឡាយដែលត្រូវបានបង្កើតដោយទ្រង់ ។ វាជានិន្នៅលើសពីការស្មាននៃរង្វាស់របស់មនុស្ស ឬ លើសពីការយល់ដឹងខាងសាច់ឈាម ។

« ព្រះយេស៊ូវគឺជាអង្គតែមួយគត់ ដែលអាចផ្តល់នូវជង្វាយធួនជានិន្នៅមួយបែបនោះបានដោយសារទ្រង់បានប្រសូត្រពីម្តាយជាសាច់ឈាមម្នាក់ និង ពីព្រះវរបិតាខាងវិញ្ញាណ ។ ដោយសារតែការប្រសូត្រដែលមានតែមួយគត់នោះ ព្រះយេស៊ូវគឺជាអង្គជំនិន្នៅមួយ » (« The Atonement »*Ensign,*ខែ វិច្ឆិកា ឆ្នាំ ១៩៩៦, ទំព័រ ៣៥) ។

សូមសួរ ៖ តើការបង្រៀនរបស់អាមូឡេក និងការពន្យល់ពីអែលឌើរ ណែលសុន នេះបានជួយយើងឲ្យយល់ថា ហេតុអ្វីព្រះយេស៊ូវគ្រីស្ទគឺជាយេស៊ូវគឺជាអង្គតែមួយគត់ ដែលអាចផ្តល់នូវជង្វាយធួនសម្រាប់អំពើបាបនៃលោកិយដោយរបៀបណា ?

សូមឲ្យសិស្សសង្ខេបអ្វីដែលពួកគេបានរៀនកន្លងមកពី អាលម៉ា ៣៤ អំពីជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមពន្យល់ថា គោលការណ៍ដ៏សំខាន់មួយដែលយើងអាចរៀនពីផ្នែកនេះគឺថា **ជង្វាយធួនជំនិន្នៅ និងអស់កល្បជានិច្ចរបស់ព្រះយេស៊ូវគ្រីស្ទធ្វើឲ្យមានសេចក្តីសង្គ្រោះសម្រាប់មនុស្សទាំងអស់ ។**

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ឬ ក្រដាសមួយ ៖ *សូមស្រមៃពីជីវិតដែលគ្មាន . . .*

សូមលើកវត្ថុមួយដែលយុវវ័យជាច្រើនឲ្យតម្លៃ (ដូចជាទូរស័ព្ទដៃមួយ) ។ សូមសួរ ៖ តើជីវិតនឹងទៅជាយ៉ាងណាបើគ្មានវត្ថុនេះ ?

បន្ទាប់មក សូមលើកដប ឬ កែវទឹកមួយ (ឬអ្វីមួយផ្សេងទៀតដែលសំខាន់ដើម្បីចិញ្ចឹមជីវិត) ។ សូមសួរ ៖ តើជីវិតនឹងទៅជាយ៉ាងណាបើគ្មានទឹក ?

ក្រោយពីសិស្សបានឆ្លើយនឹងសំណួរនេះហើយ សូមបំពេញប្រយោគនៅលើក្តារខៀន ៖ *សូមស្រមៃពីជីវិតដែលគ្មានជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។*

សូមសួរសំណួរខាងក្រោម ៖

- តើអ្នកស្រមៃមនុស្សនឹងមើលទៅជីវិតយ៉ាងណាដែរ ប្រសិនបើពួកគេមិនស្គាល់ព្រះយេស៊ូវគ្រីស្ទ ឬ ប្រសិនបើពួកគេមិនជឿថាមានព្រះនោះ ?

- តើអ្នកស្រមៃថាជីវិតនឹងខុសគ្នាយ៉ាងណាសម្រាប់អ្នក បើគ្មានដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ? (សូមឲ្យសិស្សសញ្ជឹងគិតមួយស្របក់នូវសំណួរនេះ មុនពេលឲ្យពួកគេឆ្លើយ ។)

សូមពន្យល់ថា អាមូលេកបានបង្រៀនពួកសាសន៍សូរ៉ាំថា ពួកគេត្រូវប្រែចិត្តដើម្បីនាំមកនូវពរជ័យនៃដង្វាយធួនមកកាន់ជីវិតរបស់ពួកគេ (សូមមើល អាលម៉ា ៣៤:១៥–១៧) ។ សូមសួរសិស្សថា តើពួកគេធ្លាប់ពន្យារពេលប្រែចិត្ត ដោយសារពួកគេខ្លាចនឹងសារភាពអំពើបាបរបស់ពួកគេ ឬ ខ្លាចថាពួកគេមិនរឹងមាំល្មមដើម្បីផ្លាស់ប្តូរទេ ។ បន្ទាប់មកសូមសួរ ៖ ហេតុអ្វីបានជាវាគ្រោះថ្នាក់ក្នុងការពន្យារពេលប្រែចិត្ត ?

សូមឲ្យសិស្សប្តូរវេនគ្នាអានឲ្យពី អាលម៉ា ៣៤:៣០–៣៥ ដោយរកមើលអ្វីដែលអាមូលេកបានបង្រៀនអំពីមូលហេតុដែលយើងមិនគួរពន្យារពេលប្រែចិត្ត ។ សូមពិភាក្សាខគម្ពីរទាំងនេះដោយការសួរសំណួរខាងក្រោម ៖

- សូមមើលទៅ អាលម៉ា ៣៤:៣២ ។ ហេតុអ្វីបានជាយើងគួរប្រែចិត្តថ្ងៃនេះ ? (នៅពេលសិស្សឆ្លើយតប សូមជួយពួកគេឲ្យយល់ពីគោលការណ៍នេះ ៖ **ជីវិតនេះគឺជាពេលវេលាសម្រាប់ឲ្យយើងប្រុងប្រៀបខ្លួនទៅជួបនឹងព្រះ ។**)
- សូមមើលទៅ អាលម៉ា ៣៤:៣៣ ។ តើអ្វីគឺជាគោលបំណងនៃជីវិតនេះ ? តើនឹងមានអ្វីកើតឡើងដល់អស់អ្នកពន្យារពេលប្រែចិត្ត ?
- សូមមើលទៅអាលម៉ា ៣៤:៣១ ។ តើសេចក្តីសន្យាអ្វីដែលត្រូវបានផ្តល់ទៅអ្នកដែលប្រែចិត្តនាពេលឥឡូវ ?

សូមអានសេចក្តីថ្លែងការណ៍ដោយប្រធាន ប៊ិយដ៍ យេ ផាកកឺនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« អ្នកមិនត្រូវដឹងអ្វីៗ មុនពេលព្រះចេស្តានៃដង្វាយធួននឹងធ្វើការសម្រាប់អ្នកនោះទេ ។ សូមមានសេចក្តីជំនឿលើព្រះគ្រីស្ទ ; វាចាប់ផ្តើមមានអំណាចនៅថ្ងៃដែលអ្នកសុំ ! » (« Washed Clean »*Ensign,*ខែ ឧសភា ឆ្នាំ ១៩៩៧,ទំព័រ ១០ ។)

សូមសួរ ៖ តើសេចក្តីថ្លែងការណ៍ដោយប្រធានផាកកឺនេះបង្រៀនអ្នកអ្វីខ្លះ ? ហេតុអ្វីបានជាវាជួយដល់អ្នក ?

អាលម៉ា ៣៦

អាលម៉ាបង្រៀនកូនប្រុសរបស់គាត់ ហេលេមិន

សិស្សរបស់អ្នកបានសិក្សាការបង្រៀនរបស់អាលម៉ាដល់កូនប្រុសរបស់គាត់ ហេលេមិន នៅក្នុងអាលម៉ា ៣៦ ហើយបានរៀនអំពីសេចក្តីអំណរដែលអាលម៉ាបានមាន នៅពេលគាត់បានប្រែចិត្តដោយស្មោះត្រង់ពីអំពើបាបរបស់គាត់ ។ សិស្សត្រូវបានសុំឲ្យអាន អាលម៉ា ៣៦:១៩–២២ ហើយបន្ទាប់មកសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេអំពីអ្វីដែលខគម្ពីរទាំងនេះបានបង្រៀនដល់ពួកគេអំពីព្រះចេស្តានៃដង្វាយធួន (ថ្ងៃទី ២ កិច្ចការទី ៣) ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីដែលពួកគេបានសរសេរ ។ សូមបញ្ចប់ដោយទីបន្ទាល់ផ្ទាល់របស់អ្នកអំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និងសេចក្តីអំណរដែលមកពីការប្រែចិត្ត ។

មេរៀនបន្ទាប់ (អាលម៉ា ៣៩–៤៤)

សូមឲ្យសិស្សគិតអំពីរបៀបដែលឯពុកម្តាយដែលបារម្ភ និងស្រឡាញ់ម្នាក់ដែលអាចកែតម្រូវកូនប្រុស ឬ កូនស្រីដែលបានរំលងច្បាប់ផ្លូវភេទយ៉ាងខ្លាំង ។ អាលម៉ាបានជួបនឹងស្ថានភាពនេះ ហើយបានបង្រៀនសេចក្តីពិតដ៏សំខាន់ដល់កូនប្រុសរបស់គាត់ កូរីអានតុន ដែលបានប្រព្រឹត្តអំពើបាបអំឡុងពេលបម្រើបេសសកម្ម ។

មេរៀនទី ៩៦

អាលម៉ា ៣៩

សេចក្តីផ្តើម

អាលម៉ាស្តីបន្ទោសដល់កូនប្រុសដ៏ខូចខិលរបស់គាត់ កូរីអានតុន ដែលបានលះបង់ការបម្រើ ហើយប្រព្រឹត្តអំពើបាបខាងផ្លូវភេទ ។ អាលម៉ាបានបង្រៀនគាត់ពីភាពធ្ងន់ធ្ងរនៃសកម្មភាពរបស់គាត់ ហើយបានបង្ហាញពីការខកចិត្តដែលកូរីអានតុនបានធ្វើខុសនឹងអំពើបាបដ៏ធ្ងន់ធ្ងរបែបនោះ ។ អាលម៉ាបានបញ្ជាឲ្យកូនប្រុសរបស់គាត់ឈប់ដេញតាមចំណង់អ្វីដែលគាត់ឃើញនឹងភ្នែក ហើយប្រែចិត្ត ។ (ការបង្រៀនរបស់អាលម៉ាដល់កូរីអានតុនលើប្រធានបទផ្សេងទៀតនៅក្នុងជំពូក ៤០–៤២ ។)

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៣៩:១–៨

អាលម៉ាពន្យល់ដល់កូនប្រុសរបស់គាត់កូរីអានតុនពីភាពធ្ងន់ធ្ងរនៃអំពើបាបខាងផ្លូវភេទ

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖ *ហេតុអ្វីបានជាអំពើបាបខ្លះធ្ងន់ធ្ងរជាងអំពើបាបផ្សេងទៀត ?*

សូមឲ្យសិស្សគិតដោយស្ងាត់ស្ងៀមពីចម្លើយចំពោះសំណួរនេះ ។ សូមផ្តល់យោបល់ថា ការបង្រៀនរបស់អាលម៉ាដែលបានកត់ត្រានៅក្នុង អាលម៉ា ៣៩ អាចជួយយើងឲ្យយល់ពីលក្ខណៈធ្ងន់ធ្ងរនៃអំពើបាបមួយចំនួន ។

សូមឲ្យសិស្សមើលទៅកំណត់ចំណាំលើក្បាលជំពូកទី ៣៩ ។ សូមឲ្យពួកគេរកមើលនរណាដែលកំពុងនិយាយនៅក្នុងជំពូកនេះ ហើយគាត់កំពុងនិយាយទៅនរណា (អាលម៉ាកំពុងនិយាយទៅកាន់កូនប្រុសរបស់គាត់ កូរីអានតុន) ។ សូមពន្យល់ថា កូរីអានតុនបានរួមដំណើរនឹងបងប្រុសរបស់គាត់ សិ៊ាបឡុន និងអាលម៉ាដើម្បីទៅបង្រៀនដំណឹងល្អដល់ពួកសាសន៍ស្ងាំ ប៉ុន្តែគាត់បានធ្លាក់ទៅក្នុងអំពើបាប ។ សូមបង្ហាញថា ការយល់ពីអ្វីដែលកូរីអានតុនបានធ្វើខុស នឹងជួយសិស្សឲ្យយល់កាន់តែច្បាស់ពីការបង្រៀនរបស់អាលម៉ាដល់គាត់នៅក្នុងជំពូកនេះ និងជំពូកបីក្រោយទៀត ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣៩:១–៥ ឲ ៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលកូរីអានតុនបានធ្វើខុស ។ (អ្នកអាចពន្យល់ថាពាក្យ *ស្រីខូច* នៅក្នុងខទី ៣ សំដៅលើស្រីដែលអសីលធម៌ ឬស្រីរកស៊ីផ្លូវភេទ) ។

- តើកូរីអានតុនបានធ្វើអ្វីខុស ? តើអំពើបាបរបស់គាត់មួយណាដែលធ្ងន់ធ្ងរបំផុតនោះ ? (ភាពអសីលធម៌ខាងផ្លូវភេទ ។)
- ក្នុងចំណោមពួកសាសន៍ស្ងាំ កូរីអានតុនបានអួតពីកម្លាំង និងប្រាជ្ញារបស់គាត់ (សូមមើល អាលម៉ា ៣៩:២) ។ តើឥរិយាបថអួតអាងអាចនាំទៅរកអំពើបាបដ៏ធ្ងន់ធ្ងរដូចជាភាពអសីលធម៌ខាងផ្លូវភេទដោយរបៀបណា ? តើគំរូនៅសម័យនេះណាខ្លះនៃឥរិយាបថអួតអាងនាំមនុស្សឲ្យប្រព្រឹត្តអំពើបាបខាងផ្លូវភេទ ? (នៅពេលសិស្សពិភាក្សាពីសំណួរទាំងនេះ សូមបង្ហាញថា នៅពេលមនុស្សមានអំនួត ជាញឹកញាប់ពួកគេឲ្យតម្លៃលើកម្លាំងខ្លួនឯងខ្លាំងហួស រួមមានសមត្ថភាពក្នុងការប្រឆាំងនឹងការល្បួង ។ គំរូសម័យនេះខ្លះនៃការណាត់ជួបដៃគូនៅក្មេងពេក និងការណាត់ជួបដៃគូតែបុគ្គលម្នាក់) ។

សូមឲ្យសិស្សអាន អាលម៉ា ៣៩:៥ ដោយស្ងាត់ ៗ ដោយរកមើលរបៀបដែលអាលម៉ាបានពន្យល់ពីភាពធ្ងន់ធ្ងរនៃអំពើបាបខាងផ្លូវភេទ ។ (វាអាចជួយអ្នកបើអ្នកពន្យល់ថាពាក្យ *អំពើគួរខ្ពើមឆ្អើម* សំដៅលើអ្វីដែលមានបាប ទុច្ចរិត ឬអាក្រក់ ។)

- តើព្រះអម្ចាស់មានព្រះទ័យយ៉ាងណាអំពីអំពើបាបខាងផ្លូវភេទ ? (នៅពេលសិស្សឆ្លើយតប សូមជួយពួកគេឲ្យរកឃើញនូវសេចក្តីពិតថា **អំពើបាបខាងផ្លូវភេទ គឺជាអំពើគួរខ្ពើមឆ្អើមមួយនៅក្នុងព្រះនេត្រនៃព្រះអម្ចាស់) ។**
- តើអ្នកគិតថា ហេតុអ្វីបានជាកាមគុណ និងការផិតក្បត់ជាអំពើបាបដ៏ធ្ងន់ធ្ងរក្បែរនឹងឃាតកម្ម ?

ដើម្បីជួយសិស្សឲ្យយល់ពីបទដ្ឋានរបស់ព្រះអម្ចាស់ និងសេចក្តីសន្យាទាំងឡាយដែលទាក់ទងនឹងភាពបរិសុទ្ធខាងផ្លូវភេទ សូមឲ្យពួកគេអានឃ្លាពីរដំបូងនៃផ្នែក « ភាពបរិសុទ្ធខាងផ្លូវភេទ » នៅក្នុង *ដើម្បីកម្លាំងនៃយុវជន ដោយស្ងាត់ស្ងៀម* ។សូមឲ្យពួកគេរកមើលចម្លើយនឹងសំណួរខាងក្រោម នៅពេលពួកគេអាន ។ (អ្នកអាចសរសេរសំណួរនេះនៅលើក្តារខៀន ។ អ្នកក៏អាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំចម្លើយដែលពួកគេរកឃើញក្នុងកូនសៀវភៅ) ។

- តើមានប្រយោជន៍អ្វីខ្លះ ក្នុងការរក្សាមានភាពបរិសុទ្ធខាងផ្លូវភេទ ?

ក្រោយពីសិស្សមានពេលអាន និងរៀបរាប់ចម្លើយដែលពួកគេរកឃើញហើយ សូមឲ្យពួកគេអានផ្នែក « ភាពបរិសុទ្ធខាងផ្លូវភេទ» ទាំងអស់ដោយស្ងាត់ ៗ ដោយរកមើលចម្លើយចំពោះសំណួរខាងក្រោម ៖

- តើបទដ្ឋានអ្វីដែលព្រះអម្ចាស់បានដាក់សម្រាប់ឲ្យយើងរក្សាបរិសុទ្ធភាពខាងផ្លូវភេទ ?

សូមឲ្យសិស្សសញ្ជឹងគិតពីសារលិខិតអ្វីដែលពួកគេមានអារម្មណ៍ថា ព្រះអម្ចាស់នឹងឲ្យពួកគេរៀនពីអ្វីដែលពួកគេទើបតែបានអាននោះ ។ សូមថ្លែងទីបន្ទាល់ពីភាពធ្ងន់ធ្ងរនៃអំពើបាបខាងផ្លូវភេទ និងពីពរជ័យដែលមកពីការមានបរិសុទ្ធភាពខាងផ្លូវភេទ ។

សូមបង្ហាញថា ដោយការប្រឹក្សាដល់កូនប្រុសរបស់គាត់អំពីបញ្ហាដ៏ធ្ងន់នេះ អាលម៉ាបានបំពេញកាតព្វកិច្ចរបស់គាត់ជាឪពុកម្នាក់ ។ សូមឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេអាចឆ្លើយតបនឹងការប្រឹក្សាពីឪពុកម្តាយរបស់ពួកគេ ឬ អ្នកដឹកនាំសាសនាចក្រទាក់ទង

នឹងភាពបរិសុទ្ធខាងផ្លូវភេទ ។ សូមឲ្យពួកគេអាន អាលម៉ា ៣៩:៧–៨ ដោយស្ងាត់ៗ ដោយរកមើលគោលបំណងរបស់អាលម៉ាក្នុងការបង្រៀនកូរីអានតុនពីភាពធ្ងន់ធ្ងរនៃអំពើបាបខាងផ្លូវភេទនេះ ។

- តើអ្វីជាមូលហេតុរបស់អាលម៉ាសម្រាប់ការបង្រៀនកូរីអានតុនអំពីភាពធ្ងន់ធ្ងរនៃអំពើបាបរបស់គាត់ ? (ដើម្បីជួយកូរីអានតុនឲ្យប្រែចិត្ត ដើម្បីឲ្យគាត់នឹងមិនត្រូវឈរមានទោសចំពោះមុខព្រះ) ។
- តើយើងគួរឆ្លើយតបយ៉ាងណា នៅពេលនរណាម្នាក់សុំយើងឲ្យប្រែចិត្ត ?

ដើម្បីជួយសិស្សឲ្យយល់ពីមូលហេតុដែលឪពុកម្តាយ ដូចជា អាលម៉ា នឹងសុំឲ្យកូនៗប្រែចិត្ត សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« ការអញ្ជើញឲ្យប្រែចិត្តគឺជាការបង្ហាញនៃសេចក្តីស្រឡាញ់មួយ ។ . . . ប្រសិនបើយើងមិនអញ្ជើញឲ្យអ្នកដទៃផ្លាស់ប្តូរ ឬ ប្រសិនបើយើងមិនទាមទារការប្រែចិត្តពីខ្លួនយើងទេ យើងនឹងបរាជ័យក្នុងកាតព្វកិច្ចគ្រិះមួយដែលយើងមានចំពោះគ្នាទៅវិញទៅមក និងចំពោះខ្លួនយើង ។ ឪពុកម្តាយដ៏មានសណ្តោស មិត្តភក្តិដ៏មានសណ្តានចិត្ត អ្នកដឹកនាំសាសនាចក្រដ៏បារម្ភម្នាក់គឺតាមពិតមានការខ្វល់ខ្វាយពីខ្លួនឯងជាងសុខុមាលភាព និងសុភមង្គលនៃអ្នកដែលពួកគេអាចជួយ ។ មែនហើយ ការហៅឲ្យប្រែចិត្តពេលខ្លះចាត់ទុកថាដូចជាមិនសណ្តោស ឬបំបាក់មុខ ហើយពេលខ្លះអាចថែមទាំងអន់ចិត្ត ប៉ុន្តែបានដឹកនាំដោយព្រះវិញ្ញាណ ការពិតវាជាសកម្មភាពមួយនៃការថែទាំដ៏ខ្លាំងក្លា » (« The Divine Gift of Repentance »*Ensign*ឬ*លេអាហូណា*,ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ៣៩) ។

អាលម៉ា ៣៩:៩–១៩

អាលម៉ាណែនាំកូរីអានតុនឲ្យប្រែចិត្ត

ដើម្បីណែនាំការបង្រៀនដែលអាលម៉ាបានផ្តល់ដល់កូនប្រុសរបស់គាត់អំពីរបៀបដើម្បីប្រែចិត្ត និងត្រឡប់មកកាន់ព្រះអម្ចាស់វិញ សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ការប្រែចិត្តរួមមាន . . .*

អាលម៉ា ៣៩:៩ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមយោងទៅគំនិតនៃការបង្រៀនទាំងឡាយនៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សឲ្យចាំចំណេះចំណានខគម្ពីរលើវគ្គនេះ ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗ អាលម៉ា ៣៩:៩–១៣ ។ សូមឈប់នៅចន្លោះខគម្ពីរនីមួយៗដើម្បីសួរសិស្សនូវសំណួរខាងក្រោម ៖

អាលម៉ា ៣៩:៩

- តើ « លះបង់ចោលអំពើបាបទាំងឡាយរបស់កូន » មានន័យយ៉ាងណា ? (ឈប់ប្រព្រឹត្តវាទៀត) ។
- តើឃ្លា « កុំទៅតាមសេចក្តីសម្រើបនៃភ្នែករបស់ខ្លួនទៀតឡើយ » និង « ត្រូវចៀសវាងនូវអំពើទាំងនេះ » មានន័យយ៉ាងណាចំពោះការលះបង់ចោលអំពើបាប ? (វាអាចជួយច្រើនបើអ្នកពន្យល់ថា នៅក្នុងជំនាន់របស់យើងឃ្លា « សេចក្តីសម្រើបនៃភ្នែករបស់ខ្លួន » អាចសំដៅលើរូបភាព និងតន្ត្រីដែលមានរូបអាសអាភាសតាមគ្រប់មធ្យោបាយ ។ ដើម្បីបញ្ជាក់ពីគ្រោះថ្នាក់នៃរូបអាសអាភាស សូមគិតពីការសុំសិស្សឲ្យអានការបង្រៀនលើប្រធានបទនេះក្នុងទំព័រ ១២ នៃ *កម្លាំងនៃយុវជន* ។អ្នកក៏អាចពន្យល់ថាឃ្លា « ចៀសវាង » មានន័យយ៉ាងត្រូវអនុវត្តការគ្រប់គ្រង់ខ្លួនឯង ឬ ការបញ្ឈប់ខ្លួនឯង ; សូមមើល លេខយោង *ខ*) ។
- តើពួកបរិសុទ្ធថ្ងៃចុងក្រោយក្មេងៗអាចអនុវត្តការគ្រប់គ្រងខ្លួនឯងលើបញ្ហាបរិសុទ្ធភាពខាងផ្លូវភេទ និងចៀសវាងសេចក្តីសម្រើបនៃភ្នែករបស់ខ្លួនតាមរបៀបណាខ្លះ ? (ដើម្បីជួយសិស្សឲ្យពិភាក្សាពីសំណួរនេះកាន់តែលម្អិត អ្នកអាចពិពណ៌នាពីស្ថានភាពខ្លះដែលទាក់ទងនឹងវប្បធម៌ និងកាលៈទេសៈរបស់សិស្សអ្នក ។ ឧទាហរណ៍ អ្នកអាចនិយាយពីអ្វីមួយដូចខាងក្រោម ៖ យុវនារីបរិសុទ្ធថ្ងៃចុងក្រោយបានសម្រេចចិត្តដើម្បី « ចៀសវាងខ្លួនឯង » ប៉ុន្តែពេលនោះមានយុវជនដែលនាងកោតសរសើរម្នាក់បានអញ្ជើញនាងឲ្យទៅពិធីជប់លៀងដ៏មិនសមរម្យមួយ ។ តើនាងគួរឆ្លើយតបយ៉ាងណា ?)

សូមបង្ហាញថា អាលម៉ា ៣៩:៩ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ អ្នកអាចស្នើថា សិស្សគួរគូសចំណាំវគ្គនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ដើម្បីឲ្យពួកគេអាចរកឃើញវាងាយស្រួល ។

អាលម៉ា ៣៩:១០

- តើការស្វែងរកការថែទាំខាងវិញ្ញាណ —អាចជាឪពុកម្តាយ អ្នកដឹកនាំសាសនាចក្រ បងប្អូនបង្កើត ឬ មិត្តដ៏ទុកចិត្តម្នាក់— អាចជួយយើងឲ្យប្រែចិត្តតាមរបៀបណា ?

អាលម៉ា ៣៩:១១

- តើ « កុំបណ្តោយខ្លួនឲ្យវង្វេង » មានន័យយ៉ាងណា ? (អ្នកអាចពន្យល់ថាពាក្យ *បណ្តោយ* មានន័យថាអនុញ្ញាតឲ្យ ។)
- តើអ្វីខ្លះជា « ការឥតប្រយោជន៍ ឬ ឆ្គួតលីលា » ដែលអ្នកឃើញថាមនុស្សត្រូវឈ្លក់វង្វេងនាសព្វថ្ងៃនេះ ?

អាលម៉ា ៣៩:១២

- តើវាមានន័យយ៉ាងណាដើម្បីឈប់ធ្វើនូវអំពើទុច្ចរិត ? (ចៀសវាងអំពើបាប) ។

អាលម៉ា ៣៩:១៣

សូមពន្យល់ថា ការប្រែចិត្តមានន័យថា « ការប្រែដួងចិត្ត និងឆន្ទៈទៅរកព្រះ » (សូមមើលBible Dictionary, “Repentance”) ។ នៅក្នុងព្រះគម្ពីរឃ្លា « បែរទៅរកព្រះអម្ចាស់ » ជាធម្មតាជាសញ្ញានៃការប្រែចិត្ត ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « បែរទៅរកព្រះអម្ចាស់ដោយអស់ពីដួងចិត្ត និងអស់សមត្ថភាព និងអស់កម្លាំង » ?

សូមរំឭកសិស្សថា អំឡុងពេលបេសកកម្មបម្រើដល់ពួកសាសន៍ស្លាំ ការប្រព្រឹត្តរបស់ភូមីអានតុនបានដឹកនាំប្រជាជនខ្លះមិនជឿលើសម្តីរបស់អាលម៉ា (សូមមើល អាលម៉ា ៣៩:១១) ។

- នៅពេលអំពើបាបរបស់យើងជះឥទ្ធិពលដល់អ្នកដទៃ តើយើងត្រូវធ្វើអ្វីជាផ្នែកនៃការប្រែចិត្តរបស់យើង ? (ការទទួលស្គាល់ ឬ សារភាពពីកំហុសរបស់យើងដល់អ្នកដែលយើងបានធ្វើបាប ហើយត្រូវរកវិធីព្យាបាលការឈឺចុកនោះ) ។

សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***ការប្រែចិត្តរួមមានការទទួលស្គាល់ និងការលះបង់ចោលនូវអំពើបាបរបស់យើង ហើយបែរទៅរកព្រះអម្ចាស់ដោយអស់ពីដួងចិត្ត និងអស់សមត្ថភាព និងអស់កម្លាំង ។*** អ្នកអាចផ្តល់យោបល់ថា សិស្សគួរសរសេរប្រយោគនេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ៣៩:១៣ ។ សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពីអ្វីដែលពួកគេមានអារម្មណ៍ថា ព្រះអម្ចាស់នឹងចង់ឲ្យពួកគេធ្វើដើម្បីបែរដួងចិត្ត និងឆន្ទៈរបស់គេទៅរកទ្រង់ដោយពេញលេញជាងនេះ ។

ដើម្បីបញ្ជាក់ពីតួនាទីរបស់ព្រះអម្ចាស់នៅក្នុងដំណើរការនៃការប្រែចិត្ត សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៣៩:១៥–១៦, ១៩ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលឃ្លាមួយ ដែលលើកឡើងបីដងនៅក្នុងខគម្ពីរទាំងនេះ ។ (ឃ្លានោះគឺ « ដំណឹងដ៏រីករាយ » ដែលអ្នកអាចពន្យល់ថាវាមានន័យថា « ដំណឹងល្អ ») ។

- តើ « ដំណឹងល្អដ៏រីករាយ» អ្វីដែលអាលម៉ាបានបង្រៀនកូនប្រុសរបស់គាត់ ? (ក្នុងចំណោមចម្លើយដែលសិស្សឆ្លើយគួរបង្ហាញសេចក្តីពិតថា **ព្រះយេស៊ូវគ្រីស្ទបានមកដើម្បីនាំអំពើបាបចេញពីពិភពលោក ។** អ្នកអាចសរសេរវានៅលើក្តារខៀន) ។
- ហេតុអ្វីបានជាការយោងមកនៃព្រះយេស៊ូវគ្រីស្ទជាដំណឹងល្អសម្រាប់ភូមីអានតុន ? (នៅពេលសិស្សឆ្លើយនឹងសំណួរនេះ អ្នកអាចប្រាប់ពួកគេថា ភូមីអានតុនបានប្រែចិត្តពីអំពើបាបរបស់គាត់ក្រោយមក ហើយបានត្រឡប់ទៅជាអ្នកផ្សព្វផ្សាយសាសនាវិញ [សូមមើលអាលម៉ា ៤៩:៣០]) ។

សូមគិតពីការចែកចាយដល់សិស្សនូវរបៀបដែលសារលិខិតនៃដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទបានក្លាយជា « ដំណឹងដ៏រីករាយ » សម្រាប់អ្នក ឬអ្នកដែលស្គាល់ ។ សូមបន្ថែមទីបន្ទាល់របស់អ្នកទាក់ទងនឹងគោលការណ៍ដែលសិស្សបានពិភាក្សាពី អាលម៉ា ៣៩ ។ សូមណែនាំឲ្យសិស្សធ្វើតាមការបំផុសគំនិតដែលពួកគេបានទទួល អំឡុងពេលមេរៀនដើម្បីការពារដល់បរិសុទ្ធភាពរបស់គេ ហើយបែរទៅរកព្រះអម្ចាស់តាមរយៈការប្រែចិត្ត ។

ចំណេះចំណានខគម្ពីរ—អាលម៉ា ៣៩:៩

សូមបែងចែកសិស្សទៅជាក្រុមមានសមាជិកប្លន់ទៅប្រាំនាក់ ។ សូមឲ្យក្រុមនីមួយៗនូវគ្រាប់ឡុកឡាក់មួយ និងខ្មៅដៃមួយ ។ (ប្រសិនបើគ្មានគ្រាប់ឡុកឡាក់ទេ សូមគិតពីការសម្របសកម្មភាពនេះដោយការដាក់ក្រដាសតូចៗប្រាំមួយ ដោយក្រដាសនីមួយៗមានសរសេរលេខពីមួយដល់ប្រាំមួយ នៅក្នុងស្រោមសំបុត្រ ឬប្រអប់ផ្សេងទៀត) ។ សិស្សម្នាក់ៗក៏នឹងត្រូវមានក្រដាសទទេមួយដែរ ។ សូមសមាជិកក្រុមនីមួយៗអង្គុយជិតគ្នាជុំវិញតុមួយ ឬ អង្គុយជារង្វង់មួយ ។ សូមឲ្យពួកគេបើកព្រះគម្ពីររបស់ពួកគេទៅ អាលម៉ា ៣៩:៩ ។

សូមពន្យល់ថា កម្មវត្ថុនៃសកម្មភាពនេះគឺដើម្បីឲ្យបុគ្គលទីមួយនៅក្នុងក្រុមសរសេរ អាលម៉ា ៣៩:៩ ពេញលេញពីខនេះ ។ ទោះយ៉ាងណាក្តី ដោយសារមានតែខ្មៅដៃមួយក្នុងមួយក្រុម នោះបុគ្គលក្នុងក្រុមត្រូវសរសេរម្តងម្នាក់ៗ ។ បុគ្គលម្នាក់អាចប្រើខ្មៅដៃបានដោយការចោះគ្រាប់ឡុកឡាក់ត្រូវនឹងលេខ ១ ។

សូមឲ្យសមាជិកក្នុងក្រុមនីមួយៗប្តូរវេនគ្នាចោះគ្រាប់ឡុកឡាក់ (ឬចាប់យកក្រដាសមួយ ហើយដាក់វាទៅក្នុងស្រោមសំបុត្រវិញ) ។ នៅពេលបុគ្គលម្នាក់ចោះ (រើសបាន) លេខ ១ គាត់ត្រូវយកខ្មៅដៃ ហើយចាប់ផ្តើមសរសេរ ដោយអានឮៗនូវពាក្យដែលគាត់កំពុងសរសេរ ។ ទន្ទឹមពេលនេះដែរ អ្នកផ្សេងទៀតនៅក្នុងក្រុមប្តូរវេនគ្នាចោះគ្រាប់ឡុកឡាក់ដើម្បីអាចប្រើខ្មៅដៃ ។ នៅពេលសិស្សផ្សេងទៀតនៅក្នុងក្រុមចោះបានលេខ ១ បុគ្គលនោះត្រូវយកខ្មៅដៃពីអ្នកសរសេរមុន ហើយចាប់ផ្តើមសរសេរខគម្ពីរនោះនៅលើក្រដាសគេ ខណៈពេលអានឮៗនូវពាក្យនោះ ។ អ្នកសរសេរមុនត្រូវចូលរួមនឹងសមាជិកក្រុមម្តងទៀតដើម្បីចោះគ្រាប់ឡុកឡាក់ ។ នៅពេលសិស្សអាចប្រើខ្មៅដៃ ហើយបានសរសេរផ្នែកមួយនៃខគម្ពីរនៅលើក្រដាសរបស់គេហើយ ពួកគេត្រូវអានវាឮៗនូវផ្នែកដែលពួកគេបានសរសេរមុនពេលសរសេរខគម្ពីរបន្ថែមទៀត ។ (ការណ៍នេះផ្តល់នូវការធ្វើសារឡើងវិញ ដែលនឹងជួយសិស្សឲ្យចងចាំខគម្ពីរនេះ) ។ សកម្មភាពនេះបញ្ចប់នៅពេលសិស្សម្នាក់ពីក្រុមនីមួយៗសរសេរ អាលម៉ា ៣៩:៩ បានពេញទាំងមូលចប់ ។

សូមឲ្យសិស្សក្នុងថ្នាក់អានខឡើងវិញទាំងអស់គ្នាក្រោយពីបញ្ចប់សកម្មភាពនេះ ។

កំណត់ចំណាំ ៖ ដោយសារតែលក្ខណៈ និងប្រវែងនៃមេរៀននេះ អ្នកអាចប្រើសកម្មភាពនេះនៅថ្ងៃក្រោយ នៅពេលអ្នកមានពេលបន្ថែម ។

អាលម៉ា ៤០

សេចក្តីផ្តើម

នៅពេលអាលម៉ាបានព្រមានដល់កូនប្រុសរបស់គាត់ កូរីអានតុន អំពីលទ្ធផលនៃអំពើបាប គាត់ដ៏បានបង្រៀនអំពីជីវិតក្រោយសេចក្តីស្លាប់ដែរ ។ គាត់បានពន្យល់ថា តាមរយៈ ជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ មនុស្សទាំងអស់នឹងត្រូវរស់ឡើងវិញ ។ គាត់បានបង្រៀនអំពី ពិភពវិញ្ញាណ ដែលអ្នកស្លាប់ ដោយផ្អែកលើជម្រើសរបស់ពួកគេនៅក្នុងជីវិតមែងស្លាប់ រង់ចាំ ទាំងនៅក្នុងស្ថានបរមសុខ ឬ ក្នុងគុកហួតដល់ការរស់ឡើងវិញ ។

កំណត់ចំណាំ ៖ នៅក្នុងមេរៀននេះ សិស្សនឹងមានឱកាសបង្រៀនដល់គ្នាទៅវិញទៅមក ។ មុនចាប់ផ្តើមបង្រៀន សូមរៀបចំក្រដាសដែលមានការណែនាំសម្រាប់ភាពជាដៃគូ ។ សូមយល់ពីការណែនាំនីមួយៗ ដើម្បីអ្នកអាចជួយសិស្ស នៅពេលពួកគេរៀបចំបង្រៀន ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៤០

អាលម៉ាបង្រៀនកូរីអានតុនអំពីពិភពវិញ្ញាណ និងការរស់ឡើងវិញ

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀនមុនពេលបង្រៀន ៖

១. តើវាអាចកើតមានសម្រាប់យើងដើម្បីរស់នៅក្រោយពីយើងស្លាប់ទេ ? តើនរណានឹងត្រូវរស់ឡើងវិញ ?

២. តើយើងនឹងទៅកន្លែងណា នៅពេលយើងស្លាប់ ? តើវាមានសភាពដូចម្តេចនៅទីនោះ ?

៣. តើអ្វីទៅជាការរស់ឡើងវិញ ? តើរាងកាយដែលរស់ឡើងវិញរបស់យើងនឹងខុសពីរាងកាយខាងសាច់ឈាមរបស់យើងដោយរបៀបណា ? តើយើងនឹងធ្វើអ្វី ក្រោយពីយើងបានរស់ឡើងវិញ ?

សូមឲ្យសិស្សស្រមៃថា ពួកគេគឺជាអ្នកផ្សព្វផ្សាយសាសនា ហើយថាពួកគេមានការណាត់ជួបនឹងនរណាម្នាក់ដែលកំពុងស្វែងរកចម្លើយនឹងសំណួរដែលបានសរសេរនៅលើក្តារខៀននេះ ។ សូមពន្យល់ថា អាលម៉ា ៤០ គឺជាការបន្តនៃការបង្រៀនរបស់អាលម៉ាដល់កូនប្រុសរបស់គាត់កូរីអានតុន និងរួមមានចម្លើយទៅនឹងសំណួរទាំងនោះ ។

សូមឲ្យសិស្សអាន អាលម៉ា ៤០:១ ដោយស្ងាត់ៗ ។ សូមឲ្យសិស្សរកមើលមូលហេតុដែលអាលម៉ាបានពិភាក្សាពីការរស់ឡើងវិញជាមួយនឹងកូនប្រុសរបស់គាត់ ។

- ហេតុអ្វីបានជាអាលម៉ាបង្រៀនកូរីអានតុនអំពីការរស់ឡើងវិញ ?
- នៅពេលអ្នករំឭកពីជម្រើសរបស់កូរីអានតុន ហេតុអ្វីបានជាគាត់អាចបារម្ភអំពីការរស់ឡើងវិញ ?

សូមជួយសិស្សជាដៃគូ ឬក្រុម

នៅពេលសិស្សធ្វើការជាដៃគូ ឬជាក្រុម សូមគិតពីការដើរមើលក្នុងថ្នាក់ ហើយស្តាប់ការពិភាក្សារបស់ពួកគេ ។ ការណ៍នេះអាចជួយអ្នកឲ្យដឹងពីពេលវេលាដែលពួកគេត្រូវការដើម្បីបំពេញកិច្ចការរបស់ពួកគេ ។ វាក៏អាចឲ្យអ្នកស្តាប់សិស្សចែកចាយគំនិតដែលអាចចង់យោងនាពេលក្រោយក្នុងមេរៀននេះ ។ សូមចំណាំថា ជាញឹកញាប់សិស្សនឹងមានអារម្មណ៍សុំនឹងការដែលអ្នកស្តាប់ការពិភាក្សារបស់ពួកគេ នៅពេលអ្នកសរសេរដល់ពួកគេចំពោះការខិតខំប្រឹងនិងគំនិតរបស់ពួកគេ ។

សូមបែងចែកសិស្សជាដៃគូ ។ សូមឲ្យដៃគូនីមួយៗនូវលេខមួយ ៖ ១, ២, ឬ ៣ ។ សូមឲ្យដៃគូនីមួយៗធ្វើការហាក់ដូចជាពួកគេជាដៃគូផ្សព្វផ្សាយសាសនា ដោយរៀបចំបង្រៀនមេរៀនដ៏ខ្លីមួយដើម្បីឆ្លើយតបនឹងសំណួរនៅលើក្តារខៀនដែលសឹគ្នានឹងលេខកិច្ចការរបស់ពួកគេ ។ ដើម្បីជួយពួកគេឲ្យរៀបចំ សូមឲ្យពួកគេនូវច្បាប់ចម្លងនៃការណែនាំដែលសឹគ្នានឹងលេខរបស់ពួកគេ (សូមមើលខាងក្រោម) ។ នៅពេលសិស្សធ្វើការ អ្នកអាច ដើរមើលក្នុងថ្នាក់ ដើម្បីអ្នកអាចស្តាប់ និងជួយនៅពេលចាំបាច់ ។

ដៃគូទី ១—អាលម៉ា ៤០:១–៥

សំណួរ ៖ តើវាអាចកើតមានដល់យើងដើម្បីរស់នៅក្រោយពីយើងស្លាប់ទេ ? តើនរណានឹងត្រូវរស់ឡើងវិញ ?

សូមរៀបចំប្រើ អាលម៉ា ៤០:១–៥ ដើម្បីឆ្លើយតបនឹងសំណួរទាំងនេះ ។ នៅពេលអ្នករៀបចំ សូមសម្រេចថាផ្នែកណានៃមេរៀនដែលដៃគូនីមួយៗនឹងបង្រៀន ។ សូមត្រៀមខ្លួនដើម្បីធ្វើដូចខាងក្រោម ៖

សូមឲ្យព័ត៌មានខ្លះសម្រាប់វគ្គដែលអ្នកដាក់នោះ ។ (នៅពេលអ្នកបង្រៀនពីព្រះគម្ពីរ សូមពន្យល់នរណាកំពុងនិយាយ នរណាកំពុងស្តាប់ ហើយកាលៈទេសៈផ្សេងទៀតដែលអាចជួយដល់អ្នករៀនឲ្យយល់ពីវគ្គនេះ) ។

សូមអានខគម្ពីរដែលឆ្លើយតបនឹងសំណួរ ។ សូមពន្យល់ពីរបៀបដែលសេចក្តីពិតក្នុងខគម្ពីរទាំងនេះជួយឆ្លើយនឹងសំណួរទាំងឡាយ ។ នៅពេលអ្នកធ្វើដូច្នោះ សូមប្រាកដថាគ្រប់គ្នាយល់ថា **ដោយសារតែព្រះយេស៊ូវគ្រីស្ទ មនុស្សទាំងអស់នឹងត្រូវរស់ឡើងវិញ ។** អ្នកក៏អាចផ្តល់យោបល់ថា អ្នកដែលអ្នកកំពុងបង្រៀនគួរសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ៤០:១–៥ ។

សូមចែកចាយពីមូលហេតុដែលសេចក្តីសន្យានៃការរស់ឡើងវិញសំខាន់ដល់អ្នក ។ អ្នកក៏អាចសួរឲ្យអ្នកដែលអ្នកបង្រៀនថា ហេតុអ្វីបានជាពួកគេកោតសរសើរដល់សេចក្តីសន្យានៃការរស់ឡើងវិញ ។

សូមថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលអ្នកបានបង្រៀន ។

ដៃគូទី ២—អាលម៉ា ៤០:៦–១៤

សំណួរ ៖ តើយើងនឹងទៅកន្លែងណា នៅពេលយើងស្លាប់ ? តើវាមានសភាពយ៉ាងណានៅទីនោះ ?

សូមរៀបចំប្រើ អាលម៉ា ៤០:៦–៧, ១១–១៤ ដើម្បីឆ្លើយសំណួរទាំងនេះ ។ នៅពេលអ្នករៀបចំ សូមសម្រេចថាផ្នែកណានៃមេរៀនដែលដៃគូនីមួយៗនឹងបង្រៀន ។ សូមត្រៀមខ្លួនដើម្បីធ្វើដូចខាងក្រោម ៖

សូមឲ្យព័ត៌មានខ្លះសម្រាប់វគ្គដែលអ្នកដាក់នោះ ។ (នៅពេលអ្នកបង្រៀនពីព្រះគម្ពីរ សូមពន្យល់នរណាកំពុងនិយាយ នរណាកំពុងស្តាប់ ហើយកាលៈទេសៈផ្សេងទៀតដែលអាចជួយដល់អ្នករៀនឲ្យយល់ពីវគ្គនេះ) ។

សូមអានខគម្ពីរដែលឆ្លើយតបនឹងសំណួរ ។ សូមពន្យល់ពីរបៀបដែលសេចក្តីពិតក្នុងខគម្ពីរទាំងនេះជួយឆ្លើយនឹងសំណួរទាំងឡាយ ។ (វាអាចជួយពេលអ្នកបង្ហាញថា នៅពេលអាលម៉ាបានប្រើឃ្លា « ភាពងងឹតខាងក្រៅ » គាត់មិនសំដៅលើសភាពចុងក្រោយរបស់សាតាំង និងអ្នកដែលត្រូវបណ្តាសានោះឡើយ ។ គាត់បានសំដៅលើសភាពនៃភាពទុច្ចរិតរវាងពេលនៃការស្លាប់របស់ពួកគេ និងពេលនៃការរស់ឡើងវិញរបស់ពួកគេ ។ សព្វថ្ងៃនេះ ជាធម្មតាយើងសំដៅលើសភាពនេះថាជាគុកខាងវិញ្ញាណ) ។ នៅពេលអ្នកអានខគម្ពីរទាំងនេះ សូមប្រាកដថាគ្រប់គ្នាយល់ថា **នៅចន្លោះសេចក្តីស្លាប់ និងការរស់ឡើងវិញ វិញ្ញាណទាំងឡាយនៃពួកសុចរិតនឹងរស់នៅក្នុងស្ថានបរមសុខ ហើយវិញ្ញាណនៃពួកទុច្ចរិតនឹងរស់នៅក្នុងគុក ។** អ្នកអាចផ្តល់យោបល់ថា អ្នកដែលអ្នកកំពុងបង្រៀនគួរសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកកេក្បែរ អាលម៉ា ៤០:១១–១៤ ។

សូមចែកចាយពីរបៀបដែលការយល់របស់អ្នកពីសេចក្តីពិតនេះមានឥទ្ធិពលដល់ជម្រើសដែលអ្នកនឹងធ្វើនៅក្នុងជីវិតនេះ ។ អ្នកក៏អាចសួរដល់សិស្សថា តើការយល់របស់ពួកគេពីជីវិតក្រោយសេចក្តីស្លាប់បានជួយដល់ពួកគេយ៉ាងណាខ្លះ ។

សូមថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលអ្នកបានបង្រៀន ។

ដៃគូទី ៣—អាលម៉ា ៤០:២១–២៦

សំណួរ ៖ តើអ្វីទៅជាការរស់ឡើងវិញ ? តើរាងកាយដែលរស់ឡើងវិញរបស់យើងនឹងខុសគ្នាពីរាងកាយនៃជីវិតរមែងស្លាប់របស់យើងដោយរបៀបណា ? តើយើងនឹងធ្វើអ្វី ក្រោយពីយើងបានរស់ឡើងវិញ ?

សូមរៀបចំប្រើ អាលម៉ា ៤០:២១–២៦ដើម្បីឆ្លើយសំណួរទាំងនេះ ។ នៅពេលអ្នករៀបចំ សូមសម្រេចថាផ្នែកណានៃមេរៀនដែលដៃគូនីមួយៗនឹងបង្រៀន ។ សូមត្រៀមខ្លួនដើម្បីធ្វើដូចខាងក្រោម ៖

សូមឲ្យព័ត៌មានខ្លះសម្រាប់វគ្គដែលអ្នកដាក់នោះ ។ (នៅពេលអ្នកបង្រៀនពីព្រះគម្ពីរ សូមពន្យល់នរណាកំពុងនិយាយ នរណាកំពុងស្តាប់ ហើយកាលៈទេសៈផ្សេងទៀតដែលអាចជួយដល់អ្នករៀនឲ្យយល់ពីវគ្គនេះ) ។

សូមអានខគម្ពីរដែលឆ្លើយតបនឹងសំណួរ ។ សូមពន្យល់ពីរបៀបដែលសេចក្តីពិតក្នុងខគម្ពីរទាំងនេះជួយឆ្លើយនឹងសំណួរទាំងឡាយ ។ (នៅពេលអ្នករៀបចំបង្រៀន វាអាចជួយពេលអ្នកយល់ថាពាក្យ*ព្រលឹង*នៅក្នុងខគម្ពីរទាំងនេះសំដៅលើវិញ្ញាណរបស់មនុស្សម្នាក់) ។ សូមប្រាកដថាគ្រប់គ្នាយល់ថា **ការរស់ឡើងវិញគឺជាការរួបរួមនៃវិញ្ញាណ និងរាងកាយដោយអ្វីៗទាំងអស់នឹងត្រូវបានស្តារឡើងវិញដល់ភាពពេញលេញ និងភាពឥតខ្ចោះរបស់ពួកគេ ។** អ្នកអាចផ្តល់យោបល់ថា អ្នកដែលអ្នកកំពុងបង្រៀនគួរសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ៤០:២១–២៣ ។

សូមចែកចាយពីមូលហេតុដែលអ្នកមានសេចក្តីអំណរដែលរាងកាយ និងវិញ្ញាណរបស់អ្នកនឹងត្រូវស្តារឡើងវិញនៅថ្ងៃមួយដល់ភាពពេញលេញ និងឥតខ្ចោះរបស់វា ។ អ្នកក៏អាចរៀបរាប់ពីរបៀបដែលជម្រើសរបស់អ្នកត្រូវបានជះឥទ្ធិពលដោយចំណេះដឹងរបស់អ្នកថា អ្នកនឹងឈរនៅចំពោះមុខព្រះ និងត្រូវកាត់សេចក្តីនៅថ្ងៃមួយ ។ សូមឲ្យសិស្សចែកចាយពីអារម្មណ៍របស់គេអំពីគោលលទ្ធិនៃការរស់ឡើងវិញ និងការជំនុំជម្រះនៅថ្ងៃចុងក្រោយ ។

សូមថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលអ្នកបានបង្រៀន ។

ក្រោយពីសិស្សបានរៀបចំឆ្លើយនឹងសំណួរក្នុងកិច្ចការរបស់ពួកគេហើយ សូមរៀបចំឲ្យពួកគេធ្វើការក្នុងក្រុមតូចៗដើម្បីឲ្យពួកគេអាចបង្រៀនដល់គ្នាទៅវិញទៅមកនៅក្នុងការដើរតួជាអ្នកផ្សព្វផ្សាយសាសនា ។ ក្រុមនីមួយៗគួរមានដៃគូបី ដោយដៃគូនីមួយៗបានរៀបចំចម្លើយចំពោះសំណួរខុសៗគ្នា ។ (ប្រសិនបើមានសិស្សតិច សូមឲ្យក្រុមនីមួយៗបង្រៀនដល់សិស្សក្នុងថ្នាក់ទាំងមូល) ។ សូមណែនាំសិស្សឲ្យក្លាយជាខ្លួនគេ នៅពេលពួកគេបង្រៀន និងនៅបេលពួកគេរៀនពីអ្នកដទៃអំឡុងពេលដើរតួ ។ សូមធានាពួកគេថា ព្រះវិញ្ញាណបរិសុទ្ធអាចបំផុសគំនិតដល់ពួកគេ និងដល់អ្នកដែលពួកគេបង្រៀន ប្រសិនបើពួកគេស្មោះត្រង់នៅក្នុងការណែនាំ និងចម្លើយរបស់ពួកគេ ។ សូមស្តាប់ នៅពេលពួកគេបង្រៀនដល់គ្នាទៅវិញទៅមក ហើយសូមផ្តល់គំនិតនៅពេលអ្នកមានអារម្មណ៍ថាបានបំផុស ។

ក្រោយពីសិស្សមានពេលបង្រៀនដល់គ្នាទៅវិញទៅមកនៅក្នុងក្រុមហើយ សូមគិតពីការសួរសិស្សនូវសំណួរខាងក្រោមខ្លះ ៖

- តើអ្នកបានរៀនអ្វី នៅពេលអ្នកបានរៀបចំឆ្លើយនឹងសំណួរក្នុងកិច្ចការរបស់អ្នក ? តើអ្នកបានរៀនអ្វីខ្លះ នៅពេលអ្នកត្រូវបានបង្រៀនដោយដៃគូដទៃទៀត ?
- ដោយដឹងថា ក្បាលអានតុនបានតស៊ូក្នុងការគោរពតាមច្បាប់នៃបរិសុទ្ធភាព តើអ្នកគិតថា ការយល់ពីលក្ខណៈនៃជីវិតក្រោយពីសេចក្តីស្លាប់អាចជួយគាត់ឲ្យតស៊ូនឹងការល្បួងនាពេលខាងមុខដោយរបៀបណា ?
- ហេតុអ្វីបានជាសេចក្តីពិតដែលយើងបានពិភាក្សាថ្ងៃនេះមានន័យដល់អ្នកយ៉ាងណា ?

សូមឲ្យសិស្សអាន អាលម៉ា ៤០:២៥–២៦ ដោយស្ងាត់ៗ ដោយរកមើលភាពខុសគ្នារវាងសភាពទីបញ្ចប់នៃពួកសុចរិត និងសភាពទីបញ្ចប់នៃពួកទុច្ចរិត ។ ក្រោយពីពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ សូមឲ្យពួកគេចែកចាយពីរបៀបដែលវគ្គនេះជះឥទ្ធិពលដល់ការតាំងចិត្តរបស់ពួកគេដើម្បីរស់នៅតាមដំណឹងល្អ ។ អ្នកអាចចែកចាយចម្លើយរបស់អ្នកទៅនឹងសំណួរដូចគ្នានេះ ។ សូមថ្លែងទីបន្ទាល់ពីតួនាទីរបស់ព្រះយេស៊ូវគ្រីស្តក្នុងការធ្វើឲ្យមានពរជ័យនៃការរស់ឡើងវិញ ។

ការរំឭកចំណេះចំណានខគម្ពីរ

ការយល់របស់សិស្សអំពីវគ្គព្រះគម្ពីរនឹងបង្កើន នៅពេលពួកគេបង្កើតសំណួរដោយខ្លួនគេអំពីវគ្គនោះ ។ សូមឲ្យសិស្សធ្វើការរួមគ្នាជាថ្នាក់ទាំងមូល ឬ ក្រុមតូចៗ ដើម្បីសរសេរពីសញ្ញាដែលបង្ហាញពីវគ្គចំណេះចំណានខគម្ពីរដ៏សំខាន់ ។ (អ្នកអាចជ្រើសរើសក្រុមនៃវគ្គមួយដែលអ្នកចង់ឲ្យសិស្សរៀន ឬរំឭក) ។ បន្ទាប់មក សូមឲ្យពួកគេអានសញ្ញារបស់ពួកគេដល់អ្នក ។ ពិន្ទុត្រូវបានទៅអ្នក ប្រសិនបើអ្នកទាយវគ្គចំណេះចំណានខគម្ពីរត្រូវ ។ ពិន្ទុត្រូវបានទៅសិស្ស ប្រសិនបើអ្នកមិនអាចទាយត្រូវទេនោះ ។

កំណត់ចំណាំ ៖ ប្រវែងនៃមេរៀននេះអាចឲ្យមានពេលសម្រាប់ធ្វើសកម្មភាពចំណេះចំណានខគម្ពីរនេះ ។ ទោះយ៉ាងណាក្តី ដើម្បីប្រាកដថាសិស្សមានពេលគ្រប់គ្រាន់ដើម្បីរៀបចំ និងចូលរួមក្នុងមេរៀននេះ អ្នកអាចប្រើសកម្មភាពនេះនៅចុងបញ្ចប់នៃមេរៀន បើមានពេល ។ ប្រសិនបើអ្នកមិនមានពេលប្រើសកម្មភាពនេះជាផ្នែកនៃមេរៀនទេ អ្នកអាចប្រើវានាពេលក្រោយទៀត ។ សម្រាប់សកម្មភាពរំឭកផ្សេងទៀត សូមមើលឧបសម្ព័ន្ធនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អាលម៉ា ៤០:១១ ។ « នឹងបានត្រឡប់ទៅផ្ទះវិញ គឺទៅជួបនឹងព្រះដែលទ្រង់បានប្រទានជីវិតដល់គេ »

ប្រធាន យ៉ូសែប ហ្វីលឌីង ស្មីធ បានពន្យល់ថាពាក្យនៅក្នុង អាលម៉ា ៤០:១១ មិនបានបង្រៀនថា យើងនឹងត្រូវនាំទៅក្នុងវត្តមាននៃព្រះភ្លាមៗក្រោយពីយើងស្លាប់នោះទេ ។

« ពាក្យនៃអាលម៉ាទាំងនេះ [អាលម៉ា ៤០:១១–១៤] នៅពេលខ្ញុំយល់វា វាមិនមានបំណងដើម្បីនាំគំនិតថា គ្រប់វិញ្ញាណទាំងអស់ត្រូវត្រឡប់ទៅវត្តមាននៃព្រះសម្រាប់កិច្ចការមួយចំពោះកន្លែងមួយនៃសន្តិភាព ឬកន្លែងមួយនៃការដាក់ទោស និងនៅចំពោះមុខទ្រង់ដើម្បីទទួលការដាក់ទោសផ្ទាល់ខ្លួនគេទេ ។ ‹ នឹងបានត្រឡប់ទៅផ្ទះវិញ › [ប្រៀបធៀបនឹងសាស្តា ១២:៧] មានន័យសាមញ្ញថា ជីវិតរមែងស្លាប់របស់ពួកគេបានមកដល់ទីបញ្ចប់ ហើយពួកគេបានត្រឡប់ទៅពិភពវិញ្ញាណវិញ ជាកន្លែងដែលពួកគេត្រូវបានដាក់ទៅកន្លែងមួយស្របតាមកិច្ចការរបស់ពួកគេដោយសេចក្តីយុត្តិធម៌ ឬ ដោយមិនយុត្តិធម៌ នៅទីនោះដើម្បីរង់ចាំការរស់ឡើងវិញ ។ ‹ ត្រឡប់ទៅព្រះវិញ › គឺជាឃ្លាមួយដែលស្រដៀងគ្នាជាខ្លាំងទៅនឹងលក្ខខណ្ឌផ្សេងទៀត ។ ឧទាហរណ៍ ៖ បុរសម្នាក់ចំណាយពេលមួយរយៈនៅក្នុងតំបន់របស់កកកុនៅបរទេសខ្លះ ។ នៅពេលគាត់បានដោះលែង ហើយត្រឡប់មកកាន់សហរដ្ឋអាមេរិកវិញ គាត់អាចនិយាយថា ‹ វាអស្ចារ្យដើម្បីត្រឡប់មកផ្ទះវិញ › ; ដោយឡែកផ្ទះរបស់គាត់អាចនៅកន្លែងណាមួយនៅក្នុងរដ្ឋយូថាហ៍ ឬអាយដាហូ ឬផ្នែកផ្សេងទៀតនៃភាពខាងលិច » (*Answers to Gospel Questions,* comp. Joseph Fielding Smith Jr., 5 vols ។ [ឆ្នាំ ១៩៥៧–៦៦], ២:៨៥) ។

អាលម៉ា ៤០:១១–១៥ ។ តើពិភពវិញ្ញាណនៅឯណា ?

ប្រធាន ព្រិកហាំ យ៉ង់ បានបង្រៀន ៖

« តើពិភពវិញ្ញាណនៅឯណា ? វាគឺនៅទីនេះ ។ តើពួកគេ [វិញ្ញាណនៃអ្នកដែលបានស្លាប់ទៅ] ទៅហួសពីព្រំដែននៃផែនដីដែលបានរៀបចំនេះទេ ? ទេ ពួកគេមិនទៅហួសទេ ។ ពួកគេត្រូវបាននាំមកកាន់ផែនដីនេះ » (*Discourses of Brigham Young,* sel. John A. Widtsoe [ឆ្នាំ ១៩៥៤], ទំព័រ ៣៧៦) ។

អាលម៉ា ៤០:១១–១៥ ។ តើនឹងមានអ្វីកើតឡើងដល់វិញ្ញាណទាំងឡាយដែលនៅក្នុងពិភពវិញ្ញាណ ?

« នៅពេលរាងកាយខាងសាច់ឈាមស្លាប់ វិញ្ញាណបន្តរស់នៅ ។ នៅក្នុងពិភពវិញ្ញាណ វិញ្ញាណរបស់ពួកសុចរិត‹ នឹងបានទទួលស្ថានភាពនៃសុភមង្គល ដែលជាស្ថានបរមសុខដែលជាស្ថានភាពឈប់សម្រាក ស្ថានភាពសុខសាន្ត ជាកន្លែងដែលគេនឹងបានសម្រាកពីអស់ទាំងកង្វល់ ពីអស់ទាំងការបារម្ភ និងពីទុក្ខព្រួយ ›(អាលម៉ា ៤០:១២) ។ កន្លែងមួយហៅថាគុកខាងវិញ្ញាណត្រូវបានក្សាទុកសម្រាប់ ‹ អ្នកដែលបានស្លាប់នៅក្នុងអំពើបាបរបស់ពួកគេ ដោយមិនបានដឹងពីសេចក្តីពិត ឬនៅក្នុងការរំលង ដោយបានបដិសេធព្យាការី ›(គ . និង ស . ១៣៨:៣២) ។ វិញ្ញាណទាំងឡាយនៅក្នុងគុកត្រូវបាន ‹ បង្រៀនពីសេចក្តីជំនឿលើព្រះ ការប្រែចិត្តពីអំពើបាប ការជ្រមុជទឹកជំនួសសម្រាប់ការផ្តាច់បាប អំណោយទានជាព្រះវិញ្ញាណបរិសុទ្ធដោយការដាក់ដៃលើក្បាល ហើយនិងគោលការណ៍ផ្សេងទាំងឡាយនៃជំណឹងល្អដែលចាំបាច់សម្រាប់ពួកគេដឹង › (គ . និង ស . ១៣៨:៣៣–៣៤) ។ ប្រសិនបើពួកគេទទួលយកគោលការណ៍នៃជំណឹងល្អ ប្រែចិត្តពីអំពើបាបរបស់ពួកគេ ហើយទទួលយកពិធីការទាំងឡាយដែលបានធ្វើជំនួសនៅក្នុងព្រះវិហារបរិសុទ្ធ ពួកគេនឹងស្វាគមន៍មកកាន់ស្ថានបរមសុខ » (*ពិគ្គហ៍ពោះសេចក្តីជំនឿ ៖ សេចក្តីរៀបរាប់ដំណឹងល្អ* [ឆ្នាំ ២០០៤], ទំព័រ ៤៦–៤៧) ។

អាលម៉ា ៤១

សេចក្តីផ្តើម

ដោយបន្តណែនាំដល់កូនប្រុសរបស់គាត់ កូរីអានតុន អាលម៉ាបានបង្រៀនថាផែនការនៃការស្តារឡើងវិញមិនត្រឹមតែរួមមានការរស់ឡើងវិញខាងរាងកាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការស្តារឡើងវិញខាងវិញ្ញាណមួយដែលសភាពដ៏អស់កល្បរបស់យើងឆ្ពុះបញ្ចាំងពីសកម្មភាពនិងបំណងខាងសាច់ឈាមរបស់យើង ។ អាលម៉ាបញ្ជាក់ថា អំពើទុច្ចរិតមិនអាចនាំទៅរកសុភមង្គលឡើយ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៤១

អាលម៉ាបង្រៀនកូរីអានតុនអំពីផែនការនៃការស្តារឡើងវិញ

សូមឲ្យសិស្សក្នុងថ្នាក់គិតពីរបៀបដែលសកម្មភាពរបស់មនុស្សម្នាក់អាចមានឥទ្ធិពល ប្រសិនបើពួកគេជឿលើប្រយោគខាងក្រោម (សូមឈប់បន្ទាប់ពីបញ្ចប់ប្រយោគនីមួយៗដើម្បីឲ្យសិស្សឆ្លើយ) ៖

គ្មានជីវិតបន្ទាប់ពីសេចក្តីស្លាប់នោះទេ ។

ក្រោយពីយើងស្លាប់ យើងនឹងត្រូវធ្វើឲ្យបានឥតខ្ចោះ ដោយមិនគិតពីកិច្ចការរបស់យើងនៅលើផែនដីនោះទេ ។

នៅក្នុងការជំនុំជម្រះលើកចុងក្រោយ យើងនឹងទទួលបានរង្វាន់សម្រាប់អំពើល្អរបស់យើង ហើយដាក់ទោសចំពោះអំពើអាក្រក់របស់យើង ។

- ហេតុអ្វីបានជាវាសំខាន់ដើម្បីយល់ឲ្យបានត្រឹមត្រូវពី អ្វីដែលនឹងកើតឡើងដល់យើងបន្ទាប់ពីយើងស្លាប់ទៅ ?

សូមរំឭកសិស្សថានៅក្នុង អាលម៉ា ៤០ ពួកគេបានរៀនអំពីការបង្រៀនរបស់អាលម៉ាដល់កូរីអានតុនអំពីពិភពវិញ្ញាណ ការរស់ឡើងវិញ និងការជំនុំជម្រះ ។ សូមពន្យល់ថានៅក្នុង អាលម៉ា ៤១ យើងរៀនថា កូរីអានតុនបានច្រឡំនឹងអ្វីដែលមនុស្សខ្លះកំពុងបង្រៀនអំពីការរស់ឡើងវិញ ។ សូមបង្ហាញឃ្លា « បានដើរវង្វេងទៅឆ្ងាយ » នៅក្នុង អាលម៉ា ៤១:១ ហើយសូមឲ្យសិស្សអានខនេះដោយរកមើលអ្វីដែលបណ្តាលឲ្យមនុស្សខ្លះដើរវង្វេង ។

- ហេតុអ្វីបានជាមនុស្សខ្លះដើរវង្វេង ? (អ្នកអាចពន្យល់ថា ការប្រកួតព្រះគម្ពីរ គឺត្រូវត្រួតជាន់វាចូលគ្នា ប្រែប្រួលវា ឬ ផ្លាស់ប្តូរអត្ថន័យរបស់វា) ។
- តើអាលម៉ាបាននិយាយថាគាត់នឹងពន្យល់អ្វីដល់កូរីអានតុន ?

នៅពេលសិស្សរកឃើញពាក្យ *ការសាងឡើងវិញ* អ្នកអាចសរសេរវានៅក្នុងក្តារខៀន ។ សូមពន្យល់ថា *ការសាងឡើងវិញ* មានន័យថាការនាំមកវិញ ឬការដាក់មកវិញនូវសភាពដើមវាមុន ។

សូមពន្យល់ថា អាលម៉ាចង់ឲ្យកូរីអានតុនយល់ថា មានចំណែកខាងរាងកាយ និងចំណែកខាងវិញ្ញាណដែលជាអ្វីដែលគាត់ហៅថា « ផែនការនៃការសាងឡើងវិញ » (អាលម៉ា ៤១:២) ។ សូមឲ្យសិស្សសិក្សា អាលម៉ា ៤១:២–៥ ដោយស្ងាត់ៗ ដោយរកមើលអ្វីៗដែលនឹងត្រូវបានសាងឡើងវិញខាងរូបកាយដល់យើង បន្ទាប់ពីការស្លាប់ និងអ្វីដែលនឹងត្រូវសាងឡើងវិញខាងវិញ្ញាណ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំអ្វីដែលពួកគេរកឃើញ ។ មុនពេលសិស្សអាន វាអាចជួយដល់អ្នកបើអ្នកពន្យល់ថា *ជាការចាំបាច់* មានន័យថាដែលត្រូវការ ឬចាំបាច់ ។

- តើអ្វីជាផ្នែកនៃរាងកាយនៃផែនការនៃការសាងឡើងវិញដែលបានលើកឡើងនៅក្នុង អាលម៉ា ៤១:២ ? (នៅក្នុងការរស់ឡើងវិញ ព្រលឹងមនុស្សនឹងត្រូវផ្គុំទៅក្នុងរាងកាយ ហើយផ្នែកទាំងអស់នៃរាងកាយនឹងបានផ្គុំឡើងវិញ) ។
- តើអ្វីជាផ្នែកនៃវិញ្ញាណនៃផែនការនៃការសាងឡើងវិញដែលបានលើកឡើងនៅក្នុង អាលម៉ា ៤១:៣–៥? (នៅពេលសិស្សឆ្លើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***យើងនឹងត្រូវសាងឡើងវិញអាចទាំងសុភមង្គល ឬអាចជាទុក្ខវេទនាយោងតាមកិច្ចការរបស់យើង និងបំណងយើងនៅក្នុងជីវិតរមែងស្លាប់***) ។

សូមឲ្យសិស្សស្រមៃថា ពួកគេកំពុងបង្រៀនខគម្ពីរទាំងនេះដល់សិស្សក្នុងថ្នាក់កុមារ ។

- តើអ្នកនឹងពន្យល់ពីគោលលទ្ធិនៃការសាងឡើងវិញខាងវិញ្ញាណ ដើម្បីឲ្យក្មេងៗអាចយល់ដោយរបៀបណា ?

សូមរំឭកសិស្សថា កូរីអានតុនបានរំលងច្បាប់ព្រហ្មចារីយភាព ហើយបានលះបង់ចោលការទទួលខុសត្រូវបេសកកម្មរបស់គាត់ (សូមមើល អាលម៉ា ៣៩:២–៤) ។

- តើការយល់ដ៏ត្រឹមត្រូវនៃគោលលទ្ធិនៃការសាងឡើងវិញខាងវិញ្ញាណអាចជួយដល់ក្ងរីអានតុនឲ្យធីសជម្រើសដ៏ល្អជាងមុនដោយរបៀបណា ? តើការយល់ពីគោលលទ្ធិនេះអាចជះឥទ្ធិពលដល់សកម្មភាព និងបំណងរបស់យើងដោយរបៀបណា ?

សូមថ្លែងទីបន្ទាល់ពីសេចក្តីពិតនៃគោលលទ្ធិនេះ ហើយសូមចែកចាយពីគំនិតរបស់អ្នកអំពីសេចក្តីយុត្តិធម៌នៃព្រះនៅក្នុងការសាងយើងម្នាក់ៗឡើងវិញដល់សេចក្តីល្អ ឬ សេចក្តីអាក្រក់ស្របតាមបំណង និងសកម្មភាពរបស់យើងទាំងឡាយ ។

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖ *ចុះបើខ្ញុំបានធ្វើអំពើបាប ?*

- យោងតាមផែនការនៃការសាងឡើងវិញ តើយើងទទួលបានអ្វី បើសិនជាបានធ្វើអំពើបាបនោះ ?
- តើមានវិធីណាដើម្បីសាងឡើងវិញនូវសេចក្តីល្អ និងសុភមង្គលដល់យើង នៅពេលយើងបានធ្វើខុសទេ ?

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៤១:៦–៩ ព្ធ៦ ។ សូមឲ្យសិស្សរកមើលអ្វីដែលយើងអាចធ្វើដើម្បីទទួលបានសេចក្តីល្អ និងសុភមង្គលសាងឡើងវិញដល់យើង ទោះបីជាជានៅពេលយើងបានធ្វើអំពើបាបក្តី ។ (យើងត្រូវតែប្រែចិត្ត ហើយចង់ធ្វើសុចរិតពេញមួយជីវិតរបស់យើង) ។

- តើពាក្ស ឬឃ្លាណានៅក្នុង អាលម៉ា ៤១:៦–៧ ប្រាប់ថាយើងទទួលខុសត្រូវចំពោះអ្វីដែលយើងទទួលពេលរស់ឡើងវិញ ? តើយើងជាចៅក្រមផ្ទាល់ខ្លួនឯងតាមវិធីណា ? (ជម្រើសរបស់យើងនៅក្នុងជីវិតរមែងស្លាប់សម្រេចពីប្រភេទនៃសេចក្តីជំនុំជម្រះដែលយើងនឹងទទួល នៅពេលយើងឈរនៅចំពោះមុខព្រះ) ។

សូមបង្ហាញថា មនុស្សខ្លះគិតថា ពួកគេអាចត្រឡប់ទៅរស់នៅជាមួយនឹងព្រះវិញ ដោយមិនទទួលខុសត្រូវចំពោះសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេ ។ ជាញឹកញាប់ ពួកគេនិយាយថាជម្រើសដ៏មានបាបរបស់គេគឺជាការរីករាយ ។ ពេលខ្លះអ្នកដែលធ្វើអំពើបាបអាចទាំងមើលទៅសប្បាយរីករាយថែមទៀតផង ។

សូមអានកិច្ចសន្យា

ការអានកិច្ចសន្យាអាចបន្ថែមការសង្គត់ធ្ងន់លើវគ្គព្រះគម្ពីរ ក៏ដូចជាបន្ថែមភាពសាមគ្គីនៅក្នុងថ្នាក់ ។ វាក៏ជារបៀបមួយដើម្បីបន្ថែមភាពផ្សេងគ្នាទៅក្នុងមេរៀនដែរ ។ សូមប្រើគំនិតនេះ នៅពេលអ្នកឃើញថាសិស្សអាចត្រូវការការផ្លាស់ប្តូរ ។ សូមណែនាំពួកគេឲ្យនិយាយពាក្យអ្វីតាមចិត្ត ហើយរួមគ្នានៅពេលពួកគេអាន ។

សូមឲ្យសិស្សឈរ ហើយអាន អាលម៉ា ៤១:១០ឬនៅក្នុងកិច្ចសន្យា ។ សូមបង្ហាញថា អាលម៉ា ៤១:១០ គឺជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំវគ្គនេះដើម្បីឲ្យងាយស្រួលរកវាឃើញ ។ (ដោយោសារនេះគឺជាវគ្គចំណេះចំណានខគម្ពីរ អ្នកអាចឲ្យពួកគេអានវារួមគ្នាម្តងហើយម្តងទៀត ។ អ្នកអាចសុំឲ្យសិស្សណាម្នាក់ក្នុងថ្នាក់សូត្រវាក៏បាន ។) នៅពេលពួកគេបញ្ចប់ សូមឲ្យសិស្សក្នុងថ្នាក់អង្គុយ ។ សូមសរសេរ « ***សេចក្តីទុច្ចរិតពុំដែលជាសុភមង្គលឡើយ*** » នៅលើក្តារខៀន ។

- ហេតុអ្វីបានជាវាពិតដែលថា « សេចក្តីទុច្ចរិតពុំដែលជាសុភមង្គលឡើយ » ?
- តើអ្វីជាគំរូនៃរបៀបដែលសាតាំងនឹងឲ្យយើងរំលងច្បាប់មួយ ហើយជឿថាយើងនៅតែអាចទទួលបានសុភមង្គល ?

ដើម្បីជួយសិស្សឲ្យសរសើរពីភាពខុសគ្នារវាងការសប្បាយនៃលោកិយតែមួយភ្លែត និងសុភមង្គលដែលព្រះអម្ចាស់បានប្រទាន សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ គ្លែន អិល ផេស នៃក្រុមចិតសិបនាក់ ៖

« សកម្មភាពដែលតែងតែហាមឃាត់ដោយព្រះអម្ចាស់ និងអស់រយៈពេលជាច្រើនឆ្នាំដែលសង្គមមិនពេញចិត្តឥឡូវនេះត្រូវបានគេទទួលយក ហើយតម្កើងដោយសង្គមដូចគ្នានោះ ។ ព័ត៌មានបម្រើដល់សកម្មភាពទាំងនេះនៅក្នុងរបៀបមួយដើម្បីធ្វើឲ្យពួកគេមើលទៅគួរឲ្យចង់បាន ។ . . .

« . . . កុំច្រឡំការសប្បាយនៃស្ថានតេឡេស្ទាល និងសុភមង្គលនិងសេចក្តីអំណរនៃស្ថានសេឡេស្ទាលឡើយ ។ សូមកុំច្រឡំការខ្ចះការគ្រប់គ្រងលើខ្លួនឯងថាជាសេរីភាព ។ ការបំពេញសេរីភាពដោយគ្មានការរឹតត្បិតដ៏មិនសមរម្ស ធ្វើឲ្យយើងក្លាយជាខ្ចុំបម្រើដល់ចំណង់របស់យើង ។ សូមកុំច្រណែននឹងជីវិតដែលតិចតួច និងទប់ទាបជាងឡើយ ។ . . .

« . . . ព្រះបញ្ញត្តិទាំងឡាយដែលអ្នកសង្កេត មិនមែនផ្តល់ដោយព្រះដ៏គ្មានមេត្តា ដើម្បីរាវាំងអ្នកពីការសប្បាយនោះទេ ប៉ុន្តែដោយព្រះវរបិតាជាទីស្រឡាញ់នៅលើស្ថានសួគ៌ដែលចង់ឲ្យអ្នករីករាយ ខណៈពេលដែលអ្នកកំពុងរស់នៅលើផែនដីនេះ ក៏ដូចជានៅក្នុងភពក្រោយពីជីវិតនេះ » (« They're Not Really Happy »*Ensign,*ខែ វិច្ឆិកា ឆ្នាំ ១៩៨៧, ទំព័រ ៣៩–៤០) ។

អាលម៉ា ៤១:១០គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមបើកទៅគំនិតសម្រាប់ការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សឲ្យចងចាំវគ្គចំណេះចំណានខគម្ពីរនេះ ។

សូមសរសេរនូវឃ្លាដូចខាងក្រោមនៅលើក្តារខៀន ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរសរសេរវានៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ៤១:១០ ។ (ឃ្លានេះមាននៅក្នុង "To 'the Rising Generation,'" *New Era,*ខែ មិថុនា ឆ្នាំ ១៩៨៦, ទំព័រ ៥ ។)

« អ្នកមិនធ្វើខុស ហើយមានអារម្មណ៍ថាត្រូវនោះទេ ។ វាមិនអាចឡើយ ! » (ប្រធាន អែរិសរ៉ា ថាហ្ធ បែនសឹន) ។

សូមប្រាប់សិស្សថា អាលម៉ា ៤១:១១ពន្យល់ពីមូលហេតុដែលវាមិនអាចមានការសប្បាយរីករាយដ៏ពិត នៅពេលធីសជម្រើសខុសនោះទេ ។ សូមចម្លងតារាងខាងក្រោមនៅលើក្តារខៀន (អ្នកអាចចម្លងវាមុនចាប់ផ្តើមថ្នាក់) ឬរៀបចំវាជាក្រដាសចែកដល់សិស្ស ។ សូមរៀបចំសិស្សធ្វើការជាដៃគូ ហើយណែនាំពួកគេឲ្យផ្គូផ្គងឃ្លានីមួយៗពី អាលម៉ា ៤១:១១ទៅនឹងអត្ថន័យរបស់វា ។ សូមឲ្យពួកគេពិភាក្សាពីសំណួរដែលអមមកផងដែរ ។

ឃ្លានៅក្នុង អាលម៉ា ៤១:១១ ដែលពិពណ៌នាពីការនៅក្នុង « ស្ថានភាពខាងសាច់ឈាម »	អត្ថន័យ
១. « នៅក្នុងស្ថានភាពខាងរូបកាយ »	ក. កម្រិត និងរងទុក្ខដោយអំពើបាបរបស់យើង
២. « នៅក្នុងប្រមាត់ល្វីងជូរចត់ និងនៅក្នុងចំណងទាំងឡាយនៃអំពើទុច្ចរិត »	ខ. ការខ្វះពរជ័យ និងការណែនាំពីព្រះ ; ការបាត់បង់ដៃគូជាព្រះវិញ្ញាណបរិសុទ្ធ
៣. « គ្មានព្រះនៅក្នុងលោកិយ »	គ. គ្រប់គ្រងដោយចំណង់នៃសាច់ឈាម

នៅក្នុងខគម្ពីរនេះ យើងឃើញថា « ព្រះហឫទ័យនៃព្រះ » គឺជា « ស្ថានភាពនៃសុភមង្គល » ។ តើការណ៍នេះប្រាប់អ្នកអំពីមូលហេតុដែលអំពើបាបផ្តួយពីស្ថានភាពនៃសុភមង្គលអ្វីខ្លះ ?

តើគំរូដ៏ជាក់លាក់ណាខ្លះនៃមូលហេតុដែលមនុស្សអាចឃើញថាខ្លួនគេនៅក្នុងស្ថានភាពនៃអសុភមង្គលនោះ ?

(ចម្លើយ ៖ ១-គ, ២-ក, ៣-ខ)

ដើម្បីជួយសិស្សឲ្យឃើញពីរបៀបដែលការទទឹងនៅក្នុង « ស្ថានភាពខាងសាច់ឈាម » ទាក់ទងនឹងគោលលទ្ធិនៃការសាងឡើងវិញ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៤១:១២ ។ ក្រោយពីអានខគម្ពីរនេះហើយ សូមឲ្យសិស្សឆ្លើយនឹងសំណួររបស់អាលម៉ា ។ បន្ទាប់មក សូមឲ្យសិស្សអានចម្លើយរបស់អាលម៉ាទៅនឹងសំណួររបស់គាត់នៅក្នុង អាលម៉ា ៤១:១៣ ។ (អ្នកអាចផ្តល់យោបល់ថា ពួកគេគួរគូសចំណាំអ្វីដែលអាលម៉ាបាននិយាយថា នឹងត្រឡប់មកដល់យើងជាផ្នែកនៃផែនការនៃការសាងឡើងវិញ) ។

សូមឲ្យសិស្សស្រមៃថា ពួកគេមានមិត្តម្នាក់ដែលកំពុងជ្រើសរើសដើរផ្លូវដែលផ្ទុយពីព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ប៉ុន្តែចង់បានសាងឡើងវិញនៅក្នុងសេចក្តីសុចរិត ។ សូមឲ្យសិស្ស ពន្យល់ ពីគោលលទ្ធិនៃការសាងឡើងវិញដល់ដៃគូ ដូចជាពួកគេគឺជាមិត្តម្នាក់នោះ ដោយប្រើ អាលម៉ា ៤១:១២–១៣ ។ (សិស្សអាចប្រើសម្ភីខ្លួនឯង ឬ ៣ក្យនៃប្រយោគដែលបានសរសេរនៅលើក្តារខៀន ៖ *« យើងនឹងត្រូវបានសាងឡើងវិញដល់សុភមង្គល ឬដល់សេចក្តីទុក្ខវេទនាយោងតាមកិច្ចការ និងបំណងរបស់យើងនៅក្នុងជីវិតរមែងស្លាប់ »*) ។

សូមបង្ហាញសិស្សរូបដំបងប៊ូម៉ឺរ៉ង់មួយ ឬ គូសរូបដំបងប៊ូម៉ឺរ៉ង់មួយនៅលើក្តារខៀន ។

សូមសួរសិស្សថា តើដំបងប៊ូម៉ឺរ៉ង់មួយធ្វើអ្វី នៅពេលគប់វាបានត្រឹមត្រូវនោះ ។ (វាត្រឡប់ទៅកន្លែងដែលវាត្រូវបានគប់ចេញទៅនោះ) ។ សូមឲ្យពួកគេអាន អាលម៉ា ៤១:១៤–១៥ ដោយស្ងាត់ៗ ដោយរកមើលរបៀបដែលដំបងប៊ូម៉ឺរ៉ង់អាចតំណាងឲ្យការទុកចិត្តដែលបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ ។ (អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំខគម្ពីរទាំងនេះ) ។ (សូមឲ្យសិស្សពន្យល់ពីអ្វីដែលពួកគេបានរកឃើញ ។

- តើអ្វីខ្លះដែលអ្នកសង្ឃឹមថានឹងបានទទួលពីអ្នកដទៃ និងពីព្រះអម្ចាស់នៅក្នុងជីវិតនេះ និងនៅក្នុងជីវិតបន្ទាប់ពីនេះ ? (ចម្លើយអាចរួមមានសន្តានចិត្ត សេចក្តីមេត្តាករុណា និងសេចក្តីស្រឡាញ់ ។ សូមគិតពីការសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀន ។)
- តើនៅពេលណាដែលអ្នកបានផ្តល់សេចក្តីល្អ សេចក្តីមេត្តាករុណា ឬសន្តានចិត្តដល់អ្នកដទៃ ហើយក្រោយមកបានទទួលវាវិញ ?

សូមណែនាំសិស្សឲ្យដាក់គោលដៅដើម្បីធ្វើតាមរបៀបទាំងឡាយ និងអភិវឌ្ឍគំរិយាបថទាំងឡាយដែលឆ្លុះបញ្ចាំងពីអ្វីដែលពួកគេសង្ឃឹមថានឹងបានសាងពួកគេឡើងវិញនៅក្នុងជីវិតនេះ និងជីវិតបន្ទាប់ពីនេះ ។ សូមថ្លែងទីបន្ទាល់ពីសុភមង្គលដែលមក នៅពេលយើងធ្វើអ្វីដែលសុចរិត ។

សូមឲ្យសិស្សពន្យល់ពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយ

សូមផ្តល់ឱកាសដល់សិស្សឲ្យពន្យល់ដល់អ្នកដទៃនូវគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលពួកគេកំពុងរៀននៅក្នុងថ្នាក់ ។ នៅពេលពួកគេរៀបចំពន្យល់ពីសេចក្តីពិតនៃដំណឹងល្អ ពួកគេនឹងរៀនដើម្បីសញ្ជឹងគិតពីគ្តីព្រះគម្ពីរឲ្យកាន់តែជ្រៅជ្រះ ហើយរៀបចំគំនិតរបស់ពួកគេ ។ នៅពេលពួកគេពន្យល់ពីសេចក្តីពិតទាំងនេះដល់អ្នកដទៃ ព្រះវិញ្ញាណបរិសុទ្ធនឹងពង្រីកការយល់ដឹងរបស់គេ និងទីបន្ទាល់នៃសេចក្តីពិតដែលពួកគេកំពុងបង្រៀន ។

ចំណេះចំណាននខគម្ពីរ—អាលម៉ា ៤១:១០

កំណត់ចំណាំ ៖ ដោយសារតែលក្ខណៈនៃប្រវែងនៃមេរៀននេះ សកម្មភាពខាងក្រោមនឹងបំផុតសម្រាប់ប្រើនៅថ្ងៃក្រោយ នៅពេលអ្នកមានពេលបន្ថែម ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ . . . *គឺជាសុភមង្គល* ។

សូមឲ្យសិស្សបំពេញប្រយោគមួយដែលផ្ទុយនឹងគោលលទ្ធិដែលបានបង្រៀននៅក្នុង អាលម៉ា ៤១:១០ ។ (ចម្លើយមួយអាចថា « សេចក្តីសុចរិតគឺជាសុភមង្គល » ។) បន្ទាប់មក សូមឲ្យសិស្សសរសេរទង្វើសុចរិតជាក់លាក់នានាដែលពួកគេមានអារម្មណ៍នឹងត្រូវក្នុងចន្លោះនេះ ។ (ឧទាហរណ៍ « ការបម្រើដល់អ្នកដទៃគឺជាសុភមង្គល » ។) សូមសួរសិស្សថាតើពួកគេអាចថ្លែងទីបន្ទាល់ថា ទង្វើសុចរិតទាំងនេះដឹកនាំទៅរកសុភមង្គលទេ ។ ក្រោយពីសិស្សពីរបីនាក់បានចែកចាយបទពិសោធន៍ និងទីបន្ទាល់របស់ពួកគេហើយ សូមឲ្យសិស្សក្នុងថ្នាក់សរសេរលើកាតទំហំតូចមួយ ឬ ក្រដាសមួយនូវទង្វើសុចរិតមួយ ឬពីរដែលពួកគេអាចធ្វើ អំឡុងពេលសប្តាហ៍នេះដើម្បីបង្កើនសុភមង្គលរបស់ពួកគេ ។ សូមណែនាំពួកគេឲ្យយកក្រដាសពួកគេដាក់តាមខ្លួនគេជាការរំឭក ហើយរៀបរាប់ពីការខិតខំរបស់គេនៅថ្ងៃក្រោយ ។

អាលម៉ា ៤២

សេចក្តីផ្តើម

អាលម៉ាបញ្ចប់ការបង្រៀនដល់កូនប្រុសរបស់គាត់ កូរីអានតុន ដោយការពន្យល់ថា ព្រះវរបិតាសួគ៌បានផ្តល់របៀបមួយដល់អ្នកដែលបានធ្វើបាបឲ្យទទួលបានសេចក្តីមេត្តាករុណា ។ គាត់បានបង្រៀនថា សេចក្តីយុត្តិធម៌នៃព្រះទាមទារឲ្យអ្នកមានបាបទាំងឡាយត្រូវកាត់ចេញពីវត្តមាននៃព្រះ ។ បន្ទាប់មក គាត់បានថ្លែងទីបន្ទាល់ថា ព្រះយេស៊ូវគ្រីស្ទនឹង « ធ្វើឲ្យស្កប់ស្កល់ដល់ការទាមទារនៃសេចក្តីយុត្តិធម៌ » (អាលម៉ា ៤២:១៥) ដោយការរងទុក្ខសម្រាប់មនុស្សទាំងអស់ ដែលបានធ្វើអំពើបាប ហើយដោយការផ្តល់នូវសេចក្តីមេត្តាករុណាដល់អ្នកប្រែចិត្ត ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៤២:១–១៤

អាលម៉ាបង្រៀនកូរីអានតុនអំពីសេចក្តីយុត្តិធម៌របស់ព្រះ

មុនចាប់ផ្តើមថ្នាក់ សូមគូសរូបជញ្ជីងសាមញ្ញមួយនៅលើក្តារខៀន ដូចដែលបានបង្ហាញនៅក្នុងទំព័របន្ទាប់ ។ (សូមកុំបន្ថែមពាក្យលើគំនូសនោះ រហូតដល់បានណែនាំឲ្យធ្វើដូច្នោះនៅក្នុងមេរៀននេះ ។ អ្នកអាចណែនាំសិស្សឲ្យចម្លងរូបនេះទៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។)

នៅលើជញ្ជីងនោះ សូមសរសេរប្រយោគខាងក្រោម ៖ *ខ្ញុំចង់ឲ្យការជំនុំជម្រះលើកចុងក្រោយមានសេចក្តីយុត្តិធម៌ ។*

សូមឲ្យសិស្សលើកដៃប្រសិនបើពួកគេយល់ស្របនឹងប្រយោគនៅលើក្តារខៀន ។

- ហេតុអ្វីបានជាអ្នកចង់ឲ្យការជំនុំជម្រះលើកចុងក្រោយមានសេចក្តីយុត្តិធម៌ ?
- តើពាក្យ *យុត្តិធម៌* មានន័យយ៉ាងណា ?

សូមស្នើថា *យុត្តិធម៌* អាចមានន័យថា ការទទួលបានអ្វីដែលអ្នកសមនឹងទទួល ។ គំនិតនៃភាពយុត្តិធម៌ទាក់ទងនឹងពាក្យក្នុងព្រះគម្ពីរថា *សេចក្តីយុត្តិធម៌* សូមសរសេរពាក្យ *សេចក្តីយុត្តិធម៌* នៅលើក្តារខៀននៅក្រោមរូបជញ្ជីង ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលគំនិតនៃភាពយុត្តិធម៌ សូមឲ្យសិស្សម្នាក់អានការពន្យល់ខាងក្រោមដោយអែលឌើរ ដាល្លិន អេក. អូកស៍ នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« *សេចក្តីយុត្តិធម៌* មានអត្ថន័យជាច្រើន ។ អត្ថន័យទីមួយគឺតុល្យភាព ។ សញ្ញាដ៏ល្បីល្បាញនៃសេចក្តីយុត្តិធម៌គឺជាជញ្ជីងដែលមានតុល្យភាព ។ ហេតុដូច្នេះហើយ នៅពេលគេរំលងច្បាប់នៃមនុស្ស ជាធម្មតាសេចក្តីយុត្តិធម៌តម្រូវឲ្យមានការដាក់ទោស ការពិន័យមួយដែលនឹងសាងឡើងវិញនូវតុល្យភាព [ដល់ជញ្ជីង] ។ . . .

« ច្បាប់នៃព្រះគឺដូចគ្នាដែរ វាទាក់ទងនឹងសេចក្តីយុត្តិធម៌ ។ គំនិតនៃសេចក្តីយុត្តិធម៌ដូចដែលអ្វីដែលមនុស្សម្នាក់សមនឹងទទួល គឺជាគោលការណ៍គ្រឹះនៃព្រះគម្ពីរទាំងឡាយដែលនិយាយពីមនុស្សដែលត្រូវជំនុំជម្រះស្របតាមកិច្ចការរបស់ពួកគេ » (« Sins, Crimes, and Atonement » [សុន្ទរកថាថ្លែងទៅកាន់អ្នកអប់រំសាសនា CES នៅថ្ងៃទី ៧ខែ កុម្ភៈ ឆ្នាំ ១៩៩២], ១, si.lds.org) ។

សូមពន្យល់ថា កូនប្រុសរបស់អាលម៉ា កូរីអានតុនបានព្រួយបារម្ភអំពីសេចក្តីយុត្តិធម៌នៃសេចក្តីជំនុំជម្រះលើកចុងក្រោយ ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៤២:១ ឮៗខណៈពេលសិស្សក្នុងថ្នាក់រកមើលអ្វីដែលកូរីអានតុនបានគិតថានឹងមិនយុត្តិធម៌ ឬមិនត្រឹមត្រូវអំពីសេចក្តីជំនុំជម្រះលើកចុងក្រោយ ។

- តើកូរីអានតុនមានអារម្មណ៍យ៉ាងណាដែលមិនយុត្តិធម៌នោះ ? (អ្នកធ្វើបាបនោះនឹងត្រូវបញ្ជូនទៅ ឬដាក់ទៅក្នុងសភាពនៃទុក្ខវេទនា ។)
- ហេតុអ្វីបានជាកូរីអានតុនអាចចង់ជឿថា វាមិនយុត្តិធម៌សម្រាប់អ្នកដែលបានធ្វើអំពើបាបត្រូវតែបានដាក់ទោស ? (ប្រសិនបើសិស្សត្រូវការរំឭកថា កូរីអានតុនកំពុងតស៊ូនឹងអំពើបាបផ្សេងៗជាច្រើន សូមឲ្យពួកគេបើកទៅ អាលម៉ា ៣៩:២–៣ ។)
- ប្រសិនបើសេចក្តីយុត្តិធម៌មានន័យថាការទទួលបានអ្វីដែលយើងសមនឹងទទួល ហើយដាក់ទោសចំពោះអំពើបាបរបស់យើងនោះ តើការណ៍នេះក៏នឹងអាចព្រួយបារម្ភដល់យើងទេ ? (យើងទាំងអស់គ្នាធ្វើបាប ហើយរងនឹងការទាមទារនៃសេចក្តីយុត្តិធម៌ ។)

សូមសង្ខេបស អាលម៉ា ៤២:២–១១ ដោយការពន្យល់ថា អាលម៉ាបានដោះស្រាយការខ្វល់ខ្វាយរបស់កូរីអានតុន ។ គាត់បានបង្រៀនថា ការធ្លាក់របស់អ័ដាមបាននាំមនុស្សទាំងអស់ឲ្យធ្លាក់ ដែលពួកគេត្រូវតែទទួលនូវសេចក្តីស្លាប់ខាងរូបកាយ និងសេចក្តីស្លាប់ខាងវិញ្ញាណ (សូមមើល អាលម៉ា ៤២:៩) ។ គាត់ក៏បានពន្យល់ថា បើគ្មានរបៀបមួយដើម្បីដោះលែងពីស្ថានភាពធ្លាក់នេះទេ នោះព្រលឹងនៃមនុស្សទាំងអស់នឹងរងទុក្ខ ហើយកាត់ចេញពីវត្តមាននៃព្រះជារៀងរហូត (សូមមើល អាលម៉ា ៤២:១១) ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៤២:១២ ឮៗ ។ សូមពន្យល់ថា ខគម្ពីរនេះបញ្ជាក់ថា ការធ្លាក់និងលទ្ធផលរបស់វា រួមមានការកាត់ចេញពីវត្តមាននៃព្រះ ត្រូវបាននាំមកដោយការមិនគោរពរបស់អ័ដាមតាមព្រះបញ្ញត្តិរបស់ព្រះ។ សូមជួយសិស្សឲ្យយល់ថា នៅពេលយើងមិនគោរពតាមព្រះបញ្ញត្តិ —នៅពេលយើងធ្វើអំពើបាប —យើងពង្រីកចម្ងាយកាន់តែឆ្ងាយថែមទៀតរវាងខ្លួនយើង

ខាងវិញ្ញាណនឹងព្រះ ហើយខ្លួនត្រូវរងទុក្ខនឹងការទាមទារនៃសេចក្តីយុត្តិធម៌ ។ (អ្នកអាចឲ្យសិស្សម្នាក់អាន មាត្រានៃសេចក្តីជំនឿ ១:២ ឮៗ ។) សូមឲ្យសិស្សអាន អាលម៉ា ៤២:១៤ ដោយស្ងាត់ៗ ដោយរកមើលលទ្ធផលដែលសេចក្តីយុត្តិធម៌ត្រូវការចំពោះការមិនគោរពតាម ។

- តើ « កាត់ចេញ » ពីវត្តមាននៃព្រះ មានន័យយ៉ាងណា ? (ការបែកចេញពីព្រះ ហើយមិនអាចត្រឡប់ទៅរស់នៅក្នុងវត្តមានរបស់ទ្រង់បានទៀតឡើយ ។ អ្នកក៏អាចលើកឡើងថា នៅពេលយើងធ្វើអំពើបាប យើងដកខ្លួនយើងចេញពីដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ដែលជាសមាជិកនៃក្រុមព្រះ ។)

សូមបន្ថែមឃ្លា *ការមិនគោរពតាម ឬ អំពើបាប* និង *កាត់ចេញពីវត្តមាននៃព្រះ* លើតារាងដូចដែលបានបង្ហាញនៅលើក្តារខៀន ។

ចេញពីអ្វីដែលអ្នកបានរៀននៅក្នុង អាលម៉ា ៤២:១–១៤ តើអ្នកនឹងសង្ខេបចេញជាមួយប្រយោគថាអ្វីទៅជាច្បាប់នៃសេចក្តីយុត្តិធម៌តម្រូវឲ្យមាន នៅពេលបុគ្គលម្នាក់មិនគោរពតាមនោះ ? (សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀននៅក្រោមជញ្ជីង ៖ ***ដោយសារតែការមិនគោរពតាមរបស់យើង ច្បាប់នៃសេចក្តីយុត្តិធម៌តម្រូវឲ្យយើងត្រូវកាត់ចេញពីវត្តមាននៃព្រះ ។*** អ្នកអាចផ្តល់យោបល់ថា សិស្សគួរសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ៤២:១–១៤ ។)

សូមឲ្យសិស្សអាន អាលម៉ា ៤២:១៨ ដោយស្ងាត់ៗ ដោយរកមើលលទ្ធផលផ្សេងទៀតនៃអំពើបាប ។

- តើការសោកស្តាយនៅក្នុងស្មារតីមានន័យយ៉ាងណា ?

សូមឲ្យសិស្សសញ្ជឹងគិតពីពេលមួយដែលពួកគេបានជួបនឹងការក្រៀមក្រំ និងការសោកស្តាយ ឬអវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធ ដោយសារពួកគេបានធ្វើអំពើបាប ។ សូមឲ្យពួកគេស្រមៃថា អារម្មណ៍ច្រើនច្រួលច្រាលដោយអ្វីៗដែលពួកគេបានធ្លាប់បានធ្វើខុស ។ បន្ទាប់មក សូមឲ្យពួកគេស្រមៃថា អារម្មណ៍នោះនៅតែបន្តនៅនឹងពួកគេជារហូតមក ។

ដើម្បីជួយសិស្សឲ្យយល់ និងមានអារម្មណ៍ថាត្រូវការសេចក្តីមេត្តាករុណា អ្នកអាចសួរសំណួរខាងក្រោម ៖

- ដោយផ្អែកលើអ្វីដែលអ្នកបានរៀននៅក្នុង អាលម៉ា ៤២:១–១៤ តើអ្នកចង់បានសេចក្តីជំនុំជម្រះលើកចុងក្រោយដោយផ្អែកតែលើសេចក្តីយុត្តិធម៌ទេ ?

អាលម៉ា ៤២:១៥–៣១

អាលម៉ាបង្រៀនកូរីអានគុនអំពីផែនការនៃសេចក្តីមេត្តាករុណា

ដើម្បីជួយសិស្សឲ្យយល់ថា ការទាមទារនៃសេចក្តីយុត្តិធម៌ត្រូវតែបំពេញ សូមបង្ហាញចំហៀងនៃជញ្ជីងនៃការដាក់ទោសនៅលើក្តារខៀន ។ អ្នកអាចគិតពីការលើកជំរុលុបហាក់ដូចជាអ្នកនឹងលុបការទាមទារសេចក្តីយុត្តិធម៌ ។ សូមសួរ ៖

- តើមានរបៀបណាសម្រាប់ការទាមទារនៃសេចក្តីយុត្តិធម៌ដើម្បីអាចលុបចេញ ឬបណ្តេញចេញទេ ? (ទេ ។ នៅពេលច្បាប់របស់ព្រះត្រូវបានរំលង សេចក្តីយុត្តិធម៌ត្រូវការការដាក់ទោស ។ ការទាមទារនៃសេចក្តីយុត្តិធម៌ត្រូវតែបំពេញទោះជាយ៉ាងណាក្តី ។)

សូមជួយសិស្សឲ្យយល់ថា វានឹងមិនយុត្តិធម៌ទេបើលុបលទ្ធផលដែលសេចក្តីយុត្តិធម៌ទាមទារនោះ ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៤២:២៥ ឮៗ ។

- យោងតាមអាលម៉ា តើនឹងអ្វីកើតឡើង ប្រសិនបើលទ្ធផលនៃអំពើបាបត្រូវបានលុបចេញ ហើយសេចក្តីយុត្តិធម៌ត្រូវបានទុកចោលមិនបានបំពេញនោះ ?

សូមឲ្យសិស្ស សញ្ជឹងគិត ពីសំណួរខាងក្រោមមុនពេលឲ្យពួកគេអានសេចក្តីយោងព្រះគម្ពីរកចន្លើយ ។

- ប្រសិនបើការទាមទារនៃសេចក្តីយុត្តិធម៌មិនអាចលុបចោលទេ នោះតើអ្នកដែលបានធ្វើអំពើបាប (យើងម្នាក់ៗ) អាចនឹងទទួលបានសេចក្តីសុខសាន្តក្នុងស្មារតី ហើយបានសាងឡើងវិញដល់វត្តមាននៃព្រះដោយរបៀបណា ? (ក្រោយពីឲ្យពេលដល់សិស្សសញ្ជឹងគិតពីសំណួរនេះហើយ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៤២:១៥ ។ វាអាចជួយអ្នកបើពន្យល់ថាឃ្លា « ធ្វើឲ្យស្កប់ស្កល់ដល់ការទាមទារនៃសេចក្តីយុត្តិធម៌ » មានន័យថា ត្រូវបង់ថ្លៃ ឬ រងទុក្ខនឹងការដាក់ទោសដែលសេចក្តីយុត្តិធម៌ទាមទារ) ។

- យោងតាម អាលម៉ា ៤២:១៥ តើវាអាចទៅរួចទេ ដែលសេចក្តីមេត្តាករុណាអាចនឹងត្រូវពង្រីកដល់យើងនោះ ?

សូមសន្និដ្ឋានចម្លើយរបស់សិស្ស សូមលុបឃ្លា « កាត់ចេញពីវត្តមានរបស់ព្រះ » ពីក្តារខៀន ហើយសរសេរថា *ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ* និង*សេចក្តីមេត្តាករុណា* ។ នៅក្រោមជញ្ជីង សូមសរសេរសេចក្តីពិតខាងក្រោម ៖ ***ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទបំពេញការទាមទារនៃសេចក្តីយុត្តិធម៌ ដើម្បីឲ្យសេចក្តីមេត្តាករុណាអាចត្រូវបានពង្រីកដល់យើង ។***

> ***សូមឲ្យសិស្សសញ្ជឹងគិតពីសំណួរមួយ***
>
> ការសួរសំណួរមួយដែលតម្រូវឲ្យសិស្សគិតមុនពេលឆ្លើយជួយជាសះគឿនបំណងរបស់ពួកគេឲ្យចង់ដឹងពីចម្លើយ និងបណ្តាលឲ្យពួកគេមើលព្រះគម្ពីរ ឬ មើលទៅបទពិសោធន៍ផ្ទាល់ខ្លួនរបស់គេដើម្បីរកកអត្ថន័យកាន់តែជ្រៅជ្រះ ។ សូមឲ្យសិស្សមានពេលគិតអំពីសំណួរ មុនពេលសុំឲ្យពួកគេមើលព្រះគម្ពីរដើម្បីឆ្លើយ ។

- តើវាមានន័យយ៉ាងណាដល់អ្នកដែលដឹងថា ព្រះអង្គសង្គ្រោះនឹងរងទុក្ខជំនួសអ្នកដោយស្មគ្រ័ចិត្ត ដើម្បីឲ្យអ្នកអាចទទួលបានសេចក្តីមេត្តាករុណា ?

សូមឲ្យសិស្សអាន អាលម៉ា ៤២:២២–២៤ ហើយរកមើលអ្វីដែលចាំបាច់ដើម្បីឲ្យសេចក្តីមេត្តាករុណាត្រូវបានពង្រីកដល់យើង ។

- តើអ្វីដែលចាំបាច់សម្រាប់យើងដើម្បីទទួលបានសេចក្តីមេត្តាករុណា ហើយចៀសវាងការទាមទារនៃសេចក្តីយុត្តិធម៌ដ៏ពេញលេញនោះ ? (នៅពេលសិស្សរកឃើញការប្រែចិត្តជាវិធីដែលយើងទទួលបានសេចក្តីមេត្តាករុណាហើយ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀននោះក្រោមជញ្ជីង ៖ ***ប្រសិនបើយើងប្រែចិត្ត យើងនឹងទទួលបានសេចក្តីមេត្តាករុណាតាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ។*** អ្នកក៏អាចផ្តល់យោបល់ថា ពួកគេគួរសរសេរវានៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ៤២:២២–២៤) ។
- តើអ្នកគិតថាឃ្លា « ជនណាដែលប្រែចិត្ត » មានន័យយ៉ាងណា ? (អ្នកដែលប្រែចិត្តដោយស្មោះពិត) ។
- ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីយល់ថា ព្រះអង្គសង្គ្រោះបានរងទុក្ខនឹងការដាក់ទោសសម្រាប់អំពើបាបរបស់យើងជំនួសយើង ?

សូមពន្យល់ថា ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកកណ្តាលរបស់យើង ។ អ្នកកណ្តាលម្នាក់គឺជាអ្នកដែលឈរនៅចន្លោះគូភាគីពីរដើម្បីជួយដោះស្រាយវិបត្តមួយ ។ សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ិយដ៏ ឃេ. ផាកគី នៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់ហើយរកមើលនូវមូលហេតុដែលជនទីបីម្នាក់ត្រូវតែមានដើម្បីឲ្យសេចក្តីមេត្តាករុណាអាចបានពង្រីកដល់អ្នកមានបាប ៖

« ហើយតាមរយៈច្បាប់ដ៏អស់កល្បជានិច្ច នោះសេចក្តីមេត្តាករុណាមិនអាចផ្តល់នូវការសង្គ្រោះបានឡើយ លុះត្រាតែមានមនុស្សម្នាក់ដែលសុខចិត្ត ហើយមានសមត្ថភាពទទួលយកបំណុលរបស់យើង ហើយបង់ថ្លៃនោះ ហើយរៀបចំលក្ខខណ្ឌសម្រាប់ការប្រោសលោះរបស់យើង ។

« រហូតដល់មានអ្នកកណ្តាល រហូតដល់យើងមានមិត្តម្នាក់ បើពុំដូចនោះទេទម្ងន់ដ៏ពេញលេញនៃសេចក្តីយុត្តិធម៌ដែលមិនបង្អន់ មិនមានមេត្តា នឹងត្រូវធ្លាក់លើយើងជាប្រាកដ ។ ការផ្តន្ទាទោសទាំងស្រុងសម្រាប់គ្រប់អំពើរំលង ទោះតូច ឬធំ នឹងត្រូវទាមទារពីយើងឲ្យគ្រប់ ។

« ប៉ុន្តែសូមដឹងការណ៍នេះ ៖ សេចក្តីពិត សេចក្តីពិតដ៏រុងរឿង បានប្រកាសថាពិតជាអ្នកកណ្តាលម្នាក់មែន ។ . . .

« តាមរយៈទ្រង់ ក្តីមេត្តាអាចលូកទៅរកយើងម្នាក់ៗ ដោយពុំមានការបង្អាក់បង្អន់ដល់ក្រិត្យវិន័យដ៏អស់កល្បនៃក្តីយុត្តិធម៌ឡើយ ។ . . .

« ការពង្រីកនៃសេចក្តីមេត្តាករុណាមិនមែនស្ងួយប្រវត្តិនោះទេ ។ វាត្រូវធ្វើតាមរយៈសេចក្តីសញ្ញាជាមួយនឹងទ្រង់ ។ វានឹងអាស្រ័យលើលក្ខខណ្ឌរបស់ទ្រង់ ជាលក្ខខណ្ឌដ៏ប្រោសប្រណីរបស់ទ្រង់ » (« The Mediator » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៧៧, ទំព័រ ៥៥–៥៦) ។

សូមឲ្យសិស្សអាន អាលម៉ា ៤២:២៩–៣១ដោយស្ងាត់ៗ ដោយរកមើលអ្វីដែលអាលម៉ាចង់ឲ្យកូរីអានតុនមាន ។ (អ្នកអាចស្នើថាសិស្សគួរគូសចំណាំអ្វីដែលពួកគេរកឃើញ) ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីឲ្យសេចក្តីយុត្តិធម៌ និងសេចក្តីមេត្តាករុណា និងការរងទុក្ខរបស់ព្រះអម្ចាស់ « មានប្រសិទ្ធិភាពយ៉ាងពេញទំហឹងនៅក្នុងចិត្តកូនចុះ » ?

សូមឲ្យសិស្សសរសេរគម្រោងមេរៀនសង្ខេបមួយដែលបង្ហាញពីរបៀបដែលពួកគេអាចបង្រៀនគោលគំនិតនៃសេចក្តីយុត្តិធម៌ និងសេចក្តីមេត្តាករុណាដល់អ្នកដទៃ ។ សូមណែនាំពួកគេឲ្យបង្រៀនគ្រួសាររបស់ពួកគេពីអ្វីដែលពួកគេបានរៀននៅថ្ងៃនេះ ។

សូមរំឭកសិស្សអំពីការព្រួយបារម្ភរបស់កូរីអានតុនទាក់ទងនឹងភាពយុត្តិធម៌នៃសេចក្តីយុត្តិធម៌របស់ព្រះ ។ អ្នកអាចថ្លែងទីបន្ទាល់ថា សេចក្តីជំនុំជម្រះនៅថ្ងៃចុងក្រោយនឹងយុត្តិធម៌ ហើយថាយើងនឹងទទួលបានអ្វីដែលយើងសមនឹងទទួលនៅទីបញ្ចប់ យោងតាមសេចក្តីយុត្តិធម៌ និងសេចក្តីមេត្តាករុណារបស់ព្រះ ។ អ្នកក៏អាចចង់បង្ហាញថា កូរីអានតុនបានប្រែចិត្តពីអំពើបាបរបស់គាត់ ហើយបានមានឥទ្ធិពលដ៏វិជ្ជមានលើការលូតលាស់នៃសាសនាចក្រ (សូមមើល អាលម៉ា ៤៩:៣០) ។ សូមឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេអាចត្រូវបន្តដំណើរការនៃការប្រែចិត្តថ្ងៃខ្លួនគេ ។

សូមឲ្យសិស្សពីរបីនាក់ចែកចាយការដឹងគុណ និងទីបន្ទាល់របស់ពួកគេចំពោះព្រះទ័យរបស់ព្រះអង្គសង្គ្រោះដើម្បីធ្វើឲ្យធួនសម្រាប់អំពើបាបរបស់យើង ហើយបំពេញការទាមទារនៃសេចក្តីយុត្តិធម៌ជំនួសយើង ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីមេត្តាករុណា និងការប្រោសលោះដែលមានតាមរយៈការលះបង់ដ៏ធួនរបស់ព្រះអង្គសង្គ្រោះ ។

អាលម៉ា ៤៣–៤៤

សេចក្តីផ្តើម

នៅពេលអាលម៉ា និងកូនប្រុសរបស់គាត់បានបន្តបង្រៀនដំណឹងល្អ ពួកសាសន៍សូរ៉ាំបានចូលរួមនឹងកងទ័ពពួកសាសន៍លេមិនដើម្បីវាយប្រហារពួកសាសន៍នីហ្វៃ ។ មេទ័ពម៉ូរ៉ូណៃបានបង្ហាញសេចក្តីជំនឿ និងប្រាជ្ញាក្នុងការដឹកនាំពួកសាសន៍នីហ្វៃឲ្យការពារខ្លួនគេប្រឆាំងនឹងកងទ័ពពួកសាសន៍លេមិន ។ ទោះបីជាពួកគេមានចំនួនច្រើនក្តី ការរៀបចំរបស់កងទ័ពសាសន៍នីហ្វៃ និងសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទបានផ្តល់ប្រយោជន៍ដល់ពួកគេនៅក្នុងចម្បាំង ។ នៅពេលពួកសាសន៍លេមិនបានប្រឈមមុខនឹងការបរាជ័យមួយចំនួន ពួកគេបានធ្វើសេចក្តីសញ្ញាសន្តិភាពមួយ ហើយចាកចេញពីដែនដីមួយរដូវកាល ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៤៣

ការរៀបចំ និងយុទ្ធសាស្ត្ររបស់មេទ័ពម៉ូរ៉ូណៃធ្វើឲ្យរំខានដល់ការគ្រោងរបស់កងទ័ពសាសន៍លេមិន

សូមឲ្យសិស្សសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេនូវបញ្ជីនៃផែនការ គោលដៅ និងបំណងទាំងឡាយសម្រាប់អនាគតរបស់ពួកគេ ។ នៅពេលពួកគេសរសេរ សូមរំឭកពួកគេឲ្យគិតអំពីគោលដៅ និងបំណងប្រាថ្នាខាងវិញ្ញាណដូចជាការបម្រើបេសកកម្ម ការផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ និងការចិញ្ចឹមថែទាំគ្រួសារ ។ មុនចាប់ផ្តើមថ្នាក់ អ្នកអាចសរសេរបញ្ជីនៃគោលដៅ និងបំណងរបស់អ្នកផ្ទាល់ខ្លួន ។ អ្នកអាចចែកចាយគម្រោង និងបំណងរបស់អ្នកខ្លះជាគំរូដើម្បីជួយសិស្សឲ្យចាប់ផ្តើមសរសេរ ។

ក្រោយពីសិស្សសរសេរគម្រោងរបស់ពួកគេហើយ សូមឲ្យពួកគេរកមើលបំណង និងគោលដៅដែលពួកគេមានអារម្មណ៍ថា សាតាំងនឹងមិនចង់ឲ្យពួកគេសម្រេចវាបាន ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយគោលដៅដែលពួកគេបានរកឃើញ ។ សូមឲ្យពួកគេពន្យល់ពីមូលហេតុដែលសាតាំងនឹងមិនចង់ឲ្យពួកគេសម្រេចគោលដៅទាំងនោះ ។ អ្នកក៏អាចសួរឲ្យពួកគេពីមូលហេតុដែលពួកគេមានអារម្មណ៍ខ្លាំងមាំអំពីការសម្រេចបានគោលដៅទាំងនោះ ។ សូមស្មើថាការសិក្សាមួយលើ អាលម៉ា ៤៣–៤៤ អាចជួយយើងឲ្យឃើញពីរបៀបដែលយើងអាចសម្រេចគោលដៅ ដ៏សុចរិតរបស់យើង ទោះបីមានឧបសគ្គនៃការខិតខំដើម្បីបំផ្លាញក្តី ។

សូមសង្ខេប អាលម៉ា ៤៣:១–៤ ដោយការពន្យល់ថា ថ្វីបើអាលម៉ាខិតខំដើម្បីនាំពួកសាសន៍សូរ៉ាំឲ្យត្រឡប់មកកាន់សាសនាចក្រវិញក្តី ក៏ពួកគេជាច្រើនបានចូលរួមនឹងពួកសាសន៍លេមិន ហើយបានរៀបចំវាយប្រហារពួកសាសន៍នីហ្វៃ ។ ពួកគេក៏បានចូលរួមដោយពួកសាសន៍អាម៉ាលេកៃ ដែលដូចជាពួកសាសន៍សូរ៉ាំដែរ ធ្លាប់បានជាសាសន៍នីហ្វៃ ប៉ុន្តែបានវង្វេងពីសេចក្តីពិត ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៤៣:៥–៨ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលគម្រោង ឬ « គោលបំណងទាំងឡាយ» របស់អ្នកដឹកនាំពួកសាសន៍នីហ្វៃឈ្មោះថា សេរ៉ាហិមណា ។

សូមពន្យល់ថា នៅពេលសិស្សសិក្សាពីដំណើររឿងនៃការច្បាំងខាងរូបកាយនៅក្នុងព្រះគម្ពីរមរមន យើងអាចប្រៀបធៀបពួកគេទៅនឹងចម្បាំងខាងវិញ្ញាណដែលយើងជួប ។

- តើគោលបំណងរបស់សេរ៉ាហិមណាប្រឆាំងនឹងពួកសាសន៍នីហ្វៃអាចដូចជាគោលបំណងដែលសាតាំងមានប្រឆាំងនឹងយើងដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៤៣:៩–១២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលគោលបំណងរបស់ពួកសាសន៍នីហ្វៃ ។

- តើអ្វីជាគោលបំណងរបស់ពួកសាសន៍នីហ្វៃ ?

សូមឲ្យសិស្សអាន អាលម៉ា ៤៣:១៦–១៩ ដោយស្ងាត់ៗ ។ សូមឲ្យពួកគេរកមើលអ្វីដែលម៉ូរ៉ូណៃ ជាមេទ័ពនៃពួកសាសន៍នីហ្វៃបានធ្វើដើម្បីរៀបចំប្រជាជនឲ្យការពារដែនដី និងគ្រួសាររបស់ពួកគេ ។

- តើរឿងជាក់លាក់អ្វីខ្លះដែលសាសន៍នីហ្វៃបានធ្វើ ដើម្បីរៀបចំសម្រាប់ការវាយប្រហារពួកសាសន៍លេមិន ?

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៤៣:២០–២២ ឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលប្រតិកម្មរបស់ពួកសាសន៍លេមនទៅនឹងការរៀបចំរបស់សាសន៍នីហ្វៃ ។

- ហេតុអ្វីបានជាពួកសាសន៍លេមិនបានដកថយការវាយប្រហាររបស់ពួកគេ ទោះបីជាពួកគេមានចំនួនដ៏ច្រើនក្រៃលើសពួកសាសន៍នីហ្វៃក្តី ?
- តើយើងអាចរៀនអ្វីខ្លះពីហេតុការណ៍នេះអំពីការការពារខ្លួនយើងប្រឆាំងនឹងគោលបំណងរបស់សាតាំង ?

សូមឲ្យសិស្សអាន អាលម៉ា ៤៣:២៣–២៤ ដោយស្ងាត់ៗដើម្បីរកមើលអ្វីដែលម៉ូរ៉ូណៃបានធ្វើ នៅពេលគាត់មិនប្រាកដពីរបៀបដែលសត្រូវរបស់គាត់បានគ្រោងដើម្បីវាយលុកលើកក្រោយ ។

- ហេតុអ្វីបានជាម៉ូរ៉ូណៃបានបញ្ជូនអ្នកនាំសារទៅនិយាយជាមួយនឹងអាលម៉ា ?

- តើគំរូរបស់មរ៉ូណៃអាចបង្រៀនយើងអ្វីខ្លះ អំពីរបៀបដែលយើងអាចត្រូវបានរៀបចំខាងវិញ្ញាណប្រឆាំងនឹងឧបសគ្គ ? (សូមជួយសិស្សឲ្យរកឃើញនូវគោលការណ៍ខាងក្រោម ៖ **ប្រសិនបើយើងស្វែងរក និងធ្វើតាមការប្រឹក្សារបស់ព្យាការី យើងនឹងអាចការពារខ្លួនយើងកាន់តែប្រសើរប្រឆាំងនឹងឧបសគ្គ**) ។

សូមសង្ខេប អាលម៉ា ៤៣:២៥–៤៣ ដោយការនិយាយថា មរ៉ូណៃបានធ្វើសកម្មភាពតាមចំណេះដឹងដែលគាត់បានទទួលពីព្យាការី ។ គាត់បានបែងចែកកងទ័ពរបស់គាត់ជាពីរផ្នែក ។ ទាហានខ្លះស្នាក់នៅក្នុងទីក្រុងយើសុនដើម្បីការពារប្រជាជនអាំម៉ូន ។ កងទ័ពផ្សេងទៀតឆ្ពោះទៅដែនដីម៉ាន់តែ ។ មរ៉ូណៃបានបញ្ជូនគិញសម្ងាត់ដើម្បីរកមើលកន្លែងដែលពួកសាសន៍លេមិនស្នាក់នៅ ហើយគាត់បានឲ្យទាហានផ្សេងទៀតលាក់ខ្លួនតាមបណ្តោយផ្លូវដែលពួកសាសន៍លេមិនធ្វើដំណើរ ។ នៅពេលពួកសាសន៍លេមិនទៅដល់ ទាហានសាសន៍នីហ្វៃបានឡោមព័ទ្ធពួកគេ ។ នៅពេលពួកសាសន៍លេមិនបានឃើញថា ពួកគេត្រូវបានឡោមព័ទ្ធហើយ ពួកគេបានប្រយុទ្ធយ៉ាងសាហាវ ។ សាសន៍នីហ្វៃជាច្រើនបានស្លាប់ ប៉ុន្តែពួកសាសន៍លេមិនបានរងទុក្ខនិងមានរបួសជាច្រើនអនេក ។

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៤៣:៤៣–៥៤ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលភាពខុសគ្នារវាងការលើកទឹកចិត្តនិងប្រភពនៃកម្លាំងរបស់សាសន៍លេមិន និង ការលើកទឹកចិត្ត និងប្រភពនៃកម្លាំងរបស់សាសន៍នីហ្វៃ ។

- តើអ្នកបានកត់សម្គាល់អ្វីអំពីមូលហេតុសម្រាប់ការប្រយុទ្ធរបស់ពួកសាសន៍លេមិន ? តើអ្នកបានកត់សម្គាល់អ្វីអំពីមូលហេតុសម្រាប់ការប្រយុទ្ធរបស់ពួកសាសន៍នីហ្វៃ ? តើប្រភពនៃកម្លាំងរបស់សាសន៍នីហ្វៃខុសពីប្រភពនៃកម្លាំងរបស់សាសន៍លេមិនដោយរបៀបណា ? (នៅពេលចាំបាច់ សូមបង្ហាញថាខណៈពេលដែលពួកសាសន៍លេមិនបានប្រយុទ្ធដោយសារការស្អប់ និងកំហឹង ពួកសាសន៍នីហ្វៃត្រូវបានបំផុសដោយបុព្វហេតុដ៏ល្អជាង [សូមមើលអាលម៉ា ៤៣:៤៥–៤៧] ។ ពួកគេបានស្រែកសុំជំនួយពីព្រះអម្ចាស់ ហើយទ្រង់បានពង្រឹងដល់ពួកគេ [សូមមើលអាលម៉ា ៤៣:៤៩–៥០] ។)
- តើយើងអាចរៀនអ្វីខ្លះ ពីគំរូរបស់មរ៉ូណៃ និងកងទ័ពរបស់គាត់ដើម្បីជួយយើងនៅក្នុងចម្បាំងរបស់យើងប្រឆាំងនឹងឧបសគ្គ ?

សូមឲ្យសិស្សសរសេរចម្លើយរបស់ពួកគេទៅនឹងសំណួរនេះ ។ បន្ទាប់មក សូមឲ្យពួកគេចែកចាយអ្វីដែលពួកគេបានសរសេរ ។ ពួកគេអាចលើកឡើងនូវគោលការណ៍ខាងក្រោមខ្លះ ៖

នៅពេលយើងអធិស្ឋានសុំជំនួយដើម្បីសម្រេចគម្រោង និងបំណងដ៏សុចរិតរបស់យើង ព្រះនឹងជួយយើងឲ្យសម្រេចវាបាន ។

យើងត្រូវបានបំផុសដោយបុព្វហេតុដ៏ល្អជាងអ្នកដែលប្រឆាំងនឹងសេចក្តីពិត ។

ព្រះអម្ចាស់នឹងជួយយើងឲ្យបំពេញកាតព្វកិច្ចរបស់យើងដើម្បីការពារគ្រួសារ សេរីភាព និងសាសនារបស់យើង ។

សូមឲ្យសិស្សប្រាប់ពីពេលខ្លះដែលពួកគេបានទទួលជំនួយពីព្រះអម្ចាស់ដើម្បីសម្រេចបានគោលដៅដ៏សុចរិត ។ សូមគិតពីការចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនអ្នក ។ សូមថ្លែងទីបន្ទាល់ពីសមត្ថភាពរបស់ព្រះអម្ចាស់ដើម្បីជួយយើងឲ្យសម្រេចបានការធ្វើសុចរិត ។ សូមឲ្យសិស្សដាក់គោលដៅសុចរិតជាផ្នែកមួយនៃការអធិស្ឋានដ៏ឥតដាច់របស់ពួកគេ ។

អាលម៉ា ៤៤

មេទ័ពមរ៉ូណៃបញ្ជាពួកសាសន៍លេមិនឲ្យធ្វើសេចក្តីសញ្ញាសន្តិភាព

សូមឲ្យយុវជនម្នាក់ដែលចង់អានឮៗ ឲ្យឡើងមកខាងមុខថ្នាក់ជាមួយនឹងព្រះគម្ពីររបស់គាត់ ។ សូមរំឭកសិស្សក្នុងថ្នាក់ថា នៅពេលមេទ័ពមរ៉ូណៃបានឃើញការភ័យខ្លាចរបស់ពួកសាសន៍លេមិន គាត់បានបញ្ជាឲ្យកងទ័ពរបស់គាត់ឈប់ប្រយុទ្ធ (សូមមើល អាលម៉ា ៤៣:៥៤) ។ សូមឲ្យយុវជននោះអានសម្តីរបស់មរ៉ូណៃនៅក្នុង អាលម៉ា ៤៤:១–៦ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកនូវ ការពន្យល់របស់មរ៉ូណៃនៃជ័យជំនះរបស់ពួកសាសន៍នីហ្វៃ ។

- តើមរ៉ូណៃចង់ឲ្យសេរ៉ាហិមណាយល់អំពីប្រភពនៃកម្លាំងរបស់ពួកសាសន៍នីហ្វៃនៅក្នុងចម្បាំង ? តើគាត់បានផ្តល់អ្វីដល់ពួកសាសន៍លេមិន ? (គាត់បាននិយាយថា ពួកសាសន៍នីហ្វៃនឹងមិនធ្វើបាបពួកគេទៀតឡើយ ប្រសិនបើពួកគេទម្លាក់អាវុធ ហើយចូលទៅក្នុងសេចក្តីសញ្ញាសន្តិភាពមួយ) ។
- តើសេចក្តីពិតអ្វីដែលយើងអាចរៀនពី អាលម៉ា ៤៤:៤–៦ ដែលអាចជួយយើងនៅក្នុងចម្បាំងខាងវិញ្ញាណរបស់យើង ? (សិស្សអាចចែកចាយគោលការណ៍បីបួន ដែលបានរៀនរួចហើយនៅក្នុងមេរៀននេះ ។ សូមប្រាកដថា ពួកគេរាប់បញ្ចូលសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះអម្ចាស់នឹងពង្រឹង ហើយការពារយើងស្របតាមសេចក្តីជំនឿរបស់យើងលើទ្រង់** ។អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំខគម្ពីរទាំងនេះដែលបង្រៀនពីសេចក្តីពិតនេះ) ។

សូមឲ្យសិស្សម្នាក់អានឮៗនូវការប្រឹក្សាខាងក្រោមដល់យុវវ័យនៃសាសនាចក្រ ពីប្រធាន ឋិយដ៏ ឃេ ងាកកី នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ។ អ្នកអាចចែកច្បាប់ចម្លងដល់សិស្សម្នាក់ៗ ។

« យុវវ័យសព្វថ្ងៃនេះត្រូវបានចិញ្ចឹមធំធាត់ឡើងនៅក្នុងដែនដីសត្រូវដោយមានបទដ្ឋានសីលធម៌ធ្លាក់ចុះយ៉ាងខ្លាំង ។ ប៉ុន្តែក្នុងនាមជាអ្នកបម្រើរបស់ព្រះអម្ចាស់ ខ្ញុំសន្យានឹងអ្នកថា អ្នកនឹងត្រូវបានការពារ និងបាំងពីការវាយប្រហារនៃឧបសគ្គ *ប្រសិនបើ* អ្នកធ្វើតាមការបំផុសដែលមកពីព្រះវិញ្ញាណបរិសុទ្ធ ។

« សូមស្ងៀកពាក់ឲ្យបានសមរម្យ សូមនិយាយដោយមានគារវភាព សូមស្តាប់តន្ត្រីណាដែលលើកកម្លាំង ។ សូមចៀសវាងការអនុវត្តជីវិតមែងស្លាប់ទាំងអស់ និងការអនុវត្តដែលបន្ទោកផ្ទាល់ខ្លួន ។ សូមក្តាប់ជីវិតរបស់អ្នក ហើយបញ្ឈប់ខ្លួនអ្នកឲ្យឆ្ងាតវៃ ។ ដោយសារយើងពឹងលើអ្នកខ្លាំង អ្នកនឹងត្រូវបានពរជ័យយ៉ាងខ្លាំងដែរ ។ អ្នកនឹងមិនដែលចេញឆ្ងាយពីក្រសែព្រះនេត្រនៃព្រះវរបិតាសួគ៌ជាទីស្រឡាញ់របស់អ្នកឡើយ » (« Counsel to Youth »*Ensign*ឬ*លេអាហូណា*,ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ១៨) ។

- នៅក្នុងប្រសាសន៍របស់ប្រធាន ជាកកី តើអ្វីដែលអ្នកចាប់អារម្មណ៍ ? ហេតុអ្វី ?

សូមសង្ខេប អាលម៉ា ៤៤:៧–១០ ដោយការពន្យល់ថា សេរ៉ាហិមណាបានប្រកាសថា គាត់និងប្រជាជនរបស់គាត់មិនជឿថា ពួកសាសន៍នីហ្វៃត្រូវបានពង្រឹងដោយព្រះនោះទេ ។ គាត់បានឲ្យពួកសាសន៍លេមិនទម្លាក់អាវុធចុះ ប៉ុន្តែគាត់បានបដិសេធធ្វើសេចក្តីសញ្ញាសន្តិភាពមួយ ។ សូមឲ្យសិស្សដែលអាន អាលម៉ា ៤៤:១–៦ បន្តអានឮៗនូវសម្តីរបស់ម្ល៉ឺណៃដល់សេរ៉ាហិមណា ដែលមាននៅក្នុង អាលម៉ា ៤៤:១១ ។ សូមសួរសិស្ស ៖

- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ខ្លាំងម្ល៉ះដែលម្ល៉ឺណៃឲ្យពួកសាសន៍លេមិនធ្វើសេចក្តីសញ្ញាសន្តិភាពមួយនោះ ?

សូមសង្ខេប អាលម៉ា ៤៤:១២–២០ ដោយការពន្យល់ថា ខណៈពេលដែលសាសន៍លេមិនជាច្រើនបានធ្វើសេចក្តីសញ្ញាសន្តិភាពមួយ សេរ៉ាហិមំណាបានប្រជុំពួកទ័ពរបស់គាត់ផ្សេងទៀតឲ្យប្រយុទ្ធនឹងទ័ពរបស់ម្ល៉ឺណៃ ។ នៅពេលសាសន៍នីហ្វៃបានចាប់ផ្តើមសម្លាប់ពួកគេ សេរ៉ាហិមណាបានឃើញការបំផ្លាញដ៏ខ្លាំង ហើយបានសន្យាថានឹងធ្វើសេចក្តីសញ្ញាសន្តិភាពមួយ ។

សូមថ្លែងទីបន្ទាល់អំពីព្រះហស្តការពាររបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់អ្នកដែលស្មោះត្រង់នឹងទ្រង់ ។ សូមលើកទឹកចិត្តសិស្សឲ្យប្រយុទ្ធដោយក្លាហានសម្រាប់គោលដៅ និងបំណងដ៏សុចរិតរបស់ពួកគេ ហើយទុកចិត្តលើសេចក្តីសន្យារបស់ព្រះថានឹង « ទ្រទ្រង់ ហើយនឹងថែរក្សាយើងឲ្យគង់វង្ស ដរាបណាយើងមានចិត្តស្មោះត្រង់ចំពោះទ្រង់ » (អាលម៉ា ៤៤:៤) ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អាលម៉ា ៤៣:៣ ។ សង្គ្រាមទាំងឡាយដែលយើងកំពុងប្រយុទ្ធបានចាប់ផ្តើមនៅក្នុងជីវិតមុនជីវិតរមែងស្លាប់របស់យើង

ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី បានមានប្រសាសន៍អំពីភាពពិតនៃសង្គ្រាមដែលយើងបានធ្វើតាំងពីពីមុនពិភពលោកបានចាប់ផ្តើម ៖

« មានសង្គ្រាមដែលបានចាប់ផ្តើមឡើង តាំងពីមុនលោកិយត្រូវបានបង្កើត ហើយដែលហាក់ដូចជាបន្តអស់រយៈពេលជាយូរឥឡូវមកដល់ហើយ ។ . . .

« សង្គ្រាមនេះ . . . គឺជាសង្គ្រាមរវាងសេចក្តីពិត និងកំហុសឆ្គង រវាងសិទ្ធិសេរីភាព និងការបង្ខំ រវាងអ្នកជើរតាមព្រះគ្រីស្ទ និងអ្នកដែលបានបដិសេធទ្រង់ ។ សត្រូវរបស់ទ្រង់ទាំងឡាយបានប្រើរាល់ឧបាយកលនៅក្នុងវិបត្តិនោះ ។ . . .

« . . . វាហាក់ដូចជាវាស្ថិតនៅកន្លែងចាប់ផ្តើម ។ . . . ជនរងគ្រោះដែលធ្លាក់ គឺមានតម្លៃដូចដែលអ្នកដែលបានធ្លាក់នៅក្នុងអតីតកាលដែរ ។ វាគឺជាសង្គ្រាមបន្តឥតដាច់មួយ ។ . . .

« សង្គ្រាមបន្ត ។ . . . វាបានធ្វើសង្គ្រាមដ៏ខ្លាំងនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់យើង ទាំងថ្ងៃទាំងយប់ នៅក្នុងផ្ទះ នៅកន្លែងធ្វើការ នៅសាលារៀន សហគមន៍យើង ។ វាបានប្តាំងនឹងសំណូរនៃសេចក្តីស្រឡាញ់ និងការគោរព នៃភាពស្មោះត្រង់ និងការក្បត់ នៃការគោរពតាម និងសេចក្តីសុចរិត ។ យើងទាំងអស់គ្នាពាក់ព័ន្ធនឹងសង្គ្រាមនេះ ។ . . . យើងកំពុងតែឈ្នះ ហើយអនាគតកាលនឹងមិនដែលភ្លឺថាជាងនេះឡើយ » (« The War We Are Winning »*Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៨៦, ទំព័រ ៨២, ៨៤–៨៥) ។

អាលម៉ា ៤៣:៩, ៤៥ ការពារ និងពង្រឹងគ្រួសារ

សិស្ទើរ ជីរជីនា យូ. ជិនសិន នៃគណៈប្រធានសមាគមសង្គ្រោះស្ត្រីទូទៅបានយោងលើការព្រមានមួយនៅក្នុងសេចក្តីប្រកាសអំពីគ្រួសារ « ថាការបែកបាក់នៅក្នុងគ្រួសារនឹងនាំមកនូវមហន្តរាយមកដល់បុគ្គលនោះ សហគមន៍ និងជាតិសាសន៍ដូចដែលបានទាយទុកជាមុនដោយពួកព្យាការីសម័យបុរាណ និងពួកព្យាការីសម័យទំនើប » (« ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Ensign*ឬ*លេអាហូណា,* ខែ វិច្ឆិកា ឆ្នាំ ២០១០, ទំព័រ ១២៩)) សិស្ទើរ ជិនសិន បានសង្កេតឃើញថា ៖ « បងប្អូនប្រុសស្រី យើងស្ថិតនៅក្នុងពេលដ៏ចំនៃចំណុចកណ្តាលនៃភាពពិតនោះ ។ វាគឺជាភាតព្វកិច្ចរបស់យើងទាំងអស់គ្នាដើម្បីការពារ និងពង្រឹងគ្រួសារ » (« Come, Listen to a Prophet's Voice »*Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៨, ទំព័រ ១៣–១៤) ។

មេរៀនសិក្សានៅផ្ទះ

អាលម៉ា ៣៩–៤៤ (មេរៀនទី ២០)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀននៅពេលពួកគេសិក្សា អាលម៉ា៣៩–៤៤(មេរៀនទី ២០) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (អាលម៉ា ៣៩)

ខណៈពេលដែលសិក្សាសម្តីរបស់អាលម៉ាដល់កូនប្រុសខុសឆ្គងរបស់គាត់ កូរីអានតុន នោះសិស្សបានរៀនថា អំពើបាបខាងផ្លូវភេទគឺជាអំពើគួរខ្ពើមឆ្អើមនៅក្នុងព្រះនេត្រ របស់ព្រះអម្ចាស់ ។ អាលម៉ាក៏បានបង្រៀនកូនប្រុសរបស់គាត់ថា ការប្រែចិត្តរួមមាន ការទទួលស្គាល់ និងការលះបង់អំពើបាបរបស់យើង ហើយបែរទៅរកព្រះអម្ចាស់ដោយ អស់ពីគំនិត អស់ពីកម្លាំង និងអស់ពីពល ។ សិស្សអានទីបន្ទាល់របស់អាលម៉ាថា ព្រះយេស៊ូវគ្រីស្ទបានមកដើម្បីនាំយកអំពើបាបនៃមនុស្សលោកចេញទៅ ។

ថ្ងៃទី ២ (អាលម៉ា ៤០–៤១)

កូរីអានតុនបានបារម្ភអំពីការរស់ឡើងវិញ និងសេចក្តីជំនុំជម្រះនៅថ្ងៃចុងក្រោយ ចេញពី ចម្លើយរបស់អាលម៉ាចំពោះការបារម្ភទាំងនេះ សិស្សបានរៀនពីគោលលទ្ធិខុសគ្នា ជាច្រើនដែលទាក់ទងនឹងការរស់ឡើងវិញ ដោយរួមមានសេចក្តីពិតថា យើងនឹងត្រូវ សាងឡើងវិញអាចដល់សុភមង្គល ឬសេចក្តីទុក្ខវេទនាស្របតាមកិច្ចការ និងបំណង របស់យើងនៅក្នុងជីវិតរមែងស្លាប់ ។ អាលម៉ាក៏បានបញ្ជាក់ថា « សេចក្តីទុច្ចរិតពុំដែល ជាសុភមង្គលឡើយ » (អាលម៉ា ៤១:១០) ។

ថ្ងៃទី ៣ (អាលម៉ា ៤២)

អាលម៉ាបានជួយកូរីអានតុនឲ្យយើញថា ការមិនគោរពតាមបណ្តាលឲ្យបុគ្គលទាំងឡាយ ត្រូវកាត់ចេញពីវត្តមាននៃព្រះ ។ ផ្ទុយទៅវិញ សិស្សបានរៀនពីរបៀបដែលផែនការនៃ សេចក្តីប្រោសលោះបានអនុញ្ញាតឲ្យបុគ្គលទាំងឡាយយកឈ្នះលើស្ថានភាពធ្លាក់របស់ ពួកគេ ។ ការបង្រៀនរបស់អាលម៉ាបញ្ជាក់ថា ការរងទុក្ខរបស់ព្រះយេស៊ូវគ្រីស្ទបំពេញ ដល់ការទាមទារនៃសេចក្តីយុត្តិធម៌ ដើម្បីឲ្យសេចក្តីមេត្តាករុណាអាចត្រូវបានពង្រីកដល់ អ្នកដែលប្រែចិត្ត ។

ថ្ងៃទី ៤ (អាលម៉ា ៤៣–៤៤)

សិស្សបានរៀនអំពីសង្គ្រាមមួយរវាងពួកសាសន៍លេមិន និងពួកសាសន៍នីហ្វៃ ។ មេរៀន មួយដែលពួកគេបានរៀនពី អាលម៉ា ៤៣–៤៤ គឺថាប្រសិនបើយើងស្វែងរក និង ធ្វើតាមការប្រឹក្សារបស់ព្យាការី យើងនឹងអាចការពារខ្លួនយើងប្រឆាំងនឹងឧបសគ្គកាន់តែ ប្រសើរជាងមុន ។ បន្ថែមលើនេះ សិស្សបានកេរយើញថា នៅពេលយើងអធិស្ឋានដល់ ព្រះអម្ចាស់ទាក់ទងនឹងផែនការ និងបំណងដ៏សុចរិតរបស់យើង ទ្រង់នឹងជួយយើងឲ្យ សម្រេចវាបាន ។

សេចក្តីផ្តើម

ដូចដែលបានកត់ត្រានៅក្នុង អាលម៉ា ៣៩–៤២ អាលម៉ាបានជួយកូនប្រុសរបស់គាត់ កូរីអានតុន ឲ្យយល់ពីភាពធ្ងន់ធ្ងរនៃអំពើបាបខាងផ្លូវភេទ គោលលទ្ធិនានាដែលទាក់ទងនឹងការរស់ឡើងវិញ និងសេចក្តីជំនុំជម្រះនៅថ្ងៃចុងក្រោយ និងលទ្ធផលដ៏អស់កល្បនៃចម្បាប់នៃសេចក្តីយុត្តិធម៌ និង សេចក្តីមេត្តាករុណា ។ មេរៀននេះនឹងផ្តល់ឱកាសដល់សិស្សឲ្យបង្រៀន និងពន្យល់ពីគោលលទ្ធិ ទាំងនេះដល់អ្នកដទៃ ។

យោបល់សម្រាប់ការបង្រៀន

មុនចាប់ផ្តើមបង្រៀន សូមរៀបចំក្រដាសដែលមានការណែនាំនៅក្នុងមេរៀននេះ ។ សូមឲ្យអ្នកចាំ ការណែនាំទាំងឡាយ ដើម្បីអ្នកអាចជួយសិស្សឲ្យសម្រេចបានការខិតខំរបស់គេក្នុងការបង្រៀន ដល់គ្នាទៅវិញទៅមក ។

អាលម៉ា ៣៩–៤១

អាលម៉ាបង្រៀនថា ការប្រែចិត្តនាំមកនូវសុភមង្គល

សូមចាប់ផ្តើមថ្នាក់ដោយការឲ្យសិស្សទន្ទេញរួមគ្នាក្នុង អាលម៉ា ៣៩:៩ ដែលជាវគ្គចំណោះចំណានខគម្ពីរមួយ ដែលពួកគេត្រូវបានណែនាំឲ្យសូត្រនៅក្នុងសប្តាហ៍នេះ ។ សូមសួរប្រសិនបើមាន នរណាម្នាក់អាចរំឭកសិស្សពីមូលហេតុដែលអាលម៉ាបានណែនាំកូនប្រុសរបស់គាត់ កូរីអានតុន ឲ្យ ប្រែចិត្ត ហើយលះបង់អំពើបាបរបស់គាត់ចោលនៅក្នុងខគម្ពីរនេះ ។

សូមរំឭកសិស្សថានៅក្នុង អាលម៉ា ៤០–៤១ អាលម៉ាក៏បាននិយាយអំពីការបារម្ភរបស់កូរីអានតុន អំពីការរស់ឡើងវិញនៃអ្នកស្លាប់ និងសេចក្តីជំនុំជម្រះនៅថ្ងៃចុងក្រោយដែរ ។ ដើម្បីជួយសិស្សឲ្យ ពន្យល់ពីអ្វីដែលពួកគេបានរៀន និងចែកចាយពីអារម្មណ៍ និងទីបន្ទាល់របស់ពួកគេអំពីសេចក្តីពិត ដែលមាននៅក្នុង អាលម៉ា ៣៩–៤១ សូមសរសេរសំណួរខាងក្រោម និងសេចក្តីយោងព្រះគម្ពីរ នៅលើក្តារខៀនមុនចាប់ផ្តើមបង្រៀន ៖

1. *ហេតុអ្វីបានជាវាសំខាន់ដើម្បីកាន់តាមច្បាប់ព្រហ្មចារីយភាព ? (សូមមើល អាលម៉ា ៣៩:១–៩) ។*
2. *តើអ្វីទៅជាការរស់ឡើងវិញ ? តើអ្វីជាភាពខុសគ្នារវាងរាងកាយខាងសាច់ឈាម និងរាងកាយដែលបានរស់ឡើងវិញ ? តើនឹងមានអ្វីកើតឡើង បន្ទាប់ពីយើងបាន រស់ឡើងវិញ ? (សូមមើលអាលម៉ា ៤០:២១–២៦) ។*
3. *តើខ្ញុំនឹងត្រូវកាត់សេចក្តីនៅថ្ងៃជំនុំជម្រះចុងក្រោយដោយរបៀបណា ? (សូមមើល អាលម៉ា ៤១:១–៧) ។*
4. *វាហាក់ដូចជាអ្នកខ្លះដែលរំលងព្រះបញ្ញត្តិសប្បាយរីករាយ ។ តើវាពិតទេ ? (សូមមើល អាលម៉ា ៤១:១០–១៥) ។*

សូមឲ្យសិស្សស្រមៃថា ពួកគេគឺជាអ្នកផ្សព្វផ្សាយសាសនា ហើយថាពួកគេមានការណាត់ជួបមួយ ជាមួយនឹងនរណាម្នាក់ដែលកំពុងរកចម្លើយទៅនឹងសំណួរទាំងនេះ ។ សូមប្រាប់ពួកគេថា ពួកគេ នឹងមានពេលខ្លះរៀបចំ ហើយបន្ទាប់មកពួកគេនឹងមានឱកាសមួយដើម្បីឆ្លើយនឹងសំណួរខ្លះដោយ ប្រើអ្វីដែលពួកគេបានរៀនពី អាលម៉ា ៣៩–៤១ ។

ប្រសិនបើអ្នកសិស្សមានច្រើន សូមឲ្យពួកគេធ្វើការជាមួយដៃគូដែលតំណាងឲ្យដៃគូអ្នកផ្សព្វផ្សាយ សាសនា ។ សូមឲ្យដៃគូនីមួយៗឆ្លើយនឹងសំណួរមួយនៅលើក្តារខៀន ។ (ប្រសិនបើសិស្សអ្នក មានតិច អ្នកអាចចាត់ចែងសំណួរនានាដល់សិស្សម្នាក់ៗ) ។ សូមឲ្យដៃគូនីមួយៗនូវច្បាប់ចម្លង នៃការណែនាំខាងក្រោម ហើយសូមឲ្យពួកគេប្រើខយោងទាំងឡាយនៅចុងបញ្ចប់នៃសំណួរ ដែលគេធ្វើ ដើម្បីឆ្លើយនឹងសំណួររបស់អ្នករៀនរបស់ពួកគេ ។ សូមផ្តល់ពេលដល់សិស្សឲ្យរំឭក

ខគម្ពីរ ហើយរៀបចំមេរៀនខ្លីមួយសម្រាប់អ្នករៀនរបស់គេ ។ សូមលើកទឹកចិត្តដៃគូឲ្យចែកផ្នែកនៃការណែនាំណាដែលពួកគេម្នាក់ៗនឹងទទួលខុសត្រូវនៅពេលបង្រៀន ។

នៅពេលសិស្សរៀបចំ អ្នកអាចដើរមើលពួកគេ ដូច្នេះអ្នកអាចស្តាប់ និងជួយនៅពេលចាំបាច់ ។ ប្រសិនបើចាំបាច់ សូមជួយសិស្សឲ្យកេីញគោលលទ្ធិពី អាលម៉ា ៣៩–៤១ ដែលជួយឆ្លើយនឹងសំណួរដែលពួកគេធ្វើ ។ សូមប្រើគោលលទ្ធិខាងក្រោមជាការណែនាំ ៖

អំពើបាបខាងផ្លូវភេទ គឺជាអំពើដ៏គួរខ្ពើមឆ្អើមមួយនៅក្នុងព្រះនេត្រនៃព្រះអម្ចាស់ (សូមមើល អាលម៉ា ៣៩:១–៩) ។

ការរស់ឡើងវិញ គឺជាការផ្គុំឡើងវិញនៃព្រលឹង និងរាងកាយ ដោយអ្វីៗទាំងអស់ត្រូវសោងឡើងវិញទៅជារូបរាងដ៏ត្រឹមត្រូវ និងដ៏ឥតខ្ចោះ: (សូមមើល អាលម៉ា ៤០:២១–២៦) ។

យើងនឹងត្រូវសោងឡើងវិញឲ្យទទួលបានសុភមង្គល ឬឲ្យដល់ទុក្ខវេទនាស្របតាមកិច្ចការ និងបំណងរបស់យើងនៅក្នុងជីវិតរមែងស្លាប់ (សូមមើល អាលម៉ា ៤១:១–៧) ។

សេចក្តីទុច្ចរិតពុំដែលជាសុភមង្គលឡើយ (សូមមើល អាលម៉ា ៤១:១០–១៥) ។

សេចក្តីណែនាំ

សូមត្រៀមធ្វើនូវសំណួរខាងក្រោម នៅពេលអ្នកបង្រៀន ៖

១. សូមផ្តល់ព័ត៌មានសាវតាខ្លះអំពីខគម្ពីរ (ដូចជាការពន្យល់ពីនរណាកំពុងនិយាយ តើគេកំពុងនិយាយទៅកាន់នរណា ហើយហេតុអ្វី) ។

២. សូមអានផ្នែកនៃវគ្គព្រះគម្ពីរដែលបានផ្តល់ឲ្យដើម្បីជួយអ្នកឆ្លើយនឹងសំណួរ ដែលអ្នកត្រូវធ្វើ ។

៣. សូមសរសេរគោលលទ្ធិ ឬ គោលការណ៍មួយដែលបានបង្រៀននៅក្នុងខគម្ពីរ ដែលអ្នកសិក្សាដែលត្រូវនឹងសំណួរដែលអ្នកធ្វើ ។

៤. សូមពន្យល់ពីរបៀបដែលគោលលទ្ធិ ឬ គោលការណ៍មួយដែលអ្នកបានសរសេរនោះ: ជួយឆ្លើយនឹងសំណួរដែលអ្នកធ្វើ ។ អ្នកអាចស្នើថា អ្នកដែលអ្នកបង្រៀនគួរសរសេរគោលលទ្ធិ ឬ គោលការណ៍មួយនេះនៅក្នុងព្រះគម្ពីរបស់គេ ។

៥. សូមចែកចាយពីមូលហេតុដែលគោលលទ្ធិ ឬ គោលការណ៍នេះសំខាន់ដល់អ្នក ហើយសូមថ្លែងទីបន្ទាល់អំពីសេចក្តីពិតដែលអ្នកបានបង្រៀន ។

ក្រោយពីសិស្សបានរៀបចំឆ្លើយនឹងសំណួររបស់គេហើយ សូមដាក់គេជាក្រុមតូចៗដើម្បីឲ្យពួកគេអាចបង្រៀនដល់គ្នាទៅវិញទៅមក ។ (ប្រសិនបើសិស្សអ្នកមានតិច សូមឲ្យសិស្សនីមួយៗ ឬដៃគូនីមួយៗបង្រៀនដល់សិស្សក្នុងថ្នាក់ទាំងមូល) ។ ក្រោយពីសិស្សបានបញ្ចប់ការបង្រៀនហើយ សូមសួរសិស្សនូវសំណួរខាងក្រោមនេះ ៖

- នៅពេលអ្នកគិតពីអំពើបាបរបស់កូរីអានតុន តើអ្នកគិតថា ហេតុអ្វីបានជាការយល់ពីគោលលទ្ធិទាំងនេះនឹងជួយដល់គាត់ ?
- ហេតុអ្វីបានជាវាសំខាន់ដើម្បីអាចពន្យល់សេចក្តីពិតទាំងនេះដល់អ្នកដែលអ្នកនឹងទាក់ទងនៅក្នុងជីវិតរបស់អ្នក ?
- ហេតុអ្វីបានជាវាសំខាន់ដែលអ្នកត្រូវយល់ ហើយរស់នៅតាមសេចក្តីពិតទាំងនេះ ?

អាលម៉ា ៤២

អាលម៉ាបង្រៀនកូរីអានតុនអំពីសេចក្តីយុត្តិធម៌ និងសេចក្តីមេត្តាករុណា

សូមគូសជញ្ជីងសាមញ្ញមួយនៅលើក្តារខៀន ។ សូមឲ្យសិស្សម្នាក់បង្រៀនពីគោលគំនិតនៃសេចក្តីយុត្តិធម៌ និងសេចក្តីមេត្តាករុណាដល់សិស្សក្នុងថ្នាក់ ដោយប្រើការបញ្ជាក់ និងអ្វីដែលគេបានរៀនពីការណែនាំរបស់អាលម៉ាដល់កូរីអានតុននៅក្នុង អាលម៉ា ៤២ ។ សូមឲ្យសិស្សបើកទៅអាលម៉ា ៤២ នៅក្នុងព្រះគម្ពីររបស់គេ ហើយរកមើលឃ្លា និងប្រយោគអំពីសេចក្តីយុត្តិធម៌ និងសេចក្តីមេត្តាករុណាដែលពួកគេបានគូសចំណាំ ។

ដើម្បីជួយសិស្សឲ្យយល់ពីលក្ខខណ្ឌដែលសេចក្តីមេត្តាករុណាកើតមានបាន សូមសួរសំណួរខាងក្រោម ៖

- តើព្រះយេស៊ូវគ្រីស្ទបានធ្វើអ្វីដើម្បីឲ្យមានសេចក្តីមេត្តាករុណាកើតមានដល់យើង ?
- តើយើងត្រូវធ្វើអ្វីដើម្បីទទួលបានសេចក្តីមេត្តាករុណានោះ ?

សូមឲ្យសិស្សពីរបីនាក់ចែកចាយពីមូលហេតុដែលពួកគេមានអំណរសម្រាប់ជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។

អាលម៉ា ៤៣–៤៤

ការធ្វើតាមការណែនាំរបស់ព្យាការីការពារយើងពីឧបសគ្គ

ប្រសិនបើមានពេល សូមគិតពីការសុំសិស្សឲ្យរំឭកអ្វីដែលពួកគេបានរៀនពី អាលម៉ា ៤៣–៤៤ ដោយការចែកចាយពីអ្វីដែលពួកគេបានសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីររបស់ពួកគេអំពីការប្រយុទ្ធនឹងសង្គ្រាមខាងវិញ្ញាណរបស់គេ (ថ្ងៃទី ៤កិច្ចការទី ៣ និង ៤) ។ សូមថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និងព្រះចេស្តារបស់ទ្រង់ដើម្បីពង្រឹកសេចក្តីមេត្តាករុណា នៅពេលយើងប្រែចិត្ត ហើយទ្រង់នឹងការពារយើង នៅពេលយើងមករកទ្រង់ ។

មេរៀនបន្ទាប់ (អាលម៉ា ៤៥–៦៣)

ហេតុអ្វីបានជាសាសន៍នីហ្វៃបានជោគជ័យជាខ្លាំងលើសត្រូវរបស់ពួកគេ ? តើពួកគេអាចប្រយុទ្ធដោយកម្លាំងនៃព្រះអម្ចាស់ដោយរបៀបណា ? ចម្លើយអាចរកឃើញដោយការសិក្សាគំរូរបស់មេទ័ពម៉ូរ៉ូណៃ និងហេលេមិន និងអ្នកចម្បាំងជំក្លាហានរបស់គាត់ ។

អាលម៉ា ៤៥–៤៨

សេចក្តីផ្តើម

ក្រោយពីអាលម៉ាបានផ្តល់ការបង្រៀនចុងក្រោយដល់កូនប្រុសរបស់គាត់ ហេលេមិន គាត់បានចេញពីប្រជាជននីហ្វៃ ហើយមិនដែលបានឮពីគាត់ទៀតឡើយ ។ ហេលេមិនបានក្លាយជាទៅអ្នកដឹកនាំខាងវិញ្ញាណដ៏ចម្បង ហើយមេទ័ពម៉ូរ៉ូណៃក្លាយជាអ្នកដឹកនាំទាហានដ៏សំខាន់មួយអំឡុងពេលលំបាកមួយសម្រាប់ពួកសាសន៍នីហ្វៃ ។ អាម៉ាលេកៃ ជាអ្នកដឹកនាំក្រុមប្រឆាំងសាសន៍នីហ្វៃ បានជាក់គម្រោងដ៏មានកលល្បិចមួយដើម្បីទទួលបានអំណាចលើសាសន៍នីហ្វៃ ។ មេទ័ពម៉ូរ៉ូណៃបានជួយសាសន៍នីហ្វៃឲ្យពង្រឹងខ្លួនគេប្រឆាំងនឹងការវាយលុករបស់សត្រូវ ដើម្បីពួកគេអាចបន្តមានសេរីភាព និងសិទ្ធិនៃការថ្វាយបង្គំរបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៤៥

ហេលេមិនជឿលើពាក្យសម្តីរបស់អាលម៉ា ហើយចាប់ផ្តើមការបម្រើរបស់គាត់

សូមឲ្យសិស្សគិតអំពីការសម្ភាសន៍មួយដែលពួកគេបានធ្វើជាមួយនឹងឪពុកម្តាយ ឬអ្នកដឹកនាំបព្វជិតភាពម្នាក់ ។

- **តើសំណួរបែបណាដែលឪពុកម្តាយ និងអ្នកដឹកនាំបព្វជិតភាពនឹងសួរនៅក្នុងការសម្ភាសន៍ជាទូទៅ ?**

ក្រោយពីការពិភាក្សាដ៏ខ្លីមួយ សូមពន្យល់ថា មុនពេលអាលម៉ាបានឲ្យកូនប្រុសរបស់គាត់ ហេលេមិន ទទួលបន្ទុកលើកំណត់ត្រាដ៏ពិសិដ្ឋទាំងឡាយ ហើយចាកចេញពីដែនដី (សូមមើល អាលម៉ា ៤៥:១៨–១៩) គាត់បានសួរហេលេមិនន្ទវសំណួរទាំងនេះ: ។ សូមឲ្យសិស្សអាន អាលម៉ា ៤៥:២–៨ ដោយស្ងាត់ៗ ដោយរកមើលសំណួរដែលអាលម៉ាបានសួរ និងចម្លើយដែលហេលេមិនបានផ្តល់ ។

- **ពួកសាសន៍នីហ្វៃបានធ្វើសង្គ្រាមនឹងពួកសាសន៍លេមិន នៅពេលអាលម៉ានិងហេលេមិនបានធ្វើការសន្ទនានេះ: ។ តើអ្នកគិតថាសេចក្តីជំនឿរបស់ហេលេមិនអាចជួយគាត់ អំឡុងពេលសង្គ្រាម និងពេលគាត់បម្រើដោយរបៀបណា ?**
- **តើនៅពេលណាដែលអ្នកទទួលបានកម្លាំងពីសេចក្តីជំនឿរបស់អ្នកលើព្រះយេស៊ូវគ្រីស្ទ និងពាក្យសម្តីរបស់ព្យាការី និងពីការប្តេជ្ញាចិត្តរបស់អ្នកក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយ ?**

សូមសង្ខេប អាលម៉ា ៤៥:៩–១៩ ដោយការប្រាប់សិស្សថា ក្រោយពីអាលម៉ាបានព្យាករណ៍អំពីការបំផ្លាញនៅទីបញ្ចប់នៃជាតិសាសន៍នីហ្វៃហើយ គាត់បានចាកចេញពីដែនដី ហើយមិនដែលបានឮពីគាត់ទៀតឡើយ ។ មុនពេលគាត់បានចាកចេញ គាត់បានព្យាករណ៍លើកចុងក្រោយ ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៤៥:១៦ ឮៗ ។

- **តើសេចក្តីពិតណាដែលយើងអាចរៀនពីការព្យាករណ៍នេះ: ? (សិស្សអាចឆ្លើយគោលការណ៍បឋម ប៉ុន្តែសូមប្រាកដថា ពួកគេបង្ហាញការយល់ថា ព្រះអម្ចាស់ទ្រង់មិនអាចទតមើលអំពើបាប សូម្បីតែបន្តិចបន្តួចក៏មិនបានឡើយ) ។**

សូមពន្យល់ថា ហេលេមិនបានចាប់ផ្តើមបម្រើដោយការតែងតាំងពួកសង្ឃ និងគ្រូបង្រៀនក្នុងសាសនាចក្រទូទាំងដែនដី ។ សូមឲ្យសិស្សសិក្សា អាលម៉ា ៤៥:២៣–២៤ ដោយរកមើលរបៀបដែលប្រជាជនបានប្រតិកម្មនឹងអ្នកដឹកនាំសាសនាចក្រទាំងឡាយ ។

- **តើប្រជាជនបានឆ្លើយតបនឹងអ្នកដឹកនាំសាសនាចក្រទាំងឡាយដោយរបៀបណា ? ហេតុអ្វីបានជាប្រជាជនខ្លះបដិសេធមិនព្រមស្តាប់តាមអ្នកដឹកនាំសាសនាចក្រទាំងឡាយ ?**

អាលម៉ា ៤៦

មេទ័ពម៉ូរ៉ូណៃប្រជុំជាមួយនឹងពួកសុចរិតដើម្បីការពារសិទ្ធិរបស់ពួកគេ និងសាសនារបស់ពួកគេ

សូមសង្ខេប អាលម៉ា ៤៦:១–៣ដោយការពន្យល់ថា អស់អ្នកទាំងឡាយដែលមិនគោរពតាមអ្នកដឹកនាំសាសនាចក្រទាំងឡាយត្រូវបានដឹកនាំដោយបុរសម្នាក់ឈ្មោះថា អាម៉ាលិកាយ ។ សូមឲ្យសិស្សអាន អាលម៉ា ៤៦:៤–៥ ដោយស្ងាត់ៗ ដោយរកមើលអ្វីដែលអាម៉ាលិកាយ និងអ្នកដើរតាមគាត់ចង់បាន ។ សូមឲ្យសិស្សពន្យល់ពីអ្វីដែលពួកគេរកឃើញ ។

សូមឲ្យសិស្សអាន អាលម៉ា ៤៦:៦–៧ ដោយស្ងាត់ៗ ដោយរកមើលលទ្ធផលនៃឥទ្ធិពលរបស់អាម៉ាលិកាយទៅលើអ្នកដែលដើរតាមគាត់ ។

- **តើមានអ្វីកើតឡើងជាលទ្ធផលនៃឥទ្ធិពលរបស់អាម៉ាលិកាយ ?**

សូមឲ្យសិស្សអាន អាលម៉ា ៤៦:៨–១០ ដោយស្ងាត់ៗ ដោយរកមើលមេរៀនដែលមរមនចង់ឲ្យយើងរៀនពីសកម្មភាពរបស់អាម៉ាលិកាយ ។ អ្នកអាចបង្ហាញថា មេរៀនបីបួនទាំងនេះត្រូវបានបង្ហាញដោយពាក្យ « ហេតុដូច្នេះហើយយើងឃើញថា» ឬ « យើងឃើញថា » ។ (អ្នកអាចស្នើថា សិស្សគួរគូសចំណាំមេរៀនទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។ សិស្សអាចរកឃើញមេរៀនខាងក្រោម ៖

មនុស្សជាច្រើនងាយនឹងភ្លេចព្រះអម្ចាស់ ហើយប្រព្រឹត្តអំពើទុច្ចរិតណាស់ ។

មនុស្សទុច្ចរិតម្នាក់អាចនាំឲ្យមានអំពើទុច្ចរិតជាច្រើន ។

ដើម្បីបង្ហាញសអាម៉ាលិកាយនឹងមេទ័ពម៉ូរៃណៃ សូមឲ្យសិស្សអាន អាលម៉ា ៤៦:១១–១៨ និង អាលម៉ា ៤៨:១១–១៣, ១៧ ដោយស្ងាត់ៗ ។ សូមឲ្យសិស្សពាក់កណ្តាលថ្នាក់រិក្សាអ្វីដែលម៉ូរៃណៃចង់បាន ។ សូមឲ្យសិស្សពាក់កណ្តាលថ្នាក់ទៀតរកមើលពាក្យ និងឃ្លាដែលពិពណ៌នាអ្វីដែលម៉ូរៃណៃដូច ។ (សូមជួយសិស្សឲ្យឃើញភាពខុសគ្នារវាងការជម្រុញដ៏សុចរិតរបស់ម៉ូរៃណៃ និងការជម្រុញដ៏ទុច្ចរិតរបស់អាម៉ាលិកាយ ។ ម៉ូរៃណៃបានគាំទ្របុព្វហេតុនៃសេរីភាព និងសុចរិតភាព ខណៈពេលដែលអាម៉ាលិកាយឃ្លានចង់បានអំណាច និងចង់នាំប្រជាជននីហ្វៃឲ្យធ្លាក់ទៅក្នុងសេវកភាព) ។

- ដោយផ្អែកលើអ្វីដែលអ្នកបានអាន តើអ្នកនឹងរៀបរាប់មេទ័ពម៉ូរៃណៃយ៉ាងណា ? តើគោលការណ៍អ្វីដែលយើងអាចរៀនពីខគម្ពីរទាំងនេះ ? (សិស្សអាចឆ្លើយគោលការណ៍ខុសៗគ្នាជាច្រើន រួមមានសេចក្តីពិតថា **បុរសសុចរិតម្នាក់អាចនាំមកនូវសេចក្តីសុចរិតជាច្រើន ។**)
- យោងតាម អាលម៉ា ៤៦:១១–១៨ តើម៉ូរៃណៃបានអធិស្ឋានសុំអ្វី ? (សុំពរជ័យនៃសេរីភាព និងសិទ្ធិសេរីឲ្យបន្តនៅជាមួយនឹងសាសន៍នីហ្វៃ និងសុំឲ្យ « ឧត្តមគតិនៃពួក » ដើម្បីឲ្យព្រះសព្វព្រះទ័យ) ។

ម៉ូរៃណៃបានអធិស្ឋានអំពី « ឧត្តមគតិនៃពួកគ្រីស្ទាន » ។ យោងតាម អាលម៉ា ៤៦:១២ តើគោលការណ៍ចុងក្រោយដែលម៉ូរៃណៃមានអារម្មណ៍ថាពួកគ្រីស្ទានគួរការពារ និងគាំទ្រមានអ្វីខ្លះ ? (សូមជួយសិស្សឲ្យឃើញថា **វាគឺជាភាពពូកចិច្ចរបស់យើងដើម្បីការពារគ្រួសារយើង សាសនាយើង និងសេរីភាពរបស់យើង ។**សូមមើលជង្គង់ដៃរអាលម៉ា ៤៣:៤៥–៤៨) ។

- តើឧបសគ្គអ្វីខ្លះដែលគ្រួសារ ពួកគ្រីស្ទាន និងសេរីភាពនាសព្វថ្ងៃជួប ? តើរបៀបត្រឹមត្រូវណាខ្លះដែលយើងអាចការពារដល់គ្រួសារយើង សាសនាយើង និងសេរីភាពរបស់យើង ?

សូមឲ្យសិស្សអាន អាលម៉ា ៤៦:១៨–២២ ដោយស្ងាត់ៗ ដោយរកមើលអ្វីដែលម៉ូរៃណៃបានសុំឲ្យប្រជាជនធ្វើ ។ (អ្នកអាចស្នើថា សិស្សគួរគូសចំណាំ៣ពាក្យ *សេចក្តីសញ្ញា* នៅក្នុងខគម្ពីរទាំងនេះ) ។

- តើប្រជាជនសេចក្តីសញ្ញាបានធ្វើអ្វី ? (បន្តរក្សាសិទ្ធិរបស់ពួកគេ និងសាសនារបស់ពួកគេ ; មិនលះបង់ចោលព្រះអម្ចាស់ ; មិនរំលងព្រះបញ្ញត្តិទាំងឡាយនៃព្រះ ; ហើយមិនខ្មាសអៀននឹងលើកដាក់មកលើខ្លួនគេនូវព្រះនាមនៃព្រះគ្រីស្ទ) ។
- យោងតាម អាលម៉ា ៤៦:២២ តើប្រជាជនបានធ្វើអ្វីជាសញ្ញានៃសេចក្តីសញ្ញាដែលពួកគេបានធ្វើ ? (ពួកគេបានហែកអាវរបស់គេ ហើយបានបោះអាវរបស់ពួកគេទៅក្បែរជើងរបស់ម៉ូរៃណៃ) ។

សូមលើកក្រណាត់មួយផ្ទាំងឡើង ហើយហែកវាជាពីរ ។ អ្នកអាចពន្យល់ថា ដោយការហែកអាវរបស់ពួកគេ ប្រជាជនកំពុងបង្ហាញពីការប្តេជ្ញារបស់គេដើម្បីរក្សាសេចក្តីសញ្ញាដែលពួកគេបានធ្វើ ។

- យោងតាម អាលម៉ា ៤៦:២១–២២ តើប្រជាជនបាននិយាយអ្វីខ្លះដែលគួរកើតឡើង ប្រសិនបើពួកគេរំលងសេចក្តីសញ្ញារបស់គេ ?
- តើការណ៍នេះជួយអ្នកឲ្យយល់ពីលក្ខណៈម៉ឺងម៉ាត់នៃសេចក្តីសញ្ញាដែលយើងធ្វើជាមួយនឹងព្រះដោយរបៀបណា ?

សូមរំឭកសិស្សថា ម៉ូរៃណៃនិងប្រជាជនរបស់គាត់បានប្រឈមមុខនឹងសត្រូវដែលចង់បំផ្លាញពួកគេ ។

- យោងតាម អាលម៉ា ៤៦:១៨ តើម៉ូរៃណៃបាននិយាយអ្វីខ្លះ ដែលអាចនាំប្រជាជនរបស់គាត់ឲ្យជួបនឹងការបំផ្លាញ ?

សូមសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ៖ *ប្រសិនបើយើងរក្សាសេចក្តីសញ្ញារបស់យើង ព្រះនឹង . . .*

សូមឲ្យសិស្សចែកចាយរបៀបដែលពួកគេអាចបំពេញប្រយោគនេះដោយផ្អែកលើអ្វីដែលពួកគេបានរៀនពី អាលម៉ា ៤៦:១៨–២២ ។ សូមឲ្យពួកគេជ្រើសរើសមួយនៃរបៀបដែលពួកគីដឹងថា ប្រយោគនេះគឺពិត ។ ចម្លើយអាចខុសៗគ្នា ។ សូមសង្កេបចម្លើយដោយការបំពេញឃ្លានៅលើក្តារខៀនដូចខាងក្រោម ៖ ***ប្រសិនបើយើងរក្សាសេចក្តីសញ្ញារបស់យើង ព្រះនឹងប្រទានពរដល់យើង ។***សូមណែនាំឲ្យសិស្សរកមើលភស្តុតាងដែលគាំទ្រដល់គោលការណ៍នេះ នៅពេលពួកគេសិក្សាជំពូកបន្តទៀតនៅក្នុងអាលម៉ា ។ អ្នកអាចប្រាប់អំពីពេលមួយនៅពេលព្រះអម្ចាស់ប្រទានពរដល់អ្នកដោយសារការគោរពតាមសេចក្តីសញ្ញារបស់អ្នក ។

សូមសង្កេបអាលម៉ា ៤៦:២៩–៤១ ។ សូមពន្យល់ថា អាម៉ាលិកាយ និងអ្នកដើរតាមវាបានយល់ថា ពួកគេមានចំនួនច្រើន ដូច្នេះពួកគេបានទៅដែនដីនីហ្វៃ ដោយចង់ចូលរួមនឹងសាសន៍លេមិន ។ កងទ័ពរបស់ម៉ូរៃណៃបានបញ្ឈប់ក្រុមរបស់អាម៉ាលិកាយភាគច្រើនពីការទៅដល់ដែនដីនីហ្វៃ ។ អ្នកដើរតាមអាម៉ាលិកាយជាច្រើនបានចូលទៅក្នុងសេចក្តីសញ្ញាមួយដើម្បីគាំទ្រសេរីភាព ។ ពួកគេភាគតិចដែលមិនចូលទៅក្នុងសេចក្តីសញ្ញាត្រូវបានប្រហារជីវិត ។ អាម៉ាលិកាយ និងអ្នកដើរតាមវាមួយចំនួនតូចបានរត់ចេញ ហើយចូលរួមនឹងសាសន៍លេមិន ។

អាលម៉ា ៤៧

ដោយការក្បត់ អាម៉ាលិកាយបានក្លាយជាស្តេចនៃសាសន៍លេមិន

សូមសួរពីរបៀបដែលពួកគេមានអារម្មណ៍ ប្រសិនបើពួកគេនៅក្នុងការលេងប្រកួតប្រជែងមួយ ឬការប្រកួតមួយ ហើយទទួលបានសៀវភៅជាកម្មសិទ្ធិរបស់ពួកគេដែលមានបញ្ជីនៃអ្វីដែលដៃគូប្រកួតរបស់គេមានបំណងចង់ធ្វើដើម្បីយកឈ្នះលើការប្រកួតនោះ ។ សូមប្រាប់សិស្សថា ដោយការប្រៀបធៀប អាលម៉ា ៤៧ ទៅនឹងខ្លួនយើង យើងអាចរៀនពីមេរៀនដ៏សំខាន់ខ្លះអំពីយុទ្ធវិធីរបស់សាតាំងក្នុងការព្យាយាមយកឈ្នះលើយើង ។

សូមសង្កេប អាលម៉ា ៤៧:១–៦ ដោយការប្រាប់សិស្សថា អាម៉ាលិកាយមិនបានលះបង់គោលដៅរបស់វាក្នុងការចង់បានអំណាចលើសាសន៍នីហ្វៃទេ។ វារៀបចំគម្រោងការដ៏មានកលល្បិចមួយដើម្បីទម្លាក់ស្តេចនៃសាសន៍លេមិន ហើយក្លាយជាស្តេចដើម្បីវាអាចដឹកនាំសាសន៍លេមិនឲ្យទៅច្បាំងនឹងសាសន៍នីហ្វៃនៅទីបញ្ចប់ ។ នៅពេលអាម៉ាលិកាយបានចូលរួមនឹងសាសន៍លេមិន វាបានបំពេញចិត្តរបស់ស្តេច ដែលបានតែងតាំងឲ្យគ្រប់គ្រងលើចំណែកមួយនៃកងទ័ពសាសន៍លេមិន ។ ស្តេចបានបញ្ជាឲ្យអាម៉ាលិកាយ និង

កងទ័ពរបស់វាដេញតាមផ្នែកនៃកងទ័ពដែលមិនគោរពតាមសាសន៍លេមិនខ្លះ ដែលបានដឹកនាំដោយបុរសម្នាក់ឈ្មោះ លីហុនតៃ ។ អាម៉ាលិកាយត្រូវបានបញ្ជាឲ្យបង្ខំកងទ័ពរបស់លីហុនតៃទៅប្រយុទ្ធនឹងសាសន៍នីហ្វៃ ប៉ុន្តែអាម៉ាលិកាយបានមានគម្រោងការផ្សេង ។

សូមឲ្យសិស្សសិក្សា អាលម៉ា ៤៧:៧–១៩ ហាក់ដូចជាពួកគេគឺជាលីហុនតៃ ហើយអាម៉ាលិកាយហាក់ដូចជាសាតាំង ។ សូមឲ្យពួកគេអាន អាលម៉ា ៤៧:៧–១០ ដោយស្ងាត់ៗ ដោយរកមើលកន្លែងដែលលីហុនតៃបានទៅដើម្បីការពារកងទ័ពរបស់គាត់ ហើយអ្វីដែលអាម៉ាលិកាយបានព្យាយាមធ្វើដើម្បីចាប់លីហុនតៃ ។

- តើលីហុនតៃបានរួមគ្នានឹងកងទ័ពរបស់គាត់រៀបចំច្បាំងនៅកន្លែងណា ? តើកងទ័ពមួយមានប្រយោជន៍អ្វី ប្រសិនបើគេស្ថិតនៅលើទីទួលខ្ពស់ជាងសត្រូវរបស់វានោះ ?
- តើអាម៉ាលិកាយចង់ឲ្យលីហុនតៃធ្វើអ្វី ? តើយុទ្ធវិធីអ្វីខ្លះដែលសាតាំងប្រើដើម្បីចាប់យើងឲ្យចុះមកពីទីទួលខ្ពស់នោះ ? (ចម្លើយអាចមានការទាក់ទាញយើងឲ្យបន្ទាបបទដ្ឋានរបស់យើង ហើយទាក់ទាញយើងឲ្យទៅកន្លែងដែលយើងមិនមានសុវត្ថិភាពខាងវិញ្ញាណ) ។

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៤៧:១១–១៩ ។ សូមឲ្យសិស្សមើលតាម ដោយគិតពីយុទ្ធវិធីរបស់អាម៉ាលិកាយអាចដូចទៅនឹងយុទ្ធវិធីរបស់សាតាំងប្រើដើម្បីបំផ្លាញយើង ។

- តើយុទ្ធវិធីរបស់អាម៉ាលិកាយស្រដៀងទៅនឹងយុទ្ធវិធីរបស់សាតាំងប្រើដើម្បីបំផ្លាញយើងតាមរបៀបណា ? (ចម្លើយអាចរួមមានថាសាតាំងគឺរឹងទទឹង បោកបញ្ឆោត ពុតត្បុត និងព្រៃផ្សៃ) ។
- តើគំរូណាខ្លះប្រាប់ពីរបៀបដែលសាតាំងចង់បំពុលយើង « ដោយបន្តិចបន្តួច » ?

សូមសង្ខេប អាលម៉ា ៤៧:២០–៣៦ ដោយការពន្យល់ថា អាម៉ាលិកាយបានបន្តបញ្ឆោត និងសម្លាប់រហូតដល់វាបានក្លាយជាស្តេចនៃសាសន៍លេមិន ។ សូមបញ្ជាក់ថា បំណងនិងយុទ្ធវិធីរបស់អាម៉ាលិកាយគឺដូចខ្លាំងនឹងបំណងនិងយុទ្ធវិធីរបស់សាតាំងចំពោះយើងណាស់ ។ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***សាតាំងចង់បំផ្លាញយើង ហើយវាល្បួងយើងដោយបន្តិចបន្តួច ៗដើម្បីបន្ទាបបទដ្ឋានរបស់យើង ។***

អាលម៉ា ៤៨

មេទ័ពម៉ូរ៉ូណៃបំផុសគំនិតដល់សាសន៍នីហ្វៃឲ្យរៀបចំខ្លួន និងមានចិត្តស្មោះត្រង់

សូមឲ្យសិស្សអាន អាលម៉ា ៤៨:៧–១០ ដោយស្ងាត់ៗ ដោយរកមើលអ្វីដែលម៉ូរ៉ូណៃកំពុងធ្វើ ខណៈពេលដែលអាម៉ាលិកាយកំពុងចង់បានអំណាចក្នុងចំណោមសាសន៍លេមិន ។

- តើម៉ូរ៉ូណៃបានធ្វើអ្វី ណៈពេលដែលអាម៉ាលិកាយកំពុងចង់បានអំណាចក្នុងចំណោមសាសន៍លេមិននោះ ?
- តើម៉ូរ៉ូណៃបានធ្វើអ្វីដើម្បីពង្រឹងប្រជាជនរបស់គាត់ និងទីក្រុងទាំងឡាយរបស់ពួកគេប្រឆាំងនឹងការវាយលុកលើកក្រោយ ? តើទីតាំងជាក់លាក់ណាខ្លះដែលម៉ូរ៉ូណៃយកចិត្តទុកដាក់លើជាពិសេស ?

សូមឲ្យសិស្សមានពេលសញ្ជឹងគិតពីចំណុចខ្សោយនៅក្នុងជីវិតរបស់ពួកគេ ហើយតើពួកគេអាចធ្វើអ្វីដើម្បីពង្រឹងចំណុចទាំងនោះ ។ សូមឲ្យពួកគេសរសេរពីគំនិតរបស់គេ ។

- យោងតាម អាលម៉ា ៤៨:១០ តើហេតុអ្វីបានជាម៉ូរ៉ូណៃខិតខំយ៉ាងខ្លាំងដើម្បីពង្រឹងប្រជាជនរបស់គាត់ដើម្បីត្រៀមប្រឆាំងនឹងការវាយលុករបស់សត្រូវ ? (សូមបញ្ជាក់ថា ម៉ូរ៉ូណៃចង់ជួយរក្សាសេរីភាពរបស់សាសន៍នីហ្វៃដើម្បីអនុវត្តសាសនារបស់ពួកគេ) ។
- តើគំរូណាខ្លះនៃអ្វីៗដែលអ្នកដឹកនាំសាសនាចក្រនាសម័យទំនើបបង្រៀនដើម្បីជួយយើងឲ្យពង្រឹងចំណុចខ្សោយខាងវិញ្ញាណរបស់យើង ?
- ហេតុអ្វីបានជាអ្នកដឹកនាំសាសនាចក្រខិតខំយ៉ាងខ្លាំងដើម្បីពង្រឹងយើងខាងវិញ្ញាណ ?

សូមធានាសិស្សថា **នៅពេលយើងធ្វើតាមការណែនាំរបស់អ្នកបម្រើរបស់ព្រះអម្ចាស់ យើងនឹងត្រូវបានពង្រឹងទាស់នឹងការល្បួង ។**

សូមលើកទឹកចិត្តសិស្សឲ្យមើលដោយប្រយ័ត្នប្រយែងនៅក្នុងជំពូកបន្ទាប់នៃអាលម៉ា ដើម្បីរកមើលគោលការណ៍អំពីតម្លៃនៃការកាន់តាមសេចក្តីសញ្ញា និងសារសំខាន់នៃការពង្រឹងខ្លួនយើងប្រឆាំងនឹងសាតាំង ។

អាលម៉ា ៤៩–៥១

សេចក្តីផ្តើម

ការរៀបចំការពារបស់មរ៉ូណៃសំខាន់ក្នុងការការពារសាសន៍នីហ្វៃប្រឆាំងនឹងសត្រូវរបស់ពួកគេ ។ សាសន៍នីហ្វៃបានជោគជ័យក្នុងការការពារខ្លួនគេប្រឆាំងនឹងសាសន៍លេមិន រហូតដល់ការបះបោរ និងសេចក្តីទុច្ចរិតក្នុងចំណោមប្រជាជនខ្លួនគេបានចាប់ផ្តើមធ្វើឲ្យពួកគេទន់ខ្សោយ ។ ម៉ូរីអានតុន និងពួកបែកចេញរបស់វាព្យាយាមចង់បំបែកបំបាក់ និងបង្កការទាស់ទែងនៅក្នុងចំណោមប្រជាជន ។ មរ៉ូណៃបានព្យាយាមបំបាត់ការបែកបាក់ និងការទាស់ទែង ហើយស្ថាបនាសន្តិភាព ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៤៩; ៥០:១–២៤

សាសន៍នីហ្វៃកសាងការពង្រឹង រីកចម្រើន ហើយរក្សាបាននូវសេរីភាពរបស់ពួកគេ

សូមអានរឿងខាងក្រោមដល់សិស្សក្នុងថ្នាក់ ហើយសូមសួរសំណួរដែលអមមក (ឬ បង្កើតរឿងខ្លួនអ្នក ហើយបង្កើតសំណួរ) ៖

យុវជនម្នាក់មានអារម្មណ៍ហត់នឿយ ប៉ុន្តែមិនចង់ចូលទៅគេងនោះទេ ដូច្នេះគាត់បានចាប់ផ្តើមបើកអ៊ិនធើណិត ។ គាត់ឃើញខ្លួនគាត់ចង់ទៅមើលទំព័រ ដែលមានរូបអាសអាភាសជាច្រើន ។

- តើការរៀបចំអ្វីខ្លះដែលយុវជននេះអាចបានធ្វើដើម្បីចៀសវាងការល្បួងនេះ ?
- តើគាត់អាចធ្វើអ្វីដើម្បីចៀសវាងការល្បួងនៅក្នុងថ្ងៃអនាគត ?

សូមពន្យល់ដល់សិស្សថា នៅពេលពួកគេសិក្សា អាលម៉ា ៤៩–៥១ ពួកគេអាចរកមើលពីរបៀបដែលការរៀបចំរបស់មេទ័ពម៉ូរ៉ូណៃបានធ្វើប្រឆាំងនឹងសាសន៍លេមិនអាចត្រូវប្រៀបធៀបទៅនឹងការរៀបចំដែលយើងគួរធ្វើប្រឆាំងនឹងការល្បួងរបស់សាតាំងសព្វថ្ងៃនេះ ។

សូមពន្យល់ថា ខណៈពេលដែលអាម៉ាលិកាយកំពុងបង្កឲ្យកងទ័ពរបស់សាសន៍លេមិនមួយទៅច្បាំង មេទ័ពម៉ូរ៉ូណៃកំពុងពង្រឹងដល់ទីក្រុងទាំងឡាយនៃសាសន៍នីហ្វៃ ។ សូមឲ្យសិស្សអាន អាលម៉ា ៤៩:១, ៦–៧ ដោយស្ងាត់ៗ ។ សូមឲ្យពួកគេគិតពីរបៀបដែលការរៀបចំរបស់មេទ័ពម៉ូរ៉ូណៃដើម្បីប្រឈមមុខនឹងសាសន៍លេមិន អាចដូចជាតម្រូវការរបស់យើងដើម្បីរៀបចំសម្រាប់ការវាយប្រហាររបស់សាតាំងលើយើង ។ សូមឲ្យសិស្សអាន អាលម៉ា ៤៩:២–៤; ៥០:១–៦ ដោយស្ងាត់ៗ ដោយរកមើលរបៀបដែលសាសន៍នីហ្វៃបានរៀបចំសម្រាប់ការវាយលុករបស់ពួកសាសន៍លេមិន ។

- ប្រសិនបើអ្នកជាកងទ័ពសាសន៍លេមិនម្នាក់ តើអ្នកអាចមានអារម្មណ៍យ៉ាងណា នៅពេលអ្នកបានឃើញការពង្រឹងទាំងនេះលើកដំបូង ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៤៩:៨–១២ ។ សូមឲ្យសិស្សមើលតាម ដោយរកមើលរបៀបដែលសាសន៍លេមិនឆ្លើយតបនឹងការរៀបចំរបស់សាសន៍នីហ្វៃ ។

- តើសាសន៍លេមិនបានធ្វើអ្វី នៅពេលពួកគេបានឃើញថា អាំម៉ូណៃហាត្រូវបានពង្រឹងនោះ ? (ពួកគេបានដកថយ) ។

សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ដៃមស៍ អឹ ហ្វោស្ត នៃគណៈប្រធានទីមួយ ៖

« សាតាំងគឺជាសត្រូវដ៏ចំពប់ផុសរបស់យើង ហើយវាធ្វើការទាំងយប់ទាំងថ្ងៃដើម្បីបំផ្លាញយើង ។ ប៉ុន្តែយើងមិនត្រូវភ័យខ្លាចនឹងអំណាចរបស់សាតាំងឡើយ ។ វាមិនអាចមានអំណាចលើយើង រហូតដល់យើងអនុញ្ញាតឲ្យវាមានអំណាច ។ វាគឺពិតជាកំសាកណាស់ ហើយប្រសិនបើយើងឈរដោយរឹងមាំ វានឹងដកថយ » (« Be Not Afraid » *Ensign*, ខែ តុលា ឆ្នាំ ២០០២, ទំព័រ ៤) ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៤៩:១៨–២០, ២៣ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយគិតពីរបៀបដែលយើងអាចប្រើការរៀបចំសម្រាប់សង្គ្រាមរបស់សាសន៍នីហ្វៃជាគំរូមួយដើម្បីជួយយើងឲ្យរៀបចំសង្គ្រាមខាងវិញ្ញាណប្រឆាំងនឹងសាតាំង ។

- មេទ័ពម៉ូរ៉ូណៃបានធ្វើការដើម្បីការពារសាសន៍នីហ្វៃពីពួកសាសន៍លេមិន ។ តើអ្នកដឹកនាំរបស់យើងធ្វើការដើម្បីការពារ និងថែរក្សាយើងពីឧបសគ្គដោយរបៀបណា ?
- តើយើងអាចធ្វើអ្វីខ្លះដើម្បីកសាងជញ្ជាំងខាងវិញ្ញាណឲ្យបានខ្ពស់ដើម្បីការពារការល្បួងរបស់សាតាំង ? (ចម្លើយអាចរួមមានការអធិស្ឋានដ៏មានអត្ថន័យប្រចាំថ្ងៃ ការសិក្សាព្រះគម្ពីរប្រចាំថ្ងៃ ការទៅព្រះវិហារជាទៀងទាត់ ការបម្រើដល់អ្នកដទៃ និងការតមអាហារ) ។

សូមគិតពីការឲ្យសិស្សឆ្លើយតបនឹងសំណួរខាងក្រោមនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ (អ្នកអាចសរសេរសំណួរទាំងនេះនៅលើក្តារខៀនមុនចាប់ផ្តើមបង្រៀន) ។

- តើអ្នកនឹងរៀបរាប់ការខិតខំប្រចាំថ្ងៃរបស់អ្នកដើម្បីពង្រឹងជញ្ជាំងការពារខាងវិញ្ញាណរបស់អ្នកដោយរបៀបណា ?

ការសម្របរឿង

អ្នកស្ថិតនៅក្នុងកន្លែងដ៏ល្អបំផុតមួយដែលយល់ពីវប្បធម៌ និងអត្តចរិតរបស់សិស្សនៅក្នុងថ្នាក់អ្នក ក៏ដូចជាការល្បួងដែលពួកគេជួប ។ សូមរើសរឿងដែលនឹងឲ្យសិស្សឆ្លុះបញ្ចាំងស្ថានភាពដែលស្រដៀងទៅនឹងស្ថានភាពរបស់គេផ្ទាល់ ។ ការណ៍នេះនឹងផ្តល់ឱកាសមួយដល់ព្រះវិញ្ញាណបំផុសគំនិតដល់សិស្សស្របតាមតម្រូវការរបស់គេ ។ នៅពេលអ្នកសុំការដឹកនាំរបស់ព្រះវរបិតាសួគ៌ ទ្រង់នឹងជួយអ្នកឲ្យសម្របរឿងនៅក្នុងសៀវភៅណែនាំនេះឲ្យសមនឹងជីវិតរបស់សិស្សអ្នកកាន់តែខ្លាំង ។

- សូមជ្រើសរើសរឿងមួយដែលអ្នកកំពុងធ្វើដើម្បីពង្រឹងខ្លួនអ្នកខាងវិញ្ញាណ ឬរឿងមួយដែលអ្នកមិនបានធ្វើ ។ តើអ្នកអាចធ្វើអ្វីខ្លះដើម្បីបង្កើនប្រសិទ្ធិភាពនៃសកម្មភាពនោះដើម្បីពង្រឹងខ្លួនអ្នកប្រឆាំងនឹងអំពើអាក្រក់ ?

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៤៩:២៨–៣០ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលនរណា ក្រៅពីម៉ូរំណៃ ដែលកំពុងបម្រើដើម្បីការពារដល់សាសន៍នីហ្វៃទាស់នឹងសាសន៍លេមិន ។ សូមបញ្ជាក់ថា ដោយការជួយសាសន៍នីហ្វៃឲ្យនៅបន្តសុចរិត ហេលេមិន និងបងប្អូនប្រុសរបស់គាត់បានជួយពួកនីហ្វៃឲ្យទទួលបានពរជ័យជាច្រើន និងការការពារពីព្រះអម្ចាស់ ។

សូមឲ្យសិស្សមានពេលសិក្សា អាលម៉ា ៥០:១០–១២ ។ បន្ទាប់មក សូមឲ្យពួកគេពិភាក្សាពីរឿងខាងក្រោមជាមួយនឹងមិត្តភក្តិម្នាក់ ។ (ប្រសិនបើអាច សូមរៀបចំជាក្រុដាសមុនចាប់ផ្តើមថ្នាក់ ។ ប្រសិនបើមិនអាចទេ សូមអានរឿងម្តងមួយៗ ដោយឲ្យសិស្សមានពេលគ្រប់គ្រាន់ដើម្បីពិភាក្សាពីរឿងនោះ ។

១. ម៉ូរំណៃ « បញ្ចប់ចំណងដ៏មាំទាំងឡាយនៃពួកសាសន៍លេមិន » ។ តើយុវនារីម្នាក់អាច « បញ្ចប់ » ស្ថានភាពការនិយាយដើមគេនៅពេលនាងជួបជុំគ្នានឹងមិត្តភក្តិនាងនាអាហារថ្ងៃត្រង់ដោយរបៀបណា ?

២. ម៉ូរំណៃពង្រឹងខ្សែ ឬព្រំដែនរវាងសាសន៍នីហ្វៃ និងសាសន៍លេមិន ។ តើយុវជនម្នាក់ និងយុវនារីម្នាក់អាចពង្រឹងខ្សែរវាងការកាន់តាមច្បាប់ព្រហ្មចារីយភាព និងការរំលងចូលទៅភាពអសីលធម៌ដោយរបៀបណា ?

៣. កងទ័ពរបស់ម៉ូរំណៃបានកសាងភាពរឹងមាំដើម្បីធានាសន្តិសុខប្រជាជនរបស់គាត់ប្រឆាំងនឹងសត្រូវគេ ។ យុវជនម្នាក់ទទួលស្គាល់ថាគាត់បានចំណាយពេលច្រើនហួសលើការប្រើព័ត៌មានសង្គម (តាមអ៊ិនធើណិត ឬតាមរយៈការផ្ញើរតាមទូរសព្ទ) ។ អាកប្បកិរិយានេះមើលទៅហាក់ដូចជាកាត់បន្ថយការបារម្ភរបស់គាត់ចំពោះគ្រួសារគាត់ ហើយគាត់ធ្វេសប្រហែសលើទំនួលខុសត្រូវក្នុងផ្ទះរបស់គាត់ ។ តើគាត់អាចធ្វើអ្វីដើម្បីពង្រឹង និងធានាដល់ទំនាក់ទំនងរបស់គាត់ជាមួយនឹងគ្រួសាររបស់គាត់ ?

សូមឲ្យសិស្សពីរបីនាក់សង្ខេបអ្វីដែលពួកគេបានរៀនពីសកម្មភាពរបស់មេទ័ពម៉ូរំណៃ អំពីរបៀបដែលយើងអាចការពារខ្លួនយើងប្រឆាំងនឹងការវាយប្រហារនៃឧបសគ្គ ។ សូមធានាថាសិស្សយល់ថា **ប្រសិនបើយើងរៀបចំខ្លួនយើង យើងអាចប្រឈមមុខនឹងការវាយប្រហារ (ការល្បួង) ពីឧបសគ្គទាំងឡាយ ។**អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៥០:១ ឮៗ ។ សូមសួរសិស្ស ៖

- ដោយទទួលបានជោគជ័យក្នុងការរៀបចំរបស់មេទ័ពម៉ូរំណៃ តើការយល់ដឹងបន្ថែមអ្វីខ្លះដែលយើងអាចរៀនពីខគម្ពីរនេះ ? (ម៉ូរំណៃ « មិនបានឈប់ » រៀបចំឡើយ គាត់បានបន្តពង្រឹងការការពាររបស់គាត់ ទោះបីជានៅពេលមិនមានការគម្រាមភ្លាមៗក្តី ។)

ដើម្បីជួយសិស្សឲ្យរៀនពីតម្រូវការដើម្បីបន្តពង្រឹងខាងវិញ្ញាណជាដរាប សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ៖

« នៅពេលកម្លាំងនៅជុំវិញយើងកើនឡើង មិនថាកម្លាំងខាងវិញ្ញាណដែលធ្លាប់មានប្រសិទ្ធិភាពនោះទេ វានឹងមិនគ្រប់គ្រានឡើយ ។ ហើយការីកចម្រើនខាងកម្លាំងវិញ្ញាណណាដែលយើងធ្លាប់គិតថាអាចកើតមានការីកចម្រើនដ៏អស្ចារ្យជាងនេះនឹងអាចកើតមានដល់យើង ។ ទាំងតម្រូវការកម្លាំងខាងវិញ្ញាណ និងឱកាសដើម្បីទទួលបានវា នឹងកើតឡើងក្នុងកម្រិតមួយដែលយើងមើលងាយគ្រោះថ្នាក់របស់យើង »
(« Always, »*Ensign,*ខែ តុលា ឆ្នាំ ១៩៩៩, ទំព័រ ៩) ។

សូមសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ៖

ខ្ញុំនឹងរៀបចំប្រឈមមុខនឹងការល្បួងដោយ . . .

ខ្ញុំនឹងឈរដោយរឹងមាំនៅពេល . . .

សូមឲ្យសិស្សបំពេញប្រយោគទាំងនេះនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។ ក្រោយពីសិស្សបញ្ចប់ការសរសេរហើយ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អែសរ៉ា ថាហ្វ ប៊ែនសឹន ។ (អ្នកអាចស្នើថា សិស្សគួរសរសេរប្រយោគនេះនៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ អាលម៉ា ៥០:១០–១២) ។

« ការរៀបចំនិងការពារ វាប្រសើរជាងការព្យាបាល និងប្រែចិត្ត » (*The Teachings of Ezra Taft Benson* | ឆ្នាំ ១៩៨៨ |, ទំព័រ ២៨៥) ។

- តើអ្នកគិតថា ហេតុអ្វីបានជាប្រយោគនេះត្រឹមត្រូវ ? តើនៅពេលណាដែលអ្នកឃើញគំរូនៃគោលការណ៍ក្នុងប្រយោគនេះត្រូវបានបង្រៀន ?

សូមពន្យល់ថា ការរៀបចំរបស់សាសន៍នីហ្វៃបានដឹកនាំឲ្យមានការីកចម្រើន និងសន្តិភាពដ៏អស្ចារ្យរយៈពេលពីរបីឆ្នាំ ។ សូមបង្ហាញថា ខណៈពេលដែលអាម៉ាលិកាយបានប្រមាទព្រះដោយសារវាចាញ់ សាសន៍នីហ្វៃ « បានថ្លែងអំណរគុណដល់ព្រះអម្ចាស់ជាព្រះរបស់គេ » (« អាលម៉ា ៤៩:២៨) ។

សូមឲ្យសិស្សស្រមៃថា ពួកគេមិនមិត្តម្នាក់ដែលរស់នៅក្នុងតំបន់ដែលមានសង្គ្រាមកើតឡើង ។ គាត់មានអារម្មណ៍ថា វាមិនអាចរកឃើញសន្តិភាព និងសុភមង្គលឡើយ ដោយសារតែចលាចលនៅជុំវិញខ្លួនគាត់ ។ សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖ *អាលម៉ា ៥០:១៨–២៣ ។*សូមឲ្យសិស្សអានវគ្គនេះ ហើយបង្កើតចម្លើយមួយដែលពួកគេអាចធ្វើដល់មិត្តរបស់

គេ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីដែលពួកគេនឹងនិយាយ ។ សេចក្តីពិតមួយដែលពួកគេអាចរួមបញ្ចូលនៅក្នុងចម្លើយរបស់គេគឺថា **ភាពស្មោះត្រង់ចំពោះព្រះនាំមកនូវសុភមង្គល ទោះបីជានៅក្នុងកណ្តាលចលាចលក្តី ។**(អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។ សូមជួយសិស្សឲ្យយល់ថា សេចក្តីពិតនេះអនុវត្តមិនត្រឹមតែក្នុងសង្គ្រាមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដល់ឧបសគ្គផ្ទាល់ខ្លួនដូចជាការធ្លាក់ចុះហិរញ្ញវត្ថុ ការបាត់បង់ការងារ ការស្លាប់នៃមនុស្សជាទីស្រឡាញ់ ទំនាក់ទំនងដ៏មានបញ្ហាជាមួយនឹងសមាជិកគ្រួសារ និងគ្រោះធម្មជាតិនានា ។

- យោងតាម អាលម៉ា ៥០:១៨–២៣ ហេតុអ្វីបានជាសាសន៍នីហ្វៃទទួលបានពេលមួយដ៏មានសុភមង្គល ?
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់ទ្រង់បានពង្រឹកព្រះចេស្តារបស់ទ្រង់ និងពរជ័យទាំងឡាយដល់អ្នកដោយសារការគោរពតាម និងការពង្រឹងខ្លួនអ្នកទាស់នឹងការល្បួង ?
- តើនៅពេលណាដែលព្រះអម្ចាស់បានប្រទានពរដល់អ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ឲ្យមានការរីកចម្រើន សេចក្តីសុខសាន្ត និងសុភមង្គលនៅក្នុងពេលដ៏លំបាក ? (ក្រោយពីសិស្សបានឆ្លើយហើយ សូមគិតពីការចែកចាយគំរូមួយពីជីវិតរបស់អ្នក) ។

អាលម៉ា ៥០:២៥–៤០; ៥១

ការការពាររបស់ពួកនីហ្វៃត្រូវបានធ្វើឲ្យទន់ខ្សោយ ហើយមរ៉ូណៃប្រឈមមុខនឹងការបះបោរក្នុងចំណោមប្រជាជនរបស់គាត់

(*កំណត់ចំណាំ ៖* ដោយសារប្រវែងនៃមេរៀនវែង អ្នកអាចសង្ខេបខ្លី ៗនូវចំណុចនៃមេរៀនផ្សេងទៀត ។ ប្រសិនបើអ្នកធ្វើដូច្នោះ សូមពន្យល់ថា អាលម៉ា ៥០:២៥–៤០ រួមមានដំណើររឿងនៃការបះបោររបស់ម៉ូរីអានតុន និងការស្លាប់ និងការណាត់ជួបនៃស្តេចពេហ្ម៉ានជាមេចៅក្រម ។ អាលម៉ា ៥១ប្រាប់អំពីក្រុមមួយដែលហៅថាពួកនិយមស្តេច ដែលព្យាយាមផ្លាស់ប្តូរច្បាប់ដើម្បីឲ្យស្តេចគ្រប់គ្រងលើសាសន៍នីហ្វៃ ។ ពួកគេបានបរាជ័យនៅក្នុងការប៉ុនប៉ងនោះ ។ ដោយការខឹងសម្បារនឹងបរាជ័យរបស់គេ ពួកនិយមស្តេចបានបដិសេធមិនប្រយុទ្ធ នៅពេលអាម៉ាលិកាយ និងពួកសាសន៍លេមិនបានមកធ្វើសង្គ្រាមនឹងពួកសាសន៍នីហ្វៃ ។ យោងតាមច្បាប់ មរ៉ូណៃត្រូវឲ្យពួកគេទៅប្រយុទ្ធ ឬត្រូវដាក់ទោស ។ កងទ័ពរបស់អាម៉ាលិកាយបានដាក់ទីក្រុងសាសន៍នីហ្វៃជាច្រើនក្នុងសេរីភាព និងបានសម្លាប់សាសន៍នីហ្វៃជាច្រើន ។ នៅពេលអាម៉ាលិកាយបានព្យាយាមដាក់ដែនដីបរិបូរណ៍ក្នុងសេរីភាព គាត់បានជួបនឹងទីអានតុម និងកងទ័ពរបស់គាត់ ។ ទីអានតុមបានសម្លាប់អាម៉ាលិកាយ ហើយបានរារាំងការរីកចម្រើននៃកងទ័ពសាសន៍លេមិន ។)

សូមសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ៖ *សាមគ្គីរស់ បែកបាក់សាមគ្គីស្លាប់ ។*

សូមឲ្យសិស្សអាន អាលម៉ា ៥០:២៥–២៦ ដោយស្ងាត់ៗ ដោយរកមើលពាក្យនៅក្នុងខគម្ពីរនីមួយៗដែលរៀបរាប់ពីមូលហេតុនៃការបែកបាក់ក្នុងចំណោមសាសន៍នីហ្វៃ ។

- តើអ្វីដែលបណ្តាលឲ្យមានការបែកបាក់ក្នុងចំណោមប្រជាជន ?

សូមសង្ខេប អាលម៉ា ៥០ ទាំងអស់ដោយការពន្យល់ថា ម៉ូរីអានតុន និងប្រជាជនរបស់គាត់បានព្យាយាមចាកចេញសាសន៍នីហ្វៃ ហើយគេចចេញទៅដែនដីភាគខាងជើង ។ មរ៉ូណៃបានខ្លាចថា ការបែកបាក់នេះនឹងនាំទៅរកការបាត់បង់សេរីភាពរបស់សាសន៍នីហ្វៃ ។ គាត់បានបញ្ជូនកងទ័ពមួយ ដែលដឹកនាំដោយបុរសម្នាក់ឈ្មោះ ទីអានតុម ទៅបញ្ឈប់ប្រជាជនរបស់ម៉ូរីអានតុនកុំឲ្យចាកចេញ ។ កងទ័ពរបស់ទីអានតុមបានរារាំងប្រជាជនរបស់ម៉ូរីអានតុនពីការទៅដល់គោលដៅរបស់គេ ហើយម៉ូរីអានតុនត្រូវបានសម្លាប់ ។ ប្រជាជនដែលនៅសេសសល់ « បានធ្វើសេចក្តីសញ្ញាថានឹងរក្សាសន្តិភាព » (អាលម៉ា ៥០:៣៦) ។ ភ្លាម ៗក្រោយពីការបះបោររបស់ម៉ូរីអានតុន ការបែកបាក់ខាងនយោបាយដ៏គ្រោះថ្នាក់មួយបានលេចឡើងក្នុងចំណោមប្រជាជនសាសន៍នីហ្វៃ ។ សាសន៍នីហ្វៃខ្លះចង់បណ្តេញពេហ្ម៉ានពីតំណែងចៅក្រម ហើយដាក់ស្តេចជំនួសគាត់ ។ ប្រជាជនផ្សេងទៀតចង់ឲ្យបន្តប្រព័ន្ធដឹកនាំគ្រប់គ្រងជាចៅក្រម ។

សូមឲ្យសិស្សសិក្សា អាលម៉ា ៥១:៥–៦ រកឈ្មោះនៃក្រុមប្រឆាំងពីរ (ពួកនិយមស្តេចនិងពួកសេរី) ។ សូមឲ្យសិស្សមានពេលរកនៅក្នុង អាលម៉ា ៥១:៨ នូវការជម្រុញរបស់ពួកនិយមស្តេច ។

សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***ការបែកបាក់ និងការទាស់ទែងគ្នាបំផ្លាញសន្តិភាពរបស់យើង ។***

- តើគោលការណ៍នេះត្រូវបានបង្ហាញនៅក្នុងដំណើររឿងនៃការបែកបាក់ និងការទាស់ទែងគ្នាដែលបានកត់ត្រានៅក្នុង អាលម៉ា ៥០និង៥១ ដោយរបៀបណា ?
- តើអ្នកអាចធ្វើអ្វីនៅក្នុងគ្រួសាររបស់អ្នក ក្នុងចំណោមមិត្តរបស់អ្នក ឬ នៅក្នុងសហគមន៍របស់អ្នកដើម្បីដោះស្រាយការទាស់ទែងគ្នា ?
- តើនៅពេលណាដែលអ្នកឃើញពរជ័យដែលមកពីការសាមគ្គីគ្នាពង្រឹងដល់គ្រួសារ ឬ ក្រុម ឬ ថ្នាក់ ?

សូមថ្លែងទីបន្ទាល់អំពីសេចក្តីពិតទាំងនោះដែលអ្នកមានអារម្មណ៍ថាត្រូវបញ្ជាក់ ។ សូមរំឭកសិស្សថា មេរៀនពីរបីបន្ទាប់ទៀតនឹងផ្តល់ឱកាសដល់ពួកគេឲ្យរកនូវគោលការណ៍នានា ហើយរៀនមេរៀនពីសង្គ្រាមរវាងសាសន៍នីហ្វៃ និងសាសន៍លេមិន ។

មេរៀនទី ១០៣

អាលម៉ា ៥២–៥៥

សេចក្តីផ្តើម

នៅពេលនេះក្នុងសង្ត្រាមជាមួយនឹងសាសន៍លេមិន ពួកសាសន៍នីហ្វៃបានបាត់បង់ទីក្រុងជាច្រើនដោយសារតែការទាស់ទែងគ្នារបស់ពួកគេ ។ មរ៉ូណៃ ទីអានគុម និងលីហៃបានវាយលុកទីក្រុងមូលេក ហើយបង្ត្រាបកងទ័ពដ៏ធំបំផុតមួយរបស់សាសន៍លេមិន ។ មរ៉ូណៃ បដិសេធសំណើររបស់អាំម៉ូរ៉ុន ជាអ្នកដឹកនាំសាសន៍លេមិន ឲ្យផ្លាស់ប្តូរអ្នកទោស ហើយអនុវត្តគម្រោងមួយដើម្បីរំដោះអ្នកទោសសាសន៍នីហ្វៃដោយគ្មានការបង្ហូរឈាម ។ មរ៉ូណៃ បានឈររឹងមាំ ហើយមិនបានចុះចាញ់នឹងអំពើទុច្ចរិតរបស់អាំម៉ូរុន និងអ្នកដើរតាមរបស់វាឡើយ ។

កំណត់ចំណាំ ៖ មេរៀននេះផ្តោតលើហេតុការណ៍នៅក្នុងជីវិតរបស់មរ៉ូណៃ ទីអានគុម និងលីហៃ ។ នៅក្នុងមេរៀនបន្ទាប់ សិស្សនឹងរៀនបន្ថែមអំពីកងទ័ពដ៏ក្លាហានរបស់ហេលេមិន ២០០០ នាក់ដែលបានលើកឡើងនៅក្នុង អាលម៉ា ៥៣:១៦–២៣ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៥២–៥៣

មរ៉ូណៃ ទីអានគុម និងលីហៃធ្វើការរួមគ្នាដើម្បីយកឈ្នះលើសាសន៍លេមិន

មុនចាប់ផ្តើមថ្នាក់ សូមសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ៖

« យុវជនសព្វថ្ងៃនេះត្រូវបានចិញ្ចឹមនៅក្នុងដែនដីរបស់សត្រូវ » (ប្រធាន ប៊ីយដ៍ យេ. ផាកកឺ) ។

ពេលចាប់ផ្តើមថ្នាក់ សូមឲ្យសិស្សម្នាក់អានប្រយោគនេះ ។ បន្ទាប់មកសូមសួរ ៖

- តើនរណាជាសត្រូវ ? (សាតាំង ។)
- តើភស្តុតាងនៃឥទ្ធិពលរបស់សាតាំងណាខ្លះ ដែលអ្នកឃើញនៅក្នុងពិភពជុំវិញអ្នក ? (សិស្សអាចនិយាយពីភាសា និងសំលៀកបំពាក់ដែលមិនសមរម្ស អាកប្បកិរិយាដែលមិនស្មោះត្រង់ និងអសីលធម៌ និងការល្បួងដែលជាញឹកញាប់បង្កតាមរយៈ ព័ត៌មាន និងបច្ចេកវិទ្យា ។)

សូមណែនាំសិស្សឲ្យគិតពីរបៀបដែលពួកគេអាចប្រៀបធៀបឧបសគ្គទាំងឡាយដែលពួកគេជួបទៅនឹងហេតុការណ៍ និងស្ថានភាពដែលបានរៀបរាប់នៅក្នុង អាលម៉ា ៥២–៥៥ ។ បន្ទាប់សូមអានការនិយាយថ្លែងបន្តរបស់ប្រធាន ផាកកឺ ៖

« « យុវវ័យសព្វថ្ងៃនេះត្រូវបានចិញ្ចឹមធំធាត់ឡើងនៅក្នុងដែនដីសត្រូវដោយមានបទដ្ឋានសីលធម៌ធ្លាក់ចុះយ៉ាងខ្លាំង ។ ប៉ុន្តែក្នុងនាមជាអ្នកបម្រើរបស់ព្រះអម្ចាស់ ខ្ញុំសន្យានឹងអ្នកថា អ្នកនឹងត្រូវបានការពារ និងបាំងពីការវាយប្រហារនៃឧបសគ្គ *ប្រសិនបើ*អ្នកធ្វើតាមការបំផុសដែលមកពីព្រះវិញ្ញាណបរិសុទ្ធ » (« Counsel to Youth »*Ensign*ឬ*លេអាហូណា*ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ១៨) ។

សូមលើកទឹកចិត្តសិស្សឲ្យស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យពួកគេអាចប្រឈមមុខនឹងអំពើអាក្រក់ ។

សូមរំឭកសិស្សថា ខណៈពេលដែលមរ៉ូណៃកំពុងបង្ត្រាបការបះបោរនៃពួកនិយមស្តេច ពួកសាសន៍លេមិនបានវាយយកទីក្រុងជាច្រើននៃសាសន៍នីហ្វៃដែលបានពង្រឹងហើយ (សូមមើល អាលម៉ា ៥១:២៦) ។ សូមឲ្យសិស្សអាន អាលម៉ា ៥២:១៤ ដោយស្វាត់ៗដោយរកមើលការរៀបរាប់របស់មរ៉ូណៃនៃស្ថានភាពរបស់សាសន៍នីហ្វៃនាពេលនោះ ។ បន្ទាប់សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៥៣:៩ ព្ធៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលមូលហេតុដែលធ្វើឲ្យស្ថានភាពរបស់សាសន៍នីហ្វៃមានគ្រោះថ្នាក់ ។

- តើប្រជាជនដាក់ខ្លួនគេនៅក្នុងស្ថានភាពដែលមានគ្រោះថ្នាក់ខាងវិញ្ញាណតាមរបៀបណា ?

សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖ *អាលម៉ា ៥២:៥–១០, ១៦–១៩ ។*ដើម្បីជួយសិស្សឲ្យយល់ពីបរិបទនិងខ្សែរឿងក្នុងខគម្ពីរទាំងនេះ សូមឲ្យសិស្សពីរនាក់អានសេចក្តីសង្ខេបជំពូកនៃ អាលម៉ា ៥២និង ៥៣ ព្ធៗ ។ បន្ទាប់មក សូមឲ្យសិស្សសិក្សាខគម្ពីរទាំងឡាយដែលអ្នកបានសរសេរនៅលើក្តារខៀន ដោយរកមើលគោលការណ៍នានាដែលអាចជួយដល់ពួកគេឲ្យចៀសវាងឬដកថយចេញអំពើអាក្រក់ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមសួរ ៖

- តើគោលការណ៍អ្វីដែលយើងអាចរៀនពីខគម្ពីរទាំងនេះ ? (ក្នុងចំណោមគោលការណ៍ផ្សេងទៀត សិស្សអាចរកឃើញនូវសេចក្តីពិតខាងក្រោម ៖ **ប្រសិនបើយើងចៀសវាងពីចំណងនៃឧបសគ្គទាំងឡាយ យើងអាចចៀសវាង និងតស៊ូនឹងការល្បួងបានកាន់តែខ្លាំង**) ។

សូមឲ្យសិស្សគិតពីទីកន្លែងរស់នៅ ទីកន្លែងសង្គម ឬស្ថានភាពដែលទាក់ទងនឹងការប្រើបច្ចេកវិទ្យា (ដូចជាអ៊ិនធើណិត) ដែលពួកគេមានអារម្មណ៍ថានឹងដឹកនាទៅរកស្ថានភាពគ្រោះថ្នាក់នៅក្នុងជីវិតរបស់ពួកគេ ។

សូមពន្យល់ថា មរ៉ូណៃបានរៀបរាប់ជំហានរបស់ទីអានគុមប្រឆាំងនឹងពួកសាសន៍លេមិនដោយការប្រើពាក្យដូចជា *ការពារ លើកកម្លាំងធានាសន្តិសុខ វាយ* និង*ពង្រឹង* ។សូមឲ្យសិស្សសញ្ជឹងគិតពីអ្វីដែលអាចត្រូវ « វាយ » ឬបណ្តេញចេញពីជីវិតរបស់គេជ្ទាល់ដើម្បីជួយពួកគេឲ្យមានសុវត្ថិភាពខាងវិញ្ញាណកាន់តែខ្លាំង ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៥២:១៩ ព្ធៗ ។ សូមសួរសិស្ស ៖

សូមជួយសិស្សឲ្យរកមើលគោលការណ៍ដែលបង្ក់ប់ទាំងឡាយ

គោលការណ៍ជាច្រើនមិនមែនបង្ហាញដោយចំៗដោយអ្នកសរសេរព្រះគម្ពីរនោះទេ ។ ផ្ទុយទៅវិញ គោលការណ៍មួយអាចបង្ក់ប់នៅក្នុងខ្សែរឿង ឬនៅក្នុងហេតុការណ៍ ឬការប្រៀបធៀបមួយជាក់លាក់ ។ វាអាចត្រូវបានបង្ហាញដោយរឿងគម្ពីរទាំងមូលមួយ ជំពូកមួយ ឬ ខគម្ពីរតែមួយ ។ ជាញឹកញាប់គោលការណ៍បង្ក់ប់អាចរកឃើញដោយការវិភាគសកម្មភាព និងឥរិយាបថរបស់បុគ្គលទាំងឡាយ ឬក្រុមនានានៅក្នុងព្រះគម្ពីរ ហើយបន្ទាប់មកដោយរកនូវលទ្ធផលនៃសកម្មភាព និងឥរិយាបថទាំងនោះ ។

- តើអ្នកដឹកនាំសាសន៍នីហ្វៃបានធ្វើអ្វីមុនពេលទៅប្រយុទ្ធ ? (ពួកគេបានប្រជុំក្រុមប្រឹក្សាសង្គ្រាម) ។
- តើក្រុមប្រឹក្សាគ្រួសារមួយ ឬក្រុមប្រឹក្សាសាសនាចក្រមួយអាចស្រដៀងនឹង « ក្រុមប្រឹក្សាសង្គ្រាម » តាមរបៀបណា ? តើក្រុមប្រឹក្សាបែបនោះអាចពង្រឹងយើងនៅក្នុងសង្គ្រាមរបស់យើងប្រឆាំងនឹងឧបសគ្គដោយរបៀបណា ?

សូមសង្ខេប អាលម៉ា ៥២:២០–៤០ និង អាលម៉ា ៥៣ ដោយការពន្យល់ថា ក្រោយពីក្រុមប្រឹក្សាសង្គ្រាម មេទ័ពម៉ូរ៉ូណៃ និងកងទ័ពរបស់កាត់បានដណ្តើមយកទីក្រុងម៉ូលេកមកវិញដោយការវាយសាសន៍លេមិនចេញពីតំបន់ការពាររបស់ពួកគេ ។ ពួកសាសន៍នីហ្វៃបានចាប់យកអ្នកទោសសាសន៍លេមិនជាច្រើន ហើយបានបញ្ជូនពួកគេទៅធ្វើការដើម្បីពង្រឹងទីក្រុងបរិបូរណ៍ ។ ទោះជាយ៉ាងណាក្តី សាសន៍លេមិនបានបន្តមានជោគជ័យលើតំបន់ផ្សេងទៀត ដោយសារតែការប្រឆាំងក្នុងចំណោមពួកសាសន៍នីហ្វៃ ។

អាលម៉ា ៥៤–៥៥

ម៉ូរ៉ូណៃបដិសេធលក្ខខណ្ឌរបស់អាំម៉ូរ៉ុនក្នុងការផ្លាស់ប្តូរអ្នកទោស ហើយប្រើយុទ្ធសាស្ត្ររំដោះអ្នកទោសសាសន៍នីហ្វៃ

សូមពន្យល់ថា អាលម៉ា ៥៤ គឺជាកំណត់ត្រាមួយនៃសំបុត្រដែលបានផ្ញើរវាងអាំម៉ូរ៉ុន (ស្តេចនៃសាសន៍លេមិន) និងមេទ័ពម៉ូរ៉ូណៃ ។ មុនការណ៍នេះ សាសន៍លេមិន និងសាសន៍នីហ្វៃបានការពារអ្នកទោសសង្គ្រាមជាច្រើន ។ ជំពូកនេះកត់ត្រាន៖ចម្លើយរបស់ម៉ូរ៉ូណៃចំពោះសំណើររបស់អាំម៉ូរ៉ុនដែលថា សាសន៍លេមិន និងសាសន៍នីហ្វៃគួរផ្លាស់ប្តូរអ្នកទោស ។

សូមពន្យល់ថា អាលម៉ា ៥៤:៩–១២ រួមមានពាក្យសម្តីរបស់មេទ័ពម៉ូរ៉ូណៃទៅអាំម៉ូរ៉ុន ។ សូមឲ្យសិស្សម្នាក់អានខគម្ពីរទាំងនេះឮៗ ។ បន្ទាប់មក សូមឲ្យសិស្សផ្សេងទៀតអានចម្លើយរបស់អាំម៉ូរ៉ុនទៅនឹងមេទ័ពម៉ូរ៉ូណៃនៅក្នុង អាលម៉ា ៥៤:១៨–២០ ។

- តើការជម្រុញរបស់មេទ័ពម៉ូរ៉ូណៃក្នុងការផ្លាស់ប្តូរអ្នកទោសខុសពីការជម្រុញរបស់អាំម៉ូរ៉ុនដោយរបៀបណា ? (អ្នកអាចបង្ហាញថា ម៉ូរ៉ូណៃព្រួយបារម្ភអំពីគ្រួសារ ខណៈពេលដែលអាំម៉ូរ៉ុនគិតតែពីទាហានសង្គ្រាមរបស់ទ្រង់ ដោយសារទ្រង់ចង់បំផ្លាញសាសន៍នីហ្វៃ) ។
- តើប្រសាសន៍របស់អាំម៉ូរ៉ុននៅក្នុង អាលម៉ា ៥៤:១៨–២០ ឆ្លុះបញ្ចាំងពីការជម្រុញរបស់សាតាំងនៅក្នុងសង្គ្រាមរបស់វាទាស់នឹងយើងដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៥៥:១–២ ឮៗ ។ សូមឲ្យសិស្សរកមើលចម្លើយរបស់ម៉ូរ៉ូណៃទៅនឹងការទាមទាររបស់អាំម៉ូរ៉ុន ។

- ហេតុអ្វីបានជាម៉ូរ៉ូណៃមិនចង់ធ្វើអ្វីដែលអាំម៉ូរ៉ុនបាននិយាយ ? (គាត់បានដឹងថាអាំម៉ូរ៉ុនកុហក ហើយគាត់មិនចង់ឲ្យអាំម៉ូរ៉ុនមានអំណាចជាងនេះទៀតទេ) ។
- តើយើងអាចរៀនអ្វីខ្លះពីចម្លើយរបស់ម៉ូរ៉ូណៃចំពោះអាំម៉ូរ៉ុន ? (ទោះបីជាសិស្សអាចនិយាយពីសេចក្តីពិតមួយចំនួនក្តី សូមប្រាកដថាពួកគេយល់ថា **នៅពេលយើងឈរដោយរឹងមាំចំពោះអ្វីដែលត្រូវ យើងអាចការពារឥទ្ធិពលអាក្រក់កុំឲ្យមានអំណាចលើយើង ។**)

សេចក្តីថ្លែងការណ៍ខាងក្រោមដោយ យ៉ូសែប ស៊្មីធ អាចជួយដល់អ្នកនៅក្នុងការពិភាក្សាពីខគម្ពីរទាំងនេះ ៖

« សាតាំងមិនអាចទាក់ចិត្តយើងដោយការល្បួងរបស់វាទេ រហូតដល់យើងព្រមព្រៀងនៅក្នុងចិត្តយើង ហើយចុះចាញ់ » (*Teachings of Presidents of the Church: Joseph Smith* | ឆ្នាំ ២០០៧ |, ទំព័រ ២១៣) ។

« អារក្សគ្មានអំណាចលើយើងទេ លើកលែងតែយើងអនុញ្ញាតឲ្យវាមានអំណាច » (*Teachings of Presidents of the Church: Joseph Smith,* ទំព័រ ២១៤) ។

សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖ ***អាលម៉ា ៥៥:១៥–២៤, ២៨–៣១ ។***

សូមពន្យល់ថានៅក្នុង អាលម៉ា ៥៥ យើងរៀនថា មេទ័ពម៉ូរ៉ូណៃបានរំដោះអ្នកទោសសាសន៍នីហ្វៃនៅក្នុងទីក្រុងគីឌដោយយុទ្ធសាស្ត្រ (របៀបមួយដែលប្រើនៅក្នុងសង្គ្រាមដើម្បីបោកបញ្ឆោត ឬមានប្រៀបលើសត្រូវ) ។ នៅក្នុង អាលម៉ា ៥៥:៣–១៤ យើងរៀនថា ម៉ូរ៉ូណៃអាចប្រើទាហាននីហ្វៃម្នាក់ឈ្មោះ លេមិន ឲ្យនាំទាហានសាសន៍លេមិនដែលយាមអ្នកទោសសាសន៍នីហ្វៃពីកស្រឹង ។ សូមឲ្យសិស្សអានខគម្ពីរទាំងឡាយដែលអ្នកបានសរសេរនៅលើក្តារខៀនដោយស្ងាត់ៗ ដោយរកមើលអ្វីដែលមេទ័ពម៉ូរ៉ូណៃបានធ្វើ នៅពេលគាត់បានឡោមព័ទ្ធសាសន៍លេមិននៅក្នុងទីក្រុងគីឌ ។ សូមរំឭកសិស្សឲ្យរកមើលគោលការណ៍ នៅពេលពួកគេសិក្សា ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យពួកគេរៀបរាប់អ្វីដែលពួកគេបានរកឃើញ ។ អ្នកក៏អាចសួរថា ៖

- តើខគម្ពីរទាំងនេះបង្រៀនអ្នកអ្វីខ្លះអំពីម៉ូរ៉ូណៃ ?

សូមសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ហើយឲ្យសិស្សបំពេញចន្លោះ ៖

យើងមិនអាចរីករាយនឹង . . . ; ផ្ទុយទៅវិញ យើងនឹងរីករាយក្នុង . . .

- តើយើងអាចអនុវត្តគំរូរបស់ម៉ូរ៉ូណៃនៃការមិនរីករាយនឹងការបង្ហូរឈាមតាមរបៀបណា ? ឧទាហរណ៍ តើយើងអាចអនុវត្តគំរូរបស់ម៉ូរ៉ូណៃចំពោះអ្វីដែលយើងអាន ហើយមើលល្បែងដែលយើងលេងដោយរបៀបណា ?

សូមឲ្យសិស្សគិតពីសំណួរខាងក្រោម ៖

- តើអ្នកមានអារម្មណ៍ថា ម៉ូរ៉ូណៃចង់ឲ្យអ្នករៀនអ្វីពីមេរៀន នៅថ្ងៃនេះដែលនឹងជួយអ្នកឲ្យស្មោះត្រង់ នៅពេលអ្នកច្បាំងនឹងឧបសគ្គ ?

សូមគិតពីការឲ្យសិស្សមានពេលសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពី អ្វីដែលពួកគេនឹងធ្វើដើម្បីប្រឆាំងមិនចូលទៅក្នុងដែនដីរបស់សាតាំង ហើយឈរដោយរឹងមាំប្រឆាំងនឹងការវាយលុករបស់វា ។

សូមបញ្ចប់ដោយការថ្លែងទីបន្ទាល់ពីសេចក្តីពិតដែលអ្នកបានពិភាក្សានៅក្នុងថ្នាក់ថ្ងៃនេះ ។

គំនិតបន្ថែមទាំងឡាយសម្រាប់ការបង្រៀន

អាលម៉ា ៥៣:២០–២១ ។ ការដើរដោយស្មោះត្រង់នៅចំពោះព្រះ

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៥៣:២០–២១ ឮៗ ។

- តើវាមានន័យយ៉ាងក្នុងការដើរដោយស្មោះត្រង់នៅចំពោះព្រះ ?

សូមឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេអាចក្លាយជា « មនុស្សស្មោះត្រង់គ្រប់ពេលវេលា ទោះនៅក្នុងកិច្ចការណាក៏ដោយដែលពួកគេទទួលផ្ដុក » ដូចជាទព័ជ៌ក្លាហានទាំងឡាយ ។ សូមអានសេចក្ដីថ្លែងការណ៍ខាងក្រោមដែលប្រធាន ចច អ័លប៊ើត ស្ម៊ីធ បានចែកចាយនូវការប្រឹក្សាដ៏ឆ្លាតវៃពីជីតារបស់គាត់ ចច អេ ស្ម៊ីធ ៖

« ជីតារបស់ខ្ញុំបានធ្លាប់និយាយទៅកាន់គ្រួសារថា ‹ មានបន្ទាត់មួយបែងចែកដ៏ច្បាស់រវាងដែនដីរបស់ព្រះអម្ចាស់ និងដែនដីរបស់អារក្ស ។ ប្រសិនបើអ្នកនឹងនៅខាងបន្ទាត់របស់ព្រះអម្ចាស់ អ្នកនឹងនៅក្រោមឥទ្ធិពលរបស់ទ្រង់ ហើយនឹងមិនមានបំណងធ្វើខុសឡើយ ; ប៉ុន្តែបើអ្នកឆ្លងទៅខាងបន្ទាត់របស់អារក្សតែមួយសង់ទីម៉ែត្រក្ដី អ្នកនឹងស្ថិតនៅក្នុងអំណាចរបស់វា ហើយបើសិនជាវាមានជោគជ័យ អ្នកនឹងមិនអាចគិត ឬសូម្បីតែពិចារណាឲ្យបានត្រឹមត្រូវឡើយ ដោយសារអ្នកបាត់បង់ព្រះវិញ្ញាណនៃព្រះអម្ចាស់ › ។

« នៅពេលខ្លះខ្ញុំត្រូវបានល្បួងឲ្យធ្វើអ្វីមួយ ខ្ញុំបានសួរខ្លួនឯងថា ‹ តើខ្ញុំនៅខាងបន្ទាត់មួយណា › ? ប្រសិនបើខ្ញុំប្ដេជ្ញាដើម្បីនៅខាងបន្ទាត់មានសុវត្ថិភាព នៅខាងព្រះអម្ចាស់ ខ្ញុំនឹងធ្វើអ្វីដែលត្រូវគ្រប់ពេលវេលា ។ ដូច្នេះនៅពេលការល្បួងមក សូមគិតដោយការអធិស្ឋានអំពីបញ្ហារបស់អ្នក និងឥទ្ធិពលរបស់ព្រះអម្ចាស់ដែលនឹងជួយអ្នកឲ្យសម្រេចចិត្តដោយឆ្លាតវៃ ។ មានសុវត្ថិភាពជល់យើងតែនៅខាងបន្ទាត់របស់ព្រះអម្ចាស់ប៉ុណ្ណោះ » (« A Faith Founded upon Truth, » *Deseret News,* ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៤៤, Church section, ៩) ។

សូមគិតពីការគូសបន្ទាត់បញ្ឈរមួយចំកណ្ដាលក្ដារខៀន ។ សូមសរសេរម្ខាងនៃក្ដារខៀនថា *ដែនដីរបស់ព្រះអម្ចាស់* និងម្ខាងទៀតថា *ដែនដីរបស់អារក្ស* ។ សូមសួរសិស្ស ៖

- ទាក់ទងនឹងបន្ទាត់ដែលចែកដែនដីដាពីរ តើកន្លែងដែលមានសុវត្ថិភាពបំផុតនៅកន្លែងណា ? (នៅខាងព្រះអម្ចាស់ កាន់តែឆ្ងាយពីបន្ទាត់នោះកាន់តែល្អ ។)
- តើគ្រោះថ្នាក់អ្វីខ្លះដែលអាចកើតមាន ក្នុងការព្យាយាមរស់នៅខាងព្រះអម្ចាស់ ប៉ុន្តែកៀកទៅនឹងបន្ទាត់ជាខ្លាំង ?
- តើអ្វីដែលជួយអ្នកឲ្យនៅឆ្ងាយពីបន្ទាត់នោះ ?

អាលម៉ា ៥៦–៥៨

សេចក្តីផ្តើម

ហេលេមិន និងមេទ័ពម៉ូរ៉ូណៃបានប្រយុទ្ធនឹងសាសន៍លេមិននៅក្នុងផ្នែកខុសគ្នានៃដែនដី ហេលេមិនបានផ្ញើសំបុត្រមួយទៅមេរ៉ូណៃ ដោយរៀបរាប់ពីសង្គ្រាមនៃកងទ័ពរបស់គាត់ជាមួយនឹងសាសន៍លេមិន ហើយបង្ហាញពីទំនុកចិត្តរបស់គាត់លើសេចក្តីជំនឿនៃកងទ័ពដ៏ក្លាហាន ២០០០ នាក់ដែលបានចូលរួមក្នុងជួរទ័ពរបស់គាត់ ។ ហេលេមិនក៏បានរៀបរាប់ពីអ្វីដែលកងទ័ពរបស់គាត់មិនធ្វើដើម្បីយកឈ្នះលើសង្គ្រាម និងដើម្បីទទួលបានសេចក្តីសង្ឃឹមអំឡុងពេលសេចក្តីវេទនារបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៥៦

កងទ័ពរបស់អាន់ទីផុស និងហេលេមិនមានជ័យជំនះលើកងទ័ពដ៏រឹងមាំបំផុតរបស់សាសន៍លេមិន

សូមសួរសិស្សថា តើពួកគេធ្លាប់ទទួលបានសំបុត្រ ឬសារមួយដែលពង្រឹងពួកគេឲ្យតស៊ូនឹងការពិបាកជាក់លាក់ណាមួយទេ ។ សូមពន្យល់ថា អាលម៉ា ៥៦–៥៨ រួមមានអត្ថបទនៃសារ ឬសំបុត្រដែលហេលេមិនបានសរសេរទៅមេទ័ពម៉ូរ៉ូណៃអំឡុងពេលដ៏លំបាកក្នុងសង្គ្រាម ។ សូមឲ្យសិស្សអាន អាលម៉ា ៥៩:១–២ ដោយស្ងាត់ៗដើម្បីរកមើលរបៀបដែលមេទ័ពម៉ូរ៉ូណៃឆ្លើយតបនឹងសំបុត្រនោះ ។ សូមលើកទឹកចិត្តសិស្សនៅពេលពួកគេសិក្សាសំបុត្រនោះ ឲ្យរកមើលមូលហេតុដែលមេទ័ពម៉ូរ៉ូណៃអាចអរអរគុណទោះបីជាគាត់ស្ថិតនៅក្នុងស្ថានភាពលំបាកក្តី ។

សូមសង្ខេប អាលម៉ា ៥៦:២–១៧ ដោយការពន្យល់ថា ហេលេមិនបានបញ្ជាកងទ័ពមួយក្រុមតូចដែលរួមមានកូនប្រុសនៃសាសន៍អាន់តៃ-នីហ្វៃ-លីហៃ ២០០០ នាក់ ឬប្រជាជនអាំម៉ូន ។ ជាញឹកញាប់ កងទ័ពទាំងនេះសំដៅលើកងពលកំលោះ២០០០នាក់ ។ (អ្នកអាចពន្យល់ថាពាក្យ *កំលោះ* មានន័យថាក្មេង ។) ឪពុកម្តាយរបស់យុវជនទាំងនេះបានធ្វើសេចក្តីសញ្ញាថានឹងលើកអាវុធម្តងទៀតឡើយ ។ យុវជនដែលមិនបានចងនឹងសេចក្តីសញ្ញាដូចគ្នានោះ បានស្ម័គ្រចិត្តទៅការពារឪពុកម្តាយរបស់គេ និងសាសន៍នីហ្វៃដទៃទៀតនៅពេលពួកគេត្រូវបានគំរាមកំហែងដោយកងទ័ពសាសន៍លេមិន ។

សូមពន្យល់ថា ហេលេមិនបានដឹកនាំកងពលកំលោះ ២០០០នាក់ទៅកាន់ទីក្រុងយូដាដើម្បីជួយកងទ័ពនីហ្វៃមួយដែលដឹកនាំដោយអាន់ទីផុស ។ សាសន៍លេមិនបានវាយយកទីក្រុងជាច្រើនរបស់សាសន៍នីហ្វៃ ហើយបានបន្តយកចំនួនដ៏អស្ចារ្យរបស់ទ័ពនៃអាន់ទីផុស ។ អាន់ទីផុសបានអរអរគុណ នៅពេលហេលេមិន និងកងទ័ពរបស់គាត់បានមកដល់ដើម្បីជួយ ។

សូមឲ្យសិស្សអាន អាលម៉ា ៥៣:១៧–២១ ដោយស្ងាត់ៗដោយរកមើលពាក្យ និងឃ្លាដែលរៀបរាប់ពីកម្លាំងខាងវិញ្ញាណដែលយុវជនទាំងនេះបាននាំមកដល់កងទ័ព ។ នៅពេលពួកគេអាន សូមចង្អុលតារាងខាងក្រោមនៅលើក្តារខៀន ។ សូមឲ្យសិស្សបីបួននាក់ឡើងមកកាន់ក្តារខៀន ហើយសរសេរពាក្យ និងឃ្លាដែលពួកគេបានរកឃើញនៅក្រោមចំណងជើង « មុនសង្គ្រាម » ។

មុនសង្គ្រាម		អំឡុងពេលសង្គ្រាម
		
	កងពលកំលោះ/ យុវជនពួកបរិសុទ្ធថ្ងៃចុងក្រោយ	

- តើអ្នកគិតថា ហេលេមិនអាចចង់មានន័យយ៉ាងណា នៅពេលគាត់រៀបរាប់ពីកងពលកំឡោះ ២,០០០ ថាជា « មនុស្សស្មោះត្រង់ហើយម៉ឺងម៉ាត់ » ? (អ្នកអាចពន្យល់ថាពាក្យ ម៉ឺងម៉ាត់ មានន័យថា ម៉ាត់ចត់ សូប់ស្ងាត់ និងគ្រប់គ្រងលើខ្លួនឯង ។)
- តើគុណសម្បត្តិដែលសរសេរនៅលើក្តារខៀនអាចជួយយើងឲ្យប្រឈមមុខនឹងសង្គ្រាមខាងវិញ្ញាណ និងឧបសគ្គផ្សេងទៀតដោយរបៀបណា ?

សូមសង្ខេបខ្លីៗពីការចាប់ផ្តើមដំបូងនៃសង្គ្រាមទីមួយរបស់កងពលកំឡើនៅក្នុង អាលម៉ា ៥៦:២៩–៤៣ ។ អាន់ទីផុសបានប្រើហេលេមិន និងកងពលកំឡោះ ២,០០០ នាក់ជានុយមួយដើម្បីទាក់ទាញកងទ័ពដ៏រឹងមាំរបស់សាសន៍លេមិនចេញពីទីក្រុងអានទីប៉ារ៉ា ។ កងទ័ពសាសន៍លេមិនភាគច្រើនបានចាកចេញពីអានទីប៉ារ៉ាដើម្បីដេញតាមកងទ័ពរបស់ហេលេមិន ដោយឲ្យកងទ័ពរបស់អាន់ទីផុសមានឱកាសដេញតាមពួកវាពីក្រោយ ។ នៅពេលកងទ័ពរបស់អាន់ទីផុសដេញទាន់កងទ័ពរបស់សាសន៍លេមិន ពួកគេបានវាយលុកតាមដែនការ ។ នៅពេលកងទ័ពសាសន៍លេមិនបានឈប់ដេញតាមកងទ័ពរបស់ហេលេមិន ហេលេមិនមិនដឹងច្បាស់ថាតើកងទ័ពសាសន៍លេមិនព្យាយាមដាក់អន្ទាក់កងទ័ពរបស់គាត់ ឬថាកងទ័ពរបស់អាន់ទីផុសបានចាប់វាយកងទ័ពសាសន៍លេមិនក្នុងសង្គ្រាមទៅហើយ ។ ហេលេមិន និងកងពលក្មេងរបស់គាត់បានសម្រេចថាត្រូវបន្តរត់ ឬវាយបកសាសន៍លេមិន ។

សូមឲ្យសិស្សអាន អាលម៉ា ៥៦:៤៤–៤៨ ដោយស្ងាត់ៗ ។ សូមឲ្យពួកគេរកមើលពាក្យ និងឃ្លាដែលបង្ហាញពីភស្តុតាងនៃរបៀបដែលយុវជនទាំងនេះធ្វើសកម្មភាពដោយសេចក្តីជំនឿ ។ សូមឲ្យសិស្សពីរបីនាក់សរសេរពីអ្វីដែលពួកគេរកឃើញនៅលើក្តារខៀននៅក្រោមចំណងជើង « អំឡុងពេលសង្គ្រាម » ។

- តើយុវជនទាំងនេះមិនបានសង្ស័យអ្វី ? (ថាព្រះនឹងដោះលែងពួកគេ ។)
- ហេតុអ្វីបានជាពួកគេមិនសង្ស័យថា ព្រះនឹងដោះលែងពួកគេ ?
- តើគុណសម្បត្តិដែលពួកគេបានធ្វើ មុនពេលសង្គ្រាមបានជួយពួកគេអំឡុងពេលសង្គ្រាមដោយរបៀបណា ?

សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***នៅពេលយើងធ្វើសកម្មភាពដោយសេចក្តីជំនឿ យើងអាចទទួលបានកម្លាំងពីព្រះ ។*** សូមឲ្យសិស្សរកមើលភស្តុតាងនៃសេចក្តីពិតនេះ នៅពេលពួកគេសិក្សា អាលម៉ា ៥៦ ។

សូមសង្ខេប អាលម៉ា ៥៦:៤៩–៥៣ ដោយការពន្យល់ថា កងទ័ពរបស់ហេលេមិនបានឃើញថាកងទ័ពរបស់អាន់ទីជុសស្ថិតក្នុងស្ថានភាពលំបាកមួយ ។ អាន់ទីជុស និងអ្នកដឹកនាំទាហានផ្សេងទៀតជាច្រើនបានស្លាប់ ហើយសាសន៍នីហ្វៃដែលហត់នឿយ និងរងរង្វេងទាំងឡាយរៀបនឹងបរាជ័យ ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៥៦:៥៤–៥៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរបៀបដែលព្រះបានប្រទានពរដល់កងពលរបស់ហេលេមិនដោយសារតែសេចក្តីជំនឿរបស់ពួកគេ ។

- តើអ្នកគិតថា តរិយាបថខាងវិញ្ញាណដែលបានសរសេរនៅលើក្តារខៀន បានរួមចំណែកនឹងហេតុការណ៍ដែលបានកត់ត្រានៅក្នុង អាលម៉ា ៥៦:៥៦ ដោយរបៀបណា ?
- តើនៅពេលណាដែលអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់បានធ្វើសកម្មភាពដោយសេចក្តីជំនឿ ហើយបានទទួលកម្លាំងពីព្រះនៅក្នុងស្ថានភាពលំបាកមួយ ?

អាលម៉ា ៥៧

ហេលេមិន និងកងពលកំឡាំងរបស់គាត់បានដណ្តើមយកទីក្រុងគូមេណៃ ហើយត្រូវបានការពារនៅក្នុងសង្គ្រាម

សូមពន្យល់ថា អាលម៉ា ៥៧ គឺជាការបន្តសំបុត្ររបស់ហេលេមិនចំពោះមេទ័ពម៉ូរ៉ូណៃ ។ វាចាប់ផ្តើមដោយដំណើររឿងនៃសាសន៍នីហ្វៃដណ្តើមយកទីក្រុងពីរពីសាសន៍លេមិនមកវិញ ។ អំឡុងពេលនេះ ហេលេមិនបានទទួលយុវជន ៦,០០០ ដើម្បីពង្រឹងកងទ័ពរបស់គាត់ ដោយមានកូនប្រុសប្រជាជនអាំម៉ូនបន្ថែម ៦០ នាក់ ។ សាសន៍លេមិនក៏បានទទួលការពង្រឹងដែរ ហើយបានបន្តពង្រឹងទីក្រុងដែលពួកគេបានវាយយកបាន ។

សូមបង្ហាញថា នៅក្នុងសង្គ្រាមមួយ សាសន៍លេមិនរៀបនឹងយកឈ្នះលើសាសន៍នីហ្វៃទៅហើយ (សូមមើល អាលម៉ា ៥៧:១៨) ។ សូមឲ្យសិស្សអាន អាលម៉ា ៥៧:១៩–២២ ដោយស្ងាត់ៗដោយរកមើលមូលហេតុដែលសាសន៍នីហ្វៃអាចយកឈ្នះបាន ។

- ហេតុអ្វីបានជាសាសន៍នីហ្វៃអាចយកឈ្នះលើសាសន៍លេមិន ?
- ហេលេមិនបាននិយាយថា កងពលរបស់គាត់ « បានប្រតិបត្តិតាមគ្រប់ពាក្យបញ្ជាដោយឥតល្អៀង » (អាលម៉ា ៥៧:២១) ។ តើអ្នកគិតថាការណ៍នេះមានន័យយ៉ាងណា ? តើការគោរពនេះជាការបង្ហាញសេចក្តីជំនឿរបស់ពួកគេដោយរបៀបណា ?

ដើម្បីគាំទ្រចម្លើយរបស់សិស្សទៅនឹងសំណួរនេះ សូមអានសេចក្តីថ្លែងការណ៍ដោយអែលឌើរ រ៉ាសុល អិម ណិលសុននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« [អ្នក] នឹងជួបមនុស្សដែលរើសព្រះបញ្ញត្តិណាដែលពួកគេនឹងកាន់តាម ហើយចោះចោលព្រះបញ្ញត្តិផ្សេងទៀតដែលពួកគេរំលង ។ ខ្ញុំសូមហៅការធ្វើបែបនេះឲ្យទៅជាការគោរព ។ ការអនុវត្តការរើស និងការជ្រើសបែបនេះនឹងមិនមានប្រយោជន៍ឡើយ ។ វានឹងនាំទៅរកភាពវេទនា ។ ដើម្បីរៀបចំទៅជួបនឹងព្រះ បុគ្គលម្នាក់ត្រូវកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ *ទាំងអស់* ។ វាត្រូវការសេចក្តីជំនឿដើម្បីគោរពតាម ហើយការកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់នឹងពង្រឹងសេចក្តីជំនឿនោះ » (« Face the Future with Faith »*Ensign* ឬ *លេខអាហ្វណា*,ខែឧសភា ឆ្នាំ ២០១១, ទំព័រ ៣៤) ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៥៧:២៣–២៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលព្រះអម្ចាស់ថែរក្សាកងទ័ពក្មេងរបស់ហេលេមិន និងមូលហេតុដែលទ្រង់បានថែរក្សាពួកគេ ។ ដើម្បីជួយសិស្សឲ្យពិភាក្សាពីអ្វីដែលពួកគេរកឃើញ សូមសួរសំណួរតាមដានទាំងនេះ ៖

- ហេលេមិនបាននិយាយថា « គំនិតគេរឹងប៉ឹង » អំពីទាហានរបស់គាត់ ។ តើអ្នកគិតថាវាមានន័យយ៉ាងណា ? ហេតុអ្វីបានជាយើងត្រូវរក្សាគំនិតយើងឲ្យរឹងប៉ឹង នៅពេលយើងជួបនឹងឧបសគ្គ ?
- តើកងទ័ពរបស់ហេលេមិនបានបង្ហាញថាពួកគេ « ដាក់ទីទុកចិត្តរបស់គេទៅលើព្រះរហូត» ដោយរបៀបណា ?

វាអាចជួយបើអ្នកពន្យល់ថា នៅក្នុងកាលៈទេសៈខ្លះ ពួកសុចរិតនឹងរងទុក្ខ ឬស្លាប់ គឺដូចជាកងពលកំឡោះបានរងទុក្ខ ហើយដូចជាកងទ័ពនីហ្វៃខ្លះបានស្លាប់ ។ ទោះជាយ៉ាងណាក្តី ព្រះនឹងតែងតែការពារអ្នកទាំងឡាយណាដែលគោរពដល់ទ្រង់ ហើយពួកសុចរិតដែលស្លាប់នឹងត្រូវបានប្រទានពរ ។

- តើអ្នកឃើញភាពស្រដៀងគ្នាអ្វីរវាងសង្គ្រាមរបស់កងពលកំឡោះជាមួយនឹងសត្រូវរបស់គេ និងសង្គ្រាមរបស់យើងជាមួយនឹងឧបសគ្គ ?

សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ដោយ អែលឌើរ អិម រ័សុល បាឡឺដនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« សព្វថ្ងៃនេះ យើងកំពុងធ្វើសង្គ្រាមមួយដែលមានរបៀបជាច្រើនមានគ្រោះថ្នាក់ខ្លាំង . . . ជាងសង្គ្រាមរវាងសាសន៍នីហ្វៃ និងលេមិនទៅទៀត ។ សត្រូវរបស់យើងមានកលល្បិត ហើយប្រសព្វលៃលក ។ យើងប្រយុទ្ធនឹងលូស៊ីហ្វើរ ជាបិតានៃសេចក្តីកុហកទាំងឡាយ សត្រូវនៃមនុស្សទាំងអស់ដែលធ្វើល្អ និងត្រឹមត្រូវ និងបរិសុទ្ធ ។ . . .

« . . . យើងធ្វើសង្គ្រាមយ៉ាងខ្លាំងសម្រាប់ព្រលឹងមនុស្ស ។ សត្រូវនោះមិនចេះអភ័យទោស ហើយសាហាវព្រៃផ្សៃ ។ វាកំពុងដាក់អ្នកទោសដ៏អស់កល្បនៅក្នុងកម្រិតមួយដ៏ខ្លាំង ។ ហើយវាមិនបានបង្ហាញសញ្ញានៃការដោះលែងឡើយ ។

« ខណៈពេលដែលយើងមានសេចក្តីអំណរជាខ្លាំងចំពោះសមាជិកជាច្រើននៃសាសនាចក្រដែលកំពុងធ្វើអ្វីៗដ៏អស្ចារ្យនៅក្នុងសង្គ្រាមសម្រាប់សេចក្តីពិត និងត្រឹមត្រូវ ខ្ញុំត្រូវប្រាប់អ្នកដោយត្រង់ៗថា វានៅតែមិនគ្រប់គ្រាន់ឡើយ ។ យើងត្រូវការជំនួយបន្ថែមទៀតជាច្រើន ។ . . . យើងត្រូវការអ្នក ។ ដូចជាកងពលកំឡោះ ២០០០នាក់ដែរ . . . អ្នកអាចត្រូវបានប្រសិទ្ធពរឲ្យមានអំណាចដើម្បីកសាង និងការពារនគររបស់ទ្រង់ ។ យើងត្រូវការអ្នកឲ្យធ្វើសេចក្តីសញ្ញាដ៏ពិសិដ្ឋ គឺដូចជាពួកគេបានធ្វើ ។ យើងត្រូវការអ្នកឲ្យគោរព និងស្មោះត្រង់ដោយឥតល្អៀង គឺដូចជាពួកគេបានធ្វើ » (« The Greatest Generation of Missionaries »*Ensign*ឬ*លេខាហ្គណា*,ខែ វិច្ឆិកា ឆ្នាំ ២០០២, ទំព័រ ៤៦–៤៧) ។

សូមសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ៖ *ប្រសិនបើយើងទុកចិត្តលើព្រះអម្ចាស់ ហើយគោរពតាមទ្រង់ដោយឥតល្អៀង . . .*

- ដោយផ្អែកលើអ្វីដែលអ្នកបានអានអំពីកងពលរបស់ហេលេមិន តើអ្នកនឹងបំពេញប្រយោគនេះដោយរបៀបណា ? (បំពេញប្រយោគនៅលើក្តារខៀនស្របតាមការឆ្លើយរបស់សិស្ស ។ ឧទាហរណ៍ អ្នកអាចសរសេរសេចក្តីពិតខាងក្រោម ៖ ***ប្រសិនបើយើងទុកចិត្តលើព្រះអម្ចាស់ ហើយគោរពតាមទ្រង់ដោយឥតល្អៀង ទ្រង់នឹងគាំទ្រយើងនៅក្នុងសង្គ្រាម ។***

សូមឲ្យសិស្សគិតពីពេលមួយដែលពួកគេ ឬនរណាម្នាក់ដែលគេស្គាល់បានគោរពតាមដោយឥតល្អៀងនៅក្នុងស្ថានភាពមួយដ៏លំបាកមួយនៅសាលា នៅផ្ទះ ឬនៅទីកន្លែងសង្គមមួយ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់គេ ។ សូមសួរពួកគេពីរបៀបដែលព្រះអម្ចាស់បានជួយដល់គេនៅក្នុងស្ថានភាពនោះ ។

សូមឲ្យសិស្សមានពេលសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពី អ្វីដែលពួកគេនឹងធ្វើដើម្បីគោរពតាមការបញ្ជារបស់ព្រះ « ដោយឥតល្អៀង » (អាលម៉ា ៥៧:២១) និង “put their trust in God continually” (**អាលម៉ា ៥៧:២៧**) ។

អាលម៉ា ៥៨

ទាហានសាសន៍នីហ្វៃទុកចិត្តថា ព្រះនឹងថែរក្សាពួកគេនៅក្នុងឧបសគ្គដែលគេជួប

សូមពន្យល់ថា អាលម៉ា ៥៨ រួមានទីបញ្ចប់នៃសំបុត្ររបស់ហេលេមិនទៅដល់មរ៉ូណៃ ។ ហេលេមិនបានប្រាប់ពីរបៀបដែលកងទ័ពនីហ្វៃបានជួបនឹងស្ថានភាពលំបាកជាច្រើនដែលធ្វើឲ្យស្មុគស្មាញដល់លក្ខខណ្ឌដ៏ពិបាកដែលពួកគេបានជួបរួចហើយ ។ សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៥៨:២, ៦–៩ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលស្ថានភាពលំបាកទាំងនោះ (ខ្វះអាហារ ទំនុកបម្រុង ខ្វះការពង្រឹង ខ្លាចថាពួកគេនឹងត្រូវបំផ្លាញដោយសត្រូវរបស់គេ) ។

សូមឲ្យសិស្សអាន អាលម៉ា ៥៨:១០–១២ ដោយស្ងាត់ៗដោយរកមើលចម្លើយទៅនឹងសំណួរខាងក្រោម ។ (សូមសរសេរសំណួរនៅលើក្តារខៀនមុនចាប់ផ្តើមថ្នាក់ ។ សូមអានសំណួរដល់សិស្ស មុនពេលពួកគេអានវគ្គព្រះគម្ពីរ ហើយបន្ទាប់មកសូមរំឭកពួកគេក្រោយពីពួកគេបានអានហើយ ។ ការណ៍នេះនឹងជួយសិស្សឲ្យផ្តោតលើរបៀបដែលកងទ័ពរបស់ហេលេមិនបានឆ្លើយតបនឹងស្ថានភាពដ៏លំបាកនេះ) ។

តើសាសន៍នីហ្វៃបានធ្វើអ្វី នៅពេលពួកគេជួបនឹងស្ថានភាពដ៏លំបាកនេះ ?

តើព្រះអម្ចាស់បានឆ្លើយតបនឹងការអង្វរ និងការអធិស្ឋានដោយស្មោះត្រង់របស់គេដោយរបៀបណា ?

តើការធានារបស់ព្រះអម្ចាស់បានជួយហេលេមិន និងកងទ័ពរបស់គាត់តាមរបៀបណា ?

សូមឲ្យសិស្សសង្ខេបសេចក្តីពិតមួយដែលពួកគេបានរៀនពី អាលម៉ា ៥៨:១០–១២ ។ (សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេរកឃើញនូវគោលការណ៍ខាងក្រោម ៖ **ប្រសិនបើយើងបែរទៅរកព្រះក្នុងពេលលំបាក យើងអាចទទួលបានការធានាដ៏មានទេវភាពដែលអាចពង្រឹងសេចក្តីជំនឿរបស់យើង ហើយផ្តល់សេចក្តីសង្ឃឹមដល់យើង**) ។

- តើនៅពេលណាដែលព្រះអម្ចាស់បានប្រទានពរដល់អ្នកឲ្យមានសេចក្តីសុខសាន្ត និងការធានាអំឡុងពេលការជួបនឹងទុក្ខលំបាកមួយ ?

សូមពន្យល់ថា អាលម៉ា ៥៨ ទាំងអស់ប្រាប់ពីការខិតខំប្រឹងដែលបានជោគជ័យនៃកងទ័ពសាសន៍នីហ្វៃក្នុងការដណ្តើមយកទីក្រុងដែលបានវាយយកដោយសាសន៍លេមិនមកវិញ (សូមមើល អាលម៉ា ៥៨:៣១) ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៥៨:៣៩–៤០ ឮៗ ។

- តើកងពលកំឡោះរបស់ហេលេមិនបានបង្ហាញសេចក្តីជំនឿលើព្រះ ទោះបីជាពួកគេបានទទួលនូវ « របួសជាច្រើន » ក្តី ?
- នៅពេលអ្នកជួបនឹងឧបសគ្គនៅក្នុងជីវិត តើអ្នកអាចទទួលប្រយោជន៍ពីការធ្វើតាមគំរូនៃកូនប្រុសរបស់ហេលេមិនដោយរបៀបណា ?

សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍ដែលបានបង្រៀននៅក្នុងមេរៀននេះ ។

អាលម៉ា ៥៩–៦៣

សេចក្តីផ្តើម

មេទ័ពម៉ូរ៉ូណៃបានមានសេចក្តីអរីកវាយចំពោះជោគជ័យរបស់ហេលេមិនក្នុងការទទួលបានទីក្រុងសាសន៍នីហ្វៃខ្លះមកវិញដែលវាត្រូវបានបាត់បង់ទៅសាសន៍លេមិនពីមុន ទោះជាយ៉ាងណាក្តី នៅពេលគាត់បានដឹងថា ទីក្រុងនីហ្វៃហាត្រូវបានសាសន៍លេមិនវាយយក គាត់ខឹងនឹងរដ្ឋាភិបាលដែលធ្វេសប្រហែសមិនបានពង្រឹងទ័ព ។ នៅក្នុងសំបុត្រមួយដល់ពេហូរ៉ាន ជាមេចៅក្រម គាត់បានថ្លែងទុក្ខនៃពួកសុចរិត ហើយបន្ទោសដល់ពេហូរ៉ានដែលមិនបានគាំទ្រដល់បុព្វហេតុនៃសេរីភាព ។ ដោយមិនបានដឹងដល់ម៉ូរ៉ូណៃ ពេហូរ៉ានបានគេចទៅដែនដីគេឌាន ដោយសារតែការបះបោរនៃពួកនិយមស្តេចសាសន៍នីហ្វៃ ។ ពេហូរ៉ានមិនប្រកាន់នឹងការបន្ទោសរបស់ម៉ូរ៉ូណៃទេ ផ្ទុយទៅវិញ គាត់បានអរីកវាយនឹងសេចក្តីស្រឡាញ់សើភាពរបស់ម៉ូរ៉ូណៃ ។ ព្រះអម្ចាស់បានពង្រឹងដល់សាសន៍នីហ្វៃ ហើយដោយរួមគ្នា ម៉ូរ៉ូណៃ ពេហូរ៉ាន និងប្រជាជនរបស់គេបានបង្ក្រាបពួកនិយមស្តេច និងពួកសាសន៍លេមិន ។ បន្ទាប់ពីសង្គ្រាមជាច្រើនមក សាសន៍នីហ្វៃបានទទួលនូវសេចក្តីសុខសាន្តម្តងទៀត ហើយហេលេមិនបានស្ថាបនាសាសនាចក្រជាថ្មី ។

មេរៀនដែលរួមមានជំពូកជាច្រើន

នៅពេលមេរៀនមួយរួមមានជំពូកជាច្រើននៅក្នុងព្រះគម្ពីរ អ្នកមិនចាំបាច់ផ្តល់ការបញ្ជាក់ជាដែលៗចំពោះអ្វីៗដែលមាននៅក្នុងជំពូកទាំងនោះទេ ។ អ្នកអាចសង្ខេបផ្នែកនៃវគ្គព្រះគម្ពីរ ហើយបន្ទាប់មកសូមចំណាយពេលបន្ថែមលើផ្នែកនៃវគ្គណាដែលទាក់ទងជាពិសេសទៅនឹងសិស្សរបស់អ្នក ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៥៩

សាសន៍នីហ្វៃបាត់បង់តំបន់ការពារមួយ ហើយមេទ័ពម៉ូរ៉ូណៃកើតទុក្ខដោយសារតែអំពើទុច្ចរិតនៃប្រជាជន

មុនចាប់ផ្តើមថ្នាក់ សូមសរសេរនៅលើក្តារខៀននូវសេចក្តីថ្លែងការណ៍ដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន (ពី *The Teachings of Ezra Taft Benson* | ឆ្នាំ ១៩៨៨ |, ទំព័រ ២៨៥) ៖

« វាប្រសើរជាងដើម្បីរៀបចំ និងការពារជាជាងព្យាបាលហើយប្រែចិត្ត » (ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន) ។

អ្នកអាចដកស្រង់សេចក្តីថ្លែងការណ៍នេះជាផ្នែកនៃមេរៀនសម្រាប់ អាលម៉ា ៤៩–៥១ ។ ប្រសិនបើអ្នកធ្វើដូច្នេះ សូមគិតពីការទុកចន្លោះនៅកន្លែង៣ក្យខ្លះ នៅពេលអ្នកសរសេរវានៅលើក្តារខៀន ។ សូមឲ្យសិស្សបំពេញចន្លោះទាំងនោះ ។

សូមឲ្យសិស្សប្រាប់ពីពេលវេលានៅក្នុងជីវិតរបស់គេ ឬនៅក្នុងជីវិតរបស់នរណាម្នាក់ដែលគេស្គាល់ នៅពេលការរៀបចំបានជួយការពារកុំឲ្យមានការអន់ចិត្ត ឬស្តាយក្រោយ ។

សូមរំឭកសិស្សថា នៅក្នុងមេរៀនថ្មីៗនេះ ពួកគេបានសិក្សាជំពូកអំពីសង្គ្រាមរវាងសាសន៍នីហ្វៃ និងសាសន៍លេមិន សូមឲ្យសិស្សអាន អាលម៉ា ៥៩:៥–១១ ដោយស្ងាត់ៗដោយគិតអំពីរបៀបដែលប្រយោគនៅលើក្តារខៀនទាក់ទងនឹងស្ថានភាពដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ ។

- **តើអ្វីខ្លះដែលមើលទៅហាក់អាចឲ្យសាសន៍លេមិនយកឈ្នះលើទីក្រុងនីហ្វៃហា ? (ភាពទុច្ចរិតនៃប្រជាជននីហ្វៃហា ។)**
- **តើអ្នកបានរកឃើញអ្វីនៅក្នុងខគម្ពីរទាំងនេះដែលជាប់ទាក់ទងនឹងប្រយោគដែលសរសេរនៅលើក្តារខៀន ?**

ប្រសិនបើសិស្សមិនបានឆ្លើយនឹងប្រយោគខាងក្រោមនៅក្នុង អាលម៉ា ៥៩:៩ ទេ សូមបង្ហាញថាដល់ពួកគេ ៖ « វាជាការងាយក្នុងការក្សាកុំឲ្យទីក្រុងនោះធ្លាក់ទៅក្នុងកណ្តាប់ដៃនៃពួកសាសន៍លេមិន ជាងវាយយកវាពីពួកគេមកវិញ » ។ អ្នកអាចស្នើថា សិស្សគួរគូសចំណាំប្រយោគនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។ ដើម្បីជួយសិស្សឲ្យគិតអំពីរបៀបដែលសេចក្តីពិតនេះអាចអនុវត្តនៅក្នុងជីវិតរបស់ពួកគេ សូមឲ្យពួកគេប្រៀបធៀបទីក្រុងទាំងឡាយនៅក្នុងរឿងនេះទៅនឹងខ្លួនគេ និងសង្គ្រាមខាងវិញ្ញាណដែលគេជួប ។ បន្ទាប់មក សូមសួរសំណួរខាងក្រោមមួយ ឬពីរ ៖

- **តើសេចក្តីពិតនេះទាក់ទងនឹងយើងដោយរបៀបណា ? (សូមជួយសិស្សឲ្យឃើញថា *វាជាការងាយស្រួលជាងដើម្បីនៅបន្តស្មោះត្រង់ជាជាងត្រឡប់ទៅមានសេចក្តីជំនឿក្រោយពីបានវង្វេងចេញ*) ។**
- **តើហេតុអ្វីបានជាការនៅស្មោះត្រង់នៅក្នុងសាសនាចក្រងាយស្រួលជាងការត្រឡប់មកកាន់សាសនាចក្រ ក្រោយពីមួយរយៈពេលនៃការអសកម្ម ?**
- **ហេតុអ្វីបានជាវាងាយស្រួលជាងដើម្បីមានទីបន្ទាល់មួយជាជាងការទទួលបានទីបន្ទាល់មួយថ្មីក្រោយពីការធ្លាក់ចេញនោះ ?**

សូមឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលអារក្ស និងអ្នកដើរតាមវាអាចវាយប្រហារលើទីបន្ទាល់ទាំងនោះ ។ សូមលើកទឹកចិត្តឲ្យពួកគេសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពីអ្វីដែលពួកគេនឹងធ្វើដើម្បីរៀបចំចំពោះសង្គ្រាមខាងវិញ្ញាណ ។

អាលម៉ា ៦០–៦២

ម៉ូរ៉ូនៃបានចោទប្រកាន់ដោយខុសឆ្គងលើពេហូរ៉ាន ដែលឆ្លើយតបដោយសេចក្តីស្រឡាញ់ និងគោរព

សូមអានអាលម៉ា ៥៩:១៣ឮៗ ។ សូមប្រាកដថាសិស្សយល់ថា ម៉ូរ៉ូនៃបានខឹងដោយសារគាត់បានគិតថា រដ្ឋាភិបាលមិនខ្វល់ខ្វាយនឹងសេរីភាពរបស់ប្រជាជន ។ ដោយមានកំហឹង គាត់បានសរសេរសំបុត្រមួយទៅពេហូរ៉ាន ជាមេចៅក្រមនៅក្នុងដែនដីសារ៉ាហិមឡា ។ សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៦០:៦–១១ ។

- តើមេទ័ពម៉ូរ៉ៃណាបានចោទប្រកាន់ពេហូរ៉ាំពីអ្វី ?
- តើអារម្មណ៍អ្វីដែលអ្នកឃើញក្នុងការចោទប្រកាន់របស់ម៉ូរ៉ៃណ ?

សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖ *អាលម៉ា ៦០:១៧–២០, ២៣–២៤* ។សូមឲ្យសិស្សអានខគម្ពីរទាំងនេះដោយស្ងាត់ៗ ។ សូមលើកទឹកចិត្តគេឲ្យស្រមៃពីអារម្មណ៍ដែលពួកគេមាន បើគេស្ថិតនៅក្នុងតំណែងរបស់ព្ធហោរ៉ាន ។

- តើការចោទប្រកាន់របស់មេទ័ពម៉ូរ៉ៃណអាចធ្វើឲ្យពេហូរ៉ានឈឺចាប់យ៉ាងណា ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អាលម៉ា ៦០:៣៣–៣៦ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលមេទ័ពម៉ូរ៉ៃណបានរៀបចំធ្វើ ប្រសិនបើពេហូរ៉ានមិនឆ្លើយនឹងសំណើររបស់គាត់ដោយសមស្របទេនោះ ។ ក្រោយពីឲ្យសិស្សរៀបរាប់អ្វីដែលពួកគេរកឃើញហើយ សូមឲ្យពួកគេរកមើលពាក្យ ឬឃ្លានៅក្នុងខគម្ពីរទាំងនេះដែលបង្ហាញពីមូលហេតុ ឬការជម្រុញរបស់ម៉ូរ៉ៃណក្នុងការធ្វើសំណើរនេះ: ។

សូមឲ្យសិស្សអាន អាលម៉ា ៦១:១–៥ ដោយស្ងាត់ៗដោយរកមើលមូលហេតុដែលម៉ូរ៉ៃណមិនបានទទួលការពង្រឹង ។

- តើព័ត៌មានអ្វីខ្លះដែលពេហូរ៉ានបានចែកចាយនឹងម៉ូរ៉ៃណ ?
- តើប្រជាជនបានឆ្លើយតប នៅពេលពួកគេបានចោទប្រកាន់អ្វីមួយខុសឆ្គង ដោយរបៀបណា ?
- តើអ្នកធ្លាប់ចោទប្រកាន់អ្វីមួយដោយខុសឆ្គងទេ ? តើអ្នកមានអារម្មណ៍យ៉ាងណាអំពីការចោទប្រកាន់នោះ: និងចំពោះអ្នកចោទប្រកាន់គេនោះ: ?

សូមឲ្យសិស្សអាន អាលម៉ា ៦១:៩–១០, ១៥–១៨ ដោយស្ងាត់ៗដោយរកមើលអ្វីដែលបង្ហាញពីភាពអស្ចារ្យនៃអាកប្បកិរិយារបស់ពេហូរ៉ាន ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីដែលពួកគេរកឃើញ ។

- តើមេរៀនអ្វីដែលយើងអាចរៀនពីរបៀបដែលពេហូរ៉ានបានឆ្លើយតបនឹងការចោទប្រកាន់របស់ម៉ូរ៉ៃណ ? (សូមជួយសិស្សឲ្យរកឃើញនូវគោលការណ៍ខាងក្រោម ៖ **យើងអាចជ្រើសរើសមិនប្រកាន់នឹងពាក្យសម្តី និងសកម្មភាពរបស់អ្នកដទៃ** ។សេចក្តីពិតផ្សេងទៀតដែលសិស្សអាចរកឃើញរួមមាន **យើងគួរចៀសវាងការកាត់សេចក្តីមិនល្អអំពីអ្នកដទៃ** ហើយថា **នៅពេលយើងរួមរួមដោយសេចក្តីសុចរិតនឹងអ្នកដទៃ យើងនឹងរឹងមាំជាងមុននៅក្នុងសង្គ្រាមរបស់យើងប្រឆាំងនឹងអារក្ស** ។អ្នកអាចសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ។)
- តើយើងអាចជ្រើសរើសមិនប្រកាន់គេវិញដោយរបៀបណា ?

សូមគិតពីការសួរសិស្សថាតើពួកគេនឹងចែកចាយបទពិសោធន៍ខ្លះៗដែលពួកគេបានមាននៅក្នុងការជ្រើសរើសមិនប្រកាន់ នៅពេលមនុស្សបាននិយាយអ្វីមិនល្អ ឬមិនពិតអំពីពួកគេ ។ អ្នកក៏អាចគិតពីការប្រាប់អំពីបទពិសោធន៍មួយរបស់អ្នកផ្ទាល់ដែរ ។ សូមថ្លែងទីបន្ទាល់អំពីសារសំខាន់នៃការអភ័យទោសដល់អ្នកដទៃចំពោះសម្តី ឬអាកប្បកិរិយាទាស់នឹងយើង ។ សូមលើកទឹកចិត្តឲ្យសិស្សធ្វើតាមគំរូរបស់ពេហូរ៉ាន ។

សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៦២:១ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលអារម្មណ៍ដែលម៉ូរ៉ៃណមាន នៅពេលគាត់បានទទួលចម្លើយពីពេហូរ៉ាន ។

សូមពន្យល់ថា ទោះបីជាមេទ័ពម៉ូរ៉ៃណបានខុសក្នុងការចោទប្រកាន់ពេហូរ៉ានក្តី ក៏គាត់បានបង្រៀនគោលការណ៍ពិតដែលយើងអាចអនុវត្តនៅក្នុងជីវិតរបស់យើងដែរ ។ សូមឲ្យសិស្សម្នាក់អាន អាលម៉ា ៦០:២៣ ឮៗ ។ សូមបង្ហាញថា ពាក្យសម្តីរបស់ម៉ូរ៉ៃណអំពីការលាង « ខាងក្នុងប្រដាប់ » អាចអនុវត្តដល់គ្រប់គ្នាដែលត្រូវប្រែចិត្ត ។ សូមពន្យល់ថា ប្រដាប់មួយ គឺជាប្រដាប់ដាក់ទឹក ដូចជាពែង ឬចានគោម ។ សូមដាក់ដី ឬភក់ទៅក្នុង និងប៉ាតលើខាងក្រៅពែងមួយ (បើមាន សូមយកពែងថ្លាដែលអាចមើលឃើញ) ។ សូមសួរសិស្សថា តើពួកគេនឹងផឹកទឹកពីពែងនោះទេ ។ សូមសម្អាតខាងក្រៅពែង ហើយសូមសួរសិស្សថា តើពួកគេនឹងព្រមផឹកទឹកពីពែងនោះទេ ។

- ប្រសិនបើពួកគេគិតថាខ្លួនយើងគឺជាដូចជាពែងនោះ: តើវាអាចមានន័យយ៉ាង ដើម្បីលាងប្រដាប់ខាងក្នុង ឬពែងខាងក្នុងនោះ: ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះ: ដែលថ្លែងដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន ៖

« យើងត្រូវតែសម្អាតប្រដាប់ខាងក្នុង (សូមមើល អាលម៉ា ៦០:២៣) ដោយចាប់ផ្តើមដំបូងពីខ្លួនយើង បន្ទាប់មកគ្រួសារយើង ហើយទីបញ្ចប់ជាមួយនឹងសាសនាចក្រ » (« Cleansing the Inner Vessel »*Ensign,*ខែ ឧសភា ឆ្នាំ ១៩៨៦, ទំព័រ ៤) ។

- ហេតុអ្វីបានជាវាសំខាន់ដែលយើងត្រូវស្អាតខាងក្នុង (ជាអ្វីដែលមនុស្សមិនអាចមើលឃើញ) ក៏ដូចជាខាងក្រៅ (ជាអ្វីដែលមនុស្សអាចមើលឃើញ) ?
- ហេតុអ្វីបានជាវាសំខាន់ដើម្បីសម្អាតប្រដាប់ខាងក្នុងជីវិតរបស់យើង មុនពេលយើងអាចមានប្រសិទ្ធិភាពពេញលេញនៅក្នុងនគររបស់ព្រះអម្ចាស់ ?

សូមសង្ខេប អាលម៉ា ៦២:១–៣៨ ដោយការពន្យល់ថា មេទ័ពម៉ូរ៉ៃណបាននាំផ្នែកមួយនៃកងទ័ពរបស់គាត់ទៅជួយពេហូរ៉ានដើម្បីបង្ក្រាបពួកនិយមស្តេចនៅក្នុងដែនដីសារ៉ាហិមឡា ។ បន្ទាប់មក ដោយមានកងទ័ពរួបរួមគ្នា និងជំនួយពីកងកម្លាំងរបស់សាសន៍នីហ្វៃដទៃទៀត ម៉ូរ៉ៃណ និងពេហូរ៉ានបានវាយយកទីក្រុងផ្សេងទៀតដែលបានបាត់បង់លើសាសន៍លេមិនមកវិញ ។ ពួកគេបានបណ្តេញសាសន៍លេមិនចេញពីដែនដី ហើយកសាងសន្តិភាពក្នុងចំណោមប្រជាជន ។

- តើឧបសគ្គណាខ្លះដែលបុគ្គល និងគ្រួសារជាច្រើនអាចជួបក្រោយពីពេលមានសង្គ្រាម ?

សូមឲ្យសិស្សអាន អាលម៉ា ៦២:៣៩–៤១ ដោយស្ងាត់ៗដើម្បីរកមើលរបៀបដែលសាសន៍នីហ្វៃបានប៉ះពាល់ដោយឧបសគ្គនៃសង្គ្រាម ។

- តើគោលការណ៍អ្វីដែលអ្នកអាចរកឃើញនៅក្នុង អាលម៉ា ៦២:៤០–៤១ ?

នៅពេលសិស្សពិភាក្សាពីសំណួរនេះ ពួកគេអាចឆ្លើយដូចតទៅ ៖

ការអធិស្ឋានដ៏សុចរិតរបស់យើងអាចមានឥទ្ធិពលដ៏វិជ្ជមានមួយដល់សហគមន៍របស់យើង ។

នៅក្នុងពេលមានឧបសគ្គ មនុស្សខ្លះបន្ទាបខ្លួនគេចំពោះមុខព្រះ ខណៈពេលអ្នកដទៃបានរឹងទទឹង ។

- តើអ្នកគិតថា ហេតុអ្វីបានជាមនុស្សខ្លះខិតកាន់តែជិតទៅព្រះអម្ចាស់ នៅពេលពួកគេជួបនឹងឧបសគ្គនានា ? ហេតុអ្វីបានជាមនុស្សខ្លះបែរចេញពីព្រះអម្ចាស់ នៅពេលពួកគេជួបនឹងឧបសគ្គនានា ? (សូមជួយសិស្សឲ្យយល់ថា នៅក្នុងពេលមានឧបសគ្គ ជម្រើសរបស់យើងសម្រេចថាតើយើងនឹងខិតកាន់តែជិតទៅព្រះអម្ចាស់ឬយ៉ាងណា) ។
- នៅពេលអ្នកអានជំពូកក្នុងព្រះគម្ពីរមរមនអំពីសង្គ្រាម តើពួកគេបានបង្រៀនអ្នកអំពីការក្លាយជាកូនសិស្សរបស់ព្រះយេស៊ូវគ្រីស្ទក្នុងពេលមានសង្គ្រាម ឬការទាស់ទែងគ្នាអ្វីខ្លះ ?

អាលម៉ា ៦៣

សាសន៍នីហ្វៃជាច្រើនធ្វើដំណើរទៅកាន់ដែនដីភាគខាងជើង

សូមសង្ខេបពាក្យសម្តីរបស់ម៉ូរ៉ំណៃនៅក្នុងជំពូកនេះដោយការពន្យល់ថា សាសន៍នីហ្វៃជាច្រើនបានចាប់ផ្តើមភៀសខ្លួនទៅភាគខាងជើងក្បែរដែនដី និងក្បែរសមុទ្រ ។ សិបឡុនបានប្រគល់កំណត់ត្រាដ៏ពិសិដ្ឋដល់ហេលេមិន ។ មេទ័ពម៉ូរ៉ំណៃបានស្លាប់ ហើយកូនប្រុសរបស់គាត់ ម៉ូរ៉ំណៃហា បានដឹកនាំកងទ័ពដែលបង្ក្រាបការវាយប្រហាររបស់សាសន៍លេមិនម្តងទៀត ។

អ្នកអាចបញ្ចប់មេរៀននេះដោយការប្រាប់អំពីនរណាម្នាក់ដែលបានជួបនឹងឧបសគ្គ និងការរងទុក្ខ ហើយបានជ្រើសរើសបន្ទន់ដួងចិត្ត ហើយបង្កើនការទុកចិត្តលើព្រះ ។ សូមគិតពីការចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនមួយ ។

ការរំឭកអាលម៉ា

សូមចំណាយពេលខ្លះដើម្បីជួយសិស្សឲ្យរំឭកគម្ពីរអាលម៉ា ។ សូមឲ្យពួកគេគិតអំពីអ្វីដែលពួកគេបានរៀនពីគម្ពីរនេះ ទាំងក្នុងថ្នាក់សិក្ខាសាលា និងនៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់គេ ។ ប្រសិនបើចាំបាច់ សូមឲ្យពួកគេរំឭកសេចក្តីសង្ខេបជំពូកខ្លះនៅក្នុងអាលម៉ាដើម្បីជួយពួកគេឲ្យចងចាំ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបីបួននាក់ចែកចាយពីគំនិត និងអារម្មណ៍របស់គេអំពីអ្វីដែលគម្ពីរនេះបានធ្វើឲ្យពួកគេរំភើប ។

មេរៀនសិក្សានៅផ្ទះ

អាលម៉ា ៤៥–៦៣ (មេរៀនទី ២១)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេសិក្សា អាលម៉ា៤៥–៦៣(មេរៀនទី ២១) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (អាលម៉ា ៤៥–៤៩)

អាលម៉ាបានពន្យល់ដល់កូនប្រុសរបស់គាត់ថា ព្រះអម្ចាស់មិនអាចទតមើលអំពើបាបសូម្បីតែបន្តិចបន្តួចឡើយ ។ ដោយការប្រៀបធៀបសង្គ្រាមនៃសាសន៍នីហ្វៃនឹងសង្គ្រាមផ្ទាល់ខ្លួនរបស់គេ សិស្សបានរៀនពីសេចក្តីពិតខាងក្រោម ៖ នៅពេលយើងក្លាហានក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយដូចជាមេទ័ពមរ៉ូណៃបានធ្វើ ព្រះនឹងពង្រឹងនិងប្រទានពរដល់យើង ។ សាតាំងចង់បំផ្លាញយើង ហើយវាទាក់ទាញយើងដោយបន្តិចម្តងៗឲ្យយើងបន្ទាបបទដ្ឋានរបស់យើង ។

ថ្ងៃទី ២ (អាលម៉ា ៥០–៥២; ៥៤–៥៥)

ទោះបីជាសាសន៍នីហ្វៃបានរីកចម្រើនក្នុងមួយរយៈពេលក្រោយពីការចាកចេញរបស់អាម៉ាលិកាយ មរ៉ូណៃបានបន្តរៀបចំប្រជាជនសម្រាប់ការវាយលុកនាពេលអនាគត ។ គំរូរបស់សាសន៍នីហ្វៃអំឡុងពេលមានការលំបាក បានជួយសិស្សឲ្យយល់ថា ភាពស្មោះត្រង់នឹងព្រះនាំមកនូវសុភមង្គល ទោះបីជាពួកគេនៅកណ្តាលភាពច្របូកច្របលល់ក្តី —ប៉ុន្តែការបែកបាក់ និងការទាស់ទែងគ្នាអាចបំផ្លាញសន្តិភាពរបស់យើង ។ សិស្សក៏បានរៀនដែរថា នៅពេលយើងឈរដោយរឹងមាំចំពោះអ្វីដែលត្រូវ យើងអាចរាវាំងតទ្ធិពលដ៏អាក្រក់ពីការមានអំណាចមកលើយើង ។

ថ្ងៃទី ៣ (អាលម៉ា ៥៣; ៥៦–៥៨)

អំឡុងពេលដ៏លំបាកបំផុតខ្លះក្នុងសង្គ្រាម ហេលេមិនបានដឹកនាំកងទ័ពយុវជនរបស់គាត់ដែលជាប្រជាជនអាំម៉ូន ។ កងពលកំឡោះទាំងនេះបានបង្ហាញថា នៅពេលយើងធ្វើសកម្មភាពដោយសេចក្តីជំនឿ យើងអាចទទួលបានកម្លាំងពីព្រះ ។ សិស្សបានរៀនពីគំរូនៃកងពលដ៏ក្លាហានទាំងនេះថា ប្រសិនបើយើងទុកចិត្តលើព្រះអម្ចាស់ ហើយគោរពដល់ទ្រង់ដោយតតណ្ឌៀង ទ្រង់នឹងគាំទ្រយើងនៅក្នុងសង្គ្រាមរបស់យើង ។ ទោះបីជាមានអ្នករបួសជាច្រើន និងមានការលំបាកជាច្រើនដែលពួកគេបានទទួល និងតស៊ូ ក៏កងទ័ពសាសន៍នីហ្វៃ និងកងពលកំឡោះនៅតែបង្ហាញថា ប្រសិនបើយើងបែរទៅរកព្រះក្នុងពេលលំបាក យើងអាចទទួលបានការធានាពីស្ថានសួគ៌ដែលអាចពង្រឹងសេចក្តីជំនឿរបស់យើង និងផ្តល់សេចក្តីសង្ឃឹមដល់យើង ។

ថ្ងៃទី ៤ (អាលម៉ា ៥៩–៦៣)

ដោយសារតែការបះបោរផ្ទៃក្នុង សាសន៍នីហ្វៃបានបាត់បង់ទីក្រុងជាច្រើន ; ការណ៍នេះបង្ហាញដល់សិស្សថា វាងាយស្រួលក្នុងការបន្តស្មោះត្រង់ជាងការត្រឡប់មកមានសេចក្តីជំនឿក្រោយពីការដើរវង្វេង ។ មរ៉ូណៃបានចោទប្រកាន់ដោយមិនបានដឹងលើមេចៅក្រមពេហូរ៉ាន ថាបានធ្វេសប្រហែសនឹងកាតព្វកិច្ចរបស់គាត់ ហើយសិស្សបានរៀនពីចម្លើយរបស់ពេហូរ៉ានថា យើងអាចជ្រើសរើសមិនប្រកាន់ខឹងនឹងពាក្យ និងសកម្មភាពរបស់អ្នកដទៃ ។ បន្ថែមលើនេះ សិស្សបានរៀនថា នៅពេលយើងរួបរួមគ្នាក្នុងសេចក្តីសុចរិតជាមួយនឹងអ្នកដទៃ យើងនឹងរឹងមាំជាងនេះនៅក្នុងសង្គ្រាមប្រឆាំងនឹងអំពើអាក្រក់របស់យើង ដូចដែលបានបង្ហាញដោយមរ៉ូណៃ និងពេហូរ៉ាន ។

សេចក្តីផ្តើម

ដោយសារមេរៀននេះរួមមាន១៩ នៃគម្ពីរអាលម៉ា អ្នកមិនអាចបង្រៀន ឬបញ្ជាក់បរិបទប្រវត្តិសាសន៍ទាំងអស់ និងគោលលទ្ធិ និងគោលការណ៍ទាំងអស់ឲ្យសិស្សបានរៀនពេញមួយសប្តាហ៍នេះបានទេ ។ យោបល់ក្នុងការបង្រៀនខាងក្រោមផ្តល់ឱកាសដល់សិស្សឲ្យអនុវត្តសេចក្តីពិត ដែលពួកគេបានរៀនពីការសិក្សាសង្គ្រាមសាសន៍នីហ្វៃទៅនឹងសង្គ្រាមនៅក្នុងជីវិតរបស់គេផ្ទាល់ ។ សូមសិក្សាព្រះគម្ពីរសម្រាប់មេរៀនេះប្រកបដោយការអធិស្ឋាន ដើម្បីឲ្យអ្នកអាចត្រូវបានបំផុសឲ្យបញ្ជាក់លើសេចក្តីពិតណាដែលសិស្សត្រូវការផ្តោតលើពេលរៀនក្នុងថ្នាក់ ។

យោបល់សម្រាប់ការបង្រៀន

អាលម៉ា ៤៥–៦៣

ដោយការទុកចិត្តលើព្រះ និងការធ្វើតាមអ្នកដឹកនាំដែលទទួលបានការបំផុសគំនិតសាសន៍នីហ្វៃអាចយកឈ្នះលើសាសន៍លេមិន

សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អែសរ៉ា ថាហ្ វ ប៊ែនសឹន នៅលើក្តារខៀន មុនចាប់ផ្តើមបង្រៀន ៖ « *ពីព្រះគម្ពីរមរមន យើងរៀនពីរបៀបដែលសិស្សរបស់ព្រះគ្រីស្ទរស់នៅក្នុងពេលមានសង្គ្រាម* » (“The Book of Mormon—Keystone of Our Religion,” *Ensign*,ខែ វិច្ឆិកា ឆ្នាំ ១៩៨៦,ទំព័រ ៧) ។

សូមឲ្យសិស្សសរសេរឈ្មោះសង្គ្រាមខ្លះ នៃប្រទេសដែកគេរស់នៅបានធ្វើ ។ បន្ទាប់មក សូមឲ្យពួកគេដាក់ឈ្មោះឧបសគ្គខ្លះដែលមនុស្សអាចជួបអំឡុងពេលសង្គ្រាម ។

សូមសួរ ៖ ហេតុអ្វីបានជាវាពិបាកដើម្បីក្លាយជាសិស្សនៃព្រះយេស៊ូវគ្រីស្ទអំឡុងពេលមានសង្គ្រាម ?

សូមឲ្យសិស្សគិតអំពីសង្គ្រាមដែលពួកគេបានសិក្សាពីសប្តាហ៍កន្លងទៅ ដូចដែលបានកត់ត្រានៅក្នុង អាលម៉ា ៤៥–៦៣ ។ អ្នកអាចលើកទឹកចិត្តពួកគេឲ្យរំឲ្យកខ្លីៗពីសេចក្តីសង្ខេបជំពូកក្នុង អាលម៉ា ៤៥–៦៣ ។ សូមឲ្យពួកគេដាក់ឈ្មោះឧបសគ្គខ្លះដែលសាសន៍នីហ្វៃបានជួបនៅក្នុងសង្គ្រាម ។

សូមរំឲ្យកសិស្សថា ទោះបីជាយើងមិនដែលច្បាំងនឹងសង្គ្រាមមែនទែនក្តី យើងទាំងអស់គ្នាស្ថិតនៅក្នុងសង្គ្រាមខាងវិញ្ញណា ។ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ដែលបានរៀបរាប់សង្គ្រាមខាងវិញ្ញាណដែលយើងកំពុងធ្វើ ។ អ្នកអាចចែកច្បាប់ចម្លងដល់សិស្សម្នាក់ៗ ។

« អ្នកបានចូលជួរទ័ពរបស់ព្រះអម្ចាស់នៅក្នុងសម័យកាន់កាប់ត្រូតត្រាលើកចុងក្រោយ ។ នេះមិនមែនជាពេលមានសន្តិភាពមួយទេ ។ វាបានក្លាយជាដូច្នេះ តាំងពីសាតាំងបានប្រមូលកម្លាំងរបស់វាប្រឆាំងនឹងផែនការរបស់ព្រះវរបិតាសួគ៌នៅក្នុងជីវិតមុនជីវិតលើផែនដីនេះ ។ យើងមិនដឹងពីសេចក្តីលម្អិតនៃការប្រយុទ្ធនោះទេ ។ ប៉ុន្តែយើងដឹងពីលទ្ធផលមួយ ។ សាតាំង និងអ្នកដើរតាមវាត្រូវបានបណ្តេញចុះមកលើផែនដី ។ ហើយតាំងពីការបង្កើតអ័ដាម និងអេវ៉ា វិបត្តិនេះនៅតែបន្ត ។ យើងបានឃើញវាកាន់តែរីកខ្លាំងទៅ ។ ហើយព្រះគម្ពីរបានប្រាប់ថា សង្គ្រាមនឹងកាន់តែហិង្សាទៅ ហើយការចលាចលខាងវិញ្ញាណនៅខាងព្រះអម្ចាស់នឹងជុះកាន់តែខ្លាំង » (« Man Down! » *Ensign*ឬ*លេអាហូណា*,ខែ ឧសភា ឆ្នាំ ២០០៩,ទំព័រ ៦៣) ។

សូមឲ្យសិស្សយោងទៅសេចក្តីថ្លែងការណ៍ដោយប្រធាន ប៊ែនសឹន នៅលើក្តារខៀន ។ សូមប្រាប់ពួកគេថា មិនថាយើងកំពុងនិយាយអំពីសង្គ្រាមខាងរាងកាយ ឬ សង្គ្រាមខាងវិញ្ញាណទេ សេចក្តីថ្លែងការណ៍នេះគឺពិត ។ សូមពន្យល់ថា ដោយការសិក្សាពីជីវិតនៃសិស្សទាំងឡាយ ដែលបានរស់នៅក្នុងពេលសង្គ្រាមនៅក្នុងជំនាន់ព្រះគម្ពីរមរមនអាចជួយយើងឲ្យមានចរិត ដែលនឹងសំខាន់នៅក្នុងសង្គ្រាមខាងវិញ្ញាណរបស់យើងផ្ទាល់កាន់តែខ្លាំង ។

សូមសរសេរឈ្មោះខាងក្រោម និងសេចក្តីយោងព្រះគម្ពីរនៅលើក្តារខៀន ឬរៀបចំវាជាក្រដាសមួយ ។ សូមឲ្យសិស្សរើសយកបុគ្គលឬជាក្រុមទាំងនេះមួយដើម្បីសិក្សា ។ សូមឲ្យសិស្សសិក្សាពីបុគ្គល ឬក្រុមនីមួយៗយ៉ាងហោចណាស់មួយ ។

១. មរ៉ូណៃ—អាលម៉ា ៤៦:១១–២១; ៤៨:៧–១៧

២. ហេលេមិន—អាលម៉ា ៤៨:១៩–២០; ៥៦:២–៥; ៥៨:៤–១២, ៣២–៣៧

៣. កងពលកំឡោះ ២,០៦០—អាលម៉ា ៥៣:១៦–២២; ៥៦:៤៧–៥៦; ៥៧:១៩–២៧

៤. ពេហូរ៉ាន—អាលម៉ា ៥០:៣៥–៤០; ៥១:១–៧; ៦១:១–២១

សូមឲ្យសិស្សមានពេលខ្លះដើម្បីសិក្សាព្រះគម្ពីរកាន់តែច្រើនតាមដែលអាចធ្វើទៅបានអំពីបុគ្គល ឬក្រុមដែលពួកគេបានរើស ។ សូមឲ្យពួកគេរៀបចំដើម្បីបង្រៀនពីគំនិតខាងក្រោមដល់សិស្សក្នុងថ្នាក់ (អ្នកអាចសរសេរវានៅលើក្តារខៀន ឬចែកជាក្រដាសដល់សិស្ស) ៖

- ហេតុការណ៍មួយពីជីវិតនៃបុគ្គល ឬក្រុមនេះដែលបង្ហាញថា ប្រជាជនគឺជាសិស្សដ៏ពិតរបស់ព្រះអង្គសង្គ្រោះ ។
- លក្ខណៈសម្បត្តិមួយ ឬច្រើននៃបុគ្គល ឬក្រុមនេះដែលជួយពួកគេឲ្យនៅបន្តក្លាហានក្នុងពេលមានសង្គ្រាមជាមួយនឹងសាសន៍លេមិន ។
- គោលការណ៍មួយនៃជំនឿល្អដែលយើងអាចរៀនពីបុគ្គល ឬក្រុមនេះដែលអាចពង្រឹងយើងនៅក្នុងសង្គ្រាមខាងវិញ្ញាណរបស់យើងនាសព្វថ្ងៃនេះ ។

សូមឲ្យសិស្សជាច្រើនតាមដែលអាចធ្វើទៅបាន ចែកចាយអ្វីដែលពួកគេបានរៀនជាមួយនឹងសិស្សក្នុងថ្នាក់ ។ អ្នកអាចសុំឲ្យសិស្សសរសេរគោលការណ៍ជំនឿល្អដែលពួកគេបានរៀននៅលើក្តារខៀន ។

សូមគិតពីការស្នើសុំល្អខាងក្រោមដើម្បីជួយសិស្សឲ្យអនុវត្តអ្វីដែលពួកគេបានរៀនពីការសិក្សារបស់គេនៅក្នុងអាលម៉ា ៤៥–៦៣ ៖

- សូមគិតអំពីគុណសម្បត្តិនៃសិស្សរបស់ព្រះយេស៊ូវគ្រីស្ទម្នាក់ដែលអ្នកបានឃើញនៅក្នុងមនុស្សដែលបានរស់នៅអំឡុងពេលមានសង្គ្រាមនឹងសាសន៍លេមិន ។ តើគុណសម្បត្តិអ្វីខ្លះដែលអ្នកនឹងធ្វើតាមនៅក្នុងជីវិតរបស់អ្នក ? ហេតុអ្វី ?
- តើសង្គ្រាមខាងវិញ្ញាណណាខ្លះ ដែលយើងជួបនាពេលសព្វថ្ងៃនេះ ? តើគំរូនៃសិស្សរបស់ព្រះអង្គសង្គ្រោះទាំងនេះអាចជួយអ្នកឲ្យមានសេចក្តីជំនឿ និងទំនុកចិត្ត នៅពេលអ្នកជួបនឹងសង្គ្រាមទាំងនេះដោយរបៀបណា ?

អ្នកអាចចែកចាយវគ្គដែលអ្នកចូលចិត្តមួយពី អាលម៉ា ៤៥–៦៣ ។ សូមថ្លែងទីបន្ទាល់ថា គោលការណ៍ដែលយើងរៀនពីជំពូកទាំងនេះអាចជួយយើងឲ្យក្លាយជាសិស្សដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទអំឡុងពេលមានសង្គ្រាមខាងវិញ្ញាណនៅសម័យចុងក្រោយនេះ ។

មេរៀនបន្ទាប់ (ហេលេមិន ១–៩)

សូមប្រាប់សិស្សថា ជំពូកជំបូងនៃគម្ពីរហេលេមិនកត់ត្រាពីការស្លាប់របស់មេចៅក្រមបីរូប ។ សូមប្រាប់ពួកគេថា ពួកគេនឹងរកចម្លើយចំពោះសំណួរខាងក្រោម ៖ តើចៅក្រមទាំងនេះស្លាប់ដោយរបៀបណា ? តើអព្ភូតហេតុអ្វីបានកើតឡើងដល់នីហ្វៃ និងលីហៃ នៅពេលពួកគេនៅក្នុងគុក ? តើពួកគេបានឮសំឡេងរបស់អ្នកណា ? សូមប្រាប់សិស្សថា ព្យាការីនីហ្វៃអាចជោះស្រាយឃាតកម្មមួយតាមរយៈអំណាចនៃការព្យាករណ៍ ។

សេចក្តីផ្តើមអំពី

គម្ពីរហេលេមិន

ហេតុអ្វីបានជាត្រូវសិក្សាគម្ពីរនេះ ?

នៅក្នុងការសិក្សាគម្ពីរហេលេមិនរបស់ពួកគេ សិស្សនឹងរៀនពីគំរូ និងការបង្រៀននៃបុរសដ៏អស្ចារ្យដូចជា ហេលេមិន កូនប្រុសរបស់គាត់គឺ នីហ្វៃ និងលីហៃ និង សាំយូអែលជាសាសន៍លេមិនដែលបានគោរពតាមព្រះអម្ចាស់យ៉ាងអង់អាចក្លាហាន ហើយបានថ្លែងទីបន្ទាល់ពីទ្រង់ ។ ការបម្រើរបស់បុរសទាំងនេះបង្ហាញថា ព្រះប្រទានអំណាចដើម្បីជួយពួកអ្នកបម្រើរបស់ទ្រង់ឲ្យសម្រេចបានព្រះរាជបំណងរបស់ទ្រង់ ហើយថាការខិតខំរបស់មនុស្សសុចរិតអាចប្រទានពរដល់មនុស្សរាប់ពាន់នាក់ ។ សិស្សក៏នឹងរៀនផងដែរអំពីសេចក្តីបំផ្លិចបំផ្លាញដែលកើតមានមកពីភាពឆ្មើងឆ្មៃ អំពើទុច្ចរិត និង បក្សពួកសម្ងាត់ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

មរមន បានចងក្រង និងសង្ខេបកំណត់ត្រាជាច្រើនចេញពីផ្នាំងចំណារជំរបស់នីហ្វៃដើម្បីបង្កើតគម្ពីរហេលេមិន ។ គម្ពីរនេះត្រូវបានដាក់ឈ្មោះតាមហេលេមិន ដែលជាកូនប្រុសរបស់ហេលេមិន និងជាចៅប្រុសរបស់អាលម៉ាជាកូន ។ ហេលេមិនបានទទួលកំណត់ត្រាពីសិបឡុន ជាឪពុកមា ហើយបានបម្រើជាមេចៅក្រមដ៏សុចរិតលើប្រជាជននីហ្វៃ ។ គាត់បានបង្រៀនកូនប្រុសរបស់គាត់ នីហ្វៃ និងលីហៃឲ្យកាន់តាមព្រះបញ្ញត្តិទាំងឡាយ ហើយចងចាំដល់ព្រះប្រោសលោះរបស់គេ ព្រមទាំងយកទ្រង់ធ្វើជាមូលដ្ឋាននៃជីវិតរបស់ពួកគេផងដែរ (សូមមើល ហេលេមិន ៥:៩–១៤) ។ ដោយបានបំផុសគំនិតតាមរយៈការបង្រៀនទាំងនេះ ហើយព្រួយបារម្ភអំពីអំពើទុច្ចរិតនៃប្រជាជន នោះ នីហ្វៃ និងលីហៃបានបង្រៀនពីការប្រែចិត្តដល់ប្រជាជននីហ្វៃ និងប្រជាជនលេមិន ។ ដើម្បីធ្វើកិច្ចការទាំងនោះ នីហ្វៃបានលះបង់តំណែងរបស់គាត់ជាមេចៅក្រម ។ ក្រោយពីសាសន៍លេមិនរាប់ពាន់បានប្រែចិត្តជឿហើយ មានព្យាការីសាសន៍លេមិនម្នាក់ឈ្មោះថា សាំយូអែល ត្រូវបានបំផុសគំនិតឲ្យបង្រៀនពីការប្រែចិត្ត និងការព្យាករណ៍ក្នុងចំណោមប្រជាជននីហ្វៃ ។ គម្ពីរហេលេមិនដកស្រង់ពីកំណត់ត្រាដែលបានរក្សានៅក្នុងរជ្ជកាល និងការបម្រើរបស់ហេលេមិន (ហេលេមិន ១–៣) និងនីហ្វៃ (ហេលេមិន ៤–១៦) ។ កំណត់ត្រារបស់នីហ្វៃរួមបញ្ចូលនូវការព្យាករណ៍ និងការបង្រៀនទាំងឡាយរបស់សាំយូអែលជាសាសន៍លេមិន ។

តើគម្ពីរនេះត្រូវបានសរសេរដល់នរណា ហើយហេតុអ្វី ?

មរមនបានកត់ត្រាគម្ពីរហេលេមិនសម្រាប់ប្រជាជននៅថ្ងៃចុងក្រោយដែលនឹងទទួលបានកំណត់ត្រារបស់គាត់ ។ ដូចជាសេចក្តីសង្ខេបផ្សេងទៀតរបស់គាត់ពីផ្នាំងចំណារជំរបស់នីហ្វៃដែរ គម្ពីរហេលេមិនថ្លែងទីបន្ទាល់អំពីបេសកកម្មដ៏ទេវភាព និងសេចក្តីប្រោសលោះរបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល ហេលេមិន ៣:២៧–៣០, ៥:៩–១២, ៨:១៣–២៣, ១៤:១–២៩, ១៦:៤–៥) ។

តើគម្ពីរនេះត្រូវបានសរសេរនៅពេលណា និងនៅកន្លែងណា ?

កំណត់ត្រាដើមត្រូវបានប្រើជាប្រភពនៃគម្ពីរហេលេមិន ទំនងជាត្រូវបានសរសេររវាងឆ្នាំ ៥២ មុន.គ.ស. និង ឆ្នាំ ១ មុន.គ.ស. ។ មរមនបានសង្ខេបកំណត់ត្រាទាំងនោះក្នុងចន្លោះពេលប្រហែលឆ្នាំ ៣៨៥ នៃ គ.ស.និង ឆ្នាំ ៣៨៥នៃ គ.ស ។ មរមនមិនបានកត់ត្រាពីទីកន្លែងដែលគាត់នៅ កាលគាត់បានចងក្រងគម្ពីរនេះទេ ។

តើមានលក្ខណៈពិសេសអ្វីខ្លះនៅក្នុងគម្ពីរនេះ ?

គម្ពីរហេលេមិនបង្ហាញពីការផ្លាស់ប្តូរដោយច្រើនលើកច្រើនសារបស់សាសន៍នីហ្វៃរវាងសេចក្តីសុចរិត និងអំពើទុច្ចរិត ជាង ពេលណាៗទាំងអស់នៅក្នុងប្រវត្តិសាសន៍របស់ពួកគេ ។ គម្ពីរនេះប្រាប់ពីគំរូជាច្រើននៃការបះបោរប្រឆាំង សង្គ្រាម ឃាតកម្ម និងបក្សពួកសម្ងាត់ ។ វាក៏បង្ហាញ និងពិពណ៌នាផងដែរពីសកម្មភាពនៃពួកចោរកាឌីអានតុន ដែលធ្វើកិច្ចការនៃសេចក្តីងងឹត ហើយទីបញ្ចប់បាននាំមកនូវការបំផ្លិចបំផ្លាញដល់សាសន៍នីហ្វៃ (សូមមើល ហេលេមិន ២:១៣–១៤) ។ គម្ពីរហេលេមិនក៏មានលក្ខណៈពិសេសផងដែរ ដោយសារវារៀបរាប់ពីគ្រាមួយ នៅពេលដែល « ផ្នែកជាច្រើន » នៃសាសន៍លេមិនបានប្រែចិត្តជឿ ហើយ « សេចក្តីសុចរិតរបស់ពួកគេបានកើនឡើងដូចជាសេចក្តីសុចរិតរបស់សាសន៍នីហ្វៃដែរ » (ហេលេមិន ៦:១) ។ បន្ថែមលើនេះ វាបង្ហាញពីអំណាចដែលព្រះបានប្រទានដល់ព្យាការីរបស់ទ្រង់ ដូចជាពេលនីហ្វៃបានលាតត្រដាងពីឃាតកម្មមេចៅក្រមម្នាក់ និងបានព្យាករណ៍ពីការសោកភាពពីសំណាក់បងប្រុសរបស់ចៅក្រមនោះ (សូមមើល ហេលេមិន ៨–៩) និងនៅពេលនីហ្វៃបានទទួលអំណាចផ្សារភ្ជាប់ពីព្រះអម្ចាស់ ហើយបន្ទាប់មកអនុវត្តវាដើម្បីបញ្ចុះបញ្ចូល និងដកហូតនូវគ្រោះទុរកិក្សវិញ (សូមមើល ហេលេមិន ១០–១១) ។ លើសពីនេះទៅទៀត នៅក្នុងការក្សាទុកនៃពាក្យសម្តីរបស់សាំយូអែល គម្ពីរនេះរួមមានតែកំណត់ត្រានៃទេសនកថាមួយរបស់ព្យាការីសាសន៍លេមិនម្នាក់ដែលបានធ្វើដល់សាសន៍នីហ្វៃ (សូមមើល ហេលេមិន ១៣–១៥) ។ នៅក្នុងទេសនកថានេះ សាំយូអែលបានព្យាករណ៍ពីទីសម្គាល់ទាំងឡាយនៃការប្រសូត និងការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ ។

សេចក្តីសង្ខេប

ហេលេមិន ១–៣ មេចៅក្រមពីរបូគឺ ពេហូរ៉ាន និង ពេគូមេណៃ ត្រូវបានគេធ្វើឃាត ។ មរ៉ូណៃហាវាយច្រានការឈ្លានពានរបស់សាសន៍លេមិនមួយដែលដឹកនាំដោយកូរីអានទុមើរ ។ គិសគូមេនត្រូវបានគេសម្លាប់ ខណៈដែលប៉ុនប៉ងសម្លាប់ហេលេមិន ជាមេចៅក្រមដែលបានតែងតាំងថ្មី ។ ទោះបីជាកាឌីអានតុន និងក្រុមចោររបស់វាបានពង្រីកបក្សពួកសម្ងាត់ក្តី ក៏ប្រជាជនរាប់ពាន់ម៉ឺននាក់ត្រូវបានជ្រមុជទឹកទៅក្នុងសាសនាចក្រដែរ ។ នីហ្វៃក្លាយជាមេចៅក្រម ក្រោយពីការស្លាប់របស់ហេលេមិន ។

ហេលេមិន ៤–៦ កងទ័ពនៃពួកប្រឆាំងសាសន៍នីហ្វៃ និងសាសន៍លេមិនបានកាន់កាប់ដែនដីភាគខាងត្បូងទាំងអស់របស់សាសន៍នីហ្វៃ រួមមានដែនដីសារ៉ាហិមឡាដែរ ។ សាសន៍នីហ្វៃបានចុះខ្សោយ ដោយសារតែអំពើទុច្ចរិតរបស់ពួកគេ ។ នីហ្វៃលះលែងតំណែងជាចៅក្រមទៅឲ្យសេស្រាំ ។ នីហ្វៃ និងលីហៃចងចាំសម្តីរបស់ឪពុករបស់ខ្លួន គឺហេលេមិន ហើយបានលះបង់ខ្លួនគេក្នុងការបង្រៀនដំណឹងល្អ ។ ពួកអ្នកប្រឆាំងជាច្រើនបានប្រែចិត្ត ហើយត្រឡប់មកកាន់សាសន៍នីហ្វៃវិញ ។ ក្រោយពីព្រះអម្ចាស់បានការពារនីហ្វៃ និងលីហៃនៅក្នុងគុកដោយអព្ភូតហេតុមក សាសន៍លេមិនភាគច្រើនត្រូវបានផ្លាស់ប្តែចិត្តជឿ ហើយបានប្រគល់ដែនដីដែលពួកគេដណ្តើមបានឲ្យទៅសាសន៍នីហ្វៃវិញ ។ អំឡុងពេលដ៏រីកចម្រើនមួយ បក្សពួកកាឌីអានតុនបានមានចំនួនកាន់តែច្រើន ។ សាសន៍នីហ្វៃជាច្រើនចូលរួមនៅក្នុងអំពើទុច្ចរិតរបស់ពួកគេ ដោយបង្កឲ្យមានអំពើពុករលួយនៅក្នុងរដ្ឋាភិបាលសាសន៍នីហ្វៃ ។

ហេលេមិន ៧–១២ នីហ្វៃអធិស្ឋានលើកំពូលនៃប៉មសួនរបស់គាត់ ហើយព្រមានប្រជាជនឲ្យប្រែចិត្ត ។ គាត់បានលើកឡើងពីទីបន្ទាល់នៃមនុស្សជាច្រើនដែលបានព្យាករណ៍ពីព្រះគ្រីស្ទ ។ គាត់ក៏បានបង្ហាញថា សេស្រាំ ជាមេចៅក្រមត្រូវបានធ្វើឃាតដោយបងប្រុសរបស់គាត់គឺ សឺអានទុម ។ នីហ្វៃទទួលបានអំណាចផ្សារភ្ជាប់ និងបន្តបង្រៀនពីការប្រែចិត្ត ។ គាត់ទូលសុំព្រះអម្ចាស់ឲ្យជំនួសសង្គ្រាមរបស់សាសន៍នីហ្វៃដោយគ្រោះទុរកិក្ស ហើយការអធិស្ឋានរបស់គាត់នាំមកនូវភ្លៀងដើម្បីបញ្ចប់គ្រោះទុរកិក្សនោះ ក្រោយពីប្រជាជនបានប្រែចិត្ត ។ ក្រោយពីមានការរីកចម្រើន និងសេចក្តីសុខសាន្តមួយរយៈពេលខ្លីមក ការទាស់ទែងគ្នា និងអំពើទុច្ចរិតបានរីករាលដាលនៅក្នុងចំណោមប្រជាជននេះ ។ មរមនទួញសោកនឹងរបៀបដ៏មិនស្ថិតស្ថេរ និងឆ្កួតលីលារបស់មនុស្ស ។

ហេលេមិន ១៣–១៦ សាំយូអែល ជាសាសន៍លេមិនព្រមានសាសន៍នីហ្វៃឲ្យប្រែចិត្ត ព្យាករណ៍ពីចុងបញ្ចប់នៃការបំផ្លិចបំផ្លាញរបស់ពួកគេ និងទស្សន៍ទាយពីទីសម្គាល់ដែលទាក់ទងនឹងការប្រសូត និងការសុគតនៃព្រះយេស៊ូវគ្រីស្ទ ។ អ្នកទាំងឡាយណាដែលជឿតាមពាក្យសម្តីរបស់គាត់បានជ្រមុជទឹក ។ ទោះជាយ៉ាងណាក្តី មានមនុស្សភាគច្រើនបដិសេធសាំយូអែល និងមិនខ្វល់នឹងទីសម្គាល់ និងការអស្ចារ្យទាំងឡាយដែលបានផ្តល់ឲ្យឡើយ ។

លេហេមិន ១–២

សេចក្តីផ្តើម

ក្រោយពីពេហូរ៉ានបានស្លាប់ទៅ ការទាស់ទែងគ្នាបានកើតឡើងនៅក្នុងចំណោមពួកសាសន៍នីហ្វៃ ទាក់ទងនឹងបញ្ហាថាតើនរណាគួរធ្វើជាមេចៅក្រមបន្ទាប់ ។ កូនប្រុសរបស់គាត់ពេហូរ៉ាន ត្រូវបានតែងតាំងដោយសំឡេងរបស់ប្រជាជន ។ ទោះជាយ៉ាងណាក្តី មេចៅក្រមថ្មីនេះត្រូវបានធ្វើឃាតដោយគិសគូមេន ដែលបានចូលរួមចំណែកនៃបក្សព័ន្ធសម្ងាត់ ។ ដោយឆ្លៀតឱកាសពេលកំពុងមានការទាស់ទែងគ្នា និងការបែងចែកគ្នានេះ ពួកសាសន៍លេមិនបានឈ្លានពានយកអដ្ឋធានីសារ៉ាហិមឡាបាន ។ សាសន៍នីហ្វៃបានដណ្តើមយកដែនដីសារ៉ាហិមឡាមកវិញ ហើយគិសគូមេនត្រូវបានគេសម្លាប់ ខណៈប៉ុនប៉ងសម្លាប់ហេលេមិន (ជាកូនប្រុសរបស់ហេលេមិន) ជាមេចៅក្រមថ្មី ។

យោបល់សម្រាប់ការបង្រៀន

លេហេមិន ១

ការទាស់ទែងគ្នាបានបំបែកសាសន៍នីហ្វៃ ហើយធ្វើឲ្យសាសន៍លេមិនឈ្លានពានយកសារ៉ាហិមឡាបាន

មុនចាប់ផ្តើមថ្នាក់ សូមសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ៖

ហេលេមិន ១:១–៤ ។ តើអ្វីទៅដែលបណ្តាលឲ្យមានការទាស់ទែងគ្នា និងការបែកបាក់នៅក្នុងចំណោមប្រជាជនសាសន៍នីហ្វៃ ?

លេហេមិន ១:៥–៨ ។ តើនរណាត្រូវបានតែងតាំងជាមេចៅក្រម ហើយតើបងប្អូនប្រុសទាំងពីររបស់គាត់មានប្រតិកម្មយ៉ាងណាដែរ ?

ដើម្បីចាប់ផ្តើមមេរៀននេះ សូមឲ្យសិស្សរៀបរាប់ពីភាពខុសគ្នារវាង *ការពិភាក្សា*ពីបញ្ហាមួយ និង*ការទាស់ទែងគ្នា*អំពីបញ្ហាមួយ ។ ប្រសិនបើសិស្សត្រូវការជំនួយដើម្បីយល់ពីភាពខុសគ្នាចំពោះចំណុចទាំងពីរនេះ សូមឲ្យពួកគេគិតពីស្ថានភាពដូចមានខាងក្រោម ហើយរកមើលថាស្ថានភាពមួយណាដែលជាឧទាហរណ៍នៃការទាស់ទែងគ្នា ។ (ពួកគេគួរយល់នៅក្នុងស្ថានភាពទីពីរ និងទីបី) ។

១. ការពន្យល់ពីគោលជំហររបស់អ្នកតាមរយៈការបញ្ចុះបញ្ចូល និងការពិតដ៏រួសរាយ

២. ការបង្ហាញការមិនគោរពដល់បុគ្គលម្នាក់ ដែលមានទស្សនខុសពីអ្នក

៣. ការមានអារម្មណ៍ថា ការយកឈ្នះលើការប្រកែកគ្នាមួយវាសំខាន់ជាងសុខុមាលភាពរបស់មនុស្សម្នាក់ទៀត

សូមឲ្យសិស្សរកមើលគ្រោះថ្នាក់នៃការទាស់ទែងគ្នា នៅពេលពួកគេសិក្សា ហេលេមិន ១ ។ សូមលើកទឹកចិត្តពួកគេឲ្យគិតរៀង។ខ្លួនពីរបៀបដែលការទាស់ទែងគ្នាអាចកើតមានច្បាស់នៅក្នុងជីវិតរបស់ពួកគេ ។

សូមឲ្យសិស្សអានបទគម្ពីរដែលអ្នកបានសរសេរនៅលើក្តារខៀនដោយស្ងៀមស្ងាត់ ដោយរកមើលចម្លើយចំពោះសំណួរដែលត្រូវគ្នា ។ សូមអញ្ជើញពួកគេឲ្យរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមគូសផ្លូវមួយនៅលើក្តារខៀន ហើយសរសេរពាក្យ *ការទាស់ទែងគ្នា*នៅលើវា ។



សូមពន្យល់ថា ការទាស់ទែងគ្នាប្រៀបដូចជាផ្លូវមួយដែលនាំទៅរកអំពើបាប និងលទ្ធផលអវិជ្ជមានផ្សេងទៀត ។ សូមឲ្យសិស្សម្នាក់អានហេលេមិន១:៩ ឮៗ ។

សូមឲ្យសិស្សក្នុងថ្នាក់រកមើលថាតើនៅទីបញ្ចប់ការទាស់ទែងគ្នាក្នុងចំណោមពួកសាសន៍នីហ្វៃបានដឹកនាំទៅរកអ្វី ។ (ឃាតកម្ម) ។ សូមសរសេរពាក្យ *ឃាតកម្ម* នៅលើក្តារខៀន នៅលើរូបផ្លូវដែលអ្នកបានគូស ។

សូមឲ្យសិស្សអាន ហេលេមិន ១:១០–១២ ដោយស្ងៀមស្ងាត់ ដោយរកមើលអ្វីដែលគិសគូមេន និងអ្នកទាំងឡាយដែលបានបញ្ជូនគាត់ទៅបានធ្វើ ដើម្បីបិទបាំងរឿងឃាតកម្មដែលគាត់បានប្រព្រឹត្ត ។

- ហេតុអ្វីបានជាគិសគូមេន និងបក្សពួកគាត់ចង់លាក់ការសម្ងាត់ពីសកម្មភាពរបស់ពួកគេ ?
- តើមានឧទាហរណ៍អ្វីខ្លះពីមនុស្សសម័យទំនើបមួយចំនួនដែលកំពុងព្យាយាមរក្សាសកម្មភាពដ៏មិនសុចរិតរបស់គេជាការសម្ងាត់នោះ ? (ចម្លើយអាចរួមមានការកុហកឪពុកម្តាយ ឬនៅក្នុងការសម្ភាសន៍ជាមួយនឹងប៊ីស្សព ឬប្រធានសាខា) ។
- ហេតុអ្វីបានជាវាមិនមែនជាការឆ្លាតវៃដើម្បីជួយនរណាម្នាក់ឲ្យបិទបាំងអំពើបាបរបស់ខ្លួននោះ ?

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១:១៨–២១ ឮៗ ។ សូមឲ្យសិស្សផ្សេងទៀតមើលតាម ហើយរកមើលនូវលទ្ធផលផ្សេងទៀតនៃការទាស់ទែងគ្នារបស់សាសន៍នីហ្វៃ ។ នៅពេលសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ សូមសរសេរចម្លើយរបស់ពួកគេនៅកន្លែងណាមួយនៅលើរូបផ្លូវនៅលើក្តារខៀន ។ អ្នកក៏អាចឲ្យពួកគេផ្តល់យោបល់ និងសរសេរពីលទ្ធផលផ្សេងទៀតនៃការទាស់ទែងគ្នាដែលពួកគេបានឃើញ ។

សូមសង្ខេប ហេលេមិន ១:២២–៣០ ដោយពន្យល់ថា ក្រោយពីសាសន៍លេមិនបានកាន់កាប់ដែនដីសារ៉ាហិមឡា កងទ័ពសាសន៍នីហ្វៃបានយកឈ្នះលើពួកគេនៅក្នុងសង្គ្រាមមួយដែលមានមនុស្សជាច្រើនបានស្លាប់ ។

សូមឲ្យសិស្សសង្ខេបគោលការណ៍មួយស្តីពីការទាស់ទែងគ្នាដែលពួកគេបានរៀនពីការសិក្សា ហេលេមិន ១ ។ គោលការណ៍មួយដែលសិស្សអាចរកឃើញគឺថា **ការទាស់ទែងគ្នាធ្វើឲ្យយើងងាយនឹងរងឥទ្ធិពលពីមារសត្រូវ** ។ អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍នេះកាន់តែច្បាស់ និងអនុវត្តវានៅក្នុងជីវិតរបស់ពួកគេ សូមគិតពីការសួរសំណួរមួយចំនួនដូចមានខាងក្រោម ៖

- ប្រសិនបើយុវនារីម្នាក់បានឈ្លោះគ្នានឹងឪពុកម្តាយរបស់នាងអំពីមិត្តភក្តិរបស់នាង តើវាអាចប៉ះពាល់ដល់ឥរិយាបថរបស់នាងចំពោះការណែនាំរបស់ឪពុកម្តាយរបស់នាងនៅក្នុងផ្នែកផ្សេងទៀតនៃជីវិតនាងដោយរបៀបណា ?
- ប្រសិនបើបងប្អូនបានឈ្លោះគ្នា តើអាកប្បកិរិយារបស់ពួកគេអាចជះឥទ្ធិពលដល់ទំនាក់ទំនងរយៈពេលយូររបស់ពួកគេដោយរបៀបណា ? តើវាអាចប៉ះពាល់ដល់គ្រួសារទាំងមូលដោយរបៀបណា ?
- តើការទាស់ទែងគ្នានៅក្នុងវួដ ឬសាខាមួយអាចធ្វើឲ្យសមាជិកនៃសាសនាចក្រងាយនឹងរងការវាយប្រហារពីសាតាំងខ្លាំងជាងមុនដោយរបៀបណា ?
- ប្រសិនបើយុវជនម្នាក់ខឹងនឹងនរណាម្នាក់នៅក្នុងក្លុំមបព្វជិតភាពរបស់គាត់ តើអារម្មណ៍របស់គាត់អាចជះឥទ្ធិពលដល់សកម្មភាពរបស់គាត់នៅក្នុងសាសនាចក្រដោយរបៀបណា ? តើវាអាចជះឥទ្ធិពលដល់ការមកព្រះវិហាររបស់គាត់ដោយរបៀបណា ?
- តើអារម្មណ៍ទាស់ទែងគ្នាអាចធ្វើឲ្យយើងទន់ខ្សោយបែបណា នៅពេលយើងជួបនឹងសេចក្តីល្បួង ?

សូមឲ្យសិស្សផ្តល់យោបល់ពីស្ថានភាពផ្សេងទៀតដែលការទាស់ទែងគ្នាអាចធ្វើឲ្យយើងទន់ខ្សោយ ហើយងាយរងនឹងការល្បួងរបស់មារសត្រូវ ។

សូមឲ្យសិស្សមានពេលគិតពីរឿងមួយចំនួនក្នុងជីវិតរបស់គេដែលពួកគេអាចមានអារម្មណ៍ទាស់ទែងគ្នា ។ សូមឲ្យពួកគេរកមើលសកម្មភាពជាក់លាក់មួយដែលពួកគេអាចធ្វើដើម្បីចៀសវាងពីឥរិយាបថទាស់ទែងគ្នា ។

ហេលេមិន ២

ហេលេមិនក្លាយជាមេចៅក្រម ហើយអ្នកបម្រើរបស់គាត់រារាំងគិសគូមេនកុំឲ្យសម្លាប់គាត់បាន

- ហេតុអ្វីបានជាវាប្រសើរជាងក្នុងការសម្អាតភាពរញ៉ៃរញ៉ៃមួយជាជាងបិទបាំងវា ?
- ហេតុអ្វីបានជាមនុស្សម្នាក់ចង់បិទបាំងអ្វីមួយដែលគេបានធ្វើ ?

សូមឲ្យសិស្សអាន ហេលេមិន ២:៣–៤ និង គ. និង ស. ៥៨:៤៣ ដោយស្ងៀមស្ងាត់ ។

- យោងតាមខគម្ពីរទាំងនេះ តើមានភាពខុសគ្នាយ៉ាងណារវាងរបៀបដែលព្រះអម្ចាស់សព្វព្រះហឫទ័យឲ្យយើងដោះស្រាយអំពើបាប និងរបៀបដែលពួកចោរកាឌីអានតុនដោះស្រាយអំពើបាប ?

សូមពន្យល់ថានៅក្នុង ហេលេមិន ២ យើងបានអានពីការប៉ុនប៉ងសម្លាប់ហេលេមិនរបស់គិសគូមេន ដែលជាមេចៅក្រមបន្ទាប់ ។ សូមឲ្យសិស្សស្រមៃថា ពួកគេជាអ្នកកាសែតដែលត្រូវចាត់តាំងឲ្យរាយការណ៍ពីការប៉ុនប៉ងសម្លាប់មេចៅក្រមនោះ ។ សូមឲ្យពួកគេអានហេលេមិន ២:២–៩ ជាមួយនឹងដៃគូម្នាក់ ហើយសរសេរចំណងជើងមួយដើម្បីសង្ខេបអ្វីដែលបានកើតឡើង ។ សូមឲ្យសិស្សបីបួននាក់អានចំណងជើងរបស់គេដល់សិស្សក្នុងថ្នាក់ ។

សូមឲ្យសិស្សអាន ហេលេមិន ២:១០–១១ដោយស្ងៀមស្ងាត់ ដោយរកមើលសកម្មភាពដែលហេលេមិនបានធ្វើប្រឆាំងនឹងពួកចោរកាឌីអានតុន ។ សូមឲ្យសិស្សម្នាក់សង្ខេបខគម្ពីរទាំងនេះ ។

សូមពន្យល់ថា ក្រុមរបស់កាឌីអានតុនគឺជាគំរូមួយនៃបក្សពួកសម្ងាត់មួយ ។ សូមឲ្យសិស្សម្នាក់អាន ហេលេមិន ២:១២–១៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលពីឥទ្ធិពលដែលបក្សពួកសម្ងាត់បានមានលើប្រជាជននីហ្វៃ ។

- តើយើងអាចរៀនអ្វីខ្លះពីខគម្ពីរទាំងនេះស្តីពីគ្រោះថ្នាក់នៃបក្សព័ន្ធសម្ងាត់ ? (នៅពេលសិស្សឆ្លើយ សូមប្រាកដថាសេចក្តីពិតដូចតទៅនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ ៖ **បក្សព័ន្ធសម្ងាត់អាចដឹកនាំទៅរកការបំផ្លិចបំផ្លាញនៃសង្គមទាំងឡាយ** ។ អ្នកអាចពន្យល់ថា បន្ថែមលើការនាំមកនូវសេចក្តីបំផ្លិចបំផ្លាញនៃសាសន៍នីហ្វៃ បក្សព័ន្ធសម្ងាត់បានដឹកនាំទៅរកសេចក្តីបំផ្លិចបំផ្លាញនៃសាសន៍យ៉ារេឌ ជាប្រជាជនដែលសិស្សនឹងអាននៅក្នុងគម្ពីរអេធើរ សូមមើល អេធើរ ៨:២០–២១)) ។

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ អិម រ័សុល បាឡឺដ នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សស្តាប់រកមើលឧទាហរណ៍នៃបក្សព័ន្ធសម្ងាត់នាសព្វថ្ងៃនេះ ៖

> *ការរកមើលគោលលទ្ធិ និងគោលការណ៍ទាំងឡាយ*
>
> ពេលខ្លះ សិស្សអាចនិយាយពីគោលលទ្ធិ ឬគោលការណ៍នានានៅពេលពួកគេឆ្លើយនឹងសំណួរ ឬសង្ខេបអ្វីដែលពួកគេបានរៀននៅក្នុងបទគម្ពីរមួយ ។ ដោយសារពេលខ្លះពួកគេមិនបានដឹងថា ពួកគេកំពុងនិយាយពីសេចក្តីពិតដ៏សំខាន់មួយ វាអាចជាការល្អបើអ្នកសរសេរវានៅលើក្តារខៀន ឬលើកទឹកចិត្តសិស្សឲ្យសរសេរវានៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬសៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។

« ព្រះគម្ពីរមរមនបង្រៀនថា បក្សព័ន្ធសម្ងាត់ដែលបានទាក់ទិននឹងបទឧក្រិដ្ឋធ្វើឲ្យមានបញ្ហាដ៏ធ្ងន់ធ្ងរមួយ មិនត្រឹមតែចំពោះបុគ្គលម្នាក់ៗ និងក្រុមគ្រួសារប៉ុណ្ណោះទេ តែចំពោះប្រជាជាតិទាំងមូលផងដែរ ។ ក្នុងចំណោមបក្សព័ន្ធសម្ងាត់បច្ចុប្បន្នមានដូចជា ក្រុមក្មេងពាល ការជួញដូរគ្រឿងញៀន និងក្រុមឧក្រិដ្ឋជនដែលបានបង្កើតឡើង ។ . . .

« បើសិនជាយើងមិនបានប្រុងប្រយត្ន័ទេ នោះបក្សព័ន្ធសម្ងាត់សព្វថ្ងៃនេះអាចមានអំណាច និងឥទ្ធិពលយ៉ាងលឿន និងពេញលេញដូចដែលពួកវាបានធ្វើនៅក្នុងសម័យកាលព្រះគម្ពីរមរមនដូច្នោះដែរ » ។ . . .

« . . . [អារក្ស] ប្រើបក្សព័ន្ធសម្ងាត់ រួមទាំងក្រុមក្មេងពាលផងដែរ ‹ ពីតំណមួយទៅតំណមួយ តាមការណ៍ដែលវាអាចក្តាប់យកចិត្តនៃកូនចៅមនុស្ស › ។ [ហេលេមិន ៦:៣០ ។] បំណងរបស់វាគឺដើម្បីបំផ្លាញបុគ្គលម្នាក់ៗ ក្រុមគ្រួសារ សហគមន៍ និងជាតិសាសន៍ទាំងអស់ ។ [សូមមើល នីហ្វៃទី ២៩:៩ ។] មានពេលមួយ វាមានជោគជ័យក្នុងជំនាន់នៃព្រះគម្ពីរមរមន ។ ហើយវាមានជោគជ័យខ្លាំងណាស់នាសព្វថ្ងៃនេះ ។ នេះជាមូលហេតុដែលវាសំខាន់សម្រាប់យើង . . . ដើម្បីឈរឲ្យរឹងមាំសម្រាប់សេចក្តីពិត និងការត្រឹមត្រូវដោយការធ្វើអ្វីដែលយើងអាចធ្វើបាន ដើម្បីរក្សាសហគមន៍របស់យើងឲ្យមានសុវត្ថិភាព » (« Standing for Truth and Right » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ទំព័រ ៣៨) ។

សូមឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេអាចអនុវត្តតាមការបង្រៀនរបស់អែលឌើរ បាឡឺដ ។ សូមឲ្យពួកគេសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពីអ្វីដែលពួកគេនឹងធ្វើដើម្បីចៀសវាងពីបក្សព័ន្ធសម្ងាត់គ្រប់រូបភាព និងអ្វីដែលពួកគេនឹងធ្វើដើម្បី « ឈរឲ្យរឹងមាំសម្រាប់សេចក្តីពិត និងការត្រឹមត្រូវ » នៅក្នុងសហគមន៍របស់ពួកគេ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

ហេលេមិន ១:១–២១ ។ ការទាស់ទែងគ្នានាំឲ្យមានការបំផ្លិចបំផ្លាញ

គម្ពីរហេលេមិនប្រាប់ពីគ្រានៃអំពើទុច្ចរិតដ៏ធំមួយក្នុងចំណោមសាសន៍នីហ្វៃ ។ ពួកចោរកាឌីអានតុនបានកើកធំឡើង ហើយប្រជាជនបានជួបនឹងវដ្តនៃអំពើទុច្ចរិត សេចក្តីបំផ្លិចបំផ្លាញ និងការប្រែចិត្ត គឺដើម្បីតែត្រឡប់ទៅរកអំពើទុច្ចរិតវិញប៉ុណ្ណោះ ។ បញ្ហាទាំងនេះបានចាប់ផ្តើមដោយការទាស់ទែងគ្នា ដូចដែលបានរៀបរាប់នៅក្នុងជំពូកទីមួយនៃគម្ពីរហេលេមិន ។ មនុស្សខ្លះគិតថាការទាស់ទែងគ្នាគឺជាអំពើបាបដ៏តូចតាចមួយ ។ ទោះជាយ៉ាងណាក្តី សេចក្តីថ្លែងការណ៍ពីរដោយព្យាការីថ្ងៃចុងក្រោយបានបញ្ជាក់ពីភាពធ្ងន់ធ្ងរនៃអំពើបាបមានខ្លឹមសារដូចតទៅនេះ ៖

ប្រធាន ជែមស៍ អ៊ី ហ្វោស្ត នៃគណៈប្រធានទីមួយបានព្រមានថា « នៅពេលមានការទាស់ទែងគ្នា ព្រះវិញ្ញាណនៃព្រះអម្ចាស់នឹងចាកចេញ មិនថាអ្នកណាខុសនោះទេ » (« What I Want My Son to Know before He Leaves on His Mission » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៦ ទំព័រ ៤១) ។

អែលឌើរ យ៉ូសែប ប៊ី វ៉ែតលីន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានព្រមានថា ៖ « អំពើបាបនៃអំពើពុករលួយ ភាពមិនស្មោះត្រង់ ការលំបាក ការទាស់ទែងគ្នា និងអំពើអាក្រក់ផ្សេងទៀតក្នុងពិភពលោកនេះមិនមែនកើតឡើងដោយចៃដន្យនោះទេ ។ ពួកវាជាកស្តូតាងនៃការឃោសនាដ៏ឥតបង្អង់របស់សាតាំង និងអ្នកដែលដើរតាមវា ។ វាប្រើឧបករណ៍ និងគ្រឿងសម្ភារគ្រប់ប្រភេទដែលវាមានដើម្បីបញ្ឆោត ពង្វក់ និងដឹកនាំទៅរកផ្លូវខុស » (« Deep Roots » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ទំព័រ ៧៦) ។

ផ្តុំយកឥទ្ធិពលដ៏បំផ្លិចបំផ្លាញនៃការទាស់ទែងគ្នា ប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយបានបញ្ជាក់ពីសាមគ្គីភាព និងសន្តិភាពដែលព្រះវិញ្ញាណនៃព្រះអម្ចាស់បាននាំមក ៖

« កន្លែងណាដែលមនុស្សមានព្រះវិញ្ញាណនៅជាមួយនឹងគេ នោះជាកន្លែងដែលយើងអាចមានសុភមង្គល ។ ព្រះវិញ្ញាណជាក់ទីបន្ទាល់នៃសេចក្តីពិតនៅក្នុងដួងចិត្តយើង ដែលរួបរួមអ្នកទាំងឡាយណាដែលចែកចាយទីបន្ទាល់នោះ ។ ព្រះវិញ្ញាណនៃព្រះមិនដែលបង្កើតការទាស់ទែងគ្នានោះទេ (សូមមើល នីហ្វៃទី ៣ ១១:២៩) ។ ព្រះវិញ្ញាណមិនដែលបង្កើតអារម្មណ៍នៃការខុសគ្នារវាងមនុស្សដែលជឹកនាំទៅរកការលំបាកនោះទេ (សូមមើល យ៉ូសែប អេហ្វ ស្ម៊ីធ *Gospel Doctrine* ការកែសម្រួលលើកទី ១៣ [ឆ្នាំ ១៩៦៣] ទំព័រ ១៣១) ។ ព្រះវិញ្ញាណនាំទៅរកសេចក្តីសុខសាន្តផ្ទាល់ខ្លួន និងអារម្មណ៍នៃការរួបរួមមួយជាមួយនឹងអ្នកដទៃ ។ ព្រះវិញ្ញាណបង្រួបបង្រួមព្រលឹងទាំងឡាយ ។ គ្រួសារដ៏មានសាមគ្គីភាព សាសនាចក្រដែលរួបរួមមួយ និងពិភពលោកមួយដែលមានសន្តិភាពគឺអាស្រ័យលើមនុស្សដែលចេះរួបរួមគ្នា » (« That We May Be One » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៨ ទំព័រ ៦៧) ។

ហេលេមិន ៣–៤

សេចក្តីផ្តើម

នាពេលនេះនៅក្នុងប្រវត្តិសាស្ត្រនៃព្រះគម្ពីរមរមន សាសន៍នីហ្វៃបានរីករាយនឹងគ្រានៃសេចក្តីសុខសាន្ត ប៉ុន្តែក៏បានជួបនឹងគ្រានៃការទាស់ទែងគ្នាដែរ ។ សាសន៍នីហ្វៃរាប់ពាន់រាប់ម៉ឺននាក់បានចូលរួមក្នុងសាសនាចក្រ នៅគ្រានៃសេចក្តីសុខសាន្តនេះ ។ ក្រោយពីគ្រានៃការីកចម្រើនដ៏អស្ចារ្យនេះ ភាពឆ្មើងឆ្មៃបានចាប់ផ្តើមចូលទៅក្នុងដួងចិត្តនៃប្រជាជន ។ ទោះជាយ៉ាងណាក្តី សមាជិកសាសនាចក្រដ៏រាបសាជាច្រើនបានរីកចម្រើននៅក្នុងសេចក្តីជំនឿរបស់ពួកគេ ថ្វីបើត្រូវបានបៀតបៀនពីសំណាក់អ្នកដែលមានអំនួតក្តី ។ ដោយសារតែអំពើទុច្ចរិតនៅក្នុងចំណោមប្រជាជននីហ្វៃជាច្រើន ពួកគេបានបាត់បង់ដែនដីភាគខាងត្បូងរបស់គេទាំងអស់ឲ្យទៅសាសន៍លេមិន ។

យោបល់សម្រាប់ការបង្រៀន

ហេលេមិន ៣

សាសន៍នីហ្វៃជាច្រើនបានធ្វើដំណើរទៅភាគខាងជើង ខណៈដែលសាសនាចក្ររីកចម្រើននៅអំឡុងភាពទុច្ចរិត និងការបៀតបៀន

សូមសរសេរពាក្យខាងក្រោមនៅលើក្តារខៀន (អ្នកអាចធ្វើដូច្នេះ មុនចាប់ផ្តើមបង្រៀន) ៖

ប្រជាជននៅ . . . (ឈ្មោះនៃប្រទេសរបស់អ្នក)

ប្រជាជននៅ. . . (ឈ្មោះនៃទីក្រុងរបស់អ្នក)

សមាជិកនៅក្នុងវួដ ឬសាខារបស់ខ្ញុំ

សមាជិកនៅក្នុងគ្រួសាររបស់ខ្ញុំ

ខ្លួនខ្ញុំ

សូមសួរសិស្សថាក្នុងចំណោមមនុស្សដែលបានសរសេរនៅលើក្តារខៀនខាងលើ តើនរណាដែលពួកគេមានអារម្មណ៍ថាពួកគេអាចគ្រប់គ្រងបាន ។ បន្ទាប់មក សូមឲ្យពួកគេលើកដៃ ប្រសិនបើពួកគេធ្លាប់បាក់ទឹកចិត្តដោយសារតែសកម្មភាពរបស់ដទៃ ។ សូមឲ្យពួកគេបន្តលើកដៃ ប្រសិនបើពួកគេធ្លាប់បានបាក់ទឹកចិត្តនាពេលថ្មីៗនេះ ដោយសារតែសកម្មភាពមិនសុចរិតរបស់អ្នកដទៃ ។ សូមពន្យល់ថានៅពេលពួកគេសិក្សា ហេលេមិន ៣ ពួកគេនឹងរកឃើញការយល់ដឹងអំពីអ្វីដែលពួកគេអាចធ្វើ នៅពេលមនុស្សដែលរស់នៅជុំវិញគេមិនធ្វើតាមដំណឹងល្អ ។

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៣:១–២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលការកើតឡើងនៃឃ្លាថា « គ្មានការទាស់ទែងគ្នា » ។ សូមឲ្យសិស្សអាន ហេលេមិន ៣:៣, ១៩ ដោយស្ងៀមស្ងាត់ដោយរកមើលពាក្យ ឬឃ្លាដែលបង្ហាញពីរបៀបដែលអ្វីៗបានផ្លាស់ប្តូរក្នុងចំណោមប្រជាជននីហ្វៃ ។

- តើអ្នកគិតថា ហេតុអ្វីបានជាសាសន៍នីហ្វៃចាកចេញយ៉ាងរហ័សពីគ្រានៃការគ្មានការទាស់ទែងគ្នាទៅរកគ្រានៃការទាស់ទែងគ្នា ?

សូមសង្ខេប ហេលេមិន ៣:៣–១៦ ដោយការពន្យល់ថា នៅគ្រានៃការទាស់ទែងគ្នានេះ សាសន៍នីហ្វៃជាច្រើនបានចាកចេញទៅភាគខាងជើង ។

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៣:២០ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលហេលេមិនត្រូវបានពិពណ៌នានៅគ្រានៃការទាស់ទែងគ្នានេះ ។

- តើអ្វីទៅដែលធ្វើឲ្យអ្នកចាប់អារម្មណ៍ស្តីពីគំរូរបស់ហេលេមិន នៅគ្រានៃការទាស់ទែងគ្នានេះ ? (នៅពេលសិស្សឆ្លើយ អ្នកអាចផ្តល់យោបល់ឲ្យពួកគេគូសចំណាំពាក្យ *រហូត* នៅក្នុង ហេលេមិន ៣:២០) ។

សូមឲ្យសិស្សអាន ហេលេមិន ៣:២២–២៦ ដោយស្ងៀមស្ងាត់ ហើយរកមើលថាតើស្ថានភាពនៅក្នុងចំណោមសាសន៍នីហ្វៃបានផ្លាស់ប្តូរយ៉ាងណាដែរ ។

- តើអ្វីទៅដែលធ្វើឲ្យអ្នកដឹកនាំសាសនាចក្រត្រូវបានគេកោតសរសើរ ?
- តើយើងអាចរៀនអ្វីខ្លះពីខគម្ពីរទាំងនេះស្តីពីឥទ្ធិពលដ៏មានសក្តានុពលដែលសាសនាចក្រអាចមានទៅលើមនុស្សទូទៅ ?

សូមរំឭកសិស្សថា នៅពេលមរមនបានរៀបចំកំណត់ត្រានៃព្រះគម្ពីរមរមន ពេលខ្លះគាត់បានបង្ហាញ មេរៀន ដែលគាត់ចង់ឲ្យអ្នកអានរៀនពីដំណើររឿងមួយចំនួន ។ នៅក្នុងករណីរបស់ ហេលេមិន ៣ គាត់បានប្រើឃ្លា « ម្ល៉ោះហើយ យើងអាចឃើញថា » « ម្ល៉ោះហើយ យើងឃើញថា » និង « យើងឃើញថា » ដើម្បីចាប់ផ្តើមមេរៀនរបស់គាត់ ។ សូមឲ្យសិស្សអាន ហេលេមិន ៣:២៧–៣០ ដោយស្ងៀមស្ងាត់ ហើយរកមើលមេរៀនដែលមរមនចង់ឲ្យយើងរៀន ។ ក្រោយពីសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញហើយ ដោយសួរថា ៖

- តើមរមនចង់ឲ្យយើងដឹងអ្វីខ្លះអំពីព្រះបន្ទូលនៃព្រះ ?

សូមរកមើលឃ្លាដែលមាន « ម្ល៉ោះហើយ យើងឃើញថា »

ក្នុងការរៀបចំព្រះគម្ពីរមរមន ព្យាការីមរមនពេលខ្លះបានប្រើឃ្លាដូចជា « ម្ល៉ោះហើយ យើងឃើញថា » ដើម្បីបញ្ជាក់ពីសេចក្តីពិតដែលគាត់ចង់បង្រៀន ។ ដោយការបញ្ជាក់ឃ្លាទាំងនេះនៅក្នុងហេលេមិន ៣ អ្នកអាចរៀបចំសិស្សឲ្យរកឃើញមេរៀនដែលមរមនមានបំណងចង់ឲ្យយើងដឹង នៅក្នុងផ្នែកផ្សេងទៀតនៃព្រះគម្ពីរមរមន ។

សូមឲ្យសិស្សមានពេលខ្លះសញ្ជឹងគិតពីរបៀបដែលការសិក្សាព្រះគម្ពីររបស់ពួកគេបានជួយឲ្យពួកគេទទួលបានពរជ័យដូចដែលបានសន្យានៅក្នុង ហេលេមិន ៣:២៩ ។ សូមគិតពីការហៅសិស្សពីរបីនាក់ឲ្យចែកចាយបទពិសោធន៍របស់គេ ។

សូមពន្យល់ថា ខគម្ពីរនៅសេសសល់ផ្សេងទៀតក្នុង ហេលេមិន ៣ ប្រាប់ពីរបៀបដែល មានភាពឆ្មើងឆ្មៃកាលដាលនៅក្នុងចំណោមសាសន៍នីហ្វៃ ក្រោយពីពេលនៃការរីកចម្រើនដ៏អស្ចារ្យនោះ ។ សមាជិកសាសនាចក្រដ៏របសាជាច្រើនបានរងការបៀតបៀនពីសមាជិកសាសនាចក្រដែលមានដួងចិត្តឆ្មើងឆ្មៃ ។ សូមអានស្ថានភាពខាងក្រោមឮៗ ។ សូមឲ្យសិស្សសញ្ជឹងគិតពីពេលដែលពួកគេបានឃើញ ឬបានជួបស្ថានភាពស្រដៀងគ្នានេះ ។

១. យុវនារីម្នាក់សើចចំអកឲ្យក្មេងស្រីផ្សេងទៀតនៅក្នុងវួដរបស់នាង ។

២. យុវជនម្នាក់ចំអកឲ្យសមាជិកក្លុំមរបស់គាត់ដែលរីករាយជ្រុលពេកដើម្បីឆ្លើយនឹងសំណួរនៅក្នុងថ្នាក់ ឬស្មគ័ច្រិតសម្រាប់កាតព្វកិច្ចនៃបព្វជិតភាព ។

៣. ក្រុមយុវជនមួយនៅក្នុងវួដបានមិនរាប់រកយុវជនម្នាក់ទៀតនៅក្នុងការសន្ទនា និងសកម្មភាពរបស់ពួកគេខាងក្រៅសាសនាចក្រ ។

៤. យុវនារីមួយក្រុមបាននិះគន់អំពីសំលៀកបំពាក់របស់យុវនារីផ្សេងទៀតដែលធ្វើឲ្យនាងឈឺចាប់ ។

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៣:៣៣–៣៤ ឮៗ ។ សូមឲ្យសិស្សរកមើលភាពស្រដៀងគ្នារវាងស្ថានភាពរបស់សាសន៍នីហ្វៃ និងស្ថានភាពដែលបានរៀបរាប់ខាងលើ ។ ក្រោយពីសិស្សមានពេលឆ្លើយហើយ សូមសួរសំណួរដូចខាងក្រោម ៖

- តើអ្នកគិតថា ហេតុអ្វីបានជាការបៀតបៀននៃសមាជិកសាសនាចក្រដោយសមាជិកសាសនាចក្រផ្សេងទៀតត្រូវបានចាត់ទុកថាជា « អំពើអាក្រក់ដ៏ខ្លាំងមួយ» ក្នុងចំណោមសាសន៍នីហ្វៃ ?
- តើយើងបានបំពានគោលការណ៍អ្វីខ្លះនៃដំណឹងល្អ នៅពេលយើងធ្វើខុស ឬខ្វះសន្តានចិត្តល្អចំពោះសមាជិកសាសនាចក្រផ្សេងទៀត ? តើយើងអាចពង្រឹងសេចក្តីស្រឡាញ់របស់យើងចំពោះពួកបរិសុទ្ធដែលជាបងប្អូនរបស់យើងដោយរបៀបណា ?

សូមឲ្យសិស្សអាន ហេលេមិន ៣:៣៥ ដោយស្ងៀមស្ងាត់ ហើយរកមើលរបៀបដែលពួកអ្នកមានចិត្តរាបសានៅក្នុងចំណោមសាសន៍នីហ្វៃបានឆ្លើយតបនឹងការបៀតបៀន ។

- តើសេចក្តីជំនឿនៃមនុស្សដែលគេបៀតបៀនបានកើតឡើង ថយចុះ ឬនៅដដែល ?
- តើសកម្មភាពអ្វីខ្លះដែលមនុស្សត្រូវគេបៀតបៀនបានធ្វើដើម្បីបង្កើនសេចក្តីជំនឿរបស់គេ ? (ពួកគេបានតមអាហារ ហើយបានអធិស្ឋានជាញឹកញាប់ ព្យាយាមបន្ទាបខ្លួន និងបែរដួងចិត្តគេទៅកាន់ព្រះ ។)
- ក្រៅពីការបង្កើនសេចក្តីជំនឿ តើមានអ្វីផ្សេងទៀតដែលសកម្មភាពនៃសាសន៍ដែលបន្ទាបខ្លួនបាននាំទៅរក ? (សេចក្តីអំណរ ការរួបរួម និងការបន្សុទ្ធ និងការថ្វាយដួងចិត្តរបស់គេ ។)

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *នៅពេលយើង . . . សេចក្តីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទនឹងត្រូវបានបង្កើនទោះបីជាមានការបៀតបៀន និងការសាកល្បងក្តី ។* សូមឲ្យសិស្សបំពេញប្រយោគនេះដោយផ្អែកលើអ្វីដែលពួកគេបានរៀនពីហេលេមិន ៣:៣៣–៣៥ ។ អ្នកអាចឲ្យសិស្សបីបួននាក់ចែកចាយពីរបៀបដែលពួកគេបានបំពេញប្រយោគនេះ ។ ទោះបីជាចម្លើយរបស់សិស្សអាចខុសគ្នាក្តី ក៏សូមប្រាកដថា ពួកគេបង្ហាញពីសេចក្តីពិតដូចតទៅនេះ ៖ **នៅពេលយើងខិតខំរស់នៅដោយសុចរិត ទោះសេចក្តីជំនឿរបស់យើងលើព្រះយេស៊ូវគ្រីស្ទនឹងកើនឡើង ទោះបីមានការបៀតបៀន និងការសាកល្បងក្តី ។** ដើម្បីជួយសិស្សឲ្យយល់ពីការបង្រៀនក្នុងខគម្ពីរទាំងនេះកាន់តែស៊ីជម្រៅ អ្នកអាចសួរសំណួរដូចខាងក្រោម ៖

- តើការអធិស្ឋាន និងការតមអាហារបានជួយអ្នកនៅក្នុងពេលមានការបៀតបៀន ឬការសាកល្បងដោយរបៀបណា ?
- តើអ្នកគិតថា ការបែរដួងចិត្តរបស់អ្នកទៅរកព្រះមានន័យដូចម្តេច ?
- ហេតុអ្វីបានជាការបែរដួងចិត្តអ្នកទៅព្រះចាំបាច់ដើម្បីបង្កើនសេចក្តីជំនឿរបស់អ្នកនៅក្នុងពេលមានការបៀតបៀន ឬការសាកល្បង ?

សូមសួរសិស្សថា តើពួកគេធ្លាប់មានអារម្មណ៍ថាសេចក្តីជំនឿរបស់ពួកគេកើនឡើង នៅពេលពួកគេបានឆ្លើយតបដោយសុចរិតទៅនឹងការបៀតបៀនដែរឬទេ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់គេ ។ អ្នកក៏អាចចែកចាយបទពិសោធន៍ផ្ទាល់ខ្លួនផងដែរ ។

ដើម្បីរៀបចំសិស្សឲ្យសិក្សា ហេលេមិន ៤ សូមឲ្យពួកគេអាន ហេលេមិន ៣:៣៦ ដោយស្ងៀមស្ងាត់ ។ សូមឲ្យពួកគេរកមើលស្ថានភាពទូទៅរបស់សាសន៍នីហ្វៃ ។ (សាសន៍នីហ្វៃកំពុងកើនឡើងនៅក្នុងភាពឆ្មើងឆ្មៃ ទោះបីជាមានគំរូរបស់អ្នកដើរតាមព្រះគ្រីស្ទដ៏របសាក្តី) ។

ហេលេមិន ៤

ដោយសារតែអំពើទុច្ចរិត នោះព្រះវិញ្ញាណនៃព្រះអម្ចាស់បានយាងចេញពីសាសន៍នីហ្វៃ ហើយសាសន៍លេមិនបានយកឈ្នះលើដែនដីភាគខាងត្បូងរបស់សាសន៍នីហ្វៃទាំងអស់

សូមពន្យល់ថា ហេលេមិន ៤:៤–៨ ប្រាប់ពីសង្គ្រាមមួយដែលសាសន៍នីហ្វៃបានធ្វើនឹងសាសន៍លេមិន និងអ្នកប្រឆាំងនឹងសាសន៍នីហ្វៃ ។ សូមឲ្យសិស្សម្នាក់អានខគម្ពីរទាំងនេះឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលដែនដីរបស់សាសន៍នីហ្វៃមួយណាដែលត្រូវបានឈ្លានពានក្នុងពេលសង្គ្រាមនេះ ។

សូមសរសេរការណែនាំដូចខាងក្រោមនៅលើក្តារខៀន ។ (អ្នកគួរធ្វើការណ៍នេះ មុនពេលចាប់ផ្តើមបង្រៀន) ។ សូមឲ្យសិស្សចម្លងវាទៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។

សូមសរសេរពាក្យបីឃ្លាដែលបង្ហាញពីឥរិយាបថ និងសកម្មភាពរបស់សាសន៍នីហ្វៃ ។

សូមសរសេរពាក្យបីឃ្លាដែលបង្ហាញពីអ្វីដែលបានកើតឡើងដោយសារតែសកម្មភាពទាំងនេះ ។

សូមចែកសិស្សជាគូៗ ។ សូមឲ្យដៃគូទាំងឡាយអាន ហេលេមិន ៤:១១–១៣, ២៣–២៦ រួមគ្នា ដោយរកមើល ហើយសរសេរឃ្លាដ៏សំខាន់ស្របតាមការណែនាំនៅលើក្តារខៀន ។

សូមឲ្យដៃគូពីរបីរៀបរាប់ពីចម្លើយរបស់ពួកគេ ។ នៅពេលសិស្សចែកចាយអ្វីដែលពួកគេបានសរសេរហើយ អ្នករាចណែនាំឲ្យពួកគេគូសចំណាំឃ្លាខាងក្រោមនៅក្នុងគម្ពីររបស់ពួកគេ ។ « ត្រូវបានទុកឲ្យប្រើកម្លាំងរបស់គេផ្ទាល់ » (ហេលេមិន ៤:១៣) « ពួកគេបានក្លាយទៅជាមនុស្សទន់ខ្សោយ » (ហេលេមិន ៤:២៤) ហើយ « មែនហើយ ពួកគេបានក្លាយទៅជាមនុស្សទន់ខ្សោយ » (ហេលេមិន ៤:២៦) ។

សូមសួរសិស្សថា តើគោលការណ៍អ្វីដែលពួកគេអាចរកឃើញពីការសិក្សាក្នុង ហេលេមិន ៤ ។ សូមជួយពួកគេឲ្យរកឃើញគោលការណ៍ដូចតទៅនេះ ៖ ភាពឆ្មើងឆ្មៃ និងអំពើទុច្ចរិតបំបែកយើងចេញពីព្រះវិញ្ញាណនៃព្រះអម្ចាស់ ហើយទុកឲ្យយើងប្រើកម្លាំងផ្ទាល់ខ្លួន ។ អ្នករាចសរសេរគោលការណ៍នេះនៅលើក្តារខៀន ។ អ្នកក៏អាចណែនាំសិស្សឲ្យសរសេរវានៅក្នុងព្រះគម្ពីររបស់ពួកគេ គឺនៅក្បែរ ហេលេមិន ៤:២៣–២៤ ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍នេះ សូមឲ្យពួកគេម្នាក់ឡើងមកខាងមុខក្តារខៀន ។ សូមឲ្យសិស្សនោះស្រមៃថា គេត្រូវបានបញ្ជាឲ្យទៅច្បាំងតែម្នាក់ឯងក្នុងចម្បាំងមួយប្រឆាំងនឹងសាសន៍លេមិន ។ សូមសួរសិស្សផ្សេងទៀតថា តើពួកគេនឹងមានឱកាសប៉ុណ្ណាអាចយកឈ្នះកងទ័ពដ៏ច្រើននោះ ។ សូមឲ្យសិស្សផ្សេងឡើងមកខាងមុខក្តារខៀន ហើយឈរនៅក្បែរសិស្សទីមួយ ។ សូមសួរសិស្សទីមួយថាបើមានជំនួយពីសិស្សទីពីរតើឱកាសយកឈ្នះនឹងកម្លាំងសត្រូវនោះមានប៉ុណ្ណា ។ (ដោយការប្រយុទ្ធនឹងកងទ័ពដ៏ច្រើន ការបន្ថែមសិស្សទីពីរនឹងមិនបង្កើនឱកាសយកឈ្នះបានច្រើននោះទេ) ។ បន្ទាប់មក សូមសរសេរពាក្យ*ព្រះអម្ចាស់*នៅលើក្តារខៀន ។ សូមសួរសិស្សទីមួយថា ៖

- **តើអ្នកគិតថា ឱកាសយកឈ្នះរបស់អ្នកលើសង្គ្រាមមានច្រើនប៉ុណ្ណា ប្រសិនបើព្រះអម្ចាស់ស្ថិតនៅខាងអ្នកនោះ ?**

សូមសួរសិស្សថា តើសកម្មភាពនេះទាក់ទងនឹងគោលការណ៍ដែលបានរកឃើញក្នុងហេលេមិន ៤ ដោយរបៀបណា ។ សូមគិតពីការសួរសំណួរខាងក្រោម ៖

- **នៅក្នុងបទពិសោធន៍របស់សាសន៍នីហ្វៃ ការត្រូវបានទុកឲ្យប្រើកម្លាំងខ្លួនឯងផ្ទាល់ មានន័យថាជាការចាញ់សង្គ្រាម និងការបាត់បង់ដែនដី ។ តើ « សង្គ្រាម » អ្វីខ្លះដែលយើងអាចចាញ់ ប្រសិនបើយើងគ្មានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយនឹងយើងនោះ ?**

សូមឲ្យសិស្សសញ្ជឹងគិតពីរឿងមួយ ដែលពួកគេអាចធ្វើដើម្បីរក្សាភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់គេ ហើយសូមឲ្យពួកគេធ្វើដូច្នោះ ។ សូមចែកចាយទីបន្ទាល់របស់អ្នកពីសារៈសំខាន់នៃព្រះវិញ្ញាណនៅក្នុងជីវិតរបស់អ្នក ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

ហេលេមិន ៣:៣៣–៣៤, ៣៦, ៤:១២ ។ ឥទ្ធិពលនៃភាពឆ្មើងឆ្មៃទៅលើសាសនាចក្រ

មរមនបានបង្ហាញថា ភាពឆ្មើងឆ្មៃមិនមែនជាផ្នែកមួយនៃសាសនាចក្ររបស់ព្រះអម្ចាស់ឡើយ ប៉ុន្តែដោយសារតែមានទ្រព្យសម្បត្តិច្រើន វាបានចាប់ផ្តើមចូលទៅក្នុងដួងចិត្តរបស់សមាជិកសាសនាចក្រខ្លះ (សូមមើល ហេលេមិន ៣:៣៣, ៣៦) ។

ប្រធាន អែសរ៉ា ថាហ្វ បែនសឹន បានបង្រៀនថា ៖

« សូមគិតពីអ្វីដែលភាពឆ្មើងឆ្មៃបានធ្វើឲ្យយើងខាតបង់កាលពីអតីតកាល និងអ្វីដែលវាកំពុងធ្វើឲ្យយើងខាតបង់នៅក្នុងជីវិតរបស់យើងផ្ទាល់ គ្រួសាររបស់យើង និងសាសនាចក្រនាពេលនេះ ។

« សូមគិតពីការប្រែចិត្តដែលអាចកើតមានដោយធ្វើឲ្យជីវិតផ្លាស់ប្តូរ អាពាហ៍ពិពាហ៍ដែលបានរក្សាទុក និងផ្ទះដែលបានពង្រឹង ប្រសិនបើភាពឆ្មើងឆ្មៃមិនបានរាំងយើងមិនឲ្យសារភាពពីអំពើបាប ហើយលះបង់វាចោលនោះ ។ (សូមមើល គ. និង ស. ៥៨:៤៣) ។

« សូមគិតពីមនុស្សជាច្រើនដែលជាសមាជិកសាសនាចក្រមិនសូវសកម្ម ដោយសារពួកគេបានប្រកាន់ ហើយភាពឆ្មើងឆ្មៃរបស់គេមិនឲ្យពួកគេអត់ឱនទោស ឬទទួលទាននៅតុរបស់ព្រះអម្ចាស់ពេញលេញនោះទេ ។

« សូមគិតពីយុវជន និងគូស្វាមីភរិយារាប់ពាន់រាប់ម៉ឺននាក់បន្ថែមទៀតដែលអាចចេញទៅបេសកកម្ម បើគ្មានភាពឆ្មើងឆ្មៃរាំងពួកគេមិនឲ្យបែរដួងចិត្តរបស់គេទៅកព្រះទេនោះ ។ (សូមមើល អាលម៉ា ១០:៦, ហេលេ. ៣:៣៤–៣៥ ។)

« សូមគិតថាតើកិច្ចការព្រះវិហារបរិសុទ្ធនឹងកើនឡើង បែបណា ប្រសិនបើការចំណាយពេលលើកិច្ចការរបស់ព្រះនេះមានសារៈសំខាន់ជាងការធ្វើតាមអំនួតជាច្រើនដែលប្រជែងនឹងពេលវេលារបស់យើងនោះ » (« Beware of Pride » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨៩ ទំព័រ ៦) ។

ហេលេមិន ៥

សេចក្តីផ្តើម

សាសន៍នីហ្វៃបានបន្តនៅក្នុងអំពើទុច្ចរិត រហូតដល់ពួកគេកាគាមច្រើនបានជ្រើសយកសេចក្តីទុច្ចរិតជាជាងសេចក្តីសុចរិត ។ នីហ្វៃ និងលីហៃបានលះបង់ខ្លួនដើម្បីបង្រៀនព្រះបន្ទូលនៃព្រះ ឪពុករបស់ពួកគេ ហេលេមិន បានបង្រៀនពួកគេឲ្យចងចាំដល់ព្រះជំរាបសួរលោះរបស់ពួកគេ ហើយធ្វើឲ្យទ្រង់ជាគ្រឹះនៃជីវិតរបស់គេ ។ ក្រោយពីបានបង្រៀនសាសន៍នីហ្វៃហើយ នីហ្វៃ និងលីហៃបានបង្រៀនសាសន៍លេមិន ជាប្រជាជនដែលបានចាប់ពួកគេជាក់គុក ។ ព្រះអម្ចាស់បានដោះលែងពួកគេដោយអព្ភូតហេតុ ហើយសាសន៍លេមិនកាគាមច្រើនបានប្រែចិត្ត ហើយបានផ្លាស់ចិត្តជឿលើជំណឹងល្អ ។

បង្រៀនដោយព្រះវិញ្ញាណបរិសុទ្ធ

នៅពេលអ្នករៀបចំបង្រៀន សូមអធិស្ឋានថាព្រះវិញ្ញាណបរិសុទ្ធនឹងគង់នៅជាមួយនឹងអ្នក និងសិស្សរបស់អ្នក ។

យោបល់សម្រាប់ការបង្រៀន

ហេលេមិន ៥:១–១៣

ហេលេមិនណែនាំកូនប្រុសរបស់គាត់ឲ្យកាន់តាមព្រះបញ្ញត្តិនៃព្រះ បង្រៀនដំណឹងល្អ និងចងចាំដល់ព្រះរចស្តាដ៏ប្រោសលោះរបស់ព្រះយេស៊ូវគ្រីស្ទ

មុនចាប់ផ្តើមថ្នាក់ សូមរៀបចំក្រដាសឆ្នូតប្រាំមួយដើម្បីបង្ហាញ ។ ក្រដាសទីមួយសូមសរសេរឈ្មោះរបស់អ្នកនៅលើវា ។ ក្រដាសប្រាំផ្សេងទៀតគួរមានពាក្យ និងឃ្លាដូចខាងក្រោម ៖ *ឪពុកម្តាយ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ព្យាការី ការប្រែចិត្តនាំទៅរកសេចក្តីសង្គ្រោះ* និង*ការពារព្រះបញ្ញត្តិ* ។

សូមឲ្យសិស្សម្នាក់ៗនូវក្រដាសតូចមួយ ។ សូមពន្យល់ថាអ្នកនឹងបង្ហាញគេដោយខ្លីៗពីក្រដាសឆ្នូតប្រាំមួយដោយមានពាក្យសរសេរលើនោះ ។ បន្ទាប់មក ពួកគេនឹងសរសេរពាក្យទាំងនោះតាមការចងចាំ ។ សូមបង្ហាញសិស្សក្រដាសឆ្នូតម្តងមួយ ។

សូមឲ្យសិស្សសរសេរពាក្យដែលពួកគេចាំ ។ បន្ទាប់មក សូមបង្ហាញក្រដាសឆ្នូតទាំងប្រាំមួយម្តងទៀត ។ សូមសួរ ៖

- **តើវាងាយ ឬក៏ពិបាកដើម្បីចាំពាក្យ និងឃ្លាទាំងនេះទេ ?**
- **តើអ្នកគិតថា មានភាពខុសគ្នាយ៉ាងណាបើអ្នកត្រូវបានប្រាប់ថា អ្នកត្រូវចាំអ្វីដែលមាននៅលើក្រដាសឆ្នូតទាំងនេះ ?**

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ស្តែនសើរ ដបុលយូ ឃីមបឹល ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកអ្វីដែលគាត់បានមានប្រសាសន៍អំពីសារៈសំខាន់នៃការចងចាំការបង្រៀនដំណឹងល្អដែលយើងបានទទួល ៖

« នៅពេលអ្នកមើលក្នុងវចនានុក្រមរកពាក្យសំខាន់បំផុតនោះ តើអ្នកដឹងថាវាជាពាក្យអ្វីទេ ? វាអាចជាពាក្យ *ចងចាំ* ។ ដោយសារអ្នករាល់គ្នាធ្វើសេចក្តីសញ្ញា —អ្នកនឹងដឹងអ្វីដែលត្រូវធ្វើ ហើយអ្នកដឹងពីរបៀបដើម្បីធ្វើវា— តម្រូវការដ៏ធំបំផុតរបស់យើងនោះគឺត្រូវចងចាំ » (« Circles of Exaltation » | address to CES religious educators នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៦៨ | ទំព័រ ៥ si.lds.org) ។

សូមពន្យល់ដល់សិស្សថា ថ្ងៃនេះពួកគេនឹងរៀនអំពីមនុស្សពីរនាក់ដែលបានផ្លាស់ប្តូរជីវិតមនុស្សរាប់ពាន់នាក់ ដោយសារពួកគេបានចងចាំ ហើយធ្វើតាមសេចក្តីពិតជាក់លាក់ ។ សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតអំឡុងពេលមេរៀនថ្ងៃនេះពីអ្វីដែលពួកគេគិតថាព្រះអម្ចាស់ចង់ឲ្យពួកគេចងចាំ ។

សូមសង្ខេប ហេលេមិន ៥:១–៤ ។ សូមពន្យល់ថា ដោយសារតែអំពើទុច្ចរិតរបស់ប្រជាជន នីហ្វៃបានលាលែងពីតំណែងជាមេចៅក្រមដើម្បីគាត់និងបងប្រុសរបស់គាត់លីហៃអាចលះបង់ខ្លួនក្នុងការបង្រៀនព្រះបន្ទូលនៃព្រះ ។

សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖ (សូមកុំបញ្ចូលពាក្យនៅក្នុងវង់ក្រចក ។

ហេលេមិន ៥:៥–៧ (កាន់តាមព្រះបញ្ញត្តិទាំងឡាយ ចងចាំពីគំរូដ៏សុចរិតនៃបុព្វបុរសទាំងឡាយ) ។

ហេលេមិន ៥:៩–១១ (ចងចាំដង្វាយធួននៃព្រះគ្រីស្ទ ចងចាំថាយើងមិនអាចត្រូវបានសង្គ្រោះនៅក្នុងអំពើបាបរបស់យើងទេ ប៉ុន្តែថាយើងអាចត្រូវបានសង្គ្រោះចេញពីអំពើបាបរបស់យើង តាមរយៈការប្រែចិត្ត និងព្រះចេស្តានៃដង្វាយធួន) ។

ហេលេមិន ៥:១២ (ចងចាំថា ព្រះយេស៊ូវគ្រីស្ទត្រូវតែជាគ្រឹះរបស់យើង) ។

សូមឲ្យសិស្សមើលខគម្ពីរទាំងអស់ដែលមាននៅលើក្តារខៀនត្រួសៗ ដោយរកមើលពាក្យ *ចងចាំ* ។ អ្នករាជណែនាំឲ្យពួកគេគូសចំណាំគំនូរនៃពាក្យនេះ ។ បន្ទាប់មក សូមឲ្យសិស្សមានពេលពីរបីនាទីអានវគ្គទាំងនេះដោយស្ងៀមស្ងាត់ ដោយរកមើលអ្វីដែលហេលេមិនចង់ឲ្យកូនប្រុសរបស់គាត់ចាំ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។ អ្នករាជសរសេរចម្លើយរបស់គេនៅលើក្តារខៀនក្បែរសេចក្តីយោងព្រះគម្ពីរដែលត្រូវគ្នា ។

ដើម្បីជួយសិស្សឲ្យវិភាគ ហើយយល់ពីខគម្ពីរទាំងនេះ សូមសួរសំណួរដូចតទៅនេះ ៖

- **តើការចងចាំពីគំរូដ៏សុចរិតរបស់អ្នកដទៃអាចជួយអ្នកឲ្យជ្រើសរើស « ធ្វើការណ៍ល្អ» ដោយរបៀបណា ?**
- **តើអ្នកធ្វើអ្វីខ្លះដើម្បីចងចាំដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ?**

សូមសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ៖ *ប្រសិនបើយើង . . . សាតាំងនឹងគ្មានអំណាចលើយើងឡើយ ។*

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៥:១២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរបៀបមួយដែលពួកគេអាចបំបេញប្រយោគនៅលើក្តារខៀន ។ ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាក្តី សូមប្រាកដថា ពួកគេបង្ហាញថា **ប្រសិនបើយើងកសាងគ្រឹះរបស់យើងនៅលើព្រះយេស៊ូវគ្រីស្ទ សាតាំងនឹងគ្មានអំណាចលើយើងឡើយ ។** អ្នកអាចឲ្យសិស្សគូសចំណាំឃ្លានៅក្នុង ហេលេមិន ៥:១២ ដែលបង្ហាញពីគោលការណ៍នេះ ។ សូមបង្ហាញថា ហេលេមិន ៥:១២ គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ អ្នកអាចណែនាំឲ្យសិស្សគូរគូសចំណាំវគ្គនេះដើម្បីឲ្យពួកគេអាចរកវាឃើញដោយងាយ ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍ដែលបានបង្រៀននៅក្នុងខនេះ សូមធ្វើប៉មតូចមួយ ឬផ្ទះមួយពីរបស់អ្វីមួយ (ដូចជាប្រអប់ ឬសៀវភៅ) ហើយសួរសំណួរដូចខាងក្រោម ៖

- ហេតុអ្វីបានជាអគារមួយចាំបាច់ត្រូវមានគ្រឹះដ៏រឹងមាំ ?
- តើអ្នកគិតថា ការសង់គ្រឹះយើងលើព្រះយេស៊ូវគ្រីស្ទមានន័យបែបណា?
- តើការសន្យាអ្វីខ្លះដែលត្រូវបានធ្វើឡើងដល់អ្នកដែលសង់គ្រឹះរបស់ខ្លួននៅលើ « សិលានៃព្រះដ៏ប្រោសលោះរបស់យើង » ?
- តើយើងអាចធ្វើអ្វីខ្លះដើម្បីសង់គ្រឹះរបស់យើងនៅលើសិលានៃព្រះយេស៊ូវគ្រីស្ទ ? (អ្នកអាចសួរសិស្សពីរបៀបដែលសេចក្តីពិតបានបង្រៀននៅក្នុង ហេលេមិន ៥:៦–១១ ជាគំរូនៃរបៀបដែលយើងអាចសង់គ្រឹះរបស់យើងនៅលើព្រះយេស៊ូវគ្រីស្ទ) ។

អ្នកអាចបង្ហាញថា ការសង់នៅលើគ្រឹះរបស់ព្រះអង្គសង្គ្រោះនឹងមិនការពារការវាយលុករបស់សាតាំងនោះទេ ប៉ុន្តែវានឹងឲ្យយើងមានកម្លាំងយកឈ្នះលើវា ។

- តើនៅពេលណាដែលអ្នកបានតស៊ូនឹងការល្បួង ឬស៊ូទ្រាំនឹងការសាកល្បង ដោយសារគ្រឹះរបស់អ្នកត្រូវបានសង់លើព្រះយេស៊ូវគ្រីស្ទ ?

សូមថ្លែងទីបន្ទាល់អំពីកម្លាំងដែលអ្នកបានទទួល ដោយសារអ្នកបានសង់គ្រឹះរបស់អ្នកនៅលើសិលានៃព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សមានពេលសរសេរនៅក្នុងកំណត់ហេតុសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេររបស់ពួកគេអំពីរបៀបមួយដែលពួកគេនឹងខិតខំធ្វើតាមដោយឧស្សាហ៍ដើម្បីសង់គ្រឹះរបស់គេនៅលើសិលានៃព្រះដ៏ប្រោសលោះរបស់គេ ។

> **ហេលេមិន ៥:១២** គឺជាវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមសំដៅលើគំនិតក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះដើម្បីជួយសិស្សឲ្យចាំវគ្គនេះ ។

ហេលេមិន ៥:១៤–៥២

ព្រះអម្ចាស់ការពារនីហ្វៃ និងលីហៃនៅក្នុងគុក ហើយសាសន៍លេមិនជាច្រើនបានប្រែចិត្តជឿ

សូមសង្ខេប ហេលេមិន ៥:១៤–១៩ ដោយពន្យល់ថា នីហ្វៃនិងលីហៃបានបង្រៀនដំណឹងល្អដោយអំណាចដ៏អស្ចារ្យនៅក្នុងចំណោមសាសន៍នីហ្វៃ និងសាសន៍លេមិន ។ ជាលទ្ធផល អ្នកប្រឆាំងនឹងសាសន៍នីហ្វៃជាច្រើនបានត្រឡប់មកមានសេចក្តីជំនឿវិញ ។ នៅក្នុងដែនដីសារ៉ាហិមឡា និងតំបន់ជុំវិញ មានសាសន៍លេមិន ៨,០០០ នាក់ត្រូវបានជ្រមុជទឹក ។

សូមចម្លងតារាងខាងក្រោមនៅលើក្តារខៀន ។ សូមបែងចែកសិស្សក្នុងថ្នាក់ជាគូ ហើយសុំឲ្យដៃគូនីមួយៗចម្លងតារាងនៅលើក្តារខៀនដាក់លើក្រដាសមួយ ។ សូមឲ្យដៃគូធ្វើការរួមគ្នាដើម្បីអានវគ្គដែលមាននៅក្នុងតារាង ហើយបន្ទាប់មកសូមគូសរូបធម្មតាមួយ ឬសរសេរសេចក្តីសង្ខេបខ្លីមួយពីអ្វីដែលវគ្គនីមួយៗពិពណ៌នា ។ (នៅពេលសិស្សចម្លងតារាង សូមណែនាំឲ្យពួកគេទុកកន្លែងល្មមនៅក្រោមសេចក្តីយោងព្រះគម្ពីរនីមួយៗសម្រាប់រូបភាព ឬសេចក្តីសង្ខេបរបស់គេ) ។

ហេលេមិន ៥:២០–២១	ហេលេមិន ៥:២២–២៥	ហេលេមិន ៥:២៦–២៨
ហេលេមិន ៥:២៩–៣៤	ហេលេមិន ៥:៣៥–៤១	ហេលេមិន ៥:៤២–៤៤

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបង្ហាញខ្លីៗ ហើយពន្យល់ពីរូបភាព ឬសេចក្តីសង្ខេបរបស់គេដល់ដៃគូសិស្សផ្សេងទៀត ។ ដើម្បីជួយសិស្សឲ្យយល់កាន់តែសឹងជម្រៅក្នុងខគម្ពីរនេះ សូមសួរសំណួរដូចខាងក្រោម ៖

- នៅពេលសាសន៍លេមិនត្រូវបានគ្របដណ្តប់ដោយសេចក្តីងងឹត តើសំឡេងនោះបានទាមទារឲ្យពួកគេធ្វើអ្វី ? (សូមមើល ហេលេមិន ៥:២៩, ៣២) ។
- តើ ហេលេមិន ៥:៣០ ពិពណ៌នាសំឡេងនោះដោយរបៀបណា ?
- តើអ្នកធ្លាប់មានអារម្មណ៍ ឬឮសំឡេងខ្សឹបនៃ « សំឡេងរហៀងនៃភាពស្រទន់ឥតខ្ចោះ » នៅពេលណា ?
- តើអ័មីណាដាប់បានបង្រៀនបងប្អូនប្រុសរបស់គាត់ឲ្យធ្វើអ្វីខ្លះដើម្បីបណ្តេញភាពងងឹតនេះចេញ ?(សូមមើល ហេលេមិន ៥:៤១) ។
- តើមានអ្វីបានកើតឡើង នៅពេលសាសន៍លេមិនបានគោរពតាមការណែនាំរបស់អ័មីណាដាប់ និងបានអនុវត្តសេចក្តីជំនឿលើព្រះគ្រីស្ទនោះ? (សូមមើល ហេលេមិន ៥:៤៣–៤៤) ។

សូមឲ្យសិស្សអាន ហេលេមិន ៥:៤៤–៤៧ ដោយស្ងៀមស្ងាត់ដោយរកមើលពាក្យដែលរៀបរាប់ពីលទ្ធផលខ្លះនៃការប្រែចិត្ត ។

- ចេញពីខគម្ពីរទាំងនេះ តើអ្នករៀនអ្វីខ្លះអំពីការប្រែចិត្ត ? (សូមជួយសិស្សឲ្យរកឃើញសេចក្តីពិតខាងក្រោម ៖ **នៅពេលយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ហើយប្រែចិត្តពីអំពើបាបរបស់យើង នោះព្រះវិញ្ញាណបរិសុទ្ធនឹងបំពេញដួងចិត្តយើងដោយសេចក្តីសុខសាន្ត និងសេចក្តីអំណរ**) ។

សូមសង្ខេប ហេលេមិន ៥:៤៨–៥២ ដោយការពន្យល់ថាសាសន៍លេមិន និងអ្នកប្រឆាំងនឹងសាសន៍នីហ្វៃដែលបានទទួលនូវអព្ពូតហេតុនេះបានចេញទៅ ហើយបម្រើដល់ប្រជាជន ហើយ « សាសន៍លេមិនភាគច្រើន » បានប្រែចិត្តជឿលើដំណឹងល្អ ។

សូមលើកទឹកចិត្តសិស្សឲ្យគិតថា តើពួកគេថ្មីៗនេះមានអារម្មណ៍សុខសាន្ត និងអំណរនៅក្នុងជីវិតរបស់គេដែរទេ ។ ប្រសិនបើពួកគេមិនមានទេ សូមឲ្យពួកគេសញ្ជឹងគិតពីអ្វីដែលពួកគេអាចធ្វើដើម្បីសង់គ្រឹះរបស់គេនៅលើព្រះយេស៊ូវគ្រីស្ទ ហើយបណ្តេញពពកនៃសេចក្តីងងឹតពីជុំវិញពួកគេចេញ ។

ចំណេះចំណានខគម្ពីរ—ហេលេមិន ៥:១២

សូមឲ្យសិស្សអាន ហេលេមិន ៥:១២ ។ ដើម្បីជួយពួកគេឲ្យចាំខគម្ពីរនេះ សូមឲ្យក្រដាសទទេដល់ពួកគេ ។ សូមឲ្យពួកគេសរសេរខនេះនៅលើក្រដាសដោយការប្រើតែរូបភាព និងអក្សរមួយប៉ុណ្ណោះ ។ សម្រាប់ពាក្យដែលណែនាំរូបភាព (ដូចជា *ថ្ម គ្រឹះ ខ្យល់ ព្រិល* និង*ខ្យល់ព្យុះ*) សូមឲ្យពួកគេគូសរូបភាពសាមញ្ញ ។ សម្រាប់ពាក្យដែលមិនណែនាំនូវរូបភាព (ដូចជា *ឥឡូវ* និង*របស់ខ្ញុំ*) សូមឲ្យពួកគេសរសេរអក្សរដំបូងនៃពាក្យនោះ ។ សូមឲ្យសិស្សអនុវត្តការទន្ទេញខគម្ពីរនេះដោយការប្រើតែរូបភាព និងអក្សរដែលពួកគេបានគូស និងសរសេរ ។ អ្នកក៏អាចឲ្យពួកគេប្តូរក្រដាសជាមួយគ្នាទៅវិញទៅមក ហើយទន្ទេញខនេះដោយការប្រើក្រដាសដែលមិត្តរបស់គេបានគូស និងសរសេរនោះ ។ សូមណែនាំសិស្សឲ្យយកក្រដាសនោះទៅផ្ទះ ហើយបិតវានៅកន្លែងដែលពួកគេមើលឃើញញឹកញាប់ដើម្បីពួកគេអាចទន្ទេញវគ្គនេះឲ្យចាំ ។

កំណត់ចំណាំ ៖ ដោយសារតែមេរៀនថ្ងៃនេះវែង អ្នកអាចប្រើសកម្មភាពនេះនៅថ្ងៃក្រោយ នៅពេលអ្នកមានពេលបន្ថែម ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

ហេលេមិន ៥:១២ ។ តើយើងអាចទប់ទល់នឹង « ខ្យល់ដ៏ខ្លាំងក្លា » នៃមារសត្រូវបានដោយរបៀបណា ?

ប្រធាន ស្តែនស៊ើរ ដបុលយូ ឃឹមបឹល បានបង្រៀនថា យើងត្រូវតែតោងឲ្យជាប់ទៅនឹងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនៅពេលមារសត្រូវបញ្ចេញកម្លាំងរបស់វាប្រឆាំងនឹងយើង ៖

« យើងក៏ត្រូវជួបនឹងកម្លាំងដែលបំផ្លាញដ៏ខ្លាំងក្លា ដែលបញ្ចេញដោយមារសត្រូវដែរ ។ រលកនៃអំពើបាប អំពើទុច្ចរិត ភាពអសីលធម៌ ការបន្ថោក ការរំលង ការបោកបញ្ឆោត គម្រោងទុច្ចរិត និងភាពមិនស្មោះត្រង់គំរាមកំហែងយើងគ្រប់គ្នា ។ វាមកដោយមានអំណាច និងល្បឿនដ៏ខ្លាំង ហើយនឹងបំផ្លាញយើង ប្រសិនបើយើងមិនបានប្រុងប្រយ័ត្នទេនោះ ។

« ប៉ុន្តែការព្រមាននឹងបន្លឺដល់យើង ។ វាធ្វើឲ្យយើងប្រុងប្រយ័ត្ន ហើយស្តាប់តាម ព្រមទាំងរត់ចេញពីអំពើអាក្រក់សម្រាប់ជីវិតដ៏អស់កល្បជានិច្ចរបស់យើង ។ បើយើងគ្មានជំនួយទេ យើងមិនអាចទ្រាំទ្រនឹងវាបានទេ ។ យើងត្រូវតែរត់ចេញទៅរកទីទួលខ្ពស់ ឬតោងឲ្យជាប់ទៅនឹងអ្វីដែលអាចរក្សាយើងកុំឲ្យបក់បោកទៅតាមកម្លាំងនោះ ។ អ្វីដែលយើងត្រូវតោងដើម្បីមានសុវត្ថិភាពនោះគឺ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ វាគឺជាការការពាររបស់យើងពីកម្លាំងណាដែលអំពើអាក្រក់អាចបោកបក់មក ។ ព្យាការីដ៏បំផុសគំនិតម្នាក់នៅក្នុងព្រះគម្ពីរមរមនបានទូន្មានដល់ប្រជាជនរបស់គាត់ថា ៖ ‹ ចូរចងចាំចុះថា គឺនៅលើសិលានៃព្រះដ៏ប្រោសលោះនៃយើង គឺព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះ ដែលកូនត្រូវសង់គ្រឹះរបស់កូន ដើម្បីកាលណាអារក្សបញ្ចេញខ្យល់ដ៏ខ្លាំងក្លារបស់វាមក មែនហើយព្ពួញរបស់វានៅក្នុងខ្យល់គួច មែនហើយ កាលណាព្រិល និងខ្យល់ព្យុះកំណាចទាំងអស់របស់វាបោកបក់មកលើនោះវានឹងគ្មានអំណាចមកលើកូនឡើយ ដើម្បីទាញកូនចុះទៅក្នុងជង្ហុកនៃសេចក្តីវេទនា និងទុក្ខលំបាកដ៏មិនចេះចប់មិនចេះហើយ › (ហេលេមិន ៥:១២) » (« Hold Fast to the Iron Rod » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ទំព័រ ៦) ។

ហេលេមិន ៦–៧

សេចក្តីផ្តើម

បន្ទាប់ពីការខិតខំផ្សព្វផ្សាយរបស់នីហ្វៃ និងលីហៃ សាសន៍លេមិនបានកើនឡើងនៅក្នុងសេចក្តីសុចរិត ។ ទោះជាយ៉ាងណាក្តី សាសន៍នីហ្វៃបានក្លាយជាទុច្ចរិត ហើយបានចាប់ផ្តើមគាំទ្រពួកចោរកាឌីអានតុន ហើយព្រះវិញ្ញាណនៃព្រះអម្ចាស់បានដកចេញពីពួកគេ ។ នីហ្វៃបានព្យាករថា ប្រសិនបើសាសន៍នីហ្វៃបន្តរស់នៅក្នុងសេចក្តីទុច្ចរិត ពួកគេនឹងត្រូវបំផ្លាញចោល ។ គាត់ក៏បានព្យាករថា ដោយសារតែសេចក្តីសុចរិតរបស់សាសន៍លេមិន ព្រះអម្ចាស់នឹងមានសេចក្តីមេត្តាករុណាដល់ពួកគេ ហើយរក្សាពួកគេវិញ ។

យោបល់សម្រាប់ការបង្រៀន

ហេលេមិន ៦

សាសន៍លេមិនបានក្លាយជាសុចរិត និងប្រយុទ្ធនឹងពួកចោរកាឌីអានតុន ខណៈដែលសាសន៍នីហ្វៃកើនឡើងនៅក្នុងភាពទុច្ចរិត ហើយគាំទ្រដល់ពួកចោរកាឌីអានតុន

សូមគូសតារាងខាងក្រោមនៅកណ្តាលក្តារខៀន ៖

⇧

ព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់អ្នក

⇩

សូមឲ្យសិស្សរកមើល ហើយគិតអំពីឥរិយាបថ និងសកម្មភាពដែលធ្វើឲ្យមានការកើនឡើងនូវព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់ពួកគេ និងការថយចុះនូវព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។

សូមពន្យល់ថា មរមនបានកត់ត្រាថា ព្រះអម្ចាស់បានដកព្រះវិញ្ញាណរបស់ទ្រង់ចេញពីសាសន៍នីហ្វៃ ហើយចាប់ផ្តើមស្រោចព្រះវិញ្ញាណរបស់ទ្រង់មកលើសាសន៍លេមិន (សូមមើល ហេលេមិន ៦:៣៥–៣៦) ។ សូមរំឭកសិស្សថា សាសន៍នីហ្វៃ « បានក្លាយទៅជាមនុស្សទន់ខ្សោយ ដោយសារតែអំពើរំលងរបស់គេ » (ហេលេមិន ៤:២៦) ។ « ព្រះវិញ្ញាណនៃព្រះអម្ចាស់ឈប់ក្សាគេទៀតហើយ » (ហេលេមិន ៤:២៤) ហើយពួកគេ « បានទុំល្មមសម្រាប់ការបំផ្លិចបំផ្លាញហើយ » (ហេលេមិន ៥:២) ។

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៦:២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលសកម្មភាព និងឥរិយាបថដែលនឹងនាំសាសន៍នីហ្វៃបន្ត « ។ ទុំ ។ ល្មមសម្រាប់ការបំផ្លិចបំផ្លាញដ៏អស់កល្បជានិច្ច » (ហេលេមិន ៦:៤០) ។ នៅពេលសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ សូមឲ្យសិស្សម្នាក់សរសេរចម្លើយរបស់គេនៅខាងក្រោមក្តារខៀន នៅក្រោម ឬនៅក្បែរសញ្ញាព្រួញចុះក្រោម ។ (អ្នកអាចពន្យល់ថាពាក្យ *រំលងខ្លាចបាប* មានន័យថាមិនប្រែចិត្ត ហើយគ្មានការសោកស្តាយ ។

សូមរំឭកសិស្សថា ដោយសារតែការខិតខំផ្សព្វផ្សាយសាសនារបស់នីហ្វៃ និងលីហៃកាលពីឆ្នាំមុន សាសន៍លេមិនរាប់ពាន់នាក់នៅក្នុងដែនដីសារ៉ាហិមឡាបានជ្រមុជទឹក ហើយសាសន៍លេមិនភាគច្រើននៅក្នុងដែនដីនីហ្វៃបានប្រែចិត្តជឿលើដំណឹងល្អ (សូមមើល ហេលេមិន ៥:១៩–២០, ៥០–៥១) ។ សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៦:១, ៣–៥ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលសកម្មភាព និងឥរិយាបថដែលនាំសាសន៍លេមិនឲ្យរីករាយនឹងការកើនឡើងនូវព្រះចេស្តានៃព្រះវិញ្ញាណ ។ នៅពេលសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញហើយ សូមឲ្យសិស្សម្នាក់សរសេរចម្លើយរបស់គេនៅពាក់កណ្តាលនៃក្តារខៀន នៅលើ ឬនៅក្បែរសញ្ញាព្រួញឡើងលើ ។

- តើការរឹងប៉ឹង និងការខ្ជាប់ខ្ជួននៅក្នុងសេចក្តីជំនឿមានន័យយ៉ាងណាចំពោះអ្នក ? (សូមមើល ហេលេមិន ៦:១ ។)
- តើសមាជិកសាសនាចក្របានឆ្លើយតបយ៉ាងណាទៅនឹងការប្រែចិត្តជឿរបស់សាសន៍លេមិន ? (អ្នកអាចបង្ហាញថា ការចែកចាយដំណឹងល្អ និងមានមិត្តភាពល្អនឹងពួកបរិសុទ្ធអាចនាំមកនូវសេចក្តីអំណរដ៏ខ្លាំង ទោះបីជានៅពេលយើងហ៊ុំព័ទ្ធដោយអំពើទុច្ចរិតក្តី ។)

សូមសង្ខេប ហេលេមិន ៦:៧–១៤ ដោយការពន្យល់ថា ប្រហែលរយៈពេលបីឆ្នាំ សាសន៍នីហ្វៃ និងសាសន៍លេមិនបានរីករាយនឹងសន្តិភាព ។ នៅពេលឧស្សាហកម្ម និងជំនួញបានកើនឡើងរវាងពួកគេ ប្រជាជនទាំងពីរបានរីកចម្រើន ។ បន្ទាប់មក នៅក្នុងឆ្នាំទី ៦៦ នៃរជ្ជកាលនៃចៅក្រម នោះមានមេចៅក្រមពីរូបត្រូវបានគេធ្វើឃាត ។ សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៦:១៦–១៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលឥរិយាបថ និងសកម្មភាពបន្ថែមទៀតដែលបណ្តាលមកឲ្យព្រះវិញ្ញាណចាកចេញពីសាសន៍នីហ្វៃ ។ នៅពេលសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ សូមឲ្យសិស្សម្នាក់សរសេរចម្លើយរបស់គេនៅពាក់កណ្តាលខាងក្រោមនៃក្តារខៀន នៅក្រោម ឬនៅក្បែរសញ្ញាព្រួញចុះក្រោម ។

សូមចែកចាយការពិតខាងក្រោមដល់សិស្សរបស់អ្នក ៖

បេះដូងមានសារសំខាន់ដល់ការរស់នៅខាងរាងកាយរបស់យើង ។ វាបូមឈាមតាមរយៈរាងកាយយើង ដើម្បីអុកស៊ីសែន និងជីវជាតិផ្សេងទៀតអាចទៅកាន់កោសិការបស់យើងទាំងអស់ ។ ដោយមានទំហំប្រហែលប៉ុនកណ្តាប់ដៃ បេះដូងរបស់មជ្ឈិមវ័យបូមឈាមជាមធ្យម ៧,៥៧០ លីត្រប្រចាំថ្ងៃ ។ បេះដូងលោតប្រហែល ៧០ ដងក្នុងមួយនាទី ឬប្រហែល ១០០,០០០ ដងក្នុងមួយថ្ងៃ ។

- ដោយដឹងពីលក្ខណៈដ៏សំខាន់នៃបេះដូងក្នុងរាងកាយរបស់អ្នក តើអ្នកនឹងសុខចិត្តធ្វើអ្វីខ្លះដើម្បីរក្សាបេះដូងឲ្យមានសុខភាពល្អ ?

សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖ *ហេលេមិន ៦:១៧, ២១, ២៦, ២៨–៣១* ។ សូមបង្ហាញថា ខគម្ពីរនីមួយ ៗនៅក្នុងសេចក្តីយោងនេះប្រើពាក្យ *ចិត្ត* ឬ*ដូងចិត្ត*, សំដៅលើបេះដូងខាងវិញ្ញាណរបស់យើង ។ សូមឲ្យសិស្សមានពេលសិក្សាខគម្ពីរទាំងនេះ និងសញ្ជឹងគិតដល់ចម្លើយចំពោះសំណួរខាងក្រោម ។ (ដើម្បីចំណេញពេល សូមសរសេរសំណួរទាំងនេះនៅលើក្តារខៀន មុនចាប់ផ្តើមថ្នាក់ ឬរៀបចំវាជាក្រដាសចែកដល់សិស្ស ខណៈសិស្សសិក្សាខគម្ពីរទាំងនេះដែលបានសរសេរនៅលើក្តារខៀន) ។

តើអ្នកគិតថា ហេតុអ្វីបានជាសាតាំងចាប់អារម្មណ៍នឹងចិត្តរបស់កូនចៅព្រះ ?

តើសាសន៍នីហ្វៃបានធ្វើអ្វីខ្លះដែលអាចឲ្យសាតាំងក្តាប់ចិត្តរបស់ពួកគេបាន ? (សូមមើល ហេលេមិន ៦:១៧) ។

តើមានអ្វីខ្លះបានកើតឡើងដល់បុគ្គលម្នាក់ដែលចិត្តរបស់គាត់ត្រូវបានរងឥទ្ធិពល ឬគ្រប់គ្រងដោយសាតាំង ? (សូមមើល ហេលេមិន ៦:២១, ២៨, ៣០–៣១) ។

សូមឲ្យសិស្សពីរបីនាក់ឆ្លើយនឹងសំណួរ ។ បន្ទាប់មកសូមឲ្យសិស្សម្នាក់អានព្ធ ៗនូវសេចក្តីថ្លែងការណ៍ដោយប្រធាន ប៊ិយដ៍ យេ ផាកកឺនៃក្វរ៉ុមនៃពួកដប់សាវកពីរនាក់ ។ សូមឲ្យសិស្សស្តាប់រកមើលដោយប្រុងប្រយ័ត្ននូវរបៀបដែលសាតាំងព្យាយាមល្បួងចិត្តយើង ។

« វាអាចមានវិវរណៈក្លែងបន្លំ ការបំផុសគំនិតមកពីអារក្ស ការល្បួង ! ដរាបណាអ្នកនៅរស់ ទោះតាមរបៀបមួយណាក្តី មារសត្រូវនឹងព្យាយាមដឹកនាំអ្នកឲ្យវង្វេង ។ . . .

« ប្រសិនបើអ្នកធ្លាប់ទទួលបានការបំផុសគំនិតមួយឲ្យធ្វើអ្វីមួយដែលធ្វើឲ្យអ្នក មាន*អារម្មណ៍* ថាមិនស្រណុកក្នុងចិត្ត អ្វីមួយដែលអ្នកដឹងនៅក្នុង *គំនិត*បេស់អ្នកថាខុស ហើយផ្ទុយទៅនឹងគោលការណ៍នៃសេចក្តីសុចរិត សូមកុំឆ្លើយតបនឹងវា ! » (« Personal Revelation: The Gift, the Test, and the Promise » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ទំព័រ ៦១) ។

សូមបន្ថែម *ការស្តាប់តាម និងការចុះចាញ់ការល្បួង* ទៅលើបញ្ជីនៅពាក់កណ្តាលក្តារខៀនខាងក្រោម ។ សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានព្ធ ៗក្នុង ហេលេមិន ៦:២០–២១, ៣៧–៣៨ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលប្រតិកម្មខុសគ្នារវាងសាសន៍លេមិន និងសាសន៍នីហ្វៃចំពោះឥទ្ធិពលនៃពួកចោរកាឌីអានតុន ។

សូមប្រាប់សិស្សថា ក្រោយពីមរមនបានកត់ត្រាអ្វីដែលបានកើតឡើងដល់សាសន៍នីហ្វៃ និងសាសន៍លេមិនហើយ គាត់បានបង្ហាញពីមេរៀនដែលយើងអាចរៀនពីបទពិសោធន៍របស់ពួកគេ ។ សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖

សាសន៍នីហ្វៃបានបាត់បង់ព្រះវិញ្ញាណដោយសារ . . .

ព្រះអម្ចាស់បានស្រោចព្រះវិញ្ញាណរបស់ទ្រង់ទៅលើសាសន៍លេមិនដោយសារ . . .

សូមឲ្យសិស្សអាន ហេលេមិន ៦:៣៤–៣៦ ដោយរកមើលព័ត៌មានដែលនឹងជួយពួកគេឲ្យបំពេញប្រយោគនៅលើក្តារខៀន ។

- ដោយផ្អែកលើអ្វីដែលអ្នកបានអាននៅក្នុងខគម្ពីរទាំងនេះ តើអ្នកនឹងបំពេញប្រយោគទាំងឡាយនៅលើក្តារខៀនដោយរបៀបណា ? (អ្នកអាចបំពេញប្រយោគទាំងឡាយនៅលើក្តារខៀនដោយប្រើចម្លើយរបស់សិស្ស) ។
- តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះអំពីអ្វីដែលយើងអាចធ្វើដើម្បីទទួលបានព្រះវិញ្ញាណគង់នៅជាមួយនឹងយើង? (ទោះបីជាសិស្សអាចមានចម្លើយខុសគ្នាច្រើនក្តី សូមប្រាកដថាពួកគេបង្ហាញថា **នៅពេលយើងជឿ ហើយគោរពតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ទ្រង់នឹងស្រោចព្រះវិញ្ញាណរបស់ទ្រង់មកលើយើង** ។ សិស្សក៏គួរបង្ហាញថា **នៅពេលយើងអនុញ្ញាតឲ្យសាតាំងក្តាប់ដូងចិត្តរបស់យើងបាន នោះព្រះវិញ្ញាណនៃព្រះអម្ចាស់នឹងដកថយចេញពីយើង**) ។

សូមទាញចំណាប់អារម្មណ៍របស់សិស្សទៅលើបញ្ជីដែលពួកគេបានសរសេរនៅខាងលើ និងនៅខាងក្រោមសញ្ញាព្រួញនៅលើក្តារខៀន ។ សូមបង្ហាញថា សកម្មភាព និងឥរិយាបថនៅពាក់កណ្តាលខាងលើនៃក្តារខៀនតំណាងឲ្យឆន្ទៈជឿលើ ហើយគោរពតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ខណៈដែលសកម្មភាព និងឥរិយាបថនៅពាក់កណ្តាលខាងក្រោមនៃក្តារខៀនតំណាងឲ្យអំពើទុច្ចរិត និងដូងចិត្តរឹងរូស ។

- តើអ្នកកំពុងធ្វើអ្វីខ្លះ ដើម្បីអញ្ជើញព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធមកក្នុងជីវិតរបស់អ្នក ហើយធ្វើឲ្យឥទ្ធិពលរបស់សាតាំងនៅក្រៅដូងចិត្តរបស់អ្នក ?
- តើការធ្វើសកម្មភាពមួយនៅលើពាក់កណ្តាលខាងលើនៃក្តារខៀនបានជួយអញ្ជើញព្រះវិញ្ញាណបរិសុទ្ធមកក្នុងជីវិតរបស់អ្នកដោយរបៀបណា ? (អ្នកក៏អាចសុំឲ្យសិស្សសញ្ជឹងគិតថាតើពួកគេបានធ្វើសកម្មភាពណាខ្លះ ឬបានប្រកាន់យកឥរិយាបថណាខ្លះដែលបានសរសេរនៅលើពាក់កណ្តាលខាងក្រោមនៃក្តារខៀន ហើយគិតពីរបៀបដែលវានឹងមានលទ្ធផលធ្វើឲ្យចុះខ្សោយនូវព្រះចេស្តានៃព្រះវិញ្ញាណនៅក្នុងជីវិតរបស់ពួកគេ) ។

សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពីអ្វីមួយដែលពួកគេនឹងធ្វើដើម្បីអញ្ជើញព្រះវិញ្ញាណនៃព្រះអម្ចាស់មកក្នុងជីវិតរបស់ពួកគេ ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមគោលដៅរបស់ពួកគេ ។

ហេលេមិន ៧

នីហ្វៃបង្រៀនដល់សាសន៍នីហ្វៃទុច្ចរិតទាំងឡាយ ហើយបញ្ជាពួកគេឲ្យប្រែចិត្ត

សម្រាប់សំណួរនីមួយៗដូចមានខាងក្រោមនេះ សូមឲ្យសិស្សប្រើព្រះគម្ពីររបស់ពួកគេដើម្បីស្វែងរកចម្លើយឲ្យបានលឿនតាមដែលពួកគេអាចធ្វើទៅបាន ។ សូមណែនាំពួកគេឲ្យឈរ នៅពេលពួកគេបានរកឃើញចម្លើយ ។ សូមហៅសិស្សដែលក្រោកឈរមុនគេឆ្លើយនឹងសំណួរនីមួយៗ ។ បន្ទាប់មក សូមឲ្យសិស្សអង្គុយចុះមុនពេលអ្នកអានសំណួរបន្ទាប់ទៀត ។

- យោងតាម ហេលេមិន ៧:១ តើព្យាការីឈ្មោះអ្វីដែលបានត្រឡប់មកពីដែនដីភាគខាងជើងវិញ ?
- តើឃ្លាមួយណានៅក្នុង ហេលេមិន ៧:២ ពិពណ៌នាពីអ្វីដែលនីហ្វៃបានបង្រៀនប្រជាជននៅក្នុងដែនដីភាគខាងជើង ?
- យោងតាម ហេលេមិន ៧:៣ ហេតុអ្វីបានជានីហ្វៃបានចាកចេញពីដែនដីទៅភូមិភាគខាងជើង ?
- យោងតាម ហេលេមិន ៧:៤ តើនរណាដែលបានទទួលតំណែងជាចៅក្រមនៅពេលនីហ្វៃបានត្រឡប់ទៅកាន់ដែនដីសារ៉ាហិមឡាវិញ ?

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៧:៥ ឮៗហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលរបៀបដែលពួកចោរកាឌីអានតុនបានគ្រប់គ្រងប្រជាជន ។

សូមសង្ខេប ហេលេមិន ៧:៦–១២ ដោយការពន្យល់ថា នៅពេលនីហ្វៃបានឃើញស្ថានភាពប្រជាជនរបស់លោក « នោះចិត្តលោកបានពោរពេញទៅដោយសេចក្តីព្រួយនៅក្នុងទ្រូងលោក » (ហេលេមិន ៧:៦) ។ លោកបានទៅលើប៉មក្នុងសួនច្បាររបស់លោកដើម្បីអធិស្ឋាន ហើយបានទួញយំដោយសារអំពើទុច្ចរិតរបស់ប្រជាជន ។ នៅពេលប្រជាជនបានឮលោកអធិស្ឋាន ហើយទួញយំ នោះមានមនុស្សជាច្រើនបានប្រមូលគ្នាចង់ដឹងពីមូលហេតុដែលលោកបានក្រៀមក្រំយ៉ាងនេះ ។ លោកបានប្រើឱកាសនេះដើម្បីបង្រៀនដល់ពួកគេ ។

សូមឲ្យសិស្សអាន ហេលេមិន ៧:១៥–១៦ ដោយស្ងៀមស្ងាត់ ។

- ហេតុអ្វីបានជានីហ្វៃនិយាយថាប្រជាជន « ត្រូវតែមានចិត្តអស្ចារ្យ » ?
- តើសាតាំងចង់បានអ្វី ?

សូមឲ្យសិស្សឈប់បន្តិច ហើយគិតអំពីរូបភាពដែលនីហ្វៃបានប្រើ ។ ក្រោយពីសាតាំងបានក្តាប់ដួងចិត្តរបស់ប្រជាជនហើយ នោះវាចង់ទាញទម្លាក់ព្រលឹងរបស់ពួកគេចុះទៅក្នុងភាពវេទនាដ៏អស់កល្ប ។

- តើអ្នកគិតថា ហេតុអ្វីបានជានីហ្វៃបានព្រមានប្រជាជនអំពីបំណងរបស់សាតាំង ? តើនីហ្វៃចង់ឲ្យពួកគេចៀសចេញពីអ្វី ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី ហេលេមិន ៧:១៧–២២, ២៦–២៨ ។ សូមឲ្យសិស្សពាក់កណ្តាលថ្នាក់រកមើលអំពើបាបរបស់សាសន៍នីហ្វៃ ហើយសូមឲ្យសិស្សពាក់កណ្តាលថ្នាក់ទៀតរកមើលផលវិបាកដែលនីហ្វៃបានព្រមានថានឹងកើតឡើង ប្រសិនបើប្រជាជនមិនព្រមប្រែចិត្តទេនោះ ។

នៅពេលសិស្សពាក់កណ្តាលថ្នាក់ដំបូងរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញហើយ សូមបង្ហាញពីភាពស្រដៀងគ្នាទៅនឹងអ្វីដែលបានសរសេរនៅពាក់កណ្តាលខាងក្រោមនៃក្តារខៀន ។ នៅពេលសិស្សពាក់កណ្តាលទៀតរៀបរាប់ សូមស្វែងរកសំណួរខាងក្រោមនេះ ៖

- តើឃ្លាអ្វីខ្លះនៅក្នុង ហេលេមិន ៧:២២ ដែលបង្ហាញពីអ្វីមួយដែលព្រះអម្ចាស់ដកយកពីអ្នកទាំងឡាយណាដែលមិនព្រមប្រែចិត្តនោះ ? (អ្នកអាចស្នើសុំឲ្យសិស្សគូសចំណាំឃ្លានេះនៅក្នុងព្រះគម្ពីររបស់គេ) ។
- យោងតាម ហេលេមិន ៧:២៨ តើមានអ្វីខ្លះកើតឡើងនៅពេលប្រជាជនបដិសេធមិនព្រមប្រែចិត្តនោះ ? (ពួកគេនឹងត្រូវវិនាសបង់ ។ អ្នកអាចពន្យល់ថា នៅក្នុងករណីរបស់សាសន៍នីហ្វៃ ការមិនព្រមប្រែចិត្តរបស់ពួកគេមានន័យថា ពួកគេនឹងត្រូវវិនាសបង់ទាំងខាងរាងកាយ និងខាងវិញ្ញាណ) ។

សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***ប្រសិនបើយើងមិនព្រមប្រែចិត្តពីអំពើបាបរបស់យើងទេ នោះយើងនឹងបាត់បង់ការការពារពីព្រះអម្ចាស់ និងពរជ័យទាំងឡាយនៃជីវិតដ៏នៅអស់កល្បជានិច្ច ។***

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍នេះ សូមឲ្យពួកគេពន្យល់ពីផលវិបាកដែលអាចកើតដល់ប្រជាជននៅក្នុងស្ថានភាពខាងក្រោម ៖ (១) យុវជនម្នាក់មិនព្រមសារភាពពីការញៀននឹងរឿងអាសអាភាសរបស់គាត់ឡើយ (២) អាទិភាពដ៏សំខាន់របស់យុវនារីម្នាក់គឺត្រូវក្លាយជាអ្នកល្បីល្បាញ ហើយមានប្រជាប្រិយភាពម្នាក់ ទោះបីជាឪពុកម្តាយនាងបានបង្រៀននាងរឿងផ្សេងពីនេះក្តី (៣) ទោះបីជាគាត់បានស្តាប់តាមការបង្រៀនរបស់ព្យាការីឲ្យធ្វើការសិក្សាស្រាវជ្រាវព្រះគម្ពីរ ហើយអធិស្ឋានក្តី ក៏យុវជនម្នាក់បដិសេធមិនព្រមធ្វើដូច្នោះដែរ ។

សូមឲ្យសិស្សសញ្ជឹងគិតអំពីរបៀបដែលពួកគេអាចត្រូវប្រែចិត្ត ។ សូមលើកទឹកចិត្តពួកគេឲ្យប្រែចិត្ត ដើម្បីឲ្យពួកគេអាចមានកម្លាំង និងការការពារពីព្រះអម្ចាស់នៅក្នុងជីវិតរបស់គេជានិច្ច ។

ហេលេមិន ៨–៩

សេចក្តីផ្តើម

ក្រោយពីនីហ្វៃបានប្រកាសឲ្យប្រជាជនត្រូវតែប្រែចិត្ត បើមិនដូច្នោះទេពួកគេនឹងត្រូវបំផ្លាញ នោះចៅក្រមពុករលួយជាច្រើនចាក់រុកប្រជាជនជាច្រើនឲ្យប្រឆាំងទាស់នឹងគាត់ ។ ប្រជាជនខ្លះការពារគាត់យ៉ាងដាច់ខាត ។ នីហ្វៃបានបង្រៀនថា ប្រជាជនដែលបដិសេធសាក្សីរបស់គាត់ក៏បានបដិសេធនូវទីបន្ទាល់ទាំងឡាយនៃព្យាការីទាំងឡាយដែលបានរស់នៅពីមុនគាត់ ដែរ ព្យាការីទាំងអស់នោះបានធ្វើទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ។ ដើម្បីបង្ហាញថាគាត់គឺជាព្យាការីម្នាក់ នីហ្វៃបានលាតត្រដាងថា មេចៅក្រមត្រូវបានគេធ្វើឃាត ។ នៅពេលសម្តីរបស់នីហ្វៃត្រូវបានបញ្ជាក់ ប្រជាជនខ្លះទទួលស្គាល់គាត់ថាជាព្យាការីម្នាក់ ។

យោបល់សម្រាប់ការបង្រៀន

ហេលេមិន ៨:១–១០

ចៅក្រមពុករលួយទាំងឡាយមានបំណងចាក់រុកប្រជាជនឲ្យប្រឆាំងនឹងនីហ្វៃ

- តើឥទ្ធិពលមួយចំនួនដែលព្យាយាមបញ្ចុះបញ្ចូលអ្នកមិនឲ្យជឿលើពាក្យសម្តីរបស់ព្យាការីនោះមានអ្វីខ្លះ ?

នៅពេលសិស្សពិភាក្សាសំណួរនេះ សូមឲ្យសិស្សម្នាក់សរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ សូមឲ្យសិស្សរកមើលទីសម្គាល់អំពីអ្វីដែលពួកគេគួរធ្វើ នៅពេលពួកគេដូចនឹងឥទ្ធិពលដូចដែលពួកគេនឹងអាននៅក្នុង ហេលេមិន ៨ នាពេលសព្វថ្ងៃនេះ ។

សូមរំឭកសិស្សថា នីហ្វៃបានថ្លែងសារលិខិតនៃការប្រែចិត្តដ៏ដោយម៉ឺងម៉ាត់មួយដល់ប្រជាជនរបស់គាត់ (សូមមើល ហេលេមិន ៧) ។ សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗពី ហេលេមិន ៨:១–៦ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពីរបៀបដែលចៅក្រមមានប្រតិកម្មទៅនឹងការបង្រៀនរបស់នីហ្វៃ ។ អ្នកអាចបង្ហាញថា ចៅក្រមខ្លះជាបក្សពួកនៃក្រុមសម្ព័ន្ធសម្ងាត់ពួកចោរកាឌីអានតុន ។

- តើសារលិខិតរបស់ចៅក្រមទៅកាន់ប្រជាជនមានអ្វីខ្លះ ? (ពួកគេបានព្យាយាមបញ្ចុះបញ្ចូលប្រជាជនឲ្យខឹងនឹងនីហ្វៃ) ។
- យោងតាម ហេលេមិន ៨:៤, តើហេតុអ្វីបានជាចៅក្រមមិនដាក់ទោសនីហ្វៃ ?

សូមឲ្យសិស្សគិតអំពីអ្វីដែលពួកគេនឹងធ្វើ ប្រសិនបើមាននរណាម្នាក់ព្យាយាមបញ្ចុះបញ្ចូលពួកគេមិនឲ្យស្តាប់តាមពាក្យសម្តីរបស់ព្យាការី ។

សូមប្រាប់សិស្សថា ប្រជាជនខ្លះបាននិយាយប្រឆាំងនឹងគំនិតរបស់ចៅក្រម ។ សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៨:៧–៩ ឮៗ ។ សូមបង្ហាញថា ដូចជាប្រជាជនខ្លះនៅក្នុងហ្វូងមនុស្សនោះដែរ *យើងអាចបង្កើនសំឡេងរបស់យើងដើម្បីគាំទ្រព្យាការី ទោះបីជានៅពេលដែលវាជារឿងដែលគេមិនស្រឡាញ់ក៏ដោយ* ។

- នៅក្នុងជីវិតរបស់អ្នក តើអ្នកធ្លាប់បានតំឡើងសំឡេងរបស់អ្នកគាំទ្រព្យាការីដែលកំពុងរស់នៅដែរឬទេ ទោះបីជាការបង្រៀនរបស់គាត់មិនមានប្រជាប្រិយភាពក្តីនោះ ? តើការណ៍នេះបានធ្វើឲ្យមានភាពខុសគ្នាយ៉ាងណានៅក្នុងជីវិតរបស់អ្នក ? តើវាជះឥទ្ធិពលដល់អ្នកដទៃដោយរបៀបណា ?

សូមឲ្យសិស្សអាន ហេលេមិន ៨:១០ ដោយស្ងៀមស្ងាត់ដើម្បីរកមើលពីរបៀបដែលពាក្យសម្តីរបស់ប្រជាជនទាំងនេះធ្វើឲ្យមានភាពខុសគ្នា ។

- តើមានភាពខុសគ្នាយ៉ាងណា នៅពេលប្រជាជនខ្លះបានគាំទ្រដល់ព្យាការីនោះ ? តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីធ្វើរឿងបែបនេះក្នុងពេលសព្វថ្ងៃ ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ អិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« យើងត្រូវចាំដល់សម្តីរបស់អេដមុន ប៊ូក ថា ៖ ‹ រឿងចាំបាច់តែមួយគត់សម្រាប់ជោគជ័យរបស់អំពើអាក្រក់នោះគឺធ្វើឲ្យមនុស្សល្អមិនធ្វើអ្វីទាំងអស់ › ។ | Attributed in John Bartlett, comp., *Familiar Quotations,* 15th ed. (ឆ្នាំ ១៩៨០), lx ។ | យើងត្រូវបន្លឺសំឡេងរបស់យើងជាមួយនឹងពលរដ្ឋដទៃទៀតនៅទូទាំងពិភពលោកដែលខ្វល់ខ្វាយ ដើម្បីប្រឆាំងនឹងនិន្នាការនាពេលថ្មីៗនេះ ។ យើងត្រូវប្រាប់អ្នកឧបត្ថម្ភការចាក់ផ្សាយដ៏មិនល្អទាំងឡាយថា យើងទទួលបានគ្រប់គ្រាន់ហើយ ។ យើងត្រូវគាំទ្រកម្មវិធី និងការជជែកដែលវិជ្ជមាន និងលើកតម្កើង ។ ដោយចូលរួមជាមួយគ្នានឹងអ្នកជិតខាង និងមិត្តភក្តិដែលចែកចាយពីការខ្វាយខ្វល់ទាំងឡាយ យើងអាចផ្ញើសារលិខិតដ៏ច្បាស់មួយទៅដល់អ្នកដែលទទួលខុសត្រូវ » (« Let Our Voices Be Heard » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៣ ទំព័រ ១៨) ។

- តើយើងអាចប្រឆាំងនឹងឥទ្ធិពលដែលមានបំណងបញ្ចុះបញ្ចូលយើងឲ្យប្រឆាំងនឹងពាក្យសម្តីរបស់ព្យាការីដោយរបៀបណា ?
- តើមានរបៀបដ៏សមរម្យណាខ្លះដើម្បីនិយាយប្រឆាំងនឹងឥទ្ធិពលអាក្រក់ និងគាំទ្រដល់ពាក្យសម្តីរបស់ព្យាការី ?

សូមឲ្យសិស្សប្រាប់ពីពេលមួយដែលពួកគេ ឬនរណាម្នាក់ដែលគេស្គាល់បានក្រោកឈរឡើងប្រឆាំងនឹងឥទ្ធិពលបែបនោះ ។

ហេលេមិន ៨:១១–២៤

ហេលេមិនបង្រៀនថា ព្យាការីទាំងអស់ថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៨:១៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយរកមើលអ្វីដែលនីហ្វៃបាននិយាយថា ប្រជាជនបានបដិសេធ ។ សូមបង្ហាញសិស្សរូបភាពម៉ូសេ និងសត្វពស់លង្ហិន (៦២០២ *សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ | លេខកូដ ១៦) ។ សូមឲ្យពួកគេអាន ហេលេមិន ៨:១៤–១៥ ហើយរកមើលអ្វីដែលម៉ូសេបានបង្រៀនអំពីព្រះអង្គសង្គ្រោះ ។

- តើមានរបៀបអ្វីខ្លះ ដែលបុគ្គលម្នាក់អាច « នឹងសម្លឹងមើលទៅព្រះរាជបុត្រានៃព្រះដោយនូវសេចក្តីជំនឿ » ?
- ដើម្បីមាន « វិញ្ញាណទន់ទាប » ដូចដែលបានបង្ហាញនៅក្នុង ហេលេមិន ៨:១៥ គឺត្រូវបន្ទាបខ្លួន ប្រែចិត្ត ហើយទទួលយកតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ ។ ហេតុអ្វីបានជាគំរិយាបថនេះសំខាន់ នៅពេលយើងសម្លឹងមើលទៅព្រះអង្គសង្គ្រោះ ?
- តើការដឹងពីបេសកកម្មរបស់ព្រះអង្គសង្គ្រោះអាចជួយយើងឲ្យប្រឆាំងនឹងអំពើអាក្រក់បានដោយរបៀបណា ?

សូមឲ្យសិស្សនិយាយការបង្រៀននៅក្នុង ហេលេមិន ៨:១៥ ម្តងទៀត ដោយនិយាយពីសម្ពីខ្លួនឯង ។ ឧទាហរណ៍ ពួកគេអាចនិយាយថា **ប្រសិនបើយើងផ្តោតទៅលើព្រះយេស៊ូវគ្រីស្ទ ហើយអនុវត្តសេចក្តីជំនឿទៅលើទ្រង់ យើងនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។**

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៨:១៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្នកផ្សេងទៀតដែលបានបង្រៀននូវសារលិខិតដែលបានបង្ហាញនៅក្នុង ហេលេមិន ៨:១៥ ។ ហើយបន្ទាប់មក សូមឲ្យសិស្សសិក្សាត្រួសៗក្នុង ហេលេមិន ៨:១៧–២២ រកមើលឈ្មោះនៃព្យាការីផ្សេងទៀតដែលបានថ្លែងទីបន្ទាល់អំពីព្រះគ្រីស្ទ ។ សូមឲ្យសិស្សពិចារណាពីទីបន្ទាល់ជាច្រើនអំពីព្រះយេស៊ូវគ្រីស្ទ ដែលពួកគេបានអាន ឬបានឮពីព្យាការីពីបុរាណ និងព្យាការីថ្ងៃចុងក្រោយទាំងឡាយ ។

សូមពន្យល់ថា មនុស្សជាច្រើនបានបដិសេធនីហ្វៃ និងសារលិខិតរបស់គាត់ ។ សូមឲ្យសិស្សអាន ហេលេមិន ៨:២៤–២៦ ហើយរកមើលផលវិបាកដែលសាសន៍នីហ្វៃបានជួប ដោយសារពួកគេបានបដិសេធទីបន្ទាល់របស់ព្យាការីទាំងឡាយ ។

- តើអ្នកគិតថា ហេតុអ្វីបានជាអ្នកទាំងឡាយដែលបដិសេធនសេចក្តីពិត ហើយបះបោរប្រឆាំងនឹងព្រះម្តងហើយម្តងទៀតជួបនឹងផលវិបាកដ៏ធ្ងន់ធ្ងរបែបនេះ ?
- តើសារលិខិតរបស់ព្យាការីបានជួយអ្នកឲ្យងាកមករកព្រះអម្ចាស់វិញនៅពេលណា ?

សូមឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេអាចខិតខំបន្ថែមទៀតដើម្បីងាកមករកព្រះអង្គសង្គ្រោះវិញ ។ សូមលើកទឹកចិត្តពួកគេឲ្យផ្តោតលើរបៀបមួយដែលពួកគេនឹងកែលម្អនៅក្នុងសប្តាហ៍ក្រោយ ។

សូមឲ្យសិស្សមានពេលសញ្ជឹងគិត

សូមសួរដោយប្រុងប្រយ័ត្ននូវសំណួររូបមន្តដែលបណ្តុះគំនិត ។ សំណួរខ្លះអាចត្រូវឲ្យសិស្សយកពេលសញ្ជឹងគិតមុននឹងពួកគេឆ្លើយតប ។ នៅក្នុងករណីបែបនោះ អ្នកអាចនិយាយថា « សូមគិតបន្តិចអំពីចម្លើយរបស់អ្នក ហើយបន្ទាប់មកខ្ញុំនឹងសួរពីចម្លើយ » ។

ហេលេមិន ៨:២៥–៩:៤១

នីហ្វៃបង្ហាញថា មេចៅក្រមត្រូវបានធ្វើឃាត

សូមសង្ខេប ហេលេមិន ៨:២៥–២៨ ដោយការពន្យល់ថា ជាភស្តុតាងថា ប្រជាជនស្ថិតនៅក្នុងស្ថានភាពដ៏មានបាបមួយ ហើយថានីហ្វៃបាននិយាយប្រាប់ពីព្រះបន្ទូលព្រះ នោះនីហ្វៃបានបង្ហាញថា មេចៅក្រមត្រូវបានគេធ្វើឃាត ។ សូមចាត់សិស្សជាដៃគូ ។ សូមឲ្យដៃគូនីមួយៗស្រមៃថា ពួកគេជាអ្នកសើបអង្កេតម្នាក់លើករណីនេះ ដើម្បីរកមើល ហើយសម្រេចចិត្តថាតើនរណាជាអ្នកសម្លាប់មេចៅក្រម ។ សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ឬបញ្ចូលវានៅលើក្រដាសសម្រាប់ចែកឲ្យដៃគូនីមួយៗ ។

ថ្ងៃទីមួយនៃការស៊ើបអង្កេត ៖

១. នៅពេលមនុស្សប្រាំនាក់បានស៊ើបអង្កេតលើការប្រកាសរបស់នីហ្វៃ តើពួកគេបានរកឃើញអ្វីខ្លះ ? ហេតុអ្វីបានជាពួកគេបានដួលទៅលើដី ? (សូមមើល ហេលេមិន ៩:១–៥) ។

២. តើប្រជាជនសង្ស័យថានរណាជាឃាតករ ? (សូមមើល ហេលេមិន ៩:៧–៩) ។

ថ្ងៃទីពីរនៃការស៊ើបអង្កេត ៖

៣. តើនរណាត្រូវបានគេដោះលែង ? (សូមមើល ហេលេមិន ៩:១០–១៣, ១៨) ។

៤. តើនរណាត្រូវបានចោទប្រកាន់ ? (សូមមើល ហេលេមិន ៩:១៦–១៧, ១៩) ។

៥. តើព័ត៌មានបន្ថែមអ្វីខ្លះដែលនីហ្វៃបានចែកចាយ ? (សូមមើល ហេលេមិន ៩:២៥–៣៦) ។

៦. តើនរណាជាឃាតករ ? (សូមមើល ហេលេមិន ៩:៣៧–៣៨) ។

សូមឲ្យដៃគូស្វែងរកចម្លើយនៅក្នុងសំណួរទី ១ និងទី ២ ។ នៅពេលពួកគេមានពេលគ្រប់គ្រាន់ហើយ សូមសួរ ៖

- នៅពេលបុរសទាំងប្រាំនាក់នោះបានរកឃើញឃាតករដែលសម្លាប់មេចៅក្រម តើពួកគេជឿលើអ្វី ? តើពួកគេភ័យខ្លាចអ្វី ? (សូមមើល ហេលេមិន ៩:៥) ។

សូមឲ្យដៃគូឆ្លើយសំណួរទាំងអស់ដើម្បីបំពេញការស៊ើបអង្កេតរបស់គេ ។ រួចសួរថា ៖

- យោងតាមនីហ្វៃ តើសឺរអានទុមបាននិយាយអ្វីខ្លះ ក្រោយពីការសារភាពកំហុសរបស់ខ្លួនមក ? (សូមមើល ហេលេមិន ៩:៣៦) ។
- យោងតាម ហេលេមិន ៩:៣៩–៤១ហេតុអ្វីបានជាមនុស្សខ្លះជឿតាមនីហ្វៃ ?

សូមឲ្យសិស្សសង្ខេបពីអ្វីដែលពួកគេបានរៀននៅក្នុង ហេលេមិន ៩ អំពីពាក្យសម្តីរបស់ព្យាការី ។ សិស្សអាចបង្ហាញគំនិតជាច្រើនខុសៗគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេរកឃើញនូវគោលការណ៍ខាងក្រោម ៖ ពាក្យសម្តីរបស់ព្យាការីនឹងត្រូវបានបំពេញ ។ ដើម្បីបញ្ជាក់ពីសេចក្តីពិតនេះ អ្នកអាចឲ្យសិស្សអាន គោលលទ្ធិ និង សេចក្តីសញ្ញា ១:៣៧–៣៨ ។

- **តើបទពិសោធន៍អ្វីខ្លះដែលបានពង្រឹងទីបន្ទាល់របស់អ្នកថា យើងមានព្យាការីនៅលើផែនដីសព្វថ្ងៃនេះ ?**

សូមបញ្ចប់ជាមួយនឹងទីបន្ទាល់របស់អ្នកថា ពាក្យសម្តីព្យាការីនឹងត្រូវបានបំពេញ ។

សេចក្តីពន្យល់ និង ព័ត៌មានសាច់រឿង

ហេលេមិន ៨:១៤–១៥ ។ « សត្វពស់លង្ហិន »

នៅពេលនីហ្វៃបាននិយាយអំពីម៉ូសេដែលបានលើក « សត្វពស់លង្ហិន » ឡើង នោះលោកបានសំដៅទៅលើគ្រាមួយដែលកូនចៅអ៊ីស្រាអែលត្រូវបានញ៉ាំញីដោយ « ពស់ភ្លើង » (សូមមើល ជនគណនា ២១:៦–៩ សូមចំណាំថាពាក្យ*លង្ហិន* មានន័យថាទង់ដែង) ។ ការផ្តើមចំពោះបញ្ហារបស់សាសន៍អ៊ីស្រាអែលគឺថា ពួកគេបាននិយាយអាក្រក់អំពីព្រះ និងព្យាការីរបស់ទ្រង់ (សូមមើល ជនគណនា ២១:៥) ។ អ្នកទាំងឡាយណាដែលមើលទៅរូបពស់លង្ហិននោះនឹងបានជាសះស្បើយ ហើយអ្នកទាំងឡាយណាដែលមិនមើលទេនឹងត្រូវវិនាសបង់ (សូមមើល ជនគណនា ២១:៩, នីហ្វៃទី ១ ១៧:៤១) ។

ដូចជាសាសន៍អ៊ីស្រាអែលទាំងនោះដែរ មនុស្សជាច្រើននៅក្នុងសម័យរបស់នីហ្វៃបាននិយាយប្រឆាំងទាស់នឹងព្រះ និងព្យាការីរបស់ទ្រង់ ។ នៅពេលនីហ្វៃលើកឡើងពីដំណើររឿងនៃសត្វពស់លង្ហិននេះ លោកបានបញ្ជាក់ថា ប្រជាជនរបស់គាត់ « នឹងសម្លឹងមើលទៅព្រះរាជបុត្រានៃព្រះដោយនូវសេចក្តីជំនឿ » ហើយរស់នៅតាម (ហេលេមិន ៨:១៥, សូមមើលផងដែរ យ៉ូហាន ៣:១៤–១៥ ដែលព្រះយេស៊ូវគ្រីស្តទ្រង់ផ្ទាល់បានយោងទៅលើសត្វពស់លង្ហិនមួយជាទីសម្គាល់នៃការមកដល់នៃការឆ្កាងរបស់ទ្រង់ ។ ព្រះយេស៊ូវគ្រីស្ត ព្រះយេស៊ូវគ្រីស្ត) ។ បន្ទាប់មក នីហ្វៃបានរំឭកប្រជាជនថា ព្យាការីទាំងអស់បានធ្វើទីបន្ទាល់អំពីព្រះគ្រីស្ត (សូមមើល ហេលេមិន ៨:១៦–២៣) ។

គំនិតបន្ថែមទាំងឡាយសម្រាប់ការបង្រៀន

ហេលេមិន ៧–៩ ។ ការចាក់វីដេអូ

ជំនួសឲ្យការប្រើសកម្មភាពការសើបអង្កេតនៅក្នុងមេរៀននេះ អ្នកអាចចាក់វីដេអូដែលមានចំណងជើងថា « The Pride Cycle » ដែលជាការបង្ហាញមួយនៃដំណើររឿងនៅក្នុងហេលេមិន ៧–៩ និងខគម្ពីរពីរបីដំបូងនៅក្នុង ហេលេមិន ១០ ។ វីដេអូនេះមាននៅក្នុង *Book of Mormon DVD Presentations 1–19* (៥៤០១១) និង LDS.org ។

មេរៀនសិក្សានៅផ្ទះ

ហេលេមិន ១–៩ (មេរៀនទី ២២)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមស្តីពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេសិក្សា ហេលេមិន ១–៩ (មេរៀនទី ២២) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ហេលេមិន ១–២)

នៅពេលសិស្សសិក្សាពីទំនាស់ខាងនយោបាយ និងឃាតកម្មនៅក្នុងចំណោមសាសន៍នីហ្វៃ និង ការវាយយកទីក្រុងសារ៉ាហិមឡាដោយសាសន៍លេមិន ពួកគេបានរៀនថា ការទាស់ទែងគ្នាគឺជាការបែកបាក់ ហើយវាធ្វើឲ្យយើងងាយនឹងរងគ្រោះពីមារសត្រូវ ។ ពួកគេក៏បានរៀនដែរថា បក្សពួនសម្ងាត់អាចនាំទៅរកការបំផ្លាញជាច្រើនក្នុងសង្គម ។

ថ្ងៃទី ២ (ហេលេមិន ៣–៤)

ដោយការសិក្សាពីរបៀបដែលសាសន៍ដ៏ឯកសារដើរតាមព្រះអង្គសង្គ្រោះបានស៊ូទ្រាំនឹងការបៀតបៀនជាច្រើន សិស្សបានរៀនថា ទោះបីជាមានការបៀតបៀន និងការសាកល្បងក្តី ក៏សេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទអាចកើនឡើង នៅពេលយើងអំពាវនាវរហៀព្រះដោយបន្ទាបខ្លួន និងបែរដួងចិត្តរបស់យើងទៅរកទ្រង់ ។ នៅពេលសិស្សបានសិក្សាពីរបៀបដែលការកើនឡើងនូវភាពឆ្មើងឆ្មៃរបស់សាសន៍នីហ្វៃបានធ្វើឲ្យសាសន៍លេមិនទទួលបានដែនដីពាក់កណ្តាលពីសាសន៍នីហ្វៃ ពួកគេបានរៀនថា ភាពឆ្មើងឆ្មៃ និងអំពើទុច្ចរិតធ្វើឲ្យយើងឃ្លាតឆ្ងាយពីព្រះវិញ្ញាណនៃព្រះអម្ចាស់ ហើយទុកឲ្យយើងប្រើកម្លាំងរបស់យើងផ្ទាល់ ។

ថ្ងៃទី ៣ (ហេលេមិន ៥)

ដោយសិក្សាពីការណែនាំដែលហេលេមិនបានផ្តល់ទៅដល់កូនប្រុសរបស់គាត់នីហ្វៃ និង លីហៃ សិស្សបានរៀនថា ប្រសិនបើយើងសង់គ្រឹះរបស់យើងនៅលើព្រះយេស៊ូវគ្រីស្ទ សាតាំងនឹងគ្មានអំណាចមកលើយើងឡើយ ។ តាមរយៈព្រះចេស្តានៃព្រះ និងសេចក្តីជំនឿ ហើយនិងការខិតខំផ្សព្វផ្សាយសាសនារបស់នីហ្វៃ និងលីហៃ សាសន៍លេមិនជាច្រើនបានប្រែចិត្ត ។ សិស្សបានរៀនថា នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយប្រែចិត្តពីអំពើបាបរបស់យើង នោះព្រះវិញ្ញាណបរិសុទ្ធនឹងបំពេញដួងចិត្តយើងដោយសេចក្តីសុខសាន្ត និងសេចក្តីអំណរ ។

ថ្ងៃទី ៤ (ហេលេមិន ៦–៩)

សិស្សបានរៀនថា នៅពេលយើងជឿ ហើយគោរពតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ នោះទ្រង់នឹងចាក់ស្រោចព្រះវិញ្ញាណរបស់ទ្រង់មកលើយើង ។ នីហ្វៃបានព្រមានពួកសាសន៍នីហ្វៃដ៏ទុច្ចរិតអំពីលទ្ធផលនៃអំពើទុច្ចរិតរបស់គេ ហើយបញ្ជាក់ថា ប្រសិនបើយើងមិនព្រមប្រែចិត្តពីអំពើបាបរបស់យើងទេ យើងនឹងបាត់បង់ការការពាររបស់ព្រះអម្ចាស់ និងពរជ័យនៃជីវិតដ៏នៅអស់កល្បជានិច្ច ។ ក្រោយពីបានស្តាប់ពាក្យសម្តីរបស់នីហ្វៃ មនុស្សខ្លះបានក្រោកឈរឡើងគាំទ្រគាត់ ។ សិស្សបានរៀនថា ប្រសិនបើយើងប្រឆាំងនឹងអំពើអាក្រក់ យើងអាចការពារាំងវាពីការបន្តទៅទៀតបាន ។ នីហ្វៃបានព្រមានប្រជាជនថា ព្យាការីជាច្រើនបានថ្លែងទីបន្ទាល់អំពីព្រះអង្គសង្គ្រោះ ហើយបានបង្រៀនថា នៅពេលយើងផ្តោតលើព្រះយេស៊ូវគ្រីស្ទ ហើយអនុវត្តសេចក្តីជំនឿលើទ្រង់ នោះយើងនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។ ចេញពីការបង្រៀនរបស់នីហ្វៃដែលបានកត់ត្រានៅក្នុង ហេលេមិន ៧–៩ សិស្សបានរៀនថា ពាក្យសម្តីរបស់ព្យាការីនឹងត្រូវបានបំពេញ ។

សេចក្តីផ្តើម

នៅក្នុងចំណោមការទាស់ទែងគ្នា និងអំពើទុច្ចរិតដែលកំពុងរីកចម្រើន នីហ្វៃបានបង្រៀនកូនប្រុសរបស់គាត់ថា គ្រឹះនៃសេចក្តីជំនឿរបស់ពួកគេគួរសង់នៅលើព្រះយេស៊ូវគ្រីស្ទ ។ ការបង្រៀនរបស់នីហ្វៃអំពីការប្រែចិត្ត និងការស្តាប់តាមពាក្យសម្តីរបស់ព្យាការីនៃព្រះអម្ចាស់ មានសារសំខាន់ដល់សុភមង្គលរបស់មនុស្ស ។

យោបល់សម្រាប់ការបង្រៀន

ហេលេមិន ១–៥

សាសន៍នីហ្វៃរងភាពបរាជ័យដោយសារតែការទាស់ទែងគ្នា និងអំពើទុច្ចរិត ។ សាសន៍លេមិនជាច្រើនបានប្រែចិត្តជឿនៅពេលនីហ្វៃ និងលីហៃផ្សាយដំណឹងល្អ

សូមឲ្យសិស្សសញ្ជឹងគិតពីមូលហេតុដែលអគារខ្លះនៅរឹងមាំរយៈពេលយូរ ខណៈអគារផ្សេងទៀតត្រូវរលំ ។ រួចសួរថា ៖ ហេតុអ្វីបានជាវាសំខាន់ដែលអគារមួយត្រូវមានគ្រឹះដ៏មាំមួន ?

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៥:១២ ឮៗ ។ ដោយសារនេះគឺជាវគ្គចំណេះចំណានខគម្ពីរមួយ សូមឲ្យសិស្សពីរបីនាក់ព្យាយាមសូត្រវា ។ សូមលើកទឹកចិត្តពួកគេឲ្យព្យាយាម ទោះបីជាពួកគេមិនអាចចាំវាទាំងអស់ក្តី ។ បន្ទាប់មក សួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- តើការសន្យានៅក្នុងខគម្ពីរនេះមានអ្វីខ្លះ ប្រសិនបើយើងសង់ជីវិតយើងនៅលើគ្រឹះរបស់ព្រះយេស៊ូវគ្រីស្ទ ? (ចម្លើយរបស់សិស្សអាចបង្ហាញថា **ប្រសិនបើយើងសង់គ្រឹះរបស់យើងនៅលើព្រះយេស៊ូវគ្រីស្ទ នោះសាតាំងនឹងគ្មានអំណាចមកលើយើងឡើយ) ។**
- តើអ្នកបានធ្វើអ្វីខ្លះដើម្បីសាងជីវិតរបស់អ្នកនៅលើគ្រឹះរបស់ព្រះយេស៊ូវគ្រីស្ទ ?

សូមឲ្យសិស្សប្រាប់អំពីពេលដែលទីបន្ទាល់របស់គេអំពីព្រះអង្គសង្គ្រោះបានជួយពួកគេឲ្យយកឈ្នះលើការល្បួង ឬតស៊ូនឹងឧបសគ្គ ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីកម្លាំងខាងវិញ្ញាណដែលអ្នកបានទទួល ដោយសារអ្នកបានសាងជីវិតរបស់អ្នកលើគ្រឹះរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមលើកទឹកចិត្តឲ្យសិស្សគិតពីរបៀបមួយ ឬច្រើនដែលពួកគេនឹងខំសាងជីវិតរបស់គេនៅលើសិលានៃព្រះគ្រីស្ទឲ្យកាន់តែប្រសើរ ។

ហេលេមិន ៦–៧

សាសន៍លេមិនបានក្លាយជាសុចរិតច្រើនជាងមុន ខណៈដែលសាសន៍នីហ្វៃក្លាយទៅជាទុច្ចរិតជាងមុន នីហ្វៃបង្រៀនដល់សាសន៍នីហ្វៃទុច្ចរិត ហើយបញ្ជាឲ្យពួកគេប្រែចិត្ត

សូមរំឭកសិស្សថា ខណៈដែលសាសន៍លេមិនជាច្រើនបានប្រែចិត្ត ហើយបានរឹងមាំនៅក្នុងដំណឹងល្អ នោះសាសន៍នីហ្វៃបានរស់នៅក្នុងអំពើទុច្ចរិត ហើយព្រះវិញ្ញាណបរិសុទ្ធបានដកថយចេញពីពួកគេ ។ សូមឲ្យសិស្សគិតអំពីពេលមួយនៅក្នុងជីវិតរបស់គេ នៅពេលពួកគេមានអារម្មណ៍ថាព្រះវិញ្ញាណបានដកថយចេញពីពួកគេដោយសារតែដម្រើសរបស់ពួកគេ ។

សូមពន្យល់ថា នៅពេលនីហ្វៃបានឃើញពីស្ថានភាពរបស់ប្រជាជនគាត់ « នោះចិត្តលោកពោរពេញទៅដោយសេចក្តីព្រួយនៅក្នុងទ្រូងលោក » (ហេលេមិន ៧:៦) ។ លោកបានចេញទៅប៉មនៅក្នុងសួនច្បាររបស់លោកដើម្បីអធិស្ឋាន ហើយទូញយំចំពោះអំពើទុច្ចរិតរបស់ប្រជាជន ។ ហ្វូងមនុស្សបានប្រមូលគ្នាជុំវិញលោក ហើយនីហ្វៃបានប្រើឱកាសនេះដើម្បីបង្រៀនដល់ពួកគេ ។

សូមឲ្យសិស្សម្នាក់ឡើងមកខាងមុខថ្នាក់ជាតំណាងឲ្យនីហ្វៃនៅលើប៉មលោក ។ សូមឲ្យសិស្សនោះអាន ហេលេមិន ៧:២៥–២៦, ២៦–២៨ ឮៗនៅពេលសិស្សក្នុងថ្នាក់ផ្សេងទៀតមើលតាម ។ មុនពេលសិស្សនោះអាន សូមបំបែកសិស្សជាពីក្រុម ។ សូមឲ្យសិស្សក្រុមទីមួយរកមើលអ្វីដែលនីហ្វៃបានបង្រៀនដែលជាអំពើបាបរបស់សាសន៍នីហ្វៃ ហើយសុំឲ្យក្រុមទីពីររកមើលលទ្ធផលដែលនីហ្វៃបានថ្លែងថានឹងកើតឡើង ប្រសិនបើសាសន៍នីហ្វៃមិនព្រមប្រែចិត្តទេនោះ ។ បន្ទាប់មក សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

ក្រោយពីសិស្សបានឆ្លើយ សូមឲ្យពួកគេនិយាយពីគោលការណ៍ដែលយើងអាចរៀនពីដំណើររឿងនេះ ។ សិស្សអាចចែកចាយនូវគោលការណ៍ខុសគ្នា ប៉ុន្តែពួកគេគួរបង្ហាញថា **ប្រសិនបើយើងមិន**

ព្រមប្រែចិត្តពីអំពើបាបរបស់យើង នោះយើងនឹងបាត់បង់ការការពារ និងពរជ័យទាំងឡាយនៃជីវិតដ៏នៅអស់កល្បជានិច្ច ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍នេះ សូមឲ្យពួកគេពន្យល់ពីផលវិបាកដែលនឹងកើតឡើងដល់ប្រជាជននៅក្នុងស្ថានភាពខាងក្រោម ៖ (១) យុវជនម្នាក់មិនព្រមប្រែចិត្តពីការញៀននឹងរូបអាសគ្រាម ។ (២) អាទិភាពដ៏ចម្បងរបស់យុវនារីម្នាក់គឺត្រូវក្លាយជាអ្នកល្បីល្បាញ និងមានប្រជាប្រិយភាពម្នាក់ ទោះបីជាត្រូវបានបង្រៀនដោយឪពុកម្តាយនាងខុសគ្នាក្តី ។ (៣) យុវជនម្នាក់បានស្តាប់តាមការណែនាំរបស់ព្យាការីក្នុងការសិក្សាស្រាវជ្រាវព្រះគម្ពីរ ហើយអធិស្ឋាន ប៉ុន្តែគាត់បដិសេធដើម្បីធ្វើតាម ។

សូមឲ្យសិស្សសញ្ជឹងគិតថាតើមានអ្វីខ្លះដែលពួកគេត្រូវប្រែចិត្ត ដើម្បីឲ្យពួកគេអាចមានកម្លាំងរបស់ព្រះអម្ចាស់ពេញលេញបន្ថែមទៀតនៅក្នុងជីវិតរបស់ពួកគេ ។

ហេលេមិន ៨

នីហ្វៃបង្រៀនថា ព្យាការីទាំងអស់ថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ

សូមសរសេរពាក្យ *ទទួលយក* និង*បដិសេធ* នៅលើក្តារខៀន ។ សូមឲ្យសិស្សពន្យល់ពីភាពខុសគ្នារវាងពាក្យទាំងពីរនេះ ។ សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៨:១៣ ខណៈដែលសិស្សក្នុងថ្នាក់រកមើលអ្វីដែលនីហ្វៃបាននិយាយអ្វីប្រជាជនបានបដិសេធ ។ អ្នកអាចណែនាំសិស្សឲ្យគូសចំណាំអ្វីដែលពួកគេរកឃើញ ។

សូមបង្ហាញសិស្សនូវរូបភាពរបស់ម៉ូសេ និងសត្វពស់លង្ហិន (៦២០២ *សៀវភៅរូបភាពដំណឹងល្អ* [ឆ្នាំ ២០០៩] ល.រ. ១៦) ។ សូមឲ្យពួកគេអាន ហេលេមិន ៨:១៤–១៥ ហើយរកមើលអ្វីដែលម៉ូសេបានបង្រៀនអំពីព្រះអង្គសង្គ្រោះ ។ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរៀន ។ រួចសួរថា ៖

- តើវិធីមួយចំនួនដែលបុគ្គលម្នាក់អាចសម្លឹងមើលទៅព្រះអង្គសង្គ្រោះដោយសេចក្តីជំនឿមានអ្វីខ្លះ ?
- តើការមាន « វិញ្ញាណទន់ទាប » មានន័យដូចម្តេច ? (ការបន្ទាបខ្លួន ប្រែចិត្ត ហើយទទួលយកព្រះឆន្ទៈរបស់ព្រះអម្ចាស់) ។ ហេតុអ្វីបានជាឥរិយាបថនេះសំខាន់នៅពេលយើងសម្លឹងមើលទៅព្រះអង្គសង្គ្រោះ ?
- តើការដឹងអំពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះអាចជួយយើងឲ្យប្រឆាំងនឹងអំពើអាក្រក់ ហើយប្រែចិត្តនៅពេលយើងធ្វើបាបបានដោយរបៀបណា ?

សូមឲ្យសិស្សនិយាយពីគោលការណ៍មួយដែលយើងអាចរៀនពីខគម្ពីរទាំងនេះ ។ សិស្សអាចប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរបង្ហាញថា **ប្រសិនបើយើងផ្តោតទៅលើព្រះយេស៊ូវគ្រីស្ទ ហើយអនុវត្តសេចក្តីជំនឿទៅលើទ្រង់ យើងនឹងទទួលបាននូវជីវិតដ៏នៅអស់កល្បជានិច្ច ។**

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ៨:១៦ ឮៗហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលថាតើនណាទៀតដែលបានបង្រៀនអំពីបេសកកម្មរបស់ព្រះអង្គសង្គ្រោះ ។ សូមឲ្យសិស្សសិក្សាត្រួសៗលើ ហេលេមិន ៨:១៧–២២ រកឈ្មោះព្យាការីផ្សេងទៀតដែលបានថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សគិតអំពីរបៀបដែលព្យាការីកាលពីសម័យបុរាណ ក៏ដូចជាព្យាការីនៅជំនាន់យើងនេះ បានថ្លែងទីបន្ទាល់អំពីបេសកកម្ម និងពលិកម្មដែលធួន របស់ព្រះអង្គសង្គ្រោះ ។

សូមឲ្យសិស្សចែកចាយទីបន្ទាល់របស់ពួកគេថាតើដង្វាយធួនរបស់ព្រះអង្គសង្គ្រោះមានន័យយ៉ាងណានៅក្នុងជីវិតរបស់ពួកគេ ។ អ្នកក៏អាចចែកចាយទីបន្ទាល់របស់អ្នកផងដែរ ។

មេរៀនបន្ទាប់ (ហេលេមិន ១០–១៦)

សូមឲ្យសិស្សស្រមៃថា ព្រះអម្ចាស់បានសន្យានឹងពួកគេថា ទ្រង់នឹងធ្វើអ្វីដែលពួកគេសុំទ្រង់ឲ្យធ្វើ ។ នីហ្វៃមានចិត្តស្មោះត្រង់ជាខ្លាំង រហូតដល់ព្រះអម្ចាស់បានសន្យាការណ៍នេះដល់លោក ហើយបានប្រគល់ដល់លោកនូវអំណាចផ្សារភ្ជាប់ ។ សូមណែនាំឲ្យសិស្សសិក្សា ហេលេមិន ១០–១១ នៅសប្តាហ៍នេះ ដោយរកមើលរបៀបដែលនីហ្វៃបានប្រើអំណាចដែលព្រះអម្ចាស់បានប្រគល់ដល់លោកដើម្បីជួយប្រជាជនរបស់លោក ។ សូមឲ្យពួកគេរកមើលពីរបៀបដែលទីសម្គាល់ជាច្រើនអំពីការសូត្រ និងការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ ដែលពួកគេអាចរកឃើញ នៅពេលពួកគេសិក្សាពីការព្យាការរបស់សាំយូអែល ជាសាសន៍លេមិននៅក្នុងហេលេមិន ១៣–១៦ ។

ហេលេមិន ១០

សេចក្តីផ្តើម

ការសោកល្វងដើម្បីសម្រេចថាតើនរណាបានធ្វើឃាតមេចៅក្រមបានបញ្ចប់ នៅពេលវិវរណៈរបស់នីហ្វៃអំពីឃាតករត្រូវបានបញ្ជាក់ ។ ដោយបានរួចពីការដាក់ទោសនៃការចោទប្រកាន់ខុសដែលបានសំដៅចំទៅលើលោក នីហ្វៃបានចាប់ផ្តើមដើរទៅផ្ទះ ។ លោកបានសញ្ជឹងគិតពីអ្វីដែលព្រះអម្ចាស់បានបង្ហាញដល់លោក ដោយមានអារម្មណ៍ទន់ខ្សោយជាខ្លាំងដោយសារតែភាពទុច្ចរិតរបស់ប្រជាជន ។ នៅក្នុងពេលនៃការគិត និងភាពក្រៀមក្រំនេះ លោកបានឮសំឡេងរបស់ព្រះអម្ចាស់ ។ ព្រះអម្ចាស់បានប្រទានពរដល់លោកដោយផ្តល់នូវអំណាចផ្សារភ្ជាប់ ហើយបញ្ជាឲ្យលោកបន្តបង្រៀនអំពីការប្រែចិត្តដល់ប្រជាជន ។ នីហ្វៃបានគោរពតាមបញ្ជារបស់ព្រះអម្ចាស់ភ្លាម ។

យោបល់សម្រាប់ការបង្រៀន

ហេលេមិន ១០:១–១១

នីហ្វៃទទួលបានអំណាចនៃការផ្សារភ្ជាប់

សូមរំឭកសិស្សពីវិវរណៈរបស់នីហ្វៃអំពីឃាតកម្មនៃមេចៅក្រម ដែលបានកត់ត្រានៅក្នុង ហេលេមិន ៨–៩ ។ សូមឲ្យសិស្សស្រមៃថាខ្លួនគេនៅក្នុងតំណែងរបស់នីហ្វៃ គឺបន្ទាប់ពីលោកបានលាតត្រដាងពីអ្នកដែលបានសម្លាប់មេចៅក្រម

- តើអ្នកមានអារម្មណ៍យ៉ាងម៉េចដែរ ? តើអ្នករំពឹងថាអ្នកផ្សេងនឹងមានប្រតិកម្មយ៉ាងណាដែរ ?
- តើអ្នកចង់និយាយអ្វីខ្លះដល់ប្រជាជន ?
- តើអ្នកមានអារម្មណ៍យ៉ាងណា ប្រសិនបើប្រជាជនមិនស្តាប់តាមអ្នក ហើយទុកអ្នកឲ្យនៅម្នាក់ឯងនោះ ?

សូមពន្យល់ថា ក្រោយពីបានបញ្ជាក់យ៉ាងច្បាស់ពីឃាតកម្មសម្លាប់មេចៅក្រមនោះហើយ នីហ្វៃបានចាប់ផ្តើមត្រឡប់ទៅផ្ទះវិញ ។ សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១០:១–៣ ឮៗហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលនីហ្វៃបានធ្វើ នៅពេលគាត់បានដើរម្នាក់ឯង ។ អ្នកអាចស្នើថា សិស្សគួរគូសចំណាំ៣ក្យ *សញ្ជឹងគិត* ពេលវាលេចឡើងនៅក្នុងខគម្ពីរនេះ ។

- ហេតុអ្វីបានជានីហ្វៃ « ទន់ខ្សោយជាខ្លាំង » ?
- តើមានអ្វីបានកើតឡើងនៅពេលនីហ្វៃកំពុងតែសញ្ជឹងគិតនោះ ? (សម្លេងនៃព្រះអម្ចាស់បានបន្លឺមកកាន់លោក ។) តើអ្វីជាទំនាក់ទំនងរវាងការសញ្ជឹងគិត និងការទទួលបានវិវរណៈ ?

នៅពេលសិស្សឆ្លើយ សូមជួយពួកគេឲ្យរកឃើញគោលការណ៍ខាងក្រោម ៖ **ការសញ្ជឹងគិតនូវអ្វីដែលព្រះអម្ចាស់រៀបចំឲ្យយើងដើម្បីទទួលបាននូវវិវរណៈ** ។ អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន ។

សូមសួរសិស្សថាតើពួកគេអាចគិតឃើញពីដំណើររឿងនៅក្នុងព្រះគម្ពីរ ឬប្រវត្តិសាសនាចក្រ នៅពេលប្រជាជនបានទទួលវិវរណៈដែលជាលទ្ធផលនៃការសញ្ជឹងគិតនូវរឿងរបស់ព្រះអម្ចាស់ដែរឬទេ ។ (ឧទាហរណ៍រួមមានកូនប្រុសរបស់លីហៃ នីហ្វៃ ដែលបានទទួលការនិមិត្តមួយក្រោយពីចង់ទទួលបាននូវអ្វីៗដែលឪពុករបស់គាត់បានឃើញ ហើយ « បានអង្គុយរំពឹងគិតនៅក្នុងចិត្ត [លោក] » [សូមមើល នីហ្វៃទី ១ ១០:១៧, ១៩:១] យ៉ូសែប ស៊្មីធ ដែលការនិមិត្តដំបូងរបស់លោកបានកើតមានក្រោយពីលោក « បានគិត . . . ម្តងហើយម្តងទៀត » អំពី យ៉ាកុប ១:៥ [សូមមើល យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:១១–១៧] និង យ៉ូសែប អេហ្ស ស៊្មីធ ដែលបានទទួលការនិមិត្តអំពីការប្រោសលោះនៃអ្នកស្លាប់ ក្រោយពីបានសញ្ជឹងគិត ហើយគិតអំពីព្រះបន្ទូលនៃព្រះអម្ចាស់ [សូមមើល គ . និង ស . ១៣៨:១–៦, ១១]) ។

- តើការសញ្ជឹងគិតបានជួយអ្នកឲ្យទទួលបានវិវរណៈផ្ទាល់ខ្លួននៅពេលណាដែរ ? (អ្នកអាចលើកឡើងថា ការទទួលបានវិវរណៈផ្ទាល់ខ្លួនជាធម្មតាគឺមិនមែនជាក់ច្បាស់ដូចជាឧទាហរណ៍ខ្លះនៅក្នុងព្រះគម្ពីរឡើយ ។ បទពិសោធន៍ទទួលវិវរណៈជាធម្មតាគឺជាពេលនៃការបំភ្លឺភ្លាមមួយ ដូចជានៅពេលយើងយល់អ្វីមួយភ្លាមនៅពេលយើងបានព្យាយាមរកពីពេលមុន) ។
- តើមានគ្រា ឬស្ថានភាពណាខ្លះដែលការសញ្ជឹងគិតរឿងរបស់ព្រះអម្ចាស់នឹងមានភាពសមរម្យជាពិសេសនោះ ? (ឧទាហរណ៍នៃពេលបែបនោះរួមមាន អំឡុងពេល និង ក្រោយពីការប្រជុំសាក្រាម៉ង់ មុនពេល និង ក្រោយពេលអធិស្ឋាន ហើយនិងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន ក្រោយពេលមើល ឬស្តាប់សន្និសីទទូទៅ ខណៈតមអាហារ ខណៈបម្រើនៅក្នុងព្រះវិហារបរិសុទ្ធ និងខណៈដែលថ្វាយបង្គំដល់ព្រះអម្ចាស់នៅថ្ងៃឈប់សម្រាក ។)

សូមលើកទឹកចិត្តសិស្សឲ្យទុកពេលសញ្ជឹងគិតជាទៀងទាត់ ។ សូមណែនាំឲ្យពួកគេសរសេរនូវការបំផុសដែលពួកគេបានទទួលនៅពេលពួកគេសញ្ជឹងគិត ។

ដើម្បីរៀបចំសិស្សឲ្យបន្តសិក្សាបទពិសោធន៍របស់នីហ្វៃ សូមឲ្យពួកគេស្រមៃថា អ្នកជិតខាងរបស់ពួកគេនឹងទៅឆ្ងាយមួយរយៈពេល ហើយត្រូវការនរណាម្នាក់ជួយមើលផ្ទះ និងកម្មសិទ្ធិរបស់គេ ។

- តើអ្នកគិតថា មនុស្សបែបណាដែលអ្នកជិតខាងរបស់អ្នកនឹងចង់ឲ្យជួយមើលផ្ទះគេនោះ ?
- តើអ្នកអាចបង្ហាញដល់អ្នកជិតខាងរបស់អ្នកថា អ្នកបានរៀបចំខ្លួនដើម្បីធ្វើការទទួលខុសត្រូវបែបនោះបានដោយរបៀបណា ?

បរិយាកាសក្នុងថ្នាក់រៀន

កន្លែងដ៏សំខាន់សម្រាប់ការរៀនដ៏ណឹងល្អ ជម្រុញអារម្មណ៍ឲ្យមានសេចក្តីស្រឡាញ់ ការគោរព គារវភាព និងសេចក្តីសុខសាន្ត ។ វាជាកន្លែងនៃរបៀបរៀបរយ ដោយរួមចំណែកដល់អត្ថន័យនៃគោលបំណង ។ ប្រធាន ប៊ិចម៍ យេ ផាកក៏បានបង្រៀនថា« ការបំផុសគំនិតមកកាន់តែងាយស្រួលនៅក្នុងកន្លែងមានសេចក្តីសុខសាន្ត » ហើយថា « គារវភាពអញ្ជើញវិវរណៈ » (« Reverence Invites Revelation » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩១ ទំព័រ ២១–២២) ។

សូមឲ្យសិស្សអាន ហេលេមិន ១០:៤–៥ ដោយស្ងៀមស្ងាត់ ដោយរកមើលមូលហេតុដែលព្រះអម្ចាស់ទុកព្រះទ័យលើនីហ្វៃជាមួយនឹងពរជ័យ និងមានទំនួលខុសត្រូវដ៏មហិមា ។ (អ្នកអាចពន្យល់ថា *ដោយគ្មាននឿយហត់* មានន័យថាដោយឥតនឿយណាយ ឬដោយឧស្សាហ៍ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

- តើការបម្រើដ៏គ្មាននឿយហត់បង្ហាញថា ព្រះអម្ចាស់អាចទុកចិត្តយើងឲ្យទទួលពរជ័យ និងការទទួលខុសត្រូវដោយរបៀបណា ?
- តើការធ្វើតាមគំរូរបស់នីហ្វៃនៃការមិនភ័យខ្លាចមនុស្សអាចជួយយើងឲ្យរៀបចំសម្រាប់ការទទួលខុសត្រូវនៅក្នុងនគររបស់ព្រះអម្ចាស់បានដោយរបៀបណា ?
- តើឃ្លាថា « អ្នក . . . ពុំបានរកជីវិតរបស់អ្នកផ្ទាល់ » មានន័យយ៉ាងណាដល់អ្នក ?

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ព្រះអម្ចាស់ប្រទានពរដល់យើងនូវពរជ័យ និងការទទួលខុសត្រូវនៅពេលយើង ។ . . .* សូមឲ្យសូរសិស្សថា តើពួកគេនឹងបំពេញប្រយោគនេះដោយរបៀបណា ដោយផ្អែកលើអ្វីដែលពួកគេបានរៀនអំពីនីហ្វៃនៅក្នុងហេលេមិន ១០:៤–៥ ។ របៀបមួយដែលសិស្សអាចបំពេញប្រយោគនេះគឺមានដូចខាងក្រោម ៖ **ព្រះអម្ចាស់ប្រទានពរដល់យើងនូវពរជ័យ និងការទទួលខុសត្រូវ នៅពេលយើងដាក់ព្រះបំណងរបស់ទ្រង់មុនបំណងរបស់យើងផ្ទាល់ ។** អ្នកអាចណែនាំថា សិស្សគួរសរសេរសេចក្តីពិតនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។

សូមឲ្យសិស្សសញ្ជឹងគិតពីសំណួរខាងក្រោម ហើយសរសេរចម្លើយរបស់គេសម្រាប់សំណួរមួយ ។

- តើអ្នកបានធ្វើអ្វីខ្លះនៅក្នុងជីវិតរបស់អ្នកថ្មីៗនេះ ដើម្បីបង្ហាញដល់ព្រះអម្ចាស់ថា ព្រះរាជបំណងរបស់ទ្រង់មានសារៈសំខាន់ជាងបំណងរបស់អ្នកផ្ទាល់ ?
- តើផ្នែកមួយនៃជីវិតរបស់អ្នកដែលអ្នកអាចនឹងធ្វើតាមព្រះរាជបំណងរបស់ព្រះអម្ចាស់គឺជាអ្វី ?

សូមថ្លែងទីបន្ទាល់អំពីព្រះឆន្ទៈរបស់ព្រះអម្ចាស់ក្នុងការប្រទានដល់យើងនូវពរជ័យដ៏មហិមា និងអស្ចារ្យជាងនេះ នៅពេលយើងស្វែងរកធ្វើតាមព្រះរាជបំណងរបស់ទ្រង់ ហើយកាន់តាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

សូមឲ្យសិស្សអាន ហេលេមិន ១០:៥–៧ ដោយស្ងៀមស្ងាត់ ដោយរកមើលពរជ័យ និងការទទួលខុសត្រូវដែលព្រះអម្ចាស់បានប្រទានដល់នីហ្វៃ ។ ខណៈដែលសិស្សកំពុងអាន សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖

ខទី ៥

ខទី ៦

ខទី ៧

សូមឲ្យសិស្សពីរបីនាក់សរសេរនៅលើក្តារខៀន ក្បែរលេខខគម្ពីរដែលត្រូវគ្នា នូវពរជ័យដែលព្រះអម្ចាស់បានប្រទានដល់នីហ្វៃ ។

សូមបញ្ជាក់ថា ពរជ័យមួយដែលព្រះអម្ចាស់បានប្រទានដល់នីហ្វៃគឺ អំណាចផ្សារភ្ជាប់ ។ បន្ទាប់មក សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***អំណាចផ្សារភ្ជាប់ចង និងស្រាយចំណងនៅលើផែនដី និងនៅលើស្ថានសួគ៌ ។*** អ្នកអាចណែនាំថាសិស្សគួរសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់គេនៅក្បែរ ហេលេមិន ១០:៧ ។

សូមសូរសិស្សថា តើពួកគេស្គាល់អ្នកដទៃក្រៅពីហេលេមិនដែលត្រូវបានប្រទាននូវអំណាចផ្សារភ្ជាប់ទេ ។ ក្រោយពីសិស្សឆ្លើយតបហើយ អ្នកអាចឲ្យពួកគេអានឆ្លងសេចក្តីយោង ហេលេមិន ១០:៧ ជាមួយនឹងព្រះគម្ពីរខាងក្រោម ៖ របាក្សត្រទី ១ ១៧:១ (អេលីយ៉ា) ម៉ាថាយ ១៦:១៥–១៩ (ពេត្រុស) គោលលទ្ធិ និង សេចក្តីសញ្ញា ១៣២:៤៦ (យ៉ូសែប ស៊្មីធ) ។

សូមពន្យល់ថា កូនសោនៃអំណាចដូចគ្នានេះមានដល់សព្វថ្ងៃនេះនៅក្នុងដៃប្រធានសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ដូចជានីហ្វៃដែរ ប្រធានសាសនាចក្របានបម្រើដោយគ្មាននឿយហត់ ហើយបានបង្ហាញថា ព្រះអម្ចាស់អាចប្រទានដល់ពួកគាត់នូវពរជ័យ និងការទទួលខុសត្រូវដ៏មហិមាបាន ។ ជាញឹកញាប់ យើងសំដៅភាគច្រើនលើអំណាចផ្សារភ្ជាប់ទាក់ទងនឹងការផ្សារភ្ជាប់គ្រួសារតាមរយៈពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់អំពីអំណាចផ្សារភ្ជាប់ សូមឲ្យសិស្សម្នាក់អានន្ទរសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ័សុល អិម ណិលសុន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ព្រះវិហារបរិសុទ្ធ ពិធីបរិសុទ្ធ សេចក្តីសញ្ញា អំណោយទានពិសិដ្ឋ និងពិធីផ្សារភ្ជាប់ត្រូវបានស្តារឡើងវិញយ៉ាងត្រឹមត្រូវដូចដែលបានព្យាករ ។ ពិធីបរិសុទ្ធទាំងឡាយនៃព្រះវិហារបរិសុទ្ធផ្តល់ឲ្យសម្រាប់ការផ្សះផ្សារជាមួយព្រះអម្ចាស់ ហើយផ្សារភ្ជាប់ក្រុមគ្រួសារឲ្យរស់នៅជាមួយគ្នាជារៀងរហូត ។ ការគោរពតាមសេចក្តីសញ្ញាដ៏ពិសិដ្ឋដែលបានធ្វើនៅក្នុងព្រះវិហារបរិសុទ្ធ ធ្វើឲ្យយើងសក្តិសមនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច—អំណោយទានដ៏អស្ចារ្យបំផុតរបស់ព្រះដល់មនុស្សលោក » (« Prepare for the Blessings of the Temple » *Ensign* ខែ តុលា ឆ្នាំ ២០១០ ទំព័រ ៤២) ។

- តើអ្នកត្រូវបានប្រទានពរដោយចំណេះដឹងថា គ្រួសារអាចរួបរួមគ្នាអស់កល្បជានិច្ចដោយរបៀបណា ?
- តើអ្នកអាចស្វែងរកពរជ័យនៃអំណាចផ្សារភ្ជាប់នាពេលអនាគតដោយរបៀបណា ? (ចម្លើយអាចរួមមានថា សិស្សអាចរៀបចំសម្រាប់អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ ហើយថាពួកគេអាចធ្វើកិច្ចការព្រះវិហារបរិសុទ្ធ និង ពង្សប្រវត្តិនាពេលឥឡូវនេះ ដែលនឹងជួយឲ្យគេត្រូវបានផ្សារភ្ជាប់ទៅនឹងពីដូនជីតារបស់គេដែលបានស្លាប់ទៅហើយនោះ ។

សូមចែកចាយអារម្មណ៍របស់អ្នកអំពីពរជ័យនៃអំណាចផ្សារភ្ជាប់ និងសារៈសំខាន់នៃការទទួលបានពិធីបរិសុទ្ធផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។

ហេលេមិន ១០:១២–១៩

នីហ្វៃគោរពតាមការបញ្ជារបស់ព្រះអម្ចាស់ដើម្បីបង្រៀនអំពីការប្រែចិត្តដល់ប្រជាជន

សូមសួរសិស្សថា តើពួកគេធ្លាប់ពន្យារពេលធ្វើអ្វីមួយដែលពួកគេត្រូវបានសុំឲ្យធ្វើទេ ។ (ឧទាហរណ៍អាចមានដូចជាការពន្យារពេលធ្វើកិច្ចការក្នុងផ្ទះ ឬកិច្ចការសាលា ឬពីកន្លែងធ្វើការ ។)

- តើសារលិខិតអ្វីដែលយើងអាចបង្ហាញទៅអ្នកដទៃ នៅពេលយើងពន្យារពេលធ្វើអ្វីដែលពួកគេសុំឲ្យយើងធ្វើនោះ ?

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១០:១១–១២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរបៀបដែលនីហ្វៃបានឆ្លើយតបនៅពេលព្រះអម្ចាស់បានបញ្ជាលោកឲ្យទៅបង្រៀនពីការប្រែចិត្តដល់ប្រជាជន ។

- តើយើងបង្ហាញអ្វីខ្លះដល់ព្រះអម្ចាស់ នៅពេលយើងឆ្លើយតបភ្លាមៗទៅនឹងការណែនាំរបស់ទ្រង់ និងព្រះបញ្ញត្តិទាំងឡាយ ?

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១០:១៣–១៤ ឮៗ ។ បន្ទាប់មក សូមឲ្យសិស្សផ្សេងទៀតអាន ហេលេមិន ១០:១៥–១៧ ឮៗ ។

- តើគំរូរបស់នីហ្វៃនៅក្នុងខគម្ពីរទាំងនេះបង្រៀនដល់យើងអ្វីខ្លះ ?
- តើព្រះអម្ចាស់បានជួយនីហ្វៃដោយរបៀបណា ?

សូមជួយសិស្សឲ្យឃើញថា ដោយសារតែភាពស្មោះត្រង់របស់នីហ្វៃ ព្រះអម្ចាស់បានការពារលោក និងបានប្រទានដល់លោកឲ្យមានអំណាចដ៏អស្ចារ្យ ។ នីហ្វៃបានតាំងចិត្តដើម្បីបំពេញបេសកកម្មដែលព្រះអម្ចាស់បានដាក់ឲ្យលោកធ្វើ ។

- តើអ្នកអាចបង្ហាញការប្តេជ្ញាចិត្តរបស់អ្នកដើម្បីបម្រើដល់ព្រះអម្ចាស់ដោយរបៀបណា ?

សូមណែនាំសិស្សឲ្យស្វែងរករបៀបដើម្បីដាក់ព្រះឆន្ទៈរបស់ព្រះអម្ចាស់ពីមុនបំណងរបស់យើងផ្ទាល់ ហើយគោរពតាមភ្លាមៗ ។ សូមធ្វើទីបន្ទាល់អំពីពរជ័យដែលកើតមាន នៅពេលយើងគោរពតាមព្រះអម្ចាស់ ។

ការរំឭកពីចំណេះចំណានខគម្ពីរ

ប្រវែងនៃមេរៀននេះអាចអនុញ្ញាតឲ្យមានពេលសម្រាប់ការធ្វើតាមសកម្មភាពរំឭកចំណេះចំណានខគម្ពីរ ។

សូមឲ្យសិស្សម្នាក់ៗនូវខគម្ពីរចំណេះចំណានខាងក្រោមមួយហើយអានដោយស្ងៀមស្ងាត់ ៖ នីហ្វៃទី ១ ៣:៧, នីហ្វៃទី ២ ២:២៧, នីហ្វៃទី ២ ៣១:១៩–២០, ម៉ូសាយ ២:១៧ ។ សុំឲ្យសិស្សអានវគ្គដែលពួកគេទទួលបាន ហើយគិតពីរបៀបដែលវាអនុវត្តដល់នីហ្វៃ និងការបម្រើរបស់លោកដូចដែលបានកត់ត្រានៅក្នុង ហេលេមិន ១០ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សុំឲ្យសិស្សពីរបីនាក់ឆ្លើយ ។

ហេលេមិន ១១–១២

សេចក្តីផ្តើម

ជំពូកទី ១១ និង ១២ នៅក្នុងគម្ពីរហេលេមិនមាននូវប្រវត្តិសាស្ត្រនៃសាសន៍នីហ្វៃរយៈពេល ១៤ ឆ្នាំដែលប្រជាជនបានឆ្លងកាត់វដ្តនៃសេចក្តីសុចរិត និងសេចក្តីទុច្ចរិត ។ ប្រវត្តិសាស្ត្រនេះបង្ហាញពីរបៀបដែលប្រជាជនអាចស្តែចព្រះអម្ចាស់យ៉ាងរហ័ស និងរបៀបដែលទ្រង់ផ្លាស់ផ្លាលពួកគេដើម្បីជួយពួកគេឲ្យប្រែចិត្ត ហើយត្រឡប់មករកទ្រង់វិញ ។

យោបល់សម្រាប់ការបង្រៀន

ហេលេមិន ១១

សាសន៍នីហ្វៃឆ្លងកាត់វដ្តនៃសេចក្តីសុចរិត និងសេចក្តីទុច្ចរិតមួយ

សូមចម្លងតារាងខាងក្រោមនៅលើក្តារខៀន ។ សូមពន្យល់ថា តារាងនេះបង្ហាញអ្វីដែលជាញឹកញាប់ហៅថាវដ្តនៃសេចក្តីឆ្មើងឆ្មៃ ។



សូមឲ្យសិស្សគិតពីអ្វីដែលពួកគេនឹងសរសេរសម្រាប់ធាតុទាំងបួននៃវដ្តនេះ ។ សូមឲ្យសិស្សពិភាក្សាពីចម្លើយ ។ ក្រោយពីបានពិភាក្សាខ្លះហើយ សូមសរសេរពាក្យ *សេចក្តីរាបសា និងការប្រែចិត្ត* ក្បែរលេខ ៤ នៅក្នុងតារាងនេះ ។ សូមពន្យល់ថា សកម្មភាពព្រះគម្ពីរខាងក្រោមនឹងបង្ហាញពីរបៀបដែលប្រជាជនក្នុងព្រះគម្ពីរមរមនបានឆ្លងកាត់វដ្តនេះ ។ សូមបង្ហាញថា វដ្តនេះជាញឹកញាប់ត្រូវបានឃើញនៅក្នុងសង្គមដ៏ធំនានា ប៉ុន្តែវាក៏អាចបង្ហាញពីគំរូនៅក្នុងជីវិតរបស់គ្រួសារ និងបុគ្គលម្នាក់ៗផងដែរ ។

សូមរំឭកសិស្សថា ទោះបីជាក្រោយពីនីហ្វៃបានប្រាប់ប្រជាជនអំពីសេចក្តីស្លាប់របស់មេចៅក្រមហើយក្តី ក៏គង់តែ « ពួកគេបានធ្វើចិត្តរឹងរូស ហើយពុំបានស្តាប់តាមព្រះបន្ទូលទាំងឡាយនៃព្រះអម្ចាស់ឡើយ » (ហេលេមិន ១០:១៣) ។ នៅចុងបញ្ចប់នៃឆ្នាំទី ៧១ នៃរជ្ជកាលនៃចៅក្រម ប្រជាជន « បានបែកគ្នាហើយបានចាប់ផ្តើមសម្លាប់គ្នាទៅវិញទៅមកដោយដាវ » (ហេលេមិន ១០:១៨) ។

- **នៅពេលនេះ តើអ្នកគិតថាសាសន៍នីហ្វៃទាំងនេះស្ថិតនៅក្នុងវដ្តនៃភាពឆ្មើងឆ្មៃកន្លែងណា ?**

មុនចាប់ផ្តើមថ្នាក់ សូមចម្លងតារាងខាងក្រោមនៅលើក្តារខៀន ។ សូមកុំបញ្ចូលចម្លើយជាអក្សរទ្រេតនៅក្នុងជួរឈរទីបី និងទីបួន ។ ប្រសិនបើអាច សូមចម្លងតារាងនោះជាក្រដាសចែកដល់សិស្ស ។ ប្រសិនបើពិបាក សូមឲ្យពួកគេចម្លងតារាងនេះទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។

គំរូ របៀបដើម្បីបំពេញតារាងដោយការធ្វើរួមគ្នានៅបន្ទាត់ទីមួយរួមគ្នា ។ សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១១:១–២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់សង្កេតខ្លីពីស្ថានភាពរបស់ប្រជាជនដូចដែលបានរៀបរាប់នៅក្នុងខគម្ពីរទាំងនេះ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើតារាង ។ បន្ទាប់មក សូមឲ្យសិស្សរកមើលវគ្គមួយណានៃវដ្តនេះដែលប្រជាជនស្ថិតនៅ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើតារាង ។

> ***សកម្មភាពព្រះគម្ពីរគំរូ***
>
> នៅពេលអ្នករៀបចំឲ្យសិស្សបំពេញសកម្មភាពព្រះគម្ពីរ សូមកំណត់ពីកម្រិតពិបាកនៃសកម្មភាព និងនិងសមត្ថភាពរបស់សិស្សអ្នក ។ នៅក្នុងស្ថានភាពខ្លះ អ្នកអាចបង្ហាញចំណែកនៃសកម្មភាពគំរូខ្លួនអ្នក ដើម្បីឲ្យសិស្សអាចឃើញអ្វីដែលពួកគេនឹងធ្វើ នៅពេលពួកគេបំពេញកិច្চការនេះដោយខ្លួនគេ ។

នៅពេលសិស្សយល់ពីរបៀបបំពេញតារាងនេះហើយ សូមឲ្យពួកគេមានពេលបំពេញវា ។ អ្នកអាចសុំឲ្យពួកគេធ្វើការរៀង៣ខ្លួន ជាដៃគូ ឬជាក្រុមតូច៣ ឬរួមគ្នាក្នុងថ្នាក់ ។

ឆ្នាំនៃរជ្ជកាលនៃចៅក្រម	ខគម្ពីរនៅក្នុងហេលេមិន ១១	ការពិពណ៌នាពីស្ថានភាពរបស់ប្រជាជន	វគ្គនៅក្នុងវដ្ត
៧២–៧៣	១–២	*ការទាស់ទែងគ្នា និងសង្គ្រាមកើនឡើង ហើយក្រុមចោរសម្ងាត់ធ្វើការបំផ្លិចបំផ្លាញ ។*	២, ៣

ឆ្នាំនៃរជ្ជកាលនៃចៅក្រម	ខគម្ពីរនៅក្នុងហេលេមិន ១១	ការពិពណ៌នាពីស្ថានភាពរបស់ប្រជាជន	វគ្គនៅក្នុងវង្ក
៧៣–៧៥	៣–៦	*ដោយសារតែសំណើររបស់នីហ្វៃទៅដល់ព្រះអម្ចាស់ គ្រោះទុរភិក្សត្រូវជំនួសដោយសង្គ្រាម ហើយមនុស្សរាប់ពាន់នាក់ចាប់ផ្តើមវិនាសបង់ដោយការអត់ឃ្លាន ។*	២, ៣
៧៥	៧–១១	*ប្រជាជនចាប់ផ្តើមចងចាំដល់ព្រះអម្ចាស់ និងបន្ទាបខ្លួន ហើយពួកគេសម្អាតចេញនូវក្រុមការីអានតុនពីក្នុងចំណោមពួកគេ ។*	៣, ៤
៧៦	១៧–២០	*ប្រជាជនរីករាយ ហើយសរសើរតម្កើងដល់ព្រះ ។ ពួកគេមានសេចក្តីសុចរិត ហើយពួកគេចាប់ផ្តើមកែចម្រើនម្តងទៀត ។*	៤, ១
៧៧–៧៩	២១–២៣	*ការចម្រុងចម្រើន និងសន្តិភាពត្រូវបានស្តារឡើងវិញ ។ ការទាស់ទែងគ្នាមានតិច ហើយវាត្រូវបានដោះស្រាយដោយវិវរណៈ និងការបង្រៀនដ៏ណឹងល្អ ។*	១
៨០	២៤–២៦	*ប្រជាជនភ្លាយជាមានចិត្តឆ្មើងឆ្មៃ ខឹងសម្បារ និងទុច្ចរិតម្តងទៀត ។ ក្រុមចោរទុច្ចរិតរីកចម្រើនម្តងទៀតនៅក្នុងចំណោមប្រជាជន ដោយមានយោគករ និងគម្រោងសម្ងាត់ ។*	២, ៣
៨០–៨១	២៧–៣៥	*ពួកចោរធ្វើឲ្យមានចលាចល និងការបំផ្លិចបំផ្លាញ ហើយកងទ័ពសាសន៍នីហ្វៃ និងសាសន៍លេមិនមិនអាចបំផ្លាញក្រុមទុច្ចរិតនោះបានឡើយ ។ ពួកចោរបានសម្លាប់មនុស្សជាច្រើន ហើយបានចាប់យកប្រជាជនមួយចំនួន រួមមានស្ត្រី និងកូនក្មេង ជាចំណាប់ខ្មាំងទៅក្នុងទឹកដីរបស់ពួកគេ ។ ឧបសគ្គទាំងឡាយនាំឲ្យប្រជាជនចងចាំដល់ព្រះអម្ចាស់ ។*	៣, ៤

ក្រោយពីសិស្សមានពេលបំពេញតារាងនេះហើយ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរៀនពីសកម្មភាពនេះ ។ បន្ទាប់មក សូមសួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- **យោងតាម ហេលេមិន ១១:៤ ហេតុអ្វីបានជានីហ្វៃអធិស្ឋានសូមឲ្យមានគ្រោះទុរភិក្ស ? (គាត់សង្ឃឹមថា គ្រោះទុរភិក្សនេះនឹងនាំប្រជាជនឲ្យចងចាំដល់ព្រះអម្ចាស់ ហើយប្រែចិត្ត) ។**
- **តើប្រជាជនអាចធ្វើអ្វីបានខ្លះដើម្បីចៀសវាងគន្លងនៃវដ្តនៃ « ការរងទុក្ខ និងសេចក្តីបំផ្លិចបំផ្លាញ » ?**

សិស្សអាចមានចម្លើយល្អៗជាច្រើនចំពោះសំណួរនេះ ។ សូមប្រាកដថា ពួកគេរកឃើញគោលការណ៍ខាងក្រោម ៖ តាមរយៈការបន្ទាបខ្លួន និងការប្រែចិត្ត យើងអាចចៀសវាងពីភាពឆ្មើងឆ្មៃ និងសេចក្តីបំផ្លិចបំផ្លាញ ។ **សូមបង្ហាញថា សាសន៍នីហ្វៃអាចរំលងវគ្គទីពីរ និងទីបីនៃវដ្តនេះបាន ។ ពួកគេអាចរស់នៅដោយសុចរិត និងដោយបន្ទាបខ្លួនជានិច្ច ដោយការប្រែចិត្តដោយពុំមានការពន្យារពេលនៅពេលណាដែលពួកគេប្រព្រឹត្តអំពើបាប ។ ប្រសិនបើពួកគេបានរស់នៅតាមរបៀបនេះ ពួកគេនឹងនៅតែជួបនឹងការសាកល្បងខ្លះ ប៉ុន្តែពួកគេនឹងមិនចាំបាច់ត្រូវស៊ូទ្រាំនឹងការរងទុក្ខ និងការបំផ្លាញដ៏ខ្លាំងក្លាដែលបណ្តាលមកពីអំពើទុច្ចរិតរបស់ពួកគេនោះឡើយ ។**

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១១:៣៦–៣៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយស្តាប់រកនូវការផ្លាស់ប្តូរដែលកើតឡើងនៅក្នុងរយៈពេលដ៏ខ្លី ។

- **តើមានរយៈពេលយូរប៉ុណ្ណាក្រោយពីការចងចាំដល់ព្រះអម្ចាស់ ដែលវាធ្វើឲ្យសាសន៍នីហ្វៃ « ទុំល្មមសម្រាប់ការបំផ្លាញ » ? (ប្អូនឆ្នាំ) ។**
- **តើនៅក្នុងជំហាននៃវដ្តនៃភាពឆ្មើងឆ្មៃអ្វីដែលត្រូវបានពិពណ៌នានៅចុងបញ្ចប់នៃ ហេលេមិន ១១ ?**

សូមឲ្យសិស្សរកមើល ហើយគិតអំពីពេលជាក់លាក់ណាមួយ ដែលពួកគេបានឃើញវដ្តនេះកើតឡើងក្នុងកម្រិតណាមួយនៅក្នុងជីវិតរបស់គេផ្ទាល់ ឬជីវិតរបស់មនុស្សដែលគេស្គាល់ ។ សូមឲ្យពួកគេសញ្ជឹងគិតពីអ្វីដែលពួកគេអាចធ្វើដើម្បីចៀសវាងពីវគ្គទីពីរ និងទីបីនៃវដ្តនេះ ។ សូមលើកទឹកចិត្តពួកគេឲ្យសរសេរគំនិតជាក់លាក់ខ្លះដែលពួកគេទទួលបាន នៅពេលពួកគេសញ្ជឹងគិត ។

ហេលេមិន ១២

មរមនពន្យល់ពីមូលហេតុដែលព្រះអម្ចាស់ផ្ទាញ់ផ្ទាលប្រជាជន ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ។ « *មែនហើយ ហើយយើងអាចយើញថា . . .* » សូមពន្យល់ថា មរមនបានប្រើឃ្លានេះ ដើម្បីបង្ហាញពីមេរៀនដែលត្រូវរៀនពីដំណើររឿងដែលគាត់បានកត់ត្រា ។

- ដោយផ្អែកលើ ហេលេមិន ១១ តើអ្នកនឹងបំពេញប្រយោគនេះដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១២:១ ព្ធ ៗហើយសូមឲ្យសិស្សក្នុងថ្នាក់ផ្សេងទៀតរកមើលរបៀបដែលមរមនបំពេញប្រយោគនេះ ។

- តើឃ្លា « ភាពមិននឹងនរនៃចិត្តនៃកូនចៅមនុស្ស » មានន័យយ៉ាងណាចំពោះអ្នក ?
- តើអ្វីដែលជួយឲ្យចិត្តរបស់អ្នកនៅបន្តខ្ជាប់ខ្ជួនស្មោះត្រង់នឹងព្រះអម្ចាស់ ?

សូមឲ្យសិស្សសិក្សា ហេលេមិន ១២:២–៣ ដោយស្ងៀមស្ងាត់ ដោយរកមើលមេរៀនផ្សេងទៀតដែលមរមនចង់ឲ្យយើងរៀនពីប្រវត្តិសាស្ត្រនៃសាសន៍នីហ្វៃនេះ ។ សូមរំឦកសិស្សថា ជាញឹកញាប់មរមនប្រើឃ្លាដូចជា « ហើយយើងអាចយើញថា » (ខទី ២) និង « ម្លោ៉ះហើយ យើងឃើញថា » (ខទី ៣) នៅពេលលោកបានចែកចាយនូវសេចក្តីពិតដែលយើងអាចរៀនពីដំណើររឿងនៅក្នុងព្រះគម្ពីរ ។

- និយាយជាសម្តីខ្លួនផ្ទាល់ តើមេរៀនអ្វីដែលមរមនចង់ឲ្យយើងរៀន ? (សិស្សអាចឆ្លើយដូចខាងក្រោម ៖ **ប្រសិនបើយើងមិនប្រុងប្រយ័ត្នទេ សេចក្តីចម្រុងចម្រើនរបស់យើងអាចនាំយើងឲ្យភ្លេចព្រះអម្ចាស់ ។ ព្រះអម្ចាស់នឹងផ្ទាញ់ផ្ទាលប្រជាជនរបស់ទ្រង់ឲ្យពួកគេចងចាំងដល់ទ្រង់**) ។
- តើអ្នកគិតថា ហេតុអ្វីបានជាប្រជាជនដែលរីកចម្រើន ពេលខ្លះភ្លេចព្រះអម្ចាស់ ?
- តើអ្នកគិតថា ហេតុអ្វីបានជាប្រជាជនពេលខ្លះត្រូវតែទទួលការផ្ទាញ់ផ្ទាលមុនពេលពួកគេចងចាំដល់ព្រះអម្ចាស់ ? (អ្នកអាចពន្យល់ថាពាក្យ *ផ្ទាញ់ផ្ទាល* មានន័យថា ការកែតម្រូវនរណាម្នាក់តាមរយៈការដាក់ទោស ឬការរងទុក្ខមួយចំនួន) ។

សូមឲ្យសិស្សសញ្ជឹងគិតពីសំណួរខាងក្រោម ៖

- តើព្រះអម្ចាស់អាចផ្ទាញ់ផ្ទាលយើងនាសព្វថ្ងៃនេះតាមរបៀបណា ?

ដើម្បីជួយសិស្សឲ្យឆ្លើយនឹងសំណួរនេះ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្ទូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« ការផ្ទាញ់ផ្ទាលពីស្ថានសួគ៌មានគោលបំណងយ៉ាងហោចណាស់បីយ៉ាង ៖ (១) ដើម្បីបញ្ចុះបញ្ចូលយើងឲ្យប្រែចិត្ត (២) ដើម្បីបន្សុទ្ធ ហើយញែកយើងចេញ និង (៣) នៅពេលខ្លះតម្រង់ផ្លូវយើងជាថ្មីនៅក្នុងជីវិតឲ្យចំនឹងអ្វីដែលព្រះដឹងថាជាផ្លូវដ៏ប្រសើរអមួយ » (« As Many as I Love, I Rebuke and Chasten » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ៩៨) ។

- តើការផ្ទាញ់ផ្ទាលរបស់ព្រះអម្ចាស់គឺជាភស្តុតាងនៃសេចក្តីស្រឡាញ់របស់ទ្រង់ដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១២:៤–៦ ព្ធ ៗ ។ សូមឲ្យសិស្សផ្សេងទៀតក្នុងថ្នាក់មើលតាម ដោយរកមើលឥរិយាបថដែលធ្វើឲ្យវាពិបាកសម្រាប់មនុស្សដើម្បីចងចាំដល់ព្រះ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមពន្យល់ថា មរមនបានពិពណ៌នាពីប្រជាជនដែលបដិសេធមិនឲ្យព្រះអម្ចាស់ក្លាយជាមគ្គុទេសន៍របស់ពួកគេថា « អន់ជាងធូលីដីទៅទៀត » (ហេលេមិន ១២:៧) ។ សូមឲ្យសិស្សអាន ហេលេមិន ១២:៧–៨ ព្ធ ៗ ។

- ហេតុអ្វីបានជាមនុស្សបែបនោះអាចចាត់ទុកថា « អន់ជាងធូលីដីទៅទៀត » ? (សូមជួយសិស្សឲ្យយល់ថា មរមនមិនមែនកំពុងបង្រៀនថា ប្រជាជនមានតម្លៃចំពោះព្រះវរបិតាសួគ៌តិចជាងធូលីដីនោះទេ ។ ផ្ទុយទៅវិញ លោកបានទាក់ទាញការយកចិត្តទុកដាក់ចំពោះការពិតថា ធូលីដីតែងតែគោរពតាមការបញ្ជារបស់ព្រះជានិច្ច ប៉ុន្តែមនុស្សជាញឹកញាប់មិនធ្វើតាមនោះទេ) ។

សូមសង្ខេប ហេលេមិន ១២:៩–២២ ដោយការលើកឡើងថា នៅក្នុងខគម្ពីរទាំងនេះ មរមនរំឦកយើងពីព្រះចេស្តាដ៏អស្ចារ្យរបស់ព្រះអម្ចាស់—ថាព្រះអម្ចាស់អាចបញ្ជាធាតុខាងរាងកាយឲ្យរំកិល ឬផ្លាស់ប្តូរ ហើយថាទ្រង់អាចបណ្តាលឲ្យមនុស្សមានបានម្នាក់កាត់ចេញពីវត្តមានរបស់ទ្រង់ ។ សូមឲ្យសិស្សសិក្សាស្រាវជ្រាវ ហេលេមិន ១២:២៣–២៦ ដោយរកមើលភស្តុតាងដែលបង្ហាញថាយើងគឺមានតម្លៃជាងធូលីដីខ្លាំងណាស់ ។ អ្នកអាចណែនាំសិស្សថាគូរគូសចំណាំពាក្យ និងឃ្លាដែលសំខាន់ដល់ពួកគេ ។

- តើអំណោយអ្វីដែលមានដល់យើង នៅពេលយើងប្រែចិត្ត ហើយស្តាប់តាមសំឡេងនៃព្រះអម្ចាស់ ?
- តើភស្តុតាងនៃតម្លៃរបស់យើងចំពោះព្រះមានន័យយ៉ាងណាដែរ ?

សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ។ សូមឲ្យសិស្សសរសេរសេចក្តីសន្និដ្ឋានមួយសម្រាប់មេរៀនថ្ងៃនេះ ដោយការបញ្ចប់ប្រយោគទាំងនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ ។

ហេតុដូច្នេះហើយខ្ញុំមើលនៅក្នុង ហេលេមិន ១១–១២ ថា . . .

ហើយម្ល៉ះហើយខ្ញុំនឹង . . .

សូមធ្វើទីបន្ទាល់ថា នៅពេលយើងចងចាំដល់ព្រះអម្ចាស់ ស្តាប់តាមសំឡេងរបស់ទ្រង់ ហើយប្រែចិត្ត នោះយើងបង្ហាញពីការបន្ទាបខ្លួន និងសេចក្តីជំនឿរបស់យើងលើទ្រង់ ។ ជាការតបស្នងវិញ ទ្រង់រក្សាសេចក្តីសន្យារបស់ទ្រង់ដើម្បីប្រទានពរ និងធ្វើឲ្យយើងចម្រុងចម្រើន ហើយនៅទីបញ្ចប់ប្រទានដល់យើងនូវជីវិតដ៏នៅអស់កល្បជានិច្ច ។

ហេលេមិន ១៣

សេចក្តីផ្តើម

ពីរបីឆ្នាំមុនពេលការប្រសូត្ររបស់ព្រះអង្គសង្គ្រោះ ព្រះអម្ចាស់បានបញ្ជូនព្យាការីសាសន៍លេមិនម្នាក់ឈ្មោះថា សាំយូអែល ឲ្យទៅបង្រៀនពីការប្រែចិត្តដល់សាសន៍នីហ្វៃ ។ លោកបានប្រកាសដល់សាសន៍នីហ្វៃនៅក្នុងដែនដីសារ៉ាហិមឡាពីដំណឹងល្អដ៏រីករាយនៃសេចក្តីប្រោសលោះតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ លោកក៏បានប្រឈមនឹងពួកគេអំពីការបដិសេធព្យាការី និងធម្មជាតិរបស់គេដែលស្វែងរកសុភមង្គលនៅក្នុងអំពើទុច្ចរិត ។ លោកបានព្រមានពួកគេអំពីសេចក្តីបំផ្លិចបំផ្លាញដែលនឹងមកដល់ពួកគេ ប្រសិនបើពួកគេមិនព្រមប្រែចិត្តទេនោះ ។

យោបល់សម្រាប់ការបង្រៀន

ហេលេមិន ១៣

សាំយូអែលព្រមានសាសន៍នីហ្វៃអំពីសេចក្តីបំផ្លិចបំផ្លាញរបស់គេ ប្រសិនបើពួកគេពុំប្រែចិត្តទេ

មុនចាប់ផ្តើមថ្នាក់សូមរៀបចំក្រដាសចែកដល់សិស្សដែលមាននៅចុងបញ្ចប់នៃមេរៀននេះ ។ អ្នកអាចកាត់ក្រដាសជាបី ដោយមានកិច្ចការក្រុមមួយនៅលើក្រដាសនីមួយៗ ។ មុនបង្រៀន សូមចម្លងគម្រោងខាងក្រោមនៃ ហេលេមិន ១៣ ដាក់លើក្តារខៀនផងដែរ ។

ហេលេមិន ១៣:១–៤ ។ ព្រះអម្ចាស់ហៅសាំយូអែលជាសាសន៍លេមិនឲ្យបង្រៀនដល់សាសន៍នីហ្វៃ ។

ហេលេមិន ១៣:៥–២៣ ។ សាំយូអែលព្រមានសាសន៍នីហ្វៃអំពីសេចក្តីបំផ្លិចបំផ្លាញដែលនឹងមកដល់ពួកគេ ប្រសិនបើពួកគេពុំព្រមប្រែចិត្តទេ ។

ហេលេមិន ១៣:២៤–៣៩ ។ សាំយូអែលព្រមានដល់ប្រជាជនអំពីលទ្ធផលនៃការបដិសេធព្យាការីទាំងឡាយ និងការមិនព្រមប្រែចិត្ត ។

សូមចាប់ផ្តើមមេរៀនដោយបង្ហាញរូបភាពរបស់សាំយូអែល ជាសាសន៍លេមិននៅលើកំផែង (៦២៣៧០ *សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ | ល.រ. ៨១) ។ សូមសួរសិស្សថា តើពួកគេដឹងពីមូលហេតុដែលសាសន៍នីហ្វៃចង់សម្លាប់សាំយូអែលទេ ។ ក្រោយពីសិស្សឆ្លើយហើយ សូមពន្យល់ថា ហេលេមិន ១៣–១៦ រួមមានដំណើររឿងពីព្យាការីសាសន៍លេមិន គឺសាំយូអែល ។ ដំណើររឿងនេះគឺចម្លែកដោយសារមានរយៈពេលតែមួយគត់នៅក្នុងព្រះគម្ពីរមរមនដែលយើងរៀនអំពីព្យាការីជាសាសន៍លេមិន ដែលហៅសាសន៍នីហ្វៃឲ្យប្រែចិត្ត ។ អំឡុងពេលនេះ សាសន៍លេមិនគឺសុចរិតជាងសាសន៍នីហ្វៃ ។ សូមយោងទៅគម្រោងនៅលើក្តារខៀនដើម្បីឲ្យសិស្សយល់ពីសេចក្តីសង្ខេបខ្លីមួយនៃ ហេលេមិន ១៣ ។

សូមបំបែកថ្នាក់ជាបីក្រុម ។ (បើអាច សូមឲ្យក្រុមនីមួយៗមានចំនួនស្មើគ្នា) ។ សូមឲ្យសិស្សម្នាក់ៗមានកិច្ចការនៃក្រុមរបស់ខ្លួន (ដែលមាននៅចុងបញ្ចប់នៃមេរៀននេះ) ។ សូមប្រាប់សិស្សថា ពួកគេនឹងសិក្សាចំណែកមួយនៃ ហេលេមិន ១៣ រៀងៗខ្លួន ហើយបន្ទាប់មកបង្រៀនដល់គ្នាទៅវិញទៅមកនូវអ្វីដែលពួកគេបានរៀន ។ សូមឲ្យសិស្សម្នាក់ៗរៀបចំដើម្បីបង្រៀនគោលការណ៍ពីវគ្គព្រះគម្ពីរក្នុងកិច្ចការរបស់គេ ហើយរៀបចំចម្លើយចំពោះសំណួរដែលមានមកនោះ ។ សូមឲ្យសិស្សមានជម្រើសដើម្បីសរសេរចម្លើយរបស់គេ ។ (សកម្មភាពនេះនឹងឲ្យសិស្សទាំងអស់ចូលរួម និងអនុញ្ញាតឲ្យមានបរិយាកាសល្អមួយដែលសិស្សអាចចែកចាយអារម្មណ៍ គំនិត និងទីបន្ទាល់របស់គេដល់គ្នាទៅវិញទៅមក) ។

> *សូមឲ្យសិស្សបង្ហាញអ្វីដែលពួកគេបានរៀនពីគ្នាទៅវិញទៅមក ។*
>
> តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ សម្តី និងការបង្ហាញរបស់សិស្សអាចមានឥទ្ធិពលដ៏សំខាន់មួយទៅលើជួងចិត្ត និងគំនិតរបស់មិត្តរួមថ្នាក់របស់ពួកគេ ។ នៅពេលអ្នកសុំឲ្យគេបង្ហាញសេចក្តីពិតដែលពួកគេបានរៀនពីគ្នាទៅវិញទៅមកនោះ អ្នកជួយពួកគេឲ្យបង្កើតបរិយាកាសមួយនៃសេចក្តីស្រឡាញ់ ការគោរព និងភាពសាមគ្គីគ្នា ។

ក្រោយពីសិស្សមានពេលល្មមដើម្បីសិក្សារៀងៗខ្លួនហើយ សូមឲ្យពួកគេធ្វើការជាក្រុមដែលមានគ្នាបីនាក់ ។ បើអាច សូមឲ្យក្រុមនីមួយៗមានសិស្សម្នាក់ដែលបានសិក្សា ហេលេមិន ១៣:១–៧, ១១ ម្នាក់ដែលបានសិក្សា ហេលេមិន ១៣:១៧–២៣ និងម្នាក់ដែលបានសិក្សា ហេលេមិន ១៣:២៤–៣៣ ។ សូមឲ្យសិស្សម្នាក់ៗមានពេលគ្រប់គ្រាន់ដើម្បីចែកចាយចម្លើយរបស់ពួកគេជាមួយនឹងសមាជិកក្រុមដទៃទៀត ។ អំឡុងពេលពិភាក្សាក្នុងក្រុមតូចៗ សូមដើរមើលជុំវិញ ហើយជួយដឹកនាំចម្លើយរបស់សិស្ស ។ នៅពេលសមរម្យ សូមបន្ថែមគំនិតរបស់អ្នកទៅនឹងការពិភាក្សាដែលអ្នកឮ ។

នៅពេលសិស្សមានពេលបង្រៀនដល់គ្នាគ្រប់គ្រាន់ហើយ សូមឲ្យពួកគេពីរបីនាក់ ចែកចាយ ដល់សិស្សក្នុងថ្នាក់ទាំងមូលនូវសេចក្តីពិត ឬគំនិតមួយដែលពួកគេបានរៀនពីសិស្សផ្សេងទៀតអំឡុងពេលធ្វើសកម្មភាពនេះ ។

សូមសង្ខេប ហេលេមិន ១៣:៩–១៤ ដោយពន្យល់ថា សាសន៍នីហ្វៃនឹងត្រូវបានបំផ្លាញក្នុងពេល ៤០០ ឆ្នាំ (សូមមើល ហេលេមិន ១៣:៩–១០) ហើយមូលហេតុតែមួយគត់ដែលពួកគេមិនត្រូវបានបំផ្លាញបង់នោះគឺថា ប្រជាជនសុចរិតនៅតែរស់នៅក្នុងចំណោមពួកគេ (សូមមើល ហេលេមិន ១៣:១៣–១៤) ។ សូមថ្លែងទីបន្ទាល់ថា សាំយូអែលត្រូវបានបញ្ជូនទៅដល់សាសន៍នីហ្វៃដោយព្រះអម្ចាស់ ហើយលោកបាននិយាយអ្វីដែលព្រះអម្ចាស់បានបញ្ចូលទៅក្នុងដួងចិត្តរបស់លោក នៅពេលលោកសុំឲ្យសាសន៍នីហ្វៃប្រែចិត្ត ហើយត្រឡប់មករកព្រះអម្ចាស់វិញ (សូមមើល ហេលេមិន ១៣:១១) ។

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១៣:២៧–២៨ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរបៀបដែលសាសន៍នីហ្វៃបានឆ្លើយតបចំពោះពួកព្យាការីក្លែងក្លាយ ។

- យោងតាមសាំយូអែល តើសាសន៍នីហ្វៃបានឆ្លើយតបយ៉ាងណាដល់អ្នកដែលបានបង្រៀនការណ៍ខុសឆ្គងនោះ? តើអ្នកគិតថាហេតុអ្វីបានជាអ្នកខ្លះទទួលយកការដាស់តឿនរបស់លោក ហើយអ្នកផ្សេងទៀតបានបដិសេធ ?
- តើប្រយោគ និងឥរិយាបថដែលយើងអាចនៅក្នុង ហេលេមិន ១៣:២៧ កើតមានច្បាស់នៅក្នុងជំនាន់របស់យើងដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន ៖

« របៀបដែលយើងឆ្លើយតបនឹងពាក្យសម្តីរបស់ព្យាការីដែលកំពុងរស់នៅ នៅពេលលោកប្រាប់យើងពីអ្វីដែលយើងត្រូវដឹង ប៉ុន្តែដែលយើងមិនចង់ស្តាប់ គឺជាការសាកល្បងមួយនៃសេចក្តីស្មោះត្រង់របស់យើង » (« Fourteen Fundamentals in Following the Prophet » [BYU devotional address, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ១៩៨០] ទំព័រ ៣–៤, speeches.byu.edu) ។

- តើការណែនាំអ្វីខ្លះពីព្យាការីដែលអាចមានការពិបាកសម្រាប់មនុស្សមួយចំនួនដើម្បីធ្វើតាមនាសព្វថ្ងៃនេះ ?
- តើអ្វីទៅជាគំរូមួយនៃការណែនាំពីព្យាការីដែលអ្នកបានជ្រើសរើសដើម្បីគោរពតាម ? តើអ្នកត្រូវបានប្រទានពរដោយសារអ្នកបានធ្វើតាមការណែនាំនេះដោយរបៀបណា ?

សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេអំពីរបៀបមួយដែលពួកគេអាចចម្រើនឡើងនៅក្នុងការធ្វើតាមការណែនាំរបស់ព្យាការីដែលកំពុងរស់នៅ ។

នៅពេលសិស្សបានមានពេលសរសេរគ្រប់គ្រាន់ហើយ សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១៣:៣៣–៣៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលសាសន៍នីហ្វៃដែលមិនប្រែចិត្តនឹងជួបនៅទីបញ្ចប់ និងអ្វីដែលពួកគេនឹងនិយាយអំពីខ្លួនគេ ។ បន្ទាប់មក សូមឲ្យសិស្សផ្សេងទៀតអាន ហេលេមិន ១៣:៣៨ ឮៗ ។ សូមឲ្យសិស្សរកមើលសេចក្តីពិតដ៏ក្រៀមក្រំដែលសាំយូអែលបានប្រកាស ទាក់ទងនឹងកូនចៅជំនាន់ក្រោយនៃសាសន៍នីហ្វៃ ។

- តើសេចក្តីពិតដ៏ក្រៀមក្រំអ្វី ដែលសាំយូអែលបានប្រកាសអំពីកូនចៅជំនាន់ក្រោយនៃសាសន៍នីហ្វៃ ?
- តើអ្នកគិតថា សាំយូអែលចង់មានន័យយ៉ាងណា នៅពេលលោកបានមានប្រសាសន៍ថា « ថ្ងៃសាកល្បងរបស់ពួកគេបានកន្លងទៅហើយ » ? (កូនចៅជំនាន់ក្រោយនៃសាសន៍នីហ្វៃនឹងពន្យារពេលនៃការប្រែចិត្តរហូតដល់វាហួសពេលសម្រាប់ពួកគេប្រែចិត្ត ។ ហើយដោយសារពួកគេមិនប្រែចិត្ត អំពើបាបរបស់ពួកគេនឹងដឹកនាំពួកគេទៅរកសេចក្តីបំផ្លិចបំផ្លាញ) ។
- តើមានអ្វីខុសក្នុងការស្វែងរក « សុភមង្គលនៅក្នុងអំពើទុច្ចរិត » ? (សូមជួយសិស្សឲ្យឃើញថា **សុភមង្គលដ៏ពិតចេញមកតែនៅពេលយើងរក្សាតាមបញ្ញត្តិទាំងឡាយរបស់ព្រះប៉ុណ្ណោះ**) ។
- តើមានរបៀបណាខ្លះដែលប្រជាជនស្វែងរកសុភមង្គលនៅក្នុងការធ្វើអំពើទុច្ចរិតនោះ ?

សូមរំឭកសិស្សពីដំណើររឿងផ្សេងទៀតនៅក្នុងព្រះគម្ពីរមរមន ដែលបន្តក្នុងការបះបោរ និងអំពើទុច្ចរិតរហូតដល់ដួងចិត្តរបស់ពួកគេរឹងទទឹងមិនទទួលព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។ (ឧទាហរណ៍រួមមាន លេមិន និងលេមយូលដែលក្លាយជា « មិនអាចចាប់អារម្មណ៍ » [នីហ្វៃទី ១ ១៧:៤៥] ហើយបដិសេធមិនព្រមស្តាប់តាមព្រះ ហើយស្តេចណូអេ និងប្រជាជនរបស់ទ្រង់ ដែលបានបដិសេធមិនព្រមប្រែចិត្ត ទោះបីជាឮការព្រមានរបស់ព្យាការីអ័ប៊ីណាដៃក្តី) ។ សាំយូអែលបានបញ្ជាក់ថា ការបដិសេធរបស់សាសន៍នីហ្វៃមិនព្រមប្រែចិត្តនឹងនាំទៅរកសេចក្តីបំផ្លិចបំផ្លាញនៃប្រជាជនជំនាន់ក្រោយរបស់គេ ។

សូមជួយឲ្យសិស្សយល់ថា នៅក្នុងកម្រិតផ្ទាល់ខ្លួនមួយ មានសេចក្តីសង្ឃឹមសម្រាប់អ្នកទាំងអស់ដែលនឹងជ្រើសរើសដើម្បីប្រែចិត្ត ។ តាមរយៈការប្រែចិត្ត យើងអាចទទួលបានការអភ័យទោសពីព្រះអម្ចាស់ ហើយរារាំងដួងចិត្តរបស់យើងកុំឲ្យរឹងទទឹង ។ ដើម្បីជួយសិស្សឲ្យយល់ថា យើងអាចកែតម្រូវផ្លូវរបស់យើងតាមរយៈការប្រែចិត្ត សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរ អេស អុជដូហ្វ នៃគណៈប្រធានទីមួយ ៖

« អំឡុងពេលខ្ញុំហ្វឹកហ្វាត់ដើម្បីក្លាយជាមេបញ្ជាការទ័ពជើងអាកាស ខ្ញុំបានរៀនពីរបៀបដើម្បីរុករកយន្តហោះក្នុងរយៈចម្ងាយដ៏ឆ្ងាយ ។ ការហោះនៅលើមហាសមុទ្រដ៏ធំធេង ការឆ្លងកាត់វាលខ្យាច់ដ៏ល្វឹងល្វើយ និងការភ្ជាប់ទីបន្ទាន់ត្រូវការការគ្រោងដ៏ប្រុងប្រយ័ត្នដើម្បីធានាពីការទៅដល់គោលដៅដែលបានគ្រោងទុកដោយសុវត្ថិភាព ។ ការហោះហើរមិនឈប់ទាំងនេះខ្លះអាចមានរយៈពេលទៅដល់ ១៤ ម៉ោង និងនៅលើចម្ងាយផ្លូវជិត ៩,០០០ ម៉ាយល៍ ។

« មានចំណុចនៃការសម្រេចចិត្តដ៏សំខាន់មួយអំឡុងពេលការហោះហើរដ៏យូរបែបនោះ ដែលជាទូទៅហៅថា *ចំណុចនៃការត្រឡប់មកវិញដោយសុវត្ថិភាព* ។ មកដល់ចំណុចនេះ យន្តហោះមានសាំងគ្រប់គ្រាន់ដើម្បីបែរយន្តហោះ ហើយត្រឡប់ទៅវិញដោយសុវត្ថិភាពទៅកាន់អាកាសយានដ្ឋានដែលបានចាកចេញមក ។ ដោយឆ្លងចំណុចនៃការត្រឡប់មកវិញដោយសុវត្ថិភាព មេបញ្ជាការបានបាត់បង់ជម្រើសនេះ ហើយត្រូវតែបន្តទៅមុខ ។ នេះជាមូលហេតុដែលចំណុចនេះជាញឹកញាប់សំដៅលើ *ចំណុចនៃការមិនត្រឡប់មកវិញ* ។

« . . . សាតាំងចង់ឲ្យយើងគិតថា នៅពេលយើងបានធ្វើអំពើបាប យើងបានឆ្លងហួសពី ‹ ចំណុចនៃការមិនត្រឡប់មកវិញ ›—ថាវាហួសពេលនឹងប្តូរផ្លូវរបស់យើង ។ . . .

« . . . ដើម្បីធ្វើឲ្យយើងអស់សង្ឃឹម មានអារម្មណ៍ថេទនាដូចជាវាដែរ ហើយជឿថាយើងលែងត្រូវបានអភ័យទោសឲ្យ នោះសាតាំងអាចប្រើពាក្យខុសពីព្រះគម្ពីរដែលបញ្ជាក់ពីសេចក្តីយុត្តិធម៌របស់ព្រះ ដើម្បីបង្កប់ន័យថាគ្មានសេចក្តីមេត្តាករុណាឡើយ ។ . . .

« ព្រះគ្រីស្ទបានយាងមកដើម្បីសង្គ្រោះយើង ។ ប្រសិនបើយើងបានដើរលើផ្លូវខុស នោះដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទអាចធានាដល់យើងថា អំពើបាបគឺ*មិនមែន*ជាចំណុចនៃការមិនអាចត្រឡប់មកវិញនោះទេ ។ ការត្រឡប់មកវិញដោយសុវត្ថិភាពកើតមាន ប្រសិនបើយើងនឹងធ្វើតាមផែនការរបស់ព្រះសម្រាប់សេចក្តីសង្គ្រោះរបស់យើង » (« Point of Safe Return » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ៩៩) ។

- តើសម្តីរបស់ប្រធាន អុជដូហ្វ អាចផ្តល់សេចក្តីសង្ឃឹមដល់ជនម្នាក់ដែលបានធ្វើបាបដោយរបៀបណា ?

សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតពីសេចក្តីពិតដែលពួកគេបានពិភាក្សា ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមការបំផុសគំនិតនានាដែលពួកគេបានទទួលពីព្រះវិញ្ញាណបរិសុទ្ធ ។ សូមធ្វើទីបន្ទាល់ថា សុភមង្គលនឹងមកដល់អ្នកទាំងឡាយណាដែលធ្វើតាមការអញ្ជើញរបស់ព្រះអម្ចាស់ក្នុងការប្រែចិត្ត ។

កំណត់ចំណាំ ៖ សូមរៀបចំក្រដាសខាងក្រោមសម្រាប់ក្រុមទាំងបីដែលបានរៀបរាប់នៅក្នុងមេរៀននេះពីមុន ។

ក្រុមទី ១—ហេលេមិន ១៣:១–៧, ១១

ព្យាការីនិយាយពីសារលិខិតដែលព្រះបានបញ្ជូលទៅក្នុងដួងចិត្តលោក ។

១. តើខមួយណាដែលអ្នកមានអារម្មណ៍ថាបង្រៀនពីសេចក្តីពិតនេះ ?

២. តើសារលិខិតអ្វីដែលព្រះបានបញ្ជូលទៅក្នុងដួងចិត្តរបស់សាំយូអែល ?

៣. តើអ្នកគិតថា ហេតុអ្វីបានជាវាអាចជារឿងពិបាកសម្រាប់សាំយូអែលដើម្បីបញ្ជូនសារលិខិតនេះ ?

៤. តើឥទ្ធិពលអ្វីដែលសាំយូអែលបានសង្ឃឹមថាសារលិខិតលោកនឹងមានដល់សាសន៍នីហ្វៃ ?

៥. តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ឪពុកម្តាយ ឬអ្នកដឹកនាំសាសនាចក្រត្រូវបានបំផុសឲ្យចែកនូវសារលិខិតមួយដល់អ្នក ? តើវាបានជះឥទ្ធិពលដល់អ្នកយ៉ាងណាដែរ ?

៦. តើសេចក្តីពិតបន្ថែមអ្វីខ្លះដែលអ្នកអាចរកឃើញនៅក្នុងខគម្ពីរនេះ ?

ក្រុមទី ២—ហេលេមិន ១៣:១៧–២៣

នៅពេលណាដែលយើងមិនបានចងចាំដល់ព្រះអម្ចាស់ នោះយើងងាយនឹងក្លាយជាមានភាពឆ្មើងឆ្មៃ ហើយធ្វើអំពើទុច្ចរិត ។

១. តើខមួយណាដែលអ្នកមានអារម្មណ៍ថាបង្រៀនសេចក្តីពិតនេះ ?

២. តើបណ្តាសាអ្វីដែលសាំយូអែលបាននិយាយថានឹងមកដល់សាសន៍នីហ្វៃ ប្រសិនបើពួកគេរឹងទទឹងនៅក្នុងអំពើទុច្ចរិត ?

៣. តើអំពើបាបផ្សេងទៀតដែលសេចក្តីស្រឡាញ់លើទ្រព្យសម្បត្តិរបស់សាសន៍នីហ្វៃបាននាំទៅរកមានអ្វីខ្លះ ?

៤. តើរឿងមួយចំនួនដែលយុវជនអាចផ្តោតចិត្តគេលើ ហើយដែលវានាំទៅរកភាពឆ្មើងឆ្មៃ និងអំពើបាបនោះមានអ្វីខ្លះ ?

៥. តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បី « ចងចាំដល់ព្រះអម្ចាស់ជាព្រះរបស់អ្នកនូវអ្វីៗដែលទ្រង់បានប្រទានពរដល់អ្នក » ? (ហេលេមិន ១៣:២២) ។

៦. តើសេចក្តីពិតបន្ថែមអ្វីខ្លះដែលអ្នកអាចរកឃើញនៅក្នុងខគម្ពីរនេះ ?

ក្រុមទី ៣—ហេលេមិន ១៣:២៤–៣៣

ប្រសិនបើយើងបដិសេធពាក្យសម្តីនៃព្យាការីរបស់ព្រះអម្ចាស់ យើងនឹងជួបនឹងការសោកស្តាយ និងភាពសោកសង្រេង ។

១. តើខមួយណាដែលអ្នកមានអារម្មណ៍ថាបង្រៀនពីសេចក្តីពិតនេះ ?

២. យោងតាមសាំយូអែល ហេតុអ្វីបានជាសាសន៍នីហ្វៃបានបដិសេធពួកព្យាការីដ៏ពិត ?

៣. តើអ្នកគិតថា ហេតុអ្វីបានជាមនុស្សខ្លះទទួលយកព្យាការីក្លែងក្លាយជាព្យាការី ដូចដែលសាំយូអែលបានរៀបរាប់នោះ ?

៤. តើមានការបង្រៀនជាក់លាក់ណាខ្លះពីព្យាការី និងសាវកដែលកំពុងរស់នៅ ?

៥. តើអ្វីខ្លះជា « ការដឹកនាំដោយពួកឆ្កួតវង្វេង និងពួកខ្វាក់ » (ហេលេមិន ១៣:២៩) ដែលព្យាការី និងសាវកដែលកំពុងរស់នៅបានព្រមានដល់យើងឲ្យចៀសវាង ?

៦. តើសេចក្តីពិតបន្ថែមអ្វីខ្លះដែលអ្នកអាចរកឃើញនៅក្នុងខគម្ពីរនេះ ?

ហេលេមិន ១៤

សេចក្តីផ្តើម

ដោយការបន្តបង្រៀនដល់សាសន៍នីហ្វៃនៅក្នុងដែនដីសារ៉ាហិមឡា សាំយូអែលជាសាសន៍លេមិនបានប្រកាសពីទីសម្គាល់ដែលនឹងបង្ហាញពីការប្រសូត្រ និងការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ ។ លោកបានពន្យល់ថា លោកបានព្យាករពីទីសម្គាល់ទាំងនេះដើម្បីជួយប្រជាជនឲ្យជឿលើព្រះយេស៊ូវគ្រីស្ទ ហើយបញ្ចុះបញ្ចូលពួកគេឲ្យប្រែចិត្តពីអំពើបាបរបស់ពួកគេ ។ លោកបានបង្រៀនថា តាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ នោះមនុស្សលោកទាំងអស់នឹងត្រូវបាននាំទៅកាន់វត្តមានរបស់ព្រះវិញ ។ ដោយហៅប្រជាជនឲ្យប្រែចិត្ត នោះលោកបានសន្យាថា អ្នកប្រែចិត្តនឹងត្រូវបានអភ័យទោសពីអំពើបាបរបស់ពួកគេ ប៉ុន្តែថាអ្នកដែលមិនព្រមប្រែចិត្តនឹងត្រូវកាត់ចេញពីវត្តមាននៃព្រះម្តងទៀត ។

ការផ្ញើទីបន្ទាល់

ទីបន្ទាល់មួយគឺជាការប្រកាសដ៏សាមញ្ញចំៗនៃសេចក្តីពិត ។ សូមថ្លែងទីបន្ទាល់របស់អ្នកឲ្យបានញឹកញាប់អំពីព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អដែលបានស្តារឡើងវិញរបស់ទ្រង់ ។ ការណ៍នេះនឹងអញ្ជើញឲ្យមានព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ដែលនឹងពង្រឹងដល់សិស្សនៅក្នុងការខិតខំរបស់ពួកគេដើម្បីរៀន យល់ ហើយរស់នៅតាមដំណឹងល្អ ។

យោបល់សម្រាប់ការបង្រៀន

ហេលេមិន ១៤:១–១៣

សាំយូអែលព្យាករពីទីសម្គាល់ទាំងឡាយទាក់ទងនឹងការប្រសូត្ររបស់ព្រះអង្គសង្គ្រោះ

ពីមុនចាប់ផ្តើមបង្រៀន សូមគូសរូបព្រួញបីដូចខាងក្រោមនៅលើក្តារខៀន ។ អ្នកនឹងបញ្ចូលពាក្យ និងឃ្លានៅជុំវិញរូបព្រួញនៅពេលមេរៀនបន្តទៅមុខ ។

→ → →

សូមឲ្យសិស្សរំឭកពីអ្វីដែលពួកគេបានពិភាក្សានៅក្នុងមេរៀនមុន ដែលនិយាយអំពី ហេលេមិន ១៣ ។ ប្រសិនបើពួកគេត្រូវការជំនួយដើម្បីចងចាំវា សូមរំឭកពួកគេថា ពួកគេបានរៀនអំពីព្យាការីម្នាក់ឈ្មោះ សាំយូអែល ។ សូមឲ្យពួកគេចែកចាយពីសេចក្តីលម្អិតដែលពួកគេចាំអំពីលោក ដូចជាថាតើលោកជានរណា តើលោកបានទៅណា តើលោកបានបង្រៀនអ្វីខ្លះ ហើយស្ថានភាពខាងវិញ្ញាណនៃអ្នកដែលលោកបានបង្រៀន ។ សូមឲ្យសិស្សរំឭកពីរបៀបដែលប្រជាជនឆ្លើយតបនឹងសារលិខិតរបស់សាំយូអែល ។ សូមពន្យល់ថា ហេលេមិន ១៤ រួមមានការបង្រៀនបន្តរបស់សាំយូអែល ។

សូមពន្យល់ថា សាំយូអែលបានព្យាករពីហេតុការណ៍នានាដែលនឹងកើតឡើងនាពេលអនាគត ព្រឹត្តិការណ៍ខ្លះមានចម្ងាយរាប់ពាន់ម៉ាយល៍ពីដែនដីសារ៉ាហិមឡា ។ សូមឲ្យសិស្សមើលត្រួសៗលើ ហេលេមិន ១៤:១–២ ហើយរកមើលហេតុការណ៍មួយដែលសាំយូអែលបានព្យាករ (ការប្រសូត្រនៃព្រះយេស៊ូវគ្រីស្ទ) ។

សូមឲ្យសិស្សអាន ហេលេមិន ១៤:៣–៦ ដោយស្ងៀមស្ងាត់ ដោយរកមើលទីសម្គាល់ដែលសាសន៍នីហ្វៃនឹងឃើញក្នុងពេលនៃការប្រសូត្ររបស់ព្រះអង្គសង្គ្រោះ ។ដ អ្នកអាចណែនាំថា សិស្សគួរគូសចំណាំទីសម្គាល់ទាំងនេះនៅក្នុងព្រះគម្ពីររបស់គេ ។ អ្នកក៏អាចទាញចំណាប់អារម្មណ៍របស់សិស្សទៅលើលេខយោងនៃខគម្ពីរទាំងនេះ ដែលបង្ហាញពីការបំពេញនៃការព្យាកររបស់សាំយូអែលបានផងដែរ ។

- តើការប្រសូត្ររបស់ព្រះអង្គសង្គ្រោះមានន័យចំពោះអ្នកយ៉ាងដូចម្តេចដែរ ?

សូមរកមើលបំណងរបស់អ្នកនិពន្ធ ឬអ្នកនិយាយ

ក្នុងការរៀបចំព្រះគម្ពីរ ព្យាការីពីបុរាណត្រូវបានបំផុសឲ្យបញ្ចូលនូវសារលិខិតដែលនឹងទាក់ទងដល់តម្រូវការរបស់យើងនាសព្វថ្ងៃនេះ ។ នៅពេលអ្នកចង់កំណត់ពីបំណងរបស់អ្នកនិពន្ធ ឬអ្នកនិយាយនៅក្នុងព្រះគម្ពីរមេរម សូមប្រយ័ត្នកុំទៅហួសពីអ្វីដែលបញ្ជាក់ច្បាស់នៅក្នុងអត្ថបទ ។ សូមចាំថា បំណងចម្បងរបស់ព្យាការីគឺតែងតែដើម្បីថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ។

សូមអាន ហេលេមិន ១៤:៨–៩ ឮៗ ។ សូមបញ្ជាក់ពីសារៈសំខាន់នៃការជឿលើព្រះអង្គសង្គ្រោះដើម្បីទទួលបានជីវិតដ៏អស់កល្បជានិច្ច ។ សូមសរសេរ *ជីវិតដ៏អស់កល្បជានិច្ច* បន្ទាប់ពីព្រួញចុងក្រោយគេនៅលើក្តារខៀន ។ សូមពន្យល់ថា « ជីវិតដ៏អស់កល្បជានិច្ច » មានន័យដូចគ្នានឹង « ជីវិតដ៏អស់កល្ប » ។ វាមានន័យថា ការរស់នៅដូចជាព្រះ ហើយរស់នៅជារៀងរហូតក្នុងវត្តមានរបស់ទ្រង់ជាមួយនឹងគ្រួសាររបស់យើង ។ សាំយូអែលបានបង្រៀនសាសន៍នីហ្វៃនៅក្នុងដែនដីសារ៉ាហិមឡាពីអ្វីដែលពួកគេត្រូវធ្វើដើម្បីទទួលជីវិតដ៏អស់កល្បជានិច្ច ។

សូមឲ្យសិស្សអាន ហេលេមិន ១៤:១១–១៣ ដោយស្ងៀមស្ងាត់ ដោយរកមើល អ្វីដែលសាំយូអែលចង់ឲ្យប្រជាជនដឹង ហើយធ្វើតាម ។ អ្នកអាចណែនាំថា សិស្សគួរគូសចំណាំអ្វីដែលសាំយូអែលចង់ឲ្យប្រជាជនដឹង ហើយធ្វើតាម ។

ទៅខាងឆ្វេងនៃព្រួញទីមួយនៅលើក្តារខៀន សូមសរសេរ *ចំណេះដឹង ។* បន្ទាប់មក សូមសួរសិស្សថាតើពួកគេបានរកឃើញអ្វីខ្លះដែលសាំយូអែលចង់ឲ្យប្រជាជនដឹង ។ សូមឲ្យសិស្សពីរបីនាក់សរសេរនូវរឿងទាំងនេះនៅលើក្តារខៀនក្រោមពាក្យ *ចំណេះដឹង ។* (ចម្លើយអាចរួមមាន សាំយូអែលចង់ឲ្យប្រជាជនដឹងអំពីការជំនុំជម្រះរបស់ព្រះសម្រាប់អ្នកទាំងឡាយណាដែលធ្វើបាប លក្ខខណ្ឌនៃការប្រែចិត្ត ការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ និងទីសម្គាល់ទាំងឡាយដែលទាក់ទងនឹងការយាងមករបស់ទ្រង់) ។

- តើសាំយូអែលបានសង្ឃឹមថាចំណេះដឹងនេះនឹងដឹកនាំប្រជាជនឲ្យធ្វើអ្វីខ្លះ ? (ជឿលើព្រះយេស៊ូវគ្រីស្ទ ហើយប្រែចិត្តពីអំពើបាបរបស់គេ) ។

សូមឲ្យសិស្សសរសេរគោលការណ៍មួយដោយផ្អែកលើ ហេលេមិន ១៤:១៣ ។ បន្ទាប់មក សូមឲ្យសិស្សពីរបីនាក់អានឮៗនូវអ្វីដែលពួកគេបានសរសេរ ។ (ចម្លើយមួយអាចថា **ជំនឿលើព្រះយេស៊ូវគ្រីស្ទដឹកនាំទៅរកការប្រែចិត្ត និងការផ្តាច់បាប**) ។

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃឃ្លា « តាមរយៈព្រះគុណទ្រង់ » សូមពន្យល់ថា ព្រះគុណគឺជាលក្ខណៈសម្បត្តិ ឬសកម្មភាព ដែលធ្វើឲ្យមនុស្សម្នាក់សក្តិសមនឹងទទួលរង្វាន់ ។ ដើម្បីសក្តិសមនឹងទទួលបានការផ្តាច់បាបរបស់យើង យើងត្រូវធ្វើរឿងដាក់លាក់ខ្លះ ដូចជាត្រូវប្រែចិត្តដោយស្មោះសរ ជ្រមុជទឹក ហើយទទួលការបញ្ជាក់ និងកាន់តាមព្រះបញ្ញត្តិទាំងឡាយ ។ ទោះបីជាយ៉ាងណាក៏ដោយ យើងទទួលបានអំណោយទាននៃការអភ័យទោសដោយសារតែព្រះគុណរបស់ព្រះអង្គសង្គ្រោះប៉ុណ្ណោះ មិនមែនដោយគុណសម្បត្តិរបស់យើងនោះទេ ។ អ្នកអាចរំឭកសិស្សអំពី នីហ្វៃទី ២ ២៥:២៣ ជាវគ្គមួយនៃចំណេះចំណានខគម្ពីរ ។ « វាតាមរយៈព្រះគុណដែលយើងត្រូវបានសង្គ្រោះ ក្រោយពីយើងអាចធ្វើអ្វីៗទាំងអស់ » ។ អ្នកក៏អាចណែនាំថា សិស្សគួរអាន អាលម៉ា ២២:១៤ និង អាលម៉ា ២៤:១០–១១ ។

សូមបញ្ចប់តារាងនៅលើក្តារខៀនដូចខាងក្រោម ៖

ចំណេះដឹង ⟶ ជំនឿលើព្រះគ្រីស្ទ ⟶ ការប្រែចិត្ត ⟶ ជីវិតដ៏នៅអស់កល្បជានិច្ច

- តើការទទួលបានចំណេះដឹងពីព្រះអង្គសង្គ្រោះ បានបង្កើនជំនឿរបស់អ្នកលើទ្រង់ដោយរបៀបណា ?
- តើជំនឿរបស់អ្នកលើព្រះអង្គសង្គ្រោះបានដឹកនាំអ្នកឲ្យប្រែចិត្ត ហើយខិតខំដើម្បីក្លាយដូចជាទ្រង់ដោយរបៀបណា ?

សូមធ្វើទីបន្ទាល់ មានតែតាមរយៈព្រះគុណនៃព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះដែលយើងអាចយើងទទួលបានការផ្តាច់បាប ហើយទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។

ហេលេមិន ១៤:១៤–៣១

សាំយូអែលព្យាករអំពីទីសម្គាល់ទាក់ទងទៅនឹងការសុគតរបស់ព្រះអង្គសង្គ្រោះ

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១៤:១៤ ឮៗ ។ បន្ទាប់មក សូមឲ្យសិស្សអាន ហេលេមិន ១៤:២០–២៧ ដោយស្ងៀមស្ងាត់ ដោយរកមើលទីសម្គាល់ដែលសាសន៍នីហ្វៃនឹងឃើញនៅពេលព្រះយេស៊ូវគ្រីស្ទសុគត ។ អ្នកអាចណែនាំថា ពួកគេគួរគូសចំណាំទីសម្គាល់ទាំងនេះ ។ នៅពេលពួកគេមានពេលអានគ្រប់គ្រាន់ហើយ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។ សូមប្រាប់ពួកគេថា ការបំពេញតាមទីសម្គាល់ទាំងនេះត្រូវបានកត់ត្រានៅក្នុង នីហ្វៃទី ៣ (សូមមើល ហេលេមិន ១៤:២០, លេខយោង *ក*) ។

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១៤:២៨–២៩ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលមូលហេតុដែលព្រះអម្ចាស់ផ្តល់ទីសម្គាល់ និងការអស្ចារ្យទាំងឡាយ ។ សូមឲ្យសិស្សពីរបីនាក់បង្ហាញមូលហេតុទាំងនេះជាពាក្យសម្តីរបស់គេផ្ទាល់ ។ (សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេរកឃើញសេចក្តីពិតខាងក្រោម ៖ **ព្រះអម្ចាស់ប្រទានទីសម្គាល់ និងការអស្ចារ្យទាំងឡាយ ដើម្បីជួយប្រជាជនឲ្យជឿលើទ្រង់**) ។

- តើសេចក្តីពិតនេះអាចបង្រៀនយើងអ្វីខ្លះអំពីទីសម្គាល់ដែលនឹងនាំទៅរកការយាងមករបស់ព្រះអង្គសង្គ្រោះ ?

សូមឲ្យសិស្សគិតអំពីទីសម្គាល់ ឬករណីតាងនានាដែលព្រះអម្ចាស់បានប្រទានដល់ពួកគេដើម្បីជួយពួកគេឲ្យជឿលើទ្រង់ ។ អ្នកអាចលើកទឹកចិត្តសិស្សឲ្យចែកចាយបទពិសោធន៍របស់ពួកគេ (ប៉ុន្តែសូមរំឭកពួកគេថា ពួកគេមិនគួរមានអារម្មណ៍ថាត្រូវចែកចាយអ្វីៗដែលផ្ទាល់ខ្លួន ឬឯកជនពេកនោះទេ) ។ សូមថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់ផ្តល់នូវទីសម្គាល់ និងបញ្ជូនព្យាការីដូចជាសាំយូអែល នៅក្នុងជំនាន់របស់យើងដើម្បីបញ្ចុះបញ្ចូលប្រជាជនឲ្យជឿលើទ្រង់ ។

កំណត់ចំណាំ ៖ ដោយសារវគ្គព្រះគម្ពីរជាច្រើនព្រមានយើងកុំឲ្យស្វែងរកទីសម្គាល់នានា នោះសិស្សអាចយល់ច្រឡំអំពីការពិភាក្សាពីទីសម្គាល់នេះ ។ សូមជួយពួកគេឲ្យយល់ថា មានភាពខុសគ្នាមួយរវាងការទទួលស្គាល់ទីសម្គាល់នៃសេចក្តីស្រឡាញ់របស់ព្រះ និងការស្វែងរកទីសម្គាល់សម្រាប់មូលហេតុអត្តទត្ថភាពនិយម (សូមមើល យ៉ាកុប ៧:៩–១៤, អាលម៉ា ៣០:៤៣–៥០, គ . និង ស . ៤៦:៩, ៦៣:៧–១១) ។ នៅពេលព្យាការីព្រមានអំពីការស្វែងរកទីសម្គាល់ ពួកលោកសំដៅលើមនុស្សដែលមិនព្រមជឿរហូតដល់ពួកគេឃើញថាមានទីសម្គាល់ មិនមែនមនុស្សដែលអនុវត្តសេចក្តីជំនឿក្នុងការស្វែងរកអព្ភូតហេតុស្របតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់នោះទេ ។

សូមពន្យល់ថា ខណៈពេលដែលវាល្អដើម្បីដឹងអំពីទីសម្គាល់ដែលសាសន៍នីហ្វៃនឹងឃើញដែលទាក់ទងទៅនឹងការសុគតរបស់ព្រះអង្គសង្គ្រោះ វាសំខាន់ជាងដើម្បីយល់ពីការបង្រៀនរបស់សាំយូអែលអំពីផ្នែកសំខាន់នៃការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមគូសតារាងខាងក្រោមនៅលើក្តារខៀន ដោយទុកចន្លោះចំពោះការពន្យល់ ។ សូមបន្ថែមការពន្យល់ទាំងនេះនៅពេលសមរម្យអំឡុងពេលការពិភាក្សានៃ ហេលេមិន ១៤:១៥–១៩ ។ (អ្នកអាចគិតពីការសុំឲ្យសិស្សចម្លងតារាងនេះទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ) ។



សូមពន្យល់ថាឃ្លា « ការស្លាប់ខាងវិញ្ញាណ » សំដៅលើការបែងចេញពីវត្តមានរបស់ព្រះ ។ សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១៤:១៥–១៦ ឮៗ ។

- **តើអ្វីជាសេចក្តីស្លាប់ខាងវិញ្ញាណទីមួយ ដែលបាននិយាយនៅក្នុង ហេលេមិន ១៤:១៦ ? (អ្នកអាចពន្យល់ថា ដោយសារតែការធ្លាក់នៃលោកអ័ដាម និងអេវ៉ា យើងត្រូវបែកចេញពីវត្តមានរបស់ព្រះ) ។**

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១៤:១៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយសញ្ជឹងគិតពីរបៀបដែលពួកគេអាចយកឈ្នះលើសេចក្តីស្លាប់ខាងវិញ្ញាណទីមួយ ។ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ *ព្រះយេស៊ូវគ្រីស្ទសង្រ្គោះលោះមនុស្សលោកទាំងអស់ពីការធ្លាក់ ដើម្បីឲ្យយើងអាចត្រឡប់ទៅកាន់វត្តមានរបស់ព្រះវិញបាន ។* **សូមពន្យល់ថា មនុស្សលោកទាំងអស់នឹងត្រឡប់ទៅកាន់វត្តមានរបស់ព្រះដើម្បីទទួលការជំនុំជម្រះ (សូមមើល នីហ្វៃទី ២ ២:១០) ។**

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១៤:១៨–១៩ ឮៗ ។

- **តើអ្វីទៅគឺជាសេចក្តីស្លាប់ខាងវិញ្ញាណទីមួយ ដែលបាននិយាយនៅក្នុង ហេលេមិន ១៤:១៨–១៩ ? (អ្នកអាចពន្យល់ថា អ្នកដែលមិនប្រែចិត្តនឹងត្រូវកាត់ចេញពីវត្តមានរបស់ព្រះរវិបិតាសួគ៌ម្តងទៀត) ។**
- **តើយើងអាចធ្វើអ្វីខ្លះដើម្បីចៀសវាងសេចក្តីស្លាប់ខាងវិញ្ញាណទីមួយ ដែលបាននិយាយដោយសាំយូអែល ? (សូមគិតពីការឲ្យសិស្សអាន ហេលេមិន ១៤:១៣ និង មរមន ៧:៧–៨ ។ សូមបង្ហាញថា *តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ អ្នកដែលប្រែចិត្តនឹងរស់នៅក្នុងវត្តមាននៃព្រះជារៀងរហូត*) ។**

ដើម្បីបញ្ជាក់ពីសារៈសំខាន់នៃសិទ្ធិជ្រើសរើសនៅពេលយើងស្វែងរកពរ័យនៃដង្វាយធួនរបស់ព្រះអង្គសង្រ្គោះ សូមឲ្យសិស្សអានហេលេមិន ១៤:៣០–៣១ ដោយស្ងៀមស្ងាត់ ។ សូមឲ្យពួកគេរកមើលពាក្យ និងឃ្លាអំពីសិទ្ធិជ្រើសរើសរបស់ពួកគេ ។ សូមឲ្យពួកគេចែកចាយពាក្យ និងឃ្លាដែលពួកគេរកឃើញ ។ សូមឲ្យពួកគេពន្យល់ពីរបៀបដែលពាក្យ និងឃ្លាទាំងនេះជួយពួកគេឲ្យយល់ពីសារៈសំខាន់នៃជម្រើសដែលពួកគេធ្វើរាល់ថ្ងៃ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

ហេលេមិន ១៤:១៨–១៩ ។ អំណោយដ៏ទេវភាពនៃការប្រែចិត្ត

អែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានថ្លែងទីបន្ទាល់អំពីសេចក្តីអំណរដែលកើតមានតាមរយៈការប្រែចិត្តថា ៖

« ខ្ញុំទទួលស្គាល់ ហើយថ្លែងទីបន្ទាល់ដោយអំណរថា ការរងទុក្ខដែលមិនអាចយល់បាន ការសុគត និងការរស់ឡើងវិញរបស់ព្រះអម្ចាស់របស់យើង ‹ នាំមកនូវលក្ខខណ្ឌទាំងឡាយនៃការប្រែចិត្ត › (ហេលេមិន ១៤:១៨) ។ អំណោយដ៏ទេវភាពនៃការប្រែចិត្តគឺជាកូនសោទៅកាន់សុភមង្គលនៅទីនេះ និងនៅកន្លែងបន្ទាប់ពីនេះ ។ នៅក្នុងព្រះបន្ទូលរបស់ព្រះអង្គសង្រ្គោះ និងនៅក្នុងជម្រាំនៃសេចក្តីបន្ទាបខ្លួន និងសេចក្តីស្រឡាញ់ ខ្ញុំសូមអញ្ជើញអ្នកទាំងអស់គ្នាឲ្យ ‹ ប្រែចិត្ត ៖ ដោយសារនគស្ថានសួគ៌នៅកៀកបង្កើយ › (ម៉ាថាយ ៤:១៧) ។ ខ្ញុំដឹងថា ដោយការទទួលយកការអញ្ជើញនេះ អ្នកនឹងរកឃើញនូវសេចក្តីអំណរទាំងពេលឥឡូវនេះ និងជារៀងរហូត » (« The Divine Gift of Repentance » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៤១) ។

ហេលេមិន ១៥–១៦

សេចក្តីផ្តើម

សាំយូអែលជាសាសន៍លេមិនបានព្រមានសាសន៍នីហ្វៃថា ជាបណ្តាពួកគេមិនប្រែចិត្តទេ នោះពួកគេនឹងត្រូវបំផ្លាញបង់ ។ លោកបានប្រកាសថា ព្រះអម្ចាស់នឹងពន្យារពេលរបស់សាសន៍លេមិន ដែលបានក្លាយជាសុចរិតជាងសាសន៍នីហ្វៃ ។ សាសន៍នីហ្វៃខ្លះជឿតាមការបង្រៀនរបស់សាំយូអែល ហើយត្រូវបានជ្រមុជទឹកដោយនីហ្វៃ ។ អ្នកទាំងឡាយដែលមិនជឿតាមសាំយូអែល មានបំណងចង់សម្លាប់លោក ។ ប៉ុន្តែ សាំយូអែលត្រូវបានការពារដោយព្រះចេស្តានៃព្រះ ហើយលោកបានត្រឡប់ទៅដែនដីរបស់លោកវិញ ។

យោបល់សម្រាប់ការបង្រៀន

ហេលេមិន ១៥

សាំយូអែលព្រមានដល់សាសន៍នីហ្វៃ ហើយពន្យល់ពីរបៀបដែលសាសន៍លេមិនបានក្លាយជាប្រជាជននៃសេចក្តីសន្យា

សូមអានការពិពណ៌នាខាងក្រោមនេះឮៗ ៖

យុវជនម្នាក់ត្រូវបានចិញ្ចឹមដោយឪពុកម្តាយដែលមិនមែនជាសមាជិកនៃសាសនាចក្រ ហើយមិនបានបញ្ជាក់ពីការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទឡើយ ។ ពួកគេអនុញ្ញាតឲ្យគាត់ធីកស្រា ជាទម្លាប់ដែលគាត់បានបន្តដល់មហាវិទ្យាល័យ ។ បន្ទាប់មក គាត់បានជួបនឹងអ្នកផ្សព្វផ្សាយសាសនានៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ក្រោយពីការជួបជាមួយនឹងអ្នកផ្សព្វផ្សាយសាសនាពីរបីដង គាត់បានឈប់ធីកស្រា ។ ពីរបីថ្ងៃក្រោយមក គាត់បាននៅជាមួយនឹងមិត្តភក្តិមួយក្រុម ។ ពួកគេបានឲ្យស្រាគាត់មួយកែវ ។

យុវជនម្នាក់ទៀតត្រូវបានចិញ្ចឹមនៅក្នុងគ្រួសារនៃពួកបរិសុទ្ធថ្ងៃចុងក្រោយមួយ ។ ឪពុកម្តាយរបស់គាត់បានធ្វើរាត្រីជួបជុំក្រុមគ្រួសារ និងការសិក្សាព្រះគម្ពីរជាគ្រួសារ ។ គាត់បានមានទម្លាប់សិក្សាព្រះគម្ពីរប្រចាំថ្ងៃ និងអធិស្ឋានផ្ទាល់ខ្លួន ។ គាត់បានចូលរួមថ្នាក់កុមារបម្រើនៅក្នុងភូរ៉ុមបព្វជិតភាពអើរ៉ុន ហើយបានបញ្ចប់ពីថ្នាក់សិក្ខាសាលា ដោយទទួលបានចំណេះដឹងពីព្រះបញ្ញត្តិ និងរបៀបទាំងឡាយរបស់ព្រះអម្ចាស់ ។ ខណៈរៀននៅក្នុងមហាវិទ្យាល័យ គាត់បានមានមិត្តថ្មីជាច្រើន ។ យប់មួយមិត្តម្នាក់បានឲ្យគាត់នូវស្រាមួយកែវ ។

- តើការទទួលយកស្រានោះជាកំហុសដ៏ធ្ងន់ធ្ងរមួយសម្រាប់យុវជនទីមួយ ឬ យុវជនទីពីរ ? ហេតុអ្វី ?

សូមសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ៖

ស្ថានភាពខាងវិញ្ញាណរបស់សាសន៍នីហ្វៃ—ហេលេមិន ១៥:១–៣, ១៧

ស្ថានភាពខាងវិញ្ញាណរបស់សាសន៍លេមិន—ហេលេមិន ១៥:៤–៦

សូមឲ្យសិស្សអានវគ្គព្រះគម្ពីរដែលមាននៅលើក្តារខៀនស្ងៀមស្ងាត់ ។ (មុនពេលពួកគេអាន អ្នកអាចណែនាំចំណាប់អារម្មណ៍របស់គេទៅលើពាក្យ *ដោយប្រយត្នប្រយែង* នៅក្នុង ហេលេមិន ១៥:៥ ។ ដើម្បីធ្វើអ្វីមួយដោយប្រយត្នប្រយែងមានន័យថា ធ្វើដោយការយកចិត្តដាក់ខ្លាំង) ។ សូមឲ្យសិស្សសរសេរប្រយោគពីរ—ប្រយោគមួយសង្ខេបពីលក្ខខណ្ឌខាងវិញ្ញាណនៃសាសន៍នីហ្វៃ និងប្រយោគមួយទៀតសង្ខេបពីលក្ខខណ្ឌខាងវិញ្ញាណនៃសាសន៍លេមិន ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមសួរថា ៖

- យុវជនទាំងពីរនាក់ដែលយើងបានពិភាក្សានៅដើមដំបូងនៃមេរៀន តើយុវជនម្នាក់ណាមានភាពស្រដៀងគ្នាទៅនឹងសាសន៍នីហ្វៃដែលបានពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ ? តើយុវជនម្នាក់ណាស្រដៀងនឹងសាសន៍លេមិន ?
- ទោះបីជាសាសន៍លេមិនមានប្រវត្តិធ្វើអំពើទុច្ចរិតដ៏យូរក្តី ហេតុអ្វីបានជាពួកគេអាចទទួលបានពរជ័យដ៏ច្រើនបែបនេះ ?
- ហេតុអ្វីបានជាសាសន៍នីហ្វៃស្ថិតក្នុងគ្រោះថ្នាក់នៃការត្រូវបំផ្លាញបង់ដូច្នេះ ?
- តើការផ្គាប់ផ្គាលរបស់ព្រះអម្ចាស់ជាសញ្ញាមួយនៃសេចក្តីស្រឡាញ់របស់ទ្រង់ដោយរបៀបណា ? (អ្នកអាចពន្យល់ថាពាក្យ *ផ្គាប់ផ្គាល* មានន័យថា ការកែតម្រូវនរណាម្នាក់តាមរយៈការដាក់ទោស ឬការរងទុក្ខមួយចំនួន ។)

សូមសរសេរប្រយោគខាងក្រោមនៅលើក្តារខៀន ៖

នៅពេលប្រជាជនដឹងពីសេចក្តីពិត ហើយជឿលើព្រះគម្ពីរ ពួកគេត្រូវបានដឹកនាំទៅ . . . និង . . . ដែលនាំមកនូវ . . .

សូមឲ្យសិស្សអាន ហេលេមិន ១៥:៧ ដោយស្ងៀមស្ងាត់ ដោយរកមើលរបៀបដែលពួកគេអាចបំពេញប្រយោគនៅលើក្តារខៀន ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមសួរសិស្សពីរបីនាក់ថា តើពួកគេនឹងបំពេញប្រយោគនេះដោយរបៀបណា ។ (ឧទាហរណ៍ សិស្សអាចនិយាយពីគោលការណ៍ខាងក្រោម ៖ **នៅពេលប្រជាជនដឹងពីសេចក្តីពិត ហើយជឿលើព្រះគម្ពីរ ពួកគេត្រូវបានដឹកនាំទៅរកសេចក្តីជំនឿ និងការប្រែចិត្ត ដែលនាំមកនូវការផ្លាស់ប្តូរក្នុងដួងចិត្ត**) ។

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១៥:៨ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលការរៀបរាប់របស់សាំយូអែលអំពីសាសន៍លេមិនដែលបានទទួលការផ្លាស់ប្តូរចិត្តគំនិតមួយ ។ (ពួកគេ « រឹងមាំ និងខ្ជាប់ខ្ជួននៅក្នុងសេចក្តីជំនឿ ») ។

សូមឲ្យសិស្សមានពេលសញ្ជឹងគិតថាតើការសិក្សាព្រះគម្ពីរបាននាំពួកគេឲ្យមានសេចក្តីជំនឿដ៏អស្ចារ្យមួយទៅលើព្រះអម្ចាស់ឬទេ ។ សូមឲ្យពួកគេសញ្ជឹងគិតដែរថាតើការណ៍នេះបាននាំពួកគេឲ្យរឹងមាំ និងខ្ជាប់ខ្ជួននៅក្នុងសេចក្តីជំនឿ ឬទេ ។ សូមគិតពីការឲ្យសិស្សម្នាក់ឬពីរនាក់ពន្យល់ពីរបៀបដែលការសិក្សាបទគម្ពីរបានបង្កើនសេចក្តីជំនឿរបស់គេទៅលើព្រះយេស៊ូវគ្រីស្ទ ។

សូមទាញចំណាប់អារម្មណ៍របស់សិស្សលើ ហេលេមិន ១៥:៩–១៧ ។ សូមពន្យល់ថា នៅក្នុងខគម្ពីរទាំងនេះ ពាក្យ *អ្នក* សំដៅលើសាសន៍នីហ្វៃហើយពាក្យ *ពួកគេ* និង *ពួកគេ* សំដៅលើសាសន៍លេមិន ។ សូមអានខគម្ពីរទាំងនេះឮៗដល់សិស្ស ដោយឈប់ពេលត្រូវការពន្យល់ ឬឆ្លើយនឹងសំណួរ ។ បន្ទាប់មក សូមឲ្យសិស្សមានពេលមើលខនោះម្តងទៀត ហើយសរសេរប្រយោគមួយដែលបញ្ជាក់ពីសេចក្តីពិតដែលបានបង្រៀននៅក្នុងខគម្ពីរទាំងនេះ ។

សូមឲ្យសិស្សបីឬបួននាក់អានអ្វីដែលពួកគេបានសរសេរ ។ នៅក្នុងចំណោមសេចក្តីពិតផ្សេងទៀត សិស្សអាចសរសេរអ្វីមួយដូចនេះ ៖ **ប្រសិនបើប្រជាជនភ្លាយជាមិនជឿ បន្ទាប់ពីទទួលបានភាពពោរពេញនៃដំណឹងល្អហើយ នោះពួកគេនឹងទទួលការដាក់ទោសដ៏ខ្លាំង ។** អ្នកអាចណែនាំថា សិស្សគួរសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់គេក្បែរ ហេលេមិន ១៥:៩–១៧ ។

នៅពេលសិស្សពិភាក្សាពីសេចក្តីពិតនេះ សូមបញ្ជាក់ពីពរជ័យដ៏អស្ចារ្យដែលកើតមានពីការយល់ និងការរស់នៅតាមដំណឹងល្អនាពេលនេះ ។ ការបង្រៀនរបស់សាំយូអែលមិនបានអត់ទោសដល់សមាជិកសាសនាចក្រថ្មីដែលបានប្រព្រឹត្តអំពើបាបនោះទេ ។ ហើយក៏វាមិនបង្កប់ថា យើងអាចរត់ចេញពីការទទួលខុសត្រូវ និងការដាក់ទោសដោយការបដិសេធមិនរៀនអំពីដំណឹងល្អដែរ ។ ខណៈដែលវាពិតថា ការមានចំណេះដឹងអំពីដំណឹងល្អនាំទៅរកការទទួលខុសត្រូវកើនឡើង ប្រសិនបើយើងធ្វើអ្វីមួយខុស វាក៏នាំទៅរកកម្លាំងដ៏ខ្លាំងជាងក្នុងការដែលយើងខិតខំធ្វើអ្វីដែលត្រូវដែរ ។ ហើយនៅពេលយើងធ្វើតាមឆន្ទៈរបស់ព្រះ និងជួយអ្នកដទៃឲ្យធ្វើដូច្នោះ ទ្រង់នឹងប្រទានពរដល់យើងឲ្យមានសន្តិភាព និងសុភមង្គលដែលយើងមិនអាចទទួលបានតាមរបៀបផ្សេងទៀត ។

ហេលេមិន ១៦

អ្នកទាំងឡាយណាដែលជឿលើសាំយូអែលបានប្រែចិត្ត ហើយបានជ្រមុជទឹក ខណៈដែលអ្នកផ្សេងទៀតមានចិត្តរឹងរូស

សូមបង្ហាញរូបភាពមួយរបស់ប្រធានសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយចុងក្រោយបច្ចុប្បន្ន ។ សូមឲ្យសិស្សពិពណ៌នាពីរបៀបខុសគ្នាដែលពួកគេបានឃើញប្រជាជន (ទាំងខាងក្នុង និងក្រៅសាសនាចក្រ) ឆ្លើយតបនឹងសារលិខិតរបស់ព្យាការី ។

សូមឲ្យសិស្សពាក់កណ្តាលអាន ហេលេមិន ១៦:១–៥ ដោយស្ងៀមស្ងាត់ ដោយរកមើលសកម្មភាពនៃប្រជាជនដែលជឿលើសារលិខិតរបស់សាំយូអែល ។ សូមឲ្យសិស្សពាក់កណ្តាលទៀតអាន ហេលេមិន ១៦:២–៣, ៦–៧ ដោយស្ងៀមស្ងាត់ ដោយរកមើលសកម្មភាពរបស់មនុស្សដែលមិនជឿលើសារលិខិតរបស់សាំយូអែល ។ (អ្នកអាចសរសេរសេចក្តីយោងព្រះគម្ពីរទាំងនេះនៅលើក្តារខៀន) ។ សូមឲ្យសិស្សពីរបីនាក់រៀបរាប់ពីអ្វីដែលពួកគេបានរៀន ។

- តើអ្នកគិតថា ហេតុអ្វីបានជាមនុស្សឆ្លើយតបនឹងព្យាការី និងសារលិខិតរបស់លោកតាមរបៀបខុសៗគ្នា ?
- តើអ្នកគិតថា ហេតុអ្វីបានជាមនុស្សខឹងសម្បារ នៅពេលព្យាការីផ្តល់ការណែនាំដូចជាពាក្យនៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន ៖

« នៅពេលព្យាការីបង្ហាញពីអំពើបាបនៃមនុស្សលោក នោះមនុស្សខាងលោកិយ ដោយមិនបានប្រែចិត្តពីអំពើបាបរបស់គេហើយ ថែមទាំងចង់បិតមាត់របស់ព្យាការី ឬធ្វើទង្វើបាក់ដូចជាគ្មានព្យាការីទៅវិញ ។ ភាពល្បីល្បាញមិនដែលជាការសាកល្បងនៃសេចក្តីពិតនោះទេ ។ ជាច្រើនដងដែលព្យាការីមួយរូបត្រូវបានសម្លាប់ ឬបណ្តេញចេញ ។ នៅពេលយើងខិតកាន់តែជិតការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ អ្នកអាចសង្ឃឹមថា នៅពេលមនុស្សក្នុងលោកិយកាន់តែមានភាពទុច្ចរិតកាន់តែខ្លាំង នោះព្យាការីនឹងមានតម្លៃចំពោះពួកគេកាន់តែតិចទៅ » (*The Teachings of Ezra Taft Benson* | ឆ្នាំ ១៩៨៨ | ទំព័រ ១៣៣) ។

- តើគំរូណាខ្លះនៃប្រជាជនដែលធ្វើតាមការណែនាំរបស់ព្យាការី ទោះបីជាអ្នកដទៃបានបដិសេធការណែនាំនោះក្តី ?

សូមឲ្យសិស្សបិទព្រះគម្ពីររបស់គេ ។ សូមឲ្យសិស្សម្នាក់បើកគម្ពីររបស់គេ ហើយអាន ហេលេមិន ១៦:១៣–១៤ ខណៈពេលសិស្សផ្សេងទៀតស្តាប់ ។ សូមសួរសិស្ស តើពួកគេគិតថាពួកអ្នកមិនជឿនឹងឆ្លើយតបចំពោះទីសម្គាល់ និងការលេចឡើងទាំងនេះដោយរបៀបណា ?

សូមឲ្យសិស្សបើកគម្ពីររបស់គេ ហើយមើលតាមនៅពេលអ្នកអាន ហេលេមិន ១៦:១៥–១៦ ដល់គេ ។ បន្ទាប់មក សូមឲ្យពួកគេស្រមៃថា ពួកគេត្រូវបានអនុញ្ញាតឲ្យនិយាយជាមួយនឹងប្រជាជនដែលនៅក្នុងដែនដីសាអ៊ាហិមឡានៅពេលទីសម្គាល់បានផ្តល់មក ។ សូមឲ្យពួកគេគិតអំពីសំណួរ ដែលពួកគេនឹងសួរអ្នកជឿ ឬអ្នកមិនជឿម្នាក់ ។ ក្រោយពីសិស្សមានពេលគិតពីសំណួរហើយ សូមឲ្យពួកគេពីរបីនាក់ចែកចាយសំណួររបស់គេជាមួយនឹងសិស្សក្នុងថ្នាក់ ។

សូមឲ្យសិស្សសញ្ជឹងគិតពីសំណួរខាងក្រោមនេះនៅក្នុងចិត្ត។

- ប្រសិនបើអ្នកបាននៅទីនោះ ហើយធ្វើជាសាក្សីពីទីសម្គាល់ និងការអស្ចារ្យទាំងឡាយ តើអ្នកគិតថា អ្នកនឹងឆ្លើយតបដោយរបៀបណា ?

នៅពេលសិស្សមានពេលសញ្ជឹងគិតហើយ សូមសួរ ៖

- យោងតាម ហេលេមិន ១៦:១៦ ហេតុអ្វីបានជាមនុស្សខ្លះបដិសេធការបំពេញតាមការព្យាករណ៍របស់ព្យាការី រួមមានទីសម្គាល់មកពីស្ថានសួគ៌ ?

សូមឲ្យសិស្សមានពេលពីរបីនាទីអាន ហេលេមិន ១៦:១៧–២១ ដោយស្វាត់ៗដោយរកមើលការដោះសារបន្ថែមនានាដែលពួកទុច្ចរិតមានក្នុងការដែលមិនជឿដល់ការព្យាករណ៍របស់សាំយូអែល ។ សូមហៅសិស្សពីរបីនាក់ឲ្យប្រាប់ថាតើមានការដោះសារអ្វីខ្លះដែលពួកគេបានរកឃើញនៅក្នុងខទាំងនេះ ។

- នៅក្នុងចំណោមការដោះសារ ឬទស្សនៈទាំងនេះដែលប្រឆាំងនឹងព្យាការី តើអ្នកគិតថាការដោះសារ ឬ ទស្សនៈមួយណាដែលកើតមានច្រើនជាងគេនៅក្នុងជំនាន់យើង ?

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១៦:២២–២៣ ឮៗ ហើយសុំឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលបានកើតឡើងនៅពេលប្រជាជនជាច្រើនបានបន្តព្រងើយកន្តើយនឹងការព្រមានរបស់សាំយូអែល ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើនឹងមានអ្វីកើតឡើងដល់យើង ប្រសិនបើយើងបដិសេធព្យាការីថ្ងៃចុងក្រោយរបស់ព្រះអម្ចាស់ ?

នៅពេលសិស្សឆ្លើយ សូមបញ្ចាក់នូវគោលការណ៍ខាងក្រោម ៖ **នៅពេលយើងបដិសេធសាក្សីរបស់ព្រះអម្ចាស់ យើងនឹងអនុញ្ញាតឲ្យសាតាំងភ្ជាប់ដួងចិត្តរបស់យើង ។** (អ្នកអាចសរសេរប្រយោគនេះនៅលើក្តារខៀន) ។

ដើម្បីបញ្ចប់មេរៀនថ្ងៃនេះ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ។ សូមឲ្យសិស្សផ្សេងទៀតស្តាប់រកមើលអ្វី ដែលយើងពិតជាកំពុងជ្រើសរើសនៅពេលយើងបដិសេធមិនស្តាប់តាមការណែនាំពីព្រះ ដែលភាគច្រើនមកតាមរយៈព្យាការីថ្ងៃចុងក្រោយ ៖

« នៅពេលយើងបដិសេធការណែនាំមកពីព្រះ យើងមិនបានជ្រើសរើសដើម្បីឯករាជ្យពីឥទ្ធិពលខាងក្រៅនោះទេ ។ យើងជ្រើសរើសឥទ្ធិពលផ្សេងទៀត ។ យើងបដិសេធការការពារពីព្រះវរបិតាដែលគង់នៅស្ថានសួគ៌ដ៏ជាទីស្រឡាញ់ឥតខ្ចោះ ដែលមានព្រះចេស្តាទាំងអស់ ដែលជ្រាបនូវគ្រប់ការណ៍ទាំងអស់ ដែលមានគោលបំណងទាំងមូលដូចជាព្រះរាជបុត្រាជាទីស្រឡាញ់របស់ទ្រង់ដែរ គឺដើម្បីប្រទានដល់យើងនូវជីវិតដ៏នៅអស់កល្បជានិច្ច ដើម្បីប្រទានដល់យើងនូវអ្វីៗទាំងអស់ដែលទ្រង់មាន និងដើម្បីនាំយើងទៅផ្ទះវិញជាក្រុមគ្រួសារទៅកាន់ព្រះហស្តនៃសេចក្តីស្រឡាញ់របស់ទ្រង់ ។ ដោយការបដិសេធការណែនាំរបស់ទ្រង់ យើងជ្រើសរើសយកឥទ្ធិពលនៃអំណាចផ្សេងទៀត ដែលមានបំណងធ្វើឲ្យយើងវេទនា និងដែលការជម្រុញរបស់វាគឺឲ្យស្លប់ ។ យើងមានសិទ្ធិជ្រើសរើសខាងសីលធម៌ដែលជាអំណោយទានមួយមកពីព្រះ ។ ជាជាងសិទ្ធិជ្រើសរើសដើម្បីមានសេរីភាពចេញពីឥទ្ធិពល វាជាសិទ្ធិដ៏ជាក់ច្បាស់ដើម្បីដាក់ខ្លួនយើងទៅនឹងអំណាចអ្វីក៏ដោយដែលយើងជ្រើសរើស » (« Finding Safety in Counsel » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៧ ទំព័រ ២៥) ។

- យោងតាមប្រធាន អាវរិង តើយើងពិតជាកំពុងជ្រើសរើសអ្វី ប្រសិនបើយើងបដិសេធការណែនាំពីព្រះ និងព្យាការីរបស់ទ្រង់ ?

សូមឲ្យសិស្សពិចារណាដោយស្ងប់ស្ងាត់ថាតើពួកគេធ្លាប់ធ្វើឲ្យចិត្តពួកគេរឹងរូសទាស់នឹងការណែនាំដែលព្រះបានប្រទានឲ្យតាមរយៈព្យាការី និងសាវកដែរឬទេ ។ សូមលើកទឹកចិត្តឲ្យពួកគេរឹងមាំ ហើយខ្ជាប់ខ្ជួននៅក្នុងការរស់នៅតាមដំណឹងល្អ និងនៅក្នុងការធ្វើតាមការណែនាំរបស់ព្រះអម្ចាស់មកពីព្យាការីរបស់ទ្រង់ ។ សូមធ្វើទីបន្ទាល់អំពីសេចក្តីពិតដែលអ្នកបានពិភាក្សានៅក្នុងមេរៀននេះ ។

ការរំឭកហេលេមិនឡើងវិញ

សូមយកពេលខ្លះជួយសិស្សឲ្យរំឭកគម្ពីរហេលេមិនឡើងវិញ ។ សូមឲ្យពួកគេគិតអំពីអ្វីដែលពួកគេបានរៀនពីគម្ពីរនេះ ទាំងនៅក្នុងថ្នាក់សិក្ខាសាលា និងនៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់គេ ។ សូមឲ្យពួកគេរំឭកដោយខ្លីនូវសេចក្តីសង្ខេបជំពូកនៅក្នុងហេលេមិនដើម្បីជួយពួកគេឲ្យចងចាំ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីមួយពីហេលេមិន ដែលបានបំផុសដល់ពួកគេ ឬដែលបានជួយដល់ពួកគេឲ្យមានសេចក្តីជំនឿកាន់តែខ្លាំងទៅលើព្រះយេស៊ូវគ្រីស្ទ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបីបួននាក់ចែកចាយគំនិត និងអារម្មណ៍របស់គេ ។

មេរៀនសិក្សានៅផ្ទះ

ហេលេមិន ១០–១៦ (មេរៀនទី ២៣)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយខាងក្រោមដែលសិស្សបានរៀន នៅពេលពួកគេសិក្សា ហេលេមិន ១០–១៦ (មេរៀនទី ២៣) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ហេលេមិន ១០)

ហេលេមិន ១០ បានផ្តល់ដល់សិស្សនូវឱកាសមួយដើម្បីរៀនបន្ថែមទៀតអំពីកម្លាំងខាងវិញ្ញាណរបស់នីហ្វៃ ។ តាមរយៈគំរូរបស់គាត់ សិស្សបានរៀនថា ការសញ្ជឹងគិតនូវរឿងរបស់ព្រះអម្ចាស់រៀបចំយើងឲ្យទទួលបានវិវរណៈ ។ ពួកគេក៏បានរៀនថា ព្រះអម្ចាស់បានប្រទានដល់យើងនូវពរជ័យ និងការទទួលខុសត្រូវនៅពេលយើងដាក់ព្រះបំណងរបស់ទ្រង់មុនបំណងរបស់យើងផ្ទាល់ ។ នៅពេលនីហ្វៃដាក់ព្រះបំណងរបស់ព្រះអម្ចាស់មុនបំណងផ្ទាល់របស់លោក ព្រះអម្ចាស់បានប្រទានដល់លោកនូវអំណាចផ្សារភ្ជាប់ ។

ថ្ងៃទី ២ (ហេលេមិន ១១–១២)

ដោយសិក្សាពីប្រវត្តិសាស្ត្រ ១៤ ឆ្នាំ នៃសាសន៍នីហ្វៃ សិស្សបានរៀនថា តាមរយៈសេចក្តីរាបសារ និងការប្រែចិត្ត នោះយើងអាចចៀសវាងនូវភាពឆ្មើងឆ្មៃ និងការបំផ្លាញ ។ ប្រសិនបើយើងមិនប្រយ័ត្នទេ ការកែចម្រើនរបស់យើងអាចដឹកនាំយើងឲ្យភ្លេចព្រះអម្ចាស់ ។ នីហ្វៃបានបង្រៀនថា ដើម្បីជួយប្រជាជនឲ្យចៀសវាងកំហុសនេះ ព្រះអម្ចាស់បានផ្ញាញ់ផ្ញាលប្រជាជនរបស់ទ្រង់ឲ្យពួកគេចងចាំដល់ទ្រង់ ។

ថ្ងៃទី ៣ (ហេលេមិន ១៣–១៤)

សាំយូអែល ជាព្យាការីសាសន៍លេមិនម្នាក់ បានបង្ហាញថា ព្យាការីទាំងឡាយនិយាយពីសារលិខិតដែលព្រះបានដាក់ទៅក្នុងចិត្តរបស់លោក ។ នៅក្នុងការសិក្សាពីការព្រមានរបស់ព្យាការី សិស្សបានរៀនថា ប្រសិនបើយើងបដិសេធពាក្យសម្តីព្យាការីរបស់ព្រះអម្ចាស់ យើងនឹងជួបការសោកស្តាយ និងការសោកសង្រេង ។ សាំយូអែលបានជាស់តឿនប្រជាជនឲ្យជឿលើព្រះយេស៊ូវគ្រីស្ទ ហើយបានថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់នឹងផ្តល់នូវទីសម្គាល់ និងការអស្ចារ្យនានាដើម្បីជួយមនុស្សឲ្យជឿលើទ្រង់ ។

ថ្ងៃទី ៤ (ហេលេមិន ១៥–១៦)

ដោយសារព្រះអម្ចាស់បានប្រទានពរដល់សាសន៍នីហ្វៃយ៉ាងច្រើនក្រៃលែង សាំយូអែលបានព្យាយាមជួយពួកគេឲ្យយល់ថាការជំនុំជម្រះរបស់ព្រះដែលពួកគេនឹងជួប ប្រសិនបើពួកគេមិនប្រែចិត្តទេ ។ នៅក្នុងបញ្ហានេះ សិស្សបានរៀនថា ប្រសិនបើមនុស្សភ្លាយជាមិនជឿក្រោយពីបានទទួលភាពពេញលេញនៃដំណឹងល្អហើយ ពួកគេនឹងទទួលការដាក់ទោសយ៉ាងខ្លាំងជាងមុន ។ នៅក្នុងចម្លើយរបស់សាសន៍នីហ្វៃទៅកាន់សាំយូអែល សិស្សបានរៀនថា នៅពេលយើងជ្រើសរើសបដិសេធទីបន្ទាល់របស់ព្រះអម្ចាស់ យើងនឹងអនុញ្ញាតឲ្យសាតាំងក្តាប់យកដួងចិត្តរបស់យើង ។

សេចក្តីផ្តើម

នៅក្នុង ហេលេមិន ១០–១៦ តួនាទីរបស់ព្យាការីនៅក្នុងការប្រកាសពីការប្រែចិត្តត្រូវបានបញ្ជាក់ ។ ពេញមួយសប្តាហ៍នេះ សិស្សបានមានឱកាសមួយដើម្បីសិក្សាពីភាពស្មោះត្រង់នៃព្យាការីនីហ្វៃ និងសាំយូអែលជាសាសន៍លេមិន ។ បុរសទាំងពីរបូបនេះបានទទួលការបើកបង្ហាញខាងព្រះវិញ្ញាណ ហើយមានអំណាចដើម្បីបម្រើក្នុងចំណោមសាសន៍នីហ្វៃដ៏ទុច្ចរិត ។ ទោះបីជាជួបនឹងភាពរឹងរូសនៃដួងចិត្តរបស់ប្រជាជនក្តី ក៏បុរសទាំងពីរនេះបានប្រកាសពីការប្រែចិត្ត ។ ពួកលោកបានបង្រៀនថា សុភមង្គលកើតមាននៅក្នុងការរស់នៅតាមគោលការណ៍ដែលបានគ្រោងដោយព្រះរបស់ព្រីស្ទ ហើយមិនមែនដោយការធ្វើអំពើទុច្ចរិតឡើយ ។

យោបល់សម្រាប់ការបង្រៀន

ហេលេមិន ១០–១៦

ហេលេមិន និងសាំយូអែលបម្រើដោយស្មោះត្រង់ដល់ប្រជាជន

សូមសួរសិស្សថា តើពួកគេធ្លាប់នៅក្នុងស្ថានភាពមួយដែលការគាំទ្របទដ្ឋានត្រូវបានបង្រៀននៅក្នុងកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* មិនមានភាពល្បីជាមួយនឹងមិត្តរបស់គេទេ ។ អ្នកអាចសុំឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់ពួកគេ ហើយប្រាប់អំពីអ្វីដែលពួកគេមានអារម្មណ៍ និងបានរៀន ។

សូមប្រាប់សិស្សថា ហេលេមិន ១០–១៦ ផ្តល់នូវគំរូពីបុរសពីរូបដែលបានក្រោកឈរដើម្បីបទដ្ឋានរបស់ព្រះអម្ចាស់ ទោះបីជាវាមិនល្បីជាមួយនឹងមនុស្សក្តី ។ សូមឲ្យសិស្សពិចារណាពីអ្វីដែលពួកគេអាចរៀនពីគំរូរបស់នីហ្វៃ និងសាំយូអែលជាសាសន៍លេមិន ដែលអាចជួយពួកគេនៅក្នុងកាលៈទេសៈស្រដៀងគ្នានេះ ។

សូមគូសតារាងខាងក្រោមនៅលើក្តារខៀន ឬនៅលើក្រដាសមួយ ៖

ភាពស្រដៀងគ្នារវាងនីហ្វៃ និងសាំយូអែលជាសាសន៍លេមិន		
នីហ្វៃ (ហេលេមិន ១០:៩–៥, ១២, ១៥–១៦)		សាំយូអែល (ហេលេមិន ១៣:១–៦; ១៦:១–២)

សូមឲ្យសិស្សសិក្សាខគម្ពីរដែលមាននៅលើតារាង ដោយរកមើលភាពស្រដៀងគ្នារវាងនីហ្វៃ និងសាំយូអែល ។ សូមឲ្យសិស្សពីរបីនាក់សរសេរភាពស្រដៀងគ្នាទាំងនេះនៅក្នុងចន្លោះទទេនៅក្នុងតារាង ។ ភាពស្រដៀងគ្នានោះអាចរួមមានដូចខាងក្រោម ៖ បានបដិសេធដោយប្រជាជន បានឮសំឡេងរបស់ព្រះអម្ចាស់ បានធ្វើតាមការណែនាំរបស់ព្រះអម្ចាស់ភ្លាមៗ បាននិយាយអ្វីដែលព្រះអម្ចាស់បានដាក់ទៅក្នុងចិត្តលោក បានព្រមានសាសន៍នីហ្វៃថា ប្រសិនបើពួកគេមិនប្រែចិត្តទេ ពួកគេនឹងត្រូវបំផ្លាញបង់ បានការពារដោយព្រះចេស្តានៃព្រះដើម្បីឲ្យលោកអាចបញ្ចូនសារលិខិតរបស់ទ្រង់ ។

ក្រោយពីសិស្សបានសរសេរភាពស្រដៀងគ្នាដែលពួកគេរកឃើញហើយ សូមឲ្យសិស្សម្នាក់អានហេលេមិន ១០:៤ ឮៗ ។ បន្ទាប់មក សួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- តើមូលហេតុអ្វីខ្លះដែលនីហ្វៃគ្មានការនឿយហត់ ?
- តើសាំយូអែលបានបង្ហាញការមិននឿយហត់ដៃរតាមរបៀបណា ? តើយើងអាចអភិវឌ្ឍការមិននឿយហត់បែបនោះដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អានដល់សិស្សក្នុងថ្នាក់នូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ នែល អេ ម៉ាក់ស្វែល នៃក្រុមនៃពួកសាវកដប់ពីរនាក់ ដែលលោកបង្រៀនយើងពីរបៀបដែលយើងអាចអភិវឌ្ឍលក្ខណៈសម្បត្តិនេះ ៖

« ប្រសិនបើយើងផ្តោតលើព្រះយេស៊ូវ និងកិច្ចការរបស់ទ្រង់ ទាំងសេចក្តីអំណរ និងសមត្ថភាពដើម្បីបន្តរបស់យើងនឹងកើនឡើង ។ . . . នីហ្វៃមិនបានស្វែងរក ‹ ជីវិតរបស់លោកផ្ទាល់ › ដោយភាពអត្មានិយមឡើយ ប៉ុន្តែលោកបានស្វែងរកធ្វើតាមចន្ទះរបស់ព្រះ ។ ការណ៍នេះបានឲ្យលោកមានកម្លាំងបន្ថែម ហើយមិនអាចបំបែកបាន ដែលធ្វើឲ្យការខិតខំរបស់លោកដោយឧស្សាហ៍ ហើយគ្មានការនឿយហត់កើតមាន ។ នីហ្វៃបានដឹងថាទិសដៅមួយណាដែលលោកបែរទៅរកព្រះ » (*If Thou Endure It Well* [ឆ្នាំ ១៩៩៦] ទំព័រ ១១៦) ។

សូមសួរថា ៖

- យោងតាមអែលឌើរ ម៉ាក់ស្វែល តើយើងអាចធ្វើអ្វីដើម្បីបម្រើដោយឧស្សាហ៍ព្យាយាម ហើយឥតនឿយហត់ ?
- តើឃ្លាណានៅក្នុង ហេលេមិន ១០:៤ បង្ហាញថានីហ្វៃ « បានបែរទៅរកព្រះ » ឬនិយាយម៉្យាងទៀតថា បានផ្តោតលើការធ្វើតាមព្រះរាជបំណងរបស់ព្រះ ?
- តើឃ្លាណានៅក្នុង ហេលេមិន ១៣:៣–៥ បង្ហាញថាសាំយូអែលបានដាក់ចន្ទះរបស់ព្រះលើបំណងរបស់លោកផ្ទាល់ ?
- តើសេចក្តីពិតពិតអ្វីខ្លះដែលយើងអាចរៀនពីបទពិសោធន៍របស់នីហ្វៃ និងសាំយូអែល ? (ចម្លើយមួយអាចប្រាប់ពីសេចក្តីពិតមួយដែលសិស្សបានរៀននៅក្នុងការសិក្សាផ្ទាល់ខ្លួននាសប្តាហ៍នេះ ៖ **ព្រះអម្ចាស់បានប្រទានដល់យើងនូវពេជ្ឈ និងការទទួលខុសត្រូវនៅពេលយើងដាក់ព្រះរាជបំណងរបស់ទ្រង់ពីមុនបំណងរបស់យើង) ។**

សូមអានរឿងខាងក្រោមដែលបាននិទានដោយអែលឌើរ ដាល្លិន អេក អូក នៃក្រុមនៃពួកសាវកដប់ពីរនាក់អំពីក្មេងស្រីអាយុ ១២ ឆ្នាំ ដែលបានទទួលយកឆន្ទៈរបស់ព្រះមុនបំណងរបស់នាងផ្ទាល់ ។

« យើងមិនអាចមានសេចក្តីជំនឿជឿតទៅលើព្រះអម្ចាស់ដោយគ្មានការទុកចិត្តដ៏ពេញលេញទៅលើឆន្ទៈរបស់ព្រះអម្ចាស់ និងទៅលើពេលវេលារបស់ព្រះអម្ចាស់បានឡើយ ។ នៅពេលយើងមានសេចក្តីជំនឿបែបនោះ និងការទុកចិត្តទៅលើព្រះអម្ចាស់ យើងមានការការពារដ៏ពិតនៅក្នុងជីវិតរបស់យើង ។ . . .

« ខ្ញុំអានអំពីយុវនារីម្នាក់ដែលបានអនុវត្តសេចក្តីជំនឿ និងការទុកចិត្តបែបនោះ ។ ជាច្រើនខែមកហើយដែលម្តាយរបស់នាងបានឈឺធ្ងន់ ។ ទីបំផុត ឪពុកដ៏ស្មោះត្រង់បានហៅកូនៗឲ្យមកក្បែរគ្រែម្តាយ ហើយប្រាប់ពួកគេឲ្យនិយាយលាទៅម្តាយរបស់គេដោយសារគាត់ជិតស្លាប់ហើយ ។ កូនស្រីអាយុដប់ពីរឆ្នាំបានប្រកែក ៖

« ‹ ប៉ា! ខ្ញុំមិនចង់ឲ្យម៉ាក់ស្លាប់ទេ ។ ខ្ញុំបាននៅជាមួយនឹងគាត់នៅក្នុងមន្ទីរពេទ្យ . . . រយៈពេលប្រាំមួយខែ ; ម្តងហើយម្តងទៀត . . . ប៉ាបានបម្រើដល់ម៉ាក់ ហើយម៉ាក់បានជាពីដំណឹងរបស់គាត់ ហើយបានគេងយ៉ាងស្ងប់ ។ ខ្ញុំចង់ឲ្យប៉ាដាក់ដៃលើម៉ាក់ ហើយព្យាបាលគាត់ › ។

« លោកឪពុកដែលជាអែលឌើរ ហ៊ីប៊ើរ ចេ ក្រាន្ត បានប្រាប់កូនៗថា គាត់បានមានអារម្មណ៍នៅក្នុងចិត្តគាត់ថា ពេលវេលារបស់ម្តាយពួកគេបានមកដល់ហើយ ។ កូនៗបានចាកចេញទៅ ហើយគាត់បានលុតជង្គង់ក្បែរគ្រែរបស់ភរិយាគាត់ ។ ក្រោយមក គាត់បានរំឭកការអធិស្ឋានរបស់គាត់ថា ៖ ‹ ខ្ញុំបានប្រាប់ព្រះអម្ចាស់ថា ខ្ញុំបានទទួលស្គាល់ព្រះហស្តរបស់ទ្រង់នៅក្នុងជីវិត [និង] នៅក្នុងសេចក្តីស្លាប់ ។ . . . ប៉ុន្តែខ្ញុំបានប្រាប់ព្រះអម្ចាស់ថា ខ្ញុំបានខ្វះកម្លាំងដើម្បីឲ្យភរិយារបស់ខ្ញុំស្លាប់ ហើយឲ្យវាប៉ះពាល់ដល់សេចក្តីជំនឿរបស់កូនតូចៗរបស់ខ្ញុំ › ។ គាត់បានអង្វរដល់ព្រះអម្ចាស់សុំឲ្យកូនស្រីរបស់គាត់មាន ‹ ចំណេះដឹងមួយថា វាបាននៅក្នុងគំនិតរបស់គាត់ ហើយនិងឆន្ទៈរបស់គាត់ដែលម្តាយរបស់នាងនឹងត្រូវស្លាប់ › ។

« ក្នុងរយៈពេលប៉ុន្មានមួយម៉ោង ម្តាយក៏បានស្លាប់ ។ នៅពេលអែលឌើរ ក្រាន្ត បានហៅកូនៗត្រឡប់មកវិញទៅក្នុងបន្ទប់របស់ម្តាយហើយប្រាប់ពួកគេ កូនប្រុសតូចអាយុប្រាំមួយឆ្នាំ [ឈ្មោះថា ហ៊ីប៊ើរ] បានចាប់ផ្តើមយំដោយឈឺចាប់ ។ បងស្រីអាយុដប់ពីរឆ្នាំបានឱបគេហើយបាននិយាយថា ៖ ‹ កុំយំអី ហ៊ីប៊ើរ ; ដោយសារយើងបានចេញទៅក្រៅបន្ទប់នេះ សំឡេងរបស់ព្រះអម្ចាស់ពីស្ថានសួគ៌បានមានបន្ទូលមកបងថា ការស្លាប់របស់ម៉ាក់នឹងធ្វើឲ្យឆន្ទៈរបស់ព្រះអម្ចាស់ត្រូវបានបំពេញ › (Bryant S. Hinckley, *Heber J. Grant: Highlights in the Life of a Great Leader,* Salt Lake City: Deseret Book Co. ឆ្នាំ ១៩៥១ ទំព័រ ២៤៣–៤៤) ។

« នៅពេលយើងមានសេចក្តីជំនឿបែបនេះ និងការទុកចិត្តដែលបានបង្ហាញដោយយុវនារីនោះ យើងនឹងមានកម្លាំងដើម្បីគាំទ្រខ្លួនយើងនៅក្នុងគ្រប់ស្ថានភាពដ៏សំខាន់ទាំងឡាយនៅក្នុងជីវិតរបស់យើង » (« Faith in the Lord Jesus Christ » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៩៤ ទំព័រ ១០០) ។

សូមសួរថា ៖

- តើមានអ្វីជួយដល់ប្រធាន ហ៊ីប៊ើរ ចេ ក្រាន្ត និងគ្រួសាររបស់លោកដើម្បីដាក់ចន្ទះរបស់ព្រះអម្ចាស់មុនបំណងរបស់ពួកគេផ្ទាល់ ?
- តើអ្នកធ្លាប់បានមានបទពិសោធន៍មួយដែលអ្នកត្រូវដាក់ការទុកចិត្តរបស់អ្នកលើព្រះ ហើយដាក់ចន្ទះរបស់ទ្រង់មុនបំណងរបស់អ្នកទេ ? (សូមគិតពីការឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍របស់គេដល់សិស្សក្នុងថ្នាក់ ។ សូមរំឭកពួកគេថា ពួកគេមិនគួរចែកចាយអ្វីដែលផ្ទាល់ខ្លួន ឬឯកជនពេកនោះទេ) ។

សូមអះអាងដល់សិស្សថា នៅពេលយើងដាក់ការទុកចិត្តយើងទៅលើព្រះ ហើយដាក់ព្រះរាជបំណងទ្រង់មុនបំណងរបស់យើងផ្ទាល់ ទ្រង់នឹងគាំទ្រយើងក្នុងគ្រាលំបាកនានា ។

សូមពន្យល់ថា ផ្នែកដ៏សំខាន់មួយនៃការបម្រើរបស់នីហ្វៃគឺជួយប្រជាជនឲ្យចងចាំដល់ព្រះ ហើយប្រែចិត្តពីអំពើបាបរបស់គេ ។ ទោះជាយ៉ាងណាក្តី ពួកគេបានបន្តមានចិត្តរឹងរូស ហើយមិនចង់ឲ្យគេកែតម្រូវ ។

សូមចែកសិស្សជាពីរក្រុម ។ សូមឲ្យក្រុមទីមួយអាន ហេលេមិន ១០:១៥–១៨; ១១:៣–១០ ហើយក្រុមទីពីរអាន ហេលេមិន ១១:៣០–៣៧; ១២:១–៣ ។ (អ្នកអាចសរសេរសេចក្តីយោងទាំងនេះនៅលើក្តារខៀន ។) សូមឲ្យក្រុមនីមួយៗរៀបចំពិភាក្សាពីមូលហេតុដែលព្រះអម្ចាស់បានផ្ទាញ់ផ្ទាលប្រជាជនរបស់ទ្រង់ ។ សិស្សអាចលើកឡើងពីមូលហេតុពីរបីខុសគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេបង្ហាញថា **ព្រះអម្ចាស់ផ្ទាញ់ផ្ទាលប្រជាជនរបស់ទ្រង់ដើម្បីឲ្យពួកគេចងចាំដល់ទ្រង់ ។**

- តើការផ្ទាញ់ផ្ទាលបែបណាដែលព្រះអម្ចាស់បានប្រើដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់ប្រជាជន ?
- យោងតាម ហេលេមិន ១២:៣ ប្រជាជនជាច្រើនមិនចាំព្រះអម្ចាស់ឡើយ រហូតដល់ទ្រង់ផ្ទាញ់ផ្ទាលពួកគេ ។ តើអ្នកគិតថា ហេតុអ្វីបានជាដូច្នេះ ?

សូមឲ្យសិស្សម្នាក់អាន ហេលេមិន ១៥:៣ ឮៗ ។

- តើការផ្ទាញ់ផ្ទាលរបស់ព្រះអម្ចាស់ជាការបង្ហាញសេចក្តីស្រឡាញ់មួយដោយរបៀបណា ?

សូមឲ្យសិស្សចែកចាយចម្លើយរបស់គេចំពោះកិច្ចការទី ៥ នៅថ្ងៃទី ២ នៃសប្តាហ៍នេះ ។ អ្នកអាចនិយាយម្តងទៀតថា **តាមរយៈសេចក្តីបន្ទាបខ្លួន និងការប្រែចិត្ត យើងអាចចៀសវាងភាពឆ្មើងឆ្មៃ និងសេចក្តីប៉ងប្លិចបំផ្លាញ** ហើយថា **ប្រសិនបើយើងមិនប្រយ័ត្នទេ ការរីកចម្រើនរបស់យើងអាចនាំយើងឲ្យភ្លេចព្រះអម្ចាស់បាន** ។

មេរៀនបន្ទាប់ (នីហ្វៃទី ៣ ១–១១)

នៅក្នុងកិច្ចការសិស្សបន្ទាប់ទៀត ពួកគេនឹងអានអំពីជាតិសាសន៍នីហ្វៃទាំងមូលរួមគ្នាប្រយុទ្ធនឹងពួកចោរកាឌីអានតុននៅក្នុងចម្បាំងដ៏ខ្លាំងមួយ ។ តើសាសន៍នីហ្វៃអាចយកឈ្នះលើពួកចោរទុច្ចរិតបានដោយរបៀបណា ? សិស្សក៏នឹងអានអំពីសេចក្តីបំផ្លិចបំផ្លាញដ៏ធំដែលបានកើតឡើងនៅក្នុងដែនដីអាមេរិក នៅក្នុងពេលដែលព្រះយេស៊ូវគ្រីស្តសុគតនៅក្នុងទីក្រុងយេរូសាឡិម ។ នៅក្នុងភាពងងឹត ប្រជាជនបានឮសំឡេងរបស់ព្រះយេស៊ូវគ្រីស្ត ។ បន្ទាប់មក ព្រះអង្គសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញបានមកបម្រើដល់ពួកគេ ។ សូមឲ្យសិស្សគិតថាតើពួកគេមានអារម្មណ៍បែបណា ប្រសិនបើពួកគេបាននៅទីនោះ ។

សេចក្តីផ្តើមអំពី នីហ្វៃទីបី

ព្រះគម្ពីរនីហ្វៃ

ហេតុអ្វីបានជាសិក្សាគម្ពីរនេះ ?

ក្នុងការសិក្សាពីនីហ្វៃទី ៣ សិស្សនឹងរៀនអំពីព្រះបន្ទូល និងសកម្មភាពរបស់ព្រះអង្គសង្គ្រោះអំឡុងពេលបម្រើមិថ្ងៃក្នុងចំណោមសាសន៍នីហ្វៃ ។ ប្រធាន អែសរ៉ា ថាហ្វ ប៊ែនសិន បានបង្រៀនថា ៖ « នីហ្វៃទី ៣ រួមមានវគ្គមួយចំនួនដែលធ្វើឲ្យចិត្តរំជើបរំជួល និងមានឥទ្ធិពលលើសព្រះគម្ពីរទាំងអស់ ។ វាថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ព្យាការីរបស់ទ្រង់ និងគោលលទ្ធិនៃសេចក្តីសង្គ្រោះ » (« The Savior's Visit to America » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៨៧, ទំព័រ ៦) ។ នៅពេលសិស្សឃើញពីរបៀបដែលព្រះយេស៊ូវគ្រីស្ទបានបង្ហាញសេចក្តីមេត្តាដល់ប្រជាជន « ម្តងមួយៗ » ពួកគេអាចកោតសរសើរកាន់តែខ្លាំងដល់ការព្រួយបារម្ភរបស់ទ្រង់ដល់ពួកគេម្នាក់ៗ (សូមមើល នីហ្វៃទី ៣ ១១:១៥; ១៧:២១) ។ ពួកគេអាចរៀនពីមេរៀនដ៏សំខាន់ៗពីគំរូដ៏សុចរិតនៃអ្នកទាំងឡាយណា ដែលបានរៀបចំខ្លួនដើម្បីទៅជួបនឹងព្រះអង្គសង្គ្រោះ ។ ពួកគេក៏បានរៀនពីគំរូទុច្ចរិតនៃអ្នកទាំងឡាយណាដែលមិនបានរៀបចំទៅជួបនឹងព្រះអង្គសង្គ្រោះ ។

តើអ្នកណាជាអ្នកសរសេរគម្ពីរនេះ ?

លោកមរមនបានសង្ខេបកំណត់ត្រាពីផ្នាំងចំណារជើងរបស់នីហ្វៃដើម្បីបង្កើតជាគម្ពីរនីហ្វៃទី ៣ ។ គម្ពីរនេះដាក់ឈ្មោះតាមនីហ្វៃ (ជាកូនប្រុសរបស់នីហ្វៃ) ដែលបានបម្រើពីមុនអំឡុងពេល និងក្រោយពេលដែលព្រះអង្គសង្គ្រោះបានយាងមកជួបនឹងប្រជាជន ។ អំឡុងពេលមានអំពើទុច្ចរិតដ៏ខ្លាំងដែលកើតឡើងមុនពេលព្រះយេស៊ូវគ្រីស្ទបានយាងមក នីហ្វៃបានធ្វើការងារ « ដោយអានុភាព និងដោយសិទ្ធិអំណាចដ៏ធំ » (នីហ្វៃទី ៣ ៧:១៧) ។ ការខិតខំរបស់លោកគឺជាការចាប់ផ្តើមមួយនៃការបម្រើរបស់ព្រះយេស៊ូវគ្រីស្ទ ដែលព្រះបន្ទូល និងទង្វើរបស់ទ្រង់នាំឲ្យមានការយកចិត្តទុកដាក់នៅក្នុងនីហ្វៃទី ៣ ។ ខណៈពេលដែលកំពុងសង្ខេបផ្នាំងចំណារបស់នីហ្វៃ ព្យាការីមរមនក៏បានបញ្ចូលបទអត្ថាធិប្បាយ និងទីបន្ទាល់របស់គាត់ដែរ (សូមមើល នីហ្វៃទី ៣ ៥:៨–២៦; ២៦:៦–១២; ២៩–៣០) ។

តើគម្ពីរនេះត្រូវបានសរសេរសម្រាប់អ្នកណា និងហេតុអ្វី ?

មរមនមានបំណងឲ្យអត្ថបទរបស់លោកនៅក្នុងនីហ្វៃទី ៣ បានទៅដល់មនុស្សពីរក្រុម ។ ក្រុមទីមួយ លោកបានពន្យល់ថា លោកបានសរសេរវាសម្រាប់កូនចៅលីហៃ (សូមមើល នីហ្វៃទី ៣ ២៦:៨) ។ ក្រុមទីពីរ មរមនបានបញ្ជាក់ពីសាសន៍ដទៃនៅក្នុងជំនាន់ចុងក្រោយ និងបានកត់ត្រាពីការព្រមានរបស់ព្រះអម្ចាស់ឲ្យ ពួកគេមករកទ្រង់ ហើយក្លាយជាផ្នែកមួយនៃប្រជាជនក្នុងសេចក្តីសញ្ញារបស់ទ្រង់ (សូមមើល នីហ្វៃទី ៣ ៣០) ។ គម្ពីរនីហ្វៃទី ៣ បញ្ជាក់ពីការអញ្ជើញនេះដោយមានសាក្សីដ៏មានអានុភាពពីព្រះយេស៊ូវគ្រីស្ទ និងការបញ្ជាក់ទៅលើសារៈសំខាន់នៃសេចក្តីសញ្ញា ។

តើនៅពេលណា និងនៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

កំណត់ត្រាដើមដែលប្រើជាប្រភពសម្រាប់គម្ពីរនីហ្វៃទី ៣ ប្រហែលត្រូវបានសរសេរនៅរវាងឆ្នាំទី ១ ម.គ.ស. និង នៃ គ.ស. ។ ៣៥. មរមនបានសង្ខេបកំណត់ត្រាទាំងនោះនៅចន្លោះឆ្នាំ ៣៨៥ នៃ គ.ស. និង ឆ្នាំ ៣៨៥ នៃ គ.ស. ។ មរមនមិនបានកត់ត្រាពីកន្លែងដែលលោកស្ថិតនៅ នៅពេលលោកបានចងក្រងគម្ពីរនេះឡើយ ។

តើលក្ខណៈពិសេសមួយចំនួននៃគម្ពីរនេះជាអ្វីខ្លះ?

នីហ្វៃទី ៣ ចងក្រងការបំពេញនៃការព្យាករណ៍ដែលទាក់ទងនឹងការប្រសូត ការសុគត និងការរស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ (សូមមើល នីហ្វៃទី ៣ ១; ៨; ១១) ។ កំណត់ត្រានេះចងក្រងពីការយោងមករបស់ព្រះអង្គសង្គ្រោះទៅដល់សាសន៍នីហ្វៃ តំណាងឲ្យអ្វីដែលអែលឌើរ ដៃហ្វ្រី អ័រ ហូវិន បានហៅថាជា « ចំណុចបង្គោល ដ៏សំខាន់ នៅក្នុងប្រវត្តិសាស្ត្រទាំងមូលនៃព្រះគម្ពីរមរមន » (*Christ and the New Covenant: The Messianic Message of the Book of Mormon* [ឆ្នាំ ១៩៩៧], ទំព័រ ២៥០) ។ ជំពូកចំនួនម្ភៃក្នុងចំណោមសាមសិបជំពូកនៅក្នុងនីហ្វៃទីបីរួមមានការបង្រៀនដែលព្រះអង្គសង្គ្រោះបានបង្រៀនដល់ប្រជាជនផ្ទាល់ (សូមមើល នីហ្វៃទី ៣ ៩–២៨) ។

គម្រោង

នីហ្វៃទី ៣ ១–៥ នីហ្វៃទទួលបានកំណត់ត្រាពីឪពុករបស់លោក ។ ទីសម្គាល់នៃការប្រសូតរបស់ព្រះគ្រីស្ទត្រូវបានផ្តល់ឲ្យ គម្រោងមួយដើម្បីបំផ្លាញដល់អ្នកជឿគឺត្រូវបានខកខាន ហើយមនុស្សជាច្រើនបានប្រែចិត្តជឿ ។ សាសន៍នីហ្វៃ និងសាសន៍លេមិនបានរួបរួមគ្នាប្រឆាំងនឹងពួកចោរកាឌីអានតុន ។ ពួកគេបានប្រែចិត្តពីអំពើបាបរបស់ខ្លួន ហើយនៅទីបញ្ចប់បានបង្រាបពួកចោរនៅក្រោមការដឹកនាំរបស់ឡាកូនីអូស និងគីឌគីឌជូណែ ។ មរមនអធិប្បាយពីតួនាទីរបស់លោកក្នុងនាមជាសាវកម្នាក់របស់ព្រះគ្រីស្ទ និងជាអ្នករក្សាកំណត់ត្រាម្នាក់ ។

នីហ្វៃទី ៣ ៦–៧ ការីកចម្រើនរបស់សាសន៍នីហ្វៃនាំទៅរកភាពឆ្មើងឆ្មៃ អំពើទុច្ចរិត និងបក្សពួកទ្វន់សម្ងាត់ ។ រដ្ឋាភិបាលត្រូវបានផ្តួលរំលំ ហើយប្រជាជនបែងចែកទៅជាកុលសម្ព័ន្ធ ។ នីហ្វៃធ្វើការបម្រើព្រះដោយអានុភាពដ៏ខ្លាំង ។

នីហ្វៃទី ៣ ៨–១០ កំហឹង សេចក្តីបំផ្លិចបំផ្លាញ និងភាពងងឹតជាសញ្ញាសម្គាល់នៃការឆ្កាង និងការសុគតរបស់ព្រះអង្គសង្គ្រោះ ។ ប្រជាជនទួញយំនឹងការស្លាប់របស់អស់អ្នកដែលត្រូវបានគេសម្លាប់នៅក្នុងសេចក្តីបំផ្លិចបំផ្លាញ ។ សំឡេងរបស់ព្រះយេស៊ូវគ្រីស្ទអំពាវនាវឲ្យអ្នកនៅសេសទាំងឡាយ ប្រែចិត្ត និងមករកទ្រង់ ។

នីហ្វៃទី ៣ ១១–១៨ ព្រះយេស៊ូវគ្រីស្ទលេចចេញមកដល់ហ្វូងមនុស្សនៅឯព្រះវិហារបរិសុទ្ធ ហើយអញ្ជើញឲ្យមនុស្សម្នាក់ៗស្ទាបស្នាមដៃកគោលនៅលើព្រះហស្ត និងព្រះបាទរបស់ទ្រង់ ។ ទ្រង់តែងតាំងសាវកដប់ពីរនាក់ និងផ្តល់ដល់ពួកលោកនូវសិទ្ធិអំណាចដើម្បីធ្វើពិធីបរិសុទ្ធ និងដឹកនាំសាសនាចក្រ ។ ព្រះអង្គសង្គ្រោះបង្រៀនពីគោលលទ្ធិរបស់ទ្រង់ ចេញប្បាប់នៃសេចក្តីសុចរិត និងពន្យល់ថា ទ្រង់បានបំពេញប្បាប់ម៉ូសេរួចហើយ ។ ទ្រង់ព្យាបាលជំងឺរបស់ប្រជាជន អធិស្ឋានសម្រាប់ពួកគេ ហើយប្រទានពរដល់កូនចៅរបស់ពួកគេ ។ ក្រោយពីការបម្រើសាក្រាម៉ង់ និងផ្តល់ការបង្រៀនបន្ថែម នោះទ្រង់យាងចេញទៅ ។

នីហ្វៃទី ៣ ១៩–២៦ ពួកសាវកដប់ពីរនាក់បម្រើដល់ប្រជាជន ហើយព្រះវិញ្ញាណបរិសុទ្ធត្រូវបានចាក់ស្រោចមកលើពួកលោក ។ ព្រះយេស៊ូវគ្រីស្ទលេចមកជាលើកទីពីរ ហើយអធិស្ឋានសម្រាប់អ្នកទាំងឡាយណាដែលនឹងជឿលើទ្រង់ ។ ទ្រង់បម្រើសាក្រាម៉ង់ និងបង្រៀនពីរបៀបដែលព្រះវរបិតានឹងបំពេញសេចក្តីសញ្ញារបស់ទ្រង់ជាមួយនឹងសាសន៍អ៊ីស្រាអែល ។ ព្រះអង្គសង្គ្រោះបញ្ជាប្រជាជនឲ្យសិក្សាពាក្យសម្តីរបស់អេសាយ និងព្យាការីទាំងអស់ ហើយទ្រង់ណែនាំនីហ្វៃឲ្យកត់ត្រាពីការបំពេញនៃការព្យាករណ៍ដែលបានប្រកាសដោយសាំយូអែលជាសាសន៍លេមិននោះ ។ ទ្រង់បង្រៀនថា ព្រះវរបិតាប្រទានដល់ម៉ាឡាគី និងពន្យល់ប្រាប់ « ការណ៍ទាំងអស់ . . . តាំងពីដំបូងរហូតដល់ពេលដែលទ្រង់នឹងយាងមកក្នុងសិរីល្អរបស់ទ្រង់ » (នីហ្វៃទី ៣ ២៦:៣) ។ ហើយបន្ទាប់មក ទ្រង់ក៏យាងចេញទៅ ។

នីហ្វៃទី ៣ ២៧–២៨ ព្រះយេស៊ូវគ្រីស្ទយាងមក ហើយបង្រៀនដល់ពួកសាវកដប់ពីរនាក់ឲ្យហៅសាសនាចក្រតាមព្រះនាមរបស់ទ្រង់ ។ ទ្រង់បង្រៀនជំណឹងល្អ និងបញ្ជាពួកសាវករបស់ទ្រង់ឲ្យក្លាយដូចជាទ្រង់ ។ ព្រះយេស៊ូវគ្រីស្ទផ្តល់អោយពួកសាវកទាំងដប់ពីរនាក់ស្របតាមបំណងរបស់ពួកលោក ។

នីហ្វៃទី ៣ ២៩–៣០ មរមនពន្យល់ថា ការលេចមកនៃព្រះគម្ពីរមរមនគឺជាទីសម្គាល់មួយដែលព្រះបានហៅឲ្យបង្រួបបង្រួមសាសន៍អ៊ីស្រាអែលនៅក្នុងថ្ងៃចុងក្រោយ ។ ព្រះអម្ចាស់ទុទ្ទានពួកសាសន៍ដទៃឲ្យប្រែចិត្ត ហើយក្លាយជាផ្នែកនៃវាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់ ។

នីហ្វៃ ទី៣ ជំពូកទី ១

សេចក្តីផ្តើម

នៅពេលដែលពេលវេលាខិតជិតមកដល់ការបំពេញតាមការព្យាករណ៍របស់សាំយូអែលជាសាសន៍លេមិនអំពីការប្រសូតរបស់ព្រះអង្គសង្គ្រោះ នោះអ្នកជឿទាំងឡាយនឹងចាំមើលទីសម្គាល់ដែលសាំយូអែលបាននិយាយថានឹងកើតឡើង ។ អ្នកដែលមិនជឿបានគំរាមសម្លាប់អ្នកជឿ ប្រសិនបើការព្យាករណ៍មិនបានបំពេញនៅថ្ងៃដែលបានកំណត់នោះ ។ នីហ្វៃជាកូនប្រុសរបស់នីហ្វៃ និងជាចៅប្រុសរបស់ហេលេមិន បានសុំអង្វរព្រះអម្ចាស់ជំនួសឲ្យពួកអ្នកជឿ ។ ជាការឆ្លើយតបចំពោះការអធិស្ឋានរបស់នីហ្វៃ សំឡេងរបស់ព្រះអម្ចាស់បានបន្លឺដល់លោក ដោយប្រកាសថា ទីសម្គាល់នឹងត្រូវបានផ្តល់នៅយប់នោះ ។ នៅពេលព្រះអាទិត្យលិច នឹងគ្មានភាពងងឹតឡើយ ហើយផ្កាយថ្មីមួយនឹងលេចឡើង ។ ថ្វីបើបំណងរបស់សាតាំងដែលចង់បន្តបំផ្លាញសេចក្តីជំនឿរបស់ប្រជាជនក្តី ក៏ប្រជាជនភាគច្រើនបានប្រែចិត្តជឿដល់ព្រះអម្ចាស់ដែរ ។ ប៉ុន្តែពីឆ្នាំក្រោយមក ពួកចោរកាឌីអានតុនបានចាប់ផ្តើមដឹកនាំសាសន៍នីហ្វៃ និងសាសន៍លេមិនជាច្រើនទៅក្នុងសេចក្តីទុច្ចរិត ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៣ ១:១–២៦

ការព្យាករណ៍ដែលទាក់ទងនឹងការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានបំពេញ ហើយសាសន៍នីហ្វៃជាច្រើនត្រូវបានប្រែចិត្ត

សូមអញ្ជើញសិស្សរៃអង្គិតពីប្រជាជនដែលបានលះបង់ជីវិតរបស់គេដើម្បីដំណឹងល្អ ។ (ឧទាហរណ៍ខ្លះមាន ព្រះយេស៊ូវគ្រីស្ទ អ័ប៊ីណាដៃ សាសន៍អាន់តៃ-នីហ្វៃ-លីហៃខ្លះ និងយ៉ូសែប និងហៃរ៉ុម ស្មីធ ។) សូមឲ្យសិស្សពន្យល់ពីមូលហេតុដែលពួកគេគិតថាប្រជាជនមានឆន្ទៈដើម្បីធ្វើការលះបង់បែបនោះ ។ សូមឲ្យសិស្សមានពេលសញ្ជឹងគិតពីរបៀបដែលពួកគេនឹងឆ្លើយតប ប្រសិនបើពួកគេស្ថិតនៅក្នុងស្ថានភាពមួយដែលតម្រូវឲ្យពួកគេលះបង់ជីវិតរបស់ពួកគេដើម្បីដំណឹងល្អ ។ សូមពន្យល់ថា ប្រាំឆ្នាំក្រោយពីសាំយូអែលជាសាសន៍លេមិនបានបង្រៀននៅក្នុងដែនដីសារ៉ាហិមឡា ក្រុមសាសន៍នីហ្វៃដ៏ស្មោះត្រង់មួយក្រុមបានប្រឈមមុខនឹងការណ៍នេះ: ។

សូមសង្កេប នីហ្វៃទី ៣ ១:១–៣ ដោយការប្រាប់សិស្សថា កូនប្រុសរបស់ហេលេមិនគឺ នីហ្វៃ បានប្រគល់កំណត់ត្រាដ៏ពិសិដ្ឋដល់កូនប្រុសរបស់លោកដែលជា នីហ្វៃ ហើយបន្ទាប់មកលោកបានចាកចេញពីដែនដីទៅ ។ គ្មាននរណាម្នាក់បានដឹងថាលោកទៅណានោះទេ ។

សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗពី នីហ្វៃទី ៣ ១:៤–៩ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលឧបសគ្គដែលពួកសាសន៍នីហ្វៃស្មោះត្រង់បានជួប ។

- តើឧបសគ្គអ្វីដែលពួកអ្នកជឿបានជួបប្រទះ: ?
- ហេតុអ្វីបានជាមនុស្សខ្លះអាចតស៊ូដើម្បីនៅតែស្មោះត្រង់នៅក្នុងស្ថានភាពនេះ: ?
- តើអ្នកស្គាល់ នរណាដែលអ្នកជឿថា នឹងនៅបន្តស្មោះត្រង់នៅក្នុងស្ថានភាពបែបនេះ: ? តើអ្នកគិតថា ហេតុអ្វីបានជាប្រជាជនទាំងនោះនឹងនៅបន្តស្មោះត្រង់ ?

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១:១០–១២ ដោយស្ងាត់ៗ សូមរកមើលអ្វីដែលនីហ្វៃបានធ្វើនៅក្នុងពេលដ៏ពិបាកនេះ: ។

- តើអ្វីដែលធ្វើឲ្យអ្នកចាប់អារម្មណ៍អំពីចម្លើយរបស់នីហ្វៃទៅនឹងស្ថានភាពនេះ: ? ហេតុអ្វី?

សូមឲ្យសិស្សម្នាក់អាននីហ្វៃទី ៣ ១:១៣–១៤ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់យកចិត្តទុកដាក់ជាពិសេសលើចម្លើយនៃព្រះអម្ចាស់ចំពោះការអធិស្ឋានរបស់នីហ្វៃ ។

- តើព្រះអម្ចាស់បានមានបន្ទូលយ៉ាងណាថាទ្រង់នឹង « បង្ហាញដល់មនុស្សលោក » ? (ចម្លើយរបស់សិស្សគួរបញ្ជាក់ថា **ព្រះអម្ចាស់នឹងបំពេញព្រះបន្ទូលដែលទ្រង់បានបណ្តាលឲ្យព្យាការីរបស់ទ្រង់មានប្រសាសន៍**) ។
- នៅពេលព្រះអម្ចាស់បានមានបន្ទូលអំពីការយាងមកក្នុងពិភពលោកនេះ: « ដើម្បីធ្វើតាមឆន្ទៈ: ទាំងព្រះវរបិតា និងព្រះរាជបុត្រា » នោះទ្រង់សំដៅលើដង្វាយធួនរបស់ទ្រង់ ។ តើសារលិខិតនេះជួយយើងឲ្យ « មានសង្ឃឹមឡើង » ដោយរបៀបណា ?

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១:៤, ១៤–១៥, ១៩–២១ ស្ងាត់ៗ ដោយរកមើលឃ្លាដែលបញ្ជាក់ថា ព្រះអម្ចាស់បំពេញតាមពាក្យសម្តីរបស់ព្យាការីទាំងឡាយ ។

- តើអ្នកគិតថា អ្នកនឹងមានអារម្មណ៍យ៉ាងណា ប្រសិនបើអ្នកស្ថិតនៅក្នុងចំណោមអ្នកជឿ នៅពេលដែលទីសម្គាល់បានកើតឡើងនោះ: ?
- តើការដឹងថា ព្រះអម្ចាស់នឹងបំពេញតាមពាក្យសម្តីរបស់ព្យាការីអាចជួយអ្នក នៅពេលនរណាម្នាក់សើចចំអកនឹងបទដ្ឋានរបស់អ្នក ឬបៀតបៀនអ្នកចំពោះសេចក្តីជំនឿរបស់អ្នកដោយរបៀបណា ?

សូមឲ្យសិស្សពីរ ឬបីនាក់ប្តូរវេនគ្នាអានឮៗពី នីហ្វៃទី ៣ ១:១៦–១៨ ។ សូមឲ្យសិស្សមើលតាម ដោយរកមើលពីរបៀបដែលពួកទុច្ចរិតឆ្លើយតប នៅពេលពួកគេឃើញទីសម្គាល់ដែលត្រូវបានព្យាករណ៍នោះ: ។

- តើពួកទុច្ចរិតបានដឹងពីអ្វីខ្លះ ក្រោយពីទីសម្គាល់ត្រូវបានប្រទាននោះ ?
- ហេតុអ្វីបានជាអំពើបាប និងការឥតជំនឿនាំទៅរកសេចក្តីភ័យខ្លាច ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១:២២–២៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលសាតាំងបានធ្វើ ដើម្បីបញ្ឆោះបញ្ឆូលប្រជាជនកុំឲ្យជឿលើទីសម្គាល់លើការប្រសូតរបស់ព្រះអម្ចាស់ ។

- តើសាតាំងបានធ្វើអ្វីខ្លះ ? (វាបានកុហកប្រជាជន) ។ តើការកុហកបែបណាខ្លះ ដែលសាតាំងបាននិយាយនាសព្វថ្ងៃនេះ ?
- តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនពីប្រតិកម្មរបស់ប្រជាជនចំពោះការកុហករបស់សាតាំង ? (សូមជួយសិស្សឲ្យរកមើលគោលការណ៍ខាងក្រោម ៖ **នៅពេលយើងជួបនឹងការភ្ញាក់កុហករបស់សាតាំង យើងអាចជ្រើសរើសដើម្បីជឿតាមព្រះយេស៊ូវគ្រីស្ទ ហើយប្រែចិត្តជឿ ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សឲ្យបានទទួលអារម្មណ៍ពីសេចក្តីពិត និងពីសារៈសំខាន់នៃគោលការណ៍នេះ សូមចែកចាយនូវសេចក្តីថ្លែងការណ៍ខាងក្រោមរបស់ប៊ីស្សព រីឆាឌ ស៊ី អែជ្ជលី នៃគណៈប៊ីស្សពជាអធិបតី ។ សូមគិតពីការចែកចាយនូវសំណៅចម្លងនៃសេចក្តីថ្លែងការណ៍នេះដល់សិស្ស ដែលអាចសំគ្នាទៅនឹងព្រះគម្ពីររបស់ពួកគេ ។

« ដោយសារតែវិបត្តិ និងឧបសគ្គដែលយើងជួបប្រទះនៅក្នុងពិភពលោកនាសព្វថ្ងៃនេះ ខ្ញុំសូមណែនាំនូវការជ្រើសរើសមួយ—ជាជម្រើសនៃសេចក្តីសុខសាន្ត និងការការពារមួយ ហើយជាជម្រើសដែលសមរម្យសម្រាប់មនុស្សគ្រប់គ្នា ។ ជម្រើសនោះគឺជាសេចក្តីជំនឿ ។ . . . សូមជ្រើសយកសេចក្តីជំនឿឲ្យលើសពីការសង្ស័យ ជ្រើសយកសេចក្តីជំនឿឲ្យលើសភាពភ័យខ្លាច ជ្រើសយកសេចក្តីជំនឿឲ្យលើសពីអ្វីដែលមិនដឹង ហើយមើលមិនឃើញ និងជ្រើសយកសេចក្តីជំនឿឲ្យលើសពីភាពទុទិដ្ឋិនិយម ។ . . .

« នៅពេលភាពសមហេតុផល មូលហេតុ ឬបញ្ហាផ្ទាល់ខ្លួន ខ្វែងជំទាស់នឹងការបង្រៀន និងគោលទ្ធិដ៏ពិសិដ្ឋ ឬសារលិខិតខុសដែលវាយប្រហារដល់សេចក្តីជំនឿរបស់អ្នក . . . *សូមជ្រើសរើសកុំ*បោះចោលគ្រាប់ពូជនោះចេញពីចិត្តរបស់អ្នកដោយការឥតជំនឿឡើយ [សូមមើល អាលម៉ា ៣២:២៨] ។ សូមចងចាំថា យើងនឹងមិនទទួលបានទីបន្ទាល់ឡើយ ទាល់តែសេចក្តីជំនឿរបស់យើងជួបនឹងការសាកល្បងជាមុនសិន (សូមមើល អេធើរ ១២:៦) » (« Faith—the Choice Is Yours » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ៣១, ៣២–៣៣) ។

- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីជ្រើសយកសេចក្តីជំនឿជាជាងការសង្ស័យ ការភ័យខ្លាច និងទុទិដ្ឋិនិយម ? (ចម្លើយអាចរួមមាន យើងអាចជ្រើសរើសការអធិស្ឋាន ហើយស្វែងរកជំនួយពីព្រះអម្ចាស់ សិក្សាព្រះគម្ពីរ កាន់តាមព្រះបញ្ញត្តិ ចូលរួមការប្រជុំក្នុងព្រះវិហារ និងបម្រើដល់អ្នកដទៃ) ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១:២៤–២៥ ដោយស្ងៀមស្ងាត់ ហើយរកមើលឧបសគ្គមួយបន្ថែមទៀតដែលអ្នកជឿខ្លះបានជួបប្រទះ ។

- តើអ្វីទៅដែលមនុស្សមួយចំនួនបានខំប្រឹងប្រែងដើម្បីបញ្ឆោតពីច្បាប់ម៉ូសេ ?
- តើអ្វីដែលធ្វើឲ្យអ្នកចាប់អារម្មណ៍ពីចម្លើយរបស់មនុស្សទាំងនេះ នៅពេលពួកគេបានដឹងថា ពួកគេបានធ្វើខុសនោះ ?

សូមសរសេរសំណួរនៅលើក្តារខៀន ៖ *នៅពេលបច្ចាមិត្ត ព្យាយាមធ្វើឲ្យខ្ញុំមានការសង្ស័យ តើខ្ញុំនឹងបន្តរក្សាសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អដែលបានស្តារឡើងវិញរបស់ទ្រង់បានដោយរបៀបណា ?* សូមឲ្យសិស្សកត់ត្រាសំណួរនេះទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេររបស់ពួកគេ ។ សូមទុកពេលឲ្យពួកគេពីរបីនាទីដើម្បីសរសេរចម្លើយរបស់ពួកគេ ។

នីហ្វៃទី ៣ ១:២៧–៣០

ពួកសាសន៍នីហ្វៃដែលប្រឆាំង និងពួកយុវជនសាសន៍លេមិនខ្លះចូលរួមនឹងពួកចោរកាឌីអានតុន ។

សូមឲ្យសិស្សពីរនាក់ឡើងមកខាងមុខថ្នាក់ ។ សូមឲ្យសិស្សម្នាក់បិទភ្នែក ហើយឈរជើងមួយ ។ សូមពន្យល់ថា សិស្សរូបនេះតំណាងឲ្យនរណាម្នាក់ដែលដឹងអំពីសេចក្តីពិត ប៉ុន្តែមិនអនុវត្តសេចក្តីជំនឿលើព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ហើយមិនខំឧស្សាហ៍ក្នុងការរស់នៅតាមដំណឹងល្អ ។

សូមពន្យល់ថា នៅក្នុងការសម្តែងនេះ សិស្សទីពីរតំណាងឲ្យឥទ្ធិពលដែលអាចដឹកនាំនរណាម្នាក់ឲ្យឃ្លាតចេញពីសេចក្តីពិត ។ សូមឲ្យសិស្សទីពីរទាញដៃសិស្សទីមួយថ្មមៗ រហូតដល់សិស្សទីមួយឈរលែងនឹង ឬ បាត់បង់ជំហរ ។ សូមបង្ហាញថា នៅពេលមនុស្សម្នាក់មិនខិតខំរស់នៅតាមដំណឹងល្អទេ នោះភាគច្រើនគេនឹងត្រូវចាញ់បោកដោយការកុហក និងការល្បួងរបស់សាតាំង ។

- តើសិស្សទីមួយត្រូវធ្វើអ្វីខ្លះដើម្បីឲ្យឈរមានលំនឹង ? (សិស្សនេះគួរបើកភ្នែករបស់គេ និងឈរលើជើងទាំងពីរ) ។

សូមណែនាំឲ្យសិស្សទីមួយឲ្យបើកភ្នែករបស់គេ ហើយឈរលើជើងទាំងពីរឲ្យត្រង់ខ្លួន ។ សូមពន្យល់ថា សិស្សរូបនេះឥឡូវតំណាងឲ្យមនុស្សម្នាក់ដែល « រឹងមាំ ហើយខ្ជាប់ខ្ជួននៅក្នុងសេចក្តីជឿ » (ហេលេមិន ១៥:៨) ។ បន្ទាប់មក សូមឲ្យសិស្សទីពីរទាញដៃសិស្សទីមួយថ្មមៗម្តងទៀត ។ សូមបង្ហាញថា នៅពេលបុគ្គលម្នាក់ខិតខំសិក្សាដំណឹងល្អ ហើយកាន់តាមព្រះបញ្ញត្តិរបស់ព្រះ គាត់នឹងនៅរឹងមាំទោះបីជានៅពេលមានឧបសគ្គយ៉ាងណាក្តី ។

សូមឲ្យសិស្សពីរនាក់ត្រឡប់ទៅកាន់កន្លែងអង្គុយវិញ ។ សូមពន្យល់ថា ពីរបីឆ្នាំក្រោយពីទីសម្គាល់នៃការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ សាតាំងបានបន្តល្បួងមនុស្សឲ្យសង្ស័យនឹងសេចក្តីពិតនៃដំណឹងល្អ ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី នីហ្វៃទី ៣ ១:២៧–២៩ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលឥទ្ធិពលដែលមនុស្សទុច្ចរិតបានមានលើយុវជនខ្លះនៃសាសន៍លេមិន ។

- តើមានអ្វីបានកើតឡើងដល់យុវជនខ្លះនៃសាសន៍លេមិន ? (ពួកគេ « ត្រូវបានដឹកនាំទៅផ្លូវខុសដោយប្រជាជនស្លាំខ្លះ » ហើយពួកគេបានចូលរួមនឹងពួកចោរកាឌីអានតុន) ។
- យោងតាម៣ នីហ្វៃទី ១:២៩ តើហេតុអ្វីបានជាយុវជនសាសន៍លេមិនខ្លះបានជឿលើ « ការភូតកុហក » និង « ពាក្យបញ្ឆោរ » របស់សាសន៍ស្លាំ ? (ប្រសិនបើសិស្សមិនលើកឡើងអំពីប្រសាសន៍របស់មរមនថា យុវជន « ក្លាយទៅជាមានគំនិតផ្ទាល់ខ្លួន » ទេ សូមបង្ហាញវាដល់សិស្ស) ។
- តើអ្នកគិតថាវាមានន័យយ៉ាងណាចំពោះឃ្លា « ក្លាយជាទៅមានគំនិតផ្ទាល់ខ្លួន » ?

នៅពេលសិស្សពិភាក្សាពីសំណួរនេះ សូមអានអ្វីដែលស៊ីស្ទើរ ខាតលីន អេច. ហ៊ិនហ្គ ជាសមាជិកនៃគណៈប្រធានសមាគមសង្គ្រោះទូទៅបានមានប្រសាសន៍អំពីឃ្លានេះ ៖

« វាបញ្ជាក់អត្ថន័យចំពោះខ្ញុំថា ពួកគេមើលឃើញខ្លួនឯងមុនគេ ហើយមិនធ្វើតាមបំណងដែលព្យាការីបានព្រមានពួកគេឲ្យចៀសវាង ។ ពួកគេចុះចាញ់តាមការល្បួង ការទាក់ទាញដ៏ខ្លាំងរបស់សាតាំង » (« Grow Up unto the Lord » *Ensign,* ខែ កុម្ភៈ ឆ្នាំ ២០១០, ទំព័រ ១៨) ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១:៣០ ព្ញ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលឥទ្ធិពលនៃ « ជំនាន់ដែលកំពុងពេញវ័យ » (យុវជន) ទៅលើអ្នកដទៃ ។

- តើឥទ្ធិពលអ្វីខ្លះដែលជំនាន់ដែលកំពុងពេញវ័យបានមានចំពោះសេចក្តីជំនឿនៃអ្នកនៅជុំវិញខ្លួនគេ ?

ដើម្បីជួយសិស្សឲ្យភ្ជាប់ដំណើររឿងនេះទៅនឹងស្ថានភាពនាសម័យទំនើបនេះ សូមសួរសំណួរខាងក្រោម ៖

- តើ« ការភូតកុហក » និង « ពាក្យបញ្ឆោរ » ណាខ្លះដែលអាចទាក់ទាញយុវវ័យសព្វថ្ងៃនេះឲ្យមានទំនាក់ទំនងនឹងក្រុមដែលទុច្ចរិត ?
- តើនៅពេលណាដែលអ្នកឃើញយុវវ័យមានឥទ្ធិពលអវិជ្ជមានចំពោះសេចក្តីជំនឿរបស់អ្នកដទៃ ?

សូមឲ្យសិស្សរៀបរាប់ពីគោលការណ៍មួយដោយសង្ខេបពីអ្វីដែលយើងអាចរៀនពី នីហ្វៃទី ៣ ១:២៩–៣០ ។ ពួកគេអាចប្រើពាក្យខុសគ្នាដើម្បីប្រាប់ពីចម្លើយរបស់គេ ប៉ុន្តែសូមប្រាកដថា ពួកគេរកឃើញនូវសេចក្តីពិតខាងក្រោម ៖ **ប្រសិនបើយើងធ្លាក់ទៅក្នុងការល្បួង គំរូរបស់យើងអាចមានឥទ្ធិពលអវិជ្ជមានចំពោះសេចក្តីជំនឿ និងភាពសុចរិតរបស់អ្នកដទៃបាន ។** អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

សូមបង្ហាញថា ទោះបីជាយុវជនដែលបានលើកឡើងនៅក្នុង នីហ្វៃទី ៣ ១:៣០ បានមានឥទ្ធិពលអវិជ្ជមានចំពោះសេចក្តីជំនឿរបស់អ្នកដទៃក្តី ក៏យុវជនទាំងនោះអាចមានឥទ្ធិពលសុចរិតទៅដល់អ្នកនៅជុំវិញគេដែរ ។ សូមឲ្យសិស្សម្នាក់ឡើងមកកាន់ក្តារខៀន ហើយធ្វើជាអ្នកកត់ត្រាសម្រាប់ថ្នាក់រៀន ។ សូមឲ្យអ្នកកត់ត្រាសរសេរចម្លើយរបស់សិស្សចំពោះសំណួរខាងក្រោម ៖

- តើរបៀបណាខ្លះដែលអ្នកអាចមានឥទ្ធិពលវិជ្ជមានចំពោះសេចក្តីជំនឿនៃគ្រួសាររបស់អ្នក វួដឬសាខា និងសហគមន៍របស់អ្នក ?

សូមលើកទឹកចិត្តសិស្សឲ្យជ្រើសរើសគំនិតមួយ ឬពីរនៅលើក្តារខៀនដែលពួកគេនឹងធ្វើតាមភ្លាម។ ។ សូមប្រាកដថា ពួកគេអាចពង្រឹងសេចក្តីជំនឿរបស់អ្នកដទៃតាមរយៈអំណាចនៃគំរូដ៏សុចរិត ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ៣ ១:២៩–៣០ ។ « អំពើទុច្ចរិតនៃជំនាន់ដែលកំពុងពេញវ័យ »

ប្រធាន ហិនរី ប៊ី អារិង នៃគណៈប្រធានទីមួយបានពន្យល់ពីឥទ្ធិពលរបស់បុគ្គលម្នាក់ដែលបានដើរវង្វេង អាចមានមកលើគ្រួសារមួយ ៖

« យុវវ័យនៃសាសនាចក្រ . . . ក្តោបអនាគតពួកគេនៅក្នុងកណ្តាប់ដៃរបស់គេ ។ សាសនាចក្រតែងតែស្ថិតនៅក្នុងមួយជំនាន់ផុតពីភាពវិនាសបាត់បង់ ដោយសំអាងទាំងស្រុងទៅលើជម្រើសរបស់ពួកគេ ។ ប្រសិនបើតំណរយុវវ័យទាំងមូលនេះវង្វេងបាត់បង់ យើងនឹងបាត់បង់សាសនាចក្រនេះផងដែរ ប៉ុន្តែយើងដឹងថារឿងហេតុនេះនឹងមិនអាចកើតឡើងបានឡើយ ។ ប៉ុន្តែសូម្បីតែបុគ្គលតែម្នាក់បានវង្វេងពីជំណឹងល្អរបស់ព្រះរបស់ព្រះយេស៊ូវគ្រីស្ទ វានឹងបិទទ្វារដល់កូនចៅនៃជំនាន់ក្រោយ លើកលែងតែព្រះអម្ចាស់លូកព្រះសហ្គាទៅយកពួកគេខ្លះមកវិញ » (We Must Raise Our Sights » [សុន្ទរកថាថ្លែងទៅកាន់អ្នកអប់រំសាសនា CES នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០១], ១, si.lds.org) ។

នីហ្វៃទី ៣ ២–៥

សេចក្តីផ្តើម

ក្រោយពីប្រជាជនបានឃើញទីសម្គាល់នៃការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទហើយ ពួកគេបានចាប់ផ្តើមលែងមានការភ្ញាក់ផ្អើលអំពីទីសម្គាល់ទាំងឡាយ ហើយពួកគេបានមាន ចិត្តរឹងរូស ។ ប្រជាជនជាច្រើនបានបដិសេធទីសម្គាល់ និងការជំអស្ចារ្យជាច្រើនទៀត ហើយកាន់តែបន្តសេចក្តីទុច្ចរិត ។ ជាលទ្ធផល ក្រុមពួកចោរកាឌីអានតុនបានរីកចម្រើនយ៉ាងរឹងមាំរហូតដល់ពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិនត្រូវបង្ខំឲ្យលើកអាវុធឡើងប្រយុទ្ធនឹងពួកគេ ។ ពួកសាសន៍លេមិនដែលបានប្រែចិត្តបានចូលរួមនឹងសាសន៍នីហ្វៃ ហើយត្រូវបានហៅថា សាសន៍នីហ្វៃ ។ ឡាកូនីអូស ជាមេចៅក្រមនៃពួកសាសន៍នីហ្វៃ បានអំពាវនាវដល់ប្រជាជនឲ្យប្រែចិត្ត ហើយរៀបចំខ្លួនគេដើម្បីទៅច្បាំង ។ ដោយសារតែការប្រែចិត្តរបស់ពួកគេ សេចក្តីជំនឿគេទៅលើព្រះអម្ចាស់ និងការរៀបចំដ៏ឧស្សាហ៍ព្យាយាមរបស់គេ សាសន៍នីហ្វៃបានយកឈ្នះលើពួកចោរកាឌីអានតុន ។ បន្ទាប់ពីការរំដោះរបស់ពួកគេ ប្រជាជនបានទទួលស្គាល់ព្រះចេស្តារបស់ព្រះក្នុងការថែរក្សាពួកគេ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃ ទី៣ ជំពូក ២

ពួកសាសន៍លេមិនដែលបានប្រែចិត្តរួបរួមជាមួយនឹងពួកសាសន៍នីហ្វៃ ដើម្បីការពារខ្លួនគេពីពួកចោរកាឌីអានតុន

សូមឲ្យសិស្សចំណាយពេលពីរបីនាទី ដើម្បីសរសេរពីបទពិសោធន៍ខ្លះៗខាងវិញ្ញាណដែលពួកគេបានមានទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេររបស់ពួកគេ ។ សូមរំឭកពួកគេថា បទពិសោធន៍ខាងវិញ្ញាណមិនចាំបាច់តែជារឿងដែលគួរឲ្យរំភើប ឬអស្ចារ្យដើម្បីឲ្យមានន័យនោះឡើយ ។ សូមណែនាំថា ពួកគេគួរសញ្ជឹងគិតពីពេលដែលពួកគេបានមានអារម្មណ៍ពីសេចក្តីស្រឡាញ់នៃព្រះវរបិតាសួគ៌ ឬពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។ ឧទាហរណ៍ ពួកគេអាចសរសេរអំពីបទពិសោធន៍ដែលពួកគេបានមាននៅពេលពួកគេបានទទួលចម្លើយចំពោះការអធិស្ឋាន នៅពេលពួកគេបានទទួលពរជ័យនៃបព្វជិតភាព ឬនៅពេលពួកគេបានបម្រើដល់អ្នកដទៃ ។ នៅពេលពួកគេសរសេរចប់ហើយ សូមសួរពួកគេថា ហេតុអ្វីបានជាពួកគេគិតថា វាអាចមានសារៈសំខាន់ដើម្បីចងចាំពីបទពិសោធន៍ខាងវិញ្ញាណទាំងនេះនៅថ្ងៃនេះ និងនៅក្នុងរយៈពេល ១០ ឬ ២០ ឆ្នាំនាពេលអនាគតនោះ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២:១–៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលបានកើតឡើងនៅពេលប្រជាជនបានចាប់ផ្តើមភ្លេចពីទីសម្គាល់ដែលទាក់ទងទៅនឹងការប្រសូតរបស់ព្រះអង្គសង្គ្រោះ ។

- **តើសេចក្តីពិតអ្វីខ្លះដែលដំណើររឿងនេះបានបង្រៀនយើងអំពីគ្រោះថ្នាក់នៃការបំភ្លេចបទពិសោធន៍ខាងវិញ្ញាណ ?**

នៅពេលសិស្សចែកចាយពីសេចក្តីពិតដែលពួកគេបានរកឃើញ សូមបញ្ជាក់ពីគោលការណ៍ខាងក្រោម ៖ ប្រសិនបើយើងភ្លេចពីបទពិសោធន៍ខាងវិញ្ញាណពីមុនៗ នោះយើងនឹងកាន់តែងាយរងការល្បួង និងការបោកបញ្ឆោតរបស់សាតាំង ។ អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន ។ អ្នកក៏អាចជម្រុញឲ្យសិស្សសរសេរវានៅក្នុងបញ្ជីនៃបទពិសោធន៍ខាងវិញ្ញាណរបស់ពួកគេដែរ ។

- **តើអ្នកគិតថា ហេតុអ្វីបានជាការបំភ្លេចនូវបទពិសោធន៍ខាងវិញ្ញាណអាចធ្វើឲ្យយើងងាយនឹងរងគ្រោះពីសាតាំង ?**
- **តើយើងអាចធ្វើអ្វីខ្លះ ដើម្បីធានាថា យើងមិនភ្លេចបទពិសោធន៍ខាងវិញ្ញាណដែលយើងបានមាននោះ ? (ចម្លើយអាចរួមមានការចែកចាយបទពិសោធន៍ជាមួយនឹងអ្នកដទៃតាមដែលសមរម្យ ការសរសេរវាក្នុងកំណត់ហេតុផ្ទាល់ខ្លួន ឬការអត់ធ្មត់ពីសកម្មភាពក្នុងសៀវភៅ កាតព្វកិច្ចចំពោះព្រះ ឬការអភិវឌ្ឍន៍ខ្លួន) ។**

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោម ដែលប្រធានហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយបានពន្យល់ពីរបៀបដែលការកត់ត្រាបទពិសោធន៍ខាងវិញ្ញាណនៅក្នុងកំណត់ហេតុ បានជួយដល់លោក ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកនូវពរជ័យនានា ដែលអាចមកពីការរក្សាកំណត់ហេតុបែបនោះ ។

« ខ្ញុំបានសរសេររឿងពីរបីបន្ទាត់ជារៀងរាល់ថ្ងៃអស់ជាច្រើនឆ្នាំ ។ ខ្ញុំមិនដែលខកខានមួយថ្ងៃណាឡើយ មិនថាខ្ញុំនឿយហត់ប៉ុណ្ណា ឬ មិនថាព្រលឹមយ៉ាងណាដែលខ្ញុំត្រូវចាប់ផ្តើមថ្ងៃថ្មីនោះទេ ។ មុនពេលខ្ញុំចាប់សរសេរ ខ្ញុំបានសញ្ជឹងគិតពីសំណួរនេះ ៖ ‹ តើខ្ញុំបានឃើញព្រះហស្តរបស់ព្រះឡោងមកពាល់យើង ឬកូនចៅយើង ឬគ្រួសារយើងនាថ្ងៃនេះទេ ? › នៅពេលខ្ញុំរក្សាទម្លាប់នេះបាន អ្វីមួយបានចាប់ផ្តើមកើតឡើង ។ នៅពេលខ្ញុំនឹងគិតទៅដល់ថ្ងៃមួយនោះ ខ្ញុំបានឃើញភស្តុតាងដែលព្រះបានធ្វើសម្រាប់សមាជិកម្នាក់ | ក្នុងគ្រួសាររបស់យើង | ដែលខ្ញុំមិនបានចាប់អារម្មណ៍ក្នុងពេលដ៏វែងនាថ្ងៃនេះ ។ នៅពេលដែលការណ៍នោះកើតឡើង ហើយវាបានកើតឡើងជាញឹកញាប់ នោះខ្ញុំបានយល់ថា ការព្យាយាមចងចាំនេះបានអនុញ្ញាតឲ្យព្រះបង្ហាញដល់រូបខ្ញុំនូវអ្វីដែលទ្រង់បានធ្វើ ។

« វាលើសពីសេចក្តីអំណរគុណដែលបានចាប់ផ្តើមដុះដាលឡើងនៅក្នុងចិត្តរបស់ខ្ញុំ ។ ទីបន្ទាប់បានរីកចម្រើនឡើង ។ ខ្ញុំកាន់តែមានភាពច្បាស់លាស់បន្ថែមទៀតថា ព្រះវរបិតាសួគ៌របស់យើងឮ និងឆ្លើយតបនូវការអធិស្ឋានទាំងឡាយ ។ ខ្ញុំបានមានអារម្មណ៍ដឹងគុណកាន់តែច្រើនចំពោះការបន្ទន់ចិត្ត និងការបន្សុទ្ធដែលកើតមានដោយសារដង្វាយធួនរបស់ព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ។ ហើយខ្ញុំកាន់តែមានទំនុកចិត្តជាងមុនថា ព្រះវិញ្ញាណបរិសុទ្ធអាចធ្វើឲ្យយើងចងចាំអ្វីៗទាំងអស់— សូម្បីតែរឿងដែលយើងមិនបាន

កត់សម្គាល់ ឬចាប់អារម្មណ៍ នៅពេលវាបានកើតឡើងក្តី » (« O Remember, Remember » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៦៧) ។

សូមឲ្យសិស្សចែកចាយពីរបៀបដែលការចងចាំដល់បទពិសោធន៍ខាងវិញ្ញាណ— តាមរយៈការសរសេរក្នុងកំណត់ហេតុ ឬរបៀបផ្សេងទៀត— បានជួយពួកគេឲ្យនៅបន្តស្មោះត្រង់ ទោះបីជាសាតាំងបានខិតខំល្បួង ឬបោកបញ្ឆោតពួកគេក្តី ។

សូមសង្ខេប នីហ្វៃទី ៣ ២:៤–១៩ ដោយពន្យល់ថា នៅពេលប្រជាជនបានបន្តនៅក្នុងសេចក្តីទុច្ចរិត នោះពួកចោរកាឌីអានតុនបានកើនឡើងទាំងចំនួន និងកម្លាំង ។ ពួកចោរកាឌីអានតុនបានក្លាយជាឆេវឆាវប្រើហិង្សាកាន់តែខ្លាំង ហើយពួកសាសន៍លេមិនដែលបានប្រែចិត្តបានចូលរួមជាមួយនឹងកម្លាំងរបស់សាសន៍នីហ្វៃដើម្បីប្រយុទ្ធប្រឆាំងនឹងពួកគេ ។ ទោះបីជាពួកគេមានជ័យជំនះខ្លះៗនៅក្នុងការបណ្តេញពួកចោរកាឌីអានតុនចេញពីដែនដីរបស់ពួកគេក្តី ក៏ពួកសាសន៍នីហ្វៃ (ជាមួយនឹងពួកសាសន៍លេមិនដែលបានប្រែចិត្ត ដែលឥឡូវនេះត្រូវបានហៅថាជា សាសន៍នីហ្វៃ) នៅតែស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់រយៈពេល ១៥ ឆ្នាំ ក្រោយពីមានទីសម្គាល់នៃការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ។

នីហ្វៃទី ៣ ១–១០

អ្នកដឹកនាំពួកចោរកាឌីអានតុនទាមទារឲ្យពួកសាសន៍នីហ្វៃចុះចាញ់

សូមពន្យល់ថានៅក្នុង នីហ្វៃទី ៣៣:១–១០ ពេលខ្លះ យើងឃើញពីគំរូមួយ ដែលមារសត្រូវអាចប្រើប្រាស់អ្នកដទៃ ក្នុងការព្យាយាមធ្វើឲ្យសេចក្តីជំនឿរបស់យើងចុះខ្សោយ ហើយដឹកនាំយើងឲ្យវង្វេង ។ គីឌឌីអានហៃ ជាអ្នកដឹកនាំរបស់ពួកចោរកាឌីអានតុន បានសរសេរសំបុត្រមួយច្បាប់ទៅឡាកូនីអូស ដែលជាមេចៅក្រមនៃពួកសាសន៍នីហ្វៃ ដើម្បីបញ្ចុះបញ្ចូលលោកឲ្យចុះចាញ់ពួកក្រុមចោរកាឌីអានតុន ។

សូមសរសេរ *គីឌឌីអានហៃ ល្បួងឡាកូនីអូស* នៅលើក្តារខៀន ។ សូមឲ្យសិស្សពាក់កណ្តាលថ្នាក់អាន នីហ្វៃទី ៣ ៣:២–៥ ដោយស្ងៀមស្ងាត់ ហើយសិស្សដទៃទៀតអាន នីហ្វៃទី ៣ ៣:៦–១០ ដោយស្ងៀមស្ងាត់ ។ នៅពេលសិស្សអាន សូមឲ្យពួកគេរកមើលពាក្យ ឬឃ្លាដែលបង្ហាញពីវិធីសាស្ត្រដែល គីឌឌីអានហៃ បានប្រើដើម្បីព្យាយាមធ្វើឲ្យសេចក្តីជំនឿរបស់ឡាកូនីអូសទន់ខ្សោយ ហើយដឹកនាំលោកឲ្យវង្វេង ។ ក្រោយពីសិស្សអានចប់ហើយ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។ សូមឲ្យសិស្សសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។

ដើម្បីសង្ខេបពីវិធីសាស្ត្រដែលសិស្សបានរកឃើញនៅក្នុង នីហ្វៃទី ៣ ៣:២–១០ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន នៅក្រោមបញ្ជីចម្លើយរបស់សិស្ស ៖ ***ជារឿយៗ សាតាំង និងអ្នកដើរតាមវា ប្រើនូវពាក្យបញ្ជោរ ការសន្យាក្លែងក្លាយ និងការគំរាមកំហែងដើម្បីនាំមនុស្សឲ្យវង្វេង ។*** សូមឲ្យសិស្សរើសយកវិធីសាស្ត្រមួយដែលគីឌឌីអានហៃប្រើ ដែលមានសរសេរស្រាប់នៅលើនៅលើក្តារខៀន ហើយពន្យល់ពីរបៀបដែលសាតាំង និងពួកអ្នកដើរតាមវាអាចប្រើរបៀបស្រដៀងគ្នានេះទៅលើយុវជននាសព្វថ្ងៃនេះ ។ ដើម្បីជួយសិស្សឲ្យរកឃើញនូវការប្រៀបធៀបទាំងនេះមួយចំនួន អ្នកអាចសួរសំណួរដូចខាងក្រោម ៖

- តើគំរូមួយចំនួននៃរបៀបដែលសាតាំងអាចប្រើពាក្យបញ្ជោរ (ការសរសើរដោយមិនស្មោះត្រង់ ឬហួសហេតុពេក) ទៅលើយុវជននាសព្វថ្ងៃនេះមានអ្វីខ្លះ ? តើការសន្យាក្លែងក្លាយឬការគំរាមទទេអ្វីខ្លះ ដែលបច្ចាមិត្តអាចប្រើ ? តើអ្នកគិតថា យុវជនអាចយកឈ្នះលើវិធីសាស្ត្រទាំងនេះតាមរបៀបណា ?

នីហ្វៃទី ៣ ៣:១១–៥:៧

ប្រជាជនរបស់ឡាកូនីអូសរៀបចំការពារខ្លួន ហើយបានបង្ក្រាបពួកចោរកាឌីអានតុន

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ៣:១១–១២ ព្ធៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរបៀបដែលឡាកូនីអូសបានឆ្លើយតបទៅនឹងសំបុត្រគំរាមរបស់គីឌឌីអានហៃ ។

- តើសេចក្តីពិតអ្វីខ្លះដែលយើងអាចរៀនពីរបៀបដែលឡាកូនីអូសបានឆ្លើយតបនឹងគីឌឌីអានហៃ ? (សេចក្តីពិតមួយដែលសិស្សអាចរកឃើញនោះគឺ **បុរស និងស្ត្រីសុចរិតមិនត្រូវខ្លាចពួកទុច្ចរិតឡើយ ហើយមិនគួរចុះចាញ់ការគំរាមរបស់ពួកគេដែរ**) ។

សូមបំបែកសិស្សក្នុងថ្នាក់ទៅជាបួនក្រុម ។សូមចែកក្រដាសមួយផ្ទាំងធំមួយឲ្យក្រុមនីមួយៗ ។ សូមឲ្យក្រុមទាំងឡាយគូសចែកក្រដាសរបស់គេជាពីរជួរឈរ ដោយជួរមួយដាក់ចំណងជើងថា *ការរៀបចំរបស់ឡាកូនីអូស* ហើយមួយទៀតដាក់ចំណងជើងថា *រឿងដូចគ្នាក្នុងសម័យទំនើប ។* សូមសរសេរវគ្គព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ហើយឲ្យវគ្គគម្ពីរមួយទៅក្រុមនីមួយៗ ៖ *នីហ្វៃទី ៣ ៣:១២–១៥, នីហ្វៃទី ៣ ៣:១៦–២១, នីហ្វៃទី ៣ ៣:២២–២៦, នីហ្វៃទី ៣ ៤:១–៤ ។* សូមឲ្យសិស្សអានខគម្ពីរដែលពួកគេមាន ដោយរកមើលរបៀបដែលឡាកូនីអូសបានរៀបចំប្រជាជនរបស់លោកខាងវិញ្ញាណ និងខាងសាច់ឈាមដើម្បីប្រឈមនឹងការវាយប្រហារពីពួកចោរកាឌីអានតុន ។ នៅក្រោមចំណងជើង *ការរៀបចំរបស់ឡាកូនីអូស* សូមឲ្យសិស្សម្នាក់ពីក្រុមនីមួយៗសរសេរនូវអ្វីដែលប្រជាជនបានធ្វើក្នុងការរៀបចំខ្លួន ។ (*កំណត់ចំណាំ ៖* នៅពេលសិស្សសិក្សាពីខគម្ពីរទាំងនេះ សូមប្រាកដថា ពួកគេបែងចែកភាពខុសគ្នារវាងគីឌឌីអានហៃ ជាអ្នកដឹកនាំរបស់ពួកចោរកាឌីអានតុន និងគីឌគីឌដូណៃ ដែលជាព្យាការីដ៏អស្ចារ្យ និងជាមេទ័ពដ៏សំខាន់ក្នុងចំណោមពួកសាសន៍នីហ្វៃ ។

ក្រោយពីសិស្សបានមានពេលគ្រប់គ្រាន់ដើម្បីបញ្ចប់បញ្ជីរបស់គេនៅក្រោមចំណងជើង *ការរៀបចំរបស់ឡាកូនីអូស* ហើយសូមឲ្យពួកគេសរសេរនៅក្រោម *រឿងដូចគ្នាក្នុងសម័យទំនើប* នូវការរៀបចំខាងវិញ្ញាណ និងខាងសាច់ឈាមដែលយើងត្រូវបានណែនាំឲ្យធ្វើតាមនៅក្នុងថ្ងៃចុងក្រោយនេះ ។ នៅពេលសិស្សបានមានពេលគ្រប់គ្រាន់ដើម្បីបញ្ចប់កិច្ចការនេះហើយ សូមឲ្យសិស្សម្នាក់ពីក្រុមនីមួយៗ

ចែកចាយនូវអ្វីដែលក្រុមរបស់គេបានរៀនដល់សិស្សដទៃទៀត ។ ដើម្បីជួយសិស្សឲ្យកំណត់ពីរបៀបដែលពួកគេអាចអនុវត្តនូវអ្វីដែលពួកគេបានរៀន សូមសួរសំណួរដូចខាងក្រោមអំឡុងពេល ឬក្រោយពីការធ្វើបទបង្ហាញរបស់គេ ៖

- តើយើងអាចការពារផ្ទះរបស់យើងប្រឆាំងនឹងការវាយប្រហាររបស់សាតាំងដោយរបៀបណា ?
- ហេតុអ្វីបានជាការរៀបចំខាងសាច់ឈាម —ដូចជាការទទួលបានការអប់រំ និងការស្អុកទុកក្នុងគេហដ្ឋាន— មានសារៈសំខាន់នៅថ្ងៃចុងក្រោយ ?
- តើការជួបជុំក្នុងក្រុមគ្រួសារ និងនៅក្នុងវួដ ឬសាខាផ្តល់នូវការការពារដល់យើងយ៉ាងដូចម្តេចខ្លះ ?
- តើនៅពេលណាដែលការអធិស្ឋានបានជួយដល់អ្នកឲ្យទទួលបានកម្លាំងខាងវិញ្ញាណ ?
- តើការប្រែចិត្តអាចរៀបចំយើងសម្រាប់ពេលអនាគតដោយរបៀបណា ?
- តើពរជ័យអ្វីខ្លះនឹងកើតមាន នៅពេលយើងធ្វើតាមព្យាការី និងសាវកដែលនៅរស់ទាំងឡាយ ?
- តើយើងអាចអញ្ជើញឲ្យវិញ្ញាណនៃវិវរណៈចូលមកក្នុងជីវិតរបស់យើងដោយរបៀបណា ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេណគ្នាអានឮៗក្នុង នីហ្វៃទី ៣ ៤:៧–១២ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរបៀបដែលប្រជាជនត្រូវបានប្រទានពរដោយសារតែការរៀបចំខាងវិញ្ញាណ និងខាងសាច់ឈាមរបស់ពួកគេ ។

- តើសេចក្តីពិតអ្វីខ្លះដែលអ្នកបានរៀនពីដំណើររឿងនេះ ? (នៅពេលសិស្សចែកចាយចម្លើយរបស់គេ សូមសង្កត់ធ្ងន់លើគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងរៀបចំខ្លួនយើងខាងវិញ្ញាណ និងខាងសាច់ឈាម នោះព្រះអម្ចាស់នឹងពង្រឹងយើងឲ្យយកឈ្នះលើឧបសគ្គទាំងឡាយ**) ។

សូមសង្ខេប នីហ្វៃទី ៣៤:១៣–២៩ ដោយពន្យល់ថា ឡាកូនីអូស និងប្រជាជនរបស់លោកបានវាយបង្ក្រាបពួកចោរកាឌីអានតុន ហើយបានកាត់ទោសអ្នកដឹកនាំរបស់វា ។ សូមអាន នីហ្វៃទី ៣ ៤:៣០–៣៣ ឮៗ ។សូមឲ្យសិស្សមើលតាម ដោយរកមើលរបៀបដែលប្រជាជនបានឆ្លើយតបទៅនឹងជ័យជំនះនេះ ។

- តើប្រជាជនបានឆ្លើយតបយ៉ាងណា ក្រោយពីព្រះអម្ចាស់បានដោះលែងពួកគេពីពួកសត្រូវរបស់គេ ?
- តើប្រជាជនបានទទួលស្គាល់អ្វីខ្លះ ដែលជាបុព្វហេតុនៃសេរីភាពរបស់ពួកគេរួចផុតពីពួកចោរកាឌីអានតុន ? (ការប្រែចិត្ត និងការបន្ទាបខ្លួនរបស់ពួកគេ និងសេចក្តីល្អរបស់ព្រះ ។ អ្នកអាចបង្ហាញថា **នៅពេលយើងប្រែចិត្ត ហើយបន្ទាបខ្លួនយើង នោះព្រះនឹងទ្រទ្រង់យើងឲ្យឆ្លងផុតពីឧបសគ្គ ហើយធ្វើឲ្យយើងរួចផុតពីការសោកល្បួងរបស់យើង**) ។

អ្នកអាចចែកចាយបទពិសោធន៍មួយដែលអ្នកបានទុកចិត្តលើព្រះ ហើយទ្រង់បានជួយអ្នកឲ្យស៊ូទ្រាំ ឬយកឈ្នះនឹងឧបសគ្គនោះ ។ អ្នកក៏អាចសុំឲ្យសិស្សម្នាក់ ឬពីរនាក់ចែកចាយបទពិសោធន៍បែបនោះផងដែរ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ៥:១–៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលពួកសាសន៍នីហ្វៃបានធ្វើដែលជាលទ្ធផលនៃជំនួយ និងពរជ័យដែលពួកគេបានទទួលនៅក្នុងចម្បាំងរបស់គេជាមួយនឹងពួកចោរកាឌីអានតុន ។ នៅពេលសិស្សចែកចាយអ្វីដែលពួកគេរកឃើញ សូមបញ្ជាក់ថា របៀបមួយដែលប្រជាជននោះបានឆ្លើយតបគឺ ការប្រកាសដំណឹងល្អដល់អ្នកដទៃ ។

នីហ្វៃទី ៣ ៥:៨–២៦

សេចក្តីសុខសាន្តត្រូវបានកើតមានឡើងវិញនៅក្នុងចំណោមពួកប្រជាជន មរមនពន្យល់នូវសេចក្តីសង្ខេបរបស់លោកស្តីពីកំណត់ត្រាទាំងឡាយ

សូមប្រាប់សិស្សថា ផ្នែកផ្សេងទៀតនៃ នីហ្វៃទី ៣ ៥ មាននូវការពន្យល់របស់មរមនស្តីពីមូលហេតុដែលលោកសង្ខេបកំណត់ត្រានេះ ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ៥:១២–១៥ ដោយស្ងៀមស្ងាត់ ដោយរកមើលអ្វីដែលមរមនបានថ្លែងអំពីទំនួលខុសត្រូវរបស់លោក ក្នុងការសរសេរសេចក្តីសង្ខេបនៃកំណត់ត្រារបស់ពួកសាសន៍នីហ្វៃ ។

- តើសេចក្តីពិតអ្វីខ្លះដែលអ្នកបានរៀនពីឧទាហរណ៍ទាំងនេះ ដែលពិពណ៌នាពីទំនួលខុសត្រូវរបស់យើងក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ? (ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាក្តី ក៏ពួកគេគួរតែឃើញនូវសេចក្តីពិតដូចខាងក្រោមនេះ ៖ **ក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ យើងមានការទទួលខុសត្រូវដើម្បីបង្រៀនដល់អ្នកដទៃពីរបៀបទៅរកជីវិតដ៏នៅអស់កល្បជានិច្ច ។** អ្នកអាចសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមបង្ហាញថា របៀបដ៏មានសារៈសំខាន់បំផុតមួយដែលយើងអាចបង្ហាញអំណរគុណរបស់យើងចំពោះព្រះអម្ចាស់សម្រាប់ពរជ័យដែលទ្រង់ប្រទានដល់យើងគឺ ដោយការជួយអ្នកដទៃឲ្យចូលមករកទ្រង់ ហើយទទួលបានពរជ័យទាំងនោះដូចគ្នា ។ សូមឲ្យសិស្សលើកឡើងនូវរបៀបមួយចំនួនដែលពួកគេអាចបង្រៀនដល់អ្នកដទៃពីផ្លូវទៅរកជីវិតដ៏នៅអស់កល្បជានិច្ច ក្នុងនាមគេជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមលើកទឹកចិត្តសិស្សឲ្យជ្រើសរើសការណែនាំទាំងនេះមួយ ឬពីរដើម្បីចែកចាយដំណឹងល្អ និងដើម្បីស្វែងរកជំនួយរបស់ព្រះអម្ចាស់ប្រកបដោយការអធិស្ឋាននៅក្នុងការអនុវត្តអ្វីដែលពួកគេជ្រើសរើសធ្វើនោះ ។

មេរៀនទី ១១៨

នីហ្វៃទី៣ ៦–៧

សេចក្តីផ្តើម

បន្ទាប់ពីការដោះលែងដ៏អព្ភូតហេតុរបស់ពួកគេចេញពីក្រុមពួកចោរកាឌីអានតុន ពួកសាសន៍នីហ្វៃបានអររីករាយនឹងសេចក្តីសុខសាន្តរយៈពេលប្រហែលបីឆ្នាំ ។ ប៉ុន្តែសេចក្តីផ្នើងឆ្នៃ ការបែងចែកហាន: និងការបៀតបៀនកើតមាននៅក្នុងចំណោមប្រជាជន ។ ខណៈពេលដែលអ្នកខ្លះនៅតែបន្តស្មោះត្រង់ចំពោះព្រះអម្ចាស់ មានមនុស្សជាច្រើនបានចូលទៅក្នុងបក្សព័ន្ធសម្ងាត់ ។ ដោយសារតែបក្សព័ន្ធសម្ងាត់ ទើបមេចៅក្រមត្រូវបានគេធ្វើឃាត ហើយការគ្រប់គ្រងរបស់ពួកសាសន៍នីហ្វៃត្រូវបានផ្តួលរំលំ ។ ប្រជាជនបែងចែកទៅជាកុលសម្ព័ន្ធ ហើយបានចាត់តាំងអ្នកដឹកនាំផ្ទាល់ខ្លួនរបស់ពួកគេ ។ នីហ្វៃបានបម្រើដល់ប្រជាជនដោយអំណាចនិងសិទ្ធិអំណាចដ៏អស្ចារ្យ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៣ ៦:១–១៨

បន្ទាប់ពីរយៈពេលដ៏រុងរឿង សាសន៍នីហ្វៃបានក្លាយទៅជាផ្នើងឆ្នៃ ហើយសាសនាចក្រត្រូវបាក់បែក

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀនមុនចាប់ផ្តើមបង្រៀន ។ សូមឲ្យសិស្សឆ្លើយនឹងសំណួរ ហើយពន្យល់ពីចម្លើយរបស់ពួកគេ ។

តើវាអាចទៅរួចទេដែលនរណាម្នាក់ក្លាយជា . . .

មានបាន ហើយបន្ទាបខ្លួន ?

ក្រីក្រ ហើយឆ្នើងឆ្នៃ ?

ចេះដឹង ហើយបន្ទាបខ្លួន ?

មិនចេះដឹង ហើយឆ្នើងឆ្នៃ ?

សូមលើកទឹកចិត្តឲ្យសិស្សបន្តគិតអំពីសំណួរទាំងនេះ នៅពេលពួកគេសិក្សា នីហ្វៃទី ៣ ៦ ។ សូមសង្ខេប នីហ្វៃទី ៣ ៦:១–៩ ដោយការពន្យល់ថា ក្រោយពីពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិនបានបង្ក្រាបពួកចោរកាឌីអានតុនហើយ ពួកគេបានស្ថាបនាសេចក្តីសុខសាន្តនៅលើដែនដី ហើយបានចាប់ផ្តើមរីកចម្រើនឡើង ។ ប៉ុន្តែបានតែមួយរយៈពេលខ្លីប៉ុណ្ណោះ សេចក្តីសុខសាន្ត និងការរីកចម្រើនរបស់ពួកគេត្រូវបានគំរាមកំហែង ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ៦:៥, ១០–១២ ព្ធ ។ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលបានចាប់ផ្តើមគំរាមកំហែងដល់សេចក្តីសុខសាន្ត និងការរីកចម្រើនរបស់ប្រជាជន ។

- តើអ្វីបានចាប់ផ្តើមកើតឡើង ដែលគំរាមកំហែងដល់សេចក្តីសុខសាន្ត និងការរីកចម្រើនរបស់ប្រជាជន ?
- តើអ្នកធ្លាប់បានឃើញថាការមានទ្រព្យកាន់តែច្រើន ឬការរៀនសូត្រកាន់តែច្រើន ដឹកនាំទៅរកបញ្ហាដូចគ្នានេះ នៅក្នុងសាលារៀន សហគមន៍ ឬប្រទេសរបស់អ្នកដែរឬទេ ? ប្រសិនបើមាន តើតាមរបៀបណា ?

សូមគូសបន្ទាត់ពុះក្តារខៀនជាពីរ ។ សូមសរសេរ *ភាពឆ្នើងឆ្នៃ* នៅផ្នែកខាងលើនៃក្តារខៀនម្ខាង ហើយ *បន្ទាបខ្លួន* នៅម្ខាងទៀត ។ សូមឲ្យសិស្សសិក្សា នីហ្វៃទី ៣ ៦:១៣–១៤ ដោយរកមើលពាក្យ និងឃ្លាទាំងឡាយដែលពិពណ៌នាពីរបៀបដែលប្រជាជនបានឆ្លើយតប នៅពេលការមានបាន និងការរៀនសូត្រកាន់តែច្រើន ចាប់ផ្តើមបំបែកពួកគេ ។ (អ្នកអាចត្រូវពន្យល់ថា *បណ្តុះបង្អាប់* ឬ *ជេរប្រមាថ* មានន័យថា ការរិះគន់ដោយកំហឹង ឬនិយាយពាក្យត្រគោះបោះបោកដាក់នរណាម្នាក់) ។ នៅពេលសិស្សអានចប់ សូមឲ្យពួកគេសរសេរនៅក្នុងផ្នែកត្រឹមត្រូវលើក្តារខៀននូវពាក្យ ឬឃ្លាដែលពួកគេបានរកឃើញ ។

- តើភស្តុតាងអ្វីខ្លះដែលអ្នកឃើញនៅក្នុង នីហ្វៃទី ៣ ៦:១៣ ដែលអ្នកខ្លះដែលត្រូវបានបៀតបៀនដោយភាពឆ្នើងឆ្នៃហើយប្រព្រឹត្តិអំនួតខ្លួនគេ ?
- តើអ្នកគិតថា ហេតុអ្វីបានជាការត្រឡប់នូវ « ការបណ្តុះបង្អាប់សងនឹងការបណ្តុះបង្អាប់ » វិញ (ឬការរិះគន់សងនឹងការរិះគន់វិញនោះ) គឺជាការសម្តែងនៃសេចក្តីឆ្នើងឆ្នៃមួយ ?
- តើអ្វីដែលធ្វើឲ្យអ្នកស្ងើចសរសើរ ចំពោះ ពួកសាសន៍លេមិនដែលបានប្រែចិត្តជឿ បានឆ្លើយតបនៅពេលនេះ ?
- តើគោលការណ៍អ្វីដែលយើងអាចរៀនពី នីហ្វៃទី ៣ ៦:១៣–១៤ ? (ចម្លើយរបស់សិស្សអាចខុសគ្នា ប៉ុន្តែពួកគេគួរបង្កប់នូវគោលការណ៍ដូចខាងក្រោមនេះ ៖ **យើងអាចជ្រើសរើសដើម្បីបន្ទាបខ្លួន និងស្មោះត្រង់ដោយមិនគិតពីកាលៈទេសៈរបស់យើង**) ។

សូមនាំសិស្សឲ្យមើលទៅក្តារខៀនផ្នែកខាងចម្លើយនៃការបន្ទាបខ្លួន ។ សូមសួរសំណួរដូចខាងក្រោម ៖

- តើសកម្មភាពអ្វីខ្លះដែលយើងអាចធ្វើ ដើម្បីជួយខ្លួនយើងឲ្យនៅតែបន្ទាបខ្លួន និងស្មោះត្រង់ទោះបីស្ថិតក្នុងកាលៈទេសៈណាក៏ដោយនោះ ? (សូមសរសេរចម្លើយរបស់សិស្សនៅលើក្តារខៀនខាងផ្នែកមានចំណងជើងថា *បន្ទាបខ្លួន*) ។

- សូមគិតពីបុគ្គលម្នាក់ដែលអ្នកមានអារម្មណ៍ថាជាគំរូដ៏ល្អមួយក្នុងការជ្រើសរើសយកការបន្ទាបខ្លួន និងស្មោះត្រង់ ដោយមិនគិតពីកាលៈទេសៈរបស់គាត់ ។ តើបុគ្គលនេះជាគំរូមួយនៃការបន្ទាបខ្លួនដោយរបៀបណា ?

សូមពន្យល់ថា ដោយសារតែពួកសាសន៍នីហ្វៃភាគច្រើនមិនបានប្រែចិត្តចេញពីសេចក្តីឆ្មើងឆ្មៃរបស់គេ នោះស្ថានភាពរបស់ពួកគេកាន់តែលំបាកទៅៗ ។ សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី នីហ្វៃទី ៣ ៦:១៥–១៨ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរបៀបដែលអំនួតរបស់មនុស្សអាចនាំឲ្យសាតាំងអាចគ្រប់គ្រងលើពួកគេបាន ។

- តើខគម្ពីរទាំងនេះបង្រៀនអ្វីខ្លះ អំពីទំនាក់ទំនងរវាងអំនួត និងអំណាចរបស់សាតាំងក្នុងការល្បួងយើង ? (នៅពេលសិស្សឆ្លើយ សូមជួយពួកគេឲ្យរកឃើញនូវសេចក្តីពិតខាងក្រោម ៖ **នៅពេលយើងអួតអាង នោះយើងនាំឲ្យសាតាំងមានអំណាចកាន់តែខ្លាំងក្នុងការល្បួងយើង ហើយដឹកនាំយើងឲ្យប្រព្រឹត្តអំពើបាបបន្ថែមទៀត ។** អ្នកអាចលើកទឹកចិត្តឲ្យពួកគេសរសេរគោលការណ៍នេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់របស់ពួកគេ) ។
- យោងតាម នីហ្វៃទី ៣ ៦:១៥–១៨ តើពាក្យ និងឃ្លាណាខ្លះដែលពិពណ៌នាពីការផ្លាស់ប្តូរដួងចិត្តដ៏ទុច្ចរិតដែលប្រជាជនទាំងនេះបានជួបប្រទះដោយសារតែសេចក្តីឆ្មើងឆ្មៃ ? (ពួកគេ « បានប្រគល់ខ្លួន . . . ឲ្យដឹកនាំដោយ . . . | សាតាំង | នោះជាវាមានសេចក្តីប៉ងប្រាថ្នាចង់នាំពួកគេទៅទីណា ហើយឲ្យធ្វើអំពើទុច្ចរិតណាក៏ដោយដែលវាមានសេចក្តីប៉ងប្រាថ្នាចង់ឲ្យពួកគេធ្វើ » ។ ពួកគេស្ថិតនៅក្នុង « ស្ថានភាពទុច្ចរិតមួយដ៏គួរស្អែងខ្លាច » ហើយបាន « បះបោរដោយចេតនាទាស់នឹងព្រះ ») ។
- តើអ្នកគិតថា ហេតុអ្វីបានជាសេចក្តីឆ្មើងឆ្មៃប៉ះពាល់ដល់កម្រិតដែលសាតាំងអាចមានឥទ្ធិពលលើយើង ?

បន្ថែមលើចម្លើយរបស់សិស្ស សូមគិតពីការសុំឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ។ សូមឲ្យសិស្សស្តាប់និងរកមើលនូវអ្វីដែលប្រធាន អាវរិង បានព្រមានថាជាគ្រោះថ្នាក់មួយនៃការឆ្មើងឆ្មៃ ។

« ការឆ្មើងឆ្មៃបង្កើតសំឡេងមួយពីក្នុងខ្លួនយើង ដែលធ្វើឲ្យយើងពិបាកនឹងស្តាប់ឮសំឡេងដ៏ស្ងាត់ៗនៃព្រះវិញ្ញាណ ។ នៅក្នុងការឥតប្រយោជន៍របស់យើង នោះមិនយូរមិនឆាប់ យើងនឹងលែងស្តាប់ឮសំឡេងនៃព្រះវិញ្ញាណ ។ យើងអាចគិតភ្លាមថា យើងមិនត្រូវការសំឡេងនោះទេ » (« Prayer » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ២០០១, ទំព័រ ១៦) ។

- ហេតុអ្វីបានជាវាមានគ្រោះថ្នាក់ពេលយើងលែងស្តាប់ឮសំឡេងនៃព្រះវិញ្ញាណនោះ ? (សូមជួយសិស្សឲ្យយល់ថា នៅពេលយើងព្រងើយកន្តើយនឹងសំឡេងខ្សឹបនៃព្រះវិញ្ញាណបរិសុទ្ធ នោះយើងនឹងងាយចាញ់ការល្បួងរបស់ពួកអារក្ស) ។

សូមនាំសិស្សមើលទៅបញ្ជីនៃចម្លើយខាងផ្នែកបន្ទាបខ្លួននៅលើក្តារខៀនម្តងទៀត ។ សូមឲ្យពួកគេរើសយកចម្លើយពីការបន្ទាបខ្លួនមួយដែលពួកគេមានអារម្មណ៍ថា វានឹងជួយដល់ពួកគេផ្ទាល់បានខ្លាំងបំផុត ។ សូមឲ្យពួកគេមានពេលពីរបីនាទីដើម្បីសរសេរអំពីរបៀបដែលពួកគេអាចចាប់ផ្តើមអនុវត្តសំណើរនោះភ្លាមៗនៅឯសាលារៀន ឬនៅផ្ទះ ។

នីហ្វៃទី៣ ៦:១៩–៧:១៤

បក្សព័ន្ធសម្ងាត់បំផ្លាញការគ្រប់គ្រងនៃពួកសាសន៍នីហ្វៃ ហើយប្រជាជនបាក់បែកទៅជាកុលសម្ព័ន្ធ

សូមចម្លងបន្ទាត់ពេលវេលាខាងក្រោមដាក់លើក្តារខៀន ៖

នីហ្វៃទី៣ ៦:១៩–២៤	នីហ្វៃទី៣ ៦:២៥–៣០	នីហ្វៃទី៣ ៧:១–៨	នីហ្វៃទី៣ ៧:៩–១៤

សូមបំបែកសិស្សក្នុងថ្នាក់ទៅជាបួនក្រុម ហើយចាត់តាំងឲ្យក្រុមនីមួយៗអាននូវវគ្គព្រះគម្ពីរមួយដែលសរសេរនៅលើក្តារខៀន ។ សូមឲ្យសិស្សអានវគ្គដែលដាក់ឲ្យគេអានស្ងាត់ៗ ដោយរកមើលព្រឹត្តិការណ៍ដ៏សំខាន់ៗដែលបានកើតឡើងចំពោះពួកសាសន៍នីហ្វៃ ។ ក្រោយពីសិស្សបានមានពេលអានគ្រប់គ្រាន់ហើយ សូមឲ្យសិស្សម្នាក់ពីក្រុមនីមួយៗសរសេរនូវព្រឹត្តិការណ៍ដ៏សំខាន់ៗពីវគ្គដែលដាក់ឲ្យពួកគេអានតាមផ្នែកដែលត្រឹមត្រូវតាមបន្ទាត់ពេលវេលា (សិស្សផ្សេងទៀតពីក្រុមនីមួយៗអាចជួយគ្នាបាន) ។ នៅពេលពួកគេអានបញ្ចប់ហើយ សូមពន្យល់ថាបញ្ជីព្រឹត្តិការណ៍នេះបង្ហាញពីរបៀបដែលពួកបក្សព័ន្ធសម្ងាត់បានដឹកនាំទៅរកការធ្លាក់ចុះនៃការគ្រប់គ្រងរបស់ពួកសាសន៍នីហ្វៃ និងការបែកបាក់ប្រជាជនទៅជាកុលសម្ព័ន្ធដ៏ច្រើន ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី នីហ្វៃទី ៣ ៦:២៧–៣០ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយរកមើលអ្នកបង្កើត និងគោលបំណងនៃបក្សព័ន្ធសម្ងាត់ ។ នៅពេលសិស្សបានរកឃើញអ្នកបង្កើតនៃបក្សព័ន្ធសម្ងាត់ (អារក្ស) ហើយ សូមសួរថា ៖

- តើពាក្យ និងឃ្លាណាខ្លះដែលរៀបរាប់ពីគោលបំណងរបស់បក្សព័ន្ធសម្ងាត់នេះ ? (ចម្លើយអាចរួមមាន « រួបរួមគ្នាប្រឆាំងនឹងភាពសុចរិតទាំងឡាយ » « បំផ្លាញ » ប្រភាស្ករបស់ព្រះអម្ចាស់ « រឹងទទឹងនឹងច្បាប់ និងសិទ្ធិទាំងឡាយរបស់ប្រទេសគេ » ហើយ « ដែនដីលែងមានឥស្សរភាពតទៅទៀត ») ។
- តើអ្នកដែលធ្វើឃាតព្យាការីបានរួចពីការដាក់ទោសដោយរបៀបណា ? (មិត្តភក្តិ និងគ្រួសាររបស់គេ ដែលធ្លាប់ជាសមាជិកនៃបក្សព័ន្ធសម្ងាត់ បានរួបរួមគ្នាជួយពួកគេឲ្យលាក់សកម្មភាពរបស់គេជាការសម្ងាត់ ហើយបញ្ឈៀសលទ្ធផលនៃទង្វើរបស់គេ) ។
- សូមស្រមៃថា អ្នកមានមិត្តភក្តិខ្លះដែលចង់បញ្ឈៀសលទ្ធផលនៃសកម្មភាពរបស់ពួកគេ ។ តើអ្នកអាចជួយពួកគេឲ្យបែរជារស់នៅតាមដំណឹងល្អ និងបទដ្ឋាននៃដំណឹងល្អដោយរបៀបណា ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី នីហ្វៃទី ៣ ៧:១–៨ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយរកមើលឥទ្ធិពលនៃបក្សព័ន្ធសម្ងាត់ទាំងនេះនៅក្នុងចំណោមពួកសាសន៍នីហ្វៃ ។ សូមពន្យល់ថា **អារក្សទាក់ទាញមនុស្សឲ្យចូលទៅក្នុងបក្សព័ន្ធសម្ងាត់តាមគ្រប់**

រៀប ដើម្បីបំផ្លាញភាពសុចរិត និងបង្កើននូវអំពើទុច្ចរិត ។ សូមជួយសិស្សឲ្យយល់ថា រៀប និងការជម្រុញរបស់ពួកបក្សព័ន្ធសម្ងាត់ជាញឹកញាប់មិនអាចមើលឃើញទេ ហើយជានិច្চកាលវាមិនងាយនឹងការពារនោះទេ ។ សូមលើកទឹកចិត្តសិស្សឲ្យចៀសចេញពីទំនាក់ទំនងជាមួយនឹងក្រុម ឬបុគ្គលណាដែលចូលរួមនឹងបក្សព័ន្ធសម្ងាត់ ទោះតាមទំរង់ណាក្តី ។

នីហ្វៃទី៣ ៧:១៥–២៦

អំឡុងពេលដែលមានតែមនុស្សមួយចំនួនស្មោះត្រង់ នីហ្វៃបន្តបម្រើ ហើយអ្នកខ្លះបានប្រែចិត្តជឿ ។

- តើអ្នកគិតថា អ្នកនឹងមានអារម្មណ៍យ៉ាងណា ប្រសិនបើអ្នកបានរស់នៅក្នុងចំណោមប្រជាជននីហ្វៃ ក្រោយពេលរដ្ឋាភិបាលត្រូវបានគេផ្ទួលរំលោះ ? ហេតុអ្វី ?
- តើអ្នកគិតថា អ្នកនឹងបែរទៅរកការដឹកនាំ និង ការបង្ហាញផ្លូវពីទីណាវិញទៅ ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី នីហ្វៃទី ៣ ៧:១៥–២០ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលមូលហេតុដែលពួកគេអាចចង់ធ្វើតាមនីហ្វៃនៅក្នុងកាលៈទេសៈបែបនេះ ។ សូមគិតពីការឲ្យសិស្សឈប់បន្តិច បន្ទាប់ពីអានខនីមួយៗ ឬឈប់រាល់ពីរខគម្តីម្តង ដើម្បី អ្នកអាចសុំឲ្យសិស្សពន្យល់ពីមូលហេតុដែលពួកគេអាចត្រូវបានបំផុសគំនិតក្នុងការធ្វើតាមនីហ្វៃ ។

- តើអ្វីជាសារលិខិតរបស់នីហ្វៃទៅដល់ប្រជាជននៅពេលនេះ ? (សូមមើល នីហ្វៃទី៣ ៧:១៦) ។
- តើអ្នកដឹកនាំសាសនាចក្រសព្វថ្ងៃនេះដូចជានីហ្វៃដោយរបៀបណា ?
- តើនៅពេលណាដែលអ្នកបានឃើញអ្នកដឹកនាំសាសនាចក្រម្នាក់ « បម្រើដោយអានុភាព និងសិទ្ធិអំណាចដ៏ធំ » ? (នីហ្វៃទី ៣ ៧:១៧) ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ៧:២១–២៦ ដោយស្ងាត់ស្ងៀម ហើយរកមើលរបៀបនៃអស់អ្នកដែលបានប្រែចិត្តត្រូវបានប្រទានពរដោយសារការធ្វើតាមនីហ្វៃ និងការប្រែចិត្តពីអំពើបាបរបស់គេ ។ សូមឲ្យសិស្សបីបួននាក់ពន្យល់ពីអ្វីដែលពួកគេបានរកឃើញ ។

- តើគោលការណ៍អ្វីដែលយើងអាចរៀនពីគំរូនៃអស់អ្នកដែលបានប្រែចិត្ត ហើយធ្វើតាមនីហ្វៃ ?

សិស្សអាចចែកចាយសេចក្តីពិតជាច្រើន ប៉ុន្តែពួកគេគួររកឃើញនូវគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងប្រែចិត្ត ហើយធ្វើតាមអ្នកបម្រើរបស់ព្រះអម្ចាស់ នោះយើងនឹងទទួលបានការតាមថែរក្សាពីព្រះវិញ្ញាណបរិសុទ្ធ ។**

- ហេតុអ្វីបានជាការប្រែចិត្តមានសារៈសំខាន់ដើម្បីឲ្យយើងមានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយនឹងយើង ?
- តើអ្នកគិតថា ហេតុអ្វីបានជាការធ្វើតាមអ្នកបម្រើរបស់ព្រះអម្ចាស់ជួយយើងឲ្យកាន់តែទទួលបាន ការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ដៃមស៍ អឹ ហ្វោស្ត នៃគណៈប្រធានទីមួយ ៖

« ខ្ញុំបានបញ្ជាក់ថា ការដឹកនាំនៃព្រះវិញ្ញាណនៅក្នុងទំហំដ៏ធំ អាស្រ័យលើការមានភាពសុខដុមជាមួយនឹងប្រធាននៃសាសនាចក្រ គណៈប្រធានទីមួយ និងក្រុមនៃពួកដប់ពីរនាក់— អ្នកទាំងឡាយណាដែលត្រូវបានតែងតាំង . . . ជាព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈ ។ ខ្ញុំមិនដឹងថា យើងអាចនឹងរំពឹងថាមានភាពសុខដុមពេញលេញជាមួយនឹងព្រះវិញ្ញាណនៃព្រះអម្ចាស់បានដោយរបៀបណាទេ ប្រសិនបើយើងមិនចុះសម្រុងនឹងប្រធាននៃសាសនាចក្រ និងព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈផ្សេងទៀតផងនោះ » (« Called and Chosen » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ៥៣) ។

- តើនៅពេលណាដែលអ្នកមានអារម្មណ៍ពីព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ដោយសារអ្នកបានជ្រើសរើសគោរពតាមអ្នកបម្រើរបស់ព្រះអម្ចាស់នោះ ?

សូមលើកទឹកចិត្តសិស្សឲ្យសរសេរពីអារម្មណ៍ដែលពួកគេមានអំពីអ្វីដែលពួកគេអាចធ្វើ ដើម្បីអនុវត្តសេចក្តីពិតដែលពួកគេបានរៀននៅថ្ងៃនេះ ។ សូមបញ្ជាក់ថា ទោះបីជានៅពេលអ្នកដទៃជ្រើសរើសរស់នៅជុំយនឹងព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ក្តី ដូចជាក្នុងករណីនៃប្រជាជននីហ្វៃ ក៏យើងអាចជ្រើសរើសធ្វើតាមព្រះ និងអ្នកបម្រើដែលទ្រង់បានជ្រើសរើសដោយរាបសាបានដែរ ។

នីហ្វៃទី៣ ៨–១០

សេចក្តីផ្តើម

សាមសិបបីឆ្នាំក្រោយពីការឃើញទីសម្គាល់នៃការប្រសូតរបស់ព្រះអង្គសង្គ្រោះ ពួកសាសន៍នីហ្វៃបានចាប់ផ្តើមរកមើលទីសម្គាល់ដែលព្យាការីសាំយូអែល ជាសាសន៍លេមិន បានព្យាករពីការសុគតរបស់ព្រះអង្គសង្គ្រោះ ។ ទោះបីជាមានទីសម្គាល់ជាច្រើនត្រូវបានផ្តល់ឲ្យក្តី ក៏ការសង្ស័យ និងការជំទាស់នៅតែកើតមាននៅក្នុងចំណោមប្រជាជនដែរ ។ នៅឆ្នាំបន្ទាប់ការព្យាករណ៍របស់លោកសាំយូអែលត្រូវបានបំពេញ ។ ក្រោយពីមានព្យុះ ការរញ្ជួយដី និងវិបត្តិភ័យផ្សេងទៀតដ៏ធំ ដែលបណ្តាលឲ្យមានការរីករាលដាលនៃការបំផ្លិចបំផ្លាញ នោះភាពងងឹតបានគ្របដណ្តប់ផែនដីនោះអស់រយៈពេលបីថ្ងៃ ។ នៅក្នុងភាពងងឹតនោះ ប្រជាជនដែលនៅរស់ក្រោយពីការបំផ្លាញនោះបានឮសំឡេងរបស់ព្រះយេស៊ូវគ្រីស្ទ ។ ទ្រង់បានអញ្ជើញឲ្យពួកគេប្រែចិត្ត ហើយត្រឡប់មករកទ្រង់វិញ ។ នៅពេលភាពងងឹតបានសោត់បាត់ទៅ ការទួញយំរបស់ប្រជាជនបានប្រែក្លាយទៅជាសេចក្តីអំណរ និងការសរសើរដល់ព្រះយេស៊ូវគ្រីស្ទ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៣ ៨:១–១៨

ការបំផ្លិចបំផ្លាញដ៏ធំបង្ហាញពីទីសម្គាល់នៃការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ ដើម្បីបំពេញការព្យាករណ៍របស់ព្យាការីសាំយូអែល ជាសាសន៍លេមិន ។

សូមចាប់ផ្តើមបង្រៀនដោយការសួរសំណួរខាងក្រោមនេះ ៖

- តើអ្នកដឹងពីទីសម្គាល់នានាដែលបានកើតឡើងរួចហើយ ដោយបង្ហាញថាការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះនៅជិតបង្កើយដែរទេ ? (អ្នកអាចបង្ហាញថា ការព្យាករណ៍ជាច្រើន ដូចជាការស្តារឡើងវិញនៃដំណឹងល្អ ការមកដល់របស់ព្យាការីអេលីយ៉ា និងកាលដែលដំណឹងល្អត្រូវបានចែកចាយទូទៅពិភពលោក ត្រូវបានបំពេញ ឬកំពុងត្រូវបានបំពេញ) ។
- តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលអ្នកស្គាល់អ្វីមួយដែលជាសញ្ញាមួយយ៉ាងច្បាស់ថា ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះជិតមកដល់ហើយនោះ ?

សូមពន្យល់ថា យើងរស់នៅក្នុងជំនាន់មួយ ដែលស្រដៀងគ្នាទៅនឹងជំនាន់ ពីមុនព្រះយេស៊ូវគ្រីស្ទបានយាងមកជួបនឹងពួកសាសន៍នីហ្វៃដែរ ។ ដូចជាពួកសាសន៍នីហ្វៃដែលបានរកមើលទីសម្គាល់ដែលព្យាការីសាំយូអែល ជាសាសន៍លេមិនបានព្យាករណ៍ថាជាទីសម្គាល់នៃការសុគត និងការរស់ឡើងវិញនៃព្រះយេស៊ូវគ្រីស្ទ នោះយើងគួររកមើលទីសម្គាល់នៃការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះដែរ ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ៨:៣–៤ ដោយស្ងៀមស្ងាត់ ដោយរកមើលពីរបៀបខុសគ្នាដែលពួកសាសន៍នីហ្វៃខ្លះមានអារម្មណ៍អំពីទីសម្គាល់ទាំងឡាយ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ (ទោះបីជាប្រជាជនបានស្វែងរកទីសម្គាល់ « ដោយម៉ឺងម៉ាត់ » ក្តី ក៏ « ការសង្ស័យ និងការប្រកែកគ្នាយ៉ាងខ្លាំង » បានកើតមាននៅក្នុងចំណោមពួកគេដែរ) ។

- តើស្ថានភាពដែលបានរៀបរាប់នៅក្នុងនីហ្វៃទី ៣ ៨:៣–៤ ស្រដៀងគ្នាទៅនឹងលក្ខខណ្ឌនៅក្នុងពិភពលោកនាសព្វថ្ងៃនេះដោយរបៀបណា ?
- តើយើងអាចពង្រឹងសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទបានដោយរបៀបណា ទោះបីជានៅពេលមនុស្សជាច្រើនជុំវិញយើងមានភាពសង្ស័យក្តី ?

សូមសួរសិស្សថា តើពួកគេធ្លាប់ជួបព្យុះ ការរញ្ជួយដី មួយដ៏សាហាវ ឬគ្រោះមហន្តរាយផ្សេងទៀតដែរឬទេ ។ នៅពេលសិស្សឆ្លើយ សូមឲ្យពួកគេចែកចាយពីអារម្មណ៍ដែលពួកគេមានអំឡុងពេលនោះ និងក្រោយពេលជួបនឹងបទពិសោធន៍នោះ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ៨:៥–៧ ឮ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលបានកើតឡើងនៅក្នុងឆ្នាំទី ៣៤ ក្រោយពីការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ។ បន្ទាប់មកសូមឲ្យសិស្សអាន នីហ្វៃទី ៣ ៨:៨–១៨ ដោយស្ងៀមស្ងាត់ ដោយរកមើលអ្វីដែលបានកើតឡើងដល់ប្រជាជននៅក្នុងទីក្រុង ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមរំឭកសិស្សថា សាំយូអែលជាសាសន៍លេមិនបានព្យាករណ៍ពីហេតុការណ៍ទាំងនេះ (សូមមើល ហេលេមិន ១៤:២០–២៧) ។ សូមបញ្ជាក់ថា **ពាក្យសម្តីរបស់ព្យាការីនឹងត្រូវបានបំពេញទាំងអស់** ហើយថា **ព្រះនឹងឲ្យពួកទុច្ចរិតទទួលខុសត្រូវចំពោះសកម្មភាពរបស់ពួកគេ ។**

នីហ្វៃទី ៣ ៨:១៩–២៥

ភាពងងឹតគ្របដណ្តប់ផែនដីអស់រយៈពេលបីថ្ងៃ

សូមពន្យល់ថា ក្រោយពីព្យុះ និងការរញ្ជួយផែនដីបានស្ងប់ នោះភាពងងឹតបានគ្របដណ្តប់មកលើផែនដីអស់រយៈពេលបីថ្ងៃ ។ សូមបិទភ្លើងនៅក្នុងថ្នាក់មួយភ្លែត ។ បន្ទាប់មក សូមសួរសិស្សថាតើពួកគេធ្លាប់នៅកន្លែងមួយដែលមានភាពងងឹតទាំងស្រុង ដូចជានៅក្នុងរូងភ្នំ ឬបន្ទប់ដែលគ្មានបង្អួចដែរទេ ។

- តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលអ្នកស្ថិតនៅក្នុងកន្លែងបែបនោះ ?

សូមបង្ហាញថា ភាពងងឹតដែលបានគ្របដណ្តប់មកលើដែនដីអស់រយៈពេលបីថ្ងៃខុសគ្នាពីភាពងងឹតដែលបានកើតឡើង នៅពេលយើងបិទភ្លើង ឬទៅកន្លែងមួយដែលគ្មានបង្អួច ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ៨:១៩–២៣ ដោយស្ងៀមស្ងាត់ ដោយរកមើលឃ្លាដែលរៀបរាប់ពីភាពងងឹតដែលពួកសាសន៍នីហ្វៃបានជួប ។ (ចម្លើយអាចរួមមាន « ភាពងងឹតយ៉ាងក្រាស់» « ចំហាយនៃសេចក្តីងងឹត» « អ័ព្ទនៃសេចក្តីងងឹត » និង « គ្មានពន្លឺ ») ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣៨:២៣–២៥ ដោយស្ងៀមស្ងាត់ ដោយរកមើលឥទ្ធិពលនៃភាពងងឹតមានលើពួកសាសន៍នីហ្វៃ ដែលបានរស់ពីការបំផ្លាញនោះ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

នីហ្វៃទី ៣ ៩:១–១៤

នៅក្នុងភាពងងឹត ព្រះយេស៊ូវគ្រីស្ទអញ្ជើញឲ្យអស់អ្នកដែលបានរស់ពីសេចក្តីបំផ្លិចបំផ្លាញនោះឲ្យប្រែចិត្ត ហើយមកកាន់ទ្រង់

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖សូមឲ្យសិស្សអាន នីហ្វៃទី ៣ ៩:១–១២ ដោយស្ងៀមស្ងាត់ ដោយរកមើលចម្លើយចំពោះសំណួរទាំងនេះ ។

ហេតុអ្វីបានជាការបំផ្លាញនេះបានកើតឡើង ?

តើសាតាំងមានប្រតិកម្មយ៉ាងណាចំពោះសេចក្តីបំផ្លិចបំផ្លាញនេះ ?

តើការណ៍នេះបង្រៀនអំពីសាតាំង និងរបៀបដែលវាប្រព្រឹត្តនឹងអ្នកដែលដើរតាមវាយ៉ាងណាខ្លះ ?

សូមអាន នីហ្វៃទី ៣ ៩:១៣–១៤ ឮៗដល់សិស្សក្នុងថ្នាក់ ។ សូមឲ្យសិស្សមើលតាម ដោយរកមើលការអញ្ជើញរបស់ព្រះអង្គសង្គ្រោះចំពោះអស់អ្នកទាំងឡាយណាដែលបានរស់ពីសេចក្តីបំផ្លិចបំផ្លាញ ។ សូមឲ្យសិស្សស្រមៃពីសាសន៍នីហ្វៃទាំងនោះ ដែលស្តាប់សំឡេងរបស់ព្រះអង្គសង្គ្រោះនៅក្នុងភាពងងឹតទាំងស្រុង ។ ពួកគេបាន « នៅរស់ដោយសារ ! ពួកគេ ! សុចរិតជាង » អ្នកដែលត្រូវបានបំផ្លាញ ប៉ុន្តែពួកគេនៅតែត្រូវប្រែចិត្ត និងផ្លាស់ប្តូរ (សូមមើល នីហ្វៃទី ៣ ៩:១៣, ១០:១២) ។

- តើអ្នកគិតថា សាសន៍នីហ្វៃមានអារម្មណ៍យ៉ាងណា នៅពេលពួកគេបានឮការអញ្ជើញនេះពីព្រះអង្គសង្គ្រោះ ? ហេតុអ្វី ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ស៊ី ស្កុត ប្រ្វូ នៃពួកចិតសិបនាក់ ៖

« ព្រះយេស៊ូវគ្រីស្ទគឺជាអ្នកព្យាបាលដ៏អស្ចារ្យនៃព្រលឹងរបស់យើង ។ . . .

« នៅពេលយើងធ្វើអំពើបាប សាតាំងប្រាប់យើងថា យើងវង្វេងហើយ ។ ផ្ទុយទៅវិញ ព្រះដ៏ប្រោសលោះរបស់យើងផ្តល់សេចក្តីប្រោសលោះដល់មនុស្សទាំងអស់— មិនថាអ្វីដែលយើងបានធ្វើខុសនោះទេ— សូម្បីតែអ្នក និងខ្ញុំ » (« The Miracle of the Atonement » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១១ ទំព័រ ១០៩) ។

សូមបញ្ជាក់ថា ការអញ្ជើញរបស់ព្រះអង្គសង្គ្រោះនៅក្នុង នីហ្វៃទី ៣ ៩:១៣— ឲ្យមកកាន់ទ្រង់ ហើយទទួលការប្រោស —ត្រូវបានប្រគល់ដល់យើងម្នាក់ៗ ។ ដើម្បីឲ្យព្រះអង្គសង្គ្រោះប្រោសយើង យើងត្រូវទទួលយកការអញ្ជើញរបស់ទ្រង់ឲ្យមកកាន់ទ្រង់ ប្រែចិត្តចេញពីអំពើបាបរបស់យើង ហើយប្រែចិត្តជឿ ។ សូមឲ្យសិស្សគិតអំពីផ្នែកនៃជីវិតរបស់គេ ដែលពួកគេត្រូវការការប្រោសរបស់ព្រះអង្គសង្គ្រោះ ។ បន្ទាប់មក សូមឲ្យពួកគេឆ្លើយនឹង សំណួរ ខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ ក្នុងសៀវភៅសរសេរ ៖

- តើអ្នកត្រូវធ្វើអ្វីខ្លះ ដើម្បីឲ្យអ្នកអាចទទួលបានការប្រោសពីព្រះអង្គសង្គ្រោះនៅក្នុងជីវិតរបស់អ្នក ?

សំណួរផ្ទាល់ខ្លួន

សំណួរផ្ទាល់ខ្លួនអាចជួយសិស្សឲ្យអនុវត្តន៍សេចក្តីពិតនៃដំណឹងល្អបាន ។ ប៉ុន្តែ ដោយសារតែលក្ខណៈនៃសំណួរទាំងនេះ សិស្សអាចស្ទាក់ស្ទើរនឹងឆ្លើយវាផ្ទាល់មាត់ ។ ការសុំឲ្យសិស្សឆ្លើយនឹងសំណួរផ្ទាល់ខ្លួនទាំងឡាយដោយការសរសេរ អនុញ្ញាតឲ្យពួកគេឆ្លើយដោយឯកជន ដែលអាចឆ្លើយដោយបើកចំហ និងស្មោះត្រង់ ។ ប៉ុន្តែ អ្នកគួរហាមពួកគេកុំឲ្យសរសេរអំពីបញ្ហាផ្ទាល់ខ្លួន ដូចជាអំពើបាបនានា អតីតកាល ឬការរំលងនានា ។

នីហ្វៃទី ៣ ៩:១៥–២២

ព្រះអង្គសង្គ្រោះប្រកាសថា តាមរយៈពលិកម្មរបស់ទ្រង់ នោះច្បាប់ម៉ូសេត្រូវបានបំពេញ ។

សូមអាន នីហ្វៃទី៣ ៩:១៩ ឮៗ ។សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលព្រះយេស៊ូវគ្រីស្ទបានមានបន្ទូលថាទ្រង់នឹងមិនទទួលពីពួកសាសន៍នីហ្វៃទៀតឡើយ ។ វាអាចចាំបាច់ដើម្បីរំឭកសិស្សថា ពួកសាសន៍នីហ្វៃកំពុងរស់នៅតាមច្បាប់ម៉ូសេនៅពេលនេះ ។ ជាផ្នែកនៃច្បាប់ម៉ូសេ ព្រះអម្ចាស់បានបញ្ជាឲ្យប្រជាជនរបស់ទ្រង់ថ្វាយយញ្ញបូជាសត្វជាប្រភេទ និងស្រមោលនៃការពលិដែលព្រះអង្គសង្គ្រោះនឹងធ្វើតាមរយៈដង្វាយធួនរបស់ទ្រង់ ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ៩:២០ ដោយស្ងៀមស្ងាត់ ដោយរកមើលអ្វីដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថាសាសន៍នីហ្វៃត្រូវថ្វាយអ្វីជាការបូជានាពេលនេះ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាក្នុងការថ្វាយការបូជានៃ « ការមានចិត្តសង្រេង និងវិញ្ញាណទន់ទាប » ?
- តើពរជ័យអ្វីខ្លះដែលព្រះអង្គសង្គ្រោះសន្យាដល់អស់អ្នកទាំងឡាយណាដែលមកកាន់ទ្រង់ដោយមានចិត្តសង្រេង និងវិញ្ញាណទន់ទាប ?

សូមពន្យល់ថាអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនរបៀបមួយដើម្បីគិតអំពីឃ្លា « ចិត្តសង្រេង » និង « វិញ្ញាណទន់ទាប » ។ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោម ដោយសុំឲ្យសិស្សស្តាប់រកនូវពាក្យសម្តីដែលអែលឌើរ គ្រីស្តូហ្វឺសិន បានប្រើដើម្បីជួយយើងឲ្យយល់ពីឃ្លាទាំងនេះ ៖

« អ្នកអាចថ្វាយដល់ព្រះអម្ចាស់នូវអំណោយនៃចិត្តសង្រេង ឬការប្រែចិត្ត និងវិញ្ញាណទន់ទាប ឬការគោរពតាម ។ ជាក់ស្តែង វាគឺជាអំណោយនៃខ្លួនអ្នក —អ្វីដែលជាអ្នក និងអ្វីដែលអ្នកនឹងក្លាយទៅជា ។

« តើមានអ្វីនៅក្នុងខ្លួនអ្នក ឬនៅក្នុងជីវិតរបស់អ្នកដែលមិនបរិសុទ្ធ ឬមិនស្អាតស្អំដែរទេ ? នៅពេលអ្នកចៀសចេញពីវា នោះគឺជាអំណោយដល់ព្រះអង្គសង្គ្រោះមួយ ។ តើមានទម្លាប់ល្អ ឬគុណភាពល្អដែលខ្វះនៅក្នុងជីវិតរបស់អ្នកទេ ? នៅពេលអ្នកទទួលយកវា ហើយធ្វើឲ្យវាក្លាយជាចរិតលក្ខណៈរបស់អ្នក អ្នកកំពុងតែថ្វាយដង្វាយដល់ព្រះអម្ចាស់ហើយ » (« When Thou Art Converted » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៤ ទំព័រ ១២) ។

- តើពាក្យអ្វីខ្លះដែលអែលឌើរ គ្រីស្តូហ្វឺសិនបានប្រើដើម្បីជួយយើងឲ្យយល់ពីឃ្លា « ដួងចិត្តសង្រេង » ? (ការប្រែចិត្ត) ។ តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីមានដួងចិត្តដែលប្រែចិត្ត ?
- តើពាក្យអ្វីខ្លះដែលអែលឌើរ គ្រីស្តូហ្វឺសិន បានប្រើដើម្បីជួយយើងឲ្យយល់ពីឃ្លា « វិញ្ញាណទន់ទាប » ? (ការគោរពប្រតិបត្តិ) ។ តើអ្នកនឹងរៀបរាប់នរណាម្នាក់ដែលមានវិញ្ញាណប្រកបដោយការគោរពតាមយ៉ាងណា ?

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ៩:២១–២២ ដោយស្ងៀមស្ងាត់ ដោយរកមើលការពិពណ៌នារបស់ព្រះអង្គសង្គ្រោះពីរបៀបដែលយើងគួរមកកាន់ទ្រង់ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមលើកឫបភាពក្មេងតូចមួយ ប្រហែលនរណាម្នាក់នៅក្នុងគ្រួសាររបស់អ្នក ។

- តើអ្នកស្រមៃថាក្មេងតូចនេះមកកាន់ព្រះអង្គសង្គ្រោះដោយរបៀបណា ? តើការណ៍នេះជួយអ្នកឲ្យយល់ពីរបៀបដែលយើងគួរមកកាន់ព្រះអង្គសង្គ្រោះដោយរបៀបណា ?

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖

ប្រសិនបើយើងមកកាន់ព្រះគ្រីស្ទដោយមានដួងចិត្តសង្រេង និងវិញ្ញាណទន់ទាបនោះ ទ្រង់នឹង . . .

សូមឲ្យសិស្សរំឭកនីហ្វៃទី ៣ ៩:១៣–១៥, ១៩–២២ ដើម្បីរកមើលវិធីដើម្បីបំពេញប្រយោគនៅលើក្តារខៀន ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ ចម្លើយអាចរួមមាន ទ្រង់នឹងប្រោសយើង (សូមមើល នីហ្វៃទី ៣ ៩:១៣) ប្រទានដល់យើងនូវជីវិតដ៏នៅអស់កល្បជានិច្ច (សូមមើល នីហ្វៃទី ៣ ៩:១៤) ហើយទទួលយកយើង (សូមមើល នីហ្វៃទី ៣ ៩:២២) ។ ក្រោយពីសិស្សបានឆ្លើយហើយ សូមបំពេញប្រយោគនៅលើក្តារខៀន ៖ ***ប្រសិនបើយើងមកកាន់ព្រះគ្រីស្ទដោយមានដួងចិត្តសង្រេង និងវិញ្ញាណទន់ទាបនោះ ទ្រង់នឹងទទួលយកយើង ព្រោះយើង ហើយប្រទានដល់យើងនូវជីវិតដ៏នៅអស់កល្បជានិច្ច ។***

នីហ្វៃទី ៣ ១០

ព្រះអម្ចាស់ផ្តល់នូវការប្រមូលរាស្ត្ររបស់ទ្រង់ ដូចជាមេមាន់ប្រមូលកូនរបស់វាដែរ ។

សូមសង្ខេប នីហ្វៃទី ៣ ១០:១–៣ ដោយពន្យល់ថា ក្រោយពីឮសំឡេងរបស់ព្រះអង្គសង្គ្រោះហើយ ប្រជាជនបានរំភើបជាខ្លាំងរហូតដល់ពួកគេស្ងប់ស្ងាត់អស់រយៈពេលជាច្រើនម៉ោង ។ បន្ទាប់មក ទ្រង់បានមានបន្ទូលម្តងទៀតទៅកាន់ប្រជាជន ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអាន នីហ្វៃទី ៣ ១០:៤–៦ ឮៗ។ សូមបង្ហាញថានៅក្នុងខគម្ពីរទាំងនេះ ព្រះអង្គសង្គ្រោះមានបន្ទូលអំពីរង្សីអ៊ីស្រាអែល រាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់ ។

- តើព្រះអង្គសង្គ្រោះប្រៀបដូចជាមេមាន់ដែលការពារកូនពីគ្រោះថ្នាក់ដោយរបៀបណា ? ហេតុអ្វីបានជាព្រះអង្គសង្គ្រោះមិនប្រមូលនិងការពាររង្សីអ៊ីស្រាអែលទាំងអស់ ? (ពួកគេមិនមកកាន់ទ្រង់) ។
- តើព្រះអង្គសង្គ្រោះបានសន្យាអ្វីខ្លះ ដល់អស់អ្នកទាំងឡាយណាដែលប្រែចិត្ត និងត្រឡប់មកកាន់ទ្រង់វិញ ? (ទ្រង់នឹងប្រមូលពួកគេដូចជាមេមាន់ប្រមូលកូនរបស់វា) ។

សូមឲ្យសិស្សឆ្លើយនឹងសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរ ។ (អ្នកអាចសរសេរសំណួរនេះនៅលើក្តារខៀន ឬអានវាយឺតៗដើម្បីឲ្យសិស្សអាចកត់ត្រាវាបាន) ។

- តើនៅពេលណាដែលអ្នកមានអារម្មណ៍ពីការអញ្ជើញរបស់ព្រះអង្គសង្គ្រោះ ឲ្យទទួលយកការថែទាំ និងការការពាររបស់ទ្រង់ ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១០:៩–១១ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលបានកើតឡើងក្រោយពេលដែលព្រះអង្គសង្គ្រោះបានមានបន្ទូលទៅកាន់ប្រជាជន ។ អ្នកអាចបញ្ចប់ដោយការថ្លែងទីបន្ទាល់ថា ព្រះអង្គសង្គ្រោះមានសេចក្តីមេត្តាករុណាដល់អស់អ្នកទាំងឡាយណាដែលមករកទ្រង់ដោយមានចិត្តសង្រេង និងវិញ្ញាណទន់ទាប ។ អ្នកក៏អាចពន្យល់ថានៅក្នុងមេរៀនបន្ទាប់ សិស្សនឹងពិភាក្សាពីការយាងមករបស់ព្រះអង្គសង្គ្រោះទៅជូបនឹងប្រជាជន និងរបៀបដែលទ្រង់ថ្លាល់បានបម្រើដល់ពួកគេម្នាក់ៗ ។

នីហ្វៃទី ៣ ១១:១–១៧

សេចក្តីផ្តើម

បន្ទាប់ពីសេចក្តីបំផ្លិចបំផ្លាញ និងភាពងងឹតបីថ្ងៃដែលជាសម្គាល់ពីការសុគតរបស់ព្រះអង្គសង្គ្រោះមក ពួកបុរស ស្ត្រី និងកូនក្មេងសាសន៍នីហ្វៃប្រហែល ២,៥០០ នាក់ ប្រមូលគ្នានៅជុំវិញព្រះវិហារនៅក្នុងដែនដីបរិបូរណ៍ (សូមមើល នីហ្វៃទី ៣ ១៧:២៥) ។ នៅពេលពួកគេនិយាយជាមួយនឹងគ្នា ពួកគេបានឮសំឡេងរបស់ព្រះវរបិតាសួគ៌ ដែលណែនាំព្រះរាជបុត្រារបស់ទ្រង់គឺ ព្រះយេស៊ូវគ្រីស្ទ ដែលពេលនោះបានលេចចេញមក ។ ព្រះយេស៊ូវគ្រីស្ទបានអញ្ជើញប្រជាជនឲ្យធ្វើជាសាក្សីផ្ទាល់ខ្លួនថា ទ្រង់ត្រូវគេធ្វើគតដើម្បីអំពើបាបនៃមនុស្សលោក ។ ពួកគេបានមកកាន់ទ្រង់ម្នាក់ម្តងៗ ហើយស្ទាបនូវស្នាមរបួសនៅលើអង្គទ្រង់ និងស្នាមដៃកគោលនៅលើព្រះហស្ត និងព្រះបាតរបស់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

ការពន្លឿនមេរៀន

ពន្លឿនមេរៀននីមួយៗ ដើម្បីឲ្យអ្នកមានពេលគ្រប់គ្រាន់លើចំណុចដ៏សំខាន់បំផុត ។ ឧទាហរណ៍ នៅចុងបញ្ចប់នៃមេរៀននេះ សិស្សនឹងមានឱកាសថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ។ ទោះបីជាផ្នែកផ្សេងទៀតនៃមេរៀនសំខាន់ក្តី ក៏ត្រូវប្រាកដថា ទុកពេលគ្រប់គ្រាន់ដើម្បីឲ្យសិស្សថ្លែងទីបន្ទាល់ដែរ ។

នីហ្វៃទី ៣ ១១:១–១៧

ពួកសាសន៍នីហ្វៃឮសំឡេងរបស់ព្រះវរបិតាប្រកាសពីការប្រោកដឡើងនូវព្រះរាជបុត្រារបស់ទ្រង់

នៅពេលសិស្សចូលមកក្នុងថ្នាក់ សូមចាក់តន្ត្រីដ៏ពិសិដ្ឋ ឬសន្និសីទទូទៅតិច ៗកំដរអារម្មណ៍ —ឮល្មមដែលអាចស្តាប់បានហើយ ។ សូមបិទសំឡេងនៅពេលដល់ពេលអធិស្ឋានបើក និងការចែកចាយគំនិតខាងវិញ្ញាណ ។ បន្ទាប់ពីការអធិស្ឋាន សូមសួរសិស្សថាតើពួកគេបានឮការចាក់នោះទេ ។ (ប្រសិនបើអ្នកមិនមានអ្វីសម្រាប់ធ្វើសកម្មភាពនេះទេ សូមគិតពីឲ្យសិស្សអាន នីហ្វៃទី៣ ១១ ដោយសំឡេងដ៏ស្រទន់នៅពេលសិស្សដើរចូលមកក្នុងថ្នាក់ ។ ប្រសិនបើអ្នកជ្រើសរើសជម្រើសនេះ វានឹងមានប្រសិទ្ធភាពប្រសិនបើអ្នកដាក់កិច្ចការមួយថ្ងៃមុន ប្រហែលឲ្យសិស្សម្នាក់ដែលជាទៀតទាត់មកលឿនជាងគេ) ។

- តើបុគ្គលម្នាក់ត្រូវតែធ្វើអ្វីដើម្បីឮ និងយល់ពីសំឡេងដ៏ស្រទន់នេះ ?
- តើអ្វីជាសារលិខិតនៃចម្រៀងនេះ (ឬសុន្ទរកថាសន្និសីទទូទៅ ឬ វគ្គព្រះគម្ពីរ) ដែលបានចាក់នៅពេលអ្នកចូលមកក្នុងថ្នាក់រៀនថ្ងៃនេះ ?
- តើវាងាយ ឬពិបាកដើម្បីឮ និងយល់ពីពាក្យសម្តី នៅពេលគ្រប់គ្នាដើរចូលមកក្នុងថ្នាក់ ? ហេតុអ្វី ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១១:១–៣ ឮ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលពួកសាសន៍នីហ្វៃពិបាកនឹងយល់ ។

- តើអ្វីជាសំឡេងដែលបានរៀបរាប់នៅក្នុង នីហ្វៃទី ៣ ១១:៣ ? (អ្នកអាចណែនាំថា សិស្សគួរគូសចំណាំការរៀបរាប់នៃសំឡេងនោះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។
- តើឥទ្ធិពលអ្វីដែលសំឡេងបានមានទៅលើអស់អ្នកណាដែលបានស្តាប់ឮ ?

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១១:៤–៧ ស្ងាត់ស្ងៀម ដោយរកមើលអ្វីដែលខុសគ្នាដែលពួកសាសន៍នីហ្វៃបានធ្វើដើម្បីអាចយល់ពីសំឡេងនោះ នៅពេលដែលពួកគេឮសំឡេងនោះជាលើកទីបីដែរ ។

- តើមានអ្វីខ្លះដែលពួកសាសន៍នីហ្វៃបានធ្វើខុសពីមុននៅលើកទីបីពេលពួកគេបានឮសំឡេងនោះ ?
- ដោយផ្អែកលើអ្វីដែលអ្នកបានអាននៅក្នុង នីហ្វៃទី ៣ ១១:៧ តើសំឡេងដែលប្រជាជនបានឮនោះជាសំឡេងរបស់អ្នកណា ? (ពួកគេបានឮសំឡេងរបស់ព្រះវរបិតាសួគ៌ ដែលបានណែនាំព្រះរាជបុត្រារបស់ទ្រង់គឺ ព្រះយេស៊ូវគ្រីស្ទ) ។

សូមគិតពីការសុំសិស្សឲ្យអាននៅក្នុង ហេលេមិន ៥:៣០ ដោយរកមើលការរៀបរាប់ផ្សេងទៀតនៃសំឡេងរបស់ព្រះអម្ចាស់ ។

- តើសំឡេងដែលពួកសាសន៍នីហ្វៃបានឮ ស្រដៀងទៅនឹងការបំផុសគំនិតដែលយើងទទួលបានពីព្រះវិញ្ញាណបរិសុទ្ធដោយរបៀបណា ? (ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាក្តី ក៏ពួកគេគួររកឃើញនូវសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលមកកាន់យើងជាញឹកញាប់តាមរយៈអារម្មណ៍របស់យើង**) ។
- ហេតុអ្វីបានជាវាមានសារៈសំខាន់ដើម្បីយកចិត្តទុកដាក់លើការបំផុសគំនិត ដែលយើងទទួលបានពីព្រះអម្ចាស់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ?

សូមឲ្យសិស្សចែកចាយបទពិសោធន៍ដែលពួកគេធ្លាប់មាន នៅពេលពួកគេបានទទួលអារម្មណ៍ពីការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធនៅក្នុងគំនិត ឬដួងចិត្តរបស់គេ ។ សូមឲ្យពួកគេរៀបរាប់ពីអារម្មណ៍ដែលពួកគេបានមាន ។ អ្នកក៏អាចចែកចាយពីបទពិសោធន៍ផ្ទាល់ខ្លួនដែរ ។

សូមឲ្យសិស្សអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ិយដ៍ ឃេ ផាកគី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់អំពីអ្វីដែលយើងត្រូវធ្វើដើម្បីស្តាប់តាម និងយល់ពីសំឡេងរបស់ព្រះអម្ចាស់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ៖

« ព្រះវិញ្ញាណមិនឲ្យយើងទទួលចំណាប់អារម្មណ៍ ដោយពាក្យស្រែកនោះទេ ។ ទ្រង់មិនដែលកន្ត្រាក់យើងដោយដៃធ្ងន់នោះទេ ។ ព្រះវិញ្ញាណខ្សឹប ។ ទ្រង់អង្អែលដោយថ្នមៗ ហើយតាមពិតប្រសិនបើយើងមិនយកចិត្តទុកដាក់នោះយើងមិនអាចទទួលអារម្មណ៍ពីទ្រង់សោះឡើយ ។

« ឃ្លះៗម្តង ព្រះវិញ្ញាណនឹងបញ្ជាក់ខ្លាំងល្មម ឬជាញឹកញាប់ល្មម ដើម្បីឲ្យយើងយកចិត្តទុកដាក់ ប៉ុន្តែតាមរយៈបទពិសោធន៍របស់ខ្ញុំ ភាគច្រើនប្រសិនបើយើងមិនគោរពស្តាប់តាមអារម្មណ៍ដ៏សុភាពរាបសាទេ ប្រសិនបើយើងមិនស្តាប់ដោយអារម្មណ៍ទាំងនោះទេ នោះព្រះវិញ្ញាណនឹងដកថយ ហើយរង់ចាំរហូតទាល់តែយើងស្វែងរក និងស្តាប់តាមទ្រង់តាមរបៀបរបស់យើង និងការបង្ហាញរបស់យើង » (« How Does the Spirit Speak to Us? » *New Era,* ខែ កុម្ភៈ ឆ្នាំ ២០១០, ទំព័រ ៣) ។

- តើគោលការណ៍អ្វីដែលយើងអាចរៀនពី នីហ្វៃទី ៣ ១១:១–៧ និងពីប្រធាន ជាកកី ? (សិស្សអាចផ្តល់ចម្លើយផ្សេងៗគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេរកឃើញនូវសេចក្តីពិតខាងក្រោម ៖ **នៅពេលយើងរៀនពីរបៀបដើម្បីស្តាប់តាមសំឡេងនៃព្រះអម្ចាស់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ នោះយើងនឹងអាចយល់ពីទំនាក់ទំនងដែលទ្រង់ប្រទានដល់យើងបាន**) ។
- តើអ្វីដែលជួយអ្នកឲ្យរៀបចំគំនិត និងដួងចិត្តរបស់អ្នក និងយល់ពីសំឡេងខ្សឹបនៃព្រះវិញ្ញាណបរិសុទ្ធ ?

នីហ្វៃទី ៣ ១១:៨–១៧

ព្រះយេស៊ូវគ្រីស្ទប្រោកដឡើងចំពោះពួកសាសន៍នីហ្វៃ ហើយអញ្ជើញពួកគេម្នាក់ម្តងៗឲ្យស្ទាបស្នាមរបួសនៅលើព្រះហស្ត ព្រះបាត និងព្រះកាយរបស់ទ្រង់

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១១:៨–៣ ឮ ។ សូមឲ្យសិស្សមើលតាម ហើយស្រមៃពីអ្វីដែលវាអាចមានសភាពដូចប្រសិនបើពួកគេស្ថិតនៅក្នុងចំណោមសាសន៍នីហ្វៃនាពេលនេះ ។ សូមបង្ហាញរូបភាពនៃព្រះយេស៊ូវកំពុងបង្រៀននៅអឌ្ឍគោលខាងលិច (លេខកូដ ៦២៣៨០; *កញ្ចប់រូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ |, លេខ ៨២) ហើយសូមសួរ ៖

- តើគំនិត និងអារម្មណ៍អ្វីដែលអ្នកគិតថា អ្នកនឹងមាន ប្រសិនបើអ្នកស្ថិតនៅក្នុងចំណោមពួកសាសន៍នីហ្វៃ នៅពេលព្រះអង្គសង្គ្រោះបានទៅជួបនឹងពួកគេ ?

សូមរំឭកសិស្សពីសេចក្តីងងឹត និងសេចក្តីបំផ្លិចបំផ្លាញដែលពួកសាសន៍នីហ្វៃបានជួបពីមុនពេលព្រះអង្គសង្គ្រោះបានបង្ហាញខ្លួន ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដៃហ្វ្រី អ័រ. ហូឡិន នៃក្លុំមនៃពួកសាវក ដប់ពីរនាក់អំពីសារៈសំខាន់នៃការបង្ហាញខ្លួនរបស់ព្រះអង្គសង្គ្រោះចំពោះពួកសាសន៍នីហ្វៃ ៖

« ការបង្ហាញខ្លួននោះ និងការប្រកាសនោះបង្កើតចំណុចប្រសព្វ ពេលដ៏សំខាន់ នៅក្នុងប្រវត្តិសាស្ត្រទាំងមូលនៃព្រះគម្ពីរមរមន ។ វាគឺជាការសម្តែង និងការបង្ហាញដែលត្រូវបានប្រាប់ និងបំផុសគំនិតទៅដល់ព្យាការីសាសន៍នីហ្វៃគ្រប់រូប រយៈពេលប្រាំមួយរយឆ្នាំមុន ដើម្បីកុំឲ្យនិយាយអ្វីអំពីពួកអយ្យកោសាសន៍អ៊ីស្រាអែល និងសាសន៍យ៉ារេឌរបស់ពួកគេក្នុងរយៈពេលរាប់ពាន់ឆ្នាំពីមុននោះ ។

« មនុស្សគ្រប់គ្នាបាននិយាយអំពីទ្រង់ ច្រៀងពីទ្រង់ យល់សុបិន្តអំពីទ្រង់ ហើយបានអធិស្ឋានសម្រាប់ការបង្ហាញខ្លួនរបស់ទ្រង់—ប៉ុន្តែទ្រង់ពិតជាបានមកមែន ។ ថ្ងៃនៃអស់ទាំងថ្ងៃ ! ព្រះដែលបង្វែរពេលយប់ដ៏ងងឹតរាល់យប់ទៅជាពន្លឺនៃពេលព្រឹក បានមកដល់ហើយ » (*Christ and the New Covenant:The Messianic Message of the Book of Mormon* | ឆ្នាំ ១៩៩៧ |, ទំព័រ ២៥០–៥១) ។

សូមពន្យល់ដល់សិស្សក្នុងថ្នាក់ថា ផ្នែកបន្ទាប់នៃមេរៀននេះគឺត្រូវបានរចនាឡើងដើម្បីឲ្យពួកគេសញ្ជឹងគិតអំពីការយាងមករបស់ព្រះអង្គសង្គ្រោះដោយខ្លួនគេ ។ មុនពេលចាប់ផ្តើមថ្នាក់ សូមរៀបចំការណែនាំ និងសំណួរខាងក្រោមជាក្រដាសសម្រាប់ចែកដល់សិស្សម្នាក់ៗ (ឬសរសេរវានៅលើក្តារខៀន ឬនៅលើបណ្តាប្រកាស) ។ សូមឲ្យពេលវេលាសិស្សគ្រប់គ្រាន់ដើម្បីអាន នីហ្វៃទី ៣ ១១:១១–១៧ និងធ្វើតាមសេចក្តីណែនាំ ដែលមាននៅលើក្រដាសនេះ ។ សូមលើកទឹកចិត្តពួកគេឲ្យសញ្ជឹងគិតដោយយកចិត្តទុកដាក់ពីអត្ថន័យនៃខគម្ពីរទាំងនេះ នៅពេលពួកគេសិក្សាវា ។

១. សូមអាន នីហ្វៃទី ៣ ១១:១១–១២ ដោយស្ងាត់ស្ងៀម ។ សូមរកមើលអ្វីដែលព្រះយេស៊ូវគ្រីស្ទចង់ឲ្យប្រជាជនដឹងអំពីទ្រង់ និងអំពីអ្វីដែលទ្រង់បានធ្វើអំឡុងពេលធ្វើការបម្រើខាងសាច់ឈាមរបស់ទ្រង់ ។ សូមសញ្ជឹងគិតនូវសំណួរដូចខាងក្រោម ៖

- តើការមានបន្ទូលរបស់ព្រះអង្គសង្គ្រោះនៅក្នុង នីហ្វៃទី ៣ ១១:១១ មួយណាដែលមានន័យបំផុតដល់អ្នក ? ហេតុអ្វី ?
- តើព្រះអង្គសង្គ្រោះចង់មានន័យយ៉ាងណា នៅពេលទ្រង់បានមានបន្ទូលថា « យើងបានដឹកនូវពែងល្វីងដែលព្រះវរបិតាបានប្រគល់ដល់យើង » ? ហេតុអ្វីបានជាវាមានសារៈសំខាន់ដើម្បីដឹងថា ព្រះយេស៊ូវគ្រីស្ទតែងតែរាបសាគោរពតាមព្រះឆន្ទៈរបស់ព្រះវរបិតាសួគ៌ជានិច្ច ?

២. សូមអាន នីហ្វៃទី ៣ ១១:១៣–១៥ ហើយសញ្ជឹងគិតពីសំណួរខាងក្រោម ៖

- តើព្រះអង្គសង្គ្រោះបានអញ្ជើញសាសន៍នីហ្វៃឲ្យធ្វើអ្វី ? តើទ្រង់ចង់ឲ្យពួកគេដឹងអ្វី ដែលជាលទ្ធផលនៃបទពិសោធន៍នេះ ?
- ប្រជាជនបានទៅរកព្រះអង្គសង្គ្រោះ « ម្តងម្នាក់ៗរហូតដល់ទាំងអស់គ្នាបានទៅ » (នីហ្វៃទី ៣ ១១:១៥) ។ សូមគិតថា មានប្រជាជនប្រហែល ២៥០០ នាក់នៅក្នុងហ្វូងមនុស្សនោះ (សូមមើល នីហ្វៃទី ៣ ១៧:២៥) តើការណ៍នេះបង្រៀនអ្នកអំពីអារម្មណ៍របស់ព្រះអង្គសង្គ្រោះចំពោះយើងម្នាក់ៗដោយរបៀបណា ?

៣. សូមឲ្យសិស្សឆ្លើយនឹងសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរ ។

- តើអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់ចង់ឲ្យប្រជាជនឃើញ និងពាល់ទ្រង់ « ម្នាក់ម្តង់ ៗ » ?
- តើអ្នកគិតថា វានឹងប៉ះពាល់ដល់អ្នកយ៉ាងណា ដើម្បីអាចពាល់របូសដែលព្រះអង្គសង្ក្រោះបានទទួល ខណៈពេលដែលធ្វើដង្វាយធួនសម្រាប់អំពើបាបរបស់អ្នក ?

៤. សូមគិតពីការសរសេរនូវសេចក្តីពិតខាងក្រោមនៅចំហៀងនៃព្រះគម្ពីររបស់អ្នកក្បែរ នីហ្វៃទី ៣ ១១:១១–១៥ ។ **ព្រះយេស៊ូវគ្រីស្ទអញ្ជើញខ្ញុំឲ្យទទួលនូវទីបន្ទាល់ផ្ទាល់ខ្លួនមួយថា ទ្រង់គឺជាព្រះអង្គសង្ក្រោះរបស់ខ្ញុំ ។** សូមឆ្លើយនឹងសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរ ។

- តើបទពិសោធន៍អ្វីដែលបានដឹកនាំអ្នកឲ្យទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនរបស់អ្នកថា ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គសង្ក្រោះរបស់អ្នក ?
- តើអ្នកគិតថា ព្រះអង្គសង្ក្រោះនឹងចង់ឲ្យអ្នកធ្វើអ្វីដើម្បីពង្រឹងទីបន្ទាល់របស់អ្នកអំពីទ្រង់ ?
- តើនៅពេលណាដែលអ្នកបានមានអារម្មណ៍ថា ព្រះអង្គសង្ក្រោះដឹងពីអ្នក ហើយបានប្រទានពរដល់អ្នករៀង ៗខ្លួន ?

ក្រោយពីសិស្សបានមានពេលគ្រប់គ្រាន់ដើម្បីបញ្ចប់សកម្មភាពនេះហើយ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១១:១៦–១៧ ឲ ៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលប្រជាជនបានធ្វើ ក្រោយពីពួកគេបានទទួលបទពិសោធន៍ផ្ទាល់ខ្លួនជាមួយនឹងព្រះអង្គសង្ក្រោះនេះហើយ ។ អ្នកអាចពន្យល់ថា *ហូសាណា* គឺជាពាក្យនៃភាសាហេព្រើរដែលមានន័យថា « សង្ក្រោះហើយ » ឬ « សូមសង្ក្រោះយើង » ហើយត្រូវបានប្រើពេញទាំងព្រះគម្ពីរជាសម្រែកនៃការសរសើរ និងពាក្យសូមអង្វរ (សូមមើល Bible Dictionary, “Hosanna”; Guide to the Scriptures, “Hosanna,” scriptures.lds.org) ។

- តើអ្នកគិតថា ហេតុអ្វីបានជាប្រជាជនបានស្រែក « ហូសាណា » ក្រោយពីពួកគេបានជួបនឹងព្រះអង្គសង្ក្រោះហើយ ?

សូមឲ្យសិស្សពិនិត្យកាន់តែច្បាស់នៅក្នុង នីហ្វៃទី ៣ ១១:១៥ ។ សូមឲ្យពួកគេរកអ្វីដែលប្រជាជនបានធ្វើ ក្រោយពីពួកគេបានឃើញ និងបានពាល់ស្នាមរបូសរបស់ព្រះអង្គសង្ក្រោះហើយ ។ (ប្រជាជនបានកត់ត្រា ឬបានថ្លែងទីបន្ទាល់ថា ទ្រង់គឺជាព្រះយេស៊ូវគ្រីស្ទ) ។

- តើយើងចាំបាច់ឲ្យអាចមើលឃើញ និងពាល់ព្រះអង្គសង្ក្រោះដើម្បីដឹងថា ទ្រង់នៅរស់ឬ ? (សូមមើល ម៉ូណៃ ១០:៥) ។តើយើងអាច « កត់ត្រា » អំពីព្រះយេស៊ូវគ្រីស្ទបានដោយរបៀបណា ?
- តើយើងអាចប្រៀបធៀប នីហ្វៃទី ៣ ១១:១៥ ទៅនឹងខ្លួនយើងដោយរបៀបណា ? តើយើងម្នាក់ ៗត្រូវធ្វើអ្វីខ្លះ ក្រោយពីយើងទទួលបានទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទហើយ ? (**នៅពេលយើងទទួលបានទីបន្ទាល់ផ្ទាល់ខ្លួនអំពីព្រះយេស៊ូវគ្រីស្ទហើយ វាគឺជាការទទួលខុសត្រូវរបស់យើងដើម្បីថ្លែងអំពីទ្រង់**) ។

សូមបញ្ចប់ដោយការអញ្ជើញឲ្យសិស្សប្រាប់អំពីពេលដែលពួកគេបានចែកចាយទីបន្ទាល់របស់ពួកគេអំពីព្រះយេស៊ូវគ្រីស្ទជាមួយនឹងអ្នកដទៃ ។ បើមានពេល សូមឲ្យសិស្សទាំងអស់ណាដែលចង់ធ្វើដូច្នោះ ដើម្បីចែកចាយទីបន្ទាល់ខ្លីមួយអំពីព្រះអង្គសង្ក្រោះ ហើយប្រហែលសូមប្រាប់អ្វីដែលពួកគេត្រូវធ្វើដើម្បីទទួលបានទីបន្ទាល់របស់ពួកគេ ។ ប្រសិនបើមានពេល អ្នកក៏អាចសុំឲ្យពួកគេចែកចាយខ្លះ ៗពីអ្វីដែលពួកគេបានសរសេរ ឬមានអារម្មណ៍អំឡុងពេល ពួកគេសិក្សានីហ្វៃទី ៣ ១១ នាថ្ងៃនេះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ៣ ១១:៣ ។« សំឡេងតូច »

ប្រធាន ប៊ីយង៍ យេ ផាកកឺ នៃក្លុ៉ម៉ែនៃពួកសាវកដប់ពីរនាក់បានពន្យល់ពីរបៀបដែលសំឡេងនៃព្រះវិញ្ញាណបរិសុទ្ធប្រតិបត្តិការនៅក្នុងគំនិត និងដួងចិត្តរបស់យើង ៖

« សំឡេងនៃព្រះវិញ្ញាណបំផុសតាម *អារម្មណ៍* ជាជាងតាមសំឡេង ។ អ្នកនឹងរៀន ដូចជាខ្ញុំបានរៀន ដើម្បី « ស្តាប់រក » សំឡេងនោះដែល*ទទួលជាអារម្មណ៍* ជាជាង*ស្តាប់ឲ្ម* ។ . . .

« បើអ្នកយល់ស្រប អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធនឹងដឹកនាំ ហើយការពារអ្នក និងថែមទាំងកែតម្រូវទង្វើទាំងឡាយរបស់អ្នក ។វាជាសំឡេងខាងវិញ្ញាណដែលមកក្នុងដួងចិត្តជាគំនិត ឬជាអាម្មរណ៍ដែលជាក់ក្នុងដួងចិត្តរបស់អ្នក ។ . . .

« វាមិនត្រូវបានរំពឹងថា អ្នកនឹងត្រូវឆ្លងកាត់ជីវិតដោយគ្មានកំហុសនោះទេ ប៉ុន្តែអ្នកនឹងមិនធ្វើកំហុសធំៗដោយមិនត្រូវបានព្រមានជាមុនដោយការបំផុសពីព្រះវិញ្ញាណនោះឡើយ » (« Counsel to Youth » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ១៧–១៨) ។

មេរៀនសិក្សានៅផ្ទះ

នីហ្វៃទី ៣ ១–១១:១៧ (មេរៀនទី ២៤)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេសិក្សា នីហ្វៃទី ៣ ១–១១:១៧ (មេរៀនទី ២៤) មិនមែនសម្រាប់បង្រៀនក្នុងផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (នីហ្វៃទី ៣ ១)

នៅពេលសិស្សបានសិក្សាអំពីការបំពេញនៃការព្យាករណ៍របស់ព្យាការីសាំយូអែល ជាសាសន៍លេមិន ដែលព្យាករណ៍ពីការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ពួកគេបានរៀនថា ព្រះអម្ចាស់នឹងបំពេញតាមពាក្យទាំងឡាយដែលទ្រង់បានបណ្តាលឲ្យព្យាការីទាំងឡាយរបស់ទ្រង់បានប្រសាសន៍ ។ ចេញពីគំរូនៃអស់អ្នកទាំងឡាយណាដែលស្មោះត្រង់ ទោះបីជានៅពេលពួកអ្នកមិនជឿបានគ្រោងនឹងបំផ្លាញពួកគេក្តី នោះសិស្សបានរៀនថា នៅពេលយើងប្រឈមមុខនឹងការកុហករបស់សាតាំង យើងអាចជ្រើសរើសដើម្បីជឿតាមព្រះយេស៊ូវគ្រីស្ទ និងនៅតែបន្តស្មោះត្រង់ ។ ការបះបោរនៃពួកយុវជនសាសន៍លេមិនខ្លះបានបង្ហាញដល់សិស្សថា ប្រសិនបើយើងចុះចាញ់នឹងការល្បួង នោះគំរូរបស់យើងអាចមានឥទ្ធិពលអវិជ្ជមានលើសេចក្តីជំនឿ និងភាពសុចរិតរបស់អ្នកដទៃបាន ។

ថ្ងៃទី ២ (នីហ្វៃទី ៣ ២–៥)

ខណៈពេលដែលកំពុងសិក្សាពីការធ្លាក់ចុះនៃភាពសុចរិតរបស់ប្រជាជន នោះសិស្សបានសង្កេតឃើញថា ប្រសិនបើយើងភ្លេចពីបទពិសោធន៍ខាងវិញ្ញាណពីមុនៗ នោះយើងនឹងងាយរងការល្បួង និងការបោកបញ្ឆោតរបស់សាតាំងជាងពេលមុន ។ នៅពេលពួកគេបានវិភាគពីសំបុត្របោកបញ្ឆោតរបស់គីឌឌីអានហៃទៅកាន់ឡាកូនីអូស សិស្សបានរកឃើញពីរបៀបដែលសាតាំង និងពួកបរិវាររបស់វា ជារឿយៗប្រើនូវពាក្យបញ្ឆោរការសន្យាក្លែងក្លាយ និងការគំរាមកំហែងដើម្បីដឹកនាំប្រជាជនឲ្យវង្វេង ។ សិស្សបានរៀនពីពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន ដែលបានការពារខ្លួនពួកគេដោយជោគជ័យប្រឆាំងនឹងពួកចោរកាឌីអានតុន ថានៅពេលពួកយើងរៀបចំខ្លួនយើងខាងវិញ្ញាណ និងខាងសាច់ឈាមជាស្រេច នោះព្រះអម្ចាស់នឹងពង្រឹងយើងឲ្យយកឈ្នះលើឧបសគ្គទាំងឡាយ ។ នៅពេលសិស្សបានអានអំពីការសរសើររបស់ពួកសាសន៍នីហ្វៃទៅដល់ព្រះអម្ចាស់ចំពោះការរំដោះពួកគេ នោះសិស្សបានរៀនថា ការទទួលស្គាល់សេចក្តីល្អ និងសេចក្តីមេត្តាករុណារបស់ព្រះនៅក្នុងការដោះលែងយើងពីភាពលំបាកជួយយើងឲ្យនៅតែបន្តបន្ទាបខ្លួន ។ ការខិតខំប្រឹងប្រែងរបស់ពួកសាសន៍នីហ្វៃក្នុងការចែកចាយដំណឹងល្អ និងការប្រកាសរបស់លោកមរមនអំពីកាតព្វកិច្ចរបស់លោកបានបង្ហាញថា ក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងមានការទទួលខុសត្រូវមួយដើម្បីបង្រៀនដល់អ្នកដទៃពីផ្លូវទៅកាន់ជីវិតដ៏នៅអស់កល្បជានិច្ច ។

ថ្ងៃទី ៣ (នីហ្វៃទី ៣ ៦–១០)

នៅពេលសិស្សអានអំពីរបៀបដែលពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិនធ្លាក់ចុះទៅក្នុងភាពទុច្ចរិតម្តងទៀត នោះពួកគេបានរកឃើញថា នៅពេលយើងមានសេចក្តីផ្ទើងផ្ទៃ នោះយើងបណ្តោយឲ្យសាតាំងមានអំណាចដ៏ខ្លាំងក្នុងការល្បួងយើង និងនាំយើងឲ្យធ្វើអំពើបាបបន្ថែមទៀត ។ ប៉ុន្តែគំរូដ៏ស្មោះត្រង់នៃប្រជាជនខ្លះបានបង្ហាញថា យើងអាចជ្រើសរើសដើម្បីបន្ទាបខ្លួន និងស្មោះត្រង់ ទោះស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ។ ដូចជាការគ្រប់គ្រងនៃសាសន៍នីហ្វៃត្រូវបាន បានដោះស្រាយហើយ នោះអ្នកទាំងឡាយណាដែលបានដើរតាមនីហ្វៃបានបង្ហាញថា ប្រសិនបើយើងប្រែចិត្ត ហើយធ្វើតាមអ្នកបម្រើរបស់ព្រះអម្ចាស់ នោះយើងនឹងរីករាយនឹងឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់យើង ។ បន្ទាប់ពីសេចក្តីបំផ្លិចបំផ្លាញដ៏ខ្លាំងក្លា នោះប្រជាជនទូទាំងដែនដីបានស្គាប់ឲ្យសំឡេងរបស់ព្រះយេស៊ូវគ្រីស្ទដែលបានប្រកាសនៅក្នុងភាពងងឹតថា ប្រសិនបើយើងមកកាន់ទ្រង់ដោយមានចិត្តសង្រេង និងវិញ្ញាណទន់ទាប នោះទ្រង់នឹងព្យាបាលយើង ហើយប្រទានដល់យើងនូវជីវិតដ៏នៅអស់កល្បជានិច្ច ។

ថ្ងៃទី ៤ (នីហ្វៃទី ៣ ១១:១–១៧)

នៅពេលសិស្សបានសិក្សាពីការប្រកាសរបស់ព្រះវរបិតាអំពីព្រះយេស៊ូវគ្រីស្ទ នោះពួកគេបានឃើញថា ព្រះវិញ្ញាណបរិសុទ្ធជារឿយៗមានបន្ទូលមកកាន់យើងតាមរយៈអារម្មណ៍របស់យើង ។ ពួកគេក៏បានរៀនដែរថា នៅពេលយើងរៀនពីរបៀបដើម្បីស្តាប់តាមសំឡេងនៃព្រះអម្ចាស់តាមរយៈព្រះវិញ្ញាណបរិសុទ្ធ នោះយើងនឹងអាចយល់ពីទំនាក់ទំនងដែលទ្រង់ប្រទានដល់យើងបាន ។ ចេញពីដំណើររឿងរបស់ព្រះអង្គសង្គ្រោះដែលចាប់ផ្តើមពីការបម្រើរបស់ទ្រង់នៅក្នុងចំណោមពួកសាសន៍នីហ្វៃ នោះសិស្សបានរៀនថា ព្រះយេស៊ូវគ្រីស្ទអញ្ជើញយើងទាំងអស់គ្នាឲ្យទទួលបាននូវទីបន្ទាល់ផ្ទាល់ខ្លួនមួយថា ទ្រង់គឺជាព្រះអង្គសង្គ្រោះរបស់យើង ហើយថានៅពេលយើងទទួលបានទីបន្ទាល់នោះហើយ យើងមានទំនួលខុសត្រូវមួយក្នុងការថ្លែងអំពីទ្រង់ ។

សេចក្តីផ្តើម

សកម្មភាពសម្រាប់ នីហ្វៃទី ៣ ១–៧ នៅក្នុងមេរៀននេះសង្កត់ធ្ងន់លើគោលលទ្ធិ និងគោលការណ៍ខ្លះៗដែលអាចជួយសិស្សឲ្យយល់កាន់តែច្បាស់នូវអត្ថន័យនៃការប្រែចិត្តជឿដល់ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ សកម្មភាពក្នុងការបង្រៀននៅ នីហ្វៃទី ៣ ៨–១០ នឹងរៀបចំសិស្សឲ្យឆ្លុះបញ្ចាំងពីទីបន្ទាល់របស់ពួកគេអំពីព្រះអង្គសង្គ្រោះ នៅពេលពួកគេរៀនអំពីការយាងមករបស់ទ្រង់ទៅដល់កូនចៅរបស់លីហៃនៅក្នុង នីហ្វៃទី ៣ ១១ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី៣ ១–៧

ទីសម្គាល់ និងការអស្ចារ្យទាំងឡាយប្រកាសពីការប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ ប្រជាជនវិលជុំវវាងភាពសុចរិត និងភាពទុច្ចរិតរហូតដល់ការគ្រប់គ្រងត្រូវបានដួលរលំ

សូមគូសបន្ទាត់មួយដូចខាងក្រោមនៅលើក្តារខៀន ៖



សូមសួរ ៖ ដោយផ្អែកលើការសិក្សារបស់អ្នកនៅក្នុងសប្តាហ៍កន្លងទៅ តើបន្ទាត់នេះអាចតំណាងឲ្យពួកសាសន៍នីហ្វៃនៅក្នុង នីហ្វៃទី ៣ ១–៧ ដោយរបៀបណា ? (អ្នកអាចសុំឲ្យសិស្សរំឲ្យកពីសេចក្តីសង្ខេបក្បាលជំពូកក្នុង នីហ្វៃទី ៣ ១–៧ ដើម្បីជួយពួកគេចាំពីរបៀបដែលពួកសាសន៍នីហ្វៃប្រែប្រួលរវាងសេចក្តីសុចរិត និងអំពើទុច្ចរិតពីឆ្នាំទី ១ នៃ គ.ស. ដល់ឆ្នាំទី ៣៣ នៃ គ.ស.) ។

ដើម្បីជួយសិស្សឲ្យគិតអំពីអ្វីដែល នីហ្វៃទី ៣ ១–៧ អាចបង្រៀនយើងអំពីការធ្វើជាមនុស្សដែលប្រែចិត្តជឿយ៉ាងពិតប្រាកដលើព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ សូមឲ្យសិស្សម្នាក់អានឲ្យៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ម៉ារ៉ុន ជី រ៉មនី នៃគណៈប្រធានទីមួយ ។ (ប្រសិនបើអាច សូមចែកសំណៅចម្លងដល់សិស្សម្នាក់ៗ ហើយសូមឲ្យពួកគេគូសបន្ទាត់ពីក្រោមឃ្លា ឬពាក្យទាំងឡាយណាដែលពួកគេមានអារម្មណ៍ថា ពិពណ៌នាពីបុគ្គលដែលប្រែចិត្តជឿបានល្អបំផុត) ។

« ការប្រែចិត្តជឿគឺជាការផ្លាស់ប្តូរខាងវិញ្ញាណ និងខាងសាច់ឈាម ។ *ប្រែចិត្តជឿ* មិនត្រឹមតែបញ្ជាក់អត្ថន័យពីការទទួលយកព្រះយេស៊ូវ និងការបង្រៀនរបស់ទ្រង់ផ្នែកអារម្មណ៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាសេចក្តីជំនឿដែលលើកទឹកឲ្យមានចិត្តទៅលើទ្រង់ និងដំណឹងល្អរបស់ទ្រង់ ។ . . . នៅក្នុងបុគ្គលម្នាក់ដែលពិតជាបានប្រែចិត្តជឿទាំងស្រុងមែន នោះបំណងលើវត្ថុនានាដែលផ្ទុយទៅនឹងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទពិតជាបានបាត់បង់ទៅហើយ ។ ហេតុដូច្នេះហើយជំនួសមកវិញ វាគឺជាសេចក្តីស្រឡាញ់មួយដល់ព្រះ ដោយការប្តេជ្ញាចិត្តដ៏ម៉ឹងម៉ាត់ និងម៉ត់ចត់ក្នុង

ការកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ » (នៅក្នុងរបាយការណ៍សន្និសីទទូទៅ សន្និសីទប្រចាំតំបន់ប្រទេសក្វាតេម៉ាឡា ឆ្នាំ ១៩៧៧, ៨) ។

សូមសួរ ៖ តើឃ្លា ឬពាក្យអ្វីដែលអ្នកមានអារម្មណ៍ថាពិពណ៌នាបានល្អបំផុតអំពីបុគ្គលដែលបានប្រែចិត្តជឿ ?

សូមគូសតារាងខាងក្រោមនៅលើក្តារខៀន ឬរៀបចំជាក្រដាសចែកដល់សិស្ស ៖

	សេចក្តីជំនឿ និងទង្វើរដែលនាំទៅរកការប្រែចិត្ត	សេចក្តីជំនឿ និងទង្វើរដែលធ្វើឲ្យការប្រែចិត្តទន់ខ្សោយ
នីហ្វៃទី ៣ ១:១៥–២៣, ២៧–៣០		
នីហ្វៃទី ៣ ២:១–៣; ៣:១–១០		
នីហ្វៃទី ៣ ៤:៧–១២, ៣០–៣៣		
នីហ្វៃទី ៣ ៦:១៣–១៨; ៧:១–៥		
នីហ្វៃទី ៣ ៧:១៥–២២		

សូមដាក់វគ្គព្រះគម្ពីរមួយពីក្នុងតារាងដល់សិស្សម្នាក់ៗ ។ សូមឲ្យសមាជិកក្នុងថ្នាក់មានពេលស្រាវជ្រាវលើវគ្គកិច្ចការរបស់ពួកគេចំពោះសេចក្តីជំនឿ និងទង្វើរដែលអាចទាំងជឹកនាំ ឬធ្វើឲ្យការប្រែចិត្តមានភាពទន់ខ្សោយ ។ គោលការណ៍ជាច្រើនដែលសិស្សអាចរកឃើញដែលមាននៅក្នុងសេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃសម្រាប់ថ្ងៃទី ១–៣ នៅចំណុចចាប់ផ្តើមនៃមេរៀននេះ ។ នៅពេលសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញហើយ សូមសរសេរឆ្លើយរបស់គេនៅលើក្តារខៀន ឬលើកទឹកចិត្តពួកគេឲ្យសរសេរនៅលើក្រដាសរបស់ពួកគេ ។ សូមជួយសិស្សឲ្យអនុវត្តគោលការណ៍ទាំងឡាយដែលពួកគេបានរកឃើញដោយសួរសំណួរដូចខាងក្រោមដែលទាក់ទងទៅនឹងសេចក្តីពិតមួយ ឬពីរដែលសិស្សបានរកឃើញ ៖

- តើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់បានរស់នៅតាមសេចក្តីពិត ឬមានបទពិសោធន៍ពីគោលការណ៍នោះដោយរបៀបណា ?
- ផ្អែកលើសេចក្តីពិតដែលអ្នកបានរកឃើញ តើជំហ៊ានអ្វីដែលអ្នកនឹងផ្តល់ដល់នរណាម្នាក់ដើម្បីជួយគេឲ្យកាន់តែប្រែចិត្តជឿ ហើយនឹងនរខាងវិញ្ញាណថែមទៀត ?

នីហ្វៃទី ៣ ៨–១១:១៧

សេចក្តីបំផ្លិចបំផ្លាញដ៏ជំ និងភាពងងឹតបង្ហាញពីការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ ក្រោយពីការរស់ឡើងវិញរបស់ទ្រង់ ទ្រង់ទៅសួរដល់កូនចៅរបស់លីហៃ

សូមឲ្យសិស្សម្នាក់សង្ខេបហេតុការណ៍ទាំងឡាយនៅក្នុង នីហ្វៃទី៣)៨ ហើយចែកចាយដល់សិស្សក្នុងថ្នាក់ពីអារម្មណ៍ ឬ ចំណាប់អារម្មណ៍ដែលគេបានមាន ខណៈពេលដែលសិក្សាជំពូកនេះកាលពីសប្តាហ៍កន្លងទៅ ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ៨:២០–២៣ ។ សូមឲ្យសិស្សក្នុងថ្នាក់ពន្យល់ពីមូលហេតុដែលការរៀបរាប់នៃទីសម្គាល់ក្នុងខគម្ពីរទាំងនេះ គឺជាទីសម្គាល់ដ៏សមរម្យមួយដើម្បីបង្ហាញពីការសុគតរបស់ព្រះយេស៊ូវគ្រីស្ទ ។ ដើម្បីបញ្ជាក់ពីភាពងងឹតដែលពួកសាសន៍នីហ្វៃបានជួប អ្នកអាចប្រើនូវសកម្មភាពខាងក្រោមនេះ ៖

សូមចែកឲ្យសិស្សម្នាក់ៗនូវពិលមួយ ហើយបិទភ្លើងនៅក្នុងបន្ទប់ ។ (ប្រសិនបើអ្នកមិនមានពិលគ្រប់គ្រាន់ទេ សិស្សអាចចែកគ្នាប្រើ) ។ សូមឲ្យសិស្សចុចបើកពិល ហើយសូមឲ្យពួកគេពីរបីនាក់ប្តូរវេនគ្នាអានឮៗពី នីហ្វៃទី ៣ ៩:១៣–២០ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលសេចក្តីពិតដែលប្រជាជនបានរៀនអំពីព្រះយេស៊ូវគ្រីស្ទ នៅពេលដែលពួកគេជួបនឹងបទពិសោធន៍ក្នុងភាពងងឹតក្រោយពីការសុគតរបស់ទ្រង់ ។ ពេលបើកភ្លើងវិញ សូមសង្កេបលើក្តារខៀននូវសេចក្តីពិតដែលសិស្សបានរកឃើញ ។ សូមបញ្ជាក់នូវគោលការណ៍ខាងក្រោម ៖ **ព្រះយេស៊ូវគ្រីស្ទគឺជាពន្លឺ ហើយជាជីវិតនៃពិភពលោក ។ ប្រសិនបើយើងមកកាន់ព្រះគ្រីស្ទដោយមានដួងចិត្តសង្រេង និងវិញ្ញាណទន់ទាបនោះ ទ្រង់នឹងទទួលយកយើង ប្រោសយើង ហើយប្រទានដល់យើងនូវជីវិតដ៏នៅអស់កល្បជានិច្ច ។**

សូមសង្កេប នីហ្វៃទី ៣ ១១:១–៧ ដោយការពន្យល់ថា ប្រជាជនដែលបាននៅស់ពីសេចក្តីបំផ្លិចបំផ្លាញនោះបានប្រជុំគ្នានៅឯព្រះវិហារបរិសុទ្ធនៅក្នុងដែនដីបរិសុទ្ធ ។

សូមបង្ហាញរូបភាពព្រះយេស៊ូវកំពុងបង្រៀននៅឯអឌ្ឍគោលខាងលិច (៦២៣៨០; *កញ្ចប់រូបភាពដំណឹងល្អ* [ឆ្នាំ ២០០៩], លេខ ៨២) ឬ ព្រះយេស៊ូវព្យាបាលដល់ពួកសាសន៍នីហ្វៃ (*កញ្ចប់រូបភាពដំណឹងល្អ* លេខ ៨៣) ។ សូមឲ្យសិស្សមើល នីហ្វៃទី ៣ ១១:៨–១៧ នៅពេលអ្នកអានឲ្យពួកគេស្តាប់ ។ ពេលអានសូមឈប់ម្តងៗ ហើយសូមឲ្យសិស្សចែកចាយអារម្មណ៍ដែលពួកគេមាន នៅពេលពួកគេឃើញពីបទពិសោធន៍នេះដាពិសេសបទពិសោធន៍ « ម្តងម្នាក់ៗ » ដែលពួកសាសន៍នីហ្វៃបានមានជាមួយនឹងព្រះអង្គសង្គ្រោះ ដូចដែលបានរៀបរាប់នៅក្នុង នីហ្វៃទី ៣ ១១:១៥ ។

ក្រោយពីការអាន នីហ្វៃទី ៣ ១១:៨–១៧ ហើយ សូមសួរសំណួរខាងក្រោមដល់សិស្ស ។ សូមឲ្យពួកគេសញ្ជឹងគិតពីសំណួរដោយស្ងប់ស្ងាត់មួយសន្ទុះ មុននឹងពួកគេឆ្លើយ ។ (សូមប្រាកដថាអ្នកទុកពេលឲ្យសិស្សឆ្លើយនឹងសំណួរទាំងនេះគ្រប់គ្រាន់ដើម្បីកុំឲ្យពួកគេមានអារម្មណ៍ប្រញាប់នៅពេលពួកគេសញ្ជឹងគិត និងចែកចាយពីអារម្មណ៍ និងទីបន្ទាល់របស់ពួកគេ) ។

- ប្រសិនបើអ្នកស្ថិតនៅក្នុងចំណោមពួកសាសន៍នីហ្វៃ និងបានមានឱកាសដើម្បីស្ទាបស្ទាមរបួសរបស់ព្រះអង្គសង្គ្រោះ តើអ្នកចង់ទូលអ្វីទៅកាន់ទ្រង់ ?
- នៅពេលព្រះយេស៊ូវគ្រីស្ទបានបង្ហាញព្រះអង្គទ្រង់ដល់ពួកសាសន៍នីហ្វៃ តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដែលទ្រង់បានឲ្យពួកគេយកចិត្តទុកដាក់លើ « ពែងល្វីង » ? (នីហ្វៃទី ៣ ១១:១១) ។
- តើអ្វីទៅជា « ពែងល្វីង » ដែលព្រះយេស៊ូវគ្រីស្ទបានសំដៅលើ ? (សូមមើល គ. និង ស. ១៩:១៦–១៩ ។)

សូមចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះអង្គសង្គ្រោះ និងពន្លឺដែលទ្រង់បានមាននៅក្នុងជីវិតរបស់អ្នក នៅពេលអ្នកបានធ្វើតាមទ្រង់ ។ (អ្នកក៏អាចសុំឲ្យសិស្សចងចាំដល់អារម្មណ៍ដែលពួកគេបានមាន អំឡុងរៀនមេរៀននេះ និងកត់ត្រាវាទុកនៅក្នុងកំណត់ហេតុផ្ទាល់ខ្លួនរបស់ពួកគេនៅផ្ទះ) ។

មេរៀនបន្ទាប់ (នីហ្វៃទី ៣ ១១:១៨–១៦:២០)

សូមឲ្យសិស្សគិតពីសំណួរខាងក្រោម នៅពេលពួកគេសិក្សាមេរៀនបន្ទាប់ ៖ តើខ្ញុំចាត់ទុកនរណាម្នាក់ថាជាសត្រូវរបស់ខ្ញុំដែរឬទេ ? បើមាន តើខ្ញុំប្រព្រឹត្តនឹងមនុស្សនោះយ៉ាងណាដែរ ? តើគុណធម៌អ្វីដែលព្រះមានអារម្មណ៍ថាសំខាន់នៅក្នុងជីវិតរបស់ខ្ញុំ ? តើវាអាចទទួលយកបានទេក្នុងការកាត់សេចក្តីមនុស្សផ្សេងទៀតនោះ ? សិស្សអាចរកឃើញចម្លើយទៅនឹងសំណួរទាំងនេះ នៅពេលពួកគេសិក្សាពីព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះនៅក្នុងមេរៀនទី ២៥ ។

នីហ្វៃទី ៣ ១១:១៨–៤១

សេចក្តីផ្តើម

ក្រោយពីពួកសាសន៍នីហ្វៃបានចេញមក ហើយបានទៅស្ថាបស្នាមបួសនៅលើព្រះហស្ត ព្រះបាត និងព្រះកាយរបស់ព្រះអង្គសង្គ្រោះហើយ ព្រះអម្ចាស់បានឲ្យនីហ្វៃ និងអ្នកផ្សេងទៀតនូវអំណាចដើម្បីជ្រមុជទឹក និងសម្តែងគួនាទីបព្វជិតភាពផ្សេងទៀត ។

ព្រះអង្គសង្គ្រោះក៏បានព្រមានដល់ប្រជាជនឲ្យចៀសវាងការទាស់ទែងគ្នា ហើយបានសន្យាថា អស់អ្នកទាំងឡាយណាដែលរស់នៅតាមគោលលទ្ធិរបស់ទ្រង់ នឹងទទួលគ្រងមរតកនគរនៃព្រះ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៣ ១១:១៨–២៧

ព្រះយេស៊ូវគ្រីស្ទប្រគល់ដល់នីហ្វៃ និងអ្នកដទៃនូវអំណាចដើម្បីជ្រមុជទឹក

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀនមុនចាប់ផ្តើមបង្រៀន ៖ *តើនរណាអាចជ្រមុជទឹកឲ្យខ្ញុំ ? តើពិធីបុណ្យជ្រមុជទឹកត្រូវបានធ្វើឡើងដោយរបៀបណា ?*

ប្រសិនបើអ្នកបង្រៀនសិស្សម្នាក់ ឬច្រើននាក់ដែលទើបតែចូលមកក្នុងសាសនាចក្រនាពេលថ្មីៗនេះ អ្នកអាចចាប់ផ្តើមមេរៀនដោយការសុំឲ្យពួកគេចែកចាយបទពិសោធន៍ខ្លះដែលពួកគេបានមាន ខណៈពេលកំពុងរៀនអំពីសាសនាចក្រ ។ សូមសួរពួកគេថាតើពួកគេបានឆ្ងល់អំពីចម្លើយនៃសំណួរទាំងពីរនៅលើក្តារខៀននេះ នៅពេលពួកគេបានសម្រេចចិត្តជ្រមុជទឹកទេ ។

អ្នកក៏អាចចាប់ផ្តើមមេរៀននេះ ដោយការសុំឲ្យសិស្សស្រមៃថា មិត្តភក្តិរបស់ពួកគេម្នាក់បានសម្រេចចិត្តនាពេលថ្មីៗនេះដើម្បីចូលរួមក្នុងសាសនាចក្រ ហើយបានសួរគេសំណួរទាំងពីរនៅលើក្តារខៀននេះ ។ សូមឲ្យសិស្សពន្យល់ពីរបៀបដែលពួកគេអាចឆ្លើយសំណួរទាំងនេះ ។ ឬ អ្នកអាចសុំឲ្យសិស្សពីរនាក់សម្តែងក្នុងការពិភាក្សាមួយរវាងសមាជិកសាសនាចក្រ និងមិត្តភក្តិរបស់គេដោយប្រើសំណួរទាំងនេះ ។

> *ការសម្របសម្រួលមេរៀន*
>
> មេរៀនជាច្រើននៅក្នុងសៀវភៅណែនាំនេះ ចាប់ផ្តើមដោយការស្នើនូវសកម្មភាពមួយ ឬសំណួរមួយក្នុងគោលបំណងដើម្បីរៀបចំសិស្សឲ្យសិក្សាព្រះគម្ពីរ ។ យោបល់ស្នើសុំទាំងនេះអាចត្រូវសម្របសម្រួល ដោយយោងតាមតម្រូវការ និងកាលៈទេសៈរបស់សិស្ស ។

សូមរំឭកសិស្សថា នៅក្នុងមេរៀនពីមុនដែលពួកគេបានរៀនអំពីការលេចចេញមករបស់ព្រះយេស៊ូវគ្រីស្ទទៅដល់ក្រុមសាសន៍នីហ្វៃមួយ ។ ព្រះយេស៊ូវគ្រីស្ទបានអញ្ជើញពួកគេឲ្យធ្វើជាសាក្សីដល់ខ្លួនគេអំពីការរស់ឡើងវិញរបស់ទ្រង់ និងទេវភាពដោយការស្ថាបស្នាមរបួសនៅលើព្រះហស្ត ព្រះបាត និងព្រះកាយរបស់ទ្រង់ ។ សូមពន្យល់ថា ភ្លាមៗបន្ទាប់ពីបទពិសោធន៍នេះ ព្រះអង្គសង្គ្រោះបានបង្រៀនប្រជាជនអំពីគោលលទ្ធិរបស់ទ្រង់ ដែលត្រូវជឿលើទ្រង់ ត្រូវជ្រមុជទឹក ហើយទទួលបានព្រះវិញ្ញាណបរិសុទ្ធ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១១:១៨–២២ ឮ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលចម្លើយចំពោះសំណួរ *តើនរណាអាចជ្រមុជទឹកឲ្យខ្ញុំ ?* សូមឲ្យសិស្សម្នាក់សរសេរចម្លើយនៅលើក្តារខៀននៅក្រោមសំណួរនេះ ។ ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាក្តី ក៏ពួកគេគួររកឃើញនូវសេចក្តីពិតខាងក្រោមនេះដែរ ៖ **ពិធីបុណ្យជ្រមុជទឹកត្រូវតែធ្វើដោយបុគ្គលម្នាក់ដែលកាន់សិទ្ធិអំណាចត្រឹមត្រូវ ។** (ប្រសិនបើគំនិតនេះមិនទាន់បានសរសេរនៅលើក្តារខៀនទេ អ្នកអាចបន្ថែមវាទៅលើបញ្ជីនៃចម្លើយបាន) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែស៊ីជម្រៅពីសេចក្តីពិតនេះ អ្នកអាចសង្ខេបដោយខ្លីៗថា ពិធីបុណ្យជ្រមុជទឹកអាចត្រូវបានធ្វើឡើងតែតាមរយៈបុគ្គលដែលកាន់ តំណែងសង្ឃនៅក្នុងបព្វជិតភាពអើរ៉ុន (សូមមើល គ. និង ស. ២០:៤៦) ឬដោយនរណាម្នាក់ដែលទទួលបានបព្វជិតភាពមីលគីស្សាដែក (សូមមើល គ. និង ស. ២០:៣៨–៣៩; ១០៧:១០–១១) ។ បន្ថែមលើនេះ បុគ្គលនេះត្រូវតែធ្វើការនៅក្រោមការដឹកនាំរបស់អ្នកដឹកនាំបព្វជិតភាពដែលកាន់កូនសោបព្វជិតភាព ដែលចាំបាច់ដើម្បីផ្តល់ការអនុញ្ញាតឲ្យពិធីបរិសុទ្ធអាចធ្វើទៅបាន (អ្នកទាំងនោះមានដូចជា ប៊ីស្សព ប្រធានសាខា ឬប្រធានបេសកកម្ម) ។

- តើអ្នកគិតថា ហេតុអ្វីបានជាព្រះអម្ចាស់តម្រូវឲ្យពិធីការបរិសុទ្ធនៃពិធីបុណ្យជ្រមុជទឹកត្រូវបានធ្វើដោយអ្នកកាន់បព្វជិតភាពដែលមានអំណាច ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១១:២៣–២៧ ឮ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលចម្លើយចំពោះសំណួរ *តើពិធីបុណ្យជ្រមុជទឹកធ្វើឡើងដោយរបៀបណា ?* សូមឲ្យសិស្សម្នាក់សរសេរចម្លើយនៅលើក្តារខៀននៅក្រោមសំណួរនេះ ។

- តើអ្វីត្រូវបានធ្វើឡើង អំឡុងពេលពិធីបុណ្យជ្រមុជទឹក ប្រសិនបើឃ្លាឃ្លោងនៃពិធីបរិសុទ្ធនិយាយមិនត្រូវ ឬប្រសិនបើបុគ្គលដែលទទួលពិធីជ្រមុជទឹក មិនបាន ត្រូវពន្លិចទាំងស្រុងទៅក្នុងទឹក នោះទេ ? (ពិធីបរិសុទ្ធនោះត្រូវធ្វើម្តងទៀត) ។ តើសេចក្តីពិតអ្វីដែលយើងអាចរៀនពីរឿងនេះ ? (ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាក្តី ក៏ពួកគេគួររកឃើញនូវសេចក្តីពិតខាងក្រោមនេះដែរ ៖ **ពិធីបុណ្យជ្រមុជទឹកត្រូវតែបានធ្វើឡើងតាមរបៀបដែលបានរៀបចំឡើងដោយព្រះអម្ចាស់ ។** អ្នកអាចសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- តើអ្នកគិតថា ហេតុអ្វីបានជាវាមានសារៈសំខាន់ដែលពិធីបុណ្យជ្រមុជទឹកត្រូវបានធ្វើឡើងដោយពិសិដ្ឋតាមរបៀបមួយដែលត្រូវបានដាក់ដោយព្រះអម្ចាស់ ?

ដើម្បីជួយសិស្សឲ្យទទួលបានអារម្មណ៍ពីសារៈសំខាន់នៃសេចក្តីពិតដែលអ្នកបានពិភាក្សានៅក្នុង នីហ្វៃទី ៣ ១១:១៨–២៧ អ្នកអាចសួរសំណួរខាងក្រោមខ្លះៗ ៖

- តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលអ្នកជ្រមុជទឹក ? តើវាមានន័យយ៉ាងណាដល់អ្នកដើម្បីដឹងថា អ្នកត្រូវបានជ្រមុជទឹកដោយបុគ្គលម្នាក់ដែលកាន់សិទ្ធិអំណាចដ៏ត្រឹមត្រូវ និងតាមរបៀបមួយដែលបានរៀបចំឡើងដោយព្រះអម្ចាស់ ?
- តើអ្នកបានធ្វើជាសាក្សីក្នុងពិធីបុណជ្រមុជទឹកនាពេលថ្មីៗនេះទេ ? តើអ្នកមានអារម្មណ៍យ៉ាងណា ?

ប្រសិនបើសិស្សរបស់អ្នកកាន់ដំណែងជាសង្ឃនៅក្នុងបព្វជិតភាពអើរ៉ុន សូមសួរ ៖

- តើការដឹងថា អ្នកមានសិទ្ធិអំណាចដើម្បីជ្រមុជទឹក ជះឥទ្ធិពលដល់អ្នកយ៉ាងដូចម្តេច ? (អ្នកសួរដើម្បីដឹងថាតើសិស្សណាខ្លះ នៅក្នុងថ្នាក់អ្នកបានមានឱកាសជ្រមុជទឹកឲ្យនរណាម្នាក់ឬទេ ។ ប្រសិនបើមាន សូមឲ្យពួកគេចែកចាយអារម្មណ៍ដែលពួកគេបានមាន និងបានរៀនអំឡុងពេលបទពិសោធន៍នេះ) ។

អ្នករអាចចែកចាយបទពិសោធន៍របស់អ្នក និងអារម្មណ៍ផ្ទាល់អំពីពិធីការបរិសុទ្ធដ៏ពិសិដ្ឋនៃពិធីបុណជ្រមុជទឹកនេះ ។

នីហ្វៃទី ៣ ១១:២៨–៣០

ព្រះយេស៊ូវគ្រីស្ទព្រមានថា ការទាស់ទែងគ្នាគឺជារបស់ផងអារក្ស

សូមសរសេរពាក្យ *ការទាស់ទែងគ្នា* នៅលើក្តារខៀន ។

- តើអ្វីជាការទាស់ទែងគ្នា ? (ជម្លោះ វិវាទ ឬការប្រកែកគ្នា) ។

សូមឲ្យសិស្សសរសេរខ្លីៗនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរអំពីស្ថានភាព ឬសកម្មភាពខ្លះដែលអាចនាំឲ្យកើតមានការទាស់ទែងគ្នា ។ ក្រោយពីសិស្សបានមានពេលគ្រប់គ្រាន់ដើម្បីសរសេរហើយ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១១:២៨–៣០ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម និងរកអ្វីដែលពួកសាសន៍នីហ្វៃខ្លះបានទាស់គ្នាអំពីវា ។

- តើពួក សាសន៍នីហ្វៃមួយចំនួន កំពុងទាស់គ្នាអំពីអ្វីឲ្យពិតប្រាកដទៅ ? (ពិធីបរិសុទ្ធនៃពិធីបុណជ្រមុជទឹក | សូមមើលផងដែរ នីហ្វៃទី ៣ ១១:២២| និងអំពីគោលលទ្ធិនៃព្រះគ្រីស្ទ) ។
- យោងតាម នីហ្វៃទី ៣ ១១:២៩ តើវិញ្ញាណនៃការទាស់ទែងគ្នានេះចេញមកពីណា ? (សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***ព្រះវិញ្ញាណនៃការទាស់ទែងគ្នាគឺពុំមែនជារបស់ផងព្រះទេ ប៉ុន្តែជារបស់ផងអារក្សវិញ ។*** អ្នករអាចណែនាំថា សិស្សគួរគូសចំណាំសេចក្តីពិតនេះនៅក្នុង នីហ្វៃទី ៣ ១១:២៩) ។
- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីចៀសវាងការទាស់ទែងគ្នា នៅពេលពិភាក្សាគ្នាអំពីដំណឹងល្អជាមួយនឹងអ្នកដទៃ ? ហេតុអ្វីបានជាការឈ្លោះគ្នាជាផ្លូវមួយខុសឆ្គងក្នុងការបង្រៀនដំណឹងល្អ ? (សិស្សអាចផ្តល់ចម្លើយខុសគ្នា ប៉ុន្តែសូមប្រាកដថាពួកគេយល់ថា នៅពេលយើងទាស់គ្នា ឬឈ្លោះគ្នាជាមួយនឹងអ្នកដទៃអំពីដំណឹងល្អ នោះព្រះវិញ្ញាណបរិសុទ្ធនឹងមិនគង់នៅដើម្បីជួយយើងឲ្យបង្រៀន ឬថ្លែងទីបន្ទាល់អំពីសេចក្តីពិតនៅក្នុងដួងចិត្តនៃអស់អ្នកទាំងឡាយណាដែលយើងកំពុងបង្រៀននោះទេ) ។

ដើម្បីបញ្ជាក់ពីលទ្ធផលនៃការទាស់ទែងគ្នា សូមសរសេរនៅលើក្តារខៀននូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ដែមស៍ អឹ ហ្វោស្ត នៃគណៈប្រធានទីមួយ ។ អ្នករអាចជម្រុញឲ្យសិស្សសរសេរវានៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ នីហ្វៃទី ៣ ១១:២៩ ។ (សេចក្តីថ្លែងការណ៍មាននៅក្នុង « What I Want My Son to Know before He Leaves on His Mission » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៩៦, ទំព័រ ៤១) ។

> *« នៅពេលមានការទាស់ទែងគ្នា នោះព្រះវិញ្ញាណនៃព្រះអម្ចាស់នឹងចាកចេញ ដោយមិនគិតថានរណាជាអ្នកខុសនោះទេ » (ប្រធាន ដែមស៍ អឹ ហ្វោស្ត) ។*

- តើអ្នកធ្លាប់មានអារម្មណ៍ថា ព្រះវិញ្ញាណនៃព្រះអម្ចាស់ចាកចេញដោយសារតែការទាស់ទែងគ្នាដែរឬទេ ? តើអ្នកបានដឹងថាព្រះវិញ្ញាណបានចាកចេញដោយរបៀបណា ?

សូមបង្ហាញប្រយោគរបស់ព្រះអង្គសង្គ្រោះដែលទាក់ទងទៅនឹងការទាស់ទែងគ្នានៅក្នុង នីហ្វៃទី ៣ ១១:៣០ ៖ « នេះពុំមែនជាគោលលទ្ធិរបស់យើងទេ គឺត្រូវលះបង់ការណ៍ទាំងនោះចោលវិញ » ។

- តើយើងអាច « លះបង់ចោល » នូវការទាស់ទែងគ្នា និងការប្រកែកគ្នាដោយរបៀបណា ? (ចម្លើយអាចរួមមានដូចខាងក្រោម ៖ យើងអាចស្វែងរក ដើម្បីក្លាយជាអ្នកដែលផ្សះផ្សាគេ | សូមមើល នីហ្វៃទី ៣ ១២:៩| ។ យើងអាចអធិស្ឋានសុំរកចំណេះដឹង និងការអត់ធ្មត់ដើម្បីយកឈ្នះលើការទាស់ទែងគ្នា ។ យើងអាចព្យាយាមចៀសវាងស្ថានភាពដែលយើងអាចត្រូវបានល្បួងឲ្យឈ្លោះនឹងអ្នកដទៃបាន) ។
- តើនៅពេលណាដែលអ្នកបានមានអារម្មណ៍ថា អ្នកត្រូវបានប្រទានពរដោយសារការខិតខំ ដើម្បីចៀសវាង ឬយកឈ្នះលើការទាស់ទែងគ្នា ?
- តើការចងចាំដល់ការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុង នីហ្វៃទី ៣ ១១:២៩–៣០ អាចជួយអ្នក នៅពេលអ្នកឃើញថាខ្លួនអ្នកស្ថិតនៅក្នុងស្ថានភាពមួយដែលនឹង ឬអាចនឹងឈ្លោះគ្នាដោយរបៀបណា ?

អ្នករអាចចែកចាយពីបទពិសោធន៍មួយដែលអ្នក មានអារម្មណ៍ថា អ្នកត្រូវបានប្រទានពរដោយសារការខិតខំរបស់អ្នកដើម្បីចៀសវាង ឬយកឈ្នះលើការទាស់ទែងគ្នានោះ ។ ដើម្បីលើកទឹកចិត្តសិស្សឲ្យអនុវត្តអ្វីដែលពួកគេបានរៀនពី នីហ្វៃទី ៣ ១១:២៨–៣០ សូមឲ្យពួកគេបើកទៅបញ្ជីនៃស្ថានភាព ឬសកម្មភាពដែលពួកគេអាចឆាប់ជួបនឹងការទាស់ទែងគ្នា សូមឲ្យពួកគេដាក់គោលដៅ និងសរសេរគោលដៅមួយអំពីរបៀបដែលពួកគេនឹងខំចៀសវាង ឬយកឈ្នះលើការទាស់ទែងគ្នានៅក្នុងស្ថានភាព ឬសកម្មភាពមួយដែលពួកគេបានសរសេរ ។

នីហ្វៃទី ៣ ១១:៣១–៤១

ព្រះយេស៊ូវគ្រីស្ទប្រកាសគោលលទ្ធិរបស់ទ្រង់

ដើម្បីរៀបចំសិស្សឲ្យសិក្សា នីហ្វៃទី ៣ ១១:៣១–៤១ សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖

សកម្មភាព ⟶ លទ្ធផល

សូមឲ្យសិស្សនិយាយសង្ខេប ៗដល់មិត្តរួមថ្នាក់ អំពីអ្វីមួយដែលពួកគេបានធ្វើនាពេលថ្មីៗនេះដែលបានផ្តល់លទ្ធផលវិជ្ជមាន និងពន្យល់ពីអ្វីដែលជាលទ្ធផល ។ អ្នកក៏អាចសុំឲ្យពួកគេប្រាប់អំពីអ្វីមួយដែលពួកគេបានធ្វើ ឬបានឃើញដែលមានលទ្ធផលអវិជ្ជមាន ។ (សូមហាមសិស្សកុំឲ្យចែកចាយអ្វីៗដែលអាចមិនសមរម្យ ឬផ្ទាល់ខ្លួនពេក) ។

សូមអាន នីហ្វៃទី ៣ ១១:៣១ ឮៗដល់សិស្សក្នុងថ្នាក់ ។ សូមពន្យល់ថា ផ្នែកដែលនៅសល់ក្នុង នីហ្វៃទី ៣ ១១ រួមមានការប្រកាសរបស់ព្រះយេស៊ូវគ្រីស្តអំពីគោលលទ្ធិរបស់ទ្រង់ដល់ប្រជាជនរបស់នីហ្វៃ ។ ជំពូកនេះក៏ដាក់ចេញនូវលទ្ធផលនៃការទទួលយក ឬការបដិសេធគោលលទ្ធិរបស់ទ្រង់ដែរ ។

សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖ *នីហ្វៃទី ៣ ១១:៣២–៣៤; នីហ្វៃទី ៣ ១១:៣៥–៣៦; នីហ្វៃទី ៣ ១១:៣៧–៣៨; នីហ្វៃទី ៣ ១១:៣៩–៤០* ។ សូមឲ្យសិស្សធ្វើការជាដៃគូ ហើយសូមដាក់កិច្চការដល់ដៃគូនីមួយ ៗឲ្យសិក្សាវគ្គព្រះគម្ពីរមួយ ។ សូមឲ្យពួកគេរកមើលសកម្មភាព និងលទ្ធផលដែលព្រះយេស៊ូវគ្រីស្តបានបង្រៀន ។ (អ្នកអាចណែនាំថា សិស្សគួរប្រៀបធៀបការបង្រៀនទាំងនេះទៅនឹង មាត្រាទីបួននៃសេចក្តីជំនឿ) ។

ក្រោយពីសិស្ស មានពេលសិក្សាគ្រប់គ្រាន់ហើយ សូមឲ្យពួកគេពីរបីនាក់រៀបរាប់ពីសកម្មភាព និងលទ្ធផលដែលពួកគេបានរកឃើញនៅក្នុងខគម្ពីរដែលបានដាក់ឲ្យគេ ។ សូមឲ្យពួកគេសរសេរចម្លើយរបស់គេនៅលើក្តារខៀននៅក្រោម *សកម្មភាព* ឬ *លទ្ធផល* ។ នៅពេលសិស្សរៀបរាប់ពីវគ្គនីមួយ ៗ សូមសួរសំណួរស្របគ្នាដូចខាងក្រោម ៖

សម្រាប់ដៃគូដែលដាក់កិច្চការ នីហ្វៃទី ៣ ១១:៣២–៣៤ សូមសួរ ៖

- តើព្រះវិញ្ញាណបរិសុទ្ធជួយយើងឲ្យជឿទៅលើព្រះយេស៊ូវគ្រីស្ត និងព្រះវរបិតាសួគ៌ដោយរបៀបណា ? (**ព្រះវិញ្ញាណបរិសុទ្ធថ្លែងទីបន្ទាល់អំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ត ។**) តើនៅពេលណាដែលព្រះវិញ្ញាណបរិសុទ្ធថ្លែងទីបន្ទាល់ដល់អ្នកអំពីភាពពិត និងសេចក្តីស្រឡាញ់របស់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ត ?

សម្រាប់ដៃគូដែលដាក់កិច្চការ នីហ្វៃទី ៣ ១១:៣៥–៣៦ សូមសួរ ៖

- យោងតាមខគម្ពីរទាំងនេះ តើការជ្រើសរើសជឿទៅលើព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្តអញ្ជើញឲ្យមានឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់យើងដោយរបៀបណា ?

សម្រាប់ដៃគូដែលដាក់កិច្চការ នីហ្វៃទី ៣ ១១:៣៧–៣៨ សូមសួរ ៖

- តើអ្នកបានរកឃើញ ភាពស្រដៀងគ្នាអ្វីខ្លះរវាង ខគម្ពីរ នីហ្វៃទី ៣ ១១:៣៧ និង នីហ្វៃទី ៣ ១១:៣៨ ?
- តើអ្វីខ្លះជាលក្ខណៈល្អនៃកូនក្មេងតូចម្នាក់ ? តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បី « ក្លាយជាដូចជាកូនក្មេងតូច » ?

សម្រាប់ដៃគូដែលដាក់កិច្চការ នីហ្វៃទី ៣ ១១:៣៩–៤០ សូមសួរ ៖

- តើការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងខគម្ពីរទាំងនេះបញ្ជាក់ពីសារៈសំខាន់នៃជម្រើសរបស់យើងក្នុងការគោរពតាម ឬ មិនគោរពតាមគោលលទ្ធិរបស់ទ្រង់ដោយរបៀបណា ?

សូមឲ្យសិស្សសង្ខេបសកម្មភាពសំខាន់ ៗដែលព្រះយេស៊ូវគ្រីស្តបានបង្រៀន ដែលយើងត្រូវធ្វើដើម្បីចូលទៅក្នុងនគរស្ថានសួគ៌ ។ សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរបង្ហាញនូវសេចក្តីពិតខាងក្រោមនេះ ៖ **ដើម្បីចូលទៅក្នុងនគរស្ថានសួគ៌ យើងត្រូវតែប្រែចិត្ត ជឿលើព្រះយេស៊ូវគ្រីស្ត ជ្រមុជទឹក និងទទួលយកព្រះវិញ្ញាណបរិសុទ្ធ ។** អ្នកអាចបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតនេះ ។ សូមលើកទឹកចិត្តសិស្សឲ្យរស់នៅតាមគោលលទ្ធិរបស់ព្រះយេស៊ូវគ្រីស្ត ដើម្បីឲ្យពួកគេនឹងអាចគ្រងនគរព្រះទុកជាមរតក ។ អ្នកក៏អាចរំឭកពួកគេឲ្យធ្វើតាមគោលដៅរបស់ពួកគេដើម្បីចៀសវាង និងយកឈ្នះលើការទាស់ទែងគ្នាផងដែរ ។

នីហ្វៃទី ៣ ១២

សេចក្តីផ្តើម

ព្រះយេស៊ូវគ្រីស្ទបានបង្រៀនដល់ពួកសាសន៍នីហ្វៃអំពីរបៀបដើម្បីទទួលបានពរជ័យនៃជំណឹងល្អរបស់ទ្រង់ និងបានណែនាំពួកគេឲ្យមានឥទ្ធិពលដល់អ្នកដទៃចំពោះការណ៍ល្អ ។ ទ្រង់ប្រកាសថា ទ្រង់បានបំពេញច្បាប់របស់ម៉ូសេ ហើយទ្រង់បានប្រទានដល់ប្រជាជននូវច្បាប់ដ៏ខ្ពស់ជាងដើម្បីរៀបចំពួកគេឲ្យក្លាយដូចជាទ្រង់ និងព្រះវរបិតាដែលគង់នៅស្ថានសួគ៌របស់យើង ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៣ ១២:១–១២

ព្រះយេស៊ូវគ្រីស្ទបង្រៀនដល់ហ្វូងមនុស្សអំពីពរជ័យដែលយើងទទួលបាន នៅពេលយើងរស់នៅតាមជំណឹងល្អរបស់ទ្រង់

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀនមុនចាប់ផ្តើមបង្រៀន ៖

តើព្រះវរបិតាសួគ៌សង្ឃឹមថាយើងនឹងល្អឥតខ្ចោះទេ ?

តើយើងត្រូវក្លាយជាល្អឥតខ្ចោះនៅក្នុងជីវិតនេះដើម្បីចូលទៅក្នុងនគរសេឡេស្ទាលទេ ?

តើយើងអាចល្អឥតខ្ចោះទេ ?

នៅពេលចាប់ផ្តើមមេរៀននេះ សូមឲ្យសិស្សសញ្ជឹងគិតអំពីសំណួរទាំងនេះ ។ សូមឲ្យពួកគេគិតពីសំណួរនេះពេញមួយមេរៀននេះ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១២:៤៨ ឮៗ ។ សូមបង្ហាញថា នេះគឺជាវគ្គចំណោះចំណានខព្រះគម្ពីរ ។ អ្នកអាចណែនាំថាសិស្សគួរគូសចំណាំវគ្គនេះដើម្បីឲ្យងាយស្រួលនឹងរកឃើញវា ។

> **នីហ្វៃទី ៣ ១២:៤៨**
> គឺជាវគ្គចំណោះចំណានខគម្ពីរ ។ សូមបើកទៅយោបល់សម្រាប់ការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះដើម្បីជួយសិស្សជាមួយនឹងចំណោះចំណានខគម្ពីរ ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ័សុល អិម ណិលសុន នៃក្រុមនៃពួកសាវកដប់ពីរនាក់អំពីព្រះបញ្ញត្តិដើម្បីបានល្អឥតខ្ចោះ ៖

« យើងមិនត្រូវអាក់អន់ចិត្ត ប្រសិនបើការព្យាយាមទៅកាន់ភាពល្អឥតខ្ចោះ ហាក់ដូចជាយ៉ាប់យ៉ឺន ។ ពិបាក ។ និងមិនចេះចប់មិនចេះហើយនោះ ។ ភាពល្អឥតខ្ចោះគឺជាការរង់ចាំ ។ យើងអាចទទួលបានពេញលេញតែក្រោយពីការរស់ឡើងវិញ និងតែតាមរយៈព្រះអម្ចាស់ប៉ុណ្ណោះ ។ ការល្អឥតខ្ចោះរង់ចាំដល់អ្នកទាំងឡាយណាដែលស្រឡាញ់ទ្រង់ ហើយកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់» (« Perfection Pending » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៥, ទំព័រ ៨៨) ។

- តើអ្នកគិតថា ហេតុអ្វីបានជាការឥតខ្ចោះអាចមក « តែតាមរយៈព្រះអម្ចាស់ » ?

សូមរំឭកសំណួរបីនៅពេលចាប់ផ្តើមមេរៀននេះ ។ សូមស្ងាសិស្សថា តើពួកគេអាចនឹងផ្លាស់ប្តូរចម្លើយរបស់គេចំពោះសំណួរទាំងនោះទេក្រោយពីការអាន នីហ្វៃទី ៣ ១២:៤៨ និងការស្តាប់ការពន្យល់របស់អែលឌើរ ណិលសុន ហើយ ។ សូមជួយសិស្សឲ្យយល់ថាព្រះវរបិតាសួគ៌មិនរំពឹងឲ្យយើងឥតខ្ចោះ កាលមានជីវិតលើផែនដីនោះទេ ប៉ុន្តែនៅពេលយើងខិតខំយ៉ាងឧស្សាហ៍ព្យាយាមកាន់តាមព្រះបញ្ញត្តិទាំងឡាយ និងនៅពេលយើងទុកចិត្តទៅលើដង្វាយធួន នោះយើងអាចនឹងល្អឥតខ្ចោះនៅទីបញ្ចប់ ។

សូមសរសេរពាក្យថា *ត្រូវបានប្រទានពរ* នៅលើក្តារខៀន ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១២:១–១២ ដោយស្ងាត់ស្ងៀមដោយរកមើលឥរិយាបទដែលព្រះអង្គសង្គ្រោះសុំឲ្យយើងកែប្រែ ព្រមទាំងពរជ័យទាំងឡាយដែលទ្រង់សន្យានឹងប្រទានជាលទ្ធផល ។

- តើពរជ័យអ្វីខ្លះដែលបានមកក្នុងជីវិតរបស់អ្នក ជាលទ្ធផលនៃការរស់នៅតាមការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុង នីហ្វៃទី ៣ ១២:១–១២ ?

សូមបង្ហាញពីភាពញឹកញាប់នៃពាក្យថា *ត្រូវបានប្រទានពរ* មាននៅក្នុងខគម្ពីរទាំងនេះ ។ សូមចែកចាយទីបន្ទាល់អ្នកអំពីរបៀបដែលអ្នកត្រូវបានប្រទានពរ នៅពេលអ្នកបានរស់នៅតាមការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ។

សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់អំពីពរជ័យមួយដែលពួកគេចង់បានដូចដែលបានរៀបរាប់នៅក្នុង នីហ្វៃទី ៣ ១២:១–១២ ។ សូមពួកគេសរសេរនូវឥរិយាបទដែលពួកគេត្រូវកែប្រែដើម្បីទទួលបាននូវពរជ័យនោះ ។ បន្ទាប់មក សូមឲ្យពួកគេសរសេរអ្វីដែលពួកគេនឹងធ្វើដើម្បីកែប្រែឥរិយាបទនោះ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយនូវអ្វីដែលពួកគេបានសរសេរ និងពីមូលហេតុ ។

នីហ្វៃទី៣ ១២:១៣–១៦

ព្រះអង្គសង្គ្រោះជាស់តឿនដល់ហ្វូងមនុស្សឲ្យធ្វើជាគំរូដ៏សុចរិតដល់ពិភពលោក

សូមបង្ហាញក្រឡអំបិល ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលផលប្រយោជន៍នៃអំបិល ។ នៅពេលសិស្សឆ្លើយ សូមប្រាកដថា បានពន្យល់ថា អំបិលបន្ថែមរសដល់អាហារ ហើយថាវាជាគ្រឿងប្រឡាក់មិនឲ្យសាច់ស្អុយ ។ អ្នកក៏អាចនឹងពន្យល់ថា នៅក្រោមច្បាប់ម៉ូសេ ពួកសង្ឃត្រូវបានបញ្ជាឲ្យថ្វាយអំបិលជាមួយនឹងការថ្វាយយញ្ញបូជារបស់ពួកគេ (សូមមើល លេវីវិន័យ ២:១៣) ។ ហេតុដូច្នេះហើយ អំបិលគឺជាសញ្ញាមួយនៃសេចក្តីសញ្ញារវាងព្រះអម្ចាស់ និងប្រជាជនរបស់ទ្រង់ ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១២:១៣ ដោយស្ងាត់ស្ងៀម និងរកមើលអ្នកដែលព្រះអង្គសង្គ្រោះបានប្រៀបធៀបទៅនឹងអំបិល ។ នៅពេលសិស្សឆ្លើយ សូមពន្យល់ថា ព្រះអង្គសង្គ្រោះសំដៅមិនត្រឹមតែសំដៅលើហ្វូងមនុស្សនៅឯព្រះវិហារបរិសុទ្ធនៅថ្ងៃនោះប៉ុណ្ណោះទេ គឺថែមទាំងទៅដល់អស់អ្នកទាំងឡាយណាដែលត្រូវបានជ្រមុជទឹកចូលក្នុងសាសនាចក្ររបស់ទ្រង់ និងរស់នៅតាមដំណឹងល្អរបស់ទ្រង់ទៀតផង ។

- ក្នុងនាមជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ តើយើងអាចក្លាយដូចជាអំបិលតាមវិធីណា ? (យើងត្រូវជួយរក្សា ឬសង្គ្រោះប្រជាជន និងត្រូវពង្រឹងពិភពលោកដោយការមានឥទ្ធិពលលើអ្នកដទៃដោយអំពើល្អ) ។
- តើអ្នកគិតថា វាមានន័យយ៉ាងណាដែលអំបិលនឹងត្រូវបាត់បង់រសជាតិរបស់វានោះ ?

នៅពេលសិស្សពិភាក្សាពីសំណួរនេះ អ្នកអាចអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ខាឡុស អឺ. អាសាយ នៃក្រុមចិតសិបនាក់ ៖

« អំបិលនឹងមិនបាត់បង់រសរបស់វាតាមពេលវេលានោះទេ ។ រសជាតិត្រូវបាត់បង់តាមរយៈការលាយ និងការបំពុល ។ . . . រសជាតិ និងគុណភាពចាកចេញពីមនុស្ស នៅពេលគេបំពុលគំនិតរបស់គេដោយគំនិតមិនស្អាតស្អំ ពេលពាក្យប្រមាថដោយការនិយាយកុហក់ និងអនុវត្តកម្លាំងរបស់គេខុសទៅលើការធ្វើអំពើអាក្រក់ » (« Salt of the Earth: Savor of Men and Saviors of Men » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៨០, ទំព័រ ៤២) ។

- ហេតុអ្វីបានជាយើងត្រូវតែបរិសុទ្ធដើម្បីមានឥទ្ធិពលលើអ្នកដទៃចំពោះការណ៍ល្អ ?

សូមពន្យល់ថា ព្រះអង្គសង្គ្រោះបានប្រើនិមិត្តសញ្ញាផ្សេងទៀតដើម្បីបង្រៀនពីរបៀបដែលសមាជិកក្នុងសេចក្តីសញ្ញានៃសាសនាចក្ររបស់ទ្រង់គួរមានឥទ្ធិពលលើអ្នកដទៃចំពោះការណ៍ល្អ ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១២:១៤–១៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពីរបៀបដែលព្រះអង្គសង្គ្រោះបានប្រើពន្លឺដើម្បីបង្រៀនពីតួនាទីរបស់សាស្ត្រានៃសេចក្តីសញ្ញារបស់ទ្រង់នៅក្នុងពិភពលោកនេះ ។ មុនពេលសិស្សអាន អ្នកអាចពន្យល់ថា កញ្ចើគឺជាកន្ត្រកមួយ ។

- តើសមាជិកនៃសាសនាចក្រអាចក្លាយជាពន្លឺដល់អ្នកដទៃដោយរបៀបណា ? តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បីឲ្យពន្លឺរបស់យើងចែងចាំងឡើង ? (នៅពេលសិស្សឆ្លើយនឹងសំណួរនេះ សូមជួយពួកគេឲ្យឃើញពីរបៀបដែលគំរូរបស់ពួកគេចំពោះការរស់នៅដ៏សុចរិតអាចជួយដល់មនុស្សផ្សេងទៀត) ។
- តើសមាជិកសាសនាចក្រខ្លះអាចគ្របពន្លឺរបស់គេយ៉ាងដូចម្តេច ?
- យោងតាម នីហ្វៃទី ៣ ១២:១៦ តើហេតុអ្វីបានជាព្រះអង្គសង្គ្រោះចង់ឲ្យយើងបំភ្លឺពន្លឺរបស់យើង ? (**នៅពេលយើងធ្វើជាគំរូដ៏សុចរិត នោះយើងអាចជួយដល់អ្នកដទៃឲ្យតម្កើងដល់ព្រះវរបិតាសួគ៌ ។** អ្នកអាចណែនាំថា សិស្សគួរសរសេរគោលការណ៍នេះជាសម្តីរបស់គេផ្ទាល់នៅក្នុងព្រះគម្ពីររបស់គេ) ។
- តើគំរូដ៏សុចរិតរបស់នរណាដែលបានជួយអ្នកឲ្យខិតកាន់តែជិតទៅរកព្រះវរបិតាសួគ៌ និងពង្រឹងបំណងរបស់អ្នកក្នុងការរស់នៅតាមដំណឹងល្អ ?

សូមឲ្យសិស្សញ៉ែងគិតពីគំរូដែលពួកគេបានធ្វើដល់អ្នកដែលនៅជុំវិញខ្លួនគេ ។ សូមលើកទឹកចិត្តពួកគេឲ្យគិតអំពីរបៀបដែលពួកគេអាចជួយអ្នកដទៃឲ្យបង្កើនសេចក្តីស្រឡាញ់របស់គេទៅលើព្រះវរបិតាសួគ៌ និងជម្រុញចំណងរបស់គេដើម្បីធ្វើតាមទ្រង់កាន់តែខ្លាំង ។

នីហ្វៃទី៣ ១២:១៧–៤៨

ព្រះយេស៊ូវគ្រីស្ទបង្រៀនដល់ហ្វូងមនុស្សអំពីក្រិត្យវិន័យដ៏ខ្ពស់ដែលនឹងជួយពួកគេឲ្យក្លាយដូចជាទ្រង់ និងព្រះវរបិតាសួគ៌

សូមពន្យល់ថា ព្រះអង្គសង្គ្រោះបានបន្តបង្រៀនដល់ពួកសាសន៍នីហ្វៃពីរបៀបដើម្បីមកកាន់ទ្រង់ និងចូលទៅក្នុងនគរស្ថានសួគ៌ ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១២:១៩–២០ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពាក្យមួយដែលសរសេរច្រើនដងនៅក្នុងខគម្ពីរទាំងនេះ ។

- តើពាក្យសំខាន់អ្វីដែលព្រះអង្គសង្គ្រោះទ្រង់បានប្រើបីដង សម្រាប់ជាផ្នែកនៃការអញ្ជើញឲ្យមករកទ្រង់នេះ ? (ព្រះបញ្ញត្តិ) ។

សូមពន្យល់ថា នីហ្វៃទី ៣ ១២:២១–៤៧ រួមមានព្រះបញ្ញត្តិជាក់លាក់ខ្លះដែលព្រះអង្គសង្គ្រោះបានប្រទានដែលនឹងជួយយើងឲ្យមករកទ្រង់ ហើយកាន់តែក្លាយដូចជាទ្រង់ ។ នៅពេលទ្រង់បានបង្រៀនពីព្រះបញ្ញត្តិទាំងនេះដល់ពួកសាសន៍នីហ្វៃ ទ្រង់បានសំដៅទៅលើបញ្ញត្តិដែលជាផ្នែកនៃក្រិត្យវិន័យរបស់ម៉ូសេ ហើយបន្ទាប់មកបានបង្រៀនអំពីច្បាប់ដ៏ខ្ពស់ជាង ។ ទ្រង់បានសំដៅលើការយល់ដឹងតាមបែបប្រពៃណី អំពីក្រិត្យវិន័យរបស់ម៉ូសេ នៅពេលទ្រង់បានប្រើឃ្លាដូចជា « សេចក្តីដែលមនុស្សពីបុរាណបានថ្លែង » និង « បានចែងទុកមកថា » ។ នៅពេលទ្រង់បានមានបន្ទូលថា « ប៉ុន្តែយើងប្រាប់អ្នករាល់គ្នាថា » នោះទ្រង់បានបង្ហាញពីរបៀបដែលទ្រង់ចង់ឲ្យយើងកាន់តាមព្រះបញ្ញត្តិនោះនាសព្វថ្ងៃនេះ ។

ដើម្បីជួយសិស្សឲ្យសិក្សាពីខគម្ពីរទាំងនេះ សូមគូសតារាងខាងក្រោមដាក់លើក្តារខៀន ។ សូមបំបែកសិស្សទៅជាបួនក្រុម ។សូមដាក់កិច្ចការមួយជូរដល់ក្រុមនីមួយៗ ក្នុងតារាង ហើយសូមឲ្យពួកគេអានខគម្ពីរដែលអមមកជាមួយ ហើយឆ្លើយនឹងសំណួរ ។

តើការយល់ដឹងបែបប្រពៃណីពីក្រិត្យវិន័យរបស់ម៉ូសេជាអ្វី ?	តើព្រះអង្គសង្គ្រោះបានណែនាំយើងឲ្យរស់នៅដោយរបៀបណា ?	តើយុវជន ឬយុវនារីអាចធ្វើអ្វីខ្លះដើម្បីអនុវត្តការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ?
នីហ្វៃទី ៣ ១២:២១	នីហ្វៃទី ៣ ១២:២២–២៦	
នីហ្វៃទី ៣ ១២:២៧	នីហ្វៃទី ៣ ១២:២៨–៣០	
នីហ្វៃទី ៣ ១២:៣៨	នីហ្វៃទី ៣ ១២:៣៩–៤២	
នីហ្វៃទី ៣ ១២:៤៣	នីហ្វៃទី ៣ ១២:៤៤–៤៦	

ចំពោះអត្ថប្រយោជន៍ដែលសិស្សអាន នីហ្វៃទី ៣ ១២:២២ អ្នកអាចពន្យល់ថា *អាចារអ្យ៉ាត* គឺជាពាក្យប្រមាថ ឬចំអក ដែលបង្ហាញពីការស្អប់ខ្ពើម ឬការមើលងាយ (សូមមើល ម៉ាថាយ ៥:២២) ។ អ្នកក៏អាចពន្យល់ថា អែលឌើរ ដេវីឌ អ៊ី. ស៊ូវិនសុន នៃក្រុមចិតសិបនាក់បានបង្រៀនថាឃ្លា « ព្រមព្រៀងជាមួយនឹងអ្នកដើមចោទអ្នកជាប្រញាប់ » (នីហ្វៃទី ៣ ១២:២៥) មានន័យថា « ដោះស្រាយភាពខុសគ្នារបស់យើងភ្លាមៗ ក្រែងចំណង់នៃពេលនោះទាក់ទាញទៅក្នុងភាពសាហាវខាងសាច់ឈាម ឬស្មារតី ហើយយើងធ្លាក់ជាចំណាប់ខ្មាំងនៃកំហឹងរបស់យើង » (« Forgiveness Will Change Bitterness to Love » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៣ ទំព័រ ១១) ។

នៅពេលសិស្សបានសិក្សាខគម្ពីរដែលដាក់ឲ្យគេហើយ សូមឲ្យក្រុមនីមួយៗរៀបរាប់ពីចម្លើយរបស់គេ ។ អ្នកអាចឲ្យពួកគេសរសេរចម្លើយរបស់ពួកគេនៅក្នុងតារាងនៅលើក្តារខៀន ។

- តើអ្វីដែលហាក់ដូចជាបានផ្លាស់ប្តូររវាងក្រិត្យវិន័យរបស់ម៉ូសេ និងក្រិត្យវិន័យដ៏ខ្ពស់ដែលបានបង្រៀនដោយព្រះយេស៊ូវគ្រីស្ទ ?

អ្នកអាចបង្ហាញថា ក្រិត្យវិន័យដ៏ខ្ពស់ផ្តោតខ្លាំងទៅលើបំណង គំនិត និងការលើកទឹកចិត្តរបស់យើង ជាជាងសំបកក្រៅរបស់យើង ។

- នៅពេលយើងខិតខំក្លាយទៅជាឥតខ្ចោះ ហេតុអ្វីបានជាវាសំខាន់ដើម្បីផ្តោតទៅលើបំណង គំនិត និងការលើកទឹកចិត្តយើង ?

សូមឲ្យសិស្សជ្រើសរើសការបង្រៀនមួយរបស់ព្រះអង្គសង្គ្រោះនៅក្នុង នីហ្វៃទី ៣ ១២ និងសរសេរឲ្យបានមួយកថាខ័ណ្ឌអំពីរបៀបដែលពួកគេនឹងពង្រឹងលើផ្នែកនោះ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១២:១៩–២០ ឮៗ ។ សូមជួយសិស្សឲ្យយល់ថា តាមរយៈការប្រែចិត្ត និងការខិតខំដោយឧស្សាហ៍ព្យាយាម ដើម្បីកាន់តាមព្រះបញ្ញត្តិដែលព្រះអង្គសង្គ្រោះបានបង្រៀន នោះយើងអាចក្លាយជាឥតខ្ចោះតាមរយៈដង្វាយធួន ហើយ « ចូលទៅក្នុងនគរស្ថានសួគ៌ » (នីហ្វៃទី ៣ ១២:២០) ។

ក្រោយពីសិស្សបានបញ្ចប់សកម្មភាពទាំងនេះហើយ សូមឲ្យពួកគេចែកចាយអ្វីដែលមានអត្ថន័យបំផុតចំពោះពួកគេ ។ សូមសង្ខេបជំពូកនេះ ដោយសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***នៅពេលយើងមកកាន់ព្រះគ្រីស្ទ ហើយកាន់តាមព្រះបញ្ញត្តិរបស់ទ្រង់ យើងអាចក្លាយដូចជាទ្រង់ និងព្រះវរបិតាដែលគង់នៅឯស្ថានសួគ៌របស់យើង ដែលទ្រង់បានឥតខ្ចោះ ។*** សូមពួកសិស្សថា ដើម្បីទទួលបានកម្រិតណាមួយ នៃភាពឥតខ្ចោះ យើងត្រូវតែពឹងផ្អែកលើដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សសរសេរអំពីរបៀបមួយ ឬពីរដែលពួកគេនឹងអនុវត្តតាមការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ដែលពួកគេបានរៀននាថ្ងៃនេះ ។ សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍ដែលអ្នកបានសរសេរនៅលើក្តារខៀន ។

ចំណេះចំណានខគម្ពីរ—នីហ្វៃទី ៣ ១២:៤៨

សូមឲ្យសិស្សបើកព្រះគម្ពីរទៅ នីហ្វៃទី ៣ ១២:៤៨ ។ សូមឲ្យពួកគេអានវគ្គនេះរៀងៗខ្លួន ។ សូមឲ្យសិស្សមានពេលដើម្បីសិក្សាខគម្ពីរនេះ ហើយបន្ទាប់មកសុំឲ្យពួកគេបិទព្រះគម្ពីរ ហើយទន្ទេញខគម្ពីរនេះម្តងទៀតឲ្យល្អឥតខ្ចោះ តាមដែលពួកគេអាចធ្វើបាន ។ សូមឲ្យពួកគេអានខគម្ពីរនេះម្តងទៀត ដោយបិទព្រះគម្ពីរ ហើយបន្ទាប់មកទន្ទេញខគម្ពីរនេះ ។

- តើអ្នកបានរីកចម្រើនដោយការខិតខំដោយរបៀបណា ?
- តើសកម្មភាពនេះជួយអ្នកឲ្យយល់ពីដំណើរការណ៍ឆ្ពោះទៅរកភាពឥតខ្ចោះដោយរបៀបណា ?

សូមបង្ហាញថា ការខិតខំរបស់យើងនៅក្នុងជីវិតនេះគឺសំខាន់ណាស់ ។ ទោះជាយ៉ាងណាក្តី សូមរំឭកសិស្សថា ព្រះអម្ចាស់មិនរំពឹងយើងឲ្យ ឥតខ្ចោះក្នុងគ្រប់ការណ៍ទាំងអស់អំឡុងពេលជីវិតរស់នៅលើផែនដីនោះទេ ។ តាមរយៈដង្វាយធួន និងការខិតខំដ៏ឧស្សាហ៍ព្យាយាមរបស់យើង ដើម្បីធ្វើតាមព្រះអង្គសង្គ្រោះ នោះនៅទីបញ្ចប់ យើងអាចក្លាយជាឥតខ្ចោះបាន ។ សូមឲ្យសិស្សគិតអំពីរបៀបមួយដែលពួកគេអាចខិតខំធ្វើតាមព្រះអង្គសង្គ្រោះ ។

កំណត់ចំណាំ ៖ ដោយសារតែមេរៀននេះវែង អ្នកអាចប្រើសកម្មភាពនេះនៅថ្ងៃក្រោយ នៅពេលអ្នកមានពេលច្រើន ។

នីហ្វៃទី ៣ ជំពូក ១៣

សេចក្តីផ្តើម

ព្រះអង្គសង្គ្រោះបានបន្តទេសនកថារបស់ទ្រង់នៅឯព្រះវិហារបរិសុទ្ធនៅដែនដីបរិបូរណ៍ ។ ទ្រង់បានព្រមានប្រជាជនកុំឲ្យធ្វើការលាក់ពុត និងបានបង្រៀនពួកគេឲ្យធ្វើកិច្ចការសុចរិត ដើម្បីឲ្យសព្វព្រះហឫទ័យដល់ព្រះវរបិតាសួគ៌ ។ ទ្រង់ក៏បានណែនាំហ្វូងមនុស្សឲ្យដាក់ទ្រព្យសម្បត្តិរបស់ពួកគេនៅឯស្ថានសួគ៌ និងបានណែនាំសាវករបស់ទ្រង់ឲ្យស្វែងរកនគរនៃព្រះពីមុនការខ្វាយខ្វល់ ខាងសាច់ឈាមរបស់ពួកគេផ្ទាល់ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៣ ១៣:១–១៩

ព្រះអង្គសង្គ្រោះបានព្រមានពួកសាសន៍នីហ្វៃកុំឲ្យធ្វើការលាក់ពុត និងបានបង្រៀនពួកគេឲ្យធ្វើកិច្ចការសុចរិត ដើម្បីឲ្យសព្វព្រះហឫទ័យដល់ព្រះវរបិតាសួគ៌

មុនចាប់ផ្តើមថ្នាក់ សូមរៀបចំក្រដាសនៃការវាយតម្លៃខ្លួនដូចខាងក្រោម និងថតចម្លងឲ្យសិស្សម្នាក់ៗ ។ ប្រសិនបើអ្នកមិនអាចធ្វើបានទេ អ្នកអាចរៀបរាប់ពីការវាយតម្លៃនេះ ឬសរសេរវានៅលើក្តារខៀន ។

១. ខ្ញុំធ្វើទាន (ទង្វើនៃការបូជាខាងសាសនា ឬការបម្រើដល់អ្នកដទៃ) ដោយសារ ៖

ក. ខ្ញុំគួរតែធ្វើ ។

ខ. ខ្ញុំស្រឡាញ់ព្រះអម្ចាស់ ហើយខ្ញុំពេញចិត្តនឹងជួយដល់មនុស្សផ្សេងទៀត ។

គ. ខ្ញុំចង់ឲ្យអ្នកដទៃគិតល្អអំពីខ្ញុំ ។

២. ខ្ញុំអធិស្ឋានដោយសារ ៖

ក. ខ្ញុំចង់ធ្វើដើម្បីអាចប្រាប់ដល់ឪពុកម្តាយរបស់ខ្ញុំ ឬប៊ីស្សពរបស់ខ្ញុំថា « បាទ/ចាំស » នៅពេលពួកលោកសួរខ្ញុំថា តើខ្ញុំបានអធិស្ឋានទេ ។

ខ. វាគ្រាន់តែជាផ្នែកមួយនៃទម្លាប់ប្រចាំថ្ងៃរបស់ខ្ញុំប៉ុណ្ណោះ ។

គ. ខ្ញុំចង់ទាក់ទងជាមួយនឹងព្រះវរបិតាសួគ៌ ។

៣. ខ្ញុំតមអាហារដោយសារ ៖

ក. ការតមអាហារជួយខ្ញុំឲ្យខិតកាន់តែជិតទៅរកព្រះអម្ចាស់ ។

ខ. អ្នកផ្សេងទៀតនឹងគិតថា ខ្ញុំទន់ខ្សោយ ប្រសិនបើខ្ញុំមិនតមអាហារទេ ។

គ. ឪពុកម្តាយរបស់ខ្ញុំប្រាប់ខ្ញុំថា ខ្ញុំគួរតែធ្វើការតមអាហារ ។

ដើម្បីចាប់ផ្តើមមេរៀននេះ សូមឲ្យសិស្សបំពេញការវាយតម្លៃខ្លួននេះ (មិនថាជាក្រដាស ឬនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ទេ) ដោយការបង្ហាញឃ្លាមួយណាដែលរៀបរាប់បានល្អបំផុតពីការតាំងចិត្តរបស់គេ ឬមូលហេតុនៃការធ្វើទាន ការអធិស្ឋាន ឬការតមអាហារ ។ សូមធានាសិស្សថា អ្នកនឹងមិនសុំគេឲ្យចែកចាយចម្លើយរបស់ពួកគេជាមួយនឹងអ្នកដទៃឡើយ ។ ក្រោយពីសិស្សបញ្ចប់ការវាយតម្លៃហើយ សូមបង្ហាញថា ចម្លើយដែលអាចមានសរសេរនៅក្រោមការធ្វើទាន ការអធិស្ឋាន ឬការតមអាហារ ឆ្លុះបញ្ចាំងពីការតាំងចិត្ត និងមូលហេតុខុសគ្នាដែលយើងអាចមានសម្រាប់ការធ្វើការណ៍ទាំងនេះ ឬសកម្មភាពដែលទាក់ទងទៅនឹងដំណឹងល្អផ្សេងទៀត (ឧទាហរណ៍ យើងអាចធ្វើវា ចេញពីកាតព្វកិច្ច ឬការណីយកិច្ច ដើម្បីបំផុសដល់មនុស្សផ្សេងទៀត ឬធ្វើឲ្យព្រះវរបិតាសួគ៌សព្វព្រះទ័យ) ។

- តើវាចោទជាបញ្ហាទេ ថាហេតុអ្វីបានជាយើងធ្វើកិច្ចការសុចរិតនោះ ? ហេតុអ្វីចោទ ឬហេតុអ្វីបានជាវាមិនចោទជាបញ្ហា ?

សូមសរសេរប្រធានបទខាងក្រោម និងសេចក្តីយោងព្រះគម្ពីរដែលមាននៅក្នុងប្រធានបទអមមកនៅលើក្តារខៀន (អ្នកអាចសរសេរវាមុនពេលចាប់ផ្តើមថ្នាក់) ៖

ទាន ៖ នីហ្វៃទី ៣ ១៣:១–៤

ការអធិស្ឋាន ៖ នីហ្វៃទី ៣ ១៣:៥–៦

ការតមអាហារ ៖ នីហ្វៃទី ៣ ១៣:១៦–១៨

សូមពន្យល់ថា នីហ្វៃទី ៣ ១៣ ប្រាប់ពីរបៀបដែលព្រះយេស៊ូវគ្រីស្ទបានបន្តណែនាំដល់ពួកសាសន៍នីហ្វៃនៅឯព្រះវិហារបរិសុទ្ធ និងបានបង្រៀនពួកគេអំពីសារៈសំខាន់នៃការតាំងចិត្តរបស់មនុស្សក្នុងការធ្វើទាន ការអធិស្ឋាន និងការតមអាហារ ។

សូមឲ្យសិស្សជ្រើសរើសប្រធានបទមួយក្នុងចំណោមប្រធានបទទាំងបីដែលសរសេរនៅលើក្តារខៀន ។ សូមឲ្យពួកគេអានវគ្គព្រះគម្ពីរដែលទាក់ទងដោយស្ងាត់ស្ងៀម ដោយរកមើលចម្លើយចំពោះសំណួរខាងក្រោម (អ្នកអាចសរសេរសំណួរទាំងនេះនៅលើក្តារខៀន) ៖

- តើការតាំងចិត្តអ្វីដែលព្រះអម្ចាស់បានព្រមានកុំឲ្យធ្វើ នៅពេលយើងធ្វើសកម្មភាពនេះ ?
- ចំពោះការធ្វើសកម្មភាពនោះ តើព្រះអម្ចាស់បានមានបន្ទូលថាយ៉ាងដូចម្តេច ?

មុនពេលសិស្សចាប់ផ្តើម វាអាចជួយដល់ពួកគេដើម្បី ឲ្យនិយមន័យ ពាក្យ *ការលាក់ពុត* ថាជានរណាម្នាក់ដែលក្លែងរូបរាងនៃភាពសុចរិត ឬអ្នកដែលនិយាយបាតដៃខ្នងដៃ ។

សូមឲ្យសិស្សពីរបីនាក់ចែកចាយចម្លើយដែលពួកគេបានរកឃើញដែលត្រូវនឹងសំណួរទាំងពីរនេះ ។ (ចេញពីការស្រាវជ្រាវរបស់ពួកគេ សិស្សអាចរកឃើញថា ព្រះអម្ចាស់បានព្រមានកុំឲ្យធ្វើកិច្ចការសុចរិតដើម្បីឲ្យមនុស្សឃើញឡើយ ហើយបានបង្រៀនថា យើងគួរធ្វើកិច្ចការសុចរិតដើម្បីធ្វើឲ្យព្រះវរបិតាសួគ៌សព្វព្រះទ័យ) ។ ដើម្បីជួយសិស្សឲ្យគិតកាន់តែជ្រៅអំពីការណ៍នេះ និងអនុវត្តតាមការបង្រៀនរបស់ព្រះអង្គសង្គ្រោះ សូមសួរសំណួរខាងក្រោម ៖

- តើការតាំងចិត្តរបស់យើងក្នុងការធ្វើកិច្ចការសុចរិត អាចជះឥទ្ធិពលចំពោះរបៀបដែលយើងធ្វើវាដោយរបៀបណា ?
- តើការតាំងចិត្តសុចរិតណាខ្លះដែលអាចបំផុសបុគ្គលម្នាក់ឲ្យធ្វើទាន អធិស្ឋាន ឬតមអាហារជាការសម្ងាត់ ?

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ប្រសិនបើយើងធ្វើកិច្ចការសុចរិតដើម្បីធ្វើឲ្យព្រះវរបិតាសួគ៌សព្វព្រះទ័យ . . .*

- យោងតាម នីហ្វៃទី ៣ ១៣:៤, ៦, ១៨ តើពរជ័យអ្វីខ្លះដែលនឹងមកដល់អស់អ្នកទាំងឡាយណាដែលធ្វើកិច្ចការសុចរិតដើម្បីធ្វើឲ្យព្រះវរបិតាសួគ៌សព្វព្រះទ័យ ? (នៅពេលសិស្សឆ្លើយ សូមបំពេញប្រយោគនៅលើក្តារខៀន ៖ ***ប្រសិនបើយើងធ្វើកិច្ចការសុចរិតដើម្បីធ្វើឲ្យព្រះវរបិតាសួគ៌សព្វព្រះទ័យ ទ្រង់នឹងប្រទានអង្វាន់ដល់យើងយ៉ាងបរិបូរណ៍***) ។

សូមឲ្យសិស្សរំឭកដោយសង្ខេបពីការវាយតម្លៃខ្លួនរបស់ពួកគេ ហើយវាយតម្លៃការតាំងចិត្តរបស់ពួកគេក្នុងការធ្វើទាន ការអធិស្ឋាន ឬការតមអាហារ ។ សូមឲ្យពួកគេគិតពីរបៀបដែលពួកគេអាចអនុវត្តការបង្រៀនរបស់ព្រះអង្គសង្គ្រោះដើម្បីពង្រឹងការតាំងចិត្តរបស់ពួកគេក្នុងការធ្វើការណ៍ទាំងនេះ ឬសកម្មភាពផ្សេងទៀត ដូចជា ការសិក្សាព្រះគម្ពីរ ការបង់ដង្វាយមួយភាគក្នុងដប់ ការចូលរួមក្នុងព្រះវិហារ និងការទទួលសាក្រាម៉ង់ ។

> ***ការឲ្យនិយមន័យពាក្យ ឬ ឃ្លាពិបាក***
>
> ភាសាព្រះគម្ពីរពេលខ្លះសិស្សអាចពិបាកយល់ ការឲ្យនិយមន័យពាក្យ ឬឃ្លាពិបាកអាចជួយសិស្សឲ្យយល់កាន់តែច្បាស់ មិនត្រឹមតែលើបរិបទនៃគ្នាជាក់លាក់មួយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសារលិខិតទាំងមូលរបស់អ្នកនិពន្ធដែលប្រកបដោយការព្យាករណ៍ ។ វចនានុក្រម លេខយោង និងជំនួយក្នុងការសិក្សាព្រះគម្ពីរអាចជាឧបករណ៍ដ៏មានប្រយោជន៍ដើម្បីជួយសិស្សឲ្យរកឃើញនូវអត្ថន័យនៃពាក្យ ឬឃ្លាពិសេសណាមួយ ។

នីហ្វៃទី ៣ ១៣:១៩–២៤

ព្រះយេស៊ូវគ្រីស្ទបង្រៀនហ្វូងមនុស្សឲ្យទុកទ្រព្យសម្បត្តិខ្លួនឯងនៅឯស្ថានសួគ៌វិញ

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ទ្រព្យសម្បត្តិនៅលើផែនដី* និង *ទ្រព្យសម្បត្តិនៅឯស្ថានសួគ៌* ។ សូមឲ្យសិស្សពិភាក្សាពីសំណួរខាងក្រោមជាមួយនឹងដៃគូ ៖

- តើគំរូណាខ្លះនៃទ្រព្យសម្បត្តិនៅលើផែនដី និងទ្រព្យសម្បត្តិនៅឯស្ថានសួគ៌ ?

ក្រោយពីសិស្សមានពេលពិភាក្សាគ្នាអំពីសំណួរនេះជាដៃគូហើយ អ្នកអាចសុំឲ្យសិស្សពីរបីនាក់ចែកចាយចម្លើយរបស់ពួកគេដល់សិស្សក្នុងថ្នាក់ ។ សូមគិតពីការលើកឡើងអំពីគំរូចេញពីជីវិតរបស់អ្នកនៃទ្រព្យសម្បត្តិនៅលើផែនដី (អ្នកអាចបង្ហាញរូបភាពពីរបស់ដ៏មានតម្លៃដែលអ្នកមាន) និងគំរូមួយនៃទ្រព្យសម្បត្តិនៅឯស្ថានសួគ៌ (អ្នកអាចបង្ហាញរូបភាពនៃគ្រួសារអ្នក ឬនិយាយអំពីសារៈសំខាន់នៃទីបន្ទាល់របស់អ្នក) ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៣:១៩–២៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយរកមើលការណែនាំដែលព្រះអង្គសង្គ្រោះបានប្រទានអំពីការស្វែងរកទ្រព្យសម្បត្តិនៅលើផែនដី និងទ្រព្យសម្បត្តិនៅឯស្ថានសួគ៌ ។

- យោងតាម នីហ្វៃទី ៣ ១៣:១៩–២០ តើទ្រព្យសម្បត្តិនៅលើផែនដីខុសពីទ្រព្យសម្បត្តិនៅឯស្ថានសួគ៌យ៉ាងដូចម្តេច ?
- តើការស្វែងរកទ្រព្យសម្បត្តិនៅលើផែនដី ទាញយើងឲ្យឯកចេញពីការស្វែងរកទ្រព្យសម្បត្តិនៅឯស្ថានសួគ៌យ៉ាងដូចម្តេច ? (អ្នកអាចបញ្ជាក់ថា ព្រះអង្គសង្គ្រោះមិនបានបង្រៀនថា ប្រាក់កាស ឬកម្មសិទ្ធិលើផែនដីអាក្រក់នោះទេ ប៉ុន្តែទ្រង់បានបញ្ជាក់ពីសារៈសំខាន់នៃការដាក់ដួងចិត្តរបស់យើងទៅលើទ្រព្យសម្បត្តិនៅឯស្ថានសួគ៌ដែលនៅឃ្លាតឆ្ងាយ) ។
- តើអ្នកគិតពីឃ្លាថា « បើភ្នែកអ្នកស្មោះស្ម័គ្រទាំងស្រុង » មានន័យយ៉ាងណានៅក្នុង នីហ្វៃទី ៣ ១៣:២២ ? (ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃឃ្លានេះ សូមនាំពួកគេឲ្យមើល សេចក្តីយោងការណែនាំតាមប្រធានបទនៅក្នុងលេខយោង ២២*គ* ។) តើអ្នកអាចបង្ហាញការស្មោះត្រង់ក្នុងការប្រមូលទ្រព្យសម្បត្តិនៅឯស្ថានសួគ៌ដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់សរសេរពាក្យ *ព្រះ* នៅលើក្រដាស ហើយបិទវាទៅមួយចំហៀង ។ សូមឲ្យសិស្សម្នាក់ទៀតសរសេរពាក្យ *រោកិយ* នៅលើក្រដាស ហើយដាក់វាទៅមួយចំហៀងទៀតផ្ទុយពីក្រដាសមុន ។ សូមឲ្យសិស្សទីបីឈរខាងមុខថ្នាក់ និងមើលទៅក្រដាសដែលសរសេរថា *ព្រះ* ។ បន្ទាប់មក សូមឲ្យសិស្សនោះបែរ ហើយមើលទៅក្រដាសដែលសរសេរថា *រោកិយ* ។ សូមឲ្យសិស្សនោះព្យាយាមមើលទៅក្រដាសទាំងពីរនៅពេលតែមួយ ។ សូមឲ្យសិស្សក្នុងថ្នាក់អាន នីហ្វៃទី ៣ ១៣:២៤ ដោយស្ងាត់ស្ងៀម ហើយគិតពីរបៀបដែលខគម្ពីរនេះទាក់ទងទៅនឹងបំណងរបស់សិស្សក្នុងការមើលទៅក្រដាសទាំងពីរក្នុងពេលតែមួយដូម្តេច ។ សូមពន្យល់ថាពាក្យ *ទ្រព្យសម្បត្តិ* តំណាងឲ្យភាពខាងលោកិយ ឬភាពមានបាន ។

- តើការបម្រើព្រះ និងទ្រព្យសម្បត្តិដូចជាការព្យាយាមមើលទៅជញ្ជាំងទាំងពីរនៅពេលតែមួយដោយរបៀបណា ?
- តើគំរូអ្វីខ្លះអាចជាការព្យាយមដើម្បីបម្រើដល់ព្រះ និងទ្រព្យសម្បត្តិនៅពេលតែមួយ ?

សូមឲ្យសិស្សក្នុងថ្នាក់ក្រោកឈរ ហើយមើលទៅក្រដាសដែលសរសេរថា *ព្រះ* ។

- ហេតុអ្វីបានជាវាសំខាន់ចំពោះអ្នកដើម្បីមានព្រះជាចៅហ្វាយរបស់អ្នក ?

- ផ្អែកលើព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះនៅក្នុង នីហ្វៃទី ៣ ១៣:២៤ តើអ្នកអាចប្រាប់ថា តើព្រះគឺជាចៅហ្វាយរបស់អ្នកដោយរបៀបណា ? (ទោះបីជាសិស្សអាចមានចម្លើយត្រូវច្រើនក្តី សូមប្រាកដថា ពួកគេរកឃើញគោលការណ៍ខាងក្រោម៖ **ដើម្បីមានព្រះជាចៅហ្វាយរបស់យើង យើងត្រូវតែស្រឡាញ់ និងបម្រើដល់ទ្រង់លើសពីអ្វីៗនៅលើផែនដីនេះ**) ។

ខណៈពេលដែលសិស្សកំពុងឈរ សូមអានគំរូខាងក្រោម ហើយសូមឲ្យពួកគេមើលទៅថ្នាក់រៀនម្ខាង ដែលតំណាងឲ្យចៅហ្វាយដែលពួកគេគិតថា មនុស្សកំពុងបម្រើ—*ព្រះ* ឬក៏ *លោកិយ* (ទ្រព្យសម្បត្តិ) ។ សូមឲ្យសិស្សពន្យល់ពីមូលហេតុដែលពួកគេបានជ្រើសរើសដើម្បីបែរទៅផ្លូវដែលពួកគេបានរើស ។ (អ្នកអាចសម្របខ្លួនទាហរណ៍ទាំងនេះទៅតាមកាលៈទេសៈ និងចំណាប់អារម្មណ៍របស់សិស្សអ្នក) ។

១. យុវជនម្នាក់បោះបង់ការងារមួយដែលធ្វើឲ្យគាត់ខកខានទៅចូលរួមប្រជុំនៅថ្ងៃអាទិត្យ ហើយផ្ទុយទៅវិញគាត់បានរើសយកការងារដែលទទួលបានប្រាក់ខែតិច តែមិនធ្វើ ឲ្យគាត់ខកខានទៅចូលរួមការប្រជុំឡើយ ។

២. យុវនារីម្នាក់រអ៊ិជាញឹកញាប់ទៅកាន់ឪពុកម្តាយរបស់នាងអំពីតម្រូវការសំលៀកបំពាក់ថ្មី ។ សំលៀកបំពាក់ដែលនាងចង់ទិញមានតម្លៃថ្លៃជាងអ្វីដែលគ្រួសារនាងអាចទិញបាន ។

៣. យុវជនម្នាក់បង់ដង្វាយមួយភាគដប់របស់គាត់ជាប្រចាំ ពីលុយដែលគាត់ទទួលបានពីការងារ ។ ទោះជាយ៉ាងណាក្តី គាត់ប្រើប្រាក់ចំណូលទាំងអស់ដែលនៅសល់របស់គាត់ទៅទិញឧបករណ៍កំសាន្ត ដែលមានរឿង និងចម្រៀងមិនសមរម្យខ្លះ ហើយមិនបានសន្សំលុយដើម្បីបង់ថ្លៃបេសកកម្ម ឬសម្រាប់ការអប់រំឡើយ ។

៤. យុវនារីម្នាក់ប្រើចំណូលរបស់នាងខ្លះទៅទិញអំណោយតូចតាចដើម្បីបង្ហាញសេចក្តីស្រឡាញ់ដល់អ្នកដទៃជាញឹកញាប់ ។

បន្ទាប់ពីសកម្មភាពនេះហើយ សូមឲ្យសិស្សរអង្គុយចុះ ហើយបន្ទាប់មកសូមសួរពួកគេនូវសំណួរខាងក្រោម ៖

- ផ្អែកលើបទពិសោធន៍អ្នក ហេតុអ្វីបានជាវាពិបាក ដើម្បីស្រឡាញ់ និងបម្រើព្រះជានិច្ច ជាងរឿងខាងលោកិយ ? ហេតុអ្វីបានជាការដាក់ព្រះជាមុន សក្តិសមនឹងការខិតខំនេះ ?

នីហ្វៃទី ៣ ១៣:២៥–៣៤

ព្រះអង្គសង្គ្រោះណែនាំពួកសាវកដប់ពីរនាក់ឲ្យស្វែងរកនគរព្រះ មុនខ្វល់នឹងសាច់ឈាមរបស់គេ

សូមសង្ខេប នីហ្វៃទី ៣ ១៣:២៥–៣១ ដោយប្រាប់សិស្សថា ព្រះយេស៊ូវគ្រីស្ទបានណែនាំពួកសាវកដប់ពីរនាក់របស់ទ្រង់កុំឲ្យបារម្ភអំពីសេចក្តីត្រូវការខាងសាច់ឈាមដែលជាអាហារ និងសំលៀកបំពាក់របស់ពួកលោកឡើយ ។ សូមបង្ហាញថា ទោះបីជាការបង្រៀនទាំងនេះត្រូវបានផ្តល់ជាពិសេសទៅដល់ពួកសាវកទាំងដប់ពីរនាក់ក្តី ក៏គោលការណ៍នេះបង្ហាញថា វាអាចត្រូវបានអនុវត្តជាទូទៅដែរ ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៣:៣២–៣៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយរកមើលរបៀបដែលព្រះអង្គសង្គ្រោះបានលួងលោមពួកសាវករបស់ទ្រង់ទាក់ទងទៅនឹងតម្រូវការខាងសាច់ឈាមរបស់ពួកលោក ។

- តើការដឹងថា ព្រះទ្រង់ញាណដឹងពីសេចក្តីត្រូវការរបស់យើង អាចជួយយើងយ៉ាងដូចម្តេចដែរ ?
- យោងតាម នីហ្វៃទី ៣ ១៣:៣៣ តើព្រះយេស៊ូវគ្រីស្ទបានសន្យាអ្វីខ្លះដល់អស់អ្នកទាំងឡាយណាដែលបានដាក់ព្រះ និងនគររបស់ទ្រង់ជាចម្បងនៅក្នុងជីវិតរបស់គេ ? (ទោះបីជាសិស្សអាចមានចម្លើយខុសគ្នាក្តី សូមប្រាកដថា ពួកគេរកឃើញគោលការណ៍ខាងក្រោម៖ **ប្រសិនបើយើងស្វែងរកនគររបស់ព្រះជាមុន នោះទ្រង់នឹងជួយយើងឲ្យទទួលបានតម្រូវការរបស់យើង ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលមិត្តជិតដិតរបស់អ្នក ឬ សមាជិកគ្រួសាររបស់អ្នកម្នាក់ដាក់ចំណាប់អារម្មណ៍ និងតម្រូវការរបស់អ្នកលើសពីចំណាប់អារម្មណ៍ និងតម្រូវការរបស់ខ្លួនគេផ្ទាល់នោះ ? តើយើងទាក់ទងទៅនឹងព្រះវរបិតាសួគ៌ និងព្រះអង្គសង្គ្រោះអ្វីខ្លះ នៅពេលយើងដាក់ទ្រង់លើសពីតម្រូវការ និងចំណាប់អារម្មណ៍ខាងសាច់ឈាមរបស់យើងផ្ទាល់នោះ ?

សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅសរសេរ ឬ កំណត់ហេតុសិក្សាព្រះគម្ពីរក្នុងថ្នាក់នូវគោលដៅមួយទាក់ទងទៅនឹងរឿងមួយដែលពួកគេអាចធ្វើ ដើម្បីដាក់ព្រះជាមុននៅក្នុងជីវិតរបស់គេ ។ អ្នកអាចបញ្ចប់មេរៀននេះដោយការថ្លែងទីបន្ទាល់អំពីពរជ័យដែលអ្នកទទួលបាន នៅពេលអ្នកបានព្យាយាមដាក់ព្រះ និងនគររបស់ទ្រង់ជាចម្បងនៅក្នុងជីវិតរបស់អ្នក ។

នីហ្វៃទី៣ ជំពូកទី ១៤

សេចក្តីផ្តើម

នៅពេលដែលព្រះយេស៊ូវគ្រីស្ទបានបន្តទេសនកថារបស់ទ្រង់នៅឯព្រះវិហារបរិសុទ្ធនៅក្នុងដែនដីបរិបូរណ៍ នោះទ្រង់បានព្រមានដល់ប្រជាជនអំពីការកាត់សេចក្តីអ្នកដទៃ និងបានបង្រៀនពួកគេឲ្យស្វែងរកនូវពរជ័យពីព្រះវរបិតាសួគ៌ដោយការអធិស្ឋាន និងការធ្វើតាមព្រះឆន្ទៈរបស់ទ្រង់ ។ ព្រះអង្គសង្គ្រោះក៏បានព្រមានពួកគេអំពីព្យាការីក្លែងក្លាយ និងបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការធ្វើតាមព្រះឆន្ទៈរបស់ព្រះវរបិតា ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៣ ១៤:១–៦

ព្រះអង្គសង្គ្រោះបង្រៀនអំពីការកាត់សេចក្តីសុចរិត

ដើម្បីរៀបចំសិស្សឲ្យសិក្សាពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះ អំពីការកាត់សេចក្តីសុចរិត សូមអានរឿងខាងក្រោមដែលបានតំណាលដោយប្រធាន ថូម៉ាស អេស ម៉ុនសុន ៖

« គូស្វាមីភរិយាក្មេងមួយគូ លីសា និងចន បានផ្លាស់ទីលំនៅទៅសង្កាត់ថ្មីមួយ ។ នាព្រឹកមួយខណៈពេលដែលពួកគេកំពុងបរិភោគអាហារពេលព្រឹក លីសាបានមើលទៅក្រៅបង្អួច ហើយបានឃើញអ្នកជិតខាងរបងតែមួយកំពុងតែហាលខោអាវ ។

« ‹ ខោអាវនោះបោកមិនស្អាតសោះ ! › លីសាលាន់មាត់ ។ ‹ អ្នកជិតខាងរបស់យើងមិនដឹងពីរបៀបដើម្បីបោកខោអាវឲ្យស្អាតទេ ! ›

ចនបានក្រឡេកមើល ប៉ុន្តែមិនមាត់ឡើយ ។

« រាល់ពេលដែលអ្នកជិតខាងរបស់នាងហាលខោអាវ លីសានិយាយពាក្យដដែលៗ ។

« ពីរបីសប្តាហ៍ក្រោយមក លីសា ភ្ញាក់ខ្លួនពេលមើលទៅបង្អួចរបស់នាង ហើយឃើញខោអាវយ៉ាងស្អាតដាក់ហាលនៅសួនច្បាររបស់អ្នកជិតខាងនាង ។ នាងបាននិយាយទៅកាន់ស្វាមីនាងថា ‹ មើលន៎ ចន !— នាងបានរៀនចេះពីរបៀបបោកខោអាវឲ្យស្អាតហើយ ខ្ញុំឆ្ងល់ថាតើនាងបានធ្វើវាដោយរបៀបណា ។ ›

« ចនបានឆ្លើយថា ‹ អូនសម្លាញ់ បងមានចម្លើយសម្រាប់អូន ។ អូននឹងចាប់អារម្មណ៍ពេលដឹងថា បងបានក្រោកពីព្រលឹមនាព្រឹកនេះ ហើយបានជូតសម្អាតបង្អួចរបស់យើង ! › » (« Charity Never Faileth » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ១២២) ។

- តើមេរៀនអ្វីដែលយើងអាចរៀនពីរឿងនេះ ?

សូមពន្យល់ថា នីហ្វៃទី ៣ ១៤ រួមមានការបន្តនៃការបង្រៀនរបស់ព្រះអង្គសង្គ្រោះមួយទៅដល់ប្រជាជននីហ្វៃនៅឯព្រះវិហារបរិសុទ្ធ ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៤:១–២ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយរកមើលការព្រមានដែលព្រះយេស៊ូវគ្រីស្ទបានប្រាប់អំពីការកាត់សេចក្តីអ្នកដទៃ ។ អ្នកអាចពន្យល់ថាពាក្យ *វាល់* ដែលមាននៅក្នុង នីហ្វៃទី ៣ ១៤:២ មានន័យថាវាស់ ឬកាត់សេចក្តី ។ ឃ្លា « ដោយរង្វាល់ដែលអ្នករាល់គ្នាវាល់ » សំដៅលើបទដ្ឋានដែលបុគ្គលម្នាក់ប្រើដើម្បីវាល់ ឬកាត់សេចក្តីមនុស្សផ្សេងទៀត ។

- តើអ្នកនឹងបង្ហាញសេចក្តីពិតនៅក្នុង នីហ្វៃទី ៣ ១៤:២ ជាសម្តីរបស់អ្នកផ្ទាល់ដោយរបៀបណា ? (ចម្លើយរបស់សិស្សអាចឆ្លុះបញ្ចាំងអំពីសេចក្តីពិតខាងក្រោមនេះ ៖ **យើងនឹងត្រូវគេកាត់សេចក្តីស្របតាមរបៀបដែលយើងកាត់សេចក្តីអ្នកដទៃ ។**)

ដើម្បីជួយសិស្សឲ្យយល់ពីការបញ្ជារបស់ព្រះអង្គសង្គ្រោះដើម្បី « កុំកាត់សេចក្តី » នៅក្នុង នីហ្វៃទី ៣ ១៤:១ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក នៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សស្តាប់រកនូវប្រភេទនៃការកាត់សេចក្តីដល់អ្នកដទៃដែលយើងត្រូវចៀសវាង ។

« ការវិនិច្ឆ័យចុងក្រោយ . . . គឺថាឱកាសនាពេលអនាគតដែលយើងទាំងអស់គ្នានឹងឈរនៅខាងមុខកៅអីនៃការជំនុំជម្រះរបស់ព្រះគ្រីស្ទដើម្បីទទួលការជំនុំជម្រះស្របតាមកិច្ចការរបស់យើង ។ . . . ខ្ញុំជឿថា ការបញ្ជានៃព្រះគម្ពីរដើម្បី ‹ កុំកាត់សេចក្តី › សំដៅយ៉ាងច្បាស់បំផុតទៅលើការវិនិច្ឆ័យចុងក្រោយនេះ ។ . . .

« . . . ហេតុអ្វីបានជាព្រះអង្គសង្គ្រោះដាក់បញ្ញត្តិថា កុំឲ្យយើងវិនិច្ឆ័យការកាត់សេចក្តីនៅថ្ងៃចុងក្រោយ ? ខ្ញុំជឿថា បទបញ្ញត្តិនេះត្រូវបានប្រទានឲ្យ ដោយសារយើងគិតថានឹងធ្វើការវិនិច្ឆ័យថ្ងៃចុងក្រោយ នៅពេលណាដែលយើងស្តែងថា មនុស្សមួយចំនួននឹងទៅស្ថាននរក (ឬទៅស្ថានសួគ៌) ដោយសារទង្វើមួយចំនួន នៅក្នុងពេលណាមួយ ។ នៅពេលយើងធ្វើដូចនេះ —ហើយមានការល្បួងដ៏ធំមួយឲ្យធ្វើដូច្នេះ— យើងនឹងធ្វើឲ្យខ្លួនឯង និងបុគ្គលដែលយើងវិនិច្ឆ័យឈឺចាប់ ។ . . .

« . . . ដំណឹងល្អគឺជាដំណឹងល្អនៃសេចក្តីសង្រ្គឹម ហើយគ្មាននរណាម្នាក់ក្នុងចំណោមយើងត្រូវបានប្រគល់សិទ្ធិឲ្យបដិសេធអំណាចនៃដង្វាយធួន ដើម្បីនាំមកនូវការសម្អាតនៃអំពើបាបរបស់បុគ្គល ការអភ័យទោស និងការកែប្រែជីវិតទៅតាមលក្ខខណ្ឌសមរម្យឡើយ » (« 'Judge Not' and Judging » *Ensign,* ខែ **សីហា** ឆ្នាំ **១៩៩៩**, ទំព័រ **៧**, **៩**) ។

- តើសេចក្តីថ្លែងការណ៍របស់អែលឌើរ អូក ជួយអ្នកឲ្យយល់ពីបទបញ្ញត្តិរបស់ព្រះអង្គសង្រ្គោះដើម្បី « វិនិច្ឆ័យ » គេ ដោយរបៀបណា ?

សូមបង្ហាញរបស់ដែលល្អិតៗ ដូចជាបំណែកឈើតូច ។ សូមពន្យល់ថាអត្ថន័យផ្សេងទៀត នៃពាក្យល្អិតគឺ *កំទេច* ។ បន្ទាប់មកសូមបង្ហាញ (ឬ សូមគូសនៅលើក្តារខៀន) នូវធ្នឹមឈើមួយ ឬឈើវែងមួយមែក ។ សូមប្រាប់សិស្សថា ព្រះអង្គសង្រ្គោះបានសំដៅលើកំទេចមួយ និងធ្នឹមមួយ ដើម្បីជួយយើងឲ្យយល់ពីបញ្ហាដែលនឹងកើតឡើង នៅពេលយើងវិនិច្ឆ័យអ្នកដទៃដោយមិនសុចរិត ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៤:៣–៥ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់គិតអំពីអ្វីដែលតំណាងឲ្យកំទេច និងធ្នឹម ។

- តើកំទេចតំណាងឲ្យអ្វី ? (កំហុសមួយដែលយើងមើលឃើញនៅលើអ្នកដទៃ) ។ តើធ្នឹមតំណាងឲ្យអ្វី ? (កំហុសរបស់យើងផ្ទាល់ ។)

សូមបង្ហាញថា រឿងតំណាលរបស់ព្រះអង្គសង្រ្គោះផ្តោតលើវត្ថុដែលជាប់នៅក្នុងភ្នែក ។ របស់បែបនោះនឹងប៉ះពាល់ដល់ការគិតរបស់បុគ្គលម្នាក់ ។

- តើកំហុសរបស់យើងអាចប៉ះពាល់ដល់របៀបដែលយើងមើលទៅអ្នកដទៃដោយរបៀបណា ?

សូមឲ្យសិស្សគិតថាតើវាសមទេ ដែលវិនិច្ឆ័យអ្នកដទៃនោះ ។ សូមឲ្យពួកគេសញ្ជឹងគិតពីសំណួរនេះមួយសន្ទុះ ។ បន្ទាប់មក សូមពន្យល់ថា នៅក្នុងការបកប្រែដ៏បំផុសគំនិតនៃ ម៉ាថាយ ៧:១ ព្យាការី យ៉ូសែប ស៊្មីធ បានបញ្ជាក់ពីការបង្រៀនរបស់ព្រះអង្គសង្រ្គោះអំពីការវិនិច្ឆ័យអ្នកដទៃ ។ យោងតាម យ៉ូសែប ស៊្មីធ ព្រះអង្គសង្រ្គោះ បានមានបន្ទូលថា « កុំថ្កោលទោសគេឡើយ ដើម្បីមិនឲ្យមានគេថ្កោលអ្នកវិញ ៖ ប៉ុន្តែកាត់សេចក្តីសុចរិតវិញ » (ការបកប្រែរបស់ យ៉ូសែប ស៊្មីធ ម៉ាថាយ ៧:១ | នៅក្នុង ម៉ាថាយ ៧:១, លេខយោង *ក* |) ។ សូមឲ្យសិស្សម្នាក់អានការពន្យល់ខាងក្រោមនៅក្នុង *ពិតចំពោះសេចក្តីជំនឿ ៖*

« ពេលខ្លះមនុស្សមានអារម្មណ៍ថា វាខុសក្នុងការវិនិច្ឆ័យអ្នកដទៃតាមរបៀបណាក្តី ។ ខណៈពេលដែលវាពិតថា អ្នកមិនគួរដាក់ទោសអ្នកដទៃ ឬវិនិច្ឆ័យពួកគេដោយមិនសុចរិត នោះអ្នកនឹងត្រូវវិនិច្ឆ័យលើគំនិត ស្ថានភាព ហើយនិងមនុស្សនោះពេញមួយជីវិតរបស់អ្នក ។ ព្រះអម្ចាស់បានប្រទានព្រះបញ្ញត្តិជាច្រើនថា អ្នកមិនអាចរក្សាបានទេ បើអ្នកកាត់សេចក្តីនោះ » (*ពិតចំពោះសេចក្តីជំនឿ ៖ សេចក្តីយោងដំណឹងល្អ* | ឆ្នាំ ២០០៤ |, ទំព័រ ៩០) ។

ដើម្បីជួយសិស្សឲ្យឃើញថា ព្រះអង្គសង្រ្គោះបានបង្រៀនអំពីសារៈសំខាន់នៃការវិនិច្ឆ័យសុចរិត សូមឲ្យពួកគេអាន នីហ្វៃទី ៣ ១៤:៦ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើលការវិនិច្ឆ័យខ្លះដែលទ្រង់បានណែនាំយើងឲ្យធ្វើ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើវាមានន័យយ៉ាងណា កុំឲ្យរបស់បរិសុទ្ធដល់ឆ្កែ ឬបោះកែវមុក្តារបស់ខ្លួននៅមុខជ្រូកឡើយ ? (ការចែកចាយអ្វីមួយដែលពិសិដ្ឋដល់អ្នកទាំងឡាយណាដែលនឹងមិនកោតសរសើរដល់វា ឬផ្តល់កិត្តិយសដល់ភាពពិសិដ្ឋរបស់វា) ។
- តើការបង្រៀនរបស់ព្រះអង្គសង្រ្គោះនៅក្នុង នីហ្វៃទី ៣ ១៤:៦ តម្រូវឲ្យយើងវិនិច្ឆ័យអ្នកដទៃដោយរបៀបណា ?

ក្រោយពីសិស្សឆ្លើយហើយ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាលិន អេក អូក អំពីស្ថានភាពផ្សេងទៀតដែលយើងត្រូវធ្វើការវិនិច្ឆ័យ ៖

« យើងទាំងអស់គ្នាធ្វើការ វិនិច្ឆ័យក្នុងការជ្រើសរើសមិត្តភក្តិ ក្នុងការជ្រើសរើសរបៀបដែលយើងនឹងចំណាយពេលរបស់យើង និងប្រាក់កាសរបស់យើង ហើយប្រាកដណាស់ គឺក្នុងការជ្រើសរើសដៃគូដ៏អស់កល្បជានិច្ច ។ . . .

« . . . ការវិនិច្ឆ័យដ៏សុចរិតនឹងត្រូវបានដឹកនាំដោយព្រះវិញ្ញាណនៃព្រះអម្ចាស់ មិនមែនដោយកំហឹង ដោយការសងសឹក ការច្រណែន ឬការចាប់អារម្មណ៍ផ្ទាល់ខ្លួននោះទេ » (« 'Judge Not' and Judging » ទំព័រ **៩**) ។

- តើហេតុអ្វីបានជាវាសំខាន់ដើម្បីធ្វើការវិនិច្ឆ័យសុចរិតក្នុងផ្នែកដូចជា ការជ្រើសរើសមិត្តភក្តិ ការសម្រេចចិត្តលើរបៀបដែលយើងចំណាយពេល និងប្រាក់កាសរបស់យើង និងការជ្រើសរើសដៃគូដ៏អស់កល្បជានិច្ច ?
- តើមានស្ថានភាពផ្សេងទៀតណាខ្លះដែលយើងត្រូវធ្វើការវិនិច្ឆ័យដោយសុចរិតលើអ្នកដទៃ ? (សិស្សអាចលើកឡើងពីការជ្រើសរើសរវាងនិយោជកមានសក្តានុពល ឬការជ្រើសរើសថាតើត្រូវទទួលយកការអញ្ជើញទៅជួបគ្នាឬទេ) ។

នីហ្វៃទី ៣ ១៤:៧–១១

ព្រះអង្គសង្រ្គោះបង្រៀនអំពីការស្វែងរកពរជ័យទាំងឡាយពីព្រះវរបិតាសួគ៌

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១៤:៧–១១ ស្ងាត់ៗ ដោយរកមើលការបង្រៀនរបស់ព្រះអង្គសង្រ្គោះអំពីព្រះឆន្ទៈរបស់ព្រះវរបិតាសួគ៌ក្នុងការឆ្លើយតបចំពោះការអធិស្ឋានរបស់យើង ។ សូមពន្យល់ថា ប្រសិនបើឪពុកលើផែនដី ដែលមានចិត្តល្អ និងជាទីស្រឡាញ់ប៉ុន្តែមិនឥតខ្ចោះ នឹងផ្តល់នំប៉័ង និងត្រីដល់កូនចៅរបស់ខ្លួន ជំនួសឲ្យដុំថ្ម និងពស់ពិស នោះព្រះវរបិតាសួគ៌ដែលមានព្រះទ័យល្អ និងជាទីស្រឡាញ់ដ៏ឥតខ្ចោះ ប្រាកដជាឆ្លើយតបនឹងការអធិស្ឋានសុំជំនួយរបស់ទ្រង់ ។

- តើគោលការណ៍អ្វីដែលយើងអាចរៀនពី នីហ្វៃទី ៣ ១៤:៧–១១ ? (សិស្សអាចរកឃើញនូវគោលការណ៍ខុសគ្នា ។ គោលការណ៍មួយដែលអ្នកអាចបញ្ជាក់គឺ **ព្រះវរបិតាសួគ៌ប្រទានពរដល់យើង នៅពេលយើងអធិស្ឋានសុំជំនួយពីទ្រង់**) ។
- ហេតុអ្វីបានជាវាសំខាន់ដល់អ្នកដើម្បីដឹងថា ព្រះវរបិតាសួគ៌នឹងឆ្លើយចំពោះការអធិស្ឋានរបស់អ្នក ?

- តើនៅពេលណាដែលអ្នកទទួលអារម្មណ៍នៃសេចក្តីស្រឡាញ់របស់ព្រះវរបិតាសួគ៌ដល់អ្នក តាមរយៈរបៀបដែលទ្រង់បានឆ្លើយតបទៅនឹងការអធិស្ឋានរបស់អ្នក ? (អ្នកអាចឲ្យសិស្សសញ្ជឹងគិតពីសំណួរនេះមួយសន្ទុះ មុនពេលពួកគេឆ្លើយ ។ សូមគិតដងដែរពីការចែកចាយបទពិសោធន៍របស់អ្នកផ្ទាល់) ។

នីហ្វៃទី ៣ ១៤:១២–២៧

ព្រះអង្គសង្គ្រោះបង្រៀនយើងពីសារៈសំខាន់នៃការធ្វើតាមព្រះឆន្ទៈរបស់ព្រះវរបិតាសួគ៌

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១៤:១២ ដោយស្ងាត់ស្ងៀម ហើយសុំឲ្យពួកគេគិតពីរបៀបដែលការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងខគម្ពីរនេះអាចជួយពួកគេឲ្យក្លាយដូចជាព្រះវរបិតាសួគ៌កាន់តែខ្លាំង ។

- តើការគោរពតាមការណែនាំនៅក្នុង នីហ្វៃទី ៣ ១៤:១២ អាចជួយយើងឲ្យក្លាយដូចជាព្រះវរបិតាសួគ៌កាន់តែខ្លាំងដោយរបៀបណា ?

សូមប្រាប់សិស្សថា នៅពេលដែលព្រះអង្គសង្គ្រោះបន្តបង្រៀន នោះទ្រង់បានប្រើ ភាពស្រដៀងគ្នា ដ៏មានព្រះចេស្តាដើម្បីជួយយើងឲ្យយល់ពីសារៈសំខាន់នៃការធ្វើតាមព្រះឆន្ទៈរបស់ព្រះវរបិតាសួគ៌ ។

ដើម្បីរៀបចំសិស្សឲ្យសិក្សាពី ភាពស្រដៀងគ្នារបស់ព្រះអង្គសង្គ្រោះនៅក្នុង នីហ្វៃទី ៣ ១៤ សូមដឹកនាំនូវសកម្មភាពខាងក្រោម ។

សូមបំបែកសិស្សជាក្រុមដែលមានគ្នា ២ ឬ ៤ នាក់ក្នុងមួយក្រុម ។ សូមឲ្យក្រដាសដល់សិស្ស ។ សូមសរសេរវគ្គព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ហើយសូមដាក់កិច្চការមួយឲ្យដល់ក្រុមនីមួយៗ ៖ *នីហ្វៃទី ៣ ១៤:១៣–១៤; នីហ្វៃទី ៣ ១៤:១៥–២០; នីហ្វៃទី ៣ ១៤:២៤–២៧* ។ (ប្រសិនបើអ្នកមានសិស្សច្រើន សូមដាក់វគ្គព្រះគម្ពីរឲ្យសិស្សច្រើនជាងមុនក្នុងក្រុមនីមួយៗ) ។ សូមឲ្យសិស្សអានកិច្চការព្រះគម្ពីររបស់គេ ហើយគូសរូបភាពនៃភាពស្រដៀងគ្នាដែលព្រះអង្គសង្គ្រោះបានប្រើ ។ សូមឲ្យពួកគេសរសេរអ្វីដែលពួកគេរៀនពីភាពស្រដៀងគ្នាដងដែរ ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបង្ហាញរូបភាពរបស់គេដល់សិស្សក្នុងថ្នាក់ ហើយពន្យល់អ្វីដែលពួកគេបានរៀន ។ នៅពេលសិស្សបង្ហាញពីអ្វីដែលពួកគេបានរៀន សូមសួរសំណួរដូចខាងក្រោម ៖

- តើការគោរពតាមការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទដូចជាការដើរតាមផ្លូវដ៏តូចចង្អៀតមួយដោយរបៀបណា ? តើការបដិសេធការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទដូចជាការដើរតាមផ្លូវដ៏ធំទូលាយមួយដោយរបៀបណា ? (សូមមើល នីហ្វៃទី ៣ ១៤:១៣–១៤) ។តើរបៀបណាខ្លះដែលការបង្រៀនរបស់ព្រះអង្គសង្គ្រោះខុសពីការបង្រៀនរបស់ពិភពលោក ?
- ហេតុអ្វីបានជាសត្វចចកនឹងក្លែងខ្លួនធ្វើជាចៀម ? (សូមអាន នីហ្វៃទី ៣ ១៤:១៥) ។តើភាពស្រដៀងគ្នានេះប្រាប់យើងអំពីបំណាងនិងសកម្មភាពរបស់ព្យាការីក្លែងក្លាយអ្វីខ្លះ ?
- ប្រសិនបើដើមឈើនៅក្នុង នីហ្វៃទី ៣ ១៤:១៦–២០ តំណាងឲ្យមនុស្ស តើផ្លែវាអាចតំណាងឲ្យអ្វី ? (ចម្លើយអាចរួមមាន គំនិតរបស់មនុស្ស សម្តី សកម្មភាព និងឥទ្ធិពលទៅលើអ្នកដទៃ) ។
- នៅពេលណាដែលយើងស្តាប់តាមព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ និងធ្វើតាមទ្រង់ តើយើងអាចដូចជាបុរសម្នាក់ដែលសង់ផ្ទះរបស់គាត់នៅលើថ្មដោយរបៀបណា ? (សូមមើល នីហ្វៃទី ៣ ១៤:២៤–២៥) ។ប្រសិនបើយើងជ្រើសធ្វើសមិនធ្វើតាមព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ តើយើងអាចដូចជាបុរសម្នាក់ដែលសង់ផ្ទះរបស់គាត់នៅលើខ្សាច់ដោយរបៀបណា ? (សូមមើល នីហ្វៃទី ៣ ១៤:២៦–២៧) ។

ក្រោយពីការបង្ហាញ និងការពិភាក្សារបស់សិស្សហើយ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៤:២១–២៣ ឮៗ ។

- តើយើងអាចរៀនអ្វីខ្លះពី នីហ្វៃទី ៣ ១៤:២១ ? (សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរបង្ហាញនូវសេចក្តីពិតដូចខាងក្រោម [សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន] ៖ ***យើងត្រូវតែធ្វើតាមព្រះឆន្ទៈរបស់ព្រះវរបិតាសួគ៌ដើម្បីចូលទៅក្នុងនគរស្ថានសួគ៌*** ។)
- តើសេចក្តីពិតនេះទាក់ទងទៅនឹងការបង្ហាញនៃផ្លូវដ៏ធំ និងចង្អៀត ដើមឈើដ៏ល្អ និងអាក្រក់ និងបុរសដ៏ឆ្លាត និងបុរសល្ងង់ដោយរបៀបណា ?

សូមឲ្យសិស្សមានពេលសញ្ជឹងគិត និងអនុវត្តអ្វីដែលពួកគេបានរៀនពី នីហ្វៃទី ៣ ១៤ ។ សូមឲ្យពួកគេសរសេរនៅក្នុងសៀវភៅសរសេរឬកំណត់ហេតុការសិក្សាព្រះគម្ពីរអំពីរបៀបដែលពួកគេនឹងពង្រឹងការខិតខំរបស់ពួកគេ ក្នុងការធ្វើតាមការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុង នីហ្វៃទី ៣ ១៤ ។ បើមានពេលវេលា សូមឲ្យសិស្សពីរបីនាក់សង្ខេបពីអ្វីដែលពួកគេបានរៀន និងចែកចាយអ្វីដែលពួកគេនឹងធ្វើដោយសារតែអ្វីដែលពួកគេបានរៀននេះ ។ អ្នកអាចបញ្ចប់ដោយការថ្លែងទីបន្ទាល់អំពីពរជ័យដែលអ្នកបានទទួល នៅពេលដែលអ្នកបានធ្វើតាមព្រះឆន្ទៈរបស់ព្រះវរបិតាសួគ៌ ។

នីហ្វៃទី ៣ ១៥–១៦

សេចក្តីផ្តើម

នៅពេលដែលព្រះយេស៊ូវគ្រីស្តបានបន្តបង្រៀនដល់ប្រជាជននៅឯព្រះវិហារបរិសុទ្ធនៅក្នុងដែនដីបរិបូរណ៍ ទ្រង់បានប្រកាសថា ក្រិត្យវិន័យរបស់ម៉ូសេត្រូវបានបំពេញហើយ ថាទ្រង់គឺជាពន្លឺ និងជាច្បាប់ដែលប្រជាជនត្រូវមើលតាម ។ បន្ទាប់មក ទ្រង់បានពន្យល់ដល់ពួកសាវកទាំងដប់ពីរនាក់ថា ប្រជាជននៅក្នុងដែនដីអាមេរិកគឺជា « ចៀមឯទៀត » ដែលទ្រង់បានមានបន្ទូលនៅក្នុងទីក្រុងយេរូសាឡិម (សូមមើល យ៉ូហាន ១០:១៤–១៦) ។ ទ្រង់ក៏បានសន្យាថា អស់អ្នកណាដែលប្រែចិត្ត ហើយត្រឡប់មកកន្រែងទ្រង់វិញនឹងត្រូវបានរាប់នៅក្នុងចំណោមប្រជាជនសេចក្តីសញ្ញារបស់ទ្រង់ដែរ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៣ ១៥:១–១០

ព្រះអង្គសង្គ្រោះប្រកាសថា ទ្រង់បានបំពេញច្បាប់របស់ម៉ូសេហើយ

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀនមុនចាប់ផ្តើមបង្រៀន ។

ហេតុអ្វីបានជាបង់ដង្វាយមួយភាគក្នុងដប់ ? ហេតុអ្វីបានជារក្សាថ្ងៃឈប់សម្រាកទុកជាបរិសុទ្ធ ? ហេតុអ្វីត្រូវគោរពឪពុកម្តាយរបស់អ្នក ?

ដើម្បីចាប់ផ្តើមមេរៀននេះ សូមបង្ហាញសំណួរនៅលើក្តារខៀន ហើយសួរ ៖

- អ្នកខ្លះអាចឆ្ងល់ថាហេតុអ្វីបានជាព្រះអម្ចាស់ប្រទានព្រះបញ្ញត្តិទាំងឡាយ ។ តើអ្នកអាចពន្យល់ពីគោលបំណងនៃព្រះបញ្ញត្តិទាំងឡាយបានទេ ?

សូមប្រាប់សិស្សថា នៅពេលព្រះយេស៊ូវគ្រីស្តបានបង្រៀនពួកសាសន៍នីហ្វៃ ទ្រង់បានបង្រៀនពួកគេថា គោលបំណងមួយនៃព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់គឺដើម្បីនាំប្រជាជនទៅរកទ្រង់ ។ សូមឲ្យសិស្សរកមើលគោលបំណងនេះនៅពេលពួកគេសិក្សា នីហ្វៃទី ៣ ១៥ ។

សូមពន្យល់ថា នៅពេលដែលព្រះអង្គសង្គ្រោះបានមានបន្ទូលទៅកាន់ហ្វូងមនុស្ស ទ្រង់បានជ្រាបថា អ្នកខ្លះនៅក្នុងចំណោមពួកគេបានមានសំណួរ ។ សូមឲ្យសិស្សអានត្រួសៗ នីហ្វៃទី ៣ ១៥:១–២ ដើម្បីរកមើលអ្វីដែលប្រជាជនទាំងនេះចង់ដឹង ។ (ពួកគេបានឆ្ងល់ថា តើព្រះអង្គសង្គ្រោះចង់ឲ្យពួកគេធ្វើអ្វី « ទាក់ទងទៅនឹងក្រឹត្យវិន័យរបស់ម៉ូសេ » ។ ការថ្វាយបង្គំ ប្រពៃណី និងការរៀបចំសាសនាចក្ររបស់ពួកសាសន៍នីហ្វៃត្រូវបានកសាងឡើងនៅលើច្បាប់ម៉ូសេដើម្បីរៀបចំប្រជាជនសម្រាប់ការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ និងដើម្បីជួយពួកគេឲ្យទន្ទឹងរង់ចាំដល់ពលិកម្មដ៏ធួនរបស់ទ្រង់ ។ ពិតប្រាកដណាស់ មនុស្សខ្លះច្រឡំអំពីអ្វីដែលពួកគេត្រូវធ្វើជំនួសឲ្យការកាន់តាមក្រឹត្យវិន័យរបស់ម៉ូសេ)។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៥:៣–៥, ៩ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលឃ្លានៅក្នុងការពន្យល់របស់ព្រះអង្គសង្គ្រោះដែលអាចបានធានាដល់ពួកសាសន៍នីហ្វៃថា សេចក្តីជំនឿរបស់ពួកគេមិនចាំបាច់ផ្លាស់ប្តូរទេ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយឃ្លាដែលពួកគេរកឃើញ ។ សូមឲ្យពួកគេពន្យល់ពីមូលហេតុដែលពួកគេគិតថា ឃ្លាទាំងនេះអាចជួយដល់ពួកសាសន៍នីហ្វៃ ។

- តើអ្នកគិតថា ព្រះយេស៊ូវកំពុងបង្រៀនអ្វី នៅពេលទ្រង់បានប្រកាសថា ទ្រង់គឺជា « ក្រឹត្យវិន័យ » ? (នីហ្វៃទី ៣ ១៥:៩) ។

សិស្សអាចផ្តល់ចម្លើយខុសៗគ្នា ។ នៅពេលពួកគេឆ្លើយ សូមជួយពួកគេឲ្យរកឃើញនូវសេចក្តីពិតខាងក្រោមនេះ (សូមសរសេរសេចក្តីពិតទាំងនេះនៅលើក្តារខៀន) ៖ ***ព្រះយេស៊ូវគ្រីស្តគឺជាប្រភពនៃក្រឹត្យវិន័យ ។ ក្រឹត្យវិន័យទាំងអស់នៃដំណឹងល្អបង្ហាញយើងឲ្យមើលទៅព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ ។ ប្រសិនបើយើងធ្វើតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ នោះយើងនឹងទទួលជីវិតដ៏នៅអស់កល្បជានិច្ច ។***

- ហេតុអ្វីបានជាសេចក្តីពិតទាំងនេះអាចនឹងសំខាន់សម្រាប់ពួកសាសន៍នីហ្វៃយល់នាពេលនេះ ? (អ្នកអាចលើកឡើងថា ដូចជាក្រឹត្យវិន័យរបស់ម៉ូសេដែរ ក្រឹត្យវិន័យថ្មីបានបង្ហាញទៅរកព្រះអង្គសង្គ្រោះ និងដង្វាយធួនរបស់ទ្រង់ ។ ខណៈពេលដែលរបៀបនៃការថ្វាយបង្គំរបស់មនុស្សខ្លះអាចផ្លាស់ប្តូរ ពួកគេអាចនឹងបន្តអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ និងគោរពតាមព្រះវរបិតាក្នុងព្រះនាមរបស់ទ្រង់) ។

សូមសង្ខេប នីហ្វៃទី ៣ ១៥:៦–៨ ដោយការពន្យល់ថា ព្រះអង្គសង្គ្រោះបានបញ្ជាក់ដល់ប្រជាជនថា គឺដូចជាពាក្យសម្តីរបស់ព្យាការីទាក់ទងទៅនឹងព្រះដ៏ប្រោសលោះមួយអង្គដែលត្រូវបានបំពេញនៅក្នុងទ្រង់ នោះការព្យាករណ៍របស់ពួកលោកទាក់ទងទៅនឹងហេតុការណ៍អនាគតក៏នឹងកើតឡើងដែរ ។ ទ្រង់ក៏បានពន្យល់ថា សេចក្តីសញ្ញាដែលទ្រង់បានធ្វើជាមួយនឹងប្រជាជនរបស់ទ្រង់គឺនៅតែបន្ត ហើយនឹងត្រូវបានបំពេញ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៥:៩–១០ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាមដោយរកមើលអ្វីដែលព្រះអង្គសង្គ្រោះចង់ឲ្យប្រជាជនរបស់ទ្រង់ធ្វើជាមួយនឹងចំណេះដឹងរបស់ពួកគេអំពីសេចក្តីពិតដែលត្រូវបានសរសេរនៅលើក្តារខៀននេះ ។

- តើវាមានន័យយ៉ាងណាចំពោះអ្នកដើម្បី « ថ្លង់ទៅ » ព្រះគ្រីស្ទ ?

សូមឲ្យសិស្សរំឭក នីហ្វៃទី ៣ ១៥:៩–១០ ហើយសង្ខេបពីរបៀបដែលព្រះអម្ចាស់ចង់ឲ្យយើងរស់នៅតាមដំណឹងល្អ ហើយជាលទ្ធផលយើងទទួលបាន ពរជ័យ ។ (សិស្សអាចសង្ខេបវគ្គនេះខុសៗគ្នា ប៉ុន្តែចម្លើយរបស់ពួកគេគួរបង្ហាញពីគោលការណ៍ដូចខាងក្រោម ៖ **ប្រសិនបើយើងផ្ចង់ទៅព្រះយេស៊ូវគ្រីស្ទដោយការកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ និងតស៊ូដល់ទីបញ្ចប់ នោះទ្រង់នឹងប្រទានឲ្យជីវិតដ៏នៅអស់កល្បជានិច្ចដល់យើង**) ។

- តើវាអាចទៅរួចទេដើម្បីធ្វើតាមព្រះយេស៊ូវគ្រីស្ទដោយមិនកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ? ហេតុអ្វីមិនអាច ?

សូមឲ្យសិស្សគិតពីសំណួរដែលអ្នកបានសរសេរនៅលើក្តារខៀនមុនពេលចាប់ផ្តើមថ្នាក់ ។

- តើវាអាចទៅរួចទេដែលបុគ្គលម្នាក់កាន់តាមព្រះបញ្ញត្តិទាំងឡាយតែខាងក្រៅដោយមិនផ្ចង់ទៅលើព្រះយេស៊ូវគ្រីស្ទ ?
- តើមូលហេតុអ្វីខ្លះដែលបុគ្គលម្នាក់អាចគោរពតាមព្រះបញ្ញត្តិទាំងឡាយតែខាងក្រៅដោយមិនផ្ចង់ទៅលើព្រះយេស៊ូវគ្រីស្ទ ? (ចម្លើយអាចមានកាតព្វកិច្ច ការភ័យខ្លាចការដាក់ទោស បំណងមួយដើម្បីមើលទៅល្អខាងសំបកក្រៅ ឬការស្រឡាញ់ច្បាប់) ។
- តើអ្វីទៅជាមូលហេតុដែលយើងគោរពតាមព្រះបញ្ញត្តិ ? (យើងគួរកាន់តាមព្រះបញ្ញត្តិ ដោយសារយើងស្រឡាញ់ព្រះអម្ចាស់ យើងចង់ធ្វើឲ្យទ្រង់សព្វព្រះទ័យ ហើយយើងចង់ទៅកាន់ទ្រង់) ។
- តើអ្នកត្រូវបានប្រទានពរយ៉ាងណាខ្លះ នៅពេលអ្នកបានកាន់តាមព្រះបញ្ញត្តិទាំងឡាយដោយបំណងដ៏ពិតប្រាកដនោះ ?

សូមឲ្យសិស្សគិតពីព្រះបញ្ញត្តិមួយ ឬបទដ្ឋានដំណឹងល្អមួយដែលពិបាកសម្រាប់ពួកគេយល់ និងធ្វើតាម ។ សូមឲ្យពួកគេគិតពីអារម្មណ៍ដែលពួកគេមានអំពីព្រះបញ្ញត្តិ ឬបទដ្ឋាននេះ ប្រសិនបើសេចក្តីស្រឡាញ់របស់ពួកគេដល់ព្រះអម្ចាស់ក្លាយជាមូលហេតុរបស់គេក្នុងការគោរពតាម ។ សូមលើកទឹកចិត្តឲ្យពួកគេគោរពតាមព្រះបញ្ញត្តិទាំងឡាយចេញពីសេចក្តីស្រឡាញ់ដល់ព្រះអម្ចាស់ ។ សូមចែកចាយពីរបៀបដែលព្រះបញ្ញត្តិបានជួយដល់អ្នកឲ្យខិតកាន់តែជិតទៅរកព្រះវរបិតាសួគ៌ និងព្រះអង្គសង្គ្រោះ ។

នីហ្វៃទី ៣ ១៥:១១–១៦:៥

ព្រះយេស៊ូវគ្រីស្ទមានបន្ទូលទៅកាន់សាវករបស់ទ្រង់ពាក់ព័ន្ធនឹងចៀមឯទៀតរបស់ទ្រង់

សូមឲ្យសិស្សលើកដៃ ប្រសិនបើពួកគេធ្លាប់មានអារម្មណ៍ថាមិនសូវសំខាន់ដូចមនុស្សម្នាក់ទៀត ។ សូមឲ្យពួកគេគិតថាតើពួកគេធ្លាប់មានអារម្មណ៍ថាត្រូវបានគេបំភ្លេច ឬឯកោ ឬប្រសិនបើពួកគេធ្លាប់ឆ្ងល់ថាតើព្រះវរបិតាសួគ៌ដឹងថាពួកគេជានរណាទេ ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ ***ព្រះមានព្រះទ័យយកចិត្តទុកដាក់ដល់កូនចៅរបស់ទ្រង់ទាំងអស់ ហើយទ្រង់សម្តែងអង្គទ្រង់ដល់ពួកគេ ។*** សូមបញ្ជាក់ពីសេចក្តីពិតនៃប្រយោគនេះ ហើយសូមឲ្យពួកគេរកមើលភស្តុតាងនៃសេចក្តីពិតនៅពេលដែលពួកគេសិក្សា នីហ្វៃទី ៣ ១៥ ទាំងឡាយ និងសេចក្តីផ្តើមនៃ នីហ្វៃទី ៣ ១៦ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៥:១១–១៧ ហើយសូមឲ្យសិស្សរកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលទៅកាន់ប្រជាជននៅក្នុងទីក្រុងយេរូសាឡិមអំពីប្រជាជនរបស់ទ្រង់នៅឯដែនដីអាមេរិក ។ អ្នកក៏អាចសុំឲ្យសិស្សអាន យ៉ូហាន ១០:១៤–១៦ ។ (សូមជួយសិស្សឲ្យយល់ថា « ចៀមឯទៀត » គឺសំដៅទៅលើអ្នកដើរតាមផ្សេងទៀតរបស់អ្នកគង្វាល ដែលគឺជាព្រះយេស៊ូវគ្រីស្ទ ។ ពាក្យ *រួចក្រោយ* អាចសំដៅទៅលើហ្វូងចៀមមួយ ប៉ុន្តែវាក៏តំណាងឲ្យក្រុមមនុស្សមួយដែលមានសេចក្តីជំនឿដូចគ្នាដែរ) ។

- យោងតាម នីហ្វៃទី ៣ ១៥:១៧ តើព្រះអម្ចាស់បានសន្យាថានឹងបង្ហាញអង្គទ្រង់ដល់ចៀមឯទៀតរបស់ទ្រង់ ឬអ្នកដើរតាមផ្សេងទៀតដោយរបៀបណា ? (ពួកគេនឹងស្តាប់តាមសំឡេងរបស់ទ្រង់) ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៥:១៨–១៩ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលមូលហេតុដែលព្រះវរបិតាសួគ៌បានបញ្ជាឲ្យព្រះយេស៊ូវគ្រីស្ទបង្អង់ចំណេះដឹងរបស់ចៀមផ្សេងទៀតរបស់ទ្រង់ពីប្រជាជននៅក្នុងទីក្រុងយេរូសាឡិម ។ ក្រោយពីសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញហើយ សូមសួរ ៖

- តើគោលការណ៍អ្វីដែលយើងអាចរៀនពីការណ៍នេះ ? (ចម្លើយរបស់សិស្សគួរឆ្លុះបញ្ចាំងអំពីគោលការណ៍ខាងក្រោមនេះ ៖ **ព្រះប្រទានចំណេះដឹង និងសេចក្តីពិតដល់យើងស្របតាមសេចក្តីជំនឿ និងការគោរពតាមរបស់យើង**) ។

សូមសង្ខេប នីហ្វៃទី ៣ ១៥:២១–២៣ ដោយការពន្យល់ថា ព្រះអម្ចាស់បានប្រាប់ពួកសាសន៍នីហ្វៃថា ពួកគេគឺជាចៀមផ្សេងទៀតដែលទ្រង់បានមានបន្ទូល ទោះជាយ៉ាងណាក្តី ពួកសាសន៍យូដានៅក្នុងទីក្រុងយេរូសាឡិមនឹងមិនបានគិតថា ទ្រង់បានមានបន្ទូលអំពីពួកសាសន៍ដទៃ ឬពួកមិនមែនសាសន៍អ៊ីស្រាអែល។ ពួកគេមិនបានយល់ថា ពួកសាសន៍ដទៃនឹងមិនស្តាប់ឮសំឡេងរបស់ទ្រង់ដោយផ្ទាល់ទេ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៥:២៤ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកនូវរបៀបដែលព្រះអម្ចាស់បានធានាដល់ពួកសាសន៍នីហ្វៃអំពីការយកចិត្តទុកដាក់របស់ទ្រង់ដល់ពួកគេ ។ អ្នកអាចសួរសិស្សពីអារម្មណ៍ដែលពួកគេអាចមាន ប្រសិនបើពួកគេបានឮព្រះអម្ចាស់មានបន្ទូលទាំងនេះមកកាន់ពួកគេ ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១៦:១–៣ ដោយស្ងាត់ស្ងៀម និងរកមើលថាតើនរណាផ្សេងទៀតដែលអាចនឹងស្តាប់ឮសំឡេងព្រះអង្គសង្គ្រោះ ។ សូមពន្យល់ថា យើងមិនមានកំណត់ត្រានៃកន្លែងផ្សេងទៀត និងប្រជាជនផ្សេងទៀតដែលព្រះអង្គសង្គ្រោះបានយាងទៅនោះទេ ប៉ុន្តែវាច្បាស់ណាស់ថា ទ្រង់បានយាងទៅក្រុមផ្សេងទៀត ឬ« ក្រោយ » ផ្សេងទៀត ។

ដើម្បីណែនាំគំនិតថា ព្រះអង្គសង្គ្រោះក៏សម្តែងអង្គទ្រង់ដល់អ្នកដែលមិនស្តាប់សំឡេងរបស់ទ្រង់នោះ សូមសួរសំណួរខាងក្រោមមុនពេលឲ្យសិស្ស ស្រាវជ្រាវ ព្រះគម្ពីរកចម្លើយ ៖

- ចុះអ្នកដែលមិនស្តាប់ឮសំឡេងរបស់ព្រះអង្គសង្គ្រោះវិញ ? តើទ្រង់បង្ហាញដល់ពួកគេថា ទ្រង់យកចិត្តទុកដាក់លើពួកគេដោយរបៀបណា ?

សំណួរស្រាវជ្រាវ

សំណួរស្រាវជ្រាវជួយសិស្សឲ្យសាងការយល់ដឹងជាគ្រឹះរបស់គេអំពីវគ្គព្រះគម្ពីរដោយសុំឲ្យពួកគេរកមើលសេចក្តីលម្អិតសំខាន់ៗ នៅពេលពួកគេអាន ។ វាផ្តល់អត្ថប្រយោជន៍ជាច្រើនដើម្បីសួរសំណួរបែបនោះ៖ មុនពេលឲ្យសិស្សអានខគម្ពីរដែលចម្លើយនឹងត្រូវរកឃើញនៅក្នុងនោះ ។ ការណ៍នេះផ្តោតទៅលើការយកចិត្តទុកដាក់របស់សិស្ស និងជួយសិស្សឲ្យរកឃើញនូវចម្លើយនៅក្នុងអត្ថបទព្រះគម្ពីរ នៅពេលដែលពួកគេអាន ។

សូមឲ្យសិស្សស្រាវជ្រាវ នីហ្វៃទី ៣ ១៥:២២–២៣ និង នីហ្វៃទី ៣ ១៦:៤ ដោយរកមើលរបៀបដែលព្រះអម្ចាស់បានប្រកាសថា ទ្រង់នឹងសម្តែងអង្គទ្រង់ដល់ពួកសាសន៍ដទៃ (តាមរយៈការចែកចាយរបស់អ្នកដទៃ តាមរយៈសាក្សីនៃព្រះវិញ្ញាណបរិសុទ្ធ និងតាមរយៈការសរសេររបស់ព្យាការីទាំងឡាយ) ។

- តើការសម្តែងទាំងនេះបង្ហាញថា ព្រះយកចិត្តទុកដាក់ដល់កូនចៅរបស់ទ្រង់ទាំងអស់ដោយរបៀបណា ?
- តើព្រះអម្ចាស់បានសម្តែងអង្គទ្រង់ដល់អ្នក និងគ្រួសាររបស់អ្នកតាមរបៀបណា ?
- តើអ្នកអាចជួយដល់ការខិតខំរបស់ព្រះអម្ចាស់ដើម្បីសម្តែងអង្គទ្រង់ដល់ប្រជារាស្ត្រទ្រង់ដោយរបៀបណា ?

នីហ្វៃទី ៣ ១៦:៦–២០

ព្រះយេស៊ូវគ្រីស្ទប្រកាសពីពរជ័យ និងការព្រមានដល់ពួកសាសន៍ដទៃ ដែលនឹងទទួលដំណឹងល្អនៅថ្ងៃចុងក្រោយ

សូមសួរសិស្សថា តើពួកគេធ្លាប់ចង់ក្លាយជាចំណែកមួយនៃក្រុមមួយ ឬក្លិបមួយទេ ។ សូមសួរថា តើលក្ខណៈសម្បត្តិអ្វីដែលតម្រូវឲ្យមានដើម្បីក្លាយជាសមាជិកនៃក្រុមដែលពួកគេចង់ចូលរួមនោះ ។ សូមណែនាំថា ក្រុមដ៏ធំបំផុតដែលយើងអាចក្លាយជាសមាជិកនោះគឺជាក្រុមនៃរាស្ត្រនៃសេចក្តីសញ្ញារបស់ព្រះអម្ចាស់ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៦:៦–៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលថានឹងកើតឡើងនៅក្នុងថ្ងៃចុងក្រោយ ដោយសារសាសន៍ដទៃដែលនឹងជឿលើទ្រង់ ព្រមទាំងវង្សអ៊ីស្រាអែលដែលនឹងលែងជឿលើទ្រង់នោះ ។ (អ្នកអាចពន្យល់ថា ព្យាការីក្នុងព្រះគម្ពីរមរមនបានប្រើពាក្យ *ពួកសាសន៍ដទៃ* ដើម្បីសំដៅលើប្រជាជនដែលមិនបានចេញមកពីដែនដីបរិសុទ្ធ ។ ហេតុដូច្នេះហើយ ពាក្យនេះអាចសំដៅទៅលើសមាជិកនៃសាសនាចក្រ ក៏ដូចជាដល់អ្នកដែលមិនជឿ និងសមាជិកនៃសេចក្តីជំនឿផ្សេងទៀតដែរ) ។ ក្រោយពីសិស្សឆ្លើយហើយ សូមសង្ខេប នីហ្វៃទី ៣ ១៦:៨–៩ ដោយការពន្យល់ថា ព្រះយេស៊ូវគ្រីស្ទបានព្យាករណ៍ថា វាក៏នឹងមានពួកសាសន៍ដទៃដែលមិនជឿនៅថ្ងៃចុងក្រោយ ដែលនឹងខ្ចាត់ខ្ចាយ ហើយធ្វើបាបដល់សមាជិកនៃវង្សអ៊ីស្រាអែល ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៦:១០ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលនឹងកើតឡើងដល់ពួកសាសន៍ដទៃដែលមិនជឿទាំងនេះ ។

- តើព្រះអម្ចាស់បានប្រកាសថា ពួកសាសន៍ដទៃដែលមិនជឿនឹងចាត់បង់អ្វី ?
- តើការណ៍នេះអាចអនុវត្តចំពោះអស់អ្នកទាំងឡាយណាដែលដឹងអំពីសេចក្តីពិត ប៉ុន្តែធ្លាក់ទៅក្នុងសេចក្តីអំនួតដោយរបៀបណា ?

សូមពន្យល់ថា ព្រះអម្ចាស់បានសន្យាថានឹងរក្សាសេចក្តីសញ្ញារបស់ទ្រង់ជាមួយនឹងវង្សអ៊ីស្រាអែល ដោយការនាំយកដំណឹងល្អទៅដល់ពួកគេ (សូមមើល នីហ្វៃទី ៣ ១៦:១១–១២) ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៦:១៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលតម្រូវឲ្យបុគ្គលម្នាក់មានដើម្បីក្លាយជាសមាជិកនៃរាស្ត្រនៃសេចក្តីសញ្ញារបស់ព្រះអម្ចាស់ ។ សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ « *ប្រសិនបើយើង . . . នោះយើងនឹង . . .* » ។ សូមឲ្យសិស្សប្រើ នីហ្វៃទី ៣ ១៦:១៣ ដើម្បីបំពេញប្រយោគនេះ ។ សិស្សគួរតែអាចរកឃើញខ្លះសេចក្តីពិតខាងក្រោមនេះ ៖ ***ប្រសិនបើយើងរំលែចិត្ត ហើយត្រឡប់មកព្រះយេស៊ូវគ្រីស្ទវិញ នោះយើងនឹងអាចត្រូវបានរាប់ចូលនៅក្នុងចំណោមប្រជាជនរបស់ទ្រង់ដែរ ។***

- ហេតុអ្វីបានជាការរាប់ចូលនៅក្នុងចំណោមប្រជាជនរបស់ទ្រង់ ជាពរជ័យមួយនោះ ?

សូមបញ្ចប់ដោយការចែកចាយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតដែលបានបង្រៀននៅក្នុងមេរៀនថ្ងៃនេះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ៣ ១៥:៥–៨ ។ សេចក្តីសញ្ញាមិនទាន់ត្រូវបានបំពេញអស់នៅឡើយទេ

តើព្រះយេស៊ូវបានចង់មានន័យយ៉ាងណា នៅពេលទ្រង់មានបន្ទូលថា « សេចក្តីសញ្ញាដែលយើងបានធ្វើជាមួយនឹងប្រជាជនរបស់យើង មិនទាន់ត្រូវបានបំពេញអស់នៅឡើយទេ » ?

(នីហ្វៃទី ៣ ១៥:៨) ព្រះយេហូវ៉ាបានបង្កើតសេចក្តីសញ្ញាមួយជាមួយនឹងអ័ប្រាហាំកាលពីជំនាន់បុរាណ ។ អ័ប្រាហាំត្រូវបានសន្យាឲ្យមាន (១) ការកើតចម្រើនដ៏អស់កល្បជានិច្ច (២) ដែនដីនៃការគ្រងមរតក និង (៣) អំណាចបព្វជិតភាពរបស់ព្រះ ។ សេចក្តីសន្យាទាំងនេះក៏ត្រូវបានធ្វើដល់កូនចៅរបស់អ័ប្រាហាំដែរ (សូមមើល គ. និង ស. ១៣២:៣០–៣១) ហើយនឹងត្រូវបានបំពេញនៅក្នុងពេលអនាគត ។

មេរៀនសិក្សានៅផ្ទះ

នីហ្វៃទី ៣ ១១:១៨–១៦:២០ (មេរៀនទី ២៥)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀននៅពេលពួកគេសិក្សា នីហ្វៃទី ៣ ១–១១:១៨–១៦:២០ (មេរៀនទី ២៥)) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែទៅលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (នីហ្វៃទី ៣ ១១:១៨–១២:៤៨)

សិស្សបានរៀនថា ពិធីបុណ្យជ្រមុជទឹកត្រូវតែធ្វើឡើងដោយបុគ្គល ដែលកាន់អំណាចដ៏ត្រឹមត្រូវ ហើយត្រូវតែធ្វើឡើងតាមរបៀបដែលបានដាក់ឡើងដោយព្រះអម្ចាស់ ។ ពួកគេក៏បានសិក្សាពីគោលលទ្ធិនៃព្រះគ្រីស្ទ ហើយបានរៀនថា ព្រះវិញ្ញាណបរិសុទ្ធធ្វើទីបន្ទាល់អំពីព្រះវរបិតាសួគ៌ និង ព្រះយេស៊ូវគ្រីស្ទ ។ នៅក្នុងការសិក្សារបស់ពួកគេអំពីពរជ័យនៃសេចក្តីសុខសាន្ត និងការពន្យល់របស់ព្រះអង្គសង្គ្រោះអំពីក្រិត្យវិន័យដ៏ខ្ពស់ជាង នោះពួកគេបានរៀនថា ប្រសិនបើយើងរស់នៅតាមការបង្រៀនរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងត្រូវបានប្រទានពរ និងបានរៀបចំដើម្បីចូលទៅក្នុងនគរស្ថានសួគ៌ ។ ពួកគេក៏បានរៀនដែរថា នៅពេលយើងមករកព្រះគ្រីស្ទ ហើយកាន់តាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ នោះយើងអាចក្លាយជូចជាទ្រង់ និងព្រះវរបិតាគង់នៅស្ថានសួគ៌របស់យើងដែលឥតខ្ចោះ កាន់តែខ្លាំង ។

ថ្ងៃទី ២ (នីហ្វៃទី ៣ ១៣)

ចេញពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីការលើកទឹកចិត្តឲ្យធ្វើទាន អធិស្ឋាន និងតមអាហារ សិស្សបានរៀនថា ប្រសិនបើយើងធ្វើកិច្ចការសុចរិតដើម្បីធ្វើឲ្យព្រះវរបិតាសួគ៌សព្វព្រះទ័យ នោះទ្រង់នឹងប្រទានពរដល់យើងដោយបើកចំហរ ។ នៅពេលពួកគេបានសិក្សាពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីការមិនអាចបម្រើចៅហ្វាយពីរបាន នោះពួកគេបានរៀនពីគោលការណ៍ដូចខាងក្រោម ៖ ដើម្បីមានព្រះជាចៅហ្វាយរបស់យើង យើងត្រូវតែស្រឡាញ់ និងបម្រើដល់ទ្រង់លើសពីអ្វីៗនៅលើផែនដីនេះ ។ ប្រសិនបើយើងស្វែងរកនគររបស់ព្រះជាមុន នោះទ្រង់នឹងជួយយើងផ្គត់ផ្គង់តម្រូវការរបស់យើង ។

ថ្ងៃទី ៣ (នីហ្វៃទី ៣ ១៤)

ការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីការកាត់សេចក្តីសុចរិតបានជួយសិស្សឲ្យយល់ថា យើងនឹងត្រូវកាត់សេចក្តីស្របតាមរបៀបដែលយើងកាត់សេចក្តីអ្នកដទៃ ។ ពួកគេក៏បានរៀនដែរថា ព្រះវរបិតាសួគ៌ប្រទានពរដល់យើង នៅពេលយើងអធិស្ឋានសុំជំនួយពីទ្រង់ ។ សិស្សបានគូសរូបភាពដែលបង្ហាញពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ហើយបានរៀនថា យើងត្រូវតែធ្វើតាមព្រះឆន្ទៈរបស់ព្រះវរបិតាសួគ៌ដើម្បីចូលទៅក្នុងនគរស្ថានសួគ៌ ។

ថ្ងៃទី ៤ (នីហ្វៃទី ៣ ១៥–១៦)

សិស្សបានរៀនថា ព្រះយេស៊ូវគ្រីស្ទគឺជាប្រភពនៃក្រឹត្យវិន័យ និងព្រះបញ្ញត្តិទាំងឡាយនៃដំណឹងល្អ ។ ប្រសិនបើយើងផ្ទង់ទៅព្រះយេស៊ូវគ្រីស្ទដោយការកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ និងតស៊ូដល់ទីបញ្ចប់ នោះទ្រង់នឹងប្រទាននូវជីវិតដ៏នៅអស់កល្បជានិច្ចដល់យើង ។ នៅពេលសិស្សបានសិក្សាពីព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះអំពី « ចៀមឯទៀត » (នីហ្វៃទី ៣ ១៥:២១) ពួកគេបានរៀនថា ព្រះយកចិត្តទុកដាក់ដល់កូនចៅរបស់ទ្រង់ទាំងអស់ និងបើកសម្តែងអង្គទ្រង់ដល់ពួកគេ ។ ព្រះប្រទានចំណេះដឹង និងសេចក្តីពិតដល់យើងស្របតាមសេចក្តីជំនឿ និងការគោរពតាមរបស់យើង ។

សេចក្តីផ្តើម

នៅក្នុងមេរៀននេះ សិស្សនឹងគិតពីរបៀបដែលការទាស់ទែងគ្នាប៉ះពាល់ដល់សមត្ថភាពរបស់គេក្នុងការទទួលអារម្មណ៍ពីព្រះវិញ្ញាណ ។ ពួកគេក៏នឹងអាចគិតអំពីអ្នកទាំងឡាយណាដែលបានក្លាយជាគំរូដ៏វិជ្ជមានដល់ពួកគេ ហើយគិតពីរបៀបដែលពួកគេអាចធ្វើជាគំរូដ៏ប្រសើរដោងដល់អ្នកដទៃ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៣ ១១:១៨–៤១

ព្រះយេស៊ូវគ្រីស្ទ រៀបចំ នូវរបៀបនៃពិធីបុណ្យជ្រមុជទឹក ដាក់ទោសចំពោះការទាស់ទែងគ្នា និងប្រកាសពីគោលលទ្ធិរបស់ទ្រង់

សូមសរសេរពាក្យ *ការទាស់ទែងគ្នា* នៅលើក្តារខៀន ហើយសូមឲ្យសិស្សឲ្យនិយមន័យនៃពាក្យនេះ (ការឈ្លោះគ្នា បៃតិ្ត ឬការប្រកែកគ្នា) ។

សូមឲ្យសិស្សសរសេរដោយសង្ខេបនៅលើក្តារខៀននូវស្ថានភាព ឬសកម្មភាពខ្លះដែលពួកគេអាចងាយនឹងជួបនឹងការទាស់ទែងគ្នា ។ (អ្នកអាចឲ្យសិស្សម្នាក់ធ្វើជាអ្នកសរសេរ ខណៈពេលដែលសិស្សក្នុងថ្នាក់ឆ្លើយ) ។ ខណៈពេលដែលធ្វើសកម្មភាពនេះ សូមចៀសវាងនូវអ្វីដែលអែលឌើរ ដាល្លិន អេក អ៊ុក នៃក្រុមនៃពួកសាវកដប់ពីរនាក់បានហៅថាជា « បច្ចេកវិទ្យារបស់សត្រូវ » ដែលអាចនាំឲ្យមាន « ការដេញដោលគ្នា និងការឈ្លោះប្រកែក » (*The Lord's Way* [ឆ្នាំ ១៩៩១],ទំព័រ ១៣៩) ។

សូមរំឭកសិស្សថានៅក្នុង នីហ្វៃទី ៣ ១១ ពួកគេបានអានថា ព្រះយេស៊ូវគ្រីស្ទបានយាងមកជួបនឹងពួកសាសន៍នីហ្វៃដែលបានប្រជុំគ្នានៅឯព្រះវិហារបរិសុទ្ធ ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១១:២៨ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលប្រធានបទដែលបង្កឲ្យពួកសាសន៍នីហ្វៃខ្លះបានឈ្លោះគ្នា ។ (ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់អំពីខគម្ពីរនេះ អ្នកអាចពន្យល់ពាក្យ *ការប្រកែកគ្នា* មានន័យថាការឈ្លោះគ្នា ឬការមិនចុះសម្រុងនឹងគ្នា) ។

សូមសួរ ៖ តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីចៀសវាងការទាស់ទែងគ្នា នៅពេលពិភាក្សាគ្នាអំពីដំណឹងល្អជាមួយនឹងអ្នកដទៃ ?

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *វិញ្ញាណនៃការទាស់ទែងគ្នាគឺមិនមែនជារបស់ផងព្រះទេ ប៉ុន្តែ* . . . សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១១:២៩–៣០ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់មើលថាតើវិញ្ញាណនៃការទាស់ទែងគ្នាចេញមកពីណា ។ សេចក្តីពិតដែលពួកគេរកឃើញអាចត្រូវបានបង្ហាញដូចខាងក្រោម ៖ **ព្រះវិញ្ញាណនៃការទាស់ទែងគ្នាគឺពុំមែនជារបស់ផងព្រះទេ ប៉ុន្តែជារបស់ផងអារក្សវិញ ។** អ្នកអាចណែនាំថា សិស្សគួរគូសចំណាំសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

សូមសួរថា ៖ តើការចង់ចាំដល់ការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុង នីហ្វៃទី ៣ ១១:២៩–៣០ អាចជួយអ្នក នៅពេលអ្នកឃើញថាខ្លួនអ្នកស្ថិតនៅក្នុងស្ថានភាពមួយដែលបង្កឲ្យមានជម្លោះដោយរបៀបណា ? (អ្នកអាចបង្ហាញពីស្ថានភាពដាក់លាក់ណាមួយដែលបានសរសេរនៅលើក្តារខៀន ឬ សូមឲ្យសិស្សគិតពីស្ថានភាពមួយដែលនរណាម្នាក់ចង់ឈ្លោះគ្នាអំពីចំណុចណាមួយនៃដំណឹងល្អ) ។

ដើម្បីជួយសិស្សឲ្យយល់ពីលទ្ធផលដ៏សំខាន់នៃការទាស់ទែងគ្នា សូមអាន ឬបង្ហាញនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ដៃមស៍ អឹ ហ្វោស្ត នៃគណៈប្រធានទីមួយ ។ « នៅពេលមានការទាស់ទែងគ្នា នោះព្រះវិញ្ញាណនៃព្រះអម្ចាស់នឹងចាកចេញ ដោយមិនគិតថានរណាជាអ្នកខុសនោះទេ » (« What I Want My Son to Know before He Leaves on His Mission » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៩៦, ទំព័រ ៤១) ។

អ្នកអាចណែនាំ ដល់សិស្សថា ពួកគេគួរសរសេរប្រយោគនេះនៅក្នុងព្រះគម្ពីររបស់គេ ឬនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ។

សូមសួរថា ៖ តើអ្នកធ្លាប់មានអារម្មណ៍ថា ព្រះវិញ្ញាណនៃព្រះអម្ចាស់ចាកចេញពីអ្នកដោយសារតែការទាស់ទែងគ្នាដែរទេ ? តើវាមានអារម្មណ៍យ៉ាងណា ?

សូមលើកឡើងថា ព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះទាក់ទងទៅនឹងការទាស់ទែងគ្នានៅក្នុង នីហ្វៃទី ៣ ១១:៣០ ៖ « នេះពុំមែនជាគោលលទ្ធិរបស់យើងទេ គឺត្រូវលះបង់ការណ៍ទាំងនោះចោលវិញ » ។ បន្ទាប់មក សួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- តើយើងអាច « លះបង់ចោល » នូវការទាស់ទែងគ្នា និងការប្រកែកគ្នាដោយរបៀបណា ?
- តើយើងអាចមិនចុះសម្រុងជាមួយនឹងអ្នកដទៃ និងចៀសវាងពីការទាស់ទែងគ្នាដោយរបៀបណា ?
- តើអ្នកបានមានអារម្មណ៍ថាត្រូវបានប្រទានពរដោយសារការខិតខំរបស់អ្នកដើម្បីចៀសវាង ឬយកឈ្នះលើការទាស់ទែងគ្នាដោយរបៀបណា ?

អ្នកអាចចែកចាយបទពិសោធន៍មួយដែលអ្នកបានមានអារម្មណ៍ថាអ្នកត្រូវបានប្រទានពរដោយសារការខិតខំរបស់អ្នកដើម្បីចៀសវាង ឬយកឈ្នះលើការទាស់ទែងគ្នានោះ ។ សូមឲ្យសិស្សមើលទៅបញ្ជីនៅលើក្តារខៀន ហើយជ្រើសរើសស្ថានភាពមួយដែលពួកគេអាចមានអារម្មណ៍ថាទាស់គ្នាជារឿយៗ ។ សូមឲ្យពួកគេមានពេលសរសេរនូវគោលដៅមួយអំពីរបៀបដែលពួកគេនឹងខំចៀសវាង ឬយកឈ្នះលើការទាស់ទែងគ្នានៅក្នុងស្ថានភាពសកម្មភាពមួយនោះ ។

នីហ្វៃទី ៣ ១២–១៦

ព្រះយេស៊ូវគ្រីស្ទបង្រៀនពីគោលការណ៍នានាដែលជួយដល់កូនចៅរបស់ទ្រង់ឲ្យដើរទៅរកភាពឥតខ្ចោះ

សូមឲ្យសិស្សក្រោកឈរ ហើយសូត្រ នីហ្វៃទី ៣ ១២:៤៨ ។ អ្នកអាចសុំឲ្យពួកគេអនុវត្តពីរបីដង ដើម្បីឲ្យពួកគេអាចសូត្រឱ្យគ្គចំណេះចំណានខគម្ពីរនេះបានយ៉ាងឥតខ្ចោះ ។ សូមឲ្យសិស្សប្រើព្រះគម្ពីររបស់ពួកគេដើម្បីបង្ហាញពីលក្ខណៈខ្លះនៃភាពឥតខ្ចោះដែលបានលើកឡើងនៅក្នុងនីហ្វៃទី ៣ ១២:១–១២ ដែលពួកគេសង្ឃឹមថានឹងអភិវឌ្ឍបានកាន់តែខ្លាំងជាងនេះ ។

សូមដាក់អំបិលបន្តិចនៅលើស្លាបព្រាមួយ ហើយសូមឲ្យសិស្សទាយថាវាជាអ្វី ។ បន្ទាប់មក សូមឲ្យសិស្សឡើងមកខាងមុខ ហើយបញ្ជាក់មើលថាវាជាអ្វីដោយការភ្លក់ ។ ក្រោយពីសិស្សបានកេរឃើញថាវាជាអំបិលហើយ សូមឲ្យសិស្សក្នុងថ្នាក់សរសេរពីសារៈប្រយោជន៍របស់អំបិល ។ នៅពេលសិស្សឆ្លើយ សូមប្រាកដថា ក្រៅពីវាជាគ្រឿងបន្ថែមរស់ជាតិដល់អាហារ អំបិលត្រូវបានប្រើប្រាស់សម្រាប់ប្រឡាក់សាច់មិនឲ្យស្អុយ ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១២:១៣ ដើម្បីរកមើលអ្នកដែលព្រះអង្គសង្គ្រោះបានប្រៀបធៀបទៅនឹងអំបិល ។ នៅពេលសិស្សឆ្លើយ សូមពន្យល់ថា ព្រះអង្គសង្គ្រោះសំដៅមិនត្រឹមតែលើហ្វូងមនុស្សនៅឯព្រះវិហារបរិសុទ្ធនៅថ្ងៃនោះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទៅដល់អស់អ្នកទាំងឡាយណាដែលត្រូវបានជ្រមុជទឹកចូលក្នុងសាសនាចក្ររបស់ទ្រង់ និងរស់នៅតាមដំណឹងល្អរបស់ទ្រង់ ។

សូមសួរថា ៖ ក្នុងនាមយើងជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទ តើយើងអាចក្លាយដូចជាអំបិលតាមវិធីណា ? (យើងត្រូវជួយរក្សា ឬសង្គ្រោះប្រជាជន និងត្រូវពង្រឹងពិភពលោកដោយការមានឥទ្ធិពលលើអ្នកដទៃដោយអំពើល្អ) ។

សូមពន្យល់ថានៅក្នុង នីហ្វៃទី ៣ ១២:១៣ ៣ក្យ *(រស)ជាតិ* មិនមែនសំដៅតែលើរសជាតិរបស់អំបិលនោះទេ ប៉ុន្តែវាក៏សំដៅលើតួនាទីរបស់វាជាអ្នកការពារមួយដែរ ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ខាឡូស អឺ. អាសាយ នៃក្រុមចិតសិបនាក់ទាក់ទងទៅនឹងរបៀបដែលអំបិលអាចបាត់បង់រសជាតិរបស់វា ។

« អំបិលនឹងមិនបាត់បង់រសរបស់វាតាមពេលវេលានោះទេ ។ រសជាតិត្រូវបាត់បង់តាមរយៈការលាយ និងការបំពុល ។ ដូចគ្នានេះដែរ រសជាតិ និងគុណភាពចាកចេញពីមនុស្ស នៅពេលគេបំពុលគំនិតរបស់គេដោយគំនិតមិនស្អាតស្អំ ពោលពាក្យប្រមាថ ដោយការនិយាយកុហក់ និងអនុវត្តកម្លាំងរបស់គេខុសទៅលើការធ្វើអំពើអាក្រក់ » (« Salt of the Earth: Savor of Men and Saviors of Men » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៨០, ទំព័រ ៤២) ។

សូមសួរថា ៖ ហេតុអ្វីបានជាយើងត្រូវតែបរិសុទ្ធដើម្បីមានឥទ្ធិពលលើអ្នកដទៃចំពោះការណ៍ល្អ ?

សូមបង្ហាញដល់សិស្សនូវពិលមួយ ។ ចុចបើកវា ហើយសូមឲ្យសិស្សអាន នីហ្វៃទី ៣ ១២:១៤–១៦ ហើយរកមើលរបៀបដែលព្រះអង្គសង្គ្រោះបានប្រើពន្លឺដើម្បីបង្រៀនអំពីតួនាទីរបស់រាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់នៅក្នុងពិភពលោកនេះកាន់តែច្បាស់ ។ មុនពេលពួកគេអាន វាអាចជួយសិស្សដើម្បីពន្យល់ថា *ល្ប៊ី* គឺជាកន្ត្រកមួយ ។

សូមសួរថា ៖ តើសមាជិកនៃសាសនាចក្រដែលកាន់តាមសេចក្តីសញ្ញារបស់ពួកគេ អាចជាពន្លឺមួយដល់អ្នកដទៃដោយរបៀបណា ?

សូមដាក់កន្ត្រក ឬកន្សែងមួយគ្របលើពន្លឺ ហើយសូមសួរសំណួរខាងក្រោមនេះ ៖

- តើមានរបៀបណាខ្លះ ដែលយើងអាចត្រូវបានល្បួងឲ្យបាំងគ្របពន្លឺរបស់យើង ?
- យោងតាម នីហ្វៃទី ៣ ១២:១៦ ហេតុអ្វីបានជាព្រះអង្គសង្គ្រោះចង់ឲ្យយើងធ្វើជាគំរូនៃសេចក្តីសុចរិត ? (**នៅពេលយើងធ្វើជាគំរូនៃសេចក្តីសុចរិត នោះយើងអាចជួយដល់អ្នកដទៃឲ្យតម្កើងដល់ព្រះវរបិតាសួគ៌ ។** អ្នកអាចណែនាំថា សិស្សគួរសរសេរគោលការណ៍នេះនៅក្បែរមីមទំព័រនៃព្រះគម្ពីររបស់គេ ។
- តើគំរូនៃសេចក្តីសុចរិតរបស់នរណាដែលបានជួយអ្នកឲ្យខិតកាន់តែជិតទៅរកព្រះវរបិតាសួគ៌ ឬពង្រឹងបំណងប្រាថ្នារបស់អ្នកក្នុងការរស់នៅតាមដំណឹងល្អកាន់តែពេញលេញជាងនេះ ?

សូមលើកទឹកចិត្តសិស្សឲ្យក្លាយដូចជាអំបិល និងដូចជាពន្លឺទៅកាន់ពិភពលោក ដោយការជ្រើសរើសដើម្បីធ្វើជាគំរូនៃសេចក្តីសុចរិត ។

សូមពន្យល់ថា ព្រះអង្គសង្គ្រោះបានបន្តបង្រៀនដល់ពួកសាសន៍នីហ្វៃថា ង្វាន់ពិតប្រាកដសម្រាប់ការធ្វើតាមព្រះបញ្ញត្តិដោយសុចរិតនឹងមក នៅពេលពួកគេគោរពតាមដោយមិនមានពុតត្បុត និងដោយមិនដាក់ដួងចិត្តរបស់ពួកគេទៅលើទ្រព្យសម្បត្តិ ឬង្វាន់ខាងលោកិយ ។ សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖ នីហ្វៃទី ៣ ១៣:២២; ១៣:៣១–៣៣; ១៤:៧–៨; ១៥:៥; ១៦:១៣ ។ សូមឲ្យសិស្សស្រាវជ្រាវលើគ្រែទាំងនេះ និងរកមើលង្វាន់ខ្លះៗដែលព្រះវរបិតាគង់នៅស្ថានសួគ៌បានសន្យានឹងយើងថា ប្រសិនបើដួងចិត្តរបស់យើងផ្តោតទៅលើការរស់នៅជីវិតមួយដ៏សុចរិតនោះ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

សូមចែកចាយទីបន្ទាល់របស់អ្នកជាមួយនឹងសិស្សថា ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទនឹងជួយ ហើយប្រទានពរដល់ពួកគេក្នុងកិច្ចខំប្រឹងរបស់ពួកគេដើម្បីលះបង់ចោលការទាស់ទែងគ្នា និងក្លាយជាទៅគំរូដ៏សុចរិតមួយចំពោះពិភពលោក ។

មេរៀនបន្ទាប់ (នីហ្វៃទី ៣ ១៧–២២)

សូមប្រាប់សិស្សថា នៅពេលពួកគេសិក្សា នីហ្វៃទី ៣ ១៧–២២ ពួកគេនឹងអានថា ព្រះយេស៊ូវគ្រីស្ទបានព្រះកន្សែង នៅពេលទ្រង់បានគង់នៅជាមួយនឹងកូនក្មេងសាសន៍នីហ្វៃ ។ សូមលើកទឹកចិត្តពួកគេឲ្យរកមើលចម្លើយចំពោះសំណួរខាងក្រោមនេះ ៖ តើទ្រង់បានធ្វើអ្វីខ្លះសម្រាប់ពួកគេ ? តើមានអត្ថតហេតុផ្សេងទៀតអ្វីខ្លះដែលព្រះយេស៊ូវបានសម្តែង ខណៈពេលដែលកំពុងបម្រើដល់ពួកសាសន៍នីហ្វៃ ?

នីហ្វៃទី ៣ ១៧

សេចក្តីផ្តើម

នៅថ្ងៃទីមួយរបស់ព្រះអង្គសង្គ្រោះជាមួយនឹងពួកសាសន៍នីហ្វៃជិតនឹងបញ្ចប់ នោះទ្រង់បានដឹងថា មនុស្សជាច្រើនមិនបានយល់ច្បាស់អំពីព្រះបន្ទូលរបស់ទ្រង់នោះទេ ។ ទ្រង់បានបង្រៀនពួកគេអំពីរបៀបដើម្បីទទួលបានការយល់ដឹងបន្ថែម ហើយទ្រង់បានបញ្ជាក់ពីសារៈសំខាន់នៃការអធិស្ឋាន និងការសញ្ជឹងគិត ។ ប្រជាជនបានយំ នៅពេលទ្រង់បានប្រកាសថា ទ្រង់នឹងយាងចាកចេញទៅ ។ ដោយពោរពេញដោយសេចក្តីមេត្តាករុណា ព្រះអង្គសង្គ្រោះបាននៅយូរបន្តិចដើម្បីព្យាបាលអ្នកឈឺ អធិស្ឋានឲ្យប្រជាជន និងប្រទានពរដល់កូនចៅរបស់ពួកគេ ។ ពួកសាសន៍នីហ្វៃត្រូវបានយកឈ្នះដោយសេចក្តីអំណរ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៣ ១៧:១–៣

ព្រះយេស៊ូវណែនាំប្រជាជននីហ្វៃឲ្យសញ្ជឹងគិតពីព្រះបន្ទូលរបស់ទ្រង់ ហើយអធិស្ឋានសុំការយល់ដឹង

សូមឲ្យសិស្សស្រមៃថា ខ្លួនគេនៅក្នុងស្ថានភាពដូចខាងក្រោម ៖ អ្នក និងមិត្តភក្តិអង្គុយនៅជួរខាងមុខនៅសន្និសីទទូទៅ ឬនៅសន្និសីទប្រចាំតំបន់ដែលមានព្យុះកំពុងមានប្រសាសន៍ ។ ខណៈពេលដែលអ្នកនៅទីនោះ អ្នកទាំងពីរនាក់បានជួបនឹងលោក ។ នៅពេលដែលសន្និសីទចប់ អ្នកនិងមិត្តរបស់អ្នកទៅផ្ទះ ។

- តើអ្នកគិតថា អ្នក និងមិត្តរបស់អ្នកនឹងនិយាយអំពីរឿងនេះក្រោយពីការប្រជុំទេ ?

សូមរំឭកសិស្សថា ភាគច្រើនព្រះយេស៊ូវគ្រីស្ទបានបង្រៀនពួកសាសន៍នីហ្វៃពីអ្វីដែលនឹងកើតឡើង ។ នៅពេលទ្រង់រៀបនឹងចេញទៅ ទ្រង់បានដឹងថា ប្រជាជនមិនបានយល់ច្បាស់ពីអ្វីដែលទ្រង់បានបង្រៀនឡើយ ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១៧:១–៣ ដោយស្ងាត់ស្ងៀម ដោយរកមើលអ្វីព្រះអង្គសង្គ្រោះបានមានបន្ទូលទៅដល់ពួកសាសន៍នីហ្វៃ ថាពួកគេគួរធ្វើដើម្បីទទួលបានការយល់ដឹងបន្ថែមទៀតនោះ ។ (អ្នកអាចណែនាំថា សិស្សគួរគូសចំណាំអ្វីដែលពួកគេរកឃើញ) ។ ក្រោយពីសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញហើយ សូមសួរ ៖

- តើវាមានន័យយ៉ាងណាដើម្បីសញ្ជឹងគិតនោះ ?

សូមឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកនូវអ្វីដែលលោកបានបង្រៀនអំពីអត្ថន័យនៃការសញ្ជឹងគិត ។

« ការអាន ការសិក្សា និងការសញ្ជឹងគិតគឺមិនដូចគ្នាទេ ។ យើងអានពាក្យ ហើយយើងអាចទទួលបានគំនិត ។ យើងសិក្សា ហើយយើងអាចរកឃើញនូវគំរូ និងការទាក់ទងគ្នានៅក្នុងព្រះគម្ពីរ ។ ប៉ុន្តែនៅពេលយើងសញ្ជឹងគិត យើងបានអញ្ជើញវិវរណៈដោយព្រះវិញ្ញាណ ។ ចំពោះរូបខ្ញុំ ការសញ្ជឹងគិតគឺជាការគិត និងការអធិស្ឋានដែលខ្ញុំធ្វើក្រោយពីការអាន និងការសិក្សានៅក្នុងព្រះគម្ពីរយ៉ាងយកចិត្តទុកដាក់ » (« Serve with the Spirit » *Ensign* ឬ *លីអាហូណា*, ខែ វិច្ឆិកា ឆ្នាំ ២០១០, ទំព័រ ៦០) ។

- តើអ្នកគិតថា ការសញ្ជឹងគិត និងការអធិស្ឋានអាចធ្វើការរួមគ្នាដើម្បីជួយយើងឲ្យយល់ពីអ្វីដែលយើងរៀននៅក្នុងព្រះវិហារ ឬថ្នាក់សិក្ខាសាលាដោយរបៀបណា ?

សូមបង្ហាញថា ការណែនាំរបស់ព្រះអង្គសង្គ្រោះនៅក្នុង នីហ្វៃទី ៣ ១៧:៣ ថាពួកសាសន៍នីហ្វៃគួរតែ « រៀបចំគំនិត [របស់ពួកគេ] សម្រាប់ថ្ងៃស្អែក » នៅពេលទ្រង់ត្រឡប់មកបង្រៀនពួកគេម្តងទៀត ។

- តើបុគ្គលម្នាក់អាចធ្វើអ្វីខ្លះ ដើម្បីរៀបចំគំនិតរបស់គេមុនពេលចូលរួមនៅក្នុងព្រះវិហារ ឬថ្នាក់សិក្ខាសាលា ?
- តើមានភាពខុសគ្នាអ្វីខ្លះ នៅពេលដែលយើងរៀបចំគំនិតរបស់យើងសម្រាប់ការសិក្សាពីឱកាសបែបនោះ ?

ដើម្បីជួយសិស្សឲ្យរកមើលគោលការណ៍មួយដែលបានបង្រៀននៅក្នុង នីហ្វៃទី ៣ ១៧:១–៣ សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ហើយសូមឲ្យសិស្សបំពេញវាដោយផ្អែកលើអ្វីដែលពួកគេបានរៀន ។

តាមរយៈការសញ្ជឹងគិត និងការអធិស្ឋានដល់ព្រះវរបិតា យើងអាច . . .

ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាក្តី ក៏ពួកគេគួរឃើញនូវគោលការណ៍ខាងក្រោមនេះដែរ ៖ **តាមរយៈការសញ្ជឹងគិត និងការអធិស្ឋានដល់ព្រះវរបិតា យើងអាចទទួលបានការយល់ដឹងដ៏ធំអស្ចារ្យ ។**

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖

រៀបចំគំនិតរបស់ខ្ញុំ មុនពេលខ្ញុំចូលរួមក្នុងព្រះវិហារ ឬថ្នាក់សិក្ខាសាលា

សញ្ជឹងគិតអ្វីដែលខ្ញុំស្តាប់ឮនៅក្នុងព្រះវិហារ ឬថ្នាក់សិក្ខាសាលា

អធិស្ឋានអំពីអ្វីដែលខ្ញុំស្តាប់ឮនៅក្នុងព្រះវិហារ ឬថ្នាក់សិក្ខាសាលា

សូមឲ្យសិស្សជ្រើសរើសសកម្មភាពមួយដែលបានសរសេរនៅលើក្តារខៀន ។ សូមឲ្យពួកគេមានពេលគិតអំពី (១) របៀបដែលពួកគេបានធ្វើវា និង (២) របៀបដែលវាបានជួយពួកគេឲ្យរៀនបន្ថែមពីបទពិសោធន៍នៅក្នុងព្រះវិហារ ឬថ្នាក់សិក្ខាសាលារបស់ពួកគេ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយគំនិតរបស់ពួកគេជាមួយនឹងសិស្សក្នុងថ្នាក់ ។ សូមលើកទឹកចិត្តសិស្សឲ្យគិតពីរបៀបដែលពួកគេអាចពង្រីកផ្នែកមួយក្នុងចំណោមផ្នែកទាំងបី និងបង្កើតគម្រោងពីរបៀបដែលពួកគេនឹងធ្វើដូច្នោះ ។ អ្នកអាចណែនាំថា ពួកគេគួរសរសេរដែនការរបស់ពួកគេនៅក្នុងសៀវភៅសរសេរ ឬនៅក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីរ ។ សូមប្រាប់សិស្សថា ផ្នែកបន្ទាប់ទៀតនៃមេរៀននេះនឹងផ្តល់ឱកាសដល់ពួកគេដើម្បីអនុវត្តការសញ្ជឹងគិត ។

នីហ្វៃទី ៣ ១៧:៤–២៥

ព្រះអង្គសង្គ្រោះព្យាបាលអ្នកឈឺនៅក្នុងពួកសាសន៍នីហ្វៃ អធិស្ឋានដល់ព្រះវរបិតាសម្រាប់ប្រជាជន និងប្រទានពរដល់កូនចៅរបស់ពួកគេ

សូមបង្ហាញរូបភាពនៃព្រះយេស៊ូវកំពុងបង្រៀននៅក្នុងអឌ្ឍគោលខាងលិច (លេខកូដ ៦២៣៨០; *កញ្ចប់រូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ |, លេខ ៨២) ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៧:៤ ។ សូមបង្ហាញឃ្លា « ឥឡូវនេះ យើងយាងទៅឯព្រះវរបិតាវិញ » ។ សូមឲ្យសិស្សស្រមៃថា ពួកគេទើបតែចំណាយពេលមួយថ្ងៃជាមួយនឹងព្រះអង្គសង្គ្រោះ ហើយទ្រង់បានប្រកាសថា ដល់ពេលទ្រង់ត្រូវយាងទៅវិញហើយ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយរបៀបដែលពួកគេអាចមានអារម្មណ៍នៅក្នុងស្ថានភាពនេះ ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៧:៥ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពីរបៀបដែលពួកសាសន៍នីហ្វៃបានឆ្លើយតប នៅពេលដែលព្រះអង្គសង្គ្រោះបានបង្ហាញបំណងរបស់ទ្រង់ថានឹងចាកចេញ ។

សូមពន្យល់ថា ប្រសិនបើវាមិនមែនសម្រាប់បំណងដ៏សុចរិតនៃសាសន៍នីហ្វៃទេ ហេតុការណ៍ដែលបានកត់ត្រានៅក្នុង នីហ្វៃទី ៣ ១៧ និង ១៨ នឹងមិនអាចកើតមានឡើងឡើយ ។ សកម្មភាពខាងក្រោមត្រូវបានរចនាឡើងដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់អំពីសេចក្តីស្រឡាញ់ដែលព្រះយេស៊ូវគ្រីស្ទមានដល់ប្រជាជនរបស់ទ្រង់ និងដើម្បីជួយពួកគេឲ្យស្វែងរកសេចក្តីពិតទាំងឡាយដោយឯករាជ្យនៅក្នុងព្រះគម្ពីរអំពីលក្ខណៈរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ហើយសូមឲ្យសិស្សចម្លងវាចូលទៅក្នុងសៀវភៅសរសេរ ឬក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ។

នីហ្វៃទី ៣ ១៧:៦–១០

នីហ្វៃទី ៣ ១៧:១១–១៨

នីហ្វៃទី ៣ ១៧:១៩–២៥

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះ ដែលថ្លែងដោយប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន ៖

« បុរសនោះគឺអស្ចារ្យបំផុត និងត្រូវបានប្រទានពរ និងរីករាយបំផុត ដែលមានជីវិតខិតជិតកៀកទៅនឹងគំរូនៃព្រះគ្រីស្ទ ។ នេះគ្មានអ្វីទាក់ទងទៅនឹងទ្រព្យសម្បត្តិ អំណាច ឬកិត្តិនាមនៃពិភពលោកនោះទេ ។ ការសាកល្បងដ៏ពិតតែមួយគត់នៃភាពអស្ចារ្យ ការប្រទានពរខ្លាំង ភាពរីករាយគឺជារបៀបមួយដែលជីវិតមួយអាចក្លាយទៅកាន់តែដូចជាលោកចៅហ្វាយ គឺព្រះយេស៊ូវគ្រីស្ទ ។ ទ្រង់គឺជាផ្លូវដ៏ពិត សេចក្តីពិតដ៏ពេញលេញ និងជីវិតដ៏បរិបូរណ៌» (« Jesus Christ—Gifts and Expectations » *Ensign,* ខែ ធ្នូ ឆ្នាំ ១៩៨៨, ទំព័រ ២) ។

សូមឲ្យសិស្សមានពេលពី ៥ ទៅ ១០ នាទីដើម្បីសិក្សាដោយស្ងាត់ស្ងៀមអំពីវគ្គព្រះគម្ពីរនីមួយៗដែលអ្នកបានសរសេរនៅលើក្តារខៀន ។ សូមឲ្យពួកគេរកមើលសេចក្តីពិតអំពីលក្ខណៈសម្បត្តិរបស់ព្រះអង្គសង្គ្រោះ ។ នៅពេលពួកគេសិក្សា ពួកគេគួររកឃើញយ៉ាងតិចណាស់សេចក្តីពិតមួយពីវគ្គព្រះគម្ពីរនីមួយៗ ។ សូមឲ្យពួកគេសរសេរនូវសេចក្តីពិតដែលពួកគេរកឃើញ ។

នៅពេលសិស្សបានបញ្ចប់ការសិក្សាហើយ សូមឲ្យពួកគេបីបួននាក់សរសេរនៅលើក្តារខៀន នៅក្រោមសេចក្តីយោងព្រះគម្ពីរដែលត្រូវគ្នា នូវសេចក្តីពិតមួយដែលពួកគេបានរៀនអំពីព្រះអង្គសង្គ្រោះ ។ នៅពេលសិស្សបានបញ្ចប់សកម្មភាពនេះហើយ សូមសួរសំណួរខាងក្រោមនេះ ៖

- ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីដឹងពីសេចក្តីពិតទាំងនេះអំពីព្រះអង្គសង្គ្រោះ ?
- តើមានភស្តុតាងអ្វីខ្លះដែលអ្នកបានរកឃើញថា ព្រះអង្គសង្គ្រោះងាយដឹងពីតម្រូវការ និងបំណងរបស់យើង ?
- តើផ្នែកនៃដំណើររឿងនេះមួយណាដែលបំផុសគំនិតអ្នកបំផុត ? ហេតុអ្វី ?
- តើអ្នកគិតថា ហេតុអ្វីបានជាប្រជាជនត្រូវបានយកឈ្នះដោយសេចក្តីរីករាយ ? (សូមមើល នីហ្វៃទី ៣ ១៧:១៨) ។
- តើអ្នកគិតថា ហេតុអ្វីបានជាសេចក្តីរីករាយរបស់ព្រះអង្គសង្គ្រោះពេញលេញនៅថ្ងៃនោះ ? (សូមមើល នីហ្វៃទី ៣ ១៧:២០) ។

សូមឲ្យសិស្សសង្ខេបអ្វីដែលពួកគេបានរៀនពី នីហ្វៃទី ៣ ១៧:៦–២៥ ។ សិស្សអាចផ្តល់នូវចម្លើយផ្សេងៗគ្នា ។ សេចក្តីពិតមួយដែលពួកគេអាចរកឃើញនោះគឺ ***ព្រះអង្គសង្គ្រោះមានសេចក្តីមេត្តាករុណាដ៏ធំធេងសម្រាប់យើង*** ។ សូមសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ។ អ្នកអាចណែនាំថា សិស្សគួរសរសេរសេចក្តីពិតនេះ ឬសេចក្តីពិតផ្សេងទៀតដែលពួកគេបានរកឃើញនៅរឹមទំព័រនៃព្រះគម្ពីររបស់ពួកគេក្បែរ នីហ្វៃទី ៣ ១៧:៦ ។

ដើម្បីជួយសិស្សឲ្យកោតសរសើរដល់របៀបនៃការយល់ដឹងអំពីលក្ខណៈសម្បត្តិរបស់ព្រះយេស៊ូវគ្រីស្ទ ជួយយើងឲ្យបង្កើនសេចក្តីជំនឿរបស់យើង សូមអានសេចក្តីថ្លែងការណ៍ខាងក្រោម ៖

« អ្នកអាចអនុវត្តសេចក្តីជំនឿទៅលើព្រះគ្រីស្ទ នៅពេលអ្នកមានការធានាមួយថា ទ្រង់នៅរស់ គំនិតដ៏ត្រឹមត្រូវមួយនៃលក្ខណៈសម្បត្តិរបស់ទ្រង់ និងចំណេះដឹងមួយថា អ្នកកំពុងខិតខំរស់នៅតាមឆន្ទៈរបស់ ទ្រង់ » ((*ពិតចំពោះសេចក្តីជំនឿ ៖ សេចក្តីយោងដំណឹងល្អ* | ឆ្នាំ ២០០៤ |, ទំព័រ ៥៤) ។

- តើការយល់ដឹងពីធម្មជាតិនៃសេចក្តីមេត្តាករុណារបស់ព្រះអង្គសង្គ្រោះជួយអ្នកឲ្យអនុវត្តសេចក្តីជំនឿទៅលើទ្រង់ដោយរបៀបណា ?

សូមបង្ហាញឃ្លា « រងទុក្ខដោយជំងឺណាក៏ដោយ » នៅក្នុង នីហ្វៃទី ៣ ១៧:៩ ។

- តើជំងឺប្រភេទណាខ្លះអាច មាននៅក្នុងការរងទុក្ខ « ណាក៏ដោយ » នោះ ? (ជំងឺគ្រប់ប្រភេទនៃរាងកាយ សតិអារម្មណ៍ ស្មារតី និងខាងវិញ្ញាណ) ។

សូមឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេអាច « រងទុក្ខ » និងអ្វីដែលពួកគេនឹងសុំឲ្យព្រះអង្គសង្គ្រោះព្យាបាលពួកគេ ប្រសិនបើទ្រង់នឹងប្រទានពរដល់ពួកគេរៀងៗខ្លួននោះ ។ សូមរំឭកពួកគេថា ទោះបីជាព្រះអង្គសង្គ្រោះមិននៅទីនេះដើម្បីបម្រើដល់យើងផ្ទាល់អង្គទ្រង់ក្តី ក៏ព្រះចេស្តារបស់ទ្រង់ដើម្បីប្រទានពរ និងព្យាបាលនៅមានតាមរយៈបព្វជិតភាព ដែរ ។

- តើអ្នកនឹងទៅរកនរណាសម្រាប់ការប្រសិទ្ធពរដោយបព្វជិតភាព ?
- តើនៅពេលណាដែលជាលើកចុងក្រោយដែលអ្នកមានអារម្មណ៍ថាកំពុងព្យាបាលដោយឥទ្ធិពលរបស់ព្រះអង្គសង្គ្រោះនៅក្នុងជីវិតរបស់អ្នក ?

សូមរំឭកសិស្សអំពីគោលការណ៍នៃការសញ្ជឹងគិតដែលពួកគេបានពិភាក្សានៅពេលដើមដំបូង ។ សូមណែនាំថា របៀបមួយដែលពួកគេអាចសញ្ជឹងគិតគឺតាមរយៈ ការស្រមៃថាខ្លួនគេនៅក្នុងស្ថានភាពដែលបានរៀបរាប់នៅក្នុងដំណើររឿងព្រះគម្ពីរដែលពួកគេអាន ។ សូមឲ្យសិស្សដាក់ខ្លួនគេនៅក្នុងចំណោមពួកសាសន៍នីហ្វៃ នាពេលនៃហេតុការណ៍ដែលបានប្រាប់នៅក្នុង នីហ្វៃទី ៣ ១៧ នោះ ។ សូមឲ្យសិស្សមានពេលសរសេរនៅក្នុងសៀវភៅសរសេរ ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ អំពីអ្វីដែលពួកគេអាចបានឮ ឃើញ មានអារម្មណ៍ និងបានរៀន ប្រសិនបើពួកគេស្ថិតនៅក្នុងចំណោមពួកសាសន៍នីហ្វៃ និងបានទាក់ទងជាមួយនឹងព្រះអង្គសង្គ្រោះនាឱកាសនោះ ។ អ្នកអាចណែនាំថា ពួកគេគួរសរសេរអំពីការរងទុក្ខមួយដែលពួកគេអាចសុំឲ្យព្រះអង្គសង្គ្រោះព្យាបាល ។ នៅពេលពួកគេសរសេរចប់ហើយ សូមគិតពីការឲ្យសិស្សពីរបីនាក់អានអ្វីដែលពួកគេបានសរសេរទៅដល់សិស្សក្នុងថ្នាក់ ។ សូមប្រាកដថា ពួកគេយល់ថា ពួកគេមិនគួរមានអារម្មណ៍ថាត្រូវតែចែកចាយអ្វីៗដែលផ្ទាល់ខ្លួនពេក ឬឯកជនពេកនោះទេ ។

ក្រោយពីសិស្សពីរបីនាក់បានចែកចាយអ្វីដែលពួកគេបានសរសេររួចហើយ អ្នកអាចសុំឲ្យពួកគេម្នាក់ ឬពីរនាក់ចែកចាយពីរបៀបដែលពួកគេដឹងថា ព្រះយេស៊ូវគ្រីស្ទស្រឡាញ់ និងមានសេចក្តីមេត្តាករុណាដល់ពួកគេ ។ សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតអំពីមេរៀននេះ និងទុកចិត្តលើសេចក្តីមេត្តាករុណារបស់ព្រះអង្គសង្គ្រោះ នៅពេលពួកគេពឹងផ្អែកសុំជំនួយពីទ្រង់ សម្រាប់បំណង ភាពទន់ខ្សោយ ការឈឺចិត្ត និងឧបសគ្គរបស់ពួកគេ ។

ការស្រមៃឃើញ

ការស្រមៃឃើញ គឺជាជំនាញសិក្សាព្រះគម្ពីរមួយដែលអាចជួយសិស្សឲ្យ វិភាគ យល់ និងអនុវត្តអ្វីដែលពួកគេបានអាន ។ សូមជួយសិស្សឲ្យរៀនដើម្បីដាក់ខ្លួននៅក្នុងហេតុការណ៍នៃព្រះគម្ពីរ ដោយការលើកទឹកចិត្តឲ្យពួកគេព្យាយាមស្រមៃរូបភាពនៅក្នុងចិត្តរបស់គេថាមានមនុស្ស ទីកន្លែង និងហេតុការណ៍ដែលពួកគេបានអាននោះ ។ របៀបមួយដែលសិស្សអាចសម្រេចការណ៍នេះបានគឺដោយការស្រមៃថា ពួកគេគឺជាអ្នកចូលរួមនៅក្នុងរឿងដែលពួកគេកំពុងអាននេះ ។

មេរៀនទី ១២៧

នីហ្វៃទី ៣ ជំពូក ១៨

សេចក្តីផ្តើម

នៅពេលព្រះយេស៊ូវគ្រីស្ទបានបញ្ចប់ថ្ងៃទីមួយនៃការបម្រើរបស់ទ្រង់នៅក្នុងចំណោមពួកសាសន៍នីហ្វៃ ទ្រង់បានដឹកនាំពិធីសាក្រាម៉ង់ ។ ទ្រង់បានបញ្ជាពួកគេឲ្យទទួលទានសាក្រាម៉ង់ អធិស្ឋានទៅព្រះវរបិតាជានិច្ច ហើយពង្រីកសម្ព័ន្ធមិត្តជាមួយនឹងមនុស្សទាំងអស់ ។ ព្រះអង្គសង្គ្រោះបានសន្យានូវពរជ័យដ៏ធំដល់អ្នកទាំងឡាយណាដែលគោរពតាម ។ បន្ទាប់មក ទ្រង់បានផ្តល់ការណែនាំដល់ពួកសាវកសាសន៍នីហ្វៃដប់ពីរនាក់ ដែលទាក់ទងទៅនឹងការបម្រើរបស់ពួកលោកនៅក្នុងសាសនាចក្រ ។ មុនពេលយាងទៅស្ថានសួគ៌វិញ ទ្រង់បានប្រទានដល់ពួកលោកនូវអំណាចដើម្បីផ្តល់នូវអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៣ ១៨:១–១៤

ព្រះយេស៊ូវគ្រីស្ទធ្វើពិធីសាក្រាម៉ង់ដល់ពួកសាសន៍នីហ្វៃ

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ជើរ៉ល អិន ឡាន នៃពួកចិតសិបនាក់ ។ (សូមប្រាប់សិស្សថាឈ្មោះ *Czenkusch* គឺអានថា « សិន ឃុស ») ។ សូមលើកទឹកចិត្តសិស្សឲ្យស្រមៃអ្វីដែលអាចដូចកាលដែលក្លាយជាអ្នកឡើងភ្នំដែលបានលើកឡើងដោយអែលឌើរ ឡាន ។

« មួយរយៈពេលកន្លងទៅ មានអត្ថបទមួយដ៏គួរឲ្យចាប់អារម្មណ៍អំពីការឡើងភ្នំនៅក្នុងទស្សនាវដ្ដីវេជ្ជសាស្ត្រ ។ . . .

« អត្ថបទនេះគឺអំពីបុរសម្នាក់ឈ្មោះ សិនឃុស ដែលបើកសាលាហាត់ឡើងភ្នំ ។ . . . សិនឃុស បានពិពណ៍នាប្រាប់អ្នកសម្ភាសន៍ម្នាក់អំពីប្រព័ន្ធខ្សែពួរយឺតនៅក្នុងការឡើងភ្នំ ។ នេះគឺជាប្រព័ន្ធដែលអ្នកឡើងភ្នំការពារខ្លួនគេកុំឲ្យធ្លាក់ចុះ ។ អ្នកឡើងភ្នំម្នាក់មានសុវត្ថិភាពហើយការពារខ្សែពួរនោះសម្រាប់អ្នកឡើងភ្នំបន្ទាប់ទៀត ជាធម្មតាវាព័ទ្ធជុំវិញខ្លួនរបស់គេ ។ ‹ អ្នកស្ថិតនៅក្នុងខ្សែយឺត › មានន័យថា ‹ ខ្ញុំការពារអ្នកបានហើយ ។ ប្រសិនបើមានអ្វីមួយកើតឡើង ខ្ញុំនឹងការពារអ្នកកុំឲ្យធ្លាក់ចុះ ។ › វាជាផ្នែកដ៏សំខាន់មួយនៃការឡើងភ្នំ ។ ឥឡូវ សូមកត់ចំណាំអ្វីដែលកើតឡើងបន្ទាប់នៅក្នុងអត្ថបទនេះ ៖ ‹ ខ្សែយឺតបានធ្វើឲ្យសិនឃុសបានមានពេលដ៏ល្អបំផុត និងអាក្រក់បំផុតក្នុងការឡើងភ្នំ ។ ពេលមួយ សិនឃុស ធ្លាប់បានធ្លាក់ពីជ្រោះដ៏ខ្ពស់មួយ ដោយការកន្ត្រាក់មេបច្ចេកវិទ្យាបីចេញ ហើយទាញខ្សែយឺតរបស់គាត់ចេញពីផ្នែកលយចេញក្រៅ ។ គាត់ត្រូវបានបញ្ឈប់ ដាំក្បាលចុះ ១០ ហ្វីតថ៉ កម្ពស់ពីដី នៅពេលអ្នកយឺតខ្សែរបស់គាត់ [ដន] បានចាប់ការធ្លាក់ដោយកម្លាំងសន្ធឹងដែរបស់គាត់ ។ សិនឃុស បាននិយាយថា « ដន បានសង្គ្រោះជីវិតរបស់ខ្ញុំ » ។ « តើអ្នកឆ្លើយតបទៅនឹងបុរសម្នាក់ដូចនោះយ៉ាងណា ? ជួនគាត់នូវខ្សែឡើងភ្នំដែលប្រើហើយមួយសម្រាប់កាដូថ្ងៃគ្រីស្ទម៉ាស ? ទេ *អ្នកចងចាំគាត់ ។ អ្នកនឹងតែងតែចងចាំដល់គាត់* › » [Eric G. Anderson « The Vertical Wilderness » *Private Practice,* ខែ វិច្ឆិកា ឆ្នាំ ១៩៧៩, ទំព័រ ២១ ; សេចក្តីបញ្ជាក់បន្ថែម] » (« The Grace and Mercy of Jesus Christ » នៅក្នុង *Jesus Christ: Son of God, Savior,* ed. Paul H. Peterson, Gary L. Hatch, and Laura D. Card [ឆ្នាំ ២០០២], ទំព័រ ៤៨) ។

- តើហេតុអ្វីបានជាអ្នកគិតថា អ្នកឡើងភ្នំបានមានអារម្មណ៍ថា ការជួនអំណោយជាវត្ថុដល់អ្នកសង្គ្រោះរបស់គាត់អាចនឹងជារបៀបមួយដែលមិនគ្រប់គ្រាន់ដើម្បីបង្ហាញអំណរគុណ ?

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១៨:១–៧ ដោយស្ងាត់ស្ងៀម ដោយរកមើលអ្វីព្រះអង្គសង្គ្រោះបានមានបន្ទូលទៅដល់ពួកសាសន៍នីហ្វៃ ថាពួកគេគួរធ្វើដើម្បីចងចាំដល់ទ្រង់ ។ (អ្នកអាចណែនាំ សិស្សឲ្យគូរគូសចំណាំពាក្ស *ការចងចាំ* និង *ចងចាំ* នៅក្នុង នីហ្វៃទី ៣ ១៨:៧ ។) ក្រោយពីសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញហើយ សូមសួរសំណួរខាងក្រោម ៖

- តើការទទួលយកពិធីសាក្រាម៉ង់ជួយយើងឲ្យចងចាំដល់ពលិកម្មរបស់ព្រះអង្គសង្គ្រោះជំនួសយើងដោយរបៀបណា ?
- យោងតាម នីហ្វៃទី ៣ ១៨:៧ តើពួកសាសន៍នីហ្វៃត្រូវចងចាំអ្វី នៅពេលពួកគេទទួលបាននំបុ័ង ?

សូមឲ្យសិស្សមានពេលមើលនៅ នីហ្វៃទី ៣ ១១:១៤–១៥ ។ បន្ទាប់មក សួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- ហេតុអ្វីបានជាការចងចាំដល់ព្រះកាយរបស់ព្រះអង្គសង្គ្រោះអាចជាការណ៍ដ៏សំខាន់ជាពិសេសសម្រាប់ពួកសាសន៍នីហ្វៃ ?
- ទោះបីជាអ្នកមិនបានឃើញស្នាមរបួសនៅលើព្រះកាយរបស់ព្រះអង្គសង្គ្រោះដូចជាពួកសាសន៍នីហ្វៃក្តី ហេតុអ្វីបានជាវានៅតែសំខាន់សម្រាប់អ្នកដើម្បីទទួលយកនំបុ័ងសាក្រាម៉ង់ដើម្បី « រំពួកពីព្រះកាយ » នៃព្រះអង្គសង្គ្រោះ ? (គ. និង ស. ២០:៧៧) ។
- តើយើងអាចធ្វើអ្វីខ្លះដើម្បីតែងតែចងចាំដល់ព្រះអង្គសង្គ្រោះនោះ ?

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *នៅពេលយើងទទួលយកសាក្រាម៉ង់ យើងធ្វើជាសាក្សីដល់ព្រះវរបិតាថា . . .*

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១៨:៨–១១ ដោយស្ងាត់ស្ងៀម ដោយរកមើលពាក្ស ឬឃ្លាដែលបំពេញប្រយោគនៅលើក្តារខៀន ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីដែលពួកគេបានរកឃើញ ។ (សិស្សអាចបំពេញប្រយោគតាមរបៀបនេះ ៖ **នៅពេលយើងទទួលទានសាក្រាម៉ង់ យើងធ្វើជាសាក្សីដល់ព្រះវរបិតាថា យើងនឹងតែងតែចងចាំដល់ព្រះយេស៊ូវគ្រីស្ទជានិច្ច ។** ចម្លើយមួយទៀតអាចដូចខាង

ក្រោម ៖ **នៅពេលយើងទទួលយកសាក្រាម៉ង់ យើងធ្វើជាសាក្សីដល់ព្រះវរបិតាថា យើងនឹងព្រមធ្វើអ្វីៗទាំងអស់ដែលព្រះអង្គសង្គ្រោះបានបញ្ជាដល់យើង**) ។

សូមប្រើសំណួរខាងក្រោមនេះខ្លះ ឬទាំងអស់ដើម្បីជួយសិស្សឲ្យយល់កាន់តែសឹងជម្រៅ និងកោតសរសើរដល់តួនាទីនៃពិធីសាក្រាម៉ង់ក្នុងការជួយយើងឲ្យចងចាំដល់ព្រះអង្គសង្គ្រោះ ៖

- តើផ្នែកនៃជីវិត និងការបម្រើរបស់ព្រះអង្គសង្គ្រោះណាខ្លះ ដែលយើងអាចចងចាំក្នុងពេលពិធីបរិសុទ្ធសាក្រាម៉ង់ ? (ចម្លើយអាចរួមមាន ការសុគត និងការពលិកម្មដ៏ធួនរបស់ទ្រង់ ការប្រសូតដ៏បន្ទាបខ្លួនរបស់ទ្រង់ អព្ភូតហេតុ និងការបង្រៀនរបស់ទ្រង់ ការយកចិត្តទុកដាក់ដោយសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះអ្នកដទៃ និងការដែលទ្រង់ស្តាប់បង្គាប់តាមព្រះវរបិតាសួគ៌) ។
- ទោះបីជាការទទួលយកពិធីសាក្រាម៉ង់ចំណាយពេលតិចក្តី ក៏ឥទ្ធិពលនៃការរៀបចំ និងការចូលរួមនៅក្នុងពិធីបរិសុទ្ធនេះអស់កល្បជៃរ ។ តើយើងអាចធ្វើអ្វីខ្លះ ដើម្បីតែងតែចងចាំដល់ព្រះអង្គសង្គ្រោះ ក្រោយពីយើងបានទទួលទានពិធីសាក្រាម៉ង់ និងអំឡុងពេលពេញមួយសប្តាហ៍នោះ ?
- តើសេចក្តីស្មោះស និងការយកចិត្តទុកដាក់ដែលយើងផ្តល់នៅក្នុងការទទួលទានសាក្រាម៉ងអាចជួយយើងឲ្យរំឭកដល់ព្រះអង្គសង្គ្រោះពេញមួយសប្តាហ៍ដោយរបៀបណា ?
- តើពិធីសាក្រាម៉ង់មានន័យយ៉ាងណា ប្រសិនបើយើងមិនបានចងចាំដល់ទ្រង់ទេនោះ ?
- យោងតាម នីហ្វៃទី ៣ ១៨:៧, ១១ តើព្រះអង្គសង្គ្រោះបានសន្យាដល់អស់អ្នកទាំងឡាយណាដែលទទួលយកពិធីសាក្រាម៉ង់ និងចងចាំដល់ទ្រង់អ្វីខ្លះ ? (**នៅពេលយើងទទួលពិធីសាក្រាម៉ង់ និងចងចាំដល់ព្រះអង្គសង្គ្រោះជានិច្ចនោះ យើងនឹងទទួលបានព្រះវិញ្ញាណរបស់ទ្រង់នៅជាមួយនឹងយើង**) ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៨:១២–១៤ ឮៗ ហើយបន្ទាប់មក សូមឲ្យសិស្សម្នាក់ទៀតអាន ហេលេមិន ៥:១២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់ទាំងអស់មើលតាម ដោយសញ្ជឹងគិតពីទំនាក់ទំនងរវាងវគ្គព្រះគម្ពីរទាំងពីរ ។

- តើការទទួលទានសាក្រាម៉ង់ជាទៀងទាត់អាចជួយអ្នកឲ្យយកព្រះយេស៊ូវគ្រីស្ទធ្វើជាមូលដ្ឋានគ្រឹះដែលអ្នកត្រូវសង់ជីវិតរបស់អ្នកលើដោយរបៀបណា ?

ដើម្បីជួយសិស្សឲ្យចងចាំដល់ព្រះយេស៊ូវគ្រីស្ទជាងមុន សូមឲ្យពួកគេសរសេរនៅក្នុងសៀវភៅសរសេរ សៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅកំណត់ហេតុផ្ទាល់ខ្លួនអំពីអ្វីដែលពួកគេធ្វើដើម្បីចងចាំដល់ព្រះអង្គសង្គ្រោះរាល់ថ្ងៃសម្រាប់សប្តាហ៍ក្រោយ ។ សូមលើកទឹកចិត្តសិស្សឲ្យគិតពីការសរសេរអំពីគំនិតដែលពួកគេបានមាន អំឡុងពេលសាក្រាម៉ង់ ឬរបៀបដែលការចងចាំដល់ព្រះអង្គសង្គ្រោះដែលត្រូវបានទទួលនៅក្នុងគំនិត ពាក្យសម្តី និងសកម្មភាពរបស់គេ ។

សូមតាមដានសិស្សនៅពេលបង្រៀនលើកក្រោយៗ ដោយការជម្រុញពួកគេឲ្យបន្តសរសេររាល់ថ្ងៃ ។ អំឡុងពេលសប្តាហ៍ អ្នកអាចឲ្យពួកគេមានពេលពីរបីនាទីនៅពេលចាប់ផ្តើមថ្នាក់ដើម្បីសរសេរអ្វីដែលពួកគេកំពុងធ្វើដើម្បីចងចាំដល់ព្រះអង្គសង្គ្រោះ ។

នីហ្វៃទី ៣ ១៨:១៥–២៥

ព្រះយេស៊ូវបង្រៀនដល់ពួកសាសន៍នីហ្វៃឲ្យអធិស្ឋានដល់ព្រះវរបិតាជានិច្ច និងជួបជុំគ្នាជាញឹកញាប់

សូមបំបែកសិស្សធ្វើការជាដៃគូ ។ សូមឲ្យដៃគូនីមួយៗអាន នីហ្វៃទី ៣ ១៨:១៥–២១ រួមគ្នា ដោយរកមើលអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនយើងឲ្យធ្វើដើម្បីប្រឆាំងនឹងការល្បួង ។ នៅពេលពួកគេអានចប់ហើយ សូមឲ្យដៃគូទាំងអស់សរសេរប្រយោគមួយ ដែលពួកគេមានអារម្មណ៍ថានឹងសង្ខេបការបង្រៀនទាំងនេះអំពីការយកឈ្នះលើការល្បួង ។ សូមឲ្យដៃគូបីបួនគូចែកចាយអ្វីដែលពួកគេបានសរសេរ ។ (ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាដើម្បីបង្ហាញពីការសង្ខេបរបស់ពួកគេក្តី ក៏ពួកគេគួរតួសបញ្ជាក់នូវសេចក្តីពិតខាងក្រោមនេះ ៖ **ប្រសិនបើយើងប្រយ័ត្ន និងអធិស្ឋានជានិច្ចទៅរកព្រះវរបិតា នោះយើងនឹងអាចប្រឆាំងនឹងការល្បួងរបស់សាតាំង**) ។

- តើអ្នកគិតថាពាក្យ *ប្រយ័ត្ន* មានន័យយ៉ាងណានៅក្នុង នីហ្វៃទី ៣ ១៨:១៨ ? (ការទទួលការព្រមានខាងវិញ្ញាណ ការមិនធ្វេសប្រហែស ឬការចាំយាម) ។
- តើអ្នកគិតថា ហេតុអ្វីបានជាទាំងការប្រយ័ត្ន និងការអធិស្ឋានមានសារៈសំខាន់ក្នុងការប្រឆាំងនឹងការល្បួង ?

សូមបង្ហាញថា នីហ្វៃទី ៣ ១៨:១៥, ២០–២១ នេះគឺជាវគ្គចំណេះចំណានព្រះគម្ពីរ ។ អ្នកអាចណែនាំថា សិស្សគួរគូសចំណាំវគ្គនេះដើម្បីឲ្យងាយស្រួលនឹងរកឃើញវា ។

- តើការអធិស្ឋានជួយយើងឲ្យនៅតែប្រយ័ត្ន និងទទួលបានការដាស់តឿនចំពោះការខំល្បួងរបស់សាតាំងលើយើងដោយរបៀបណា ?

សូមឲ្យសិស្សឆ្លើយនឹងសំណួរខាងក្រោមនៅក្នុងសៀវភៅសរសេរ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ ។ (អ្នកអាចសរសេរសំណួរនេះនៅលើក្តារខៀន ឬអានវាយឺតៗដើម្បីឲ្យសិស្សអាចកត់វាបាន) ។

- តើការអធិស្ឋានបានជួយអ្នកឲ្យប្រឆាំងការល្បួងរបស់សាតាំងដោយរបៀបណា ?
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីពង្រឹងការអធិស្ឋានផ្ទាល់ខ្លួនរបស់អ្នក ?
- តើពរជ័យអ្វីខ្លះដែលអ្នកបានឃើញពីការអធិស្ឋានជាមួយនឹងក្រុមគ្រួសាររបស់អ្នក ?
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីជួយគ្រួសាររបស់អ្នកឲ្យមានការអធិស្ឋានជាគ្រួសារដ៏ចិតថេរ និងមានអត្ថន័យ ?

ប្រសិនបើមានពេល សូមគិតពីការសុំសិស្សពីរបីនាក់ឲ្យចែកចាយដល់សិស្សក្នុងថ្នាក់នូវអ្វីដែលពួកគេបានសរសេរ ។

📖 **នីហ្វៃទី ៣ ១៨:១៥, ២០–២១** គឺជាវគ្គចំណេះចំណានខគម្ពីរ ។ សូមបើកទៅយោបល់នៃការបង្រៀន នៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរ ។

សូមឲ្យសិស្សគិតពីនរណាម្នាក់ ដែលពួកគេនឹងជួយឲ្យខិតកាន់តែជិតទៅរកព្រះអង្គសង្គ្រោះ ។ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ហើយលើកទឹកចិត្តសិស្សឲ្យសរសេរ ។ ***នៅពេលយើងបម្រើដល់អ្នកដទៃ យើងអាចជួយពួកគេឲ្យមកកាន់ព្រះគ្រីស្ទ*** ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១៨:២២–២៤ ដោយស្ងាត់ស្ងៀម ។

- តើព្រះអង្គសង្គ្រោះសុំឲ្យយើងធ្វើអ្វីខ្លះ ដើម្បីជួយអ្នកដទៃឲ្យមកកាន់ទ្រង់ ? (យើងមិនគួរព្រួយអ្នកដទៃឲ្យចេញពីការប្រជុំនៃសាសនាចក្រយើងទេ ហើយយើងគួរអធិស្ឋានសម្រាប់ពួកគេ) ។
- ព្រះអង្គសង្គ្រោះបានមានបន្ទូលថា ទ្រង់គឺជាពន្លឺ ដែលយើងត្រូវលើកឡើងបង្ហាញដល់ពិភពលោក ។ តើយើងម្នាក់ៗអាចដោះស្រាយនឹងជីវិតរបស់យើងដោយការលើកពន្លឺរបស់ព្រះអង្គសង្គ្រោះឡើងដោយរបៀបណា ?

សូមអានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ៉ូបឺត ឌី ហៃល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សស្តាប់រកអ្វីដែលអែលឌើរ ហៃល បានមានប្រសាសន៍ថានឹងកើតឡើង នៅពេលយើងរស់នៅដោយសុចរិត ។

« តើវាមិនធ្វើឲ្យព្រះយេស៊ូវគាប់ព្រះទ័យទេឬ នៅពេលយើងអាចអនុញ្ញាតឲ្យពន្លឺរបស់យើងបញ្ចាំងចេញទៅរហូតដល់អស់អ្នកទាំងឡាយដែលធ្វើតាមយើងនឹងដើរតាមព្រះអង្គសង្គ្រោះដែរនោះ ? មានអ្នកដែលកំពុងស្វែងរកពន្លឺដែលនឹងឆ្លងកាត់ទ្វារនៃពិធីបុណ្យជ្រមុជទឹកដោយរីករាយទៅរកផ្លូវដ៏ត្រង់ និងតូចចង្អៀតដែលនាំទៅរកជីវិតដ៏អស់កល្បជានិច្ច (សូមមើល នីហ្វៃទី ២ ៣១) ។ តើអ្នកនឹងធ្វើជាពន្លឺនោះដែលនឹងដឹកនាំពួកគេទៅរកកំពង់ផែដ៏មានសុវត្ថិភាពមួយទេ ? (« That Ye May Be the Children of Light » | Brigham Young University fireside address, ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ |, ទំព័រ ៨, speeches.byu.edu) ។

- តើអ្នកគិតយ៉ាងណា នៅពេលអ្នកគិតអំពីសំណួរ « តើវាមិនធ្វើឲ្យព្រះយេស៊ូវគាប់ព្រះទ័យទេឬ នៅពេលយើងអាចអនុញ្ញាតឲ្យពន្លឺរបស់យើងបញ្ចាំងចេញទៅ រហូតដល់អស់អ្នកទាំងឡាយដែលធ្វើតាមយើងនឹងដើរតាមព្រះអង្គសង្គ្រោះដែរនោះ ?

សូមពន្យល់ថា ការអធិស្ឋានសម្រាប់អ្នកដទៃ ការអញ្ជើញឲ្យពួកគេឲ្យចូលរួមនៅក្នុងការប្រជុំសាសនាចក្រ និងការធ្វើជាគំរូដូចជាព្រះគ្រីស្ទ គឺជារបៀបដែលយើងអាចបម្រើដល់អ្នកដទៃ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយបទពិសោធន៍មួយដែលពួកគេបានលើកពន្លឺរបស់ព្រះអង្គសង្គ្រោះឡើង ដើម្បីជួយដល់នរណាម្នាក់ដែលមករកទ្រង់ ។

នីហ្វៃទី ៣ ១៨:២៦–៣៩

ព្រះអង្គសង្គ្រោះបង្រៀនពួកសាវករបស់ទ្រង់ឲ្យពង្រីកការអាន់ទៅដល់មនុស្សគ្រប់រូប

សូមសង្កេប នីហ្វៃទី ៣ ១៨:២៦–៣៩ ដោយការពន្យល់ថា ក្រោយពីព្រះអង្គសង្គ្រោះបានមានបន្ទូលដល់ហ្វូងមនុស្សថា ទ្រង់ងាកទៅរកពួកសាវកដប់ពីរនាក់ដែលទ្រង់បានជ្រើសរើស និងបានណែនាំពួកលោកអំពីរបៀបដឹកនាំ និងចាត់ចែងការងារនៃសាសនាចក្រ ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១៨:៣២ ដោយស្ងាត់ស្ងៀមដោយរកមើលរបៀបដែលយើងគួរឆ្លើយតបទៅនឹងមនុស្សដែលបានវង្វេងចេញពីសេចក្តីជំនឿ ។

- ហេតុអ្វីបានជាវាជាការសំខាន់ដែលយើងត្រូវបន្តបម្រើដល់មនុស្សដែលបានវង្វេងចេញពីសេចក្តីជំនឿ ?

សូមគិតពីការចែកចាយបទពិសោធន៍មួយដែលអ្នកបានជួយបម្រើដល់កូនចៅរបស់ព្រះម្នាក់ និងបានជួយបុគ្គលម្នាក់ឲ្យមករកព្រះគ្រីស្ទ ។

ចំណេះចំណានខគម្ពីរ—នីហ្វៃទី ៣ ១៨:១៥, ២០–២១

កំណត់ចំណាំ ៖ ដោយសារតែមេរៀននេះវែង អ្នកអាចចាប់ផ្តើមមេរៀនក្រោយដោយសកម្មភាពចំណេះចំណានខគម្ពីរខាងក្រោម ។ ឬថា សកម្មភាពនេះអាចត្រូវបានប្រើនៅក្នុងមេរៀនថ្ងៃក្រោយ នៅពេលអ្នកមានពេលច្រើនដើម្បីរំឭកវគ្គចំណេះចំណានខគម្ពីរនេះ ។

សូមចំណាយពេលបីបួននាទីដើម្បីជួយសិស្សឲ្យទន្ទេញ នីហ្វៃទី ៣ ១៨:១៥, ២០–២១ ។ សូមសរសេរខគម្ពីរទាំងបីនៅលើក្តារខៀន ហើយសូមឲ្យសិស្សអនុវត្តអានវាឮៗ ។ ក្រោយពីសិស្សបានអានខគម្ពីរទាំងអស់ពីរបីដងហើយ សូមចាប់ផ្តើមលុបផ្នែកខុសៗគ្នានៃខគម្ពីរនេះ ខណៈពេលដែលសិស្សបន្តទន្ទេញវគ្គទាំងមូល ។ សូមធ្វើសកម្មភាពនេះសារឡើងវិញរហូតដល់ពាក្យទាំងអស់ត្រូវលុបចេញពីក្តារខៀនអស់ ។

នីហ្វៃទី ៣ ១៩

សេចក្តីផ្តើម

ក្រោយពីព្រះអង្គសង្គ្រោះបានបញ្ចប់ការសំណេះសំណាលជាមួយសាសន៍នីហ្វៃនៅថ្ងៃទីមួយ របស់ទ្រង់ ដំណឹងនៃការយាងមករបស់ទ្រង់បានចែកចាយនៅក្នុងចំណោមប្រជាជន ពេញមួយយប់នោះ ។ (ហេតុការណ៍នេះបានកត់ត្រានៅក្នុង នីហ្វៃទី ៣ ១១–១៨ បានកើតឡើងទាំងស្រុងតែក្នុងមួយថ្ងៃទេ) ។ នៅពេញមួយយប់ ប្រជាជនបានធ្វើការ « យ៉ាងខិតខំ . . . ដើម្បីស្អែកឡើងគេអាចទៅកាន់ទីកន្លែង » ដែលព្រះយេស៊ូវទ្រង់នឹង បង្ហាញរូបអង្គទ្រង់ទៀត (នីហ្វៃទី ៣ ១៩:៣) ។ នាពេលព្រឹក ពួកសាវកដប់ពីរនាក់ បានបង្រៀនប្រជាជន និងបានអធិស្ឋានជាមួយនឹងពួកគេ ។ ព្រះយេស៊ូវគ្រីស្ទបានយាង មក និងបានបញ្ជាប្រជាជនឲ្យអធិស្ឋាន ខណៈពេលដែលទ្រង់បានអធិស្ឋានទៅកព្រះវរបិតា ជំនួសពួកគេ ។ ដោយសារតែសេចក្តីជំនឿរបស់ពួកគេ ពួកសាវកដប់ពីរនាក់ត្រូវបានធ្វើឲ្យ បរិសុទ្ធ ។ ព្រះយេស៊ូវបានអធិស្ឋានថា ពួកសាវក និងអស់អ្នកទាំងឡាយណាដែលបានជឿ លើពាក្យរបស់ពួកលោកអាចនឹងក្លាយជាតែមួយជាមួយនឹងទ្រង់ និងព្រះបិតារបស់ទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៣ ១៩:១–១៤

ពួកសាវកទាំងដប់ពីរនាក់បម្រើដល់ប្រជាជន ដូចដែលព្រះអង្គសង្គ្រោះបានបញ្ជា

សូមឲ្យសិស្សស្រមៃពីអ្វីដែលពួកគេអាចធ្វើ ឬរបៀបដែលពួកគេអាចមានអារម្មណ៍ ប្រសិនបើពួកគេបានដឹងថា ថ្ងៃស្អែកព្រះយេស៊ូវគ្រីស្ទ នឹងយាងមកនៅឯព្រះវិហារបរិសុទ្ធ (ឬមជ្ឈមណ្ឌលស្តេក ឬទីប្រជុំជនក្នុងក្រុង ឬទីតាំងផ្សេងទៀតខ្លះ ដែលនឹងតម្រូវឲ្យសិស្សមាន ការខិតខំខ្លះដើម្បីធ្វើដំណើរទៅ) ។

- តើអ្នកនឹងទៅដល់ទីនោះដោយរបៀបណា ?
- តើអ្នកណាដែលអ្នកចង់ឲ្យទៅជាមួយនឹងអ្នក ?
- តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីរៀបចំសម្រាប់ទទួលបទពិសោធន៍នេះ ?

សូមរំឭកសិស្សថា នៅពេលនៃការសំណេះសំណាលរបស់ព្រះអង្គសង្គ្រោះជាមួយពួកសាសន៍នីហ្វៃនៅថ្ងៃទីមួយជិតចប់ ទ្រង់បាន លើកទឹកចិត្តប្រជាជនឲ្យទៅផ្ទះរបស់ពួកគេ ហើយសញ្ជឹងគិត និងអធិស្ឋានអំពីការបង្រៀនរបស់ទ្រង់ ដើម្បីរៀបចំសម្រាប់ការជួបទ្រង់ នៅថ្ងៃបន្ទាប់ទៀត (សូមមើល នីហ្វៃទី ៣ ១៧:៣) ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១៩:១–៣ ដោយស្ងាត់ស្ងៀម ដោយរកមើល ចម្លើយរបស់ពួកសាសន៍នីហ្វៃចំពោះការសន្យារបស់ព្រះអង្គសង្គ្រោះដែលថា ទ្រង់នឹងត្រឡប់មកវិញនៅថ្ងៃបន្ទាប់នោះ ។ ក្រោយពី សិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញហើយ សូមសង្ខេប នីហ្វៃទី ៣ ១៩:៤–៨ ដោយការពន្យល់ថា ក្រោយពីហ្វូងមនុស្សបានប្រជុំ គ្នានៅថ្ងៃបន្ទាប់ នោះពួកសាវកទាំងដប់ពីរនាក់បានបំបែកប្រជាជនទៅជាដប់ពីរក្រុម ហើយចាប់ផ្តើមបង្រៀនដល់ពួកគេ ។ ក្រោយពី ការបង្រៀនដល់ហ្វូងមនុស្សឲ្យលុតជង្គង់ចុះអធិស្ឋានហើយ ពួកសាវកដប់ពីរនាក់ក៏បានអធិស្ឋាន ហើយបន្ទាប់មកបានបង្រៀនប្រជាជន នូវសេចក្តីពិតដូចគ្នាដែលព្រះអង្គសង្គ្រោះបានបង្រៀនរួចហើយកាលពីថ្ងៃមុន ។ បន្ទាប់មក ពួកសាវកបានលុតជង្គង់ចុះអធិស្ឋានម្តងទៀត ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៩:៨–៩ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលពួកសាវកបានអធិស្ឋាន សុំ ។

- តើពួកសាវកចង់បានអ្វីបំផុត ?
- ពួកសាវកដប់ពីរនាក់នឹងចាត់ចែងកិច្ចការសាសនាចក្រនៅក្នុងចំណោមពួកសាសន៍នីហ្វៃ ក្រោយពីព្រះអង្គសង្គ្រោះបានចាកចេញ ទៅ ។ តើអ្នកគិតថា ហេតុអ្វីបានជាពួកគេត្រូវការព្រះវិញ្ញាណបរិសុទ្ធនៅក្នុងកិច្ចការបម្រើរបស់ពួកលោក ?
- នៅក្នុងការអធិស្ឋានដែលអ្នកធ្វើ តើរឿងអ្វីខ្លះដែលអ្នកចង់បានបំផុត ?
- តើអ្នកបានអធិស្ឋានសុំព្រះវិញ្ញាណបរិសុទ្ធទេ ? ហេតុអ្វីសុំ ឬហេតុអ្វីបានជាមិនសុំ ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៩:១០–១២ ឮៗ ។ ក្រោយពីគេអានចប់ហើយ សូមពន្យល់ថា បុណ្យជ្រមុជទឹកលើកទីពីរនេះគឺជា កាលៈទេសៈដ៏ពិសេសមួយ ។ ទោះបីជាពួកសាសន៍នីហ្វៃត្រូវបានជ្រមុជទឹកពីមុនមកសម្រាប់ការផ្តាច់បាប និងមានភាពសក្តិសមដើម្បី នៅក្នុងវត្តមានរបស់ព្រះយេស៊ូវគ្រីស្ទក្តី ក៏ព្រះអង្គសង្គ្រោះបានបញ្ជាពួកគេឲ្យជ្រមុជទឹកម្តងទៀត ដោយសារទ្រង់បានរៀបចំសាសនាចក្រ ជាថ្មី ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៩:១៣–១៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពរជ័យដែលពួកសាវក បានទទួលជាការឆ្លើយតបទៅនឹងបំណងដ៏សុចរិតរបស់ពួកលោក ។ ដើម្បីជួយសិស្សបង្កើនបំណងរបស់គេដើម្បីសុំរកឥទ្ធិពលរបស់ ព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់ពួកគេ សូមធ្វើសកម្មភាពដូចខាងក្រោម ៖

សូមបំបែកសិស្សធ្វើការជាដៃគូ ។ សូមឲ្យដៃគូនីមួយៗធ្វើបញ្ជីនៅក្នុងសៀវភៅសរសេរ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរអំពីអ្វីដែល ព្រះវិញ្ញាណបរិសុទ្ធធ្វើសម្រាប់អ្នកដែលរស់នៅដោយស្អាតស្អំ ។ បន្ទាប់មក សូមឲ្យសិស្សប្រៀបធៀបបញ្ជីរបស់ពួកគេជាមួយនឹង

សេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ៉ូបឺត ឌី ហៃល នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ។ (មុនចាប់ផ្តើមថ្នាក់ សូមចម្លងប្រយោគនេះ ឬសរសេរវានៅលើក្តារខៀន) ។ សូមឲ្យសិស្សបន្ថែមលើបញ្ជីរបស់ពួកគេនូវគំនិតថ្មីៗដែលពួកគេរកឃើញ នៅពេលពួកគេអានសេចក្តីថ្លែងការណ៍នេះ ។

« ព្រះវិញ្ញាណបរិសុទ្ធ . . . គឺជាប្រភពនៃទីបន្ទាល់របស់យើងអំពីព្រះវរបិតា និងព្រះរាជបុត្រា ។ . . .

« យើងត្រូវការព្រះវិញ្ញាណបរិសុទ្ធជាដៃគូដ៏ខ្ជាប់ខ្ជួនរបស់យើងដើម្បីជួយយើងឲ្យធ្វើការសម្រេចដ៏ល្អប្រសើរដែលយើងជួបជាប្រចាំថ្ងៃ ។ . . . ដៃគូជាមួយនឹងព្រះវិញ្ញាណនឹងផ្តល់ដល់ពួកគេ | យុវជនរបស់យើង | នូវកម្លាំងដើម្បីប្រឆាំងនឹងអំពើអាក្រក់ ហើយនៅពេលដែលចាំបាច់ ជួយឲ្យប្រែចិត្ត និងត្រឡប់មកកាន់ផ្លូវដ៏ត្រង់ និងតូចចង្អៀតវិញ ។ . . . យើងទាំងអស់គ្នាត្រូវការការពង្រឹងដែលមានតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ . . . ការមានអំណោយទានព្រះវិញ្ញាណបរិសុទ្ធជួយសមាជិកគ្រួសារឲ្យធ្វើការសម្រេចចិត្តដ៏ឆ្លាតវៃ —ជម្រើសដែលនឹងជួយពួកគេឲ្យត្រឡប់ទៅជាមួយនឹងគ្រួសាររបស់ពួកគេ ទៅរកព្រះវរបិតាសួគ៌ និងព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ ដើម្បីរស់នៅជាមួយនឹងទ្រង់ដ៏អស់កល្ប » (« The Covenant of Baptism: To Be in the Kingdom and of the Kingdom » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ២០០០, ទំព័រ ៨) ។

- តើពរជ័យនៅក្នុងបញ្ជីរបស់អ្នកអាចនឹងជួយដល់យុវជននៅក្នុងសាសនាចក្របានយ៉ាងដូចម្តេច ?

សូមឲ្យសិស្សរំឭកបញ្ជីនៃពរជ័យដែលពួកគេបានសរសេរ និងសូមគិតពីអ្វីដែលយើងត្រូវធ្វើដើម្បីសក្តិសមនឹងទទួលពរជ័យទាំងនេះ ។ សូមឲ្យពួកគេអាន នីហ្វៃទី ៣ ១៩:៩, ១៣ ដោយស្ងាត់ស្ងៀម ដោយរកមើលគោលការណ៍មួយអំពីការទទួលបានឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។ សូមឲ្យសិស្សសរសេរគោលការ៍ដែលពួកគេរកឃើញ ។ សូមឲ្យពួកគេពីរបីនាក់ចែកចាយអ្វីដែលពួកគេបានសរសេរ ។ (សិស្សអាចចែកចាយអ្វីមួយដូចខាងក្រោម ៖ **បំណង និងការអធិស្ឋានដ៏សុចរិតរបស់យើង អាចធ្វើឲ្យយើងសក្តិសមដើម្បីពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ**) ។

- តើនៅពេលណាខ្លះដែលបំណង និងការអធិស្ឋានដ៏សុចរិតរបស់អ្នកបានជួយអ្នកឲ្យមានអារម្មណ៍ពីឥទ្ធិពលនៃព្រះវិញ្ញាណ ?

សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនៅលើក្តារខៀន៖ សូមឲ្យសិស្សសរសេរប្រយោគមិនពេញលេញនេះ ហើយបន្ទាប់មកបំពេញវាតាមការយល់ឃើញផ្ទាល់ខ្លួន ។

ខ្ញុំនឹងបង្ហាញដល់ព្រះវរបិតាសួគ៌នូវបំណងរបស់ខ្ញុំដើម្បីសុំដៃគូជាព្រះវិញ្ញាណបរិសុទ្ធដោយ . . .

នីហ្វៃទី ៣ ១៩:១៥–៣៦

ព្រះអង្គសង្គ្រោះយាងមក ហើយអធិស្ឋានសម្រាប់ប្រជាជនដើម្បីឲ្យបានបរិសុទ្ធតាមរយៈសេចក្តីជំនឿរបស់ពួកគេ

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៩:១៥–១៦ ឮៗ ។ សូមបង្ហាញថា ខណៈពេលដែលប្រជាជនកំពុងលុតជង្គង់ចុះ ពួកគេបានធ្វើជាសាក្សីថា ព្រះយេស៊ូវគ្រីស្ទបានធ្វើការអធិស្ឋានបីដងដោយឡែកពីគ្នា សម្រាប់សាវករបស់ទ្រង់ និងសម្រាប់ហ្វូងមនុស្ស ។ (សូមពន្យល់ថា ចំណុចបន្ទាប់នៅក្នុងមេរៀននេះ សិស្សនឹងសិក្សាពីការអធិស្ឋានទីបីរបស់ព្រះអង្គសង្គ្រោះ) ។

សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោម និងសំណួរខាងក្រោមនៅលើក្តារខៀន មុនពេលចាប់ផ្តើមថ្នាក់ (ឬរៀបចំវាជាក្រដាសសម្រាប់ចែកដល់សិស្សម្នាក់ៗ) ៖

នីហ្វៃទី ៣ ១៩:១៧–១៨, ២៤–២៦, ៣០

នីហ្វៃទី ៣ ១៩:១៩–២៣

នីហ្វៃទី ៣ ១៩:២៧–២៩

តើអ្នកអាចរៀនអ្វីខ្លះអំពីការអធិស្ឋានពីវគ្គនេះ ?

តើអ្នកអាចអនុវត្តអ្វីដែលអ្នកបានរៀននៅក្នុងខគម្ពីរទាំងនេះនៅក្នុងការអធិស្ឋានផ្ទាល់ខ្លួនរបស់អ្នកដោយរបៀបណា ?

សូមបំបែកសិស្សជាក្រុមដែលមានសិស្សបីនាក់ក្នុងក្រុមនីមួយៗ ។ (ប្រសិនបើអ្នកមានសិស្សតិច អ្នកអាចត្រូវបំបែកសិស្សទៅជាក្រុមតូចៗ) ។ សូមដាក់ឲ្យសិស្សម្នាក់នៅក្នុងក្រុមនីមួយៗអានវគ្គព្រះគម្ពីរមួយដែលបានសរសេរនៅលើក្តារខៀន ។ សូមប្រាប់សិស្សថាពួកគេគួររៀបចំឆ្លើយតបនៅក្នុងក្រុមរបស់ពួកគេចំពោះសំណួរនៅលើក្តារខៀនទាំងអស់ ។

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សចែកចាយចម្លើយរបស់ពួកគេជាមួយនឹងសមាជិកផ្សេងទៀតនៃក្រុមរបស់ពួកគេ ។ សូមរៀបចំឆ្លើយ ប្រសិនបើសិស្សសួរថាតើហេតុអ្វីបានជាពួកសាវកបានអធិស្ឋានដល់ព្រះអង្គសង្គ្រោះ (សូមមើល នីហ្វៃទី ៣ ១៩:១៨) ។ សូមបង្ហាញថា នៅក្នុងឧទាហរណ៍ដ៏ពិសេសនេះ ពួកសាវកបានអធិស្ឋានទៅដល់ព្រះយេស៊ូវគ្រីស្ទ ដោយសារទ្រង់នៅជាមួយនឹងពួកលោកផ្ទាល់ ដូចជាអ្នកតំណាងមួយពីព្រះវរបិតា (សូមមើល នីហ្វៃទី ៣ ១៩:២២) ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៩:៣១–៣៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយគិតពីមូលហេតុដែលការអធិស្ឋានរបស់ព្រះអង្គសង្គ្រោះបានជ្រោតជ្រាបដល់ប្រជាជនយ៉ាងខ្លាំង ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ ខណៈពេលដែលសិស្សអាចរៀនសេចក្តីពិតជាច្រើនពីគ្នាទៅវិញទៅមក កាលពួកគេចែកចាយ នោះសកម្មភាពខាងក្រោមនឹងបញ្ជាក់ពីគោលការណ៍ពីរដែលពួកគេអាចរកឃើញនៅក្នុងការសិក្សារបស់ពួកគេ ។

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *នៅពេលយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ . . .*

សូមឲ្យសិស្សរំឭកនីហ្វៃទី ៣ ២៨ដោយស្ងាត់ស្ងៀម ដើម្បីរកមើលវិធីដើម្បីបំពេញប្រយោគនៅលើក្តារខៀន ។ (សូមឲ្យសិស្ស សរសេរចម្លើយរបស់ពួកគេ ។ សិស្សអាចបំពេញប្រយោគតាមរបៀបដូចខាងក្រោមនេះ ៖ **នៅពេលយើងអនុវត្តសេចក្តីជំនឿលើ ព្រះយេស៊ូវគ្រីស្ទ យើងអាចត្រូវបានបន្សុទ្ធ**) ។

- តើការដែលបានត្រូវបានបន្សុទ្ធមានន័យដូចម្តេច ?តើអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទជួយយើងឲ្យបានជ្រះស្អាតដោយ របៀបណា ?
- តើពួកសាវកបានអនុវត្តសេចក្តីជំនឿអំឡុងពេលហេតុការណ៍បានកត់ត្រានៅក្នុង នីហ្វៃទី ៣ ១៩ តាមរបៀបណា ?

ដើម្បីជួយសិស្សឲ្យយល់ថា យើងត្រូវបានបន្សុទ្ធដោយព្រះវិញ្ញាណបរិសុទ្ធ សូមរំឭកពួកគេថា ពួកសាវកបានទទួលបាន ព្រះវិញ្ញាណបរិសុទ្ធ ហើយត្រូវ « ពោរពេញដោយភ្លើង » (នីហ្វៃទី ៣ ១៩:១៣) ។ សូមពន្យល់ថាឃ្លា « ពោរពេញដោយភ្លើង » គឺជានិមិត្តសញ្ញាដែលសំដៅលើពរជ័យនៃការត្រូវបានសម្អាតតាមរយៈឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១៩:២៣, ២៩ ដោយស្ងាត់ៗម្តងទៀត ដោយរកមើលពរជ័យផ្សេងទៀតដែលមកដល់អស់អ្នកដែលមាន ព្រះវិញ្ញាណនៃព្រះអម្ចាស់ស្ថិតនៅជាមួយនឹងពួកគេ ។ (ក្រោយពីសិស្សអានហើយ អ្នកណែនាំថា ពួកគេគួរគូសចំណាំខគម្ពីរទាំងពីរនេះ ឃ្លា « ដើម្បីឲ្យយើងអាចទៅជាមួយ ») ។

- តើព្រះយេស៊ូវគ្រីស្ទ និងព្រះវរបិតាតែមួយដោយរបៀបណា ? (ពួកទ្រង់ដាច់ពីគ្នា ជាអង្គមានរូបកាយបីផ្សេងគ្នា ប៉ុន្តែពួកទ្រង់ គឺតែមួយក្នុងគោលបំណង និងគោលលទ្ធិ ។ សាមគ្គីគ្នាដ៏ឥតខ្ចោះ ទ្រង់ទាំងបីអង្គនាំមកនូវផែនការសង្គ្រោះដ៏ទេវភាពរបស់ ព្រះវរបិតាសួគ៌) ។
- តើវាមានន័យយ៉ាងណាសម្រាប់យើងដើម្បីក្លាយជាតែមួយជាមួយនឹងព្រះជាព្រះវរបិតា និងព្រះរាជបុត្រា ?
- តើយើងរៀនអ្វីខ្លះពី នីហ្វៃទី ៣ ១៩:២៣, ២៩ អំពីរបៀបដែលយើងអាចក្លាយជាតែមួយជាមួយនឹងពួកទ្រង់ ? (**តាមរយៈ សេចក្តីជំនឿ យើងអាចត្រូវបានបន្សុទ្ធ និងក្លាយជាតែមួយជាមួយនឹងព្រះយេស៊ូវគ្រីស្ទ ដូចដែលទ្រង់គឺតែមួយជាមួយនឹង ព្រះវរបិតា**) ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យ សិស្សស្តាប់ពីរបៀបដែលយើងអាចក្លាយជាតែមួយជាមួយនឹងព្រះវរបិតា និងព្រះរាជបុត្រា ៖

« ព្រះយេស៊ូវបានសម្រេចបានភាពសាមគ្គីដ៏ឥតខ្ចោះជាមួយនឹងព្រះវរបិតាដោយការថ្វាយអង្គទ្រង់ទាំងខាងសាច់ឈាម និងខាងវិញ្ញាណ ប្រគល់ជូនតាមព្រះឆន្ទៈរបស់ព្រះបិតា ។ ការបម្រើរបស់ទ្រង់តែងតែជ្ជិតថ្លង់យ៉ាងច្បាស់ ដោយសារគ្មានការទន់ខ្សោយ ឬការស្វាក់ស្ទើរបែកគំនិតពីរចំពោះទ្រង់ឡើយ ។ ដោយសំដៅទៅរកព្រះបិតារបស់ទ្រង់ ព្រះយេស៊ូវបានមានបន្ទូលថា ‹ ខ្ញុំចេះតែធ្វើការដែលគាប់ដល់ព្រះហឫទ័យទ្រង់ជាដរាប › (យ៉ូហាន ៨:២៩) ។. . .

« ពិតណាស់យើងនឹងមិនក្លាយជាតែមួយជាមួយនឹងព្រះ និងព្រះគ្រីស្ទឡើយ រហូតទាល់តែយើងដាក់បំណងដ៏ធំបំផុតរបស់យើងតាមបំណង និងការចាប់អារម្មណ៍របស់ទ្រង់ ។ ការបន្ទាបខ្លួនបែបនោះមិនមែនអាចធ្វើបានភ្លាមៗនោះទេ ប៉ុន្តែតាមរយៈព្រះវិញ្ញាណបរិសុទ្ធ នោះព្រះអម្ចាស់នឹងបង្រៀនយើង ប្រសិនបើយើងមានឆន្ទៈរហូតនោះ តាមដំណើរពេលវេលា វាអាចនិយាយដោយត្រឹមត្រូវថា ទ្រង់គឺនៅក្នុងយើង ដូចជាព្រះបិតានៅក្នុងទ្រង់ដែរ » (« That They May Be One in Us » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ២០០២, ទំព័រ ៧២, ៧៣) ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ១៩:៣៥–៣៦ ដោយស្ងាត់ស្ងៀមហើយសញ្ជឹងគិតពីកម្លាំងនៃការអធិស្ឋានផ្ទាល់ខ្លួនរបស់គេ ។ សូម សន្យានឹងសិស្សថា យើងក៏អាចមានបទពិសោធន៍ខាងវិញ្ញាណដ៏អស្ចារ្យ និងរីកចម្រើនទៅកាន់ការក្លាយជាតែមួយជាមួយនឹងព្រះវរបិតា និងព្រះរាជបុត្រាបានដែរ ប្រសិនបើយើងបង្កើនសេចក្តីជំនឿរបស់យើង និងអធិស្ឋានដោយស្មោះត្រង់សុំដៃគូនៃព្រះវិញ្ញាណនោះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ៣ ១៩:១៨, ២២ ។ « ពួកគេបានអធិស្ឋានដល់ព្រះយេស៊ូវ »

ចេញពីព្រះគម្ពីរ និងការបង្រៀនរបស់ព្យាការីថ្ងៃចុងក្រោយ យើងដឹងថា យើងត្រូវថ្វាយបង្គំព្រះជាព្រះវរបិតា និងអធិស្ឋានដល់ទ្រង់តែមួយគត់ ។ យើងមិនត្រូវអធិស្ឋានដល់ព្រះយេស៊ូវគ្រីស្ទឡើយ ។ ឧទាហរណ៍ ព្រះអង្គសង្គ្រោះបានបង្រៀនពួកសាសន៍នីហ្វៃថា « អ្នករាល់គ្នាត្រូវអធិស្ឋានដល់ព្រះវរបិតា ដោយនូវនាមយើងជានិច្ច » (នីហ្វៃទី ៣ ១៨:១៩) ។ ទោះជាយ៉ាងណាក្តី រយៈពេលខ្លីក្រោយពីព្រះអង្គសង្គ្រោះបានបង្រៀនការណ៍នេះ ពួកសាវកសាសន៍នីហ្វៃបានអធិស្ឋានដោយផ្ទាល់ទៅទ្រង់ (សូមមើល នីហ្វៃទី ៣ ១៩:១៨) ។ ពួកគេបានធ្វើដូច្នោះ ទ្រង់បានមានបន្ទូលថា ដោយសារទ្រង់គឺនៅជាមួយនឹងពួកគេ (សូមមើល នីហ្វៃទី ៣ ១៩:២២) ។ អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី នៃក្រុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ថា នេះគឺជាការលើកលែងមួយ —ស្ថានភាពពិសេស ៖

« វាមានមូលហេតុដ៏ពិសេសមួយដែលការណ៍នេះត្រូវកើតឡើងក្នុងកាលៈទេសៈនេះ និងនៅក្នុងមូលដ្ឋានពេលតែមួយនេះ ។ ព្រះយេស៊ូវបានបង្រៀនពួកគេរួចមកហើយថាឲ្យអធិស្ឋាននៅក្នុងព្រះនាមរបស់ទ្រង់ទៅកព្រះវរបិតា ដែលពួកគេបានធ្វើជាលើកជំបូង ។. . . ព្រះយេស៊ូវបានមានវត្តមាននៅនឹងមុខពួកគេជានិមិត្តសញ្ញានៃព្រះវរបិតា ។ ដោយការឃើញទ្រង់ វាដូចជាពួកគេបានឃើញព្រះវរបិតាដែរ ដោយការអធិស្ឋានទៅកទ្រង់ វាដូចជាពួកគេបានអធិស្ឋានទៅព្រះវរបិតាដែរ ។ វាគឺជាស្ថានភាពដ៏ពិសេស និងមានតែមួយគត់ » (« *The Promised Messiah* [ឆ្នាំ ១៩៧៨], ទំព័រ ៥៦០, ៥៦១) ។

នីហ្វៃ ទី៣ ជំពូក ២០

សេចក្តីផ្តើម

នៅពេលថ្ងៃទីពីរនៃការបម្រើរបស់ទ្រង់នៅក្នុងចំណោមពួកសាសន៍នីហ្វៃ ព្រះយេស៊ូវគ្រីស្ទបានដឹកនាំពិធីសាក្រាម៉ង់ដល់ប្រជាជនម្តងទៀត ។ ទ្រង់បានថ្លែងទីបន្ទាល់ថា សេចក្តីសញ្ញា និងសេចក្តីសន្យាទាំងឡាយរបស់ព្រះវរបិតានឹងត្រូវបានបំពេញនៅថ្ងៃចុងក្រោយ ។ ពួកសាសន៍អ៊ីស្រាអែលនឹងត្រូវបានប្រមូលផ្តុំ ហើយសាសន៍ទាំងឡាយនៅលើផែនដីនឹងត្រូវបានប្រទានពរ ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៣ ២០:១–៩

ព្រះអង្គសង្គ្រោះបម្រើពិធីសាក្រាម៉ង់ដល់ប្រជាជនម្តងទៀត

ដើម្បីចាប់ផ្តើមមេរៀននេះ សូមពន្យល់ថា អ្នកចង់ឲ្យយុវជន និងយុវនារីនៅក្នុងថ្នាក់ឆ្លើយនឹងសំណួរខុសៗគ្នា ។ សូមឲ្យយុវជនពីរ បីនាក់ដែលកាន់អំណាចបព្វជិតភាពអ៊ីរ៉ុនច្រាប់ដល់សិស្សក្នុងថ្នាក់អំពីការទទួលខុសត្រូវរបស់ពួកគេក្នុងការរៀបចំ ការប្រសិទ្ធពរ ឬការចែកសាក្រាម៉ង់ ។ សូមជួយពួកគេចែកចាយពីអារម្មណ៍អំពីការបំពេញកាតព្វកិច្ចទាំងនេះដោយការសួរពួកគេនូវសំណួរខាងក្រោមនេះ ៖

- តើការជួយបម្រើពិធីសាក្រាម៉ង់មានន័យយ៉ាងណាដល់អ្នក ?
- តើអ្នកបង្ហាញដល់ព្រះអម្ចាស់ថា អ្នកយល់ពីលក្ខណៈសម្បត្តិដ៏ពិសិដ្ឋនៃពិធីបរិសុទ្ធនេះដោយរបៀបណា ?

សូមជួយយុវនារីពីរបីនាក់ឲ្យចែកចាយអារម្មណ៍របស់ពួកគេអំពីភាពពិសិដ្ឋនៃពិធីសាក្រាម៉ង់ដោយការសួរពួកគេនូវសំណួរខាងក្រោម ៖

- តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលអ្នកឃើញយុវជនដ៏មានភាពសក្តិសមបម្រើពិធីសាក្រាម៉ង់ ?
- តើអ្នកធ្វើអ្វីខ្លះអំឡុងពេលការបម្រើពិធីសាក្រាម៉ង់ ដែលបង្ហាញថាអ្នកយល់ពីលក្ខណៈសម្បត្តិដ៏ពិសិដ្ឋរបស់ពិធីសាក្រាម៉ង់ ?

សូមពន្យល់ថា នៅថ្ងៃទីពីរនៃការបម្រើរបស់ទ្រង់ដល់ពួកសាសន៍នីហ្វៃ ព្រះអង្គសង្គ្រោះ និងពួកសាវករបស់ទ្រង់បានបម្រើពិធីសាក្រាម៉ង់ដល់ប្រជាជនជាលើកទីពីរ ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២០:១ ដោយស្ងាត់ស្ងៀម ។ សូមបង្ហាញនូវប្រយោគខាងក្រោម ៖ « ហើយទ្រង់បានបញ្ជាពួកគេថា ពួកគេមិនគួរឈប់អធិស្ឋាននៅក្នុងដួងចិត្តរបស់គេទេ » ។

- តើឃ្លា « មិនគួរឈប់អធិស្ឋាន » នៅក្នុងដួងចិត្តរបស់អ្នកមានន័យយ៉ាងណាដល់អ្នក ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២០:៣–៥ ឮៗ ។

- តើអ្នកគិតថាការអធិស្ឋាននៅក្នុងចិត្តរបស់អ្នកអាចមានអានុភាពលើបទពិសោធន៍ប្រចាំសប្តាហ៍របស់អ្នកក្នុងការទទួលយកពិធីសាក្រាម៉ង់ដោយរបៀបណា ?
- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីនៅតែបន្តផ្តោតលើព្រះអង្គសង្គ្រោះ នៅពេលយើងទទួលយកសាក្រាម៉ង់ ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២០:៨ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលនំប៉័ង និងស្រាទំពាំងបាយជូរតំណាងឲ្យ ។ (វាអាចជួយប្រើនដើម្បីពន្យល់ថា ការអនុវត្តសព្វថ្ងៃនៅក្នុងសាសនាចក្រគឺប្រើទឹកជំនួសឲ្យស្រាទំពាំងបាយជូរ ។ | សូមមើល គ. និង ស. ២៧:២ |) ។

- តើនំប៉័ង និងទឹកនៅក្នុងពិធីសាក្រាម៉ង់តំណាងឲ្យអ្វី ? (ព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គសង្គ្រោះ) ។

អ្នកអាចអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដេម អិ ថាល់មេហ្គ នៃក្រុមនៃពួកសាវកដប់ពីរនាក់ ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យប្រៀបធៀបនៃការអញ្ជើញរបស់ព្រះអង្គសង្គ្រោះឲ្យទទួលទានសាច់របស់ទ្រង់ និងផឹកឈាមរបស់ទ្រង់ ៖

« *ទទួលទានសាច់ និងផឹកឈាមរបស់ព្រះគ្រីស្ទ គឺត្រូវជឿលើនិងទទួលយកទ្រង់ជាព្រះរាជបុត្រានៃព្រះពិតប្រាកដ និងជាព្រះអង្គសង្គ្រោះនៃពិភពលោក ហើយត្រូវគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់* ។ ដោយយោងតាមអត្ថន័យនេះ វាមានន័យថា ការអាចធ្វើឲ្យព្រះវិញ្ញាណនៃព្រះក្លាយជាផ្នែកដ៏ខ្ជាប់ខ្ជួនមួយនៃការរស់នៅរបស់បុគ្គលម្នាក់ៗ ថែមទាំងជារសជាតិនៃអាហារដែលគេទទួលទាន ក៏ត្រូវបានប្រដូចទៅនឹងព្រះកាយរបស់ទ្រង់ដែរ » (*Jesus the Christ*, ការបោះពុម្ពលើកទី ៣ | ឆ្នាំ ១៩១៦ |, ទំព័រ ៣៤២; អក្សរទ្រេតត្រូវបានបន្ថែម) ។

- តើមាននិមិត្តសញ្ញាអ្វីដែលមាននៅក្នុងការទទួលយកនំប៉័ង និងទឹក ?
- យោងតាម នីហ្វៃទី ៣ ២០:៨ តើព្រះយេស៊ូវគ្រីស្ទបានសន្យាដល់អស់អ្នកទាំងឡាយណាដែលទទួលយកពិធីសាក្រាម៉ង់អ្វីខ្លះ ? (ព្រលឹងរបស់ពួកគេនឹងត្រូវបានបំពេញ) ។

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃការដែលព្រលឹងរបស់ពួកគេត្រូវបានបំពេញ សូមឲ្យពួកគេគិតអំពីចំនួននៃនំប៉័ង និងទឹកដែលពួកគេតែងទទួលយក នៅពេល ពួកគេទទួលទានសាក្រាម៉ង់ ។ បន្ទាប់មកសួរ ៖

- ប្រសិនបើអ្នកឃ្លាន និងស្រេកទឹក តើអ្នកនឹងត្រូវឆ្អែតដោយរបស់ទាំងនេះទេ ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២០:៩ ឮៗ ហើយសូមសួរសិស្សក្នុងថ្នាក់ ៖

- តើគោលការណ៍អ្វីដែលយើងអាចរៀនពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុង នីហ្វៃទី ៣ ២០:៨–៩ ? (សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរតែឃើញនូវគោលការណ៍ដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងសក្តិសមទទួលទានសាក្រាម៉ង់ នោះយើងអាចត្រូវបានបំពេញដោយព្រះវិញ្ញាណបរិសុទ្ធ**) ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អ្នក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រកបៀបដែលយើងត្រូវអាចប្រទានពរ នៅពេលយើងត្រូវបានពោរពេញដោយព្រះវិញ្ញាណ ៖

« សូមឲ្យយើងធ្វើខ្លួនយើងឲ្យសក្តិសមនឹងសេចក្តីសន្យារបស់ព្រះអង្គសង្គ្រោះរបស់យើងថា ដោយការទទួលយកពិធីសាក្រាម៉ង់ យើងនឹង ‹ ត្រូវបានបំពេញ › (នីហ្វៃទី ៣ ២០:៨; សូមមើលផងដែរ នីហ្វៃទី ៣ ១៨:៩) ដែលមានន័យថា យើងនឹងត្រូវបាន ‹ បំពេញដោយព្រះវិញ្ញាណ › (នីហ្វៃទី ៣ ២០:៩) ។ព្រះវិញ្ញាណនោះ—ព្រះវិញ្ញាណបរិសុទ្ធ — គឺជាអង្គលួងលោមរបស់យើង ជាអង្គជួយយើងស្វែងរកទិសដៅ ជាអង្គទំនាក់ទំនងរបស់យើង ជាអង្គបកប្រែរបស់យើង សាក្សីរបស់យើង និងជាអង្គដែលបន្សុទ្ធយើង— ជាអង្គដឹកនាំយើងពិតប្រាកដ និងជាអង្គឲ្យយើងរួចពីបាប នៅដំណើរខាងសាច់ឈាមរបស់យើងទៅរកជីវិតដ៏នៅអស់កល្បជានិច្ច ។

« . . . ចេញពីសកម្មភាពដែលមើលទៅតូចតាចនៃការបន្តសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹកដោយមនៈសិការ និងដោយការគោរព នោះវានាំមកនូវការបន្តនៃពរជ័យនៃពិធីបុណ្យជ្រមុជទឹកដោយទឹក និងដោយព្រះវិញ្ញាណ ដែលយើងអាចមានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយនឹងយើងជានិច្ច ។ តាមរបៀបនេះ យើងទាំងអស់គ្នានឹងត្រូវបានដឹកនាំ ហើយតាមរបៀបនេះ យើងទាំងអស់គ្នាអាចត្រូវបានសម្អាត » (« Always Have His Spirit » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៦, ទំព័រ ៦១) ។

- តើមានរបៀបណាខ្លះដែលយើងអាចត្រូវបានប្រទានពរ នៅពេលយើងពោរពេញដោយព្រះវិញ្ញាណ ?
- តើនៅពេលណាដែលការទទួលយកពិធីសាក្រាម៉ង់បានជួយអ្នក ឲ្យពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ ?

សូមធ្វើទីបន្ទាល់អំពីពរជ័យដែលអ្នកបានមានពីការទទួលយកពិធីសាក្រាម៉ង់ ហើយនិងភាពពោរពេញដោយព្រះវិញ្ញាណ ។ សូមបញ្ជាក់ថា ការអធិស្ឋាននៅក្នុងចិត្តរបស់យើងគឺជារបៀបមួយដែលយើងអាចរៀបចំនឹងទទួលយកពិធីសាក្រាម៉ង់ និងដើម្បីត្រូវបានពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ ។ សូមលើកទឹកចិត្តសិស្សឲ្យចំណាយពេលអធិស្ឋានមុនពេលទទួលយកសាក្រាម៉ង់ ។

នីហ្វៃទី ៣ ២០:១០–៤៦

ព្រះអង្គសង្គ្រោះបង្រៀនដល់ពួកសាសន៍នីហ្វៃអំពីសេចក្តីសញ្ញា ដែលនឹងត្រូវបំពេញនៅថ្ងៃចុងក្រោយ

សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅសរសេរ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរនូវការរៀបរាប់ដ៏សង្ខេបមួយអំពីគុណសម្បត្តិដ៏សំខាន់បំផុតរបស់ពួកគេ ។ ក្រោយពីពួកគេបញ្ចប់ហើយ សូមឲ្យពួកគេរកមើលគុណសម្បត្តិដែលពួកគេបានផ្តោតលើ ។ តើវាជាលក្ខណៈសម្បត្តិខាងរាងកាយឬ ? លក្ខណៈសម្បត្តិខាងចរិយាសម្បត្តិឬ ? លក្ខណៈសម្បត្តិខាងវិញ្ញាណឬ ? (ប្រសិនបើមានពេល អ្នកអាចសុំឲ្យសិស្សពីរបីនាក់អានអ្វីដែលពួកគេបានសរសេរ) ។ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាវីឌ អេ

បៃដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ហើយសូមឲ្យសិស្សស្តាប់នូវអ្វីដែលលោកបានមានប្រសាសន៍គួរកំណត់អត្តសញ្ញាណរបស់បុគ្គលម្នាក់ ៖

« អ្នកអាចចូលចិត្ត តន្ត្រី កីឡា ឬបច្ចេកវិទ្យា ហើយថ្ងៃណាមួយអ្នកអាចធ្វើការនៅក្នុងក្រុមហ៊ុនពាណិជ្ជកម្ម ឬវិជ្ជាជីវៈ ឬខាងសិល្បៈ ។ វាអាចសំខាន់ដូចជាសកម្មភាព និងការងារបែបនេះ វាមិនបានបង្ហាញថាតើយើងជានរណានោះទេ ។ ជាចំបង និងការណ៍ដ៏សំខាន់បំផុតនោះ យើងមានរូបកាយខាងវិញ្ញាណ ។ យើងគឺជា | កូនចៅ | របស់ព្រះ និងជាពូជរបស់អ័ប្រាហាំ » (« Becoming a Missionary » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ៤៧) ។

- តើអែលឌើរ បៃដណា បានឲ្យនិយមន័យថាយើងជានរណា ? តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីឃើញខ្លួនយើង « ជាចំបង ហើយសំខាន់បំផុត » ថាជាមនុស្សមានរូបកាយខាងវិញ្ញាណដែលជាកូនចៅនៃព្រះ ?

សូមបង្ហាញថា បន្ថែមលើការនិយាយថា យើងគឺជាកូនចៅរបស់ព្រះ អែលឌើរ បៃដណាបានមានប្រសាសន៍ថា យើងគឺជាពូជរបស់អ័ប្រាហាំ ។ សូមពន្យល់ថាឃ្លា « ពូជរបស់អ័ប្រាហាំ » អាចសំដៅលើប្រជាជនដែលជាកូនចៅរបស់អ័ប្រាហាំតាមន័យត្រង់ ។ វាក៏អាចសំដៅលើប្រជាជនដែលទទួលយកភាពពេញលេញនៃដំណឹងល្អ ពរជ័យនៃបព្វជិតភាព និងសេចក្តីសន្យា និងសេចក្តីសញ្ញាដូចគ្នាដែលព្រះបានធ្វើជាមួយនឹងអ័ប្រាហាំ ដោយការទទួលយក និងការគោរពតាមច្បាប់ និងពិធីបរិសុទ្ធនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។

សូមប្រាប់សិស្សថានៅក្នុង នីហ្វៃទី ៣ ២០ ទាំងមូល ពួកគេនឹងសិក្សាអំពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះដល់ពួកសាសន៍នីហ្វៃអំពីសេចក្តីសញ្ញា និងសេចក្តីសន្យាទាំងឡាយដែលបានធ្វើ ជាមួយនឹងអ័ប្រាហាំ និងកូនចៅរបស់លោក (រាស្ត្រអ៊ីស្រាអែល) ។ ទ្រង់បានមានបន្ទូលថា ពួកគេអាចរៀនអំពីសេចក្តីសញ្ញាទាំងនេះដោយការសិក្សាពាក្យពេចន៍របស់អេសាយ ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២០:១១–១២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលព្រះអង្គសង្គ្រោះបានមានបន្ទូលថានឹងកើតឡើង នៅពេលពាក្យរបស់អេសាយត្រូវបានបំពេញ ។ ក្រោយពីសិស្សបានរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញហើយ អ្នកអាចពន្យល់ថា ពាក្យរបស់អេសាយនឹងត្រូវបានបំពេញនៅក្នុងថ្ងៃចុងក្រោយ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២០:១៣ ឮៗ ហើយសូមឲ្យសិស្សរកមើលរបៀបដែលព្រះវរបិតាសួគ៌នឹងបំពេញតាមសេចក្តីសញ្ញារបស់ទ្រង់ជាមួយនឹងរាស្ត្រអ៊ីស្រាអែលនៅក្នុងថ្ងៃចុងក្រោយ ។ សូមឲ្យសិស្សសង្ខេបសេចក្តីពិតដែលពួកគេបានរៀនពី នីហ្វៃទី ៣

២០:១១–១៣ ។ (ចម្លើយរបស់សិស្សអាចខុសគ្នា ប៉ុន្តែពួកគេគួរតែឃើញនូវសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះអម្ចាស់នឹងបំពេញតាមសេចក្តីសញ្ញារបស់ទ្រង់ដើម្បីប្រទានពរដល់វង្សអ៊ីស្រាអែលនៅក្នុងថ្ងៃចុងក្រោយ ។** សូមគិតពីការសរសេរសេចក្តីពិតនេះនៅលើក្តារខៀន)។

- យោងតាម នីហ្វៃទី ៣ ២០:១៣ តើចំណេះដឹងអ្វីដែលប្រជាជននៃវង្សអ៊ីស្រាអែលនឹងទទួលបាន ដែលជាផ្នែកដ៏សំខាន់មួយនៃការប្រមូលផ្តុំនោះ ? (ពួកគេនឹងទទួលបាន « នាំមកឲ្យស្គាល់ព្រះអម្ចាស់ ជាព្រះរបស់គេ ដែលបានប្រោសលោះពួកគេ ») ។

ដើម្បីជួយសិស្សឲ្យឃើញពីរបៀបដែលការស្គាល់ព្រះយេស៊ូវគ្រីស្ទគឺជាផ្នែកមួយដ៏សំខាន់នៃការប្រមូលផ្តុំពួជអ៊ីស្រាអែល សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខន់ឃី នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សស្តាប់រកអ្វីដែលទាក់ទងនឹងការប្រមូលផ្តុំពួជអ៊ីស្រាអែល ។

« ការប្រមូលផ្តុំពួជអ៊ីស្រាអែលរួមមានការជឿ និងការទទួល និងការរស់នៅដោយសុខដុមជាមួយនឹងអ្វីទាំងអស់ដែលព្រះអម្ចាស់ធ្លាប់បានផ្តល់ដល់ប្រជាជនជំរើសរបស់ទ្រង់កាលពីបុរាណ ។ វារួមមានការមានសេចក្តីជំនឿទៅលើព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ លើការប្រែចិត្ត លើការជ្រមុជទឹក និងការទទួលបានអំណោយទានព្រះវិញ្ញាណបរិសុទ្ធ និងការកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ ។ វារួមមានការជឿលើដំណឹងល្អ ការចូលរួមក្នុងសាសនាចក្រ និងការមកកាន់នគរនៃព្រះ ។ វារួមមានការទទួលបានបព្វជិតភាពដ៏បរិសុទ្ធ ការទទួលធ្វើពិធីការបរិសុទ្ធនៅក្នុងកន្លែងដ៏បរិសុទ្ធដោយអំណាចពីទីខ្ពស់ និងការទទួលបានពរជ័យទាំងឡាយនៃអ័ប្រាហាំ អ៊ីសាក និងយ៉ាកុប តាមរយៈពិធីការនៃអាពាហ៍ពិពាហ៍សេឡេស្ទាល ។ ហើយវាក៏អាចរួមមានការប្រជុំគ្នានៅកន្លែង ឬដែនដីជ្រើសរើសមួយដើម្បីថ្វាយបង្គំព្រះ » (*A New Witness for the Articles of Faith* | ឆ្នាំ ១៩៨៥ | ទំព័រ ៥១៥) ។

- តើការជឿលើ និងការធ្វើតាមព្រះយេស៊ូវគ្រីស្ទជាផ្នែកមួយដ៏សំខាន់នៃការប្រមូលផ្តុំអ៊ីស្រាអែលដោយរបៀបណា ?

សូមសង្ខេប នីហ្វៃទី ៣ ២០:១៤–២២ ។ សូមពន្យល់ថា ព្រះអង្គសង្គ្រោះបានបង្រៀនពួកសាសន៍នីហ្វៃថា ជាផ្នែកនៃការប្រមូលផ្តុំអ៊ីស្រាអែល និងក្នុងការបំពេញតាមសេចក្តីសញ្ញារបស់ព្រះអម្ចាស់ជាមួយនឹងអ័ប្រាហាំ ព្រះវរបិតាស្ថគ៌បានប្រទានដល់កូនចៅរបស់លីហៃនូវដែនដីដែលពួកគេបានរស់នៅជាមរតក ។ ទ្រង់ក៏បានពន្យល់ពីរបៀបមួយទៀតដែលសាសន៍នីហ្វៃត្រូវបានប្រទានពរក្នុងនាមជាកូនចៅនៃសេចក្តីសញ្ញា ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២០:២៣–២៤ ដោយស្ងាត់ស្ងៀម ដោយរកមើលអ្នកដែលម៉ូសេបានព្យាករណ៍ថានឹងប្រទានដល់វង្សអ៊ីស្រាអែល ។ ក្រោយពីសិស្សរៀបរាប់អ្វីដែលពួកគេបានរកឃើញហើយ សូមឲ្យពួកគេអាន នីហ្វៃទី ៣ ២០:២៥–២៦ ដោយស្ងៀមស្ងាត់ ។ សូមឲ្យពួកគេរកមើលរបៀបដែលកូនចៅរបស់លីហៃត្រូវបានប្រទានពរដោយសារតែសេចក្តីសញ្ញាដែលព្រះអម្ចាស់បានធ្វើជាមួយនឹងអ័ប្រាហាំ ។ នៅពេលសិស្សរៀបរាប់អ្វីដែលពួកគេរកឃើញ សូមបញ្ជាក់ថា ព្រះវរបិតាស្ថគ៌បានបញ្ជូនព្រះយេស៊ូវគ្រីស្ទទៅជួបនឹងកូនចៅរបស់លីហៃ និងសង្គ្រោះពួកគេចេញពីអំពើបាប « ដោយសារ | ពួកគេគឺជា | កូនចៅនៃសេចក្តីសញ្ញា » ។

- តើយើងត្រូវបានប្រទានពរដោយសេចក្តីសញ្ញាដែលយើងធ្វើជាមួយនឹងព្រះវរបិតាស្ថគ៌ដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២០:២៧ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលការទទួលខុសត្រូវមួយដែលមកជាមួយនឹងសេចក្តីសញ្ញាដែលយើងធ្វើជាមួយនឹងព្រះអម្ចាស់ ។

- នៅពេលយើងបានធ្វើសេចក្តីសញ្ញាជាមួយនឹងព្រះអម្ចាស់ តើការទទួលខុសត្រូវរបស់យើងចំពោះមនុស្សផ្សេងទៀតទូទាំងពិភពលោកមានអ្វីខ្លះ ? (សិស្សនឹងអាចរកឃើញនូវសេចក្តីពិតខាងក្រោមនេះ ៖ **ក្នុងនាមជាកូនចៅរបស់អ័ប្រាហាំ យើងមានការទទួលខុសត្រូវតាមសេចក្តីសញ្ញាមួយដើម្បីប្រទានពរដល់មនុស្សផ្សេងទៀតនៅលើផែនដី ។** សូមគិតពីការសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

- តើអ្នកគិតថា យើងអាចជាពរជ័យមួយដល់មនុស្សទាំងអស់នៅលើផែនដីដោយរបៀបណា ? (ប្រសិនបើអ្នកបានសរសេរប្រយោគនៃគោលលទ្ធិនៅលើក្តារខៀន សូមបន្ថែមពាក្យ « **ដោយការចែកចាយដំណឹងល្អជាមួយនឹងពួកគេ** ។

សូមសង្ខេប នីហ្វៃទី ៣ ២០:២៩–៤៦ ដោយពន្យល់សង្ខេបថា បន្ថែមលើការបង្រៀនដល់ពួកសាសន៍នីហ្វៃអំពីពរជ័យ និងការទទួលខុសត្រូវរបស់ពួកគេក្នុងនាមជាកូនចៅនៃសេចក្តីសញ្ញា នោះព្រះអង្គសង្គ្រោះបានបញ្ជាក់ថា ដែនដីមរតករបស់ពួកសាសន៍យូដានឹងជាទីក្រុងយេរូសាឡិម ។ ទ្រង់បានដកស្រង់ការព្យាករណ៍របស់អេសាយ ដែលបានប្រាប់ជាមុនពីពេលដែលពួកសាសន៍យូដានឹងត្រូវស្តារឡើងវិញទៅកាន់ដែនដី មរតករបស់ពួកគេ ក្រោយពីពួកគេជឿលើព្រះយេស៊ូវគ្រីស្ទ និងអធិស្ឋានទៅកាន់ព្រះបិតាក្នុងព្រះនាមរបស់ទ្រង់ ។

ដើម្បីបញ្ចប់ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២០:៤៦ ឮៗ ។ សូមឲ្យសិស្សដទៃទៀតមើលតាម ហើយរកមើលរបៀបមួយដែលពួកគេអាចប្រទានពរដល់ជីវិតរបស់មនុស្សផ្សេងទៀតជាមួយនឹងដំណឹងល្អអំឡុងពេលសប្តាហ៍ក្រោយ ។ សូមដាក់ដែនការដើម្បីតាមដានសិស្សអំឡុងពេលបង្រៀនលើកក្រោយដើម្បីផ្តល់ឱកាសដល់ពួកគេឲ្យរៀបរាប់ពីបទពិសោធន៍របស់គេ ។ សូមធ្វើទីបន្ទាល់អំពីសារៈសំខាន់នៃការបំពេញទំនួលខុសត្រូវរបស់យើងដើម្បីជួយប្រមូលសាសន៍អ៊ីស្រាអែល ។

មេរៀនទី ១៣០

នីហ្វៃទី ៣ ២១–២២

សេចក្តីផ្តើម

នៅពេលព្រះយេស៊ូវគ្រីស្ទបានបន្តបង្រៀនដល់ពួកសាសន៍នីហ្វៃ ទ្រង់បានពន្យល់ថា ការលេចចេញមកនៃព្រះគម្ពីរមរមននៅក្នុងថ្ងៃចុងក្រោយនឹងក្លាយជាទីសម្គាល់មួយដែលទ្រង់បានចាប់ផ្តើមប្រមូលសាសន៍អ៊ីស្រាអែល ហើយបំពេញតាមសេចក្តីសញ្ញាជាមួយនឹងប្រជាជនរបស់ទ្រង់ ។ ដោយការបញ្ជាក់ពីសេចក្តីស្រឡាញ់ដ៏ធំធេងរបស់ទ្រង់សម្រាប់រាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់ ព្រះអង្គសង្គ្រោះបានដកស្រង់ការព្យាករណ៍របស់អេសាយអំពីការស្តារឡើងវិញនៃរាស្ត្រនៃសេចក្តីសញ្ញា ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៣ ២១:១–១១

ព្រះយេស៊ូវគ្រីស្ទបង្រៀនថា ការលេចចេញមកនៃព្រះគម្ពីរមរមននៅក្នុងថ្ងៃចុងក្រោយនឹងក្លាយជាទីសម្គាល់មួយដែលទ្រង់បានចាប់ផ្តើមប្រមូលសាសន៍អ៊ីស្រាអែល

មុនចាប់ផ្តើមថ្នាក់ សូមគូសសញ្ញាខាងក្រោមនៅលើក្តារខៀន (ឬ ប្រើសញ្ញាផ្សេងទៀតដែលប្រើទូទៅក្នុងតំបន់ដែលអ្នករស់នៅ) ។



សូមឲ្យសិស្សរកមើលអត្ថន័យនៃសញ្ញានីមួយៗ ។ បន្ទាប់មក សូរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- តើសញ្ញាទាំងឡាយនេះប្រើដើម្បីអ្វី ? (ដើម្បីរៀបចំ ព្រមាន និងណែនាំយើង) ។
- ហេតុអ្វីបានជាវាសំខាន់ដែលសញ្ញាមួយត្រូវបានដាក់បង្ហាញដោយត្រឹមត្រូវ ហើយថា អត្ថន័យរបស់ សញ្ញានោះងាយយល់ ?

សូមរំពួកសិស្សថា ជារឿយៗព្រះគម្ពីរបានលើកឡើងពីសញ្ញាដែលរៀបចំ ព្រមាន និងណែនាំយើងទាក់ទងនឹងការបំពេញតាមផែនការរបស់ព្រះវរបិតាសួគ៌ ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២១:១– ២, ៧ ដោយរកមើលពាក្យ *ទីសម្គាល់* ។ អ្នកអាចស្នើថា ពួកគេគូរគូសចំណាំពាក្យនេះពេលណាដែលវាលេចឡើងនៅក្នុងខគម្ពីរទាំងនោះ ។ បន្ទាប់មក សូមឲ្យពួកគេអាន ខគម្ពីរទី ១ ដោយស្ងៀមស្ងាត់ និងដោយយកចិត្តទុកដាក់ ។

- តើហេតុអ្វីបានជាព្រះអម្ចាស់បានមានបន្ទូលថា ទ្រង់នឹងប្រទានន្ទវទីសម្គាល់ជាក់លាក់នេះ ? (ដើម្បីប្រជាជនបានដឹងថា ទ្រង់កំពុងប្រមូលវង្សអ៊ីស្រាអែល) ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២១:១–៧ ដោយស្ងាត់ៗ ហើយសូមឲ្យពួកគេកត់ចំណាំឃ្លា « ការណ៍ទាំងនេះ» និង « កិច្ចការទាំងនេះ » ហើយគិតពីអ្វីដែលឃ្លាទាំងនេះសំដៅលើ ។

- ដោយមានបន្ទូលទៅពួកសាសន៍នីហ្វៃ ព្រះអង្គសង្គ្រោះបានមានបន្ទូលអំពី « ការណ៍ទាំងនេះដែលយើងបានប្រកាសដល់អ្នកវាល់គ្នា » (នីហ្វៃទី ៣ ២១:២) ។ តើព្រះបន្ទូលរបស់ទ្រង់ដល់ពួកសាសន៍នីហ្វៃត្រូវបានកត់ត្រានៅទីណា ? (នៅក្នុងព្រះគម្ពីរមរមន) ។
- យោងតាមខគម្ពីរទាំងនេះ តើអ្វីទៅជាទីសម្គាល់មួយដែលព្រះកំពុងបំពេញសេចក្តីសញ្ញារបស់ទ្រង់នៅក្នុងថ្ងៃចុងក្រោយ ? (សូមជួយសិស្សឲ្យរកមើលសេចក្តីពិតខាងក្រោម [សូមសរសេរវានៅលើក្តារខៀន] ៖ ***ការលេចចេញមកនៃព្រះគម្ពីរមរមនគឺជាទីសម្គាល់មួយដែលព្រះកំពុងបំពេញសេចក្តីសញ្ញារបស់ទ្រង់ដើម្បីប្រមូលពួកសាសន៍អ៊ីស្រាអែលនៅក្នុងថ្ងៃចុងក្រោយ***) ។

សូមឲ្យសិស្សម្នាក់អានឲ្យៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ័សុល អិម ណិលសុន នៃក្វរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់រករបៀបដែលព្រះគម្ពីរមរមន ជួយប្រជាជនឲ្យប្រមូលផ្តុំគ្នាទៅរកកិច្ចការរបស់ព្រះអម្ចាស់ ។

« ព្រះគម្ពីរមរមនគឺជាស្នូលចំពោះកិច្ចការនេះ ។ វាប្រកាសពីគោលលទ្ធិនៃការប្រមូលផ្តុំ ។ វាបណ្តាលឲ្យប្រជាជនរៀនអំពីព្រះយេស៊ូវគ្រីស្ទ ជឿលើដំណឹងល្អរបស់ទ្រង់ និងចូលរួមក្នុងសាសនាចក្ររបស់ទ្រង់ ។ តាមពិត ប្រសិនបើគ្មានព្រះគម្ពីរមរមនទេ ការប្រមូលផ្តុំសាសន៍អ៊ីស្រាអែលដែលបានសន្យានឹងមិនកើតឡើងទេ » (« The Gathering of Scattered Israel » *Ensign* ឬ *Liahona* ខែ វិច្ចិកា ឆ្នាំ ២០០៦ ទំព័រ ៨០) ។

- តើនៅពេលណាដែលព្រះគម្ពីរមរមនបានជួយអ្នកតាមរបៀបទាំងនេះ ? តើនៅពេលណាដែលអ្នកបានឃើញព្រះគម្ពីរមរមនជួយដល់អ្នកដទៃតាមរបៀបទាំងនេះ ?

បង្រៀនដោយព្រះវិញ្ញាណបរិសុទ្ធ

សូមអធិស្ឋានដើម្បីសុំការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នករៀបចំ និងខណៈពេលដែលអ្នកបង្រៀន ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣២១:៩ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់កត់ចំណាំឃ្លា « កិច្ចការដ៏ធំ ហើយអស្ចារ្យ » ។ សូមបង្ហាញថា ឃ្លានេះសំដៅលើការស្តារឡើងវិញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដែលរួមមានការលេចចេញមកនៃព្រះគម្ពីរមរមន ។

- តើអ្វីជាការណ៍ដ៏ធំ ហើយអស្ចារ្យអំពីការស្តារឡើងវិញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ?

សូមបង្ហាញថា នីហ្វៃទី ៣ ២១:៩ សំដៅលើ « បុរសម្នាក់ » ។ សូមឲ្យសិស្សគិតថាតើបុរសនេះអាចជានរណា ។ បន្ទាប់មក សូមបង្ហាញរូបភាពនៃ យ៉ូសែប ស៊្មីធ (ប្រហែលរូបភាពបងប្រុសយ៉ូសែប ឬរូបភាពការនិមិត្តលើកដំបូង | *Gospel Art Book* (ឆ្នាំ ២០០៩) លេខ ៨៧ ឬលេខ ៩០ |) ។ សូមប្រាប់សិស្សថា អែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃក្រុមនៃពួកសាវកដប់ពីរនាក់បានរកឃើញថាបុរសនោះជា យ៉ូសែប ស៊្មីធ (សូមមើល *Christ and the New Covenant : The Messianic Message of the Book of Mormon*| ឆ្នាំ ១៩៩៧ | ទំព័រ ២៨៧–៨៨) ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២១:១០–១១ ដោយស្ងាត់ស្ងៀមដោយសញ្ជឹងគិតពីរបៀបដែលព្យាការី យ៉ូសែប ស៊្មីធ សមនឹងការពិពណ៌នានៅក្នុងខគម្ពីរទាំងនេះ: ។

- តើព្រះបានបង្ហាញតាមរយៈ យ៉ូសែប ស៊្មីធ ថា « ចំណេះដឹងគឺអស្ចារ្យជាងកលល្បិចរបស់អារក្ស » ដោយរបៀបណា ?
- យោងតាម នីហ្វៃទី ៣ ២១:១១ តើនឹងមានអ្វីកើតឡើងដល់អស់អ្នកទាំងឡាយណាដែលមិនជឿលើព្រះបន្ទូលរបស់ព្រះគ្រីស្ទដែលបាននាំចេញមកតាមរយៈ យ៉ូសែប ស៊្មីធ នោះ ? (ពួកគេនឹងត្រូវ « កាត់ចេញ » ពីពរជ័យដែលនាំមកតាមរយៈសេចក្តីសញ្ញា) ។

នីហ្វៃទី ៣ ២១:១២–២២:១៧

ព្រះអង្គសង្គ្រោះមានបន្ទូលអំពីសេចក្តីបំផ្លិចបំផ្លាញនៃពួកអ្នកមិនប្រែចិត្ត និងការស្តារឡើងវិញនូវារាស្ត្ររបស់ទ្រង់ដែលនឹងប្រែចិត្ត ហើយត្រឡប់មកទ្រង់

សូមសង្ខេប នីហ្វៃទី ៣ ២១:១២–២១ ដោយពន្យល់ថា ព្រះអង្គសង្គ្រោះបានប្រទានន្យការព្រមានមួយដល់អ្នកទាំងឡាយនៅក្នុងថ្ងៃចុងក្រោយដែលមិនជឿលើទ្រង់ និងមិនព្រមប្រែចិត្ត ។ ទ្រង់បានមានបន្ទូលថា សម្ភារជាកម្មសិទ្ធិរបស់ពួកគេ ទីក្រុងទាំងឡាយ កន្លែងដ៏រឹងមាំទាំងឡាយ និងការអនុវត្តតាមការអាក្រក់នឹងត្រូវបំផ្លាញ ។ ទ្រង់ក៏បានមានបន្ទូលថា ពួកគេនឹងត្រូវកាត់ចេញពីវាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់ ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២១:២២, ២៥–២៨ ដោយស្ងាត់ៗដោយរកមើលពរជ័យ និងការទទួលខុសត្រូវទាំងឡាយដែលនឹងមកដល់អ្នកទាំងឡាយនៅក្នុងថ្ងៃចុងក្រោយដែលនឹងប្រែចិត្ត ហើយស្តាប់តាមសំឡេងរបស់ព្រះអង្គសង្គ្រោះ: ។

សូមសួរសិស្សពីរបៀបដែលពួកគេអាចសង្ខេបការបង្រៀនទាំងឡាយនៅក្នុង នីហ្វៃទី ៣ ២១:១២–២២, ២៥–២៨ ។ សូមអញ្ជើញសិស្សម្នាក់ឲ្យសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ បន្ទាប់មក សង្ខេបចម្លើយទាំងអស់នៅលើក្តារខៀនដោយការបង្ហាញថា **នៅពេលយើងប្រែចិត្ត និងស្តាប់តាមព្រះបន្ទូលរបស់ព្រះអង្គសង្គ្រោះ នោះយើងនឹងរួបរួមគ្នាជាផ្នែកនៃវាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់ ។** (អ្នកអាចសរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។

សូមគូសរូបតង់មួយនៅលើក្តារខៀន ឬនៅលើក្រដាសមួយ (អ្នកអាចធ្វើការណ៍នេះមុនចាប់ផ្តើមថ្នាក់) ។ សូមពន្យល់ថា ព្រះយេស៊ូវគ្រីស្ទបានដកស្រង់ការព្យាករណ៍មួយថា ទ្រង់បានបំផុសដល់ព្យាការី អេសាយ ឲ្យសរសេរតាំងពីរាប់សតវត្សរ៍មុន ។ នៅក្នុងការព្យាករណ៍នេះ អេសាយបានបង្រៀនសាសនាចក្រ ជាមួយនឹងសេចក្តីសញ្ញា និងពរជ័យទាំងឡាយទៅនឹងត្រសាលមួយ ។



- តើមានអត្ថប្រយោជន៍អ្វីខ្លះក្នុងការនៅក្រោមត្រសាលមួយ ? (ចម្លើយអាចរួមមាន ត្រសាលមួយផ្តល់នូវការការពារពីព្យុះ និងចាំងព្រះអាទិត្យ) ។
- តើសាសនាចក្រប្រៀបដូចជាត្រសាលមួយដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២២:២ ឮៗ ។

- ហេតុអ្វីបានជា « ត្រសាល » នេះអាចត្រូវពង្រីក និងពង្រឹងនៅក្នុងថ្ងៃចុងក្រោយ ? (ដោយសារមនុស្សជាច្រើននឹងចូលរួមនៅក្នុងសាសនាចក្រ ឬត្រឡប់មកវិញសេចក្តីសញ្ញារបស់ពួកគេជាមួយនឹងព្រះអម្ចាស់) ។ តើអ្នកអាចធ្វើអ្វីខ្លះដើម្បីជួយពង្រីកត្រសាលនេះ និងពង្រឹងដល់ចំរឹងទាំងឡាយ ? (សូមលើកទឹកចិត្តសិស្សឲ្យធ្វើសកម្មភាពតាមចម្លើយរបស់ពួកគេទៅនឹងសំណួរនេះ:) ។

សូមពន្យល់ថា នៅក្នុងការព្យាករណ៍ដដែលនេះ អេសាយបានប្រើការប្រៀបធៀបផ្សេងទៀត ។ លោកបានសំដៅលើវង្សអ៊ីស្រាអែលជាភរិយាមួយ ដែលមានស្វាមីជាព្រះអម្ចាស់ ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២២:៤–៥ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលពាក្យនៃការលួងលោមសម្រាប់ភរិយានោះ: ។

- តើពាក្យនៃការលួងលោមអ្វីខ្លះដែលអ្នកឃើញនៅក្នុង នីហ្វៃទី ៣ ២២:៤ ? (ចម្លើយអាចរួមមាន « អ្នកនឹងមិនដែលត្រូវខ្មាស់ឡើយ » និង « អ្នកនឹងមិននឹកចាំពីសេចក្តីដែលគេត្មះដៀលពីកាលនៅវ័យក្មេង ») ។ ហេតុអ្វីបានជាវាជាការលួងលោមដែលដឹងថា« ស្វាមី» គឺជា « ព្រះដ៏ប្រោសលោះ ជាអង្គដ៏បរិសុទ្ធនៃអ៊ីស្រាអែល » ? (នីហ្វៃទី ៣ ២២:៥) ។

- តើខគម្ពីរទាំងនេះស្រដៀងគ្នាទៅនឹងចម្លើយរបស់ព្រះអង្គសង្គ្រោះចំពោះយើងនៅពេលយើងមានបាបដោយរបៀបណា ?

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២២:៧–១០ ដោយស្ងាត់ស្ងៀមដោយរកមើលសេចក្តីសន្យាដែលព្រះអង្គសង្គ្រោះធ្វើជាមួយនឹងរាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់ដែលត្រឡប់មកកាន់ទ្រង់វិញ ។

- តើព្រះអង្គសង្គ្រោះបានសន្យាអ្វីខ្លះ ដល់អស់អ្នកទាំងឡាយណាដែលត្រឡប់មកកាន់ទ្រង់វិញ ?
- តើសេចក្តីពិតណាខ្លះដែលយើងរៀនអំពីព្រះអម្ចាស់នៅក្នុងខគម្ពីរទាំងនេះ ? (សិស្សអាចចែកចាយចម្លើយខុសគ្នាខ្លះៗចំពោះសំណួរនេះ ។ សូមប្រាកដថា ពួកគេរកឃើញសេចក្តីពិតដូចខាងក្រោម ៖ **ព្រះអម្ចាស់បង្ហាញនូវសេចក្តីល្អ និងសេចក្តីមេត្តាករុណាដ៏និរន្តរ៍ដល់ប្រជាជនដែលត្រឡប់មកកន្ទ្រង់វិញ ។** អ្នកអាចសរសេរសេចក្តីពិតនេះនៅលើក្តារខៀន ។ អ្នកក៏អាចគិតពីការសុំឲ្យសិស្សសរសេរវានៅក្នុងព្រះគម្ពីររបស់ពួកគេក្បែរ នីហ្វៃទី ៣ ២២:៧– ១០) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់អំពី នីហ្វៃទី ៣ ២២:៤–១០ សូមគិតពីសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ជែហ្វ្រី អ័រ ហូឡិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ទោះបីជាមានភាពសោះកក្រោះ និងពេលខ្លះ មិនស្មោះត្រង់ ប៉ុន្តែស្វាមី (ព្រះគ្រីស្ទ) នឹងនៅតែទទួលយក និងប្រោសលោះដល់កូនក្រមុំរបស់ទ្រង់ (អ៊ីស្រាអែល) ។ រូបភាពនៃព្រះយេហូវ៉ាជាកូនកំលោះ ហើយសាសន៍អ៊ីស្រាអែលជាកូនក្រមុំគឺនៅក្នុងចំណោមការប្រៀបធៀបដែលត្រូវបានគេប្រើទូទៅបំផុតនៅក្នុងព្រះគម្ពីរ ដោយការប្រើដោយព្រះអម្ចាស់ និងព្យាការីរបស់ទ្រង់ដើម្បីរៀបរាប់ពីទំនាក់ទំនងរវាងទេវតា និងកូនចៅនៃសេចក្តីសញ្ញា ។

« . . . ក្នុងឱកាសនេះ ព្រះគ្រីស្ទបានខឹងយ៉ាងខ្លាំងនឹងពួកសាសន៍អ៊ីស្រាអែលដែលបានត្រឡប់ក្រោយ ប៉ុន្តែនោះតែងតែជាការណ៍ខ្លី និងបណ្តោះអាសន្ន—‘ មួយរយៈតូច ’ ។ សេចក្តីមេត្តា និងករុណាតែងតែត្រឡប់ និងយកឈ្នះលើផ្លូវដ៏មានការធានាដ៏ខ្លាំងបំផុតជានិច្ច ។ ភ្នំ និងទីទួលទាំងឡាយអាចលិចបាត់ ។ ទឹកសមុទ្រដ៏ធំធេងអាចរីងស្ងួត ។ រឿងដែលកម្រនៅក្នុងពិភពលោកនេះអាចកើតឡើង ប៉ុន្តែសណ្តានចិត្តល្អ និងសេចក្តីសុខសាន្តរបស់ព្រះអម្ចាស់នឹងមិនដែលត្រូវបានយកចេញពីរាស្ត្រនៃសេចក្តីសញ្ញារបស់ទ្រង់ឡើយ ។ ទ្រង់បានស្បថនឹងសម្បថស្ថានសួគ៌ថា ទ្រង់នឹងមិនខឹងពួកគេជារៀងរហូតឡើយ » (*Christ and the New Covenant,* ២៩០) ។

- តើមានភស្តុតាងអ្វីខ្លះនៃសេចក្តីមេត្តាករុណា និងសណ្តានចិត្តរបស់ព្រះអង្គសង្គ្រោះដែលអ្នកបានឃើញនៅក្នុងជីវិតរបស់អ្នក ? (សូមប្រាកដថា សិស្សយល់ថា ពួកគេមិនចាំបាច់ត្រូវចែកចាយអ្វីដែលផ្ទាល់ខ្លួនពេកនោះទេ) ។
- តើការស្គាល់ពីសេចក្តីមេត្តាករុណា និងព្រះទ័យល្អរបស់ព្រះអង្គសង្គ្រោះអាចជះឥទ្ធិពលដល់សេចក្តីស្មោះត្រង់របស់យើងចំពោះសេចក្តីសញ្ញាដោយរបៀបណា ?

សូមពន្យល់ថា ព្រះអង្គសង្គ្រោះបានបន្តបង្រៀនដល់ពួកសាសន៍នីហ្វៃអំពីពរជ័យដែលរង់ចាំពួកសុចរិត ។ សូមឲ្យសិស្សស្រាវជ្រាវក្នុងនីហ្វៃទី ៣ ២២:១៣–១៧ ដោយស្ងាត់ស្ងៀមដោយរកមើលពរជ័យដែលបានសន្យាមួយដែលមានអត្ថន័យជាពិសេសដល់ពួកគេ ។ សូមបង្ហាញថា នៅពេលយើងអានអំពីពរជ័យដែលបានសន្យាទាំងនេះ យើងឃើញថា **ប្រជាជនរបស់ព្រះអម្ចាស់នឹងត្រូវបានស្តាបនានៅក្នុងសេចក្តីសុចរិត ហើយព្រមទាំងនឹងអាចយកឈ្នះលើសេចក្តីទុច្ចរិតបាន ។**

សូមបញ្ចប់ដោយទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតដែលត្រូវបានពិភាក្សានៅក្នុងមេរៀននេះ ។ សូមឲ្យសិស្សសរសេរប្រយោគបី ឬបួននៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរ អំពីរឿងមួយដែលពួកគេអាចធ្វើនៅថ្ងៃនេះដើម្បីសមនឹងទទួលបានពរជ័យដែលព្រះអម្ចាស់ចង់ប្រទានដល់ពួកគេ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ៣ ២១:២២–២៥ ។ ទីក្រុងយេរូសាឡិមថ្មី

ជានីយ៉ែល អេចធ៍ ល័ដឡូ បានបញ្ជាក់អ្នកដែលនឹងកសាងទីក្រុងយេរូសាឡិមថ្មី ៖

« ទីក្រុង ‹ យេរូសាឡិមថ្មី › នៅថ្ងៃចុងក្រោយនឹងត្រូវបានកសាងនៅលើទ្វីបអាមេរិកដោយ (១) ‹ ពួកសំណល់នៃយ៉ាកុប › (២) ពួកសាសន៍ដទៃដែល ‹ នឹងចូលមកក្នុងសេចក្តីសញ្ញា ហើយត្រូវបានរាប់នៅក្នុងចំណោម . . . ពួកសំណល់នៃយ៉ាកុប › និង (៣) ‹ ពួកវង្ស អ៊ីស្រាអែលជាច្រើនដែលនឹងចូលមក › ។ (នីហ្វៃទី ៣ ២១:២២–២៥ ។ សូមអានផងដែរ នីហ្វៃទី ៣ ២០:២២; អេធើរ ១៣:១–១២) » ។ (*A Companion to Your Study of the Book of Mormon* [ឆ្នាំ ១៩៧៦] ទំព័រ ២៨១) ។

មេរៀនសិក្សានៅផ្ទះ

នីហ្វៃទី ៣ ១៧–២២ (មេរៀនទី ២៦)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀននៅពេលពួកគេសិក្សា នីហ្វៃទី ៣ ១៧–២២ (មេរៀនទី ២៦) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (នីហ្វៃទី ៣ ១៧)

នៅពេលសិស្សបានសិក្សាពីព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទទៅកាន់បណ្តាជនសាសន៍នីហ្វៃ នោះពួកគេបានរៀនថា ដោយការសញ្ជឹងគិត និងការអធិស្ឋានដល់ព្រះវរបិតា នោះយើងអាចទទួលបានការយល់កាន់តែច្បាស់អំពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ។ ព្រះអង្គសង្គ្រោះបានឆ្លើយតបទៅនឹងបំណងរបស់ពួកសាសន៍នីហ្វៃថា ទ្រង់នឹងគង់នៅជាមួយនឹងពួកគេយូរបន្តិចទៀត ដោយព្យាបាលជំងឺដល់ពួកគេ ហើយប្រទានពរដល់កូនចៅរបស់គេ ។ នៅពេលសិស្សអានអំពីព្រឹត្តិការណ៍ទាំងនេះហើយ ពួកគេបានដឹងថា ព្រះយេស៊ូវគ្រីស្ទមានព្រះទ័យមេត្តាដល់យើងខ្លាំងណាស់ ។

ថ្ងៃទី ២ (នីហ្វៃទី ៣ ១៨)

ព្រះអង្គសង្គ្រោះបានបម្រើពិធីសាក្រាម៉ង់ដល់ហ្វូងមនុស្ស ។ សិស្សបានដឹងថា នៅពេលយើងទទួលយកសាក្រាម៉ង់ យើងធ្វើជាសាក្សីដល់ព្រះវរបិតាថា យើងនឹងមានឆន្ទៈធ្វើអ្វីៗទាំងអស់ដែលទ្រង់បានបញ្ជា ហើយថាយើងនឹងចងចាំដល់ព្រះយេស៊ូវគ្រីស្ទជានិច្ច ។ ពួកគេក៏បានរៀនថា នៅពេលយើងទទួលពិធីសាក្រាម៉ង់ ហើយចងចាំដល់ព្រះអង្គសង្គ្រោះជានិច្ចនោះ យើងនឹងទទួលបានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយនឹងយើង ។ ការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីការអធិស្ឋានបានជួយសិស្សឲ្យយល់ថា ប្រសិនបើយើងប្រយ័ត្ន ហើយអធិស្ឋានទៅកព្រះវរបិតាជានិច្ច នោះយើងអាចការពារនឹងការល្បួងរបស់សាតាំងបាន ។ ពួកគេក៏បានដឹងថា នៅពេលយើងបម្រើដល់អ្នកដទៃ យើងអាចជួយពួកគេឲ្យមកកាន់ព្រះគ្រីស្ទ ។

ថ្ងៃទី ៣ (នីហ្វៃទី ៣ ១៩)

ក្រោយពីព្រះអង្គសង្គ្រោះបានចាកចេញនៅចុងបញ្ចប់នៃថ្ងៃទីមួយជាមួយនឹងពួកសាសន៍នីហ្វៃហើយ ពួកសិស្សបានបង្រៀនដល់ប្រជាជន ។ ពួកគេបានអធិស្ឋាន និងបានទទួលព្រះវិញ្ញាណបរិសុទ្ធ ។ សិស្សបានរៀនថា បំណង និងការអធិស្ឋានដ៏សុចរិតរបស់យើង អាចធ្វើឲ្យយើងសាកសមនឹងបំពេញដោយព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះអង្គសង្គ្រោះបានយាងមកម្តងទៀត ហើយទ្រង់បានថ្លែងអំណរគុណដល់ព្រះវរបិតាសម្រាប់ការបន្សុទ្ធពួកសិស្សរបស់ទ្រង់ ។ សិស្សបានរៀនថា នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចត្រូវបានបន្សុទ្ធ ហើយក្លាយជាមនុស្សតែមួយជាមួយនឹងព្រះយេស៊ូវគ្រីស្ទ ក៏ដូចជា ទ្រង់តែមួយ ជាមួយនឹងព្រះវរបិតាដែរ ។

ថ្ងៃទី ៤ (នីហ្វៃទី ៣ ២០–២២)

ព្រះយេស៊ូវគ្រីស្ទបានបម្រើពិធីសាក្រាម៉ង់ម្តងទៀត ។ សិស្សបានរៀនថា ប្រសិនបើយើងទទួលទានសាក្រាម៉ង់ដោយសក្តិសម នោះយើងនឹងមានព្រះវិញ្ញាណបរិសុទ្ធ ។ បន្ទាប់មក ព្រះអម្ចាស់បានបង្រៀនដល់ពួកសាសន៍នីហ្វៃថា ព្រះវរបិតានឹងបំពេញតាមសេចក្តីសញ្ញារបស់ទ្រង់ដើម្បីប្រមូលវង្សអ៊ីស្រាអែលនៅក្នុងថ្ងៃចុងក្រោយ ។ សិស្សក៏បានរៀនផងដែរថា ក្នុងនាមជាកូនចៅរបស់អ័ប្រាហាំ យើងមានការទទួលខុសត្រូវមួយស្របតាមសេចក្តីសញ្ញា ដើម្បីប្រទានពរដល់មនុស្សផ្សេងទៀតនៅលើផែនដី ។

សេចក្តីផ្តើម

មេរៀននេះអាចជួយសិស្សឲ្យយល់ពីការយកចិត្តទុកដាក់ និងសេចក្តីមេត្តាករុណាដែលព្រះអង្គសង្គ្រោះមានដល់រាស្ត្ររបស់ទ្រង់ ។ លើសពីនេះទៀត នៅពេលសិស្សរំឭកពីការណែនាំរបស់ព្រះអម្ចាស់ឲ្យអធិស្ឋាន ពួកគេអាចគិតពីរបៀបដើម្បីធ្វើឲ្យការអធិស្ឋានផ្ទាល់ខ្លួន និងជាគ្រួសាររបស់គេកាន់តែមានន័យថែមទៀត ។

យោបល់ទាំងឡាយសម្រាប់ការបង្រៀន

នីហ្វៃទី ៣ ១៧

ព្រះអង្គសង្គ្រោះព្យាបាលអ្នកឈឺ អធិស្ឋានដល់ព្រះវរបិតាសម្រាប់ប្រជាជន និងប្រទានពរដល់កូនចៅរបស់ពួកគេ

សូមឲ្យសិស្សគិតអំពីបុគ្គលដែលចេះជួយទុក្ខធុរៈបំផុតដែលពួកគេស្គាល់ ។ បន្ទាប់មក សូមសួរថា ៖ តើអ្នកបានគិតអំពីនរណា ? តើបុគ្គលនេះបង្ហាញសេចក្តីស្រឡាញ់ដល់អ្នកដទៃ និងដល់អ្នកដោយរបៀបណា ?

សូមបង្ហាញរូបភាពព្រះយេស៊ូវព្យាបាលសាសន៍នីហ្វៃ (*Gospel Art Book* [ឆ្នាំ ២០០៩] លេខ ៨៣) និងព្រះយេស៊ូវប្រទានពរដល់កូនចៅសាសន៍នីហ្វៃ (*Gospel Art Book* លេខ ៨៤) ។ បន្ទាប់មក សូមសួរថា ៖ តើអ្នកបានរៀនអ្វីខ្លះអំពីសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះចំពោះប្រជាជន អំឡុងពេលការសិក្សារបស់អ្នកក្នុងព្រះគម្ពីរមរមនកាលពីសប្តាហ៍មុននេះ ?

សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***ព្រះអង្គសង្គ្រោះមានសេចក្តីមេត្តាករុណាជាខ្លាំងដល់យើង ។*** នៅពីក្រោមប្រយោគនេះ សូមសរសេរសេចក្តីយោងខាងក្រោម ៖ *នីហ្វៃទី ៣ ១៧:៧, ៩, ១១, ១៥–១៧, ២១, ២៤* ។ សូមឲ្យសិស្សរំឭកខគម្ពីរទាំងនេះ ហើយជ្រើសរើសខគម្ពីរមួយដែលបង្ហាញជាពិសេសពីសេចក្តីពិតដែលបានសរសេរនៅលើក្តារខៀន ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ អ្នកអាចសួរសំណួរខាងក្រោមនេះ ៖

- តើខគម្ពីរដែលអ្នកបានជ្រើសរើសនេះបង្ហាញថា ព្រះអង្គសង្គ្រោះមានសេចក្តីមេត្តាករុណាជាខ្លាំងដល់យើងដោយរបៀបណា ?
- តើអ្នករៀនអ្វីខ្លះអំពីព្រះអង្គសង្គ្រោះនៅក្នុងការដែលទ្រង់បានបម្រើដល់ប្រជាជន « ម្តងម្នាក់ៗ » នោះ ? (នីហ្វៃទី ៣ ១៧:២១) ។
- តើការដឹងអំពីសេចក្តីមេត្តាករុណារបស់ព្រះអង្គសង្គ្រោះអាចជួយអ្នកឲ្យអនុវត្តសេចក្តីជំនឿដ៏អស្ចារ្យបន្ថែមទៀតទៅលើទ្រង់ ហើយមានអារម្មណ៍ពីសេចក្តីស្រឡាញ់ដ៏ជំជំចំពោះទ្រង់ដោយរបៀបណា ?

នីហ្វៃទី ៣ ១៨–១៩

ព្រះយេស៊ូវបានបង្រៀនដល់ពួកសាសន៍នីហ្វៃឲ្យអធិស្ឋានដល់ព្រះវរបិតាជានិច្ច និងជួបជុំគ្នាជាញឹកញាប់

សូមបែងចែកសិស្សជាគូ ហើយសូមឲ្យដៃគូនីមួយៗបង្កើតបញ្ជីមួយស្តីពីជីវិតនៃការល្បួងដ៏ខ្លាំងបំផុតដែលពួកគេជឿថាយុវជននាសព្វថ្ងៃនេះកំពុងមាន ។ នៅពេលពួកគេបានបញ្ចប់ សូមឲ្យដៃគូនីមួយៗអាន នីហ្វៃទី ៣ ១៨:១៥–២០ ហើយរកមើលការណែនាំដែលព្រះអង្គសង្គ្រោះបានប្រទានសម្រាប់ការយកឈ្នះលើការល្បួង ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយគោលការណ៍មួយដែលពួកគេរកឃើញនៅក្នុងខគម្ពីរទាំងនេះ ។ គោលការណ៍មួយដែលពួកគេអាចរកឃើញនោះគឺ **ប្រសិនបើយើងប្រុងប្រយ័ត្ន ហើយអធិស្ឋានជានិច្ចទៅរកព្រះវរបិតា នោះយើងនឹងអាចតតាំងនឹងការល្បួងរបស់សាតាំងបាន ។**

សូមសួរសិស្សនូវសំណួរដូចខាងក្រោម ៖

- តើអ្នកគិតថា យុវជនម្នាក់គួរប្រុងប្រយ័ត្នចំពោះអ្វីខ្លះដើម្បីតតាំងនឹងការល្បួងមួយដែលមាននៅលើបញ្ជីរបស់អ្នក ?

- តើយុវជនម្នាក់អាចអធិស្ឋានសូមអ្វីខ្លះ ដើម្បីជួយគេឲ្យតតាំងនឹងការល្បួងមួយដែលមាននៅលើបញ្ជីរបស់អ្នក ? តើការអធិស្ឋានដល់ព្រះវរបិតាសួគ៌ជួយអ្នកឲ្យនៅតែបន្តរឹងមាំដោយរបៀបណា ?

ដើម្បីជួយសិស្សឲ្យពង្រឹងទីបន្ទាល់របស់ពួកគេអំពីការអធិស្ឋានជាគ្រួសារ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៨:២១ ឮៗ ។ បន្ទាប់មក សូមសួរថា ៖ តើពរដ៏ធំអ្វីខ្លះដែលអ្នកបានទទួលពីការអធិស្ឋានជាមួយនឹងក្រុមគ្រួសាររបស់អ្នក ?

សូមឲ្យសិស្សម្នាក់អានរឿងខាងក្រោមពីប្រធាន ដៃមស៍ អឹ ហ្វោស្ត នៃគណៈប្រធានទីមួយ ដែលបានមានប្រសាសន៍អំពីអំណាចនៃការអធិស្ឋានជាគ្រួសារ ៖

« ការអធិស្ឋានជាគ្រួសារគឺជាឥទ្ធិពលគាំទ្រដ៏មានអំណាចមួយ ។ អំឡុងពេល ជំងឺឆឹតនៃសង្គ្រាមលោកលើកទីពីរ គ្រាប់បែកទម្លាក់ទម្ងន់ ៥០០ ផោនបានធ្លាក់នៅក្រៅផ្ទះដ៏តូចមួយរបស់បងប្រុស ផាធី ដែលជាឪពុកដ៏វ័យក្មេងនៅក្នុងទីក្រុងលីវើរភូល ប្រទេសអង់គ្លេស ប៉ុន្តែគ្រាប់បែកទម្លាក់នោះមិនបានផ្ទុះទេ ។ ភរិយារបស់គាត់បានស្លាប់ ដូច្នេះគាត់ត្រូវចិញ្ចឹមកូនទាំងប្រាំនាក់របស់គាត់តែម្នាក់ឯង គាត់បានប្រមូលពួកគេជុំគ្នានៅពេលដ៏ព្រួយបារម្ភនេះដើម្បីអធិស្ឋានជាគ្រួសារ ។ ពួកគេ ‹ បានអធិស្ឋានទាំងអស់ . . . ដោយស្មោះត្រង់ ហើយនៅពេលពួកគេបានអធិស្ឋានចប់ហើយ កូនៗបាននិយាយថា ៖ « ប៉ា យើងនឹងមិនអីទេ ។ យើងនឹងមិនអីទេ នៅយប់នេះនៅក្នុងផ្ទះរបស់យើង » ។

« ‹ ដូច្នេះហើយពួកគេបានចូលទៅសំរាក ទាំងនឹកឃើញពីគ្រាប់បែកទម្លាក់ដ៏សាហាវនោះដែលលិចពាក់កណ្តាលទៅក្នុងដីនៅពីមុខទ្វារគេនោះ › ។ . . .

« ‹ លុះស្អែកឡើង . . .ក្នុងរយៈពេលសែសិបប្រាំបីម៉ោងនោះ អ្នកភូមិទាំងអស់បានចាកចេញ ហើយនៅទីបំផុតគ្រាប់បែកទម្លាក់នោះត្រូវបានគេយកចេញទៅ ។ . . .

« ‹ តាមផ្លូវត្រឡប់មកផ្ទះវិញ បងប្រុសផាធី បានសួរមេក្រុម A.R.P.ថា « មែនហើយ តើលោកបានរកឃើញអ្វីខ្លះ ? »

« ‹ « លោក ផាធី យើងបានយកគ្រាប់ទម្លាក់នោះចេញពីទ្វាររបស់លោក ហើយបានរកឃើញគ្រាប់នោះវាអាចនឹងផ្ទុះបានគ្រប់ពេល ។ គ្រាប់បែកនោះគ្មានអ្វីខុសប្រក្រតីទេទេ ។ យើងឆ្ងល់ថា ហេតុអ្វីបានជាវាមិនផ្ទុះ › » ។ រឿងដ៏អស្ចារ្យបានកើតឡើង នៅពេលគ្រួសារអធិស្ឋានរួមគ្នា » (« The Lifeline of Prayer » *Ensign* ខែ ឧសភា ឆ្នាំ ២០០២ ទំព័រ ៦១) ។

សូមសួរសិស្សនូវសំណួរខាងក្រោម ដោយប្រយ័ត្នចំពោះសិស្សដែលមានគ្រួសារមិនអាចអធិស្ឋានជុំគ្នាបាន ៖

- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីជួយគ្រួសាររបស់អ្នកឲ្យមានការអធិស្ឋានជាគ្រួសារជាទៀងទាត់ ហើយមានអត្ថន័យ ?
- តើអ្នកគ្រោងជាក់អទិភាពលើការអធិស្ឋានជាគ្រួសារនៅក្នុងគ្រួសារអនាគតរបស់អ្នកដោយរបៀបណា ?

សូមពន្យល់ថា នៅពេលព្រះអង្គសង្គ្រោះបានត្រឡប់ទៅជាលើកទីពីរដើម្បីបង្រៀនពួកសាសន៍នីហ្វៃ ដូចដែលបានកត់ត្រានៅក្នុង នីហ្វៃទី ៣ ១៩ ទ្រង់បានទូន្មានដល់ពួកសិស្សសាសន៍នីហ្វៃឲ្យអធិស្ឋានម្តងទៀត ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១៩:៩, ១៣ ឮៗ ហើយសូមឲ្យសិស្សផ្សេងទៀតរកមើលអ្វីដែលពួកសាវកបានអធិស្ឋានសុំ ។ សូមសួរថា ៖ តើគោលការណ៍អ្វីខ្លះដែលយើងអាចរៀនពីបទពិសោធន៍របស់ពួកសិស្សសាសន៍នីហ្វៃ ? (រឿងខាងក្រោមគឺជារបៀបមួយដែលសិស្សអាចបង្ហាញគោលការណ៍នេះ ៖ **បំណង និងការអធិស្ឋានដ៏សុចរិតរបស់យើងអាចធ្វើឲ្យយើងសក្តិសមនឹងបំពេញដោយព្រះវិញ្ញាណបរិសុទ្ធ**) ។

បន្ទាប់មក សូមសួរសិស្ស ៖ តើនៅពេលណាខ្លះដែលអ្នកធ្លាប់បានមានបំណងប្រាថ្នាដ៏ខ្លាំង ហើយបានអធិស្ឋានដោយស្មោះត្រង់សម្រាប់ការមានដៃគូជាព្រះវិញ្ញាណបរិសុទ្ធ ? តើអ្នកបានទទួលពរជ័យចំពោះការធ្វើដូច្នោះយ៉ាងដូចម្តេច ?

នីហ្វៃទី ៣ ២០–២២

នៅថ្ងៃចុងក្រោយ ព្រះនឹងចាប់ផ្តើមប្រមូលផ្តុំវង្សអ៊ីស្រាអែល

សូមពន្យល់ថា ក្រោយពីការបង្រៀនដល់សាសន៍នីហ្វៃអំពីការអធិស្ឋាន នោះព្រះអង្គសង្គ្រោះបានចាប់ផ្តើមបង្រៀនពួកគេអំពីការប្រមូលផ្តុំវង្សអ៊ីស្រាអែលនៅថ្ងៃចុងក្រោយ ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២១:៩ ។ សូមឲ្យសិស្សផ្សេងទៀតមើលតាម ដោយរកមើលពាក្យដែលរៀបរាប់ពីកិច្ចការរបស់ព្រះអម្ចាស់ ។ បន្ទាប់មក សូមសួរថា ៖

- តើអ្នកគិតថា « កិច្ចការដ៏ធំ ហើយអស្ចារ្យ » មួយសំដៅទៅលើអ្វី ? (ការស្តារឡើងវិញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដែលរួមមានការលេចចេញមកនៃព្រះគម្ពីរមរមន) ។
- នៅក្នុងគំនិតរបស់អ្នក តើអ្វីជាការណ៍ដ៏ធំ ហើយអស្ចារ្យអំពីការស្តារឡើងវិញនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ?

សូមឲ្យសិស្សរំឮក នីហ្វៃទី ៣ ២១:១០–១១ ហើយគិតអំពីអ្នកដែលព្រះអម្ចាស់កំពុងរៀបរាប់ថាជា « អ្នកបម្រើរបស់យើង » ។ សូមសួរ ៖ តើ៣ក្យ ឬឃ្លាអ្វីដែលជួយអ្នកឲ្យដឹងថា ព្រះអម្ចាស់កំពុងរៀបរាប់ពីព្យាការី យ៉ូសែប ស្ម៊ីធ ? បន្ទាប់មក សូមបង្ហាញរូបភាព យ៉ូសែប ស្ម៊ីធ នៅក្នុងគុកលីបើធី (*Gospel Art Book* លេខ ៥៧) ។

សូមសួរ ៖ តើព្រះបានបង្ហាញតាមរយៈ យ៉ូសែប ស្ម៊ីធថា « ចំណេះដឹងរបស់ទ្រង់គឺអស្ចារ្យជាងកលល្បិចរបស់អារក្ស » ដោយរបៀបណា ?

ជាទីបញ្ចប់ សូមឲ្យសិស្សចែកចាយទីបន្ទាល់របស់ពួកគេអំពីព្យាការី យ៉ូសែប ស្ម៊ីធ និងការស្តារឡើងវិញនៃដំណឹងល្អ ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីរឿងទាំងនេះជាមួយនឹងសិស្សរបស់អ្នក ។

មេរៀនបន្ទាប់ (នីហ្វៃទី ៣ ២៣–៣០)

សូមឲ្យសិស្សស្រមៃថា ព្រះអង្គសង្គ្រោះបានប្រាប់ពួកគេថា ទ្រង់នឹងយល់ព្រមនឹងអ្វីៗទាំងឡាយដែលពួកគេបានប៉ង ។ សូមពន្យល់ថា នៅពេលពួកគេសិក្សា នីហ្វៃទី ៣ ២៣–៣០ នៅសប្តាហ៍ក្រោយ ពួកគេនឹងរៀនអំពីបុរសដប់ពីរនាក់ដែលទទួលបានបទពិសោធន៍នេះ និងអ្វីដែលពួកលោកបាន សុំ ។

នីហ្វៃទី ៣ ជំពូក ២៣

សេចក្តីផ្តើម

ក្រោយពីដកស្រង់ពាក្យរបស់អេសាយហើយ (សូមមើល ៣នីហ្វៃទី ៣ ២២) ព្រះយេស៊ូវគ្រីស្ទបានបញ្ជាពួកសាសន៍នីហ្វៃឲ្យសិក្សាពាក្យរបស់ព្យាការីនេះ ។ ទ្រង់បានមានបន្ទូលថា ពាក្យរបស់អេសាយគឺជាពរជ័យ ដោយសារអេសាយ « បានមានប្រសាសន៍ជាប្រាកដពីគ្រប់ទាំងការណ៍ដែលទាក់ទងនឹងរាស្ត្រយើង គឺជាវង្សអ៊ីស្រាអែល » (នីហ្វៃទី ៣ ២៣:២) ។ ទ្រង់ក៏បានមានព្រះបន្ទូលថា ពាក្យរបស់អេសាយទាំងឡាយត្រូវបាន ឬនឹងត្រូវបានបំពេញ ។ បន្ទាប់មក ព្រះអង្គសង្គ្រោះបានបញ្ជាពួកសាសន៍នីហ្វៃឲ្យសិក្សាពាក្យនៃព្យាការីទាំងឡាយ និងបានណែនាំពួកគេឲ្យបន្ថែមសម្ភារដើម្បីកត់ត្រា ។

យោបល់ទាំងឡាយសម្រាប់ការបង្រៀន

នីហ្វៃទី ៣ ២៣:១–៥

ព្រះយេស៊ូវគ្រីស្ទបញ្ជាប្រជាជនឲ្យសិក្សាពាក្យទាំងឡាយរបស់ពួកព្យាការី

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន៖ ***ពរជ័យពីការសិក្សាព្រះគម្ពីរ*** ។ សូមឲ្យសិស្សគិតពីបទពិសោធន៍របស់ពួកគេក្នុងការសិក្សាព្រះគម្ពីរមរមននៅផ្ទះ និងនៅក្នុងថ្នាក់សិក្ខាសាលាឆ្នាំនេះ ។ សូមឲ្យពួកគេឡើងមកកាន់ក្តារខៀន ហើយសរសេរពាក្យមួយ ឬឃ្លាមួយខ្លីដែលបង្ហាញពីពរជ័យដែលបានមកដល់ជីវិតរបស់ពួកគេ ជាលទ្ធផលនៃការសិក្សាព្រះគម្ពីរ ។ អ្នកអាចសុំឲ្យសិស្សពីរបីនាក់រៀបរាប់លម្អិតបន្ថែមទៀតពីអ្វីដែលពួកគេបានសរសេរ ។ បន្ទាប់មក សូមចង្អុលទៅពរជ័យដែលបានសរសេរនៅលើក្តារខៀន ។

- តើអ្នកគិតថា ហេតុអ្វីបានជាយើងត្រូវបានប្រទានពរឲ្យតាមរបៀបទាំងនេះ នៅពេលយើងអានព្រះគម្ពីរ ?

សូមឲ្យសិស្សរំឭកពីមេរៀនមុនដែលព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទត្រូវបានដកស្រង់ នៅពេលទ្រង់បានបង្រៀនដល់ពួកសាសន៍នីហ្វៃ ។ (ពាក្យរបស់អេសាយ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២៣:១–៣ ឮៗ ។ អ្នកគួរណែនាំឲ្យសិស្សគូសចំណាំពាក្យ និងឃ្លាដែលលេចធ្លោដល់ពួកគេនៅក្នុងខគម្ពីរទាំងនេះ ។ សូមឲ្យពួកគេចែកចាយអ្វីដែលពួកគេរកឃើញ ។

- ហេតុអ្វីបានជាព្រះអម្ចាស់ចង់ឲ្យប្រជាជនសិក្សាពាក្យរបស់អេសាយ ? (សូមមើល នីហ្វៃទី ៣ ២៣:២–៣) ។
- ហេតុអ្វីបានជាវាគឺជាពរជ័យមួយដែលដឹងថា ពាក្យទាំងឡាយរបស់អេសាយនឹងត្រូវបានបំពេញ ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២៣:៤–៥ ឮៗ ។ សូមបង្ហាញថា ក្រោយពីព្រះអង្គសង្គ្រោះបានមានបន្ទូលឲ្យសិក្សាពាក្យរបស់អេសាយហើយ ទ្រង់បានមានបន្ទូលថាឲ្យ « សិក្សាស្រាវជ្រាវពីព្យាការីទាំងឡាយ » ។ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន៖ ***ព្រះអង្គសង្គ្រោះបញ្ជាឲ្យយើងសិក្សាស្រាវជ្រាវដោយឧស្សាហ៍ព្យាយាមទង្វើពាក្យរបស់អេសាយ និងពីព្យាការីផ្សេងទៀត ។***

- យោងតាម នីហ្វៃទី ៣ ២៣:៥ តើយើងត្រូវធ្វើអ្វីដើម្បីត្រូវបានសង្គ្រោះ ? តើពាក្យរបស់ព្យាការីជួយយើងឲ្យធ្វើតាមព្រះបញ្ញត្តិទាំងនេះដោយរបៀបណា ?
- តើការសិក្សាពាក្យរបស់ព្យាការីដោយឧស្សាហ៍ព្យាយាមខុសពីការគ្រាន់តែអានពាក្យរបស់ព្យាការីដោយរបៀបណា ? តើអ្នកគិតថាហេតុអ្វីបានជាវាសំខាន់ដើម្បីសិក្សាពាក្យរបស់អេសាយ និងព្យាការីផ្សេងទៀតដោយឧស្សាហ៍ព្យាយាម ?
- តើរបៀបសិក្សាព្រះគម្ពីរអ្វីខ្លះ ដែលជួយអ្នកឲ្យសិក្សាពាក្យរបស់អេសាយ និងព្យាការីផ្សេងទៀតជាផ្នែកដ៏មានន័យខ្លាំងនៅក្នុងជីវិតរបស់អ្នក ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ មើរិល ជេ ប៊ែតមែន នៃពួកចិតសិបនាក់ ៖

« មានពរជ័យជាក់លាក់ដែលមានជាប់ នៅពេលបុគ្គលម្នាក់សិក្សាស្រាវជ្រាវព្រះគម្ពីរ ។ នៅពេលបុគ្គលម្នាក់សិក្សាព្រះបន្ទូលរបស់ព្រះអម្ចាស់ និងគោរពតាមវា គេនឹងខិតកាន់តែជិតទៅរកព្រះអង្គសង្គ្រោះ ហើយទទួលបានបំណងប្រាថ្នាដ៏ធំជាងមុនមួយដើម្បីរស់នៅដ៏សុចរិត ។ អំណាចដើម្បីប្រឆាំងនឹងការល្បួងកើនឡើង ហើយភាពទន់ខ្សោយខាងវិញ្ញាណនឹងត្រូវយកឈ្នះ ។ របួសខាងវិញ្ញាណនឹងត្រូវបានព្យាបាល » (« Coming unto Christ by Searching the Scriptures » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩២ ទំព័រ ២៨) ។

- តើយើងអាចស្វែងរកពាក្យរបស់ព្យាការីនៅឯណាទៀត ក្រៅពីព្រះគម្ពីរ ?

សូមឲ្យសិស្សឆ្លើយនឹងសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ ។

- តើការផ្លាស់ប្តូរអ្វីខ្លះដែលអ្នកអាចធ្វើដើម្បីសិក្សាពាក្យរបស់ព្យាការីទាំងឡាយដោយឧស្សាហ៍ព្យាយាម ?

សូមឲ្យសិស្សពីរបីនាក់ថ្លែងទីបន្ទាល់អំពីពរជ័យដែលកើតមានពីការសិក្សាស្រាវជ្រាវពាក្យរបស់ព្យាការីទាំងឡាយ ។

នីហ្វៃទី ៣ ២៣:៦–១៤

ព្រះអង្គសង្គ្រោះណែនាំពួកសិស្សរបស់ទ្រង់ឲ្យបន្ថែមហេតុការណ៍ដ៏សំខាន់មួយនៅក្នុងកំណត់ត្រាព្រះគម្ពីររបស់ពួកគេ

សូមឲ្យសិស្សពីរបីនាក់រៀបរាប់ពីចំណាងជើងដំណើររឿងដែលគេចូលចិត្តនៅក្នុងព្រះគម្ពីរមរមន ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ បន្ទាប់មក សូមលុបចម្លើយមួយ ។ សូមឲ្យសិស្សស្រមៃថា មរមន ឬនីហ្វៃ ឬអ្នករក្សាទុកកំណត់ត្រាផ្សេងទៀតបានឆ្ងេរប្រហែសមិនបញ្ចូលដំណើររឿងនោះ ។

- តើមេរៀនដ៏សំខាន់អ្វីខ្លះនឹងមិនត្រូវបានកត់ត្រានៅក្នុងព្រះគម្ពីរមរមន ប្រសិនបើដំណើររឿងនេះមិនត្រូវបានបញ្ចូលនោះ ?

សូមពន្យល់ថា នៅពេលព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកសាសន៍នីហ្វៃ ទ្រង់បានបង្ហាញថា អ្នករក្សាកំណត់ត្រារបស់ពួកគេបានប្រហែសមិនបានបញ្ចូលនូវព្រឹត្តិការណ៍ដ៏សំខាន់មួយដែលត្រូវបានបំពេញតាមការព្យាករណ៍ ។ សូមឲ្យសិស្សបីឬនាក់ប្តូរវេនគ្នាអានឮៗក្នុង នីហ្វៃទី ៣ ២៣:៦–១៣ ។ សូមឲ្យសិស្សផ្សេងទៀតមើលតាម ដោយរកមើលអ្វីដែលពួកសាសន៍នីហ្វៃមិនកត់ត្រានោះ ។

- ពួកសាសន៍នីហ្វៃបានមានកំណត់ត្រាមួយអំពីការព្យាករណ៍របស់លោក សាំយូអែល រួចហើយ (សូមមើល ហេលេមិន ១៤:២៥) ។ តើអ្នកគិតថា ហេតុអ្វីបានជាវាជាការណ៍ដ៏សំខាន់សម្រាប់ពួកគេដើម្បីមានកំណត់ត្រាមួយអំពីការបំពេញនេះ ?

សូមបង្ហាញថា ទោះបីជាយើងមិនត្រូវបានបញ្ជាឲ្យរក្សាកំណត់ត្រាខាងវិញ្ញាណសម្រាប់សាសនាចក្រក្តី យើងត្រូវបានប្រឹក្សាឲ្យរក្សាកំណត់ហេតុផ្ទាល់ខ្លួន ។

- តើការណែនាំរបស់ព្រះអង្គសង្គ្រោះនៅក្នុង នីហ្វៃទី ៣ ២៣:៦–១៣ អាចអនុវត្តចំពោះការខិតខំរបស់យើងដើម្បីរក្សាកំណត់ហេតុផ្ទាល់ខ្លួនដោយរបៀបណា ?

ដើម្បីជួយសិស្សឲ្យឃើញពីរបៀបមួយដែលពួកគេអាចរក្សាកំណត់ហេតុមួយ សូមឲ្យសិស្សម្នាក់អានឮៗនូវបទពិសោធន៍ខាងក្រោមដែលបានចែកចាយដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ៖

« ខ្ញុំបានធ្វើកិច្ចការសាសនាមួយហើយមកដល់ផ្ទះយឺត ។ មេឃងងឹតខ្លាំងណាស់ ។ ឪពុកក្មេករបស់ខ្ញុំ ដែលបានរស់នៅក្បែរយើង បានធ្វើឲ្យខ្ញុំភ្ញាក់នៅពេលខ្ញុំបានដើរឆ្ពោះទៅទ្វារមុខផ្ទះខ្ញុំ ។ គាត់កំពុងលើបំពង់លើស្មារបស់គាត់ដោយដើរយ៉ាងលឿន ក្នុងសំលៀកបំពាក់ធ្វើការរបស់គាត់ ។ ខ្ញុំបានដឹងថា គាត់កំពុងសង់ប្រព័ន្ធបូមទឹកពីស្ទឹងមួយមកដល់ដីរបស់យើង ។

« គាត់បានញញឹម ហើយនិយាយដោយស្រទន់ រួចប្រញាប់ដើរទៅក្នុងទីងងឹតដើម្បីបន្តកិច្ចការរបស់គាត់ ។ ខ្ញុំបានដើរពីរបីជំហានទៅផ្ទះ ដោយគិតអំពីអ្វីដែលគាត់បានកំពុងធ្វើសម្រាប់យើង ហើយនៅពេលខ្ញុំបានដើរទៅដល់មាត់ទ្វារ ខ្ញុំបានឮនៅក្នុងគំនិតរបស់ខ្ញុំ —មិនមែនជាសំឡេងរបស់ខ្ញុំឡើយ— នូវពាក្យទាំងនេះថា ៖ ‹ យើងមិនបានប្រទានដល់អ្នកនូវបទពិសោធន៍ទាំងនេះសម្រាប់ខ្លួនអ្នកនោះទេ ។ សូមសរសេរវាទុក ។ ›

« ខ្ញុំបានដើរទៅក្នុងផ្ទះ ។ ខ្ញុំមិនបានចូលទៅដេកនោះទេ ។ ទោះបីជាខ្ញុំហត់នឿយយ៉ាងណាក្តី ខ្ញុំបានយកសៀវភៅចេញមកសរសេរវា ។ ហើយនៅពេលខ្ញុំបានធ្វើវា ខ្ញុំបានយល់ពីសារលិខិតដែលខ្ញុំបានឮនៅក្នុងគំនិតរបស់ខ្ញុំ ។ ខ្ញុំត្រូវកត់វាទុកឲ្យកូនចៅរបស់ខ្ញុំដើម្បីអាននៅថ្ងៃណាមួយនាពេលអនាគត អំពីរបៀបដែលខ្ញុំបានឃើញព្រះហស្តរបស់ព្រះប្រទានពរដល់គ្រួសាររបស់យើង ។ លោកតាមិនចាំបាច់ធ្វើអ្វីដែលគាត់បានធ្វើសម្រាប់យើងនោះទេ ។ គាត់អាចឲ្យនរណាម្នាក់ទៀតធ្វើវា ឬមិនចាំបាច់ធ្វើវាឡើយ ។ ប៉ុន្តែគាត់បានបម្រើដល់យើង ដែលជាគ្រួសាររបស់គាត់ តាមរបៀបដែលសិស្សនៃសេចក្តីសញ្ញារបស់ព្រះយេស៊ូវគ្រីស្ទតែងតែធ្វើ ។ ខ្ញុំបានដឹងថា វាគឺជាការពិត ។ ដូច្នេះហើយទើបខ្ញុំបានសរសេរវាទុក ដើម្បីឲ្យកូនចៅរបស់ខ្ញុំអាចចងចាំ នៅពេលពួកគេត្រូវការវានៅថ្ងៃណាមួយ ។

« ខ្ញុំបានសរសេររឿងពីរបីបន្ទាត់ជារៀងរាល់ថ្ងៃអស់រយៈពេលជាច្រើនឆ្នាំ ។ ខ្ញុំមិនដែលខកខានមួយថ្ងៃណាឡើយ មិនថាខ្ញុំនឿយហត់ប៉ុណ្ណា ឬ មិនថាព្រលឹមយ៉ាងណាដែលខ្ញុំត្រូវចាប់ផ្តើមថ្ងៃថ្មីនោះទេ ។ មុនពេលខ្ញុំចាប់សរសេរ ខ្ញុំបានសញ្ជឹងគិតពីសំណួរនេះ ៖ ‹ តើខ្ញុំបានឃើញព្រះហស្តរបស់ព្រះកំពុងឈោងមកប៉ះយើង ឬកូនចៅរបស់យើង ឬគ្រួសាររបស់យើងនៅថ្ងៃនេះដោយរបៀបណា ? › » (« O Remember, Remember » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ៦៦–៦៧) ។

- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីសរសេរអំពីបទពិសោធន៍ដែលពង្រឹងដល់យើងខាងវិញ្ញាណ ?
- តើយើងអាចទទួលបានប្រយោជន៍ពីការធ្វើតាមគំរូរបស់ប្រធាន អាវរិង ដោយរបៀបណា ? តើកំណត់ត្រារបស់យើងអាចជួយអ្នកដទៃដោយរបៀបណា ?

សូមពន្យល់ថា ប្រធាន អាវរិង បានប្រាប់អំពីពរជ័យដែលលោកបានទទួល ដោយសារលោកបានរក្សាកំណត់ត្រាប្រចាំថ្ងៃពីពរជ័យរបស់ព្រះចំពោះគ្រួសារលោក ។ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមឲ្យឮៗ ។ (អ្នកអាចចែកចាយផ្នែកនៃសេចក្តីថ្លែងការណ៍នេះនៅក្នុងមេរៀនទី ១១៧ ។ សិស្សអាចទទួលបានប្រយោជន៍ពីការស្តាប់វាម្តងទៀត) ។

« នៅពេលខ្ញុំបន្តធ្វើវា នោះអ្វីមួយបានចាប់ផ្តើមកើតឡើង ។ នៅពេលខ្ញុំគិតពីថ្ងៃនោះ ខ្ញុំបានឃើញពីភស្តុតាងនៃអ្វីដែលព្រះបានធ្វើសម្រាប់យើងម្នាក់ៗដែលខ្ញុំមិនបានកត់ចំណាំនៅក្នុងពេលដ៏រវល់នាថ្ងៃនេះ ។ នៅពេលវាបានកើតឡើង ហើយវាបានកើតឡើងជាញឹកញាប់ ខ្ញុំបានយល់ថា ការព្យាយាមចងចាំបានអនុញ្ញាតឲ្យព្រះបង្ហាញដល់ខ្ញុំនូវអ្វីដែលទ្រង់បានធ្វើ ។

« វាលើសពីអំណរគុណទៅទៀតដែលបានចាប់ផ្តើមដុះដាលឡើងនៅក្នុងចិត្តរបស់ខ្ញុំ ។ ទីបន្ទាល់បានរីកចម្រើនឡើង ។ ខ្ញុំកាន់តែមានការជឿជាក់ថា ព្រះវរបិតាសួគ៌របស់យើងឮ ហើយឆ្លើយនូវការអធិស្ឋានទាំងឡាយ ។ ខ្ញុំមានអារម្មណ៍នូវការដឹងគុណបន្ថែមទៀតចំពោះការបន្ទន់ចិត្ត និងការបន្សុទ្ធដែលកើតមាន ដោយសារតែដង្វាយធួនរបស់ព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ។ ហើយខ្ញុំកាន់តែមានទំនុកចិត្តជាងមុនថា ព្រះវិញ្ញាណបរិសុទ្ធអាចធ្វើឲ្យយើងចងចាំអ្វីៗទាំងអស់— ទោះបីជារឿងដែលយើងមិនចាប់អារម្មណ៍ ឬយកចិត្តទុកដាក់លើ នៅពេលវាបានកើតឡើងក្តី » (« O Remember, Remember » ទំព័រ ៦៧) ។

- តើគោលការណ៍អ្វីដែលយើងអាចរៀនពីដំណើររឿងនៅក្នុង នីហ្វៃទី ៣២៣ និងពីបទពិសោធន៍របស់ប្រធាន អាវរិង ? (សិស្សអាចឆ្លើយនឹងសំណួរនេះតាមរបៀបខុសៗគ្នា ។ ចម្លើយរបស់ពួកគេគួរបង្ហាញពីសេចក្តីពិតដូចតទៅនេះ ៖ **នៅពេលយើងកត់ត្រាពីបទពិសោធន៍ខាងវិញ្ញាណ នោះខ្លួនយើងផ្ទាល់ និងគ្រួសាររបស់យើងនឹងត្រូវបានប្រទានពរឲ្យ**) ។

សិស្សខ្លះអាចមានអារម្មណ៍ថា ពួកគេមិនធ្លាប់មានអ្វីមួយដែលមានតម្លៃសមនឹងឲ្យពួកគេកត់ត្រានោះឡើយ ។ ដើម្បីជួយដល់ពួកគេ អ្នកអាចសុំឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ចន អេច ព្រូបេក នៃក្រុមចិតសិបនាក់ ៖

« មនុស្សខ្លះនិយាយថា ‹ ខ្ញុំគ្មានអ្វីដែលត្រូវកត់ត្រានោះទេ ។ គ្មានរឿងខាងវិញ្ញាណណាមួយកើតឡើងចំពោះខ្ញុំសោះ › ។ ខ្ញុំនិយាយថា ‹ សូមចាប់ផ្តើមកត់ត្រា ហើយរឿងខាងវិញ្ញាណនឹងកើតឡើង ។ វានៅទីនោះគ្រប់ពេល ប៉ុន្តែយើងនឹងដឹងពីវាកាន់តែខ្លាំង នៅពេលយើងសរសេរវា › » (« Writing Your Personal and Family History » *Ensign* ខែ ឧសភា ឆ្នាំ ១៩៨០ ទំព័រ ៤៨) ។

សូមតាមដានគោលដៅ និងឧបសគ្គទាំងឡាយ

ក្រោយពីអ្នកសុំឲ្យសិស្សតាំងចិត្តធ្វើអ្វីមួយជាក់លាក់ហើយ ដូចជាសរសេរនៅក្នុងសៀវភៅកំណត់ហេតុ គិតពីរបៀបដើម្បីតាមដាន ចងចាំដល់ការប្តេជ្ញាចិត្តដែលពួកគេបានធ្វើ ។ សូមផ្តល់ឱកាសដល់ពួកគេឲ្យចែកចាយបទពិសោធន៍របស់ពួកគេ នៅពេលពួកគេអនុវត្តសេចក្តីពិតដែលពួកគេរៀននៅក្នុងថ្នាក់ ។ តាមរយៈការចែកចាយបទពិសោធន៍របស់គេ ពួកគេអាចបំផុសដល់គ្នាទៅវិញទៅមក ឲ្យរស់នៅតាមជំណឹងល្អ ។ អ្នកអាចគិតពីការផ្តល់ឱកាសបែបនោះនៅពេលចាប់ផ្តើមមេរៀនមួយ ។ មិនចាំបាច់ឲ្យសិស្សគ្រប់គ្នាចែកចាយនោះទេ ។

សូមឲ្យសិស្ស សួរខ្លួនឯងថាតើពួកគេធ្លាប់ធ្វេសប្រហែសមិនបានសរសេរអំពីបទពិសោធន៍ដែលបានពង្រឹងដល់ពួកគេខាងវិញ្ញាណដែរទេ ។ សូមលើកទឹកចិត្តពួកគេឲ្យសរសេរអំពីបទពិសោធន៍ទាំងនេះ ហើយបន្តកត់ត្រាបទពិសោធន៍ផ្សេងទៀតពេញមួយជីវិតរបស់គេ ។ អ្នកអាចណែនាំថា ពួកគេគួរធ្វើតាមគំរូរបស់ប្រធាន អាវរិង ដោយសរសេរពីអ្វីមួយជារៀងរាល់ថ្ងៃ ។

ការរំឭកចំណេះចំណានខគម្ពីរ

ការរៀនពីរបៀបដើម្បីដោះស្រាយបញ្ហាតាមរយៈការប្រើព្រះគម្ពីរអាចជួយសិស្សពេញមួយជីវិតរបស់ពួកគេ ។ សូមឲ្យសិស្សម្នាក់ៗនូវក្រដាសតូចមួយ ។ សូមឲ្យពួកគេសរសេរអំពីសំណួរមួយដែលពួកគេមាន ឬឧបសគ្គមួយដែលពួកគេជួប ។ សូមពន្យល់ថា អ្នកនឹងប្រមូលក្រដាស ហើយអានវាខ្លះៗដល់សិស្សទាំងអស់ ។ សូមណែនាំសិស្សកុំឲ្យដាក់ឈ្មោះនៅលើក្រដាស ហើយសូមរំឭកពួកគេកុំឲ្យសរសេររឿងលម្អិតផ្ទាល់ខ្លួន ឬមិនសមរម្យដើម្បីពិភាក្សានៅក្នុងថ្នាក់ ។ (ក្រោយពីប្រមូលក្រដាសហើយ អ្នកអាចមើលវាដោយសង្ខេបដើម្បីធានាថា ពួកគេសរសេរអ្វីសមរម្យ និងមិនផ្ទាល់ខ្លួនពេក) ។ សូមអានសំណួរ ឬឧបសគ្គមួយដល់សិស្ស ហើយសូមមើលថាសិស្សអាចប្រើវគ្គចំណេះចំណានខគម្ពីរដើម្បីជួយដោះស្រាយនឹងសំណួរ ឬឧបសគ្គនេះទេ ។

សូមពន្យល់ថា ព្រះអង្គសង្គ្រោះបានបញ្ជាយើងឲ្យបង្រៀនដល់អ្នកដទៃនូវអ្វីដែលទ្រង់បានបង្រៀនដល់យើង (សូមមើល នីហ្វៃទី ៣២៣:១៨) ។ ដើម្បីជួយរៀបចំសិស្សឲ្យកាន់តាមព្រះបញ្ញត្តិទាំងនេះ សូមលើកទឹកចិត្តពួកគេឲ្យអនុវត្តជំនាញបង្រៀនដូចជាការពន្យល់គោលលទ្ធិ ឬគោលការណ៍នានា ការចែកចាយបទពិសោធន៍ និងការថ្លែងទីបន្ទាល់នៅពេលពួកគេប្រើវគ្គចំណេះចំណានខគម្ពីរដើម្បីដោះស្រាយបញ្ហា ។ អ្នកគួរទុកសំណួរ ឬឧបសគ្គផ្សេងទៀតដែលសិស្សបានសរសេរ ហើយពិភាក្សាវិតាមរបៀបដូចគ្នានៅថ្ងៃណាដែលពួកគេមានពេលបន្ថែម ។

កំណត់ចំណាំ ៖ ប្រសែងមេរៀននេះអាចនឹងមានពេលសម្រាប់ការរំឭកចំណេះចំណានខគម្ពីរ ។ អ្នកអាចដឹកនាំសកម្មភាពនេះនៅពេលចាប់ផ្តើមថ្នាក់ នៅពេលសម្រាកវាងវគ្គនៃមេរៀននេះ ឬនៅចុងម៉ោង ។ សូមរក្សាសកម្មភាពនេះឲ្យខ្លីដើម្បីឲ្យមានពេលសម្រាប់មេរៀន ។ សម្រាប់សកម្មភាពរំឭកផ្សេងទៀត សូមមើលឧបសម្ព័ន្ធនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។

មេរៀនទី ១៣២

នីហ្វៃទី ៣ ២៤–២៦

សេចក្តីផ្តើម

ព្រះយេស៊ូវគ្រីស្ទបានបំពេញព្រះបញ្ញត្តិមួយមកពីព្រះវរបិតាស្ទត់ដើម្បីចែកចាយជាមួយនឹងពួកសាសន៍នីហ្វៃពីការព្យាករណ៍ខ្លះរបស់ព្យាការីម៉ាឡាគី (សូមមើល នីហ្វៃទី ៣២៦:២) ។ ការព្យាករណ៍ទាំងនេះបានបង្រៀនថា សមាជិកនៃវង្សអ៊ីស្រាអែលត្រូវតែប្រែចិត្ត ហើយត្រឡប់មករកព្រះអម្ចាស់ដើម្បីរៀបចំសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។

ព្រះយេស៊ូវគ្រីស្ទក៏បានដាស់តឿនដល់ពួកសាសន៍នីហ្វៃអំពី « ការណ៍ទាំងអស់ តាំងពីដំបូងរហូតដល់ពេលដែលទ្រង់នឹងយាងមកក្នុងសិរីល្អរបស់ទ្រង់ » (នីហ្វៃទី ៣ ២៦:៣) ។ មរមនបានបង្រៀនថា អ្នកទាំងឡាយណាដែលជឿលើព្រះគម្ពីរមរមននឹងមានការណ៍ដែលធំលើសលប់ទៀតនឹងត្រូវបានសម្តែងដល់ពួកគេ (សូមមើល នីហ្វៃទី ៣ ២៦:៩) ។

យោបល់ទាំងឡាយសម្រាប់ការបង្រៀន

នីហ្វៃទី ៣ ២៤:១–៦

ព្រះយេស៊ូវគ្រីស្ទដកស្រង់ការព្យាករណ៍របស់ម៉ាឡាគីទាក់ទងនឹងការយាងមកជាលើកទីពីរ

សូមចាប់ផ្តើមដោយការលើកឈើគូសមួយ និងសាប៊ូមួយដុំ (ឬ សូមគូសនៅលើក្តារខៀនន្ទវរូបភាពភ្លើង ឬសាប៊ូ) ។ សូមសួរសិស្សថា តើភ្លើង និងសាប៊ូមានអ្វីដូចគ្នា ។ (ទាំងសាប៊ូ និងភ្លើងអាចត្រូវប្រើដើម្បីសម្អាត ឬបន្សុទ្ធអ្វីមួយ) ។

សូមពន្យល់ថា ព្រះយេស៊ូវគ្រីស្ទបានបំពេញតាមព្រះបញ្ញត្តិមួយមកពីព្រះវរបិតា (សូមមើល នីហ្វៃទី ៣ ២៦:២) ដើម្បីឲ្យសាសន៍នីហ្វៃនូវការព្យាករណ៍ខ្លះពីម៉ាឡាគី ជាព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់ ដែលបានរស់នៅក្នុងដែនដីដ៏បរិសុទ្ធប្រហែល ១៧០ ឆ្នាំ ក្រោយពីលីហៃ និងគ្រួសាររបស់លោកបានចាកចេញពីទីក្រុងយេរូសាឡិម ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២៤:១–៣ ដោយស្ងៀមស្ងាត់ ដោយរកមើលនរណាដែលម៉ាឡាគីបានប្រៀបធៀបទៅនឹង « ភ្លើងរបស់ជាងសំរង » និង « ក្បុងរបស់ជាងប្រមោក » ។

- តើនរណាទៅដែលត្រូវបានប្រៀបធៀបទៅនឹងភ្លើងរបស់ជាងសំរង និងក្បុងរបស់ជាងប្រមោក ? (ព្រះយេស៊ូវគ្រីស្ទ) ។
- តើហេតុការណ៍អ្វីត្រូវបានរៀបរាប់នៅក្នុងខគម្ពីរទាំងនេះ ? (« ថ្ងៃនៃការយាងមករបស់ទ្រង់ » ។ និយាយម្យ៉ាងទៀតថា ការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ ។ ដើម្បីជួយសិស្សឲ្យឆ្លើយនឹងសំណួរនេះ អ្នកគូរណែនាំឲ្យពួកគេគូរអានក្បាលជំពូកសង្ខេបត្រួស ៗ ឬលេខយោង) ។
- តើការប្រៀបធៀបព្រះយេស៊ូវគ្រីស្ទទៅនឹងភ្លើង និងក្បុងបានប្រាប់ថានឹងមានអ្វីខ្លះកើតឡើងនៅពេលនៃការយាងមកជាលើកទីពីររបស់ទ្រង់ ? (សិស្សអាចប្រើពាក្យខុស ៗគ្នាប៉ុន្តែពួកគេគូររកឃើញនូវសេចក្តីពិតដូចតទៅនេះ ៖ **នៅពេលនៃការយាងមកជាលើកទីពីរ ព្រះយេស៊ូវគ្រីស្ទនឹងបន្សុទ្ធពិភពលោក ។** អ្នកអាចសុំឲ្យសិស្សសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់គេក្បែរ នីហ្វៃទី ៣ ២៤:២–៣) ។

សូមពន្យល់ថា ជាងសំរងប្រើភ្លើងដើម្បីកំដៅដែក ដូចជាប្រាក់ ឬមាសរហូតដល់វារលាយ ។ ដំណើរការដុតធ្វើឲ្យស្ទឹម ឬអ្វីមិនសុទ្ធលេចឡើងមកលើផ្ទៃរាវនៃលោហធាតុ ដែលជាងសំរងអាចយកវាចេញ ហេតុដូច្នេះហើយអាចយកលោហធាតុចេញពីភាពមិនសុទ្ធរបស់វា ។ ជាងប្រមោកគឺជាអ្នកដែលសម្អាត ឬធ្វើឲ្យក្រណាត់ស្អាតដោយប្រើសាប៊ូ ។ អ្នកក៏អាចពន្យល់ថា « កូនប្រុសរបស់លេវី » គឺជាអ្នកកាន់បព្វជិតភាពនៅក្នុងប្រទេសអ៊ីស្រាអែលពីបុរាណ ។ សព្វថ្ងៃនេះ ឃ្លានេះអាចសំដៅលើអ្នកកាន់បព្វជិតភាពនាសម័យទំនើប (សូមមើល គ. និង ស. ៨៤:៣៣–៣៤) ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២៤:៥–៦ ឲ្យ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្នកដែលនឹងវិនាស ឬបំផ្លាញនៅការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ និងអ្នកដែលនឹងមិនត្រូវវិនាស ។ (អ្នកអាចពន្យល់ថាឃ្លា « កូនប្រុសនៃយ៉ាកុប » សំដៅលើរាស្ត្រនៃសេចក្តីសញ្ញារបស់ព្រះអម្ចាស់នៅក្នុងវង្សអ៊ីស្រាអែល) ។

- យោងតាម នីហ្វៃទី ៣ ២៤:៥ តើព្រះយេស៊ូវគ្រីស្ទនឹងធ្វើអ្វីនៅការយាងមកជាលើកទីពីររបស់ទ្រង់ ? (ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាក្តី ក៏ពួកគេគូររកឃើញនូវសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះយេស៊ូវគ្រីស្ទនឹងបំផ្លាញពួកទុច្ចរិតនៅពេលនៃការយាងមកជាលើកទីពីររបស់ទ្រង់**) ។

នីហ្វៃទី ៣ ២៤:៧–១៨

ព្រះយេស៊ូវគ្រីស្ទដកស្រង់ការបង្រៀនរបស់ម៉ាឡាគីទាក់ទងនឹងរបៀបដែលវង្សអ៊ីស្រាអែលអាចត្រឡប់មកកាន់ព្រះអម្ចាស់វិញ

សូមឲ្យសិស្សស្រមៃថា ពួកគេមានមិត្ត ឬសមាជិកគ្រួសារដ៏ជិតស្និទ្ធម្នាក់ដែលកំពុងខិតខំទទួលអារម្មណ៍ពីសេចក្តីស្រឡាញ់និងព្រះចេស្តារបស់ព្រះអម្ចាស់ ហើយបន្តមានទីបន្ទាល់អំពីដំណឹងល្អមួយ ។

- តើអ្នកនឹងធ្វើអ្វីខ្លះដើម្បីជួយដល់បុគ្គលនេះ ?

សម្រេចចិត្តអំពីអ្វីដែលត្រូវបង្រៀន

មេរៀននេះរួមមានសម្ភារច្រើនជាងអ្វីដែលអ្នកនឹងមានពេលបង្រៀន ។ សូមគិតប្រកបដោយការអធិស្ឋានអំពីគោលលទ្ធិគោលការណ៍ និងគំនិតបង្រៀនមួយណាដែលនឹងមានប្រយោជន៍បំផុតដល់សិស្សរបស់អ្នក ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២៤:៧ ដោយស្ងៀមស្ងាត់ ហើយសុំឲ្យពួកគេរកមើលការណែនាំរបស់ព្រះអម្ចាស់ចំពោះអស់អ្នកណាដែលបានចាប់ផ្តើមដកថយពីទ្រង់ និងពីការកាន់តាមសេចក្តីសញ្ញារបស់គេជាមួយនឹងទ្រង់ ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដែលប្រជាជន « បានបោះបង់ចោល » ពិធីបរិសុទ្ធរបស់ព្រះអម្ចាស់ ? (ពួកគេលែងកាន់តាមសេចក្តីសញ្ញា និងពិធីបរិសុទ្ធនៃដំណឹងល្អទៀត) ។
- តើសេចក្តីសន្យាអ្វីខ្លះដែលព្រះអម្ចាស់បានប្រទានដល់អស់អ្នកណាដែលមិនកាន់តាមសេចក្តីសញ្ញារបស់គេ ? (« វិលមកឯយើងវិញចុះ ហើយយើងនឹងវិលទៅអ្នក ») ។
- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « វិល » ទៅរកព្រះអម្ចាស់វិញ ? តើអ្នកគិតថា វាមានន័យយ៉ាងណាដែលព្រះអម្ចាស់នឹង « វិលទៅ » អ្នកដែលវិលមករកទ្រង់នោះ ?

សូមសរសេរគោលការណ៍ដូចតទៅនេះនៅលើក្តារខៀន ៖ ***ប្រសិនបើយើងវិលទៅរកព្រះអម្ចាស់ ទ្រង់នឹងវិលមករកយើង ។***

- តើគោលការណ៍នេះបង្រៀនអ្នកអ្វីខ្លះអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ?

នៅលើក្តារខៀន សូមសរសេរ *វិលទៅព្រះអម្ចាស់ ។* សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២៤:៨–១២ ដោយស្ងៀមស្ងាត់ ដោយរកមើលរបៀបមួយដែលព្រះអម្ចាស់បានបង្ហាញប្រជាជនថាពួកគេអាចវិលទៅរកទ្រង់វិញ ។ នៅពេលសិស្សឆ្លើយ សូមសរសេរ *បង់ដង្វាយមួយភាគដប់ និងដង្វាយផ្សេងទៀត* នៅក្រោម *វិលទៅរកព្រះអម្ចាស់ ។*

- តើឆន្ទៈដើម្បីបង់ដង្វាយមួយភាគក្នុងដប់ជាការបង្ហាញថា មនុស្សម្នាក់បានដាក់សេចក្តីស្រឡាញ់ និងការជ្នាក់ថ្នមរបស់គេលើព្រះអម្ចាស់ដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ៖

« យើង *អាច* បង់ដង្វាយមួយភាគក្នុងដប់របស់យើង ។ នេះមិនមែនជាបញ្ហាច្រើនលើប្រាក់កាស ដូចដែលវាជាបញ្ហានៃសេចក្តីជំនឿនោះឡើយ » (« Let Us Move This Work Forward » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៨៥ ទំព័រ ៨៥) ។

- តើឆន្ទៈរបស់យើងក្នុងការបង់ដង្វាយមួយភាគក្នុងដប់ និងដង្វាយផ្សេងទៀតជាការបង្ហាញមួយនៃសេចក្តីជំនឿរបស់យើងទៅលើព្រះអម្ចាស់ដោយរបៀបណា ?

សូមឲ្យសិស្សមានពេលរំឭក នីហ្វៃទី ៣ ២៤:១០–១២ ដោយស្ងៀមស្ងាត់ ។ សូមឲ្យពួកគេរកមើលសេចក្តីសន្យាដែលព្រះអម្ចាស់បានធ្វើដល់អស់អ្នកណាដែលបង់ដង្វាយមួយភាគក្នុងដប់ពេញលេញ និងដោយស្មោះត្រង់ ។

- តើអ្នកត្រូវបានប្រទានពរជាលទ្ធផលនៃការបង់ដង្វាយមួយភាគក្នុងដប់យ៉ាងដូចម្តេច ? តើឧទាហរណ៍ទាំងនេះនៃ « បង្ហូចស្ថានសួគ៌ » ត្រូវបានបើកដល់អ្នកតាមរបៀបណា ?

សូមសង្កេប នីហ្វៃទី ៣ ២៤:១៣–១៨ ដោយពន្យល់ថា នៅក្នុងខគម្ពីរទាំងនេះព្រះអម្ចាស់បានបង្ហាញថា មានអ្នកខ្លះនៅក្នុងប្រទេសអឺស្រាអែលពីបុរាណបានសួរអំពីតម្រូវការដើម្បីកាន់តាមពិធីបរិសុទ្ធនៃដំណឹងល្អ ។ ពួកគេបានរអ៊ូរទាំថា ពួកមានអំណួត និងពួកទុច្ចរិតហាក់ដូចជាវិកចម្រើន ទោះបីជាពួកគេធ្វើមិនសុចរិតក្តី ។ នៅក្នុង នីហ្វៃទី ៣ ២៤:១៦ ព្រះអម្ចាស់បានឆ្លើយតបថា « សៀវភៅរំឭក » បានកត់ត្រាពីឈ្មោះនៃអ្នកស្មោះត្រង់ដែលនឹងត្រូវបានកត់ត្រា (សូមមើល គ. និង ស. ៨៥:៧–៩, ១២៨:៦–៧, ម៉ូសេ ៦:៥–៨) ។ បន្ទាប់មក ព្រះអម្ចាស់បានបង្ហាញថា នៅពេលទ្រង់យាងមកម្តងទៀត ទ្រង់នឹងរក្សាទុកពួកអ្នកជឿ ហើយទុកពួកគេជាទ្រព្យមួយសម្រាប់អង្គទ្រង់ ឬ « ប្រណិតគ្រឿងអលង្ការ [របស់ទ្រង់] » ។

- តើវាជាពរជ័យមួយដោយរបៀបណា ពេលដែលដឹងថា ព្រះអម្ចាស់នឹងរក្សាពួកអ្នកស្មោះត្រង់ ហើយធ្វើឲ្យពួកគេជាទ្រព្យរបស់ទ្រង់នោះ ?
- នៅក្នុង នីហ្វៃទី ៣ ២៤:១៦ តើឃ្លាមួយណារៀបរាប់ពីអ្នកដែលព្រះអម្ចាស់នឹងរក្សាជាទ្រព្យរបស់ទ្រង់ ? (« ពួកគេដែលកោតខ្លាចដល់ទ្រង់ » និង ពួកអ្នក « ដែលនឹកដល់ព្រះនាមទ្រង់ ») ។

សូមសរសេរ *កោតខ្លាចដល់ទ្រង់* និង *នឹកដល់ព្រះនាមរបស់ព្រះអម្ចាស់* នៅក្រោម *វិលទៅរកព្រះអម្ចាស់ ។* (អ្នកអាចពន្យល់ថា នៅក្នុងបរិបទនេះពាក្យ *កោតខ្លាច* មានន័យថាការគោរព ឬការស្តាប់តាម) ។ សូមឲ្យសិស្សឆ្លើយនឹងសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ ៖

- សូមគិតពីរបៀបដែលអ្នកកំពុងធ្វើនៅក្នុងផ្នែកនៃការបង់ដង្វាយមួយភាគក្នុងដប់ និងដង្វាយផ្សេងទៀត និងការនឹកដល់ព្រះគ្រីស្ទជាញឹកញាប់ ។ តើអ្នកអាច « វិល » ទៅរកទ្រង់ ឬពង្រឹងផ្នែកនេះតាមរបៀបណាខ្លះ ?

នីហ្វៃទី ៣ ជំពូក ២៥

ព្រះយេស៊ូវគ្រីស្ទដកស្រង់ការព្យាករណ៍របស់ម៉ាឡាគីថា អេលីយ៉ានឹងត្រឡប់មកវិញពីមុនការយាងមកជាលើកទីពីរ

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២៥:១–៣ ឮៗ ។ សូមឲ្យសិស្សមើលតាម ដោយរកមើលមូលហេតុមួយដែលការយាងមកជាលើកទីពីរនឹងក្លាយជាពរជ័យមួយចំពោះអស់ទាំងឡាយណាដែលស្មោះត្រង់នឹងព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ អ្នកអាចពន្យល់ថានៅក្នុង នីហ្វៃទី ៣ ២៥:១ ពាក្យ *ឫស* ហាក់សំដៅលើបុព្វបុរស ហើយពាក្យ *មែក* សំដៅលើកូនចៅ ។ ហេតុដូច្នេះហើយ នៅក្នុងជីវិតក្រោយ ពួកទុច្ចរិតនឹងមិនរីករាយនឹងពរជ័យនៃការត្រូវបានផ្សារភ្ជាប់ទៅនឹងបុព្វបុរស និងកូនចៅរបស់គេទេ ។ នៅក្នុង នីហ្វៃទី ៣ ២៥:២ ឃ្លា « កូនគោនៅក្នុងក្រោល » សំដៅលើកូនគោដែលមានសុវត្ថិភាព មានចំណីគ្រប់គ្រាន់ និងត្រូវបានគេយកចិត្តទុកដាក់ ។ ព្រះអម្ចាស់សន្យាថា ទ្រង់នឹងការពារ និងថែរក្សាដល់អ្នកដែល « កោតខ្លាចដល់ព្រះនាមទ្រង់ » ដូចគ្នា ។

សូមពន្យល់ថា ម៉ាឡាគីបានព្យាករណ៍អំពីហេតុការណ៍មួយដែលនឹងកើតឡើងមុនពេលនៃការយាងមកជាលើកទីពីរ ហើយដែលទាក់ទងនឹងព្យាការីក្នុងព្រះគម្ពីរសញ្ញាចាស់គឺ អេលីយ៉ា ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២៥:៥–៦ ឮៗ ហើយសូមឲ្យសិស្សផ្សេងទៀតរកមើលអ្វីដែលលោកអេលីយ៉ា បានធ្វើដើម្បីជួយរៀបចំពិភពលោកសម្រាប់ការយាងមករបស់ព្រះអម្ចាស់ ។

សូមសួរសិស្សថា តើពួកគេដឹងអ្វីខ្លះអំពីការវិលមកកាន់ផែនដីវិញរបស់អេលីយ៉ា ជាផ្នែកនៃការស្តារឡើងវិញនៃដំណឹងល្អ ។ អ្នកអាចបន្ថែមចម្លើយរបស់គេដោយពន្យល់ថា នៅថ្ងៃទី ៣ ខែ មេសា ឆ្នាំ ១៨៣៦ លោកអេលីយ៉ាបានលេចមកឯ យ៉ូសែប ស៊្មីធ និងអូលីវើរ ខៅឌើរី នៅក្នុងព្រះវិហារបរិសុទ្ធខឺតឡង់ ដែលទើបតែឧទ្ទិសថ្មីៗ (សូមមើល គ. និង ស. ១១០:១៣–១៦) ។ នៅពេលនោះ លោកអេលីយ៉ាបានស្តារឡើងវិញនូវកូនសោនៃបព្វជិតភាពទាំងឡាយដែលចាំបាច់ដើម្បីផ្សារភ្ជាប់គ្រួសារដ៏អស់កល្បនៅក្នុងព្រះវិហារបរិសុទ្ធរបស់ព្រះអម្ចាស់ ។ តាមរយៈការស្រាវជ្រាវពង្សប្រវត្តិ យើងរកឃើញសមាជិកគ្រួសារសម្រាប់ពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធអាចត្រូវបានធ្វើឡើង ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដែលអេលីយ៉ានឹង « បង្វែរចិត្តពួកឪពុកមកឯកូន និងចិត្តកូនមកឯឪពុក » ?
- តើវាជាពរជ័យសម្រាប់អ្នកដោយរបៀបណា ដើម្បីដឹងថា អ្នករអាចត្រូវបានផ្សារភ្ជាប់នឹងគ្រួសាររបស់អ្នកដ៏អស់កល្បជានិច្ចនោះ ?

សូមថ្លែងទីបន្ទាល់ថា **នៅពេលចិត្តរបស់យើងបែរទៅរកឪពុករបស់យើង តាមរយៈពង្សប្រវត្តិ និងកិច្ចការព្រះវិហារបរិសុទ្ធ យើងកំពុងជួយរៀបចំផែនដីសម្រាប់ការយាងមកជាលើកទីពីរនៃព្រះយេស៊ូវគ្រីស្ទ ។**

នីហ្វៃទី ៣ ២៦:១–១២

ព្រះយេស៊ូវគ្រីស្ទបរិយាយអំពីព្រះគម្ពីរ ហើយលោកមរមនបង្រៀនពីអ្វីដែលត្រូវធ្វើ ដើម្បីទទួលបានអ្វីដ៏អស្ចារ្យដែលព្រះអង្គសង្គ្រោះបានបង្ហាញ

សូមសង្ខេប នីហ្វៃទី ៣ ២៦:១–៥ ដោយការពន្យល់ថា ក្រោយពីព្រះអង្គសង្គ្រោះបានចែកចាយការព្យាករណ៍របស់ម៉ាឡាគីហើយទ្រង់បានបង្រៀនប្រជាជនពី « ការណ៍ទាំងអស់ដែលកើតឡើងនៅលើផ្ទៃផែនដីនេះ » ពីការបង្កើតទៅដល់ការជំនុំជំរះចុងក្រោយ (នីហ្វៃទី ៣ ២៦:៣–៤) ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២៦:៦–៨ ឮៗ ហើយសូមឲ្យសិស្សផ្សេងទៀតរកមើលពីអ្វីដែលព្រះយេស៊ូវគ្រីស្ទបានបង្រៀន ដែលត្រូវបានកត់ត្រានៅក្នុងព្រះគម្ពីរមរមន ។ បន្ទាប់មក សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២៦:៩–១១ ដោយស្ងៀមស្ងាត់ ដោយរកមើលមូលហេតុដែល មរមន មិនបានបញ្ចូលនៅក្នុងការសង្ខេបរបស់លោកពីអ្វីៗដែលព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកសាសន៍នីហ្វៃ ។ សូមបញ្ជាក់ថាពាក្យ *រឿ* នៅក្នុងខគម្ពីរទាំងនេះបង្ហាញន័យថា យើងត្រូវធ្វើសកម្មភាពលើគោលលទ្ធិ និងគោលការណ៍នានាដែលព្រះបានបង្ហាញ ហើយមិនគ្រាន់តែសង្ឃឹមថា វាពិតនោះទេ ។

- យោងតាម នីហ្វៃទី ៣ ២៦:៩ តើព្រះអម្ចាស់សន្យាអ្វីខ្លះដល់អ្នកណាដែលជឿ ហើយធ្វើសកម្មភាពលើអ្វីដែលទ្រង់បានបង្ហាញនោះ ? (នៅពេលសិស្សឆ្លើយ សូមបញ្ជាក់ថា **នៅពេលយើងជឿ ហើយធ្វើសកម្មភាពលើអ្វីដែលព្រះបានបង្ហាញ នោះយើងរៀបចំខ្លួនយើងដើម្បីទទួលបានវិវរណៈដ៏អស្ចារ្យ**) ។
- តើអ្នកគិតថា ហេតុអ្វីបានជាវាចាំបាច់ថាយើងត្រូវជឿលើសេចក្តីពិត ដែលយើងបានទទួលរួចហើយ ពីមុនពេលយើងអាចទទួលបានសេចក្តីពិតបន្ថែមទៀត ?
- តើយើងអាចបង្ហាញថា យើងជឿលើអ្វីដែលព្រះអម្ចាស់បានបើកសម្តែងតាមរបៀបណា ?

សូមសន្យានឹងសិស្សថា នៅពេលពួកគេសិក្សាប្រកបដោយសេចក្តីជំនឿ និងអនុវត្តតាមគោលការណ៍នានានៅក្នុងព្រះគម្ពីរមរមន នោះពួកគេនឹងទទួលបានការយល់បន្ថែមទៀតពីដំណឹងល្អ ។ សូមជួយសិស្សឲ្យសញ្ជឹងគិតពីសេចក្តីពិតដែលពួកគេទទួលបាននៅក្នុងព្រះគម្ពីរមរមន ដោយការសុំឲ្យពួកគេឆ្លើយតបនឹងសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរ (អ្នកអាច សរសេរសំណួរទាំងនេះនៅលើក្តារខៀន) ៖

- តើអ្នកកំពុងធ្វើអ្វីនៅក្នុងជីវិតរបស់អ្នកដែលបង្ហាញពីជំនឿរបស់អ្នកលើព្រះគម្ពីរមរមន ?
- តើនៅពេលណាដែលការអានព្រះគម្ពីរមរមនដោយបំណងពិតបានដឹកនាំអ្នកឲ្យទទួលបានវិវរណៈផ្ទាល់ខ្លួន ?

នីហ្វៃទី ៣ ២៦:១៣–២១

ព្រះអង្គសង្គ្រោះបញ្ចប់ការបម្រើនៅលើផែនដីរបស់ទ្រង់ក្នុងចំណោមពួកសាសន៍នីហ្វៃ ហើយពួកសាវករបស់ទ្រង់ធ្វើតាមគំរូរបស់ទ្រង់នៅក្នុងការបម្រើរបស់ពួកលោក

សូមពន្យល់ថានៅក្នុង នីហ្វៃទី ៣ ២៦ មរមនបានសង្ខេបការបម្រើរបស់ព្រះអង្គសង្គ្រោះទាំងអស់នៅក្នុងចំណោមពួកសាសន៍នីហ្វៃ ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២៦:១៣–១៦ ដោយស្ងាត់ស្ងៀម ។ អ្នកអាចណែនាំថា ពួកគេគួរគូសចំណាំរឿងខ្លះដែលព្រះអង្គសង្គ្រោះបានធ្វើ ដែលមរមនបានជ្រើសរើសដើម្បីគូសបញ្ជាក់ ។

ប្រសិនបើមានពេល សូមឲ្យសិស្សរំឭក ហើយសញ្ជឹងគិតពីកំណត់ចំណាំរបស់គេ និងការគូសចំណាំព្រះគម្ពីរពីការសិក្សារបស់គេក្នុងនីហ្វៃទី ៣ ១១–២៥ ។ សូមលើកទឹកចិត្តគេឲ្យរកមើលការបង្រៀន និងហេតុការណ៍នានាពីការបម្រើរបស់ព្រះអង្គសង្គ្រោះក្នុងចំណោមពួកសាសន៍នីហ្វៃដែលសំខាន់ ឬដែលគួរឲ្យពួកគេចងចាំ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយគំនិត និងអារម្មណ៍របស់គេអំពីការបម្រើរបស់ព្រះអង្គសង្គ្រោះក្នុងចំណោមពួកសាសន៍នីហ្វៃ ។

នីហ្វៃ ទី ៣ ២៧

សេចក្តីផ្តើម

ក្រោយពីកិច្ចការបម្រើរបស់ព្រះអង្គសង្គ្រោះនៅក្នុងចំណោមពួកសាសន៍នីហ្វៃមិនយូរប៉ុន្មាន ពួកដប់ពីរដែលត្រូវបានហៅថ្មីថាជាពួកសាវកសាសន៍នីហ្វៃបានជួបប្រជុំគ្នានៅក្នុងការអធិស្ឋាន និងការតមអាហារដ៏ខ្លាំងក្លាមួយ ។ ព្រះយេស៊ូវគ្រីស្ទបានលេចឡើងចំពោះពួកគេ ហើយបានឆ្លើយតបនឹងសំណូរដែលពាក់ព័ន្ធនឹងឈ្មោះដែលពួកគេដាក់សម្រាប់សាសនាចក្រ ។ ទ្រង់បានបង្រៀនពួកគេអំពីជំណឹងល្អរបស់ទ្រង់ និងបានបញ្ជាពួកគេឲ្យក្លាយដូចជាទ្រង់ ។

យោបល់ទាំងឡាយសម្រាប់ការបង្រៀន

នីហ្វៃទី ៣ ២៧:១–១២

ព្រះយេស៊ូវគ្រីស្ទបង្រៀនដល់ពួកសាវកដប់ពីរនាក់ថា សាសនាចក្ររបស់ទ្រង់គួរដាក់តាមព្រះនាមរបស់ទ្រង់

សូមបំបែកសិស្សទៅជាបី ឬបួនក្រុម ។ ប្រសិនបើអ្នកមានសិស្សតិច សូមឲ្យសិស្សធ្វើការរៀង។ខ្លួន ។ សូមឲ្យក្រុមនីមួយ។ (ឬ បុគ្គលម្នាក់។) ស្រមៃថា ពួកគេនឹងចាប់ផ្តើមក្លិប ឬក្រុមកីឡាថ្មីមួយ ។ សូមឲ្យក្រុមនីមួយ។សម្រេចចិត្តនូវប្រភេទនៃក្លិប ឬក្រុមកីឡាដែលពួកគេនឹងបង្កើត ដូចជាក្លិបវិទ្យាសាស្ត្រ ឬក្រុមបាល់ទាត់ ហើយបន្ទាប់មក សូមឲ្យពួកគេជ្រើសរើសឈ្មោះមួយសម្រាប់ក្លិបរបស់គេ ។ សូមឲ្យក្រុមនីមួយ។សរសេរឈ្មោះរបស់ពួកគេនៅលើក្រដាសមួយ ។ បន្ទាប់មក សូមប្រមូលក្រដាសពីក្រុមទាំងឡាយ ។ (សកម្មភាពនេះគួរតែខ្លី ។ វាមិនគួរសឹងពេល ឬការយកចិត្តទុកដាក់ខ្លាំងជាងលើគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៅក្នុង នីហ្វៃទី ៣ ២៧ ឡើយ) ។

សូមអានឮ។នូវឈ្មោះលើក្រដាសនីមួយ។ ។ ក្រោយពីអ្នកអានឈ្មោះរួចហើយ សូមឲ្យសិស្សទាយ ដោយផ្អែកលើឈ្មោះ ប្រភេទនៃក្លិប ឬក្រុមនោះ ។

- តើឈ្មោះមួយអាចទាក់ទងទៅនឹងក្លិប និងសមាជិករបស់ក្លិបនោះយ៉ាងណា ?

សូមពន្យល់ថា ភ្លាម។ក្រោយពីការយាងមករបស់ព្រះយេស៊ូវគ្រីស្ទទៅជួបនឹងសាសន៍នីហ្វៃ ពួកសាវកសាសន៍នីហ្វៃទាំងដប់ពីររួបរបស់ទ្រង់បានរួមគ្នាតមអាហារ និងអធិស្ឋាន (សូមមើល នីហ្វៃទី ៣២៧:១) ។ សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮ។ពី នីហ្វៃទី ៣ ២៧:២–៧ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលសំណួររបស់សាវក និងចម្លើយរបស់ព្រះអង្គសង្គ្រោះ ។

- តើព្រះអង្គសង្គ្រោះបានមានបន្ទូលយ៉ាងណាអំពីរបៀបដែលត្រូវហៅសាសនាចក្ររបស់ទ្រង់ ?
- តើហេតុអ្វីបានជាទ្រង់ដាក់ឈ្មោះសាសនាចក្រតាមព្រះនាមរបស់ទ្រង់ ?

សូមឲ្យសិស្សស្រាវជ្រាវ នីហ្វៃទី ៣ ២៧:៨–១២ ដោយស្ងាត់។ដោយរកមើលការរៀបរាប់របស់ព្រះអង្គសង្គ្រោះអំពីសាសនាចក្រដ៏ពិតរបស់ទ្រង់ ។ ខណៈពេលដែលពួកគេសិក្សា សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនៅលើក្តារខៀន៖

សាសនាចក្រដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទត្រូវតែ . . .

ក្រោយពីសិស្សបានមានពេលគ្រប់គ្រាន់សិក្សាខគម្ពីរទាំងនេះហើយ សូមសួរពួកគេពីរបៀបដែលពួកគេនឹងបំពេញប្រយោគនៅលើក្តារខៀនដោយផ្អែកលើអ្វីដែលពួកគេបានអាន ។ (សិស្សនឹងអាចរកឃើញនូវសេចក្តីពិតខាងក្រោមនេះ ៖ **សាសនាចក្រដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទត្រូវតែបានហៅតាមព្រះនាមរបស់ទ្រង់ ហើយត្រូវបានកសាងឡើងលើដំណឹងល្អរបស់ទ្រង់**) ។

- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដែលសាសនាក្ររបស់ព្រះអង្គសង្គ្រោះមានព្រះនាមរបស់ទ្រង់ ?
- តើអ្នកគិតថា វាមានន័យយ៉ាងណាដែលសាសនាចក្រត្រូវបាន « កសាងឡើងនៅលើដំណឹងល្អ | របស់ទ្រង់ | » ? (នីហ្វៃ ទី ៣ ២៧:១០) ។ អ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដែលសាសនាក្រត្រូវបានកសាងឡើងនៅលើដំណឹងល្អរបស់ទ្រង់ជាជាងលើកិច្ចការរបស់មនុស្ស ?

សូមឲ្យសិស្សបំពេញប្រយោគខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរ ៖ « ការក្លាយជាសមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទគឺសំខាន់សម្រាប់ខ្ញុំដោយសារ . . .»

នីហ្វៃទី ៣ ២៧:១៣–២២

ព្រះយេស៊ូវគ្រីស្ទផ្តល់និយមន័យដំណឹងល្អរបស់ទ្រង់ និងបង្រៀនអ្វីដែលយើងត្រូវធ្វើដើម្បីឈរដោយឥតកំហុសនៅចំពោះព្រះភក្ត្រទ្រង់ និងព្រះបិតារបស់ទ្រង់

សូមឲ្យសិស្សគិតអំពីរបៀបដែលពួកគេបានមានអារម្មណ៍ នៅពេលពួកគេត្រូវបានគេចាប់ថាពួកគេបានធ្វើអ្វីមួយខុស ។ (សូមកុំឲ្យពួកគេចែកចាយបទពិសោធន៍ទាំងនេះ) ។ បន្ទាប់មក សូមឲ្យពួកគេស្រមៃថាតើការឈរនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ដើម្បីកាត់សេចក្តីមានទិដ្ឋភាពបែបណា ។ សូមលើកទឹកចិត្តពួកគេឲ្យសញ្ជឹងគិតពីសំណួរខាងក្រោម ៖

- តើអ្នកនឹងមានអារម្មណ៍យ៉ាងណា នៅពេលអ្នកនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ប្រសិនបើអ្នកមានទោសនោះ ?

សូមពន្យល់ថាពាក្យ *ដំណឹងល្អ* មានន័យថា « ព័ត៌មានល្អ » ។ សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗក្នុង នីហ្វៃទី ៣ ២៧:១៣–១៦ ហើយសូមឲ្យសិស្សរកមើលដំណឹងល្អនៅក្នុងខគម្ពីរទាំងនេះ ។ សូមឲ្យពួកគេគិតជង់ដៃអំពីរបៀបដែលដំណឹងល្អនេះទាក់ទងនឹងថ្ងៃដែលពួកគេនឹងឈរនៅមុខព្រះដើម្បីកាត់សេចក្តី ។

- ព្រះអង្គសង្គ្រោះបានថ្លែងទីបន្ទាល់ថា ទ្រង់បានមកកាន់ពិភពលោកដើម្បីធ្វើតាមព្រះឆន្ទៈរបស់ព្រះវរបិតារបស់ទ្រង់ ។ យោងតាម នីហ្វៃទី ៣ ២៧:១៤ តើព្រះវរបិតាសួគ៌បានបញ្ជូនព្រះយេស៊ូវគ្រីស្ទមកកាន់ពិភពលោកដើម្បីធ្វើអ្វី ?
- ដោយផ្អែកលើ នីហ្វៃទី ៣ ២៧:១៣–១៤ តើអ្វីគឺជាគ្រឹះនៃដំណឹងល្អ ? (ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាក្តី ក៏ពួកគេគួររកឃើញនូវសេចក្តីពិតខាងក្រោមនេះ ៖ **គ្រឹះនៃដំណឹងល្អគឺថា ព្រះយេស៊ូវគ្រីស្ទបានធ្វើតាមព្រះឆន្ទៈរបស់ព្រះបិតាទ្រង់ដើម្បីសម្រេចបានដង្វាយធួន ។** អ្នកអាចសុំឲ្យសិស្សសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់គេក្បែរ នីហ្វៃទី ៣ ២៧:១៣–១៤) ។
- ដោយសារព្រះអង្គសង្គ្រោះបានបំពេញតាមព្រះឆន្ទៈរបស់ព្រះបិតាទ្រង់ តើនឹងមានអ្វីកើតឡើងដល់មនុស្សលោក? (យើងនឹងត្រូវបានលើកឡើងនៅចំពោះទ្រង់ដើម្បីកាត់សេចក្តីតាមកិច្ចការរបស់យើង ។)

សូមឲ្យសិស្សស្រាវជ្រាវ នីហ្វៃទី ៣២៧:១៦ ដោយស្ងៀមស្ងាត់ ដោយរកមើលកិច្ចការដែលយើងត្រូវធ្វើដើម្បីទទួលបានពរជ័យទាំងឡាយនៃដង្វាយធួន និងរៀបចំសម្រាប់ការកាត់សេចក្តី ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ សុំឲ្យសិស្សសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។

- យោងតាមខគម្ពីរនេះ តើពរជ័យអ្វីដែលនឹងកើតមាន ដល់អ្នកដែលប្រែចិត្ត ជ្រមុជទឹក និងកាន់ខ្ជាប់ដរាបដល់ចុងបំផុត ? (ចម្លើយរបស់សិស្សអាចឆ្លុះបញ្ចាំងអំពីសេចក្តីពិតខាងក្រោមនេះ ៖ **ប្រសិនបើយើងប្រែចិត្ត ជ្រមុជទឹក និងកាន់ខ្ជាប់ដរាបដល់ចុងបំផុត យើងនឹងគ្មានទោសឡើយ នៅពេលយើងឈរនៅចំពោះព្រះដើម្បីកាត់សេចក្តីនោះ**) ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២៧:១៧–១៩ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលនឹងកើតឡើងដល់អ្នកណាដែលមិនប្រែចិត្ត ឬស៊ូទ្រាំដល់ទីបញ្ចប់ ។

- ចេញពីអ្វីដែលអ្នកបានអាន ហេតុអ្វីបានជាកូនចៅរបស់ព្រះវរបិតាសួគ៌ទាំងអស់ត្រូវ ការដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ?
- តើមានដំណឹងល្អអ្វីសម្រាប់យើង នៅពេលយើងគិតអំពីការឈរនៅចំពោះព្រះភក្ត្រព្រះអម្ចាស់ដើម្បីកាត់សេចក្តី ?

សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដៃវ្រ៊ី អ័រ ហូឡិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« ‹ ដំណឹងល្អ › | គឺ |ថា សេចក្តីស្លាប់ និងនរក | អាច |ត្រូវបានរួចផុត ថាកំហុស និងអំពើបាប| អាច |ត្រូវបានយកឈ្នះ ថាមានសេចក្តីសង្ឃឹម ថាមានជំនួយ ថាការណ៍កំបាំងនឹងត្រូវដោះស្រាយ ថាសត្រូវត្រូវបានបង្ក្រាប ។ ដំណឹងល្អគឺថាផ្នូររបស់ *មនុស្សគ្រប់គ្នា* | នឹង |ត្រូវទទេនៅថ្ងៃមួយ ថាព្រលឹងរបស់*មនុស្សគ្រប់គ្នា*| អាច |បរិសុទ្ធម្តងទៀត ថាកូនរបស់ព្រះ *គ្រប់ៗរូប*| អាច |ត្រឡប់មកកាន់ព្រះបិតា ដែលបានប្រទានជីវិតដល់ពួកគេម្តងទៀត » (« Missionary Work and the Atonement » *Ensign* ខែ មីនា ឆ្នាំ ២០០១ ទំព័រ ៨, ១០) ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២៧:២០–២១ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលការអញ្ជើញរបស់ព្រះអង្គសង្គ្រោះចំពោះយើង ។

- តើអ្វីទៅជាការអញ្ជើញរបស់ព្រះអង្គសង្គ្រោះនៅក្នុងខគម្ពីរទាំងនេះ ?

ដើម្បីជួយសិស្សឲ្យគិតអំពីការឧិតខំរបស់គេក្នុងការទទួលការអញ្ជើញនេះ សូមឲ្យពួកគេឆ្លើយតបនឹងសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរ ។ (អ្នកអាចសរសេរសំណួរនេះនៅលើក្តារខៀន ឬអានវាយឺតៗដើម្បីឲ្យសិស្សអាចកត់វាបាន) ។

- ហេតុអ្វីបានជាព្រះអង្គសង្គ្រោះសព្វព្រះទ័យឲ្យអ្នកប្រែចិត្ត ហើយមករកទ្រង់ ?
- តើអ្នកទទួលយកការអញ្ជើញរបស់ព្រះអង្គសង្គ្រោះនៅក្នុង នីហ្វៃទី ៣ ២៧:២០–២១ ដោយរបៀបណា ?
- តើអ្នកអាចធ្វើអ្វីខ្លះនាថ្ងៃនេះដើម្បីរៀបចំឈរដោយឥតមានកំហុសនៅចំពោះព្រះភក្ត្រព្រះអម្ចាស់នោះ ?

សូមឲ្យសិស្សម្នាក់អាន គោលលទ្ធិ និង សេចក្តីសញ្ញា ៧៦:៤០–៤២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលការយល់ដឹងបន្ថែមទៀតអំពីមូលហេតុដែលដំណឹងល្អគឺជាព័ត៌មានដ៏ល្អមួយ ។ (អ្នកអាចសុំឲ្យសិស្សសរសេរ *គ. និង ស. ៧៦:៤០–៤២* នៅក្នុងព្រះគម្ពីររបស់គេក្បែរ នីហ្វៃទី ៣ ២៧:១៣) ។

នៅដើមមេរៀននេះ អ្នកបានសុំឲ្យសិស្សញឹងគិតអំពីអារម្មណ៍ដែលពួកគេអាចមាននៅចំពោះព្រះភក្ត្រព្រះអម្ចាស់ ប្រសិនបើពួកគេមានកំហុស ។ នៅចំណុចនេះនៃមេរៀន សូមឲ្យពួកគេសញឹងគិតពីអារម្មណ៍ដែលពួកគេអាចមានចំពោះព្រះភក្ត្រព្រះអង្គសង្គ្រោះ ប្រសិនបើពួកគេបានស្អាតបាតតាមរយៈដង្វាយធួនរបស់ទ្រង់ និងដោយការគោរពតាមគោលការណ៍ ព្រះបញ្ញត្តិទាំងឡាយ និងពិធីបរិសុទ្ធនៃដំណឹងល្អ ។

- ប្រសិនបើអ្នកអាចនិយាយជាមួយនឹងព្រះអង្គសង្គ្រោះនៅពេលនោះ តើអ្នកនឹងនិយាយអ្វី ?
- ដោយផ្អែកលើអ្វីដែលបានសិក្សាថ្ងៃនេះ តើអ្នកនឹងពន្យល់ពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដល់មិត្តដោយរបៀបណា ?

ធ្វើទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ

ជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទគឺជាមូលដ្ឋាននៃសេចក្តីពិតដែលគោលលទ្ធិ និងគោលការណ៍ទាំងឡាយនៃដំណឹងល្អទាំងអស់បានស្ថាបនាលើ ។ វាគួរតែជាស្នូលនៃរាល់ការបង្រៀន និងការរៀនសូត្រពីដំណឹងល្អ ។ សូមរកមើលឱកាសដើម្បីធ្វើទីបន្ទាល់ជាញឹកញាប់អំពីព្រះយេស៊ូវគ្រីស្ទ ហើយជួយសិស្សឲ្យបង្កើនសេចក្តីស្រឡាញ់លើទ្រង់ និងបំណងចង់ក្លាយជាសិស្សដ៏ពិតរបស់ទ្រង់ ។

នីហ្វៃទី ៣ ២៧:២៣–៣៣

ព្រះយេស៊ូវគ្រីស្ទណែនាំពួកសិស្សរបស់ទ្រង់ឲ្យក្លាយដូចជាទ្រង់

សូមសង្កេប នីហ្វៃទី ៣២៧:២៣–២៦ ដោយការពន្យល់ថា ព្រះអង្គសង្គ្រោះបានប្រទានការណែនាំដល់ពួកសាវកសាសន៍នីហ្វៃទាំងដប់ពីររបស់ទ្រង់ និងបានបង្រៀនពួកលោកអំពីការទទួលខុសត្រូវរបស់ពួកលោក ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣២៧:២៧ ដោយស្ងៀមស្ងាត់ដោយរកមើលព្រះបញ្ញត្តិដែលទ្រង់បានប្រទានដល់ពួកសាវកដើម្បីជួយពួកគេឲ្យបំពេញតួនាទីជាចៅក្រមរបស់ប្រជាជន ។

- ហេតុអ្វីបានជាវាសំខាន់សម្រាប់ចៅក្រមរបស់ប្រជាជនដើម្បីក្លាយដូចជាព្រះអង្គសង្គ្រោះ ?

សូមឲ្យសិស្សរំឭក នីហ្វៃទី ៣២៧:២១ ។

- តើព្រះអង្គសង្គ្រោះបានបញ្ជាពួកសិស្សឲ្យធ្វើអ្វី ?
- តើអ្វីទៅជាទំនាក់ទំនងរវាងការធ្វើកិច្ចការរបស់ព្រះអង្គសង្គ្រោះ និងការក្លាយដូចជាទ្រង់ ?

នៅពេលសិស្សពិភាក្សាពីសំណួរនេះ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ *ព្រះអម្ចាស់រំពឹងថាពួកសិស្សរបស់ទ្រង់ធ្វើកិច្ចការរបស់ទ្រង់ ហើយក្លាយដូចជាទ្រង់ ។*

- តើមានរបៀបណាខ្លះដែលយើងអាចក្លាយដូចជាព្រះអង្គសង្គ្រោះ ? តើមានកិច្ចការណាខ្លះដែលយើងអាចធ្វើ នៅពេលយើងធ្វើតាមគំរូរបស់ទ្រង់ ?
- តើអ្នកធ្លាប់ត្រូវបានប្រទានពរ នៅពេលអ្នកបានព្យាយាមធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះតាមវិធីណាខ្លះ ?

សូមបញ្ចប់មេរៀនដោយធ្វើទីបន្ទាល់អំពីពរជ័យដែលកើតមាន នៅពេលយើងខិតខំដើម្បីក្លាយដូចជាព្រះយេស៊ូវគ្រីស្ទ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ៣ ២៧:១៣–២១ ។ ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ

ព្យាការី យ៉ូសែប ស្ម៊ីធ បានពន្យល់ពីសារលិខិតដ៏សំខាន់នៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

« គោលការណ៍គ្រឹះនៃសាសនារបស់យើង គឺទីបន្ទាល់អំពីពួកសាវក និងពួកព្យាការី អំពីព្រះយេស៊ូវគ្រីស្ទ ថាទ្រង់បានសុគត បានបញ្ចៃ ហើយបានរស់ឡើងវិញម្តងទៀតនៅថ្ងៃទីបី ហើយបានយាងឡើងទៅស្ថានសួគ៌ ហើយអ្វីៗផ្សេងទៀតទាំងអស់ ដែលទាក់ទងនឹងសាសនារបស់យើង គឺជាសេចក្តីបន្ថែមទៅលើវាប៉ុណ្ណោះ » (*Teachings of Presidents of the Church: Joseph Smith* [ឆ្នាំ ២០០៧] ទំព័រ ៤៩) ។

អែលឌើរ អិម រ័សុល បាឡឺដ នៃក្រុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖

« ពាក្យ *ដំណឹងល្អ* មានន័យថា ‹ ព័ត៌មានល្អ › ។ ព័ត៌មានល្អគឺជាព្រះអម្ចាស់យេស៊ូវគ្រីស្ទ និងសារនៃសេចក្តីសង្គ្រោះរបស់ទ្រង់ ។ [សូមមើល Bible Dictionary «Gospels»ទំព័រ ៦៨២–៦៨៣]។ ព្រះយេស៊ូវបានប្រៀបធៀបដំណឹងល្អទៅនឹងបេសកកម្មរបស់ទ្រង់ និងការបម្រើរបស់ទ្រង់នៅក្នុងជីវិតរមែងស្លាប់ ។ នៅក្នុងកថាខណ្ឌ *ពីគោលបំណង* របស់ទ្រង់ ព្រះយេស៊ូវបានមានបន្ទូល ៖

« នេះគឺជាដំណឹងល្អដែលយើងបានប្រទានដល់អ្នករាល់គ្នា—គឺយើងបានមកឯលោកិយនេះ ដើម្បីធ្វើតាមព្រះហឫទ័យនៃព្រះវរបិតារបស់យើ ពីព្រោះព្រះវរបិតារបស់យើង ទ្រង់បានចាត់ឲ្យយើងមក ។

« ‹ ហើយព្រះវរបិតាយើង ទ្រង់បានចាត់ឲ្យយើងមក ដើម្បីឲ្យយើងអាចត្រូវបានលើកឡើងលើឈើឆ្កាង › ។ [នីហ្វៃទី ៣២៧:១៣–១៤]។

« បេសកកម្មខាងសាច់ឈាមរបស់ព្រះអង្គសង្គ្រោះដែលយើងដឹងនោះគឺ *ជង្វាយធួន* ។ « *ការបម្រើ*ខាងសាច់ឈាមរបស់ព្រះអង្គសង្គ្រោះ រួមមានអ្វីៗផ្សេងទៀតដែលទ្រង់បានធ្វើ— ការបង្រៀនរបស់ទ្រង់ ការបង្ហាញសេចក្តីស្រឡាញ់ ការយកចិត្តទុកដាក់ដល់ពិធីបរិសុទ្ធ គំរូនៃការអធិស្ឋាន ការខ្ជាប់ខ្ជួន និងការណ៍ផ្សេងទៀត ។ ទ្រង់បានរស់នៅជាគំរូរបស់យើង ដែលទ្រង់ក៏បានប្រៀបធៀបទៅនឹងដំណឹងល្អនៅក្នុងប្រយោគនៃការបង្រៀនរបស់ទ្រង់ដែរ ។ ទ្រង់បានមានបន្ទូលថា ‹ នេះគឺជាដំណឹងល្អរបស់យើង › . . . ដ្បិតអ្វីៗដែលអ្នករាល់គ្នាបានឃើញយើងធ្វើយ៉ាងណា នោះអ្នកត្រូវធ្វើតាមយ៉ាងនោះដែរ › ។ [នីហ្វៃទី ៣ ២៧:២១ ។] ហេតុដូច្នេះហើយ សេចក្តីជំនឿ ការប្រែចិត្ត ពិធីបុណ្យជ្រមុជទឹកដោយទឹក ភ្លើង និងដោយព្រះវិញ្ញាណបរិសុទ្ធ ការប្រមូលផ្តុំនៃអ្នករើសតាំង និងការតស៊ូដល់ទីបញ្ចប់គឺជាផ្នែកនៃដំណឹងល្អទាំងឡាយ » (« Senior Missionaries and the Gospel » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៤ ទំព័រ ៨១) ។

នីហ្វៃទី ៣២៧:២៧ ។ ការក្លាយដូចជាព្រះយេស៊ូវគ្រីស្ទ

ប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឺន បានបង្រៀន ៖

« បុរសនោះគឺអស្ចារ្យបំផុត ហើយមានពរ និងរីករាយបំផុត ដោយមានជីវិតសាកសមបំផុតទៅនឹងគំរូនៃព្រះគ្រីស្ទ ។ ការណ៍នេះមិនទាក់ទងនឹងទ្រព្យសម្បត្តិ អំណាច ឬកិត្តិយសខាងលោកិយឡើយ ។ ការសោកល្អងដ៏ពិតតែមួយគត់នៃសេចក្តីអស្ចារ្យ ការប្រទានពរភាពអំណរគឺជារបៀបដែលជីវិតខិតទៅកាន់តែជិតដើម្បីក្លាយដូចជាលោកចៅហ្វាយ គឺជាព្រះយេស៊ូវគ្រីស្ទ ។ ទ្រង់គឺជាផ្លូវដ៏ត្រឹមត្រូវ សេចក្តីពិតដ៏ពេញលេញ និងជីវិតដ៏បរិបូរណ៍ » (« Jesus Christ—Gifts and Expectations » [សុន្ទរកថាការប្រជុំសកលវិទ្យាល័យព្រិកហាំយ៉ង់ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៧៤] ទំព័រ ១, speeches.byu.edu) ។

នីហ្វៃទី ៣ ជំពូកទី ២៨

សេចក្តីផ្តើម

នៅពេលព្រះយេស៊ូវគ្រីស្ទបានសួរដល់ពួកសាវកសាសន៍នីហ្វៃទាំងដប់ពីររបស់ទ្រង់ម្តងម្នាក់ៗ អំពីអ្វីដែលពួកលោកចង់បានពីទ្រង់ មានប្រាំបួននាក់បានស្នើសុំឲ្យត្រឡប់ទៅកាន់ទ្រង់កាន់តែលឿន នៅពេលការបម្រើរបស់ពួកគេនៅលើផែនដីបានបញ្ចប់ ។ បីនាក់បានសុំនៅបន្តនៅលើផែនដីដើម្បីនាំព្រលឹងទាំងឡាយមកកាន់ទ្រង់រហូតដល់ការយាងមកជាលើកទីពីររបស់ទ្រង់ ។ ព្រះអម្ចាស់បានធ្វើតាមបំណងដ៏សុចរិតទាំងពីរនោះ ។ មមនបានផ្តល់សេចក្តីលម្អិតខ្លះអំពីការបម្រើរបស់សាសន៍នីហ្វៃបីរូប ហើយលោកក៏បានចែកចាយអ្វីដែលព្រះអម្ចាស់បានបើកសម្តែងដល់លោកអំពីការផ្លាស់ប្តូរខាងរាងកាយនៃសាសន៍នីហ្វៃទាំងបីរូបបានមាន ដើម្បីឲ្យពួកលោកនៅតែបន្តនៅលើផែនដី ។

យោបល់ទាំងឡាយសម្រាប់ការបង្រៀន

នីហ្វៃទី ៣ ២៨:១–១១

ព្រះយេស៊ូវគ្រីស្ទប្រទានតាមបំណងរបស់ពួកសិស្សសាសន៍នីហ្វៃរបស់ទ្រង់

សូមឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេនឹងឆ្លើយតប ប្រសិនបើព្រះយេស៊ូវគ្រីស្ទបានមកជួបពួកគេហើយសួរថា « តើអ្នកចង់បានប្រាថ្នាអ្វីពីយើង » ? សូមឲ្យពួកគេសរសេរចម្លើយរបស់ពួកគេនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ ក្នុងសៀវភៅសរសេរ ។ សូមឲ្យពួកគេមានឱកាសចែកចាយអ្វីដែលពួកគេបានសរសេរ ប្រសិនបើពួកគេមានអារម្មណ៍ថាចង់ ធ្វើដូច្នោះ ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២៨:១–៣ ដោយស្ងៀមស្ងាត់ ដោយរកមើលចម្លើយរបស់ពួកសិស្សប្រាំបួនរូបសាសន៍នីហ្វៃ នៅពេលព្រះអម្ចាស់បានសួរពួកលោកនូវសំណួរនេះ ។ បន្ទាប់ពីសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរៀនហើយ សូមសួរ ៖

- តើព្រះអង្គសង្គ្រោះមានអារម្មណ៍យ៉ាងណាអំពីបំណងរបស់ពួកសិស្សទាំងប្រាំបួននេះ ?

សូមឲ្យសិស្សអាន នីហ្វៃទី ៣២៨:៤–៩ ដោយស្ងៀមស្ងាត់ ដោយរកមើលអ្វីដែលពួកសិស្សទាំងបីចង់បានពីព្រះអង្គសង្គ្រោះ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ (វាអាចជួយក្នុងការនាំចំណាប់អារម្មណ៍របស់សិស្សទៅមើលប្រយោគខាងក្រោមនៅក្នុងនីហ្វៃទី ៣ ២៨:៩ ៖ « អ្នករាល់គ្នាប្រាថ្នាចង់នាំព្រលឹងមនុស្សមករកយើង »)។

- តើព្រះអង្គសង្គ្រោះមានអារម្មណ៍យ៉ាងណាអំពីបំណងរបស់ពួកសិស្សទាំងបីនេះ ?
- យោងតាម នីហ្វៃទី ៣ ២៨:៨–៩ តើព្រះអង្គសង្គ្រោះបានសន្យាអ្វីខ្លះដល់ សាសន៍នីហ្វៃទាំងបី ដើម្បីឲ្យបំណងដ៏សុចរិតរបស់ពួកលោកអាចបានសម្រេច ?

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២៨:១០ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលនូវពរជ័យដែលព្រះអម្ចាស់បានសន្យានឹងពួកសាសន៍នីហ្វៃទាំងបីរូប ។

- តើព្រះអម្ចាស់បានសន្យាអ្វីខ្លះនឹងពួកសាសន៍នីហ្វៃទាំងបីរូប ? តើនៅពេលណាដែលអ្នកបានឃើញការបម្រើដល់អ្នកដទៃនាំទៅរកសេចក្តីអំណរ ?
- តើយើងអាចរៀនអ្វីខ្លះអំពីព្រះអម្ចាស់នៅក្នុងនីហ្វៃទី ៣ ២៨:១–១០ ? (ចម្លើយរបស់សិស្សចំពោះសំណួរនេះអាចរួមមាន **ព្រះអម្ចាស់ប្រទានពរដល់យើងស្របតាមបំណងដ៏សុចរិតរបស់យើង** និងថា **ព្រះអម្ចាស់សព្វព្រះទ័យ នៅពេលយើងមានបំណងជួយដល់អ្នកដទៃឲ្យមករកទ្រង់**)។

ដើម្បីជួយសិស្សឲ្យយល់ពីសារៈសំខាន់នៃបំណងដ៏សុចរិត សូមអានសេចក្តីថ្លែងការណ៍ខាងក្រោម ៖

អែលឌើរ នែល អេ ម៉ាក់ស្វែលក្នុងក្រុមប្រឹក្សានៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា ៖

« អ្វីដែលយើងប្រាថ្នាចង់បានរយៈពេលជាយូរ គឺជាអ្វីដែលយើងនឹងក្លាយជានៅទីបញ្ចប់ និងអ្វីដែលយើងនឹងទទួលបាននៅក្នុងភាពអស់កល្ប ។ . . .

« ហេតុដូច្នេះហើយ បំណងដ៏សុចរិតត្រូវតែមានឥតឈប់ឈរ »(« According to the Desire of [Our] Hearts » *Ensign* ខែ វិច្ឆិកា ឆ្នាំ ១៩៩៦ ទំព័រ ២១–២២) ។

ប្រធាន ព្រិកហាំ យ៉ង់ បានបង្រៀន ៖

« បុរស និងស្ត្រី ដែលប្រាថ្នាចង់បានកន្លែងនៅក្នុងនគរសេឡេស្ទាលនឹងឃើញថា ពួកគេត្រូវធ្វើសង្គ្រាមជាមួយនឹងសត្រូវនៃសេចក្តីសុចរិតទាំងឡាយរាល់ថ្ងៃ » (« Remarks » *Deseret News* ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៨៦៤ ទំព័រ ៩៨) ។

- តើអ្នកគិតថា ហេតុអ្វីបានជាយើងត្រូវធ្វើសង្គ្រាមរាល់ថ្ងៃដើម្បីឲ្យបំណងដ៏សុចរិតរបស់យើងអាចទៅបានសម្រេចនោះ ?
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់បានប្រទានពរដល់អ្នក ដោយសារតែបំណងដ៏សុចរិតរបស់អ្នក ?

សូមឲ្យសិស្សមើលបំណងដែលពួកគេបានសរសេរនៅពេលចាប់ផ្តើមថ្នាក់ ។ សូមឲ្យពួកគេសរសេរប្រយោគពីរបីអំពីអ្វីដែលពួកគេនឹងចាប់ផ្តើមធ្វើនៅថ្ងៃនេះដើម្បីធ្វើឲ្យប្រាកដថា បំណងដ៏សុចរិតទាំងនោះអាចនឹងបានសម្រេច ។

ចៀសវាងការទស្សន៍ទាយអំពីសាសន៍នីហ្វៃទាំងបី

មនុស្សជាច្រើនបានឮរឿងអំពីជំណើររបស់សាសន៍នីហ្វៃទាំងបី ។ ជំនួសឲ្យការចែកចាយរឿងទាំងនេះ សូមបង្រៀនអ្វីដែលត្រូវបានបង្រៀននៅក្នុងព្រះគម្ពីរ ។ សូមចាំពីប្រយោគរបស់ មមនដែលលោកបានមានប្រសាសន៍ថា សាសន៍នីហ្វៃទាំងបីនឹងមកក្នុងចំណោមពួកសាសន៍ដទៃ និងពួកសាសន៍យូដា ដែលនឹង « ពុំស្គាល់ពួកគេឡើយ » (នីហ្វៃទី ៣ ២៨:២៧–២៨) ។ សូមចាកចេញពីការពិភាក្សារឿង ឬព័ត៌មានផ្សេងទៀតដែលមិនមាននៅក្នុងប្រភពដែលសាសនាចក្របានអនុម័ត ។

នីហ្វៃទី ៣ ២៨:១២–៣៥

មរមនបានរៀបរាប់ការបម្រើរបស់ សាសន៍នីហ្វៃទាំងបីរូប

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២៨:១២–១៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលបានកើតឡើងដល់សិស្សសាសន៍នីហ្វៃ ក្រោយពីព្រះអង្គសង្គ្រោះបានចាកចេញពីពួកលោក ។ សូមពន្យល់ថា ពួកសិស្សបានជួបនឹងការប្រែរូប—ការផ្លាស់ប្តូរបណ្តោះអាសន្នចំពោះរាងកាយរបស់ពួកលោក ។

- យោងតាម នីហ្វៃទី ៣ ២៨:១៥ តើអ្វីជាមូលហេតុមួយដែលពួកសិស្សត្រូវតែប្រែរូប ? (ដើម្បីឲ្យ « ពួកគេអាចឃើញការណ៍ទាំងឡាយនៃព្រះបាន » ។)

សូមពន្យល់ថា ដោយការចាប់ផ្តើមជាមួយនឹង នីហ្វៃទី ៣ ២៨:១៧ យើងនឹងអានការរៀបរាប់របស់ មរមនអំពីការបម្រើរបស់ពួកសាសន៍នីហ្វៃទាំងបី ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២៨:១៧ ដោយស្ងៀមស្ងាត់ ដោយរកមើលអ្វីដែលមរមនមិនបានដឹងអំពីលក្ខខណ្ឌនៃរាងកាយរបស់ពួកសាសន៍នីហ្វៃទាំងបី នៅពេលលោកបានសរសេរពីដំណើររឿងនេះ ។ (អ្នកអាចប្រាប់សិស្សថា នៅពេលក្រោយក្នុងមេរៀននេះ ពួកគេនឹងរៀនបន្ថែមទៀតអំពីការផ្លាស់ប្តូរដែលពួកសាសន៍នីហ្វៃទាំងបីបានជួប) ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី នីហ្វៃទី ៣ ២៨:១៨–២៣ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពីរបៀបដែលព្រះអម្ចាស់បានប្រទានពរដល់ពួកសាសន៍នីហ្វៃទាំងបី ដើម្បីឲ្យពួកលោកអាចបន្តបំណងដ៏សុចរិតរបស់ពួកលោក ។

- តើសាសន៍នីហ្វៃទាំងបីបានធ្វើអ្វីខ្លះដើម្បីបំពេញតាមបំណងរបស់គេក្នុងការនាំអ្នកដទៃមកកាន់ព្រះអង្គសង្គ្រោះ ?
- តើព្រះអម្ចាស់បានប្រទានពរយ៉ាងណាដល់ពួកលោក ដើម្បីអាចសម្រេចបំណងរបស់ពួកលោកបាន ?

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២៨:២៥–៣២ ដោយស្ងៀមស្ងាត់ ដោយរកមើលប្រជាជនដែលទទួលបានប្រយោជន៍ ហើយដែលនឹងទទួលបានប្រយោជន៍ពីការបម្រើរបស់សាសន៍នីហ្វៃទាំងបីនេះ ។ អ្នកអាចស្នើថា សិស្សគួរគូសចំណាំអ្វីដែលពួកគេរកឃើញ ។ (សូមចំណាំថា នីហ្វៃទី ៣ ២៨:២៧–២៨ បង្ហាញពីមូលហេតុមួយដែលយើងគួរប្រុងប្រយ័ត្នអំពីការជឿ និងការចែកចាយរឿងពីមនុស្សដែលអះអាងថាបានជួបនឹងសាសន៍នីហ្វៃទាំងបីនេះ ៖ មរមនលោកបានមានប្រសាសន៍ថា នៅក្នុងចំណោមប្រជាជនដែលពួកសាសន៍នីហ្វៃទាំងបីបានបម្រើ « នឹងពុំស្គាល់ពួកគេឡើយ ») ។

នីហ្វៃទី ៣ ២៨:៣៦–៤០

មរមនរៀនអំពីលក្ខណៈនៃការប្រែរូប

សូមសួរសិស្សថា តើពួកគេធ្លាប់មានសំណួរមួយអំពីដំណឹងល្អ ឬថាតើពួកគេធ្លាប់អានអ្វីមួយនៅក្នុងព្រះគម្ពីរដែលពួកគេមិនយល់ដែរឬទេ ។ សូមរំឭកពួកគេថា នៅពេលមរមនបានសរសេរអំពីការប្រែរូបជាលើកដំបូងអំពីពួកសាសន៍នីហ្វៃទាំងបី លោកបានមានប្រសាសន៍ថា លោកមិនបានយល់ច្បាស់ពីការផ្លាស់ប្តូរនៃលក្ខខណ្ឌរូបកាយរបស់ពួកគេក្នុងពេលពួកគេបម្រើនៅលើផែនដីឡើយ (សូមមើល នីហ្វៃទី ៣ ២៨:១៧) ។

- តើជាធម្មតាអ្នកនឹងទៅរកអ្នកណា នៅពេលអ្នកមានសំណួរអំពីដំណឹងល្អ ឬអំពីវគ្គព្រះគម្ពីរនោះ ? ហេតុអ្វី ?

សូមឲ្យសិស្សអាន នីហ្វៃទី ៣ ២៨:៣៦–៣៧ ដោយស្ងៀមស្ងាត់ ដើម្បីស្វែងរកអ្វីដែលមរមនបានធ្វើដើម្បីស្វែងរកចម្លើយចំពោះសំណួររបស់លោក ។

- តើគោលការណ៍អ្វីដែលយើងអាចរៀនពីមរមនអំពីរបៀបដើម្បីទទួលបានការយល់ដឹងបន្ថែមទៀត ? (ទោះបីជាសិស្សអាចមានចម្លើយខុសគ្នាក្តី សូមប្រាកដថា ពួកគេរកឃើញគោលការណ៍ដូចតទៅនេះ ៖ **នៅពេលយើងខ្វះការយល់ដឹង យើងគួរសូមដល់ព្រះវរបិតា នោះយើងនឹងទទួលបានការដឹកនាំ**) ។
- តើឧទាហរណ៍អ្វីខ្លះដែលបង្ហាញពីគោលការណ៍នេះ ?
- តើស្ថានភាពណាខ្លះដែលយើងអាចត្រូវសុំដល់ព្រះវរបិតាសូគ៌សម្រាប់ការយល់ដឹងបន្ថែមទៀត ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដែល ប្រធាន ស្តែនស៊ើរ ដបុលយូ ឃីមប៊ឹល បញ្ជាក់ពីកាលៈទេសៈមួយចំនួនដែលយើងគួរអធិស្ឋានសុំជំនួយ ៖

« យើងម្នាក់ៗត្រូវការជំនួយពីទ្រង់ជាខ្លាំង នៅពេលយើងស្វែងរកដើម្បីសិក្សាពីសេចក្តីពិតនៃដំណឹងល្អ ហើយបន្ទាប់មករស់នៅតាមវា នៅពេលយើងស្វែងរកជំនួយពីទ្រង់នៅក្នុងការសម្រេចចិត្តដ៏សំខាន់នៅក្នុងជីវិតរបស់យើង ការសម្រេចចិត្តដែលទាក់ទងនឹងការរៀនសូត្រ អាពាហ៍ពិពាហ៍ ការងារ កន្លែងរស់នៅ ការចិញ្ចឹមគ្រួសារ ការបម្រើដល់គ្នាទៅវិញទៅមកនៅក្នុងកិច្ចការនៃព្រះអម្ចាស់ និងការស្វែងរកការអភ័យទោសពីទ្រង់ និងការណែនាំបន្ត និងការការពារនៅក្នុងគ្រប់ការណ៍ដែលយើងធ្វើ ។ បញ្ជីនៃតម្រូវការរបស់យើងវែង ហើយពិត និងស្មោះត្រង់ ។ . . .

« ក្រោយពីការអធិស្ឋានដ៏យូរមក ខ្ញុំស្គាល់ពីសេចក្តីស្រឡាញ់ និងអំណាច ព្រមទាំងកម្លាំងដែលមកពីការអធិស្ឋានដ៏ស្មោះត្រង់ ហើយនិងដោយស្មោះស្ម័គ្រ ។ ខ្ញុំដឹងពីការត្រៀមរួចជាស្រេចរបស់ ព្រះវរបិតាយើងដើម្បីជួយយើងនៅក្នុងជីវិតរមែងស្លាប់របស់យើង ដើម្បីបង្រៀនយើង ដឹកនាំយើង ណែនាំយើង ។ ហេតុដូច្នេះហើយ ដោយសេចក្តីស្រឡាញ់ដ៏ធំ ព្រះអង្គសង្គ្រោះរបស់យើងបានមានបន្ទូលថា ‹ អ្វីដែលយើងប្រាប់ដល់មនុស្សម្នាក់យ៉ាងណា នោះយើងប្រាប់ដល់មនុស្សទាំងអស់យ៉ាងនោះដែរ ចូរអធិស្ឋានជានិច្ច › ។ (គ. និង ស. ៩៣:៤៩ ។) »(« Pray Always » *Ensign* ខែ តុលា ឆ្នាំ ១៩៨១ ទំព័រ ៣, ៦) ។

- តើអ្នកអាចបង្កើនសេចក្តីជំនឿរបស់អ្នកទៅលើអំណាចនៃការអធិស្ឋានដោយរបៀបណា ? តើនៅពេលណាដែលអ្នក និងគ្រួសាររបស់អ្នកទទួលបានចម្លើយចំពោះការអធិស្ឋានរបស់អ្នក ?

សូមលើកទឹកចិត្តសិស្សឲ្យទៅរកព្រះវរបិតាសូគ៍នៅក្នុងការអធិស្ឋាន នៅពេលពួកគេស្វែងរកការយល់ដឹងពីដំណឹងល្អ និងពេលជួបនឹងឧបសគ្គទាំងឡាយនៃជីវិត ។ សូមធ្វើទីបន្ទាល់អំពីពរជ័យដែលបានមកដល់ក្នុងជីវិតរបស់អ្នក នៅពេលអ្នកបាននាំយកឧបសគ្គ និងសំណួរទាំងឡាយទៅកាន់ព្រះវរបិតាសូគ៍ ។

សូមពន្យល់ថា បទពិសោធន៍នៃការផ្លាស់ប្តូរដែលពួកសាសន៍នីហ្វៃបីរូបនោះមាន ត្រូវបានហៅថា ការប្រែរូប ។ **អ្នកបម្រើដ៏ស្មោះត្រង់របស់ព្រះអម្ចាស់ខ្លះត្រូវបានប្រែរូបដើម្បីពួកគេអាចបន្តការបម្រើរបស់ពួកគេនៅលើផែនដី ។** នៅពេលមរមនបានបន្តសូរអំពីការផ្លាស់ប្តូរនេះ លោកបានរៀនអំពីលក្ខណៈនៃមនុស្សដែលបានប្រែរូប ។

សូមសរសេរ *មនុស្សដែលបានប្រែរូប* នៅលើក្តារខៀន ។ សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២៨:៣៧–៣៨ ព្ធ។ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលលោកមរមនបានរៀនអំពីការផ្លាស់ប្តូរដែលបានកើតឡើងនៅក្នុងរាងកាយនៃពួកសាសន៍នីហ្វៃទាំងបីនោះ ។

- តើមរមនបានរៀនអ្វីខ្លះអំពីមនុស្សដែលបានប្រែរូប ? (សូមឲ្យសិស្សម្នាក់ធ្វើជាអ្នកសរសេរ ហើយសរសេរនូវចម្លើយរបស់សិស្សផ្សេងទៀតនៅលើក្តារខៀន ។ ចម្លើយគួររួមមានថា មនុស្សដែលបានប្រែរូបមិនបាន « ភ្លក់នូវសេចក្តីស្លាប់ » ថាពួកគេមិនមានអារម្មណ៍ឈឺចាប់ ហើយថាពួកគេមិនបានជួបនឹងទុក្ខសោក លើកលែងតែទុក្ខសោកដែលពួកគេមានដោយសារតែអំពើបាបនៃមនុស្សលោកប៉ុណ្ណោះ) ។
- ហេតុអ្វីបានជាការផ្លាស់ប្តូររូបកាយរបស់ពួកគេគឺជារឿងដ៏ចាំបាច់ ? (អ្នកអាចឲ្យស្សិសរំពឹកឡើងវិញក្នុង នីហ្វៃទី ៣ ២៨:៦–៧ ។ ការផ្លាស់ប្តូរនេះចាំបាច់ ដើម្បីពួកគេអាចបំពេញបំណងដ៏សុចរិតរបស់គេដើម្បីបន្តនៅលើផែនដី និងបន្តនាំព្រលឹងមកកាន់ព្រះគ្រីស្ទរហូតដល់ការយាងមកជាលើកទីពីរបស់ព្រះអង្គសង្ត្រោះ) ។

សូមឲ្យសិស្សអាន នីហ្វៃទី ៣២៨:៣៩–៤០ ដោយស្ងៀមស្ងាត់ ដោយរកមើលព័ត៌មានបន្ថែមទៀតពីមនុស្សដែលបានប្រែរូប ។ នៅពេលសិស្សរៀបរាប់ សូមឲ្យអ្នកសរសេរផ្សេងទៀតសរសេរការរកឃើញរបស់គេនៅលើក្តារខៀន ។ (ចម្លើយអាចរួមមានថា មនុស្សដែលបានប្រែរូបមិនអាចត្រូវបានល្បួងដោយសាតាំងឡើយ ថាពួកគេត្រូវបានបន្សុទ្ធ និងបរិសុទ្ធ ហើយថា « អំណាចនៅលើផែនដី [មិនអាច] មានអំណាចលើពួកគេឡើយ » ។) អ្នកគួរពន្យល់ថា ទោះបីជាមនុស្សដែលបានប្រែរូបមិនត្រូវរងការឈឺចាប់នៃការស្លាប់ក្តី ពួកគេមិនត្រូវបានប្រោសឲ្យរស់ឡើងវិញនោះឡើយ ។ ពួកគេនឹងមិនទទួលបាន « ការផ្លាស់ប្តូរដ៏ធំ » នោះឡើយរហូតដល់ថ្ងៃនៃការជំនុំជម្រះ នៅពេលពួកគេនឹងត្រូវផ្លាស់ប្តូរពីភាពរមែងស្លាប់ទៅអមតភាពភ្លាម។— « តែក្នុងមួយពព្រិចភ្នែក » (សូមមើល នីហ្វៃទី ៣ ២៨:៨, ៤០) ។

សូមបញ្ចប់ដោយការធ្វើទីបន្ទាល់អំពីគោលការណ៍ និងគោលលទ្ធិដែលបានពិភាក្សានៅក្នុងថ្នាក់ ។ សូមឲ្យសិស្សធ្វើសកម្មភាពតាមការបំផុសគំនិតដែលពួកគេបានទទួលពីព្រះវិញ្ញាណ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ៣ ជំពូក ២៨ ។ ការប្រែរូប និងការផ្លាស់ប្តូរ

ពួកសាសន៍នីហ្វៃទាំងបីត្រូវបានប្រែរូប និងផ្លាស់ប្តូរ ។

ការប្រែរូប ដែលត្រូវបានលើកឡើងនៅក្នុង នីហ្វៃទី ៣២៨:១៣–១៧ គឺជា « លក្ខខណ្ឌនៃបុគ្គលដែលបានផ្លាស់ប្តូរជាបណ្តោះអាសន្ឋនៅក្នុងរូបកាយ និងនៅក្រៅរូបកាយ— ដែលត្រូវបានលើកឡើងទៅក្នុងកម្រិតខាងវិញ្ញាណដ៏ខ្ពស់មួយ— ដើម្បីឲ្យពួកគេអាចតស៊ូនឹងវត្តមាន និងសិរីល្អនៃរាងកាយនៃស្ថានសួគ៌ » (Guide to the Scriptures, «Transfiguration» scriptures.lds.org សូមមើលផងដែរ គ. និង ស. ៦៧:១១, ម៉ូសេ ១:១១) ។ ព្រះគម្ពីរប្រាប់ពីមនុស្សដែលត្រូវបានប្រែរូប រួមមានម៉ូសេ (សូមមើល ម៉ូសេ ១:៩–១១), ព្រះយេស៊ូវគ្រីស្ទ, ពេត្រុស, យ៉ាកុប និងយ៉ូហាន (សូមមើល ម៉ាថាយ ១៧:១–៨)និង យ៉ូសែប ស្មឹធ (សូមមើល យ៉ូសែបស្មឹធ—ប្រវត្តិ ១:១៤–២០) ។

មនុស្សដែលបានផ្លាស់ប្តូរគឺជា « បុគ្គលដែលត្រូវបានផ្លាស់ប្តូរដើម្បីឲ្យពួកគេមិនជួបនឹងការឈឺចាប់ ឬសេចក្តីស្លាប់រហូតដល់ការរស់ឡើងវិញរបស់គេទៅដល់អមតៈភាព » (Guide to the Scriptures «Translated Beings» scriptures.lds.org សូមមើលផងដែរ នីហ្វៃទី ៣២៨:៧–៩, ២០–២២, ៣៧–៤០) ។ គោលបំណងរបស់ពួកគេគឺដើម្បីនាំព្រលឹងទាំងឡាយមករកព្រះគ្រីស្ទ (សូមមើល នីហ្វៃទី ៣ ២៨:៩) ។ ព្រះគម្ពីររួមមានជំណើរឿងនៃមនុស្សដែលត្រូវបានផ្លាស់ប្តូរ រួមមានអេណុស (សូមមើល លោកុប្បត្តិ ៥:២៤, ហេព្រើរ ១១:៥), ម៉ូសេ (សូមមើល អាលម៉ា ៤៥:១៩), អេលីយ៉ា (សូមមើល របាក្សត្រទី ២ ២:១១), និង យ៉ូហាន ជាទីសំណព្ធ (សូមមើល យ៉ូហាន ២១:២២–២៣, គ. និង ស. ៧) ។

នីហ្វៃទី ៣ ២៩–៣០

សេចក្តីផ្តើម

នៅពេលមមនបានបញ្ចប់ដំណើររឿងនៃការយាងមករបស់ព្រះអង្គសង្គ្រោះនៅក្នុងចំណោមពួកសាសន៍នីហ្វៃនេះហើយ លោកបានពន្យល់ថា ការលេចចេញមកនៃព្រះគម្ពីរមរមននឹងជាទីសម្គាល់មួយដែលព្រះអម្ចាស់កំពុងបំពេញតាមសេចក្តីសញ្ញារបស់ទ្រង់ជាមួយនឹងវង្សអ៊ីស្រាអែល ។ លោកក៏បានព្រមានថា អ្នកណាដែលបដិសេធកិច្ចការរបស់ព្រះនឹងត្រូវឆ្លងការកាត់សេចក្តីរបស់ព្រះ ។ នៅទីបញ្ចប់ លោកបានកត់ត្រាពីការអញ្ជើញរបស់ព្រះអង្គសង្គ្រោះដល់មនុស្សទាំងអស់ឲ្យប្រែចិត្ត និងត្រូវបានរាប់នៅក្នុងចំណោមវង្សអ៊ីស្រាអែល ។

សូមតាមដានគោលដៅ និងឧបសគ្គទាំងឡាយ

នៅផ្នែកនៃមេរៀនទី ១៣១ អ្នកបានលើកទឹកចិត្តសិស្សឲ្យសរសេរអំពីបទពិសោធន៍ដែលបានពង្រឹងដល់ពួកគេខាងវិញ្ញាណ ។ មុនពេលអ្នកចាប់ផ្តើមមេរៀនថ្ងៃនេះ សូមគិតពីការរំឭកពួកគេអំពីឧបសគ្គនេះ ។ អ្នកក៏អាចផ្តល់ឱកាសដល់ពួកគេឲ្យនិយាយអំពីរបៀបដែលពួកគេបានទទួលប្រយោជន៍ពីការកត់ត្រាបទពិសោធន៍របស់ពួកគេដែរ ។

យោបល់ទាំងឡាយសម្រាប់ការបង្រៀន

នីហ្វៃទី ៣ ២៩

មរមនបានថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់នឹងបំពេញតាមសេចក្តីសញ្ញារបស់ទ្រង់ជាមួយនឹងវង្សអ៊ីស្រាអែលនៅក្នុងថ្ងៃចុងក្រោយ

សូមគូសតារាងខាងក្រោមនៅលើក្តារខៀនមុនពេលចាប់ផ្តើមថ្នាក់ (ឬរៀបចំជាក្រដាសចែកដល់សិស្សម្នាក់ៗ) ៖

_____ ១. ពួកសាសន៍ដទៃ	ក. អត្ថន័យពីរ ៖ (១) កូនចៅនៃព្យាការី យ៉ាកុប ព្រះគម្ពីរសញ្ញាចាស់(អ៊ីស្រាអែល) ដែលព្រះអម្ចាស់បានធ្វើសេចក្តីសញ្ញាជាមួយ និង (២) អ្នកជឿដ៏ពិតលើព្រះយេស៊ូវគ្រីស្ទ ដែលបានធ្វើសេចក្តីសញ្ញាជាមួយនឹងព្រះ
_____ ២. វង្សអ៊ីស្រាអែល	ខ. សេចក្តីសន្យាមួយដល់ពួកអ្នកស្មោះត្រង់ដែលបានបញ្ចូលពរជ័យនៃដំណឹងល្អ អ្នកដឹកនាំបព្វជិតភាព គ្រួសារដ៏អស់កល្បជានិច្ច និងដែនដីមរតក
_____ ៣. ការច្រានចេញ	គ. អត្ថន័យពីរ ៖ (១) ប្រជាជនដែលមិនមែនជាសាសន៍អ៊ីស្រាអែល ឬមិនមែនជាខ្សែស្រឡាយសាសន៍យូដា និង (២) ប្រជាជនដែលគ្មានដំណឹងល្អ
_____ ៤. សេចក្តីសញ្ញារបស់ព្រះអម្ចាស់ជាមួយនឹងអ៊ីស្រាអែល	ឃ.ការក្រៀមក្រំ និងការសោកស្តាយជាខ្លាំង
_____ ៥. វេទនា	ង. ដើម្បីបដិសេធ ឬច្រានចោលដោយការមើលងាយ ឬស្អប់ខ្ពើម

សូមចាប់ផ្តើមថ្នាក់ដោយការសុំឲ្យសិស្សផ្គូរផ្គងពាក្យនៅក្នុងកូឡោនទីមួយនៃតារាងទៅនឹងនិយមន័យត្រឹមត្រូវរបស់វានៅក្នុងកូឡោនទីពីរ (ចម្លើយ ៖ ១-គ, ២-ក, ៣-ង, ៤-ខ, ៥-ឃ) ។ នៅពេលសិស្សរៀបរាប់ពីចម្លើយរបស់គេ សូមប្រាកដថា ពួកគេយល់ពីនិយមន័យនីមួយៗ ។ អ្នកអាចធ្វើការណ៍នេះដោយសុំឲ្យសិស្សពន្យល់ពីនិយមន័យជាពាក្យសម្តីពួកគេផ្ទាល់ ឬដោយការប្រើពាក្យ ឬឃ្លានីមួយៗជាប្រយោគ ។ សូមប្រាប់សិស្សថា និយមន័យទាំងនេះនឹងជួយពួកគេឲ្យយល់ នីហ្វៃទី ៣ ២៩–៣០ កាន់តែច្បាស់ ។

សូមពន្យល់ថា ក្រោយពីមមនបានសរសេរអំពីការយាងមករបស់ព្រះអង្គសង្គ្រោះទៅជូបនឹងពួកសាសន៍នីហ្វៃហើយ លោកបានព្យាករណ៍អំពីការបំពេញនៃសេចក្តីសន្យារបស់ព្រះអម្ចាស់នៅក្នុងថ្ងៃចុងក្រោយ ។ សូមសួរសិស្សថា តើពួកគេធ្លាប់ជួបនឹងការបំពេញនៃការសន្យាដ៏ទេវភាពឬទេ មិនថាត្រូវបានផ្តល់នៅក្នុងព្រះគម្ពីរ ដោយព្យាការី តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ឬតាមរយៈពរជ័យនៃបព្វជិតភាពមួយ ។ សូមឲ្យសិស្សពីរបីនាក់ភ្ជាប់បទពិសោធន៍របស់ពួកគេ ប៉ុន្តែសូមប្រាកដដើម្បីរំឭកពួកគេថា ពួកគេមិនគួរចែកចាយបទពិសោធន៍ណាដែលឯកជន ឬផ្ទាល់ខ្លួនពេកនោះទេ ។

- **តើអ្នកគិតថា ហេតុអ្វីបានជាមនុស្សខ្លះអាចសង្ស័យថា ព្រះនឹងរក្សាសេចក្តីសន្យារបស់ទ្រង់ ?**
- **តើអ្នកដឹងថា ព្រះរក្សាសេចក្តីសន្យារបស់ទ្រង់ដោយរបៀបណា ?**

សូមសរសេរពាក្យ *នៅពេល* និង *បន្ទាប់មក* នៅលើក្តារខៀន ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣២៩:១–៣ ដោយស្ងាត់ស្ងៀម ដោយរកមើលពាក្យ ឬឃ្លាដែលមាននៅលើក្តារខៀន ។ សូមពន្យល់ថា ពាក្យទាំងនេះនឹងជួយពួកគេឲ្យរកឃើញហេតុការណ៍មួយដែលនឹង

បង្ហាញថា ព្រះអម្ចាស់រក្សាសេចក្តីសន្យារបស់ទ្រង់ជាមួយនឹងវង្សអ៊ីស្រាអែលនៅថ្ងៃចុងក្រោយ ។ (វាអាចជួយបានច្រើនដើម្បីពន្យល់ថា ឃ្លា « ពាក្យទាំងឡាយ » នៅក្នុង នីហ្វៃទី ៣ ២៩:១ សំដៅលើការសរសេរនៃព្រះគម្ពីរមរមន) ។

- តើអ្នកនឹងសង្ខេបការព្យាករណ៍ដែលបានកត់ត្រានៅក្នុងខគម្ពីរទាំងនេះដោយរបៀបណា ? (សិស្សអាចប្រើពាក្យខុសៗគ្នា ប៉ុន្តែពួកគេគួរតែឃើញនូវសេចក្តីពិតខាងក្រោមនេះ ៖ **ការលេចចេញមកនៃព្រះគម្ពីរមរមនគឺជាទីសម្គាល់មួយដែលព្រះកំពុងបំពេញសេចក្តីសញ្ញារបស់ទ្រង់ដើម្បីប្រមូលពួកសាសន៍អ៊ីស្រាអែលនៅថ្ងៃចុងក្រោយ ។** អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំសេចក្តីពិតនេះនៅក្នុងការសង្ខេបជំពូកនៃ នីហ្វៃទី ៣២៩) ។

សូមឲ្យសិស្សលើកព្រះគម្ពីរមរមនរបស់គេឡើង ។ សូមពន្យល់ថា ពួកគេមាននៅក្នុងដៃរបស់ពួកគេនូវការបំពេញនៃការព្យាករណ៍របស់មរមន ហើយថាពួកគេអាចប្រាកដថា ព្រះអម្ចាស់កំពុងរៀបចំវាស្រ្តារបស់ទ្រង់សម្រាប់ការយាងមករបស់ទ្រង់ ។ សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ័សុល អិម ណិលសុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« ព្រះគម្ពីរមរមនគឺជាទីសម្គាល់ដ៏ពិតមួយថា ព្រះអម្ចាស់បានចាប់ផ្តើមប្រមូលកូនចៅនៃសេចក្តីសញ្ញាអ៊ីស្រាអែលរបស់ទ្រង់ហើយ ។ . . .

« ពិតណាស់ ព្រះអម្ចាស់មិនបានភ្លេចនោះទេ ! ទ្រង់បានប្រទានពរដល់យើង និងអ្នកដទៃទូទាំងពិភពលោកដោយព្រះគម្ពីរមរមន ។ . . . ព្រះគម្ពីរនេះជួយយើងឲ្យធ្វើសេចក្តីសញ្ញាជាមួយនឹងព្រះ ។ ព្រះគម្ពីរនេះអញ្ជើញយើងឲ្យចងចាំដល់ទ្រង់ ហើយស្គាល់បុត្រាដ៏ជាទីស្រលាញ់របស់ទ្រង់ ។ ព្រះគម្ពីរនេះគឺជាសក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ » (« Covenants » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ៨៨) ។

- តើការពិតដែលថាយើងមានព្រះគម្ពីរមរមន ជាសាក្សីមួយថា ព្រះនឹងរក្សាសេចក្តីសន្យារបស់ទ្រង់ដោយរបៀបណា ?

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖ *ហេតុអ្វីបានជាពួកបរិសុទ្ធថ្ងៃចុងក្រោយចាប់អារម្មណ៍នឹងសេចក្តីសញ្ញារបស់ព្រះអម្ចាស់ជាមួយនឹងវង្សអ៊ីស្រាអែល ?* សូមឲ្យសិស្សស្តាប់រកចម្លើយចំពោះសំណួរនេះ នៅពេលអ្នកអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រ័សុល អិម ណិលសុន ដែលបានរៀបរាប់ពីសេចក្តីសន្យាដែលជាផ្នែកនៃសេចក្តីសញ្ញារបស់ព្រះអម្ចាស់ជាមួយនឹងវាស្រ្តារបស់ទ្រង់ ។ (អ្នកគួរឲ្យក្រដាសនៃសេចក្តីថ្លែងការណ៍នេះដល់សិស្សម្នាក់ៗ ។)

« សេចក្តីសញ្ញាដែលព្រះបានធ្វើជាមួយនឹងអ័ប្រាហាំ ហើយក្រោយមកបានបញ្ជាក់ជាថ្មីជាមួយនឹងអ៊ីសាក និងយ៉ាកុប . . . រួមមានសេចក្តីសន្យាមួយចំនួន ៖

«• ព្រះយេស៊ូវ ជាព្រះគ្រីស្ទនឹងប្រសូតតាមរយៈពូជពង្សរបស់អ័ប្រាហាំ ។

“• កូនចៅរបស់អ័ប្រាហាំនឹងមានចំនួនច្រើន នឹងទទួលបានការកើនឡើងដ៏អស់កល្បមួយ ហើយក៏ទទួលបានបព្វជិតភាពផងដែរ ។

“• អ័ប្រាហាំនឹងក្លាយជាឪពុកនៃសាសន៍ជាច្រើន ។

«• ដែនដីមួយចំនួននឹងត្រូវទទួលគ្រងដោយកូនចៅរបស់លោក ។

«• ជាតិសាសន៍ទាំងអស់នៅលើផែនដីនឹងមានពរដោយសារពូជពង្សរបស់លោក ។

«• ហើយសេចក្តីសញ្ញានោះនឹងមានជារៀងរហូត— ទោះបីជា ‹ រាប់ពាន់ជំនាន់ក្តី › ។

« សេចក្តីសន្យាទាំងនេះមួយចំនួនត្រូវបានបំពេញហើយ ខ្លះទៀតនៅមិនទាន់សម្រេចទេ ។ . . .

« ពួកយើងខ្លះគឺជាពូជពិតរបស់អ័ប្រាហាំ អ្នកខ្លះទៀតត្រូវបានប្រមូលទៅក្នុងគ្រួសាររបស់លោកដោយការអនុញ្ញាត ។ ព្រះអម្ចាស់មិនបានធ្វើឲ្យមានការខុសគ្នាទេ ។ រួមគ្នា យើងទទួលបានពរជ័យដែលបានសន្យាទាំងនេះ —ប្រសិនបើយើងស្វែងរកព្រះអម្ចាស់ ហើយគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ។ . . .

« . . . ព្រិកហាំ យ៉ង់ បានមានប្រសាសន៍ថា ៖ ‹ ពួកបរិសុទ្ធថ្ងៃចុងក្រោយទាំងអស់ចូលទៅក្នុងសេចក្តីសញ្ញាថ្មី ហើយអស់កល្បជានិច្ចនោះ នៅពេលពួកគេចូលទៅក្នុងសាសនាចក្រនេះ › » (« Covenants » ទំព័រ ៨៧–៨៨ ដោយដកស្រង់ពី *Teachings of Presidents of the Church: Brigham Young* | ឆ្នាំ ១៩៩៧ | ទំព័រ ៦២) ។

- ដោយការប្រើអ្វីដែលអ្នកបានរៀនពីសេចក្តីថ្លែងការណ៍របស់អែលឌើរ ណែលសុន តើអ្នកអាចឆ្លើយនឹងសំណួរនៅលើក្តារខៀនបានដោយរបៀបណា ? (សិស្សអាចផ្តល់ចម្លើយផ្សេងៗគ្នា ប៉ុន្តែសូមប្រាកដថា ពួកគេរកឃើញនូវសេចក្តីពិតខាងក្រោម ៖ **ពួកបរិសុទ្ធថ្ងៃចុងក្រោយគឺជាផ្នែកនៃវាស្រ្តានៃសេចក្តីសញ្ញារបស់ព្រះអម្ចាស់ ហើយយើងមានទំនួលខុសត្រូវដើម្បីប្រទានពរដល់សាសន៍ទាំងឡាយ ។**
- តើពួកបរិសុទ្ធថ្ងៃចុងក្រោយស្វែងរកបៀបដើម្បីប្រទានពរដល់សាសន៍ទាំងឡាយនៅលើផែនដីបានដោយរបៀបណា ?
- តើព្រះគម្ពីរមរមនមានតួនាទីអ្វីខ្លះនៅក្នុងការខិតខំនេះ ?

សូមសំដៅលើពាក្យ *ប្រានចេញ* និង*វេទនា* ពីសកម្មភាពផ្គូផ្គង ។ សូមពន្យល់ថា មរមនបានដឹងថា នៅក្នុងថ្ងៃចុងក្រោយ នឹងមានអ្នកដែលបដិសេធព្រះគម្ពីរមរមន និងភស្តុតាងផ្សេងទៀតនៃការបំពេញសេចក្តីសញ្ញារបស់ព្រះអម្ចាស់ជាមួយនឹងវាស្រ្តារបស់ទ្រង់ ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣២៩:៤–៩ ដោយស្ងៀមស្ងាត់ ដោយរកមើលអ្វីដែលនឹងកើតឡើងដល់អ្នកដែលបដិសេធព្រះអង្គសង្គ្រោះ និងកិច្ចការរបស់ទ្រង់ ។ ក្រោយពីសិស្សពន្យល់អ្វីដែលពួកគេបានរកឃើញហើយ អ្នកអាចណែនាំឲ្យពួកគេសរសេរសេចក្តីពិតខាងក្រោមនៅក្នុងព្រះគម្ពីររបស់គេ ៖ **ទុក្ខសោកនឹងកើតមានដល់អ្នកដែលបដិសេធព្រះយេស៊ូវគ្រីស្ទ និងកិច្ចការរបស់ទ្រង់ ។**

- តើហេតុអ្វីបានជាទុក្ខសោកគឺជាលទ្ធផលពីធម្មជាតិមួយនៃការបដិសេធព្រះយេស៊ូវគ្រីស្ទ និងកិច្ចការរបស់ទ្រង់ ?
- តើអ្នកនឹងឆ្លើយតបចំពោះនរណាម្នាក់ដែលនិយាយថា ព្រះអម្ចាស់មិនបានមានបន្ទូលមកកាន់មនុស្ស ឬបានសម្តែងអព្ភូតហេតុនោះទេដោយរបៀបណា ?

- តើយើងអាចស្គាល់ ហើយកោតសរសើរដល់ព្រះអម្ចាស់ និងកិច្ចការរបស់ទ្រង់នៅក្នុងជីវិតរបស់យើងឲ្យបានប្រសើរជាងមុនដោយរបៀបណា ?

នីហ្វៃទី ៣ ជំពូក ៣០

ព្រះអម្ចាស់ជាស់គឿនដល់សាសន៏ដទៃឲ្យប្រែចិត្ត ហើយមករកទ្រង់

សូមសំដៅលើពាក្យ *សាសន៏ដទៃ* ពីសកម្មភាពផ្តួផ្គង ។ សូមប្រាប់សិស្សថានៅក្នុង នីហ្វៃទី ៣ ៣០ មរមនបានបំពេញតាមព្រះបញ្ញត្តិមួយពីព្រះអម្ចាស់ដើម្បីកត់ត្រាការអញ្ជើញពីព្រះយេស៊ូវគ្រីស្ទជាពិសេសដល់ពួកសាសន៏ដទៃ ឬមនុស្សដែលគ្មានដំណឹងល្អ ។ សូមឲ្យសិស្សអាន នីហ្វៃទី ៣ ៣០:១–២ ដោយស្ងៀមស្ងាត់ ដោយរកមើលការអញ្ជើញដល់សាសន៏ដទៃឲ្យបានច្រើនតាមដែលពួកគេអាចរកឃើញ ។ ក្រោយពីពួកគេរៀបរាប់អ្វីដែលពួកគេបានរកឃើញ សូមស្វរ ៖

- តើការអញ្ជើញទាំងនេះណាមួយ ដែលអ្នកគិតថា អាចជាការសង្ខេបមួយនៃការអញ្ជើញផ្សេងទៀត ? (ការអញ្ជើញឲ្យមករកព្រះគ្រីស្ទ រួមមាន ការប្រែចិត្ត បុណ្យជ្រមុជទឹក ការទទួលព្រះវិញ្ញាណបរិសុទ្ធ និងការត្រូវបានរាប់នៅក្នុងចំណោមរាស្ត្ររបស់ព្រះអម្ចាស់ ។)
- តើពរជ័យអ្វីដែលព្រះយេស៊ូវគ្រីស្ទសន្យានឹងសាសន៏ដទៃ ប្រសិនបើពួកគេនឹងមករកទ្រង់ ? (ការផ្តាច់បាប ការពោរពេញដោយព្រះវិញ្ញាណបរិសុទ្ធ និងការត្រូវបានរាប់នៅក្នុងចំណោមរាស្ត្ររបស់ទ្រង់) ។
- ហេតុអ្វីបានជាការដែលត្រូវបានរាប់បញ្ចូលទៅក្នុងរាស្ត្ររបស់ទ្រង់គឺជាពរជ័យមួយ ?

សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***ប្រសិនបើយើងមករកព្រះគ្រីស្ទ នោះយើងនឹងត្រូវបានរាប់ចូលនៅក្នុងរាស្ត្ររបស់ទ្រង់ ។*** សូមពន្យល់ថា ទោះបីជា នីហ្វៃទី ៣ ៣០:២ សំដៅទៅកាន់អ្នកដែលមិនមែនជាសមាជិកនៃសាសនាចក្រក្តី យើងអាចប្រើការអញ្ជើញរបស់ព្រះយេស៊ូវគ្រីស្ទដើម្បីវាស់វែងពីការខិតខំរបស់យើងផ្ទាល់ដើម្បីរក្សាសេចក្តីសញ្ញាដែលយើងបានធ្វើជាមួយនឹងព្រះ ។ សូមធ្វើទីបន្ទាល់អំពីពរជ័យដែលបានកើតមានតាមរយៈការរក្សាសេចក្តីសញ្ញារបស់យើង និងព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ។

ការរំឲ្យក នីហ្វៃទី ៣

សូមចំណាយពេលខ្លះដើម្បីជួយសិស្សឲ្យរំឲ្យក គម្ពីរនីហ្វៃទី ៣ ឡើងវិញ ។ សូមឲ្យពួកគេគិតអំពីអ្វីដែលពួកគេបានរៀនពីគម្ពីរនេះទាំងនៅក្នុងថ្នាក់សិក្ខាសាលា និងនៅក្នុងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួនរបស់គេ ។ ប្រសិនបើចាំបាច់ សូមឲ្យពួកគេសង្ខេបដោយខ្លីៗ អំពីសេចក្តីសង្ខេបជំពូកខ្លះនៅក្នុងនីហ្វៃទី ៣ ដើម្បីជួយពួកគេឲ្យចងចាំ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សបីបួននាក់ចែកចាយអ្វីមួយក្នុងនីហ្វៃទី ៣ ដែលបំផុសគំនិតដល់ពួកគេ ឬដែលបានជួយដល់ពួកគេឲ្យមានសេចក្តីជំនឿកាន់តែខ្លាំងទៅលើព្រះយេស៊ូវគ្រីស្ទ ។

ការរំឲ្យកចំណេះចំណានខគម្ពីរ

សូមឲ្យក្រជាសមួយសន្លឹកដល់សិស្សម្នាក់ៗ ។ សូមឲ្យពួកគេសរសេរសំបុត្រមួយទៅកាន់មនុស្សម្នាក់ (មិនថាមនុស្សដែលពួកគេស្រមើស្រមៃឃើញ ឬមនុស្សដែលគេស្គាល់ឡើយ) ដែលមិនមែនជាសមាជិកសាសនាចក្រ ។ សូមណែនាំឲ្យពួកគេសិក្សាវគ្គចំណេះចំណានខគម្ពីររកសេចក្តីពិត ដែលពួកគេអាចប្រើដើម្បីអញ្ជើញអ្នកទទួលសំបុត្រនេះឲ្យមករកព្រះគ្រីស្ទ ហើយត្រូវបានរាប់បញ្ចូលនៅក្នុងចំណោមរាស្ត្ររបស់ទ្រង់ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីដែលពួកគេបានសរសេរ ។

កំណត់ចំណាំ ៖ ប្រវែងនៃមេរៀននេះអាចឲ្យមានពេលសម្រាប់សកម្មភាពនេះ ។ សម្រាប់សកម្មភាពរំឲ្យកចំណេះចំណានខគម្ពីរផ្សេងទៀត សូមមើលឧបសម្ព័ន្ធនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

នីហ្វៃទី ៣៣០:១–២ ។ ការប្រមូលអ៊ីស្រាអែល

ប្រធាន ស្តែនស៊ើរ ជបុលយូ យ៉ឺមប៉ឺល បានបង្រៀនថា ៖

« ការប្រមូលអ៊ីស្រាអែលរួមមាននូវការចូលរួមក្នុងសាសនាចក្រដ៏ពិត និងការទទួលបានចំណេះដឹងពីព្រះដ៏ពិត ។ . . . ហេតុដូច្នេះហើយ មនុស្សណាក៏ដោយដែលបានទទួលយកដំណឹងល្អដែលស្តារឡើងវិញ និងអ្នកដែលពេលនេះស្វែងរកថ្វាយបង្គំដល់ព្រះអម្ចាស់ជាកាសាកំណើតរបស់គេ និងជាមួយនឹងពួកបរិសុទ្ធនៅក្នុងសាសន៍ដែលពួកគេរស់នៅបានអនុវត្តតាមច្បាប់នៃការប្រមូលអ៊ីស្រាអែល ហើយគឺជាអ្នកគ្រងមរតកនៃពរជ័យដែលបានសន្យាទាំងឡាយដល់ពួកបរិសុទ្ធនៅក្នុងថ្ងៃចុងក្រោយនេះ » (*The Teachings of Spencer W. Kimball* ,ed. Edward L. Kimball [ឆ្នាំ ១៩៨២] ទំព័រ ៤៣៩) ។

មេរៀនសិក្សានៅផ្ទះ

នីហ្វៃទី ៣២៣–៣០ (មេរៀនទី ២៧)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀននៅពេលពួកគេសិក្សា នីហ្វៃទី ៣ ២៣–៣០ (មេរៀនទី ២៧) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និងគោលការណ៍ទាំងនេះតែពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធនៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (នីហ្វៃទី ៣ ២៣)

សិស្សបានបន្តសិក្សាព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទទៅដល់ពួកសាសន៍នីហ្វៃ ។ ពួកគេបានរៀនថា ព្រះអង្គសង្គ្រោះបានបង្គាប់ឲ្យយើងសិក្សាស្រាវជ្រាវដោយឧស្សាហ៍ព្យាយាមនូវពាក្យរបស់អេសាយ និងពីព្យាការីផ្សេងទៀត ។ នៅពេលព្រះអង្គសង្គ្រោះបានដាក់ទោសប្រជាជនដោយសារការមិនរក្សាកំណត់ត្រាដ៏ត្រឹមត្រូវនៃប្រវត្តិខាងវិញ្ញាណផ្ទាល់ខ្លួនរបស់គេ នោះសិស្សបានរៀនថា នៅពេលយើងកត់ត្រាបទពិសោធន៍ខាងវិញ្ញាណ យើងអញ្ជើញឲ្យព្រះអម្ចាស់ប្រទានដល់យើងនូវវិវរណៈបន្ថែមទៀត ។

ថ្ងៃទី ២ (នីហ្វៃទី ៣ ២៤–២៦)

នៅពេលសិស្សបានសញ្ជឹងគិតពីពាក្យរបស់ម៉ាឡាគី ព្រះយេស៊ូវគ្រីស្ទបានបង្រៀនដល់សាសន៍នីហ្វៃ នោះពួកគេត្រូវបានព្រមានថា នៅពេលការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ទ្រង់នឹងបន្សុទ្ធប្រជាជនរបស់ទ្រង់ ហើយកាត់សេចក្តីពួកទុច្ចរិត ។ ការឆ្លុះបញ្ចាំងបន្ថែមទៀតនៅលើគោលការណ៍នៃជង្វាយមួយភាគក្នុងដប់ និងការត្រឡប់មកវិញរបស់អេលីយ៉ានៅថ្ងៃចុងក្រោយដូចដែលបានព្យាករណ៍នោះ បានជួយសិស្សឲ្យដឹងថា ប្រសិនបើយើងវិលទៅរកព្រះអម្ចាស់វិញ ទ្រង់នឹងវិលមករកយើង ហើយថា នៅពេលដួងចិត្តរបស់យើងបានបែរទៅរកពួកឪពុករបស់យើង យើងកំពុងជួយរៀបចំផែនដីសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ ការពន្យល់របស់មរមនពីហេតុផលដែលលោកមិនបានបញ្ចូលរាល់ការបង្រៀនរបស់ព្រះអង្គសង្គ្រោះនៅក្នុងចំណោមសាសន៍នីហ្វៃ បានជួយឲ្យសិស្សរកឃើញថា នៅពេលយើងជឿលើអ្វីដែលព្រះបានបើកសម្តែង នោះយើងរៀបចំខ្លួនយើងដើម្បីទទួលបានវិវរណៈដ៏ធំជាងនេះ ។

ថ្ងៃទី ៣ (នីហ្វៃទី ៣ ២៧)

ខណៈពេលដែលពួកសិស្សសាសន៍នីហ្វៃទាំងដប់ពីរនាក់បានបន្តអធិស្ឋាន ហើយតមអាហារ នោះព្រះអង្គសង្គ្រោះបានយាងមកជួបនឹងពួកគេ ហើយបានពន្យល់ថា សាសនាចក្រដ៏ពិតនៃព្រះយេស៊ូវគ្រីស្ទត្រូវបានហៅតាមព្រះនាមរបស់ទ្រង់ ហើយស្ថាបនានៅលើដំណឹងល្អរបស់ទ្រង់ ។ ពួកសិស្សក៏បានរៀនចេញពីអ្វីដែលព្រះអង្គសង្គ្រោះបានបង្រៀនដល់ពួកសិស្សទ្រង់ផងដែរថា គ្រឹះនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទគឺថា ទ្រង់បានធ្វើតាមព្រះឆន្ទៈរបស់ព្រះវរបិតាទ្រង់ដើម្បីសម្រេចបានជង្វាយធួន ។ ដោយមានការយល់ដឹងនៃដំណឹងល្អនេះ សិស្សក៏បានរៀនថា ប្រសិនបើយើងរស់នៅតាមគោលការណ៍នៃដំណឹងល្អ នោះយើងអាចឈរដោយឥតកំហុសនៅចំពោះមុខព្រះនៅថ្ងៃចុងក្រោយ ។

ថ្ងៃទី ៤ (នីហ្វៃទី ៣ ២៨–៣០)

នៅពេលព្រះយេស៊ូវគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញបានផ្តល់កិត្តិយសដល់បំណងប្រាថ្នារបស់សិស្សទ្រង់ដែលជាសាសន៍នីហ្វៃនោះ សិស្សបានរៀនថា ព្រះអម្ចាស់ប្រទានពរដល់យើងស្របតាមបំណងប្រាថ្នាដ៏សុចរិតរបស់យើង ។ ចេញពីគំរូរបស់មរមនក្នុងការទូលសូមចំណេះដឹងបន្ថែមទៀតពីព្រះអម្ចាស់ដែលទាក់ទងទៅនឹងពួកសាសន៍នីហ្វៃទាំងបីរូបនោះ សិស្សបានរៀនថា ប្រសិនបើយើងទូលសូមការយល់ដឹងពីព្រះអម្ចាស់ នោះយើងនឹងទទួលបានវិវរណៈ ។ ការសរសេរបញ្ចប់របស់ មរមនស្តីពីការបម្រើរបស់ព្រះអង្គសង្គ្រោះនៅក្នុងចំណោមពួកសាសន៍នីហ្វៃបានបង្រៀនសិស្សថា ការលេចចេញមកនៃព្រះគម្ពីរមរមនគឺជាទីសម្គាល់មួយថា ព្រះអម្ចាស់កំពុងបំពេញតាមសេចក្តីសញ្ញារបស់ទ្រង់ជាមួយនឹងវង្សនៃអ៊ីស្រាអែល ហើយថាប្រសិនបើយើងមករកព្រះគ្រីស្ទ នោះយើងអាចត្រូវបានរាប់បញ្ចូលនៅក្នុងចំណោមការស្រែរបស់ទ្រង់ ។

សេចក្តីផ្តើម

ខណៈពេលមានគោលការណ៍ដ៏មានតម្លៃជាច្រើនដែលមាននៅក្នុង នីហ្វៃទី ៣ ២៣–៣០ មេរៀននេះពាក់កណ្តាលដំបូងផ្តោតលើអ្វីដែលសិស្សអាចរៀននៅក្នុង នីហ្វៃទី ៣ ២៤–២៥ អំពីការរៀបចំសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ ។ មេរៀនពាក់កណ្តាលទៀតផ្តោតលើគោលការណ៍នៅក្នុង នីហ្វៃទី ៣ ២៧ ដែលអាចជួយសិស្សឲ្យគិតពីអត្តន័យនៃការធ្វើជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ និងពីរបៀបដែលពួកគេអាចប្រែក្លាយដូចជាទ្រង់ ។

យោបល់ទាំងឡាយសម្រាប់ការបង្រៀន

នីហ្វៃទី ៣ ២៣–២៦

ព្រះយេស៊ូវគ្រីស្ទដែលបានរស់ឡើងវិញអធិប្បាយព្រះគម្ពីរដល់ពួកសាសន៍នីហ្វៃ

សូមឲ្យសិស្សផ្តល់ឧទាហរណ៍ពីហេតុការណ៍ដែលតម្រូវឲ្យមានការរៀបចំដោយយកចិត្តទុកដាក់ក្នុងរយៈពេលមួយដ៏យូរ ។ (ឧទាហរណ៍អាចរួមមានការប្រកួតក្នុងចម្ងាយឆ្ងាយ ការប្រគុំតន្ត្រី ឬការសម្តែងល្ខោន) ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលអាចកើតឡើងដល់មនុស្សម្នាក់ដែលបានព្យាយាមចូលរួមនៅក្នុងព្រឹត្តិការណ៍នេះដោយគ្មានការរៀបចំខ្លួនដ៏ចាំបាច់នោះ ។

សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ២៤:២ ហើយបន្ទាប់មកសូមសួរសិស្សថា តើពួកគេគិតថាហេតុការណ៍អ្វីទៅដែលព្យាការីម៉ាឡាគី បានប្រាប់ឲ្យដឹងជាមុន ។ នៅពេលសិស្សបានរកឃើញ « ថ្ងៃនៃការយាងមករបស់ទ្រង់ » ជាការយាងមកជាលើកទីពីររបស់ព្រះយេស៊ូវគ្រីស្ទ សូមឲ្យពួកគេគូសចំណាំសំណួរដែលម៉ាឡាគីបានសួរ ៖ « តើនរណាដែលអាចគោរពតាមថ្ងៃនៃការយាងមករបស់ទ្រង់ ហើយតើនរណាដែលនឹងឈរនៅពេលទ្រង់បានលេចមក ?»

សូមសួរ ៖ ហេតុអ្វីបានជាសំណួរនេះសំខាន់ចំពោះអ្នកដែលរស់នៅក្នុងថ្ងៃចុងក្រោយដើម្បីគិតពិចារណា ?

សូមឲ្យសិស្សម្នាក់អានឮៗនូវការពន្យល់ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយដែលទាក់ទងនឹងរបៀបដែលការបង់ដង្វាយមួយភាគក្នុងដប់ អាចជួយយើងឲ្យរៀបចំសម្រាប់ការយាងមកជាលើកទីពីររបស់ព្រះអង្គសង្គ្រោះ ។

« តាមរយៈការសម្រេចចិត្តរបស់យើងនាពេលនេះដើម្បីក្លាយជាអ្នកបង់ដង្វាយមួយភាគក្នុងដប់ពេញលេញ និងការខិតខំដ៏ខ្ជាប់ខ្ជួនដើម្បីគោរពតាម នោះយើងនឹងត្រូវបានពង្រឹងនៅក្នុងសេចក្តីជំនឿយើង ហើយនៅពេលកំណត់ ដួងចិត្តរបស់យើងនឹងត្រូវបានបន្ទន់ ។ វាគឺជាការផ្លាស់ប្តូរនៅក្នុងដួងចិត្តរបស់យើងតាមរយៈជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ លើសពីការថ្វាយប្រាក់កាស ឬរបស់បរបស់យើងនោះហើយ ដែលអាចធ្វើឲ្យព្រះអម្ចាស់សន្យានូវការការពារដល់អ្នកបង់ដង្វាយមួយភាគក្នុងដប់ពេញលេញនៅក្នុងថ្ងៃចុងក្រោយ ។ យើងអាចមានទំនុកចិត្តថា យើងនឹងសក្តិសមចំពោះពរជ័យនៃការការពារនោះ ប្រសិនបើយើងតាំងចិត្តបង់ដង្វាយមួយភាគក្នុងដប់ឲ្យពេញលេញឥឡូវនេះ ហើយខ្ជាប់ខ្ជួនក្នុងការធ្វើដូច្នោះ » (« “Spiritual Preparedness: Start Early and Be Steady” *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ៤០) ។

សូមសួរ ៖ យោងតាមប្រធាន អាវរិង តើការបង់ដង្វាយមួយភាគក្នុងដប់អាចជួយយើងឲ្យរៀបចំទៅជួបនឹងព្រះអង្គសង្គ្រោះ តាមរបៀបណា?

សូមឲ្យសិស្សម្នាក់អានឮៗនូវការព្យាករណ៍របស់ម៉ាឡាគីដែលទាក់ទងទៅនឹងការមកដល់របស់អេលីយ៉ានៅក្នុង នីហ្វៃទី ៣២៥:៥–៦ ។ ដើម្បីជួយពួកគេឲ្យយល់កាន់តែច្បាស់ពីរបៀបដែលការបំពេញការព្យាករណ៍នេះអាចជះឥទ្ធិពលដល់ពួកគេ សូមឲ្យសិស្សម្នាក់អានការអញ្ជើញខាងក្រោមពីអែលឌើរ ដេវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ខ្ញុំសូមអញ្ជើញយុវជននៃសាសនាចក្រឲ្យរៀន ហើយមានបទពិសោធន៍ពីព្រះបន្ទូលនៃអេលីយ៉ា ។ . . .

« នៅពេលអ្នករាល់គ្នាឆ្លើយតបដោយសេចក្តីជំនឿចំពោះការអញ្ជើញនេះ ដួងចិត្តរបស់អ្នកនឹងបែរទៅរកពួកឪពុក ។ សេចក្តីសន្យាទាំងឡាយដែលបានធ្វើដល់អ័ប្រាហាំ អ៊ីសាក និងយ៉ាកុបនឹងត្រូវបានបណ្តុះនៅក្នុងចិត្តរបស់អ្នក ។ . . . សេចក្តីស្រឡាញ់ និងអំណរគុណរបស់អ្នកសម្រាប់បព្វការីជនរបស់អ្នកនឹងកើនឡើង ។ ទីបន្ទាល់របស់អ្នក និងការប្រែចិត្តជឿលើព្រះអង្គសង្គ្រោះនឹងកាន់តែសឹងម្រៅ និងគោរពតាមកាន់តែខ្លាំង ។ ហើយខ្ញុំសូមសន្យានឹងអ្នកថា អ្នកនឹងត្រូវបានការពារពីឥទ្ធិពលដ៏ខ្លាំងក្លារបស់ពួកមារសត្រូវ ។ នៅពេលអ្នកចូលរួម និងស្រឡាញ់កិច្ចការដ៏បរិសុទ្ធនេះ អ្នកនឹងត្រូវបានការពារនៅក្នុងយុវវ័យរបស់អ្នក និងពេញមួយជីវិតរបស់អ្នក » (« The Hearts of the Children Shall Turn » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១១ ទំព័រ ២៦–២៧) ។

សូមសួរ ៖ តើបទពិសោធន៍អ្វីខ្លះដែលអ្នកបានមាន ក្នុងការធ្វើពង្សប្រវត្តិ និងកិច្ចការព្រះវិហារបរិសុទ្ធដែលបានពង្រឹងដល់អ្នកខាងវិញ្ញាណ ?

នីហ្វៃទី ៣ ២៧–៣០

ព្រះយេស៊ូវគ្រីស្ទបង្ហាញពីឈ្មោះ និងលក្ខណៈពិសេសដ៏សំខាន់នៃសាសនាចក្រ និងផ្តល់កិត្តិយសដល់បំណងដ៏សុចរិតនៃពួកសិស្សរបស់ទ្រង់ មរមន បញ្ចប់កំណត់ត្រារបស់លោកអំពីការបម្រើរបស់ព្រះអង្គសង្គ្រោះនៅក្នុងចំណោមពួកសាសន៍នីហ្វៃ

សូមសរសេរសេចក្តីថ្លែងការណ៍ខាងក្រោមដោយព្យាការី យ៉ូសែប ស៊្មីធ នៅលើក្តារខៀន (អ្នកអាចធ្វើការណ៍នេះមុនពេលចាប់ផ្តើមថ្នាក់ រហូតដល់ចំណុចនេះនៅក្នុងមេរៀននេះ) ។ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍នេះឮៗ ។ សេចក្តីថ្លែងការណ៍នេះមាននៅក្នុង *Teachings of Presidents of the Church: Joseph Smith* [ឆ្នាំ ២០០៧] ទំព័រ ៤០៩) ។

« គោលការណ៍គ្រឹះនៃសាសនារបស់យើង គឺជាទីបន្ទាល់អំពីពួកសាវក និងពួកព្យាការី អំពីព្រះយេស៊ូវគ្រីស្ទ ថាទ្រង់បានសុគត បានបញ្ចៃ ហើយបានរស់ឡើងវិញម្តងទៀតនៅថ្ងៃទីបី ហើយបានយាងឡើងទៅស្ថានសួគ៌ » (យ៉ូសែប ស៊្មីធ) ។

សូមពន្យល់ថា ដូចជាព្យាការី យ៉ូសែប ស៊្មីធ បានប្រកាស ព្រះអង្គសង្គ្រោះបានបង្រៀនពួកសាសន៍នីហ្វៃថា ស្នូលនៃដំណឹងល្អរបស់ទ្រង់គឺជាពលិកម្មធួនរបស់ទ្រង់ ។ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***គ្រឹះនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទគឺថា ទ្រង់បានធ្វើតាមព្រះឆន្ទៈរបស់ព្រះបិតាទ្រង់ដើម្បីសម្រេចបានជង្វាយធួន ។***

សូមឲ្យសិស្សអានត្រួសៗក្នុង នីហ្វៃទី ៣ ២៧ ហើយស្វែងរកឃ្លាដែលព្រះអង្គសង្គ្រោះបានបង្រៀនពីគោលលទ្ធិនេះ ។ សូមឲ្យសិស្សឲ្យចែកចាយគ្នាដែលពួកគេបានរកឃើញ ។

សូមពន្យល់ថា នីហ្វៃទី ៣២៧:១៦–២០ រួមមានការបង្រៀនរបស់ព្រះអង្គសង្គ្រោះអំពីរបៀបដែលយើងអាចអញ្ជើញឲ្យអំណាចនៃជង្វាយធួនរបស់ទ្រង់នៅក្នុងជីវិតរបស់យើង ។ សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ប្រសិនបើយើង . . . បន្ទាប់មកយើង . . . ។* . . . សូមឲ្យសិស្សឲ្យអាន នីហ្វៃទី ៣២៧:២០ ដោយស្ងៀមស្ងាត់ ដោយរកមើលពាក្យ ឬឃ្លាដែលពួកគេអាចប្រើដើម្បីបំពេញក្នុងចន្លោះនៅលើក្តារខៀន ។ សូមសួរ ៖ តើការធ្វើតាមគោលការណ៍នេះអាចជួយយើងឲ្យក្លាយជាសិស្សដ៏ពិតនៃព្រះយេស៊ូវគ្រីស្ទដោយរបៀបណា ?

សូមពន្យល់ដល់សិស្សថា ឧបសគ្គនៅទីបញ្ចប់ និងកំពូលនៃភាពជាសិស្សរបស់យើងមាននៅក្នុងនីហ្វៃទី ៣ ២៧:២១ ២៧ ។ សូមឲ្យសិស្សអានខគម្ពីរទាំងនេះដោយស្ងាត់ស្ងៀម ។ នៅពេលពួកគេអាន សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ព្រះអម្ចាស់យេស៊ូវគ្រីស្ទវិពីងថាពួកសិស្សរបស់ទ្រង់ធ្វើកិច្ចការរបស់ទ្រង់ ហើយភ្លាយដូចជាដូចជាទ្រង់ ។* . . .

សូមសួរសិស្សពីរបៀបដែលពួកគេនឹងបំពេញប្រយោគនេះ ដោយផ្អែកលើអ្វីដែលពួកគេអាននៅក្នុង នីហ្វៃទី ៣២៧:២៧ ។ (នៅពេលសិស្សឆ្លើយ សូមបំពេញប្រយោគនៅលើក្តារខៀនដើម្បីអានទៅដូចខាងក្រោម ៖ ***ព្រះអម្ចាស់យេស៊ូវគ្រីស្ទវិពីងថាពួកសិស្សរបស់ទ្រង់ធ្វើកិច្ចការរបស់ទ្រង់ ហើយភ្លាយដូចជាទ្រង់) ។*** សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមឮៗដោយប្រធាន ដៃមស៍ អ៊ីហ្សាស្ត នៃគណៈប្រធានទីមួយ ៖

« ចូរយើងគិតពីរឿងខ្លះដែលព្រះយេស៊ូវបានធ្វើ ដែលយើងទាំងអស់គ្នាអាចត្រាប់តាម ។

“១. ព្រះយេស៊ូវ ‘បានធ្វើការណ៍ល្អ ’ ។ [កិច្ចការ ១០:៣៨ ។] យើងទាំងអស់គ្នាអាចធ្វើអ្វីមួយល្អរាល់ថ្ងៃ—សម្រាប់សមាជិកគ្រួសារ មិត្តភក្តិ ឬក៏ជនចម្លែក—ប្រសិនបើយើងនឹងរកមើលឱកាសទាំងនោះ ។

“២. ព្រះយេស៊ូវគឺជាអ្នកគង្វាលដ៏ល្អ ដែលមើលថែចៀមរបស់ទ្រង់ ហើយបារម្ភដល់ចៀមណាដែលវង្វេងបាត់ ។ យើងអាចស្វែងរកអ្នកឯកោ ឬអ្នកដែលមិនសូវសេកម្ម ហើយក្លាយជាមិត្តនឹងពួកគេ ។

“៣. ព្រះយេស៊ូវបានមានសេចក្តីមេត្តាករុណាដល់មនុស្សជាច្រើន រួមទាំងអ្នកក្រផង ។ យើងក៏អាចមានសេចក្តីមេត្តាករុណាដែរ ។ យើងត្រូវបានរំឭកនៅក្នុងព្រះគម្ពីរមរមនថា យើង ‹ ទួញយំ ជាមួយនឹងអ្នកណាដែលទួញយំ › ។ [ម៉ូសាយ ១៨:៩ ។]

“៤. ព្រះយេស៊ូវបានថ្លែងទីបន្ទាល់អំពីបេសកកម្មដ៏ទេវភាពរបស់ទ្រង់ និងអំពីកិច្ចការដ៏អស្ចារ្យរបស់ព្រះវរបិតាទ្រង់ ។ សម្រាប់ផ្នែករបស់យើង យើងទាំងអស់គ្នាអាច ‹ ឈរជាសាក្សីនៃព្រះនៅគ្រប់ពេល › ។ [ម៉ូសាយ ១៨:៩ ។] » (« Discipleship *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៦ ទំព័រ ២១) ។

សូមចែកសិស្សធ្វើការជាដៃគូ ឬជាក្រុមតូចៗ ។ សូមឲ្យដៃគូ ឬក្រុមនីមួយៗសរសេររបៀបពីរ ឬបីដែលពួកគេអាចអនុវត្តសំណើរទាំងបួនរបស់ប្រធាន ហ្វោស្ត នៅក្នុងជីវិតរបស់គេ ។

ក្រោយពីពួកគេបានបញ្ចប់រួចហើយ សូមឲ្យដៃគូ ឬក្រុមនីមួយៗចែកចាយគំនិតមួយម្តងៗពីបញ្ជីរបស់គេ ។ នៅលើក្តារខៀន សូមសរសេរគំនិតរបស់គេពីរបៀបដែលយើងអាចធ្វើកិច្ចការរបស់ព្រះអង្គសង្គ្រោះ និងក្លាយដូចជាទ្រង់កាន់តែខ្លាំង ។ សូមឲ្យសិស្សធ្វើសកម្មភាពដោយស្ងាត់ស្ងៀមលើគំនិតនេះមួយ ឬពីរអំឡុងពេលសប្តាហ៍ក្រោយ ។ សូមថ្លែងទីបន្ទាល់របស់អ្នកថា យើងទាំងអស់គ្នាអាចក្លាយដូចជាព្រះអង្គសង្គ្រោះ ប្រសិនបើយើងអនុវត្តសេចក្តីជំនឿលើទ្រង់ ។

មេរៀនបន្ទាប់ (នីហ្វៃទី ៤ ១–មរមន ៩)

សូមលើកទឹកចិត្តសិស្សឲ្យរកមើលចម្លើយចំពោះសំណួរខាងក្រោម នៅពេលពួកគេសិក្សាមេរៀនបន្ទាប់ ៖ តើមនុស្សម្នាក់អាចចេញពីការមានសន្តិភាព និងរីកចម្រើនទៅជាទុច្ចរិតដោយរបៀបណា ? តើពួកសាសន៍នីហ្វៃអាចចេញពីការីកចម្រើនដ៏ខ្លាំងបំផុត និងចេញពីភាពជាប្រជាជនដ៏រីករាយបំផុតដែលរស់នៅលើផែនដីទៅជាទុច្ចរិតទាំងស្រុងដោយរបៀបណា តើពាក្យសម្តីចុងក្រោយរបស់ មរមនមានអ្វីខ្លះ ?

សេចក្តីផ្តើមអំពីគម្ពីរនីហ្វៃទីបួន ៖

គម្ពីរនីហ្វៃ

ហេតុអ្វីបានជាត្រូវសិក្សាគម្ពីរនេះ ?

នៅពេលសិស្សសិក្សានីហ្វៃទី ៤ ពួកគេនឹងរៀនអំពីពរជ័យដែលកើតមានដល់ប្រជាជនដែលរួបរួមគ្នានៅក្នុងការរស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ ដោយធ្វើតាមការបម្រើរបស់ព្រះអង្គសង្គ្រោះនៅក្នុងចំណោមកូនចៅរបស់លីហៃ ប្រជាជនទាំងអស់នៅទូទាំងដែនដីបានប្រែចិត្តជឿ ។ នៅពេលពួកគេគោរពតាមព្រះបញ្ញត្តិទាំងឡាយ នោះពួកគេបានអរសប្បាយនឹងសេចក្តីសុខសាន្ត ការរីកចម្រើន និងពរជ័យខាងវិញ្ញាណដ៏អស្ចារ្យ ។ មរមនបានប្រកាសថា « ហើយពិតជាគ្មានប្រជាជនណាដែលរីករាយសប្បាយជាងប្រជាជនដែលបានត្រូវបង្កើតដោយព្រះហស្តនៃព្រះឡើយ » (« នីហ្វៃទី ៤ ១:១៦) ។ សិស្សក៏នឹងរៀនពីមេរៀនដ៏សំខាន់ចេញពីការធ្លាក់ចុះបន្តិចម្តងៗរបស់ប្រជាជននេះទៅក្នុងស្ថានភាពមួយនៃអំពើទុច្ចរិតផងដែរ ។

តើនរណាជាអ្នកសរសេរគម្ពីរនេះ ?

មរមន បានចងក្រង ហើយសង្ខេបកំណត់ត្រាទាំងបួនដើម្បីបង្កើតជាគម្ពីរនីហ្វៃទី ៤ ។ គម្ពីរដំបូងគេបង្អស់ត្រូវបានដាក់ឈ្មោះ នីហ្វៃ ។ នីហ្វៃគឺជាកូនប្រុសរបស់នីហ្វៃ ដែលជាសិស្សម្នាក់ក្នុងចំណោមសិស្សទាំងដប់ពីរដែលត្រូវបានជ្រើសរើសដោយព្រះអម្ចាស់ អំឡុងពេលការបម្រើរបស់ទ្រង់នៅក្នុងចំណោមកូនចៅរបស់លីហៃ (សូមមើល នីហ្វៃទី ៣ ១១:១៨–២២, ១២:១) ។ អ្នកសរសេរបីរូបទៀតគឺជាកូនប្រុសរបស់នីហ្វៃគឺ អេម៉ុស និង កូនប្រុសរបស់អេម៉ុសគឺ អេម៉ុស និង អាំម៉ារ៉ុន (សូមមើល នីហ្វៃទី ៤ ១:១៩, ២១, ៤៧) ។

តើគម្ពីរនេះត្រូវបានសរសេរសម្រាប់នរណា ? ហេតុអ្វី ?

មរមនមិនបានបញ្ជាក់ថាគម្ពីរនីហ្វៃទី ៤ នេះត្រូវបានសរសេរសម្រាប់អ្នកអានជាក់លាក់ណាម្នាក់ឡើយ ហើយលោកក៏មិនបានលើកឡើងពីមូលហេតុដែលលោកបានសរសេរសៀវភៅនេះដែរ ។ ទោះជាយ៉ាងណាក្តី គម្ពីរនេះរួមចំណែកដល់គោលបំណងដ៏សំខាន់នៃព្រះគម្ពីរមរមន— ដើម្បីធ្វើជាសាក្សីថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ហើយដើម្បីប្រកាសពីសេចក្តីសញ្ញានៃព្រះអម្ចាស់ (សូមមើលទំព័រចំណងជើងនៃព្រះគម្ពីរមរមន) ។ គម្ពីរនេះដើរតួនាទីដូច្នេះដោយការបង្ហាញនូវពរជ័យដែលកើតមាន នៅពេលប្រជាជនប្រែចិត្ត ចូលមករកព្រះយេស៊ូវគ្រីស្ទ ហើយធ្វើសេចក្តីសញ្ញាជាមួយនឹងទ្រង់ ។ គម្ពីរនេះក៏បង្ហាញពីលទ្ធផលដ៏បំផ្លិចបំផ្លាញដែលកើតឡើង នៅពេលប្រជាជនបដិសេធមិនព្រមទទួលព្រះអង្គសង្គ្រោះ និងដំណឹងល្អរបស់ទ្រង់ ហើយបោះបង់សេចក្តីសញ្ញារបស់ពួកគេចោល ។

តើនៅពេលណា និងនៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

កំណត់ត្រាដើមត្រូវបានប្រើជាប្រភពនៃគម្ពីរនីហ្វៃទី ៤ ដែលប្រហែលជាត្រូវបានសរសេរវាងឆ្នាំ ៣៤ .គ.ស. និង ឆ្នាំ ៣២១ .គ.ស. ។ មរមនបានសង្ខេបកំណត់ត្រាទាំងនោះក្នុងចន្លោះពេលប្រហែលឆ្នាំ ៣៤៥ នៃគ.ស. និង ឆ្នាំ ៣៨៥នៃគ.ស ។ មរមនមិនបានកត់ត្រាពីទីកន្លែងដែលគាត់នៅ នៅពេលគាត់បានចងក្រងគម្ពីរនេះទេ ។

តើមានលក្ខណៈពិសេសអ្វីខ្លះនៅក្នុងគម្ពីរនេះ ?

មានតែខគម្ពីរចំនួន ៤៩ ប៉ុណ្ណោះ ដែលគម្ពីរនីហ្វៃទី ៤ ដំណាលពីរយៈពេលមួយនៃពេលជិត ៣០០ ឆ្នាំ— ស្ទើរតែមួយភាគបីនៃប្រវត្តិសាស្ត្រនៃសាសន៍នីហ្វៃទាំងមូលដែលមាននៅក្នុងព្រះគម្ពីរមរមន ។ ការសង្ខេបនៃគម្ពីរនីហ្វៃទី ៤ រួមចំណែកដល់អានុភាពរបស់វា ។ វាលើកឡើងយ៉ាងខ្លីនិងច្បាស់លាស់ពីភាពផ្ទុយគ្នារវាងភាពសុចរិតរបស់ប្រជាជនក្លាមៗបន្ទាប់ពីការបម្រើរបស់ព្រះអង្គសង្គ្រោះនៅក្នុងចំណោមពួកគេ និងភាពទុច្ចរិតរបស់ពួកគេរយៈពេលបួនជំនាន់ក្រោយមក ។ ខគម្ពីរចំនួន ១៨ ដំបូងនៃគម្ពីរនេះបង្ហាញពីពរជ័យដែលសង្គមមួយរីករាយ ដែលការណ៍នេះត្រូវបានសាងលើដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ ខគម្ពីរបន្ទាប់ក្រោយមករួមមាននូវសាក្សីមួយនៃការបំផ្លិចបំផ្លាញនៃភាពឆ្មើងឆ្មៃ ដោយការបង្ហាញពីរបៀបដែលសង្គមនេះចុះទន់ខ្សោយបន្តិចម្តងៗ រហូតដល់វាស្ទើរតែធ្លាក់ទៅក្នុងអំពើបាបទាំងស្រុង ។

គម្រោង

នីហ្វៃទី ៤ ១:១–១៨ ដោយធ្វើតាមការបម្រើរបស់ព្រះយេស៊ូវគ្រីស្ទ ប្រជាជនទាំងអស់ទូទាំងដែនដីបានផ្លាស់ប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ។ ពួកគេលែងបែងចែកខ្លួនគេជាសាសន៍នីហ្វៃ និងសាសន៍លេមិនទៀតហើយ ។ ពួកគេ « មានរបស់របរទាំងអស់រួមគ្នា » (នីហ្វៃទី ៤ ១:៣) ពួកគេទទួលបាននូវអត្ថហេតុជាច្រើន ហើយពួកគេរីកចម្រើន និងរស់នៅក្នុងសាមគ្គីភាព និងសុភមង្គលអស់រយៈពេល ១៩០ ឆ្នាំ ។

នីហ្វៃទី ៤ ១:១៩–៣៤ នីហ្វៃស្លាប់ ហើយកូនប្រុសរបស់ អេម៉ុស រក្សាកំណត់ត្រាទាំងឡាយ ។ ក្រោយមក អេម៉ុស ប្រគល់កំណត់ត្រាទាំងឡាយដល់កូនប្រុសរបស់លោកឈ្មោះ អេម៉ុស ។ ប្រជាជនជាច្រើនបានអនុញ្ញាតឲ្យសាតាំង « ក្តាប់ជាប់នូវដួងចិត្តរបស់ពួកគេ » (នីហ្វៃទី ៤ ១:២៨) ។ ការបែកបាក់គ្នា ភាពឆ្មើងឆ្មៃ និងសាសនាចក្រក្លែងក្លាយកើតឡើងនៅក្នុងចំណោមប្រជាជន ។ ពួកទុច្ចរិតចាប់ផ្តើមរៀបចំសមាជិកនៃសាសនាចក្រដ៏ពិត និង « ពួកសិស្សនៃព្រះយេស៊ូវដែលបាននៅជាមួយនឹងពួកគេ » (នីហ្វៃទី ៤ ១:៣០) ។

នីហ្វៃទី ៤ ១:៣៥–៤៩ ប្រជាជនបែងចែកខ្លួនគេជាសាសន៍នីហ្វៃ និងសាសន៍លេមិនម្តងទៀត ។ សាសន៍លេមិនប្រឆាំងនឹងដំណឹងល្អយ៉ាងខ្លាំង ហើយបង្កើតជាបក្សសម្ព័ន្ធសម្ងាត់នៃការឃុបឃិតគ្នា ។ នៅទីបំផុត ពួកសាសន៍នីហ្វៃក៏ក្លាយទៅជាទុច្ចរិត ។ អេម៉ុសស្លាប់ ហើយប្អូនប្រុសរបស់លោកឈ្មោះ អាំម៉ារ៉ុន រក្សាកំណត់ត្រាមួយរយៈមុនពេលត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធឲ្យលាក់នូវបញ្ជីពិសិដ្ឋទាំងនេះ ។

នីហ្វៃទី ៤

សេចក្តីផ្តើម

ក្រោយពីការបម្រើរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងចំណោមកូនចៅរបស់លីហៃ នោះប្រជាជនបានអនុវត្តតាមការបង្រៀនរបស់ទ្រង់ និងបានរីករាយអស់រយៈពេលជាង ១០០ ឆ្នាំនៃការសោមគ្គីភាព ការរីកចម្រើន និងសុភមង្គល ។ ពួកគេរួបរួមគ្នាជា « កូនចៅនៃព្រះគ្រីស្ទ » ហើយលែងហៅខ្លួនគេថាជាសាសន៍នីហ្វៃ ឬសាសន៍លេមិនទៀតហើយ (នីហ្វៃទី ៤ ១:១៧) ។ ទោះជាយ៉ាងណាក្តី នៅទីបំផុតពួកគេបានក្លាយជាមានភាពឆ្មើងឆ្មៃ និងរីកចម្រើនឡើងនៅក្នុងការណ៍ទុច្ចរិត ហើយពួកគេបានបែងចែកខ្លួនគេជាសាសន៍នីហ្វៃ និងសាសន៍លេមិនម្តងទៀត ។ ប្រហែល ៣០០ ឆ្នាំក្រោយពីការយាងមករបស់ព្រះអង្គសង្គ្រោះ មនុស្សស្ទើរតែទាំងអស់បានក្លាយជាទុច្ចរិត ។

យោបល់ទាំងឡាយសម្រាប់ការបង្រៀន

នីហ្វៃទី ៤ ១:១–១៨

មនុស្សទាំងអស់បានផ្លាស់ប្រែចិត្ត ហើយទទួលបានសេចក្តីសុខសាន្ត និងសុភមង្គល

សូមទាក់ទាញចំណាប់អារម្មណ៍របស់សិស្សនៅពេលពួកគេមកដល់ថ្នាក់

សូមរកមធ្យោបាយណាដើម្បីជួយសិស្សឲ្យចាប់ផ្តើមគិតអំពីមេរៀននេះ នៅពេលពួកគេចូលមកក្នុងថ្នាក់ភ្លាម ។ អ្នកអាចសរសេរសំណួរមួយនៅលើក្តារខៀន ឬអ្នកអាចបង្ហាញរបស់មួយ ឬរូបភាពមួយ ។ ការណ៍នេះជួយសិស្សឲ្យផ្តោតអារម្មណ៍ និងរៀបចំចិត្តគំនិតរបស់ពួកគេដើម្បីរៀនសូត្រ ។

មុនពេលចាប់ផ្តើមការបង្រៀន សូមរៀបចំក្រដាសទទេរពីរសន្លឹកសម្រាប់សិស្សម្នាក់ៗ— ប្រសិនបើអាច ក្រដាសមួយស ហើយក្រដាសមួយទៀតមានពណ៌ផ្សេង (ក្រដាសមួយចំហៀងក៏បានដែរ) ។ សូមដាក់ក្រដាសពណ៌សនៅលើតុ ឬកៅអីរបស់សិស្ស មុនពេលពួកគេមកដល់ថ្នាក់ ។ សូមដាក់ក្រដាសពណ៌មួយទៀតសម្រាប់ប្រើពេលក្រោយនៅក្នុងមេរៀន ។ សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖ *តើអ្វីដែលធ្វើឲ្យអ្នកពិតជារីករាយ ?* នៅពេលសិស្សមកដល់ សូមឲ្យពួកគេសរសេរចម្លើយរបស់គេចំពោះសំណួរនេះនៅលើក្តារខៀន ។

សូមចាប់ផ្តើមថ្នាក់ដោយការពិភាក្សាពីចម្លើយដែលពួកគេបានសរសេរនៅលើក្តារខៀន ។ សូមសួរសិស្សនូវសំណួរដូចខាងក្រោម ៖

- តើអ្វីជាភាពខុសគ្នារវាងរឿងដែលធ្វើឲ្យយើងរីករាយម្តងកាល និងរឿងដែលនាំទៅរកការរីករាយជានិរន្តរ៍ ? (នៅពេលសិស្សឆ្លើយ អ្នកអាចបញ្ជាក់ថា សេចក្តីរីករាយដ៏ពិតមិនអាចរកបាននៅក្នុងអ្វីៗដែលមិនបិតថេរដូចជាភាពល្បីល្បាញ ភាពមានបាន និងកម្មសិទ្ធិខាងសម្ភារនោះឡើយ) ។

សូមពន្យល់ថា នីហ្វៃទី ៤ គឺជាកំណត់ត្រាមួយនៃបីឬនជំនាន់នៃកូនចៅរបស់លីហៃ ដែលបានរស់នៅក្រោយពីការយាងមករបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សអាន នីហ្វៃទី ៤ ១:១៦ ដោយស្ងាត់ៗដោយរកមើលរបៀបដែលមរមនបានរៀបរាប់ប្រជាជនដែលបានរស់នៅប្រហែល ១០០ ឆ្នាំក្រោយពីការយាងមករបស់ព្រះអង្គសង្គ្រោះ ។ អ្នកអាចស្នើថា សិស្សអាចគូសចំណាំឃ្លា « ពិតជាគ្មានប្រជាជនណាដែលរីករាយសប្បាយជាងប្រជាជននេះឡើយ » ។ សូមឲ្យសិស្សសរសេរ *ពិតជាគ្មានប្រជាជនណាដែលរីករាយសប្បាយជាងប្រជាជននេះឡើយ* នៅផ្នែកខាងលើនៃក្រដាសពណ៌ស ដែលអ្នកបានចែកឲ្យ ។ បន្ទាប់មក សូមឲ្យពួកគេគូសរង្វង់ដ៏ធំមួយនៅចំកណ្តាលនៃក្រដាសពួកគេ ។



សូមឲ្យសិស្សអាន នីហ្វៃទី ៤ ១:១–២ ដោយរកមើលអ្វីដែលប្រជាជនបានធ្វើដើម្បីឲ្យសុភមង្គលនេះកើតឡើងបាន ។ សូមឲ្យពួកគេសរសេរអ្វីដែលពួកគេរកឃើញនៅក្នុងរង្វង់នេះ ។ (ចម្លើយគួរមានដូចជា ប្រជាជនដែលបានប្រែចិត្ត បានជ្រមុជទឹក បានទទួលព្រះវិញ្ញាណបរិសុទ្ធ និង « ប្រជាជនទាំងអស់បានប្រែចិត្តជឿដល់ព្រះអម្ចាស់ » ។

- តើការប្រែចិត្តជឿមានន័យដូចម្តេច ?

ដើម្បីជួយសិស្សឲ្យយល់ថា ការផ្លាស់ប្រែចិត្តគឺជ្រៅជាងការគ្រាន់តែមានទីបន្ទាល់មួយ ឬការក្លាយជាសមាជិកនៃសាសនាចក្រ នោះសូមឲ្យសិស្សម្នាក់អានឮៗពីសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រីឆាត ជី ស្តុត ក្នុងក្លុំមនៃពួកសាវកដប់ពីរនាក់ ។ ប្រសិនបើអាច សូមចែកក្រដាសនៃប្រយោគនេះដល់សិស្ស ហើយសូមលើកទឹកចិត្តពួកគេឲ្យរកមើលពាក្យ និងឃ្លាដែលផ្តល់និយមន័យដល់ពាក្យការប្រែចិត្តជឿ ។

« សុភមង្គលរបស់អ្នកនាពេលនេះ និងជារៀងរហូតតទៅគឺស្ថិតនៅលើកម្រិតនៃការប្រែចិត្តជឿរបស់អ្នក និងការកែប្រែដែលវានាំមកដល់ជីវិតរបស់អ្នក ។ ដូច្នេះ តើអ្នកអាចប្រែចិត្តជឿយ៉ាងពិតប្រាកដដោយរបៀបណា ? ប្រធាន ។ ម៉ារ៉ុន ជី ។ រ៉មនី រៀបរាប់ពីជំហានដែលអ្នកត្រូវតែធ្វើតាម ៖

“« . . . សមាជិកភាពនៅក្នុងសាសនាចក្រ និងការប្រែចិត្តជឿមិនមែនជាពាក្យដែលមានន័យដូចដំចាំបាច់ឡើយ ។ ការប្រែចិត្តជឿ និងការមានទីបន្ទាល់មួយក៏មិនមែនជារឿងដូចគ្នាដែលចាំបាច់ជាងដែរ ។ ទីបន្ទាល់មួយកើតឡើង នៅពេលព្រះវិញ្ញាណបរិសុទ្ធផ្តល់ដល់អ្នកស្វែងរកដ៏ស្មោះត្រង់ម្នាក់នូវសាក្សីមួយនៃសេចក្តីពិត ។ ទីបន្ទាល់ដ៏រស់រវើកមួយបង្ហាញពីសេចក្តីជំនឿ ។ នោះមានន័យថា វានាំឲ្យមានការប្រែចិត្តជឿ និងការគោរពតាមព្រះបញ្ញត្តិទាំងឡាយ ។ ការប្រែចិត្តជឿ គឺជាផលផ្លែ ឬរង្វាន់សម្រាប់ការប្រែចិត្ត និងការគោរពប្រតិបត្តិតាម › ។ ។ នៅក្នុង Conference Report, Guatemala Area Conference ឆ្នាំ ១៩៧៧ ទំព័រ ៨–៩ ។ ។

« បើនិយាយដោយសាមញ្ញ ការប្រែចិត្តជឿដ៏ពិតគឺជាផលផ្លែនៃ *សេចក្តីជំនឿ ការប្រែចិត្ត* និង *ការគោរពតាមដ៏ខ្ជាប់ខ្ជាន់ ។* . . .

« ការប្រែចិត្តជឿដ៏ពិតនាំមកនូវផលផ្លែនៃសុភមង្គលដ៏រីងមាំ ដែលអាចរីករាយទោះបីជានៅពេលពិភពលោកនេះស្ថិតនៅក្នុងភាពចលាចលក្តី ហើយភាគច្រើនគឺជាការរីករាយ » (« Full Conversion Brings Happiness » *Ensign* ខែ ឧសភា ឆ្នាំ ២០០២ ទំព័រ ២៥, ២៦) ។

- តើពាក្យ និងឃ្លាអ្វីដែលអ្នកបានឮ ផ្តល់នូវនិយមន័យដល់ពាក្យការប្រែចិត្តជឿ ?
- តើអ្នកគិតថា វានឹងទៅជាយ៉ាងណា ប្រសិនបើមនុស្សគ្រប់គ្នានៅជុំវិញអ្នកបានប្រែចិត្តជឿដល់ព្រះអម្ចាស់នោះ ?

សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖ *នីហ្វៃទី ៤ ១:២–៣, ៥, ៧, ១០–១៣, ១៥–១៨ ។* សូមឲ្យសិស្សបីបួននាក់ប្តូរវេនគ្នាអានឮៗពីខគម្ពីរទាំងនេះ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពាក្យ និងឃ្លាដែលរៀបរាប់ពីអ្វីដែលប្រជាជនបានជួប ដោយសារពួកគេទាំងអស់គ្នាបានប្រែចិត្តជឿដល់ព្រះអម្ចាស់ ។ សូមឲ្យសិស្សសរសេរពាក្យ និងឃ្លាទាំងនេះនៅជុំវិញរង្វង់លើក្រដាសរបស់ពួកគេ ។ (ចម្លើយអាចរួមមានដូចខាងក្រោម ៖ គ្មានការទាស់ទែង ឬការឈ្លោះគ្នា ពួកគេប្រាស្រ័យទាក់ទងជាមួយនឹងគ្នាទៅវិញទៅមកដោយសេចក្តីយុត្តិធម៌ ពួកគេមានរបស់របរទាំងអស់រួមគ្នា មានអព្ភូតហេតុជាច្រើនបានកើតឡើងនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ព្រះអម្ចាស់បានពង្រឹងដល់ប្រជាជន ពួកគេបានកសាងទីក្រុងជាច្រើនដែលត្រូវបានបំផ្លាញ ពួកគេបានរៀបការ និងបានបង្កើតគ្រួសារជាច្រើន ពួកគេបានមានចំនួនច្រើន ហើយបានក្លាយជារឹងមាំ សេចក្តីស្រឡាញ់នៃព្រះស្ថិតនៅក្នុងដួងចិត្តរបស់ពួកគេ ហើយពួកគេរីករាយ និងមានសាមគ្គីភាព) ។

សូមឲ្យសិស្សរកមើលគោលការណ៍មួយអំពីសុភមង្គលដែលពួកគេបានរៀនពី នីហ្វៃទី ៤ ១ ៣ក់កណ្តាលដំបូង ។ ទោះបីជាសិស្សអាចរកឃើញគោលការណ៍បីបួនក្តី សូមប្រាកដថា ពួកគេបង្ហាញថា **នៅពេលប្រជាជនធ្វើការរួមគ្នាដើម្បីប្រែចិត្តជឿដល់ព្រះអម្ចាស់ ពួកគេបានសាមគ្គីគ្នា ហើយទទួលបានសុភមង្គលកាន់តែច្រើនឡើង ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន ។

- តើអ្នកគិតថា ពរជ័យអ្វីនឹងកើតមានដល់ថ្នាក់របស់យើង ប្រសិនបើយើងទាំងអស់គ្នារស់នៅដូចជាប្រជាជនទាំងនេះបានរស់នៅនោះ ? តើអ្នកគិតថា ពរជ័យអ្វីនឹងកើតមានដល់គ្រួសាររបស់អ្នក ? តើអ្នកគិតថា ពរជ័យអ្វីនឹងកើតមានដល់វួដ ឬ សាខារបស់អ្នក ?

សូមឲ្យសិស្សប្រាប់អំពីពេលមួយដែលពួកគេគឺជាផ្នែកនៃក្រុមមួយ ដែលបានរួបរួមគ្នានៅក្នុងសេចក្តីសុចរិត ដូចជាគ្រួសាររបស់គេ កូរ៉ុមឬថ្នាក់មួយ ឬមិត្តភក្តិមួយក្រុម ។ អ្នកក៏អាចចែកចាយបទពិសោធន៍មួយដែរ ។

- តើការខិតខំរបស់អ្នកដើម្បីមានភាពសុចរិត អាចជះឥទ្ធិពលដល់សុភមង្គល និងសុខុមាលភាពនៃអ្នកដែលនៅជុំវិញអ្នកដោយរបៀបណា ? (សូមប្រាកដថា សិស្សយល់ថា ការប្រែចិត្តជឿ និងសកម្មភាពសុចរិតរបស់យើងរួមចំណែកមិនត្រឹមតែដល់សុភមង្គលរបស់យើងផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដល់សុភមង្គល និងសុខុមាលភាពរបស់អ្នកដទៃផងដែរ ។ នៅពេលសមាជិកគ្រួសារ កូរ៉ុមថ្នាក់ ឬក្រុមផ្សេងទៀតបានរួបរួមគ្នានៅក្នុងសេចក្តីសុចរិត ពួកគេអាចទទួលបានសេចក្តីរីករាយដ៏អស្ចារ្យជាងដែលពួកគេនឹងអាចទទួលបានដោយខ្លួនឯងទៅទៀត) ។
- តើអំពើបាបរបស់មនុស្សម្នាក់អាចជះឥទ្ធិពលដល់ក្រុមទាំងមូល ដែលកំពុងខិតខំភ្ជាយទៅជាសុចរិតដោយរបៀបណា ?

សូមលើកទឹកចិត្តសិស្សឲ្យពង្រឹងការផ្លាស់ប្រែចិត្តរបស់ពួកគេជឿលើព្រះអម្ចាស់ ហើយជួយដល់អ្នកដែលនៅជុំវិញពួកគេឲ្យធ្វើដូចគ្នាដែរ ។ ដើម្បីជួយសិស្សជាមួយនឹងការតាំងចិត្តនេះ សូមឲ្យពួកគេរំពឹក៣ក្យ និងឃ្លាដែលពួកគេបានសរសេរនៅលើក្រដាសរបស់ពួកគេ ។ សូមឲ្យពួកគេជ្រើសរើសឃ្លាមួយ ឬពីរដែលពិពណ៌នាពីរបៀបនៃការរស់នៅ ដែលពួកគេនឹងអាចជួប ។ សូមឲ្យពួកគេមានពេលពីរបីនាទីដើម្បីសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់អំពីរបៀបដែលពួកគេនឹងរ្យាយមរស់នៅតាមរបៀបទាំងនេះ ។ សូមធ្វើទីបន្ទាល់អំពីសុភមង្គលដែលកើតមកពីការប្រែចិត្តជឿដ៏ពិត និងការរួបរួមគ្នានៅក្នុងសេចក្តីសុចរិត ។

នីហ្វៃទី ៤ ១:១៩–៤៩

ពួកសាសន៍នីហ្វៃក្លាយជាទុច្ចរិតកាន់តែខ្លាំង រហូតដល់សល់តែប្រជាជនសុចរិតពីរបីនាក់ប៉ុណ្ណោះ

- តើអ្នកគិតថា អ្វីទៅដែលបានបំផ្លាញសង្គមមួយដូចជាសង្គមដែលបានពិពណ៌នានៅក្នុង នីហ្វៃទី ៤ ១:១–១៨ ?

សូមឲ្យសិស្សអាន នីហ្វៃទី ៤ ១:២០, ២៣–២៤ ដោយស្ងៀមស្ងាត់ ដោយរកមើលអ្វីដែលបានគំរាមកំហែងដល់សាមគ្គីភាព និងសុភមង្គលរបស់ប្រជាជន ។ អ្នកអាចស្នើថា ពួកគេគួរគូសចំណាំអ្វីដែលពួកគេរកឃើញ ។ ក្រោយពីពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញហើយ សូមសរសេរនៅលើក្តារខៀននូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ។

(សេចក្តីថ្លែងការណ៍នេះត្រូវបានរកឃើញនៅក្នុង « Our Hearts Knit as One » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ៧០ ។) អ្នកអាចសុំឲ្យសិស្សចម្លងសេចក្តីថ្លែងការណ៍នេះទៅក្នុងក្នុងព្រះគម្ពីររបស់គេក្បែរ នីហ្វៃទី ៤ ១:២៤ ។

« ភាពឆ្មើងឆ្មៃគឺជាសត្រូវដ៏ធំនៃសាមគ្គីភាព » (ប្រធាន ហិនរី ប៊ី អាវរិង) ។

- តើអ្នកគិតថា ភាពឆ្មើងឆ្មៃគឺជាសត្រូវដ៏ធំនឹងសាមគ្គីភាពតាមរបៀបណា ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរ អេស អុជដូហ្វ នៃគណៈប្រធានទីមួយ ៖ សូមឲ្យសិស្សក្នុងថ្នាក់ស្តាប់ពីរបៀបមួយដែលភាពឆ្មើងឆ្មៃអាចបំផ្លាញសាមគ្គីភាព ។

« ចំណុចដ៏សំខាន់គឺថា ភាពឆ្មើងឆ្មៃគឺជាអំពើបាបនៃការប្រៀបផ្ទឹម ទោះបីជាវាជាទូទៅចាប់ផ្តើមដោយ ‹ មើលន៎! ខ្ញុំជាមនុស្សដ៏អស្ចារ្យ ហើយខ្ញុំបានធ្វើរឿងដ៏អស្ចារ្យ › វាតែងហាក់ដូចជាបង្ហាញថា ‹ ហេតុដូច្នេះ ខ្ញុំធ្វើបានល្អជាង អ្នក › ។

« នៅពេលដួងចិត្តរបស់យើងបានពោរពេញដោយភាពឆ្មើងឆ្មៃ នោះយើងបានធ្វើអំពើបាបដ៏ធ្ងន់មួយ ដោយសារយើងបានរំលងច្បាប់ដ៏ធំពីរ | សូមមើល ម៉ាថាយ ២២:៣៦–៤០| ។ ជំនួសឲ្យការថ្វាយបង្គំព្រះ និងការស្រឡាញ់អ្នកជិតខាងរបស់យើង យើងបង្ហាញនូវកម្មវត្ថុដ៏ពិតនៃការថ្វាយបង្គំ និងសេចក្តីស្រឡាញ់របស់យើង —គឺជារូបភាពដែលយើងឃើញនៅក្នុងកញ្ចក់ » (« Pride and the Priesthood » *Ensign* ឬ *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១០ ទំព័រ ៥៦) ។

- ដោយផ្អែកលើសេចក្តីថ្លែងការណ៍របស់ប្រធាន អុជដូហ្វ តើភាពឆ្មើងឆ្មៃអាចបំផ្លាញសាមគ្គីភាពដោយរបៀបណា ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗក្នុង នីហ្វៃទី ៤ ១:២៤–៣៥, ៣៨–៤៥ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលឥទ្ធិពលនៃភាពឆ្មើងឆ្មៃនៅក្នុងចំណោមពួកសាសន៍នីហ្វៃ ។ អ្នកអាចស្នើថា សិស្សគួរគូសចំណាំអ្វីដែលពួកគេរកឃើញ ។ (ចម្លើយអាចរួមមានដូចខាងក្រោម ៖ ការស្លៀកសម្លៀកបំពាក់ដែលមានតម្លៃថ្លៃ ការបែងចែកជាឋានៈសង្គម ឬបែងចែកក្រុមមិនមែនជាមិត្តភក្តិ ការកសាងសាសនាចក្រដើម្បីទទួលបានផលចំណេញ ការបដិសេធសាសនាចក្រដ៏ពិត ការបៀតបៀនលើពួកអ្នកស្មោះត្រង់ ការបង្កើតបក្សសម្ព័ន្ធសម្ងាត់ និងអំពើទុច្ចរិត)។

សូមឲ្យសិស្សរៀបរាប់ពីរឿងមួយដែលគេបានរកឃើញម្នាក់ម្តងៗ ។ (សិស្សអាចឆ្លើយចម្លើយដូចគ្នាម្តងទៀត) ។ នៅពេលសិស្សម្នាក់ៗឆ្លើយហើយ សូមសរសេរចម្លើយរបស់គេនៅលើក្រដាសពណ៌មួយ ដែលអ្នកបានដាក់ទៅមួយកន្លែងមុនពេលចាប់ផ្តើមនោះ ។ សូមឲ្យក្រដាសពណ៌នោះទៅសិស្សដើម្បីប្តូរនឹងក្រដាសសរបស់គេ ដែលរៀបរាប់ពីសុភមង្គល និងសាមគ្គីភាពរបស់ប្រជាជន ។ សូមធ្វើសកម្មភាពនេះម្តងហើយម្តងទៀត រហូតដល់សិស្សទាំងអស់គ្នានៅក្នុងថ្នាក់បានប្តូរក្រដាសសរបស់គេជាមួយនឹងក្រដាសពណ៌ទាំងអស់គ្នា ។

សូមឲ្យសិស្សមើលជុំវិញ និងរកមើលថា គ្រប់គ្នានៅក្នុងថ្នាក់មានក្រដាសពណ៌ ដែលតំណាងឲ្យភាពឆ្មើងឆ្មៃ ។ សូមឲ្យពួកគេសញ្ជឹងគិតពីអារម្មណ៍ដែលសិស្សទាំងបីនាក់របស់ព្រះគ្រីស្ទមាន នៅពេលពួកលោកបានឃើញភាពឆ្មើងឆ្មៃ និងអំពើទុច្ចរិតដែលបានរីករាលដាលនៅក្នុងចំណោមប្រជាជនមួយដែលធ្លាប់តែរីករាយ និងរួបរួមគ្នាជាខ្លាំង ។

- តើសេចក្តីពិតអ្វីដែលយើងអាចរៀនពីខគម្ពីរទាំងនេះ ? (ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាក្តី ក៏ពួកគេគួររកឃើញនូវគោលការណ៍ខាងក្រោមនេះ ៖ **អំពើបាបនៃភាពឆ្មើងឆ្មៃនាំឲ្យមានការបែកបាក់ ហើយដឹកនាំទៅរកអំពើទុច្ចរិត ។** អ្នកអាចសរសេរសេចក្តីពិតនេះនៅលើក្តារខៀន)។
- តើភាពឆ្មើងឆ្មៃរបស់មនុស្សពីរបីនាក់អាចមានឥទ្ធិពលលើសុភមង្គលរបស់ក្រុមទាំងមូលដោយរបៀបណា ?

សូមឲ្យសិស្សគិតពីរបៀបដែលភាពឆ្មើងឆ្មៃរបស់មនុស្សម្នាក់អាចមានឥទ្ធិពលលើអ្នកដទៃ នៅក្នុងឧទាហរណ៍ដូចខាងក្រោម ៖

១. ជំនួសឲ្យការលើកទឹកចិត្តពីគ្រួសាររបស់គាត់ បងប្រុសម្នាក់សម្រេចចិត្តធ្វើតាមចំណាប់អារម្មណ៍ផ្ទាល់ខ្លួន ជាជាងទៅបម្រើបេសកកម្ម ។

២. សមាជិកម្នាក់នៃថ្នាក់យុវនារី ឬក្លុំមបព្វជិតភាពអើរ៉ុនមានបំណងបង្កើតបញ្ហា បដិសេធមិនចូលរួមក្នុងថ្នាក់ ហើយរឹងទទឹងមិនធ្វើតាមការណែនាំ ។

៣. យុវជន ឬយុវនារីម្នាក់ចំអក ឬបង្អាប់សមាជិកផ្សេងទៀតនៃក្រុមមិត្តភក្តិរបស់គេជាញឹកញយ ។

សូមឲ្យសិស្សគិតអំពីពេលដែលពួកគេបានឃើញសេចក្តីឆ្មើងឆ្មៃបំផ្លាញសុភមង្គល និងសាមគ្គីភាព ។

សូមឲ្យសិស្សគិតពីតួនាទីរបស់ពួកគេនៅក្នុងក្រុមផ្សេងៗគ្នាដែលពួកគេជាសមាជិក ដូចជាគ្រួសាររបស់ពួកគេ ក្លុំម ឬថ្នាក់ រួដ ឬសាខា និងថ្នាក់សិក្ខាសាលា ។ (អ្នកអាចចង់លើកឡើងពីក្រុមផ្សេងទៀតដែលសិស្សរបស់អ្នកជាសមាជិក)។ សូមឲ្យពួកគេសញ្ជឹងគិតថាតើពួកគេបានធ្វើ ឬកំពុងធ្វើអ្វីដែលបង្ហាញពីភាពឆ្មើងឆ្មៃនៅក្នុងទំនាក់ទំនងរបស់គេជាមួយនឹងមនុស្សផ្សេងទៀតនៅក្នុងក្រុមទាំងនេះដែរឬទេ ។ សូមលើកទឹកចិត្តពួកគេឲ្យប្រែចិត្ត ហើយគិតអំពីរបៀបដែលពួកគេអាចយកឈ្នះលើភាពឆ្មើងឆ្មៃ និងបង្កើនសាមគ្គីភាព និងសេចក្តីសុខរីតនៅក្នុងក្រុមទាំងនេះ ។ សូមលើកទឹកចិត្តពួកគេឲ្យសញ្ជឹងគិតដងដែរពីអ្វីដែលពួកគេបានសរសេរអំពីរបៀបដែលពួកគេគ្រោងនឹងរស់នៅតាមឲ្យបានកាន់តែដូចជាកូនចៅរបស់លីហៃ ដែលបានប្រែចិត្តជឿដល់ព្រះអម្ចាស់ ។

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងព្យាយាមប្រែចិត្តជឿលើព្រះយេស៊ូវគ្រីស្ទកាន់តែខ្លាំង ហើយរស់នៅជាមួយនឹងអ្នកដទៃដោយសាមគ្គីភាព នោះយើងអាចទទួលបានសុភមង្គលដូចជាអ្វីដែលបានរៀបរាប់នៅក្នុង នីហ្វៃទី ៤ ១:១–១៨ ដូច្នោះដែរ ។

សេចក្តីផ្តើមអំពី

គម្ពីរមរមន

ហេតុអ្វីបានជាត្រូវសិក្សាព្រះគម្ពីរនេះ ?

នៅពេលសិស្សសិក្សាគម្ពីរនេះ ពួកគេនឹងរៀននូវមេរៀនដ៏មានតម្លៃពីមរមន ដែលជាសិស្សម្នាក់របស់ព្រះយេស៊ូវគ្រីស្ទ ដែលបានរស់នៅដោយស្មោះត្រង់ ទោះបីជាក្នុងមួយជីវិតរបស់លោកបានព័ទ្ធជុំវិញទៅដោយ « ឆាកអំពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយកើតឡើងមិនឈប់ឈរ » (មរមន ២:១៨) ។ សិស្សក៏នឹងទទួលបានប្រយោជន៍ពីការសិក្សាប្រសាសន៍របស់ម៉ូរ៉ូណៃ ដែលបានថ្លែងទីបន្ទាល់ដល់អ្នកអាននៅថ្ងៃចុងក្រោយថា « ព្រះយេស៊ូវគ្រីស្ទទ្រង់បង្ហាញអ្នករាល់គ្នាដល់ខ្ញុំ ហើយខ្ញុំដឹងនូវអ្វីៗដែលអ្នករាល់គ្នាធ្វើ » (មរមន ៨:៣៥) ។ នៅពេលសិស្សអានអំពីសេចក្តីបំផ្លិចបំផ្លាញដែលបានកើតឡើងដោយសារអំពើទុច្ចរិតរបស់ពួកសាសន៍នីហ្វៃ នោះពួកគេនឹងរៀនពីសារៈសំខាន់នៃការរស់នៅតាមបទបញ្ញត្តិទាំងឡាយ និងសេចក្តីសញ្ញានៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។

តើនរណាជាអ្នកសរសេរព្រះគម្ពីរនេះ ?

មរមន បានសរសេរប្រាំពីរជំពូកដំបូងនៃគម្ពីរនេះ ជាដំណើររឿងសង្ខេបមួយនៃអំពើទុច្ចរិត និងសង្គ្រាមនៅក្នុងចំណោមពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិននៅក្នុងជំនាន់របស់លោក ។ លោកក៏បានដំណាលពីរឿងទាំងមូលនៃហេតុការណ៍ពីជីវិតរបស់លោកនៅក្នុងផ្នាំងចំណារនីហ្វៃធំ (សូមមើល មរមន ២:១៨ , ៥:៩) ។ នៅពេលមរមន មានអាយុប្រហែល ១០ ឆ្នាំ អ្នករក្សាបញ្ជីទាំងឡាយគឺ អាម៉ូរ៉ុន បានប្រគល់ទំនួលខុសត្រូវដល់លោកដើម្បីរក្សាផ្នាំងពិសិដ្ឋទាំងឡាយនៅពេលលោកបានពេញវ័យ ។ លោកត្រូវឆ្លាក់កត់ត្រានូវការណ៍ទាំងអស់ដែលលោកបានសង្កេតឃើញអំពីប្រជាជន (សូមមើល មរមន ១:៤) ។ នៅអាយុ ១៥ ឆ្នាំ មរមន បានជួបនឹងព្រះអម្ចាស់ ហើយបានភ្លក់ ហើយបានស្គាល់នូវសេចក្តីល្អសប្បុរសនៃព្រះយេស៊ូវ » (មរមន ១:១៥) ។ នាឆ្នាំដដែលនោះដែរ ពួកសាសន៍នីហ្វៃបានតែងតាំងមរមនឲ្យដឹកនាំកងទ័ពរបស់ពួកគេ (សូមមើល មរមន ២:១) ។ ដោយគោរពតាមការណែនាំរបស់ អាំម៉ូរ៉ុន លោកបានទទួលនូវផ្នាំងចំណារនីហ្វៃធំនាពេលក្រោយមក ហើយបានចាប់ផ្តើមធ្វើការកត់ត្រា ។ លោកក៏បានសង្ខេបនូវផ្នាំងចំណារនីហ្វៃធំ ដែលបានរួមមាននូវការសរសេរពីព្យាការី និងអ្នករក្សាផ្នាំងទាំងឡាយពីលីហៃរហូតដល់អាំម៉ូរ៉ុន ហើយបានបញ្ចូលនូវផ្នាំងចំណារនីហ្វៃតូចទៅក្នុងការសង្ខេបនោះដែរ ។ នៅជិតពេលចុងបញ្ចប់នៃជីវិតរបស់លោក មរមនបានលាក់ផ្នាំងចំណារទាំងឡាយនៅក្នុងកូនភ្នំគូម៉ូរ៉ា លើកលែងតែផ្នាំងមួយចំនួនដែលលោកបានប្រគល់ដល់កូនប្រុសរបស់លោកគឺ ម៉ូរ៉ូណៃ (សូមមើល មរមន ៦:៦) ។ បន្ទាប់មក លោកបានដឹកនាំពួកសាសន៍នីហ្វៃទៅក្នុងសង្គ្រាមដ៏ធំចុងក្រោយប្រឆាំងនឹងពួកសាសន៍លេមិន ។ មុនពេលមរមនបានស្លាប់ លោកបានណែនាំម៉ូរ៉ូណៃឲ្យបញ្ចប់កំណត់ត្រារបស់លោក ។ ម៉ូរ៉ូណៃ បានបន្ថែមពាក្យទាំងឡាយដែលបង្កើតបានជាជំពូកទី ៨ –៩ នៃគម្ពីរនេះ ។

តើគម្ពីរនេះត្រូវបានសរសេរដល់នរណា ហើយតើហេតុអ្វី ?

មរមនបានសរសេរទៅកាន់ពួកសាសន៍ដទៃ និងសមាជិកនៃវង្សអ៊ីស្រាអែលនៅថ្ងៃចុងក្រោយ ដោយមានបំណងចង់ « បញ្ចុះបញ្ចូលអស់អ្នករាល់គ្នានៅចុងផែនដីឲ្យប្រែចិត្ត ហើយប្រុងប្រៀបឈរនៅចំពោះវេទិកាជំនុំជម្រះនៃព្រះគ្រីស្ទ » (មរមន ៣:២២) ។ នៅពេល ម៉ូរ៉ូណៃ បានបញ្ចប់គម្ពីររបស់ឪពុកលោកហើយ លោកបានបញ្ជាក់ដោយចំៗនូវអស់អ្នកដែលនឹងអានប្រសាសន៍របស់លោក ។ លោកបានព្រមានពួកគេពីលទ្ធផលនៃអំពើបាបរបស់ពួកគេ និងបានអញ្ជើញឲ្យពួកគេ « មករកព្រះអម្ចាស់ដោយអស់ពីដួងចិត្ត [របស់ពួកគេ] ចុះ » (« មរមន ៩:២៧) ។

តើនៅពេលណា និងនៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរឡើង ?

មរមន ប្រហែលជាបានសរសេរជំពូកទី ១–៧ នៃគម្ពីរនេះ នៅចន្លោះឆ្នាំ ៣៨៥ នៃគ្រិស្តសករាជ និងឆ្នាំ ៤០១ នៃគ្រិស្តសករាជ (សូមមើល មរមន ២:១៥–១៧; ៨:៥–៦) ។ លោកបានបញ្ចប់ការសរសេររបស់លោក ក្រោយពីចម្បាំងចុងក្រោយរវាងពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិននៅឯគូម៉ូរ៉ា នៅក្នុងឆ្នាំ ៣៨៥ នៃគ្រិស្តសករាជ (សូមមើល មរមន ៦:១០–១៥; ៧:១) ។ លោកម៉ូរ៉ូណៃ ប្រហែលជាបានធ្វើការកត់ត្រានៅក្នុងជំពូកទី ៨–៩ រវាងឆ្នាំ ៤០១ នៃគ្រិស្តសករាជ និងឆ្នាំ ៤២១ នៃគ្រិស្តសករាជ នៅពេលលោកបានទៅ « ដើម្បីសុវត្ថិភាពនៃជីវិតរបស់លោក » (សូមមើល មរមន ៨:៤–៦; ម៉ូរ៉ូណៃ ១:១–៣) ។១–៣) ។

តើមានលក្ខណៈពិសេសអ្វីខ្លះនៅក្នុងគម្ពីរនេះ ?

គម្ពីរនេះរៀបរាប់ពីការព្យាករណ៍ដែលបានបំពេញដោយនីហ្វៃ អាលម៉ា សាំយូអែលជាសាសន៍លេមិន និងព្រះយេស៊ូវគ្រីស្ទទាក់ទងទៅនឹងសេចក្តីបំផ្លិចបំផ្លាញនៃសាសន៍នីហ្វៃ (សូមមើល នីហ្វៃទី ១ ១២:១៩; អាលម៉ា ៤៥:៩–១៤; ហេលេមិន ១៣:៨–១០; នីហ្វៃទី ៣ ២៧:៣២) ។ លោក មរមន សំដៅលើការសរសេររបស់លោកខ្លះថាជា « បញ្ជីខ្ញុំអំពីសេចក្តីបំផ្លិចបំផ្លាញនៃអំពើទុច្ចរិតរបស់ពួកគេ » (មរមន ៦:១) ។ លោកបានបង្ហាញថា ការធ្លាក់របស់ពួកសាសន៍នីហ្វៃគឺជាលទ្ធផលមួយនៃអំពើទុច្ចរិតរបស់ពួកគេ (សូមមើល មរមន ៤:១២; ៦:១៥ –១៨) ។

គម្រោង

មរមន ១ អាំម៉ូរ៉ូនតែងតាំងមរមនឲ្យរក្សាកំណត់ត្រានៃប្រជាជននៅក្នុងជំនាន់របស់លោក ។ ពួកសាសន៍នីហ្វៃយកឈ្នះលើសាសន៍លេមិននៅក្នុងចម្បាំង ។ អំពើទុច្ចរិតផ្សព្វផ្សាយទូទាំងដែនដី ពួកសាវកសាសន៍នីហ្វៃបីរូបបានឈប់បម្រើដល់ប្រជាជន ហើយអំណោយទាននៃព្រះវិញ្ញាណត្រូវបានដកចេញទាំងស្រុង ។ ទោះជាយ៉ាងណាក្តី លោកមរមនបាន « ជួបនឹងព្រះអម្ចាស់ » ។

មរមន ២–៣ ពួកសាសន៍នីហ្វៃតែងតាំងមរមនឲ្យដឹកនាំកងទ័ពរបស់ពួកគេ ។ ទោះបីជាមានសេចក្តីបំផ្លិចបំផ្លាញដ៏ខ្លាំង និងការឈឺចុកដ៏ធំក្តី ពួកសាសន៍នីហ្វៃបដិសេធមិនព្រមប្រែចិត្តឡើយ ។ លោកមរមនទៅយកផ្នាំងនីហ្វៃពីកូនភ្នំមួយដែលហៅថា សិម ហើយចាប់ផ្តើមធ្វើកំណត់ត្រារបស់គាត់ ។ ក្រោយពីទទួលបានជ័យជំនះបីបួនលើកមក ប្រជាជនបានចាប់ផ្តើមមានភាពឆ្មើងឆ្មៃលើកម្លាំងរបស់ខ្លួន ហើយស្បថថានឹងប្រឆាំងនឹងពួកសាសន៍លេមិន ។ លោកមរមន បដិសេធមិនព្រមដឹកនាំពួកគេទៀតឡើយ ។ លោកសរសេរដើម្បីបញ្ចុះបញ្ចូលមនុស្សទាំងអស់នៅក្នុងថ្ងៃចុងក្រោយ ដើម្បីរៀបចំខ្លួនឈរនៅចំពោះមុខកៅអីការជំនុំជម្រះរបស់ព្រះគ្រីស្ទ ។

មរមន ៤ ដោយគ្មានការដឹកនាំពីមរមនទៀត នោះពួកកងទ័ពសាសន៍នីហ្វៃបន្តទៅច្បាំងប្រឆាំងនឹងពួកសាសន៍លេមិន ។ កងទ័ពរាប់ពាន់នាក់ពីទាំងសងខាងត្រូវស្លាប់ ។ កូនចៅរបស់លីហៃ ធ្លាក់ខ្លួនទុច្ចរិតកាន់តែខ្លាំងជាងពេលណាៗទាំងអស់នៅក្នុងប្រវត្តិសាស្ត្ររបស់ពួកគេ ហើយពួកសាសន៍លេមិនចាប់ផ្តើមបំផ្លាញពួកសាសន៍នីហ្វៃ ។ លោកមរមន ទទួលបន្ទុកលើកំណត់ត្រាសាសន៍នីហ្វៃទាំងអស់ ហើយផ្លាស់ទីចេញពីកូនភ្នំ សិម ទៅកូនភ្នំមួយហៅថា គូម៉ូរ៉ា ។

មរមន ៥–៧ លោកមរមនបន្តគ្រប់គ្រងកងទ័ពរបស់សាសន៍នីហ្វៃ ទោះបីជាលោកដឹងថា ពួកគេនឹងត្រូវបំផ្លាញក្តី ។ លោកព្យាករណ៍អំពីការលេចចេញមកនៃព្រះគម្ពីរមរមន ។ លោកប្រមូលពួកសាសន៍នីហ្វៃនៅឯកូនភ្នំគូម៉ូរ៉ា ដើម្បីធ្វើចម្បាំងប្រឆាំងនឹងពួកសាសន៍លេមិនជាលើកចុងក្រោយ ។ លោកមរមនសរសេរដើម្បីបញ្ចុះបញ្ចូលកូនចៅរបស់សាសន៍លេមិនឲ្យជឿទៅលើព្រះយេស៊ូវគ្រីស្ទ ហើយទទួលបុណ្យជ្រមុជទឹក ។

មរមន ៨–៩ ក្រោយពីការស្លាប់របស់លោកមរមន ម៉ូរ៉ូណៃបន្តការកត់ត្រា ។ លោកព្យាករណ៍អំពីព្រះគម្ពីរមរមនថានឹងលេចចេញមកដោយព្រះចេស្តានៃព្រះនៅក្នុងថ្ងៃមួយនៃការតេតជំនឿ និងអំពើទុច្ចរិត ។ លោកថ្លែងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ហើយបង្រៀនថា អព្ភូតហេតុ និងទីសម្គាល់នានាអមមកដោយសេចក្តីជំនឿទៅលើទ្រង់ ។ លោកដាស់តឿនអស់អ្នកទាំងឡាយណាដែលអានពាក្យរបស់លោកឲ្យមករកព្រះអម្ចាស់ ហើយត្រូវបានសង្គ្រោះ ។

មរមន ១–២

សេចក្តីផ្តើម

ទោះបីជាលោកមរមនបានធំឡើងនៅក្នុងសម័យដែលមានអំពើទុច្ចរិតច្រើនក្រាស់ក្រែក្តី ក៏លោកបានជ្រើសរើសធ្វើជាមនុស្សស្មោះត្រង់ដែរ ។ ដោយសារតែសេចក្តីស្មោះត្រង់របស់លោក លោកត្រូវបានប្រាប់ថា លោកនឹងត្រូវទទួលបន្ទុកលើបញ្ជីដ៏ពិសិដ្ឋរបស់ប្រជាជននាពេលក្រោយនៃជីវិតរបស់លោកដែរ ។ នៅអាយុ ១៥ ឆ្នាំ លោកបាន « ជួបនឹងព្រះអម្ចាស់ » (មរមន ១:១៥) ។ លោកបានប្រាថ្នាជួយដល់ពួកសាសន៍នីហ្វៃឲ្យប្រែចិត្ត ប៉ុន្តែដោយសារតែការបះបោរដ៏ខ្លាំងរបស់ពួកគេ នោះលោកត្រូវបានព្រះអម្ចាស់ហាមឃាត់មិនឲ្យបង្រៀនពួកគេ ។ នៅវ័យដ៏ក្មេងនេះ លោកត្រូវបានតែងតាំងដើម្បីឲ្យដឹកនាំកងទ័ពពួកសាសន៍នីហ្វៃ ។ ដោយសារពួកសាសន៍នីហ្វៃជាច្រើនបានបាត់បង់ព្រះវិញ្ញាណបរិសុទ្ធ និងអំណោយទានផ្សេងទៀតពីព្រះ នោះពួកគេត្រូវបានទុកឲ្យប្រយុទ្ធនឹងចម្បាំងដោយកម្លាំងរបស់ខ្លួនគេផ្ទាល់ប្រឆាំងនឹងពួកសាសន៍លេមិន ។

យោបល់សម្រាប់ការបង្រៀន

មរមន ១:១–៥

លោកមរមនដឹងថា នៅថ្ងៃណាមួយលោកនឹងត្រូវទទួលបន្ទុកលើបញ្ជីដ៏ពិសិដ្ឋរបស់ពួកសាសន៍នីហ្វៃ

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន មុនពេលចាប់ផ្តើមបង្រៀនដើម្បីឲ្យសិស្សអាចគិតអំពីសំណួរនេះ៖ នៅពេលពួកគេមកដល់ថ្នាក់ ៖ ***តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលមនុស្សផ្សេងហៅអ្នកថាជាពួកមរមន ?***

នៅពេលចាប់ផ្តើមថ្នាក់ សូមឲ្យសិស្សឆ្លើយនឹងសំណួរនៅលើក្តារខៀន ។ ក្រោយពីពួកគេបានពិភាក្សាពីសំណួរនេះហើយ សូមឲ្យសិស្សម្នាក់អានន្យវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហ្គរដុន ប៊ី ហិងគ្លី ៖

« ទោះពេលខ្លះខ្ញុំសោកស្តាយដែលមានមនុស្សខ្លះមិនហៅសាសនាចក្រនេះតាមឈ្មោះត្រឹមត្រូវយ៉ាងណាក្តី តែខ្ញុំរីករាយដែលឈ្មោះខ្លីដែលពួកគេប្រើនេះគឺជាកិត្តិយសដ៏ខ្ពង់ខ្ពស់មួយដែលបានបង្កើតដោយបុរសដ៏អស្ចារ្យម្នាក់ និងគម្ពីរមួយដែលផ្តល់នូវទីបន្ទាល់ដ៏ឥតប្រៀបផ្ទឹមទាក់ទងទៅនឹងព្រះប្រោសលោះនៃពិភពលោកនេះ ។

« អ្នកណាដែលបានស្គាល់បុរសឈ្មោះ មរមន នេះ តាមរយៈការអាន និងការសញ្ជឹងគិតពីប្រសាសន៍របស់លោក អ្នកណាដែលអានគម្ពីរដ៏មានតម្លៃនៃប្រវត្តិសាស្ត្រនេះ ដែលបានប្រមូល និងរក្សាទុកជាច្រើនផ្នែកដោយសារលោក នោះគេនឹងដឹងថា *មរមន* គឺមិនមែនជាពាក្យនៃការប្រមាថនោះទេ ប៉ុន្តែថាវាតំណាងឲ្យការល្អដ៏អស្ចារ្យ —ការល្អដែលចេញពីព្រះ: » (« *Mormon* Should Mean ‘More Good’ » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩០, ទំព័រ ៥២–៥៣) ។

ដើម្បីជួយសិស្សឲ្យយល់ពីបរិបទនៃ មរមន ១–២ សូមពន្យល់ថា ៣២០ ឆ្នាំក្រោយពីព្រះអង្គសង្គ្រោះបានយាងមកជួបនឹងពួកសាសន៍នីហ្វៃ មនុស្សស្ទើរគ្រប់គ្នានៅលើដែនដីបានរស់នៅក្នុងភាពទុច្ចរិត ។ នៅអំឡុងពេលនេះ អាំម៉ូរ៉ុន ដែលជាបុរសសុចរិតបានបម្រើជាអ្នករក្សាកំណត់ត្រាម្នាក់ ត្រូវបាន « បង្ខិតបង្ខំដោយព្រះវិញ្ញាណបរិសុទ្ធបានលាក់នូវបញ្ជីដ៏ពិសិដ្ឋទាំងនេះ: » (សូមមើល នីហ្វៃទី ៨ ១:៨៧–៤៩) ។ ក្នុងពេលប្រហែលគ្នានេះដែរ អាំម៉ូរ៉ុនបានទៅជួបនឹងក្មេងប្រុសអាយុ ១០ ឆ្នាំម្នាក់ឈ្មោះ មរមន ហើយបានណែនាំគាត់អំពីការទទួលខុសត្រូវនាពេលអនាគតរបស់គាត់លើបញ្ជីទាំងនេះ ។

សូមឲ្យសិស្សអាន មរមន ១:២ ស្ងាត់ៗ ដោយរកមើលពាក្យ និងឃ្លាដែលអាំម៉ូរ៉ុនបានប្រើដើម្បីរៀបរាប់ពីលោក មរមន ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមសរសេរឈ្មោះ *មរមន* នៅលើក្តារខៀន ហើយសរសេរន្យវចម្លើយរបស់គេនៅពីក្រោមវា ។ អ្នកអាចត្រូវពន្យល់ថាពាក្យ *ដ៏ម៉ឺងម៉ាត់* មានន័យថា ស្ងាត់ស្ងៀម ម៉ត់ចត់ និងគិតគូរវែងឆ្ងាយ ។

- **តើអ្នកគិតថា យើងគួរតែម៉ឺងម៉ាត់ក្នុងការណ៍អ្វីខ្លះ ? (ចម្លើយអាចរួមមាន ការបម្រើ និងការទទួលទានសាក្រាម៉ង់ ការសិក្សាព្រះគម្ពីរ ភាពបរិសុទ្ធ និងការនិយាយ និងថ្លែងពីព្រះអង្គសង្គ្រោះ:) ។ ហេតុអ្វីបានជាយើងគួរតែម៉ឺងម៉ាត់អំពីរឿងទាំងនេះ ?**

សូមពន្យល់ថា មនុស្សម្នាក់អាចម៉ឺងម៉ាត់ និងនៅតែមានការរីករាយ និងសំណើច ។ ទោះជាយ៉ាងណាក្តី មនុស្សម៉ឺងម៉ាត់ម្នាក់យល់ពីពេលដែលត្រូវលេងសើច និងពេលដែលត្រូវម៉ត់ចត់ ។

- **តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « ចេះសង្កេតដោយឆាប់រហ័ស » ?**

ជាផ្នែកនៃការពិភាក្សានេះ សូមឲ្យសិស្សម្នាក់អានការពន្យល់ខាងក្រោមដោយអែលឌើរ ដាវីឌ អេ បែដណា ជាក្លុំមនៃពួកសាវកដប់ពីរនាក់ ៖

« នៅពេលយើងចេះសង្កេតដោយឆាប់រហ័ស យើងនឹងត្រូវបំផុសឲ្យមើល ឬកត់ចំណាំ និងគោរពតាម ។ មូលដ្ឋានគ្រឹះទាំងពីរនេះ —ទាំងការមើល និងការគោរពតាម— គឺសំខាន់ដើម្បីចេះសង្កេតដោយឆាប់រហ័ស ។ ហើយព្យាការី មរមន គឺជាគំរូដ៏អស្ចារ្យមួយនៃការអនុវត្តអំណោយទាននេះ ។ . . .

« . . . អំណោយទានខាងព្រះវិញ្ញាណនៃការចេះសង្កេតដោយឆាប់រហ័ស គឺសំខាន់ជាខ្លាំងសម្រាប់យើងនៅក្នុងពិភពលោកមួយដែលយើងរស់នៅនាពេលនេះ និងនឹងរស់នៅនាពេលខាងមុខ » (« Quick to Observe » *Ensign,* ខែ ធ្នូ ២០០៦, ទំព័រ ៣៨) ។

- **តើសមត្ថភាពដើម្បីមើល និងគោរពតាមការណែនាំរបស់ព្រះអម្ចាស់យ៉ាងឆាប់រហ័សអាចជួយយើងដោយរបៀបណា ?**

សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅសរសេរ ឬក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីរអំពីអ្វីមួយដែលពួកគេគួរតែម៉ត់ចត់ជាងនេះ—អ្វីមួយដែលពួកគេគួរកាន់តែម៉ឹងម៉ាត់ ។ សូមឲ្យពួកគេសរសេរពីការដឹកនាំពីព្រះអម្ចាស់ដែល ពួកគេអាចគោរពតាមបានដោយល្អជាងនេះផងដែរ ។ សូមលើកទឹកចិត្តសិស្សឲ្យខិតខំធ្វើការដោយម៉ឹងម៉ាត់ និងចេះសង្កេតដោយឆាប់រហ័សជាងនេះ ។

សូមឲ្យសិស្សម្នាក់អាន មរមន ១:៣–៥ ឮៗហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលការណែនាំរបស់អាំម៉ូរ៉ុនដល់លោកមរមន ។

- តើអាំម៉ូរ៉ុនបានសុំឲ្យមរមនធ្វើអ្វី ?
- តើអ្នកគិតថា ហេតុអ្វីបានជាលោកមរមនត្រូវតែម៉ឹងម៉ាត់ និងចេះសង្កេតដោយឆាប់រហ័សដើម្បីបំពេញតាមការទទួលខុសត្រូវទាំងនេះ ?

មរមន ១:៦–១៩

ដោយសារតែការបះបោរដោយចេតនារបស់ប្រជាជន ព្រះអម្ចាស់ហាមលោកមរមនមិនឲ្យបង្រៀនពួកគេ

សូមសួរសិស្សថា តើពួកគេធ្លាប់បានបាត់បង់អ្វីមួយដែលពួកគេស្រឡាញ់ ឬមានអ្វីមួយដ៏មានតម្លៃដែលត្រូវបានគេយកទេ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយពីបទពិសោធន៍ទាំងនេះ ។

សូមសង្ខេប មរមន ១:៦–១២ ដោយការពន្យល់ថា ខណៈពេលដែលលោកមរមននៅក្នុងវ័យយុវវ័យរបស់លោក លោកបានថ្លែងជាសាក្សីពីសង្គ្រាមមួយចំនួនរវាងពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន ។ លោកក៏បានធ្វើជាសាក្សីពីការីករាលដាលនៃអំពើទុច្ចរិតនៅក្នុងចំណោមប្រជាជនទាំងឡាយនៅលើដែនដីដែរ ។

សូមពន្យល់ថា ដោយសារសាសន៍នីហ្វៃបានធ្លាក់ខ្លួនទុច្ចរិតបំផុត ពួកគេបានបាត់បង់អំណោយទានដ៏មានតម្លៃពីព្រះអម្ចាស់ ។ សូមបំបែកសិស្សជាពីរក្រុម ។ សូមចាត់ឲ្យក្រុមទីមួយអាន មរមន ១:១៣–១៤, ១៨ ស្ងាត់ៗ ដោយរកមើលអំណោយទានដែលព្រះអម្ចាស់បានចាប់ផ្តើមដកចេញពីពួកសាសន៍នីហ្វៃ ។ សូមចាត់ឲ្យក្រុមទីពីរអាន មរមន ១:១៤, ១៦–១៧, ១៩ ដោយរកមើលមូលហេតុដែលព្រះអម្ចាស់បានយកអំណោយទានទាំងនេះចេញពីពួកសាសន៍នីហ្វៃ ។ សូមឲ្យសិស្សពីក្រុមនីមួយៗចែកចាយគំហើញរបស់គេដល់សិស្សក្នុងថ្នាក់ ។

- យោងតាម មរមន ១:១៣–១៤ តើមានអ្វីកើតឡើង នៅពេលប្រជាជនបះបោរ ហើយបែរចេញពីព្រះអម្ចាស់ ? (សិស្សអាចឆ្លើយផ្សេងៗគ្នា ។ សូមគិតពីការសង្ខេបចម្លើយរបស់គេ ដោយការសរសេរនូវសេចក្តីពិតខាងក្រោមនៅលើក្តារខៀនថា ៖ **នៅពេលប្រជាជនប្រែជាទុច្ចរិត ហើយលែងជឿលើព្រះ ពួកគេចាត់បង់អំណោយទានខាងព្រះវិញ្ញាណ ដែលពួកគេបានទទួលពីព្រះអម្ចាស់ ហើយមិនអាចទទួលបាននូវឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធបានឡើយ**) ។

សូមបង្ហាញថា ការបះបោររបស់ពួកសាសន៍នីហ្វៃគឺខ្លាំងក្លា ។ ទោះជាយ៉ាងណាក្តី គោលការណ៍នេះអនុវត្តចំពោះយើងរៀងៗខ្លួន នៅពេលយើងមិនគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះ ។

- តើអំណោយទានមួយណាដែលមាននៅក្នុង មរមន ១:១៣–១៤, ១៨ ដែលពិបាកបំផុតសម្រាប់អ្នកពេលបាត់បង់វា ?

សូមឲ្យសិស្សម្នាក់អាន មរមន ១:១៥ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលលោកមរមនបានជួប ខណៈពេលដែលពួកសាសន៍នីហ្វៃជាច្រើនបានបាត់បង់អំណោយទានពីព្រះ និងឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។

- តើអ្នកគិតថា ហេតុអ្វីបានជាលោកមរមនអាចមានបទពិសោធន៍ខាងវិញ្ញាណ ទោះបីជាលោកស្ថិតនៅក្នុងកណ្តាលនៃអំពើទុច្ចរិតដ៏ខ្លាំងក្លាយ៉ាងណាក្តី ?

មរមន ២:១–១៥

លោកមរមនដឹកនាំកងទ័ពសាសន៍នីហ្វៃ និងសោកស្តាយចំពោះអំពើទុច្ចរិតរបស់ពួកគេ

សូមឲ្យសិស្សម្នាក់ដែលមានអាយុ ១៥ ឆ្នាំ (ឬជិតអាយុ ១៥ ឆ្នាំ) ឲ្យអាន មរមន ២:១–២ ឮៗ ។ សូមឲ្យសិស្សរកមើលការទទួលខុសត្រូវដែលមរមនបានទទួល នៅពេលលោកមានអាយុ ១៥ ឆ្នាំ (កាលលោក « ដប់ប្រាំមួយឆ្នាំ ») ។ សូមឲ្យសិស្សស្រមៃពីអ្វីដែលនឹងកើតឡើងសម្រាប់មនុស្សអាយុ ១៥ ឆ្នាំម្នាក់ត្រូវដឹកនាំកងទ័ពមួយ ។

- តើលក្ខណៈទាំងឡាយដែលត្រូវបានរៀបរាប់នៅក្នុង មរមន ២:១ បានជួយលោកមរមន ជាអ្នកដឹកនាំម្នាក់នៃកងទ័ពមួយនេះតាមរបៀបណាខ្លះ ?

សូមសង្ខេប មរមន ២:៣–៩ ដោយប្រាប់សិស្សថា ពួកសាសន៍លេមិនបានវាយប្រហារលើពួកកងទ័ពសាសន៍នីហ្វៃដោយកម្លាំងមួយដែលពួកសាសន៍នីហ្វៃខ្លាច និងបានដកថយទ័ព ។ ពួកសាសន៍លេមិនបានបង្ក្រាបពួកគេពីកន្លែងមួយទៅកន្លែងមួយទៀត រហូតដល់ពួកសាសន៍នីហ្វៃបានប្រជុំគ្នានៅក្នុងកន្លែងមួយ ។ នៅទីបំផុត កងទ័ពរបស់មរមនតទល់នឹងពួកសាសន៍លេមិន ហើយបានធ្វើឲ្យពួកគេគេចខ្លួនបាត់ទៅ ។

សូមឲ្យសិស្សអាន មរមន ២:១០–១៥ ដោយស្ងាត់ៗដោយរកមើលស្ថានភាពខាងវិញ្ញាណនៃពួកសាសន៍នីហ្វៃ ក្រោយពីសង្គ្រាមទាំងនេះ ។

- ហេតុអ្វីបានជាសាសន៍នីហ្វៃសោកសង្រេង ? (សូមមើល មរមន ២:១០–១៣ ។ ពួកគេសោកស្តាយ ដោយសារពួកគេមិនអាចរក្សារបស់របរបស់ពួកគេ ។ និយាយម្យ៉ាងទៀតថា ពួកគេសោកសង្រេងដោយសារតែលទ្ធផលនៃអំពើបាបរបស់ពួកគេ មិនមែនដោយសារពួកគេសោកស្តាយចំពោះសកម្មភាពរបស់គេឡើយ) ។

- យោងតាម មរមន ២:១៣–១៤ តើលោកមរមនបានដឹងថា ទុក្ខសោករបស់ប្រជាជនមិនមែនជាការបង្ហាញនៃការប្រែចិត្តដ៏ពិតដោយរបៀបណា ?

ដើម្បីជួយសិស្សឲ្យឃើញពីភាពខុសគ្នារវាង « សេចក្តីទុក្ខសោក . . . នាំទៅរកសេចក្តីប្រែចិត្ត » និង « សេចក្តីទុក្ខព្រួយរបស់អ្នកជាប់ទោស » សូមសរសេរពាក្យខាងក្រោមនៅលើក្តារខៀន ៖

អ្នកដែលមានទុក្ខសោកទៅរកសេចក្តីប្រែចិត្ត . . .

អ្នកដែលមានទុក្ខព្រួយដោយគ្រាន់តែព្រោះលទ្ធផលនៃអំពើបាប . . .

សូមឲ្យសិស្សរំឭក មរមន ២:១២–១៥ ដោយរកមើលលក្ខណៈនៃក្រុមប្រជាជនទាំងពីរនេះ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ ចម្លើយរបស់ពួកគេគួរបង្ហាញពីសេចក្តីពិតខាងក្រោម ៖

អ្នកដែលមានទុក្ខសោកទៅរកសេចក្តីប្រែចិត្ត ទទួលស្គាល់នូវសេចក្តីល្អនៃព្រះ និងមករកព្រះគ្រីស្ទដោយមានចិត្តទន់ទាប ។

អ្នកដែលមានទុក្ខព្រួយដោយគ្រាន់តែព្រោះលទ្ធផលនៃអំពើបាប បន្តបះបោរប្រឆាំងនឹងព្រះ ។

សូមពន្យល់ថា លោកមរមនបានប្រើឃ្លា « សេចក្តីទុក្ខព្រួយរបស់អ្នកជាប់ទោស » (មរមន ២:១៣) ដើម្បីរៀបរាប់ពីទុក្ខសោកនៃអ្នកដែលរងទុក្ខដោយសារតែលទ្ធផលនៃសកម្មភាពរបស់ពួកគេ ប៉ុន្តែមិនព្រមប្រែចិត្ត ។ លក្ខណៈនេះមិនដឹកនាំទៅរកការអត់ទោស និងសន្តិភាពឡើយ ។ វានាំទៅរកការជាប់ទោស ដែលមានន័យថា មនុស្សម្នាក់ត្រូវបានបញ្ឈប់ពីការរីកចម្រើនទៅរកជីវិតដ៏នៅអស់កល្បជានិច្ចរបស់គេ ។

សូមឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេឆ្លើយតប នៅពេលពួកគេដឹងថា ពួកគេមានអំពើបាប ។ សូមលើកទឹកចិត្តពួកគេឲ្យមករកព្រះអង្គសង្គ្រោះដោយមានចិត្តទន់ទាប ដើម្បីឲ្យពួកគេអាចត្រូវបានអភ័យទោស ទទួលបានសន្តិភាព ហើយរួបរួមនឹងព្រះ ។

មរមន ២:១៦–២៩

លោកមរមនទទួលបានផ្នាំងចំណារ ហើយកត់ត្រាដំណើររឿងនៃអំពើទុច្ចរិតរបស់ប្រជាជន ។

សូមសង្ខេប មរមន ២:១៦–១៨ ដោយការពន្យល់ថា នៅពេលសង្គ្រាមជាមួយនឹងពួកសាសន៍លេមិនបានបន្ត លោកមរមនបានឃើញថា ខ្លួនលោកនៅក្បែរភូនភ្នំមួយហៅថា សិម ជាកន្លែងដែលអាំម៉ូរ៉ុនបានលាក់បញ្ជីនៃសាសន៍នីហ្វៃ ។ លោកបានប្តូរទីតាំងថ្នាំងនីហ្វៃ ហើយបានចាប់ផ្តើមកត់ត្រាអ្វីដែលលោកបានសង្កេតនៅក្នុងចំណោមប្រជាជន តាំងពីពេលដែលលោកនៅជាកុមារ ។

សូមឲ្យសិស្សម្នាក់អាន មរមន ២:១៨–១៩– ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលការរៀបរាប់របស់មរមនអំពីស្ថានភាពខាងវិញ្ញាណរបស់ប្រជាជននៅក្នុងជំនាន់របស់លោក ។ សូមឲ្យពួកគេរកមើលផងដែរនូវការបង្ហាញថ្នាល់ខ្លួនរបស់លោកអំពីសេចក្តីសង្ឃឹម ។

- តើលោកមរមនបានរៀបរាប់ពីស្ថានភាពខាងវិញ្ញាណនៅក្នុងជំនាន់របស់លោកដោយរបៀបណា ? (« ឆាកអំពីអំពើទុច្ចរិត និងអំពើគួរខ្ពើមឆ្អើមទាំងឡាយមិនឈប់ឈរ ») ។
- តាមរយៈអ្វីដែលអ្នកបានរៀនអំពីលោកមរមន តើអ្នកគិតថា ហេតុអ្វីបានជាលោកអាចមានទំនុកចិត្តរហូតដល់លោកអាច « នឹងត្រូវបានតម្កើងឡើងនៅថ្ងៃចុងក្រោយបង្អស់ » ? (អ្នកអាចជួយសិស្សឲ្យយល់ថា នៅពេលលោកមរមនបាននិយាយអំពី « ការនឹងត្រូវបានតម្កើងឡើងនៅថ្ងៃចុងក្រោយបង្អស់ » លោកបានសំដៅទៅលើការត្រូវរស់ឡើងវិញ និងបាននាំទៅក្នុងវត្តមាននៃព្រះដើម្បីនៅជាមួយនឹងទ្រង់ជារៀងរហូត) ។
- តើគំរូសុចរិតរបស់មរមន ជួយដល់អ្នកដូចម្តេចខ្លះ ? (សិស្សអាចចែកចាយនូវចម្លើយខុសៗគ្នា ។ ចម្លើយរបស់ពួកគេគួរតែបង្ហាញពីគោលការណ៍ខាងក្រោម ៖ **យើងអាចជ្រើសរើសដើម្បីរស់នៅដោយសុចរិត ទោះបីជារស់នៅក្នុងសង្គមដ៏ទុច្ចរិតមួយក្តី ។** អ្នកអាចសុំឲ្យសិស្សម្នាក់សរសេរសេចក្តីពិតនេះនៅលើក្តារខៀន) ។
- តើនៅពេលណាដែលអ្នកបានឃើញមិត្តភក្តិ ឬសមាជិកគ្រួសារឈរយ៉ាងរឹងមាំក្នុងការគោរពប្រតិបត្តិតាមព្រះឆន្ទៈរបស់ព្រះ ទោះបីជានៅពេលអ្នកនៅជុំវិញគេមិនគោរពប្រតិបត្តិតាមក្តី ?

សូមលើកទឹកចិត្តសិស្សឲ្យគិតអំពីផ្នែកដ៏ជាក់លាក់មួយនៃជីវិតរបស់គេ ដែលពួកគេអាចធ្វើអ្វីច្រើនជាងនេះដើម្បីឈរសម្រាប់អ្វីដែលត្រូវ ។ សូមឲ្យពួកគេសរសេរនៅក្នុងសៀវភៅសរសេរ ឬក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីរ អំពីរបៀបដែលពួកគេនឹងឆ្លើយតបនៅពេលដែលពួកគេជួបនឹងឧបសគ្គណាមួយនៅពេលក្រោយ ។ សូមថ្លែងទីបន្ទាល់ថា ដូចជាមរមនដែរ យើងអាចជ្រើសរើសដើម្បីរស់នៅដោយសុចរិត ហើយថាព្រះអម្ចាស់នឹងជួយយើងឲ្យឈរដោយរឹងមាំសម្រាប់អ្វីដែលត្រូវ ទោះបីជានៅពេលអ្នកដទៃនៅជុំវិញយើងមិនធ្វើក្តី ។

មរមន ៣–៤

សេចក្តីផ្តើម

ក្រោយពីការដេញដោលដែនដីរបស់គេពីពួកសាសន៍លេមិនវិញបាន ពួកសាសន៍នីហ្វៃបានរៀបចំខ្លួនទៅច្បាំងម្តងទៀត ។ លោកមរមនបានសុំអង្វរឲ្យពួកសាសន៍នីហ្វៃប្រែចិត្ត ។ ផ្ទុយទៅវិញ ពួកគេមានភាពឆ្មើងឆ្មៃចំពោះកម្លាំងខ្លួនឯង ហើយបានស្បថថានឹងសងសឹកចំពោះបងប្អូនរបស់គេដែលបានបរាជ័យនោះ ។ ដោយសារព្រះអម្ចាស់បានហាមឃាត់ប្រជាជនរបស់ទ្រង់កុំឲ្យសងសឹក នោះលោកមរមនបានបដិសេធមិនព្រមដឹកនាំកងទ័ពសាសន៍នីហ្វៃ ហើយពួកគេបានជួបនឹងបរាជ័យ ។ នៅពេលពួកសាសន៍នីហ្វៃរឹងទទឹងនៅក្នុងសេចក្តីទុច្ចរិត នោះព្រះបានស្រោចការជំនុំជម្រះរបស់ទ្រង់មកលើពួកគេ ហើយពួកសាសន៍លេមិនបានចាប់ផ្តើមបំផ្លាញពួកគេចេញពីផែនដីនេះ ។

យោបល់សម្រាប់ការបង្រៀន

មរមន ៣:១–៨

ព្រះអម្ចាស់ជួយពួកសាសន៍នីហ្វៃនៅក្នុងចម្បាំង ដើម្បីផ្តល់ឱកាសដល់ពួកគេឲ្យប្រែចិត្ត ប៉ុន្តែពួកគេបែរជាពង្រឹងដួងចិត្តរបស់ខ្លួនទៅវិញ

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀនមុនចាប់ផ្តើមបង្រៀន ៖ *តើអ្នកធ្លាប់មានអារម្មណ៍ថា ព្រះអម្ចាស់បានព្យាយាមទាញចំណាប់អារម្មណ៍របស់អ្នក ហើយលើកទឹកចិត្តដល់អ្នកឲ្យផ្លាស់ប្តូរអ្វីមួយនៅក្នុងជីវិតរបស់យើងដែរឬទេ ?*

សូមចាប់ផ្តើមដោយការសុំឲ្យសិស្សចែកចាយចម្លើយរបស់ពួកគេចំពោះសំណួរនៅលើក្តារខៀន ។ (សូមប្រាកដថា ពួកគេមិនមានអារម្មណ៍ត្រូវតែចែកចាយអ្វីដែលផ្ទាល់ខ្លួន ឬឯកជនពេកនោះទេ) ។ សូមគិតផងដែរពីការចែកចាយបទពិសោធន៍របស់អ្នកផ្ទាល់) ។

សូមពន្យល់ថា ព្រះអម្ចាស់បានចង់ទាញចំណាប់អារម្មណ៍របស់សាសន៍នីហ្វៃ ដើម្បីឲ្យពួកគេនឹងផ្លាស់ប្តូរផ្លូវដ៏ទុច្ចរិតរបស់ពួកគេ ។ ទោះជាយ៉ាងណាក្តី ពួកសាសន៍នីហ្វៃបានពង្រឹងចិត្តរបស់ពួកគេ ហើយបានខកខានមិនបានយល់ថា ព្រះអម្ចាស់បានប្រទានពរដល់ពួកគេនៅក្នុងសង្គ្រាមប្រឆាំងនឹងពួកសាសន៍លេមិនឡើយ ។ ក្រោយពីពួកសាសន៍នីហ្វៃបានធ្វើសន្ធិសញ្ញាជាមួយនឹងពួកសាសន៍លេមិន និងពួកចោរកាឌីអានតុនហើយ (សូមមើល មរមន ២:២៨) ព្រះអម្ចាស់បានការពារពួកគេ ដោយឲ្យពួកគេរស់នៅរយៈពេល ១០ ឆ្នាំ ដោយគ្មានជម្លោះ ។ អំឡុងពេលប៉ុន្មានឆ្នាំនោះ លោកមរមនបានជួយពួកសាសន៍នីហ្វៃឲ្យរៀបចំខ្លួនសម្រាប់ការវាយប្រហារនៅថ្ងៃក្រោយ (សូមមើល មរមន ៣:១) ។

សូមឲ្យសិស្សម្នាក់អាន មរមន ៣:២–៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលព្រះអម្ចាស់បានមានព្រះទ័យឲ្យពួកសាសន៍នីហ្វៃធ្វើ អំឡុងពេលនៃសន្តិភាពដែលទ្រង់បានប្រទានដល់ពួកគេ ។

- **តើព្រះអម្ចាស់បានបញ្ជាលោកមរមនឲ្យផ្តល់សារអ្វីទៅដល់ពួកសាសន៍នីហ្វៃ ? តើពួកសាសន៍នីហ្វៃបានយល់ពីសារនេះដែរឬទេ ? តើពួកសាសន៍នីហ្វៃបានឆ្លើយតបទៅនឹងសារនេះដោយរបៀបណា ?**
- **យោងតាម មរមន ៣:៣ ហេតុអ្វីបានជាព្រះអម្ចាស់ថែរក្សាពួកសាសន៍នីហ្វៃនៅក្នុងសង្គ្រាមច្បាំងរបស់ពួកគេ ទោះបីជាមានអំពើទុច្ចរិតរបស់គេយ៉ាងណាក្តី ?**
- **តើសេចក្តីពិតអ្វីដែលអ្នកអាចរកឃើញពីការទាក់ទងរបស់ព្រះអម្ចាស់ជាមួយនឹងពួកសាសន៍នីហ្វៃនៅក្នុង មរមន ៣:២–៣ ? (សិស្សអាចឆ្លើយខុសៗគ្នា ។ សូមសង្កេបចម្លើយរបស់ពួកគេ ដោយការសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ ***ព្រះអម្ចាស់ប្រទានដល់យើងនូវឱកាសដ៏គ្រប់គ្រាន់ល្មមដើម្បីប្រែចិត្តពីអំពើបាបរបស់យើង*** ។ អ្នកអាចណែនាំឲ្យ សិស្សអាចសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។**

សូមសង្កេប មរមន ៣:៤–៨ ដោយការពន្យល់ថា ព្រះអម្ចាស់បានការពារពួកសាសន៍នីហ្វៃពីរដងទៀតនៅក្នុងសង្គ្រាម ទោះបីជាពួកគេទុច្ចរិត ហើយគ្មានឆន្ទៈបែរទៅរកទ្រង់វិញក្តី ។

- **តើការការពាររបស់ព្រះអម្ចាស់លើពួកសាសន៍នីហ្វៃបានបង្រៀនអ្នកអំពីអត្តចរិតរបស់ទ្រង់យ៉ាងដូចម្តេចខ្លះ ? (ចម្លើយអាចរួមមាន ព្រះអម្ចាស់មានមេត្តាករុណា និងអត់ធ្មត់) ។**

សូមបង្ហាញថា ព្រះអម្ចាស់ប្រទានដល់យើងទាំងអស់គ្នានូវ « ឱកាសមួយសម្រាប់ការប្រែចិត្ត » (មរមន ៣:៣) ។ បន្ទាប់មក សូមឲ្យសិស្ស សញ្ជឹងគិត ក្នុងចិត្តពីសំណួរខាងក្រោម ៖

- **តើអ្នកធ្លាប់មានឆន្ទៈដើម្បីប្រែចិត្ត ហើយធ្វើការផ្លាស់ប្តូរទៅតាមអ្វីដែលព្រះមានព្រះទ័យចង់ឲ្យអ្នកធ្វើដែរឬទេ ? តើមានការផ្លាស់ប្តូរអ្វីដែលអ្នកអាចធ្វើនាពេលនេះ ដើម្បីក្លាយជាមនុស្សម្នាក់ដែលព្រះមានព្រះទ័យចង់ឲ្យអ្នកក្លាយទៅជាដែរឬទេ ?**

សូមថ្លែងទីបន្ទាល់អំពីសេចក្តីល្អ និងការអត់ធ្មត់របស់ព្រះ ក្នុងការប្រទានដល់យើងនូវឱកាសដើម្បីប្រែចិត្ត ។ សូមឲ្យសិស្សរកមើលឱកាស និងការអញ្ជើញឲ្យធ្វើការផ្លាស់ប្តូរនៅក្នុងជីវិតរបស់គេ ហើយសូមលើកទឹកចិត្តពួកគេឲ្យធ្វើការផ្លាស់ប្តូរតាមការបំផុសគំនិតនោះ ។

> ***ការសញ្ជឹងគិត***
>
> របៀបមួយដើម្បីជួយសិស្សឲ្យយល់កាន់តែសឹងជម្រៅលើអ្វីដែលពួកគេកំពុងរៀននេះ គឺត្រូវផ្តល់ពេលដល់ពួកគេនៅក្នុងថ្នាក់ឲ្យសញ្ជឹងគិត ។ អ្នកអាចសុំឲ្យសិស្សគិតពិចារណាដោយស្ងាត់ស្ងៀមពីរបៀបដែលគោលការណ៍មួយបានមានឥទ្ធិពលដល់ជីវិតរបស់ពួកគេ ឬរបៀបដែលពួកគេអាចអនុវត្តវា ។ នៅពេលសិស្សរៀនដើម្បីសញ្ជឹងគិតពីព្រះគម្ពីរនៅក្នុងថ្នាក់ និងដោយខ្លួនឯង នោះព្រះវិញ្ញាណបរិសុទ្ធនឹងបង្ហាញសេចក្តីពិតដល់ពួកគេជាញឹកញាយ ។

មរមន ៣:៩–២២

ពួកសាសន៍នីហ្វៃកើនឡើងនៅក្នុងសេចក្តីទុច្ចរិត ហើយលោកមរមនបដិសេធមិនព្រមដឹកនាំកងទ័ពរបស់ពួកគេ

សូមពន្យល់ថា ពួកសាសន៍នីហ្វៃមិនបានឆ្លើយតបទៅនឹងការអញ្ជើញរបស់ព្រះអម្ចាស់ឲ្យប្រែចិត្តឡើយ ប៉ុន្តែគេបែរជាពង្រឹងដួងចិត្តរបស់ពួកគេទៅវិញ ។ សូមឲ្យសិស្សម្នាក់អាន មរមន ៣:៩–១០ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរបៀបដែលពួកសាសន៍នីហ្វៃធ្វើសកម្មភាពឆ្លើយតបទៅនឹងជ័យជំនះដ៏ច្រើនរបស់គេលើពួកសាសន៍លេមិន ។ (អ្នកអាចប្រាប់សិស្សថាពាក្យ *សងសឹក* នៅក្នុង ខគម្ពីរទី ៩ មានន័យថាចង់ព្យាយាមចង់សងសឹក) ។

- តើពួកសាសន៍នីហ្វៃបានឆ្លើយតបយ៉ាងណា បន្ទាប់ពីជ័យជំនះរបស់ពួកគេលើពួកសាសន៍លេមិន ?
- ហេតុអ្វីបានជាវាខុសឆ្គងដែលពួកសាសន៍នីហ្វៃមានការលើកខ្លួនឡើងចំពោះកម្លាំងខ្លួនឯង ? តើមានការមានការលើកខ្លួនឡើងនេះបង្ហាញអំពីទំនាក់ទំនងរបស់ពួកគេដូចម្តេចជាមួយនឹងព្រះ ?

សូមឲ្យសិស្សម្នាក់អាន មរមន ៣:១១–១៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលចម្លើយរបស់មរមន នៅពេលពួកសាសន៍នីហ្វៃបានស្បថថានឹងសងសឹក ។

- តើមរមនបានធ្វើអ្វី នៅពេលពួកសាសន៍នីហ្វៃបង្ហាញពីបំណងដើម្បីសងសឹកនឹងពួកសាសន៍លេមិន ?
- តើអ្នកធ្លាប់ចង់ព្យាយាមសងសឹកនឹងនរណាម្នាក់ដែរឬទេ ? តើអ្នកគិតថា ហេតុអ្វីបានជាការចង់ព្យាយាមសងសឹកគឺជាប្រតិកម្មពីធម្មជាតិមួយសម្រាប់មនុស្សជាច្រើន ?
- មរមនបានដឹកនាំកងទ័ពពួកសាសន៍នីហ្វៃអស់រយៈពេលជាង ៣០ ឆ្នាំ ទោះបីជាពួកគេទុច្ចរិតក្តី ។ តើការបដិសេធរបស់មរមនមិនព្រមដឹកនាំកងទ័ព បង្រៀនអ្វីខ្លះអំពីភាពធ្ងន់ធ្ងរក្នុងការសងសឹក ?

សូមឲ្យសិស្សម្នាក់អាន មរមន ៣:១៤–១៦ ហើយសូមលើកទឹកចិត្តសិស្សឲ្យរកមើលអ្វីដែលព្រះអម្ចាស់បានបង្រៀនដល់មរមនអំពីការសងសឹក ។

- តើព្រះអម្ចាស់មានព្រះទ័យយ៉ាងណាចំពោះការចង់ព្យាយាមសងសឹក ? (ចម្លើយរបស់សិស្សអាចខុសៗគ្នា ។ សូមសង្ខេបចម្លើយរបស់ពួកគេ ដោយការសរសេរសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ ***ព្រះអម្ចាស់ហាមមិនឲ្យយើងព្យាយាមសងសឹកឡើយ***) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ពីការណែនាំរបស់ព្រះអម្ចាស់នៅក្នុង ខគម្ពីរទី ១៤–១៦ សូមឲ្យសិស្សនិយាយម្តងទៀតនូវផ្នែកទីមួយនៃ មរមន ៣:១៥ (« ការសងសឹកគឺជារបស់យើង ហើយយើងនឹងសង ») ជាសម្តីខ្លួនឯង ។

- ហេតុអ្វីបានជាវាសំខាន់ដើម្បីមិនសងសឹកគេ ? តើយើងអាចយកឈ្នះលើបំណងចង់សងសឹកដោយរបៀបណា ?

ដើម្បីជួយសិស្សឲ្យរៀនពីរបៀបយកឈ្នះលើអារម្មណ៍សងសឹក សូមឲ្យសិស្សម្នាក់អានឮៗនូវការណែនាំខាងក្រោមពីប្រធាន ដៃមស៍ អឹ ហ្វោស្ត នៃគណៈប្រធានទីមួយ ។ ប្រសិនបើអាច សូមផ្តល់ច្បាប់ចម្លងនៃប្រសាសន៍ដកស្រង់នេះដល់សិស្សម្នាក់ៗ ។

« យើងត្រូវស្គាល់ ហើយទទួលយកនូវអារម្មណ៍ខឹងសម្បារនេះ ។ វាត្រូវការការបន្ទាបខ្លួនដើម្បីធ្វើបែបនេះបាន ប៉ុន្តែប្រសិនបើយើងលុតជង្គង់ចុះ ហើយសុំព្រះវរបិតាដើម្បីមានអារម្មណ៍នៃការអភ័យទោស នោះទ្រង់នឹងជួយយើង ។ ព្រះអម្ចាស់សុំឲ្យយើង ‹ អត់ទោសដល់មនុស្សទាំងអស់ › [គ. និង ស. ៦៤:១០] ដើម្បីការល្អរបស់យើងផ្ទាល់ ដោយសារ ‹ ការស្អប់បង្អាក់ការរីកចម្រើនខាងវិញ្ញាណ › ។ [Orson F. Whitney, *Gospel Themes* (ឆ្នាំ ១៩១៤), ទំព័រ ១៤៤ ។] មានតែនៅពេលយើងបញ្ចៀសខ្លួនយើងចេញពីការស្អប់ និងភាពជូរចត់ទេ ទើបព្រះអម្ចាស់អាចផ្តល់នូវការលួងលោមដល់ដួងចិត្តរបស់យើងបាន ។ . . .

« . . . នៅពេលសោកនាដកម្មកើតឡើង យើងមិនគួរឆ្លើយតបដោយការព្យាយាមសងសឹកផ្ទាល់ខ្លួននោះទេ ប៉ុន្តែយើងត្រូវអនុញ្ញាតឲ្យសេចក្តីយុត្តិធម៌ដើរតាមផ្លូវរបស់វា ហើយបន្ទាប់មកបណ្តោយឲ្យវាកន្លងទៅចុះ ។ វាមិនងាយស្រួលទេដើម្បីបណ្តោយឲ្យវាទៅ ហើយធ្វើឲ្យដួងចិត្តយើងទទេស្អាតពីការឈឺចាប់ ។ ព្រះអង្គសង្គ្រោះបានប្រទានដល់យើងទាំងអស់គ្នានូវសេចក្តីសុខសាន្តដ៏មានតម្លៃមួយតាមរយៈដង្វាយធួនរបស់ទ្រង់ ប៉ុន្តែការណ៍នេះអាចកើតឡើងតែនៅពេលយើងមានឆន្ទៈបោះបង់ចោលនូវអារម្មណ៍អវិជ្ជមាន គឺកំហឹង ការស្អប់ ឬការសងសឹកប៉ុណ្ណោះ » (« The Healing Power of Forgiveness » *Ensign* ឬ ***លីអាហូណា*** ខែ ឧសភា ឆ្នាំ ២០០៧, ទំព័រ ៦៩) ។

សូមឲ្យសិស្សម្នាក់អាន មរមន ៣:១៧, ២០–២២ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលលោកមរមនបានចង់ឲ្យយើងដឹង ។ អ្នកអាចសុំឲ្យសិស្សគូសចំណាំការណែនាំរបស់លោកមរមនក្នុង « ការប្រែចិត្ត និងរៀបចំខ្លួនដើម្បីឈរនៅចំពោះការជំនុំជម្រះរបស់ព្រះគ្រីស្ទ » (មរមន ៣:២២) ។

មរមន ៤

ពួកសាសន៍លេមិនចាប់ផ្តើមកំចាយពួកសាសន៍នីហ្វៃចេញពីផែនដី

សូមឲ្យសិស្សលើកដៃ ប្រសិនបើពួកគេស្គាល់នរណាម្នាក់ដែលបានធ្វើអ្វីមួយខុស ប៉ុន្តែមិនត្រូវបានគេចាប់បាន ឬជួបនឹងលទ្ធផលនៃការធ្វើខុសនោះ ។ សូមឲ្យសិស្សសញ្ជឹងគិតពីសំណួរខាងក្រោមនេះ ៖

- តើអ្នកធ្លាប់ឆ្ងល់ទេថា តើនៅពេលណាដែលលទ្ធផលនៃជម្រើសខុសនឹងតាមទាន់នរណាម្នាក់ដែលជ្រើសរើសធ្វើខុសដោយចេតនា ?

សូមឲ្យសិស្សអាន មរមន ៤:១–២ ដោយស្ងាត់ៗដោយរកមើលអ្វីដែលបានកើតឡើងដល់កងទ័ពសាសន៍នីហ្វៃ នៅពេលពួកគេបានចង់សងសឹកនឹងពួកសាសន៍លេមិន ។ បន្ទាប់មក សូមឲ្យសិស្សអាន មរមន ៤:៤ ដោយស្ងាត់ៗដោយរកមើលមូលហេតុដែលកងទ័ពសាសន៍នីហ្វៃមិនបានជោគជ័យ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមឲ្យសិស្សម្នាក់អាន មរមន ៤:៥ ឮ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលសេចក្តីពិតដែលខគម្ពីរនេះបង្រៀនអំពីលទ្ធផលនៃការរឹងទទឹងនៅក្នុងអំពើទុច្ចរិត ។ នៅពេលសិស្សចែកចាយអ្វីដែលពួកគេបានរកឃើញ សូមសរសេរនៅលើក្តារខៀននូវសេចក្តីពិតខាងក្រោមពី មរមន ៤:៥ ៖ « ***សេចក្តីជំនុំជម្រះនៃព្រះនឹងយកឈ្នះលើពួកទុច្ចរិត*** » ។ អ្នករាចណែនាំថា សិស្សអាចគូសចំណាំសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

សូមឲ្យសិស្សអាន មរមន ៤:១០–១២ ដោយស្ងាត់ៗដោយរកមើលការពិពណ៌នានៃអំពើទុច្ចរិតរបស់ពួកសាសន៍នីហ្វៃ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី មរមន ៤:១៣–១៤, ១៨, ២១– ២២ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយរកមើលរបៀបដែលការជំនុំជម្រះនៃព្រះដែលបានស្រោចមកលើពួកសាសន៍នីហ្វៃ ។

- សម្រាប់អ្នក តើអ្វីជាផ្នែកដ៏ក្រៀមក្រំបំផុតនៃដំណើររឿងនេះ ?

សូមឲ្យសិស្សមើលទៅគោលការណ៍ដែលអ្នកបានសរសេរនៅលើក្តារខៀន ។ សូមឲ្យពួកគេសញ្ជឹងគិតពីរបៀបដែលពួកគេអាចអនុវត្តសេចក្តីពិតទាំងនេះនៅក្នុងជីវិតរបស់ពួកគេ ។ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមការបំផុសពីព្រះវិញ្ញាណបរិសុទ្ធ ដែលពួកគេទទួលបាននៅពេលពួកគេសញ្ជឹងគិត ។

សូមថ្លែងទីបន្ទាល់ពីសេចក្តីល្អ និងសេចក្តីស្រឡាញ់នៃព្រះអម្ចាស់ក្នុងការប្រទានដល់យើងនូវឱកាសដ៏គ្រប់គ្រាន់ល្មមដើម្បីប្រែចិត្ត ។ សូមថ្លែងទីបន្ទាល់ផងដែរថា លទ្ធផលនឹងតែងតែមកដល់អ្នកណាដែលរឹងទទឹងមិនព្រមប្រែចិត្ត ។

វិចារណកថា និង ព័ត៌មានសាច់រឿង

មរមន ៣:៩–១០ ។ ការស្បថសម្បថ

លោកមរមនបានមានប្រសាសន៍ថា ពួកសាសន៍នីហ្វៃបានស្បថ « ដល់ស្ថានសួគ៌ និងចំពោះបល្ល័ង្កនៃព្រះផង » ថាពួកគេនឹងសងសឹកលើពួកសាសន៍លេមិន (សូមមើល មរមន ៣:៩–១០) ។ សេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ពន្យល់ពីសារៈសំខាន់នៃការស្បថសម្បថនៅក្នុងជំនាន់នៃព្រះគម្ពីរមរមន ហេតុដូច្នេះវាផ្តល់ដល់យើងនូវការយល់ដឹងពីធម្មជាតិនៃការមើលងាយព្រះនៃបំណងរបស់សាសន៍នីហ្វៃដែលពាក់ព័ន្ធនឹងព្រះក្នុងការសងសឹករបស់គេ ។

« បញ្ហានៃការស្បថជាមួយនឹងសម្បថក្នុងជំនាន់បុរាណនេះ គឺសំខាន់ខ្លាំងជាងអ្វីដែលយើងភាគច្រើនបានយល់ ។

« ឧទាហរណ៍ ៖ នីហ្វៃ និងបងប្អូនរបស់លោកបានខំទៅរកផ្នាំងលង្ហិនពីឡាបាន់ ។ ជីវិតរបស់ពួកគេស្ថិតក្នុងគ្រោះថ្នាក់ ។ ប៉ុន្តែនីហ្វៃបានស្បថ ៖ ‹ ប្រាកដដូចជាព្រះអម្ចាស់ទ្រង់មានព្រះជន្មរស់នៅ ហើយប្រាកដដូចជាយើងមានជីវិត នោះយើងនឹងមិនចុះទៅរកឪពុកយើងនៅក្នុងទីរហោស្ថានឡើយ ទាល់តែយើងបានសម្រេចនូវកិច្ចការដែលព្រះអម្ចាស់ទ្រង់បានបញ្ជាយើងសិន › ។ (នីហ្វៃទី ១ ៣:១៥) ។

« ហេតុដូច្នេះហើយ នីហ្វៃបានយកព្រះធ្វើជាដៃគូរបស់លោក ។ ប្រសិនបើលោកបរាជ័យយកផ្នាំងចំណារមិនបានទេ វាមានន័យថា ព្រះបានបរាជ័យដែរ ។ ហើយដោយសារព្រះមិនបរាជ័យ វាបានក្លាយទៅជាភារកិច្ចរបស់នីហ្វៃថា លោកត្រូវតែទៅយកផ្នាំងចំណារ បើពុំនោះសោតទេ លោកនឹងលះបង់ជីវិតរបស់នៅក្នុងការខំប្រឹងប្រែងនោះ » (« The Doctrine of the Priesthood » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៨២, ទំព័រ ៣៣) ។

មរមន ៥–៦

សេចក្តីផ្តើម

លោកមរមនបានព្យាករណ៍ថា បញ្ជីរបស់លោកនឹងលេចចេញមកនៅក្នុងថ្ងៃចុងក្រោយដើម្បីបញ្ចុះបញ្ចូលអស់អ្នកដែលអានវាថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ។ លោកបានលើកទឹកចិត្តអស់អ្នកដែលនឹងអានកំណត់ត្រាឲ្យប្រែចិត្ត ហើយត្រៀមខ្លួនសម្រាប់ការជំនុំជម្រះរបស់ខ្លួននៅចំពោះមុខព្រះ ។ នៅក្នុងចំណោមប្រជាជនរបស់លោកផ្ទាល់ លោកមរមនបានពិចារណាជាថ្មីអំពីការលាលែងពីតំណែងរបស់លោកពីមេទ័ពរបស់កងទ័ពសាសន៍នីហ្វៃ ដោយយល់ព្រមដឹកនាំពួកគេនៅក្នុងចម្បាំងម្តងទៀត ។ ទោះជាយ៉ាងណាក្តី ប្រជាជនបានបដិសេធមិនព្រមប្រែចិត្ត ហើយពួកគេត្រូវបានពួកសាសន៍លេមិនដេញតាម រហូតដល់សាសន៍នីហ្វៃទាំងមូលត្រូវបានបំផ្លាញ ។ នៅពេលលោកមរមនបានឃើញទិដ្ឋភាពនៃសេចក្តីស្លាប់ និងសេចក្តីបំផ្លិចបំផ្លាញនេះ លោកបានទុញយំចំពោះការធ្លាក់នៃប្រជាជនរបស់លោក និងការមិនមានឆន្ទៈបែរទៅរកព្រះយេស៊ូវគ្រីស្ទរបស់គេ ។

យោបល់សម្រាប់ការបង្រៀន

មរមន ៥:១–៩

លោកមរមនសម្រេចចិត្តដឹកនាំកងទ័ពនីហ្វៃម្តងទៀត ប៉ុន្តែពួកសាសន៍លេមិនបានយកឈ្នះ:

សូមលើកឡើងពីគ្រោះមហន្តរាយដែលអាចជាការគំរាមកំហែងមួយនៅក្នុងតំបន់របស់អ្នក —ឧទាហរណ៍ ការរញ្ជួយផែនដី ព្យុះសូរ៉ាណាមី ការផ្ទុះភ្នំភ្លើង ឬខ្យល់ព្យុះសង្ឃរា ។ សូមឲ្យសិស្សស្រមៃថា ពួកគេត្រូវបានព្រមានថា គ្រោះធម្មជាតិនេះនឹងកើតឡើងនៅក្នុងសហគមន៍របស់គេក្នុងអំឡុងប៉ុន្មានថ្ងៃទៀត ។

- តើអ្នកនឹងទៅរកជំនួយនៅកន្លែងណា ?

សូមរំឭកសិស្សថា ពួកសាសន៍នីហ្វៃបានជួបនឹងគ្រោះថ្នាក់បែបស្រដៀងគ្នានេះ ប៉ុន្តែគ្រោះថ្នាក់ដែលនឹងកើតមានគឺខាងវិញ្ញាណ ។ សូមរំឭកសិស្សជាដែរថា ពួកសាសន៍នីហ្វៃស្ថិតនៅក្នុងសង្គ្រាម ហើយថាដោយសារតែអំពើទុច្ចរិតរបស់គេ លោកមរមនបានបដិសេធមិនព្រមដឹកនាំកងទ័ពរបស់ពួកគេឡើយ (សូមមើល មរមន ៣:១៦) ។

សូមឲ្យសិស្សម្នាក់អាន មរមន ៥:១–២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយរកមើលនរណាដែលពួកសាសន៍នីហ្វៃបានជឿថាអាចរំដោះពួកគេពីសេចក្តីទុក្ខវេទនារបស់គេបាន ។

- ទោះបីជាវាគឺជាការពិតថា លោកមរមនអាចដឹកនាំពួកសាសន៍នីហ្វៃនៅក្នុងចម្បាំងទ័ពមួយក្តី ហេតុអ្វីបានជាលោកមរមនបានជឿថាប្រជាជននឹងមិនត្រូវបានរំដោះពីសេចក្តីទុក្ខវេទនារបស់ពួកគេ ?
- តើយើងអាចរៀនពី មរមន ៥:១–២ អំពីកន្លែងណាខ្លះដែលយើងគួរទៅរកជំនួយដំបូងគេនៅក្នុងសេចក្តីទុក្ខវេទនារបស់យើង ? (យើងអាចទៅរកជំនួយពីព្រះជាដំបូង ដែលនឹងឆ្លើយតបដល់អ្នកណាដែលប្រែចិត្ត និងអង្វរសុំទ្រង់ក្នុងពេលសេចក្តីវេទនារបស់គេ) ។

សូមសង្ខេប មរមន ៥:៣–៧ ដោយការពន្យល់ថា នៅក្រោមការដឹកនាំរបស់លោកមរមន សាសន៍នីហ្វៃបានវាយបកលលកសង្គ្រាមពីរបីដងលើសាសន៍លេមិន ។ ប៉ុន្តែនៅទីបញ្ចប់ពួកសាសន៍លេមិន « បានជាន់ឈ្លីប្រជាជនសាសន៍នីហ្វៃនៅក្រោមជើងគេ » (មរមន ៥:៦) ។ នៅពេលពួកសាសន៍នីហ្វៃបានចាញ់ អ្នកដែលមិនអាចរត់ចេញលឿនល្មមត្រូវបានបំផ្លាញ ។

សូមឲ្យសិស្សម្នាក់អាន មរមន ៥:៨–៩ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលមូលហេតុរបស់លោកមរមនដែលមិនបានសរសេរដំណើររឿងទាំងមូលនៃរឿងដែលលោកបានឃើញ ។

- ហេតុអ្វីបានជាលោកមរមនមិនព្រមផ្តល់នូវការរៀបរាប់ពេញលេញនៃអ្វីដែលលោកបានឃើញ ?

មរមន ៥:១០–២៤

លោកមរមនពន្យល់ថា គោលបំណងនៃកំណត់ត្រានៃព្រះគម្ពីរមរមនគឺ ដើម្បីបញ្ចុះបញ្ចូលប្រជាជនឲ្យជឿលើព្រះយេស៊ូវគ្រីស្ទ ។

សូមឲ្យសិស្សម្នាក់អាន មរមន ៥:១០–១១ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយរកមើលពាក្យមួយដែលលោកមរមនបានប្រើបីដង ដើម្បីរៀបរាប់ពីរបៀបដែលប្រជាជននៅក្នុងថ្ងៃចុងក្រោយនឹងមានដឹង នៅពេលពួកគេបានដឹងអំពីការធ្លាក់នៃជាតិសាសន៍នីហ្វៃ ។ (លោកបានមានប្រសាសន៍ថា យើងនឹង « កើតទុក្ខ » ។)

- តើអ្វីដែលអ្នកឃើញថា ដំណើររឿងនេះក្រៀមក្រំ ?

សូមបង្វែរការយកចិត្តទុកដាក់របស់សិស្សទៅលើប្រយោគរបស់លោកមរមននៅក្នុង មរមន ៥:១១ ថាប្រសិនបើប្រជាជនរបស់លោកបានប្រែចិត្ត នោះពួកគេអាចនឹងត្រូវ « ឱបខ្ជាប់នៅក្នុងព្រះហស្តនៃព្រះយេស៊ូវ » ។

- តើអ្នកគិតថា វាមានន័យដូចម្តេចដើម្បី « ត្រូវបានឱបខ្ចាប់នៅក្នុងព្រះហស្តនៃព្រះយេស៊ូវ » ? (អ្នកអាចបង្ហាញថាពាក្យ *ឱបខ្ចាប់* មានន័យថាត្រូវបានកាន់យ៉ាងជាប់ ឬយ៉ាងមានសុវត្ថិភាព ឬត្រូវបានឱបក្រសោប) ។
- តើឃ្លានេះបង្រៀនយើងអំពីលទ្ធផលនៃការប្រែចិត្តផ្ទាល់ខ្លួនយើងដូចម្តេចខ្លះ ? (សូមជួយសិស្សឲ្យរកមើលគោលការណ៍ខាងក្រោម ៖ **តាមរយៈការប្រែចិត្ត យើងអាចត្រូវបាន « ឱបខ្ចាប់នៅក្នុងព្រះហស្តរបស់ព្រះយេស៊ូវ » ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ពីគោលការណ៍នេះ សូមឲ្យពួកគេម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ឃេន អេហ្វ. រីឆាត នៃក្រុមចិតសិបនាក់ ៖

« អ្នកទាំងអស់ណាដែលនឹងមកអាចត្រូវបាន ‹ ឱបខ្ចាប់នៅក្នុងព្រះហស្តនៃព្រះយេស៊ូវ › ។ | មរមន ៥:១១ | ។ ព្រលឹងទាំងអស់អាចត្រូវបានព្យាបាលដោយព្រះចេស្តារបស់ទ្រង់ ។ ការឈឺចាប់ទាំងអស់អាចត្រូវបានលុបលោម ។ នៅក្នុងទ្រង់ យើងអាច ‹ រកឃើញការសម្រាកដល់ព្រលឹង | របស់យើង | › ។ | ម៉ាថាយ ១១:២៩ ។ | ស្ថានភាពខាងសាច់ឈាមរបស់យើងមិនអាចផ្លាស់ប្តូរភ្លាមៗនោះទេ ប៉ុន្តែការឈឺចាប់ ការព្រួយបារម្ភ ការរងទុក្ខ និងការភ័យខ្លាចរបស់យើងអាចត្រូវបានលេបចូលក្នុងសេចក្តីសុខសាន្តនិងថ្នាំព្យាបាលរបស់ទ្រង់ » (« The Atonement Covers All Pain » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១១, ទំព័រ ១៦) ។

សូមឲ្យសិស្សឆ្លើយនឹងសំណួរខាងក្រោមមួយនៅក្នុងសៀវភៅសរសេរ ឬក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីរ ។ (អ្នកអាចសរសេរសំណួរនេះនៅលើក្តារខៀន ឬអានវាយឺតៗដើម្បីឲ្យសិស្សអាចកត់វាបាន) ។

- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថាត្រូវបាន « ឱបខ្ចាប់នៅក្នុងព្រះហស្តរបស់ព្រះយេស៊ូវ » ?
- តើអ្នកអាចធ្វើអ្វីខ្លះដើម្បីទទួលបានការលួងលោម ការការពារ និងការអភ័យទោសពីព្រះអម្ចាស់បានយ៉ាងពេញលេញ ?

សូមពន្យល់ថា មរមន ៥:១២–១៣ រួមមានការព្យាករណ៍របស់មរមនថា ការសរសេររបស់លោកនឹងត្រូវបានលាក់ទុក ហើយបន្ទាប់មកត្រូវបានយកចេញដើម្បីត្រូវបានអានដោយមនុស្សទាំងអស់ ។ សូមឲ្យសិស្សអាន មរមន ៥:១៤–១៥ ដោយស្ងាត់ៗដោយរកមើលអ្វីដែលព្រះអម្ចាស់បានមានព្រះទ័យឲ្យការសរសេររបស់មរមនធ្វើសម្រាប់ប្រជាជននៅក្នុងថ្ងៃចុងក្រោយ ។ អ្នកអាចណែនាំថា សិស្សគួរគូសចំណាំឃ្លាដែលសំខាន់ដល់ពួកគេ ។

- យោងតាម មរមន ៥:១៤–១៥ តើអ្វីជាគោលបំណងនៃព្រះគម្ពីរមរមន ? (សូមប្រាកដថា សិស្សថ្លែងថា **ព្រះគម្ពីរមរមនត្រូវបានសរសេរដើម្បីបញ្ចុះបញ្ចូលមនុស្សទាំងអស់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ ដើម្បីជួយព្រះឲ្យបំពេញសេចក្តីសញ្ញារបស់ទ្រង់ជាមួយនឹងវង្សអ៊ីស្រាអែល ហើយដើម្បីជួយកូនចៅពួកសាសន៍លេមិនឲ្យជឿលើដំណឹងល្អយ៉ាងពេញលេញជាងនេះ) ។**

នៅពេលសិស្សឆ្លើយថា ការសរសេររបស់មរមនមានបំណងដើម្បីបញ្ចុះបញ្ចូលមនុស្សថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ សូមចែកចាយទីបន្ទាល់របស់អ្នកទាក់ទងនឹងការណ៍នេះជាគោលបំណងចម្បងនៃព្រះគម្ពីរមរមន ។

- តើគោលបំណងចម្បងនៃព្រះគម្ពីរមរមននេះប្រទានពរដល់អ្នកដែលអានវាតាមរបៀបណាខ្លះ ?
- តើការសិក្សារបស់អ្នកអំពីព្រះគម្ពីរមរមនបានជួយអ្នកឲ្យជឿ ហើយស្រឡាញ់ព្រះយេស៊ូវគ្រីស្ទយ៉ាងពេញលេញជាងនេះដោយរបៀបណា ?

សូមបង្ហាញថា ព្រះគម្ពីរមរមនជួយដល់មនុស្សជាច្រើនឲ្យប្រែចិត្តថ្មីៗនេះ ហើយត្រូវបាន « ឱបខ្ចាប់នៅក្នុងព្រះហស្តនៃព្រះយេស៊ូវ » ប៉ុន្តែថានៅតែមានមនុស្សជាច្រើនដែលបដិសេធមិនជឿលើព្រះគ្រីស្ទ ។

នៅលើក្តារខៀននៅក្បែរគោលការណ៍អំពីការប្រែចិត្តដែលអ្នកបានសរសេរពីមុននៅក្នុងមេរៀននេះ សូមសរសេរដូចខាងក្រោម ៖ *ប្រសិនបើយើងបដិសេធមិនព្រមប្រែចិត្តទេ . . .* សូមឲ្យសិស្សម្នាក់អាន មរមន ៥:១៦–១៩ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលលទ្ធផលនៃការបដិសេធមិនព្រមប្រែចិត្តរបស់ពួកសាសន៍នីហ្វៃ ។ សូមឲ្យសិស្សប្រើអ្វីដែលពួកគេរកឃើញនៅក្នុងខគម្ពីរទាំងនេះដើម្បីបំពេញប្រយោគនៅលើក្តារខៀន ។ នៅពេលពួកគេធ្លើយ អ្នកអាចសួរសំណួរខាងក្រោមនេះខ្លះដើម្បីជួយពួកគេឲ្យយល់ពាក្យ និងឃ្លានៅក្នុងខគម្ពីរនេះ ៖

- តើអ្នកគិតថា វាមានន័យដូចម្តេចដែលថា « គ្មានព្រះគ្រីស្ទ និងព្រះនៅក្នុងលោកិយ » ឡើយ ? (មរមន ៥:១៦) ។ (ចម្លើយអាចរួមមាន វាមានន័យថាដែលរស់នៅដោយគ្មានសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ឬព្រះវរបិតាសួគ៌ និងដោយគ្មានឥទ្ធិពល និងការដឹកនាំពីស្ថានសួគ៌) ។
- អង្កាមគឺជាសំបកខាងក្រៅដ៏ស្រាលរបស់ស្រូវ ។ នៅពេលគេច្រូតកាត់ស្រូវ អង្កាមត្រូវបានគេចោះចោល ។ តើអ្នកគិតថា អ្វីជាអត្ថន័យនៃឃ្លា « ត្រូវរុញច្រានដូចជាអង្កាមដែលខ្យល់ជាត់ » ? (មរមន ៥:១៦) ។
- តើវានឹងទៅជាយ៉ាងណា ដែលស្ថិតនៅលើទូកមួយដោយគ្មានទិសដៅដើម្បីទៅ ឬចង្កូត ហើយគ្មានយុថ្កា ? (សូមមើល មរមន ៥:១៨ ។)តើស្ថានភាពនេះស្រដៀងទៅនឹងស្ថានភាពនៃពួកសាសន៍នីហ្វៃយ៉ាងដូចម្តេច ?
- តើប្រសាសន៍របស់មរមនបង្រៀនយើងអំពីអ្នកដែលបដិសេធមិនព្រមប្រែចិត្តអ្វីខ្លះ ? (ចម្លើយរបស់សិស្សគួរបង្ហាញថា ការបដិសេធមិនព្រមប្រែចិត្តនាំមកនូវការបាត់បង់ការដឹកនាំពីព្រះអម្ចាស់ ។សូមបំពេញប្រយោគនៅលើក្តារខៀនដោយការសរសេរសេចក្តីពិតខាងក្រោមនេះ ៖ ***ប្រសិនបើយើងបដិសេធមិនព្រមប្រែចិត្តទេ នោះព្រះវិញ្ញាណនឹងដកថយ ហើយយើងនឹងបាត់បង់នូវការដឹកនាំពីព្រះអម្ចាស់ ។***)

សូមឲ្យសិស្សសញ្ជឹងគិតក្នុងចិត្តអំពីរបៀបដែលពួកគេបានឃើញគោលការណ៍នេះនៅក្នុងជីវិតរបស់គេ ឬនៅក្នុងជីវិតរបស់អ្នកដទៃ ។

សូមឲ្យសិស្សរំឭក មរមន ៥:១១, ១៦–១៨ និងគោលការណ៍ចំនួនពីរបន្តិច ដែលអ្នកបានសរសេរនៅលើក្តារខៀន ។

- ជាសម្តីខ្លួនឯង តើអ្នកនឹងបង្ហាញពីភាពខុសគ្នារវាងលទ្ធផលនៃការប្រែចិត្តដោយស្មោះត្រង់ និងលទ្ធផលនៃការបដិសេធមិនព្រមប្រែចិត្តដោយរបៀបណា ?

សូមឲ្យសិស្សអាន មរមន ៥:២២–២៤ ដោយស្ងាត់ៗដោយរកមើលអ្វីដែលមរមនបានដាស់តឿនប្រជាជននៅក្នុងថ្ងៃចុងក្រោយឲ្យធ្វើ ។ អ្នកអាចណែនាំថា សិស្សគួរគូសចំណាំអ្វីដែលពួកគេរកឃើញ ។

សូមធ្វើទីបន្ទាល់អំពីសេចក្តីពិតនៃគោលការណ៍ផ្ទុយគ្នាទាំងពីរនេះនៅលើក្តារខៀន ។

មរមន ៦

លោកមរមនតំណាលពីសង្គ្រាមចុងក្រោយរបស់សាសន៍នីហ្វៃ ហើយទួញយំចំពោះសេចក្តីបំផ្លិចបំផ្លាញនៃប្រជាជនរបស់លោក

សូមសួរសំណួរដូចខាងក្រោម ៖

- តើអ្នកអាចមានអារម្មណ៍យ៉ាងដូចម្តេចនៅពេលមនុស្សជាទីស្រឡាញ់ម្នាក់ស្លាប់ ដែលមានជំនឿលើព្រះពេញមួយជីវិតរបស់គេ ?
- តើអ្នកអាចមានអារម្មណ៍យ៉ាងដូចម្តេចនៅពេលមនុស្សជាទីស្រឡាញ់ម្នាក់ស្លាប់ ដែលមិនបានគោរពប្រតិបត្តិតាមព្រះបញ្ញត្តិរបស់ព្រះពេញមួយជីវិតរបស់គេ ?

សូមពន្យល់ថា លោកមរមនបានមានអារម្មណ៍សោកស្តាយជាខ្លាំងចំពោះការស្លាប់នៃមនុស្សទាំងអស់ ដោយសារលោកបានដឹងថា ពួកគេមិនបានរៀបចំខ្លួនដើម្បីទៅជួបនឹងព្រះទេ ។ សូមសង្ខេប មរមន ៦:១–៦ ដោយការពន្យល់ថា ពួកសាសន៍លេមិនបានអនុញ្ញាតឲ្យពួកសាសន៍នីហ្វៃប្រជុំគ្នាទៅដែនដីគូម៉ូរ៉ាដើម្បីធ្វើចម្បាំង ។ លោកមរមនបានឈានដល់វ័យចំណាស់ ហើយលោកបានដឹងថា ការណ៍នេះនឹងជា « ការតស៊ូចុងក្រោយបំផុតរបស់ប្រជាជន [លោក] » (មរមន ៦:៦) ។ លោកបានប្រគល់បញ្ជីពិសិដ្ឋមួយចំនួនឲ្យទៅកូនប្រុសរបស់លោក គឺម៉ូរ៉ូណៃ ហើយលោកបានលាក់ទុកបញ្ជីទាំងឡាយនៅក្នុងភ្នំគូម៉ូរ៉ា ។ លោកបានកត់ត្រាអ្វីដែលលោកបានឃើញអំពីសេចក្តីបំផ្លិចបំផ្លាញចុងក្រោយនៃប្រជាជនរបស់លោក ។ សូមឲ្យសិស្សអាន មរមន ៦:៧–១៥ ដោយស្ងាត់ៗដោយគិតអំពីរបៀបដែលលោកមរមនអាចមានអារម្មណ៍ នៅពេលលោកបានសរសេរពាក្យទាំងនេះ ។

- តើអ្នកគិតថា ហេតុអ្វីបានជាពួកសាសន៍នីហ្វៃបានរង់ចាំសេចក្តីស្លាប់ដោយ « សេចក្តីភិតភ័យជាខ្លាំង » ? (មរមន ៦:៧) ។

សូមអាន មរមន ៦:១៦–២២ ឮៗដល់សិស្ស នៅពេលពួកគេមើលតាមនៅក្នុងព្រះគម្ពីររបស់គេ ។ បន្ទាប់មក សូមឲ្យពួកគេសរសេរនៅក្នុងសៀវភៅសរសេរ ឬក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីរអំពីគំនិត និងអារម្មណ៍ដែលពួកគេមាន នៅពេលពួកគេអាន និងស្តាប់ខគម្ពីរទាំងនេះ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ អ្នករអាចឲ្យពួកគេមានឱកាសចែកចាយគំនិតខ្លះដែលពួកគេបានសរសេរនោះ ។

សូមថ្លែងទីបន្ទាល់ដល់សិស្សអំពីសេចក្តីស្រឡាញ់ដែលព្រះវរបិតាសួគ៌ ព្រះយេស៊ូវគ្រីស្ទ ព្យាការី ថ្នាក់ដឹកនាំ និងឪពុកម្តាយមានចំពោះពួកគេ ។ សូមលើកទឹកចិត្តពួកគេឲ្យអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ហើយប្រែចិត្តពីអំពើបាបរបស់ពួកគេ ដើម្បីឲ្យពួកគេអាចត្រូវបាន « ឱបខ្ជាប់នៅក្នុងព្រះហស្តនៃព្រះយេស៊ូវ » (មរមន ៥:១១) ។

វិចារណកថា និង ព័ត៌មានសាច់រឿង

មរមន ៥:១១ ។ « ឱបខ្ជាប់នៅក្នុងព្រះហស្តនៃព្រះយេស៊ូវ »

អែលឌើរ វ៉ែលុល អិម ណិលសុន ក្នុងក្រុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ពីការភ្ជាប់រវាងពាក្យ *ដង្វាយធួន* និងឃ្លា « ឱបខ្ជាប់នៅក្នុងព្រះហស្តនៃព្រះយេស៊ូវ » ។

« អត្ថន័យនៃការមានបាន ត្រូវបានរកឃើញនៅក្នុងការសិក្សានៃពាក្យ *ដង្វាយធួន* នៅក្នុងភាសាសេមីកនៃជំនាន់ព្រះគម្ពីរសញ្ញាចាស់ ។ ជាភាសាហេព្រើរ ពាក្យគ្រឹះនៃដង្វាយធួន គឺ ***kaphar*** ជាកិរិយាស័ព្ទដែលមានន័យថា ‹ គ្របលើ › ឬ ‹ អភ័យទោស › ។ ទំនាក់ទំនងយ៉ាងជិតជិតនៃពាក្យអារ៉ាម៉ាយ និងពាក្យអារ៉ាប់ ***kafat*** មានន័យថា ‹ ការក្រសោបយ៉ាងជាប់ › —នោះគ្មានចម្ងល់ទាក់ទងនឹងការក្រសោបនៃបុណ្យនៅប្រទេសអេហ្ស៊ីបឡើយ ។ សេចក្តីយោងទៅការក្រសោបនោះគឺជាកស្តុតាងនៅក្នុងព្រះគម្ពីរមរមន ។ ឃ្លាមួយនិយាយថា ‹ ព្រះអម្ចាស់ទ្រង់បានប្រោសលោះព្រលឹង . . . ឪពុកបានឃើញសិរីល្អរបស់ទ្រង់ ហើយឪពុកត្រូវបានឱបក្រសោបជាអង្វែងតទៅ ដោយព្រះពាហុនៃសេចក្តីស្រឡាញ់របស់ទ្រង់ › ។ [នីហ្វៃទី ២ ១:១៥ ។] ឃ្លាមួយទៀតផ្តល់នូវសេចក្តីសង្ឃឹមដ៏រុងរឿងនៃការត្រូវបាន ‹ ឱបខ្ជាប់នៅក្នុងព្រះហស្តនៃព្រះយេស៊ូវ › ។ [មរមន ៥:១១ ។] » (« The Atonement » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៦, ទំព័រ ៣៤) ។

មរមន ៧–៨:១១

សេចក្តីផ្តើម

ក្រោយពីចម្បាំងចុងក្រោយរវាងពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន លោកមរមនបានសរសេរទៅកាន់កូនចៅនាពេលអនាគតនៃប្រជាជនក្នុងព្រះគម្ពីរមរមនអំពីសារៈសំខាន់នៃការជឿថា ពួកគេជានរណា ហើយអ្វីដែលពួកគេត្រូវធ្វើដើម្បីត្រូវបានសង្គ្រោះ ។ ដោយមានសេចក្តីស្រឡាញ់ដ៏ជំជំដល់កូនចៅនាពេលអនាគតនៃសត្រូវរបស់លោក លោកមរមនបានបង្រៀនពីសារៈសំខាន់នៃការធ្វើតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យវាអាចនឹង « បានស្រួលដល់ នៅក្នុងដំនុំជម្រះ » (មរមន ៧:១០) ។ បន្ទាប់ពីមរណភាពរបស់លោកមរមន លោកបានបន្សល់ទុកកូនប្រុសរបស់លោក គឺមរ៉ូណៃ ឲ្យនៅតែម្នាក់ឯងដើម្បីសរសេរអំពីការបំផ្លិចបំផ្លាញនៃប្រជាជនរបស់លោក ។

យោបល់សម្រាប់ការបង្រៀន

មរមន ៧

នៅក្នុងទីបន្ទាល់ចុងក្រោយរបស់លោកមរមន លោកជាស់តឿនដល់កូនចៅរបស់ពួកសាសន៍លេមិនឲ្យជឿលើព្រះយេស៊ូវគ្រីស្ទ ហើយធ្វើតាមដំណឹងល្អរបស់ទ្រង់

សូមសរសេរលេខ *២៣០,០០០* នៅលើក្តារខៀន ។ សូមសួរសិស្សថាតើពួកគេចងចាំពីតួលេខនេះទាក់ទងទៅនឹងសេចក្តីបំផ្លិចបំផ្លាញនៃពួកសាសន៍នីហ្វៃដែរឬទេ ។ (តួលេខនេះគឺជាតួលេខនៃកងទ័ពសាសន៍នីហ្វៃ ដែលបានស្លាប់នៅក្នុងចម្បាំងលើកចុងក្រោយ ដែលបានកត់ត្រានៅក្នុង មរមន ៦ ។ អ្នកអាចបញ្ជាក់ថា តួលេខនៅក្នុង មរមន ៦:១០–១៥ បង្ហាញសំដៅតែលើអ្នកដែលបានធ្វើសង្គ្រាមប៉ុណ្ណោះ មិនមែនអ្នកដទៃផ្សេងទៀតដែលត្រូវបានសម្លាប់ជាលទ្ធផលនៃសង្គ្រាមឡើយ) ។ សូមផ្តល់ពេលឲ្យពួកគេគិតអំពីអ្វីដែលពួកគេអាចនិយាយ ប្រសិនបើពួកគេបានសរសេរសារលិខិតមួយដល់កូនចៅនៃប្រជាជនដែលបានសម្លាប់មនុស្សជាទីស្រឡាញ់របស់គេ និងបានដណ្តើមជាតិរបស់គេ ។

សូមឲ្យសិស្សអានម៉ូរ៉ូណៃ ៧:១–៤ស្ងាត់ៗដោយរកមើលប្រសាសន៍ចុងក្រោយរបស់លោកមរមនខ្លះទៅដល់កូនចៅរបស់ពួកសាសន៍លេមិន ។

- តើលោកមរមនបានចង់ឲ្យកូនចៅរបស់ពួកសាសន៍លេមិនដឹងអំពីអ្វី ?
- តើលក្ខណៈនៃព្រះអង្គសង្គ្រោះអ្វីខ្លះដែលអ្នកឃើញមាននៅក្នុងប្រសាសន៍របស់លោកមរមនទៅកាន់សត្រូវរបស់លោក ?

សូមជួយសិស្សឲ្យយល់ថា លោកមរមនបានបង្រៀនកូនចៅរបស់សាសន៍លេមិនពីអ្វីដែលពួកគេត្រូវធ្វើដើម្បីបានសង្គ្រោះ ។ លោកបានមានចិត្តសប្បុរសដល់ប្រជាជនទាំងអស់ ទោះបីជាសត្រូវរបស់លោកក្តី ។

សូមឲ្យសិស្សអាន មរមន ៧:៥, ៨, ១០ ស្ងាត់ៗដោយរកមើលអ្វីដែលលោកមរមនបានបង្រៀនអ្នកអានរបស់លោក ថាត្រូវតែធ្វើ ។ សូមឲ្យសិស្សចែកចាយអ្វីដែលពួកគេរកឃើញ ហើយសរសេរចម្លើយរបស់គេនៅលើក្តារខៀន ។ អ្នកអាចលើកឡើងថា ការបង្រៀនរបស់លោកមរមនគឺដូចគ្នានឹងគោលការណ៍នៃដំណឹងល្អដែលអាចបានសង្គ្រោះដល់ពួកសាសន៍នីហ្វៃចេញពីសេចក្តីបំផ្លិចបំផ្លាញ (សូមមើល មរមន ៣:២) ។

សូមឲ្យសិស្សម្នាក់អាន មរមន ៧:៦–៧ ឮៗ ។ សូមឲ្យសិស្សមើលតាម ដោយរកមើលអ្វីដែលព្រះអម្ចាស់ប្រទានដល់អ្នកទាំងឡាយណាដែលជឿលើទ្រង់ ហើយទទួលយកដំណឹងល្អរបស់ទ្រង់ ។ ក្រោយពីសិស្សរៀបរាប់អ្វីដែលពួកគេបានរកឃើញហើយ សូមលើកទឹកចិត្តពួកគេឲ្យសរសេរនូវសេចក្តីពិតខាងក្រោមក្បែរ មរមន ៧:៦–៧ ៖ **ព្រះអម្ចាស់ប្រទានសេចក្តីសង្គ្រោះដល់មនុស្សទាំងអស់ ហើយទ្រង់នឹងព្រោសលោះអ្នកទាំងឡាយណាដែលទទួលយកគោលការណ៍ និងពិធីបរិសុទ្ធនៃដំណឹងល្អរបស់ទ្រង់ ។**

សូមសរសេរនូវសំណួរដូចខាងក្រោមនៅលើក្តារខៀន ។សូមឲ្យសិស្សសរសេរចម្លើយរបស់គេដូចខាងក្រោមនៅក្នុងសៀវភៅសរសេរ ឬកំណត់ហេតុការសិក្សាព្រះគម្ពីរ ។

យោងតាម មរមន ៧:៧ តើអ្វីខ្លះគឺជាពរជ័យសម្រាប់អស់អ្នកដែលឃើញថា « ឥតទោស » នៅចំពោះមុខព្រះ ?

សូមឲ្យសិស្សពីរបីនាក់ចែកចាយនូវអ្វីដែលពួកគេបានសរសេរ ។

មរមន ៨:១–១១

ក្រោយពីមរមនស្លាប់ កូនប្រុសរបស់លោក មរ៉ូណៃ មានតែម្នាក់ឯងដើម្បីសរសេរអំពីសេចក្តីបំផ្លិចបំផ្លាញនៃប្រជាជនរបស់លោក

សូមឲ្យសិស្សគិតពីពេលមួយ ដែលពួកគេនៅតែម្នាក់ឯងនៅក្នុងស្ថានភាពមួយដែលពិបាកដល់សេចក្តីជំនឿរបស់គេ— ប្រហែលជាស្ថានភាពមួយដែលពួកគេងាយនឹងអាចធ្វើអ្វីមួយខុសដោយគ្មាននរណាម្នាក់ឃើញពួកគេ ។ សូមឲ្យពួកគេពិចារណាថាតើ ការប្តេជ្ញាចិត្តរបស់គេដើម្បីធ្វើតាមព្រះអង្គសង្គ្រោះ និងកាន់តាមបទបញ្ញត្តិរបស់ទ្រង់អំឡុងពេលនោះកើតឡើង នៅដដែល ឬចុះថយ ។

- ហេតុអ្វីបានជាមនុស្សខ្លះអាចជ្រើសរើសមិននៅស្មោះត្រង់ នៅពេលពួកគេនៅតែម្នាក់ឯងនៅក្នុងស្ថានភាពមួយដែលពិបាកដល់សេចក្តីជំនឿរបស់ពួកគេ ?
- ហេតុអ្វីបានជាមនុស្សខ្លះអាចជ្រើសរើសនៅតែស្មោះត្រង់នៅក្នុងស្ថានភាពមួយដូចគ្នានេះ ?

សូមពន្យល់ថា លោកមរមនត្រូវបានសម្លាប់ក្រោយពីចម្បាំងចុងក្រោយរវាងពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន ហើយកូនប្រុសរបស់លោក ម៉ូរ៉ូណៃ ត្រូវបានទុកឲ្យនៅតែម្នាក់ឯង ដោយគ្មានសមាជិកគ្រួសារ ឬនរណាម្នាក់នៃប្រជាជនរបស់លោកឡើយ ។ សូមឲ្យសិស្សម្នាក់អានឮៗនូវប្រសាសន៍របស់ម៉ូរ៉ូណៃនៅក្នុង មរមន ៨:១–៩ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលការពិពណ៌នានៃស្ថានភាពរបស់ម៉ូរ៉ូណៃ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

- តើអ្នកគិតថា អ្នកអាចមានអារម្មណ៍ដូចម្តេច ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពរបស់ម៉ូរ៉ូណៃ ?

ដោយការប្រើកាលបរិច្ឆេទនៅខាងក្រោមទំព័រ ឬនៅក្នុងការសង្ខេបជំពូក សូមជួយសិស្សឲ្យឃើញថា ប្រហែល ១៦ ឆ្នាំបានកន្លងផុតទៅរវាងពាក្យសរសេរចុងក្រោយរបស់មរមន និងពេលដែលម៉ូរ៉ូណៃបានចាប់ផ្តើមសរសេរនៅលើផ្ទាំងចំណារ ។ បន្ទាប់មក សូមឲ្យសិស្សមើលម្តងទៀតនៅ មរមន ៨:១–៤ ដើម្បីឃើញពីអ្វីដែលម៉ូរ៉ូណៃប្តេជ្ញាថានឹងធ្វើ ទោះបីជាលោកនៅតែម្នាក់ឯងជាយូរក្តី ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ (ពួកគេគួរឃើញថា លោកបានប្តេជ្ញាចិត្តគោរពតាមឪពុករបស់លោក ហើយសរសេរនៅលើផ្ទាំងចំណារ) ។

- តើគោលការណ៍អ្វីដែលយើងអាចរៀនពីការគោរពតាមរបស់ម៉ូរ៉ូណៃ ថ្វីបើស្ថានភាពរបស់លោកពិបាកក្តី ? (នៅពេលសិស្សចែកចាយគំនិតរបស់ពួកគេ សូមបញ្ជាក់ពីសេចក្តីពិតខាងក្រោម ៖ **ទោះបីជាយើងនៅតែម្នាក់ឯងក្តី ក៏យើងអាចជ្រើសរើសដើម្បីបន្តនៅស្មោះត្រង់ដែរ ។** អ្នកអាចសុំឲ្យសិស្សសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់គេក្បែរ មរមន ៨:១–៤) ។

សូមបង្ហាញថា ម៉ូរ៉ូណៃបានមានបេសកកម្មដ៏ពិសេសមួយ ។ លោក « [បាន] នៅតែម្នាក់ឯងដែលសរសេរនូវរឿងដ៏សោកសៅអំពីការបំផ្លិចបំផ្លាញដល់ប្រជាជន [របស់លោក] » (មរមន ៨:៣) ។ ទោះបីជាសិស្សនឹងមិនជួបស្ថានភាពដូចគ្នាបេះបិទក្តី ក៏ពួកគេអាចជួបនឹងស្ថានភាពដែលពួកគេនៅតែម្នាក់ឯង ហើយត្រូវនៅបន្តស្មោះត្រង់ដែរ ។ ពួកគេក៏អាចជួបនឹងស្ថានភាព ដែលពួកគេមានអារម្មណ៍ថាឯកោ ទោះបីជានៅពេលពួកគេនៅជាមួយនឹងមនុស្សផ្សេងទៀតក្តី —ដូចជាពេលដែលពួកគេនៅជាមួយនឹងមនុស្សដែលមិនរស់នៅតាមបទដ្ឋានដែលបានស្តាបនាដោយព្រះអម្ចាស់ និងពួកព្យាការីរបស់ទ្រង់ ។

សំណួរតាមដាន

ការសួរសំណួរដែលតាមដានចម្លើយដំបូងរបស់សិស្ស អាចជួយពួកគេឲ្យគិតបានសឹងជម្រៅអំពីចម្លើយដែលពួកគេបានផ្តល់ ហើយចែកចាយនូវគំនិត និងអារម្មណ៍ដ៏មានអត្ថន័យ ។ អ្នកអាចសួរសំណួរតាមដានដល់សិស្សដែលផ្តល់ចម្លើយត្រិះរិះពិចារណាមួយ ឬអ្នកអាចបង្កើតនូវការពិភាក្សាដោយការដឹកនាំសំណួរតាមដានដល់សិស្សផ្សេងទៀត ។

- តើអ្នកស្គាល់នរណាម្នាក់ ដែលនៅតែស្មោះត្រង់ ទោះបីជានៅពេលពួកគេនៅតែម្នាក់ឯងនៅក្នុងស្ថានភាពមួយដ៏ពិបាកក្តី ?

នៅពេលសិស្សឆ្លើយនឹងសំណួរនេះ សូមសួរពួកគេនូវ សំណួរតាមដាន ខ្លះៗ ឬទាំងអស់ ៖

- តើបុគ្គលនេះប្រព្រឹត្តដូចម្តេចនៅក្នុងស្ថានភាពទាំងនោះ ?
- តើមនុស្សម្នាក់ត្រូវបានប្រទានពរនៅទីបំផុត ដោយសារការធ្វើអ្វីដែលព្រះបានបញ្ជាគេឲ្យធ្វើដោយរបៀបណា ?
- តើគំរូទាំងនេះជួយអ្នកដោយរបៀបណា ?

សូមឲ្យសិស្សអាន មរមន ៨:១០–១១ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើលរបៀបមួយដែលព្រះអម្ចាស់បានគាំទ្រលោកម៉ូរ៉ូណៃ និងមរមន កាលលោកកំពុងជួបប្រទះនឹងស្ថានភាពលំបាក ។ (ព្រះអម្ចាស់បានបញ្ជូនសាសន៍នីហ្វៃទាំងបីនាក់ទៅបម្រើមរមន និងម៉ូរ៉ូណៃ សូមមើលផងដែរ នីហ្វៃទី ៣ ២៨:២៥–២៦) ។ សូមបញ្ជាក់ថា **ប្រសិនបើយើងនៅស្មោះត្រង់ដល់ព្រះនៅក្នុងស្ថានភាពឯកោ ឬពិបាក នោះទ្រង់នឹងជួយយើងឲ្យនៅបន្តស្មោះត្រង់ ។** សូមប្រើសំណួរខាងក្រោមដើម្បីពិភាក្សាពីសេចក្តីពិតនេះ ៖

- តើអ្នកធ្លាប់បានគោរពតាមព្រះបញ្ញត្តិមួយរបស់ព្រះវរបិតាសួគ៌នៅក្នុងស្ថានភាពពិបាកជាពិសេសណាមួយនៅពេលណា ? តើអ្នកមានអារម្មណ៍ថា អ្នកបានទទួលពរជ័យចំពោះការធ្វើដូច្នោះយ៉ាងដូចម្តេច?
- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីរៀបចំខ្លួននាពេលឥឡូវនេះ ដើម្បីនៅស្មោះត្រង់នៅក្នុងស្ថានភាពលំបាកនៅក្នុងពេលអនាគត ?

ដើម្បីលើកទឹកចិត្តសិស្សឲ្យនៅស្មោះត្រង់ ទោះបីជានៅក្នុងស្ថានភាពដែលពួកគេត្រូវតែឈរតែម្នាក់ឯងក្តី សូមចែកចាយសេចក្តីថ្លែងការណ៍ខាងក្រោមដោយ ប្រធាន ថូម៉ាស អេស. ម៉នសុន ៖

« នៅពេលយើងរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ វាស្ទើរតែមិនអាចចៀសវាងបានថា សេចក្តីជំនឿរបស់យើងនឹងអាចត្រូវសាកល្បង ។ ពេលខ្លះ យើងអាចឃើញថាខ្លួនយើងព័ទ្ធជុំវិញដោយអ្នកដទៃ ហើយនៅតែឈរនៅក្នុងភាគតិចឬឈរតែម្នាក់ឯងចំពោះអ្វីដែលគួរទទួលយកបាន និងអ្វីដែលមិនគួរទទួលយកបាន ។ តើយើងមានសេចក្តីក្លាហានផ្នែកសីលធម៌ ដើម្បីឈរដោយរឹងមាំចំពោះជំនឿរបស់យើង ទោះជាយើងធ្វើដូច្នោះ ដោយត្រូវតែឈរម្នាក់ឯងក្តីដែរឬទេ ? . . . សូមឲ្យយើងមានភាពក្លាហាន ហើយត្រៀមខ្លួនដើម្បីឈរឡើងចំពោះអ្វីដែលយើងជឿ ហើយប្រសិនបើយើងត្រូវតែឈរម្នាក់ឯងនៅក្នុងដំណើរការនេះក្តី សូមឲ្យយើងធ្វើដូច្នោះបានដោយភាពក្លាហាន ដែលត្រូវបានពង្រឹងដោយចំណេះដឹងថា ការពិតយើងមិនដែលនៅម្នាក់ឯងឡើយ នៅពេលយើងឈរជាមួយនឹងព្រះវរបិតាគង់នៅស្ថានសួគ៌នោះ » (« Dare to Stand Alone,” *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ៦០, ៦៧) ។

សូមបញ្ចប់ដោយការចែកចាយបទពិសោធន៍មួយ ដែលព្រះអម្ចាស់បានប្រទានពរដល់អ្នកដោយសារការនៅស្មោះត្រង់របស់អ្នកនៅក្នុងស្ថានភាពដ៏ឯកោ ឬពិបាកមួយ ។

ការរំឭកចំណេះចំណានខគម្ពីរ

សូមសរសេរពាក្យ *ដាស់តឿន* នៅលើក្តារខៀន ។ សូមពន្យល់ថាពាក្យ *ដាស់តឿន* មានន័យថា ខិតខំជម្រុញឲ្យអ្នកដទៃធ្វើសកម្មភាពតាមរបៀបណាមួយ ។ សូមពន្យល់ថា ប្រសាសន៍ចុងក្រោយរបស់មរមននៅក្នុង មរមន ៧ គឺជាគំរូដ៏ល្អមួយនៃការដាស់តឿន ។

សូមចែកក្រដាសដល់សិស្ស ហើយប្រាប់ពួកគេថា ពួកគេនឹងសរសេរនូវការដាស់តឿនមួយដោយផ្អែកលើវគ្គចំណេះចំណានខគម្ពីរដែលពួកគេចូលចិត្តនៅក្នុងព្រះគម្ពីរមរមន ។ នៅក្បាលលើនៃក្រដាស សូមឲ្យសិស្សសរសេរថា ៖ « ខ្ញុំនឹងនិយាយរឿងខ្លះទៅកាន់យុវវ័យនៅថ្ងៃចុងក្រោយ » ។ សូមឲ្យសិស្សម្នាក់ៗជ្រើសរើសវគ្គចំណេះចំណានខគម្ពីរដែលគេចូលចិត្ត ហើយបន្ទាប់មកសរសេរពាក្យដាស់តឿនមួយដល់យុវវ័យនៅថ្ងៃចុងក្រោយ ដោយផ្អែកលើសារលិខិតដែលពួកគេបានជ្រើសរើស ។ ការដាស់តឿនរបស់គេអាចរួមមាន ការសង្ខេបនៃសេចក្តីពិតដ៏សំខាន់ដែលមាននៅក្នុងវគ្គចំណេះចំណានខគម្ពីរ ការពន្យល់មួយពីមូលហេតុដែលសេចក្តីពិតទាំងនេះសំខាន់សម្រាប់យុវវ័យសព្វថ្ងៃនេះ និងការអញ្ជើញមួយដើម្បីធ្វើសកម្មភាពតាមសេចក្តីពិតទាំងនេះ ។ ការទូន្មាននេះអាចបញ្ចប់ដោយការសន្យាមួយដូចជាអ្វីដែលមាននៅក្នុង មរមន ៧:៧ ឬ មរមន ៧:១០ ។ អ្នកអាចសុំឲ្យសិស្សពីរបីនាក់ចែកចាយការទូន្មានដែលគេសរសេរចប់ហើយដល់សិស្សក្នុងថ្នាក់ ។ អ្នកក៏អាចប្រមូលការទូន្មានទាំងនេះដើម្បីធ្វើជាតម្រុយសម្រាប់ចំណេះចំណានខគម្ពីរនាសកម្មភាពពេលក្រោយ ឬដើម្បីបង្ហាញដល់សិស្ស ។

កំណត់ចំណាំ ៖ អ្នកអាចប្រើសកម្មភាពនេះនៅពេលណាក៏បានអំឡុងពេលបង្រៀន ។ ឧទាហរណ៍ អ្នកអាចប្រើវានៅពេលបញ្ចប់មេរៀននេះ ឬអ្នកអាចប្រើវាក្រោយពីការពិភាក្សា មរមន ៧ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

មរមន ៧ ។ការអង្វរចុងក្រោយរបស់លោកមរមន ឲ្យជឿលើព្រះគ្រីស្ទ ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានពន្យល់ពីការអង្វរចុងក្រោយរបស់លោកមរមន ឲ្យជឿលើព្រះគ្រីស្ទ ជាការអង្វរមួយដែលលោកបានសរសេរដល់ប្រជាជននៅក្នុងជំនាន់របស់យើង ក្រោយពីបានឃើញពីសេចក្តីបំផ្លិចបំផ្លាញនៃជាតិសាសន៍របស់លោកទាំងមូល ។

« នៅក្នុងការស្លាប់តែឯង មរមនបានឆ្លងកាត់ពេលវេលា និងទីកន្លែងជាច្រើន ជាពិសេសដល់ ‹ សំណល់នៃវង្សអ៊ីស្រាអែល › ដែលនឹងអានបញ្ជីដ៏អស្ចារ្យរបស់លោកនាថ្ងៃណាមួយ ។ អ្នកទាំងឡាយណាដែលនៅក្នុងសម័យ និងកន្លែងផ្សេងត្រូវតែរៀនអ្វីដែលមានចំពោះមុខលោកត្រូវបានបំផ្លិចចោល —ថាអ្នកទាំងអស់ត្រូវ ‹ ជឿលើព្រះយេស៊ូវគ្រីស្ទ ថាទ្រង់គឺជាព្រះរាជបុត្រានៃព្រះ › ថាបន្ទាប់ពីគេឆ្កាងទ្រង់នៅទីក្រុងយេរូសាឡិម ‹ ដោយព្រះចេស្តានៃព្រះវរបិតា . . . បានរស់ឡើងវិញជាថ្មី ដែលទ្រង់បានទទួលបានជ័យជំនះលើផ្នូរ ហើយនៅក្នុងទ្រង់ផងដែរគឺជាខ្សែនៃសេចក្តីស្លាប់ដែលលេចឡើង ។

បន្ទាប់មក អស់អ្នកណាដែលត្រូវបានប្រោសលោះអាចនឹងរីករាយ ‹ នៅក្នុងស្ថានភាពមួយដ៏សប្បាយរីករាយហើយគ្មានទីបំផុត › ដោយសារតែព្រះគ្រីស្ទ ។ [មរមន ៧:២, ៥–៧ ។] . . .

« ដើម្បី ‹ ជឿលើព្រះគ្រីស្ទ › ជាពិសេសនៅពេលប្រឆាំងនឹងលទ្ធផលដ៏សោកនាដកម្ម ប៉ុន្តែដែលអាចចៀសវាងបាននេះ គឺជាការអង្វរចុងក្រោយរបស់លោកមរមន និងជាសេចក្តីសង្ឃឹមតែមួយគត់របស់លោក ។ វាគឺជាគោលបំណងចុងក្រោយនៃគម្ពីរទាំងមូលដែលនឹងចេញមកដល់ពិភពលោកនាថ្ងៃចុងក្រោយ ដោយមានឈ្មោះរបស់លោក » (*Christ and the New Covenant: The Messianic Message of the Book of Mormon* [ឆ្នាំ ១៩៩៧], ទំព័រ ៣២១–២២) ។

គំនិតបន្ថែមទាំងឡាយសម្រាប់ការបង្រៀន

មរមន ៧:៨–៩ ។ព្រះគម្ពីរបរិសុទ្ធ និង ព្រះគម្ពីរមរមន

សូមបង្ហាញព្រះគម្ពីរមរមនមួយក្បាល ដោយសរសេរថា « នេះ » ។ បន្ទាប់មក សូមបង្ហាញព្រះគម្ពីរបរិសុទ្ធមួយក្បាលដោយសរសេរថា « នោះ » ។ សូមឲ្យសិស្សអាន មរមន ៧:៨–៩ ដោយស្ងាត់ៗដោយរកមើលអ្វីដែលលោកមរមនបានមានប្រសាសន៍អំពីទំនាក់ទំនងរវាង « នេះ » (ព្រះគម្ពីរមរមន) និង « នោះ » (ព្រះគម្ពីរបរិសុទ្ធ) ។

- តើការសិក្សាព្រះគម្ពីរមរមនបានពង្រឹងដល់ទីបន្ទាល់របស់អ្នកនៃសេចក្តីពិតនៅក្នុងព្រះគម្ពីរបរិសុទ្ធដោយរបៀបណា ? តើការសិក្សាព្រះគម្ពីរបរិសុទ្ធបានពង្រឹងដល់ទីបន្ទាល់របស់អ្នកនៃព្រះគម្ពីរមរមនដោយរបៀបណា ?

មេរៀនសិក្សានៅផ្ទះ

នីហ្វៃទី ៤ ១–មរមន ៨:១១ (មេរៀនទី ២៨)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀននៅពេលពួកគេសិក្សា នីហ្វៃទី ៤ ១–មរមន ៨:១១ (មេរៀនទី ២៨) មិនមែនសម្រាប់បង្រៀនជាផ្នែកមួយនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (នីហ្វៃទី៤ ១)

នៅពេលសិស្សបានសិក្សាពីស្ថានភាពរបស់ពួកសាសន៍នីហ្វៃ អំឡុងពេលជិត ២០០ ឆ្នាំក្រោយពីការយោងមករបស់ព្រះអង្គសង្គ្រោះ ពួកគេបានរៀនថា នៅពេលប្រជាជនធ្វើការរួមគ្នាដើម្បីប្រែចិត្តជឿលើព្រះអម្ចាស់ នោះពួកគេនឹងមានសាមគ្គីភាព ហើយទទួលបានសុភមង្គលបន្ថែមទៀត ។ ពួកគេក៏បានទទួលស្គាល់ថា ភាពឆ្មើងឆ្មៃបង្កើតជាការបែកបាក់ ហើយដឹកនាំទៅរកអំពើទុច្ចរិតដ៏ធំ ។

ថ្ងៃទី ២ (មរមន ១–២) ។

តាមរយៈគំរូនៃជីវិតដ៏សុចរិតរបស់លោកមរមន សិស្សបានរៀនអំពីគុណសម្បត្តិនៃការម៉ឺងម៉ាត់ និងចេះសង្កេតឆាប់រហ័ស ។ ពួកគេបានរៀនថា យើងអាចជ្រើសរើសដើម្បីរស់នៅដោយសុចរិត ទោះបីជារស់នៅក្នុងសង្គមដ៏ទុច្ចរិតក្តី ។ តាមរយៈគំរូនៃអំពើទុច្ចរិតរបស់ប្រជាជនសាសន៍នីហ្វៃ សិស្សបានយល់ពីគោលការណ៍ខាងក្រោមនេះថា ៖ អំពើទុច្ចរិត និងការឥតជំនឿបណ្តេញចេញនូវអំណោយទាននៃព្រះអម្ចាស់ និងឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។ ប្រសិនបើសេចក្តីសោកស្តាយរបស់យើងចំពោះអំពើបាបនាំទៅរកការប្រែចិត្ត វានឹងនាំយើងមករកព្រះគ្រីស្ទដោយមានដួងចិត្តទន់ទាប ។ សេចក្តីសោកស្តាយដែលគ្រាន់តែជាលទ្ធផលនៃអំពើបាប នាំទៅរកការដាប់ទោស (ឬការបញ្ឈប់នៅក្នុងដំណើរបស់យើងទៅរកជីវិតដ៏នៅអស់កល្បជានិច្ច) ។

ថ្ងៃទី ៣ (មរមន ៣–៦) ។

នៅពេលពួកគេបានសិក្សាពីព្រះទ័យអំណត់របស់ព្រះអម្ចាស់ជាមួយនឹងពួកសាសន៍នីហ្វៃ សិស្សបានរៀនថា ព្រះអម្ចាស់ប្រទានដល់យើងនូវឱកាសគ្រប់គ្រាន់ដើម្បីប្រែចិត្តពីអំពើបាបយើង ។ ទោះបីជាយ៉ាងណាក្តី ពួកសាសន៍នីហ្វៃបានបដិសេធមិនព្រមប្រែចិត្ត ហើយចង់សងសឹកនឹងពួកសាសន៍លេមិន ។ ដោយសារព្រះអម្ចាស់ហាមប្រាមកុំឲ្យសងសឹក លោកមរមនបានជ្រើសរើសលាចេញពីការដើរតាមកងទ័ពសាសន៍នីហ្វៃ ។ លទ្ធផលនៃការខិតខំសងសឹករបស់ពួកសាសន៍នីហ្វៃ បានអនុញ្ញាតឲ្យសិស្សយល់ថា ការជំនុំជម្រះនៃព្រះនឹងយកឈ្នះលើពួកទុច្ចរិត ។ លោកមរមនបានធ្វើជាសាក្សីដល់សេចក្តីបំផ្លិចបំផ្លាញទាំងមូលនៃប្រជាជនរបស់លោក ហើយបានទួញយំចំពោះការធ្លាក់របស់គេ ។

ថ្ងៃទី ៤ (មរមន ៧:១–៨:១១) ។

លោកបានបញ្ចប់កំណត់ត្រារបស់លោក ដោយនិយាយអំពីកូនចៅនៃពួកសាសន៍លេមិន ។ សិស្សបានរៀនថា ព្រះអម្ចាស់ប្រទាននូវសេចក្តីប្រោសលោះដល់មនុស្សទាំងអស់ដែលទទួលយកគោលការណ៍ និងពិធីការបរិសុទ្ធនៃជំនឿគ្រិស្តរបស់ទ្រង់ ។ លោកមរមនបានស្លាប់ ហើយម៉ូរ៉ូណៃបានសរសេរពីស្ថានភាពក្រោយពីសេចក្តីបំផ្លិចបំផ្លាញនៃពួកសាសន៍នីហ្វៃ ។ តាមរយៈគំរូរបស់ម៉ូរ៉ូណៃ សិស្សបានរៀនថា ទោះបីជានៅពេលពួកគេនៅតែម្នាក់ឯងក្តី ក៏ពួកគេអាចជ្រើសរើសដើម្បីបន្តនៅស្មោះត្រង់ដែរ ។

សេចក្តីផ្តើមពីមេរៀននេះ

នៅក្នុងមេរៀននេះ សិស្សនឹងរំឭកពីសេចក្តីបំផ្លិចបំផ្លាញនៃពួកសាសន៍នីហ្វៃ ហើយរៀនអំពីបំណងប្រាថ្នារបស់លោកមរមនសម្រាប់ប្រជាជនរបស់លោកដើម្បី « បានឱបខ្ជាប់នៅក្នុងព្រះហស្តនៃព្រះរបស់ស៊ូរ៉ែ » (មរមន ៥:១១) ។ សិស្សនឹងរៀនពីរបៀបដើម្បីអញ្ជើញឲ្យមានសេចក្តីស្រឡាញ់ពីព្រះអម្ចាស់នៅក្នុងជីវិតរបស់ពួកគេផ្ទាល់ ។ តាមរយៈការបដិសេធមិនព្រមប្រែចិត្តនៃពួកសាសន៍នីហ្វៃ សិស្សនឹងយល់ពីលទ្ធផលដ៏សោកសៅដែលប្រជាជននឹងជួប នៅពេលពួកគេមិនប្រែចិត្ត ។

យោបល់សម្រាប់ការបង្រៀន

នីហ្វៃទី ៤ ១–មរមន ៤

ប្រជាជនសាសន៍នីហ្វៃឃ្លាតចេញពីសេចក្តីសុចរិត និងសុភមង្គលទៅរកអំពើទុច្ចរិត

សូមឲ្យសិស្សប្រាប់ថាពួកគេបានសិក្សាប្រវត្តិសាស្ត្រនៃពួកសាសន៍នីហ្វៃអស់ប៉ុន្មានឆ្នាំនាសប្តាហ៍នេះ ។ សូមជួយពួកគេឲ្យប្រើកាលបរិច្ឆេទនេះនៅក្នុងការសង្ខេបជំពូកនេះ ឬនៅផ្នែកខាងក្រោមនៃចំណងជើងក្នុង នីហ្វៃទី ៤ ១ និង មរមន ៨ ដើម្បីរកមើលការណ៍នេះ ។ (ជំពូកទាំងនេះកើតឡើងជិត ៤០០ ឆ្នាំ ឬជាងមួយភាគបីនៃប្រវត្តិសាស្ត្រនៃពួកសាសន៍នីហ្វៃ) ។

សូមឲ្យសិស្សពាក់កណ្តាលថ្នាក់ប្រើព្រះគម្ពីររបស់ពួកគេ និងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរដើម្បីរំឭកពីអ្វីដែលពួកគេបានរៀនអំពីសុភមង្គលរបស់ពួកសាសន៍នីហ្វៃនៅក្នុងនីហ្វៃទី ៤ ១ ។ សូមឲ្យសិស្សពាក់កណ្តាលថ្នាក់ទៀតប្រើ មរមន ១–២ និងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់គេដើម្បីរំឭកថាតើអ្នកណាជាលោកមរមន ហើយហេតុអ្វីបានជាលោកគួរឲ្យកោតសរសើរម្ល៉េះ ។ សូមឲ្យក្រុមនីមួយៗសង្ខេបអ្វីដែលពួកគេបានរៀន ។ បន្ទាប់មក សូមឲ្យក្រុមទាំងអស់បង្ហាញពីសេចក្តីសង្ខេបរបស់ពួកគេ ។

សូមសួរសិស្សថា ៖ តើសេចក្តីពិតមួយដែលអ្នកបានរៀនពីការសិក្សាជំពូកទាំងនេះគឺជាអ្វី ហើយហេតុអ្វីបានជាវាសំខាន់ចំពោះអ្នក ?

សូមពន្យល់ថា ថ្វីបើលោកមរមនខិតខំជួយពួកសាសន៍នីហ្វៃខាងវិញ្ញាណឲ្យរៀបចំខ្លួនគេដើម្បីទៅច្បាំងក្តី ក៏ពួកគេនៅតែបដិសេធមិនព្រមប្រែចិត្ត ហើយបែរទៅរកព្រះអម្ចាស់ដែរ ។ ជាលទ្ធផលមកពីអំពើទុច្ចរិតរបស់ពួកគេ ពួកគេត្រូវបានទុកឲ្យប្រើកម្លាំងរបស់ខ្លួនឯងផ្ទាល់ ហើយពួកសាសន៍លេមិនបានចាប់ផ្តើមយកឈ្នះលើពួកគេ (សូមមើល មរមន ៣–៤) ។

មរមន ៥:៨–២៤

លោកមរមនពន្យល់ថា ព្រះគម្ពីរមរមនត្រូវបានសរសេរដើម្បីបញ្ចុះបញ្ចូលប្រជាជនឲ្យជឿលើព្រះយេស៊ូវគ្រីស្ទ ។

សូមសួរសិស្សថា តើពួកគេធ្លាប់មានអារម្មណ៍សោកស្តាយចំពោះនរណាម្នាក់ដែលត្រូវពិបាកដោយសារលទ្ធផលដែលពីសធ្វើខុសនោះដែរឬទេ ។ អ្នកអាចចែកចាយឧទាហរណ៍ដែលសមរម្យ (និងមិនវិនិច្ឆ័យសំបកក្រៅ) នៃការសោកស្តាយដែលអ្នកមានចំពោះនរណាម្នាក់ដែលបានរងទុក្ខនឹងលទ្ធផលអវិជ្ជមានសម្រាប់ជម្រើសមួយដែលគេបានធ្វើ ។ សូមពន្យល់ថា លោកមរមនបានសរសេរថា ប្រជាជននៅថ្ងៃចុងក្រោយនឹងសោកស្តាយ នៅពេលពួកគេអានអំពីសេចក្តីបំផ្លិចបំផ្លាញនៃពួកសាសន៍នីហ្វៃ ។

សូមឲ្យសិស្សអាន មរមន ៥:១០–១១ ស្ងាត់ៗ ដោយរកមើលអ្វីដែលលោកមរមនបានមានប្រសាសន៍ថា ពួកសាសន៍នីហ្វៃអាចបានរីករាយ ។ ក្រោយពីសិស្សឆ្លើយ សូមសួរសិស្សនូវសំណួរដូចខាងក្រោម ៖

- តើអ្នកគិតថា វាមានន័យដូចម្តេចដើម្បី « ត្រូវបានឱបខ្ជាប់នៅក្នុងព្រះហស្តនៃព្រះយេស៊ូវ » ? (ពាក្យ *ឱបខ្ជាប់* មានន័យថា កាន់ឲ្យជាប់ ឬមានសុវត្ថិភាព ឬត្រូវបានឱបក្រសោប ដែលជាសញ្ញាមួយនៃការការពារ និងសេចក្តីស្រឡាញ់) ។
- យោងតាម មរមន ៥:១១ តើយើងអាចធ្វើអ្វីខ្លះដើម្បីទទួលបានការឱបក្រសោបប្រកេទនេះ ? (**តាមរយៈការប្រែចិត្ត យើងអាចត្រូវបាន « ឱបខ្ជាប់នៅក្នុងព្រះហស្តរបស់ព្រះយេស៊ូវ » ។** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមអាន ឬសូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ យេន អេហ្វ. វីឆាត នៃពួកចិតសិបនាក់ ៖ សូមឲ្យសិស្សស្តាប់រកអត្ថន័យនៃ « ឱបខ្ជាប់នៅក្នុងព្រះហស្តរបស់ព្រះយេស៊ូវ » ។

« អ្នកទាំងអស់ណាដែលនឹងមក អាចត្រូវបាន ‹ ឱបខ្ជាប់នៅក្នុងព្រះហស្តនៃព្រះយេស៊ូវ › ។ [មរមន ៥:១១ ។] ព្រលឹងទាំងអស់អាចត្រូវបានព្យាបាលដោយព្រះចេស្តារបស់ទ្រង់ ។ ការឈឺចាប់ទាំងអស់អាចត្រូវបានលួងលោម ។ នៅក្នុងទ្រង់ យើងអាច ‹ រកឃើញការសម្រាកដល់ព្រលឹង [របស់យើង] › ។ [ម៉ាថាយ ១១:២៩] ។ ស្ថានភាពខាងសាច់ឈាមរបស់យើងមិនអាចផ្លាស់ប្តូរភ្លាមៗទេ ប៉ុន្តែការឈឺចាប់ ការព្រួយបារម្ភ ការរងទុក្ខ និងការភ័យខ្លាចរបស់យើងអាចត្រូវបានលេបចូលក្នុងសេចក្តីសុខសាន្ត និងថ្នាំព្យាបាលរបស់ទ្រង់ » (« The Atonement Covers All Pain » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១១, ទំព័រ ១៦) ។

សូមឲ្យសិស្សគិតអំពីពេលដែលពួកគេបានមានអារម្មណ៍ថាត្រូវបាន « ឱបខ្ជាប់នៅក្នុងព្រះហស្តរបស់ព្រះយេស៊ូវ » ជាលទ្ធផលនៃការប្រែចិត្តមួយ ។ សូមឲ្យពួកគេសញ្ជឹងគិតផងដែរពីអ្វីដែលពួកគេអាចត្រូវធ្វើដើម្បីបានឱបខ្ជាប់នៅក្នុងព្រះហស្តរបស់ទ្រង់នាពេលនេះ ។ សូមធ្វើទីបន្ទាល់អំពីការលួងលោម និងលទ្ធផលនៃការការពារដោយសារការប្រែចិត្ត ។

ដើម្បីបង្ហាញគោលការណ៍ផ្សេងទៀតនៅក្នុង មរមន ៥ សូមដាក់គម្របមួយ ឬរបស់ដែលអណ្តែតទឹកណាមួយនៅលើខ្នះទឹក ។ សូមឲ្យសិស្សពីរ ឬបីនាក់ផ្លុំវាទៅក្នុងទិសដៅមានខុសគ្នា ។ សូមសួរថា តើឥទ្ធិពលខ្លាំងប៉ុណ្ណាដែលគម្របនោះទៅទិសដៅដែលវានឹងទៅ ។ សូមលើកទឹកចិត្តសិស្សនៅពេលពួកគេបន្តសិក្សា ដើម្បីឲ្យរកមើលរបៀបដែលគម្របនេះអាចដូចជាពួកសាសន៍នីហ្វៃ ។

សូមសរសេរនៅលើក្តារខៀនថា ៖ *នៅពេលយើងបដិសេធមិនព្រមប្រែចិត្ត . . .* បន្ទាប់មក សូមឲ្យសិស្សម្នាក់អាន –មរមន ៥:២, ១៦–១៩ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលលទ្ធផលនៃការបដិសេធមិនព្រមប្រែចិត្តរបស់ពួកសាសន៍នីហ្វៃ ។ នៅពេលពួកគេឆ្លើយ អ្នកអាចសួរសំណួរខាងក្រោមនេះខ្លះដើម្បីជួយពួកគេឲ្យយល់ពាក្យ និងឃ្លានៅក្នុងខគម្ពីរនេះ ៖

- នៅក្នុង ខទី ១៦ តើអ្នកគិតថា វាមានន័យយ៉ាងណាដែល « គ្មានព្រះគ្រីស្ទនិងព្រះនៅក្នុងពិភពលោកនេះ » ? (ការរស់នៅដោយគ្មានសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ ឬព្រះវរបិតាសួគ៌ និងដោយគ្មានឥទ្ធិពល និងការដឹកនាំពីស្ថានសួគ៌) ។
- តើអ្នកគិតថា វាមានន័យយ៉ាងណាដែលត្រូវ « រុញច្រានដូចជាអង្កាមដែលខ្យល់ផាត់ » ? (មរមន ៥:១៦) ។ (អ្នកអាចពន្យល់ថា អង្កាមសំដៅលើស្មៅ និងសំបកស្រូវដែលត្រូវខ្យល់ផាត់នៅពេលប្រូតកាត់) ។
- តើអ្នកគិតថា អ្នកនឹងមានអារម្មណ៍យ៉ាងណា ប្រសិនបើអ្នកស្ថិតនៅលើទូកដែលគ្មានយុថ្កាមួយនៅលើសមុទ្រ ដោយគ្មានផ្លូវដើម្បីចែវ ឬបត់បែនបានទេនោះ ? តើស្ថានភាពនេះស្រដៀងទៅនឹងស្ថានភាពនៃសាសន៍នីហ្វៃយ៉ាងដូចម្តេច ?

សូមពន្យល់ថា មរមន ៥ បង្រៀនថា **នៅពេលយើងបដិសេធមិនព្រមប្រែចិត្ត ព្រះវិញ្ញាណនឹងដកព្រះកាយចេញ ហើយយើងនឹងបាត់ការដឹកនាំពីព្រះអម្ចាស់ ។** សូមសរសេរគោលការណ៍នេះ៖ នៅលើក្តារខៀន ដើម្បីបំពេញប្រយោគដែលអ្នកបានចាប់ផ្តើមសរសេរពីមុននោះ ។ សូមឲ្យសិស្សញ្ជឹងគិតពីពេលវេលានៅក្នុងជីវិតរបស់ពួកគេ នៅពេលពួកគេអាចជួបនឹងគោលការណ៍នេះ ។

អ្នកអាចសុំឲ្យសិស្សនិយាយផ្ទួយទៅនឹងគោលការណ៍ទាំងពីរដែលបានសរសេរនៅលើក្តារខៀននេះ ដោយការសួរនូវសំណួរខាងក្រោមនេះ ៖ តាមរយៈសេចក្តីពិតទាំងពីរដែលបានសរសេរនៅលើក្តារខៀននេះ តើលទ្ធផលនៃការប្រែចិត្តខុសពីលទ្ធផលនៃការបដិសេធមិនព្រមប្រែចិត្តដូចម្តេច ?

សូមឲ្យសិស្សអាន មរមន ៥:២២–២៤ ស្ងាត់ៗ ដោយរកមើលអ្វីដែលលោកមរមនបានអញ្ជើញឲ្យយើងទាំងអស់គ្នាធ្វើ ដើម្បីឲ្យយើងនឹងមិនអាចក្លាយដូចជាពួកសាសន៍នីហ្វៃនៅក្នុងជំនាន់របស់គេ ។ អ្នកអាចលើកទឹកចិត្តឲ្យសិស្សគូសចំណាំអ្វីដែលពួកគេរកឃើញ ។

សូមថ្លែងទីបន្ទាល់អំពីសេចក្តីពិតនៃគោលការណ៍ទាំងពីរនេះនៅលើក្តារខៀន ។

មរមន ៦:១–៨:១១

ក្រោយពីបានឃើញពីសេចក្តីបំផ្លិចបំផ្លាញចុងក្រោយនៃប្រជាជនរបស់លោក លោក មរមនសរសេរដល់កូនចៅពួកសាសន៍លេមិន ហើយបន្ទាប់មកបានស្លាប់ ដោយទុកឲ្យកូនប្រុសរបស់លោក មរ៉ូណៃ នៅតែម្នាក់ឯង

សូមឲ្យសិស្សសង្ខេបសេចក្តីបំផ្លិចបំផ្លាញចុងក្រោយនៃប្រជាជនសាសន៍នីហ្វៃ ដោយប្រើក្បាលជំពូកនៃ មរមន ៦–៨ បើចាំបាច់ ។

សូមឲ្យសិស្សអានដោយស្ងាត់ៗ ហើយសញ្ជឹងគិតពី មរមន ៧:១០ ជាពាក្យចុងក្រោយដែលលោកមរមនបានសរសេរ មុនពេលលោកបានលាចាកលោកនេះ ។

មេរៀនបន្ទាប់ (មរមន ៨:១២–អេធើរ ៣)

មរ៉ូណៃបាននិយាយជាមួយនឹងព្រះយេស៊ូវគ្រីស្ទ ហើយត្រូវបានបង្ហាញឲ្យឃើញពីជំនាន់របស់យើង ។ តើលោកមរ៉ូណៃបានព្រមានយើងអំពីអ្វីខ្លះ ? បងប្រុសរបស់យ៉ារេឌក៏បានមានសេចក្តីជំនឿដ៏អស្ចារ្យដែរ ។ លោកបានឃើញព្រះយេស៊ូវគ្រីស្ទ ហើយបាននិយាយជាមួយនឹងទ្រង់ទល់មុខគ្នា ។ តើការដឹងថា ទាំងមរ៉ូណៃ និងបងប្រុសរបស់យ៉ារេឌបានឃើញ និងបាននិយាយជាមួយនឹងព្រះគ្រីស្ទ បានជួយអ្នកឲ្យទុកចិត្តលើប្រសាសន៍របស់ពួកលោកដោយរបៀបណា ?

មរមន ៨:១២–៤១

សេចក្តីផ្តើម

ក្រោយពីបានសរសេរអំពីសេចក្តីបំផ្លិចបំផ្លាញនៃប្រជាជន និងការស្លាប់នៃឪពុករបស់លោក ហើយ ម៉រ៉ូណៃបានព្យាករណ៍អំពីការលេចចេញមកនៃព្រះគម្ពីរមរមន និងបានព្រមានពីលទ្ធផលនៃការបដិសេធគម្ពីរនេះ ។ លោកម៉រ៉ូណៃបានឃើញថា កំណត់ត្រាសាសន៍នីហ្វៃនឹងចេញមកនៅក្នុងថ្ងៃមួយក្នុងគ្រាអំពើទុច្ចរិតដ៏ខ្លាំងក្លា នៅពេលមនុស្សជាច្រើននឹងស្រឡាញ់ទ្រព្យសម្បត្តិលោកិយច្រើនជាងព្រះ ។ លោកបានថ្លែងទីបន្ទាល់ថា ព្រះគម្ពីរមរមននឹងជារបស់ដ៏មានតម្លៃបំផុតមួយនៅក្នុងស្ថានភាពដ៏គ្រោះថ្នាក់ខាងវិញ្ញាណ ដែលនឹងមាននៅថ្ងៃចុងក្រោយ ។

យោបល់សម្រាប់ការបង្រៀន

មរមន ៨:១២–៣២

លោកព្យាករណ៍អំពីការលេចចេញមកនៃព្រះគម្ពីរមរមន

មុនពេលបង្រៀន សូមរៀបចំបង្ហាញនូវរបស់ ឬរូបភាពដែលតំណាងឲ្យភាពរឿនលឿននៃបច្ចេកវិទ្យា ។ នៅពេលចាប់ផ្តើមបង្រៀន សូមទាញចំណាប់អារម្មណ៍របស់សិស្សទៅមើលរូបភាពនោះ ។ សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយ ប្រធាន អ៊ែសរ៉ា ថាហ្វ បែនសិន ៖

« ខ្ញុំចង់និយាយអំពីអំណោយទានដ៏មានសំខាន់បំផុតមួយដែលត្រូវបានប្រទានដល់ពិភពលោកនេះនាសម័យទំនើប ។ អំណោយទានដែលខ្ញុំកំពុងគិត គឺសំខាន់ជាងអ្វីៗដែលឧស្សាហកម្ម និងបច្ចេកវិទ្យាបានបង្កើតឡើងទៅទៀត ។វាគឺជាអំណោយទានមួយដ៏មានតម្លៃបំផុត ចំពោះមនុស្សច្រើនជាងអ្វីដែលយើងឃើញនៅក្នុងការលូតលាស់នៃឱសថក្នុងសម័យទំនើប ។អំណោយទាននេះ មានតម្លៃសក្តិសមចំពោះមនុស្ស ជាងការអភិវឌ្ឍន៍នៃការហោះហើរ ឬការធ្វើដំណើរលើអាកាសទៅទៀត ។ខ្ញុំនិយាយអំពីអំណោយទាននៃ . . . » (« The Book of Mormon—Keystone of Our Religion » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៨៦, ទំព័រ ៤) ។

- តើអ្នកចង់បាននូវអំណោយទានដែលប្រធាន បែនសិន បានមានប្រសាសន៍ដែរឬទេ ? ហេតុអ្វី ?
- តើអ្នកគិតថា អំណោយទាននោះអាចជាអ្វី ?

សូមពន្យល់ថា លោកម៉រ៉ូណៃបានបង្រៀនអំពីអំណោយទាននេះ ។ សូមឲ្យសិស្សអាន មរមន ៨:១២ ដើម្បីរកមើលថាតើអំណោយទាននោះជាអ្វី ។ សូមជួយសិស្សឲ្យយល់ថាឃ្លា « បញ្ជីនេះ » សំដៅទៅលើព្រះគម្ពីរមរមន ។ សូមពន្យល់ថា ប្រធាន បែនសិន បានមានប្រសាសន៍អំពីអំណោយទាននៃព្រះគម្ពីរមរមន ។

ដើម្បីជួយសិស្សឲ្យយល់ពីតម្លៃនៃព្រះគម្ពីរមរមន សូមឲ្យពួកគេអាន មរមន ៨:១៣–១៦ ដោយស្ងាត់ៗ ។ មុនពេលពួកគេអាន សូមឲ្យពួកគេរកមើលអ្វីដែលលោកម៉រ៉ូណៃបានបង្រៀនអំពីតម្លៃនៃព្រះគម្ពីរមរមន ។ បន្ទាប់មក សូមសួរនូវសំណួរខាងក្រោមនេះខ្លះ ឬទាំងអស់ដើម្បីជួយពួកគេឲ្យពិភាក្សា ហើយវិភាគនូវអ្វីដែលពួកគេបានរកឃើញ ៖

- មនុស្សខ្លះអាចគិតអំពីតម្លៃនៃរូបិយវត្ថុដ៏មានតម្លៃនៃផ្នាំងមាសនេះ ។ យោងតាម មរមន ៨:១៤ តើផ្នែកណាមួយនៃផ្នាំងចំណារដែលពិតជា « មានតម្លៃ » នោះ ? (សូមជួយសិស្សឲ្យឃើញថា ដោយសារព្រះអម្ចាស់នឹងមិនអនុញ្ញាតឲ្យនរណាម្នាក់ « ស្វែងរកកម្រៃ » ពីផ្នាំងមាសទាំងនេះ នោះផ្នាំងទាំងនេះ « ពុំមានតម្លៃអ្វីឡើយ » ។ ទោះជាយ៉ាងក្តី បញ្ជីដែលត្រូវបានសរសេរនៅលើផ្នាំងនេះ « មានតម្លៃ ») ។
- លោកម៉រ៉ូណៃបានមានប្រសាសន៍ថា ព្រះគម្ពីរមរមនមិនត្រឹមតែអាចនាំចេញមកដោយមនុស្សម្នាក់ដែល « មានភ្នែកស្មោះស្ម័គ្រទាំងស្រុងចំពោះសិរីល្អ [របស់ព្រះ] » ប៉ុណ្ណោះទេ (មរមន ៨:១៥) ។ តើអ្នកគិតថា វាមានន័យដូចម្តេច ? (នៅពេលសិស្សពិភាក្សាពីសំណួរនេះ អ្នកអាចសុំឲ្យពួកគេអាន យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:៤៦ ដែលរួមមាននូវការណែនាំចុងក្រោយរបស់លោកម៉រ៉ូណៃដល់យ៉ូសែប ស៊្មីធ មុនពេលលោកបាននាំព្រះគម្ពីរមរមនចេញមក) ។
- នៅក្នុង មរមន ៨:១៦ តើការរៀបរាប់របស់លោកម៉រ៉ូណៃពីការលេចចេញមកនៃព្រះគម្ពីរមរមន ជួយពន្យល់ពីតម្លៃដ៏មហិមានៃព្រះគម្ពីរនេះដូចម្តេចខ្លះ ?

ដូចដែលបានកត់ត្រានៅក្នុង មរមន ៨:១៧–២១ លោកម៉រ៉ូណៃបានព្រមានអ្នកដែលនឹងដាក់ទោស ឬប្រឆាំងនឹងព្រះគម្ពីរមរមននេះ ។ សូមឲ្យសិស្សអានខគម្ពីរទាំងនេះ ហើយរកមើលការព្រមានរបស់ម៉រ៉ូណៃ ។

- តើអ្វីទៅជាការព្រមានរបស់ម៉រ៉ូណៃដល់អស់អ្នកណាដែលបដិសេធ ឬប្តោលទោសដល់ព្រះគម្ពីរមរមន ?
- តើសេចក្តីពិតអ្វីខ្លះដែលអ្នករៀនពី មរមន ៨:២២ នេះ ? តើការលេចចេញមកនៃព្រះគម្ពីរមរមននៅក្នុងជំនាន់ចុងក្រោយនេះ ជួយបំពេញដល់គោលបំណងដ៏អស់កល្បរបស់ព្រះអម្ចាស់បានដោយរបៀបណា ?

សូមពន្យល់ថា មរមន ៨:២៣–២៥ រួមមានប្រសាសន៍របស់ម៉ូរ៉ូណៃអំពីការអធិស្ឋានរបស់ពួកបរិសុទ្ធដ៏ស្មោះត្រង់ ដែលបានរស់នៅពីមុនជំនាន់របស់លោក ។ លោកបានមានប្រសាសន៍ថា ពួកគេបានអំពាវនាវដល់ព្រះអម្ចាស់ « ចេញពីធូលីដីមក » ។ សូមឲ្យសិស្សអានវគ្គនេះដោយស្ងៀមស្ងាត់ ដោយរកមើលអ្វីដែលពួកបរិសុទ្ធនៅក្នុងដែនដីអាមេរិកពីបុរាណបានអធិស្ឋានសុំ ដែលទាក់ទងទៅនឹងព្រះគម្ពីរមរមន ។

- តើពួកបរិសុទ្ធសម័យបុរាណបានអធិស្ឋានសុំអ្វីខ្លះ ? (ពួកគេបានអធិស្ឋានសម្រាប់បងប្អូនរបស់គេ —មានន័យថា ពួកសាសន៍លេមិន និងកូនចៅរបស់គេ— និងដល់មនុស្សដែលនឹងនាំព្រះគម្ពីរមរមនចេញមក— មានន័យថា ព្យាការី យ៉ូសែប ស្ម៊ីធ)។

សូមពន្យល់ថា លោកម៉ូរ៉ូណៃបានរៀបរាប់ពីស្ថានភាពដែលនឹងកើតមាន នៅពេលព្រះគម្ពីរមរមននឹងលេចចេញមក ។ បន្ទាប់មក សូមឲ្យពួកគេស្រមៃថាខ្លួនគេស្ថិតនៅក្នុងសម័យរបស់ម៉ូរ៉ូណៃ ដោយបានរស់នៅកាលពីជាង ១,៦០០ ឆ្នាំកន្លងទៅ ហើយទទួលបានការនិមិត្តមួយពីជំនាន់របស់យើង ។

សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅសរសេរ ឬ ក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេមួយកថាខណ្ឌ ដោយរៀបរាប់ពីស្ថានភាពខាងវិញ្ញាណនៃជំនាន់របស់យើង ។ នៅពេលសិស្សបានមានពេលសរសេរគ្រប់គ្រាន់ហើយ សូមឲ្យពួកគេបីបួននាក់ ចែកចាយអ្វីដែលពួកគេបានសរសេរ ។ បន្ទាប់មក សូមឲ្យសិស្សអាន មរមន ៨:២៦– ៣២ ដោយស្ងាត់ៗ ហើយប្រៀបធៀបកថាខណ្ឌរបស់គេទៅនឹងការរៀបរាប់នៃការព្យាករណ៍របស់ម៉ូរ៉ូណៃពីជំនាន់របស់យើង ។ សូមបំបែកសិស្សជាដៃគូ ។ សូមឲ្យដៃគូនីមួយៗចែកចាយភាពស្រដៀងគ្នាពីរបី និងភាពខុសគ្នារវាងការរៀបរាប់របស់គេ និងរបស់ម៉ូរ៉ូណៃ ។

- តើអ្នកគិតថា ការរៀបរាប់របស់លោកម៉ូរ៉ូណៃអំពីជំនាន់របស់យើងត្រឹមត្រូវដែរឬទេ ?

សូមសរសេរសេចក្តីសង្ខេបខាងក្រោមនៃការព្យាករណ៍របស់លោកម៉ូរ៉ូណៃនៅលើក្តារខៀនថា ៖ ***ព្រះគម្ពីរមរមននឹងចេញមកដោយព្រះចេស្តានៃព្រះ អំឡុងពេលថ្ងៃដ៏ទុច្ចរិតដ៏ធំមួយ ។*** ប្រសិនបើអ្នកបានបង្ហាញរបស់ ឬរូបភាពណាមួយដែលតំណាងឲ្យការបង្កើតផ្នែកបច្ចេកវិទ្យា ឬវេជ្ជសាស្ត្រ សូមពិចារណាពីការដាក់ព្រះគម្ពីរមរមនមួយក្បាលនៅក្បែររបស់នោះ ។ ដើម្បីជួយសិស្សឲ្យសញ្ជឹងគិត និងថ្លែងទីបន្ទាល់អំពីតម្លៃនៃព្រះគម្ពីរមរមននៅក្នុងជីវិតរបស់ពួកគេ សូមសួរសំណួរដូចខាងក្រោម ៖

- តើព្រះគម្ពីរមរមនអាចជួយយើងឲ្យតទល់នឹងអំពើទុច្ចរិតនៅក្នុងជំនាន់របស់យើងដោយរបៀបណា ?
- តើព្រះគម្ពីរមរមនមានតម្លៃជាងការបង្កើតថ្មីនៃបច្ចេកវិទ្យា ឬវេជ្ជសាស្ត្រយ៉ាងដូចម្តេច ?
- តើអ្នកគិតថា ហេតុអ្វីបានជាព្រះគម្ពីរមរមនគឺជា « អំណោយទានមួយដ៏មានសារៈសំខាន់បំផុតចំពោះពិភពលោកនៅក្នុងសម័យទំនើបនេះ » ដូចដែលប្រធាន ប៊ែនសឹន បានមានប្រសាសន៍ ?
- ប្រសិនបើមានមិត្តភក្តិសួរអ្នកថា ហេតុអ្វីបានជាព្រះគម្ពីរមរមនមានតម្លៃចំពោះអ្នក តើអ្នកនឹងនិយាយដូចម្តេច ?

ការសុំឲ្យសិស្សចែកចាយចម្លើយដែលបានសរសេរ

ពេលខ្លះ សូមលើកទឹកចិត្តសិស្សឲ្យចែកចាយអ្វីដែលពួកគេសរសេរនៅក្នុងសៀវភៅសរសេរ ឬក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីរក្នុងថ្នាក់ ។ សូមកុំភ្លេច ថ្លែងអំណរគុណដល់សិស្សចំពោះការចែកចាយ ហើយសរសើរពួកគេដោយស្មោះពីចិត្ត ។ នៅពេលអ្នកយកពេលនៅក្នុងថ្នាក់ដើម្បីធ្វើការណ៍នេះ អ្នកនឹងជួយបង្កើនបរិយាកាសសិក្សាមួយដែលពោរពេញដោយសេចក្តីស្រឡាញ់ និងការគោរព ។

មរមន ៨:៣៣–៤១

លោកម៉ូរ៉ូណៃមើលឃើញពីជំនាន់ចុងក្រោយ ហើយដាក់ទោសដល់អំពើទុច្ចរិតខាងវិញ្ញាណនៃជំនាន់របស់យើង

សូមឲ្យសិស្សម្នាក់អាន មរមន ៨:៣៥ ឮៗ ។ មុនពេលគេអាន សូមបង្ហាញថា នៅក្នុងខគម្ពីរនេះ លោកម៉ូរ៉ូណៃកំពុងមានប្រសាសន៍ដោយចំៗមកយើង ។

- តើខគម្ពីរនេះអាចមានឥទ្ធិពលលើរបៀបដែលយើងអានព្រះគម្ពីរមរមនយ៉ាងដូចម្តេច ?

នៅពេលសិស្សបានពិភាក្សាពីសំណួរនេះ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន អែសរ៉ា ថាហ្វ ប៊ែនសឹន ដែលលោកបានមានប្រសាសន៍អំពីពួកព្យាការីក្នុងព្រះគម្ពីរមរមន ៖

« បើសិនជាពួកលោកបានមើលឃើញសម័យរបស់យើង ហើយបានជ្រើសរើសការណ៍ទាំងនោះដែលអាចមានតម្លៃអស្ចារ្យបំផុតដល់យើង តើនោះមិនមែនជារបៀបដែលយើងគួរតែសិក្សាព្រះគម្ពីរមរមនដែរឬទេឬអី ?យើងគួរតែសួរខ្លួនឯងជាញឹកញាប់ថា ‹ ហេតុអ្វីបានជាព្រះអម្ចាស់បំផុសគំនិតមរមន (ឬម៉ូរ៉ូណៃ ឬ អាលម៉ា) ឲ្យកត់ត្រាបញ្ចូលការណ៍នោះក្នុងបញ្ជីរបស់លោក ?តើមេរៀនអ្វីដែលខ្ញុំអាចរៀនចេញពីនោះ ដើម្បីជួយខ្ញុំរស់នៅក្នុងសម័យកាលនេះ និងក្នុងស្ថានភាពនេះបាន › » ?(« ព្រះគម្ពីរមរមន— ជាមូលដ្ឋានគ្រឹះនៃសាសនារបស់យើង » ៦) ។

សូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមការណែនាំនេះ នៅពេលពួកគេសិក្សាពីប្រសាសន៍របស់លោកម៉ូរ៉ូណៃ មរមន ៨ ។

សូមឲ្យសិស្សគិតអំពីពេលវេលាដែលពួកគេបានឃើញនរណាម្នាក់មានសេចក្តីត្រូវការ— ផ្នែករាងកាយ អារម្មណ៍ សង្គម ឬផ្នែកវិញ្ញាណ ។ សូមឲ្យពួកគេពិចារណាពីអ្វីដែលពួកគេបានធ្វើដើម្បីជួយដល់បុគ្គលនោះ —ឬប្រសិនបើពួកគេមិនផ្តល់ជំនួយទេ តើពួកគេអាចធ្វើអ្វីបាន ។ សូមជួយពួកគេឲ្យសញ្ជឹងគិតពីមូលហេតុដែលពួកគេបានជ្រើសរើសជួយ ឬមិនជួយផងដែរ ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី មរមន ៨:៣៣–៤១ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលមូលហេតុដែលមនុស្សខ្លះនៅក្នុងជំនាន់ចុងក្រោយមិនជួយដល់អ្នកដែលមានសេចក្តីត្រូវការ ។

- តើហេតុអ្វីបានជាមនុស្សខ្លះនៅក្នុងថ្ងៃចុងក្រោយមិនជួយអ្នកដែលត្រូវការជំនួយ ? (ចម្លើយអាចរួមមានភាពឆ្មើងឆ្មៃ អំពើទុច្ចរិត ការស្រឡាញ់លុយ និងសម្លៀកបំពាក់ល្អៗជាងពួកគេស្រឡាញ់អ្នកដែលត្រូវការជំនួយ ហើយប្រាថ្នាចង់បានការកោតសរសើរពីលោកិយ) ។
- នៅក្នុង មរមន ៨:៣៨ លោកមរមនប្រើពាក្យ *កខ្វក់* ។ តើឥទ្ធិពលអ្វីខ្លះនៅលើពិភពលោកនាពេលបច្ចុប្បន្ននេះដែលអាចត្រូវបានចាត់ទុកថាជាការកខ្វក់ ? (ចម្លើយអាចរួមមាន ភាពឆ្មើងឆ្មៃ រូបអាសគ្រាម និងការស្រឡាញ់លុយ) ។

សូមឲ្យសិស្សសរសេរប្រយោគមួយដែលសង្ខេបពីអ្វីដែលពួកគេបានរៀនពី មរមន ៨:៣៦–៤១ អំពីការទទួលខុសត្រូវដើម្បីយកចិត្តទុកដាក់ដល់ជនក្រីក្រ និងអ្នកដែលទីទាល់ ។ សូមឲ្យសិស្សពីរ ឬបីនាក់អានប្រយោគរបស់គេដល់សិស្សក្នុងថ្នាក់ ។ ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាក្តី ក៏ពួកគេគួរអកឃើញនូវសេចក្តីពិតខាងក្រោមនេះ ៖ **ព្រះនឹងប្រទានឲ្យយើងនូវការទទួលខុសត្រូវចំពោះរបៀបដែលយើងប្រព្រឹត្តចំពោះជនក្រីក្រ និងអ្នកដែលទីទាល់ ។**

- តើអ្នកគិតថា អ្វីខ្លះជាតម្រូវការទូទៅបំផុតនៅក្នុងសាលា ឬសហគមន៍របស់អ្នក ? តើយុវវ័យនៃសាសនាចក្រអាចធ្វើអ្វីខ្លះដើម្បីជួយមើលថែមនុស្សដែលមានតម្រូវការទាំងនេះ ? (សូមជួយសិស្សឲ្យយល់ថា ពួកគេមិនត្រូវបានរំពឹងថាឲ្យផ្តល់ប្រាក់ និងពេលវេលាចំពោះបុព្វហេតុដ៏មានតម្លៃគ្រប់យ៉ាង ឬចំពោះបុគ្គលគ្រប់រូបដែលសុំជំនួយនោះទេ ។ នៅក្នុងគ្រួសាររបស់ពួកគេ និងនៅក្នុងសាសនាចក្រ យុវវ័យទទួលបានឱកាសជាច្រើនដើម្បីជួយដល់អ្នកដែលទីទាល់ ។ លើសពីនេះទៅទៀត ពួកគេអាចធ្វើតាមការដឹកនាំនៃព្រះវិញ្ញាណដើម្បីជួយដោយខ្លួនឯង) ។
- តើអ្នកគិតថា យុវវ័យនៅក្នុងសាសនាចក្រអាចធ្វើអ្វីខ្លះដើម្បីមើលថែជនក្រីក្រ ? (ប្រសិនបើសិស្សមិនលើកឡើងពីដង្វាយតមអាហារទេ អ្នកអាចបញ្ជាក់ពីការបង់ដង្វាយតមអាហារដោយការអានវគ្គនៅក្រោម « សប្តាហ៍តមអាហារ » នៅក្នុង *ពិតចំពោះសេចក្តីជំនឿ ៖ សេចក្តីយោងដំណឹងល្អមួយ* | ឆ្នាំ ២០០៤ | ទំព័រ ១៦–១៧) ។

បន្ទាប់ពីការពិភាក្សានេះ សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅសរសេរ ឬក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីរអំពីរឿងមួយ ឬពីរដែលពួកគេអាចធ្វើបានក្នុងការមើលថែជនក្រីក្រ និងអ្នកដែលទីទាល់ ។ ពួកគេអាចសរសេរនូវយោបល់ ដែលពួកគេបានឮអំឡុងពេលរៀន ឬពីគំនិតរបស់គេផ្ទាល់ ។ សូមឲ្យពួកគេសរសេរគោលដៅមួយដើម្បីធ្វើរឿងមួយក្នុងចំណោមរឿងទាំងនេះនៅសប្តាហ៍ក្រោយ ។ សូមលើកទឹកចិត្តពួកគេឲ្យបំពេញតាមគោលដៅរបស់ខ្លួន ។

វិចារណកថា និង ព័ត៌មានសាច់រឿង

មរមន ៨:១៤–១៨ ។ « អ្នកទទួលបានពរចំពោះអ្នកដែលនាំបញ្ជីនោះមកឯពន្លឺ »

ម៉ូណៃបានព្យាករណ៍អំពីព្យាការី យ៉ូសែប ស្មីធ ដែលត្រូវបានជ្រើសរើសដើម្បីនាំយកព្រះគម្ពីរមរមនចេញមកដល់ពិភពលោក (សូមមើល មរមន ៨:១៥–១៦) ។ ព្យាការីពីបុរាណជាច្រើនផ្សេងទៀតក៏បានដឹងពីយ៉ូសែប ស្មីធ ហើយបានអធិស្ឋានសម្រាប់ជោគជ័យរបស់លោកក្នុងការបកប្រែ ហើយបោះពុម្ពផ្ទាំងមាស ដើម្បីបានបំពេញគោលបំណងរបស់ព្រះ (សូមមើល មរមន ៨:២៣–២៥; គ. និង ស. ១០:៤៦) ។ ប្រធាន ប៊ិយដ៍ ឃេ ផាកកឺ ក្នុងក្រុ៉មនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍អំពីតួនាទីរបស់ យ៉ូសែប ស្មីធ ក្នុងការនាំយកព្រះគម្ពីរមរមនចេញមក ។

« សេចក្តីពិតគឺសាមញ្ញថា លោកគឺជាព្យាការីម្នាក់របស់ព្រះ— គ្មានលើសពីនេះទៀតឡើយ ហើយក៏គ្មានអ្វីតិចជាងនេះដែរ !

« ព្រះគម្ពីរមិនបានចេញមកច្រើនពី យ៉ូសែប ស្មីធ ដូចដែលវាបានចេញមកតាមរយៈលោកឡើយ ។ លោកគឺជាឧបករណ៍មួយដែលវិវរណៈត្រូវបានប្រទានមក ។ . . .

« ព្យាការី យ៉ូសែប ស្មីធ គឺជាក្មេងអ្នកចម្ការដែលមិនបានរៀនសូត្រ ។ ដើម្បីអានលិខិតដើមរបស់លោកខ្លះ បង្ហាញថាលោកមិនបានល្អឥតខ្ចោះក្នុងអក្ខរាវិរុទ្ធ និង វេយ្យាករណ៍ ព្រមទាំងកន្សោមពាក្យផងដែរ ។

« កាលដែលវិវរណៈបានមកតាមរយៈលោកនៅក្នុងទម្រង់នានានៃការបន្សុទ្ធខាងអក្សរសាស្ត្រ គឺគ្មានអ្វីក្រៅពីអព្ភូតហេតុនោះទេ » (« We Believe All That God Has Revealed » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៧៤ ទំព័រ ៩៤) ។

មរមន ៨:៣៧–៣៨ ។ តើការថែទាំដល់ជនក្រីក្រ និងអ្នកទីទាល់ទាក់ទងនឹងសុភមង្គលដ៏អស់កល្បដោយរបៀបណា ?

ប៊ីស្សព អេក ដេវីឌ ប៊ើរតុន នៃប៊ីស្សពជាអធិបតី បានថ្លែងទីបន្ទាល់អំពីលទ្ធផលដ៏អស់កល្បនៃការថែទាំដល់ជនក្រីក្រ និងអ្នកទីទាល់ថា ៖

« គោលបំណង សេចក្តីសន្យា និងគោលការណ៍នានាដែលសង្កត់ធ្ងន់លើកិច្ចការរបស់យើងក្នុងការថែទាំដល់ជនក្រីក្រ និងអ្នកទីទាល់ នឹងមានលើសពីព្រំដែននៃជីវិតរមែងស្លាប់ទៅទៀត ។ កិច្ចការដ៏ពិសិដ្ឋនេះ គឺមិនត្រឹមតែផ្តល់ប្រយោជន៍ ហើយប្រទានពរដល់អ្នកដែលរងទុក្ខ ឬអ្នកទីទាល់ប៉ុណ្ណោះទេ ។ ក្នុងនាមជាបុត្រា និងបុត្រីនៃព្រះ យើងមិនអាចគ្រងបានជីវិតដ៏នៅអស់កល្បជានិច្ចពេញលេញ ដោយមិនបានជួយមើលថែទាំដល់គ្នាទៅវិញទៅមកខណៈពេលយើងនៅលើផែនដីនោះទេ ។ វាគឺជាទង្វើដ៏សណ្តោសមួយនៃការធ្វើពលិកម្ម និងលះបង់ខ្លួនយើងដល់អ្នកដទៃ រហូតដល់យើងរៀនពីគោលការណ៍សេឡេស្ទាលនៃការពលិកម្ម និងការញែកចេញ » (« The Sanctifying Work of Welfare » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១១, ទំព័រ ៨១–៨២) ។

មរមន ៩

សេចក្តីផ្តើម

ម៉ូរ៉ូណៃបានបញ្ចប់បញ្ជីរបស់ឪពុកលោក ដោយការដង្ហោយហៅអ្នកដែលមិនជឿលើព្រះយេស៊ូវគ្រីស្ទ ឲ្យត្រឡប់មករកព្រះអម្ចាស់តាមរយៈការប្រែចិត្ត ។ លោកបានបង្រៀនថា ព្រះគឺជាព្រះនៃអព្ភូតហេតុ ដែលមិនបានផ្លាស់ប្តូរ ហើយថាអព្ភូតហេតុនឹងឈប់មានដោយសារតែការខ្វះជំនឿប៉ុណ្ណោះ ។ លោកបានលើកទឹកចិត្តប្រជាជនឲ្យជឿលើព្រះយេស៊ូវគ្រីស្ទ និងអធិស្ឋានដល់ព្រះវរបិតាដោយអស់ពីចិត្តរបស់គេនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទដើម្បីទទួលបានអ្វីដែលពួកគេត្រូវការ ។

យោបល់សម្រាប់ការបង្រៀន

មរមន ៩:១–៦

លោកម៉ូរ៉ូណៃហៅអស់អ្នកទាំងឡាយណាដែលមិនជឿលើព្រះយេស៊ូវគ្រីស្ទឲ្យប្រែចិត្ត

សូមឲ្យសិស្សគិតអំពីស្ថានភាពមួយ ដែលពួកគេមានអារម្មណ៍ថាមិនស្រណុកចិត្ត ។ សូមឲ្យសិស្សពីរបីនាក់ប្រាប់អំពីបទពិសោធន៍របស់ពួកគេ និងពន្យល់ពីមូលហេតុដែលពួកគេមានអារម្មណ៍ថាមិនស្រណុកចិត្ត ។ អ្នកក៏អាចសួរពួកគេពីអ្វីដែលនឹងធ្វើឲ្យពួកគេមានអារម្មណ៍ស្រណុកចិត្តជាងនេះនៅក្នុងស្ថានភាពទាំងនេះ: ។

សូមឲ្យសិស្សអាន ម៉ូរ៉ូណៃ ៩:១–៥ ស្ងាត់ៗដោយរកមើលស្ថានភាពមិនស្រណុកចិត្តដែលលោកម៉ូរ៉ូណៃបានរៀបរាប់ ។ (អ្នកក៏អាចសុំឲ្យសិស្សអាន អាលម៉ា ១២:១២–១៥ ហើយសរសេរសេចក្តីយោងនេះនៅក្បែរ មរមន ៩:១–៥) ។

- **នៅពេលថ្ងៃនៃសេចក្តីជំនុំជំរះចុងក្រោយ តើពួកទុច្ចរិតនឹងមានអារម្មណ៍ដូចម្តេចនៅក្នុងវត្តមាននៃព្រះ ជាព្រះវរបិតា និងព្រះយេស៊ូវគ្រីស្ទ ? ហេតុអ្វីបានជាពួកគេមានអារម្មណ៍បែបនេះ ?**

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន យ៉ូសែប ហ្វីលឌីង ស្មីធ ៖

« មិនអាចមានសេចក្តីសង្គ្រោះនោះទេ បើគ្មានការប្រែចិត្តនោះ: ។ មនុស្សម្នាក់មិនអាចចូលទៅក្នុងនគរព្រះនៅក្នុងអំពើបាបរបស់គេបានឡើយ ។ វានឹងជារឿងមិនអាចទៅរួចដែលមនុស្សម្នាក់អាចចូលមកក្នុងវត្តមាននៃព្រះវរបិតា ហើយរស់នៅក្នុងវត្តមានរបស់ព្រះនៅក្នុងអំពើបាបរបស់គេនោះ: ។ . . .

« ខ្ញុំគិតថា មានមនុស្សដ៏អស្ចារ្យជាច្រើននៅលើផែនដី ដែលពួកគេភាគច្រើនប្រហែលជានៅក្នុងសាសនាចក្រ—យ៉ាងហោចណាស់ពួកគេខ្លះនៅក្នុងសាសនាចក្រ— ដែលមានគំនិតមួយថា ពួកគេអាចឆ្លងកាត់ជីវិតនេះដោយការធ្វើអ្វីដែលពួកគេរីករាយ រំលងក្រឹត្យវិន័យរបស់ព្រះអម្ចាស់ ហើយនៅទីបញ្ចប់ពួកគេនឹងមកក្នុងវត្តមានរបស់ទ្រង់ ។ ពួកគេគិតថា ពួកគេនឹងប្រែចិត្ត ប្រហែលជានៅក្នុងពិភពវិញ្ញាណ ។

« ពួកគេគួរតែអានពាក្យទាំងនេះរបស់លោកម៉ូរ៉ូណៃ (ការដកស្រង់ មរមន ៩:៣–៥) ។

« តើអ្នកគិតថា មនុស្សម្នាក់ដែលមានជីវិតពោរពេញទៅដោយការពុករលួយ ដែលបានប្រឆាំងនឹងព្រះ ដែលមិនបានមានវិញ្ញាណនៃការប្រែចិត្ត នឹងរីករាយ ឬសុខស្រួល នឹងអាចត្រូវបានអនុញ្ញាតឲ្យចូលមកក្នុងវត្តមាននៃព្រះឬ ? » (*Doctrines of Salvation*, ed. ប្រ៊ូស អ័រ ម៉ាក់ខនឃី, វ៉ុលទី ៣ (ឆ្នាំ ១៩៥៤–៥៦), ២:១៩៥–៩៦; អក្សរផ្តេកនៅក្នុងច្បាប់ដើមត្រូវបានលុបចេញ) ។

- **ហេតុអ្វីបានជាយើងត្រូវប្រែចិត្តពីអំពើបាបរបស់យើងថ្ងៃនេះ ហើយមិនចាំដល់ថ្ងៃនៃការជំនុំជម្រះ ? (ដើម្បីជួយសិស្សឲ្យឆ្លើយនឹងសំណួរនេះ: អ្នកអាចសុំឲ្យពួកគេអាន អាលម៉ា ៣៤:៣៣–៣៨) ។**

សូមឲ្យសិស្សម្នាក់អាន មរមន ៩:៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលអ្នកដែលមិនជឿ ត្រូវធ្វើដើម្បីឲ្យពួកគេអាចមានអារម្មណ៍សុខស្រួលនៅក្នុងវត្តមាននៃព្រះ: ។ ក្រោយពីសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញហើយ សូមឲ្យពួកគេរកមើលពាក្យ និងឃ្លានៅក្នុង មរមន ៩:៦ ដែលរៀបរាប់ពីអ្នកដែលបានត្រឡប់ទៅរកព្រះអម្ចាស់ និងបានអធិស្ឋានសុំការអភ័យទោស ។ អ្នកអាចណែនាំថា សិស្សគួរគូសចំណាំពាក្យ និងឃ្លាដែលពួកគេរកឃើញ ។

សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅសរសេរ ឬក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីរនូវគោលការណ៍មួយដែលសង្ខេប មរមន ៩:៦ ។ អំពាវនាវឲ្យ សិស្សពីរ ឬបីនាក់ អានអ្វីដែលពួកគេបានសរសេរ ។ ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរបង្ហាញនូវសេចក្តីពិតខាងក្រោមនេះ: ៖ ប្រសិនបើយើងប្រែចិត្ត យើងនឹងមិនមានកំហុស នៅពេលយើងមកកាន់វត្តមាននៃព្រះឡើយ ។

សូមធ្វើទីបន្ទាល់ថា តាមរយៈការប្រែចិត្ត និងការរស់នៅដោយសុចរិត នោះយើងអាចរៀបចំខ្លួនដើម្បីរស់នៅដោយស្រណុកចិត្តនៅក្នុងវត្តមានរបស់ព្រះអម្ចាស់ ។ សូមឲ្យសិស្សសញ្ជឹងគិតពីអ្វីដែលពួកគេគួរធ្វើនាពេលនេះ ដើម្បីរៀបចំខ្លួនទៅជួបនឹងព្រះអម្ចាស់ ។

ការចុចឈ្មោះហៅសិស្សជាបុគ្គល

ការចុចឈ្មោះហៅសិស្សជាម្នាក់ៗ អាចលើកទឹកចិត្តឲ្យមានការចូលរួមពីសិស្សដែលមិនចែកចាយញឹកញាប់ ។ សូមជួយសិស្សឲ្យរៀបចំខ្លួនរួមចំណែកដោយការឲ្យពួកគេមានពេលគិត មុនពេលហៅពួកគេ ។ សូមប្រយ័ត្នថា មិនធ្វើឲ្យពួកគេមានអារម្មណ៍ខ្មាស់អៀន ឬដាក់សម្ពាធលើពួកគេឲ្យរួមចំណែក ប្រសិនបើពួកគេមិនមានអារម្មណ៍ល្អក្នុងការធ្វើដូច្នោះទេនោះ ។

មរមន ៩:៧–២០

លោកម៉ូរ៉ូណៃប្រកាសថា ព្រះសម្តែងនូវអព្ភូតហេតុ ហើយឆ្លើយតបនឹងការអធិស្ឋាននៃពួកអ្នកស្មោះត្រង់

សូមសរសេរពាក្យ *អព្ភូតហេតុ* នៅលើក្តារខៀន ។ សូមសួរសិស្សថា តើពួកគេនឹងឲ្យនិយមន័យពាក្យនេះដូចម្តេច ។ ក្រោយពីសិស្សពីរបីនាក់បានឆ្លើយហើយ សូមឲ្យសិស្សក្នុងថ្នាក់បើកមើល *អព្ភូតហេតុ* នៅក្នុងវចនានុក្រមនៃព្រះគម្ពីរបរិសុទ្ធ ។ សូមឲ្យពួកគេអានការផ្តើម ដោយរកមើលព័ត៌មានដែលអាចបញ្ជាក់ ឬបន្ថែមលើនិយមន័យដែលពួកគេបានស្នើនោះ ។

- **តើអ្នកគិតថា ហេតុអ្វីបានជាមនុស្សខ្លះមិនជឿលើអព្ភូតហេតុ ?**

សូមសង្ខេប មរមន ៩:៧–៨ ដោយការពន្យល់ថា លោកម៉ូរ៉ូណៃបានមានប្រសាសន៍ដល់ប្រជាជននៅក្នុងថ្ងៃចុងក្រោយ ដែលនឹងថ្លែងថា វិវរណៈ ការព្យាករណ៍ អំណោយទានខាងវិញ្ញាណ និងអព្ភូតហេតុលែងកើតមានទៀតហើយ ។

សូមបំបែកសិស្សធ្វើជាគូ ។ សូមឲ្យដៃគូមួយអាន មរមន ៩:៩–១១ ដោយស្ងាត់ៗ ខណៈពេលដែលដៃគូដទៃទៀតអាន មរមន ៩:១៥–១៩ ដោយស្ងាត់ៗ ។ សូមឲ្យសិស្សម្នាក់ៗសរសេរចំណុចសំខាន់ៗ ដែលលោកម៉ូរ៉ូណៃបានសរសេរដើម្បីបញ្ចុះបញ្ចូលប្រជាជនឲ្យជឿលើអព្ភូតហេតុ ។ នៅពេលសិស្សបានមានពេលសរសេរគ្រប់គ្រាន់ហើយ សូមឲ្យពួកគេរៀបរាប់ដល់ដៃគូរបស់ពួកគេ នូវអ្វីដែលពួកគេបានសរសេរ ។

នៅខាងឆ្វេងនៃក្តារខៀន សូមសរសេរ *អព្ភូតហេតុនឹងឈប់ នៅពេលយើង* . . .

នៅខាងស្តាំនៃក្តារខៀន សូមសរសេរ *អព្ភូតហេតុអាចកើតឡើង នៅពេលយើង* . . .

សូមឲ្យសិស្សម្នាក់អាន មរមន ៩:២០ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលមូលហេតុចំនួនបី ដែលព្រះអាចនឹងឈប់សម្តែងនូវអព្ភូតហេតុដល់កូនចៅរបស់ទ្រង់ ។ សូមឲ្យសិស្សម្នាក់សរសេរមូលហេតុទាំងនេះនៅលើក្តារខៀនដើម្បីបំពេញប្រយោគនៅលើខាងឆ្វេងនៃក្តារខៀន ដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ ។

សូមឲ្យសិស្សរៀបប្រយោគនីមួយៗឡើងវិញ ដែលទាក់ទងទៅនឹងមូលហេតុដែលបណ្តាលឲ្យអព្ភូតហេតុឈប់កើតមានតាមរបៀបមួយដែលបង្ហាញលក្ខខណ្ឌមួយដែលធ្វើឲ្យអព្ភូតហេតុកើតមានបាន ។ ចម្លើយរបស់ពួកគេគួរស្រដៀងទៅនឹងឧទាហរណ៍ដែលមាននៅខាងស្តាំនៃតារាងនេះ ។

អព្ភូតហេតុនឹងឈប់ នៅពេលយើង . . .	អព្ភូតហេតុអាចកើតមាន នៅពេលយើង . . .
ការធ្លាក់ចុះនៅក្នុងការគ្មានជំនឿ	ការកើនឡើងសេចក្តីជំនឿរបស់យើង
ការចាកចេញពីផ្លូវត្រូវ	ការរស់នៅតាមផ្លូវត្រូវ ឬកាន់តាមព្រះបញ្ញត្តិរបស់ព្រះ
ការមិនស្គាល់ព្រះដែលយើងគួរទុកចិត្ត	មកស្គាល់ ហើយទុកចិត្តលើព្រះ

សូមឲ្យសិស្សរំឭកមួយភ្លែតនូវ មរមន ៩:៩, ១៩ ដោយរកមើលការបង្រៀនរបស់ម៉ូរ៉ូណៃអំពីលក្ខណៈរបស់ព្រះ ។ ក្រោយពីពួកគេរៀបរាប់អ្វីដែលពួកគេបានរកឃើញ សូមសួរថា ៖

- **ដោយសារយើងដឹងថា ព្រះមិនផ្លាស់ប្តូរ ហើយថាទ្រង់បានសម្តែងនូវអព្ភូតហេតុនៅក្នុងចំណោមកូនចៅរបស់ទ្រង់ពីពេលមុនៗមក តើយើងអាចដឹងអ្វីខ្លះអំពីព្រះឆន្ទៈរបស់ទ្រង់ដើម្បីសម្តែងអព្ភូតហេតុនៅក្នុងជីវិតរបស់យើងសព្វថ្ងៃនេះ ? (ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាក្តី ក៏ពួកគេគួរបង្ហាញនូវគោលការណ៍ខាងក្រោមនេះ ៖ **ព្រះតែងតែបានសម្តែងនូវអព្ភូតហេតុ ហើយដោយសារទ្រង់មិនផ្លាស់ប្តូរ នោះទ្រង់នៅតែធ្វើនូវអព្ភូតហេតុស្របតាមសេចក្តីជំនឿរបស់យើង ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀនហើយអ្នកអាចណែនាំថា សិស្សគួរសរសេរវានៅក្បែរ មរមន ៩:១៩–២០ នៅក្នុងព្រះគម្ពីររបស់គេ) ។**

សូមពន្យល់ថា យើងអាចទទួលបាននូវអំណាចដ៏ប្រកបដោយអព្ភូតហេតុនៃព្រះនៅក្នុងជីវិតរបស់យើងតាមរបៀបជាច្រើន ។ ដើម្បីជួយសិស្សឲ្យពិចារណាពីរបៀបដែលព្រះនៅតែជាព្រះនៃអព្ភូហេតុ សូមឲ្យសិស្សម្នាក់អានន្ទវសេចក្តីថ្លែងការណ៍ខាងក្រោមដោយសិស្សើរ ស៊ីឌនី រិកដុន នៃគណៈប្រធានថ្នាក់បឋមសិក្សាទូទៅ ៖

« ខ្ញុំបានរៀន . . . ថាព្រះអម្ចាស់នឹងជួយយើងនៅគ្រប់ផ្នែកនៃជីវិតរបស់យើង នៅពេលយើងព្យាយាមបម្រើដល់ទ្រង់ ហើយធ្វើតាមព្រះឆន្ទៈរបស់ទ្រង់ ។

« ខ្ញុំជឿថា យើងទាំងអស់គ្នាអាចថ្លែងជាសាក្សីដល់អព្ភូតហេតុដ៏តូចៗទាំងនេះ ។ យើងដឹងថា កូនក្មេងតូចៗដែលអធិស្ឋានសុំជំនួយដើម្បីស្វែងរករបស់ដែលបាត់ ហើយក៏រកឃើញរបស់នោះ ។ យើងដឹងថាយុវវ័យដែលបង្កើនសេចក្តីក្លាហានដើម្បីឈរជាសាក្សីម្នាក់ចំពោះព្រះ និងទទួលបានព្រះហស្តសជាជំនួយរបស់ទ្រង់ ។ យើងស្គាល់មិត្តភក្តិដែលបង់ដង្វាយមួយភាគក្នុងដប់របស់ពួកគេ នូវប្រាក់ដែលនៅសេសសល់ ហើយបន្ទាប់មក តាមរយៈអព្ភូតហេតុ ពួកគេឃើញថាខ្លួនគេអាចបង់ថ្លៃសាលារបស់គេ ឬថ្លៃជួលរបស់គេ ឬអាចមានអាហារសម្រាប់គ្រួសាររបស់គេ ។ យើងអាចចែកចាយបទពិសោធន៍នៃការអធិស្ឋានដែលបានឆ្លើយតប និងពរជ័យនៃបព្វជិតភាពដែលបានផ្តល់នូវការជម្រុញទឹកចិត្ត នាំមកនូវការលួងលោម ឬស្តារបនាសុខភាពឡើងវិញ ។ អព្ភូតហេតុប្រចាំថ្ងៃទាំងនេះមកជាមួយយើងដោយព្រះហស្តរបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់យើង » (« A God of Miracles » *Ensign,* ខែ ឧសភា ឆ្នាំ ២០០១, ទំព័រ ១២) ។

- **តើបទពិសោធន៍អ្វីដែលអ្នកបានមានដែលបញ្ជាក់ថា ព្រះនៅតែជាព្រះនៃអព្ភូហេតុដដែល ?**

មរមន ៩:២១–៣៧

លោកម៉ូរ៉ូណៃទូន្មានដល់អ្នកមិនជឿទាំងឡាយឲ្យជឿលើព្រះយេស៊ូវគ្រីស្ទ ហើយអធិស្ឋាននៅក្នុងព្រះនាមរបស់ទ្រង់

សូមឲ្យសិស្សម្នាក់អាន មរមន ៩:២១ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលលោកម៉ូរ៉ូណៃបានបង្រៀនអំពីការអធិស្ឋានទៅរកព្រះវរបិតាសួគ៌ ។

- តើសេចក្តីសន្យាអ្វីដែលលោកម៉ូរ៉ូណៃបានផ្តល់ ? (ចម្លើយរបស់សិស្សគួរឆ្លុះបញ្ចាំងអំពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងអធិស្ឋានដោយសេចក្តីជំនឿ និងនៅក្នុងព្រះនាមនៃព្រះគ្រីស្ទ នោះព្រះវរបិតាសួគ៌នឹងប្រទានដល់យើងនូវអ្វីដែលយើងសុំ**) ។

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃការអធិស្ឋាន « នៅក្នុងព្រះនាមនៃព្រះគ្រីស្ទ » សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោម ៖

« យើងអធិស្ឋាននៅក្នុងព្រះនាមនៃព្រះគ្រីស្ទ នៅពេលគំនិតរបស់យើងគឺជាគំនិតរបស់ព្រះគ្រីស្ទ ហើយបំណងរបស់យើងគឺជាបំណងរបស់ព្រះគ្រីស្ទ —នៅពេលព្រះបន្ទូលរបស់ទ្រង់ស្ថិតនៅជាមួយយើង (យ៉ូហាន ១៥:៧) ។ នោះយើងនឹងសុំអ្វីដែលសមរម្យសម្រាប់ព្រះប្រទានឲ្យយើង ។ ការអធិស្ឋានជាច្រើនបន្តមិនទាន់បានឆ្លើយ ដោយសារពួកវាមិនបានធ្វើឡើងនៅក្នុងព្រះនាមនៃព្រះគ្រីស្ទសោះឡើយ ពួកវាមិនបានតំណាងឲ្យគំនិតរបស់ទ្រង់ទោះតាមរបៀបណាក្តី ជ្រុយទៅវិញចេញពីបំណងផ្ទាល់ខ្លួននៃដួងចិត្តរបស់មនុស្ស » (Bible Dictionary, “Prayer”) ។

អ្នករាចសួរសំណួរខាងក្រោមនេះ ៖

- តើយើងអាចធានាថា អ្វីៗដែលយើងអធិស្ឋានសុំ ឆ្លុះបញ្ចាំងពីអ្វីដែលព្រះអម្ចាស់មានព្រះទ័យចង់បានពីយើងដែរឬទេ ?
- តើនៅពេលណាដែលអ្នកបានឃើញសេចក្តីសន្យាដែលមាននៅក្នុង មរមន ៩:២១ ត្រូវបានបំពេញ ? (អ្នករាចឲ្យពេលដល់សិស្សគិតអំពីសំណួរនេះ មុនពេលពួកគេឆ្លើយ) ។

សូមសង្ខេប មរមន ៩:២២–២៥ ដោយការពន្យល់ថា ព្រះអង្គសង្គ្រោះបានសន្យាដល់ពួកសិស្សរបស់ទ្រង់នូវពរជ័យជាច្រើន នៅពេលទ្រង់បានបញ្ជូនពួកគេចេញទៅបង្រៀនដំណឹងល្អ ។ សូមឲ្យសិស្សមើលត្រួសៗក្នុង មរមន ៩:២២–២៥ ហើយរកមើលពរជ័យទាំងនោះមួយចំនួន ។

- តើវាមានន័យចំពោះអ្នកថា ព្រះអង្គសង្គ្រោះនឹង « បញ្ជាក់ពាក្យ | របស់ទ្រង់ | ទាំងអស់ » ? (មរមន ៩:២៥) ។

សូមឲ្យសិស្សអាន មរមន ៩:២៧–២៩ ស្ងាត់ៗ ដោយរកមើលលក្ខណៈ និងសកម្មភាពដែលនឹងជួយពួកគេឲ្យសក្តិសមនឹងទទួលបានជំនួយពីព្រះ ។ អ្នករាចសុំឲ្យសិស្សសរសេរសេចក្តីសង្ខេបនៃខគម្ពីរទាំងនេះនៅក្នុងសៀវភៅសរសេរ ឬក្នុងកំណត់ហេតុការសិក្សាព្រះគម្ពីរ ។

ដើម្បីបញ្ចប់មេរៀននេះ សូមសង្ខេប មរមន ៩:៣០–៣៤ ដោយការប្រាប់សិស្សថា លោកម៉ូរ៉ូណៃបានបារម្ភថា មនុស្សខ្លះនៅក្នុងថ្ងៃចុងក្រោយនឹងបដិសេធសារលិខិតនៃព្រះគម្ពីរមរមន ដោយសារតែភាពមិនឥតខ្ចោះនៃអ្នកទាំងឡាយដែលសរសេរវា និងដោយសារភាសាដែលវាបានសរសេរនោះ ។ សូមឲ្យសិស្សម្នាក់អាន មរមន ៩:៣៥–៣៧ ឮៗ ។ សូមឲ្យសិស្សក្នុងមើលតាម ដោយរកមើលមូលហេតុដែលលោកម៉ូរ៉ូណៃ និងអ្នកផ្សេងទៀតបានអធិស្ឋានសូមឲ្យព្រះគម្ពីរមរមននឹងចេញមកនៅក្នុងជំនាន់ចុងក្រោយ ។ (ដូច្នេះកូនចៅនៃបងប្អូនរបស់ពួកគេ សាសន៍លេមិន អាចត្រូវបានស្តារឡើងវិញទៅដល់ « ចំណេះដឹងនៃព្រះគ្រីស្ទ » ហើយដល់សេចក្តីសញ្ញាដែលព្រះបានធ្វើជាមួយនឹងវង្សអ៊ីស្រាអែល) ។

ដើម្បីជួយសិស្សឲ្យសង្ខេបអ្វីដែលពួកគេបានរៀនថ្ងៃនេះ សូមសួរសំណួរដូចខាងក្រោមនេះ ៖

- តើព្រះគម្ពីរមរមនគឺជាភស្តុតាងថា ព្រះគឺជាព្រះនៃអព្ភូហេតុ ហើយថាទ្រង់ឆ្លើយតបការអធិស្ឋានដោយរបៀបណា ?
- តើសេចក្តីពិតអ្វីដែលអ្នកបានរៀននៅថ្ងៃនេះ ដែលនឹងមានឥទ្ធិពលដល់ការអធិស្ឋានផ្ទាល់ខ្លួនរបស់អ្នក ?

ការរំឭកគម្ពីរមរមន

សូមចំណាយពេលខ្លះដើម្បីជួយសិស្សឲ្យរំឭកគម្ពីរមរមន ។ សូមឲ្យពួកគេគិតអំពីអ្វីដែលពួកគេបានរៀនពីគម្ពីរនេះ ទាំងនៅក្នុងថ្នាក់សិក្ខាសាលា និងនៅក្នុងការសិក្សាវគ្គគម្ពីរផ្ទាល់ខ្លួនរបស់គេ ។ ប្រសិនបើចាំបាច់ សូមឲ្យពួកគេសង្ខេបដោយខ្លីៗអំពីសេចក្តីសង្ខេបជំពូកខ្លះនៅក្នុងមរមន ដើម្បីជួយពួកគេឲ្យចងចាំ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីមួយពីគម្ពីរមរមន ដែលបំផុសគំនិតដល់ពួកគេ ឬដែលបានជួយដល់ពួកគេឲ្យមានសេចក្តីជំនឿកាន់តែខ្លាំងទៅលើព្រះយេស៊ូវគ្រីស្ទ ។

សេចក្តីផ្តើមអំពី

គម្ពីរអេធើរ

ហេតុអ្វីបានជាត្រូវសិក្សាគម្ពីរនេះ ?

នៅពេលសិស្សសិក្សាគម្ពីរអេធើរ ពួកគេនឹងរៀនអំពីពួកសាសន៍យ៉ារេឌ —ប្រជាជនមួយក្រុមដែលបានធ្វើដំណើរទៅប៉ែកខាងលិច និងបានរស់នៅទីនោះអស់រយៈពេលជាច្រើនសតវត្សរ៍ មុនពេលប្រជាជនលីហៃទៅដល់ទីនោះ ។ សិស្សនឹងរៀនពីគោលការណ៍ដ៏សំខាន់ៗអំពីការអធិស្ឋាន វិវរណៈ និងទំនាក់ទំនងរវាងការអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ និងការទទួលបានចំណេះដឹងខាងវិញ្ញាណ ។ ពួកគេក៏នឹងរៀនអំពីតួនាទីរបស់ព្យាការីក្នុងការបញ្ចុះបញ្ចូលមនុស្សឲ្យប្រែចិត្ត និងអំពីលទ្ធផលដែលបានកើតចំពោះអ្នកដែលបដិសេធព្រះយេស៊ូវគ្រីស្ទ និងព្យាការីរបស់ទ្រង់ ។

តើនរណាជាអ្នកនិពន្ធគម្ពីរនេះ ?

លោកម៉ូរ៉ូណៃបានសង្ខេបគម្ពីរនេះពីផ្ទាំងមាសទាំង ២៤ ដែលហៅថាផ្ទាំងអេធើរ ។ គម្ពីរនេះត្រូវបានហៅតាមឈ្មោះព្យាការីអេធើរ ដែលជាព្យាការីចុងក្រោយនៃពួកសាសន៍យ៉ារេឌ ហើយដែលបានបង្កើតកំណត់ត្រានៃប្រវត្តិសាស្ត្ររបស់ពួកគេ (សូមមើល អេធើរ ១៥:៣៣–៣៤) ។ ប្រហែលជា ៥០០ ឆ្នាំ មុនពេលលោកម៉ូរ៉ូណៃបានសង្ខេបបញ្ជីពិសិដ្ឋរបស់លោក ប្រជាជនលីមហៃខ្លះបានរកឃើញផ្ទាំងអេធើរ នៅពេលពួកគេស្វែងរកដែនដីសាវ៉ាហិមឡា (សូមមើល ម៉ូសាយ ៨:៧–១១; អេធើរ ១:២) ។ ព្យាការីសាសន៍នីហៃ និងអ្នករក្សាកំណត់ត្រាទាំងឡាយបានប្រគល់ផ្ទាំងអេធើរបន្តគ្នា រហូតដល់ផ្ទាំងទាំងនេះបានមកដល់ជាកម្មសិទ្ធិរបស់លោកម៉ូរ៉ូណៃ ។ លោកម៉ូរ៉ូណៃបានមានប្រសាសន៍ថា លោកមិនបានបញ្ចូលសូម្បីតែ « មួយភាគរយ » នៃកំណត់ត្រានេះនៅក្នុងសេចក្តីសង្ខេបរបស់លោកឡើយ (អេធើរ ១៥:៣៣) ។

តើគម្ពីរនេះត្រូវបានសរសេរដល់នរណា ហើយតើហេតុអ្វី ?

ដោយសារម៉ូរ៉ូណៃបានសង្ខេបផ្ទាំងអេធើរ ក្រោយពីពួកសាសន៍យ៉ារេឌ និងប្រជាជនរបស់លោកផ្ទាល់ត្រូវបានបំផ្លាញ លោកបានមានបំណងចង់ឲ្យគម្ពីរនេះបានមកដល់ប្រជាជននៅក្នុងជំនាន់របស់យើង ។ លោកម៉ូរ៉ូណៃបានទូន្មានដល់ពួកសាសន៍ដទៃនៅថ្ងៃចុងក្រោយឲ្យប្រែចិត្ត បម្រើដល់ព្រះ និងបោះបង់ចោលនូវបក្សព័ន្ធសម្ងាត់ (សូមមើល អេធើរ ២:១១–១២; ៨:២៣) ។ លោកក៏បានកត់ត្រានូវព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទដែលបានអញ្ជើញដល់ « អស់អ្នករាល់គ្នានៅចុងផែនដីអើយ » ឲ្យប្រែចិត្ត មករកទ្រង់ ហើយទទួលបានចំណេះដឹងដែលបានបង្ហាក់ពីលោកិយ ដោយសារតែការឥតជំនឿ (សូមមើល អេធើរ ៤:១៣–១៨) ។

តើនៅពេលណា និងនៅកន្លែងណាដែលគម្ពីរនេះត្រូវបាននិពន្ធ ?

លោកអេធើរបានបញ្ចប់កំណត់ត្រានៃប្រជាជនរបស់លោកក្នុងអំឡុងពេលនិងក្រោយពេលសង្គ្រាមដ៏ធំចុងក្រោយដែលបានសម្លាប់មនុស្សទាំងអស់ ប៉ុន្តែពួកសាសន៍យ៉ារេឌពីរនាក់បាននៅរស់ —ខ្លួនលោក និងកូរីអានទុមើរ (សូមមើល អេធើរ ១៣:១៣–១៤; ១៥:៣២–៣៣) ។ បន្ទាប់មក លោកបានលាក់ទុកកំណត់ត្រារបស់លោក « តាមរបៀបម្យ៉ាងដែលប្រជាជនលីមហៃបានប្រទះឃើញ » (អេធើរ ១៥:៣៣; សូមមើលផងដែរ ម៉ូសាយ ៨:៧–៩) ។ លោកម៉ូរ៉ូណៃបានសង្ខេបបញ្ជីអេធើរនៅរវាងឆ្នាំ ៤០០ ក្រោយគ្រិស្តសករាជ និងឆ្នាំ ៤២១ ក្រោយគ្រិស្តសករាជ (សូមមើល មរមន ៨:៣–៦; ម៉ូរ៉ូណៃ ១០:១) ។ លោកម៉ូរ៉ូណៃបានសរសេរថា ពួកសាសន៍យ៉ារេឌត្រូវបានបំផ្លាញនៅក្នុង « ផ្ទៃដែនដីខាងជើងនេះ » (អេធើរ ១:១) ដោយបង្ហាញថាលោកអាចបាននៅក្នុងដែនដី ដែលពួកគេត្រូវបានបំផ្លាញ នៅពេលលោកបានសង្ខេបកំណត់ត្រារបស់ពួកគេ ។

តើគម្ពីរនេះ មានលក្ខណៈពិសេសអ្វីខ្លះ?

មិនដូចជាគម្ពីរផ្សេងទៀតនៅក្នុងព្រះគម្ពីរមរមនឡើយ គម្ពីរអេធើរមិនបានទាក់ទងទៅនឹងប្រវត្តិសាស្ត្រនៃកូនចៅរបស់លីហៃទេ ។ គម្ពីរនេះពណ៌នាពីរបៀបដែលពួកសាសន៍យ៉ារេឌបានចេញពីបាបិល ហើយបានធ្វើដំណើរទៅដែនដីសន្យា ដែលនៅទីបញ្ចប់ពួកគេត្រូវបានបំផ្លាញ ។ គម្ពីរអេធើរនេះ គឺជាសាក្សីទីពីរចំពោះកំណត់ត្រានៃពួកសាសន៍នីហៃ ដោយបង្ហាញថា « សាសន៍ណាក៏ដោយដែលនឹងយកបានដែនដីនេះ [ដែនដីសន្យា] គឺត្រូវបម្រើព្រះ បើពុំនោះសោតទេ ពួកគេនឹងត្រូវកំចាត់ចេញ . . . កាលណាពួកគេទុំសុសនៅក្នុងអំពើទុច្ចរិត » (អេធើរ ២:៩) ។

ការយោងមកជាសាច់ឈាមរបស់ព្រះយេស៊ូវគ្រីស្ទទៅជួបនឹងបងប្អូនប្រុសរបស់យ៉ារេឌ « រាប់នៅក្នុងពេលដ៏អស្ចារ្យបំផុតនៅក្នុងប្រវត្តិសាស្ត្រដែលបានកត់ត្រាទុក » ។ ហេតុការណ៍នេះ « បានធ្វើឲ្យបងប្រុសរបស់យ៉ារេឌជាព្យាការីម្នាក់នៅក្នុងព្យាការីដ៏អស្ចារ្យបំផុតរបស់ព្រះជារៀងរហូត » (ដៃហ្វ្រី អ័រ ហូឡិន *Christ and the New Covenant : The Messianic Message of the Book of Mormon* [ឆ្នាំ ១៩៩៧], ទំព័រ ១៧) ។ ដំណើររឿងរបស់ម៉ូរ៉ូណៃអំពីការនិមិត្តនេះ ផ្តល់ជាសាក្សីមួយដ៏មានអំណាចអំពីព្រះយេស៊ូវគ្រីស្ទ និងបង្ហាញពីការបង្រៀនដ៏ប្លែកអំពីលក្ខណៈនៃរាងកាយខាងវិញ្ញាណ (សូមមើល អេធើរ ៣:៤–១៧) ។

គម្រោង

អេធើរ ១–៣ ព្រះអម្ចាស់ក្បាតាសារបស់ពួកសាសន៍យ៉ារេឌនៅឯប៉មបាបិល ហើយសន្យាថានឹងដឹកនាំពួកគេទៅកាន់ដែនដីដម្រើសមួយ និងធ្វើឲ្យពួកគេក្លាយជាសាសន៍មួយដ៏ធំអស្ចារ្យ ។ ទ្រង់ដឹកនាំពួកគេទៅកាន់មាត់សមុទ្រ និងណែនាំពួកគេឲ្យធ្វើសំពៅសម្រាប់ការធ្វើដំណើររបស់ពួកគេ ឆ្លងកាត់មហាសមុទ្រ ។ ព្រះអម្ចាស់បង្ហាញអង្គទ្រង់ និង « ការណ៍ទាំងអស់ » (អេធើរ ៣:២៦) ដល់បងប្រុសរបស់យ៉ារេឌ ។

អេធើរ ៤–៥ ម៉ូរ៉ូណៃបិទត្រាការសរសេររបស់បងប្រុសរបស់យ៉ារេឌ ។ លោកកត់ត្រាពីការពន្យល់របស់ព្រះយេស៊ូវគ្រីស្ទថា កំណត់ត្រាទាំងនេះនឹងត្រូវបានបង្ហាញដល់អស់អ្នកណាដែលអនុវត្តសេចក្តីជំនឿលើទ្រង់ ។ លោកម៉ូរ៉ូណៃបង្រៀនថា សាក្សីទាំងបីនៅថ្ងៃចុងក្រោយនឹងចូលរួមជាមួយនឹងព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធក្នុងការធ្វើទីបន្ទាល់អំពីព្រះគម្ពីរមរមន ។

អេធើរ ៦–១១ ពួកសាសន៍យ៉ារេឌធ្វើដំណើរទៅកាន់ដែនដីសន្យា ។ ប្រជាជនបានមានកំណើនកើនឡើង ហើយចាប់ផ្តើមរស់នៅពេញទូទាំងដែនដី ។ ចំណងនៃពួកសុចរិត និងស្តេចទុច្ចរិតបានគ្រប់គ្រងលើជំនាន់ជាច្រើន ។ ពួកសាសន៍យ៉ារេឌស្ទើរតែត្រូវបានបំផ្លាញបង់ទាំងស្រុង ដោយសារតែបក្សព័ន្ធសម្ងាត់ ។ ព្យាការីជាច្រើនព្រមានប្រជាជនឲ្យប្រែចិត្ត ប៉ុន្តែប្រជាជនបដិសេធចំពោះការណ៍នេះ ។

អេធើរ ១២ លោកម៉ូរ៉ូណៃបង្រៀនថា សេចក្តីជំនឿតម្រូវឲ្យមាន មុនពេលបុគ្គលម្នាក់អាចទទួលបានសាក្សីខាងវិញ្ញាណ ។ លោកបង្ហាញដល់ព្រះអម្ចាស់នូវការបារម្ភរបស់លោកថា ពួកសាសន៍ដទៃនាថ្ងៃអនាគតនឹងសើចចំអកដល់ភាពទន់ខ្សោយរបស់លោក ក្នុងការសរសេរនូវបញ្ជីពិសិដ្ឋ ហើយលោកកត់ត្រានូវចម្លើយរបស់ព្រះអម្ចាស់ដល់លោក ។ លោកម៉ូរ៉ូណៃជាស់តឿនដល់អ្នកអាននៅថ្ងៃចុងក្រោយឲ្យស្វែងរកព្រះយេស៊ូវគ្រីស្ទ ។

អេធើរ ១៣–១៥ លោកម៉ូរ៉ូណៃពិភាក្សាពីការព្យាករណ៍របស់លោកអេធើរអំពីទីក្រុងយេរូសាឡិមថ្មី ។ ក្រោយពីពួកសាសន៍យ៉ារេឌបដិសេធលោកអេធើរ លោកធ្វើជាសាក្សី និងកត់ត្រានូវសេចក្តីបំផ្លិចបំផ្លាញទាំងមូលរបស់ពួកគេ ។

អេធើរ ១

សេចក្តីផ្តើម

លោកម៉ូរ៉ូណៃបានសង្ខេបគម្ពីរអេធើរពីផ្ទាំងមាសទាំង ២៤ ដែលបានរកឃើញដោយក្រុមស្រាវជ្រាវដែលបានបញ្ជូនទៅដោយស្តេចលីមហៃ (សូមមើល ម៉ូសាយ ៨:៧–១១) ។ ផ្ទាំងទាំងនេះ បានរួមមាននូវប្រវត្តិសាស្ត្រនៃប្រជាជនសាសន៍យ៉ារេឌ ។ ដំណើររឿងនៃពួកសាសន៍យ៉ារេឌចាប់ផ្តើមដោយលោកយ៉ារេឌ និងបងប្រុសរបស់លោកក្នុងការស្វែងរកសេចក្តីមេត្តាករុណា និងការដឹកនាំពីព្រះអម្ចាស់សម្រាប់គ្រួសារ និងមិត្តទាំងឡាយរបស់លោក នៅពេលព្រះអម្ចាស់បានបំភាន់ភាសារបស់ប្រជាជននៅឯប៉ែមបាបិល (សូមមើល លោកុប្បត្តិ ១១) ។ ដោយសារបងប្រុសរបស់យ៉ារេឌបានអធិស្ឋានទៅរកព្រះអម្ចាស់ដោយស្មោះត្រង់ នោះព្រះអម្ចាស់បានក្សាភាសារបស់យ៉ារេឌ បងប្រុសរបស់លោក និងគ្រួសាររបស់លោក និងមិត្តទាំងឡាយ ។ ព្រះអម្ចាស់បានប្រកាសថា ទ្រង់នឹងដឹកនាំពួកគេទៅកាន់ដែនដីសន្យា ជាកន្លែងដែលពួកគេនឹងក្លាយជាជាតិសាសន៍ដ៏អស្ចារ្យ ។

យោបល់សម្រាប់ការបង្រៀន

អេធើរ ១:១–៣២

លោកម៉ូរ៉ូណៃកត់ត្រាពីពង្សាវតារនៃលោកអេធើរ រហូតដល់ជំនាន់របស់យ៉ារេឌនៅឯប៉ែមបាបិល

ដើម្បីជួយសិស្សឲ្យចងចាំពីប្រភពដែលគម្ពីរអេធើរបានចេញមក សូមរំឭកពួកគេអំពីការសង្ខេបនៃការធ្វើដំណើរនៅក្នុង ម៉ូសាយ ៧–២៤ នៅក្នុងឧបសម្ព័ន្ធនៃសៀវភៅណែនាំនេះ ។ សូមឲ្យពួកគេយោងទៅការធ្វើដំណើរទី ៤ ៖ បំណងដើម្បីស្វែងរកដែនដីសាវ៉ាហិមឡា ។ បន្ទាប់មក សូមឲ្យពួកគេរកមើលអ្វីដែលប្រជាជនរបស់លីមហៃបានរកឃើញនៅក្នុងការធ្វើដំណើរនេះ ។ បន្ទាប់មក សូមឲ្យពួកគេបើកទៅទំព័រទីមួយនៃគម្ពីរអេធើរ ។ សេចក្តីសង្ខេបនៅខាងក្រោមចំណងជើងពន្យល់ថា គម្ពីរអេធើរ ត្រូវបានដកស្រង់ចេញពីផ្ទាំងទាំង ២៤ ដែលបានរកឃើញដោយប្រជាជនលីមហៃ ។



សេចក្តីសង្ខេបនៃការធ្វើដំណើរនៅក្នុង ម៉ូសាយ ៧–២៤

សូមពន្យល់ថា ក្រោយពីលោកម៉ូរ៉ូណៃបានបញ្ចប់កំណត់ត្រារបស់ឪពុកលោក លោកបានសរសេរនូវសេចក្តីសង្ខេប ឬវគ្គសង្ខេបនៃកំណត់ត្រាដែលមាននៅក្នុងផ្ទាំងមាសទាំង ២៤ ។ កំណត់ត្រានេះរួមមានប្រវត្តិសាស្ត្រនៃពួកសាសន៍យ៉ារេឌ ដែលបានរស់នៅលើទ្វីបអាមេរិក មុនជំនាន់ពួកសាសន៍នីហ្វៃ និងសាសន៍លេមិន ។ សូមឲ្យសិស្សអានអេធើរ ១:១–៥ ដោយស្ងាត់ៗដោយរកមើលអ្វីដែលលោកម៉ូរ៉ូណៃបានជ្រើសរើសដើម្បីបញ្ចូលនៅក្នុងសេចក្តីសង្ខេបរបស់លោកអំពីកំណត់ត្រានៃពួកសាសន៍យ៉ារេឌ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

ប្រសិនបើអ្នកមានរូបភាពប៉ែមបាបិល សូមគិតពីការដាក់តាំងវាបង្ហាញ ។ សូមឲ្យសិស្សសង្ខេបអ្វីដែលពួកគេដឹងអំពីប៉ែមនេះ ដោយសំដៅទៅលើ អេធើរ ១:៥ និងអ្វីដែលបានកើតឡើងដល់អស់អ្នកដែលបានព្យាយាមកសាងវា ។ (វាត្រូវបានហៅថា ប៉ែមបាបិល ។ ព្រះអម្ចាស់បានបំភាន់ភាសារបស់ប្រជាជន ដែលបានព្យាយាមកសាងវា និងបានកម្ចាយវាដោយសារតែអំពើទុច្ចរិតរបស់ពួកគេ ; សូមមើល លោកុប្បត្តិ ១១:១–៩) ។

ដើម្បីជួយសិស្សឲ្យយល់ពីទំនាក់ទំនងរវាងប្រវត្តិសាស្ត្ររបស់ប្រជាជនយ៉ារេឌ និងប្រវត្តិសាស្ត្ររបស់ប្រជាជននីហ្វៃ អ្នកគួរប្រាប់ឲ្យពួកគេបើកទៅកាលប្បវត្តិនៅលើប្រដាប់សៀតសៀវភៅនៃព្រះគម្ពីរមរមន (លេខកូដ ៣២៣៣៦) ។ សូមពន្យល់ថា លោកម៉ូរ៉ូណៃបានចាប់ផ្តើមដំណើររឿងរបស់លោកអំពីប្រវត្តិសាស្ត្ររបស់ប្រជាជនយ៉ារេឌ ដោយការកត់ត្រាពូជរបស់ព្យាការីអេធើរ ដែលបានសរសេរប្រវត្តិសាស្ត្រនៅលើផ្ទាំងមាស ២៤ ។ លោកម៉ូរ៉ូណៃបានកត់ត្រាពូជពង្សរបស់អេធើរ ត្រឡប់ទៅរកបុរសម្នាក់ឈ្មោះថា យ៉ារេឌ ដែលបានរស់នៅអំឡុងពេលនៃប៉ែមបាបិល ។

អេធើរ ១:៣៣–៤៣

តាមរយៈការអធិស្ឋានរបស់បងប្រុសយ៉ារេឌ នោះគ្រួសារ និងមិត្តទាំងឡាយរបស់លោកបានទទួលសេចក្តីមេត្តា និងការដឹកនាំ

សូមសួរសិស្ស ថាតើមានពួកគេណាខ្លះធ្លាប់បានទៅកន្លែងណាមួយ ដែលពួកគេមិនអាចយល់ភាសាដែលប្រជាជននៅជុំវិញខ្លួននិយាយដែរទេ ។ សូមឲ្យពួកគេចែកចាយនូវអារម្មណ៍ដែលពួកគេបានមាននៅក្នុងស្ថានភាពនោះ ។ បន្ទាប់មក សូមឲ្យពួកគេស្រមៃថាតើប្រជាជននៅជុំវិញប៉ែមបាបិលបានមានអារម្មណ៍យ៉ាងណា នៅពេលពួកគេបានដឹងថា ភាសារបស់មនុស្សគ្រប់គ្នាត្រូវបានបំភាន់នោះ ។ សូមឲ្យពួកគេសញ្ជឹងគិតដោយស្ងាត់ៗអំពីសំណួរដូចខាងក្រោមនេះ ៖

- ប្រសិនបើអ្នកស្ថិតនៅក្នុងស្ថានភាពនោះ តើទំនាក់ទំនងរបស់អ្នកណាដែលអ្នកនឹងនឹកខ្លាំងបំផុត ? ហេតុអ្វី ?

សូមឲ្យសិស្សអាន អេធើរ ១:៣៣–៣៤ ដោយស្ងាត់ស្ងៀម ។ មុនពេលពួកគេអាន សូមឲ្យពួកគេរកមើល (១) អ្នកដែលលោកយ៉ារេឌចង់អាចនិយាយជាមួយ និង (២) របៀបដែលលោកបានស្នើឡើងដើម្បីដោះស្រាយបញ្ហា ។ (លោកចង់អាចនិយាយជាមួយនឹងគ្រួសាររបស់លោក ហើយលោកបានសុំឲ្យបងប្រុសរបស់លោកអធិស្ឋានថា ភាសារបស់ពួកគេនឹងមិនត្រូវបានបំភាន់ឡើយ) ។ ក្រោយពីពួកគេរៀបរាប់អ្វីដែលពួកគេបានរកឃើញ សូមសួរ ៖

- តើឃ្លា « អំពាវនាវដល់ព្រះអម្ចាស់ » មានអត្ថន័យយ៉ាងណាដល់អ្នក ?
- ចេញពី អេធើរ ១:៣៣–៣៤ តើអ្នកបានរៀនអ្វីខ្លះអំពីអារម្មណ៍របស់លោកយ៉ារេឌអំពី បងប្រុសរបស់លោក និងអំពីការអធិស្ឋានរបស់បងប្រុសលោក ?

សូមបែងចែកសិស្សជាគូៗ ។ ចំពោះគូនីមួយៗ សូមឲ្យសិស្សប្តូរវេនគ្នាអានឮៗពីអេធើរ ១:៣៥–៤២ ។ សូមឲ្យពួកគេរកមើលការអធិស្ឋានរបស់បងប្រុសយ៉ារេឌ និងរកមើលចម្លើយរបស់ព្រះអម្ចាស់ចំពោះការអធិស្ឋានទាំងនោះ ។ នៅពេលសិស្សបានមានពេលគ្រប់គ្រាន់ក្នុងការអានហើយ សូមសួរ ៖

- តើអ្វីដែលបំផុសគំនិតអ្នកអំពីការអធិស្ឋានរបស់បងប្រុសយ៉ារេឌ ?
- តើព្រះអម្ចាស់បានឆ្លើយតបទៅនឹងការអធិស្ឋានរបស់បងប្រុសយ៉ារេឌយ៉ាងដូចម្តេច ?
- តើយើងអាចរៀនគោលការណ៍អ្វីខ្លះ ពីរបៀបដែលបងប្រុសយ៉ារេឌបានអធិស្ឋាន និងរបៀបដែលព្រះអម្ចាស់បានឆ្លើយតបចំពោះការអធិស្ឋានរបស់លោក ? (នៅពេលសិស្សចែកចាយនូវគំនិតរបស់ពួកគេ សូមលើកទឹកចិត្តពួកគេឲ្យពិចារណាពីសេចក្តីមេត្តាករុណារបស់ព្រះវរបិតាសួគ៌ និងសេចក្តីស្រឡាញ់របស់ទ្រង់ចំពោះពួកគេ ។ សូមសរសេរគោលការណ៍ខាងក្រោមនេះនៅលើក្តារខៀន ៖ ***នៅពេលយើងអំពាវនាវដល់ព្រះដោយសេចក្តីជំនឿគ្រប់ពេលវេលា នោះទ្រង់នឹងមានសេចក្តីមេត្តាករុណាមកដល់យើង ។***)

មុនចាប់ផ្តើមបង្រៀន សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖ (ឬ អ្នកអាចចែកជាក្រដាស ឬអានវាឮៗយឺតៗដើម្បីឲ្យសិស្សអាចកត់ត្រាវាបាន) ។

តើការអំពាវនាវដល់ព្រះវរបិតាសួគ៌ខុសពីការគ្រាន់តែ « ទូលក្នុងការអធិស្ឋាន » តាមរបៀបណាខ្លះ ?

តើនៅពេលណាដែលអ្នកបានមានអារម្មណ៍ដឹងអំពីសេចក្តីមេត្តារបស់ព្រះវរបិតាសួគ៌នៅក្នុងចម្លើយចំពោះការអធិស្ឋាន ? តើនៅពេលណាដែលសមាជិកគ្រួសារ ឬមិត្តភក្តិបានប្រាប់អ្នកអំពីសេចក្តីមេត្តារបស់ព្រះវរបិតាសួគ៌នៅក្នុងចម្លើយចំពោះការអធិស្ឋាន ?

តើចម្លើយរបស់ព្រះចំពោះការអធិស្ឋានរបស់យើង បង្រៀនយើងអ្វីខ្លះអំពីព្រះទ័យរបស់ទ្រង់ចំពោះយើង ?

តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឲ្យការអធិស្ឋានរបស់អ្នកឲ្យកាន់តែមានអត្ថន័យ ?

សូមឲ្យសិស្សឆ្លើយនឹងសំណួរទាំងនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ ។ អ្នកអាចផ្តល់ឱកាសមួយដល់ពួកគេដើម្បីចែកចាយនូវអ្វីដែលពួកគេបានសរសេរ ។ សូមធ្វើទីបន្ទាល់ថា អ្នកដឹងថា ព្រះវរបិតាសួគ៌ស្រឡាញ់យើង ហើយចង់ប្រទានពរដល់យើង នៅពេលយើងអំពាវនាវដល់ទ្រង់ជាទៀងទាត់ ។

សូមពន្យល់ថា ដំណើររឿងនៅក្នុង អេធើរ ១ អាចផ្តល់នូវការយល់ជ្រៅបន្ថែមទៀតដល់យើងអំពីសេចក្តីស្រឡាញ់របស់ព្រះចំពោះយើង និងពរជ័យទាំងឡាយដែលនឹងមកតាមរយៈការអធិស្ឋាន ។ សូមឲ្យសិស្សរំឭក អេធើរ ១:៣៤, ៣៦, ៣៨ ដោយស្ងាត់ៗ ដោយរកមើលអ្វីដែលយ៉ារេឌបានសុំឲ្យបងប្រុសរបស់លោកទូលសុំនៅក្នុងការអធិស្ឋានរបស់គាត់ ។ សូមឲ្យសិស្សម្នាក់ធ្វើជាអ្នកកត់ត្រា និងសរសេរនូវចម្លើយរបស់សិស្សនៅលើក្តារខៀន ។ អ្នកអាចផ្តល់ជាយោបល់ថា អ្នកកត់ត្រាគួរសរសេរនូវចម្លើយទាំងនេះនៅក្រោមពាក្យ « អំពាវនាវដល់ព្រះវរបិតាសួគ៌ » នៅក្រោមគោលការណ៍ដែលអ្នកបានសរសេរនៅលើក្តារខៀន ។

អ្នកអាចណែនាំ សិស្សគួរគូសចំណាំឃ្លា « ចូរយើងមានចិត្តស្មោះត្រង់ចំពោះព្រះអម្ចាស់ » នៅចុងបញ្ចប់នៃ អេធើរ ១:៣៨ ។ សូមបញ្ជាក់ថា សកម្មភាពរបស់យ៉ារេឌ និងបងប្រុសលោកបង្ហាញពីសេចក្តីជំនឿរបស់ពួកលោក និងឆន្ទៈដើម្បីគោរពតាមព្រះអម្ចាស់ ។ ពួកលោកបានសុំពរជ័យដែលពួកលោកត្រូវការ ដោយសេចក្តីជំនឿ ។

សូមឲ្យសិស្សរំឭក អេធើរ ១:៣៥, ៣៧, ៤០–៤២ ដោយស្ងាត់ៗដោយរកមើលរបៀបដែលព្រះបានប្រទានពរដល់យ៉ារេឌ និងបងប្រុសលោក និងគ្រួសារ ព្រមទាំងមិត្តភក្តិរបស់ពួកគេ ។ សូមឲ្យសិស្សដែលធ្វើជាអ្នកកត់ត្រា សរសេរនូវការរកឃើញរបស់សិស្សនៅលើក្តារខៀននៅក្រោមពាក្យ *សេចក្តីមេត្តាករុណា* នៅក្រោមគោលការណ៍ដែលអ្នកបានសរសេរនោះ ។ សូមប្រាកដថា សិស្សឃើញពីទំនាក់ទំនងរវាងការស្នើសុំរបស់បងប្រុសយ៉ារេឌ និងពរជ័យដែលព្រះអម្ចាស់បានប្រទាន ។

សូមឲ្យសិស្សម្នាក់អាន អេធើរ ១:៤៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពរជ័យដែលព្រះបានសន្យា ទោះបីជាបងប្រុសរបស់យ៉ារេឌមិនបានសុំវាដោយជាក់លាក់ក្តី ។

- តើពរជ័យបន្ថែមអ្វីខ្លះ ដែលព្រះអម្ចាស់បានសន្យាដល់ប្រជាជននេះ ? (យ៉ារេឌបានសុំឲ្យបងប្រុសលោកទូលសុំដល់ព្រះអម្ចាស់ ពីកន្លែងដែលពួកគេគួរទៅ ។យ៉ារេឌបានគិតថា ព្រះអម្ចាស់អាចដឹកនាំពួកគេទៅកាន់ដែនដីមួយដែលជា « ជម្រើសលើដែនដីឯទៀតនៅលើដែនដី » | អេធើរ ១:៣៨| ។ ព្រះអម្ចាស់បានសន្យាថានឹងដឹកនាំពួកគេទៅកាន់ដែនដីសន្យាមួយ ។

សូមអញ្ជើញសិស្សឲ្យបើកទៅកាន់ នីហ្វៃទី ២ ៤:៣៥។ (អ្នកអាចនឹងឲ្យយោបល់ថា ពយកគេសរសេរ*នីហ្វៃទី ២ ៤:៣៥*នៅជិតនឹងអេធើរ ១:៤៣ នៅក្នុងគម្ពីររបស់ពួកគេ)។ បន្ទាប់មកសុំពួកគេឲ្យអាននីហ្វៃទី ២ ៤:៣៥ និង អេធើរ ១:៤៣ ស្ងាត់ៗ ស្វែងរកមើលនូវអ្វីដែលខគម្ពីរទាំងនេះបង្រៀនអំពីពរជ័យទាំងឡាយដែលព្រះអម្ចាស់ប្រទានដល់យើងក្នុងការឆ្លើយតបចំពោះការអធិស្ឋានរបស់យើង ។

- នៅក្នុង នីហ្វៃទី ២ ៤:៣៥ តើលោកនីហ្វៃបង្រៀនអ្វីខ្លះអំពីចម្លើយរបស់ព្រះចំពោះការអធិស្ឋាន ?(ព្រះនឹងប្រទានដល់អ្នកទាំងឡាយណាដែលស្វែងរកទ្រង់នៅក្នុងការអធិស្ឋានចិត្តស្មោះ ។ អ្នកអាចពន្យល់ថាពាក្យ *ដោយសទ្ធា* មានន័យថាដោយសប្បុរស) ។ តើដំណើររឿងនៅក្នុង អេធើរ ១:៤៣ បញ្ជាក់ពីអ្វីដែលលោកនីហ្វៃបានប្រកាសនៅក្នុង នីហ្វៃទី ២ ៤:៣៥ ដោយរបៀបណា ?
- យោងតាម អេធើរ ១:៤៣ តើមានមូលហេតុអ្វីដែលព្រះអម្ចាស់បានប្រទានក្នុងការសន្យាថានឹងប្រទាននូវពរជ័យលើសពីអ្វីដែលពួកសាសន៍យ៉ារេឌបានទូលសុំទៅទៀតនោះ ? (ព្រះអម្ចាស់បានសន្យាថានឹងប្រទានពរជ័យបន្ថែម ដោយសារពួកគេបាននៅស្មោះត្រង់នៅក្នុងការអធិស្ឋានរបស់ពួកគេ ។ អ្នកអាចណែនាំ សិស្សគួរគូសចំណាំឃ្លាខាងក្រោមនៅក្នុង អេធើរ ១:៤៣ ៖ « ដោយសារពេលដ៏យូរនេះ អ្នករាល់គ្នាបានអង្វរដល់យើង ») ។
- តើគោលការណ៍អ្វីដែលយើងអាចរៀនពី អេធើរ ១:៤៣ ? (ចម្លើយរបស់សិស្សអាចខុសគ្នា ប៉ុន្តែពួកគេគួររកឃើញនូវគោលការណ៍ដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងអធិស្ឋានទៅដល់ព្រះដោយសេចក្តីជំនឿជាទៀងទាត់ នោះយើងអាចនឹងទទួលបាននូវពរជ័យទាំងឡាយដែលហួសពីអ្វីដែលយើងបានសុំទៅទៀត** ។ អ្នកអាចណែនាំ សិស្សគួរសរសេរគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់គេ ។
- តើអ្នកធ្លាប់បានឃើញគោលការណ៍នេះនៅក្នុងជីវិតរបស់អ្នក ឬ នៅក្នុងជីវិតរបស់នរណាម្នាក់ដែលអ្នកស្គាល់ដែរឬទេ ?

ក្រោយពីសិស្សបានចែកចាយនូវចម្លើយរបស់ពួកគេហើយ អ្នកអាចចែកចាយនូវឧទាហរណ៍ពីជីវិតរបស់អ្នក ឬជីវិតរបស់អ្នកដទៃបាន ។ ព្យាការី យ៉ូសែប ស៊្មីធ គឺជាគំរូមួយដ៏ល្អពីគោលការណ៍នេះ ។ លោកបានទទួលនូវពរជ័យនានា ដែលហួសពីអ្វីដែលលោកបានទូលសុំនៅពេលលោកបានអធិស្ឋានសុំដើម្បីដឹងថា តើសាសនាចក្រមួយណាដែលពិតនោះ (សូមមើល យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:១០–២០) និងនៅពេលដែលលោកបានអធិស្ឋានសុំដើម្បីដឹងពីគោលដំហររបស់លោកនៅចំពោះព្រះអម្ចាស់ (សូមមើល យ៉ូសែប ស៊្មីធ—ប្រវត្តិ ១:២៩–៤៧) ។

ដើម្បីបញ្ចប់ សូមអញ្ជើញសិស្សឲ្យខិតខំអធិស្ឋានដោយមានចិត្តដ៏ស្មោះត្រង់ ។ សូមអញ្ជើញពួកគេឲ្យចងចាំផងដែរថា ព្រះវរបិតាសួគ៌គឺពោរពេញទៅដោយសេចក្តីមេត្តាករុណា ហើយថាទ្រង់នឹងឆ្លើយតបចំពោះការអធិស្ឋានរបស់ពួកគេ ស្របតាមសេចក្តីស្មោះត្រង់របស់គេ និងស្របតាមអ្វីដែលទ្រង់បានជ្រាបថានឹងនាំមកនូវពរជ័យដ៏អស្ចារ្យដល់ជីវិតរបស់ពួកគេ ។

ការរំឭកចំណេះចំណានខគម្ពីរ

សូមបែងចែកសិស្សជាដៃគូ ។ សូមឲ្យពួកគេមានពេលជួយដល់គ្នាទៅវិញទៅមកដើម្បីរំឭកសេចក្តីយោង និងឃ្លាគន្លឹះនៃវគ្គទាំង ២៥ នៃចំណេះចំណានខគម្ពីរនៃព្រះគម្ពីរមរមនទាំងអស់ ។ អ្នកអាចណែនាំ ពួកគេគួរតែប្រើកាតចំណេះចំណានខគម្ពីរដើម្បីធ្វើការប្រឡងសាកល្បងដល់គ្នាទៅវិញទៅមក (សូមមើលគំនិតនៃការរំឭកចំណេះចំណានខគម្ពីរនៅចុងបញ្ចប់នៃមេរៀនទី ៤៥) ។ បន្ទាប់មក សូមឲ្យពួកគេធ្វើតេស្តសាកអំពីវគ្គនេះ ប្រហែលដោយប្រើតម្រុយនានាពីកាតចំណេះចំណានខគម្ពីរ ។ សូមកែតម្រូវការប្រឡងនេះរួមគ្នានៅក្នុងថ្នាក់ ។ សូមឲ្យសិស្សកត់ចំណាំពីវគ្គដែលពួកគេត្រូវរំឭក ហើយសូមអញ្ជើញដល់ពួកគេឲ្យសិក្សាបន្ថែមដោយខ្លួនឯង ។ នៅពេលឆ្ពោះសិក្សាជិតឈានមកដល់ទីបញ្ចប់ សូមគិតពីការធ្វើការប្រឡងបញ្ចប់អំពីវគ្គនានានៃចំណេះចំណានខគម្ពីរនៅក្នុងព្រះគម្ពីរមរមន ។

កំណត់ចំណាំ ៖ អ្នកអាចធ្វើសកម្មភាពនេះនៅពេលចាប់ផ្តើម ឬបញ្ចប់ថ្នាក់រៀន ។ ប្រសិនបើអ្នកប្រើសកម្មភាពនេះនៅពេលចាប់ផ្តើមថ្នាក់ សូមរក្សាវាឲ្យខ្លីដើម្បីមានពេលគ្រប់គ្រាន់បង្រៀន ។ សម្រាប់សកម្មភាពរំឭកផ្សេងទៀត សូមមើលឧបសម្ព័ន្ធនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អេធើរ ១:៣៤–៣៥ ។ តើបងប្រុសរបស់យ៉ារេឌឈ្មោះអ្វី ?

អែលឌើរ ចច វ៉េណុលស៍ នៃក្រុមចិតសិបនាក់បានតំណាលនូវដំណើររឿងខាងក្រោម ដែលបង្ហាញថា ឈ្មោះរបស់បងប្រុសយ៉ារេឌត្រូវបានបង្ហាញដល់ព្យាការី យ៉ូសែប ស៊្មីធ ៖

« ខណៈពេលដែលរស់នៅក្នុងទីក្រុង ខឺតឡង់ អែលឌើរ វ៉េណុលស៍ ខាហូន បានមានកូនប្រុសម្នាក់ ។ ថ្ងៃមួយ នៅពេលប្រធាន យ៉ូសែប ស៊្មីធ បានដើរកាត់ទ្វារបស់លោក លោកបានហៅព្យាការីឲ្យចូលមកក្នុងផ្ទះ ហើយបានសុំលោកឲ្យប្រទានពរ និងដាក់ឈ្មោះដល់ទារកនេះ ។ យ៉ូសែប បានធ្វើការណ៍នេះ ហើយបានដាក់ឈ្មោះឲ្យក្មេងប្រុសនោះថា ម៉ាហូនរី ម៉ូរ៉ានឃូមើរ ។ នៅពេលលោកបានបញ្ចប់ការប្រទានពរហើយ លោកបានដាក់ទារកនោះឲ្យគេងវិញ ហើយបែរទៅរកអែលឌើរ ខាហូន ដោយមានប្រសាសន៍ថា ឈ្មោះដែលខ្ញុំបានដាក់ឲ្យកូនប្រុសរបស់អ្នក គឺជាឈ្មោះរបស់បងប្រុសយ៉ារេឌ ; ព្រះអម្ចាស់ទើបតែបានបង្ហាញដល់ខ្ញុំ ។ អែលឌើរ វិល្លាម អេហ្វ. ខាហូន ដែលបានឈរនៅក្បែរនោះបានស្តាប់ឮព្យាការីបានមានប្រសាសន៍នេះទៅកាន់ឪពុករបស់លោក ហើយនេះគឺជាលើកដំបូងដែលឈ្មោះរបស់បងប្រុសយ៉ារេឌត្រូវបានស្តាប់នៅក្នុងសាសនាចក្រនៅក្នុងការកាន់កាប់ត្រួតត្រានេះ » (« The Jaredites » *Juvenile Instructor,* ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ១៨៩២, ទំព័រ ២៨២) ។

អេធើរ ២

សេចក្តីផ្តើម

ក្រោយពីការចាកចេញពីប៉មបាបិល លោកយ៉ារេឌ និងបងប្រុសរបស់លោក និងគ្រួសារ ព្រមទាំងមិត្តភក្តិរបស់លោក ត្រូវបានដឹកនាំដោយព្រះអម្ចាស់ឆ្ពោះកាត់ទីរហោស្ថាន ។ ព្រះអម្ចាស់បានបញ្ជាបងប្រុសរបស់យ៉ារេឌឲ្យសាងសង់ទូកធំចំនួនប្រាំបី ដើម្បីដាក់ប្រជាជនរបស់លោកឆ្លងកាត់សមុទ្រទៅកាន់ដែនដីសន្យា ។ នៅពេលបងប្រុសរបស់យ៉ារេឌ និងប្រជាជនរបស់លោកបានគោរពតាមព្រះអម្ចាស់ដោយសេចក្តីជំនឿ នោះព្រះអម្ចាស់បានប្រទានការណែនាំ និងការដឹកនាំដែលចាំបាច់ណាដល់ពួកគេដើម្បីទទួលបានជោគជ័យនៅក្នុងការធ្វើដំណើររបស់ពួកគេ ។

យោបល់សម្រាប់ការបង្រៀន

អេធើរ ២:១–១២

ការបង្កើតចំណាប់អារម្មណ៍ និងការផ្តោតការយកចិត្តទុកដាក់

សូមគ្រោងសកម្មភាពណាដែលនឹងបង្កើនចំណាប់អារម្មណ៍ និងជួយដល់អ្នករៀនទាំងឡាយឲ្យផ្តោតចំណាប់អារម្មណ៍របស់គេទៅលើព្រះគម្ពីរនៅក្នុងមេរៀននេះ ។ សកម្មភាពទាំងនេះនឹងមានប្រសិទ្ធភាពបំផុត នៅពេលវាខ្លី និងពេលវាដឹកនាំអ្នករៀនទាំងឡាយឲ្យផ្តោតទៅលើគោលការណ៍ដ៏សំខាន់នៃមេរៀននេះ ។

ប្រជាជនយ៉ារេឌចាប់ផ្តើមការធ្វើដំណើរបស់ពួកគេទៅកាន់ដែនដីសន្យា

ដើម្បីជួយសិស្សឲ្យឃើញពីលំដាប់នៃការណែនាំដែលយើងទទួលបានពីព្រះ អាចរៀបចំយើងឲ្យទទួលបានការណែនាំ និងការដឹកនាំផ្សេងទៀតពីទ្រង់ សូមធ្វើ សកម្មភាពខាងក្រោម ៖

មុនពេលចាប់ផ្តើមថ្នាក់ សូមលាក់អ្វីមួយដែលតំណាងឲ្យរបស់មានតម្លៃនៅក្នុងបន្ទប់ដែលអ្នកបង្រៀន ។ សូមរៀបចំតម្រុយបី ឬបួនដែលអាចដឹកនាំសិស្សឲ្យរកឃើញរបស់ដ៏មានតម្លៃនោះ ។ អ្នកនឹងត្រូវផ្តល់នូវតម្រុយទីមួយដល់សិស្ស ។ តម្រុយនោះនឹងនាំទៅរកតម្រុយមួយទៀត ដែលនឹងដឹកនាំទៅរកតម្រុយមួយថែមទៀត ហើយបន្តទៀតរហូតដល់សិស្សរកឃើញនូវរបស់មានតម្លៃនោះ ។ ក្រោយពីពួកគេបានរកឃើញរបស់នោះហើយ សូមសួរ ៖

- តើនឹងមានអ្វីកើតឡើង ប្រសិនបើអ្នកមិនបានយកចិត្តទុកដាក់នឹងតម្រុយទីមួយទេនោះ ? (ពួកគេនឹងមិនរកឃើញនូវតម្រុយទីពីរឡើយ) ។

សូមឲ្យសិស្សរំឭកពី អេធើរ ១:៤១–៤២ ដោយស្ងាត់ស្ងៀម ដោយរកមើលវគ្គនៃការណែនាំដំបូងរបស់ព្រះអម្ចាស់ក្នុងការដឹកនាំដល់ពួកសាសន៍យ៉ារេឌទៅកាន់ដែនដីសន្យា ។

ដើម្បីជួយសិស្សឲ្យឃើញពីចម្លើយរបស់ពួកសាសន៍យ៉ារេឌចំពោះការណែនាំទាំងនេះ សូមឲ្យសិស្សម្នាក់អាន អេធើរ ២:១–៣ ឮៗ ។

- តើពួកសាសន៍យ៉ារេឌបានឆ្លើយតបយ៉ាងណាចំពោះវគ្គនៃការណែនាំដំបូងរបស់ព្រះអម្ចាស់ ?

សូមឲ្យសិស្សម្នាក់អាន អេធើរ ២:៤–៦ ឮ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពរជ័យដែលពួកសាសន៍យ៉ារេឌបានទទួលក្រោយពីពួកគេបានធ្វើតាមវគ្គនៃការណែនាំដំបូង ។

- តើមានអ្វីកើតឡើង ក្រោយពីពួកសាសន៍យ៉ារេឌបានធ្វើតាមវគ្គនៃការណែនាំដំបូងរបស់ព្រះអម្ចាស់ ? (ព្រះអម្ចាស់បានប្រទានដល់ពួកគេនូវការណែនាំបន្ថែមទៀត តាមរយៈបងប្រុសរបស់យ៉ារេឌ) ។
- តើយើងអាចរៀនអ្វីខ្លះពីដំណើររឿងនេះអំពីរបៀបដើម្បីទទួលបានការដឹកនាំពីព្រះអម្ចាស់ ? (សិស្សអាចប្រើពាក្យខុសៗគ្នា ប៉ុន្តែចម្លើយរបស់ពួកគេគួរបង្ហាញពីគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងធ្វើសកម្មភាពដោយសេចក្តីជំនឿតាមការដឹកនាំដែលព្រះអម្ចាស់បានប្រទានដល់យើង នោះយើងអាចទទួលបាននូវការដឹកនាំបន្ថែមទៀតពីទ្រង់ ។** អ្នកអាចណែនាំ ពួកគេគួរសរសេរសេចក្តីពិតនេះនៅក្នុងព្រះគម្ពីររបស់ពួកគេនៅក្បែរ អេធើរ ២:៦) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ និងអាចអនុវត្តគោលការណ៍នេះ សូមឲ្យពួកគេគិតអំពីអារម្មណ៍ ឬការបំផុសគំនិតណាមួយដែលពួកគេបានទទួលនាពេលថ្មីៗនេះពីព្រះអម្ចាស់ ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់អាននូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រីឆាត ជី ស្តត នៃក្រុមនៃពួកសាវកដប់ពីរនាក់ អំពីរបៀបដែលយើងទទួលបានវិវរណៈជាញឹកញាប់ ៖

« វានឹងមកម្តងបន្តិចៗ ជាបំណែក ជាកញ្ចប់ ដើម្បីឲ្យសមត្ថភាពរបស់អ្នកអាចរីកចម្រើនឡើង ។ នៅពេលបំណែកនីមួយៗបានធ្វើឡើងដោយសេចក្តីជំនឿ អ្នកនឹងត្រូវបានដឹកនាំទៅរកបំណែកផ្សេងទៀត រហូតដល់អ្នកទទួលបានចម្លើយទាំងមូល ។ ទម្លាប់នោះតម្រូវឲ្យអ្នកអនុវត្តសេចក្តីជំនឿទៅលើសមត្ថភាពនៃព្រះវរបិតាយើង ដើម្បីឆ្លើយតបការអធិស្ឋានរបស់យើង។ ខណៈពេលដែលពេលខ្លះវាពិបាកជាខ្លាំង វាផ្តល់នូវលទ្ធផលយ៉ាងសំខាន់ក្នុងការរីកចម្រើនផ្ទាល់ខ្លួន » (« Using the Supernal Gift of Prayer » *Ensign* ឬ *លីអាហូណា*, ខែ ឧសភា ឆ្នាំ ២០០៧, ទំព័រ ៩) ។

សូមឲ្យសិស្សឆ្លើយនឹងសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ ។ អ្នកអាចសរសេរសំណួរនេះនៅលើក្តារខៀន ឬអានវាយឺតៗដើម្បីឲ្យសិស្សអាចកត់វាបាន ។

- តើនៅពេលណាដែលអ្នកបានធ្វើតាមការបំផុសគំនិតខាងវិញ្ញាណ ហើយបន្ទាប់មកបានទទួលនូវការដឹកនាំបន្ថែមទៀតពីព្រះនោះ ?

- តើអ្នកគិតថា ហេតុអ្វីបានជាពេលខ្លះយើងត្រូវឆ្លើយតបទៅនឹងការបំផុសគំនិតខាងវិញ្ញាណ មុនពេលយើងអាចទទួលបាននូវវិវរណៈបន្ថែម ?

សូមសង្ខេប អេធើរ ២:៨–១២ ដោយការពន្យល់ថា ព្រះអម្ចាស់បានមានបន្ទូលទៅកាន់បងប្រុសរបស់យ៉ារេឌថា នៅពេលពួកសាសន៍យ៉ារេឌបានមកដល់ដែនដីសន្យា ពួកគេនឹងត្រូវ « បម្រើទ្រង់ ដែលជាព្រះដ៏ពិតតែមួយ » (អេធើរ ២:៨) ប្រសិនបើពួកគេចង់ក្លាយជាប្រជាជាតិដ៏ខ្លាំងក្លាមួយ ដែលទ្រង់បានសន្យាថា ពួកគេនឹងអាចធ្វើបាន ។ ប្រសិនបើពួកគេមិនបម្រើដល់ទ្រង់នោះទេ ពួកគេនឹងត្រូវ « កំចាត់ចេញ » ពីដែនដី (អេធើរ ២:៨–១០) ។ លោកម៉រ៉ូណៃ បានមានប្រសាសន៍ថា នេះគឺជា « ក្រិតក្រមដ៏អស់កល្បជានិច្ចនៃព្រះ » (អេធើរ ២:១០) ដែលមានន័យថា វានឹងអនុវត្តដល់មនុស្សទាំងឡាយដែលនឹងរស់នៅក្នុងដែនដីនោះ ។

អេធើរ ២:១៣–១៥

ព្រះអម្ចាស់វាយផ្ចាលដល់បងប្រុសរបស់យ៉ារេឌ ដោយសារលោកមិនបានអំពាវនាវដល់ទ្រង់នៅក្នុងការអធិស្ឋាន

សូមឲ្យសិស្សអាន អេធើរ ២:១៣–១៥ ដោយស្ងាត់ស្ងៀម ដោយរកមើលអ្វីដែលពួកសាសន៍យ៉ារេឌបានធ្វើ នៅពេលពួកគេបានទៅដល់មាត់សមុទ្រ ។

- តើពួកសាសន៍យ៉ារេឌបានធ្វើអ្វីខ្លះ ? (ពួកគេបានបោះតង់របស់ពួកគេ ហើយបានស្នាក់នៅក្បែរមាត់សមុទ្រអស់រយៈពេលបួនឆ្នាំ) ។
- ហេតុអ្វីបានជាព្រះអម្ចាស់បានវាយផ្ចាលដល់បងប្រុសរបស់យ៉ារេឌ ?
- តើមេរៀនអ្វីខ្លះដែលយើងអាចរៀនពី អេធើរ ២:១៤ ? (សិស្សអាចរកឃើញនូវសេចក្តីពិតខុសគ្នា ដែលរួមមានដូចខាងក្រោមនេះ ៖ **ព្រះអម្ចាស់ចង់ឲ្យយើងអំពាវនាវដល់ទ្រង់ជាទៀងទាត់នៅក្នុងការអធិស្ឋាន ; ព្រះអម្ចាស់នឹងមិនសព្វព្រះទ័យឡើយ នៅពេលយើងខកខានមិនបានអំពាវនាវដល់ទ្រង់នៅក្នុងការអធិស្ឋាននោះ** ; ហើយ **ព្រះវិញ្ញាណនឹងមិនអាចគង់នៅជាមួយយើងឡើយ ប្រសិនបើយើងមានអំពើបាបនោះ**) ។

សូមឲ្យសិស្សគិតអំពីការអធិស្ឋានផ្ចាល់ខ្លួនរបស់ពួកគេ នៅពេលអ្នកអានសេចក្តីថ្លែងការណ៍ខាងក្រោមនេះដោយអែលឌើរ ដូណាល អេល. ស្តាហេលី នៃក្រុមចិតសិបនាក់ ៖

« ការអធិស្ឋានដែលពោរពេញដោយការប្រឹងប្រែងប្រចាំថ្ងៃក្នុងការស្វែងរកការអភ័យទោស និងជំនួយព្រមទាំងការដឹកនាំជាពិសេស គឺជាការសំខាន់ដល់ជីវិតរបស់យើង និងការរីកចម្រើននៃទីបន្ទាល់របស់យើង ។ នៅពេលយើងប្រញាប់ប្រញាល និយាយដដែលៗ គិតថាធម្មតា ឬភ្លេចអធិស្ឋានរបស់យើង យើងហាក់នឹងបាត់បង់ភាពជិតជិតទៅនឹងព្រះវិញ្ញាណ ដែលជាការណ៍ដ៏សំខាន់មួយនៅក្នុងការដឹកនាំជាបន្តបន្ទាប់ដែលយើងត្រូវការដើម្បីយកឈ្នះលើឧបសគ្គនៅក្នុងជីវិតរបស់យើងរាល់ថ្ងៃនេះដោយជោគជ័យ » (« Securing Our Testimonies » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៤, ទំព័រ ៣៩) ។

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀនមុនចាប់ផ្តើមបង្រៀន ។ (ឬ អ្នកអាចរៀបចំសំណួរជាក្រដាសចម្លងចែកដល់សិស្ស ឬអានវាយឺតៗដើម្បីឲ្យសិស្សអាចកត់វាបាន) ។ សូមឲ្យសិស្សមានពេលពីរបីនាទីដើម្បីសរសេរចម្លើយខ្លីៗរបស់ពួកគេទៅនឹងសំណួរទាំងនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ ។

តើអ្នកគិតថា អ្នកបានអធិស្ឋានផ្ចាល់ខ្លួនញឹកញាប់ប៉ុណ្ណា?

តើអ្នកគិតថា អ្នកស្មោះសរយ៉ាងណាចំពោះការអធិស្ឋានផ្ចាល់ខ្លួនរបស់អ្នក ?

នៅក្នុងការអធិស្ឋានផ្ចាល់ខ្លួនរបស់អ្នក តើអ្នកមានអារម្មណ៍ថា អ្នកពិតជាទាក់ទងជាមួយនឹងព្រះវរបិតាសួគ៌មែនឬទេ ? ហេតុអ្វីបានជាមានអារម្មណ៍ថាពិតមែន ឬហេតុអ្វីបានជាមិនមានអារម្មណ៍ថាពិត ?

ប្រសិនបើអ្នកអាចធ្វើការផ្លាស់ប្តូរមួយដើម្បីពង្រឹងដល់ការអធិស្ឋានផ្ចាល់ខ្លួនរបស់អ្នក តើអ្នកនឹងផ្លាស់ប្តូរអ្វី ?

អេធើរ ២:១៦–២៥ (សូមមើលផងដែរ អេធើរ ៣:១–៦; ៦:៤–៩)

ពួកសាសន៍យ៉ារេឌធ្វើទុកដ៏ធំដើម្បីឆ្លងកាត់មហាសមុទ្រទៅកាន់ដែនដីសន្យា

សូមឲ្យសិស្សគិតអំពីឧបសគ្គមួយដែលពួកគេអាចមាន ឬការសម្រេចចិត្តដ៏សំខាន់មួយដែលពួកគេអាចត្រូវធ្វើ នាពេលនេះ ឬនាពេលអនាគត ។ ឧទាហរណ៍ ពួកគេអាចគិតអំពីស្ថានភាពគ្រួសារដ៏ពិបាកមួយ ឧបសគ្គនៅក្នុងសាលារៀន ការសម្រេចចិត្តថារៀបការជាមួយនឹងអ្នកណា ឬការជ្រើសរើសជំនាញការងារ ។ សូមឲ្យពួកគេសញ្ជឹងគិតអំពីរបៀបដែលព្រះអម្ចាស់អាចប្រទានដល់ពួកគេនូវការដឹកនាំឬជំនួយ ។ នៅពេលពួកគេសិក្សាពី អេធើរ ២ ទាំងមូល សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍នានាដែលនឹងជួយពួកគេឲ្យទទួលបានជំនួយពីព្រះអម្ចាស់នៅក្នុងការធ្វើការសម្រេចចិត្តដ៏ល្អមួយ ។

សូមឲ្យសិស្សម្នាក់អាន អេធើរ ២:១៦–១៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលព្រះអម្ចាស់បានមានបន្ទូលទៅកាន់ពួកសាសន៍យ៉ារេឌថា ពួកគេត្រូវធ្វើដើម្បីបន្តដំណើរឆ្ពោះទៅដែនដីសន្យា ។ នៅពេលសិស្សបានបញ្ចប់ការអានហើយ សូមសួរពួកគេថា តើមាននរណាម្នាក់ចង់ឡើងមកខាងមុខថ្នាក់ ហើយគូសព្រាងនូវអ្វីដែលពួកគេគិតថាទូកដ៏ធំរបស់ពួកសាសន៍យ៉ារេឌអាចមានរូបរាងដូចម្តេច ។

សូមចម្លងតារាងខាងក្រោមដាក់លើក្តារខៀន ដោយកុំបញ្ចូលចម្លើយនៅក្នុងជួរបីខាងក្រោមឡើយ ។ សូមចែកតារាងនេះជាក្រដាសដល់សិស្ស ឬសូមឲ្យសិស្សចម្លងវានៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ ។

អេធើរ ២:១៨–១៩	អេធើរ ២:២០–២៥ ; ៣:១–៦; ៦:៤–៩		
បញ្ហាជាមួយនឹងទូកដ៏ធំនេះ	ដំណោះស្រាយ	អ្វីដែលព្រះអម្ចាស់បានធ្វើ	អ្វីដែលបងប្រុសរបស់យ៉ារេឌបានធ្វើ
គ្មានខ្យល់	ចោះរន្ធដែលអាចបើក និងបិទបាននៅលើដំបូល និងបាតនៃទូកដ៏ធំនេះ	បានផ្តល់ការណែនាំដល់យ៉ារេឌ	បានចោះរន្ធ
គ្មានចង្កូត	ខ្យល់នឹងបក់ទូកដ៏ធំនេះទៅកាន់ដែនដីសន្យា	បានធ្វើឲ្យខ្យល់បក់	បានទុកចិត្តលើព្រះអម្ចាស់
គ្មានពន្លឺ	រៀបចំគ្រួសពិសេស និងសុំឲ្យព្រះអម្ចាស់ពាល់វា ដើម្បីឲ្យវានឹងមានពន្លឺ	បានប្រឹក្សាដល់បងប្រុសរបស់យ៉ារេឌអំពីអ្វីៗដែលនឹងមិនកើតឡើងបាន និងបានណែនាំលោកឲ្យស្វែងរកដំណោះស្រាយដែលនឹងដំណើរការ បានពាល់គ្រួសទាំងអស់ក្រោយពីបងប្រុសរបស់យ៉ារេឌបានរៀបចំរួច	បានរៀបចំគ្រួស និងបានសុំឲ្យព្រះអម្ចាស់ពាល់ពួកវា ដើម្បីឲ្យវានឹងមានពន្លឺនៅក្នុងទីងងឹត

សូមឲ្យសិស្សស្រាវជ្រាវនៅក្នុង អេធើរ ២:១៨–១៩ ដោយខ្លួនគេដើម្បីស្វែងរកបញ្ហាបីដែលបងប្រុសរបស់យ៉ារេឌបានកត់ចំណាំពីទូកដ៏ធំនេះ ។

- **តើមានបញ្ហាអ្វីខ្លះដែលបងប្រុសរបស់យ៉ារេឌបានកត់សម្គាល់ ? (សូមសរសេរចម្លើយរបស់សិស្សនៅក្នុងកូឡោនទីមួយនៃតារាងដូចដែលបានបង្ហាញ ។ សូមអញ្ជើញពួកគេឲ្យសរសេរដូចគ្នាពីក្តារខៀនទៅក្នុងតារាងរបស់ពួកគេ) ។**

ក្រោយពីសិស្សបានរកឃើញនូវបញ្ហាទាំងឡាយហើយ សូមឲ្យពួកគេសិក្សា អេធើរ ២:២០–២៥; ៣:១–៦; ៦:៤–៩ ។ (*កំណត់ចំណាំ ៖* វគ្គនៅក្នុង អេធើរ ៣ និង ៦ នឹងត្រូវបង្រៀនកាន់តែ ក្បោះក្បាយជាក់ច្បាស់នៅក្នុងមេរៀនទី ១៤៥ និង ១៤៧) ។ សូមឲ្យពួកគេមានពេលបំពេញតារាងទាំងអស់រៀងៗខ្លួន ។

នៅពេលសិស្សបានមានពេលគ្រប់គ្រាន់ដើម្បីបំពេញតារាងនេះហើយ សូមសួរសំណួរខាងក្រោមនេះដើម្បីជួយពួកគេឲ្យរកឃើញនូវគោលការណ៍នានាពីបទពិសោធន៍របស់បងប្រុសរបស់យ៉ារេឌ ៖

- **ដោយផ្អែកលើដំណោះស្រាយដែលទាក់ទងទៅនឹងខ្យល់ តើពេលខ្លះព្រះអម្ចាស់ជួយយើងឲ្យដោះស្រាយនឹងបញ្ហារបស់យើង ឬឆ្លើយតបទៅនឹងសំណូររបស់យើងយ៉ាងដូចម្តេចដែរ ? (ពេលខ្លះព្រះអម្ចាស់មានបន្ទូលប្រាប់យើងនូវរបៀបដើម្បីដោះស្រាយបញ្ហា ហើយសង្ឃឹមថាយើងនឹងធ្វើតាមការណែនាំរបស់ទ្រង់) ។**
- **ដោយផ្អែកលើដំណោះស្រាយដែលទាក់ទងទៅនឹងចង្កូត តើពេលខ្លះព្រះអម្ចាស់ជួយយើងឲ្យដោះស្រាយនឹងបញ្ហារបស់យើង ឬឆ្លើយតបទៅនឹងសំណូររបស់យើងយ៉ាងដូចម្តេចដែរ ? (ពេលខ្លះព្រះអម្ចាស់យកចិត្តទុកដាក់ចំពោះដំណោះស្រាយដោយអង្គទ្រង់) ។**
- **ដោយផ្អែកលើដំណោះស្រាយដែលទាក់ទងទៅនឹងពន្លឺ តើពេលខ្លះព្រះអម្ចាស់ជួយដល់យើងឲ្យដោះស្រាយនឹងបញ្ហារបស់យើង ឬឆ្លើយតបទៅនឹងសំណូររបស់យើងយ៉ាងដូចម្តេចដែរ ? (ពេលខ្លះព្រះអម្ចាស់តម្រូវឲ្យយើងមានដំណោះស្រាយមួយ និងសុំការអនុម័ត ហើយនិងជំនួយពីទ្រង់ក្នុងការអនុវត្តវា) ។**

សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ *នៅពេលយើងអំពាវនាវហៅដល់ព្រះអម្ចាស់ និងធ្វើនូវចំណែករបស់យើងដើម្បីដោះស្រាយបញ្ហាយើងហើយ នោះយើងអាចទទួលបាននូវជំនួយពីព្រះអម្ចាស់ ។* **ដើម្បីជួយសិស្សឲ្យអនុវត្តគោលការណ៍នេះ សូមឲ្យពួកគេពិចារណាពីការសម្រេចចិត្តដ៏សំខាន់ដែលពួកគេបានគិតរយៈពេលពីរបីនាទីកន្លងទៅនេះ ។ បន្ទាប់មក សូមឲ្យពួកគេសញ្ជឹងគិតពីសំណួរខាងក្រោម ៖**

- **តើអ្នកគិតថា ព្រះអម្ចាស់នឹងរំពឹងថាអ្នកនឹងធ្វើដូចម្តេចខ្លះ នៅក្នុងការធ្វើការសម្រេចចិត្តនេះ ?**
- **តើព្រះអម្ចាស់នឹងធ្វើអ្វីខ្លះដើម្បីជួយដល់អ្នកនោះ ?**
- **តើអ្នកអាចបង្ហាញពីទំនុកចិត្តទៅលើព្រះអម្ចាស់ នៅពេលអ្នកគិតអំពីការសម្រេចចិត្តនេះដោយរបៀបណា ?**

សូមឲ្យសិស្សមានពេលពីរបីនាទីសរសេរអំពីអ្វី ដែលពួកគេបានរៀននៅថ្ងៃនេះ ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា នៅពេលយើងអំពាវនាវដល់ព្រះអម្ចាស់ដោយសេចក្តីស្មោះត្រង់ និងធ្វើនូវចំណែករបស់យើងដើម្បីដោះស្រាយបញ្ហាយើងនោះ ទ្រង់នឹងដឹកនាំយើង និងជួយយើងស្របតាមព្រះបញ្ញា និងព្រះចេស្តារបស់ទ្រង់ ។

មេរៀនទី ១៤៥

អេធើរ ៣

សេចក្តីផ្តើម

ដោយផ្លើយតបទៅនឹងសំណួររបស់ព្រះអម្ចាស់—« តើអ្នកចង់ឲ្យយើងធ្វើអ្វីដើម្បីឲ្យអ្នកមានពន្លឺ នៅក្នុងភេត្រាទាំងឡាយរបស់អ្នក ? »— បងប្រុសរបស់យ៉ារេឌបានរៀបចំគ្រួសចំនួនដប់ប្រាំមួយគ្រាប់ ហើយបានសុំព្រះអម្ចាស់ដោយបន្ទាបខ្លួនថាទ្រង់នឹងពាល់គ្រួសទាំងនេះ « ដើម្បីរៀបចំឲ្យវាអាចបានភ្លឺចែងតាំងក្នុងទីងងឹត » (អេធើរ ២:២៣; ៣:៤) ។ ដោយសារបងប្រុសរបស់យ៉ារេឌបានមានសេចក្តីជំនឿដ៏ខ្លាំងក្លា នោះលោកបានឃើញនូវព្រះអង្គុលីរបស់ព្រះអង្គសង្គ្រោះពាល់នូវគ្រួសទាំងនោះ ។ នោះព្រះអម្ចាស់បានបង្ហាញអង្គទ្រង់ដល់បងប្រុសរបស់យ៉ារេឌ និងបានលាតត្រដាងនូវរឿងជាច្រើនដល់លោក ។ ព្រះអម្ចាស់បានបញ្ជាបងប្រុសរបស់យ៉ារេឌឲ្យសរសេរអ្វីដែលលោកបានឃើញ និងបានឲ្ម និងត្រូវបិទត្រានូវការសរសេរទាំងនេះរហូតដល់ព្រះអម្ចាស់នឹងមានព្រះទ័យចង់ឲ្យវាលេចចេញមក ។

ឃោបល់សម្រាប់ការបង្រៀន

អេធើរ ៣:១–២០

ព្រះម្ចាស់បានពាល់គ្រួសទាំងនោះ ដើម្បីប្រទាននូវពន្លឺដល់ភេត្រារបស់ពួកសាសន៍យ៉ារេឌ និងបង្ហាញអង្គទ្រង់ដល់បងប្រុសរបស់យ៉ារេឌ

សូមឲ្យសិស្សម្នាក់ធ្វើជាអ្នកកត់ត្រា ។ បន្ទាប់មក សូមសូរសិស្សនូវសំណួរខាងក្រោមនេះ ហើយសូមឲ្យអ្នកកត់ត្រាសរសេរនូវចម្លើយរបស់សិស្សនៅលើក្តារខៀន ។

- តើមានរឿងអ្វីខ្លះ ដែលយុវវ័យបានអធិស្ឋានសុំដោយស្មោះពីចិត្តនោះ ?

សូមឲ្យសិស្សស្រមៃថា មិត្តរបស់ពួកគេម្នាក់កំពុងអធិស្ឋានសុំរឿងមួយដែលបានសរសេរនៅលើក្តារខៀន ៖ មិត្តម្នាក់នេះចង់ដឹងពីរបៀបដើម្បីអភិវឌ្ឍការអធិស្ឋាន និងសកម្មភាពទាំងឡាយរបស់គេ ដើម្បីអាចទទួលបានជំនួយ និងការដឹកនាំពីព្រះអម្ចាស់ ។ សូមឲ្យសិស្សគិតអំពីសំណើរនេះ នៅពេលពួកគេសិក្សាពីគំរូរបស់បងប្រុសរបស់យ៉ារេឌនៅក្នុង អេធើរ ៣ ដោយរកមើលការយល់ដឹងដែលពួកគេអាចចែកចាយជាមួយនឹងមិត្តរបស់គេ ។

សូមរំពួកសិស្សថា នៅក្នុងមេរៀនពីមុន ពួកគេបានពិភាក្សាគ្នាអំពីដំណើរឿងរបស់បងប្រុសរបស់យ៉ារេឌ ដែលបានសូរព្រះអម្ចាស់អំពីរបៀបដើម្បីទទួលបានពន្លឺនៅក្នុងភេត្រារបស់ពួកសាសន៍យ៉ារេឌទាំងឡាយ ។

- តើបងប្រុសរបស់យ៉ារេឌបានធ្វើអ្វីខ្លះដើម្បីជួយផ្តល់នូវពន្លឺក្នុងភេត្រាទាំងឡាយនោះ ? (សូមមើល អេធើរ ៣:១) ។
- តើបងប្រុសរបស់យ៉ារេឌបានសុំអ្វីខ្លះដើម្បីឲ្យព្រះអម្ចាស់ជួយផ្តល់នូវពន្លឺក្នុងភេត្រាទាំងឡាយនោះ ? (សូមមើល អេធើរ ៣:១, ៤) ។
- តើអ្វីដែលធ្វើឲ្យអ្នករំភើបចិត្តអំពីការខិតខំប្រឹងរបស់បងប្រុសយ៉ារេឌ ?

សូមបង្ហាញថា បងប្រុសរបស់យ៉ារេឌបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីរៀបចំនូវគ្រួសទាំងនោះ ។ បន្ទាប់មក សូមឲ្យសិស្សគិតពិចារណាថាតើគ្រួសទាំងនោះនឹងមាអាចផ្តល់ពន្លឺបានបុណ្ណា ប្រសិនបើព្រះអម្ចាស់មិនបានពាល់វាទេនោះ ។ សូមឲ្យសិស្សអាន អេធើរ ៣:២–៥ ដោយស្ងាត់ស្ងៀមដោយរកមើលឃ្លាដែលបង្ហាញថា បងប្រុសរបស់យ៉ារេឌបានយល់ដឹងនូវការពឹងពាក់របស់លោកទៅលើព្រះអម្ចាស់ទាំងស្រុង ។

ក្រោយពីសិស្សបានមានពេលអានហើយ សូមឲ្យពួកគេធ្វើការជាគូ ។ សូមឲ្យពួកគេរៀបរាប់ពីចម្លើយរបស់ពួកគេដល់គ្នាទៅវិញទៅមក ។ សូមប្រាប់ពួកគេផងដែរថា ពួកគេគួរចែកចាយនូវអ្វីដែលធ្វើឲ្យពួកគេរំភើបអំពីការអធិស្ឋានរបស់បងប្រុសយ៉ារេឌ ។

នៅពេលសិស្សអាន អេធើរ ៣:២ នោះពួកគេអាចមានសំណួរខ្លះអំពីឃ្លា « យើងខ្ញុំនេះមិនសក្តិសមនៅចំពោះព្រះអង្គទេ » និង « ធម្មជាតិនៃយើងខ្ញុំបានក្លាយទៅជាអាក្រក់ជានិច្ច » ។ សូមជួយសិស្សឲ្យឃើញថា នៅពេលបងប្រុសរបស់យ៉ារេឌបានប្រើពាក្យទាំងនេះ នោះលោកបានសំដៅទៅលើស្ថានភាពដែលយើងបានទទួល « ដោយសារតែការធ្លាក់ » ។ យើងត្រូវបានបែងចែកចេញពីព្រះទាំងខាងរាងកាយ និងខាងវិញ្ញាណ ហើយយើងនឹងបំបែកខ្លួនយើងពីទ្រង់កាន់តែខ្លាំងទៀត នៅពេលយើងមានអំពើបាប ។ បើប្រៀបធៀបទៅនឹងទ្រង់ យើងគឺទន់ខ្សោយ និងមិនសក្តិសម ។ ដោយគ្មានជំនួយពីទ្រង់ទេនោះ យើងមិនអាចត្រឡប់ទៅរស់នៅនៅក្នុងវត្តមានរបស់ទ្រង់វិញបានឡើយ ។

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃខគម្ពីរដែលពួកគេបានអាននេះកាន់តែជ្រៅជ្រះ សូមសូរនូវសំណួរខាងក្រោមនេះ ៖

- តើអ្នកគិតថា ហេតុអ្វីបានជាសំខាន់សម្រាប់យើងដើម្បីទទួលស្គាល់ពីការពឹងពាក់របស់យើងទាំងស្រុងទៅលើព្រះអម្ចាស់ នៅពេលយើងសុំជំនួយពីទ្រង់ ?
- នៅក្នុង អេធើរ ៣:១–៥ តើមានភស្តុងតាងអ្វីខ្លះដែលអ្នកឃើញថា បងប្រុសរបស់យ៉ារេឌបានមានសេចក្តីជំនឿថា ព្រះអម្ចាស់អាចជួយលោកដោះស្រាយបញ្ហារបស់លោកបាន ? (ប្រសិនបើចាំបាច់ សូមបំផុសសិស្សឲ្យរកមើលឃ្លាដែលរៀបរាប់ពីការខិតខំរបស់បងប្រុសយ៉ារេឌ និងឃ្លាដែលបង្ហាញពីទំនុកចិត្តរបស់លោកទៅលើព្រះអម្ចាស់) ។

ដើម្បីសង្កត់អត្ថន័យអំពីអំណាចនៃសេចក្តីជំនឿរបស់បងប្រុសយ៉ារេឌ សូមឲ្យសិស្សម្នាក់អាននូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអៃលឌើរ ដៃហ្ស្រី អ័រ ហូឡិន នៃក្ងរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« ពិតណាស់ថា ព្រះអង្គក៏ដូចជាអ្នកអាន មានអារម្មណ៍ពីអ្វីមួយដែលហាក់ដូចជាការប៉ះទង្គិចដ៏ខ្លាំងមួយលើភាពស្មោះត្រង់កាលពីវ័យកុមារ និងមានអារម្មណ៍ពីការប្តេជ្ញាទៅលើសេចក្តីជំនឿរបស់មនុស្ស ។ ‹ *ហេតុដូច្នេះហើយ ឱ ព្រះអម្ចាស់ ទ្រង់អាចធ្វើការណ៍នេះបាន* › ។ ប្រហែលជាគ្មានអំណាចណាដ៏មានអានុភាពជាងអក្សរមួយបន្ទាត់នៃសេចក្តីជំនឿដែលបាននិយាយដោយមនុស្សនៅក្នុងព្រះគម្ពីរនោះទេ ។ . . . ថ្វីបើព្យាការីស្វាគ៌ាស្ទើរអំពីសមត្ថភាពរបស់លោកផ្ទាល់ លោក *គ្មាន* ការមិនជឿជាក់អំពីព្រះចេស្តារបស់ព្រះនោះឡើយ » (« Rending the Veil of Unbelief » in *Nurturing Faith through the Book of Mormon* ៖ The 24th Annual Sidney B. Sperry Symposium | ឆ្នាំ ១៩៩៥ | ទំព័រ ១២) ។

សូមបង្ហាញរូបភាព បងប្រុសយ៉ាកុបឧមើលឃើញនូវព្រះអង្គុលីរបស់ព្រះអម្ចាស់ (លេខកូដ ៦២៤៧៨; *សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ | ទំព័រ ៨៥) ។ សូមឲ្យសិស្សម្នាក់អាន អេធើរ ៣:៦ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយស្រមៃថានឹងមានអ្វីកើតឡើងពីបទពិសោធន៍ដែលបានកត់ត្រានៅក្នុងខគម្ពីរនេះរបស់បងប្រុសយ៉ារេឧ ។

- តើអ្នកគិត ឬមានអារម្មណ៍យ៉ាងណា ប្រសិនបើអ្នកបានមានបទពិសោធន៍មួយដែលស្រដៀងទៅនឹងបទពិសោធន៍របស់បងប្រុសរបស់យ៉ារេឧដូច្នេះ ?

សូមសង្ខេប អេធើរ ៣:៦–៨ ដោយការពន្យល់ថា នៅពេលបងប្រុសរបស់យ៉ារេឧបានឃើញនូវព្រះអង្គុលីរបស់ព្រះអម្ចាស់ នោះលោកបាន « ដួលចុះនៅចំពោះព្រះអម្ចាស់ » (អេធើរ ៣:៦) ។ លោកត្រូវស្រឡាំងកាំងដែលបានឃើញព្រះអង្គុលីរបស់ព្រះអម្ចាស់ « គឺដូចជាម្រាមដៃរបស់មនុស្ស ដូចសាច់ និងឈាម » (អេធើរ ៣:៦) ។ (ក្រោយមក បងប្រុសរបស់យ៉ារេឧបានដឹងថា លោកបានឃើញនូវចំណែកមួយនៃព្រះកាយខាងវិញ្ញាណរបស់ព្រះអម្ចាស់ | សូមមើល អេធើរ ៣:១៦|) ។

សូមឲ្យសិស្សអាន អេធើរ ៣:៩ ដោយស្ងាត់ស្ងៀម ដោយរកមើលមូលហេតុដែលបងប្រុសរបស់យ៉ារេឧអាចមើលឃើញនូវព្រះអង្គុលីរបស់ព្រះអម្ចាស់ ។

ក្រោយពីសិស្សឆ្លើយហើយ សូមសរសេរឃ្លាដែលមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖

នៅពេលយើងបន្ទាបខ្លួនយើងដង្ហោយហៅរកព្រះអម្ចាស់ នោះទ្រង់នឹងប្រទានពរដល់យើងស្របតាម . . . របស់យើង និងព្រះឆន្ទៈរបស់ទ្រង់ ។

សូមឲ្យសិស្សផ្តល់យោបល់នូវពាក្យដែលអាចត្រូវបំពេញនៅក្នុងប្រយោគនេះ ។ សិស្សអាចនិយាយនូវពាក្យ *សេចក្តីជំនឿ* ដើម្បីបំពេញក្នុងប្រយោគនេះ ។ ពួកគេក៏អាចលើកឡើងនូវពាក្យដូចជា *ការខិតខំប្រឹងប្រែង ការបន្ទាបខ្លួន តម្រូវការ* និង *ភាពស្មោះត្រង់* ។ សូមជួយពួកគេឲ្យឃើញថា ពាក្យទាំងនេះតំណាងឲ្យការបង្ហាញនូវសេចក្តីជំនឿរបស់យើង ។ បន្ទាប់មក សូមបំពេញប្រយោគនេះនៅលើក្តារខៀន ៖ ***នៅពេលយើងបន្ទាបខ្លួនយើងដង្ហោយហៅរកព្រះអម្ចាស់ នោះទ្រង់នឹងប្រទានពរដល់យើងស្របតាមសេចក្តីជំនឿរបស់យើង និងព្រះឆន្ទៈរបស់ទ្រង់ ។***

សូមសំដៅទៅលើការសរសេរនៅលើក្តារខៀនតាំងពីការចាប់ផ្តើមនៃមេរៀននេះ ។ សូមជ្រើសរើសពីរទៅបីពាក្យមួយ ឬពីរពីលើក្តារខៀន ។ សូមឲ្យសិស្សចែកចាយនូវគំនិតរបស់ពួកគេអំពីរបៀបដែលនរណាម្នាក់អាចបង្ហាញសេចក្តីជំនឿរបស់គេទៅលើព្រះអម្ចាស់នៅក្នុងស្ថានភាពជាក់លាក់មួយចំនួនទាំងនោះ ។ ក្រោយពីសិស្សបានចែកចាយហើយ សូមសំដៅទៅគោលការណ៍ដែលអ្នកទើបតែបានសរសេរនៅលើក្តារខៀន ។

- តើមានបទពិសោធន៍អ្វីខ្លះដែលអ្នកបានមាន ដែលបានជួយអ្នកឲ្យដឹងថា គោលការណ៍នេះគឺពិត ?

ដើម្បីជួយសិស្សឲ្យអនុវត្តគោលការណ៍នេះនៅក្នុងជីវិតរបស់ពួកគេ សូមឲ្យពួកគេគិតអំពីស្ថានភាពមួយដែលពួកគេត្រូវការជំនួយពីព្រះអម្ចាស់ ។ សូមឲ្យពួកគេមានពេលសរសេរនៅក្នុងសៀវភៅកំណត់ត្រា ឬសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ អំពីរបៀបមួយដែលពួកគេអាចអនុវត្តសេចក្តីជំនឿឲ្យបានកាន់តែខ្លាំងជាងនេះ នៅពេលពួកគេបន្ទាបខ្លួនដើម្បីស្វែងរកជំនួយរបស់ព្រះអម្ចាស់ ។ សូមអញ្ជើញសិស្សឲ្យមើលអ្វីដែលពួកគេបានកត់ត្រា ។ អ្នកអាចចែករំលែកនូវ បទពិសោធន៍ មួយដែលអ្នកបានទទួលបាន នៅពេលអ្នកបានទទួលនូវពរជ័យ ដោយសារអ្នកបានអនុវត្តសេចក្តីជំនឿក្នុងព្រះអម្ចាស់ ។

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោម ដែលអែលឌើរ ជែហ្វ្រី អ័រ ហូឡិន ពន្យល់ថាបទពិសោធន៍ពីអតីតកាលរបស់យើងអាចពង្រឹងដល់នូវសេចក្តីជំនឿរបស់យើង ។

« សេចក្តីជំនឿដែលបានរៀបចំទុកត្រូវកើតជាប្រយោជន៍ដោយសារបទពិសោធន៍កាលពីអតីតកាល —ដោយការទទួលស្គាល់ ដែលផ្តល់នូវមូលដ្ឋានមួយដល់ជំនឿ » (*Christ and the New Covenant* ៖ *The Messianic Message of the Book of Mormon* | ឆ្នាំ ១៩៩៧ |, ទំព័រ ១៨) ។

- ការចាប់ផ្តើមនូវឯប័មបាបិល តើមានបទពិសោធន៍អ្វីខ្លះដែលបងប្រុសរបស់យ៉ារេឧបានទទួលបាន ដែលហាក់ដូចជាពង្រឹងដល់សេចក្តីជំនឿរបស់លោកទៅលើព្រះអម្ចាស់ ? តើអ្នកគិតថា បទពិសោធន៍ទាំងនេះបានរៀបចំលោកឲ្យអនុវត្តសេចក្តីជំនឿដ៏អស្ចារ្យបែបនោះយ៉ាងណាដែរ នៅពេលលោកបានយកគ្រួសទាំងឡាយទៅដល់ព្រះអម្ចាស់នោះ ?

សូមឲ្យសិស្សធ្វើការជាគូៗ និងពិភាក្សាពីសំណួរដូចខាងក្រោម ៖

- តើមានបទពិសោធន៍អ្វីខ្លះដែលបានពង្រឹងដល់សេចក្តីជំនឿរបស់អ្នកទៅលើព្រះអម្ចាស់ ? តើបទពិសោធន៍ទាំងនោះអាចរៀបចំអ្នកឲ្យអនុវត្តនូវសេចក្តីជំនឿដ៏អស្ចារ្យជាងនេះនៅពេលក្រោយនៅក្នុងជីវិតរបស់អ្នកដោយរបៀបណា ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អេធើរ ៣:៩–១២ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ។ បន្ទាប់មក សូរសំណួរដូចខាងក្រោមនេះ ៖

- តើនៅពេលណាដែលព្រះអម្ចាស់បានសួរថា « តើអ្នកជឿពាក្យដែលយើងនឹងប្រាប់ឬទេ » ? បងប្រុសរបស់យ៉ារេឧបានមានប្រសាសន៍ថា « ព្រះពរ ព្រះអម្ចាស់ » (អេធើរ ៣:១១–១២) ។ ហេតុអ្វីបានជាអ្នកគិតថា វាសំខាន់ដែលបងប្រុសរបស់យ៉ារេឧត្រូវជឿលើព្រះបន្ទូលរបស់ព្រះអម្ចាស់ មុនពេលលោកនឹងស្តាប់ឮនូវព្រះបន្ទូលទាំងនោះ ?

ការចែករំលែកនូវបទពិសោធន៍ផ្ទាល់ខ្លួន

នៅពេលអ្នកចែករំលែកនូវបទពិសោធន៍ដែលអ្នកបានទទួលបាន នៅពេលអ្នកបានស្វែងរកដើម្បីរស់នៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ នោះអ្នកអាចជួយសិស្សឲ្យយល់បានពីរបៀបដើម្បីអនុវត្តគោលការណ៍ទាំងនោះដោយខ្លួនគេ ។ សូមសង្ខេបនូវដំណើររឿងរបស់អ្នក ហើយសូមបញ្ចូលនូវឃ្លានៃទីបន្ទាល់នានាដែលបង្កប់នូវអ្វីដែលអ្នកបានរៀនសូត្រជានិច្ច ឬពីរបៀបដែលអ្នកត្រូវបានប្រទានពរតាមរយៈបទពិសោធន៍របស់អ្នកនោះ ។ ការណ៍នេះនឹងអញ្ជើញនូវព្រះវិញ្ញាណបរិសុទ្ធដើម្បីឲ្យថ្លែងជាសាក្សីអំពីសេចក្តីពិតដែលអ្នកចែករំលែក ។

សូមពន្យល់ថា ក្រោយពីអែលឌើរ ហូឡិន បានបង្រៀនអំពីសេចក្តីជំនឿដោយផ្អែកលើបទពិសោធន៍កាលពីអតីតកាល លោកបានបង្រៀនអំពីសេចក្តីជំនឿដ៏ពេញលេញដែលយើងត្រូវអភិវឌ្ឍន៍ ។ សូមឲ្យសិស្សម្នាក់អានឮៗនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ហូឡិន ៖

« សេចក្តីជំនឿដ៏ប្រោសលោះជាញឹកញាប់ត្រូវតែត្រូវបានអនុវត្តដើម្បីនាំយកនូវបទពិសោធន៍ទាំងឡាយទៅរកពេលអនាគត — ការដែលមិនដឹងច្បាស់ ដែលផ្តល់នូវឱកាសមួយសម្រាប់បង្កើតនូវអព្ភូតហេតុ ។ សេចក្តីជំនឿដ៏ជាក់លាក់ សេចក្តីជំនឿដែលអាចរំកិលភ្នំបាន សេចក្តីជំនឿដែលដូចជាសេចក្តីជំនឿរបស់បងប្រុសរបស់យ៉ារេឌ *នាំមុខនូវ* ការណ៍អព្ភូតហេតុ និងចំណេះដឹងនានា ។ . . . សេចក្តីជំនឿគឺជាការយល់ព្រមដោយឥតលក្ខខណ្ឌ —ហើយឈានមុខចំពោះ— លក្ខខណ្ឌអ្វីៗទាំងអស់ដែលព្រះអាចតម្រូវឲ្យមានទាំងនៅក្នុងអនាគតកាលខាងមុខ និងឯនាយ ។

« សេចក្តីជំនឿរបស់បងប្រុសរបស់យ៉ារេឌគឺពេញលេញ » (*Christ and the New Covenant,* ១៨–១៩) ។

សូមអញ្ជើញសិស្សឲ្យគិតពិចារណាថាតើ ពួកគេមានសេចក្តីជំនឿគ្រប់គ្រាន់ទៅលើព្រះអម្ចាស់ហើយឬនៅ ដើម្បីជឿលើ និងធ្វើតាមអ្វីដែលទ្រង់នឹងបង្ហាញដល់ពួកគេ ឬក៏មុនពេលទ្រង់បង្ហាញវាដល់ពួកគេផង ។

សូមឲ្យសិស្សអាន អេធើរ ៣:១៣–២០ ដោយស្ងាត់ស្ងៀមដោយរកមើលពរជ័យដែលបងប្រុសរបស់យ៉ារេឌបានទទួល ដោយសារតែសេចក្តីជំនឿរបស់លោក ។ អ្នកអាចផ្តល់ពេលវេលាដល់ពួកគេឲ្យសរសេរអំពីសេចក្តីពិតដែលគេបានរៀន និងបទពិសោធន៍ដែលគេបានទទួល ។ នៅពេលសិស្សបានមានពេលសរសេរគ្រប់គ្រានហើយ សូមគិតពីការឲ្យពួកគេពីរបីនាក់ចែកចាយអ្វីដែលពួកគេបានសរសេរ ។

នៅក្នុងមេរៀនដដែលនេះពីមុន នៅពេលសិស្សអានអំពីបងប្រុសរបស់យ៉ារេឌដែលបានឃើញនូវព្រះអង្គុលីរបស់ព្រះអម្ចាស់ នោះអ្នកបានសួរថា តើពួកគេនឹងមានអារម្មណ៍យ៉ាងណា ប្រសិនបើពួកគេបានមាននូវបទពិសោធន៍ស្រដៀងគ្នានេះ ។ ក្រោយពីពួកគេបានអានបន្ថែមអំពីបទពិសោធន៍របស់បងប្រុសរបស់យ៉ារេឌហើយ ឥឡូវនេះ អ្នកអាចគិតពីថាសួរសំណួរនេះម្តងទៀត ។

សូមថ្លែងទីបន្ទាល់ថា **នៅពេលយើងអនុវត្តសេចក្តីជំនឿដូចជាសេចក្តីជំនឿរបស់បងប្រុសរបស់យ៉ារេឌ នោះយើងនឹងខិតកាន់តែជិតទៅរកព្រះអម្ចាស់ ។**

អេធើរ ៣:២១–២៨

ព្រះអម្ចាស់បញ្ជាឲ្យបងប្រុសរបស់យ៉ារេឌកត់ត្រានូវការណ៍ទាំងឡាយដែលលោកបានឃើញ និងឲ្យបិទត្រានូវកំណត់ត្រារបស់លោក ។

សូមឲ្យសិស្សម្នាក់អាន អេធើរ ៣:២៥–២៦ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះអម្ចាស់បានបង្ហាញដល់បងប្រុសរបស់យ៉ារេឌនៅក្នុងការនិមិត្តនោះ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរៀន ។

សូមសង្ខេប អេធើរ ៣:២១–២៤, ២៧–២៨ ដោយពន្យល់ថា ព្រះអម្ចាស់បានបញ្ជាឲ្យបងប្រុសរបស់យ៉ារេឌកត់ត្រានូវអ្វីៗទាំងឡាយដែលបានលោកបានឃើញ និងបានឮ និងបានបិទត្រានូវកំណត់ត្រារបស់លោកទុក ។ ព្រះអម្ចាស់ក៏បានពន្យល់ថា ទ្រង់នឹងរៀបចំផ្លូវមួយសម្រាប់កំណត់ត្រាទាំងឡាយរបស់បងប្រុសយ៉ារេឌ ដើម្បីឲ្យត្រូវបានបកប្រែនៅក្នុងពេលអនាគត— តាមរយៈត្បូងពីរដុំ ។ ត្បូងទាំងនេះគឺជាផ្នែកមួយនៃត្បូងដែលត្រូវបានហៅថា យូរីម និង ធូមីម (សូមមើល គ. និង ស. ១៧:១; សូមមើលផងដែរ Bible Dictionary, “Urim and Thummim”) ។

សូមបញ្ចប់ដោយការអញ្ជើញសិស្សឲ្យអនុវត្តនូវអ្វីដែលពួកគេបានរៀនពីថ្ងៃនេះ —ដើម្បីស្វែងរកវិធីបង្ហាញពីសេចក្តីជំនឿ និងទំនុកចិត្តរបស់ពួកគេទៅលើព្រះអម្ចាស់ ។ សូមចែកចាយការធានារបស់អ្នកថា នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះព្រះនឹងប្រទានពរដល់យើង គឺដូចនៅពេលទ្រង់បានប្រទានពរដល់បងប្រុសរបស់យ៉ារេឌដែរ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អេធើរ ៣:១៥ ។ « ហើយយើងមិនដែលបង្ហាញរូបយើងដល់មនុស្ស »

អែលឌើរ ដៃហ្វ្រី អ័រ ហូឡិន នៃក្រុមនៃពួកសាវកដប់ពីរនាក់បានបង្ហាញពីការពន្យល់ដ៏សមរម្យមួយអំពីព្រះបន្ទូលរបស់ព្រះយេស៊ូវថា ទ្រង់មិនដែលបានបង្ហាញអង្គទ្រង់ដល់មនុស្សមុនពេលបង្ហាញអង្គទ្រង់ដល់បងប្រុសរបស់យ៉ារេឌឡើយ ៖

« ព្រះគ្រីស្ទបានមានបន្ទូលដល់បងប្រុសរបស់យ៉ារេឌថា ‹ ហើយយើងមិនដែលបង្ហាញរូបយើងដល់មនុស្ស *ដែលយើងបានបង្កើតឡើងទេ តាំតែមិនដែលមានមនុស្សណាជឿដល់យើងដូចជាអ្នកជឿឡើយ* › ។ តាមច្បាប់ ព្យាការីគឺត្រូវបាន *អញ្ជើញ* ចូលទៅក្នុងវត្តមានរបស់ព្រះអម្ចាស់ ហើយទ្រង់បានរង់ចាំឲ្យចូលទៅក្នុងវត្តមានរបស់ទ្រង់ និងដោយមានតែតាមរយៈការអនុញ្ញាតរបស់ទ្រង់ប៉ុណ្ណោះ ។ ផ្ទុយទៅវិញ បងប្រុសរបស់យ៉ារេឌហាក់ដូចជាត្រូវបានជម្រុញខ្លួនលោកឲ្យឆ្លងកាត់វាំងនន មិនមែនដូចជាភ្ញៀវដែលមិនត្រូវបានស្វាគមន៍នោះទេ ប៉ុន្តែប្រហែលជាភ្ញៀវម្នាក់ដែលមិនបានអញ្ជើញមក ។ . . . ច្បាស់ណាស់ថា ព្រះអម្ចាស់ផ្ទាល់បានភ្ជាប់នូវសេចក្តីជំនឿដ៏ពិសេស ជាមួយនឹងការនិមិត្តដ៏ពិសេសនេះ ។ ប្រសិនបើការនិមិត្តនេះមិនមែនជារឿងពិសេសនោះទេ វាប្រាកដជាសេចក្តីជំនឿ ហើយរបៀបដែលការនិមិត្តនោះត្រូវបានទទួលគឺជារឿងដែលគ្មានអ្វីមកប្រៀបផ្ទឹមបានឡើយ ។ របៀបតែមួយគត់ដែលសេចក្តីជំនឿអស្ចារ្យហួសប្រមាណ ដែលសមត្ថភាពរបស់វា ដើម្បីនាំព្យាការីដែលមិនបានអញ្ជើញរូបនេះទៅកាន់ទីកន្លែងដែលអ្នកដទៃមិនអាចទៅបាន លើកលែងតែមានបង្គាប់ពីព្រះប៉ុណ្ណោះ » (*Christ and the New Covenant ៖ The Messianic Message of the Book of Mormon* [ឆ្នាំ ១៩៩៧], ទំព័រ ២៣) ។

មេរៀនសិក្សានៅផ្ទះ

មរមន ៨:១២–អេធើរ ៣ (មេរៀនទី ២៩)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមអំពីគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេសិក្សា មរមន ៨:១២–អេធើរ ៣ (មេរៀនទី ២៩) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (មរមន ៨:១២–៤១) ។

សិស្សបានរកឃើញថា លោកម៉ូរ៉ូណៃបានឃើញនូវជំនាន់របស់យើង ហើយថាលោកបានសរសេរនូវការព្យាករណ៍អំពីស្ថានភាពដែលយើងរស់នៅ ។ ពួកគេអាចឃើញពីមូលហេតុដែលព្រះគម្ពីរមរមនគឺជាអំណោយដ៏មានតម្លៃមួយមកពីព្រះអម្ចាស់ ដែលអាចដឹកនាំពួកគេឆ្លងកាត់ថ្ងៃចុងក្រោយនេះ ។ ដោយផ្អែកលើការរៀបរាប់របស់លោកម៉ូរ៉ូណៃនៅថ្ងៃចុងក្រោយ សិស្សក៏បានសិក្សាដែរថា ព្រះនឹងឲ្យយើងទទួលខុសត្រូវចំពោះរបៀបដែលយើងប្រព្រឹត្តនឹងពួកអ្នកក្រីក្រ និងអ្នកដែលត្រូវការជំនួយទាំងឡាយ ។

ថ្ងៃទី ២ (មរមន ៩)

លោកម៉ូរ៉ូណៃបានបញ្ចប់កំណត់ត្រារបស់ឪពុកលោកដោយប្រកាសថា ប្រសិនបើយើងនឹងប្រែចិត្ត ហើយអំពាវនាវរកព្រះ នោះយើងនឹងឥតទោស នៅពេលយើងចូលទៅក្នុងវត្តមានរបស់ទ្រង់ ។ សិស្សបានរៀនមកពីលោកម៉ូរ៉ូណៃថា ដោយសារតែព្រះពុំដែលផ្លាស់ប្តូរ នោះទ្រង់នឹងប្រទាននូវអែលហេតុឲ្យកើតមាន ស្របតាមសេចក្តីជំនឿរបស់កូនចៅទ្រង់ ហើយថាប្រសិនបើយើងអធិស្ឋានដោយសេចក្តីជំនឿទៅកាព្រះវរបិតាសួគ៌ដោយនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ នោះត្រូវនឹងប្រទានដល់យើងនូវពរជ័យជាច្រើនដែលនឹងជួយយើងឲ្យសម្រេចបាននូវសេចក្តីសង្គ្រោះរបស់យើង ។

ថ្ងៃទី ៣ (អេធើរ ១–២)

សិស្សបានរៀនថា គម្ពីរអេធើរ គឺជាសេចក្តីសង្ខេបរបស់លោកម៉ូរ៉ូណៃពីផ្ទាំងមាសទាំង ២៤ ដែលត្រូវបានរកឃើញដោយប្រជាជនរបស់ស្តេចលីមហៃ ដូចដែលបានកត់ត្រានៅក្នុងគម្ពីរម៉ូសាយ ។ ផ្ទាំងទាំងនេះបានរ៉ាយរ៉ាប់នូវដំណើររឿងរបស់ប្រជាជនសាសន៍យ៉ារេឌ ដែលត្រូវបានដឹកនាំដោយព្រះអម្ចាស់ទៅកាន់ដែនដីសន្យា ។ ដោយការសិក្សាពីបទពិសោធន៍របស់សាសន៍យ៉ារេឌ សិស្សបានរៀនថា នៅពេលយើងធ្វើសកម្មភាពដោយសេចក្តីជំនឿតាមការដឹកនាំដែលព្រះអម្ចាស់បានប្រទានដល់យើងនោះ យើងអាចទទួលបានការដឹកនាំបន្តទៀតមកពីទ្រង់ ។ នៅត្រង់ចំណុចមួយនៅក្នុងការធ្វើដំណើរទៅកាន់ដែនដីសន្យា ព្រះអម្ចាស់បានផ្ទាញ់ផ្ទាលបងប្រុសរបស់យ៉ារេឌក្នុងការដែលខកខានមិនបានអំពាវនាវរកទ្រង់ ។ ដោយការសិក្សាពីបទពិសោធន៍នេះ សិស្សបានរៀនពីសារៈសំខាន់នៃការអំពាវនាវរកព្រះវរបិតាសួគ៌ជាទៀងទាត់នៅក្នុងការអធិស្ឋានរបស់ពួកគេ ។ បទពិសោធន៍បងប្រុសរបស់យ៉ារេឌជាមួយនឹងព្រះអម្ចាស់ នៅពេលកសាងកែត្រាទាំងឡាយបានជួយដល់សិស្សឲ្យយល់បានច្បាស់ថា នៅពេលយើងអំពាវនាវរកព្រះអម្ចាស់ ហើយធ្វើនូវចំណែករបស់យើងដើម្បីដោះស្រាយបញ្ហា នោះយើងអាចទទួលបានជំនួយពីព្រះអម្ចាស់ ។

ថ្ងៃទី ៤ (អេធើរ ៣)

នៅពេលបងប្រុសរបស់យ៉ារេឌបានព្យាយាមដោះស្រាយបញ្ហាស្តីពីការមានពន្លឺនៅក្នុងកែត្រានោះ លោកបានបង្ហាញថា នៅពេលយើងអំពាវនាវរកព្រះអម្ចាស់ដោយសេចក្តីពិបសា នោះទ្រង់នឹងប្រទានពរដល់យើងស្របតាមសេចក្តីជំនឿរបស់យើង និងព្រះឆន្ទៈរបស់ទ្រង់ ។ សិស្សបានរៀនថា នៅពេលយើងអនុវត្តសេចក្តីជំនឿក្នុងព្រះអម្ចាស់ នោះយើងនឹងខិតកាន់តែជិតទៅរកទ្រង់ ។ បងប្រុសរបស់យ៉ារេឌបានរស់នៅតាមគោលការណ៍ទាំងនេះ ហើយលោកបានឃើញនូវព្រះកាយខាងវិញ្ញាណរបស់ព្រះអង្គសង្គ្រោះ និងការនិមិត្តដ៏អស្ចារ្យមួយនៃប្រជាជននៅលើផែនដីទាំងអស់ ។

សេចក្តីផ្តើម

គម្ពីរអេធើរ គឺជាសេចក្តីសង្ខេបរបស់លោកម៉ូរ៉ូណៃពីបញ្ជីរបស់ពួកសាសន៍យ៉ារេឌ ។ ព្យាការីអេធើរបានកត់ត្រាអ្វីទាំងអស់នៅលើផ្ទាំងមាសទាំង ២៤ ដែលត្រូវបានរកឃើញដោយក្រុមប្រជាជនមួយក្រុមរបស់ស្តេចលីមហៃ ។ គំនិតនៃការបង្រៀនខាងក្រោមនេះនឹងជួយសិស្សឲ្យយល់ពីគោលការណ៍ខ្លះៗអំពីការអធិស្ឋាន ដែលត្រូវបានបង្រៀននៅក្នុង អេធើរ ១ ។

យោបល់សម្រាប់ការបង្រៀន

អេធើរ ១

តាមរយៈការអធិស្ឋានរបស់បងប្រុសរបស់យ៉ារេឌ លោក និងគ្រួសាររបស់លោក និងមិត្តភក្តិទាំងឡាយទទួលបានសេចក្តីមេត្តាករុណា និងការដឹកនាំ

សូមចាប់ផ្តើមថ្នាក់ដោយការសុំឲ្យសិស្សគិតអំពីស្ថានភាពមួយ ដែលពួកគេបានស្ថិតនៅ នៅពេលពួកគេពិតជាបានមានអារម្មណ៍ថាត្រូវតែអធិស្ឋានដើម្បីសុំរកជំនួយ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយពីបទពិសោធន៍របស់ពួកគេ ឬក៏ចែកចាយពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកមួយ ។

សូមរំឭកសិស្សថា គម្ពីរអេធើរ គឺជាសេចក្តីសង្ខេបរបស់លោកម៉ូរ៉ូណៃពីបញ្ជីរបស់ពួកសាសន៍យ៉ារេឌ ។ លោកយ៉ារេឌ បងប្រុសរបស់លោក មិត្តភក្តិរបស់ពួកលោក និងគ្រួសាររបស់ពួកលោកបានរស់នៅអំឡុងពេលនៃជំនាន់ប៉មបាបិល (ប្រហែលជាឆ្នាំ ២២០០ មុន.គ.ស.) នៅពេលព្រះបានបំភ័ន្តភាសារបស់មនុស្ស ។ សូមឲ្យសិស្សម្នាក់អាន អេធើរ ១:៣៣–៣៥ ឮៗ ហើយសូមឲ្យសិស្សផ្សេងទៀតរកមើលមូលហេតុដែលលោកយ៉ារេឌ និងបងប្រុសរបស់លោកបានមានអារម្មណ៍ថាត្រូវតែអធិស្ឋានដើម្បីសុំរកជំនួយ ។ មុនពេលសិស្សអាន អ្នកអាចពន្យល់ថាឃ្លា « ចូរអំពាវនាវដល់ព្រះអម្ចាស់ » គឺអាចនិយាយម្យ៉ាងទៀតថា « អធិស្ឋាន » ។ បន្ទាប់មក សូមសួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- តើលោកយ៉ារេឌ និងបងប្រុសរបស់លោកត្រូវការជំនួយអ្វីពីព្រះអម្ចាស់ ?
- តើខគម្ពីរទាំងនេះបានប្រាប់អ្នកអំពីអារម្មណ៍ដែលលោកយ៉ារេឌបានមានអំពីសេចក្តីជំនឿរបស់បងប្រុសលោកយ៉ាងណាដែរ ?

សូមបែងចែកសិស្សជាដៃគូ ។ សូមឲ្យដៃគូនីមួយៗប្តូរវេនគ្នាអានឮៗដល់គ្នាទៅវិញទៅមកចេញពីខគម្ពីរ អេធើរ ១:៣៥–៤២ ។ មុនពេលពួកគេអាន សូមឲ្យពួកគេរកមើល (១) ពេលនីមួយៗដែលបងប្រុសរបស់យ៉ារេឌអំពាវនាវដល់ព្រះអម្ចាស់ និង (២) ពេលនីមួយៗដែលព្រះអម្ចាស់បានបង្ហាញនូវសេចក្តីមេត្តាដល់បងប្រុសរបស់យ៉ារេឌ ជាលទ្ធផលនៃការអធិស្ឋានរបស់លោក ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពីរបីនាក់ចែករំលែកនូវគំរូមួយដែលព្រះអម្ចាស់បានបង្ហាញពីសេចក្តីមេត្តាដល់បងប្រុសរបស់យ៉ារេឌ និងគ្រួសាររបស់លោក ដោយសារតែការអធិស្ឋានជាច្រើនដងរបស់ពួកលោក ។

សូមសួរ ៖ ចេញពីខគម្ពីរទាំងនេះ តើគោលការណ៍អ្វី ដែលយើងអាចរៀនអំពីការអធិស្ឋាន ? ***នៅពេលយើងអំពាវនាវដល់ព្រះដោយសេចក្តីជំនឿជានិច្ចនោះទ្រង់នឹងមានសេចក្តីមេត្តាដល់យើង ។*** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។

សូមពន្យល់ដល់សិស្សថា វាជាការសំខាន់ដែលត្រូវចងចាំថា «ការអធិស្ឋាន គឺជាទង្វើមួយ ដែលតាមរយៈការណ៍នេះព្រះហឫទ័យរបស់ព្រះវរបិតា និងឆន្ទៈរបស់បុត្រទាំងពីរព្រះអង្គ ត្រូវបាននាំឲ្យមានទំនាក់ទំនងនឹងគ្នា ។ កម្មវត្ថុនៃការអធិស្ឋានគឺមិនមែនដើម្បីផ្លាស់ប្តូរព្រះឆន្ទៈរបស់ព្រះនោះទេ ប៉ុន្តែដើម្បីធានាដល់ខ្លួនយើង និងដល់អ្នកដទៃនូវពរជ័យនានា ដែលព្រះមានព្រះឆន្ទៈជាស្រេចក្នុងការប្រទានដល់យើង ប៉ុន្តែវានឹងត្រូវបានប្រទានក្នុងលក្ខខណ្ឌមួយ នៅពេលយើងទូលសុំពរជ័យទាំងនោះ » (Bible Dictionary, « Prayer ») ។

សូមឲ្យសិស្សរំឭក អេធើរ ១:៣៤, ៣៦, ៣៨ ហើយរកមើលអ្វីដែលបងប្រុសរបស់យ៉ារេឌបានទូលសូមនៅក្នុងការអធិស្ឋានរបស់លោក ។ សូមឲ្យសិស្សម្នាក់សរសេរនូវអ្វីដែលសិស្សផ្សេងទៀតបានរកឃើញនៅក្រោមឃ្លា « ចូរអំពាវនាវដល់ព្រះអម្ចាស់ » នៅក្នុងគោលការណ៍ដែលអ្នកបានសរសេរនៅលើក្តារខៀន ។

សូមបញ្ជាក់ថា លោកយ៉ារេឌ និងបងប្រុសរបស់លោកបានមានសេចក្តីជំនឿ ហើយបានមានឆន្ទៈក្នុងការគោរពតាមព្រះអម្ចាស់ ។ សូមផ្តល់យោបល់ថា សិស្សគួរតែគូសចំណាំឃ្លា « ចូរយើងមានចិត្តស្មោះត្រង់ចំពោះព្រះអម្ចាស់ » នៅចុងបញ្ចប់នៃខគម្ពីរ អេធើរ ១:៣៨ ។

សូមឲ្យសិស្សរំឭក អេធើរ ១:៣៥, ៣៧, ៤០–៤២ ហើយរកមើលរបៀបជាក់លាក់នានា ដែលព្រះបានប្រទានពរដល់បងប្រុសរបស់យ៉ារេឌ និងគ្រួសាររបស់លោក ព្រមទាំងមិត្តភក្តិទាំងឡាយផង ។ នៅពេលសិស្សរកឃើញនូវពរជ័យទាំងនេះហើយ សូមឲ្យសិស្សម្នាក់សរសេរនៅក្រោមពាក្យ *សេចក្តីមេត្តា* នៅក្នុងគោលការណ៍ដែលអ្នកបានសរសេរនៅលើក្តារខៀន ។ សូមបង្ហាញថា ព្រះអម្ចាស់បានប្រទានដល់បងប្រុសរបស់យ៉ារេឌនូវពរជ័យទាំងឡាយ ដែលលោកបានអធិស្ឋានសូម ។

សូមសរសេរនូវសំណួរខាងក្រោមនៅលើក្តារខៀន ឬរៀបចំវាជាក្រដាសចែកដល់សិស្ស ។ សំណួរទាំងនេះនឹងជួយពួកគេឲ្យយល់ ហើយជ្រាបយ៉ាងច្បាស់ពីសារៈសំខាន់នៃគោលការណ៍នេះ ។

តើអ្នកគិតថា « ចូរអំពាវនាវដល់ព្រះ » ខុសគ្នាពីការគ្រាន់តែ « ពោលពាក្យអធិស្ឋាន » ដោយរបៀបណា ?

តើនៅពេលណាដែលអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ បានទទួលនូវសេចក្តីមេត្តារបស់ព្រះវរបិតាសួគ៌ដែលជាចម្លើយតបទៅនឹងការអធិស្ឋានមួយនោះ ?

តើអ្នកអាចរៀនអ្វីខ្លះពីព្រះអម្ចាស់ នៅក្នុងការឆ្លើយតបរបស់ទ្រង់ចំពោះការអធិស្ឋានរបស់បងប្រុសរបស់យ៉ារេឌនោះ ?

នៅពេលសិស្សបានមានពេលពិភាក្សាពីសំណួរទាំងនេះហើយ អ្នកអាចសុំឲ្យពួកគេចែករំលែកនូវបទពិសោធន៍មួយដែលពួកគេបានពិភាក្សានៅក្នុងក្រុមរបស់ពួកគេ ឬចែករំលែកនូវការយល់ដឹងនានាចេញពីការពិភាក្សានោះ ។

សូមចែករំលែកនូវទីបន្ទាល់របស់អ្នកអំពីសេចក្តីស្រឡាញ់របស់ព្រះវរបិតាសួគ៌សម្រាប់យើងទាំងអស់គ្នា និងព្រះរាជបំណងរបស់ទ្រង់ក្នុងការប្រទានពរដល់យើង នៅពេលយើងអំពាវនាវដល់ទ្រង់ជាទៀងទាត់នោះ ។ សូមឲ្យសិស្សគិតពិចារណាពីរបៀបដែល ពួកគេអាចអនុវត្តគោលការណ៍នៅលើក្តារខៀន ។ ឧទាហរណ៍ ពួកគេអាចដាក់គោលដៅមួយដើម្បីអធិស្ឋានកាន់តែទៀងទាត់ជាងនេះ ឬជ្រើសរើសរបៀបមួយដើម្បីធ្វើឲ្យការអធិស្ឋានរបស់ពួកគេកាន់តែស្មោះត្រង់ជាងនេះបន្ថែមទៀត ។ អ្នកអាចចង់ឲ្យពួកគេមានពេលខ្លះដើម្បីសរសេរនូវអ្វីដែលពួកគេចង់ធ្វើទៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់ពួកគេ ។

សូមពន្យល់ថា ការសិក្សាអំពីការអធិស្ឋានរបស់បងប្រុសរបស់យ៉ារេឌ អាចផ្តល់នូវការយល់ដឹងបន្ថែមទៀតដល់យើងអំពីសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ចំពោះយើងទាំងអស់គ្នា និងអំពីពរជ័យនានាដែលមកតាមរយៈការអធិស្ឋាន ។ សូមឲ្យសិស្សម្នាក់អាន អេធើរ ១:៤៣ ឭ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពរជ័យបន្ថែមទាំងឡាយដែលព្រះបានសន្យានឹងលោកយ៉ារេឌ និងបងប្រុសរបស់លោក ។ ក្រោយពីសិស្សបានរៀបរាប់ពីអ្វីដែលពួកគេបានរៀនហើយ សូមបង្ហាញថា បងប្រុសរបស់យ៉ារេឌមិនបានអធិស្ឋានជាពិសេសដើម្បីទូលសុំពរជ័យក្នុងការមានកូនចៅជំនាន់ជាជាតិសាសន៍ដ៏អស្ចារ្យមួយនោះឡើយ ។ អ្នកអាចផ្តល់យោបល់ថា សិស្សគួរគូសចំណាំនៅក្នុងព្រះគម្ពីររបស់ពួកគេនូវឃ្លានៅចុងបញ្ចប់នៃខគម្ពីរ អេធើរ ១:៤៣ ដែលបង្ហាញពីមូលហេតុដែលព្រះបានឆ្លើយតបទៅនឹងការអធិស្ឋានរបស់បងប្រុសរបស់យ៉ារេឌរបៀបនេះ ៖ « ដោយសារពេលដ៏យូរនេះ អ្នករាល់គ្នាបានអង្វរដល់យើង » ។

សូមសួរ ៖ តើគោលការណ៍អ្វីខ្លះ ដែលយើងអាចរៀនពីការសប្បុរសរបស់ព្រះអម្ចាស់ចំពោះលោកយ៉ារេឌ និងបងប្រុសរបស់លោក ដូចដែលបានបង្ហាញនៅក្នុង អេធើរ ១:៤៣ ?

មានគោលការណ៍ជាច្រើនដែលយើងអាចរៀនពីគម្ពីរនេះ ។ គោលការណ៍ដ៏សំខាន់មួយនោះគឺ ៖ **ប្រសិនបើយើងអធិស្ឋានទៅដល់ព្រះដោយសេចក្តីជំនឿជាទៀងទាត់ នោះយើងអាចនឹងទទួលបាននូវពរជ័យទាំងឡាយដែលហួសពីអ្វីដែលយើងបានសុំទៅទៀត ។**

សូមសួរ ៖ តើនៅពេលណាដែលអ្នកបានទទួលនូវបទពិសោធន៍មួយ ដែលបង្ហាញថាគោលការណ៍នេះគឺពិតមែននោះ ? តើអ្នកមានស្គាល់នរណាម្នាក់ដែលបានមានបទពិសោធន៍បែបនោះ ឬតើអ្នកអាចគិតអំពីនរណាម្នាក់នៅក្នុងគម្ពីរនេះដែលទទួលបាននូវបទពិសោធន៍បែបនេះទេ ? (សូមប្រាប់សិស្សថា អ្នកនឹងផ្តល់នូវពេលមួយសន្ទុះដល់ពួកគេដើម្បីឲ្យគិតអំពីឧទាហរណ៍នានា មុនពេលអ្នកសុំពួកគេឲ្យឆ្លើយតប ។ អ្នកក៏អាចចែករំលែកឧទាហរណ៍មួយចេញពីជីវិតរបស់អ្នកផ្ទាល់បានដែរ) ។

ដើម្បីបញ្ចប់មេរៀននេះ សូមចែកចាយទីបន្ទាល់របស់អ្នកថា ព្រះទ្រង់សណ្តាប់ និងឆ្លើយតបចំពោះការអធិស្ឋានរបស់យើងទាំងឡាយ ។ ទ្រង់មានចំណេះដឹងដ៏ពេញលេញ និងពោរពេញទៅដោយសេចក្តីមេត្តា ព្រមទាំងមានព្រះទ័យចង់ប្រទានពរដល់កូនចៅរបស់ទ្រង់ ។ ទ្រង់មានព្រះទ័យពេញចិត្ត នៅពេលយើងអធិស្ឋានទៅកាន់ទ្រង់ដោយស្មោះត្រង់ និងជាទៀងទាត់ឥតដាច់ ។ សូមអញ្ជើញសិស្សឲ្យខិតខំអធិស្ឋានដោយសេចក្តីជំនឿកាន់តែខ្លាំងថែមទៀត ។ សូមអញ្ជើញពួកគេឲ្យចងចាំថា ព្រះវរបិតាសួគ៌គឺពោរពេញទៅដោយសេចក្តីមេត្តាករុណា ហើយថាទ្រង់នឹងឆ្លើយតបចំពោះការអធិស្ឋានរបស់ពួកគេ ស្របតាមអ្វីដែលទ្រង់បានជ្រាបថានឹងនាំមកនូវពរជ័យដ៏អស្ចារ្យដល់ជីវិតរបស់ពួកគេ ។

មេរៀនបន្ទាប់ (អេធើរ ៤–១២)

នៅក្នុងមេរៀនបន្ទាប់ សិស្សនឹងរៀនបន្ថែមទៀតអំពីពួកសាសន៍យ៉ារេឌ ។ ទោះបីជាព្យាការីលោកបានព្រមានដល់ពួកសាសន៍យ៉ារេឌថា កុំឲ្យតែងតាំងស្តេចក្តី ក៏ប្រជាជននៅតែធ្វើដូច្នោះ ហើយមហាក្សត្រទាំងឡាយដឹកនាំប្រជាជនឲ្យធ្លាក់ទៅក្នុងសេវកភាព ។ អ្នកដែលចង់បានអំណាចខាងលោកិយ ជាទូទៅនឹងប្រើនូវបក្សព័ន្ធសម្ងាត់នានាដើម្បីបន្តបំណងដ៏អាត្មានិយមរបស់ពួកគេ ។ លោកម៉ូរ៉ូណៃកត់ត្រាអំពីរឿងដ៏អស្ចារ្យជាច្រើន ដែលត្រូវបានកើតឡើង ដោយសារប្រជាជនខ្លះបានមានសេចក្តីជំនឿដ៏អស្ចារ្យខ្លាំង ។ លោកបង្រៀនថា អស់អ្នកណាដែលបន្ទាបខ្លួនគេនៅចំពោះមុខព្រះ ហើយមានសេចក្តីជំនឿលើទ្រង់ នោះនឹងទទួលបានសិរីល្អរបស់ទ្រង់ដើម្បីជួយពួកគេឲ្យយកឈ្នះលើភាពទន់ខ្សោយរបស់ពួកគេ ។

អេធើរ ៤–៥

សេចក្តីផ្តើម

ព្រះអម្ចាស់បានបញ្ជាដល់លោកម៉ូរ៉ូណៃឲ្យបិទត្រានូវការនិមិត្តដែលបានកត់ត្រាទុកអំពីបងប្រុសរបស់លោកយ៉ារេឌ និងបានពន្យល់ថា ការសរសេរទាំងនេះនឹងត្រូវបានបង្ហាញនៅពេលប្រជាជនមានសេចក្តីជំនឿដូចជាបងប្រុសរបស់យ៉ារេឌ ។ លោកម៉ូរ៉ូណៃបានព្យាករណ៍ថា សាក្សីបីនាក់នឹងថ្លែងទីបន្ទាល់អំពីសេចក្តីពិតពេញលេញនៃព្រះគម្ពីរមរមនៅក្នុងថ្ងៃចុងក្រោយ ។

យោបល់សម្រាប់ការបង្រៀន

អេធើរ ៤:១–៧

លោកម៉ូរ៉ូណៃកត់ត្រា និងបិទត្រានូវដំណើររឿងពេញលេញនៃការនិមិត្តរបស់បងប្រុសរបស់យ៉ារេឌ

សូមឲ្យសិស្សគិតអំពីវត្ថុមួយដែលមានតម្លៃជាពិសេស ដល់ពួកគេ ឬដល់គ្រួសាររបស់ពួកគេ ហើយថាពួកគេអាចរក្សាទុកវាកុំឲ្យក្មេងៗប៉ះពាល់វា ។ ជាឧទាហរណ៍ អ្នកអាចបង្ហាញ ឬរៀបរាប់ពីអ្វីមួយដែលមានតម្លៃដល់អ្នក ។

- **ហេតុអ្វីបានជាអ្នកនឹងមិនអនុញ្ញាតឲ្យក្មេងម្នាក់ឈោងចាប់យកវត្ថុបែបនោះបាន ?**
- **តើក្មេងម្នាក់នោះនឹងត្រូវរៀន ឬធ្វើអ្វីខ្លះ មុនពេលអ្នកនឹងទុកចិត្តលើគេថាគេអាចកាន់វត្ថុនោះបាន ?**

សូមពន្យល់ថា សេចក្តីពិតនៃដំណឹងល្អមានតម្លៃជាខ្លាំងដល់ព្រះអម្ចាស់ ។ ទ្រង់ចង់ចែករំលែកវាទាំងអស់ដល់យើង ប៉ុន្តែទ្រង់រង់ចាំរហូតដល់យើងរួចរាល់ជាស្រេចដើម្បីទទួលវា ។ នៅពេលសិស្សសិក្សាពី អេធើរ ៤ អំឡុងពេលមេរៀននេះ សូមអញ្ជើញពួកគេឲ្យរកមើលគោលការណ៍នានាដែលអាចជួយពួកគេឲ្យរៀបចំដើម្បីទទួលបានសេចក្តីពិតមកពីព្រះអម្ចាស់ ។

សូមឲ្យសិស្សម្នាក់អាន អេធើរ ៤:១– ៥ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលព្រះអម្ចាស់បានបញ្ជាឲ្យលោកម៉ូរ៉ូណៃកត់ត្រា និងបិទត្រាទុក ។

- **តើលោកម៉ូរ៉ូណៃត្រូវបានបញ្ជាឲ្យ « បិទទុក » អ្វី ?**

សូមពន្យល់ថា លោកម៉ូរ៉ូណៃបានបញ្ចប់កំណត់ត្រាអំពីបងប្រុសរបស់យ៉ារេឌនៅក្នុងរបៀបមួយដែលជាញឹកញាប់ត្រូវបានហៅថា ចំណែកបិទត្រាទុកនៃព្រះគម្ពីរមរមន ។ (អ្នកអាចបង្ហាញតារាងដែលមានចំណងជើងថា ប្រភពនៃព្រះគម្ពីរមរមន ដែលស្ថិតនៅក្នុងឧបសម្ព័ន្ធនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ) ។

- **តើលោកម៉ូរ៉ូណៃបានរៀបរាប់អ្វីដែលបងប្រុសរបស់យ៉ារេឌបានឃើញដោយរបៀបណា ? (សូមមើល អេធើរ ៤:៤) ។**

ដើម្បីជួយសិស្សឲ្យសិក្សាបន្ថែមទៀតអំពីអ្វីដែលព្រះអម្ចាស់បានបង្ហាញដល់បងប្រុសរបស់យ៉ារេឌ សូមឲ្យពួកគេអាន អេធើរ ៣:២៥–២៦ និង នីហ្វៃទី ២ ២៧:៨–១០ ដោយស្ងាត់ស្ងៀម ។ បន្ទាប់មក សួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- **យោងតាម អេធើរ ៣:២៥–២៦ តើព្រះអម្ចាស់បានបង្ហាញអ្វីដល់បងប្រុសរបស់យ៉ារេឌ ?**
- **យោងតាម នីហ្វៃទី ២ ២៧:១០ តើចំណែកបិទត្រាទុកនៃព្រះគម្ពីរមរមនរួមមានអ្វីខ្លះ ?**

សូមឲ្យសិស្សម្នាក់អាន អេធើរ ៤:៦–៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម និងរកមើលលក្ខខណ្ឌដែលត្រូវតែមាន មុនពេលវិវរណៈទាំងឡាយដែលត្រូវបានប្រទានដល់បងប្រុសរបស់យ៉ារេឌ ត្រូវបានប្រកាសប្រាប់ ។ អ្នកអាចអញ្ជើញសិស្សឲ្យគូសចំណាំអ្វីដែលពួកគេរកឃើញនៅក្នុងព្រះគម្ពីររបស់ពួកគេ ។

- **តើលក្ខខណ្ឌអ្វីខ្លះដែលអ្នកបានរកឃើញ ?**
- **តើគោលការណ៍អ្វីខ្លះអំពីការទទួលបាននូវវិវរណៈ ដែលយើងអាចរៀនពីវគ្គគម្ពីរនេះ ? (សូមជួយសិស្សឲ្យឃើញថា **នៅពេលយើងប្រែចិត្ត និងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចទទួលបានវិវរណៈបន្ថែមទៀត**) ។**
- **តើអ្នកគិតថា ហេតុអ្វីបានជាយើងត្រូវប្រែចិត្ត និងត្រូវតែស្អាតស្អំដើម្បីទទួលបានវិវរណៈបន្ថែមទៀត ?**

ដើម្បីជួយសិស្សឲ្យយល់ពីអត្ថន័យនៃ « អនុវត្តសេចក្តីជំនឿ . . . ដូចដែលបងរបស់យ៉ារេឌបានធ្វើ » (អេធើរ ៤:៧) សូមឲ្យពួកគេសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់អំពីអ្វីដែលពួកគេអាចចងចាំឲ្យច្រើនតាមដែលអាចធ្វើទៅបានថា បងប្រុសរបស់យ៉ារេឌបានបង្ហាញសេចក្តីជំនឿលើព្រះអម្ចាស់ ។ អ្នកអាចណែនាំថា ពួកគេគួរតែរំឭក អេធើរ ១–៣ នៅពេលពួកគេប្រមូលនូវគំនិតទាំងនេះ ។ នៅពេលពួកគេមានពេលគ្រប់គ្រាន់ដើម្បីសញ្ជឹងគិត និងសរសេរហើយ សូមឲ្យសិស្សពីរបីនាក់អានឧទាហរណ៍ខ្លះដែលពួកគេបានសរសេរ និងឲ្យគេពន្យល់ពីមូលហេតុដែលឧទាហរណ៍ទាំងនោះបានធ្វើឲ្យពួកគេរំភើប ។

សូមរំឭកសិស្សអំពីវត្ថុដ៏មានតម្លៃដែលពួកគេបានគិត នៅពេលចាប់ផ្តើមថ្នាក់ និងពីលក្ខខណ្ឌដែលពួកគេនឹងដាក់មុនពេលពួកគេទុកចិត្តលើក្មេងម្នាក់ ។ សូមធ្វើទីបន្ទាល់ថា តាមរបៀបដូចគ្នានេះ ព្រះអម្ចាស់តម្រូវឲ្យកូនចៅរបស់ទ្រង់បំពេញតាមលក្ខខណ្ឌមួយចំនួន

មុនពេលទ្រង់នឹងបង្ហាញសេចក្តីពិតទាំងឡាយរបស់ទ្រង់ដល់ពួកគេ ។ ទ្រង់តម្រូវឲ្យយើងបង្ហាញនូវការរៀបចំជាស្រេចខាងវិញ្ញាណ និងសេចក្តីជំនឿរបស់យើង ។

អេធើរ ៤:៨–១៩

ព្រះអម្ចាស់បង្រៀនពីអ្វីដែលយើងត្រូវធ្វើ ដើម្បីទទួលបានវិវរណៈបន្ថែមទៀត

សូមលើកក្រណាត់មួយផ្ទាំងឡើង ។ សូមពន្យល់ថា ព្រះអម្ចាស់បានបង្រៀនគោលការណ៍ទាំងឡាយដែលអាចជួយយើងឲ្យទទួលបាននូវវិវរណៈ ។ នៅពេលទ្រង់បានបង្រៀនពីគោលការណ៍ទាំងនេះ ទ្រង់បានសំដៅទៅលើវាំងននមួយ ។ វាំងនន គឺជាស្បៃមួយឬក្រណាត់មួយផ្ទាំងដែលត្រូវបានប្រើដើម្បីគ្រប ឬបាំងអ្វីមួយ ។

សូមឲ្យសិស្សអាន អេធើរ ៤:១៥ ដោយស្ងាត់ស្ងៀម ហើយរកមើលឃ្លាដែលរួមមាននូវពាក្យ *វាំងនន* ។

- តើវាំងននប្រភេទណាដែលព្រះអម្ចាស់សំដៅលើនោះ ? (« វាំងននៃការឥតជំនឿ » មួយ) ។ តើការឥតជំនឿដូចជាវាំងននមួយដោយរបៀបណា ?
- ពាក្យ *ហែក* មានន័យថាជ្រៀក ឬបែងចែក ។ តើអ្នកគិតថា វាមានន័យយ៉ាងណាក្នុងការ « ហែកវាំងននៃការឥតជំនឿមួយ » ?

សូមឲ្យសិស្សម្នាក់អាន អេធើរ ៤:៨ ឮៗ ហើយសិស្សម្នាក់ទៀតអាន អេធើរ ៤:១១ ឮៗ ហើយម្នាក់ទៀតអាន អេធើរ ៤:១៥ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម និងរកមើលអ្វីដែលអាចរារាំងយើងពីការទទួលបាននូវវិវរណៈ និងអ្វីដែលអាចជួយយើងឲ្យ « ហែកវាំងននៃការឥតជំនឿ » ហើយទទួលបាននូវវិវរណៈបន្ថែមទៀត ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាដើម្បី « តតាំងទាស់នឹងព្រះបន្ទូលនៃព្រះអម្ចាស់ » ? (អេធើរ ៤:៨) ។
- យោងតាម អេធើរ ៤:៨ តើលទ្ធផលអ្វីដែលយើងនឹងជួប នៅពេលយើងតតាំងទាស់នឹងព្រះបន្ទូលនៃព្រះអម្ចាស់ ?
- ស្របតាម អេធើរ ៤:១១ តើអ្វីជាពរជ័យមួយ ដែលយើងទទួលបាន នៅពេលយើងជឿតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ ?

សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖

នៅពេលយើងជឿតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ . . .

សូមឲ្យសិស្សបំពេញប្រយោគនេះ ស្របតាមអ្វីដែលពួកគេបានរៀនពីក្នុងខគម្ពីរទាំងនេះ ។ ទោះបីជាសិស្សអាចមានចម្លើយខុសគ្នាក្តី សូមប្រាកដថា ពួកគេរកឃើញគោលការណ៍ខាងក្រោម ៖ ***នៅពេលយើងជឿតាមព្រះបន្ទូលរបស់ព្រះអម្ចាស់ នោះព្រះអម្ចាស់នឹងប្រទានពរដល់យើងឲ្យទទួលបានវិវរណៈបន្ថែមទៀត ។*** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន ។ អ្នកក៏អាចអញ្ជើញសិស្សឲ្យសរសេរវានៅក្នុងព្រះគម្ពីររបស់គេក្បែរ អេធើរ ៤:១១ ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍នេះ សូមសួរ ៖

- តើអ្នកគិតថា ហេតុអ្វីបានជាយើងត្រូវជឿលើសេចក្តីពិត ដែលយើងបានទទួលរួចមកហើយ មុនពេលព្រះអម្ចាស់នឹងប្រទានដល់យើងបន្ថែមទៀតនោះ ?

សូមឲ្យសិស្សម្នាក់សរសេរនៅលើក្តារខៀននូវគំរូនៃការអនុវត្តសេចក្តីជំនឿខាងក្រោមនៅក្នុងព្រះបន្ទូលព្រះអម្ចាស់ ៖ *ការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន ; ការធ្វើតាមការបំផុសគំនិតមកពីព្រះវិញ្ញាណបរិសុទ្ធ ; ការធ្វើតាមអ្នកដឹកនាំសាសនាចក្រក្នុងស្រុក ; ការសិក្សាព្រះគម្ពីរនៅក្នុងសាសនាចក្រ និងក្នុងថ្នាក់សិក្ខាសាលា ; ការធ្វើតាមពាក្យសម្តីរបស់ព្យាការីថ្ងៃចុងក្រោយ ។*

សូមឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលការបង្ហាញជំនឿទៅលើព្រះបន្ទូលព្រះអម្ចាស់តាមរបៀបមួយ នៃរបៀបទាំងនេះ បានដឹកនាំពួកគេឲ្យទទួលបានវិវរណៈបន្ថែមទៀត ។ សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែកចាយអ្វីដែលពួកគេបានជួប ។

សូមសំដៅជាថ្មីម្តងទៀតទៅលើឧទាហរណ៍ដែលបានសរសេរនៅលើក្តារខៀន ។ សូមឲ្យសិស្សពិចារណាពីឧទាហរណ៍ទាំងនោះ នៅពេលពួកគេសញ្ជឹងគិតដោយស្ងាត់ស្ងៀមអំពីរបៀបណាដែលល្អដើម្បីបង្ហាញជំនឿរបស់ពួកគេទៅលើព្រះបន្ទូលនៃព្រះ ។ សូមណែនាំ ចំពោះឧទាហរណ៍នីមួយៗ ពួកគេគួរវាយតម្លៃលើខ្លួនគេពី ១ ដល់ ១០ ដោយការដាក់លេខ ១០ មាននិយមថា ឧទាហរណ៍នេះសំដៅទៅលើអ្វីមួយដែលពួកគេបានធ្វើល្អប្រសើរ ។ សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬសៀវភៅសរសេរក្នុងថ្នាក់អំពីរបៀបមួយដែលពួកគេអាចបង្ហាញនូវសេចក្តីជំនឿកាន់តែខ្លាំងជាងមុន ទៅតាមការដឹកនាំដែលពួកគេបានទទួលពីព្រះអម្ចាស់រួចមកហើយនោះ ។ សូមចែកចាយទីបន្ទាល់របស់អ្នកអំពីគោលការណ៍ដែលអ្នកបានសរសេរនៅលើក្តារខៀន ហើយសូមលើកទឹកចិត្តសិស្សឲ្យធ្វើតាមគោលដៅដែលពួកគេបានសរសេរមកនោះ ។

សូមលុបឃ្លា « ជឿលើព្រះបន្ទូលព្រះអម្ចាស់ » ពីលើក្តារខៀន ។ សូមបង្ហាញថា ព្រះអម្ចាស់បានបង្រៀនពីគោលការណ៍បន្ថែមទៀតអំពីការទទួលបានវិវរណៈ ។ សូមឲ្យសិស្សអាន អេធើរ ៤:១៣–១៥ ដោយស្ងាត់ស្ងៀម ដោយរកមើលរឿងផ្សេងៗទៀតដែលពួកគេអាចធ្វើបាន ដើម្បីទទួលបានវិវរណៈពីព្រះអម្ចាស់ ។

នៅពេលសិស្សបានមានពេលអានហើយ សូមឲ្យពួកគេផ្តល់យោបល់ពីរបៀបដើម្បីបំពេញប្រយោគនេះ ។ ចម្លើយអាចរួមមានគោលការណ៍ដូចខាងក្រោម ៖ **នៅពេលយើងចូលមករកព្រះអម្ចាស់ នោះព្រះអម្ចាស់នឹងប្រទានពរដល់យើងឲ្យទទួលបានវិវរណៈបន្ថែមទៀត ។ នៅពេលយើងអធិស្ឋានដោយរាបសា នោះព្រះអម្ចាស់នឹងប្រទានពរដល់យើងឲ្យទទួលបានវិវរណៈបន្ថែមទៀត ។**

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍ទាំងនេះកាន់តែច្បាស់ សូមគិតពីការសួរសំណួរដូចខាងក្រោមនេះ ៖

- តើវាមានន័យយ៉ាងណាចំពោះអ្នក ដើម្បីមករកព្រះអម្ចាស់ ? (ចម្លើយអាចរួមមាន ការសិក្សាព្រះបន្ទូលរបស់ទ្រង់ ការបែរដួងចិត្តទៅរកទ្រង់ ការប្រែចិត្ត និងការធ្វើតាម ព្រមទាំងគោរពតាមទ្រង់) ។

- តើវាមានន័យយ៉ាងណា ដែលមានចិត្តសង្រេង និង វិញ្ញាណទន់ទាប ? (ការបន្ទាបខ្លួន ប្រែចិត្ត និងទទួលយកតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់) ។ តើហេតុអ្វីបានជាឥរិយាបថទាំងនេះចាំបាច់ នៅពេលយើងអធិស្ឋានសុំឲ្យមានវិវរណៈបន្តមកពីព្រះអម្ចាស់ ?

សូមឲ្យសិស្សពិចារណាពីរបៀបដែលពួកគេអាចអនុវត្តគោលការណ៍ទាំងនេះនៅក្នុងការខិតខំរបស់គេដើម្បីទទួលបានវិវរណៈ ។

សូមសង្ខេប អេធើរ ៤:១៧–១៩ ដោយការពន្យល់ថា ព្រះអម្ចាស់បានប្រកាសថា ការលេចចេញមកនៃព្រះគម្ពីរមរមនគឺជាទីសម្គាល់មួយថា កិច្ចការថ្ងៃចុងក្រោយរបស់ព្រះបានប្រកាសហើយ ។ ទ្រង់ក៏បានតឿនឲ្យប្រជាជនទាំងឡាយប្រែចិត្ត និងចូលមករកទ្រង់ដែរ ។

អេធើរ ៥

លោកម៉ូរ៉ូណៃប្រកាសថា សាក្សីបីនាក់នឹងឃើញ ព្រមទាំងថ្លែងទីបន្ទាល់អំពីផ្នាំងចំណារទាំងឡាយ

សូមលើករូបភាព យ៉ូសែប ស៊្មីធ កំពុងបកប្រែព្រះគម្ពីរមរមន ឡើង (*សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ |, លេខ ៩២) ។ សូមឲ្យសិស្សម្នាក់អាន អេធើរ ៥:១–៣ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយស្រមៃមើលនូវអ្វីដែលវាអាចកើតមានឡើង ពេលយ៉ូសែប ស៊្មីធ បកប្រែព្រះគម្ពីរមរមន ហើយដឹងថាការប្រឹក្សានេះត្រូវបានសរសេរដោយផ្ទាល់ដល់លោក ដោយលោកម៉ូរ៉ូណៃកាលពីជាង ១,៤០០ ឆ្នាំមុននោះ ។

- តើលោកម៉ូរ៉ូណៃបានមានប្រសាសន៍អ្វីខ្លះ អំពីផ្នាំងចំណារទាំងឡាយដែលលោកបាន « បិទត្រាទុក » នោះ ?
- យោងតាម អេធើរ ៥:២–៣ តើយ៉ូសែប នឹងត្រូវមានអភ័យឯកសិទ្ធិដើម្បីធ្វើអ្វីជាមួយនឹងផ្នាំងចំណារទាំងនោះ ?

សូមឲ្យសិស្សប្រាប់ឈ្មោះសាក្សីនៃព្រះគម្ពីរមរមនបីនាក់ និងរំឭកពីអ្វីដែលពួកលោកបានជួប ។ (ប្រសិនបើសិស្សត្រូវការជំនួយ សូមឲ្យពួកគេអាន « ទីបន្ទាល់នៃពួកសាក្សីបីនាក់ » នៅដើមទំព័រនៃព្រះគម្ពីរមរមន) ។ អ្នកអាចពន្យល់ថា បន្ថែមទៅលើសាក្សីបីនាក់ អ្នកផ្សេងទៀតបានថ្លែងទីបន្ទាល់អំពីភាពពិតនៃផ្នាំងចំណារមាស រួមមានសមាជិកនៃក្រុមព្រះ (សូមមើល អេធើរ ៥:៤) ម៉ូរ៉ូណៃ (សូមមើល អេធើរ ៥:៦) យ៉ូសែប ស៊្មីធ និងសាក្សីប្រាំបីនាក់ ។

- តើអ្នកអាចក្លាយជាសាក្សីម្នាក់នៃព្រះគម្ពីរមរមនដោយរបៀបណា ទោះបីជាមិនបានមើលឃើញផ្នាំងចំណារក្តី ? តើទីបន្ទាល់របស់អ្នកអំពីព្រះគម្ពីរមរមនអាចមានឥទ្ធិពលលើមនុស្សផ្សេងទៀតដោយរបៀបណា ?

ដើម្បីបញ្ចប់មេរៀននេះ សូមឲ្យសិស្សពីរបីនាក់ចែកចាយទីបន្ទាល់របស់ពួកគេអំពីព្រះគម្ពីរមរមន ។

អេធើរ ៦

សេចក្តីផ្តើម

ក្រោយពីការរៀបចំស្របតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះអម្ចាស់ហើយ ពួកប្រជាជនយ៉ារេឧបានឡើងទៅក្នុងភេត្រា ដោយទុកចិត្តថា ព្រះអម្ចាស់នឹងនាំពួកគេឆ្លងកាត់ការធ្វើដំណើរដ៏ពិបាករបស់គេទៅកាន់ដែនដីសន្យា ។ ព្រះអម្ចាស់បានបញ្ជូនខ្យល់ដែលរុញភេត្រាដោយរលកសមុទ្រ និងជ្រមុជទៅក្នុងទឹកជាច្រើនដង ប៉ុន្តែខ្យល់បានច្រានភេត្រាទាំងនោះទៅដល់ដែនដីសន្យា ។ ក្នុងការស្តាប់បន្ទាន់ខ្លួនគេនៅក្នុងដែនដីថ្មីនេះ ប្រជាជនបានជ្រើសរើសឲ្យមានស្តេចមួយអង្គ ទោះបីជាមានការព្រមានពីបងប្រុសរបស់យ៉ារេឧក្តី ។

យោបល់សម្រាប់ការបង្រៀន

អេធើរ ៦:១–១២

ព្រះអម្ចាស់បណ្តាលឲ្យមានខ្យល់បក់ដល់ភេត្រារបស់ពួកសាសន៍យ៉ារេឧទៅកាន់ដែនដីសន្យា

សូមសរសេរឃ្លាដូចខាងក្រោមនៅលើក្តារខៀនមុនចាប់ផ្តើមបង្រៀន ៖

ការចែកចាយដំណឹងល្អជាមួយនឹងមិត្តភក្តិ

ការរក្សាសីលធម៌ស្អាតស្អំ

ការជ្រើសរើសមិត្តភក្តិដែលមានបទដ្ឋានខ្ពស់

ការដាក់អាទិភាពត្រឹមត្រូវនៅក្នុងជីវិត

សូមបង្ហាញថា ទាំងនេះគឺជាឧទាហរណ៍នៃរឿងដែលព្រះអម្ចាស់ចង់ឲ្យយើងធ្វើ ។ ទោះជាយ៉ាងណាក្តី ក៏ប្រជាជនខ្លះគិតថារឿងទាំងនេះពិបាកធ្វើខ្លាំងណាស់ ។ សូមឲ្យសិស្សគិតអំពីឧទាហរណ៍ផ្សេងទៀតដែលអាចបន្ថែមទៅក្នុងបញ្ជីនេះ ។ សូមពន្យល់ថា ដំណើររឿងនៃការធ្វើដំណើររបស់ពួកសាសន៍យ៉ារេឧទៅកាន់ដែនដីសន្យារួមមានគោលការណ៍ជាច្រើនដែលអាចដឹកនាំយើង នៅពេលយើងគិតថាវាពិបាកនឹងធ្វើតាមអ្វីដែលព្រះអម្ចាស់បានបញ្ជាឲ្យយើងធ្វើ ។ សូមអញ្ជើញសិស្ស នៅពេលពួកគេសិក្សា អេធើរ ៦ ឲ្យរកមើលគោលការណ៍នានាដែលនឹងជួយពួកគេឲ្យទប់ទល់នឹងឧបសគ្គនានាដូចជាអ្វីដែលបានសរសេរនៅលើក្តារខៀន ។

សូមឲ្យសិស្សម្នាក់អាន អេធើរ ២:២៤–២៥ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលការព្រមានរបស់ព្រះអម្ចាស់ដល់ពួកសាសន៍យ៉ារេឧអំពីភាពលំបាកនៃការធ្វើដំណើររបស់ពួកគេទៅកាន់ដែនដីសន្យា ។

- តើព្រះអម្ចាស់បានសន្យាថាទ្រង់នឹងធ្វើអ្វីខ្លះ ដើម្បីជួយដល់ពួកសាសន៍យ៉ារេឧឲ្យធ្វើដំណើរដោយសុវត្ថិភាពទៅកាន់ដែនដីសន្យា ?

សូមរំឭកសិស្សថា ដើម្បីប្រឈមនឹងរលក ព្រមទាំងខ្យល់ផង ពួកសាសន៍យ៉ារេឧបានសាងសង់ភេត្រាជាច្រើនដែល « ជិតជាខ្លាំងដូចជាចានមួយ » (អេធើរ ២:១៧) ដោយមានប្រហោងនៅខាងលើ និងខាងក្រោមដែលអនុញ្ញាតឲ្យពួកគេទទួលបានខ្យល់ពីខាងក្រៅ ។ សូមឲ្យសិស្សម្នាក់អាន អេធើរ ៦:១–៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម និងរកមើលរបៀបផ្សេងទៀតដែលពួកសាសន៍យ៉ារេឧបានរៀបចំដើម្បីប្រឈមទៅនឹងភាពលំបាកទាំងនេះ ។

- តើអ្នកគិតថា វាមានន័យយ៉ាងណា ដែលពួកសាសន៍យ៉ារេឧបានចុះភេត្រា « ដោយទីពឹងដល់ព្រះអម្ចាស់ ជាព្រះរបស់ពួកគេ » ? (ពួកគេបានទុកចិត្តទៅលើព្រះក្នុងការយកចិត្តទុកដាក់ និងការថែទាំដល់ពួកគេ) ។
- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់សម្រាប់ពួកសាសន៍យ៉ារេឧដើម្បីទីពឹងដល់ព្រះអម្ចាស់ ក្រោយពីបានធ្វើអ្វីៗទាំងអស់ដែលពួកគេអាចធ្វើដើម្បីរៀបចំខ្លួនគេហើយនោះ ?
- ហេតុអ្វីបានជាវាអាចនឹងពិបាកទុកចិត្តទៅលើព្រះអម្ចាស់នៅក្នុងស្ថានភាពបែបនេះ ? (ប្រសិនបើសិស្សមិនបាននិយាយនូវចំណុចខាងក្រោមនេះទេ អ្នកអាចបង្ហាញថា ពួកសាសន៍យ៉ារេឧត្រូវតែកសាងភេត្រាផ្ទាល់ខ្លួនរបស់ពួកគេ ពួកគេមិនអាចកាច់ចង្កូតទូកទាំងនោះបាននោះទេ ហើយពួកគេក៏មិនដឹងពីផ្លូវទៅកាន់ដែនដីសន្យា ឬរយៈពេលនៃការធ្វើដំណើរដែរ) ។

ដើម្បីជួយសិស្សឲ្យ មើលឃើញ ពីព្រឹត្តិការណ៍ដែលបានតំណាលប្រាប់នៅក្នុង អេធើរ ៦ សូមឲ្យពួកគេគូសគម្រោងសាមញ្ញមួយនៃភេត្រារបស់ពួកសាសន៍យ៉ារេឧនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ ។ បន្ទាប់មក សូមឲ្យពួកគេគូស ឬសរសេរនូវមាតិកានៃភេត្រាស្របតាម អេធើរ ៦:១–៤ ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី អេធើរ ៦:៥–១១ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលរូបភាពរបស់គេដែលបានគូសហើយនោះ នៅពេលពួកគេស្តាប់ និងស្រមៃនូវអ្វីដែលវាអាចមានអារម្មណ៍បែបណាក្នុងការធ្វើដំណើរនៅក្នុងទូកបែបនោះ ។

- តើអ្នកគិតថា តើអ្វីជាការពិបាកក្នុងការធ្វើដំណើរនៅក្នុងភេត្រារបស់ពួកសាសន៍យ៉ារេឧ ?
- យោងតាម អេធើរ ៦:១១ តើពួកសាសន៍យ៉ារេឧបានធ្វើដំណើររឿងរបៀបនេះអស់រយៈពេលប៉ុន្មាន ?
- តើអ្នកគិតថាឃ្លា « រលកទាំងឡាយដូចជាភ្នំ » មានន័យយ៉ាងណា ? (អេធើរ ៦:៦) ។តើអ្នកគិតថា អ្នកនឹងមានអារម្មណ៍យ៉ាងណា ប្រសិនបើអ្នកស្ថិតនៅក្នុងភេត្រារបស់ពួកសាសន៍យ៉ារេឧ នៅពេលមានរលកបែបនោះបក់បោកមកហាក់ដូចជា « ត្រៀបកប់នៅក្នុង

> ***ការមើលឃើញ***
>
> នៅពេលសិស្សមើលឃើញ ឬស្រមៃរូបភាពនៅក្នុងគំនិតរបស់គេ នូវព្រឹត្តិការណ៍នៃដំណើររឿងក្នុងព្រះគម្ពីរ នោះព្រឹត្តិការណ៍ទាំងនោះនឹងកាន់តែជាក់ច្បាស់ និងពិតចំពោះពួកគេ ។ ការណ៍នេះអាចជួយសិស្សឲ្យភ្ជាប់ទំនាក់ទំនងរវាងមនុស្ស ទៅនឹងស្ថានភាពបានកាន់តែប្រសើរនៅក្នុងព្រះគម្ពីរ ហើយចេះវិភាគ និងយល់ពីដំណើររឿងកាន់តែបានច្បាស់ជាងមុន ។

ជម្រៅសមុទ្រជាច្រើន » ? (អ្នកអាចរំឭកសិស្សថា ពួកសាសន៍យ៉ារេឌត្រូវតែរង់ចាំភេត្រារបស់ពួកគេឲ្យរណ្តែតឡើងទៅលើទឹកមុនពេលពួកគេអាចបើកប្រហោងដើម្បីឲ្យខ្យល់ចូល) ។

ដើម្បីជួយសិស្សឲ្យរៀបចំដើម្បីស្វែងរកគោលការណ៍មួយ សូមសួរ ៖

- តើពួកសាសន៍យ៉ារេឌបានបង្ហាញការទុកចិត្តរបស់ពួកគេទៅលើព្រះអម្ចាស់ នៅពេលពួកគេបានឆ្លងកាត់សមុទ្រដោយរបៀបណា ? (សូមមើល អេធើរ ៦:៧, ៩) ។
- តើឃ្លាណាខ្លះនៅក្នុង អេធើរ ៦:៥–១១ ដែលរៀបរាប់ពីអ្វី ដែលព្រះអម្ចាស់បានធ្វើសម្រាប់ពួកសាសន៍យ៉ារេឌ ដោយសារតែការទុកចិត្តរបស់ពួកគេទៅលើទ្រង់ ?

សូមឲ្យសិស្សអាន អេធើរ ៦:១២ ដោយស្ងាត់ស្ងៀម ដោយរកមើលលទ្ធផលនៃការធ្វើដំណើររបស់ពួកសាសន៍យ៉ារេឌ ។

- ហេតុអ្វីបានជាពួកសាសន៍យ៉ារេឌបានស្រក់ទឹកភ្នែកនៃសេចក្តីអំណរ ? តើព្រះអម្ចាស់បានប្រទាន « សេចក្តីមេត្តាករុណាដ៏ទន់ភ្លន់ » អ្វីដល់ពួកគេ ?

ដើម្បីជួយសិស្សឲ្យរកឃើញនូវគោលការណ៍មួយដែលបានបង្ហាញដោយបទពិសោធន៍របស់ពួកសាសន៍យ៉ារេឌ សូមសួរ ៖

- ដោយផ្អែកលើអ្វីដែលអ្នកបានរៀនពីការធ្វើដំណើររបស់ពួកសាសន៍យ៉ារេឌ តើព្រះអម្ចាស់នឹងធ្វើអ្វីសម្រាប់យើង នៅពេលយើងទុកចិត្តទៅលើទ្រង់ និងធ្វើតាមព្រះឆន្ទៈរបស់ទ្រង់ ? (គោលការណ៍មួយនៃគោលការណ៍ទាំងឡាយដែលសិស្សគួរអោយឃើញគឺថា ***នៅពេលយើងទុកចិត្តទៅលើព្រះអម្ចាស់ និងធ្វើតាមព្រះឆន្ទៈរបស់ទ្រង់ នោះទ្រង់នឹងដឹកនាំខ្សែជីវិតរបស់យើង ។*** សូមសរសេរគោលការណ៍នេះនៅលើក្តារខៀន ។ សូមឲ្យសិស្សសញ្ជឹងគិតពីគោលការណ៍ និងចែករំលែកពី បទពិសោធន៍ ដែលបានជួយដល់ពួកគេឲ្យដឹងថា វាគឺជាការពិត ។ អ្នកក៏អាចចង់ចែករំលែករបៀបដែលអ្នកដឹងថា វាគឺជាការពិតបានដែរ) ។

> ***សូមឲ្យសិស្សចែកចាយបទពិសោធន៍នានា***
>
> នៅពេលអ្នកសុំឲ្យសិស្សសញ្ជឹងគិតពីរបៀបដែលពួកគេដឹងថា គោលការណ៍មួយគឺជាការពិតនោះ អ្នកបានផ្តល់ឱកាសមួយដើម្បីឲ្យព្រះវិញ្ញាណបំផុសគំនិតដល់ពួកគេ នៅពេលពួកគេស្វែងរកការចងចាំអំពីអារម្មណ៍ និងបទពិសោធន៍ទាំងឡាយនោះ ។ នៅពេលសិស្សឆ្លើយតប ពួកគេនឹងត្រូវថ្លែងទីបន្ទាល់ ទោះបីជាចម្លើយរបស់ពួកគេអាចមិនមានជាក់ដូចជាឃ្លាថា « ខ្ញុំចង់ថ្លែងសាក្សីភាព » ឬ « ខ្ញុំដឹង » នោះក្តី ។

សូមឲ្យសិស្សគិតពិចារណាពីរបៀបដែលពួកគេអាចទុកចិត្តទៅលើព្រះអម្ចាស់កាន់តែខ្លាំងថែមទៀត និងធ្វើតាមការដឹកនាំរបស់ទ្រង់នៅក្នុងស្ថានភាពលំបាកដែលពួកគេអាចជួបនាពេលនេះ ។ សូមពន្យល់ថា ពួកគេអាចស្វែងរកគោលការណ៍ផ្សេងទៀតបាននៅក្នុង អេធើរ ៦:១–១២ ។ សូមលុបអ្វីៗនៅលើក្តារខៀនចោល លើកលែងតែប្រយោគអំពីការទុកចិត្តទៅលើព្រះអម្ចាស់ ។ សូមគូសភេត្រាសាមញ្ញមួយនៅលើក្តារខៀនមួយចំហៀង ។ នៅលើក្តារខៀនមួយចំហៀងទៀត សូមសរសេរ *ដែនដីសន្យា* ។

- តើដែនដីសន្យាអាចត្រូវបានប្រៀបធៀបទៅនឹងអ្វីនៅក្នុងដែនការនៃសេចក្តីសង្គ្រោះ ? (ជីវិតដ៏នៅអស់កល្បជានិច្ច) ។
- នៅពេលយើងជួបនឹងការពិបាកនៃជីវិត តើយើងអាចធ្វើតាមគំរូរបស់ពួកសាសន៍យ៉ារេឌទាំងនេះដោយរបៀបណា ? តើព្រះអម្ចាស់ជួយយើង ដូចជាទ្រង់បានជួយដល់ពួកសាសន៍យ៉ារេឌ អំឡុងពេលការធ្វើដំណើររបស់យើងឆ្លងកាត់ជីវិតមែងស្លាប់នេះដោយរបៀបណា ? (ចម្លើយរបស់សិស្សគួរឆ្លុះបញ្ចាំងអំពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងទុកចិត្តទៅលើព្រះអម្ចាស់ នោះទ្រង់នឹងថែទាំយើង នៅពេលយើងឈូសឆាយធំឡើង និងរៀបចំដើម្បីទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច ។** អ្នកអាចណែនាំ សិស្សគួរសរសេរគោលការណ៍នេះនៅក្នុងព្រះគម្ពីររបស់គេក្បែរ អេធើរ ៦:៥–១២) ។

សូមឲ្យសិស្សគិតអំពីទុក្ខវេទនាដែលពួកគេបានជួបប្រទះ ឬកំពុងតែជួបនៅក្នុងជីវិតរបស់ពួកគេនាពេលបច្ចុប្បន្ននេះ ។ សូមឲ្យពួកគេសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់អំពីអារម្មណ៍របស់ពួកគេមាន នៅពេលពួកគេបានឆ្លើយតបដោយសេចក្តីជំនឿចំពោះទុក្ខវេទនាទាំងនេះ និងរបៀបដែលព្រះអម្ចាស់បានគាំទ្រពួកគេ ។

សូមអញ្ជើញសិស្សពីរបីនាក់ឲ្យចែករំលែកអ្វីដែលពួកគេបានសរសេរ ។ បន្ទាប់មក សូរសំណួរទាំងឡាយខាងក្រោមនេះ ៖

- ដោយផ្អែកលើអ្វីដែលអ្នកបានសិក្សានៅថ្ងៃនេះ តើអ្នកមានដំបូន្មានអ្វីដែលនឹងផ្តល់ទៅដល់នរណាម្នាក់ដែលកំពុងជួបនឹងឧបសគ្គ ឬក៏ទុក្ខវេទនានោះ ?

អេធើរ ៦:១៣–១៨

ពួកសាសន៍យ៉ារេឌបង្រៀនកូនចៅរបស់ពួកគេឲ្យដើរចំពោះមុខព្រះអម្ចាស់ដោយបន្ទាបខ្លួន

សូមសង្ខេប អេធើរ ៦:១៣–១៨ ដោយការពន្យល់ថា នៅពេលពួកសាសន៍យ៉ារេឌបានមកដល់ដែនដីសន្យា នោះពួកគេបានចាប់ផ្តើមកសាងគ្រួសាររបស់ពួកគេ និងដាំដំណាំជាច្រើន ។ សូមឲ្យសិស្សអាន អេធើរ ៦:១៧ ដោយស្ងាត់ស្ងៀមដោយរកមើលអ្វីដែលពួកសាសន៍យ៉ារេឌបានបង្រៀនដល់កូនចៅរបស់ពួកគេ ។ បន្ទាប់មក សូរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- តើអ្នកគិតថា វាមានន័យយ៉ាងណា « ដើម្បីដើរយ៉ាងរាបទាបនៅចំពោះព្រះអម្ចាស់ » ? តើឧទាហរណ៍ណាខ្លះដែលអ្នកបានឃើញពីមនុស្សដែលបានធ្វើតាមគោលការណ៍នេះ ? តើឪពុកម្តាយរបស់អ្នក និងអ្នកដទៃបានលើកទឹកចិត្តដល់អ្នកឲ្យដើរយ៉ាងរាបទាបនៅចំពោះព្រះអម្ចាស់ដោយរបៀបណា ?
- តើវាមានន័យយ៉ាងណាដើម្បីត្រូវបានបង្រៀន « ពីស្ថានលើ » ?
- តើអ្នកគិតដូចម្តេចដែរ អំពីទំនាក់ទំនងរវាងការដើរយ៉ាងរាបទាបនៅចំពោះព្រះអម្ចាស់ និងការត្រូវបានបង្រៀនពីស្ថានលើ ? (ចម្លើយរបស់សិស្សគួរឆ្លុះបញ្ចាំងអំពីគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងដើរយ៉ាងរាបទាបនៅចំពោះព្រះអម្ចាស់ នោះយើងនឹងត្រូវបានបង្រៀនមកពីស្ថានលើ**) ។

អ្នកអាចសុំឲ្យសិស្សសរសេរអំពីគ្រាមួយ នៅពេលដែលពួកគេបានមានអារម្មណ៍ថា ពួកគេ « ត្រូវបានបង្រៀនពីស្ថានលើ » ។ សូមអញ្ជើញពួកគេពីរបីនាក់ឲ្យចែករំលែកអ្វីដែលពួកគេបានសរសេរ ។ សូមឲ្យសិស្សធ្វើតាមគោលការណ៍ដែលបានកត់ត្រានៅក្នុងអេធើរ ៦:១៧ ។

អេធើរ ៦:១៩–៣០

ពួកសាសន៍យ៉ារេឌជ្រើសរើសស្តេច

សូមសង្ខេប អេធើរ ៦:១៩–២២ ដោយការពន្យល់ថា នៅពេលលោកយ៉ារេឌ និងបងប្រុសរបស់លោកបានមានវ័យចំណាស់ទៅ ពួកសាសន៍យ៉ារេឌបានសុំឲ្យមានស្តេចមួយអង្គ ។ សូមឲ្យសិស្សស្រាវជ្រាវនៅក្នុង អេធើរ ៦:២៣ ដើម្បីរកអ្វី ដែលបងប្រុសរបស់យ៉ារេឌបានព្រមានថានឹងកើតឡើង ប្រសិនបើពួកគេនឹងជ្រើសរើសស្តេចមួយនោះ ។

សូមបញ្ចប់ដោយទីបន្ទាល់របស់អ្នកអំពីគោលការណ៍នៅក្នុងមេរៀននេះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អេធើរ ៦:១–១២ ។ ពួកសាសន៍យ៉ារេឌឆ្លងកាត់មហាសមុទ្រដោយមានសុវត្ថិភាព

ប្រធាន ថូម៉ាស អេស ម៉នសុន បានបង្រៀនអំពីរបៀបដែលយើងអាច រៀបចំខ្លួនទទួលឧបសគ្គដែលនឹងមកជួបយើង ៖

« យើងរស់នៅក្នុងជំនាន់មួយ ដែលមនុស្សជាច្រើននៅក្នុងពិភពលោកបានធ្លាក់ចុះពីយុថ្កាសុវត្ថិភាពដែលមានទាក់ទងទៅនឹងបទបញ្ញត្តិទាំងឡាយ ។ វាគឺជាសម័យបន្ទុរពេកពន់ជាសង្គមដែលពេញចិត្តក្នុងការមិនគោរពគ្នានិងរំលងនូវច្បាប់របស់ព្រះ ។ ជាញឹកញាប់ យើងឃើញថាខ្លួនយើងកំពុងហែលបង្ហ្រាសខ្សែទឹកហូរ ហើយពេលខ្លះ ខ្សែទឹកហូរហាក់ដូចជាហូរទាញយើងចេញទៅ ។

« ខ្ញុំត្រូវបានរំលឹកអំពីព្រះបន្ទូលរបស់ព្រះអម្ចាស់ ដែលមាននៅក្នុងសៀវភៅរបស់អេធើរ នៅក្នុងព្រះគម្ពីរមរមន ។ព្រះអម្ចាស់បានមានបន្ទូលថា ‹ ត្បិតអ្នកកាល់គ្នាមិនអាចឆ្លងកាត់ទីជំរៅដ៏ជំនៃះបានទេ លើកលែងតែ យើងរៀបចំឲ្យអ្នកតទល់នឹងរលកនៃសមុទ្រ ហើយខ្យល់ដែលបក់ នឹងទឹកជំនន់ដែលនឹងមក › [អេធើរ ២:២៥] ។បងប្អូនប្រុសស្រីទាំងឡាយ ទ្រង់បានរៀបចំ យើង ។បើយើងស្តាប់តាមព្រះបន្ទូលរបស់ទ្រង់ ហើយរស់នៅតាមព្រះបញ្ញត្តិ យើងនឹងរស់នៅក្នុងសម័យកាលនៃភាពអណាធិបតេយ្យនិងអំពើអាក្រក់—ជាគ្រាដែលអាចយកមកប្រៀបទៅនឹងរលក និងខ្យល់ ហើយនិងទឹកជំនន់ ដែលអាចបំផ្លាញ ។ទ្រង់គិតអំពីយើងរាល់គ្នា ។ទ្រង់ស្រឡាញ់យើង ហើយនឹងប្រទានពរដល់យើង នៅពេលយើងធ្វើអ្វីដែលត្រឹមត្រូវ » (« Closing Remarks » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៩, ទំព័រ ១០៩) ។

អេធើរ ៦:២២–២៤ ។ ពួកសាសន៍យ៉ារេឌជ្រើសរើសស្តេចមួយអង្គ

ពាសពេញក្នុងព្រះគម្ពីរ ព្យាការីទាំងឡាយបានព្រមានអំពីគ្រោះថ្នាក់នៃការមានស្តេច ។ សូមពិចារណាអំពីគំរូខាងក្រោមនេះ ៖

១. បងប្រុសរបស់យ៉ារេឌបានព្រមានប្រជាជនរបស់លោកថា ការមានស្តេចនឹងដឹកនាំពួកគេឲ្យធ្លាក់ទៅក្នុងការជាប់ឃុំឃាំង (សូមមើល អេធើរ ៦:២៣) ។

២. ស្តេចម៉ូសាយបានព្រមានប្រជាជនរបស់ទ្រង់អំពី ភាពគ្រោះថ្នាក់នៃការត្រូវបានដឹកនាំដោយស្តេចដែលមិនសុចរិត ។ ទ្រង់បានណែនាំ ពួកគេគួរតែបង្កើតនូវប្រព័ន្ធនៃសេចក្តីយុត្តិធម៌មួយ ។ (សូមមើល ម៉ូសាយ ២៩ ។)

៣. ព្យាការីសាំយូអែលក្នុងព្រះគម្ពីរសេញ្ញាចាស់បានព្រមានអំពីបញ្ហានៃការគ្រប់គ្រងរបស់ស្តេច នៅពេលប្រជាជនរបស់លោកចង់មានស្តេចមួយអង្គដែលពួកគេអាចក្លាយ « ដូចជាសាសន៍ទាំងអស់ » (សូមមើល សាំយូអែលទី ១ ៨) ។

អេធើរ ៧–១១

សេចក្តីផ្តើម

បងប្រុសយ៉ារេឧបានក្រៀមក្រំដោយសារសំណើរបស់ប្រជាជនលោកឲ្យជ្រើសរើសស្តេចមួយអង្គ ។ លោកបានមានប្រសាសន៍ថា « ប្រាកដជាការណ៍នេះនឹងនាំទៅរកការជាប់ឃុំឃាំងជាមិនខានឡើយ » (អេធើរ ៦:២៣) ។ ការព្យាករណ៍របស់លោកត្រូវបានបំពេញក្នុងពីរជំនាន់ក្រោយមក ។ អំឡុងពេលរជ្ជកាលនៃស្តេចជាច្រើន ពួកសាសន៍យ៉ារេឧបានឆ្លងកាត់វដ្តនៃការស្តាប់តាមព្យាការីទាំងឡាយ និងការរស់នៅក្នុងសេចក្តីសុចរិត ហើយបន្ទាប់មកបដិសេធព្យាការី និងរស់នៅក្នុងសេចក្តីទុច្ចរិតម្តងហើយម្តងទៀត ។

យោបល់សម្រាប់ការបង្រៀន

អេធើរ ៧

អូរៀហា និង គិបបានសោយរាជ្យដោយសេចក្តីសុចរិត កូរីហូរប្រឆាំង និងបះបោរទាស់នឹងរាជាណាចក្រ ហើយព្រះជេដ្ឋារបស់ទ្រង់ ស៊ីល បានកែប្រែមកវិញ ហើយព្យាការីជាច្រើនដាក់ទោសដល់អំពើទុច្ចរិតរបស់ប្រជាជន

សូមគូសរូបគុកសាមញ្ញមួយនៅលើក្តារខៀន ។

សូមឲ្យសិស្សរៀបរាប់ពីរបៀបដែលប្រជាជនអាចអារម្មណ៍ ខណៈពេលដែលពួកគេនៅជាប់ឃុំឃាំង ។ សូមបង្ហាញថា អាកប្បកិរិយាដ៏មានបាប អាចដឹកនាំទៅរកការជាប់ឃុំឃាំងខាងវិញ្ញាណ និងខាងរាងកាយ ។

- **តើអាកប្បកិរិយាដ៏មានបាបបែបណាដែលអាចដឹកនាំទៅរកការជាប់ឃុំឃាំង ?**

សិស្សអាចលើកឡើងពីគំនិតដូចខាងក្រោមនេះ ៖ ការជ្រើសរើសមិនធ្វើតាមពាក្យសំដីនៃប្រាជ្ញាវាងវៃ ឬការមើលរូបអាសគ្រាមអាចដឹកនាំទៅរកការជាប់ឃុំឃាំងនៃការញៀន ។ អំពើបាបគ្រប់ទម្រង់ទាំងអស់នឹងបន្ទុយនូវព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធនៅក្នុងជីវិតរបស់យើង ។ សូមពន្យល់ថា មេរៀននេះនឹងជួយសិស្សឲ្យឃើញពីរបៀបដែលពួកគេអាចចៀសវាងពីការជាប់ឃុំឃាំង ។

សូមពន្យល់ថា នៅពេលបងប្រុសរបស់យ៉ារេឧបានដឹងថា ប្រជាជនបានចង់មានស្តេចមួយអង្គ នោះលោកបានព្រមានថា ជម្រើសរបស់ពួកគេនឹងដឹកនាំទៅរកការជាប់ឃុំឃាំង (សូមមើល អេធើរ ៦:២២–២៣) ។ ថ្វីបើមានការព្រមានក្តី ពួកប្រជាជនសាសន៍យ៉ារេឧបានជ្រើសរើសដើម្បីឲ្យមានស្តេចមួយអង្គ ។ ស្តេចទីមួយរបស់ពួកគេគឺ អូរៀហា ជាកូនប្រុសម្នាក់របស់លោកយ៉ារេឧ ។ ស្តេចទីពីររបស់ពួកគេគឺ បុត្រារបស់ស្តេចអូរៀហា គឺគិប ។

សូមឲ្យសិស្សអាន អេធើរ ៧:១–២ ដោយស្វាត់ស្ងៀមដើម្បីរៀនថាតើ ការព្យាករណ៍របស់បងប្រុសរបស់យ៉ារេឧត្រូវបានបំពេញនៅក្នុងជំនាន់របស់ស្តេចអូរៀហាដែរឬអត់ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរៀនសូត្រ ។

- **តើអ្នកនឹងនិយាយអ្វីទៅដល់នរណាម្នាក់ដែលបានរស់នៅក្នុងជំនាន់របស់ស្តេចអូរៀហា ហើយមិនបានជឿថា ការព្យាករណ៍របស់បងប្រុសរបស់យ៉ារេឧនឹងត្រូវបានបំពេញ ?**

សូមឲ្យសិស្សអាន អេធើរ ៧:៣–៧ ដោយស្វាត់ស្ងៀមដោយរកមើលរបៀបដែលការព្យាករណ៍របស់បងប្រុសរបស់យ៉ារេឧត្រូវបានចាប់ផ្តើមបំពេញ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមប្រាកដថា ពួកគេយល់ថា ស្តេចគិប និងប្រជាជនរបស់ទ្រង់ត្រូវបាននាំទៅក្នុងការជាប់ឃុំឃាំង— « គិបរស់នៅក្នុងការជាប់ឃុំឃាំង ហើយប្រជាជនរបស់ទ្រង់ » (អេធើរ ៧:៧) ។

- **តើគោលការណ៍ណាខ្លះដែលអ្នកបានឃើញកន្លងមកនៅក្នុង អេធើរ ៧ ? (នៅពេលសិស្សចែកចាយអ្វីដែលពួកគេបានរៀន សូមប្រាកដថា គោលការណ៍ខាងក្រោមនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ ៖ ការបដិសេធពាក្យសម្តីរបស់ព្យាការីអាចនាំទៅក្នុងការជាប់ឃុំឃាំង) ។**

សូមឲ្យសិស្សអាន អេធើរ ៧:៨–១៣ ដើម្បីរៀនអំពីស៊ីល ដែលបានប្រសូតចេញពីស្តេចគិប ខណៈពេលដែលស្តេចគិបស្ថិតនៅក្នុងការជាប់ឃុំឃាំង ។ មុនពេលពួកគេអាន សូមឲ្យពួកគេស្រមៃថា ពួកគេគឺជាអ្នកសារព័ត៌មានដែលត្រូវបានចាត់តាំងឲ្យសង្ខេបដំណើររឿងនៅក្នុង អេធើរ ៧:៨–១៣ ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់ៗរាយការណ៍ដល់សមាជិកផ្សេងទៀតក្នុងថ្នាក់អំពីអ្វីដែលគេនឹងដកស្រង់ចេញពីដំណើររឿងនោះ: ។

សូមសង្ខេប អេធើរ ៧:១៤–២២ ដោយការពន្យល់ថា ក្រោយពីស៊ីលបានក្លាយជាស្តេច ហើយកូរីហូរបានប្រែចិត្តពីអ្វីដែលគាត់បានធ្វើ នោះកូនប្រុសរបស់កូរីហូរឈ្មោះ ណូអេ បានដឹកនាំការបះបោរប្រឆាំងនឹងស្តេចស៊ីល និងកូរីហូរ ។ បុត្រារបស់ស្តេចស៊ីលបាន

សម្លាប់ណូអេ និងបានរំដោះស្តេចស៊ូល ហើយស្តេចស៊ូលបានត្រឡប់មកកាន់រាជាណាចក្ររបស់ទ្រង់វិញក្នុងព្រះនាមជាស្តេច ។ ទោះជាយ៉ាងណាក្តី កូនប្រុសរបស់ណូអេឈ្មោះ កូហូរ បានបន្តរជ្ជកាលដែលណូអេបានគ្រប់គ្រង ។ ប្រទេសនេះត្រូវបានបែងចែកទៅជាមានស្តេចពីរអង្ត និងប្រជាជនពីរបក្ស រហូតដល់មានចម្បាំងមួយដែលស្តេចស៊ូលបានសម្លាប់កូហូរ ។ កូនប្រុសរបស់កូហូរឈ្មោះ នីមរ៉ូឌ បានផ្តល់ចំណែកខ្លះនៃនគររបស់កូហូរទៅដល់ស្តេចស៊ូល ។

សូមពន្យល់ថា ក្រោយពីស្តេចស៊ូលបានទទួលបានអាណាចក្រមកវិញ ព្យាការីទាំងឡាយបានមកក្នុងចំណោមប្រជាជន ។ សូមឲ្យសិស្សអាន អេធើរ ៧:២៣– ២៥ ដោយស្ងាត់ស្ងៀម ដោយរកមើលអ្វីដែលព្យាការីបានមានប្រសាសន៍ និងរបៀបដែលប្រជាជនបានមានប្រតិកម្មតប ។ ក្រោយពីពួកគេរៀបរាប់អ្វីដែលពួកគេបានរកឃើញ សូមសួរ ៖

- តើប្រជាជនបានឆ្លើយតបយ៉ាងណាទៅនឹងព្យាការី ? តើស្តេចស៊ូលបានឆ្លើយតបដោយរបៀបណា ?
- តើការការពារដល់ពួកព្យាការីរបស់ស្តេចស៊ូលបានប្រទានពរដល់ប្រជាជនរបស់ទ្រង់យ៉ាងដូចម្តេចខ្លះ ?

សូមឲ្យសិស្សម្នាក់អាន អេធើរ ៧:២៦–២៧ ឲ្យ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលបានកើតឡើង នៅពេលប្រជាជនបានគោរពតាមពាក្យសម្តីរបស់ព្យាការី ។ នៅពេលសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ សូមប្រាកដថា ពួកគេរកឃើញនូវគោលការណ៍ដូចខាងក្រោមនេះ ៖ **នៅពេលយើងធ្វើតាមការណែនាំរបស់ព្យាការី និងចងចាំដល់ព្រះអម្ចាស់ នោះយើងនឹងចាប់ផ្តើមរីកចម្រើនឡើង ។**

- តើអ្នកត្រូវបានប្រទានពរ ដោយសារអ្នកបានគោរពតាមការណែនាំរបស់ព្យាការីដោយរបៀបណា ?

សូមអញ្ជើញសិស្សឲ្យគិតអំពីរបៀបមួយ ដែលពួកគេអាចស្តាប់តាម និងគោរពតាមពាក្យសម្តីរបស់ព្យាការីកាន់តែល្អជាងនេះ ។

អេធើរ ៨:១–៩:១៣

យ៉ារេឌ ហើយបន្ទាប់មក អ័គីស បានក្លាយជាស្តេចរបស់ពួកសាសន៍យ៉ារេឌដែលបានឆ្លងកាត់នូវបក្សពំន្ធសម្ងាត់ជាច្រើន

សូមសង្ខេប អេធើរ ៨:១–១៤ ដោយការពន្យល់ថា ក្រោយពីស្តេចស៊ូលបានសុគតទៅ អូមើរ បានធ្វើជាស្តេចបន្ត ។ កូនប្រុសរបស់ស្តេចអូមើរឈ្មោះ យ៉ារេឌ បានប្រឆាំងនឹងបិតារបស់ព្រះអង្ត ហើយបានដាក់ព្រះទ័យរបស់ទ្រង់ថានឹងធ្វើជាស្តេចឲ្យបាន ។ ទ្រង់បានដណ្តើមនគរបានពាក់កណ្តាលលើកទីមួយ ប៉ុន្តែក្រោយមក ទ្រង់បានបរាជ័យ ហើយត្រូវបានបង្ខំឲ្យប្រគល់នគរពាក់កណ្តាលរបស់ទ្រង់មកវិញ ។ បន្ទាប់មក បុត្រីរបស់យ៉ារេឌបានគ្រោងរបៀបមួយសម្រាប់ស្តេចយ៉ារេឌដើម្បីបានធ្វើជាស្តេច ។ ព្រះនាងរំពូកបិតារបស់ទ្រង់អំពីបក្សពំន្ធសម្ងាត់ដែលល្បីល្បាញកាលពីជំនាន់បុរាណនោះមក ។ នៅពេលអ័គីសបានសុំព្រះនាងរៀបអភិសេក យ៉ារេឌត្រូវបានប្រាប់អ័គីសថា ទ្រង់ត្រូវតែសម្លាប់អូមើរ ដែលជាស្តេចចោលសិន ។ យ៉ារេឌ និងបុត្រីរបស់ខ្លួនបានអនុវត្តគម្រោងការនេះ ។ អ័គីសបានសុំបុត្រីរបស់យ៉ារេឌរៀបអភិសេក ហើយបន្ទាប់មកបានចូលរួមជាមួយនឹងបក្សពំន្ធសម្ងាត់ជាមួយនឹងមិត្តរបស់ទ្រង់ដើម្បីសម្លាប់ស្តេចអូមើរ ។

សូមលើកឡើងថា ដោយសារតែគម្រោងការនេះ បក្សពំន្ធសម្ងាត់បានចាប់ផ្តើមដុះឡើងនៅក្នុងចំណោមពួកសាន៍យ៉ារេឌ ហើយនៅទីបញ្ចប់បានបណ្តាលឲ្យមានសេចក្តីបំផ្លិចបំផ្លាញរបស់ពួកគេ ។ សូមពន្យល់ថា បក្សពំន្ធសម្ងាត់គឺជា « អង្គការមួយដែលមានប្រជាជនរួបរួមគ្នាដោយសម្បថ ដើម្បីអនុវត្តបំណងដ៏អាក្រក់របស់ក្រុមខ្លួន » (Guide to the Scriptures, “Secret Combinations,” scriptures.lds.org) ។ ពួកចោរកាឌីអានតុនគឺជាគំរូនៃអង្គការមួយនៅក្នុងព្រះគម្ពីរមរមន ដែលបានប្រើបក្សពំន្ធសម្ងាត់ដើម្បីសម្រេចនូវបំណងដ៏អាក្រក់របស់វា ។

សូមឲ្យសិស្សអាន អេធើរ ៨:១៥–១៩ ដោយស្ងាត់ស្ងៀមដោយរកមើលអ្វីដែលអ័គីសបានធ្វើដើម្បីសម្រេចបាននូវបក្សពំន្ធសម្ងាត់នេះ ។ សូមឲ្យសិស្សរកមើលអ្វីដែលខគម្ពីរទាំងនេះបង្រៀនអំពីបក្សពំន្ធសម្ងាត់ ។

- តើគោលបំណងរបស់ពួកអស់អ្នកដែលឱបក្រសោបបក្សពំន្ធសម្ងាត់ គឺជាអ្វី? (ដើម្បីទទួលបានអំណាច ដើម្បីពួកគេអាចប្រព្រឹត្តអំពើទុច្ចរិតបាន) ។
- តើអំណាចរបស់នរណាដែល ជាអំណាចក្តោបក្តាប់បក្សពំន្ធសម្ងាត់នេះ ? (សាតាំង) ។
- តើឃ្លាមួយណានៅក្នុង អេធើរ ៨:១៨ បង្ហាញពីព្រះទ័យរបស់ព្រះអម្ចាស់អំពីបក្សពំន្ធសម្ងាត់ ? (« អំពើមួយដ៏គួរខ្ពើមឆ្អើម និងទុច្ចរិតលើសអ្វីៗទាំងអស់ ») ។

សូមឲ្យសិស្សម្នាក់អាន អេធើរ ៨:២០–២២, ២៥ ឲ្យ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរឿងបន្ថែមទៀតដែលពួកគេអាចរៀនអំពីបក្សពំន្ធសម្ងាត់ ។ សូមឲ្យពួកគេយកចិត្តទុកដាក់ជាពិសេសទៅលើឥទ្ធិពលដែលបក្សពំន្ធសម្ងាត់មានទៅលើសង្គមទាំងឡាយ ។ (សូមកត់ចំណាំថាឃ្លា « បង្កើតវាឡើង » នៅវគ្គដំបូងនៃខគម្ពីរ អេធើរ ៨:២៥ សំដៅទៅលើការបង្កើតបក្សពំន្ធសម្ងាត់) ។

- ចេញពីអ្វីដែលអ្នកបានអាន តើឥទ្ធិពលអ្វីដែលបក្សពំន្ធសម្ងាត់មានទៅលើសង្គមទាំងឡាយ ? (នៅពេលសិស្សបង្ហាញពីគំនិតរបស់ពួកគេ សូមប្រាកដថា ពួកគេរកឃើញសេចក្តីពិតដូចខាងក្រោមនេះ ៖ **ការគាំទ្របក្សពំន្ធសម្ងាត់ ដឹកនាំទៅរកសេចក្តីបំផ្លិចបំផ្លាញដល់ពហុសង្គម) ។**

សូមឲ្យសិស្សក្នុងថ្នាក់អាន អេធើរ ៨:២៣–២៤, ២៦ ដោយស្ងាត់ស្ងៀម ដោយរកមើលអ្វីដែលលោកមរ៉ូណៃចង់ឲ្យយើងធ្វើ ដែលជាលទ្ធផលនៃការព្រមានរបស់លោកអំពីបក្សពំន្ធសម្ងាត់ ។

- តើលោកអ៊ូរីណៃបានប្រាប់យើងឲ្យធ្វើអ្វីខ្លះ ? (សូមប្រយ័ត្នចំពោះបក្សពួកព័ន្ធសម្ងាត់ និងត្រូវប្រាកដថា ពួកគេចាកឆ្ងាយពីសង្គមរបស់យើង) ។
- ដូចដែលបានកត់ត្រានៅក្នុង អេធើរ ៨:២៦ តើសេចក្តីសង្ឃឹមរបស់លោកអ៊ូរីណៃសម្រាប់យើងនៅក្នុងថ្ងៃចុងក្រោយមានអ្វីខ្លះ ?

សូមសង្ខេប អេធើរ ៩:១–១៣ ដោយការពន្យល់ថា ជាលទ្ធផលនៃបក្សពួកព័ន្ធសម្ងាត់របស់ពួកគេ អ័គីស និងមិត្តភក្តិទាំងឡាយបានកម្ចាត់នគររបស់អូមើរ ។ ទោះជាយ៉ាងណាក្តី ព្រះបានព្រមានដល់អូមើរថា ទ្រង់នឹងត្រូវរត់ចេញជាមួយនឹងគ្រួសាររបស់ទ្រង់ ដើម្បីសង្គ្រោះជីវិតរបស់ពួកទ្រង់ ។ បុត្រាដ៏ទុច្ចរិតរបស់ស្តេចអូមើរឈ្មោះ យ៉ារេឌ បានក្លាយជាស្តេច ហើយបានរៀបអភិសេកបុត្រីរបស់ទ្រង់ជាមួយនឹងអ័គីស ។ អ័គីស និងមិត្តភក្តិទាំងឡាយបានបន្តគម្រោងដ៏អាក្រក់របស់ពួកគេ ដោយសម្លាប់យ៉ារេឌ និងសូម្បីតែកូនប្រុសរបស់អ័គីស ។ សកម្មភាពទាំងនេះបានដឹកនាំទៅរកសង្គ្រាមមួយ រវាងអ័គីស និងបុត្រារបស់ទ្រង់ រហូតដល់ទីបញ្ចប់បានបំផ្លាញពួកសាសន៍យ៉ារេឌស្ទើរតែទាំងអស់ និងបានស្តារឡើងវិញនូវរាជបល្ល័ង្កដល់ស្តេចអូមើរវិញ ។ សូមបញ្ជាក់ថា ហេតុការណ៍ទាំងនេះបង្ហាញថា បក្សព័ន្ធសម្ងាត់ដឹកនាំទៅរកសេចក្តីបំផ្លិចបំផ្លាញនៃសង្គមនានា ។

អេធើរ ៩:១៤–១១:២៣

ស្តេចមួយអង្គតទៅស្តេចមួយអង្គទៀត ស្តេចខ្លះគ្រប់គ្រងដោយសុចរិត ហើយខ្លះទៀតដោយទុច្ចរិត

សូមពន្យល់ថា ជំពូកទី ៩–១១ នៃគម្ពីរអេធើរកត់ត្រាថា មានស្តេចចំនួន ២៤ ទៀតដែលបានដឹកនាំពួកសាសន៍យ៉ារេឌក្រោយពី យ៉ារេឌ —ខ្លះគ្រប់គ្រងដោយសុចរិត ហើយខ្លះទៀតដោយទុច្ចរិត ។ សូមរំឭកសិស្សអំពីគោលការណ៍ខាងក្រោម ដែលត្រូវបានពិភាក្សាពីមុននេះហើយ ៖ ការបដិសេធពាក្យសម្តីរបស់ព្យាការីអាចនាំទៅក្នុងការជាប់ឃុំឃាំង ។ សូមឲ្យសិស្សពាក់កណ្តាលថ្នាក់សិក្សា អេធើរ ៩:២៦–៣៥ (អំឡុងពេលរជ្ជកាលនៃស្តេចហេត) ហើយសូមឲ្យសិស្សពាក់កណ្តាលថ្នាក់ទៀតសិក្សា អេធើរ ១១:១–៨ (អំឡុងពេលរជ្ជកាលរបស់ស្តេចកុម និងសិបឡុន) ។ សូមឲ្យក្រុមទាំងពីររកមើលភស្តុតាងនានានៃគោលការណ៍នេះ ។ សូមឲ្យសិស្សរៀបរាប់ដោយខ្លីៗពីអ្វីដែលពួកគេរកឃើញ ។

សូមចែករំលែកទីបន្ទាល់របស់អ្នកអំពីសារៈសំខាន់នៃការធ្វើតាមការណែនាំរបស់ព្យាការី ។ អ្នកអាចចែករំលែកបទពិសោធន៍មួយចេញពីជីវិតរបស់អ្នក ដែលបានបង្រៀនអ្នកពីសារសំខាន់នៃការធ្វើតាមការណែនាំរបស់ព្យាការី ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អេធើរ ៧:២៣–២៧; ៩:២៨–៣១ ។ ព្យាការី និងសារលិខិតរបស់ពួកលោកត្រូវបានគេបដិសេធជាញឹកញាប់

តើហេតុអ្វីបានជាព្យាការីប្រកាសពីសារលិខិតដែលមិនមានប្រជាប្រិយភាពល្បីល្បាញចំពោះមនុស្សជាច្រើននៅក្នុងពិភពលោកនេះដូច្នេះ ? អែលឌើរ រ៉ូបឺត ឌី ហែល នៃក្រុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ ៖

« ព្យាការីជាញឹកញាប់ ត្រូវតែព្រមានអំពីលទ្ធផលនៃការរំលងច្បាប់របស់ព្រះ ។ ពួកលោកមិនបានបង្រៀនថា មួយណាល្អីសមស្របនឹងពិភពលោកនេះនោះទេ ។ . . . ហេតុអ្វីបានជាព្យាការីប្រកាសពីបទបញ្ញត្តិដែលមិនមានប្រជាប្រិយភាពល្បីល្បាញ និងអំពាវនាវឲ្យសង្គមទាំងមូលប្រែចិត្តចេញពីការបដិសេធ ការកែប្រែ និងថែមទាំងការព្រងើយកន្តើយនឹងបទបញ្ញត្តិទាំងឡាយដូច្នេះ ? មូលហេតុនោះគឺសាមញ្ញបំផុត ។ ដោយការទទួលបានវិវរណៈនោះព្យាការីគ្មានជម្រើសអ្វីផ្សេងទៀត ក្រៅពីប្រកាស និងបញ្ជាក់ជាថ្មី នូវអ្វីដែលព្រះបានប្រទានដល់ពួកលោក ដើម្បីប្រាប់ដល់ពិភពលោកនេះនោះទេ » (« If Thou Wilt Enter into Life, Keep the Commandments » *Ensign,* ខែឧសភា ឆ្នាំ ១៩៩៦, ទំព័រ ៣៧) ។

អែលឌើរ អែល. អាលឌីន ផតឌើរ នៃគណៈប្រធាននៃពួកចិតសិបនាក់បានបង្រៀន ៖

« អ្នកខ្លះអ៊ូថា នៅពេលព្យាការីមានប្រសាសន៍ដោយភាពជាក់ច្បាស់ និងភាពរឹងមាំថា ពួកលោកកំពុងតែដកយកសិទ្ធិជ្រើសរើសរបស់យើងចេញហើយ ។ យើងនៅតែមានសេរីភាពជ្រើសរើសដដែល ។ប៉ុន្តែយើងត្រូវតែទទួលនូវលទ្ធផលនៃការសម្រេចចិត្តទាំងនោះ ។ ព្យាការីមិនបានដកយកសិទ្ធិជ្រើសរើសរបស់យើងចេញនោះទេ ។ ពួកលោកគ្រាន់តែព្រមានយើងអំពីអ្វីដែលលទ្ធផលនៃជម្រើសរបស់យើងនឹងកើតឡើងតែប៉ុណ្ណោះ ។ តើវាឆ្កួតប៉ុណ្ណាទៅ ដែលចោទលើព្យាការីចំពោះការព្រមានរបស់ពួកលោក » (« Our Destiny » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩៩, ទំព័រ ៦៦) ។

អេធើរ ១២:១–២២

សេចក្តីផ្តើម

ក្រោយពីតំណាលពីប្រវត្តិសាស្ត្រជាច្រើនឆ្នាំរបស់ពួកសាសន៍យ៉ារេឌហើយ លោកម៉ូរ៉ូណៃបានណែនាំអំពីការបម្រើរបស់ព្យាការីអេធើរ ។ បន្ទាប់មក លោកម៉ូរ៉ូណៃបានបង្អាក់ដំណើររឿងប្រវត្តិសាស្ត្រដើម្បីកត់ត្រាអំពីពរជ័យខ្លះៗដែលមកដល់អស់អ្នកណាដែលអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ។ មេរៀននេះក្តោបលើ អេធើរ ១២:១–២២ ខណៈពេលមេរៀនទី ១៥០ ទាក់ទងនឹង អេធើរ ១២:២៣–៤១ ។

យោបល់សម្រាប់ការបង្រៀន

អេធើរ ១២:១–៤

លោកអេធើរ បង្រៀនអំពីការប្រែចិត្តដល់ពួកសាសន៍យ៉ារេឌ

សូមចាប់ផ្តើមថ្នាក់រៀនដោយការសុំឲ្យសិស្សម្នាក់ឡើងមកខាងមុខថ្នាក់ ហើយគូសរូបរលកខ្លះ និងទូកមួយដែលមានសុវត្ថិភាពដោយយុថ្កាមួយ ។

- ហេតុអ្វីបានជាវាសំខាន់ដែលទូកត្រូវមានយុថ្កា ?
- តើមានគ្រោះថ្នាក់ ឬការលំបាកណាខ្លះដែលអាចនឹងកើតមាន ប្រសិនបើទូកគ្មានយុថ្កាទេនោះ ?
- តើរលកនឹងមានឥទ្ធិពលយ៉ាងណាទៅលើទូក ? (ចម្លើយអាចរួមមាន រលកនឹងបណ្តាលឲ្យទូកនោះផ្លាស់ទី រសាត់អណ្តែត ឬក៏បក់ទៅបក់មក) ។

សូមសរសេរលើទូកនោះដោយពាក្យថា *ជីវិតរបស់អ្នក* ។

- ប្រសិនបើទូកនោះតំណាងឲ្យជីវិតរបស់យើង តើរលកនោះអាចដូចជាអ្វីទៅ ? (ចម្លើយអាចរួមមាន សំពាធពីសង្គម ឧបសគ្គ ការបង្រៀនខុសឆ្គង ឬអំពើទុច្ចរិត) ។
- តើជីវិតរបស់មនុស្សម្នាក់អាចដូចជាទូកដែលគ្មានយុថ្កាដោយរបៀបណា ? (អ្នកអាចណែនាំ សិស្សគួរអានទៅក្នុង មរមន ៥:១៧–១៨ ដើម្បីជួយពួកគេឲ្យឆ្លើយតបទៅនឹងសំណួរនេះ) ។
- តើមានរឿងអ្វីខ្លះដែលព្រះអម្ចាស់បានប្រទាន ដែលអាចធ្វើជាយុថ្កាខាងវិញ្ញាណនៅក្នុងជីវិតរបស់យើងបាននោះ ? (សិស្សអាចផ្តល់ចម្លើយខុសៗគ្នា ។ ផ្នែកជាច្រើននៃដំណឹងល្អ អាចប្រៀបដូចជាយុថ្កា) ។

សូមអញ្ជើញសិស្សឲ្យរកមើលឧទាហរណ៍នៃយុថ្កាខាងវិញ្ញាណ នៅពេលពួកគេសិក្សាក្នុង អេធើរ ១២ ។

សូមពន្យល់ថា អេធើរ ១២ ចាប់ផ្តើមដោយការណែនាំរបស់លោកម៉ូរ៉ូណៃអំពីលោកអេធើរ ដែលជាព្យាការីរបស់ពួកសាសន៍យ៉ារេឌ ដែលបានបង្រៀនក្នុងពេលមួយដែលប្រជាជនបានបដិសេធព្យាការី និងបានរស់នៅក្នុងសេចក្តីទុច្ចរិត ។ សូមឲ្យសិស្សអាន អេធើរ ១២:១–៣ ដោយស្ងាត់ស្ងៀមដោយរកមើលអ្វីៗដែលធ្វើឲ្យពួកគេរំភើបអំពីសកម្មភាពរបស់លោកអេធើរ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមឲ្យសិស្សម្នាក់អាន អេធើរ ១២:៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលអស់អ្នកទាំងឡាយណាដែលជឿលើព្រះអាច « សង្ឃឹមដល់ » ទោះបីជារស់នៅក្នុងភាពលំបាក និងសេចក្តីទុច្ចរិតក្តី ។ នៅពេលសិស្សឆ្លើយ អ្នកអាចលើកឡើង « ពិភពដ៏ល្អប្រសើរមួយ » ដែលយើងសង្ឃឹមចង់បាននោះគឺជា « កន្លែងមួយដែលនៅខាងស្តាំព្រះហស្តនៃព្រះ » ។

- តើវាមានន័យយ៉ាងណា ដែលមានកន្លែងមួយនៅខាងស្តាំព្រះហស្តនៃព្រះ ? (ការត្រឡប់ទៅកាន់វត្តមានរបស់ទ្រង់វិញ និងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ច) ។
- តើអ្នកគិតថា ការមានសង្ឃឹម « ដោយភាពពិតប្រាកដ » ខុសគ្នាពីការគ្រាន់តែចង់បានអ្វីមួយដោយរបៀបណា ? (នៅក្នុងព្រះគម្ពីរ សេចក្តីសង្ឃឹមសំដៅទៅលើការមានទំនុកចិត្តថា យើងអាចទទួលបានពរជ័យដែលព្រះទ្រង់សន្យានឹងយើង ប្រសិនបើយើងកាន់តាមសេចក្តីសញ្ញារបស់យើងជាមួយនឹងទ្រង់) ។
- យោងតាម អេធើរ ១២:៤ តើយើងទទួលបានសេចក្តីសង្ឃឹមនៃការទទួលបានកន្លែងមួយនៅខាងស្តាំព្រះហស្តនៃព្រះដោយរបៀបណា ? (នៅពេលសិស្សឆ្លើយ សូមពន្យល់ថា សេចក្តីជំនឿដែលបានលើកឡើងនៅក្នុង អេធើរ ១២:៤ សំដៅទៅលើសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ) ។ តើសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទធ្វើឲ្យយើងសង្ឃឹម « ដោយភាពពិតប្រាកដ » ថានឹងបានកន្លែងមួយនៅខាងស្តាំព្រះហស្តនៃព្រះដោយរបៀបណា ?

នៅលើក្តារខៀន សូមសរសេរលើរូបយុថ្កាដោយពាក្យ *សេចក្តីជំនឿ និងសេចក្តីសង្ឃឹម* ។

- យោងតាម អេធើរ ១២:៤ តើនឹងមានអ្វីកើតឡើង នៅពេលនរណាម្នាក់មានសេចក្តីសង្ឃឹម និងសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ? (ទោះបីជាសិស្សអាចឆ្លើយដោយប្រើពាក្យខុសគ្នាក្តី ក៏ពួកគេគួរបង្ហាញនូវគោលការណ៍ខាងក្រោមនេះ ៖

នៅពេលយើងមានសេចក្តីសង្ឃឹម និងសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងនឹងខ្ជាប់ខ្ជួន ហើយយើងនឹងចងភ្ជាប់ទៅនឹងកិច្ចការល្អ) ។

- តើអ្នកគិតថា « ចងភ្ជាប់ » នៅក្នុងកិច្ចការល្អមានន័យយ៉ាងណា ? (ការធ្វើរឿងល្អៗជាច្រើន) ។
- តើកិច្ចការល្អអ្វីខ្លះដែល « តម្កើងសិរីល្អដល់ព្រះ » ? (ចម្លើយអាចរួមមាន ការអធិស្ឋាន ការសិក្សាព្រះគម្ពីរ ការបម្រើអ្នកដទៃ និងការអភិវឌ្ឍទេពកោសល្យ) ។
- សូមគិតពីមនុស្សដែលអ្នកស្គាល់ ដែលតែងតែមើលទៅចងភ្ជាប់ទៅនឹងកិច្ចការល្អ ហើយមិនខ្មាស់អៀនក្នុងការតម្កើងសិរីល្អដល់ព្រះ ។ តើមានរឿងជាក់លាក់អ្វីខ្លះដែលពួកគេបានធ្វើ ដែលធ្វើឲ្យពួកគេក្លាយជាគំរូដ៏ល្អមួយក្នុងការឆ្លុះបញ្ចាំងពីគោលការណ៍នេះ ?

សូមឲ្យសិស្សសញ្ជឹងគិតពីពេលដែលវាជាការពិបាកសម្រាប់ពួកគេ ដើម្បីបន្តខ្ជាប់ខ្ជួន និងចងភ្ជាប់នៅក្នុងកិច្ចការល្អ ។ ដើម្បីជួយសិស្សឲ្យរៀបចំសម្រាប់ស្ថានភាពដែលស្រដៀងគ្នាពេញមួយឆាកជីវិតរបស់ពួកគេ សូមអញ្ជើញពួកគេឲ្យរកមើលរបៀបដែលពួកគេអាចបង្កើនសេចក្តីជំនឿ និងសេចក្តីសង្ឃឹមរបស់ពួកគេ នៅពេលពួកគេបន្តការសិក្សានៅក្នុង អេធើរ ១២ ។

អេធើរ ១២:៥–២២

លោកម៉ូរ៉ូណៃរៀបរាប់ពីអព្ភូតហេតុ និងកិច្ចការដ៏អស្ចារ្យដែលបានកើតឡើងដោយសេចក្តីជំនឿ

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ ខ្ញុំចង់ទទួលបានសាក្សីខាងវិញ្ញាណថា . . .

សូមឲ្យសិស្សផ្តល់យោបល់អំពីសេចក្តីពិតនៃដំណឹងល្អនានា គោលការណ៍ទាំងឡាយ ឬក៏គោលលទ្ធិផ្សេងៗដែលមនុស្សអាចរកឃើញនូវសាក្សីខាងវិញ្ញាណ ។ នៅពេលសិស្សឆ្លើយ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។ (ចម្លើយអាចរួមមានសាក្សីមួយថា *ព្រះគម្ពីរមរមនគឺពិត ; ការរស់នៅក្នុងជីវិតមួយដោយមានភាពស្អាតស្អំ និងពោរពេញដោយគុណធម៌គឺមានសារសំខាន់ ; ពាក្យគតិបណ្ឌិតគឺជាច្បាប់របស់ព្រះមួយ ; ខ្ញុំគួរតែរៀបចំដើម្បីទៅបម្រើបេសកម្ម*) ។ សូមឲ្យសិស្សគិតអំពីសេចក្តីពិតនៃដំណឹងល្អមួយ ដែលពួកគេចង់ទទួលបាននូវសាក្សីខាងវិញ្ញាណ ឬក៏មានទីបន្ទាល់កាន់តែរឹងមាំឡើង ។

សូមពន្យល់ថា មនុស្សខ្លះមាននូវតែរិយាបថដូចខាងក្រោមនេះ ៖ « ខ្ញុំនឹងមិនជឿ ឬមិនរស់នៅតាមគោលការណ៍នៃដំណឹងល្អនោះទេ រហូតដល់ខ្ញុំបានឃើញភស្តុតាងដែលបញ្ជាក់ថា វាគឺជាការពិតសិន » ។ សូមឲ្យសិស្សអាន អេធើរ ១២:៥–៦ ដោយស្ងាត់ស្ងៀម ដោយរកមើលរបៀបដែលខគម្ពីរទាំងនេះទាក់ទងទៅនឹងតរិយាបថបែបនេះ ។ សូមបង្ហាញថា អេធើរ ១២:៦ នេះគឺជាវគ្គព្រះគម្ពីរចំណេះចំណាន ។ អ្នកអាចណែនាំ សិស្សគួរគូសចំណាំវគ្គនេះដើម្បីឲ្យងាយស្រួលនឹងរកឃើញវា ។

អេធើរ ១២:៦ នេះគឺជាវគ្គព្រះគម្ពីរចំណេះចំណាន ។ សូមមើលគំនិតក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរ ។

- យោងតាម អេធើរ ១២:៦ តើមានអ្វីត្រូវតែកើតឡើង មុនពេលយើងអាចទទួលបានសក្ខីភាពមួយនោះ ?
- តើគំនិតអ្វីខ្លះ ដែលអ្នកមាន នៅពេលអ្នកគិតអំពីឃ្លា « ការសាកល្បងនៃសេចក្តីជំនឿ » ?

ក្រោយពីសិស្សឆ្លើយហើយ អ្នកអាចចង់ពន្យល់ថា មនុស្សខ្លះបកប្រែន័យនៃ « ការសាកល្បងនៃសេចក្តីជំនឿ » ខុសឆ្គងថាជាការសំដៅទៅរកភាពលំបាកលំបិនទៅវិញ ។ ឃ្លា « ការសាកល្បងនៃសេចក្តីជំនឿ » អាចពិពណ៌នាថាជាអ្វីៗដែលផ្តល់ឱកាសមួយដល់យើងដើម្បីបង្ហាញ ឬអនុវត្តសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សម្នាក់អាននូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ រីឆាត ជី ស្តុត នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ៖ មុនពេលសិស្សអានសេចក្តីថ្លែងការណ៍នេះ សូមឲ្យសិស្សស្តាប់ការពន្យល់របស់អែលឌើរ ស្តុត អំពីអត្ថន័យនៃឃ្លា « ការសាកល្បងនៃសេចក្តីជំនឿ » ។

« អ្នកអាចរៀនដើម្បីប្រើសេចក្តីជំនឿឲ្យកាន់តែមានប្រសិទ្ធភាពជាងនេះទៅទៀត ដោយការអនុវត្តគោលការណ៍ដែលបានបង្រៀនដោយលោកម៉ូរ៉ូណៃនេះ ៖ ‹ . . . ត្បិតអ្នករាល់គ្នាពុំទទួលសាក្សីឡើយ លុះដល់ក្រោយពី *ការសាកល្បងនៃសេចក្តីជំនឿរបស់អ្នកសិន* › | អេធើរ ១២:៦; អក្សរទ្រេតត្រូវបានបន្ថែម | ។ ហេតុដូច្នេះហើយ រាល់ពេលដែលអ្នក *សាកល្បងសេចក្តីជំនឿរបស់អ្នក* នោះគឺថា អ្នកត្រូវធ្វើសកម្មភាពដោយភាពសកម្មចំពោះការរំភើបមួយ ដែលអ្នកនឹងទទួលបានភស្តុតាងបញ្ជាក់អំពីព្រះវិញ្ញាណ ។ អារម្មណ៍ទាំងនោះនឹងពង្រឹងដល់សេចក្តីជំនឿរបស់អ្នក ។ នៅពេលអ្នកធ្វើតាមគំរូនោះម្តងហើយម្តងទៀត សេចក្តីជំនឿរបស់អ្នកនឹងកាន់តែរឹងមាំជាងនេះទៅទៀត » (« The Sustaining Power of Faith in Times of Uncertainty and Testing » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៣, ទំព័រ ៧៦) ។

- តើដំណើរការដែលបានរៀបរាប់ដោយអែលឌើរ ស្តុត ខុសពីតរិយាបថរបស់អស់អ្នកទាំងឡាយណាដែលចង់បានភស្តុតាងមុនពេលពួកគេនឹងជឿ ឬធ្វើសកម្មភាពដោយរបៀបណា ?

សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖ អេធើរ ១២:៧–១២; អេធើរ ១២:១៣–១៨; អេធើរ ១២:១៩–២២, ៣០–៣១ ។ សូមបែងចែកសិស្សក្នុងថ្នាក់ទៅជាបីក្រុម ហើយចាត់តាំងឲ្យក្រុមនីមួយៗអាននូវវគ្គព្រះគម្ពីរមួយ ។ សូមឲ្យសិស្សរកមើលនូវពរជ័យដែលបានមកពីលទ្ធផលនៃសេចក្តីជំនឿរបស់មនុស្សដែលបានរៀបរាប់នៅក្នុងវគ្គគម្ពីរនីមួយៗ ។ សូមអញ្ជើញឲ្យពួកគេកត់ចំណាំនូវការប្រើឃ្លា « លុះត្រាក្រោយពីពួកគេមានសេចក្តីជំនឿ » ឬ « លុះត្រាក្រោយពីសេចក្តីជំនឿរបស់ពួកគេសិន » នៅក្នុងខគម្ពីរទី ៧, ១២, ១៧, ១៨, និង ៣១ ។ (អ្នកអាចណែនាំ សិស្សគួរគូសចំណាំឃ្លាទាំងនេះរាល់ពេលដែលគេអានប៉ះ) ។

ក្រោយពីសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញហើយ សូមឲ្យពួកគេសង្ខេបនូវអ្វីដែលព្រះអម្ចាស់ប្រទាន ក្រោយពីយើងបង្ហាញពីសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ។ ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរបង្ហាញនូវសេចក្តីពិតស្រដៀងនឹងឃ្លាដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងចង់បានសាក្សីខាងវិញ្ញាណ នោះយើងត្រូវតែអនុវត្តសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទជាមុនសិន ។** សូមពន្យល់ថា គឺដូចជាសាក្សីខាងវិញ្ញាណភាគច្រើនដែរ អព្ភូតហេតុនឹងមិនកើតមានឡើងនោះទេ រហូតដល់ក្រោយពីយើងបានអនុវត្តសេចក្តីជំនឿរបស់យើងសិន ។

សូមបង្ហាញស្ថានភាពដូចខាងក្រោមដល់សិស្ស ។ សូមឲ្យសិស្សពន្យល់ពីរបៀបដែលបុគ្គលម្នាក់នៅក្នុងស្ថានភាពនីមួយៗអាចនឹងបង្ហាញសេចក្តីជំនឿទៅលើព្រះអម្ចាស់ ។

១. យុវនារីម្នាក់ចង់ទទួលបានសាក្សីមួយអំពីសេចក្តីពិតពេញលេញនៃព្រះគម្ពីរមរមន ។

២. យុវជនម្នាក់មានបំណងដ៏មុតស្រួចមួយដើម្បីជួយមនុស្សជាទីស្រឡាញ់របស់គេឲ្យទទួលយកដំណឹងល្អ ។

សូមឲ្យសិស្សសញ្ជឹងគិតមួយសន្ទុះ នៅពេលពួកគេ ឬមនុស្សដែលពួកគេស្គាល់បានទទួលនូវសាក្សីខាងវិញ្ញាណ ឬក៏អព្ភូតហេតុណាមួយក្រោយពីបានបង្ហាញនូវសេចក្តីជំនឿទៅលើព្រះអម្ចាស់ ។ សូមឲ្យសិស្សចែករំលែកពីបទពិសោធន៍ដែលពួកគេបានគិតដល់ ។ (សូមប្រាកដថា សិស្សយល់ថា ពួកគេមិនគួរមានអារម្មណ៍ថាត្រូវតែចែករំលែកអំពីបទពិសោធន៍ដែលផ្ទាល់ខ្លួន ឬឯកជនពេកនោះទេ) ។ អ្នកក៏អាចចែករំលែកពីបទពិសោធន៍ផ្ទាល់ខ្លួនដែរ ។

សូមឲ្យសិស្សគិតអំពីសេចក្តីពិតនៃដំណឹងល្អមួយ ដែលពួកគេចង់ទទួលបាននូវសាក្សីខាងវិញ្ញាណ ។ សូមឲ្យពួកគេសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់អំពីអ្វីមួយ ដែលពួកគេអាចនឹងធ្វើដើម្បីអនុវត្តសេចក្តីជំនឿឲ្យកាន់តែខ្លាំងនៅលើព្រះអម្ចាស់ ។

ចំណេះចំណានខគម្ពីរ —អេធើរ ១២:៦

ដើម្បីជួយសិស្សឲ្យចងចាំ អេធើរ ១២:៦ សូមឲ្យសិស្សម្នាក់ៗសរសេរខគម្ពីរនេះនៅលើក្រដាសមួយសន្លឹក ដោយទុកចន្លោះសម្រាប់ពាក្យ ឬឃ្លាគន្លឹះ ហើយបំពេញកន្លែងចន្លោះនោះនៅក្នុងកន្លែងរបស់ពួកគេ ។ នៅពេលពួកគេធ្វើរួចហើយ សូមឲ្យសិស្សមានពេលមួយនាទីដើម្បីព្យាយាមទន្ទេញខគម្ពីរនេះឲ្យចាំ ដោយបំពេញចន្លោះនៅលើក្រដាសរបស់ពួកគេក្នុងខួរក្បាល ។

សូមឲ្យសិស្សផ្លាស់ប្តូរក្រដាសជាមួយនរណាម្នាក់ដែលនៅជិតនឹងពួកគេ ។ សិស្សម្នាក់ៗគួរតែអានក្រដាសថ្មីរបស់គេឮៗ ដោយព្យាយាមបំពេញក្នុងចន្លោះនោះចេញពីការចងចាំរបស់គេ ។ បើសិនជាមានពេល សូមឲ្យសិស្សធ្វើសកម្មភាពនេះម្តងទៀត ដោយការផ្លាស់ប្តូរក្រដាសនោះម្តងទៀត ។

សូមឲ្យសិស្សយកក្រដាសរបស់ពួកគេទៅផ្ទះ ហើយប្រើវាដើម្បីទន្ទេញ អេធើរ ១២:៦ ដល់ឪពុកម្តាយរបស់គេ ។ សូមអញ្ជើញពួកគេឲ្យសួរទៅឪពុកម្តាយរបស់គេ ក្នុងកាលឪពុកម្តាយរបស់ពួកគេបានបង្ហាញសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ និងបានទទួលនូវសាក្សី ឬអព្ភូតហេតុមួយដែលពួកគេបានស្វែងរក ។

សូមបញ្ចប់ដោយទីបន្ទាល់របស់អ្នកអំពីគោលការណ៍ដែលបានបង្រៀននៅក្នុងមេរៀននេះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អេធើរ ១២:៤–៦ ។តើសេចក្តីសង្ឃឹមគឺជាអ្វី ?

នៅក្នុង អេធើរ ១២ ការបង្រៀនរបស់លោកម៉រ៉ូណៃអំពីគោលការណ៍នៃសេចក្តីសង្ឃឹម និងសេចក្តីជំនឿ បង្ហាញថាសេចក្តីទាំងពីរនេះត្រូវទាក់ទងគ្នាយ៉ាងស្អិតរមួត ។ លោកបានឲ្យនិយមន័យអំពីសេចក្តីជំនឿថាជា « អ្វីដែលសង្ឃឹមចង់បាន ហើយមើលមិនឃើញ » (អេធើរ ១២:៦) និងបានបង្រៀនថា សេចក្តីសង្ឃឹមរបស់យើងសម្រាប់សេចក្តីសង្គ្រោះ « មកពីសេចក្តីជំនឿ » នៅក្នុងព្រះយេស៊ូវគ្រីស្ទ (អេធើរ ១២:៤) ។ កូនសៀវភៅ *ពិតចំពោះសេចក្តីជំនឿ* បង្រៀនអំពីសេចក្តីសង្ឃឹមដូចខាងក្រោមនេះ ៖

« នៅពេលយើងមានសេចក្តីសង្ឃឹម យើងនឹងទុកចិត្តទៅលើសេចក្តីសន្យារបស់ព្រះ ។ យើងមានការធានាដ៏ជាក់លាក់មួយថា ប្រសិនបើយើងធ្វើ ‹ កិច្ចការទាំងឡាយដោយសេចក្តីសុចរិត យើងនឹងទទួលរង្វាន់ [របស់យើង] គឺសេចក្តីសុខសាន្តនៅនាលោកិយនេះ និងជីវិតដ៏នៅអស់កល្បជានិច្ចនៅបរលោកនាយ (គ. និង ស. ៥៩:២៣) ។ គោលការណ៍នៃសេចក្តីសង្ឃឹមនេះបានទៅដល់ភាពដ៏អស់កល្បជានិច្ច ប៉ុន្តែវាក៏អាចទ្រទ្រង់អ្នកឲ្យឆ្លងកាត់នឹងឧបសគ្គប្រចាំថ្ងៃក្នុងជីវិតបានដែរ » (*ពិតចំពោះសេចក្តីជំនឿ ៖ សេចក្តីយោងនៃដំណឹងល្អ* [ឆ្នាំ ២០០៤], ទំព័រ ៨៥–៨៦) ។

ប្រធាន ឌៀថើរ អេស អុជដូហ្វ បានផ្តល់និយមន័យនៃពាក្យសេចក្តីសង្ឃឹមដូចខាងក្រោមនេះ ៖

« សេចក្តីសង្ឃឹមគឺជាអំណោយខាងវិញ្ញាណ ។ [សូមមើល ម៉រ៉ូណៃ ៨:២៦] ។ វាគឺជាសេចក្តីសង្ឃឹមមួយដែលតាមរយៈជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និងព្រះចេស្តានៃការរស់ឡើងវិញរបស់ទ្រង់ នោះយើងនឹងត្រូវបានក្រោកឡើងទៅរកជីវិតដ៏នៅអស់កល្ប ហើយការណ៍នេះគឺដោយសារតែសេចក្តីជំនឿរបស់យើងទៅលើព្រះអង្គសង្គ្រោះ ។ [សូមមើល ម៉រ៉ូណៃ ៧:៤១] ។ សេចក្តីសង្ឃឹមប្រភេទនេះគឺជាគោលការណ៍នៃសេចក្តីសន្យាមួយផង ហើយក៏ជាព្រះបញ្ញត្តិមួយដែរ [សូមមើល កូល៉ុស ១:២១–២៣] ហើយដូចដែលមានព្រះបញ្ញត្តិទាំងឡាយផង យើងមានការទទួលខុសត្រូវដើម្បីធ្វើឲ្យវាសកម្មនៅក្នុងផ្នែកមួយនៃជីវិតរបស់យើង ហើយយកឈ្នះលើការល្បួងដែលធ្វើឲ្យបាត់បង់សេចក្តីសង្ឃឹម ។ សេចក្តីសង្ឃឹមទៅលើផែនការនៃសុភមង្គលដ៏មានមេត្តាករុណារបស់ព្រះវរបិតាសួគ៌ ដឹកនាំទៅរកសេចក្តីសុខសាន្ត [សូមមើល រ៉ូម ១៥:១៣], សេចក្តីមេត្តាករុណា [សូមមើល ទំនុកតម្កើង ៣៣:២២], សេចក្តីអំណរ [សូមមើល រ៉ូម ១២:១២] និងសេចក្តីរីករាយ ។ [សូមមើល សុភាសិត ១០:២៨] ។ សេចក្តីសង្ឃឹមនៃសេចក្តីសង្គ្រោះគឺដូចជាមួកសឹកមួយដូច្នោះដែរ [សូមមើល ថែសាឡូនីចទី ១ ៥:៨]; វាគឺជាគ្រឹះមួយនៃសេចក្តីជំនឿរបស់យើង [សូមមើល ហេព្រើរ ១១:១; ម៉រ៉ូណៃ ៧:៤០] និងជាយុថ្កាមួយដល់ព្រលឹងរបស់យើង ។ [សូមមើល ហេព្រើរ ៦:១៩; អេធើរ ១២:៤] » ។ (« The Infinite Power of Hope » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៨, ទំព័រ ២១–២២) ។

អេធើរ ១២:២៣–៤១

សេចក្តីផ្តើម

ដោយការអធិស្ឋានដ៏របសា លោកម៉ូរ៉ូណៃបានបង្ហាញនូវការបារម្ភមួយ ។ លោកបានបារម្ភអំពីភាពទន់ខ្សោយ ដែលលោកបានទទួលនៅក្នុងការសរសេររបស់លោក និងនៅក្នុងការសរសេររបស់ព្យាការីក្នុងព្រះគម្ពីរមរមនផ្សេងទៀត ។ ព្រះអម្ចាស់បានឆ្លើយតបដោយសេចក្តីសន្យាមួយដើម្បីពង្រឹងដល់អស់អ្នកណាដែលបន្ទាបខ្លួនគេ ហើយមានសេចក្តីជំនឿទៅលើទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

អេធើរ ១២:២៣–៤១

លោកម៉ូរ៉ូណៃបង្រៀនថា សេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស គឺជាការណ៍ដ៏សំខាន់មួយសម្រាប់សេចក្តីសង្គ្រោះ ។

សូមសរសេរពាក្យ *រឹងមាំ* នៅផ្នែកម្ខាងនៃក្តារខៀន និងពាក្យ *ទន់ខ្សោយ* នៅលើផ្នែកម្ខាងទៀតនៃក្តារខៀន ។ សូមឲ្យសិស្សមានពេលដើម្បីសញ្ជឹងគិតពីអ្វីដែលពួកគេគិតថាជាភាពរឹងមាំរបស់ពួកគេ ។ បន្ទាប់មក សូមឲ្យពួកគេគិតអំពីភាពទន់ខ្សោយ ឬភាពមិនគ្រប់គ្រាន់របស់ពួកគេពីរបី ។ សូមឲ្យពួកគេលើកដៃ ប្រសិនបើពួកគេចង់ឲ្យចំណុចទន់ខ្សោយរបស់គេក្លាយទៅជាចំណុចរឹងមាំ ។ សូមពន្យល់ថា លោកម៉ូរ៉ូណៃបានបង្រៀនអំពីមូលហេតុដែលយើងមានភាពទន់ខ្សោយ និងរបៀបដែលយើងអាចយកឈ្នះលើវាបាន ។

សូមឲ្យសិស្សម្នាក់អាន អេធើរ ១២:២៣–២៥ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលភាពទន់ខ្សោយដែលលោកម៉ូរ៉ូណៃបានមានអារម្មណ៍ថា លោក និងអ្នកសរសេរដទៃទៀតនៃព្រះគម្ពីរមរមនបានមាន ។ មុនពេលសិស្សអាន អ្នកអាចពន្យល់ថា ពាក្យ *ពួកសាសន៍ដទៃ* នៅក្នុងខគម្ពីរទាំងនេះសំដៅទៅលើមនុស្សដែលនឹងរស់នៅឯស្រុកនៃជាតិសាសន៍ដទៃនៅក្នុងថ្ងៃចុងក្រោយ ។

- តើលោកម៉ូរ៉ូណៃបានព្រួយបារម្ភថានឹងមានអ្វីកើតឡើង ដោយសារតែភាពទន់ខ្សោយនៃអស់អ្នកដែលបានសរសេរព្រះគម្ពីរមរមន ?

អេធើរ ១២:២៧ នេះគឺជាវគ្គព្រះគម្ពីរចំណេះចំណាន ។ សូមបើកទៅគំនិតក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរ ។

សូមឲ្យសិស្សអានដោយស្ងាត់ស្ងៀមនូវចម្លើយរបស់ព្រះអម្ចាស់ចំពោះការបារម្ភរបស់លោកម៉ូរ៉ូណៃនៅក្នុង អេធើរ ១២:២៦–២៧ ។ សូមឲ្យពួកគេរកមើលមូលហេតុមួយដែលព្រះប្រទានដល់យើងនូវភាពទន់ខ្សោយទាំងនោះ ។ សូមបង្ហាញថា អេធើរ ១២:២៧ នេះគឺជាវគ្គព្រះគម្ពីរចំណេះចំណាន ។ អ្នកអាចស្នើ សិស្សគូរគូសចំណាំវគ្គនេះដើម្បីឲ្យងាយស្រួលនឹងរកឃើញវា ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ពីពាក្យ *ភាពទន់ខ្សោយ* នៅពេលវាត្រូវបានប្រើនៅក្នុងខគម្ពីរទាំងនេះ សូមឲ្យសិស្សម្នាក់អាននូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ នែល អេ ម៉ាក់ស្វែល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។ មុនពេលអានសេចក្តីថ្លែងការណ៍នេះ សូមឲ្យសិស្សស្តាប់រកមើលភាពទន់ខ្សោយពីរប្រភេទដែលអែលឌើរ ម៉ាក់ស្វែល បានលើកឡើងនេះ ។

« នៅពេលយើងអាននៅក្នុងព្រះគម្ពីរអំពី ‹ ភាពទន់ខ្សោយ › របស់មនុស្ស ពាក្យនេះរួមមាន . . . ភាពទន់ខ្សោយដែលមាននៅក្នុងលក្ខខណ្ឌជាមនុស្សទូទៅ ដែលក្នុងភាពជាសាច់ និងឈាមវាមានឥទ្ធិពលដ៏ឥតឈប់ឈរ | ឬឥតដាច់ | បែបនេះមកលើភាពជាវិញ្ញាណ (សូមមើល អេធើរ ១២:២៨–២៩) ។ ប៉ុន្តែ ដូចគ្នានឹងភាពទន់ខ្សោយនេះដែរ វារួមមានភាពទន់ខ្សោយជាពិសេស និងជាបុគ្គលរបស់យើង ដែលយើងត្រូវតែយកឈ្នះលើវា (សូមមើល គ. និង ស. ៦៦:៣; យ៉ាកុប ៤:៧) ។ ជីវិតនេះមានរបៀបមួយនៃការបង្ហាញនូវភាពទន់ខ្សោយទាំងនេះ » (*Lord, Increase Our Faith* | ឆ្នាំ ១៩៩៤ |, ទំព័រ ៨៤) ។

- យោងតាមសម្តីរបស់អែលឌើរ ម៉ាក់ស្វែល តើអ្វីជាភាពទន់ខ្សោយរបស់មនុស្សពីរប្រភេទដែលយើងអានអំពីវានៅក្នុងព្រះគម្ពីរ ? (អ្នកអាចពន្យល់ថាឃ្លា « លក្ខខណ្ឌជាមនុស្សទូទៅ » សំដៅទៅលើភាពទន់ខ្សោយដែលបន្សល់ទុកមកពីការធ្លាក់របស់អ័ដាម និងអេវ៉ា ឬនិយាយម្យ៉ាងទៀតថា ភាពទន់ខ្សោយដែលភ្ជាប់ទៅនឹង « មនុស្សខាងសាច់ឈាម » ដែលបាននិយាយនៅក្នុង ម៉ូសាយ ៣:១៩) ។

សូមរំឭកសិស្សថា ពេលខ្លះ ព្រះគម្ពីរបង្ហាញពីគោលការណ៍មួយដោយប្រើពាក្យ *បើសិនជា* និងពាក្យ *នោះ* ។ ពាក្យ *បើសិនជា* ប្រាប់ពីអ្វីមួយដែលយើងត្រូវតែធ្វើ ហើយពាក្យ *នោះ* ប្រាប់ពីការពន្យល់នៃអ្វីដែលនឹងកើតឡើងដែលជាលទ្ធផលនៃសកម្មភាពរបស់យើង ។ សូមឲ្យសិស្សរំឭក អេធើរ ១២:២៧ ដោយស្ងាត់ស្ងៀមដោយរកមើលគោលការណ៍ « បើសិនជា-នោះ » ដែលបានបង្រៀននៅក្នុងខគម្ពីរនេះ ។ សិស្សគួររកឃើញនូវគោលការណ៍ខាងក្រោម (សូមសរសេរវានៅលើក្តារខៀន) ៖

បើសិនជាយើងមករកព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹងបង្ហាញយើងនូវភាពទន់ខ្សោយរបស់យើង ។

បើសិនជាយើងបន្ទាបខ្លួនយើង ហើយអនុវត្តសេចក្តីជំនឿជឿលើព្រះអម្ចាស់ នោះទ្រង់នឹងធ្វើឲ្យអ្វីដែលទន់ខ្សោយក្លាយទៅជាខ្លាំងពូកែចំពោះយើងវិញ ។

- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីស្គាល់ពីភាពទន់ខ្សោយរបស់យើង ?

- សូមបង្ហាញឃ្លា « មករកព្រះយេស៊ូវគ្រីស្ទ » នៅក្នុងគោលការណ៍ទីមួយ ។ តើមានអ្វីខ្លះដែលយើងអាចធ្វើដើម្បី « មករកព្រះយេស៊ូវគ្រីស្ទ » ? (ចម្លើយអាចរួមមាន យើងអាចអធិស្ឋាន តមអាហារ ប្រែចិត្ត សិក្សាព្រះគម្ពីរ ចូលរួមក្នុងការថ្វាយបង្គំក្នុងព្រះវិហារបរិសុទ្ធ បម្រើដល់អ្នកដទៃ និងស្វែងរកដើម្បីអភិវឌ្ឍឥរិយាបថដើម្បីក្លាយដូចជាព្រះគម្ពីរ ។ អ្នកអាចបង្ហាញថា នៅក្នុងកាលៈទេសៈចាំបាច់បំផុត ការយកឈ្នះលើភាពទន់ខ្សោយ មានន័យថាលើសពីការស្វែងរកជំនួយពីព្រះអម្ចាស់ នោះយើងត្រូវតែធ្វើនូវចំណែករបស់យើង) ។
- តើន័យបង្កប់នៃគោលការណ៍ទីពីរនឹងកើតមានអ្វីខ្លះ ប្រសិនបើយើងជ្រើសរើស *មិនព្រម* បន្ទាបខ្លួនយើង និងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទទេនោះ ? (ភាពទន់ខ្សោយរបស់យើងនឹងនៅតែមាន ដោយសារយើងបានបដិសេធនូវសិរីល្អរបស់ព្រះអម្ចាស់ក្នុងការជួយយើងឲ្យយកឈ្នះលើវា) ។
- តើអ្នកគិតថាឃ្លា « គុណរបស់យើងមានគ្រប់គ្រាន់សម្រាប់មនុស្សទាំងអស់ដែលបន្ទាបខ្លួននៅចំពោះយើង » មានន័យយ៉ាងណាដែរ ? (ដើម្បីជួយសិស្សឲ្យឆ្លើយនឹងសំណួរនេះ អ្នកអាចពន្យល់ថាគុណ គឺជា « របៀបដ៏ទេវភាពមួយនៃជំនួយ ឬកម្លាំង ដែលត្រូវបានប្រទានតាមរយៈសេចក្តីមេត្តាករុណា និងសេចក្តីស្រឡាញ់ដ៏មហិមារបស់ព្រះយេស៊ូវគ្រីស្ទ » ហើយវាធ្វើឲ្យកើតមានឡើងដោយសារតែដង្វាយធួន [Bible Dictionary, “Grace”] ។ ព្រះចេស្តាធ្វើឲ្យកើតមាននេះ ឬជំនួយនេះ នឹងមិនដែលអស់—មិនថាមានមនុស្សប៉ុន្មាននាក់ចូលមករកវានោះទេ) ។

សូមឲ្យសិស្សចែករំលែក បទពិសោធន៍ ដែលពួកគេបានមាន នៅពេលព្រះអម្ចាស់បានជួយដល់ពួកគេ (ឬដល់នរណាម្នាក់ដែលពួកគេស្គាល់) ដើម្បីឲ្យយកឈ្នះលើភាពទន់ខ្សោយ ។ (សូមរំឭកសិស្សថា ពួកគេមិនគួរមានអារម្មណ៍ថាត្រូវតែចែករំលែកអំពីបទពិសោធន៍ដែលផ្ទាល់ខ្លួន ឬឯកជនពេកនោះទេ) ។ អ្នកក៏អាចចែករំលែកពីបទពិសោធន៍ផ្ទាល់ខ្លួនដែរ ។

ដើម្បីអញ្ជើញឲ្យមានការអនុវត្តលើគោលការណ៍ដែលបានបង្រៀននៅក្នុង អេធើរ ១២:២៧ នេះ សូមសរសេរឃ្លាដូចខាងក្រោមនៅលើក្តារខៀន ៖

១. ស្គាល់ភាពទន់ខ្សោយរបស់ខ្ញុំ ២. បន្ទាបខ្លួនខ្ញុំ ៣. អនុវត្តសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ

សូមឲ្យសិស្សសរសេរឃ្លាទាំងនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ ។ នៅក្រោមឃ្លាត្រឹមត្រូវ សូមឲ្យពួកគេសរសេរ (១) ភាពទន់ខ្សោយដែលពួកគេមានអារម្មណ៍ថាពួកគេមាន (២) របៀបមួយដែលពួកគេអាចបន្ទាបខ្លួនគេបាន និង (៣) របៀបមួយដែលពួកគេអាចអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ដើម្បីឲ្យពួកគេអាចទទួលបានជំនួយរបស់ទ្រង់ ឬគុណរបស់ទ្រង់ដើម្បីយកឈ្នះលើភាពទន់ខ្សោយដែលពួកគេបានសរសេរមកនោះ ។ សូមបញ្ជាក់ដល់សិស្សថា នៅពេលពួកគេធ្វើតាមអ្វីដែលពួកគេបានសរសេរ នោះព្រះអម្ចាស់នឹង « ធ្វើឲ្យអ្វីដែលទន់ខ្សោយក្លាយទៅជាខ្លាំងពូកែចំពោះពួកគេវិញ » (អេធើរ ១២:២៧) ។

សូមឲ្យសិស្សអាន អេធើរ ១២:២៦, ២៨ ដោយស្ងាត់ស្ងៀម ដោយរកមើលរបៀបដែលព្រះអម្ចាស់ឆ្លើយតបទៅនឹងការបារម្ភរបស់លោកម៉ូរ៉ូណៃអំពីភាពទន់ខ្សោយរបស់លោកបន្តទៀត ។

សូមបង្ហាញប្រយោគ « ពួកអ្នកភ្លើទេ ដែលចំអក តែពួកគេនឹងយំសោក » (អេធើរ ១២:២៦) ។

- ដោយផ្អែកលើអ្វីដែលយើងបានសិក្សានៅថ្ងៃនេះ តើអ្នកគិតថា ហេតុអ្វីបានជាវាភ្លើទៅវិញដែលចំអកដល់ភាពទន់ខ្សោយរបស់អ្នកដទៃ ?

សូមបង្ហាញថា អេធើរ ១២:២៦ លើកឡើងពីភាពស្លូតត្រង់ ។ (អ្នកអាចពន្យល់ថា ការស្លូតត្រង់គឺជាការបន្ទាបខ្លួន និងឲ្យគេបង្រៀនបាន និងការអត់ធ្មត់នៅក្នុងពេលលំបាក) ។

- តើអ្នកគិតថា ហេតុអ្វីបានជាយើងត្រូវតែស្លូតត្រង់ដើម្បីមើលរំលងពីភាពទន់ខ្សោយរបស់អ្នកដទៃ ?

មុនពេលបន្តទៀត សូមបញ្ជាក់ថា **ប្រសិនបើយើងស្លូតត្រង់ នោះយើងអាចទទួលបានគុណរបស់ព្រះអម្ចាស់ក្នុងការជួយយើងឲ្យមើលរំលងភាពទន់ខ្សោយរបស់អ្នកដទៃបាន ។**

សូមសង្ខេប អេធើរ ១២:២៩–៣២ ដោយការពន្យល់ថា លោកម៉ូរ៉ូណៃបានបង្រៀនអំពីសារៈសំខាន់នៃការអនុវត្តសេចក្តីជំនឿ និងការមានសេចក្តីសង្ឃឹម និងសេចក្តីសប្បុរស ។ អ្នកអាចពន្យល់ថា « សេចក្តីសប្បុរសគឺជាសេចក្តីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ » (ម៉ូរ៉ូណៃ ៧:៤៧) ។

សូមឲ្យសិស្សអាន អេធើរ ១២:៣៣–៣៥ ដោយស្ងាត់ស្ងៀម ដោយរកមើលមូលហេតុដែលវាសំខាន់ដើម្បីមានសេចក្តីសប្បុរសនៅពេលជួបនឹងភាពទន់ខ្សោយរបស់អ្នកដទៃ ។

- យោងតាម អេធើរ ១២:៣៤ តើអ្វីជាលទ្ធផលដែលយើងនឹងជួប ប្រសិបើយើងមិនមានសេចក្តីសប្បុរសទេនោះ ?

ដើម្បីបញ្ចប់ សូមឲ្យសិស្សអាន អេធើរ ១២:៣៨–៤១ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់អំពីអ្វីដែលពួកគេនឹងធ្វើដើម្បីឆ្លើយតបទៅនឹងការអញ្ជើញដែលបានកត់ត្រានៅក្នុង អេធើរ ១២:៤១—« ស្វែងរកព្រះយេស៊ូវគ្រីស្ទ ដែលពួកព្យាការី និងពួកសាវកបានសរសេរមកនេះ » ។

សូមថ្លែងទីបន្ទាល់ថា នៅពេលយើងបន្ទាបខ្លួន និងអនុវត្តសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹង « ធ្វើឲ្យអ្វីដែលទន់ខ្សោយក្លាយទៅជាខ្លាំងពូកែចំពោះ [យើង] » (អេធើរ ១២:២៧) ។ សូមអញ្ជើញសិស្សឲ្យធ្វើតាមដែនការដែលពួកគេបានសរសេរ ។ អ្នកក៏អាចអញ្ជើញពួកគេឲ្យស្វែងរកជំនួយពីព្រះអម្ចាស់ក្នុងការមានសេចក្តីសប្បុរស នៅពេលពួកគេជួបនឹងភាពទន់ខ្សោយរបស់អ្នកដទៃដែរ ។

សូមអញ្ជើញសិស្សឲ្យចែករំលែកបទពិសោធន៍ខាងវិញ្ញាណ

អ្នកអាចទុកចិត្តថា សិស្សរបស់អ្នកនឹងមានបទពិសោធន៍ខាងវិញ្ញាណដើម្បីចែកចាយ ។ ប្រធាន ដេ. រ៉ូប៊ីន ភ្លាក ជុញ្ញ័រ នៃគណៈប្រធានទីមួយបានសង្កេតថា « វាកម្រនឹងមានយុវជនដែលមកដល់ទ្វារថ្នាក់សិក្ខាសាលារបស់អ្នកដែលមិនបានដឹងពីសារប្រយោជន៍នៃពរជ័យខាងវិញ្ញាណ . . . មិនបានឃើញពីប្រសិទ្ធភាពនៃការអធិស្ឋាន . . . មិនធ្លាប់ជាសាក្សីអំពីអំណាចនៃសេចក្តីជំនឿក្នុងការព្យាបាលអ្នកឈឺឬ . . . មិនដែលទទួលបាននូវការចាក់ស្រោចខាងវិញ្ញាណ ខណៈពេលដែលពិភពលោកនាពេលនេះភាគច្រើនមិនបានយកចិត្តទុកដាក់នោះទេ » (*The Charted Course of the Church in Education,* rev. ed. [ឆ្នាំ ១៩៩៤], ទំព័រ ៦; សូមមើលផងដែរ si.lds.org) ។

ចំណេះចំណានខគម្ពីរ —អេធើរ ១២:២៧

ដើម្បីជួយសិស្សឲ្យចងចាំ អេធើរ ១២:២៧ សូមសរសេរពាក្យខាងក្រោមនេះនៅលើក្តារខៀន ហើយសូមឲ្យសិស្សចម្លងវានៅលើក្រដាសមួយ ៖

ហើយបើសិនជា . . . មករក . . . បង្ហាញដល់ . . . ភាពទន់ខ្សោយ . . . ឲ្យ . . . ភាពទន់ខ្សោយ . . . បានរាបសា . . . គុណ . . . មនុស្សទាំងអស់ . . . បន្ទាបខ្លួន . . . បើសិនជា . . . បន្ទាបខ្លួន . . . សេចក្តីជំនឿ . . . អ្វីដែលទន់ខ្សោយ . . . ខ្លាំងពូកែ ។

សូមឲ្យសិស្សអាន អេធើរ ១២:២៧ ដោយស្ងាត់ៗដោយកត់ចំណាំពាក្យទាំងនេះ ។ បន្ទាប់មក សូមឲ្យពួកគេទន្ទេញខគម្ពីរនេះឲ្យចាំតាមដែលពួកគេអាចធ្វើទៅបាន ដោយមើលតែពាក្យដែលនៅលើក្រដាសតែប៉ុណ្ណោះ ។ សូមអញ្ជើញសិស្សឲ្យដាក់ក្រដាសនោះនៅមួយកន្លែង ដែលពួកគេអាចរកវាឃើញនៅថ្ងៃនេះពេលក្រោយ ឬនាថ្ងៃស្អែក (ឧទាហរណ៍ នៅក្នុងហោប៉ាវ ឬនៅក្នុងព្រះគម្ពីររបស់ពួកគេ) ។ សូមឲ្យពួកគេរំឭក អេធើរ ១២:២៧ ពេលណាដែលពួកគេឃើញក្រដាសនោះ រហូតដល់ពួកគេទន្ទេញចាំវគ្គទាំងមូល ។

វិចារណកថា និង ព័ត៌មានសាច់រឿង

អេធើរ ១២:២៧ ។ « យើងនឹងបង្ហាញដល់ពួកគេនូវភាពទន់ខ្សោយរបស់ពួកគេ »

អែលឌើរ ប្រូស សឺ ហាហ្វន នៃក្រុមចិតសិបនាក់បានបង្ហាញថា ការតស៊ូរបស់យើងដើម្បីយកឈ្នះលើភាពទន់ខ្សោយ គឺជាស្នូលនៃគោលបំណងរបស់យើងនៅលើផែនដីនេះ ៖

« ផែនការរបស់ព្រះវរបិតារបស់យើងធ្វើឲ្យយើងរងការល្បួង និងទុក្ខវេទនានៅក្នុងលោកិយដែលបានធ្លាក់មួយនេះ ។ . . .

« ដូច្នេះ ប្រសិនបើអ្នកមានបញ្ហានៅក្នុងជីវិតរបស់អ្នក សូមកុំគិតថា មានអ្វីមួយខុសនឹងអ្នកឡើយ ។ ការតស៊ូនឹងបញ្ហាទាំងនោះ គឺជាស្នូលដ៏ខ្លាំងនៃគោលបំណងក្នុងជីវិតរបស់យើង ។ នៅពេលយើងខិតទៅជិតព្រះ ទ្រង់នឹងបង្ហាញដល់យើងនូវភាពទន់ខ្សោយរបស់យើង ហើយតាមរយៈភាពទន់ខ្សោយនេះហើយដែលធ្វើឲ្យយើងរាងវិ និងរឹងមាំជាងមុន ។ ប្រសិនបើអ្នកមើលឃើញភាពទន់ខ្សោយរបស់អ្នកច្រើនជាងមុន នោះគ្រាន់តែមានន័យថាអ្នកកំពុងតែខិតកាន់តែជិតទៅរកព្រះហើយ មិនមែនឃ្លាតកាន់តែឆ្ងាយនោះទេ » (« The Atonement: All for All » *Ensign* ឬ *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០០៤, ទំព័រ ៩៧) ។

រឿងខាងក្រោមនេះគឺនិយាយអំពីយុវជនម្នាក់ដែលបានជួបនឹងការបំពេញនៃសេចក្តីសន្យារបស់ព្រះអម្ចាស់នៅក្នុង អេធើរ ១២:២៧ ៖

យុវជនទាំងឡាយនៅក្នុងសាសនាចក្រ ត្រូវបានអញ្ជើញឲ្យសម្រេចបានគោលដៅតាមរយៈកម្មវិធី កាតព្វកិច្ចចំពោះព្រះ និងនៅក្នុងផ្នែកខ្លះនៃកម្មវិធីកាយវិទ្យ ។ ឪពុកម្តាយរបស់ចូណាថាន ប៉េរេស ជាប់រវល់នឹងចិញ្ចឹមគ្រួសារដ៏ធំរបស់គាត់ ហើយមិត្តភក្តិរបស់គាត់បានសើចចំអកដល់ការខិតខំរបស់គាត់ក្នុងការសម្រេចឲ្យបាននូវឋានៈឥន្ទ្រីយ៍នៅក្នុងកម្មវិធីកាយវិទ្យ ។ ថ្វីបើមានការលំបាកទាំងនេះក្តី ចូណាថាន បានដាក់គោលដៅ ហើយបានធ្វើតាមការណ៍នោះ ។ មួយរយៈកន្លងទៅ និងដោយមានជំនួយ ហើយការគាំទ្រពីអ្នកដឹកនាំថ្នាក់យុវជនរបស់គាត់ គាត់បានសម្រេចបានគោលដៅរបស់គាត់ ។ គាត់បានសរសេរថា « បទពិសោធន៍នេះបានបង្រៀនខ្ញុំថា មិនថាមាន ឧបសគ្គ ឬការប្រជែងអ្វីដែលមកពារាំងផ្លូវរបស់ខ្ញុំនោះទេ ព្រះអម្ចាស់នឹងជួយខ្ញុំឲ្យយកឈ្នះលើការល្បួង និងភាពទន់ខ្សោយរបស់ខ្ញុំ (អេធើរ ១២:២៧) ។ វាមិនមានបញ្ហាចំពោះសាវតាមួយណាដែលយើងមកពី ឬមិនថាយើងមាន ឬក្រនោះទេ ។ យើងអាចសម្រេចបានគោលដៅរបស់យើង ដោយសារយើងមានព្រះអម្ចាស់នៅក្បែរខ្លួនយើង » (“Jonathan Perez, “An Honor Earned,” *New Era,* ខែ វិច្ឆិកា ឆ្នាំ ២០០៧, ទំព័រ ៤៥) ។

គំនិតបន្ថែមទាំងឡាយសម្រាប់ការបង្រៀន

អេធើរ ១២:២៦ ។ ការមើលរំលងលើភាពទន់ខ្សោយរបស់អ្នកដទៃ

សូមបង្ហាញថា ភាពទន់ខ្សោយមួយដែលមនុស្សជាច្រើនខិតខំតស៊ូប្រឆាំងនោះគឺជាអសមត្ថភាពមួយក្នុងការបន្ទាបខ្លួន និងអនុវត្តសេចក្តីជំនឿនៅពេលពួកគេជួបនឹងភាពទន់ខ្សោយរបស់អ្នកដទៃ ។ សូមអានឮៗនូវស្ថានភាពពីរ ឬបីខាងក្រោមនេះ ។ សូមឈប់នៅចន្លោះស្ថានភាពនីមួយៗ ហើយសូមឲ្យសិស្សពន្យល់ពីរបៀបដែលការមានសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ ការមានសេចក្តីសង្ឃឹមលើការទទួលបានពរជ័យអស់កល្បជានិច្ច ឬការធ្វើសកម្មភាពដោយសប្បុរសអាចជួយដល់នរណាម្នាក់ឲ្យធ្វើសកម្មភាពដោយសមរម្យនៅក្នុងស្ថានភាពដែលដាក់មកខាងក្រោមនេះ ។

១. អ្នកស្គាល់គ្នា ឬមិត្តម្នាក់អាកប្បកិរិយា ដែលអ្នកធុញទ្រាន់ ។

២. សមាជិកវួដរបស់អ្នកថ្លែងទីបន្ទាល់ ឬបង្រៀនអ្វី ដែលធ្វើឲ្យអ្នកមានអារម្មណ៍ធុញទ្រាន់ ។

៣. នរណាម្នាក់និយាយរិះគន់អ្នក ។

៤. សមាជិកគ្រួសារម្នាក់បានធ្វើខុស រហូតដល់ពេលខ្លះធ្វើឲ្យជីវិតមានឧបសគ្គដល់អ្នក ។

មេរៀនសិក្សានៅផ្ទះ

អេធើរ ៤–១២ (មេរៀនទី ៣០)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀន ដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេសិក្សា អេធើរ ៤–១២ (មេរៀនទី ៣០) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (អេធើរ ៤–៥)

លោកម៉ូណៃបានបិទត្រាការសរសេររបស់បងប្រុសរបស់យ៉ារេឌ និងបានបង្រៀនអំពីលក្ខខណ្ឌដែលយើងត្រូវតែបំពេញ មុនពេលយើងនឹងទទួលបានកំណត់ត្រានោះ ។ ចេញពីការបង្រៀនទាំងនេះ សិស្សបានរៀនថា នៅពេលយើងអនុវត្តសេចក្តីជំនឿដ៏អស្ចារ្យនៅក្នុងព្រះបន្ទូលព្រះអម្ចាស់ នោះទ្រង់នឹងប្រទានពរដល់យើងឲ្យទទួលបានវិវរណៈបន្ថែមទៀត ។

ថ្ងៃទី ២ (អេធើរ ៦)

ចេញពីគំរូរបស់ពួកសាសន៍យ៉ារេឌក្នុងការអនុវត្តសេចក្តីជំនឿនៅលើព្រះអម្ចាស់ ខណៈពេលដែលឆ្លងកាត់ « ទឹកដ៏ធំ » (អេធើរ ៦:៣) នៅក្នុងភេត្រារបស់ពួកគេនោះ សិស្សបានរៀនថា នៅពេយើងទុកចិត្តលើព្រះអម្ចាស់ ហើយធ្វើតាមព្រះឆន្ទៈរបស់ទ្រង់ នោះទ្រង់នឹងដឹកនាំខ្សែជីវិតរបស់យើង ។ ខ្យល់បានបក់បោកភេត្រាទាំងឡាយទៅកាន់ដែនដីសន្សា ហើយសិស្សបានរៀនថា ប្រសិនបើយើងទុកចិត្តទៅលើព្រះអម្ចាស់ នោះ ឧបសគ្គ និងការលំបាកអាចជួយយើងឲ្យរីកចម្រើនឡើង និងទទួលបានពរជ័យដែលសន្សារួច ។

ថ្ងៃទី ៣ (អេធើរ ៧–១១)

នៅពេលពួកសាសន៍យ៉ារេឌមិនបានស្តាប់តាមការព្រមានរបស់បងប្រុសយ៉ារេឌ ហើយបានជ្រើសរើសដើម្បីមានស្តេចមួយអង្គ នោះសិស្សបានរកឃើញថា ការបដិសេធពាក្យសម្តីរបស់ព្យាការីនឹងនាំទៅរកការជាប់ឃុំឃាំង ។ ស៊ូលគឺជាស្តេចមួយអង្គ ដែលបានគ្រប់គ្រងដោយសេចក្តីសុចរិត ។ នៅពេលប្រជាជនរបស់ទ្រង់បានចាប់ផ្តើមប្រែចិត្ត ហើយស្តាប់តាមព្យាការី ពួកគេបានចាប់ផ្តើមរីកចម្រើនឡើង ។ សិស្សបានរៀនថា នៅពេលយើងប្រែចិត្តចេញពីអំពើទុច្ចរិតរបស់យើង នោះយើងនឹងរីកចម្រើនឡើង ។ ទីបំផុត ពួកសាសន៍យ៉ារេឌបានធ្លាក់ទៅក្នុងអំពើទុច្ចរិត ហើយបានបង្ហាញសេចក្តីពិតថា ការគាំទ្រដល់បក្សព័ន្ធសម្ងាត់ដែលនាំទៅរកសេចក្តីបំផ្លិចបំផ្លាញដល់សង្គម ។

ថ្ងៃទី ៤ (អេធើរ ១២)

តាមរយៈព្យាការីអេធើរ សិស្សបានរៀនថា នៅពេលយើងមានសេចក្តីសង្ឃឹម និងសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ យើងនឹងទទួលបានកម្លាំងដើម្បីនៅខ្ជាប់ខ្ជួន និងចងភ្ជាប់នៅក្នុងកិច្ចការល្អ ។ លោកម៉ូណៃបានសរសេរថា ប្រសិនបើយើងចង់បានសាក្សីមួយ នោះយើងត្រូវតែអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទជាដំបូងសិន ។ ចេញពីចម្លើយរបស់ព្រះអម្ចាស់ចំពោះការបារម្ភរបស់លោកម៉ូណៃអំពីភាពទន់ខ្សោយក្នុងការសរសេររបស់លោក និងអ្នកសរសេរផ្សេងទៀតក្នុងព្រះគម្ពីរមរមនោះ សិស្សបានដឹងថា ប្រសិនបើយើងបន្ទាបខ្លួន និងអនុវត្តសេចក្តីជំនឿនៅក្នុងព្រះអម្ចាស់ នោះទ្រង់នឹងធ្វើឲ្យអ្វីដែលទន់ខ្សោយក្លាយទៅជាខ្លាំងពូកែ ។

សេចក្តីផ្តើម

មេរៀននេះផ្តោតទៅលើ អេធើរ ១២:២៣–៤១ ។ លោកម៉ូណៃបានបង្រៀនពីមូលហេតុដែលប្រជាជនមានភាពទន់ខ្សោយ និងអ្វីដែលពួកគេត្រូវធ្វើដើម្បីយកឈ្នះលើភាពទន់ខ្សោយទាំងនោះ ។

យោបល់សម្រាប់ការបង្រៀន

អេធើរ ៤–១១; ១២:៦

ពួកសាសន៍យ៉ារេឌរីកចម្រើនឡើង ហើយត្រូវបានប្រទានពរ នៅពេលពួកគេសុចរិត

សូមឲ្យសិស្សបីនាក់រំឲ្យក និងសង្ខេបពីជំពូកខាងក្រោមនេះ ដោយប្រើការសង្ខេបជំពូក ៖ អេធើរ ៤–៥; អេធើរ ៦; និង អេធើរ៧–១១ ។ សូមឲ្យសិស្សម្នាក់ទៀតរំឲ្យក អេធើរ ១២:៦ ។ សូមឲ្យពួកគេចែកចាយដល់សិស្សនូវគោលការណ៍មួយ ឬពីរដែលពួកគេបានរៀន ។

អេធើរ ១២:២៣–៤១

លោកម៉ូណៃបង្ហាញពីការបារម្ភអំពីរបៀបដែលពួកសាសន៍ដទៃនឹងឆ្លើយតបចំពោះព្រះគម្ពីរមរមន

សូមសរសេរពាក្យ *រឹងមាំ* នៅលើក្តារខៀនម្ខាងហើយពាក្យ *ទន់ខ្សោយ* នៅលើក្តារខៀនម្ខាងទៀត ។ សូមឲ្យសិស្សមានពេលសញ្ជឹងគិតពីអ្វីដែលពួកគេមានអារម្មណ៍ថាជាភាពរឹងមាំរបស់គេ និងអ្វីជាភាពទន់ខ្សោយ ឬភាពមិនគ្រប់គ្រាន់របស់គេពីរបី ។ សូមពន្យល់ថានៅក្នុង អេធើរ ១២ លោកម៉ូណៃបានបង្រៀនពីរបៀបដែលភាពទន់ខ្សោយរបស់យើងក្លាយទៅជាភាពខ្លាំងពូកែ ។

សូមឲ្យសិស្សម្នាក់អាន អេធើរ ១២:២៣–២៥ ឬៗ ហើយសូមឲ្យសិស្សរកមើលភាពទន់ខ្សោយដែលលោកម៉ូណៃបានមានអារម្មណ៍ថា លោក និងអ្នកសរសេរព្រះគម្ពីរមរមនផ្សេងទៀតបានមាន ។ បន្ទាប់មក សូមសួរសំណួរទាំងឡាយខាងក្រោមនេះ ៖

- តើអ្វីជាភាពទន់ខ្សោយដែលលោកម៉ូណៃបានលើកឡើងនៅក្នុងខគម្ពីរទាំងនេះ ?
- តើលោកម៉ូណៃបានព្រួយបារម្ភថានឹងមានអ្វីកើតឡើង ដោយសារតែភាពទន់ខ្សោយនៃអស់អ្នកដែលបានសរសេរព្រះគម្ពីរមរមន ?

ក្រោយពីសិស្សឆ្លើយហើយ សូមឲ្យពួកគេអាននូវចម្លើយរបស់ព្រះអម្ចាស់ចំពោះការបារម្ភរបស់លោកម៉ូណៃនៅក្នុង អេធើរ ១២:២៦–២៧ ដោយស្ងាត់ស្ងៀម ហើយរកមើលមូលហេតុដែលព្រះបានប្រទានដល់យើងនូវភាពទន់ខ្សោយ ។ ក្រោយពីសិស្សបានមានពេលអានខគម្ពីរហើយ សូមរំឲ្យកពួកគេថា អេធើរ ១២:២៧ គឺជាវគ្គចំណេះចំណានខគម្ពីរ ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ពីពាក្យ *ភាពទន់ខ្សោយ* នៅក្នុងខគម្ពីរទាំងនេះ សូមឲ្យសិស្សម្នាក់អាននូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ នែល អេ ម៉ាក់ស្វែល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ។

« នៅពេលយើងអាននៅក្នុងព្រះគម្ពីរអំពី ‹ ភាពទន់ខ្សោយ › របស់មនុស្ស ពាក្យនេះរួមមានភាពទន់ខ្សោយដែលទូលំទូលាយ ប៉ុន្តែចាំបាច់មាននៅក្នុងលក្ខខណ្ឌជាមនុស្សទូទៅ ដែលក្នុងភាពជាសាច់ និងឈាមវាមានឥទ្ធិពលដ៏ឥតឈប់ឈរ [ឬ ឥតដាច់] បែបនេះមកលើភាពជាវិញ្ញាណ ។ . . . ប៉ុន្តែ ដូចគ្នានឹងភាពទន់ខ្សោយនេះដែរ វារួមមានភាពទន់ខ្សោយជាពិសេស និងជាបុគ្គលរបស់យើង ដែលយើងត្រូវតែយកឈ្នះលើវា » (*Lord, Increase Our Faith* [ឆ្នាំ ១៩៩៤], ទំព័រ ៨៤)

អ្នកអាចត្រូវពន្យល់ថា លក្ខខណ្ឌជាមនុស្សទូទៅ ដែលអែលឌើរ ម៉ាក់ស្វែល បានមានប្រសាសន៍អំពីនោះ សំដៅទៅលើភាពទន់ខ្សោយដែលមកកាន់មនុស្សប្រុសស្រីទាំងឡាយតាមរយៈការធ្លាក់នៃលោកអ័ដាម ។ ដោយសារតែការធ្លាក់ យើងទាំងអស់គ្នាត្រូវរងនឹងការល្បួង ហើយភាពមិនឥតខ្ចោះរបស់មនុស្សត្រូវមកបន្ថែមលើការល្បួងរៀងៗខ្លួនយើងផ្ទាល់ ។

សូមឲ្យសិស្សរកមើលគោលការណ៍មួយដែលបានបង្រៀននៅក្នុង អេធើរ ១២:២៧ ។ **បើសិនជាយើងបន្ទាបខ្លួនយើង ហើយអនុវត្តសេចក្តីជំនឿជឿលើព្រះអម្ចាស់ នោះទ្រង់នឹងធ្វើឲ្យអ្វីដែលទន់ខ្សោយក្លាយទៅជាខ្លាំងពូកែចំពោះយើងវិញ ។**

ដើម្បីលើកទឹកចិត្តឲ្យមានការអនុវត្តលើគោលការណ៍ដែលបានបង្រៀននៅក្នុង អេធើរ ១២:២៧ នេះ សូមសរសេរឃ្លាដូចខាងក្រោមនៅលើក្តារខៀន ៖

១. ទទួលស្គាល់ភាពទន់ខ្សោយរបស់ខ្ញុំ ២. បន្ទាបខ្លួនខ្ញុំ ៣. អនុវត្តសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ

សូមឲ្យសិស្សសរសេរឃ្លាទាំងនេះនៅផ្នែកខាងលើនៃក្រដាសមួយ ។ នៅក្រោមចំណងជើង សូមឲ្យសិស្សសញ្ជឹងគិត និងសរសេរនាពេលឥឡូវនេះ ឬក៏ពេលក្រោយ (១) ភាពទន់ខ្សោយមួយដែលពួកគេមានអារម្មណ៍ថា ពួកគេមាន, (២) របៀបដែលពួកគេអាចបន្ទាបខ្លួនពាក់ព័ន្ធទៅនឹងភាពទន់ខ្សោយ និង (៣) របៀបដែលពួកគេអាចអនុវត្តសេចក្តីជំនឿទៅលើព្រះគ្រីស្ទ ដើម្បីឲ្យពួកគេអាចទទួលបានជំនួយពីទ្រង់ ឬក៏ព្រះគុណ ដើម្បីយកឈ្នះលើភាពទន់ខ្សោយដែលពួកគេបានសរសេរនោះ ។

នៅពេលពួកគេបានបញ្ចប់ហើយ សូមលើកទឹកចិត្តសិស្សឲ្យដាក់ក្រដាសនោះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាផ្ទាល់ខ្លួនរបស់គេ ឬនៅកន្លែងផ្សេងទៀតដែលពួកគេនឹងមើលឃើញវាញឹកញាប់ និងត្រូវបានរំឭកឲ្យចាំពីការខិតខំដែលពួកគេចង់ធ្វើ ។ សូមថ្លែងទីបន្ទាល់ដល់សិស្សថា នៅពេលពួកគេខិតខំដោយរាបសាដើម្បីយកឈ្នះលើភាពទន់ខ្សោយរបស់ពួកគេ នោះព្រះអម្ចាស់នឹងជួយ « ធ្វើឲ្យអ្វីដែលទន់ខ្សោយក្លាយទៅជាខ្លាំងពូកែចំពោះពួកគេវិញ » (អេធើរ ១២:២៧) ។

សូមឲ្យសិស្សអាន អេធើរ ១២:២៦, ២៨ ដោយស្ងាត់ស្ងៀមដោយរកមើលរបៀបដែលព្រះអម្ចាស់ឆ្លើយតបទៅនឹងការបារម្ភរបស់លោកម៉ូរ៉ូណៃអំពីភាពទន់ខ្សោយរបស់លោកបន្តទៀត ។ អ្នកអាចសួរសំណួរខាងក្រោមនេះ ៖

- នៅក្នុង អេធើរ ១២:២៦ លោកម៉ូរ៉ូណៃបានលើកឡើងអំពីភាពស្លុតត្រង់ ដែលជាភាពរាបសាបន្ទាបខ្លួន និងមិនរឹងរូសផ្ទុយទៅនឹងព្រះឆន្ទៈព្រះ ។ តើអ្នកគិតថា ហេតុអ្វីបានជាវាតម្រូវឲ្យមានភាពស្លុតត្រង់ដើម្បីមើលរំលងភាពទន់ខ្សោយរបស់អ្នកដទៃ ?
- តើព្រះគុណរបស់ព្រះអម្ចាស់ (ជំនួយ ឬអំណាចដែលអាចធ្វើអ្វីៗជាងទេវភាពរបស់ទ្រង់) អាចជួយយើងកុំឲ្យកេងប្រវ័ញ្ចប្រយោជន៍លើភាពទន់ខ្សោយរបស់អ្នកដទៃដោយរបៀបណា ?

សូមបញ្ជាក់ថា **នៅពេលយើងអភិវឌ្ឍសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស នោះព្រះគុណរបស់ព្រះអម្ចាស់នឹងជួយយើង នៅពេលយើងប្រឈមមុខនឹងភាពទន់ខ្សោយរបស់អ្នកដទៃ ។** សូមសង្ខេប អេធើរ ១២:២៩–៣២ ដោយការពន្យល់ថា លោកម៉ូរ៉ូណៃបានរំឭកពីសារៈសំខាន់នៃការអនុវត្តសេចក្តីជំនឿ ព្រមទាំងសាក្សី និងអត្ថហេតុនានាដែលបានមកតាមរយៈការអនុវត្តសេចក្តីជំនឿ ។ សូមឲ្យសិស្សអាន អេធើរ ១២:៣៣–៣៥ ហើយរកមើលអ្វីដែលលោកម៉ូរ៉ូណៃបានសរសេរអំពីសារៈសំខាន់នៃការមានសេចក្តីសប្បុរស ។

សូមសួរ ៖ តើហេតុអ្វីបានជាវាសំខាន់ដើម្បីមានសេចក្តីសប្បុរស នៅពេលយើងប្រឈមមុខនឹងភាពទន់ខ្សោយរបស់អ្នកដទៃ ?

សូមឲ្យសិស្សចែករំលែកដល់មិត្តរបស់គេអំពីអ្វី ដែលពួកគេកំពុងធ្វើដើម្បីទទួលបានព្រះគុណរបស់ព្រះយេស៊ូវគ្រីស្ទកាន់តែពេញលេញខ្លាំងឡើងនៅក្នុងជីវិតរបស់គេ ។ បើសិនជាមានពេល អ្នកអាចសុំឲ្យសិស្សពីរបីនាក់ចែកចាយក្នុងថ្នាក់ពីរបៀបដែលការខិតខំទៅកាន់ព្រះយេស៊ូវគ្រីស្ទកាន់តែជិតបានជះឥទ្ធិពលដល់ជីវិតរបស់ពួកគេ ។

មេរៀនបន្ទាប់ (អេធើរ ១៣–ម៉ូរ៉ូណៃ ៧)

នៅពេលសិស្សរៀបចំសិក្សាមេរៀនបន្ទាប់ទៀត សូមអញ្ជើញពួកគេឲ្យពិចារណាពីអ្វីដូចខាងក្រោមនេះ ៖ តើនឹងមានអ្វីកើតឡើង ប្រសិនបើមិត្តភក្តិរបស់អ្នក និងគ្រួសាររបស់អ្នកទាំងអស់ត្រូវបានសង្គ្រាប់ ហើយអ្នកគឺជាមនុស្សតែម្នាក់គត់ ដែលនៅរស់ដែលស្មោះត្រង់ចំពោះដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនោះ ? ទាំងលោកអេធើរ និងលោកម៉ូរ៉ូណៃបានជួបនឹងភាពឯកោប្រភេទនេះ ។ តើអ្នកអាចតស៊ូនឹងឧបសគ្គនានា ហើយទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចដោយរបៀបណា ? ម៉ូរ៉ូណៃ ៧ ពន្យល់ពីរបៀបដែលសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរសមានភាពចាំបាច់ក្នុងការទទួលបានអំណោយទានទាំងនេះ ។

អេធើរ ១៣–១៥

សេចក្តីផ្តើម

កំណត់ត្រារបស់ព្យាការីអេធើរអំពីអរិយធម៌របស់ពួកសាសន៍យ៉ារេឌធ្វើជាសាក្សីមួយថា អស់អ្នកទាំងឡាយណាដែលបដិសេធព្រះអម្ចាស់ និងប្រានចោលព្យាការីរបស់ទ្រង់នឹងមិនរីកចម្រើននោះទេ ។ អេធើរបានព្រមានដល់កូរីអានទុម ជាស្តេចនៃសាសន៍យ៉ារេឌមួយអង្គ ថាប្រជាជនរបស់ទ្រង់នឹងត្រូវបានបំផ្លាញបង់ ប្រសិនបើទ្រង់ និងរាស្ត្រទាំងឡាយមិនប្រែចិត្ត នោះទេ ។ នៅពេលកូរីអានទុម និងប្រជាជនរបស់ទ្រង់បានបដិសេធមិនព្រមប្រែចិត្ត នោះ មានសង្គ្រាម និងអំពើទុច្ចរិតបានកើតឡើងជាច្រើនឆ្នាំ រហូតដល់ជាតិសាសន៍យ៉ារេឌមួយទាំងមូលត្រូវបានបំផ្លាញ ។ មានតែអេធើរ និងកូរីអានទុមប៉ុណ្ណោះ ដែលបាននៅរស់ដើម្បីធ្វើជាសាក្សីអំពីការបំពេញនៃការព្យាករណ៍របស់ព្យាការីអេធើរ ។ ជំពូកទាំងនេះក៏ជាការបំពេញតាមក្រិត្យវិន័យរបស់ព្រះមួយថា « ជាតិសាសន៍ណាក៏ដោយដែលយកបាន [ដែនដីសន្យា] ត្រូវបម្រើដល់ព្រះ ឬពួកគេនឹងត្រូវកម្ទាត់ចេញ » (អេធើរ ២:៩) ។

យោបល់សម្រាប់ការបង្រៀន

បង្កើតបរិយាកាសនៃសេចក្តីស្រឡាញ់ និង ការគោរព

សិស្សដែលមានអារម្មណ៍ថាត្រូវបានគេស្រឡាញ់ និងត្រូវបានផ្តល់តម្លៃដោយអ្នក និងពីសិស្សដទៃទៀត នឹងចង់មកកាន់ថ្នាក់រៀន ។ ពួកគេនឹងបើកចំហរកាន់តែខ្លាំងដើម្បីទទួលឥទ្ធិពលពីព្រះវិញ្ញាណបរិសុទ្ធ ហើយនឹងមានបំណងដ៏ខ្លាំងក្លាមួយដើម្បីចូលរួមក្នុងថ្នាក់ ។

អេធើរ ១៣:១–១២

លោកម៉រ៉ូណៃកត់ត្រាពីការព្យាករណ៍របស់អេធើរអំពីទីក្រុងយេរូសាឡិមថ្មី និងទីក្រុងយេរូសាឡិមចាស់

សូមពន្យល់ថា ទីក្រុងខ្លះត្រូវបានគេស្គាល់ដោយឈ្មោះដែលរៀបរាប់ពីលក្ខណៈសំខាន់របស់វា ។ សូមអានឈ្មោះដែលរៀបរាប់ពីទីក្រុងដូចខាងក្រោម ហើយសូមឲ្យសិស្សទស្សន៍ទាយថាទីក្រុងណាមួយត្រូវនឹងឈ្មោះរបស់វា ៖ ទីក្រុងនៃភ្លើង (ទីក្រុងប៉ារីស ប្រទេសបារាំង) ទីក្រុងអមតៈ (ទីក្រុងរ៉ូម ប្រទេសអ៊ីតាលី) ទីក្រុងខ្យល់ (ទីក្រុងឈីកាហ្គោ រដ្ឋអ៊ិលលីណយ សហរដ្ឋអាមេរិច) គុជនៃទិសបូព៌ា (ទីក្រុងម៉ានីល ប្រទេសភីលីពីន) និងទីក្រុងនៃព្រះរាជវាំង (ទីក្រុងម៉ិកស៊ីកូ ប្រទេសម៉ិកស៊ីកូ) ។ សូមឲ្យសិស្សផ្តល់យោបល់ថាតើឈ្មោះដែលបានរៀបរាប់ទាំងនេះអាចប្រាប់អ្វីខ្លះអំពីទីក្រុងទាំងនោះ ។

សូមបង្ហាញថា លោកម៉រ៉ូណៃបានកត់ត្រាការព្យាករណ៍របស់អេធើរអំពីទីក្រុងបី ៖ ទីក្រុងយេរូសាឡិមថ្មី (សូមមើល អេធើរ ១៣:៦–៨, ១០) ; ទីក្រុងរបស់អេណុក ដែលបាន « ចុះមកពីស្ថានសួគ៌ » (អេធើរ ១៣:៣; សូមមើលផងដែរ ម៉ូសេ ៧:៦២–៦៤) ; និងទីក្រុងយេរូសាឡិមនៅក្នុងដែនដីដ៏បរិសុទ្ធ (សូមមើល អេធើរ ១៣:១១) ។ សូមប្រាប់សិស្សថា អេធើរបង្រៀនដល់ពួកសាសន៍យ៉ារេឌថា ដែនដីដែលពួកគេបានរស់នៅគឺជាកន្លែងមួយនៃទីក្រុងអនាគតដ៏មានសារៈសំខាន់ខ្លាំងបំផុត (សូមមើល អេធើរ ១៣:២–៣) ។ សូមឲ្យសិស្សអាន អេធើរ ១៣:៤–៨ ដោយស្ងាត់ស្ងៀម ដោយរកមើលឈ្មោះរបស់ទីក្រុងដែលបានលើកឡើងនៅក្នុងខគម្ពីរទាំងនេះ ។

- តើទីក្រុងទាំងនេះមានឈ្មោះអ្វីខ្លះ ? (ទីក្រុងយេរូសាឡិម និងទីក្រុងយេរូសាឡិមថ្មី) ។ តើឈ្មោះដែលរៀបរាប់មួយណាដែលអេធើរបានប្រើសម្រាប់ទីក្រុងយេរូសាឡិម នៅក្នុងដែនដីដ៏បរិសុទ្ធ និងជាទីក្រុងយេរូសាឡិមថ្មី ដែលនឹងត្រូវកសាងនៅលើទ្វីបអាមេរិកនៅថ្ងៃណាមួយ ? (« ទីក្រុងដ៏បរិសុទ្ធ ») ។
- តើអ្នកគិតថា វានឹងដូចជាអ្វីទៅដែលបានរស់នៅក្នុងទីក្រុងមួយដែលហៅថា « ទីក្រុងដ៏បរិសុទ្ធ » ?

សូមឲ្យសិស្សអាន អេធើរ ១៣:១០–១១ ដោយស្ងាត់ស្ងៀមដោយរកមើលរបៀបដែលប្រជាជននឹងសត្តិសមក្នុងការរស់នៅក្នុងទីក្រុងដ៏បរិសុទ្ធទាំងនេះ ។

- តើប្រជាជននឹងសត្តិសមដើម្បីរស់នៅក្នុងទីក្រុងទាំងនេះដោយរបៀបណា ? (ដោយមានសំលៀកបំពាក់របស់ពួកគេធ្វើឲ្យ « សតាមរយៈឈាមនៃកូនចៀម ») ។
- តើវាមានន័យយ៉ាងណា សម្រាប់មនុស្សដែលមានសំលៀកបំពាក់របស់គេធ្វើឲ្យ « សតាមរយៈឈាមនៃកូនចៀម » ? (វាមានន័យថា មនុស្សដែលក្លាយជាស្អាតស្អំ និងធ្វើឲ្យបរិសុទ្ធចេញពីអំពើបាបតាមរយៈដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ជាកូនចៀមរបស់ព្រះ សូមមើល នីហ្វៃទី ១ ១២:១១; អាលម៉ា ៥:២១) ។

សូមពន្យល់ថា ឈ្មោះមួយទៀតសម្រាប់ទីក្រុងយេរូសាឡិមថ្មីនោះគឺ *ស៊ីយ៉ូន* (សូមមើល ម៉ូសេ ៧:៦២; មាត្រានៃសេចក្តីជំនឿ ១:១០) ។ ខណៈពេលដែលទីក្រុងយេរូសាឡិមថ្មី និងទីក្រុងនៃយេរូសាឡិមនឹងត្រូវបានស្ថាបនាឡើងនៅពេលអនាគតក្តី សមាជិកទាំងអស់នៃសាសនាចក្ររកអាចស្វែងរកឃើញនាពេលនេះដើម្បីស្ថាបនាទីក្រុងស៊ីយ៉ូន នៅកន្លែងដែលពួកគេរស់នៅ (សូមមើល គ. និង ស. ៦:៦; ១៨:៦) ។ នៅក្នុងអត្ថន័យដ៏សាមញ្ញចាំបាច់បំផុតមួយ ទីក្រុងស៊ីយ៉ូនគឺជា « ទីក្រុងដែលមានចិត្តល្អសុទ្ធសាធ » (គ. និង ស. ៩៧:២១) ។ សូមចែករំលែកនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ទីក្រុងស៊ីយ៉ូន គឺជាស៊ីយ៉ូនដោយសារតែអាកប្បកិរិយា ឥរិយាបថ និងភាពស្មោះត្រង់នៃពលរដ្ឋរបស់ខ្លួន [សូមមើល ម៉ូសេ ៧:១៨] ។ សូមចាំថា ‹ ព្រះអម្ចាស់ទ្រង់បានហៅរាស្ត្រទ្រង់ថាស៊ីយ៉ូន ពីព្រោះពួកគេមានចិត្តតែមួយ និងគំនិតតែមួយ ហើយបានរស់នៅក្នុងសេចក្តីសុចរិត ហើយគ្មានមនុស្សក្រីក្រនៅក្នុងចំណោមពួកគេឡើយ › (ម៉ូសេ ៧:១៨) ។ ប្រសិនបើយើងបានស្ថាបនាទីក្រុងស៊ីយ៉ូននៅក្នុងផ្ទះ វួដ សាខា និងស្តេករបស់យើង ហើយ យើងត្រូវតែក្រោកឡើងធ្វើតាមបទដ្ឋាននេះ ។ វាជាការចាំបាច់ (១) ដើម្បីមានសាមគ្គីភាពនៅក្នុងចិត្តតែមួយ និងគំនិតតែមួយ (២) ដើម្បីក្លាយជាខ្លួនទីពឹងខ្លួន និងជាសម្ងាហភាព ជាប្រជាជនដ៏បរិសុទ្ធ និង

(៣) ដើម្បីយកចិត្តទុកដាក់ដល់អ្នកក្រីក្រ និងអ្នកដែលត្រូវការ » (« Come to Zion » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០០៨, ទំព័រ ៣៨) ។

សូមឲ្យសិស្សមានពេលមួយសន្ទុះដើម្បីសញ្ជឹងគិតពីអ្វីដែលពួកគេអាចធ្វើដើម្បីជួយស្ថាបនាបទដ្ឋានដ៏ខ្ពស់ជាងមួយនៅក្នុងផ្ទះរបស់គេ និងនៅក្នុងសាខា ឬវួដរបស់ពួកគេ ។ អ្នកអាចឲ្យពួកគេមានពេលដើម្បីសរសេរអំពីគំនិតរបស់គេនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ ។

អេធើរ ១៣:១៣–១៥:៣៤

ពួកសាសន៍យ៉ារេឌបដិសេធការព្យាករណ៍ព្រមានរបស់អេធើរ ហើយរឹងរូសនៅក្នុងអំពើទុច្ចរិត និងសង្គ្រាមរហូតដល់ពួកគេត្រូវបានបំផ្លាញបង់

សូមសង្ខេប អេធើរ ១៣:១៣–១៤ ដោយការពន្យល់ថា ពួកសាសន៍យ៉ារេឌបានបដិសេធអេធើរ ហើយបានបណ្តេញលោកចេញពីក្នុងចំណោមពួកគេ ។ អំឡុងពេលថ្ងៃ លោកអេធើរបានលាក់ខ្លួនលោកនៅក្នុង « ក្រហែងថ្ម » ជាកន្លែងដែលលោកបានបញ្ចប់កំណត់ត្រារបស់លោកអំពីពួកសាសន៍យ៉ារេឌ ។ នៅពេលយប់ លោកបានចេញមកមើលការណ៍ទាំងឡាយ ដែលនឹងកើតឡើងដល់ប្រជាជន ជាពួកសាសន៍យ៉ារេឌ ។ លោកបានសរសេរអំពីរឿងជាច្រើនដែលលោកបានឃើញ ។

សូមឲ្យសិស្សអាន អេធើរ ១៣:១៥–១៩ ដោយស្ងាត់ស្ងៀមដោយរកមើលការពិពណ៌នាអំពីសង្គមនៃពួកសាសន៍យ៉ារេឌ ។ ក្រោយពីពួកគេមានអានហើយ សូមឲ្យពួកគេរៀបរាប់ពីសង្គមរបស់ពួកសាសន៍យ៉ារេឌជាសម្តីខ្លួនឯង ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់អាន អេធើរ ១៣:២០–២២ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលសារលិខិតដែលព្រះអម្ចាស់បានបញ្ជាដល់លោកអេធើរឲ្យប្រគល់ដល់ក្ងារអានទុមើរ ។

- តើសារលិខិតរបស់អេធើរទៅដល់ក្ងារអានទុមើរមានអ្វីខ្លះ ? (ប្រសិនបើក្ងារអានទុមើរ និងពួកបរិវាររបស់ទ្រង់បានប្រែចិត្តនោះ ព្រះអម្ចាស់នឹងទុកជីវិតឲ្យដល់ប្រជាជនទាំងឡាយ និងអនុញ្ញាតដល់ស្តេចក្ងារអានទុមឲ្យសោយរាជ្យលើនគររបស់ទ្រង់ ។ ប្រសិនបើពួកគេមិនប្រែចិត្តនោះទេ នោះគ្រប់គ្នានៅក្នុងនគរ លើកលែងតែក្ងារអានទុមើរនឹងត្រូវបំផ្លាញ) ។
- តើក្ងារអានទុម និងរាស្ត្ររបស់ទ្រង់បានឆ្លើយតបយ៉ាងណាដែរ ?

សូមសង្ខេប អេធើរ ១៣:២៣–១៤:២០ ដោយការពន្យល់ថា សង្គ្រាមបានបន្តនៅពេញដែនដី ។ បុរសបីរូបត្រូវបន្តរាជ្យ —សារេឌ កាឡាត និងលិប— បានព្យាយាមដណ្តើមនគរពីក្ងារអានទុមើរ ។ នៅទីបញ្ចប់ បក្សព័ន្ធសម្ងាត់បានទទួលអំណាចដ៏ខ្លាំង ហើយជាតិសាសន៍ទាំងមូលត្រូវបានហ៊ឹព័ទ្ធទៅដោយសង្គ្រាម ។ « ប្រជាជនទាំងអស់នៅលើផ្ទៃដែនដី កំពុងតែកម្ចាយឈាមគ្នា ហើយគ្មានអ្នកណាម្នាក់ឃាត់ពួកគេបានឡើយ » (អេធើរ ១៣:៣១) ។ សត្រូវចុងក្រោយរបស់ស្តេចក្ងារអានទុមើរគឺជាបុរសម្នាក់ឈ្មោះ: សិស ។

សូមឲ្យសិស្សអាន អេធើរ ១៤:២១–២៥, ៣០–៣១ និង ១៥:១–២ ដោយស្ងាត់ស្ងៀមដោយរកមើលកម្រិតនៃសេចក្តីបំផ្លិចបំផ្លាញដែលបានបណ្តាលមកពីសង្គ្រាមទាំងនេះ ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់អាន អេធើរ ១៥:៣–៥ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលក្ងារអានទុមើរចង់ធ្វើដើម្បីសង្គ្រោះជីវិតមនុស្សដែលនៅសល់ពីសេចក្តីបំផ្លិចបំផ្លាញ ។

- តើក្ងារអានទុមើរបានធ្វើអ្វីខ្លះ ? (ទ្រង់បានចុះចាញ់លះបង់នគររបស់ទ្រង់ទៅឲ្យសិស) ។
- តើសិស បានឆ្លើយតបយ៉ាងណាទៅនឹងសំណើររបស់ក្ងារអានទុមើរ ? (គាត់បាននិយាយថា គាត់នឹងទុកជីវិតឲ្យប្រជាជននេះ ប្រសិនបើគាត់ត្រូវបានអនុញ្ញាតឲ្យសម្លាប់ក្ងារអានទុមើរ ។ សូមមើលផងដែរ អេធើរ ១៤:២៤) ។

សូមសង្ខេប អេធើរ ១៥:៦–១១ ដោយការពន្យល់ថា ប្រជាជនរបស់ក្ងារអានទុមើរ និងប្រជាជនរបស់សិសបានបន្តច្បាំងនឹងគ្នាទៀត ។ អ្នកក៏អាចពន្យល់ថា ចម្បាំងនេះ ដែលជាចម្បាំងមួយដែលជាតិសាសន៍យ៉ារេឌត្រូវបានបំផ្លាញ បានកើតឡើងនៅជិតភ្នំមួយឈ្មោះថា រ៉ាម៉ា ។ រាប់រយឆ្នាំក្រោយមក អរិយធម៌សាសន៍នីហ្វៃត្រូវបានបំផ្លាញនៅក្នុងសង្គ្រាមមួយនៅត្បែរភ្នំដូចគ្នា ដែលពេលនោះគេហៅថា ភ្នំគូម៉ូរ៉ា ។ (សូមមើល អេធើរ ១៥:១១ ; មរមន ៦:៦) ។

សូមឲ្យសិស្សអាន អេធើរ ១៥:១២–១៧ ដោយស្ងាត់ស្ងៀម ។ មុនពេលពួកគេអាន សូមឲ្យពួកគេរកមើលសេចក្តីលម្អិតអំពីស្ថានភាពរបស់ពួកសាសន៍យ៉ារេឌ និងរកមើលរឿងមួយនៅក្នុងដំណើររឿងនេះដែលវាគួរឲ្យសោកស្តៅជាពិសេស ។ នៅពេលពួកគេបានមានពេលអានហើយ សូមឲ្យសិស្សបីបួននាក់រៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ ។

សូមរំឭកសិស្សថា អេធើរបានចំណាយពេលរាប់ឆ្នាំព្រមានដល់ប្រជាជនឲ្យប្រែចិត្ត (សូមមើល អេធើរ ១២:២–៣; ១៣:២០) ។ សូមសរសេរប្រយោគមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *ប្រសិនបើយើងបដិសេធការព្រមានរបស់ព្រះអម្ចាស់ក្នុងការឲ្យប្រែចិត្តនោះ . . .*

សូមឲ្យសិស្សម្នាក់អាន អេធើរ ១៥:១៨–១៩ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរបៀបដើម្បីបំពេញប្រយោគនៅលើក្តារខៀន ។ ក្រោយពីសិស្សចែកចាយគំនិតរបស់គេហើយ សូមបំពេញប្រយោគនេះដោយការសរសេរនូវគោលការណ៍ខាងក្រោមនេះ ៖ ***ប្រសិនបើយើងបដិសេធនូវការព្រមានរបស់ព្រះអម្ចាស់ក្នុងការឲ្យប្រែចិត្តនោះ ព្រះវិញ្ញាណរបស់ទ្រង់នឹងដកថយ ហើយសាតាំងនឹងមានអំណាចគ្រប់គ្រងលើដួងចិត្តរបស់យើង ។***

- តើការបដិសេធរបស់ពួកសាសន៍យ៉ារេឌក្នុងការប្រែចិត្តពីដំបូង បានប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការផ្លាស់ប្តូរនាពេលក្រោយដោយរបៀបណា ?

សូមសង្ខេប អេធើរ ១៥:២០–៣២ ដោយការពន្យល់ថា កងទ័ពរបស់ក្ងារអានទុមើរ និងរបស់សិសបានច្បាំងរហូតដល់សល់តែក្ងារអានទុមើរ និងសិសតែប៉ុណ្ណោះ ។ បន្ទាប់មក ក្ងារអានទុមើរបានសម្លាប់សិស ។ នៅពេលអេធើរបានព្យាករណ៍ ថាប្រជាជនទាំងអស់នៅក្នុងនគរត្រូវបានសម្លាប់លើកលែងតែក្ងារអានទុមើរម្នាក់ ដែលពេលនោះនៅរស់ដើម្បីមើលឃើញប្រជាជនផ្សេងទៀត —ប្រជាជន

សាវ៉ាហិមឡា— មកគ្រងដែនដីនេះ (សូមមើល អេធើរ ១៣:២១; អោមណៃ ១:២០–២២) ។ សូមឲ្យសិស្សអាន អេធើរ ១៥:៣៣ ដើម្បីបង្ហាញថា ព្រះបន្ទូលរបស់ព្រះអម្ចាស់ដែលបានថ្លែងដោយលោកអេធើរនោះ ត្រូវបានបំពេញ ។

សូមបង្ហាញថា ប្រវត្តិសាស្ត្ររបស់ពួកសាសន៍យ៉ារេឌគឺជាគំរូដ៏ខ្លាំងពិសេសមួយនៃអ្វីដែលកើតឡើងដល់ប្រជាជន នៅពេលពួកគេបដិសេធការអញ្ជើញដដែលៗមកពីព្រះឲ្យប្រែចិត្ត ។ ទោះបីវាគឺជាគំរូដ៏ខ្លាំងពិសេសមួយក្តី ក៏យើងអាចរកឃើញគោលការណ៍នានានៅក្នុងដំណើររឿងនេះដែលអាចជួយដល់យើងបានដែរ ។ សូមពន្យល់ថា ដូចជាសាសន៍យ៉ារេឌដែរ មនុស្សជាច្រើននៅសព្វថ្ងៃនេះបដិសេធដល់ការអញ្ជើញរបស់ព្រះឲ្យប្រែចិត្ត រហូតដល់ពួកគេបាត់បង់ព្រះវិញ្ញាណនៃព្រះអម្ចាស់ ។ ជាញឹកញាប់ ប្រជាជនទាំងនេះបដិសេធមិនប្រែចិត្តតាមវិចារណញ្ញាណរបស់គេ ។ សូមអានសនិទានកម្មខាងក្រោម ហើយសូមឲ្យសិស្សពន្យល់ពីអ្វីដែលពួកគេនឹងនិយាយឆ្លើយតបទៅនឹងនរណាម្នាក់ដែលបាននិយាយនូវរឿងទាំងនេះ: ។ នៅពេលសិស្សឆ្លើយ សូមអញ្ជើញពួកគេឲ្យយោងទៅគោលការណ៍ដែលពួកគេបានរៀននៅក្នុង អេធើរ ១៣–១៥ ។

១. « ខ្ញុំដឹងថា រឿងដែលខ្ញុំមើលនោះ មិនមែនជាបទដ្ឋានរបស់សាសនាចក្រនោះទេ ប៉ុន្តែវាមើលទៅមិនមានឥទ្ធិពលអាក្រក់ណាមួយមកលើខ្ញុំនោះទេ » ។

២. « ការទទួលទានសុរាជាមួយនឹងមិត្តភក្តិមិនមែនអាក្រក់ណាស់ណានោះទេ —យើងគ្រាន់តែមានការីករាយប៉ុណ្ណោះ » ។

៣. « ខ្ញុំគ្រាន់តែលូចមើល ដោយសារគ្រប់គ្នានៅក្នុងថ្នាក់របស់ខ្ញុំធ្វើដែរ ។ វាមិនអាចទទួលបានពិន្ទុល្អនោះទេ ប្រសិនបើខ្ញុំមិនលូចដែរទេនោះ » ។

៤. « វាគ្រាន់តែជារឿងអាសអាភាសបន្តិចបន្តួចប៉ុណ្ណោះ ។ វាមិនមែនថា ខ្ញុំនឹងចេញទៅក្រៅ ហើយប្រព្រឹត្តអសីលធម៌នោះទេ ។ ក្រៅពីនេះ ខ្ញុំអាចឈប់ពេលណាដែលខ្ញុំចង់ឈប់ » ។

៥. « ខ្ញុំមិនចាំបាច់ប្រែចិត្តនាពេលនេះនោះទេ ។ ខ្ញុំអាចរង់ចាំ រហូតដល់ខ្ញុំរៀបនឹងទៅបេសកកម្មមួយ ឬរៀបការនៅក្នុងព្រះវិហារបរិសុទ្ធសិន » ។

សូមប្រាកដថា សិស្សយល់ថា នៅពេលមនុស្សធ្វើអំពើបាប ហើយមិនប្រែចិត្ត នោះពួកគេនឹងតែងតែជួបនូវលទ្ធផលនៃអំពើបាបទាំងនោះ: ។ សូមធានាជាថ្មីដល់សិស្សថា ប្រសិនបើពួកគេបានធ្វើអំពើបាប នោះពួកគេអាចប្រែចិត្តចេញពីអំពើបាបរបស់គេបាន ហើយទទួលបានព្រះវិញ្ញាណនៃព្រះអម្ចាស់នៅក្នុងជីវិតរបស់គេសារជាថ្មីបាន ។ សូមអាននូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ នែល អិល អាន់ឌើរសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ខ្ញុំថ្លែងទីបន្ទាល់ថា ព្រះអង្គសង្គ្រោះអាច និងចង់អភ័យទោសចំពោះអំពើបាបរបស់យើងណាស់ ។ លើកលែងតែអំពើបាបនៃអស់អ្នកដែលជ្រើសរើសយកអំពើបាបធ្ងន់ធ្ងរ ក្រោយពីបានដឹងភាពពេញលេញហើយ វាគ្មានអំពើបាបណាដែលមិនអាចលើកលែងទោសឲ្យបាននោះទេ ។ ឱ! តើវាជាឯកសិទ្ធិដ៏អស្ចារ្យសម្រាប់យើងម្នាក់ៗដើម្បីត្រឡប់ចេញពីអំពើបាបរបស់យើង ហើយមករកព្រះគ្រីស្ទយ៉ាងណាទៅ ! ការអភ័យទោសពីស្ថានសួគ៌គឺជាផ្លែដ៏ផ្អែមបំផុតមួយនៃដំណើរឆ្ពោះ ដោយដកចេញនូវអំពើបាប និងការឈឺចាប់ចេញពីដួងចិត្តរបស់យើង ហើយជំនួសមកវិញដោយសេចក្តីអំណរ និងសេចក្តីសុខសាន្តនៃអារម្មណ៍នោះ » (« Repent . . . That I May Heal You » *Ensign* ឬ *លីអាហូណា* ខែវិច្ឆិកា ឆ្នាំ ២០០៩, ទំព័រ ៤០–៤១) ។

សូមឲ្យសិស្សពិនិត្យមើលជីវិតរបស់គេចំពោះអំពើបាបនានា ដែលជ្រៀតជ្រែកដល់ការមានគូជានិរន្តរ៍ជាព្រះវិញ្ញាណបរិសុទ្ធរបស់គេ ។ សូមលើកទឹកចិត្តពួកគេឲ្យខំតោងចាប់ព្រះចេស្តានៃដង្វាយធួនក្នុងការផ្លាស់ប្តូរ ដែលនឹងជួយដល់ពួកគេឲ្យរក្សាបានគូនៃព្រះវិញ្ញាណ និងប្រឆាំងនឹងអំណាចរបស់សាតាំងបាន ។

ដើម្បីជួយសិស្សឲ្យយល់ពីគោលការណ៍មួយទៀតដែលបានបង្រៀននៅក្នុង អេធើរ ១៣–១៥ សូមឲ្យពួកគេអានវគ្គខាងក្រោមនេះដោយស្ងាត់ស្ងៀម ៖ អេធើរ ១៣:២៧; ១៤:២៤; ១៥:៦, ២២, ២៨ ។ មុនពេលពួកគេអាន សូមឲ្យពួកគេគិតរកមើលពាក្យ និងឃ្លាដែលបញ្ជាក់ពីអារម្មណ៍របស់ពួកសាសន៍យ៉ារេឌដែលមានកំហឹង និងបំណងចង់សងសឹក ។ អ្នកអាចណែនាំថា សិស្សគួរគូសចំណាំពាក្យ និងឃ្លាទាំងនេះ ។

- ដោយផ្អែកលើការសិក្សារបស់អ្នកក្នុង អេធើរ ១៣–១៥ តើអ្វីជាលទ្ធផលនៃកំហឹង និងបំណងចង់សងសឹករបស់ពួកសាសន៍យ៉ារេឌ ?
- តើគោលការណ៍អ្វីអំពីកំហឹង និងការសងសឹកដែលយើងអាចរៀនពីវគ្គចុងក្រោយនៃប្រវត្តិសាស្ត្ររបស់ពួកសាសន៍យ៉ារេឌនេះ: ? (សិស្សអាចចែករំលែកនូវគោលការណ៍ពីរបីខុសគ្នា ។ សូមធានាថា ចម្លើយរបស់ពួកគេឆ្លុះបញ្ចាំងថា **កំហឹង និងការសងសឹកនឹងនាំមនុស្សទៅរកជម្រើសដែលធ្វើឲ្យពួកគេ និងអ្នកដទៃឈឺចាប់**) ។
- តើអ្វីជាលទ្ធផលដែលកំហឹងអាចមានដល់បុគ្គល ឬគ្រួសារមួយនោះ ?

សូមថ្លែងទីបន្ទាល់ថា យើងអាចយកឈ្នះលើអារម្មណ៍ខឹង និងបំណងចង់សងសឹកនេះបាន នៅពេលយើងបែរទៅព្រះយេស៊ូវគ្រីស្ទ និងទទួលបាននូវការអភ័យទោស និងការលួងលោមតាមរយៈដង្វាយធួនរបស់ទ្រង់ ។ សូមអញ្ជើញសិស្សឲ្យបែរទៅព្រះអម្ចាស់នៅក្នុងការអធិស្ឋានសុំរកជំនួយដែលពួកគេត្រូវការ ប្រសិនបើពួកគេខឹងនឹងមនុស្សផ្សេងទៀត ។

ការរំឭកគម្ពីរអេធើរ

សូមចំណាយពេលខ្លះដើម្បីជួយសិស្សឲ្យរំឭក គម្ពីរអេធើរ ។ សូមឲ្យពួកគេគិតអំពីអ្វីដែលពួកគេបានរៀនពីគម្ពីរនេះ: ទាំងនៅក្នុងថ្នាក់សិក្ខាសាលា និងនៅក្នុងការសិក្សាវគ្គគម្ពីរផ្ទាល់ខ្លួនរបស់គេ ។ ប្រសិនបើចាំបាច់ សូមឲ្យពួកគេសង្ខេបដោយខ្លីៗអំពីសេចក្តីសង្ខេបជំពូកខ្លះនៅក្នុងគម្ពីរអេធើរ ដើម្បីជួយពួកគេឲ្យចងចាំ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីខ្លះពីគម្ពីរអេធើរ ដែលបំផុសគំនិតដល់ពួកគេ ឬដែលបានជួយដល់ពួកគេឲ្យមានសេចក្តីជំនឿកាន់តែខ្លាំងទៅលើព្រះយេស៊ូវគ្រីស្ទ ។

សេចក្តីផ្តើមអំពី

គម្ពីរមរ៉ូណៃ

ហេតុអ្វីបានជាត្រូវសិក្សាគម្ពីរនេះ ?

នៅពេលសិស្សសិក្សាគម្ពីរមរ៉ូណៃ ពួកគេអាចទទួលបានកម្លាំងពីគំរូជំនឿមានអំណាច និងការបង្រៀននានារបស់លោកមរ៉ូណៃ ព្រមទាំងឪពុករបស់លោកគឺ លោកមរមន ។ ពួកគេនឹងរៀនអំពីពិធីបរិសុទ្ធ និងការអនុវត្តជាមូលដ្ឋាននៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ សារៈសំខាន់នៃការធ្វើការសុចរិតដោយមានបំណងជំពិតប្រាកដ របៀបក្នុងការកាត់សេចក្តីរវាងអំពើល្អ និងអំពើអាក្រក់ ទំនាក់ទំនងរវាងសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស ហើយនិងសេចក្តីសង្គ្រោះនៃកូនក្មេងតូចៗ ។ សិស្សក៏នឹងអានអំពីការដាស់តឿនរបស់លោកមរ៉ូណៃឲ្យអធិស្ឋានដើម្បីដឹងដោយខ្លួនឯងថា ព្រះគម្ពីរមរមនគឺជាព្រះគម្ពីរពិត (សូមមើល មរ៉ូណៃ ១០:៣–៥) និងដើម្បី « មកកាន់ព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ » (មរ៉ូណៃ ១០:៣២) ។

តើនរណាជាអ្នកសរសេរ គម្ពីរនេះ ?

លោកមរ៉ូណៃបានសរសេរគម្ពីរនេះ ដែលរួមមានពាក្យសម្តីរបស់លោកផ្ទាល់ ព្រះបន្ទូលរបស់ព្រះយេស៊ូវគ្រីស្ទដល់ពួកសិស្សរបស់ទ្រង់ទាំងដប់ពីរនាក់ជាពួកសាសន៍នីហ្វៃ (សូមមើល មរ៉ូណៃ ២) និងពាក្យសម្តីរបស់ឪពុកលោក គឺលោកមរមន (មរ៉ូណៃ ៧–៩) ។ មុនពេលពួកសាសន៍នីហ្វៃត្រូវបានបំផ្លាញបង់ លោកមរ៉ូណៃបានបម្រើនៅក្នុងចំណោមពួកគេ ជាមេទ័ពម្នាក់ និងជាអ្នកដឹកនាំសាសនាចក្រមួយរូប (សូមមើល មរមន ៦:១២ មរ៉ូណៃ ៨:១) ។ ដូចជាអ្នកសរសេរ និងអ្នកចងក្រងសំខាន់ផ្សេងទៀតក្នុងព្រះគម្ពីរមរមនដែរ លោកមរ៉ូណៃគឺជាសាក្សីម្នាក់របស់ព្រះអង្គសង្គ្រោះ ។ លោកបានថ្លែងទីបន្ទាល់ថា « ខ្ញុំបានឃើញព្រះយេស៊ូវ ហើយថាទ្រង់បានមានព្រះបន្ទូលជាមួយនឹងខ្ញុំ » (អេធើរ ១២:៣៩) ។ លោកមរ៉ូណៃស្មោះត្រង់ចំពោះទីបន្ទាល់របស់លោកជាខ្លាំង ដោយមិនព្រមបដិសេធចោលព្រះគ្រីស្ទ អំឡុងពេលមួយដែលពួកសាសន៍លេមិនបានសម្លាប់សាសន៍នីហ្វៃគ្រប់រូប ដែលមិនព្រមបដិសេធទ្រង់ (សូមមើល មរ៉ូណៃ ១:១–៣) ។ នៅក្នុងឆ្នាំ ១៨២៣ ប្រហែលជា ១,៤០០ ឆ្នាំក្រោយពីការបញ្ចប់កំណត់ត្រានៃព្រះគម្ពីរមរមន លោកមរ៉ូណៃបានចេញមកជួបនឹងព្យាការី យ៉ូសែប ស្ម៊ីធ ជាអង្គដែលបានរស់ឡើងវិញមួយ ហើយបានប្រាប់ដល់ យ៉ូសែប ថាកំណត់ត្រាត្រូវបានលាក់ទុកនៅក្នុងកូនភ្នំក្បែរផ្ទះរបស់លោក (សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:២៩–៣៥) ។ នៅពេលនោះ និងនៅអំឡុងពេលបួនឆ្នាំក្រោយមក លោកមរ៉ូណៃបានណែនាំដល់ យ៉ូសែប ស្ម៊ីធ ថា « អំពីរឿងដែលព្រះអម្ចាស់ទ្រង់នឹងធ្វើ ហើយតើដោយរបៀបណា និងដោយនូវអ្វីដែលនគរព្រះនឹងត្រូវចាត់ចែងនៅគ្រាក្រោយបង្អស់ » (យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:៥៤) ។

តើគម្ពីរនេះត្រូវបានសរសេរដល់នរណា ហើយតើហេតុអ្វី ?

លោកមរ៉ូណៃបានមានប្រសាសន៍ថា « ខ្ញុំសរសេរនូវការណ៍ខ្លះទៀត ដែលប្រហែលជាអាចមានប្រយោជន៍ដល់ពួកបងប្អូនរបស់ខ្ញុំ គឺពួកសាសន៍លេមិននៅថ្ងៃណាមួយក្នុងអនាគត » (មរ៉ូណៃ ១:៤, សូមមើលផងដែរ មរ៉ូណៃ ១០:១) ។ លោកក៏បានប្រកាសថា លោកបាននិយាយ « ទៅមនុស្សទាំងអស់នៅចុងផែនដី » ដោយព្រមានថា នៅក្នុងថ្ងៃជំនុំជម្រះនៃព្រះ នោះមនុស្សទាំងអស់នឹងត្រូវទទួលខុសត្រូវចំពោះពាក្យដែលលោកបានសរសេរ (សូមមើល មរ៉ូណៃ ១០:២៤, ២៧) ។ ក្នុងការរៀបចំហេតុការណ៍នេះ លោកមរ៉ូណៃបានអញ្ជើញមនុស្សទាំងអស់ឲ្យ « មកកាន់ព្រះគ្រីស្ទ » (មរ៉ូណៃ ១០:៣០, ៣២) ។

តើនៅពេលណា និងនៅកន្លែងណាដែលគម្ពីរនេះត្រូវបានសរសេរ ?

លោកមរ៉ូណៃ ហាក់ដូចជាបានសរសេរ និងចងក្រងគម្ពីរនេះ ចន្លោះឆ្នាំ ៤០១ គ្រិស្តសករាជ និងឆ្នាំ ៤២១ គ្រិស្តសករាជ (សូមមើល មរមន ៨:៤–៦, មរ៉ូណៃ ១០:១) ។ លោកមិនបាននិយាយពីកន្លែងដែលលោកបានស្ថិតនៅ នៅពេលលោកបានសរសេរគម្ពីរនេះនោះ —មានតែថា លោកបានដើរទៅកន្លែងណាដែលលោកអាចទៅដើម្បីមានសុវត្ថិភាពដល់ជីវិតរបស់លោក (សូមមើល មរ៉ូណៃ ១:១–៣) ។

តើមានលក្ខណៈពិសេសអ្វីខ្លះនៅក្នុងគម្ពីរនេះ ?

គម្ពីរនេះផ្តល់នូវសេចក្តីលម្អិតជាច្រើនទាក់ទងទៅនឹងការណែនាំរបស់ព្រះយេស៊ូវគ្រីស្ទដល់ពួកសិស្សសាសន៍នីហ្វៃទាំងដប់ពីរនាក់របស់ទ្រង់ នៅពេលទ្រង់បានប្រទានដល់ពួកគេនូវអំណាចដើម្បីផ្តល់នូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ (សូមមើល មរ៉ូណៃ ២; សូមមើលផងដែរ នីហ្វៃទី ៣ ១៨:៣៦–៣៧) ។ វាក៏រួមមានការណែនាំដែលមាននៅតែនៅក្នុងព្រះគម្ពីរមរមនដែលទាក់ទងទៅនឹងការសម្តែងនូវការតែងតាំងបព្វជិតភាព និងការអធិស្ឋានដែលត្រូវប្រើនៅក្នុងពិធីបរិសុទ្ធនៃពិធីសាក្រាម៉ង់ (សូមមើល មរ៉ូណៃ ៣–៥) ។ លក្ខណៈពិសេសខុសគ្នាផ្សេងទៀតនៃគម្ពីរនេះ រួមមានការបង្រៀនរបស់លោកមរមនអំពីការបែងចែកអំពើល្អ និងអំពើអាក្រក់ (សូមមើល មរ៉ូណៃ ៧:១២–១៩) ការបម្រើរបស់ពួកទេវតា (សូមមើល មរ៉ូណៃ ៧:២៩–៣៩) សេចក្តីសប្បុរស ជាសេចក្តីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ (សូមមើល មរ៉ូណៃ ៧:៤៤–៤៨) និងសេចក្តីសង្គ្រោះដល់កូនក្មេងតូចៗ (សូមមើល មរ៉ូណៃ ៨) ។ វាក៏រួមមានការរៀបរាប់របស់លោកមរមនអំពីការពុករលួយរបស់ពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន មុនពេលចម្បាំងលើកចុងក្រោយរបស់ពួកគេនៅឯភ្នំគូម៉ូរ៉ា (សូមមើល មរ៉ូណៃ ៩) ។ លោកមរ៉ូណៃក៏បញ្ចូលនូវការបង្រៀនរបស់លោកផ្ទាល់អំពីអំណោយទាននៃព្រះវិញ្ញាណ (សូមមើល មរ៉ូណៃ ១០:៨–២៦) ។ លោកក៏បានកត់ត្រាការអញ្ជើញមួយ ដែលមាននៅក្នុង មរ៉ូណៃ ១០:៣–៥ ដែលផ្តល់ជាកូនសោរមួយរួមចំណែកដល់ព្រះគម្ពីរមរមននេះ ។ ដោយយោងទៅលើវគ្គនេះ ប្រធាន ហ្គរដុន ប៊ី ហិងគ្លី បានពន្យល់ថា ព្រះគម្ពីរមរមន « គឺជាគម្ពីរតែមួយគត់ដែលរួមមាននៅក្នុងគម្របរបស់វានូវសេចក្តីសន្យាមួយថា ដោយសារព្រះចេស្តាដ៏មានអានុភាព នោះអ្នកអានអាចដឹងដោយពិតជាក់ប្តាស់អំពីសេចក្តីពិតរបស់វា » (« A Testimony Vibrant and True » *Ensign,* ខែ សីហា ឆ្នាំ ២០០៥ ទំព័រ ៤) ។

គម្រោង

មរ៉ូណៃ ១–៦ ខណៈពេលដែលដើរស្វែងរកសុវត្ថិភាពដល់ជីវិតរបស់លោក មរ៉ូណៃកត់ត្រានូវពិធីបរិសុទ្ធ និងការអនុវត្តនានានៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។ ការណ៍ទាំងនេះរួមមានការផ្តល់ជាអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ការធ្វើការតែងតាំងនៃបព្វជិតភាព ការបម្រើសាក្រាម៉ង់ និងគុណសម្បត្តិសម្រាប់ពិធីបុណ្យជ្រមុជទឹក ។ លោកមរ៉ូណៃក៏ពិភាក្សាអំពីការធំធាត់ខាងវិញ្ញាណនៃសមាជិកសាសនាចក្រ ក៏ដូចជាគោលបំណងនៃការប្រជុំក្នុងសាសនាចក្រ និងរបៀបដែលពួកគេត្រូវដឹកនាំផងដែរ ។

មរ៉ូណៃ ៧ មរ៉ូណៃកត់ត្រាពីទេសនាកថាដែលធ្វើឡើងដោយលោកមរមន ដែលបានបង្រៀនអំពីពន្លឺនៃព្រះគ្រីស្ទ សារៈសំខាន់នៃការធ្វើទង្វើសុចរិតដោយមានបំណងប្រាថ្នាពិតប្រាកដ ការបែងចែកពីភាពខុសគ្នារវាងអំពើល្អ និងអំពើអាក្រក់ ការតោងជាប់តាមការណ៍ល្អគ្រប់យ៉ាង និងទំនាក់ទំនងរវាងសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស ។

មរ៉ូណៃ ៨–៩ មរ៉ូណៃកត់ត្រាសំបុត្រពីលោកមរមនដែលពន្យល់ពីមូលហេតុដែលកូនក្មេងតូចៗមិនត្រូវជ្រមុជទឹក និងការរៀបរាប់ពីអំពើទុច្ចរិតដ៏ធំអស្ចារ្យនៅក្នុងចំណោមពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន ។

មរ៉ូណៃ ១០ មរ៉ូណៃដាស់តឿនដល់មនុស្សទាំងអស់ដែលនឹងអានព្រះគម្ពីរមរមនឲ្យអធិស្ឋានដើម្បីដឹងអំពីសេចក្តីពិតពេញលេញរបស់វា ដើម្បីកុំបដិសេធនឹងអំណាច និងអំណោយទាននៃព្រះ និងដើម្បីមករកព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ ។

មរ៉ូណៃ ១–៣

សេចក្តីផ្តើម

ក្រោយពីបញ្ចប់ការសង្ខេបរបស់លោកពីផ្នាំងមាសអេធើរហើយ លោកមរ៉ូណៃបានគិតថា លោកនឹងមិនសរសេរអ្វីទៀតឡើយ ។ ទោះជាយ៉ាងណាក្តី លោកត្រូវបានបំផុសឲ្យ « សរសេរនូវការណ៍ខ្លះទៀតដែលប្រហែលជាអាចមានប្រយោជន៍ដល់ពួកបងប្អូន [របស់លោក] គឺពួកសាសន៍លេមិន នៅថ្ងៃណាមួយក្នុងអនាគត ស្របតាមព្រះហឫទ័យនៃព្រះអម្ចាស់ » (មរ៉ូណៃ ១:៤) ។ ពាក្យសម្តីរបស់លោកបញ្ជាក់ពីភាពស្មោះត្រង់របស់លោកចំពោះព្រះយេស៊ូវគ្រីស្ទ ហើយពួកគេក៏បង្ហាញពីពិធីបរិសុទ្ធនៃជំណឹងល្អដ៏សំខាន់ៗផងដែរ ។

យោបល់សម្រាប់ការបង្រៀន

បង្រៀនដោយព្រះវិញ្ញាណ

នៅក្នុងការរៀបចំ និងការបង្រៀនរបស់អ្នក សូមព្យាយាមដើម្បីត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ ។ នៅពេលគ្រូបង្រៀន និងសិស្សត្រូវបានដឹកនាំដោយព្រះវិញ្ញាណ « អ្នកដែលផ្សាយ ហើយអ្នកដែលទទួល យល់គ្នាទៅវិញទៅមក ហើយទាំងពីរនាក់ត្រូវបានស្អាងឡើង ហើយត្រេកអរជាមួយគ្នា » (គ. និង ស. ៥០:២២) ។

មរ៉ូណៃ ១

លោកមរ៉ូណៃដើរតុសុវត្ថិភាពដល់ជីវិតរបស់លោក ហើយបន្តការសរសេររបស់លោក

សូមឲ្យសិស្សម្នាក់អានរឿងខាងក្រោមនេះឮៗ ដែលបានដំណាលដោយយុវនារីម្នាក់ ដែលបានក្រោកឈរឡើងការពារដល់សេចក្តីជំនឿរបស់នាងនៅសាលារៀន ៖

« គ្រូបង្រៀនខ្ញុំឈរនៅឯក្តារខៀនប្រាប់ពីឈុតរឿងមួយដែលយើងកំពុងមើល ។ . . . គ្រូបង្រៀនខ្ញុំ . . .បានពន្យល់ដោយសោះកក្រោះថា . . . រឿងនេះត្រូវបានចាត់ទុកថាជារឿងសម្រាប់មនុស្សពេញវ័យ ។ ខ្ញុំបានស្រឡាំងកាំង ។. . . ខ្ញុំមិនធ្លាប់គិតទេថា រឿងនេះនឹងកើតឡើង ។

« ខ្ញុំបានអង្គុយនៅ កៅអីរបស់ខ្ញុំ ដោយគិតអំពីអ្វីដែលខ្ញុំគួរធ្វើ ។ គំនិតមួយបានលេចមកក្នុងអារម្មណ៍របស់ខ្ញុំថា ៖ យើងត្រូវបានសុំកុំឲ្យមើលរឿងដែលមិនល្អ ។ ខ្ញុំបានព្យាយាមដោះសាថា ដោយសារខ្ញុំនៅរៀនក្នុងសាលា ដូច្នេះរឿងដែលយើងនឹងមើលគឺជារឿងដែលសមរម្យ ។ ប៉ុន្តែគំនិតថាមិនត្រូវមើលរឿងមិនល្អ បានយកឈ្នះលើការដោះសារបស់ខ្ញុំ ។

« ខ្ញុំបានលើកដៃដោយស្ងាត់ស្ងៀម ហើយដោយឈរនៅពីមុខថ្នាក់ទាំងមូល ខ្ញុំត្រូវបានឲ្យអង្គុយនៅក្រៅថ្នាក់ ខណៈពេលដែលរឿងបានចាប់ផ្តើមលេង ។ ខ្ញុំមានអារម្មណ៍ថា ភ្នែកគ្រប់គ្នាបានមើលមកខ្ញុំ នៅពេលខ្ញុំបានរុញកៅអីខ្ញុំចេញ ហើយប្រមូលយកសៀវភៅរបស់ខ្ញុំ ។ ខ្ញុំបានឃើញទឹកមុខរបស់ពួកគេ ពួកគេពិតជាមិនយល់វានោះទេ ។

« ខណៈពេលដែលអង្គុយនៅខាងក្រៅ ខ្ញុំមានអារម្មណ៍សប្បាយចិត្តជាខ្លាំង ។ ខ្ញុំបានដឹងថា ខ្ញុំបានធ្វើរឿងដែលត្រឹមត្រូវ មិនថាមិត្តភក្តិ ឬគ្រូរបស់ខ្ញុំនិយាយអ្វីនោះទេ ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំបានរឹងមាំជាងមុនទៀតផង ។ ខ្ញុំបានដឹងថា ខ្ញុំមិនត្រូវមើលរឿងដែលមិនសមរម្យ ដោយសារតែគ្រូរបស់ខ្ញុំបានបង្ហាញវាដល់យើងនោះទេ ។

« . . . ខ្ញុំជឿថា នៅពេលយើងប្រឈមនឹងគ្រាលំបាក ហើយយើងឈរប្រឆាំងនឹងវា នោះយើងត្រូវបានធ្វើឲ្យរឹងមាំជាង កាលដែលយើងអង្គុយចុះ ហើយអនុញ្ញាតឲ្យវាកើតឡើង ។

« នេះគឺជាភាពរឹងមាំខាងក្នុងមួយ ដែលមានឡើងតាមរយៈព្រះអង្គសង្គ្រោះរបស់យើង ។ ប្រសិនបើយើងមើលទៅរកទ្រង់នៅក្នុងគ្រាលំបាករបស់យើង នោះយើងនឹងត្រូវបានធ្វើឲ្យរឹងមាំឡើង ។ សេចក្តីជំនឿរបស់យើងទៅលើទ្រង់អាចជួយយើងឲ្យប្រឈមមុខនឹងឧបសគ្គបាន » (Catherine Hall «Standing Up, Standing Out» *New Era* ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ១១) ។

សូមឲ្យសិស្សអាន មរ៉ូណៃ ១:១–៣ ដោយស្ងាត់ស្ងៀមដោយរកមើលរបៀបដែលលោកមរ៉ូណៃបានឈរតែម្នាក់ឯងនៅក្នុងសេចក្តីជំនឿរបស់លោក ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមពិចារណាពីការសួរសំណួរខាងក្រោមនេះ ៖

- តើការ « មិនបដិសេធនឹងព្រះគ្រីស្ទ » មានន័យយ៉ាងណាចំពោះអ្នក ?
- តើនៅពេលណាដែលអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់បានបង្ហាញពីការប្តេជ្ញាចិត្តក្នុងការធ្វើតាមព្រះយេស៊ូវគ្រីស្ទ នៅពេលស្ថិតនៅគ្រាលំបាក ?

សូមពន្យល់ថា ទោះបីជាគំរូរបស់លោកមរ៉ូណៃ និងយុវនារីនៅក្នុងរឿងនោះគឺជាគំរូដ៏អស្ចារ្យក្នុងការមិនបដិសេធព្រះយេស៊ូវគ្រីស្ទក្តី ក៏យើងម្នាក់ៗអាចធ្វើឲ្យការសម្រេចចិត្តតូចតាចរាល់ថ្ងៃដែលបង្ហាញពីសេចក្តីជំនឿ ការគោរពតាម និងបំណងមិនបដិសេធព្រះគ្រីស្ទដូចគ្នា » ។

- តើមានរបៀបណាខ្លះ ដែលអ្នកអាចធ្វើតាមគំរូរបស់លោកមរ៉ូណៃ ? (សិស្សអាចនិយាយថា ពួកគេអាចត្រូវទទួលភាពខ្ជាស់អៀនពីដំណឹងល្អ និងបទដ្ឋានរបស់វា ពីការគោរពតាមព្រះបញ្ញត្តិទាំងឡាយ ការធ្វើជាគំរូដ៏សុចរិត និងការបន្តរឹងមាំនៅក្នុងទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ទោះបីជានៅពេលអ្នកដទៃមិនបានធ្វើដូច្នោះក្តី)។

សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ១:៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលមូលហេតុដែលលោកមរ៉ូណៃបានជ្រើសរើសដើម្បីបន្តសរសេរ ។ ក្រោយពីសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញហើយ សូមបង្ហាញថា លោកមរ៉ូណៃបានសរសេរដើម្បីប្រយោជន៍ដល់កូនចៅរបស់អ្នកដែលបានចង់សម្លាប់លោក ។

- តើយើងអាចរៀនអ្វីខ្លះពីចំណងរបស់លោកម៉ូរ៉ំណៃក្នុងការជួយដល់ពួកសាសន៍លេមិន ? (យើងអាចបង្ហាញពីការប្តេជ្ញាចិត្តធ្វើតាមព្រះយេស៊ូវព្រះគ្រីស្ទរបស់យើង ដោយការជ្រើសរើសដើម្បីបង្ហាញសេចក្តីស្រឡាញ់ដល់សត្រូវរបស់យើង) ។

សូមពន្យល់ថា ការប្តេជ្ញាចិត្តចំពោះព្រះយេស៊ូវគ្រីស្ទរបស់លោកម៉ូរ៉ំណៃ បានដឹកនាំលោកឲ្យសរសេរអំពីចំណុចគន្លឹះខ្លះៗរបស់សាសនាចក្រ ដែលលោកមានអារម្មណ៍ថា « មានប្រយោជន៍ » (ម៉ូរ៉ំណៃ ១:៤) ។ សូមឲ្យសិស្សគិតពិចារណាអំពីរបៀបដែល ម៉ូរ៉ំណៃ ២–៣ អាចមានប្រយោជន៍ដល់ពួកគេ នៅពេលពួកគេសិក្សាពីជំពូកទាំងនេះ ។

ម៉ូរ៉ំណៃ ២

លោកម៉ូរ៉ំណៃ កត់ត្រាពីសេចក្តីណែនាំរបស់ព្រះយេស៊ូវគ្រីស្ទអំពីការប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ

សូមឲ្យយុវជនម្នាក់ឡើងមកខាងមុខថ្នាក់ ។ សូមឲ្យសិស្សស្រមៃថា យុវជននេះនៅក្នុងពេលអនាគតនឹងក្លាយជាអ្នកផ្សាយសាសនាពេញម៉ោង ។ គាត់ និងដៃគូរបស់គាត់បានបង្រៀនដល់នរណាម្នាក់អំពីដំណឹងល្អ ហើយបុគ្គលនោះបានសម្រេចចិត្តទទួលបុណ្យជ្រមុជទឹក ។ យុវជននៅក្នុងថ្នាក់របស់អ្នកនេះ ត្រូវបានអញ្ជើញឲ្យសម្តែងពិធីការបរិសុទ្ធនៃពិធីបញ្ជាក់ ដែលរួមមាននៅក្នុងការប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ សូមសួរសំណួរទាំងឡាយខាងក្រោមនេះដល់យុវជននេះ ៖

- តើអ្នកអាចធ្វើអ្វីខ្លះ ដើម្បីរៀបចំក្នុងការធ្វើពិធីការបរិសុទ្ធនេះ ? (បន្ទាប់ពីយុវជននេះឆ្លើយតបហើយ សូមឲ្យសិស្សក្នុងថ្នាក់ទាំងអស់ចែកចាយពីគំនិតរបស់គេ) ។

សូមពន្យល់ថា នៅពេលព្រះអង្គសង្គ្រោះដែលមានព្រះជន្មរស់ឡើងវិញបានយាងទៅជួបនឹងពួកសាសន៍នីហ្វៃ « ទ្រង់ពាល់ពួកសិស្សដែលទ្រង់បានរើសម្តងម្នាក់ៗ » ហើយ « បានប្រទានពួកគេនូវអំណាចដើម្បីប្រគល់ព្រះវិញ្ញាណបរិសុទ្ធ » (៣ នីហ្វៃទី១៨:៣៦–៣៧) ។ លោកម៉ូរ៉ំណៃបានបញ្ចូលនូវការណែនាំរបស់ព្រះអង្គសង្គ្រោះខ្លះៗទៅដល់ពួកសាវកសាសន៍នីហ្វៃទាំងដប់ពីរនាក់នៅក្នុងកំណត់ត្រារបស់លោក អំពីរបៀបដើម្បីប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ សូមឲ្យសិស្សម្នាក់អាន ម៉ូរ៉ំណៃ ២:១–៣ ឮៗ ហើយសូមឲ្យសិស្សរកមើលព័ត៌មានដូចខាងក្រោមនេះ ។

១. អ្វីដែលគួរត្រូវរៀបចំចំពោះបុគ្គលដែលធ្វើពិធីបរិសុទ្ធ

២. របៀបដែលពិធីបរិសុទ្ធនេះត្រូវបានសម្តែងឡើង

ក្រោយពីសិស្សអានខគម្ពីរទាំងនេះហើយ សូមសួរពួកគេខ្លះ ឬទាំងអស់គ្នានូវសំណួរខាងក្រោមនេះ ៖

- យោងតាមលេខយោង *ខ* ក្នុង ម៉ូរ៉ំណៃ ២:២ តើបព្វជិតភាពត្រូវមានអ្វីខ្លះ ដើម្បីអាចប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធបាន ? (បព្វជិតភាពមិលគីស្សាដែក) ។
- តើអ្នកកាន់បព្វជិតភាពមិលគីស្សាដែកម្នាក់គួរធ្វើអ្វីខ្លះ ដើម្បីរៀបចំផ្តល់នូវអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ? (គាត់ត្រូវ « ហៅព្រះវរបិតានៅក្នុងព្រះនាម [របស់ព្រះយេស៊ូវគ្រីស្ទ] នៅក្នុងការអធិស្ឋានដ៏មានអំណាច ») ។
- តើអ្នកគិតថា ការអធិស្ឋានអាចជួយដល់បុគ្គលឲ្យរៀបចំធ្វើពិធីបរិសុទ្ធនៃបព្វជិតភាពដោយរបៀបណា ?
- តើពិធីបរិសុទ្ធនេះត្រូវបានសម្តែងឡើងតាមរបៀបណា ? (ដោយការដាក់ដៃលើក្បាល និងនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ។ សូមពន្យល់ថា ជាផ្នែកនៃពិធីការនេះ អ្នកកាន់បព្វជិតភាពមិលគីស្សាដែកត្រូវប្រើពាក្យមួយចំនួន ។ អ្នកផ្សាយសាសនាពេញម៉ោង ត្រូវបានផ្តល់នូវកូនសៀវភៅតូចដែលមាននូវការណែនាំពីរបៀបដើម្បីធ្វើពិធីបរិសុទ្ធនៃបព្វជិតភាព និងការប្រសិទ្ធពរ) ។

អ្នកអាចសង្ខេបពីអ្វីដែលសិស្សបានរៀនកន្លងមក ដោយការសរសេរនូវសេចក្តីពិតខាងក្រោមនេះនៅលើក្តារខៀន ៖ ***អ្នកកាន់បព្វជិតភាពមិលគីស្សាដែកប្រគល់អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដល់សមាជិកសាសនាចក្រដែលបានជ្រមុជទឹកហើយ ដោយការដាក់ដៃលើក្បាល) ។***

ម៉ូរ៉ំណៃ ៣

លោកម៉ូរ៉ំណៃកត់ត្រានូវសេចក្តីណែនាំរបស់ព្រះយេស៊ូវគ្រីស្ទអំពីការតែងតាំងពួកសង្ឃ និងគ្រូ

មុនពេលចាប់ផ្តើមបង្រៀនមេរៀននេះមួយថ្ងៃ ឬក៏ពីរថ្ងៃមុន អ្នកអាចគិតពីការសុំឲ្យយុវជនម្នាក់រៀបចំអានប្រវត្តិអំណាចបព្វជិតភាពរបស់គេដល់សិស្សក្នុងថ្នាក់ ។ (ឬ អ្នកអាចរៀបចំអានប្រវត្តិអំណាចបព្វជិតភាពរបស់អ្នក ឬប្រវត្តិអំណាចបព្វជិតភាពរបស់សមាជិកគ្រួសារអ្នក ឬអ្នកដឹកនាំបព្វជិតភាពម្នាក់នៅក្នុងវួដ ឬសាខារបស់អ្នក) ។ សូមពន្យល់ថា តំណនៃអំណាចបព្វជិតភាពបង្ហាញពីសិទ្ធិអំណាចរបស់អ្នកកាន់បព្វជិតភាពតគ្នារហូតដល់ព្រះយេស៊ូវគ្រីស្ទ ។ អ្នកកាន់បព្វជិតភាពមិលគីស្សាដែកអាចស្នើឲ្យមានកំណត់ត្រាមួយអំពីប្រវត្តិអំណាចបព្វជិតភាពរបស់គេ ដោយការទាក់ទងទីស្នាក់ការកណ្តាលរបស់សាសនាចក្រ ឬការិយាល័យរដ្ឋបាលនៅក្នុងតំបន់របស់ពួកគេ ។ សាសនាចក្រ មិនផ្តល់នូវកំណត់ត្រានៃប្រវត្តិសិទ្ធិអំណាចរបស់អ្នកកាន់បព្វជិតភាពអើរ៉ុននោះទេ ។ ទោះជាយ៉ាងណាក្តី ប្រសិនបើអ្នកកាន់បព្វជិតភាពអើរ៉ុនម្នាក់ត្រូវបានតែងតាំងដោយអ្នកកាន់បព្វជិតភាពមិលគីស្សាដែក គាត់អាចរៀនអំពីប្រវត្តិអំណាចរបស់បុរសដែលបានតែងតាំងគាត់បាន) ។

សូមឲ្យសិស្សអានប្រវត្តិអំណាចរបស់គេដល់សិស្សក្នុងថ្នាក់ (ឬសូមអានប្រវត្តិអំណាច ដែលអ្នកបាននាំមកកាន់ថ្នាក់) ។ សូមឲ្យគាត់ចែកចាយពីអត្ថន័យវាចំពោះគាត់ក្នុងការដឹងថា គាត់អាចតាមដានអំណាចបព្វជិតភាពផ្ទាល់ទៅដល់ព្រះយេស៊ូវគ្រីស្ទ (ឬចែកចាយអារម្មណ៍របស់អ្នកផ្ទាល់អំពីអ្នកកាន់បព្វជិតភាពដែលអាចតាមដានអំណាចរបស់គាត់ទៅដល់ព្រះអង្គសង្គ្រោះ) ។

ដើម្បីជួយសិស្សឲ្យយល់ថា អំណាចដើម្បីធ្វើកាតព្វកិច្ចបព្វជិតភាពទាំងអស់ចេញមកពីព្រះយេស៊ូវគ្រីស្ទ និងព្រះវរបិតាសួគ៌ សូមឲ្យសិស្សម្នាក់អាននូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដៃហ្វ្រី អ័រ ហូឡិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« ការអនុវត្តដោយសិទ្ធិអំណាចដ៏ទេវភាព តម្រូវឲ្យមានលើសពីការគ្រាន់តែមានកិច្ចសន្យាខាងសង្គមទៅទៀត ។ វាមិនអាចត្រូវបានបង្កើតដោយការហ្វឹកហ្វឺនខាងសាសនា ឬ គណៈកម្មការណាមួយមកពីក្រុមជំនុំនោះទេ ។ មិនមែនអញ្ចឹងទេ នៅក្នុងកិច្ចការដែលមានការអនុញ្ញាតពីព្រះ វាត្រូវតែមានអំណាចមួយដែលអស្ចារ្យជាងអ្វីដែលមានរួចហើយដោយមនុស្សដែលអង្គុយនៅកៅអីក្នុងព្រះវិហារ ឬ មនុស្សនៅតាមផ្លូវ ឬក៏មនុស្សនៅក្នុងថ្នាក់សិក្ខាសាលា—ជាការពិតមួយដែលថា អ្នកស្វែងយល់អំដ៏ស្មោះត្រង់ជាច្រើន អំពីសាសនា បានដឹង និងបានទទួលស្គាល់ដោយបើកចំហរជាច្រើនជំនាន់ បណ្តាលឲ្យមានការស្តារឡើងវិញនេះ ។ . . .

« . . . ដោយនៅក្នុងសាសនាចក្រដែលត្រូវបានស្តារឡើងវិញមួយរបស់ព្រះយេស៊ូវគ្រីស្ទ យើងអាចតាមដានតំណនៃសិទ្ធិអំណាចបព្វជិតភាពដែលត្រូវបានអនុវត្តដោយពួកឪកុនថ្មីបំផុតនៅក្នុងវួដ ប៊ីស្សពដែលដឹកនាំគាត់ និងព្យាការីដែលដឹកនាំយើងទាំងអស់គ្នា ។ ប្រវត្តិនោះត្រឡប់ទៅកាន់វគ្គដែលមិនអាចបំបែកបានមួយដល់អ្នកបម្រើជាទេវតា ដែលបានចេញមកពីព្រះរាជបុត្រានៃព្រះអង្គទ្រង់ផ្ទាល់ដែលទទួលអំណោយដ៏ឥតមានអ្វីប្រៀបបានពីស្ថានសួគ៌នេះ » (« Our Most Distinguishing Feature » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៥ ទំព័រ ៤៤) ។

- ហេតុអ្វីបានជាវាសំខាន់សម្រាប់អ្នកដើម្បីដឹងថា អ្នកកាន់បព្វជិតភាពគ្រប់រូបនៅក្នុងសាសនាចក្រនេះអាចតាមដានសិទ្ធិអំណាចរបស់ខ្លួនត្រឡប់ទៅរកព្រះយេស៊ូវគ្រីស្ទវិញបាន ?

សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៣:១–៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរបៀបដែលបុគ្គលម្នាក់ៗត្រូវបានតែងតាំងទៅក្នុងថ្នាក់បព្វជិតភាព ។

- តើបុគ្គលទាំងឡាយត្រូវបានតែងតាំងក្នុងតំណែងបព្វជិតភាពដោយរបៀបណា ? (**បុគ្គលទាំងឡាយត្រូវបានតែងតាំងក្នុងតំណែងបព្វជិតភាព ដោយការដាក់ដៃលើក្បាលពីអ្នកដែលមានសិទ្ធិអំណាច**) ។
- នៅក្នុងបព្វជិតភាព ហេតុអ្វីបានជាវាចាំបាច់សម្រាប់បុគ្គលម្នាក់ត្រូវបានតែងតាំងក្នុងតំណែងបព្វជិតភាពដោយនរណាម្នាក់ ដែលកំពុងតែកាន់តំណែងបព្វជិតភាពនោះ ឬតំណែងបព្វជិតភាពខ្ពស់ជាង ?

សូមឲ្យអ្នកកាន់បព្វជិតភាពនៅក្នុងថ្នាក់សង្កេបខ្លីៗអំពីកាតព្វកិច្ចបព្វជិតភាពរបស់ខ្លួន ។ សូមសួរសិស្សថា ៖

- តើនៅពេលណាដែលអ្នកត្រូវបានប្រទានពរ ដោយសារអ្នកកាន់បព្វជិតភាពម្នាក់បានបំពេញការទទួលខុសត្រូវរបស់គាត់នោះ ?

សូមឲ្យសិស្សពីរបីនាក់ចែកចាយអារម្មណ៍របស់គេអំពីរបៀបដែលបព្វជិតភាពបានប្រទានពរដល់ជីវិតរបស់ពួកគេ ។ អ្នកក៏អាចចែកចាយពីរបៀបដែលជីវិតរបស់អ្នកត្រូវបានប្រទានពរ ដោយសារតែបព្វជិតភាពនេះដែរ ។

ការរំឭកចំណេះចំណានខគម្ពីរ

សូមឲ្យសិស្សនូវបញ្ជីមួយដែលមានសេចក្តីយោងចំណេះចំណានខគម្ពីរនៃព្រះគម្ពីរមរមនទាំង ២៥ និងក្រដាសមួយចំហៀង ។ សូមឲ្យសិស្សសរសេរលេខ ១, ២, និង ៣ នៅលើក្រដាសរបស់គេ ។ បន្ទាប់មក សូមអានគំរូខាងក្រោម (ឬរៀបចំខគម្ពីរខ្លះរបស់អ្នកផ្ទាល់ដែលអាចទាក់ទងខ្លាំងទៅនឹងតម្រូវការ ព្រមទាំងចំណាប់អារម្មណ៍របស់សិស្សអ្នក) ។ នៅក្បែរលេខនីមួយៗនៅលើក្រដាសរបស់ពួកគេ សូមឲ្យសិស្សសរសេរវគ្គចំណេះចំណានខគម្ពីរ ដែលពួកគេគិតថា សឹគ្នាបំផុតនឹងគំរូដែលអ្នកបានអាន ។ បន្ទាប់មក សូមឲ្យពួកគេចែកចាយចម្លើយរបស់គេ ។ ដោយសារវាអាចមានចម្លើយច្រើន សូមឲ្យសិស្សពន្យល់ពីមូលហេតុដែលពួកគេបានជ្រើសរើសវគ្គពិសេសនោះ ។

១. អ្នកកំពុងស្វែងរកកម្លាំងដើម្បីយកឈ្នះលើការល្បួងដ៏ពិបាកជាពិសេសមួយ ។ (ចម្លើយអាចរួមមាន ៖ ហេលេមិន ៥:១២ និង នីហ្វៃទី ៣ ១៨:១៥, ២០–២១) ។

២. ខណៈពេលដែលអ្នកកំពុងសិក្សាបទគម្ពីរ ហើយគិតអំពីឧបសគ្គមួយនៅក្នុងជីវិតរបស់អ្នក អ្នកអាចទទួលបានការដឹកនាំអំពីអ្វីដែលត្រូវធ្វើ ។ (ចម្លើយអាចរួមមាន ៖ នីហ្វៃទី ២ ៣២:៣) ។

៣. អ្នកមានអារម្មណ៍ថារងសំ៣ធពីមិត្តមួយចំនួនក្នុងការចូលរួមក្នុងសកម្មភាពដែលផ្ទុយពីព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ។ ពួកគេប្រាប់អ្នកថា សកម្មភាពទាំងនេះគឺជាផ្នែកនៃភាពនៅក្មេង និងការសប្បាយ ។ (ចម្លើយអាចរួមមាន ៖ ម៉ូសាយ ៤:៣០, អាលម៉ា ៣៧:៣៥, ៤១:១០) ។

ម៉ូរ៉ូណៃ ៤–៥

សេចក្តីផ្តើម

លោកម៉ូរ៉ូណៃបានកត់ត្រាពីសេចក្តីណែនាំរបស់ព្រះអង្គសង្គ្រោះដល់ពួកសាសន៍នីហ្វៃទាក់ទងទៅនឹងការបម្រើពិធីសាក្រាម៉ង់ រួមមានការអធិស្ឋានដែលអ្នកកាន់បព្វជិតភាពត្រូវប្រើនៅក្នុងការប្រសិទ្ធិពរដល់នំបុ័ង និងទឹក ។

សូមអញ្ជើញឲ្យមានព្រះវិញ្ញាណបរិសុទ្ធជាសាក្សីដល់សេចក្តីពិតនេះ:

នៅពេលអ្នកជួយសិស្សឲ្យរក ហើយយល់ពីគោលការណ៍ និងគោលលទ្ធិនានានៃដំណឹងល្អ សូមបង្រៀនតាមរបៀបមួយដែលអញ្ជើញឲ្យមានព្រះវិញ្ញាណបរិសុទ្ធជាសាក្សីដល់សេចក្តីពិតនេះ: ។ នៅពេលសិស្សទទួលបានសាក្សីខាងវិញ្ញាណនៃគោលលទ្ធិនៃដំណឹងល្អហើយ នោះពួកគេនឹងចង់ធ្វើសកម្មភាព និងរស់នៅតាមដំណឹងល្អកាន់តែពេញលេញជាងមុន ។

យោបល់សម្រាប់ការបង្រៀន

ម៉ូរ៉ូណៃ ៤–៥

លោកម៉ូរ៉ូណៃពន្យល់ពីរបៀបដែលពិធីសាក្រាម៉ង់ត្រូវបម្រើ

ប្រសិនបើអាច សូមបង្ហាញនូវថាសដាក់នំបុ័ង និងទឹកនៃពិធីសាក្រាម៉ង់ ។ (ខណៈពេលដែលវាអាចបង្ហាញរបស់ទាំងនេះ អ្នកមិនគួរមានបំណងណាមួយក្នុងការថតចម្លងពិធីបរិសុទ្ធនានាពីពិធីសាក្រាម៉ង់នោះ ឡើយ)។ សូមចែកក្រដាសមួយសន្លឹកដល់សិស្ស ហើយសូមឲ្យពួកគេសរសេរពីការចងចាំរបស់ពួកគេនូវការអធិស្ឋានសាក្រាម៉ង់មួយ តាមដែលពួកគេអាចធ្វើទៅបាន ។ ក្រោយពីសិស្សបានមានពេលគ្រប់គ្រាន់ហើយ សូមពន្យល់ថា ជាផ្នែកនៃកំណត់ត្រារបស់លោក លោកម៉ូរ៉ូណៃបានបញ្ចូលការអធិស្ឋានទាំងនេះ ដូចដែលបានប្រទានដោយព្រះអម្ចាស់ សម្រាប់ការគ្រប់គ្រងក្នុងពិធីសាក្រាម៉ង់ ។ សូមឲ្យពួកគេបើកទៅ ម៉ូរ៉ូណៃ ៤:៣ ឬ ម៉ូរ៉ូណៃ ៥:២ ហើយពិនិត្យមើលចម្លើយរបស់គេ ។ បន្ទាប់មក សូមសួរថា ៖

- ប្រសិនបើមិត្តម្នាក់ដែលមានសេចក្តីជំនឿផ្សេងបានសម្រេចថានឹងចូលរួមនៅក្នុងការប្រជុំសាក្រាម៉ង់ជាមួយនឹងអ្នក តើអ្នកនឹងពន្យល់ពីអត្ថន័យនៃពិធីសាក្រាម៉ង់ និងអំពីសារៈសំខាន់របស់វាចំពោះអ្នកយ៉ាងដូចម្តេច ?

ដើម្បីជួយសិស្សឲ្យយល់ពីគោលបំណងមួយនៃពិធីសាក្រាម៉ង់ សូមឲ្យសិស្សម្នាក់អាន ម៉ូរ៉ូណៃ ៤:១–៣ ឮៗ ហើយសូមឲ្យសិស្សម្នាក់ទៀតអាន ម៉ូរ៉ូណៃ ៥:១–២ ។ សូមឲ្យសិស្សរកមើលឃ្លានៅក្នុង ម៉ូរ៉ូណៃ ៤:៣ និង ម៉ូរ៉ូណៃ ៥:២ ដែលពន្យល់ពីអត្ថន័យតំណាងឲ្យនំបុ័ង និងទឹកនៃពិធីសាក្រាម៉ង់ ។ អ្នកអាចស្នើថា ពួកគេគូរគូសចំណាំឃ្លាទាំងនេះនៅក្នុងព្រះគម្ពីររបស់ពួកគេ ។ (អ្នកអាចរំឭកសិស្សថា សព្វថ្ងៃនេះសាសនាចក្រប្រើទឹកនៅក្នុងពិធីសាក្រាម៉ង់ជំនួសឲ្យស្រាទំពាំងបាយជូ ដូចដែលបានអនុញ្ញាតដោយវិវរណៈមួយដែលត្រូវបានប្រទានដល់លោក យ៉ូសែប ស្ម៊ីធ | សូមមើល គ. និង ស. ២៧:២|)។

- តើនំបុ័ងតំណាងឲ្យអ្វី ? (ព្រះកាយរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមមើល ម៉ាថាយ ២៦:២៦; នីហ្វៃទី ៣ ១៨:៦–៧)។
- តើទឹកតំណាងឲ្យអ្វី ? (ព្រះលោហិតរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមមើល ម៉ាថាយ ២៦:២៧–២៨; នីហ្វៃទី ៣១៨:៨–១១)។
- ហេតុអ្វីបានជាព្រះកាយ និងព្រះលោហិតរបស់ព្រះអង្គសង្គ្រោះមានសារៈសំខាន់សម្រាប់យើង ? (នៅពេលសិស្សឆ្លើយនឹងសំណួរនេះ ពួកគេគួរលើកឡើងពីការរងទុក្ខខាងសាច់ឈាម និងការសុគតរបស់ព្រះអង្គសង្គ្រោះនៅលើឈើឆ្កាង ។ ពួកគេគួរនិយាយពីការរស់ឡើងវិញរបស់ទ្រង់ នៅពេលព្រះកាយរបស់ទ្រង់ត្រូវបានផ្គុំនឹងព្រះវិញ្ញាណរបស់ទ្រង់បីថ្ងៃ ក្រោយពីទ្រង់បានទទួលយកសេចក្តីស្លាប់ដាក់មកលើអង្គទ្រង់ ។ ពួកគេក៏គួរប្រាប់អំពីការរងទុក្ខខាងវិញ្ញាណដ៏ខ្លាំងរបស់ទ្រង់ នៅពេលទ្រង់បានទទួលយកអំពើបាបរបស់យើងដាក់លើអង្គទ្រង់ ដោយបណ្តាលឲ្យទ្រង់បានចេញឈាមតាមគ្រប់រន្ធញើស ។ ដោយសារទ្រង់បានទទួលយកសេចក្តីស្លាប់ខាងសាច់ឈាមដាក់មកលើអង្គទ្រង់ នោះមនុស្សទាំងអស់ត្រូវបានរស់ឡើងវិញ ។ ដោយសារទ្រង់បានរងទុក្ខចំពោះអំពើបាបរបស់យើង នោះយើងត្រូវអាចបានអភ័យទោសពីអំពើបាបរបស់យើង នៅពេលយើងប្រែចិត្ត)។

សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនេះនៅលើក្តារខៀន ៖ *និមិត្តសញ្ញានៃពិធីសាក្រាម៉ង់ជួយយើងឲ្យចងចាំដល់* . . . ។ សូមសួរសិស្សថាតើពួកគេនឹងសង្ខេបគោលបំណងដ៏សំខាន់អំពីពិធីសាក្រាម៉ង់នេះដោយរបៀបណា ។ បន្ទាប់មក សូមបំពេញសេចក្តីពិតនៅលើក្តារខៀនដូចខាងក្រោម ៖ ***និមិត្តនៃពិធីសាក្រាម៉ង់ជួយយើងឲ្យចងចាំដល់ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។***

សូមឲ្យសិស្សសញ្ជឹងគិតពីសំណួរខាងក្រោមនេះ ដែលបានសួរដោយអែលឌើរ ដាវីឌ ប៊ី ហេត នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« តើយើងគួរធ្វើយ៉ាងណា ក្នុងនាមជាសមាជិកសាសនាចក្រក្នុងការរំឭកចងចាំដល់ព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់យើង ពលិកម្មរបស់ទ្រង់ និងអំណរគុណរបស់យើងចំពោះទ្រង់ ? (« Remembering the Savior's Atonement » *Ensign* ខែ មេសា ឆ្នាំ ១៩៨៨ ទំព័រ ៧) ។

- តើយើងអាចធ្វើអ្វីខ្លះដើម្បីផ្តោតលើការចងចាំអំពីដង្វាយធួន អំឡុងពេលធ្វើពិធីសាក្រាម៉ង់ ?
- តើអ្នកធ្លាប់បានទទួលអ្វីខ្លះ នៅពេលអ្នកបានសញ្ជឹងគិតដោយស្មោះសដល់ដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ អំឡុងពេលនៃពិធីសាក្រាម៉ង់ ?

ក្រោយពីសិស្សចែកចាយពីការយល់ដឹងរបស់គេហើយ សូមឲ្យពួកគេសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬសៀវភៅសរសេរក្នុងថ្នាក់អំពីរបៀបមួយដែលពួកគេអាចផ្តោតលើគំនិតរបស់គេលើដង្វាយធួន អំឡុងពេលទទួលយកសាក្រាម៉ង់នាពេលក្រោយ ។ (អ្នកសុំឲ្យសិស្សពីរបីនាក់ចែកចាយនូវអ្វីដែលពួកគេបានសរសេរ)។

ដើម្បីជួយសិស្សឲ្យយល់ពីគោលបំណងបន្ថែមទៀតនៃពិធីសាក្រាម៉ង់ សូមគូសតារាងខាងក្រោមនេះនៅលើក្តារខៀនមុនពេលបង្រៀន ដោយទុកចន្លោះត្រង់ចម្លើយនៅក្នុងវង់ក្រចក ។ សូមឲ្យសិស្សគូសតារាងនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ ។

អ្វីដែលខ្ញុំធ្វើសេចក្តីសញ្ញាថានឹងធ្វើតាម	អ្វីដែលខ្ញុំគិតថាវាមានន័យក្នុងការធ្វើតាមផ្នែកនេះនៃសេចក្តីសញ្ញារបស់ខ្ញុំ	អ្វីដែលខ្ញុំអាចធ្វើបានក្នុងការធ្វើតាមផ្នែកនេះនៃសេចក្តីសញ្ញារបស់ខ្ញុំ
១. (មានឆន្ទៈនឹងលើកដាក់មកលើខ្លួនខ្ញុំនូវព្រះនាមនៃព្រះអម្ចាស់)		
២. (ចងចាំដល់ទ្រង់ជានិច្ច)		
៣. (រក្សាបទបញ្ញត្តិរបស់ទ្រង់)		

សូមរំឭកសិស្សថា នៅពេលយើងទទួលយកសាក្រាម៉ង់ នោះយើងបានធ្វើសេចក្តីសញ្ញា ឬធ្វើការព្រមព្រៀងដ៏ពិសិដ្ឋជាមួយនឹងព្រះ ។ សូមឲ្យសិស្សរំឭក មរ៉ូណៃ ៤:៣ ដោយស្ងាត់ស្ងៀម ។ នៅក្នុងភូឡោមទីមួយនៃតារាងនេះ សូមឲ្យពួកគេសរសេរសេចក្តីសន្យាបីដែលពួកគេបានធ្វើ នៅពេលពួកគេបានទទួលយកសាក្រាម៉ង់ ។ សូមឲ្យពួកគេត្រួតពិនិត្យចម្លើយរបស់ពួកគេជាមួយនឹងនរណាម្នាក់ដែលអង្គុយនៅក្បែរពួកគេ ។ បន្ទាប់មក សូមឲ្យពួកគេបំពេញក្នុងភូឡោនទីពីរវៀង ៗខ្លួន ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយនូវអ្វីដែលពួកគេបានសរសេរ ។ នៅពេលសិស្សចែកចាយនូវអ្វីដែលពួកគេបានសរសេរ សូមប្រើសម្ភារទាំងនេះខ្លះ ឬទាំងអស់ដើម្បីជួយដល់ពួកគេឲ្យយល់កាន់តែច្បាស់អំពីចំណែកនីមួយ ៗនៃសេចក្តីសញ្ញា ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែស៊ីជម្រៅអំពីអត្ថន័យនៃការលើកដាក់មកលើខ្លួនគេនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី ប៊ី អាវរិង នៃគណៈប្រធានទីមួយ ៖

« យើងសន្យាថានឹងលើកដាក់លើខ្លួនយើងនូវព្រះនាមរបស់ទ្រង់ ។ នោះមានន័យថា យើងត្រូវតែមើលខ្លួនយើងថាដូចជាទ្រង់ ។ យើងនឹងដាក់ទ្រង់ជាអាទិភាពនៅក្នុងជីវិតរបស់យើង ។ យើងនឹងចង់បានអ្វី ដែលទ្រង់ចង់បាន ជាជាងអ្វីដែលយើងចង់បាន ឬអ្វីដែលពិភពលោកបង្រៀនយើងឲ្យយើងចង់បាន » (« That We May Be One » *Ensign* **ខែ ឧសភា ឆ្នាំ ១៩៩៨ ទំព័រ ៦៧**) ។

សូមពន្យល់ថា នៅពេលយើងធ្វើជាសាក្សីដល់ឆន្ទៈរបស់យើងក្នុងការលើកដាក់នូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកលើខ្លួនយើង នោះយើងបានប្តេជ្ញាថានឹងរស់នៅជាសិស្សរបស់ទ្រង់ ។ យើងសន្យាថា យើងនឹងមិននាំមកនូវការអាប់ឱន ឬការរិះគន់មកដល់ព្រះនាមរបស់ទ្រង់ឡើយ ។ យើងប្តេជ្ញាថានឹងបម្រើដល់ទ្រង់ និងបងប្អូនរបស់យើង ។ យើងក៏បង្ហាញដែរថា យើងមានឆន្ទៈក្នុងការទទួលស្គាល់ជាមួយនឹងទ្រង់ និងសាសនាចក្ររបស់ទ្រង់ ។

- តើអ្នកធ្លាប់បានសាកល្បងបង្ហាញឆន្ទៈរបស់អ្នកក្នុងការលើកដាក់ព្រះនាមរបស់ព្រះអម្ចាស់មកលើខ្លួនអ្នកដែរឬទេ ? តើវាមានឥទ្ធិពលអ្វីខ្លះមកលើជីវិតរបស់អ្នក ?

សូមឲ្យសិស្សប្រៀបធៀបការអធិស្ឋានដល់នំបុ័ងនៅក្នុង មរ៉ូណៃ ៤:៣ ជាមួយនឹងការអធិស្ឋានដល់ស្រាទំពាំងបាយជូរនៅក្នុង មរ៉ូណៃ ៥:២ ។ សូមសួរពួកគេពីភាពខុសគ្នា និងភាពដូចគ្នាដែលពួកគេបានកត់សម្គាល់ ។ សូមបង្ហាញថា សេចក្តីសន្យាថានឹង « តែងតែចងចាំដល់ទ្រង់ជានិច្ច » លេចឡើងនៅក្នុងការអធិស្ឋានទាំងពីរ ។

- តើអ្នកគិតថាវាមានន័យយ៉ាងណាក្នុងការ « តែងតែចងចាំដល់ទ្រង់ជានិច្ច » នោះ ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សស្តាប់ និងរកនូវអ្វីដែលយើងអាចធ្វើបានដើម្បីជួយខ្លួនយើងឲ្យតែងតែចងចាំដល់ព្រះអង្គសង្គ្រោះជានិច្ច ។

« ជាបឋម យើងគួររៀបចំអ្វី ៗដែលអាចធ្វើទៅបានក្នុងការចងចាំដល់ទ្រង់ —ការអធិស្ឋានជាញឹកញាប់ និងការសិក្សាព្រះគម្ពីរ ការសិក្សាដោយផ្ចិតផ្ចង់ពីការបង្រៀនរបស់ពួកសាវក ការរៀបចំប្រចាំសប្តាហ៍ដើម្បីទទួលយកសាក្រាម៉ង់ដោយសាកសម ការថ្វាយបង្គំនៅថ្ងៃសប្ប៉ែ និងការកត់ត្រា និងចងចាំនូវអ្វីដែលព្រះវិញ្ញាណ និងបទពិសោធន៍ទាំងឡាយបង្រៀនយើងអំពីពួកសិស្ស ។

« រឿងផ្សេង ៗទៀតអាចចូលមកក្នុងគំនិតដែលសក្តិសមនឹងអ្នកជាពិសេសនៅក្នុងចំណុចនេះនៃជីវិតរបស់អ្នក ។ . . .

« . . . ខ្ញុំអាចអះអាងថា ពេលវេលាកន្លងទៅ បំណង និងសមត្ថភាពរបស់យើងក្នុងការចងចាំ និងធ្វើតាមព្រះអង្គសង្គ្រោះជានិច្ចនោះ នឹងរីកចម្រើនឡើង ។ យើងគួរអភិវឌ្ឍទៅដល់ទីបញ្ចប់នោះប្រកបដោយការអត់ធ្មត់ និងតែងតែអធិស្ឋានសុំការកាត់សេចក្តី និងជំនួយដ៏ទេវភាពដែលយើងត្រូវការ » (« To Always Remember Him » *Ensign* **ខែ មេសា ឆ្នាំ ២០១១ ទំព័រ ៥១**) ។

- តើអ្នកបានធ្វើអ្វីខ្លះដើម្បី « ចងចាំដល់ទ្រង់ជានិច្ច » ?
- តើការចងចាំដល់ព្រះអង្គសង្គ្រោះបានជួយយើងឲ្យរក្សាផ្នែកផ្សេងទៀតនៃសេចក្តីសញ្ញារបស់យើងដោយរបៀបណា ?
- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់សម្រាប់យើងដើម្បីទទួលយកពិធីសាក្រាម៉ង់រាល់សប្តាហ៍ ?

ដើម្បីបញ្ជាក់ពីសេចក្តីសន្យារបស់យើងក្នុងការកាន់តាមព្រះបញ្ញត្តិទាំងឡាយ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមពី *ដើម្បីកម្លាំងនៃយុវជន* ៖

« ព្រះវរបិតាសួគ៌បានប្រទានដល់អ្នកនូវសិទ្ធជ្រើសរើស សមត្ថភាពដើម្បីជ្រើសរើសត្រូវពីខុស និងដើម្បីអនុវត្តដោយខ្លួនអ្នកផ្ទាល់ ។សិទ្ធដើម្បីដឹកនាំជីវិតរបស់អ្នកគឺជាអំណោយមួយដ៏មហិមាក្នុងចំណោមអំណោយនានារបស់ព្រះដល់អ្នក បន្ទាប់ពីការប្រទាននូវជីវិត ។ខណៈដែលនៅលើផែនដីនេះ អ្នកគឺកំពុងតែបង្ហាញភស្តុតាងឲ្យឃើញថាប្រសិនបើអ្នកនឹងប្រើសិទ្ធជ្រើសរើសរបស់អ្នក ដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់អ្នកដល់ព្រះដោយការគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ » (*ដើម្បីកម្លាំងនៃយុវជន* | ឆ្នាំ ២០១១ | ទំព័រ ២) ។

- តើអ្នកធ្វើអ្វីខ្លះរាល់ថ្ងៃដើម្បីជួយខ្លួនអ្នកឲ្យកាន់តាមព្រះបញ្ញត្តិរបស់ព្រះ ?

ក្រោយពីសិស្សបានពិភាក្សាពីសេចក្តីសន្យាទាំងឡាយដែលយើងរំឭកវាតាមរយៈពិធីសាក្រាម៉ង់រាល់សប្តាហ៍នោះ សូមឲ្យពួកគេសរសេរវានៅលើកូឡោនទីបីនៃតារាងនូវរឿងមួយដែលពួកគេនឹងធ្វើ អំឡុងពេលសប្តាហ៍នេះដើម្បីកាន់តាមផ្នែកនីមួយៗនៃសេចក្តីសញ្ញាឲ្យបានកាន់តែប្រសើរ ។ សូមឲ្យពួកគេចែកចាយគំនិតរបស់គេខ្លះ (សូមប្រាកដថា ពួកគេយល់ថា ពួកគេមិនគួរចែកចាយអ្វីៗដែលឯកជន ឬផ្ទាល់ខ្លួនពេកនោះ) ។

សូមពន្យល់ថា នៅពេលយើងកាន់តាមសេចក្តីសញ្ញាដែលយើងបានធ្វើជាមួយនឹងព្រះអម្ចាស់ នោះទ្រង់សន្យាថានឹងប្រទានពរដល់យើង (សូមមើល គ. និង ស. ៨២:១០) ។ សូមឲ្យសិស្សសិក្សានៅក្នុង ម៉ូរ៉ូណៃ ៤:៣ និង ម៉ូរ៉ូណៃ ៥:២ ដោយរកមើលអ្វីដែលព្រះអម្ចាស់សន្យានឹងយើង ប្រសិនបើយើងកាន់តាមការសន្យាទាំងឡាយ ដែលយើងរំឭក នៅពេលយើងទទួលយកសាក្រាម៉ង់នោះ ។ សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនៅលើក្តារខៀន នៅក្រោមតារាងនេះ ៖ *នៅពេលយើងកាន់តាមសេចក្តីសញ្ញា សាក្រាម៉ង់ដោយស្មោះត្រង់ . . .* ។ សូមឲ្យសិស្សបំពេញប្រយោគនៅលើក្តារខៀនដោយផ្អែកលើអ្វីដែលពួកគេបានរៀនពី ម៉ូរ៉ូណៃ ៤:៣ និង ម៉ូរ៉ូណៃ ៥:២ ។ (របៀបមួយដើម្បីបំពេញប្រយោគនេះ អាចធ្វើដូចខាងក្រោម ៖ **នៅពេលយើងកាន់តាមសេចក្តីសញ្ញា សាក្រាម៉ង់ដោយស្មោះត្រង់ នោះយើងអាចមានព្រះវិញ្ញាណរបស់ព្រះអម្ចាស់គង់នៅជាមួយនឹងយើងជានិច្ច**) ។

- តើការសន្យាដែលថា ព្រះវិញ្ញាណតែងគង់នៅជាមួយនឹងយើងជានិច្ច មានតម្លៃសក្តិសមនឹងការខំប្រឹងប្រែងរបស់យើងក្នុងការកាន់តាមសេចក្តីសញ្ញានេះដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាវីឌ អេ បែដណា នៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សស្តាប់រកនូវអ្វីដែលព្រះវិញ្ញាណអាចធ្វើសម្រាប់យើង ។

« ព្រះវិញ្ញាណនៃព្រះអម្ចាស់អាចក្លាយជាណែនាំរបស់យើង ហើយប្រទានពរដល់យើងនូវការដឹកនាំ ការណែនាំ និងការការពារខាងវិញ្ញាណអំឡុងពេលដំណើរក្នុងជីវិតខាងសាច់ឈាមរបស់យើង » (« That We May Always Have His Spirit to Be with Us » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៦ ទំព័រ ៣១) ។

- តើនៅពេលណាដែលអ្នកបានទទួលនូវការដឹកនាំ ការប្រាប់ទិសដៅ ការណែនាំ ឬ ការការពារដោយសារតែភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធនោះ ? (បន្ថែមទៅលើការសុំសិស្សឲ្យចែកចាយនូវបទពិសោធន៍ អ្នកអាចចែកចាយនូវបទពិសោធន៍មួយពីជីវិតរបស់អ្នកផ្ទាល់បាន) ។
- រាល់សប្តាហ៍អំឡុងពេលសាក្រាម៉ង់ យើងមានឱកាសដើម្បីពិចារណាពីកម្រិតដែលយើងកាន់តាមសេចក្តីសញ្ញាបានល្អប៉ុណ្ណា ជាអ្វីដែលត្រូវបានរៀបរាប់នៅក្នុងការអធិស្ឋានសាក្រាម៉ង់ ។ តើការណ៍នេះអាចជួយយើងនៅក្នុងការខិតខំប្រឹងរបស់យើងក្នុងការតែងតែមានព្រះវិញ្ញាណគង់នៅជាមួយនឹងយើងដោយរបៀបណា ?
- នៅពេលអ្នកសញ្ជឹងគិតពីអ្វីដែលអ្នកបានរៀននៅថ្ងៃនេះ អំពីការទទួលយកពិធីសាក្រាម៉ង់ តើអ្វីដែលជាផ្នែកនៃការអធិស្ឋានសាក្រាម៉ង់ដែលមានន័យយ៉ាងពិសេសដល់អ្នក ? ហេតុអ្វី ?

សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ នៅពេលពួកគេទទួលយកសាក្រាម៉ង់ ។ សូមឲ្យពួកគេរំឭកពីតារាងរបស់ពួកគេ ហើយធ្វើតាមគំនិតរបស់គេក្នុងការរក្សានូវសេចក្តីសញ្ញានៃពិធីសាក្រាម៉ង់ឲ្យកាន់តែបានពេញលេញជាងនេះ ។ សូមរំឭកសិស្សពីសេចក្តីសន្យារបស់ព្រះអម្ចាស់ដល់យើង នៅពេលយើងរក្សានូវសេចក្តីសញ្ញានេះ ៖ យើងនឹងតែងតែមានព្រះវិញ្ញាណរបស់ទ្រង់គង់នៅជាមួយនឹងយើង ។ សូមថ្លែងទីបន្ទាល់អំពីពរជ័យនានាដែលនឹងមកដល់ក្នុងជីវិតរបស់យើង នៅពេលយើងចងចាំ និងកាន់តាមសេចក្តីសញ្ញាដែលយើងធ្វើរាល់សប្តាហ៍ នៅពេលយើងទទួលយកសាក្រាម៉ង់ ។

ការរំឭកចំណេះចំណានខគម្ពីរ

អ្នកអាចដាក់ថ្ងៃកំណត់មួយសម្រាប់ការប្រឡង ឬសកម្មភាពរំឭកចំណេះចំណានខគម្ពីរ ដើម្បីជួយសិស្សឲ្យចេះច្បាស់ពីវគ្គនៃខគម្ពីរជ្រើសរើសពីក្នុងព្រះគម្ពីរមរមន ។ សូមសម្រេចចិត្តពីរបៀបដែលអ្នកនឹងសាកល្បងចំណេះដឹងរបស់គេ ហើយគ្រោងធ្វើសកម្មភាពមួយដែលសមនឹងគោលបំណងនោះ ។ អ្នកអាចបង្កើតការប្រឡងផ្ទួផ្តួង ឬបំពេញចន្លោះដែលមានសេចក្តីយោង និង៣ក្យគន្លឹះ ឬដំណើរឿងណាមួយ ឬ អ្នកអាចឲ្យសិស្សល្បងពីការចេះចងចាំវគ្គមួយចំនួនថាតើគេចាំបានប៉ុណ្ណា ។ របៀបមួយទៀតដែលអាចធ្វើគឺត្រូវដាក់ឲ្យសិស្សម្នាក់ៗបង្រៀននូវមេរៀនខ្លីមួយ ឬផ្តល់នូវការនិយាយខ្លីមួយដោយប្រើវគ្គចំណេះចំណានខគម្ពីរជាប្រភពដ៏សំខាន់ ។ ទោះជាយ៉ាងណាក្តី អ្នកត្រូវសម្រេចដើម្បីបង្កើតនូវបទពិសោធន៍ជាមួយនឹងវគ្គចំណេះចំណានខគម្ពីរចុងបញ្ចប់ ដោយផ្តល់ពេលដល់សិស្សឲ្យសិក្សា និងរៀបចំជាមុន ។ ប្រវែងមេរៀនថ្ងៃនេះ អាចផ្តល់ពេលវេលាខ្លះឲ្យចាប់ផ្តើមការរៀបចំនេះ ។

មរ៉ូណៃ ៦

សេចក្តីផ្តើម

នៅពេលលោកមរ៉ូណៃបានរៀបចំបញ្ចប់ការសរសេររបស់លោកនៅលើផ្ទាំងចំណារហើយ លោកបានពន្យល់ពីការតម្រូវខ្លះៗចំពោះបុគ្គលនានាដើម្បីត្រូវបានជ្រមុជទឹកនៅក្នុងសាសនាចក្រ ។ បន្ទាប់មក លោកបានសង្ខេបអំពីការទទួលខុសត្រូវទាំងឡាយនៃសមាជិកសាសនាចក្រក្នុងការយកចិត្តទុកដាក់ដល់គ្នាទៅវិញទៅមក ។ លោកក៏បានពន្យល់ពីគោលបំណងនៃការប្រជុំរបស់សាសនាចក្រ និងបានបញ្ជាក់ពីតម្រូវការឲ្យមានការប្រជុំសាសនាចក្រដែលត្រូវបានដឹកនាំដោយឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។

យោបល់សម្រាប់ការបង្រៀន

មរ៉ូណៃ ៦:១–៣

លោកមរ៉ូណៃជាក់ចេញនូវតម្រូវការមុនពេលជ្រមុជទឹក

សូមឲ្យសិស្សស្រមៃថា ពួកគេមានបងប្អូនអាយុប្រាំពីរឆ្នាំ ដែលនឹងឈានចូលដល់អាយុប្រាំបីឆ្នាំក្នុងពេលពីរបីខែទៀត ។ សូមឲ្យពួកគេស្រមៃដងដែរថា ឪពុកម្តាយរបស់គេបានសុំឲ្យពួកគេបង្រៀនពីមេរៀនរាត្រីជួបជុំក្រុមគ្រួសារមួយអំពីរបៀបដើម្បីរៀបចំសម្រាប់ពិធីបុណ្យជ្រមុជទឹក ។ សូមឲ្យសិស្សពីរបីនាក់ប្រាប់ពីអ្វីដែលពួកគេនឹងបង្រៀន ដើម្បីជួយដល់ប្អូនរបស់គេរៀបចំដើម្បីជ្រមុជទឹក ។

សូមពន្យល់ថា មរ៉ូណៃ ៦ រួមមានការរៀបរាប់អំពីតម្រូវការសម្រាប់ពិធីបុណ្យជ្រមុជទឹក ។ សូមឲ្យសិស្សអាន មរ៉ូណៃ ៦:១–៣ ដោយស្ងាត់ស្ងៀមដោយរកមើលតម្រូវការសម្រាប់ពិធីបុណ្យជ្រមុជទឹក ។ បន្ទាប់មក សូមឲ្យសិស្សចែកចាយអ្វីដែលពួកគេបានរកឃើញ ។ សូមពិចារណាពីការសួរសំណួរខាងក្រោមនេះ ៖

- តើអ្នកគិតថា វាមានន័យយ៉ាងណាដែលថា អ្នកដែលចង់ជ្រមុជទឹកត្រូវនាំ « មកនូវលទ្ធផលដែលបង្ហាញឲ្យឃើញថា ពួកគេសមនឹងទទួល » ? (ពួកគេត្រូវរស់នៅដោយការគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ដោយបង្ហាញថា ពួកគេត្រៀមខ្លួនជាស្រេចដើម្បីធ្វើ និងរក្សាសេចក្តីសញ្ញានៃពិធីបុណ្យជ្រមុជទឹក)។
- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់សម្រាប់បុគ្គលម្នាក់ដើម្បីមាន « ចិត្តសង្រេង និង វិញ្ញាណទន់ទាប» មុនពេលជ្រមុជទឹក ? (អ្នកអាចពន្យល់ថាឃ្លា « ចិត្តសង្រេង និង វិញ្ញាណទន់ទាប » សំដៅលើការបន្ទាបខ្លួន និងឆន្ទៈរបស់បុគ្គលម្នាក់ក្នុងការប្រែចិត្ត និងគោរពតាមព្រះបញ្ញត្តិរបស់ព្រះអម្ចាស់)។

សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៦:៣ ឮៗហើយសូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលយើងធ្វើសេចក្តីសញ្ញាថានឹងធ្វើនៅពេលបុណ្យជ្រមុជទឹក ។ សិស្សគួរអាចឃើញនូវសេចក្តីពិតខាងក្រោមនេះ ៖ **តាមរយៈពិធីបុណ្យជ្រមុជទឹក យើងធ្វើសេចក្តីសញ្ញាថានឹងលើកដាក់មកលើខ្លួននូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ និងបម្រើទ្រង់ដល់ចុងបំផុត ។** (អ្នកអាចសុំឲ្យសិស្សរំឭកពីអ្វីដែលពួកគេបានរៀននៅក្នុងមេរៀនមុន អំពីអត្ថន័យនៃការលើកដាក់មកលើខ្លួនយើងនូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ)។

- ចេញពីបទពិសោធន៍របស់អ្នក ហេតុអ្វីបានជាបុគ្គលម្នាក់ដែលចង់ជ្រមុជទឹក ត្រូវប្តេជ្ញាចិត្តថានឹងបម្រើព្រះយេស៊ូវគ្រីស្ទដល់ចុងបំផុត ?
- តើអ្នកបានធ្វើអ្វីខ្លះដើម្បីរក្សា និងពង្រឹងការប្តេជ្ញាចិត្តរបស់អ្នកដើម្បីបម្រើដល់ព្រះអម្ចាស់ ?

មរ៉ូណៃ ៦:៤

លោកមរ៉ូណៃពន្យល់ពីរបៀបដើម្បីយកចិត្តទុកដាក់ និងជួយដល់សមាជិកសាសនាចក្រខាងវិញ្ញាណ

សូមប្រាប់សិស្សថា ក្រោយពីការរៀបរាប់ពីតម្រូវការមុនពេលជ្រមុជទឹករួចហើយ លោកមរ៉ូណៃបានពន្យល់ពីអ្វីដែលត្រូវធ្វើនៅក្នុងជំនាន់របស់លោកដើម្បីជួយដល់បុគ្គលដែលទើបបានជ្រមុជទឹកថ្មីៗឲ្យនៅបន្តស្មោះត្រង់ចំពោះសេចក្តីសញ្ញារបស់ពួកគេ ។ សូមឲ្យសិស្សអាន មរ៉ូណៃ ៦:៤ ដោយស្ងាត់ស្ងៀមដោយរកមើលអ្វីដែលសមាជិកសាសនាចក្របានធ្វើដើម្បីជួយដល់អ្នកប្រែចិត្តថ្មី ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន ។

សូមឲ្យសិស្សសង្ខេបអ្វីដែល មរ៉ូណៃ ៦:៤ បង្រៀនអំពីការទទួលខុសត្រូវរបស់យើងចំពោះសមាជិកផ្សេងទៀតនៃសាសនាចក្រជាពិសេសចំពោះសមាជិកថ្មី ។ (ឧទាហរណ៍ សិស្សអាចឆ្លើយដូចខាងក្រោម ៖ **យើងមានទំនួលខុសត្រូវមួយក្នុងការចងចាំដល់សមាជិកសាសនាចក្រផ្សេងទៀត និងជួយពួកគេខាងវិញ្ញាណដោយព្រះបន្ទូលព្រះ ។** ពួកគេក៏អាចនិយាយថា **យើងគួរជួយគ្នាទៅវិញទៅមកឲ្យប្រយ័ត្ន និងអធិស្ឋានជានិច្ច** ហើយថា **យើងគួរជួយគ្នាទៅវិញទៅមកឲ្យពឹងពាក់ទៅលើព្រះអង្គសង្គ្រោះ និងដង្វាយធួនរបស់ទ្រង់**)។

- តើយើងអាចបំពេញការទទួលខុសត្រូវក្នុងការចងចាំដល់គ្នាដោយរបៀបណា ?
- តើយើងជួយគ្នាដោយ « ព្រះបន្ទូលល្អរបស់ព្រះ » ដោយរបៀបណា ?
- តើពរជ័យអ្វីខ្លះដែលកើតចេញពីការទទួលបានជំនួយដោយព្រះបន្ទូលព្រះ ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដែហ្រ្វី អ៉រ ហូឡិន នៃក្វរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« មនុស្សភាគច្រើនមិនមកព្រះវិហារដោយគ្រាន់តែរកមើលការពិតនៃដំណឹងល្អពីបី ឬរកមើលមិត្តភក្តិចាស់ៗ ប៉ុណ្ណោះទេ ទោះបីជាទាំងអស់នេះសំខាន់ក្តី ។ ពួកគេមករកបទពិសោធន៍ខាងវិញ្ញាណ ។ ពួកគេចង់បានសេចក្តីសុខសាន្ត ។ ពួកគេចង់ឲ្យសេចក្តីជំនឿរបស់គេរឹងមាំ និងសេចក្តីសង្ឃឹមជាថ្មី ។ និយាយរួមទៅ ពួកគេចង់បានជំនួយដោយព្រះបន្ទូលល្អនៃព្រះ ដើម្បីបានរឹងមាំដោយព្រះចេស្តានៃស្ថានសួគ៌ ។ ពួកយើងទាំងអស់គ្នាដែលត្រូវបានហៅឲ្យនិយាយ ឬបង្រៀន ឬដឹកនាំ មានកាតព្វកិច្ចមួយដើម្បីជួយផ្គត់ផ្គង់បានល្អបំផុតតាមដែលយើងអាចធ្វើទៅបាន » (« A Teacher Come from God » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៨ ទំព័រ ២៦) ។

សូមឲ្យសិស្សពិចារណាពីមនុស្សដែលខិតខំ ឬដែលបានខិតខំចងចាំ និងជួយដល់ពួកគេខាងវិញ្ញាណ ។ សូមសួរពួកគេថា តើពួកគេធ្លាប់គិត ពីឧទាហរណ៍ណាមួយអំពីនរណាម្នាក់ដែល បានអធិស្ឋានសម្រាប់ពួកគេ បានរៀបចំមេរៀនសម្រាប់ពួកគេ បានលើកទឹកចិត្តដល់ពួកគេនៅក្នុងសកម្មភាពរបស់ពួកគេនៅក្នុងសាសនាចក្រ និងបានជួយពួកគេឲ្យឆ្លងកាត់ឧបសគ្គដែលពួកគេបានជួបទេ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយពីពរជ័យដែលពួកគេមាន ដោយសារនរណាម្នាក់បានចងចាំដល់ពួកគេ និងជួយពួកគេដោយព្រះបន្ទូលព្រះ ។ អ្នកអាចពិចារណាក្នុងការឲ្យសិស្សមានពេលសរសេរសំបុត្រដើម្បីថ្លែងអំណរគុណដល់មនុស្សដែលខិតខំជួយដល់ពួកគេ ។

សូមឲ្យសិស្សគិតពីបុគ្គលជាក់លាក់ដែលព្រះអម្ចាស់អាចចង់ឲ្យពួកគេចងចាំ ឬជួយ ។ សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់អំពីអ្វីដែលពួកគេអាចធ្វើបានដើម្បីបំពេញទំនួលខុសត្រូវដែលពួកគេមានចំពោះសមាជិកផ្សេងទៀតនៃសាសនាចក្របានកាន់តែប្រសើរ ។ សូមលើកទឹកចិត្តពួកគេឲ្យយកចិត្តទុកដាក់ជាពិសេសដល់តម្រូវការរបស់សមាជិកថ្មី ។

មរ៉ូណៃ ៦:៥–៩

លោកមរ៉ូណៃរៀបរាប់ពីគោលបំណងនៃការប្រជុំក្នុងសាសនាចក្រ និងរបៀបដែលការប្រជុំនោះត្រូវធ្វើ

សូមឲ្យសិស្សស្រមៃថា ពួកគេម្នាក់ៗគឺជាឪពុករបស់យុវជន ឬយុវនារីម្នាក់ ដែលបាននិយាយកាលពីពីរបីសប្តាហ៍មុនថា គេមិនចង់ទៅព្រះវិហារ ដោយសារវាគ្មានន័យ និងគួរឲ្យធុញទ្រាន់ ។ សូមឲ្យសិស្សពិចារណាពីអ្វីដែលពួកគេនឹងនិយាយដើម្បីលើកទឹកចិត្តដល់យុវវ័យរួបនេះឲ្យទៅព្រះវិហារ និងរបៀបដែលពួកគេអាចជួយគេឲ្យយល់ពីមូលហេតុត្រឹមត្រូវក្នុងការចូលរួមក្នុងព្រះវិហារឲ្យបានទៀងទាត់ ។

សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនេះនៅលើក្តារខៀន ៖

ក្នុងនាមជាសមាជិកសាសនាចក្រ យើងត្រូវជួបប្រជុំគ្នាឲ្យបានញឹកញាប់ . . .

សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៦:៥–៦ ឲ្យ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរបៀបដើម្បីបំពេញប្រយោគនៅលើក្តារខៀន ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ សូមសរសេរចម្លើយរបស់គេនៅលើក្តារខៀន ។ ចម្លើយរបស់ពួកគេអាចរួមមានសេចក្តីពិតដូចខាងក្រោម ៖

ក្នុងនាមជាសមាជិកសាសនាចក្រ យើងត្រូវជួបប្រជុំគ្នាឲ្យបានញឹកញាប់ដើម្បីតមអាហារ និងអធិស្ឋាន ។

ក្នុងនាមជាសមាជិកសាសនាចក្រ យើងត្រូវជួបប្រជុំគ្នាឲ្យបានញឹកញាប់ដើម្បីពង្រឹងដល់គ្នាទៅវិញទៅមកខាងវិញ្ញាណ ។

ក្នុងនាមជាសមាជិកសាសនាចក្រ យើងត្រូវជួបប្រជុំគ្នាឲ្យបានញឹកញាប់ដើម្បីទទួលយកសាក្រាម៉ង់ដើម្បីចងចាំដល់ព្រះយេស៊ូវគ្រីស្ទ ។

អែលឌើរ ដាល្លិន អេច អូក នៃក្វរ៉ុមនៃពួកសាវកដប់ពីរនាក់ បានចែកចាយផ្នែកមួយនៃសំបុត្រមួយច្បាប់ពីមិត្តម្នាក់ ដែលបានរៀនពីរបៀបដើម្បីរកបានសេចក្តីអំណរក្នុងការចូលរួមក្នុងព្រះវិហារ ៖

« ជាច្រើនឆ្នាំកន្លងទៅ ខ្ញុំបានផ្លាស់ប្តូរឥរិយាបថរបស់ខ្ញុំអំពីការទៅព្រះវិហារ ។ ខ្ញុំលែងទៅព្រះវិហារដើម្បីខ្លួនខ្ញុំទៀតហើយ ប៉ុន្តែដើម្បីគិតដល់អ្នកដទៃ ។ ខ្ញុំបាននិយាយសូស្តីដល់មនុស្សដែលអង្គុយម្នាក់ឯង ស្វាគមន៍អ្នកមកចូលរួម . . . ស្មគ្រ័ចិត្តចំពោះការហៅបម្រើ ។ . . .

« សរុបទៅ ខ្ញុំទៅព្រះវិហាររាល់សប្តាហ៍ដោយមានបំណងចង់សកម្ម ឬមិនមែនអសកម្ម ហើយធ្វើឲ្យមានភាពខុសគ្នាជាវិជ្ជមានដល់ជីវិតរបស់មនុស្សផ្សេងទៀត ។ ជាលទ្ធផល ការចូលរួមក្នុងការប្រជុំនៃព្រះវិហាររបស់ខ្ញុំវារីករាយ និងពេញលេញយ៉ាងខ្លាំងជាងមុន » (បានដកស្រង់នៅក្នុង « Unselfish Service » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០០៩ ទំព័រ ៩៦) ។

នៅពេលអ្នកគិតអំពីតម្រូវការរបស់អ្នកនៅក្នុងថ្នាក់របស់អ្នក សូមគិតពីសូរសំណួរនេះខ្លះ ឬទាំងអស់ដើម្បីជួយពួកគេឲ្យវិភាគ និងអនុវត្តនូវគោលការណ៍ដែលពួកគេបានរកឃើញពី មរ៉ូណៃ ៦:៥–៦ ៖

- តើបទពិសោធន៍អ្វីខ្លះដែលបានបង្រៀនដល់អ្នកពីសារៈសំខាន់នៃការអធិស្ឋាន និងការតមអាហារជាមួយនឹងសមាជិកក្នុងវួដ ឬសាខារបស់អ្នក ?
- តើអ្នកគិតថា វាមានន័យយ៉ាងណាដែលថា យើងត្រូវ « ពិគ្រោះគ្នាទៅវិញទៅមកអំពីសុខុមាលភាពដល់ព្រលឹង [របស់យើង] » ? (មរ៉ូណៃ ៦:៥) ។តើយើងធ្វើការណ៍នៅក្នុងព្រះវិហារដោយរបៀបណា ?
- តើបទពិសោធន៍របស់យើងនៅឯសាសនាចក្រអាចមានឥទ្ធិពលបែបណា ប្រសិនបើយើងចូលរួមដោយមានបំណងចង់ពង្រឹងដល់អ្នកដទៃខាងវិញ្ញាណនោះ ?

- តើមានរឿងអ្វីខ្លះដែលយើងអាចចងចាំអំពីព្រះអង្គសង្គ្រោះ នៅពេលយើងទទួលយកសាក្រាម៉ង់ ? តើការទទួលយកពិធីសាក្រាម៉ង់អាចជួយយើងឲ្យចងចាំដល់ទ្រង់ពេញមួយសប្តាហ៍ដោយរបៀបណា ?
- តើការទៅព្រះវិហារដោយមានគោលបំណង ដូចដែលយើងបានពិភាក្សានេះ អាចជួយ « រក្សា [យើង] ឲ្យនៅក្នុងផ្លូវត្រូវ » ដោយរបៀបណា ? (ម៉ូរ៉ូណៃ ៦:៤) ។តើអ្នកអាចធ្វើអ្វីខ្លះដើម្បីលើកទឹកចិត្តដល់យុវជនដទៃទៀតឲ្យចូលរួមក្នុងការប្រជុំសាសនាចក្រ ?

សូមអានឮៗសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ៖

« គ្មានកន្លែងណានៅក្នុងសិរីយ៉ូនសម្រាប់អ្នកមានអំពើបាបដោយចេតនានោះទេ ។ មានតែកន្លែងសម្រាប់អ្នកមានអំពើបាបដែលបានប្រែចិត្ត សម្រាប់អ្នកដែលបែរចេញពីអំពើទុច្ចរិត ហើយស្វែងរកជីវិតដ៏អស់កល្បជានិច្ច និងពន្លឺនៃដំណឹងល្អ » (Conference Report ខែ មេសា ឆ្នាំ ១៩១៥ ទំព័រ ១២០) ។

បន្ទាប់មក សូមឲ្យសិស្សអាន ម៉ូរ៉ូណៃ ៦:៧–៨ ដោយស្វាត់ស្ងៀមដោយរកមើលអ្វីដែលអ្នកដឹកនាំសាសនាចក្រនៅក្នុងជំនាន់របស់ម៉ូរ៉ូណៃត្រូវ « គោរពយ៉ាងតឹងរ៉ឹង » ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរៀន ។ អ្នកអាចពន្យល់ថា នៅក្នុងខគម្ពីរនេះឃ្លា « លុបចេញ » មានន័យថា ការផ្តាច់ទំនាក់ទំនង ។ ប្រសិនបើសមាជិកនៃសាសនាចក្រប្រព្រឹត្តអំពើបាបដ៏ធ្ងន់ធ្ងរ ហើយមិនប្រែចិត្តទេ ពួកគេអាចត្រូវលុបចេញ ឬបាត់បង់សមាជិកភាពរបស់គេនៅក្នុងសាសនាចក្រ និងពរជ័យទាំងឡាយនៃសេចក្តីសញ្ញារបស់ពួកគេ ។

- តើមានរឿងអ្វីខ្លះដែលអ្នកដឹកនាំសាសនាចក្រនាពេលសព្វថ្ងៃនេះធ្វើដើម្បីជួយដល់យើងចៀសផុតពីអំពើទុច្ចរិត ?
- យោងតាម ម៉ូរ៉ូណៃ ៦:៨ តើសេចក្តីសន្យាអ្វីដែលត្រូវបានប្រទានដល់យើង ប្រសិនបើយើងប្រែចិត្តពីអំពើបាបរបស់យើងដោយស្មោះសនោះ ? (**យើងប្រែចិត្ត និងស្វែងរកការអភ័យទោសឲ្យបានញឹកញាប់ដោយមានបំណងពិតប្រាកដ នោះយើងនឹងត្រូវបានអភ័យទោសឲ្យ**) ។

សូមឲ្យសិស្សពិចារណាពីឱកាសដែលពួកគេមានដើម្បីមានអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធ អំឡុងពេលការប្រជុំជាប្រចាំក្នុងសាសនាចក្រនៅថ្ងៃអាទិត្យ (ឧទាហរណ៍ អំឡុងពេលការអធិស្ឋាន អំឡុងពេលសាក្រាម៉ង់ ពេលសមាជិកនិយាយ ឬបង្រៀន ពេលច្រៀងទំនុកតម្កើង ឬពេលសញ្ជឹងគិតពីព្រះគម្ពីរ អំឡុងពេលបង្រៀន) ។ សូមឲ្យសិស្សម្នាក់អាន ម៉ូរ៉ូណៃ ៦:៩ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលតួនាទីអ្វីដែលព្រះវិញ្ញាណបរិសុទ្ធគួរមាននៅក្នុងការប្រជុំទាំងឡាយ ។

- តើសេចក្តីពិតអ្វីដែលយើងរៀនពី ម៉ូរ៉ូណៃ ៦:៩ អំពីរបៀបដែលការប្រជុំសាសនាចក្រគួរប្រព្រឹត្ត ? (**ការប្រជុំសាសនាចក្រត្រូវធ្វើឡើងដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ**) ។
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ការប្រជុំសាសនាចក្រត្រូវបានដឹកនាំដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ?

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលការពិតនេះអនុវត្តដល់គ្រប់ផ្នែកទាំងឡាយនៃការប្រជុំក្នុងសាសនាចក្រ សូមឲ្យពួកគេស្រមៃថាខ្លួនគេនៅក្នុងតំណែងរបស់បុគ្គលនៅក្នុងស្ថានភាពដូចខាងក្រោមនេះ ។ (អ្នកអាចចង់សរសេរស្ថានភាពទាំងនេះនៅលើក្តារខៀនមុនពេលបង្រៀន ឬរៀបចំវាជាក្រដាសចែក) ។ សូមឲ្យសិស្សពន្យល់ពីរបៀបដែលគោលការណ៍ដែលពួកគេបានរកឃើញនៅក្នុងម៉ូរ៉ូណៃ ៦:៩ នេះអាចត្រូវបានអនុវត្តនៅក្នុងស្ថានភាពនីមួយៗ ។

១. អ្នកធ្លាប់បានសុំឲ្យនិយាយនៅក្នុងការប្រជុំសាក្រាម៉ង់អំពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។

២. អ្នកធ្លាប់បានសុំឲ្យធ្វើការសម្តែងតន្ត្រីសម្រាប់ការប្រជុំសាក្រាម៉ង់នាពេលខាងមុខនេះ ។

៣. អ្នកកំពុងអង្គុយនៅក្នុងការប្រជុំសាក្រាម៉ង់ ហើយមានការបំផុសគំនិតឲ្យចែកចាយទីបន្ទាល់របស់អ្នក ប៉ុន្តែអ្នកមិនដឹងច្បាស់ថាត្រូវនិយាយអ្វី ។

សូមរំឭកសិស្សថា នៅក្នុងមេរៀននេះពីដំបូង អ្នកបានសុំឲ្យពួកគេគិតអំពីអ្វីដែលឪពុកម្តាយអាចនិយាយដើម្បីលើកទឹកចិត្តយុវជន ឬយុវនារីឲ្យចូលរួមក្នុងសាសនាចក្រ ។ ដើម្បីបញ្ចប់មេរៀននេះ សូមសួរសិស្សថា តើពួកគេបានគិតពីអ្វីដែលពួកគេអាចចែកចាយទេ ។ បន្ទាប់មក សូមចែកចាយទីបន្ទាល់របស់អ្នកអំពីពរជ័យនៃការចូលរួមក្នុងសាសនាចក្រ និងគោលការណ៍ផ្សេងទៀតដែលអ្នកបានពិភាក្សានៅថ្ងៃនេះ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

ម៉ូរ៉ូណៃ ៦:៤ ។ « លាងជម្រះដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ »

យើងទទួលបានអំណាចបន្សុទ្ធពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះតាមរយៈដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ (សូមមើលនីហ្វៃទី ៣ ២៧:១៩–២០, ម៉ូរ៉ូណៃ ៦:៤) ។ អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី នៃក្រុមនៃពួកសាវកដប់ពីរនាក់បានពន្យល់ ៖

« អំពើបាបមិនមែនត្រូវបានអតិនិនៅក្នុងទឹកនៃបុណ្យជ្រមុជទឹក ដូចដែលពេលយើងនិយាយដោយន័យបង្កប់ តែតាមពិតនៅពេលយើងទទួលបានព្រះវិញ្ញាណបរិសុទ្ធ ។ វាគឺជាព្រះវិញ្ញាណបរិសុទ្ធនៃព្រះដែលលុបចេញនូវការខុសឆ្គង និងនាំមកឲ្យយើងនូវសភាពនៃសេចក្តីសុចរិត ។ យើងបានលាងជម្រះ នៅពេលយើងពិតជាទទួលបានភាពជាមិត្ត និងភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ។ បន្ទាប់មក វាគឺជាអំពើបាប និងស្នាម និងអំពើអាក្រក់នោះ ដែលត្រូវបានដុតចេញពីព្រលឹងរបស់យើង ដូចជាភ្លើង ។ បុណ្យជ្រមុជទឹកជាព្រះវិញ្ញាណបរិសុទ្ធ គឺជាបុណ្យជ្រមុជទឹកដោយភ្លើង » (*A New Witness for the Articles of Faith* [ឆ្នាំ ១៩៨៥] ទំព័រ ២៩០ សូមមើលទំព័រ ២៣៩ ផងដែរ) ។

មរ៉ូណៃ ៧:១–១៩

សេចក្តីផ្តើម

លោកមរ៉ូណៃបានកត់ត្រាទេសនកថាដែលឪពុករបស់លោក លោកមរមន បានធ្វើជាច្រើនកន្លងទៅ ។ មេរៀននេះ រួមមានផ្នែកទីមួយនៃទេសនកថា ដែលលោកមរមនបានបង្រៀនអំពីការធ្វើកិច្ចការសុចរិតដោយមានបំណងដ៏ពិតប្រាកដ និងអំពីរបៀបដែលយើងអាចបែងចែករវាងការល្អ និងការអាក្រក់ ។ មេរៀនទី ១៥៦ ប្រាប់ពីទេសនកថាទាំងស្រុង ។

សូមធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធ

នៅពេលអ្នកសម្រេចចិត្តពីគោលការណ៍និងគោលលទ្ធិដែលត្រូវគូស បញ្ជាក់ សូមបន្តស្វែងរកការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធ ។

យោបល់សម្រាប់ការបង្រៀន

មរ៉ូណៃ ៧:១–១១

លោកមរមនបង្រៀនដល់អ្នកដើរតាមព្រះយេស៊ូវគ្រីស្ទឲ្យធ្វើកិច្ចការល្អដោយមានបំណងពិតប្រាកដ

សូមបង្ហាញផ្លែឈើមួយដែលបង្ហាញពីភាពល្អខាងក្រៅ ។

- តើអ្នកធ្លាប់រកឃើញផ្លែឈើមួយដែលមិនល្អខាងក្នុង ដូចជាអ្វីដែលមើលឃើញពីខាងក្រៅដែរទេ ? (សូមឲ្យសិស្សពីរបីនាក់ចែកចាយឧទាហរណ៍ ។ អ្នកក៏អាចភ្ជាប់ទៅនឹងបទពិសោធន៍ផ្ទាល់ខ្លួនដែរ) ។
- តើបុគ្គលម្នាក់អាចដូចជាផ្លែឈើមួយដែលមើលទៅល្អខាងក្រៅ ប៉ុន្តែរលួយខាងក្នុងដោយរបៀបណា ?

សូមពន្យល់ថា លោកមរ៉ូណៃបានកត់ត្រាពាក្យសម្តីរបស់ឪពុករបស់លោក លោកមរមន អំពីសារៈសំខាន់នៃការមាន ភាពសុចរិតនៅក្នុងចិត្តរបស់យើង ក៏ដូចជាការធ្វើកិច្ចការសុចរិតដែរ ។ សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៧:២–៣ ឮៗហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលដែលលោកមរមនបានសំដៅលើ ។ (លោកបានសំដៅលើសមាជិកនៃសាសនាចក្រ) ។

បន្ទាប់ពីសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរៀនហើយ សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៧:៤–៥ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់រកមើលតាមហើយកំណត់ពីរបៀបដែលលោកមរមនបានដឹងពីមនុស្សទាំងនេះថាជា « អ្នកដើរតាមព្រះគ្រីស្ទដោយសុខសាន្ត » (មរ៉ូណៃ ៧:៣) ។

សូមសរសេរឃ្លា *បំណងពិត* នៅលើក្តារខៀន ។

- តើអ្នកគិតថាឃ្លានេះមានអត្ថន័យយ៉ាងណា ?

នៅពេលសិស្សពិភាក្សាពីសំណួរនេះ អ្នកអាចសុំឲ្យពួកគេម្នាក់អានការពន្យល់ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« យើងមិនត្រឹមតែត្រូវ *ធ្វើ* អ្វីដែលត្រូវនោះទេ ។ យើងត្រូវចែមទាំងត្រូវធ្វើសកម្មភាពសម្រាប់មូលហេតុត្រឹមត្រូវផងដែរ ។ ពាក្យសម័យថ្មីគឺ *ការជម្រុញដែលល្អ* ។ ជាញឹកញាប់ ព្រះគម្ពីរបង្ហាញពីតរិយោបថខាងសតិដ៏សមរម្យដោយពាក្យ *បំណងដ៏ពេញលេញនៃដួងចិត្ត* ឬ *បំណងពិត* ។

« ព្រះគម្ពីរបញ្ជាក់យ៉ាងច្បាស់ថា ព្រះទ្រង់ជ្រាបពីការជម្រុញរបស់យើង ហើយនឹងកាត់សេចក្តីសកម្មភាពរបស់យើងដោយសមស្រប » (*Pure in Heart* | ឆ្នាំ ១៩៨៨ | ទំព័រ ១៥) ។

សូមឲ្យសិស្សស្រាវជ្រាវ មរ៉ូណៃ ៧:៦–១០ ដោយស្ងាត់ស្ងៀមដោយរកមើលការព្រមានរបស់ព្រះអម្ចាស់ដល់មនុស្សដែលធ្វើអំពើល្អដោយគ្មានបំណងពិត ។

- តើការព្រមានអ្វីខ្លះ ដែលព្រះអម្ចាស់បានប្រទានដល់អស់អ្នកដែលធ្វើកិច្ចការល្អដោយគ្មានបំណងពិតនោះ ? (ទ្រង់បានព្រមានថាកិច្ចការរបស់ពួកគេនឹងមិនបានប្រយោជន៍ដល់ពួកគេឡើយ ហើយថាកិច្ចការរបស់ពួកគេនឹងត្រូវរាប់ថាជាទុច្ចរិត ជាជាងសុចរិត) ។
- តើគោលការណ៍អ្វី ដែលយើងអាចរៀនអំពីខគម្ពីរទាំងនេះ ? (ខណៈពេលដែលសិស្សអាចលើកឡើងពីសេចក្តីពិតមួយចំនួន សូមជួយពួកគេឲ្យរកឃើញពីគោលការណ៍ខាងក្រោមនេះ ៖ **ដើម្បីត្រូវបានប្រទានពរចំពោះកិច្ចការល្អរបស់យើង យើងត្រូវតែធ្វើវាដោយមានបំណងពិត**) ។
- បន្ថែមលើពរជ័យដែលចង់បានពីព្រះអម្ចាស់ តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីធ្វើការល្អដោយមានបំណងពិត ?
- តើមានភាពខុសគ្នាអ្វីខ្លះដែលអ្នកបានកត់សម្គាល់ នៅពេលអ្នកបានធ្វើកិច្ចការល្អដោយមានបំណងសុចរិតនោះ ?

សូមបង្ហាញថា លោកមរមនបានលើកទឹកចិត្តយើងឲ្យអធិស្ឋានដោយស្មោះអស់ពីចិត្ត (សូមមើល មរ៉ូណៃ ៧:៩) ។ សូមឲ្យសិស្សម្នាក់អានការប្រឹក្សាខាងក្រោមពីប្រធាន ព្រិកហាំ យ៉ង់ ៖

« វាមិនសំខាន់ថា អ្នក ឬ ក៍ខ្ញុំមានអារម្មណ៍ថាចង់អធិស្ឋានឬក៏អត់នោះទេ នៅពេលការអធិស្ឋានមកដល់ចូរអធិស្ឋានចុះ ។ ប្រសិនបើយើងមិនមានអារម្មណ៍ថាចង់អធិស្ឋាន យើងត្រូវអធិស្ឋានរហូតដល់យើងចង់ធ្វើ » (*Teachings of Presidents of the Church: Brigham Young* | ឆ្នាំ ១៩៩៧ |. ទំព័រ ៤៥) ។

- តើការជ្រើសរើសដើម្បីអធិស្ឋាន ទោះបីជានៅពេលយើងមិនចង់ អាចជួយយើងឲ្យអធិស្ឋានដោយស្មោះអស់ពីចិត្តនៅចុងបញ្ចប់ដោយរបៀបណា ?

- តើការប្រឹក្សារបស់ប្រធាន ព្រិកហាំ យ៉ង់ អាចទាក់ទងទៅនឹងការគោរពតាមព្រះបញ្ញត្តិផ្សេងទៀតក្រៅពីការអធិស្ឋាន ដោយរបៀបណា ? (ប្រសិនបើសិស្សពិបាកនឹងឆ្លើយសំណួរនេះ សូមគិតពីការចែកចាយគំរូខាងក្រោម ៖ មនុស្សខ្លះអាចមិនចូលរួម សាសនាចក្រដោយអស់ពីចិត្តទេ ។ ទោះជាយ៉ាងណាក្តី ប្រសិនបើពួកគេបន្តមកព្រះវិហារ និងធ្វើអ្វីទាំងអស់ដែលពួកគេអាចធ្វើដើម្បីចូលរួម និងថ្វាយបង្គំ នោះពួកគេនឹងទទួលបានបទពិសោធន៍ដែលនឹងជួយពួកគេឲ្យរកឃើញសេចក្តីអំណរក្នុងការមកព្រះវិហារ ។ មូលហេតុមកព្រះវិហាររបស់គេនឹងផ្លាស់ប្តូរ ។ ពួកគេនឹងចូលរួម ដោយសារពួកគេចង់ទៅទីនោះ —ពួកគេចង់ថ្វាយបង្គំព្រះ រំពឹកសេចក្តីសញ្ញារបស់គេ និងបម្រើដល់អ្នកដទៃ) ។

ដើម្បីជួយសិស្សឲ្យអនុវត្តការបង្រៀនរបស់លោកមរមនក្នុងការធ្វើកិច្ចការល្អដោយស្មោះអស់ពីចិត្ត នោះសូមរៀបចំសកម្មភាពខាងក្រោមនេះមុនបង្រៀន ៖ សូមរៀបចំកាត់ក្រដាសបីបួនតូចៗ ។ នៅលើក្រដាសនីមួយៗ សូមសរសេរព្រះបញ្ញត្តិមួយ ។ ឧទាហរណ៍ដូចជាការតមអាហារ ការបង់ដង្វាយមួយភាគក្នុងដប់ ការបម្រើដល់អ្នកដទៃ ការសិក្សាបទគម្ពីរ ការគោរពដល់ឱពុកម្តាយ និងព្រះបញ្ញត្តិផ្សេងទៀតដែលអ្នកមានអារម្មណ៍ថា អាចជួយដល់សិស្សរបស់អ្នកពិភាក្សា ។ សូមដាក់ក្រដាសនោះនៅក្នុងប្រអប់មួយ ។

នៅក្នុងថ្នាក់ សូមឲ្យសិស្សម្នាក់មកខាងមុខថ្នាក់ ។ សូមឲ្យគាត់យកក្រដាសមួយពីប្រអប់នោះ ហើយអានវាដល់សិស្សក្នុងថ្នាក់ ។ បន្ទាប់មក សូមឲ្យសិស្សធ្វើតាមការណ៍ខាងក្រោមមួយ ឬក៏ទាំងពីរ ៖

១. សូមចែកចាយពីអារម្មណ៍ពេលពួកគេទទួលបានពរជ័យ នៅពេលពួកគេបានគោរពតាមព្រះបញ្ញត្តិដោយស្មោះអស់ពីចិត្ត ។

២. សូមជ្តល់យោបល់ក្នុងការគោរពតាមព្រះបញ្ញត្តិដោយស្មោះអស់ពីចិត្ត ។

អ្នកអាចធ្វើសកម្មភាពនេះពីរបីដង ។

ក្រោយពីធ្វើសកម្មភាពនេះហើយ សូមគិតពីការចែកចាយបទពិសោធន៍ដែលអ្នកបានមាន នៅពេលអ្នកបានគោរពតាមបទបញ្ញត្តិមួយរបស់ព្រះដោយស្មោះអស់ពីចិត្ត ។

មរ៉ូណៃ ៧:១២–១៩

លោកមរមនបង្រៀនពីរបៀបដើម្បីវិនិច្ឆ័យរវាងសេចក្តីល្អ និងសេចក្តីអាក្រក់

សូមពន្យល់ថា អេសាយបានព្យាករណ៍ថា នៅក្នុងថ្ងៃចុងក្រោយ មនុស្សខ្លះនឹងហៅសេចក្តីអាក្រក់ថាជាល្អ ហើយល្អថាជាអាក្រក់ (សូមមើល អេសាយ ៥:២០; នីហ្វៃទី ២ ១៥:២០) ។

- តើមានគំរូអ្វីខ្លះនៃមនុស្សដែលហៅសេចក្តីអាក្រក់ថាជាល្អ ហើយសេចក្តីល្អថាជាអាក្រក់ ?
- តើអ្នកគិតថា ហេតុអ្វីបានជាវាសំខាន់ដើម្បីកុំច្រឡំការល្អ ជាមួយនឹងការអាក្រក់ ?

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានព្ធៗពី មរ៉ូណៃ ៧:១២–១៧ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម និងរកមើលគោលការណ៍ដែលអាចជួយយើងឲ្យកាត់សេចក្តីល្អ ពីសេចក្តីអាក្រក់ ។ អ្នកអាចលើកទឹកចិត្តពួកគេឲ្យគូសចំណាំឃ្លាដែលមានន័យជាពិសេសដល់ពួកគេ ។ ដើម្បីជួយដល់សិស្សឲ្យរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញហើយ សូមសួរសំណួរខាងក្រោម ៖

- តើយើងអាចដឹងថា អ្វីមួយចេញពីព្រះដោយរបៀបណា ? (សូមប្រាកដថា សិស្សគួររកឃើញនូវសេចក្តីពិតខាងក្រោមនេះ ៖ **អ្វីដែលមកពីព្រះ អញ្ជើញឲ្យយើងធ្វើការល្អ ជឿដល់ព្រះយេស៊ូវគ្រីស្ទ និងសេចក្តីស្រឡាញ់ បម្រើដល់ព្រះ) ។**
- តើយើងអាចដឹងថា អ្វីមួយចេញពីសាតាំងដោយរបៀបណា ? (សូមប្រាកដថា សិស្សគួររកឃើញនូវសេចក្តីពិតខាងក្រោមនេះ ៖ **អ្វីៗដែលបញ្ចុះបញ្ចូលយើងឲ្យធ្វើអាក្រក់ បដិសេធព្រះយេស៊ូវគ្រីស្ទ ឬប្រឆាំងនឹងព្រះ ចេញមកពីសាតាំង) ។**
- តើមានរបៀបណាខ្លះដែលព្រះអញ្ជើញ និងទាក់ទាញយើងឲ្យធ្វើការល្អជានិច្ច ?
- តើសាតាំងហៅ និងអូសទាញយើងឲ្យធ្វើអំពើបាបដោយរបៀបណា ?

ដើម្បីរៀបចំសិស្សឲ្យអនុវត្តតាមការបង្រៀនរបស់លោកមរមនអំពីការកាត់សេចក្តីរវាងការល្អ និងការអាក្រក់ សូមឲ្យពួកគេសរសេរពីកម្មវិធីទូរទស្សន៍ដែលពួកគេចូលចិត្ត រឿង ចម្រៀង ក្រុមតន្ត្រី ទំព័រអិនធើណិត កម្មវិធីទូរស័ព្ទ ល្បែងវីដេអូ ឬរបស់ផ្ទាល់ខ្លួននានា ។ (អ្នកអាចបញ្ជាក់បញ្ជីនេះដោយយោងតាមតម្រូវការ និងចំណាប់អារម្មណ៍របស់សិស្ស) ។ ក្រោយពីសិស្សបានមានពេលសរសេរគ្រប់គ្រាន់ហើយ សូមឲ្យពួកគេទុកវាមួយអន្លើសិន ។ សូមប្រាប់ពួកគេថា ពួកគេនឹងមានឱកាសមួយដើម្បីគិតថែមទៀតអំពីបញ្ជីរបស់គេក្នុងពេលពីរបីនាទីទៀត ។

- យោងតាម មរ៉ូណៃ ៧:១៦ តើអ្វីដែលត្រូវបានជ្តល់មនុស្សគ្រប់គ្នាដើម្បីជួយយើងឲ្យស្គាល់ល្អ ចេញពីអាក្រក់ ?

សូមពន្យល់ថា ព្រះវិញ្ញាណនៃព្រះគ្រីស្ទក៏ត្រូវបានហៅថាជាពន្លឺនៃព្រះគ្រីស្ទដែរ (សូមមើល មរ៉ូណៃ ៧:១៨) ។ ដើម្បីជួយសិស្សឲ្យយល់ពីពន្លឺនៃព្រះគ្រីស្ទ សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ប៊ិយដ៏ យេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖

« ព្រះវិញ្ញាណបរិសុទ្ធ និងពន្លឺនៃព្រះគ្រីស្ទខុសពីគ្នា ។ . . .

« ដោយមិនគិតពីពន្លឺខាងក្រោមនេះ ចំណេះដឹងនៃការត្រូវ និងខុសនេះ ត្រូវបានហៅថាជាពន្លឺនៃព្រះគ្រីស្ទ ន័យខាងសីលធម៌ ឬសតិសម្បជញ្ញៈ វាអាចដឹកនាំយើងទៅរកការចេះប្រមាណដល់សកម្មភាពរបស់យើង —រហូតដល់យើងកាត់បន្ថយ ឬបំបាត់វាបាន ។ . . .

« បុរស ស្ត្រី និងកុមាររាល់រូបក្នុងគ្រប់ជាតិសាសន៍ ជំនឿ ឬពណ៌សម្បុរ —គ្រប់គ្នាមិនថាកន្លែងណាដែលពួកគេរស់នៅ ឬអ្វីដែលពួកគេជឿ ឬអ្វីដែលពួកគេធ្វើ —មាននៅក្នុងខ្លួនគេនូវពន្លឺនៃព្រះគ្រីស្ទដែលមិនអាចត្រូវបំផ្លាញបាន » (« The Light of Christ » *Ensign,* ខែ មេសា ឆ្នាំ ២០០៥, ទំព័រ ៨–១០) ។

- តើបុគ្គលម្នាក់អាចកាត់បន្ថយ ឬបំបាត់ពន្លឺនៃព្រះគ្រីស្ទដែលមាននៅក្នុងខ្លួនគេដោយរបៀបណា ?

សូមឲ្យសិស្សអាន ម៉ូរ៉ូណៃ ៧:១៨–១៩ ដោយស្ងាត់ស្ងៀម និងរកមើលការប្រឹក្សារបស់លោកមរមនអំពីរបៀបដើម្បីឆ្លើយតបទៅនឹងពន្លឺនៃព្រះគ្រីស្ទដែលមាននៅក្នុងខ្លួនយើង ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរៀន ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាក្នុងការ « ព្យាយាមស្វែងរកនៅក្នុងពន្លឺនៃព្រះគ្រីស្ទ » ?
- តើគោលការណ៍អ្វីដែលយើងអាចរៀនពី ម៉ូរ៉ូណៃ ៧:១៩ ? (ចម្លើយរបស់សិស្សគួរតែរកឃើញនូវគោលការណ៍ដូចខាងក្រោមនេះ ៖ **នៅពេលយើងព្យាយាមស្វែងរកនៅក្នុងពន្លឺនៃព្រះគ្រីស្ទ យើងអាចបែងចែករវាងល្អ និងអាក្រក់បាន ។ ប្រសិនបើយើងភ្ជាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ យើងនឹងក្លាយជាកូនរបស់ព្រះគ្រីស្ទ ។** ប្រសិនបើសិស្សត្រូវការជំនួយដើម្បីយល់ពីឃ្លា « កូនរបស់ព្រះគ្រីស្ទ » អ្នកអាចបើកទៅមើលមេរៀនទី ៥៥ នៅក្នុងសៀវភៅណែនាំសិក្សានេះ) ។
- តើនៅពេលណាដែលអ្នកបានស្វែងចង់ដឹងថា តើអ្វីមួយល្អ ឬសមរម្យនោះ ? តើអ្នកបានធ្វើអ្វីខ្លះដើម្បី « ព្យាយាមស្វែងរក » ដើម្បីដឹងថាតើវាជាការណ៍ល្អ ឬសមរម្យឬអត់នោះ ?

សូមឲ្យសិស្សបើកទៅបញ្ជីដែលពួកគេបានសរសេរមុននេះ ។ សូមបង្ហាញ ឬអានឮៗនូវសំណួរខាងក្រោមនេះ ហើយសូមឲ្យសិស្ស « ព្យាយាមស្វែងរកនៅក្នុងពន្លឺនៃព្រះគ្រីស្ទ » (ម៉ូរ៉ូណៃ ៧:១៩) នៅពេលពួកគេកត់ត្រាចម្លើយរបស់គេចំពោះសំណួរទាំងនេះ ។ សូមកុំបង្ខំក្នុងការធ្វើសកម្មភាពនេះ ។ សូមឲ្យសិស្សមានពេលគ្រប់គ្រាន់ដើម្បីសញ្ជឹងគិត និងសរសេរ ។ សូមប្រាប់សិស្សថា អ្នកនឹងមិនសុំឲ្យពួកគេចែកចាយចម្លើយរបស់គេទេ ។

- តើរឿងទាំងនេះអញ្ជើញអ្នកឲ្យធ្វើល្អ ជឿលើព្រះយេស៊ូវគ្រីស្ទ និងស្រឡាញ់ព្រះ និងបម្រើដល់ទ្រង់បានល្អប៉ុណ្ណា ?
- តើរឿងទាំងនេះណាខ្លះដែលព្យាយាមបញ្ចុះបញ្ចូលអ្នកឲ្យធ្វើអាក្រក់ សង្ស័យលើព្រះយេស៊ូវគ្រីស្ទ ឬឈប់បម្រើដល់ព្រះនោះ ?
- តើអ្នកមានអារម្មណ៍ថា អ្នកគួរលុបចោលរឿងទាំងនេះខ្លះៗចេញពីជីវិតរបស់អ្នកទេ ? បើដូច្នោះ តើអ្នកនឹងធ្វើវាដោយរបៀបណា ?

សូមបង្ហាញថា ពេលខ្លះវាអាចពិបាកដើម្បីធ្វើអ្វីដែលយើងដឹងថាត្រឹមត្រូវ នៅពេលវាតម្រូវឲ្យលះបង់អ្វីដែលយើងចូលចិត្ត ។ ដើម្បីជួយសិស្សឲ្យគាំទ្រដល់គ្នាទៅវិញទៅមកក្នុងការខិតខំនេះ សូមសួរ ៖

- តើដំបូន្មានអ្វីដែលអ្នកនឹងផ្តល់ ដើម្បីជួយដល់នរណាម្នាក់ឲ្យលះបង់អ្វីដែលមិនល្អ ឬសមរម្យ ?

ដើម្បីបញ្ចប់ សូមបញ្ជាក់ថា នៅពេលយើងធ្វើតាមពន្លឺនៃព្រះគ្រីស្ទ នោះយើងអាចស្គាល់ថា អ្វីដែលល្អ ចៀសវាងការចោកបញ្ឆោតរបស់សាតាំង និងរស់នៅជាអ្នកដើរតាមរបស់ព្រះយេស៊ូវគ្រីស្ទ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

ម៉ូរ៉ូណៃ ៧:១៧ ។ អារក្សមិនបញ្ចុះបញ្ចូលឲ្យយើងធ្វើល្អទេ

អែលឌើរ ដែហ្ក្រី អ័រ ហូឡិន នៃក្រុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖

« សាតាំង ឬក៏លូស៊ីហ្វើរ ឬក៏បិតានៃសេចក្តីកុហក —ហៅវាតាមរបៀបដែលអ្នកចង់— វាមានពិត វាជាបុគ្គលដ៏អាក្រក់បំផុត ។ ការជម្រុញរបស់វាគឺគួរឲ្យស្អប់ ទោះនៅក្នុងករណីណាក៏ដោយ ។ . . . វាប្រឆាំងនឹងសេចក្តីស្រឡាញ់នៃព្រះ ជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និង កិច្ចការនៃសេចក្តីសុខសាន្ត ព្រមទាំងសេចក្តីសង្គ្រោះអស់កល្បជានិច្ច ។ វាប្រឆាំងនឹងការណ៍ទាំងនេះនៅគ្រប់ពេលដែលវាអាច ។ វាដឹងថា វានឹងត្រូវចាញ់ ហើយបណ្តេញចេញនៅទីបញ្ចប់ ប៉ុន្តែវាបានប្តេជ្ញាថានឹងនាំមនុស្សឲ្យដើរតាមវាឲ្យបានកាន់តែច្រើនតាមដៃលវាអាចធ្វើបាន » (« We Are All Enlisted » *Ensign* ឬ *លីអាហូណា*, ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ៤៤) ។

មេរៀនសិក្សានៅផ្ទះ

អេធើរ ១៣–ម៉ូរ៉ូណៃ ៧:១៩ (មេរៀនទី ៣១)

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេសិក្សា អេធើរ ១៣–ម៉ូរ៉ូណៃ ៧:១៩ (មេរៀនទី ៣១) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (អេធើរ ១៣–១៥)

ពួកសាសន៍យ៉ារ៉ែឌបានបដិសេធព្យាការី អេធើរ និងបានរឹងទទឹងក្នុងអំពើទុច្ចរិត និងសង្គ្រាម រហូតដល់នៅទីបំផុតពួកគេបានបំផ្លាញគ្នាទៅវិញទៅមក ។ ចេញពីដំណើររឿងនេះ សិស្សបានរៀនថា ប្រសិនបើយើងបដិសេធការព្រមានរបស់ព្រះអម្ចាស់ក្នុងការប្រែចិត្ត នោះព្រះវិញ្ញាណរបស់ទ្រង់នឹងដកចេញ ហើយសាតាំងនឹងទទួលបានអំណាចលើដួងចិត្តរបស់យើង ។ សិស្សក៏អាចឃើញថា កំហឹង និងការសងសឹកនឹងដឹកនាំយើងឲ្យសម្រេចចិត្តដែលនឹងធ្វើឲ្យខ្លួនយើង និងអ្នកដទៃឈឺចាប់ ។ នៅក្នុងដំណើររឿងរបស់លោកអំពីសេចក្តីបំផ្លិចបំផ្លាញនៃសាសន៍យ៉ារ៉ែឌ លោកម៉ូរ៉ូណៃបានផ្តល់នូវសេចក្តីសង្ឃឹមដល់អ្នកអានរបស់លោកដោយប្រកាសថា ទីក្រុងយេរូសាឡិមថ្មី ឬក៏ទីក្រុងសីយ៉ូន នឹងត្រូវបានកសាងឡើងនៅក្នុងថ្ងៃចុងក្រោយ ។

ថ្ងៃទី ២ (ម៉ូរ៉ូណៃ ១–៥)

ខណៈពេលដែលលោកម៉ូរ៉ូណៃបានដើរស្វែងរកសុវត្ថិភាពដល់ជីវិតរបស់លោក លោកបានកត់ត្រានូវព័ត៌មានជាច្រើនអំពីបព្វជិតភាព និងពិធីបរិសុទ្ធនៃដំណឹងល្អ ។ លោកបានសរសេរថា ការផ្តល់នូវអំណោយទានព្រះវិញ្ញាណបរិសុទ្ធ និងការតែងតាំងថ្នាក់បព្វជិតភាពត្រូវតែធ្វើដោយការដាក់ដៃលើក្បាលដោយអ្នកមានសិទ្ធិអំណាចនោះ ។ ការយកចិត្តទុកដាក់របស់លោកម៉ូរ៉ូណៃចំពោះពិធីសាក្រាម៉ង់បានផ្តល់ឱកាសដល់សិស្សដើម្បីសញ្ជឹងគិតដល់របៀបដែលនំប៉័ង និងទឹកនៃពិធីសាក្រាម៉ង់អាចជួយពួកគេឲ្យចងចាំដល់ជង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ពួកគេក៏ត្រូវបានរំឭកថា នៅពេលពួកគេកាន់តាមសេចក្តីសញ្ញាទាក់ទងនឹងពិធីសាក្រាម៉ង់ដោយស្មោះត្រង់ នោះពួកគេអាចមានព្រះវិញ្ញាណរបស់ព្រះអម្ចាស់គង់នៅជាមួយនឹងពួកគេជានិច្ច ។

ថ្ងៃទី ៣ (ម៉ូរ៉ូណៃ ៦)

លោកម៉ូរ៉ូណៃបានបញ្ជាក់ពីសារៈសំខាន់នៃបុណ្យជ្រមុជទឹក សមាជិកភាពក្នុងសាសនាចក្រ និងការដឹកនាំការប្រជុំសាសនាចក្រតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ សិស្សបានរៀនថា តាមរយៈពិធីបុណ្យជ្រមុជទឹក យើងធ្វើសេចក្តីសញ្ញាថានឹងលើកដាក់មកលើខ្លួននូវព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ និងបម្រើទ្រង់ដល់ចុងបំផុត ។ ពួកគេក៏បានរៀនអំពីការទទួលខុសត្រូវដែលពួកគេមានដើម្បីជួយដល់សមាជិកសាសនាចក្រផ្សេងទៀត ជាពិសេសដោយការជួបពិគ្រោះគ្នាញឹកញាប់ដើម្បីតមអាហារ និងអធិស្ឋាន និងទទួលយកសក្រាម៉ង់ដើម្បីចងចាំដល់ព្រះយេស៊ូវគ្រីស្ទ ។ បន្ថែមលើនេះ សិស្សបានរៀនថា នៅពេលយើងប្រែចិត្ត និងស្វែងរកការអភ័យទោសឲ្យបានញឹកញាប់ដោយមានបំណងពិតប្រាកដ នោះយើងនឹងត្រូវបានអភ័យទោសឲ្យ ។

ថ្ងៃទី ៤ (ម៉ូរ៉ូណៃ ៧:១–១៩) ។

លោកម៉ូរ៉ូណៃបានកត់ត្រានូវពាក្យសំដីដែលត្រូវបាននិយាយដោយឪពុករបស់លោក ដែលបានបង្រៀនថា ដើម្បីទទួលបានពរជ័យចំពោះកិច្ចការល្អរបស់យើង យើងត្រូវតែធ្វើកិច្ចការទាំងនោះដោយមានចិត្តស្មោះត្រង់ ។ នៅក្នុងការបង្រៀននេះ លោកមរមនក៏បានបង្រៀនពីរបៀបដែលយើងអាចធ្វើការកាត់សេចក្តីដោយសុចរិតដែរ ។ សិស្សបានរកឃើញថា អ្វីមកពីព្រះ នោះវានឹងអញ្ជើញយើងឲ្យធ្វើល្អ ហើយស្រឡាញ់ និងបម្រើដល់ព្រះ ហើយអ្វីដែលបញ្ចុះបញ្ចូលយើងឲ្យធ្វើអាក្រក់ និងប្រឆាំងផ្ទុយនឹងព្រះ វាចេញមកពីសាតាំង ។ លោកមរមនបានអង្វរដល់អ្នកស្តាប់របស់លោកឲ្យព្យាយាមស្វែងរកនៅក្នុងពន្លឺនៃព្រះគ្រីស្ទ ដែលនឹងផ្តល់ដល់ពួកគេនូវអំណាចដើម្បីបែងចែករវាងការល្អ និងការអាក្រក់ ។

សេចក្តីផ្តើម

នៅក្នុងមេរៀនថ្ងៃនេះ វាផ្តោតលើមូលហេតុ និងតម្រូវការចំពោះយើងម្នាក់ៗដើម្បីចូលរួមក្នុងការប្រជុំសាសនាចក្រ ។ វាក៏លើកទឹកចិត្តសិស្សឲ្យប្តេជ្ញាចិត្តបែងចែករវាងការល្អ និងអាក្រក់ ហើយព្យាយាមស្វែងរកនៅក្នុងពន្លឺនៃព្រះគ្រីស្ទដើម្បីធ្វើការកាត់សេចក្តីដោយសុចរិត ។

យោបល់សម្រាប់ការបង្រៀន

អេធើរ ១៤–១៥

លោកម៉ូរ៉ូណៃកត់ត្រានូវទីបញ្ចប់នៃអរិយធម៌របស់ពួកសាសន៍យ៉ារ៉ែឌ

សូមសរសេរ *២,០០០,០០០* នៅលើក្តារខៀន ។ សូមឲ្យសិស្សស្រមៃថា មនុស្សច្រើនប៉ុណ្ណាទៅបើមានចំនួនពីរលាននាក់ត្រូវបានប្រៀបធៀបទៅនឹងចំនួនមនុស្សដែលរស់នៅក្នុងទីក្រុងរបស់ពួកគេ ។ សូមឲ្យសិស្សម្នាក់អាន អេធើរ ១៥:១–២ ឮៗ នៅពេលសិស្សរំឭកអ្វីដែលបានកើតឡើងដល់ពួកសាសន៍យ៉ារ៉ែឌពីរលាននាក់នោះ ។

សូមសួរ ប្រសិនបើសិស្សណាម្នាក់អាចសង្ខេបហេតុការណ៍ដែលបានដឹកនាំទៅរកសេចក្តីបំផ្លិចបំផ្លាញនៃពួកសាសន៍យ៉ារ៉ែឌ ដូចដែលបានកត់ត្រានៅក្នុង អេធើរ ១៤–១៥ ។ ប្រសិនបើសិស្សមានការលំបាកក្នុងការឆ្លើយ សូមឲ្យពួកគេរំឭកនូវគ្នាព្រះគម្ពីរខាងក្រោមនេះ ៖ អេធើរ ១៤:៥–១០, ២៤; ១៥:១–៦, ១៩, ២២ ។

សូមសួរ ៖ តើមានមេរៀនណាខ្លះ ដែលយើងអាចរៀនពីសេចក្តីបំផ្លិចបំផ្លាញនៃពួកសាសន៍យ៉ារ៉ែឌ ?

សេចក្តីពិតទាំងពីរនេះត្រូវបានបញ្ជាក់នៅក្នុងមេរៀនរបស់សិស្សនៅសប្តាហ៍នេះ ៖ (១) **ប្រសិនបើយើងបដិសេធនូវការព្រមានរបស់ព្រះអម្ចាស់ក្នុងការឲ្យប្រែចិត្ត នោះព្រះវិញ្ញាណរបស់ទ្រង់នឹងដកថយ ហើយសាតាំងនឹងទទួលបានអំណាចមកលើដួងចិត្តរបស់យើង ។** (២) **កំហឹង និងការសងសឹកនឹងដឹកនាំមនុស្សឲ្យសម្រេចចិត្តដែលធ្វើឲ្យខ្លួនគេ និងអ្នកដទៃឈឺចាប់ ។**

សូមសួរ ៖ តើមានស្ថានភាពណាខ្លះដែលមេរៀនទាំងនេះអាចអនុវត្តនៅក្នុងជីវិតរបស់យុវជន ឬយុវនារីនាសព្វថ្ងៃនេះ ?

ម៉ូរ៉ូណៃ ១–៣

លោកម៉ូរ៉ូណៃថ្លែងទីបន្ទាល់ថា លោកនឹងមិនបដិសេធព្រះគ្រីស្ទឡើយ

សូមឲ្យសិស្សម្នាក់អាន ម៉ូរ៉ូណៃ ១:១–៤ ឮៗ ។ បន្ទាប់មក សួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- ហេតុអ្វីបានជាពួកសាសន៍លេមិនចង់សម្លាប់លោកម៉ូរ៉ូណៃ ?
- តើការណ៍នេះបង្ហាញអ្វីខ្លះអំពីសេចក្តីជំនឿ និងទំនុកចិត្តរបស់លោកម៉ូរ៉ូណៃ ? តើយើងអាចអភិវឌ្ឍទីបន្ទាល់ដ៏រឹងមាំអំពីព្រះយេស៊ូវគ្រីស្ទបានដោយរបៀបណា ?

ម៉ូរ៉ូណៃ ៤–៦

លោកម៉ូរ៉ូណៃកត់ត្រាអំពីការអធិស្ឋានសាក្រាម៉ង់ លក្ខខណ្ឌសម្រាប់បុណ្យជ្រមុជទឹក និងមូលហេតុនៃការប្រជុំក្នុងសាសនាចក្រ

សូមសរសេរឃ្លាខាងក្រោមនៅលើក្តារខៀន ៖ *ហេតុអ្វីខ្ញុំត្រូវទៅព្រះវិហារនៅថ្ងៃអាទិត្យ* ។ សូមឲ្យសិស្សស្រាវជ្រាវ ម៉ូរ៉ូណៃ ៤–៦ ហើយរៀបចំចម្លើយចំពោះប្រយោគនេះដោយកត់ចំណាំនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីររបស់គេ ។ សូមលើកទឹកចិត្តពួកគេឲ្យបញ្ចូលចម្លើយរបស់

គេយ៉ាងហោចណាស់ពីរពីអ្វីខាងក្រោមនេះ (អ្នកអាចសរសេរវានៅលើក្តារខៀន ឬរៀបចំជាក្រដាសចែកក៏បាន) ៖

១. វគ្គព្រះគម្ពីរពី មរ៉ូណៃ ៤–៦ ដែលពន្យល់ពីមូលហេតុក្នុងការជួបប្រជុំគ្នានៅឯព្រះវិហារ ។

២. គោលលទ្ធិ ឬគោលការណ៍ដែលពន្យល់ពីមូលហេតុដែលយើងគួរចូលរួមក្នុងការប្រជុំសាសនាចក្រ ។

៣. បទពិសោធន៍ផ្ទាល់ខ្លួនមួយដែលបង្ហាញពីមូលហេតុដែលយើងត្រូវចូលរួមក្នុងការប្រជុំសាសនាចក្រ ។

៤. ទីបន្ទាល់ផ្ទាល់ខ្លួនមួយអំពីសារៈសំខាន់នៃការចូលរួមការប្រជុំក្នុងសាសនាចក្រ ។

នៅពេលសិស្សបានមានពេលរៀបចំគំនិតរបស់គេគ្រប់គ្រាន់ហើយ សូមឲ្យពួកគេពីរបីនាក់ចែកចាយនូវការយល់ឃើញរបស់គេដល់សិស្សក្នុងថ្នាក់ ។

ក្រោយពីសិស្សបានចែកចាយអ្វីដែលពួកគេបានរៀនហើយ សូមបន្ថែមទីបន្ទាល់របស់អ្នកអំពីសេចក្តីពិតដែលពួកគេបានរកឃើញ និង អំពីសារៈសំខាន់នៃការជួបជុំគ្នានៅក្នុងការប្រជុំសាសនាចក្រឲ្យបានទៀងទាត់ ។

មរ៉ូណៃ ៧:១–១៩

លោកមរមនបង្រៀនពីរបៀបដើម្បីកាត់សេចក្តីរវាងសេចក្តីល្អ និងសេចក្តីអាក្រក់

មុនពេលបង្រៀន សូមចាក់ទឹកក្នុងកែវមួយពេញ ហើយកែវមួយទៀតដាក់លាយទឹកជាមួយនឹងទឹកខ្មេះ (ឬអំបិល) ។ កែវនោះគួរមើលទៅដូចគ្នា ។ សូមប្រាប់សិស្សថា អ្នកមានកែវពីរ ដែលមើលទៅដូចគ្នា ប៉ុន្តែមួយមានសជាតិជូរ (ឬប្រៃ) ។ សូមសួរកអ្នកស្ម័គ្រចិត្តម្នាក់ដើម្បីសម្រេចថាកែវណាមួយមានទឹកល្អ ហើយកែវណាមួយមានទឹកសជាតិជូរ (ឬប្រៃ) (អ្នកអាចធ្វើការណ៍នេះ ដោយការភ្លក់វា ឬហិតក្លិនវា) ។

សូមសួរ ៖ តើយើងអាចប្រាប់ថា អ្វីមួយអាក្រក់ដោយពិតជាមិនភ្លក់វាបានដោយរបៀបណា ?

សូមពន្យល់ថា នៅក្នុងកំណត់ត្រារបស់លោក លោកមរ៉ូណៃបានបញ្ចូលនូវទេសនាថាពីឪពុករបស់លោក លោកមរមន ដែលផ្តល់នូវការយល់ដឹងអំពីសំណួរនេះ ។ សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៧:១១–១៣, ១៥–១៦ ឮៗ ។ សូមឲ្យសិស្សជ្រើសរើសយ៉ាងហោចណាស់ឃ្លាមួយដែលលេចធ្លោចំពោះពួកគេដែលពន្យល់ពីរបៀបដែលយើងអាចបែងចែករវាងការល្អ និងការអាក្រក់ ។ សូមឲ្យសិស្សពីរបីនាក់មានឱកាសដើម្បីចែកចាយពីឃ្លាដែលពួកគេបានជ្រើសរើស ។

សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៧:១៩ ឮៗ ហើយសូមឲ្យសិស្សរកមើលអ្វីដែលលោកមរមនបានមានប្រសាសន៍ថា យើងគួរតែធ្វើដើម្បីដឹងការល្អ ពីការអាក្រក់ ។

សូមសួរ ៖ តើលោកមរមនបានប្រាប់ដល់យើងឲ្យធ្វើអ្វីខ្លះ ដើម្បីឲ្យយើងអាចបែងចែករវាងការល្អ និងអាក្រក់បាន ?

សិស្សគួរតែអាចរកឃើញនូវគោលការណ៍ខាងក្រោមនេះ ៖ **នៅពេលយើងព្យាយាមស្វែងរកនៅក្នុងពន្លឺនៃព្រះគ្រីស្ទ នោះយើងអាចបែងចែករវាងការណ៍ល្អ និងអាក្រក់បាន ។**

សូមសួរសិស្សនូវសំណួរដូចខាងក្រោម ៖

- ចេញពីការសិក្សារបស់អ្នកនៅក្នុងសប្តាហ៍នេះ តើអ្នកយល់ថាតើពន្លឺនៃព្រះគ្រីស្ទគឺជាអ្វី ?
- តើពន្លឺរបស់ព្រះគ្រីស្ទបានជួយអ្នកឲ្យបែងចែករវាងការល្អ និងការអាក្រក់នៅពេលណាខ្លះ ?

សូមឲ្យសិស្សមានពេលមួយ ឬពីរនាទីសរសេរនូវកម្មវិធីទូរទស្សន៍ ចម្រៀង ក្រុមតន្ត្រី គេហទំព័រ អ៊ិនធើណិត កម្មវិធីទូរស័ព្ទ ល្បែងវីដេអូ ឬរបស់ផ្ទាល់ខ្លួនដែលគេចូលចិត្ត ។ សូមឲ្យពួកគេប្រើ មរ៉ូណៃ ៧:១៦–១៩ ដើម្បីសម្រេចថាតើរបស់នៅក្នុងបញ្ជីរបស់គេជួយពួកគេឲ្យខិតទៅកាន់តែជិតនឹងព្រះ ឬឃ្លាតឆ្ងាយពីទ្រង់ ។

សូមរំឭកសិស្សអំពីការអញ្ជើញដែលពួកគេបានទទួលនៅក្នុងការសិក្សាក្នុងសប្តាហ៍នេះ ដើម្បីលុបចេញពីជីវិតរបស់គេនូវរឿងទាំងឡាយដែលមិនល្អ ហើយ « ក្តាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ » (មរ៉ូណៃ ៧:១៩) ។ អ្នកអាចចែកចាយបទពិសោធន៍មួយដែលអ្នកបានមាននៅពេលអ្នកបានធ្វើតាមពន្លឺនៃព្រះគ្រីស្ទ ហើយអាចបែងចែករវាងការល្អ និងការអាក្រក់បាន ។

មេរៀនបន្ទាប់ (មរ៉ូណៃ ៧:២០–១០:៣៤)

សូមឲ្យសិស្សគិតពីសំណួរខាងក្រោម នៅពេលពួកគេសិក្សាមេរៀនបន្ទាប់ ៖ តើសេចក្តីសប្បុរសជាអ្វី ? តើបុគ្គលម្នាក់អាចទទួលបានសប្បុរសធម៌ដោយរបៀបណា ? ហេតុអ្វីបានជាកូនក្មេងតូចៗឬទារកមិនត្រូវជ្រមុជទឹក ? តើលោកមរមន និងម៉រ៉ូណៃបាននៅស្មោះត្រង់ ទោះបីជានៅពេលពួកលោកត្រូវបានហឹុតទ្វេដោយអំពើទុច្ចរិតដោយរបៀបណា ? តើអ្វីជាសម្តីចុងក្រោយរបស់លោកម៉រ៉ូណៃ ? ហេតុអ្វីបានជាវាសំខាន់ ?

ម៉ូរ៉ូណៃ ៧:២០–៤៨

សេចក្តីផ្តើម

លោកម៉ូរ៉ូណៃបានកត់ត្រាសេចក្តីបញ្ចប់នៃទេសនកថាដែលឪពុករបស់លោក លោកមរមនបានធ្វើជាច្រើនកន្លងទៅនៅក្នុងសាលាប្រជុំ ។ នៅក្នុងទេសនកថានោះ លោកមរមនបានបង្រៀនដល់អ្នកស្តាប់របស់លោកពីរបៀប « ក្តាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ » (ម៉ូរ៉ូណៃ ៧:២០, ២៥) ។ លោកបានពន្យល់ពីទំនាក់ទំនងរវាងសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស ហើយបានបញ្ចប់ដោយការអង្វរដល់ប្រជាជនរបស់លោកឲ្យអធិស្ឋានទៅកាន់ព្រះវរបិតាដោយអស់ពីកម្លាំងចិត្តសុំរកអំណោយទាននៃសេចក្តីសប្បុរស « ជាសេចក្តីស្រឡាញ់ដ៏សុទ្ធសាធនៃព្រះគ្រីស្ទ » (ម៉ូរ៉ូណៃ ៧:៤៧) ។

យោបល់សម្រាប់ការបង្រៀន

ម៉ូរ៉ូណៃ ៧:២០–៣៩

លោកមរមនបង្រៀនថា តាមរយៈសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចក្តាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ

សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀនមុនចាប់ផ្តើមបង្រៀន ៖

តើរឿងល្អណាខ្លះដែលព្រះវរបិតាសួគ៌បានប្រទានពរដល់អ្នក ?

នៅពេលចាប់ផ្តើមថ្នាក់ សូមឲ្យសិស្សមានពេលមួយ ឬពីរនាទីឆ្លើយនឹងសំណួរនេះនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬសៀវភៅសរសេរក្នុងថ្នាក់ ។ បន្ទាប់មក សូមឲ្យពួកគេអានរឿងខ្លះដែលពួកគេបានសរសេរ ។

សូមអាន ម៉ូរ៉ូណៃ ៧:២៤ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលប្រភពនៃរឿងល្អទាំងអស់ដែលបានមកកាន់ជីវិតរបស់ពួកគេ ។

- តើអ្នកណាជាប្រភពនៃរឿងល្អទាំងអស់ដែលបានកើតឡើងដល់អ្នក ? (ចម្លើយរបស់សិស្សអាចខុសគ្នា ប៉ុន្តែពួកគេគួរបង្ហាញនូវសេចក្តីពិតដូចខាងក្រោមនេះ ៖ **រឿងល្អទាំងអស់កើតឡើង ដោយសារតែព្រះយេស៊ូវគ្រីស្ទ**) ។

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ពីគោលលទ្ធិដែលបានបង្រៀននៅក្នុង ម៉ូរ៉ូណៃ ៧:២៤ សូមពន្យល់ថា ក្នុងនាមជាកូនចៅរបស់អ័ដាម និងអេវ៉ា យើងបាន « ធ្លាក់ » ហើយមិនអាចទទួលបានពរជ័យទាំងឡាយដោយខ្លួនឯងបានទេ (សូមមើលផងដែរ អាលម៉ា ២២:១៤; អេធើរ ៣:២; មាត្រានៃសេចក្តីជំនឿ ១:៣) ។ បើគ្មានព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ទេ « នោះគ្មានរឿងល្អកើតឡើងដល់ [យើង] ទេ » ។ ការណ៍ល្អគ្រប់យ៉ាងដែលយើងបានទទួលពីព្រះវរបិតាសួគ៌បានមកតាមរយៈព្រះអង្គសង្គ្រោះ និងដង្វាយធួនរបស់ទ្រង់ ។

សូមពន្យល់ថា ព្រះវរបិតាសួគ៌មានពរជ័យជាច្រើនទុកសម្រាប់យើង ។ ទ្រង់ចង់ឲ្យយើង « ក្តាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ » (ម៉ូរ៉ូណៃ ៧:១៩) ហើយទ្រង់ចង់ប្រទានដល់យើងនូវអ្វីៗទាំងអស់ដែលទ្រង់មាន (សូមមើល គ. និង ស. ៨៤:៣៨) ។

សូមឲ្យសិស្សម្នាក់អានឮៗនូវសំណួររបស់លោកមរមននៅក្នុង ម៉ូរ៉ូណៃ ៧:២០ ។ បន្ទាប់មក សូមឲ្យសិស្សអាន ម៉ូរ៉ូណៃ ៧:២១–២៤ ដោយស្ងាត់ស្ងៀម ដោយរកមើលអ្វីដែលខគម្ពីរទាំងនេះបង្រៀនអំពីរបៀបដែលយើងអាចក្តាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ ។

- ផ្អែកលើអ្វីដែលអ្នកបានអាន ម៉ូរ៉ូណៃ ៧:២១–២៤ តើអ្នកនឹងឆ្លើយតបនឹងសំណួររបស់លោកមរមននៅក្នុង ម៉ូរ៉ូណៃ ៧:២០ ដោយរបៀបណា ? (នៅពេលសិស្សឆ្លើយ សូមជួយពួកគេឲ្យរកមើលគោលការណ៍ខាងក្រោមនេះ ៖ **នៅពេលយើងអនុវត្តសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ នោះយើងអាចក្តាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ**) ។

ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលពួកគេអាច « ក្តាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ » សូមឲ្យពួកគេពីរបីនាក់ប្តូរវេនគ្នាអានឮៗពី ម៉ូរ៉ូណៃ ៧:២៥–២៦, ៣២–៣៨ ។ សូមឲ្យសិស្ស៣ក់កណ្តាលថ្នាក់រកឃើញរបៀបដែលយើងអាចបង្ហាញសេចក្តីជំនឿរបស់យើងទៅលើព្រះយេស៊ូវគ្រីស្ទ ។ សូមឲ្យសិស្សផ្សេងទៀតរកមើលរឿងល្អដែលកើតឡើងចំពោះយើង ដែលជាលទ្ធផល ។ (នៅពេលសិស្សម្នាក់អាន ខគម្ពីរទី ៣៣ អ្នកអាចពន្យល់ថាឃ្លា « ការចាំបាច់ដល់យើង » សំដៅលើអ្វីដែលស្របតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់) ។

ក្រោយពីសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញហើយ សូមគិតពីការសុំឲ្យពួកគេសរសេរនូវគោលដៅមួយ ដែលនឹងជួយពួកគេឲ្យអនុវត្តសេចក្តីជំនឿដ៏អស្ចារ្យជាងនេះនៅក្នុងព្រះយេស៊ូវគ្រីស្ទ និងក្តាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អដែលព្រះវរបិតាសួគ៌ចង់ប្រទានដល់ពួកគេ ។ សូមចែកចាយទីបន្ទាល់របស់អ្នកថា ពរជ័យដ៏អស្ចារ្យកើតឡើងតាមរយៈព្រះអង្គសង្គ្រោះ ដំណឹងល្អរបស់ទ្រង់ និងដង្វាយធួនរបស់ទ្រង់ ។ សូមលើកទឹកចិត្តសិស្សឲ្យអនុវត្តសេចក្តីជំនឿលើទ្រង់កាន់តែខ្លាំងជាងនេះ ។

ម៉ូរ៉ូណៃ ៧:៤០–៤៣

លោកមរមនបង្រៀនថា សេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទនាំយើងឲ្យមានសេចក្តីសង្ឃឹមចំពោះជីវិតដ៏នៅអស់កល្បជានិច្ច

សូមគូសរូបភាពកៅអីជើងបីមួយនៅលើក្តារខៀន (ឬបង្ហាញរូបកៅអីជើងបី) ។



សូមអានន្ទវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ អិម រ័សុល បាឡឺដ នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« គោលការណ៍ទេវភាពបី បង្កើតជាមូលដ្ឋានគ្រឹះមួយ ដែលយើងអាចសង់ជីវិតរបស់យើងលើបាន ។ . . . រួមគ្នា វាផ្តល់ដល់យើងនូវមូលដ្ឋាននៃការគាំទ្រដូចជាជើងនៃកៅអីជើងបីនេះ » (« The Joy of Hope Fulfilled » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៩២, ទំព័រ ៣៣) ។

សូមសរសេរឃ្លា *សេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ* លើជើងកៅអីមួយ ។ សូមឲ្យសិស្សគិតអំពីអ្វីដែលជើងពីរទៀតអាចតំណាងឲ្យ ។ បន្ទាប់មក សូមឲ្យសិស្សអាន ម៉ូរ៉ូណៃ ៧:៤០ ដោយស្ងាត់ស្ងៀមដើម្បីរកមើលអ្វីដែលជើងទីពីរនៃកៅអីនោះតំណាងឲ្យ ។ (ជើងទីពីរនៃកៅអីនោះតំណាងឲ្យសេចក្តីសង្ឃឹម) ។

សូមអានប្រយោគនៃសេចក្តីសង្ឃឹមខាងក្រោមនេះឮៗ ។ សូមឲ្យសិស្សស្តាប់រកភាពខុសគ្នារវាងប្រយោគទាំងពីរនេះ ។

១. ខ្ញុំសង្ឃឹមថា វានឹងភ្លៀងនៅថ្ងៃនេះ ។

២. ខ្ញុំមានសេចក្តីសង្ឃឹមលើសេចក្តីសន្យារបស់ព្រះអម្ចាស់ថា ខ្ញុំអាចមានអារម្មណ៍នៃសេចក្តីសុខសាន្តតាមរយៈការប្រែចិត្ត ។

- តើប្រយោគទាំងនេះខុសគ្នាដូចម្តេចខ្លះ ? (សូមជួយសិស្សឲ្យឃើញថា នៅក្នុងឧទាហរណ៍ទីមួយពាក្យ *សេចក្តីសង្ឃឹម* សំដៅលើចំណងមិនប្រាកដមួយ ។ នៅក្នុងឧទាហរណ៍ទីពីរពាក្យ *សេចក្តីសង្ឃឹម* គឺជាការសម្តែងនៃទំនុកចិត្តមួយ ។ វាគឺជាការជម្រុញមួយឲ្យមានសកម្មភាព ហើយវាផ្តោតលើដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ) ។

ដើម្បីជួយសិស្សឲ្យយល់ពាក្យ *សេចក្តីសង្ឃឹម* ដូចដែលបានប្រើនៅក្នុងព្រះគម្ពីរ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ឌៀថើរ អេស អុជដូហ្វ នៃគណៈប្រធានទីមួយ ៖

« សេចក្តីសង្ឃឹមគឺជាអំណោយខាងវិញ្ញាណ ។ . . .

« សេចក្តីសង្ឃឹមមិនមែនជាចំណេះដឹងនោះទេ ប៉ុន្តែវាជាទំនុកចិត្តប្រកបដោយការគោរពថា ព្រះអម្ចាស់នឹងបំពេញសេចក្តីសន្យារបស់ទ្រង់ចំពោះយើង ។ វាគឺជាទំនុកចិត្តថា ប្រសិនបើយើងរស់នៅតាមក្រឹត្យវិន័យរបស់ព្រះ និងពាក្យសម្តីរបស់ព្យាការីរបស់ទ្រង់ឥឡូវនេះ នោះយើងនឹងទទួលបានពរជ័យដែលយើងចង់បាននាពេលអនាគត ។ វាជាការជឿ និងការសង្ឃឹមថា ការអធិស្ឋានរបស់យើងនឹងទទួលបានចម្លើយ ។ វាត្រូវបានសម្តែងនៅក្នុងទំនុកចិត្ត សុទិដ្ឋិនិយម ការពេញចិត្ត និងសេចក្តីខ្ជាប់ខួនដ៏អត់ធ្មត់ » (« The Infinite Power of Hope » *Ensign* ឬ *លីអាហូណា,* ខែ វិច្ឆិកា ឆ្នាំ ២០០៨, ទំព័រ ២១–២២) ។

ម៉ូរ៉ូណៃ ៧:៤១ នេះគឺជាវគ្គចំណេះចំណានខគម្ពីរ។ សូមបើកទៅគំនិតក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរ ។

សូមឲ្យសិស្សម្នាក់អាន ម៉ូរ៉ូណៃ ៧:៤១ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលអ្វីដែលលោកមរមនបានបង្រៀនថាយើងគួរសង្ឃឹមលើ ។ នៅពេលសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ សូមសរសេរលើជើងកៅអីទីពីរនូវឃ្លា *សេចក្តីសង្ឃឹមដល់ជីវិតដ៏នៅអស់កល្បជានិច្ច* ។

សូមបង្ហាញថា ម៉ូរ៉ូណៃ ៧:៤១ នេះគឺជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកអាចណែនាំថា សិស្សគួរគូសចំណាំវគ្គនេះដើម្បីឲ្យងាយស្រួលនឹងរកឃើញវា ។

- យោងតាម ម៉ូរ៉ូណៃ ៧:៤១ តើយើងអាចមានសង្ឃឹមថានឹងរស់នៅក្នុងជីវិតដ៏នៅអស់កល្បជានិច្ចដោយរបៀបណា ? (ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នាក្តី ក៏ពួកគេគួររកឃើញនូវគោលការណ៍ខាងក្រោមនេះ ៖ **ប្រសិនបើយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ យើងអាចទទួលបានសេចក្តីសង្ឃឹមតាមរយៈដង្វាយធួនរបស់ទ្រង់ថានឹងបានរស់នៅក្នុងជីវិតដ៏នៅអស់កល្បជានិច្ច**) ។

សូមឲ្យសិស្សអាន ម៉ូរ៉ូណៃ ៧:៤២–៤៣ ដោយខ្លួនឯង ដោយរកមើលលក្ខណៈដែលយើងត្រូវការដើម្បីមានសេចក្តីជំនឿ និងសេចក្តីសង្ឃឹម ។ សូមឲ្យសិស្សរៀបរាប់អ្វីដែលពួកគេបានរកឃើញ ។ (អ្នកអាចពន្យល់ថា ការទន់ភ្លន់ និងដួងចិត្តរាបទាបមានន័យថា បន្ទាបខ្លួន សុភាពរាបសា និងចេះស្តាប់បង្គាប់តាមព្រះឆន្ទៈរបស់ព្រះអម្ចាស់) ។

- តើអ្នកគិតថា ហេតុអ្វីបានជាសេចក្តីទន់ភ្លន់ និងការមានដួងចិត្តរាបសា ចាំបាច់ដើម្បីមានសេចក្តីជំនឿ និងសេចក្តីសង្ឃឹមនៅក្នុងដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ?

សូមឲ្យសិស្សឆ្លើយនឹងសំណួរខាងក្រោមនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ ៖

- តើសេចក្តីជំនឿរបស់អ្នកទៅលើព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ផ្តល់ដល់អ្នកនូវសេចក្តីសង្ឃឹម ដែលអ្នកនឹងទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចដោយរបៀបណា ?

មរ៉ូណៃ ៧:៤៤–៤៨

លោកមរមនបង្រៀនពីសារៈសំខាន់នៃសេចក្តីសប្បុរស

សូមមើលទៅកៅអីជើងបីវិញ ។ សូមឲ្យសិស្សអាន មរ៉ូណៃ ៧:៤៤ ដោយស្ងាត់ស្ងៀម ហើយរកមើលពាក្យសម្រាប់ជើងទីបីនៃកៅអីនេះ ។ នៅពេលសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ សូមសរសេរលើជើងទីបីនូវពាក្យ *សេចក្តីសប្បុរស* ។ សូមឲ្យពួកគេឲ្យនិយមន័យនៃពាក្យ *សេចក្តីសប្បុរស* ជាសម្តីរបស់ខ្លួនគេ ។

សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៧:៤៥–៤៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលរបៀបដែលលោកមរមនបានរៀបរាប់ និងផ្តល់និយមន័យនៃពាក្យសេចក្តីសប្បុរស ។

- តើលោកមរមនផ្តល់និយមន័យនៃពាក្យសេចក្តីសប្បុរសនៅក្នុង មរ៉ូណៃ ៧:៤៧ ? (« សេចក្តីស្រឡាញ់សុទ្ធសាធនៃព្រះគ្រីស្ទ ») ។
- តើអ្នកគិតថា វាមានន័យយ៉ាងណាដែលថា សេចក្តីសប្បុរសពុំបាត់បង់ទៅឡើយ ?
- តើអ្នកគិតថា ហេតុអ្វីបានជាយើងគ្មានជាអ្វីទាំងអស់ ប្រសិនបើយើងគ្មានសេចក្តីសប្បុរសទេនោះ ?

សូមឲ្យសិស្សជ្រើសរើសការពិពណ៌នាអំពីពាក្យ សេចក្តីសប្បុរស នៅក្នុង មរ៉ូណៃ ៧:៤៥ ហើយពន្យល់ពីអត្ថន័យដែលពួកគេគិតអំពីការពិពណ៌នានេះ ។ សូមបញ្ជាក់ពីការពន្យល់របស់ពួកគេ ពេលចាំបាច់ ។ (ឧទាហរណ៍ « តែងតែតស៊ូ » មានន័យថា នរណាម្នាក់តស៊ូនឹងឧបសគ្គនានាដោយការអត់ធ្មត់ ។ « ពុំចេះឈ្នានីស » មានន័យថា បុគ្គលម្នាក់មិនច្រណែននឹងអ្នកដទៃ ។ « ពុំចេះអួតខ្លួន » មានន័យថា នរណាម្នាក់បន្ទាបខ្លួន ។ « ពុំរកប្រយោជន៍ផ្ទាល់ខ្លួន » រៀបរាប់ពីគុណសម្បត្តិនៃការដាក់ព្រះ និងអ្នកដទៃមុនខ្លួនយើង ។ « ពុំរហ័សខឹង » មានន័យថា មិនងាយនឹងក្រោធខឹង ។ « ជឿដល់ការណ៍ទាំងអស់ » រៀបរាប់ពីនរណាម្នាក់ដែលទទួលយកសេចក្តីពិតទាំងអស់) ។

សូមសួរសិស្សថា តើពួកគេនឹងឆ្លើយតបចំពោះស្ថានភាពខាងក្រោមនីមួយៗដោយរបៀបណា ប្រសិនបើពួកគេខ្វះសេចក្តីសប្បុរសនោះ ។ បន្ទាប់មក សូមសួរថា តើពួកគេនឹងឆ្លើយតបយ៉ាងណា ប្រសិនបើពួកគេត្រូវបានបំពេញដោយសេចក្តីសប្បុរស ។ (អ្នកអាចសម្របតាមស្ថានភាពទាំងនេះ ដោយយោងតាមតម្រូវការ និងចំណាប់អារម្មណ៍របស់សិស្សអ្នក) ។

១. មនុស្សសើចចំអកដល់អ្នក ឬនរណាម្នាក់ផ្សេងនៅឯសាលារៀន ។

២. អ្នកមានបងប្រុស ឬបងស្រីម្នាក់ដែលរំខានដល់អ្នកជារឿយៗ ។

៣. នរណាម្នាក់ដែលអ្នកស្គាល់បានប្រព្រឹត្តនូវអំពើបាបមួយយ៉ាងធ្ងន់ ។

៤. អ្នកមិនចូលចិត្តអ្នកប្រឹក្សាភូរ៉ុម ឬថ្នាក់ថ្មី ដូចដែលអ្នកបានចូលចិត្តអ្នកប្រឹក្សាមុននោះទេ ។

សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៧:៤៨ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយរកមើលអ្វីដែលយើងត្រូវធ្វើដើម្បីត្រូវបានប្រទានពរដោយនូវអំណោយទាននៃសេចក្តីសប្បុរស ។ នៅពេលសិស្សឆ្លើយ សូមប្រាកដថា គោលការណ៍ខាងក្រោមនេះត្រូវបានបញ្ជាក់ច្បាស់ ៖ **ប្រសិនបើយើងអធិស្ឋានទៅកាន់ព្រះវរបិតាដោយអស់ពីកម្លាំងចិត្ត និងរស់នៅជាអ្នកដើរតាមដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចត្រូវបានបំពេញដោយសេចក្តីសប្បុរស ។**

សូមបង្ហាញថា មរ៉ូណៃ ៧:៤៥, ៤៧–៤៨ នេះគឺជាវគ្គចំណេះចំណានខគម្ពីរ ។ អ្នកអាចណែនាំថា សិស្សគួរគូសចំណាំវគ្គនេះដើម្បីឲ្យងាយស្រួលនឹងរកឃើញវា ។

- តើអ្នកគិតថា ហេតុអ្វីបានជាយើងត្រូវអធិស្ឋានសុំរកអំណោយទាននៃសេចក្តីសប្បុរសដោយអស់ពីកម្លាំងចិត្ត ?
- តើនៅពេលណាដែលអ្នកធ្វើទីបន្ទាល់អំពីគំរូនៃសេចក្តីសប្បុរស ? (សូមឲ្យសិស្សពីរបីនាក់ចែកចាយពីបទពិសោធន៍ទាំងនេះ ។ អ្នកក៏អាចចែកចាយពីបទពិសោធន៍ផ្ទាល់ខ្លួនដែរ) ។
- តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា ព្រះអម្ចាស់បានជួយដល់អ្នកឲ្យមានអារម្មណ៍ថាមានចិត្តសប្បុរសចំពោះអ្នកដទៃជាងមុន ?

សូមឲ្យសិស្សរំឭក មរ៉ូណៃ ៧:៤៥ ហើយជ្រើសរើសធាតុមួយនៃសេចក្តីសប្បុរស ដែលពួកគេត្រូវអភិវឌ្ឍ ។ សូមលើកទឹកចិត្តពួកគេឲ្យអធិស្ឋានសុំអំណោយទាននៃសេចក្តីសប្បុរស នៅពេលពួកគេខិតខំអភិវឌ្ឍផ្នែកនេះ ។ សូមធ្វើទីបន្ទាល់អំពីឥទ្ធិពលថា សេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរសបានមាននៅក្នុងជីវិតរបស់អ្នក ។

ចំណេះចំណានខគម្ពីរ—មរ៉ូណៃ ៧:៤១

សូមជួយសិស្សឲ្យទន្ទេញចាំ មរ៉ូណៃ ៧:៤១ ។ សូមគិតពីការប្រើវិធីនេះមួយដែលបានពន្យល់នៅក្នុងឧបសម្ព័ន្ធនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ ។

ចំណេះចំណានខគម្ពីរ—មរ៉ូណៃ ៧:៤៥, ៤៧–៤៨

សូមឲ្យសិស្សជ្រើសរើសបុគ្គលមួយដែលពួកគេចង់មានសេចក្តីសប្បុរសដល់គេពីបញ្ជីខាងក្រោមនេះ ៖ សមាជិកគ្រួសារ សមាជិកភ្លូមឬថ្នាក់ មិត្តនៅសាលារៀន មិត្តភក្តិ ឬអ្នកជិតខាង ។ សូមលើកទឹកចិត្តពួកគេឲ្យគិតអំពីបុគ្គលដែលពួកគេបានជ្រើសរើស នៅពេលពួកគេអាន មរ៉ូណៃ ៧:៤៥ និងគិតពិចារណារបៀបដែលពួកគេអាចបង្ហាញដល់បុគ្គលនោះនូវសេចក្តីស្រលាញ់ដូចព្រះគ្រីស្ទបន្ថែមទៀត ។ សូមឲ្យពួកគេសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់នូវរបៀបមួយ ឬពីរដែលពួកគេនឹងបង្ហាញសេចក្តីសប្បុរសដល់បុគ្គលម្នាក់ ដែលពួកគេបានជ្រើសរើសនោះ ។ សូមឲ្យពួកគេយកការខិតខំនេះជាផ្នែកមួយនៃការអធិស្ឋានរបស់គេនៅសប្តាហ៍ក្រោយ ។ អ្នកអាចគិតពីការឲ្យសិស្សមានឱកាសមួយដើម្បីចែកចាយបទពិសោធន៍របស់គេនៅក្នុងថ្ងៃខាងមុខនេះ ។

កំណត់ចំណាំ ៖ ដោយសារតែប្រវែងនៃមេរៀននេះ អ្នកអាចចង់ប្រើសកម្មភាពនេះនៅថ្ងៃក្រោយ នៅពេលអ្នកមានពេលបន្ថែម ។

មរ៉ូណៃ ៧:៤៥, ៤៧–៤៨ នេះគឺជាវគ្គចំណេះចំណានខគម្ពីរ ។ សូមបើកទៅគំនិតក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរ ។

មរ៉ូណៃ ៨

សេចក្តីផ្តើម

ដោយបន្តបន្ថែមក្នុងបញ្ជីពិសិដ្ឋ លោកមរ៉ូណៃបានបញ្ចូលនូវសារ ឬសំបុត្រ ដែលលោកបានទទួលពីឪពុករបស់លោក គឺលោកមរមន ។ នៅក្នុងសារនោះ លោកមរមនបានកត់ត្រានូវវិវរណៈមួយដែលលោកបានទទួលអំពីមូលហេតុដែលក្មេងតូចៗមិនត្រូវជ្រមុជទឹក ។ លោកមរមនក៏បានបង្រៀនអំពីរបៀបដែលយើងអាចរៀបចំដើម្បីរស់នៅជាមួយនឹងព្រះ ។ លោកបានបញ្ចប់សាររបស់លោកដោយការបង្ហាញការបារម្ភអំពីអំពើទុច្ចរិតរបស់ពួកគេសាសន៍នីហ្វៃ និងសេចក្តីបំផ្លិចបំផ្លាញក្នុងពេលដ៏ខ្លីខាងមុខនេះរបស់គេ ។

បង្រៀនដោយព្រះវិញ្ញាណ

ព្រះអម្ចាស់បានមានព្រះបន្ទូល « ព្រះវិញ្ញាណត្រូវបានប្រទានដល់អ្នក ដោយពាក្យអធិស្ឋាននៃសេចក្តីជំនឿ ហើយបើសិនជាអ្នករាល់គ្នាមិនបានទទួលព្រះវិញ្ញាណទេ នោះអ្នករាល់គ្នានឹងមិនត្រូវបង្រៀនឡើយ » (គ. និង ស. ៤២:១៤) ។ សូមអធិស្ឋានសុំសមត្ថភាពដើម្បីត្រូវបានដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធ ហើយសូមយកចិត្តទុកដាក់ជាពិសេសដល់សំឡេងតូចរហៀងនៃព្រះវិញ្ញាណបរិសុទ្ធ ពេលអ្នកបង្រៀន ។

យោបល់សម្រាប់ការបង្រៀន

មរ៉ូណៃ ៨:១–២៤

លោកមរមនបង្រៀនថា កូនក្មេងតូចៗរស់នៅក្នុងព្រះគ្រីស្ទ

មុនពេលបង្រៀន សូមបង្ហាញរូបភាពកុមារីកំពុងទទួលបុណ្យជ្រមុជទឹក (*សៀវភៅរូបភាពដំណឹងល្អ* | ឆ្នាំ ២០០៩ | លេខ ១០៤) ឬរូបភាពផ្សេងទៀតនៃកុមារអាយុប្រាំបីឆ្នាំនៅក្នុងការបម្រើនៃបុណ្យជ្រមុជទឹករបស់គេ ។ សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន ៖

ហេតុអ្វីបានជាកូនក្មេងតូចៗមិនត្រូវជ្រមុជទឹក រហូតដល់ពួកគេអាយុប្រាំបីឆ្នាំ ?

នៅពេលសិស្សមកដល់ សូមឲ្យពួកគេមើលរូបភាព ហើយសញ្ជឹងគិតពីសំណួរនៅលើក្តារខៀននេះ ។

នៅពេលអ្នកចាប់ផ្តើមបង្រៀន សូមប្រាប់សិស្សថា នៅក្នុងសំបុត្រមួយដល់កូនប្រុសរបស់លោក គឺមរ៉ូណៃ លោកមរមនបានបង្រៀនអំពីសេចក្តីសង្គ្រោះដល់កូនក្មេងតូចៗ ។ សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៨:៤–៦ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលអ្វីដែលលោកមរមនបានបារម្ភដល់ ។ (អ្នករាល់គ្នាអាចពន្យល់ថានៅក្នុង ខគម្ពីរទី ៦ ពាក្យ *ដ៏ធំ* មានន័យថាធ្ងន់ធ្ងរ ខ្លាស់អៀន ឬកាចសាហាវ) ។

ក្រោយពីសិស្សរៀបរាប់អ្វីដែលពួកគេបានរកឃើញហើយ សូមឲ្យពួកគេអាន មរ៉ូណៃ ៨:៧ ដោយស្ងាត់ស្ងៀម ហើយរកមើលអ្វីដែលលោកមរមនបានធ្វើ នៅពេលលោកបានដឹងអំពីបញ្ហានេះ ។

- តើយើងអាចរៀនអ្វីពីគំរូរបស់លោកមរមន ?

សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៨:៨–៩ ឮៗ ហើយសូមឲ្យសិស្សក្នុងថ្នាក់រកមើលចម្លើយចំពោះការអធិស្ឋានរបស់លោកមរមន ។ នៅពេលសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ អ្នកអាចពន្យល់ថាឃ្លា « ពាក្យបណ្តាសាដល់លោកអ័ដាម » សំដៅលើការបែងចែកពីវត្តមាននៃព្រះរបស់លោកអ័ដាម ជាលទ្ធផលនៃការធ្លាក់ ។ មនុស្សខ្លះជឿខុសថា កូនក្មេងទាំងអស់បានកើតមកដោយមានអំពើបាបដោយសារតែការធ្លាក់ ។ ដោយមានគំនិតមិនត្រឹមត្រូវនេះហើយ ពួកគេគិតថា កូនក្មេងតូចមិនសក្តិសមនៅក្នុងវត្តមានរបស់ព្រះទេ ប្រសិនបើពួកគេស្លាប់ដោយមិនបានជ្រមុជទឹកនោះ ។ នៅពេលអ្នកពន្យល់ការណ៍នេះ អ្នកអាចសុំឲ្យសិស្សទន្ទេញមាត្រាទីពីរនៃសេចក្តីជំនឿ ។ អ្នកអាចផ្តល់យោបល់ថា ពួកគេគួរធ្វើសេចក្តីយោងឆ្លង មរ៉ូណៃ ៨:៨–៩ ជាមួយនឹង មាត្រានៃសេចក្តីជំនឿ ១:២ ។

សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *ការរៀបចិត្ត និងបុណ្យជ្រមុជទឹកគឺចាំបាច់សម្រាប់អ្នកទាំងឡាយណាដែល . . .*

សូមឲ្យសិស្សអាន មរ៉ូណៃ ៨:១០ ដោយស្ងាត់ស្ងៀមដោយរកមើលពាក្យ និងឃ្លាដែលបំពេញប្រយោគនៅលើក្តារខៀន ។ ក្រោយពីសិស្សរៀបរាប់ចម្លើយរបស់គេហើយ សូមបំពេញប្រយោគដូចខាងក្រោម ៖ ***ការរៀបចិត្ត និងបុណ្យជ្រមុជទឹកគឺចាំបាច់សម្រាប់អ្នកទាំងឡាយណាដែលអាចទទួលខុសត្រូវ និងមានសមត្ថភាពនឹងប្រព្រឹត្តអំពើបាប ។*** អ្នកអាចលើកទឹកចិត្តសិស្សឲ្យគូសចំណាំនៅក្នុងមរ៉ូណៃ ៨:១០ ដែលបង្រៀនពីសេចក្តីពិតនេះ ។

វាអាចជួយបញ្ជាក់ថា អំពើបាបគឺជា « ការមិនគោរពតាមច្បាប់របស់ព្រះដោយចេតនា » (Guide to the Scriptures, “Sin,” scriptures.lds.org) ។ សូមអានន្ទវសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដាល្លិន អេក អូក នៃក្លុំមនៃពួកសាវកដប់ពីរនាក់ ៖

« យើងយល់ពីគោលលទ្ធិរបស់យើងថា មុនវ័យនៃការចេះទទួលខុសត្រូវ នោះកុមារ ‹ មិនមានសមត្ថភាពប្រព្រឹត្តអំពើបាបនោះទេ › (មរ៉ូណៃ ៨:៨) ។ អំឡុងពេលនោះ កូនក្មេងអាចប្រព្រឹត្តកំហុស ទោះជាកំហុសដ៏ធ្ងន់ធ្ងរក្តី ហើយមានការខូចខាត ដែលត្រូវតែកែតម្រូវក៏ដោយ ក៏ទង្វើរបស់គេមិនត្រូវទទួលខុសត្រូវថាជាអំពើបាបនោះទេ » (« Sins and Mistakes » *Ensign,* ខែ តុលា ឆ្នាំ ១៩៩៦, ទំព័រ ៦៥) ។

សូមបែងចែកសិស្សជាពីរក្រុម ។ សូមឲ្យសិស្សពាក់កណ្តាលថ្នាក់អាន មរ៉ូណៃ ៨:១១–១៨ ដោយស្ងាត់ស្ងៀម ហើយសិស្សផ្សេងទៀតអាន មរ៉ូណៃ ៨:១១, ១៩–២៤ ដោយស្ងាត់ស្ងៀម ។ (អ្នកអាចសរសេរសេចក្តីយោងទាំងនេះនៅលើក្តារខៀន) ។ មុនពេលពួកគេអាន សូមឲ្យសិស្សទាំងពីរក្រុមរកមើលអ្វីដែលលោកមរមនបានបង្រៀនអំពីពិធីបុណ្យជ្រមុជទឹកដល់កូនក្មេងតូចៗ ។ នៅពេលសិស្សមានពេលអានគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពីរបីនាក់ចេញពីក្រុមនីមួយៗ

រៀបរាប់អ្វីដែលពួកគេបានរកឃើញ ។ អ្នកអាចប្រើសំណួរខាងក្រោមនេះខ្លះដើម្បីជួយសិស្សឲ្យគិតបន្ថែមទៀតអំពីការបង្រៀនរបស់លោកមរមន ៖

- តើអ្នកគិតថា វាមានន័យយ៉ាងណាដែលកូនក្មេងតូចៗ « រស់នៅក្នុងព្រះគ្រីស្ទ » ? (មរ៉ូណៃ ៨:១២, ២២) ។ (ពួកគេត្រូវបានប្រោសលោះតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ពួកគេមិនអាចធ្វើបាបបានទេ ដោយសារអំណាចនេះមិនត្រូវបានផ្តល់ទៅដល់សាតាំងដើម្បីល្បួងកូនក្មេងឡើយ ។ សូមមើលដងដែរ មរ៉ូណៃ ៨:១០; គ. និង ស. ២៩:៤៦–៤៧) ។
- តើយើងត្រូវធ្វើអ្វីដើម្បីរស់នៅក្នុងព្រះគ្រីស្ទ ? (សូមមើល នីហ្វៃទី ២ ២៥:២៣–២៦; មរ៉ូណៃ ៨:១០) ។
- តើយើងអាចរៀនអ្វីខ្លះពីខគម្ពីរទាំងនេះអំពីរបៀបដែលកូនក្មេងតូចត្រូវបានសង្គ្រោះ ? (សិស្សអាចប្រើពាក្យខុសគ្នាក្តី ក៏ពួកគេគួរតែឃើញនូវសេចក្តីពិតខាងក្រោមនេះ ៖ **កូនក្មេងតូចៗត្រូវបានសង្គ្រោះតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។** សិស្សក៏អាចបង្ហាញដែរថា **កូនក្មេងតូចរស់នៅក្នុងព្រះគ្រីស្ទ** ថា **ព្រះមិនមែនជាព្រះនៃចំណែកនោះទេ** ហើយថា **ព្រះគឺមិនផ្លាស់ប្តូរ** ។)

សូមសរសេរនូវគំរូដូចខាងក្រោមនៅលើក្តារខៀន ឬរៀបចំវាជាក្រដាសចែកដល់សិស្ស ។ សូមឲ្យសិស្សម្នាក់ៗជ្រើសរើសគំរូមួយ ។ បន្ទាប់មក សូមឲ្យសិស្សជ្រើសរើសខគម្ពីរមួយ ឬពីរពី មរ៉ូណៃ ៨:៨–២៣ ហើយពន្យល់ពីរបៀបដែលសេចក្តីពិតនៅក្នុងខគម្ពីរទាំងនោះនិយាយពីការបារម្ភដែលបានបង្ហាញនៅក្នុងគំរូដែលពួកគេបានជ្រើសរើស ។

គំរូទី ១ ៖ក្នុងនាមជាអ្នកផ្សព្វផ្សាយសាសនាម្នាក់ អ្នកជួបនឹងគូស្វាមីភរិយាមួយគូដែលក្រៀមក្រំជាខ្លាំង ដោយសារកូនស្រីអាយុពីរខែរបស់គេបានស្លាប់ ។ អ្នកដឹកនាំសាសនាចក្ររបស់គេបានប្រាប់ពួកគេថា កូនក្មេងតូចបានកើតមកដោយមានបាប ដោយសារតែការរំលងរបស់លោកអ័ដាម ។ លោកនិយាយថា ដោយសារកូនស្រីរបស់ពួកគេមិនបានជ្រមុជទឹក មុនពេលនាងស្លាប់ ដូច្នេះនាងមិនអាចត្រូវបានសង្គ្រោះឡើយ ។

គំរូទី ២ ៖ អ្នកមានមិត្តម្នាក់ដែលបានជួបជាមួយនឹងអ្នកផ្សព្វផ្សាយសាសនា និងចូលរួមក្នុងព្រះវិហារជាមួយនឹងអ្នក ។ នាងសម្រេចចិត្តថា នាងចង់ចូលរួមក្នុងសាសនាចក្រ ប៉ុន្តែនាងស្ទាក់ស្ទើរនឹងការជ្រមុជទឹក ។ នាងពន្យល់ « ខ្ញុំត្រូវបានជ្រមុជទឹក នៅពេលខ្ញុំនៅជាទារក » ។ « តើវាមិនល្អគ្រប់គ្រាន់ទេឬ » ?

នៅពេលសិស្សចែកចាយគំនិតរបស់ពួកគេអំពីគំរូទីពីរ អ្នកអាចរំឭកពួកគេថា ការប្រែចិត្ត និងពិធីបុណ្យជ្រមុជទឹកដល់ « អស់អ្នកណាដែលដឹងខុស និងត្រូវ ហើយមានសមត្ថភាពនឹងប្រព្រឹត្តអំពើបាប » (មរ៉ូណៃ ៨:១០) ។ ព្រះអម្ចាស់បានមានបន្ទូលថា កូនចៅទាំងឡាយចាប់ផ្តើមដឹងខុស និងត្រូវ នៅចំពោះមុខទ្រង់នៅអាយុប្រាំបីឆ្នាំ ។ វិវរណៈអំពីសេចក្តីពិតនេះមាននៅក្នុងការបកប្រែរបស់យ៉ូសែប ស៊្មីធ លោកុប្បត្តិ ១៧:១១ (នៅក្នុងឧបសម្ព័ន្ធនៃការបោះពុម្ពរបស់ពួកបរិសុទ្ធថ្ងៃចុងក្រោយនៃកំណែថ្មីនៃព្រះគម្ពីរចីបរបស់ស្តេចជេមស៍) និង គោលលទ្ធិ និង សេចក្តីសញ្ញា ៦៨:២៥–២៧ ។

មរ៉ូណៃ ៨:២៥–៣០

លោកមរមនបង្រៀនពីអ្វីដែលអស់អ្នកណាដែលដឹងខុស និងត្រូវ ត្រូវតែធ្វើដើម្បីរស់នៅជាមួយនឹងព្រះ

សូមពន្យល់ថា ក្រោយពីមរមនបានបង្រៀនមរ៉ូណៃអំពីមូលហេតុដែលកូនក្មេងតូចមិនចាំបាច់ត្រូវជ្រមុជទឹក លោកបានបង្រៀនពីមូលហេតុដែលបុណ្យជ្រមុជទឹកចាំបាច់សម្រាប់អស់អ្នកណាដែលដឹងខុស និងត្រូវ ។ សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៨:២៥–២៦ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពរជ័យដែលមកកាន់មនុស្សដែលអនុវត្តសេចក្តីជំនឿ ប្រែចិត្ត និងបានជ្រមុជទឹក ។

- តើពរជ័យអ្វីខ្លះដែលអ្នកបានឃើញនៅក្នុងខគម្ពីរទាំងនេះ ? (នៅពេលសិស្សរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញ អ្នកអាចសរសេរចម្លើយរបស់គេនៅលើក្តារខៀន ។ ចម្លើយអាចរួមមាន សេចក្តីជំនឿ ការប្រែចិត្ត និងពិធីបុណ្យជ្រមុជទឹក នាំទៅរកការផ្តាច់បាប ការរាបសា និងភាពទន់ទាបក្នុងចិត្ត ការមានព្រះវិញ្ញាណបរិសុទ្ធ សេចក្តីសង្ឃឹម សេចក្តីស្រឡាញ់ដ៏ឥតខ្ចោះ និងចុងបញ្ចប់ ពរជ័យនៃការរស់នៅជាមួយនឹងព្រះ) ។

នៅពេលសិស្សសរសេរពរជ័យទាំងឡាយដែលពួកគេឃើញនៅក្នុង មរ៉ូណៃ ៨:២៥–២៦ អ្នកអាចសួរសំណួរតាមដានទាំងនេះ ៖

- តើអ្នកគិតថា ហេតុអ្វីបានជាការទទួលបានការផ្តាច់បាបរបស់យើង នាំទៅរកការទន់ទាប និងការរាបសានៃដួងចិត្ត ?
- តើការទន់ភ្លន់ និងការរាបសាក្នុងចិត្តអញ្ជើញព្រះវិញ្ញាណបរិសុទ្ធមកកាន់ជីវិតរបស់យើងដោយរបៀបណា ?
- ហេតុអ្វីបានជាព្រះវិញ្ញាណបរិសុទ្ធជួយយើងឲ្យរៀបចំដើម្បីរស់នៅជាមួយនឹងព្រះ ?
- តើអ្នកគិតថា ហេតុអ្វីបានជាយើងត្រូវអត់ធ្មត់ និងប្រកបដោយការអធិស្ឋានដើម្បីមានសេចក្តីស្រឡាញ់ដ៏ឥតខ្ចោះដើម្បីតស៊ូនៅក្នុងជីវិតរបស់យើង ?

សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *តាមរយៈការគោរពដ៏ស្មោះត្រង់តាមព្រះបញ្ញត្តិ យើងអាចទទួលបានព្រះវិញ្ញាណបរិសុទ្ធ ដែលរៀបចំយើង* . . .

សូមឲ្យសិស្សរកមើលឃ្លាមួយពី មរ៉ូណៃ ៨:២៥–២៦ ដែលបំពេញគោលការណ៍នេះ ៖ ***តាមរយៈការគោរពដ៏ស្មោះត្រង់តាមព្រះបញ្ញត្តិ យើងអាចទទួលបានព្រះវិញ្ញាណបរិសុទ្ធ ដែលរៀបចំយើងឲ្យរស់នៅជាមួយនឹងព្រះ ។***

សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៨:២៧ ឮៗ ហើយសូមឲ្យសិស្សរកមើលលទ្ធផលនៃភាពឆ្មើងឆ្មៃរបស់ពួកសាសន៍នីហ្វៃ ។ បន្ទាប់មក សូមឲ្យសិស្សរំឭក មរ៉ូណៃ ៨:២៦ និង មរ៉ូណៃ ៨:២៧ ដោយស្ងាត់ស្ងៀមដែលផ្ទុយទៅនឹងលទ្ធផលនៃការរាបសា និងភាពទន់ភ្លន់ក្នុងដួងចិត្តជាមួយនឹងលទ្ធផលនៃភាពឆ្មើងឆ្មៃ ។

សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៨:២៨ ព្ធ។ ។ សូមបង្ហាញថា ក្រោយពីលោកមរមនបានបង្ហាញពីការបារម្ភអំពីពួកសាសន៍នីហ្វៃ លោកបានមានប្រសាសន៍ថា « ចូរកូនអធិស្ឋានឲ្យពួកគេ ដើម្បីឲ្យពួកគេប្រែចិត្ត » ។ សូមរំពួកសិស្សពីអំណាចដែលអាចមកដល់ក្នុងជីវិតរបស់មនុស្ស នៅពេលអ្នកដទៃអធិស្ឋានសម្រាប់ពួកគេ ។

ដើម្បីបញ្ចប់មេរៀននេះ សូមឲ្យសិស្សចែកចាយពីអារម្មណ៍របស់គេអំពីអំណាចនៃដង្វាយធួនដើម្បីសង្គ្រោះដល់កូនក្មេងតូច និងសង្គ្រោះដល់យើងទាំងអស់គ្នា នៅពេលយើងខិតខំដើម្បីមានការស្មោះត្រង់ចំពោះសេចក្តីសញ្ញារបស់យើង ។

វិចារណកថា និង ព័ត៌មានសាច់រឿង

មរ៉ូណៃ ៨:៨ ។ « ពាក្យបណ្តាសាដល់លោកអ័ដាម ត្រូវបានយកចេញពីពួកកូនក្មេងទាំងនេះដោយសារយើង »

មនុស្សខ្លះជឿថា ដោយសារតែការធ្លាក់នៃលោកអ័ដាម និងអេវ៉ា នោះកូនក្មេងដែលកើតមកក្នុងពិភពលោកដោយមានអំពើបាប ។ ប្រធាន យ៉ូសែប ហ្វីលឌិង ស្មីធ បានពន្យល់ថា ការបង្រៀននេះគឺខុសឆ្គង ៖

« អ្នកទាំងអស់ណាដែលជឿថា មនុស្ស មែនហើយទោះបីជាកូនក្មេងដែលទើបកើតមកក្តីមាននូវ ‹ អំពើបាបដើម › (និយាយម្យ៉ាងទៀតថា ការរំលងរបស់លោកអ័ដាម) បដិសេធនូវសេចក្តីមេត្តាករុណានៃព្រះលោហិតធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ ព្រះគម្ពីរបរិសុទ្ធ (ក៏ដូចជាព្រះគម្ពីរសម័យទំនើបរបស់យើង) បង្រៀនថា ព្រះយេស៊ូវគ្រីស្ទទ្រង់ជួយយើងអស់ពីព្រះទ័យ ជាព្រះប្រោសលោះនៃមនុស្សជាតិចេញពីការធ្លាក់ ។ ទ្រង់បានបង់ថ្លៃ ដើម្បីឲ្យមនុស្សក្លាយជាអ្នកគ្រងមរតកតាមរយៈការរំលងរបស់លោកអ័ដាម ។ បំណុលមកលើព្រលឹងរបស់យើងត្រូវបានបង់ថ្លៃជំនួសពេញថ្លៃ ។ វាគ្មានបន្សល់នូវការពិន័យ ដែលតម្រូវឲ្យមនុស្សខ្លះធ្វើសកម្មភាពតាម ឬជំនួសឲ្យភាវៈដែលមានជីវិតនានាដើម្បីរំដោះខ្លួនគេពី ‹ អំពើបាបដើម › ឡើយ ។ គោលលទ្ធិដែលថា ទារកកើតមកក្នុងពិភពលោកនេះដោយមានពាក្យបណ្តាសានៃ ‹ អំពើបាបដើម › គឺជាគោលលទ្ធិខុសឆ្គងនៅក្នុងព្រះនេត្រនៃព្រះ ហើយវាបដិសេធនូវភាពជ៏អស្ចារ្យ និងសេចក្តីមេត្តានៃដង្វាយធួន ។ (សូមមើល មរ៉ូណៃ ជំពូកទី ៨ » ។ (*Church History and Modern Revelation: A Course of Study for the Melchizedek Priesthood Quorums,* រ៉ុលទី ៤ [ឆ្នាំ ១៩៤៩], ៤:៩៩) ។

មរ៉ូណៃ ៨:៨–២៤ ។ បុណ្យជ្រមុជទឹកដល់ទារក

ព្យាការី យ៉ូសែប ស្មីធ បានបង្រៀនថា កូនក្មេងតូចមិនត្រូវទទួលពិធីបុណជ្រមុជទឹក ៖

« ‹ តើ[យើង]ជឿដល់បុណ្យជ្រមុជទឹកសម្រាប់ទារកទេ › ? . . . លេខ . . . ដោយសារវាមិនបានសរសេរនៅក្នុងព្រះគម្ពីរបរិសុទ្ធឡើយ ។ . . . បុណ្យជ្រមុជទឹកគឺសម្រាប់ការផ្តាច់បាប ។ កូនក្មេងគ្មានបាបនោះទេ ។ . . . កូនក្មេងត្រូវរស់នៅក្នុងព្រះគ្រីស្ទទាំងអស់គ្នា និងអ្នកដែលទុំច្រើនឆ្នាំតាមរយៈសេចក្តីជំនឿ និងការប្រែចិត្ត » (*History of the Church,* ៥:៤៩៩) ។

ប្រធាន បិយដ៍ យេ ផាកកឺ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានប្រាប់ពីពួកអ្នកផ្សាយសាសនាពេញម៉ោងដែលអាចលួងលោកដល់អ្នកម្តាយម្នាក់ ដែលមានទុក្ខក្រៀមក្រំដោយសារកូនប្រុសរបស់គាត់បានស្លាប់ ៖

« អ្នកផ្សព្វផ្សាយសាសនាពីរូបបានបម្រើនៅតំបន់ភ្នំភាគខាងត្បូងនៃសហរដ្ឋអាមេរិក ។ ថ្ងៃមួយ ដោយមើលពីកំពូលភ្នំ ពួកគេបានឃើញមនុស្សប្រជុំគ្នានៅតំបន់ដ៏ឆ្ងាយមួយនៅផ្នែកខាងក្រោម ។ ជាញឹកញាប់ អ្នកផ្សព្វផ្សាយសាសនានោះ មិនសូវមានមនុស្សច្រើនដើម្បីបង្រៀននោះទេ ដូច្នេះពួកគេបានធ្វើដំណើរចុះទៅកន្លែងដែលមើលឃើញច្បាស់នោះ ។

« ក្មេងប្រុសម្នាក់បានលង់ទឹក ហើយគេកំពុងធ្វើបុណ្យសព ។ ឪពុកម្តាយរបស់គេ បានសុំគ្រូគង្វាលដើម្បី ‹ និយាយពាក្យខ្លះ › អំពីកូនប្រុសរបស់គេ ។ អ្នកផ្សព្វផ្សាយសាសនានោះ បានឈរនៅខាងក្រោយ នៅពេលគ្រូគង្វាលបានមើលទៅឪពុក និងម្តាយដ៏ក្រៀមក្រំ ហើយបានចាប់ផ្តើមទេសនកថារបស់លោក ។ ប្រសិនបើឪពុកម្តាយនោះបានរំពឹងថានឹងទទួលបានការលួងលោមពីបុរសនេះ នោះពួកគេនឹងបាក់ទឹកចិត្ត ។

« លោកបានបន្ទោសដល់ពួកគេយ៉ាងធ្ងន់ថាមិនបានឲ្យក្មេងប្រុសនេះទទួលបុណ្យជ្រមុជទឹក ។ ពួកគេបានរង់ចាំ ដោយសាររឿងនេះរឿងនោះ ហើយឥឡូវនេះ វាយឺតពេលហើយ ។ លោកបានប្រាប់ពួកគេត្រង់ៗច្បាស់ថា កូនប្រុសរបស់គេបានធ្លាក់ទៅក្នុងនរកហើយ ។ វាគឺជាកំហុសរបស់គេ ។ ពួកគេត្រូវតែទទួលការបន្ទោសចំពោះការដាក់ទោសដ៏ឥតមានទីបញ្ចប់នេះ ។

« ក្រោយពីទេសនកថាបានបញ្ចប់ទៅ ហើយផ្ទូរត្រូវបានកប់ត្រឹមត្រូវហើយ ពួកអែលឌើរបានទៅរកឪពុកម្តាយដែលកើតទុក្ខនោះ ។ ‹ យើងគឺជាអ្នកបម្រើរបស់ព្រះអម្ចាស់ › ពួកគេបានប្រាប់អ្នកម្តាយនោះទៀតថា ‹ ហើយយើងមកដោយមានសារលិខិតមួយដល់អ្នក › ។ នៅពេលឪពុកម្តាយដ៏កំសត់នោះបានស្តាប់ ពួកអែលឌើរទាំងពីរបានអានពីវិវរណៈ និងបានថ្លែងទីបន្ទាល់អំពីការស្តារឡើងវិញនៃកូនសោរសម្រាប់សេចក្តីប្រោសលោះដល់ទាំងអ្នកនៅរស់ និងអ្នកស្លាប់ ។

« ខ្ញុំមានការអាណិតដល់អ្នកបង្រៀននោះ ។ គាត់បានធ្វើអស់ពីសមត្ថភាពដោយមានពន្លឺ និងចំណេះដឹងដែលគាត់បានមាននោះ ។ ប៉ុន្តែវាមានបន្ថែមទៀតដែលគាត់គួរតែអាចផ្តល់ ។ វាមានភាពពោរពេញនៃដំណឹងល្អ ។

« ពួកអែលឌើរបានមកក្នុងនាមជាអ្នកលួងលោម ជាគ្រូបង្រៀន ជាអ្នកបម្រើរបស់ព្រះអម្ចាស់ ជាអ្នកបម្រើដែលមានការ អនុញ្ញាតក្នុងការផ្សាយដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ » (« And a Little Child Shall Lead Them » *Ensign* ឬ *លីអាហូណា,* ខែ ឧសភា ឆ្នាំ ២០១២, ទំព័រ ៧) ។

មេរៀនទី ១៥៨

មរ៉ូណៃ ៩

សេចក្តីផ្តើម

នៅក្នុងសំបុត្រដែលត្រូវបានកត់ត្រាចុងក្រោយគេដល់កូនប្រុសរបស់លោក គឺមរ៉ូណៃ លោកមរមនបានកើតទុកដោយសារសភាពដ៏ទុច្ចរិតរបស់ពួកសាសន៍នីហ្វៃ ។ លោកបានសុំឲ្យមរ៉ូណៃធ្វើការយ៉ាងឧស្សាហ៍ដើម្បីជួយឲ្យពួកសាសន៍នីហ្វៃប្រែចិត្ត ។ លោកមរមនក៏បានរៀបរាប់ពីការរងទុក្ខរបស់ប្រជាជន ដែលបណ្តាលមកពីអំពើទុច្ចរិតរបស់ពួកគេ ។ ថ្វីបើមានស្ថានភាពពុករលួយក្នុងចំណោមប្រជាជនក្តី លោកបានលើកទឹកចិត្តដល់មរ៉ូណៃឲ្យស្មោះត្រង់នៅក្នុងព្រះយេស៊ូវគ្រីស្ទ ហើយមានសេចក្តីសង្ឃឹមនៅក្នុងសេចក្តីសន្យានៃជីវិតដ៏នៅអស់កល្បជានិច្ច ។

យោបល់សម្រាប់ការបង្រៀន

មរ៉ូណៃ ៩:១–២០

លោកមរមនត្អូញត្អែរដោយសារអំពើទុច្ចរិតរបស់ពួកសាសន៍នីហ្វៃ និងពួកសាសន៍លេមិន

សូមឲ្យសិស្សសញ្ជឹងគិតថាតើពួកគេធ្លាប់បានព្យាយាមជួយដល់នរណាម្នាក់ តែទង្វើររបស់ពួកគេត្រូវបានបដិសេធ ។

- តើមនុស្សខ្លះអាចប្រតិកម្មយ៉ាងណា នៅពេលបំណងល្អរបស់ពួកគេត្រូវបានបដិសេធម្តងហើយម្តងទៀត ដោយសារអ្នកដែលពួកគេព្យាយាមជួយនោះ ?

សូមពន្យល់ដល់សិស្សថា មរ៉ូណៃ ៩ គឺជាសំបុត្រមួយដែលបានសរសេរដោយព្យាការី មរមន ដល់កូនបុស្ររបស់លោក គឺមរ៉ូណៃ ។ សូមឲ្យពួកគេរកមើលរបៀបដែលលោកមរមនបានលើកទឹកចិត្តដល់កូនប្រុសរបស់លោក ។

សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៩:១ ព្ម ៣ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលពាក្យដែលលោកមរមនបានប្រើដើម្បីរៀបរាប់ពីស្ថានភាពរបស់ពួកសាសន៍នីហ្វៃ ។ ក្រោយពីសិស្សឆ្លើយហើយ អ្នកអាចពន្យល់ថាពាក្យ *ក្តីទុក្ខព្រួយ* សំដៅលើអ្វីមួយដែលឈឺចាប់ខ្លាំង តានតឹង ឬ ដែលសោកស្តាយខ្លាំង ។

សូមសរសេរសេចក្តីយោងព្រះគម្ពីរខាងក្រោមនៅលើក្តារខៀន ៖ *មរ៉ូណៃ ៩:២–៥; មរ៉ូណៃ ៩:៧–១០; មរ៉ូណៃ ៩:១៦–១៩* ។ សូមបែងចែកសិស្សជាបីក្រុម ។ សូមឲ្យក្រុមនីមួយ ៣អានវគ្គព្រះគម្ពីរមួយដែលសរសេរនៅលើក្តារខៀន ដោយរកមើលការណ៍ដែលប្រកបទៅដោយក្តីទុក្ខព្រួយ ដែលលោកមរមនបានរៀបរាប់ ។ សូមឲ្យសិស្សម្នាក់ពីក្រុមនីមួយ ៣រៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។ (ប្រសិនបើសិស្សត្រូវបានចាត់ឲ្យអាន មរ៉ូណៃ ៩:២–៥ មិនបានលើកឡើងពីកំហឹង នោះអ្នកអាចលើកឡើងពីតួនាទីដែលកំហឹងមាននៅក្នុងហេតុការណ៍ដ៏អាក្រក់ដែលលោកមរមនបានរៀបរាប់នោះ) ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានព្ម ៣ពី មរ៉ូណៃ ៩:១១–១៥, ២០ ។ សូមឲ្យសិស្សរកមើលមូលហេតុដែលលោកមរមនមានទុក្ខព្រួយដោយសារស្ថានភាពនៃប្រជាជនរបស់លោក ។ សូមសូរសំណូរខាងក្រោមនេះដើម្បីជួយសិស្សឲ្យវិភាគខគម្ពីរទាំងនេះ ។

- តើអ្នកគិតថា វាមានន័យយ៉ាងណាបើ « គ្មានអារ្យធម៌ » ? (មរ៉ូណៃ ៩:១១) ។ ទង្វើរដែលគ្មានអារ្យធម៌—ដោយគ្មានការបន្តឹង ឬ ការរឹតត្បិត ការគ្មានការគោរពដល់បុគ្គលផ្សេងទៀត ការមិនគោរពច្បាប់ដែលគ្រងគ្រងសង្គមមួយទាំងមូល) ។
- តើអ្នកគិតថា វាមានន័យយ៉ាងណាបើ « គ្មានក្រិត្យវិន័យ » ? (មរ៉ូណៃ ៩:២០) ។ (ការរស់នៅដោយគ្មានបទដ្ឋាន និងគ្មានការផ្តល់កិត្តិយស និងកាន់តាមព្រះបញ្ញត្តិរបស់ព្រះ) ។
- តើអ្នកគិតថា « ចិត្តវក់ » មានន័យយ៉ាងណា ? (មរ៉ូណៃ ៩:២០) ។ (ការមានចិត្តរឹងទទឹងនឹងព្រះវិញ្ញាណនៃព្រះអម្ចាស់ និងពន្លឺនៃព្រះគ្រីស្ទ ព្រមទាំងមិនបែងចែករវាងការល្អ និងការខុសឆ្គង) ។
- តើមានភស្តុតាងអ្វីខ្លះដែលអ្នកឃើញនៅក្នុងពិភពលោកនាពេលសព្វថ្ងៃនេះ ដែលមនុស្សខ្លះគ្មានអារ្យធម៌ គ្មានក្រឹត្យវិន័យ និងមានចិត្តវក់ ?

អ្នកអាចបង្ហាញថា លោកមរមនបានមានប្រសាសន៍ថា ប្រជាជនរបស់លោកទើបតែបានធ្លាក់ទៅក្នុងសភាពនៃអំពើទុច្ចរិតនេះពីរបីឆ្នាំប៉ុណ្ណោះ (សូមមើល មរ៉ូណៃ ៩:១២) ។

សូមពន្យល់ថា ស្ទើរតែដូចជាព្យាការី អេធើរ នៃជាតិសាសន៍យ៉ារេឧ លោកមរមនបានធ្វើជាសាក្សីនៃកំហឹង និងអំពើទុច្ចរិតដែលបានយកឈ្នះលើប្រជាជនរបស់លោក ។ សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៩:៤ ព្ម ៣ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយរកមើលអ្វីដែលលោកមរមនបានភ័យខ្លាចអំពីពួកសាសន៍នីហ្វៃ ។ (លោកបានខ្លាចថា « ព្រះវិញ្ញាណនៃព្រះអម្ចាស់ [បាន] ឈប់តស៊ូគង់នៅជាមួយនឹងពួកគេ ») ។

- លោកមរមនបានលើកឡើងថា លោកបាន « ព្យាយាមធ្វើការជាមួយ [ប្រជាជនរបស់លោក] » ។ ហេតុអ្វីបានជាលោកមរមន ឬ អ្នកដឹកនាំសាសនាចក្រសព្វថ្ងៃនេះអាចបន្តធ្វើការនៅក្នុងចំណោមមនុស្សដែលខឹង ឬមានចិត្តរឹងរូសទាស់នឹងព្រះបន្ទូលព្រះ ?

សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***យើងត្រូវធ្វើការដោយព្យាយាមនៅក្នុងការបម្រើដល់ព្រះ ទោះបីជាអ្នកដែលយើងបម្រើមិនឆ្លើយតបជាវិជ្ជមានក្តី ។*** សូមពន្យល់ថា នេះគឺជាការពិត ទោះបីជានៅពេលមនុស្សដែលយើងបម្រើមានអំពើបាបដ៏ធ្ងន់ធ្ងរ

ការបង្រៀនដ៏ឈ្លាសវៃ

នៅពេលអ្នកសម្រេចចិត្តពីអ្វីដែលត្រូវបង្រៀនពីបណ្តុំបទគម្ពីរ និងពីវិធីបង្រៀន ហើយ សូមជ្រើសរើសសេចក្តីពិត និងរបៀបដើម្បីបង្រៀនដែលនឹងជួយសិស្ស និងអនុញ្ញាតឲ្យពួកគេអាចត្រូវបានលើកឡើងដោយព្រះវិញ្ញាណបរិសុទ្ធ ។

ក្តី ។ សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ៩:៦ ព្ធ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលមូលហេតុដែលយើងត្រូវធ្វើការដោយ ព្យាយាមនៅក្នុងការបម្រើដល់ព្រះ ទោះបីជាអ្នកដែលយើងបម្រើមិនឆ្លើយតបជាវិជ្ជមានក្តី ។ ក្រោយពីសិស្សរៀបរាប់ពីអ្វីដែលពួកគេ បានរកឃើញហើយ សូមបង្ហាញស្ថានភាពខាងក្រោមដល់ពួកគេ (ឬបង្កើតថ្មីពីរបី) ដើម្បីជួយដល់ពួកគេឲ្យគិតអំពីរបៀបដែលការពិត នេះអាចអនុវត្តបាននៅក្នុងជីវិតរបស់ពួកគេ ។ សូមឲ្យសិស្សម្នាក់ ឬច្រើននាក់ពន្យល់ពីរបៀបដែលពួកគេអាចអនុវត្តសេចក្តីពិតនៅលើ ក្តារខៀននៅក្នុងស្ថានភាពនីមួយ ៗដែលអ្នកបង្ហាញនេះ ។

១. ក្នុងនាមជាប្រធានថ្នាក់យុវនារីរបស់អ្នក អ្នកត្រូវទទួលខុសត្រូវចំពោះយុវនារីប្រាំនាក់នៅក្នុងវួដរបស់អ្នក ។ យុវនារីម្នាក់មិនបានមក ចូលរួមការប្រជុំក្នុងព្រះវិហារ ឬសកម្មភាពនានាអស់រយៈពេលមួយឆ្នាំហើយ ។ ក្រោយពីអ្នកបានអញ្ជើញនាងឲ្យមកវិញកាលពីបីខែ មុន នាងនៅតែមិនបានមកចូលរួមការប្រជុំ ឬសកម្មភាពនានាដដែល ។

២. ក្នុងនាមជាគ្រូបង្រៀនតាមផ្ទះ អ្នកធ្វើការបម្រើដោយឧស្សាហ៍ដើម្បីបង្រៀនដល់គ្រួសារដែលអ្នកត្រូវបានចាត់តាំងឲ្យទៅបង្រៀន ។ ទោះជាយ៉ាងណាក្តី រយៈពេលពីរបីខែកន្លងទៅ គ្រួសារមួយដែលអ្នកទៅបង្រៀនមិនបានទទួលទូរសព្ទ៍ ឬបើកទ្វារនៅពេលអ្នកបាន ទៅលេងនោះទេ ។

៣. អ្នកមានអារម្មណ៍បំផុសឲ្យអញ្ជើញមិត្តល្អរបស់អ្នកម្មាក់ឲ្យជួបជាមួយនឹងអ្នកផ្សព្វផ្សាយសាសនា ។ គេបដិសេធការអញ្ជើញរបស់អ្នក ហើយអ្នកនៅតែបន្តមានអារម្មណ៍បំផុសដើម្បីសុំដល់គាត់ម្តងទៀត ។

សូមចែកចាយនូវសេចក្តីថ្លែងការណ៍ខាងក្រោមដោយប្រធាន ហិនរី បឺ អាវរិង នៃគណៈប្រធានទីមួយ ដែលបានលើកទឹកចិត្តយើងឲ្យ បន្តការខិតខំបម្រើនៅក្នុងចំណោមកូនចៅរបស់ព្រះ ។ សូមឲ្យសិស្សស្តាប់រកអ្វីដែលជម្រុញឲ្យពួកគេបម្រើដោយឧស្សាហ៍ដើម្បីជួយដល់ អ្នកដទៃ ។

« វាគឺជាសេចក្តីសញ្ញាមួយដែលយើងបានធ្វើជាមួយនឹងព្រះដើម្បីកាន់តាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ និង ធ្វើការបម្រើដូចដែលទ្រង់នឹងធ្វើ ប្រសិនបើទ្រង់មានវត្តមាននៅទីនោះ ។ ការរស់នៅតាមបទដ្ឋាននោះឲ្យអស់ពី លទ្ធភាពដែលយើងអាច បង្កើនកម្លាំងដែលយើងនឹងត្រូវការដើម្បីកាន់ខ្ជាប់ដរាបដល់ចុងបំផុត ។

« អ្នកហ្វឹកហ្វឺនបព្វជិតភាពដ៏អស្ចារ្យបានបង្ហាញដល់ខ្ញុំនូវរបៀបដើម្បីកសាងកម្លាំងនោះ ៖ វាត្រូវការបង្កើត ទម្លាប់មួយដើម្បីបន្តទៅមុខ ឆ្លងកាត់ភាពនឿយហត់ និងការភ័យខ្លាចដែលអាចធ្វើឲ្យអ្នកគិតថានឹងចង់ឈប់ ។ អ្នកបង្រៀនដ៏អស្ចារ្យរបស់ព្រះអម្ចាស់បានបង្ហាញដល់ខ្ញុំថា អំណាចស្ថិតនៅខាងវិញ្ញាណបានមកពីការខិតខំធ្វើឥត ឈប់ឈរ កាលដែលអ្នកដទៃចង់ឈប់សម្រាក ។ . . .

« . . . ខ្ញុំសន្យាដល់អ្នកថា ប្រសិនបើអ្នកធ្វើនូវការណ៍ទាំងអស់ដែលអ្នកអាចធ្វើបាន នោះព្រះនឹងពង្រឹងដល់កម្លាំងរបស់អ្នក និង ចំណេះដឹងរបស់អ្នក » (« Preparation in the Priesthood: ‹ I Need Your Help › » *Ensign* ឬ *លីអាហូណា*, ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ៥៨–៥៩) ។

- តើប្រធាន អាវរិង បានបង្រៀនអ្វីខ្លះ ដែលជម្រុញឲ្យអ្នកធ្វើការដោយឧស្សាហ៍នៅក្នុងការបម្រើរបស់អ្នកដល់ព្រះអម្ចាស់ ដោយមិន គិតពីរបៀបដែលការខិតខំរបស់អ្នកត្រូវបានទទួលនោះ ?

សូមអាននូវរឿងខាងក្រោមដោយអែលឌើរ មើវីន បឺ អាណូល នៃក្រុមចិតសិបនាក់អំពីអ្នកដឹកនាំបព្វជិតភាពម្នាក់ដែលបានបម្រើ ដោយឧស្សាហ៍ដល់យុវជនម្នាក់ ទោះបីជាគាត់បានបដិសេធន៍ច្រើនដងហើយក្តី ៖ សូមឲ្យសិស្សស្តាប់រកអ្វីដែលយុវជននោះបានឃើញ នៅទីបញ្ចប់នៅក្នុងអ្នកដឹកនាំបព្វជិតភាពរបស់គាត់ ។

« ក្នុងនាមជាសមាជិកនៃគណៈប្រធានសាខា ហ្វតធេលេហ្សា ប្រទេសប្រេស៊ីល បងប្រុស ម៉ាក ជាមួយនឹងអ្នកដឹកនាំបព្វជិតភាព ផ្សេងទៀតបានអភិវឌ្ឍគម្រោងមួយដើម្បីធ្វើឲ្យអ្នកដែលមិនសូវសកម្មនៅក្នុងសាខារបស់លោកបែរជាសកម្មវិញ ។ មានសមាជិកជា យុវជនម្នាក់មិនសូវសកម្ម ដែលមានឈ្មោះថា ហ្វែរណាដូ អារូយូ ។ ថ្មីៗនេះ ខ្ញុំបាននិយាយជាមួយហ្វែរណាដូ ហើយគាត់បានប្រាប់ខ្ញុំពី បទពិសោធន៍របស់គាត់ ៖

« ‹ ខ្ញុំបានចូលរួមនៅក្នុងការប្រកូតជិះស្គីលើទឹកនៅពេលព្រឹកថ្ងៃអាទិត្យ ហើយបានឈប់ទៅចូលរួមការប្រជុំក្នុងព្រះវិហារ ។ នៅព្រឹក ថ្ងៃអាទិត្យមួយ បងប្រុសម៉ាក បានគោះទ្វារផ្ទះខ្ញុំ ហើយបានសុំម្តាយដែលមិនមែនជាសមាជិករបស់ខ្ញុំថា តើគាត់អាចនិយាយជាមួយនឹង ខ្ញុំបានទេ ។ នៅពេលម្តាយខ្ញុំបានប្រាប់គាត់ថា ខ្ញុំកំពុងតែដេក នោះគាត់បានសុំការអនុញ្ញាតដើម្បីដាស់ខ្ញុំ ។ គាត់បាននិយាយមកកាន់ខ្ញុំ ថា « ហ្វែរណាដូ ប្អូនយឺតទៅព្រះវិហារហើយ ! » ដោយមិនបានស្តាប់ការដោះសាររបស់ខ្ញុំ គាត់បាននាំខ្ញុំទៅព្រះវិហារ › ។

« ‹ ថ្ងៃអាទិត្យក្រោយ រឿងដដែលបានកើតឡើង ដូច្នេះនៅថ្ងៃអាទិត្យទីបី ខ្ញុំបានសម្រេចចិត្តចេញពីផ្ទះពីព្រលឹមដើម្បីគេចពីគាត់ ។ នៅពេលខ្ញុំបានបើកទ្វាររបង ខ្ញុំបានឃើញគាត់អង្គុយនៅក្នុងឡានរបស់គាត់ កំពុងអានព្រះគម្ពីរ ។ នៅពេលគាត់បានឃើញខ្ញុំ គាត់បាន និយាយថា « ល្អ ! ប្អូនបានក្រោកពីព្រលឹម ។ ថ្ងៃនេះ យើងនឹងទៅរកយុវជនផ្សេងទៀត ! » ខ្ញុំបាននិយាយដល់សិទ្ធិជ្រើសរើសរបស់ខ្ញុំ ប៉ុន្តែគាត់បាននិយាយថា « យើងអាចនិយាយអំពីរឿងនេះពេលក្រោយ › » ។

« ‹ អស់រយៈពេលប្រាំបីអាទិត្យក្រោយមក ខ្ញុំមិនអាចគេចចេញពីគាត់បាន ដូច្នេះខ្ញុំក៏សម្រេចចិត្តទៅដេកនៅឯផ្ទះមិត្តភក្តិរបស់ខ្ញុំម្នាក់ ។ ខ្ញុំបានទៅឯសមុទ្រនាព្រឹកបន្ទាប់ នៅពេលខ្ញុំបានឃើញបុរសម្នាក់ស្លៀកពាក់ខោអាវធំ និងមានក្រវ៉ាត់កដើរសំដៅមកខ្ញុំ ។ នៅពេល ខ្ញុំបានឃើញគាត់ នោះគឺជាបងប្រុសម៉ាក ខ្ញុំបានរត់ចូលក្នុងសមុទ្រ ។ មួយរំពេចនោះ ខ្ញុំបានមានអារម្មណ៍ថា ដៃរបស់នរណាម្នាក់ បានចាប់ស្មារបស់ខ្ញុំ ។ គឺបងប្រុសម៉ាក នៅក្នុងទឹកត្រឹមទ្រូងរបស់គាត់ ! គាត់បានចាប់ដៃខ្ញុំហើយបាននិយាយថា « ប្អូនយឺតហើយ » តោះ ទៅព្រះវិហារ » ។ នៅពេលខ្ញុំដោះសារថា ខ្ញុំមិនមានសំលៀកបំពាក់ទេ គាត់បានឆ្លើយថា « សំលៀកបំពាក់ប្អូនមាននៅក្នុង ឡានហើយ › » ។

« ‹ នៅថ្ងៃនោះ នៅពេលយើងដើរចេញពីសមុទ្រ ខ្ញុំបានចាប់ជ្រោតជ្រាបពីសេចក្តីស្រឡាញ់ដ៏ស្មោះពីបងប្រុសម៉ាក និងការបារម្ភរបស់ គាត់ចំពោះខ្ញុំ ។ . . . បងប្រុសម៉ាកមិនត្រឹមតែបានផ្តល់ឲ្យខ្ញុំនូវឡានជិះទៅព្រះវិហារប៉ុណ្ណោះទេ —ក្រវ៉ុមនោះបានធានាថា ខ្ញុំនឹងនៅ

បន្តសកម្ម ។ ពួកគាត់បានគ្រោងសកម្មភាពដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ថាខ្ញុំសំខាន់ ហើយគេត្រូវការខ្ញុំខ្ញុំបានទទួលការហៅបម្រើ ហើយសមាជិកក្លុំមក្លាយជាមិត្តភក្តិរបស់ខ្ញុំ › » (« Strengthen Thy Brethren » *Ensign* ឬ ***លីអាហូណា***, ខែ ឧសភា ឆ្នាំ ២០០៤, ទំព័រ ៤៦–៤៧) ។

សូមពន្យល់ថា ក្នុងនាមជាសមាជិកនៃសាសនាចក្រ យើងទាំងអស់គ្នាមានការងារដ៏សំខាន់ដើម្បីធ្វើនៅក្នុងជីវិតនេះ ។ គំរូរបស់លោក មរមន ម៉ូរ៉ូណៃ និងបងប្រុសម៉ាកអាចលើកទឹកចិត្តយើងឲ្យធ្វើការទាំងនោះ នៅពេលយើងបាក់ទឹកចិត្ត ឬឃើញថាខ្លួនឯងត្រូវបានបដិសេធដោយអ្នកដែលយើងចង់បម្រើ ។

ម៉ូរ៉ូណៃ ៩:២១–២៦

លោកមរមនលើកទឹកចិត្តម៉ូរ៉ូណៃឲ្យនៅស្មោះត្រង់

សូមឲ្យសិស្សដាក់ឈ្មោះហេតុការណ៍ថ្មីៗនេះនៅក្នុងសហគមន៍ ឬប្រទេសរបស់គេ ឬនៅក្នុងពិភពលោកដែលអាចបណ្តាលឲ្យមនុស្សមានអារម្មណ៍ថាបាក់ទឹកចិត្ត ។

សូមឲ្យសិស្សម្នាក់អាន ម៉ូរ៉ូណៃ ៩:២១–២២, ២៥–២៦ ដោយស្ងាត់ស្ងៀម ។ សូមឲ្យពួកគេរកមើលការប្រឹក្សាដែលលោកមរមនបានផ្តល់ដល់ម៉ូរ៉ូណៃអំពីអ្វីដែលលោកគួរធ្វើ ពេលស្ថិតក្នុងស្ថានភាពបាក់ទឹកចិត្ត ។ សូមសួរសំណួរខាងក្រោមនេះ ដើម្បីជួយសិស្សឲ្យវិភាគខគម្ពីរទាំងនេះ ។

- នៅក្នុងខគម្ពីរទាំងនេះ តើពាក្យ និងឃ្លាមួយណាដែលបង្ហាញពីអារម្មណ៍របស់លោកមរមនចំពោះកូនប្រុសរបស់លោក ម៉ូរ៉ូណៃ ?
- តើលោកមរមនបានផ្តល់យោបល់អ្វីខ្លះដើម្បី « ស្ថិតនៅក្នុងគំនិត | របស់ម៉ូរ៉ូណៃ | រៀងរហូតតទៅ » ? (ម៉ូរ៉ូណៃ ៩:២៥) ។ តើការចងចាំដល់ព្រះអង្គសង្គ្រោះ និងដង្វាយធួនរបស់ទ្រង់អាចជួយយើង នៅពេលបាក់ទឹកចិត្ត ឬនៅពេលយើងហ៊ុំព័ទ្ធដោយអំពើទុច្ចរិតដោយរបៀបណា ?
- តើយើងអាចរៀនអ្វីខ្លះពីខគម្ពីរទាំងនេះអំពីរបៀបឆ្លើយតបទៅនឹងភាពលំបាក និងអំពើទុច្ចរិតដែលអាចហ៊ុំព័ទ្ធយើង ? (ទោះបីជាសិស្សអាចប្រើពាក្យខុសគ្នា ពួកគេគួរបង្ហាញថា **ប្រសិនបើយើងនៅស្មោះត្រង់ក្នុងព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹងតម្កើងយើងឡើង ទោះបីជានៅពេលមានភាពលំបាក និងអំពើទុច្ចរិតជុំវិញយើងក្តី ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន ហើយអ្នកអាចណែនាំថា សិស្សគួរសរសេរវានៅក្នុងព្រះគម្ពីររបស់គេ) ។
- តើមានបទពិសោធន៍អ្វីខ្លះ នៅក្នុងជីវិតរបស់អ្នក ឬនៅក្នុងជីវិតរបស់អ្នកដែលជិតស្និទ្ធនឹងអ្នកដែលបង្ហាញថា គោលការណ៍នេះគឺពិត ?

សូមលើកទឹកចិត្តសិស្សឲ្យសញ្ជឹងគិតពីរបៀបដែលពួកគេអាចកាន់តែស្មោះត្រង់ និងកាន់តែគិតអំពីព្រះយេស៊ូវគ្រីស្ទ ទោះបីជានៅពេលពួកគេបាក់ទឹកចិត្ត ឬហ៊ុំពទ្ធំដោយអំពើទុច្ចរិតក្តី ។ សូមធ្វើទីបន្ទាល់អំពីកម្លាំងដែលអ្នកបានទទួលពីការនៅស្មោះត្រង់នៅក្នុងព្រះយេស៊ូវគ្រីស្ទ ។

មរ៉ូណៃ ១០:១–៧, ២៧–២៩

សេចក្តីផ្តើម

លោកមរ៉ូណៃបានដាស់តឿនដល់ពួកសាសន៍លេមិន និងអ្នកផ្សេងទៀតដែលនឹងអានទីបន្ទាល់របស់លោក ឲ្យសុំដល់ព្រះដើម្បីបញ្ជាក់ពីសេចក្តីពិតនៃពាក្យសម្តីរបស់លោក ។ លោកបានបង្រៀនថា ព្រះនឹងបញ្ជាក់ពីសេចក្តីពិតនៃព្រះគម្ពីរមរមន និងពីការមានពិតនៃព្រះយេស៊ូវគ្រីស្ទដោយព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ។ មរ៉ូណៃក៏បានប្រកាសថា លោកនឹងជួបយើងមុនពេលជំនុំជម្រះរបស់ព្រះ ដែលព្រះអម្ចាស់ទ្រង់ផ្ទាល់នឹងបញ្ជាក់ពីសេចក្តីពិតនៃពាក្យសម្តីរបស់លោកមរ៉ូណៃនេះ ។ (*កំណត់ចំណាំ ៖* អ្នកអាចទុកពេលនៅចុងបញ្ចប់នៃមេរៀនេះសម្រាប់សិស្សឲ្យចែកចាយពីទីបន្ទាល់របស់គេអំពីព្រះគម្ពីរមរមន ។ ដើម្បីធានាថាមានពេលគ្រប់គ្រាន់ សូមជ្រើសរើសប្រកបដោយការអធិស្ឋាន ពីសយកចំណែកនៃមេរៀននេះដែលនឹងមានប្រយោជន៍ដល់សិស្សរបស់អ្នក) ។

ការចែករំលែកទីបន្ទាល់របស់អ្នក

សូមយកឱកាសឲ្យបានញឹកញាប់ដើម្បីធ្វើទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ ដំណឹងល្អរបស់ទ្រង់ និងព្រះគម្ពីរមរមន ។ សូមលើកទឹកចិត្តសិស្សឲ្យធ្វើទីបន្ទាល់ផងដែរ ។ ការចែករំលែកទីបន្ទាល់ ប្រទានពរដល់មនុស្សដែលថ្លែងទីបន្ទាល់នោះផ្ទាល់ ហើយក៏អាចពង្រឹងដល់សេចក្តីជំនឿ និងទីបន្ទាល់របស់អ្នកដទៃទៀតផងដែរ ។

យោបល់សម្រាប់ការបង្រៀន

មរ៉ូណៃ ១០:១–៧

លោកមរ៉ូណៃដាស់តឿនយើងឲ្យទទួលបាននូវទីបន្ទាល់មួយអំពីព្រះគម្ពីរមរមន និងអំពីព្រះយេស៊ូវគ្រីស្ទ

មុនពេលចាប់ផ្តើមបង្រៀន សូមគូសរូបភ្លោងទ្វារមួយដោយមានថ្មគោលនៅលើក្តារខៀន (អ្នកអាចបើកទៅរូបភាពដែលប្រើនៅក្នុងមេរៀនទី ៤ បាន) ។ សូមចាប់ផ្តើមមេរៀនដោយបើកទៅរូបភាពនេះ ។

- តើអ្វីជាគោលបំណងនៃថ្មគោលនៃភ្លោងទ្វារនេះ ?
- តើថ្មគោលនេះទាក់ទងទៅនឹងព្រះគម្ពីរមរមនយ៉ាងដូចម្តេច ? (ប្រសិនបើសិស្សត្រូវការជំនួយ ក្នុងការឆ្លើយនឹងសំណួរនេះ អ្នកអាចណែនាំថា ពួកគេគួរអានប្រយោគរបស់ព្យាការី យ៉ូសែប ស៊្មីធ នៅក្នុងកថាខណ្ឌទីប្រាំមួយនៃបុព្វកថានៃព្រះគម្ពីរមរមន) ។

សូមឲ្យសិស្សអានកថាខណ្ឌចុងក្រោយដោយស្ងាត់ស្ងៀមក្នុងបុព្វកថានៃព្រះគម្ពីរមរមន ។ មុនពេលពួកគេអាន សូមឲ្យពួកគេរកមើលសេចក្តីពិតបីយ៉ាងដែលបុគ្គលម្នាក់អាចដឹង ដោយការទទួលបានទីបន្ទាល់អំពីព្រះគម្ពីរមរមន ។

- តើដូចជាភ្លោងទ្វារដែលត្រូវបានដាក់រួមគ្នាពីថ្មគោល តើផ្នែកផ្សេងទៀតណាខ្លះនៃទីបន្ទាល់របស់យើងត្រូវបានពង្រឹងដោយការទទួលបានទីបន្ទាល់អំពីព្រះគម្ពីរមរមន ?
- ហេតុអ្វីបានជាវាសំខាន់សម្រាប់បុគ្គលម្នាក់ៗដើម្បីទទួលបាននូវទីបន្ទាល់ផ្ទាល់ខ្លួនអំពីព្រះគម្ពីរមរមន ?

សូមសង្ខេប មរ៉ូណៃ ១០:១–២ ដោយការពន្យល់ថាប្រហែលជា ១,៤០០ ឆ្នាំ មុនពេលព្យាការី យ៉ូសែប ស៊្មីធ បានទទួលឆ្នាំងមាស លោកមរ៉ូណៃបានបញ្ចប់កំណត់ត្រាពីឪពុករបស់លោកដោយការសរសេរនូវការដាស់តឿនលើកចុងក្រោយរបស់លោកដល់អ្នកដែលនឹងទទួលបានព្រះគម្ពីរមរមននៅក្នុងថ្ងៃចុងក្រោយនេះ ។ (វាប្រហែលជានឹងជួយបានច្រើនក្នុងការពន្យល់ពាក្យ *ដាស់តឿន* មានន័យថាលើកទឹកចិត្ត ឬជម្រុញដល់នរណាម្នាក់យ៉ាងមុតមាំ ។ ពាក្យនេះលេចឡើងប្រាំបីដងនៅក្នុង មរ៉ូណៃ ១០) ។

សូមពន្យល់ថា លោកមរ៉ូណៃបានដាស់តឿនដល់អ្នកទាំងឡាយណាដែលទទួលបានព្រះគម្ពីរមរមន ឲ្យស្វែងរកនូវទីបន្ទាល់មួយអំពីសេចក្តីពិត និងទេវភាពនៃគម្ពីរនេះ ។ សូមឲ្យសិស្សអាន មរ៉ូណៃ ១០:៣–៤ ដោយស្ងាត់ស្ងៀមដោយរកមើលឃ្លាដែលរៀបរាប់ពីតម្រូវការដើម្បីទទួលបានទីបន្ទាល់មួយអំពីព្រះគម្ពីរមរមនតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ អ្នកអាចប្រាប់ថា ពួកគេគួរគូសចំណាំឃ្លាទាំងនេះ នៅពេលពួកគេរកឃើញវា ។ នៅពេលសិស្សរៀបរាប់ពីឃ្លាដែលពួកគេបានរកឃើញ សូមសរសេរវានៅលើក្តារខៀន ។ ចម្លើយរបស់ពួកគេអាចរួមមានដូចខាងក្រោម ៖

- *« អានការណ៍ទាំងនេះ »*
- *« នឹកឃើញថា តើព្រះអម្ចាស់ទ្រង់មានសេចក្តីមេត្តាករុណាយ៉ាងណា »*
- *« រំពឹងគិតនៅក្នុងចិត្តអ្នកចុះ »*
- *« សូមសួរដោយចិត្តស្មោះស គឺដោយស្មោះអស់ពីចិត្ត ដោយមានសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទ »*

ដើម្បីជួយសិស្សឲ្យយល់កាន់តែច្បាស់ពីអ្វីដែលនរណាម្នាក់ត្រូវតែធ្វើដើម្បីទទួលបានសាក្សីមួយពីព្រះវិញ្ញាណបរិសុទ្ធថា ព្រះគម្ពីរមរមនគឺពិត សូមប្រើគំនិតក្នុងការបង្រៀនខាងក្រោមដើម្បីពិភាក្សាពីតម្រូវការនីមួយៗដែលលោកមរ៉ូណៃបានបង្រៀន ។

១.« អានការណ៍ទាំងនេះ »

លោកមរ៉ូណៃបានអញ្ជើញឲ្យយើង « អានការណ៍ទាំងនេះ » ឬអានព្រះគម្ពីរមរមន ។ សូមឲ្យសិស្សម្នាក់អានឮៗនូវរឿងខាងក្រោមដែលបានតំណាលដោយអែលឌើរ ថាត អរ ខាលីស្ទើរ នៃកូរ៉ុមនៃពួកចិតសិបនាក់អំពីរបៀបដែលយុវនារីម្នាក់បានទទួលប្រយោជន៍ពីការបានអានព្រះគម្ពីរមរមន ៖

« យុវនារីអាយុ ១៤ ឆ្នាំម្នាក់ . . . មាននិយាយថា នាងបានពិភាក្សាអំពីសាសនាជាមួយនឹងមិត្តភក្តិរបស់នាងម្នាក់នៅសាលារៀន ។ មិត្តរបស់នាងបាននិយាយទៅកាន់នាងថា ‹ តើឯងកាន់សាសនាមួយណា › ?

« នាងបានឆ្លើយថា ‹ សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ឬ ពួកមរមន › ។

« មិត្តរបស់នាងបានឆ្លើយថា ‹ ខ្ញុំស្គាល់ព្រះវិហារនោះ ហើយខ្ញុំដឹងថា វាមិនពិតនោះទេ › ។

« ‹ តើឯងដឹងដោយរបៀបណា ›? នាងបានឆ្លើយ ។

« មិត្តនាងបាននិយាយថា ‹ ដោយសារ ខ្ញុំបានស្រាវជ្រាវអំពីព្រះវិហារនោះ › ។

« ‹ តើឯងធ្លាប់អានព្រះគម្ពីរមរមនទេ › ?

« នាងឆ្លើយថា ‹ ទេ ខ្ញុំមិនដែលទេ › ។

« បន្ទាប់មក យុវនារីដ៏ល្អនេះបានឆ្លើយថា ‹ ដូច្នេះឯងមិនបានស្រាវជ្រាវពីសាសនាចក្ររបស់ខ្ញុំទេ ដោយសារខ្ញុំបានអានព្រះគម្ពីរមរមនគ្រប់ទំព័រ ហើយខ្ញុំដឹងថា វាពិត › » (« The Book of Mormon—a Book from God » *Ensign* ឬ ***លីអាហូណា***, ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ៧៦) ។

- តើហេតុអ្វីបានជាការអានព្រះគម្ពីរមរមនជាគន្លឹះក្នុងការទទួលបានទីបន្ទាល់អំពីសេចក្តីពិតពេញលេញរបស់វា ?
- តើការអានព្រះគម្ពីរមរមនឆ្នាំនេះបានពង្រឹងដល់ទីបន្ទាល់របស់អ្នកអំពីវា និងសេចក្តីពិតដែលវាបង្រៀនដោយរបៀបណា ?

២.« នឹកឃើញថា តើព្រះអម្ចាស់ទ្រង់មានសេចក្តីមេត្តាករុណាយ៉ាងណា »

លោកម៉ូរ៉ូណៃបានបង្រៀនថា អ្នកដែលអានព្រះគម្ពីរមរមន ហើយមានបំណងចង់ដឹងពីសេចក្តីពិតពេញលេញរបស់វាត្រូវ « នឹកឃើញថា តើព្រះអម្ចាស់ទ្រង់មានសេចក្តីមេត្តាករុណាយ៉ាងណា » (មរ៉ូណៃ ១០:៣) ។ សូមពន្យល់ថា ការទទួលស្គាល់ និងការចងចាំដល់គំរូនៃសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់ អាចបន្ធូរបន្ថយដួងចិត្តរបស់យើង ហើយរៀបចំយើងឲ្យមានអារម្មណ៍ពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។ អត្ថន័យមួយនៃពាក្យ *រំដោះ* គឺប្រកបដោយករុណា ។ សូមឲ្យសិស្សសញ្ជឹងគិតមួយសន្ទុះអំពីពេលដែលពួកគេបានទទួលនូវសេចក្តីមេត្តាករុណា ឬការអាណិតអាសូររបស់ព្រះអម្ចាស់ចំពោះពួកគេ ឬទទួលស្គាលវានៅក្នុងជីវិតរបស់នរណាម្នាក់ដែលពួកគេស្គាល់ ។

សូមឲ្យសិស្សចែកចាយគំរូនៃសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់នៅក្នុងព្រះគម្ពីរមរមន ដែលមានន័យដល់ពួកគេ ។

- តើអ្នកគិតថា ការចងចាំដល់សេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់អាចជួយដល់នរណាម្នាក់ឲ្យទទួលបានព្រះវិញ្ញាណបរិសុទ្ធ និងទទួលបានទីបន្ទាល់មួយអំពីព្រះគម្ពីរមរមនដោយរបៀបណា ?
- តើមានភស្តុតាងអ្វីខ្លះអំពីសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់ដែលអ្នកបានធ្វើជាសាក្សីនៅក្នុងជីវិតរបស់អ្នក ?
- តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលអ្នកចងចាំដល់សេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់នៅក្នុងជីវិតរបស់អ្នក ?

៣.« រំពឹងគិត | អំពីសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់ | នៅក្នុងចិត្តអ្នកចុះ »

លោកម៉ូរ៉ូណៃបានបង្រៀនថា យើងត្រូវតែសញ្ជឹងគិតអំពីសេចក្តីមេត្តាករុណារបស់ព្រះអម្ចាស់នៅក្នុងចិត្តយើង ។ សូមពន្យល់ថា ការសញ្ជឹងគិតពីរបៀបដែលព្រះអម្ចាស់មានមេត្តាករុណាដល់អ្នកដទៃ និងដល់ខ្លួនយើង រៀបចំយើងឲ្យទទួលបានឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។ ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលវាទៅដូច្នោះ សូមឲ្យសិស្សម្នាក់អានការពន្យល់ខាងក្រោមដោយអែលឌើរ ម៉ាវីន ជេ អាស្តុន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ៖

« វចនានុក្រមចែងថា *រំពឹងគិត* មានន័យថា ថ្លឹងថ្លែងខាងអារម្មណ៍ គិតយ៉ាងជ្រៅជ្រះ ផ្ចង់សតិសម្បជញ្ញៈ ការស្មើងស្មាត ។ . . .

« ដោយការសញ្ជឹងគិត យើងបានផ្តល់ឱកាសដល់ព្រះវិញ្ញាណឲ្យបំផុស និងដឹកនាំយើង ។ ការសញ្ជឹងគិត គឺជាតំណាក់មានអំណាចរវាងដួងចិត្ត និងគំនិត ។ នៅពេលយើងអានព្រះគម្ពីរ ដួងចិត្ត និងគំនិតរបស់យើងទទួលបានឥទ្ធិពល ។ ប្រសិនបើយើងប្រើអំណោយទាននេះដើម្បីសញ្ជឹងគិត នោះយើងអាចយកសេចក្តីពិតអស់កល្បទាំងនេះ និងយល់ពីរបៀបដែលយើងអាចអនុវត្តវានៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់យើងបាន ។ . . .

« ការសញ្ជឹងគិត គឺជាការតស៊ូខាងសតិអារម្មណ៍ដ៏រីកចម្រើនមួយ ។ វាគឺជាអំណោយទានដ៏អស្ចារ្យមួយ ដល់អស់អ្នកណាដែលបានរៀនប្រើវា ។ យើងរកឃើញនូវការយល់ដឹង ទស្សនវិស័យ និងការអនុវត្តក្នុងការប្រើប្រាស់ ប្រសិនបើយើងនឹងប្រើអំណោយទាននៃការរំពឹងគិតនេះ » (« There Are Many Gifts » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៨៧, ទំព័រ ២០) ។

- នៅពេលអ្នកបានសិក្សាព្រះគម្ពីរមរមន តើនៅពេលណាដែលការសញ្ជឹងគិតបានជួយដល់អ្នកឲ្យមានអារម្មណ៍ពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ?
- តើយើងអាចធ្វើអ្វីខ្លះ ដើម្បីសញ្ជឹងគិតយ៉ាងផ្ចិតផ្ចង់កាន់តែខ្លាំង នៅពេលយើងសិក្សាព្រះគម្ពីរ ?

៤.« សូមសួរដោយចិត្តស្មោះស គឺដោយស្មោះអស់ពីចិត្ត ដោយមានសេចក្តីជំនឿជឿដល់ | ព្រះយេស៊ូវ | គ្រីស្ទ »

លោកម៉ូរ៉ូណៃបានបង្រៀនថា ប្រសិនបើយើងចង់ទទួលបានសាក្សីនៃសេចក្តីពិតពេញលេញនៃព្រះគម្ពីរមរមន យើងត្រូវតែសុំដល់ព្រះ « ដោយចិត្តស្មោះស គឺដោយស្មោះអស់ពីចិត្ត ដោយមានសេចក្តីជំនឿជឿដល់ | ព្រះយេស៊ូវ | គ្រីស្ទ » ។ សូមពន្យល់ថា ការអធិស្ឋានដោយស្មោះ និងដោយអស់ពីចិត្តមានន័យថា « មានបំណងចង់ធ្វើសកម្មភាពចំពោះចម្លើយដែល | យើង | នឹងទទួលបានពីព្រះ » (*Preach My Gospel: A Guide to Missionary Service* | ឆ្នាំ ២០០៤ | ទំព័រ ១១១) ។ សូមគិតពីការចែកចាយរឿងខាងក្រោម ដែលបុរសម្នាក់បានអធិស្ឋានដោយមានចិត្តស្មោះដើម្បីទទួលបានទីបន្ទាល់នៃសេចក្តីពិតពីព្រះគម្ពីរមរមន ៖

« យូរៗម្តង ខ្ញុំបានអធិស្ឋានដើម្បីដឹងពីអ្វីដែលត្រូវ ប៉ុន្តែភាគច្រើន វាជាគំនិតដែលចេះតែមាន ជាជាងសំឡេងដ៏ស្មោះស ។ក្រោយមក មានយប់មួយខ្ញុំបានសម្រេចចិត្តអធិស្ឋានដោយ ‹ ចិត្តស្មោះស › ។

« ខ្ញុំបានទូលទៅកាន់ព្រះវរបិតាថា ទូលបង្គំចង់ស្គាល់ទ្រង់ និងធ្វើជាផ្នែកមួយនៃសាសនាចក្រដ៏ពិតរបស់ទ្រង់ ។ខ្ញុំបានសន្យាថា ៖ ‹ ប្រសិនបើទ្រង់នឹងឲ្យទូលបង្គំដឹងបើយ៉ូសែប ស៊្មីធ ជាព្យាការីពិត និងព្រះគម្ពីរមរមនពិត នោះទូលបង្គំនឹងធ្វើអ្វីៗទាំងអស់ដែលព្រះអង្គសព្វព្រះទ័យឲ្យទូលបង្គំធ្វើ ។ប្រសិនបើសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយជាសាសនាចក្រពិត នោះទូលបង្គំនឹងធ្វើតាមសាសនាចក្រ ហើយនឹងពុំដែលបោះបង់ចោលឡើយ › ។

« ខ្ញុំពុំមានការបើកសម្តែងដ៏អស្ចារ្យណាមួយនោះទេ ប៉ុន្តែខ្ញុំបានទទួលអារម្មណ៍សន្តិភាព រួចបានចូលដេក ។ជាច្រើនម៉ោងក្រោយមកខ្ញុំបានក្រោកពីដេកដោយមានគំនិតមួយផ្សេងទៀតថា ៖ ‹ យ៉ូសែប ស៊្មីធ ជាព្យាការីពិត និងព្រះគម្ពីរមរមនពិត › ។គំនិតនោះបានមានឡើងជាមួយនឹងសន្តិភាពដែលពុំអាចពិពណ៌នាបាន ។ខ្ញុំបានដេកលក់ម្តងទៀត ហើយក្រោកឡើងនៅពេលក្រោយ ដោយមានគំនិត និងអារម្មណ៍ដដែលដូចមុន ។

« ចាប់តាំងពីពេលនោះមក ខ្ញុំពុំដែលមានអារម្មណ៍សង្ស័យថា យ៉ូសែប ស៊្មីធ ជាព្យាការីពិត ឬមិនពិតទៀតឡើយ ។ខ្ញុំដឹងថា នេះគឺជាកិច្ចការរបស់ព្រះអង្គសង្គ្រោះ ហើយថាព្រះវរបិតាសួគ៌នឹងឆ្លើយតបនូវការអង្វរដ៏ស្មោះសរបស់យើង » (Rodolfo Armando Pérez Bonilla, “How I Know,” *Ensign,* ខែ តុលា ឆ្នាំ ២០១១, ទំព័រ ៦៤) ។

សូមឲ្យសិស្សស្រាវជ្រាវ មរ៉ូណៃ ១០:៤ ហើយរកមើលអ្វីដែលព្រះនឹងធ្វើសម្រាប់អស់អ្នកណាដែលធ្វើតាមដំណើរការដែលលោកមរ៉ូណៃបានបង្ហាញ ។

- តើសេចក្តីសន្យាដែលលោកមរ៉ូណៃបានធ្វើដល់អស់អ្នកដែលស្វែងរកទីបន្ទាល់ពីព្រះគម្ពីរមរមនតាមរបៀបដែលលោកបានរៀបរាប់អ្វីខ្លះ ?
- តើព្រះវិញ្ញាណបរិសុទ្ធអាចធ្វើទីបន្ទាល់ដល់យើងអំពីសេចក្តីពិតនៃព្រះគម្ពីរមរមនតាមរបៀបណា ? (សូមប្រាកដថា សិស្សយល់ថា វិវរណៈភាគច្រើនមិនបានមកតាមរបៀបដ៏អស្ចារ្យនោះ ។ ខណៈពេលដែលបុគ្គលខ្លះអាចមានបទពិសោធន៍ខាងវិញ្ញាណលើសលុបមនុស្សភាគច្រើននឹងទទួលបានអ្វីមួយដែលស្ងៀមស្ងាត់ និងរហៀង ដូចជាអារម្មណ៍ដ៏កក់ក្តៅ សុខសាន្ត ឬមានការធានា ។ អ្នកក៏អាចពន្យល់ថា នៅពេលយើងសិក្សាព្រះគម្ពីរ នោះព្រះវិញ្ញាណអាចថ្លែងទីបន្ទាល់អំពីសេចក្តីពិតនៃអ្វីដែលយើងកំពុងអាន ។ បន្ទាប់មក នៅពេលយើងសុំចង់ដឹងពីសេចក្តីពិតនៃព្រះគម្ពីរមរមនជាពិសេស នោះព្រះគម្ពីរមរមននឹងបញ្ជាក់ជាសាក្សីចំពោះអ្វីដែលយើងបានទទួល) ។

មរ៉ូណៃ ១០:៤–៥ នេះគឺជាវគ្គចំណេះចំណានខគម្ពីរ ។ សូមបើកទៅគំនិតក្នុងការបង្រៀននៅចុងបញ្ចប់នៃមេរៀននេះដើម្បីជួយសិស្សជាមួយនឹងចំណេះចំណានខគម្ពីរ ។

សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ១០:៥–៧ ឮៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ហើយរកមើលអ្វីដែលលោកមរ៉ូណៃបានសន្យាថា យើងអាចដឹងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ សូមបង្ហាញថា មរ៉ូណៃ ១០:៤–៥ នេះគឺជាវគ្គព្រះគម្ពីរចំណេះចំណាន ។ អ្នកអាចណែនាំថា សិស្សគួរគូសចំណាំវគ្គនេះដើម្បីឲ្យងាយស្រួលនឹងរកឃើញវា ។

- តើគោលការណ៍អ្វីដែលយើងអាចរៀនពី មរ៉ូណៃ ១០:៣–៧ ? (ចម្លើយរបស់សិស្សអាចប្រើពាក្យខុសគ្នា ប៉ុន្តែពួកគេគួរតែរកឃើញនូវគោលការណ៍ដូចខាងក្រោមនេះ ៖ **ប្រសិនបើយើងសុំព្រះដោយនូវសេចក្តីជំនឿ និងដោយមានចិត្តស្មោះស នោះយើងអាចទទួលបានទីបន្ទាល់អំពីព្រះគម្ពីរមរមន និងអំពីព្រះយេស៊ូវគ្រីស្ទតាមរយៈព្រះវិញ្ញាណបរិសុទ្ធ**) ។

សូមឲ្យសិស្សសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់អំពីគោលដៅមួយទាក់ទងទៅនឹងអ្វីដែលពួកគេនឹងធ្វើដើម្បីទទួលបាន ឬពង្រឹងដល់ទីបន្ទាល់របស់គេអំពីព្រះគម្ពីរមរមន ។ សូមលើកទឹកចិត្តពួកគេឲ្យអនុវត្តគោលការណ៍ដែលបានបង្រៀនដោយ មរ៉ូណៃ ១០:៤ ។

មរ៉ូណៃ ១០:២៧–២៩

លោកមរ៉ូណៃថ្លែងទីបន្ទាល់ថា លោកនឹងជួបយើងនៅពេលជំនុំជម្រះរបស់ព្រះ

សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ១០:២៧–២៩ ឮៗ ។ សូមឲ្យសិស្សគិតអំពីរបៀបដែលពួកគេអាចឆ្លើយនឹងសំណួរនេះដែលមាននៅក្នុង មរ៉ូណៃ ១០:២៧ ។ សូមថ្លែងទីបន្ទាល់ថា **អស់អ្នកណាដែលបានទទួលព្រះគម្ពីរមរមន នឹងទទួលខុសត្រូវចំពោះព្រះអំពីរបៀបដែលពួកគេឆ្លើយតបនឹងវា** ។

សូមទុកពេលវេលាគ្រប់គ្រាន់នៅចុងបញ្ចប់នៃមេរៀននេះ ដើម្បីសុំឲ្យសិស្សចែកចាយទីបន្ទាល់របស់គេអំពីព្រះគម្ពីរមរមន ។ សូមគិតពីការថ្លែងទីបន្ទាល់របស់អ្នកថ្មាល់អំពីព្រះគម្ពីរមរមន ។ សូមធានាដល់សិស្សថា នៅពេលពួកគេបន្តសិក្សាក្នុងព្រះគម្ពីរមរមនពេញមួយជីវិតរបស់គេ នោះសេចក្តីជំនឿរបស់គេទៅលើព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់នឹងកើនឡើង ។

ចំណេះចំណានខគម្ពីរ—មរ៉ូណៃ ១០:៤–៥

សិស្សដែលទន្ទេញ មរ៉ូណៃ ១០:៤–៥ នឹងរៀបចំខ្លួនបានប្រសើរដើម្បីចែកចាយសារលិខិតនៃព្រះគម្ពីរមរមនជាមួយនឹងអ្នកដទៃ ។ សូមសរសេរវគ្គនេះនៅលើក្តារខៀន ហើយសូមឲ្យសិស្សទាំងអស់អានវឮៗ ។ សូមលុបប្រាំមួយពាក្យ ហើយបន្ទាប់មក សូមឲ្យសិស្សអានវាម្តងទៀត ដោយបំពេញនូវពាក្យដែលលុបចេញនៅពេលពួកគេអាន ។ សូមបន្តធ្វើដូច្នេះ រហូតដល់វគ្គភាគច្រើន ឬទាំងអស់ត្រូវបានលុបអស់ ។

មេរៀនទី ១៦០

មរ៉ូណៃ ១០:៨–២៦, ៣០–៣៤

សេចក្តីផ្តើម

ក្រោយពីការបង្រៀនពីរបៀបដើម្បីទទួលបានសាក្សីមួយអំពីសេចក្តីពិតនៃការណ៍ទាំងអស់តាមរយៈព្រះវិញ្ញាណបរិសុទ្ធហើយ លោកមរ៉ូណៃបានដាស់តឿនអស់អ្នកដែលអានពាក្យរបស់លោកឲ្យទទួលបាន និងទទួលស្គាល់អំណោយទានខាងវិញ្ញាណ ។ លោកមរ៉ូណៃ បានបញ្ចប់កំណត់ត្រាព្រះគម្ពីរមរមនដោយការដាស់តឿនដល់មនុស្សទាំងអស់ឲ្យមករកព្រះយេស៊ូវគ្រីស្ទ ក្តាប់ជាប់នូវអំណោយទានល្អគ្រប់យ៉ាងដែលទ្រង់បានប្រទាន និងបានឥតខ្ចោះតាមរយៈទ្រង់ ។

យោបល់សម្រាប់ការបង្រៀន

មរ៉ូណៃ ១០:៨–២៦

លោកមរ៉ូណៃបង្រៀនអំពីអំណោយទានទាំងឡាយនៃព្រះវិញ្ញាណ និងគោលបំណងរបស់វានៅក្នុងកិច្ចការរបស់ព្រះអម្ចាស់

សូមឲ្យសិស្សគិតអំពីពេលមួយដែល ព្រះវរបិតាសួគ៌បានជួយដល់ពួកគេឲ្យធ្វើអ្វីមួយដែលពួកគេមិនអាចធ្វើបានដោយសមត្ថភាពខ្លួនឯង ។ សូមឲ្យសិស្សអាន មរ៉ូណៃ ១០:៨ ដោយស្ងាត់ស្ងៀមដោយរកមើលឃ្លាដែលពិពណ៌នាពីសមត្ថភាពខាងវិញ្ញាណ ឬពរជ័យដែលព្រះបានប្រទានដល់អ្នកស្មោះត្រង់ (« អំណោយទាននៃព្រះ ») ។ សូមពន្យល់ថា ជារៀយ ៗ យើងសំដៅលើអំណោយទានទាំងនេះថាជាអំណោយទានទាំងឡាយនៃព្រះវិញ្ញាណ ឬអំណោយទាននៃវិញ្ញាណ ។

- យោងតាម មរ៉ូណៃ ១០:៨ ហេតុអ្វីបានជាព្រះប្រទានអំណោយទានទាំងឡាយនៃព្រះវិញ្ញាណដល់កូនចៅរបស់ទ្រង់ ? (ក្រោយពីសិស្សឆ្លើយហើយ សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***ព្រះប្រទានអំណោយទានទាំងឡាយនៃព្រះវិញ្ញាណដើម្បីជាប្រយោជន៍ដល់កូនចៅរបស់ទ្រង់ ។*** អ្នកអាចពន្យល់ថានៅក្នុងបរិបទនេះ *ជាប្រយោជន៍* មានន័យថាប្រទានពរ ឬជួយ) ។

សូមឲ្យសិស្សអាន មរ៉ូណៃ ១០:៩–១៦ ដោយស្ងាត់ស្ងៀមដោយរកមើលអំណោយទានរបស់ព្រះ ដែលលោកមរ៉ូណៃបានរៀបរាប់នៅក្នុងខគម្ពីរទាំងនេះ ។ អ្នកអាចណែនាំថា សិស្សគួរគូសចំណាំអ្វីដែលពួកគេរកឃើញ ។

- តើអំណោយទានទាំងឡាយនៃព្រះវិញ្ញាណមួយណា ដែលអ្នករកឃើញនៅក្នុងខគម្ពីរទាំងនេះ ? (នៅពេលសិស្សឆ្លើយ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន) ។
- តើអ្នកបានឃើញគំរូអ្វីខ្លះនៃអំណោយទានទាំងនេះនៅក្នុងសាសនាចក្រ ?
- តើនៅពេលណាដែលអ្នកបានឃើញមនុស្សខ្លះទទួលបានពរជ័យ ដោយសារអ្នកដទៃបានអនុវត្តអំណោយទាននៃវិញ្ញាណរបស់គេនោះ ? (អ្នកអាចរៀបចំចែកចាយគំរូមួយដែលអ្នកបានឃើញ) ។
- តើអំណោយទានទាំងឡាយនៃព្រះវិញ្ញាណមានផលចំណេញ ដល់មនុស្សដែលទទួលបានវាដោយរបៀបណា ?

សូមឲ្យសិស្សម្នាក់អាន មរ៉ូណៃ ១០:១៩, ២៤ ឲ ៗ ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលឧបសគ្គមួយក្នុងការទទួលបាន និងទទួលស្គាល់នូវអំណោយទានខាងវិញ្ញាណ ។

- តើអ្វីជាឧបសគ្គក្នុងការទទួលបាន និងស្គាល់អំណោយទានខាងវិញ្ញាណដែលអ្នករកឃើញ ?
- តើអ្នកគិតថា ហេតុអ្វីបានជាមនុស្សនៅក្នុងស្ថានភាពនៃការឥតជំនឿមិនអាចទទួលស្គាល់ ឬទទួលបាននូវអំណាច និងអំណោយទាននេះពីព្រះ ?

សូមឲ្យសិស្សអាន មរ៉ូណៃ ១០:២៥–២៦ ដោយស្ងាត់ស្ងៀម ដោយរកមើលអ្វីដែលនឹងកើតឡើងដល់អស់អ្នកណាដែលបដិសេធអំណោយទាន និងអំណាចរបស់ព្រះ ។ សូមឲ្យសិស្សរៀបរាប់ពីអ្វីដែលពួកគេរកឃើញ ។

សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឲ ៗពី មរ៉ូណៃ ១០:២០–២៣ ។ សូមឲ្យសិស្សមើលតាម ដោយរកមើលពរជ័យនៃការមានសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស ។ (មុនពេលសិស្សអាន អ្នកអាចពន្យល់ថាឃ្លា « ចាំបាច់ដល់យើង » នៅក្នុង មរ៉ូណៃ ១០:២៣ សំដៅលើអ្វីដែលស្របតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់) ។

- តើពរជ័យអ្វីដែលលោកមរ៉ូណៃបានបង្រៀនថានឹងមកដល់អស់អ្នកណាដែលមានសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស ?

នៅពេលសិស្សឆ្លើយហើយ សូមសរសេរគោលការណ៍ខាងក្រោមនៅលើក្តារខៀន ៖ ***ប្រសិនបើយើងមានសេចក្តីជំនឿ យើងនឹងអាចធ្វើអ្វីដែលព្រះអង្គសង្គ្រោះចង់ឲ្យយើងធ្វើ ។*** អ្នកអាចណែនាំថា ពួកគេគួរគូសចំណាំគោលការណ៍នេះនៅក្នុង មរ៉ូណៃ ១០:២៣ ។

- តើអ្នកគិតថា គោលការណ៍ពីរនៅលើក្តារខៀនអាចទាក់ទងនឹងគ្នាដោយរបៀបណា ? (ប្រសិនបើយើងមានសេចក្តីជំនឿ នោះព្រះនឹងប្រទានដល់យើងនូវអំណោយទានដែលយើងត្រូវការ ដើម្បីធ្វើកិច្ចការដែលទ្រង់បានប្រទានដល់យើងធ្វើ) ។
- តើការដឹងពីគោលការណ៍ទាំងពីរនេះអាចជួយដល់អ្នកនាពេលនេះ និងនៅក្នុងពេលអនាគតបានដូចម្តេច ?

ស្រឡាញ់សិស្សរបស់អ្នក

នៅពេលអ្នកបង្ហាញសេចក្តីស្រឡាញ់ និងបារម្ភពីសិស្សរបស់អ្នក អ្នកនឹងឆ្លុះបញ្ចាំងសេចក្តីស្រឡាញ់ដែលព្រះបានមានសម្រាប់ពួកគេ ។ នៅពេលអ្នកបញ្ចប់វគ្គសិក្សានេះ សូមជួយសិស្សឲ្យដឹងថាពួកគេត្រូវបានស្រឡាញ់ជាបុត្រា និងបុត្រីនៃព្រះ ។

សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ ដើម្បីជួយសិស្សឲ្យយើញពីរបៀបដែលសេចក្តីសន្យានេះដែលមាននៅក្នុង ម៉ូរ៉ូណៃ ១០:២៣ ត្រូវបានបំពេញ ឬអាចត្រូវបានបំពេញនៅក្នុងជីវិតរបស់គេ សូមឲ្យពួកគេមានពេលពីរបីនាទីដើម្បីបំពេញប្រយោគមួយនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់ ។

ខ្ញុំបានទទួលសេចក្តីសន្យានេះនៅក្នុង ម៉ូរ៉ូណៃ ១០:២៣ នៅពេល . . .

សេចក្តីសន្យាដែលមាននៅក្នុង ម៉ូរ៉ូណៃ ១០:២៣ អាចជួយខ្ញុំ នៅពេល . . .

ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សចែកចាយនូវអ្វីដែលពួកគេបានសរសេរជាមួយនឹងដៃគូគេ ។

ម៉ូរ៉ូណៃ ១០:៣០–៣៤

លោកម៉ូរ៉ូណៃអញ្ជើញមនុស្សទាំងអស់ឲ្យមករកព្រះយេស៊ូវគ្រីស្ទ ហើយបានឥតខ្ចោះនៅក្នុងទ្រង់

សូមសរសេរពាក្យ ការឥតខ្ចោះ នៅលើក្តារខៀន ។ នៅពីក្រោមវា សូមសរសេរ *អាចកើតមាន ឬ មិនអាច ?*

សូមឲ្យសិស្សចែកចាយគំនិតរបស់គេទាក់ទងនឹងសំណួរនៅលើក្តារខៀន ។ ក្រោយពីការពិភាក្សាបន្តិចរួចមក សូមឲ្យសិស្សម្នាក់អាន នីហ្វៃទី ៣ ១២:៤៨ ឮៗ ។

- តើព្រះអង្គសង្គ្រោះបានមានបន្ទូលអ្វីខ្លះដែលជាគោលដៅនៅទីបញ្ចប់សម្រាប់យើងម្នាក់ៗ ? (ដើម្បីក្លាយជាឥតខ្ចោះ) ។ តើការណ៍នេះអាចកើតឡើងទេ ?

ក្រោយពីសិស្សចែកចាយការយល់ដឹងរបស់គេហើយ សូមឲ្យសិស្សម្នាក់អានការពន្យល់ខាងក្រោមដោយប្រធាន ដែមស៍ អឺ ហ្វោស្ត នៃគណៈប្រធានទីមួយ ៖

« ការឥតខ្ចោះ គឺជាគោលដៅដ៏អស់កល្បជានិច្ចមួយ ។ ខណៈពេលដែលយើងមិនអាចឥតខ្ចោះបាននៅក្នុងជីវិតរមែងស្លាប់នេះ ការខិតខំធ្វើតាមនេះគឺជាព្រះបញ្ញត្តិមួយ ដែលនៅទីបំផុត តាមរយៈដង្វាយធួន នោះយើងអាចរក្សាវាបាន » (« This Is Our Day » *Ensign,* ខែ ឧសភា ឆ្នាំ ១៩៩៩, ទំព័រ ១៩) ។

សូមពន្យល់ថា ទោះបីជាការឥតខ្ចោះមិនអាចទទួលបាននៅក្នុងជីវិតនេះក្តី ក៏យើងអាចក្លាយជាឥតខ្ចោះនៅទីបំផុតបានដែរ ។ លោកម៉ូរ៉ូណៃបានបង្រៀនពីអ្វី ដែលយើងអាចធ្វើបានដើម្បីក្លាយជាឥតខ្ចោះតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ សូមចម្លងតារាងខាងក្រោមនេះដាក់លើក្តារខៀន ដោយទុកចន្លោះនូវចន្លើយនៅក្នុងរង្វង់ក្រចក ។

អ្វីដែលខ្ញុំត្រូវធ្វើ . . .	អ្វីដែលព្រះសន្យា . . .
(ចម្លើយអាចរួមមាន យើងត្រូវតែមករកព្រះយេស៊ូវគ្រីស្ទ ស្វែងរក និងទទួលបានអំណោយទានដ៏ល្អ ចៀសវាងអំណោយអាក្រក់ និងរឿងដែលមិនស្អាតស្អំ បដិសេធក្នុងខ្លួនយើងពីអំពើមិនស្របនឹងព្រះទាំងអស់ និងស្រឡាញ់ព្រះដោយអស់ពីពលំ គំនិត និងអស់ពីកម្លាំង) ។	(ចម្លើយអាចរួមមាន ទ្រង់នឹងបំពេញសេចក្តីសញ្ញារបស់ទ្រង់ ព្រះគុណរបស់ទ្រង់នឹងគ្រប់គ្រាន់សម្រាប់យើង យើងនឹងបានឥតខ្ចោះនៅក្នុងព្រះយេស៊ូវគ្រីស្ទ យើងនឹងទទួលបានព្រះគុណនៃព្រះ យើងនឹងត្រូវបានបន្សុទ្ធ និងទទួលបានការផ្តាច់បាបរបស់យើង ហើយយើងនឹងក្លាយជាបរិសុទ្ធដោយគ្មានកំហុស) ។

សូមឲ្យសិស្សសិក្សា ម៉ូរ៉ូណៃ ១០:៣០–៣៣ រកឃ្លាដែលរៀបរាប់ពីអ្វីដែលយើងត្រូវតែធ្វើ និងអ្វីដែលព្រះបានសន្យាថានឹងធ្វើ ដើម្បីជួយដល់យើងឲ្យក្លាយជាបរិសុទ្ធ និងឥតខ្ចោះ ។ សូមឲ្យសិស្សម្នាក់កត់ត្រានូវចម្លើយរបស់សិស្សនៅក្នុងកូឡោនដែលត្រឹមត្រូវនៅក្នុងតារាងនេះ ។ សូមបង្ហាញថាពាក្យ *ព្រះគុណ* សំដៅលើជំនួយពីស្ថានសួគ៌ ព្រមទាំងកម្លាំងដែលយើងទទួលបាន ដោយសារតែដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។

- តើប្រយោគដែលអ្នកសរសេរនៅក្រោមតារាងនេះ សង្ខេបអ្វីដែលលោកម៉ូរ៉ូណៃបង្រៀនអំពីការក្លាយជាបរិសុទ្ធ និងឥតខ្ចោះអ្វីខ្លះ ? (សិស្សអាចប្រើពាក្យខុសៗគ្នា ប៉ុន្តែចម្លើយរបស់ពួកគេគួរបង្ហាញពីសេចក្តីពិតដូចខាងក្រោម ៖ **នៅពេលយើងមករកព្រះយេស៊ូវគ្រីស្ទ នោះយើងអាចត្រូវបានបន្សុទ្ធ និងបានឥតខ្ចោះតាមរយៈដង្វាយធួនរបស់ទ្រង់**) ។

បើអាច សូមចែកដល់សិស្សនូវច្បាប់ចម្លងនៃសេចក្តីថ្លែងការណ៍ខាងក្រោមដោយអែលឌើរ ដៃប្រ៊ី អ័រ ហូឡិន នៃក្រុមនៃពួកសាវកដប់ពីរនាក់ ។ សូមឲ្យសិស្សម្នាក់អានសេចក្តីថ្លែងការណ៍ឮៗ នៅពេលដែលសិស្សផ្សេងទៀតមើលតាម ។ មុនពេលសិស្សអាន សូមលើកទឹកចិត្តសិស្សឲ្យស្តាប់រកដោយយកចិត្តទុកដាក់ ដោយគិតពីអ្វីដែលពួកគេអាចធ្វើដើម្បីមករកព្រះយេស៊ូវគ្រីស្ទ ជាលទ្ធផលនៃការសិក្សាព្រះគម្ពីរមរមនក្នុងឆ្នាំនេះ ។

« ការលេចចេញនៃថ្មគោលនៃសាសនាចក្ររបស់យើងចុងក្រោយគេបង្អស់ និងតែឯងនេះ ព្រមទាំងគម្ពីរដ៏ត្រឹមត្រូវបំផុតដែលត្រូវបានសរសេរឡើង គឺមិនត្រូវប៉ះពាល់ដល់រឿងមិនស្អាតឡើយ វាត្រូវតែនៅបរិសុទ្ធ និងដោយគ្មានកំហុស វាត្រូវតែបរិសុទ្ធ ។ ហើយភាពបរិសុទ្ធនោះអាចមកតែតាមរយៈលោហិតនៃកូនចៀមនោះ ដែលបានយកនូវសេចក្តីទុក្ខរបស់យើង ហើយបាននាំសេចក្តីព្រួយរបស់យើងចេញ កូនចៀមនោះដែលបានរងរបួសចំពោះអំពើរំលងរបស់យើង ហើយបានឈឺចាប់ដោយសារអំពើទុច្ចរិតរបស់យើង កូនចៀមដែលត្រូវបានគេស្អប់ និងរងទុក្ខ ប៉ុន្តែដែលយើងមិនបានគោរព » (ម៉ូសាយ ១៤) ។ . . .

« ភាពបរិសុទ្ធ —តាមរយៈព្រះលោហិតនៃកូនចៀម ។ នេះគឺជាអ្វីដែលគម្ពីរនេះមាន » (« A Standard unto My People » | សុន្ទរកថាថ្លែងទៅកាន់អ្នកអប់រំសាសនា CES នៅថ្ងៃទី ៩ ខែ សីហា ឆ្នាំ ១៩៩៤ | ទំព័រ ១៣–១៤, si.lds.org) ។

សូមឲ្យសិស្សរកមើលឃ្លានៅក្នុង ម៉ូរ៉ូណៃ ១០:៣២–៣៣ ដែលបញ្ជាក់ថា យើងអាចបានឥតខ្ចោះតែ « នៅក្នុងព្រះគ្រីស្ទ » ប៉ុណ្ណោះ ឬតាមរយៈអំណាចសម្អាត និងព្រះគុណនៃដង្វាយធួនរបស់ទ្រង់ ។

- **ហេតុអ្វីបានជាយើងត្រូវការដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទដើម្បីក្លាយជាបរិសុទ្ធ និងបានឥតខ្ចោះ ?**
- **តើឃ្លាអ្វីនៅក្នុង ម៉ូរ៉ូណៃ ១០:៣២–៣៣ ដែលអ្នករកឃើញនូវការលើកទឹកចិត្ត នៅពេលអ្នកខិតខំស្វែងរកភាពបរិសុទ្ធ និងគោលដៅដ៏អស់កល្បជានិច្ចនៃការឥតខ្ចោះ ?**

សូមឲ្យសិស្សជ្រើសរើសយកឃ្លាមួយ ឬពីរពីកូឡោនទីមួយនៃតារាងនៅលើក្តារខៀននេះ ។ សូមឲ្យពួកគេមានពេលពីរបីនាទីដើម្បីសរសេរនៅក្នុងសៀវភៅកំណត់ហេតុការសិក្សាព្រះគម្ពីរ ឬ សៀវភៅសរសេរក្នុងថ្នាក់អំពីគំនិត ឬការបំផុសនានាដែលពួកគេមាន អំពីរបៀបដែលពួកគេអាចអភិវឌ្ឍផ្នែកទាំងនេះ ។

សូមបញ្ចប់មេរៀននេះដោយអាន ម៉ូរ៉ូណៃ ១០:៣៤ ដល់សិស្ស ។ សូមឲ្យសិស្សក្នុងថ្នាក់មើលតាម ដោយរកមើលភស្តុតាងដែលលោក ម៉ូរ៉ូណៃបានមានសេចក្តីជំនឿ និងសេចក្តីសង្ឃឹមនៅលើព្រះយេស៊ូវគ្រីស្ទ ។ ក្រោយពីពួកគេរៀបរាប់ពីអ្វីដែលពួកគេបានរកឃើញហើយ សូមឲ្យសិស្សសរសេរពីគំនិត ឬការបំផុសនានាដែលពួកគេមាន នៅពេលពួកគេបញ្ចប់វគ្គសិក្សាអំពីព្រះគម្ពីរមរមនៅក្នុងឆ្នាំនេះ ។ សូមគិតពីការសុំឲ្យសិស្សចែកចាយអ្វីដែលពួកគេបានសរសេរដល់សិស្សក្នុងថ្នាក់ ។ សូមថ្លែងទីបន្ទាល់អំពីពរជ័យដែលព្រះវរបិតាសួគ៌បានសន្យាដល់ពួកគេ ប្រសិនបើពួកគេនឹងមករកព្រះយេស៊ូវគ្រីស្ទដោយការធ្វើតាមការបង្រៀនរបស់ទ្រង់ និងអនុវត្តសេចក្តីជំនឿនៅក្នុងដង្វាយធួនរបស់ទ្រង់ ។ សូមលើកទឹកចិត្តសិស្សឲ្យយកការសិក្សាព្រះគម្ពីរមរមនរបស់គេជាគោលដៅពេញមួយជីវិត ។

ការរំឭកគម្ពីរម៉ូរ៉ូណៃ

សូមចំណាយពេលខ្លះដើម្បីជួយសិស្សឲ្យរំឭក គម្ពីរម៉ូរ៉ូណៃ ។ សូមឲ្យពួកគេគិតអំពីអ្វីដែលពួកគេបានរៀនពីគម្ពីរនេះ ទាំងនៅក្នុងថ្នាក់សិក្ខាសាលា និងនៅក្នុងការសិក្សាវគ្គគម្ពីរផ្ទាល់ខ្លួនរបស់គេ ។ ប្រសិនបើចាំបាច់ សូមឲ្យពួកគេសង្ខេបដោយខ្លីៗអំពីសេចក្តីសង្ខេបជំពូកខ្លះនៅក្នុងគម្ពីរម៉ូរ៉ូណៃ ដើម្បីជួយពួកគេឲ្យចងចាំ ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយអ្វីខ្លះពីគម្ពីរម៉ូរ៉ូណៃ ដែលបំផុសគំនិតដល់ពួកគេ ឬដែលបានជួយដល់ពួកគេឲ្យមានសេចក្តីជំនឿកាន់តែខ្លាំងទៅលើព្រះយេស៊ូវគ្រីស្ទ ។

វិចារណកថា និង ព័ត៌មានសាច់រឿង

ម៉ូរ៉ូណៃ ១០:៨–១៩ ។ អំណោយទានទាំងឡាយនៃព្រះវិញ្ញាណ

អែលឌើរ ប្រ៊ូស អ័រ ម៉ាក់ខនឃី បានរៀបរាប់ពីគោលបំណង និងមូលហេតុក្នុងការទទួលបានអំណោយទានខាងវិញ្ញាណ ៖

« [គោលបំណងនៃអំណោយទានខាងវិញ្ញាណ] គឺដើម្បីបំភ្លឺ លើកទឹកចិត្ត និងអប់រំដល់អ្នកស្មោះត្រង់ ដើម្បីឲ្យពួកគេនឹងត្រង់នូវសេចក្តីសុខសាន្តនៅក្នុងជីវិតនេះ និងត្រូវបានដឹកនាំទៅកាន់ជីវិតដ៏អស់កល្បជានិច្ចនៅក្នុងពិភពបន្ទាប់ ។ វត្តមានរបស់គេគឺជាភស្តុតាងនៃទេវភាពនៃកិច្ចការរបស់ព្រះអម្ចាស់ កន្លែងណាដែលគ្មានពួកគេ នោះសាសនាចក្រ និងនគរព្រះមិនមានឡើយ ។ សេចក្តីសន្យាគឺថា ពួកគេមិនត្រូវចាកចេញ ដរាបណាផែនដីបន្តនៅមានវត្តមាន លើកលែងតែពួកមិនជឿ (ម៉ូរ៉ូណៃ ១០:១៩) ប៉ុន្តែនៅពេលថ្ងៃឥតខ្ចោះមកដល់ ហើយពួកបរិសុទ្ធទទួលបានការតេតម្តើង នោះពួកគេនឹងមិនត្រូវការទៀតឡើយ ។ ដូចដែលសាវកប៉ុលបានបង្ហាញថា ‹ នៅពេលអ្វីដែលឥតខ្ចោះមកដល់ នោះអ្វីដែលជាផ្នែកនឹងត្រូវចាកចេញ › ។ (កូរិនថូសទី ១ ជំពូកទី ១៣) ។

« បុគ្គលស្មោះត្រង់ត្រូវបានសង្ឃឹមថា ត្រូវស្វែងរកអំណោយទានទាំងឡាយនៃព្រះវិញ្ញាណដោយអស់ពីចិត្តគេ ។ ពួកគេត្រូវ ‹ ព្យាយាមស្វែងរកអំណោយទាននានាដែលវិសេសបំផុត › (កូរិនថូសទី ១ ១២:៣១; គ. និង ស. ៤៦:៨) ត្រូវ ‹ ចង់បានអំណោយទានខាងវិញ្ញាណ › (កូរិនថូសទី ១ ១៤:១) ‹ សូមដល់ព្រះដែលប្រទានដោយសទ្ធា › ។ (គ. និង ស. ៤៦:៧; ម៉ាថាយ ៧:៧–៨) ។ ចំពោះអ្នកខ្លះនឹងត្រូវបានប្រទាននូវអំណោយទានមួយ ចំពោះអ្នកផ្សេង មានអំណោយទានផ្សេងទៀត ‹ ប្រយោជន៍ឲ្យមនុស្សខ្លះអាចត្រូវបានប្រទានឲ្យមានអំណោយទានទាំងអស់នោះ ប្រយោជន៍ឲ្យអ្នកអាចមានមេដើម្បីឲ្យសមាជិកគ្រប់គ្នាអាចបានផលប្រយោជន៍ដោយសារបៀបនេះ › ។ (គ. និង ស. ៤៦:២៩ ។) »(*Mormon Doctrine,* 2nd ed.[ឆ្នាំ ១៩៦៦], ទំព័រ ៣១៤) ។ [១៩៦៦], ៣១៤).

អែលឌើរ ម៉ាវីន ជេ អាស្តុន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖

« សម្រាប់ខ្ញុំ សោកនាដកម្មដ៏ខ្លាំងបំផុតមួយនៃជីវិតនោះគឺ នៅពេលបុគ្គលម្នាក់បែងចែកខ្លួនគាត់ថាជានរណាម្នាក់ដែលគ្មានទេពកោសល្យ ឬ គ្មានអំណោយទាន ។ . . .

« ចេញពី គោលលទ្ធិ និង សេចក្តីសញ្ញា ៤៦:១១–១២ យើងមានសេចក្តីពិតនេះ ៖ ‹ ជ្បិតមនុស្សទាំងអស់ពុំបានគ្រប់អំណោយទានដែលបានប្រទានដល់ពួកគេឡើយ ត្បិតមានអំណោយទានជាច្រើនហើយមនុស្សរាល់គ្នាត្រូវបានប្រទានអំណោយទានមួយដោយព្រះវិញ្ញាណនៃព្រះ › ។

« ‹ ចំពោះមនុស្សខ្លះត្រូវប្រទានឲ្យមួយ រីឯចំពោះមនុស្សខ្លះត្រូវបានប្រទានឲ្យមួយផ្សេងទៀត ដើម្បីឲ្យមនុស្សទាំងអស់អាចបានប្រយោជន៍ដោយសារបៀបនេះ › ។

« ព្រះបានប្រទានដល់យើងម្នាក់ៗនូវអំណោយទានពិសេសមួយ ឬច្រើន ។ . . . វាស្ថិតនៅលើយើងម្នាក់ៗថានឹងសិក្សារកវា និងកសាងអំណោយទានទាំងឡាយដែលព្រះបានប្រទានឬអត់ ។ . . .

« ព្រះពិតជាមានព្រះជន្មរស់នៅ ។ ទ្រង់បានប្រទានដល់យើងនូវអំណោយទាននានា ។ នៅពេលយើងអភិវឌ្ឍ និងចែកចាយនូវអំណោយទានដែលព្រះបានប្រទានដល់យើង និងទទួលប្រយោជន៍ពីអំណោយទាននៃអ្នកនៅជុំវិញយើង នោះពិភពលោកអាចក្លាយជាកន្លែងដ៏ប្រសើរមួយ ហើយកិច្ចការរបស់ព្រះនឹងបន្តទៅមុខក្នុងល្បឿនលឿនជាងនេះ » (« There Are Many Gifts » *Ensign,* ខែ វិច្ឆិកា ឆ្នាំ ១៩៨៧, ទំព័រ ២០, ២៣) ។

មេរៀនសិក្សានៅផ្ទះ

<u>ម៉ូរ៉ូណៃ ៧:២០–១០:៣៤ (មេរៀនទី ៣២)</u>

ការរៀបចំសម្ភារសម្រាប់គ្រូបង្រៀនដល់សិស្សដែលសិក្សានៅផ្ទះ

សេចក្តីសង្ខេបនៃមេរៀនសិក្សានៅផ្ទះប្រចាំថ្ងៃ

សេចក្តីសង្ខេបខាងក្រោមនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលសិស្សបានរៀន នៅពេលពួកគេសិក្សា ម៉ូរ៉ូណៃ ៧:២០–១០:៣៤ (មេរៀនទី ៣២) មិនមែនសម្រាប់បង្រៀនជាផ្នែកនៃមេរៀនរបស់អ្នកឡើយ ។ មេរៀនដែលអ្នកបង្រៀនផ្តោតតែលើគោលលទ្ធិ និង គោលការណ៍ទាំងនេះពីរបីប៉ុណ្ណោះ ។ សូមធ្វើតាមការបំផុសនៃព្រះវិញ្ញាណបរិសុទ្ធ នៅពេលអ្នកគិតអំពីតម្រូវការរបស់សិស្ស ។

ថ្ងៃទី ១ (ម៉ូរ៉ូណៃ ៧:២០–៤៨)

នៅពេលសិស្សបានបន្តការសិក្សារបស់គេអំពីទេសនកថារបស់លោកមរមនទៅកាន់ប្រជាជននៅក្នុងសាលាប្រជុំ ពួកគេបានរៀនពីគោលការណ៍ដ៏សំខាន់នានាអំពីសេចក្តីជំនឿ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស ៖ នៅពេលយើងអនុវត្តសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ នោះយើងអាចក្តាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ ។ ប្រសិនបើយើងអនុវត្តសេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ យើងអាចទទួលបានសេចក្តីសង្ឃឹមតាមរយៈដង្វាយធួនរបស់ទ្រង់ថានឹងបានរស់នៅក្នុងជីវិតដ៏នៅអស់កល្បជានិច្ច ។ ប្រសិនបើយើងអធិស្ឋានទៅកាន់ព្រះវរបិតាដោយអស់ពីកម្លាំងចិត្ត និងរស់នៅជាអ្នកដើរតាមដ៏ពិតរបស់ព្រះយេស៊ូវគ្រីស្ទ នោះយើងអាចត្រូវបានបំពេញដោយសេចក្តីសប្បុរស ។

ថ្ងៃទី ២ (ម៉ូរ៉ូណៃ ៨–៩)

ដោយការសិក្សាសំបុត្រពីលោកមរមនដល់ម៉ូរ៉ូណៃដែលបានកត់ត្រានៅក្នុង ម៉ូរ៉ូណៃ ៨ សិស្សបានរៀនថា ការប្រែចិត្ត និងបុណ្យជ្រមុជទឹកគឺចាំបាច់ដល់អ្នកទាំងឡាយណាដែលទទួលខុសត្រូវ និងអាចប្រព្រឹត្តអំពើបាបបាន ។ ពួកគេក៏បានសិក្សាពីគោលលទ្ធិដែលថា កូនក្មេងតូចៗត្រូវបានសង្គ្រោះតាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។ ដោយការសិក្សាសំបុត្រដែលបានកត់ត្រានៅក្នុង ម៉ូរ៉ូណៃ ៩ សិស្សបានរៀនថា យើងត្រូវធ្វើការដោយឧស្សាហ៍ព្យាយាមនៅក្នុងការបម្រើដល់ព្រះ ទោះបីជាអ្នកដែលយើងបម្រើមិនឆ្លើយតបដោយវិជ្ជមានក្តី ។ បន្ថែមលើនេះ សិស្សបានរៀនពីគំរូរបស់លោកមរមន និងម៉ូរ៉ូណៃថា ប្រសិនបើយើងស្មោះត្រង់នៅក្នុងព្រះយេស៊ូវគ្រីស្ទ នោះទ្រង់នឹងលើកយើងឡើង ទោះបីជានៅពេលមានការលំបាក និងអំពើទុច្ចរិតនៅជុំវិញយើងក្តី ។

ថ្ងៃទី ៣ (ម៉ូរ៉ូណៃ ១០:១–៧, ២៧–២៩)

នៅពេលសិស្សបានសិក្សាពីទីបន្ទាល់ចុងបញ្ចប់របស់លោកម៉ូរ៉ូណៃហើយ ពួកគេនឹងត្រូវបានរំឭកថា ប្រសិនបើយើងសុំព្រះដោយនូវសេចក្តីជំនឿ និងដោយមានចិត្តស្មោះសនោះយើងអាចទទួលបានទីបន្ទាល់អំពីព្រះគម្ពីរមរមន និងអំពីព្រះយេស៊ូវគ្រីស្ទតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។ ពួកគេក៏បានរៀនថា អស់អ្នកដែលបានទទួលព្រះគម្ពីរមរមន នឹងទទួលខុសត្រូវចំពោះព្រះចំពោះប្រតិកម្មរបស់គេចំពោះវា ។

ថ្ងៃទី ៤ (ម៉ូរ៉ូណៃ ១០:៨–២៦, ៣០–៣៤)

សិស្សបានរៀនថា ព្រះប្រទានអំណោយទានទាំងឡាយនៃព្រះវិញ្ញាណដើម្បីជាប្រយោជន៍ដល់កូនចៅរបស់ទ្រង់ ។ ពួកគេក៏បានរៀនដែរថា ប្រសិនបើយើងមានសេចក្តីជំនឿ យើងនឹងអាចធ្វើអ្វីដែលព្រះអង្គសង្គ្រោះចង់ឲ្យយើងធ្វើ ។ ពួកគេក៏បានសិក្សាពីពាក្យសម្តីចុងក្រោយរបស់លោកម៉ូរ៉ូណៃនៅក្នុងព្រះគម្ពីរមរមន ដែលបង្រៀនថា នៅពេលយើងមករកព្រះយេស៊ូវគ្រីស្ទ នោះយើងអាចត្រូវបានបន្សុទ្ធ និងបានឥតខ្ចោះតាមរយៈដង្វាយធួនរបស់ទ្រង់ ។

សេចក្តីផ្តើម

មេរៀននេះអាចជួយសិស្សឲ្យយល់កាន់តែច្បាស់ពីអត្ថន័យក្នុងការក្តាប់ជាប់នូវអ្វីដែលជាសេចក្តីល្អ ។ សិស្សនឹងមានឱកាសដើម្បីពន្យល់ពីរបៀបដែលបុគ្គលម្នាក់អាចរៀនដឹងដោយខ្លួនគេថា ព្រះគម្ពីរមរមនគឺពិត ។ ពួកគេក៏នឹងអាចចែកចាយទីបន្ទាល់របស់គេអំពីព្រះគម្ពីរមរមន និងពិភាក្សាពីរបៀបដែលទីបន្ទាល់របស់គេត្រូវបានពង្រឹងនៅក្នុងឆ្នាំនេះ ។ ម៉ូរ៉ូណៃ ៧–៩ រួមមានសារឬសំបុត្រពីលោកមរមន ដែលលោកម៉ូរ៉ូណៃបានបញ្ចូលនៅក្នុងគម្ពីររបស់លោក ។

យោបល់សម្រាប់ការបង្រៀន

ម៉ូរ៉ូណៃ ៧:២០–៤៨

លោកម៉ូរ៉ូណៃកត់ត្រានូវការបង្រៀនរបស់លោកមរមនអំពីសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ សេចក្តីសង្ឃឹម និងសេចក្តីសប្បុរស

សូមសរសេរពាក្យ *ប៉ះ* និង *ក្តាប់ជាប់* នៅលើក្តារខៀន ។ សូមឲ្យសិស្សម្នាក់ឡើងមកខាងមុខថ្នាក់ ហើយបង្ហាញដល់សិស្សពីអត្ថន័យនៃការប៉ះព្រះគម្ពីរមរមន ។ បន្ទាប់មក សូមឲ្យសិស្សបង្ហាញពីអត្ថន័យនៃការក្តាប់ជាប់នូវព្រះគម្ពីរមរមន ។

សូមឲ្យសិស្សអាន ម៉ូរ៉ូណៃ ៧:១៩ ដោយស្ងាត់ស្ងៀម ហើយរកមើលអ្វីដែលលោកមរមនបានមានប្រសាសន៍ថា យើងគួរក្តាប់ជាប់ ។ បន្ទាប់មក សួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- តើលោកមរមនបានមានប្រសាសន៍អំពីអ្វី ដែលយើងត្រូវក្តាប់ជាប់នោះ ?
- តើអ្នកគិតថា « ក្តាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ » មានន័យដូចម្តេច ? (សូមជួយសិស្សឲ្យយល់ថា « គ្រប់អ្វីៗដែលល្អ » អាចរួមមានគោលដៅសុចរិត សកម្មភាព គំនិត គោលការណ៍ និងកម្មវត្ថុ) ។

សូមពន្យល់ថា លោកមរមនបានទៅបង្រៀនពីរបៀបដែលយើងអាច « ក្តាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ » ។ សូមឲ្យសិស្សពីរបីនាក់ប្តូរវេនគ្នាអានឮៗពី ម៉ូរ៉ូណៃ ៧:២០–២២, ២៥ ។ សូមឲ្យសិស្សរកមើលការប្រឹក្សារបស់លោកមរមនអំពីអ្វីដែលយើងត្រូវធ្វើដើម្បី « ក្តាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ » ។

សូមសរសេរឃ្លាមិនពេញលេញខាងក្រោមនៅលើក្តារខៀន ៖ *នៅពេលយើង . . . នោះយើងអាចក្តាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ* ។

សូមសួរ ៖ ក្រោយពីអានខគម្ពីរទាំងនេះហើយ តើអ្នកនឹងបពេញប្រយោគនេះដោយរបៀបណា ? (ចម្លើយមួយដែលសិស្សអាចឆ្លើយគឺថា **នៅពេលយើងអនុវត្តសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចក្តាប់ជាប់នូវគ្រប់ទាំងអ្វីៗដែលល្អ**) ។

សូមរំឭកសិស្សថា នៅក្នុងជំពូកនេះ លោកមរមនក៏បានថ្លែងទីបន្ទាល់ថា តាមរយៈសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ នោះយើងអាចត្រូវបានពោរពេញដោយអំណោយទាននៃសេចក្តីសប្បុរស (សូមមើល ម៉ូរ៉ូណៃ ៧:៤៨) ។ សូមឲ្យសិស្សព្យាយាមទន្ទេញវគ្គចំណេះចំណានខគម្ពីរ ម៉ូរ៉ូណៃ ៧:៤៥, ៤៧–៤៨ ឲ្យចាំ ។ សិស្សក៏អាចអាចខគម្ពីរនេះឮៗបានដែរ ។

សូមសួរសំណួរដូចខាងក្រោម ៖

- តើឃ្លានៅក្នុង ម៉ូរ៉ូណៃ ៧:៤៥, ៤៧–៤៨ មួយណាដែលអ្នកចូលចិត្ត ? ហេតុអ្វីបានជាឃ្លានោះមានន័យដល់អ្នក ?
- តើនៅពេលណាដែលអ្នកបានឃើញនរណាម្នាក់មានចិត្តសប្បុរស ឬនៅពេលអ្នកមានអារម្មណ៍ថាព្រះអម្ចាស់បានជួយអ្នកឲ្យមានចិត្តសប្បុរសទេ ? (អ្នកអាចចែកចាយចម្លើយរបស់អ្នកផ្ទាល់ចំពោះសំណួរទាំងនេះ) ។

ម៉ូរ៉ូណៃ ១០

លោកម៉ូរ៉ូណៃជាស់តឿនដល់យើងឲ្យទទួលបាននូវទីបន្ទាល់មួយអំពីព្រះគម្ពីរមរមន និងមករកព្រះយេស៊ូវគ្រីស្ទ

សូមរំឭកឡើងវិញជាមួយនឹងសិស្សអំពីគោលបំណងនៃថ្នាគោលនៃក្លោងទ្វារ ។ សូមពិភាក្សាពីរបៀបដែលគំនិតនៃថ្នាគោលទាក់ទងទៅនឹងព្រះគម្ពីរមរមន ។ (អ្នកអាចចង់ឲ្យសិស្សមើលទៅរូបភាពនៅក្នុងមេរៀនទី ១ ថ្ងៃ ៣ នៃសៀវភៅណែនាំការសិក្សារបស់គេ) ។ សូមឲ្យសិស្សចែកចាយពីរបៀបដែលព្រះគម្ពីរមរមន គឺជាថ្នាគោលនៃទីបន្ទាល់របស់ពួកគេ ។

សូមឲ្យសិស្សម្នាក់អាន ម៉ូរ៉ូណៃ ១០:៣–៥ ។ សូមឲ្យសិស្សគិតពិចារណាអំពីមូលហេតុដែលខគម្ពីរទាំងនេះសំខាន់ក្នុងការចែកចាយដល់មនុស្សទាំងអស់ មិនថាពួកគេជាសមាជិកនៃព្រះវិហារយើងឬក៏អត់នោះទេ ។ សូមឲ្យសិស្សពីរបីនាក់ចែកចាយពីគំនិតរបស់គេ ហើយបន្ទាប់មក សូមសួរ ៖ តើលោកម៉ូរ៉ូណៃបានមានប្រសាសន៍ថា យើងត្រូវធ្វើអ្វីដើម្បីដឹងពីសេចក្តីពិតនោះ ? (នៅពេលសិស្សឆ្លើយ សូមសរសេរចម្លើយរបស់ពួកគេនៅលើក្តារខៀន) ។ សូមបង្ហាញថា ចម្លើយរបស់ពួកគេគឺជារបៀបដែលយើងអាចស្វែងរកនៅក្នុងសេចក្តីជំនឿដើម្បីដឹង « សេចក្តីពិតនៃគ្រប់ការណ៍ទាំងអស់ ») ។

សូមឲ្យសិស្សម្នាក់អាន ម៉ូរ៉ូណៃ ១០:៦–៧ ហើយបន្ទាប់មក សូមសួរ ៖ បន្ថែមលើសេចក្តីពិតនៃព្រះគម្ពីរមរមន តើមានអ្វីទៀតដែលយើងអាចដឹងដោយសារព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ? (ព្រះវិញ្ញាណបរិសុទ្ធនឹងបញ្ជាក់ថា ព្រះយេស៊ូវគឺជាព្រះគ្រីស្ទ) ។

(សូមសរសេរសេចក្តីពិតខាងក្រោមនៅលើក្តារខៀន ៖ ***ប្រសិនបើយើងសុំព្រះដោយនូវសេចក្តីជំនឿ និងដោយមានចិត្តស្មោះស នោះយើងអាចទទួលបានទីបន្ទាល់អំពីព្រះគម្ពីរមរមន និងអំពីព្រះយេស៊ូវគ្រីស្ទតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។***

សូមរំឭកសិស្សថា លោកម៉ូរ៉ូណៃបានទុកការអញ្ជើញចុងក្រោយមួយសម្រាប់មនុស្សទាំងអស់ ដែលនឹងអានព្រះគម្ពីរមរមន ។ សូមឲ្យសិស្សម្នាក់អានសេចក្តីអញ្ជើញរបស់លោក ដែលមាននៅក្នុងម៉ូរ៉ូណៃ ១០:៣០, ៣២–៣៣ ។ សូមឲ្យសិស្សរកមើលរបៀបដែលយើងអាច « មករក ព្រះគ្រីស្ទ » ។ (អ្នកអាចណែនាំថា សិស្សគួរគូសចំណាំអ្វីដែលពួកគេរកឃើញ) ។ បន្ទាប់មក សួរពួកគេនូវសំណួរដូចខាងក្រោមនេះ ៖

- តើការអញ្ជើញអ្វីដែលលោកម៉ូរ៉ូណៃបានប្រាប់យើងនៅចុងបញ្ចប់នៃបញ្ជីពិសិដ្ឋនេះ ?
- តើឃ្លានៅក្នុងខគម្ពីរទាំងនេះជួយអ្នកឲ្យដឹងពីរបៀបដើម្បី « មករកព្រះគ្រីស្ទ » អ្វីខ្លះ ?
- តើគោលការណ៍អ្វី ដែលយើងអាចរៀនអំពីខគម្ពីរទាំងនេះ ? (សិស្សអាចឆ្លើយនូវគោលការណ៍ខាងក្រោមនេះ ៖ **នៅពេលយើងមករកព្រះយេស៊ូវគ្រីស្ទ នោះយើងអាចត្រូវបានបន្សុទ្ធ និងបានឥតខ្ចោះតាមរយៈជង្វាយធួនរបស់ទ្រង់ ។** អ្នកអាចសរសេរគោលការណ៍នេះនៅលើក្តារខៀន) ។
- តើវាមានន័យដល់អ្នកយ៉ាងណាដែរ ដែលថា អ្នកអាចបានឥតខ្ចោះតែតាមរយៈព្រះយេស៊ូវគ្រីស្ទ ?

សូមឲ្យសិស្សម្នាក់ៗជ្រើសរើសសំណួរមួយខាងក្រោមនេះ ហើយគិតពីចម្លើយវា ។ (អ្នកអាចចង់បង្ហាញសំណួរទាំងនេះនៅលើក្តារខៀន ឬរៀបចំវាជាក្រដាសចែកមុនពេលបង្រៀន) ។ ក្រោយពីមានពេលគ្រប់គ្រាន់ហើយ សូមឲ្យសិស្សពីរបីនាក់ចែកចាយចម្លើយរបស់គេជាមួយនឹងសិស្សក្នុងថ្នាក់ ។

- តើអ្នកបានដឹងថា ព្រះគម្ពីរមរមនពិតដោយរបៀបណា ?
- តើព្រះអង្គសង្គ្រោះបានជួយអ្នកឲ្យក្លាយជាខ្លួនអ្នក ជាងអ្វីដែលអ្នកអាចជួយដល់ខ្លួនអ្នកដោយរបៀបណា ?
- នៅពេលអ្នកត្រឡប់មើលទៅក្រោយពីការសិក្សារបស់អ្នកអំពីព្រះគម្ពីរមរមននៅក្នុងឆ្នាំនេះ តើមានអ្វីដែលអ្នកចង់ធ្វើដើម្បីអភិវឌ្ឍការសិក្សាព្រះគម្ពីររបស់អ្នកទេ ?

ក្រោយពីសិស្សបានចែកចាយចម្លើយរបស់ពួកគេហើយ អ្នកអាចចែកចាយទីបន្ទាល់របស់អ្នកអំពីព្រះគម្ពីរមរមន និងអំពីជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ លើសពីនេះ សូមបង្ហាញសិស្សនូវការកោតសរសើររបស់អ្នកចំពោះពួកគេ និងការខិតខំរបស់គេក្នុងការសិក្សា និងរៀនសូត្រនៅក្នុងថ្នាក់សិក្ខាសាលាឆ្នាំនេះ ។ សូមលើកទឹកចិត្តពួកគេឲ្យបន្តអានព្រះគម្ពីរារាល់ថ្ងៃ និងខិតខំអនុវត្តអ្វីដែលពួកគេរៀននៅក្នុងជីវិតរបស់ពួកគេ ។

សេចក្តីបន្ថែម

តារាងការអានព្រះគម្ពីរ

យើងជួយសម្រេចបំណងនៃថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា នៅពេលយើងលើកទឹកចិត្តសិស្សឲ្យ (១) អាន ហើយសិក្សាព្រះគម្ពីរប្រចាំថ្ងៃ និង (២) អានព្រះគម្ពីរសម្រាប់វគ្គសិក្សានេះ ។ អ្នកអាចចែកតារាង ដែលមានដូចបានបង្ហាញនៅខាងក្រោមនេះ ដល់សិស្សដើម្បីជួយពួកគេឲ្យតាមដានដំណើរការរបស់ពួកគេ ។ ប្រសិនបើអ្នកចង់រាយការណ៍ការអានព្រះគម្ពីរប្រចាំថ្ងៃរបស់សិស្ស សូមធ្វើតាមការដឹកនាំនៃការណែនាំក្នុងការធ្វើរបាយការណ៍អានព្រះគម្ពីរនេះ ។ សូមស្រាវជ្រាវរកការណែនាំទាំងនេះនៅក្នុង si.lds.org ដោយប្រើឃ្លា « scripture reading reporting instructions » ។

តារាងការអានព្រះគម្ពីរមមន

នីហ្វៃទី ១	១	២	៣	៤	៥	៦	៧	៨	៩	១០	១១
	១២	១៣	១៤	១៥	១៦	១៧	១៨	១៩	២០	២១	២២
នីហ្វៃទី២	១	២	៣	៤	៥	៦	៧	៨	៩	១០	១១
	១២	១៣	១៤	១៥	១៦	១៧	១៨	១៩	២០	២១	២២
	២៣	២៤	២៥	២៦	២៧	២៨	២៩	៣០	៣១	៣២	៣៣
យ៉ាកុប	១	២	៣	៤	៥	៦	៧				
អេណុស	១										
យ៉ារ៉ុម	១										
អោមណៃ	១										
ពាក្យសម្តីរបស់មមន			១								
ម៉ូសាយ	១	២	៣	៤	៥	៦	៧	៨	៩	១០	១១
	១២	១៣	១៤	១៥	១៦	១៧	១៨	១៩	២០	២១	២២
	២៣	២៤	២៥	២៦	២៧	២៨	២៩				
អាលម៉ា	១	២	៣	៤	៥	៦	៧	៨	៩	១០	១១
	១២	១៣	១៤	១៥	១៦	១៧	១៨	១៩	២០	២១	២២
	២៣	២៤	២៥	២៦	២៧	២៨	២៩	៣០	៣១	៣២	៣៣
	៣៤	៣៥	៣៦	៣៧	៣៨	៣៩	៤០	៤១	៤២	៤៣	៤៤
	៤៥	៤៦	៤៧	៤៨	៤៩	៥០	៥១	៥២	៥៣	៥៤	៥៥
	៥៦	៥៧	៥៨	៥៩	៦០	៦១	៦២	៦៣			
ហេលេមិន	១	២	៣	៤	៥	៦	៧	៨	៩	១០	១១
	១២	១៣	១៤	១៥	១៦						
នីហ្វៃទី ៣	១	២	៣	៤	៥	៦	៧	៨	៩	១០	១១
	១២	១៣	១៤	១៥	១៦	១៧	១៨	១៩	២០	២១	២២
	២៣	២៤	២៥	២៦	២៧	២៨	២៩	៣០			
នីហ្វៃទី ៤	១										
មរមន	១	២	៣	៤	៥	៦	៧	៨	៩		
អេធើរ	១	២	៣	៤	៥	៦	៧	៨	៩	១០	១១
	១២	១៣	១៤	១៥							
មរ៉ូណៃ	១	២	៣	៤	៥	៦	៧	៨	៩	១០	

តារាងសម្រាប់អានព្រះគម្ពីរប្រចាំថ្ងៃ

មករា	កុម្ភៈ	មិនា	មេសា	ឧសភា	មិថុនា	កក្កដា	សីហា	កញ្ញា	តុលា	វិច្ឆិកា	ធ្នូ
១	១	១	១	១	១	១	១	១	១	១	១
២	២	២	២	២	២	២	២	២	២	២	២
៣	៣	៣	៣	៣	៣	៣	៣	៣	៣	៣	៣
៤	៤	៤	៤	៤	៤	៤	៤	៤	៤	៤	៤
៥	៥	៥	៥	៥	៥	៥	៥	៥	៥	៥	៥
៦	៦	៦	៦	៦	៦	៦	៦	៦	៦	៦	៦
៧	៧	៧	៧	៧	៧	៧	៧	៧	៧	៧	៧
៨	៨	៨	៨	៨	៨	៨	៨	៨	៨	៨	៨
៩	៩	៩	៩	៩	៩	៩	៩	៩	៩	៩	៩
១០	១០	១០	១០	១០	១០	១០	១០	១០	១០	១០	១០
១១	១១	១១	១១	១១	១១	១១	១១	១១	១១	១១	១១
១២	១២	១២	១២	១២	១២	១២	១២	១២	១២	១២	១២
១៣	១៣	១៣	១៣	១៣	១៣	១៣	១៣	១៣	១៣	១៣	១៣
១៤	១៤	១៤	១៤	១៤	១៤	១៤	១៤	១៤	១៤	១៤	១៤
១៥	១៥	១៥	១៥	១៥	១៥	១៥	១៥	១៥	១៥	១៥	១៥
១៦	១៦	១៦	១៦	១៦	១៦	១៦	១៦	១៦	១៦	១៦	១៦
១៧	១៧	១៧	១៧	១៧	១៧	១៧	១៧	១៧	១៧	១៧	១៧
១៨	១៨	១៨	១៨	១៨	១៨	១៨	១៨	១៨	១៨	១៨	១៨
១៩	១៩	១៩	១៩	១៩	១៩	១៩	១៩	១៩	១៩	១៩	១៩
២០	២០	២០	២០	២០	២០	២០	២០	២០	២០	២០	២០
២១	២១	២១	២១	២១	២១	២១	២១	២១	២១	២១	២១
២២	២២	២២	២២	២២	២២	២២	២២	២២	២២	២២	២២
២៣	២៣	២៣	២៣	២៣	២៣	២៣	២៣	២៣	២៣	២៣	២៣
២៤	២៤	២៤	២៤	២៤	២៤	២៤	២៤	២៤	២៤	២៤	២៤
២៥	២៥	២៥	២៥	២៥	២៥	២៥	២៥	២៥	២៥	២៥	២៥
២៦	២៦	២៦	២៦	២៦	២៦	២៦	២៦	២៦	២៦	២៦	២៦
២៧	២៧	២៧	២៧	២៧	២៧	២៧	២៧	២៧	២៧	២៧	២៧
២៨	២៨	២៨	២៨	២៨	២៨	២៨	២៨	២៨	២៨	២៨	២៨
២៩	(២៩)	២៩	២៩	២៩	២៩	២៩	២៩	២៩	២៩	២៩	២៩
៣០		៣០	៣០	៣០	៣០	៣០	៣០	៣០	៣០	៣០	៣០
៣១		៣១		៣១		៣១	៣១		៣១		៣១

ការណែនាំល្បឿនសម្រាប់គ្រូបង្រៀនប្រចាំថ្ងៃ

ផ្តល់យោបល់ចំពោះកាលវិភាគសម្រាប់ឆ្នាំសិក្សារយៈពេល ៣៦ សប្តាហ៍

សប្តាហ៍	បណ្តុំបទគម្ពីរដែលត្រូវបង្រៀន	វគ្គត្រូវអាន
១	ថ្ងៃទី ១ ៖ មេរៀនទី ១ តួនាទីរបស់អ្នករៀន ថ្ងៃទី ២ ៖មេរៀនទី ២ ការសិក្សាព្រះគម្ពីរ ថ្ងៃទី ៣ ៖មេរៀនទី ៣ ផែនការសង្គ្រោះ ថ្ងៃទី ៤ ៖មេរៀនទី ៤ ទំព័រចំណងជើង សេចក្តីផ្តើម និង ទីបន្ទាល់នៃពួកសាក្សី ថ្ងៃទី ៥ ៖មេរៀនទី ៥ ទិដ្ឋភាពទូទៅនៃព្រះគម្ពីរមរមន	ទំព័រចំណងជើង សេចក្តីផ្តើមនៃព្រះគម្ពីរមរមន ទីបន្ទាល់នៃពួកសាក្សីទីបន្ទាល់នៃព្យាការី យ៉ូសែប ស្ម៊ីធ និង ការពន្យល់សង្ខេបអំពីព្រះគម្ពីរមរមន ។
២	ថ្ងៃទី ១ ៖មេរៀនទី ៦ នីហ្វៃទី១១ ថ្ងៃទី ២ ៖មេរៀនទី ៧ នីហ្វៃទី១២ ថ្ងៃទី ៣ ៖មេរៀនទី ៨ នីហ្វៃទី១ ៣–៤ ថ្ងៃទី ៤ ៖ថ្ងៃបត់បែនតាមពេល (សូមមើលយោបល់សម្រាប់ ថ្ងៃបត់បែនតាមពេលនេះ) ថ្ងៃទី ៥ ៖មេរៀនទី ៩ នីហ្វៃទី១ ៥	នីហ្វៃទី ១ ១–៥
៣	ថ្ងៃទី ១ ៖មេរៀនទី ១០ នីហ្វៃទី១ ៦ និង ៩ ថ្ងៃទី ២ ៖មេរៀនទី ១១ នីហ្វៃទី១ ៧ ថ្ងៃទី ៣ ៖មេរៀនទី ១២ នីហ្វៃទី១ ៨ ថ្ងៃទី ៤ ៖មេរៀនទី ១៣ នីហ្វៃទី១ ១០–១១ ថ្ងៃទី ៥ ៖មេរៀនទី ១៤ នីហ្វៃទី១ ១២–១៣	នីហ្វៃទី ១ ៦–១៣
៤	ថ្ងៃទី ១ ៖មេរៀនទី ១៥ នីហ្វៃទី ១ ១៤ ថ្ងៃទី ២ ៖ថ្ងៃបត់បែនតាមពេល (សូមមើលយោបល់សម្រាប់ ថ្ងៃបត់បែនតាមពេលនេះ) ថ្ងៃទី ៣ ៖មេរៀនទី ១៦ នីហ្វៃទី១ ១៥ ថ្ងៃទី ៤ ៖មេរៀនទី ១៧ នីហ្វៃទី១ ១៦ ថ្ងៃទី ៥ ៖មេរៀនទី ១៨ នីហ្វៃទី១ ១៧	នីហ្វៃទី១ ១៤–១៧
៥	ថ្ងៃទី ១ ៖មេរៀនទី ១៩ នីហ្វៃទី១ ១៨ ថ្ងៃទី ២ ៖មេរៀនទី ២០ នីហ្វៃទី ១ ១៩ ថ្ងៃទី ៣ ៖មេរៀនទី ២១ នីហ្វៃទី១ ២០–២២ ថ្ងៃទី ៤ ៖ថ្ងៃបត់បែនតាមពេល (សូមមើលយោបល់សម្រាប់ ថ្ងៃបត់បែនតាមពេលនេះ) ថ្ងៃទី ៥ ៖មេរៀនទី ២២ នីហ្វៃទី២ ១	នីហ្វៃទី ១ ១៨–នីហ្វៃទី២ ១
៦	ថ្ងៃទី ១ ៖មេរៀនទី ២៣ នីហ្វៃទី២ ២ (ផ្នែកទី ១) ថ្ងៃទី ២ ៖មេរៀនទី ២៤ នីហ្វៃទី ២ ២ (ផ្នែកទី ២) ថ្ងៃទី ៣ ៖មេរៀនទី ២៥ នីហ្វៃទី ២ ៣ ថ្ងៃទី ៤ ៖មេរៀនទី ២៦ នីហ្វៃទី ២ ៤ ថ្ងៃទី ៥ ៖មេរៀនទី ២៧ នីហ្វៃទី ២ ៥	នីហ្វៃទី ២ ២–៥
៧	ថ្ងៃទី ១ ៖មេរៀនទី ២៨ នីហ្វៃទី ២ ៦–៨ ថ្ងៃទី ២ ៖មេរៀនទី ២៩ នីហ្វៃទី ២ ៩:១–២៦ ថ្ងៃទី ៣ ៖មេរៀនទី ៣០ នីហ្វៃទី ២ ១៩:២៧–៥៤ និង នីហ្វៃទី ២ ១០ ថ្ងៃទី ៤ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់ សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ) ថ្ងៃទី ៥ ៖មេរៀនទី ៣១ នីហ្វៃទី ២ ១១ និង ១៦	នីហ្វៃទី ២ ៦–១១; ១៦
៨	ថ្ងៃទី ១ ៖មេរៀនទី ៣២ នីហ្វៃទី ២ ១២–១៥ ថ្ងៃទី ២ ៖មេរៀនទី ៣៣ នីហ្វៃទី ២ ១៧–២០ ថ្ងៃទី ៣ ៖មេរៀនទី ៣៤ នីហ្វៃទី ២ ២១–២៤ ថ្ងៃទី ៤ ៖មេរៀនទី ៣៥ នីហ្វៃទី ២ ២៥ ថ្ងៃទី ៥ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់ សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ)	នីហ្វៃទី ២ ១២–១៥; ១៧–២៥
៩	ថ្ងៃទី ១ ៖មេរៀនទី ៣៦ នីហ្វៃទី ២ ២៦ ថ្ងៃទី ២ ៖មេរៀនទី ៣៧ នីហ្វៃទី ២ ២៧ ថ្ងៃទី ៣ ៖មេរៀនទី ៣៨ នីហ្វៃទី ២ ២៨ ថ្ងៃទី ៤ ៖មេរៀនទី ៣៩ នីហ្វៃទី ២ ២៩–៣០ ថ្ងៃទី ៥ ៖មេរៀនទី ៤០ នីហ្វៃទី ២ ៣១	នីហ្វៃទី ២ ២៦–៣១

សប្តាហ៍	បណ្តុំបទគម្ពីរដែលត្រូវបង្រៀន	វគ្គត្រូវអាន
១០	ថ្ងៃទី ១ ៖មេរៀនទី ៤១ នីហ្វៃទី ២ ៣២ ថ្ងៃទី ២ ៖មេរៀនទី ៤២ នីហ្វៃទី ២ ៣៣ ថ្ងៃទី ៣ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់ សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ) ថ្ងៃទី ៤ ៖មេរៀនទី ៤៣ យ៉ាកុប ១–២:១១ ថ្ងៃទី ៥ ៖មេរៀនទី ៤៤ យ៉ាកុប ២:១២–៣៥	នីហ្វៃទី ២ ៣២–យ៉ាកុប ២
១១	ថ្ងៃទី ១ ៖មេរៀនទី ៤៥ យ៉ាកុប ៣–៤ ថ្ងៃទី ២ ៖មេរៀនទី ៤៦ យ៉ាកុប ៥:១–៥១ ថ្ងៃទី ៣ ៖មេរៀនទី ៤៧ យ៉ាកុប ៥:៥២–៧៧; យ៉ាកុប ៦ ថ្ងៃទី ៤ ៖មេរៀនទី ៤៨ យ៉ាកុប ៧ ថ្ងៃទី ៥ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់ សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ)	យ៉ាកុប ៣–៧
១២	ថ្ងៃទី ១ ៖មេរៀនទី ៤៩ អេណុស ថ្ងៃទី ២ ៖មេរៀនទី ៥០ យ៉ារ៉ុម និង អេមណៃ ថ្ងៃទី ៣ ៖មេរៀនទី ៥១ ពាក្យសម្ដីនៃមរមន–ម៉ូសាយ ១ ថ្ងៃទី ៤ ៖មេរៀនទី ៥២ ម៉ូសាយ ២ ថ្ងៃទី ៥ ៖មេរៀនទី ៥៣ ម៉ូសាយ ៣	អេណុស–ម៉ូសាយ ៣
១៣	ថ្ងៃទី ១ ៖មេរៀនទី ៥៤ ម៉ូសាយ ៤ ថ្ងៃទី ២ ៖មេរៀនទី ៥៥ ម៉ូសាយ ៥–៦ ថ្ងៃទី ៣ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់ សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ) ថ្ងៃទី ៤ ៖មេរៀនទី ៥៦ ម៉ូសាយ ៧–៨ ថ្ងៃទី ៥ ៖មេរៀនទី ៥៧ ម៉ូសាយ ៩–១០	ម៉ូសាយ ៤–១០
១៤	ថ្ងៃទី ១ ៖មេរៀនទី ៥៨ ម៉ូសាយ ១១–១២:១៧ ថ្ងៃទី ២ ៖មេរៀនទី ៥៩ ម៉ូសាយ ១២:១៨–១៤:១២ ថ្ងៃទី ៣ ៖មេរៀនទី ៦០ ម៉ូសាយ ១៥–១៧ ថ្ងៃទី ៤ ៖មេរៀនទី ៦១ ម៉ូសាយ ១៨ ថ្ងៃទី ៥ ៖មេរៀនទី ៦២ ម៉ូសាយ ១៩–២០	ម៉ូសាយ ១១–២០
១៥	ថ្ងៃទី ១ ៖មេរៀនទី ៦៣ ម៉ូសាយ ២១–២២ ថ្ងៃទី ២ ៖មេរៀនទី ៦៤ ម៉ូសាយ ២៣–២៤ ថ្ងៃទី ៣ ៖មេរៀនទី ៦៥ ម៉ូសាយ ២៥ ថ្ងៃទី ៤ ៖មេរៀនទី ៦៦ ម៉ូសាយ ២៦ ថ្ងៃទី ៥ ៖មេរៀនទី ៦៧ ម៉ូសាយ ២៧	ម៉ូសាយ ២១–២៧
១៦	ថ្ងៃទី ១ ៖មេរៀនទី ៦៨ ម៉ូសាយ ២៨–២៩ ថ្ងៃទី ២ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់ សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ) ថ្ងៃទី ៣ ៖មេរៀនទី ៦៩ អាលម៉ា ១–២ ថ្ងៃទី ៤ ៖មេរៀនទី ៧០ អាលម៉ា ៣–៤ ថ្ងៃទី ៥ ៖មេរៀនទី ៧១ អាលម៉ា ៥:១–៣៦	ម៉ូសាយ ២៨–អាលម៉ា ៥:៣៦
១៧	ថ្ងៃទី ១ ៖មេរៀនទី ៧២ អាលម៉ា ៥:៣៧–៦២ ថ្ងៃទី ២ ៖មេរៀនទី ៧៣ អាលម៉ា ៦–៧ ថ្ងៃទី ៣ ៖មេរៀនទី ៧៤ អាលម៉ា ៨២ ថ្ងៃទី ៤ ៖មេរៀនទី ៧៥ អាលម៉ា ៩–១០ ថ្ងៃទី ៥ ៖មេរៀនទី ៧៦ អាលម៉ា ១១	អាលម៉ា ៥:៣៧–១១:៤៦
១៨	ថ្ងៃទី ១ ៖មេរៀនទី ៧៧ អាលម៉ា ១២ ថ្ងៃទី ២ ៖មេរៀនទី ៧៨ អាលម៉ា ១៣ ថ្ងៃទី ៣ ៖មេរៀនទី ៧៩ អាលម៉ា ១៤ ថ្ងៃទី ៤ ៖មេរៀនទី ៨០ អាលម៉ា ១៥–១៦ ថ្ងៃទី ៥ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់ សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ)	អាលម៉ា ១២–១៦
១៩	ថ្ងៃទី ១ ៖មេរៀនទី ៨១ អាលម៉ា ១៧ ថ្ងៃទី ២ ៖មេរៀនទី ៨២ អាលម៉ា ១៨ ថ្ងៃទី ៣ ៖មេរៀនទី ៨៣ អាលម៉ា ១៩–២០ ថ្ងៃទី ៤ ៖មេរៀនទី ៨៤ អាលម៉ា ២១–២២ ថ្ងៃទី ៥ ៖មេរៀនទី ៨៥ អាលម៉ា ២៣–២៤	អាលម៉ា ១៧–២៤
២០	ថ្ងៃទី ១ ៖មេរៀនទី ៨៦ អាលម៉ា ២៥–២៦ ថ្ងៃទី ២ ៖មេរៀនទី ៨៧ អាលម៉ា ២៧–២៩ ថ្ងៃទី ៣ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់ សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ) ថ្ងៃទី ៤ ៖មេរៀនទី ៨៨ អាលម៉ា ៣០ ថ្ងៃទី ៥ ៖មេរៀនទី ៨៩ អាលម៉ា ៣១	អាលម៉ា ២៥–៣១
២១	ថ្ងៃទី ១ ៖មេរៀនទី ៩០ អាលម៉ា ៣២ ថ្ងៃទី ២ ៖មេរៀនទី ៩១ អាលម៉ា ៣៣ ថ្ងៃទី ៣ ៖មេរៀនទី ៩២ អាលម៉ា ៣៤–៣៥ ថ្ងៃទី ៤ ៖មេរៀនទី ៩៣ អាលម៉ា ៣៦ ថ្ងៃទី ៥ ៖មេរៀនទី ៩៤ អាលម៉ា ៣៧	អាលម៉ា ៣២–៣៧

សប្តាហ៍	បណ្តុំបទគម្ពីរដែលត្រូវបង្រៀន	វគ្គត្រូវអាន
២២	ថ្ងៃទី ១ ៖មេរៀនទី ៥៥ អាលម៉ា ៣៨ ថ្ងៃទី ២ ៖មេរៀនទី ៥៦ អាលម៉ា ៣៩ ថ្ងៃទី ៣ ៖មេរៀនទី ៥៧ អាលម៉ា ៤០ ថ្ងៃទី ៤ ៖មេរៀនទី ៥៨ អាលម៉ា ៤១ ថ្ងៃទី ៥ ៖មេរៀនទី ៥៩ អាលម៉ា ៤២	អាលម៉ា ៣៨–៤២
២៣	ថ្ងៃទី ១ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ) ថ្ងៃទី ២ ៖មេរៀនទី ១០០ អាលម៉ា ៤៣–៤៤ ថ្ងៃទី ៣ ៖មេរៀនទី ១០១ អាលម៉ា ៤៥–៤៨ ថ្ងៃទី ៤ ៖មេរៀនទី ១០២ អាលម៉ា ៤៩–៥១ ថ្ងៃទី ៥ ៖មេរៀនទី ១០៣ អាលម៉ា ៥២–៥៥	អាលម៉ា ៤៣–៥៥
២៤	ថ្ងៃទី ១ ៖មេរៀនទី ១០៤ អាលម៉ា ៥៦–៥៨ ថ្ងៃទី ២ ៖មេរៀនទី ១០៥ អាលម៉ា ៥៩–៦៣ ថ្ងៃទី ៣ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ) ថ្ងៃទី ៤ ៖មេរៀនទី ១០៦ ហេលេមិន ១–២ ថ្ងៃទី ៥ ៖មេរៀនទី ១០៧ ហេលេមិន ៣–៤	អាលម៉ា ៥៦–ហេលេមិន ៤
២៥	ថ្ងៃទី ១ ៖មេរៀនទី ១០៨ ហេលេមិន ៥២ ថ្ងៃទី ២ ៖មេរៀនទី ១០៩ ហេលេមិន ៦–៧ ថ្ងៃទី ៣ ៖មេរៀនទី ១១០ ហេលេមិន ៨–៩ ថ្ងៃទី ៤ ៖មេរៀនទី ១១១ ហេលេមិន ១០ ថ្ងៃទី ៥ ៖មេរៀនទី ១១២ ហេលេមិន ១១–១២	ហេលេមិន ៥–១២
២៦	ថ្ងៃទី ១ ៖មេរៀនទី ១១៣ ហេលេមិន ១៣ ថ្ងៃទី ២ ៖មេរៀនទី ១១៤ ហេលេមិន ១៤ ថ្ងៃទី ៣ ៖មេរៀនទី ១១៥ ហេលេមិន ១៥–១៦ ថ្ងៃទី ៤ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ) ថ្ងៃទី ៥ ៖មេរៀនទី ១១៦ នីហ្វៃទី ៣ ១	ហេលេមិន ១៣–នីហ្វៃទី ៣ ១
២៧	ថ្ងៃទី ១ ៖មេរៀនទី ១១៧ នីហ្វៃទី ៣ ២–៥ ថ្ងៃទី ២ ៖មេរៀនទី ១១៨ នីហ្វៃទី ៣ ៦–៧ ថ្ងៃទី ៣ ៖មេរៀនទី ១១៩ នីហ្វៃទី ៣ ៨–១០ ថ្ងៃទី ៤ ៖មេរៀនទី ១២០ នីហ្វៃទី ៣ ១១:១–១៧ ថ្ងៃទី ៥ ៖មេរៀនទី ១២១ នីហ្វៃទី ៣ ១១:១៨–៤១	នីហ្វៃទី ៣ ២–១១
២៨	ថ្ងៃទី ១ ៖មេរៀនទី ១២២ នីហ្វៃទី ៣ ១២ ថ្ងៃទី ២ ៖មេរៀនទី ១២៣ នីហ្វៃទី ៣ ១៣ ថ្ងៃទី ៣ ៖មេរៀនទី ១២៤ នីហ្វៃទី ៣ ១៤ ថ្ងៃទី ៤ ៖មេរៀនទី ១២៥ នីហ្វៃទី ៣ ១៥–១៦ ថ្ងៃទី ៥ ៖មេរៀនទី ១២៦ នីហ្វៃទី ៣ ១៧	នីហ្វៃទី ៣ ១២–១៧
២៩	ថ្ងៃទី ១ ៖មេរៀនទី ១២៧ នីហ្វៃទី ៣ ១៨ ថ្ងៃទី ២ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ) ថ្ងៃទី ៣ ៖មេរៀនទី ១២៨ នីហ្វៃទី ៣ ១៩ ថ្ងៃទី ៤ ៖មេរៀនទី ១២៩ នីហ្វៃទី ៣ ២០ ថ្ងៃទី ៥ ៖មេរៀនទី ១៣០ នីហ្វៃទី ៣ ២១–២២	នីហ្វៃទី ៣ ១៨–២២
៣០	ថ្ងៃទី ១ ៖មេរៀនទី ១៣១ នីហ្វៃទី ៣ ២៣ ថ្ងៃទី ២ ៖មេរៀនទី ១៣២ នីហ្វៃទី ៣ ២៤–២៦ ថ្ងៃទី ៣ ៖មេរៀនទី ១៣៣ នីហ្វៃទី ៣ ២៧ ថ្ងៃទី ៤ ៖មេរៀនទី ១៣៤ នីហ្វៃទី ៣ ២៨ ថ្ងៃទី ៥ ៖មេរៀនទី ១៣៥ នីហ្វៃទី ៣ ២៩–៣០	នីហ្វៃទី ៣ ២៣–៣០

សប្តាហ៍	បណ្តុំបទគម្ពីរដែលត្រូវបង្រៀន	វគ្គត្រូវអាន
៣១	ថ្ងៃទី ១ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ) ថ្ងៃទី ២ ៖មេរៀនទី ១៣៦ នីហ្វៃទី ៤ ថ្ងៃទី ៣ ៖មេរៀនទី ១៣៧ មរមន ១–២ ថ្ងៃទី ៤ ៖មេរៀនទី ១៣៨ មរមន ៣–៤ ថ្ងៃទី ៥ ៖មេរៀនទី ១៣៩ មរមន ៥–៦	នីហ្វៃទី ៤ –មរមន ៦
៣២	ថ្ងៃទី ១ ៖មេរៀនទី ១៤០ មរមន ៧–៨:១១ ថ្ងៃទី ២ ៖មេរៀនទី ១៤១ មរមន ៨:១២–៤១ ថ្ងៃទី ៣ ៖មេរៀនទី ១៤២ មរមន ៩ ថ្ងៃទី ៤ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ) ថ្ងៃទី ៥ ៖មេរៀនទី ១៤៣ អេធើរ ១	មរមន ៧–អេធើរ ១
៣៣	ថ្ងៃទី ១ ៖មេរៀនទី ១៤៤ អេធើរ ២ ថ្ងៃទី ២ ៖មេរៀនទី ១៤៥ អេធើរ ៣ ថ្ងៃទី ៣ ៖មេរៀនទី ១៤៦ អេធើរ ៤–៥ ថ្ងៃទី ៤ ៖មេរៀនទី ១៤៧ អេធើរ ៦ ថ្ងៃទី ៥ ៖មេរៀនទី ១៤៨ អេធើរ ៧–១១	អេធើរ ២–១១
៣៤	ថ្ងៃទី ១ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ) ថ្ងៃទី ២ ៖មេរៀនទី ១៤៩ អេធើរ ១២:១–២២ ថ្ងៃទី ៣ ៖មេរៀនទី ១៥០ អេធើរ ១២:២៣–៤១ ថ្ងៃទី ៤ ៖មេរៀនទី ១៥១ អេធើរ ១៣–១៥ ថ្ងៃទី ៥ ៖មេរៀនទី ១៥២ ម៉រ៉ូណៃ ១–៣	អេធើរ ១២–ម៉រ៉ូណៃ ៣
៣៥	ថ្ងៃទី ១ ៖មេរៀនទី ១៥៣ ម៉រ៉ូណៃ ៤–៥ ថ្ងៃទី ២ ៖មេរៀនទី ១៥៤ ម៉រ៉ូណៃ ៦ ថ្ងៃទី ៣ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ) ថ្ងៃទី ៤ ៖មេរៀនទី ១៥៥ ម៉រ៉ូណៃ ៧:១–១៩ ថ្ងៃទី ៥ ៖មេរៀនទី ១៥៦ ម៉រ៉ូណៃ ៧:២០–៤៨	ម៉រ៉ូណៃ ៤–៧
៣៦	ថ្ងៃទី ១ ៖មេរៀនទី ១៥៧ ម៉រ៉ូណៃ ៨ ថ្ងៃទី ២ ៖មេរៀនទី ១៥៨ ម៉រ៉ូណៃ ៩ ថ្ងៃទី ៣ ៖មេរៀនទី ១៥៩ ម៉រ៉ូណៃ ១០:១–៧, ២៧–២៩ ថ្ងៃទី ៤ ៖មេរៀនទី ១៦០ ម៉រ៉ូណៃ ១០:៨–២៦, ៣០–៣៤ ថ្ងៃទី ៥ ៖ថ្ងៃដែលអាចបត់បែនតាមពេល (សូមមើលយោបល់សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេលនេះ)	ម៉រ៉ូណៃ ៨–១០

យោបល់សម្រាប់ថ្ងៃដែលអាចបត់បែនតាមពេល

ការណែនាំពីល្បឿនក្នុងការបង្រៀនសម្រាប់គ្រូបង្រៀនប្រចាំថ្ងៃ ផ្អែកលើឆ្នាំសិក្សា ៣៦ សប្តាហ៍ ឬ ១៨០ ថ្ងៃ ។ សៀវភៅណែនាំនេះមាននូវ ១៦០ មេរៀនប្រចាំថ្ងៃ ដោយមាន ២០ ថ្ងៃដែលមិនមានអ្វីត្រូវបង្រៀន ។ « ថ្ងៃដែលអាចបត់បែនតាមពេល » ទាំង ២០ ថ្ងៃនេះគួរប្រើដោយឈ្លាសវៃសម្រាប់គោលដៅ និងសកម្មភាពមាននំយ រួមមានដូចខាងក្រោមនេះ ៖

១. ការសម្របមេរៀនប្រចាំថ្ងៃ ។ អ្នកអាចចំណាយពេលបន្ថែមលើមេរៀនមួយ ដែលត្រូវការពេលយូរបង្រៀនឲ្យមានប្រសិទ្ធភាព ។ អ្នកក៏អាចប្រើគំនិតជំនួយក្នុងការបង្រៀនដែលមាននៅចុងបញ្ចប់នៃមេរៀនមួយចំនួន ឬយកពេលដើម្បីឆ្លើយនឹងសំណួររបស់សិស្សអំពីវគ្គព្រះគម្ពីរពិសេសណាមួយ ឬប្រជានបទដ៏ណឹងល្អណាមួយ ។ ថ្ងៃដែលអាចបត់បែនតាមពេលនេះ នាំឲ្យអ្នកមានផលប្រយោជន៍ពីឱកាសទាំងនេះ ខណៈពេលធ្វើតាមកាលវិភាគបង្រៀន និងបំពេញកិច្ចការរបស់អ្នកក្នុងការបង្រៀនតាមស៊េរីព្រះគម្ពីរ ។

២. ការចេះចាំស្ទាត់នូវវគ្គបទគម្ពីរសំខាន់ៗ និងគោលលទ្ធិគ្រឹះទាំងឡាយ ។អ្នកអាចប្រើសកម្មភាពរំឭកទាំងឡាយសម្រាប់វគ្គចំណេះចំណានខគម្ពីរ ដែលមាននៅក្នុងសៀវភៅណែនាំ និងនៅក្នុងសេចក្តីបន្ថែមនេះ ។ អ្នកអាចបង្កើតសកម្មភាពរំឭកចំណេះចំណានខគម្ពីរបន្ថែមដែលបំពេញតាមតម្រូវការ និងចំណាប់អារម្មណ៍ជាពិសេសដល់សិស្សអ្នក ។ អ្នកក៏អាចប្រើផ្នែកនៃថ្ងៃដែលអាចបត់បែនតាមពេលនេះសម្រាប់សកម្មភាព ដែលជួយដល់សិស្សឲ្យរំឭក និងយល់កាន់តែច្បាស់អំពីគោលលទ្ធិគ្រឹះទាំងឡាយ ។ នៅដើមឆ្នាំនេះ អ្នកអាចប្រើថ្ងៃដែលអាចបត់បែនតាមពេល ដើម្បីធ្វើការវាយតម្លៃលើគោលលទ្ធិគ្រឹះ (BDA) ដែលរៀបចំឡើងដើម្បីជួយដល់គ្រូបង្រៀនស្ទង់មើលពីទំហំដែលសិស្សអាចយល់ជឿតាម ដឹងពីរបៀបអនុវត្ត និងអាចពន្យល់គោលលទ្ធិគ្រឹះនៃសាសនាចក្រខ្លះ ។ សូមរកមើលកម្មវិធីវាយតម្លៃលើគោលលទ្ធិគ្រឹះ និងកម្មវិធីស្ទង់មើលផ្សេងទៀតនៅក្នុងគេហទំព័រ ស&វ (si.lds.org) សូមប្រើពាក្យគន្លឹះ *assessment* ។ របាយការណ៍ BDA ជួយដល់គ្រូបង្រៀនដែលបានធ្វើតាមកម្មវិធីនេះឲ្យវិភាគពីតម្រូវការរបស់សិស្ស និងចេះសម្រួលការបង្រៀនឲ្យត្រូវនឹងតម្រូវការរបស់សិស្សល្អបំផុត ។

៣. ការរំឭកឡើងវិញនូវឯកសារចាស់ៗ ។ វានឹងជួយសិស្សឲ្យក្រឡេកមើលទៅពេលដែលគេបានរៀននៅក្នុងមេរៀនមុនៗ ឬពីគម្ពីរក្នុងព្រះគម្ពីរណាមួយ ។ អ្នកអាចផ្តល់ឱកាសដល់សិស្សឲ្យពន្យល់ពីសេចក្តីពិតមួយពីមេរៀនមុន ហើយចែកចាយរបៀបដែលសេចក្តីពិតនោះបានមានឥទ្ធិពលដល់ជីវិតរបស់អ្នក ។ អ្នកក៏អាចបង្កើត និងធ្វើសំណួរចម្លើយមួយ ឬសកម្មភាពរៀនសូត្រដែលរំឭកពីឯកសារមេរៀនមុនៗ ។

៤. ការអាក់ខានមិនបង្រៀនតាមកាលវិភាគ ។ សកម្មភាព ឬការប្រជុំនៅសាលារៀន ព្រឹត្តិការណ៍ក្នុងសហគមន៍ អាកាសធាតុ និងការអាក់ខានផ្សេងទៀតដែលអាចតម្រូវឲ្យអ្នកមិនបង្រៀន ឬបង្រៀនក្នុងពេលខ្លីតាមកាលៈទេសៈ ។ ថ្ងៃដែលអាចបត់បែនតាមពេលនេះ អាចត្រូវប្រើជំនួសការអាក់ខានបែបនោះ ។

ការណែនាំល្បឿនបង្រៀនសម្រាប់គ្រូបង្រៀនមេរៀននៅផ្ទះ

សៀវភៅណែនាំនេះក៏មានមេរៀនចំនួន ៣២ សម្រាប់ថ្នាក់សិក្សានៅផ្ទះប្រចាំសប្តាហ៍ដែលស្របទៅនឹង ៣២ មេរៀនដែលមាននៅក្នុងសៀវភៅមគ្គុទេសន៍ការសិក្សាព្រះគម្ពីរមរមនសម្រាប់សិស្ស សិក្ខាសាលាសិក្សានៅផ្ទះ ។ អ្នកអាចសម្របសម្រួលមេរៀននេះ និងល្បឿននៃមេរៀនតាមត្រូវការតាមពេលដែលអ្នកមានដើម្បីបង្រៀនវគ្គនេះ ។

មេរៀន	មេរៀនសិក្សានៅផ្ទះ
មេរៀនទី ១	ថ្ងៃទី ១ ៖ ការសិក្សាបទគម្ពីរ ថ្ងៃទី ២ ៖ ផែនការនៃសេចក្តីសង្គ្រោះ ថ្ងៃទី ៣ ៖ ទំព័រចំណងជើង សេចក្តីផ្តើម និងទីបន្ទាល់នៃ ពួកសាក្សី ថ្ងៃទី ៤ ៖ ទិដ្ឋភាពទូទៅនៃព្រះគម្ពីរមរមន *មេរៀនសម្រាប់គ្រូបង្រៀន ៖ ការសិក្សាបទគម្ពីរ–ទិដ្ឋភាពទូទៅនៃព្រះគម្ពីរមរមន*
មេរៀនទី ២	ថ្ងៃទី ១ ៖ នីហ្វៃទី១ ១ ថ្ងៃទី ២ ៖ នីហ្វៃទី១ ២ ថ្ងៃទី ៣ ៖ នីហ្វៃទី១ ៣–៤ ថ្ងៃទី ៤ ៖ នីហ្វៃទី១ ៥–៦; ៥ *មេរៀនសម្រាប់គ្រូបង្រៀន ៖ នីហ្វៃទី១ ១–៦; ៥*
មេរៀនទី ៣	ថ្ងៃទី ១ ៖ នីហ្វៃទី១ ៧ ថ្ងៃទី ២ ៖ នីហ្វៃទី១ ៨ ថ្ងៃទី ៣ ៖ នីហ្វៃទី១ ១០–១១ ថ្ងៃទី ៤ ៖ នីហ្វៃទី១ ១២–១៤ *មេរៀនសម្រាប់គ្រូបង្រៀន ៖ នីហ្វៃទី១ ៧–៨; ១០–១៤*
មេរៀនទី ៤	ថ្ងៃទី ១ ៖ នីហ្វៃទី១ ១៥ ថ្ងៃទី ២ ៖ នីហ្វៃទី ១ ១៦ ថ្ងៃទី ៣ ៖ នីហ្វៃទី១ ១៧ ថ្ងៃទី ៤ ៖ នីហ្វៃ១ ១៨–១៩ *មេរៀនសម្រាប់គ្រូបង្រៀន ៖ នីហ្វៃទី១ ១៥–១៩*
មេរៀនទី ៥	ថ្ងៃទី ១ ៖ នីហ្វៃទី១ ២០–២២ ថ្ងៃទី ២ ៖ នីហ្វៃទី ២ ១ ថ្ងៃទី ៣ ៖ នីហ្វៃទី ២ ២ ថ្ងៃទី ៤ ៖ នីហ្វៃទី ២ ៣ *មេរៀនសម្រាប់គ្រូបង្រៀន ៖ នីហ្វៃទី១ ២០–នីហ្វៃទី ២ ៣*
មេរៀនទី ៦	ថ្ងៃទី ១ ៖ នីហ្វៃទី២ ៤–៥ ថ្ងៃទី ២ ៖ នីហ្វៃទី២ ៦–៨ ថ្ងៃទី ៣ ៖ នីហ្វៃទី ២ ៩ ថ្ងៃទី ៤ ៖ នីហ្វៃទី២ ៩–១០ *មេរៀនសម្រាប់គ្រូបង្រៀន ៖ នីហ្វៃទី២ ៤–១០*
មេរៀនទី ៧	ថ្ងៃទី ១ ៖ នីហ្វៃទី២ ១១–១៦ ថ្ងៃទី ២ ៖ នីហ្វៃទី២ ១៧–២០ ថ្ងៃទី ៣ ៖ នីហ្វៃទី២ ២១–២៤ ថ្ងៃទី ៤ ៖ នីហ្វៃទី២ ២៥ *មេរៀនសម្រាប់គ្រូបង្រៀន ៖ នីហ្វៃទី២ ១១–២៥*
មេរៀនទី ៨	ថ្ងៃទី ១ ៖ នីហ្វៃទី២ ២៦–២៧ ថ្ងៃទី ២ ៖ នីហ្វៃទី២ ២៨ ថ្ងៃទី ៣ ៖ នីហ្វៃទី២ ២៩–៣០ ថ្ងៃទី ៤ ៖ នីហ្វៃទី២ ៣១ *មេរៀនសម្រាប់គ្រូបង្រៀន ៖ នីហ្វៃទី២ ២៦–៣១*
មេរៀនទី ៩	ថ្ងៃទី ១ ៖ នីហ្វៃទី២ ៣២ ថ្ងៃទី ២ ៖ នីហ្វៃទី២ ៣៣ ថ្ងៃទី ៣ ៖ យ៉ាកុប ១–២ ថ្ងៃទី ៤ ៖ យ៉ាកុប ៣–៤ *មេរៀនសម្រាប់គ្រូបង្រៀន ៖ នីហ្វៃទី ២ ៣២–យ៉ាកុប ៤*
មេរៀនទី ១០	ថ្ងៃទី ១ ៖ យ៉ាកុប ៥–៦ ថ្ងៃទី ២ ៖ យ៉ាកុប ៧ ថ្ងៃទី ៣ ៖ អេណុស ថ្ងៃទី ៤ ៖ យ៉ារ៉ុម និង អេមណៃ *មេរៀនសម្រាប់គ្រូបង្រៀន ៖ យ៉ាកុប ៥–អេមណៃ*
មេរៀនទី ១១	ថ្ងៃទី ១: ៖ ពាក្យសម្តីនៃមរមន–ម៉ូសាយ ២ ថ្ងៃទី ២ ៖ ម៉ូសាយ ៣ ថ្ងៃទី ៣ ៖ ម៉ូសាយ ៤ ថ្ងៃទី ៤ ៖ ម៉ូសាយ ៥–៦ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ពាក្យសម្តីនៃមរមន–ម៉ូសាយ ៦*
មេរៀនទី ១២	ថ្ងៃទី ១ ៖ ម៉ូសាយ ៧–៨ ថ្ងៃទី ២ ៖ ម៉ូសាយ ៩–១០ ថ្ងៃទី ៣ ៖ ម៉ូសាយ ១១–១៤ ថ្ងៃទី ៤ ៖ ម៉ូសាយ ១៥–១៧ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ម៉ូសាយ ៧–១៧*
មេរៀនទី ១៣	ថ្ងៃទី ១ ៖ ម៉ូសាយ ១៨ ថ្ងៃទី ២ ៖ ម៉ូសាយ ១៩–២០ ថ្ងៃទី ៣ ៖ ម៉ូសាយ ២១–២៤ ថ្ងៃទី ៤ ៖ ម៉ូសាយ ២៥ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ម៉ូសាយ ១៨–២៥*
មេរៀនទី ១៤	ថ្ងៃទី ១ ៖ ម៉ូសាយ ២៦ ថ្ងៃទី ២ ៖ ម៉ូសាយ ២៧ ថ្ងៃទី ៣ ៖ ម៉ូសាយ ២៨–២៩ ថ្ងៃទី ៤ ៖ អាលម៉ា ១–៤ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ម៉ូសាយ ២៦–អាលម៉ា ៤*
មេរៀនទី ១៥	ថ្ងៃទី ១: ៖ អាលម៉ា ៥:១–៣៦ ថ្ងៃទី ២: ៖ អាលម៉ា ៥:៣៧–៦២ ថ្ងៃទី ៣ ៖ អាលម៉ា ៦–៧ ថ្ងៃទី ៤ ៖ អាលម៉ា ៨–១០ *មេរៀនសម្រាប់គ្រូបង្រៀន ៖ អាលម៉ា ៥–១០*
មេរៀនទី ១៦	ថ្ងៃទី ១ ៖ អាលម៉ា ១១ ថ្ងៃទី ២ ៖ អាលម៉ា ១២ ថ្ងៃទី ៣ ៖ អាលម៉ា ១៣ ថ្ងៃទី ៤ ៖ អាលម៉ា ១៤–១៦ *មេរៀនសម្រាប់គ្រូបង្រៀន ៖ អាលម៉ា ១១–១៦*
មេរៀនទី ១៧	ថ្ងៃទី ១ ៖ អាលម៉ា ១៧–១៨ ថ្ងៃទី ២ ៖ អាលម៉ា ១៩–២០ ថ្ងៃទី ៣ ៖ អាលម៉ា ២១–២២ ថ្ងៃទី ៤ ៖ អាលម៉ា ២៣–២៤ *មេរៀនសម្រាប់គ្រូបង្រៀន ៖ អាលម៉ា ១៧–២៤*
មេរៀនទី ១៨	ថ្ងៃទី ១ ៖ អាលម៉ា ២៥–២៩ ថ្ងៃទី ២ ៖ អាលម៉ា ៣០ ថ្ងៃទី ៣ ៖ អាលម៉ា ៣១ ថ្ងៃទី ៤ ៖ អាលម៉ា ៣២ *មេរៀនសម្រាប់គ្រូបង្រៀន ៖ អាលម៉ា ២៥–៣២*
មេរៀនទី ១៩	ថ្ងៃទី ១ ៖ អាលម៉ា ៣៣–៣៥ ថ្ងៃទី ២ ៖ អាលម៉ា ៣៦ ថ្ងៃទី ៣ ៖ អាលម៉ា ៣៧ ថ្ងៃទី ៤ ៖ អាលម៉ា ៣៨ *មេរៀនសម្រាប់គ្រូបង្រៀន ៖ អាលម៉ា ៣៣–៣៨*
មេរៀនទី ២០	ថ្ងៃទី ១ ៖ អាលម៉ា ៣៩ ថ្ងៃទី ២ ៖ អាលម៉ា ៤០–៤១ ថ្ងៃទី ៣ ៖ អាលម៉ា ៤២ ថ្ងៃទី ៤ ៖ អាលម៉ា ៤៣–៤៤ *មេរៀនសម្រាប់គ្រូបង្រៀន ៖ អាលម៉ា ៣៩–៤៤*
មេរៀនទី ២១	ថ្ងៃទី ១ ៖ អាលម៉ា ៤៥–៤៩ ៖ទី ២ : អាលម៉ា ៥០–៥២; ៥៤–៥៥ ថ្ងៃទី ៣: ៖ អាលម៉ា ៥៣; ៥៦–៥៨ ថ្ងៃទី ៤ ៖ អាលម៉ា ៥៩–៦៣ *មេរៀនសម្រាប់គ្រូបង្រៀន ៖ អាលម៉ា ៤៥–៦៣*
មេរៀនទី ២២	ថ្ងៃទី ១ ៖ ហេលេមិន ១–២ ថ្ងៃទី ២ ៖ ហេលេមិន ៣–៤ ថ្ងៃទី ៣ ៖ ហេលេមិន ៥ ថ្ងៃទី ៤ ៖ ហេលេមិន ៦–៩ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ហេលេមិន ១–៩*
មេរៀនទី ២៣	ថ្ងៃទី ១ ៖ ហេលេមិន ១០ ថ្ងៃទី ២ ៖ ហេលេមិន ១១–១២ ថ្ងៃទី ៣ ៖ ហេលេមិន ១៣–១៤ ថ្ងៃទី ៤ ៖ ហេលេមិន ១៥–១៦ *មេរៀនសម្រាប់គ្រូបង្រៀន ៖ ហេលេមិន ១០–១៦*
មេរៀនទី ២៤	ថ្ងៃទី ១ ៖ នីហ្វៃទី៣ ១ ថ្ងៃទី ២ ៖ នីហ្វៃទី៣ ២–៥ ថ្ងៃទី ៣ ៖ នីហ្វៃទី៣ ៦–១០ ថ្ងៃទី ៤ ៖ នីហ្វៃទី៣ ១១:១–១៧ *មេរៀនសម្រាប់គ្រូបង្រៀន ៖ នីហ្វៃទី៣ ១–១១:១៧*
មេរៀនទី ២៥	ថ្ងៃទី ១ ៖ នីហ្វៃទី៣ ១១:១៨–១២:៤៨ ថ្ងៃទី ២ ៖ នីហ្វៃទី៣ ១៣ ថ្ងៃទី ៣ ៖ នីហ្វៃទី៣ ១៤ ថ្ងៃទី ៤ ៖ នីហ្វៃទី៣ ១៥–១៦ *មេរៀនសម្រាប់គ្រូបង្រៀន ៖ នីហ្វៃទី៣ ១១:១៨–១៦:២០*
មេរៀនទី ២៦	ថ្ងៃទី ១ ៖ នីហ្វៃទី៣ ១៧ ថ្ងៃទី ២ ៖ នីហ្វៃទី៣ ១៨ ថ្ងៃទី ៣ ៖ នីហ្វៃទី៣ ១៩ ថ្ងៃទី ៤ ៖ នីហ្វៃទី៣ ២០–២២ *មេរៀនសម្រាប់គ្រូបង្រៀន ៖ នីហ្វៃទី៣ ១៧–២២*
មេរៀនទី ២៧	ថ្ងៃទី ១ ៖ នីហ្វៃទី៣ ២៣ ថ្ងៃទី ២ ៖ នីហ្វៃទី៣ ២៤–២៦ ថ្ងៃទី ៣ ៖ នីហ្វៃទី៣ ២៧ ថ្ងៃទី ៤ ៖ នីហ្វៃទ៣ ២៨–៣០ *មេរៀនសម្រាប់គ្រូបង្រៀន ៖ នីហ្វៃទី៣ ២៣–៣០*
មេរៀនទី ២៨	ថ្ងៃទី ១ ៖ នីហ្វៃទី៤ ១ ថ្ងៃទី ២ ៖ មរមន ១–២ ថ្ងៃទី ៣ ៖ មរមន ៣–៦ ថ្ងៃទី ៤: ៖ មរមន ៧:១–៨:១១ *មេរៀនសម្រាប់គ្រូបង្រៀន ៖ នីហ្វៃទី ៤ ១–មរមន ៨:១១*
មេរៀនទី ២៩	ថ្ងៃទី ១ ៖ មរមន ៨:១២–៤១ ថ្ងៃទី ២ ៖ មរមន ៩ ថ្ងៃទី ៣ ៖ អេធើរ ១–២ ថ្ងៃទី ៤: ៖ អេធើរ ៣ *មេរៀនសម្រាប់គ្រូបង្រៀន ៖ មរមន ៨:១២–អេធើរ ៣*
មេរៀនទី ៣០	ថ្ងៃទី ១ ៖ អេធើរ ៤–៥ ថ្ងៃទី ២ ៖ អេធើរ ៦ ថ្ងៃទី ៣ ៖ អេធើរ ៧–១១ ថ្ងៃទី ៤ ៖ អេធើរ ១២ *មេរៀនសម្រាប់គ្រូបង្រៀន ៖ អេធើរ ៤–១២*
មេរៀនទី ៣១	ថ្ងៃទី ១ ៖ អេធើរ ១៣–១៥ ថ្ងៃទី ២ ៖ មរ៉ូណៃ ១–៥ ថ្ងៃទី ៣ ៖ មរ៉ូណៃ ៦ ថ្ងៃទី ៤ ៖ មរ៉ូណៃ ៧:១–១៩ *មេរៀនសម្រាប់គ្រូបង្រៀន ៖ អេធើរ ១៣–មរ៉ូណៃ ៧:១៩*
មេរៀនទី ៣២	ថ្ងៃទី ១ ៖ មរ៉ូណៃ ៧:២០–៤៨ ថ្ងៃទី ២ ៖ មរ៉ូណៃ ៨–៩ ថ្ងៃទី ៣ ៖ មរ៉ូណៃ ១០:១–៧, ២៧–២៩ ថ្ងៃទី ៤ ៖ មរ៉ូណៃ ១០:៨–២៦, ៣០–៣៤ *មេរៀនសម្រាប់គ្រូបង្រៀន ៖ មរ៉ូណៃ ៧:២០–១០:៣៤*

សេចក្តីផ្តើមនៃចំណេះចំណានខគម្ពីរ

ថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនាបានជ្រើសរើសវគ្គចំណេះចំណានខគម្ពីរចំនួន ២៥ សម្រាប់វគ្គសិក្សាថ្នាក់សិក្ខាសាលាទាំងបួន ។ វគ្គទាំងនេះផ្តល់នូវមូលដ្ឋានគ្រឹះខាងព្រះគម្ពីរដ៏សំខាន់មួយក្នុងការយល់ និងចែកចាយដំណឹងល្អ និងដើម្បីពង្រឹងដល់សេចក្តីជំនឿ ។ វគ្គចំណេះចំណានខគម្ពីរសម្រាប់ព្រះគម្ពីរមេរមនមានដូចខាងក្រោម ៖

នីហ្វៃទី១ ៣:៧

នីហ្វៃទី២ ២:២៥

នីហ្វៃទី២ ២:២៧

នីហ្វៃទី២ ៩:២៨–២៩

នីហ្វៃទី២ ២៥:២៣, ២៦

នីហ្វៃទី២ ២៨:៧–៩

នីហ្វៃទី២ ៣២:៨–៩

ម៉ូសាយ ២:១៧

ម៉ូសាយ ៣:១៩

ម៉ូសាយ ៤:៣០

អាលម៉ា ៧:១១–១៣

អាលម៉ា ៣២:២១

អាលម៉ា ៣៧:៣៥

អាលម៉ា ៣៩:៩

អាលម៉ា ៤១:១០

ហេលេមិន ៥:១២

នីហ្វៃទី៣ ១២:៤៨

នីហ្វៃទី ៣ ១៨:១៥, ២០–២១

អេធើរ ១២:៦

អេធើរ ១២:២៧

មរ៉ូណៃ ៧:៤១

មរ៉ូណៃ ៧:៤៥, ៤៧–៤៨

មរ៉ូណៃ ១០:៤–៥

សិស្សថ្នាក់សិក្ខាសាលាត្រូវបានលើកទឹកចិត្តឲ្យបង្កើនការ « ចេះចាំស្ទាត់ » នៃវគ្គចំណេះចំណាននេះ ។ អ្នកនឹងអាចជួយដល់សិស្សអ្នកកាន់តែខ្លាំង ប្រសិនបើអ្នកចាំវគ្គទាំងនេះដែរ ។ វគ្គចំណេះចំណានខគម្ពីរនេះរួមមានដូចតទៅ ៖

- ការរកឃើញទីតាំងខគម្ពីរទាំងឡាយដោយការដឹងពីសេចក្តីយោងព្រះគម្ពីរដែលទាក់ទងគ្នា
- ការយល់ពីបរិបទ និង មាតិកានៃវគ្គខគម្ពីរ
- ការអនុវត្តន៍តាម គោលការណ៍ និង គោលលទ្ធិទាំងឡាយនៃដំណឹងល្អដែលបានបង្រៀននៅក្នុងវគ្គនៃខគម្ពីរនោះ
- ការទន្ទេញចាំ វគ្គខគម្ពីរទាំងឡាយ

ភាពជាប់លាប់ ការរំពឹងទុក និងវិធីសាស្ត្រ

នៅពេលអ្នកចង់ជួយសិស្សឲ្យចងចាំវគ្គខគម្ពីរ អ្នកនឹងមានជោគជ័យកាន់តែខ្លាំង ប្រសិនបើអ្នកបើកទៅវគ្គចំណេះចំណានខគម្ពីរដោយមានភាពជាប់លាប់ រក្សាការរំពឹងទុកដ៏សមល្មម និងប្រើវិធីសាស្ត្រដែលសមនឹងរបៀបរៀនខុសគ្នា ។

ភាពជាប់លាប់ និងការធ្វើសារឡើងវិញនៅក្នុងការបង្រៀនចំណេះចំណានខគម្ពីរនឹងជួយដល់សិស្សឲ្យចាំនូវសេចក្តីពិតក្នុងការប្រើប្រាស់នាពេលខាងមុខ ។ វាអាចជួយច្រើន បើសិនជាអ្នកគ្រោងវគ្គសិក្សាពេញមួយឆ្នាំ ហើយបង្កើតផែនការដើម្បីផ្តល់ឱកាសដល់សិស្សក្នុងថ្នាក់ឲ្យទន្ទេញវគ្គខគម្ពីរទាំងនេះបានជាប់លាប់ ។ សូមឆ្លាតវៃក្នុងការសម្រេចចិត្តថាតើត្រូវចំណាយពេលប៉ុណ្ណា និងភាពញឹកញាប់យ៉ាងណាដើម្បីជួយដល់សិស្សឲ្យរៀនពីវគ្គចំណេះចំណានខគម្ពីរទាំងឡាយ ។ សូមបញ្ជាក់ថា សកម្មភាពចំណេះចំណានខគម្ពីរមិនត្រូវមានប្រចាំថ្ងៃដូចជាការសិក្សាព្រះគម្ពីរនោះឡើយ ។ អ្នកអាចសម្រេចថាត្រូវចំណាយពេលពីរបីនាទីរាល់ថ្ងៃ ដើម្បីរំឭកពីវគ្គចំណេះចំណានខគម្ពីរជាមួយនឹងសិស្សរបស់អ្នក ។ ឬ អ្នកអាចសម្រេចថានឹងធ្វើសកម្មភាពទន្ទេញនេះម្តង ឬពីរដងក្នុងមួយសប្តាហ៍រយៈពេលពី ១០ ទៅ ១៥ នាទី ។ មិនថា អ្នកមានផែនការជួយសិស្សឲ្យរៀនវគ្គចំណេះចំណានខគម្ពីរបៀបណានោះទេ សូមមានភាពជាប់លាប់ និងសមរម្យក្នុងការខិតខំរបស់អ្នក ។

សូមផ្អែកការរំពឹងទុករបស់អ្នកលើសមត្ថភាពរបស់សិស្សម្នាក់ៗ អំពីការចេះចំណេះចំណានខគម្ពីរ ។ ការទន្ទេញចេះវគ្គព្រះគម្ពីរត្រូវការការខិតខំពីអ្នករៀន ។ សូមនិយាយជាមួយនឹងសិស្សថាជោគជ័យរបស់គេក្នុងការសិក្សាចំណេះចំណានខគម្ពីរអាស្រ័យទាំងស្រុងទៅលើតវិយោបថ និងឆន្ទៈរបស់គេក្នុងការរៀនសូត្រ ។ សូមលើកទឹកចិត្តពួកគេឲ្យដាក់គោលដៅដែលជម្រុញសមត្ថភាពរបស់គេទៅដល់កម្រិតខ្ពស់មួយ ។ សូមប្រយ័ត្នចំពោះសិស្សដែលអាចមានការពិបាកក្នុងការទន្ទេញ ហើយសូមសម្របការរំពឹងទុក និងវិធីសាស្ត្រក្នុងការបង្រៀនដោយយោងតាមតម្រូវការរបស់សិស្សអ្នក ។

ដើម្បីធ្វើឲ្យមានទំហំធំជាងមុននៃបុគ្គលិកលក្ខណៈ និងរបៀបរៀនសូត្រ សូមផ្លាស់ប្តូរវិធីសាស្ត្រដែលអ្នកប្រើជួយសិស្សឲ្យទន្ទេញវគ្គខគម្ពីរទាំងឡាយ ។ ដូចមាននៅក្នុងការបង្រៀន និងការរៀនសូត្រដំណឹងល្អទាំងអស់ សូមប្រយ័ត្នចំពោះជម្រើសលើសកម្មភាពរបស់អ្នក ដើម្បីឲ្យព្រះវិញ្ញាណបរិសុទ្ធអាចគាំទ្រដល់ចំណេះចំណានខគម្ពីរ និងគោលលទ្ធិរបស់សិស្ស ។ អ្នកនឹងឃើញនូវវិធីសាស្ត្រក្នុងការបង្រៀនចំណេះចំណានខគម្ពីរដ៏សមរម្យជាច្រើននៅក្នុងមេរៀនទាំងឡាយនៅក្នុងសៀវភៅណែនាំនេះ ។ សម្រាប់វិធីសាស្ត្របង្រៀនចំណេះចំណានខគម្ពីរបន្ថែមទៀត សូមមើលសកម្មភាពចំណេះចំណានខគម្ពីរដែលមានដូចខាងក្រោម ៖

ចំណេះចំណានខគម្ពីរនៅក្នុងកម្មវិធីសិក្សា

ចំណេះចំណានខគម្ពីរត្រូវបានសរសេរទៅក្នុងកម្មវិធីសិក្សាតាមរបៀបជាច្រើន ។ និមិត្តសញ្ញាចំណេះចំណានខគម្ពីរ រកនូវការរៀនពីវគ្គចំណេះចំណានខគម្ពីរនៅក្នុងឯកសារមេរៀននេះ ។ វគ្គចំណេះចំណានខគម្ពីរត្រូវបានបង្ហាញ និងពិភាក្សានៅក្នុងបរិបទនៃដំពូកនោះ ។

គំនិតបន្ថែមសម្រាប់ការបង្រៀនក្នុងវគ្គចំណេះចំណានខគម្ពីរមាននៅចុងបញ្ចប់នៃមេរៀននោះ ។

គំនិតបន្ថែមសម្រាប់ការបង្រៀនជួយឲ្យមានតុល្យភាពនៃមូលដ្ឋានគ្រឹះទាំងបួននៃការសិក្សាចំណេះចំណានខគម្ពីរ (ទីតាំង ការយល់ ការអនុវត្ត ការទន្ទេញ) ដែលទាក់ទងទៅនឹងវគ្គនីមួយៗ ។ ឧទាហរណ៍ ប្រសិនបើមេរៀននេះជួយសិស្សឲ្យយល់ និងអនុវត្តតាមខគម្ពីរចំណេះចំណានខគម្ពីរ នោះគំនិតបន្ថែមក្នុងការបង្រៀននឹងជួយពួកគេឲ្យរកមើលទីតាំង ឬចងចាំដល់ខគម្ពីរនេះ ។

កម្មវិធីសិក្សានេះក៏ផ្តល់នូវសេកម្មភាពរំឭកចំណេះចំណានខគម្ពីរជាប្រចាំផងដែរ ដែលអាចយកមកប្រើបាន នៅពេលវេលាអំណោយផល និងស្របគ្នានឹងគោលដៅក្នុងការសិក្សាចំណេះចំណានខគម្ពីរក្នុងថ្នាក់របស់អ្នក ។ ការរំឭកទាំងនេះអាចត្រូវគ្នានឹងសកម្មភាពសិក្សាចំណេះចំណានខគម្ពីរដែលមានដូចខាងក្រោមនេះ ។ អ្នកអាចចំណាយពេលច្រើននៅពេលចាប់ផ្តើម ឬពេលបញ្ចប់នៃមេរៀនខ្លីមួយ ដើម្បីធ្វើសកម្មភាពរំឭកនេះ ។

សំណើរអំពីរបៀបរៀនចំណេះចំណានខគម្ពីរ

ដើម្បីជួយសិស្សក្នុងដំនាញ រកទីតាំង អ្នកអាចដាក់ផែនការដើម្បីណែនាំវគ្គចំណេះចំណានទាំង ២៥ នៅពេលចាប់ផ្តើមវគ្គសិក្សា ហើយបន្ទាប់មករៀនបន្ថែមនៅក្នុងវគ្គសិក្សាទាំងមូល ។ ឬ អ្នកអាចណែនាំពីរបីវគ្គរាល់ខែ ហើយផ្តោតលើការទន្ទេញវគ្គទាំងនោះក្នុងខែនោះ ។ ការចាប់ផ្តើមបែបនោះអាចរួមទាំងការស្នើឲ្យសិស្សថា សិស្សគួរគូសចំណាំវគ្គចំណេះចំណានខគម្ពីរនៅក្នុងព្រះគម្ពីររបស់គេរៀងៗខ្លួន ដោយជួយសិស្សឲ្យគិតពីរបៀបដើម្បីចងចាំពាក្យគន្លឹះ និងសេចក្តីយោងទាំងឡាយ ហើយពន្យល់ពីគោលលទ្ធិ និងគោលការណ៍ដែលមាននៅក្នុងវគ្គនីមួយៗ ។ អ្នកក៏អាចឲ្យសិស្សធ្វើការណែនាំវគ្គចំណេះចំណានខគម្ពីរ ដោយការដាក់កិច្ចការឲ្យពួកគេប្រើវគ្គនោះនៅក្នុងការប្រជុំជម្មនិដ្ឋានរបស់គេ ឬដោយការសុំឲ្យពួកគេបង្រៀនដល់គ្នាទៅវិញទៅមកពីរបៀបដើម្បីទន្ទេញ និងរកទីតាំងវគ្គខគម្ពីរទាំងឡាយ ។ សូមចែកលំហាត់ និងសកម្មភាពរកទីតាំងក្នុងអំឡុងពេលណាមួយដោយមានការទទួលខុសត្រូវក្នុងការចងចាំវគ្គចំណេះចំណានខគម្ពីរនោះ (សូមមើលសកម្មភាពចំណេះចំណានខគម្ពីរខាងក្រោម ជាឧទាហរណ៍) ។ បញ្ជីនៃវគ្គចំណេះចំណានខគម្ពីរទាំង ២៥ សម្រាប់វគ្គសិក្សានេះអាចមាននៅក្នុងវត្ថុស័កក្នុងសៀវភៅសម្រាប់ចំណាំរបស់សិស្ស និងនៅលើកាតចំណេះចំណានខគម្ពីរ ។

ដើម្បីជួយសិស្សឲ្យ យល់ដឹង អំពីវគ្គចំណេះចំណានខគម្ពីរ សូមបញ្ជាក់ថាវគ្គទាំងនេះនឹងមាននៅក្នុងមេរៀនប្រចាំថ្ងៃរបស់អ្នក ។ អ្នកក៏អាចប្រើសកម្មភាពចំណេះចំណានខគម្ពីរទាំងឡាយខាងក្រោមនេះ ដើម្បីពង្រីកចំណេះដឹង និងសមត្ថភាពរបស់សិស្សក្នុងការពន្យល់ពីសេចក្តីពិតដែលមាននៅក្នុងខគម្ពីរទាំងឡាយ ។ សូមឲ្យសិស្សមានឱកាសនៅក្នុងការប្រជុំជម្មនិដ្ឋាន ឬនៅក្នុងថ្នាក់ពន្យល់ពីរបៀបដែលសេចក្តីពិតនៅក្នុងវគ្គចំណេះចំណានខគម្ពីរបានជួយឲ្យពួកគេយល់កាន់តែច្បាស់អំពីគោលលទ្ធិគ្រឹះទាំងឡាយ ។

ដើម្បីគាំទ្រសិស្សនៅក្នុង ការអនុវត្ត សេចក្តីពិតរបស់ពួកគេដែលមាននៅក្នុងវគ្គចំណេះចំណានខគម្ពីរ សូមលើកទឹកចិត្តពួកគេឲ្យធ្វើតាមការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធដើម្បីយល់ពីរបៀបដែលសេចក្តីពិតនៅក្នុងខគម្ពីរទាំងឡាយអាចអនុវត្តនៅក្នុងជីវិតរបស់ពួកគេ ។ ដើម្បីជួយសិស្សឲ្យធ្វើសកម្មភាពតាមសេចក្តីពិតដែលពួកគេរៀន អ្នកអាចបិទទៅលើក្តារខៀនប្រកាសព័ត៌មាននៅក្នុងថ្នាក់ នូវការប្រឈមមួយដែលទាក់ទងទៅនឹងវគ្គចំណេះចំណានខគម្ពីរនេះមួយ ម្តងម្កាល ។ ឬ អ្នកអាចឲ្យសិស្សមានឱកាសនៅក្នុងថ្នាក់អនុវត្តគោលលទ្ធិ និងគោលការណ៍ដំណឹងល្អដែលបានបង្រៀន ដោយប្រើវគ្គចំណេះចំណានខគម្ពីរ (សូមមើលសកម្មភាពចំណេះចំណានខគម្ពីរខាងក្រោម ដើម្បីមានគំនិតបន្ថែម) ។ អ្នកក៏អាចសុំឲ្យសិស្សអនុវត្តគោលការណ៍ដែលពួកគេរៀននៅក្នុងមេរៀនទាំងឡាយ

ដែលមានវគ្គចំណេះចំណានខគម្ពីរលេចឡើងដែរ ។ សូមផ្តល់ឱកាសឲ្យសិស្សនៅក្នុងការប្រជុំជម្មនិដ្ឋាន ឬនៅពេលផ្សេងៗ ឲ្យរៀបរាប់ពីបទពិសោធន៍របស់គេ ។ ការណ៍នេះនឹងជួយពួកគេឲ្យបង្កើននូវសាក្សីនៃសេចក្តីពិតដែលពួកគេបានរៀនពីវគ្គចំណេះចំណានខគម្ពីរទាំងឡាយ ។

ដើម្បីជួយសិស្សឲ្យ ទន្ទេញ វគ្គចំណេះចំណានខគម្ពីរទាំង ២៥ ចំបាន អ្នកអាចត្រៀមទន្ទេញពីរបីខគម្ពីរពាល់ខែនៅក្នុងថ្នាក់ ។ អ្នកក៏អាចដាក់ជាកិច្চការឲ្យសិស្សឲ្យទន្ទេញខគម្ពីរមួយចំនួននៅផ្ទះបានដែរ (ពួកគេអាចធ្វើជុំវិញ៖ជាមួយនឹងគ្រួសាររបស់គេ ឬទន្ទេញខគម្ពីរដល់ឱពុកម្តាយ ឬសមាជិកគ្រួសាររបស់គេ) ។ អ្នកអាចធ្វើឲ្យការទន្ទេញក្លាយជាផ្នែកមួយនៃការប្រជុំជម្មនិដ្ឋានប្រចាំថ្ងៃ ដោយសុំឲ្យសិស្សទន្ទេញខគម្ពីរ ឬផ្តល់ពេលឲ្យសិស្សទន្ទេញវាជាដៃគូក៏បាន ។ ការផ្តល់ឱកាសឲ្យសិស្សទន្ទេញវគ្គចំណេះចំណានខគម្ពីរជាដៃគូ ឬក្រុមតូចៗ ឬនៅខាងមុខថ្នាក់អាចជួយពួកគេកាន់តែមានការខិតខំ និងទទួលខុសត្រូវ ។ សកម្មភាពចំណេះចំណានខគម្ពីរខាងក្រោមនេះរួមមាននូវវិធីសាស្ត្រទន្ទេញផ្សេងទៀត ។ សូមយកចិត្តទុកដាក់ចំពោះការរំពឹងទុកពីសមត្ថភាព និងកាល:ទេស:របស់សិស្សម្នាក់ៗក្នុងការទន្ទេញ ។ សិស្សមិនគួរត្រូវបានធ្វើឲ្យខ្មាស់អៀន ឬអន់ចិត្តឡើយ បើសិនជាពួកគេមិនអាចទន្ទេញចាំនោះ ។

សកម្មភាពចំណេះចំណានខគម្ពីរ

សេចក្តីផ្តើម

ផ្នែកនេះផ្តល់នូវគំនិតខ្លះៗដែលអ្នកអាចប្រើដើម្បីជួយដល់សិស្សនៅក្នុងការទន្ទេញវគ្គខគម្ពីរគន្លឹះៗ ។ នៅពេលអ្នកជួយ និងលើកទឹកចិត្តសិស្សឲ្យអភិវឌ្ឍជំនាញទាំងនេះ អ្នកអាចជួយពួកគេឲ្យក្លាយជាមនុស្សខ្លួនទីពឹងខ្លួននៅក្នុងការសិក្សាព្រះគម្ពីរ ។ សិស្សអាចប្រើជំនាញចំណានទាំងនេះពេញមួយជីវិតរបស់គេដើម្បីកេទីតាំង យល់ អនុវត្ត និងចងចាំខគម្ពីរទាំងនោះបានកាន់តែប្រសើរ ។ គំនិតក្នុងការបង្រៀនសម្រាប់មូលដ្ឋាននៃចំណេះចំណានខគម្ពីរនីមួយៗមានដូចខាងក្រោមនេះ ។ ការប្រើប្រកេទសកម្មភាពទាំងនេះផ្សេងៗជាច្រើនអាចជួយសិស្សឲ្យចងចាំវគ្គខគម្ពីរកាន់តែច្បាស់ឡើង ។

សកម្មភាពដែលជួយសិស្សឲ្យ *រកទីតាំង* នៃវគ្គចំណេះចំណានខគម្ពីរ

វគ្គដែលគូសចំណាំ

ការគូសចំណាំវគ្គចំណេះចំណានខគម្ពីរអាចជួយសិស្សឲ្យចងចាំវគ្គទាំងនេះ និងរកវាបានដោយងាយស្រួល ។ សូមគិតពីការលើកទឹកចិត្តសិស្សឲ្យគូសចំណាំវគ្គគន្លឹះទាំងនេះនៅក្នុងព្រះគម្ពីរបស់គេ តាមរបៀបមួយដែលបែងចែកពីខគម្ពីរដទៃនៅពេលពួកគេគូសចំណាំវា ។

ការដឹងពីគម្ពីរទាំងឡាយ

ការទន្ទេញចាំឈ្មោះ និងលំដាប់នៃព្រះគម្ពីរនៅក្នុងព្រះគម្ពីរមរមន អាចជួយសិស្សឲ្យរកទីតាំងនៃវគ្គចំណេះចំណានខគម្ពីរបានយ៉ាងលឿន ។ ខាងក្រោមនេះ គឺជាសកម្មភាពគំរូដែលអាចជួយសិស្សឲ្យស្គាល់ព្រះគម្ពីរនៅក្នុងព្រះគម្ពីរមរមន ។

- រកតារាងមាតិកា—ជួយសិស្សឲ្យរកឃើញនូវតារាងមាតិកានៅក្នុងព្រះគម្ពីរមរមន ដែលមានចំណងជើងថា « ឈ្មោះ និងលំដាប់នៃព្រះគម្ពីរនៅក្នុងព្រះគម្ពីរមរមន » ។
- ច្រៀងចម្រៀង— បង្រៀនសិស្សនូវចម្រៀង « គម្ពីរនៅក្នុងព្រះគម្ពីរមរមន » (*សៀវភៅចម្រៀងកុមារ* ទំព័រ ១១៩) ។ សូមឲ្យពួកគេច្រៀងវាម្តងម្កាលពេញមួយឆ្នាំ ដើម្បីជួយពួកគេឲ្យចងចាំពីឈ្មោះ និងលំដាប់នៃគម្ពីរនៅក្នុងព្រះគម្ពីរមរមន ។
- ប្រើអក្សរដំបូង— សរសេរតួអក្សរដំបូងនៃគម្ពីរនៅក្នុងព្រះគម្ពីរមរមននៅលើក្តារខៀន (ន១, ន២, ឃ, អ ។ល។) ។ សូមឲ្យសិស្សអនុវត្តដោយការនិយាយឈ្មោះគម្ពីរដែលសឹតគ្នា ។ សូមធ្វើសកម្មភាពនេះសារឡើងវិញរហូតដល់ពួកគេអាចទន្ទេញឈ្មោះនៃគម្ពីរចាំអស់ ។
- ការទាយគម្ពីរ—ហៅឈ្មោះគម្ពីរមួយដែលមានវគ្គចំណេះចំណានខគម្ពីរ ហើយសូមឲ្យសិស្សបើកព្រះគម្ពីរបស់គេទៅរកទំព័រណាមួយក៏បាននៅក្នុងគម្ពីរនោះ ។ សូមកំណត់ពេលដែលសិស្សទាំងអស់អាចកេនូវគម្ពីរទាំងនោះ ។ សកម្មភាពនេះអាចធ្វើសារឡើងវិញដើម្បីឲ្យសិស្សកាន់តែចងចាំ និងជំនាញក្នុងការរកគម្ពីរនៅក្នុងព្រះគម្ពីរមរមន ។

ការចាំសេចក្តីយោង និងមាតិកា

នៅពេលសិស្សរៀនពីទីតាំង និងមាតិកានៃវគ្គចំណេះចំណានខគម្ពីរ នោះព្រះវិញ្ញាណបរិសុទ្ធអាចជួយពួកគេឲ្យចងចាំពីសេចក្តីយោងព្រះគម្ពីរដែលត្រូវការ (សូមមើល យ៉ូហាន ១៤:២៦) ។ ៣ក្យ ឬឃ្លាគន្លឹះដូចជា « ខ្ញុំនឹងទៅ ហើយធ្វើ » (នីហ្វៃទី ១ ៣:៧) និង « សិទ្ធិសេរីភាពដើម្បីរើស » (នីហ្វៃទី ២ ២:២៧) អាចជួយសិស្សឲ្យចងចាំមាតិកា និងការបង្រៀនគោលលទ្ធិនៃវគ្គនីមួយៗ ។ វិធីសាស្ត្រខាងក្រោមនេះអាចជួយសិស្សឲ្យភ្ជាប់សេចក្តីយោងចំណេះចំណានខគម្ពីរទៅនឹងមាតិកា ឬ៣ក្យគន្លឹះរបស់វា ។ (អ្នកអាចចង់ទុកសកម្មភាពដែលទាក់ទងទៅនឹងការប្រកួត ការប្រណាំងប្រជែង ឬការផ្ទៀងនៅពេលក្រោយនៅក្នុងឆ្នាំនេះ ក្រោយពីសិស្សបានបង្ហាញថា ពួកគេដឹងពីកន្លែងនៃវគ្គចំណេះចំណានខគម្ពីរ ។ សកម្មភាពបែបនោះនឹងជួយពង្រឹងអ្វីដែលពួកគេបានរៀន) ។

- សេចក្តីយោង និង៣ក្យគន្លឹះ— សូមលើកទឹកចិត្តសិស្សឲ្យទន្ទេញចាំសេចក្តីយោង និង៣ក្យគន្លឹះនៃវគ្គចំណេះចំណានខគម្ពីរនីមួយៗដែលមាននៅក្នុងកាតចំណេះចំណានខគម្ពីរ ។ (កាតចំណេះចំណានខគម្ពីរអាចបញ្ជាទិញបានតាមអ៊ិនធើណិតនៅក្នុង store.lds.org ។ អ្នកក៏អាចឲ្យសិស្សបង្កើតកាតចំណេះចំណានខគម្ពីរដោយខ្លួនគេបានដែរ) ។ ទុកពេលឲ្យសិស្សសិក្សាពីកាតខគម្ពីរជាមួយនឹងដៃគូ ហើយបន្ទាប់មកសួរគ្នាទៅវិញទៅមក ។ សូមលើកទឹកចិត្តសិស្សឲ្យមានមានភាពច្នៃប្រឌិតក្នុងរបៀបដែលពួកគេសិក្សាជាមួយនឹគ្នា និងពេលសួរសាកល្បងគ្នាទៅវិញទៅមក ។ នៅពេលពួកគេកាន់តែចេះចាំច្បាស់នូវវគ្គចំណេះចំណានខគម្ពីរ នោះអ្នកអាចសុំឲ្យពួកគេប្រើគម្រុយនានា ដែលទាក់ទងទៅនឹងបរិបទ ឬការអនុវត្តគោលលទ្ធិ និងគោលការណ៍នានាពីខគម្ពីរទាំងនោះបាន ។ បុគ្គលដែលត្រូវគេសួរ អាចឆ្លើយក៏បាន ឬសរសេរក៏បាន ។
- កាតចំណេះចំណានខគម្ពីរ—សកម្មភាពនេះអាចត្រូវប្រើដើម្បីណែនាំ ឬរំឭកពីវគ្គចំណេះចំណានខគម្ពីរទាំងឡាយ ។ សូមជ្រើសរើសកាតចំណេះចំណានខគម្ពីរមួយចំនួន ហើយរៀបចំចែកវាដល់សិស្សរបស់អ្នក ។ (សូមប្រាកដថាមានកាតច្រើនដម្រើសដើម្បីឲ្យសិស្សម្នាក់ៗអាចទទួលបានវគ្គចំណេះចំណានខគម្ពីរខុសគ្នា ។ អ្នកក៏អាចមានកាតច្រើនលួមសម្រាប់សិស្សម្នាក់ៗអាចមានវគ្គខគម្ពីរពីរ ឬបីខុសៗគ្នា ។) សូមចែកវាដល់សិស្សក្នុងថ្នាក់ ។ សូមឲ្យសិស្សមានពេលសិក្សាវគ្គចំណេះចំណានខគម្ពីរ សេចក្តីយោង ៣ក្យគន្លឹះ បរិបទ គោលលទ្ធិ ឬគោលការណ៍ និងគំនិតក្នុងការអនុវត្តចំពោះកាតនីមួយៗ ។ សូមលើកឡើងនូវតម្រុយខ្លះៗពីកាតនីមួយៗ (ឧទាហរណ៍ ៣ក្យចេញពីវគ្គចំណេះចំណានខគម្ពីរ ឬ៣ក្យគន្លឹះ បរិបទ គោលលទ្ធិ ឬគោលការណ៍ ឬការអនុវត្តន៍) ។ សិស្សដែលមានកាតដែលត្រូវនឹងតម្រុយនោះ គួរក្រោកឈរ ហើយអានសេចក្តីយោងចំណេះចំណានខគម្ពីរនោះឮៗ ។
- ការទាយព្រះគម្ពីរ— សូមប្រើតម្រុយដើម្បីជួយសិស្សឲ្យអនុវត្តការរកឃើញវគ្គខគម្ពីរនៅក្នុងព្រះគម្ពីររបស់ពួកគេបានលឿន ។ សម្រាប់តម្រុយនានា អ្នកអាចប្រើ៣ក្យគន្លឹះ បរិបទ គោលលទ្ធិ និងគោលការណ៍នានា និងគំនិតក្នុងការអនុវត្តពីកាតចំណេះចំណានខគម្ពីរ ។ អ្នកក៏អាចប្រើតម្រុយរបស់អ្នកបានដែរ ។ សកម្មភាពទាយព្រះគម្ពីរដែលសិស្សប្រកួតក្នុងការរកទីតាំងវគ្គខគម្ពីរ អាចជួយពួកគេឲ្យចូលរួមនៅក្នុងការរៀនវគ្គចំណេះចំណានខគម្ពីរយ៉ាងសកម្ម ។ នៅពេលប្រើសកម្មភាពសាកល្បងទាយព្រះគម្ពីរដើម្បីជួយដល់ការសិក្សាចំណេះចំណានខគម្ពីរ សូមធ្វើវាតាមរបៀបមួយ ដែលមិនបណ្តាលឲ្យសិស្សមានអារម្មណ៍ឈឺចាប់ ឬរាំងព្រះវិញ្ញាណឡើយ ។ សូមជួយសិស្សឲ្យចៀសវាងការមិនគោរពដល់ព្រះគម្ពីរ ឬមានការប្រកួតប្រជែងហួសពេក ។ សូមគិតពីការឲ្យសិស្សប្រកួតតាមស្តង់ដា ប៉ុន្តែកុំប្រជែងនឹងសមត្ថភាពរវាងគ្នានិងគ្នា ។ ឧទាហរណ៍ សិស្សអាចប្រកួតប្រជែងនឹងគ្រូបង្រៀន ឬអ្នកអាចសុំឲ្យសិស្សប្រណាំងគ្នារកមើលថា មានប៉ុន្មានភាគរយនៃសិស្សដែលរកវគ្គពិសេសណាមួយក្នុងពេលកំណត់ពិសេសណាមួយ ។
- ការសាកល្បងរឿង— សូមផ្តល់តម្រុយដោយការនិទានរឿងដែលបង្ហាញពីការទាក់ទងគ្នានៃវគ្គចំណេះចំណានខគម្ពីរចំពោះជីវិតប្រចាំថ្ងៃ ។ ឧទាហរណ៍ ជាតម្រុយសម្រាប់នីហ្វៃទី ១ ៣:៧ អ្នកអាចនិយាយថា « បនដឹងថាព្រះអម្ចាស់បានបញ្ជាដល់យុវជនសក្តិសមទាំងអស់ឲ្យទៅបម្រើបេសកកម្ម ប៉ុន្តែលោកបារម្ភថា ភាពអៀនខ្មាស់របស់លោកនឹងរាំងលោកមិនឲ្យបម្រើដោយមានប្រសិទ្ធភាព ។ បន្ទាប់មក លោកចងចាំពីរបៀបដែលនីហ្វៃបានឆ្លើយតបទៅនឹងកិច្চការដ៏លំបាកក្នុងការទៅរកផ្នាំងលង្ហិន ។ បនមានទំនុកចិត្តថា ព្រះអម្ចាស់នឹងប្រទាននូវមធ្យោបាយមួយដល់លោកដើម្បីឲ្យក្លាយជាអ្នកផ្សព្វផ្សាយសាសនាដ៏មានសមត្ថភាពមួយរូប ។ នៅពេលសិស្សស្តាប់រឿងតំណាលនេះ សូមឲ្យពួកគេរកនូវវគ្គចំណេះចំណានខគម្ពីរដែលទាក់ទងនៅក្នុងព្រះគម្ពីររបស់គេ ។
- លំហាត់ និងការប្រឡង— សូមផ្តល់ឱកាសឲ្យសិស្សសាកសួរវគ្គចំណេះចំណានខគម្ពីរ ។ តម្រុយនានាអាចរួមមានៗក្យគន្លឹះ ឬសេចក្តីយោងព្រះគម្ពីរ សម្តីដកស្រង់ពីវគ្គខគម្ពីរ ឬរឿងផ្សេងដែលបង្ហាញពីសេចក្តីពិតដែលបង្រៀននៅក្នុងខគម្ពីរនោះ ។ លំហាត់ និងការប្រឡងអាចធ្វើឡើងដោយផ្ទាល់មាត់ ធ្វើនៅលើក្តារខៀន ឬនៅលើក្រដាស ។ ក្រោយពីសិស្សបានធ្វើលំហាត់ ឬការប្រឡងហើយ សូមគិតពីការចាប់ដៃគូសិស្សដែលមានពិន្ទុខ្ពស់ជាមួយនឹងសិស្សដែលមានពិន្ទុទាប ។ សិស្សដែលមានពិន្ទុខ្ពស់អាចធ្វើជាគ្រូបង្រៀនម្នាក់ដើម្បីជួយដល់សិស្សដែលមានពិន្ទុទាបឲ្យ

រៀនសូត្រ និងរីកចម្រើន ។ ជាផ្នែកនៃការខិតខំនេះ ដៃគូសិស្សក៏អាចជាក់គោលដៅដើម្បីទទួលបាននូវពិន្ទុរួមគ្នាខ្ពស់ជាងមុននៅក្នុងការប្រឡងលើកក្រោយ ។ សូមគិតពីការធ្វើតារាងមួយ ឬសរសេរចំណុចគោលបង្ហាញគោលដៅរបស់សិស្ស និងទទួលស្គាល់ការរីកចម្រើនរបស់ពួកគេ ។

សកម្មភាពដែលជួយសិស្សឲ្យ *យល់* វគ្គ ចំណេះចំណានខគម្ពីរ

ការឲ្យនិយមន័យពាក្យ និងឃ្លាទាំងឡាយ

ការឲ្យនិយមន័យពាក្យ និងឃ្លាទាំងឡាយនៅក្នុងវគ្គ ចំណេះចំណានខគម្ពីរ (ឬការជួយសិស្សឲ្យស្គាល់និយមន័យវា) នឹងជួយសិស្សឲ្យយល់ពីអត្ថន័យនៃវគ្គខគម្ពីរទាំងមូល ។ នៅពេលពិបាកយល់និយមន័យពីគោលលទ្ធិ និងគោលការណ៍នានានៅក្នុងខគម្ពីរនេះ អ្នកអាចលើកទឹកចិត្តសិស្សឲ្យសរសេរនិយមន័យទាំងនេះនៅក្នុងព្រះគម្ពីររបស់គេ ។ សូមរំឭកពីអត្ថន័យនៃពាក្យ និងឃ្លា នៅពេលអ្នករំឭកវគ្គ ចំណេះចំណានខគម្ពីរ ។

ការស្វែងរកបរិបទ

ការស្វែងរកបរិបទនៃវគ្គខគម្ពីរព្រះគម្ពីរ អាចជួយសិស្សឲ្យយល់កាន់តែច្បាស់អំពីអត្ថន័យនៃវគ្គខគម្ពីរនោះ ។ បរិបទរួមបញ្ចូលនូវព័ត៌មានដែលទាក់ទងនឹងអ្នកណានិយាយទៅកអ្នកណា ហើយមូលហេតុអ្វី វារួមមាននូវទីកន្លែងនៃវគ្គខគម្ពីរ (ប្រវត្តិសាស្ត្រ វប្បធម៌ និងភូមិសាស្ត្រ) និងសំណួរ ឬស្ថានភាពដែលបរិបទនៃវគ្គព្រះគម្ពីរនោះកើតឡើង ។ ឧទាហរណ៍ បរិបទនៃ នីហ្វៃទី ១ ៣:៧ រួមមានការពិតដែលនីហ្វៃត្រូវបានសុំដោយឪពុកលោកគឺ លីហៃ ដែលជាព្យាការីម្នាក់ ឲ្យត្រឡប់ទៅកាន់ទីក្រុងយេរូសាឡិមវិញ ហើយនាំយកផ្ទាំងលង្ហិនមក ។ ការដឹងពីព័ត៌មាននេះ អាចជួយសិស្សឲ្យយល់កាន់តែច្បាស់ពីមូលហេតុដែលនីហ្វៃនិយាយថា « ខ្ញុំនឹងទៅ ហើយធ្វើនូវអ្វីៗដែលព្រះអម្ចាស់បានបញ្ជា » ។ នៅពេលអ្នកបង្រៀនមេរៀនដែលរួមមានវគ្គចំណេះចំណានខគម្ពីរ សូមសង្កត់ធ្ងន់ពីបរិបទដែលនៅជុំវិញវគ្គខគម្ពីរទាំងនោះ ។ សកម្មភាពបន្ថែមដូចជាសកម្មភាពខាងក្រោមនេះមួយ ក៏អាចជួយសិស្សឲ្យយល់ពីវគ្គខគម្ពីរគន្លឹះទាំងនេះដែរ ។

- ការស្វែងរកបរិបទ—សូមសរសេរចំណងជើងខាងក្រោមនេះនៅលើផ្នែកខាងលើនៃក្តារខៀន ៖ *អ្នកឡើងនិយាយ អ្នកមើល គោលបំណង ការយល់ដឹងជំនួយផ្សេងទៀត* ។ សូមឲ្យសិស្សធ្វើការជាក្រុម ហើយដាក់កិច្চការដល់ក្រុមនីមួយៗឲ្យអានវគ្គចំណេះចំណានខគម្ពីរមួយ ។ សូមឲ្យពួកគេរកមើលបរិបទនៃវគ្គកិច្চការខគម្ពីររបស់គេ ដោយការរកមើលព័ត៌មានដែលសមស្របទៅនឹងចំណងជើងនៅលើក្តារខៀន ។ សូមឲ្យពួកគេសរសេរអ្វីដែលពួកគេរកឃើញនៅលើក្តារខៀន ។ បន្ទាប់មក សូមឲ្យក្រុមនីមួយៗពន្យល់ពីបរិបទនៃវគ្គកិច្চការខគម្ពីររបស់គេ និងរបៀបដែលព័ត៌មាននេះមានឥទ្ធិពលដល់ការយល់ដឹងពីសេចក្តីពិតនៅក្នុងខគម្ពីរនីមួយៗ ។ ដើម្បីពង្រីកទំហំនៃសកម្មភាពនេះ អ្នកអាចតាំងចិត្តសិស្សឲ្យទស្សន៍ទាយសេចក្តីយោងចំណេះចំណានខគម្ពីរដោយផ្អែកលើការពិពណ៌នានៅលើក្តារខៀន មុនពេលក្រុមនីមួយៗពន្យល់ពីអ្វីដែលពួកគេបានសរសេរ ។

ធ្វើការវិភាគ

ការវិភាគទាក់ទងទៅនឹងការស្វែងរកគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលមាននៅក្នុងវគ្គខគម្ពីរ ។ វាក៏រួមមានជំនួយជួយសិស្សឲ្យយល់ពីរបៀបដែលសេចក្តីពិតទាំងនេះទាក់ទងទៅនឹងពួកគេដែរ ។ ការណ៍នេះអាចនាំទៅរកការអនុវត្តដ៏ជ្រៅជ្រះមួយនៃគោលលទ្ធិ និងគោលការណ៍នានានៅក្នុងជីវិតរបស់ពួកគេ ។ សកម្មភាពខាងក្រោមនេះអាចជួយសិស្សឲ្យវិភាគវគ្គចំណេះចំណានខគម្ពីរបាន ៖

- សរសេរតម្រុយ— នៅពេលសិស្សកាន់តែស្គាល់វគ្គចំណេះចំណានខគម្ពីរហើយ សូមឲ្យពួកគេបង្កើតសំណួរ រឿង ឬតម្រុយផ្សេងទៀតដែលបង្ហាញពីគោលលទ្ធិ និងគោលការណ៍នានាដែលបានបង្រៀននៅក្នុងវគ្គខគម្ពីរនោះ ។ ការណ៍ទាំងនេះអាចត្រូវប្រើដើម្បីធ្វើលំហាត់នៅក្នុងថ្នាក់ ។

ការពន្យល់

ការសុំឲ្យសិស្សពន្យល់ពីវគ្គព្រះគម្ពីរ នឹងជួយសិស្សឲ្យយល់កាន់តែសឹងជម្រៅ និងអភិវឌ្ឍសមត្ថភាពរបស់គេក្នុងការបង្រៀនគោលលទ្ធិ និងគោលការណ៍ពីព្រះគម្ពីរ ។ ខាងក្រោមនេះគឺជាវិធីសាស្ត្រពីរដែលអាចជួយសិស្សឲ្យរៀនពន្យល់ពីវគ្គចំណេះចំណានខគម្ពីរ ៖

- ពាក្យ និងឃ្លាគន្លឹះ— សូមឲ្យសិស្សអានវគ្គចំណេះចំណានខគម្ពីរដូចគ្នាដោយខ្លួនគេ ហើយស្វែងរកពាក្យ ឬឃ្លាមួយដែលពួកគេគិតថា មានន័យសំខាន់ជាពិសេសនៅក្នុងខគម្ពីរនេះ ។ បន្ទាប់មក សូមឲ្យសិស្សម្នាក់អានវគ្គខគម្ពីរនោះដល់សិស្ស ហើយផ្តល់នូវការបញ្ជាក់ចំពោះពាក្យ ឬឃ្លាដែលគេបានរើស ។ សូមឲ្យសិស្សពន្យល់ពីមូលហេតុដែលពាក្យ ឬឃ្លានេះសំខាន់ដើម្បីយល់ពីខគម្ពីរនេះ ។ សូមឲ្យសិស្សពីរបីនាក់ផ្សេងទៀតធ្វើដូចគ្នានេះដែរ ។ សិស្សអាចរើសពាក្យ ឬឃ្លាខុសគ្នាសម្រាប់វគ្គខគម្ពីរដូចគ្នា ។ នៅពេលសិស្សក្នុងថ្នាក់ឃើញពីទស្សនៈខុសគ្នានេះហើយ ពួកគេអាចទទួលបានការយល់ដឹងពីវគ្គខគម្ពីរនេះកាន់តែច្បាស់ថែមទៀត ។
- រៀបចំខ្លួនសម្រាប់ការប្រជុំជម្មនិដ្ឋាន—សូមឲ្យសិស្សមានឱកាសប្រើវគ្គចំណេះចំណានខគម្ពីរ នៅពេលពួកគេរៀបចំ និងនិយាយនៅក្នុងការប្រជុំជម្មនិដ្ឋាននៅពេលចាប់ផ្តើមថ្នាក់ ។ សូមជួយពួកគេឲ្យរៀបចំសង្ខេបបរិបទ ពន្យល់ពីគោលលទ្ធិ និងគោលការណ៍ ចែកចាយពីបទពិសោធន៍ ឬឧទាហរណ៍ដ៏មានន័យ និងថ្លែងទីបន្ទាល់អំពីគោលលទ្ធិ និងគោលការណ៍នៅក្នុងវគ្គខគម្ពីរនោះ ។ អ្នកក៏អាចណែនាំថាសិស្សគួរគិតពីការប្រើការអនុវត្តន៍ដាក់ស្តែងដើម្បីពន្យល់ពីគំនិតនៅក្នុងខគម្ពីរនេះដែរ ។

ការស្គាល់ពីសារៈសំខាន់នៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយ

សូមជួយសិស្សឲ្យយល់ និងទទួលបានសាក្សីខាងវិញ្ញាណនៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលបានបង្រៀននៅក្នុងវគ្គចំណេះចំណានខគម្ពីរ ។ អែលឌើរ រ៉ូប៊ឺត ឌី ហែល បានពន្យល់ថា « គ្រូបង្រៀនដ៏ពិតម្នាក់ នៅពេលគាត់បានបង្រៀនពីការពិត [នៃដំណឹងល្អ] . . . នោះគាត់បានជួយ [សិស្ស] ឲ្យបោះជំហានទៅមុខមួយឲ្យបោះឆ្ងាយជាងមុន ដើម្បីទទួលបានសាក្សីខាងវិញ្ញាណ និងការយល់ដឹងនៅក្នុងដួងចិត្តរបស់ពួកគេដែលនាំឲ្យមានសកម្មភាព និងការផ្វើការ » (« Teaching by Faith » [សុន្ទរកថាទៅកាន់អ្នកអប់រំសាសនា CES ថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ ២០០២] ទំព័រ ៥ si.lds.org) ។នៅពេលសិស្សទទួលអារម្មណ៍ពីសេចក្តីពិត សារៈសំខាន់ និងភាពបន្ទាន់នៃគោលការណ៍ ឬ គោលលទ្ធិតាមរយៈឥទ្ធិពលពីព្រះវិញ្ញាណ នោះការតាំងចិត្តដើម្បីអនុវត្តសេចក្តីពិតនោះនៅក្នុងជីវិតរបស់ពួកគេក៏លូតលាស់ឡើងដែរ ។គ្រូបង្រៀនអាចជួយសិស្សឲ្យអញ្ជើញ និងចិញ្ចឹមអារម្មណ៍នៃព្រះវិញ្ញាណបរិសុទ្ធទាំងនេះ ដោយការផ្តល់ឱកាសដល់ពួកគេឲ្យចែកចាយនូវបទពិសោធន៍ដែលពួកគេបានមាននៅក្នុងការរស់នៅតាមគោលការណ៍នៃដំណឹងល្អ ដែលមាននៅក្នុងវគ្គចំណេះចំណានខគម្ពីរនេះ ។ ការណ៍នេះនឹងជួយសិស្សឲ្យយល់កាន់តែច្បាស់ពីសេចក្តីពិតដែលបានបង្រៀននៅក្នុងវគ្គចំណេះចំណានខគម្ពីរនេះ ហើយជានាថាសេចក្តីពិតទាំងនេះត្រូវបានឆ្លាក់ជាប់នៅក្នុងចិត្តរបស់សិស្ស ។ សកម្មភាពខាងក្រោមនេះអាចជួយសិស្សឲ្យមានដឹងពីសារៈសំខាន់នៃគោលលទ្ធិ និងគោលការណ៍ទាំងឡាយដែលមាននៅក្នុងវគ្គចំណេះចំណានខគម្ពីរ ៖

- ការស្តាប់រកវគ្គខគម្ពីរ—អញ្ជើញឲ្យសិស្សស្តាប់រកនូវវគ្គចំណេះចំណានខគម្ពីរនៅក្នុងការនិយាយ និងមេរៀននានានៅក្នុងសាសនាចក្រ នៅក្នុងការថ្លែងសន្និសីទទូទៅ និងនៅក្នុងការពិភាក្សាជាមួយនឹងគ្រួសារ និងមិត្តទាំងឡាយ ។ សូមឲ្យសិស្សរៀបរាប់ម្តងម្កាលពីខគម្ពីរដែលពួកគេបានស្តាប់ របៀបដែលខគម្ពីរនោះត្រូវបានប្រើ សេចក្តីពិតដែលវាបង្រៀន និងបទពិសោធន៍ដែលពួកគេ ឬអ្នកដទៃបានទទួលបានពីសេចក្តីពិតដែលបានបង្រៀននោះ ។ សូមរកមើលឱកាសដើម្បីធ្វើទីបន្ទាល់ (ហើយសូមឲ្យសិស្សធ្វើទីបន្ទាល់) អំពីសេចក្តីពិតដែលបង្រៀនដោយវគ្គចំណេះចំណានខគម្ពីរនេះ ។

សកម្មភាពដែលជួយសិស្សឲ្យ *អនុវត្ត* វគ្គ ចំណេះចំណានខគម្ពីរ

ការបង្រៀន

វគ្គចំណេះចំណានខគម្ពីរ និងគោលលទ្ធិគ្រឹះត្រូវបានបង្កើតឡើងជាមួយគ្នា ហើយមានបំណងដើរទន្ទឹមគ្នាដើម្បីជាប្រយោជន៍ដល់សិស្ស ។ (វគ្គចំណេះចំណានខគម្ពីរត្រូវបានបង្ហាញនៅក្នុងឯកសារគោលលទ្ធិគ្រឹះ) ។ នៅពេលសិស្សរៀន និងបង្ហាញពីគោលលទ្ធិ និងគោលការណ៍ដែលមាននៅក្នុងវគ្គចំណេះចំណានខគម្ពីរ នោះពួកគេក៏នឹងអាចរៀន និងបង្ហាញពីគោលលទ្ធិគ្រឹះបានដែរ ។ ហើយនៅពេលសិស្សរៀនដើម្បីបង្ហាញពីគោលលទ្ធិគ្រឹះជាសម្ដីខ្លួនឯងនោះ ពួកគេអាចពឹងលើវគ្គចំណេះចំណានខគម្ពីរដែលទន្ទេញចាំដើម្បីជួយដល់ពួកគេ ។ ការឲ្យសិស្សមានឱកាសបង្រៀនគោលលទ្ធិ និងគោលការណ៍នៃដំណឹងល្អដោយប្រើវគ្គចំណេះចំណានខគម្ពីរ អាចជួយបង្កើនទំនុកចិត្តសិស្សទៅលើខ្លួនគេ និងទៅលើចំណេះដឹងរបស់គេអំពីព្រះគម្ពីរ ។ នៅពេលសិស្សបង្រៀន និងធ្វើទីបន្ទាល់អំពីគោលលទ្ធិ និងគោលការណ៍ដែលមាននៅក្នុងវគ្គចំណេះចំណានខគម្ពីរ នោះពួកគេអាចពង្រឹងទីបន្ទាល់របស់ពួកគេ ។ សូមលើកទឹកចិត្តសិស្សឲ្យប្រើវគ្គចំណេះចំណានខគម្ពីរដើម្បីបង្រៀន និងពន្យល់ដំណឹងល្អនៅក្នុងថ្នាក់ និងក្នុងការសន្ទនាជាមួយនឹងមិត្តភក្តិ គ្រួសារ និងអ្នកដទៃ ។

- ការបង្ហាញសារលិខិត—សូមចាត់ឲ្យសិស្សរៀបចំខ្លួនដើម្បីនិយាយ ឬបង្រៀនពី ៣ ទៅ ៥ នាទីដោយផ្អែកលើវគ្គចំណេះចំណានខគម្ពីរ ។ សូមឲ្យពួកគេរៀបចំនៅក្នុងថ្នាក់ ឬនៅផ្ទះ ។ បន្ថែមទៅលើវគ្គចំណេះចំណានខគម្ពីរ ពួកគេអាចប្រើធនធានផ្សេងទៀតដើម្បីជួយពួកគេឲ្យរៀបចំ ដូចជាកាតចំណេះចំណានខគម្ពីរ ការណែនាំតាមប្រធានបទ សេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ឬ*ពិភាក្សោះ៖ សេចក្តីជំនឿ ៖ សេចក្តីយោងនៃដំណឹងល្អ* ។ ការនិយាយឬមេរៀនមួយៗគួររួមមាននូវបុព្វប្រយោគ វគ្គចំណេះចំណានខគម្ពីរ ការតំណាលរឿង ឬឧទាហរណ៍ពីគោលការណ៍ដែលបានបង្រៀន និងទីបន្ទាល់របស់សិស្ស ។ សិស្សអាចស្ម័គ្រចិត្តនិយាយនៅក្នុងថ្នាក់ នៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ ឬដល់ក្លុំម ឬថ្នាក់របស់គេជាផ្នែកនៃ

ការធ្វើសៀវភៅកាតព្វកិច្ចចំពោះព្រះ ឬការអភិវឌ្ឍន៍ខ្លួនរបស់ក្រុមយុវនារីរបស់គេ ។ ប្រសិនបើសិស្សធ្វើការនិយាយ ឬបង្រៀនខាងក្រៅថ្នាក់ សូមឲ្យពួកគេរៀបរាប់ពីបទពិសោធន៍របស់គេ ។

- ការសម្តែងជាអ្នកផ្សព្វផ្សាយសាសនា—សូមរៀបចំកាតមួយចំនួនដោយមានសំណួរដែលអ្នករៀនជាមួយនឹងអ្នកផ្សព្វផ្សាយសាសនាអាចសួរ ដែលអាចត្រូវឆ្លើយដោយមានជំនួយពីវគ្គចំណេះចំណានខគម្ពីរ (ឧទាហរណ៍ « តើសមាជិកនៃសាសនារបស់អ្នកជឿអ្វីខ្លះអំពីព្រះយេស៊ូវគ្រីស្ទ » ?) សូមអញ្ជើញសិស្សមួយគូឡើងមកខាងមុខថ្នាក់ដើម្បីឆ្លើយនឹងសំណួរដែលជ្រើសរើសពីសំណាកទាំងនោះ ។ ដើម្បីជួយសិស្សឲ្យយល់ពីរបៀបដែលអ្នកផ្សព្វផ្សាយសាសនាអាចឆ្លើយនឹងសំណួរដូចគ្នានេះ អ្នកអាចបង្រៀនវិធីសាស្ត្រដ៏មានប្រសិទ្ធភាពក្នុងការបង្រៀនពីរបីដូចជា (១) ការនិយាយពីបរិបទនៃវគ្គខគម្ពីរ (២) ការពន្យល់ពីគោលលទ្ធិ ឬគោលការណ៍មួយ (៣) ការសួរសំណួរដើម្បីដឹងថាតើអ្នកដែលពួកគេបង្រៀននោះយល់ ឬជឿដល់អ្វីដែលពួកគេបង្រៀនដែរឬទេ (៤) ការចែកចាយបទពិសោធន៍ និងទីបន្ទាល់ ហើយនិង (៥) អញ្ជើញអ្នកដែលពួកគេបង្រៀនឲ្យធ្វើសកម្មភាពតាមសេចក្តីពិតដែលបានបង្រៀននោះ ។ សូមឲ្យសិស្សផ្តល់នូវមតិយោបល់រិះគន់ចំពោះអ្វីដែលពួកគេចូលចិត្តពីរបៀបដែលដៃគូនីមួយៗបានឆ្លើយតបចំពោះសំណួររបស់គេ ។
- ថ្លែងទីបន្ទាល់—អញ្ជើញសិស្សឲ្យអានវគ្គចំណេះចំណានខគម្ពីរ ហើយជ្រើសរើសខគម្ពីរមួយដែលរួមមានគោលលទ្ធិ ឬគោលការណ៍ដែលពួកគេអាចថ្លែងទីបន្ទាល់បាន ។ សូមឲ្យពួកគេធ្វើទីបន្ទាល់អំពីសេចក្តីពិតដែលពួកគេបានជ្រើសរើស និងចែកចាយបទពិសោធន៍ដែលបាននាំពួកគេឲ្យអាចធ្វើទីបន្ទាល់ពីវាបាន ។ នៅពេលសិស្សចែករំលែកទីបន្ទាល់របស់គេ នោះព្រះវិញ្ញាណបរិសុទ្ធនឹងបញ្ជាក់ពីសេចក្តីពិតនៃគោលលទ្ធិ ឬគោលការណ៍ដែលពួកគេកំពុងធ្វើទីបន្ទាល់នោះ ។ ទីបន្ទាល់របស់គេក៏អាចបំផុសគំនិតដល់អ្នកដទៃឲ្យធ្វើសកម្មភាពដោយសេចក្តីជំនឿបានដែរ ។

  កំណត់ចំណាំ ៖ ឱកាសសម្រាប់សិស្សចែកចាយទីបន្ទាល់របស់គេ គួរធ្វើដោយការស្ម័គ្រចិត្ត ។ សិស្សមិនត្រូវបានបង្ខំឲ្យចែកចាយទីបន្ទាល់របស់គេ ឬធ្វើឲ្យមានអារម្មណ៍ថាពួកគេត្រូវមានចំណេះដឹងត្រឹមត្រូវដែលពួកគេមានអារម្មណ៍ថា ពួកគេមិនមាននោះទេ ។ បន្ថែមលើនេះ សិស្សខ្លះអាចស្ទាក់ស្ទើរនឹងចែកចាយទីបន្ទាល់របស់គេ ដោយសារពួកគេគិតខុសថា ពួកគេត្រូវចាប់ផ្តើមដោយ « ខ្ញុំចង់ថ្លែងទីបន្ទាល់របស់ខ្ញុំ . . . » ឬថាការបង្ហាញទីបន្ទាល់របស់គេត្រូវតែប្រកបដោយអារម្មណ៍ទោទន់ ។ សូមជួយសិស្សឲ្យយល់ថា នៅពេលពួកគេធ្វើទីបន្ទាល់ ពួកគេអាចគ្រាន់តែចែករំលែកនូវគោលលទ្ធិ ឬគោលការណ៍ដែលពួកគេដឹងថា វាពិតប៉ុណ្ណោះ ។ ការចែករំលែកទីបន្ទាល់ អាចធ្វើដោយគ្រាន់តែនិយាយថា « ខ្ញុំជឿថាការណ៍នេះគឺពិត » ឬ « ខ្ញុំដឹងថាវាពិត » ឬ « ខ្ញុំជឿដល់ការណ៍នេះដោយអស់ពីចិត្តខ្ញុំ » ។

ការរស់នៅ

សូមស្នើពីរបៀបដែលសិស្សអាចអនុវត្តនូវគោលលទ្ធិ និងគោលការណ៍ដែលមាននៅក្នុងវគ្គព្រះគម្ពីរ (ឬសូមឲ្យសិស្សគិតពីរបៀបនានា) ផ្តល់ឱកាសឲ្យពួកគេរៀនដោយការអនុវត្តន៍សេចក្តីជំនឿ ។ អែលឌើរ ដាវីឌ អេ បែឌណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា ៖

« អ្នករៀនម្នាក់ដែលអនុវត្តសិទ្ធិជ្រើសរើសដោយការធ្វើសកម្មភាពតាមគោលការណ៍ត្រឹមត្រូវបានបើកដួងចិត្តរបស់គេចំពោះព្រះវិញ្ញាណបរិសុទ្ធ និងអញ្ជើញការបង្រៀនរបស់ទ្រង់ធ្វើទីបន្ទាល់អំពីព្រះចេស្តា និងបញ្ជាក់ពីទីបន្ទាល់ ។ ការរៀនដោយសេចក្តីជំនឿតម្រូវឲ្យមានការខិតខំខាងវិញ្ញាណ ស្មារតី និងរាងកាយ ហើយមិនមែនការទទួលដោយអសកម្មនោះទេ ។ « វាគឺនៅក្នុងសេចក្តីស្មោះត្រង់ និងភាពខ្ជាប់ខ្ជួននៃសេចក្តីជំនឿដែលបានបំផុសគំនិតរបស់យើងឲ្យធ្វើសកម្មភាពដែលយើងបង្ហាញចំពោះព្រះវរបិតាសួគ៌ និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ នូវការស្ម័គ្រចិត្តរបស់យើងដើម្បីរៀន និងទទួលយកការបង្ហាត់បង្រៀនពីព្រះវិញ្ញាណបរិសុទ្ធ » (« Seek Learning by Faith » *Ensign,* ខែ កញ្ញា ឆ្នាំ ២០០៧, ទំព័រ ៦៤) ។

សូមឲ្យសិស្សមានឱកាសចែកចាយ និងធ្វើទីបន្ទាល់អំពីបទពិសោធន៍ដែលពួកគេបានមានក្នុងការអនុវត្តគោលលទ្ធិ និងគោលការណ៍ទាំងឡាយ ។ ខាងក្រោមនេះគឺជារបៀបមួយដើម្បីលើកទឹកចិត្តសិស្សឲ្យអនុវត្តវគ្គចំណេះចំណានខគម្ពីរនៅក្នុងជីវិតរបស់គេ ៖

- ការដាក់គោលដៅ—ដោយផ្អែកលើផ្នែកដែលអនុវត្តនៃកាតចំណេះចំណានខគម្ពីរ សូមឲ្យសិស្សដាក់គោលដៅជាក់លាក់ដើម្បីរស់នៅតាមគោលការណ៍ដែលមាននៅក្នុងវគ្គចំណេះចំណានខគម្ពីរនេះបានកាន់តែប្រសើរ ។ សូមឲ្យពួកគេសរសេរគោលដៅរបស់គេនៅលើក្រដាសមួយ យកតាមខ្លួនគេដើម្បីរឭក ។ សូមឲ្យសិស្សរៀបរាប់ពីជោគជ័យរបស់គេនៅពេលមានពេលវេលាសមរម្យ ។

សកម្មភាពដែលជួយសិស្សឲ្យ *ទន្ទេញចាំ* វគ្គចំណេះចំណានខគម្ពីរ

ការទន្ទេញចាំ

ការទន្ទេញចាំវគ្គព្រះគម្ពីរ អាចពង្រីកការយល់ដឹង និងពង្រឹងសមត្ថភាពរបស់សិស្សក្នុងការបង្រៀនដ៏ណឹងល្អ ។ នៅពេលសិស្សទន្ទេញបទគម្ពីរ នោះព្រះវិញ្ញាណបរិសុទ្ធអាចធ្វើឲ្យពួកគេចាំឃ្លា និងគំនិត នៅពេលដែលពួកគេជួបការពិបាក (សូមមើល យ៉ូហាន ១៤:២៦; គ. និង ស. ១១:២១) ។ សូមចាំថាត្រូវសម្របសកម្មភាពទន្ទេញចាំនេះតាមសមត្ថភាពរបស់សិស្សអ្នក ។ អែលឌើរ រីឆាត ជី. ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានលើកទឹកចិត្តឲ្យមានការទន្ទេញចាំខគម្ពីរ នៅពេលលោកបានមានប្រសាសន៍ថា ៖

« អំណាចដ៏អស្ចារ្យអាចចេញមកពីការទន្ទេញចាំខគម្ពីរ ។ ការទន្ទេញចាំខគម្ពីរ គឺការបង្កើតនូវមិត្តភាពថ្មីមួយ ។ វាដូចជាការស្វែងរកបុគ្គលថ្មីមួយ ដែលអាចជួយអ្នកក្នុងពេលអាសន្ន ផ្តល់នូវការបំផុសគំនិត និងការលួងលោម និងជាប្រភពនៃការជម្រុញទឹកចិត្តឲ្យមានការផ្លាស់ប្តូរចាំបាច់ » (« The Power of Scripture » *Ensign* ឬ *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ៦) ។

សកម្មភាពខាងក្រោមនីមួយៗអាចធ្វើដដែលៗបីបួនថ្ងៃជាប់ៗគ្នានៅពេលចាប់ផ្តើមថ្នាក់ ឬពេលបញ្ចប់ដើម្បីជួយសិស្សឲ្យទន្ទេញចាំវាបានយូរ ៖

- ការប្រកួតតែមួយពាក្យ— សូមតាំងចិត្តសិស្សឲ្យសូត្រវគ្គចំណេះចំណានខគម្ពីរ តែមួយពាក្យម្នាក់ៗ ម្តងម្នាក់ៗ ។ ឧទាហរណ៍ នៅពេលជួយសិស្សឲ្យទន្ទេញ អាលម៉ា ៣៩:៩ សិស្សទីមួយនឹងនិយាយពាក្យ *ឥឡូវនេះ* សិស្សទីពីរនឹងនិយាយថា *ឱកូនប្រុស* សិស្សទីបីនិយាយថា *របស់ឪពុកអើយ* ហើយបន្តបន្ទាប់រហូតដល់ខគម្ពីរទាំងមូលបញ្ចប់ ។ សូមផ្លាស់ពេលដល់សិស្ស ហើយឲ្យពួកគេមានព្យាយាមធ្វើឲ្យបានច្រើនដងដើម្បីសម្រេចក្នុងពេលកំណត់មួយ ។ នៅពេលអ្នកធ្វើសកម្មភាពនេះសារឡើងវិញ សូមគិតពីការប្តូរលំដាប់សិស្ស ដើម្បីឲ្យពួកគេអាចនិយាយពាក្យខុសគ្នា ។
- អក្សរដំបូង—សរសេរនៅលើក្តារខៀននូវអក្សរដំបូងនៃពាក្យនីមួយៗនៅក្នុងវគ្គចំណេះចំណានខគម្ពីរ ។ សូមចង្អុលអក្សរនៅពេលសិស្សថាខគម្ពីរឡើងវិញជាមួយនឹងអ្នក ដោយប្រើព្រះគម្ពីររបស់គេពេលត្រូវការ ។ សូមធ្វើសកម្មភាពនេះឡើងវិញ រហូតដល់សិស្សមានទំនុកចិត្តលើសមត្ថភាពរបស់គេក្នុងការទន្ទេញចាំខគម្ពីរមួយដោយគ្រាន់តែមានជំនួយពីអក្សរដំបូងមួយប៉ុណ្ណោះ ។ អ្នកអាចលុបអក្សរពីរបីរាល់ពេលដែលសិស្សទន្ទេញខគម្ពីរនេះ ។ ការណ៍នេះនឹងបង្កើនការពិបាកបន្តិចម្តងៗរហូតដល់សិស្សអាចទន្ទេញចាំខគម្ពីរដោយមិនចាំបាច់ប្រើអក្សរដំបូង ។
- ល្បែងតម្រៀបពាក្យ— សរសេរ ឬសូមឲ្យសិស្សសរសេរពាក្យមកពីវគ្គចំណេះចំណានខគម្ពីរនៅលើក្រដាសមួយដែលមានជួរ ។ សូមកាត់ក្រដាសនោះតាមជួរ ដោយទុកជួរខគម្ពីរទាំងមូល ។ សូមកាត់ជួរខ្លះចេញឲ្យខ្លីជាងមុនដើម្បីបញ្ចូលនូវពាក្យពីរបីនៃខគម្ពីរនៅលើក្រដាសនីមួយៗ ។ សូមច្របល់ក្រដាសចូលគ្នា ហើយឲ្យសិស្សធ្វើការដោយដៃគូ ឬក្រុមតូចមួយ ។ សូមឲ្យសិស្សតម្រៀបក្រដាសជាជួរតាមលំដាប់ដោយប្រើព្រះគម្ពីររបស់គេជាអ្នកណែនាំ ។ សូមឲ្យពួកគេធ្វើរហូតដល់ពួកគេលែងត្រូវការប្រើព្រះគម្ពីររបស់គេ ។ ក្រោយពីពួកគេបានបញ្ចប់ហើយ សូមឲ្យពួកគេទន្ទេញខគម្ពីរនោះឮៗ ។ អ្នកក៏អាចកំណត់ពេលដល់សិស្សដើម្បីដឹងថា តើក្រុមមួយណាអាចរៀបចំពាក្យត្រឹមត្រូវតាមលំដាប់បានលឿនជាងគេបំផុត ។ ឬ អ្នកអាចកំណត់ពេលដល់សិស្សទាំងអស់ដើម្បីដឹងថាតើវាត្រូវការពេលប៉ុន្មានសម្រាប់ក្រុមទាំងអស់បញ្ចប់ល្បែងនេះ (នៅពេលក្រុមទីមួយបញ្ចប់ សូមឲ្យពួកគេជួយដល់ក្រុមដែលយឺតជាង) ។

វគ្គចំណេះចំណានខគម្ពីរទាំង ១០០

ព្រះគម្ពីរសញ្ញាចាស់	ព្រះគម្ពីរសញ្ញាថ្មី	ព្រះគម្ពីរមរមន	គោលលទ្ធិ និង សេចក្តីសញ្ញា
ម៉ូសេ ១:៣៩	ម៉ាថាយ ៥:១៤–១៦	នីហ្វៃទី១ ៣:៧	គ. និង ស. ១:៣៧–៣៨
ម៉ូសេ ៧:១៨	ម៉ាថាយ ១១:២៨–៣០	នីហ្វៃទី ២ ២:២៥	គ. និង ស. ៦:៣៦
អ័ប្រាហាំ ៣:២២–២៣	ម៉ាថាយ ១៦:១៥–១៩	នីហ្វៃទី២ ២:២៧	គ. និង ស. ៨:២–៣
លោកុប្បត្តិ ១:២៦–២៧	ម៉ាថាយ ២២:៣៦–៣៩	នីហ្វៃទី២ ៩:២៨–២៩	គ. និង ស. ១០:៥
លោកុប្បត្តិ ២:២៤	ម៉ាថាយ ២៨:១៩–២០	នីហ្វៃទី ២ ២៥:២៣, ២៦	គ. និង ស. ១៣:១
លោកុប្បត្តិ ៣៩:៩	លូកា ២៤:៣៦–៣៩	នីហ្វៃទី ២ ២៨:៧–៩	គ. និង ស. ១៨:១០–១១
និក្ខមនំ ១៩:៥–៦	យ៉ូហាន ៣:៥	នីហ្វៃ ២: ៣១:១៩–២០	គ. និង ស. ១៨:១៥–១៦
និក្ខមនំ ២០:៣–១៧	យ៉ូហាន ១៤:៦	នីហ្វៃទី ២ ៣២:៣	គ. និង ស. ១៩:១៦–១៩
យ៉ូស្វេ ២៤:១៥	យ៉ូហាន ១៤:១៥	នីហ្វៃទី ២ ៣២:៨–៩	គ. និង ស. ១៩:២៣
សាំយ៉ូអែលទី ១ ១៦:៧	យ៉ូហាន ១៧:៣	ម៉ូសាយ ២:១៧	គ. និង ស. ២៥:១៣
ទំនុកដំកើង ២៤:៣–៤	កិច្ចការ ២:៣៦–៣៨	ម៉ូសាយ ៣:១៩	គ. និង ស. ៤៦:៣៣
ទំនុកតម្កើង ១១៩:១០៥	កិច្ចការ ៣: ១៩–២១	ម៉ូសាយ ៤:៣០	គ. និង ស. ៥៨:២៧
ទំនុកតម្កើង ១២៧:៣	កូរិនថូស ទី១ ៦:១៩–២០	អាលម៉ា ៧:១១–១៣	គ. និង ស. ៥៨:៤២–៤៣
សុភាសិត ៣:៥–៦	កូរិនថូស ទី១ ១៥:២០–២២	អាលម៉ា ៣២:២១	គ. និង ស. ៦៤:៩–១១
អេសាយ ១:១៨	កូរិនថូស ទី១ ១៥:៤០–៤២	អាលម៉ា ៣៧:៣៥	គ. និង ស. ៧៦:២២–២៤
អេសាយ ៥:២០	កាឡាទី ៥:២២–២៣	អាលម៉ា ៣៩:៩	គ. និង ស. ៧៦:៤០–៤១
អេសាយ ២៩:១៣–១៤	អេភេសូរ ៤:១១–១៤	អាលម៉ា ៤១:១០	គ. និង ស. ៧៨:១៩
អេសាយ ៥៣:៣–៥	ភីលីព ៤:១៣	ហេលេមិន ៥:១២	គ. និង ស. ៨២:១០
អេសាយ ៥៨:៦–៧	ថែស្សាឡូនីច ទី២ ២:១–៣	នីហ្វៃទី ៣ ១២:៤៨	គ. និង ស. ៨៨:១២៤
អេសាយ ៥៨:១៣–១៤	ធីម៉ូថេទី ២ ៣: ១៥–១៧	នីហ្វៃទី ៣ ១៨:១៥, ២០–២១	គ. និង ស. ៨៩:១៨–២១
យេរេមា ១:៤–៥	ហេព្រើរ ១២:៩	អេធើរ ១២:៦	គ. និង ស. ១០៧:៨
អេសេគាល ៣៧:១៥–១៧	យ៉ាកុប ១:៥–៦	អេធើរ ១២:២៧	គ. និង ស. ១២១:៣៦, ៤១–៤២
អេម៉ុស ៣:៧	យ៉ាកុប ២:១៧–១៨	មរ៉ូណៃ ៧:៤១	គ. និង ស. ១៣០:២២–២៣
ម៉ាឡាគី ៣:៨–១០	ពេត្រុស ទី១ ៤:៦	មរ៉ូណៃ ៧:៤៥, ៤៧–៤៨	គ. និង ស. ១៣១:១–៤
ម៉ាឡាគី ៤:៥–៦	វិវរណៈ ២០:១២	មរ៉ូណៃ ១០:៤–៥	យ.ស — ប្រ. ១:១៥–២០

សេចក្តីផ្តើមនៃគោលលទ្ធិគ្រឹះ

គោលលទ្ធិគ្រឹះខាងក្រោមគួរត្រូវបានបញ្ចាក់នៅក្នុងថ្នាក់សិក្ខាសាលា ៖

- ក្រុមព្រះ
- ផែនការនៃសេចក្តីសង្គ្រោះ
- ជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ
- គ្រាកាន់កាប់ត្រួតត្រា ការក្បត់សាសនា និងការស្តារឡើងវិញ
- ព្យាការី និង វិវរណៈ
- បព្វជិតភាព និង កូនសោនៃបព្វជិតភាព
- ពិធីបរិសុទ្ធ និង សេចក្តីសញ្ញា
- អាពាហ៍ពិពាហ៍ និង គ្រួសារ
- បទបញ្ញត្តិទាំងឡាយ

គ្រូបង្រៀនត្រូវជួយសិស្សឲ្យរកមើល យល់ ជឿតាម ពន្យល់ និងអនុវត្តគោលទ្ធិគ្រឹះនៃដំណឹងល្អទាំងនេះ នៅពេលពួកគេសិក្សាព្រះគម្ពីរ ។ ការធ្វើដូច្នោះនឹងជួយសិស្សពង្រឹងទីបន្ទាល់ទាំងឡាយ ហើយបង្កើនអំណរគុណរបស់គេ ចំពោះដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ ។ការរៀនពីគោលលទ្ធិគ្រឹះក៏នឹងជួយសិស្សឲ្យរៀបចំខ្លួនកាន់តែប្រសើរដើម្បីរស់នៅតាមដំណឹងល្អ និងបង្រៀនសេចក្តីពិតដ៏សំខាន់ទាំងនេះដល់អ្នកដទៃ ។ មេរៀននៅក្នុងសៀវភៅណែនាំនេះត្រូវបានធ្វើឡើងដោយបានគិតដល់គោលលទ្ធិគ្រឹះទាំងឡាយ ។ វាជាការណ៍សំខាន់ដើម្បីដឹងថា គោលលទ្ធិដ៏សំខាន់ផ្សេងទៀតនៃដំណឹងល្អក៏នឹងត្រូវបានបញ្ចាក់នៅក្នុងសៀវភៅណែនាំនេះដែរ បើទោះជាវាមិនបានសរសេរនៅក្នុងចំណោមគោលលទ្ធិគ្រឹះក្តី ។

ការបង្រៀនគោលលទ្ធិគ្រឹះទាំងឡាយនៃដំណឹងល្អកើតឡើងនៅពេលអ្នកសិក្សាព្រះគម្ពីរប្រចាំថ្ងៃជាមួយនឹងសិស្ស និងនៅពេលអ្នកជួយពួកគេឲ្យចងចាំវគ្គខគម្ពីរគន្លឹះទាំងឡាយ ។ អ្នកមិនគួរចាកចេញពីការសិក្សាព្រះគម្ពីរប្រចាំថ្ងៃដើម្បីផ្តោតលើគោលលទ្ធិទាំងនេះនោះឡើយ ។ ប៉ុន្តែ អ្នកគួរយកចិត្តទុកដាក់ចំពោះពួកវា នៅពេលវាលេចឡើងមកក្នុងវគ្គសិក្សា និងនៅពេលអ្នកជួយសិស្សឲ្យចងចាំវគ្គខគម្ពីរគន្លឹះទាំងឡាយ ។ ឧទាហរណ៍ នៅពេលអ្នកបង្រៀនសេចក្តីពិតថា « ព្យាការីព្រមានប្រឆាំងនឹងអំពើបាប និងបង្រៀនពីសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវគ្រីស្ទ » នៅក្នុង នីហ្វៃទី ១ ១ អ្នកអាចបង្ហាញដល់សិស្សថា សេចក្តីពិតនេះអាចជួយពួកគេឲ្យយល់ពីគោលលទ្ធិគ្រឹះនៃ « ព្យាការី និងវិវរណៈ » ។ អ្នកអាចសុំឲ្យសិស្សពន្យល់ពីអ្វីផ្សេងទៀតដែលពួកគេដឹងអំពីព្យាការី និងវិវរណៈ ។ នៅពេលសិស្សរៀនពីវគ្គចំណេះចំណានខគម្ពីរ នីហ្វៃទី ២ ២៥:២៣, ២៦ អ្នកអាចជួយពួកគេឲ្យឃើញថា វគ្គនេះបង្ហាញពីរបៀបមួយដែលព្យាការីបំពេញកាតព្វកិច្ចរបស់លោកក្នុងការបង្រៀនពីសេចក្តីសង្គ្រោះតាមរយៈព្រះយេស៊ូវគ្រីស្ទ ។ ការរីកចម្រើនលើការយល់ដឹង ការជឿ និងការរស់នៅតាមគោលលទ្ធិគ្រឹះគឺជាដំណើរការមួយដែលកើតឡើងក្នុងរយៈពេលបួនឆ្នាំនៃថ្នាក់សិក្ខាសាលា និងបន្តរហូតពេញមួយជីវិតរបស់សិស្ស ។

អ្នកអាចចែកបញ្ជីគោលលទ្ធិគ្រឹះដល់សិស្ស ។

ការវាយតម្លៃគោលលទ្ធិគ្រឹះ

ការវាយតម្លៃគោលលទ្ធិគ្រឹះ ត្រូវបានធ្វើឡើងដើម្បីផ្តល់ព័ត៌មានដល់គ្រូបង្រៀន នូវអ្វីដែលពួកគេអាចប្រើដើម្បីប្រទានពរដល់ជីវិតសិស្សរបស់គេ ។ យើងផ្តល់អនុសាសន៍ថា គ្រូបង្រៀនគួរធ្វើការវាយតម្លៃនេះ នៅពេលសប្តាហ៍ទីមួយ ហើយបន្តរហូតដល់ចុងឆ្នាំសិក្សា ។ សូមរកមើលកម្មវិធីវាយតម្លៃគោលលទ្ធិគ្រឹះ និងកម្មវិធីវាយតម្លៃផ្សេងទៀតនៅក្នុងគេហទំព័រ ss&i (si.lds.org) សូមប្រើពាក្យគន្លឹះ *assessment* ។

គ្រូបង្រៀនដែលបញ្ជូនលទ្ធផលនៃការវាយតម្លៃរបស់សិស្សខ្លួនទៅការិយាល័យស្រាវជ្រាវ ss&iនឹងទទួលបានបាយការណ៍មួយដែលនឹងជួយពួកគេឲ្យសម្របការបង្រៀនរបស់គេឲ្យបំពេញតាមតម្រូវការរបស់សិស្សខ្លួនកាន់តែប្រសើរ ។ ឧទាហរណ៍ ប្រសិនបើលទ្ធផលបង្ហាញថា សិស្សមិនយល់ពីគោលលទ្ធិនៃការប្រែចិត្តនោះទេ នោះមេរៀនបីបួននៅក្នុងកម្មវិធីសិក្សាប្រចាំឆ្នាំនឹងលេចឡើង ដើម្បីជួយសិស្សឲ្យយល់ពីគោលលទ្ធិនេះកាន់តែច្បាស់ ។ នៅពេលគ្រូបង្រៀនប្រើព័ត៌មាននេះប្រកបដោយការអធិស្ឋាននៅក្នុងការបង្រៀនព្រះគម្ពីរតាមលំដាប់នោះ យុវវ័យ និងយុវមជ្ឈិមវ័យរបស់យើងនឹងត្រូវបានរៀបចំកាន់តែល្អប្រសើរដើម្បីសម្រេចបាននូវគោលដៅនៃថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា ។

គោលលទ្ធិគ្រឹះទាំងឡាយ

គោលលទ្ធិគ្រឹះទាំងឡាយនឹងត្រូវបានបញ្ជាក់ថាសំខាន់ទាំងនៅក្នុងថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថាន ។ គ្រូបង្រៀនត្រូវជួយសិស្សឲ្យចេះស្គាល់ យល់ ជឿ ពន្យល់ ហើយអនុវត្តគោលលទ្ធិគ្រឹះនៃដំណឹងល្អទាំងនេះ ។ការធ្វើដូច្នោះនឹងជួយសិស្សពង្រឹងទីបន្ទាល់ទាំងឡាយ ហើយបង្កើនអំណរគុណរបស់គេ ចំពោះដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទដែលបានស្តារឡើងវិញ ។ការសិក្សាគោលលទ្ធិទាំងនេះ ក៏នឹងជួយពួកគេឲ្យរៀបចំបានយ៉ាងប្រសើរ ដើម្បីបង្រៀនពីសារៈសំខាន់នៃសេចក្តីពិតទាំងនេះដល់អ្នកដទៃទៀតផងដែរ ។

វគ្គចំណេះចំណានខគម្ពីរទាំង ១០០ ត្រូវបានជ្រើសរើសដោយថ្នាក់សិក្ខាសាលា និងថ្នាក់វិទ្យាស្ថានសាសនា ត្រូវបានរើសដើម្បីទ្រទ្រង់ដល់ការចេះដឹងរបស់សិស្សអំពីគោលលទ្ធិគ្រឹះទាំងឡាយ ។ សេចក្តីយោងព្រះគម្ពីរភាគច្រើនត្រូវបានសរសេរដូចខាងក្រោមនេះ គឺសំដៅលើគ្នីចំណេះចំណានខគម្ពីរ ។ វាត្រូវបានដាក់បញ្ចូលដើម្បីបង្ហាញពីរបៀបដែលវាទាក់ទងទៅនឹងគោលលទ្ធិគ្រឹះទាំងឡាយ ។

១ . ក្រុមព្រះ

នៅក្នុងក្រុមព្រះមានអង្គបីដាច់ដោយឡែកពីគ្នា ៖ ព្រះ ជាព្រះវរបិតាដ៏អស់កល្បជានិច្ច ព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ និងព្រះវិញ្ញាណបរិសុទ្ធ (សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៥–២០) ។ ព្រះវរបិតា និងព្រះរាជបុត្រាមានព្រះកាយជាសាច់ និងឆ្អឹង ហើយព្រះវិញ្ញាណបរិសុទ្ធគឺជាអង្គនៃវិញ្ញាណ (សូមមើល គ. និង ស. ១៣០:២២–២៣) ។ ពួកទ្រង់គឺតែមួយនៅក្នុងគោលបំណង និងគោលលទ្ធិ ។ ពួកទ្រង់សាមគ្គីគ្នាដោយឥតខ្ចោះ ក្នុងការនាំមកនូវផែនការសង្គ្រោះដ៏ទេវភាពរបស់ព្រះវរបិតាសួគ៌ ។

ព្រះជាព្រះវរបិតា

ព្រះជាព្រះវរបិតា គឺជាអ្នកគ្រប់គ្រងដ៏ខ្ពស់បំផុតនៃសកលលោកនេះ ។ ទ្រង់គឺជាព្រះវរបិតានៃវិញ្ញាណរបស់យើង (សូមមើល ហេព្រើរ ១២:៩) ។ ទ្រង់គឺល្អឥតខ្ចោះ មានគ្រប់ទាំងព្រះចេស្តាទាំងអស់ ហើយទ្រង់ជ្រាបគ្រប់ការណ៍ទាំងអស់ ។ ទ្រង់ក៏ជាព្រះមួយអង្គប្រកបដោយសេចក្តីមេត្តាដ៏ឥតខ្ចោះ សេចក្តីសណ្តោស និងសេចក្តីសប្បុរស ។

ព្រះយេស៊ូវគ្រីស្ទ

ព្រះយេស៊ូវគ្រីស្ទ គឺជាវិញ្ញាណដំបូងបំផុតរបស់ព្រះវរបិតា ហើយគឺជាព្រះរាជបុត្រាតែមួយគត់របស់ព្រះវរបិតាជាសាច់ឈាម ។ ទ្រង់គឺជាព្រះយេហូវ៉ានៃព្រះគម្ពីរសញ្ញាចាស់ និងជាព្រះមែស៊ីនៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។

ព្រះយេស៊ូវគ្រីស្ទ បានរស់នៅក្នុងជីវិតមួយដែលគ្មានអំពើបាបសោះ ហើយបានធ្វើជង្វាយធួនដ៏ឥតខ្ចោះមួយសម្រាប់លោះអំពើបាបទាំងឡាយរបស់មនុស្សជាតិទាំងអស់ (សូមមើល អាលម៉ា ៧:១១–១៣) ។ ជីវិតរបស់ទ្រង់គឺជាតំរូងដ៏ឥតខ្ចោះមួយនៃជីវិតដែលមនុស្សទាំងអស់គួរធ្វើតាម (សូមមើល យ៉ូហាន ១៤:៦; នីហ្វៃទី ៣ ១២:៤៨) ។ ទ្រង់គឺជាមនុស្សដំបូងនៅលើផែនដីដែលបានរស់ឡើងវិញ (សូមមើល កូរិនថូសទី ១ ១៥:២០–២២)។ ទ្រង់នឹងយាងមកម្តងទៀតដោយមានព្រះចេស្តា និងសិរីល្អ ហើយនឹងគ្រងរាជ្យនៅលើផែនដីនេះ អំឡុងពេលសហវត្សរ៍ ។

ការអធិស្ឋាន ពរជ័យ និងពិធីបរិសុទ្ធនៃបព្វជិតភាពទាំងឡាយត្រូវបានធ្វើឡើងដោយនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ (សូមមើល នីហ្វៃទី ៣ ១៨:១៥, ២០–២១) ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ ហេលេមិន ៥:១២; គ. និង ស. ១៩:២៣; គ. និង ស. ៧៦:២២–២៤

ព្រះវិញ្ញាណបរិសុទ្ធ

ព្រះវិញ្ញាណបរិសុទ្ធ គឺជាអង្គទីបីនៃសមាជិកក្រុមព្រះ ។ទ្រង់គឺជាអង្គមួយនៃវិញ្ញាណដែលគ្មានព្រះកាយជាសាច់ និងឆ្អឹងឡើយ ។ ជាញឹកញាប់ ទ្រង់ត្រូវបានសំដៅថាជា ព្រះវិញ្ញាណ ព្រះវិញ្ញាណបរិសុទ្ធ ព្រះវិញ្ញាណនៃព្រះ ព្រះវិញ្ញាណនៃព្រះអម្ចាស់ និងព្រះជំជាដំនួយ ។

ព្រះវិញ្ញាណបរិសុទ្ធថ្លែងជាសាក្សីនៃព្រះវរបិតា និងព្រះរាជបុត្រា ដោយបង្ហាញនូវសេចក្តីពិតនៃគ្រប់អស់ទាំងការណ៍ និងបន្សុទ្ធអស់អ្នកដែលប្រែចិត្ត និងត្រូវបានជ្រមុជទឹក (សូមមើល មរ៉ូណៃ ១០:៤–៥) ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ កាឡាទី ៥:២២–២៣; គ. និង ស. ៨:២–៣

២ . ផែនការនៃសេចក្តីសង្គ្រោះ

នៅក្នុងជីវិតមុនជីវិតខាងសាច់ឈាម ព្រះវរបិតាសួគ៌បានបង្ហាញដល់យើងនូវផែនការមួយដើម្បីជួយយើងឲ្យក្លាយដូចជាទ្រង់ ហើយទទួលបាននូវជីវិតខាងសាច់ឈាម និងជីវិតដ៏នៅអស់កល្បជានិច្ច (សូមមើល ម៉ូសេ ១:៣៩) ។ ព្រះគម្ពីរសំដៅលើផែនការនេះថាជាផែនការនៃសេចក្តីសង្គ្រោះ ជាផែនការដ៏អស្ចារ្យនៃសុភមង្គល ផែនការនៃការប្រោសលោះ និងផែនការនៃសេចក្តីមេត្តាករុណា ។

ផែនការនៃសង្គ្រោះរួមមាននូវការបង្កបង្កើត ការធ្លាក់ ជង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ និងក្រឹត្យវិន័យទាំងអស់ពិធីបរិសុទ្ធ និងគោលលទ្ធិនៃដំណឹងល្អទាំងឡាយ ។ សិទ្ធិជ្រើសរើសគឺជាម— សមត្ថភាពដើម្បីជ្រើសរើស និងធ្វើសកម្មភាពសម្រាប់ខ្លួនយើង— ក៏ជាការណ៍ដ៏សំខាន់មួយនៅក្នុងផែនការនៃព្រះវរបិតាសួគ៌ដែរ (សូមមើល នីហ្វៃទី ២ ២:២៧) ។ ដោយសារតែផែនការនេះ យើងអាចក្លាយជាឥតខ្ចោះតាមរយៈជង្វាយធួន ទទួលបាននូវសេចក្តីរីករាយដ៏ពេញលេញ និងរស់នៅក្នុងវត្តមាននៃព្រះជារៀងរហូតតទៅ (សូមមើល នីហ្វៃទី ៣ ១២:៤៨) ។ ទំនាក់ទំនងគ្រួសាររបស់យើងអាចបន្តរហូតដល់កាពអស់កល្បជានិច្ច ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ យ៉ូហាន ១៧:៣; គ. និង ស. ៥៨:២៧

ជីវិតមុនផែនដី

មុនពេលយើងកើតមកនៅលើផែនដីនេះ យើងបានរស់នៅក្នុងវត្តមាននៃព្រះវរបិតាសួគ៌ជាកូនវិញ្ញាណរបស់ទ្រង់ (សូមមើល អ័ប្រាហាំ ៣:២២–២៣) ។ នៅក្នុងជីវិតមុនជីវិតនៅលើផែនដីនេះ យើងបានចូលរួមនៅក្នុងការប្រឹក្សាមួយជាមួយនឹងកូនវិញ្ញាណដទៃទៀតរបស់ព្រះវរបិតាសួគ៌ ។ អំឡុងពេលការប្រឹក្សានោះ ព្រះវរបិតាសួគ៌បានបង្ហាញនូវផែនការរបស់ទ្រង់ ហើយព្រះយេស៊ូវគ្រីស្ទមុនជីវិតនៅលើផែនដីនេះបានធ្វើសេចក្តីសញ្ញាដើម្បីក្លាយជាព្រះអង្គសង្គ្រោះ ។

យើងបានប្រើសិទ្ធិជ្រើសរើសរបស់យើងដើម្បីធ្វើតាមផែនការនៃព្រះវរបិតាសួគ៌ ។ យើងបានរៀបចំដើម្បីចុះមកឯផែនដី ដែលជាកន្លែងដែលយើងអាចបន្តរីកចម្រើន ។

អ្នកដែលបានធ្វើតាមព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទត្រូវអនុញ្ញាតឲ្យចុះមកឯផែនដីនេះដើម្បីទទួលបាននូវជីវិតរមែងស្លាប់ និងបន្តរីកចម្រើនរហូតដល់ជីវិតដ៏នៅអស់កល្បជានិច្ច ។ លូស៊ីហ្វើរ ជាកូនវិញ្ញាណមួយទៀតរបស់ព្រះ បានប្រឆាំងនឹងផែនការនេះ ។ វាបានក្លាយជាសាតាំង ហើយវា និងអ្នកដើរតាមរបស់វាត្រូវបានបណ្តេញចេញពីស្ថានសួគ៌ និងត្រូវបានបដិសេធមិនឲ្យមានសិទ្ធិទទួលបានរូបកាយ និងទទួលបានជីវិតរមែងស្លាប់ឡើយ ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ យេរេមា ១:៤–៥

ការបង្កបង្កើត

ព្រះយេស៊ូវគ្រីស្ទបានបង្កើតស្ថានសួគ៌ និងផែនដី នៅក្រោមការដឹកនាំរបស់ព្រះវរបិតា ។ ផែនដីមិនមែនត្រូវបានបង្កើតចេញពីភាពទទេស្អាតនោះទេ វាត្រូវបានរៀបចំឡើងពីអ្វីដែលមាននៅស្រាប់ ។ ព្រះយេស៊ូវគ្រីស្ទបានបង្កើតពិភពលោកជាច្រើន(សូមមើល គ. និង ស. ៧៦:២២–២៤) ។

ការបង្កបង្កើតនៃផែនដីនេះគឺជាផ្នែកដ៏សំខាន់មួយនៃផែនការរបស់ព្រះ ។ វាបានផ្តល់កន្លែងមួយដែលយើងអាចទទួលបាននូវរូបកាយ ត្រូវទទួលការសោកល្បង និងឧបសគ្គ និងអភិវឌ្ឍលក្ខណៈដូចជាព្រះ ។

យើងត្រូវប្រើធនធានរបស់ផែនដីដោយប្រាជ្ញា ការនិច្ចឹយ និងសេចក្តីអំណរ (សូមមើល គ. និង ស. ៧៨:១៩) ។

អ័ដាមគឺជាមនុស្សដំបូងបំផុតដែលត្រូវបានបង្កើតឡើងនៅលើផែនដីនេះ ។ ព្រះបានបង្កើតអ័ដាម និងអេវ៉ាតាមរូបភាពរបស់ទ្រង់ផ្ទាល់ ។ មនុស្សទាំងអស់—ទាំងប្រុស ទាំងស្រី—ត្រូវបានបង្កើតឡើងតាមរូបភាពនៃព្រះ (សូមមើល លោកុប្បត្តិ ១:២៦–២៧) ។

ការធ្លាក់

នៅក្នុងសួនច្បារអេដែន ព្រះបានបញ្ជាឲ្យអ័ដាម និងអេវ៉ាកុំឲ្យទទួលទានផ្លែនៃដើមដឹងខុសត្រូវ បើមិនដូច្នោះទេ លទ្ធផលនៃការធ្វើដូច្នោះនឹងត្រូវទទួលសេចក្តីស្លាប់ខាងសាច់ឈាម និងខាងវិញ្ញាណ ។ ការស្លាប់ខាងវិញ្ញាណ គឺជាការបែងចែកចេញពីព្រះ ។ សេចក្តីស្លាប់ខាងសាច់ឈាមគឺជាការបែងចែកនៃវិញ្ញាណចេញពីរាងកាយខាងសាច់ឈាម ។ ដោយសារអ័ដាម និងអេវ៉ាបានរំលងបទបញ្ញត្តិរបស់ព្រះ នោះពួកគាត់ត្រូវបានបណ្តេញចេញពីវត្តមានរបស់ទ្រង់ ហើយទទួលបានជីវិតរមែងស្លាប់ ។ ការរំលងរបស់អ័ដាម និងអេវ៉ា និងលទ្ធផលនោះបានផ្លាស់ប្តូរអ្វីដែលពួកគេបានជួប រួមមានសេចក្តីស្លាប់ខាងសាច់ឈាម និងខាងវិញ្ញាណ ដែលត្រូវបានហៅថាជា ការធ្លាក់ ។

ជាលទ្ធផលនៃការធ្លាក់ លោកអ័ដាម និងអេវ៉ា និងកូនចៅរបស់លោកអាចទទួលបានសេចក្តីរីករាយ និងទុក្ខសោក ជីវិតល្អ និងអាក្រក់ ហើយមានកូនចៅ (សូមមើល នីហ្វៃទី ២ ២:២៥) ។ ជាកូនចៅរបស់អ័ដាម និង អេវ៉ា យើងបន្តមរតកនៃស្ថានភាពធ្លាក់អំឡុងពេលជីវិតរមែងស្លាប់នេះ ។ យើងត្រូវបានបែកចេញពីវត្តមាននៃព្រះអម្ចាស់ ហើយត្រូវរងនឹងសេចក្តីស្លាប់ខាងសាច់ឈាម ។ យើងក៏ត្រូវបានសាកល្បងដោយសេចក្តីលំបាកនៅក្នុងជីវិតនេះ ហើយនិងការល្បួងពីមារសាតាំ ។ (សូមមើល ម៉ូសាយ ៣:១៩ ។)

ការឆ្លាក់ គឺជាផ្នែកដ៏សំខាន់មួយនៃផែនការនៃសេចក្តីសង្គ្រោះ នៃព្រះវរបិតាសួគ៌ា ។ វាមានទិសដៅពីរ —ទៅក្រោម ប៉ុន្តែទៅមុខ ។ បន្ថែមទៅលើការណែនាំនៃសេចក្តីស្លាប់ខាងរាងកាយ និងខាងវិញ្ញាណ វាផ្តល់ដល់យើងនូវឱកាសដើម្បីបានកើត នៅលើផែនដីនេះ ហើយរៀន និងរីកចម្រើន ។

ជីវិតរមែងស្លាប់

ជីវិតរមែងស្លាប់គឺជាពេលវេលាមួយសម្រាប់រៀនសូត្រ នៅពេលយើងអាចរៀបចំសម្រាប់ជីវិតអស់កល្បជានិច្ច ហើយបង្ហាញថា យើងនឹងប្រើសិទ្ធិជ្រើសរើសរបស់យើងដើម្បីធ្វើអ្វីទាំងអស់ដែលព្រះអម្ចាស់បានបញ្ជា ។ អំឡុងពេលជីវិតរមែងស្លាប់នេះ យើងត្រូវស្រឡាញ់ និងបម្រើដល់អ្នកដទៃ (សូមមើល ម៉ូសាយ ២:១៧; ម៉ូរ៉ូណៃ ៧:៤៥, ៤៧–៤៨) ។

នៅក្នុងជីវិតរមែងស្លាប់ វិញ្ញាណរបស់យើង ត្រូវបានរួមគ្នាជាមួយនឹងរូបកាយសាច់ឈាម ដោយផ្តល់ឲ្យយើងនូវឱកាសដើម្បីធំធាត់ និងរីកចម្រើនតាមរបៀបដែលមិនអាចកើតមាននៅក្នុងជីវិតមុនឆាកជីវិតនេះបាន ។ រាងកាយរបស់យើងគឺជាផ្នែកដ៏សំខាន់នៃផែនការសង្គ្រោះ ហើយត្រូវទទួលបានការគោរពជាអំណោយទានមួយមកពីព្រះវរបិតាសួគ៌ (សូមមើល កូរិនថូសទី ១ ៦:១៩–២០) ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ យ៉ូស្វេ ២៤:១៥; ម៉ាថាយ ២២:៣៦–៣៩; នីហ្វៃទី ២ ២៨:៧–៩; អាលម៉ា ៤១:១០; គ. និង ស. ៥៨:២៧

ជីវិតក្រោយការស្លាប់

នៅពេលយើងស្លាប់ទៅ វិញ្ញាណរបស់យើងនឹងចូលទៅក្នុងពិភពវិញ្ញាណ ហើយរង់ចាំការរស់ឡើងវិញ ។ វិញ្ញាណនៃពួកសុចរិត ត្រូវបានទទួលនៅក្នុងសភាពមួយនៃសុភមង្គល ដែលត្រូវហៅថាជាស្ថានបរមសុខ ។ អ្នកជឿស្មោះត្រង់ជាច្រើននឹងផ្សាយដំណឹងល្អទៅដល់អស់អ្នកដែលនៅក្នុងស្ថានឃុំវិញ្ញាណ ។

ស្ថានឃុំវិញ្ញាណគឺជាកន្លែងបណ្តោះអាសន្នមួយនៅក្នុងពិភពក្រោយពីជីវិតនេះ សម្រាប់អស់អ្នកណាដែលស្លាប់ដោយមិនបានដឹងពីសេចក្តីពិត និងអស់អ្នកណាដែលមិនបានគោរពតាមនៅក្នុងជីវិតនៅលើផែនដីនេះ ។ នៅទីនោះ វិញ្ញាណទាំងឡាយត្រូវបានបង្រៀនដំណឹងល្អ និងមានឱកាសដើម្បីប្រែចិត្ត និងទទួលយកពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះដែលត្រូវបានធ្វើឡើងសម្រាប់ពួកគេនៅក្នុងព្រះវិហារបរិសុទ្ធ (សូមមើល ពេត្រុសទី ១ ៤:៦) ។ អស់អ្នកដែលទទួលយកដំណឹងល្អ នឹងរស់នៅក្នុងស្ថានបរមសុខរហូតដល់ការរស់ឡើងវិញ ។

ការរស់ឡើងវិញគឺជាការរួបរួមគ្នានៃរាងកាយខាងវិញ្ញាណរបស់យើង ជាមួយនឹងរូបកាយសាច់ឈាមដ៏តន់ខ្ចោះរបស់យើង ដែលជាសាច់ និងឆ្អឹង (សូមមើល លូកា ២៤:៣៦–៣៩) ។ ក្រោយពីការរស់ឡើងវិញ នោះវិញ្ញាណ និងរាងកាយនឹងមិនដែលត្រូវបែកគ្នាទៀតឡើយ ហើយយើងនឹងក្លាយជាអមតៈ ។ បុគ្គលគ្រប់រូបដែលបានកើតមកលើផែនដីនេះ នឹងត្រូវបានរស់ឡើងវិញ ដោយសារព្រះយេស៊ូវគ្រីស្ទបានយកជ័យជំនះលើសេចក្តីស្លាប់ (សូមមើល កូរិនថូសទី ១ ១៥:២០–២២) ។ ពួកសុចរិត នឹងត្រូវបានរស់ឡើងវិញ មុនពួកទុច្ចរិត ហើយនឹងចេញមកនៅក្នុងការរស់ឡើងវិញលើកទីមួយ ។

សេចក្តីជំនុំជំរះចុងក្រោយនឹងកើតឡើង ក្រោយពីជំណើរឡើងវិញ ។ ព្រះយេស៊ូវគ្រីស្ទនឹងកាត់ក្តីបុគ្គលម្នាក់ៗ ដើម្បីសម្រេចពីសិរីល្អអស់កល្បជានិច្ច ដែលគេនឹងទទួលបាន ។ ការជំនុំជម្រះនេះនឹងធ្វើឡើងដោយផ្អែកលើការគោរពតាមរបស់បុគ្គលម្នាក់ៗតាមបញ្ញត្តិរបស់ព្រះ (សូមមើល វិវរណៈ ២០:១២; ម៉ូសាយ ៤:៣០) ។

មាននគរបីនៅក្នុងសិរីល្អ (សូមមើល កូរិនថូសទី ១ ១៥:៤០–៤២) ។ នគរខ្ពស់បំផុតនោះគឺជានគរសេឡេស្ទាល ។ អស់អ្នកដែលនឹងអង់អាចនៅក្នុងគោលការណ៍អំពីព្រះយេស៊ូវ និងគោរពតាមគោលការណ៍នៃដំណឹងល្អទាំងឡាយ នឹងរស់នៅក្នុងនគរសេឡេស្ទាលនៅក្នុងវត្តមាននៃព្រះ ជាព្រះវរបិតា និងព្រះរាជបុត្រា គឺព្រះយេស៊ូវគ្រីស្ទ (សូមមើល គ. និង ស. ១៣១:១–៤) ។

នគរទីពីរនៃនគរទាំងបីនៃសិរីល្អនេះ គឺជានគរទេរេស្ទ្រាល ។ អស់អ្នកដែលរស់នៅក្នុងនគរនេះនឹងជាបុរស និងស្ត្រីណាដែលឲ្យតម្លៃកិត្តិយសលើផែនដី ដែលមិនអង់អាចនៅក្នុងទីបន្ទាល់អំពីព្រះយេស៊ូវ ។

នគរទេឡេស្ទាលគឺជានគរទាបបំផុតនៃនគរសិរីល្អទាំងបី ។ អស់អ្នកណាដែលគ្រងនគរនេះ នឹងជាអ្នកដែលបានជ្រើសរើសអំពើទុច្ចរិត ជាជាងសេចក្តីសុចរិតកាលមានជីវិតរមែងស្លាប់របស់គេ ។ បុគ្គលទាំងនេះនឹងទទួលបានសិរីល្អរបស់គេ ក្រោយពីការប្រោសលោះចេញពីស្ថានឃុំវិញ្ញាណ ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ យ៉ូហាន ១៧:៣

៣ . ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ

ការធួន គឺជាការរងទុក្ខចំពោះការពិន័យនៃអំពើបាប ដោយការណ៍នេះវានឹងលុបចេញឥទ្ធិពលនៃអំពើបាបចេញពីអ្នកមានបាបដែលបានប្រែចិត្ត និងធ្វើឲ្យគេរួបរួមនឹងព្រះ ។ ព្រះយេស៊ូវគ្រីស្ទគឺជាអង្គតែមួយគត់ដែលអាចធ្វើឲ្យមានដង្វាយធួនដ៏តន់ខ្ចោះសម្រាប់មនុស្សលោកទាំងអស់ ។ ដង្វាយធួនរបស់ទ្រង់រួមមាននូវការរងទុក្ខរបស់ទ្រង់ចំពោះអំពើបាបរបស់មនុស្សលោកនៅក្នុងច្បារគែតសេម៉ានី ការបង្ហូរលោហិតរបស់ទ្រង់ ការរងទុក្ខរបស់ទ្រង់ និងការសុគតនៅលើឈើឆ្កាង ព្រមទាំងការរស់ឡើងវិញរបស់ទ្រង់ចេញពីផ្នូរ (សូមមើល លូកា ២៤:៣៦–៣៩; គ. និង ស. ១៩:១៦–១៩) ។ ព្រះអង្គសង្គ្រោះក៏អាចនាំមកនូវដង្វាយធួន ដោយសារទ្រង់បានក្បាអង្គទ្រង់ពីអំពើបាប និងបានមានអំណាចដើម្បីយកឈ្នះលើសេចក្តីស្លាប់ ។ ដោយបានប្រសូតចេញពីមាតាខាងសាច់ឈាមរបស់ទ្រង់ ទ្រង់បានគ្រងមរតកការសុគត ។ ចេញពីព្រះវរបិតាអមតៈរបស់ទ្រង់ ទ្រង់បានគ្រងមរតកនូវអំណាចដើម្បីយកជីវិតរបស់ទ្រង់មកវិញ ។

តាមរយៈព្រះគុណ ដែលធ្វើឲ្យកើតឡើងដោយសារពលិកម្មធួនរបស់ព្រះអង្គសង្គ្រោះ នោះមនុស្សទាំងអស់នឹងត្រូវបានរស់ឡើងវិញ និងទទួលបានអមតភាព ។ ដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទក៏ធ្វើឲ្យយើងអាចទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចផងដែរ (សូមមើល ម៉ូរ៉ូណៃ ៧:៤១) ។ ដើម្បីទទួលបានអំណោយទាននេះ យើងត្រូវតែរស់នៅតាមដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ដែលរួមមានការមានសេចក្តីជំនឿទៅលើទ្រង់ ការប្រែចិត្តចេញពីអំពើបាបរបស់យើង ការទទួលបុណ្យជ្រមុជទឹក ការទទួលបានអំណោយទានព្រះវិញ្ញាណបរិសុទ្ធ និងការតស៊ូដោយស្មោះត្រង់ដល់ទីបញ្ចប់ (សូមមើល យ៉ូហាន ៣:៥) ។

ជាផ្នែកនៃដង្វាយធួនរបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទមិនត្រឹមតែបានរងទុក្ខសម្រាប់អំពើបាបរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើកដាក់មកលើអង្គទ្រង់នូវការឈឺចាប់ ជំងឺ និងទុក្ខវេទនានៃមនុស្សទាំងអស់ផងដែរ (សូមមើល អាលម៉ា ៧:១១–១៣) ។ ទ្រង់យល់ដឹងពីការឈឺចាប់របស់យើង ដោយសារទ្រង់បានជួបនឹងវា ។ ព្រះគុណរបស់ទ្រង់ ឬព្រះចេស្តាធ្វើឲ្យកើតមានរបស់ទ្រង់ ពង្រឹងយើងឲ្យតស៊ូនឹងការល់បាក ហើយសម្រេចបាននូវកិច្ចការដែលយើងមិនអាចធ្វើដោយខ្លួនយើងបាន (សូមមើល ម៉ាថាយ ១១:២៨–៣០; កីលីព ៤:១៣; អេធើរ ១២:២៧) ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ យ៉ូហាន ៣:៥; កិច្ចការ ៣:១៩–២១

សេចក្តីជំនឿលើព្រះយេស៊ូវគ្រីស្ទ

សេចក្តីជំនឿ គឺជា « សេចក្តីសង្ឃឹមចំពោះការណ៍ដែលមើលមិនឃើញ តែពិត » (អាលម៉ា ៣២:២១; សូមមើលផងដែរ អេធើរ ១២:៦) ។ វាគឺជាអំណោយទានមួយមកពីព្រះ ។

សេចក្តីជំនឿត្រូវតែផ្តោតលើព្រះយេស៊ូវគ្រីស្ទដើម្បីឲ្យវាដឹកនាំមនុស្សម្នាក់ទៅរកសេចក្តីសង្គ្រោះ ។ ការមានសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទមានន័យថា ការពឹងទៅលើទ្រង់ទាំងស្រុង និងការទុកចិត្តទៅលើដង្វាយធួនដ៏និរន្តរ៍របស់ទ្រង់ ព្រះចេស្តា និងសេចក្តីស្រឡាញ់របស់ទ្រង់ ។ វារួមមានការជឿលើការបង្រៀនរបស់ទ្រង់ និងការជឿថា ទោះបីជាយើងមិនយល់ពីអ្វីៗទាំងអស់ ប៉ុន្តែទ្រង់យល់ (សូមមើល សុភាសិត ៣:៥–៦; គ. និង ស. ៦:៣៦) ។

សេចក្តីជំនឿ ដែលលើសពីការជឿអកម្ម គឺត្រូវបានបង្ហាញដោយរបៀបដែលយើងរស់នៅ (សូមមើល យ៉ាកុប ២:១៧–១៨) ។ សេចក្តីជំនឿអាចកើនឡើងនៅពេលយើងអធិស្ឋាន សិក្សាព្រះគម្ពីរ និងគោរពតាមព្រះបញ្ញត្តិរបស់ព្រះ ។

ពួកបរិសុទ្ធថ្ងៃចុងក្រោយក៏មានសេចក្តីជំនឿទៅលើព្រះ ជាព្រះវរបិតា ព្រះវិញ្ញាណបរិសុទ្ធ និងអំណាចនៃបព្វជិតភាព ក៏ដូចជាផ្នែកសំខាន់ផ្សេងទៀតនៃដំណឹងល្អដែលបានស្តារឡើងវិញដែរ ។ សេចក្តីជំនឿជួយយើងឲ្យទទួលបានការព្យាបាល និងកម្លាំងខាងវិញ្ញាណ និងរាងកាយដើម្បីបន្តទៅមុខទៀត ប្រឈមមុខនឹងការល់បាករបស់យើង និងយកឈ្នះលើការល្បួង (សូមមើល នីហ្វៃទី ២ ៣១:១៩–២០) ។ ព្រះអម្ចាស់នឹងធ្វើការដោយអត្ថតហេតុដ៏មានអានុភាពនៅក្នុងជីវិតរបស់យើង ស្របតាមសេចក្តីជំនឿរបស់យើង ។

តាមរយៈសេចក្តីជំនឿទៅលើព្រះយេស៊ូវគ្រីស្ទ បុគ្គលម្នាក់អាចទទួលបានការផ្តាច់បាប និងនៅទីបញ្ចប់នឹងអាចរស់នៅក្នុងវត្តមានរបស់ព្រះ ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ ម៉ាថាយ ១១:២៨–៣០

ការប្រែចិត្ត

ការប្រែចិត្តគឺជាការផ្លាស់ប្តូរគំនិត និងដួងចិត្តដែលផ្តល់ដល់យើងនូវគំនិតថ្មីមួយអំពីព្រះ អំពីខ្លួនយើង និងអំពីពិភពលោក ។ វារួមមានការបែរចេញពីអំពើបាប ហើយទៅរកព្រះសម្រាប់ការអភ័យទោស ។ វាត្រូវបានជម្រុញទឹកចិត្ត ដោយសេចក្តីស្រឡាញ់ចំពោះព្រះ និងបំណងប្រាថ្នាដ៏ពិតប្រាកដដើម្បីគោរពតាមព្រះបញ្ញត្តិទាំងឡាយរបស់ទ្រង់ ។

អំពើបារបស់យើងធ្វើឲ្យយើងមិនស្អាត —មិនសក្តិសមនឹងត្រឡប់ទៅរក និងរស់នៅក្នុងវត្តមានរបស់ព្រះវរបិតាសួគ៌របស់យើង ។ តាមរយៈដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ នោះព្រះវរបិតាគង់នៅស្ថានសួគ៌របស់យើងបានផ្តល់នូវរបៀបតែមួយគត់ដើម្បីឲ្យយើងត្រូវបានអភ័យទោសចំពោះអំពើបាបរបស់យើង (សូមមើល អេសាយ ១:១៨) ។

ការប្រែចិត្តក៏រួមមានអារម្មណ៍សោកស្តាយចំពោះការធ្វើអំពើបាប ការសោរសោពចំពោះព្រះវរបិតាសួគ៌ និងដល់អ្នកដទៃបើសិនជាចាំបាច់ លះបង់ចោលអំពើបាប ការស្វែងរកធ្វើឲ្យល្អឡើងវិញ តាមការដែលអាចធ្វើទៅបានអស់ពីសមត្ថភាពនូវអ្វីដែលបានធ្វើឲ្យខូចដោយសារអំពើបាបរបស់មនុស្សម្នាក់ និងរស់នៅតាមជីវិតមួយដោយការគោរពតាមព្រះបញ្ញត្តិរបស់ព្រះ (សូមមើល គ. និង ស. ៥៨:៤២–៤៣) ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ អេសាយ ៥៣:៣–៥; យ៉ូហាន ១៤:៦; នីហ្វៃទី ២ ២៥:២៣, ២៦; គ. និង ស. ១៨:១០–១១; គ. និង ស. ១៩:២៣; គ. និង ស. ៧៦:៤០–៤១

៤. គ្រាកាន់កាប់ត្រួតត្រា ការក្បត់សាសនា និងការស្តារឡើងវិញ

គ្រាកាន់កាប់ត្រួតត្រា

គ្រាកាន់កាប់ត្រួតត្រា គឺជាយុៈពេលមួយដែលព្រះអម្ចាស់បានបង្ហាញនូវគោលលទ្ធិ គោលការណ៍ និងបព្វជិតភាពរបស់ទ្រង់ ។ វាគឺជាពេលមួយដែលព្រះអម្ចាស់បានមានសេចក្តីអនុញ្ញាតយ៉ាងហោចណាស់ដល់អ្នកបម្រើម្នាក់នៅលើផែនដី ដែលមានបព្វជិតភាពដ៏បរិសុទ្ធ និងដែលមានការអនុញ្ញាតដ៏ទេវភាពដើម្បីកាន់កាប់ដំណឹងល្អ និងបម្រើតាមពិធីបរិសុទ្ធនោះ ។ សព្វថ្ងៃនេះ យើងរស់នៅក្នុងគ្រាកាន់កាប់ត្រួតត្រាចុងក្រោយ—សម័យកាន់កាប់ត្រួតត្រានៃពេលពេញកំណត់ ដែលបានចាប់ផ្តើមដោយវិវរណៈនៃដំណឹងល្អដល់លោក យ៉ូសែប ស្ម៊ីធ ។

ការកាន់កាប់ត្រួតត្រាពីមុនត្រូវបានបង្ហាញដោយលោកអ័ដាម អេណុក ណូអេ អ័ប្រាហាំ ម៉ូសេ និងព្រះយេស៊ូវគ្រីស្ទ ។ បន្ថែមលើនេះ មានគ្រាកាន់កាប់ត្រួតត្រាផ្សេងទៀត ដែលរួមមានអ្នកដែលនៅក្នុងចំណោមពួកសាសន៍នីហ្វៃ និងពួកសាសន៍យ៉ារេឌ ។ ផែនការនៃសង្គ្រោះ និងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទត្រូវបានបើកសម្តែង និងត្រូវបានបង្រៀននៅក្នុងគ្រប់គ្រាកាន់កាប់ត្រួតត្រា ។

ការក្បត់សាសនា

នៅពេលមនុស្សបែរចេញពីគោលការណ៍នៃដំណឹងល្អ និងមិនមានកូនសៅនៃបព្វជិតភាព នោះពួកគេស្ថិតនៅក្នុងការក្បត់សាសនា ។

អំឡុងពេលនៃការក្បត់សាសនាទូទៅ បានកើតឡើងពេញមួយប្រវត្តិសាស្ត្រនៃពិភពលោក ។ ឧទាហរណ៍មួយគឺជាការក្បត់សាសនាដ៏ធំមួយ ដែលបានកើតឡើងក្រោយពីព្រះអង្គសង្គ្រោះបានស្ថាបនាសាសនាចក្ររបស់ទ្រង់ (សូមមើល ថែសាឡូនិចទី ២ ២:១–៣) ។ បន្ទាប់ពីការស្លាប់របស់ពួកសាវករបស់ព្រះអង្គសង្គ្រោះ នោះគោលការណ៍នៃដំណឹងល្អបានក្លាយជាពុករលួយ ហើយការផ្លាស់ប្តូរដែលមិនមានអំណាចត្រូវបានបង្កើតនៅក្នុងអង្គការសាសនាចក្រ និងពិធីបរិសុទ្ធនៃបព្វជិតភាព ។ ដោយសារតែអំពើទុច្ចរិតដែលបានកែចម្រើននេះ ព្រះអម្ចាស់បានដកចេញនូវសិទ្ធិអំណាច និងកូនសៅនៃបព្វជិតភាពចេញពីផែនដី ។

អំឡុងពេលការក្បត់សាសនាដ៏ធំ មនុស្សបាននៅដោយគ្មានការដឹកនាំពីស្ថានសួគ៌ពីពួកព្យាការីដែលនៅរស់ ។ ព្រះវិហារជាច្រើនត្រូវបានស្ថាបនាឡើង ប៉ុន្តែពួកគេមិនមានសិទ្ធិអំណាចដើម្បីប្រគល់អំណោយទានព្រះវិញ្ញាណបរិសុទ្ធ ឬសម្តែងពិធីបរិសុទ្ធនៃបព្វជិតភាពផ្សេងទៀតឡើយ ។ ផ្នែកនៃព្រះគម្ពីរដ៏បរិសុទ្ធបានក្លាយទៅជាពុករលួយ ឬបាត់បង់ ហើយប្រជាជនលែងមានការយល់ដឹងដ៏ត្រឹមត្រូវពីព្រះទៀត ។

ការក្បត់សាសនានេះបានបន្តរហូតដល់ព្រះវរបិតាសួគ៌ និងបុត្រាដ៏ជាទីស្រឡាញ់របស់ទ្រង់បានលេចមក ឯ យ៉ូសែប ស្ម៊ីធ និងបានផ្តើមថ្មីនូវការស្តារឡើងវិញនៃភាពពោរពេញនៃដំណឹងល្អ ។

ការស្តារឡើងវិញ

ការស្តារឡើងវិញ គឺជាការបង្កើតឡើងវិញនៃសេចក្តីពិតរបស់ព្រះ និងពិធីការនៃដំណឹងល្អនៅក្នុងចំណោមកូនចៅរបស់ទ្រង់នៅលើផែនដីនេះ (សូមមើល កិច្ចការ ៣:១៩–២១) ។

នៅក្នុងការរៀបចំសម្រាប់ការស្តារឡើងវិញ ព្រះអម្ចាស់បានបង្កើតអភិជនឡើងអំឡុងពេលដែលហៅថា ការប្រែសាសនា ។ ពួកលោកបានមានបំណងដើម្បីធ្វើឲ្យគោលលទ្ធិ ការអនុវត្តន៍ និងអង្គការសាសនាទៅតាមរបៀបដែលព្រះអង្គសង្គ្រោះបានស្ថាបនាវាឡើង ។ ទោះជាយ៉ាងណាក្តី ពួកលោកមិនបានមានបព្វជិតភាព ឬក៏ភាពពោរពេញនៃដំណឹងល្អនោះទេ ។

ការស្តារឡើងវិញបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ ១៨២០ នៅពេលព្រះជាព្រះវរបិតា និងព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទ បានលេចមកឯ យ៉ូសែប ស្ម៊ីធ ឆ្លើយតបតាមការអធិស្ឋានរបស់លោក (សូមមើល យ៉ូសែប ស្ម៊ីធ—ប្រវត្តិ ១:១៥–២០) ។ ព្រឹត្តិការណ៍គន្លឹះខ្លះនៃការស្តារឡើងវិញគឺជាការបកប្រែនៃព្រះគម្ពីរមរមន ការស្តារឡើងវិញនៃបព្វជិតភាពអើរ៉ុន និងមីលគីស្សាដែក និងអង្គការនៃសាសនាចក្រនៅថ្ងៃទី ៦ ខែ មេសា ឆ្នាំ ១៨៣០ ។

បព្វជិតភាពអើរ៉ុនត្រូវបានស្តារឡើងវិញទៅដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ដោយយ៉ូហាន បាទីស្ទ នៅថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៨២៩ ។ បព្វជិតភាពមីលគីស្សាដែក និងកូនសៅនៃព្រះនគរក៏ត្រូវបានស្តារឡើងវិញនៅក្នុងឆ្នាំ ១៨២៩ ដែរ នៅពេលដែលសាវកប៉ុល យ៉ាកុប និងយ៉ូហានបានប្រគល់វាដល់ យ៉ូសែប ស្ម៊ីធ និង អូលីវើរ ខៅឌើរី ។

ភាពពោរពេញនៃដំណឹងល្អត្រូវបានស្តារឡើងវិញ ហើយសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺជា « សាសនាចក្រដ៏ពិត និងនៅរស់តែមួយគត់នៅលើផែនដីនេះ » (គ. និង ស. ១:៣០) ។ នៅទីបញ្ចប់ សាសនាចក្រនឹងមានពេលពេញផែនដីទាំងមូល និងឈរនៅជារៀងរហូតទៅ ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ អេសាយ ២៩:១៣–១៤; អេសេគា ៣៧:១៥–១៧; អេភេសូ ៤:១១–១៤; យ៉ាកុប ១:៥–៦

៥. ព្យាការី និង វិវរណៈ

ព្យាការីគឺជាបុគ្គលមួយរូបដែលត្រូវបានហៅបម្រើដោយព្រះដើម្បីមានប្រសាសន៍ជំនួសទ្រង់ (សូមមើល អេម៉ុស ៣:៧) ។ ព្យាការីធ្វើទីបន្ទាល់អំពីព្រះយេស៊ូវគ្រីស្ទ និងបង្រៀនដំណឹងល្អរបស់ទ្រង់ ។ ពួកលោកផ្សព្វផ្សាយអំពីព្រះរាជបំណង និងបុគ្គលិកលក្ខណៈពិតរបស់ព្រះ ។ពួកលោកបានដាក់ទោសដល់អំពើបាប និងព្រមានអំពីលទ្ធផលរបស់វា ។ នៅគ្រប់ពេលពួកលោកព្យាករពីរហេតុការណ៍ដែលកើតឡើងនៅអនាគត (សូមមើល គ. និង ស. ១:៣៧–៣៨) ។ ការបង្រៀនរបស់ព្យាការីជាច្រើន ត្រូវបានកេឃើញនៅក្នុងព្រះគម្ពីរ ។ នៅពេលយើងសិក្សាពាក្យសម្តីរបស់ព្យាការី នោះយើងអាចរៀនពីសេចក្តីពិត និងទទួលបានការដឹកនាំ (សូមមើល នីហ្វៃទី ២ ៣២:៣) ។

យើងគាំទ្រដល់ប្រធាននៃសាសនាចក្រជាព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈ និងជាបុគ្គលតែមួយគត់នៅលើផែនដីនេះដែលទទួលបានវិវរណៈក្នុងការដឹកនាំសាសនាចក្រទាំងមូល ។ យើងក៏គាំទ្រដល់ទីប្រឹក្សានៅក្នុងគណៈប្រធានទីមួយ និងពួកសាវកដប់ពីរនាក់ ជាព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈ ។

វិវរណៈ គឺជាទំនាក់ទំនងពីព្រះជាមួយនឹងកូនចៅរបស់ទ្រង់ ។ នៅពេលព្រះអម្ចាស់បើកសម្តែងព្រះឆន្ទៈរបស់ទ្រង់ដល់សាសនាចក្រ ទ្រង់មានបន្ទូលតាមរយៈព្យាការីរបស់ទ្រង់ ។

ព្រះគម្ពីរ—ព្រះគម្ពីរបរិសុទ្ធ ព្រះគម្ពីរមរមន គោលលទ្ធិ និងសេចក្តីសញ្ញា និងមុក្តាដ៏មានតម្លៃមហិមា—មានន្ទវិវរណៈដែលបានប្រទានតាមរយៈព្យាការីពីបុរាណ និងនៅថ្ងៃចុងក្រោយ ។ ប្រធាននៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយគឺជាព្យាការីរបស់ព្រះនៅលើផែនដីនាសព្វថ្ងៃនេះ ។

បុគ្គលម្នាក់ៗអាចទទួលបានវិវរណៈដើម្បីជួយពួកគេពេលត្រូវការនៅពេលណាមួយ ការទទួលខុសត្រូវ និងសំណួរពិសេសរបស់ពួកគេ និងដើម្បីជួយពង្រឹងដល់ទីបន្ទាល់របស់ពួកគេ ។ វិវរណៈភាគច្រើនចំពោះអ្នកដឹកនាំ និងសមាជិកនៃសាសនាចក្រមកតាមរយៈការរំពើប និងគំនិតមកពីព្រះវិញ្ញាណបរិសុទ្ធ ។ ព្រះវិញ្ញាណបរិសុទ្ធមានបន្ទូលដល់គំនិត និងដួងចិត្តរបស់យើងដោយសំឡេងតូចរហៀងៗ (សូមមើល គ. និង ស. ៨:២–៣) ។ វិវរណៈក៏អាចមកតាមរយៈការនិមិត្ត សុបិន្ត និងការយាងមកជួបពីទេវតា ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ ទំនុកតម្កើង ១១៩:១០៥; អេភេសូ ៤:១១–១៤; ធីម៉ូថេទី ២ ៣:១៥–១៧; យ៉ាកុប ១:៥–៦; ម៉រ៉ូណៃ ១០:៤–៥

៦. បព្វជិតភាព និង កូនសៅនៃបព្វជិតភាព

បព្វជិតភាព គឺជាព្រះចេស្តា និងជាសិទ្ធិអំណាចរបស់ព្រះ ។តាមរយៈបព្វជិតភាព ព្រះបានបង្កើត និងគ្រប់គ្រងស្ថានសួគ៌ និងផែនដី ។ តាមរយៈអំណាចនេះ ទ្រង់ប្រោសលោះ និងតម្កើងកូនចៅរបស់ទ្រង់ ដោយនាំមកនូវ « ជីវិតរមែងស្លាប់ និងជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្សលោក » (ម៉ូសេ ១:៣៩) ។

ព្រះប្រទានសិទ្ធិអំណាចបព្វជិតភាពដល់បុរសដែលមានភាពសក្តិសមនៃសាសនាចក្រ ដើម្បីឲ្យពួកគាត់អាចធ្វើការនៅក្នុងព្រះនាមរបស់ទ្រង់សម្រាប់សេចក្តីសង្គ្រោះរបស់កូនចៅទ្រង់ ។ កូនសៅនៃបព្វជិតភាព គឺជាសិទ្ធិនៃគណៈប្រធាន ឬអំណាចដែលត្រូវបានប្រគល់ដល់មនុស្សដោយព្រះ ដើម្បីគ្រប់គ្រង និងដឹកនាំនគរបស់ព្រះនៅលើផែនដី (សូមមើល ម៉ាថាយ ១៦:១៥–១៩) ។ តាមរយៈកូនសៅទាំងនេះ អ្នកកាន់បព្វជិតភាពអាចមានអំណាចដើម្បីបង្រៀនដំណឹងល្អ និងបម្រើពិធីការនៃសេចក្តីសង្គ្រោះ ។ អ្នកទាំងឡាយដែលបម្រើនៅក្នុងសាសនាចក្រត្រូវបានហៅនៅក្រោមការដឹកនាំរបស់បុគ្គលម្នាក់ដែលកាន់កូនសៅនៃបព្វជិតភាព ។ ហេតុដូច្នេះហើយ ពួកគេត្រូវមានអំណាចដែលតម្រូវឲ្យបម្រើ និងបំពេញតួនាទីនៃការហៅបម្រើរបស់គេនោះ ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ គ. និង ស. ១២១:៣៦, ៤១–៤២

បព្វជិតភាពអើរ៉ុន

បព្វជិតភាពអើរ៉ុន ជាញឹកញាប់ត្រូវបានហៅថាជាបព្វជិតភាពរៀបចំ ។ មុខតំណែងនៅក្នុងបព្វជិតភាពអើរ៉ុន គឺមានឱកុន គ្រូបង្រៀន សង្ឃ និងប៊ីស្សព ។នៅក្នុងសាសនាចក្រសព្វថ្ងៃនេះ សមាជិកបុរសដែលមានភាពសក្តិសមអាចទទួលបានបព្វជិតភាពអើរ៉ុនពេលមានអាយុ ១២. ឆ្នាំ ។

បព្វជិតភាពអើរ៉ុន « កាន់នូវកូនសៅនៃការបម្រើនៃពួកទេវតា និងនៃដំណឹងល្អនៃការប្រែចិត្ត និងបុណ្យជ្រមុជទឹក » (គ. និង ស. ១៣:១) ។

បព្វជិតភាពមិលគីស្សាដែក

បព្វជិតភាពមិលគីស្សាដែកគឺជាបព្វជិតភាពខ្ពស់ជាង ឬធំជាង ហើយបម្រើកិច្ចការខាងវិញ្ញាណ (សូមមើល គ. និង ស. ១០៧:៨) ។ បព្វជិតភាពដ៏ធំជាងនេះ ត្រូវបានប្រទានដល់

លោកអ័ដាម និងបានមាននៅលើផែនដីនេះ៖ នៅពេលដែលព្រះអម្ចាស់បានបើកសម្តែងដំណឹងល្អរបស់ទ្រង់ ។

វាត្រូវបានហៅជាដំបូងថា « បព្វជិតភាពដ៏បរិសុទ្ធ តាមរបៀបនៃព្រះបុត្រានៃព្រះ »(គ. និង ស. ១០៧:៣) ។ ក្រោយមក វាត្រូវបានស្គាល់ថាជាបព្វជិតភាពមីលគីស្សាដែក ដែលហៅឈ្មោះតាមសង្ឃដ៏ខ្ពស់ដ៏អស្ចារ្យម្នាក់ ដែលបានរស់នៅអំឡុងពេលព្យាការី អ័ប្រាហាំ ។

នៅក្នុងបព្វជិតភាពមិលគីស្សាដែក មុខតំណែងទាំងឡាយមានដូចជា អែលឌើរ សង្ឃជាន់ខ្ពស់ លោកអយ្យកោ ពួកចិតសិបនាក់ និងសាវក ។ប្រធាននៃបព្វជិតភាពមិលគីស្សាដែក គឺជាប្រធាននៃសាសនាចក្រ ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ អេភេសូរ ៤:១១–១៤

៧. ពិធីបរិសុទ្ធ និង សេចក្តីសញ្ញាទាំងឡាយ

ពិធីបរិសុទ្ធទាំងឡាយ

នៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្តនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ពិធីបរិសុទ្ធមួយគឺជាទង្វើដ៏ពិសិដ្ឋ និងផ្លូវការ ដែលមានន័យខាងវិញ្ញាណ ។ ពិធីបរិសុទ្ធនីមួយៗត្រូវបានធ្វើឡើងដោយព្រះ ដើម្បីបង្រៀនពីសេចក្តីពិតខាងវិញ្ញាណ ។ ពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះត្រូវបានសម្តែងឡើងដោយសិទ្ធិអំណាចនៃបព្វជិតភាព និងនៅក្រោមការដឹកនាំពីអ្នកដែលកាន់កូនសោនៃបព្វជិតភាព ។ ពិធីបរិសុទ្ធខ្លះមានសារៈសំខាន់ចំពោះសិរីល្អ និងត្រូវបានហៅថាជាពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះ ។

ពិធីបរិសុទ្ធសង្គ្រោះទីមួយនៃដំណឹងល្អគឺជាបុណ្យជ្រមុជទឹកដោយការពន្លិចទៅក្នុងទឹក ដោយបុគ្គលម្នាក់ដែលមានអំណាច ។ បុណ្យជ្រមុជទឹកគឺចាំបាច់សម្រាប់បុគ្គលម្នាក់ដើម្បីក្លាយជាសមាជិកនៃសាសនាចក្រ និងដើម្បីចូលទៅក្នុងនគរសេឡេស្ទាល (សូមមើល យ៉ូហាន ៣:៥) ។

ពាក្យ បុណ្យជ្រមុជទឹកមកពីពាក្យភាសាក្រិក ដែលមានន័យថាជ្រមុជ ឬ ពន្លិច ។ ការជ្រមុជក្នុងទឹកគឺជានិមិត្តសញ្ញានៃការស្លាប់របស់ជីវិតដ៏មានបាបរបស់មនុស្សម្នាក់ និងការកើតជាថ្មីរបស់គេទៅក្នុងជីវិតខាងវិញ្ញាណមួយ ឧទ្ទិសដល់ការបម្រើដល់ព្រះ និងកូនចៅរបស់ទ្រង់ ។ វាក៏ជានិមិត្តសញ្ញានៃការស្លាប់ និងការរស់ឡើងវិញដែរ ។

ក្រោយពីបុគ្គលម្នាក់បានជ្រមុជទឹក នោះអ្នកកាន់បព្វជិតភាពមិលគីស្សាដែកម្នាក់ ឬច្រើននាក់នឹងដាក់ដៃលើក្បាលរបស់គេ ហើយបញ្ជាក់គេថាជាសមាជិកនៃសាសនាចក្រ ។ ជាផ្នែកនៃពិធីបរិសុទ្ធនេះ ដែលហៅថាជាពិធីបញ្ជាក់ នោះបុគ្គលនោះត្រូវបានប្រទានទៅអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ។

អំណោយទានព្រះវិញ្ញាណបរិសុទ្ធខុសពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធ ។ មុនពេលបុណ្យជ្រមុជទឹក បុគ្គលនោះអាចមានអារម្មណ៍ពីឥទ្ធិពលនៃព្រះវិញ្ញាណបរិសុទ្ធគ្រប់ពេល ហើយតាមរយៈឥទ្ធិពលនោះ គេអាចទទួលបានទីបន្ទាល់មួយអំពីសេចក្តីពិត (សូមមើល មរ៉ូណៃ ១០:៤–៥) ។ ក្រោយពីទទួលបានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ បុគ្គលនោះបានមានសិទ្ធិដើម្បីមានដៃគូជាជារបស់ទ្រង់ ប្រសិនបើគេកាន់តាមព្រះបញ្ញត្តិ ។

ពិធីការសង្គ្រោះផ្សេងទៀតរួមបញ្ចូលនូវការតែងតាំងដល់បព្វជិតភាពមិលគីស្សាដែក (សម្រាប់បុរស) អំណោយទានពិសិដ្ឋនៅក្នុងព្រះវិហារបរិសុទ្ធ និងការផ្សះភ្ជាប់អាពាហ៍ពិពាហ៍ (សូមមើល គ. និង ស. ១៣១:១–៤) ។ ពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះទាំងអស់នៃបព្វជិតភាពមានមកជាមួយនឹងសេចក្តីសញ្ញា ។ នៅក្នុងព្រះវិហារបរិសុទ្ធ ពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះទាំងនេះក៏អាចត្រូវបានធ្វើឡើងជំនួសមរណៈជនដែរ ។ ពិធីបរិសុទ្ធជំនួសនឹងមានប្រសិទ្ធភាពតែនៅពេលបុគ្គលដែលស្លាប់នោះ ទទួលយកវានៅក្នុងពិភពវិញ្ញាណ និងផ្តល់កិត្តិយសដល់សេចក្តីសញ្ញាដែលទាក់ទងប៉ុណ្ណោះ ។

ពិធីបរិសុទ្ធផ្សេងទៀត ដូចជាការព្យាបាលអ្នកឈឺ និងការដាក់ឈ្មោះ និង ប្រសិទ្ធពរឲ្យកុមារ ក៏មានសារៈសំខាន់ដល់ការរីកចម្រើនខាងវិញ្ញាណរបស់យើងដែរ ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ កិច្ចការ ២: ៣៦–៣៨

សេចក្តីសញ្ញាទាំងឡាយ

សេចក្តីសញ្ញាមួយគឺជាកិច្ចព្រមព្រៀងដ៏ពិសិដ្ឋមួយរវាងព្រះ និងមនុស្ស ។ ព្រះប្រទាននូវលក្ខខណ្ឌសម្រាប់សេចក្តីសញ្ញា ហើយយើងយល់ព្រមធ្វើតាមអ្វីដែលទ្រង់សុំយើងឲ្យធ្វើ បន្ទាប់មក ព្រះបានសន្យានឹងយើងនូវពរជ័យមួយចំនួនចំពោះការគោរពប្រតិបត្តិរបស់យើង (សូមមើល គ. និង ស. ៨២:១០) ។

ពិធីបរិសុទ្ធនៃសេចក្តីសង្គ្រោះទាំងអស់នៃបព្វជិតភាព អមដោយសេចក្តីសញ្ញា ។ យើងធ្វើសេចក្តីសញ្ញាជាមួយនឹងព្រះអម្ចាស់នៅពេលជ្រមុជទឹក ហើយបន្តធ្វើសេចក្តីសញ្ញាទាំងនោះដោយការទទួលយកពិធីសាក្រាម៉ង់ ។ បងប្អូនប្រុសដែលទទួលយកបព្វជិតភាពមិលគីស្សាដែក ចូលទៅក្នុងពាក្យសម្បថ និង សេចក្តីសញ្ញានៃបព្វជិតភាព ។ យើងធ្វើសេចក្តីសញ្ញាបន្ថែមទៀតនៅក្នុងព្រះវិហារបរិសុទ្ធ ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ ជនគណនា ១៩:៥–៦; ទំនុកតម្កើង ២៤:៣–៤; នីហ្វៃទី ២ ៣១:១៩–២០; គ. និង ស. ២៥:១៣

៨. អាពាហ៍ពិពាហ៍ និង គ្រួសារ

អាពាហ៍ពិពាហ៍រវាងបុរសម្នាក់ និងស្ត្រីម្នាក់ត្រូវបានតែងតាំងឡើងដោយព្រះ ហើយគ្រួសារគឺជាស្នូលនៃផែនការនៃសេចក្តីសង្គ្រោះរបស់ទ្រង់ និងចំពោះសុភមង្គលរបស់យើង ។ សុភមង្គលនៅក្នុងជីវិតគ្រួសារ អាចកើតមានឡើងបាន នៅពេលធ្វើតាមការបង្រៀនរបស់ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ ។

អំណាចដ៏ពិសិដ្ឋនៃការបង្កើតកូនចៅ ប្រើបានសម្រាប់តែរវាងប្រុស និងស្រីដែលបានរៀបអាពាហ៍ពិពាហ៍ពេញច្បាប់ជាប្តីប្រពន្ធតែប៉ុណ្ណោះ ។ឪពុកម្តាយ ត្រូវបង្កើតកូនឲ្យចម្រើនជាច្រើនឡើង ឲ្យមានពេញពាសលើផែនដី ចិញ្ចឹមកូនចៅរបស់គេនៅក្នុងសេចក្តីស្រឡាញ់ និងសេចក្តីសុចរិត ហើយបំពេញតម្រូវការខាងរាងកាយ និងខាងវិញ្ញាណដល់កូនចៅរបស់ខ្លួន ។

ស្វាមី និង ភរិយា មានការទទួលខុសត្រូវដ៏ឧឡារិកដើម្បីស្រឡាញ់ និង ថែរក្សាគ្នាទៅវិញទៅមក ។ ឪពុកត្រូវដឹកនាំគ្រួសារដោយសេចក្តីស្រឡាញ់ និងសេចក្តីសុចរិត និងបំពេញនូវតម្រូវការចាំបាច់នៃជីវិត ។ ម្តាយ មានភារកិច្ចសំខាន់ដើម្បីថែរក្សាបីបាច់កូនចៅរបស់ខ្លួន ។នៅក្នុងការទទួលខុសត្រូវដ៏ពិសិដ្ឋទាំងនេះ ឪពុក និងម្តាយមានកាតព្វកិច្ចដើម្បីជួយគ្នាទៅវិញទៅមកជាដៃគូស្មើគ្នា ។

ផែនការនៃសុភមង្គលដ៏ទេវភោពនេះ ផ្តល់លទ្ធភាពដល់ទំនាក់ទំនងក្រុមគ្រួសារឲ្យចេះតែបន្តមានហូតហួសពីសេចក្តីស្លាប់ ។ផែនដីនេះត្រូវបានបង្កើតឡើង ហើយដំណឹងល្អត្រូវបានបើកសម្តែង ដើម្បីឲ្យគ្រួសារអាចត្រូវបានបង្កើតឡើង ផ្សារភ្ជាប់ និងតម្កើងឡើងនៅអស់កល្បជានិច្ច ។ (សម្រួលពី « គ្រួសារ ៖ ការប្រកាសដល់ពិភពលោក» *Ensign,* ខែ វិច្ឆិកា ឆ្នាំ ២០១០, ទំព័រ ១២៩) ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ លោកុប្បត្តិ ២:២៤; ទំនុកតម្កើង ១២៧:៣; ម៉ាឡាគី ៤:៥–៦; គ. និង ស. ១៣១:១–៤

៩. បទបញ្ញត្តិទាំងឡាយ

បទបញ្ញត្តិទាំងឡាយ គឺជាច្បាប់ និងតម្រូវការដែលព្រះប្រទានដល់មនុស្សលោក ។ យើងបង្ហាញសេចក្តីស្រឡាញ់របស់យើងដល់ទ្រង់ ដោយការកាន់តាមព្រះបញ្ញត្តិទាំងឡាយ (សូមមើល យ៉ូហាន ១៤:១៥) ។ ការកាន់តាមព្រះបញ្ញត្តិទាំងឡាយ នឹងនាំមកនូវពរជ័យពីព្រះអម្ចាស់ (សូមមើល គ. និង ស. ៨២:១០) ។

ព្រះបញ្ញត្តិគ្រឹះដ៏សំខាន់ពីរគឺ « ស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់ពីព្រលឹង ហើយអស់អំពីគំនិតឯង ។ . . . ហើយ . . . ស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង » (ម៉ាថាយ ២២:៣៦–៣៩) ។

ក្រិត្យវិន័យទាំងដប់ប្រការគឺជាផ្នែកមួយដ៏សំខាន់នៃដំណឹងល្អ និងជាគោលការណ៍ដ៏អស់កល្បជានិច្ចដែលចាំបាច់សម្រាប់ភាពតម្កើងឡើងរបស់យើង (សូមមើល ជនគណនា ២០:៣–១៧) ។ ព្រះអម្ចាស់បានបើកសម្តែងវាដល់លោកម៉ូសេនៅក្នុងគ្រាបុរាណ ហើយទ្រង់បានបញ្ជាក់ជាថ្មីនៅក្នុងវិវរណៈថ្ងៃចុងក្រោយ ។

ព្រះបញ្ញត្តិផ្សេងទៀតរួមមានការអធិស្ឋានប្រចាំថ្ងៃ (សូមមើល នីហ្វៃទី ២ ៣២:៨–៩) បង្រៀនដំណឹងល្អដល់អ្នកដទៃ (សូមមើល ម៉ាថាយ ២៨:១៩–២០) កាន់តាមច្បាប់ព្រហ្មចារីយភាព (សូមមើល គ. និង ស. ៤៦:៣៣) បង់ដង្វាយមួយភាគដប់ពេញលេញ (សូមមើល ម៉ាឡាគី ៣:៨–១០) តមអាហារ (សូមមើលអេសាយ ៥៨:៦–៧) អភ័យទោសដល់អ្នកដទៃ (សូមមើល គ. និង ស. ៦៤:៩–១១) មានវិញ្ញាណនៃសេចក្តីអំណរគុណ (សូមមើល គ. និង ស. ៧៨:១៩) និងធ្វើតាមពាក្យគតិបណ្ឌិត (សូមមើល គ. និង ស. ៨៩:១៨–២១) ។

សេចក្តីយោងដែលទាក់ទងគ្នា ៖ លោកុប្បត្តិ ៣៩:៩; អេសាយ ៥៨:១៣–១៤; នីហ្វៃទី ១ ៣:៧; ម៉ូសាយ ៤:៣០; អាលម៉ា ៣៧:៣៥; អាលម៉ា ៣៩:៩; គ. និង ស. ១៨:១៥–១៦; គ. និង ស. ៨៨:១២៤

សម្រាប់ព័ត៌មានបន្ថែមអំពីប្រធានបទទាំងនេះ សូមចូលទៅ LDS.org, Teachings, Gospel Topics; ឬ សូមមើល *ពិតចំពោះសេចក្តីជំនឿ ៖ សេចក្តីយោងដំណឹងល្អ (ឆ្នាំ ២០០៤)* ។

ផ្នាំងចំណារ និងទំនាក់ទំនងរបស់វាទៅនឹងព្រះគម្ពីរមរមនដែលបានបោះពុម្ពរួច



* កាលបរិច្ឆេទតំណាងឲ្យអំឡុងពេលប្រហាក់ប្រហែលដែលកើតមាននៅក្នុងហេតុការណ៍នៃផ្នាំងចំណារនីមួយៗ ។

† វាមិនត្រូវបានដឹងច្បាស់លាស់ថានៅពេលណាដែលព្យាការី អេធើរ បានបញ្ចប់កំណត់ត្រារបស់លោកឡើយ ប៉ុន្តែពេលខ្លះវាប្រហែលជានៅចន្លោះឆ្នាំ ៥៨៩ មុន.គ.ស. និង ១៣១ មុន.គ.ស. ។

សេចក្តីសង្ខេបនៃការធ្វើដំណើរនៅក្នុង ម៉ូសាយ ៧–២៤

១ ពួកសាសន៍នីហ្វៃមួយចំនួនចង់បានដែនដីនីហ្វៃមកវិញ ។ ពួកគេប្រយុទ្ធនឹងគ្នា ហើយអ្នកនៅស៊ែត្រឡប់ទៅដែនដីសាំាហិមឡាវិញ ។ សិនិព្វគឺជាផ្នែកមួយនៃក្រុមនេះ ។ (សូមមើល អោមណៃ ១:២៧–២៨; ម៉ូសាយ ៩:១–២ ។)

២ ក្រុមសាសន៍នីហ្វៃដែលដឹកនាំដោយសីនិព្វ ស្នាក់នៅក្នុងចំណោមពួកសាសន៍លេមិនៅក្នុងដែនដីនីហ្វៃ (សូមមើល អោមណៃ ១:២៩–៣០; ម៉ូសាយ ៩:៣–៥) ។

ក្រោយពីសីនិព្វសុគតទៅ បុត្រារបស់ទ្រង់គឺ ណូអេ បានគ្រងរាជ្យនៅក្នុងអំពើទុច្ចរិត ។ អ័ប៊ីណាដៃ បានព្រមានប្រជាជនឲ្យប្រែចិត្ត ។ អាលម៉ាបានគោរពតាមសារលិខិតរបស់អ័ប៊ីណាដៃ ហើយបានបង្រៀនវាដល់អ្នកដទៃនៅក្បែរទឹកមរមន ។ (សូមមើល ម៉ូសាយ ១១–១៨ ។)

៣ អាលម៉ា និងប្រជាជនរបស់លោកចាកចេញ ពីស្តេចណូអេ ហើយបានធ្វើដំណើរទៅកាន់ដែនដីហេឡាម (សូមមើល ម៉ូសាយ ១៨:៤–៥, ៣២–៣៥; ២៣:១–៥, ១៩–២០) ។

ពួកសាសន៍លេមិនបានវាយលុកប្រជាជនរបស់ស្តេចណូអេនៅក្នុងដែនដីនីហ្វៃ ។ បុត្រារបស់ស្តេចណូអេគឺ ស្តេចលីមហៃ បានគ្រងរាជ្យ ខណៈពេលដែលប្រជាជនរបស់ទ្រង់បានរស់នៅក្នុងសេវកភាពនៃពួកសាសន៍លេមិន ។ (សូមមើល ម៉ូសាយ ១៩–២០ ។)

៤ បំណងដើម្បីស្វែងរកដែនដីសាំាហិមឡា ៖ ស្តេចលីមហៃបានបញ្ជូនក្រុមមួយទៅស្វែងរកដែនដីសាំាហិមឡា និងដើម្បីសុំជំនួយ ។ ក្រុមនេះបានរកឃើញតំបន់បោះបង់ចោលមួយនៃជាតិសាសន៍ដែលត្រូវបំផ្លាញបង់ និងផ្នាំងមាសទាំង ២៤ ។ (សូមមើល ម៉ូសាយ ៨:៧–៩; ២១:២៥–២៧ ។)

៥ ក្រុមស្វែងរកដែលដឹកនាំដោយលោកអាំម៉ូន ធ្វើដំណើរពីដែនដីសាំាហិមឡាទៅរកកូនចៅរបស់អ្នកដែលបានទៅដែនដីនីហ្វៃ (សូមមើល ម៉ូសាយ ៧:១–៦; ២១:២២–២៤) ។

៦ ប្រជាជនរបស់ស្តេចលីមហៃរត់ចេញ ពីសេវកភាព និងបានដឹកនាំដោយលោកអាំម៉ូនត្រឡប់ទៅកាន់ដែនដីសាំាហិមឡាវិញ (សូមមើល ម៉ូសាយ ២២:១០–១៣) ។

ពួកសាសន៍លេមិនបានបញ្ជូនកងទ័ព ដេញតាមស្តេចលីមហៃ និងប្រជាជនរបស់ទ្រង់ ។ ក្រោយពីវង្វេងនៅក្នុងទីវាលរហោស្ថាន កងទ័ពនោះបានរកឃើញអាលម៉ា និងប្រជាជនរបស់លោកនៅក្នុងដែនដីហេឡាម ។ ពួកសាសន៍លេមិនបានដាក់ពួកគេនៅក្នុងការជាប់ឃុំឃាំង ។ (សូមមើល ម៉ូសាយ ២២–២៤ ។)

៧ ប្រជាជនរបស់អាលម៉ារត់ចេញ ពីសេវកភាព និងបានធ្វើដំណើរទៅកាន់ដែនដីសាំាហិមឡា (សូមមើល ម៉ូសាយ ២៤:២០–២៥) ។



តំបន់ដែលអាចមាននៅក្នុងព្រះគម្ពីរមេរមន (ទំនាក់ទំនងដល់គ្នាទៅវិញទៅមក)*

* ទំនាក់ទំនងនៃតំបន់ដែលអាចមាននៅក្នុងព្រះគម្ពីរមេរមន ដោយផ្អែកលើកស្តូតាងផ្ទៃក្នុង ។ គ្មានការខិតខំប្រឹងប្រែងណាបានធ្វើឡើយ ដើម្បីកន្លុះចំណុចនៅលើផែនទីនេះ ជាមួយនឹងទីតាំងភូមិសាស្ត្រដែលមានស្រាប់នោះ ។

ថ្នាក់សិក្សាសាលា និង
ថ្នាក់ចិញ្ចឹមគ្រានសាសនា

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

CAMBODIAN
4 02094 11258 2
09411 258